01006291

E313

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007/ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 08 / 2014
ម៉ោង (Time/Heure) : 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យូរ ឧត្តរា** |
| ក្រឡាបញ្ជីសវនាការ | លឹម ស៊ុយហុង Matteo CRIPPA សែ គុលវុឌ្ឍី ឯម ហ៊ិយ<br>Roger PHILLIPS Sophie MAURICE Robynne CROFT |
| កាលបរិច្ឆេទសវនាការ | ចាប់ផ្តើមពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ |
| កាលបរិច្ឆេទប្រកាសសាលក្រម | ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ |
| ភាសាដើម | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

---

# សាលក្រមសំណុំរឿង ០០២/០១

---

| **សហព្រះរាជអាជ្ញា** | **ជនជាប់ចោទ** |
|---|---|
| ជា លាង | នួន ជា |
| Nicholas KOUMJIAN | ខៀវ សំផន |

01006292

E313

| **<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>** | **<u>មេធាវីជនជាប់ចោទ</u>** |
|---|---|
| ពេជ អង្គ | សុន អរុណ |
| Marie GUIRAUD/Elisabeth SIMONNEAU-FORT (ត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤) | Victor KOPPE |
| | គង់ សំអុន |
| | Arthur VERCKEN<br>Anta GUISSÉ |

# សាលក្រម សំណុំរឿងលេខ ០០២/០១

## មាតិកា

១. សេចក្តីផ្តើម.......................................................................................1
១.១ ប្រវត្តិសង្ខេបនៃកិច្ចដំណើរការនីតិវិធីនៃរឿងក្តី ........................................ 1
១.២ សេចក្តីសង្ខេបអំពីបទចោទប្រឆាំងនឹងជនជាប់ចោទ ........................................ 8
២. បញ្ហាអញ្ញត្រកម្ម...................................................................................10
២.១ យុត្តាធិការ..........................................................................................10
២.២ គោលការណ៍នីត្យានុកូលភាព....................................................................12
២.៣ គោលការណ៍នៃភស្តុតាង និងនីតិវិធី ........................................................15
២.៣.១ សេចក្តីផ្តើម...................................................................................15
២.៣.២ បន្ទុក និងបទដ្ឋាននៃភស្តុតាង ...........................................................16
២.៣.៣ សំណុំរឿង.....................................................................................17
២.៣.៤ ភាពទទួលយកបាននៃភស្តុតាង ...........................................................18
២.៣.៤.១ ក្របខណ្ឌគតិយុត្តិ ........................................................................18
២.៣.៤.២ ប្រភពនៃភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះ.....................................19
២.៣.៤.២.១ ភស្តុតាងរបស់ជនជាប់ចោទ ............................................................19
២.៣.៤.២.២ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ........21
២.៣.៤.២.៣ ភស្តុតាងជាឯកសារ ...................................................................24
២.៣.៥ ការវាយតម្លៃជាចុងក្រោយលើភស្តុតាង.................................................25
២.៣.៥.១ តម្លៃនៃភស្តុតាង...........................................................................25
២.៣.៥.២ ការប្រកបឈ្មោះ និង ទីកន្លែង..........................................................29
២.៣.៥.៣ ភាពមិនស៊ីសង្វាក់គ្នានៃការបកប្រែផ្ទាល់មាត់ ការបកប្រែឯកសារ និង ប្រតិចារឹក ......................................................................................29
២.៣.៥.៤ ព័ត៌មានដែលត្រូវបានធ្វើចំណាត់ថ្នាក់...................................................30
២.៤ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ..............................................31
២.៤.១ សេចក្តីផ្តើម...................................................................................31
២.៤.២ វិការៈក្នុងការស៊ើបសួរតាមផ្លូវតុលាការដែលរងការចោទប្រកាន់..................33

២.៤.៣ ភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង....................................35
២.៤.៤ ពេលវេលា និងមធ្យោបាយដែលមានសម្រាប់ត្រៀមរៀបចំការការពារក្ដី .........36
២.៤.៥ ការជូនដំណឹងអំពីបទចោទ និងដំណើរការនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿង ០០២/០១ .....................................................................................38
២.៤.៦ សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី.............................................................41
២.៤.៧ លទ្ធភាពរបស់ក្រុមមេធាវីការពារក្ដីក្នុងការបង្ហាញឧក្រិដ្ឋកម្មនៅក្នុងបរិបទរបស់ខ្លួន .....................................................................................45
២.៤.៨ សិទ្ធិក្នុងការសួរដេញដោលទៅកាន់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ 47
២.៤.៩ សិទ្ធិក្នុងការសួរតទល់ ......................................................................51
២.៤.៩.១ បញ្ជីភស្តុតាងបឋម (វិធាន ៨០(៣) នៃវិធានផ្ទៃក្នុង) ..........................52
២.៤.៩.២ សវនាការស្ដីពីភាពអាចទទួលយកបាននៃភស្តុតាង.............................53
២.៤.៩.៣ សវនាការស្ដីពីការបង្ហាញឯកសារគន្លឹះ ..........................................55
២.៤.៩.៤ សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ............................57
២.៤.៩.៥ សេចក្ដីសន្និដ្ឋាន ........................................................................60
២.៤.១០ សិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើសេចក្ដីសន្និដ្ឋាន និងឆ្លើយតបចំពោះការចោទសួរ .....................................................................................61
៣. បរិបទប្រវត្តិសាស្ត្រ.......................................................................... 64
៣.១ ទិដ្ឋភាពទូទៅ និងការបង្កើតបក្សកុម្មុយនីស្តកម្ពុជា ...........................................65
៣.២ ការទម្លាក់សម្ដេច នរោត្ដម សីហនុ និងការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និង រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា.................................................................80
៣.៣ ការបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ............................................86
៣.៣.១ ការផ្លាស់ទីលំនៅប្រជាជនមុនឆ្នាំ ១៩៧៥...................................................88
៣.៣.២ ការបង្កើតសហករណ៍ និងការដ្ឋាន មុនខែ មេសា ឆ្នាំ ១៩៧៥ ....................94
៣.៣.៣ ការអប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង.............................97
៣.៣.៤ ការកំណត់គោលដៅលើក្រុមជាក់លាក់៖ ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ .................................. 102
៣.៣.៤.១ ការកំណត់គោលដៅលើ ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ102

៣.៣.៤.២ "បទពិសោធន៍" នៅឧត្តុង្គ ........ 108

៣.៣.៥ ការរៀបការដោយបង្ខំ ........ 111

៣.៤ ការសម្រេច "រំដោះ" និងជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត ........ 114

៣.៤.១ ខែ មិថុនា ឆ្នាំ ១៩៧៤ ........ 114

៣.៤.២ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ........ 124

៣.៤.៣ ដើមខែ មេសា ឆ្នាំ ១៩៧៥ ........ 125

៣.៤.៤ បទបញ្ជាដែលត្រូវបានបញ្ជូនទៅកម្មាភិបាលថ្នាក់ក្រោម ........ 128

៣.៤.៥ សេចក្តីសន្និដ្ឋាន ........ 132

៣.៥ យុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ - ការទម្លាក់គ្រាប់បែករបស់អាមេរិក ........ 133

៣.៦ ស្ថានភាពជនភៀសខ្លួន និងកង្វះម្ហូបអាហារនៅក្នុងទីក្រុងភ្នំពេញ ........ 139

៣.៧ ការវាយលុកចុងក្រោយមកលើទីក្រុងភ្នំពេញ ........ 144

៤. និដ្ឋភាពទូទៅៈ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ........ 149

៤.១ លក្ខខណ្ឌទូទៅចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ........ 158

៤.១.១ ច្បាប់ ........ 158

៤.១.២ សំអាងច្បាប់ ........ 170

៥ រចនាសម្ព័ន្ធរដ្ឋបាល ........ 173

៥.១ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ........ 173

៥.១.១ សន្និបាតបក្ស ........ 175

៥.១.២ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ........ 176

៥.១.៣ គណៈកម្មាធិការយោធា ........ 180

៥.១.៤ មជ្ឈិមបក្ស ........ 181

៥.១.៥ មន្ទីរ ៨៧០ ........ 182

៥.១.៦ មន្ទីររដ្ឋាភិបាល (ស-៧១) និងមន្ទីរចំណុះផ្សេងៗទៀត ........ 185

៥.១.៧ អង្គភាពភូមិភាគ តំបន់ ស្រុក និង ឃុំ ...... 190

៥.១.៨ អង្គការ ...... 198

៥.១.៩ ប្រជាធិបតេយ្យប្រមូលផ្តុំ ...... 200

៥.២ រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ...... 203

៥.៣ រចនាសម្ព័ន្ធនៃកងកម្លាំងយោធាបក្សកុម្មុយនីស្តកម្ពុជា ...... 211

៥.៣.១ ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ...... 211

៥.៣.២ រចនាសម្ព័ន្ធនៃកងទ័ពបដិវត្តន៍កម្ពុជា ...... 214

៥.៣.៣ កងទ័ពតំបន់ និងកងឈ្លប ...... 215

៦. រចនាសម្ព័ន្ធទំនាក់ទំនងការងារ ...... 216

៦.១ វិធីសាស្រ្តទំនាក់ទំនង ...... 216

៦.១.១ ទូរលេខ ...... 216

៦.១.២ សំបុត្រ ...... 220

៦.១.៣ ទូរស័ព្ទ ...... 220

៦.១.៤ វិទ្យុផ្សាយសម្លេង ...... 222

៦.១.៥ ទស្សនាវដ្តី ...... 226

៦.១.៦ ការតាមដានសេចក្តីរាយការណ៍សារព័ត៌មានបរទេស ...... 231

៦.២ ប្រព័ន្ធទំនាក់ទំនង ...... 233

៦.២.១ ទំនាក់ទំនងនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស ...... 234

៦.២.២ ទំនាក់ទំនងរវាងគណៈកម្មាធិការមជ្ឈិម នឹងភូមិភាគ ឬតំបន់ស្វយ័ត ...... 235

៦.២.៣ ទំនាក់ទំនងរវាងភូមិភាគ នឹងតំបន់ ...... 239

៦.២.៤ ទំនាក់ទំនងរវាងតំបន់នឹងស្រុក ...... 240

៦.២.៥ ទំនាក់ទំនងរវាងស្រុកនឹងឃុំ ...... 241

៦.២.៦ ទំនាក់ទំនងក្រៅប្រទេស ...... 242

៦.៣ ទំនាក់ទំនងផ្នែកយោធា ...... 245

៦.៣.១ ទំនាក់ទំនងជាមួយមជ្ឈិមបក្ស ...... 246

៦.៣.២ ទំនាក់ទំនងរវាងអគ្គសេនាធិការ និងកងពលធំ ...... 246

៦.៣.៣ ទំនាក់ទំនងនៅក្នុងកងពលធំ ...... 249

៦.៣.៤ ទំនាក់ទំនងរវាងកងពលធំ ........ 250
៧. តួនាទី និង មុខងាររបស់ នួន ជា ........ 250
៧.១ ព័ត៌មានអំពីសាវតារ និងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ ........ 251
៧.២ ឋានៈ និងតួនាទីរបស់ នួន ជា នៅក្នុងបក្ស ........ 260
៧.៣ កន្លែងស្នាក់នៅ ការធ្វើការងារ និងទីតាំងធ្វើដំណើរក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ 264
៧.៤ តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ 265
៧.៤.១ ប្រធានសភាតំណាងប្រជាជន ........ 265
៧.៤.២ នាយករដ្ឋមន្ត្រីស្តីទី ........ 267
៧.៥ តួនាទីក្នុងការឃោសនា និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត ........ 269
៧.៦ តួនាទីក្នុងក្បាលម៉ាស៊ីនយោធា និងសន្តិសុខ ........ 275
៧.៦.១ សមាជិកភាពក្នុងគណៈកម្មាធិការយោធានៃបក្សកុម្មុយនីស្តកម្ពុជា ........ 275
៧.៦.២ ការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាយោធា និងសន្តិសុខផ្សេងទៀត ........ 277
៧.៦.៣ ការគ្រប់គ្រងមន្ទីរសន្តិសុខ ស-២១ ........ 282
៧.៧ សេចក្តីសន្និដ្ឋាន ........ 286
៨. តួនាទី និងមុខងាររបស់ ខៀវ សំផន ........ 288
៨.១ ព័ត៌មានអំពីសាវតារ និងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ ........ 289
៨.១.១ ជីវិតកុមារភាព និងវិជ្ជាជីវៈ ........ 289
៨.១.២ សមាជិកបក្ស ........ 296
៨.១.៣ ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ........ 299
៨.២ កន្លែងស្នាក់នៅ ការធ្វើការងារ និងទីតាំងធ្វើដំណើរក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ 305
៨.៣ តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ 307
៨.៣.១ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការ ........ 307
៨.៣.២ ប្រធានគណៈប្រធានរដ្ឋ ........ 311
៨.៣.៣ សមាជិកភាពនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ... 314
៨.៣.៤ សមាជិកភាពមន្ទីរ ៨៧០ ........ 319

៨.៣.៥ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម (ក្រសួងពាណិជ្ជកម្ម) ................ 325
៨.៤ សេចក្តីសន្និដ្ឋាន ................ 333
៩. ច្បាប់ជាធរមាន: ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ................ 334
៩.១ ការធ្វើមនុស្សឃាត ................ 334
៩.២ ការសម្លាប់រង្គាល ................ 336
៩.៣ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ................ 342
៩.៤ អំពើអមនុស្សធម៌ផ្សេងៗទៀត ................ 348
៩.៤.១ ការបាត់ខ្លួនដោយបង្ខំ ................ 352
៩.៤.២ ការផ្លាស់ទីលំនៅដោយបង្ខំ ................ 356
៩.៤.៣ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ ................ 361
១០. ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) ................ 363
១០.១ ដីកាដំណោះស្រាយ ................ 363
១០.២ ហេតុការណ៍ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃបន្តបន្ទាប់ ................ 364
១០.២.១ ការអនុវត្ត ................ 364
១០.២.២ ការចាក់ផ្សាយតាមវិទ្យុ ................ 368
១០.២.៣ បរិយាកាសនៅក្នុងទីក្រុងភ្នំពេញ និងសេចក្តីប្រកាសស្តីពីការជម្លៀស ................ 370
១០.២.៤ លក្ខណៈបណ្តោះអាសន្ន និងការវិលត្រឡប់មកវិញ “ក្នុងរយៈពេល៣ថ្ងៃ” ................ 373
១០.២.៥ ការអះអាងអំពីការព្រួយបារម្ភផ្នែកសន្តិសុខ ................ 377
១០.២.៦ ការជម្លៀស “ដោយប្រើប្រាស់គ្រប់មធ្យោបាយ” ................ 383
១០.២.៧ គ្មានការលើកលែង ................ 395
១០.២.៨ ការធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ................ 407
១០.២.៩ គោលដៅដែលត្រូវទៅ ................ 413
១០.២.១០ បន្ទាប់ពីរយៈពេល៣ថ្ងៃ ................ 417
១០.២.១១ អំពើហឹង្សាដែលបានទទួលរង ................ 422
១០.២.១២ លក្ខខណ្ឌផ្សេងៗដែលបានទទួលរង ................ 425
១០.២.១៣ ជំនួយដែលត្រូវបានផ្តល់ ................ 430
១០.២.១៤ ការស្លាប់ ................ 435

១០.២.១៥ សាកសព....438
១០.២.១៦ ការប្រព្រឹត្តិមកលើអ្នករដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ....442
១០.២.១៧ ប៉ុស្តិ៍ត្រួតពិនិត្យ....464
១០.២.១៨ ការប្រព្រឹត្តិមកលើអ្នកដែលត្រូវបានជម្លៀសនៅពេលទៅដល់ភ្លាម....472
១០.២.១៩ ការបញ្ចប់ការផ្លាស់ទីលំនៅប្រជាជន....477
១០.២.២០ ចំនួនប្រជាជនសរុបដែលត្រូវបានផ្លាស់ទីលំនៅ....481
១០.២.២១ ចំនួនមនុស្សស្លាប់សរុប....482
១០.២.២២ ផលប៉ះពាល់ទៅលើអ្នកដែលត្រូវបានជម្លៀស....483
១០.៣ គោលនយោបាយ និងយុត្តិកម្មចំពោះការជម្លៀស....485
១០.៣.១ ការធ្វើឲ្យមានសន្តិសុខដើម្បីប្រឆាំងនឹងសត្រូវ និងការធ្វើឲ្យសត្រូវចុះខ្សោយ..485
១០.៣.២ ការខ្វះស្បៀងអាហារ និងលក្ខខណ្ឌនៅក្នុងទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥....494
១០.៣.៣ ផែនការដែលត្រូវបានបង្កើតទុកជាមុន និងគោលនយោបាយរួម....500
១០.៣.៤ គុណតម្លៃផ្នែកមនោគមវិជ្ជា និងបដិវត្តន៍កសិកម្ម....503
១០.៤ សម្អាងច្បាប់....505
១០.៤.១ ការផ្លាស់ទីលំនៅដោយបង្ខំ....505
១០.៤.២ ការធ្វើមនុស្សឃាត....509
១០.៤.៣ ការសម្លាប់រង្គាល....513
១០.៤.៤ អំពើអមនុស្សធម៌ផ្សេងៗទៀតដែលជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ....515
១០.៤.៥ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ....516
១១. **ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)**....523
១១.១ ទិដ្ឋភាពទូទៅ....524
១១.២ ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ទក្សិណ ទៅកាន់តំបន់ឧត្តរនៃប្រទេស....536
១១.២.១ ដំណាក់កាលទី១៖ ការបញ្ជូនទៅដាក់នៅទីតាំងប្រមូលផ្តុំ....549
១១.២.២ ដំណាក់កាលទី២៖ ការបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគ (ឧត្តរចាស់) កណ្តាល និងតំបន់ ១០៣....555

១១.២.៣ ដំណាក់កាលទី៣៖ ការចាត់តាំងទៅតាមការដ្ឋានធ្វើការងារ និង សហករណ៍ ........ 564

១១.៣ ទិសដៅនៃការបង្កបង្កើនផល៖ ការផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់ទក្សិណ និងតំបន់កណ្តាល........ 570

១១.៣.១ ទិសដៅឆ្នាំ ១៩៧៦៖ ៣ តោន ក្នុង ១ ហិកតា........ 572

១១.៣.២ ទិសដៅ ឆ្នាំ១៩៧៧៖ ៣ តោន ឬ ៦ តោន ក្នុង ១ ហិកតា........ 581

១១.៤ ការតស៊ូវណ្ណៈប្រឆាំងនឹង "ប្រជាជនថ្មី"៖ ការផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់ទក្សិណ និងតំបន់កណ្តាល ........ 586

១១.៤.១ ការកសាងខ្លួននៅក្នុងសហករណ៍ (ខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៦) ........ 589

១១.៤.២ ការបែងចែកសមាសភាពឲ្យបានច្បាស់លាស់ (ឆ្នាំ ១៩៧៧) ........ 596

១១.៥ ការផ្លាស់ទីលំនៅចេញឲ្យឆ្ងាយពីព្រំដែនវៀតណាម........ 598

១១.៦ សម្អាងច្បាប់ ........ 601

១១.៦.១ ការជម្លៀសដោយបង្ខំ........ 604

១១.៦.២ ការបាត់ខ្លួនដោយបង្ខំ........ 610

១១.៦.៣ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ........ 612

១១.៦.៤ ការសម្លាប់រង្គាល ........ 613

១១.៦.៥ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ........ 615

១២ ទួលពោធិ៍ជ្រៃ ........ 620

១២.១ ការបរាជ័យនៅខេត្តពោធិ៍សាត់ និងកិច្ចប្រជុំរបស់គណៈភូមិភាគ ........ 622

១២.២ កិច្ចប្រជុំជាមួយអ្នករដ្ឋការ លន់ នល់ នៅសាលាខេត្តពោធិ៍សាត់ ........ 627

១២.៣ ការដឹកជញ្ជូនទៅទួលពោធិ៍ជ្រៃ ........ 635

១២.៤ ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ........ 639

១២.៥ សម្អាងច្បាប់ ........ 643

១៣. ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល........ 646

១៣.១ សេចក្តីផ្តើម ........ 646

១៣.២ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ........ 647

១៣.៣ ការរៀបចំផែនការ ....... 652
១៣.៤ ការញុះញង់ ....... 653
១៣.៥ ការបញ្ជា ....... 655
១៣.៦ ការជួយ និងការជំរុញ ....... 656
១៣.៦.១ ការជួយ និងការជំរុញតាមរយៈអំពើអកម្ម ....... 658
១៣.៦.២ គោលដៅជាក់លាក់ ....... 659
១៣.៦.៣ ការជួយជ្រោមជ្រែងក្រោយពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម ....... 662
១៣.៧ ការទទួលខុសត្រូវរបស់ថ្នាក់លើ ....... 664
១៣.៧.១ ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ....... 666
១៣.៧.២ កាតព្វកិច្ចក្នុងការចាត់វិធានការ ....... 669
១៣.៧.៣ ទំនាក់ទំនងរបស់អ្នកនៅក្រោមបង្គាប់ ....... 670
១៤. សហឧក្រិដ្ឋកម្មរួម ....... 670
១៤.១ គោលបំណងរួម ....... 671
១៤.១.១ ដំណាក់កាលទី១៖ ការកសាងបក្ស ....... 673
១៤.១.២ ដំណាក់កាលទី២៖ ការផ្តួចផ្តើមបដិវត្តន៍ប្រដាប់អាវុធ ....... 676
១៤.១.៣ ដំណាក់កាលទី៣៖ បដិវត្តន៍ប្រជាធិបតេយ្យ ....... 680
១៤.១.៤ ដំណាក់កាលទី៤៖ បដិវត្តន៍សង្គមនិយម ....... 686
១៤.១.៤.១ ការកាន់កាប់ និងការគ្រប់គ្រងអំណាចជាបណ្តោះអាសន្នរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោយពេលរំដោះ ....... 695
១៤.១.៤.២ ការចងក្រងបង្កើតមាគ៌ាបក្ស ....... 708
១៤.១.៤.៣ ការរំលាយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ....... 711
១៤.១.៤.៤ កម្ពុជាប្រជាធិបតេយ្យ ....... 718
១៤.១.៥ សំអាងច្បាប់ ....... 731
១៤.២ គោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន ....... 735
១៤.២.១ ទិដ្ឋភាពទូទៅ ....... 737
១៤.២.២ ការជម្លៀសប្រជាជនចេញពីខេត្ត-ក្រុង ....... 747
១៤.២.២.១ គោលនយោបាយ ....... 747

១៤.២.២.២ យុត្តិកម្ម.....750
១៤.២.២.៣ វិធីសាស្ត្រ.....754
១៤.២.៣ ការផ្លាស់ទីលំនៅក្នុងទីជនបទ.....757
១៤.២.៣.១ គោលនយោបាយ.....757
១៤.២.៣.២ យុត្តិកម្ម.....760
១៤.២.៣.៣ វិធីសាស្ត្រ.....760
១៤.២.៤ សំអាងច្បាប់.....763
១៤.៣ គោលនយោបាយកំណត់គោលដៅ.....766
១៤.៣.១ គោលនយោបាយ.....769
១៤.៣.២ យុត្តិកម្ម និងការបដិសេធ.....776
១៤.៣.២.១ សេចក្តីប្រកាសរបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា.....777
១៤.៣.២.២ សង្គ្រាមជាមួយពួកចក្រពត្តិនៅតែបន្ត.....783
១៤.៣.២.៣ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរកំពុងធ្វើការនៅតាមជនបទ.....787
១៤.៣.៣ វិធីសាស្ត្រ.....789
១៤.៣.៤ សំអាងច្បាប់.....798
**១៥. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា.....800**
១៥.១ ការដឹង ដែលទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ.....801
១៥.១.១ ការដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម.....803
១៥.១.២ ការដឹងនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម.....807
១៥.១.២.១ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១).....808
១៥.១.២.២ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២).....809
១៥.១.២.៣ ការសម្លាប់នៅទួលពោធិ៍ជ្រៃ.....810
១៥.១.៣ ការដឹងនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម.....812
១៥.២ ការទទួលខុសត្រូវរបស់ភូមិភាគនានាចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត.....813
១៥.៣ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម.....814
១៥.៣.១ ការរួមចំណែក.....814

១៥.៣.១.១ ការបង្កើតគោលនយោបាយ ៖ ការរៀបចំផែនការអនុវត្តគោលបំណងរួម ........................................................................................ 815

១៥.៣.១.២ ការឃោសនា ការអប់រំ និងការបណ្តុះបណ្តាលមហាជន៖ ការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួម ........................................ 819

១៥.៣.២ ចេតនា........................................................................ 822

១៥.៣.៣ សេចក្តីសន្និដ្ឋាន ............................................................... 823

១៥.៤ ទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវ ........................................... 823

១៥.៤.១ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១)........................................................... 823

១៥.៤.១.១ ការរៀបចំផែនការ ............................................... 823

១៥.៤.១.២ ការបញ្ជា ........................................................ 826

១៥.៤.១.៣ ការញុះញង់........................................................ 828

១៥.៤.១.៤ ការជួយ និងជំរុញ ................................................ 830

១៥.៤.១.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ................................. 831

១៥.៤.១.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់ ................ 832

១៥.៤.១.៥.២ បានដឹង ឬ មានហេតុផលដឹង........................................ 833

១៥.៤.១.៥.៣ ការខកខានក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម ..................... 833

១៥.៤.២ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ......................................................... 834

១៥.៤.២.១ ការរៀបចំផែនការ ............................................... 834

១៥.៤.២.២ ការបញ្ជា ....................................................... 838

១៥.៤.២.៣ ការញុះញង់ ..................................................... 839

១.៤.២.៤ ការជួយ និងជំរុញ................................................... 841

១៥.៤.២.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ................................ 842

១៥.៤.២.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់................ 842

១៥.៤.២.៥.២ បានដឹង ឬ មានហេតុផលដឹង ....................................... 843

១៥.៤.២.៥.៣ ការខកខានក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម..................... 843

១៥.៤.៣ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ........ 844

១៥.៤.៣.១ ការរៀបចំផែនការ ........ 844

១៥.៤.៣.២ ការបញ្ជា ........ 847

១៥.៤.៣.៣ ការញុះញង់ ........ 849

១៥.៤.៣.៤ ការជួយ និងជំរុញ ........ 850

១៥.៤.៣.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 852

១៥.៤.៣.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់ ........ 852

១៥.៤.៣.៥.២ បានដឹង ឬ មានហេតុផលដឹង ........ 854

១៥.៤.៣.៥.៣ ការមិនបានទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម ........ 855

១៥.៥ សេចក្តីសន្និដ្ឋាន ........ 856

១៦. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ........ 857

១៦.១ ការដឹង ដែលទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ ........ 858

១៦.១.១ ការដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ........ 860

១៦.១.២ ការដឹងនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ........ 864

១៦.១.២.១ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ........ 864

១៦.១.២.២ ការសម្លាប់នៅទួលពោធិ៍ជ្រៃ ........ 865

១៦.១.២.៣ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ........ 866

១៦.១.៣ ការដឹងនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម ........ 867

១៦.២ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ........ 869

១៦.២.១ ការរួមចំណែក ........ 869

១៦.២.១.១ កិច្ចប្រជុំគោលនយោបាយ៖ ការរៀបចំគោលបំណងរួម ........ 872

១៦.២.១.២ កិច្ចប្រជុំណែនាំ៖ ការផ្សព្វផ្សាយគោលបំណងរួម ........ 875

១៦.២.១.៣ សេដ្ឋកិច្ចវិទូ៖ ការអនុវត្តគោលបំណងរួម ........ 877

១៦.២.១.៤ សេចក្តីថ្លែងការណ៍ជាសាធារណៈ៖ ការឯកភាពលើគោលបំណងរួម ........ 878

១៦.២.១.៥ កម្មាភិបាលតំណាងទូត៖ ការការពារគោលបំណងរួម ........ 882

១៦.២.២ ចេតនា ........ 885

១៦.២.៣ ការសន្និដ្ឋាន ........ 887

01006305



១៦.៣ ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ ........ 887
១៦.៣.១ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ........ 887
១៦.៣.១.១ ការរៀបចំផែនការ ........ 887
១៦.៣.១.២ ការបញ្ជា ........ 891
១៦.៣.១.៣ ការជួយ និងជំរុញ ........ 893
១៦.៣.១.៤ ការញុះញង់ ........ 895
១៦.៣.១.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 897
១៦.៣.២ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ........ 900
១៦.៣.២.១ ការរៀបចំផែនការ ........ 900
១៦.៣.២.២ ការបញ្ជា ........ 904
១៦.៣.២.៣ ការញុះញង់ ........ 905
១៦.៣.២.៤ ការជួយ និងជំរុញ ........ 906
១៦.៣.២.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 908
១៦.៣.៣ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ........ 909
១៦.៣.៣.១ ការរៀបចំផែនការ ........ 909
១៦.៣.៣.២ ការបញ្ជា ........ 911
១៦.៣.៣.៣ ការញុះញង់ ........ 912
១៦.៣.៣.៤ ការជួយ និងជំរុញ ........ 913
១៦.៣.៣.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 915
១៦.៤ សេចក្តីសន្និដ្ឋាន ........ 916
១៧. ពិរុទ្ធពីបទល្មើសច្រើន ........ 917
១៨. ការផ្តន្ទាទោស ........ 920
១៨.១ សារណា ........ 920
១៨.២ ច្បាប់ជាធរមាន ........ 922
១៨.២.១ បទប្បញ្ញត្តិ និងក្របខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនៅ អ.វ.ត.ក ........ 922

១៨.២.២ គោលការណ៍ និងកត្តានានាដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស ..................... 923
១៨.២.៣ អានុភាពនៃការរកឃើញពិរុទ្ធពីបទល្មើសច្រើននៅពេលផ្តន្ទាទោស ........... 926
១៨.៣ សំអាងហេតុ ............................................................................ 927
១៨.៣.១ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ......................................................... 927
១៨.៣.១.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ ......................... 927
១៨.៣.១.២ តួនាទីរបស់ នួន ជា ........................................................ 929
១៨.៣.១.៣ តួនាទីរបស់ ខៀវ សំផន.................................................... 930
១៨.៣.២ ស្ថានទម្ងន់ទោស ................................................................ 931
១៨.៣.២.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ ......................... 931
១៨.៣.២.២ ការពិចារណាចំពោះ នួន ជា ............................................... 932
១៨.៣.២.៣ ការពិចារណាចំពោះ ខៀវ សំផន.......................................... 932
១៨.៣.៣ ស្ថានសម្រាលទោស............................................................... 933
១៨.៣.៣.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ........................ 933
១៨.៣.៣.២ ការពិចារណាចំពោះ នួន ជា............................................... 934
១៨.៣.៣.៣ ការពិចារណាចំពោះ ខៀវ សំផន ......................................... 936
១៨.៣.៤ សាក្សីអំពីអត្តចរិតរបស់ជនជាប់ចោទ........................................ 937
១៨.៣.៥ ការផ្តន្ទាទោស.................................................................... 941
១៨.៣.៥.១ ទោសជាប់ពន្ធនាគារ ....................................................... 941
១៨.៣.៥.២ ការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាប់ចោទ .............................. 942
**១៩. សំណងរដ្ឋប្បវេណី**.......................................................................... 942
១៩.១ សេចក្តីផ្តើម ............................................................................ 942
១៩.២ ក្របខណ្ឌច្បាប់.......................................................................... 945
១៩.៣ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ................................................. 951
១៩.៣.១ គម្រោងទី ១៖ ទិវាជាតិនៃការចងចាំ ............................................ 953
១៩.៣.២ គម្រោងទី ២៖ គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រម្លឹកជាសាធារណៈ... 954
១៩.៣.៣ គម្រោងទី ៣៖ ការសាងសង់ស្តូបនៅរាជធានីភ្នំពេញសម្រាប់រម្លឹកដល់ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំ ............................................................ 955

១៩.៣.៤ គម្រោងទី ៤៖ ការសាងសង់ស្តូបសម្រាប់រម្លឹកដល់ជនរងគ្រោះរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរដែលរស់នៅប្រទេសបារាំង.................................. 956
១៩.៣.៥ គម្រោងទី ៥៖ វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម ................ 957
១៩.៣.៦ គម្រោងទី ៦៖ ក្រុមជួយខ្លួនឯង.................................................. 959
១៩.៣.៧ គម្រោងទី ៧៖ ការតាំងពិពណ៌ជាអចិន្ត្រៃយ៍...................................... 959
១៩.៣.៨ គម្រោងទី ៨៖ ការតាំងពិពណ៌ចល័ត និងគម្រោងអប់រំ៖ សិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រ និងយុត្តិធម៌អន្តរកាល ....................................................... 960
១៩.៣.៩ គម្រោងទី ៩៖ ការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និង ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា ........ 961
១៩.៣.១០ គម្រោងទី ១០៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព.................... 962
១៩.៣.១១ គម្រោងទី ១១៖ គម្រោងបោះពុម្ពកូនសៀវភៅអំពីអង្គហេតុដែលត្រូវបានសម្រេចសេចក្តីក្នុងសំណុំរឿង ០០២/០១ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី .. 963
១៩.៣.១២ គម្រោងទី ១២៖ បោះពុម្ព និងផ្សព្វផ្សាយសាលក្រមសំណុំរឿង ០០២/០១ ជាពីរប្រភេទ ....................................................................................... 964
១៩.៣.១៣ គម្រោងទី ១៣៖ គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក ......................................................................... 964
១៩.៤ ព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ..................................... 965
១៩.៥ ការវាយតម្លៃលើរាល់សំណាងទាំងអស់ដែលសហមេធាវីនាំមុខបានស្នើសុំ............. 973
១៩.៥.១ គម្រោងទាក់ទងការចងចាំ និងបូជនីយដ្ឋានសម្រាប់រម្លឹក៖ គម្រោងទី ១ និងគម្រោងទី ៣............................................................................ 973
១៩.៥.២ គម្រោងទាក់ទងវិធីសាស្ត្រព្យាបាល និងជំនួយផ្នែកផ្លូវចិត្តដល់ជនរងគ្រោះ៖ គម្រោង ទី ៥ និងគម្រោងទី ៦ ..................................................... 974
១៩.៥.៣ ការចងក្រងឯកសារ និងការអប់រំ៖ គម្រោងទី ៧, ៨, ៩, ១០, ១១, ១២, និងគម្រោងទី ១៣.......................................................................... 975
១៩.៥.៤ គម្រោងនានាដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនទទួលយក៖ គម្រោងទី ២ និងគម្រោងទី ៤ ........................................................................ 977
២០. សេចក្តីសម្រេច............................................................................ 978

# ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូង "អង្គជំនុំជម្រះ" នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ក្រោយពីបានទទួលសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង ("សំណុំរឿង០០២") សម្រេចចេញសាលក្រមប្រឆាំងឈ្មោះ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១។

## ១.១ ប្រវត្តិសង្ខេបនៃកិច្ចដំណើរការនីតិវិធីនៃរឿងក្តី

២. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អនុលោមតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង ដោយចោទប្រកាន់ នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[១]។ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានសម្រេចចេញដីកាបំបែកការចោទប្រកាន់ ដោយធ្វើការស៊ើបសួរជាសំណុំរឿងពីរផ្សេងគ្នា គឺៈ សំណុំរឿង ០០១ ដែលវិសាលភាពនៃសំណុំរឿងនេះគឺត្រូវបានកម្រិតត្រឹមការចោទប្រកាន់ប្រឆាំងនឹងឈ្មោះ កាំង ហ្គេកអ៊ាវ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ និងសំណុំរឿង ០០២ បានដាក់បញ្ចូលការចោទប្រកាន់ទាំងអស់ដែលនៅសេសសល់[២]។ នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១០ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើ

[១] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារ D3 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ។ សហព្រះរាជអាជ្ញាមានយុត្តាធិការតែមួយគត់គឺចាប់ផ្តើមការចោទប្រកាន់លើឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក តាមរយៈការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (វិធាន ៤៩(១) និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ បង្កើតឲ្យមានការស៊ើបសួរតាមផ្លូវតុលាការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត (វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង)។ នៅពេលដែលដំណើរការនីតិវិធីតាមផ្លូវតុលាការបានចាប់ផ្តើម ការស៊ើបសួរតាមផ្លូវតុលាការគឺចាំបាច់ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក (វិធាន ៥៥(១) នៃវិធានផ្ទៃក្នុង)។ សហព្រះរាជ-អាជ្ញាមិនអាចបន្ថយ ឬទម្លាក់ចោលការចោទប្រកាន់ផ្នែកណាមួយឬទាំងអស់ ដែលការកាត់បន្ថយ ឬទម្លាក់ចោលការចោទប្រកាន់នេះ ត្រូវតែកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ។

[២] ដីកាបំបែកសំណុំរឿង (ក.ស.ច.ស) ឯកសារ D18 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ។

អនុសញ្ញាទីក្រុងហ្សឺណែវ[៣]។ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបាន សម្រេចលើកលែងការចោទប្រកាន់ប្រឆាំងលើឈ្មោះ កាំង ហ្គេកអ៊ាវ នៅក្នុងសំណុំរឿង ០០២[៤]។

៣. នៅចន្លោះពីថ្ងៃទី ១៩ ខែ កញ្ញា ដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នួន ជា, អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួនដោយដីការបស់សហចៅក្រមស៊ើបអង្កេត ហើយត្រូវ បានបញ្ជូនមកមន្ទីរឃុំឃាំង អ.វ.ត.ក និងត្រូវបានជូនដំណឹងអំពីការចោទប្រកាន់មកលើរូបគាត់[៥]។ ក្រោយពីការស៊ើបសួរតាមផ្លូវតុលាការអស់រយៈពេល ៣ ឆ្នាំ ដែលក្នុងអំឡុងពេលនោះ បុគ្គលចំនួន ៣.៨៦៦ នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បទប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភ បំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[៦]។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១១ នៅក្នុងសាលដីកាលើបណ្តឹង ឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានរក្សាការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែលមានទំហំធំធេង ដដែល តែបានធ្វើការកែប្រែលើចំណុចមួយចំនួន និងបានបញ្ជូនជនជាប់ចោទចំនួន ៤ រូបទៅ ជំនុំជម្រះ[៧]។

---

[៣] សាលក្រមសំណុំរឿង ០០១ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ (“សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ*”)។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង០០១ (អ.ជ.ត.ក) ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ (“សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ*”)។

[៤] ដីកាសម្រេចលើកលែងការចោទប្រកាន់ (ក.ស.ច.ស) ឯកសារ D420 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ ។

[៥] កំណត់ហេតុនាំខ្លួនជនសង្ស័យ នួន ជា (ក.ស.ច.ស) ឯកសារ C7 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ។ ដីកាសម្រេចឃុំខ្លួន នួន ជា ជាបណ្តោះអាសន្ន (ក.ស.ច.ស) ឯកសារ C9 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ។ ដីកាបង្គាប់ឲ្យឃុំខ្លួន អៀង សារី (ក.ស.ច.ស) ឯកសារ C23 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ សេចក្តីសម្រេចឃាត់ខ្លួន (ក.ស.ច.ស) ឯកសារ C14 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ កំណត់ហេតុនាំខ្លួនជនសង្ស័យ ខៀវ សំផន (ក.ស.ច.ស) ឯកសារ C24/I ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (ក.ស.ច.ស) ឯកសារ C26 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ សេចក្តីសម្រេចឃាត់ខ្លួន (ក.ស.ច.ស) ឯកសារ C15 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ កំណត់ហេតុនាំខ្លួនជនសង្ស័យ (ក.ស.ច.ស) ឯកសារ C13/I ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។ ដីកាបង្គាប់ឲ្យនាំខ្លួន (ក.ស.ច.ស) ឯកសារ C13 ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

[៦] ដីកាដំណោះស្រាយ (ក.ស.ច.ស) ឯកសារ D427 ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០១០ (“ដីកាដំណោះស្រាយ”) កថាខណ្ឌ ១៦១៣ ។

[៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) D427/2/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ ទំព័រ៦ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកា

៤. បន្ទាប់ពីចេញសេចក្ដីសម្រេចលើពាក្យសុំដោះលែងឲ្យនៅក្រៅឃុំ និងក្រោយពីបានទទួលសំណើសុំរបស់ភាគីនានាឲ្យស្ដាប់សក្ខីកម្មសាក្សីសរុបទាំងអស់ចំនួន ១.០៥៤ នាក់ និងស្នើសុំដាក់ឯកសារក្នុងសំណុំរឿងចំនួនប្រហែល ៧.៦០០ ឯកសារ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ក្នុងគោលបំណងដើម្បីចាប់ផ្ដើមកិច្ចដំណើរការសវនាការឲ្យបានឆាប់រហ័ស។ សវនាការបឋមត្រូវបានធ្វើឡើងពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១១ ក្នុងគោលបំណងដើម្បីជូនដំណឹងដល់ភាគីជាមុនអំពីអាទិភាពនៃសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងបំផុតក្នុងសំណុំរឿង០០២[៨]។ អង្គជំនុំជម្រះក៏បានស្ដាប់នូវសំណើសុំពាក់ព័ន្ធនឹងអញ្ញត្រកម្មជាច្រើនអំពីបញ្ហាយុត្តាធិការ។ ក្នុងរយៈពេលប៉ុន្មានខែបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយលើបញ្ហាអញ្ញត្រកម្មដែលអង្គជំនុំជម្រះពិចារណាឃើញថា អាចបង្កើតជាឧបសគ្គរារាំងដល់ការចាប់ផ្ដើមការជំនុំជម្រះ[៩]។

---

ដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤ ។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤-៥។ អង្គបុរេជំនុំជម្រះបានកែប្រែដីកាដំណោះស្រាយដើម្បីតម្រូវឲ្យមានចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ និងបានបញ្ជាក់ថា ការរំលោភផ្លូវភេទត្រូវបានចាត់ក្នុងប្រភេទជាអំពើអមនុស្សធម៌ដទៃទៀត។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនោះ (សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/8 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៣៣)។

[៨] សេចក្ដីណែនាំដល់ភាគី (មុនពេលមានការពិភាក្សានៅក្នុងកិច្ចសវនាការបឋមស្ដីពីបញ្ជីបណ្ដោះអាសន្នឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី) (អ.ជ.ស.ដ) ឯកសារ E108 ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ។

[៩] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ឯកសារ E51/14 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ ។ សេចក្ដីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ។ សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ។ សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) ឯកសារ E51/15 ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។ ទោះបីជាភាគីបានរៀបរាប់ថាជាអញ្ញត្រកម្មក្ដី អង្គជំនុំជម្រះបែរជាចាត់ទុកថាជាការសមស្របសម្រាប់ការដោះស្រាយបញ្ហានៅក្នុងសាលក្រម ឬពន្យារពេលសម្រាប់ការជំនុំជម្រះពេលខាងមុខនៅក្នុងសំណុំរឿង០០២ ដោយសារតែសារណាទាំងនេះ ពាក់ព័ន្ធនឹងបញ្ហាដែលស្ថិតនៅខាងក្រៅវិសាលភាពសំណុំរឿង ០០២/០១ (ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេល

ជាពិសេស អង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះបានទទួលសំណុំរឿងដែលពុំមានសុពលភាព ពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលមាននៅក្នុងផ្នែកនៃសេចក្តីសម្រេចនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ និងថា អង្គជំនុំជម្រះពុំមានមូលដ្ឋានជំនុំជម្រះជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយល់ព្រមតាមសំណើសុំរបស់ អៀង សារី ក្នុងការលុបចោលចំណុចដែលមានក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹងការជំនុំជម្រះលើបទឧក្រិដ្ឋតាមច្បាប់ជាតិនៅចំពោះមុខ អ.វ.ត.ក[១០]។

៥. ដើម្បីធានាលទ្ធភាពរបស់ខ្លួន ក្នុងការចេញសាលក្រមឲ្យទាន់ពេលវេលានៅក្នុងសំណុំរឿង ០០២ ដោយពិចារណាលើរយៈពេល និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ ព្រមទាំងការចុះខ្សោយផ្នែករាងកាយ និងវ័យចំណាស់របស់ជនជាប់ចោទទាំងអស់នោះ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះបានកំណត់វិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២ ត្រឹមការចោទប្រកាន់ផ្នែកអង្គហេតុ ដែលមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ដែលកម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលផ្លាស់ទីលំនៅប្រជាជននោះ[១១]។ ក្រោយមក អង្គជំនុំជម្រះបានពង្រីកវិសាលភាពសំណុំរឿង ០០២/០១ ដោយរួមបញ្ចូលការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ផងដែរ[១២]។

---

សវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១)។

[១០] សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ឯកសារ E122 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ។

[១១] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលកែប្រែបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (ឯកសារ E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (ឯកសារ E163) ឯកសារ E124/7.3។

[១២] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់

៦. នៅខែ កុម្ភៈ ឆ្នាំ ២០១១ នួន ជា និង អៀង ធីរិទ្ធ បានស្នើសុំឱ្យតែងតាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់ពួកគាត់ក្នុងការចូលរួមសវនាការ[១៣]។ អង្គជំនុំជម្រះបានតែងតាំងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រសម្រាប់ធ្វើការវាយតម្លៃលើសម្បទានោះនៅខែ មេសា ឆ្នាំ ២០១១[១៤]។ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសម្រេចថា អៀង ធីរិទ្ធ មិនមានសម្បទាក្នុងការចូលរួមក្នុងសវនាការ ដោយសារតែឥទ្ធិពលនៃជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តន៍ទៅមុខ (ទំនងជាជំងឺ Alzheimer) និងបានសម្រេចចេញដីកាបង្គាប់ឱ្យបំបែកការចោទប្រកាន់ប្រឆាំងលើរូបគាត់ ចេញពីសំណុំរឿង ០០២ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់ ព្រមទាំងបានបង្គាប់ឱ្យដោះលែងគាត់[១៥]។

---

សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[១៣] សំណើជាបន្ទាន់សុំចាត់តាំងអ្នកជំនាញផ្នែកសម្បទា ឯកសារ E30 ចុះថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ ២០១១ ។ សំណើរបស់មេធាវីការពារក្តីស្នើសុំចាត់តាំងអ្នកជំនាញផ្នែកវិកលចរិត (Neuropsychiatrist) ដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E52 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ។ សូមមើលផងដែរ ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ ឯកសារ E20 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១១ ។

[១៤] ដីកាចាត់តាំងអ្នកជំនាញ ឯកសារE62/3 ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ ។

[១៥] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបង្គាប់ឱ្យជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្របន្ថែម (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (អ.ជ.ត.ក) ឯកសារ E138/1/7 ចុះថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០១១ ។ ក្រោយពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្របន្ថែមលើជនជាប់ចោទ ក្នុងអំឡុងពេលឆមាសទីមួយនៃឆ្នាំ ២០១២ និងបានកោះអញ្ជើញអ្នកជំនាញដែលអង្គជំនុំជម្រះបានចាត់តាំង ឱ្យធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការនៅខែ សីហា ឆ្នាំ ២០១២។ ផ្អែកតាមមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានតម្កល់ការរកឃើញរបស់ខ្លួនដែលសម្រេចថា អៀង ធីរិទ្ធ មិនមានសម្បទាក្នុងការចូលរួមសវនាការ និងជាថ្មីម្តងទៀត សម្រេចបង្គាប់ឱ្យដោះលែងជនជាប់ចោទ (សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះបន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ E138/1/10 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២)។ បន្ទាប់ពីមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលសម្រេចបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តនូវលក្ខខណ្ឌមួយចំនួនក្រោយពេលដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (អ.ជ.ត.ក) ឯកសារ E138/1/10/1/5/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១២)។ ក្រោយពីមានការបញ្ជាក់បំភ្លឺរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទិននឹងលក្ខខណ្ឌទាំងនេះ អង្គជំនុំជម្រះ

នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១[១៦] អង្គជំនុំជម្រះសម្រេចថា នួន ជា មានសម្បទាក្នុងការចូលរួមសវនាការ ហើយនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបញ្ជាក់សាជាថ្មីថា នួន ជា មានសម្បទាក្នុងការចូលរួមសវនាការ[១៧]។ អៀង សារី និង ខៀវ សំផន មិនបានតវ៉ាចំពោះរបាយការណ៍បឋមរបស់អ្នកជំនាញ ដែលបានសន្និដ្ឋានថា ពួកគាត់មានសម្បទាក្នុងការចូលរួមសវនាការនោះទេ[១៨]។ ក្រោយពីសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យជាច្រើនដង និងក្រោយពីបានចូលរួមសវនាការពីចម្ងាយ អង្គជំនុំជម្រះបានតែងតាំងអ្នកជំនាញសាជាថ្មីឱ្យវាយតម្លៃសម្បទារបស់ អៀង សារី កាលពីខែ សីហា និងខែ វិច្ឆិកា ឆ្នាំ ២០១២[១៩]។ ផ្អែកលើលទ្ធផលនៃរបាយការណ៍របស់អ្នកជំនាញនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២[២០] អង្គជំនុំជម្រះសម្រេចថា អៀង សារី មានសម្បទាក្នុងការចូលរួមសវនាការ។ មរណភាពរបស់ អៀង សារី នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ បានរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងលើរូបគាត់[២១]។

---

សាលាដំបូងបានអនុវត្តលក្ខខណ្ឌទាំងនេះនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ (សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺអំពីការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹង សាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (ឯកសារ E138/1/10/1/5/8) (អ.ជ.ស.ដ) ឯកសារ E138/1/10/1/5/8/3 ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣)។ ដីកាបង្គាប់ស្តីពីវិធានការដែលត្រូវអនុវត្តចំពោះជនជាប់ចោទ អៀង ធីរិទ្ធ (អ.ជ.ស.ដ) ឯកសារ E138/1/10/1/5/8/4 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣)។

[១៦] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

[១៧] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២។ សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ ។

[១៨] ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ (អ.ជ.ស.ដ) ឯកសារ E110 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១ ។

[១៩] ការពិនិត្យសុខភាពរបស់ជនជាប់ចោទ អៀង សារី ឯកសារ E222 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២ ។ របាយការណ៍សុខភាពរបស់លោក អៀង សារី ឯកសារ E222/1 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២ ។ ការតែងតាំងសាស្ត្រាចារ្យ A. John CAMPBELL សម្រាប់ជនជាប់ចោទ អៀង សារី (អ.ជ.ស.ដ) ឯកសារ E238 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ។

[២០] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារ E238/9 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

[២១] សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ឯកសារ E270/1 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ។ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះនៅតែពិចារណាទៅលើសារណាពាក់ព័ន្ធទាំង

៧. ការបើកធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ បានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចបដិសេធមិនពង្រីកវិសាលភាពនៃការជំនុំជម្រះ ដោយដាក់បញ្ចូលមន្ទីរសន្តិសុខ ស-២១ និងស្រុក ១២ នោះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធចោល ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្តីសម្រេចពាក់ព័ន្ធទាំងអស់[២២]។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យភាគីដាក់សារណាបន្ថែមស្តីពីវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១[២៣]។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ សាជាថ្មី ដោយបានកំណត់វិសាលភាពសំណុំរឿង ០០២/០១ ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២ និងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[២៤]។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងបានកំណត់បណ្តាកថាខណ្ឌជាក់លាក់មួយ

---

អស់ ដែលដាក់ដោយមេធាវីការពារក្តី អៀង សារី មុនពេលមរណភាពរបស់គាត់ ដែលនៅតែទាក់ទិននឹងបញ្ហានានានៅក្នុងសំណុំរឿង ០០២/០១ (*សូមមើលខទា.* សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៥៣។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ជើងទំព័រ ២)។

[២២] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ឯកសារ E163/5/1/13/1 ចុះថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។

[២៣] អនុស្សរណៈស្តីពីការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (អ.ជ.ស.ដ) ឯកសារ E163/5/1/13/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។

[២៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២-៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។ កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី និង កំណត់វិសាលភាពសំណុំរឿង០០២/០១ (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២, សេចក្តីសង្ខេបនៃសំអាងហេតុ ឯកសារ E284/4/7 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំង

ចំនួនក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[២៥]។ ដំណើរការសវនាការជំនុំ-ជម្រះនៃសំណុំរឿង០០២/០១ បានចាប់ផ្ដើមបន្តឡើងវិញនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣។

៨. សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ បានបញ្ចប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ បន្ទាប់ពីបើកសវនាការអស់រយៈពេល ២១៤ ថ្ងៃមក។ ភាគីបានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី ២៦ និងទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣។ ភាគីបានធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលនៅចន្លោះពីថ្ងៃទី ១៦ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣។

## **១.២ សេចក្តីសង្ខេបអំពីបទចោទប្រឆាំងនឹងជនជាប់ចោទ**

៩. ដីកាដំណោះស្រាយចោទប្រកាន់ថា នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នួន ជា *ហៅ* "បងធំទីពីរ" បានបំពេញមុខនាទីជាអនុលេខានៃគណៈកម្មា-ធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ហើយក្នុងពេលជាមួយគ្នានេះដែរ នួន ជា មានតួនាទីផ្សេងៗទៀត នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដូចជា រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ជានាយករដ្ឋមន្ត្រីស្តីទី ជាប្រធានសភាតំណាងប្រជាជន និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន[២៦]។

១០. ដីកាដំណោះស្រាយចោទប្រកាន់ថា នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ខៀវ សំផន *ហៅ* "ហែម" "ខាង" និង "ណន" មានតួនាទី និងមុខងារផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងជាប្រធាន

---

នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣) ។

[២៥] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១ (E163) ឯកសារ E124/7.3 ។

[២៦] ដីកាដំណោះស្រាយ កថាខណ្ឌ ៨៦៩-៨៩៤។

គណៈប្រធានរដ្ឋ ជាប្រធានមន្ទីរនយោបាយ៨៧០ និងជាសមាជិកគណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា[២៧]។

១១. ដីកាដំណោះស្រាយចោទប្រកាន់ថា នៅក្នុងអំឡុងពេលនៃការបំពេញមុខងារទាំងនេះ ជនជាប់ចោទបានប្រព្រឹត្ត (*តាមរយៈ*សហឧក្រិដ្ឋកម្មរួម) នូវ៖ ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមានការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) ។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ។ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[២៨] ។ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ជនជាប់ចោទបន្ថែមថា បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយនិងជម្រុញ និងជាអ្នកទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលក្នុងនោះមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការផ្លាស់ទីលំនៅដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ[២៩]។

---

[២៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៣១-១១៥០។

[២៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥ (i), ១៥២៥ (iv)។ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ។ សូមមើលផងដែរផ្នែកស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨០-៧៨១, ៨១២-៨១៣។ នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះសំដៅទៅលើទាំងពីរ “ទាហានសាធារណរដ្ឋខ្មែរ និងមន្ត្រីសាធារណរដ្ឋខ្មែរ” និងនៅពេលខ្លះសំដៅទៅលើ “មន្ត្រីសាធារណរដ្ឋខ្មែរ” ។ ចំពោះការប្រើពាក្យមន្ត្រីសាធារណរដ្ឋខ្មែរនេះគឺរួមបញ្ចូលទាំង “ទាហានសាធារណរដ្ឋផងដែរ” ។

[២៩] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

# ២. បញ្ហាអញ្ញត្រកម្ម

## ២.១ យុត្តាធិការ

១២. បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័ត "ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលសំណៅចុងក្រោយនៃច្បាប់នេះត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤[៣០]។ អនុលោមតាមមាត្រា២(១)នៃកិច្ចព្រមព្រៀង និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិការលើរូបបុគ្គលដែលជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[៣១]។

---

លើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១ (E163) ឯកសារ E124/7.3។

[៣០] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១, ២។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិតេយ្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយរួមបញ្ចូលការធ្វើវិសោធនកម្មដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/ ១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២។

[៣១] អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា គុណវុឌ្ឍិរបស់ជនជាប់ចោទក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺជាបញ្ហាចាំបាច់មួយនៃគោលការណ៍ស៊ើបសួរ និងការចោទប្រកាន់ នៅក្នុងឆន្ទានុសិទ្ធិតែមួយគត់របស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត។ ហេតុដូចនេះ បញ្ហានេះមិនអាចធ្វើការវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ លុះត្រាតែមានការចោទប្រកាន់អំពីការរំលោភលើឆន្ទានុសិទ្ធិសិន។ ថាតើជនជាប់ចោទជាមន្ត្រីខ្មែរក្រហម ឬមិនមែនជាមន្ត្រីខ្មែរក្រហម គឺជាលក្ខខណ្ឌតម្រូវយុត្តាធិការដែលត្រូវធ្វើការវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៧៩-៨០)។

១៣. សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ខ្លួនមានយុត្តាធិការលើរូបបុគ្គលចំពោះ នួន ជា និង ខៀវ សំផន ដោយយល់ឃើញថា ពួកគាត់គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[៣២]។ ជនជាប់ចោទមិនបានតវ៉ាចំពោះសេចក្ដីសម្រេចនេះទៅអង្គបុរេជំនុំជម្រះទេ។

១៤. ទោះជាយ៉ាងណាក្ដី ខៀវ សំផន នៅតែរក្សាជំហរថា អ.វ.ត.ក មិនមានយុត្តាធិការលើរូបបុគ្គលគាត់ទេ។ គាត់ជំទាស់ថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនធ្លាប់ធ្វើជាអ្នកសម្រេចចិត្តផ្នែកនយោបាយ ហើយគាត់ក៏មិនមានអំណាចជាក់ស្ដែង ឬអំណាចប្រតិបត្តិការទេ សូម្បីតែពេលដែលគាត់បានក្លាយជាប្រធានគណៈប្រធានរដ្ឋ ដែលជាប្រមុខរដ្ឋនិមិត្តរូបក៏ដោយ[៣៣]។ អំណាច និងការគ្រប់គ្រង ដែលជនជាប់ចោទមានក្នុងនាមជាសមាជិករបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា ឬក្នុងនាមជាប្រមុខរដ្ឋ គឺជាបញ្ហានៃអង្គហេតុដែលពាក់ព័ន្ធដល់ការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ហេតុដូច្នេះ មិនអាចជាការរារាំងដល់យុត្តាធិការនៅដំណាក់កាលជំនុំជម្រះទេ។ លើសពីនេះទៀត យោងតាមទម្ងន់នៃភ័ស្ដុតាងលើសលប់ និងតាមរយៈការសារភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទគឺជាមន្ត្រីខ្មែរក្រហមនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[៣៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះមានយុត្តាធិការលើរូបបុគ្គល នួន ជា និង ខៀវ សំផន។

១៥. លើសពីនេះទៀត ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០១ បានរងការចោទប្រកាន់ គឺជាបទល្មើសដែលបានប្រព្រឹត្តនៅក្នុងចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ស្ថិតនៅក្នុងយុត្តាធិការលើរឿងក្ដី និងយុត្តាធិការ

[៣២] ដីកាដំណោះស្រាយ កថាខណ្ឌ១៣២៧-១៣២៨។

[៣៣] អញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការ ឯកសារ E46 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១១-១៥។ *សូមមើលផងដែរ* សេចក្ដីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ (អ.ជ.ស.ដ) ឯកសារ E51/7 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៤ (ដោយពិចារណាឃើញថា ដំណោះស្រាយចំពោះអញ្ញត្រកម្មរបស់ ខៀវ សំផន ដែលទាក់ទិននឹងយុត្តាធិការបុគ្គល បង្ហាញពីការវាយតម្លៃរួមចូលគ្នាមួយទៅលើអង្គហេតុ និងអង្គច្បាប់ អង្គជំនុំជម្រះពន្យារពេលការពិចារណាសារណាទាំងនេះរហូតបន្ទាប់ពីសវនាការស្ដីពីភ័ស្ដុតាងសិន)។

[៣៤] *សូមមើល* ផ្នែកទី ៧ ស្ដីពីតួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៧-៣៤៨។ ផ្នែកទី ៨ ស្ដីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៨-៤០៩ ។

តាមពេលវេលារបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងមាត្រា ១ និងមាត្រា ៩ នៃកិច្ចព្រមព្រៀង និង មាត្រា ១ និងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

## ២.២ គោលការណ៍នីត្យានុកូលភាព

១៦. ទាំងគោលការណ៍នីត្យានុកូលភាពកម្ពុជា និងគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលទាក់ទងនឹងគោលការណ៍ទូទៅគឺ *គ្មានការផ្តន្ទាទោស បើគ្មានច្បាប់ចែង* (nulla poena sine lege) និងគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* (nullum crimen sine lege) តម្រូវឱ្យច្បាប់ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមានភាពច្បាស់លាស់ពិតប្រាកដ និងមិនប្រតិសកម្ម[៣៥]។ ដូច្នេះ នៅក្នុងបរិបទជាក់លាក់នៃ អ.វ.ត.ក គោលការណ៍នីត្យានុ-កូលភាពតម្រូវឱ្យបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ ត្រូវតែមាននៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយជនជាប់ចោទអាចប្រមើលមើលឃើញ និងដឹងផងដែរ[៣៦]។ គោលការណ៍នេះមិនបានហាមឃាត់អង្គជំនុំជម្រះក្នុងការធ្វើការបកស្រាយ និងបញ្ជាក់បំភ្លឺអំពីច្បាប់ ឬក៏ផ្អែកលើសេចក្តីសម្រេចនានានៅក្នុងរឿងក្តីផ្សេងៗទៀតនោះទេ បើទោះបីជារឿងក្តីទាំងនោះកើតមាននៅក្រោយអំឡុងពេលដែលស្ថិតនៅក្រោមការពិនិត្យក៏ដោយ។ ទោះជាយ៉ាងណាក្តី គោលការណ៍នេះ

---

[៣៥] សាលដីកាអង្គជំនុំជម្រះតុលាការកំពូល *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ៩១។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៖ (“ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ”) មាត្រា ៣ (“មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន”)។ មាត្រា ៥ (“ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬបកស្រាយតាមសទិសភាពបានឡើយ”)។ មាត្រា ៨ (“បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាអាណាចក្រកម្ពុជាឡើយ”)។

[៣៦] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៦-៣៤។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៨៩-៩៧។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣។

ពិតជាហាមឃាត់អង្គជំនុំជម្រះមិនឱ្យ "បង្កើតច្បាប់ថ្មី ឬបកស្រាយច្បាប់ដែលមានស្រាប់ឱ្យហួសពីដែនកំណត់សមហេតុផលនៃការបញ្ជាក់បំភ្លឺដែលអាចទទួលយកបាននោះឡើយ"[៣៧]។

១៧. ខៀវ សំផន និង នួន ជា លើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការជំនុំជម្រះលើឧក្រិដ្ឋកម្មអន្តរជាតិទេ ដោយសារតែ អ.វ.ត.ក មិនមែនជាតុលាការអន្តរជាតិ មិនអាចអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់ ហើយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនៅក្រោមច្បាប់ជាតិនោះទេ នៅក្នុងអំឡុងពេលដែលបទល្មើសនោះត្រូវបានគេចោទប្រកាន់ថា បានប្រព្រឹត្តនោះ។ ខៀវ សំផន និង នួន ជា ក៏បានអះអាងថា នៅគ្រប់ករណីទាំងអស់ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបានផ្តល់និយមន័យលម្អិតអំពីបទឧក្រិដ្ឋ និងការផ្តន្ទាទោសជាធរមាន ដូចដែលតម្រូវដោយគោលការណ៍នីត្យានុកូលភាពនោះទេ[៣៨]។ អង្គជំនុំជម្រះយល់ឃើញថា សារណាទាំងនេះមិនមានមូលដ្ឋានគាំទ្រទេ។

១៨. ជាគោលការណ៍ ជនជាប់ចោទមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្រោមច្បាប់អន្តរជាតិ ដោយគ្រាន់តែលើកឡើងថា ឧក្រិដ្ឋកម្មអន្តរជាតិមិនមានចែងនៅក្នុងច្បាប់ជាតិនោះទេ[៣៩]។ ក្នុងករណីដែលច្បាប់ជាតិមិនមានចែងអំពីចរិតលក្ខណៈជាក់លាក់នៃឧក្រិដ្ឋកម្មអន្តរជាតិ តុលាការអាចផ្អែកទៅលើច្បាប់អន្តរជាតិ ហើយមិនត្រូវបានគេចាត់ទុកថាជាការរំលោភលើ

---

[៣៧] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៩៥ *ដោយដកស្រង់* សាលដីកាក្នុងរឿងក្តី *Aleksovski* កថាខណ្ឌ ១២៦-១២៧។

[៣៨] អញ្ញត្រកម្មរួមបញ្ចូលគ្នា ឯកសារE51/3 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤៣-៤៨, ៥៣។ អញ្ញត្រកម្មបឋមលើយុត្តាធិការ ឯកសារ E46 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤-៥, ១៩, ២៤។ *សូមមើលផងដែរ* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានា នាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍ ឯកសារ E51/4 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤(ង) *ដោយយោងលើ* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ ១០៦, ១០៨, ១២៥។

[៣៩] គោលការណ៍តុលាការNuremberg គោលការណ៍ II ("ការពិតដែលថា ច្បាប់ផ្ទៃក្នុងមិនបានដាក់ទណ្ឌកម្មចំពោះអំពើមួយដែលជាបទល្មើសផ្អែកតាមច្បាប់អន្តរជាតិ មិនអាចជួយឱ្យបុគ្គលដែលប្រព្រឹត្តអំពើនោះ រួចផុតពីការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិនោះទេ")។ សេចក្តីសម្រេច*ក្នុងរឿងក្តី Justice* ទំព័រ ៩៧៥ ("ការអនុវត្តគោលការណ៍*អានុភាពមិនប្រតិសកម្ម*ទៅលើសេចក្តីសម្រេចតុលាការចំពោះច្បាប់អន្តរជាតិទូទៅ គឺជាការរារាំងច្បាប់នោះតាំងពីដំបូងមក")។

គោលការណ៍នីត្យានុកូលភាពនោះឡើយ[៤០]។ អនុលោមតាមកិច្ចព្រមព្រៀង អ្នកបង្កើតច្បាប់កម្ពុជាច្បាស់ជាមានគោលបំណងផ្តល់យុត្តាធិការទៅ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ ហើយនិយមន័យនេះត្រូវបានចាត់ទុកថា អាចយកមកអនុវត្តដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះនេះ[៤១]។ ក្រុមប្រឹក្សាធម្មនុញ្ញបានចាត់ទុកច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ថាមានសុពលភាព រួមទាំងបទប្បញ្ញត្តិនៃច្បាប់នេះអនុញ្ញាតឲ្យយុត្តាធិការរបស់ អ.វ.ត.ក មានទៅលើច្បាប់អន្តរជាតិ[៤២]។

១៩. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ៩ នៃកិច្ចព្រមព្រៀង កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយយោងទៅលើលក្ខន្តិកៈទីក្រុងរ៉ូម ប៉ុន្តែមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានយោងទៅលើលក្ខន្តិកៈនេះ នោះទេ ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចហើយថា យុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់ដោយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលអំពើនេះត្រូវបានប្រព្រឹត្ត[៤៣]។ ដូច្នេះ ទាំងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឬមាត្រា ៩ នៃកិច្ចព្រមព្រៀង មិនអាចត្រូវបានបកស្រាយថា ជាវិសោធនកម្មច្បាប់ដែលមានអានុភាព

---

[៤០] *សាលក្រមក្នុងរឿងក្តី* Kononov *តទល់នឹង* Latvia តុលាការECtHR (បណ្តឹងលេខ ៣៦៣៧៦/០៤) ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ២០៨។ *សូមមើលផងដែរ* សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី កាំង ហ្គេកអ៊ាវ ជើងទំព័រលេខ ១៨៨។

[៤១] នៅពេលអនុម័តក្រមព្រហ្មទណ្ឌថ្មី ដែលបញ្ចូលនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមទៅក្នុងច្បាប់ជាតិ អ្នកបង្កើតច្បាប់កម្ពុជាលើកឡើងច្បាស់បន្ថែមនៅក្នុងមាត្រា៨ ដែលលើកឡើងថា “បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឲ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ”។

[៤២] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្តីសម្រេចលេខ ០៤០/០០២/២០០១ សំណុំរឿងលេខៈ ០៣៨/០០១/២០០១ ឯកសារ E9/7.2 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ ទំព័រ ១-៣។ ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះបានសម្រេចថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចូលអញ្ញត្រកម្មលើបទល្មើសអន្តរជាតិ ឲ្យកំណត់ទៅតាមគោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់ជាតិរបស់ខ្លួន (សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ D427/3/15 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ កថាខណ្ឌ ៩៦-៩៧)។

[៤៣] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៩៩-១០០។

ប្រតិសកម្មចំពោះនិយមន័យនេះនោះទេ[៤៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះមាន យុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិនានា ដែលត្រូវបានកំណត់នៅក្នុងច្បាប់ អ.វ.ត.ក ដែលបានបំពេញតាមគោលការណ៍នីត្យានុកូលភាព។

២០. ទោះបីអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មិនបានវាយតម្លៃពីមុនមកថា តើឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលជាបញ្ហាត្រូវដោះស្រាយក្នុងសំណុំរឿង ០០២/០១ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនៅត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះធ្វើការវាយតម្លៃចំពោះបញ្ហានេះនៅក្នុងសាលក្រមនេះ[៤៥]។ អង្គជំនុំជម្រះក៏ពិចារណាផងដែរ ថាតើឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ និងទម្រង់នៃការទទួលខុសត្រូវ អាចឲ្យជនជាប់ចោទប្រមើលមើលឃើញ និងដឹងថាមានច្បាប់ចែងដែរទេ[៤៦] ។

## ២.៣ គោលការណ៍នៃភ័ស្តុតាង និងនីតិវិធី

### ២.៣.១ សេចក្តីផ្តើម

២១. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ការណែនាំក៏អាចត្រូវបានស្វែងរកពីច្បាប់អន្តរជាតិ នៅក្នុងស្ថានភាពដែល

---

[៤៤] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៩៩-១០០។

[៤៥] *សូមមើល* ផ្នែកទី ៩ ស្តីពីច្បាប់អនុវត្តនៃ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤១១-៤១៥, ៤២៦, ៤៣៥-៤៣៦ ។

[៤៦] *សូមមើល* ផ្នែកទី ១៣ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៨៩, ៦៩១, ៦៩៧, ៦៩៩, ៧០១, ៧០៣, ៧១៤។ ដើម្បីកំណត់ថាតើឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ អាចត្រូវបានជនជាប់ចោទប្រមើលមើលឃើញច្បាស់ថាជាបទឧក្រិដ្ឋ និងដឹងថាមានច្បាប់ចែងឬយ៉ាងណានោះ អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានពិចារណាទៅលើ៖ ថាតើឧក្រិដ្ឋកម្មស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ថាតើឧក្រិដ្ឋកម្មនេះមានចែងនៅក្នុងអនុសញ្ញា, ប្រភេទធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម, កំណត់ហេតុបទចោទ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅតុលាការអន្តរជាតិ និងតុលាការផ្សេងទៀតដែលកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ថាតើឧក្រិដ្ឋកម្មត្រូវបានចាត់ទុកជាបទល្មើសនៅក្នុងច្បាប់ជាតិ និងតួនាទីរបស់ជនជាប់ចោទនៅក្នុង (សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៥៣, ២៥៧, ២៦៣, ៣៣១-៣៣២, ៣៥៥, ៤៦០។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង*កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៩៦, ១៦០-១៦២, ២១១-២១២, ២៨០។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង*កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣១-៣២)។

នីតិវិធីមានស្រាប់មិនបានដោះស្រាយលើបញ្ហាណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើនីតិវិធីទាំងនេះមិនស្របជាមួយនឹងបទដ្ឋានអន្តរជាតិ[៤៧]។ វិធានផ្ទៃក្នុងធ្វើការច្របាច់បញ្ចូលនូវច្បាប់នីតិវិធីកម្ពុជា ដែលអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក និងប្រើប្រាស់នីតិវិធីអន្តរជាតិ ក្នុងគោលបំណងដើម្បីធានានូវយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់[៤៨]។ នៅក្នុងក្របខណ្ឌនេះ អង្គជំនុំជម្រះត្រូវតែ "ធានាថា ការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់រហ័ស [...] ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី"[៤៩]។

### ២.៣.២ បន្ទុក និងបទដ្ឋាននៃភ័ស្តុតាង

២២. ជនជាប់ចោទ ត្រូវបានសន្មតថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ[៥០]។ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង[៥១]។ ដើម្បីអាចផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែមានជំនឿ "ដោយលើសពីវិមតិសង្ស័យ" អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ[៥២]។ ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នារវាងការចែងខុសគ្នានៅក្នុងសំណៅភាសាផ្សេងៗនៃវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង ដែលបង្ហាញពីបទដ្ឋាន "ដោយលើសពីវិមតិសង្ស័យ" តាមច្បាប់កុំមិនឡ (Common Law) និងទស្សនាទាន "*ជំនឿដោយឥស្សរចិត្ត (intime convinction)*" តាមច្បាប់ស៊ីវិល (Civil Law) អង្គជំនុំជម្រះបានប្រើប្រាស់វិធីសាស្ត្រមួយ

---

[៤៧] ច្បាប់អ.វ.ត.ក មាត្រា ២០ ថ្មី មាត្រា ២៣ ថ្មី និងមាត្រា ៣៣ ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១)។ វិធាន ២ នៃវិធានផ្ទៃក្នុង។

[៤៨] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។ បុព្វកថា នៃវិធានផ្ទៃក្នុង។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៥។

[៤៩] ច្បាប់ អ.វ.ត.ក មាត្រា ៣៣ ថ្មី។ ជនជាប់ចោទត្រូវបានធានានូវសិទ្ធិជាសារវ័ន្តច្បាស់លាស់ក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី (*សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១៣(១) (សំដៅចំពោះកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ និងមាត្រា ១៥)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៤ ថ្មី មាត្រា ៣៥ ថ្មី)។

[៥០] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។

[៥១] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[៥២] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

វាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃភ័ស្តុតាង។ បន្ទាប់ពីបានវាយតម្លៃទៅលើភ័ស្តុតាងដោយមានសំអាងហេតុរួច អង្គជំនុំជម្រះនឹងធ្វើការបកស្រាយវិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ[៥៣] ។

### ២.៣.៣ សំណុំរឿង

២៣. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង បន្ទាប់ពីរាល់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានសម្រេចនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[៥៤]។ សម្ភារៈដែលមាននៅក្នុងសំណុំរឿង ហើយដែលមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងនោះ គឺមិនត្រូវបានអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋានក្នុងការពិចារណាទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ[៥៥]។ នៅពេលទទួលបានការជូនដំណឹងអំពីបទចោទ ជនត្រូវចោទ បន្ទាប់មកក្លាយជាជនជាប់ចោទ ក្រោយពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទទួលបានការអនុញ្ញាតឲ្យចូលមើលសំណុំរឿង ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល[៥៦]។ ដូច្នេះ នួន ជា ទទួលបានការអនុញ្ញាតឲ្យចូលមើលសំណុំរឿងចាប់តាំងពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ហើយ ខៀវ សំផន អាចចូលមើលសំណុំរឿងចាប់តាំងពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧[៥៧]។

---

[៥៣] សំណៅជាភាសាអង់គ្លេស និងភាសាខ្មែរ នៃវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងអំពីបទដ្ឋាន "លើសពីវិមតិសង្ស័យ" ខណៈពេលដែលពាក្យពេចន៍ "*ជំនឿដោយឥស្សរចិត្ត*" មានចែងនៅក្នុងសំណៅជាភាសាបារាំង (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៥)។

[៥៤] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (អ.ជ.ស.ដ) ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ទំព័រ ១។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះ-ស្រាយ (អ.ប.ជ) ឯកសារ D427/2/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៨-៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤-៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ ទំព័រ ៥-៦។

[៥៥] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៨។

[៥៦] វិធាន ៩(៥)-(៦), ១០(៤), ៥៥(៦), ៥៥(១១), ៨៦ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/3, E241 និង E241/1) ឯកសារ E251 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៨។

[៥៧] កំណត់ហេតុចូលខ្លួនដំបូងរបស់ នួន ជា (ក.ស.ច.ស) ឯកសារ D20 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ។ កំណត់ហេតុចូលខ្លួនដំបូងរបស់ ខៀវ សំផន (ក.ស.ច.ស) ឯកសារ D42 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

### ២.៣.៤ ភាពទទួលយកបាននៃភស្តុតាង

#### ២.៣.៤.១ ក្របខណ្ឌគតិយុត្តិ

២៤. លើកលែងតែមានចែងផ្សេងពីនេះ រាល់ភស្តុតាងទាំងអស់គឺអាចទទួលយកបាន[៥៨] ហើយ ដោយត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន៨៧(៣)(៤)នៃវិធានផ្ទៃក្នុង ភាគីអាច ស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាងនៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ[៥៩]។ អង្គជំនុំជម្រះ មានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការកំណត់អំពីសាក្សីដែលត្រូវស្តាប់សក្ខីកម្ម និងភស្តុតាងដែលត្រូវ ទទួលយក[៦០]។

២៥. ភស្តុតាងទាំងអស់ ត្រូវតែបានសង្ខេបនូវខ្លឹមសារ បានអាន ឬកំណត់អត្តសញ្ញាណយ៉ាង សមស្រប[៦១]។ មុនពេលចាប់ផ្តើមការជំនុំជម្រះ អង្គជំនុំជម្រះអាចបង្គាប់ឲ្យភាគីទាំងអស់ដាក់បញ្ជី ភស្តុតាងបឋម ដែលកំណត់អត្តសញ្ញាណ រៀបរាប់ដោយសង្ខេប និងបង្ហាញពីភាពពាក់ព័ន្ធនៃ ភស្តុតាងដែលស្នើសុំទាំងនោះ[៦២]។ គ្រប់ភស្តុតាងដែលបានស្នើសុំទាំងអស់ដែលមិនទាន់រកបាននៅ ពេលអង្គជំនុំជម្រះទទួលយកសំណុំរឿង ត្រូវបានចាត់ទុកថាជាភស្តុតាង “ថ្មី” អនុលោមតាម

---

[៥៨] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[៥៩] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១។ សេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា មកអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E211) (អ.ជ.ស.ដ) ឯកសារ E211/2 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៤។ សំណុំរឿង០០១ សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់ សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២) ឯកសារ E176 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ១៣។

[៦០] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២០។ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹង ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១៨-២០។ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវី ការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1) ឯកសារ E251 ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២៥។

[៦១] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[៦២] វិធាន ៨០(១)-(៣) នៃវិធានផ្ទៃក្នុង។

លក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ភាគីត្រូវតែបង្ហាញថា ភស្តុតាងថ្មីគឺមិនអាចរកបាននោះទេ មុនពេលបើកការជំនុំជម្រះ និង/ឬ មិនអាចរកបានពីមុនមក ទោះបីជាបានខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្តី[៦៣]។ មុនពេលដាក់ភស្តុតាងថ្មីនៅក្នុងសំណុំរឿង អង្គជំនុំជម្រះត្រូវតែសម្រេចថា តើភស្តុតាងថ្មីនេះអាចនាំទៅដល់ការស្វែងរកការពិតដែរ ឬទេ[៦៤]។

២៦. អង្គជំនុំជម្រះអាចបដិសេធចោលនូវរាល់សម្ភារៈដែលមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី[៦៥]។ ដូច្នេះ ភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវតែពាក់ព័ន្ធ និងអាចជឿទុកចិត្ត *ជាបឋម*។ ភាគីត្រូវតែមានឱកាសក្នុងការជំទាស់ទៅលើភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោល ទោះបីជាភាគីមិនបានប្រើប្រាស់ឱកាសនេះក្តី[៦៦]។

### ២.៣.៤.២ ប្រភពនៃភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះ

#### ២.៣.៤.២.១ *ភស្តុតាងរបស់ជនជាប់ចោទ*

២៧. បន្ទាប់ពីការធ្វើសេចក្តីថ្លែងការណ៍បើក សវនាការលើអង្គសេចក្តីបានចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋាន និងការសួរដេញដោលទៅជនជាប់ចោទតាមលំដាប់លំដោយ ដូចមានរាយឈ្មោះនៅក្នុងដីកាដំណោះស្រាយ[៦៧]។ អនុលោមតាមវិធាន២១ (១)(ឃ) និងវិធាន៩០(១) នៃវិធាន

---

[៦៣] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ១៧, ២៣, ២៨, ៣៨។

[៦៤] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៧ ជើងទំព័រ ៣៨។ បទដ្ឋាននេះផ្អែកលើបទដ្ឋានដែលបានអនុវត្ត នៅក្នុងដំណាក់កាលស៊ើបសួរចំពោះកិច្ចស៊ើបសួរ ដែលនាំដល់ការដាក់បញ្ចូលនូវសម្ភារៈទៅក្នុងសំណុំរឿង (វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង)។

[៦៥] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[៦៦] *សូមមើលឧទា.* សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៤០-៤៣។

[៦៧] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ (ឯកសារ E101 និង E101/1) (អ.ជ.ស.ដ) ឯកសារ E101/5 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ ទំព័រ

ផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះជូនដំណឹងដល់ជនជាប់ចោទនីមួយៗអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបមុនពេលជនជាប់ចោទធ្វើសេចក្តីថ្លែងការណ៍បើក[៦៨]។ បន្ថែមលើសេចក្តីថ្លែងការណ៍បើកដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង នៅពេលជនជាប់ចោទស្ម័គ្រចិត្តឆ្លើយ អង្គជំនុំជម្រះនឹងសួរសំណួរទាំងឡាយណាដែលខ្លួនយល់ឃើញថាពាក់ព័ន្ធ ទោះបីជាសំណួរដាក់បន្ទុក ឬ ដោះបន្ទុក ចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទក៏ដោយ។ ភាគីក៏ត្រូវបានផ្តល់ឱកាសដើម្បីតាំងសំណួរដល់ជនជាប់ចោទផងដែរ[៦៩]។ ចម្លើយរបស់ជនជាប់ចោទ គឺជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ[៧០]។

២៨. ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍បើក និងបានផ្តល់ភ័ស្តុតាងកាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ និងថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ប៉ុន្តែក្រោយមក ខៀវ សំផន បានបដិសេធមិនឆ្លើយតបទៅនឹងសំណួរ ដោយបង្ហាញថា គាត់មានបំណងចង់ស្តាប់សក្ខីកម្មប្រឆាំងលើរូបគាត់ជាមុនសិន[៧១]។ នៅខែ ឧសភា ឆ្នាំ ២០១៣ ខៀវ សំផន បានឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន[៧២]។ នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ខៀវ សំផន បានប្រើសិទ្ធិនៅស្ងៀម

---

១-២។ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១ ទំព័រ ៥។

[៦៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៣២-៣៣ (នួន ជា)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៣៩-៤០ (អៀង សារី)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៤៥-៤៦ (ខៀវ សំផន)។ ជនជាប់ចោទត្រូវបានលើកលែងមិនឲ្យធ្វើសច្ចាប្រណិធាន (វិធាន៩០ នៃវិធានផ្ទៃក្នុង)។

[៦៩] វិធាន ៩០(១) នៃវិធានផ្ទៃក្នុង។ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ (ឯកសារ E101 និង E101/1) (អ.ជ.ស.ដ) ឯកសារ E101/5 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១-២។ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៥។

[៧០] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣២-៣៣។ *សូមមើលផងដែរ* វិធាន ៨៧(៥) នៃវិធានផ្ទៃក្នុង។

[៧១] ប្រតិចារឹក ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៤២-៦៥។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៣៨-៦៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៥៥-៥៧។

[៧២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១៤-១៨, ២០-២១, ៤០-៤១, ៦៣-៦៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១៤-១៦, ៦៨-៧១។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២០-២១, ៥៣-៥៥, ៨៧-៨៨។

មិនឆ្លើយតបម្តងទៀត[៧៣]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល[៧៤]។

២៩. នៅចន្លោះពីខែ ធ្នូ ឆ្នាំ ២០១១ ដល់ខែ មេសា ឆ្នាំ ២០១២ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍មួយចំនួន និងបានឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគី[៧៥]។ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ នួន ជា បានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប[៧៦]។ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍បន្ថែម និងបានឆ្លើយតបទៅនឹងសំណួរនៅក្នុងឱកាសមួយចំនួននៅចន្លោះពីខែ មិថុនា ឆ្នាំ ២០១២ ដល់ខែ កក្កដា ឆ្នាំ ២០១៣[៧៧]។ នួន ជា បានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបជាថ្មីម្តងទៀតនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣[៧៨]។ នួន ជា បានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣[៧៩]។

### ២.៣.៤.២.២ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ

---

[៧៣] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣១។

[៧៤] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៥២-៥៥។

[៧៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៣-២១។ ប្រតិចារឹក ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ២-៣៧។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ២-៤០។ ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ៣០-៨៣ ។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៧-៥៣។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៧-៣៨។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៦-៣៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ទំព័រ ១-២២។ ប្រតិចារកថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ទំព័រ ១-៤១។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៦-៤០។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២៩-៣៨។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៣-៧។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៤២-៤៣។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣-៤។

[៧៦] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣-៦។

[៧៧] ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៥៦-៥៨។ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៤-៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២៨-៣១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១២-២០។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១៩-២០, ២០-២១, ៤១-៤២។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១៥-១៧, ៧០-៧២។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២១-២២, ៥៤-៥៥។

[៧៨] ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១៣-១៤។

[៧៩] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ១-២៦។

៣០. យោងតាមឋានៈពិសេសរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការមិនតម្រូវឲ្យពួកគាត់ធ្វើសម្បថនោះទេ[៨០]។ សាក្សីត្រូវបានជូនដំណឹងអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង និងមានមេធាវីជួយ ប្រសិនបើពួកគាត់ស្នើសុំ[៨១]។ អង្គជំនុំជម្រះបានស្តាប់មតិយោបល់អ្នកជំនាញលើបញ្ហាបច្ចេកទេសជាក់លាក់មួយចំនួន ដើម្បីជួយឲ្យអង្គជំនុំជម្រះបានយល់អំពីភ័ស្តុតាង ដែលបានបង្ហាញនៅក្នុងពេលជំនុំជម្រះក្តីផងដែរ[៨២]។

៣១. អង្គជំនុំជម្រះបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីមុនៗ ដែលស្របទៅនឹងសក្ខីកម្មរបស់ពួកគាត់ដែលបានធ្វើឡើងដោយផ្ទាល់មាត់ ឬទទួលយកកំណត់ហេតុទាំងនោះតែម្តងក្នុងករណីដែលបុគ្គលនោះមិនបានមកផ្តល់សក្ខីកម្ម។ សក្ខីកម្មពីពេលមុនៗរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានផ្តល់ក្នុងសវនាការ ត្រូវបានទទួលយកដោយអង្គជំនុំជម្រះរួចហើយ[៨៣]។ ចាប់ផ្តើមពីខែ មិថុនា ឆ្នាំ ២០១២ ដើម្បីជាប្រយោជន៍នៃភាពឆាប់រហ័ស ប្រធានអង្គជំនុំជម្រះបានចាប់ផ្តើមសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំ-ជម្រះ ដើម្បីឲ្យគាត់បញ្ជាក់អំពីភាពត្រឹមត្រូវនៃចម្លើយ ដែលពួកគាត់ធ្លាប់បានឆ្លើយឲ្យទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានសរសេរនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនោះ។ បន្ទាប់ពីសួរបញ្ជាក់រួចហើយ និងដោយកត់សម្គាល់អំពីសិទ្ធិរបស់ភាគីក្នុងការពិនិត្យទៅលើភាពគួរឲ្យជឿទុកចិត្តបាន នូវអ្វីដែលបុគ្គលទាំងនោះធ្លាប់បានឆ្លើយកន្លងមក ឬ បញ្ហាទាក់ទងនឹងចម្លើយទាំងនោះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីសួរសំណួរបន្ថែមដល់បុគ្គលទាំងនោះ ប៉ុន្តែកម្រិតត្រឹមសំណួរដែលចាំបាច់ដើម្បីបញ្ជាក់ពីភាពពាក់ព័ន្ធទៅលើបញ្ហាដែល

---

[៨០] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៥២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ១០០។ ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 នៅបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E74 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ១។

[៨១] ទោះជាយ៉ាងនេះក្តី សាក្សីទាំងអស់បានធ្វើសក្ខីកម្មដោយត្រូវធ្វើសច្ចាប្រណិធាន លើកលែងតែក្នុងករណីអាយុ ឬទំនាក់ទំនងពិសេសជាមួយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។

[៨២] វិធាន ៣១ នៃវិធានផ្ទៃក្នុង វិធាន ៨០*ស្ទួន*(២)។

[៨៣] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២ និង ២៦។

មិនទាន់បានរៀបរាប់គ្រប់គ្រាន់នៅឡើយនៅក្នុងចម្លើយទាំងនេះ ឬ មិនត្រូវបានសួរកាលពីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ[៨៤]។ ក្នុងករណីមិនមានឱកាសសម្រាប់សួរដេញដោលទៅលើសាក្សី អង្គជំនុំជម្រះនឹងមិនពិចារណាទៅលើសក្ខីកម្មរបស់សាក្សី ដែលជាភ័ស្តុតាងបញ្ជាក់ពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះឡើយ លើកលែងតែសក្ខីកម្មរបស់សាក្សីដែលបានទទួលមរណភាព។ អង្គជំនុំជម្រះបានទទួលយកសក្ខីកម្មរបស់បុគ្គលទាំងនោះ ដើម្បីបញ្ជាក់ពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ ដោយហេតុថា ការស្លាប់របស់សាក្សីនោះរារាំងមិនឲ្យមានឱកាសក្នុងការសួរដេញដោលគ្នាបាន ។ ឧទាហរណ៍ សាក្សី TCW-699 បានស្លាប់នៅមុនពេលសវនាការចប់ ដែលបានរារាំងអង្គជំនុំជម្រះមិនឲ្យស្តាប់សក្ខីកម្មរបស់គាត់បាន ។ ជំនួសឲ្យការមិនបានស្តាប់សក្ខីកម្មរបស់គាត់ អង្គជំនុំជម្រះបានទទួលយកចម្លើយលើកមុនរបស់គាត់ ដោយធ្វើការកត់សម្គាល់ថាអង្គជំនុំជម្រះនឹងមិនសម្រេចសេចក្តីលើការដាក់ទោសណាមួយ ដោយផ្អែកតែលើចម្លើយបែបនេះទាំងស្រុងនោះទេ ។ ការធ្វើដូច្នេះ គឺដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ[៨៥]។

៣២. ក្នុងអំឡុងពេលនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ បុគ្គលចំនួន ៩២ នាក់ បានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្មលើអង្គហេតុនានាដែលបានចោទប្រកាន់។ បុគ្គល

---

[៨៤] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ៣១។ សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារ ក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201) (អ.ជ.ស.ដ) ឯកសារ E201/2 ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១។ ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និង វិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៧ (ក្នុងករណីដែលផលប្រយោជន៍ព័ត៌មានសាធារណៈតម្រូវ អង្គជំនុំជម្រះអាចសង្ខេបត្រួសៗអំពីខ្លឹមសារនៃចម្លើយទាំងនេះនៅក្នុងសវនាការ)។

[៨៥] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២១-២២ និង ៣២-៣៣។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៩-៣០។

ទាំងនេះរួមមាន សាក្សី ៥៨ នាក់ (ក្នុងចំណោមសាក្សីទាំងនេះ សាក្សី ៥ នាក់ គឺជាសាក្សីអត្តចរិតដែលត្រូវបានកោះហៅតាមសំណើរបស់ជនជាប់ចោទ ខៀវ សំផន) អ្នកជំនាញ ៣ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ៣១ នាក់។ បុគ្គល ៥ នាក់ បានផ្តល់សក្ខីកម្មពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍[៨៦]។ អង្គជំនុំជម្រះបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ចំនួន ១.១២៤ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់[៨៧]។

## ២.៣.៤.២.៣ ភស្តុតាងជាឯកសារ

៣៣. បន្ទាប់ពីបើកឱកាសឱ្យមានសវនាការ ពិភាក្សាដេញដោលតទល់គ្នាជាសាធារណៈរួចមក អង្គជំនុំជម្រះបានទទួលយកភស្តុតាងជាឯកសារចំនួន ៥.៨២៤ ឯកសារ ហើយដែលឯកសារទាំងនោះរួមមាន ឯកសារក្នុងសម័យខ្មែរក្រហម និងឯកសារវិភាគ កំណត់ហេតុជាសម្លេង និងរូបភាព និងភស្តុតាងដែលជាកំណត់ហេតុរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី[៨៨]។

---

[៨៦] ឡុង នរិន្ទ, Denise AFFONÇO, Sydney SCHANBERG, Phillipe JULLIAN-GAUFRES និង ចៅ សុខុន។ វិធាន ២៦(១) អនុញ្ញាតឱ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍ ក្នុងករណីដែលផ្តល់សក្ខីកម្មបែបនេះ "មិនបានរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនជាប់ចោទ ឬ មិនស្របទៅនឹងសិទ្ធិការពារខ្លួន"។

[៨៧] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និង ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ។

[៨៨] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានដាក់ស្នើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 របស់សហព្រះរាជអាជ្ញា និង ឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធ A6-A11 ឯកសារ E185/1 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ ។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និង ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ។ បន្ថែមលើភស្តុតាងដែលត្រូវបានទទួលយកនៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទាំងនេះ ភាគីត្រូវបានអនុញ្ញាតឱ្យដាក់

## ២.៣.៥ ការវាយតម្លៃជាចុងក្រោយលើភ័ស្តុតាង

### ២.៣.៥.១ តម្លៃនៃភ័ស្តុតាង

៣៤. នៅក្នុងការសម្រេចសេចក្តី អង្គជំនុំជម្រះពឹងផ្អែកទៅលើភ័ស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបានដាក់ឲ្យពិភាក្សាដេញដោលតទល់គ្នា[៨៩]។ អង្គជំនុំជម្រះបានពិចារណាទាំងទៅលើសេចក្តីសន្និដ្ឋានចុងក្រោយ និងសេចក្តីជំទាស់លើតម្លៃនៃភ័ស្តុតាង ដែលធ្វើឡើងនៅពេលជំនុំជម្រះក្តី ជាពិសេសភ័ស្តុតាងទាំងឡាយណាមានសេចក្តីបញ្ជាក់ដំបូងអំពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភ័ស្តុតាងដែលបានស្នើសុំ[៩០]។ កត្តាមួយចំនួនគឺមានភាពពាក់ព័ន្ធទៅនឹងតម្លៃនៃភ័ស្តុតាង ដែលកត្តាទាំងនោះរួមមានលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧ (៣)[៩១] នៃ

---

ភ័ស្តុតាងតាមរយៈបុគ្គលដែលបង្ហាញខ្លួនផ្ទាល់ (សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារ ក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201) (អ.ជ.ស.ដ) ឯកសារ E201/2 ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២។

[៨៩] វិធាន ៨៧(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាសាខ្មែរក្នុងវិធាននេះតម្រូវឲ្យ "ភ័ស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល" ភាសាអង់គ្លេសចែងថាភ័ស្តុតាងនោះ "*subjected to examination*" ចំណែកឯភាសាបារាំងចែងថាភ័ស្តុតាងនោះ "*débattues contradictoirement*"។

[៩០] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងពីរនៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១ និង ៣០។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានដាក់ស្នើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងឧបសម្ព័ន្ធ A6-A11 របស់សហព្រះរាជអាជ្ញា និង ឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ E185/1 នៅក្នុងឧបសម្ព័ន្ធ A6-A11 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៣ និង ១៩។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២០ ២៤ និង ២៦។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹក នៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២១, ២៣, ២៦, ៣០ និង ៣២។

[៩១] អង្គជំនុំជម្រះពិចារណាថាតើភ័ស្តុតាងនោះមិនជាប់ពាក់ព័ន្ធ ជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី (វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង)។

វិធានផ្ទៃក្នុង កាលៈទេសៈជុំវិញការបង្កើត ឬកត់ត្រាភ័ស្តុតាង តើឯកសារដែលត្រូវបានទទួលយកនោះជាឯកសារដើម ឬ ឯកសារថតចម្លង លទ្ធភាពអានបាន ភាពមិនស៊ីសង្វាក់ខ្លះៗទៅនឹងសំណៅដទៃទៀត ភាពខ្វះចន្លោះ ដែលអាចចោទប្រកាន់បានថាតើភាគីមានឱកាសសួរដេញដោលភ័ស្តុតាង និងសញ្ញាណផ្សេងៗទៀតនៃភាពអាចទុកចិត្តបាន រួមទាំងដំណើរការនៃការរក្សាភ័ស្តុតាង និងប្រភពភ័ស្តុតាង[៥២]។ អង្គជំនុំជម្រះក៏ពិចារណាផងដែរទៅលើការកំណត់អត្តសញ្ញាណ ការពិនិត្យលើភ័ស្តុតាង ភាពលំអៀង ប្រភព និងបុព្វហេតុរបស់បុគ្គលដែលជាម្ចាស់ភ័ស្តុតាងនោះ (ឬ មិនមានចំណុចទាំងពីរនេះ) ឬ ប្រភពផ្សេងៗទៀតនៃភ័ស្តុតាងទាំងនោះ[៥៣]។ ក្នុងករណីពុំមានឱកាសដើម្បីពិនិត្យទៅលើប្រភពនៃភ័ស្តុតាង ឬ បុគ្គលដែលជាម្ចាស់ភ័ស្តុតាងទាំងនោះ ដូច្នេះ ទម្ងន់នៃភ័ស្តុតាងបែបនេះត្រូវមានតិចតួច[៥៤]។

---

[៥២] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣០ និង ៣៤ និង លេខចុងទំព័រ ៥៩។ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1) ឯកសារ E251 ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២៦, ២៨ និង ៣៦។ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១៧, ២៥-២៩។

[៥៣] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៤។ សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ឯកសារ E215 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ១៥។សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ១៤។

[៥៤] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៣។ សាលដីកាក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥៤៧ និង ៥៥៧។ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២១-២២ និង ៣២-៣៣។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុង

៣៥. ដើម្បីដាក់ទោសជនជាប់ចោទបាន រាល់សេចក្តីសន្និដ្ឋានដែលអាចទាញចេញពីភ័ស្តុតាង ត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ[៥៥]។ លើសពីនេះទៅទៀត ភ័ស្តុតាងមួយចំនួនដែលត្រូវបានទទួលយកសម្រាប់គោលបំណងជាក់លាក់ណាមួយ ដូចជាភ័ស្តុតាងដែលជាចម្លើយដែលបានមកពីការធ្វើទារុណ្ឌកម្មនោះ អង្គជំនុំជម្រះអាចពឹងផ្អែកលើភ័ស្តុតាងបែបនេះតែសម្រាប់គោលបំណងដែលមានដែនកំណត់ប៉ុណ្ណោះ និងមិនចាត់ទុកវាជាសច្ចភាពនៃចម្លើយនោះឡើយ[៥៦]។

៣៦. អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគី ត្រូវធ្វើយ៉ាងណាត្រូវធានាថា រាល់ភ័ស្តុតាងទាំងអស់ដែលបានទទួលយករួចហើយនោះ គឺត្រូវមានជាបីភាសាផ្លូវការរបស់ អ.វ.ត.ក នៅត្រឹមពេលដែលភាគីដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ករណីលើកលែងគឺអនុវត្តចំពោះតែភ័ស្តុតាងណាដែលបានបង្ហាញជាក់ច្បាស់ថា ឯកសារទាំងនោះពុំតម្រូវឲ្យមានការបកប្រែ។ ប៉ុន្តែ នៅពេលដែលភាគីដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួននៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ នោះ ឯកសារមួយចំនួនដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅតែមានមួយ ឬពីរភាសាផ្លូវការរបស់ អ.វ.ត.ក ដដែល ។ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះនៅតែពិចារណាលើភ័ស្តុតាងទាំងនេះនៅក្នុងសាលក្រមរបស់ខ្លួន ។ ប៉ុន្តែ អង្គជំនុំជម្រះពឹងផ្អែកទៅលើភ័ស្តុតាងទាំងនេះ នៅពេលដែលភ័ស្តុតាងទាំងនេះមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងប្រភពផ្សេងៗទៀត ដែលអង្គជំនុំជម្រះអាចជឿទុកចិត្តបាន តែប៉ុណ្ណោះ[៥៧]។ លើសពីនេះទៀត អង្គជំនុំជម្រះពិចារណាផងដែរថា តើ

---

សំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩, ២៣, ២៩-៣០។

[៥៥] សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៦។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Mugenzi និង Mugiraneza* កថាខណ្ឌ ៨៨។ សាលដីកាក្នុងរឿងក្តី *Delalić និងអ្នកផ្សេងទៀត* កថាខណ្ឌ ៤៥៨។

[៥៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៧៨-៨០។ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E74 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ០៣។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំរបស់ភាគីនានា សុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង ឯកសារ E176 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៨។

[៥៧] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អ.វ.ត.ក (ឯកសារ E223/2/6) និងចម្លើយតបរបស់សហមេធាវីនាំ

ជនជាប់ចោទបានបង្ហាញពីការយល់ដឹងលើភស្តុតាងទាំងនេះដែរ ឬអត់ ឬមួយថា តើជនជាប់ចោទបានពឹងផ្អែកលើភស្តុតាងទាំងនេះនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរ ឬទេ[៥៨] ។

---

មុខទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដាក់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារផ្សេងៗ (ឯកសារ E223/2/7 និង E223/2/7/1) (អ.វ.ត.ក) ឯកសារ E223/2/6/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២ (អង្គជំនុំជម្រះបានពន្យារកាលបរិច្ឆេទកំណត់សម្រាប់ដាក់ភស្តុតាងជាបីភាសាដែលផុតនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៣ រហូតដល់ថ្ងៃដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០១។ អង្គជំនុំ-ជម្រះក៏បានសម្រេចផងដែរថា បញ្ជីអ្នកទោសនៅ ស-២១ ស្ថិតនៅក្នុងចំណោមប្រភេទភស្តុតាងដែលពុំតម្រូវឱ្យបកប្រែជាបីភាសាឡើយ។ វាជាប្រភេទភស្តុតាងរូបថត ដ្យាក្រាម គំនូរ និងផែនទី)។

[៥៨] *សូមមើល ឧទា.* សៀវភៅនិពន្ធដោយ ខៀវ សំផនៈ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្ត-បន្ទាប់ ឯកសារ E3/18 ទំព័រ v-vi, ERN (ភាសាខ្មែរ) 00103805-00103806 (ខៀវ សំផន បានកត់សម្គាល់ថា ជារឿយៗ គាត់យោងលើសៀវភៅមានចំណងជើងថា *សកម្មភាពរបស់ Nixon និង Kissinger និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* (ឯកសារ E3/88) និពន្ធដោយ William SHAWCROSS ហើយ ខៀវ សំផន បានលើកឡើងផងដែរថា គាត់បានដឹងអំពីហេតុការណ៍ "យ៉ាងច្រើនសន្ធឹកនេះ" នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងឆ្នាំ ១៩៨០ ពីសៀវភៅនិពន្ធដោយ David CHANDLER, Ben KIERNAN និង Michael VICKERY) ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00103814 (យោងលើអត្ថបទដកស្រង់ចេញពីឯកសារ E3/88) ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00103815 (យោងលើអត្ថបទដកស្រង់ចេញពីសៀវភៅមានចំណងជើងថា *ប្រទេសកម្ពុជា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៨២* (ឯកសារ E3/1757) និពន្ធដោយ Michael VICKERY) ទំព័រ ២២-២៤ ERN (ភាសាខ្មែរ) 00103819-00103820 (យោងលើអត្ថបទដកស្រង់ចេញពីសៀវភៅមានចំណងជើងថា *បងធំទី១* ជីវប្រវត្តិនយោបាយរបស់ ប៉ុល ពត (ឯកសារ E3/2816) និពន្ធដោយ David CHANDLER) ទំព័រ ៨៣ ERN (ភាសាខ្មែរ) 00103849 (ដកស្រង់ចេញពីសៀវភៅមានចំណងជើងថា *សត្រូវបងប្អូនឯង* (ឯកសារ E3/2376) និពន្ធដោយ Nayan CHANDA)។ សៀវភៅនិពន្ធដោយ ខៀវ សំផនៈ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3855 ទំព័រ ៥៤-៥៨ ERN (ភាសាអង់គ្លេស) 00498275-7 (យោងលើ និងដកស្រង់ចេញពីសៀវភៅមានចំណងជើងថា *ប៉ុល ពតៈ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* (ឯកសារ E3/9) និពន្ធដោយ Philip SHORT និងសៀវភៅមានចំណងជើងថា *របប ប៉ុល ពតៈ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍* (ឯកសារ E3/1593) និពន្ធដោយ Ben KIERNAN)។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ លេខជើងទំព័រ ៥៨១ (យោងលើសៀវភៅនិពន្ធដោយ William SHAWCROSS មានចំណងជើងថា *សកម្មភាពរបស់ Nixon និង Kissinger និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ឆ្នាំ ១៩៧៩)។

### ២.៣.៥.២ ការប្រកបឈ្មោះ និង ទីកន្លែង

៣៧. ឈ្មោះ និងទីកន្លែងជាក់លាក់មួយចំនួននៅក្នុងសំណុំរឿងអាចប្រកបខុសគ្នា ដោយសារកត្តាជាច្រើន ជាអាទិ៍ ប្រភពដើមនៃភ័ស្តុតាង ការបញ្ចេញសម្លេងក្នុងការអានឈ្មោះ ឬ ការបកប្រែផ្ទាល់មាត់។ អង្គជំនុំជម្រះទទួលស្គាល់ថា ឈ្មោះ និងទីកន្លែងដែលមានសំនៀងស្រដៀងគ្នា ប៉ុន្តែមិនប្រកបដូចគ្នា អាចជាឈ្មោះរបស់បុគ្គល ឬទីកន្លែងតែមួយ។ មិនតែប៉ុណ្ណោះ ដោយសារតែប្រជាជនកម្ពុជាមានទម្លាប់មានឈ្មោះច្រើនផ្សេងៗគ្នា និងមានឈ្មោះហៅក្រៅ និងឈ្មោះបដិវត្តន៍ក្នុងបក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បុគ្គលមួយចំនួនមានឈ្មោះពីរ បីខុសៗគ្នា[៩៩]។

### ២.៣.៥.៣ ភាពមិនស៊ីសង្វាក់គ្នានៃការបកប្រែផ្ទាល់មាត់ ការបកប្រែឯកសារ និងប្រតិចារឹក

៣៨. ទោះបីជា អ.វ.ត.ក មានការធានានិងត្រួតពិនិត្យច្រើនកម្រិតយ៉ាងណាក្តី ក៏កំហុសឆ្គងផ្នែកបកប្រែផ្ទាល់មាត់ បកប្រែឯកសារ និងប្រតិចារឹក អាចកើតមានឡើងផងដែរ។ អង្គភាពបកប្រែភាសា ចៅក្រម និងអង្គជំនុំជម្រះបានចាត់វិធានការជាហូរហែរនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ក្នុងបំណងជួយកាត់បន្ថយកំហុសឆ្គង និងជួយកែកំហុសដែលរកឃើញ[១០០]។ ក្នុងពេលស៊ើបសួរ និងជំនុំជម្រះក្តី មេធាវីការពារក្តីមានលទ្ធភាពអាចប្រើប្រាស់សេវាបកប្រែរបស់អ្នកបកប្រែផ្ទាល់មាត់ និងអ្នកបកប្រែឯកសារ។ ជាងនេះទៅទៀត ភាគីទាំងអស់សុទ្ធតែមានសមត្ថភាពប្រើប្រាស់ភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក[១០១] ហេតុដូចនេះ ទើបពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរកឃើញកំហុសឆ្គងក្នុងការបកប្រែភាសា និងប្រតិចារឹក និងបានស្នើសុំឲ្យកែកំហុសទាំងនោះ[១០២]។

---

[៩៩] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៨។

[១០០] អនុស្សរណៈពីប្រធានផ្នែកគ្រប់គ្រងតុលាការ ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ឯកសារ E195/2 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ២-៣។ សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែឯកសារ (អ.ប.ជ) លេខ ២ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ១០។

[១០១] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំឲ្យអង្គជំនុំជម្រះតុលាការកំពូលជូនដំណឹងជាបីភាសាផ្លូវការ (អ.ជ.ត.ក) ឯកសារ E163/5/1/15 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។

[១០២] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញនូវការបកប្រែឯកសារពាក់ព័ន្ធ “៨៧០” ដែលបានដាក់ក្នុងសំណុំរឿង (E296) ឯកសារ E296/1 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ (អ.ប.ជ) ឯកសារ A190/I/20 ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៤៦-៤៩។ សំណើ

ក្នុងករណីដែលមានភាពពាក់ព័ន្ធ អង្គជំនុំជម្រះនឹងពិចារណាលើកំហុសឆ្គងទាំងនេះ នៅពេលខ្លួនវាយតម្លៃទៅលើតម្លៃនៃភ័ស្តុតាង។

### ២.៣.៥.៤ ព័ត៌មានដែលត្រូវបានធ្វើចំណាត់ថ្នាក់

៣៩. គិតត្រឹមពេលបញ្ចប់នៃការដាក់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ឯកសារចំនួន ៥.១០២ ឯកសារ និងសម្ភារៈមួយចំនួនទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងនោះ គឺនៅតែជាឯកសារ "សម្ងាត់" ដដែល។ ភាគច្រើនលើសលប់នៃសម្ភារៈទាំងនោះនៅតែរក្សាចំណាត់ថ្នាក់ដដែល ជាចំណាត់ថ្នាក់ដែលត្រូវបានចាត់ថ្នាក់ដោយស្វ័យប្រវត្តិកាលក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការ ។ ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារដែលបានប្រមូល និងបានធ្វើឡើងក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការ លែងជាហានិភ័យនៃការរំលោភទៅលើសិទ្ធិរបស់ភាគី ឬសុចរិតភាពនៃការស៊ើបអង្កេតទៀតហើយ[១០៣]។ ទោះជាយ៉ាងនេះក្តី យុត្តិកម្មជាក់លាក់មួយចំនួននៃការមិនបង្ហាញឯកសារជាសាធារណៈ គឺនៅតែមានសុពលភាពដដែល[១០៤]។ ដូច្នេះ ដើម្បីឈានដល់ការចេញសាលក្រម និងការពឹងផ្អែក និង/ឬ ការយោងទៅលើព័ត៌មានដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈនោះ អង្គជំនុំជម្រះត្រូវពិចារណាថា តើមានយុត្តិកម្មណាមួយចំពោះការរក្សាឯកសារដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការស៊ើបសួរនៅតែជាឯកសារសម្ងាត់ មានដែរឬទេ[១០៥]។ តាមគំនិតផ្តួចផ្តើមរបស់

---

E195 របស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន និងនីតិវិធីទៅថ្ងៃមុខ ដែលនឹងអនុវត្តចំពោះការកែតម្រូវប្រតិចារឹក (អ.ជ.ស.ដ) ឯកសារ E195/1 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ។ អនុស្សរណៈពីប្រធានផ្នែកគ្រប់គ្រងតុលាការផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ឯកសារ E195/2 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៤។ ការពិនិត្យឡើងវិញលើកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០២ (ITU) លេខ ៣ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១១ ទំព័រ ០៣។ សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែឯកសារ (អ.ប.ជ) លេខ ២ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ១១។

[១០៣] សំណុំរឿង ០០១ សាលដីកាស្តីពីគោលការណ៍ណែនាំសម្រាប់ការចាត់ចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿងឡើងវិញ (អ.ជ.ត.ក) ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៦។

[១០៤] ការចាត់ចំណាត់ថ្នាក់ និង ចាត់ថែងព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/Rev.1 ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ មាត្រា ៥-៧។

[១០៥] ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះចងចាំនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការចេញសាលក្រមរបស់ខ្លួនជាសាធារណៈ រួមទាំងផ្នែកសម្រេចសេចក្តីសំខាន់ៗ និង ភ័ស្តុតាង និង សម្អាងហេតុតាមផ្លូវច្បាប់ (វិធាន ១០២(១) និង វិធាន ៧៩(៦)(ឃ) នៃវិធានផ្ទៃក្នុង, អនុសញ្ញា ICCPR មាត្រា ១៤(១)។ មតិទូទៅលេខ ៣២៖ សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខ

ខ្លួន អង្គជំនុំជម្រះបានសម្រេចថា ការសម្ងាត់គឺលែងមានភាពចាំបាច់ទៀតហើយ សម្រាប់ឯកសារដែលបានបង្ហាញជាសាធារណៈនៅក្នុងសាលក្រមនេះ[១០៦]។

## ២.៤ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

### ២.៤.១ សេចក្តីផ្តើម

៤០. នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថា សិទ្ធិពួកគាត់ក្នុងការទទួលបានការស៊ើបសួរដោយឥតលម្អៀង និងការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានរងការរំលោភបំពាន។ អង្គជំនុំជម្រះបានពិនិត្យលើការចោទប្រកាន់ទាំងនេះ ទៅតាមករណីជាក់ស្តែងនីមួយៗ និងផ្តល់ជាដំណោះស្រាយ ក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវដូច្នេះ។ បើទោះបីជាដំបូងឡើយ ជនជាប់ចោទទាំងពីរបានបង្ហាញពីចេតនារបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសំណួររបស់ភាគី និងសំណួររបស់អង្គជំនុំជម្រះក៏ដោយ ក៏នៅចុងបញ្ចប់នៃសវនាការលើភ័ស្តុតាង ពួកគាត់បានប្រកែកមិនព្រមឆ្លើយតបទៅនឹងសំណួរ ដោយលើកឡើងថា ការមិនឆ្លើយតបនេះគឺដោយសារតែអង្គជំនុំជម្រះបានរំលោភទៅលើសិទ្ធិរបស់ពួកគាត់ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ តាំងពីដើមរហូតដល់ចប់កិច្ចដំណើរការនីតិវិធី[១០៧]។ ជនជាប់ចោទបានបន្តលើកឡើងអំពីបញ្ហាទាំងនេះនៅក្នុងសារណាបិទបញ្ចប់ការពិភាក្សាដេញដោល និងសេចក្តី-សន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ហើយបានស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធរាល់

---

តុលាការនិងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌, គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/GC/32 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ២៩)។

[១០៦] កន្លងមក នៅពេលអង្គជំនុំជម្រះបានចាត់ចំណាត់ថ្នាក់ឡើងវិញ លើផ្នែកជាក់លាក់មួយចំនួននៃឯកសារនៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះបញ្ជាក់ថាការបង្ហាញផ្នែកនេះមិនប៉ះពាល់ដល់ការចាត់ចំណាត់ថ្នាក់ឡើងវិញ ពាក់ព័ន្ធនឹងផ្នែកដែលមិនត្រូវបង្ហាញ និង ព័ត៌មានក្នុងឯកសារ ឬ សម្ភារៈដទៃទៀតទាំងមូលនោះឡើយ។

[១០៧] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣០, ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៣-៥៤។ ការដកសេចក្តីជូនដំណឹងពីបំណងអនុលោមតាមវិធាន ៩០ ឯកសារ E287/2 ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣-៤ និង ១៨។

បទចោទទាំងអស់ ឬផ្នែកខ្លះ ផ្អាកកិច្ចដំណើរការនីតិវិធី និង/ឬ ពិចារណាលើការចោទប្រកាន់អំពីការរំលោភបំពានលើសិទ្ធិរបស់ពួកគាត់ នៅក្នុងការវាយតម្លៃជាចុងក្រោយលើភ័ស្តុតាង[១០៨]។

៤១. អង្គជំនុំជម្រះនឹងសម្រេចលើសំណើទាំងនេះនៅក្នុងផ្នែកខាងក្រោមនេះ ហើយសេចក្តីសម្រេចនេះគឺធ្វើឡើងដើម្បីបំពេញបន្ថែមទៅលើរាល់សេចក្តីសម្រេច ដែលបានចេញ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះ។ អង្គជំនុំជម្រះក៏នឹងពិនិត្យមើលផងដែរថា តើកំហុសឆ្គងផ្នែកនីតិវិធី (ប្រសិនបើមាននោះ) មានផលប៉ះពាល់ជារួមអ្វីខ្លះទៅលើការជំនុំជម្រះក្តីដោយយុត្តិធម៌នោះ[១០៩]។

---

[១០៨] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 កថាខណ្ឌ ១៦-១១៥។ ប្រតិចារឹក ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ២, ៤-៦, ១៦-២០, ២១-៣២, ៣៧-៣៨, ៤០-៤៤។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ២-៣, ២២-២៤។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់ក្រុមមេធាវី នួន ជា) ទំព័រ ២៦-២៩, ៣១-៣៤។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤-៨, ៩៤-១០១, ១០៩។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ខៀវ សំផន) ទំព័រ ២-១៧, ១៨-២០, ២៣-២៩, ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន) ទំព័រ៤៧-៥០។ ការចោទប្រកាន់ពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី បង្កើតបានជាមូលដ្ឋានសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន (សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធី ឯកសារ E275/2/1/1, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣)។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន មិនបានបង្ហាញឱ្យឃើញ នូវភាពចាំបាច់ឱ្យមានអន្តរាគមន៍ផ្នែកបណ្តឹងសាទុក្ខនោះឡើយ ពេលខ្លួនដាក់បណ្តឹងសាទុក្ខនោះ។ អង្គជំនុំជម្រះយល់ឃើញថា ក្រុមមេធាវីការពារក្តីនៅតែអាចលើកបញ្ហានោះឡើងបាន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខចេញពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយអង្គជំនុំជម្រះបានប្រកាសថាបណ្តឹងសាទុក្ខនោះមិនអាចទទួលយកបាន (សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបញ្ឈប់កិច្ចដំណើរការនីតិវិធី ឯកសារ E275/2/1/4 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៧-៨។

[១០៩] សូម្បីតែគ្មានកំហុសណាមួយ នាំឱ្យប៉ះពាល់ដល់ជនជាប់ចោទយ៉ាងណាក្តី ក៏អង្គជំនុំជម្រះនៅតែត្រូវវាយតម្លៃលើផលប៉ះពាល់ទូទៅនៃកំហុសដែលមិនបង្កគ្រោះថ្នាក់ ដើម្បីកំណត់ថាតើជនជាប់ចោទបានទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ឬយ៉ាងណា (*Ntagerura និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ១១៤)។

## ២.៤.២ វិការៈក្នុងការស៊ើបសួរតាមផ្លូវតុលាការដែលរងការចោទប្រកាន់

៤២. ដោយបញ្ជាក់សាជាថ្មីពីទឡ្ហីករណ៍ដដែលៗ និងសារណាមួយចំនួនដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ កន្លងមកនោះ ជនជាប់ចោទបានលើកឡើងនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលថា ការស៊ើបសួរតាមផ្លូវតុលាការគឺមានភាពទន់ខ្សោយយ៉ាងខ្លាំង ដោយសារតែវិការៈផ្នែកនីតិវិធី និងការជាប់ពាក់ព័ន្ធនឹងការជ្រៀតជ្រែកខាងនយោបាយ ដែលបញ្ហានេះហើយធ្វើឱ្យអង្គជំនុំជម្រះមិនអាចពឹងផ្អែកលើការស៊ើបសួរ ដែលជៀសមិនផុតពីការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះឡើយ[១១០]។ អង្គជំនុំជម្រះធ្លាប់បានសម្រេចថា នៅក្នុងដំណាក់កាលមុនអង្គសេចក្តី ជនជាប់ចោទបានប្រើប្រាស់យ៉ាងទូលំទូលាយនូវការធានាផ្នែកនីតិវិធី ដែលមានក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក ដើម្បីដោះស្រាយវិការៈនៅក្នុងការស៊ើបសួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬនៅក្នុងបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ជនជាប់ចោទមិនបានធ្វើឱ្យអង្គជំនុំជម្រះជឿថា វិការៈផ្នែកនីតិវិធីដូចបានចោទប្រកាន់ ឬការចោទប្រកាន់អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលមានផលប៉ះពាល់ជាក់ស្តែងទៅលើសំណុំរឿង ០០២/០១ ឡើយ[១១១]។ បណ្តឹង

---

[១១០] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 កថាខណ្ឌ ១៦-២៦ (ចោទប្រកាន់លើភាពមិនយុត្តិធម៌ ដែលកើតចេញពីការចោទប្រកាន់ជាលក្ខណៈចោះៗ និង ការចោទប្រកាន់ដែលថា អ.វ.ត.ក អនុវត្ត"ទម្រង់មិនសមរម្យនៃយុត្តិធម៌សម្រាប់តែ"អ្នកឈ្នះ") កថាខណ្ឌ ២៧-៣៧ (បញ្ហាដែលកើតមានជាប្រព័ន្ធនៅក្នុងការបំពេញការស៊ើបសួរតាមផ្លូវតុលាការ) កថាខណ្ឌ ៤៥-៤៦ (សហចៅក្រមស៊ើបអង្កេតមិនបានកោះហៅសាក្សីសំខាន់ៗមួយចំនួន) កថាខណ្ឌ ៥១ (សហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យពិច័យលើបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្ម) កថាខណ្ឌ ៧១ (សហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យពិច័យលើដំណើរការរក្សាភ័ស្តុតាង និងប្រភពដើមនៃភ័ស្តុតាង) កថាខណ្ឌ ៧៣-៧៧ (របៀបស៊ើបសួរក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការមានបញ្ហា) កថាខណ្ឌ ៨០-៨១ (សហចៅក្រមស៊ើបអង្កេតលម្អៀង និងរងការជ្រៀតជ្រែកពីរដ្ឋាភិបាល)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ៦-៨, ២៨-៣៧, ៤៥-៤៧, ៤៩-៥១, ៥៥-៦០។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ៣៣-៣៤។ ប្រតិចារឹក ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន) ទំព័រ ៦៣-៦៤។

[១១១] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ឯកសារ E71/1 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ (អង្គជំនុំជម្រះបានបដិសេធញត្តិរបស់ក្រុមមេធាវីការពារក្តី ដោយបានរកឃើញថា ពុំមានបញ្ហាជាក់លាក់ ឬ ពុំមានលើកឡើងអំពីកំហុសនីតិវិធីណាមួយដូចដែលបានចោទប្រកាន់ និង ពុំមានឃើញស្នើសុំដំណោះស្រាយជាក់លាក់ណាមួយនោះឡើយ។ អង្គជំនុំជម្រះយោងទៅវិធាន

01006341



សាទុក្ខប្រឆាំងនឹង សេចក្តីសម្រេចទាំងអស់នេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធ[១១២]។ ជនជាប់ចោទមិនបានលើកអង្គហេតុ ឬកាលៈទេសៈថ្មី ចាប់តាំងពីពេលចេញសេចក្តីសម្រេចទាំងនេះ ហេតុដូចនេះ សំណើ*តាមការជាក់ស្តែង* របស់គាត់ ដែលបានស្នើសុំឱ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗទាំងអស់នោះ សុទ្ធតែមិនអាចទទួលយកបាន។ ទោះជាយ៉ាងនេះក្តី ក្នុងករណីវិការៈក្នុងការស៊ើបសួរដែលរងការចោទប្រកាន់ទាំងនោះ មានភាពជាក់លាក់គ្រប់គ្រាន់ និង

---

៧៦(៧) នៃវិធានផ្ទៃក្នុង ដែលចែងថា"លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល")។ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ឯកសារ E142/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ (ភាពមិនស្របគ្នារវាងកំណត់ហេតុសម្លេង និង លាយលក្ខណ៍អក្សរគឺជាបញ្ហាមួយដែលពាក់ព័ន្ធនឹងការវាយតម្លៃចុងក្រោយលើភ័ស្តុតាង)។ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (E221, E223, E224, E224/2, E234, E234/2, E241 និង E241/1) ឯកសារ E251 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E189/3 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។ នួន ជា លើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការជ្រៀតជ្រែកខាងនយោបាយ មានលក្ខណៈ "ខ្សោយជាប្រព័ន្ធ និងគេចយករួចខ្លួន" (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៩)។ លើសពីការអះអាងបែបទូទៅនេះ គាត់មិនបានបញ្ជាក់ឱ្យច្បាស់អំពីសេចក្តីសម្រេចដែលគាត់ជឿថាមានភាពខ្វះចន្លោះទាំងនោះ ឬមិនបានរកភ័ស្តុតាងមកគាំទ្រទឡ្ហីករណ៍នេះ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចវាយតម្លៃលើសេចក្តីសន្និដ្ឋាននេះបាន និងបដិសេធសេចក្តីសន្និដ្ឋាននេះភ្លាមៗ។

[១១២] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (អ.ជ.ត.ក) ឯកសារ E116/1/7 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់តាមវិធាន ៣៥" (អ.ជ.ត.ក) ឯកសារ E189/3/1/8 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (អ.ជ.ត.ក) ឯកសារ E176/2/1/4 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ។

ពាក់ព័ន្ធច្បាស់លាស់ទៅនឹងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហាទាំងនេះនៅក្នុងការវាយតម្លៃលើភ័ស្តុតាងជាចុងក្រោយរបស់ខ្លួន[១១៣]។

### ២.៤.៣ ភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង

៤៣. នួន ជា ជំទាស់ទៅនឹងភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង និងវិធានការមួយចំនួនរបស់អង្គជំនុំជម្រះក្នុងការទប់ទល់នឹងសម្ពាធមិនត្រឹមត្រូវ និងការជ្រៀតជ្រែកដូចដែលបានចោទប្រកាន់នោះ[១១៤]។ ការជំទាស់ទាំងនេះមានលក្ខណៈច្រំដែលទៅនឹងសារណាដែលបានដាក់កន្លងមកក្នុងសំណុំរឿង០០២/០១ ហើយការជំទាស់នេះមិនមានលក្ខណៈជាសារធាតុ ហេតុដូច្នេះហើយ គឺត្រូវបានសម្រេចបដិសេធ[១១៥]។ នៅខែកុម្ភៈ និង សីហា ឆ្នាំ ២០១២ ជនជាប់ចោទបានប្រាប់អង្គជំនុំជម្រះឲ្យបានដឹងអំពីការថ្លែងជាសាធារណៈរបស់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ និងសិទ្ធិរបស់មេធាវីការពារក្តី[១១៦]។ ទាំងអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីរំលឹកដល់ការថ្លែងការណ៍មិនសមរម្យរបស់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងបានអះអាងបញ្ជាក់អំពីភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង ហើយបានគូសបញ្ជាក់អំពីករណីកិច្ច និងលទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការមិនធ្វើការពិចារណាទៅ

---

[១១៣] សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុ ជាលាយលក្ខណ៍អក្សរ និង ជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ឯកសារ E142/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៦-១៥។

[១១៤] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣-២៦, ៥៨, ៨០-៨៦។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា) ទំព័រ ៥-៧, ២២-២៤, ៣៦-៣៩។

[១១៥] សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និង សំណើពាក់ព័ន្ធផ្សេងៗ ឯកសារ E5/3 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ។ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១។

[១១៦] សំណើសុំឲ្យមានចំណាត់ការបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥ ឯកសារ E176 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៧-២៣។ សំណើសុំតាមវិធាន ៣៥ សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ឯកសារ E219 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១២-២២។

លើសេចក្តីថ្លែងការណ៍ទាំងនេះ នៅពេលខ្លួនពិចារណាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ[១១៧]។ នួន ជា មិនបានលើកអង្គហេតុ ឬ កាលៈទេសៈថ្មី ចាប់តាំងពីពេលចេញសេចក្តីសម្រេចទាំងនេះនោះទេ ហេតុដូចនេះ សំណើ*តាមការជាក់ស្តែង* របស់គាត់ ដែលបានស្នើសុំឱ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗទាំងអស់នោះ សុទ្ធតែមិនអាចទទួលយកបាន។ លើសពីនេះទៀត អង្គជំនុំជម្រះបានបញ្ជាក់ជាថ្មីម្តងទៀតអំពីភាពមិនលម្អៀងរបស់ខ្លួន ហេតុដូច្នេះ អង្គជំនុំជម្រះនឹងមិនធ្វើការពិចារណាលើព័ត៌មាន ដែលមិនពាក់ព័ន្ធ និងដែលមិនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង នោះឡើយ។

### ២.៤.៤ ពេលវេលា និងមធ្យោបាយដែលមានសម្រាប់ត្រៀមរៀបចំការការពារក្តី

៤៤. ជនជាប់ចោទលើកឡើងនូវបញ្ហាជាច្រើនពាក់ព័ន្ធនឹងពេលវេលា និងមធ្យោបាយដែលមានសម្រាប់ត្រៀមរៀបចំការការពារក្តី រួមទាំងការយឺតយ៉ាវក្នុងការបកប្រែឯកសារទៅជាភាសាផ្លូវការរបស់ពួកគេ សមភាពនៃកម្លាំងរវាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី និងថិរវេលារវាងការជូនដំណឹងអំពីបទចោទ និងកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ភ័ស្តុតាង[១១៨]។ បញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំងអស់នេះ គឺត្រូវបានអង្គជំនុំជម្រះពិចារណា និងផ្តល់ជាដំណោះស្រាយរួចហើយ នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ (ឧទាហរណ៍ ការផ្តល់អ្នកបកប្រែផ្ទាល់មាត់ និងការកែសម្រួលនីតិវិធីដែលពាក់ព័ន្ធ)។ ដោយពិចារណាជាពិសេសលើការស៊ើបអង្កេតតាមផ្លូវតុលាការដែលប្រើពេលយូរនោះ អង្គជំនុំជម្រះបានបញ្ជាក់សាជាថ្មីថា ជនជាប់ចោទទទួលបានពេលវេលា

---

[១១៧] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (អ.ជ.ត.ក) ឯកសារ E176/2/1/4 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើសំណើសុំចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ។

[១១៨] បញ្ហាខ្លះក្នុងចំណោមបញ្ហាទាំងនេះត្រូវបានលើកឡើងជាថ្មីម្តងទៀត ដោយក្រុមមេធាវីការពារក្តីនៅពេលបិទបញ្ចប់សវនាការ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៦៣-៦៧ និង ៨៧-៨៨ (ពាក់ព័ន្ធនឹងនីតិវិធីហួសពីសមត្ថកិច្ចដែលរងការចោទប្រកាន់ ក្នុងការដាក់បញ្ជីភ័ស្តុតាងដំបូង)។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ២-៣, ២២-២៣ (សមភាពនៃគូក្តី)។ សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៦ និង ៩៣-៩៤ (ពាក់ព័ន្ធនឹងការបកប្រែឯកសារភ័ស្តុតាង និងការដាក់ឯកសារ)។

និងមធ្យោបាយជាសមាមាត្រ ដើម្បីត្រៀមរៀបចំការការពារក្តី នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល[១១៩]។ ភាគីក៏ទទួលបាននូវសមភាពខាងផ្នែកនីតិវិធីផងដែរក្នុងការបង្ហាញពីរឿងក្តីរបស់ខ្លួន ហើយជនជាប់ចោទមិនបានបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ស្តីពីការរំលោភបំពានលើគោលការណ៍សមភាពនៃកម្លាំងនោះទេ[១២០]។ ពាក់ព័ន្ធនឹងពេលវេលានិងមធ្យោបាយសម្រាប់ត្រៀមរៀបចំការការពារក្តី ជនជាប់ចោទមិនបានលើកពីអង្គហេតុ ឬកាលៈទេសៈថ្មី ចាប់តាំងពីពេលចេញសេចក្តីសម្រេចមុនៗនោះទេ ហេតុដូចនេះសំណើ *តាមការជាក់ស្តែង* របស់គាត់ ដែលបានស្នើសុំឲ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗទាំងអស់នោះមិនអាចទទួលយកបាននោះទេ។

[១១៩] *សូមមើល ឧទាហរណ៍* ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ (អ.ជ.ស.ដ) ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ។ ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេលដាក់ឯកសារភ័ស្តុតាង (ឯកសារ E9/6) (អ.ជ.ស.ដ) ឯកសារ E9/6/1 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ។ សេចក្តីសម្រេចលើសំណើនានាដែលបានស្នើសុំពន្យារពេល ដើម្បីដាក់បញ្ជីឯកសារ និង វត្ថុតាង ឯកសារ E9/16/4 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១។ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់មេធាវីការពារក្តីជន-ជាប់ចោទ អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (ឯកសារ E118) (អ.ជ.ស.ដ) ឯកសារ E118/4 ចុះថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។ ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ចំពោះឯកសារបន្ថែមនៅក្នុងសំណុំរឿង (អ.ជ.ស.ដ) ឯកសារ E118/5 ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២។ សេចក្តីជូនដំណឹងអំពីឯកសារសម្ងាត់បំផុត ពាក់ព័ន្ធនឹងសុខភាពរបស់ជនជាប់ចោទ (អ.ជ.ស.ដ) ឯកសារ E118/6 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២។ ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារបន្ថែមក្នុងសំណុំរឿង (អ.ជ.ស.ដ) ឯកសារ E118/7 ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ឯកសារ E51/14 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យប្រកាសមិនទទួលយកសារណាបញ្ចប់របស់សហព្រះរាជអាជ្ញា (ឯកសារ E295/7) ឯកសារ E295/7/2 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៦។

[១២០] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនិងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២១ ("តួនាទីរបស់សហព្រះរាជអាជ្ញា នៅក្នុងការស៊ើបសួរបឋម និងនៅក្នុងសំណុំរឿងផ្សេងទៀត ពុំមានផលប៉ះពាល់លើសមភាពនៃកម្លាំងឡើយ ដរាបណាភាគីទាំងអស់មានសមភាពផ្នែកនីតិវិធីក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន")។

## ២.៤.៥ ការជូនដំណឹងអំពីបទចោទ និងដំណើរការនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿង ០០២/០១

៤៥. ជនជាប់ចោទលើកឡើងថាៈ ការបំបែកដីកាដំណោះស្រាយគឺមិនអាចគ្រប់គ្រងបាននោះទេ ដូច្នេះហើយធ្វើឲ្យមានភាពមិនច្បាស់លាស់អំពីទំហំនៃសំណុំរឿង០០២/០១ ការបំបែកការជំនុំជម្រះទៅតាមប្រធានបទ គឺធ្វើឲ្យមានភាពមិនច្បាស់លាស់ពាក់ព័ន្ធទៅនឹងការទទួលយកភ័ស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និងធ្វើឲ្យមានភាពមិនច្បាស់លាស់ផងដែរអំពីការជំនុំជម្រះក្ដីទៅថ្ងៃអនាគត ដូច្នេះហើយ បញ្ហានេះធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពនៃការការពារក្ដីប្រកបដោយប្រសិទ្ធភាពរបស់គាត់[១២១]។

៤៦. នៅថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា ខ្លួននឹងចាប់ផ្ដើមការជំនុំជម្រះក្ដី ដោយធ្វើសវនាការពិនិត្យលើភ័ស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និង

---

[១២១] សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៩៣-១០១។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានតបរបស់ក្រុមមេធាវីការពារក្ដី នួន ជា) ទំព័រ ២៦-២៩។ សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤-៨, ៩៤-១០១, ១០៩។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោយរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន) ទំព័រ ២-១៧, ១៨-២០, ២១-២៣, ២៤-២៩។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានតបរបស់ ខៀវ សំផន) ទំព័រ៤៧-៥០។ សេចក្ដីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ឯកសារ E288/4 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៨ , ៣០។ សំណើបន្ទាន់ស្នើសុំសេចក្ដីបំភ្លឺលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃចម្លើយជាលាយលក្ខណ៍អក្សរ និង ការពន្យាររយៈពេលកំណត់សម្រាប់ដាក់សារណាបញ្ចប់ ឯកសារ E299/1 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៣-៣៦។ សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២០-៦៨។ បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី និង សារណាតបចំពោះបណ្ដឹងសាទុក្ខរបស់ សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/4/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១២, ៣៣។ ការចង្អុលបង្ហាញពាក់ព័ន្ធនឹងសាក្សី ព្រមទាំងឯកសារនានាសម្រាប់ដំណាក់កាលទីមួយនៃការជំនុំជម្រះដំបូង ឯកសារ E131/1/6 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ១៦។ សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម ឯកសារ E93/9 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ២-១១។

គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ[១២២]។ ក្រោយមកនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ភស្តុតាងនៃអង្គហេតុណាដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ អាចទទួលយកបាន ប្រសិនបើមានការបង្ហាញថាវាមានភាពពាក់ព័ន្ធ[១២៣]។ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានទទួលយកភស្តុតាងនៃអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ នៅពេលមានការបង្ហាញថាវាមានភាពពាក់ព័ន្ធ ជាអាទិ៍ទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកា-ដំណោះស្រាយ បរិបទធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះ[១២៤]។

៤៧. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបំបែកការចោទប្រកាន់ក្នុងសំណុំរឿង ០០២ ហើយបានជូនដំណឹងដល់ភាគីអំពីវិសាលភាពនៃសំណុំរឿង ០០២/០១ និងបានជូនដំណឹងផងដែរថា បទចោទបន្ថែមអាចនឹងត្រូវដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នៅ

---

[១២២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៤៨-៤៩។ *សូមមើលផងដែរ* សេចក្តីណែនាំមុនសវនាការបឋម ពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ (អ.ជ.ស.ដ) ឯកសារ E93 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ២។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ទំព័រ ៦-៨។

[១២៣] សេចក្តីណែនាំមុនសវនាការបឋម ពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ (អ.ជ.ស.ដ) ឯកសារ E93 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ២។

[១២៤] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣-២៤។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហ-មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២០។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៧។

ពេលក្រោយ[១២៥]។ នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះបានបញ្ជាក់ថា ទោះបីជាការបង្កើតគោលនយោបាយទាំងប្រាំ គឺជាបញ្ហាទូទៅមួយ ដែលស្ថិតនៅក្នុងវិសាលភាព ហើយអាចត្រូវពិនិត្យនៅក្នុងសំណុំរឿង ០០២/០១ ក៏អង្គជំនុំជម្រះនឹងមិនពិនិត្យលើការអនុវត្តគោលនយោបាយណា ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងការចោទប្រកាន់លើអង្គហេតុជាក់លាក់ ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ឡើយ[១២៦]។ នៅថ្ងៃដដែល អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីលំដាប់លំដោយនៃប្រធានបទ និងលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធី ហើយដែលនៅក្នុងនោះអង្គជំនុំជម្រះនឹងពិនិត្យលើភ័ស្តុតាងដែលមានក្នុងសំណុំរឿង ០០២/០១[១២៧]។ បន្ទាប់ពីការជំនុំជម្រះពីរវគ្គដំបូងពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្រ្ត គោលនយោបាយកម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងរួចមក នៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចាប់ផ្តើមពិនិត្យលើភ័ស្តុតាងពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងការទទួលខុសត្រូវរបស់ជនជាប់ចោទ។

៤៨. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយបញ្ចូលការសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[១២៨]។ បន្ទាប់

---

[១២៥] ដីកាបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៥-៦។

[១២៦] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និង សំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ១១។ *សូមមើលផងដែរ* ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។

[១២៧] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និង សំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ។ *សូមមើលផងដែរ* ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១(អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។

[១២៨] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និង ពេលវេលាកំណត់នៃការដាក់

ពីអង្គជំនុំជម្រះតុលាការកំពូលសម្រេចលុបចោល ដីកាបំបែកកិច្ចដំណើរការនីតិវិធីជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្ដីសម្រេចដែលពាក់ព័ន្ធផ្សេងៗទៀត[១២៩] អង្គជំនុំជម្រះសាលាដំបូងបានពិគ្រោះយោបល់ជាមួយភាគី ទៅតាមការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល និងបានសម្រេចជាថ្មីម្ដងទៀតដោយបំបែកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ដូចទៅនឹងអ្វីដែលបានសម្រេចកាលពីលើកមុន[១៣០]។ សវនាការពិនិត្យលើភស្តុតាងពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ បានចាប់ផ្ដើមនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣។

៤៩. សរុបសេចក្ដីមក អង្គជំនុំជម្រះបានផ្ដល់ជូនភាគីយ៉ាងគ្រប់គ្រាន់នូវពេលវេលា និងការជូនដំណឹងយ៉ាងជាក់ច្បាស់អំពីបទចោទដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងដំណើរការនៃការជំនុំជម្រះក្ដី។ អង្គជំនុំជម្រះបានបញ្ជាក់ជាថ្មីថា រាល់ការតវ៉ាដែលបានលើកឡើងពីមុនៗទាក់ទងនឹងវិសាលភាព និងដំណើរការនៃការជំនុំជម្រះក្ដីទៅថ្ងៃអនាគតក្នុងសំណុំរឿង ០០២ នោះ មិនបានបង្ហាញពីផលប៉ះពាល់ជាក់លាក់ណាមួយ ទៅលើការជំនុំជម្រះក្ដីប្រកបដោយភាពយុត្តិធម៌នៅក្នុងសំណុំរឿង ០០២/០១ ឡើយ[១៣១]។

### ២.៤.៦ សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី

៥០. នួន ជា អះអាងថា អង្គជំនុំជម្រះមានបំណងកោះហៅតែសាក្សីដាក់បន្ទុក និងមិនបានកោះហៅសាក្សីសំខាន់ៗរបស់មេធាវីគាត់ឡើយ[១៣២]។ ជនជាប់ចោទទាំងពីរលើកឡើងថា អង្គជំនុំ-

---

សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ។

[១២៩] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 ។

[១៣០] ឯកសារលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៨។

[១៣១] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៣៣-៣៤, ៣៩។

[១៣២] សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤១-៥៩, ៩១។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដី-សន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា) ទំព័រ ២៧-៣០, ៣១-៣២។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ

ជម្រះមិនបានផ្តល់សំអាងហេតុនៅក្នុងសេចក្តីសម្រេច ដែលសម្រេចមិនកោះហៅសាក្សីជាក់លាក់មួយចំនួន ដូច្នេះហើយ ធ្វើឱ្យជនជាប់ចោទត្រូវតែប្រើវិធីសាស្ត្រការពារក្តីដោយព្រាវៗ និងមិនស៊ីសង្វាក់[១៣៣]។

៥១. ភាគីបានស្នើសុំឱ្យកោះហៅសាក្សីសរុបទាំងអស់ចំនួន ១.០៥៤ នាក់ ដើម្បីជាការឆ្លើយតបទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ដែលបានបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ[១៣៤]។ នៅក្នុងការពិចារណាដើម្បីសម្រេចថា តើត្រូវកោះហៅបុគ្គលណាខ្លះក្នុងចំណោមបុគ្គលទាំងអស់នោះ អង្គជំនុំជម្រះបានថ្លឹងថ្លែងទៅលើសិទ្ធិទាំងឡាយរបស់ភាគីទាំងអស់ដែលបានស្នើសុំឱ្យពិនិត្យភ័ស្តុតាង ភាពចាំបាច់ក្នុងការធ្វើសវនាការជាសាធារណៈបន្ទាប់ពីការស៊ើបសួរដែលបានធ្វើឡើងជាសម្ងាត់ សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរតទល់គ្នាជាមួយសាក្សី និងសិទ្ធិរបស់ជនជាប់ចោទម្នាក់ៗក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស[១៣៥]។ នៅក្នុងអំឡុងពេលសវនាការបឋមនៅខែ មិថុនា ឆ្នាំ ២០១១ និងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅក្នុងខែ មេសា ឆ្នាំ ២០១១ និង ខែ សីហា ឆ្នាំ ២០១២ និង ខែ មិថុនា ឆ្នាំ

---

២០១៣ (នួន ជា) ទំព័រ ២៣-២៣។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានតបរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ២៩-៣០។

[១៣៣] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៩។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ៥៥-៥៧។ សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងការកោះហៅសាក្សី ដែលបានស្នើឡើងដោយមេធាវីការពារក្តី ឯកសារ E212 ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១៣, ១៨-២៤។ ការចង្អុលបង្ហាញពាក់ព័ន្ធនឹងសាក្សី ព្រមទាំងឯកសារនានាសម្រាប់ដំណាក់កាលទីមួយនៃការជំនុំជម្រះ ឯកសារ E131/1/6 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ៤-៨, ១១-១៤។

[១៣៤] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (អ.ជ.ស.ដ) ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[១៣៥] *សូមមើល ឧទាហរណ៍* កិច្ចព្រមព្រៀង មាត្រា ១៣(១)។ សេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ។ ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និង ការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១២។ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ១។

២០១៣ អង្គជំនុំជម្រះបានចង្អុលបង្ហាញទៅភាគីឲ្យបានដឹងអំពីសាក្សីទាំងឡាយ ដែលអង្គជំនុំជម្រះមានបំណងកោះហៅ ឬមិនកោះហៅពាក់ព័ន្ធនឹងវគ្គនៃការជំនុំជម្រះក្តីនាពេលឆាប់ៗខាងមុខ ហើយអង្គជំនុំជម្រះបានស្នើភាគីឲ្យដាក់សារណាជាលាយលក្ខណ៍អក្សរ និងបានស្នើឲ្យភាគីបញ្ជាក់នូវអត្តសញ្ញាណសាក្សី ដែលខ្លួនយល់ថាមានសារៈសំខាន់បំផុតចំពោះរឿងក្តីរបស់ខ្លួន[១៣៦]។ រាល់បុគ្គលដែលភាគីបានស្នើសុំឲ្យកោះហៅ ត្រូវបានអង្គជំនុំជម្រះរក្សាទុកសម្រាប់ពិនិត្យឡើងវិញ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះក្តីទាំងមូល។

៩២. ជាចុងក្រោយ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មបុគ្គលចំនួន ៩២ នាក់ ដែលក្នុងនោះ ២០ នាក់ ត្រូវបានស្នើឡើងដោយ នួន ជា និង ២៣ នាក់ ត្រូវបានស្នើឡើងដោយ ខៀវ សំផន (ក្នុងចំណោមបុគ្គល ២៣ នាក់ក្រោយនេះ មាន ៣ នាក់ ជាសាក្សីអត្តចរិត)។ ភាគច្រើននៃបុគ្គលដែលបានស្នើសុំដោយ នួន ជា និង ខៀវ សំផន រួមទាំងអ្នកដែលត្រូវបានកំណត់ថាជាបុគ្គលសំខាន់នោះ ត្រូវបានអង្គជំនុំជម្រះបដិសេធចោល ដោយហេតុថា បុគ្គលទាំងនោះមិនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ (ដូច្នេះហើយបុគ្គលទាំងនោះត្រូវបានទុកសម្រាប់ការជំនុំជម្រះនៅថ្ងៃអនាគត) ឬមិនមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ទាំងមូល (រួមមានបុគ្គលជាច្រើនដែលត្រូវបានស្នើសុំពាក់ព័ន្ធនឹងដំណើរការនៃការស៊ើបសួរតាមផ្លូវតុលាការ ឬដើម្បីគាំទ្រការចោទប្រកាន់ជាទូទៅចំពោះឯករាជ្យភាពរបស់តុលាការ និងការជ្រៀតជ្រែកខាងផ្នែកនយោបាយ) និងជាបុគ្គលដែលបានស្នើសុំច្រំដែល ឬ មិនបានកំណត់អត្តសញ្ញាណគ្រប់គ្រាន់[១៣៧]។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា សាក្សីមួយចំនួនដែលជនជាប់ចោទបានស្នើឡើង បានស្លាប់នៅមុនពេលបញ្ចប់សវនាការពិនិត្យលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ (*សូមមើល ឧទាហរណ៍* TCW-482 និង TCW-699) ឬ រកមិនឃើញបន្ទាប់ពីបានអនុវត្តការងារយ៉ាងយកចិត្តដាក់សមស្របរួចមក[១៣៨]។ ទោះជាយ៉ាងនេះក្តី យន្តការដទៃទៀតត្រូវបានផ្តល់ជូនដល់ភាគី ដើម្បីមានលទ្ធភាពបង្ហាញជាលាយលក្ខណ៍អក្សរនូវសេចក្តីថ្លែង

---

[១៣៦] សេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ។

[១៣៧] ឧបសម្ព័ន្ធ II និង III នៃសេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។

[១៣៨] អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដាក់ជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ក្រោមចំណងជើងថា "សាក្សីសក្តានុពល-មិនអាចរកឃើញ" ឯកសារ E292/1/2 ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ ។

និងព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងសាក្សីដែលមិនបានកោះហៅ ឬប្រធានបទដែលចង់ឲ្យសាក្សីទាំងនោះធ្វើសក្ខីកម្ម[១៣៩]។

៩៣. ដើម្បីបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ត្រូវបានរំលោភបំពានដោយសារតែអវត្តមានរបស់សាក្សីនោះ ជនជាប់ចោទត្រូវតែបង្ហាញថា ខ្លួនបានប្រើប្រាស់វិធានការទាំងអស់ដែលមាន ដើម្បីទទួលបានសក្ខីកម្មរបស់សាក្សីរូបនោះ ឬស្នើសុំឲ្យផ្តល់ភស្តុតាងតាមទម្រង់មួយផ្សេង ដូចជា កំណត់ហេតុស្តាប់ចម្លើយសាក្សី ជាដើម[១៤០]។

៩៤. អង្គជំនុំជម្រះពិចារណាឃើញថា ភាគីទាំងអស់អាចស្នើសុំឲ្យកោះហៅសាក្សីដែលខ្លួនយល់ថាមានសារៈសំខាន់បំផុតចំពោះរឿងក្តីរបស់ខ្លួន និងសុំឲ្យដាក់ភស្តុតាងដទៃទៀតដែលខ្លួនយល់ឃើញថាជាភស្តុតាងដោះបន្ទុក ឬដែលអាចជួយបង្ហាញការពិត រួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះបាន ក្នុងករណីដែលសាក្សីទាំងនោះមិនត្រូវបានកោះហៅ ។ អនុលោមតាមវិធាន ៨៤ (៤) នៃវិធានផ្ទៃក្នុង ភាគីអាចប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនានាទាក់ទងនឹងការកោះហៅសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពេលជាមួយគ្នានឹងការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[១៤១]។

---

[១៣៩] សូមមើល *ឧទាហរណ៍* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២០-២៦។ កាលកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ ។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤។

[១៤០] សាលដីកាក្នុងរឿងក្តី *Renzaho* កថាខណ្ឌ ១៦៩ (“ការខកខានរបស់ជនជាប់ចោទមិនបានសុំឲ្យមានដំណោះស្រាយនៅក្នុងសវនាការធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទាមទារព្យសនកម្មរបស់ខ្លួន”) កថាខណ្ឌ ១៩១, ១៩៦, ២១៦, ២១៧ (“ជាការពិតហើយ ភាគីណាក៏ដោយមានសិទ្ធិដកខ្លួនចេញពីការសុំឲ្យមានវិធានការបែបនេះបាន។ ប៉ុន្តែ ភាគីមិនអាចគេចវេសពីកាតព្វកិច្ចរបស់ខ្លួនដើម្បីប្រើប្រាស់ឲ្យអស់ពីមធ្យោបាយដែលអាចមានដើម្បីបង្ហាញពីរឿងក្តីរបស់ខ្លួន ដោយការសម្រេចជាឯកតោភាគីថា វិធានការជាក់លាក់មួយចំនួនគឺមិនសមហេតុផល ឬ គ្មានប្រសិទ្ធភាពនោះឡើយ”) កថាខណ្ឌ ២១៦។ *Lukić* និង *Lukić* សាលដីកា កថាខណ្ឌ ៤៤-៤៥។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ៥៥។

[១៤១] សូមមើលសេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ត្រង់ផ្នែកទី ៣.២.៨ ស្តីអំពីមតិយោបល់របស់ចៅក្រម

### ២.៤.៧ លទ្ធភាពរបស់ក្រុមមេធាវីការពារក្តីក្នុងការបង្ហាញឧក្រិដ្ឋកម្មនៅក្នុងបរិបទរបស់ខ្លួន

៩៥. នួន ជា លើកឡើងថា ការកម្រិតទៅលើសវនាការលើភ័ស្តុតាងពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មមួយចំនួននោះ បានរារាំងដល់លទ្ធភាពរបស់គាត់ក្នុងការរៀបចំការការពារខ្លួនឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ ជាពិសេស គាត់លើកឡើងថា ប្រធានបទផ្នែកប្រវត្តិសាស្ត្រមួយចំនួន ដូចជា ការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជានៅចន្លោះពីឆ្នាំ ១៩៦៩ ដល់ឆ្នាំ ១៩៧៣ ស្ថានភាពរស់នៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ ១៩៧៥ និងបរិបទនយោបាយក្រោយឆ្នាំ ១៩៧៩ (ដោយសារតែប្រធានបទទាំងនេះពាក់ព័ន្ធទៅនឹងការប្រមូលភ័ស្តុតាង និង តួនាទីរបស់ប្រទេសវៀតណាមនៅក្នុងការកត់ត្រាប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា "ដើម្បីឲ្យស្របទៅនឹងរបៀបវារៈនយោបាយរបស់ខ្លួន") គួរតែត្រូវបានដាក់បញ្ចូល ដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចវាយតម្លៃទៅលើបរិបទនៃសកម្មភាពរបស់គាត់បាន។ នួន ជា ក៏លើកឡើងផងដែរថា សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យលើកឡើងអំពីភ័ស្តុតាងដែលជាបរិបទប្រវត្តិសាស្ត្រ ចំណែករូបគាត់មិនត្រូវបានអនុញ្ញាតនោះឡើយ ហេតុដូច្នេះ វាជាការរំលោភទៅលើគោលការណ៍សមភាពនៃកម្លាំង[១៤២]។

---

និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម យូរ ឧត្តរា និងសេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ត្រង់ចំណុច ៣.២.៨ ស្តីពីមតិយោបល់របស់ចៅក្រម Silvia CARTWRIGHT និងចៅក្រម Jean-Marc LAVERGNE។

[១៤២] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៥១-៥៥, ៥៧-៥៩, ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញរបស់ក្រុមមេធាវី នួន ជា) ទំព័រ ១៦-២០, ២៩-៣១។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ លើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/4/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣-១៩។ សារណាគាំទ្រដល់សារណារបស់ អៀង សារី សុំដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការ ទៅក្នុងកម្មវិធីសវនាការ និងសំណើសុំដាក់បន្ថែមប្រធានបទថ្មីៗទៀត ឯកសារ E89/1 ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ២, ៨-៩។ សំណើសុំស្តាប់ចម្លើយសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី និងចាត់ឲ្យមានវិធានការខាងនីតិវិធីដទៃទៀត ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើបរិបទប្រវត្តិសាស្ត្រ ឯកសារ E182 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ពីកថាខណ្ឌ ១៤-២៩។

៥៦. ក្នុងករណីដែលជនជាប់ចោទជំទាស់ថា សិទ្ធិទទួលបានការជំនុំជម្រះរបស់ខ្លួនត្រូវបានរំលោភបំពាន ដោយការកំហិតលទ្ធភាពរបស់ខ្លួនក្នុងការបង្ហាញពីភ័ស្តុតាងពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មទាំងឡាយនោះ ជនជាប់ចោទត្រូវបង្ហាញព្យសនកម្មជាក់ស្តែង មានន័យថា តើវាអាចប៉ះពាល់ដល់ពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ខ្លួនដោយរបៀបណាដែរ[១៤៣]។

៥៧. សវនាការវគ្គទីមួយក្នុងសំណុំរឿង០០២/០១ ផ្តោតទៅលើបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មនានា។ ក្នុងវគ្គនេះ និងនៅក្នុងការជំនុំជម្រះទាំងមូល អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងយុទ្ធនាការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកក្នុងប្រទេសកម្ពុជានៅចន្លោះពីឆ្នាំ ១៩៦៩ ដល់ឆ្នាំ ១៩៧៣ ស្ថានភាពរស់នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបរិបទក្រោយឆ្នាំ ១៩៧៩ ពីសាក្សី និងអ្នកជំនាញមួយចំនួន រួមទាំងបុគ្គលចំនួន ៧ រូបដែល នួន ជា បានស្នើផងដែរ។ ភ័ស្តុតាងឯកសារជាច្រើន ដែលភាគីបានស្នើសុំ ហើយដែលពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ (រួមទាំងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាចន្លោះពីឆ្នាំ ១៩៦៩ ដល់ឆ្នាំ ១៩៧៣ ស្ថានភាពរស់នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបរិបទក្រោយឆ្នាំ១៩៧៩) ក៏ត្រូវបានទទួលយកផងដែរ[១៤៤]។

៥៨. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង អង្គជំនុំ-ជម្រះត្រូវវិនិច្ឆ័យត្រឹមតែអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលត្រូវបានបំបែកនៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថាការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់រហ័ស។ ហេតុដូច្នេះ អង្គជំនុំជម្រះបានច្រានចោលភ័ស្តុតាងខ្លះដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមទាំង

---

[១៤៣] *Nahimana និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ២៤៩-២៥០។

[១៤៤] David CHANDLER, SAO Sarun, Al ROCKOFF, Sydney SCHANBERG, កាំង ហ្កេកអ៊ាវ, Stephen HEDER និង Philip SHORT។ នួន ជា បានស្នើសុំឲ្យកោះហៅសាក្សីចំនួន ១៣២ នាក់ ពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ (សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ ឯកសារ E9/10 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ។ *ជាឧទាហរណ៍ សូមមើល* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ។

អង្គហេតុខ្លះទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រនេះ[១៤៥]។ ទោះជាយ៉ាងណាក្តី នួន ជា ខកខានក្នុងការបង្ហាញថា ភ័ស្តុតាងដែលបានទទួលយកពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មនានាមិនមានលក្ខណៈគ្រប់គ្រាន់ ឬថា តើភ័ស្តុតាងដទៃទៀតអាចមានផលប៉ះពាល់ជាក់ស្តែងទៅលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ខ្លួន ឬយ៉ាងណា។ តាមពិតទៅ នួន ជា បានបញ្ជាក់ថា គាត់បានសម្រេចមិនពិនិត្យលើបរិបទប្រវត្តិសាស្ត្រឲ្យបានពេញលេញ ឬបញ្ហាផ្សេងទៀតដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយសារតែមួយផ្នែកនៃបញ្ហានេះគឺជាយុទ្ធសាស្ត្រនៃការការពារក្តី មិនមែនដោយសារតែការគ្មានលទ្ធភាពនោះទេ[១៤៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការការពារខ្លួនមិនត្រូវបានរំលោភបំពាននោះឡើយ។

### ២.៤.៨ សិទ្ធិក្នុងការសួរដេញដោលទៅកាន់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ

៩៩. ជនជាប់ចោទលើកឡើងថា សិទ្ធិរបស់ខ្លួនក្នុងការសួរដេញដោលប្រកបដោយប្រសិទ្ធភាពទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ និងគោលការណ៍ស្តីពីសមភាពនៃកម្លាំងត្រូវបានរំលោភដោយការកម្រិតតាមទំនើងចិត្ត និងមិនយុត្តិធម៌ទៅលើវិសាលភាពនៃការចោទសួរ និងឯកសារដែលអាចត្រូវបានយកមកប្រើប្រាស់ ដើម្បីតវ៉ាទៅលើភាពអាចឲ្យជឿជាក់បានរបស់បុគ្គលទាំងឡាយដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ[១៤៧]។ លើសពីនេះទៀត នួន ជា និង

---

[១៤៥] *ជាឧទាហរណ៍ សូមមើល* សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងការអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤។

[១៤៦] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/4/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៨-១៩។

[១៤៧] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៥៨, ៦០-៧៩, ៩១។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ៣០-៣៥។ ប្រតិចារឹកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ២៣-២៤។ សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៩៥-៩៦។ ការដកសេចក្តីជូនដំណឹងពីគោលបំណងអនុវត្តតាមវិធាន ៩០ ឯកសារ E287/2 ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២, ១០-

ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះបានរំលោភសិទ្ធិរបស់ពួកគេ ដោយទទួលយកកំណត់ហេតុ និងសក្ខីកម្មមុនៗរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយមិនបានផ្តល់ឱកាសសម្រាប់ការសួរដេញដោលឡើយ[១៤៨]។

៦០. អនុលោមតាមវិធាន ៨៥ និង ៨៧ នៃវិធានផ្ទៃក្នុង ប្រធានសវនាការ និងអង្គជំនុំជម្រះអាចបដិសេធនូវរាល់នីតិវិធី និងការតាំងសំណួរដែលនាំឱ្យប្រើប្រាស់ពេលវេលាជំនុំជម្រះដោយមិនចាំបាច់ ឬដែលមិនអាចនាំទៅដល់ការបង្ហាញការពិតបាន។ អង្គជំនុំជម្រះបានជំរុញឱ្យភាគីទាំងអស់កម្រិតការសួរសំណួររបស់ពួកគេទៅលើបុគ្គលទាំងឡាយ ដែលត្រូវបានកោះហៅឱ្យចូលខ្លួនមកក្នុងសវនាការ ត្រឹមតែចំពោះបញ្ហានានាដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ប៉ុណ្ណោះ[១៤៩]។ លើសពីនេះទៀត ដោយពិចារណាទៅលើសមត្ថភាពរបស់បុគ្គលដែលត្រូវបាន

---

១១, ១៣-១៤។ បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណារតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/4/1ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៧។ នួន ជា ជំទាស់តវ៉ាថា សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះទាក់ទងនឹងវិសាលភាព និងនីតិវិធីសម្រាប់ការសួរដេញដោលបុគ្គលទាំងឡាយដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការ "មិនមាន ឬពិតជាមិនមានសម្អាងហេតុមែន)។ ហេតុដូច្នេះ ជាការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសេចក្តីសម្រេចមួយដែលមានសម្អាងហេតុ (សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៩)។ ក្រៅពីការអះអាងជាទូទៅនេះ គាត់ខកខានមិនបានបង្ហាញពីសេចក្តីសម្រេចដែលគាត់ជឿជាក់ថា មានភាពខ្វះចន្លោះ ឬអះអាងទៅលើការជំទាស់តវ៉ានេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនមានលទ្ធភាពវាយតម្លៃទៅលើសារណានេះបានឡើយ និងបដិសេធសារណានេះចោល។

[១៤៨] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់លោក នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ១០២-១១៥ (ដែលស្នើសុំឱ្យអង្គជំនុំជម្រះយកអង្គហេតុនេះទៅពិចារណានៅក្នុងការវាយតម្លៃជាចុងក្រោយរបស់ខ្លួនទៅលើភ័ស្តុតាង និង សុំឱ្យច្រានចោលសេចក្តីសន្និដ្ឋាននានាដែលអះអាងទៅលើបញ្ហាជាក់ស្តែងក្នុងសំណុំរឿង ០០២/០១ ដែលមិនមានឱកាសដើម្បីសួរតទល់គ្នា។ ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី នួន ជា) ទំព័រ ៣១។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ការជំទាស់តវ៉ារបស់មេធាវីការពារក្តី នួន ជា) ទំព័រ ២៧-២៨។ ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ខៀវ សំផន) ទំព័រ ៥៩។

[១៤៩] ការឆ្លើយតបទៅលើបញ្ហា ដែលបានលើកឡើងដោយភាគីនានាមុនពេលពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ) ឯកសារ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។ ការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញ សម្រាប់ដើមឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E236/4ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

កោះហៅឲ្យមកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានកម្រិតវិសាលភាពនៃការសួរសំណួរ ដើម្បីធានាថា ការសួរសំណួរមិនបានងាកចូលទៅក្នុងប្រធានបទដែលមិនពាក់ព័ន្ធនោះឡើយ[១៥០]។

៦១. ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់រាល់ឯកសារ ដែលមាននៅក្នុងបញ្ជីរបស់ខ្លួន អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង នៅក្នុងការសួរសំណួរទៅកាន់បុគ្គលនានាដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម ដើម្បីរំលឹកដល់ការចងចាំរបស់ពួកគេ ដើម្បីគាំទ្រ ឬដើម្បីទាញការសន្និដ្ឋានដែលពាក់ព័ន្ធចេញពីខ្លឹមសារនៃឯកសារមួយ ដោយយោងទៅលើការដឹងផ្ទាល់របស់ពួកគេ ឬដើម្បីពិសោធទៅលើភាពអាចឲ្យជឿជាក់បាន[១៥១]។ លើសពីនេះទៀត ភាគីទាំងអស់អាចស្នើសុំដាក់ភ័ស្តុតាងថ្មីសម្រាប់ប្រើប្រាស់នៅក្នុងអំឡុងពេលនៃការសួរសំណួរ ឲ្យតែពួកគេបានបំពេញតាមលក្ខខណ្ឌវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឬបានបង្ហាញថា ភ័ស្តុតាងដែលបានស្នើសុំនោះគឺស្នើឡើងដើម្បីប្រយោជន៍នៃយុត្តិធម៌ ឧទាហរណ៍ ដោយសារតែភ័ស្តុតាងនោះជាភ័ស្តុតាងដោះបន្ទុក ឬ ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសក្ខីកម្មរបស់សាក្សីណាម្នាក់[១៥២]។ ជាចុងក្រោយ ដើម្បី

---

[១៥០] ជាឧទាហរណ៍ លោក Stephen HEDER បានបដិសេធការតែងតាំងជាអ្នកជំនាញ ហើយហេតុដូច្នេះ ត្រូវបានកោះហៅក្នុងឋានៈជាសាក្សី តែក្នុងបញ្ហាទាក់ទងនឹងឯកសារមួយចំនួនដែលគាត់បាននិពន្ធ ដែលមាននៅក្នុងសំណុំរឿង (ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ៤)។ ហេតុដូច្នេះការសួរដេញដោលទៅលើប្រធានបទ ក្រៅពីឯកសារទាំងឡាយដែលគាត់បាននិពន្ធ ដែលមាននៅក្នុងសំណុំរឿង មិនត្រូវបានអនុញ្ញាតនោះឡើយ។

[១៥១] សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីដែលបានកែសម្រួលសម្រាប់ការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានា ក្នុងពេលស្តាប់សក្ខីកម្មរបស់សាក្សី (E201) (អ.ជ.ស.ដ) ឯកសារ E201/2 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ។

[១៥២] សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣៦។ ចម្លើយតបទៅនឹងសំណើនានាតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីៗទៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលោក François PONCHAUD និងលោក Sydney SCHANBERG (E243) ព្រមទាំងអ្នកជំនាញលោក Experts Philip SHORT (E226, E226/1 និង E230) និងលោកស្រី Elizabeth Becker (E232 និង E232/1) (អ.ជ.ស.ដ) ឯកសារ E260 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ ចម្លើយតបទៅនឹងលិខិតលោក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់ជនជាប់ចោទ អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) (E172/24/4/1) (អ.ជ.ស.ដ) ឯកសារ E172/24/4/4 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ៤។

ជាផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងឆាប់រហ័ស អង្គជំនុំជម្រះបានទទួលយក កំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលជាក់លាក់មួយចំនួន ដែលមិនត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ដោយកត់សំគាល់ថា ការផ្តន្ទាទោសមិនអាចផ្អែកទាំងស្រុង ឬដាច់ខាតតែទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយ ឬភស្តុតាងដោយផ្ទាល់មាត់បានឡើយ[១៥៣]។ ឧទាហរណ៍ កន្លងមក អង្គជំនុំជម្រះបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជំនួសឱ្យភស្តុតាងផ្ទាល់មាត់ ដោយហេតុថា កំណត់ហេតុទាំងនោះពាក់ព័ន្ធតែទៅនឹងការបញ្ជាក់ភស្តុតាងលើបញ្ហានានាលើសពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលក្នុងនោះមាន បរិបទប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង ទីតាំងឧក្រិដ្ឋកម្ម គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ផលប៉ះពាល់ពីឧក្រិដ្ឋកម្មមកលើជនរងគ្រោះ និង/ឬ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៥៤]។

៦២. ទោះបីជាជនជាប់ចោទ លើកឡើងពីការកម្រិតដែលមិនមានភាពស្មើគ្នាចំពោះលទ្ធភាពរបស់ពួកគេក្នុងការជំទាស់ទៅនឹងភស្តុតាង និងការសួរដេញដោលសាក្សីក៏ដោយ ក៏ជនជាប់ចោទមិនបានបង្ហាញពីផលប៉ះពាល់ ឬ មិនបានបង្ហាញថាពួកគេបានប្រើប្រាស់មធ្យោបាយដទៃទៀតដែលមាននោះទេ ឧទាហរណ៍ តាមរយៈការស្នើសុំការជំទាស់តវ៉ា ឬការស្នើសុំផ្តល់ភស្តុតាងជាឯកសារ។ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការជំទាស់ទៅលើភស្តុតាង និងក្នុងការសួរសំណួរដល់សាក្សីមិនត្រូវបានរំលោភបំពាននោះឡើយ។

---

[១៥៣] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៨ (ដែលលើកឡើងថា អង្គជំនុំជម្រះនឹងមិនឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋាននានាដែលបានទទួលយក ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់នៅពេលពិចារណាទៅលើអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់) កថាខណ្ឌ ២៩។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២១។

[១៥៤] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៨ ។

## ២.៤.៩ សិទ្ធិក្នុងការសួរតទល់

៦៣. ខៀវ សំផន លើកឡើងថា សវនាការស្តីពីការបង្ហាញឯកសារគន្លឹះនោះគឺត្រូវបានកម្រិតតែការបង្ហាញឯកសារ មិនមានការពិភាក្សាដេញដោលនោះទេ ពីព្រោះឱកាសដើម្បីជំទាស់ទៅលើភ័ស្តុតាងទាំងមូលដែលបានដាក់ក្នុងពេលសវនាការ គឺអាចធ្វើបានតែនៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តីតែប៉ុណ្ណោះ[១៥៥]។ លើសពីនេះទៀត ខៀវ សំផន និង នួន ជា លើកឡើងថា ពេលវេលា និងមធ្យោបាយដែលបានផ្តល់ឲ្យ សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលគឺមិនមានភាពគ្រប់គ្រាន់នោះទេ បើពិចារណាទៅលើឯកសារដែលបានទទួលយកនៅក្នុងសំណុំរឿង ០០២/០១ មានចំនួនរាប់ពាន់ទំព័រនោះ (ជាពិសេសឯកសារដែលបានទទួលយកដោយការយឺតយ៉ាវក្នុងពេលសវនាការ) ការចូលខ្លួនរបស់បុគ្គលចំនួន ៩២ នាក់ ភាពស្មុគស្មាញនៃរឿងក្តី និងការបកប្រែភាសាមិនបានត្រឹមត្រូវ[១៥៦]។

---

[១៥៥] សំណើជាបន្ទាន់សុំការបំភ្លឺទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសេចក្តីជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងសុំការពន្យារពេលវេលាដើម្បីដាក់សារណាចុងក្រោយ ឯកសារ E299/1 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៧-៤៣។ សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៦៧, ៧៨-៩១, ៩៧-៩៨។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៣២-៣៤, ៥០-៦០ (ដែលបានជំទាស់តវ៉ា *នៅក្នុងចំណោមបញ្ហាដទៃទៀត* ថាមិនមានភាពច្បាស់លាស់ទាក់ទងនឹងចំនួនសរុបនៃភ័ស្តុតាងដែលត្រូវទទួលយក ហើយហេតុដូច្នេះ ក្រុមមេធាវីការពារក្តីមិនធ្វើសេចក្តីសន្និដ្ឋាននានាទៅលើតម្លៃនៃភ័ស្តុតាងបានទេ លុះណាតែភាពមិនច្បាស់លាស់ទាំងនេះត្រូវបានដោះស្រាយរួចរាល់សិន។ សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E288/4 កថាខណ្ឌ ៣១-៣២។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៨-១៥។ សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយគោរពគោលការណ៍ចំពោះមុខនិងដោយយុត្តិធម៌ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤, ៣៥-៣៦, ៣៩-៤០, ៤៦, ៥៥។ ប្រតិវិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៦-៧, ៤៤-៤៥, ៤៩-៥០។ សំណើឆ្លើយតបទៅនឹងការលំបាកមួយចំនួន ដែលបានលើកឡើងនៅក្នុងអ៊ីមែលរបស់លោកស្រី LAMB ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១០, ១៣, ១៤, ២២។

[១៥៦] សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ឯកសារលេខ E288/4 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៣-៣៤។ សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយគោរពគោលការណ៍ចំពោះមុខ និងប្រកបដោយយុត្តិធម៌ ឯកសារលេខ E263 ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៤១, ៤៨, ៥១-៥៣។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧-៨, ២៨-៣១ (ខៀវ សំផន បានស្នើសុំដាក់សារណាដែលមាន

៦៤. តុលាការអាចផ្ដល់ឱកាសសម្រាប់ការសួរតទល់គ្នាតាមមធ្យោបាយផ្សេងៗ ប៉ុន្ដែ "ទោះបីជាជ្រើសរើសវិធីសាស្ត្រអ្វីក៏ដោយ តុលាការត្រូវធានាថា ភាគីផ្សេងទៀតនឹងដឹងអំពីការកត់សម្គាល់ផ្សេងៗដែលបានដាក់ក្នុងសំណុំរឿង ហើយខ្លួនមានឱកាសពិតប្រាកដក្នុងការឆ្លើយតបទៅនឹងការកត់សម្គាល់ទាំងអស់នោះ"[១៥៧]។ តាមមូលហេតុដែលនឹងបញ្ជាក់ខាងក្រោមនេះ អង្គជំនុំជម្រះសម្រេចថា ភាគីបានទទួលនូវឱកាសសម្រាប់ការសួរតទល់គ្នា។

### ២.៤.៩.១ បញ្ជីភ័ស្ដុតាងបឋម (វិធាន ៨០(៣) នៃវិធានផ្ទៃក្នុង)

៦៥. ក្រោយពីការស៊ើបសួរតាមផ្លូវតុលាការអស់រយៈពេលជាង ៣ ឆ្នាំ ដែលនៅក្នុងអំឡុងពេលនោះជនជាប់ចោទមានសិទ្ធិពិនិត្យមើលសំណុំរឿង រួមទាំងព័ត៌មានដាក់បន្ទុក និងព័ត៌មានដោះបន្ទុក អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីដាក់បញ្ជីភ័ស្ដុតាងដែលបានស្នើសុំត្រឹមថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ ដោយអនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង[១៥៨]។ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង០០២ និងក្រោយពីបានពង្រីកវិសាលភាពនៃការជំនុំជម្រះដោយដាក់បញ្ចូលការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃរួចមក អង្គជំនុំជម្រះបានណែនាំដល់ភាគីឲ្យដាក់បញ្ជីភ័ស្ដុតាង ដែលបានកែប្រែទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុដែលស្ថិត

---

កម្រាស់ ៣០០ ទំព័រ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៣៤ និង ៥៣។ ការសង្កេតពាក់ព័ន្ធនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលផ្នែកអង្គច្បាប់ត្រឹមថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ E163/5/5 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៣-៩, ១៣, ២៦ (នួន ជា បានស្នើសុំដាក់សារណាដែលមានកម្រាស់ ១៨០ ទំព័រ)។ សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៣-៧៤, ៧៧។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្ដីលោក ខៀវ សំផន) ទំព័រ ២៣-២៤។

[១៥៧] រឿងក្ដីរវាង *Öcalan តទល់នឹង ប្រទេសទួគី* តុលាការសិទ្ធិមនុស្សអឺរ៉ុប (សំណុំរឿងលេខ ៤៦២២១/៩៩) សាលក្រម ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ១៤៦ ដែលសម្អាងទៅលើរឿងក្ដីរវាង *Brandstetter តទល់នឹងអូទ្រីស* តុលាការសិទ្ធិមនុស្សអឺរ៉ុប (សំណុំរឿងលេខ ១១១៧០/៨៤, ១២៨៧៦/៨៧ និង ១៣៤៦៨/៨៧) សាលក្រម ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩១ កថាខណ្ឌ ៦៧។ *សូមមើលផងដែរ សាលដីកាលើសំណុំរឿង Kayishema និង Ruzindana* កថាខណ្ឌ ៨០។

[១៥៨] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១១ ។

នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[១៥៩]។ បន្ទាប់មក អង្គជំនុំជម្រះបានទទួលយកភ័ស្តុតាងដែលពាក់ព័ន្ធនឹងប្រធានបទផ្សេងៗ និងសាក្សីមួយចំនួនផ្សេងទៀតផងដែរ។ ក្នុងករណីសហព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានអនុវត្តការខិតខំប្រឹងប្រែងសមល្មមនៅក្នុងការបង្ហាញភ័ស្តុតាង ដែលធ្វើឱ្យរារាំងដល់ការពិភាក្សាដេញដោល អង្គជំនុំជម្រះច្រានចោលភ័ស្តុតាងទាំងនោះ[១៦០]។ ក្នុងករណីដែលមិនមានការបង្ហាញពីការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ជនជាប់ចោទត្រូវបានរំពឹងថានឹងពឹងផ្អែកទៅលើបញ្ជីភ័ស្តុតាងបឋម ដែលភាគីដទៃទៀតបានដាក់នៅក្នុងការត្រៀមរៀបចំ និងការបង្ហាញពីរឿងក្ដីរបស់ខ្លួន[១៦១]។

### ២.៤.៩.២ សវនាការស្ដីពីភាពអាចទទួលយកបាននៃភ័ស្តុតាង

៦៦. នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល អង្គជំនុំជម្រះបានផ្ដល់ឱកាសដល់ភាគីដើម្បីធ្វើការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃភ័ស្តុតាង តាមរយៈការដាក់សារណាដោយ

---

[១៥៩] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន *៨៩ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ។ សេចក្ដីជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (E163) និងពេលវេលាកំណត់នៃការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ។

[១៦០] *សូមមើលជាឧទាហរណ៍* សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៤០-៤២។ សំណើតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276, E276/1) (អ.ជ.ស.ដ) ឯកសារ E276/2 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារ D366/7.1.366 នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (អ.ជ.ស.ដ) ឯកសារ E298 ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣ ។

[១៦១] សាលដីកាលើសំណុំរឿង *Kanyarukiga* កថាខណ្ឌ ៥២-៥៣ (ការអះអាងជាទូទៅរបស់ជនជាប់ចោទថា ខ្លួនត្រូវតែលើកឡើងនូវព័ត៌មានដែលមិនសំខាន់ [ដោយសារតែសេចក្ដីសម្រេចអំពីភាពអាចទទួលយកបាននៃភ័ស្តុតាងដែលបានចេញនៅចុងបញ្ចប់នៃសវនាការ] មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញថា ខ្លួនបានទទួលរងព្យសនកម្ម ហើយភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីត្រូវបានធ្វើឱ្យប៉ះអន្តរាយ)។

ផ្ទាល់មាត់និងជាលាយលក្ខណ៍អក្សរ[១៦២]។ អង្គជំនុំជម្រះបានស្នើភាគីឲ្យដាក់ និងបានទទួលយកសារណាមួយចំនួនពីភាគី ដោយបានផ្ដល់ពេលវេលា និងមធ្យោបាយសមស្របដើម្បីឲ្យពួកគេដាក់ការជំទាស់របស់ខ្លួនឲ្យបានគ្រប់គ្រាន់[១៦៣]។ ទោះបីជាការជំទាស់ទាំងនោះធ្វើឡើងហួសពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន*ជាបឋម*នៃភស្តុតាងដែលបានស្នើសុំក៏ដោយ ក៏មិនធ្វើឲ្យប៉ះពាល់ដល់ភាពអាចទទួលយកបាននៃភស្តុតាងទាំងនោះទេ។ ភាគីមានឱកាសក្នុងការដាក់សារណាលំអិតលើបញ្ហានានាដែលពាក់ព័ន្ធនឹងតម្លៃ និងទម្ងន់នៃភស្តុតាង ដែលនឹងត្រូវពិចារណានៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះ អង្គជំនុំជម្រះធ្វើការពិចារណាលើសារណា និងការជំទាស់ទាំងនេះក្នុងអំឡុងពេលនៃការវាយតម្លៃលើភស្តុតាងចុងក្រោយរបស់ខ្លួន[១៦៤]។

---

[១៦២] បន្ថែមទៅលើឱកាសដើម្បីដាក់សេចក្ដីជំទាស់ជាលាយលក្ខអក្សរ ភាគីទាំងអស់ត្រូវបានផ្ដល់ឱកាសឲ្យធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃភស្តុតាង នៅក្នុងអំឡុងសវនាការសរុបចំនួន ១៤ ថ្ងៃ (ពីថ្ងៃទី ១៦-១៩ ខែ មករា ឆ្នាំ ២០១២, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ពីថ្ងៃទី ១២-១៥ ខែ មីនា ឆ្នាំ ២០១២, និងពីថ្ងៃទី ២១-២៤ ខែ មករា ឆ្នាំ ២០១៣)។

[១៦៣] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E159 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ។ ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦-៧។ សវនាការផ្ទាល់មាត់បន្ថែមលើឯកសារ (ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ (អ.ជ.ស.ដ) ឯកសារ E172/1 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។ បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្ដីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១២) (អ.ជ.ស.ដ) ឯកសារ E172/5 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១២ កថាខណ្ឌ ២។ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញានៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅក្នុងសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223) (អ.ជ.ស.ដ) ឯកសារ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។ កាលបរិច្ឆេទដែលបានកែសម្រួលជាថ្មីសម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ដែលនឹងចាប់ផ្ដើមពីថ្ងៃច័ន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E223/3 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣។ សេចក្ដីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើសុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៤-១២ (ដែលកំណត់ពីសារៈតារនីតិវិធីនៃសវនាការទៅលើភាពអាចទទួលយកបាននៅចំពោះមុខអង្គជំនុំ-ជម្រះ)។

[១៦៤] *សូមមើល* ផ្នែកទី ២ ស្ដីពីបញ្ហាអញ្ញត្រកម្ម ត្រង់ចំណុច ២.៣.៣ និង ២.៣.៤ (ភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង និងពេលវេលា និងមធ្យោបាយដែលមានសម្រាប់ត្រៀមរៀបចំការការពារក្ដី)។

## ២.៤.៩.៣ សវនាការស្តីពីការបង្ហាញឯកសារគន្លឹះ

៦៧. ក្រោយពីបានស្នើឱ្យភាគីដាក់សារណា និងឱ្យបញ្ជាក់ពីពេលវេលាចាំបាច់សម្រាប់បង្ហាញនូវឯកសារគន្លឹះទាំងនោះ និងក្រោយពីបានពិចារណាលើសារណាទាំងនោះ អង្គជំនុំជម្រះបានផ្តល់ឱកាសដល់ភាគីទៅតាមសមាមាត្រនៅក្នុងសវនាការចំនួនបួនផ្សេងៗគ្នា ដែលសរុបមានចំនួន ១៦ ថ្ងៃ ដើម្បីលើកឡើងអំពីឯកសារទាំងឡាយដែលពួកគេយល់ថាមានការពាក់ព័ន្ធខ្លាំងបំផុតទៅនឹងវគ្គនៃសវនាការជាក់លាក់ណាមួយ[១៦៥]។ ដោយសារតែភស្តុតាងជាឯកសារនៅ អ.វ.ត.ក មិនចាំបាច់ត្រូវយកមកបង្ហាញនៅក្នុងអំឡុងពេលនៃការសួរដេញដោលទៅលើបុគ្គល ដែលចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ សវនាការទាំងនេះធ្វើឡើងក្នុងគោលបំណងដើម្បីជួយដល់អង្គជំនុំជម្រះ និងភាគីក្នុងការកំណត់អំពីអត្តសញ្ញាណឯកសារ ដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសវនាការវគ្គដែលបានកំណត់ និងដើម្បីផ្តល់លទ្ធភាពដល់សាធារណជនក្នុងការចូលរួមតាមដានសវនាការស្តីពីឯកសារនេះ[១៦៦] ។

---

[១៦៥] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់ (ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ។ សេចក្តីណែនាំទៅភាគីក្រោយពីសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ (អ.ជ.ស.ដ) ឯកសារ E233 ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ ។ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅក្នុងសវនាការ (ឯកសារ E208/4) និងសំណើសុំរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223) (អ.ជ.ស.ដ) ឯកសារ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ។ កាលបរិច្ឆេទដែលបានកែសម្រួលជាថ្មីសម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ដែលនឹងចាប់ផ្តើមពីថ្ងៃ ច័ន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E223/3 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣ ។ ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣។ កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និង E288/1 (អ.ជ.ស.ដ) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ។

[១៦៦] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់ (ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៥-៦។

៦៨. នៅក្នុងពីរសវនាការដំបូងទាក់ទងនឹងការបង្ហាញឯកសារគន្លឹះនេះ មេធាវីការពារក្តីទាំងអស់បានច្រានចោលជាមុន មិនព្រមឆ្លើយតបទៅនឹងឯកសារទាំងឡាយ ដែលភាគីដទៃទៀតបានបង្ហាញ[១៦៧]។ ទោះជាយ៉ាងណាក្តី ជនជាប់ចោទត្រូវបានផ្តល់ឱកាសឲ្យផ្តល់យោបល់ទៅលើឯកសារគន្លឹះដែលបានបង្ហាញនោះ[១៦៨]។ នៅក្នុងសវនាការបង្ហាញឯកសារគន្លឹះចំនួនពីរបន្ទាប់មកទៀត អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ និង មេធាវីការពារក្តីផ្តល់យោបល់ទៅលើឯកសារដែលបានដាក់បង្ហាញទាំងនោះ[១៦៩]។ លើសពីនេះទៀត នៅក្នុងសវនាការបង្ហាញឯកសារគន្លឹះជាចុងក្រោយ ជនជាប់ចោទ និងមេធាវីការពារក្តីរបស់ពួកគេ ក៏ត្រូវបានផ្តល់ឱកាសឲ្យផ្តល់យោបល់ទៅលើឯកសារទាំងអស់នោះ ដែលបានដាក់បង្ហាញនៅក្នុងសវនាការបង្ហាញឯកសារគន្លឹះ និងត្រូវបានស្នើសុំឲ្យបញ្ជាក់ទៅលើពេលវេលាសម្រាប់ការបង្ហាញនេះ[១៧០]។ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ បានបដិសេធមិនព្រមប្រើប្រាស់ឱកាសនេះទេ[១៧១]។

---

[១៦៧] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់ (ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ។ សេចក្តីណែនាំទៅភាគីក្រោយពីសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ (អ.ជ.ស.ដ) ឯកសារ E233 ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៣-៤។

[១៦៨] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់ (ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ) ឯកសារ E170 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ។ សេចក្តីណែនាំទៅភាគីក្រោយពីសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E233 ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ២-៣។

[១៦៩] សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅក្នុងសវនាការ (ឯកសារ E208/4) និងសំណើសុំរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223) (អ.ជ.ស.ដ) ឯកសារ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។ កាលបរិច្ឆេទដែលបានកែសម្រួលជាថ្មីសម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ដែលនឹងចាប់ផ្តើមពីថ្ងៃច័ន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E223/3 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣។ ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣។ កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និង E288/1 (អ.ជ.ស.ដ) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

[១៧០] ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់ មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ

## ២.៤.៩.៤ សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល

៦៩. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានស្នើសុំឱ្យមានការកំណត់កាលបរិច្ឆេទដ៏ឆាប់រហ័សមួយ សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ និងបានណែនាំដល់ភាគីឱ្យប្រើប្រាស់ធនធានចាំបាច់នានា ដើម្បីឱ្យពួកគេអាចរៀបចំសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ស្របជាមួយនឹងកិច្ចដំណើរការនីតិវិធីដែលកំពុងតែបន្តធ្វើនោះ[១៧២]។ ភាគីត្រូវបានផ្តល់ឱកាសដើម្បីលើកឡើងនូវសំណើនានា ដែលពាក់ព័ន្ធទៅនឹងនីតិវិធីសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល នៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២។

៧០. នៅក្នុងខែ តុលា និងខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីនីតិវិធី និងកាលបរិច្ឆេទសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល[១៧៣]។ សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវបានកម្រិតត្រឹមចំនួន ២០០ ទំព័រ សម្រាប់សហព្រះរាជអាជ្ញា ចំនួន ៨០ ទំព័រ សម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចំនួន ១០០ ទំព័រ សម្រាប់ជនជាប់ចោទនីមួយៗ និងត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃចុងក្រោយនៃសវនាការ

---

មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ) ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៥-៦។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៤៩-៥០, ៦២-៦៤។ កាលបរិច្ឆេទសម្រាប់ សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និង E288/1 (អ.ជ.ស.ដ) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ។

[១៧១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៨-១៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥២-៥៣, ៥៤-៥៦, ៥៧-៦០។

[១៧២] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ២០។

[១៧៣] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ដ) ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ។ សេចក្តីជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (អ.ជ.ស.ដ) ឯកសារ E163/5/4 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

លើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១[១៧៤]។ ភាគីក៏ទទួលបានឱកាសដើម្បីដាក់សេចក្តីសន្និដ្ឋានដាច់ដោយឡែកមួយទៀត ដែលមានចំនួន ២០ ទំព័រ ស្តីពីច្បាប់ជាធរមានត្រឹមថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២[១៧៥]។ ក្នុងករណីដែលភាគីមិនបានប្រើប្រាស់ឱកាសនេះទេនោះ ភាគីអាចដាក់សេចក្តីសន្និដ្ឋានណាមួយក្នុងចំនួនទំព័រ ដែលបានកំណត់សម្រាប់ការដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ឬ ទៅតាមពេលវេលាដែលបានកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល[១៧៦]។ បន្ទាប់មក អង្គជំនុំជម្រះបានពន្យារថ្ងៃផុតកំណត់សម្រាប់ការដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលចំនួនពីរដង ដែលនាំឲ្យកាលបរិច្ឆេទចុងក្រោយនេះគឺនៅត្រឹមថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣។ អង្គជំនុំជម្រះក៏បានបន្ថែមចំនួនទំព័រឲ្យភាគីនីមួយៗត្រឹមចំនួន ២៥ ទំព័រ ហើយក៏បានបញ្ជាក់ផងដែរថា លេខយោងជើងទំព័រមិនរាប់បញ្ចូលក្នុងចំនួនទំព័រដែលបានកម្រិតនោះទេ[១៧៧]។

៧១. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទសម្រាប់ដាក់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយផ្តល់ពេលវេលាចំនួន ៣ ថ្ងៃ

---

[១៧៤] សេចក្តីជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល(អ.ជ.ស.ង) ឯកសារ E163/5/4 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

[១៧៥] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ង) ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៤។

[១៧៦] សេចក្តីជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល(អ.ជ.ស.ង) ឯកសារ E163/5/4 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២០-២១។

[១៧៧] កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (ឯកសារE295/1 E295/1/2, E295/1/3, E295/2 និង E295/3) (អ.ជ.ស.ង) ឯកសារ E295/4 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២ (ដែលពន្យារកាលបរិច្ឆេទចុងក្រោយរហូតដល់ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣)។ ចម្លើយតបទៅនឹងសំណើតាមអ៊ីមែលសុំបន្ថែមពេលវេលា (អ.ជ.ស.ង) ឯកសារ E295/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារចុងក្រោយ និងសវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និង E288/1 (អ.ជ.ស.ង) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៦-៥៧ (ដោយកម្រិតត្រឹម ២២៥ ទំព័រ សម្រាប់សហព្រះរាជអាជ្ញា, ១២៥ ទំព័រ សម្រាប់ជនជាប់ចោទម្នាក់ៗ និង ១០៥ ទំព័រ សម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី)។

សម្រាប់សហព្រះរាជអាជ្ញា ១ ថ្ងៃសម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង ២ ថ្ងៃសម្រាប់ជនជាប់ចោទម្នាក់ៗ[១៧៨]។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហ-ព្រះរាជអាជ្ញាបានទទួលពេលវេលា ១ ថ្ងៃដូចគ្នាសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានតប ហើយជនជាប់ចោទម្នាក់ៗមានរយៈពេលពីរម៉ោងសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ[១៧៩]។ ដំបូងឡើយ សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវបានកំណត់ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលជាភាសាផ្លូវការមួយរបស់ អ.វ.ត.ក ហើយក្រោយមក ត្រូវបានកែតម្រូវពេលវេលាពីថ្ងៃទី ១៦ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ វិញ[១៨០]។ ដើម្បីជួយដល់ភាគីក្នុងការត្រៀមរៀបចំធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះ និងអង្គភាពគាំពារការការពារក្ដី បានផ្ដល់លទ្ធភាពដល់ជនជាប់ចោទក្នុងការទទួលបានអ្នកបកប្រែភាសា[១៨១]។

---

[១៧៨] កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និង សវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និង E288/1 (អ.ជ.ស.ដ) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ។ *សូមមើលផងដែរ* វិធាន ៩៤ នៃវិធានផ្ទៃក្នុង។ កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារ E295/1 E295/1/2, E295/1/3, E295/2 និង E295/3) (អ.ជ.ស.ដ) ឯកសារ E295/4 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៦។

[១៧៩] កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារE295/1 E295/1/2, E295/1/3, E295/2 និង E295/3) (អ.ជ.ស.ដ) ឯកសារ E295/4 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៤ និងកថាខណ្ឌ ៦។ *សូមមើលផងដែរ* វិធាន ៩៤ នៃវិធានផ្ទៃក្នុង។

[១៨០] កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារE295/1 E295/1/2, E295/1/3, E295/2 និង E295/3) (អ.ជ.ស.ដ) ឯកសារ E295/4 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៥-៦។

[១៨១] កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារE295/1, E295/1/2, E295/1/3, E295/2 និង E295/3) (អ.ជ.ស.ដ) ឯកសារ E295/4 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ ចម្លើយតបទៅនឹងសំណើតាមអ៊ីមែលសុំបន្ថែមពេលវេលា (អ.ជ.ស.ដ) ឯកសារ E295/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យប្រកាសមិនទទួលយកសារណាបញ្ចប់របស់សហព្រះរាជអាជ្ញា (ឯកសារ E295/7) ឯកសារ E295/7/2 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៦ (ដែលលើកឡើងថា តាមពិតទៅ មេធាវីការពារក្ដីរបស់ ខៀវ សំផន បានប្រើប្រាស់មធ្យោបាយនេះរួចហើយ)។

៧២. នៅចន្លោះពីថ្ងៃទីមួយនៃការធ្វើសេចក្តីថ្លែងបើកសវនាការនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ រហូតដល់ថ្ងៃទីមួយនៃការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះមិនបានបើកសវនាការចំនួន ៤៨០ ថ្ងៃ (រួមទាំងថ្ងៃចុងសប្តាហ៍ ថ្ងៃឈប់សម្រាកបុណ្យជាតិ ថ្ងៃវិស្សមកាល និងថ្ងៃផ្អាកសវនាការមួយចំនួន ដូចជា បញ្ហាសុខភាពរបស់ជនជាប់ចោទ)។ ជនជាប់ចោទបានទទួលការជូនដំណឹងចាប់តាំងពីថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ មកម្ល៉េះ ដែលថា ពួកគាត់ត្រូវប្រើប្រាស់នូវមធ្យោបាយ និងធនធានដែលមាននៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះមិនធ្វើសវនាការ និងនៅថ្ងៃធ្វើសវនាការ ក្នុងការរៀបចំសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ជាចុងក្រោយ អង្គជំនុំជម្រះបានពន្យារកាលបរិច្ឆេទចុងក្រោយ និងបានកែសម្រួលការកំណត់ចំនួនទំព័រ និងមធ្យោបាយផ្សេងៗទៀតដោយសារកាលៈទេសៈ និងប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យធ្វើបែបនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរតទល់គ្នា ឬក្នុងការការពារខ្លួនមិនត្រូវបានរំលោភដោយនីតិវិធីដែលត្រូវបានកំណត់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនោះទេ[១៨២]។

### ២.៤.៩.៥ សេចក្តីសន្និដ្ឋាន

៧៣. ជនជាប់ចោទខកខានមិនបានបង្ហាញថា តើសេចក្តីសម្រេចផ្នែកនីតិវិធីមុនៗ ជាប្រភេទសេចក្តីសម្រេចតែមួយ ឬរួមបញ្ចូលគ្នានោះ បានរារាំងមិនឲ្យមានឱកាសសម្រាប់ការសួរតទល់គ្នាយ៉ាងដូម្តេចនោះទេ។ វាមិនមែនជាការទទួលខុសត្រូវរបស់អង្គជំនុំជម្រះនោះទេ ចំពោះការខកខានរបស់ជនជាប់ចោទ ឬ មេធាវីការពារក្តីរបស់ជនជាប់ចោទក្នុងការប្រើប្រាស់ឱកាសដែលបានផ្តល់ឲ្យនោះ ជាពិសេសនៅពេលដែលអង្គជំនុំជម្រះបានព្យាយាមច្រើនលើកច្រើនសាក្នុងការដោះស្រាយបញ្ហារបស់ពួកគាត់ តាមរយៈការផ្តល់ពេលវេលាបន្ថែម ឬផ្តល់ឱកាសដើម្បីឲ្យអនុវត្តមុខងាររបស់ខ្លួននោះ ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរតទល់គ្នានេះមិនត្រូវបានរំលោភបំពានឡើយ។

---

[១៨២] អង្គជំនុំជម្រះតុលាការកំពូល ICTY បានពិចារណាឃើញថា កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងរយៈពេល ១១ ថ្ងៃ បន្ទាប់ពីបញ្ចប់សវនាការលើភ័ស្តុតាងនោះ មិនបានរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទនោះទេ ព្រោះថាក្នុងអំឡុងពេលនៃកិច្ចដំណើរការជំនុំជម្រះ មានថ្ងៃជាច្រើនដែលអង្គជំនុំជម្រះមិនធ្វើសវនាការ ហើយភាគីក៏បានទទួលការជូនដំណឹងគ្រប់គ្រាន់ (រយៈពេលមួយឆ្នាំ) រួចមកហើយ ដោយរំពឹងថា ពួកគេបានប្រើប្រាស់ធនធានទាំងឡាយតាមមធ្យោបាយមួយដែលអនុញ្ញាតឲ្យពួកគេរៀបចំសារណានៅក្នុងអំឡុងពេលនៃការជំនុំជម្រះ (*Krajišnik*) សាលដីកា កថាខណ្ឌ ៩៤)។

## ២.៤.១០ សិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើសេចក្តីសន្និដ្ឋាន និងឆ្លើយតបចំពោះការចោទសួរ

៧៤. ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះបានរារាំងដល់សិទ្ធិរបស់គាត់ក្នុងការការពារខ្លួន និងក្នុងការផ្តល់យោបល់ទៅលើភ័ស្តុតាងប្រឆាំងនឹងខ្លួន នៅពេលដែលអង្គជំនុំជម្រះបានបដិសេធលើសំណើរបស់គាត់ ដែលសុំឱ្យផ្តល់នូវបញ្ជីសំណួរ និងឯកសារនានាដែលនឹងត្រូវយកមកប្រើប្រាស់នៅក្នុងការចោទសួរ កម្រិតការចោទសួរមកត្រឹមតែកន្លះថ្ងៃ និងសុំរយៈពេលបីសប្តាហ៍ដើម្បីពិគ្រោះយោបល់ជាមួយមេធាវីការពារក្តីរបស់គាត់មុនការចោទសួរ។ ខៀវ សំផន ក៏បានចោទប្រកាន់ថា មានការរំលោភលើសិទ្ធិរបស់គាត់ផងដែរ ព្រោះអង្គជំនុំជម្រះខកខានមិនបានធានាថា មេធាវីការពារក្តីរបស់គាត់ អាចចូលជួបគាត់ក្នុងមន្ទីរឃុំឃាំងនៅថ្ងៃចុងសប្តាហ៍បាន[១៨៣]។ ដូច្នេះដោយយល់ឃើញថា អង្គជំនុំជម្រះបានបដិសេធមិនផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិទទួលបាន "ពេលវេលាដើម្បីតាំងសំណួរប្រកបដោយភាពថ្លៃថ្នូរ យុត្តិធម៌ និងសន្តិវិធី" នោះជនជាប់ចោទ "បានអនុវត្តតែសិទ្ធិរបស់គាត់ដែលនៅសេសសល់ គឺការនៅស្ងៀមមិនឆ្លើយតប រហូតដល់ការបិទបញ្ចប់ "កិច្ចពិភាក្សាដេញដោល" និងសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយបន្ទាប់ពីសេចក្តីសន្និដ្ឋានស្តាពរ"[១៨៤]។ លើសពីនេះទៅទៀត ទាំង នួន ជា និង ខៀវ សំផន បានបញ្ជាក់ថា ខ្លួនបានបដិសេធមិនឆ្លើយទៅនឹងការតាំងសំណួរនៅចុងបញ្ចប់នៃសវនាការសួរដេញដោលទៅលើភ័ស្តុតាង ដោយផ្អែកទៅលើមូលដ្ឋានថា សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ត្រូវបានរំលោភនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល[១៨៥]។

---

[១៨៣] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣២។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២៧-២៨។ សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ឯកសារ E288/4 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១-២២, ២៦-២៧, ៣៨។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ១០-១៩។ សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ឯកសារ E275/2/1/1 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៧១-៧២, ៧៥, ៩៩។

[១៨៤] សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ ឯកសារ E288/4 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៥, ២៣-២៤, ៤០។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣០, ៣០-៣២។

[១៨៥] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣២។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៣-៥៤។ ការដកសេចក្តីជូនដំណឹងពីគោលបំណងអនុវត្តតាមវិធាន ៩០ នៃវិធានផ្ទៃក្នុង ឯកសារ E287/2 ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣-៤, ១៨។

៧៥. អនុលោមតាមវិធាន ៨៥ និងវិធាន ៩០ នៃវិធានផ្ទៃក្នុង ប្រធានសវនាការ ដោយមានការពិគ្រោះយោបល់ជាមួយនឹងចៅក្រមផ្សេងៗនៃអង្គជំនុំជម្រះសាលាដំបូង អាចសម្រេចទៅលើនីតិវិធីដែលសមស្របសម្រាប់ការធ្វើសេចក្ដីសន្និដ្ឋាន ឬការចោទសួរទៅជនជាប់ចោទបាន ដរាបណាសិទ្ធិរបស់ជនជាប់ចោទត្រូវបានគោរព[១៨៦]។

៧៦. អង្គជំនុំជម្រះបានសម្រេចយល់ព្រមតាមសំណើរបស់ ខៀវ សំផន ដែលសុំឲ្យមានការជូនដំណឹងជាមុន អំពីឯកសារដែលភាគីមានបំណងយកមកប្រើប្រាស់ក្នុងការចោទសួរ និងការផ្ដល់សក្ខីកម្មសម្រាប់រយៈពេលតែកន្លះថ្ងៃ។ ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់រួចហើយថា អង្គជំនុំជម្រះមិនមានលទ្ធភាពក្នុងការគណនា ថាតើជនជាប់ចោទអាចមានលទ្ធភាព ឬមានបំណងឆ្លើយតបទៅនឹងសំណួរត្រឹមកម្រិតណានោះទេ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធលើការកំណត់ពេលវេលាបន្ថែមសម្រាប់ការចោទសួរ។ ដោយពិចារណាទៅលើរយៈពេលនៃការស៊ើបសួរ និងរយៈពេលនៃការជំនុំជម្រះ និងការណ៍ដែលថា ជនជាប់ចោទបានទទួលការជូនដំណឹងអំពីបទចោទប្រឆាំងនឹងខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល អង្គជំនុំជម្រះក៏បានបដិសេធលើសំណើរបស់ ខៀវ សំផន ដែលបានសុំផ្អាកសវនាការចំនួនបីសប្ដាហ៍ដើម្បីត្រៀមរៀបចំឆ្លើយតបទៅនឹងការចោទសួរ និងសំណើសុំឲ្យមានការជូនដំណឹងជាមុនអំពីប្រធានបទ និងសំណួរដែលភាគីមានបំណងយកមកសួរគាត់[១៨៧]។

៧៧. ទាក់ទងទៅនឹងសំណើសុំឲ្យផ្ដល់បញ្ជីប្រធានបទ ឬបញ្ជីសំណួរ ដែលគ្របដណ្ដប់នៅក្នុងការចោទសួរនេះ អង្គជំនុំជម្រះសូមបញ្ជាក់នូវការយល់ឃើញរបស់ខ្លួនពីមុនៗមកដែលថា ជនជាប់ចោទបានដឹងពីរឿងក្ដីប្រឆាំងនឹងខ្លួន និងបរិបទនៃការចោទសួរនេះរួចហើយ ជាពិសេស នៅចុងបញ្ចប់នៃសវនាការ[១៨៨]។ ទោះជាយ៉ាងណាក្ដី សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើម-

[១៨៦] *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្ដី *Seromba* កថាខណ្ឌ ១៩-២០។ សាលដីកាក្នុងរឿងក្ដី *Blagojević* និង *Jokić* កថាខណ្ឌ ២៧-២៩។

[១៨៧] កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារ និងសវនាការផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ ឯកសារ E263 និងឯកសារ E288/1 (អ.ជ.ស.ជ) ឯកសារ E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៨-៩។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ១៩-២០។

[១៨៨] សាលដីកាក្នុងរឿងក្ដី *Krajišnik* កថាខណ្ឌ ៣៧០ (ដោយពិចារណាទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះសារណាមុនការជំនុំជម្រះ បញ្ជីឈ្មោះសាក្សី និងភស្តុតាង និងវត្តមានរបស់គាត់នៅក្នុងសវនាការ អង្គជំនុំជម្រះយល់

បណ្តឹងរដ្ឋប្បវេណីមានបំណងផ្តល់នូវបញ្ជីសំណួរទៅឲ្យ ខៀវ សំផន[១៨៩]។ លើសពីនេះទៀត ការបដិសេធរបស់អង្គជំនុំជម្រះ ចំពោះការកំណត់ពេលវេលាទៅលើការចោទសួរទៅជនជាប់ចោទគឺមានភាពសមស្រប ហើយអង្គជំនុំជម្រះមានបំណងជួយសម្រួលទៅលើលទ្ធភាព និងចេតនារបស់គាត់ក្នុងការបន្តការឆ្លើយតបទៅនឹងសំណួរនៅពេលណាមួយ។ នៅចុងបញ្ចប់ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងជនជាប់ចោទ និងមេធាវីការពារក្តីរបស់គាត់បានអះអាងថា ទោះបីជាសំណើទាំងអស់ពាក់ព័ន្ធនឹងរបៀប និងនីតិវិធីសម្រាប់ការសួរសំណួរដល់ជនជាប់ចោទ ត្រូវបានទទួលយកក្តី ក៏ជនជាប់ចោទនៅតែមិនបានឆ្លើយតបទៅនឹងការចោទសួរនោះដែរ ដោយហេតុថាសិទ្ធិរបស់ខ្លួនត្រូវបានរំលោភនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល[១៩០]។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសូមបញ្ជាក់អះអាងពីការយល់ឃើញរបស់ខ្លួនដែលបានបង្ហាញជូនខាងលើ និងការយល់ឃើញនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូលដែលថា សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទទាំងពីរ គឺត្រូវបានគោរពនៅក្នុងដំណើរការនៃការជំនុំជម្រះទាំងមូល។

៧៨. នួន ជា និង ខៀវ សំផន បានអនុវត្តសិទ្ធិមិនផ្តល់សក្ខីកម្មរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យពួកគាត់ធ្វើដូច្នោះ[១៩១]។ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការទាំងមូល ជនជាប់ចោទមានឱកាសជាច្រើនដើម្បីធ្វើសេចក្តីថ្លែងការណ៍ និងឆ្លើយតបទៅនឹងសំណួរ។ ពួកគាត់បានប្រើប្រាស់ឱកាសទាំងនេះ នៅក្នុងករណីជាច្រើន[១៩២]។ អនុលោមតាមវិធាន៩៤(៣) ជនជាប់ចោទបានប្រើឱកាសចុងក្រោយដើម្បីធ្វើសេចក្តីសន្និដ្ឋាននៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ ផងដែរ។

---

ឃើញថា ជនជាប់ចោទ "បានដឹងយ៉ាងច្បាស់អំពីខ្លឹមសារនៃសំណួររបស់រដ្ឋអាជ្ញា និងករណីរបស់រដ្ឋអាជ្ញាតទល់នឹងរូបគាត់" នៅពេលដែលគាត់បានផ្តល់សក្ខីកម្មនៅក្នុងការការពារខ្លួនរបស់គាត់ផ្ទាល់)។

[១៨៩] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៣-២៨។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការដកខ្លួនរបស់ ខៀវ សំផន មិនផ្តល់សក្ខីកម្ម និងសំណើសុំធ្វើសេចក្តីសន្និដ្ឋានអវិជ្ជមាន ឯកសារ E288/4/1 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១០។

[១៩០] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ២៩-៣៤។

[១៩១] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Blagojević និង Jokić* កថាខណ្ឌ ២៨ (ដែលបង្ហាញថាជម្រើសរបស់ជនជាប់ចោទខ្លួនឯងគឺធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការបង្ហាញភ័ស្តុតាងរបស់គាត់ ដូច្នេះ គាត់មិនលើកឡើងថាមានការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌បានឡើយ)។

[១៩២] *សូមមើល* ផ្នែកទី ២ ស្តីពី បញ្ហាអញ្ញត្រកម្ម ត្រង់ចំណុច ២.៣.៤.២ (ប្រភពនៃភ័ស្តុតាង)។

ពួកគាត់បានប្រើនូវឱកាសដែលបានផ្ដល់ឲ្យនេះ[១៩៣]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើសេចក្ដីថ្លែងការណ៍ ឬ ឆ្លើយតបទៅនឹងការចោទសួរ ដូចមានចែងក្នុងវិធាន ៨១(៦) វិធាន ៨៩*ស្ទួន* វិធាន ៩១*ស្ទួន* និងវិធាន ៩៤ នៃវិធានផ្ទៃក្នុងនោះទេ[១៩៤]។

## ៣. បរិបទប្រវត្តិសាស្ត្រ[១៩៥]

៧៩. ហេតុការណ៍នានានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែស្វែងយល់ ដោយពិនិត្យទៅលើបរិបទនៃហេតុការណ៍ទាំងឡាយដែលបានកើតឡើងមុនសម័យកាលនេះ ជាពិសេស ការបង្កើតបក្សកុម្មុយនីស្តកម្ពុជា។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានរីកលូតលាស់ បក្សនេះបានបង្កើតនិងអនុវត្តគោលនយោបាយមួយចំនួនដើម្បីសម្រេចគោលបំណងរបស់ខ្លួន ។ អត្ថិភាពនៃគោល-នយោបាយនីមួយៗនឹងត្រូវយកមកពិនិត្យនៅក្នុងផ្នែកនេះ ដើម្បីផ្ដល់ជាទិដ្ឋភាពរួមអំពីស្ថានភាពនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ផ្នែកនេះពិនិត្យពិចារណាទៅលើការវិវត្តនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចំណែកឯការអនុវត្តគោលនយោបាយទាំងមូលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងជំពូកក្រោយៗទៀត ដែលរួមមានទិដ្ឋភាពទូទៅនៃហេតុការណ៍នានានៅក្នុងអំឡុងយុត្តាធិការតាមពេលវេលានៃបទចោទ ឬបទល្មើសជាក់លាក់នានា ដែលត្រូវបានចោទប្រកាន់នៅក្នុងរឿងក្ដីនេះ[១៩៦]។ គោលនយោបាយចំនួនពីរគឺការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីខេត្ត-

---

[១៩៣] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៥១-៥៥។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ១-២៦។

[១៩៤] អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដោយសារវិធានទាំងនេះផ្ដល់សិទ្ធិឲ្យភាគីដទៃទៀតសួរសំណួរទៅកាន់ជនជាប់ចោទ នោះវិធានទាំងនេះក៏ប្រគល់សិទ្ធិដូចគ្នានេះដល់ជនជាប់ចោទដើម្បីធ្វើការឆ្លើយតបដែរ ប្រសិនណាបើជនជាប់ចោទមានបំណងឆ្លើយតប ដោយសិទ្ធិក្នុងការឆ្លើយតបនេះមានមូលដ្ឋានមកពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប សិទ្ធិធ្វើការពិភាក្សាដេញដោល និងសិទ្ធិការពារក្ដីរបស់ជនជាប់ចោទ។

[១៩៥] ភ័ស្តុតាងដែលត្រូវបានពិភាក្សានៅក្នុងផ្នែកនេះត្រូវបានផ្ដល់ក្នុងគោលបំណងបង្ហាញអំពីបរិបទប្រវត្តិសាស្ត្រ និងអង្គហេតុនៃហេតុការណ៍ទាំងឡាយដែលស្ថិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក។ ភ័ស្តុតាងបែបនេះអាចរួមមាន៖ ការបញ្ជាក់បំភ្លឺទៅលើបរិបទជាក់លាក់ណាមួយ ដោយបង្ហាញតាមរយៈការទាញសេចក្ដីសន្និដ្ឋានពីធាតុផ្សំនៃអំពើឧក្រិដ្ឋនៅក្រោយមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ឬដោយបង្ហាញអំពីបែបផែននៃអំពើដោយចេតនាណាមួយ។ *សូមមើល* សាលដីកា *Nahimana* កថាខណ្ឌ ៣១៥។

[១៩៦] សូមមើលផ្នែកទី ៤ ស្ដីពី ទិដ្ឋភាពទូទៅ ។ ផ្នែកទី ១០ ស្ដីពី ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) ។ ផ្នែកទី ១១ ស្ដីពី ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ។ ផ្នែកទី ១២ ស្ដីពី ទួលពោធិ៍ជ្រៃ ។

ក្រុង និងការកំណត់គោលដៅដែលជាទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាកម្មវត្ថុនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ដូច្នេះ គោលនយោបាយទាំងពីរនេះនឹងត្រូវយកយកមកពិនិត្យឱ្យកាន់តែលម្អិតថែមទៀត។ បន្ថែមទៅលើអត្ថិភាព និងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រសិនបើមានការពាក់ព័ន្ធ អង្គជំនុំជម្រះនឹងពិនិត្យទៅលើស្ថានភាពទូទៅនៅក្នុងទីក្រុងភ្នំពេញ ដែលនាំឱ្យមានការវាយសម្រុកចុងក្រោយទៅលើទីក្រុងនេះ ដែលចាប់ផ្តើមនៅក្នុងខែ មករា ឆ្នាំ ១៩៧៥ រហូតឈានដល់ការកាន់កាប់ និងការជម្លៀសប្រជាជននៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

## ៣.១ ទិដ្ឋភាពទូទៅ និងការបង្កើតបក្សកុម្មុយនីស្តកម្ពុជា

៨០. នៅក្នុងការកំណត់អំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាខាងក្រោមនេះ អង្គជំនុំជម្រះបានពឹងផ្អែកទៅលើសក្ខីកម្មរបស់ជនជាប់ចោទ នួន ជា និងឯកសារសំខាន់ៗជាច្រើនទៀត រួមទាំង ទស្សនាវដ្តីទង់បដិវត្ត និងប្រតិចារឹកនៃកិច្ចសម្ភាសន៍ឆ្នាំ ១៩៨៨[១៩៧] ដែលជនជាប់ចោទ នួន ជា បានសម្ភាសជាមួយ ខែម ងួន ដែលជាអតីតជំនួយការរបស់ តា ម៉ុក[១៩៨]។ នៅពេលដែលជនជាប់ចោទ នួន ជា ត្រូវបានសួរសំណួរអំពីកិច្ចសម្ភាសន៍នេះ ជនជាប់ចោទ នួន ជា បានព្យាយាមបង្ខូចកិត្តិយសរបស់ ខែម ងួន ដោយលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថា ខែម ងួន គឺជាគិញរបស់ ហ៊ុន សែន ដែលជាសហនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជា នៅពេលធ្វើកិច្ចសម្ភាសន៍នោះ។ នៅដើមដំបូងនៃកិច្ចសម្ភាសន៍ នួន ជា បានបញ្ជាក់ថា គាត់ពុំអាចចងចាំបានពេញលេញទាំងអស់នោះទេ ហើយគាត់ពិបាកចាំហេតុការណ៍ជាក់លាក់នានា ដែលបានកើតឡើងជាច្រើនឆ្នាំកន្លងមកហើយនោះណាស់។ អង្គជំនុំជម្រះយល់ឃើញថា ចម្លើយរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍នេះ ស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយផ្សេងៗទៀតដែលគាត់បានឆ្លើយ រួមទាំងចម្លើយដែលគាត់បានឆ្លើយនៅក្នុងតុលាការផងដែរ។ អង្គជំនុំជម្រះមិនឃើញមានការលើកឡើងណាមួយថា គាត់ឆ្លើយមិនពិតនៅក្នុងកិច្ចសម្ភាសន៍នេះនោះទេ ឬក៏ថា ប្រតិចារឹកនៃកិច្ចសម្ភាសន៍នោះមិនត្រឹមត្រូវនោះដែរ។ នៅក្នុងតុលាការ ជនជាប់ចោទ

---

[១៩៧] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២៧-៣០។ ខ្សែអាត់វីដេអូស្តីពីសក្ខីកម្មរបស់ នួន ជា ឯកសារ E1/23R ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (វគ្គទី ២) ត្រង់ម៉ោង 50:00-50:15 (មេធាវីលើកឡើងសាជាថ្មីថា ឆ្នាំ ១៩៨៨ គឺជាកាលបរិច្ឆេទនៃកិច្ចសម្ភាសន៍)។

[១៩៨] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងួន ឯកសារ E3/3 លេខយោងជើងទំព័រ ១។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤២-៤៣។

នួន ជា បានទទួលស្គាល់ថា "ភាគច្រើន" គាត់បានប្រាប់ការពិតដល់ ខែម ងុន នៅក្នុងកិច្ចសម្ភាសន៍នេះ ដោយលើកឡើងត្រឹមតែថា គាត់អាចលាក់ទុកព័ត៌មានខ្លះមិនប្រាប់ ខែម ងុន ឡើយ[១៩៩]។ ដោយហេតុថា បញ្ហានៅទីនេះគឺត្រង់ខ្លឹមសារពិតប្រាកដនៃកិច្ចសម្ភាសន៍ មិនមែនភាពអាចទុកចិត្តបាននៃកំណត់ហេតុកិច្ចសម្ភាសន៍របស់ ខែម ងុន នោះទេ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ប្រតិចារឹកនៃកិច្ចសម្ភាសន៍នេះគឺជាមូលដ្ឋានមួយដែលអាចទុកចិត្តបានសម្រាប់ធ្វើជាសំអាងហេតុ។

៨១. ការវិវត្តដំបូងនៃប្រវត្តិកុម្មុយនីស្តនិយមនៅក្នុងប្រទេសកម្ពុជាមានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការវាយប្រឆាំងជាមួយអាជ្ញាធរអាណានិគមនិយមបារាំង និងជាពិសេសការតស៊ូប្រដាប់អាវុធនៅក្រោយសង្គ្រាមលោកលើកទី II របស់ខ្មែរឥស្សរៈ និងបក្សកុម្មុយនីស្តឥណ្ឌូ-ចិន[២០០]។ នៅក្នុងឆ្នាំ ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិនដែលដឹកនាំដោយ ហូ ជីមិញ ជាមួយនឹងសាខាបក្សនៅក្នុងប្រទេសវៀតណាម ប្រទេសឡាវ និងប្រទេសកម្ពុជា[២០១] បានរៀបចំសន្និបាតមួយដែល នួន ជា បានចូលរួមផងដែរ។ នៅក្នុងសន្និបាតនោះ បក្សដែលដឹកនាំដោយវៀតណាម បានប្តូរឈ្មោះសាខាបក្សរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ទៅជាបក្សប្រជាជនបដិវត្តន៍ខ្មែរ[២០២]។

៨២. នៅចុងឆ្នាំ ១៩៥៣ ក្រោយពីព្រះមហាក្សត្រ នរោត្តម សីហនុ បានទទួលជ័យជម្នះនៅក្នុង "ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ" ប្រទេសកម្ពុជាបានទទួលឯករាជ្យឡើងវិញ។ ក្រោយពីបានចុះហត្ថលេខាលើអនុសញ្ញាទីក្រុងហ្សឺណែវក្នុងឆ្នាំ ១៩៥៤ ដែលអះអាងថាបញ្ចប់សង្គ្រាមនៅ

---

[១៩៩] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤២ ("ឯស្មោះត្រង់ ឬ មិនស្មោះត្រង់ អាហ្នឹងសម្រេចលើខ្ញុំមើលសភាពការណ៍។ តើ ខែម ងុន នេះជាមនុស្សយ៉ាងម៉េច? មានការខ្លះ ខ្ញុំប្រាប់ការពិតឲ្យ ខែម ងុន ហ្នឹងយល់ហើយមានការខ្លះ ក៏ខ្ញុំមិននិយាយដែរ") ទំព័រ ៥០-៥១។

[២០០] សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ៦៦-៧០ ERN (ភាសាខ្មែរ) 0232064-68 (ក្រៅពីពួកកុម្មុយនីស្ត និងក្រុមឥស្សរៈ ពួកអ្នកជាតិនិយមនៃគណបក្សប្រជាធិបតេយ្យក៏ទាមទារឯករាជ្យសម្រាប់ប្រទេសកម្ពុជាផងដែរ ប៉ុន្តែ បានបដិសេធការតស៊ូដោយអាវុធ ហើយអួតសរសើរពីការផ្លាស់ប្តូរសង្គមតាមនយោបាយនិយមផ្លូវកណ្តាលវិញ)។

[២០១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤១ ("អ្វីៗគឺនៅក្រោមការបញ្ជាដឹកនាំរបស់យួនទាំងអស់ពីហាណូយមកទាំងអស់ ពីហូជីមិញមកទាំងអស់") ទំព័រ ៥០-៥១។

[២០២] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៤ ERN (ភាសាខ្មែរ) 00078186។ ប្រតិចារឹក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ២៩-៣០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១២ (នួន ជា) ទំព័រ ៣០។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ៩ ERN (ភាសាខ្មែរ) 00062299។

ឥណ្ឌូចិនលើកទី ១ រួចមក[២០៣] ប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាមបានទទួលឯករាជ្យពេញលេញ ហើយកងទ័ពបរទេសនៅឥណ្ឌូចិន រួមទាំងកងកម្លាំងវៀតមិញដែលឈរជើងនៅក្នុងប្រទេសកម្ពុជា ត្រូវមានកាតព្វកិច្ចដកកងកម្លាំងចេញពីទីតាំងដែលពួកគេឈរជើង[២០៤]។ ទោះបីជាយ៉ាងនេះក្តី អ្នកតំណាងជនកុម្មុយនីស្តកម្ពុជាពុំត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការចរចានោះទេ ហើយក៏ពុំទទួលបានសម្បទានណាមួយ ដោយសារពួកគេបានគាំទ្រកងកម្លាំងវៀតមិញនៅក្នុងអំឡុងពេលវាយប្រយុទ្ធរួមគ្នាប្រឆាំងនឹងកងទ័ពបារាំងនោះឡើយ[២០៥]។ បន្ទាប់ពីការដកកងកម្លាំងវៀតមិញចេញពីប្រទេសកម្ពុជារួចមក អង្គការចាត់តាំងទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានរំលាយចោល[២០៦] ដែលធ្វើឲ្យអតីតសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរងាយរងគ្រោះពីការបង្ក្រាបដោយអាជ្ញាធររដ្ឋាភិបាល នរោត្តម សីហនុ[២០៧]។ ក្រោយមក ប៉ុល ពត នួន ជា និង

---

[២០៣] សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១០៣-១០៧ ERN (ភាសាខ្មែរ) 00232101-00232105។

[២០៤] ការបោះពុម្ពផ្សាយរបស់គណៈកម្មាធិការអ្នកស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសបារាំង៖ *ដើម្បីភាពរស់រានមានជីវិតនៃប្រជាជាតិកម្ពុជា* ឯកសារ E3/617 ចុះខែ កញ្ញា ឆ្នាំ ១៩៧៩ ទំព័រ ១០ ERN (ភាសាខ្មែរ) S 00722152 (បានចោទប្រកាន់ថា “យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ (ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៥៤) ពួកវៀតណាមត្រូវបានបង្ខំចិត្តឲ្យដកចេញពីប្រទេសកម្ពុជា។ ប៉ុន្តែ ពួកវាបាននាំប្រជាជនខ្មែរជិត ២.០០០ នាក់ ទៅជាមួយ ភាគច្រើនជាយុវជន។ បន្ទាប់ពីអប់រំបំពាក់បំប៉នអស់រយៈពេល ១៥ ឆ្នាំ ពួកវាបានបណ្តុះបណ្តាលយុវជនទាំងនោះមួយផ្នែកឲ្យក្លាយទៅជាភ្នាក់ងារកញ្ចុះរបស់ពួកវា)។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៦ ERN (ភាសាខ្មែរ) 00078187 (យោងតាម “កិច្ចព្រមព្រៀងចំពោះប្រទេសកម្ពុជាកងទ័ពបរទេសទាំងអស់ត្រូវដកចេញពីកម្ពុជា”)។

[២០៥] ផ្ទុយមកវិញ ពួកកុម្មុយនីស្តឡាវបានទទួលខេត្តពីរនៅជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាម ព្រមទាំងសិទ្ធិគ្រប់បែបយ៉ាង ដែលគេបដិសេធមិនផ្តល់ឲ្យពួកកុម្មុយនីស្តខ្មែរ៖ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១០៣-១០៤ ERN (ភាសាខ្មែរ) 00232101-00232102។

[២០៦] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១១៨-១២១ ERN (ភាសាខ្មែរ) 00380352-00380355។

[២០៧] ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ( នួន ជា) ទំព័រ ៩ (ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នៅមានមនុស្សសេសសល់តែ បី ឬ បួន នាក់ តែប៉ុណ្ណោះ)។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៦ ERN (ភាសាខ្មែរ) 00078188 (“យោងតាមកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ ១៩៥៤ មិត្តយើងទាំងអស់ដែលគេហៅថា ខ្មែរយៀកមិញនោះក៏ចូលមករស់នៅក្នុងសង្គមកម្ពុជា ត្រូវរដ្ឋអំណាច សីហនុ នេះបង្ក្រាប ចាប់ចង ដាក់គុក ដាក់ច្រវ៉ាក់ លួចសម្លាប់ [...] និយាយរួមគឺថា បក្សប្រជាជនបដិវត្តន៍ខ្មែរ វាស្ទើរតែរលាយទៅហើយ”)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៤៤-៤៥ (ស្ថានភាពមានការលំបាកក្រោយពីការផ្តាច់

ខៀវ សំផន បានហៅស្ថានភាពនេះថាជាសញ្ញាដំបូងដែលពួកគេមិនអាចជឿទុកចិត្តលើមេដឹកនាំវៀតមិញ ក្នុងការការពារផលប្រយោជន៍របស់ប្រទេសកម្ពុជា ហើយពួកគេយល់ថា គោលបំណងតែមួយគត់របស់មេដឹកនាំវៀតមិញទាំងនេះគឺចង់បង្កើត និងគ្រប់គ្រងសហព័ន្ធឥណ្ឌូចិន[២០៨]។

៨៣. នៅក្នុងឆ្នាំ ១៩៥៥ សម្តេច នរោត្តម សីហនុ បានប្រកាសដាក់រាជដើម្បីឡើងធ្វើជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា។ ព្រះអង្គបានទទួលជ័យជម្នះនៅក្នុងការបោះឆ្នោត ហើយបានចាប់ផ្តើមដំណើរការបក្សសង្គមរាស្ត្រនិយម ដែលបានបង្កើតគោលនយោបាយការបរទេសអព្យាក្រឹត្យមួយដែលនៅក្នុងនោះមាន គោលនយោបាយបដិសេធមិនចូលរួមអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (SEATO)[២០៩]។ នៅពេលនោះ សឺង ង៉ុកមិញ បានទៅទីក្រុងហាណូយ ហើយ ស៊ីវ ហេង បានគ្រប់គ្រងចលនាជនកុម្មុយនីស្តខ្មែរ ជាពិសេស នៅតាមទីជនបទ ចំណែក ទូ សាមុត គឺជាអនុលេខាបក្សទទួលខុសត្រូវទីក្រុងភ្នំពេញ។ ក្រោយមក នៅពេលដែលលេចឮព័ត៌មានថា ស៊ីវ ហេង បានចុះចូល ជាមួយសម្តេច នរោត្តម សីហនុ នោះ ទូ សាមុត បានឡើងធ្វើជាប្រធានបក្សជំនួស ស៊ីវ ហេង[២១០]។ នួន ជា បានធ្វើការងារជាសម្ងាត់ជំនួសមុខឲ្យបក្សប្រជាជនបដិវត្តន៍ខ្មែរ ហើយនៅ

---

ខ្លួនរបស់ ស៊ីវ ហេង ដែលជាសាច់ថ្លៃរបស់ នួន ជា។ កាលពេលនោះ ស៊ីវ ហេង គឺជាប្រធានបក្សប្រជាជនបដិវត្តន៍ខ្មែរ និងបានចុះចូលជាមួយ សីហនុ នៅក្នុងឆ្នាំ ១៩៥៩)។

[២០៨] ការបោះពុម្ពផ្សាយរបស់គណៈកម្មាធិការអ្នកស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសបារាំង៖ *ដើម្បីភាពរស់រានមានជីវិតនៃប្រជាជាតិកម្ពុជា* ឯកសារ E3/617 ចុះខែ កញ្ញា ឆ្នាំ ១៩៧៩ ទំព័រ ១០ ERN (ភាសាខ្មែរ) S 00722152 (បានចោទប្រកាន់ថា នៅចន្លោះឆ្នាំ ១៩៤៥ ដល់ ឆ្នាំ ១៩៥៤ "ពួកវៀតមិញបានមកតាំងទីលំនៅក្នុងប្រទេសកម្ពុជា និងឡាវ ក្រោមលេសតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង ហើយបានឆ្លៀតឱកាសនេះជ្រើសរើសភ្នាក់ងារជាឧបករណ៍បម្រើឲ្យពួកវា ដោយឈរលើ "អន្តរជាតិនិយមនៃវណ្ណៈអធន" ក្លែងក្លាយ និងផែនការ "សហព័ន្ធឥណ្ឌូចិន"")។ *សូមមើលផងដែរ* ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4027 ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786545-00786546 (ការបង្កើតកងកម្លាំងបដិវត្តន៍ខ្មែរគឺ "ឈរលើគោលជំហរឯករាជ្យម្ចាស់ការ ដែលចេញមកពីការរៀនសូត្រពិសោធន៍នៃកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ ១៩៥៤ និងដែលបានសន្និដ្ឋានថា ពឹងលើវៀតណាម ពឹងលើបរទេស មិនបានទេ")។

[២០៩] សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១០៧-១១២ ERN (ភាសាខ្មែរ) 00232105-00232110។

[២១០] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៨-១០ ERN (ភាសាខ្មែរ) 00078190-00078192។

ចុងឆ្នាំ ១៩៥៥ គាត់ត្រូវបានតែងតាំងជាលេខាបក្សនៅទីក្រុងភ្នំពេញ[២១១] និងជាទីកន្លែងដែលគាត់ និង ប៉ុល ពត បានបំពេញតួនាទីជាជំនួយការរបស់ ទូ សាមុត[២១២]។ ទោះបីជាយ៉ាងនេះក្តី នៅចន្លោះ ឆ្នាំ ១៩៥៥ និងឆ្នាំ ១៩៦០ បក្សនៅតែពុំមានការរៀបចំត្រឹមត្រូវដដែល ហើយស្ទើរតែរលាយទៅហើយ[២១៣]។

៨៤. នៅក្នុងឆ្នាំ ១៩៥៩ ទូ សាមុត ប៉ុល ពត និង នួន ជា បានចាប់ផ្តើមដំណើរការបង្កើតគណបក្សកម្ពុជាថ្មីមួយដែលមិនស្ថិតក្រោមឥទ្ធិពលរបស់វៀតណាម ដែលមានឥទ្ធិពលទៅលើបក្សកុម្មុយនីស្តឥណ្ឌូចិន[២១៤]។ យោងតាម ខៀវ សំផន អ្នកទាំងបីនាក់នេះបានបង្កើតគណៈកម្មាធិការក្រុងភ្នំពេញដោយរង់ចាំការជ្រើសតាំងថ្នាក់ដឹកនាំថ្មីក្នុងពេលខាងមុខ[២១៥]។ លោក Philip Short បានកត់សម្គាល់ថា ខៀវ សំផន បានទទួលការងារខាងកៀងគរការគាំទ្រពីបញ្ញាជន និងទាក់ទងជាមួយនឹង

---

[២១១] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៦ ERN (ភាសាខ្មែរ) 00078188។ សូមមើលផ្នែកទី៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៨ ។

[២១២] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00078188-00078189។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ១១-១៤ ERN (ភាសាខ្មែរ) 00062301-00062304។

[២១៣] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៦ ERN (ភាសាខ្មែរ) 00078188។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ១១-១៣ ERN (ភាសាខ្មែរ) 00062301-00062303។

[២១៤] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ១៩-២០។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៣-១៣២ ERN (ភាសាខ្មែរ) 00380357-00380366។ សមាជិកស្ថាបនិកពីរនាក់គឺ ម៉ី ម៉ាន់ និង ចាន់ សាម៉ន បានបោះបង់ចោលការងារនេះតាំងពីមុនម្ល៉េះ៖ ខៀវ សំផន "កម្ពុជាប្រជាធិបតេយ្យ" *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៣-១២៤ ERN (ភាសាខ្មែរ) 00380357-00380358។ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១២៣-១២៤ ERN (ភាសាខ្មែរ) 00232121-00232122 ("ចាប់តាំងពីពេលដែលពួកកុម្មុយនីស្តកម្ពុជាបានរួមប្រជុំគ្នាដើម្បីជ្រើសរើសគណៈដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរ ចលនានេះបានឈប់ធ្វើតាមគម្រូដែលមានលំនាំតែមួយដូចអតីតបក្សកុម្មុយនីស្តឥណ្ឌូចិនទៀតហើយ")។

[២១៥] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៣-១២៤ ERN (ភាសាខ្មែរ) 00380357-00380358, 00380362-00380364។

អ្នកដែលអាចគាំទ្រជនកុម្មុយនីស្តនៅក្នុងពិភពអ្នកនយោបាយ[២១៦]។ អៀង សារី ក៏ជាសមាជិកម្នាក់នៅក្នុងគណៈកម្មាធិការក្រុងភ្នំពេញផងដែរ[២១៧]។

៨៥. នៅក្នុងអំឡុងពេលនោះដែរសម្តេច នរោត្តម សីហនុ បានបង្កើតពាក្យ "ខ្មែរក្រហម" ដោយសំដៅទៅលើប្រជាជន ដែលជាក្រុមប្រដាប់អាវុធស្របច្បាប់ពាក់កណ្តាលរបស់បក្សកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា[២១៨]។ ទោះបីជាយ៉ាងនេះក្តី ពាក្យ "ខ្មែរក្រហម" មិនដែលត្រូវបានសមាជិកចលនាកុម្មុយនីស្តប្រើប្រាស់ដើម្បីពិពណ៌នាអំពីពួកគេដោយខ្លួនឯងនោះទេ[២១៩]។

---

[២១៦] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៣២ ERN (ភាសាអង់គ្លេស) 00396332។ ប្រតិចារឹក ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៧-១៨។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ អ៊ិន សុភាព៖ *ខៀវ សំផន៖ រឿងដែលគេពង្រីកឲ្យធំ និងរឿងពិត* ឯកសារ E3/4602, ERN (ភាសាខ្មែរ) 00907074 (រាយការណ៍អំពីចម្លើយរបស់ នួន ជា ដូចតទៅនេះ៖ "ពិតហើយអ្វីៗទាំងអស់ដែលគាត់ធ្វើ ពុំមែនជាគំនិតផ្តួចផ្តើមរបស់គាត់ទេ៖ គាត់ធ្វើអ្វីៗតាមការបង្គាប់បញ្ជា និងដោយការជួយរបស់បក្ស ដែលគាត់តែងតែមានសេចក្តីទៀងត្រង់ សេចក្តីសុចរិត និងស្មោះត្រង់ជានិច្ចចំពោះបក្ស។ [...] បក្សជាអ្នកចង្អុលបង្ហាញពីមាគ៌ាធំៗប្រាប់គាត់។ គាត់អធិប្បាយពីមាគ៌ាទាំងនោះ ហើយផ្សព្វផ្សាយតាមកាសែតរបស់គាត់ និងក្នុងរដ្ឋសភា ហើយធ្វើឲ្យមាគ៌ាទាំងនោះបានទៅដល់មហាជនថែមទៀត។ [...] ខៀវ សំផន ដឹងតិចតួចណាស់ពីបណ្តាសកម្មភាពពិតប្រាកដរបស់បក្ស។ តួនាទីរបស់គាត់តម្រូវឲ្យធ្វើការក្នុងចំណោមពួកបញ្ញាជន ពីព្រោះគាត់ជាអ្នកមានវិជ្ជាជ្រៅជ្រះម្នាក់។ គាត់ដឹកនាំធ្វើ "ការងាររណសិរ្សស្រទាប់លើ" របស់គាត់យ៉ាងល្អ) ERN (ភាសាខ្មែរ) 00906903-00906904 ("[និស្សិត] គ្រប់គ្នាបានផ្សាយពីសកម្មភាពប្រយុទ្ធផ្សេងៗរបស់បណ្តាចលនាដែលជាទីគាប់ចិត្តរបស់ពួកគេ។ ខ្ញុំស្តាប់ពួកគេនិយាយ ដោយគ្រាន់តែមិនជឿពួកគេប៉ុណ្ណោះ ប៉ុន្តែ ខ្ញុំមិនចូលចិត្តប្រឡូកឡើយ។ រឿងទាំងនេះវាមានលក្ខណៈ "នយោបាយ" ខ្លាំងណាស់សម្រាប់ខ្ញុំ [...] ខ្ញុំពិតជាមិនដឹងនូវអ្វីដែលកើតមានឡើងនៅជំនាន់នោះទេ) ERN (ភាសាខ្មែរ) 00906907 (អ៊ិន សុភាព បន្ថែមថា "ខៀវ សំផន ពុំត្រូវបានគេស្គាល់ ដើម្បីប្រែក្លាយខ្លួនជាយុទ្ធជនប្រជាធិបតេយ្យម្នាក់ដែរ។ គាត់នៅតែកូនប្រុសសាមញ្ញដ៏ល្អម្នាក់ និងជាកូនសិស្សម្នាក់ដែលស្លូតបូតយ៉ាងខ្លាំង (និងសាមញ្ញបំផុត តាមគាត់បញ្ជាក់)។ ដោយប្រៀបធៀបនឹងមិត្តរួមវិទ្យាល័យដទៃៗទៀត ដែលយើងទើបនឹងស្គាល់ដូចជា សៅ ង៉ុយ, វ៉ន វ៉េត, ហ៊ូ នឹម, ទីវ អុល ជាដើម (ដែលមានអាយុប្រហាក់ប្រហែលគាត់) គាត់ហាក់ដូចជាបញ្ចេញឲ្យឃើញការចូលចិត្តតិចតួចណាស់ចំពោះបដិវត្តន៍")។

[២១៧] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00078189-90។

[២១៨] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១១៤-១១៥ ERN (ភាសាអង់គ្លេស) 00396306-396307។ សៀវភៅនិពន្ធដោយ D. Chandler *ប៉ុល ពត៖ បងទី១* ឯកសារ E3/17 ឆ្នាំ ១៩៩៩ ទំព័រ ៦៦, ២១៤ ERN (ភាសាអង់គ្លេស) 00392980, 00393128។ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១៣៤-១៣៥ ERN (ភាសាខ្មែរ) 00232132-00232133។

[២១៩] សៀវភៅនិពន្ធដោយ D. Chandler *ប៉ុល ពត៖ បងទី១* ឯកសារ E3/17 ឆ្នាំ ១៩៩៩ ទំព័រ ៦៦, ២១៤ ERN (ភាសាអង់គ្លេស) 00392980, 00393128។

៨៦. ប៉ុល ពត និង នួន ជា បានព្រាងលក្ខន្តិកៈបក្ស មាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្ស តាមបញ្ជារបស់ ទូ សាមុត ឬ តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ពួកគេខ្លួនឯង[២២០]។ យោងតាម នួន ជា មាគ៌ាយុទ្ធសាស្ត្រមានមូលដ្ឋានទៅលើការវិភាគសង្គមកម្ពុជា ដែលមានការបែងចែកវណ្ណៈ ជាវណ្ណៈពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ។ ការងារដំបូងគឺត្រូវធ្វើបដិវត្តន៍ជាតិ ដោយផ្អែកលើសម្ព័ន្ធភាពកម្មករ-កសិករ ដែលប្រមូលកម្លាំងប្រជាជន រួមទាំងនាយទុន (ដែលស្មារតីស្នេហាជាតិរបស់ពួកគេគឺវាយប្រហារអាមេរិក) ពួកចក្រពត្តិនិយម និងពួកសក្តិភូមិ ក្នុងគោលបំណងដើម្បីរំដោះជាតិ។ លក្ខន្តិកៈបក្សក៏បានយកលទ្ធិម៉ាក្សលេនីន និង "ប្រជាធិបតេយ្យប្រមូលផ្តុំ" មកធ្វើជាគោលការណ៍គ្រឹះរបស់បក្សផងដែរ។ យោងតាម នួន ជា "បក្សត្រូវកសាងតាំងពីជនបទ និង ទីក្រុង យកជនបទធ្វើជាមូលដ្ឋានបង្អែក និង យកទីក្រុងធ្វើឆ្នួ"[២២១]។

៨៧. ចាប់ពីថ្ងៃទី ២៨ ដល់ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦០[២២២] សន្និបាតបក្សលើកទី ១ ត្រូវបានរៀបចំឡើងជាសម្ងាត់នៅក្នុងផ្ទះទំនេរមួយដែលធ្លាប់ជាផ្ទះរបស់ អ៊ុក សុគន្ធ នៅស្ថានីយ៍រថភ្លើងក្នុងក្រុងភ្នំពេញ ដើម្បីអនុម័តលក្ខន្តិកៈ និងតែងតាំងគណៈកម្មាធិការដឹកនាំបក្ស[២២៣]។ ពីដំបូងបក្សថ្មីនេះ

[២២០] ប្រតិចារឹក ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១០-១១។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ១៦-១៩ ERN (ភាសាខ្មែរ) 00062306-00062309 (នួន ជា លើកឡើងថា៖ "តា ទូ សាមុត អត់ធ្វើអីកើតទេ ព្រោះគាត់ចាស់ ហើយអត់សូវយល់អីផង។ ដូច្នេះមានតែខ្ញុំ ជាមួយនឹង សាឡុត ស ។ ឯ អៀង សារី ជាមនុស្សឆ្វេង ចចេស")។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៨-១៣២ ERN (ភាសាខ្មែរ) 00380362-00380366។

[២២១] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ១៣ ERN (ភាសាខ្មែរ) 00078195។ សូមមើលផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៣-២២៨ (លទ្ធិប្រជាធិបតេយ្យប្រមូលផ្តុំ) ។

[២២២] ពីរសប្តាហ៍នៅមុនពេលសន្និបាតលើកទីមួយ វៀតណាមនៅទីក្រុងហាណូយបានចេញសេចក្តីសម្រេចរបស់ខ្លួនជាផ្លូវការ ធ្វើការវាយប្រយុទ្ធនៅវៀតណាមខាងត្បូង "ដើម្បីរំដោះវៀតណាមខាងត្បូងពីការគ្រប់គ្រងរបស់ចក្រពត្តិអាមេរិក និងបរិវាររបស់វា"។ បីខែក្រោយមក រណសិរ្សរំដោះជាតិត្រូវបានបង្កើតឡើងដើម្បីបំពេញតាមគោលបំណងនេះ។ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១២៤-១២៦ ERN (ភាសាខ្មែរ) 00232122-00232124។

[២២៣] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៩-៦០។ ទង់បដិវត្ត ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៣១-៣៨ ERN (ភាសាខ្មែរ) 00063134-00063136។ អត្ថបទសម្ភាសន៍ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤១-៤៣ ERN (ភាសាខ្មែរ) 00062492-00062494 (អ៊ុក សុគន្ធ)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើម*

មានឈ្មោះថា បក្សពលករកម្ពុជា ហើយក្រោយមកត្រូវបានប្ដូរឈ្មោះទៅជាបក្សកុម្មុយនីស្ត-កម្ពុជា[២២៤]។ យោងតាម ខៀវ សំផន សមាជិកគណៈកម្មាធិការក្រុងភ្នំពេញ ក្រោយមកបានក្លាយជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា[២២៥]។ ទូ សាមុត ត្រូវបានតែងតាំងជាលេខាបក្ស ហើយ នួន ជា ជាអនុលេខាបក្ស ចំណែក ប៉ុល ពត, ម៉ា ម៉ង់, អៀង សារី, កែវ មាស ចុង និង វន វ៉េត ជាសមាជិកគណៈកម្មាធិការមជ្ឈិម[២២៦]។ លើសពីនេះទៀត សមាជិកគណៈកម្មា-ធិការអចិន្ត្រៃយ៍ក៏ត្រូវបានជ្រើសរើសផងដែរ ដែលក្នុងនោះមាន ទូ សាមុត, នួន ជា, សាឡុត ស ម៉ា ម៉ង់[២២៧]។ នួន ជា បាននិយាយថា សុន សេន និង សោ ភឹម ក៏ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរនាពេលនោះ ប៉ុន្តែ ចុង មិនត្រូវបានតែងតាំងជាសមាជិកគណៈ-កម្មាធិការនេះឡើយ[២២៨]។ ក្រៅពីតំណាងក្រុង បក្សបានអញ្ជើញតំណាងមកពីជនបទចំនួន ១០ ទៅ

---

*វហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៨-១៣៣ ERN (ភាសាខ្មែរ) 00380362-00380367។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00078191-92។

[២២៤] ប្រតិចារឹក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥១-៥២, ៥៣-៥៤។ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១២៥-១២៦ ERN (ភាសាខ្មែរ) 00232122-00232124។

[២២៥] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១២៨-១៣០ ERN (ភាសាខ្មែរ) 00380362-00380364។

[២២៦] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៩-៦០។ អត្ថបទសម្ភាសន៍ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤១-៤២ ERN (ភាសាខ្មែរ) 00062492-00062493។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00078191-00078192។

[២២៧] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ១៦-១៩ ERN (ភាសាខ្មែរ) 00062306-00062309។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៤-១៨, ២៦-២៧។ អត្ថបទសម្ភាសន៍ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤១-៤២ ERN (ភាសាខ្មែរ) 00062492-00062493។

[២២៨] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៨, ២៣-២៨។ សូមមើលផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣ (ដើម្បីបែងចែករវាងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍)។

១៥ នាក់ ឲ្យមករៀនសូត្រមាគ៌ាបក្ស និងលក្ខន្តិកៈបក្ស[២២៩]។ គ្មានឯកសារណាមួយត្រូវបានបន្សល់ទុកពីការប្រជុំនេះទេ ប្រហែលជាដោយសារតែការប្រជុំនេះមិនបានរៀបចំឯកសារអ្វីផ្សេងក្រៅពីលក្ខន្តិកៈបក្សនោះឡើយ[២៣០]។

៨៨. យោងតាមចម្លើយរបស់ នួន ជា សន្និបាតបក្សលើកទី ១ បានសម្រេចប្រើប្រាស់អាវុធតែក្នុងករណីចាំបាច់ប៉ុណ្ណោះដើម្បីការពារកម្លាំងរបស់ពួកគេ[២៣១]។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[២៣២] មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួន ជា អៀង សារី និង ប៉ុល ពត បានលើកឡើងជាច្រើនលើកច្រើនសាថា សន្និបាតបក្សលើកទី ១ នៅក្នុងឆ្នាំ ១៩៦០ បានអនុម័តយក "ហិង្សាបដិវត្តន៍" និងបានសម្រេចឲ្យប្រើប្រាស់ "ការតស៊ូប្រដាប់អាវុធ" ដើម្បីសម្រេចគោលបំណងរបស់បក្ស[២៣៣]។ ការប្រើប្រាស់"ហិង្សាប្រដាប់អាវុធ" ធ្លាប់ជា

---

[២២៩] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ១៨-១៩ ERN (ភាសាខ្មែរ) 00062308-00062309; ទង់បដិវត្ត ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៣១-៣៨ ERN (ភាសាខ្មែរ) 00063134-00063136។ សន្និសីទកាសែតរបស់ ប៉ុល ពត នៅទីក្រុងប៉េងកាំង (នៅក្នុងកម្រង SWB FE/5631/A3) ឯកសារ E3/2072 ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) S 00296200-00296202។

[២៣០] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៣២-១៣៣ ERN (ភាសាខ្មែរ) 00380366-00380367។

[២៣១] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦០។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២២-២៣, ២៦-២៨។

[២៣២] *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (បានកំណត់រយៈកាលកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ និងបានបង្កើតយុត្តាធិការពេលវេលាចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩)។ *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១-៨។

[២៣៣] *សមមិត្ត នួន ជា ថ្លែងក្នុងវិទិវាខួបកំណើតកងទ័ពបដិវត្តកម្ពុជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/147 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00679796 ("ចាប់តាំងពីឆ្នាំ ១៩៦០ អង្គការបដិវត្តកម្ពុជាយើងបានដាក់ចេញនូវមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធី សម្រាប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ [...] ក្រោយឆ្នាំ ១៩៦០ អង្គការបដិវត្តន៍យើងបានសម្រេចច្បាស់ថា យើងត្រូវប្រើសកម្មភាពនយោបាយ និងហិង្សាប្រដាប់អាវុធដើម្បី ផ្តួលរំលំ និងកម្ទេចខ្មាំង")។ ទង់បដិវត្ត ឯកសារ E3/25 ចុះខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៤០ ERN (ភាសាខ្មែរ) 00063023 ("ហិង្សាបដិវត្តខាងនយោបាយ និងហិង្សាអាវុធ") ទំព័រ ៥២-៥៤ ERN (ភាសាខ្មែរ) 00063030-00063031 ("ចាប់ពីឆ្នាំ ១៩៦០ [...] បក្សមានមាគ៌ាជាយុទ្ធសាស្ត្រ មានមាគ៌ាជាយុទ្ធវិធី ហើយក្នុងនោះ មានរៀបចំហិង្សាបដិវត្ត មានរៀបចំកងទ័ព")។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៣២-១៣៣ ERN (ភាសា

ប្រធានបទដែលមានការមិនចុះសម្រុងគ្នារវាងមេដឹកនាំខ្មែរក្រហម និងជនកុម្មុយនីស្តវៀតណាម ចាប់តាំងពីពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ រហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៦០។ ឧទាហរណ៍ នៅក្នុងខែ មករា និងខែ ឧសភា ឆ្នាំ ១៩៥៩ បក្សពលករវៀតណាមបានយល់ព្រមផ្លាស់ប្តូរពីការតស៊ូនយោបាយ មកជាការតស៊ូប្រដាប់អាវុធប្រឆាំងនឹងសាធារណរដ្ឋវៀតណាមខាងត្បូង ប៉ុន្តែពួកគេជំទាស់នឹងជនកុម្មុយនីស្តកម្ពុជាមិនឲ្យប្រើប្រាស់យុទ្ធសាស្ត្រដូចគ្នានេះទេ[២៣៤]។

៨៩. ក្នុងអំឡុងខែ កុម្ភៈ ឆ្នាំ ១៩៦២ លេខាបក្ស ទូ សាមុត ប្រហែលជាត្រូវបានគេចាប់ខ្លួន ហើយក្រោយមកក៏បានបាត់ខ្លួន ដែលនាំឲ្យមានការចាំបាច់ត្រូវតែងតាំងលេខាបក្សថ្មីម្នាក់នៅក្នុងអំឡុងពេលសន្និបាតបក្សលើកទី ២ ដែលត្រូវបានរៀបចំឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៦៣ នៅលើវិថីឆាលឌឺហ្គោលក្នុងទីក្រុងភ្នំពេញ[២៣៥]។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៅពេលនោះរួមមាន

---

ខ្មែរ) 00380366-00380367 (“វណ្ណៈជិះជាន់” ជាសត្រូវសំខាន់ជាងគេនៃបដិវត្តន៍កម្ពុជា ហើយ “ជាឧបករណ៍នៃចក្រពត្តិអាមេរិក។ ដូច្នេះ ប្រជាជនកម្ពុជាត្រូវតែកម្ទេច “របបសក្តិភូមិ” តាមមធ្យោបាយសន្តិវិធី ឬ តាមវិធីផ្សេងទៀត”)។ Dan Burstein “កិច្ចសម្ភាសន៍ជាមួយនឹងឧបនាយករដ្ឋមន្ត្រី អៀង សារី” នៅក្នុងសៀវភៅចំណងជើងថា *ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន៖ របាយការណ៍សាក្សីមកពីប្រទេសកម្ពុជា* ឯកសារ E3/707 ចុះខែ ធ្នូ ឆ្នាំ ១៩៧៨ ទំព័រ ១៧-១៨ ERN (ភាសាខ្មែរ) S 00728132-00728133 (“ការតស៊ូអាវុធ”)។ សន្និសីទកាសែតរបស់ ប៉ុល ពត នៅទីក្រុង ប៉េងកាំង (នៅក្នុងកម្រង SWB FE/5631/A3) ឯកសារ E3/2072 ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) S 00296200-00296202 (“យើងបានប្រកាន់យកការតស៊ូពុះពារដែលប្រកបដោយអំពើហិង្សា ដោយបានបង្កើននូវការប្រយុទ្ធផ្នែកនយោបាយប្រកបដោយហិង្សាផង និងការប្រយុទ្ធប្រើប្រាស់ដោយអាវុធផង ដោយយកការប្រយុទ្ធប្រើប្រាស់ដោយអាវុធជាទ្រង់ទ្រាយសំខាន់”)។

[២៣៤] សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១២០-១២១ ERN (ភាសាខ្មែរ) 00232117-00232118។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៣០-១៣៣ ERN (ភាសាខ្មែរ) 00380364-00380367 (យោងតាម ខៀវ សំផន ក្នុងសំបុត្រមួយមកអ្នកដឹកនាំខ្មែរនៅចុងឆ្នាំ ១៩៥៩ បក្សពលករវៀតណាមកត់សម្គាល់ថាវៀតណាមគាំទ្ររបប សីហនុ និងលើកទឹកចិត្តបក្សកុម្មុយនីស្តកម្ពុជាឲ្យឈានទៅកាន់អំណាចតាមរយៈការបោះឆ្នោត ជៀសវាងការតស៊ូវណ្ណៈ និងការប្រើហិង្សាបដិវត្តន៍។ ដើម្បីគាំទ្រដល់អនុសាសន៍នេះ ពួកគេបានយោងលើគំនិតរបស់ (Khrushchev) អំពី “ផ្លូវទៅសង្គមនិយមតាមសភា” ដែលសន្និបាតលើកទី ២០ របស់បក្សកុម្មុយនីស្តសូវៀតនៅមូស្គូបានលើកឡើង)។

[២៣៥] ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៨; ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៧-៥៩។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ

ប៉ុល ពត សោ ភឹម អៀង សារី និង នួន ជា[២៣៦]។ សមាជិកផ្សេងទៀត ដែលមានវត្តមានផងដែររួម មាន កឹ (ហៅ សុផល) ចុង, វន វេត, មូល សម្បត្តិ ហៅ រស់ ញឹម, តា ម៉ុក និង ម៉ា ម៉ង់[២៣៧]។ សុន សេន ក៏អាចមានវត្តមានផងដែរនាពេលនោះ បើទោះបីជាសេចក្តីថ្លែងការណ៍របស់ នួន ជា អំពីការណ៍នេះមិនមានលក្ខណៈច្បាស់លាស់ក៏ដោយ [២៣៨]។ សន្និបាតបក្សលើកទី ២ បានតែងតាំង ប៉ុល ពត ជាលេខាបក្ស និង នួន ជា ជាអនុលេខាបក្ស ហើយបានបញ្ជាក់សាជាថ្មីអំពីការ ប្រើប្រាស់ហិង្សានយោបាយ និងហិង្សាបដិវត្តន៍ប្រដាប់អាវុធ[២៣៩]។ នៅក្នុងឆ្នាំ ១៩៦៣ អៀង សារី ប៉ុល ពត និងបុគ្គលមួយចំនួនផ្សេងទៀតនោះ ត្រូវបានដាក់ឈ្មោះថាជា "ជនចម្រើន" ហើយត្រូវបាន សម្តេច នរោត្តម សីហនុ កោះហៅរួមជាមួយនឹងបុគ្គលផ្សេងទៀត ក្រោមលេសថាបង្កើត រដ្ឋាភិបាលថ្មីមួយ។ ដោយមានការភ័យខ្លាចអំពីការចាប់ខ្លួន ពួកគេបានរត់ទៅលាក់ខ្លួននៅជិត ព្រំប្រទល់វៀតណាម[២៤០]។

---

១២-១៣ ERN (ភាសាខ្មែរ) 00078194-00078195; អត្ថបទសម្ភាសន៍ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤១-៤៣ ERN (ភាសាខ្មែរ) 00062492-00062494។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២១-២៣ ERN (ភាសាខ្មែរ) 00062311-00062313 (និយាយអំពីមហាសន្និបាតបក្សលើកទីបី ប៉ុន្តែ នៅក្នុងឆ្នាំ ១៩៦៣)។

[២៣៦] កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ១៤ ERN (ភាសាខ្មែរ) 00078196។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១១-១២។

[២៣៧] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២២-២៤ ERN (ភាសាខ្មែរ) 00062312-00062314។

[២៣៨] ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១២។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ១៤ ERN (ភាសាខ្មែរ) 00078196។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៤-២៦ ERN (ភាសាខ្មែរ) 00062314-00062316។

[២៣៩] ទង់បដិវត្ត ឯកសារ E169/4/1.1.2 ចុះខែ ធ្នូ ឆ្នាំ ១៩៧៥ ដល់ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 000809833។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៨-១៩ (សីហនុ ពុំបានផ្តល់ឱកាសឲ្យមានការប្រឆាំងនោះទេ ដូច្នេះអំពើហិង្សាគឺជាជម្រើសតែមួយគត់សម្រាប់ខ្មែរក្រហម)។

[២៤០] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៤៣-៤៤។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៤២-១៤៥ ERN (ភាសាខ្មែរ) 00380376-00380379។

៩០. នៅក្នុងឆ្នាំ ១៩៦៥ ប៉ុល ពត បានធ្វើដំណើរទៅប្រទេសវៀតណាម និងប្រទេសចិន ដើម្បីឧទ្ទេសនាមមាគ៌ាយុទ្ធសាស្ត្រដែលទើបត្រូវបានបង្កើតថ្មីរបស់បក្សកុម្មុយនីស្តកម្ពុជា[២៤១]។ ទោះបីជាវៀតណាមមិនសប្បាយចិត្ត ដោយសារបក្សកុម្មុយនីស្តកម្ពុជាខកខានមិនបានពិគ្រោះយោបល់ជាមួយពួកគេនៅពេលបង្កើតលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានោះក្តី ក៏បក្សកុម្មុយនីស្តចិនបានចាត់ទុកថា មាគ៌ាបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាមានលក្ខណៈសមស្រប ហើយជំហរបក្សកុម្មុយនីស្តចិននេះអាចឲ្យបក្សកុម្មុយនីស្តកម្ពុជា ធ្វើការរួមជាមួយនឹងបក្សកុម្មុយនីស្តផ្សេងទៀតនៅពេលនោះ[២៤២]។ នៅក្នុងអំឡុងពេលនោះ ទីស្នាក់ការមន្ទីរ ១០០ របស់បក្សកុម្មុយនីស្តកម្ពុជាបានប្តូរទៅខេត្តរតនគិរី[២៤៣]។

៩១. នៅក្នុងឆ្នាំ ១៩៦៧ ការបះបោរដោយឯកឯងមួយបានកើតមានឡើងនៅភូមិសំឡូតក្នុងខេត្តបាត់ដំបង ដោយសារតែជម្លោះដីធ្លីដែលបង្កឡើងដោយពួកទាហាន និងអ្នករដ្ឋការ ដែលបានរឹបយកដីធ្លីពីអ្នកភូមិសំឡូត[២៤៤]។ មេដឹកនាំបក្សបានពិចារណាឃើញថា វាមិនទាន់ដល់ពេលផ្តួចផ្តើមឲ្យមានបដិវត្តន៍ប្រដាប់អាវុធនៅពេលនេះទេ[២៤៥]។ ក៏ប៉ុន្តែ ការបះបោរនៅសំឡូតនៅក្នុងឆ្នាំ ១៩៦៧

---

[២៤១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៤-១៥។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00062315-00062316 (ប៉ុល ពត បានធ្វើដំណើរទៅវៀតណាមខាងជើងដើម្បីទាក់ទងផ្លូវបក្ស ហើយទៅចិនដែរដើម្បីឧទ្ទេសនាមពីចលនាតស៊ូ)។

[២៤២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៤-១៥។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00062315-00062316។

[២៤៣] ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៣-១៦ (លើកឡើងអំពីការធ្វើដំណើររបស់គាត់ទៅកាន់មន្ទីរ ១០០ "ទៅរតនគិរី តាមខ្ញុំចាំ មុនឆ្នាំ ១៩៦៦")។

[២៤៤] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-១១។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៣-២៤។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៤៦-៤៨។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00062315-00062316។

[២៤៥] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00062315-00062316។

ក្នុងខេត្តបាត់ដំបង គឺជាចំណុចចាប់ផ្តើមនៃការតស៊ូប្រដាប់អាវុធ និងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា[២៤៦]។

៩២. ដោយមិនបានគិតទាល់តែសោះថា កសិករអាចបះបោរប្រឆាំងនឹងសម្តេចនោះ សម្តេចនរោត្តម សីហនុ មិនសប្បាយព្រះទ័យយ៉ាងខ្លាំងនឹងការបះបោរនៅសំឡូតនេះ ហើយសម្តេចបានប្រើប្រាស់កម្លាំងយ៉ាងខ្លាំងដើម្បីបង្ក្រាបការបះបោរនេះ[២៤៧]។ សម្តេចបានបន្ទោសលើឥទ្ធិពលវប្បធម៌បដិវត្តន៍ចិន ហើយបានបញ្ជាឱ្យរំលាយសមាគមមិត្តភាពកម្ពុជា-ចិន ដែលមាន ហ៊ូ នឹម ជាប្រធាន[២៤៨]។ ខៀវ សំផន ដែលបានចូលបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹង ហ៊ូ នឹម បានទទួលរងនូវការគំរាមចាប់ខ្លួន ហើយត្រូវបាននាំខ្លួនមកកាន់តុលាការយោធា ក្រោមលេសថា គាត់ជាមេខ្យល់នៃការបះបោរនោះ[២៤៩]។ ឃើញដូច្នេះ នួន ជា បាននាំ ខៀវ សំផន ហ៊ូ នឹម និងបញ្ញាជនផ្សេងទៀត រួមទាំង ហ៊ូ យន់ ផងនោះ ចូលព្រៃ ពីព្រោះពួកគេកំពុងរងគ្រោះថ្នាក់នៅក្នុងទីក្រុងភ្នំពេញ[២៥០]។

---

[២៤៦] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៣-២៤។

[២៤៧] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៣៦-៣៩ ERN (ភាសាខ្មែរ) 00103826-00103827។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦០។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-៨។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៤។

[២៤៨] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ៣៦-៣៩ ERN (ភាសាខ្មែរ) 00103826-00103827។

[២៤៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៥៩-៦០, ៦២។

[២៥០] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៣០-៣១, ៣៤-៣៥។ កិច្ចសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយនឹង ខៀវ សំផន ឯកសារ E3/581 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00424230។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ទំព័រ ២២-២៥, ២៧, ២៨-៣១ ERN (ភាសាខ្មែរ) 00103819-00103820, 00103821, 00103822-00103823។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើងពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៦-២៧, ២៩-៣០ ERN (ភាសាខ្មែរ) 00062316-00062317, 00062319-00062320។

៩៣. ហេតុការណ៍ទាំងឡាយនៅសំឡូតបានជំរុញឲ្យមានការបះបោរផ្សេងៗទៀត។ នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៦៨ ការវាយប្រហារប្រដាប់អាវុធមួយ បានកើតមានឡើងនៅបាយដំរាំក្នុងខេត្តបាត់ដំបង ដោយនៅពេលនោះ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាអាចរឹបអូសបានអាវុធខ្លះពីប៉ុស្តិ៍-នគបាល[២៥១]។ ក្រោយមក បក្សបានកំណត់យកហេតុការណ៍នេះថាជាថ្ងៃកំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា[២៥២]។

៩៤. វៀតណាមខាងជើងត្រូវការការគាំទ្រពីរដ្ឋាភិបាល សីហនុ ឬយ៉ាងហោចណាស់ ការបន្តរក្សាអព្យាក្រឹត្យរបស់កម្ពុជាទៅមុខទៀត ដើម្បីផ្គត់ផ្គង់ដល់សង្គ្រាមប្រឆាំងនឹងអាមេរិកនៅក្នុងប្រទេសវៀតណាម[២៥៣]។ ដូច្នេះ វៀតណាមខាងជើងបានបន្តជំទាស់នឹងការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជា ហើយបានស្នើសុំឲ្យបក្សកុម្មុយនីស្តកម្ពុជាបញ្ឈប់ការវាយប្រហារប្រដាប់អាវុធ ឬ យ៉ាងហោចណាស់ កុំឲ្យបក្សកុម្មុយនីស្តកម្ពុជាផ្តាច់ស្ពាន ដើម្បីទុកសម្រាប់ពួកគេដឹកអាវុធ និងអង្ករពីកំពង់ធំទៅកាន់ព្រំដែនកម្ពុជា-វៀតណាម[២៥៤]។ ដោយសារការជំទាស់នេះហើយ ទើប

[២៥១] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៥-២៧ ERN (ភាសាខ្មែរ) 00062315-00062317។

[២៥២] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៦-២៧ ERN (ភាសាខ្មែរ) 00062316-00062317។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦-១១ (នួន ជា ពុំចាំថ្ងៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា ឬ ហេតុការណ៍នេះ ច្បាស់នោះទេ។ គាត់លើកឡើងថា៖ "តាមខ្ញុំចាំ ថ្ងៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា គឺថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៧៨ ជាថ្ងៃកំណើតរបស់បដិវត្តន៍")។ សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00003137។ ទង់បដិវត្ត ឯកសារ E3/25 ចុះខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៣៦-៤១ ERN (ភាសាខ្មែរ) 00063021-00063023។ ទង់បដិវត្ត ឯកសារ E3/744 ចុះខែ កុម្ភៈ ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00064422-00064448។

[២៥៣] នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៦-២៧ ERN (ភាសាខ្មែរ) 00062316-00062317 (ក្នុងការផ្ទុះអាវុធរបស់យើង បក្សវៀតណាមគេមិនយល់ស្របទេ ដោយចោទថា បក្សកុម្មុយនីស្តកម្ពុជាវៃឌីឯង ព្រោះ សីហនុ ពេលនោះ កំពុងអនុវត្តនយោបាយអព្យាក្រឹត្យ។ ចិនក៏អត់យល់ព្រមដែរ)។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៥៣-១៥៦ ។

[២៥៤] ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣១-៣៣។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៦-២៧ ERN (ភាសាខ្មែរ) 00062316-00062317។

ជនកុម្មុយនីស្តវៀតណាមមិនផ្តល់អាវុធ ឬការជួយជ្រោមជ្រែង តាមរូបភាពណាមួយក៏ដោយ ដល់កងទ័ពខ្មែរក្រហមឡើយ[២៥៥]។

៩៥. សន្និបាតបក្សលើកទី ៣ ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ១៩៧១ នៅមន្ទីរបក្សនៅក្នុងព្រៃជិតភូមិត្រពាំងព្រៃ[២៥៦]។ សន្និបាតនេះស្ថិតក្រោមអធិបតីភាពរបស់ ប៉ុល ពត និង នួន ជា និងមានវត្តមានចូលរួមពីគ្រប់សមាជិកនៃថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងតំណាងពីគ្រប់ភូមិភាគដែលភាគច្រើនឃើញនៅក្នុងរូបថតដែលត្រូវបានថតនៅក្នុងពេលសន្និបាតនោះ[២៥៧]។ ទោះបីជា ភី ភួន មិនបានចាំថា ខៀវ សំផន មានវត្តមាននាពេលនោះក៏ដោយ ក៏ ខៀវ សំផន ខ្លួនឯង បានលើកឡើងថា គាត់បានចូលរួមប្រជុំសន្និបាតបក្សនៅក្នុងឆ្នាំ ១៩៧១ នោះដែរ ហើយគាត់បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ ១៩៧១[២៥៨]នោះតែម្តង។ សន្និបាតបានសម្រេច

---

[២៥៥] ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣២-៣៣។ នួន ជា៖ ប្រវត្តិចលនាតស៊ូរបស់កសិករកម្ពុជាយើង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ឯកសារ E3/131 ទំព័រ ២៦-២៧ ERN (ភាសាខ្មែរ) 00062316-00062317 (“យើងបានស្នើសុំអាវុធពីវៀតណាម តែពួកវៀតណាមពុំផ្តល់អាវុធនោះទេ ដូច្នេះយើងបានលួចអាវុធទាំងនោះ”)។

[២៥៦] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ែចាម តុន *ហៅ ភី ភួន*) ទំព័រ ៧-៩, ២៨។

[២៥៧] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ែចាម តុន *ហៅ ភី ភួន*) ទំព័រ ២៨-២៩។ សាក្សីបានលើកឡើងថាសមាសភាពដូចតទៅនេះមានវត្តមាននៅក្នុងពេលធ្វើសន្និបាតបក្សលើកទីបី (ភូមិភាគ ៣០៤ - កុយ ធួន, កែ ពក និង ឌឿន។ ភូមិភាគ ២០៣ - សោ ភឹម, ភួង និង តាទុំ ឬ ជូ ចេត *ហៅ* ស៊ី សូមផ្ទៀងជាមួយនឹងឈ្មោះខ្មែរ។ ភូមិភាគពិសេស - វន វ៉េត។ ភូមិភាគនិរតី - តា ម៉ុក, តា ចុង។ ភូមិភាគពាយ័ព្យ - រស់ ញឹម, តា កឺ និង តា ខ្ទិល។ តំបន់ ១០៣ - មេដឹកនាំមិនស្គាល់ឈ្មោះ។ ភូមិភាគឦសាន - យ៉ា និង វ៉ង់។ មណ្ឌលគីរី - ឡាំង)។ រូបថត ឯកសារ E3/136 P00416593។ រូបថត ឯកសារ E3/137 P 00416592។ រូបថត ឯកសារ E3/1595 P 00416590។ ក្រៅពី កុយ ធួន នួន ជា មិន អាច កំណត់ អត្តសញ្ញាណមនុស្សផ្សេងទៀតនៅក្នុងរូបថតដែលមាន ERN (ភាសាខ្មែរ) P 00416593 នោះទេ។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ទំព័រ ១៨-២០។ នួន ជា ត្រូវបានផ្តល់ជូនរូបថតច្បាប់ថតចម្លងគ្រប់សន្លឹក ហើយមេធាវីរបស់គាត់បានបញ្ជាក់ថា ពួកគេនឹងឆ្លើយតបក្នុងពេលសមស្របខាងមុខ។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៧៣-៧៤។

[២៥៨] ប្រតិចារឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២(រ៉ែចាម តុន *ហៅ* ភី ភួន)ទំព័រ២៩។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ២១៤-២១៥ ERN (ភាសាខ្មែរ) 00380486-00380487។ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦២-៦៣។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00156619-00156620។

ប្តូរឈ្មោះបក្ស ពីបក្សពលករកម្ពុជាមកជាបក្សកុម្មុយនីស្តកម្ពុជា ហើយបានបង្កើតភូមិភាគពិសេស ដោយគ្របដណ្តប់ទាំងក្រុងភ្នំពេញ និងស្ថិតក្រោមការគ្រប់គ្រងរបស់ វន វ៉េត[២៥៩]។ សន្និបាតបានគូសបញ្ជាក់ឡើងវិញអំពីមាគ៌ាយុទ្ធសាស្ត្របក្ស ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទី ១ និងលើក ទី ២[២៦០]។

## ៣.២ ការទម្លាក់សម្តេច នរោត្តម សីហនុ និងការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

៩៦. រហូតដល់ឆ្នាំ ១៩៦៩ សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ ហើយមានភាពមិនច្បាស់ថា កម្ពុជាអាចនឹងធ្លាក់ចូលក្នុងសង្គ្រាមក្នុងប្រទេសវៀតណាមដែរឬក៏អត់នោះទេ ទោះបីជាសម្តេច សីហនុ មានគោលនយោបាយអព្យាក្រឹត្យផ្លូវការក៏ដោយ[២៦១]។ ចាប់តាំងពីឆ្នាំ ១៩៦៩ មកការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងប្រទេសកម្ពុជា បានរុញច្រានឲ្យកងទ័ពវៀតណាមខាងជើងកាន់តែខិតចូលមកក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យវិបត្តិនេះកាន់តែមានភាពតានតឹងថែមទៀត[២៦២]។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៧០ ខណៈពេលដែលសម្តេច នរោត្តម សីហនុ ស្ថិតនៅក្នុងទីក្រុងប៉ារីស អនុប្រធានាធិបតីវៀតណាមខាងត្បូង Nguyen Cao Ky បានមកធ្វើទស្សនកិច្ចសម្ងាត់នៅទីក្រុងភ្នំពេញ ហើយបានបង្កើតសម្ព័ន្ធភាពជាមួយនឹងនាយករដ្ឋមន្ត្រី លន់ នល់[២៦៣]។

---

[២៥៩] សៀវភៅនិពន្ធដោយ ខៀវ សំផនៈ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ២១៤-២១៧ ERN (ភាសាខ្មែរ) 00380486-00380489។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១២-១៤, ៥៣-៥៤។

[២៦០] ទង់បដិវត្ត ឯកសារ E169/4/1.1.2 ចុះខែ ធ្នូ ឆ្នាំ ១៩៧៥ ដល់ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ២៦-២៩ ERN (ភាសាខ្មែរ) 00809842-00809843។

[២៦១] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពតៈ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៨៥-១៨៧ ERN (ភាសាអង់គ្លេស) 00396385-00396387។

[២៦២] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពតៈ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៨៥ ERN (ភាសាអង់គ្លេស) 00396385។ សៀវភៅនិពន្ធដោយ W. Shawcross៖*Sideshow* សកម្មភាពរបស់ Nixon និង Kissinger និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា ឯកសារ E3/88 ទំព័រ ៦៧-៦៨ ERN (ភាសាអង់គ្លេស) 00429754-55។ សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៥៣-១៥៦។

[២៦៣] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពតៈ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៩៥-១៩៦ ERN (ភាសាអង់គ្លេស) 00396395-00396396។

៩៧. ក្រោមការជំរុញទឹកចិត្តពី សិរិមតៈ ដែលជាអនុរបស់ លន់ នល់ ទើបនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ លន់ នល់ បានចុះហត្ថលេខាលើក្រឹត្យយល់ព្រមទម្លាក់សម្តេច នរោត្តម សីហនុ ដែលកំពុងស្ថិតនៅក្នុងទីក្រុងមូស្គូ ហើយកំពុងធ្វើដំណើរមកកាន់ទីក្រុងប៉េកាំង នាពេលនោះ[២៦៤]។ នៅក្នុងថ្ងៃដដែលនោះ រដ្ឋសភាជាតិកម្ពុជាបានអនុម័តលើការបោះឆ្នោតទម្លាក់សេចក្តីទុកចិត្តលើសម្តេច សីហនុ ហើយតម្រូវឱ្យសម្តេចលាលែងពីតំណែងជាប្រមុខរដ្ឋ[២៦៥]។ ដោយប្រឈមនឹងហេតុការណ៍ទាំងនេះ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧០ សម្តេច នរោត្តម សីហនុ បានប្រកាសតាមវិទ្យុផ្សាយសម្លេងពីទីក្រុងប៉េកាំង ពីការបង្កើតចលនានយោបាយមួយ គឺរណសិរ្សរួបរួមជាតិកម្ពុជា ហើយអំពាវនាវឱ្យអ្នកស្នេហាជាតិរបស់សម្តេច ចូលរួមក្នុងការតស៊ូវាយប្រឆាំងនឹងអ្នកផ្តួចផ្តើមឱ្យមានរដ្ឋប្រហារនេះ។ សម្តេចក៏បានសន្យាផ្តល់ការបណ្តុះបណ្តាលផ្នែកយោធា និងអាវុធជូនដល់ពួកគេផងដែរ[២៦៦]។ យោងតាម ប៉ុល ពត ដំបូងឡើយ សម្តេច នរោត្តម សីហនុ បានបង្ហាញសេចក្តីព្រាងព្រះរាជសារនេះជូននាយករដ្ឋមន្ត្រីចិន ជូ អេងឡាយ ឱ្យបានជ្រាប។ ក្រោយមក ជូ អេងឡាយ បានទទួលយោបល់ពី ប៉ុល ពត ដែលនៅពេលនោះគាត់កំពុងស្ថិតនៅក្នុងទីក្រុងប៉េកាំង ហើយបានដកចំណុចណាដែលលើកឡើងពីសង្គមនិយមចេញពីសេចក្តីថ្លែងការណ៍នោះ[២៦៧]។ បន្ទាប់មក ប៉ុល ពត

---

[២៦៤] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៩៧ ERN (ភាសាអង់គ្លេស) 00396397។ ("នាយករដ្ឋមន្ត្រី Alexei Kosygin បានទូលថ្វាយ សីហនុ អំពីរដ្ឋប្រហារ នៅពេលព្រះអង្គនៅក្នុងទីក្រុងមូស្គូ ក្នុងពេលនាយករដ្ឋមន្ត្រី និងព្រះអង្គធ្វើដំណើរមកកាន់អាកាសយានដ្ឋានដើម្បីយាងចាកចេញទៅកាន់ទីក្រុងប៉េកាំង")។ ព្រះរាជសារ និងសេចក្តីថ្លែងការណ៍ជាឱឡារិករបស់សម្តេច នរោត្តម សីហនុ ឯកសារ E3/1756 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧០ ERN (ភាសាអង់គ្លេស) 00852373។ សៀវភៅនិពន្ធដោយ E. Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ឆ្នាំ ១៩៨៦ ទំព័រ ១៥២-១៥៨ ERN (ភាសាខ្មែរ) 00232152-00232156។

[២៦៥] សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ១៩៧ ERN (ភាសាអង់គ្លេស) 00396397។

[២៦៦] ព្រះរាជសារ និងសេចក្តីថ្លែងការណ៍ជាឱឡារិករបស់សម្តេច នរោត្តម សីហនុ ឯកសារ E3/1756 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧០។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៣៩, ៤១-៤៣។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៥៧-៥៩។

[២៦៧] អត្ថបទបោះពុម្ពផ្សាយដោយក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ៖ *សៀវភៅខ្មៅ* ឯកសារ E3/23 ចុះខែកញ្ញា ឆ្នាំ១៩៧៨ ទំព័រ ៣៦-៣៧ ERN (ភាសាខ្មែរ) 00289679-00289680 ("ពេលរដ្ឋប្រហារផ្ទុះឡើងនៅកម្ពុជា គណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជាកំពុងតែស្ថិតនៅក្នុងទីក្រុងប៉េកាំងនៅឡើយ។ ចំពោះព្រះអង្គម្ចាស់ នរោត្តម សីហនុ

បានព្រាងសារគាំទ្រសម្តេច នរោត្តម សីហនុ ក្នុងនាម ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ហើយបានឲ្យគេបញ្ជូនសារនោះជូនទៅសម្តេច នរោត្តម សីហនុ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧០ ដោយមិនបានមកជួបជាមួយសម្តេចផ្ទាល់ ឬបង្ហើបប្រាប់ថា គាត់កំពុងស្ថិតនៅក្នុងទីក្រុងប៉េកាំងដែរនោះទេ[២៦៨]។ ការរៀបរាប់នេះស្របគ្នាជាមួយនឹងការលើកឡើងរបស់ ខៀវ សំផន[២៦៩]។

៩៨. នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧០ សម្តេច នរោត្តម សីហនុ បានបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយ គឺរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ សម្តេចមានមុខនាទីជាប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាផងដែរ[២៧០]។ ខៀវ សំផន បានក្លាយជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះជាផ្លូវការ[២៧១]។ ខៀវ សំផន បានផ្តល់ចម្លើយថា ប៉ុល ពត បានតែងតាំងគាត់ឲ្យកាន់មុខតំណែងទាំងនេះដោយគាត់

---

ព្រះអង្គ បានយាងចេញពីទីក្រុងប៉ារីស ធ្វើដំណើរទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ទីក្រុងម៉ូស្គូ ហើយមកដល់ទីក្រុងប៉េកាំងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧០ [...] គណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជាបានពិនិត្យមើល និងកែប្រែកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិ ដែលរៀបចំឡើងដោយព្រះអង្គម្ចាស់ នរោត្តម សីហនុ [...] នេះជាមូលហេតុ ដែលសេចក្តីប្រកាសនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧០ បានប្រកាសផ្តន្ទាទោសការធ្វើរដ្ឋប្រហារថាជាអំពើក្បត់ជាតិ [...] មិនមានការចោទសួរអំពីសង្គមនិយម ឬកុម្មុយនីស្តឡើយនៅក្នុងឯកសារនោះ")។ សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ២០០, ៤៨៨ ERN (ភាសាអង់គ្លេស) 00396400, 00396704។

[២៦៨] អត្ថបទបោះពុម្ពផ្សាយដោយក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ៖ *សៀវភៅខ្មៅ* ឯកសារ E3/23 ចុះខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៣១, ៣៣ ERN (ភាសាខ្មែរ) 00289674, 00289676។ សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ២០០, ៤៨៨ ERN (ភាសាអង់គ្លេស) 00396400, 00396704។

[២៦៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦០-៦១។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៥១-១៦០ ERN (ភាសាខ្មែរ) 00380418-00380422។

[២៧០] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦១។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៧-៨, ៩-១០។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២ (អ៊ុង ចុងហឿង) ទំព័រ ១១-១២។ របាយការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា៖ *អាសនៈរបស់ប្រទេសកម្ពុជានៅអង្គការសហប្រជាជាតិ* ឯកសារ E3/28 ចុះឆ្នាំ 1973 ទំព័រ ២៤-២៧ ERN (ភាសាអង់គ្លេស) 00068116-00068117។

[២៧១] របាយការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា៖ *អាសនៈរបស់ប្រទេសកម្ពុជានៅអង្គការសហប្រជាជាតិ* ឯកសារ E3/28 ចុះឆ្នាំ 1973 ទំព័រ ១ ERN (ភាសាអង់គ្លេស) 00290197។

មិនដឹងខ្លួន ហើយមុខងារទាំងនេះគ្មានន័យអ្វីឡើយ[២៧២]។ ទោះបីជាយ៉ាងណាក្តី គាត់បានទទួលស្គាល់ថា គាត់បានបម្រើការងារជាអ្នកទំនាក់ទំនងរវាងសម្តេច នរោត្តម សីហនុ និង ប៉ុល ពត ដោយបានលើកឡើងថា "លុះត្រាខ្ញុំចេញមុខជាអ្នកដឹកនាំមួយសំខាន់នៃកម្លាំងតស៊ូនៅក្នុងប្រទេសតែម្តង។ ការពិតជាក់ស្តែង ខ្ញុំមិនមានតួនាទីជាអ្នកដឹកនាំអ្វីទាំងអស់។ នេះហើយដែលធ្វើឲ្យខ្ញុំមានការទើសទាល់ខ្លាំងណាស់។ តែសភាពការណ៍តម្រូវឲ្យខ្ញុំកាត់ខ្មាស់ កាត់អៀន សុខចិត្តធ្វើការ "លះបង់" ហើយបំពេញភារកិច្ចដើម្បីរួមចំណែកក្នុងការតស៊ូសង្គ្រោះជាតិតាមសមត្ថភាព និងសភាពការណ៍ជាក់ស្តែងរបស់ខ្ញុំ"[២៧៣]។ ខៀវ សំផន បានទទួលស្គាល់ថា ដោយសារថា សម្តេច នរោត្តម សីហនុ ពុំស្គាល់ ប៉ុល ពត ដូច្នេះគាត់ចាំបាច់ត្រូវទទួលបន្ទុកបង្កើតទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[២៧៤]។

៩៩. គោលនយោបាយជាផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺបង្រួបបង្រួម និងកៀងគរប្រជាជនគ្រប់ជាន់ថ្នាក់នៅក្នុងសង្គម និងដើម្បី "ផ្តួលរំលំរបបផ្តាច់ការហ្វាស៊ីស ពូជសាសន៍និយមនៃបរិវាររបស់ពួកចក្រពត្តិនិយមអាមេរិក ដែលដឹកនាំដោយ លន់ នល់ និងសិរិមតៈ"[២៧៥]។ រណសិរ្សរួបរួមជាតិកម្ពុជាក៏បានធានាផងដែរចំពោះជនកម្ពុជាទាំងអស់នូវសេរីភាពជាមូលដ្ឋាន រួមទាំងសេរីភាពសាសនានិងជំនឿផ្សេងៗទៀត[២៧៦]។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាពិសេស ខៀវ សំផន បានគាំទ្រជាផ្លូវការចំពោះចក្ខុវិស័យនេះ[២៧៧]។

---

[២៧២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦១។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00156616-00156617។

[២៧៣] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦១។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៤៥-៤៧ ERN (ភាសាខ្មែរ) 00103830-00103831។

[២៧៤] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសា ខ្មែរ) 00156615-00156616។

[២៧៥] កម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ឯកសារ E3/1391, ERN (ភាសាខ្មែរ) S 00722338។

[២៧៦] កម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ឯកសារ E3/1391, ERN (ភាសាខ្មែរ) S 00722341។ (គោលដៅរបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺកសាងកម្ពុជាមួយដែលប្រកបដោយលិទ្ធិប្រជាធិបតេយ្យ និងភាពរុងរឿង និងដើម្បីធានាចំពោះជនកម្ពុជាទាំងអស់ លើកលែងតែពួកក្បត់ជាតិដែលគេស្គាល់នៅទូទាំងប្រទេសនោះ នូវសេរីភាពក្នុងការនិយាយស្តី សេរីភាពក្នុងការបញ្ចេញមតិ ការចូលរួមនៅក្នុងសកម្មភាពនានា ក្នុងការធ្វើបាតុកម្ម ការតាំងទីលំនៅ ការធ្វើដំណើរទាំងនៅក្នុងស្រុក និងក្រៅប្រទេស ជាដើម [...] ការពារភាពមិនអាចរំលោភបំពានបានរបស់មនុស្ស

01006391



១០០. ជាក់ស្តែង ការងាររដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺគ្រាន់តែជាសំបកក្រៅប៉ុណ្ណោះ បើទោះបីជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬរណសិរ្សរួបរួមជាតិកម្ពុជា មានមុខងារឃោសនាមួយចំនួននៅក្រៅប្រទេសកម្ពុជាក៏ដោយ[២៧៨] ។ សួង ស៊ីគឿន បានផ្តល់សក្ខីកម្មថា សម្តេច នរោត្តម សីហនុ នៅរក្សាឥទ្ធិពលនៅក្រៅប្រទេស និងក្នុងទំនាក់ទំនងការទូត ចំណែកបក្សកុម្មុយនីស្តកម្ពុជាទទួលខុសត្រូវលើការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជា[២៧៩]។ជាឧទាហរណ៍ ក្នុងឆ្នាំ ១៩៧៣ សម្តេច នរោត្តម សីហនុ បានធ្វើព្រះរាជទស្សនកិច្ចទៅតំបន់រំដោះរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ការគាំទ្រដល់បក្សកុម្មុយនីស្តកម្ពុជាក្នុងការវាយប្រយុទ្ធជាមួយរបប លន់ នល់[២៨០]។ ក៏ប៉ុន្តែ បើយោងតាមសម្តេច នរោត្តម សីហនុ សម្តេចបានលះបង់ចោល

---

អចលនវត្ថុ ទ្រព្យសម្បត្តិ និងឯកជនភាពក្នុងការឆ្លើយឆ្លងព័ត៌មាន។ ធានាឲ្យបានសមភាពរវាងភេទទាំងពីរ [...] ព្រះពុទ្ធសាសនានៅតែជាសាសនារបស់រដ្ឋដដែល។ ប៉ុន្តែ រណសិរ្សរួបរួមជាតិកម្ពុជាទទួលស្គាល់ និងធានាដល់សេរីភាពនៃសាសនា និងជំនឿផ្សេងទៀតទាំងអស់[...]”)។

[២៧៧] របាយការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានចំណងជើងថា “អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ” ឯកសារ E3/28 ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៧៣ ERN (ភាសាអង់គ្លេស) 00068116-7។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២៦។ ខៀវ សំផន បានចេញផ្សាយសេចក្តីថ្លែងការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ មេសា ឆ្នាំ ១៩៧៥), ឯកសារ E3/118, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700268-00700269 ទំព័រ ២-៣ (“បច្ចុប្បន្នពួកក្បត់ជាតិទាំង ៧ នាក់ បានបោះបង់ចោលបងប្អូនហើយ។ បងប្អូនត្រូវតែដើរតាមផ្លូវដ៏មានកិត្តិយស និងសាមគ្គីភាពជាតិតាមរយៈការចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា [...] ដើម្បីកសាងប្រទេសជាតិឲ្យមានភាពថ្កើងថ្កើន ស្របតាមគោលនយោបាយឯករាជ្យភាព សន្តិភាព អព្យាក្រិតភាព អធិបតេយ្យភាព ប្រជាធិបតេយ្យ បូរណភាពទឹកដី និងមិនចូលបក្សសម្ព័ន្ធ”)។

[២៧៨] សូមមើលផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ២៣០-២៣៩ ។

[២៧៩] ប្រតិចារឹក ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៣; ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៤៨-៥០។

[២៨០] សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ ឯកសារ E3/9, ឆ្នាំ ២០០៤ ទំព័រ ២៤២ ដល់ ២៤៤ ERN (ភាសាអង់គ្លេស) 00396442-44។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ទំព័រ ១៩១-១៩២, ERN (ភាសាខ្មែរ) 00380455-00380456; ខ្សែវីដេអូរបស់ ខៀវ សំផន ដែលមានចំណងជើងថា “Justice Delayed, Justice Denied”, ឯកសារ E3/3902R (បង្ហាញពីខៀវសំផន និងនរោត្តម សីហនុ នៅក្នុងព្រៃ ក្នុងព្រះរាជទស្សនកិច្ចរបស់សីហនុ ក្នុងឆ្នាំ ១៩៧៣ ទៅកាន់តំបន់រំដោះ)។ ខ្សែវីដេអូរបស់ខៀវ សំផន ដែលមានចំណងជើងថា “Justice Delayed, Justice Denied”, ឯកសារ E3/3904R (បង្ហាញពី ខៀវ សំផន, ហ៊ូ នឹម ហៅ ភាស់, ហ៊ូ យន់ និង ប៉ុល ពត ព្រមទាំងសម្តេច នរោត្តម សីហនុ ក្នុងព្រះរាជទស្សនកិច្ចរបស់ សីហនុ ក្នុងឆ្នាំ ១៩៧៣ ទៅកាន់តំបន់រំដោះ)។

សិទ្ធិអំណាចទាំងអស់ដែលសម្តេចមានទៅឲ្យខ្មែរក្រហមអស់ហើយ ហើយសម្តេចនៅគង់ត្រឹមតែជានិមិត្តរូបនៃការរួបរួមជាតិតែប៉ុណ្ណោះ[២៨១]។ សម្តេចបានមានព្រះរាជបន្ទូលបញ្ជាក់ថា "ខ្ញុំប្រគល់អ្វីៗទាំងអស់ឲ្យទៅខ្មែរក្រហម [...] លោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអ្នកដឹកនាំក្រុមចលនាតស៊ូខ្មែរនៅនឹងកន្លែងផ្ទាល់ ដោយសហការជាមួយវៀតណាមខាងជើង និងពួកវៀតកុង"[២៨២]។ ជាផ្នែកមួយនៃការងាររបស់ខ្លួន រណសិរ្សរួបរួមជាតិកម្ពុជាបានបង្កើតស្ថានីយវិទ្យុ ដែលដឹកនាំដោយ អៀង ធីរិទ្ធ ដោយស្ថានីយនេះត្រូវបានប្រើប្រាស់សម្រាប់ការជ្រើសរើសកម្មាភិបាលបក្ស និងដើម្បីផ្សព្វផ្សាយការឃោសនាទាំងក្នុង និងក្រៅប្រទេសកម្ពុជា[២៨៣]។ បើទោះបីជាបទអត្ថាធិប្បាយនៅលើវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា ជាញឹកញាប់មិនបានលើកឡើងក៏ដោយ ប៉ុន្តែ ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍មួយចំនួនអំពីរណសិរ្សរួបរួមជាតិ-កម្ពុជា[២៨៤]។ ហេតុដូច្នេះ ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជាមានគោលបំណងដើម្បីបង្រួបបង្រួម

---

ខ្សែវីដេអូរបស់សម្តេច នរោត្តម សីហនុ ដែលមានចំណងជើងថា "Pol Pot et les Khmer Rouges", ឯកសារ E3/3942R (បង្ហាញពីសម្តេច នរោត្តម សីហនុ ជួបសួរសុខទុក្ខមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ ១៩៧៣ ហើយបាននិយាយថា "ខ្ញុំ នៅទីនេះ និយាយអំពីប្រទេសរបស់ខ្ញុំ ជាមួយអ្នកសហការណ៍របស់ខ្ញុំគឺលោក អៀង សារី ហៅវ៉ាន់)។

[២៨១] របាយការណ៍ដោយលោក L. Trivière: ប្រទេសចិន និង ប្រទេសកម្ពុជា ឯកសារ E3/482, ទំព័រ ២០ ERN (ភាសាខ្មែរ) 00538853 (នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៣ សម្តេច នរោត្តម សីហនុ បានប្រាប់ដល់អ្នកកាសែតចិន និងបរទេស ថា "ក្រោយពេលសង្គ្រាមចប់ទៅ ទ្រង់នឹងឋិតនៅជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ និងជាប្រមុខរដ្ឋដដែល តែទ្រង់នឹងមិនកាន់អំណាចដូចពេលមុនព្រឹត្តិការណ៍ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ នោះទៀតឡើយ។ គឺខ្មែរក្រហមនឹងជាអ្នកកាន់អំណាចពិតប្រាកដ សម្រាប់កិច្ចការសំខាន់ៗ") និងទំព័រ ២៦ ERN (ភាសាខ្មែរ) 00538859 (សម្តេច នរោត្តម សីហនុ បានឆ្លើយតបនៅក្នុងកិច្ចសម្ភាសន៍មួយថា "ខ្ញុំខំតស៊ូប្រយុទ្ធ ដើម្បីឲ្យពួកគេទុកកន្លែងមួយឲ្យខ្ញុំរស់នៅប្រទេសកម្ពុជា ជាមួយពួកគេ។ តើពួកគេនឹងទុកកន្លែងណាមួយឲ្យខ្ញុំ? ខ្ញុំចង់ដឹងថានៅក្នុងកែវភ្នែក ពួកគេ ពួកគេចាត់ទុកខ្ញុំជាអ្វី។ តើខ្ញុំគ្រាន់តែជាប្រជាពលរដ្ឋសាមញ្ញម្នាក់ ឬជាប្រមុខរដ្ឋ? ខ្ញុំសឹងតែលែងមានទំនាក់ទំនងជាមួយខ្មែរក្រហមទៀតហើយ")។

[២៨២] របាយការណ៍ដោយលោក L. Trivière: ប្រទេសចិន និង ប្រទេសកម្ពុជា ឯកសារ E3/482, ទំព័រ ១១ ERN (ភាសាខ្មែរ) 00538844។

[២៨៣] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (ឡុង នរិន្ទ) ទំព័រ ៦៤-៦៥, ៦៨-៦៩ (អៀង ធីរិទ្ធ ទទួលខុសត្រូវខាងវិទ្យុនៅទីក្រុង ហាណូយ)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៨១-៨៣ (អៀង ធីរិទ្ធ គឺជានាយក ខៀវ សំផន និងអៀង សារីមិនមានសិទ្ធិអំណាចលើស្ថានីយវិទ្យុនោះទេ)។

[២៨៤] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៦៩ (ខៀវ សំផន លើកទឹកចិត្តប្រជាជនឲ្យប្រមូលផ្តុំកម្លាំងទាំងនៅក្នុង និងក្រៅប្រទេស)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៥៣ (ខៀវ សំផន

ជនកុម្មុយនីស្តជាមួយនឹងសម្តេច នរោត្តម សីហនុ ហើយក៏ត្រូវប្រើប្រាស់ផងដែរដើម្បីទាក់ទាញកសិករជាច្រើនឲ្យចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា និងបុព្វហេតុរបស់ពួកគេ[២៨៥]។

១០១. ក្រោយពីបានសិក្សាទៅលើប្រវត្តិដើមរបស់បក្សកុម្មុយនីស្តកម្ពុជា និងបណ្តាហេតុការណ៍នានាដែលនាំទៅដល់សង្គ្រាមស៊ីវិលឆ្នាំ ១៩៧០ ដល់ ១៩៧៥ អង្គជំនុំជម្រះក្នុងពេលនេះនឹងពិនិត្យមើលលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងតំបន់ "រំដោះ" ដោយបក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ ១៩៧៥។

## ៣.៣ ការបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

១០២. យោងតាមដីកាដំណោះស្រាយ តាំងពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មក មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំ និងអនុវត្តការកែទម្រង់ជាបន្តបន្ទាប់ ដោយរួមបញ្ចូលទាំងការបង្កើតគោលនយោបាយទាំងប្រាំដែលជាកម្មវត្ថុនៃសំណុំរឿង ០០២៖

---

ជម្រុញឲ្យទាហាន លន់ នល់ ចូលរួមក្នុងបដិវត្ត)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៣-៤ (សេចក្តីថ្លែងការណ៍ពាក់ព័ន្ធជនក្បត់ទាំង ៧ នាក់ គឺជាអាវុធមុខពីរ ដែលចង់បង្ហាញថាអ្នកណាដែលមិនចូលរួមបដិវត្ត នឹងទទួលជោគវាសនាដូចគ្នា)។ មានការជំរុញឲ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារ ក្នុងពេលចូលឆ្នាំថ្មី (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស), ឯកសារ E3/30, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ERN (ភាសាខ្មែរ) 00783125។ ទូរលេខស្ថានទូតអាមេរិក, កម្មវត្ថុ៖ របាយការណ៍ស្ថានភាពប្រទេសកម្ពុជា ឯកសារ E3/3292, ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៧០ ERN (ភាសាខ្មែរ) 00726576។ទូរលេខស្ថានទូតអាមេរិក របាយការណ៍អំពីស្រុកខ្មែរ, ឯកសារ E3/3294, ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧១, ERN (ភាសាខ្មែរ) 00790035។

[២៨៥] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ( ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៩-១០។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៦០-៦៣។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន, ឯកសារ E3/27, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧, ទំព័រ ៤ ដល់ ៥, ERN (ភាសាខ្មែរ) 00156615-00156616។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ, ឯកសារ E3/16, ទំព័រ ១៥៨-១៥៩, ERN (ភាសាខ្មែរ) 00380420-00380421។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់, ឯកសារ E3/18, ឆ្នាំ ២០០៤, ទំព័រ ៤៥ ដល់ ៤៦ ERN (ភាសាខ្មែរ) 00103830-31។ ភាពយន្តឯកសារ ដោយ D. Aronowitsch និង S. Lindberg entitled "ប្រឈមមុខនិងអំពើប្រល័យពូជសាសន៍ - ខៀវ សំផន និង ប៉ុល ពត" ឯកសារ E3/4201R (ព្រមទាំងឯកសារ E109/2.3R)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ( ឆោម សែ) ទំព័រ ២៧-២៨។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆោម សែ ឯកសារ E3/405 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩, ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00401298-00401299។

១. ការផ្លាស់ទីលំនៅប្រជាជនជាច្រើនលើកច្រើនសាចេញពីទីប្រជុំជន ទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត។

២. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន។

៣. ការអប់រំ "សមាសភាពមិនល្អ" និងការកម្ទេច "ខ្មាំង" ទាំងនៅក្នុង និងនៅក្រៅបក្ស។

៤. ការកំណត់គោលដៅចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរដ្ឋការស៊ីវិល និង អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។

៥. ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[២៨៦] ។

១០៣. ក្នុងចំណោមគោលនយោបាយទាំងនេះ គោលនយោបាយចំនួនពីរដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ និងការកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការសាធារណរដ្ឋខ្មែរ គឺជាកម្មវត្ថុនៃការចោទប្រកាន់ ដែលត្រូវបានលើកយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បើទោះបីជាអត្ថិភាពនៃគោលនយោបាយដទៃទៀតក៏មានការពាក់ព័ន្ធក៏ដោយ[២៨៧]។

---

[២៨៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦ ដល់ ១៥៧, កថាខណ្ឌ ១៥២៤ ដល់ ១៥២៥។

[២៨៧] តាំងពីពេលចាប់ផ្តើមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានជម្រាបដល់ភាគីថា ភាគីអាចចាប់ផ្តើមលើភ័ស្តុតាងដែលពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំជាមូលដ្ឋាន ប៉ុន្តែអង្គជំនុំជម្រះនឹងពិនិត្យមើលតែលើការអនុវត្តគោល-នយោបាយណាដែលពាក់ព័ន្ធសំណុំរឿង ០០២/០១ ប៉ុណ្ណោះ (ឧទាហរណ៍ ការផ្លាស់ទីលំនៅដោយបង្ខំ និងការសម្លាប់ខ្មាំង)។ សូមមើលសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៨ ("ការដាក់បញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការសម្លាប់ដែលត្រូវបានប្រព្រឹត្តនៅឯទួលពោធិ៍ជ្រៃ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលពាក់ព័ន្ធ ដែលត្រូវបានចោទប្រកាន់ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ផ្តល់លទ្ធភាពឲ្យមានការពិនិត្យបានលើប្រធានបទចំនួន ០២ ក្នុងចំណោមប្រធានបទចំនួន០៥នៃដីការដំណោះស្រាយនៃសំណុំរឿង ០០២ ដែលរួមមានការជម្លៀសដោយបង្ខំ និងការសម្លាប់ខ្មាំងនៃរបបនោះ")។ សូមមើលផងដែរ ចម្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគី មុនពេលសវនាការ និងការកំណត់កាលបរិច្ឆេទកិច្ចប្រជុំក្រៅផ្លូវការជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារE141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៣ ("ទាក់ទិនការសួរដេញដោលទៅលើគោលនយោបាយផ្សេងៗក្រៅពីគោលនយោបាយដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ គោលបំណងនៃការបញ្ចូលការលើកឡើង គោលនយោបាយ

### ៣.៣.១ ការផ្លាស់ទីលំនៅប្រជាជនមុនឆ្នាំ ១៩៧៥

១០៤. នៅមុនឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការផ្លាស់ទីលំនៅប្រជាជននៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ គោលនយោបាយនេះត្រូវបានពន្យល់នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ចេញខែ កក្កដា ឆ្នាំ ១៩៧៣៖

> ក្នុងការជម្លៀសប្រជាជនពីតំបន់ខ្មាំង មកតំបន់រំដោះ បើយើងគ្មានទស្សនៈមហាជនរឹងប៉ឹងទេនោះមុខជាមិនហ៊ានដកប្រជាជនមកទេ ដោយខ្លាចប្រជាជនទ្រាំទ្រការលំបាក ខ្វះខាតសព្វគ្រប់មិនបាននេះម៉្យាង ហើយម៉្យាងទៀតខ្លាចប្រជាជនក្នុងតំបន់រំដោះ ធានារ៉ាប់រងជួយប្រជាជនជម្លៀសមិនបាន។ តែដោយយើងមានទស្សនៈមហាជនរឹងប៉ឹង ជឿជាក់លើមហាជន ប្រជាជនថាគេអាចធ្វើអ្វីៗបានទាំងអស់ ដូច្នេះទោះជាក្នុងសភាពដែលយើងកំពុងខ្វះខាតស្រូវអង្ករដូចសព្វថ្ងៃនេះក៏ដោយក៏យើងហ៊ានដកប្រជាជនមកច្រើនថែមទៀត។ តាមពិសោធន៍មកនេះ ឃើញថាប្រជាជនអាចដោះស្រាយបាន។[២៨៨]

---

ផ្សេងៗទៀតទាំងនោះនៅក្នុងសវនាការដំណាក់កាលដំបូង គឺដើម្បីឲ្យមានលទ្ធភាពបង្ហាញពីរបៀបដែលគោលនយោបាយ ត្រូវបានបង្កើតឡើង។ ដូច្នេះអ្វីដែលរំពឹងទុកគឺការបង្ហាញជាទូទៅពីគោលនយោបាយទាំងប្រាំ ទោះបីជាបញ្ហាជាក់ស្តែងសម្រាប់ស្នួរដេញដោល នៅក្នុងសវនាការដំណាក់ដំបូងត្រូវបានកម្រិតនៅត្រឹមការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និង ទី ២) យ៉ាងណាក៏ដោយ។ ដូច្នេះនឹងមិនមានការពិនិត្យលើការអនុវត្តគោលនយោបាយផ្សេងៗ ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី ១ និងទី ២) ឡើយ”)។ អត្ថិភាពនៃគោលនយោបាយដទៃទៀត ត្រូវបានត្រួតពិនិត្យជាលក្ខណៈមូលដ្ឋានតែប៉ុណ្ណោះ។ ការអនុវត្តគោលនយោបាយទាំងនោះ នឹងក្លាយជាប្រធានបទនៃសវនាការនៅពេលអនាគត។ សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៨៤-៨៥ ។

[២៨៨] ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/785, ចុះខែ កក្កដា ឆ្នាំ ១៩៧៣, ទំព័រ ១៦-១៧ ERN (ភាសាខ្មែរ) 00442035-00442036។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពាក្យ “ជម្លៀស” ត្រូវបានខ្មែរក្រហមខ្លួនឯងប្រើ ដើម្បីពិពណ៌នាអំពីគោលនយោបាយរបស់ពួកគេផ្ទាល់តែម្តង។ ទោះបីជាពាក្យនេះសំដៅទៅលើគំនិតនៃការបញ្ជូនប្រជាជនចេញពីកន្លែងគ្រោះថ្នាក់ ឬការផ្តល់ទីកន្លែងមានសុវត្ថិភាពក៏ដោយ តែអង្គជំនុំជម្រះប្រើពាក្យនេះដើម្បីពិពណ៌នាអំពីការផ្លាស់ទីលំនៅប្រជាជនចេញពីទីប្រជុំជន ជាពិសេស ពីទីក្រុងភ្នំពេញ។ ការវាយតម្លៃត្រឹមត្រូវទៅលើការផ្លាស់ទីលំនៅ មាននៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះមិនយកការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហមនេះនោះទេ។

១០៥. ហេតុដូច្នេះ កងទ័ពខ្មែរក្រហមបានផ្លាស់ទីប្រជាជនចេញពីតំបន់ដែលគ្រប់គ្រងដោយខ្មាំងទៅទីជនបទ បើទោះជាមានការខ្វះអង្ករក្តី។ អ្នកជំនាញ Philip SHORT បានពន្យល់ថា ចាប់តាំងពីឆ្នាំ ១៩៧០ អ្នកភូមិ ដែលរស់នៅក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហម ត្រូវបានគេផ្លាស់ទី និងបញ្ជូនទៅតំបន់ភ្នំ និងតំបន់ព្រៃដាច់ស្រយាល។ "ទោះបីជាផ្ទះសម្បែងរបស់ពួកគេមិនត្រូវបានបំផ្លាញក៏ដោយ ក៏ត្រូវបានគេដុតចោលដែរ ដើម្បីកុំឲ្យពួកគេត្រឡប់មកវិញ [...] ពួកគេត្រូវបានបង្ខំឲ្យចូលក្នុងសហករណ៍ ដែលមានគ្រួសារប្រហែលសាមសិបទៅសែសិបគ្រួសារ ដើម្បីបង្កបង្កើនផលរួមគ្នា"[២៨៩]។

១០៦. ជាឧទាហរណ៍ ទីរួមខេត្តក្រចេះត្រូវបានខ្មែរក្រហមកាន់កាប់ប្រហែលជារយៈពេលពីរខែក្រោយពីសម្តេច នរោត្តម សីហនុ ត្រូវបានទម្លាក់ពីតំណែង ហើយក្រោយមកបានជម្លៀសប្រជាជនក្នុងឆ្នាំ ១៩៧៣[២៩០]។ សាក្សី យុន គីម បានរម្លឹកថា ដំបូងបណ្តាផ្សារនៅក្នុងក្រុងមិនទទួលរងការប៉ះពាល់នោះទេ ហើយពាណិជ្ជកម្មនៅតែបន្ត[២៩១]។ ប៉ុន្តែមានការពន្យល់នៅក្នុងទស្សនាវដ្តីទង់បដិវត្តខែ សីហា ឆ្នាំ ១៩៧៥ ថា ផ្សារក្រចេះមិនត្រូវបានអនុញ្ញាតឲ្យបន្តទៅទៀតបានទេ ព្រោះ "ពាណិជ្ជកម្មនេះបម្រើជីវភាពប្រជាជនអត់បាន បម្រើសង្គ្រាមរំដោះជាតិអត់បាន។ ឃើញច្បាស់ដល់កណ្តាលឆ្នាំ ៧៣ យើងចេញមិនរួចទេ។ ប្រមូលប្រជាជនអត់បានទេ។ គឺឈ្មួញធ្វើម្ចាស់"[២៩២]។ ដូច្នេះ ដំណោះស្រាយគឺត្រូវដាក់ប្រជាជនឲ្យនៅរួមគ្នា ។ បន្ទាប់ពីប្រជាជនត្រូវបានប្រមូលផ្តុំជាសមូហភាព ហើយការហូបរួមបានចាប់ផ្តើម រូបិយប័ណ្ណត្រូវបានបញ្ឈប់លែងឲ្យចរាចរ ផ្សារនានានៅក្នុងខេត្តក្រចេះត្រូវបានបិទ ហើយប្រជាជននៅទីរួមខេត្តក៏ត្រូវបានជម្លៀសផងដែរ[២៩៣]។

---

[២៨៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៦-៦៧ (បញ្ជាក់ពីភាពត្រឹមត្រូវផ្នែកដែលពាក់ព័ន្ធ លើកលែងតែចំណុចដែលមានក្នុងសៀវភៅរបស់គាត់)។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ, ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ ២៤៦, ERN (ភាសាអង់គ្លេស) 00396446។

[២៩០] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៤។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៦។

[២៩១] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៤-២៥។

[២៩២] ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/5 ចុះខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063319-00063320។

[២៩៣] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៦។

១០៧. ជាឧទាហរណ៍មួយផ្សេងទៀត សាក្សី François PONCHAUD បានផ្តល់សក្ខីកម្មពីការផ្លាស់ទីប្រជាជននៅខេត្តកំពង់ចាមក្នុងឆ្នាំ ១៩៧៣ ជាកន្លែងដែលគាត់រស់នៅកាលពីមុនឆ្នាំ ១៩៧០[២៩៤]។ ផ្អែកតាមព័ត៌មានពីអ្នកភូមិដែលត្រូវបានបណ្តេញចេញពីផ្ទះសម្បែងរបស់ខ្លួន សាក្សីបានផ្តល់សក្ខីកម្មថា នៅពេលដែលកងទ័ពខ្មែរក្រហមកាន់កាប់ភូមិមួយបាន ផ្ទះសម្បែងនៅក្នុងភូមិនោះត្រូវបានគេដុត ហើយមេឃុំត្រូវបានគេសម្លាប់ ឯប្រជាជនត្រូវបានគេជម្លៀសចូលទៅក្នុងព្រៃ[២៩៥]។ ទោះបីជាសាក្សី ភី ភួន បានអះអាងថា ខ្មែរក្រហមគ្រប់គ្រងខេត្តកំពង់ចាមមិនបានយូរគ្រប់គ្រាន់ដែលអាចឲ្យជម្លៀសប្រជាជនចេញបាន ហើយប្រជាជនបានត្រឡប់មកវិញភ្លាមៗបន្ទាប់ពីខ្មែរក្រហមដកចេញក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនេះមិនអាចជឿជាក់បានឡើយទាក់ទងនឹងបញ្ហានេះ[២៩៦]។ ទស្សនៈរបស់គាត់គឺជាការប៉ាន់ស្មាន និង ខុសប្លែកទាំងស្រុងពីព័ត៌មានលម្អិតនានាស្តីពីការផ្លាស់ទីលំនៅប្រជាជន[២៩៧]។

---

[២៩៤] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១១, ៥០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៤-៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី François PONCHAUD ឯកសារ E3/370 ERN (ភាសាខ្មែរ) 00286607-00286609 ទំព័រ ៧-៩ ។ ខុសពីសាក្សីជាជនបរទេសផ្សេងទៀត លោក François Ponchaud បានផ្តល់សក្ខីកម្មភាគច្រើនជាភាសាខ្មែរ។ ដោយមានការព្រួយបារម្ភអំពីគុណភាពនៃការបកប្រែផ្ទាល់មាត់អំពីសក្ខីកម្មរបស់គាត់ (សូមមើល ឧ.ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៦៦) អង្គភាពបកប្រែភាសារបស់ អ.វ.ត.ក បានពិនិត្យឡើងវិញនូវសក្ខីកម្មរបស់គាត់ ហើយថ្មីៗនេះបានកែប្រែប្រតិចារឹកពាក់ព័ន្ធ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការកែប្រែទៅលើផ្នែកផ្សេងៗនៃប្រតិចារឹកដែលត្រូវបានដកស្រង់នៅក្នុងសាលក្រមនេះ ទំនងជាគ្មានផលប៉ះពាល់លើខ្លឹមសារនៃភស្តុតាងនោះទេ។ យ៉ាងណាក៏ដោយ អង្គជនុំជម្រះពឹងផ្អែកទៅលើភាសាដើមនៃសក្ខីកម្ម ក្នុងករណីមានមន្ទិលសង្ស័យណាមួយ"។

[២៩៥] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤៣-៤៤ ។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២-៣។

[២៩៦] ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម គុន) ទំព័រ ២៨។

[២៩៧] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៦-៦៧។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ, ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ 257, ERN (ភាសាអង់គ្លេស) 00396465 (ពិភាក្សាពីការជម្លៀសប្រជាជនចំនួន ១៥,០០០ នាក់ ពីខេត្តកំពង់ចាម នៅឆមាសទីពីរ ឆ្នាំ ១៩៧៣ ដោយបញ្ជាក់ថាអ្នកខ្លះស្លាប់ដោយសារការអត់អាហារ ព្រមទាំងដោយសារការទម្លាក់គ្រាប់បែកនៅតាមផ្លូវ ប៉ុន្តែប្រជាជនភាគច្រើនបានតាំងទីលំនៅឡើងវិញនៅក្នុងភូមិ ដែលកសិករបានបានរៀបរាប់ថា "ពួកគេរស់នៅក្នុងជីវភាពធម្មតា")។ ជីវប្រវត្តិ កែ ពក ពីឆ្នាំ ១៩៥៧ រហូតដល់បច្ចុប្បន្ន ឯកសារ E3/2782, ERN (ភាសាខ្មែរ) 00095549-00095550 (ពន្យល់ថាមានការវាយប្រហាជាពីរមុខព្រួញយកខេត្តកំពង់ចាម ប៉ុន្តែកងទ័ពកុយ ធួន មិនបានវាយ ទើបពួកគេមិនអាចរំដោះក្រុង

១០៨. យុទ្ធសាស្ត្រនៃការជម្លៀសនៅតំបន់រំដោះត្រូវបានពន្យល់បន្ថែមនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ខែ ធ្នូ ឆ្នាំ ១៩៧៦៖

> នៅក្នុងសាកលលោកគេមិនដែលដណ្ដើមប្រជាជនទេ។ មាគ៌ាយើងគឺដណ្ដើមប្រជាជន ម្នាក់ក៏យក ពីរនាក់ក៏យក មួយរយនាក់ក៏យក មួយពាន់នាក់ក៏យក រហូតដល់ដណ្ដើមប្រជាជនពីភ្នំពេញទៀត។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងរបស់បក្ស គឺត្រឹមត្រូវណាស់។ [...] បើខ្មាំងគ្មានប្រជាជន វាគ្មានកម្លាំងយោធា គ្មានកម្លាំងសេដ្ឋកិច្ច។ ហេតុផលយើងត្រឹមត្រូវ។ ដូច្នេះមាគ៌ាយើងត្រឹមត្រូវណាស់។ កន្លែងណាក៏យើងវាយដណ្ដើមប្រជាជនដែរ[២៩៨]។

---

កំពង់ចាមបានទាំងស្រុង ហើយក៏ឡោមព័ទ្ធចោលទៅ)។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ W. Shawcross: ករណីបន្ទាប់បន្សំ៖*Kissinger, Nixon* និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា,ឯកសារ E3/88, ឆ្នាំ ១៩៩១, ទំព័រ ៣១២ (“នៅថ្ងៃបន្ទាប់ពីការទម្លាក់គ្រាប់បែករបស់អាមេរិកបានបញ្ចប់ ពួកកុម្មុយនីស្ដបានបើកការវាយប្រយុទ្ធទៅលើទីរួមខេត្តកំពង់ចាម ដែលជាផ្លូវ និងជាទីប្រសព្វទន្លេដ៏សំខាន់នៅភាគឦសាននៃទីក្រុងភ្នំពេញ។ ពេញមួយរដូវក្ដៅ ពួកគេបានរំកិលបន្ទាយដើម្បីការពារការឆ្ពោះទៅកាន់ទីរួមខេត្ត តាមផ្លូវជាតិលេខ ៦ និង លេខ ៧។ ឥឡូវនេះពួកគេបានកាន់កាប់ទីរួមខេត្តមួយភាគធំ ហើយនាំប្រជាជន ១៥ 000 នាក់ ទៅកាន់ទីជនបទ ព្រមទាំងស្ថិតនៅចម្ងាយប្រហែលមួយរយម៉ែត្រពីភូមិគ្រឹះចៅហ្វាយខេត្ត។ [...] បន្ទាប់ពីការវាយប្រយុទ្ធបង្ហូរឈាមអស់រយៈពេលយ៉ាងយូរនៅតាមដងផ្លូវរួចមក ពួកកុម្មុយនីស្ដជាចុងក្រោយបានដកថយ។ នៅពេលក្រោយមក សីហនុ បានតវ៉ាយ៉ាងខ្លាំងថា បើកុំដោយសារតែពួកហាណូយក្បត់ រារាំងការផ្គត់ផ្គង់ ម្ល៉េះទីរួមខេត្តនេះនឹងត្រូវបានកាន់កាប់”)។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ, ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ 246, ERN (ភាសាអង់គ្លេស) 00396446 (បានដកស្រង់ពីមន្ត្រីកុងស៊ុលអាមេរិកម្នាក់ នៅប្រទេសវៀតណាម ដែលបានបញ្ជាក់ដោយផ្អែកលើមូលដ្ឋាននៃការសម្ភាសន៍ជាមួយជនភៀសខ្លួន ដែលរត់គេចពីការផ្លាស់ទីលំនៅ ក្នុងឆ្នាំ ១៩៧៣ អំពី “រឿងរ៉ាវដែលរៀបរាប់ដោយអ្នកនៅរស់រានពីការផ្លាស់ទីលំនៅពេលមុន ដែលបាននិយាយប្រាប់ពីមនុស្សដែលបានស្លាប់តាមផ្លូវ និងស្លាប់ដោយពលកម្មដោយបង្ខំបន្ទាប់ពីមកដល់ទីកន្លែង”)។

[២៩៨] ទស្សនាវដ្ដីទង់បដិវត្ត ឯកសារ E3/25, ចុះខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៣៩ ដល់៤០ ERN (ភាសាខ្មែរ) 00063038-00063039។ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ អង្គភាពបកប្រែភាសារបស់ អក .ត.វ. បានប្ដូរឃ្លាការបកប្រែឯកសារនេះ ដោយបានកែប្រែ“seize the people” ទៅជា “capture the people”។ លើសពីនេះទៀត ពាក្យ “drying up the people” ត្រូវបានប្ដូរទៅជា “taking away the people”។ អង្គជំនុំជម្រះបានពឹងផ្អែកទៅលើសំណៅឯកសារដើមជាភាសាខ្មែរ ដែលមិនមានការកែប្រែទេ ប៉ុន្តែ អង្គជំនុំជម្រះបានយោងទៅលើឯកសារបកប្រែជាភាសាបារាំង និងអង់គ្លេស ដែលត្រូវបានកែប្រែរួចនៅក្នុងសាលក្រមនេះ។

១០៩. ក្នុងទស្សនាវដ្តីទង់បដិវត្តដដែលនេះ មានការដកស្រង់យកបាណាមធ្វើជាឧទាហរណ៍នៃការអនុវត្តយុទ្ធសាស្ត្រនេះ៖ “ការវាយ [...] នៅក្រុងបាណាម បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលីស យកទាំងអស់។ ពង្រឹងប្រជាជនពីខ្មាំង”[២៩៩]។

១១០. មានការបកស្រាយផ្សេងៗគ្នាជាច្រើនចំពោះអត្ថន័យ “ដណ្តើមប្រជាជន”។ តាមទស្សនៈរបស់អ្នកជំនាញ លោក Philip SHORT “ការដណ្តើមប្រជាជន” មានន័យថា ធ្វើការត្រួតត្រាទៅលើប្រជាជន ជាជាងត្រួតត្រាទៅលើទឹកដី ហើយលោកបានរម្លឹកពីវិធីសាស្ត្រដូចគ្នានេះ ដែលត្រូវបានប្រើពីមុនមកដោយពួកកុម្មុយនីស្តក្នុងប្រទេសចិន[៣០០]។ សាក្សី Stephen HEDER បានកត់សម្គាល់ថា “ដណ្តើមប្រជាជន” អាចមានន័យត្រង់ថា ចាប់យកក្រុមប្រជាជន ប៉ុន្តែលោកបញ្ជាក់ថា វាក៏អាចមានន័យថាជាការផ្លាស់ប្តូរលើការត្រួតត្រា ឬគ្រប់គ្រងទៅលើតំបន់វាយប្រយុទ្ធដែរ[៣០១]។ នួន ជា បានយល់ស្របជាមួយការបកស្រាយក្រោយនេះ ដោយបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាចាំបាច់ត្រូវរៀបចំប្រជាជនឲ្យស្ថិតក្នុងបែបបទសេដ្ឋកិច្ចដែលត្រូវបានបង្កើតថ្មី[៣០២]។ ស្របជាមួយការបកស្រាយរបស់ នួន ជា នោះ ប៉ុល ពត បានពន្យល់ដល់ ខៀវ សំផន ថា ការបណ្តេញចេញឲ្យអស់ពីទីក្រុង គឺជាផ្នែកមួយនៃគោលនយោបាយសមូហភាវូបនីយកម្ម ដែលមានតាំងពីមុនសង្គ្រាម ដែលធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាអាចរក្សាបានការគ្រប់គ្រងទៅលើការផ្គត់ផ្គង់ស្រូវ[៣០៣]។ យោងតាម ប៉ុល ពត លទ្ធភាពរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការគ្រប់គ្រងលើការផ្គត់ផ្គង់ស្រូវ បានបង្ខំឲ្យវៀតណាមត្រូវគោរពអធិបតេយ្យភាពរបស់កម្ពុជា នៅពេលដែលកងទ័ពវៀតណាមធ្វើប្រតិបត្តិការ

---

[២៩៩] ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/25, ខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៤០ ERN (ភាសាខ្មែរ) 00063039។

[៣០០] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៤៩-៥១។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត, ឯកសារ E3/1762, ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧, ទំព័រ ២, ERN (ភាសាខ្មែរ) 00752090 (“ដោយយកគំរូតាមយុទ្ធសាស្ត្ររបស់ម៉ៅ បក្សកុម្មុយនីស្តកម្ពុជា បានសម្រេចឡោមព័ទ្ធទីក្រុង ចេញពីជនបទ”)។

[៣០១] ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ១៦-១៧។

[៣០២] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា កថាខណ្ឌ ២៥៥ ដល់ ២៥៦។ សារណានេះស៊ីសង្វាក់គ្នាជាមួយការបិទផ្សារនៅក្នុងខេត្តក្រចេះ ដូចបានពិភាក្សាខាងលើ។

[៣០៣] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់, ឯកសារ E3/18, ចុះខែ កក្កដា ឆ្នាំ ២០០៤, ទំព័រ ៦៣-៦៤, ERN (ភាសាខ្មែរ) 00103839-00103840។

នៅក្នុងប្រទេសកម្ពុជា[៣០៤]។ អង្គជំនុំជម្រះជឿជាក់ថា មានហេតុផលខាងផ្នែកសេដ្ឋកិច្ចសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុង ដើម្បីធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាអាចគ្រប់គ្រងទៅលើការផ្គត់ផ្គង់អាហារ ព្រមទាំងផ្តល់កម្លាំងពលកម្មទៅតាមវាលស្រែ[៣០៥]។

១១១. ទោះជាយ៉ាងណាក្តី ការជម្លៀសក៏ជាការវាយប្រហារទៅលើខ្មាំងផងដែរ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយតម្លៃរបស់អ្នកជំនាញលោក David CHANDLER អាចជឿជាក់បាន។ លោកបានកត់សម្គាល់ថា មានគំរូដដែលៗដូចគ្នាក្នុងគោលនយោបាយរបស់ខ្មែរក្រហម ដែលឈានដល់កម្រិតខ្ពស់បំផុតនៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនដទៃទៀត បន្ទាប់ពីជ័យជម្នះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ប្រជាជននៅក្នុងទីក្រុងត្រូវបានចាត់ទុកថាមិនស្មោះត្រង់ ហើយចាំបាច់ត្រូវតែដកចេញ[៣០៦]។ តាមប្រភពភស្តុតាងមួយចំនួនបានបង្ហាញថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចថា អ្នករស់នៅក្នុងទីក្រុងនៅតែពុករលួយ ទាំងផ្នែកនយោបាយ និងផ្នែកមនោគមន៍វិជ្ជា ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងទីក្រុង ហើយនឹងពិបាកក្នុងការគ្រប់គ្រង[៣០៧]។ ចំណុចនេះគឺជាជំនឿតាំងពីយូរមកហើយរបស់ នួន ជា ដែលបានពន្យល់ថា អ្នករស់នៅក្នុងទីក្រុងតាំងពីដើមរៀងមកជា "សង្គមពុករលួយ សង្គមស្រីញី ស្រា" ដែលផ្ទុយពីអ្នករស់នៅជនបទ អ្នករស់នៅក្នុងព្រៃ ដែលជាមនុស្ស "ស្អាតស្អំ"[៣០៨]។ ដូចបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ និងសក្ខីកម្មរបស់គាត់មុនៗបានបង្ហាញថា ប្រជាជនត្រូវបានគេ "ដណ្តើម" និង "ពង្រឹង" ពីខ្មាំង ដោយផ្លាស់ទីលំនៅប្រជាជនចេញពីតំបន់ទីក្រុង ដូចជានៅឧត្តុង្គ ក្រចេះ បាណាម និងកំពង់ចាម ទៅកាន់ទីជនបទ[៣០៩]។

---

[៣០៤] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់, ឯកសារ E3/18, ចុះខែ កក្កដា ឆ្នាំ ២០០៤, ទំព័រ ៦៣-៦៤, ERN (ភាសាខ្មែរ) 00103839-00103840។

[៣០៥] សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣-១១៦ ។

[៣០៦] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៣៩-៤១។

[៣០៧] សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ, ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ ២៥៦ ដល់ ២៥៧, ERN (ភាសាអង់គ្លេស) 00396456, 00396465។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៦។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន) ទំព័រ ១២-១៣។

[៣០៨] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦០។

[៣០៩] ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/25, ចុះខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៧, ទំព័រ ៦៩-៧២, ERN (ភាសាខ្មែរ) 00063039-00063041។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៤។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៩។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣

១១២. តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបណ្ដុះកំហឹងយ៉ាងខ្លាំងក្លា ក្នុងចំណោមអ្នកគាំទ្រខ្លួន ប្រឆាំងនឹងអ្នករស់នៅទីក្រុង[៣១០]។ ហេតុដូច្នេះ ការជម្លៀសចេញពីទីក្រុងបម្រើគោលដៅពីរ ដែលក្នុងនោះដើម្បីរារាំងខ្មាំងមិនឲ្យផ្ដួលកម្លាំងបក្សកុម្មុយនីស្តកម្ពុជា និងដើម្បីការពារកម្មាភិបាលមិនឲ្យពុករលួយតាមអ្នករស់នៅទីក្រុង[៣១១]។ ផ្អែកលើចំណុចខាងលើ អង្គជំនុំជម្រះយល់ថា គោលនយោបាយនៃការផ្លាស់ទីលំនៅម្ដងហើយម្ដងទៀត ពីទីប្រជុំជន និងទីក្រុងទៅកាន់ទីជនបទ បានកើតមានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ។ អង្គជំនុំជម្រះយល់ឃើញថា មានហេតុផលទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចនៅពីខាងក្រោយការផ្លាស់ទីលំនៅនេះ។

### ៣.៣.២ ការបង្កើតសហករណ៍ និងការដ្ឋាន មុនខែ មេសា ឆ្នាំ ១៩៧៥

១១៣. នៅក្នុងដំណើរការមួយដែលបានផ្ដួចផ្ដើមឡើងកាលពីខែ ឧសភា ឆ្នាំ ១៩៧២ ហើយត្រូវបានអនុម័តជាផ្លូវការមួយឆ្នាំក្រោយមកនោះ គណៈកម្មាធិការមជ្ឈិមបានសម្រេចបិទផ្សារនៅក្នុងតំបន់រំដោះ ហើយបង្កើតសហករណ៍ដើម្បី "វាយអានុភាពរបស់វណ្ណៈសក្ដិភូមិ-ម្ចាស់ដី និងវណ្ណៈនាយទុន និងដើម្បីលុបបំបាត់ជំនួញឯកជន"[៣១២]។ ដំណើរការនៃការបង្កើតសហករណ៍ជាបណ្ដើរៗ មានភាពខុសគ្នានៅតាមភូមិភាគ ព្រមទាំងនៅកម្រិតសហករណ៍ ប៉ុន្តែគោលដៅចម្បងគឺ

---

(François PONCHAUD) ទំព័រ ៤៣។ ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣៤។

[៣១០] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៣២។

[៣១១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ោម គុន) ទំព័រ ២៧-២៨, ៥៥-៥៦ (គាត់ដឹងអំពីបញ្ហានេះនៅក្នុងវគ្គរៀនសូត្រ ដែលដឹកនាំដោយ ប៉ុល ពត នួន ជា ឬ ខៀវ សំផន ដែលបានពិភាក្សាពីបទពិសោធន៍ជាវិជ្ជមានរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសដោយបង្ខំ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ោម គុន) ទំព័រ ២១ (ដើម្បីប្រយុទ្ធនឹងពួកចក្រពត្តិអាមេរិក និងរបបពួកវា ប្រជាជនទាំងអស់ត្រូវតែដាច់ខាត និងប្ដេជ្ញាថា "យើង" មិនឲ្យពួកចក្រពត្តិអាមេរិកទិញបានឡើយ៖ "យើងត្រូវតែជាបុគ្គលស្អាតស្អំ ត្រឹមត្រូវ ដើម្បីសម្រេចជោគជ័យនេះ")។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៨៩-៩០ (ក៏បានដឹងពីទស្សនាវដ្ដីទង់បដិវត្តថា ប្រជាជនត្រូវបានគេជម្លៀសដើម្បីធានាថា នៅពេលដែលខ្មាំងវាយប្រយុទ្ធ ពួកខ្មាំងនឹងមិនមានប្រជាជនដើម្បីគាំទ្រពួកវា ដូច្នេះខ្មាំងនឹងឯកោ ហើយគ្មានអ្នកជួយ)។

[៣១២] ខួបឆ្នាំទី ៣ នៃការចាត់តាំង សហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00442208-00442209។ ទស្សនាវដ្ដីទង់បដិវត្ត ឯកសារ E169/4/1.1.2, ចុះ ខែ ធ្នូ ឆ្នាំ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៦, ទំព័រ ៣៤-៣៥, ERN (ភាសាខ្មែរ) 00809847-00809848។ ទស្សនាវដ្ដីទង់បដិវត្ត ឯកសារ E3/10 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦, ទំព័រ ១៧-១៨ ERN (ភាសាខ្មែរ) 00063071-00063072។

ដើម្បីលុបបំបាត់កម្មសិទ្ធិឯកជនលើដីធ្លី ព្រមទាំងមធ្យោបាយផលិតកម្ម ហើយដាក់ជំនួសដោយប្រព័ន្ធកម្មសិទ្ធិសហករណ៍ ដោយរដ្ឋជាអ្នកគ្រប់គ្រងទាំងស្រុងទៅលើពាណិជ្ជកម្ម និងការអនុវត្ត "បដិវត្តប្រជាធិបតេយ្យដាច់ខាត"[៣១៣]។ បក្សកុម្មុយនីស្តកម្ពុជាបានចែកផ្សាយសារាចរហាមឃាត់ប្រជាជនមិនឲ្យលក់អាហារ និងគ្រឿងផ្គត់ផ្គង់នានាទៅឲ្យពួកខ្មាំង ហើយបានបញ្ជូនពួកគាត់ឲ្យទៅដាំដុះកសិផលជាសមូហភាព[៣១៤]។ ក្នុងឆ្នាំ ១៩៧២ ដល់ ១៩៧៣ សហករណ៍ត្រូវបានបង្កើតឡើងនៅតាមតំបន់មួយចំនួន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក្នុងករណីខ្លះទៀត ការបង្កើតសហករណ៍នេះគឺផ្អែកទៅលើបញ្ហាពីខាងតំបន់[៣១៥]។ ដំណើរការនេះកាន់តែវិវឌ្ឍទៅមុខ ជាឧទាហរណ៍ ដូចដែលបានពិភាក្សាដោយលម្អិតនៅផ្នែកខាងក្រោមនេះ នៅក្នុងខែ មីនា ឆ្នាំ ១៩៧៤ ទីប្រជុំជនឧត្តុង្គត្រូវបានខ្មែរក្រហមកាន់កាប់ ហើយមានប្រជាជនប្រហែល ១៥.០០០ នាក់ ទៅ ២០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ និងបញ្ជូនទៅតាំងទីលំនៅឡើងវិញនៅក្នុងសហករណ៍[៣១៦]។

១១៤. ស្របជាមួយនឹងការត្រួតត្រាទៅលើសេដ្ឋកិច្ចនោះ ប្រព័ន្ធដោះដូរដែលត្រូវបានប្រើប្រាស់ច្រើនបានចាប់ផ្តើមឡើង ហើយការប្រើប្រាស់រូបិយប័ណ្ណរបប លន់ នល់ ត្រូវបានរារាំងដោយផ្នែក ឬត្រូវហាមឃាត់តែម្តង[៣១៧]។ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់ចេញនូវលក្ខខណ្ឌការងារដែលមានលក្ខណៈកាន់តែលំបាកខ្លាំងឡើងៗទៅលើសមាជិកសហករណ៍[៣១៨]។ ផ្អែកតាមចម្លើយ

---

[៣១៣] ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/5 ចុះខែ សីហា ឆ្នាំ ១៩៧៥, ទំព័រ ៣-១៧, ERN (ភាសាខ្មែរ) 00063313-00063320។

[៣១៤] ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/783, ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧២, ទំព័រ ១៣-១៤, ERN (ភាសាខ្មែរ) 00442294-00442295។

[៣១៥] ប្រតិចារឹក ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ទំព័រ ៦៧-៦៩។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ២២-២៥។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស្ទួ) ទំព័រ ៧-៨។ ប្រតិចារឹក ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៧-៨។

[៣១៦] ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៥៨-៥៩។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៤។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ 257, ERN (ភាសាអង់គ្លេស) 00396465។

[៣១៧] ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Phillip SHORT), ទំព័រ ៧២-៧៣។ ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/5 ចុះខែ សីហា ឆ្នាំ ១៩៧៥, ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00063316។

[៣១៨] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ២៨-៣០ (សហករណ៍ត្រូវបានបង្កើតឡើងក្នុងតំបន់ ១០៥ តាំងពីមុនរំដោះភ្នំពេញ ដែលនៅទីនោះ ប្រជាជនហូបរួម ហើយធ្វើការជាសមូហភាព)។ ប្រតិចារឹក ថ្ងៃទី ១៧

កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអ្នកបង្កើតសហករណ៍មន្ទីរ ម-១៣ ខ សម្រាប់ដាក់អ្នកដែលមានការសង្ស័យ និងអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសតូចតាច[៣១៩] បក្សកុម្មុយនីស្ត-កម្ពុជាតម្រូវឲ្យអ្នកនៅក្នុងសហករណ៍ធ្វើការដប់ម៉ោងក្នុងមួយថ្ងៃ ហើយប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍[៣២០]។

១១៥. អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មផ្ទុយពីនេះទាក់ទងទៅនឹងគោលបំណងដែលនៅពីក្រោយការបង្កើតសហករណ៍នេះ។ នួន ជា បានទទួលស្គាល់ថា ក្នុងអំឡុងឆ្នាំ ១៩៧២ គណៈកម្មាធិការ-

---

ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៦២-៦៣ យោងទៅលើសៀវភៅនិពន្ធដោយ S. Heder, កុម្មុយនីស្តកម្ពុជា និងគំរូរបស់វៀតណាម, ឯកសារ E3/22, ទំព័រ ១៦៩, ERN (ភាសាអង់គ្លេស)00393932, ជើងទំព័រ 84 (បក្សកុម្មុយនីស្តកម្ពុជាកាន់តែកាចសហាវ និងគាបសង្កត់ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៣ ដោយទាមទារឲ្យមានសហ-ករណ៍កសិកម្ម នៅក្នុងភូមិភាគដែលខ្លួនកាន់កាប់ កាត់បន្ថយការគោរពសាសនា និងរឹតបន្តឹងលើការផ្លាស់ទីរបស់អ្នកភូមិ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ១៤-១៥ (ជាពិសេសក្រោយឆ្នាំ ១៩៧៣ ឯកសារចារកម្មអាមេរិកបានបង្ហាញថា ស្ថានភាពមានការលំបាក នៅក្នុងតំបន់ខ្មែរក្រហម ហើយប្រជាជនព្យាយាមរត់គេច)។ សៀវភៅនិពន្ធដោយ D. Chandler: ប្រវត្តិសាស្ត្រខ្មែរ, ឯកសារ E3/1686, ឆ្នាំ ២០០០, ទំព័រ ២២៧-២២៨, ERN (ភាសាខ្មែរ) 00679168-00679169 (នៅដើមឆ្នាំ ១៩៧៣ អាជ្ញាធរនៅរាជធានីភ្នំពេញបានដឹងថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានសហករណ៍ជាលក្ខណៈដាច់ខាត ដោយមានពាក្យចចាមអារាមថា គ្មានការយោគយល់ឡើយ ដោយពួកអ្នកប្រយុទ្ធបានគៀរអ្នកភូមិចូលទៅក្នុងព្រៃ គ្រប់ពេលដែលពួកគេវាយកាន់កាប់បានភូមិ ឬទីប្រជុំជនណាមួយ)។ អត្ថបទសម្ភាសន៍ជាមួយ ប៊ុន ឡឹងចូយ, ឯកសារ E3/5636, ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០១ ទំព័រ ៧ ERN (ភាសាខ្មែរ) 00042464 (ចាប់តាំងពីឆ្នាំ ១៩៧៣ ទ្រព្យសម្បត្តិឯកជន ត្រូវបានផ្ទេរទៅជាកម្មសិទ្ធិរួម)។ សៀវភៅនិពន្ធដោយ N. Chanda: សត្រូវបងប្អូនឯង៖ បន្ទាប់ពីសង្គ្រាម មានសង្គ្រាម, ឯកសារ E3/2376 ឆ្នាំ ១៩៨៦ ទំព័រ ៧៩-៨០ ERN (ភាសាខ្មែរ) 00191384-00191385 (នៅពាក់កណ្តាលឆ្នាំ១៩៧៣ កម្មសិទ្ធិឯកជនដីធ្លី និងការប្រើប្រាស់រូបិយប័ណ្ណ ត្រូវបានលប់បំបាត់ចោល។ សហករណ៍កសិកម្មបានចាប់ផ្តើម ហើយពាណិជ្ជករ និង អ្នកនេសាទវៀតណាម ត្រូវបានបណ្តេញចេញពីកម្ពុជា។ ប្រជាជនវៀតណាមទាំងឡាយណាដែលនៅបន្តរស់នៅក្នុងកម្ពុជា ត្រូវបានបង្ខំឲ្យចូល សហករណ៍ ដែលយោងតាមសីហនុ សហករណ៍នេះគឺសឹងតែជាជំរុំប្រមូលផ្តុំ)។ សៀវភៅនិពន្ធដោយ B. Kiernan: តើប៉ុល ពត ចូលកាន់អំណាចបែបណា? ដើមកំណើតកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ១៩៣០-១៩៧៥ ឯកសារ E3/1815, ឆ្នាំ ១៩៨៥, ទំព័រ ៣៩៥-៣៩៦, ERN (ភាសាខ្មែរ) 00104870-00104871 (កសិករម្នាក់បានរាយការណ៍ថា "គេបង្ខំយើងឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរ ហើយគ្មានបានទទួលអ្វីទេ"។ ពេលនោះការ ស្លៀកពាក់ខ្មៅគឺជាការចាំបាច់ ហើយការដាក់ទោសដល់ស្លាប់ត្រូវគេអនុវត្តជាទូទៅ ពិសេសចំពោះអ្នកគេចវេសពីកំណែនរបស់បក្សកុម្មុយនីស្តកម្ពុជា)។

[៣១៩] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៣៣-៣៤, ៤០។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១០-១២។

[៣២០] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១០។

អចិន្ត្រៃយ៍បានសម្រេចធ្វើការប្រមូលផ្តុំកម្លាំងសម្រាប់ផលិតស្រូវ[៣២១]។ គាត់សារភាពថា ប្រជាជននៅឧត្តុង្គត្រូវបានជម្លៀសដើម្បីបង្កើតសហករណ៍ ដែលមានគោលដៅផលិតស្បៀងអាហារ ដើម្បីទប់ទល់កង្វះខាតស្បៀងអាហារ[៣២២]។ អ្នកជំនាញ លោក Philip SHORT ក៏បានពិចារណាឃើញដែរថា ហេតុផលជាក់ស្តែងសម្រាប់ការធ្វើសមូហភាវូបនីយកម្ម គឺដើម្បីរៀបចំផលិតកម្មស្រូវ និងដើម្បីរារាំងវៀតណាមមិនឱ្យចែកចាយការផ្គត់ផ្គង់របស់ខ្លួន[៣២៣]។ តាមទស្សនៈរបស់គាត់ សំខាន់ជាងនេះទៅទៀតគឺថា ការធ្វើបែបនេះគឺដោយសារតែហេតុផលមនោគមន៍វិជ្ជាក្នុងការធ្វើសមូហ-ភាវូបនីយកម្ម ដែលជាការជ្រើសរើសយកកុម្មុយនីស្តនិយម ជាជាងការជ្រើសយកមូលធននិយម ព្រមទាំងជាការព្យាយាមអនុវត្តសមភាពសម្រាប់ប្រជាជនទាំងអស់នៅគ្រប់កម្រិតជីវភាព[៣២៤]។

១១៦. អង្គជំនុំជម្រះជឿជាក់ថា នៅមុនឆ្នាំ ១៩៧៥ ពិតជាមានគោលនយោបាយបក្សកុម្មុយនីស្ត-កម្ពុជា ដើម្បីបង្កើតសហករណ៍ ដោយកំណត់ចេញនូវលក្ខខណ្ឌការងារដ៏លំបាកសម្រាប់សមាជិកសហករណ៍ រួមទាំងអ្នកទាំងឡាយដែលត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំទៅទីនោះ។ ដូចបានកត់សម្គាល់ពីខាងលើរួចមកហើយ មានទាំងហេតុផលផ្នែកសេដ្ឋកិច្ច ក៏ដូចជាផ្នែកមនោគមន៍វិជ្ជាសម្រាប់គោលនយោបាយសមូហភាវូបនីយកម្មនេះ[៣២៥]។

### ៣.៣.៣ ការអប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង

១១៧. មានភ័ស្តុតាងបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយមួយបន្ថែមទៀត គឺការអប់រំកែប្រែ "សមាសភាពមិនល្អ" និង "កម្ទេច" អ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាជាខ្មាំង[៣២៦]។ ចាប់តាំងពីឆ្នាំ ១៩៧១ រហូតដល់ ខែ មិថុនា ឆ្នាំ ១៩៧៥ កាំង ហ្គេកអ៊ាវ គឺ

---

[៣២១] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៥។

[៣២២] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៩។

[៣២៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៦៩-៧០។

[៣២៤] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ២១-២៣; *សូមមើលផងដែរ*, ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ១០-១២។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៣៣-៣៥។

[៣២៥] សូមមើលផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៤ ។

[៣២៦] ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៥-១៦។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី០២ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៦១-៦២។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៣-៥។ ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/11, ចុះខែ កញ្ញា ឆ្នាំ ១៩៧៧, ទំព័រ ៥២-

ជាប្រធានមន្ទីរ ម-១៣ ដែលមានភារកិច្ចទទួលមនុស្ស ដែលគេចាប់ខ្លួនបានពីសមរភូមិ[៣២៧]។ មន្ទីរសន្តិសុខដទៃទៀតត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនោះផងដែរ ដូចជា មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧២[៣២៨]។ នៅក្នុងមន្ទីរសន្តិសុខ អ្នកដែលត្រូវបានគេចោទថាជាគិញ ឬ ត្រូវបានគេសន្មតថាជាខ្មាំង ត្រូវបានគេសួរចម្លើយ ហើយកម្ទេចចោល[៣២៩]។ "កម្ទេច" មានន័យលើសពីការសម្លាប់ គឺមានន័យថាចាប់ខ្លួនដោយសម្ងាត់ សួរចម្លើយហើយសម្លាប់បុគ្គលនោះដោយមិនឲ្យសមាជិកគ្រួសារបានដឹងឡើយ[៣៣០]។ អ្នកដែលត្រូវបានគេចោទថាជាគិញ គឺជាខ្មាំង ហើយត្រូវគេសួរចម្លើយនៅក្នុងមន្ទីរសន្តិសុខ និងកម្ទេច[៣៣១]។ វិធីកំណត់ថាជា "ខ្មាំង" គឺ

---

៥៤, ERN (ភាសាខ្មែរ) 00063146-00063147។ សាលក្រម កាំង ហ្កេកអ៊ាវ កថាខណ្ឌ ៩៩។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ) ទំព័រ ១២។

[៣២៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៣។

[៣២៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន់ ឆេន, ឯកសារ E3/72, ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០, ERN (ភាសាខ្មែរ) 00483946។

[៣២៩] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣៣-៣៤, ៤០។ ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/5, ចុះខែ សីហា ឆ្នាំ ១៩៧៥, ទំព័រ ១៣-១៥, ERN (ភាសាខ្មែរ) 00063318-00063319 (ការកម្ចាត់ភ្នាក់ងាររដ្ឋាភិបាលគិញ និងសន្តិសម្ព័ន្ធ ត្រូវបានរៀបរាប់ថាជាផ្នែកនៃលទ្ធផល របស់ដំណើរការបង្កើតសហករណ៍)។

[៣៣០] សាលក្រម កាំង ហ្កេកអ៊ាវ កថាខណ្ឌ ១០០។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ ប៊ូនី) ទំព័រ ៣៦ (អតីតអ្នកជាប់ឃុំនៅគុកត្រាចក្រោលបានពន្យល់ថា បក្សនឹងកម្ទេចជនណាដែលព្យាយាមរត់គេច។ ជនទាំងនោះនឹងត្រូវគេកាត់ក្បាល ឬសម្លាប់ចោល)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៨៥ (នៅពេលដែលគាត់ជាអ្នកទទួលខុសត្រូវនៅមន្ទីរសន្តិសុខ គាត់បានទទួលបញ្ជាឲ្យសម្លាប់អ្នកទោស)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៣-៥ (កម្ទេច គឺកម្ទេចជនទាំងឡាយណាដែលមិនស្មោះត្រង់អស់ពីចិត្តជាមួយបដិវត្ត។ ការសាកសួរអំពីរបបគឺជាទម្រង់មួយនៃកម្មសិទ្ធិឯកជនខាងសតិអារម្មណ៍។ ប្រសិនបើអ្នកមានទស្សនៈផ្ទាល់ខ្លួន ដែលខុសពីទស្សនៈរបស់អង្គការ នេះគឺជាសញ្ញានៃការនៅក្រៅបដិវត្ត។ អ្នកទាំងឡាយណាដែលមានទស្សនៈឯកជន ប្រឆាំងទស្សនៈសមូហភាព ត្រូវទទួលខុសត្រូវ ហើយចុងក្រោយត្រូវបានកម្ទេច)។

[៣៣១] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣៣-៣៤។ ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/785, ចុះខែ កក្កដា ឆ្នាំ ១៩៧៣, ERN (ភាសាខ្មែរ) 00442037-00442042, 00442048-00442053 (គិញត្រូវតែកម្ចាត់។ "គោលជំហរកម្ទេចគិញ គឺត្រឹមត្រូវ តែការអនុវត្តគឺមិនបានត្រឹមត្រូវ")។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៤៣ (គោលការណ៍ណែនាំគឺ៖ ការសម្លាប់មនុស្សគឺត្រឹមត្រូវនៅពេលដែលពួកទាំងនោះប្រឆាំងបដិវត្ត, គឺនៅពេលដែលពួកគេប្រឆាំងនឹងបដិវត្ត ប៉ុន្តែការសម្លាប់ត្រូវតែធ្វើឡើងក្នុងលក្ខណៈមួយដែលមិន

ជាយុទ្ធវិធី ដែលមានភាពមិនច្បាស់លាស់ ដែលនាំឱ្យមានការបកស្រាយផ្សេងៗគ្នា ព្រមទាំងបង្កើតឱ្យមានជាបរិយាកាសមិនប្រាកដប្រជា[៣៣២]។ ទោះជាយ៉ាងនេះក្ដី ពាក្យនេះត្រូវបានបកស្រាយដោយសេរី ហើយសូម្បីតែកម្មាភិបាលខ្មែរក្រហមក៏គិតថា អ្នកស្លូតត្រង់គ្មានកំហុស ត្រូវបានគេកំណត់ដោយមិនត្រឹមត្រូវថាជាខ្មាំងផងដែរ[៣៣៣]។

១១៨. គោលនយោបាយកម្ទេចខ្មាំងបន្តអនុវត្តរហូតដល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាគោលនយោបាយនេះមានការវិវត្តប្រែប្រួលក្តី[៣៣៤]។ ចាប់តាំងពីឆ្នាំ ១៩៧០ គិញដែលរួមមាន សេ.អុិ.អា

---

ប៉ះពាល់ដល់គោលដៅរបស់បដិវត្ត។ ជាឧទាហរណ៍ មិនត្រូវសម្លាប់មនុស្សនៅចំពោះមុខអ្នកដទៃ។ នៅក្នុងអំឡុងរបបខ្មែរក្រហម ប្រជាជនបានបាត់ខ្លួន ពួកគេត្រូវគេយកទៅបាត់ ហើយមិនឃើញត្រឡប់មកវិញទេ)។

[៣៣២] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៨-៩ (គាត់បានបង្ហាញទស្សនៈថា និយមន័យខ្មាំងត្រូវបានរក្សាទុកឱ្យមានភាពមិនច្បាស់លាស់ដោយចេតនា ដើម្បីឱ្យមានឥទ្ធិពលគំរាមកំហែង និងដើម្បីបង្កើតជាបរិយាកាសមិនប្រាកដប្រជា)។ ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/11, ចុះខែ កញ្ញា ឆ្នាំ ១៩៧៧, ទំព័រ ៥២-៥៤, ERN (ភាសាខ្មែរ) 00063146-00063147 (បក្សកុម្មុយនីស្តកម្ពុជានិយមប្រើវិធីសាស្ត្រជាយុទ្ធសាស្ត្រក្នុងការកំណត់និយមន័យខ្មាំង នៅក្នុងដំណាក់កាលដំបូងនៃបដិវត្ត ហើយជាការសំខាន់ក្នុងការប្រមូល "កម្លាំងទាំងអស់ដែលអាចប្រមូលបាន"។ ខ្មាំងត្រូវបានបែងចែកជាបីក្រុម អាស្រ័យលើថាតើខ្លួនអាចយកឈ្នះលើពួកនោះឬអត់ ថាតើខ្លួនអាចធ្វើឱ្យពួកនោះលែងមានប្រសិទ្ធិភាពឬអត់ ឬថាតើខ្លួនអាចបំបែកពួកនោះ ដើម្បីវាយប្រហារបានឬអត់)។

[៣៣៣] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៤០ (បញ្ជាក់ថាមិនមែនគ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅ ម-១៣ សុទ្ធតែជាគិញនោះទេ ហើយគាត់បានសម្រេចដោះលែងពួកគេខ្លះ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៦-១៧ (ក្រុមខ្លះទៀតត្រូវបានចាប់ខ្លួនដោយគ្មានហេតុផល ហើយត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ដូចជា គង់ សុជាតិ ហៅ សឿន ជាកូនរបស់ គង់ សុផល ហៅកឹ ជាមេបញ្ជាការកងវរសេនាធំ ក្នុងឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២៨-២៩ (រាជវង្សានុវង្សក៏ត្រូវបានកម្ទេចដែរ នៅចន្លោះឆ្នាំ ១៩៧២ និង ១៩៧៣ រួមមានព្រះអង្គម្ចាស់ ភូរីស្សារា និងព្រះជាយារបស់ទ្រង់ និង ស៊ីសុវត្ថិ ផាច)។

[៣៣៤] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០; ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ១៨-២០។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ១២-១៣, ៨៧។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣៩; *សូមមើលផងដែរ*, ប្រតិចារឹក ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៧៩ (enemies included all urban deportees)។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ 255, ERN (En) 00396455។

កា.ហ្សេ.បេ និងវៀតណាម (“យួន”) ត្រូវបានគេចាត់ទុកថាជាខ្មាំងសំខាន់[៣៣៥]។ ចាប់តាំងពីមុនឆ្នាំ ១៩៧៥ មក អតីតមន្ត្រី និងទាហានរបប លន់ នល់ ត្រូវបានចាត់ទុកថាជាខ្មាំងសំខាន់[៣៣៦]។ បក្សក៏បានពិនិត្យមើលផ្ទៃក្នុងដើម្បីស្វែងរកខ្មាំងរបស់ខ្លួន ដោយកំណត់អ្នកនៅក្នុងបក្ស ដែលរារាំង “មហាលោតផ្លោះ មហាអស្ចារ្យ” ដែលរួមទាំងកងទ័ពប្រជាជននៅភូមិភាគឧត្តរ និងពាយ័ព្យ ព្រមទាំងសមាជិកថ្នាក់ដឹកនាំផងដែរ[៣៣៧]។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ១៩៧៤ ប្រសិទ្ធ ដែលជា

---

[៣៣៥] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២៨-២៩។ ប្រតិចារឹក ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៣០-៣១ (វគ្គរៀនសូត្របង្រៀនដោយ ប៉ុល ពត និង នួន ជា បានពិភាក្សាពីការកម្ចាត់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដូចជាសេអ៊ីអា និង កាហ្សេបេ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន) ទំព័រ ១៨-២៣ (អៀង សារី បានកំណត់ថា ចក្រពត្តិអាមេរិក សេអ៊ីអា និង កាហ្សេបេ គឺជាខ្មាំង)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៣៨-៣៩។ អត្ថបទរបស់ S. Heder: *ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋាន ចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ការទទួលខុសត្រូវរបស់កម្ពុជា ក្នុងទស្សនវិស័យប្រៀបធៀប*, ឯកសារ E3/4527, ទំព័រ ២០, ERN (ភាសាខ្មែរ) 00830773, ជើងទំព័រ ៥៧, ៥៩។ នួន ជា បានថ្លែងនៅក្នុងខួបកំណើតកងទ័ពកម្ពុជា (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៧), ឯកសារE3/147, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧, ERN (ភាសាខ្មែរ) 00679796 (នួន ជា បញ្ជាក់ថាបន្ទាប់ពីឆ្នាំ ១៩៦១ អង្គភាពការពារសម្ងាត់មានតួនាទី ការពារកម្មាភិបាល និងប្រជាជន ហើយត្រូវកម្ទេចភ្នាក់ងារស៊ើបការខ្មាំង)។

[៣៣៦] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៥៥ (ទីក្រុងភ្នំពេញត្រូវបានគេជម្លៀសចេញ ដើម្បីសម្រួលដល់ការបោសសម្អាតខ្មាំង ដែលជាទាហានលន់ នល់)។

[៣៣៧] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០, ៣២។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន) ទំព័រ ៧០-៧១ (ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើន ដែលបង្រៀនដោយប៉ុល ពត នួន ជា និង ខៀវ សំផន ពួកគេបានពន្យល់ពីអត្ថន័យរបស់ពាក្យ “មហាលោតផ្លោះ មហាអស្ចារ្យ” ដែលតម្រូវឱ្យផ្លាស់ទៅកុម្មុយនីស្តនិយម ដោយមិនចាំបាច់ឆ្លងកាត់សង្គមនិយម ហើយកំណត់និយមន័យ “ខ្មាំង” ថាជាអ្នកទាំងឡាយណាដែលមិនអាចអនុវត្ត)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន) ទំព័រ ២៩-៣០ (ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់បន្ថែមថា ខ្មាំងរួមបញ្ចូលអ្នកទាំងឡាយណាដែលរាំងស្ទះកិច្ចការរបស់បក្ស ឬមិនបំពេញការងារបានល្អ។ គាត់បានបន្ថែមទៀតថា បក្សរំពឹងថា “សមាសភាពល្អអាចធ្វើការញែកឱ្យដាច់រវាងមិត្តនិងសត្រូវ បើទោះបីពួកគេជាកុមារ សហព័ទ្ធ ឬសាច់ញាតិផ្ទាល់ក៏ដោយ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៤៦-៤៨ (ផ្អែកតាមសក្ខីកម្មរបស់កម្មាភិបាលខ្មែរក្រហមរូបនេះបានបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់កងទ័ពខ្មែរក្រហមជាច្រើនត្រូវបានចាប់

សមាជិកគណៈកម្មាធិការមជ្ឈិមមកពីនិរតី ហើយជាជនជាតិថៃ ត្រូវបាន តាម៉ុក ចោទប្រកាន់ថាធ្វើការបម្រើក្រុងបាងកក និង សេ.អ៊ី.អា[៣៣៨]។ គាត់ត្រូវបានគេយកទៅក្នុងព្រៃ ហើយសម្លាប់ចោល។ គោលនយោបាយអប់រំកែប្រែ និងសម្លាប់ខ្មាំងក៏មានជាប់ទាក់ទងផងដែរទៅនឹងគោលនយោបាយសមូហភាវូបនីយកម្ម ដោយសារតែដំណើរការនៃការផ្លាស់ទីលំនៅប្រជាជនទៅសហករណ៍ បានជួយគាស់រម្លើង និង កំចាត់ភ្នាក់ងាររដ្ឋាភិបាល គិញ និងសន្តិសម្ព័ន្ធ[៣៣៩]។ ជាឧទាហរណ៍ ខ្មែរដែលធ្លាប់បានទៅសិក្សានៅប្រទេសវៀតណាម ហើយត្រឡប់មកកម្ពុជាវិញដើម្បីជួយដល់បដិវត្តនៅពេលក្រោយមកត្រូវបានគេសង្ស័យថាជាខ្មាំង ហើយត្រូវគេប្រមូលយកមកទាំងអស់ និងកម្ទេចចោល[៣៤០]។ ភ័ស្តុតាងទាក់ទងនឹងខ្លឹមសារ និងការអនុវត្តនូវគោលនយោបាយអប់រំកែប្រែនូវ

---

ខ្លួន។ ពួកគេចោទប្រកាន់គ្នាទៅវិញទៅមកថាជាខ្មាំង បើទោះបីជាសាក្សីមិនអាចបង្ហាញថាពួកគេគឺជាភ្នាក់ងារសេអ៊ីអា ឬ កាហ្សេបេក៏ដោយ)។ សូមប្រៀបធៀបជាមួយ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៤៦ (អ្នកដែលមិនខំប្រឹងធ្វើការ ត្រូវគេអប់រំកែប្រែប៉ុណ្ណោះ មិនមានធ្វើទារុណកម្មអ្វីទេ)។ ជីវប្រវត្តិ កែ ពក ពីឆ្នាំ ១៩៥៧ រហូតដល់បច្ចុប្បន្ន ឯកសារ E3/2782, ERN (ភាសាខ្មែរ) 00095551-00095552 ("កងទ័ពខ្លះនៅបម្រើខ្ញុំតាំងពីឆ្នាំ ១៩៦៨ ប៉ុន្តែពួកគេត្រូវបានចោទប្រកាន់ថាជាសេអ៊ីអា")។

[៣៣៨] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣(Philip SHORT) ទំព័រ ១៥-១៦។ *សូមមើលផងដែរ*, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័ ៤៨-៤៩។ សៀវភៅនិពន្ធដោយ P. Short ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ, ឯកសារ E3/9, ឆ្នាំ ២០០៤, ទំព័រ 259-260, ERN (En) 00396467-68 ("ប្រសិទ្ធ មិនមែនជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដំបូងគេ ដែលត្រូវគេកម្ចាត់នោះទេ។ ម៉ុក បានកម្ចាត់កម្មាភិបាលថ្នាក់ក្រោមមួយចំនួនរួចហើយ។ [...] ប៉ុន្តែនេះគឺជាលើកដំបូងដែលទំនាស់ផ្ទៃក្នុងបក្ស បានឈានចូលដល់កម្រិតគណកម្មាធិការមជ្ឈិម។ នេះក៏ជាលើកដំបូងដែរ ដែលថ្នាក់ដឹកនាំបក្សបានផ្តល់សិទ្ធិក្នុងការសម្លាប់សមាជិកម្នាក់របស់ខ្លួន")។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៣៦-៣៩ (បានរំលឹកថា ប្រសិទ្ធ មិនបានចូលរួមក្នុងកិច្ចប្រជុំគណកម្មាធិការមជ្ឈិមនៅខែ មិថុនា ឆ្នាំ ១៩៧៤ ទេ ហើយបានកត់សម្គាល់ថានេះជារឿងមិនធម្មតា)។

[៣៣៩] ទស្សនាវដ្តីទង់បដិវត្ត, ឯកសារ E3/5, ចុះខែ សីហា ឆ្នាំ ១៩៧៥, ទំព័រ ១៣-១៥, ERN (ភាសាខ្មែរ) 00063318-00063319។

[៣៤០] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៦៦-៦៨ (ខ្មែរដែលទៅសិក្សានៅទីក្រុងហាណូយក្នុងជំនាន់ឥស្សរៈ ហើយក្រោយមកបានត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ ១៩៧៣ ត្រូវបានកំណត់ជាគោលដៅសម្រាប់ការចាប់ខ្លួននៅកំពត។ ពួកគេជាច្រើនបានក្លាយខ្លួនជាខ្មែរក្រហម ប៉ុន្តែអ្នកផ្សេងទៀតបានបាត់ខ្លួន)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៣៤-៣៥, ៤២-៤៣ (ខ្មែរហាណូយ ប្រហែល ៧០០ ទៅ ៨០០ នាក់ បានត្រឡប់មកចូលរួមបដិវត្តកម្ពុជា នៅឆ្នាំ ១៩៧០ ហើយពួកគេភាគច្រើនត្រូវបានបោសសម្អាត)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ២៤-២៨, ៦២-៦៣ (តាម៉ុក បានប្រាប់សាក្សីថាមានខ្មែរវៀតមិញប្រហែល ២ ពាន់ ទៅ ៣ ពាន់នាក់ ដែលបានត្រឡប់មកកម្ពុជា មកជួយវាយទាហាន លន់ នល់ ត្រូវបានគេប្រមូលផ្តុំ

01006409



សមាសភាពអាក្រក់ និងការសម្លាប់សត្រូវ និងវិសាលភាពនៃគោលនយោបាយនេះគឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ។

### **៣.៣.៤ ការកំណត់គោលដៅលើក្រុមជាក់លាក់៖ ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ**

១១៩. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាគោលនយោបាយនៃការកំណត់គោលដៅលើជនជាតិចាម ពុទ្ធសាសនិក និងជនជាតិវៀតណាម ត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយក៏ដោយ[៣៤១] ក៏អង្គជំនុំជម្រះបានស្តាប់ភស្តុតាងអំពីគោលនយោបាយនេះតិចតួចប៉ុណ្ណោះរហូតមកដល់ពេលនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងយកគោលនយោបាយនេះមកពិនិត្យលម្អិតនៅក្នុងសំណុំរឿង ០០២/០២ និងនៅក្នុងការជំនុំជម្រះក្រោយៗទៀត[៣៤២]។

#### **៣.៣.៤.១ ការកំណត់គោលដៅលើ ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ**

១២០. នៅប៉ុន្មានខែដែលនាំឲ្យមានការវាយសម្រុកចុងក្រោយលើទីក្រុងភ្នំពេញ រណសិរ្សរួបរួមជាតិកម្ពុជាបានប្រើប្រាស់ភាសាសម្រុះសម្រួលតាមវិទ្យុផ្សព្វផ្សាយ សំដៅទៅអ្នករដ្ឋការ និងទាហានរបបសាធារណរដ្ឋខ្មែរ ដោយបានជូនដំណឹងថា ពួកគេអាចចូលរួមជាមួយខ្មែរក្រហម

---

តាមបញ្ជាពីថ្នាក់លើ ហើយពួកគាត់បានបាត់ខ្លួន និងប្រហែលជាស្លាប់ហើយ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៧០-៧២។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ, ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០, ទំព័រ ៥៣-៥៦, ERN (ភាសាខ្មែរ) 00324724-00324727 ("យើងបានហៅខ្មែរមកពីហាណូយទាំងនោះមករៀនសូត្រ ហើយមានគេយកពួកគាត់ទៅបាត់ [...] ដូច្នេះពួកយើងអាចកម្ចាត់ពួកគេសឹងតែទាំងអស់។ មានតិចតួចណាស់ដែលអាចដឹងទាន់ពេល ថានឹងមានអ្វីកើតឡើង ហើយអាចរត់គេចទៅវៀតណាម")។ សៀវភៅនិពន្ធដោយ B. Kiernan: តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? ដើមកំណើកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ១៩៣០-១៩៧៥៖ ឯកសារ E3/1815, ឆ្នាំ ១៩៨៥, ទំព័រ ៣៩៥-៣៩៧, ERN (ភាសាខ្មែរ) 00104870-00104871 ("វៀតណាមបានសួរខ្មែរដែលធ្វើការជាមួយខ្លួននៅក្នុងខេត្តកំពង់ធំ ថាតើពួកគេចង់ផ្ទេរចូលទៅក្នុងអង្គភាពរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ។ ពួកគេភាគច្រើនស្ម័គ្រចិត្តផ្ទេរ ប៉ុន្តែមិនយូរប៉ុន្មានក្រោយមកពួកគេពីរនាក់បានត្រឡប់មកវិញ ជាមួយដំណឹងថាអ្នកដទៃត្រូវបានគេសម្លាប់ ព្រោះពួកគេត្រូវគេចោទថាមាន "ក្បាលយួន")។

[៣៤១] ដីកាដំណោះស្រាយ ឯកសារ D 427 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ") កថាខណ្ឌ ២០៥។

[៣៤២] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៣២-៣៣។ ឧបសម្ព័ន្ធ បញ្ជីរូបថត និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ កថាខណ្ឌ (២)(iv)(ក), (ខ) និង (គ)។

ប្រសិនបើពួកគេចុះចូល[៣៤៣]។ សារទាំងនេះមានគោលបំណងដើម្បីកាត់បន្ថយការប្រឆាំងទៅនឹងការវាយសម្រុកចូលរបស់កងទ័ពខ្មែរក្រហម និងដើម្បីអូសទាញឲ្យអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ

---

[៣៤៣] *សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ស្តីពីស្ថានភាពបច្ចុប្បន្ន* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700267-00700269 (“រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិប្រជាជនកម្ពុជា សូមអំពាវនាវដល់គ្រប់មន្ត្រី យុទ្ធជន និងសមាជិកនៃស្ថាប័នប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ទាំងអស់របស់ក្រុមពួកក្បត់នៅលើសមរភូមិរួមទាំងនៅតំបន់ជុំវិញទីក្រុងភ្នំពេញ និងខេត្តមួយចំនួនទៀតដែលស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់ខ្មាំងសូមឲ្យដាក់អាវុធចុះភ្លាមៗ និងចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាក្នុងពេលនេះ។ បុគ្គលិកមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ទាំងអស់ ស្នើសុំឲ្យឈប់បម្រើការងារឲ្យមេក្បត់ទាំង ៧ រូបភ្លាមៗ និងចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ ចំពោះរាល់បងប្អូនទាហាន និងជនស៊ីវិលទាំងអស់ដែលក្រុមមេក្បត់ជាតិ ហ្វាស៊ីស និងពុករលួយ បានបង្ខំឲ្យចូលបម្រើពួកគេ និងចូលរួមក្នុងសង្គ្រាមឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក៖ បច្ចុប្បន្ន ពួកក្បត់ជាតិទាំង ៧ នាក់ បានបោះបង់ចោលបងប្អូនហើយ ។ បងប្អូនត្រូវតែដើរតាមផ្លូវដ៏មានកិត្តិយស និងសាមគ្គីភាពជាតិតាមរយៈការចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងប្រជាជនក្នុងតំបន់រំដោះទាំងមូល សូមអំពាវនាវដល់បងប្អូនទាំងអស់គ្នា [ពាក្យមិនច្បាស់] និងសូមសម្តែងការអបអរសាទរដល់បងប្អូនចំពោះការតស៊ូទ្រាំ និងជម្នះលើគ្រោះអកុសលគ្មានអ្វីប្រៀបបានក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ។ រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា បានបញ្ជាដល់គ្រប់ស្ថាប័នរបស់រណសិរ្ស និងគ្រប់អង្គភាពរបស់កងទ័ពរំដោះជាតិប្រជាជនកម្ពុជាទាំងអស់ឲ្យទទួលស្វាគមន៍បងប្អូនយ៉ាងកក់ក្តៅ”)។ *លោក ខៀវ សំផន អំពាវនាវឲ្យប្រជាពលរដ្ឋទីក្រុងភ្នំពេញចូលរួមជាមួយរណសិរ្ស- រួបរួមជាតិកម្ពុជា* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700275-00700277 (“ក្នុងនាមជារណសិរ្សរួបរួមជាតិកម្ពុជា ដែលដឹកនាំដោយព្រះប្រធាន នរោត្តម សីហនុ និងក្នុងនាមរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលមានសម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី ខ្ញុំសូមអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ រួមទាំងព្រះសង្ឃ គ្រហស្ថ នាយទាហាន ជនស៊ីវិលរស់នៅទីក្រុងភ្នំពេញ និងនៅតាមទីរួមខេត្តមួយចំនួន ដែលស្ថិតនៅក្រោមការដឹកនាំបណ្តោះអាសន្នរបស់ខ្មាំង ដូចខាងក្រោមនេះ៖ ១. យើងខ្ញុំ សូមស្នើសុំឲ្យបងប្អូនមន្ត្រី និងកងទ័ពទាំងអស់ក្នុងជួរកងកម្លាំងប្រដាប់អាវុធរបស់ពួកក្បត់ដាក់អាវុធរបស់ខ្លួនចុះភ្លាមៗ និងចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ រណសិរ្សរួបរួមជាតិកម្ពុជា មានមោទនភាព និងសូមស្វាគមន៍បងប្អូនទាំងអស់ព្រមទាំងត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលបងប្អូនធ្វើជាជនរួមជាតិរបស់យើង”។ *លោក ខៀវ សំផន អបអរសាទរកងទ័ពរំដោះជាតិប្រជាជនកម្ពុជានៅថ្ងៃជ័យជម្នះនៅអ្នកលឿង* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700272-00700274 (រៀបរាប់ឈ្មោះសមាជិក ៧ រូបនៃរបប លន់ នល់ ថាជាពួកជនក្បត់៖ លន់ នល់, សិរិមតៈ, សឺន ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត,សូស្តែន-ហ្វែណង់ដែស (Sosthene Fernandez)។ *សីហនុ ថ្លែងអំពីការទទួល រណសិរ្សរួបរួមជាតិកម្ពុជា-កងទ័ពរំដោះជាតិប្រជាជន កម្ពុជានៅថ្ងៃទី ២២ ខែ មីនា នៅទីក្រុងប៉េកាំង* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ៣១ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166907 (កត់សម្គាល់ឃើញថា ទាហានសាធារណរដ្ឋ

01006411



យល់ច្រឡំដោយមានអារម្មណ៍ថា ពួកគេមានសុវត្ថិភាពសន្តិសុខ[៣៨៤]។ ដោយដឹងថា ខៀវ សំផន គឺជាមនុស្សមិនជ្រុលនិយម និងមានសមត្ថភាពអាចបង្រួបបង្រួមខ្មែរក្រហមពីប្រភពផ្សេងៗនោះ មេដឹកនាំខ្មែរប្រហមបានឲ្យ ខៀវ សំផន ផ្តល់ការធានាដោយភូតកុហកថា នៅពេលកងទ័ពបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងប្រទេស មានតែ "ពួកជនមហាក្បត់ចំនួន ៧ នាក់" តែប៉ុណ្ណោះ ក្នុងនោះមានទាំង លន់ នល់ និងអ្នកដឹកនាំជិតដិតរបស់គាត់ ដែលនឹងត្រូវសម្លាប់ចោល[៣៨៥]។ សារនានា

---

ខ្មែរដែលចុះចាញ់ នឹងត្រូវបានអភ័យទោស និងផ្តល់ការលើកលែងទោសដោយរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងទ័ពបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែជនមហាក្បត់ទាំង ៧ នាក់ នឹងត្រូវព្យួរក)។

[៣៨៤] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៤៨-៤៩។ សៀវភៅរបស់ S. Heder៖ *ប៉ុល ពត និង ខៀវ សំផន* ឯកសារ E3/3169 ឆ្នាំ ១៩៩១ ទំព័រ ១៥-១៦, ERN (ភាសាខ្មែរ) 00711377-00711378 ("ក្នុងអ្វីដែលទំនងជាការរំលោភសេចក្តីទុកចិត្តដោយគ្រោងទុក ដែលបានរៀបចំឡើងដោយលោក ខៀវ សំផន នោះ មុនពេលសង្គ្រាមបានបញ្ចប់ លោកបានជួយយ៉ាងសកម្មក្នុងការរៀបចំការសម្លាប់យ៉ាងងាយស្រួលទៅលើបុគ្គលិកយោធា និងមន្ត្រីរាជការស៊ីវិលរបស់លោក លន់ នល់។ គុណតម្លៃដែលរូបលោកមាន មានន័យថា ជនរងគ្រោះមួយចំនួន បានធ្វើឲ្យខ្លួនឯងផ្ទាល់ក្លាយជាគោលដៅនៃការសម្លាប់។ ដូច្នេះ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជា ឈានទៅទទួលជ័យជម្នះផ្នែកយោធាទាំងស្រុង ក្នុងអំឡុងពេល៤ខែដំបូងក្នុងឆ្នាំ ១៩៧៥ លោក ខៀវ សំផន បានបង្ហាញសញ្ញាជាលើកទីពីរដល់អ្នកទាំងឡាយដែលបានកំពុងប្រយុទ្ធប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាថា មានតែថ្នាក់ដឹកនាំកំពូលទាំង ៧ រូបក្នុងចំណោមពួកគេប៉ុណ្ណោះ ដែលនឹងត្រូវប្រហារជីវិត បន្ទាប់ពីទទួលបានជ័យជម្នះ")។

[៣៨៥] ខៀវ សំផន ធ្វើជាអធិបតីសម័យប្រជុំសមាជរបស់រណសិរ្សរួបរួមជាតិកម្ពុជា - សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្សព្វផ្សាយ (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/117 ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ទំព័រ ១-២ (ភាសាខ្មែរ) ERN 00242308-00242309 ("ទាក់ទងនឹងពួកក្បត់ទាំង ៧ នាក់នៅក្នុងទីក្រុងភ្នំពេញ [...] ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជបានប្រកាសថា វាជាការចាំបាច់ជាដាច់ខាតត្រូវសម្លាប់ជនក្បត់ជាតិទាំង ៧ នាក់ចំពោះអំពើក្បត់ជាតិរបស់ពួកវាដែលប្រឆាំង នឹងប្រជាជាតិ។ [...] ប្រជាជាតិ និងប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាល រួបរួមជាតិកម្ពុជាសូមស្វាគមន៍ និងផ្តល់រង្វាន់ដ៏សមគួរដល់នាយទាហាន កងទ័ព កងឈ្លប នគរបាល អ្នកមុខអ្នកការ អ្នកនយោបាយ និងអ្នកមានបណ្តាសក្តិខ្ពង់ខ្ពស់ ដែលរស់នៅក្នុងតំបន់កាន់កាប់បណ្តោះអាសន្នរបស់ខ្មាំងដែលហ៊ានប្រឆាំងនឹងពួកក្បត់ ប្រយុទ្ធតស៊ូនឹងពួកវា និងបង្វែរចុងកាណុងដាក់ពួកវា")។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ២៣-២៤ (Philip SHORT)។ ទីភ្នាក់ងារព័ត៌មានកម្ពុជា រាយការណ៍អំពីសេចក្តីថ្លែងការណ៍អំពីឧក្រិដ្ឋជន សង្គ្រាម នៅថ្ងៃទី ២៦ ខែ មីនា របស់ សីហនុ) (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166896 ("ទោះបីជាមិនបានផ្តន្ទាទោសប្រហារជីវិត ក៏មហាជនក្បត់ផ្សេងទៀតដូចជា បញ្ជីឈ្មោះរបស់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាឧក្រិដ្ឋជនសង្គ្រាម ការពិតគ្មានអ្វីគួរឲ្យឆ្ងល់ ដែលក្រោយពីរំដោះទីក្រុងភ្នំពេញ នឹងត្រូវមកឆ្លើយនៅចំពោះមុខតុលាការរដ្ឋ ចំពោះអំពើឃោរឃៅរាប់មិនអស់ និងបទល្មើសព្រៃផ្សៃនានា [...]")។

បានអំពាវនាវឲ្យទាហាន និងមន្ត្រីរាជការរបបសាធារណរដ្ឋខ្មែរចូលរួមជាមួយចលនាបដិវត្តន៍ ប៉ុន្តែ បានក្រើនរំលឹកដោយប្រយោលថា ប្រសិនបើទាហានណា ពន្យារពេលមិនចូលរួមជាមួយបដិវត្តន៍ទេនោះ ពួកគេនឹងស្ថិតនៅក្នុងប្រភេទដូចគ្នានឹងជនមហាក្បត់ដែរ[៣៤៦]។ នៅពេលជាមួយគ្នានេះ កម្មាភិបាលត្រូវបានគេបង្រៀននៅក្នុងវគ្គរៀនសូត្រមុនពេលវាយប្រហារលើទីក្រុងភ្នំពេញថា សត្រូវរបស់ខ្មែរក្រហមគឺអ្នកទាំងឡាយណាដែលធ្វើការងារនៅក្នុងរបប លន់ នល់ និងជាទាហាន លន់ នល់[៣៤៧]។

១២១. ភ័ស្តុតាងមានភាពស៊ីសង្វាក់គ្នា ចំពោះភាពតឹងរ៉ឹងនៃគោលនយោបាយទាក់ទិននឹងការចាប់ខ្លួនទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពីឆ្នាំ ១៩៧០ រហូតដល់ ឆ្នាំ ១៩៧៥។ ពីដំបូងគេឃើញមានការបែងចែករវាងទាហាន លន់ នល់ និង “គិញ”។ ជារឿយៗ ទាហានត្រូវបានយកទៅអប់រំកែប្រែ និងអត់ឱនទោស[៣៤៨] ចំណែកឯគិញ ជាធម្មតា ត្រូវបានគេយកទៅសម្លាប់ចោល[៣៤៩]។ ការបែងចែកនេះអាចពិបាកក្នុងការអនុវត្ត ដូចដែលជនភៀសខ្លួនមួយរូប ទំនងជាអតីតសមាជិកបក្សម្នាក់ បានកត់សម្គាល់ថា “យើងមិនបានដឹងថា នរណាជាទាហាន លន់ នល់ ឬក៏ជាភ្នាក់ងារសេ.អ៊ី.អា។ ដូច្នេះយើងខ្លាចថាសត្រូវរបស់យើងអាចងើបឡើងម្តងទៀត”[៣៥០]។ ប៉ុន្តែ ក្នុងអំឡុងឆ្នាំ ១៩៧២ ឬ ឆ្នាំ ១៩៧៣ ទាហានរបបសាធារណរដ្ឋខ្មែរទំនងជាមិនសូវទទួលបានការអត់ឱនទោសឲ្យនោះទេ ហើយភាគច្រើនត្រូវបានគេសម្លាប់ចោល ប្រសិនបើកងទ័ពបក្សកុម្មុយនីស្តកម្ពុជាចាប់

---

[៣៤៦] ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ២-៤ (Philip SHORT)។

[៣៤៧] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤៣-៤៦, ៥១។

[៣៤៨] បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ERN (ភាសាខ្មែរ) 00324711 (“ទាហាន លន់ នល់ ភាគច្រើនត្រូវបានគេធ្វើការអប់រំរយៈពេលខ្លី ហើយត្រូវបានគេប្រាប់មិនឲ្យចូលបម្រើក្នុងកងទ័ព លន់ នល់ តទៅទៀត ហើយបន្ទាប់មកក៏ត្រូវបានគេដោះលែង”)។ ERN (ភាសាខ្មែរ) 00324739 (“ឈ្លើយសឹកភាគច្រើនត្រូវបានគេលើកលែងទោស ប៉ុន្តែភ្នាក់ងារខ្លាំង ត្រូវគេសម្លាប់ចោល”។ ERN (ភាសាខ្មែរ) 00324751-003252 (“មានករណីចាប់ខ្លួនទាហាន លន់ នល់ ខ្លះក៏ត្រូវបានគេលើកលែងទោសឲ្យ ខ្លះទៀតក៏អត់។ ប៉ុន្តែក្នុងករណីចាប់បានភ្នាក់ងារវិញ គេមិនដែលលើកលែងទោសឲ្យទេ ប៉ុន្តែត្រូវបញ្ជូនឲ្យថ្នាក់លើយកទៅសម្លាប់”។

[៣៤៩] របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ទំព័រ ៤០ ERN (ភាសាខ្មែរ) 00324711។

[៣៥០] របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ទំព័រ ៦០-៦២ ERN (ភាសាខ្មែរ) 00324731-00324733។

បាន[៣៥១]។ ការទម្លាក់គ្រាប់បែករបស់អាមេរិក ដែលបានបន្តធ្វើរហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៣ បានធ្វើឲ្យប្រជាជនខឹងសម្បារយ៉ាងខ្លាំង និងមានការសង្ស័យទៅលើអ្នកខាងក្រៅ ដែលអ្នកទាំងនោះមួយចំនួនត្រូវបានចោទប្រកាន់ថាជាគិញមកពីជំរំរបស់ លន់ នល់ ហើយត្រូវបានសម្លាប់ចោល[៣៥២]។ ជាឧទាហរណ៍ អតីតទាហាន លន់ នល់ ម្នាក់ បានលើកឡើងថា “នៅឆ្នាំ ១៩៧២ ទាហាន លន់ នល់ ជាច្រើន ប្រហែល ៥០០ នាក់ ត្រូវបានចាប់ខ្លួន។ អ្នកទាំងអស់នោះត្រូវបានសម្លាប់ចោល មិនមានអ្នកណាម្នាក់ត្រូវបានលើកលែងទោសឲ្យនោះទេ”[៣៥៣]។

១២២. ភ័ស្តុតាងមួយចំនួនបានបង្ហាញអំពីការអនុវត្តគោលនយោបាយនេះមិនដូចគ្នា។ ការអនុវត្តមិនដូចគ្នានេះអាចបណ្ដាលមកពីកត្តាចំនួនពីរ។ ទីមួយ ដំបូងឡើយមិនមានសេចក្ដីណែនាំជាលាយលក្ខណ៍អក្សរអំពីការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនោះ

---

[៣៥១] *សូមមើល ឧទា.* សេចក្ដីថ្លែងការណ៍របស់លោក ខៀវ សំផន, ហ៊ូ យុន, ហ៊ូ នឹម ឯកសារ E3/637 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00442328-00442329 (“តាមស្ថិតិជាបឋម កម្លាំងរបស់ខ្មាំង ១.៥៥០ ក្បាល ក្នុងនោះមានអាសក្តិ៥ សក្តិ៣ សក្តិ២ និងសក្តិ១ រាប់សិបក្បាល ត្រូវយើងកម្ទេច ប្រជាជនរាប់ម៉ឺននាក់ត្រូវបានរំដោះ”)។ ERN (ភាសាខ្មែរ) 00442332 (“រួមមក នៅពាក់កណ្ដាលខែ មករា ១៩៧៣ នេះ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានឹងប្រជាជនយើង យកបានជ័យជម្នះដ៏អស្ចារ្យណាស់។ យើងកម្ទេចខ្មាំងចំនួន ១០.២៤៥ ក្បាល រំដោះទីតាំងរាប់សិប រំដោះទន្លេមេគង្គ និងប្រជាជនរាប់ម៉ឺន ហើយរឹបអូសយកអាវុធបានរាប់ពាន់ដើមធ្វើឲ្យអាខ្មាំងកាន់តែស្គាំងឈាម និងប្រកាច់ប្រកិនថែម។ វាកាន់តែអស់កម្លាំង អស់ទីតាំង អស់ទឹកដី អស់ប្រជាជន អស់ស្បៀង អស់សាំង ហើយពិសេសអស់ផ្លូវដឹកជញ្ជូន ទាំងផ្លូវទឹក ទាំងផ្លូវគោក”)។

[៣៥២] របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ទំព័រ ៨០-៨២ ERN (ភាសាខ្មែរ) 00324751-00324753។ តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? ដើមកំណើតកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា និពន្ធដោយ Ben Kiernan ឯកសារ E3/1815 ឆ្នាំ ១៩៨៥ ERN (ភាសាខ្មែរ) 00104871 (បន្ទាប់ពីមានការផ្លាស់ប្តូរថ្នាក់ដឹកនាំ និងការទម្លាក់គ្រាប់បែករបស់អាមេរិកកាន់តែខ្លាំងឡើងនោះនៅក្នុងឆ្នាំ ១៩៧៣ មានការសម្លាប់ដោយទ្រង់ទ្រាយធំទៅលើគ្រប់ទាហាន លន់ នល់ ដែលគេចាប់ខ្លួន និងទៅលើពួកសេនាជន ព្រមទាំងពួកឈ្មួញផងដែរ”)។

[៣៥៣] របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ទំព័រ ១០៦-១០៧ ERN (ភាសាខ្មែរ) 00324777-78 (ចម្លើយរបស់ជនភៀសខ្លួន និងអតីតទាហាន លន់ នល់ ដែលបានរត់ចោលជួរនៅឆ្នាំ១៩៧៤ ឆ្លងចូលមកតំបន់រំដោះ ដែលសាច់ញាតិរបស់គាត់បានបញ្ជាក់អំពីភាពស្មោះត្រង់របស់គាត់)។

ទេ[៣៥៤]។ ទោះបីជាមិនមានគោលនយោបាយជាលាយលក្ខណ៍អក្សរក៏ដោយ លោក Philip Short យល់ឃើញថា ការប្រព្រឹត្តិដូចៗគ្នាលើទាហាននៃរបបសាធារណរដ្ឋខ្មែរបង្ហាញឲ្យឃើញថា គោលនយោបាយបែបនេះពិតជាមានអត្ថិភាព[៣៥៥]។ ទីពីរ ភ័ស្តុតាងទាក់ទិននឹងការប្រព្រឹត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាលើអតីតទាហាន ឬ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមុនឆ្នាំ ១៩៧៥ នៅក្នុងតំបន់រំដោះ ទទួលបានភាគច្រើនមកពីការសម្ភាសន៍ក្រោយឆ្នាំ ១៩៧៩ ជាមួយជនភៀសខ្លួននៅក្រៅប្រទេសកម្ពុជា ដែលអ្នកទាំងនោះជាច្រើនគឺជាអតីតកម្មាភិបាលខ្មែរក្រហម ដែលមានចិត្តចង់កាត់បន្ថយភ័ស្តុតាងអំពីការធ្វើបាបនេះ។ យ៉ាងណាក៏ដោយ សូម្បីការរៀបរាប់រឿងរ៉ាវទាំងនេះក៏គាំទ្រដល់ការសន្និដ្ឋានថា មានការកើនឡើងនៃការប្រើប្រាស់ហិង្សាបដិវត្តន៍[៣៥៦]។

១២៣. ភាពតឹងរ៉ឹងនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ស្តីពីការកំណត់គោលដៅទៅលើក្រុមបុគ្គលមួយចំនួនដែលត្រូវបានចាត់ទុកថាជាខ្មាំង ដូចជា អតីតទាហាន ឬ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏មានភាពស៊ីសង្វាក់គ្នាជាមួយនឹងការកើនឡើងនៃការប្រើប្រាស់ហិង្សា

---

[៣៥៤] ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧១-៧៣ (ដោយសារតែមិនមានសេចក្តីណែនាំជាលាយលក្ខណ៍អក្សរដែលចែងអំពីគោលនយោបាយនៃការសម្លាប់វង្គាលគោលនយោបាយនេះមិនមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ ដូចនេះមិនមែនគ្រប់ទាហាន លន់ នល់ ទាំងអស់ត្រូវបានសម្លាប់ចោលនោះទេ”)។ សូមប្រៀបធៀបជាមួយនឹងផ្នែកទី ១៤ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៤-៨១៨ (ដែលបានធ្វើការកត់សម្គាល់នូវសេចក្តីណែនាំចុងក្រោយឲ្យសម្លាប់មន្ត្រីរបបសាធារណរដ្ឋខ្មែរ)។

[៣៥៥] ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧១-៧៣។

[៣៥៦] *សូមមើល ឧទា.* របាយការណ៍ដោយ Stephen HEDER និង Masato MATSUHITA៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ទំព័រ ៦៧-៦៩ ERN (ភាសាខ្មែរ) 00324738-00324740 (ផាក លឹម ដែលត្រូវបានរៀបរាប់ថាជាអ្នកដឹកនាំម្នាក់ក្នុងចំណោមអ្នកដឹកនាំកំពូលៗរបស់ជនភៀសខ្លួនពីរបបខ្មែរក្រហម និងទំនងជាសមាជិកមួយរូបនៃបក្សកុម្មុយនីស្តកម្ពុជាបានលើកឡើងថា “ពេលនោះ ប្រហែលឆ្នាំ ១៩៧៤ ប្រសិនណាបើយើងចាប់បានអ្នកណាម្នាក់ ក្នុងតំបន់ដែលមានការប៉ះទង្គិចគ្នា ពួកយើងនឹងបញ្ជូនមនុស្សនោះទៅកាន់តំបន់ពិសេស ពុំមែនទៅកាន់ភូមិភាគនិរតីឡើយ។ មនុស្សទាំងនោះមានដូចជាពួកឈ្លើយសឹក និងពួកភ្នាក់ងារខ្មាំង។ កាលសម័យនោះ ពួកភ្នាក់ងារខ្មាំងត្រូវគេចាត់ទុកថាជាមនុស្សកាចសាហាវជាងពួកឈ្លើយសឹក។ ឈ្លើយសឹកភាគច្រើនត្រូវបានគេលើកលែងទោស ប៉ុន្តែភ្នាក់ងារខ្មាំង ត្រូវគេសម្លាប់ចោល” ។ តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? ដើមកំណើតកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ១៩៣០-១៩៧៥ និពន្ធដោយ Ben Kiernan ឯកសារ E3/1815 ឆ្នាំ ១៩៨៥ ERN (ភាសាខ្មែរ) 00104871 (“ចៅហ្វាយស្រុករាយការណ៍ថា [...] ការទម្លាក់គ្រាប់បែកកាន់តែខ្លាំងឡើងនោះនៅក្នុងឆ្នាំ១៩៧៣ មានការសម្លាប់ដោយទ្រង់ទ្រាយធំទៅលើគ្រប់ទ័ព លន់ នល់ ដែលគេចាប់ខ្លួន និងទៅលើពួកសេនាជន ព្រមទាំងពួកឈ្មួញផងដែរ”)។

បដិវត្តន៍របស់បក្ស ប្រឆាំងនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ ក្នុងនោះរួមមាន អតីតសមាជិកគណៈកម្មាធិការមជ្ឈិមឈ្មោះ ប្រសិទ្ធ និងពួកខ្មែរហាណូយ ដែលធ្លាប់បានទៅសិក្សានៅប្រទេសវៀតណាម ដូចបានកត់សម្គាល់ខាងលើដែរ[៣៥៧]។ ប្រសិនបើអំពើហិង្សានោះមានលក្ខណៈសមស្របចំពោះខ្មាំងផ្ទៃក្នុង ហិង្សានេះក៏ត្រូវប្រើប្រាស់ប្រឆាំងនឹងខ្មាំងខាងក្រៅផងដែរ។

### ៣.៣.៤.២ "បទពិសោធន៍" នៅឧត្តុង្គ

១២៤. គោលនយោបាយគ្មានត្រាប្រណីរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ក្រោយពីការជម្លៀសប្រជាជនពីទីប្រជុំជនឧត្តុង្គ។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ក្រោមការបញ្ជារួមរបស់ តា ម៉ុក ហើយក្រោយមកស្ថិតនៅក្រោមការបញ្ជារបស់ប្រធានភូមិភាគពិសេស ឈ្មោះ សុន សេន [៣៥៨] បានវាយយកទីក្រុងឧត្តុង្គ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៤[៣៥៩]។ ផ្អែកតាមបទសម្ភាសន៍ជាមួយអ្នកភូមិមួយចំនួន និងប្រភពផ្សេងៗទៀតនោះ អ្នកជំនាញ Philip SHORT វាយការណ៍ថា "អ្នករដ្ឋការ និងទាហានដែលពាក់ឯកសណ្ឋានរាប់ពាន់នាក់ ត្រូវបានគេបំបែកចេញពីអ្នកផ្សេងទៀត និងត្រូវបានគេនាំយកទៅសម្លាប់ចោល"[៣៦០]។ សាក្សីពីររូបក៏បានបញ្ជាក់ផងដែរថា ក្រោយពីដួលរលំក្រុងឧត្តុង្គ ប្រជាជនជាច្រើន

---

[៣៥៧] សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧-១១៨ ។

[៣៥៨] ប្រតិចារឹក ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៨៧-៨៨; ប្រតិចារឹក ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ឹង រ៉ែន)ទំព័រ ៣០-៣១។

[៣៥៩] ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៨-៥៩; ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៤; ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៥, ៣៣-៣៤។ ទង់បដិវត្ត ឯកសារ E3/25 ចុះខែធ្នូ ១៩៧៦ ដល់ខែមករា ១៩៧៧ ទំព័រ ៦៨-៦៩ ERN (ភាសាខ្មែរ) 00063039-00063040។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ២១-២៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១១។ ការផ្តល់សក្ខីកម្មរបស់ នី កន ដែលជាប្អូនប្រុសរបស់ សុន សេន មានលក្ខណៈមិនច្បាស់លាស់លើបញ្ហានេះ។ គាត់បានផ្តល់សក្ខីកម្មថា ក្រុងឧត្តុង្គមិនដែលត្រូវបានគេជម្លៀសនោះទេ ប៉ុន្តែគាត់ក៏បានឆ្លើយតបថា ប្រជាជនត្រូវបានជម្លៀសដោយសារមូលហេតុសន្តិសុខ ពីព្រោះតែភ័យខ្លាចការទម្លាក់គ្រាប់បែកពីលើអាកាស។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ១៩-២០។ ដោយសារតែសក្ខីកម្មរបស់គាត់មានភាពមិន ស៊ីសង្វាក់គ្នា អង្គជំនុំជម្រះយល់ឃើញថា សាក្សីនេះ មិនបានផ្តល់សក្ខីកម្មគួរឲ្យជឿជាក់លើប្រធានបទអំពីការជម្លៀសប្រជាជនចេញពីក្រុងឧត្តុង្គឆ្នាំ១៩៧៤នោះទេ។

[៣៦០] សៀវភៅ និពន្ធដោយ Philip SHORT មានចំណងជើង *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់* ឯកសារ E3/9 ទំព័រ ២៥៥ ERN (ភាសាអង់គ្លេស) 00396455។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៧។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៥, ៣៣-៣៤។

នាក់រួមទាំងកូនក្មេងផងនោះ ដំបូងឡើយ ត្រូវបានគេបញ្ជូនទៅមន្ទីរ ម-១៣ ដែលនៅទីនោះ មនុស្សមួយចំនួនត្រូវបានគេសួរចម្លើយ ហើយបន្ទាប់មកត្រូវបានគេបញ្ជូនទៅខេត្តបាត់ដំបង[៣៦១]។ ប្រហែលជានៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៤ សាក្សី Stephen HEDER បានមកទស្សនកិច្ចនៅឧត្តុង្គ និងបានសម្ភាសន៍អ្នកស្រុក ដែលនៅសេសសល់ពីរបីនាក់ ។ អ្នកស្រុកទាំងនោះបានប្រាប់គាត់អំពីការសម្លាប់ទ្រង់ទ្រាយធំទៅលើប្រភេទប្រជាជនមួយចំនួនរួមទាំងដូនជី ដែលបានធ្វើឡើងដោយកងទ័ពខ្មែរក្រហម នៅពេលដែលកងទ័ពទាំងនោះចូលកាន់កាប់ឧត្តុង្គ[៣៦២]។ ទោះបីជាអ្នកស្រុកទាំងនោះមិនចងចាំថាបានឃើញសាកសពទាហានរបបសាធារណរដ្ឋខ្មែរ ឬ បានឮការរាយការណ៍ជាក់លាក់ណាមួយអំពីការសម្លាប់នេះក្តី ក៏អ្នកស្រុកទាំងនោះបានឃើញដោយផ្ទាល់នូវសាកសពដូនជីប្រហែលប្រាំមួយនាក់នៅជើងភ្នំក្បែរវត្ត[៣៦៣]។

១២៥. សាក្សី នូ ម៉ៅ បានផ្តល់សក្ខីកម្មថា គាត់បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការឃុំបន្ទាប់ពីការជម្លៀស ហើយគាត់ត្រូវបានគេប្រាប់ថា ទាហានរបបសាធារណរដ្ឋខ្មែរបានចាញ់នៅឧត្តុង្គ ហើយប្រជាជនត្រូវបានគេជម្លៀសទៅកាន់ភូមិត្រពាំងត្រើញ[៣៦៤]។ គេបានប្រាប់ដល់គាត់ថា អ្នកដែលត្រូវបានគេជម្លៀសបានស្លាប់ដោយសារការអត់ឃ្លាន និងជំងឺ ប៉ុន្តែគាត់មិនបានដឹងថាទាហានត្រូវបានគេសម្លាប់នោះទេ[៣៦៥]។ ទោះបីជាយ៉ាងណាក៏ដោយ មួយខែក្រោយមក នៅក្នុងសន្ទរកថាដែលបានថ្លែងនៅប្រទេសកូរ៉េខាងជើង ខៀវ សំផន បានលើកឡើងយ៉ាងច្បាស់អំពីអ្វីដែលបានកើតឡើង និងនរណាដែលត្រូវកំណត់ថាជាគោលដៅ៖ “ថ្ងៃទី ១៨ ខែ មីនា កន្លងទៅនេះ កងទ័ពប្រជាជនរំដោះជាតិកម្ពុជារបស់យើងបានរំដោះទីក្រុងមួយទៀត គឺទីក្រុងឧត្តុង្គ ដោយកម្ទេចចោលឲ្យអស់នូវកងទ័ពអាយ៉ងទាំងអស់ដែលនៅទីនោះ ហើយនឹងកម្លាំងជំនួយពួកវា ដែល

---

[៣៦១] ប្រតិចារឹក ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ (កាំង ហ្គេកអ៊ាវ ហៅ ឌុច) សំណុំរឿង ០០១ ទំព័រ ២៤។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩ (អ៊ុច ស៊ីន) សំណុំរឿង ០០១ ទំព័រ ៨០-៨១ (កូនក្មេងជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរ ម-១៣ នៅពេលដែលក្រុងឧត្តុង្គបែក)។

[៣៦២] ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៨-៥៩; ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៤។

[៣៦៣] ប្រតិចារឹក ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៨-៥៩។

[៣៦៤] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣៣-៣៤។

[៣៦៥] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣៣-៣៤។

ក្នុងនោះខ្មាំងចំនួនជាង ៥.០០០ នាក់ ត្រូវបានកម្ទេច ហើយ ១.៥០០ នាក់ ត្រូវចាប់បាន”[៣៦៦]។ គាត់មិនបានបញ្ជាក់ច្បាស់លាស់ ថាតើខ្មាំងដែលត្រូវបានកម្ទេចចោល ត្រូវបានសម្លាប់ចោលនៅក្នុងអំឡុងពេលប្រយុទ្ធគ្នា ឬក្រោយពេលដែលខ្មាំងទាំងនោះត្រូវចាប់ខ្លួនបាន និងទម្លាក់អាវុធចុះ ឬក៏យ៉ាងណា នោះទេ។

១២៦. ព្រឹត្តិប័ត្រផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានចំណងជើងថា “ដំណឹងពីកម្ពុជា” ចុះខែ មេសា ឆ្នាំ ១៩៧៤ បានរៀបរាប់អំពីការកាន់កាប់ក្រុងឧត្តុង្គផ្សេងវិញ ដោយបានលើកឡើងថា “នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៤ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានរំដោះឧត្តុង្គបានទាំងស្រុង។ ខ្មាំងមួយកងពលត្រូវបានកម្ទេចចោលទាំងស្រុង ហើយប្រជាជនចំនួន ៣០.០០០ នាក់ នៅក្នុងក្រុងនេះ និងតំបន់នៅជុំវិញបានទៅដល់តំបន់រំដោះដោយជោគជ័យ។ ទាល់តែកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបំផ្លាញទាំងស្រុងនូវប្រព័ន្ធទីតាំងទ័ព អំណាចរដ្ឋបាល ជំរំឃុំឃាំង មជ្ឈមណ្ឌលសន្តិភាពនៅក្រុងឧត្តុង្គរួចហើយ ទើបពួកអាក្បត់ប្រញាប់ប្រញាល់បញ្ជូនកម្លាំងជំនួយ ដើម្បីដណ្ដើមយកក្រុងឧត្តុង្គវិញ។ ប៉ុន្តែ កម្លាំងជំនួយនេះ ត្រូវបានកម្ទេចយ៉ាងដំណំ និងសម្លាប់ចោលជាច្រើននាក់”[៣៦៧]។

១២៧. ផ្អែកតាមការលើកឡើងខាងលើ អង្គជំនុំជម្រះជឿជាក់ថា គោលនយោបាយរបស់បក្ស-កុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពតាំងពីមុនឆ្នាំ ១៩៧៥ មកម្ល៉េះ។ គោលនយោបាយនេះមានភាពខុសៗគ្នាអាស្រ័យលើ

---

[៣៦៦] ព្រឹត្តិប័ត្រព័ត៌មានរបស់រណសិរ្សរួបរួមជាតិកម្ពុជា *ដំណឹងពីកម្ពុជា លេខ ៦៩៨* ឯកសារ E3/167 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៤ ទំព័រ ២៤-២៥ ERN (ភាសាខ្មែរ) 00596141។ សូមមើលផងដែរ ឯកសារដោយ កែ ពកៈ ស្វ័យជីវប្រវត្តិរបស់ កែ ពក ពីឆ្នាំ ១៩៤៩-១៩៨៥ ឯកសារ E3/2782 ERN (ភាសាអង់គ្លេស) 0089711 (លើកឡើងថា ក្រោយពីគ្រប់គ្រងបានក្រុងឧត្តុង្គពីកងពលធំលេខ៨០នៃរបបសាធារណរដ្ឋខ្មែរ កងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា “បានកម្ទេចខ្មាំង និងរឹប-អូសបាន រថក្រោះ កាំភ្លើងធំ និងគ្រាប់រំសេវរាប់ពាន់តោន”។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៣៩-៤០ (នៅក្នុងឯកសារដើមនៃឯកសារ E3/2782)។

[៣៦៧] ទីភ្នាក់ងារព័ត៌មានកម្ពុជា ឯកសារ E3/114 ទំព័រ១១-១២ ERN (ភាសាខ្មែរ) S 00662258-S00662259។ *សូមមើលផងដែរ* ខៀវ សំផន អំពាវនាវឲ្យបង្កើនការតស៊ូប្រយុទ្ធ នៅថ្ងៃទី ១៥ ខែ មីនា (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ចុះខែ មីនា ឆ្នាំ ១៩៧៥) ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700235 (“យើងបានរំដោះឧត្តុង្គ និងទីប្រជុំជនសំខាន់ៗមួយចំនួន [...] សរុបមក ខ្មាំងកំពុងស្ថិតក្នុងស្ថានការណ៍លំបាកគ្រប់ទិសទី។ ទាហានរបស់ខ្មាំងបានបាក់ទឹកចិត្ត ធ្លាក់ក្នុងសភាពអស់សង្ឃឹម និងកំពុងបាក់ទ័ពនៅគ្រប់ទីកន្លែង។ [...] កងកម្លាំងរបស់ខ្មាំងអាចដឹងយ៉ាងច្បាស់ថា បើសិនជាពួកគេទទួលបញ្ជាឲ្យបន្តច្បាំងជាមួយពួកយើងទៀតនោះ ពួកគេនឹងត្រូវស្លាប់”)។

កាលៈទេសៈ និងទីកន្លែង[៣៦៨]។ ប៉ុន្តែ ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជាកាន់តែរីករាលដាល ហើយការអនុវត្តសិទ្ធិអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើកម្មាភិបាល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ក៏កាន់តែមានការកើនឡើង ដូច្នេះហើយ គោលនយោបាយនេះ ដែលដំបូងឡើយមានលក្ខណៈមិនសូវតឹងរ៉ឹង បែរជាកាន់តែមានលក្ខណៈដាច់ខាត ហើយក្នុងករណីមួយចំនួនក៏មានការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរក្នុងទ្រង់ទ្រាយធំ ក្រោយពេលដែលពួកគេត្រូវបានចាប់ខ្លួន។ គោលនយោបាយដែលបានអនុវត្ត មានភាពផ្ទុយគ្នាជាមួយនឹងគោលនយោបាយផ្លូវការ ដែលបានផ្សព្វផ្សាយដោយរណសិរ្សរួបរួមជាតិកម្ពុជា។ គោលនយោបាយផ្លូវការនេះបានសន្យាផ្តន្ទាទោសប្រហារជីវិតតែចំពោះ "ជនមហាក្បត់ទាំង ៧ នាក់" ប៉ុណ្ណោះ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងប្រទេស។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលមានចំនួនរាប់ពាន់នាក់នោះ ត្រូវបានគេសម្លាប់ក្នុងទ្រង់ទ្រាយធំភ្លាមៗក្រោយពីក្រុងឧត្តុង្គត្រូវបានកាន់កាប់ដោយខ្មែរប្រហម ហើយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានដឹងអំពីហេតុការណ៍នេះ ដូចបានកត់សម្គាល់ខាងក្រោម មេដឹកនាំទាំងនេះបានពិភាក្សាគ្នាអំពីបញ្ហានេះក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមដែលធ្វើឡើងនៅខែ មិថុនា ឆ្នាំ ១៩៧៤[៣៦៩]។

### ៣.៣.៥ ការរៀបការដោយបង្ខំ

១២៨. ដីកាដំណោះស្រាយលើកឡើងថា នៅមុនឆ្នាំ ១៩៧៥[៣៧០] និងនៅក្រោយឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំឱ្យមានការរៀបអាពាហ៍ពិពាហ៍ និងជំរុញឱ្យធ្វើការបង្កកំណើត ដើម្បីបង្កើនចំនួនប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[៣៧១]។ អង្គជំនុំជម្រះបានពិនិត្យភ័ស្តុតាង

---

[៣៦៨] ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧១-៧៣។

[៣៦៩] សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៥២ ។

[៣៧០] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤៧ ។

[៣៧១] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ១៨-១៩ (ប្រទេសកម្ពុជាមានដីច្រើន ហើយគេនិយាយថា ប្រទេសនេះត្រូវការប្រជាជនពី ២០ ទៅ ៣០ លាននាក់ដើម្បីការពារទឹកដី)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧-៨ (ជារឿយៗ ការរៀបការរវាងទាហាន និងនារីក្មេងៗគឺដើម្បីគោលបំណងជាក់ស្តែងក្នុងការបង្កើតកូន)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៨២ (គោលនយោបាយគឺដើម្បីបង្កើតប្រជាជនឱ្យបានច្រើន។ ការរៀបការដោយបង្ខំ និងការទទូចឱ្យប្តីប្រពន្ធដែលរៀបការហើយបង្កើតកូនគឺស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយនេះ)។ សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារE3/9 ឆ្នាំ ២០០៤ ទំព័រ៣២៥-៣២៦ ERN(ភាសាអង់គ្លេស)00396533-00396534 ("សេរីភាព

មួយចំនួន ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយមានការរៀបចំ និងដោយមិនមានការស្ម័គ្រចិត្ត រួមទាំងភ័ស្តុតាងដែលបង្ហាញថា នៅពេលខ្លះ អ្នកដែលពុំព្រមរៀបការ ត្រូវបានគេវាយដំ រំលោភផ្លូវភេទ ឬសម្លាប់ចោល[៣៧២]។ មានករណីមួយចំនួន ដែលប្តីប្រពន្ធដែលអង្គការបានរៀបការឲ្យ ត្រូវ

---

ជ្រើសរើសប្តីប្រពន្ធត្រូវបានថ្កោលទោសជាចំហតែម្តង។ ដើម្បីគូសបញ្ជាក់អំពីទិដ្ឋភាពសង្គម ការរៀបការត្រូវបានរៀបចំឡើងជាសមូហភាពសម្រាប់ប្តីប្រពន្ធតិចបំផុត ១០ គូ ម្តង។ ក្រោយពេលរួមដំណេករួចហើយនោះ, ជាធម្មតា ប្តីប្រពន្ធបានរស់នៅបែកគ្នា”)។ សម័យប្រជុំលើកទី ៣២ នៃមហាសន្និបាតអង្គការសហប្រជាជាតិ (សេចក្តីថ្លែងការណ៍របស់ អៀង សារី) ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ ត្រង់ ERN (ភាសាអង់គ្លេស) 00079815 (កម្ពុជាប្រជាធិបតេយ្យត្រូវការចំនួនប្រជាជនពីចន្លោះ ១៥ ទៅ ២០ លាន នាក់ ក្នុងរយៈពេលដប់ឆ្នាំខាងមុខ)។ ការសន្ទនារបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងគណៈប្រតិភូបែលស៊ីក ឯកសារ E3/5715 ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00106284 (បក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិប-តេយ្យមានផែនការបង្កើនចំនួនប្រជាជនពី ១៥ ទៅ ២០ លាន ក្នុងរយៈពី ១០ ទៅ ១៥ ឆ្នាំ)។ របាយការណ៍របស់សារព័ត៌មាន Reuter ឯកសារ E3/1591 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ERN (ភាសាខ្មែរ) 00291029 (អៀង ធីរិទ្ធ លើកឡើងថា ចំនួនប្រជាជនបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដោយសារកំណើតកុមារជាច្រើននាក់ ហើយកុមារទាំងនេះទទួលទានបរិបូណ៍)។ ឯកសារបោះពុម្ពផ្សាយរបស់យុវជន និងយុវនារីបក្សកុម្មុយនីស្តកម្ពុជា៖ លោកទស្សនៈ បដិវត្ត និងមិនបដិវត្ត ចំពោះបញ្ហាកសាងគ្រួសារ ឯកសារ E3/775 ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00407096-00407108។ ទង់បដិវត្ត ចុះខែតុលា-វិច្ឆិកា ១៩៧៥ ឯកសារ E3/748 ERN (ភាសាខ្មែរ) 00063244 (ដើម្បីបង្កើតការបង្កបង្កើនផល យើងត្រូវបង្កើនចំនួនប្រជាជនឲ្យបានលឿន)។ ទង់បដិវត្ត ចុះខែធ្នូ ឆ្នាំ ១៩៧៦ ដល់ខែមករា ឆ្នាំ ១៩៧៧ ឯកសារ E3/25 ERN (ភាសាខ្មែរ) 00063054 (“យើងត្រូវការប្រជា-ជនពី ១៥ ទៅ ២០ លាន ទើបគ្រប់គ្រាន់នឹងដី យើង”)។ ទង់បដិវត្ត ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/11 ERN (ភាសាខ្មែរ) 00063182-00063183 (យើងត្រូវការឲ្យមានប្រជាជនកម្ពុជាចំនួនពី ១៥ លាន ទៅ ២០ លាន ក្នុងអំឡុងជាង ១០ ឆ្នាំ ខាងមុខ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណុប កាន ឯកសារ E3/4884 មិនមានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00539344 (ត្រូវបានប្រាប់ឲ្យផ្តល់កំណើតកូនជូនអង្គការ)។

[៣៧២] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨៧-៨៩ (ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យរៀបការបុរសម្នាក់ក្រោយពេលប្តីរបស់គាត់បានស្លាប់។ គាត់ត្រូវបានវាយដំ និងឃុំឃាំងនៅពេលគាត់មិនព្រមរៀបការ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កិះ ខន ឯកសារ E3/5008 ERN (ភាសាខ្មែរ) 00559294-00559295 (ដោយមានការភ័យខ្លាចគេហៅទៅអប់រំកែប្រែ ឬ សម្លាប់ចោល ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបការជាមួយមនុស្សម្នាក់ដែលអង្គការជ្រើសរើសឲ្យ និងដើម្បីផ្តល់កំណើតកូន។ កងឈ្លបបានឃ្លាំងមើលពួកគេនៅក្នុងយប់ថ្ងៃរៀបការ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ប៉ែន សុចាន់ ឯកសារ E3/4779 ERN (ភាសាខ្មែរ) 004998255 (គាត់មានអាយុ ១៦ ឆ្នាំ។ គាត់ត្រូវបានគេបង្ខំឲ្យរៀបការ ត្រូវបានគេបៀតបៀន និងរំលោភសន្ថវៈ នៅពេលគាត់មិនព្រមរួមដំណេកជាមួយនឹងប្តីរបស់គាត់ នៅពេលកងឈ្លបតាមដាន)។

បានអង្គការឃ្លាំមើលដើម្បីឲ្យពួកគេធ្វើការបង្កកំណើត[៣៧៣]។

១២៩. ភ័ស្តុតាងផ្សេងទៀតបង្ហាញថា អង្គការបានរៀបចំអាពាហ៍ពិពាហ៍ ប៉ុន្តែមិនបានចាប់បង្ខំឡើយ។ សាក្សីទាំងនេះបានអះអាងថា អង្គការបានធ្វើជាឪពុកម្តាយ ហើយនៅក្នុងប្រពៃណីកម្ពុជា ឪពុកម្តាយជាអ្នករៀបចំអាពាហ៍ពិពាហ៍ឲ្យកូន[៣៧៤]។ ខៀវ សំផន បានអះអាងថា គាត់មិនបានដឹងអ្វីទាល់តែសោះ អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ។ តាមគាត់ដឹង គ្មានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបែបនេះបានកើតឡើងនៅក្នុងទីក្រុងភ្នំពេញឡើយ[៣៧៥]។

១៣០. ប៉ុន្តែ ភ័ស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រចិត្តនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍គឺជា

---

[៣៧៣] ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ប៊ុម ណោន ឯកសារ E3/5044 ERN (ភាសាខ្មែរ) 00562305 (“លុះនៅពេលព្រឹក គេបានទៅរាយការណ៍ដល់ប្រធានកងយុវជនឈ្មោះ សូ វ៉ន ពីការដែលខ្ញុំមិនព្រមរស់នៅជាមួយគ្នា បន្ទាប់ពីគេរាយការណ៍រួច ប្រធានកងបានហៅខ្ញុំទៅណែនាំ បើសិនជាខ្ញុំនៅតែមិនព្រមរស់នៅជាមួយប្តីរបស់ខ្ញុំទេនោះ ប្រយ័ត្នគេយកទៅវ៉ៃចោល”)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ម៉ាន យូសុះ ឯកសារ E3/4745 ERN (ភាសាខ្មែរ) 00579517-00579518 (កងឈ្លបតាមដានប្តីប្រពន្ធដែលត្រូវបានគេបង្ខំឲ្យរៀបការ។ គាត់បានឃើញប្តីប្រពន្ធមួយគូនេះ “មិនចុះសម្រុងគ្នា” ត្រូវបានគេយកទៅសម្លាប់ចោល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ស្មាន ឆវី ឯកសារ E3/5066 ERN (ភាសាខ្មែរ) 00585434-00585435 (អង្គការបានតាមដានប្តីប្រពន្ធមួយគូ ហើយបានដឹងថាមិនមានការចុះសម្រុងគ្នា ដូច្នេះ អង្គការត្រូវតែយកទៅកសាង)។

[៣៧៤] ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣(François PONCHAUD)ទំព័រ៥១។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ១៨-១៩, ៧០-៧១ (ការរៀបការពុំត្រូវបានបង្ខំឡើយ ប៉ុន្តែគេរៀបចំឲ្យរៀបការនៅតាមអង្គភាពនីមួយៗ ហើយត្រូវយល់ព្រមពីអង្គការ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស រឿន) ទំព័រ ៥០ (ការរៀបការត្រូវបានរៀបចំឲ្យ ប៉ុន្តែ គូដែលត្រូវរៀបការនេះត្រូវជួបគ្នា និងយល់ព្រមជាមុនសិន)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ២៧-២៩, ៣១-៣២, ៦៨-៦៩ (ការរៀបការកម្មាភិបាលត្រូវបានថ្នាក់លើរៀបចំឲ្យ ហើយគាត់បានយល់ព្រមរៀបការ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ (សគីម ល្មុត) ទំព័រ ៥៩-៦០ (ការរៀបការត្រូវបានរៀបចំ ប៉ុន្តែពុំមានការបង្ខំឡើយ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៤៨-៤៩ (ការរៀបការត្រូវបានរៀបចំឲ្យ ប៉ុន្តែ គេសុំការយល់ព្រមពីនារីជាមុន)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (រម៉ាម យុន) ទំព័រ ៤៣-៤៥ (នៅក្នុងសម័យ ប៉ុល ពត ប្រជាជនពុំបានរៀបការទេ ពួកគេគ្រាន់តែនៅជាមួយគ្នាតែប៉ុណ្ណោះ)។ សូមប្រៀបធៀបជាមួយ ប្រតិចារឹក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ (ខៀវ នៅ) ទំព័រ ៥១-៥២ (ថ្នាក់លើនៅក្នុងឃុំត្រូវយល់ព្រមដល់ការរៀបការ ប៉ុន្តែ គេគ្រាន់តែជូនដំណឹងទៅថ្នាក់លើថា ពួកគេនឹងរៀបការតែប៉ុណ្ណោះ)។

[៣៧៥] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៧០។

01006421



គោលនយោបាយមួយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ភ័ស្តុតាងពាក់ព័ន្ធខ្លឹមសារ និងការអនុវត្តគោល-នយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និង វិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

១៣១. ក្រោយពីបានពិនិត្យទៅលើអត្ថិភាព នៃគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ រួចមក នៅពេលនេះ អង្គជំនុំជម្រះនឹងពិចារណាទៅលើហេតុការណ៍ទាំងឡាយ ដែលបានកើតឡើងនៅមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

## ៣.៤ ការសម្រេច "រំដោះ" និងជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត

១៣២. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចជាសមូហភាពក្នុងពេលប្រជុំជាច្រើនដងចាប់តាំងពីឆ្នាំ ១៩៧៣ អំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[៣៧៦]។

### ៣.៤.១ ខែ មិថុនា ឆ្នាំ ១៩៧៤

១៣៣. នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នាជាងកន្លះខែ នៅភូមិមាយ ស្រុកព្រែកគោក នៅជិតមាត់ទន្លេមេគង្គ ដើម្បីពិភាក្សាគ្នាអំពីផែនការវាយសម្រុកចុងក្រោយ និងផែនការរំដោះទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត[៣៧៧]។ នួន ជា បានសារភាពថា

---

[៣៧៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១០-១៣។ ទោះបី នួន ជា ចង្អុលបង្ហាញថា កិច្ចប្រជុំលើប្រធានបទនេះបានចាប់ផ្តើមលើកឡើងនៅក្នុងឆ្នាំ ១៩៧៣ ក៏ដោយ ក៏អង្គជំនុំជម្រះត្រូវបានភាគីបង្ហាញត្រឹមតែភ័ស្តុតាងលម្អិតនៃកិច្ចប្រជុំនានាដែលបានចាប់ផ្តើមនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ តែប៉ុណ្ណោះ។

[៣៧៧] ទង់បដិវត្ត ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/11 ទំព័រ ៨២-៨៤ ERN (ភាសាខ្មែរ) 00063162-00063163។ ទង់បដិវត្ត ឯកសារ E3/747 ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៤៤-៤៦ ERN (ភាសាខ្មែរ) 000646446-000646447។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២(រ៉ាចាម គុន *ហៅ* ភី ភួន) ទំព័រ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៧៣-៧៤, ៧៦។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២។ ផ្អែកតាមកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង ភី ភួន, ពីដំបូង Philip SHORT បានកំណត់ថ្ងៃសម្ភាសន៍នេះបានធ្វើឡើងនៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៤ ប៉ុន្តែ ក្រោយមកបានផ្តល់សក្ខីកម្មថា នៅពេលនេះ ក៏ជឿថា កិច្ចសម្ភាសន៍

គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ហើយបានចូលរួមសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង[៣៧៨]។ អ្នកផ្សេងទៀតដែលមានវត្តមាននៅក្នុងពេលនោះដែរ រួមមាន ប៉ុល ពត, សោ ភឹម, កុយ ធួន, តា ម៉ុក វន វ៉េត, វស់ ញឹម និង សុន សេន[៣៧៩]។ អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ បានអនុម័តទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[៣៨០]។

១៣៤. ទោះបីជា អៀង សារី បានអះអាងថា គាត់មិនបានចូលរួមក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ហើយ នួន ជា[៣៨១] បានគាំទ្រទៅលើការអះអាងនេះក្តី ក៏គាត់បានទទួលស្គាល់នៅក្នុងកិច្ចសម្ភាសន៍មួយជាមួយ Stephen HEDER ថា គាត់បានពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាមួយ ប៉ុល ពត បន្ទាប់ពីគាត់វិលត្រឡប់មកពីប្រទេសចិនវិញ។ ផ្អែកទៅលើពេលវេលានៃការពិភាក្សានេះ និងសក្ខីកម្មរបស់ ភី ភួន ដែលលើកឡើងថា អៀង សារី ស្ថិតនៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ នោះ អង្គជំនុំជម្រះជឿជាក់ថា ការពិភាក្សានេះពិតជាបានកើតឡើងនៅពេលប្រហែលជាក្បែរៗកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ នោះ ប្រសិនបើមិនស្ថិតនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំគណៈកម្មាធិការនោះទេ។ ដោយសារតែមានការសាកសួរអំពីចំណុចនេះពីថ្នាក់ដឹកនាំប្រទេសចិន អៀង សារី បានសួរ ប៉ុល ពត ថា តើមានផែនការអ្វីទៀតសម្រាប់ប្រជាជនចំនួនបីលាននាក់នោះ បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ។ ប៉ុល ពត បានប្រាប់ អៀង សារី ថា "គេមានបទពិសោធន៍អស់ហើយ [...]។ បញ្ហាហ្នឹងស្រួលទេ ដោះស្រាយស្រួល [...] ពីព្រោះ យើងខ្មែរមានគោលគំនិតច្បាស់លាស់ ហើយចំពោះបញ្ហានេះ គេធ្លាប់ដោះស្រាយខេត្តស្ទឹងត្រែង ខេត្តក្រចេះអីគេធ្វើបានហើយ។ ដូច្នេះបញ្ហាហ្នឹង ត្រូវតែជម្លៀសចេញពី

---

នេះធ្វើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤។ *សូមមើល* សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ២៥៦ ERN (ភាសាអង់គ្លេស) 00396456។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៩-៥១, ៨៩-៩២។

[៣៧៨] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១២(ជនជាប់ចោទ នួន ជា) ទំព័រ១០-១៣។ ប្រតិចារឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២(រ៉ូចាម តុន ហៅ ភី ភួន) ទំព័រ ៩-១០, ៣២-៣៣, ៣៦-៣៧។ សូមមើល ផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣ ។

[៣៧៩] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន *ហៅ* ភី ភួន) ទំព័រ ៩-១០, ៣២-៣៣, ៣៦-៣៧។

[៣៨០] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន ហៅ ភី ភួន) ទំព័រ ១៤, ២០-២២។

[៣៨១] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៤។

ភ្នំពេញដែរ ទើបដោះស្រាយរួច"[៣៨២]។ ហេតុការណ៍ទាំងឡាយនៅឧត្តុង្គក៏ត្រូវបានយកមកពិភាក្សាលម្អិតផងដែរ។ យោងតាមលោក Philip SHORT "វាគឺជាជោគជ័យមួយនូវអ្វីដែលបានកើតឡើងនៅឧត្តុង្គ ដែលនេះហើយ គឺជាមូលហេតុធ្វើឱ្យមេដឹកនាំសម្រេចវាយយកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ [...]"[៣៨៣]។ ទោះបីជាការលើកឡើងរបស់ ប៉ុល ពត ទៅកាន់សហគមន៍អន្តរជាតិថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមិនត្រូវបាន "រៀបចំជាមុន" ក៏ដោយ ក៏ភស្តុតាង បង្ហាញច្បាស់ថា បញ្ហានេះពិតជាត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំជាច្រើនរបស់គណៈកម្មាធិការមជ្ឈិម ដែលចាប់ផ្តើមក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ហើយមានការលើកសំណើក្នុងការរំដោះទីក្រុងភ្នំពេញ ហើយបន្ទាប់មកជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[៣៨៤]។

១៣៥. មានការផ្តល់ព័ត៌មានខុសគ្នា អំពីថាតើ ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំដែលបានធ្វើការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬអត់។ ខៀវ សំផន អះអាងថា គាត់មិនបានចូលរួមប្រជុំនោះទេ ហើយគាត់ក៏មិននៅក្នុងប្រទេសកម្ពុជាដែរ នៅពេលប្រជុំនោះ[៣៨៥]។ នួន ជា គាំទ្រការរៀបរាប់ហេតុការណ៍ទាំងនេះ ដោយបានលើកឡើងថា ខៀវ សំផន មិនមាន

---

[៣៨២] បទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00062457-0062459 (ប៉ុន្តែបញ្ហាអំពីថាតើ វាជាការជម្លៀសប្រជាជនទាំងអស់ ឬជាការជម្លៀសតែកសិករមួយផ្នែកប៉ុណ្ណោះ មិនត្រូវបានសម្រេចដាច់ណាត់នៅឡើយទេ)។

[៣៨៣] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip Short) ទំព័រ ៥០-៥១។

[៣៨៤] កិច្ចសម្ភាសន៍ជាមួយសមមិត្ត ប៉ុល ពត (ព័ត៌មានពីប្រទេសកម្ពុជា) ឯកសារ E3/1583 ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៧៨ ERN (ភាសាអង់គ្លេស) 00011316-00011317។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00752089-00752090។ SWB/របាយការណ៍តាមដាន៖ *សន្និសីទសារព័ត៌មាន របស់ ប៉ុល ពត នៅក្នុងទីក្រុងប៉េកាំង* ឯកសារ E3/2728 ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00633034-00633036។ *កម្ពុជាផ្តល់ហេតុផលក្នុងការជម្លៀសប្រជាជន (កាសែត* New York Times) ឯកសារ E3/2316 ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៧។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពាក្យ "រំដោះ" ត្រូវបានខ្មែរក្រហមខ្លួនឯងប្រើប្រាស់ ដើម្បីពិពណ៌នាអំពីការទទួល ជ័យជំនះលើកងកម្លាំងរបបសាធារណរដ្ឋខ្មែរ ការកាន់កាប់តំបន់នានា ដែលរបបសាធារណរដ្ឋខ្មែរគ្រប់គ្រង និងការដាក់ឱ្យប្រជាជនស្ថិតក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហមផ្ទាល់។ ការវាយតម្លៃត្រឹមត្រូវទៅលើព្រឹត្តិការណ៍នេះគឺមានពន្យល់នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះមិនយកការប្រើប្រាស់ពាក្យរបស់ខ្មែរក្រហមនេះនោះទេ។

[៣៨៥] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៥២-៥៣។ *ខៀវ សំផន* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣២។

វត្តមាននៅក្នុងពេលប្រជុំនោះទេ ហេតុដូច្នេះ ខៀវ សំផន មិនបានដឹងអំពីការធ្វើសេចក្តីសម្រេចនោះឡើយ[៣៨៦]។ ផ្ទុយទៅវិញ សាក្សី ភី ភួន បានឆ្លើយថា ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ នៅមាឃ និងបានយល់ស្របលើផែនការជម្លៀសប្រជាជនចេញពីទីក្រុង[៣៨៧]។

១៣៦. ទោះបីជា ខៀវ សំផន រួមជាមួយនឹង អៀង សារី បានធ្វើទស្សនកិច្ចប្រទេសជាច្រើនចាប់ពីខែ មីនា ដល់ ខែ ឧសភា ឆ្នាំ ១៩៧៤ នៅក្នុងដំណើរទស្សនកិច្ចទៅ អាហ្វ្រិក អឺរ៉ុប និងអាស៊ី ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរណសិរ្សរួបរួមជាតិកម្ពុជាក៏ដោយ[៣៨៨] ក៏ ខៀវ សំផន បានវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ នៅពេលកិច្ចប្រជុំនោះបានប្រព្រឹត្តឡើង[៣៨៩]។ អត្ថបទសារព័ត៌មានមួយចំនួនបានរាយការណ៍អំពីទស្សនកិច្ចរបស់ ខៀវ សំផន នៅតាមបណ្តារដ្ឋបរទេសមួយចំនួននៅក្នុងខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៤ រួមមានប្រទេសចិនប្រទេសវៀតណាម និងប្រទេសឡាវ។ អត្ថបទសារព័ត៌មានចំនួនពីរ ដោយអត្ថបទមួយបានដកស្រង់សុន្ទរកថារបស់ ខៀវ សំផន បញ្ជាក់អំពីវត្តមានរបស់គាត់នៅក្នុងប្រទេសឡាវនៅក្នុងខែ

---

[៣៨៦] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៤។

[៣៨៧] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ថាម តុន ហៅ ភី ភួន) ទំព័រ ១៤, ៣៦-៣៧។

[៣៨៨] ទូរលេខក្រសួងការបរទេសអាមេរិក កម្មវត្ថុ៖ ខៀវ សំផន ធ្វើទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ឯកសារ E3/2939 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៧៤ កថាខណ្ឌ ១ ERN (ភាសាខ្មែរ) 00738341-00738342 (បានចេញនៅពេល ខៀវ សំផន បញ្ចប់ទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ២៧ ខែ ឧសភា)។ ទូរលេខក្រសួងការបរទេសអាមេរិក កម្មវត្ថុ៖ ទស្សនកិច្ចរបស់ ខៀវ សំផន ឯកសារ E3/3315 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៧៤ កថាខណ្ឌ ៤ ERN (ភាសាខ្មែរ) 00790011-00790013 (ខៀវ សំផន នឹងចាកចេញពីប្រទេសរ៉ូម៉ានីទៅកាន់ប្រទេសអាល់ហ្សេរីនៅថ្ងៃទី០២ ខែ ឧសភា)។ *ខៀវ សំផន ធ្វើគារវកិច្ចរដ្ឋមន្ត្រីកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ កុម្ភៈ ឆ្នាំ ១៩៧៥) ឯកសារ E3/488 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00782147 (ខៀវ សំផន រំលឹកដំណើរទស្សនកិច្ចផ្លូវការទៅកាន់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៤)។ របាយការណ៍ដោយលោក ឡេអុង ទ្រីវ៉ែរ ៖ *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ចុះខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២៨-២៩ ERN (ភាសាខ្មែរ) 00538861-00538862។ សៀវភៅកំណត់ត្រារបស់ ស្នួង ស៊ីគឿន ឯកសារ E3/40, ERN (ភាសាខ្មែរ) 00583605។

[៣៨៩] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៨-៥៩; ប្រតិចារឹក ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១២ (ស្នួង ស៊ីគឿន) ទំព័រ ៧៦-៧៨ (ខៀវ សំផន និង អៀង សារី នៅក្នុងប្រទេសវៀតណាម ចាប់ពីខែ ឧសភា រយៈពេលយ៉ាងហោចណាស់មួយសប្តាហ៍មុនពេលវិលត្រឡប់មកប្រទេសកម្ពុជាវិញ)។

មិថុនា ឆ្នាំ ១៩៧៤[៣៩០]។ របាយការណ៍ទាំងនេះមិនបានបញ្ជាក់អំពីកាលបរិច្ឆេទឲ្យបានច្បាស់លាស់ ឬរយៈពេលនៃទស្សនកិច្ចរបស់ ខៀវ សំផន នាពេលនោះឡើយ។ ប៉ុន្តែ សារទូរលេខមួយរបស់ស្ថានទូតអូស្ត្រាលីនៅក្នុងសម័យនោះបង្ហាញថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូអូស្ត្រាលីទៅកាន់ប្រទេសឡាវ ត្រូវបានពន្យារពេល ដោយសារតែ ខៀវ សំផន បានធ្វើទស្សនកិច្ចមួយសប្តាហ៍ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៨ ខែ មិថុនា នៅក្នុងទីក្រុង Sam Neua ប្រទេស ឡាវ[៣៩១]។

១៣៧. ចំណុចនេះស៊ីសង្វាក់គ្នាជាមួយនឹងសក្ខីកម្ម និង សៀវភៅកំណត់ត្រាលម្អិតរបស់ សួង ស៊ីគឿន។ សួង ស៊ីគឿន បានធ្វើដំណើរពីទីក្រុងប៉េកាំងទៅកាន់ទីក្រុងហាណូយ ជាមួយនឹង អៀង សារី និង ខៀវ សំផន នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៤ ដែលជាថ្ងៃកំណើតរបស់ភរិយា សួង ស៊ីគឿន[៣៩២]។ បន្ទាប់ពីស្នាក់នៅក្នុងទីក្រុងហាណូយរយៈពេលមួយសប្តាហ៍មក[៣៩៣] ពួកគាត់បានធ្វើដំណើរទៅប្រទេសឡាវរយៈពេលពីរថ្ងៃ មុនពេល ខៀវ សំផន និង អៀង សារី វិលត្រឡប់

[៣៩០] សេចក្តីសង្ខេបនៃវិទ្យុផ្សាយសម្លេងទូទាំងពិភពលោក៖ ឯកសារ E3/1379 ចុះថ្ងៃទី០៥ ដល់ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00742366-00742367 (របាយការណ៍សង្ខេបនៃកំណត់ត្រាវិចារណកថាស្តីពីទស្សនកិច្ចរបស់ ខៀវ សំផន នាខែ មិថុនា ឆ្នាំ ១៩៧៤ ទៅកាន់តំបន់រំដោះប្រទេសឡាវ)។ *ខៀវ សំផន ទទួលស្វាគមន៍ខួបទី ២៦ របស់កងទ័ពរំដោះប្រជាជនឡាវ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00786913-00786914 (លើកឡើងអំពីដំណើរទស្សនកិច្ចប្រកបដោយមេត្រីភាព ទៅកាន់តំបន់រំដោះប្រទេសឡាវ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤)។

[៣៩១] ទូរលេខ ស្ថានទូតអូស្ត្រាលី កម្មវត្ថុ៖ ព័ត៌មានបន្ថែមទៀតពីដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតអូស្ត្រាលីទៅកាន់ទីបញ្ជាការដ្ឋានរបស់ Pathet Lao នៅក្នុងទីក្រុង Sam Neua ឯកសារ E282.1.14 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៧៤ ERN (ភាសាអង់គ្លេស) 00899053។ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់ឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងសំណើនេះ ដោយសារតែសហព្រះរាជអាជ្ញាពុំបានអនុវត្តការយកចិត្តទុកដាក់សមស្រប នៅក្នុងការទទួលយកសារទូរលេខមុនពេលជំនុំជម្រះ (ឯកសារ E282/2/1/2 កថាខណ្ឌ ៤)។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលនេះ អង្គជំនុំជម្រះយល់ឃើញថា ការដាក់ឯកសារ E282.1.14 នៅចំពោះមុខអង្គជំនុំជម្រះ គឺជាផលប្រយោជន៍នៃយុត្តិធម៌ ដោយឯកសារនេះគាំទ្រផ្នែកខ្លះដល់សំអាងហេតុរបស់មេធាវីការពារក្តី ខៀវ សំផន (*សូមមើល* ឯកសារ E190 កថាខណ្ឌ ១៩-២១)។

[៣៩២] សៀវភៅកំណត់ត្រារបស់ សួង ស៊ីគឿន ឯកសារ E3/40, ERN (ភាសាខ្មែរ) 00583605។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៧៧។

[៣៩៣] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៧៧។

មកតំបន់រំដោះនៅក្នុងប្រទេសកម្ពុជាតាមផ្លូវលំហូជីមិញ[៣៩៤]។ សួង ស៊ីគឿន បានបញ្ជាក់ថា ពួកគាត់ ទាំងពីរនាក់ត្រូវត្រឡប់ទៅប្រទេសកម្ពុជាវិញ ពីព្រោះថា សង្គ្រាមរវាងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងសេនាប្រមុខ លន់ នល់ បានឆាបឆេះកាន់តែធំឡើង ហើយក្នុងនាមជាមេដឹកនាំចលនាតស៊ូ ខៀវ សំផន និង អៀង សារី មានកាតព្វកិច្ចចូលរួមក្នុងចលនាតស៊ូក្នុងប្រទេស[៣៩៥]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន ស្ថិតនៅក្នុងប្រទេសឡាវនៅសប្តាហ៍ទី១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ មុនពេលវិលត្រឡប់មកតំបន់រំដោះនៅក្នុងប្រទេសកម្ពុជាវិញជាមួយ អៀង សារី។

១៣៨. ទស្សនកិច្ចជាផ្លូវការទៅកាន់ប្រទេសចិន ដែលបានលើកឡើងខាងលើ គឺជាទស្សនកិច្ចដ៏មានសារៈសំខាន់យ៉ាងខ្លាំងណាស់។ នៅក្នុងអំឡុងពេលទស្សនកិច្ចនេះ ខៀវ សំផន បានចុះកិច្ចព្រមព្រៀងមួយ ដែលត្រូវបានប្រកាសជាសាធារណៈជាលើកដំបូង ដោយប្រទេសចិននឹងផ្តល់ជាភ័ស្តុភារ និងឧបករណ៍សម្ភារៈយោធាដល់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ដែលនេះគឺជាការផ្តល់ឱ្យលើកទីមួយ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសខែ មករា ឆ្នាំ ១៩៧៣ រវាងសាធារណរដ្ឋវៀតណាមខាងជើង និងសហរដ្ឋអាមេរិក[៣៩៦]។ ទស្សនកិច្ចនេះក៏មានសារៈសំខាន់

---

[៣៩៤] ប្រតិចារឹកថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៧៦-៧៨។ សៀវភៅកំណត់ត្រារបស់ សួង ស៊ីគឿន ឯកសារ E3/40, ERN (ភាសាខ្មែរ) 00583605, 00583606-00583607, 00583608-00583609។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Laurence PICQ ឯកសារ E3/353 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00251053-00251054 (សួង ស៊ីគឿន បានធ្វើដំណើរជាផ្លូវការជាច្រើនជាមួយនឹង អៀង សារី និង នរោត្តម សីហនុ។ សួង ស៊ីគឿន បានចាកចេញពីទីក្រុងប៉េកាំងទៅកាន់ប្រទេសកម្ពុជានៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៤)។ ជីវិតខ្ញុំក្រោមការដឹកនាំរបស់ អៀង សារី៖ សម្រែកប្រឆាំងសេចក្តីអាម៉ាស និងភាពភ័យរន្ធត់តក់ស្លុត (កាសែត ភ្នំពេញប៉ុស្តិ៍) ឯកសារ E3/2381 ចុះថ្ងៃទី ០៤-១៧ ខែ តុលា ឆ្នាំ ១៩៩៦ ERN (ភាសាខ្មែរ) 00243266-00243267 (ស៊ីគឿន បានចាកចេញទៅបម្រើចលនាតស៊ូក្នុងឆ្នាំ ១៩៧៤)។

[៣៩៥] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៧៨។

[៣៩៦] ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ខៀវ សំផន ធ្វើទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ឯកសារ E3/2939 ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៧៤ កថាខណ្ឌ ១ ERN (ភាសាខ្មែរ) 00738341 (ពិពណ៌នាអំពីកិច្ចព្រមព្រៀងយោធាដែលត្រូវបានប្រកាសជាចំហ និងការផ្តល់ជំនួយឥតសំណងជាភ័ស្តុភារ និងឧបករណ៍សម្ភារៈយោធា)។ របាយការណ៍សារព័ត៌មានបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/113 (លើកឡើងថា សាមគ្គីភាពផ្នែកយោធារវាងប្រទេសចិន និងកម្ពុជា ត្រូវបានពង្រឹង)។ របាយការណ៍សារព័ត៌មានបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/1254 (ពិពណ៌នាអំពីការពិភាក្សារវាង ខៀវ សំផន ជាមួយនឹងមន្ត្រីតំណាងប្រទេសចិន ដោយក្រោយពីការពិភាក្សានោះ

យ៉ាងខ្លាំងផងដែរ ដោយសារថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសចិនបានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រជាចំហដល់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ និងប្រទេសអាមេរិកដែលជាអ្នកគាំទ្ររបបនេះ[៣៩៧]។ ទស្សនកិច្ចរបស់ ខៀវ សំផន និង អៀង សារី នៅក្នុងអំឡុងពេលនោះដែរ ទៅកាន់តំបន់រំដោះនៅក្នុងប្រទេសឡាវ និងទៅកាន់ប្រទេសវៀតណាម ក៏មានសារៈសំខាន់ដូចគ្នាដែរ បើពិនិត្យទៅលើកម្រិតនៃការធ្វើបដិសណ្ឋារកិច្ចទទួលពួកគេ និងបញ្ហាមួយចំនួន ដែលត្រូវបានលើកយកមកពិភាក្សាជាមួយនឹងបណ្តាមេដឹកនាំកំពូលរបស់ប្រទេសទាំងនេះ ដែលបញ្ហាទាំងនោះមានដូចជាកិច្ចសហប្រតិបត្តិការខាងផ្នែកយោធា និងនយោបាយ[៣៩៨]។ នៅពេលពិចារណាអំពីទីតាំងភូមិសាស្ត្ររវាងប្រទេសចិន និងប្រទេសកម្ពុជា វៀតណាមមានលទ្ធភាពជួយសម្រួលដល់ការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌពីប្រទេសចិនមកឲ្យបក្សកុម្មុយនីស្តកម្ពុជា ឬបើមិន

---

ខៀវ សំផន បានបញ្ជាក់អំពីសាមគ្គីភាពនៅក្នុងការវាយប្រយុទ្ធរវាងប្រជាជន និងកងទ័ពប្រទេសទាំងពីរ)។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ ជើងទំព័រ ៤៥១ ។

[៣៩៧] ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ខៀវ សំផន ធ្វើទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ឯកសារ E3/2939 ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៧៤ កថាខណ្ឌ ១ ERN (ភាសាខ្មែរ) 00738341 (“ចិនបានផ្តល់កិត្តិយសដល់លោក សំផន និងគណៈប្រតិភូរបស់លោក ដែលជាធម្មតា កិត្តិយសនេះត្រូវបានត្រៀមសម្រាប់ប្រមុខរដ្ឋ។ ក្រៅពីជំនួបជាមួយលោកប្រធាន ម៉ៅ (Mao) លោកនាយករដ្ឋមន្ត្រី ជូ (Chou) និងលោកឧបនាយករដ្ឋមន្ត្រី តេង (Teng) ការអញ្ជើញជាលក្ខណៈបុគ្គលរបស់លោក ចៀង ជីង (Chiang Ching) [...] ក៏បានបង្ហាញពីការគាំទ្ររបស់ពួកឆ្វេងនិយមផងដែរ។ ក្នុងឱកាសនោះ សម្តេច សីហនុ បានដឹងដោយព្រះអង្គឯងថាត្រូវបានគេផ្តល់ឲ្យតួនាទីមួយមិនសូវសំខាន់ដែលស្រដៀងនឹងតួនាទីរបស់តួអង្គបន្ទាប់បន្សំអញ្ជើញដែរ។ ជាការពិត ដំណើរទស្សនកិច្ចនេះហាក់ដូចជាបានបង្ហាញថា ក្រុងប៉េកាំងបោះបង់ព្រះអង្គចោល និងលែងចាត់ទុកព្រះអង្គថាជាសន្លឹកបៀ ដ៏សំខាន់នៅក្នុងកិច្ចការកម្ពុជាទៀតហើយ”)។

[៣៩៨] *ខៀវ សំផន ទទួលស្វាគមន៍ខួបទី ២៦ របស់កងទ័ពរំដោះប្រជាជនឡាវ* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00786912-00786913 (ខៀវ សំផន លើកឡើងអំពី “សាមគ្គីភាព យោធា និងភាតរភាព” ដែលបង្ហាញឲ្យឃើញនៅក្នុងអំឡុងដំណើរទស្សនកិច្ចនាខែ មិថុនា ឆ្នាំ ១៩៧៤ ទៅកាន់តំបន់រំដោះក្នុងប្រទេសឡាវ)។ អត្ថបទបោះពុម្ពផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា៖ ដំណឹងពីប្រទេសកម្ពុជា លេខ ៦៩១ ឯកសារ E3/1238 ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៤ ERN (ភាសាខ្មែរ) 00702019 (ពិពណ៌នាអំពីទស្សនកិច្ចដែលបានធ្វើឡើងនាថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៤ របស់គណៈប្រតិភូរណសិរ្សរួបរួមជាតិ-កម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ទៅកាន់ទីក្រុងហាណូយ ក្រោមការដឹកនាំរបស់ ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា អៀង សារី ជាទីប្រឹក្សាពិសេសរបស់ទីស្តីការរងនៃក្រុមប្រឹក្សារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អៀង ធីរិទ្ធ លោក ទីវ អុល និងលោក សៀន អាន។

ដូច្នេះទេ ក៏អាចធ្វើការរាំងស្ទះដល់ការដឹកជញ្ជូនអាវុធទាំងនោះដែរ[៣៩៩]។ ដូច្នេះ ទស្សនកិច្ចរបស់ ខៀវ សំផន ទៅកាន់ប្រទេសវៀតណាម មានសារៈសំខាន់យ៉ាងខ្លាំងចំពោះជោគវាសនានៃការវាយប្រយុទ្ធដែលកំពុងកើតមាននៅក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញថា កិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ មុខជាត្រូវបានរៀបចំឡើងដើម្បីឲ្យ ខៀវ សំផន និង អៀង សារី អាចចូលរួមបាន និងរាយការណ៍ជូនសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាពីកិច្ចប្រជុំផ្សេងៗជាមួយនឹងមេដឹកនាំជាន់ខ្ពស់ប្រទេសចិន វៀតណាម និងឡាវ ដែលបានទទួលជោគជ័យដ៏ធំធេង។

១៣៩. សូ សុជាតិ ដែលជាប្រពន្ធរបស់ ខៀវ សំផន បានកំណត់ការវិលត្រឡប់ពីបរទេសមកកាន់ប្រទេសកម្ពុជាវិញរបស់ ខៀវ សំផន នៅក្នុងខែ មិថុនា ឬ ខែ កក្កដា ឆ្នាំ ១៩៧៤។ ប៉ុន្តែដោយពិចារណាទៅលើភាពមិនស៊ីសង្វាក់គ្នានៃសក្ខីកម្មរបស់អ្នកស្រី ទឹកចិត្តរបស់អ្នកស្រីក្នុងការជួយប្តីរបស់គាត់ សក្ខីកម្មដ៏ច្បាស់លាស់របស់ ភី ភួន និងព័ត៌មានដែល សួង ស៊ីគឿន បានផ្តល់ឲ្យយ៉ាងច្បាស់ដូចគ្នានេះ អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងរបស់ សូ សុជាតិ មិនគួរឲ្យជឿជាក់បានទេ។ ដំបូង អ្នកស្រីបានផ្តល់សក្ខីកម្មថា ខៀវ សំផន មិនបាននៅជាមួយគាត់នោះទេនៅពេលគាត់សម្រាលកូននៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៧៤ ហើយថា ខៀវ សំផន បានវិលត្រឡប់មកពីប្រទេសចិនវិញមួយខែក្រោយមក។ ប៉ុន្តែ បន្ទាប់មក អ្នកស្រីបានបញ្ជាក់ថា ខៀវ សំផន ស្ថិតនៅក្នុងប្រទេសកម្ពុជាជាមួយគាត់នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដោយគាត់បានអះអាងថា ខៀវ សំផន បានស្នាក់នៅជាមួយគាត់នៅមន្ទីរ ក-១៧ និងមន្ទីរ ប-២០ ហើយបានទៅភូមិមាយនៅពេលដែលទីក្រុងភ្នំពេញរៀបនឹងត្រូវបានរំដោះទៅហើយ[៤០០]។ គាត់បានលើកឡើងថា ក្រោយគាត់សម្រាលកូនទីមួយរបស់គាត់រួច ខៀវ សំផន នៅជិតគាត់ប្រហែលមួយខែ ដើម្បីជួយគាត់[៤០១]។ ទោះជាយ៉ាងណាក្តី គាត់ធ្លាប់បានលើកឡើងពីមុនថា គាត់បានទៅមន្ទីរមាយកាលពីពេលមុនៗ ក្រោយ

---

[៣៩៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១២-១៣ (នៅចន្លោះឆ្នាំ ១៩៦៨ និងឆ្នាំ ១៩៧៥ ចិនបានផ្តល់គ្រឿងសព្វាវុធមួយចំនួន ប៉ុន្តែ វៀតណាមជាអ្នកទទួលបន្ទុកខាងដឹកជញ្ជូនអាវុធទាំងនោះ និងបានរក្សាទុកមួយភាគបីនៃគ្រឿងសព្វាវុធដែលដឹកតាមកប៉ាល់ទាំងនោះ)។ ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៨ ( បន្ទាប់ពីកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ រួចមក ចិនបានផ្តល់អាវុធចំនួន ១៣ ឡាន ទៅឲ្យកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា ដែលអាវុធទាំងនោះត្រូវបានដឹកជញ្ជូនតាមប្រទេសវៀតណាម ។ អាវុធទាំងនោះត្រូវបានយន្តហោះទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបំផ្លាញខ្ទេចខ្ទីអស់ មុនពេលកងកម្លាំងបក្សកុម្មុយ-នីស្តកម្ពុជាយកអាវុធទាំងនោះទៅប្រើប្រាស់ ។

[៤០០] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៨-៥៩។

[៤០១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥១-៥៣។

ពេលគាត់សម្រាលកូនរួច[៤០២]។ គាត់បានលើកឡើងដោយមិនស៊ីសង្វាក់គ្នាជាថ្មីម្តងទៀត ដោយដំបូងនិយាយថា ខៀវ សំផន នៅជាមួយគាត់រយៈពេលបួន ឬប្រាំខែ បន្ទាប់មកបានកែវិញថា ខៀវ សំផន នៅជាមួយគាត់បានតែបីខែប៉ុណ្ណោះ[៤០៣]។ ក្រៅពីការលើកឡើងមិនស៊ីសង្វាក់គ្នាទាំងនេះ និងការមិនគួរឲ្យជឿលើសក្ខីកម្មរបស់គាត់ត្រង់ចំណុចខ្លះនោះ[៤០៤] អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់ សូ សុជាតិ គឺធ្វើឡើងក្នុងគោលបំណងចង់ដោះបន្ទុកឲ្យ ខៀវ សំផន រួចផុតពីការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ដែល ខៀវ សំផន ត្រូវបានចោទប្រកាន់ប៉ុណ្ណោះ។

១៤០. ទោះបីជាចម្លើយរបស់ សូ សុជាតិ ពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការធ្វើដំណើររបស់ ខៀវ សំផន ទៅភូមិមាយ មានភាពផ្ទុយគ្នាក៏ដោយ ក៏ សូ សុជាតិ បានបញ្ជាក់ថា ខៀវ សំផន ពិតជាបានធ្វើដំណើរទៅភូមិមាយនោះមែន។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា ភូមិមាយស្ថិតនៅក្នុងខេត្តកំពង់ចាម នៅជិតមន្ទីរ ប-២០[៤០៥] ហើយការធ្វើដំណើរទៅមកពីកន្លែងទាំងពីរនេះអាចធ្វើ

---

[៤០២] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៣, ទំព័រ ៥៧-៥៩។

[៤០៣] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៧-៥៩; ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៦-៦៧។

[៤០៤] សក្ខីកម្មរបស់អ្នកស្រី សូ សុជាតិ ក៏មានចំណុចគួរឲ្យសង្ស័យជាច្រើនផងដែរ។ គាត់បានលើកឡើងថា គាត់បានដឹងអំពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ក្រោយពេលដែលគាត់បានមកដល់ក្រុងភ្នំពេញតែប៉ុណ្ណោះ (ជាងមួយសប្តាហ៍ក្រោយថ្ងៃទី ១៧ ខែ មេសា)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ១៥-១៦។ គាត់បានលើកឡើងផងដែរថា នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់សម្តេច សីហនុ ទៅកាន់ដំបន់រំដោះ ឆ្នាំ ១៩៧៣ គាត់ពុំបានដឹងថា ប្តីរបស់គាត់ទទួលភារកិច្ចជាផ្លូវការក្នុងការទទួលស្វាគមន៍ព្រះអង្គម្ចាស់ឡើយ។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ១២-១៣។ ការលើកឡើងទាំងពីរចំណុចនេះមិនគួរឲ្យជឿបានឡើយ។

[៤០៥] សៀវភៅកំណត់ត្រារបស់ ស្លួង ស៊ីគឿន ឯកសារ E3/40, ERN (ភាសាខ្មែរ) 00583611 (មានជំរំរបស់បក្សកុម្មុយនីស្តកម្ពុជាជាច្រើននៅក្នុងតំបន់ស្ទឹងត្រង់ ខេត្តកំពង់ចាម រួមទាំង ប-២០ ដែលជាជំរំអប់រំកែប្រែសម្រាប់បញ្ញាជនដែលបានវិលត្រឡប់មកពីបរទេស ហើយមានចម្ងាយប្រហែលជា ១០ គីឡូម៉ែត្រពីតំបន់នេះ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន ហៅ ភី ភួន) ទំព័រ ២៤ ("មន្ទីរ ៧៤ ជិត [...] ភូមិមាយ។ ចន្លោះភូមិមាយ ហើយភូមិដីក្រហមនេះ គេហៅមន្ទីរ ៧៤ ហ្នឹង គឺនៅត្រង់ហ្នឹង។ នៅកៀកទីរួមស្រុកស្ទឹងត្រង់តែម្តង")។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ២៤-២៦ (គាត់គឺជាអតីតអ្នកយាមខ្មែរក្រហមម្នាក់ ដែលបានចូលរួមជាមួយខ្មែរក្រហមនៅឆ្នាំ ១៩៦៨ នៅពេលដែលគាត់ស្ថិតនៅខេត្តរតនគីរី ហើយបានចាកចេញជាមួយ ប៉ង់ និង ប៉ុល ពត ពីខេត្តរតនគិរី ទៅខេត្ត កំពង់ចាមនៅក្នុងឆ្នាំ ១៩៧០។ អៀង សារី នួន ជា ខៀវ សំផន បានចូលរួមប្រជុំជាច្រើនដែល ប៉ុល ពត បានដឹកនាំពី ឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៥ នៅភូមិត្រពាំងទឹម ខេត្តកំពង់ចាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាំ ផាន់ ហៅ ផាន វ៉ាន ឯកសារ E3/58 ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ)

ទៅបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់មិនបានធ្វើឱ្យមានវិមតិ-សង្ស័យនោះទេ ទាក់ទិននឹងវត្តមានរបស់ ខៀវ សំផន នៅក្នុងភូមិមាឃ ក្នុងខែមិថុនា ឆ្នាំ១៩៧៤ នោះ។

១៤១. ក្រោយកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ អ្នកចូលរួមប្រជុំគ្រប់គ្នាត្រូវបានណែនាំឱ្យផ្សព្វផ្សាយព័ត៌មាននៅតាមភូមិភាគដែលខ្លួនមានសមត្ថកិច្ចរៀងៗខ្លួនអំពីសេចក្ដីសម្រេចផ្សេងៗនៅក្នុងពេលប្រជុំនេះ[៤០៦]។ គណៈកម្មាធិការមួយដែលមាន សុន សេន ជាប្រធាន ហើយមាន កុយ ធួន និងកម្មាភិបាលភូមិភាគផ្សេងទៀតជាសមាជិកនោះ ត្រូវបានបង្កើតឡើងដើម្បីចាត់ចែងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[៤០៧]។ ប៉ុល ពត និង នួន ជា បានដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសវៀតណាម ដើម្បីជម្រាបមេដឹកនាំវៀតណាមអំពីផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការ "រំដោះ"ទីក្រុងភ្នំពេញ និង ស្នើសុំឱ្យផ្គត់ផ្គង់អាវុធបន្ថែមទៀត[៤០៨]។

១៤២. ដោយពិចារណាទៅលើកាលៈទេសៈទាំងអស់ខាងលើនេះ អង្គជំនុំជម្រះជឿជាក់ថា ទាំង ខៀវ សំផន និង អៀង សារី ពិតជាមានវត្តមាននៅក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដោយនៅក្នុងកិច្ចប្រជុំនោះមានការធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ អនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ពួកគាត់ទាំងពីរនាក់បានយល់ស្របទៅនឹងសេចក្ដី-សម្រេចនោះ[៤០៩]។ ខៀវ សំផន អាចប្រឆាំងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប៉ុន្តែ

---

00239935-00239936 (ប-២០ ជិតគីឡូលេខ ១០ ជិតបឹងកេត ក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ P. Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ERN (ភាសាអង់គ្លេស) 00396191 (ផែនទី)។

[៤០៦] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៤។

[៤០៧] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៩-៣១។ កិច្ចសម្ភាសន៍ជាមួយ អៀង ធីរិទ្ធដោយ Kassekampen ឯកសារ E3/656 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ទំព័រ ១ ERN (ភាសាខ្មែរ) S 00806232។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៩។

[៤០៨] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៩។

[៤០៩] សូមមើលផ្នែកទី ៥ ស្ដីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៣-២២៨ ។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 ទំព័រ ១៩ ERN (ភាសាខ្មែរ) 00078201 ("ហើយតាំងពីនោះមក រំដោះឆ្នាំ ៧៥ វាក៏ឯកភាពគ្នាបើតាមខ្ញុំមើល អារឿងនាំមនុស្សចេញពីក្រុងអី ប៉ុន្តែអារឿងកម្ទេចអីៗ វាមិនដឹងទេ អាពួកខាងក្រោមវាខូច [...]")។

គាត់បានជ្រើសរើសមិនប្រឆាំងជំទាស់ទេ[៦១០]។

### ៣.៤.២ ខែ កុម្ភៈ ឆ្នាំ ១៩៧៥

១៤៣. មានភស្តុតាងបង្ហាញថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញត្រូវបានលើកយកមកពិភាក្សាសាជាថ្មីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥។ ទោះបីជាអ្នកជំនាញលោក David CHANDLER បានទទួលស្គាល់ថា មានការលើកមតិយោបល់ខុសៗគ្នាអំពីកាលបរិច្ឆេទនេះក៏ដោយ[៦១១] ក៏លោក David CHANDLER យល់ឃើញថា សេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីខេត្ត-ក្រុង បានធ្វើឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥[៦១២] ដោយមកដល់ត្រឹមពេលនោះ ប្រជាជនដែលរស់នៅតាមខេត្ត និងទីប្រជុំជនតូចៗមួយចំនួន រួមទាំង ឧត្ដុង្គ និងខេត្តក្រចេះ ត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំរួចទៅហើយ ហើយគោលនយោបាយនេះក៏ត្រូវបានអនុវត្តសាកល្បងរួចហើយដែរ[៦១៣]។ នៅក្នុងកិច្ចសម្ភាសន៍ធ្វើឡើងនៅក្នុងសន្និសីទសារព័ត៌មានមួយក្នុងទីក្រុងប៉េកាំង ដោយមានវត្តមានរបស់ អៀង សារី ដែរនោះ ប៉ុល ពត ក៏បានលើកឡើងផងដែរថា សេចក្ដីសម្រេចជម្លៀសអ្នករស់នៅក្នុងទីក្រុងទៅតាមទីជនបទ គឺជាកត្តាមួយក្នុងចំណោមកត្តាធំៗចំពោះជោគជ័យនៃបដិវត្តន៍ ហើយសេចក្ដីសម្រេចនេះបានធ្វើឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥[៦១៤]។ ទោះបីជា នួន ជា មិនចាំអំពីការប្រជុំក្រោយៗទៀតអំពីការជម្លៀសប្រជាជនចេញពី

---

[៦១០] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/4051 ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786555-00786556។ វីដេអូអំពីការសម្ភាសន៍ ខៀវ សំផន ឯកសារ E152.1.52R។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ )“គាត់ [ខៀវ សំផន] ក៏មានអំណាចដែរ គាត់មិនមែនថាគ្មានសោះទេ។ ប៉ុន្តែ ការងារអី ផ្សេងៗ ដោយឡែកពីគ្នា។ [...] គាន់មាន [អំណាច] ប៉ុន្តែ មិនមានអំណាចតែឯង។ គេជំរុញជុំវិញ គេជួយមតិ ជួយអីដែរ។”)។

[៦១១] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣៥-៣៧។

[៦១២] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៤៤-៤៥, ៤៧-៤៨។

[៦១៣] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣៣-៣៥។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៦-២៨ (ក្រចេះ)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (នោម សែ) ទំព័រ ៣៨-៤១។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុន ធៀន ឯកសារ E3/5498 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00368600-00368602 (ប្រជាជនទាំងអស់នៅក្នុងទីរួមខេត្តតាកែវត្រូវបានជម្លៀសប្រហែលជានៅថ្ងៃទី ១៨ ឬ ១៩ ខែ មេសា ឆ្នាំ ១៩៧៥)។

[៦១៤] របាយការណ៍តាមដានទំនាក់ទំនងចុងបូព៌ា/SWB៖ *ចុងបូព៌ា* ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៧៧ ឯកសារ E3/2728, ERN (ភាសាអង់គ្លេស) 00390921, 00390927។ បទសម្ភាសន៍ជាមួយនឹង សាឡុត ស (ប៉ុល ពត) នៅក្នុងទីក្រុង

ទីក្រុងភ្នំពេញបន្ទាប់ពីការប្រជុំនៅពាក់កណ្តាលឆ្នាំ១៩៧៤ ក៏គាត់បានបញ្ជាក់ថា សេចក្តីសម្រេចជម្លៀសនេះត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំមិនមែនមានតែម្តងនោះទេ[៤១៥]។

### ៣.៤.៣ ដើមខែ មេសា ឆ្នាំ ១៩៧៥

១៤៤. អង្គជំនុំជម្រះជឿជាក់ថា នៅដើមខែ មេសា ឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្ត-កម្ពុជាបានជួបប្រជុំគ្នានៅមន្ទីរ ប-៥ ដែលជាទីបញ្ជាការវាយប្រហារទៅលើទីក្រុងភ្នំពេញ និងស្ថិតនៅក្នុងភូមិតាំងពូន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដើម្បីពិភាក្សាអំពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[៤១៦]។ សាក្សី ភី ភួន មានវត្តមាននៅជិតទីកន្លែងប្រជុំនោះ ហើយបានផ្តល់ការពិពណ៌នាលម្អិតច្រើនគ្រាន់បើ។ អង្គជំនុំជម្រះសាលាដំបូងទទួលយកភ័ស្តុតាងរបស់ ភី ភួន ពាក់ព័ន្ធនឹងលក្ខណៈទូទៅនៃកិច្ចប្រជុំ និងអ្នកចូលរួមក្នុងកិច្ចប្រជុំនេះ ដែលរួមមានទាំង នួន ជា និង ខៀវ សំផន។ នៅក្នុងចំណុចសំខាន់ៗជាច្រើន ភ័ស្តុតាងរបស់គាត់អំពីបញ្ហានេះ ត្រូវបានគាំទ្រដោយជនជាប់ចោទ។

១៤៥. អង្គជំនុំជម្រះសន្និដ្ឋានថា ប៉ុល ពត និងមេដឹកនាំដទៃទៀត ដែលមានវត្តមាននៅមន្ទីរ ប-៥ មុនពេលជម្លៀស បានចូលរួមប្រជុំជាមួយនឹង នួន ជា ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ផ្សេង

---

ប៉េកាំង ឯកសារ E3/2072 ERN (ភាសាខ្មែរ) S 00296205-00296207 ("កត្តាសំខាន់មួយក្នុងចំណោមកត្តាផ្សេងទៀតនៃជោគជ័យរបស់យើង គឺការជម្លៀសអ្នករស់នៅទីក្រុងឲ្យទៅនៅជនបទ។ រឿងនេះត្រូវបានសម្រេចមុនពេលទទួលជ័យជំនះ គឺ នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ពីព្រោះយើងបានដឹងថា មុនពេលកម្ទេចអង្គការចារកិច្ចរបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ កម្លាំងរបស់ពួកយើងមិនទាន់ខ្លាំងគ្រប់គ្រាន់អាចការពារបដិវត្តន៍បានទេ")។

[៤១៥] ប្រតិចារឹកថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ១២-១៥។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៩-៣១។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៨។

[៤១៦] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ទំព័រ ១០-១២, ១៤-១៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ាចាម តុន *ហៅ* ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00204068-00204069។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឯកសារ E3/424 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00418518-00418520។ កំណត់ត្រារបស់ Stephen HEDER នៃកិច្ចសម្ភាសន៍ជាមួយ ហេង សំរិន ឯកសារ E3/5593 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាអង់គ្លេស) 00419396-00419397។ កំណត់ត្រាប្រតិចារឹករបស់ Stephen HEDER នៃកិច្ចសម្ភាសន៍ជាមួយ ហេង សំរិន ឯកសារ E3/1568 ERN (ភាសាខ្មែរ) 00713946-00713947។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00156614។

ទៀត[៤១៧]។ យោងតាម នួន ជា ប៉ុល ពត ស្ថិតនៅមន្ទីរ ប-៥ ចាប់ពីដើមខែ មេសា ឆ្នាំ ១៩៧៥ មក ដើម្បី "បញ្ជាវាយរំដោះទីក្រុងភ្នំពេញ"[៤១៨]។ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានផ្លាស់ទៅ មន្ទីរ ប-៥ ដើម្បី "តាមដានការវាយសម្រុកជាចុងក្រោយទៅលើរដ្ឋធានីភ្នំពេញ" ប៉ុន្តែ គាត់បាន បដិសេធថា គាត់មិនបានចូលរួមក្នុងការងាររបស់ទីបញ្ជាការទេ[៤១៩]។ អង្គជំនុំជម្រះកត់សម្គាល់ថា អៀង សារី ក៏បានដឹងអំពីកិច្ចប្រជុំនេះដែរ (ដែលគាត់បានកំណត់កាលបរិច្ឆេទកិច្ចប្រជុំនេះថានៅ ចុងខែ មីនា ឬ ដើមខែ មេសា ឆ្នាំ ១៩៧៥) ដែលក្នុងកិច្ចប្រជុំពេលនោះ ការជម្លៀសប្រជាជនចេញ ពីទីក្រុងភ្នំពេញត្រូវបានលើកយកមកពិភាក្សា ទោះបីជាគាត់បានអះអាងថា គាត់មិនមានវត្តមាន ដោយផ្ទាល់ក្នុងពេលប្រជុំនោះក៏ដោយ[៤២០]។

---

[៤១៧] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ទំព័រ ១០-១២។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ទំព័រ ៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន *ហៅ* ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00204068-00204069។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន *ហៅ* ភី ភួន ឯកសារ E3/63 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00228843-00228845។ សូមប្រៀបធៀបជាមួយសៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦០-៦១ ERN (ភាសាខ្មែរ) 00103838 ("នៅចុងខែ មីនា ឆ្នាំ ១៩៧៥ ខ្ញុំត្រូវបានគេអញ្ជើញទៅបញ្ជាការរួម [ប.ក.ក] ដែលតាំងនៅភូមិដូង ក្នុងឃុំស្រែអណ្តូង ខាងលិចឧត្តុង្គបន្តិច ដើម្បីតាមដានការវាយសម្រុកជាចុងក្រោយទៅលើ រដ្ឋធានីភ្នំពេញ។ ហ៊ូ នឹម[...]និង ហ៊ូ យន់ [...] អត់បានមកនៅជាមួយខ្ញុំទេ")។ នួន ជា បានផ្តល់សក្ខីកម្មថា ប៉ុល ពត បានវិលត្រឡប់មក ប-៥ ក្រោយរំដោះទីក្រុងភ្នំពេញ៖ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៧-២៨។

[៤១៨] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨ (ក្នុងករណីដែលមានលក្ខណៈខុស គ្នារវាងប្រតិចារិកជាភាសាខ្មែរ និងអង់គ្លេស អង្គជំនុំជម្រះនឹងពឹងផ្អែកលើអត្ថបទដើមជាភាសាខ្មែរ)។ សូមមើល ផងដែរ កំណត់ហេតុដែលប្រើប្រាស់ដោយជនជាប់ចោទ នួន ជា ក្នុងអំឡុងសវនាការថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ERN (ភាសាខ្មែរ) 00757832-00757833។

[៤១៩] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦០-៦១ ERN (ភាសាខ្មែរ) 00103838។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00156614។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៤៥-៤៨។ សូមមើលផងដែរផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៧ ។

[៤២០] អត្ថបទសម្ភាសន៍ HEDER ជាមួយ អៀង សារី ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារ E3/89 ERN (ភាសាខ្មែរ) 00062457-00062458។

១៤៦. នៅក្នុងកិច្ចប្រជុំនោះ មេដឹកនាំបានរាយការណ៍អំពីស្ថានភាពនៅឯសមរភូមិនៅក្នុងតំបន់នានារបស់ពួកគេ[៤២១]។ ប៉ុល ពត បានលើកឡើងជាថ្មីម្តងទៀតអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[៤២២]។ មេបញ្ជាការកងទ័ពបានកត់សម្គាល់ថា វាជាការពិបាកសម្រាប់កម្មាភិបាលក្នុងការគ្រប់គ្រងប្រជាជន ប្រសិនបើមិនជម្លៀសប្រជាជនចេញពីទីក្រុងទេនោះ[៤២៣]។ ប៉ុល ពត បានពិភាក្សាអំពីជោគជ័យនៃបទពិសោធន៍កាលពីលើកមុនៗក្នុង "ការរំដោះ" ទីក្រុង និងទីប្រជុំជននានា ដូចទៅនឹងបទឧទ្ទេសនាមរបស់ នួន ជា ដែរ[៤២៤]។ យោងតាម ភី ភួន ទាំង នួន ជា និង ខៀវ សំផន បានគាំទ្រផែនការនេះ ហើយអ្នកចូលរួមទាំងអស់បានទះដៃបង្ហាញអំពីការយល់ស្របទៅនឹងសំណើជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលចំណុចនេះវាស្របនឹងគោលនយោបាយក្នុងការជម្លៀសប្រជាជនចេញពីទីប្រជុំជនផ្សេងៗទៀត ដែលគេរំដោះបានពីទឹកដីដែលគ្រប់គ្រងដោយសត្រូវ[៤២៥]។

---

[៤២១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ទំព័រ ១២-១៣ ទំព័រ ១៩-២០។

[៤២២] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ទំព័រ ១១-១២។

[៤២៣] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ទំព័រ ១២-១៣។

[៤២៤] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ទំព័រ ២០-២១។

[៤២៥] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន ហៅ ភី ភួន) ទំព័រ ១២-១៣, ១៤, ១៩-២១។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន ហៅ ភី ភួន) ទំព័រ ៣៥-៣៦។ មេធាវីការពារក្តី ខៀវ សំផន តវ៉ាអំពីភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់សាក្សីរូបនេះ ដោយលើកឡើងថា សក្ខីកម្មរបស់គាត់គឺផ្ទុយពីការពិពណ៌នារបស់គាត់អំពីទីកន្លែងប្រជុំ និងលទ្ធភាពរបស់គាត់ក្នុងការសង្កេតមើល និងស្តាប់ឮនូវអ្វីដែលបានកើតឡើង។ សូមមើល សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩-៣៣។ ដោយពិនិត្យទៅលើបរិបទនៃសក្ខីកម្មរបស់សាក្សី អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់ភាគច្រើនស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់គាត់ដែលបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេត។ សូមមើលប្រតិចារឹក ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (រ៉ាចាម តុន ហៅ ភី ភួន) ទំព័រ ១៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន ហៅ ភី ភួន) ទំព័រ ៤៥-៤៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ាចាម តុន *ហៅ* ភី ភួន ឯកសារ E3/63 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00228844-00228845។ ជាពិសេស នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ភី ភួន ជាភាសាខ្មែរ និងបារាំង ឯកសារ E3/63 និងនៅក្នុងប្រតិចារឹកនៃកំណត់ហេតុស្តាប់ចម្លើយនេះ ឯកសារ E3/63/1 សាក្សីបានពិពណ៌នាអំពីទីកន្លែង ដែលកិច្ចប្រជុំបានធ្វើឡើងនោះ ថាជាផ្ទះឈើតូចមួយ ហើយបន្ថែមលើនេះទៀតនោះចំណុចនេះគឺស្របទៅនឹងសក្ខីកម្មរបស់គាត់ ដែលបានបញ្ជាក់ថា គាត់អាចស្តាប់ឮ និងមើលឃើញអ្វីៗនៅខាងក្នុងផ្ទះនោះ ។ សូមមើលផងដែរផ្នែកទី ៣.៤.១ ស្តីពី "ខែ មិថុនា ឆ្នាំ ១៩៧៤" (ដែលនៅក្នុងចំណុចនេះ គណៈកម្មាធិការមជ្ឈិមបានសម្រេចអំពីយុត្តិសាស្ត្រនៃការវាយផ្តាច់ចុងក្រោយ ដើម្បី "រំដោះ"

១៤៧. អង្គជំនុំជម្រះកត់សម្គាល់ទៀតថា ទាំង ខៀវ សំផន និង អៀង សារី បានបង្ហាញអំពីការយល់ដឹងយ៉ាងទូលំទូលាយអំពីដំណើរការនៃការធ្វើសេចក្តីសម្រេច ដែលនាំឱ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ នៅក្នុងបទសម្ភាសន៍ថតជាខ្សែវីដេអូមួយ ខៀវ សំផន អះអាងថា ប្រសិនបើមានសំឡេងតែមួយប្រឆាំងនឹងការជម្លៀសប្រជាជន ការជម្លៀសប្រជាជននឹងមិនអាចធ្វើទៅកើតឡើយ។ គាត់បានបញ្ជាក់ថា ហេតុផលក្នុងការជម្លៀសប្រជាជន គឺដើម្បីការពារកុំឱ្យប្រជាជនស្លាប់ដោយសារអត់អាហារ[៤២៦]។ លើសពីនេះទៀត ខៀវ សំផន គឺជាអ្នកដែលបានប្រកាសតាមវិទ្យុសំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា អំពីការវាយប្រហារចុងក្រោយទៅលើទីក្រុងភ្នំពេញ ទោះបីជាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមិនត្រូវបានប្រកាសក៏ដោយ[៤២៧]។ ចំពោះ អៀង សារី វិញ គាត់បានពិភាក្សាជាមួយនឹង ប៉ុល ពត អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ យ៉ាងហោចណាស់នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងប្រហែលជានៅក្នុងខែ មេសា ឆ្នាំ ១៩៧៥។ ដូច្នេះ ទាំង ខៀវ សំផន និង អៀង សារី សុទ្ធតែបានដឹងជាមុនអំពីខ្លឹមសារលម្អិតនៃការជម្លៀសប្រជាជន ដែលចំណុចនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងការចូលរួមរបស់ពួកគាត់នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។

### ៣.៤.៤ បទបញ្ជាដែលត្រូវបានបញ្ជូនទៅកម្មាភិបាលថ្នាក់ក្រោម

១៤៨. បន្ទាប់ពីកិច្ចប្រជុំនៅដើមខែ មេសា ឆ្នាំ ១៩៧៥ នៅមន្ទីរ ប-៥ រួចមក ក៏មានការប្រជុំជាមួយនឹងកងទ័ពខ្មែរក្រហម ដែលធ្វើឡើងដើម្បីដាក់បទបញ្ជាទៅដល់ពួកមេបញ្ជាការកងពលធំនៃកងទ័ពបដិវត្តន៍កម្ពុជា ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀត[៤២៨]។

---

ប្រទេស រួមទាំងការជម្លៀសប្រជាជនផងដែរ) ។សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៨-១៥១ (បទបញ្ជាដែលបានធ្វើឡើងបន្ទាប់ពីកិច្ចប្រជុំនៅដើមខែ មេសា ឆ្នាំ ១៩៧៥ និងបទបញ្ជាទាក់ទងនឹងផែនការនៃការវាយផ្តាច់ចុងក្រោយដើម្បីរំដោះភ្នំពេញ និងដំបន់ទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សត្រូវ) ។

[៤២៦] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/4051 ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786555-00786556។ វីដេអូអំពីការសម្ភាសន៍ ខៀវ សំផន ឯកសារ E152.1.52R។

[៤២៧] *មានការជំរុញឱ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារក្នុងពេលចូលឆ្នាំថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ទំព័រ ១-៦ ERN (ភាសាខ្មែរ) 00783125-00783130។

[៤២៨] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៤៥-៤៦។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ២-៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន *ហៅ* ភី ភួន ឯកសារ E3/63 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00228844-00228845។

ឧទាហរណ៍ កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ សែម ហឿន ត្រូវបានមេបញ្ជាការរបស់គាត់ប្រាប់ថា ពួកមេបញ្ជាការទាំងអស់បានជួបប្រជុំនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយក្រោយមកក៏បានមកប្រាប់កូនចៅថ្នាក់ក្រោមឱ្យបានដឹងអំពីផែនការនេះ[៤២៩]។ សាក្សី ឈូក រិន ដែលជាអតីតមេបញ្ជាការកងទ័ពខ្មែរក្រហមបានរាយការណ៍ថា មានកិច្ចប្រជុំមួយនៅភ្នំស ដែលជាទីបញ្ជាការកងទ័ពខ្មែរក្រហមប្រចាំខេត្តកំពត ប្រហែលជាមួយខែមុនការដួលរលំទីក្រុងភ្នំពេញ ដែលនៅក្នុងកិច្ចប្រជុំនោះ តាម៉ុក បានពិភាក្សាអំពីការបិទផ្សារ ការលុបបំបាត់រូបិយប័ណ្ណ និងការជម្លៀសប្រជាជនចេញពីក្រុងកំពត[៤៣០]។ តាម៉ុក ក៏បានពិភាក្សាផងដែរអំពីផែនការជម្លៀសប្រជាជនចេញពីកំពត ដែលមានលក្ខណៈស្រដៀងគ្នាមែនទែនទៅនឹងការអនុវត្តដែលធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗទៀតក្នុងប្រទេស[៤៣១]។ ដោយយោងទៅលើហេតុផលនេះ ឈូក រិន ខ្លួនគាត់ផ្ទាល់ជឿជាក់ថា ការជម្លៀសប្រជាជនត្រូវបានគេធ្វើឡើងដោយផ្អែកទៅលើការព្រមព្រៀងក្នុងចំណោមមេដឹកនាំទាំងអស់[៤៣២]។

១៤៩. សាក្សីជាច្រើនបានបញ្ជាក់ថា ការណែនាំពីថ្នាក់លើ ត្រូវបានបញ្ជូនបន្តទៅថ្នាក់ក្រោមនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា។ សាក្សី ឃុន ប្រាក់ បានបញ្ជាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា កិច្ចប្រជុំមួយត្រូវបានធ្វើឡើងបីថ្ងៃមុនការវាយប្រហារទីក្រុងភ្នំពេញ ដោយនៅក្នុងកិច្ចប្រជុំនោះ កងទ័ពត្រូវបានគេប្រាប់ថា ពួកគេត្រូវតែជម្លៀសប្រជាជនចេញពីទីក្រុង បន្ទាប់ពីរំដោះបាន និងប្រាប់ឱ្យទាហាន លន់ នល់ ដាក់អាវុធចុះ[៤៣៣]។ ឆោម សែ បានបញ្ជាក់ថា បទបញ្ជាឱ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាបទបញ្ជាទូទៅ ដែលត្រូវអនុវត្តនៅគ្រប់សមរភូមិទាំងអស់ ដោយត្រូវជម្លៀសប្រជាជនចេញពីគ្រប់ទីក្រុងទាំងអស់ ដើម្បីឱ្យស្របទៅនឹងផែនការដែលបាន

---

[៤២៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ហឿន ឯកសារ E3/5280 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00287555-00287556។

[៤៣០] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧២-៧៨។

[៤៣១] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧២-៧៨។

[៤៣២] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧២-៧៨។

[៤៣៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន ប្រាក់ ឯកសារ E3/509 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00270157-00270159។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00204739-00204740 (បានទទួលបញ្ជាពីមេរបស់គាត់ឱ្យជម្លៀសប្រជាជន ទោះបីជាមិនច្បាស់ថានៅពេលណាក៏ដោយ)។

កំណត់ខាងលើ[៤៣៤]។ កងទ័ពខ្មែរក្រហមពីរនាក់ ឈ្មោះ ជា សាយ និង ស៊ុំ ជា នៅក្នុងពេលរំដោះទីក្រុងភ្នំពេញនោះ បានទទួលបញ្ជាឲ្យជួយជម្លៀសប្រជាជនចេញពីទីក្រុង តែត្រូវធ្វើបន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះ[៤៣៥]។ ស្រដៀងគ្នានេះដែរ នៅក្នុងអំឡុងពេលដែល គង់ គីម និងកងអនុសេនាតូចរបស់គាត់បានចូលមកដល់ទីក្រុងភ្នំពេញហើយ ទើបគាត់បានដឹងអំពីផែនការជម្លៀសប្រជាជន ហើយគាត់បានកត់សម្គាល់ឃើញថាប្រជាជនកំពុងតែធ្វើដំណើរចាកចេញពីភ្នំពេញ។ កងអនុសេនា-តូចរបស់គាត់បានទទួលបញ្ជាឲ្យកាត់ផ្តាច់ទឹក ក្នុងគោលបំណងដើម្បីបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះសម្បែងរបស់ពួកគាត់ ឬចូលទៅក្នុងផ្ទះប្រជាជនពិនិត្យមើលថា តើមានប្រជាជននៅសម្ងំក្នុងផ្ទះឬអត់ ដើម្បីធានាថាប្រជាជនត្រូវបានជម្លៀសចេញពីទីកន្លែងរបស់ពួកគាត់ និងដើម្បីសម្អាតផ្ទះ ឬផ្លូវថ្នល់នានា[៤៣៦]។ បទបញ្ជាដូចៗគ្នាទាំងនេះបង្ហាញឲ្យឃើញថា មានផែនការដែលមានការរៀបចំតាំងពីដើមដំបូងមក[៤៣៧]។

---

[៤៣៤] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ២៩ ទំព័រ ៥៦-៥៧។

[៤៣៥] ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៤០ (ជាទាហានម្នាក់នៅពេលរំដោះទីក្រុងភ្នំពេញ បាន ផ្តល់សក្ខីកម្មថា គាត់បានទទួលបញ្ជាពីមេបញ្ជាការរបស់គាត់ឲ្យជួយជម្លៀសប្រជាជនចេញពីទីក្រុង បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបាន)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៦-៧, ៩-១០ (ជាទាហានខ្មែរក្រហមម្នាក់នៅក្នុងឆ្នាំ ១៩៧២ បានបញ្ជាក់ថា កងពលធំរបស់គាត់បានទទួលបញ្ជាពីប្រធានកងវរសេនា តូច ឈ្មោះ ហាក់ ឲ្យជួយជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប៉ុន្តែគាត់មិនដឹងថា ហាក់ បានទទួលបញ្ជាពីនរណាឡើយ)។ សូមមើលផងដែរ បទសម្ភាសន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សូ រ៉េន ឯកសារ E3/2073 ERN (ភាសាខ្មែរ) 00055183-00055185 (បានទទួលបញ្ជាពីអនុប្រធានកងវរសេនាធំរបស់គាត់)។ របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ឯកសារ E3/3885 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00205117-00205119 (មេបញ្ជាការរបស់ ហ៊ឹម ហ៊ាន បានកោះប្រជុំប្រាប់ពួកគេអំពីសេចក្តីណែនាំឲ្យជម្លៀសប្រជាជន ប្រាំពីរថ្ងៃបន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ)។ សូមមើល ផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00172079-00172080។

[៤៣៦] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម), ទំព័រ ៧៥-៧៧, ៨៤-៨៥; ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ១៥-១៨, ១៨-១៩, ៤៤-៤៥, ៤៧-៤៩។

[៤៣៧] *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ឯកសារ E3/5263 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00270178-00270179 (កន្លះខែមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលអង្គភាព [...] របស់ខ្ញុំបានចូលជិតដល់ទីក្រុងភ្នំពេញ សឿន ដែលជាមេបញ្ជាការកងវរសេនាតូចរបស់ខ្ញុំ បានប្រាប់ខ្ញុំ និងយុទ្ធជនដទៃទៀតនៅក្នុងអង្គភាពថា ពួកគេត្រូវតែជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ (គាត់

១៥០. បុគ្គលិកយោធា និងកម្មាភិបាលខ្មែរក្រហមផ្សេងទៀតបានផ្តល់សក្ខីកម្មថា ពួកគាត់មិនត្រូវបានគេប្រាប់អំពីការជម្លៀសប្រជាជនជាមុនឡើយ។ សាក្សី មាស វឿន ដែលជាមេបញ្ជាការកងវរសេនាធំលេខ ១៦ នៃកងពលធំលេខ ១ នៅក្នុងភូមិភាគនិរតី ដែលកងពលនេះទទួលបន្ទុកវាយប្រហារទីក្រុងភ្នំពេញពីប៉ែកនិរតី[៤៣៨] សាក្សី ជួន ធី ដែលស្ថិតនៅក្នុងកងពលជាមួយគ្នា ហើយសាក្សី អ៊ុង រ៉េន ដែលជាកម្មាភិបាលកងទ័ពនៅក្នុងកងពលតូចលេខ ១៤ ដែលវាយប្រហារពីប៉ែកនិរតីផងដែរនោះ បានផ្តល់សក្ខីកម្មថា អង្គភាពនីមួយៗរបស់ពួកគេ ពុំបានទទួលបទបញ្ជាឲ្យជម្លៀសប្រជាជនស៊ីវិលចេញពីទីក្រុងភ្នំពេញនោះទេ[៤៣៩]។ សាក្សី សូត្រ ទៀង ដែលជាអង្គរក្សនិង/ឬជា និរសាររបស់ នួន ជា, សាក្សី ពាន ឃាន ដែលជានិរសាររបស់បក្សកុម្មុយនីស្តកម្ពុជា និងសាក្សី សួន កានិល ដែលជាអ្នកវាយសារទូរលេខ (អ្នកវ៉ៃម៉ស) ដែលធ្វើការនៅជិតនឹងពួកកម្មាភិបាលជាន់ខ្ពស់នៃភូមិភាគកណ្តាល ក៏មិនបានដឹងអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ប៉ុន្តែ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពួកគេបានឃើញប្រជាជនយ៉ាងច្រើនដើរចេញពីទីក្រុងភ្នំពេញ និងឃើញកងទ័ពខ្មែរក្រហមឈរយាមនៅតាមមន្ទីរនានាជុំវិញទីក្រុង[៤៤០]។

---

អត់និយាយអ្វីច្រើនជាងនេះទេ) រហូតទាល់តែស្ថានភាពវិលទៅរកសភាពធម្មតាវិញ ពួកគេអាចវិលត្រឡប់មកវិញបាន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ហឿន ឯកសារ E3/5280 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00287554-00287555 (“ខ្ញុំបានដឹងថា មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មេបញ្ជាការទាំងអស់ ត្រូវបានគេហៅទៅប្រជុំប្រាប់ឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ [...] បន្ទាប់មក មេបញ្ជាការទាំងនោះ បានមកប្រាប់អំពីផែនការទាំងនេះឲ្យកូនចៅថ្នាក់ក្រោមបានដឹង”)។ របាយការណ៍ដោយ S. Heder & M. Matsushita បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ខែកុម្ភៈ-ខែមីនា ឆ្នាំ ១៩៨០ ទំព័រ ៩៦-៩៧ ERN (ភាសាខ្មែរ) 00324767-00324768 (ប្រហែលជា ១០ ថ្ងៃ មុនថ្ងៃរំដោះ ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានដាក់ចេញទៅថ្នាក់ក្រោម។ ផែនការនេះបានមកដល់កន្លែងយើង ក្រោយបែកអ្នកលឿង។ ពុំមានកំណត់ថាពេលណាប្រជាជននឹងត្រូវចាកចេញពីទីក្រុងទេ គឺថា អង្គភាព និងភូមិភាគនីមួយៗជាអ្នកសម្រេចដោយខ្លួនឯង)។

[៤៣៨] ប្រតិចារឹក ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៧៣-៧៥។

[៤៣៩] ប្រតិចារឹក ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ៣៣-៣៤។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៤២-៤៣។

[៤៤០] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទៀង) ទំព័រ ៦៣-៦៦។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន), ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ២៦-២៧, ៤១, ៤២-៤៤, ៦២។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៤៦-៤៧។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ១៧-១៩។ *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ កែវ ឯកសារ

១៥១. ទោះបីជាកម្មាភិបាលមួយចំនួន មិនត្រូវបានគេប្រាប់អំពីសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅមុនការវាយប្រយុទ្ធចុងក្រោយក៏ដោយ ដោយផ្អែកទៅលើភ័ស្តុតាងពាក់ព័ន្ធនឹងផែនការផ្លាស់ទីលំនៅប្រជាជន និងកម្មាភិបាលដែលបានទទួលព័ត៌មានអំពីផែនការនេះជាមុន និងលក្ខណៈស៊ីសង្វាក់គ្នានៃការអនុវត្តការជម្លៀសប្រជាជននៅទូទាំងទីក្រុងទាំងមូលនោះ អង្គជំនុំជម្រះជឿជាក់ថា ពិតជាមានសេចក្តីសម្រេចពីមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុង ដែលសេចក្តីសម្រេចនេះត្រូវបានបញ្ជូនបន្តទៅតាមឋានានុក្រមយោធា ទោះបីជាការបញ្ជូននេះមិនត្រូវបានអនុវត្តឲ្យបានល្អឥតខ្ចោះក៏ដោយ។

### ៣.៤.៥ សេចក្តីសន្និដ្ឋាន

១៥២. ភ័ស្តុតាងខាងលើបង្ហាញឲ្យឃើញច្បាស់ថា នួន ជា មានតួនាទីសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចរំដោះ និងផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត។ ខៀវ សំផន បានប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់មិនពាក់ព័ន្ធនឹងសេចក្តីសម្រេចឲ្យផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញទេ ដោយគាត់បានដឹងអំពីការជម្លៀសប្រជាជននេះពីកងទ័ពនៅឧត្តុង្គតែប៉ុណ្ណោះ មុនពេលចេញដំណើរទៅទីក្រុងភ្នំពេញ។ គាត់បានបញ្ជាក់ថា គាត់បាន

---

E3/5173 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00189263-00189265 ("នៅពេលកងខ្ញុំចូលមកដល់ ខ្ញុំបានឃើញពួកទាហាន លន់ នល់ លើកទង់ជ័យស ប៉ុន្តែកងខ្ញុំគ្មានផែនការដេញ ឬជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ព្រោះមុនចូលភ្នំពេញ ក្រុមខ្ញុំបានទទួលបទបញ្ជាពីមេបញ្ជាការរួចហើយ។ ... នៅពេលយើងឮពួកគេប្រកាសឲ្យប្រជាជន ចេញពីទីក្រុង មេបញ្ជាការវរសេនាធំរបស់ខ្ញុំឆ្លល់ ព្រោះកងខ្ញុំបានទទួលបញ្ជាឲ្យរក្សាទុកប្រជាជនជាធម្មតា")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីម ហ៊ន ឯកសារ E3/5532 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00422484-00422485 (ពុំបានដឹងអំពីផែនការជម្លៀសប្រជាជនទេ គ្រាន់តែដឹងអំពីផែនការវាយយកទីក្រុងភ្នំពេញប៉ុណ្ណោះ)។ សូមមើលផងដែររបាយការណ៍ដោយ S. Heder & M. Matsushita បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ខែកុម្ភៈ-ខែមីនា ឆ្នាំ១៩៨០ ទំព័រ ៥៩-៦០ ERN (ភាសាខ្មែរ) 00324730-00324731 (បុរសម្នាក់មកពីតំបន់ ១៣ ខេត្តតាកែវ ក្នុងភូមិភាគនិរតី បានបញ្ជាក់ថា "តាមដែលខ្ញុំដឹង ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនត្រូវបានប្រកាសឲ្យដឹងជាមុនឡើយ។ ...ប៉ុន្តែ ខ្ញុំគិតថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាផ្នែកមួយនៃគោលនយោបាយរយៈពេលយូរទូទៅ ពីព្រោះនោះគឺជាអ្វីដែលយើងតែងតែបានធ្វើពីមុន នៅពេលដែលយើងរំដោះបានតំបន់របស់សត្រូវ។ កាលពីមុន យើងបានជម្លៀសប្រជាជនចេញពីតំបន់ដែលយើងបានរំដោះ ពីព្រោះយើងភ័យខ្លាចថា យើងមិនអាចកាន់កាប់តំបន់ទាំងនេះទប់ទល់នឹងការវាយបកមកវិញ ដូច្នេះហើយមិនអាចរក្សាសន្តិសុខជូនប្រជាជនបាន។ និងដោយសារតែ ប្រជាជនជាប្រភពនៃកម្លាំងពលកម្ម ។ ហើយប្រសិនបើយើងប្រមូលកម្លាំង ប្រជាជនយើងនឹងមានកម្លាំងវាយយកឈ្នះសត្រូវ")។

ពិភាក្សាអំពីគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាមួយ ប៉ុល ពត បន្ទាប់ពីព្រឹត្តិការណ៍ជម្លៀសនេះបានកើតឡើងរួចហើយ ហើយគាត់ចាត់ទុកថា ការជម្លៀសប្រជាជនបែបនេះគឺជាកំហុសដ៏ធ្ងន់ធ្ងរមួយ[៤៤១]។ ទោះបីជា លោក Philip SHORT យល់ឃើញថា ខៀវ សំផន មិនមែនជាផ្នែកមួយនៃក្បាលម៉ាស៊ីនក្នុងការធ្វើសេចក្តីសម្រេចក៏ដោយ[៤៤២] ក៏អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់ ខៀវ សំផន ដែលថា គាត់មិនបានដឹងទាល់តែសោះអំពីផែនការជម្លៀសប្រជាជននោះ គឺមិនគួរឲ្យជឿបានឡើយ។ ដោយពិចារណាទៅលើទំនាក់ទំនងដ៏ជិតស្និទ្ធរបស់គាត់ជាមួយនឹងជនជាប់ចោទ នួន ជា ប៉ុល ពត និង អៀង សារី និងភ័ស្តុតាងដែលលើកឡើងដោយសង្ខេបខាងលើនោះ[៤៤៣] អង្គជំនុំជម្រះជឿជាក់ថា នួន ជា ព្រមទាំង ខៀវ សំផន និង អៀង សារី ពិតជាបានចូលរួម នៅក្នុងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត។

## ៣.៥ យុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ - ការទម្លាក់គ្រាប់បែករបស់អាមេរិក

[៤៤១] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00156616-00156617 ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00156618-00156619។ កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយ ហេង រស្មី ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ ឯកសារ E3/586 ទំព័រ ១-២។ លិខិតចំហទីពីររបស់ ខៀវ សំផន ឯកសារ E3/592 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ ទំព័រ ៨៥-៨៦ ERN (ភាសាខ្មែរ) 00002799-00002800។ *ខ្ញុំមិនបានដឹងអ្វីទាំងអស់* (ដោយ Stephanie Giry សារព័ត៌មាន Newsweek International) ឯកសារ E3/629 ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦។

[៤៤២] ប្រតិចារឹក ថ្ងៃទី 0៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៨-៤០។ សូមមើលផ្នែកទី ៧ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ ខៀវ សំផន កថាខណ្ឌ ៣៨៥-៣៨៧ ។

[៤៤៣] *សូមមើល ឧទាហរណ៍* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦១-៦២ ERN (ភាសាខ្មែរ) 00103838-00103839។ ("នៅពេលខ្ញុំសួរពួកគេ ពួកគេបានប្រាប់ខ្ញុំថាមានការណែនាំឲ្យជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ។ ខ្ញុំ រន្ធត់ចិត្តយ៉ាងខ្លាំង")។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៥២-៥៣ ("ខ្ញុំមិនដែលចង់ ឬបានសម្រេចជម្លៀសប្រជាជនឡើយ ហើយខ្ញុំក៏មិនដែលរៀបចំផែនការ ឬសម្រេចធ្វើដូច្នេះឡើយ") ទំព័រ ៥៣-៥៤ ("ខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំមិនបានឃើញរឿងរ៉ាវដែលបានកើតឡើងនៅថ្ងៃក្រោយនោះទេ ហើយខ្ញុំក៏មិនមានអំណាចអ្វីទៅដាក់កំហិតឲ្យគេកែប្រែនោះដែរ។ អ្នកខ្លះថាខ្ញុំជាជនកំសាក ឯខ្ញុំ ខ្ញុំមិនមែនជាអ្នកមានអំណាចអ្វី ហើយខ្ញុំ ក៏មិនខ្វល់អ្វីពីរឿងអត់អំណាចនេះដែរ")។

១៥៣. ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានលើកឡើងពីលទ្ធភាពនៃការវាយប្រហារដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុងភ្នំពេញ ដើម្បីធ្វើជាយុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ[៤៤៤]។

១៥៤. ចាប់ពីខែ មីនា ឆ្នាំ ១៩៦៩ ដោយមានការព្រមព្រៀងពីសម្តេច នរោត្តម សីហនុ[៤៤៥] កងទ័ពសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកជាសម្ងាត់ ទៅលើទីតាំងមួយចំនួននៅតាមបណ្តាខេត្តនៅប៉ែកខាងកើតនៃប្រទេសកម្ពុជា ទោះបីជាមានយន្តហោះ ហោះឆ្លងកាត់ព្រំដែនពីប្រទេសវៀតណាមនៅមុនព្រឹត្តិការណ៍នេះក៏ដោយ[៤៤៦]។ ដំបូង ពួកគេកំណត់គោលដៅទៅលើផ្លូវលំហូជីមិញ ដែលជាផ្លូវមួយចេញពីវៀតណាមខាងជើង ឆ្លងកាត់ប្រទេសកម្ពុជាចូលទៅវៀតណាមខាងត្បូង ដែលតាមរយៈផ្លូវនេះ ពួកកុម្មុយនីស្តវៀតណាមបានជួយដល់កងទ័ព និងផ្តល់សម្ភារៈបរិក្ខារគាំទ្រដល់ជម្លោះនៅក្នុងប្រទេសវៀតណាម[៤៤៧]។ បន្ទាប់ពីសម្តេច នរោត្តម សីហនុ ត្រូវបានទម្លាក់ចេញពីអំណាច

---

[៤៤៤] សារទូរលេខ ក្រសួងការបរទេសបារាំង ដែលមានកម្មវត្ថុ៖ ស្ថានការណ៍នៅក្នុងទីក្រុងភ្នំពេញ ឯកសារ E3/2688 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00490993-00490994។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២១ (បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបាន វាមិនច្បាស់ឡើយថាតើ អាមេរិកបន្តជាប់ពាក់ព័ន្ធ ឬយ៉ាងណា)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ២៩ (“ប្រសិនបើកងទ័ពរបស់យើងមកកាន់កាប់ទីក្រុង តើអាមេរិកនឹងទម្លាក់គ្រាប់ […]”)។ ប្រតិចារឹក ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ (ស្នួង ស៊ីគឿន) ទំព័រ ៨៥-៨៧។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៤២-៤៤។

[៤៤៥] សៀវភៅ និពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ឆ្នាំ ១៩៧៩ ទំព័រ ៧០, ៩២-៩៥ ERN (ភាសាអង់គ្លេស) 00429757, 00429779-82។ មេធាវីការពារក្តី នួន ជា ផ្អែកទៅលើសៀវភៅ ដែលមានចំណងជើងថា *Sideshow* ដែលនិពន្ធដោយ William Shawcross ផងដែរ។ សូមមើល សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ជើងទំព័រ ៥៨១។

[៤៤៦] សៀវភៅ និពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ឆ្នាំ ១៩៧៩ ទំព័រ 19-24, ERN (ភាសាអង់គ្លេស) 00429706-11។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៦-២៨, ៨៦។ សៀវភៅនិពន្ធដោយ P. Short: *ប៉ុល ពត – ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ១៨២ ERN (ភាសាអង់គ្លេស) 00396382។ សូមប្រៀបធៀបជាមួយប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ែចាម តុន) ទំព័រ ២៥ (ការទម្លាក់គ្រាប់បែកចាប់ផ្តើមក្នុងឆ្នាំ ១៩៦២ ទៅលើឃុំញ៉ាង ដែលបច្ចុប្បន្ននេះជាផ្នែកនៃទឹកដីវៀតណាម ហើយកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងឆ្នាំ ១៩៦៩)។

[៤៤៧]ប្រតិចារឹកថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២(David CHANDLER) ទំព័រ៨៦-៨៧។ ប្រតិចារឹកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៦-១៨, ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ែចាម តុន) ទំព័រ ២៥-២៦ (អាមេរិកកំណត់គោលដៅកងទ័ពវៀតកុងនៅក្នុងទឹកដីកម្ពុជា)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ

សហរដ្ឋអាមេរិកក៏បានបញ្ជូនកងទ័ពថ្មើរជើងរាប់ពាន់នាក់ផងដែរ ចូលមកប្រទេសកម្ពុជាចាប់ពីខែមេសា ដល់ខែ មិថុនា ឆ្នាំ ១៩៧០[៤៤៨]។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧០ ជាការឆ្លើយតបទៅនឹងការជំទាស់នៅក្នុងប្រទេសចំពោះអន្តរាគមន៍របស់កងទ័ពសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា សភាសហរដ្ឋអាមេរិកបានហាមឃាត់មិនឱ្យផ្តល់មូលនិធិដល់ "បុគ្គលិកសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជាដែលផ្តល់នូវការណែនាំផ្នែកយោធាដល់កងកម្លាំងកម្ពុជា ឬចូលរួមក្នុងសកម្មភាពវាយប្រយុទ្ធ"[៤៤៩]។ ទោះជាយ៉ាងណាក្តី និងដូចបានបញ្ជាក់ជូនខាងក្រោមនេះ ការទម្លាក់គ្រាប់បែកពីសំណាក់កងទ័ពសហរដ្ឋអាមេរិកបានបន្តរហូតដល់ខែ សីហា ឆ្នាំ ១៩៧៣[៤៥០]។

១៥៥. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៣ សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឈប់បាញ់គ្នាជាមួយនឹងវៀតណាម[៤៥១]។ ដោយឡែក ខ្មែរក្រហមបានបដិសេធមិនចុះកិច្ចព្រមព្រៀង

---

ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៨-៩ (វៀតណាមទទួលរងនូវការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់ ហើយវៀតណាមបានទន្ទ្រានចូលទឹកដីកម្ពុជា ដើម្បីអាចឱ្យជនជាតិវៀតណាមចូលមកស្នាក់នៅក្នុងភូមិនៅទីនោះ)។

[៤៤៨] សៀវភៅ និពន្ធដោយ P. Short: *ប៉ុល ពត – ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9, ទំព័រ 204, 215, ERN (ភាសាអង់គ្លេស) 00396404, 00396415។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ឆ្នាំ ១៩៧៩ ទំព័រ 396 ERN (ភាសាអង់គ្លេស) 00430099។ សៀវភៅ និពន្ធដោយ W. Deac ដែលមានចំណងជើងថា *Road to the Killing Fields: The Cambodian War of 1970-1975* ឯកសារ E3/3328 ទំព័រ 77-78, 250 ERN (ភាសាអង់គ្លេស) 00430657-58, 00430830។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១០-១១។ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២២-២៤។

[៤៤៩] សៀវភៅ និពន្ធដោយ W. Deac ដែលមានចំណងជើងថា *Road to the Killing Fields: The Cambodian War of 1970-1975* ឯកសារ E3/3328 ទំព័រ 79, ENR (ភាសអង់គ្លេស) 00430659។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 399, ERN (ភាសាអង់គ្លេស) 00430102។

[៤៥០] សៀវភៅ និពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 213-218, ERN (ភាសាអង់គ្លេស) 00429900-05។

[៤៥១] សៀវភៅ សរសេរដោយដៃរបស់ សួង ស៊ីគឿន ឯកសារ E3/40, ERN (ភាសាខ្មែរ) 00583609។ សៀវភៅ និពន្ធដោយ F. PONCHAUD៖ កម្ពុជាឆ្នាំសូន្យ ឯកសារ E243.1 ERN (ភាសាខ្មែរ) 00862500 (បន្ទាប់ពីរដ្ឋាភិបាលសហរដ្ឋអាមេរិកចុះកិច្ចព្រមព្រៀងជាមួយវៀតណាមខាងជើង នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៣ មក សហរដ្ឋអាមេរិកមានបំណងឱ្យប្រទេសកម្ពុជាមានសន្តិភាពឡើងវិញ ដោយខិតខំបំបែកខ្មែរក្រហមចេញពីសម្តេចសីហនុ និងផ្តល់គំនិតឱ្យបង្កើតរដ្ឋាភិបាលចម្រុះដោយភាគីផ្សេងៗរួមគ្នា)។ ឯកសារបោះពុម្ពផ្សាយនៃសម័យកម្ពុជាប្រជាធិបតេយ្យ៖ សៀវភៅខ្មៅ ឯកសារ E3/23 ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៥២-៥៣ ERN (ភាសាខ្មែរ) 00289695-00289696

ឈប់បាញ់គ្នាជាមួយនឹងរដ្ឋាភិបាល លន់ នល់ ទេ ហើយក្រោយមកក៏មានការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកកាន់តែច្រើនឡើងៗ ទៅលើទីតាំងដែលត្រួតត្រាដោយពួកខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា[៤៥២]។ សរុបមក សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែករាប់រយពាន់តោនមកលើប្រទេសកម្ពុជា[៤៥៣]។ ទោះបីជាគ្រាប់បែកជាច្រើនបានធ្លាក់នៅក្នុងតំបន់ ដែលមិនមានប្រជាជនរស់នៅច្រើនយ៉ាងណាក៏ដោយ ក៏មានការប៉ាន់ប្រមាណថា ប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយសារការទំលាក់គ្រាប់នេះ[៤៥៤]។ លោក Francois PONCHAUD ដែលស្ថិតនៅក្នុងប្រទេស

---

(កម្ពុជាបដិសេធមិនធ្វើការចចារ និងបញ្ឈប់ការបាញ់ប្រយុទ្ធគ្នាឡើយ ទោះបីជាមានសម្ពាធ ការគំរាមកំហែង និងការបង្ករឿងពីសំណាក់វៀតណាមក៏ដោយ។

[៤៥២]ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៦-២៧, ៨៦។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 260-265, 272 ERN (ភាសាអង់គ្លេស) 00429947-52, 00429959។

[៤៥៣]ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៩៤-៩៥។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 272, ERN (ភាសាអង់គ្លេស) 00429959 ("ពេញមួយឆ្នាំ ១៩៧២ យន្តហោះ B-52 បានទម្លាក់គ្រាប់បែកជិត ៣៧.០០០ តោន មកលើ ប្រទេសកម្ពុជា។ ក្នុងខែ មីនា ឆ្នាំ ១៩៧៣ យន្តហោះទាំងនោះបានទម្លាក់គ្រាប់បែកជាង ២៤.០០០តោន នៅក្នុងខែ មេសា ប្រមាណជា ៣៥.០០០តោន និងនៅក្នុងខែ ឧសភា ជិត ៣៦.០០០តោន ។ ដូច្នេះមានការប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែក។ នៅក្នុងឆ្នាំ ១៩៧២ យន្តហោះទាំងនេះបានទម្លាក់គ្រាប់បែកចំនួន ១៦.៥១៣ តោន ចំគោលដៅ។ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៣ តែមួយឆ្នាំប៉ុណ្ណោះ យន្តហោះទាំងនេះបានទម្លាក់គ្រាប់បែកជិត ១៥.០០០ តោន ហើយតួលេខបានកើនឡើង ជារៀងរាល់ខែរហូតដល់ជាង ១៩.០០០តោន ក្នុងខែ កក្កដា")។

[៤៥៤] ប្រតិចារឹកថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៦-២៨, ៨៦។ ប្រតិចារឹកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) (ដែលប៉ាន់ប្រមាណថាមានស្លាប់ចំនួន ៤០.០០០ នាក់)។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 35 ERN (ភាសាអង់គ្លេស) 00429722 ("កសិករបានស្លាប់ ពុំមាននរណាដឹងថាស្លាប់ប៉ុន្មាននាក់ឡើយ […]")។ សៀវភៅ និពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ខែ កក្កដា ឆ្នាំ ២០០៤ ERN (ភាសាខ្មែរ) 00103836-00103837 (ខៀវ សំផន ប៉ាន់ប្រមាណថាការទម្លាក់គ្រាប់បែកបានសម្លាប់ប្រជាជនកម្ពុជារាប់សែននាក់)។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ុចាម តុន) ទំព័រ ២៥ (នៅក្នុងឆ្នាំ ១៩៦៨ និង ១៩៦៩ សូម្បីតែវាលស្រែ ក៏ត្រូវបានរងនូវការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរផងដែរ ហើយចាប់ផ្តើមក្នុងឆ្នាំ ១៩៦៤ ប្រជាជនបានចាកចេញពីភូមិទៅរស់នៅក្នុងព្រៃ ដោយសារតែការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់)។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ុចាម តុន) ទំព័រ ២៩ (នៅត្រឹមឆ្នាំ ១៩៦៩ អ្នកភូមិស៊ាំទៅនឹងការទម្លាក់គ្រាប់បែក និងបានចេះអំពីរបៀបគេចចេញពីការទម្លាក់គ្រាប់ដោយការភៀសខ្លួន

កម្ពុជានៅពេលនោះ បានផ្តល់សក្ខីកម្មថា ប្រជាជនមានការភ័យខ្លាច និងតក់ស្លុត ដោយសារការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់នេះ[៤៥៥]។ ឥទ្ធិពលដ៏សំខាន់នៃការទម្លាក់គ្រាប់បែកនេះគឺបានបង្ខំឱ្យប្រជាជនចាកចេញពីជនបទ រត់ទៅជ្រកកោននៅទីក្រុងភ្នំពេញ ដែលធ្វើឱ្យចំនួនប្រជាជនមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងទីក្រុង[៤៥៦]។ ការទម្លាក់គ្រាប់បែកនេះក៏មានផលប៉ះពាល់ផងដែរទៅលើកងទ័ពខ្មែរក្រហម និង បានពន្យារពេលមិនឱ្យខ្មែរក្រហមមានលទ្ធភាពកាន់កាប់ទីក្រុងភ្នំពេញអស់រយៈពេលជាច្រើនឆ្នាំ[៤៥៧]។ សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគាត់បានទទួលរងផលប៉ះពាល់ដោយសារការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក និងបានព្យាយាមរក

---

ចូលទៅក្នុងព្រៃ ដោយពុំមានគ្រោះថ្នាក់អ្វីឡើយ ប៉ុន្តែគោក្របីបានងាប់។ សមាជិកចំនួន ៣១ នាក់ ក្នុងចំណោមសមាជិកគ្រួសាររបស់សាក្សី បានស្លាប់ដោយសារការទម្លាក់គ្រាប់បែក នៅក្នុងឆ្នាំ ១៩៧៣)។

[៤៥៥] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១១-១២។ *សូមមើលផងដែរ ភាពយន្ត ឯកសារ៖ Cambodia Year Zero 5 – the Bloodiest Domino* ឯកសារ E3/3137R (សាក្សីបញ្ជាក់ថា ប្រជាជនសាមញ្ញមានការភ័យរន្ធត់យ៉ាងខ្លាំង ហើយអ្នកខ្លះកើតរោគភ័យតក់ស្លុតដោយសារការទម្លាក់គ្រាប់បែក ខួរក្បាលរបស់ពួកគាត់ដូចជាខូចអស់ហើយ។ ដោយមានការភ័យតក់ស្លុត និងហាក់ដូចជាវិលវល់ស្មារតីផងនោះ ពួកគាត់ជឿនូវអ្វីដែលគេប្រាប់ពួកគាត់ និងដោយសារតែមានការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់នោះ ពួកគាត់បានជឿនូវអ្វីដែលខ្មែរក្រហមបានប្រាប់ពួកគាត់)។

[៤៥៦] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៣ (François PONCHAUD) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០-២១, ២៨។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៤០-៤២ (បន្ទាប់ពីខ្មែរក្រហមរំដោះបានខេត្តមណ្ឌលគិរីក្នុងឆ្នាំ ១៩៧០ ភូមិរបស់សាក្សីបានទទួលរងនូវការទម្លាក់គ្រាប់បែកស្ទើរតែរាល់ថ្ងៃ ដែលបង្ខំឱ្យអ្នកភូមិភៀសខ្លួនចេញ រួមទាំងព្រះសង្ឃផងដែរ ដែលវត្តអារ៉ាមត្រូវបានបំផ្លាញនៅ ជីមៀត)។

[៤៥៧] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ១២៨-១២៩ ERN (ភាសាខ្មែរ) 00103872 (ការទម្លាក់គ្រាប់បែករបស់អាមេរិក "មិនត្រឹមតែ ធ្វើឱ្យកងទ័ពខ្មែរក្រហមខូចខាតជាទម្ងន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តាលឱ្យសង្គមខ្មែរនៅជនបទត្រូវខ្ទេចខ្ទី […]")។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន) ទំព័រ ៥៩-៦២ (យុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិកនៅ ក្នុងប្រទេសកម្ពុជា បានបង្ខំឱ្យមានចលនាបដិវត្តន៍រត់ចូលព្រៃនៅក្នុងខេត្តរតនគីរី ហើយតម្រូវឱ្យចល័តមន្ទីររបស់ពួកគេ ជាញឹកញាប់)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៧។ ប្រតិចារឹក ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១២ (គឹម វុន) ទំព័រ៤២-៤៣, ៤៨-៥០ (ការវាយប្រហារតាមអាកាស បានធ្វើឱ្យកម្មាភិបាលភ័យខ្លាចមិនហ៊ានចល័តដោយសេរីឡើយ)។

ទីកន្លែងជ្រកកោន[៤៥៨]។

១៥៦. ការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកបានបញ្ចប់នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៣ បន្ទាប់ពីសភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយ ដែលបញ្ឈប់ការផ្តល់មូលនិធិសម្រាប់បន្តការទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជា នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៣[៤៥៩]។ មានភ័ស្តុតាងមួយចំនួនបានបង្ហាញអំពីការវាយប្រហារដោយការទម្លាក់គ្រាប់បែក ក្រោយថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៣ មកលើតំបន់ដែលត្រួតត្រាដោយបក្សកុម្មុយនីស្តកម្ពុជា នៅមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បើទោះបីជាការវាយប្រហារមួយចំនួនក្នុងចំណោមការវាយប្រហារ

[៤៥៨] ប្រតិចារឹក ថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៦០-៦២ (សាក្សីបានផ្តល់សក្ខីកម្មថា ក្នុងខណៈពេលដែលគាត់ធ្វើការនៅ ម-១៣ នៅចន្លោះឆ្នាំ ១៩៧១ ដល់ឆ្នាំ ១៩៧៥ នៅពេលយន្តហោះទម្លាក់គ្រាប់បែក B-52 ហោះពីលើក្បាល គាត់ត្រូវតែចូលពួនក្នុងត្រង់សេ។ ទម្លាក់គ្រាប់ម្តងៗ ដីឡើងខ្ទរខ្ទារញ្ជួយ ហើយបន្សល់នូវរណ្តៅធំៗ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុំង រ៉ែន) ទំព័រ ៤៣-៤៥ (សាក្សីបានផ្តល់សក្ខីកម្មថាគាត់ធ្លាប់បានជួបប្រទះការទម្លាប់គ្រាប់បែករបស់អាមេរិក នៅតាមផ្លូវលេខ ២៦)។ សាក្សី ឯក ហេន បានផ្តល់សក្ខីកម្មថាឪពុករបស់អ្នកស្រីបានស្លាប់ក្នុងឆ្នាំ ១៩៧១ នៅស្វាយទៀប ដោយសារតែការទម្លាក់គ្រាប់បែក។ អ្នកស្រីចាត់ទុកការទម្លាក់គ្រាប់បែកនេះ ធ្វើឡើងដោយយន្តហោះរបស់ លន់ នល់ ទោះបីជាការទម្លាក់គ្រាប់បែករបស់អាមេរិក បានកើតឡើងនៅក្នុងអំឡុងពេលតែមួយក៏ដោយ។ សូមមើល ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ១៤-១៥, ១៧-១៨, ៥៧-៥៨។

[៤៥៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៣-៣៤, ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៣ (Al ROCKOFF) ទំព័រ ៨-៩ ("ខ្ញុំចាំកាលបរិច្ឆេទនោះច្បាស់ណាស់។ ខ្ញុំនៅលើផ្លូវជាតិលេខ ៣ នៅពេញមួយព្រឹក។ ហើយខ្ញុំចាំថាប្រហែលជាម៉ោង ១២ ថ្ងៃត្រង់ ដែលជាថ្ងៃបញ្ចប់នៃការទម្លាក់គ្រាប់បែករបស់អាមេរិក មានការទម្លាក់គ្រាប់បែកខ្លះនៅពេលនោះ។ ដូច្នេះហើយ ខ្ញុំចាំ ច្បាស់ណាស់ ថ្ងៃទី ១៥ ខែ សីហា")។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១០-១២។ ឯកសារបោះពុម្ពផ្សាយនៃសម័យកម្ពុជាប្រជាធិបតេយ្យ៖ សៀវភៅខ្មៅ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារ E3/23 ទំព័រ ៥២ ERN (ភាសាខ្មែរ) 00289695 ("ចាប់ពីខែ កុម្ភៈ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៣ ពួកចក្រពត្តិអាមេរិកបានបើកយុទ្ធនាការសង្គ្រាមអាកាសដ៏ខ្លាំងក្លាប្រឆាំងនឹងបដិវត្តន៍កម្ពុជា ដោយធ្វើការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ទាំងថ្ងៃទាំងយប់មកលើកម្ពុជា")។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជា ថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៥៦-៥៨ ERN (ភាសាខ្មែរ) 00103836-00103837 ("ចុងបញ្ចប់ ព្រឹទ្ធសភាអាមេរិកបានបោះឆ្នោតផ្អាកថវិកាសង្គ្រាមដោយកំណត់ឲ្យឈប់ទម្លាក់គ្រាប់បែកលើកម្ពុជា នៅពាក់កណ្តាលខែ សីហា ឆ្នាំ ១៩៧៣")។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ 284, 299, 400, ERN (ភាសាអង់គ្លេស) 004299987, 00430002, 04430103។

ទាំងនេះ មានជាប់ពាក់ព័ន្ធទៅនឹងទាហានអាមេរិកក្តី ក៏ប៉ុន្តែ ការវាយប្រហារខ្លះប្រហែលជាដោយសារតែសកម្មភាពរបស់ទាហានសាធារណរដ្ឋខ្មែរដែលនៅសេសសល់[៤៦០]។

## ៣.៦ ស្ថានភាពជនភៀសខ្លួន និងកង្វះម្ហូបអាហារនៅក្នុងទីក្រុងភ្នំពេញ

១៩៧. ចាប់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មានការហូរចូលជនភៀសខ្លួនយ៉ាងច្រើន[៤៦១] ពីជនបទមកកាន់ទីក្រុងភ្នំពេញ កត្តានេះធ្វើឲ្យចំនួនប្រជាជននៅក្នុងទីក្រុងមានការកើនឡើងប្រមាណពី ៥០០.០០០នាក់ នៅក្នុងឆ្នាំ ១៩៧០-១៩៧១ ទៅដល់ប្រមាណពី ២.០០០.០០០ នាក់ ទៅ ២.៥០០.០០០ នាក់ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥[៤៦២]។ យោងតាមលោក François

---

[៤៦០] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៣១ (ជាច្រើនខែមុនពេលការវាយផ្តាច់ទីក្រុងភ្នំពេញ មានការទម្លាក់គ្រាប់បែកពីលើអាកាស ក្នុងអំឡុងពេលការវាយរុករបស់ទាហាន ហើយមានមនុស្សស្លាប់ និងរបួសពី ២០ ទៅ ៣០ នាក់ នៅពេលប្រយុទ្ធគ្នាម្តងៗ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៣ (អ៊ុង រ៉េន) ទំព័រ ៤៣-៤៦ (ការទម្លាក់គ្រាប់បែកបានកើតឡើងនៅមុនពេលការវាយទីក្រុងភ្នំពេញ ហើយបញ្ឈប់នៅពេលដែលពួកខ្មែរក្រហមបានរុលទៅមុខទៅជាយៗទីក្រុងភ្នំពេញ។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ២៨-៣០ (បន្ទាប់ពី អាមេរិកឈប់ទម្លាក់គ្រាប់បែក កងកម្លាំងអាកាសខ្មែរមានលក្ខណៈទន់ខ្សោយ និងមានការប្រុងប្រយ័ត្នមែនទែនក្នុងការដាក់ពង្រាយទ័ព និងរៀបចំប្រតិបត្តិការ)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥២ (បន្ទាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៣ ការទម្លាក់គ្រាប់បែករបស់អាមេរិក បានបញ្ចប់ទាំងស្រុង ប៉ុន្តែការទម្លាក់គ្រាប់បែករបស់ទ័ពអាកាសសាធារណរដ្ឋខ្មែរ បានបន្តទម្លាក់គ្រាប់បែក គឺនៅបន្តសកម្មភាពដូចទ័ពជើងគោករបស់សាធារណរដ្ឋខ្មែរដែរ)។

[៤៦១] នៅក្នុងផ្នែកនេះ ពាក្យ "ជនភៀសខ្លួន" សំដៅទៅលើបុគ្គលដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលទាំងនេះទំនងជាត្រូវបានចាត់ទុកជាប្រភេទ "ជនភៀសសឹកក្នុងប្រទេស" អនុលោមតាមច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិ។ *សូមមើល* គោលការណ៍ណែនាំស្តីអំពីការផ្លាស់ទីលំនៅក្នុងប្រទេស UN Doc. E/CN./4/1998/53/Add.2 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៨ (ដែលកំណត់និយមន័យជនភៀសសឹកថាជា "បុគ្គល ឬក្រុមមនុស្សដែលត្រូវបានបង្ខំ ឬតម្រូវឲ្យភៀសខ្លួន ឬចាកចេញពីផ្ទះសម្បែង ឬទីកន្លែងស្នាក់អាស្រ័យរបស់ពួកគេ ជាពិសេស ដោយសារតែ ឬដើម្បីគេចចេញពីឥទ្ធិពលនៃជម្លោះប្រដាប់អាវុធ ស្ថានភាពហិង្សាជាទូទៅ ការរំលោភសិទ្ធិ មនុស្ស ឬមហន្តរាយធម្មជាតិ ឬមហន្តរាយបង្កឡើងដោយមនុស្ស និងដែលមិនបានឆ្លងកាត់ព្រំដែនរដ្ឋដែលត្រូវបានទទួល ស្គាល់ជាអន្តរជាតិ")។ សូមប្រៀបធៀបជាមួយ អនុសញ្ញាស្តីពីឋានៈរបស់ជនភៀសខ្លួន 189 UNTS 150 មាត្រា ១(ក)(២) (នៅក្នុងនិយមន័យនៃជនភៀសខ្លួន រួមបញ្ចូលលក្ខខណ្ឌតម្រូវដែលថាបុគ្គលត្រូវស្ថិតនៅក្រៅប្រទេសកំណើតរបស់ខ្លួន)។

[៤៦២] ប្រតិចារឹកថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២(David CHANDLER)ទំព័រ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៣ (François PONCHAUD) ទំព័រ ១៣-១៤ ។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François

PONCHAUD)ទំព័រ១៩-២០,២៦-២៧។ កំណត់ហេតុប្រចាំថ្ងៃរបស់ S.Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ៦,៩, ២២,៥៦-៥៧ ERN (ភាសាខ្មែរ) 00963850-00963855។ ប្រតិចារឹកថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៥-៦, ៣៣។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៣-៥៤។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនហូរចូលអ្នកលឿង ឯកសារ E3/4185 ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៤ (ដែលរាយការណ៍ អំពីការចាកចេញពីលំនៅដ្ឋានរបស់ជនភៀសខ្លួន ១៤.៣០០ នាក់ ពីតំបន់ដែលគ្រប់គ្រងដោយពួកបដិវត្តន៍ឆ្ពោះទៅកាន់ទីតាំងនានារបស់រដ្ឋាភិបាលនៅអ្នកលឿង)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥០-៥៣ (ជារៀងរាល់ថ្ងៃបានឃើញជនភៀសខ្លួនយ៉ាងច្រើនដែលបានជម្លៀសចេញពីភូមិរបស់ពួកគេដែលនៅក្បែរៗនោះ សំដៅចូលមកទីក្រុងពួកគេបានប្រាប់អ្នកស្រីអំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងភូមិរបស់ពួកគេ។ រដ្ឋធានីគឺជាកន្លែងតែមួយគត់ដែលពួកគេអាចស្វែងរកសុវត្ថិភាពបានខ្លះ)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ៥៣-៥៥ (ជារៀងរាល់ថ្ងៃ ជនភៀសខ្លួនយ៉ាងច្រើន សន្ធឹកសន្ធាប់បានមកដល់ទីក្រុងភ្នំពេញ។ នៅពេលនោះ ទីក្រុងមានប្រជាជនប្រហែល ២ លាន នាក់។ ដោយសារមានជនភៀសខ្លួនចូលមកទីក្រុង ដូច្នេះទីក្រុងមានប្រជាជនជាង ៣ លាន នាក់មុនពេលរំដោះ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៤២-៤៥, ៥៦-៥៧ (មានការហូរចូលចំនួនប្រជាជនយ៉ាងច្រើនទៅក្នុងទីក្រុងភ្នំពេញ នៅពេលដែលកងកម្លាំងខ្មែរក្រហមបានរំកិលចូលកាន់តែជិតទីក្រុង នៅក្នុងរយៈពេលប៉ុន្មានថ្ងៃមុនថ្ងៃរំដោះ។ តាមពិត ប្រជាជនទីក្រុងភ្នំពេញបានកើនឡើងមួយជាបី ដោយសារតែមានអ្នកចំណូលថ្មី។ ការកើនឡើងចំនួនប្រជាជន បានធ្វើឲ្យទីក្រុងមានមនុស្សកុះករ ដូច្នេះហើយការរស់នៅមិនមានលក្ខណៈស្រួលឡើយ។ លិខិតរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ឯកសារ E3/4188 ចុះថ្ងៃទី០៣ ខែ ឧសភាឆ្នាំ ១៩៧១(រាយការណ៍នៅក្នុងឆ្នាំ ១៩៧១ ថា ទីក្រុងដែលមានមនុស្សច្រើនចំនួន ៧៥០.០០០ នាក់ នោះ ពេលនេះ បានកើនឡើងច្រើនជាង ១,៥ លាននាក់)។ ប្រតិចារឹក ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤៤-៤៥ (ចំនួនមនុស្សនៅក្នុងទីក្រុងបានកើនឡើងពី ១ លាននាក់ ទៅ ២ លាននាក់ ចំនួនមួយលាននាក់ដែលកើនឡើងនោះ គឺជាប្រជាជនដែលបានភៀសខ្លួនចូលទៅទីក្រុងភ្នំពេញ ហើយមិនមានម្ហូបអាហារគ្រប់គ្រាន់ទេ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៧-៣៨ (ដកស្រង់សៀវភៅ និពន្ធដោយ P. Short: *ប៉ុល ពត – ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9, ទំព័រ 216 ERN (ភាសាអង់គ្លេស) 00396416 "ប្រជាជនទីក្រុងភ្នំពេញ ដែលមានចំនួន ៦៧១.០០០ នាក់ នៅក្នុងឆ្នាំ ១៩៧០ បានកើនឡើងចំនួនលើសពី ១ លាននាក់ នៅចុងឆ្នាំ ១៩៧០ និងបានកើនឡើងទៅដល់ ២,៥ លាននាក់ នៅក្នុងឆ្នាំ ១៩៧៥")។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១១-១២ ("យើងអាចនិយាយបានថា ពី ២ ទៅ ៣លាននាក់ ប៉ុន្តែចំនួននេះគឺជាការប៉ាន់ស្មាន") (ចំនួននេះគឺជាការប៉ាន់ស្មាន "ពុំមានស្ថិតិឡើយ")។ *កម្ពុជាអាច ទប់ទល់បាន ប្រសិនបើមានជំនួយចាំបាច់* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166915 (ដែលកត់សម្គាល់ថា យ៉ាងហោចណាស់មានជនភៀសខ្លួនចំនួន ២លាន នាក់ នៅក្នុងតំបន់ទីក្រុងភ្នំពេញ ហើយពួកគេត្រូវតែទទួលបាននូវម្ហូបអាហារចិញ្ចឹមជីវិត)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៣-១៤ ( នៅពេលនោះ អាចមានប្រជាជនចំនួន ២ ទៅ ៣ លាននាក់ នៅក្នុងទីក្រុងភ្នំពេញ)។ *សូមមើលផងដែរ* ទង់បដិវត្តន៍ ឯកសារ E3/166 ខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ ទំព័រ ២៤-២៧ ERN

PONCHAUD ដែលបានធ្វើការងារជាមួយនឹងអង្គការជនភៀសខ្លួននៅក្នុងទីក្រុងភ្នំពេញបានបញ្ជាក់ថា ប្រជាជនបានភៀសខ្លួនដោយសារគេចចេញពីពួកខ្មែរក្រហម និងពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក[៤៦៣]។ ទោះបីជាយ៉ាងណាក៏ដោយ លោក Sydney SCHANBERG បានអះអាងថា ជនភៀសខ្លួន ដែលគាត់បានសម្ភាសន៍ បាននិយាយអំពីការចូលមកជិតដល់របស់ទាហានខ្មែរក្រហម ការកាន់កាប់ទីប្រជុំជន និងការចិញ្ចឹមកូនៗរបស់ពួកគាត់ ដែលទាំងអស់នេះគឺជាហេតុផលនាំឲ្យពួកគាត់ភៀសខ្លួនទៅកាន់ទីក្រុងភ្នំពេញ[៤៦៤]។ ជនភៀសខ្លួនមួយចំនួនបានប្រាប់ដល់លោក Denise AFFONÇO ថា ពួកគេចាកចេញពីភូមិកំណើតរបស់ពួកគេ ដោយសារតែប្រទេសមានសង្គ្រាមនៅគ្រប់ទីកន្លែងទាំងអស់ ហើយរដ្ឋធានី គឺជាកន្លែងតែមួយគត់ដែលមានសុវត្ថិភាពជាងគេ[៤៦៥]។

១៥៨. នៅត្រឹមឆ្នាំ ១៩៧៥ មានជំរំជនភៀសខ្លួនជាច្រើននៅជុំវិញទីក្រុងភ្នំពេញ និងមានជំរំជនភៀសខ្លួនមួយចំនួននៅក្នុងទីក្រុងនេះ រួមទាំងជំរំជនភៀសខ្លួនមួយនៅស្តាតអូឡាំពិក និងជំរំជនភៀសខ្លួនមួយនៅឯការដ្ឋានសណ្ឋាគារកាំបូឌីយាណា ដែលនៅពេលនោះមិនទាន់ត្រូវបានសាងសង់ជាស្ថាពរនៅឡើយទេ។ ជាទូទៅ ស្ថានភាពម្ហូបអាហារ និងអនាម័យនៅក្នុងជំរំទាំងនេះ និងនៅក្នុងទីក្រុងភ្នំពេញមានលក្ខណៈយ៉ាប់យ៉ឺនយ៉ាងខ្លាំង[៤៦៦]។

១៥៩. រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ជំនួយទៅដល់តំបន់នានាដែលស្ថិតក្រោមការត្រួតត្រារបស់រដ្ឋាភិបាល លន់ នល់ ដោយបានដឹកជញ្ជូនស្រូវ/អង្ករពីវៀតណាមខាងត្បូងទៅកាន់ទីក្រុង

---

(ភាសាខ្មែរ) 00063202-00063203 (យោងទៅលើ "ប្រជាជនជាង ២ លាន នាក់ ដែលទើបត្រូវបានជម្លៀសមកពីទីក្រុងនានា")។

[៤៦៣] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨-១៩។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០១៣ (Denise AFFONÇO) ទំព័រ ៩-១០។

[៤៦៤] ប្រតិចារឹក ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤៤-៤៥។

[៤៦៥] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥២-៥៣។

[៤៦៦] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧២ (ទំនិញឡើងថ្លៃ ហើយអ្នកស្រីពិបាករកទិញអង្ករ)។ ប្រតិចារឹកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD)ទំព័រ ២១-២២។ សៀវភៅនិពន្ធដោយ W. Shawcross: *សកម្មភាពរបស់ Kissinger, Nixon និងការបំផ្លិចបំផ្លាញប្រទេសកម្ពុជា* ឯកសារ E3/88 ទំព័រ ២២០-២២៤, ២២៥-២២៧ ERN (ភាសាអង់គ្លេស) 00429907-14។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៦០-៦១, ៨១-៨៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៥, ៥-៦, ៨។

ភ្នំពេញ តាមទន្លេមេគង្គ ហើយក្រោយមកដឹកជញ្ជូនតាមផ្លូវអាកាសវិញ[៤៦៧]។ ខ្មែរក្រហមបានប្រើប្រាស់កាំភ្លើងត្បាល់ និងរ៉ុកកែតវាយប្រហារទៅលើក្បួនដឹកជញ្ជូនស្បៀងចូលទៅទីក្រុងភ្នំពេញនេះ និងបានបិទមិនឲ្យមានចរាចរណ៍តាមទន្លេមេគង្គតាមរយៈការដាក់មីន[៤៦៨]។ នៅក្នុងអំឡុងពេលពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មានការខ្វះខាតម្ហូបអាហាររួចស្រាប់ទៅហើយ[៤៦៩] ប៉ុន្តែ ស្ថានភាពកង្វះខាតម្ហូបអាហារនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងៗ បន្ទាប់ពីខ្មែរក្រហមបានកាត់ផ្តាច់មិនឲ្យមានចរាចរណ៍តាមទន្លេមេគង្គនៅក្នុងឆ្នាំ ១៩៧៥[៤៧០]។ យោងតាម នួន ជា ទោះបីជាពុំមានស្បៀង-

---

[៤៦៧] ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ៣៦-៣៨។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៣ (François PONCHAUD) ទំព័រ ២០-២១។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៧-៨។

[៤៦៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ២២-២៣។ កំណត់ហេតុប្រចាំថ្ងៃរបស់ S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៥-១៩៧៧ ទំព័រ ១២-១៧ ERN (ភាសាខ្មែរ) 00963850-00963855។ ទង់បដិវត្តន៍ ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៧៨-៨១ ERN (ភាសាខ្មែរ) 00063159-00063161។ *មានការជំរុញឲ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារ ក្នុងពេលចូលឆ្នាំថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ERN (ភាសា អង់គ្លេស) 00166660 (ខៀវ សំផន បញ្ជាក់ថា៖ "ផ្លូវយុទ្ធសាស្ត្រជើងគោកទាំងអស់របស់សត្រូវ ត្រូវបានកាត់ផ្តាច់ [...]។ គេប្រឈមទៅនឹងភាពលំបាកកាន់តែខ្លាំង និងឧបសគ្គកាន់តែធំថែមទៀតនៅតាមដងទន្លេមេគង្គ [...]។ ស្រូវ និងគ្រឿង ឧបភោគបរិភោគ ផ្សេងៗទៀត កាន់តែខ្សត់ខ្សោយ")។ សារចុះថ្ងៃទី ១៤ ខែ មករា របស់លោក ខៀវ សំផន ផ្ញើជូនយុទ្ធជន នៃកងទ័ពរំដោះ ជាតិប្រជាជនកម្ពុជា (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៥ ទំព័រ ២៣-២៥ ERN (ភាសាខ្មែរ) 00701478-00701480 ("ទន្លេមេគង្គដែលជាផ្លូវទឹកដ៏ចម្បងសម្រាប់ដឹកជញ្ជូនស្រូវ និងស្បៀងអាហារ ប្រេងឥន្ធនៈ និងគ្រាប់រំសេវ ពីប្រទេសវៀតណាម ដើម្បីផ្គត់ផ្គង់ក្រុមពួកក្បត់ លន់ នល់ និងបក្ខពួក ត្រូវបានកាត់ផ្តាច់ទាំងស្រុង")។ *AKI កត់សម្គាល់ឃើញកងទ័ពប្រជាជនរំដោះជាតិកម្ពុជា បានបង្កើនការ គ្រប់គ្រងលើទន្លេមេគង្គ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/488 ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ទំព័រ ២១-២៣ ERN (ភាសាខ្មែរ) 00973757-00973759 ("ចាប់តាំងពីថ្ងៃទី ១១ ខែ កុម្ភៈ [...] គ្មាននាវាណាមួយបានបើកមកដល់ ឬបានចាកចេញពីផែភ្នំពេញឡើយ")។

[៤៦៩] *របាយការណ៍* របស់ USAID, *របាយការណ៍បញ្ចប់ជំនួយនៅកម្ពុជា ភាគទី ១* ឯកសារ E3/4178 ខែ កញ្ញា ឆ្នាំ ១៩៧៥។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០-២១។

[៤៧០] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០-២១។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣ (Sydney SCHANBERG) ទំព័រ ៤៤-៤៥។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៤០-៤៥ (មុនថ្ងៃរំដោះ ទីក្រុងភ្នំពេញស្ថិតនៅក្នុងសភាពច្របូកច្របល់។ ទីក្រុងមានមនុស្សច្រើនណែនណាន់តាន់តាប់ ហើយការ ផ្គត់ផ្គង់ស្បៀងអាហារគឺជាបញ្ហា)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៣៤-៣៨, ៤១-៤៣, ៤៩-៥១ (នៅប៉ុន្មានថ្ងៃមុនការជម្លៀសនោះ ពុំមានការខ្វះខាតម្ហូបអាហារ

អាហារច្រើននៅតាមសហករណ៍ក៏ដោយ ក៏ចាំបាច់ត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ពីព្រោះកង្វះខាតស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញមានលក្ខណៈធ្ងន់ធ្ងរមែនទែន ដូច្នេះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញបែបនេះ នឹងធ្វើឱ្យពួកគាត់បានហូបគ្រប់គ្រាន់[៤៧១]។ គាត់បានពន្យល់ថា នៅពេលមានកិច្ចប្រជុំកាលពីពាក់កណ្ដាលឆ្នាំ ១៩៧៤ ដែលបានសម្រេចឱ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ សហរដ្ឋអាមេរិកបានផ្អាកការផ្ដល់ជំនួយរបស់ខ្លួនមកឱ្យប្រទេសកម្ពុជា ហើយថា ដោយសារតែការបញ្ចប់ការផ្ដល់ជំនួយនេះហើយ ទើបក្រោយមកទីក្រុងភ្នំពេញបានប្រឈមនឹងកង្វះខាតស្បៀងអាហារ[៤៧២]។ ដូច្នេះ ផែនការរបស់គាត់គឺត្រូវផ្លាស់ទីលំនៅប្រជាជនទៅកាន់តំបន់នានានៃប្រទេសកម្ពុជាដែលមានស្បៀងអាហារ ដូចជា នៅក្នុងភូមិភាគពាយ័ព្យ ជាដើម ដើម្បីជួយសម្រាលដល់បញ្ហាខ្វះខាតស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញ[៤៧៣]។

១៦០. សេចក្ដីព្រាងរបាយការណ៍ឆ្នាំ ១៩៧៥ របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានចាត់ទុកវិបត្តិស្បៀងអាហារ ថាបណ្ដាលមកពី “បញ្ហាអសន្តិសុខ”[៤៧៤]។

---

ទេ ប៉ុន្តែអីវ៉ាន់ឡើងថ្លៃពិបាករក ទិញ។ ក្នុងអំឡុងរយៈពេលពីរបីថ្ងៃចុងក្រោយ នៅក្នុងទីក្រុងភ្នំពេញ ម្ហូបអាហារឡើងថ្លៃមែនទែន ដោយសារមនុស្សកាន់តែចូលមក ទីក្រុងច្រើនឡើងៗ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ ៨-១២ (ដែលបានកត់សម្គាល់អំពីតម្លៃទំនិញសម្រាប់ទ្រទ្រង់ជីវភាព មានការឡើងថ្លៃ រួមមានតម្លៃថ្នាំសង្កូវ និងម្ហូបអាហារ។ (“ម្ហូបអាហារខ្សត់ខ្សោយ ហើយប្រជាជនកាន់តែពិបាករកទិញអ្វីដែលពួកគាត់ត្រូវការ”)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៩-៦១ (វាមិនទាន់មានគ្រោះអត់ឃ្លាននៅឡើយទេ ដោយសារតែនៅមានស្បៀងអាហារសម្រាប់ហូបចុកនៅឡើយ។ ទោះបីជាការផ្គត់ផ្គង់ស្បៀងអាហារមានលក្ខណៈខ្វះខាតក៏ដោយ ក៏ប្រជាជននៅតែអាចហូបចុកចិញ្ចឹមខ្លួនពួកគេបាន)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៩-៦១ (ស្បៀងអាហារឡើងថ្លៃ សូម្បីតែទឹកដោះគោខាប់ដែលផលិតនៅក្នុងអតីតរោងចក្ររបស់អ្នកស្រី (Sokilait) នោះ ឡើងថ្លៃមែនទែន)។

[៤៧១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-១៩។

[៤៧២]ប្រតិចារឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ (នួន ជា) ទំព័រ ១៧។ ប្រតិចារឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ (នួន ជា) ទំព័រ ១០-១៣។ ប្រតិចារឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ (នួន ជា) ទំព័រ១២-១៣។ *សូមមើល ផងដែរ ទូរលេខ ក្រសួងការបរទេសបារាំង ដែលមានកម្មវត្ថុ៖ កិច្ចសន្ទនាជាមួយឯកអគ្គរដ្ឋទូតចិន ឯកសារ* E3/2708 ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00820655-00820656 (ឯកអគ្គរដ្ឋទូតចិនយល់ថា ការជម្លៀសប្រជាជន គឺដើម្បីដោះស្រាយបញ្ហាស្បៀង)។

[៤៧៣]ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៩។

[៤៧៤] *របាយការណ៍* របស់ USAID ៖ *របាយការណ៍បញ្ចប់ជំនួយនៅកម្ពុជា ភាគទី ១* ឯកសារ E3/4178 ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00759724-00759725។

របាយការណ៍នេះបានបង្ហាញថា ស្តុកអង្ករនៅក្នុងប្រទេសកម្ពុជា “គ្រប់គ្រាន់សម្រាប់តែរយៈពេលជាងពីរបីសប្តាហ៍ប៉ុណ្ណោះ” តែនៅក្នុងពេលមួយក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៤ លទ្ធភាពផ្គត់ផ្គង់ស្បៀងអាហារមានតែរយៈពេលបីថ្ងៃប៉ុណ្ណោះ។ របាយការណ៍បានព្យាករណ៍ថា “បើគ្មានជំនួយជាអាហារ និងឧបករណ៍ពីបរទេសក្នុងទ្រង់ទ្រាយធំនោះទេ ការរីករាលដាលនៃភាពអត់ឃ្លាននឹងកើតមានឡើងចាប់ពីបច្ចុប្បន្ន [ខែ កញ្ញា ឆ្នាំ ១៩៧៥] ដល់ខែ កុម្ភៈ ឆ្នាំក្រោយ [ឆ្នាំ ១៩៧៦]”[៤៧៥]។

## ៣.៧ ការវាយលុកចុងក្រោយមកលើទីក្រុងភ្នំពេញ

១៦១. កងទ័ពខ្មែរក្រហមបានបាញ់ផ្លោងគ្រាប់រ៉ុកកែត និងគ្រាប់ប្រភេទផ្សេងៗទៀត សំដៅមកលើទីក្រុងភ្នំពេញចាប់ពីឆ្នាំ ១៩៧៣ ហើយការបាញ់ផ្លោងនេះកាន់តែកើនខ្លាំងឡើងៗនៅក្នុងឆ្នាំ ១៩៧៤-១៩៧៥[៤៧៦]។ ខ្មែរក្រហមមិនមានកាំភ្លើងរ៉ុកកែតត្រឹមត្រូវទេ ហើយគ្រាប់រ៉ុកកែតជាច្រើនបានធ្លាក់មកលើតំបន់ដែលប្រជាជនរស់នៅ[៤៧៧]។ សេនានុព័ន្ធយោធាអមស្ថានទូតជប៉ុនបានប្រាប់លោក Stephen HEDER អំពីប្រភពនៃគ្រាប់រំសេវទាំងនេះ ដោយព័ត៌មាននេះទំនងជាមានប្រភពចេញមកពីទីភ្នាក់ងារសម្ងាត់យោធារបបសាធារណរដ្ឋខ្មែរ[៤៧៨]។ លោក Stephen HEDER បានផ្តល់សក្ខីកម្មថា នៅក្រោមការបញ្ជារួមរបស់អគ្គសេនាធិការ ដែលដឹកនាំដោយ សុន សេន គ្រាប់ ១០៥ មីលីម៉ែត្រ ត្រូវបានបាញ់ផ្លោងចេញពីកងទ័ពភូមិភាគពិសេស ដែលដឹកនាំ និងបញ្ជាដោយ អ៊ុន លន ហៅ ណាត ហើយគ្រាប់ ១០៧ មីលីម៉ែត្រ ដែលចេញមកពីទិសខាងកើត ត្រូវបានបាញ់ផ្លោងដោយកងពលលេខ ១ ឬ កងពលលេខ ២ របស់ភូមិភាគបូព៌ា[៤៧៩]។

---

[៤៧៥] *របាយការណ៍* របស់ USAID ៖ *របាយការណ៍បញ្ចប់ជំនួយនៅកម្ពុជា ភាគទី ១* ឯកសារ E3/4178 ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៩ ERN (ភាសាខ្មែរ) 00759726។

[៤៧៦] ប្រតិចារឹកថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៣(Stephen HEDER) ទំព័រ ៥៣-៥៤, ៥៥-៥៦, ៥៦-៥៧។ ប្រតិចារឹកថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៦៩-៧១។

[៤៧៧] ប្រតិចារឹកថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sidney SCHANBERG) ទំព័រ ១៦-១៧ (ខ្មែរក្រហមមានគ្រាប់រ៉ុកកែតផលិតនៅប្រទេសចិន ប៉ុន្តែ មិនមានកាំភ្លើងយន្តដើម្បីបាញ់ចេញទៅក្នុងលំហទេ ដូច្នេះ ពួកគេបានច្នៃប្រដាប់បាញ់ដែលធ្វើពីឈើ)។ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៥-៥៦។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៣ (ឡាយ បូនី) ទំព័រ ៧០-៧១ ។

[៤៧៨] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ((Stephen HEDER) ទំព័រ ៥៦-៥៧។

[៤៧៩] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៤-៥៦។ សូមមើលផងដែរផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០ ។

១៦២. ដោយសារការវាយប្រយុទ្ធគ្នានៅតាមទីកន្លែង ដែលស្ថិតក្រោមការកាន់កាប់ដោយរដ្ឋាភិបាល លន់ នល់ នៅតែបន្ត កុយ ធួន និងថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត បានជួបប្រជុំគ្នានៅដំណាច់ឆ្នាំ ១៩៧៤ នៅដំណាក់ស្នាច់ (ជិតឧត្តុង្គ) ដើម្បីរៀបចំផែនការរំដោះទីក្រុងភ្នំពេញ[៤៨០]។ បន្ទាប់មក នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមបើកការវាយលុកចុងក្រោយរបស់ខ្លួនមកលើទីក្រុងភ្នំពេញ[៤៨១]។ ការវាយលុកនេះត្រូវបានប្រកាសផ្សាយតាមវិទ្យុនៅក្នុងសេចក្តីថ្លែងការណ៍មួយរបស់ ខៀវ សំផន កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤[៤៨២]។

១៦៣. ចាប់ពីខែ កុម្ភៈ ដល់ខែ មេសា ឆ្នាំ ១៩៧៥ ការបាញ់ផ្លោងបានបន្តឥតឈប់ បណ្តាលឱ្យជនស៊ីវិលស្លាប់ និងរងរបួសជាច្រើនរយនាក់[៤៨៣]។ នៅក្នុងអំឡុងពេលពីថ្ងៃទី១៤ ដល់ថ្ងៃទី ១៥ ខែ

---

[៤៨០] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៥២-៥៣។

[៤៨១] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥២-៥៣។ *ខ្មែរក្រហមបើកការវាយលុកក្នុងពេលចូលឆ្នាំថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ១៩៧៥ ERN (ភាសាអង់គ្លេស) 00166658។ សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមស្តីពីបញ្ហាមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ៣-៤ ERN (ភាសាខ្មែរ) 00003138-00003139។ ទង់បដិវត្ត ឯកសារ E3/747 ចុះខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៤៤-៤៦ ERN (ភាសាខ្មែរ) 00064646-00064647 ("នៅវេលាម៉ោង ១ ភ្លឺនាថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៥ គ្រប់អង្គភាពទ័ព រួមទាំងឈ្លប ស្រុក តំបន់ ភាគ និងទ័ពមជ្ឈិម គ្រប់មុខព្រួញត្រូវសំរុកបុកទំលាយ តាមផែនការបក្សកំណត់")។

[៤៨២] *មានការជម្រុញឱ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារក្នុងពេលចូលឆ្នាំថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ទំព័រ ១-៦ ERN (ភាសាខ្មែរ) 00783125-00783130។

[៤៨៣] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (នោម សែ) ទំព័រ ៤៧។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១៦-១៧។ កំណត់ត្រារបស់ S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ទំព័រ ៣៤ ERN (ភាសាខ្មែរ) 00963872 (ក្នុងរយៈពេល ៩ សប្តាហ៍ចាប់តាំងពីពេលវាយសម្រុកបានចាប់ផ្តើម គ្រាប់រ៉ុកកែតប្រហែលជា ១.០០០ គ្រាប់បានធ្លាក់មកលើទីក្រុង ដោយបានសម្លាប់ជនស៊ីវិលជាង ១៥០ នាក់ និងរបួសជិត ៦០០ នាក់ផ្សេងទៀត")។ ការប្រយុទ្ធគ្នាខ្លាំងបានបន្តកើតឡើងនៅជុំវិញទីក្រុងភ្នំពេញ មានការវាយប្រហារដោយគ្រាប់រ៉ុកកែតកាន់តែច្រើនឡើង ឯកសារ (ពីបរទេសកម្រងផ្សព្វផ្សាយព័ត៌មាននៅក្នុង) E3/30 ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166662 (យោងតាមទូរលេខផ្លូវការមួយ គ្រាប់រ៉ុកកែតចំនួន ១៥ គ្រាប់ បានបាញ់ចូលក្នុងទីក្រុងកាលពីមួយថ្ងៃមុន បានសម្លាប់មនុស្ស ៧ នាក់ និងធ្វើឱ្យមនុស្សចំនួន ១៣ នាក់ របួស) ។ គ្រាប់រ៉ុកែតរបស់ខ្មែរក្រហម វាយប្រហារទីក្រុងភ្នំពេញ (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166683 (គ្រាប់រ៉ុកែតចំនួន ៣ គ្រាប់ បានធ្លាក់ចំទីក្រុង បានសម្លាប់បុរសម្នាក់ និងធ្វើឱ្យមនុស្សចំនួន ៣ នាក់ របួស ដែលអ្នកទាំងនោះសុទ្ធតែជនស៊ីវិលកម្ពុជទាំងអស់) ។ គ្រាប់រ៉ុកែតបានធ្លាក់ជិតព្រះបរមរាជវាំងក្នុងទីក្រុងភ្នំពេញ (កម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166696 (រាយការណ៍ថា មានមនុស្ស ៩ នាក់ របួសណៅពេល

មេសា ឆ្នាំ ១៩៧៥ មានហ្វូងមនុស្សរាប់ពាន់នាក់បានរត់ចេញពីជំរំជនភៀសខ្លួននៅតាខ្មៅសំដៅមក កាន់កណ្ដាលទីក្រុងភ្នំពេញ ដើម្បីគេចចេញពីការបាញ់ផ្លោងគ្រាប់រ៉ុក្កែតដោយពួកខ្មែរក្រហម[៤៨៤]។ ដើមបណ្ដឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដែលជាគិលានុបដ្ឋាយិកាបម្រើការនៅមន្ទីរពេទ្យមួយនៅ

---

គ្រាប់រ៉ុក្កែតធ្លាក់ចំវត្តមួយ។ កាលពី ៣ ថ្ងៃមុន គ្រាប់រ៉ុក្កែតចំនួន ១៤ គ្រាប់ធ្លាក់ចំទីក្រុងដោយបានសម្លាប់មនុស្ស ៧ នាក់ និងធ្វើឲ្យមនុស្សចំនួន ២៤ នាក់ របួស) ។ ការបញ្ជាឲ្យមានការវាយប្រហារដ៏ធំមួយ ដើម្បីបញ្ឈប់ការវាយប្រហារដោយរ៉ុក្កែត របស់ពួកខ្មែរក្រហម (កម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166711 (គ្រាប់រ៉ុក្កែតដែលបានបាញ់ចំព្រលានយន្តហោះពោធិ៍ចិនតុង បានធ្វើឲ្យមនុស្សចំនួន ២២ នាក់ របួស) ។ ទីភ្នាក់ងារសារព័ត៌មាន AFP រាយការណ៍អំពីស្ថានភាពប្រយុទ្ធគ្នា ថ្ងៃទីទី ១៩, ២០ ខែ មករា ដែលបានបណ្ដាលឲ្យមានមនុស្សស្លាប់ចំនួន ៣០ នាក់ នៅក្នុងរាជធានី (កម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166712 (មនុស្សចំនួន ៣០ នាក់ ត្រូវបានសម្លាប់ ហើយមនុស្ស ៧៥ នាក់ ទៀត រងរបួសដោយសារតែការវាយប្រហារគ្នាយ៉ាងខ្លាំងក្លា ។ គ្រាប់រ៉ុក្កែតចំនួន ៤០ គ្រាប់ បានបាញ់ចូលទីក្រុងភ្នំពេញ និងព្រលានយន្តហោះ ដោយគ្រាប់រ៉ុក្កែតមួយគ្រាប់បានធ្លាក់ចំកណ្ដាលផ្សារ និងវារិអគ្គិសនី) ។ ទីភ្នាក់ងារសារព័ត៌មាន AFP រាយការណ៍អំពីគ្រាប់រ៉ុក្កែតវាយប្រហារទីក្រុង ព្រលានយន្តហោះពោធិ៍ចិនតុង (កម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166715 (មនុស្សចំនួន ៤ នាក់ ត្រូវបានសម្លាប់ និងមនុស្សចំនួន ១១ នាក់ ទៀត បានរងរបួសដោយគ្រាប់រ៉ុក្កែត ដែលបានធ្លាក់នៅទីក្រុងភ្នំពេញ និង ព្រលានយន្តហោះពោធិ៍ចិនតុង ក្នុងអំឡុងពេលនៃការវាយប្រហារ) ។ កំពង់ផែកំពតនៅក្រោមការឡោមព័ទ្ធ ព្រលានយន្តហោះនៅភ្នំពេញទទួលរងនូវការបាញ់ផ្លោង (កម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166764 (មនុស្សចំនួន ៣ នាក់ ត្រូវបានសម្លាប់ និងមនុស្សចំនួន ១០ នាក់ ទៀត បានរងរបួសក្នុងអំឡុងពេលនៃការវាយប្រហារដោយគ្រាប់រ៉ុក្កែត ទៅលើព្រលានយន្តហោះពោធិ៍ចិនតុង) ។ ទីភ្នាក់ងារសារព័ត៌មាន AFP សម្ភាសន៍ឧត្ដមសេនីយ៍ សូស្តែន ហ្វែណង់ដេស (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/488 ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166769 (គ្រាប់រ៉ុក្កែតចំនួន ៣០ គ្រាប់បានធ្លាក់ចំទីក្រុងភ្នំពេញ និង ពោធិ៍ចិនតុង ដែលបណ្ដាលឲ្យប្រជាជនប្រហែល ២៥ នាក់រងរបួស)។ ទីភ្នាក់ងារសារព័ត៌មាន AFP រាយការណ៍ថា មានស្ពានទូតច្រើនទៀតកំពុងជម្លៀសបុគ្គលិក (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/120 ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00903197 (មានមនុស្ស ១៥ នាក់ត្រូវបានសម្លាប់ និង ២៣ នាក់ ទៀត រងរបួសនៅពេលពួកបះបោរខ្មែរក្រហមបានផ្លោងគ្រាប់រ៉ុក្កែតចូលទីក្រុងភ្នំពេញ និងអាកាសយានដ្ឋានពោធិ៍ចិនតុង)។ កងទ័ពរដ្ឋាភិបាលដណ្ដើមបានទួលលាប មកវិញ (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/120 ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166828 (ខ្មែរក្រហមបានបាញ់គ្រាប់រ៉ុក្កែតចូលទៅពោធិ៍ចិនតុង និងប៉ែកខាងត្បូងទីក្រុងភ្នំពេញ ដោយសម្លាប់មនុស្ស ២ នាក់ និង ១៥ នាក់ទៀត រងរបួស)។ គ្រាប់រ៉ុក្កែតបានធ្លាក់ចំផ្ទះរបស់លោក ឡុង បូរ៉េត ផុតពីស្ថានទូតអាមេរិកតែបន្តិច (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/120 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00903199 (គ្រាប់រ៉ុក្កែតពួកបះបោរទាំងអស់ចំនួន ២០ គ្រាប់ ត្រូវបានផ្លោងចូលទីក្រុងភ្នំពេញ សម្លាប់មនុស្ស ៤ នាក់ និងបណ្ដាលឲ្យរបួស ១៥នាក់)។ តាខ្មៅត្រូវបោះបង់ (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានពីបរទេស) ឯកសារ E3/118 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905186 (ការបាញ់ផ្លោងចេញពីច្រាំងទន្លេបាសាក់ បានសម្លាប់ និងបង្ករបួសដល់ប្រជាជនមួយចំនួនធំ)។

[៤៨៤] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៦៧-៦៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៦-៧, ៣២-៣៣។

បុរីកីឡា ដែលជាមន្ទីរពេទ្យមួយដែលត្រូវបានរៀបចំឲ្យទទួលជនរងគ្រោះដោយសារការបាញ់ផ្លោងគ្រាប់រ៉ុកែត បានផ្តល់សក្ខីកម្មថា ប្រជាជនមានការភ័យរន្ធត់ដោយសារការបាញ់ផ្លោងគ្រាប់រ៉ុកកែតរបស់ខ្មែរក្រហម និងការហូរចូលប្រជាជនមកពីជនបទ[៤៨៥]។

១៦៤. នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ក្រោយពីការបរាជ័យខាងយុទ្ធសាស្រ្តយោធារួចមក ប្រធានាធិបតី លន់ នល់ ត្រូវបានគេបញ្ចុះបញ្ចូលឲ្យលាលែងពីតំណែង និងបាននិរទេសខ្លួន[៤៨៦]។ ពីរថ្ងៃក្រោយមក ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍មួយ ដោយបានប្រកាសថា "ពួកក្បត់ជាតិទាំងប្រាំពីរនាក់"បានរត់ចោលស្រុកបាត់ហើយ ប៉ុន្តែគាត់បានបញ្ជាក់ថា"ពួកចក្រពត្តិអាមេរិក" មានបំណងអូសបន្លាយសង្គ្រាមដោយបង្កើតឲ្យមានការចរចា[៤៨៧]។

---

[៤៨៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៧១-៧២, ៧៣,៧៤-៧៥។

[៤៨៦] *លន់ នល់ គណៈប្រតិភូចាកចេញពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ប្រទេសឥណ្ឌូណេស៊ី* សហរដ្ឋអាមេរិក (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00166888។ ទង់បដិវត្ត ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៨៤-៨៧ ERN (ភាសាខ្មែរ) 00063163-00063164។ សៀវភៅសរសេរដោយ P. Short៖ *ប៉ុល ពត: ប្រវត្តិនៃសុបិនអាក្រក់* ឯកសារ E3/9 ចុះឆ្នាំ ២០០៤ ទំព័រ ២៦៣ ERN (ភាសាអង់គ្លេស) 00396471។ កំណត់ត្រារបស់ S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ERN (ភាសាអង់គ្លេស) 00898243, 00898264។

[៤៨៧] ខៀវ សំផន អបអរសាទរកងទ័ពរំដោះជាតិប្រជាជនកម្ពុជាពីជ័យជម្នះនៅអ្នកលឿង (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៣-៨ ERN (ភាសាខ្មែរ) 00700269-00700274 (ដោយនិយាយថា សមាជិកទាំងប្រាំពីរនាក់នៃរបប លន់ នល់ គឺជាជនក្បត់៖ លន់ នល់, សិរិមតៈ, សឺន ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, សូស្តែន ហ្វែណង់ដែស)។ *ខៀវ សំផន ចេញផ្សាយសេចក្តីថ្លែង-ការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00700267-00700268 ("មេជនក្បត់ទាំង ៧ នាក់ បានរៀបចំ ឬកំពុងរៀបចំវេចបង្វេចរបស់ខ្លួន ដើម្បីគេចខ្លួនទៅបរទេស ក្នុងគោលបំណងគេចខ្លួនពីការដាក់ទណ្ឌកម្មពីសំណាក់ប្រជាជនរបស់យើង។ អាសឺន ង៉ុកថាញ់ បានចាកចេញទៅកាន់ទីក្រុងសៃហ្គន អា អ៊ិន តាំ បានបាត់ខ្លួន ហើយថ្មីៗនេះ អា សូស្តែន ហ្វែណង់ដែស និង អា ចេង ហេង ក៏បានគេចខ្លួនទៅកាន់បរទេសផងដែរ [...] អា លន់ នល់ និង អា ឡុង បូរ៉េត ក៏បានវេចបង្វិចជាច្រើនផងដែរ ដើម្បីចាកចេញទៅបរទេស ក្នុងគោលបំណងគេចខ្លួន [...]")។ *កងទ័ពរំដោះជាតិប្រជា-ជនកម្ពុជាកំពុងបន្តការវាយលុក "ដោយ គ្មានការសម្របសម្រួល"* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905182-00905183 (ដោយលើកឡើងពីឈ្មោះពួកក្បត់ជាតិ លន់ នល់, ចេង ហេង,សូស្តែន ហ្វែណង់ដែស, សឺន ង៉ុកថាញ់ និង អ៊ិន តាំ បានភៀសខ្លួនចេញពី

១៦៥. នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៥ កងទាហានជើងទឹកអាមេរិកបានជម្លៀសឯកអគ្គរដ្ឋ-ទូត និងបុគ្គលិកស្ថានទូតដែលនៅសេសសល់ចេញពីស្ថានទូតអាមេរិកប្រចាំទីក្រុងភ្នំពេញ រួមទាំងប្រធានាធិបតីស្តីទី សូ ខាំខូយ ផង[៤៨៨]។ នៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំរបស់របបសាធារណរដ្ឋខ្មែរបានផ្ញើសារមួយច្បាប់ថ្វាយជូនសម្តេច នរោត្តម សីហនុ នៅក្នុងទីក្រុងប៉េកាំង ដោយស្នើសុំផ្ទេរអំណាចជូនរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាភ្លាមៗ ប៉ុន្តែ បានស្នើសុំឲ្យមានការធានាថា កុំឲ្យមានការសងសឹកណាមួយ ចំពោះសកម្មភាពទាំងឡាយដែលបានកើតមានក្នុងអំឡុងពេលមានអរិភាពនឹងគ្នា[៤៨៩]។ សម្តេច នរោត្តម សីហនុ បានបដិសេធមិនទទួលយកសំណើនេះទេ ដោយសម្តេចមានបន្ទូលថា មានតែការសុំចុះចាញ់ដោយឥតលក្ខខណ្ឌប៉ុណ្ណោះ ទើបអាចទទួលយកបាន និងបានជំរុញឲ្យ "ជនក្បត់ជាតិលំដាប់ទីមួយ" ចាកចេញពីប្រទេស ដោយសារថា ក្នុងនាមជាឧក្រិដ្ឋជនសង្គ្រាម ពួកគេ "មិនសមនឹងទទួលបានអ្វីក្រៅពីឈើឆ្កាងព្យួរកនោះទេ"[៤៩០]។

---

ទីក្រុងភ្នំពេញ)។ *ឡុង បូរ៉េត ដោះស្រាយបញ្ហាជាតិបន្ទាប់ពីការចាកចេញរបស់ សូ ខាំខូយ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 118 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905183-00905184 (ដោយលើកឡើងអំពីការចាកចេញរបស់ឧត្តមសេនីយ៍ឯក សូ ខាំខូយ ប្រធានាធិបតីស្តីទីនៃរបបសាធារណរដ្ឋខ្មែរ)។ *ឡុង បូរ៉េត ផ្ញើសន្និសីទសារព័ត៌មានជូនអ្នកកាសែតអំពីគោលនយោបាយរបស់រដ្ឋាភិបាលថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166942 (ដោយលើកឡើងអំពីការចាកចេញរបស់សេនាប្រមុខ លន់ នល់ កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥)។

[៤៨៨] កំណត់ហេតុរបស់ S. Schanberg *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ៦៧-៧៣ 00963905-00963911។ ទង់បដិវត្ត ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៨៤-៨៧ ERN (ភាសាខ្មែរ) 00063163-00063164។ *ឡុង បូរ៉េត ដោះស្រាយបញ្ហាជាតិ បន្ទាប់ពីការចាកចេញរបស់ សូ ខាំខូយ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905183-00905184។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការបន្តកិច្ចសន្យាជាមួយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ឯកសារ E3/2938 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00715080-00715081។

[៤៨៩] *មេដឹកនាំភ្នំពេញស្នើសុំបទឈប់បាញ់ដោយផ្ទេរអំណាច* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905192។ កំណត់ហេតុរបស់ S. Schanberg *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១០១-១០២ ERN (ភាសាខ្មែរ) 00963939-00963940។

[៤៩០] *សម្តេច សីហនុ បដិសេធចំពោះសំណើ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166971។ កំណត់ហេតុរបស់ S. Schanberg *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១០២-១០៤ ERN (ភាសាខ្មែរ) 00963940-00963942។

១៦៦. នៅរសៀលថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ កងពលធំយោធារបស់បក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានទីក្រុងភ្នំពេញស្ទើរតែទាំងស្រុង[៤៩១]។ ជនភៀសខ្លួនរាប់ពាន់នាក់បានធ្វើដំណើរចូលមកកាន់កណ្តាលទីក្រុង។ លោក Sydney SCHANBERG បានរៀបរាប់នៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ថា ថ្ងៃនេះគឺជាថ្ងៃដែលមានចំនួនអ្នកស្លាប់ច្រើនបំផុតនៅក្នុងសង្គ្រាមរយៈពេលប្រាំឆ្នាំកន្លងមកនេះ និងបានរៀបរាប់អំពីមន្ទីរពេទ្យព្រះកេតុមាលាថាជា "ទីសត្តឃាត" ដែលពោរពេញទៅដោយអ្នករបួសពីបន្ទប់មួយទៅបន្ទប់មួយ [៤៩២]។

១៦៧. ខ្មែរក្រហមបានចូលមកកាន់ទីក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

## ៤. និជ្ជតាពន្ធនៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩

១៦៨. អង្គជំនុំជម្រះបានកម្រិតសំណុំរឿង ០០២/០១ ត្រឹមតែអង្គហេតុដូចជា ការផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទីមួយ) ការសម្លាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ និងការផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទីពីរ) ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ និង

---

[៤៩១] កំណត់ហេតុរបស់ S. Schanberg *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ៩៧-១០២ 00963935-00963940។ *សូមមើល* កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ឯកសារ E3/118 រួមមានព័ត៌មានដូចខាងក្រោម៖ *វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាប្រកាសថា ព្រលានយន្តហោះពោធិ៍ចិនតុង "ត្រូវរំដោះបានទាំងស្រុង"* ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905184-00905185។ *ខ្មែរក្រហមចាប់ផ្តើមវាយប្រហារជាយក្រុងភ្នំពេញភាគខាងត្បូង* ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905184-00905185។ *តាខ្មៅត្រូវបានបោះបង់ចោល* នៅថ្ងៃទី ១៥ ខែ មេសា ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905186-00905187។ *ការវាយប្រយុទ្ធនៅជុំវិញទីក្រុងភ្នំពេញ* ERN (ភាសាខ្មែរ) 00905186-00905187។ *ខ្មែរក្រហមកាន់កាប់ព្រលានយន្តហោះពោធិ៍ចិនតុង* ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905186-00905188។ *សារព័ត៌មាន KYODO៖ កងទ័ពរំដោះចូលមកកាន់ភាគខាងក្បូងទីក្រុងភ្នំពេញ* ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166961។ *វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាប្រកាសអំពីការវាយប្រហារនៅជុំវិញទីក្រុងភ្នំពេញ ការចុះចតរបស់អ្នកបើកយន្តហោះឲ្យពួកខ្មាំង* ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905189-00905190។ *វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាប្រកាសអំពីការវាយប្រហារ "ក្នុងទិសដៅឆ្ពោះមកកាន់មជ្ឈមណ្ឌលនៃរដ្ឋធានី"* ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905193។

[៤៩២] កំណត់ហេតុរបស់ S. Schanberg *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ៩៨-១០០ ERN (ភាសាខ្មែរ) 00963936-00963938។

01006457



ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៤៩៣]។ ប៉ុន្តែ យោងតាមដីកាដំណោះស្រាយ ការផ្លាស់ទីលំនៅប្រជាជន ការសម្លាប់ និងឧក្រិដ្ឋកម្មដែលជាប់ពាក់ព័ន្ធទាំងនេះ បង្កើតបានជាការវាយប្រហារមួយដែលមានលក្ខណៈរីករាលដាលមកលើប្រជាជនស៊ីវិល ដែលបានអនុវត្តនៅគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា[៤៩៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា ចាំបាច់ត្រូវតែដោះស្រាយបញ្ហាទាំងពីរដោយសង្ខេប ទាំងលើអង្គហេតុដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ និងការចោទប្រកាន់ទាំងឡាយទាក់ទងទៅនឹងបរិបទទូទៅនៃការវាយប្រហារ ដែលនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

១៦៩. នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលជាអំឡុងពេលស្ថិតនៅក្រោមការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីខេត្ត-ក្រុង និងទីប្រជុំជននានានៅទូទាំងប្រទេសកម្ពុជាទៅកាន់ដំបន់ជនបទ និងពីជនបទមួយទៅជនបទមួយ ក្នុងគោលបំណងដើម្បីធ្វើឲ្យខ្មាំងចុះខ្សោយ ទាំងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ និងដើម្បីទប់ស្កាត់កុំឲ្យមានការងើបបះបោរ ដើម្បីលុបបំបាត់ និងលត់ដំពួកវណ្ណៈនាយទុន និងសក្តិភូមិ និងដើម្បីកសាង និងពង្រីកសហករណ៍នានា[៤៩៥]។ បក្សបានកំណត់ "ប្រជាជនថ្មី" ដែលរួមមានអតីតអ្នករដ្ឋការ បញ្ញាជន ម្ចាស់ដី នាយទុន សក្តិភូមិ និងវណ្ណៈអនុធន ថាជាខ្មាំងដ៏ចម្បងរបស់បដិវត្ត និងសមូហភាវូបនីយកម្ម[៤៩៦]។ ដើម្បីឲ្យខ្មាំងទាំងនេះចុះខ្សោយ ខ្មែរក្រហមបានអប់រំ

---

[៤៩៣] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះ ដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/ ០១ (E163) ឯកសារ E124/7.3។

[៤៩៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៥០-១៣៧២។

[៤៩៥] សូមមើលផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) កថាខណ្ឌ ៥៤៧-៥៧៤។ ផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៦២៧-៦៥៧។ ផ្នែកទី ១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧-៧៧៨, ៨០៤-៨១០, ៨៣៥-៨៣៧ ។

[៤៩៦] ទង់បដិវត្ត ឯកសារ E3/5 ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ២០-២១, ៥៧-៦០, ៦៨-៧០ ERN (ភាសាខ្មែរ) 00063322, 00063340-00063342, 00063346-00063347។ ទង់បដិវត្ត ឯកសារ E3/10 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៥៧-៥៩ ERN (ភាសាខ្មែរ) 00063093-00063094 (ក្នុងចំណោមកសិករថ្មី មានពួកអនុធន នាយទុន

កែប្រែ ជម្លៀស និងលុបបំបាត់ "ប្រជាជនថ្មី" និងក្រុមមនុស្សផ្សេងទៀត ដែលមិនត្រូវគ្នាទៅនឹងការកសាងសង្គមនិយម រួមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម[៤៩៧]។

១៧០. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញយ៉ាងហោចណាស់ក៏មានចំនួនប្រហែលពីរលាននាក់ដែរ[៤៩៨]។ ប្រជាជនដែលត្រូវបានគេជម្លៀសត្រូវបានគេផ្ដល់ឲ្យនូវកន្លែងស្នាក់នៅ និងជំនួយដែលមិនគ្រប់គ្រាន់ ដែលការណ៍នេះបណ្ដាលឲ្យមានការរងទុក្ខលំបាកវេទនា និងការស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ [៤៩៩]។ នៅថ្ងៃ ១៧ ខែ មេសា ឆ្នាំ១៩៧៥ និងបន្ទាប់ពីកាលបរិច្ឆេទនេះមក ប្រជាជនក៏ត្រូវបានគេបម្លាស់ទីចេញពីទីរួមខេត្តនានានៅទូទាំងប្រទេសកម្ពុជា រួមមានខេត្តកំពង់ស្ពឺ[៥០០] តាកែវ[៥០១] កំពត[៥០២] ក្រុងព្រះសីហនុ (ពីមុន

---

សក្តិភូមិ ព្រមទាំងកម្មករ និងពលករផ្សេងទៀត។ ដូច្នេះ វាមានទំនាស់ស្លាប់រស់)។ ទង់បដិវត្ត ឯកសារ E3/743 ចុះខែកក្កដា ឆ្នាំ ១៩៧៧ ទំព័រ ១៣-១៤ ERN (ភាសាខ្មែរ) 00062886-00062887 ("ខ្មាំង" រួមមាន ចក្រពត្តិឈ្លានពាន និងបរិវារវាគ្រប់ប្រភេទ វណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន និងវណ្ណៈជិះជាន់គ្រប់ប្រភេទ)។

[៤៩៧] សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៩-១២៧។ ផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) កថាខណ្ឌ ៥០១-៥១១, ៥១៧, ៥៦៧-៥៧៤។ ផ្នែកទី ១១ ស្តីពី ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៦១៣-៦២៣, ៦៤៩-៦៥៧ ។ ផ្នែកទី ១២ ស្តីពី ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨៣-៦៨៧។ ផ្នែកទី ១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១, ៧៨៣-៧៨៥, ៧៨៧, ៧៨៩-៧៩០, ៧៩៥, ៨០៥, ៨១១-៨៣៧។ សូមមើល *ផងដែរ* ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤០-៨៤១ (ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម ពុទ្ធសាសនិកជន និងជនជាតិវៀតណាម)។

[៤៩៨] *សូមមើល* ផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) កថាខណ្ឌ ៥២០, ៥៤៧។

[៤៩៩] *សូមមើល* ផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២១-៥២៤,៥៤៧-៥៥២។

[៥០០] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៣៨-៤២។

[៥០១] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៣៨-៤២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ឯកសារ E3/5498 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00368600-00368602 (ប្រជាជនទាំងអស់នៅទីក្រុងតាកែវត្រូវបានជម្លៀសប្រហែលជានៅថ្ងៃទី ១៨ ឬ ១៩ ខែ មេសា ឆ្នាំ ១៩៧៥)។

[៥០២] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈៀន ឯកសារ E3/428 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00373483-00373484។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គីម ឯកសារ E3/360 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00186337-00186339។

ហៅថា ក្រុងកំពង់សោម)[៥០៣] កំពង់ធំ[៥០៤] ប៉ៃលិន[៥០៥] កំពង់ចាម[៥០៦] កំពង់ឆ្នាំង[៥០៧] សៀមរាប[៥០៨] ប៉ោយប៉ែត[៥០៩] បាត់ដំបង[៥១០] និងពោធិ៍សាត់[៥១១]។ ការផ្លាស់ទីប្រជាជនក្នុងចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់

---

[៥០៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាញ់ ញ៉ូ ឯកសារ E3/5197 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00206367-00206368 [ប្រហែលជានៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានគេជម្លៀសចេញពីក្រុងព្រះសីហនុ ( កាលពីមុនហៅថា កំពង់សោម) ឆ្ពោះទៅកាន់ខេត្តកំពត]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃឹម ខែន E3/5190 ឯកសារ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៨ ២-៣ ERN (ភាសាខ្មែរ) 00203843-00203844 (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានគេជម្លៀសចេញពីកំពង់សោមមកកាន់ព្រៃនប់)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី លឿង ប៊ុន្នី ឯកសារ E3/5543 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00375537-00375538 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីក្រុងព្រះសីហនុទៅតាមទិសខាងលិច)។

[៥០៤] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក្រឹម សាមីហស់ ឯកសារ E3/4933 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00546740-00546741 (រៀបរាប់អំពីការជម្លៀសប្រជាជនចេញពីខេត្តកំពង់ធំនៅក្នុងខែ មេសា ឆ្នាំ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ថេង ឯកសារ E3/5249 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00229062-00229063។

[៥០៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថាច់ សុខ ឯកសារ E3/5230 ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00267773-00267774 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ សាក្សីត្រូវបានគេជម្លៀសចេញពីប៉ៃលិនឲ្យទៅកាន់បាត់ដំបង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងគញ្ញា ទំព័រ ២៦៨-២៦៩ ERN (ភាសាខ្មែរ) 00836345-00836346 (នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមជិះឡានស្រែកតាមមីក្រូ ឲ្យប្រជាជនទាំងអស់ចេញពីក្រុងប៉ៃលិន ហើយប្រជាជនម្នាក់ៗនាំយកអីវ៉ាន់មួយចំនួនតូចទៅជាមួយ)។កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ព្រំ សារុន ឯកសារ E3/5187 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00197916 (អតីតទាហាន លន់ នល់ និងជាប្រជាពលរដ្ឋរស់នៅភូមិ ក្រពើជើង បានកត់សម្គាល់ថាក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលផ្តុំប្រជាជនជាកង និងក្រុមដើម្បីធ្វើការងារ កសាងទំនប់ ជីកប្រឡាយ ដូចជាទំនប់កាំពីងពួយជាដើម។ មានមនុស្ស ៩០ នាក់ នៅក្នុងកងរបស់គាត់ រួមទាំងអ្នកត្រូវបានគេជម្លៀសចេញពីប៉ៃលិន ភ្នំពេញ និងកំពង់ចាមផង)។

[៥០៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាយ គឹមហួន ឯកសារ E3/5257 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00243100-00243101 (ក្រោយពីយកបានខេត្តកំពង់ចាម ប្រជាជនត្រូវបានគេជម្លៀសចេញទាំងអស់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារE3/5187 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00197916 (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ មានមនុស្ស ៩០ នាក់នៅក្នុងកងវរៈសេនាធំលេខ ៤ រួមទាំងអ្នកត្រូវបានគេជម្លៀសចេញពី ប៉ៃលិន ភ្នំពេញ និងកំពង់ចាមផង)។

[៥០៧] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១៧-១៩ (ខេត្តកំពង់ឆ្នាំងត្រូវបានជម្លៀសនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ លឿ ឯកសារ E3/5233 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00269049-00269051 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានគេជម្លៀសចេញពីខេត្តកំពង់ឆ្នាំង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឿង គឹមឆុង

ហើយដែលប្រជាជនទាំងនោះត្រូវបានគេបណ្តេញចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនដទៃទៀត គឺនៅតែបន្តធ្វើរហូតដល់ក្នុងខែ សីហា ឆ្នាំ ១៩៧៥[៥១២]។

ឯកសារ E3/5272 ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00282946-00282947 (ប្រជាជនទាំងអស់នៅទីរួមខេត្តកំពង់ឆ្នាំង ត្រូវបានគេប្រកាសតាមមីក្រូឱ្យចាកចេញ)។

[៥០៨] ប្រតិចារឹក ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ទំព័រ ៨៦-៨៨ (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានគេជម្លៀសចេញពីខេត្តសៀមរាប ដោយភ្ជង់នឹងកាំភ្លើង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ធី ឯកសារ E3/5184 ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ៤ ERN(ភាសាខ្មែរ)00197874 (ប្រជាជនទាំងអស់នៅខេត្តសៀមរាបត្រូវគេជម្លៀស)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុយ មឿន ឯកសារ E3/5175 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00195442-00195443 (នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ប្រជា-ជនត្រូវបានគេជម្លៀសចេញពីក្រុងសៀមរាបនៅឡើយ ឯអ្នកដទៃទៀតត្រូវបានជម្លៀសទៅមុនអស់ហើយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តែម គឹមសេង ឯកសារ E3/5248 ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៥ ERN (ភាសាខ្មែរ) 00231711-00231714 (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបាន ជម្លៀសចេញពីខេត្តសៀមរាប)។

[៥០៩] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងគ្នា ទំព័រ ១៩ ERN (ភាសាខ្មែរ) 00836096 (នៅថ្ងៃទី ២៤ ខែ មេសា ខ្មែរក្រហមជម្លៀសប្រជាជនចេញពីប៉ោយប៉ែត ដោយបញ្ជាតាមមីក្រូ)។

[៥១០] ប្រតិចារឹក ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៥៨-៥៩ (ខេត្តបាត់ដំបងត្រូវបានជម្លៀសមួយសប្តាហ៍បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ា សាអែម ឯកសារ E3/5282 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ២-៥ ERN (ភាសាខ្មែរ) 00295951-00295954 (នៅដំណាច់ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីក្រុងបាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ឯកសារ E3/5226 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00242229-00242230 (នៅរវាងថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥ ពួកទាហានខ្មែរក្រហមដែលមានកាន់អាវុធគ្រប់ដៃ បានជម្លៀសប្រជាជននៅភ្នំសំពៅឱ្យទៅរស់នៅតាមវាលស្រែក្រៅភូមិ នៅក្នុងខេត្តបាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេស ប៊ាញ ឯកសារ E3/505 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00221596-00221598 (ពួកទាហានខ្មែរក្រហមដែលមានកាន់អាវុធគ្រប់ដៃ បានជម្លៀសប្រជាជនទាំងអស់ចេញពីក្រុងបាត់ដំបង)។

[៥១១] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុង ឆាត់) ទំព័រ ៥៦-៦៣ (ខេត្តពោធិ៍សាត់ត្រូវបានជម្លៀសនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១២-១៤ (ក្រោយពេលរំដោះឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានគេជម្លៀសចេញពីទីរួមខេត្តពោធិ៍សាត់ នៅក្នុងរយៈពេលបីសប្តាហ៍ ឬនៅក្នុងរយៈពេលប្រហែលនេះ)។

[៥១២] សូមមើលផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១)។ ផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២)។ ទង់បដិវត្ត ឯកសារ E3/166 ចុះខែ កុម្ភៈ ដល់ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥៥-៥៧ 00063219-00063220។

១៧១. ចាប់ផ្តើមពីខែ កញ្ញា ឆ្នាំ ១៩៧៥ និងបន្តរហូតដល់ក្នុងឆ្នាំ ១៩៧៧ យ៉ាងហោចណាស់ក៏មានប្រជាជនស៊ីវិលចំនួនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ដែរ ដែលត្រូវបានគេផ្លាស់ទីដោយបង្ខំទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ចំណែកឯប្រជាជនជាង ៣០.០០០ នាក់ ទៀត ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងតំបន់ផ្សេងៗ អាស្រ័យលើតម្រូវការកម្លាំងពលកម្មតាមរដូវ និងដើម្បីឈោងទៅសម្រេចការតស៊ូវណ្ណៈ[៥១៣]។ ការផ្លាស់ទីលំនៅទាំងនេះត្រូវបានអនុវត្តនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ជាច្រើន ដែលបណ្តាឲ្យមានការស្លាប់។ ប្រជាជនមួយចំនួនបានស្លាប់ដោយសារតែការអត់ឃ្លាន អស់កម្លាំង ឬមានជំងឺ និងមានប្រជាជនមួយចំនួនបានបាត់ខ្លួនផងដែរ[៥១៤]។ សរុបមក នៅក្នុងយុត្តាធិការពេលវេលានៃសំណុំរឿង ០០២/០១ ដែលត្រូវលើកយកមកជំនុំជម្រះនេះ មានប្រជាជនរាប់លាននាក់ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយក៏បានចោទប្រកាន់ផងដែរថា ការផ្លាស់ទីលំនៅដោយបង្ខំបានបន្តនៅគ្រប់ពេលក្នុងឆ្នាំ ១៩៧៨[៥១៥]។

១៧២. នៅចន្លោះពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥ មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរត្រូវបានគេកំណត់ជាគោលដៅនៃការប្រហារជីវិត ការចាប់ខ្លួន និងការឃុំខ្លួន ចំណែកប្រជាជននៅក្នុងទីក្រុង និងទីប្រជុំជននានានៅគ្រប់តំបន់ដែលទើប "រំដោះបាន" ថ្មីៗនៅក្នុងប្រទេសកម្ពុជា រួមទាំងទីក្រុងភ្នំពេញផងដែរគឺត្រូវបានគេបង្ខំឲ្យចេញពីទីនោះ[៥១៦]។ នៅអំឡុងថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥ យ៉ាងហោចណាស់ក៏មានអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរចំនួន ២៥០ នាក់ដែរ ដែលត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃ[៥១៧]។ គោលនយោបាយក្នុងការកំណត់គោលដៅចំពោះអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរនេះ បានបន្តអនុវត្តដោយមានការសម្លាប់ ការចាប់ខ្លួន និងការបាត់ខ្លួននៅទូទាំងប្រទេសកម្ពុជា[៥១៨]។

[៥១៣] សូមមើលផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ។

[៥១៤] សូមមើលផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ។

[៥១៥] ដីកាដំណោះស្រាយ កថាខណ្ឌ ២៨៣-៣០០ [ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅ ដែលបានកំណត់នៅក្នុងដីកាដំណោះ-ស្រាយថាជាការផ្លាស់ទីលំនៅ (ដំណាក់កាលទី ៣)]។

[៥១៦] សូមមើលផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ។

[៥១៧] សូមមើលផ្នែកទី ១២ ស្តីពី ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨១ ។

[៥១៨] សូមមើលផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២)។ ផ្នែកទី ១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម។

១៧៣. យោងតាមដីកាដំណោះស្រាយបានបង្ហាញថា នៅក្នុងអំឡុងពេលខាងលើ និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល (ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩) មានការកាប់សម្លាប់ជាទូទៅ ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការប្រើអំពើហិង្សាលើរូបកាយ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើការងារដោយបង្ខំ ការបាត់ខ្លួន និង/ឬ ករណីផ្សេងៗទៀតនៃការធ្វើបាបដោយអមនុស្សធម៌ ហើយការធ្វើបាបខ្លះត្រូវបានអនុវត្តដោយមានការរើសអើង[៥១៩]។ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជារាប់រយពាន់នាក់បានក្លាយជាជនរងគ្រោះដោយសាររបបខ្មែរក្រហម និង បានស្វែងរកការជ្រកកោននៅក្នុងប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសឡាវ[៥២០]។

១៧៤. នៅឆ្នាំ ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញសាកសពមនុស្សប្រមាណ ១.៣០០.០០០ នាក់ នៅក្នុងទីតាំងរណ្តៅសាកសពរួមចំនួន ៣៩០ កន្លែង នៅទូទាំងប្រទេសកម្ពុជា[៥២១]។ អ្នកជំនាញជាច្រើនបានសន្និដ្ឋានថា មានលទ្ធភាពខ្ពស់ជាងនេះដែលថា ទីតាំងរណ្តៅ

[៥១៩] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២-៨៦០ (ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ថា មានការធ្វើបាប និងអំពើហិង្សានៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស សហករណ៍ ការដ្ឋានធ្វើការងារ និងការប្រព្រឹត្តមកលើក្រុមមនុស្សជាក់លាក់មួយចំនួននៅទូទាំងប្រទេសកម្ពុជា)។

[៥២០] របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ: ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩៖ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ ឯកសារ E3/2413 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ៤១-៤៣ ERN(ភាសាខ្មែរ)00499415-00499417។ ប្រតិចារឹកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤២-៤៣។ អត្ថបទនិពន្ធដោយ P. Heuveline: *“ចន្លោះពីមួយទៅបីលាននាក់”៖ ឆ្ពោះទៅកាន់ការស្ថាបនាតួលេខប្រជាសាស្ត្រឡើង ក្នុងមួយទសវត្សទ៍នៃប្រវត្តិសាស្ត្រកម្ពុជា (១៩៧០-៧៩)* ឯកសារ E3/1799 ឆ្នាំ ១៩៩៨ ទំព័រ ២៣-២៥ ERN (ភាសាខ្មែរ) 00338256-00338258។ សរាចរក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជា ឯកសារ E3/2675 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៧៨ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00810710-00810711។

[៥២១] ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ទីតាំងរណ្តៅសាកសព ឯកសារ E3/2763 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ (នៅខេត្តបន្ទាយមានជ័យមានទីតាំងឧក្រិដ្ឋកម្ម ១៦ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៥០ នាក់ទៅ ២៥.០០០ នាក់។ នៅខេត្តបាត់ដំបងមានទីតាំងឧក្រិដ្ឋកម្ម ១៩ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៣០ នាក់ទៅ ២០.០០០ នាក់។ នៅខេត្តកំពង់ចាមមានទីតាំងឧក្រិដ្ឋកម្ម ៧៥ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០ នាក់ទៅ ៣២.៦៩០ នាក់។ នៅខេត្តកំពង់ឆ្នាំងមានទីតាំងឧក្រិដ្ឋកម្ម ៤០ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០ នាក់ទៅ ១៥០.០០០ នាក់។ នៅខេត្តកំពង់ស្ពឺ មានទីតាំងឧក្រិដ្ឋកម្ម ២៤ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០ នាក់ទៅជាង ៣០.០០០ នាក់។ នៅខេត្តកំពង់ធំមានទីតាំងឧក្រិដ្ឋកម្ម ១៧ កន្លែង

សាកសពរួមទាំងនោះមានផ្ទុកនៅតែសំណល់សាកសព ដែលគ្រាន់តែជាឧទាហរណ៍នៃអ្នកដែលបានស្លាប់ ដោយសារតែលទ្ធផលនៃគោលនយោបាយ និងការប្រព្រឹត្តិទាំងឡាយរបស់ខ្មែរក្រហម នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។ ទីតាំងរណ្តៅសាកសពរួមជាច្រើនផ្សេងទៀត ទំនងជាមិនត្រូវបានរកឃើញទេ ហើយអ្នកដែលបានស្លាប់ជាច្រើននាក់ផ្សេងទៀត ក៏មិនត្រូវបានគេយកទៅកប់ដែរ[៥២២]។ សរុបមក ការប៉ាន់ប្រមាណបង្ហាញថា មានប្រជាជនកម្ពុជាចំនួនពី ៦០០.០០០ នាក់ទៅ ៣.០០០.០០០ នាក់ បានស្លាប់ ដោយសារតែលទ្ធផលនៃគោលនយោបាយ និងការប្រព្រឹត្តិរបស់ពួកខ្មែរក្រហម។ នៅក្នុងរង្វង់តួលេខនេះ អ្នកជំនាញជាច្រើនទទួលយកការ

ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១ នាក់ទៅ ១៥០.០០០ នាក់។ នៅខេត្តបាត់ដំបងមានទីតាំងឧក្រិដ្ឋកម្ម ១៤ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៤០ នាក់ទៅ ៣២.០៤៧ នាក់ ។ នៅខេត្តកណ្តាលមានទីតាំងឧក្រិដ្ឋកម្ម ២៩ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០ នាក់ទៅ ៣៥.០២៧ នាក់។ នៅខេត្តក្រចេះមានទីតាំងឧក្រិដ្ឋកម្ម ១០ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៥០ នាក់ទៅ ៧០.០០០ នាក់។ នៅខេត្តមណ្ឌលគីរីមានទីតាំងឧក្រិដ្ឋកម្ម ០១ កន្លែង ដែលមានសាកសពចំនួន ២០០ នាក់។ នៅភ្នំពេញមានទីតាំងឧក្រិដ្ឋកម្ម ៤ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០ នាក់ទៅ ១៥.០០០ នាក់។ នៅខេត្តព្រៃវែងមានទីតាំងឧក្រិដ្ឋកម្ម ៣៦ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៣០ នាក់ទៅជាង ១៧.២០០ នាក់។ នៅខេត្តរតនគីរីមានទីតាំងឧក្រិដ្ឋកម្ម ០៣ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៤០ នាក់ទៅជាង ១.០០០ នាក់។ នៅខេត្តសៀមរាបមានទីតាំងឧក្រិដ្ឋកម្ម ២៤ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១២ នាក់ទៅ ៣៦.០០០ នាក់។ នៅកំពង់សោម (ក្រុងព្រះសីហនុ) មានទីតាំងឧក្រិដ្ឋកម្ម ០៨ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ១០០ នាក់ទៅជាង ១.៥០០ នាក់។ នៅខេត្តស្វាយរៀងមានទីតាំងឧក្រិដ្ឋកម្ម ១៨ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ៤០ នាក់ទៅ ៣០.០០០ នាក់។ នៅខេត្តតាកែវមានទីតាំងឧក្រិដ្ឋកម្ម ៣១ កន្លែង ដែលទីតាំងនីមួយៗមានចំនួនសាកសពពី ០១ នាក់ទៅ ៤០.០០០ នាក់)។ របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ៖ ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩: ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ ឯកសារ E3/2413 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ១៤-១៧ ERN (ភាសាខ្មែរ) 00499388-004991។ *សូមមើលផងដែរ* ឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការកំណត់ផែនទីវាលពិឃាតរបស់កម្ពុជា ឆ្នាំ ១៩៩៧៖ ខេត្តកំពង់ធំ ឯកសារ E3/2648 ឆ្នាំ ១៩៩៧។

[៥២២] របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ៖ *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩: ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ* ឯកសារ E3/2413 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ២៦-២៨ ERN (ភាសាខ្មែរ) 00499400-00499402។

ប៉ាន់ប្រមាណអំពីចំនួនអ្នកស្លាប់ពី ១.៥០០.០០០ ទៅ ២.០០០.០០០ នាក់ ថាជាចំនួនដែលត្រឹមត្រូវបំផុត[៥២៣]។

[៥២៣] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៦-៨ (មតិស្របគ្នានោះគឺប្រជាជនចំនួនចន្លោះពី ១,៥ លាននាក់ ទៅ ៣ លាននាក់ បានស្លាប់នៅក្នុងរបបខ្មែរក្រហម)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៥២-៥៣ (នៅក្នុងឆ្នាំ ១៩៨៦ លោក PONCHAUD បានប៉ាន់ប្រមាណថា ប្រជាជនចំនួន ៨០០.០០០ នាក់ត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សេ.អ៊ី.អា ធ្វើការប៉ាន់ប្រមាណថា ប្រជាជនចំនួន ១,៤ លាននាក់ត្រូវបានគេសម្លាប់ ហើយស្ថានទូតដទៃទៀតធ្វើការប៉ាន់ប្រមាណថា ប្រជាជនចំនួន ១ លាននាក់ត្រូវបានគេសម្លាប់)។ អត្ថបទសរសេរដោយលោក P. Heuveline៖ *ភាពមិនច្បាស់នៃការប៉ាន់ស្មានចំនួនមនុស្សស្លាប់នៅសម័យខ្មែរក្រហម* ឯកសារ E3/1798 ចុះខែ វិច្ឆិកា-ធ្នូ ឆ្នាំ ១៩៩៨ ទំព័រ ១៩-២០ ERN (ភាសាខ្មែរ) 00499388-004991 (ក្រោយពីការពិនិត្យឡើងវិញទៅលើការប៉ាន់ប្រមាណនានា មានការសម្រេចថា ចំនួនគម្លាតពី ១.៥ លាន ទៅ ២.៥ លាន អាចជាចំនួនមួយពិតច្រើនជាងគេ)។ អត្ថបទនិពន្ធដោយ P. Heuveline: *“ចន្លោះពីមួយទៅបីលាននាក់”៖ ឆ្ពោះទៅកាន់ការស្ថាបនាតួលេខប្រជាសាស្ត្រឡើងក្នុងមួយទសវត្សន៍នៃប្រវត្តិសាស្ត្រកម្ពុជា (១៩៧០-៧៩)* ឯកសារ E3/1799 ឆ្នាំ ១៩៩៨ ទំព័រ ២៣-២៥ ERN (ភាសាខ្មែរ) 00338256-00338258 (លោក Heuveline បានប៉ាន់ប្រមាណថា មានការស្លាប់លើសលុបពី ១.៥ លាន ទៅ ២ លាននាក់ក្នុងចន្លោះពីឆ្នាំ ១៩៧៥-១៩៧៨ និងលើកឡើងថា នៅក្នុងការស្ថាបនា តួលេខរបស់គាត់ យ៉ាងហោចណាស់ក៏មានប្រជាជនចំនួន ៦០០.០០០ នាក់ស្លាប់ និងអាចមានរហូតដល់ ២ លាន នាក់បានស្លាប់ដោយសារមូលហេតុពិបាកពន្យល់ អាចដោយសារការថយចុះជាទូទៅលើអត្រាអាយុសង្ឃឹមរស់ ឬក៏ដោយអត្រា មរណៈ ដែលបណ្តាលមកពីសង្គ្រាមមុនឆ្នាំ ១៩៧៥)។ អត្ថបទនិពន្ធដោយ B. SHARP៖ *គណនានរក* ឯកសារ E3/1801ទំព័រ ៥០ ERN (ភាសាខ្មែរ) 00282800 (បន្ទាប់ពីការពិនិត្យឡើងវិញទៅលើតួលេខរបស់អ្នកជំនាញដទៃទៀតរួចមក SHARP កំណត់ថា មានតួលេខអ្នកស្លាប់ក្នុងរង្វង់ពី ១.៧៤៧ លាន ទៅ ២.៤៥៩ លាននាក់ ដែលបណ្តាលមកពីតែគោលនយោបាយ និងអំពើទាំងឡាយរបស់ខ្មែរក្រហម)។ SHARP យល់ឃើញថា ចំណុចកណ្តាលក្នុងងរង្វង់ប្រមាណ ២.១២ លាននាក់ “គឺស្ថិតនៅក្បែរៗនឹងតួលេខដែលទំនងជាងគេបង្អស់”)។ សៀវភៅនិពន្ធដោយ M. VICKERY ដែលមានចំណងជើងថា៖ *កម្ពុជា ឆ្នាំ ១៩៧៥-១៩៨២* ឯកសារ E3/1757 ឆ្នាំ ១៨៨៤ ទំព័រ ៦៨-៧០ ERN (ភាសាខ្មែរ) 00789236-00789238 (លោក M. VICKERY បានប៉ាន់ប្រមាណថា ចំនួនអ្នកស្លាប់ ៧៤០.៨០០ នាក់ គឺបណ្តាលមកពីស្ថានភាពពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានប៉ាន់ប្រមាណថា ជាងពាក់កណ្តាលនៃចំនួននេះ គឺបណ្តាលមកពីភាពអត់ឃ្លាន ការបាក់កម្លាំង និងជំងឺ ហើយចំនួនប្រហែល ៣០០.០០០ នាក់ត្រូវបានគេសម្លាប់ ។ គាត់បានលើកឡើងថា តួលេខដែលកាន់តែត្រឹមត្រូវមែនទែននោះ គឺមិនអាចផ្តល់បានទេ ហើយគេមិនអាចព្យាករណ៍តួលេខនៃការសម្លាប់ពី ១ ទៅ ២ លាននាក់ ដោយយោងទៅលើទិន្នន័យដែលមាននៅក្នុងឆ្នាំ ១៩៨៤ បានទេ)។ *របាយការណ៍អ្នកជំនាញផ្នែកប្រជា-សាស្ត្រ៖ ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩៖ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ* ឯកសារ E3/2413 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣៣-៤៣, ១៣១-១៤៥ ERN (ភាសាខ្មែរ) 00499407-00499417, 00499407-00499417 (ការប៉ាន់ប្រមាណការស្លាប់ក្នុងចំនួនដ៏ច្រើនលើសលប់ ដែលបានចុះផ្សាយនៅចន្លោះឆ្នាំ ១៩៨០ និងឆ្នាំ ១៩៩៣ ខិតជិតតួលេខចំនួន ១ លាននាក់ លើក

## ៤.១ លក្ខខណ្ឌទូទៅចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក

១៧៥. នៅផ្នែកដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទ អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ពីបទល្មើសនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ដែលត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា"។ បទល្មើសនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ទាំងនោះរួមមាន (១) ការធ្វើមនុស្សឃាត (២) ការសម្លាប់រង្គាល (៣) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង (៤) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជា (ក) ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស (ខ) ការផ្លាស់ទីលំនៅដោយបង្ខំ និង (គ) ការបាត់ខ្លួនដោយបង្ខំ[៥២៤]។

### ៤.១.១ ច្បាប់

១៧៦. អង្គជំនុំជម្រះបានសម្រេចកាលពីលើកមុន ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានគាំទ្រសេចក្ដីសម្រេចនោះថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់ថា ជាបទឧក្រិដ្ឋអន្តរជាតិ

---

លែងតែលោក VICKERY ដែលបានប៉ាន់ប្រមាណថាមានចំនួន ៧៤០.០០០ នាក់។ ការប៉ាន់ប្រមាណក្រោយៗ ដែលបានធ្វើឡើងចន្លោះពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ២០០៩ មានចំនួន ១,៤ លាននាក់ ទៅ ២,២ លាននាក់។ បន្ទាប់ពីបានពិនិត្យឡើងវិញទៅលើការប៉ាន់ប្រមាណទាំងនេះរួចមក អ្នកនិពន្ធបានទទួលស្គាល់ថា ចំនួនអ្នកស្លាប់ក្នុងរង្វង់ពី ១,៧៤៧ លាន ទៅ ២,២ លាននាក់ នៅក្នុងរបបខ្មែរក្រហមគឺជាចំនួនដែលអាចពិតច្រើនជាងគេ និងបានពិចារណាឃើញថាការប៉ាន់ប្រមាណមុនៗគឺជាការប៉ាន់ប្រមាណសើរៗបំផុតនូវចំនួនអ្នកសម្លាប់ដោយខ្មែរក្រហម)។

[៥២៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៥, ១៣៧៧, ១៣៧៩-១៣៨០ (អំពើមនុស្សឃាត) កថាខណ្ឌ ១៣៨១, ១៣៨៧-១៣៨៩ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៤១៥-១៤១៨, ១៤២៣-១៤២៥ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) កថាខណ្ឌ ១៤៣៤-១៤៣៦, ១៤៣៩-១៤៤០ (អំពើអមនុស្សធម៌ផ្សេងៗទៀត,ការប៉ះ-ពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) កថាខណ្ឌ ១៤៤៨-១៤៦៩ (អំពើអមនុស្សធម៌ផ្សេងៗទៀត, ការផ្លាស់ទីដោយបង្ខំ) កថាខណ្ឌ ១៤៧០-១៤៧៨ (អំពើអមនុស្សធម៌ផ្សេងៗទៀត ការបាត់ខ្លួនដោយបង្ខំ)។ ពាក់ព័ន្ធនឹងអំពើមនុស្សឃាត *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីរាយនាមកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលត្រូវបានធ្វើវិសោធនកម្មបន្ថែម ទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ៣-៦។

ចាប់តាំងពីមានធម្មនុញ្ញរបស់តុលាការ Nuremberg ហើយបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងរយៈកាលនៃយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក[៥២៥]។ ដូច្នេះ អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក បទចោទស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានលក្ខណៈស្របទៅនឹងគោលការណ៍នីត្យានុកូលភាព[៥២៦] លុះណាតែមានសេចក្ដីសន្និដ្ឋានបន្ថែមថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬរាល់ទម្រង់នៃការទទួលខុសត្រូវ "ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថាជាបទល្មើស ហើយថាជនជាប់ចោទអាចដឹងពីច្បាប់ដែលចែងអំពីការទទួលខុសត្រូវផងដែរ នាពេលនោះ"[៥២៧]។ ការវិភាគបែបនេះត្រូវធ្វើឡើងនៅកម្រិតបទឧក្រិដ្ឋជាក់លាក់ផ្សេងៗដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬទម្រង់នៃការទទួលខុសត្រូវមិនមែនធ្វើឡើងចំពោះប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងមូលនោះទេ។

១៧៧. បទល្មើសមួយចំនួនដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន ប្រសិនបើធាតុផ្សំទូទៅដែលតម្រូវឲ្យមានជាមុន ត្រូវបានបង្កើតឡើងដើម្បីបំពេញតាមនិយាមដែលតម្រូវឲ្យមាន (១) ត្រូវតែមានការវាយប្រហារ (២) ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ (៣) ការវាយប្រហារសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល (៤) ការវាយប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា (៥) ត្រូវតែមានទំនាក់ទំនងរវាងអំពើរបស់ចារីនឹងការវាយប្រហារ និង (៦) ជនជាប់ចោទ ឬចារី ត្រូវមានការដឹងជាចាំបាច់អំពីការវាយប្រហារ[៥២៨]។ អង្គជំនុំជម្រះធ្លាប់បានសម្រេចលើកមុនថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់

---

[៥២៥] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៨៣-២៨៩។ សាលដីកាលើបណ្ដឹងសាទុក្ខក្នុងករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ១០០-១០៥។

[៥២៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៨៣-២៩៦។ សាលដីកាលើបណ្ដឹងសាទុក្ខក្នុងករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ១០០-១០៥។

[៥២៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៩៦ ដកស្រង់យុត្តិសាស្ត្រនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ *Ojdanić* (សហឧក្រិដ្ឋកម្មរួម) កថាខណ្ឌ ២១ និង ៣៧។

[៥២៨] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ១០៦។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩៧។

អន្តរជាតិក្នុងឆ្នាំ ១៩៧៥ លែងតម្រូវឲ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធទៀតហើយ[៥២៩]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធទឡ្ហីករណ៍របស់ជនជាប់ចោទដែលលើកឡើងខុសពីនេះ[៥៣០]។

១៧៨. *ការវាយប្រហារ* គឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើន[៥៣១]។ ការវាយប្រហារនេះមិនមែនគិតត្រឹមតែការប្រើកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះនោះទេ គឺត្រូវគិតទាំងការធ្វើបាបប្រជាជនស៊ីវិលរួមទាំងអំពើទាំងឡាយដែលមាននៅក្នុងបទល្មើសជាក់លាក់ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផងដែរ[៥៣២]។ ការវាយប្រហារទៅលើប្រជាជនស៊ីវិលមានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ[៥៣៣]។ ការវាយប្រហារអាចកើតមានឡើងមុន អាចអូសបន្លាយពេលយូរ ឬបន្តមានរហូតនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ដោយមិនចាំបាច់ថា ការវាយប្រហារនេះជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនោះទេ[៥៣៤]។

១៧៩. *លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ* ពាក្យថា "លក្ខណៈជាទូទៅ" គឺសំដៅទៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន ហើយពាក្យថា "ជាប្រព័ន្ធ" គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ ហើយដែលអំពើនោះមិនអាចកើតមានឡើងដោយ

---

[៥២៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩១-២៩២។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/8 ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៣៣។

[៥៣០] សារណារបស់ ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៨។ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២១៤ (យកតាមសារណារបស់ អៀង សារី)។

[៥៣១] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩១៨។

[៥៣២] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៨៦។

[៥៣៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩៩។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២៥១។

[៥៣៤] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៩៩។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៨៦។

ចៃដន្យនោះទេ[៥៣៥]។ ការវាយប្រហារជាប្រព័ន្ធ ជាទូទៅ ជាប្រភេទបទល្មើសទាំងឡាយណាដែលទាក់ទងនឹងការប្រព្រឹត្តិអំពើឧក្រិដ្ឋប្រហាក់ប្រហែលគ្នាដដែលៗ ដែលមិនមែនជាការចៃដន្យ និងមានភាពទៀងទាត់[៥៣៦]។ ការវាយប្រហារលក្ខណៈជាទូទៅ អាចសំដៅទៅលើ "ទាំងអានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអានុភាពនៃអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ"[៥៣៧]។ ភ័ស្តុតាងដែលបង្ហាញអំពីការវាយប្រហារដែលមាន "លក្ខណៈជាទូទៅ" ឬ "ជាប្រព័ន្ធ" គឺជាភ័ស្តុតាងមួយដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញអំពីការទទួលខុសត្រូវ[៥៣៨]។ មានតែការវាយប្រហារប៉ុណ្ណោះ ដែលចាំបាច់តម្រូវឲ្យមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ចំណែកឯបទល្មើសជាក់លាក់នីមួយៗនោះគឺមិនតម្រូវឲ្យមានលក្ខខណ្ឌទាំងនេះទេ[៥៣៩]។ អំពើតែមួយ ឬអំពើដែលមានចំនួនកំណត់ មានលក្ខណៈគ្រប់គ្រាន់អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន ទាល់តែអំពើទាំងនោះមិនដាច់ចេញពីគ្នា ឬមិនកើតឡើងដោយចៃដន្យ និងទាល់តែមានការបំពេញនូវរាល់លក្ខខណ្ឌដទៃទៀត[៥៤០]។

១៨០. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏តម្រូវឲ្យមានផងដែរអំពីអត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ ឬអង្គការមួយ[៥៤១]។ ក្រុមមេធាវីការពារក្តី នួន ជា ក៏បានលើកឡើងស្រដៀងគ្នានេះថា អត្ថិភាពនៃផែនការ ឬ គោលនយោបាយរបស់រដ្ឋ គឺជាលក្ខខណ្ឌតម្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[៥៣៥] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០០។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩៤។

[៥៣៦] សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១០១។

[៥៣៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០០។ សាលក្រមសាលា-ដំបូង ក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២០៦។

[៥៣៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០០។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩៣។

[៥៣៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០១។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៩៤។

[៥៤០] សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៩៤។

[៥៤១] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ពាក់ព័ន្ធច្បាប់ជាធរមាន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E163/5/9, កថាខណ្ឌ ១០, ១២ និង ៦៨។

សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរយៈពេល ដែលពាក់ព័ន្ធក្នុងដីកាដំណោះស្រាយ[៥៤២]។ ក្រុមមេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា ផ្ទុយទៅវិញ យុត្តិសាស្ត្រអន្តរជាតិ ‘ចាប់ផ្តើមពីទសវត្សរ៍ឆ្នាំ ២០០០’ គឺមិនពាក់ព័ន្ធនោះទេ នៅក្នុងការពិចារណាអំពីច្បាប់របស់រដ្ឋ នៅក្នុងរយៈពេលដែលពាក់ព័ន្ធក្នុងដីកាដំណោះស្រាយនោះ[៥៤៣]។

១៨១. នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះបីអត្ថិភាពនៃគោលនយោបាយ ឬផែនការមួយអាចជាភ័ស្តុតាងមួយទាក់ទងនឹងការបង្កើតឲ្យមាននូវការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬ ជាប្រព័ន្ធក៏ដោយ ក៏អត្ថិភាពនៃគោលនយោបាយ និងផែនការទាំងនោះមិនមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ[៥៤៤]។ ទោះបីការយល់ឃើញនេះស្របជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្រោយឆ្នាំ ១៩៧៥[៥៤៥] ក៏ដោយ ក៏ការយល់ឃើញនេះផ្អែកលើការពិនិត្យទៅលើប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងពេលវេលានៃការអនុវត្តនៅពេលនោះដែរ។ ប្រភពទាំងអស់នេះបង្ហាញនូវទស្សនៈផ្ទុយទៅលើបញ្ហានេះ។ ទោះបីជាក្រុមមេធាវីការពារក្តីបានបង្ហាញអត្តសញ្ញាណនៃប្រភពមួយចំនួនដែលគាំទ្រដល់ទឡ្ហីករណ៍គតិយុត្តិរបស់ខ្លួនក៏ដោយ[៥៤៦] ក៏

[៥៤២] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់នួន ជា ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ២១០ ដល់ ២១៣។

[៥៤៣] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល របស់នួន ជា ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ២១៣។

[៥៤៤] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០១។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១២០។

[៥៤៥] *សូមមើលជាឧទាហរណ៍* សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ១២០។ សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ៩៨ ជើងទំព័រ ១១៤។ សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ៨៤។ សាលក្រមរឿងក្តី *Sesay* កថាខណ្ឌ ៧៩។

[៥៤៦] ប្រភពទាំងអស់នេះដែលត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តី បានចាត់ទុកថាគោលនយោបាយ ឬផែនការរបស់រដ្ឋ គឺជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់ សម្រាប់ឧក្រិដ្ឋកម្មនឹងប្រឆាំងមនុស្សជាតិៈ សាលក្រមរឿងក្តីក្រសួងយុត្តិធម៌ ទំព័រ ៩៧៣ និង៩៨៤, សាលក្រមរឿងក្តី *Eichmann* កថាខណ្ឌ ៥៦ ដល់៨៨។ របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិ ដែលរៀបរាប់ពីការងាររបស់សម័យប្រជុំលើកទី៦ របស់ខ្លួន ថ្ងៃទី ៣ ខែ មិថុនា ដល់ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥៤, UN Doc. A/2693, មាត្រា ២។ ទោះបីជាសាលក្រមរឿងក្តី *Menten* មិនតម្រូវឲ្យមានការចូលរួមពីរដ្ឋក៏ដោយ តែបានតម្រូវថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ “បង្កើតជាទម្រង់នៃប្រព័ន្ធមួយដែលផ្អែកលើភេរវកម្ម ឬបង្កើតជាទំនាក់ទំនងមួយនៅក្នុងគោលនយោបាយដែលត្រូវបានអនុវត្តដោយមានការដឹងច្បាស់” (សូមមើលទំព័រ ៣៦២ ដល់ ៣៦៣)។ អង្គជំនុំជម្រះយល់ឃើញថា ប្រភពដទៃទៀតដែលកំណត់ដោយក្រុមមេធាវីការពារក្តី មិនបានគាំទ្រដល់អត្ថិភាពនៃលក្ខខណ្ឌតម្រូវអំពីគោលនយោបាយ ឬផែនការរបស់រដ្ឋឯករាជ្យឡើយ។ ការយោងទៅលើសាលក្រម

មានការគាំទ្រផងដែរដល់ទស្សនៈ ដែលបានលើកឡើងពីលើកមុនដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រម កាំង ហ្គេកអ៊ាវ ហៅ ឌុច[៥៤៧] ដែលតម្រូវឱ្យមានការសម្រេចថាការអនុវត្តរបស់រដ្ឋ និងការប្រកាសពីឆន្ទៈទទួលយកជាច្បាប់ នៅពេលនោះ គឺមិនបានគាំទ្រឱ្យបានច្បាស់លាស់ចំពោះលក្ខខណ្ឌតម្រូវអំពីគោលនយោបាយ ឬផែនការរបស់រដ្ឋ ឬអង្គការមួយឡើយ។ ដោយសារតែមិនមានកំហុសឆ្គងណាមួយត្រូវបានបង្ហាញ ដូច្នេះ អង្គជំនុំជម្រះបដិសេធការជំទាស់ទាំងពីរនេះ។

១៨២. *សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល* ការវាយប្រហារត្រូវតែ "សំដៅប្រឆាំង" ទៅលើប្រជាជនស៊ីវិល។ មានន័យថា ប្រជាជននោះត្រូវតែជាគោលដៅចម្បងនៃការវាយប្រហារ មិនមែនជាគោលដៅនៃការវាយប្រហារដោយចៃដន្យនោះទេ[៥៤៨]។ មិនចាំបាច់មានការបង្ហាញថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រពាក់ព័ន្ធណាមួយដែលមានការវាយប្រហារ ទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះឡើយ[៥៤៩]។ វាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថាបុគ្គលមួយចំនួននៅក្នុងក្រុមនោះ ត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ ឬវាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថា បុគ្គលទាំងនោះត្រូវបានគេកំណត់ថាជា

---

របស់តុលាការយោធាអន្តរជាតិត្រង់ "គោលនយោបាយភេរវកម្ម [និង] ការធ្វើទុក្ខបុកម្នេញ [...] នៅក្នុងប្រទេសអាល្លឺម៉ង់" (សូមមើលទំព័រ ៤៩៨) បានបង្ហាញពីការយល់ឃើញទៅលើអង្គហេតុ គឺមិនមែនទៅលើលក្ខខណ្ឌតម្រូវផ្លូវច្បាប់នោះទេ។ សាលក្រម *Einsatzgruppen* បង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចកើតឡើង តែក្នុងករណីដែលរដ្ឋមិនបានអនុវត្តសកម្មភាពដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មនោះ ទោះជាក្នុងហេតុផលណាក៏ដោយ (សូមមើលទំព័រ ៤៩៨)។

[៥៤៧] ប្រភពដែលមិនបានកំណត់ថា គោលនយោបាយ ឬផែនការរបស់រដ្ឋ ឬអង្គការគឺជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះរួមមាន៖ ធម្មនុញ្ញទីក្រុងតូក្យូ មាត្រា ៥។ ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង លេខ១០ មាត្រា II (គ)។ សាលក្រម *Flick* ទំព័រ ១១៩១, ១២១២ ដល់១២១៦។ សាលក្រមរឿងក្តីវេជ្ជសាស្ត្រ ទំព័រ ១៧២ ដល់១៧៣, សាលក្រមរឿងក្តី *Milch*, ហើយ Musmanno បានគាំទ្រ ទំព័រ ៧៩០ ដល់៧៩១។ សាលក្រមរឿងក្តី *Milch*, ហើយ Phillips បានគាំទ្រ ទំព័រ ៨៦៣ ដល់៨៦៤។ សាលក្រមរឿងក្តី *RuSHA* ទំព័រ ១៥១។ សាលក្រមនៅក្នុងរឿងក្តី *មេបញ្ជាការ* ទំព័រ៤៦៩។ សាលក្រមនៅក្នុងរឿងក្តី *ចំណាប់ខ្មាំង* ទំព័រ ១២៣២។ សាលក្រមនៅក្នុងរឿងក្តី *Ministries* ទំព័រ ៦៥៣ ដល់៦៥៤, ទំព័រ ៧៩៧, ៨៧៧។ សាលក្រម *Farben* ទំព័រ ១១២៩ ដល់១១៣០។

[៥៤៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៥ និង ៣០៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩១-៩២។

[៥៤៩] សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩០។

គោលដៅនៃការវាយប្រហារ ដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការវាយប្រហារនោះមានគោលដៅប្រឆាំងទៅលើ "ប្រជាជនស៊ីវិល" មិនមែនមានគោលដៅប្រឆាំងទៅលើបុគ្គលមួយចំនួនដែលបានកំណត់ និងត្រូវបានជ្រើសរើសខ្លះៗនោះទេ[៥៥០]។

១៨៣. ដើម្បីមានលក្ខណៈគ្រប់គ្រាន់អាចចាត់ទុកថាជា "ប្រជាជនស៊ីវិល" ស្របទៅនឹងស្មារតីនៃមាត្រា ៥ លុះត្រាតែប្រជាជនដែលជាគោលដៅនៃការវាយប្រហារនោះ ត្រូវតែជាជនស៊ីវិលច្រើនលើសលុប[៥៥១]។ វត្តមានរបស់បុគ្គលមួយចំនួន ក្នុងចំណោមប្រជាជនស៊ីវិល ហើយដែលបុគ្គលទាំងនោះមិនស្ថិតនៅក្រោមនិយមន័យនៃជនស៊ីវិល មិនអាចដកហូតចរិតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនេះបានទេ[៥៥២]។ ឋានៈជាជនស៊ីវិលរបស់ជនរងគ្រោះ ចំនួនជនស៊ីវិល និងចំនួនសមាមាត្រនៃជនស៊ីវិលនៅក្នុងចំណោមប្រជាជន គឺជាកត្តានានាដែលពាក់ព័ន្ធទៅនឹងការកំណត់ថាតើលក្ខខណ្ឌតម្រូវនៃការវាយប្រហារដែលត្រូវបានប្រព្រឹត្តឡើងសំដៅប្រឆាំងទៅលើ "ប្រជាជនស៊ីវិល"ត្រូវបានបំពេញហើយ ឬនៅ [៥៥៣]។

១៨៤. ប្រសិនបើការវាយប្រហារមួយត្រូវបានធ្វើឡើងនៅក្នុងទីតាំងភូមិសាស្ត្រមួយ ដែលមានទាំងជនស៊ីវិល និងទាហានផងនោះ កត្តាផ្សេងទៀតអាចមានភាពពាក់ព័ន្ធដើម្បីកំណត់ ថាតើការវាយប្រហារនោះ ត្រូវបានប្រព្រឹត្តសំដៅប្រឆាំងទៅលើ "ប្រជាជនស៊ីវិល" ដែរ ឬយ៉ាងណា។ កត្តាទាំងនេះ រួមមាន មធ្យោបាយ និងវិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងការវាយប្រហារ ឋានៈរបស់ជនរងគ្រោះ ចំនួនជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលវាយប្រហារ និងការបង្ក្រាបដល់អ្នកតស៊ូនៅពេលនោះ និងទំហំនៃ

---

[៥៥០] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០២-៣០៣ និង ៣០៥។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kordić* និង *Čerkez* កថាខណ្ឌ ៩៥។

[៥៥១] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៥។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Dragomir Milošević* កថាខណ្ឌ ៥០-៥១។

[៥៥២] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៥-៣០៦ ពឹងផ្អែកលើមាត្រា ៥០(៣) នៃពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Mrkšić និង Šljivančanin* កថាខណ្ឌ ៣១។ *សូមមើលផងដែរ* សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៣៦-១៣៨។

[៥៥៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៥។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Mrkšić និង Šljivančanin* កថាខណ្ឌ ៣២-៣៣ និង ៣៦។

កម្លាំងវាយប្រហារដែលអាចនិយាយបានថា បានគោរពតាម ឬមានចេតនាគោរពតាមលក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម[៥៥៤]។

១៨៥. ដើម្បីកំណត់ថាតើប្រជាជនអាចចាត់ទុកថាជា "ជនស៊ីវិល" បានដែរ ឬយ៉ាងណា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមាននិយមន័យដែលបានកំណត់អំពីជនស៊ីវិល នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ ក្នុងខែ មេសា ឆ្នាំ ១៩៧៥។ និយមន័យទូទៅនៃពាក្យថា "civilian" (ជាភាសាអង់គ្លេស) និង "*civil*" (ជាភាសាបារាំង) ពោលគឺសំដៅទៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងរយៈពេលដែលពាក់ព័ន្ធទៅនឹងបទចោទនៅចំពោះមុខនេះថា ប្រជាជនស៊ីវិលរាប់បញ្ចូលនូវបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវបានទទួលស្គាល់ថាជាអ្នកប្រយុទ្ធ។ ទោះបីជាអង្គជំនុំជម្រះមិនបានពឹងផ្អែកលើនិយមន័យនៃពាក្យ "ជនស៊ីវិល" ដូចមានចែងក្នុងមាត្រា ៥០ នៃពិធីសារបន្ថែម I នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលបានអនុម័តដោយតុលាការមិនអចិន្ត្រៃយ៍នានា និងមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីឲ្យសមស្របទៅតាមស្មារតីនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោយឆ្នាំ ១៩៧៧ ក៏ដោយ[៥៥៥] ក៏អង្គជំនុំជម្រះកត់សម្គាល់ថា និយមន័យនេះស្របជាមួយនឹងអត្ថន័យជាទូទៅនៃពាក្យនេះ[៥៥៦]។

១៨៦. នៅក្នុងការកំណត់អំពីឋានៈរបស់បុគ្គលណាម្នាក់ ថាជាជនស៊ីវិល ឬមិនមែនជាជនស៊ីវិល ស្ថានភាពជាក់លាក់របស់បុគ្គលនោះ នៅក្នុងពេលដែលមានបទឧក្រិដ្ឋកើតឡើង មិនអាចកំណត់អំពីឋានៈទាំងនេះបានឡើយ។ សមាជិកនៃអង្គការប្រដាប់អាវុធ មិនត្រូវទទួលបានឋានៈជាជនស៊ីវិលនោះឡើយ ទោះបីជាគាត់មិនកាន់អាវុធ ឬមិនបានចូលរួមនៅក្នុងការប្រយុទ្ធ ក្នុងពេលដែលមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះក៏ដោយ[៥៥៧]។ ហេតុដូច្នេះ ទាហាន *ដែលបាត់បង់សមត្ថភាពក្នុងការ*

---

[៥៥៤] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៩។ សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Mrkšić និង Šljivančanin* កថាខណ្ឌ ៣០។

[៥៥៥] សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១១០ ដល់ ១១៣។ មាត្រា ៥០ នៃពិធីសារបន្ថែមទី ១ ដែលយោងទៅមាត្រា ៤៣ នៃពិធីសារបន្ថែមទី ១ និងមាត្រា ៤ ក នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបី។

[៥៥៦] សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Martić* កថាខណ្ឌ ២៩៧។

[៥៥៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៤។ សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១១៤។

*ប្រយុទ្ធ* មិនត្រូវបានចាត់ទុកថាជា "ជនស៊ីវិល" នោះទេ ផ្អែកតាមគោលបំណងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[៥៥៨]។ ការសន្មតជាទូទៅ ភ្ជាក់ងារអនុវត្តច្បាប់សង្គ្រាមរបស់រដ្ឋមួយ ត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកតាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ[៥៥៩]។ បុគ្គលមួយរូបត្រូវបានចាត់ទុកថាជាជនស៊ីវិល ប្រសិនបើឋានៈរបស់បុគ្គលនោះមិនមានលក្ខណៈច្បាស់លាស់[៥៦០]។

១៨៧. នៅពេលដែលប្រជាជនស៊ីវិល គឺជាគោលដៅនៃការវាយប្រហារ "មិនតម្រូវឲ្យមានលក្ខខណ្ឌ*ឬបង្ហាញនូវធាតុផ្សំ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលថាជនរងគ្រោះនៃបទល្មើសជាក់លាក់ណាមួយនោះត្រូវតែជាជនស៊ីវិល នោះឡើយ"[៥៦១]។ ហេតុដូច្នេះ ទាហានណាម្នាក់ *ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដ៏រាបណាលក្ខខណ្ឌចាំបាច់ដទៃទៀតត្រូវបានបំពេញ[៥៦២]។ លើសពីនេះទៅទៀត ការនិយាយយោងទៅលើប្រជាជនស៊ីវិល "ណាមួយ" មិនចាំបាច់បង្ហាញថា ជនរងគ្រោះទាំងនោះជាប់ទាក់ទងជាមួយក្រុមជាក់លាក់ណាមួយនោះទេ[៥៦៣]។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចរួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយមកលើប្រជាជនរបស់ខ្លួនឯងផងដែរ[៥៦៤]។

---

[៥៥៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៤។ សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Mrkšić និង Šljivančanin* កថាខណ្ឌ ៣៥។

[៥៥៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៤។ សាលក្រមសាលាដំបូងក្នុងរឿងក្ដី *Sesay* កថាខណ្ឌ ៨៧។

[៥៦០] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣០៤។ សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១១១។

[៥៦១] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១១ ដោយយោងសាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Mrkšić និង Šljivančanin* កថាខណ្ឌ ៣២។

[៥៦២] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១១។ សាលដីកាបណ្ដឹងសាទុក្ខក្នុងរឿងក្ដី *Martić* កថាខណ្ឌ ៣០៩-៣១៣។

[៥៦៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១២។ សាលក្រមសាលាដំបូងក្នុងរឿងក្ដី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៤២៣។

[៥៦៤] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១២។ សាលក្រមសាលាដំបូងក្នុងរឿងក្ដី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៤២៣។

១៨៨. *មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា៖* មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា ការវាយប្រហារត្រូវតែធ្វើឡើងសំដៅប្រឆាំងលើប្រជាជនស៊ីវិល ដោយមូលហេតុនៃការរើសអើង ពោលគឺមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ នេះជាលក្ខខណ្ឌតម្រូវនៃយុត្តាធិការ ដែលកំណត់នូវវិសាលភាពដែលមានលក្ខណៈចង្អៀតអំពីយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បើផ្អែកទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានអនុវត្តរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩[៥៦៥]។ លក្ខខណ្ឌតម្រូវនេះកំណត់យកការវាយប្រហារដែលមានទ្រង់ទ្រាយធំទូលាយ ជាជាងបទល្មើសជាក់លាក់នីមួយៗ។ ហេតុដូច្នេះ ធាតុផ្សំចេតនានៃការរើសអើង មិនមែនជាធាតុផ្សំផ្លូវច្បាប់សម្រាប់គ្រប់បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ដោយសារតែលក្ខខណ្ឌតម្រូវនេះនឹងធ្វើឱ្យការយោងដែលបានបញ្ជាក់ទៅលើការរើសអើងនៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនមានប្រយោជន៍[៥៦៦]។

១៨៩. យុត្តិសាស្ត្រពាក់ព័ន្ធនឹងបទល្មើសធ្វើទុក្ខបុកម្នេញ កំណត់និយមន័យនៃអំពើមួយថាជាការរើសអើងនៅពេលដែលចារីកំណត់ថា ជនរងគ្រោះណាមួយជាគោលដៅនៃការវាយប្រហារដោយសារតែបុគ្គលនោះជាសមាជិក ឬត្រូវបានសន្មតថាជាសមាជិក នៅក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនា ណាមួយ[៥៦៧]។ ក្រុមគោលដៅនោះ "អាចត្រូវបានចារីកំណត់និយមន័យជាទូទៅ ក្នុងន័យអវិជ្ជមាន និងរួមទាំងអ្នកដែលមានជាប់ទាក់ទងគ្នាជិតស្និទ្ធ ឬមានសមានចិត្តចំពោះ

---

[៥៦៥] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៣-៣១៤។ មាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR ចែងអំពីលក្ខខណ្ឌតម្រូវនៃការរើសអើងស្រដៀងគ្នានេះ សម្រេចដោយសាលាក្តីនោះ ដើម្បីកំណត់ជាលក្ខខណ្ឌតម្រូវផ្អែកយុត្តាធិការ និងមិនមែនជាលក្ខខណ្ឌដែលតម្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៤៦៥។

[៥៦៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៣-៣១៤ និង ៣៧៩។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៣៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៤៦១ និង ៤៦៤។

[៥៦៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៧។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៦៧៤។

ក្រុមជនរងគ្រោះ..”[៥៦៨]។ វិធីសាស្ត្រនេះអាចយកមកអនុវត្តបានដូចគ្នានៅក្នុងការកំណត់និយមន័យនៃក្រុមជាក់លាក់ណាមួយ ដែលជាគោលដៅនៃការវាយប្រហារ។

១៩០. *ទំនាក់ទំនងរវាងអំពើរបស់ចារី និងការវាយប្រហារ៖* អំពើរបស់ចារីត្រូវតែជាផ្នែកមួយនៃការវាយប្រហារ មានន័យថា ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ជាសត្យានុម័តត្រូវតែជាផ្នែកមួយនៃការវាយប្រហារ[៥៦៩]។ ឧក្រិដ្ឋកម្មមួយ ដែលត្រូវបានប្រព្រឹត្តឡើងមុន ឬក្រោយ ឬនៅឆ្ងាយពីការវាយប្រហារជាចម្បងប្រឆាំងទៅលើប្រជាជនស៊ីវិល ក៏នៅតែអាចជាផ្នែកមួយនៃការវាយប្រហារដដែល ប្រសិនបើឧក្រិដ្ឋកម្មនោះមានទំនាក់ទំនងជិតស្និតជាមួយនឹងការវាយប្រហារនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ឧក្រិដ្ឋកម្មមិនអាចជាអំពើដាច់ដោយឡែកបាននោះទេ ពោលគឺឧក្រិដ្ឋកម្មមួយអាចចាត់ទុកថាជាអំពើដាច់ដោយឡែកបាន នៅពេលដែលឧក្រិដ្ឋកម្មនោះនៅដាច់ឆ្ងាយពីការវាយប្រហារ ដែលមិនមានហេតុផលសមស្របណាមួយអាចនិយាយបានថា ឧក្រិដ្ឋកម្មនោះគឺជាផ្នែកមួយនៃការវាយប្រហារ ក្រោយពីបានពិចារណាលើបរិបទ និងកាលៈទេសៈដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើង[៥៧០]។

១៩១. *ការដឹង* ជនជាប់ចោទ ឬចារីត្រូវតែបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងបានដឹងថា អំពើរបស់ខ្លួនបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនោះ[៥៧១]។ ជនជាប់ចោទមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារ ដែលមានលក្ខណៈធំទូលាយនោះទេ[៥៧២]។ ភស្តុតាងអំពីការដឹងនេះអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ។ ជាលទ្ធផលការបង្ហាញធាតុផ្សំតាមផ្លូវច្បាប់ថាយ៉ាងណា

---

[៥៦៨] សាលដីកាលើបណ្តឹងសាទុក្ខក្នុងករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ២៧២។

[៥៦៩] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ៨៥។ សាលដីការឿងក្តី *Šainović* និងអ្នកដទៃទៀត កថាខណ្ឌ ២៦៤។

[៥៧០] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៨។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ១០០។

[៥៧១] សាលដីការឿងក្តី *Kunarac* និងអ្នកដទៃទៀត កថាខណ្ឌ ៨៥។ សាលដីការឿងក្តី *Munyakazi* កថាខណ្ឌ ១៤១។

[៥៧២] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៩។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* កថាខណ្ឌ ១០២-១០៣។

នោះ គឺអាស្រ័យតាមកាលៈទេសៈជាក់ស្តែងនីមួយៗ[៥៧៣]។

១៩២. ក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងថា មានលក្ខខណ្ឌតម្រូវមួយបន្ថែមទៀត ក្រៅពីលក្ខខណ្ឌតម្រូវនានាដែលបានបង្ហាញពីខាងលើ ហើយលក្ខខណ្ឌតម្រូវនោះគឺ ជនជាប់ចោទត្រូវតែដឹងពីលក្ខណៈរើសអើងនៃការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធ ដែលបង្កើតបានជាមូលដ្ឋាននៃបទចោទប្រឆាំងនឹងរូបគាត់[៥៧៤]។ មេធាវីការពារក្តី មិនបានលើកឡើងពីសំអាងផ្លូវច្បាប់ណាមួយ ដើម្បីគាំទ្រដល់អំណះអំណាងនេះឡើយ។ ដោយសារតែលក្ខន្តិកៈរបស់តុលាការ ICTR គឺជាលិខិតុបករណ៍តែមួយគត់ក្រៅពីច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលបានដាក់បញ្ចូលលក្ខខណ្ឌតម្រូវយុត្តាធិការដែលថា ការវាយប្រហារត្រូវតែធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការរើសអើង ទើបយុត្តិសាស្ត្ររបស់តុលាការ ICTR អាចផ្តល់ជាគោលការណ៍ណែនាំដែលមានប្រយោជន៍ចំពោះបញ្ហានេះ។ ការពិនិត្យរបស់អង្គជំនុំជម្រះទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTR បង្ហាញស្ទើរតែដូចគ្នា[៥៧៥] ថា តុលាការ ICTR មិនតម្រូវថាជនជាប់ចោទត្រូវតែដឹងអំពីលក្ខណៈរើសអើងនៃការវាយប្រហារទ្រង់ទ្រាយធំ និងជាប្រព័ន្ធនោះឡើយ[៥៧៦]។ ស្រដៀងគ្នានេះដែរ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* អង្គជំនុំជម្រះសាលាដំបូងក៏មិនបានតម្រូវឲ្យមានការដឹងពីលក្ខណៈរើសអើងនៃការវាយប្រហារឡើយ[៥៧៧]។ អង្គជំនុំជម្រះយល់ឃើញថាការដឹងបែបនេះ គឺមិនមែនជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅចំពោះមុខ អ.វ.ត.ក ឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសារណានេះ។

---

[៥៧៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៩។ សាលដីកាបណ្តឹងសាទុក្ខក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១២៦។

[៥៧៤] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៨។

[៥៧៥] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR បានតម្រូវឲ្យមានការដឹងពីលក្ខណៈរើសអើងនៃការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធ កថាខណ្ឌ ៦៩៣។

[៥៧៦] *សូមមើលជាឧទាហរណ៍* សាលដីការឿងក្តី *Bagosora* និង *Nsengiyumva* កថាខណ្ឌ ៣៨៩។ សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ៨៦។ សាលក្រមរឿងក្តី *Kayishema and Ruzindana* កថាខណ្ឌ ១៣៣ ដល់១៣៤។ សាលក្រមរឿងក្តី *Seromba* កថាខណ្ឌ ៣៦០។ សាលក្រមរឿងក្តី *Kamuhanda* កថាខណ្ឌ ៦៥៦ ដល់៦៥៧។ សាលក្រមរឿងក្តី *Semanza* កថាខណ្ឌ ៣២៧ ដល់៣៣២។

[៥៧៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្គេកអ៊ាវ ហៅឌុច* កថាខណ្ឌ ៣១៩។

### ៤.១.២ សំអាងច្បាប់

១៩៣. អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងយ៉ាងហោចណាស់ក៏រហូតមកដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលជាអំឡុងពេលដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។ ការវាយប្រហារនេះត្រូវបានប្រព្រឹត្តឡើងក្រោមទម្រង់ជាច្រើន រួមទាំង ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ[៥៧៨]។ ការវាយប្រហារនេះបានធ្វើឲ្យប្រជាជនកម្ពុជា រាប់លាននាក់ក្លាយជាជនរងគ្រោះនៅទូទាំងប្រទេសកម្ពុជា និងធ្វើឲ្យមានជនភៀសខ្លួនរាប់រយរាប់ពាន់នាក់ភៀសខ្លួនចេញទៅកាន់ប្រទេសជិតខាង[៥៧៩]។ ការវាយប្រហារនេះត្រូវបានអនុវត្តឡើងដើម្បីជាការជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស[៥៨០]។ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះមានលក្ខណៈជាទូទៅ ដោយពិចារណាទៅលើវិសាលភាពភូមិសាស្ត្រ និងទាំងចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ការវាយប្រហារនេះមានលក្ខណៈជាប្រព័ន្ធ ដោយសារតែវិសាលភាព និងទំហំនៃឧក្រិដ្ឋកម្មទាំងនោះ មិនអាចត្រូវបានប្រព្រឹត្តឡើងដោយគ្មានការរៀបចំជាមុនទេ និងត្រូវបានអនុវត្តឡើងដើម្បីជាការជំរុញ និងឲ្យស្របតាមគោលនយោបាយរបស់បក្ស។

១៩៤. អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជា។ ជម្លោះប្រដាប់អាវុធរវាងរបបសាធារណរដ្ឋខ្មែរ និងខ្មែរក្រហម បានបញ្ចប់នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ហើយទាហាននៃរបបសាធារណរដ្ឋខ្មែរបានចុះចាញ់[៥៨១]។ ហេតុដូច្នេះ ទាហានទាំងអស់នៃរបប

[៥៧៨] សូមមើលផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧៣ ។

[៥៧៩] សូមមើលផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧៣ ។

[៥៨០] សូមមើលផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤-៧៣៨, ៧៤២-៧៤៣, ៧៧៧, ៨០៤-៨០៥, ៨៣៥ ។

[៥៨១] សូមមើលផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១) កថាខណ្ឌ ៤៦០, ៥០១-៥០២។

សាធារណរដ្ឋខ្មែរ ដែលមិនបានចូលរួមដោយផ្ទាល់នៅក្នុងជម្លោះប្រដាប់អាវុធ ឬយ៉ាងហោចណាស់ជា *ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ* មានសិទ្ធិទទួលបានការការពារដូចគ្នានឹងប្រជាជនស៊ីវិលដែរ។ ទោះជាក្នុងករណីណាក៏ដោយ អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរគ្រាន់តែជាផ្នែកមួយនៃប្រជាជនស៊ីវិលរាប់លាននាក់ ដែលត្រូវបានវាយប្រហារតែប៉ុណ្ណោះ[៥៨២]។

១៩៥. អង្គជំនុំជម្រះយល់ឃើញទៀតថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនេះត្រូវបានអនុវត្តឡើងដោយសារមូលហេតុនយោបាយ ស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ ដើម្បីសម្រេចបានទិសដៅនេះ បក្សយល់ថា វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ត្រូវតែកម្ទេចចោល[៥៨៣]។ "ប្រជាជនថ្មី" ទាំងនេះត្រូវបានគេចាត់ទុកថាជាខ្មាំងខាងនយោបាយ និងខ្មាំងខាងសង្គមរបស់បដិវត្ត និងប្រព័ន្ធសមូហភាព[៥៨៤]។ លើសពីនេះទៀត ប្រជាជនកម្ពុជាទាំងអស់ត្រូវតែជាផ្នែកមួយនៃបដិវត្ត និងប្រព័ន្ធសមូហភាពនេះ[៥៨៥]។ អ្នកដែលប្រឆាំង ឬត្រូវបានគេសន្មតថាបានប្រឆាំងនឹងបដិវត្ត និងប្រព័ន្ធសមូហភាពនេះ គឺជាគោលដៅនៃការធ្វើបាប និងអំពើហិង្សា[៥៨៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះត្រូវបានអនុវត្តឡើងដោយសារមូលហេតុនយោបាយ។

---

[៥៨២] សូមមើលផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៧០-១៧២ ។

[៥៨៣] សូមមើលផ្នែកទី៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣ ។ ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦, ៧៣១, ៧៨៨, ៨១៥ ។

[៥៨៤] សូមមើលផ្នែកទី៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧-១១៨ ។ ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦ ។

[៥៨៥] សូមមើលផ្នែកទី៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ ជើងទំព័រ ៣១៨ ។ ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤។

[៥៨៦] សូមមើលផ្នែកទី៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧-១១៨, ១២០, ១២៣។ ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩ ។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៤-៨១៨។

១៩៦. យោងតាមដីកាដំណោះស្រាយ ការវាយប្រហារខ្លះក៏មានគោលដៅមកលើពុទ្ធសាសនិក-ជន ជនជាតិចាម និងជនជាតិវៀតណាម ដោយសារសញ្ជាតិ ជាតិពិន្ទុ ពូជសាសន៍ និង/ឬ សាសនារបស់ពួកគេផងដែរ[៥៨៧]។ ការវាយប្រហារទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ក្រោយពីបានសម្រេចរួចហើយថា ការវាយប្រហារជាទូទៅនេះត្រូវបានអនុវត្តឡើង ប្រឆាំងនឹងជនស៊ីវិល ដោយសារមូលហេតុនយោបាយ ហេតុដូច្នេះ អង្គជំនុំជម្រះមិនធ្វើការ សម្រេចថាតើការវាយប្រហារខ្លះក៏ត្រូវបានធ្វើឡើងដោយសារមូលហេតុជាតិ ជាតិពិន្ទុ ពូជសាសន៍ និង/ឬ សាសនា យ៉ាងណានោះទេ ព្រោះផ្នែកនេះនឹងត្រូវពិនិត្យក្នុងអំឡុងពេលសវនាការនាពេល ខាងមុខ។

១៩៧. អង្គជំនុំជម្រះសន្និដ្ឋានផងដែរថា មានទំនាក់ទំនងរវាងអំពើរបស់ជាប់ចោទ និងការ វាយប្រហារនេះ។ អំពើរបស់ចារី និងជនជាប់ចោទនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន នៅដំណាក់ទីមួយ និងដំណាក់ទីពីរ និងក្នុងអំឡុងពេលនៃការសម្លាប់អតីតអ្នករដ្ឋការនៃរបប សាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ត្រូវបានប្រព្រឹត្តឡើងនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧ និងត្រូវបានអនុវត្តឡើងដើម្បីជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការការពារ និងកសាងសង្គមនិយម[៥៨៨]។ ចុងបញ្ចប់ ដោយពិចារណាទៅ លើទំហំ និងវិសាលភាពនៃការវាយប្រហារនេះ[៥៨៩] និងចំណុចដែលថា ការវាយប្រហារនេះត្រូវបាន អនុវត្តឡើងដើម្បីជាការជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្ស[៥៩០] នោះ អង្គជំនុំជម្រះជឿជាក់ថា ទាំងចារី និងជនជាប់ចោទ បានដឹងអំពីការវាយប្រហារប្រឆាំងនឹងប្រជាជន ស៊ីវិល និងបានដឹងថា អំពើទាំងឡាយរបស់ពួកគេបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនេះ។

[៥៨៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៦៩។

[៥៨៨] ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩ ។ ផ្នែកទី ១០ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧-៥៧៤។ ផ្នែកទី ១១ ស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣០-៦៥៧។ ផ្នែកទី ១២ ស្តីពីទួលពោធិ៍ជ្រៃ កថាខណ្ឌ៦៨២-៦៨៧។ ផ្នែកទី១៣ ស្តីពី ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩០-៧០២ ។

[៥៨៩] ផ្នែកទី ៤ ស្តីពី ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧៣។

[៥៩០] សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ១០៤, ១១១-១១២, ១១៦-១១៨។ ផ្នែកទី ៤ ស្តីពី ទិដ្ឋភាព ទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩ ។ ផ្នែកទី១៤ ស្តីពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧-៧៧៨, ៨០៤-៨១០, ៨៣៥-៨៣៧។

១៩៨. ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌទូទៅទាំងអស់សម្រាប់ការអនុវត្តមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ។

# ៥ រចនាសម្ព័ន្ធរដ្ឋបាល

## ៥.១ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា

១៩៩. រចនាសម្ព័ន្ធប្រតិបត្តិការជាក់លាក់របស់បក្សកុម្មុយនីស្តកម្ពុជាមានភាពសម្ងាត់[៥៩១]។ នៅដំណាក់កាលដំបូងនៃការវិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ការសម្ងាត់មានសារៈសំខាន់ចំពោះការរស់រានរបស់បក្ស ដែលជាចលនាបដិវត្តលាក់ខ្លួន[៥៩២]។ ប៉ុន្តែ សូម្បីតែនៅពេលបក្សកុម្មុយនីស្តកម្ពុជាបានចូលកាន់អំណាចក្នុងឆ្នាំ ១៩៧៥ ហើយក៏ដោយ ក៏បក្សបានបន្តធ្វើឲ្យកិច្ចការផ្ទៃក្នុងរបស់ខ្លួនដែលមានលក្ខណៈពិបាកយល់ និងមានការលាក់បាំង ដើម្បីការពារខ្លួនឲ្យរួចផុតពីពួកខ្មាំងខាងក្រៅ[៥៩៣]។ ក្នុងករណីខ្លះ ប្រជាជនធម្មតាអាចដឹងព័ត៌មានតិចតួចប៉ុណ្ណោះអំពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំ ដោយពួកគាត់ត្រូវបានគេតម្រូវឲ្យអនុវត្តតាម ដោយមិនត្រូវសាកសួរអំពីការសម្រេចនានារបស់ "អង្គការ" ដែលជាស្ថាប័នអនាមិក ដែលត្រូវបានគេមើលឃើញថាមានអំណាចត្រួតត្រាសង្គមទាំងមូលនោះទេ[៥៩៤]។ កម្មាភិបាលថ្នាក់ក្រោម ពេលខ្លះគ្រាន់តែយល់ដឹងតិចតួចអំពីការរៀបចំ

---

[៥៩១] សុន្ទរកថារបស់ នួន ជា ជូនចំពោះបក្សកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00224468-00224470។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២(នី កន)ទំព័រ៥៧។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00156616-00156617។ ប្រតិចារឹក ថ្ងៃទី១៤ ខែ សីហា ឆ្នាំ ២០១២(សួង ស៊ី គឿន) ទំព័រ ៧៣។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២៧-២៨។

[៥៩២] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦១-៦៣ ។

[៥៩៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៣-៦៥ ។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៦៥-៦៦។

[៥៩៤] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ក្លាន ហ្វីត) ទំព័រ ៦៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៦៧-៦៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុច ភ្លី ឯកសារ E3/5213 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00221591 ("បើអង្គការឲ្យធ្វើអ្វី ត្រូវតែធ្វើតាម។ ខ្ញុំមិនដឹងថាអ្នកណាជាអង្គការទេ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ វ៉ាដឹនី ឯកសារ E3/102 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥-៨, ERN (ភាសាខ្មែរ) 000350659-00350662 ("មនុស្សគ្រប់រូបនិយាយថា "អង្គការ" គឺជាអ្នកសម្រេច ប៉ុន្តែយើងមិនដឹងថា "អង្គការ" ជាអ្នកណានោះទេ។ សូមមើលផងដែរ ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២១។

ចាត់ចែងអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ[៥៩៥]។ ជាការពិតណាស់ គោលនយោបាយលាក់ការសម្ងាត់នេះបាននាំឱ្យមានការយល់ច្រឡំ និងមានការយល់ឃើញផ្ទុយគ្នា ក្នុងចំណោមសាក្សីនានា ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៥៩៦]។ ប៉ុន្តែ ជារួមភ័ស្តុតាងទាំងអស់ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អាចឱ្យអង្គជំនុំជម្រះពិពណ៌នាអំពីមាគ៌ាចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងពេលពាក់ព័ន្ធ។

២០០. រចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងជាផ្លូវការលើកដំបូងនៅក្នុងលក្ខន្តិកៈដែលត្រូវបានអនុម័តដោយសន្និបាតបក្សលើកដំបូងនៅក្នុងខែ កញ្ញា និង តុលា ឆ្នាំ ១៩៦០ ដែលនៅពេលនោះ បក្សមានឈ្មោះថា “បក្សពលករកម្ពុជា”[៥៩៧]។ លក្ខន្តិកៈបក្សទីពីរប្រហែលជាត្រូវបានអនុម័តិនៅក្នុងសន្និបាតបក្សលើកទីបីរបស់បក្សក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧១[៥៩៨]។ ទោះបីជាយ៉ាងណាក្តី លក្ខន្តិកៈបក្សមួយទៀតត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីបួន នៅក្នុងខែ មករា ឆ្នាំ ១៩៧៦[៥៩៩]។ មានតែលក្ខន្តិកៈបក្សចុងក្រោយនៃលក្ខន្តិកៈបក្សទាំងនេះទេ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៦០០] ប៉ុន្តែ យោងតាមចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច លក្ខន្តិកៈបក្សទាំងអស់នោះមានខ្លឹមសារស្រដៀងគ្នា យ៉ាងហោច

[៥៩៥] សូមមើលឧទា. ប្រតិចារឹក ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៨៣-៨៤។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៥១-៥២។

[៥៩៦] *សូមមើល ជាឧទា.* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌកថាខណ្ឌ ២០៧ ។

[៥៩៧] ទង់បដិវត្ត ឯកសារ E3/10 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៤-៩, ERN (ភាសាខ្មែរ) 00063064-00063066។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៦-១៧។ ទង់យុវជន និងយុវនារីបដិវត្ត ឯកសារ E3/768 ខែ មីនា ឆ្នាំ ១៩៧៧ ទំព័រ ២២-២៥ ERN (ភាសាខ្មែរ) 00376206-00376207។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៧។

[៥៩៨] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥៣។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥។

[៥៩៩] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥៣-៥៤, ៥៥-៥៦។ របាយការណ៍អ្នកជំនាញការរបស់ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00314780-00314782។

[៦០០] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ។

ណាស់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធផ្ទៃក្នុង និងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា[៦០១]។

### ៥.១.១ សន្និបាតបក្ស

២០១. លក្ខន្តិកៈបក្សឆ្នាំ ១៩៧៦ (“លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា”) បានកំណត់អំពីមាគ៌ាដែលបក្សត្រូវបានបង្កើតឡើងជាផ្លូវការ។ “សិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស” ត្រូវបានប្រគល់ឲ្យមហាសន្និបាត ឬសន្និបាតបក្ស[៦០២]។ តួនាទីរបស់សន្និបាតគឺដើម្បី “កំណត់មាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្ស” និងជ្រើសតាំងសមាជិកគណៈកម្មាធិការមជ្ឈិម[៦០៣]។ បន្ថែមលើសន្និបាតបក្សលើកទីមួយ ទីពីរ ទីបី និងទីបួន ដែលបានលើកឡើងខាងលើ សន្និបាតបក្សលើកទីប្រាំត្រូវបានកោះប្រជុំនៅចុងឆ្នាំ ១៩៧៨[៦០៤]។ សន្និបាតបក្សឆ្នាំ ១៩៧៦ និង ១៩៧៨ មានប្រជាជនចូលរួមប្រជុំរាប់រយនាក់ ក្នុងនោះមានតំណាងមកពីគ្រប់តំបន់ និងគ្រប់កងពលទាំងអស់ ក៏ដូចជាបណ្ដាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[៦០៥]។

---

[៦០១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៨។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ)ទំព័រ៦៥-៦៦។ *សូមមើលផងដែរ* អត្ថបទដែលមិនបង្ហាញប្រភព៖ប្រវត្តិសង្ខេបរបស់បក្សកុម្មុយនីស្ត-ខ្មែរ ឯកសារ E3/2 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00679880-00679882 (បញ្ជាក់ថា លក្ខន្តិកៈឆ្នាំ ១៩៦០ “បានបង្កើតគណៈកម្មាធិការមជ្ឈិមបក្សដែលមានសមាជិកប្រាំបីនាក់”)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៦-១៨ (ដែលទទួលស្គាល់អត្ថិភាពរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការ-អចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៦០ មកម្ល៉េះ)។

[៦០២] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣២-៣៤ មាត្រា ៧, ERN (ភាសាខ្មែរ) 00442269-00442270។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៤-៤៥ (បញ្ជាក់ថា ពាក្យ “មហាសន្និបាត” និង “សន្និបាតបក្ស” មានន័យដូចគ្នា)។

[៦០៣] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ មាត្រា ២១ ទំព័រ ៤៨, ERN (ភាសាខ្មែរ) 00442277។

[៦០៤] ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៤-៤៥។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ចុះថ្ងៃទី ១២ ខែ មីនា ឆ្នា ១៩៨០ ទំព័រ ៩២-៩៤, ERN (ភាសាខ្មែរ) 00324763-00324765។

[៦០៥] ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៦-១៩។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ឆោម សែ) ទំព័រ ៤៦, ៥៦-៥៨។

### ៥.១.២ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍

២០២. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា នៅក្នុងចន្លោះពេលនៃសន្និបាតបក្សទាំងនោះ គណៈកម្មាធិការមជ្ឈិមគឺជា "អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស"[៦០៦]។ ជាគោលការណ៍ គណៈកម្មាធិការមជ្ឈិមមានភារកិច្ចអនុវត្តមាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្ស នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទាំងមូល ណែនាំអង្គការភូមិភាគ អង្គការតំបន់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទៀត"ឲ្យធ្វើសកម្មភាពស្របតាមមាគ៌ានយោបាយ គោលជំហរ សតិអារម្មណ៍ និងមាគ៌ាចាត់តាំង របស់បក្ស" ដើម្បីគ្រប់គ្រង និងចាត់ចែង កម្មាភិបាល និងបក្ខជន និងទាក់ទងជាមួយបណ្តាបក្សម៉ាក្ស-លេនីន ជាបងប្អូន"[៦០៧]។ គណៈកម្មាធិការមជ្ឈិមត្រូវជួបប្រជុំយ៉ាងហោចណាស់ប្រាំមួយខែម្តងដូចបានកំណត់នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា[៦០៨]។ អត្តសញ្ញាណ និងចំនួនសមាជិក ត្រូវបានផ្លាស់ប្តូរជាហូរហែនៅចន្លោះពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៧៩ ប៉ុន្តែ នៅពេលឈានដល់ចំណុចកំពូលរបស់ខ្លួនក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ គណៈកម្មាធិការមជ្ឈិមមានសមាជិកចន្លោះពី ២០ ទៅ ៣០ នាក់[៦០៩]។ សមាជិកទាំងនោះរួមមាន ទូ សាមុត ដែលបានធ្វើជាលេខាបក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ ១៩៦០ រហូតដល់ពេលគាត់បាត់ខ្លួននៅក្នុងឆ្នាំ ១៩៦២[៦១០] ប៉ុល ពត ដែលបានចូលរួមក្នុងគណៈកម្មាធិការមជ្ឈិម បន្ទាប់ពីការបង្កើតគណៈកម្មាធិការនេះនៅក្នុងឆ្នាំ

---

[៦០៦] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣២-៣៤ មាត្រា ៧, ERN (ភាសាខ្មែរ) 00442269-00442270។

[៦០៧] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤៩-៥០ មាត្រា ២៣, ERN (ភាសាខ្មែរ) 00442277-00442278។

[៦០៨] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨, ERN (ភាសាខ្មែរ) 00156619។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥១ មាត្រា ២៥, ERN (ភាសាខ្មែរ) 00442278។

[៦០៩] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៩២-៩៣។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៩៤-៩៥, ERN (ភាសាខ្មែរ) 00324765-00324766។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ២។

[៦១០] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៤១។

១៩៦០ មក និងបានចូលមកកាន់តំណែងជាលេខាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ ១៩៦៣[៦១១] ជនជាប់ចោទ នួន ជា ដែលត្រូវបានជ្រើសតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិមក្នុងឋានៈជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ ១៩៦០[៦១២] និងជនជាប់ចោទ ខៀវ សំផន ដែលបានចូលរួមនៅក្នុងគណៈកម្មាធិការមជ្ឈិម ក្នុងឋានៈជាសមាជិកត្រៀមនៅក្នុងឆ្នាំ ១៩៧១ និងបានក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងឆ្នាំ ១៩៧៦[៦១៣]។ យោងតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា សមាជិកត្រៀមអាច "ចូលរួមប្រជុំគណៈកម្មាធិការមជ្ឈិមបាន តែមិនមានសិទ្ធិសម្រេចនោះទេ"[៦១៤]។

២០៣. ទោះបីជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ផ្តល់អំណាចប្រតិបត្តិការខ្ពស់បំផុតទៅឲ្យគណៈ-កម្មាធិការមជ្ឈិមក៏ដោយ ក៏ការត្រួតត្រាពិតប្រាកដទៅលើបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្តដោយស្ថាប័នដែលមិនមានកំណត់នៅក្នុងលក្ខន្តិកៈបក្ស ដែលគេស្គាល់ថាជាគណៈកម្មាធិការអចិន្ត្រៃយ៍[៦១៥]។ គណៈកម្មាធិការអចិន្ត្រៃយ៍បានចាប់ផ្តើមកើតមាន នៅស្របពេលជាមួយគ្នានឹងការចាប់ផ្តើមកើត

---

[៦១១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៦។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៧។

[៦១២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៦-៥៧។ សូមមើលផ្នែកទី ៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៣, ៣១៥។

[៦១៣] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦២-៦៣។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620 ។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៣១។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៨។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ២-៣។ សូមមើលផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣ ។

[៦១៤] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥០ មាត្រា ២៤, ERN (ភាសាខ្មែរ) 00442278។

[៦១៥] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨, ERN (ភាសាខ្មែរ) 00156619។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨៦-៨៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៥។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៦-១៧។

មានគណៈកម្មាធិការមជ្ឈិមដែរ នៅក្នុងឆ្នាំ ១៩៦០[៦១៦]។ គណៈកម្មាធិការអចិន្ត្រៃយ៍ជួបប្រជុំគ្នាប្រហែលពី ៧ ថ្ងៃទៅ ១០ ថ្ងៃម្តង ឬក៏ជួបប្រជុំញឹកញាប់ជាងនេះ ប្រសិនបើមានកាលៈទេសៈតម្រូវឱ្យធ្វើបែបនេះ[៦១៧]។ គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិក ៧ រូប ដោយសមាជិកទាំងអស់នេះយកចេញពីគណៈកម្មាធិការមជ្ឈិម[៦១៨]។ ដូចគ្នានឹងគណៈកម្មាធិការមជ្ឈិមដែរ យូរៗម្តង សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានផ្លាស់ប្តូរ[៦១៩]។ ប៉ុល ពត អៀង សារី សោ ភឹម និង ជនជាប់ចោទ នួន ជា គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ចាប់តាំងពីពេលបង្កើតគណៈកម្មាធិការនេះមក[៦២០]។ តា ម៉ុក បានចូលរួមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៅក្នុងឆ្នាំ ១៩៦៣[៦២១]។ សុន សេន *ហៅ* ខៀវ គឺជាសមាជិកត្រៀម ឬសមាជិកបម្រុង (មិនមែនជាសមាជិកពេញសិទ្ធ) នៃគណៈកម្មាធិការ-អចិន្ត្រៃយ៍[៦២២] ហើយ សុខ ធួក ហៅ វន វេត អាចជាសមាជិកពេញសិទ្ធិ ឬជាសមាជិកត្រៀម[៦២៣]។

---

[៦១៦] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៦-៥៧ ។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៦-១៨។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៦-៤៧ ។

[៦១៧] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨, ERN (ភាសាខ្មែរ) 00156619។ *សូមមើលផងដែរ* កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/221 ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/222 ចុះថ្ងៃទី ១៥ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/223 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦។ (បញ្ជាក់ថា ពេលខ្លះ កិច្ចប្រជុំទាំងនោះត្រូវបានធ្វើឡើងជាសម្ងាត់)។

[៦១៨] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨១-៨២។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620 ។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦-៥៧។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៩២-៩៤, ERN (ភាសាខ្មែរ) 00324763-00324765។

[៦១៩] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ២៨-២៩។

[៦២០] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ៦, ១៧-១៨។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ២០១២ (David CHANDLER) ទំព័រ ២៥។

[៦២១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៧-១៨។

[៦២២] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ២០១៣ (Philip SHORT) ទំព័រ ៥០។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍

សៀ វ៉ាស៊ី *ហៅ* ឌឿន និងជនជាប់ចោទ ខៀវ សំផន មិនធ្លាប់ជាសមាជិកផ្លូវការនៃគណៈកម្មាធិ-ការអចិន្ត្រៃយ៍ឡើយ ប៉ុន្តែពួកគេបានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់ គណៈកម្មាធិការ-អចិន្ត្រៃយ៍ដែរ[៦២៤]។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អាច (ហើយជាញឹកញាប់គឺដូច្នេះ) ត្រូវបានធ្វើឡើងដោយអវត្តមានសមាជិកមួយរូប ឬច្រើនរូបនៃគណៈកម្មាធិការនេះ[៦២៥]។

---

ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៩២-៩៤, ERN (ភាសាខ្មែរ) 00324763-00324765។

[៦២៣] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១២ ខែ មីនា ឆ្នា ១៩៨០ ទំព័រ ៩២-៩៤, ERN (ភាសាខ្មែរ) 00324763-00324765។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ D. Chandler៖ *សម្លេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ២៥ ERN (ភាសាខ្មែរ) 00191853 (ដែលបានផ្តល់ឈ្មោះពិតរបស់ វន វេត គឺឈ្មោះ សុក ធួក)។

[៦២៤] ក្នុងចំណោមកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ទាំង ២៣ ច្បាប់ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ កំណត់ហេតុចំនួន ១៩ ច្បាប់មានរាយឈ្មោះអ្នកចូលរួមក្នុងអង្គប្រជុំទាំងនោះ។ កំណត់ហេតុចំនួន ១៦ ច្បាប់មានកត់ត្រាឈ្មោះ ខៀវ សំផន *ហៅ* ហែម ថាមានវត្តមានក្នុងអង្គប្រជុំទាំងនេះ ហើយកំណត់ហេតុចំនួន ១២ ច្បាប់មានកត់ត្រាឈ្មោះ សៀ វ៉ាស៊ី *ហៅ*ឌឿន ថាមានវត្តមានក្នុងអង្គប្រជុំទាំងនេះ។ *សូមមើល* កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១-១៣ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៧៥។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/217 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/218 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គ-ប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/219 ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/220 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/221 ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/222 ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/223 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/224 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់-ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំ-គណៈអចិន្ត្រៃយ៍ ឯកសារ E3/226 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/227 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/228 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/229 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/230 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ កំណត់ហេតុ

## ៥.១.៣ គណៈកម្មាធិការយោធា

២០៤. គណៈកម្មាធិការយោធា គឺជាអនុគណៈកម្មាធិការមួយទៀតរបស់គណៈកម្មាធិការមជ្ឈិម។ គណៈកម្មាធិការយោធា ត្រូវបានដឹកនាំដោយ ប៉ុល ពត និងទទួលខុសត្រូវចំពោះកិច្ចការយោធា និងសន្តិសុខ[៦២៦]។ សុន សេន ក៏ជាសមាជិកគណៈកម្មាធិការយោធានេះដែរ[៦២៧]។ ទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះលើកឡើងថា ជនជាប់ចោទ នួន ជា ជាសមាជិកនៅក្នុងគណៈ-

នៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/230 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈ-អចិន្ត្រៃយ៍ ឯកសារ E3/231 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារលេខ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/233 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/235 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/237 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៧៦ និងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/238 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ *សូមមើលផងដែរ* ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥១, ជើងទំព័រ ១០៥២ ដែលបញ្ជាក់ថា ជនជាប់ចោទ ខៀវ សំផន បានប្រើឈ្មោះ ហៅក្រៅថា “ហែម”។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ២។ បទសម្ភាសន៍របស់ Masato Matsushita និង Stephen Heder ជាមួយ ឡុញ ហៅ ឡួន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៩២-៩៤, ERN (ភាសាខ្មែរ) 00324763-00324765។

[៦២៥] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00156619-00156620។ សូមមើលផងដែរ លេខយោងជើងទំព័រ ៦២៤ ខាងលើ។ សូមមើលផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល ជើងទំព័រ ៦២៤ ។

[៦២៦] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ២៣-២៤។ អត្ថបទសម្ភាសន៍របស់ Stephen Heder ជាមួយនឹង អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00062461-00062462។ Timothy Carney, “ការរៀបចំអំណាច” *នៅក្នុងប្រទេសកម្ពុជា*ចន្លោះពីឆ្នាំ ១៩៧៥-១៩៧៨៖ *ការណាត់ជួបនឹងមរណៈ* ឯកសារ E3/49 ទំព័រ ៨៨, ERN (ភាសាអង់គ្លេស) 00105137។

[៦២៧] កិច្ចសម្ភាសន៍របស់បណ្តាញទូរទស្សន៍ ABC ជាមួយនឹង អៀង សារី ឯកសារ E3/93 ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00224442-00224443។ បទសម្ភាសន៍របស់ Elizabeth Becker ជាមួយនឹង អៀង សារី ឯកសារ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00578895-00578896។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/83 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00398158-00398159 ។កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ឯកសារ E3/54 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00148743-00148744។

កម្មាធិការយោធាក៏ដោយ ក៏អង្គជំនុំជម្រះផ្អែកលើភស្តុតាងដែលមាន មិនជឿថា ការសន្និដ្ឋានបែប នេះជាការត្រឹមត្រូវឡើយ[៦២៨]។

### ៥.១.៤ មជ្ឈិមបក្ស

២០៥. សាក្សី និងអ្នកជំនាញជាច្រើនដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបានប្រើពាក្យថា "មជ្ឈិមបក្ស" ដោយសំដៅទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែ ដូចដែលសាក្សី Stephen HEDER បានបញ្ជាក់រួចហើយថា "មជ្ឈិមបក្ស" គឺជាពាក្យដែលមិនច្បាស់លាស់។ ពេលខ្លះពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងន័យរួម ដើម្បីសំដៅទៅលើ "កម្រិត "ទាំងមូលនៅក្នុងឋានានុក្រមបក្ស" ហើយពេលខ្លះទៀត ត្រូវបានប្រើប្រាស់សំដៅទៅលើអង្គភាព ឬស្ថាប័នជាក់លាក់ណាមួយ នៅថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា (ដូចជា គណៈកម្មាធិការ-មជ្ឈិម គណៈកម្មាធិការអចិន្ត្រៃយ៍ ឬមន្ទីរពាក់ព័ន្ធរបស់ខ្លួនណាមួយ ឬក៏ ប៉ុល ពត តែម្តង)[៦២៩]។ ពាក្យថា "មជ្ឈិមបក្ស" ក៏ត្រូវបានលើកឡើងនៅក្នុងឯកសារមួយចំនួនដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ និងការអត្ថាធិប្បាយរបស់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗមក ដោយមិនមានកំណត់និយមន័យទេ ប៉ុន្តែ ត្រូវបានប្រើនៅក្នុង

---

[៦២៨] *សូមមើល* ផ្នែកទី ៧ ស្តីពី តួនាទីនិងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៣ ។

[៦២៩] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១០។ *សូមមើលឧទា.* ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៥-៦ (ដែលនិយាយយោងទៅមជ្ឈិមបក្សថាជា "ថ្នាក់ដឹកនាំកម្រិតកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា")។ ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ១៨-១៩ (កំណត់ន័យមជ្ឈិម-បក្សថាមានកម្រិតខ្ពស់ជាងភូមិភាគ និងតំបន់)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨៥ (ដែលលើកឡើងថា "មជ្ឈិមបក្ស [...] ត្រូវបានយោងជាពិសេសសំដៅ [...] គណៈកម្មាធិការមជ្ឈិម")។ ប្រតិចារឹកថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១២ (ស្លួង ស៊ុគឿន) ទំព័រ ១០ (ដែលបានរៀបរាប់ថា "មន្ទីរ ៨៧០" គឺជា "មន្ទីរមជ្ឈិមបក្ស"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ឯកសារ E3/64 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00328028-00328029 (ប្រៀបធៀបមជ្ឈិមបក្សស្មើនឹង "មន្ទីរ ៨៧០")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ឯកសារ E3/35 ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ១៧-១៨, ERN (ភាសាខ្មែរ) 00340575-00340576 (ដែលលើកឡើងអំពី "គណៈអចិន្ត្រៃយ៍-មជ្ឈិមបក្ស"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ម៉េង ឯកសារ E3/5142 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣, ERN (ភាសាខ្មែរ) 00204119 (លើកឡើងថា ប៉ុល ពត គឺជាមជ្ឈិមបក្ស)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស សារិន ឯកសារ E3/4596 ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៩, ERN (ភាសាខ្មែរ) 00482769 (ដែលនិយាយយោងទៅលើមជ្ឈិមបក្សថាជា "ថ្នាក់លើ")។

បរិបទមួយដែលបានបង្ហាញច្បាស់លាស់ថា ពាក្យនេះគឺសំដៅទៅលើថ្នាក់កំពូលនៃឋានានុក្រមបក្ស កុម្មុយនីស្តកម្ពុជា (ផ្នែកសំខាន់ៗខ្លះ")[៦៣០]។

២០៦. នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះប្រើពាក្យថា "មជ្ឈិមបក្ស" សំដៅរួមទៅលើផ្នែកប្រតិបត្តិការជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ ដូចជា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការយោធា មន្ទីរ ៨៧០ មន្ទីររដ្ឋាភិបាល (មន្ទីរ ស-៧១) និងមន្ទីរចំណុះឱ្យមន្ទីររដ្ឋាភិបាល។

### ៥.១.៥ មន្ទីរ ៨៧០

២០៧. លេខកូដ "៨៧០" ត្រូវបានប្រើប្រាស់ដោយមិនមានន័យច្បាស់លាស់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលសំដៅទៅលើបុគ្គល និងអង្គភាពផ្សេងៗដែលជាប់ទាក់ទងទៅនឹងមជ្ឈិមបក្ស។ សាក្សីផ្សេងៗគ្នាមានការយល់ដឹងខុសៗគ្នាអំពីមន្ទីរ "៨៧០" នេះ ប៉ុន្តែ ជាទូទៅបានយល់ស្របថា មន្ទីរនេះសំដៅទៅលើផ្នែកខ្លះនៃថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ យោងតាមសាក្សី Stephen HEDER មន្ទីរ "៨៧០" ត្រូវបានប្រើប្រាស់តាំងពីដើមឆ្នាំ ១៩៧១ ដោយកំណត់ជា "ថ្នាក់ដឹកនាំមជ្ឈិមបក្ស"[៦៣១]។ អ្នកជំនាញ David CHANDLER បានជម្រាបជូនអង្គជំនុំជម្រះថា "៨៧០" គឺ "ជាទូទៅ ត្រូវបានប្រើប្រាស់សំដៅទៅលើ ប៉ុល ពត ហើយពេលខ្លះ សំដៅទៅលើ

---

[៦៣០] *សូមមើលខទា.* ទង់បដិវត្ត ឯកសារ E3/25 ចុះខែ ធ្នូ-មករា ឆ្នាំ ១៩៧៦-៧៧ ទំព័រ ២៧-៣០, ៣៦-៣៩ ERN (ភាសាខ្មែរ) 00063016-00063018, 00063021-00063022។ ទង់បដិវត្ត ឯកសារ E3/135 ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ៩-១២, ១៦-១៧, ERN (ភាសាខ្មែរ) 00062803-00062805, 00062808-00062809។ ទង់បដិវត្ត ឯកសារ E3/170 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១៣-១៥, ២៥-២៧, ៤៦-៤៨, ERN (ភាសាខ្មែរ) 00064762-00064763, 00064768-00064769, 00064780-00064781។ លិខិតរបស់ កាំង ហ្គេកអ៊ាវ ឯកសារ E3/1152 ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00002238-00002239។ សៀវភៅនិពន្ធដោយ D. Chandler៖ *សំឡេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ១៧-១៨, ERN (ភាសាខ្មែរ) 00191845-00191846។ អត្ថបទរបស់ Stephen Heder៖ *ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋានចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ការទទួលខុសត្រូវរបស់កម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប* ឯកសារ E3/4527 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២១-២៤, ERN (ភាសាខ្មែរ) 00830774-00830777។

[៦៣១] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១០-១១។

ប៉ុល ពត និងមនុស្សមួយក្រុមតូចនៅជុំវិញគាត់”[៦៣២]។ សាក្សី នង សុផង់ បានផ្តល់សក្ខីកម្មថា លេខសម្ងាត់ “៨៧០” គឺបានន័យថាលេខមជ្ឈិមហើយហ្នឹង”[៦៣៣]។ អ្នកជំនាញ Philip SHORT បានលើកឡើងថា “៨៧០” គឺជាឈ្មោះលេខកូដសម្រាប់គណៈកម្មាធិការអចិន្ត្រៃយ៍”[៦៣៤]។ ភាពមិនប្រាកដប្រជាអំពីអត្ថន័យច្បាស់លាស់របស់ “៨៧០” គឺស៊ីសង្វាក់ទៅនឹងការបញ្ជាក់ជាទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីការសម្ងាត់ ហើយដូចដែលអ្នកជំនាញ David CHANDLER បានធ្វើការកត់សម្គាល់ថា ជាចេតនា ការប្រើប្រាស់លេខកូដ គឺដើម្បីលាក់បាំង ឬធ្វើមិនឲ្យយល់អំពីលក្ខណៈពិតប្រាកដនៃថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា[៦៣៥]។

២០៨. ឯកសារមួយចំនួនពីរបបកម្ពុជាប្រជាធិបតេយ្យ មានការលើកឡើងអំពី “គណៈ ៨៧០”[៦៣៦]។ ទោះបីជាសហព្រះរាជអាជ្ញាលើកឡើងថា គណៈ ៨៧០ គឺជាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏គណៈ ៨៧០ អាចជាគណៈកម្មាធិការអចិន្ត្រៃយ៍ដូចគ្នាដែរ ហើយពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះមិនអាចធ្វើការកំណត់ឲ្យបានច្បាស់លាស់នោះទេ[៦៣៧]។

---

[៦៣២] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧៤។

[៦៣៣] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ១៦។

[៦៣៤] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៧។

[៦៣៥] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧៤-៧៥។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨៦-៨៧។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១៣-១៤។

[៦៣៦] *សូមមើល ឧទា.* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/932 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00020998-00020999។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/245 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ១ ERN (ភាសាខ្មែរ) 00001104។ មតិណែនាំរបស់គណៈ ៨៧០ ឯកសារ E3/1173 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00072485។

[៦៣៧] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧២។ ភ័ស្តុតាងខ្លះបានអះអាងថា គណៈ ៨៧០ គឺជាគណៈកម្មាធិការមជ្ឈិម៖ *សូមមើល ឧទា.* ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៥៤-៥៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ឯកសារ E3/74 ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00373519-00373520។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ឯកសារ E3/71 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00284310 ។ មតិណែនាំដែលចេញដោយគណៈ ៨៧០ បានសម្អាងទៅលើសេចក្តីណែនាំជាក់លាក់មួយចំនួនពី “គណៈមជ្ឈិមបក្ស”។ *សូមមើល* សេចក្តីណែនាំរបស់គណៈ ៨៧០ ឯកសារ E3/740 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៧៧។ ប៉ុន្តែ ភ័ស្តុតាងផ្សេងទៀតបានបង្ហាញថាគណៈ ៨៧០ គឺជាគណៈកម្មាធិការអចិន្ត្រៃយ៍។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២

២០៩. ក្រៅពីគណៈកម្មាធិការ ៨៧០ មានអង្គភាពដាច់ដោយឡែកមួយទៀតឈ្មោះថា "មន្ទីរ ៨៧០" "មន្ទីរនយោបាយ ៨៧០" "ម-៨៧០" (អក្សរ "ម" ជំនួសឲ្យពាក្យថា "មន្ទីរ" ដែលជាពាក្យខ្មែរប្រើជំនួសពាក្យ "មន្ទីរ" ឬ "មន្ទីររបស់គណៈកម្មាធិការអចិន្ត្រៃយ៍" ("មន្ទីរ ៨៧០")[៦៣៨]។ រហូតមកទល់នឹងខែតុលា ឆ្នាំ ១៩៧៥ សឿ វ៉ាស៊ី *ហៅ* ឌឿន ទទួលខុសត្រូវលើមន្ទីរ ៨៧០[៦៣៩]។ ជនជាប់ចោទ ខៀវ សំផន បានចូលរួមនៅក្នុងមន្ទីរ ៨៧០ ក្នុងអំឡុងខែ តុលា ឆ្នាំ ១៩៧៥[៦៤០]។ តាមសម្តីរបស់លោក Philip SHORT មន្ទីរ ៨៧០ បានបំពេញមុខងារជា"ផ្នែកប្រតិបត្តិ"របស់គណៈកម្មាធិការអចិន្ត្រៃយ៍[៦៤១]។ មន្ទីរនេះមានភារកិច្ចអនុវត្ត និងតាមដានការអនុវត្តសេចក្តីសម្រេចនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងដើម្បី "ទំនាក់ទំនងទៅវិញទៅមកជាមួយផ្នែកនីមួយៗ" របស់ថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងនាមជាគណៈកម្មាធិការអចិន្ត្រៃយ៍[៦៤២]។ ទាំងលោក Philip SHORT និងលោក David CHANDLER បានប្រើប្រាស់ឃ្លាថា "មជ្ឈមណ្ឌលសរសៃ

---

(នង សុផង់) ទំព័រ ៦៧-៦៨។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៧។ ចម្លើយជាលាយលក្ខណ៍អក្សររបស់ កាំង ហ្គេកអ៊ាវ ឯកសារ E3/359 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00408223-00408224។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៦៧-៦៨ (ដែលបានធ្វើការកត់សម្គាល់ថា មានភាពមិនច្បាស់លាស់នៅក្នុងការប្រើពាក្យ "គណៈ ៨៧០" និងមិនបានធ្វើសេចក្តីសន្និដ្ឋានឲ្យបានច្បាស់លាស់នោះឡើយ)។

[៦៣៨] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៩០។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៦៨-៦៩។ ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00019108-00019110។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារលេខ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣, ERN (ភាសាខ្មែរ) 00156676។

[៦៣៩] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00019108-00019110។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៩ (បញ្ជាក់ថា "ឌឿន" គឺជា សឿ វ៉ាស៊ី)។

[៦៤០] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៣ ERN (ភាសាខ្មែរ) 00103844។ សូមមើលផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៩០ ។

[៦៤១] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥២-៥៣។

[៦៤២] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00019112-00019113។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៧-១៨។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៣-៧៤, ERN (ភាសាខ្មែរ) 00103844-00103845។

01006492



ប្រសាទ" ដើម្បីរៀបរាប់អំពីតួនាទីដ៏សំខាន់បំផុតរបស់មន្ទីរ ៨៧០ ក្នុងការបញ្ជូនព័ត៌មានចេញ និងចូលមកគណៈកម្មាធិការអចិន្ត្រៃយ៍[៦៤៣]។

២១០. កំណត់ហេតុអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មួយច្បាប់ បានលើកឡើងពីអង្គភាពដាច់ដោយឡែកមួយដែលគេស្គាល់ជាភាសាខ្មែរថា "*ការិយាល័យ* ៨៧០" ជំនួសឲ្យ "*មន្ទីរ*-៨៧០"[៦៤៤]។ រហូតមកទល់នឹងខែតុលា ឆ្នាំ ១៩៧៥ ការិយាល័យនេះត្រូវបានដឹកនាំដោយឈ្មោះ ស៊ឹម សុន *ហៅ* យ៉ែម[៦៤៥]។ គេនៅតែមិនដឹងអំពីមុខងារច្បាស់លាស់របស់ការិយាល័យនេះទេ ប៉ុន្តែឈ្មោះជាភាសាខ្មែរបញ្ជាក់ថា ការិយាល័យនេះមានមុខងារពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលច្រើនជាងកិច្ចការនយោបាយ[៦៤៦]។

### ៥.១.៦ មន្ទីររដ្ឋាភិបាល (ស-៧១) និងមន្ទីរចំណុះផ្សេងៗទៀត

២១១. ដូចគ្នានឹងមន្ទីរ ៨៧០ ដែរ មជ្ឈិមបក្សបានរក្សាទុកមន្ទីររដ្ឋបាលមួយ ដែលត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ថាជា "មន្ទីររដ្ឋាភិបាល"[៦៤៧]។ រហូតមកទល់នឹងខែ តុលា ឆ្នាំ ១៩៧៥ មន្ទីររដ្ឋាភិបាលនេះត្រូវបានដឹកនាំដោយឈ្មោះ ឈឹម សំអោក

---

[៦៤៣] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៤។

[៦៤៤] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00019109-00019110។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៧១-៧២។

[៦៤៥] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00019109-00019110។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៩ (បញ្ជាក់ថា "យ៉ែម" គឺជា ស៊ឹម សុន)។

[៦៤៦] ខណៈដែលពាក្យ "មន្ទីរ" និង "ការិយាល័យ" អាចត្រូវបានបកប្រែទៅជាភាសាអង់គ្លេសថា 'office' ឬ 'bureau' នោះពាក្យថា "មន្ទីរ" មានន័យខាងផ្នែករចនាសម្ព័ន្ធរដ្ឋបាលទូលំទូលាយជាង ចំណែកឯពាក្យ "ការិយាល័យ" សំដៅជាពិសេសទៅលើអង្គភាពដែលមានឋានានុក្រមតូចជាង ឬជាអនុផ្នែក។ "មន្ទីរ" អាចមាន "ការិយាល័យ" ចំណុះច្រើនជាងមួយ។ *សូមមើលបន្ថែម* ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៧១-៧២។

[៦៤៧] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00019109-00019110។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១២។

*ហៅ* ប៉ង់[៦៤៨]។ សាក្សីជាច្រើនបានហៅអង្គភាពដែលដឹកនាំដោយ ប៉ង់ ថា“ស-៧១” ហើយផ្នែក ឬក្រសួងដែលត្រូវបានកំណត់ថាជា “ស-៧១” មានលេចឡើងជាញឹកញាប់នៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលគេបានបញ្ជូនខ្លួនមកកាន់មន្ទីរសន្តិសុខ ស-២១ ដែលបញ្ជាក់ថា “ស-៧១” គឺជាលេខកូដសម្រាប់មន្ទីររដ្ឋាភិបាលនេះ[៦៤៩]។

២១២. មន្ទីរ ស-៧១ អាចជាផ្នែកមួយនៃមន្ទីរ ៨៧០ ឬក៏អាចជាអង្គភាពដាច់ដោយឡែកមួយ។ បើទោះបីជាកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជាក់ថា មន្ទីរទាំងនោះផ្សេងពីគ្នាក៏ដោយ[៦៥០] ក៏សាក្សី Stephen HEDER បានរំលឹកថា បុគ្គលជាច្រើននាក់ដែលគាត់បានសម្ភាសន៍មានការយល់ច្រឡំទៅលើមន្ទីរទាំងពីរនេះ ហើយតាមពិតទៅ សាក្សីជាច្រើនដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានហៅអង្គភាពដែលដឹកនាំដោយ ឈឹម សំអោក

[៦៤៨] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00019109-00019110។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៩ (បញ្ជាក់ថា “ប៉ង់” គឺ ឈឹម សំអោក)។

[៦៤៩] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៩។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៧៧-៧៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នឹម សែម ឯកសារ E3/43 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00357219-00357220។ កិច្ចសម្ភាសន៍របស់ SOAS ជាមួយ គង់ យឿង ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ E3/5315។ *សូមមើលផងដែរ* បញ្ជីអ្នកទោសមកពីផ្នែកក្រសួង ស-៧១ ឯកសារ E3/1737 ដែលមិនមានចុះកាលបរិច្ឆេទ។ បញ្ជីអ្នកទោសមកពីផ្នែកក្រសួង ស-៧១ ឯកសារ E3/1738 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៨។ បញ្ជីមនុស្សចូលថ្ងៃទី ២៤ ខែ ៥ ឆ្នាំ ១៩៧៨ ឯកសារ E3/1955 ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៨ (បញ្ជីទាំងនេះបញ្ជាក់ពីអត្តសញ្ញាណអ្នកជាប់ឃុំឃាំងនៅ ស-២១ ដែលបញ្ជូនមកពី “ក្រសួង ស-៧១” ដែលភាគច្រើននៃអ្នកទាំងនេះត្រូវបានបញ្ជាក់ថា បានធ្វើការនៅក្នុងចំណោមមន្ទីរ “ក” ណាមួយ។ *សូមមើល* កថាខណ្ឌ ១៥ ខាងក្រោម)។ សូមមើលផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១៣ ។ ដំបូងឡើយ “ស-៧១” ក៏ជាលេខកូដសម្រាប់មូលដ្ឋាននៅជិតស្ទឹងជីនិត ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ប្តូរមកទីនោះក្នុងឆ្នាំ ១៩៧០ ។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ោម គុន) ទំព័រ ៦៧-៦៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00204743-00204744។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ២០ (បានរៀបរាប់អំពីការផ្លាស់ទីកន្លែងមកកាន់មូលដ្ឋានស្ទឹងជីនិត)។

[៦៥០] ការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00019108-00019110 (ធ្វើបញ្ជីដាច់ដោយឡែកពីគ្នារវាង “មន្ទីរនយោបាយ ៨៧០” និង “មន្ទីររដ្ឋាភិបាល”)។

*ហៅ* ប៉ង់ ដោយប្រើប្រាស់លេខកូដ "៨៧០"[៦៥១]។ ប៉ុន្តែ យោងតាមសម្តីរបស់សាក្សីផ្សេងទៀត មន្ទីរ ស-៧១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ បានបំពេញមុខងារផ្សេងពីមន្ទីរ ៨៧០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សឿ វ៉ាស៊ី *ហៅ* ឌឿន។ មន្ទីរ ៨៧០ របស់ ឌឿន ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ ចំណែកឯមន្ទីរ ស-៧១ របស់ ប៉ង់ ពាក់ព័ន្ធជាចម្បងទៅនឹងកិច្ចការផ្នែកភ័ស្តុភារ ការអនុវត្ត និងការងាររដ្ឋបាល[៦៥២]។

២១៣. ជាពិសេសមន្ទីរ ស-៧១ បានគ្រប់គ្រងទៅលើមន្ទីរចំណុះ និងអង្គភាពផ្សេងៗ ដែលបំពេញមុខងារជួយគាំទ្រដល់មជ្ឈិមបក្ស ហើយដែលភាគច្រើនត្រូវបានកំណត់ឈ្មោះជាលេខកូដដែលនាំ

---

[៦៥១] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ុចាម តុន) ទំព័រ ៧៦។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៦៦-៦៨។ ប្រតិចារឹក ថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ១៥-១៦។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម ) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡូត បាន) ទំព័រ ៧៥។

[៦៥២] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៩-១០, ១១-១២ (រៀបរាប់ថា ស-៧១ គឺជាមន្ទីររដ្ឋបាល ដាច់ដោយឡែកពីមន្ទីរ ៨៧០)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ១៨-១៩ (បញ្ជាក់ថា ប៉ង់ "ចាត់ចែងកិច្ចការប្រចាំថ្ងៃនៅក្នុងមន្ទីរនេះ រួមទាំង មន្ទីរ ក-១, ក-៣ និង ក-៧ ផងដែរ។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៩ (បញ្ជាក់ថា ប៉ង់ គ្រប់គ្រងនីរសារ និងផ្នែកបង្កបង្កើនផល និងបែងចែកភារកិច្ចដល់បុគ្គលិកនៅ ក-១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ុចាម តុន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00204071-00204072 ("ប៉ង់ ទទួលខុសត្រូវផ្នែករដ្ឋបាលនៅ មន្ទីរ ៨៧០ ហើយ ឌឿន ទទទួលខុសត្រូវផ្នែងគោលនយោបាយ")។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/448 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00154926-00154927 (រៀបរាប់ពី "គណៈកម្មាធិការនៃក្រុមការងារទទួលបន្ទុកមន្ទីរ ៨៧០" ដែលដឹកនាំដោយ ប៉ង់ ដោយមានការទទួល ខុសត្រូវផ្នែកសន្តិសុខ ការទទួលភ្ញៀវ ទូរគមនាគមន៍ សម្ភារៈ ស្បៀងអាហារ និងការដឹកជញ្ជូន។ គំនូសបំព្រួញរបស់ នង សួផង់ ឯកសារ E3/1736 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ (បង្ហាញថា មន្ទីរ ស-៧១ របស់ ប៉ង់ ចាត់ចែងលើមន្ទីរ "ក" ទាំងអស់)។ ប្រតិចារឹកក្នុងសវនាការលើសំណុំរឿង ០០១ (Craig ETCHESON) ឯកសារ E3/55 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៥៧ ERN (ភាសាខ្មែរ) 00330487 (ផ្តល់សក្ខីកម្មថា ស-៧១ គឺជា "សេនាធិការ" របស់មន្ទីរ ៨៧០ ដែលមានបណ្តាញមន្ទីរគាំទ្របម្រើការងារឱ្យមជ្ឈិមបក្ស)។ *សូមមើលផងដែរ* ផ្នែកទី ៥ ស្តីពីរចនា-សម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៩ ។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល លេខជើងទំព័រ ៦២៤ ខាងលើ (បង្ហាញថា ឌឿន បានចូលរួមក្នុងកិច្ចប្រជុំជាច្រើនរបស់គណៈអចិន្ត្រៃយ៍ ដែលកិច្ចប្រជុំទាំងនោះមានកំណត់ហេតុ។ ប៉ង់ មិនបានចូលរួមក្នុងកិច្ចប្រជុំទាំងនោះទេ) ។

មុខដោយអក្សរ “ក”[៦៥៣]។ មន្ទីរ ក-១ មានទីតាំងស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដែលជាទីកន្លែងធ្វើការ និងស្នាក់នៅរបស់ ប៉ុល ពត [៦៥៤]។ ក-៣ គឺជាមន្ទីរ និងជាកន្លែងស្នាក់នៅមួយផ្សេងទៀតដែលស្ថិតនៅទីក្រុងភ្នំពេញ សម្រាប់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំង ជនជាប់ចោទ នួន ជា និង ខៀវ សំផន ផងដែរ[៦៥៥]។ មន្ទីរ ក-៦ គឺជាសាលានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅឯបុរីកីឡាក្នុងទីក្រុងភ្នំពេញ[៦៥៦]។ មន្ទីរ ក-៧ គឺជាអង្គភាពនីរសារ[៦៥៧]។ មន្ទីរ ក-៨ គឺ

---

[៦៥៣] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៩, ១១, ១៤-១៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00204741-00204742។ គំនូសបំព្រួញរបស់ នង សួផង់ ឯកសារ E3/1736 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩។

[៦៥៤] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ១៥-១៦។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៣-៣៤។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៥៧-៥៨។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ (សរ វិ) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿ) ទំព័រ ៥៧។

[៦៥៥] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សួត្រ ទឿង) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៥៦-៥៨។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៧៣។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ (សរ វិ) ទំព័រ ១៩។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៦។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿ) ទំព័រ ៦០។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ៨-១៤។

[៦៥៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00204742-00204743។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស សារិន ឯកសារលេខ E3/4596 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៣៣, ៦៤-៦៦, ERN (ភាសាខ្មែរ) 00482793, 00482824-00482826។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ កែវ ឯកសារ E3/5173 លេខចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00189264-00189265។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង លីថេង ឯកសារ E3/462 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00204027-00204028។

[៦៥៧] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២១។

ជាអង្គភាពទទួលខុសត្រូវខាងដាំបន្លែ[៦៥៨]។ មន្ទីរ ក-៩ ជារោងចក្រវាយនភ័ណ្ឌ[៦៥៩]។ មន្ទីរ ក-១១ គឺជាកន្លែងផលិតថ្នាំពេទ្យ[៦៦០]។ មន្ទីរ ក-១២ គឺជាអង្គភាពរៀបចំចាត់ចែងយានជំនិះ និងអ្នកបើកបរ[៦៦១]។ មន្ទីរ ក-១៥ ជាសាលាបណ្តុះបណ្តាលនយោបាយជាសំខាន់ (ប៉ុន្តែ មិនដូច្នេះទាំងអស់ទេ) សម្រាប់អ្នកត្រឡប់មកពីបរទេសវិញ[៦៦២]។ មន្ទីរ ក-១៨ គឺជាមន្ទីរសារទូរលេខ[៦៦៣]។

២១៤. មន្ទីរ ស-៧១ ក៏មានអំណាចក្នុងការចាប់ខ្លួន និងបញ្ជូនអ្នកត្រូវបានចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខ ស-២១[៦៦៤]។ ក្នុងឆ្នាំ ១៩៧៨ ឈឹម សំអោក *ហៅ* ប៉ង់ ខ្លួនឯងក៏ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១ ហើយអនុប្រធានរបស់គាត់ឈ្មោះ ខាន់ លីន *ហៅ* កែន បានបន្ត

---

[៦៥៨] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿ) ទំព័រ ៥៦។ បទសម្ភាសន៍ជាមួយ នង សុផង់ ដោយ ចាយ ច័ន្ទតារាវណ្ណ និង Thomas Kuehnel ឯកសារ E3/1739 ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00838453-00838454។

[៦៥៩] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ២១-២២។

[៦៦០] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៣៥-៣៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា សាយ ឯកសារ E3/69 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00204084-00204085។

[៦៦១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២-៣, ៥-៦ ERN (ភាសាខ្មែរ) 00204739-00204740, 00204742-00204743។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា សាយ ឯកសារ E3/69 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00204084-00204085។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ឡាំង ឯកសារ E3/463 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00204728-00204729។

[៦៦២] ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង) ទំព័រ ៨៣, ៨៤-៨៥។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស សារិន ឯកសារ E3/4596 ទំព័រ ៣០-៣២, ERN (ភាសាខ្មែរ) 00482790-00482792។

[៦៦៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៥៤-៥៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន ឯកសារ E3/447 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១០ ទំព័រ ១១-១២, ERN (ភាសាខ្មែរ) 00483251-00483252។

[៦៦៤] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ១៥-១៦, ១៩-២០, ៣៧។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៥២។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/456 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៦ ERN (ភាសាខ្មែរ) 00198875។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/107 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00197970។

គ្រប់គ្រងដឹកនាំមន្ទីរ ស-២១ នេះ[៦៦៥]។

### ៥.១.៧ អង្គភាពភូមិភាគ តំបន់ ស្រុក និង ឃុំ

២១៥. នៅក្រោមមជ្ឈិមបក្ស កម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាតំបន់រដ្ឋបាលជាច្រើនទៅតាមឋានានុក្រម។ ថ្នាក់កំពូលនៃឋានានុក្រមនេះគឺភូមិភាគ។ ដំបូងឡើយ ភូមិភាគ នេះ ត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធមុនឆ្នាំ ១៩៧៥[៦៦៦]។ ដំបូងឡើយមានភូមិភាគចំនួន ៦ គឺៈ ភូមិភាគឧត្តរ (មានលេខកូដ ៣០៤[៦៦៧]) ភូមិភាគពាយ័ព្យ (លេខកូដ ៥៦០[៦៦៨]) ភូមិភាគព្រៃសាន្ត (លេខកូដ ១០៨ ក្រោយមកប្តូរទៅជា ១០៩[៦៦៩]) ភូមិភាគ

---

[៦៦៥] ចម្លើយរបស់ ឈឹម សំអោក នៅមន្ទីរ ស-២១ ឯកសារលេខ E3/1596 ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៧៨។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអាវ) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអាវ) ទំព័រ ៩-១០។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៨៨-៨៩។ ប្រតិចារឹក ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១២(នឹម សែន)ទំព័រ ៥, ៤២, ៤៣-៤៤។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ (សរ វី) ទំព័រ ៤១-៤២។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ រស់ ស៊ុយ) ទំព័រ ៤៥-៤៦។ T. 18 July 2013 (Stephen HEDER), ទំព័រ ៩-១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣-៥, ERN (ភាសាខ្មែរ) 00204740-00204742។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឿន តាន ឯកសារ E3/33 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧-៩, ERN (ភាសាខ្មែរ) 00231804-00231806។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង ឈឿង ឯកសារ E3/385 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00357213-00357214។

[៦៦៦] ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ - ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ៨-១១, ERN (ភាសាខ្មែរ) 00065948-00065951។

[៦៦៧] ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ១៥-១៦។

[៦៦៨] ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/475 គ្មានចុះកាលបរិច្ឆេទ ERN P 00000002។ ផែនទីកម្ពុជាប្រជាធិប-តេយ្យ ឯកសារ E3/476 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។

[៦៦៩] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស សារិន ឯកសារ E3/4596 ចុះថ្ងៃទី ០៥-០៦ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៥៨-៥៩, ERN (ភាសាខ្មែរ) 00482818-00482819។ បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4005 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00785295-00785296។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/475 គ្មានចុះកាលបរិច្ឆេទ ERN P 00000002។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារE3/476 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។

និរតី (លេខកូដ ៤០៥[៦៧០]) ភូមិភាគបូព៌ា (លេខកូដ ២០៣[៦៧១]) និងភូមិភាគពិសេស (ដែលរួមទាំងតំបន់នៅជុំវិញទីក្រុងភ្នំពេញ[៦៧២])។

២១៦. ក្រោយពីចូលកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៧៥ ព្រំប្រទល់ភូមិភាគត្រូវបានបែងចែកជាថ្មីឡើងវិញ។ ភូមិភាគបស្ចិមថ្មី (លេខកូដ ៤០១) ត្រូវបានបង្កើតបន្ថែម ហើយភូមិភាគពិសេសនៅជុំវិញទីក្រុងភ្នំពេញ ត្រូវបានរំលាយចោល និងកាត់បញ្ចូលទៅក្នុងភូមិភាគជិតខាងផ្សេងៗ[៦៧៣]។ ភូមិភាគទាំងអស់មិនបានកំណត់យកព្រំប្រទល់ខេត្តដែលមានស្រាប់ឲ្យបានច្បាស់លាស់នោះទេ។ ឧទាហរណ៍ ភូមិភាគបូព៌ា គ្របដណ្តប់ខេត្ត ព្រៃវែង និងស្វាយរៀង និងផ្នែកខ្លះនៃ

---

[៦៧០] ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/475 គ្មានចុះកាលបរិច្ឆេទ ERN P 00000002។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/476 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។

[៦៧១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន) ទំព័រ ២៨-២៩។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ១៨-១៩។

[៦៧២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៥៩-៦០។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៨៣-៨៤, ERN (ភាសាខ្មែរ) 00324754-00324755 ។ អត្ថបទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៦ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00062454-00062455។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣២-១៣៥ ERN (ភាសាខ្មែរ) 00637487-00637490។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៣២-២៣៣, ERN (ភាសាខ្មែរ) 00232230-00232231។

[៦៧៣] ប្រតិចារឹកថ្ងៃទី០៨ ខែ តុលា ឆ្នាំ ២០១២(មាស ហឿន)ទំព័រ២៩។ ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00065950-00065951។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/475 គ្មានចុះកាលបរិច្ឆេទ ERN P 00000002។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/476 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៣៥-២៣៦, ERN (ភាសាខ្មែរ) 00232233-00232234។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៤៣-១៤៤ ERN (ភាសាខ្មែរ) 00637498-00637499។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឯកសារ E3/73 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00486476-00486477 (លើកឡើងថា “ម-៤០១” គឺជាមន្ទីររបស់ តា ស៊ី លេខាភូមិភាគបស្ចិម។ សូមមើលផងដែរ កថាខណ្ឌ ២២ ខាងក្រោម)។ សូមមើលផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០ ។

ខេត្តក្រចេះ កណ្ដាល និងកំពង់ចាម[៦៧៤]។ នៅឆ្នាំ ១៩៧៥ ក៏មានតំបន់ និងទីក្រុងស្វយ័តមួយចំនួន ឬតំបន់ "ដែលត្រូវបានចាត់តាំងជាពិសេស" ដូចជា ព្រះវិហារ (លេខកូដ ១០៣) មណ្ឌលគីរី (លេខ-កូដ ១០៥) សៀមរាប-ឧត្ដរមានជ័យ (លេខកូដ ១០៦) ក្រចេះ (លេខកូដ ៥០៥) និងកំពង់សោម ដែលមិនស្ថិតនៅក្នុងភូមិភាគណាមួយឡើយ ហើយដែលត្រូវទំនាក់ទំនងការងារដោយផ្ទាល់ទៅមជ្ឈិមបក្ស[៦៧៥]។ ក្រោយមក ការកែប្រែរចនាសម្ព័ន្ធក៏ត្រូវបានធ្វើឡើងនៅក្នុង ឬអំឡុងឆ្នាំ ១៩៧៧៖ ភូមិភាគឧត្ដរថ្មី (លេខកូដ ៨០១) ត្រូវបានបង្កើតឡើងចេញពីតំបន់ស្វយ័តចាស់នៃព្រះវិហារ និង សៀមរាប-ឧត្ដរមានជ័យ ហើយភូមិភាគឧត្ដរចាស់ ត្រូវបានដាក់ឈ្មោះជា "ភូមិភាគកណ្ដាល"[៦៧៦]។

២១៧. ភូមិភាគនីមួយៗត្រូវបានបែងចែកទៅជាតំបន់មួយចំនួន ដែលត្រូវបានគេស្គាល់ជាទូទៅតាមរយៈលេខកូដរបស់តំបន់ទាំងនោះ[៦៧៧]។ តំបន់ត្រូវបានបែងចែកបន្តទៅជាស្រុក ហើយស្រុក

---

[៦៧៤] ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ - ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00065950-00065951។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/476 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។

[៦៧៥] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ ( យុន គីម) ទំព័រ ២៣-២៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤៦-៤៧។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៩។ ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ - ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00065950-00065951។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/475 គ្មានចុះកាលបរិច្ឆេទ ERN P 00000002។ ផែនទីកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/476 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00193066។ សូមមើលផ្នែកទី ៧ ស្ដីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១២ ។ ផ្នែកទី ៨ ស្ដីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៥ ។

[៦៧៦] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៦។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ស្នួន កានិល) ទំព័រ ៤៥-៤៦។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១០។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ូ) ទំព័រ ២៧-២៨។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រុំ ស៊ូ ឯកសារ E3/420 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ៦, ERN (ភាសាខ្មែរ) 00407775-00407776, 00407778។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង គឹមអឿន ឯកសារលេខ E3/425 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418569 ។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៣៥-២៣៦, ERN (ភាសាខ្មែរ) 00232233-00232234។

[៦៧៧] លក្ខន្តិកៈបក្សកុម្មុយនីស្ត ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣២-៣៤, មាត្រា ៧ ERN (ភាសាខ្មែរ) 00442269-00442270។ ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ - ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00065950-00065951។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១១-១២។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖*

ត្រូវបានបែងចែកទៅជាអង្គភាពឃុំ ក្នុងនោះរួមមានទាំងភូមិ[៦៧៨]។ ភូមិនីមួយៗនៅក្នុងឃុំ ត្រូវបានដាក់បញ្ចូលគ្នាជាបន្តបន្ទាប់ទៅជាសហករណ៍ ដែលជាកន្លែងប្រជាជនរស់នៅ ធ្វើការងារ និងហូបរួមគ្នា[៦៧៩]។ នៅកន្លែងខ្លះ សហករណ៍ត្រូវបានចាត់ទុកជាអង្គភាពចំណុះរបស់ឃុំ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការឃុំ[៦៨០]។ ប៉ុន្តែ នៅកន្លែងខ្លះទៀត សហករណ៍ធំត្រូវបានដាក់ជំនួសដោយឃុំ ដែលជាតំបន់រដ្ឋបាលថ្នាក់ក្រោមបំផុតនៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា[៦៨១]។

---

*ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣៦-១៣៧, ERN (ភាសាខ្មែរ) 00637491-00637492។

[៦៧៨] លក្ខន្តិកៈបក្សកុម្មុយនីស្ត ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣២-៣៤, មាត្រា ៧ ERN (ភាសាខ្មែរ) 00442269-00442270។ ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ - ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១២, ERN (ភាសាខ្មែរ) 00065950-00065952។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១១-១២។ អត្ថបទរបស់ S. Heder និង M. Matsushita៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ១៩៨០ ទំព័រ ៣, ERN (ភាសាអង់គ្លេស) 00170694។

[៦៧៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ក្លាន ហ្វីត) ទំព័រ ៧២។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ២១-២២។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៧-៦៨។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ូ) ទំព័រ ៧-៨។ ក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ឯកសារ E3/1398 ឆ្នាំ ១៩៧៧ ទំព័រ ១០-១២, ERN (ភាសាខ្មែរ) 00065950-00065952។

[៦៨០] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (Francois PONCHAUD) ទំព័រ ១៣-១៤ ។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃឹម បុាំង ឯកសារ E3/5510 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣, ERN (ភាសាខ្មែរ) 00402492 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភ្នៅ យ៉ាវ ឯកសារ E3/5515 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤, ERN (ភាសាខ្មែរ) 00402457 ។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៤០-៤១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ ខុន ឯកសារ E3/5506 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣, ERN (ភាសាខ្មែរ) 00398487 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នុត នូវ ឯកសារ E3/5521 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៩-១០, ERN (ភាសាខ្មែរ)00408297-00408298 (ដែលបញ្ជាក់អះអាងថា មេដឹកនាំសហករណ៍មានភាពខុសគ្នាពីថ្នាក់ដឹកនាំឃុំ) ។

[៦៨១] ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៥-៧។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១២-១៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម ឯកសារ E3/368 ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00340150-00340151។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៦

២១៨. ឋានានុក្រមគ្រប់កំរិតទាំងអស់ ដែលមានភូមិភាគ តំបន់ ស្រុក ឃុំ និងសហករណ៍ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការ[៦៨២]។ ជាធម្មតា គណៈកម្មាធិការមានលេខាមួយរូប (ឬប្រធាន) អនុលេខាមួយរូប (ឬអនុប្រធាន) និងយ៉ាងហោចណាស់ក៏មានសមាជិកមួយរូបទៀតដែរ[៦៨៣]។ ជាញឹកញាប់ នៅក្នុងគណៈកម្មាធិការនីមួយៗ ការទទួលខុសត្រូវខាងគោលនយោបាយសំខាន់ៗត្រូវបានផ្តល់ទៅឲ្យសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនីមួយៗ[៦៨៤]។ជាទូទៅ

---

ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៤៩ (ដែលលើកឡើងថា សហករណ៍ទទួលការណែនាំផ្ទាល់ពីថ្នាក់ស្រុក)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ១៩-២០ (យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទឹម រិទ្ធី ឯកសារ E3/4828) (ដែលបញ្ជាក់ថា ឃុំ និងសហករណ៍ គឺ “ដូចគ្នា”។ អត្ថបទរបស់ Timothy Carney “ការរៀបចំចាត់ចែងអំណាច” នៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៥-១៩៧៩៖ ការណាត់ជួបនឹងមរណៈ ឯកសារ E3/49 ទំព័រ ៨៥, ERN (ភាសាអង់គ្លេស) 00105137។

[៦៨២] លក្ខន្តិកៈបក្សកុម្មុយនីស្ត ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣២-៣៤ មាត្រា ៧, ERN (ភាសាខ្មែរ) 00442269-00442270។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៦៥-៦៦។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១១-១៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៣៦-៣៧, ៤៩។ ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ៣១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ឯកសារ E3/411 ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00373508-00373509។

[៦៨៣] ប្រតិចារឹកថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០១១(ក្លាន ហ្វីត) ទំព័រ៤៦-៤៨។ ប្រតិចារឹក ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៧៤។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៤៦-៤៧, ៥៤។ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ូ) ទំព័រ ១៤-១៦។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឯកសារ E3/80 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00486471-00486472 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឯកសារ E3/4628 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00373386-00373387។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣២-១៤២, ERN (ភាសាខ្មែរ) 00637487-00637497។

[៦៨៤] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ុក ប៊ុនឈឿន ឯកសារ E3/387 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00379483-00379484។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ឡឹងចូយ ឯកសារ E3/5178 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ១១-១២, ERN (ភាសាខ្មែរ) 00197865-00197866។ របាយការណ៍អ្នកជំនាញការរបស់ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ២៤-២៦, ERN (ភាសាខ្មែរ) 00314801-00314803។

លេខាគណៈកម្មាធិការនៅថ្នាក់នីមួយៗត្រូវបានតែងតាំងដោយគណៈកម្មាធិការថ្នាក់លើបន្ទាប់[៦៨៥]។ ឧទាហរណ៍ លេខាឃុំត្រូវតែងតាំងដោយគណៈកម្មាធិការស្រុក[៦៨៦] ហើយលេខាស្រុកត្រូវតែងតាំងដោយគណៈកម្មាធិការតំបន់[៦៨៧]។ ជាគោលការណ៍ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ឲ្យគណៈកម្មាធិការទាំងអស់ធ្វើការប្រជុំនៅក្នុងចន្លោះពេលមួយទៀងទាត់ដើម្បីជ្រើសតាំងសមាជិកថ្មី ប៉ុន្តែជាទូទៅ នៅក្នុងការអនុវត្តជាក់ស្តែង សមាជិកគណៈកម្មាធិការ (ដូចជាលេខា) ត្រូវបានតែងតាំងដោយគណៈកម្មាធិការថ្នាក់លើបន្ទាប់[៦៨៨]។

២១៩. ជាទូទៅ លេខាគណៈកម្មាធិការនៅតាមថ្នាក់នីមួយៗក៏ជាសមាជិកមួយរូបផងដែរ (ឬយ៉ាងហោចណាស់បានចូលរួមប្រជុំ) នៅក្នុងគណៈកម្មាធិការថ្នាក់លើបន្ទាប់ ដូច្នេះ លេខាឃុំត្រូវចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការស្រុក[៦៨៩] លេខាស្រុកត្រូវចូលរួមប្រជុំនៅក្នុង

---

[៦៨៥] ប្រតិចារឹកសវនាការលើសំណុំរឿង ០០១ (Craig ETCHESON) ឯកសារ E3/345 ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៥៣ ERN (ភាសាខ្មែរ) 00328700។

[៦៨៦] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ក្លាំង ហ្វឿត) ទំព័រ ៤២-៤៣ (លើកឡើងថា គាត់ត្រូវបានប្រធានស្រុក និងគណៈកម្មាធិការភូមិភាគតែងតាំងធ្វើជាប្រធានឃុំ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (រ៉ូម៉ាំ យុន) ទំព័រ ៣៤-៣៥។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៣។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៧៤-៧៥។ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ ៧៤-៧៥។ សៀវភៅនិពន្ធដោយ B. Kiernan៖ *តើ ប៉ុល ពត ចូលកាន់អំណាចបែបណា?* ដើមកំណើតកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ១៩៣០-១៩៧៥ ឯកសារ E3/1815 ទំព័រ ៤០១-៤០២, ERN (ភាសាខ្មែរ) 00104874-00104875។

[៦៨៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៦៧-៦៨, ៧៣-៧៤។

[៦៨៨] លក្ខន្តិកៈបក្សកុម្មុយនីស្ត ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣៨-៤៥ មាត្រា ១១, ១២, ១៥ និង ១៨, ERN (ភាសាខ្មែរ) 00442272-00442275។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី សួន ឯកសារ E3/1675 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00391854-00391855 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច ឯកសារ E3/5293 ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ២-៤, ERN (ភាសាខ្មែរ) 00348839-00348841 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន ឯកសារ E3/5294 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00348828-00348829 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ឯកសារ E3/5498 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00368599-00368600 ។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១៥-១៦។

[៦៨៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១០-១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សារ៉ាយ ហៀន ឯកសារ E3/5608 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00486494-00486495 ។

កិច្ចប្រជុំរបស់គណៈកម្មាធិការតំបន់[៦៩០] ហើយលេខាតំបន់ត្រូវចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការភូមិភាគ[៦៩១]។ ជាឧម្មតា លេខាភូមិភាគ ដូចជា មូល សម្បត្តិ *ហៅ* រស់ ញឹម (លេខាភូមិភាគពាយ័ព្យ) គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម[៦៩២]។ លេខាខ្លះទៀត ដូចជា សោ ភឹម (លេខាភូមិភាគបូព៌ា) និង តា ម៉ុក (លេខាភូមិភាគនិរតី) ក៏ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ[៦៩៣]។

[៦៩០] ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន), ទំព័រ ៣៨-៣៩។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន), ទំព័រ ៦៤-៦៥.។

[៦៩១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ឯកសារ E3/4593 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០ ទំព័រ២-៣ ERN (ភាសាខ្មែរ) 00485621-00485622 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឯកសារ E3/4628 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00373386-00373387។

[៦៩២] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា), ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១១-១២។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៨០ ទំព័រ ៩៤-៩៥ ERN (ភាសាខ្មែរ) 00324765-00324766។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៧២ (បានបញ្ជាក់ថា រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យ)។ ប្រតិចារឹក ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី), ទំព័រ ៦៨-៦៩ (បានផ្តល់ឈ្មោះពិតរបស់ រស់ ញឹម)។ រស់ ញឹម ក៏ជាអនុប្រធានទីពីរនៃគណៈប្រធានរដ្ឋ រហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួនបញ្ជូនទៅ ស-២១ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨៖ សូមមើល កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៤៦-៤៨ ERN (ភាសាខ្មែរ) 00053634-00053635។ ចម្លើយសារភាព ស-២១ – រស់ ញឹម ឯកសារ E3/3989 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៨។

[៦៩៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា), ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (ខៀវ នៅ), ទំព័រ ៨១-៨២។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ៣៦-៣៧។ ប្រតិចារឹក ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ (ស វិ), ទំព័រ ៦២-៦៤។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨ ERN (ភាសាខ្មែរ) 00156619។ *សូមមើល* ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល ជើងទំព័រ ៦២០ និង ៦២១។ សោ ភឹម ក៏ជាអនុប្រធានទី ១ នៃគណៈប្រធានរដ្ឋ រហូតដល់ពេលគាត់ស្លាប់ អាចថាដោយសារតែការធ្វើអត្តឃាតនៅពាក់កណ្តាលឆ្នាំ ១៩៧៨៖ *សូមមើល* កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៤៦-៤៧ ERN (ភាសាខ្មែរ) 00053634។ ប្រតិចារឹកសវនាការលើសំណុំរឿង ០០១ (កាំង ហ្គេកអ៊ាវ) ឯកសារ E3/5797 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥៦-៥៧ ERN (ភាសាខ្មែរ) 00338805-00338806។ សៀវភៅនិពន្ធដោយ

២២០. លេខាភូមិភាគផ្សេងទៀតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដូចជា ជូ ជេត *ហៅ* ស៊ី ដែលបានបម្រើការងារជាលេខាភូមិភាគបស្ចិម រហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧៨[៦៥៤]។ កែ វិន *ហៅ* កែ ពក បានជំនួស កុយ ធួន ជាលេខាភូមិភាគឧត្តរចាស់ (ក្រោយមកបានប្តូរទៅជាលេខាភូមិភាគកណ្តាល) នៅក្នុងឆ្នាំ ១៩៧៥[៦៥៥]។ ចាន់ សំ *ហៅ* កង ចាប *ហៅ* សែ បានបម្រើការងារជាលេខាភូមិភាគឧត្តរថ្មីរហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧៨[៦៥៦]

---

ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៨៩-៤៩០ ERN (ភាសាខ្មែរ) 00191794-00191795។

[៦៥៤] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន), ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៩៨។ ប្រតិចារឹក ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន), ទំព័រ ៩ (បានបញ្ជាក់ថា ជូ ជេត បានប្រើឈ្មោះក្រៅ 'ស៊ី' ឬ 'តា ស៊ី')។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គីម ឯកសារ E3/422 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00407755-00407756។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុល សុគន្ធ ឯកសារ E3/5202 ចុះថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ២-៣ ERN (ភាសាខ្មែរ) 00212095-00212096។ សៀវភៅនិពន្ធដោយ D. Chandler៖ *សំឡេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ៨៣-៨៤ ERN (ភាសាខ្មែរ) 00191911-00191912។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣៦-១៣៧ ERN (ភាសាខ្មែរ) 00637491-00637492។

[៦៥៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ឯកសារ E3/344 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00373494-00373495។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៤០។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ៣១-៣២ (បានបញ្ជាក់បំភ្លឺថា កែ វិន ក៏មានឈ្មោះថា កែ ពក ផងដែរ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សារ៉ាយ ហៀន ឯកសារ E3/5608 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00486495-00486496។ របាយការណ៍អ្នកជំនាញការរបស់ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ១៨-១៩ ERN (ភាសាខ្មែរ) 00314795-00314796។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣៩-១៤០ ERN (ភាសាខ្មែរ) 00637494-00637495។

[៦៥៦] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រំ ស៊ូ), ទំព័រ ២៦។ ចម្លើយសារភាព ស-២១ – ចាន់ សំ *ហៅ* សែ, ឯកសារ E3/2792, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៧៨។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ថ្ងៃទី ១២ ខែ មីនា ឆ្នា ១៩៨០ ទំព័រ ៨៨-៨៩ ERN (ភាសាខ្មែរ) 00324759-00324760។ បទសម្ភាសន៍របស់ SOAS ជាមួយ ខៀវ សំផន ឯកសារ E3/198 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00078213-00078214។ សៀវភៅនិពន្ធដោយ M. Vickery៖ *កម្ពុជា ឆ្នាំ ១៩៧៥-១៩៨២* ឯក-សារ E3/1757 ទំព័រ ៥-៦ ERN

និង ម៉ែន សាន *ហៅ* នៃ សារ៉ាន់ *ហៅ* យ៉ា បានបម្រើការងារជាលេខាភូមិភាគឦសានរហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួន និងអាចត្រូវបានជំនួស ដោយអនុលេខារបស់គាត់គឺ អ៊ុំ ណេង *ហៅ* វី[៦៩៧]។

### ៥.១.៨ អង្គការ

២២១. *ពាក្យថា* "*អង្គការ*" ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយចាប់តាំងពីថ្ងៃដំបូងៗនៃចលនាកុម្មុយនីស្តកម្ពុជា ដោយសំដៅទៅលើបក្ស ដែលក្រោយមកក្លាយជាបក្សកុម្មុយនីស្តកម្ពុជា[៦៩៨]។ *ទោះបីជាយ៉ាងណាក៏ដោយ ពាក្យថា អង្គការ នេះ មិនខុសគ្នាពីពាក្យថា "មជ្ឈិមបក្ស" នោះទេ គឺជាពាក្យមួយដែលពិបាកយល់ និងមានភាពស្រពិចស្រពិល*[៦៩៩]។ *ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន* បានហៅគណៈកម្មាធិការដែលត្រូវបានតែងតាំងដោយឃុំនៅតាមមូលដ្ឋានថាជា

---

(ភាសាខ្មែរ) 00710229-00710230។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ៥៣០-៥៣១ ERN (ភាសាខ្មែរ) 00637885-00637886។

[៦៩៧] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ១៩ (បានផ្តល់សក្ខីកម្មថា នៃ សារ៉ាន់ *ហៅ* យ៉ា គឺជាលេខាភូមិភាគឦសាន)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន), ទំព័រ ២-៣ (បានលើកឡើងថា'យ៉ា' គឺជាមេដឹកនាំនៅភូមិភាគឦសាន)។ ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦០(បានបញ្ជាក់បំភ្លឺថា'យ៉ា'ក៏មានឈ្មោះក្រៅ នៃ សារ៉ាន់ ផងដែរ)។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជិន គឹមថុង ឯកសារ E3/406 ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00401332 (បានលើកឡើងថា 'យ៉ា' ដឹកនាំភូមិភាគឦសានរហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួន)។ កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ នៅចំពោះមុខតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជា ឯកសារ E3/530 ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០២ ទំព័រ ១ ERN (ភាសាខ្មែរ) 00095688 (បានបញ្ជាក់ថា ម៉ែន សាន *ហៅ* យ៉ា គឺជាលេខាភូមិភាគឦសានរហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួន)។ របាយការណ៍អ្នកជំនាញការរបស់ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ១៨-១៩ ERN (ភាសាខ្មែរ) 00314795-00314796 (បានបញ្ជាក់ថា ម៉ែន សាន ត្រូវបានគេសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៧ និងជំនួសដោយ អ៊ុម ណេង [អ៊ុំ ណេង])។ សៀវភៅនិពន្ធដោយ B.Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៣៨-១៤០ ERN (ភាសាខ្មែរ) 00637493-00637495 (បានលើកឡើងថា អ៊ុំ ណេង បានជំនួស នៃ សារ៉ាន់ ជាលេខាភូមិភាគឦសាននៅក្នុងឆ្នាំ ១៩៧៥)។

[៦៩៨] ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៤៧-៤៨.។

[៦៩៩] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ២៧។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម),ទំព័រ៦៨-៧១ (បានរៀបរាប់ការយល់ឃើញខុសៗគ្នាអំពីពាក្យ 'អង្គការ')។

"អង្គការ"[៧០០]។ ប៉ុន្តែ សម្រាប់អ្នកផ្សេងទៀត "អង្គការ" គឺជាពាក្យសម្ងាត់សំដៅទៅលើថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា[៧០១]។ សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច បានលើកឡើងថា នៅពេលគាត់ប្រើពាក្យ "អង្គការ" គឺគាត់សំដៅទៅលើ *"នេះ សំដៅថា ប៉ុល ពត។ ហើយនិយាយមួយម៉ាត់ ចំពោះខ្ញុំ ខ្ញុំប្រើអង្គការនេះ សំដៅអចិន្ត្រៃយ៍មជ្ឈិមបក្ស។ បុគ្គលណាមួយដែលចុះមកដឹកនាំខ្ញុំក្នុងតំណាង ប៉ុល ពត គឺជាអចិន្ត្រៃយ៍មជ្ឈិមបក្ស"* គាត់បានលើកឡើង បន្ថែមទៀតថា អ្នកផ្សេងបានប្រើប្រាស់ពាក្យនេះខុសពីន័យរបស់វា[៧០២]។ ពេលខ្លះ ពាក្យថា "អង្គការ" នៅក្នុងឯកសារមួយគឺសំដៅទៅលើសមាជិកជាន់ខ្ពស់ណាម្នាក់នៃបក្សកុម្មុយនីស្តកម្ពុជា ដូចជា សុន សេន ឬ ប៉ុល ពត[៧០៣]។ សាក្សី សូត្រ ទឿង បានផ្តល់សក្ខីកម្មថា តាមគាត់យល់ "អង្គការ" មានន័យថា ប៉ុល ពត ឬ នួន ជា[៧០៤]។ ការដែលបុគ្គលមួយចំនួន និង "សមាសភាពមិនល្អ" ហៅខ្លួនឯងថាជា "អង្គការ" បានជំរុញឲ្យគណៈកម្មាធិការ ៨៧០ ចេញសេចក្តីណែនាំមួយនៅក្នុងឆ្នាំ ១៩៧៧ ដោយមានអត្ថន័យដូចខាងក្រោម៖

> ១. ពាក្យថា "អង្គការ" ឬ "បក្ស" ត្រូវបានប្រើប្រាស់សម្រាប់តែអង្គការចាត់តាំងប៉ុណ្ណោះ។ ពាក្យនេះ មិនត្រូវប្រើសំរាប់បុគ្គលឡើយ។
>
> ២. ចំពោះបុគ្គល ត្រូវប្រើពាក្យថា "សមមិត្ត" "ឈ្មោះនេះ" ឬ "សមមិត្តនៅក្នុងតំណែងនេះ ឬតំណែងនោះ" ឬ "សមមិត្តតំណាងអង្គការ ថ្នាក់នេះ ថ្នាក់នោះ"[៧០៥]។

---

[៧០០] ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១ (រ៉ម៉ាម យុន), ទំព័រ ១២-១៣។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិត្យ សុខុម ឯកសារ E3/382 ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00342563 (ហៅលេខាស្រុកថាជា 'អង្គការ')។

[៧០១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ប៊ាន ឯកសារ E3/5518 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00408315 ("ខ្ញុំទើបតែបានស្តាប់ឮថា អង្គការគឺជាថ្នាក់លើដែលបានដាក់ចេញផែនការឲ្យយើងអនុវត្ត")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ផេន ឯកសារ E3/445 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១០ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00492979-00492980 (បានចាត់ទុកអង្គការថាជា "ថ្នាក់លើរបស់ខ្មែរក្រហម" ចាប់ពីថ្នាក់ស្រុកឡើងទៅលើ)។

[៧០២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ១១-១៣។

[៧០៣] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ២៧-២៨។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ៥៥-៥៦។

[៧០៤] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទឿង), ទំព័រ ៥៩-៦០។

[៧០៥] សេចក្តីណែនាំរបស់គណៈ ៨៧០ ឯកសារ E3/740 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៧៧។

២២២. ទោះបីជាយ៉ាងនេះក្តី វាពុំមានភាពច្បាស់លាស់នោះទេដែលថាតើសេចក្តីណែនាំនេះត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមប្រជាជនសាមញ្ញក្នុងកម្រិតណានោះ។ ទោះបីជាសាក្សី ពេជ្រ ជឹម អតីតលេខាស្រុកបានចងចាំថា គាត់បានអប់រំប្រជាជនថា *"មិនមែនអង្គការទេយើងនោះ យើងបុគ្គលទេ"* វាពុំមានភាពច្បាស់លាស់សោះថាតើការអប់រំនេះគឺដោយសារតែសេចក្តីណែនាំឬយ៉ាងណានោះទេ ហើយច្បាស់ណាស់ថា សាក្សីជាច្រើននាក់ដែល ក.ស.ច.ស បានស្តាប់ចម្លើយពុំដែលក្តាប់ន័យ "អង្គការ" បានពេញលេញនោះទេ ទាំងនៅពេលមុន ឬ ក្រោយឆ្នាំ ១៩៧៧[៧០៦]។

## ៥.១.៩ ប្រជាធិបតេយ្យប្រមូលផ្តុំ

២២៣. និយាយជារួម បក្សកុម្មុយនីស្តកម្ពុជាត្រូវបានរៀបចំឡើងស្របតាមគោលការណ៍ "ប្រជាធិបតេយ្យប្រមូលផ្តុំ"។ ដូចបានកំណត់នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ទស្សនទាននេះមានពីរចំណុច។ ចំណុចទីមួយ សេចក្តីសម្រេចទាំងឡាយត្រូវធ្វើឡើងតាមបែបប្រជាធិបតេយ្យ ពោលគឺការសម្រេចត្រូវធ្វើឡើងដោយសមូហភាព ពុំមែនដោយបុគ្គលនោះទេ[៧០៧]។ ជារចនាសម្ព័ន្ធ

---

[៧០៦] ប្រតិចារឹក ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម), ទំព័រ ៧០-៧១។ *សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន លឿត ឯកសារ E3/5226 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00242230 ("ខ្ញុំមិនដឹងថាអង្គការនោះជាអ្វីទេ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មៀច ប៉ុណ្ណ ឯកសារ E3/5523 ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ៣-៤ ERN(ភាសាខ្មែរ) 00414424-00414425 ("នៅពេលនោះ ខ្ញុំមិនបានដឹងថានរណាជាអង្គការ ឬ គណៈកម្មាធិការមជ្ឈិមនោះទេ") ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុច ភ្លឹ ឯកសារ E3/5213 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00221591 ("ខ្ញុំមិនបានដឹងថានរណាជាអង្គការនោះទេ") ។ កំណត់ហេតុសួរចម្លើយ ជុំ ម៉ាញ ដោយសហព្រះរាជអាជ្ញា ឯកសារ E3/5690 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00145559-00145560 ("ពីដំបូង ខ្ញុំមិនដឹងថាអ្វីទៅអង្គការនោះទេ") ។ កំណត់ហេតុនៃការស្តាប់ចម្លើយ សួង ស៊ឹម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00349500-00349501 ("ខ្ញុំមិនបានដឹងនៅពេលនោះថានរណាជាអង្គការនោះទេ") ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិច សុខា ឯកសារ E3/403 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00389522 (បានពិភាក្សាអំពីអំឡុងពេលក្រោយឆ្នាំ ១៩៧៧ ហើយបានលើកឡើងថា "ខ្ញុំមិនបានដឹងថានរណាជា*អង្គការ*នោះទេ។ ខ្ញុំគ្រាន់តែបានឮពាក្យ*អង្គការ*") ។ កំណត់ហេតុនៃការស្តាប់ចម្លើយ គៀង វណ្ណារី ឯកសារ E3/5310 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១២ ERN (ភាសាខ្មែរ) 00349492 ("សៈ តើពាក្យថា អង្គការមានន័យយ៉ាងដូចម្តេចចំពោះអ្នកស្រី? ឆៈ ខ្ញុំអត់ដឹងទេ។ ខ្ញុំឮគេហៅថា អង្គការ ខ្ញុំក៏ហៅតាមគេទៅ") ។

[៧០៧] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣០-៣១ មាត្រា ៦ ERN (ភាសាខ្មែរ) 00442268។

01006508



ចំណុចនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈវត្តមានរបស់គណៈកម្មាធិការនៅគ្រប់ទីកន្លែងនៃឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា។ ចំណុចទីពីរ សេចក្តីសម្រេចទាំងឡាយត្រូវធ្វើឡើងដោយថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ដែលស្ថាប័ននេះទទួលសេចក្តីរាយការណ៍ផ្សេងៗពីថ្នាក់ក្រោម និងផ្តល់ការណែនាំទៅថ្នាក់ក្រោមផងដែរ[៧០៨]។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធដឹកនាំដែលមានទម្រង់ជាពីរ៉ាមីតរបស់បក្ស ដោយមានអំណាចប្រមូលផ្តុំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍តូចមួយ ដែលគ្រប់ជាន់ថ្នាក់ទាំងអស់ផ្សេងទៀតដំណើរការ នៅពីក្រោមគណៈកម្មាធិការនេះ។

២២៤. ក្រុមមេធាវីការពារក្តី នួន ជា បានជំទាស់ថា នៅទីបំផុត គឺ ប៉ុល ពត មិនមែនគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងមូលនោះទេ ដែលជាអ្នកទទួលខុសត្រូវលើសេចក្តីសម្រេចទាំងឡាយដែលទំនងជាចេញមកពីគណៈកម្មាធិការអចិន្ត្រៃយ៍[៧០៩]។ ប៉ុន្តែ ចំណុចនេះផ្ទុយនឹងសក្ខីកម្មផ្ទាល់របស់ជនជាប់ចោទ នួន ជា ដោយគាត់បានលើកឡើងយ៉ាងច្បាស់ថា គោលការណ៍នៃការធ្វើសេចក្តីសម្រេចជាសមូហភាពត្រូវបានអនុវត្ត "នៅគ្រប់កាលៈទេសៈទាំងអស់" នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងជាពិសេស នៅក្នុងពេលប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ដែលគាត់មានវត្តមាន[៧១០]។ ដូចដែលជនជាប់ចោទ នួន ជា បានពន្យល់ជូនអង្គជំនុំជម្រះ៖

> "សមូហភាព" បានន័យថា ប្រជុំរួមគ្នាទាំងអស់ មានមតិជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រជុំអីក៏អញ្ចឹងដែរ។ មិនមែនត្រឹមតែប្រជុំមជ្ឈិម ប្រជុំអចិន្ត្រៃយ៍ទេ ហើយលេខាអចិន្ត្រៃយ៍ ឬ លេខាមជ្ឈិមបក្សជាអ្នកសរុប បើកាលណាសរុបហើយមិនពេញចិត្តអង្គប្រជុំៗមានសិទ្ធិដើម្បីមានមតិតទៅទៀត ឬ មានមតិតវ៉ារហូតដល់កាលណាឯកភាពគ្នាជាផ្លុងមួយ ជាសមូហភាព ឯកភាពគ្នាជាផ្លុងមួយ ទើបចាត់ទុកជាបានការ។ បើមិនទាន់ឯកភាពគ្នាទេ ពិភាក្សាគ្នាតទៅទៀត។

ស្រដៀងគ្នានេះដែរ នៅពេលសួរសំណួរនៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ ២០០៦ អំពីថាតើ ប៉ុល ពត មានអំណាចផ្តាច់មុខតែម្នាក់ឯងនៅសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ ជនជាប់ចោទ នួន ជា បានច្រានចោលការលើកឡើងដូច្នេះ ហើយបានលើកឡើងថា សេចក្តីសម្រេចត្រូវបានធ្វើឡើងជា

---

[៧០៨] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣០-៣១ មាត្រា ៦ ERN (ភាសាខ្មែរ) 00442268។

[៧០៩] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា កថាខណ្ឌ ១៨៩។

[៧១០] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៣៣-៣៦។

សម្ហូហភាព[៧១១]។

២២៥. ជនជាប់ចោទ ខៀវ សំផន ក៏បានបញ្ជាក់ផងដែរថា សេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើជាសម្ហូហភាព។ ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គាត់បាននិយាយថា "បើមានសំឡេងតែមួយប្រឆាំងមិនឲ្យជម្លៀស ក៏អត់ជម្លៀសកើតទេ"[៧១២]។ ក៏ប៉ុន្តែ អៀង សារី បានអះអាងថា មតិជំទាស់របស់គាត់ខ្លួនឯងផ្ទាល់ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ឈប់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការឈានទៅលុបបំបាត់លុយនៅក្នុងឆ្នាំ ១៩៧៥ នោះទេ[៧១៣]។

២២៦. អ្នកជំនាញ David CHANDLER បានផ្តល់សក្ខីកម្មថា ទោះបីជា ប៉ុល ពត អាចជាអ្នក "មានសិទ្ធិចុងក្រោយ" នៅក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមជាលេខាបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏គ្មានភ័ស្តុតាងណាមួយបង្ហាញថា គាត់បានធ្វើសេចក្តីសម្រេចតែម្នាក់ឯងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ៖

> មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថា គណៈអចិន្ត្រៃយ៍ភាគច្រើនបំផុត មិនធ្វើការជាផ្តុំមួយនោះទេ។ ខ្ញុំនិយាយថា "ភាគច្រើនបំផុត" ព្រោះសមាជិកមួយចំនួនត្រូវគេយកទៅវាយចោលហើយ ប៉ុន្តែ មិនមានភ័ស្តុតាងណាមួយបញ្ជាក់ថា មានការខ្វែងគំនិតគ្នាណាមួយជាសាធារណៈដែល ប៉ុល ពត ជំទាស់ជាមួយអ្នកដទៃ ហើយគាត់ធ្វើការសម្រេចដោយឯកឯងនោះឡើយ។ បរិយាកាសពេលនោះ គឺសម្ហូហភាព។ គាត់មានសិទ្ធិអំណាចមែន ប៉ុន្តែ ខ្ញុំមិនមានភ័ស្តុតាងណាអាចយកមកបញ្ជាក់បានថា គាត់ប្រើសិទ្ធិអំណាចតែម្នាក់ឯង ហើយជំទាស់ទៅនឹងសមាជិកគណៈដឹកនាំរបស់គាត់ទេ[៧១៤]។

២២៧. អ្នកជំនាញ Philip SHORT បានពន្យល់អំពីការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងន័យមួយខុសពីនេះបន្តិច។ នៅក្នុងទស្សនៈរបស់គាត់ ប៉ុល ពត បានប្រមូលយកមតិយោបល់នានាពី

---

[៧១១] បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ជាភាសាខ្មែរ) 00000899។

[៧១២] បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4051 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00786555។

[៧១៣] អត្ថបទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤-៦ ERN (ភាសាខ្មែរ) 00062455-00062457។

[៧១៤] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ១៦-១៧។

សមាជិកផ្សេងៗនៅក្នុងពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយបានដាក់បញ្ចូលមតិយោបល់របស់ពួកគេនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ ប៉ុន្តែ *"គោលនយោបាយដែលចេញមក គឺជាគោល-នយោបាយមួយដែលភាគច្រើនបំផុត គាត់បានសម្រេចខ្លួនឯងរួចទៅហើយ តាំងពីមុនការប្រជុំចាប់ផ្តើមម្ល៉េះ"*[៧១៥]។

២២៨. ចំពោះភ័ស្តុតាងផ្តល់ជូនដោយជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ដែលជនជាប់ចោទទាំងអស់នេះមានវត្តមាន ឬបានចូលរួមនៅក្នុងពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នោះ អង្គជំនុំជម្រះជឿជាក់ថា សេចក្តីសម្រេចសំខាន់ៗរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ មិនមែនត្រូវបានធ្វើឡើងដោយ ប៉ុល ពត តែម្នាក់ឯងនោះទេ ផ្ទុយទៅវិញ សេចក្តីសម្រេចទាំងនេះត្រូវបានធ្វើឡើងជាសមូហភាព ដែលមានន័យថា មានមតិយោបល់ និងមានការឯកភាពជាឯកច្ឆន្ទពីគណៈ-កម្មាធិការទាំងមូល។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា គណៈកម្មាធិការត្រូវការការឯកភាពជាឯកច្ឆន្ទនៅក្នុងការសម្រេច ឬយ៉ាងណានោះទេ ហេតុដូច្នេះ អាចមានលទ្ធភាពថាមានពេលខ្លះ សមាជិកម្នាក់ៗអាចទំនងជាមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចជាក់លាក់ណាមួយផងដែរ។

## ៥.២ វចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ

២២៩. នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ នៅពេលក្រុងភ្នំពេញបានធ្លាក់ក្នុងកណ្តាប់ដៃរបស់កងកម្លាំងយោធានៃបក្សកុម្មុយនីស្តកម្ពុជា ហើយរបប លន់ នល់ បានដួលរំលំនោះ រដ្ឋាភិបាលបរទេសបានចាប់ផ្តើមបញ្ជូនការទទួលស្គាល់ការទូតជាផ្លូវការដល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[៧១៦]។ ការអញ្ជើញរបស់រដ្ឋាភិបាលអាមេរិកមកសម្តេច នរោត្តម សីហនុ ឱ្យវិលត្រឡប់មកប្រទេសកម្ពុជាជាបន្ទាន់ និងចូលគ្រងរាជអំណាច ពុំទទួលបានជោគជ័យនោះទេ ហើយមន្ត្រីការទូតអាមេរិកត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៥ ជាមួយនឹងនាយករដ្ឋមន្ត្រីស្តីទី

[៧១៥] ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៥៨។

[៧១៦] សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00862297-00862298។ *អត្ថបទគ្មានចំណងជើង៖ ប្រទេសស៊ុយអែតត្រូវបានទទួលស្គាល់ជាផ្លូវការ*... (កាសែត Washington Post), ឯកសារ E3/3296 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥។

ស្វខាំ ខូយ[៧១៧]។ នៅត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់នៃរបបសាធារណរដ្ឋ-ខ្មែរដែលនៅសេសសល់ស្ទើរតែទាំងអស់បានរត់គេចចេញពីប្រទេស ហើយបក្សកុម្មុយនីស្តកម្ពុជា ឬរណសិរ្សរួបរួមជាតិកម្ពុជា បានចូលកាន់កាប់អំណាចទាំងស្រុង[៧១៨]។

២៣០. ជាក់ស្តែង ការគ្រប់គ្រងប្រទេសដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅពេលដែលចូលកាន់អំណាចនៅក្នុងប្រទេសកម្ពុជាគឺគ្រាន់តែជារូបភាពបិទបាំងពីខាងក្រៅតែប៉ុណ្ណោះ។ ប៉ុន្តែតាមពិត បក្សកុម្មុយនីស្តកម្ពុជាឯណោះទេដែលគ្រប់គ្រងប្រទេសពិតប្រាកដនោះ[៧១៩]។ សម្តេច នរោត្តម សីហនុ បានមើលឃើញលទ្ធផលនេះតាំងតែពីរឆ្នាំមុនមកម្លេះ ដោយសម្តេចបានថ្លែងប្រាប់អ្នកចូលជួបសន្ទនាជាមួយព្រះអង្គនៅក្នុងប្រទេសចិនថា៖

---

[៧១៧] *សម្តេច សីហនុ ស្ងៀមស្ងាត់ ខណៈពេលកងកម្លាំងបដិវត្តន៍រង់ចាំខាងក្រៅទីក្រុងភ្នំពេញ* (កាសែត The Guardian) ឯកសារ E3/4422 ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00597538-00597540។ សៀវភៅនិពន្ធដោយ Léon Trivière: *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣៤ ERN (ភាសាខ្មែរ) 00538867។ *ទង់ជ័យសពាសពេញក្រុងភ្នំពេញ* (កាសែត Newsweek) ឯកសារ E3/3721 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) S 00655249-00655251។ *ជ្រុងខ្មៅងងឹតនៃសោកនាដកម្មកម្ពុជា* (កាសែត Washington Post), ឯកសារ E3/4479, ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៥ ERN (ភាសាខ្មែរ) 00191350។

[៧១៨] *ទង់ជ័យសពាសពេញក្រុងភ្នំពេញ* (កាសែត Newsweek) ឯកសារ E3/3721 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) S 00655254-00655258។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៣ ERN (ភាសាខ្មែរ) 00191348។

[៧១៩] ប្រតិចារឹក ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៤៦-៤៧។ សៀវភៅនិពន្ធដោយ G. Chon និង Thet Sambath៖ *នៅពីក្រោយវាល ពិឃាត៖ មេដឹកនាំខ្មែរក្រហម និងជនរងគ្រោះដោយសារគាត់ម្នាក់* ឯកសារ E3/4202 ទំព័រ ១-២ ERN (ភាសាខ្មែរ) 00858214-00858215។ *សូមមើលផងដែរ* ការប្រជុំអចិន្ត្រៃយ៍, ឯកសារ E3/182, ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៥ (បានចាត់ចែងការទទួលខុសត្រូវផ្នែកគោលនយោបាយជាក់លាក់ឲ្យទៅសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Léon Trivière: *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00538843-00538844 (បានរាយការណ៍សេចក្តីប្រកាសនាពេលមុនរបស់សម្តេច នរោត្តម សីហនុ ដោយទ្រង់បានប្រកាសថា “ឥឡូវនេះ សមាជិកភាគច្រើននៃរាជរដ្ឋាភិបាលរួបរួមជាតិគឺជាពួកខ្មែរក្រហម...រដ្ឋាភិបាលពេលនេះមាននិន្នាការទៅរកលទ្ធិកុម្មុយនីស្ត...ខ្ញុំប្រគល់អ្វីៗទាំងអស់ឲ្យទៅខ្មែរក្រហម”)។

ក្រោយពេលសង្គ្រាមចប់ទៅ ទ្រង់នឹងឋិតនៅជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ... គឺខ្មែរក្រហម នឹងជាអ្នកកាន់អំណាចពិតប្រាកដ[៧២០]។

២៣១. នៅក្នុងឆ្នាំ ១៩៧៥ អ្នកអត្ថាធិប្បាយមួយរូបបានផ្តល់ការសង្កេតថា គណៈរដ្ឋមន្ត្រីនៃរាជ-រដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានត្រួតត្រាដោយខ្មែរក្រហម ដោយមានតែ "អ្នកគាំទ្រសម្តេច សីហនុចំនួនតែពីររូបប៉ុណ្ណោះ" នៅក្នុងចំណោមសមាជិកគណៈរដ្ឋមន្ត្រី[៧២១]។ ទោះបីជាទ្រង់មាន នាមជាព្រះប្រមុខរដ្ឋក៏ដោយ ក៏សម្តេច នរោត្តម សីហនុ មិនបានយាងមកក្រុងភ្នំពេញរហូតដល់ខែ កញ្ញា ឆ្នាំ ១៩៧៥ ដោយទ្រង់បានចំណាយរយៈពេលប៉ុន្មានខែមុននេះគង់នៅក្នុងទីក្រុងប៉េកាំង និង ទីក្រុងព្យុងយ៉ាង[៧២២]។

២៣២. នៅក្នុងខែ តុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានចាត់-តាំងសមាជិកជាន់ខ្ពស់ចំនួន ១៣ រូប ឲ្យទទួលខុសត្រូវលើគោលនយោបាយជាក់លាក់មួយចំនួន ក្នុងនោះរួមមាន ជនជាប់ចោទ នួន ជា (ទទួលខុសត្រូវ "ការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ") និងជនជាប់ចោទ ខៀវ សំផន (ទទួលខុសត្រូវ "រណសិរ្ស និង រាជរដ្ឋាភិបាល ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ")[៧២៣]។ អៀង សារី ឲ្យទទួលខុសត្រូវ"ការងារ

---

[៧២០] សៀវភៅនិពន្ធដោយ Léon Trivière: *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២០ ERN (ភាសាខ្មែរ) 00538853។

[៧២១] សៀវភៅនិពន្ធដោយ Léon Trivière: *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣១-៣២ ERN (ភាសាខ្មែរ) 00538864-00538865។

[៧២២] *បដិសណ្ឋារកិច្ចទទួលស្វាគមន៍សម្តេចសីហនុ៖ សុន្ទរកថាដោយលោក ខៀវ សំផន និងសម្តេច សីហនុ* (នៅក្នុង កម្រងឯកសារ SWB/FE/5006/B collection) ឯកសារ E3/711 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសា ខ្មែរ) S 00743935។ *សម្តេច សីហនុ ប្តេជ្ញាគ្រប់គ្រងតាមបែប 'ប្រជាធិបតេយ្យ'* (កាសែត New York Times), ឯកសារ E3/3296, ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥។ របាយការណ៍ដោយ Stephen Heder និង Masato Matsushita ៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ១៩៨០ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00324681-00324682។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវ បងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៣-៤៩ ERN (ភាសាខ្មែរ) 00191348-00191354។

[៧២៣] ការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសា ខ្មែរ) 00019108។ សូមមើលផ្នែកទី ៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៨-៣២៩។ ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០០ ។

បរទេស ទាំងបក្ស ទាំងរដ្ឋ" ចំណែក ប៉ុល ពត ឲ្យ"ទទួលរួមខាងយោធា និងសេដ្ឋកិច្ច"[៧២៤]។ កុយ ធួន *ហៅ* ធុច ឲ្យទទួលខុសត្រូវ "ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស" សុន សេន ឲ្យទទួលខុសត្រូវ"សេនាធិការ និងសន្តិសុខ" វន វ៉េត ឲ្យទទួលខុសត្រូវ "ឧស្សាហកម្ម រទេះភ្លើង និងនេសាទ" អៀង ធីរិទ្ធ *ហៅ* ភា ឲ្យទទួលខុសត្រូវ "វប្បធម៌ សង្គមកិច្ច និងការងារបរទេស" យុន យ៉ាត *ហៅ* អាត ឲ្យទទួលខុសត្រូវ "ឃោសនាអប់រំ ទាំងផ្ទៃក្នុង ទាំងខាងក្រៅ" និង នង សួន *ហៅ* ជ័យ ឲ្យទទួលខុសត្រូវខាង "កសិកម្ម"[៧២៥]។

២៣៣. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៥ ជនជាប់ចោទ ខៀវ សំផន បានបង្ហាញសេចក្ដីព្រាងរដ្ឋធម្មនុញ្ញថ្មីមួយនៅក្នុងសមាជជាតិក្នុងទីក្រុងភ្នំពេញ[៧២៦]។ នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ រដ្ឋធម្មនុញ្ញថ្មីនេះ ("រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ") បានចូលជាធរមាន ហើយរដ្ឋកម្ពុជាប្រជា-ធិបតេយ្យបានចាប់បដិសន្ធិឡើងពីពេលនោះមក[៧២៧]។ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រគល់អំណាចនីតិបញ្ញត្តិជូនទៅសភាតំណាងប្រជាជន ("សភាតំណាងប្រជាជន") ដែលមានសមាជិកជ្រើសតាំងចំនួន ២៥០ រូប[៧២៨]។ រដ្ឋាភិបាលត្រូវបានជ្រើសតាំងឡើង ហើយត្រូវទទួលខុសត្រូវចំពោះមុខសមាជិកសភាតំណាងប្រជាជន[៧២៩]។ "តុលាការប្រជាជន" ក៏ត្រូវតែងតាំងដោយសភាតំណាងប្រជាជនដែរ[៧៣០]។ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យមានគណៈប្រធានរដ្ឋ

---

[៧២៤] ការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00019108-00019110។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ១៨-១៩។

[៧២៥] ការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00019108-00019110។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ១៨។

[៧២៦] *របាយការណ៍ ខៀវ សំផន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00657436-00657453។

[៧២៧] *វិចារណកថាតាមវិទ្យុអបអរសាទរការប្រកាសឲ្យប្រើប្រាស់រដ្ឋធម្មនុញ្ញថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៧៦ ERN (ជាភាសាអង់គ្លេស) 00167822។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ។

[៧២៨] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦-៧ ជំពូក ៦ ERN (ភាសាខ្មែរ) 00089846។

[៧២៩] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦-៧ ជំពូក ៦ ERN (ភាសាខ្មែរ) 00089846។

[៧៣០] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-៩ ជំពូក ៧ ERN (ភាសាខ្មែរ) 00089847។

ជំនួសព្រះមហាក្សត្រ ហើយគណៈប្រធានរដ្ឋនេះក៏ត្រូវបានតែងតាំងដោយសភាតំណាងប្រជាជនដែរ ដើម្បីតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅក្នុង និងនៅក្រៅប្រទេស[៧៣១]។

២៣៤. ទាំងអស់នេះក៏ជារូបភាពបិទបាំងពីខាងក្រៅផងដែរ។ កំណត់ហេតុកិច្ចប្រជុំរបស់គណៈ-កម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានឆ្លុះបញ្ចាំងនូវគំនិតយោបល់របស់គណៈកម្មាធិការនេះថា សភាតំណាងប្រជាជន "គ្មានតម្លៃ" ហើយប្រាប់សមាជិករបស់ខ្លួនឲ្យប្រយ័ត្នដោយ "*មិនត្រូវនិយាយលេងពីសភានៅមុខប្រជាជនឲ្យគេឃើញថាយើងបន្លំបន្លប់*"[៧៣២]។ ទោះបីជារដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានប្រមើលមើលពី "ការបោះឆ្នោតទូទាំងប្រទេសដោយផ្ទាល់ និងដោយសម្ងាត់"ដើម្បីជ្រើសរើសសមាជិកសភាតំណាងប្រជាជនក៏ដោយ ក៏គេមិនឃើញមានការបោះឆ្នោតនៅទូទាំងប្រទេសត្រូវបានរៀបចំធ្វើឡើងឡើយ។ យ៉ាងច្រើនបំផុត ការបោះឆ្នោតត្រូវបានរៀបចំធ្វើឡើងនៅតាមកន្លែងមួយចំនួនតូចតែប៉ុណ្ណោះ ហើយវាមិនច្បាស់ឡើយថាតើអ្នកបោះឆ្នោតត្រូវបានគេផ្តល់ជម្រើសបេក្ខជនសភាពិតប្រាកដឬក៏យ៉ាងណានោះទេ[៧៣៣]។ សាក្សី ប្រាក់ យុត និង អ៊ុង រ៉ែន ពុំបានដឹងថា ពួកគេគឺជាបេក្ខជនសភាតំណាងប្រជាជននោះទេ រហូតទាល់តែពួកគេត្រូវបានថ្នាក់លើខ្លួនជូនដំណឹងថា ពួកគេត្រូវបានតែងតាំងរួចហើយ ហើយសូម្បីតែនៅក្រោយការតែងតាំងនោះ ពួកគេក៏នៅតែពុំយល់ច្បាស់ថាតើពួកគេមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះក្នុងនាមជាសមាជិកសភាតំណាងប្រជាជននោះ[៧៣៤]។ ពួកគេទាំងពីរក៏ពុំចាំបានថាធ្លាប់បានចូលរួមប្រជុំសភាតំណាងប្រជាជន ឬ បោះឆ្នោតអនុម័តច្បាប់អ្វីឡើយ[៧៣៥]។

---

[៧៣១] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-៩ ជំពូក ៧ ERN (ភាសាខ្មែរ) 00089847។

[៧៣២] កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00017118-00017119។

[៧៣៣] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦-៧ ជំពូក ៥ ERN (ភាសាខ្មែរ) 00089846។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត), ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៦៨-៧០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន), ទំព័រ ២១-២២។

[៧៣៤] ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត), ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន), ទំព័រ ២១-២២, ២៣-២៥។

[៧៣៥] ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៥៦-៥៨។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ២១-២៥។

២៣៥. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ក្រោយពីការអះអាងថា មានការបោះឆ្នោតជ្រើសតាំងសភាតំណាងប្រជាជន ប៉ុន្តែមុនសម័យប្រជុំសភាដំបូងនោះ[៧៣៦] គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានតែងតាំងជនជាប់ចោទ នួន ជា ឲ្យធ្វើជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ហើយដាក់ឈ្មោះជនជាប់ចោទ ខៀវ សំផន ឲ្យធ្វើជាប្រធានគណៈប្រធាន-រដ្ឋ ពោលគឺជាប្រធានរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ[៧៣៧]។ គណៈកម្មាធិការមជ្ឈិមក៏បានតែងតាំងសមាជិករដ្ឋាភិបាលមួយចំនួនផ្សេងទៀត រួមទាំង ប៉ុល ពត ធ្វើជានាយករដ្ឋមន្ត្រី អៀង សារី ធ្វើជាឧបនាយករដ្ឋមន្ត្រី ទទួលខាងការងារបរទេស វន វ៉េត ឧបនាយករដ្ឋមន្ត្រី ទទួលខាងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង សុន សេន ឧបនាយករដ្ឋមន្ត្រី ទទួលខាងការពារប្រទេស[៧៣៨]។

២៣៦. នៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ បានប្រកាសលាលែងពីតំណែងជាប្រមុខរដ្ឋ[៧៣៩]។ ប៉ុន្មានថ្ងៃក្រោយមក សមាជិកនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទាំងអស់បានលាឈប់ពីតំណែងដើម្បីទុកលទ្ធភាពសម្រាប់ការបង្កើតរដ្ឋាភិបាលថ្មី[៧៤០]។ ចាប់ពីថ្ងៃទី ១១ ដល់ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦ សភាតំណាងប្រជាជនបានជួបប្រជុំក្នុងសម័យប្រជុំលើកដំបូងរបស់ខ្លួនដែលនៅពេលនោះ តាមការអះអាង សភាបានជ្រើសរើស និងតែងតាំងសមាជិកគណៈកម្មាធិការ-

---

[៧៣៦] តាមការអះអាង ការបោះឆ្នោតទំនងជារៀបចំធ្វើឡើងនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦៖ *សូមមើលការប្រកាសលទ្ធផលនៃការបោះឆ្នោតសភាជាតិ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/274 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00700118-00700120។ សភាតំណាងប្រជាជនបានកោះប្រជុំលើកដំបូងនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦៖ សូមមើល កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦។

[៧៣៧] សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00003140-00003141។ សូមមើលផ្នែកទី៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩។ ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១ ។

[៧៣៨] សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00003141-00003142។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧២-៧៣។

[៧៣៩] សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ, ឯកសារ E3/1371, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី), ទំព័រ ៤៦-៤៧។

[៧៤០] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00053633-00053635។

អចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ប្រធានគណៈប្រធានរដ្ឋ និងរដ្ឋាភិបាល[៧៤១]។ ជាក់ស្តែង សភាតំណាងប្រជាជន គ្រាន់តែធ្វើការងារប្រថាប់ត្រាលើជម្រើសទាំងឡាយដែលបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចរួចហើយប៉ុណ្ណោះ[៧៤២]។

២៣៧. រដ្ឋាភិបាលទៀតសោត ក៏គ្រាន់តែជាឧបករណ៍របស់បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ[៧៤៣]។ អ្នកជំនាញ David CHANDLER បានពិពណ៌នាថា "រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយបក្សកាន់អំណាច និងបម្រើបក្សកាន់អំណាច" ហើយមិនមានតុល្យភាពនៅក្នុងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាទេ[៧៤៤]។ រដ្ឋមន្ត្រីរដ្ឋាភិបាល និង បុគ្គលិកក្រសួង រាយការណ៍ និងទទួលការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា[៧៤៥]។ កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានឆ្លុះបញ្ចាំងនូវគំនិតរបស់គណៈកម្មាធិការមជ្ឈិមថា រដ្ឋាភិបាល

[៧៤១] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦។ សម័យប្រជុំពេញអង្គលើកដំបូង នីតិកាលទីមួយ នៃសភាតំណាងប្រជាជនកម្ពុជា - សេចក្តីប្រកាសព័ត៌មាន, ឯកសារ E3/262, ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៦។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ២៦-២៧។ តាមការអះអាង គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនបានកោះប្រជុំវិសាមញ្ញមួយនៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៧ ប៉ុន្តែភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះពុំបានបញ្ជាក់ថាតើកិច្ចប្រជុំនេះពិតជាធ្លាប់បានធ្វើឡើងឬក៏អត់នោះទេ៖ សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1393 ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១៣-១៥ ERN (ភាសាខ្មែរ) 00442398-00442399។

[៧៤២] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៧៥។ បទសម្ភាសន៍របស់ Stephen HEDER ជាមួយ ម៉ាត់ លី ឯកសារ E3/390 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣៧-៣៩ ERN (ភាសាខ្មែរ) 00392103-00392105។

[៧៤៣] *សូមមើល ឧទា.* ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ៤៩-៥១ (បានចាត់ទុករដ្ឋាភិបាលជា "ស្ថាប័នគ្មានអំណាច")។

[៧៤៤] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ២៥-២៦។

[៧៤៥] ឧទាហរណ៍ សូមមើល កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/223 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១-៤ ERN (ភាសាខ្មែរ) 00000829-00000832។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ១-៤, ៧-៩ ERN (ភាសាខ្មែរ) 00000837-00000840, 00000843-00000845។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍, ឯកសារ E3/226, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦។

“ត្រូវជាអង្គការរបស់បក្សសុទ្ធសាធ”[៧៤៦]។ រដ្ឋមន្ត្រីរដ្ឋាភិបាលបានជួបជាមួយ ប៉ុល ពត ដែលនៅពេលនោះ បំពេញមុខងារជានាយករដ្ឋមន្ត្រីផង និងជាលេខាបក្សកុម្មុយនីស្តកម្ពុជាផង នៅក្នុងពេលជួបប្រជុំគណៈរដ្ឋមន្ត្រី[៧៤៧]។ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទីមួយ ប៉ុល ពត បានបញ្ជាក់ច្បាស់ថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានមុខងារចម្បងត្រូវអនុវត្តមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា៖

> ធាតុពិតរបស់រដ្ឋាភិបាលថ្មីរបស់យើង គឺជារដ្ឋាភិបាលបដិវត្តរបស់ កម្មករ-កសិករ សុទ្ធសាធ ជារបស់បក្សកម្មុយនីស្តកម្ពុជាសុទ្ធសាធ...សមាជិករដ្ឋាភិបាល និងសមាជិករបស់គណៈកម្មាធិការគ្រប់តំបន់ ត្រូវក្ដាប់ធាតុពិតរបស់រដ្ឋាភិបាលយើង នូវតួនាទីរបស់យើង ហើយខិតខំបំពេញភារកិច្ចឲ្យបានល្អ ទៅតាមមាគ៌ារបស់បក្ស។ ក្ដាប់មាគ៌ារបស់បក្សបានន័យថា ក្ដាប់គោលជំហរចាត់តាំងរបស់បក្ស និងក្ដាប់សំណូមពរនយោបាយរបស់បក្សលើគ្រប់ផ្នែកដើម្បីអនុវត្តនយោបាយរបស់បក្សឲ្យបានល្អ និងត្រឹមត្រូវ...
>
> ...នៅក្នុងក្របខណ្ឌក្រសួងនីមួយៗក៏ដូច្នោះដែរ។ គឺត្រូវខិតខំបំពេញភារកិច្ច តាមមាគ៌ារបស់បក្សឲ្យបានត្រឹមត្រូវ ម៉ត់ចត់ និងពេញលេញ...[៧៤៨]។

២៣៨. ចំពោះស្ថាប័នទីបីរបស់រដ្ឋ ដូចបានប្រមើលមើលនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យពោលគឺ ស្ថាប័នតុលាការ សភាតំណាងប្រជាជន បានអះអាងថាបង្កើត និងតែងតាំងប្រធាន “គណៈកម្មាធិការតុលាការ” នៅក្នុងសម័យប្រជុំរបស់ខ្លួនក្នុងខែ មេសា ឆ្នាំ ១៩៧៦[៧៤៩]។ ប៉ុន្តែគ្មានប្រព័ន្ធតុលាការណាមួយត្រូវបានបង្កើតឡើង និងដំណើរការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

---

[៧៤៦] សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00003141-00003142។

[៧៤៧] បទឧទ្ទេសនាមរបស់សមមិត្តលេខា ឯកសារ E3/818 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គ-ប្រជុំគណៈរដ្ឋមន្ត្រី ឯកសារ E3/794 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦។ បទសម្ភាសន៍របស់ Elizabeth Becker ជាមួយ អៀង ធីរិទ្ធ ឯកសារ E3/659 ឆ្នាំ ១៩៨០ ទំព័រ ៤៣-៤៤ ERN (ភាសាខ្មែរ) 00741125-00741126។

[៧៤៨] បទឧទ្ទេសនាមរបស់សមមិត្តលេខា ឯកសារ E3/818 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00072753-00072755។

[៧៤៩] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៤៨-៤៩ ERN (ភាសាខ្មែរ) 00053635។

នោះទេ[៧៥០]។

២៣៩. ក្រុមមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា ដីកាដំណោះស្រាយសន្និដ្ឋានមិនបានត្រឹមត្រូវ ដោយហេតុថា ដីកានេះលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាដំណើរការរួមជាមួយនឹងរដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ[៧៥១]។ ក៏ប៉ុន្តែ មុខតំណែងខ្ពស់ជាងគេបំផុតនៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលជានាយករដ្ឋមន្ត្រី ប្រធានគណៈប្រធានរដ្ឋ និងប្រធានសភាតំណាងប្រជាជន ត្រូវបានកាន់កាប់ ដោយសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា។ ថ្នាក់ដឹកនាំ និងរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលត្រូវ បានតែងតាំងដោយបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ត្រូវរាយការណ៍ជូនបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ ស្ថាប័នតុលាការ និង ស្ថាប័ននីតិបញ្ញត្តិ មិនបានដំណើរការឡើយ។ សរុបមក យោងតាមសំដីរបស់ ជនជាប់ចោទ ខៀវ សំផន កម្ពុជាប្រជាធិបតេយ្យគឺជាប្រទេសមួយដែល “បក្សជាអ្នកដឹកនាំ រដ្ឋ”[៧៥២]។

## ៥.៣ រចនាសម្ព័ន្ធនៃកងកម្លាំងយោធាបក្សកុម្មុយនីស្តកម្ពុជា

### ៥.៣.១ ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា

២៤០. នៅពេលបក្សកុម្មុយនីស្តកម្ពុជា ឬ រណសិរ្សរួបរួមជាតិកម្ពុជាបានកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងកម្លាំងយោធាបក្សកុម្មុយនីស្តកម្ពុជា ដែលបានវាយប្រយុទ្ធ ក្រោមស្លាកនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា[៧៥៣] ស្ថិតនៅក្រោមការគ្រប់គ្រង

---

[៧៥០] ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៣៩-៤០។

[៧៥១] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា កថាខណ្ឌ ១៨៩។

[៧៥២] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៧ ERN (ភាសាខ្មែរ) 00156618។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់), ទំព័រ ១៥-១៦ (បានចាត់ទុកបក្សកុម្មុយនីស្តកម្ពុជាជា “ស្ថាប័នដែលមានអំណាចខ្ពស់បំផុត” និងបានសង្កេតឃើញថា “សូម្បីគណៈប្រធានរដ្ឋសភាតំណាងប្រជាជន...ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការ ៨៧០ ផងដែរ”)។

[៧៥៣] ឧទាហរណ៍ សូមមើល *មានការជំរុញឱ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារក្នុងពេលចូលឆ្នាំថ្មី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00783125-00783127។

ផ្ទាល់របស់ភូមិភាគ ពុំមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្សឡើយ[៧៥៤]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ ប៉ុល ពត បានប្រកាសបង្កើតកងទ័ពបដិវត្តន៍កម្ពុជាថ្មីមួយ (‘កងទ័ពបដិវត្តន៍កម្ពុជា’) ដោយយកកងពលតូចតាមភូមិភាគមួយចំនួនឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈ-កម្មាធិការមជ្ឈិម ជាពិសេស ឱ្យស្ថិតនៅក្រោមបញ្ជារបស់អគ្គសេនាធិការ ដែលដឹកនាំដោយ សុន សេន[៧៥៥]។ អង្គភាពទាំងឡាយដែលត្រូវបានបង្កើតឡើងក្រោមអគ្គសេនាធិការ (‘កងពលមជ្ឈិម’) រួមមាន កងពល ១៦៤ ដែលជាកងទ័ពជើងទឹក, កងពល ១៧០, កងពល ២៩០, កងពល ៣១០, កងពល ៤៥០, កងពល ៥០២ ដែលជាកងទ័ពអាកាស, កងពល ៧០៣, កងពល ៨០១ និងកងពល ៩២០[៧៥៦]។ ‘កងវរសេនាធំឯករាជ្យ’ មួយចំនួនក៏ត្រូវបានបង្កើតឡើងក្រោមអគ្គសេនាធិការ

---

[៧៥៤] បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4045 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00784359។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ), ទំព័រ ២៣-២៥។

[៧៥៥] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម), ទំព័រ ៩១-៩២។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ), ទំព័រ ២៣-២៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ឯកសារ E3/426 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00357491-00357493។ ទង់បដិវត្ត ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ២៤-២៥ ERN (ភាសាខ្មែរ) 00063324។ Timothy Carney, “ការរៀបចំអំណាច”, នៅក្នុង *ប្រទេសកម្ពុជា* ឆ្នាំ ១៩៧៥-១៩៧៨៖ *ការណាត់ជួបនឹងសេចក្តីស្លាប់* ឯកសារ E3/49 ទំព័រ ៨៨ ERN (ជាភាសាអង់គ្លេស) 00105137។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ ១៤៣-១៤៤ ERN (ភាសាខ្មែរ) 00637498-00637499។

[៧៥៦] ឯកសាររបស់សេនាធិការនៃកងទ័ពបដិវត្តកម្ពុជា – ស្ថិតិកំលាំងរួម ប្រចាំខែ ៣ - ៧៧, ឯកសារ E3/849, ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៧។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ២៤-២៥។ ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេក អ៊ាវ), ទំព័រ ៥៤-៥៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន), ទំព័រ ៤២-៤៤។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ), ទំព័រ ៣៣-៣៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ម៉ុន ឯកសារ E3/369 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00195436។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ឯកសារ E3/70 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00404633-00404635។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ឯកសារ E3/5263 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00270178។ របាយការណ៍របស់ក្រសួងការពារជាតិសហរដ្ឋអាមេរិក ឯកសារ E3/5700 ចុះខែ មិថុនា ឆ្នាំ ២០០០ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00658135-00658136។ កំណត់ហេតុនៃការប្រជុំសមមិត្ត តាល់, ឯកសារ E3/822, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦។ សៀវភៅនិពន្ធដោយ ហ៊ុយ វណ្ណៈ៖ *កងពលខ្មែរក្រហមលេខ ៧០៣៖ ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង* ឯកសារ E3/2117 ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00192940-00192941។ សៀវភៅនិពន្ធដោយ S. Colm និង

ដោយកងវរសេនាធំឯករាជ្យនីមួយៗទទួលភារកិច្ចជាក់លាក់ ឧទាហរណ៍ កងរថក្រោះ កងកាំភ្លើងធំ និងមន្ទីរសន្តិសុខ ស-២១ ជាដើម[៧៥៧]។ កងពលធំត្រូវបានរៀបចំឡើងវិញ ហើយបានប្តូរឈ្មោះលើសពីម្តងនៅក្រោយឆ្នាំ ១៩៧៥[៧៥៨]។

២៤១. តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានកំណត់នៅក្នុងមាត្រា១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។ កងទ័ពបដិវត្តន៍កម្ពុជាមានភារកិច្ច "ការពាររដ្ឋអំណាចរបស់ប្រជាជនកម្ពុជា ការពារកម្ពុជា [...] ក្នុងបូរណភាពដែនដី" និង "កសាងប្រទេសឲ្យថ្កុំថ្កើង រុងរឿង លើកស្ទួយជីវភាពប្រជាជនឲ្យបានរីកចំរើន និងសំបូរសប្បាយជាលំដាប់"[៧៥៩]។ ទោះបីជាយ៉ាងនេះក៏ដោយ កងទ័ពបដិវត្តន៍កម្ពុជា គឺជាកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងពិតប្រាកដ ពុំមែនជាស្ថាប័នរបស់រដ្ឋឡើយ។ លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជាបានចែងថា កងទ័ពបដិវត្តន៍កម្ពុជា "ត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា"[៧៦០]។ ប្រហាក់ប្រហែលគ្នានេះដែរ ទស្សនាវដ្តី"ទង់បដិវត្ត"របស់បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកកងទ័ពបដិវត្តន៍កម្ពុជាថាជា"ឧបករណ៍ផ្តាច់ការរបស់បក្សដ៏បរិសុទ្ធ"[៧៦១]។

---

Sorya Sim៖ *ការបោសសម្អាតរបស់ពួកខ្មែរក្រហម នៅតំបន់ខ្ពង់រាបខេត្តមណ្ឌលគីរី* ឯកសារ E3/1664 ទំព័រ ១-២ ERN (ភាសាខ្មែរ) 00742838-00742839។

[៧៥៧] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ), ទំព័រ ២១, ទំព័រ ៣៤-៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឆាយ ឯកសារ E3/5537 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00398504-00398505 ។ សៀវភៅនិពន្ធដោយ D. Chandler៖ *សំឡេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ១៧ ERN (ភាសាខ្មែរ) 00191845។

[៧៥៨] *ឧទាហរណ៍ សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ន ឯកសារ E3/5554 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ៤ ERN (ភាសាខ្មែរ) 00373268 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/361 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00194466-00194467។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ E3/419 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00407748។

[៧៥៩] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៨ ERN (ភាសាខ្មែរ) 00089849-00089852។

[៧៦០] លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥៣ មាត្រា ២៧ ERN (ភាសាខ្មែរ) 00442279។

[៧៦១] ទង់បដិវត្ត ឯកសារ E3/25 ខែ ធ្នូ-មករា ឆ្នាំ ១៩៧៦-៧៧ ទំព័រ ២៧-៣០ ERN (ភាសាខ្មែរ) 00063016-00063018 (អង្គជំនុំជម្រះពឹងផ្អែកទៅលើអត្ថបទជាភាសាខ្មែរ ដែលជាអត្ថបទដើម) ។ *សូមមើល ផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/915 ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00001325 "យើងខ្ញុំដែល

### ៥.៣.២ រចនាសម្ព័ន្ធនៃកងទ័ពបដិវត្តន៍កម្ពុជា

២៤២. ផ្អែកតាមរចនាសម្ព័ន្ធរដ្ឋបាលស៊ីវិលនៃបក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានរៀបចំឋានានុក្រមក្នុងទម្រង់ជាពីរ៉ាមីត។ នៅខាងលើ (ទោះបីស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធាក៏ដោយ) មានអគ្គសេនាធិការ[៧៦២]។ អគ្គសេនាធិការបញ្ជារួមលើកងពលមជ្ឈិម និងទទួលខុសត្រូវលើការងារយោធា ដូចជា ការផ្គត់ផ្គង់ភ័ស្តុភារ អាវុធ បុគ្គលិក ទំនាក់ទំនង និងព័ត៌មាន[៧៦៣]។

២៤៣. នៅផ្នែកខាងក្រោមផ្ទាល់នៃអគ្គសេនាធិការរួមមាន កងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យ ដែលកងនីមួយៗដឹកនាំដោយមេបញ្ជាការកងពលធំមួយរូប[៧៦៤]។ កងពលមជ្ឈិមត្រូវបានបែងចែកបន្តជាអង្គភាពតូចៗជាច្រើនទៀត។ ជាធម្មតា ក្នុងមួយកងពលធំរួមមានបីកងវរសេនាធំ។ បីកងវរសេនាតូចបង្កើតបានជាមួយកងវរសេនាធំ។ បីកងអនុសេនាធំបង្កើតបានជាមួយកងវរសេនាតូច។ បីកងអនុសេនាតូចបង្កើតបានជាមួយកងអនុសេនាធំ។ បីក្រុមបង្កើតបានមួយកងអនុសេនាតូច។ មួយក្រុមរួមមានកងទ័ពប្រហែលជា ១២ នាក់[៧៦៥]។ នៅថ្នាក់កងអនុសេនាធំ និង

---

មានភារកិច្ចការពារមុខសញ្ញាសមុទ្រ សូម" ពោលគឺ កងពល ១៦៤, កងទ័ពជើងទឹកប្ដេជ្ញា "កសាងកម្លាំងជាឧបករណ៍ការពារបក្ស" ព្រមទាំងរដ្ឋអំណាច។

[៧៦២] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER), ទំព័រ ៥៥-៥៦។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ២២-២៣។

[៧៦៣] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន), ទំព័រ ៩។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ៦៨-៦៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូញ ដុស ឯកសារ E3/426 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ២-៥ ERN (ភាសាខ្មែរ) 00357491-00357494 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ឯកសារ E3/35 ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00340565-00340566 ។ កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី កុយ ម៉ុន ឯកសារ E3/369 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨ ទំព័រ៣-៤ ERN (ភាសាខ្មែរ) 00195436-00195437 ។ របាយការណ៍គណៈភ័ស្តុភារសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា ឯកសារ E3/1167 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៧។ ស្ថិតិសេនាធិការ ឯកសារ E3/1048, ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៧។

[៧៦៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន), ទំព័រ ៩។

[៧៦៥] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ), ទំព័រ ៦២, ទំព័រ ៦៣-៦៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ន ឯកសារ E3/5554 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00373269 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជាតិ

ថ្នាក់ខាងលើៗ អង្គភាពនីមួយៗ ដឹកនាំដោយមេបញ្ជាការមួយរូប (“ប្រធាន”ឬ“ស្នងការ”) ដែលមានអនុបញ្ជាការ(អនុប្រធាន) ពីររូប[៧៦៦]។

២៤៤. សាក្សីមួយចំនួនបានបញ្ជាក់ថា នៅចន្លោះកងវរសេនាធំ និងកងពលធំ មានថ្នាក់បញ្ជាការមួយកម្រិតទៀត ជាពិសេស សាក្សីបានបញ្ជាក់ថា បីវរសេនាធំបង្កើតបានមួយ “កងពលតូច” ហើយកងពលធំនីមួយៗរួមមានប្រហែលបីកងពលតូច[៧៦៧]។ ដូច្នេះ រចនាសម្ព័ន្ធអង្គការចាត់តាំងជាក់លាក់អាចមានលក្ខណៈខុសៗគ្នារវាងកងពលធំផ្សេងៗ។

### ៥.៣.៣ កងទ័ពតំបន់ និងកងឈ្លប

២៤៥. ទាំងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានបែងចែកកងទ័ពបដិវត្តន៍កម្ពុជាជាបីប្រភេទគឺៈ កងទ័ពស្រួច កងទ័ពតំបន់ និង កងឈ្លប[៧៦៨]។ ភ័ស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះពុំបានញែកឲ្យបានច្បាស់លាស់រវាងរចនាសម្ព័ន្ធ “កងទ័ពស្រួច” និង “កងទ័ពតំបន់” នោះឡើយ។ ទោះបីជាយ៉ាងនេះក្តី ភ័ស្តុតាងទាំងនេះបានបង្ហាញថាថ្នាក់តំបន់ និងថ្នាក់ស្រុក មានកងទ័ពរបស់ពួកគេផ្ទាល់ដោយឡែកពីកងពលមជ្ឈិម ក្នុងគោល-

---

ឯកសារ E3/5504 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00389512 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជិន គឹមថុង ឯកសារ E3/5512 ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00401323 ។

[៧៦៦] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន), ទំព័រ ៣៦-៣៧, ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី), ទំព័រ ៧៧-៧៩។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត), ទំព័រ ៥៦-៥៧។ Timothy Carney, “ការរៀបចំអំណាច”, នៅក្នុង*ប្រទេសកម្ពុជា* ឆ្នាំ ១៩៧៥-១៩៧៨៖ *ការណាត់ជួបនឹងសេចក្តីស្លាប់* ឯកសារ E3/49 ទំព័រ ៩០ ERN (ជាភាសាអង់គ្លេស) 00105137។

[៧៦៧] ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន), ទំព័រ ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន), ទំព័រ ៣៧។ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន), ទំព័រ ៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត ឯកសារ E3/5145 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00204702 ។ *សូមមើល ផងដែរ* ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៣៤-៣៥ (ដែលបានពិពណ៌នាកងពលតូចថាជាកងពលនៅពីក្រោមកងពលធំ ប៉ុន្តែ ពុំបាននិយាយសំដៅដល់កងវរសេនាធំនោះទេ)។

[៧៦៨] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៤-១៥ មាត្រា ១៩ ERN (ភាសាខ្មែរ) 00089850។ លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥៣ មាត្រា ២៧ ERN (ភាសាខ្មែរ) 00442279។

បំណាងចំបងសម្រាប់ទុកការពារទឹកដីរបស់ពួកគេ[៧៦៩]។ ម្យ៉ាងវិញទៀត សូម្បីតែក្រោយពេល ប៉ុល ពត បានរៀបចំកងទ័ពសាជាថ្មីនៅក្នុងឆ្នាំ ១៩៧៥ ក៏ដោយ ក៏កងពលធំខ្លះនៅតែស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈភូមិភាគដដែល[៧៧០]។

២៤៦. ក្រៅពីកងទ័ពភូមិភាគ តំបន់ និងស្រុក ក៏នៅមានកងឈ្លបតាមមូលដ្ឋានផងដែរ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈឃុំ ដែលទទួលខុសត្រូវលើផ្នែកសន្តិសុខ និងវិន័យនៅតាមភូមិ ឃុំ និងសហករណ៍នានា[៧៧១]។

## ៦. រចនាសម្ព័ន្ធទំនាក់ទំនងការងារ

### ៦.១ វិធីសាស្ត្រទំនាក់ទំនង

#### ៦.១.១ ទូរលេខ

២៤៧. នៅមុនឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ទូរលេខសម្រាប់ធ្វើការទំនាក់ទំនងគ្នាទាំងនៅក្នុងប្រទេសកម្ពុជា និងទៅក្រៅប្រទេស ដើម្បីទំនាក់ទំនងជាមួយក្រុមបណ្តាញការងារ

[៧៦៩] ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យន់ គីម) ទំព័រ ១៥-១៧។ ប្រតិចារឹក ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន), ទំព័រ ៧-៨។ ប្រតិចារឹក ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន), ទំព័រ ៧៨-៨០។ ប្រតិចារឹក ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ (ស វិ), ទំព័រ ៧, ២៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ជីនិត ឯកសារ E3/5534 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00423554 ។

[៧៧០] សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៤២-២៤៣ ERN (ភាសាខ្មែរ) 00232240-00232241។ របាយការណ៍អ្នកជំនាញការរបស់ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ៤៦-៤៨ ERN (ភាសាខ្មែរ) 00314823-00314825។ សូមមើលផងដែរ លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-១៥ មាត្រា ១ ERN (ភាសាខ្មែរ) 00442257-00442260 (បានបែងចែករវាង “កងទ័ពស្រួចរបស់មជ្ឈិម” និង “កងទ័ពស្រួចរបស់ភូមិភាគ”)។

[៧៧១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ក្លាន ហ្វិត), ទំព័រ ៨២-៨៣។ ប្រតិចារឹក ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន), ទំព័រ ៧២-៧៣។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យន់ គីម), ទំព័រ ១៩-២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ផេន ឯកសារ E3/374 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00333401-00333402។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គីម ឯកសារ E3/422 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00407756-00407757។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊្រុន ឯកសារ E3/1692 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣-៦ ERN (ភាសាខ្មែរ) 00218552-00218555។

នៅក្រៅប្រទេស។ ឧទាហរណ៍ ទូរលេខត្រូវបានប្រើប្រាស់សម្រាប់បញ្ជូននិងទទួលសារ រវាងភូមិភាគនឹងមេដឹកនាំបក្សនៅតាមទីស្នាក់ការរបស់ពួកគេ ហើយក៏ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងជាមួយនឹងតំណាងនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប្រទេសវៀតណាម និងប្រទេសចិន ផងដែរ[៧៧២]។

២៤៨. ក្រោយពីបានកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៧៥ មន្ទីរទូរលេខនៃបក្សកុម្មុយនីស្ត-កម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងភ្នំពេញ[៧៧៣]។ ទូរលេខត្រូវបានបញ្ជូន និងទទួលនៅមន្ទីរ ក-១៨ ហើយត្រូវបានសរសេរជាលេខកូដ ឬបកប្រែលេខកូដ ទៅតាមការចាំបាច់ នៅមន្ទីរក-១ ឬនៅមន្ទីរមួយដែលមានទីតាំងស្ថិតនៅក្នុងសាលាសុធារស[៧៧៤]។ ភូមិភាគ តំបន់ស្វយ័ត តំបន់ និងកងពលនៅទូទាំងប្រទេស ក៏មានអង្គភាពទូរលេខរបស់ខ្លួនផ្ទាល់ផងដែរ[៧៧៥]។ ប្រព័ន្ធទំនាក់ទំនងនេះ

---

[៧៧២] ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៦។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៧៦-៧៧។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (ឡុង នរិន្ទ) ទំព័រ ៦៨-៦៩។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ស្ងួន កានិល) ទំព័រ ៤៣-៤៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៣៦-៣៧។ ចាប់ពីឆ្នាំ ១៩៧១ ដល់ ឆ្នាំ ១៩៧៥ អៀង សារី ធ្វើជា “បេសកជនពិសេស” នៃរណសិរ្សរួបរួមជាតិកម្ពុជា ឬ រដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅក្នុងប្រទេសចិន ដោយទទួលភារៈចាត់ចែងការធ្វើទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងប្រទេសចិន តាមដានសម្តេច នរោត្តម សីហនុ ជំនួសមុខឲ្យបក្សកុម្មុយនីស្តកម្ពុជា និងជ្រើសរើសបញ្ញវន្តនៃរណសិរ្សរួបរួមជាតិកម្ពុជា/ រដ្ឋាភិបាលរួបរួមជាតិកម្ពុជា សម្រាប់ជូនបក្ស៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៧១-៧៣, ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧៥-៧៦, ៧៦។ បទសម្ភាសន៍របស់ Steve Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១៣-១៥ ERN (ភាសាខ្មែរ) 00062464-00062466។ *កម្ពុជា-ការដួលរលំអ្នកដែលមានមហិច្ឆតាខ្ពស់* (Far Eastern Economic Review) ឯកសារ E3/3443 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៦ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00704259-00704261; *សម្តេច សីហនុ និងមហេសីយាងមកដល់ទីក្រុងប៉េកាំង* (អត្ថបទទស្សនាវដ្តីក្រុងប៉េកាំង) ឯកសារ E3/3710 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧២។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៧៨-៧៩ ERN (ភាសាខ្មែរ) 00191383-00191384។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៦៧-២៦៨ ERN (ភាសាខ្មែរ) 00232265-00232266។

[៧៧៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៥៣-៥៤។

[៧៧៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤៤, ៥៤-៥៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សុខា ឯកសារ E3/465 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00204750-00204751។

[៧៧៥] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤៣-៤៤ (លើកឡើងថា “មូលដ្ឋាន ភូមិភាគ និងតំបន់នីមួយៗ និងគ្រប់កងពល” មានផ្នែកទំនាក់ទំនង និងទូរលេខរបស់ពួកគេ)។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ

នៅដំណើរការរហូតដល់ពេលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៩[៧៧៦]។ ទូរលេខត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ទំនាក់ទំនងជាមួយតំបន់ឆ្ងាយៗ។ ជាធម្មតា មន្ទីរនានារបស់មជ្ឈិមពុំបានប្រើប្រាស់ទូរលេខសម្រាប់ទាក់ទងគ្នានៅក្នុងទីក្រុងភ្នំពេញឡើយ[៧៧៧]។

២៤៩. ទូរលេខរបស់បក្សកុម្មុយនីស្តកម្ពុជាភាគច្រើន គឺត្រូវបានសរសេរជាលេខកូដនៅមុនពេលបញ្ជូនចេញ តែមិនមែនទាំងអស់នោះទេ[៧៧៨]។ សារដែលពុំត្រូវបានសរសេរជាលេខកូដ ត្រូវបានបញ្ជូនចេញជាលេខសម្ងាត់ (Morse code)[៧៧៩]។ សារសម្ងាត់ត្រូវបានសរសេរជាលេខកូដដោយយកសញ្ញាមកប្រើប្រាស់ ជំនួសអក្សរ[៧៨០]។ ការសរសេរជាលេខកូដមួយជាន់ទៀតត្រូវបានធ្វើឡើងសម្រាប់សារសម្ងាត់បំផុត ដូចជា សារដែលទាក់ទងទៅនឹងផែនការនៃការធ្វើដំណើររបស់កម្មាភិបាល[៧៨១]។ លេខកូដពិសេសក៏ត្រូវបានប្រើប្រាស់ដើម្បីសំដៅលើបុគ្គល ទីតាំង និងមន្ទីរជាក់លាក់

២០១២ (សួន កានិល) ទំព័រ ៣៨, ៧៨-៧៩ (បញ្ជាក់ថា ភូមិភាគ តំបន់ និងបញ្ជាការសមរភូមិបានប្រើប្រាស់ទូរលេខ); ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ២៤ (បានផ្តល់ទីតាំងនៃមន្ទីរទូរលេខនៅក្នុងតំបន់ស្វយ័ត ១០៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន សុវណ្ណហាន ឯកសារ E3/44 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00287712-00287713 (បញ្ជាក់អំពីអត្ថិភាពនៃមន្ទីរទូរលេខនៅក្នុងតំបន់ស្វយ័ត ១០៥)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១៧-១៨ (រៀបរាប់អំពីការទាក់ទងតាមទូរលេខជាមួយនឹងកងពលយោធាមួយ)។

[៧៧៦] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៥៩-៦០។

[៧៧៧] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ២៩-៣០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៦១-៦២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ឯកសារ E3/70 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00404632-00404633។

[៧៧៨] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៩-១០។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ៥០-៥១។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ២០។

[៧៧៩] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ៥០-៥១។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៤២-៤៣។

[៧៨០] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ១៦-១៨ (ពិពណ៌នាអំពីការប្រើប្រាស់ “តារាង ១០០ ក្រឡា” សម្រាប់សរសេរជាលេខកូដ)។ ឧបសម្ព័ន្ធនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សូផង់ ឯកសារ E3/1732 គ្មានចុះកាលបរិច្ឆេទ។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៧៨-៧៩ (សំដៅលើប្រព័ន្ធ “លេខកូដ ១០ ខ្ទង់”)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សុខា ឯកសារ E3/465 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204749-00204750។

[៧៨១] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ១៩-២០។ ប្រតិចារឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ (ផាន វ៉ាន) ទំព័រ៧៨-៧៩។

មួយចំនួនផងដែរ[៧៨២]។

២៥០. ជាទូទៅ ទូរលេខត្រូវបានសរសេរជាលេខកូដ ឬបកប្រែលេខកូដ និងបញ្ជូន ឬទទួល ដោយបុគ្គលផ្សេងៗគ្នា[៧៨៣]។ ដូច្នេះ តាមធម្មតា ទូរលេខដែលត្រូវផ្ញើចេញគឺត្រូវបានគេរៀបចំជាលាយលក្ខណ៍អក្សរ និងប្រគល់ទៅឲ្យ "អ្នកបំភាន់អក្ខរ" ។ បន្ទាប់មក សារដែលត្រូវបានសរសេរជាលេខកូដ គឺត្រូវប្រគល់ទៅឲ្យអ្នកកាន់ម៉ាស៊ីនទូរលេខម្នាក់ផ្សេងទៀត ដើម្បីបញ្ជូនចេញ[៧៨៤]។ ខាងអ្នកទទួលសារវិញ ក្រោយពីបានទទួលសារដែលបានសរសេរជាលេខកូដនោះ គឺត្រូវចម្លងសារនោះឡើងវិញដោយអ្នកកាន់ម៉ាស៊ីនទូរលេខម្នាក់ទៀត មុននឹងយកទៅឲ្យ "អ្នកបកប្រែលេខកូដ" ដើម្បីធ្វើការបកប្រែលេខកូដ[៧៨៥]។ បន្ទាប់មកសារដែលបានបកប្រែលេខកូដរួចហើយនោះ គឺត្រូវបញ្ជូនទៅឲ្យអ្នកទទួលសារចុងក្រោយតាមរយៈនីរសារ[៧៨៦]។ សាក្សី នង សូផង់ ដែលជាអ្នកគ្រប់គ្រងអង្គភាពសរសេរសារជាលេខកូដ និងបកប្រែលេខកូដទូរលេខនៅសាលាសុធារស ពីឆ្នាំ

---

[៧៨២] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាំ ផាន់ ឯកសារ E3/57 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00287703-00287704។ *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ៦៤ (លើកឡើងថា "៤៧" គឺជាលេខកូដសម្រាប់ សុន សេន)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៦៦-៦៧ (លើកឡើងថា "៨៩" និង "៦២" គឺជាលេខកូដសម្រាប់ សុន សេន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ឯកសារ E3/344 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00373498-00373499 (លើកឡើងថា "១៨" "២៥" និង "៣៥" គឺជាលេខកូដសម្រាប់ កែ ពក)។ សូមមើល ផងដែរផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល ។

[៧៨៣] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៤២។

[៧៨៤] ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៣២-៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សុខា ឯកសារ E3/465 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00204750-00204751។

[៧៨៥] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៦៧-៦៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៣២-៣៣ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សុខា ឯកសារ E3/465 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00204750-00204751។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុន អុល ឯកសារ E3/373 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00326637-00326639។

[៧៨៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៥៣-៥៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៣២-៣៣។

១៩៧៥ មកនោះ[៧៨៧] បានបញ្ជាក់ថា ការបែងចែកការទទួលខុសត្រូវទាំងនេះមានបំណងដើម្បី "រក្សាគោលការណ៍សម្ងាត់" នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា[៧៨៨]។

### ៦.១.២ សំបុត្រ

២៥១. អង្គភាពនានារបស់មជ្ឈិមបក្ស ភូមិភាគ តំបន់ ស្រុក និងឃុំ ក៏ធ្វើការទំនាក់ទំនងគ្នាតាមរយៈសំបុត្រផងដែរ[៧៨៩]។ ជាទូទៅ ទោះបីជាទូរលេខត្រូវបានគេយកមកប្រើប្រាស់ជាញឹកញាប់ សម្រាប់ទំនាក់ទំនងការងារទៅតំបន់ឆ្ងាយៗក៏ដោយ ក៏សារទូរលេខ និងរបាយការណ៍ដែលមានច្រើនទំព័រទាំងនោះត្រូវបានផ្ញើតាមរយៈសំបុត្រ ដែលមាននីរសារជាអ្នកចែកចាយផងដែរ[៧៩០]។ នៅក្នុងទីក្រុងភ្នំពេញ មជ្ឈិមបក្សទទួលសំបុត្រតាមរយៈមន្ទីរក-៧ ដែលជាអង្គភាពនីរសារ[៧៩១]។ ភូមិភាគ តំបន់ និងស្រុក មានបណ្តាញនីរសាររបស់ពួកគេផ្ទាល់ផងដែរ[៧៩២]។

### ៦.១.៣ ទូរស័ព្ទ

២៥២. ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថា មេដឹកនាំនៅតាមមន្ទីរ និងអង្គភាពមួយចំនួនរបស់មជ្ឈិមបក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានទំនាក់ទំនងគ្នាតាមរយៈទូរស័ព្ទ[៧៩៣]។

---

[៧៨៧] ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៥៨-៥៩។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤៣-៤៤។

[៧៨៨] ប្រតិចារឹក ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤៥-៤៦។

[៧៨៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៥៣ (នៅចាំបានថាធ្លាប់យកសំបុត្រទៅមកពីមន្ទីរ ក-១ និង ក៧)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ក្លាន វ៉ុត) ទំព័រ ៤៧ (ពិពណ៌នាអំពីសំបុត្របញ្ជូនពីមជ្ឈិមបក្សទៅឃុំ តាមរយៈថ្នាក់ភូមិភាគ និងតំបន់)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៧២-៧៤ (និយាយសំដៅទៅសំបុត្រមួយច្បាប់ពីសាក្សី កាំង ហ្កេកអ៊ាវ ផ្ញើទៅ សុន សេន)។ លិខិតរបស់ សុន សេន ផ្ញើទៅ កាំង ហ្កេកអ៊ាវ ឯកសារ E3/1047 ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៧។

[៧៩០] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៥៦។

[៧៩១] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ១២-១៣។

[៧៩២] របាយការណ៍របស់ក្រសួងការពារជាតិសហរដ្ឋអាមេរិក ឯកសារ E3/391 ចុះខែ មករា ឆ្នាំ ២០០១ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00699310-00699311។

[៧៩៣] ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៦៧ (ពិពណ៌នាអំពីការសន្ទនាតាមទូរស័ព្ទរវាង សុន សេន និងសាក្សី កាំង ហ្កេកអ៊ាវ នៅមន្ទីរស-២១)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២៩-៣០ (បានលើកឡើងថា បណ្តាញទូរស័ព្ទបានដាក់ដំណើរការនៅមន្ទីរជិតបូរីកីឡា ដែលសាក្សី កាំង ហ្កេកអ៊ាវ

តែមិនមានន័យថា គ្រប់មន្ទីរទាំងអស់នៅក្នុងទីក្រុងភ្នំពេញ សុទ្ធតែទំនាក់ទំនងគ្នាតាមរយៈទូរស័ព្ទនោះទេ[៧៩៤]។

២៩៣. ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះពុំបានបង្ហាញច្បាស់លាស់នោះទេថា តើកម្មាភិបាលថ្នាក់ភូមិភាគ ឬតំបន់ ក៏អាចធ្វើការទំនាក់ទំនងគ្នាតាមរយៈទូរស័ព្ទបានដែរឬយ៉ាងណា[៧៩៥]។ អង្គភាពយោធាមួយចំនួន រួមទាំងកងពលធំ ១៦៤ (កងទ័ពជើងទឹក) ផងដែរនោះ ពេលខ្លះបានរាយការណ៍ជូនមជ្ឈិមបក្សតាមរយៈទូរស័ព្ទ[៧៩៦]។ ក៏ប៉ុន្តែ នៅក្នុងកិច្ចប្រជុំមួយជាមួយនឹងកម្មាភិបាលជាន់ខ្ពស់នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦ សុន សេន បានណែនាំដល់កម្មាភិបាលយោធាមិនឲ្យប្រើប្រាស់ទូរស័ព្ទ "ដោយសេរី" នោះទេ ដើម្បីជៀសវាង "ខ្មាំង" ស៊ើបការណ៍ពីទំនាក់ទំនងរបស់ពួកគេ[៧៩៧]។

---

បានជួប សុន សេន)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៧០ (និយាយសំដៅទៅទូរស័ព្ទនៅមន្ទីរក-៧)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៨-១០ (បានលើកឡើងអំពីការលើកទូរស័ព្ទនៅក្រសួងការបរទេស)។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៧៩-៨០ (ពិពណ៌នាអំពីការលើកទូរស័ព្ទនៅក្រសួងឃោសនាការ)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៤៦-៤៧ (លើកឡើងថា ការហៅទូរស័ព្ទទៅអង្គភាពសរសេរជាលេខកូដ និងបកប្រែលេខកូដទូរលេខនៅសាលាសុធារស)។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ១០-១២ (បញ្ជាក់ថា ជនជាប់ចោទ ខៀវ សំផន មានទូរស័ព្ទមួយខ្សែនៅក្នុងការិយាល័យរបស់គាត់នៅមន្ទីរ ក-៣)។ *សូមមើល ផងដែរ* ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៦៣-៦៤។

[៧៩៤] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៤៦-៤៧ (បញ្ជាក់ថា មន្ទីរបកប្រែទូរលេខនៅសាលាសុធារសមានតែបណ្តាញទូរស័ព្ទមួយខ្សែគត់ភ្ជាប់ទៅមន្ទីរមជ្ឈិមបក្សបីផ្សេងទៀតដោយមិនភ្ជាប់ទៅភូមិភាគឡើយ)។

[៧៩៥] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៣៧ (លើកឡើងថា គណៈកម្មាធិការតំបន់ ២២ ពុំមានទូរស័ព្ទប្រើប្រាស់ឡើយ)។

[៧៩៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៣២។ *សូមមើល ឧទាហរណ៍* របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/928 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ (សង្ខេបសារ "ទូរស័ព្ទសម្ងាត់" ពីកងពល ១៦៤)។ ការទាក់ទងគ្នាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/859 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ (និយាយសំដៅទៅ "ការសន្ទនាសម្ងាត់តាមទូរស័ព្ទ")។ របាយការណ៍យោធាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1082 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ (រួមមាន របាយការណ៍មួយច្បាប់ពី កងពល ១៦៤ ដែលរាយការណ៍ "តាមរយៈទូរស័ព្ទសម្ងាត់")។

[៧៩៧] កំណត់ហេតុនៃការប្រជុំយោធា កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/804 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00008483-00008484។

### ៦.១.៤ វិទ្យុផ្សាយសម្លេង

២៥៤. នៅមុនឆ្នាំ ១៩៧៥ ស្ថានីយ៍វិទ្យុផ្សាយសម្លេងរបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺស្ថិតនៅទីក្រុងហាណូយ ហើយបុគ្គលិកភាគច្រើនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា រួមទាំង អៀង ធីរិទ្ធ ផងដែរ។ ស្ថានីយ៍វិទ្យុនេះបានចាក់ផ្សាយអំពីការឃោសនាបដិវត្តន៍ជាភាសាខ្មែរ ជូនដល់ប្រជាជនកម្ពុជានៅក្នុង និងក្រៅប្រទេសកម្ពុជា[៧៩៨]។ នៅក្នុងប្រទេសកម្ពុជា បក្សកុម្មុយនីស្តកម្ពុជាក៏មានអង្គភាពវិទ្យុផ្សាយសម្លេងចល័តមួយផងដែរ ដែលមានរលកសម្លេងរយៈចម្ងាយជិត ហើយផ្សព្វផ្សាយអំពីព័ត៌មាន ការឃោសនា និងសារបដិវត្តន៍ស្រដៀងគ្នាផងដែរ[៧៩៩]។

២៥៥. ក្រោយចូលកាន់កាប់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតស្ថានីយ៍វិទ្យុផ្សាយសម្លេងមួយ ដែលមានទីតាំងស្ថិតនៅស្ទឹងមានជ័យ ក្រុងភ្នំពេញ[៨០០]។ ស្ថានីយ៍វិទ្យុផ្សាយ សម្លេងនេះចាក់ផ្សាយនូវព័ត៌មាន ការឃោសនា បទចម្រៀង ខ្សែអាត់សម្លេងដែលជាសុន្ទរកថារបស់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា (រួមទាំងជនជាប់ចោទ នួន ជា និង ខៀវ សំផន) និងខ្សែអាត់សម្លេងដែលជាបទសម្ភាសន៍របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា (រួមទាំងជនជាប់ចោទ ខៀវ សំផន) ផងដែរ[៨០១]។

---

[៧៩៨] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (ឡុង នរិន្ទ) ទំព័រ ៦៤-៦៥; ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (ស្នួង ស៊ីគឿន) ទំព័រ ៧៧-៧៨, ៧៩-៨២។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ១៨-១៩, ២០-២១, ៦២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស សៀក ឯកសារ E3/379 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00294805-00294806។

[៧៩៩] ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៦៦-៧០, ៧១។ របាយការណ៍របស់ក្រសួងការពារជាតិសហរដ្ឋអាមេរិក ឯកសារ E3/5702 ចុះខែ មករា ឆ្នាំ ២០០១ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00649930-00649931។ បទសម្ភាសន៍ជាមួយ ជា ស៊ីម ឯកសារ E3/1568 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ទំព័រ ១៥-១៧ ERN (ភាសាខ្មែរ) 00713933-00713935។

[៨០០] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00000838 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស សៀក ឯកសារ E3/379 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00294805-00294806។

[៨០១] ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៨៧-៨៨ (លើកឡើងអំពី "ផ្នែកអានព័ត៌មាន" នៅក្រសួងឃោសនាការ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៥៩-៦០ (បញ្ជាក់ថា ខ្សែអាត់សម្លេងនៃសុន្ទរកថារបស់មេដឹកនាំត្រូវបានចាក់ផ្សាយតាមវិទ្យុ)។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទឿង) ទំព័រ ៦៦-៦៧ (នៅចាំថាធ្លាប់បានស្តាប់ឮសុន្ទរកថាថ្លែងឡើងដោយជនជាប់ចោទ នួន ជា តាមវិទ្យុ)។

២៥៦. ក្រសួងឃោសនាការ និងព័ត៌មាន ទទួលខុសត្រូវលើការរៀបចំសម្ភារៈសម្រាប់ចាក់ផ្សាយក្រោមការណែនាំ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់របស់គណៈកម្មាធិការអចិន្ត្រៃយ៍[៨០២]។ កម្មវិធីវិទ្យុផ្សាយសម្លេងបានរាយការណ៍អំពីបញ្ហាមួយចំនួនដូចជា អំពីបញ្ហាកសិកម្ម គម្រោងសាងសង់ ការចាប់ខ្លួន និងអ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយបានបញ្ចុះបញ្ចូលអ្នកស្តាប់ឲ្យប្រឹងប្រែងធ្វើការងារ ការពារប្រទេស និងដើរតាមមាគ៌ាបក្ស[៨០៣]។ កម្មវិធីមួយត្រូវបានចាក់ផ្សាយ

---

ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៣៥ (នៅចាំថាធ្លាប់បានស្តាប់ឮសុន្ទរកថាថ្លែងឡើងដោយជនជាប់ចោទ ខៀវ សំផន តាមវិទ្យុ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ២២-២៥ (និយាយសំដៅទៅការចាក់ផ្សាយព័ត៌មាន ចម្រៀង និងការឃោសនា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00273433-00273434 (លើកឡើងអំពីកិច្ចសម្ភាសន៍មួយជាមួយនឹងជនជាប់ចោទ ខៀវ សំផន ដែលត្រូវបានចាក់ផ្សាយតាមវិទ្យុ)។ សូមមើល ផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧ ។

[៨០២] ប្រតិចារឹក ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ២៩-៣១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម វុន ឯកសារ E3/381 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00357205-00357206 ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ២២-២៤។ *សូមមើល ផងដែរ* កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ (បង្ហាញថា គណៈកម្មាធិការអចិន្ត្រៃយ៍បានផ្តល់ការណែនាំលម្អិត ជាឧទាហរណ៍ អំពីខ្លឹមសារនៃការចាក់ផ្សាយ និងចំនួន ព្រមទាំងសាវតារនៃអ្នកនិពន្ធ)។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/228 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៧៦។

[៨០៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជាតិ ឯកសារ E3/5504 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00389515-00389516 (“ខ្ញុំបានស្តាប់ឮតាមវិទ្យុដែលផ្សាយថា តា ធុច ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានចាប់ខ្លួន”)។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ៦៦-៦៨ (បញ្ជាក់ថា ព័ត៌មាននេះត្រូវបានចាក់ផ្សាយតាមវិទ្យុពាក់ព័ន្ធនឹងជម្លោះជាមួយនឹងវៀតណាម និងលើកឡើងថា ការចាក់ផ្សាយតាមវិទ្យុ “មានគោល-បំណងអប់រំប្រជាជនឲ្យយល់អំពីប្រទេសឈ្លានពានជិតខាង” ហើយថា អ្នកស្តាប់ “ត្រូវបានប្រាប់ឲ្យប្តេជ្ញាការពារប្រយុទ្ធ ថែរក្សាប្រទេស និងទឹកដី”)។ ប្រតិចារឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ (ស សៀក), ទំព័រ៥៧-៥៩ (បញ្ជាក់ថា ការចាក់ផ្សាយតាមវិទ្យុមានបំណងជំរុញប្រជាជន និងលើកឡើងអំពីបញ្ហានានា ដូចជា មាគ៌ាបក្ស ការដឹកប្រឡាយ និងការការពារប្រទេស)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ២២-២៣ (និយាយសំដៅទៅការអានអត្ថបទ “ដែលជំរុញឲ្យប្រជាជនជីកប្រឡាយ និង លើកទំនប់” ព្រមទាំងអត្ថបទស្តីពីការបរាជ័យរបស់ លន់ នល់ និងអាមេរិក តាមវិទ្យុ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េស ម៉ាត់ ឯកសារ E3/352 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00186561-00186562 (“ខ្ញុំបានស្តាប់ឮតាមវិទ្យុថា មានសង្គ្រាម និងការចាប់ខ្លួនវៀតណាម”)។

ដោយមានគោលដៅផ្តោតទៅអ្នកស្តាប់ជាភាសាខ្មែរនៅកម្ពុជាក្រោម[៨០៤]។ កម្មវិធីមួយទៀត ដែលធ្វើការចាក់ផ្សាយយ៉ាងហោចណាស់ផ្នែកណាមួយជាភាសាវៀតណាមនោះ បានចាក់ផ្សាយខ្សែអាត់សម្លេងសារភាពរបស់ទាហានវៀតណាម ដែលត្រូវបានចាប់ខ្លួននៅក្នុងប្រទេសកម្ពុជា[៨០៥]។ នៅក្នុងខែ មីនា ឆ្នាំ ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានបញ្ជាឲ្យវិទ្យុចាក់ផ្សាយឲ្យបានញឹកញាប់លើប្រធានបទ "ការបោះឆ្នោត" ដែលខិតចូលជិតមកដល់នាពេលខាងមុខ ដោយបានលើកឡើងថា "បើមិនផ្សាយសោះ ខ្មាំងថាយើងផ្តាច់ការ គ្មានលទ្ធិប្រជាធិបតេយ្យ"[៨០៦]។

២៥៧. ក្រសួងការបរទេសក៏បានរៀបចំការឃោសនាសម្រាប់អ្នកស្តាប់ជាជនបរទេសផងដែរ។ កម្មវិធីវិទ្យុមួយចំនួនដែលនិយាយអំពីស្ថានភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាក់ផ្សាយជាភាសាវៀតណាម អង់គ្លេស បារាំង និងចិនផងដែរ[៨០៧]។

២៥៨. នៅតាមការដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជា មេក្រុជាច្រើនត្រូវបានគេតម្លើង ដើម្បីឲ្យប្រជាជនមូលដ្ឋានអាចស្តាប់ឮការផ្សាយរបស់ស្ថានីយវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា[៨០៨]។ សាក្សី ជា សាយ បានរំឭកឡើងវិញថា លោកនិងអ្នករួមការងារជាមួយលោក បានស្តាប់វិទ្យុមួយរួមគ្នានៅមន្ទីរក-១២ ប៉ុន្តែ មិនមានវិទ្យុស្តាប់ផ្ទាល់ខ្លួននោះទេ[៨០៩]។ ជាទូទៅ ប្រជាជនសាមញ្ញនៅក្នុងប្រទេសកម្ពុជា ពុំមានសេរីភាពទទួលបានព័ត៌មានតាមរយៈវិទ្យុនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ[៨១០]។

---

[៨០៤] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៣០-៣១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម វុន ឯកសារ E3/381 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00357205-00357206។

[៨០៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ២៩-៣១។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៦១-៦២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/361 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00194469-00194470។

[៨០៦] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/231 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00017124-00017125។

[៨០៧] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ៣០-៣២។ ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៥៤-៥៦។

[៨០៨] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៧០-៧១។

[៨០៩] ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៣៥-៣៦។ *សូមមើល ផងដែរ* ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៨៥-៨៦ (បានចងចាំថាមានពេលមួយនោះ គេបានកោះហៅលោក និងអ្នករួមការងារជាមួយលោកបានមកជុំគ្នាដើម្បីស្តាប់ការចាក់ផ្សាយព័ត៌មានតាមវិទ្យុ)។

[៨១០] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ២០-២២ (លើកឡើងថា ការស្តាប់វិទ្យុផ្ទាល់ខ្លួនគឺជា "គ្រោះថ្នាក់" មួយ)។

២៥៩. ការចាក់ផ្សាយសម្លេងតាមវិទ្យុជាសាធារណៈពីប្រទេសកម្ពុជា និងតាមបណ្តាប្រទេសផ្សេងទៀតនៅក្នុងតំបន់ ត្រូវបានពិនិត្យតាមដាន ថតសម្លេងទុក និងបកប្រែដោយបុគ្គលិករដ្ឋាភិបាលសហរដ្ឋអាមេរិកនៅក្នុងប្រទេសថៃ។ សេចក្តីរាយការណ៍អំពីការចាក់ផ្សាយត្រូវបានបញ្ជូនមកស្ថានទូតនានារបស់សហរដ្ឋអាមេរិកនៅជុំវិញពិភពលោកតាមរយៈសារទូរលេខ ដែលជាផ្នែកមួយនៃ "ការិយាល័យផ្សព្វផ្សាយព័ត៌មានទៅបរទេស ("FBIS")"[៨១១]។ កម្រងនៃសេចក្តីរាយការណ៍របស់ការិយាល័យផ្សព្វផ្សាយព័ត៌មានទៅបរទេសចំនួន ៤៩ ច្បាប់ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលជំនុំជម្រះ[៨១២]។

២៦០. សេចក្តីសង្ខេប និងប្រតិចារឹកនៃការផ្សាយសម្លេងតាមវិទ្យុរបស់របបកម្ពុជាប្រជាធិបតេយ្យក៏ត្រូវបានចងក្រង បកប្រែជាភាសាអង់គ្លេស និងបោះពុម្ពផ្សាយដោយសាជីវកម្មផ្សាយសម្លេងរបស់ចក្រភពអង់គ្លេសផងដែរ ("BBC") ដែលនេះជាផ្នែកមួយនៃការ "សង្ខេបសេវាកម្មផ្សាយសម្លេងនៅទូទាំងពិភពលោក ("SWB")"[៨១៣]។ កម្រងនៃសេចក្តីរាយការណ៍សង្ខេបសេវាកម្មផ្សាយសម្លេងនៅទូទាំងពិភពលោកចំនួន ៤៥ ច្បាប់ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ[៨១៤]។

---

[៨១១] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៤៩។ *សូមមើល ផងដែរ* ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨៣។

[៨១២] កម្រងឯកសារ FBIS, ឯកសារ E3/30, E3/75, E3/76, E3/77, E3/118, E3/119, E3/120, E3/143, E3/147, E3/271, E3/272, E3/273, E3/274, E3/275, E3/276, E3/277, E3/278, E3/279, E3/280, E3/281, E3/282, E3/283, E3/284, E3/285, E3/286, E3/287, E3/288, E3/289, E3/290, E3/291, E3/292, E3/293, E3/294, E3/295, E3/296, E3/488, E3/1339, E3/1355, E3/1356, E3/1357, E3/1358, E3/1359, E3/1360, E3/1361, E3/1362, E3/1363, E3/1364, E3/1365, E3/1366, ខែ មករា ឆ្នាំ ១៩៧៥ – ខែ មករា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះបានផ្អែកលើផ្នែកទាំងនេះនៃកម្រងឯកសារ FBIS តែប៉ុណ្ណោះ ដែលជាប់ពាក់ព័ន្ធ និងដែលត្រូវបានបកប្រែទៅជាភាសាផ្លូវការនៃ អ.វ.ត.ក។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងករណីលើកលែងខ្លះ និងដើម្បីធានាដល់ការបង្ហាញភស្តុតាងឲ្យបានពេញលេញ អង្គជំនុំជម្រះបានពិនិត្យមើលរបាយការណ៍នៃការិយាល័យផ្សព្វផ្សាយព័ត៌មានទៅបរទេស។ របាយការណ៍ទាំងនេះមានតែជាភាសាអង់គ្លេស ហើយវាស៊ីសង្វាក់នឹងភស្តុតាងផ្សេងៗទៀត។

[៨១៣] សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារ E3/1593 ទំព័រ xi ERN (ភាសាអង់គ្លេស) 00678493 (បញ្ជាក់ថា របាយការណ៍របស់ SWB ត្រូវបានចងក្រងឡើងដោយ BBC)។ *សូមមើល ផងដែរ* សេចក្តីថ្លែងការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ឯកសារ E3/4198 ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00338189-00338190។

[៨១៤] កម្រងឯកសាររបស់ SWB ដូចជា E3/133, E3/298, E3/299, E3/301, E3/686, E3/1241, E3/1280, E3/1349, E3/1350, E3/1372, E3/1376, E3/1378, E3/1379, E3/1380, E3/1381, E3/1400, E3/1402,

### ៦.១.៥ ទស្សនាវដ្ដី

២៦១. ចាប់ផ្ដើមពីអំឡុងពេលមុនឆ្នាំ ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជាបានបោះពុម្ពផ្សាយទស្សនាវដ្ដីរបស់បក្សមួយចំនួន ដែលទស្សនាវដ្ដីទាំងនោះមានចំណងជើងថា "ទង់បដិវត្ត" និង "ទង់យុវជន និងយុវនារីបដិវត្ត" ហើយដែលការបោះពុម្ពនេះធ្វើឡើងប្រហែលជាមួយខែម្ដង[៨១៥]។ នៅមុនឆ្នាំ ១៩៧៥ "ទង់បដិវត្ត" ត្រូវបានរៀបចំ និងចែកចាយជាសម្ងាត់។ ឯកសារនេះត្រូវបានសរសេរដោយដៃ ហើយមានសំណៅមួយចំនួនតូចតែប៉ុណ្ណោះដែលត្រូវបានចម្លងឡើងវិញដើម្បីផ្សព្វផ្សាយ[៨១៦]។

២៦២. ចាប់ពីឆ្នាំ ១៩៧៥ មក ទស្សនាវដ្ដី "ទង់បដិវត្ត" ត្រូវបានវាយដោយអង្គុលីលេខ និងបានថតចម្លងដោយម៉ាស៊ីនអុហ្វសិត (offset printing)[៨១៧]។ ទាំង "ទង់បដិវត្ត" និង "ទង់យុវជន និងយុវនារីបដិវត្ត" ត្រូវបានបោះពុម្ពផ្សាយនៅមន្ទីរ ក-២៥ និងមន្ទីរ ក-២៦ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនាការ និងព័ត៌មាន ដែលដឹកនាំដោយ ហ៊ូ នឹម[៨១៨]។ សាក្សី គឹម វុន

---

E3/1403, E3/1404, E3/1405, E3/1406, E3/1407, E3/1408, E3/1410, E3/1412, E3/1413, E3/1414, E3/1415, E3/1418, E3/1423, E3/1486, E3/1487, E3/1590, E3/1751, E3/2306, E3/2674, E3/2726, E3/2728, E3/2730, E3/3165, E3/3742, E3/3743, E3/3749, E3/5710 ។

[៨១៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៨៦-៨៨។ ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ៦៤-៦៦។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (ស្បូត្រ ទៀង) ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៥៦។

[៨១៦] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៥-៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ៣១។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ៨៦-៨៨។

[៨១៧] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ១៦-១៧។ វាអាចថា មានតែក្របទំព័រមុខតែប៉ុណ្ណោះដែលត្រូវបានបោះពុម្ពឡើងដោយប្រើប្រាស់បច្ចេកទេសបោះពុម្ពដោយម៉ាស៊ីនអុបសិត៖ *សូមមើល* ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៦៣។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ១៧-១៨។

[៨១៨] ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៦១-៦៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ៦៥។ ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ១៤។ ក្រោយពីចាប់ខ្លួន ហ៊ូ នឹម នៅក្នុងឆ្នាំ ១៩៧៧ ក្រសួងឃោសនាការបានច្របាច់បញ្ចូលជាមួយនឹងក្រសួងសិក្សាធិការ ហើយ យុន យ៉ាត បានកាន់កាប់ក្រសួងដែលមានការច្របាច់បញ្ចូលគ្នានេះ៖ ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ហ៊ូ នឹម ឯកសារ E3/1550 ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ

ដែលធ្លាប់ធ្វើការនៅក្រសួងឃោសនាការ និងព័ត៌មាន ពុំអាចធ្វើការប៉ាន់ស្មានឲ្យបានច្បាស់អំពីចំនួនទស្សនាវដ្តីដែលត្រូវបានបោះពុម្ពផ្សាយនោះទេ។ ប៉ុន្តែ គាត់នៅចាំបានថា គាត់បានឃើញលេខផ្សាយនីមួយៗគឺ "គរជាគីប" ដែលគេបានរៀបចំដើម្បីចែកចាយ[៨១៩]។

២៦៣. ទោះបីជាទស្សនាវដ្តី "ទង់បដិវត្ត" និង "ទង់យុវជននិងយុវនារីបដិវត្ត" ត្រូវបានចែកចាយឲ្យតែសមាជិកបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ តែមិនមែនមានន័យថាសមាជិកទាំងអស់សុទ្ធតែទទួលបាននូវទស្សនាវដ្តីនេះ នោះទេ[៨២០]។ ទស្សនាវដ្តីទាំងនេះត្រូវបានរំពឹងថានឹងយកទៅអានរួមគ្នាក្នុងចំណោមបណ្តាសមាជិកបក្សផ្សេងៗទៀត[៨២១]។ ទស្សនាវដ្តីមួយចំនួនត្រូវបានចែកចាយតាមក្រសួងនានានៃរបបកម្ពុជាប្រជាធិបតេយ្យ អង្គភាពយោធា និងមន្ទីររបស់មជ្ឈិមបក្ស និងកម្មាភិបាលនៅថ្នាក់ភូមិភាគ តំបន់ ស្រុក និងឃុំផងដែរ[៨២២]។

---

១៩៧៧។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ ២៥-២៦។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៨៨-៨៩។

[៨១៩] ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ៧៤-៧៥ ៧៦-៧៧។

[៨២០] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ៤០។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៤១-៤២។ ប្រតិចារឹក ថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤៤។ Timothy Carney "ការរៀបចំអំណាច" នៅក្នុង *ប្រទេសកម្ពុជា* ឆ្នាំ ១៩៧៥-១៩៧៨៖ *Rendez vous With Death (ការណាត់ជួបនឹងសេចក្តីស្លាប់)* ឯកសារ E3/49 ទំព័រ ៨៧ ERN (ភាសាអង់គ្លេស) 00105136។

[៨២១] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៣០-៣១។

[៨២២] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៥-១៧ (លើកឡើងថា សំណៅថតចម្លងជាច្រើនច្បាប់នៃ "ទង់បដិវត្ត" ត្រូវបានចែកចាយទៅឲ្យមន្ទីរស-២១)។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន) ទំព័រ ២៤-២៥ (លើកឡើងថា សំណៅថតចម្លងនៃ "ទង់បដិវត្ត" និង "ទង់យុវជន និងយុវនារីបដិវត្ត" ត្រូវបានចែកចាយទៅគ្រប់ក្រសួង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ឯកសារ E3/4593 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00485624-00485625 (នៅចាំបានថា៖ ទស្សនាវដ្តីដែលមានទង់ ២ ឬ ៥ នៅលើគ្របមុខត្រូវបានចែកចាយទៅឲ្យយុវកក ហើយគាត់អាចអានទស្សនាវដ្តីទាំងនេះ ពីព្រោះគេបានបញ្ជូនវាទៅឲ្យ "អង្គភាពនានា")។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ៥៦ ("ទស្សនាវដ្តី "ទង់បដិវត្ត" ត្រូវបានចែកចាយទៅឲ្យកងទ័ពយកទៅអាន")។ ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ៧៤-៧៧ (បញ្ជាក់ថា ទស្សនាវដ្តី "ទង់បដិវត្ត" ត្រូវបានចែកចាយទៅប្រជាជននៅតាមភូមិភាគ និងតំបន់)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៣២-៣៤ (នៅចាំបានថា៖ ធ្លាប់ឃើញទស្សនាវដ្តី "ទង់បដិវត្ត" នៅមន្ទីរតំបន់)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ១៥-១៦ (បញ្ជាក់ថា៖ សំណៅថតចម្លងនៃ "ទង់បដិវត្ត"

២៦៤. ដំបូងឡើយ ជនជាប់ចោទ នួន ជា បានបដិសេធថា គាត់គ្មានតួនាទីក្នុងការ "រៀបចំ" ទស្សនាវដ្ដី "ទង់បដិវត្ត" ទេ[៨២៣]។ ប៉ុន្តែក្រោយមក ជនជាប់ចោទ នួន ជា បានទទួលស្គាល់ថា "ទង់បដិវត្ត" ត្រូវបានសរសេរឡើងដោយសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ភាគច្រើនត្រូវបានសរសេរឡើងដោយគាត់ផ្ទាល់ និង ប៉ុល ពត[៨២៤]។ ការទទួលស្គាល់នេះមានភាពស្របគ្នាទៅនឹងការទទួលស្គាល់របស់ជនជាប់ចោទ នួន ជា ដែលថា គាត់ជា "សមាជិកត្រៀមម្នាក់ ដែលទទួលការងារខាងឃោសនាការ និងសរសេរអត្ថបទសម្រាប់កាសែត" ឲ្យបក្សកុម្មុយនីស្តឥណ្ឌូចិន និង បក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាបុព្វាធិការីនៃបក្សកុម្មុយនីស្តកម្ពុជា[៨២៥] នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០[៨២៦]។ ក្រោយមក ជនជាប់ចោទ នួន ជា បានកែប្រែអំពីតួនាទីរបស់គាត់ម្តងទៀត ដោយបានបដិសេធថា គាត់មិនមែនជាអ្នកនិពន្ធអត្ថបទ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី "ទង់បដិវត្ត" នោះទេ ហើយបានអះអាងថា ប៉ុល ពត មាន "ក្រុមជំនួយការផ្ទាល់របស់គាត់ ដែលជាអ្នកទទួលខុសត្រូវក្នុងការសរសេរអត្ថបទ"[៨២៧]។ បន្ទាប់មកទៀត ជនជាប់ចោទ នួន ជា បាន

---

ត្រូវបានគណៈកម្មាធិការស្រុកបញ្ជូនបន្តទៅឲ្យសាក្សី យុន គីម ដែលជាមេឃុំ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ១១ (លើកឡើងថាៈ "ទង់បដិវត្ត" និង "ទង់ យុវជន និងយុវនារីបដិវត្ត" ត្រូវបានចែកចាយទៅតាមសហករណ៍)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីម វុន ឯកសារ E3/380 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00357200 (លើកឡើងថាៈ "ទង់បដិវត្ត" ត្រូវបានចែកចាយទៅថ្នាក់ភូមិភាគ តំបន់ និងស្រុក)។ ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ ៣៨-៣៩ (បញ្ជាក់ថាៈ "ទង់បដិវត្ត" ត្រូវបានបញ្ជូនទៅឲ្យផ្នែករបស់សាក្សី ខៀវ អេន នៅក្នុងក្រសួងឃោសនាការ)។ កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី ឡាញ ដុស ឯកសារ E3/70 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00404637-00404638 (លើកឡើងថាៈ "ទង់បដិវត្ត" ត្រូវបានចែកចាយទៅឲ្យ "គ្រប់មន្ទីរ និងក្រសួង")។

[៨២៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤-៥។ សូមមើលផ្នែកទី ៧ ស្តីពី តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១១ ។

[៨២៤] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ៦២-៦៣។

[៨២៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៧។ ប្រវត្តិចលនាតស៊ូពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៧០ ដោយ នួន ជា ឯកសារ E3/131 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00062298-00062299។ អត្ថបទរបស់ L. Summers៖ *បក្សកុម្មុយនីស្តកម្ពុជា៖ ទ័ពស្រួចសម្ងាត់នៃបដិវត្តរបស់ ប៉ុល ពត៖ សេចក្តី-អត្ថាធិប្បាយចំពោះសេចក្តីថ្លែងការណ៍របស់ នួន ជា* ឯកសារ E3/53 ចុះខែ មីនា ឆ្នាំ ១៩៨៧ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) S 00699283-00699284។

[៨២៦] ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ៧-៨។ ប្រវត្តិចលនាតស៊ូពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៧០ ដោយ នួន ជា ឯកសារ E3/131 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៣-១៦ ERN (ភាសាខ្មែរ) 00062303-00062306។

[៨២៧] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៥។

បដិសេធមិនឆ្លើយតបទៅនឹងសំណួរ[៨២៨]។ ដោយផ្អែកតាមការទទួលស្គាល់នាពេលមុនៗរបស់ជនជាប់ចោទ នួន ជា និងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់នៅពេលខ្លះនោះ អង្គជំនុំជម្រះយល់ឃើញថា ការបដិសេធរបស់ជនជាប់ចោទ នួន ជា មិនអាចធ្វើឱ្យអង្គជំនុំជម្រះជឿបានទេ តែអង្គជំនុំជម្រះជឿថា ជនជាប់ចោទ នួន ជា ពិតជាអ្នកនិពន្ធដ៏សំខាន់ម្នាក់នៃទស្សនាវដ្ដី "ទង់បដិវត្ត"[៨២៩]។

២៦៥. បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា វាមានសារៈសំខាន់ណាស់ដែលសមាជិករបស់ខ្លួនត្រូវអានទស្សនាវដ្ដី "ទង់បដិវត្ត"[៨៣០]។ ជាញឹកញាប់ ទស្សនាវដ្ដី"ទង់បដិវត្ត" ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងអប់រំនៅក្នុងវគ្គអប់រំ ឬ វគ្គរៀនសូត្រនយោបាយ[៨៣១]។ ទស្សនាវដ្ដី"ទង់យុវជន និងយុវនារីបដិវត្ត" មានគោលដៅជាក់លាក់អប់រំដល់សមាជិកនៃយុវកកនៃបក្សកុម្មុយនីស្តកម្ពុជា[៨៣២]។ ទស្សនាវដ្ដីទាំងនេះមានផ្ទុកនូវឯកសារមួយចំនួនដូចជាសុន្ទរកថា និងបទឧទ្ទេសនាមដែលបានធ្វើឡើងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[៨៣៣] អត្ថបទស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា សមិទ្ធផលដែលរបបកម្ពុជាប្រជាធិបតេយ្យអះអាងថាសម្រេចបាន និងមាគ៌ាបក្សជារួម[៨៣៤] ផែនការលម្អិត

[៨២៨] ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ៥៤។

[៨២៩] សូមមើលផ្នែកទី ៧ ស្ដីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១១ ។

[៨៣០] ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គីម វុន) ទំព័រ៧៤។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១០-១១។

[៨៣១] ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ១៤។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៥-១៧។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ១៥-១៦ ២១-២២។ ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៥១-៥៣។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ១៦-១៧។

[៨៣២] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គីម វុន) ទំព័រ ៥៧។ *សូមមើល ឧទាហរណ៍* ទស្សនាវដ្ដី យុវជន និងយុវនារីបដិវត្ត ឯកសារ E3/729 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063398 (និយាយសំដៅជាក់លាក់លើ "យុវកក")។

[៨៣៣] *សូមមើល ឧទាហរណ៍* ទង់បដិវត្ត ឯកសារ E3/25 ចុះខែ ធ្នូ-មករា ឆ្នាំ ១៩៧៦-៧៧ ទំព័រ ២៣-១០៣ ERN (ភាសាខ្មែរ) 00063014-00063057។ ទង់បដិវត្ត ឯកសារ E3/10 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ១-១៦ ERN (ភាសាខ្មែរ) 00063062-00063070។ ទង់បដិវត្ត ឯកសារ E3/215 ចុះខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៣-៦៧ ERN (ភាសាខ្មែរ) 00064588-00064620។

[៨៣៤] *សូមមើល ឧទាហរណ៍* ទង់បដិវត្ត ឯកសារ E3/747 ចុះខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣៥-៥៣ ERN (ភាសាខ្មែរ) 00064641-00064650។ ទង់បដិវត្ត ឯកសារ E3/736 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១-១១២ ERN (ភាសា

សម្រាប់អនាគត[៨៣៥] សេចក្តីណែនាំពីបក្សដល់សមាជិករបស់ខ្លួន[៨៣៦] និងយ៉ាងណាចណាស់នៅក្នុងទស្សនាវដ្តី "ទង់យុវជន និងយុវនារីបដិវត្ត" មានកំណាព្យបដិវត្ត ដោយកំណាព្យខ្លះបង្ហាញពីការប៉ុនប៉ងយ៉ាងច្បាស់លាស់របស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបញ្ចុះបញ្ចូល និងបំពាក់បំប៉នយុវជន និងយុវនារី[៨៣៧]។

២៦៦. ទស្សនាវដ្តី "ទង់បដិវត្ត" ចំនួន ២៤ លេខ ខុសៗគ្នា និងទស្សនាវដ្តី "ទង់យុវជន និងយុវនារីបដិវត្ត" ចំនួន ២៨ លេខ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១[៨៣៨]។ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ក្រុមមេធាវីការពារក្តី នួន ជា បានតវ៉ាអំពីយថាភាពនៃសំណៅថតចម្លងរបស់ទស្សនាវដ្តីទាំងនោះ ដែលមាននៅក្នុងសំណុំរឿង[៨៣៩]។ ក្រោយមកសាក្សី Stephen HEDER បានផ្តល់សក្ខីកម្ម អំពីប្រភព និងយថាភាពនៃសំណៅថត

---

ខ្មែរ) 00064756-00064814។ ទង់បដិវត្ត ឯកសារ E3/746 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣៣-៤៣ ERN (ភាសាខ្មែរ) 00064501-00064506។ ទង់បដិវត្ត ឯកសារ E3/768 ចុះខែ មីនា ឆ្នាំ ១៩៧៧ ទំព័រ ១៧-៣៧ ERN (ភាសាខ្មែរ) 00376203-00376214។

[៨៣៥] *សូមមើល ឧទាហរណ៍* ទង់បដិវត្ត ឯកសារ E3/748 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២៦-៣៤ ERN (ភាសាខ្មែរ) 00063252-00063256។ ទង់បដិវត្ត ឯកសារ E3/743 ចុះខែ កក្កដា ឆ្នាំ ១៩៧៧ ទំព័រ ១-១២ ERN (ភាសាខ្មែរ) 00062879-00062885។

[៨៣៦] *សូមមើល ឧទាហរណ៍* ទង់បដិវត្ត ឯកសារ E3/135 ចុះខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ៤៥-៦១ ERN (ភាសាខ្មែរ) 00062824-00062833។ ទង់បដិវត្ត ឯកសារ E3/742 ចុះខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ២៤-២៦ ERN (ភាសាខ្មែរ) 00062997-00062998។

[៨៣៧] *សូមមើល ឧទាហរណ៍* ទង់បដិវត្ត ឯកសារ E3/729 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៥ ទំព័រ ៥៩-៦១ ERN (ភាសាខ្មែរ) 00063432-00063433។ ទង់បដិវត្ត ឯកសារ E3/734 ចុះខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៤៨-៥០ ERN (ភាសាខ្មែរ) 00064151-00064152។

[៨៣៨] ទស្សនាវដ្តីទង់បដិវត្ត ឯកសារ E3/4, E3/5, E3/10, E3/11, E3/25, E3/135, E3/139, E3/166, E3/170, E3/193, E3/215, E3/736 (ឯកសារ E3/737 ផងដែរ), E3/738 (ឯកសារ E3/739 ផងដែរ), E3/742, E3/743, E3/744, E3/745, E3/746, E3/747, E3/748, E3/759, E3/760 (ឯកសារ E3/761 ផងដែរ), E3/762 និង E3/4604, ចុះខែ សីហា ឆ្នាំ ១៩៧៥ – ខែ កញ្ញា ឆ្នាំ ១៩៧៨។ ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត ឯកសារ E3/146, E3/726, E3/728, E3/729, E3/730, E3/732, E3/733, E3/734, E3/749, E3/750, E3/751, E3/752, E3/753, E3/754, E3/755, E3/756, E3/757, E3/758, E3/765, E3/766 ,E3/767, E3/768, E3/769, E3/770, E3/771, E3/772, E3/773 និង E3/774, ចុះខែ សីហា ឆ្នាំ ១៩៧៤ - ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[៨៣៩] ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០-៨៣ ។

ចម្លងរបស់ទស្សនាវដ្ដីនីមួយៗ[៨៤០] ហើយដូចគ្នានេះដែរ សាក្សី គឹម វុន ក៏បានបញ្ជាក់ស្រដៀងគ្នាផងដែរថា សំណៅថតចម្លងនៃទស្សនាវដ្ដី"ទង់បដិវត្ត" មួយច្បាប់នៅក្នុងសំណុំរឿងគឺជាសំណៅថតចម្លងចេញពីច្បាប់ដើម[៨៤១]។ អង្គជំនុំជម្រះក៏បានស្ដាប់សក្ខីកម្មរបស់សាក្សី វ៉ាន់ថាន់ ពៅដារ៉ា និង ឆាំង យុ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ។ សក្ខីកម្មរបស់សាក្សីទាំងពីរបានបញ្ជាក់អំពីរបៀបនៃការទទួល ការរក្សាទុក ការបម្លែងជាប្រព័ន្ធឌីជីថល និងការបញ្ជាក់អំពីយថាភាព មុនពេលដែលឯកសារទាំងនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង[៨៤២]។ មិនតែប៉ុណ្ណោះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រៅពីការតវ៉ាអំពីយថាភាពនៃឯកសារ ក្រុមមេធាវីការពារក្ដី នួន ជា បានពឹងផ្អែកយ៉ាងច្រើនទៅលើសំណៅថតចម្លងនៃទស្សនាវដ្ដី "ទង់បដិវត្ត" និង "ទង់យុវជន និងយុវនារីបដិវត្ត" ដែលមាននៅក្នុងសំណុំរឿង ដើម្បីធ្វើជាភ័ស្តុតាងនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន[៨៤៣]។ អង្គជំនុំជម្រះជឿជាក់ថា ទស្សនាវដ្ដី "ទង់បដិវត្ត" ទាំង ២៤ លេខ និងទស្សនាវដ្ដី "ទង់យុវជន និងយុវនារីបដិវត្ត" ទាំង ២៨ លេខ ដែលមាននៅក្នុងសំណុំរឿង គឺជាសំណៅដែលបានថតចម្លងត្រឹមត្រូវពីច្បាប់ដើមនៃទស្សនាវដ្ដីរបស់បក្សកុម្មុយនីស្តកម្ពុជាពិតប្រាកដមែន។

### ៦.១.៦ ការតាមដានសេចក្ដីរាយការណ៍សារព័ត៌មានបរទេស

២៦៧. គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាឲ្យក្រសួងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ "តាមដានដំណឹង [...] ឲ្យជាប់ រាល់ម៉ោង រាល់ថ្ងៃ" និងបញ្ជូនរបាយការណ៍ដើម្បីធ្វើយ៉ាងណាអាចចាត់វិធានការសមស្របបាន[៨៤៤]។ បែបបទលម្អិតត្រូវបាន

---

[៨៤០] ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (David CHANDLER) ទំព័រ ៩-១៥ (និយាយសំដៅទៅទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត ឯកសារ E3/724 ចុះខែ កក្កដា ឆ្នាំ ១៩៧៥ និងទង់បដិវត្ត ឯកសារ E3/731 ចុះខែ ធ្នូ ឆ្នាំ ១៩៧៥ - ខែ មករា ឆ្នាំ ១៩៧៦)។

[៨៤១] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ៧ (និយាយសំដៅទៅទង់បដិវត្ត ឯកសារ E3/10 ចុះខែ កញ្ញា - តុលា ឆ្នាំ ១៩៧៦)។

[៨៤២] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅដារ៉ា) ទំព័រ ១៨-២០, ៧៦-៧៧។ ប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាំង យុ) ទំព័រ ៦៥-៦៧។

[៨៤៣] *សូមមើល ឧទាហរណ៍* សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដី នួន ជា កថាខណ្ឌ ១៥៦, ១៥៧, ១៥៨, ១៦៣, ៤៦៥, ៤៧៤។

[៨៤៤] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/231 ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00017126-00017127 (ធ្វើកំណត់ហេតុលើកិច្ចប្រជុំការងារស្ដីពីឃោសនាការដែលបានចូលរួមដោយ ប៉ុល ពត និងជនជាប់ចោទ នួន ជា និង ខៀវ សំផន)។

បង្កើតឡើងសម្រាប់ក្រសួងឃោសនាការធ្វើការសង្ខេប និងរាយការណ៍អំពីដំណឹងបរទេសទាំងនេះ ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍[៨៤៥]។ តាមសេចក្តីណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ បុគ្គលិកក្រសួងឃោសនាការត្រូវតាមដានការផ្សាយព័ត៌មានបរទេសដែលបានផ្សាយជាភាសាអង់គ្លេស និងបារាំង[៨៤៦]។ សេចក្តីរាយការណ៍មកពីទីភ្នាក់ងារសារព័ត៌មានក្រៅប្រទេស និងសេវាកម្មព័ត៌មានបញ្ជូនតាមទូរលេខ ត្រូវបានទទួលតាមរយៈទូរពុម្ព បន្ទាប់មកត្រូវបានថតចម្លង និងបកប្រែទៅជាភាសាខ្មែរសម្រាប់ចែកចាយបន្ត[៨៤៧]។

២៦៨. បុគ្គលិកនៅក្រសួងការបរទេសបានបំពេញការងារស្រដៀងគ្នា ដូចជាការស្តាប់វិទ្យុបរទេសដែលផ្សាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងរៀបចំព្រឹត្តិប័ត្រសង្ខេបសម្រាប់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា[៨៤៨]។ សាក្សី សួង ស៊ីគឿន ដែលធ្លាប់ធ្វើការនៅក្រសួងការបរទេស ចាប់តាំងពីឆ្នាំ ១៩៧៥ ហើយក្រោយមកបានក្លាយជាប្រធាននាយកដ្ឋានព័ត៌មាន និងឃោសនាការនៅក្នុងឆ្នាំ ១៩៧៧[៨៤៩] នោះ បានលើកឡើងថា គាត់ និងសហការីរបស់គាត់ទទួលខុសត្រូវក្នុងការតាមដានកម្មវិធីផ្សាយជាភាសាបារាំង អង់គ្លេស ចិន និងវៀតណាម[៨៥០]។

---

[៨៤៥] ក្រសួងនេះបានទទួលការណែនាំចំនួនពីរ ដូចតទៅនេះ៖ (i) "ជូនដំណឹងទៅអង្គការរាល់ថ្ងៃ ដូចធម្មតា" ស្របតាមនីតិវិធីដែលបានបង្កើតឡើង ដោយយកចិត្តទុកដាក់សង្ខេប និងវិភាគព្រឹត្តិការណ៍សំខាន់ៗអំពីរបបនេះ ដើម្បីឲ្យគណៈ-កម្មាធិការអចិន្ត្រៃយ៍អាចយល់ស្ថានភាពទាំងនេះ ហើយនឹងចាត់វិធានការឲ្យបានសមស្រប ពោលគឺ នីរសារត្រូវទៅប្រមូលដំណឹងពីក្រសួងនៅវេលាម៉ោង ៥.១៥ នាទី ល្ងាច ជារៀងរាល់ថ្ងៃ។ (ii) នៅក្នុងកាលៈទេសៈពិសេស "ទូរស័ព្ទ និងរាយការណ៍ជូនអង្គការភ្លាម" ផងដែរ បើមានអ្វីសំខាន់ជាពិសេស៖ *សូមមើល* កំណត់ហេតុប្រជុំគណៈកម្មាធិការ-អចិន្ត្រៃយ៍ ឯកសារ E3/231 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00017126-00017127 ។

[៨៤៦] ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ ១៧-១៩។

[៨៤៦] ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ ១៧-១៩។

[៨៤៧] ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (ខៀវ អេន) ទំព័រ ១៧-១៩។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៥៤-៥៥។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00000838។

[៨៤៨] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣២-៣៣ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Laurence PICQ ឯកសារ E3/98 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00250804-00250805។

[៨៤៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ២៦-២៧។

[៨៥០] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣២។ *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ យូរ៉ាន់ ឯកសារ E3/46 ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ)

ពួកគាត់ត្រូវបានគេណែនាំឲ្យរាយការណ៍ជូន អៀង សារី អំពីព័ត៌មានដែលពួកគាត់បានស្ដាប់ឮ ដោយមិនត្រូវបន្ថែម ឬបន្ថយព័ត៌មានឡើយ។ យោងតាមសាក្សី សួង ស៊ីគឿន បានបញ្ជាក់ថា អៀង សារី "ចូលចិត្តឲ្យរាយការណ៍ពីអ្វីដែលកើតឡើងពិតប្រាកដ នេះហើយជាមូលហេតុដែលធ្វើឲ្យយើងត្រូវរាយការណ៍ជូនគាត់ដូច្នេះ"[៨៥១]។

## ៦.២ ប្រព័ន្ធទំនាក់ទំនង

២៦៩. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលការណ៍រួមថា "ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ" និង "ថ្នាក់លើជូនដំណឹងដល់ថ្នាក់ក្រោមអំពីសភាពការណ៍រួម និងអំពីសេចក្ដីណែនាំ ដែលជាទិសការងារផ្សេងៗ"[៨៥២]។

២៧០. ក្នុងការអនុវត្តជាក់ស្ដែង កម្រិតនីមួយៗនៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា បានទំនាក់ទំនងគ្នា ភាគច្រើនត្រឹមតែជាមួយថ្នាក់លើ និងថ្នាក់ក្រោមផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ។ ទំនាក់ទំនងខ្សែទទឹងនៅក្រៅគណៈកម្មាធិការមជ្ឈិមគឺមានតិចតួចបំផុត[៨៥៣]។ ជាទូទៅ តំបន់ (លើកលែងតែតំបន់ស្វយ័ត) ស្រុក និងឃុំមិនទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការមជ្ឈិមដោយផ្ទាល់ទេ តែបញ្ជូន និងទទួលព័ត៌មានពីថ្នាក់លើ ឬថ្នាក់ក្រោមរបស់ខ្លួនផ្ទាល់តាមរយៈខ្សែសង្វាក់នៃការបញ្ជា[៨៥៤]។

---

00407728-00407729 (លើកឡើងថា តួនាទីរបស់គាត់មួយផ្នែកនៅក្រសួងការបរទេសគឺ "ស្ដាប់ដំណឹងតាមវិទ្យុបរទេស")។

[៨៥១] ប្រតិចារឹក ថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៣-៣៤។

[៨៥២] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣០-៣១ មាត្រា ៦, ERN (ភាសាខ្មែរ) 00442268។

[៨៥៣] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ១០។ ប្រតិចារឹកសវនាការលើសំណុំរឿង ០០១ (Craig ETCHESON) ឯកសារ E3/55 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧៣-៧៤, ERN (ភាសាខ្មែរ) 00330503-00330504។ ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៨៧-៨៨ ។ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន់) ទំព័រ ១-២។

[៨៥៤] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល ) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់ ) ទំព័រ ១២។ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ )ទំព័រ ១៤-១៦។

### ៦.២.១ ទំនាក់ទំនងនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស

២៧១. កំណត់ហេតុប្រជុំដែលនៅមានរហូតដល់ពេលនេះបានបង្ហាញថា គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បានប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាគ្នាអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[៨៥៥]។ លើសពីនេះទៀត សមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលរួមមាន ប៉ុល ពត ជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន បានជួបប្រជុំគ្នាជាហូរហែរនៅមន្ទីរ ក-១ និងមន្ទីរ ក-៣[៨៥៦]។

២៧២. មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានឆ្លើយឆ្លងគ្នាតាមរយៈសំបុត្រផងដែរ។ ឧទាហរណ៍ សាក្សី អឿន តាន (ដែលធ្លាប់ធ្វើការនៅមន្ទីរ ក-១ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៨៥៧]) បានចងចាំអំពីការបញ្ជូនសំបុត្រទៅវិញទៅមករវាង ប៉ុល ពត និងជនជាប់ចោទ នួន ជា ព្រមទាំងរវាង ប៉ុល ពត និង សុន សេន [៨៥៨]។ ដូចបានកត់សម្គាល់ខាងលើ ពេលខ្លះ មន្ទីររបស់គណៈកម្មាធិការ-មជ្ឈិមបានពិភាក្សាតាមទូរស័ព្ទអំពីបទបញ្ជា សំណើ និងព័ត៌មានផងដែរ[៨៥៩]។

២៧៣. តាមធម្មតា ទូរលេខដែលគណៈកម្មាធិការមជ្ឈិមបានទទួលពីថ្នាក់ក្រោម គឺត្រូវបញ្ជូនទៅមន្ទីរ ក-១ ដើម្បីធ្វើការបកប្រែអក្សរសម្ងាត់ (ប្រសិនបើចាំបាច់) រៀបចំចាត់ចែង និងចែកចាយទៅ

---

[៨៥៥] សូមមើលផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣ ។

[៨៥៦] ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ១៥-១៧ (បានរៀបរាប់អំពីការជួបប្រជុំរវាង អៀងធីរិទ្ធ និងជនជាប់ចោទ នួន ជា)។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៥៩-៦១ (បានលើកឡើងថា ប៉ុល ពត និងជនជាប់ចោទ នួន ជា និង ខៀវ សំផន ធ្លាប់បានហូបបាយជុំគ្នានៅមន្ទីរ ក-៣)។ ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១២ (ស វី) ទំព័រ ៧២-៧៣ (បានចង្អុលបង្ហាញថា ជនជាប់ចោទ ខៀវ សំផនធ្លាប់បានទៅពិនិត្យមើលមន្ទីរ ក-១ ញឹកញាប់ជាងមេដឹកនាំជាន់ខ្ពស់ដទៃទៀត)។ ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៦១-៦២ (បានអះអាងថា អៀង សារី និង ជនជាប់ចោទ នួន ជា និង ខៀវ សំផនបានជួបគ្នានៅមន្ទីរ ក-១)។ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៤៧-៤៩ (បានលើកឡើងថា៖ មេដឹកនាំជាន់ខ្ពស់ដទៃទៀត រួមទាំង សុន សេន, វ៉ន វេត និងជនជាប់ចោទ នួន ជា ធ្លាប់បានជួបជុំគ្នា និងហូបបាយរួមគ្នា)។ សូមមើលផ្នែកទី ៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧។ សូមមើលផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៣, ៣៨៦, ៤០៨ ។

[៨៥៧] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៣-៣៤។

[៨៥៨] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៨៤-៨៥។

[៨៥៩] *សូមមើល* ផ្នែកទី ៦ ស្តីពី ប្រព័ន្ធទំនាក់ទំនង កថាខណ្ឌ ២៥២។

តាមភាពសមស្រប[860]។ សាក្សី អឿន តាន បានជម្រាបជូនអង្គជំនុំជម្រះថា ទូរលេខទាំងអស់ដែលគាត់បានយកទៅជូន ប៉ុល ពត ក្រោយមក ត្រូវបានបញ្ជូនទៅឱ្យជនជាប់ចោទ នួន ជា[៨៦១]។ ក្រោយពីបានពិនិត្យទៅលើទូរលេខនានានៅក្នុងសំណុំរឿង និងក្រោយពីបានស្តាប់ការបង្ហាញភ័ស្តុតាងដែលថាមានការប្រជុំ និងពិភាក្សាគ្នាជាញឹកញាប់រវាងជនជាប់ចោទ នួន ជា និង ប៉ុល ពត និងថាពួកគេបានធ្វើការជិតស្និទ្ធជាមួយគ្នានោះ អង្គជំនុំជម្រះជឿជាក់ថា ទូរលេខភាគច្រើនដែលគេបានបញ្ជូនទៅឱ្យ ប៉ុល ពត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ក៏បានទទួលផងដែរ[៨៦២]។

### ៦.២.២ ទំនាក់ទំនងរវាងគណៈកម្មាធិការមជ្ឈិម នឹងភូមិភាគ ឬតំបន់ស្វយ័ត

២៧៤. ភូមិភាគ និងតំបន់ស្វយ័ត បានរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិម[៨៦៣]។ នៅក្នុងអង្គប្រជុំមួយដែលតំណាងភូមិភាគ និងតំបន់ស្វយ័តមួយចំនួនបានចូលរួមនៅខែមីនា ឆ្នាំ ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានចេញសេចក្តីណែនាំដូចតទៅ ស្តីពីនីតិវិធីជាធរមានសម្រាប់សរសេររបាយការណ៍៖

> ស្នើរាយការណ៍៖ ជូនអចិន្ត្រៃយ៍រាល់អាទិត្យ អំពីសភាពការណ៍ភ្លីស្រែ។ ជូនណារាយការណ៍ជាទិដ្ឋភាពរួម ជូនណារាយការណ៍តាមមុខព្រួញមួយៗ។ ស្នើរាយការណ៍ខ្លីៗតាមទូរលេខឱ្យអចិន្ត្រៃយ៍ដឹងសភាពការណ៍ ដើម្បីណែនាំបានទាន់ពេលវេលា[៨៦៤]។

---

[៨៦០] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឿន តាន ឯកសារ E3/33 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00231807-00231808។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៥៦-៥៧។ កិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សី គង់ សុខា ឯកសារ E3/465 ចុះថ្ងៃទី ២១ ខែ មករា ឆ្នា ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00204750-00204751។ *សូមមើល* ផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៥៤-៥៥។ ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ២៤-២៥ (បានលើកឡើងថា "ប៉ុន" និង "ថៃ" ដែលធ្វើការនៅមន្ទីរ ក-១ មានសិទ្ធិសម្រេច ថាតើមេដឹកនាំណាខ្លះ ដែលត្រូវចម្លងទូរលេខទាំងនេះជូន)។

[៨៦១] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន)ទំព័រ ៥៤-៥៥។

[៨៦២] សូមមើលផងដែរផ្នែកទី៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧, ៣២៨។

[៨៦៣] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១០-១១។ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ១៣-១៤។

[៨៦៤] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/232 ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00017122-00017123 (បកប្រែក្រៅផ្លូវការពីឯកសារដើមជាភាសាខ្មែរ)។

២៧៥. សេចក្តីណែនាំនេះត្រូវបានធ្វើឡើង ស្របតាមមតិយោបល់ដែលបានលើកឡើងនៅក្នុងទស្សនាវដ្តី "ទង់បដិវត្ត" បោះពុម្ពក្នុងឆ្នាំ ១៩៧២ ដែលក្នុងនោះ បក្សបានលើកឡើងថា "យើងខ្វះខាតខាងរបាយការណ៍" បានណែនាំឲ្យរៀបចំធ្វើរបាយការណ៍ ដើម្បីឲ្យ "ថ្នាក់លើក្តាប់សភាពការណ៍បានច្បាស់ ហើយណែនាំអនុវត្តជាក់ស្តែង"[៨៦៥]។ សេចក្តីណែនាំនេះបានណែនាំថា របាយការណ៍ជាក់លាក់ និងទៀងទាត់ទាំងអស់ត្រូវរាយការណ៍ "អំពីខ្មាំង" "អំពីប្រជាជន" "អំពីសកម្មភាពការងារគ្រប់ផ្នែក" និង "អំពីទិស និងវិធានការដោះស្រាយ"[៨៦៦]។

២៧៦. ហេតុដូច្នេះ ភូមិភាគ និងតំបន់ស្វយ័ត បានចងក្រងរបាយការណ៍ជូនគណៈកម្មាធិការមជ្ឈិម ដោយផ្អែកទៅលើព័ត៌មានដែលថ្នាក់ក្រោមបញ្ជូនមកឲ្យខ្លួន[៨៦៧]។ របាយការណ៍ទាំងនោះត្រូវបានផ្ញើរចេញជាញឹកញាប់ ពេលខ្លះរាល់ថ្ងៃក៏មាន ទោះបីជារបាយការណ៍មួយចំនួនបានរៀបរាប់ដោយសង្ខេបអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងយូរមកហើយក៏ដោយ[៨៦៨]។ របាយការណ៍ទាំងនោះត្រូវបានបញ្ជូនតាមម៉ាស៊ីនផ្ញើរទូរលេខ និងតាមសំបុត្រ[៨៦៩]។ ពេលខ្លះតំណាងភូមិភាគ និងតំបន់ស្វយ័តក៏បានរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ[៨៧០]។

---

[៨៦៥] ទង់បដិវត្ត ឯកសារ E3/783 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧២ ទំព័រ ៧២-៧៥, ៨២-៨៤, ERN (ភាសាខ្មែរ) 00442319-00442320, 00442324-00442325។

[៨៦៦] ទង់បដិវត្ត ឯកសារ E3/783 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧២ ទំព័រ ៨២-៨៤, ERN (ភាសាខ្មែរ) 00442324-00442325។

[៨៦៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាំ ផាន់ ឯកសារ E3/58 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00239936។ ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ស្បូន កានិល) ទំព័រ ៨៤។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ១៣។

[៨៦៨] ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៦-១៧។ *សូមមើល ផងដែរ* សេចក្តីរាយការណ៍របស់ភូមិភាគ ៥៦០ ឯកសារ E3/179 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ (ដែលគ្របដណ្តប់រយៈពេលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧)។ សេចក្តីរាយការណ៍របស់ភូមិភាគ ៥៦០ ឯកសារ E3/1179 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ (ដែលគ្របដណ្តប់រយៈពេលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៧៧)។ សេចក្តីរាយការណ៍របស់ភូមិភាគ ៤០១ ឯកសារ E3/1094 ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ (ដែលបានរៀបរាប់ថាជា "របាយការណ៍ប្រចាំខែ")។

[៨៦៩] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន់) ទំព័រ៤៧។ ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤៩-៥០។ ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៣-១៥, ១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឿន តាន ឯកសារ E3/33 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ

២៧៧. ភូមិភាគនីមួយៗមានពេលវេលា ដែលត្រូវបានគេកំណត់ទុកជាមុនជាក់លាក់ សម្រាប់បញ្ជូនទូរលេខមកគណៈកម្មាធិការមជ្ឈិម។ ប៉ុន្តែ គេក៏អាចផ្ញើសារក្រៅពីរយៈពេលដែលបានកំណត់នេះផងដែរ ប្រសិនបើកាលៈទេសៈតម្រូវឲ្យធ្វើបែបនេះ[៨៧១]។

២៧៨. របាយការណ៍មួយចំនួនដែលត្រូវបានផ្ញើមកគណៈកម្មាធិការមជ្ឈិម ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ របាយការណ៍ទាំងនោះបានបង្ហាញថា ភូមិភាគ និងតំបន់ស្វយ័ត បានរាយការណ៍អំពីបញ្ហាផ្សេងៗ ដូចជា ការបង្កបង្កើនផលកសិកម្ម និងការប្រមូលផលស្រូវ[៨៧២] សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង និងខ្មាំងខាងក្រៅ[៨៧៣] និងជីវភាពប្រជាជនជាទូទៅ រួមទាំង បញ្ហាសុខភាព និងការខ្វះស្បៀងអាហារ[៨៧៤]។ សារដែលផ្ញើមកពីភូមិភាគក៏មានសំណូមពរសុំការ

---

១០-១១, ERN (ភាសាខ្មែរ) 00231807-00231808។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង លីន ឯកសារ E3/59 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00204722។

[៨៧០] *សូមមើល ឧទាហរណ៍* កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦។

[៨៧១] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៦១។ ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៧៤-៧៦។

[៨៧២] *ឧទាហរណ៍ សូមមើល* សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1077 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨។ សេចក្តីរាយការណ៍មកពីភូមិភាគនីរតី ឯកសារ E3/853 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧។ សេចក្តីរាយ-ការណ៍មកពីភូមិភាគ៥៦០ ឯកសារ E3/863 ចុះថ្ងៃទី ១៦-១៧ ខែ ឧសភា ឆ្នាំ ១៩៧៨។ សេចក្តីរាយការណ៍មកពីភូមិភាគ ៥៦០ ឯកសារ E3/179 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧។ សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1091 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៧៧។ *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឯកសារ E3/383 ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00345913។

[៨៧៣] *សូមមើល ផងដែរ* សេចក្តីរាយការណ៍មកពីភូមិភាគ ៤០១ ឯកសារ E3/1092 គ្មានចុះកាលបរិច្ឆេទ។ សេចក្តីរាយការណ៍មកពីភូមិភាគ ៤០១ ឯកសារ E3/1094 ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨។ សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1144 ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧។ សេចក្តីរាយការណ៍មកពីភូមិភាគ ៥៦០ ឯកសារ E3/1179 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧។

[៨៧៤] *សូមមើល ផងដែរ* សារទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/948 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/511 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦។ សេចក្តីរាយការណ៍មកពីភូមិភាគ ៥៦០ ឯកសារ E3/179 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧។ សេចក្តីរាយការណ៍មកពីភូមិភាគ ៤០១ ឯកសារ E3/1092 គ្មានចុះកាលបរិច្ឆេទ។ សារទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1144 ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧។

សម្រេច សេចក្ដីណែនាំលើបញ្ហាដូចគ្នាទាំងនេះ ឬស្នើសុំជំនួយសម្ភារ:ពីគណ:កម្មាធិការមជ្ឈិមផង ដែរ[៨៧៥]។

២៧៩. ជាទូទៅ ទូរលេខដែលផ្ញើមកពីភូមិភាគ និងតំបន់ស្វយ័តទៅគណ:កម្មាធិការមជ្ឈិមនោះគឺ ត្រូវផ្ញើទៅ "គណ: ៨៧០" ឬ "អង្គការ" ប៉ុន្តែ ពេលខ្លះ ត្រូវបានផ្ញើទៅ "អង្គការ ៨៧០" ឬ ទៅ ប៉ុល ពត ផ្ទាល់តែម្ដង[៨៧៦]។ ដូចអង្គជំនុំជម្រះបានកត់សម្គាល់រួចមកហើយថា កម្មាភិបាលនៃបក្ស កុម្មុយនីស្តកម្ពុជា មិនមែនសុទ្ធតែយល់ពាក្យថា "អង្គការ" ឬ "៨៧០" ឲ្យបានច្បាស់លាស់នោះ ទេ[៨៧៧]។ បញ្ជីឈ្មោះអ្នកទទួលនៅលើទូរលេខជាច្រើនបញ្ជាក់ថា សារត្រូវបានចម្លងជូនមេដឹកនាំបក្ស កុម្មុយនីស្តកម្ពុជាជាច្រើននាក់រួមទាំងជនជាប់ចោទ នួន ជា ផងដែរ[៨៧៨]។ ទូរលេខជាច្រើនដែល មានសរសេរជាកំណត់សម្គាល់ថា ចម្លងជូន "មន្ទីរ" ត្រូវបានគេបញ្ជូនទៅមន្ទីរ ៨៧០[៨៧៩]។

---

[៨៧៥] *សូមមើល ផងដែរ* សារទូលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/511 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦។ សារទូលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/519 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៨។ សារទូលេខ របស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1036 មិនមានចុះកាលបរិច្ឆេទ។ សារទូលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1196 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។

[៨៧៦] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៣៨-៣៩។ *សូមមើល* ផ្នែកទី ៦ ស្ដីពី រចនាសម្ព័ន្ធទំនាក់ទំនង ជើងទំព័រ ៨៧២-៨៧៥។

[៨៧៧] *សូមមើល ផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៨ "គេហៅមន្ទីរនេះថា ម-៨៧០ ប៉ុន្តែ ខ្ញុំមិនដឹងថា មន្ទីរនេះជាអ្វីទាំងអស់"។ សូមមើលផ្នែកទី ៥ ស្ដីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៧-២០៨, ២២១ ។

[៨៧៨] *សូមមើល ផងដែរ* សារទូលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/511 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ (បានចម្លងជូន សុន សេន និងជនជាប់ចោទ នួន ជា)។ សារទូលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/519 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៨ (បានចម្លងជូនជនជាប់ចោទ នួន ជា)។ សារទូលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/948 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ (បានចម្លងជូន "អ៊ំ" *មានន័យថា* ប៉ុល ពត, *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សូផង់) ទំព័រ ៤១-៤២, ជនជាប់ចោទ នួន ជា, អៀង សារី និង វន វ៉េត)។ សារទូលេខកម្ពុជា-ប្រជាធិបតេយ្យ ឯកសារ E3/1077 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ (បានចម្លងជូន "អ៊ំ" *មានន័យថា* ប៉ុល ពត។ *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង ម៉ុន ឯកសារ E3/71 ចុះថ្ងៃទី ១៤ ខែ កុម្ភ: ឆ្នាំ ២០០៩ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00284294-00284295, ជនជាប់ចោទ នួន ជា, អៀង សារី, វន វ៉េត និង សុន សេន)។ សារទូលេខកម្ពុជាប្រជាធិប-តេយ្យ ឯកសារ E3/1144 ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ (បានចម្លងជូន ប៉ុល ពត, ជនជាប់ចោទ នួន ជា, អៀង សារី, វន វ៉េត និង សុន សេន)។ សារទូលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ

២៨០. គណៈកម្មាធិការមជ្ឈិមបានបញ្ជូនសេចក្តីណែនាំរួមទៅថ្នាក់ក្រោម តាមរយៈសារទូរលេខ។ សេចក្តីណែនាំរួមនោះគឺមាន "គ្រប់ផ្នែកទាំងអស់នៃប្រទេស" និង "សភាពការណ៍រួម"[៨៨០]។ ជនជាប់ចោទ ខៀវ សំផន បានផ្ញើទូរលេខជាទៀងទាត់ទាក់ទងនឹងការបែងចែកសម្ភារៈនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ក្រោម[៨៨១]។ ក្នុងឋានៈជាលេខាតំបន់ស្វយ័ត ១០៥ សាក្សី សៅ សារុន បានជម្រាបជូនអង្គជំនុំជម្រះថា គាត់បានទទួលការណែនាំពីគណៈកម្មាធិការមជ្ឈិមតាមរយៈទូរលេខ ដែលសេចក្តីណែនាំទាំងនោះបង្ហាញនូវបញ្ហាមួយចំនួន ដូចជា ការធ្វើស្រែចម្ការ ជាដើម[៨៨២]។ កម្មាភិបាលថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ ក៏បានទទួលសំបុត្រមកពីមន្ទីរ៨៧០ និងពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនផងដែរ រួមទាំងសំបុត្រពីជនជាប់ចោទ នួន ជា និង ខៀវ សំផន[៨៨៣]។

### ៦.២.៣ ទំនាក់ទំនងរវាងភូមិភាគ នឹងតំបន់

២៨១. នៅខណៈពេលមានការកំណត់ពេលវេលាជាក់លាក់ សម្រាប់ការបញ្ជូនទូរលេខពីភូមិភាគទៅគណៈមជ្ឈិម ក៏មានកាលវិភាគពេលវេលាដាច់ដោយឡែកសម្រាប់ទំនាក់ទំនងរវាងភូមិភាគនឹង

---

E3/1196 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ (បានចម្លងជូនជនជាប់ចោទ នួន ជា និង សុន សេន)។ សូមមើលផ្នែកទី ៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥ ។

[៨៧៩] ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២ ០១២ (នង សួផង់) ទំព័រ ៣០-៣១។ ចម្លើយជាលាយលក្ខណ៍អក្សររបស់ កាំង ហ្កេកអ៊ាវ ឯកសារ E3/15 ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៦ ERN (ភាសាខ្មែរ) 00234074។

[៨៨០] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៣៩-៤០។ *ឧទាហរណ៍ សូមមើល* សារទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/254 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ (ណែនាំឲ្យអ្នកទទួលតាមដានសកម្មភាពខ្មាំងនៅមុខកំពូល និង "មានវិធានការ តាមសភាពការណ៍ជាក់ស្តែង ដោយទាក់ទងជាមួយខាងមុខកំពូលផង")។ *សូមមើល ផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៧២-៧៣។ កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី ប៉ុន អុល ឯកសារ E3/373 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00326639-00326640។

[៨៨១] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សួផង់) ទំព័រ ៣៩-៤០។

[៨៨២] ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៧-១៨។

[៨៨៣] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ៧៥-៧៦ (ដែលនិយាយយោងទៅលើការប្រាស្រ័យទាក់ទងគ្នាពី "៨៧០" និងជនជាប់ចោទ នួន ជា។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00204743-00204744 (ដែលរៀបរាប់ពីការចែកចាយសំបុត្រមកពី ប៉ុល ពត អៀង សារី ជនជាប់ចោទ នួន ជា និង ខៀវ សំផន ផ្ញើទៅភូមិភាគ)។

តំបន់ផងដែរ[៨៨៤]។ ការរៀបចំពេលវេលាបែបនេះត្រូវបានធ្វើឡើងដើម្បីធានាថា ទំនាក់ទំនងរវាងថ្នាក់ដឹកនាំផ្សេងៗមិនត្រួតគ្នាទេ[៨៨៥]។

២៨២. សាក្សី សួន កានិល ដែលធ្លាប់ធ្វើការនៅអង្គភាពបកប្រែលេខកូដទូរលេខនៃភូមិភាគកណ្ដាល បានផ្ដល់សក្ខីកម្មថា អាជ្ញាធរភូមិភាគកណ្ដាលបានទទួលទូរលេខមកពីតំបន់ផ្សេងៗ ប្រហែលជាម្ដងក្នុងមួយថ្ងៃ ហើយទទួលបានកាន់តែញឹកញាប់ជាងនេះទៀតចាប់ពីឆ្នាំ ១៩៧៨[៨៨៦]។

### ៦.២.៤ ទំនាក់ទំនងរវាងតំបន់នឹងស្រុក

២៨៣. របាយការណ៍មួយចំនួនពីថ្នាក់ស្រុក ត្រូវបានបញ្ជូនបន្តតាមរយៈថ្នាក់តំបន់ (ហើយក្នុងករណីខ្លះតាមរយៈភូមិភាគ) ទៅកាន់គណៈកម្មាធិការមជ្ឈិម[៨៨៧]។

២៨៤. ស្រុកបានរាយការណ៍ទៅតំបន់អំពីបញ្ហានានា ដូចជា ការលើកទំនប់ ជីកប្រឡាយ ការបង្កបង្កើនផល សុខាភិបាល និង "សមាសភាពល្អ និង មិនល្អ"[៨៨៨]។ ក្នុងឋានៈជាលេខាស្រុកកំពង់សៀម សាក្សី ប្រាក់ យុត បានរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែសម្រាប់គណៈ-កម្មាធិការតំបន់ ស្ដីពីការអនុវត្តផែនការ និងសភាពការណ៍នៅក្នុងស្រុក[៨៨៩]។ ដូចគ្នានេះដែរ ក្នុងឋានៈជាលេខាស្រុកពេជ្រដា សាក្សី សៅ សារុន បានរំឭកពីការផ្ញើរបាយការណ៍ស្ដីពីការបង្កបង្កើន-ផលស្រូវទៅថ្នាក់តំបន់ ប្រហែលជាមួយដងក្នុងមួយសប្ដាហ៍[៨៩០]។ មន្ទីរស្រុកមិនមានសមត្ថភាពប្រើប្រាស់ម៉ាស៊ីនផ្ញើទូរលេខទេ។ ដូច្នេះ របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅតំបន់ តាមរយៈនីរសារតែប៉ុណ្ណោះ[៨៩១]។

---

[៨៨៤] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៧៧-៧៨។

[៨៨៥] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៧៧-៧៨។

[៨៨៦] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ៤-៥, ៧៨-៧៩។

[៨៨៧] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខាំ ផាន់ ឯកសារ E3/58 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00239936។

[៨៨៨] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខាំ ផាន់ ឯកសារ E3/58 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00239936។

[៨៨៩] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៥៤។

[៨៩០] ប្រតិចារឹក ចុះថ្ងៃទី ០៦ មិថុនា ឆ្នាំ ២០១២ ទំព័រ៩-១០។ *សូមមើល ផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឆ្នាំ ២០១២ (យុន គីម) ទំព័រ១៤-១៥។

[៨៩១] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៤១-៤២, ៥៤។ ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឆ្នាំ២០១២ (យុន គីម) ទំព័រ ១៤-១៥។

២៨៥. កម្មាភិបាលថ្នាក់ស្រុក និងថ្នាក់តំបន់ ក៏បានជួបប្រជុំគ្នាជាទៀងទាត់ផងដែរ។ យោងតាម សាក្សី សៅ សារុន លេខាស្រុកមួយចំនួនបានរាយការណ៍អំពីសភាពការណ៍នៅក្នុងស្រុករបស់ខ្លួន នៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការតំបន់ដែលពាក់ព័ន្ធ[៨៥២]។

២៨៦. ខណៈពេលដែលសេចក្តីណែនាំផ្សេងៗពីគណៈកម្មាធិការមជ្ឈិមត្រូវបានបញ្ជូនទៅភូមិភាគ ហើយភូមិភាគបញ្ជូនបន្តទៅថ្នាក់តំបន់ អាជ្ញាធរតំបន់ក៏បានបញ្ជូនបន្តសេចក្តីណែនាំទាំងនោះទៅ ថ្នាក់ស្រុក ផងដែរ[៨៥៣]។

### ៦.២.៥ ទំនាក់ទំនងរវាងស្រុកនឹងឃុំ

២៨៧. កម្មាភិបាលថ្នាក់ស្រុក បានជួបគ្នាជាញឹកញាប់ជាមួយនឹងកម្មាភិបាលថ្នាក់ឃុំ ឬ ប្រធាន សហករណ៍ ដើម្បីផ្លាស់ប្តូរព័ត៌មាន ឬបទបញ្ហា ដែលខ្លួនបានទទួលដោយផ្ទាល់មាត់[៨៥៤]។ សាក្សី យុន គីម ដែលជាមេឃុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានជម្រាបជូនអង្គជំនុំជម្រះថា ថ្នាក់ដឹកនាំឃុំ បានជួបប្រជុំប្រចាំសប្តាហ៍ជាមួយអាជ្ញាធរស្រុក ដើម្បីរាយការណ៍ពីការបង្កបង្កើនផល សុខាភិបាល វប្បធម៌ និង "សភាពការណ៍ខ្មាំង" នៅក្នុងឃុំ[៨៥៥]។ ក្នុងករណីចាំបាច់ដែលត្រូវទំនាក់ទំនងគ្នានៅ ចន្លោះពេលនៃការប្រជុំប្រចាំសប្តាហ៍នោះ ស្រុកបានបញ្ជូនលិខិតសារចុះទៅដល់ឃុំផ្ទាល់[៨៥៦]។

២៨៨. ភស្តុតាងជាឯកសារដែលមានរហូតដល់ពេលនេះបង្ហាញថា ឃុំក៏បានបញ្ជូនសំណើ និង របាយការណ៍ជាលាយលក្ខណ៍អក្សរជាប្រចាំទៅស្រុក ស្តីពីបញ្ហាមួយចំនួន ដូចជា ការចាប់ខ្លួន

[៨៥២] ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១០-*១១។ សូមមើល ផងដែរ* ប្រតិចារឹក ថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១២ (ប្រាក់ យុត), ទំព័រ ៦៨-៦៩។

[៨៥៣] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៧៧-៧៩។ ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត), ទំព័រ ៤០-៤១។

[៨៥៤] ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ក្លាន វ៉ុត) ទំព័រ ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៤០-៤១។ របាយការណ៍របស់អ្នកជំនាញ Craig Etcheson ឯកសារ E3/494 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ៣៨-៣៩, ERN (ភាសាខ្មែរ) 00314815-00314816។

[៨៥៥] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៣៣-៣៤, ៦០-៦១។ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១២ (យុន គីម) ទំព័រ ៧-៨។

[៨៥៦] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៨។

អាកប្បកិរិយាគួរឲ្យសង្ស័យ និងសភាពការណ៍នៅក្នុងឃុំ និងសហករណ៍[៨៩៧]។ សាក្សី ប្រាក់ យុត បានផ្តល់សក្ខីកម្មថា គណៈកម្មាធិការស្រុកដែលមានគាត់ជាសមាជិកនោះ បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរពីថ្នាក់ឃុំ ស្តីពីបញ្ហាកសិកម្ម គម្រោងសាងសង់ ការសម្រេចទិសដៅ "កំហុសឆ្គងរបស់ប្រជាជនខ្លះ" ការខ្វះស្បៀងអាហារ និងចំនួនអ្នកឈឺ[៨៩៨]។ ក្នុងឋានៈជាលេខាស្រុកពេជ្រាដា សាក្សី សៅ សារុន ក៏បានរំលឹកឡើងវិញពីការទទួលបានរបាយការណ៍ពីឃុំនានាស្តីពីការបង្កបង្កើនផលស្រូវ សត្វពាហនៈ និងការចាត់ចែងមូលដ្ឋានជារួមផងដែរ[៨៩៩]។

### ៦.២.៦ ទំនាក់ទំនងក្រៅប្រទេស

២៨៩. ស្ថាប័នរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបានផ្ញើទូរលេខទៅកាន់ប្រទេសមួយចំនួន ដោយមានការជូនពរ ការសម្តែងសាមគ្គីភាព និងសាររអបអរសាទរក្នុងឱកាសសំខាន់ៗមួយចំនួន[៩០០]។ ប្រទេសសង្គមនិយមជាមិត្តមួយចំនួន ក៏បានផ្ញើសារស្រដៀងគ្នានេះត្រឡប់មកវិញផងដែរ[៩០១]។

២៩០. នៅក្នុងឆ្នាំ ១៩៧៦ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានផ្ញើលិខិតពីរច្បាប់។ លិខិតមួយច្បាប់ដំបូង ត្រូវបានផ្ញើក្នុងខែ កុម្ភៈ ជូនលោក ប៉ែន នុត ដែលនៅពេលនោះជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងលិខិតច្បាប់ទីពីរ ត្រូវបានផ្ញើក្នុងខែ ឧសភា

---

[៨៩៧] *ជាឧទាហរណ៍ សូមមើល* សេចក្តីរាយការណ៍របស់ឃុំ ឯកសារ E3/2044 ចុះខែ មករា-មេសា ឆ្នាំ ១៩៧៧។ របាយការណ៍របស់ឃុំត្រពាំងធំខាងជើង ឯកសារ E3/4087 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៧។ របាយការណ៍របស់ឃុំ តាភេម ឯកសារ E3/4084 ចុះខែ ឧសភា ឆ្នាំ ១៩៧៧។

[៨៩៨] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ៤៣, ៤៥, ៤៧-៤៨។

[៨៩៩] ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ១០-១២។

[៩០០] *ឧទាហរណ៍សូមមើល លោក ខៀវ សំផន ជូនពរនាឱកាសទិវាបុណ្យជាតិប៊ុលហ្គារី (Bulgary)* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ចុះខែ កញ្ញា ឆ្នាំ ១៩៧៦) ឯកសារ E3/280 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00663956-00663957 ។ *សាររបស់លោក ខៀវ សំផន ទៅកាន់ប្រទេសម៉ូសំប៊ិក (Mozambique) ស្តីពីការឈ្លានពានរបស់ពួករ៉ូដេស៊ី (Rhodesian)* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ មិថុនា ឆ្នាំ ១៩៧៧) ឯកសារ E3/288 ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧, ERN (ភាសាខ្មែរ) 00680011-00680012 ។ *សមមិត្ត ខៀវ សំផន ជូនពរប្រធានាធិបតី ទីតូ ក្នុងទិវាជាតិនៃប្រទេសយូហ្គូស្លាវី (Yugoslav)* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ វិច្ឆិកា ឆ្នាំ ១៩៧៨) ឯកសារ E3/77 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00701917-00701918។

[៩០១] *ឧទាហរណ៍សូមមើល* លិខិតពីស្ថានទូតបារាំងនៅក្នុងប្រទេសឡាវ ឯកសារ E3/487 *ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៧ (រាយការណ៍ពីទូរលេខមួយច្បាប់ មកពីសាធារណរដ្ឋប្រជាមានិតឡាវ ផ្ញើជូនក្នុងឱកាសខួបលើកទីពីរនៃការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ)*។

ជូនលោក ខៀវ សំផន ដែលទើបត្រូវបានតែងតាំងនាពេលថ្មីៗជាប្រធាននៃគណៈប្រធានរដ្ឋ។ តាមរយៈលិខិតទាំងពីរនេះ អង្គការលើកលែងទោសអន្តរជាតិបានសម្តែងនូវក្តីព្រួយបារម្ភទៅលើរបាយការណ៍ស្តីពីការសម្លាប់ក្រៅច្បាប់ និងការធ្វើទុក្ខបុកម្នេញមកលើប្រជាជនស៊ីវិល ហើយស្នើសុំឲ្យមានការស៊ើបអង្កេតលើបញ្ហាទាំងនេះ[៩០២]។ ដោយសារតែមិនមានការឆ្លើយតប អង្គការលើកលែងទោសអន្តរជាតិ រួមជាមួយនឹងគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានធ្វើការអំពាវនាវរបស់ខ្លួនជាថ្មីម្តងទៀតនៅក្នុងឆ្នាំ ១៩៧៨[៩០៣]។

២៩១. រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានរក្សាទំនាក់ទំនងជាមួយប្រទេសមួយចំនួន តាមរយៈការបញ្ជូននិងទទួលគណៈប្រតិភូផ្លូវការ ពីប្រទេសមួយចំនួនដូចជា ប្រទេសឡាវ ចិន កូរ៉េខាងជើង និងជប៉ុន[៩០៤]។ ជាពិសេស របបកម្ពុជាប្រជាធិបតេយ្យបានផ្ញើ និងទទួលសារទូលេខពីប្រទេសវៀតណាមក្នុងគោលបំណងពិភាក្សាអំពីជម្លោះព្រំដែន[៩០៥]។ អ្នកសារព័ត៌មានមកពីប្រទេសយូហ្គោស្លាវី

---

[៩០២] របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ ១៩៧៥-១៨៧៦៖ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/4520 គ្មានចុះកាលបរិច្ឆេទ។

[៩០៣] *ប្រជាជនកម្ពុជា ជាជនជាតិដែលប្រឈមនឹងការវិនាសសាបសូន្យ* (ការសែត Los Angeles Times) ឯកសារ E3/4492 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៨។ សេចក្តីប្រកាសព័តមានរបស់អង្គការលើកលែងទោសអន្តរជាតិ ឯកសារ E3/3311 ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៧។ សេចក្តីប្រកាសព័ត៌មានរបស់អង្គការលើកលែងទោសអន្តរជាតិ ឯកសារ E3/3316 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៨។

[៩០៤] *ឧទាហរណ៍ សូមមើល ឧបនាយករដ្ឋមន្ត្រីកម្ពុជានៅក្នុងប្រទេសជប៉ុន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស SWB FE/5838/A3) ឯកសារ E3/666 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) S 00716624-00716626។ *ឯកអគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសកម្ពុជា រៀបចំពិធីជប់លៀងបដិសណ្ឋារកិច្ចស្វាគមន៍ នួន ជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស SWB FE/5923/A3) ឯកសារ E3/1280 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00338108-00338109។ ខ្សែភាពយន្តរដ្ឋាភិបាលកម្ពុជាប្រជាធិប-តេយ្យ ឯកសារ E3/479R គ្មានចុះកាលបរិច្ឆេទ, ERN V 00422570។ *ប្រធានាធិបតីនៃប្រទេសឡាវក្នុងប្រទេសកម្ពុជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស SWB FE/5699/A3) ឯកសារ E3/1406 ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១-៥, ERN (ភាសាខ្មែរ) S 00797646-00797650។ *នៅខណៈពេលបញ្ចប់បេសកកម្មការទូតនៅក្នុងរបប-កម្ពុជាប្រជាធិបតេយ្យ...* (ក្នុងសារព័ត៌មានកម្ពុជា) ឯកសារ E3/1420 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) S 00704496-00704497។

[៩០៥] *ឧទាហរណ៍ សូមមើល សន្និសីទកាសែតក្រសួងការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស SWB FE/5785/C) ឯកសារ E3/2300 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ១-៣៩, ERN (ភាសាខ្មែរ) 00305301-00305339។

ទួគី កូរ៉េខាងជើង វៀតណាម និងសហរដ្ឋអាមេរិក ក៏បានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ដោយនៅពេលនោះអ្នកសារព័ត៌មានទាំងនោះបានសម្ភាសកម្មាភិបាលក្នុងរបបនោះ និងបានចុះទៅពិនិត្យមើលតាមជនបទ មានការអមដំណើរដោយកម្មាភិបាលរបស់រដ្ឋ ឬ កម្មាភិបាលរបស់បក្ស[៩០៦]។

២៩២. ក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើការទំនាក់ទំនងជាមួយបណ្ដាប្រទេសមួយចំនួន ក្នុងគោលបំណងដើម្បីធ្វើពាណិជ្ជកម្មអន្តរជាតិ[៩០៧]។ ជាញឹកញាប់ គណៈប្រតិភូពាណិជ្ជកម្មបរទេសក៏បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាផងដែរ នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[៩០៨]។

---

[៩០៦] *ឧទាហរណ៍សូមមើល* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1113 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1112 ចុះខែ មីនា ឆ្នាំ ១៩៧៨។ *សមមិត្តលេខា ប៉ុល ពត ទទួលបដិសណ្ឋារកិច្ច...* (ក្នុងសារព័ត៌មានកម្ពុជា) ឯកសារ E3/1420 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) S 00704498-00704499។ *អៀង សារី ទទួលគណៈប្រតិភូផ្នែកសារព័ត៌មាន នៃសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ នៅថ្ងៃទី ៣០ ខែ មករា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ កុម្ភៈ ឆ្នាំ ១៩៧៧) ឯកសារ E3/284 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ERN (ភាសាអង់គ្លេស) 00168400។ *ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូបក្សកុម្មុយនីស្តម៉ាក្សលេនីនមកពីប្រទេសបារាំង...* (ក្នុងព័ត៌មានកម្ពុជា) ឯកសារ E3/1420 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) S 00704499-00704500។ *ទស្សនកិច្ចជាលក្ខណៈមិត្តភាពនៅកម្ពុជាប្រជាធិបតេយ្យ...* (ក្នុងដំណឹងពីកម្ពុជាប្រជាធិបតេយ្យ)ឯកសារ E3/268 ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១៤-១៦ ERN (ភាសាខ្មែរ) 00555718-00555720។ *សមមិត្តលេខា ប៉ុល ពត ទទួលបដិសណ្ឋារកិច្ច...* (ក្នុងសារព័ត៌មានកម្ពុជា) ឯកសារ E3/1420 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) S 00704498-00704499។ *សកម្មភាពរបស់គណៈប្រតិភូនៃអ្នកសារព័ត៌មានមកពីសាធារណរដ្ឋសង្គមនិយមវៀតណាម* (ក្នុងសារព័ត៌មានកម្ពុជា) ឯកសារ E3/268 ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១២-១៤, ERN (ភាសាអង់គ្លេស) 00519789-00519791។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ៤២៥-៤២៦, ៥៣១-៥៧០, ERN (ភាសាខ្មែរ) 00232423-00232424, 00232529-00232568។

[៩០៧] *ឧទាហរណ៍ សូមមើល* លិខិតពីគណៈកម្មាធិការពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/3418 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៨។ របាយការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/2516ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[៩០៨] *សូមមើល ឧទាហរណ៍* កំណត់ហេតុប្រជុំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/827 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៧៨។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សគឹម ល្មុត ឯកសារ E3/439 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៤-៨, ERN (ភាសាខ្មែរ) 00418542-00418546។ *គណៈប្រតិភូពាណិជ្ជកម្មនៃប្រទេសរ៉ូម៉ានី* មកទស្សនកិច្ចនៅ

២៩៣. នៅចន្លោះពីឆ្នាំ ១៩៧៦ ដល់ ១៩៧៩ អៀង សារី បានចូលរួមប្រជុំជាច្រើនលើកច្រើនសា នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ដោយនៅពេលនោះ គាត់បាន បង្ហាញជំហររបស់របបកម្ពុជាប្រជាធិបតេយ្យ អំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា និងបញ្ហា អន្តរជាតិជាក់លាក់មួយចំនួន[៩០៩]។ នៅពេលដែលកងទ័ពវៀតណាមបានខិតចូលមកជិតដល់ទីក្រុង ភ្នំពេញក្នុងឆ្នាំ ១៩៧៩ អៀង សារី បានផ្ញើសារទូរលេខមួយច្បាប់ដែលជាបណ្ដឹងតវ៉ាជូនក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាជាតិ[៩១០]។

## ៦.៣ ទំនាក់ទំនងផ្នែកយោធា

២៩៤. បណ្ដាញទំនាក់ទំនងនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា បានឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធនៃការ រាយការណ៍តាមខ្សែបណ្ដោយខាងផ្នែកស៊ីវិលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលការណ៍នេះមានន័យ ថា បទបញ្ជាចេញពីអគ្គសេនាធិការទៅកាន់អង្គភាពថ្នាក់ក្រោមតាមរយៈកងពលធំ។ ព័ត៌មានត្រូវ បានរាយការណ៍ឡើងទៅថ្នាក់លើតាមរយៈខ្សែសង្វាក់នៃការបញ្ជា ហើយតាមធម្មតា មេបញ្ជាការ នៅតាមកម្រិតនីមួយៗធ្វើការទំនាក់ទំនងតែជាមួយថ្នាក់លើ និងថ្នាក់ក្រោមផ្ទាល់របស់ខ្លួនតែ ប៉ុណ្ណោះ[៩១១]។

---

កម្ពុជា (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស SWB FE/5778/A2) ឯកសារ E3/1517 ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៧៨ (របាយការណ៍ស្ដីពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃប្រទេសរ៉ូម៉ានី នៅក្នុងខែ មីនា ឆ្នាំ ១៩៧៨)។

[៩០៩] *ឧទាហរណ៍ សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿង) ទំព័រ ១៨។ សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ១០ ឯកសារ E3/547 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៧។ កំណត់ហេតុផ្លូវការនៃមហាសន្និបាតអង្គការសហប្រជាជាតិ ឯកសារ E3/1586 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៨។ កំណត់ហេតុជាផ្លូវការនៃមហាសន្និបាតអង្គការសហប្រជាជាតិ ឯកសារ E3/618 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៩។ *អៀង សារី វិលត្រឡប់ពីអង្គការសហប្រជាជាតិ ប្រទេសហ្វីលីពីន ប្រទេសឥណ្ឌូនេស៊ីវិញនៅថ្ងៃទី ២៨ ខែ តុលា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ តុលា ឆ្នាំ ១៩៧៨) ឯកសារ E3/721 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00714321។ បទអន្តរាគមន៍របស់លោក អៀង សារី នៅក្នុងមហាសន្និបាតលើកទី ៣១ របស់អង្គការសហប្រជាជាតិ ឯកសារ E3/607 ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៦។

[៩១០] ទូរលេខផ្ញើជូនអង្គការសហប្រជាជាតិ ឯកសារ E3/556 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៩។

[៩១១] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១៧-១៩, ៣០។ ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៦-៧, ២០-២១, ៣៤-៣៦។ ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៣៧-៣៨, ៤៨-៥០។

### ៦.៣.១ ទំនាក់ទំនងជាមួយមជ្ឈិមបក្ស

២៩៥. សុន សេន ដែលជានាយអគ្គសេនាធិការ[៩១២] បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើនដង និងបានរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍អំពីកិច្ចការយោធា និងបញ្ហាការពារជាតិ[៩១៣]។ សុន សេន ក៏បានបញ្ជូនសារ និងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានពីមេបញ្ជាការយោធាបន្តទៅឲ្យមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជនជាប់ចោទ នួន ជា ដោយមានចំណារផ្ទាល់ដៃ និងសំណើសុំការណែនាំផងដែរ[៩១៤]។

### ៦.៣.២ ទំនាក់ទំនងរវាងអគ្គសេនាធិការ និងកងពលធំ

២៩៦. កងពលធំ ដែលស្ថិតនៅក្រោមការបញ្ជាផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម បានរាយ-

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ឯកសារ E3/4593 ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00485627-00485628។

[៩១២] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/183 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00019108-00019110។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៥-២៦។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៤, ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ  កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៥-៥៦។

[៩១៣] *ឧទាហរណ៍ សូមមើល* កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/229 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/217 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/222 ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦។

[៩១៤] *ឧទាហរណ៍ សូមមើល* របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1135 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៧។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1082 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ (របាយការណ៍ទាំងពីរនេះ គឺសំដៅទៅលើកងពលធំលេខ ១៦៤ និងបានកំណត់អត្តសញ្ញាណអ្នកផ្ញើថាជា "មុត" *មានន័យថា* មាស មុត ដែលជាមេបញ្ជាការកងពលធំលេខ ១៦៤។ *សូមមើល* កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី សេង សឿន ឯកសារ E3/409 ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00402509-00402510។ កិច្ចសម្ភាសន៍របស់ Christine Chaumeau និង ប៊ូ សារឿន ជាមួយ មាស មុត ឯកសារ E3/346 មិនមានចុះកាលបរិច្ឆេទ)។ *សូមមើល ផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1199 ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៧៧ (គឺសំដៅទៅលើកងពលលេខ ៩២០ និងបានកំណត់អត្តសញ្ញាណអ្នកផ្ញើថាជា "សាន" *មានន័យថា* តា សាន ដែលជាមេបញ្ជាការ កងពលលេខ ៩២០។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៦៦-៦៧។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សែ ឯកសារ E3/405 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00401300-00401301។ សូមមើលផ្នែកទី ៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៧ ។

ការណ៍ជូនអគ្គសេនាធិការប្រហែលជាពីរទៅបីដងក្នុងមួយថ្ងៃ[៩១៥]។ កងពលធំ និងអគ្គសេនាធិការ ទំនាក់ទំនងគ្នាតាមរយៈវិទ្យុទាក់ទង ឬប្រសិនបើតម្រូវឲ្យមានការលាក់ការសម្ងាត់ ពួកគេទំនាក់ទំនងគ្នាតាមរយៈទូរលេខ ឬទូរស័ព្ទ[៩១៦]។

២៩៧. មេបញ្ជាការ និងអនុបញ្ជាការកងពលធំ និងកងវរៈសេនាធំឯករាជ្យ ក៏បានជួបប្រជុំជាប្រចាំជាមួយនឹង សុន សេន ដោយផ្ទាល់ផងដែរ[៩១៧]។ នៅក្នុងអង្គប្រជុំទាំងនេះ មន្ត្រីយោធាបានរាយការណ៍ដល់ សុន សេន អំពីសភាពការណ៍នៅក្នុងអង្គភាពរបស់ខ្លួន ហើយ សុន សេន បានចេញបញ្ជា និងផ្តល់ការណែនាំផ្នែកនយោបាយ[៩១៨]។ យ៉ាងហោចណាស់ ក៏មានវគ្គរៀនសូត្រនយោបាយធំមួយ ដែលរៀបចំឡើងដោយអគ្គសេនាធិការ ហើយមានការចូលរួមពីកងទ័ពមកពីថ្នាក់កងវរៈសេនាធំ កងវរៈសេនាតូច កងអនុសេនាធំ និងកងអនុសេនាតូច[៩១៩]។ ពេលខ្លះ កម្មាភិបាល

---

[៩១៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ឌុស ឯកសារ E3/70 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00404633-00404634។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ឌុស ឯកសារ E3/426 ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00357492-00357493។

[៩១៦] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១៨-១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ឌុស ឯកសារ E3/426 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ, ៣-៤ ERN (ភាសាខ្មែរ) 00357492-00357493។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ឌុស ឯកសារ E3/70 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00404633-00404634។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/421 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00407739-00407740។ ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៥០, ៥៣-៥៤, ៦១-៦២។ *សូមមើល ផងដែរ* របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/997 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ (ដែលនិយាយសំដៅទៅលើ "ការទាក់ទងតាមទូរស័ព្ទជាសម្ងាត់)។

[៩១៧] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១៨-១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ឌុស ឯកសារ E3/426 ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00357492-00357493។ ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៤៩-៥១, ៥២-៥៤។

[៩១៨] *ឧទាហរណ៍ សូមមើល* កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ឯកសារ E3/795 ចុះថ្ងៃទី ០២ សីហា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ឯកសារ E3/796 ចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ឯកសារ E3/13 ចុះថ្ងៃទី ០៩ តុលា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ឯកសារ E3/807 ចុះថ្ងៃទី ០១ មីនា ឆ្នាំ ១៩៧៧។

[៩១៩] ឯកសាររបស់សេនាធិការនៃកងទ័ពបដិវត្តកម្ពុជា៖ តារាងស្ថិតិសិក្ខាកាម លើកទី ២ ឯកសារ E3/847 ចុះថ្ងៃទី ២៣-២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។

យោធាក៏បានចូលរួមនៅក្នុងអង្គប្រជុំ ឬ សន្និបាតធំៗនៅក្នុងទីក្រុងភ្នំពេញផងដែរ ដោយអង្គប្រជុំ ឬសន្និបាតខ្លះមានការចូលរួមពីសំណាក់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ឬ/និង កម្ពុជាប្រជាធិបតេយ្យ រួមទាំងជនជាប់ចោទ នួន ជា និង ខៀវ សំផន ផងដែរ[៩២០]។

២៩៨. របាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញថា កងពលធំបានបញ្ជូនព័ត៌មានស្តីពីសកម្មភាពខ្មាំង កសិកម្ម និងការធ្វើស្រែ ខ្មាំងផ្ទៃក្នុង និងសកម្មភាពវិទ្ធង្សនានៅក្នុងអង្គភាព និងការវិវឌ្ឍគម្រោងសាងសង់នានាទៅអគ្គសេនាធិការជាទៀងទាត់[៩២១]។ កងពលធំទាំងនោះក៏បានទាក់ទងទៅអគ្គសេនាធិការដើម្បីស្នើសុំយោបល់ផ្សេងៗផងដែរ[៩២២]។

[៩២០] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤០-៤១, ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤០-៤២, ៦៦-៦៩ (បានរំឭកឡើងវិញអំពីពិធីមួយ ប្រារព្ធធ្វើនៅពហុកីឡដ្ឋានអូឡាំពិក ក្នុងឆ្នាំ ១៩៧៥ ដែល ប៉ុល ពត, សុន សេន, អៀង សារី ព្រមទាំងជនជាប់ចោទ នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងចំណោមអ្នកដទៃទៀត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00172081 (បានរៀបរាប់អំពីពិធីមួយរៀបចំឡើងក្នុងឆ្នាំ ១៩៧៥ នៅពហុកីឡដ្ឋានអូឡាំពិក ដែលជនជាប់ចោទ នួន ជា និង ខៀវ សំផន បានចូលរួម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/362 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00210210-00210212 (បានរៀបរាប់អំពីអង្គប្រជុំមួយក្នុងឆ្នាំ ១៩៧៧ នៅទីក្រុងភ្នំពេញ ដែលជនជាប់ចោទ នួន ជា បានចូលរួម។) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ម៉ុន ឯកសារ E3/369 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00195436 (បានរៀបរាប់អំពីអង្គប្រជុំមួយនៅក្នុងពហុកីឡដ្ឋានអូឡាំពិកក្នុងឆ្នាំ ១៩៧៥ ដែល ប៉ុល ពត, អៀង សារី ព្រមទាំងជនជាប់ចោទ នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងចំណោមអ្នកដទៃទៀត)។

[៩២១] *ឧទាហរណ៍ សូមមើល* របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1085 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1202 មិនមានចុះកាលបរិច្ឆេទ។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1162 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/997 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1750 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1213 ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៧៦។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1060 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧៧។

[៩២២] *ឧទាហរណ៍ សូមមើល* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1190 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦។ របាយការណ៍ផ្ញើមកពីអង្គភាពយោធានៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1168 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៧។

### ៦.៣.៣ ទំនាក់ទំនងនៅក្នុងកងពលធំ

២៩៩. បន្ទាប់ពីទទួលបានបញ្ជាពីអគ្គសេនាធិការហើយ មេបញ្ជាការកងពលនឹងបញ្ជូនសេចក្តីណែនាំទាំងនេះបន្តទៅអង្គភាពថ្នាក់ក្រោម ហើយជាទូទៅ គឺតាមរយៈការជួបប្រជុំជាមួយនឹងកម្មាភិបាល ឬជួបជាមួយនឹងមេដឹកនាំរបស់ខ្លួនផ្ទាល់តែម្តង[៩២៣]។ ដូចគ្នានេះដែរ បញ្ជាទាំងនេះត្រូវបានបញ្ជូនទៅអង្គភាពថ្នាក់ក្រោម តាមរយៈកងវរៈសេនាធំ ឬកងវរៈសេនាតូច[៩២៤]។

៣០០. មេបញ្ជាការ និងអនុបញ្ជាការកងពលធំ ព្រមទាំងថ្នាក់ក្រោមៗរបស់ខ្លួនបានធ្វើការទំនាក់ទំនងគ្នាតាមរយៈវិទ្យុទាក់ទង តាមរយៈសារទូរលេខ តាមរយៈនីរសារ និងតាមរយៈការជួបផ្ទាល់តែម្តង[៩២៥]។

៣០១. មេបញ្ជាការកងអនុសេនាធំរាយការណ៍ជូនប្រធានរបស់ខ្លួនជាលាយលក្ខណ៍អក្សរ និងតាមរយៈវិទ្យុទាក់ទង[៩២៦]។ មេបញ្ជាការកងវរៈសេនាតូចបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍

---

[៩២៣] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៣១។

[៩២៤] ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ១១។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៩-១០, ១៧, ១៩-២០,២១-២២ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៤។

[៩២៥] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៩-១០, ១៧, ១៩-២០, ២១-២២។ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ៤។ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ២៩-៣០,៥០។ ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ៣១-៣២ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន), ទំព័រ ១០-១១, ២៤-២៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡឹក សៅ ឯកសារ E3/418 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00401748-00401749។ *ឧទាហរណ៍ សូមមើល* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1222 ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1223 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1225 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ (ដែលបានកំណត់អត្តសញ្ញាណអ្នកផ្ញើថាជា “ឌឹម” មានន័យថា គុន ឌឹម អនុបញ្ជាការវរៈសេនាតូច នៅក្នុង កងពលធំលេខ ១៦៤ ។ *សូមមើល*ឯកសាររបស់សេនាធិការនៃកងទ័ពបដិវត្តកម្ពុជា៖ តារាងស្ថិតិសិក្ខាកាម លើកទី ២ ឯកសារ E3/847 ចុះថ្ងៃទី ២៣-២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ៧ ERN (ភាសាខ្មែរ) 00008466។ វគ្គសេនាធិការ លើកទី ២៖ កងពល ១៦៤ ក្រុម ២ ឯកសារ E3/1143 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ៣, ERN (ភាសាខ្មែរ) 00008512 ហើយអ្នកទទួលគឺ “មុត” *មានន័យថា* មាស មុត ដែលជាមេបញ្ជាការកងពលធំលេខ ១៦៤។ *សូមមើល* ផ្នែកទី ៦ ស្តីពីប្រព័ន្ធទំនាក់ទំនង ជើងទំព័រ ៩១៤ ។

អក្សរទៅមេបញ្ជាការកងវរៈសេនាធំតាមរយៈនីរសារ[៩២៧]។ ដូចគ្នានេះផងដែរ កងវរៈសេនាធំបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅកងពលធំតាមរយៈទូរលេខ និងតាមរយៈនីរសារ ដែលការបញ្ជូននេះត្រូវធ្វើឡើងយ៉ាងហោចណាស់មួយខែម្តង[៩២៨]។

### ៦.៣.៤ ទំនាក់ទំនងរវាងកងពលធំ

៣០២. ក្នុងគោលបំណងដើម្បីសម្របសម្រួលភារកិច្ចរបស់កងពលធំ យ៉ាងហោចណាស់ក៏មាននូវទំនាក់ទំនងខ្សែទទឹងមួយចំនួនផងដែររវាងកងវរៈសេនាធំ និងកងវរៈសេនាធំ[៩២៩]។

## ៧. តួនាទី និង មុខងាររបស់ នួន ជា

៣០៣. យោងតាមដីកាដំណោះស្រាយ នៅពេលមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា គឺជាសមាជិកសំខាន់មួយរូបរបស់មជ្ឈិមបក្ស ហើយគាត់ទទួលខុសត្រូវក្នុងការឃោសនា បណ្តុះបណ្តាល បញ្ហាវិន័យរបស់កម្មាភិបាល ព្រមទាំងបញ្ហាដែលទាក់ទងនឹងសន្តិសុខខាងក្នុង និងខាងក្រៅ[៩៣០]។

៣០៤. នៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី នួន ជា បានឡើងធ្វើសេចក្តីថ្លែងបើក[៩៣១]។ គាត់បានយល់ព្រមឆ្លើយនឹងសំណួររបស់ចៅក្រម និងភាគីនានា ហើយបានឆ្លើយជាច្រើនដងទាក់ទងនឹងតួនាទី និងមុខងាររបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងក្នុងអំឡុងពេលនៃរបប-

---

[៩២៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត ឯកសារ E3/5145 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00204702-00204703។

[៩២៧] ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ២៩-៣០, ៥០។

[៩២៨] ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៤៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គីម ឯកសារ E3/422 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00407757។

[៩២៩] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៣៣, ៣៩-៤០។

[៩៣០] តួនាទី និងមុខងាររបស់ នួន ជា ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៨៦៩-៨៩៤ នៃដីកាដំណោះស្រាយ។ បន្ថែមពីលើនេះ កថាខណ្ឌ ៨៩៥-៩៩២ លើកឡើងពីការចូលរួមរបស់ នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួម។

[៩៣១] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៤-៧៩។

កម្ពុជាប្រជាធិបតេយ្យ[៩៣២]។ ដូចដែលបានកត់សម្គាល់បន្ថែមខាងក្រោម នួន ជា បានបញ្ជាក់អំពីទំនាក់ទំនងយ៉ាងជិតស្និត និងយូរមកហើយជាមួយនឹងបក្ស រួមទាំងតួនាទីរបស់គាត់ជាអនុលេខា-បក្ស និងសមាជិកភាពរបស់គាត់នៅក្នុង គណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍-បក្ស។ ទោះបី នួន ជា បានឆ្លើយបដិសេធនូវតួនាទីជាផ្លូវការរបស់គាត់នៅក្នុងគោលនយោបាយយោធាក៏ដោយ ក៏គាត់បានឆ្លើយបញ្ជាក់អំពីតួនាទី និងមុខងារផ្សេងៗទៀតនៅក្នុង*អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ* រួមទាំងការតែងតាំងគាត់ជាប្រធានសភាតំណាងប្រជាជន និងការទទួលខុសត្រូវរបស់គាត់ទាក់ទងនឹងការបណ្ដុះបណ្ដាលកម្មាភិបាល និងការឃោសនា។ ក្រោយមក នួន ជា បានសម្រេចប្រើសិទ្ធិរបស់គាត់នៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម និងភាគីនានា[៩៣៣]។ នៅថ្ងៃសវនាការចុងក្រោយ នួន ជា បានធ្វើសេចក្ដីថ្លែងចុងក្រោយនៅចំពោះមុខអង្គជំនុំជម្រះ[៩៣៤]។

## ៧.១ ព័ត៌មានអំពីសាវតារ និងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ

៣០៥. នួន ជា ដែលមានឈ្មោះកំណើត ឡៅ គឹមលន កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង[៩៣៥]។ ដំបូង នួន ជា បានសិក្សានៅខេត្តបាត់ដំបង

---

[៩៣២] ប្រតិចារឹក ថ្ងៃទី ៥-៦, ១៣-១៥ ខែ ធ្នូ ឆ្នាំ ២០១១; ប្រតិចារឹក ថ្ងៃទី ០៥-០៦, ៣០-៣១ ខែ មករា ឆ្នាំ ២០១២; ប្រតិចារឹក ថ្ងៃទី ០៨-០៩ ខែ កុម្ភៈ ឆ្នាំ ២០១២, ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២; ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣; ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣។ សូមមើលផងដែរ កំណត់ហេតុប្រើប្រាស់ដោយ ជនជាប់ចោទ នួន ជា ក្នុងអំឡុងពេលសវនាការ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E148 ទំព័រ ៩-១១។

[៩៣៣] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៨។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៤-៦។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៣-៥៤ នួន ជា បានឆ្លើយទៅនឹងសំណួរមួយចំនួនដែលដើមបណ្ដឹងរដ្ឋប្បវេណីចោទសួរគាត់នៅពេលបង្ហាញខ្លួនក្នុងសវនាការ។ សូមមើលសេចក្ដីជូនដំណឹងអំពីបំណង ដោយអនុលោមតាមវិធាន៩០ ឯកសារ E287 ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣; ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣; ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣។ សូមមើលផ្នែកទី ២ ស្ដីពី បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ២៧, ២៩។

[៩៣៤] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ១-២៦។

[៩៣៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០-៣១។ សូមមើលផងដែរ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ឯកសារ E3/54 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧, ERN (ជាភាសាខ្មែរ) 00148740-00148741។

ហើយក្រោយមកគាត់បានបន្តការសិក្សាថ្នាក់អនុវិទ្យាល័យនៅប្រទេសថៃនៅឆ្នាំ ១៩៤១ បន្ទាប់មកទៀតគាត់បានសិក្សាច្បាប់នៅសាកលវិទ្យាល័យ Thammasat នៅទីក្រុងបាងកក ដោយពេលនោះគាត់បានប្រើឈ្មោះថា រុងឡឺត ឡាវឌី (Runglert Laodi)។ ក្នុងអំឡុងពេលនោះ គាត់ក៏បានបម្រើការងារនៅក្រសួងហិរញ្ញវត្ថុប្រទេសថៃ ហើយក្រោយមកក៏បានធ្វើការនៅក្រសួងការបរទេសប្រទេសថៃដែរ[៩៣៦]។ នៅអំឡុងពេលដែលគាត់នៅក្នុងប្រទេសថៃ នួន ជា បានចូលរួមជាមួយចលនាយុវជនដើម្បីលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសថៃ និងបានចូលរួមនៅក្នុងការពិភាក្សាអំពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ ១៩៥០ គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃ ហើយក្រោយមកបានត្រឡប់មកប្រទេសកម្ពុជាដើម្បីចូលរួមចលនាតស៊ូ[៩៣៧]។

៣០៦. ក្រោយមកទៀត នួន ជា បានចូលរួមក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន[៩៣៨] ដោយគាត់បានផ្ដល់មូលហេតុថា គាត់ព្រួយបារម្ភអំពីការប្រព្រឹត្តិចំពោះកសិករកម្ពុជាពីសំណាក់មន្ត្រីអាណានិគមនិយមបារាំង និងពួកអ្នកមានជាជនជាតិខ្មែរដែលជាម្ចាស់ដី[៩៣៩]។ ចាប់ពីអំឡុងឆ្នាំ ១៩៥០ នួន ជា

---

[៩៣៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ៣១-៣២ ទំព័រ៣៧-៣៨។ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា), ទំព័រ ៥-៦, ទំព័រ ៣៧។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា), ទំព័រ ៣០-៣១។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ERN (ជាភាសាខ្មែរ) 00380357-00380359។

[៩៣៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៦-៣៧។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៧។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078193។ ។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ERN (ជាភាសាខ្មែរ) 00380357-00380359។

[៩៣៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៦-៣៨, ៤៩-៥១។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៩។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-៣០។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ERN (ជាភាសាខ្មែរ) 00380357-00380359។ សូមមើលផ្នែកទី ៣ ស្ដីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨១-៨៤ ។

[៩៣៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៦។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២៥-២៦។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា)

មានភាពសកម្មកាន់តែខ្លាំងនៅពេលដែលគាត់បានចូលរួមនៅក្នុងសកម្មភាពអប់រំ និងឃោសនា ដែលរួមទាំងការបោះពុម្ពផ្សាយសារព័ត៌មាន និងបើកវគ្គបណ្តុះបណ្តាលសម្រាប់កសិករនៅតំបន់ជនបទ[៩៤០]។

៣០៧. ក្នុងចន្លោះឆ្នាំ ១៩៥១ ដល់ឆ្នាំ ១៩៥៤ នួន ជា ត្រូវបានបក្សបញ្ជូនឲ្យទៅសិក្សា និងទទួលការបណ្តុះបណ្តាលនយោបាយនៅប្រទេសវៀតណាម។ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវមក គាត់បានត្រឡប់មកប្រទេសកម្ពុជា ហើយបានអះអាងថា សមាជិកបក្សត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ឬបានចាកចេញពីចលនាតស៊ូនេះ ហើយថា សកម្មភាពធ្វើស្រែចំការរបស់កសិករត្រូវបានរារាំងដោយគោលនយោបាយតឹងតែងរបស់រដ្ឋាភិបាល[៩៤១]។ មុនពេលមកតាំងទីលំនៅនៅទីក្រុងភ្នំពេញ នាឆ្នាំ១៩៥៥ នួន ជា បានផ្លាស់ទីកន្លែងរស់នៅមួយចំនួននៅទីជនបទ ដូចជា នៅបឹងល្វា តាមស្ទឹងជីនិត និងនៅសំឡូត ដើម្បីលាក់បាំងការចូលរួមដ៏សកម្មរបស់គាត់នៅក្នុងចលនាតស៊ូ និងដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់[៩៤២]។

៣០៨. នៅទីក្រុងភ្នំពេញ នួន ជា បានបន្តការងារជាសម្ងាត់របស់គាត់នៅក្នុងចលនាបដិវត្តន៍ ក្នុងនាមជាសមាជិកគណៈកម្មាធិការបក្សក្រុង[៩៤៣] ខណៈពេលដែលគាត់កំពុងបម្រើការងារផ្សេងៗ

---

ទំព័រ ៦-៧។ សូមមើលផងដែរ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54, ERN (ជាភាសាខ្មែរ) 00148743-00148744។

[៩៤០] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-៨។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078158-59។

[៩៤១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៨-៣៩, ៥៤-៥៥, ៦១។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ៥។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៥-៣៧, ៣៨-៤០។ សូមមើលផងដែរ បទសម្ភាសន៍ នួន ជា ជាមួយនឹង ខែម ងុន ឯកសារ E3/3 ERN (ជាភាសាខ្មែរ) 00078188។

[៩៤២] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤-៦។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១០។

[៩៤៣] ទោះបីជា នួន ជា អះអាងថា គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការនេះក៏ដោយ ក៏វាបង្ហាញឲ្យឃើញច្បាស់ថា គាត់បានកាន់តួនាទីមួយ ថ្វីបើមានការទទួលស្គាល់ថា គាត់មិនមែនជាសមាជិកស្ថាបនិកក៏ដោយ។ *សូមមើលផងដែរ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ* E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078188 (ដែលបញ្ជាក់ថា ប៉ុល ពត, ម៉ី ម៉ាន់, ខ្មៅ និង ចាន់ សាម៉ន បានរៀបចំគណៈកម្មាធិការ មុនការចូលរួមរបស់ នួន ជា)។

01006561



ទៀត ដូចជា គ្រូបង្រៀន អ្នកលក់ដូរ ឬជាបុគ្គលិកនៅក្នុងក្រុមហ៊ុននាំចេញនាំចូល។ ក្រោយពេល ប៉ុល ពត ត្រឡប់មកពីប្រទេសបារាំងនៅអំឡុងឆ្នាំ ១៩៥៥ និងឆ្នាំ ១៩៥៦ នួន ជា ត្រូវបានគេ ណែនាំឲ្យស្គាល់ ប៉ុល ពត។ ប៉ុល ពត និង នួន ជា ដែលអ្នកទាំងពីរជាសមាជិកបក្សប្រជាជន បដិវត្តន៍កម្ពុជាដំបូង បានធ្វើការងារជាមួយគ្នាជាជំនួយការឲ្យ ទូ សាមុត[៩៤៤]។ ក្រោយមក នៅឆ្នាំ ១៩៦០ នួន ជា បានជួបជាមួយ អៀង សារី នៅក្នុងឱកាសមហាសន្និបាតបក្សលើកទី១ ដែលនៅ ពេលនោះ ទូ សាមុត ត្រូវបានតែងតាំងជាលេខាបក្ស នួន ជា ត្រូវបានតែងតាំងជាអនុលេខាបក្ស ហើយនៅពេលនោះបក្សត្រូវបានប្តូរឈ្មោះជាបក្សពលករកម្ពុជា[៩៤៥]។

៣០៩. នៅឆ្នាំ ១៩៦៣ អៀង សារី និង ប៉ុល ពត ដែលអ្នកទាំងពីរត្រូវបានចាត់ទុកជា "ពួក ចម្រើន" ត្រូវបានសម្តេច នរោត្តម សីហនុ កោះហៅ ជាមួយនឹងបុគ្គលផ្សេងៗទៀត ក្រោមហេតុ ផលថាបានបង្កើតរដ្ឋាភិបាលថ្មីមួយ។ ដោយភ័យខ្លាចអំពីការចាប់ខ្លួន ពួកគេបានចូលរួមជាមួយ ក្រុមសម្ងាត់មួយនៅក្បែរព្រំដែនប្រទេសកម្ពុជា និង វៀតណាម[៩៤៦]។ នួន ជា បានជួបជាមួយ ខៀវ សំផន លើកដំបូងនៅក្បែរភ្នំឱរ៉ាល់ បន្ទាប់ពី ខៀវ សំផន បានរត់ចូលព្រៃម៉ាគី ប៉ុន្តែគាត់មិនចាំ ថានៅពេលណាទេ[៩៤៧]។ ចាប់តាំងពីដើមទសវត្សរ៍ ១៩៦០ មក ការចូលរួមនយោបាយរបស់ នួន ជា

---

ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២១-២២ (ដែលចាំថា វន វ៉េត គឺជាគណៈ-កម្មការក្រុងភ្នំពេញ ប៉ុន្តែមិនចាំសមាជិកផ្សេងទៀតទេ)។

[៩៤៤] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៩-៤១។

[៩៤៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤១។ សូមមើលផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្រ្ត កថាខណ្ឌ ៨៧ ។

[៩៤៦] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៤២-៤៤។ សូមមើលផង ដែរ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្រ្តកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិប-តេយ្យ ឯកសារ E3/16 ERN (ជាភាសាខ្មែរ) 00380378-00380379។ សូមមើលផងដែរ ផ្នែកទី ៨ ស្តីពី តួនាទី និង មុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥៨ ។

[៩៤៧] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៤។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃ ទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៦-២៧។ ខៀវ សំផន បានបញ្ជាក់ថា គាត់បានចូលរួម ជាមួយបក្សនៅភ្នំឱរ៉ាល់ប្រហែលជាមុនរដ្ឋប្រហារឆ្នាំ១៩៧០។ សូមមើល ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ ខៀវ សំផន) ទំព័រ ១៦។ សូមមើលផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៤ ។

នៅតែជាការសម្ងាត់[៩៤៨]។ ចាប់ពីឆ្នាំ ១៩៦៣ នួន ជា បានធ្វើដំណើរទៅជនបទដើម្បីជួបជាមួយមេដឹកនាំចលនាផ្សេងៗទៀត រួមទាំង ប៉ុល ពត, អៀង សារី និង សុន សេន។ គាត់ក៏បានជួបជាមួយ វន វ៉េត, កែ ពក, សោ  ភឹម, កុយ ធួន, រស់ ញឹម នៅពេលដែលចលនាបដិវត្តន៍បានរីកចម្រើនទៅមុខ[៩៤៩]។ ម្ដងម្កាល នួន ជា បានធ្វើដំណើរជាសម្ងាត់ពីទីក្រុងភ្នំពេញទៅកាន់មន្ទីរបក្សសំខាន់ៗ រួមទាំងមន្ទីរ ១០០ ដែលដំបូងមានទីតាំងនៅតំបន់ព្រំដែនជាមួយប្រទេសវៀតណាម។ ចាប់ពីឆ្នាំ១៩៦៦ ដល់១៩៦៧ គាត់បានធ្វើដំណើរទៅកាន់មន្ទីរ ១០០ ថ្មី ដែលមានទីតាំងនៅខេត្តរតនគីរី ហើយចាប់ពីឆ្នាំ១៩៧០ គាត់បានធ្វើដំណើរទៅកាន់មន្ទីរ ស-៧១ ដែលមានទីតាំង នៅតាមដងស្ទឹងជីនិត។ ក្រោយមក នៅពេលដែលខ្មែរក្រហមចូលជិតមកដល់ទីក្រុងភ្នំពេញ គាត់ក៏បានធ្វើទស្សនកិច្ចនៅមន្ទីរ ប-៥[៩៥០] ខេត្ត និងភូមិភាគផ្សេងៗទៀតដែលគ្រប់គ្រងដោយខ្មែរក្រហម[៩៥១]។

---

[៩៤៨] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៤៤-៤៥។

[៩៤៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៦-១០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៦២-៦៣។ សូមមើលផងដែរ ERN (ជាភាសាខ្មែរ) 00062313-00062319 (ក៏បានសំដៅទៅលើកិច្ចប្រជុំរបស់ នួន ជា ដែលធ្វើឡើងនៅឆ្នាំ ១៩៦៨ ជាមួយមេដឹកនាំភូមិភាគ ដែលក្នុងចំណោមនោះរួមមាន តា ម៉ុក, រស់ ញឹម និង សោ ភឹម ដែលនៅក្នុងកិច្ចប្រជុំនេះ អ្នកចូលរួម ត្រូវបានជូនដំណឹងអំពីសេចក្ដីសម្រេចឲ្យចាប់ផ្ដើមតស៊ូផ្នែកប្រដាប់អាវុធ និងនយោបាយ ពាសពេញប្រទេសនៅភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ និងភូមិភាគអាគ្នេយ៍)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16 ទំព័រ ១២៣-១២៥ ERN (ជាភាសាខ្មែរ) 00380357-00380359។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4017, ERN (ជាភាសាខ្មែរ) 00784339-00784340 (បង្ហាញថា នៅឆ្នាំ១៩៦៧ នៅពេលមានការបះបោរនៅសំឡូត នួន ជា បានធ្វើដំណើរទៅទីនោះ និងបានប្រគល់លិខិតមួយច្បាប់ជូនទៅ រស់ ញឹម និង គង់ សុផល ដែលពាក់ព័ន្ធនឹងការណែនាំពីគណៈកម្មាធិការមជ្ឈិមឲ្យផ្អាកការតស៊ូប្រដាប់អាវុធ)។

[៩៥០] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-៩ (ពិភាក្សាអំពីការធ្វើដំណើររបស់គាត់ទៅកាន់មន្ទីរ ១០០)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៤-១៥ (ពិភាក្សាអំពីការធ្វើដំណើររបស់គាត់ទៅកាន់មន្ទីរ ១០០) ទំព័រ ២៧ (ពិភាក្សាអំពីការធ្វើដំណើររបស់គាត់ទៅកាន់តំបន់ស្ទឹងជីនិត)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨ (ពិភាក្សាអំពីការធ្វើដំណើររបស់គាត់ទៅកាន់មន្ទីរ ប-៥)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ចាម តុន) ទំព័រ ៣-៤, ៣២-៣៣ (ពិភាក្សាអំពីវត្តមានរបស់ នួន ជា នៅមន្ទីរ ស-៧១)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សាឡុត បាន) ទំព័រ ២០-២១ (បង្ហាញថា នួន ជា គឺនៅមន្ទីរបក្សក្បែរស្ទឹងជីនិត)។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ១០-១២, ១៦-២០, ២៦-២៧ (ពិភាក្សាអំពីវត្តមានរបស់ នួន ជា នៅមន្ទីរប-៥ ដែលរួមមានក្នុងអំឡុងកិច្ចប្រជុំផែនការនាឆ្នាំ១៩៧៥ស្ដីពីការវាយប្រហារចុងក្រោយ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។

៣១០. នៅឆ្នាំ១៩៧០ នៅពេលសម្ដេច នរោត្តម សីហនុ ត្រូវបានទម្លាក់ចេញពីអំណាច នួន ជា បានធ្វើដំណើរទៅកាន់ភូមិភាគបូព៌ា ហើយបានត្រឡប់មកភ្នំពេញវិញក្នុងរយៈពេលពីរបីខែក្រោយមក។ នៅពេលគាត់នៅទីនោះ គាត់បានបន្តធ្វើដំណើរទៅជួប ប៉ុល ពត និង អៀង សារី ដើម្បីពន្យល់ពួកគាត់អំពីស្ថានការណ៍នៅទីក្រុងភ្នំពេញ និងដើម្បីទទួលការណែនាំពី ប៉ុល ពត[៩៥២]។ នៅពេលដែលបដិវត្តន៍មានការរីកចម្រើនទៅមុខ នួន ជា បានចាកចេញពីទីក្រុងភ្នំពេញ ហើយបានចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់បក្សនៅមន្ទីរ ស-៧១[៩៥៣]។

៣១១. នៅប៉ុន្មានឆ្នាំដំបូងនៃការធ្វើនយោបាយយ៉ាងសកម្មរបស់គាត់នៅប្រទេសកម្ពុជា ការទទួលខុសត្រូវសំខាន់របស់ នួន ជា នៅក្នុងបក្ស រួមមាន ការចូលរួមបង្កើតគោលនយោបាយរបស់បក្ស

[៩៥១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ៤-៦, ១៥-១៦ (ពិភាក្សាអំពីការធ្វើដំណើររបស់ នួន ជា ទៅកាន់សំឡូតដើម្បីជួបជាមួយមេដឹកនាំភូមិភាគមួយចំនួន)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី យុន គីម) ទំព័រ ៣-៥, ៦២-៦៤ (ពិភាក្សាអំពីកិច្ចប្រជុំ ដែលធ្វើឡើងដោយ នួន ជា នៅឆ្នាំ១៩៧៣ នៅខេត្តក្រចេះ)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ២៨។ នៅឆ្នាំ ១៩៧៣ នួន ជា បានអមដំណើរសម្ដេច នរោត្តម សីហនុ ទៅទស្សនកិច្ចតំបន់រំដោះនានា។ សូមមើល ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦៦-៦៨។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៥-១៨។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-៣០។ *សូមមើលផងដែរ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខៀម ឌុន ឯកសារ* E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078190-00078191 (ដែលបញ្ជាក់ថា នួន ជា ទទួលបន្ទុកទំនាក់ទំនងខាងជនបទ ចាប់តាំងពីបក្សត្រូវបានបង្កើតឡើងពីដំបូង ) 00078197, 00078199។

[៩៥២] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា), ទំព័រ ៦៤ (“ក្នុងខែកុម្ភៈ [ឆ្នាំ១៩៧០] ខ្ញុំ នួន ជា ធ្វើដំណើរទៅធ្វើសន្និបាត និងបើកវគ្គសិក្សានៅភូមិភាគបូព៌ា ដើម្បីពិនិត្យសភាពការណ៍អំពីលទ្ធភាពធ្វើរដ្ឋប្រហាររបស់ក្រុម លន់ នល់ និងដាក់វិធានការទប់ទល់រដ្ឋប្រហារនេះ។”) ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-៩ (“ខ្ញុំមិនបានទៅលាក់ខ្លួននៅក្នុងព្រៃជាមួយ ប៉ុល ពត, អៀង សារី ទេ យូរៗខ្ញុំទៅជួបម្ដង មួយខែពីរខែទៅជួបគ្នាម្ដង ដើម្បីពិភាក្សា ដើម្បីខ្ញុំយកសភាពការណ៍ទៅរាយការណ៍ ហើយទទួលការណែនាំពី ប៉ុល ពត មកវិញ តើត្រូវ ដំណើរការយ៉ាងម៉េច? ត្រូវរៀបចំបក្សយ៉ាងម៉េច? អីយ៉ាងម៉េច? ជួនណាពីរខែទៅម្ដង ជួនណាមួយខែទៅម្ដង នឹងសភាពការណ៍វាអំណោយឲ្យ គឺតាមការចាំបាច់នៃសភាពការណ៍ក្នុងរយៈកាលនីមួយៗ។”)។

[៩៥៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៥-៦។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី ផាន វ៉ាន់) ទំព័រ ៣៩-៤០ (បង្ហាញថា នួន ជា មានទីតាំងស្ថិតនៅមន្ទីរ ប-២០ ដែលជាមន្ទីរចំណុះឲ្យមន្ទីរ ស-៧១ )។

និងមាគ៌ាយុទ្ធសាស្ត្រ និងកលយុទ្ធ ជាមួយនឹង ប៉ុល ពត[៩៥៤]។ នួន ជា ក៏បានបន្តសកម្មភាពផ្តោតទៅលើការឃោសនាផងដែរ តាមរយៈការធ្វើដំណើរទៅជនបទ ដើម្បីប្រមូលកម្មាភិបាល និងបើកវគ្គបណ្តុះបណ្តាលដល់កសិករ និងមេដឹកនាំចលនាតស៊ូនៅមូលដ្ឋាន[៩៥៥]។ គាត់ក៏ជាបុគ្គលសំខាន់ក្នុងការចេញទស្សនាវដ្តីទង់បដិវត្តផងដែរ[៩៥៦]។ នៅក្នុងសវនាការ នួន ជា បានថ្លែងដោយមិនស៊ីសង្វាក់គ្នាទាក់ទិននឹងការចូលរួមរបស់គាត់នៅក្នុងការផ្សព្វផ្សាយទស្សនាវដ្តីទង់បដិវត្ត ដោយបានបដិសេធថាគាត់មិនបានចូលរួមនៅក្នុងការផ្តួចផ្តើមគំនិតបង្កើតទស្សនាវដ្តីទង់បដិវត្តនេះឡើយ[៩៥៧]។ ទោះជាយ៉ាងណាក៏ដោយ ការបដិសេធរបស់គាត់មិនអាចឲ្យជឿជាក់បានទេ បើពិចារណាទៅលើភាពពាក់ព័ន្ធកាលពីដំបូងរបស់គាត់នៅក្នុងការបោះពុម្ពផ្សាយសារព័ត៌មានជាច្រើនដែលទាក់ទងនឹងបក្ស និងការពិពណ៌នាពេលក្រោយមកទៀតរបស់គាត់ អំពីការបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្តនេះ[៩៥៨]។

---

[៩៥៤] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា), ទំព័រ ៣៩។ សូមមើលផងដែរ ប្រវត្តិចលនាតស៊ូពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧០ ឯកសារ E3/131 ERN (ជាភាសាខ្មែរ) 00062305-00062306។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ទំព័រ ១៣០-១៣២ ERN (ជាភាសាខ្មែរ) 00380364-00380366។

[៩៥៥] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៥។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ៨-៩, ២៧-៣៧ (សំដៅទៅលើវគ្គសិក្សាដែលមាន ប៉ុល ពត និង នួន ជា ជាប្រធាន នៅឆ្នាំ១៩៧១ នៅមន្ទីរភូមិភាគខាងជើង រួមមានកម្មាភិបាលថ្នាក់តំបន់ និងថ្នាក់ស្រុក។ បន្ទាប់ពីកិច្ចប្រជុំនេះ នៅមានកិច្ចប្រជុំមេដឹកនាំថ្នាក់មជ្ឈិម និងមេដឹកនាំថ្នាក់ភូមិភាគ ដែល នួន ជា ក៏បានចូលរួមផងដែរ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី យុន គីម) ទំព័រ ៩-១០, ២៧-២៨, ៣០-៣១ (លើកឡើងថា នៅឆ្នាំ ១៩៧៣ នួន ជា បានកោះប្រជុំមេឃុំក្នុងខេត្តក្រចេះ នៅភូមិដារ។ ក្នុង អំឡុងកិច្ចប្រជុំ នួន ជា បានណែនាំទាក់ទិននឹងការអនុវត្ត និងការបង្កើតសហករណ៍។ សង្គ្រាមប្រឆាំងនឹងរបប លន់ នល់ ត្រូវបាន នួន ជា លើកឡើងត្រួសៗផងដែរ។)

[៩៥៦] សូមមើលផ្នែកទី ៦ ស្តីពីប្រព័ន្ធទំនាក់ទំនង កថាខណ្ឌ ២៦១-២៦៦ ។

[៩៥៧] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤-៥។

[៩៥៨] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៨-៩ ("ក៏ប៉ុន្តែ ដូចបានជម្រាបហើយ យើងកាលណោះគ្មានមធ្យោបាយអ្វីក្រៅពីសរសេរក្រដាសក្រមួនទេ ហើយយកបោះពុម្ព ហើយយកចែកអ្នកអានផ្សាយតាំងពីលើទៅដល់ក្រោមរៀនសូត្រឯកសារនេះ ដើម្បីកសាងទស្សនៈ គោលជំហរ សតិអារម្មណ៍ ឲ្យរក្សាទុកជាធាតុអ្នកស្នេហា ជាតិ ស្នេហាបដិវត្តន៍ ស្នេហាប្រជាជនតទៅទៀត កុំឲ្យខ្ចាត់ខ្ចាយ។ ដូច្នោះមានអី មានតែធ្វើឯកសារហ្នឹង បានចាប់ផ្តើមធ្វើ ឯកសារទង់បដិវត្តហ្នឹងឡើង។ នេះខ្ញុំសូមជម្រាបប្រវត្តិរបស់វាៗអ៊ីចឹង។") បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ជាភាសាខ្មែរ) 00062309-00062310 ។

ជាចុងក្រោយ នៅពេលដែល នួន ជា បានធ្វើការងារបង្កើតគោលនយោបាយបក្ស ដែលឯករាជ្យពេញលេញពីបក្សកុម្មុយនីស្តវៀតណាមជាបណ្តើរៗនោះ គាត់ក៏បានដើរតួនាទីជាអ្នកទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តវៀតណាម ដោយធ្វើដំណើរទៅកាន់ប្រទេសវៀតណាមជាច្រើនលើកច្រើនសា ដើម្បីជួបជាមួយមេដឹកនាំបក្សកុម្មុយនីស្តវៀតណាម[៩៥៩]។

៣១២. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ត្រូវបានគេហៅនាមត្រកូលរបស់គាត់ថា "បងនួន" ឬ "អ៊ំ នួន" ព្រមទាំង "សមមិត្ត អនុលេខា" ឬជាទូទៅហៅ "បង" "បងជាទីគោរព" "បងជាទីស្នេហា"[៩៦០]។ ទោះបីជាគាត់បដិសេធថាមិនបានប្រើឈ្មោះ ឬត្រូវបានគេហៅជាទូទៅថា "បងធំ

---

ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦២-៦៣ ("អ្នកធ្វើទង់បដិវត្តន៍ហ្នឹង គឺគណៈ-អចិន្ត្រៃយ៍ជាអ្នកសរសេរជាពិសេសលេខាបក្ស ហើយនិងខ្ញុំ។") *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣-៤; ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៧-៨។ បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងួន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ជាភាសាខ្មែរ) 00062303-00062306។

[៩៥៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥១-៥៥។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា), ទំព័រ ១៧-១៨។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៣-១៤, ២៤-២៥។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-២០, ២៥-២៧។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣២-៣៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជន-ជាប់ចោទ នួន ជា) ទំព័រ ៣៩-៤១។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦។ បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងួន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ជាភាសាខ្មែរ) 00062308-00062309, 00062316-00062318។ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ទំព័រ ១២៣-១២៥ ERN (ជាភាសាខ្មែរ) 00380357-00380359។ នួន ជា នៅមានតួនាទីនេះក្នុង*អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ*។ សូមមើល ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៩។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ៤-៦។

[៩៦០] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៦ ("បងនួន")។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៥៤-៥៧ ("បងនួន" ព្រមទាំង "បងជាទីគោរព" និង "បងជាទីស្នេហា"), ទំព័រ ៦៤ ("បងនួន" ព្រមទាំង "បងជាទីគោរព")។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី ផាន វ៉ាន) ទំព័រ ៨០-៨២ ("បង" និង "បង")។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ (សាក្សី វ៉ាន់ថាន់ ពៅដារ៉ា) ទំព័រ ៣០-៣១ ("បង នួន")។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (សាក្សី នង សុផង់) ទំព័រ ២៥-២៦ ("អ៊ំ នួន') ទំព័រ ២៧, ៣៥-៣៦ ("អ៊ំ នួន")។ ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ពេជ្រ ជឹម) ទំព័រ ៥៩-៦១ ("អ៊ំ នួន")។ ប្រតិចារឹក ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៨៣-៨៤

ទីពីរ”[៩៦១] ក៏សាក្សីមួយចំនួនបានបញ្ជាក់ថា *ឈ្មោះហៅក្រៅ* នេះ ត្រូវបានប្រើសំដៅចំពោះ នួន ជា[៩៦២]។ ឈ្មោះហៅក្រៅទាំងនេះ ក៏ត្រូវបានលើកឡើងនៅក្នុងទូរលេខ និងរបាយការណ៍ជាច្រើនដែលពាក់ព័ន្ធនឹងសកម្មភាពរបស់គណៈកម្មាធិការមជ្ឈិមបក្ស[៩៦៣] ក៏ដូចជានៅក្នុងចំណាររបស់កម្មាភិបាលទៅលើចម្លើយសារភាពនៅមន្ទីរ ស-២១ រួមទាំងដោយសាក្សី កាំង ហ្កេកអ៊ាវ ដែលបានផ្ញើជូន ឬ ចម្លងជូន នួន ជា[៩៦៤]។ ជាពិសេស សាក្សី សួន កានិល ដែលធ្វើការងារពាក់ព័ន្ធទូរលេខរបស់

(“សមមិត្ត អនុលេខា”)។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ឯកសារ E3/64 ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ (00328039-00328040 (“បងនួន”), 00328040-00328045 (“Uncle Nuon”) ។កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ឯកសារ E3/71 ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ជាភាសាខ្មែរ) 00284294-00284295, 00284302-00284303, 00284306-00284307 (“សមមិត្តអនុលេខា”)។

[៩៦១] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១០។

[៩៦២] ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ១៧-១៨។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៩០-៩១ (បង្ហាញថា កុយ ធួន បានហៅ នួន ជា ថាជាបងធំទី២)។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ២៩-៣០; ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី François PONCHAUD) ទំព័រ ៦៩-៧០។ ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ពេជ្រ ជឹម) ទំព័រ ៥៩-៦១។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៥, ២៦។

[៩៦៣] ទូរលេខ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/893 ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000708-00000709 (“បង នួន”)។ ទូរលេខ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/908, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00020923 (“អ៊ំ នួន”)។ ទូរលេខ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/943 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00021014 (“អ៊ំ នួន”)។ សេចក្តីរាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/860 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00021003 (“អ៊ំ នួន”)។ ពិធីជប់លៀងក្នុងឱកាសខួបលើកទី ៥១ នៃការបង្កើតកងទ័ពប្រជាជនរំដោះចិន (ព្រឹត្តិប័ត្រព័ត៌មាន កម្ពុជាប្រជាធិបតេយ្យ) ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារ E3/1417, ERN (ជាភាសាខ្មែរ) 00722155, 00722157-00722158 (“សមមិត្តអនុ-លេខា”)។ *សុន្ទរកថា សមមិត្ត តេង យីងចាវ សមាជិកគណៈមជ្ឈិមបក្សកុម្មុយ នីស្តចិន* (ព្រឹត្តិប័ត្រព័ត៌មានកម្ពុជាប្រជាធិបតេយ្យ) ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ឯកសារ E3/78 ERN (ជាភាសាខ្មែរ) 00705175 (“សមមិត្តអនុលេខា”)។

[៩៦៤] ចម្លើយរបស់ គង់ គឿន ហៅ អ៊ឹង វ៉េត នៅមន្ទីរស-២១ ឯកសារ E3/1565, ERN (ជាភាសាអង់គ្លេស) 00182773 (“បង នួន”)។ ចម្លើយរបស់ ជូត ញ៉ៅ នៅមន្ទីរស-២១ ឯកសារ E3/1687 ERN (ជាភាសាខ្មែរ) 00005403 (“បង នួន”)។ ចម្លើយរបស់ ចាប ម៉ិត នៅមន្ទីរ ស-២១ ឯកសារ E3/1688 ERN (ជាភាសាខ្មែរ) 00226401 (“បងធំ ទី២”)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៦-៨។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៣-២៦)។

គណៈកម្មាធិការមជ្ឈិមបក្សបានលើកឡើងថា ការប្រើពាក្យ ថា "អ៊ំ នួន" លើទូរលេខផ្ញើទៅកាន់មន្ទីរ ៨៧០ គឺ "ជាការពិត" សំដៅចំពោះ នួន ជា[៩៦៥]។ ក្នុងអំឡុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានធ្វើឡើងនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ប៉ុល ពត ដែលត្រូវបានកំណត់ថាជាប្រធានគណៈកម្មាធិការនេះ បានហៅ នួន ជា ថា " សមមិត្ត នួន"[៩៦៦]។

## ៧.២ ឋានៈ និងតួនាទីរបស់ នួន ជា នៅក្នុងបក្ស

៣១៣. នួន ជា បានផ្តល់សក្ខីកម្មថា ចាប់តាំងពីសន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ ១៩៦០ មក គាត់គឺជាអនុលេខាបក្ស[៩៦៧]។ នួន ជា បានរក្សាតំណែងនេះក្នុងអំឡុងសន្និបាតបក្សក្រោយៗទៀត

---

នួន ជា ក៏ត្រូវបានគេហៅថាជា "បង នួន" នៅក្នុងចំណារជាច្រើន ដែលមាននៅក្នុងចម្លើយសារភាពផ្សេងទៀតនៅក្នុងមន្ទីរ ស-២១។ *សូមមើល ឧទា.* ចម្លើយរបស់ តាំង អាន ហៅ អេន នៅមន្ទីរស-២១ ឯកសារ E3/1826, ERN (ជាភាសាអង់គ្លេស) 00183380។ ចម្លើយរបស់ ឌី ឡេង ហៅ ភាព នៅមន្ទីរស-២១ ឯកសារ E3/1839, ERN (ជាភាសាអង់គ្លេស) 00182820។ ចម្លើយរបស់ ហែម សុត ហៅ សឿន នៅមន្ទីរស-២១ ឯកសារ E3/1842, ERN (ជាភាសាខ្មែរ) 00017272)។ ចម្លើយរបស់ លុន អិន នៅមន្ទីរស-២១ ឯកសារ E3/3689, ERN (ជាភាសាខ្មែរ) 00174874។ សូមមើលផងដែរ ជើងទំព័រលេខ ១០៣៥។ សូមមើលផងដែរផ្នែកទី ៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា ជើងទំព័រ ១០៣៥។

[៩៦៥] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី សួន កានិល) ទំព័រ ៨៣-៨៤។ សូមមើលផងដែរ ទូរលេខ កម្ពុជា-ប្រជាធិបតេយ្យ ឯកសារ E3/519 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00001092។

[៩៦៦] កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ឯកសារ E3/225, ERN (ជាភាសាខ្មែរ) 00000841-00000842។ ទោះបីជាអត្ថបទបកប្រែជាភាសាអង់គ្លេសនៃឯកសារ E3/225 មិនមានពាក្យ "សមមិត្ត" ក៏ដោយ តែអង្គជំនុំជម្រះបានយោងទៅលើអត្ថបទដើមជាភាសាខ្មែរ។ នួន ជា ជារឿយៗត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុគណៈអចិន្ត្រៃយ៍ថាជា "សមមិត្តអនុលេខា" ឬជា "សមមិត្ត នួន"។ សូមមើលផងដែរ ផ្នែកទី ៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា ជើងទំព័រលេខ ៩៧៥។

[៩៦៧] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦០ និង ៦១-៦១។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៥-៥៨។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១១។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៣-៥៤។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៥-១៦។ *សូមមើលផងដែរ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ* E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078192។ ។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16 ERN (ជាភាសាខ្មែរ) 00380368-00380370។

ព្រមទាំងនៅក្នុងអំឡុងពេលទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ[៥៦៨]។ បន្ទាប់ពី ទូ សាមុត បាត់ខ្លួន ប៉ុល ពត ត្រូវបានតែងតាំងជាលេខាបក្សនៅឆ្នាំ ១៩៦៣។ ជាច្រើនលើកច្រើនសា នួន ជា បានបញ្ជាក់ថា មានការសង្ស័យមកលើរូបគាត់ ដោយសារតែពូថ្លៃរបស់គាត់ឈ្មោះ ស៊ីវ ហេង ដែលជាមេដឹកនាំមួយរូបនៃបក្សប្រជាជនបដិវត្តន៍កម្ពុជាទទួលបន្ទុកខាងសមាជិកបក្សនៅជនបទបានចុះចូលជាមួយរបប លន់ នល់។ ទោះបីជាយ៉ាងណា នួន ជា បានគាំទ្រចំពោះការជ្រើសរើស ប៉ុល ពត ជាលេខាបក្ស ទោះបីជាគាត់នៅតែជាអនុលេខាបក្សក៏ដោយ[៥៦៩] ហើយគាត់បានព្រមព្រៀងជាមួយ ប៉ុល ពត ថាពួកគេនឹងធ្វើការងារជាមួយគ្នា[៥៧០]។

៣១៤. អ្នកជំនាញ David CHANDLER សាក្សី សួង ស៊ីគឿន និង កាំង ហ្គេកអ៊ាវ ក្នុងចំណោមអ្នកផ្សេងទៀត[៥៧១] ព្រមទាំងជនជាប់ចោទ ខៀវ សំផន[៥៧២] បានបញ្ជាក់ថា នួន ជា ពិតជាកាន់តួនាទីនេះមែន។

---

[៥៦៨] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៧។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-១៩។ សូមមើលផងដែរ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54 ERN (ជាភាសាខ្មែរ) 00148743-00148744។ *សូមមើល ផងដែរ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ* E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078197។

[៥៦៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៦-៥៨។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៤៤-៤៦។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៨-១០។ *សូមមើលផងដែរ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ* E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078196-00078197។ ។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ Davide CHANDLER) ទំព័រ ៤២-៤៣។

[៥៧០] ភាពយន្តឯកសារនិពន្ធដោយ THET S.R. LEMKIN៖ សត្រូវប្រជាជន ឯកសារ E3/4001R ឈុតវីដេអូបន្ថែម-បទសម្ភាសន៍ នួន ជា ជាមួយ ថេត សម្បត្តិ 09’40-10’14 (“ហេតុនេះ ខ្ញុំបាននិយាយទៅកាន់ ប៉ុល ពត ថា នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ ខ្ញុំមិនសមជាមនុស្សដែលដឹកនាំបក្សនោះទេ ... ដូច្នេះខ្ញុំបានស្នើសុំ ប៉ុល ពត ធ្វើជាលេខា។ នៅពេលនោះ យើងទាំងពីរនាក់ បានឯកភាពគ្នាថា នៅពេលណាក៏ដោយដែលមានបញ្ហា យើងនឹងដោះស្រាយបញ្ហាទាំងនោះជាមួយគ្នា”)។

[៥៧១] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៤៣។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ (សាក្សី សួង ស៊ីគឿន) ទំព័រ ២៦-២៧; ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ១៨។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៤៧។

៣១៥. នួន ជា ក៏បានបញ្ជាក់ថា គាត់គឺជាសមាជិកពេញសិទ្ធិមួយរូបទាំងនៅក្នុងគណៈកម្មាធិការ-មជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា[៩៧៣]។ សមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នេះ ត្រូវបានសាក្សី និងអ្នកជំនាញជាច្រើនដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបញ្ជាក់ផងដែរ[៩៧៤]។

៣១៦. ភស្តុតាងនៃការតែងតាំងទាំងនេះ មានសរសេរនៅក្នុងឯកសារនានានៃរបបកម្ពុជាប្រជា-ធិបតេយ្យ។ កំណត់ហេតុកិច្ចប្រជុំជាច្រើនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបង្ហាញថា នួន ជា មានមុខតំណែងជាអនុលេខាបក្ស[៩៧៥]។ ចាប់ពីចុងឆ្នាំ ១៩៧៧ នួន ជា ត្រូវបាន

[៩៧២] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារE3/27 ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១០-១១ ("បានកំណត់ អត្តសញ្ញាណ នួន ជា ជាអនុលេខានៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងជាមួយ ប៉ុល ពត ដែលបុគ្គលសំខាន់បំផុតនៅក្នុងបក្ស")។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16 ERN (ជាភាសាខ្មែរ) 00380376-00380377។

[៩៧៣] ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣៣-៣៥។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៧-២៩។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078192, 00078197 ។ ។

[៩៧៤] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៥, ២៩។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១ (សាក្សី ឡុង នរិន្ទ) ទំព័រ ៥៧-៥៨។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សាឡុត បាន) ទំព័រ ១-២។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន), ទំព័រ ៥-៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៤៦-៤៧។ ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (សាក្សី ខៀវ អេន) ទំព័រ ៨២។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (សាក្សី អ៊ុង រ៉ែន) ទំព័រ ៥៤-៥៥។

[៩៧៥] *សូមមើល ឧទា.* កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/227 ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ERN (ជាភាសាខ្មែរ) 00019127-00019128។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/228 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00017105។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/229 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000713-00000714។ កំណត់ហេតុគណៈកម្មាធិការ-អចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ១៩៧៦ ERN (ជាភាសាខ្មែរ) 00000744-00000745។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/217 ចុះថ្ងៃទី១១ ខែ មីនា ឆ្នាំ១៩៧៦ ERN (ជាភាសាខ្មែរ) 00000736។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/218 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000751។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/220 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000827។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/221 ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ

កំណត់ជាផ្លូវការថាជាអនុលេខានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងសុន្ទរកថាដែលគាត់បានថ្លែងទៅកាន់ភ្ញៀវកិត្តិយស និងគណៈប្រតិភូបរទេស និងនៅក្នុងរបាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យទាក់ទិននឹងការធ្វើដំណើរទៅកាន់បរទេស និងកិច្ចប្រជុំនានា[៩៧៦]។

---

១៩៧៦ ERN (ជាភាសាខ្មែរ) 00000810-00000811។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/222 ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000770។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/224 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000772-00000773។ កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/225 ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00000837។

[៩៧៦] *បក្សកុម្មុយនីស្តកម្ពុជាលាតត្រដាងជាផ្លូវការអំពីខួបនៃការបង្កើតបក្ស* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/2678 ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00715810-00715811 (ដែល នួន ជា ត្រូវបានទទួលស្គាល់ជាផ្លូវការថាជាអនុលេខាគណៈកម្មាធិការមជ្ឈិម)។ សុន្ទរកថារបស់សមមិត្ត នួន ជា អនុលេខានៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឱកាសលៀងភោជនាហារធ្វើឡើងជូនជាកិត្តិយសដល់គណៈប្រតិភូនៃសភាតំណាងប្រជាជនកម្ពុជា នៅប៉េកាំង ឯកសារ E3/199 ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00224451 (ដែល នួន ជា បានលើកឡើងការកោតសរសើរចំពោះបក្សកុម្មុយនីស្តចិន ប្រជាជន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ចំពោះជំនួយ ការលើកទឹកចិត្ត និងការគាំទ្រ ដែលជួយពង្រឹងឯករាជ្យភាព និងបូរណភាពរបស់កម្ពុជាប្រជាធិបតេយ្យ)។ សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ជូនចំពោះបក្សកម្មករកុម្មុយនីស្ត-ដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០-៣១ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00224457 (សុន្ទរកថាដែលធ្វើឡើងដោយ នួន ជា ថ្លែងទៅកាន់អ្នកតំណាងបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ដែលបានមកធ្វើទស្សនកិច្ចនៅកម្ពុជា។ ការលើកឡើងអំពីប្រវត្តិសាស្ត្រ មនោគមវិជ្ជា ការគ្រប់គ្រង និងសកម្មភាពជាក់ស្តែងមួយចំនួន ក្រោយការរំដោះរបស់បក្សកុម្មុយនីស្តកម្ពុជា)។ *សុន្ទរកថារបស់សមមិត្ត នួន ជា* (ព្រឹត្តិប័ត្រព័ត៌មាន កម្ពុជាប្រជាធិបតេយ្យ) ឯកសារ E3/78 ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00705166 (សុន្ទរកថារបស់សមមិត្ត នួន ជា ក្នុងពិធីលៀងសោយភោជន៍ជាកិត្តិយសដល់សមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាអនុប្រធានគណៈអចិន្ត្រៃយ៍សភាជាតិប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិន។ ការលើកឡើងអំពីសាមគ្គីភាពយោធា និងមហាមិត្តភាពបដិវត្តរវាងប្រទេសចិន និងប្រទេសកម្ពុជា)។ *របាយការណ៍ពីការមកដល់របស់លោក ស៊ូផានុវង្ស, ប៉ុល ពត ជួបជាមួយនឹងគណៈប្រតិភូ* ហើយ *ខៀវ សំផន ទទួលលោក ស៊ូផានុវង្ស* (ព័ត៌មានកម្ពុជា) ឯកសារ E3/1499 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00714310-00714319 (របាយការណ៍អំពីការអញ្ជើញមកដល់របស់គណៈប្រតិភូរដ្ឋាភិ-បាលនៃបក្សឡាវ នៅប្រទេសកម្ពុជា ដែលទទួលស្វាគមន៍ដោយ នួន ជា និងកិច្ចប្រជុំជាបន្តបន្ទាប់ ដែល នួន ជា បានចូលរួម រវាងគណៈប្រតិភូរដ្ឋាភិបាលនៃបក្សឡាវ និងតំណាងរបស់បក្សកុម្មុយនីស្តកម្ពុជា)។ *គណៈប្រតិភូដឹកនាំដោយសមមិត្ត នួន ជា ចេញដំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០២ ខែ កញ្ញា* (ព័ត៌មាន កម្ពុជា) ឯកសារ E3/1526 ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00811136-00811138 (របាយការណ៍អំពីទស្សនកិច្ចរបស់គណៈប្រភូរបស់សភាតំណាងប្រជាជនកម្ពុជា ដែលដឹកនាំដោយ នួន ជា ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ)។

## ៧.៣ កន្លែងស្នាក់នៅ ការធ្វើការងារ និងទីតាំងធ្វើដំណើរក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

៣១៧. នៅពេលត្រឡប់មកភ្នំពេញវិញ ប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានទៅស្នាក់នៅជាអចិន្ត្រៃយ៍នៅមន្ទីរ ក-៣ ដែលជាកន្លែងគាត់រស់នៅ និងធ្វើការងារជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត រួមទាំង ប៉ុល ពត, អៀង សារី, សុន សេន, វន វេត និង ខៀវ សំផន។ ជារឿយៗ នួន ជា ធ្វើដំណើរពីមន្ទីរ ក-៣ ទៅមន្ទីរ ក-១ ដែលជាកន្លែងស្នាក់នៅរបស់ ប៉ុល ពត នៅតាមមាត់ទន្លេ ដែលកន្លែងនេះក៏ជាកន្លែងរៀបចំកិច្ចប្រជុំសំខាន់ៗរបស់គណៈកម្មាធិការមជ្ឈិមបក្សផងដែរ[៩៧៧]។ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានបន្តធ្វើដំណើរទៅកាន់ជនបទ ដើម្បីពិនិត្យមើលគម្រោងសាងសង់ និងគម្រោងកសិកម្ម ជួបប្រជុំជាមួយមេដឹកនាំភូមិភាគ និងបើកកិច្ចប្រជុំអប់រំ និងឃោសនា[៩៧៨]។ យ៉ាងហោចណាស់ក៏ម្តងដែរ នួន ជា បានធ្វើដំណើរទៅទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន និងប្រទេសកូរ៉េខាងជើង[៩៧៩]។

---

[៩៧៧] ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (សាក្សី ឡេង ឈឿង) ទំព័រ ១១-១៣, ៦៣-៦៥។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (សាក្សី នឹម សែម) ទំព័រ ៥៧-៥៨, ៥៩-៦១។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី អឿន តាន) ទំព័រ ៣៣-៣៤, ៥៣-៥៥។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (សាក្សី ពាន ឃាន) ទំព័រ ២២-២៣ ។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី ផាន វ៉ាន) ទំព័រ ១៥-១៧។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សូត្រ ទឿង) ទំព័រ ៤៣-៤៤។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៥៥-៥៦។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT), ទំព័រ ១៨-២០។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧ ។ ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល ទំព័រ ២១៣ ។

[៩៧៨] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ២០-២១។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ (សាក្សី នី កន) ទំព័រ ២-៥ (បានចូលរួមការប្រជុំភូមិភាគនៅភូមិភាគបស្ចិមនៅឆ្នាំ១៩៧៥ ដែល នួន ជា មានវត្តមានក្នុងអំឡុងកិច្ចប្រជុំនោះដែរ)។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី ព្រំ ស៊ូ) ទំព័រ ២៦-២៩ (រៀបរាប់អំពីកិច្ចប្រជុំដែលបានធ្វើឡើងនៅភូមិភាគឧត្តរថ្មី ដែល នួន ជា បានណែនាំខ្លួន កង ចាប ជាប្រធានភូមិភាគថ្មី)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ (សាក្សី ស វី) ទំព័រ ២៩-៣០ (បង្ហាញថា នួន ជា នឹងធ្វើដំណើរទៅជនបទ)។

[៩៧៩] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៣៩ (សំដៅទៅលើទស្សនកិច្ចរបស់ នួន ជា ទៅប្រទេសចិន)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សូត្រ ទឿង) ទំព័រ ៦៨-៧១ (បានបញ្ជាក់ថា នួន ជា បានធ្វើដំណើរទៅកាន់ប្រទេសចិន និងប្រទេសកូរ៉េខាងជើង នៅឆ្នាំ១៩៧៨)។ សូមមើលផងដែរ រូបថតរបស់ នួន ជា នៅទីក្រុងប៉េកាំង ឯកសារ E3/3261 មិនមានកាលបរិច្ឆេទ។ សុន្ទរកថារបស់សមមិត្ត នួន ជា អនុលេខា

01006572



## ៧.៤ តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

៣១៨. បន្ថែមទៅលើតួនាទីរបស់គាត់នៅក្នុងបក្ស នួន ជា កាន់តួនាទីជាផ្លូវការផ្សេងៗទៀតក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ យោងតាមដីកាដំណោះស្រាយ នួន ជា គឺជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ហើយនៅខែ កញ្ញា ឆ្នាំ ១៩៧៦ គាត់ត្រូវបានតែងតាំងជាផ្លូវការជានាយករដ្ឋមន្ត្រីស្ដីទីនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពេលដែល ប៉ុល ពត បានឈប់សម្រាកបណ្ដោះអាសន្នមួយរយៈ ដោយសារតែមានបញ្ហាសុខភាព[៩៨០]។

### ៧.៤.១ ប្រធានសភាតំណាងប្រជាជន

៣១៩. នួន ជា បានបញ្ជាក់អំពីតួនាទីរបស់គាត់ជាប្រធានសភាតំណាងប្រជាជនក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[៩៨១]។ បន្ទាប់ពីមានសេចក្ដីសម្រេចមួយរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា កាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[៩៨២] គាត់ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ជាមុខតំណែងដែលគាត់បន្តកាន់រហូតដល់ក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ[៩៨៣]។ ឯកសារផ្សេងៗទៀតពីរបបកម្ពុជា

---

នៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្ដកម្ពុជា នៅក្នុងឱកាសល្ងៀងសាយភោជធ្វើឡើងជូនជាកិត្តិយសដល់គណៈប្រតិភូនៃសភាតំណាងប្រជាជនកម្ពុជា នៅប៉េកាំង ឯកសារ E3/199 ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៨។

[៩៨០] ដីកាដំណោះស្រាយ កថាខណ្ឌ ៨៨៩-៨៩០ និង កថាខណ្ឌ ៨៨៨។

[៩៨១] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៥-២៦។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១២។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៩។ *សូមមើលផងដែរ* កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54 ERN (ជាភាសាខ្មែរ) 00148743-00148744។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៦។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន) ទំព័រ ២៥; ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (សាក្សី KIM Vun) ទំព័រ ២២ ។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី ឈូក រិន) ទំព័រ ៤២-៤៣។

[៩៨២] សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិប ឯកសារ E3/1435 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៩ ERN (ជាភាសាខ្មែរ) 00595273 (“សន្និបាតបានសម្រេចជាឯកច្ឆន្ទ ត្រូវរក្សាតួនាទីលោក នួន ជា ជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា”)។ សេចក្ដីប្រកាសព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1449 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨១ ERN (ជាភាសាខ្មែរ) 00578901-00578902។

[៩៨៣] សេចក្ដីសម្រេចរបស់គណៈមជ្ឈិម ឯកសារ E3/12 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00003140-00003141។ *សូមមើលផងដែរ* ឯកសារអំពីអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ

ប្រជាធិបតេយ្យ ដែលរួមទាំងសុន្ទរកថាផ្សេងៗ ដែលគាត់ថ្លែងនៅក្នុងមុខតំណែងទៅកាន់ភ្ញៀវ-កិត្តិយស និងគណៈប្រតិភូបរទេស បានបង្ហាញថា នួន ជា ជាប្រធានសភាតំណាងប្រជាជន[៩៨៤]។

៣២០. នួន ជា បានលើកឡើងថា តួនាទីនេះគឺជាតួនាទីសំខាន់មួយក្នុងចំណោមតួនាទីផ្សេងទៀត ដែលគាត់មានក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយធានាថា ច្បាប់នានាត្រូវបាន អនុម័ត ទោះបីជាជម្លោះជាមួយប្រទេសវៀតណាមធ្វើឲ្យដំណើរការនេះមានការលំបាកក្តី[៩៨៥]។ ទោះបីជាយ៉ាងណាក៏ដោយ នួន ជា បានអះអាងថា សភាតំណាងប្រជាជន ដែលទទួលខុសត្រូវលើ ការពិភាក្សាច្បាប់ គឺគ្រាន់តែជាស្ថាប័នដែលមានតែសំបកខាងក្រៅ ដែលបង្ហាញពីការប្រតិបត្តិតាម លក្ខន្តិកៈបក្ស ដូចដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានធ្វើឡើងនៅ ខែ មីនា ឆ្នាំ ១៩៧៦ ហើយគាត់បានចូលរួមផងដែរ[៩៨៦]។ សភាកម្រជួបប្រជុំណាស់ ហើយ

---

E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦។ សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ របស់សភាតំណាង ប្រជាជនកម្ពុជា-សេចក្តីប្រកាសព័ត៌មាន ឯកសារ E3/262 ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00622988-00622989។

[៩៨៤] *សូមមើល ឧទា. រាយការណ៍ពីការមកដល់របស់លោក ស៊ូផានុវង្ស, ប៉ុល ពត ជួបជាមួយនឹងគណៈប្រតិភូ* ហើយ *ខៀវ សំផន ទទួលលោក ស៊ូផានុវង្ស* (ព័ត៌មានកម្ពុជា) ឯកសារ E3/1499 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00714310-00714319។ សុន្ទរកថារបស់សមមិត្ត នួន ជា អនុលេខានៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឱកាសលៀងភោជនាហារធ្វើឡើងជូនជាកិត្តិយសដល់គណៈប្រតិភូនៃសភាតំណាងប្រជាជនកម្ពុជា នៅប៉េកាំង ឯកសារ E3/199 ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00224451។ *បក្សកុម្មុយនីស្តកម្ពុជាលាត ត្រដាងជាផ្លូវការអំពីខួបនៃការបង្កើតបក្ស* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែតុលា ឆ្នាំ១៩៧៧) ឯកសារ E3/2678 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00715810-00715811។ *សូមមើលផងដែរ* ផ្នែកទី ៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា *ជើងទំព័រ ៩៧៦*។

[៩៨៥] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៩។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ៨។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៧។

[៩៨៦] កំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00017118-00017119 (ក្រៅពី ប៉ុល ពត ខៀវ សំផន និង នួន ជា ក៏មានវត្តមានក្នុងកិច្ចប្រជុំនេះដែរ ដែលក្នុង កិច្ចប្រជុំនេះគេបានណែនាំថា "កុំកុំនិយាយលេងពីសភា នៅមុខប្រជាជនឲ្យគេឃើញថា យើងបន្លឹមបន្លំ ហើយសភា យើងគ្មានតម្លៃអី")។

ប្រហែលជាបានជួបប្រជុំតែម្តងប៉ុណ្ណោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនបានអនុម័តច្បាប់ណាមួយឡើយ[៥៨៧]។

### ៧.៤.២ នាយករដ្ឋមន្ត្រីស្តីទី

៣២១. នួន ជា បានបដិសេធថាគាត់មិនដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្តីទីនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ទោះបីជាទទួលស្គាល់ថា ប៉ុល ពត បានឈប់សម្រាកមួយរយៈនៅឆ្នាំ ១៩៧៦ ក៏ដោយ ក៏គាត់បានបញ្ជាក់ថា សុន សេន គឺជាអ្នកដែលត្រូវបានតែងតាំងឲ្យជំនួស ប៉ុល ពត[៥៨៨]។

៣២២. ភ័ស្តុតាងផ្សេងៗទៀតនៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញផ្ទុយទៅនឹងសក្ខីកម្មនេះ។ ឯកសារជាច្រើនបានរាយការណ៍អំពីការតែងតាំង នួន ជា ជាផ្លូវការឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅខែ កញ្ញា ឆ្នាំ ១៩៧៦ នៅក្នុងអំឡុងពេលអវត្តមានរបស់ ប៉ុល ពត ឬសម្រាប់ពេលដែល ប៉ុល ពត នឹងអវត្តមាននាពេលណាមួយខាងមុខ[៥៨៩]។ ឯកសារផ្សេងៗទៀត

---

[៥៨៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៧១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (សាក្សី ប្រាក់ យុត) ទំព័រ ៥៥-៦២ (បញ្ជាក់ថា ទោះបីជាគាត់ និងប្តីរបស់គាត់ ត្រូវបានគេប្រាប់ថា ពួកគេត្រូវបានគេជ្រើសតាំង ក៏ប៉ុន្តែពួកគាត់មិនបានដឹងអំពីការបោះឆ្នោតណាមួយនោះទេ ហើយពួកគាត់ក៏មិនដែលទៅចូលរួមការប្រជុំសភាណាមួយនោះ ទេ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង រ៉េន) ទំព័រ ២១-២២ (បញ្ជាក់ថា ទោះបីជាគាត់ត្រូវបានគេជូនដំណឹងអំពីការបោះឆ្នោត ក៏ប៉ុន្តែគាត់មិនបានដឹងអំពីការបោះឆ្នោតណាមួយ ដែលបានធ្វើឡើងនោះដែរ ហើយគាត់ក៏មិនដែលត្រូវបានគេកោះហៅឲ្យប្រជុំនៅសភានោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (សាក្សី នង សុផង់) ទំព័រ ២៨-២៩ (បញ្ជាក់ថា គាត់បានទទួលសារតែមួយប៉ុណ្ណោះពី នួន ជា ដែលកោះប្រជុំសមាជិកសភា)។ សូមមើលផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៣-២៣៨។

[៥៨៨] ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៣-២៦។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២០, ៤០-៤១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១០។

[៥៨៩] ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ ការអញ្ជើញលោក ប៉ុល ពត ទៅទីក្រុង ប៉េកាំង ឯកសារ E3/486 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៧, ERN (ជាភាសាខ្មែរ) 00634830-00634831 (ការប្រកាសជាផ្លូវការតាមវិទ្យុភ្នំពេញអំពីទស្សនកិច្ចរបស់ ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាទៅកាន់ប្រទេសចិន ហើយក៏បានកត់សម្គាល់ថា នួន ជា បានកាន់តំណែងជា "នាយករដ្ឋមន្ត្រីស្តីទី" ក្នុងអំឡុងពេលការបន្តអវត្តមានរបស់ ប៉ុល ពត ចាប់តាំងពីថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៦)។ ការឈប់សម្រាកឈឺរបស់ ប៉ុល ពត សម្រាកបណ្តោះអាសន្នពីនាយករដ្ឋមន្ត្រី (កម្រង

ដែលបានបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ គិតមកទល់ចុងឆ្នាំ ១៩៧៧ ដែលក្នុងនោះមានទាំងរបាយការណ៍ព័ត៌មានជាតិ និងអន្តរជាតិស្តីអំពីកិច្ចប្រជុំនៅកម្រិតអ្នកការទូត ក៏បានបញ្ជាក់អំពីការតែងតាំងនេះដែរ[៩៩០]។ ឯកសារទាំងនេះស៊ីសង្វាក់ផងដែរជាមួយនឹងសាក្សី កាំង ហ្កេកអ៊ាវ ដែលបានឮព័ត៌មានពីវិទ្យុដែលបានប្រកាសអំពីការឈប់សម្រាករបស់ ប៉ុល ពត និងការតែងតាំង នួន ជា ឲ្យកាន់តួនាទីជានាយករដ្ឋមន្ត្រីស្តីទី[៩៩១]។ លើសពីនេះទៀត នៅក្នុងកិច្ចសម្ភាសន៍ជាមួយ *Steven HEDER* នៅឆ្នាំ ១៩៩៦ អៀង សារី បានថ្លែងថា នួន ជា បានជំនួស ប៉ុល ពត ដែលជា

---

SWB/FE/5323/B/2) ឯកសារ E3/192 ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00662004 (សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ បានសម្រេចតែងតាំង នួន ជា "ឲ្យជំនួស សមមិត្ត ប៉ុល ពត បណ្តោះអាសន្ន ហើយទទួលតួនាទីជានាយករដ្ឋមន្ត្រីស្តីទី"។ *សូមមើលផងដែរ លោក ប៉ុល ពត សម្រាកពីមុខតំណែង "ជាបណ្តោះអាសន្ន"* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/280 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00663965-00663966។ *លោកប្រធាន នួន ជា ទទួលជួបឯកអគ្គរដ្ឋទូតអាល់បានី* (ព្រឹត្តិប័ត្រព័ត៌មានកម្ពុជាប្រជាធិបតេយ្យ) ឯកសារ E3/269 ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00597037។

[៩៩០] សាទូរលេខចូលក្រសួងការបរទេសបារាំង, កម្មវត្ថុ៖ ពង្សាវតាខ្មែរ (ខែកញ្ញា ឆ្នាំ ១៩៧៦) ឯកសារ E3/491 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៦ ERN (ជាភាសាខ្មែរ) 00704450-00704451 (ដែលបានចង្អុលបង្ហាញពីការចូលនិវត្តបណ្តោះ-អាសន្នរបស់នាយករដ្ឋមន្ត្រីកម្ពុជា ប៉ុល ពត ។ *នួន ជា ទទួលជួបឯកអគ្គរដ្ឋទូតអាល់បានី* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/281 ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៧៦, ERN (ជាភាសាអង់គ្លេស) 00168071; សាទូរលេខស្ថានទូតបារាំង កម្មវត្ថុ៖ ព័ត៌មាន និងសកម្មភាពអំពីប្រទេសកម្ពុជា ឯកសារ E3/485 ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00524035-00524036។ *ខៀវ សំផន, នួន ជា សម្តែងការស្វាគមន៍ដល់ថ្ងៃបុណ្យជាតិប៉ាគីស្ថាន,* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/285, ERN (ជាភាសាខ្មែរ) 00699188-00699189។ *នាយករដ្ឋ-មន្ត្រីស្តីទីស្វាគមន៍សមភាគី ភូមា នៅថ្ងៃបោះឆ្នោត, សារពីថ្នាក់ដឹកនាំប៉ុលហ្គារី, សាររបស់ឯកឧត្តម* Djuranovic *នៃប្រទេសយូហ្គោស្លាវី និងសាររបស់* Bhutto (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/286, ERN (ជាភាសាខ្មែរ) 00899399, 00899400, 00899401, 00899401-00899402។ *មេដឹកនាំ ជូនពរប្រទេសវៀតណាមក្នុងឱកាសបុណ្យខួបជ័យជំនះ និង លោក ខៀវ សំផន និង នួនជា ជូនពរមេដឹកនាំស្រីលង្កា* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/287, ERN (ជាភាសាខ្មែរ) 00679826-00679830, 00679849-00679850។ *សមមិត្ត នួន ជា សម្តែងនូវការអបអរសាទរជូនដល់មេដឹកនាំនៃប្រទេសម៉ាឡេស៊ីនៅក្នុងថ្ងៃបុណ្យជាតិ, មេដឹកនាំកម្ពុជាសម្តែងនូវការអបអរសាទរជូនដល់មេដឹកនាំនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនៅក្នុងថ្ងៃបុណ្យជាតិ, រដ្ឋមន្ត្រីការបរទេសនៃប្រទេសភូមាបានបញ្ចប់ទស្សនកិច្ច និងសាររបស់លោក ខៀវ សំផន និងលោក នួន ជា* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ កញ្ញា ឆ្នាំ ១៩៧៧) ឯកសារ E3/143, ERN (ជាភាសាខ្មែរ) 00904132, 00904133-00904134, 00904135, 00658446-00658448។

[៩៩១] ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៩-១០។

នាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ ១៩៧៦[៩៩២]។ លើសពីនេះទៀត មានភ័ស្តុតាងបញ្ជាក់ថា នៅក្នុងមុខតំណែងរបស់គាត់ជានាយករដ្ឋមន្ត្រីស្តីទី នួន ជា បានថ្លែងសុន្ទរកថាមួយនៅក្នុងឱកាសខួបលើកទី ៩ នៃកងទ័ពបដិវត្តន៍កម្ពុជា កាលពីខែ មករា ឆ្នាំ ១៩៧៧[៩៩៣]។

៣២៣. ហេតុដូច្នេះ អង្គជំនុំជម្រះមានជឿជាក់ថា ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៧ នៅមុនពេលដែល ប៉ុល ពត ត្រឡប់មកបំពេញភារកិច្ចរបស់គាត់វិញនោះ នួន ជា បានកាន់តួនាទីផ្លូវការជានាយករដ្ឋមន្ត្រីស្តីទីនៃរបបកម្ពុជាប្រជាធិបតេយ្យ[៩៩៤]។

## ៧.៥ តួនាទីក្នុងការឃោសនា និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត

៣២៤. ជាច្រើនលើក នៅចំពោះមុខអង្គជំនុំជម្រះ នួន ជា បានបញ្ជាក់ថា នៅក្នុងមជ្ឈិមបក្ស និងក្នុងអំឡុងពេលដែលមជ្ឈិមបក្សមានអត្ថិភាព គាត់ទទួលខុសត្រូវសំខាន់លើបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្តោតជាពិសេសលើគោលការណ៍សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស[៩៩៥]។

---

[៩៩២] បទសម្ភាសន៍ Steven Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ERN (ជាភាសាខ្មែរ) 00062486-00062487 (លើកឡើងថា នួន ជា បានជំនួសតួនាទី ប៉ុល ពត ជានាយករដ្ឋមន្ត្រី ទោះបីជាការពិតដែលថា គាត់បានកាន់តួនាទីជាឧបនាយករដ្ឋមន្ត្រីទីមួយ ហេតុដូច្នេះគាត់ជាអ្នកបន្ទាប់ដែលត្រូវជំនួស ប៉ុល ពត)។ *សូមមើលផងដែរ* ការពិតអំពីរបបផ្តាច់ការរបស់ ប៉ុល ពត ឯកសារ E3/86 ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៦ ERN (ជាភាសាខ្មែរ) 00224430-00224431 ("នួន ជា ដែលជាបុគ្គលទី២ នៅក្នុងបក្ស និងអតីតជាប្រធានសភាជាតិ ដែលត្រូវបាន ប៉ុល ពត ជ្រើសតាំងឲ្យជំនួសគាត់ជានាយករដ្ឋមន្ត្រីបណ្តោះអាសន្ន")។

[៩៩៣] *នួន ជា ថ្លែងនៅពេលខួបកងទ័ពបដិវត្តកម្ពុជា* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/147 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00807441។ *ខួបលើកទី៩ នៃការបង្កើតកងទ័ពបដិវត្តន៍* ឯកសារ E3/544 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00807441។ សុន្ទរកថារបស់លោក នួន ជា នៅក្នុងមេទិញទិវាខួបកងទ័ព (នៅក្នុង SWB/FE/5417/C1/1) ឯកសារ E3/191 ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៧ ERN (ជាភាសាខ្មែរ) 00649940-00649941។

[៩៩៤] របាយការណ៍ចុងក្រោយ ដែលសំដៅចំពោះ នួន ជា ថាជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចុះផ្សាយ នៅខែ កញ្ញា ឆ្នាំ ១៩៧៧ នៅក្នុងឱកាសទស្សនកិច្ចរបស់គណៈប្រតិភូនៃប្រទេសភូមា និងនៅក្នុងឱកាសខួបរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ *សូមមើល* កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/143។ សូមមើលផងដែរ ផ្នែកទី ៧ ស្តីពី តួនាទី និងមុខងាររបស់ នួន ជា ជើងទំព័រលេខ ៩៩០។

[៩៩៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦៨។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៥៨-៦១។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ

៣២៥. សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគាត់បានចូលរួមក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ឬវគ្គរៀនសូត្រ ដែល នួន ជា ធ្វើជាអធិបតី ជាគ្រូបណ្តុះបណ្តាល ឬជាអ្នកឧទ្ទេសនាម។ វគ្គទាំងអស់នេះត្រូវបានរៀបចំឡើងនៅមុន និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅតាមស្រុក តំបន់ ភូមិភាគ ឬនៅកម្រិតមជ្ឈិម នៅទូទាំងផ្ទៃប្រទេស និងនៅទីក្រុងភ្នំពេញ ជាពិសេសនៅស្តាតអូឡាំពិក និងនៅបុរីកីឡា[៥៥៦]។ នៅក្នុងវគ្គទាំងនោះ គោលនយោបាយបដិវត្តន៍ ត្រូវបានយកមកពិភាក្សា រួមទាំងគោលនយោបាយសេដ្ឋកិច្ច និងសហករណ៍ ការកេណ្ឌកម្លាំងនៅទូទាំងតំបន់រំដោះ ខ្លួនទីពឹងខ្លួន និង ភាពម្ចាស់ការ ព្រមទាំងការប្រុងប្រយ័ត្នចំពោះខ្មាំងខាងក្នុង និងខាងក្រៅ និងវគ្គទិតៀន និង ស្វ័យទិតៀន[៥៥៧]។ នួន ជា ក៏ជាមនុស្សម្នាក់ក្នុងចំណោមអ្នកផ្សេងទៀត ដែលជា

---

៣-៥។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-២៩។ *សូមមើលផងដែរ* កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54 ERN (ជាភាសាខ្មែរ) 00148743-00148744។

[៥៥៦] ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ១-៣ (លើកឡើងថា ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នួន ជា បានចូលរួមមេទិញរម្ពឹកខួប នៅខែ មេសា រាល់ឆ្នាំ ដែលប្រារព្ធធ្វើនៅស្តាតអូឡាំពិក ឬនៅបុរីកីឡា)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (សាក្សី ជា សាយ) ទំព័រ ២៥-៣១ និង ៣៣-៣៤ (បានចូលរួមក្នុងវគ្គសិក្សានយោបាយ នៅវិទ្យាស្ថានបច្ចេកវិទ្យា និង នៅបុរីកីឡា ដែល នួន ជា ជាអ្នកបង្រៀន)។ ប្រតិចារឹក ថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សូត ទឿង) ទំព័រ ២០-២៤ (តាមហែហម នួន ជា ទៅកាន់វគ្គបណ្តុះបណ្តាល នៅបុរីកីឡា ជាទៀងទាត់)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី សៅ សារុន) ទំព័រ ២៨-៣៣ (ពិពណ៌នាវគ្គបណ្តុះបណ្តាល នយោបាយ រៀបចំដោយ នួន ជា និង ប៉ុល ពត នៅភ្នំពេញ)។

[៥៥៧] ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី សៅ សារុន) ទំព័រ ១៦ (បញ្ជាក់ថា នួន ជា មានវត្តមាននៅក្នុង សន្និបាតបក្សនៅខែ កញ្ញា ឆ្នាំ ១៩៧៨ ដែលនៅពេលនោះ គាត់បានធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងមនុស្សឱ្យបានល្អ ដោយការផ្តល់លំនៅដ្ឋាន និង អាហារ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ៥២-៥៧ (គូសបញ្ជាក់ថា នៅក្រោយរំដោះភ្នំពេញ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំ ដោយធ្វើជាគ្រូ និង បង្រៀននៅវិហារព្រះកែវ។ នៅក្នុងវគ្គសិក្សានោះ ប្រធានបទសំខាន់ គឺសភាពការណ៍ទូទៅនៅក្នុងប្រទេស រួមទាំងនយោបាយ និងចលនាមហាជន បដិវត្តប្រជាជាតិប្រជាធិបតេយ្យ និង សភាពការណ៍អន្តរជាតិ។ គេអនុញ្ញាតអ្នកចូលរួមធ្វើស្វ័យ-ទិតៀនក្នុងអំឡុងកិច្ចប្រជុំ ទាំងនេះ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុន) ទំព័រ ១៧-១៨ (បញ្ជាក់ថា នួន ជា មានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាលរបស់បក្សដែលមានរយៈពេល ៣០ ថ្ងៃ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦ ដែលមានបញ្ចូលទាំងវគ្គស្វ័យទិតៀនផងដែរ។ ប្រធានបទសំខាន់ក្នុងវគ្គនោះគឺ សភាពការណ៍ទូទៅនៅក្នុង និងក្រៅប្រទេស ការកសាងបក្ស និង ចំណុចខ្សោយក្នុងការអនុវត្តរបស់ចលនា)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សាក្សី សួង ស៊ីគឿន) ទំព័រ ៥៨-៦០ (គូសបញ្ជាក់ថា នួន ជា ជាវាគ្មិននៅក្នុងវគ្គអប់រំនយោបាយសម្រាប់សមាជិកបក្សនៅបុរីកីឡា ក្នុងខែមិថុនា ឆ្នាំ ១៩៧៦។ នៅក្នុងកិច្ចប្រជុំនេះ មានពិភាក្សាអំពីដំណើរវិវឌ្ឍន៍នៃបដិវត្តប្រជា-

01006578



អ្នកទទួលទូរលេខពីកម្មាភិបាលបក្សមកពីទីកន្លែងផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ ទូរលេខទាំងនេះរៀបរាប់អំពីបញ្ហាផ្សេងៗមិនមែនត្រឹមតែ ដំណើរការនៃការអនុវត្តគោលនយោបាយកសិកម្ម និងការបណ្តុះបណ្តាលកម្មាភិបាលប៉ុណ្ណោះទេ ប៉ុន្តែ ក៏រៀបរាប់អំពីបញ្ហាវិន័យ និងការដាក់ទណ្ឌកម្មលើបុគ្គលផងដែរ[៩៩៨]។

---

ជាតិប្រជាធិបតេយ្យ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន) ទំព័រ ២៤-២៥ (បញ្ជាក់ថា នួន ជា ពិតជាបានថ្លែងនៅក្នុងវគ្គអប់រំនយោបាយ។ មុននឹងចាប់ផ្តើមបើកវគ្គ គ្រូបណ្តុះបណ្តាល រួមទាំង នួន ជា ត្រូវបានគេណែនាំខ្លួន)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន) ទំព័រ ៦៩-៧៣ (យោងទៅវគ្គបណ្តុះបណ្តាលនយោបាយ ធ្វើនៅបុរីកីឡា មានអ្នកចូលរួមមកពីតាមស្រុក ដែលនៅក្នុងវគ្គនោះ នួន ជា បាននិយាយអំពីគោលនយោបាយពង្រឹងជនកុម្មុនីស្ត និង តម្រូវការក្នុងការរែកមុខឲ្យឃើញជនស៊ីរូងផ្ទៃក្នុងបក្ស។ នួន ជា និយាយសំដៅទាហានមកពីរបបមុនៗ រួមទាំងរបប នរោត្តម សីហនុ និង របប លន់ នល់ និង បញ្ញវន្ត និង និស្សិត ជាពិសេសនិស្សិតដែលរៀនចប់នៅបរទេស)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ដើមបណ្តឹងរដ្ឋប្បវេណី ក្លាង ហ្វីត) ទំព័រ ៤៤-៤៦ (បានចូលរួមក្នុងវគ្គអប់រំនយោបាយ សម្រាប់គណៈតំបន់នៅភ្នំពេញ ដែលនៅក្នុងនោះ នួន ជា គឺជាអ្នកបង្រៀន ឬ អ្នកបណ្តុះបណ្តាល។ ប្រធានបទក្នុងវគ្គទាំងនេះ គឺការកសាងហេដ្ឋារចនាសម្ព័ន្ធប្រទេស ដើម្បីធានាភាពម្ចាស់ការរបស់ខ្លួន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ (សាក្សី នី កន) ទំព័រ ២-៥ (ចូលរួមក្នុងសន្និបាតភូមិភាគ នៅភូមិភាគបស្ចិម ក្នុងឆ្នាំ ១៩៧៥ ដែល នួន ជា មានវត្តមានក្នុងសន្និបាតនោះ។ សន្និបាតពិភាក្សាការបញ្ចប់សង្គ្រាម ការស្តារសេដ្ឋកិច្ចឡើងវិញ និង ខ្លួនទីពឹងខ្លួន និង ភាពម្ចាស់ការដោយខ្លួនឯង។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី ព្រុំ សំ) ទំព័រ ២៦-២៩ (បានពិពណ៌នាកិច្ចប្រជុំដែលរៀបចំធ្វើនៅភូមិភាគឧត្តរ ដែលនៅក្នុងនោះ នួន ជា ណែនាំឲ្យស្គាល់ កង ចាប ជាប្រធានថ្មីរបស់ភូមិភាគ និង បាននិយាយអំពីការបង្កបង្កើនផល និង តម្រូវការក្នុងការប្រុងប្រយ័ត្នចំពោះសត្រូវ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី រស់ ស៊ុយ) ទំព័រ ៤៣-៤៨ (បានចូលរួមក្នុងវគ្គសិក្សា ដែលក្នុងនោះ នួន ជា បាននិយាយថា សោ ភឹម និង កុយ ធួន គឺជាជនក្បត់)។

[៩៩៨] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦ ឯកសារ E3/874, ERN (ជាភាសាខ្មែរ) 00003703-00003704 (របាយការណ៍ពាក់ព័ន្ធនឹងទាហានតំបន់ ១០ រត់ចោលជួរទៅកាន់ប្រទេសថៃ ដែលជាប់ខ្សែខ្មាំង និង រិះគន់បក្សកុម្មុនីស្តកម្ពុជា និង ស្នើសុំការណែនាំពាក់ព័ន្ធនឹងកម្មាភិបាលពាណិជ្ជកម្ម ដែលត្រូវបានចាប់ខ្លួន)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះកាលបរិច្ឆេទមិនច្បាស់លាស់ ឯកសារ E3/1209 ERN (ជាភាសាខ្មែរ) 00001102-00001103 (និយាយយោងទៅ "ខ្មាំងខាងក្នុង និង ខ្មាំងខាងក្រៅ" ការលើកទំនប់ និងប្រឡាយនៅភូមិភាគឧត្តរ និង កង្វះថ្នាំសង្កូវ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ E3/1192 ERN (ជាភាសាខ្មែរ) 00021529 (គូសបញ្ជាក់ថា ទូរលេខត្រូវបានទទួលពី នួន ជា ថាក្រុមពាណិជ្ជកម្ម ត្រូវបានចាត់-តាំងសម្រាប់ភ្នំពេញ)។ ទូរលេខកម្ពុជា ប្រជាធិបតេយ្យ ចុះថ្ងទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/1222, ERN (ជាភាសាខ្មែរ) 00000863 (ពិពណ៌នាអំពីសភាពការណ៍នៅកំពង់សោម រួមទាំងការចាប់មនុស្ស ដែលបានរត់ចូលព្រៃ និង ការបង្កបង្កើនផលស្រូវ)។ ទូរលេខកម្ពុជា ប្រជាធិបតេយ្យ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសា E3/1221,

៣២៦. នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃកាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ នួន ជា ត្រូវបានប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវខាង "ការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និង សិក្សាធិការ"[៩៩៩]។ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែល

---

ERN (ជាភាសាខ្មែរ) 00001263 (រាយការណ៍អំពីការចាប់ខ្លួនជនក្បត់នៅខេត្តកំពង់ចាម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ E3/1200, ERN (ជាភាសាខ្មែរ) 00021518 (ទូរលេខពីក្រុមកសិកម្មរបស់លេខាភូមិភាគពាយព្យ ផ្ញើជូនទៅស្ថានទូតចិន ពិពណ៌នាអំពីសំណើសុំឧបករណ៍កសិកម្មសម្រាប់ធ្វើស្រែ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ E3/1103, ERN (ជាភាសាខ្មែរ) 00000876 (ស្នើសុំការអនុញ្ញាតដើម្បីឲ្យសមមិត្តម្នាក់ធ្វើដំណើរទៅភ្នំពេញ ដើម្បីរៀនសូត្រកូដទំនាក់ទំនងតាមវិទ្យុ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ ឯកសារ E3/953, ERN (ជាភាសាខ្មែរ) 00000766-00000767 (ពិពណ៌នាអំពីសភាពការណ៍ខ្លាំង សុខាភិបាល ការបង្កបង្កើនផល និង សីលធម៌ នៅភូមិភាគឧត្តរ រួមទាំងការតាមដាន "ភ្នាក់ងារស៊ីអ៊ីអេផ្ទៃក្នុង" និង បញ្ហាជម្ងឺគ្រុនក្តៅ និង ឈឺថ្កាត់ដោយសារ "ធ្វើការ និង ក្តៅខ្លាំង"។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ E3/1195, ERN (ជាភាសាខ្មែរ) 00057296 (រាយការណ៍អំពីការអប់រំនយោបាយ និងការបណ្តុះបណ្តាលបច្ចេកទេស និងសំណើសុំការអនុញ្ញាតឲ្យមនុស្សមួយចំនួនចូលរួមក្នុងវគ្គបណ្តុះបណ្តាល)។ ទូរលេខកម្ពុជា ប្រជាធិបតេយ្យ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ E3/1097, ERN (ជាភាសាខ្មែរ) 00001092 (រាយការណ៍អំពីការចាប់យុទ្ធជនពីរនាក់ ដែលធ្វើដំណើរដោយគ្មានការអនុញ្ញាត និង ស្នើសុំការណែនាំអំពីថាតើត្រូវមានវិធានការណ៍យ៉ាងណា)។ ទូរលេខកម្ពុជា ប្រជាធិបតេយ្យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ E3/956, ERN (ជាភាសាខ្មែរ) 00001263 (រាយការណ៍អំពីការចាប់មនុស្ស ២៤ នាក់ ពីស្រុកព្រៃឈរ និងស្នើការណែនាំអំពីថាតើត្រូវមានវិធានការណ៍យ៉ាងណា)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះកាលបរិច្ឆេទមិនច្បាស់លាស់ ឯកសារ E3/1189 ERN (ជាភាសាខ្មែរ) 00021531 (ស្នើសុំបើកសាលាបក្ស)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ E3/1663, ERN (ជាភាសាខ្មែរ) 00000872 (ទទួលស្គាល់ការទទួលទូរលេខ ដែលមានការណែនាំពាក់ព័ន្ធនឹងផែនការ ០៤ ឆ្នាំ និង បញ្ជាក់ថា បក្សតំបន់បានជ្រាបហើយ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ E3/1118, ERN (ជាភាសាខ្មែរ) 00000875 (ស្នើសុំម៉ាស៊ីនបូមទឹក និង ឡានដឹកសម្ភារៈសម្រាប់ធ្វើផ្លូវ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/1144 (ពិភាក្សាអំពីបញ្ហាជាច្រើន រួមមានសភាពការណ៍ខ្លាំងនៅតាមព្រំដែនថៃ ការរកឃើញខ្មាំង បង្កប់ផ្ទៃក្នុងជាច្រើន រួមទាំងសមាជិករបប លន់ នល់ ការធ្វើស្រែ ស្ថានភាពរស់នៅ និងការអប់រំ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារ E3/156 (រាយការណ៍អំពីការចាប់ និង ឃុំខ្លួនសមមិត្តម្នាក់ ដែលបានប្រព្រឹត្ត "ខុសសីលធម៌")។

[៩៩៩] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ឯកសារ E3/183, ERN (ជាភាសាខ្មែរ) 00019108។

មានការពិភាក្សាអំពីបញ្ហាឃោសនាការ និងសិក្សាធិការ[១០០០]។ ក្នុងកិច្ចប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ដើម្បីពិភាក្សាអំពីបញ្ហាពាក់ព័ន្ធនឹងការឃោសនា នួន ជា ដែលជាអនុលេខានៃគណៈកម្មាធិការអចិន្ត្រៃយ៍ បានឡើងមានមតិជាច្រើនអំពីដំណើរការការងាររបស់ក្រសួងឃោសនាការ ដោយបានកត់សម្គាល់អំពីការរីកចម្រើន និងចំណុចដែលត្រូវកែលម្អ។ ជាពិសេស នួន ជា បានលើកឡើងនូវការព្រួយបារម្ភអំពី "បញ្ញវន្ត" ដែលធ្វើការជាអ្នកនិពន្ធនៅតាមក្រសួង ហើយគាត់បានបញ្ជាក់ថា គួរជ្រើសរើសបុគ្គលិកពីមូលដ្ឋានដើម្បីមកបំពេញការងារ[១០០១]។

៣២៧. សាក្សី ខៀវ អេន ដែលជាអ្នកបច្ចេកទេសបម្រើការនៅក្រសួងឃោសនាការ និងព័ត៌មាន បានបញ្ជាក់ថា នួន ជា បានទៅធ្វើទស្សនកិច្ចនៅក្រសួងនោះ និងបានកាន់តួនាទីទទួលខុសត្រូវក្រសួងនេះពី យុន យ៉ាត នាពាក់កណ្ដាលឆ្នាំ ១៩៧៨[១០០២]។

៣២៨. ដីកាដំណោះស្រាយបានបញ្ជាក់ថា នៅក្នុងផ្នែកមួយនៃការទទួលខុសត្រូវរបស់គាត់ខាងកិច្ចការបក្ស ឃោសនាការ និងសិក្សាធិការ នួន ជា ទទួលខុសត្រូវខាងគណៈចាត់តាំងមជ្ឈិមបក្ស ដែលទទួលបន្ទុកខាងការងារចាត់តាំង រួមទាំងការត្រួតពិនិត្យសមាជិកបក្ស និងការតែងតាំង

---

[១០០០] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារ E3/228, ERN (ជាភាសាខ្មែរ) 00017105។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/231, ERN (ជាភាសាខ្មែរ) 00017124-00017125។ កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ឯកសារ E3/225, ERN (ជាភាសាខ្មែរ) 00000837។

[១០០១] កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ ឯកសារ E3/225, ERN (ជាភាសាខ្មែរ) 00000840-00000842។

[១០០២] ប្រតិចារឹក ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ (សាក្សី ខៀវ អេន) ទំព័រ ២៩-៣៤, ៤២-៤៤, ៥៣-៥៤, ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ (សាក្សី ខៀវ អេន) ទំព័រ ៥-៧, ២៩-៣០, ៤២-៤៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (សាក្សី គីម វុន) ទំព័រ ២៨-២៩, ៥៣-៥៥។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (សាក្សី គីម វុន) ទំព័រ ២៣, ២៨-៣០ (គូសបញ្ជាក់អំពីតួនាទីរបស់ នួន ជា នៅក្រសួងនេះ ពាក់ព័ន្ធនឹងការអបរំកសិកម្ម)។ សាក្សី ផាន វ៉ាន់ បានផ្ដល់សក្ខីកម្មថា អៀង ធីរិទ្ធ ធ្វើដំណើរជារឿយៗទៅ ក-៣ ដើម្បីរាយការណ៍ឲ្យ នួន ជា អំពីបញ្ហាពាក់ព័ន្ធនឹងក្រសួងសុខាភិបាល និង សង្គមកិច្ច។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី ផាន វ៉ាន់) ទំព័រ ១៥-១៦។

បុគ្គលិកថ្មីនៅក្នុងមន្ទីរ និង ក្រសួងនានា[១០០៣]។ ទោះបីជាពុំមានភស្តុតាងផ្ទាល់ណាមួយពាក់ព័ន្ធនឹងការតែងតាំងគាត់ជាផ្លូវការឲ្យកាន់តួនាទីនេះក៏ដោយ ក៏សាក្សី សាឡូត បាន ជាក្មួយប្រុសរបស់ ប៉ុល ពត ដែលធ្លាប់ធ្វើការនៅក្រសួងការបរទេស និងដែលបានដឹងច្បាស់អំពីតួនាទីរបស់ ប៉ុល ពត និង នួន ជា និងទំនាក់ទំនងរបស់អ្នកទាំងពីរ បានផ្តល់សក្ខីកម្មថា នួន ជា ទទួលខុសត្រូវខាងចាត់តាំង និងវិន័យរបស់សមាជិកបក្ស[១០០៤]។ សាក្សី នង សុផង់ បានបញ្ជាក់ពីការពិតនៃតួនាទីនេះ។ នង សុផង់ ជាការីសារទូរលេខ ធ្លាប់ធ្វើការនៅមន្ទីរជាច្រើន បានបញ្ជាក់ថា ទូរលេខពាក់ព័ន្ធនឹងសភាពការណ៍សន្តិសុខផ្ទៃក្នុង និងការធ្វើខុសក្រមសីលធម៌របស់កម្មាភិបាល ត្រូវបញ្ជូនផ្ទាល់ទៅ នួន ជា[១០០៥]។ ចំពោះការទទួលខុសត្រូវខាង "កិច្ចការបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ" ដែលត្រូវបានប្រគល់ទៅ នួន ជា នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ តាមរយៈគណៈប្រតិភូរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជា ដូចបានពិភាក្សាខាងលើនេះត្រូវបាន កាំង ហ្កេកអ៊ាវ បញ្ជាក់ថា "កិច្ចការបក្ស" សំដៅលើការជ្រើសរើសសមាជិកថ្មី ការត្រួតពិនិត្យ និង ដាក់វិន័យលើសមាជិកបក្ស[១០០៦]។

៣២៩. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការទទួលខុសត្រូវជាផ្លូវការរបស់ នួន ជា ខាងឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងសិក្សាធិការ ក៏រួមបញ្ចូលទាំងវិន័យរបស់កម្មាភិបាល និង បញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងទៀតផងដែរ។

---

[១០០៣] ដីកាដំណោះស្រាយ កថាខណ្ឌ ៨៨០ ដកស្រង់កិច្ចសម្ភាសន៍របស់ Steven HEDER ជាមួយ អៀង សារី ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារ E3/89, ERN (ជាភាសាខ្មែរ) 000062467-000062468។

[១០០៤] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សាឡូត បាន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សាឡូត បាន) ទំព័រ ៦០។

[១០០៥] ប្រតិចារឹក ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (សាក្សី នង សុផង់) ទំព័រ ២០-២២ (គូសបញ្ជាក់ថា បញ្ហាពាក់ព័ន្ធនឹងសភាពការណ៍សន្តិសុខផ្ទៃក្នុង និង ការធ្វើបំពានក្រមសីលធម៌ ត្រូវរាយការណ៍ទៅ នួន ជា ដោយសារគាត់ "ទទួលបន្ទុកខាងប្រជាជន")។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (សាក្សី នង សុផង់) ទំព័រ ៣៩-៤០ ("ប៉ុន្តែចំពោះកិច្ចការវប្បធម៌ ឧទាហរណ៍ ប្រសិនបើមានបញ្ហាសីលធម៌ណាមួយ ក្នុងចំណោមប្រជាជនក្នុងសង្គម ខ្ញុំជឿថាមានតែ នួន ជា ទេជាអ្នកទទួលបន្ទុក")។ *សូមមើលផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារ E3/513។

[១០០៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៧៥-៧៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៥៦។

## ៧.៦ តួនាទីក្នុងក្បាលម៉ាស៊ីនឃោសនា និងសន្តិសុខ

៣៣០. នួន ជា បានបដិសេធថាគាត់មិនដែលមានតួនាទី ឬការទទួលខុសត្រូវអ្វីពាក់ព័ន្ធនឹងការងារសន្តិសុខ រួមទាំងកិច្ចការឃោសនា និងសន្តិសុខផ្ទៃក្នុង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក្នុងអំឡុងបក្សកុម្មុយនីស្តកម្ពុជាទេ[១០០៧]។ ផ្ទុយទៅនឹងសក្ខីកម្មនេះ អង្គជំនុំជម្រះបានពិចារណាលើភស្តុតាងយ៉ាងច្រើនដែលបញ្ជាក់ថា នួន ជា មានជាប់ពាក់ព័ន្ធក្នុងកិច្ចការឃោសនា និងសន្តិសុខ ទាំងនៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

### ៧.៦.១ សមាជិកភាពក្នុងគណៈកម្មាធិការឃោសនានៃបក្សកុម្មុយនីស្តកម្ពុជា

៣៣១. យោងតាមដីកាដំណោះស្រាយ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា គឺជាសមាជិកមួយរូបរបស់គណៈកម្មាធិការឃោសនានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងទទួលខុសត្រូវខាងផ្នែកសន្តិសុខ និងកិច្ចការឃោសនា[១០០៨]។ នួន ជា បានបញ្ជាក់ថាពិតជាមានគណៈកម្មាធិការឃោសនា ប៉ុន្តែ គាត់បានបដិសេធថា គាត់មិនមែនជាសមាជិកគណៈកម្មាធិការនេះទេ[១០០៩]។

៣៣២. ទោះបីជាអង្គជំនុំជម្រះបានយល់ឃើញនៅក្នុងសាលក្រមរឿងក្ដី កាំង ហ្កេកអ៊ាវ ហៅ ឌុច ថា នួន ជា ជាសមាជិកគណៈកម្មាធិការឃោសនាក៏ដោយ[១០១០] ក៏ភស្តុតាងត្រង់ចំណុចនេះនៅក្នុង

---

[១០០៧] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៩។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-២៩។

[១០០៨] ដីកាដំណោះស្រាយ កថាខណ្ឌ ៨៧៣-៨៧៩។ សូមមើលផ្នែកទី ៥ ស្ដីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៥។

[១០០៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៧-១៩។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៨។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ១៩-២០។ *សូមមើលផងដែរ* កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54 ERN (ជាភាសាខ្មែរ) 00148743-00148744។

[១០១០] *សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៩៥។ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកសំខាន់លើសក្ខីកម្មរបស់អ្នកជំនាញ Craig ETCHESON ដែលបានផ្ដល់សក្ខីកម្មនៅក្នុងសវនាការ។ *សូមមើល*

សំណុំរឿងក្ដីបច្ចុប្បន្នមានលក្ខណៈមិនស៊ីសង្វាក់គ្នា។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ Steven HEDER អៀង សារី បានបញ្ជាក់ថា គណៈកម្មាធិការយោធាពិតជាមានមែន ហើយ នួន ជា ចូលរួមក្នុងគណៈកម្មាធិការនេះ រួមជាមួយនឹង ប៉ុល ពត និង សុន សេន និង អ្នកផ្សេងទៀតផងដែរ[១០១១]។ នៅក្នុងសវនាការ សាក្សី សួង ស៊ីគឿន បានបញ្ជាក់បំភ្លឺលើចម្លើយដែលគាត់ផ្ដល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គាត់បានឮនៅក្រោយឆ្នាំ ១៩៧៩ តែប៉ុណ្ណោះថា នួន ជា ជាសមាជិករបស់គណៈកម្មាធិការយោធា តាមរយៈអត្ថបទ និង សៀវភៅផ្សេងៗដែលគាត់បានអាន ហើយគាត់មិនបានដឹងដោយផ្ទាល់ថាតើ នួន ជា ធ្លាប់ជាសមាជិករបស់គណៈកម្មាធិការយោធានៃគណៈមជ្ឈិមបក្សក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ យ៉ាងណានោះទេ[១០១២]។ អ្នកជំនាញ Philip SHORT មិនជឿថា នួន ជា ធ្លាប់ជាសមាជិករបស់គណៈកម្មាធិការយោធានោះទេ ទោះបីជាគាត់បានបញ្ជាក់ថា តាមរយៈការដឹកនាំនយោបាយរបស់គាត់ក្នុងមជ្ឈិមបក្ស នួន ជា មានអំណាចត្រួតត្រាយោធាក៏ដោយ[១០១៣]។ ដូចគ្នានេះដែរ នៅពេលពិភាក្សាអំពីតួនាទីរបស់ នួន ជា ពាក់ព័ន្ធនឹងគណៈកម្មាធិការយោធា អ្នកជំនាញ David CHANDLER ជឿថា ដោយសារតំណែង

---

ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ (អ្នកជំនាញ Craig ETCHESON) ទំព័រ ៥៨-៥៩។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ (អ្នកជំនាញ Craig ETCHESON) ទំព័រ ៥៥។

[១០១១] កិច្ចសម្ភាសន៍របស់ Steven HEDER ជាមួយ អៀង សារី ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារ E3/89 ERN (ជាភាសាខ្មែរ) 00062461-00062462។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយ អៀង សារី ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ឯកសារ E3/94 ERN (ជាភាសាខ្មែរ) 00578893-00578895។ មានភស្តុតាងបន្ថែមមួយទៀត ដែលសន្មតថាជារបស់ អៀង សារី ដែរថា នួន ជា ជាសមាជិកម្នាក់របស់គណៈកម្មាធិការយោធារបស់គណៈមជ្ឈិម ដែលទទួលខុសត្រូវខាងកិច្ចការនយោបាយ។ *សូមមើល* កំណត់ហេតុនៃការប្រជុំសន្និបាតលើកទី ៥ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ឯកសារ E3/816, ERN (ជាភាសាខ្មែរ) 00800744-00800745។

[១០១២] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សាក្សី សួង ស៊ីគឿន) ទំព័រ ៥៤-៥៥។ សាក្សី សួង ស៊ីគឿន ធ្លាប់ប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា នួន ជា គឺជាសមាជិករបស់គណៈកម្មាធិការយោធា។ *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួង ស៊ីគឿន ឯកសារ E3/42 ERN (ជាភាសាខ្មែរ) 00327207-00327208។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួង ស៊ីគឿន ឯកសារ E3/1699 ERN (ជាភាសាខ្មែរ) 00204152-00204153។

[១០១៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៥៩-៦១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ២៣-២៤។

របស់គាត់ក្នុងមជ្ឈិមបក្សនោះ នួន ជា មានតួនាទីសំខាន់មួយក្នុងគោលនយោបាយបក្ស និងដំណើរការធ្វើសេចក្តីសម្រេច រួមទាំងបញ្ហាពាក់ព័ន្ធនឹងកិច្ចការយោធាទាំងអស់នោះផងដែរ[១០១៤]។

៣៣៣. ដោយផ្អែកលើការបដិសេធរបស់ជនជាប់ចោទថា គាត់មិនមែនជាសមាជិកគណៈកម្មាធិការយោធារបស់បក្សកុម្មុយនីស្តកម្ពុជា និងដោយសារភាពមិនស៊ីសង្វាក់គ្នានៃភ័ស្តុតាងនៅក្នុងសវនាការ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឲ្យលើសពីវិមតិសង្ស័យថា នួន ជា ជាសមាជិកគណៈកម្មាធិការយោធាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបានទេ។

### ៧.៦.២ ការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាយោធា និងសន្តិសុខផ្សេងទៀត

៣៣៤. នួន ជា ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុងការធ្វើសេចក្តីសម្រេច រួមទាំងការរៀបចំឲ្យមានគោលនយោបាយបក្សបែបហិង្សា និងនៅក្នុងឆ្នាំ ១៩៦៨ បានផ្តួចផ្តើមឲ្យមានការតស៊ូប្រដាប់អាវុធ[១០១៥]។ មានភ័ស្តុតាងបញ្ជាក់ផងដែរថា នៅក្នុងអំឡុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា នួន ជា ត្រូវបានតែងតាំងធ្វើជាអនុមេបញ្ជាការយោធាជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា និងជាប្រធានផ្នែកនយោបាយកងទ័ព ទោះបីជាការតែងតាំងដែលត្រូវបានធ្វើឡើងក្នុងបរិបទនេះ ពិតជាមិនឆ្លុះបញ្ចាំងអំពីអំណាចជាក់ស្តែងក៏ដោយ[១០១៦]។

---

[១០១៤] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៧-២៨។

[១០១៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦២-៦៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ជើងទំព័រ ៤, ៣០-៣២។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២២-២៣។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងួន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078198-00078202។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (សាក្សី យន់ គីម) ទំព័រ ៦២-៦៥ (គូសបញ្ជាក់ថា នៅក្នុងឆ្នាំ ១៩៧៣ ក្នុងអំឡុងនៃកិច្ចប្រជុំមួយនៅភូមិដា សម្រាប់ប្រធានឃុំ ខេត្តក្រចេះ នួន ជា បាននិយាយអំពីសភាពការណ៍ខ្លាំង បែងចែកដាច់ពីគ្នារវាងពួកអាមេរិក វៀតណាម និង សត្រូវខាងក្នុង)។

[១០១៦] *វណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និង រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ត្រូវបានពង្រឹង* (និរសារវៀតណាម) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៧២ ឯកសារ E3/3709។ *សូមមើលផងដែរ ប្រទេសកម្ពុជា៖ បំណែកតូចៗចាប់ផ្តើមត្រូវគ្នា* (Far Easter Economic Review) ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៧៧ ឯកសារ E3/1782, ERN (ជាភាសាខ្មែរ) 00752553-00752561។ Leon Triviere *ប្រទេសចិន និងប្រទេសកម្ពុជា* ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ឯកសារ E3/482 ទំព័រ ១២ ERN (ជាភាសាខ្មែរ) 00538847-00538848។

៣៣៥. នួន ជា ក៏ជាប់ពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មអាវុធ និងគ្រាប់រំសេវ ដើម្បីឱ្យចលនាតស៊ូយកមកប្រើប្រាស់ ជាពិសេសអាវុធ និងគ្រាប់រំសេវមកពីប្រទេសចិនដែលឆ្លងកាត់តាមប្រទេសវៀត-ណាម[១០១៧]។ នៅឆ្នាំ ១៩៧៣ នួន ជា ក៏ត្រូវបាន ប៉ុល ពត ឱ្យទទួលខុសត្រូវក្នុងការធានាសន្តិសុខសម្រាប់ព្រះរាជទស្សនកិច្ចរបស់សម្ដេច នរោត្តម សីហនុ ទៅកាន់តំបន់រំដោះនៅក្នុងប្រទេសកម្ពុជាផងដែរ[១០១៨]។ ចុងក្រោយ នួន ជា ក៏បានបញ្ជាក់ថា គាត់បានចូលរួមក្នុងការរៀបចំផែនការ និងការធ្វើសេចក្ដីសម្រេច ពាក់ព័ន្ធនឹងការវាយផ្ដាច់ព្រ័ត្រចូលទីក្រុងភ្នំពេញ និងបានចូលរួមក្នុងកិច្ចប្រជុំជាច្រើន ដែលក្នុងកិច្ចប្រជុំទាំងនេះ មានលើកផែនការអំពីចលនារុលទៅមុខរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា និងផែនការរំដោះទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ ១៩៧៥ និងការរំកិលទៅមូលដ្ឋាន ប-៥ សម្រាប់វាយផ្ដាច់ព្រ័ត្រចូលទីក្រុងភ្នំពេញ[១០១៩]។

៣៣៦. ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិតេយ្យ ការពាក់ព័ន្ធរបស់ នួន ជា ក្នុងបញ្ហាសន្តិសុខខាងក្រៅ ជាសំខាន់គឺអំពើហិង្សាដែលកាន់តែខ្លាំងឡើងរវាងប្រទេសកម្ពុជា និងវៀតណាម។ នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខែ មីនា ឆ្នាំ ១៩៧៦ ដែលក្នុងកិច្ចប្រជុំនោះ

---

[១០១៧] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦៧-៦៨។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១១-១៣, ១៧-១៨ (គូសបញ្ជាក់ថា គាត់ត្រូវបានគណៈមជ្ឈិមណែនាំឱ្យសម្របសម្រួលជាមួយប្រទេសវៀតណាម ដើម្បីទទួលបានអាវុធ និង គ្រាប់រំសេវ ដែលប្រទេសចិនផ្ដល់ឱ្យ សម្រាប់ប្រើប្រាស់ក្នុងការវាយប្រហារផ្ដាច់ព្រ័ត្រនៅទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៨, ១០-១៤។

[១០១៨] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ៦៦-៦៨។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ៤៣-៤៦។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៥-១៨។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-៣០។

[១០១៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៦-១៩។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៣។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១០-១៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ២៨-៣១។ ២៣។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00078202។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (សាក្សី មាស វឿន) ទំព័រ ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (សាក្សី មាស វុន) ទំព័រ ៦-៧។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ចាម តុន) ទំព័រ ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី រ៉ូចាម តុម) ទំព័រ ១០-១៤, ២០-២២ (បញ្ជាក់អំពីវត្តមានចូលរួមរបស់ នួន ជា នៅក្នុងកិច្ចប្រជុំគណៈមជ្ឈិមជាមួយថ្នាក់ដឹកនាំភូមិភាគ ពាក់ព័ន្ធនឹងការត្រៀមរំដោះទីក្រុងភ្នំពេញ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ក្បែរភូមិមាយ)។

ប៉ុល ពត ពុំមានវត្តមាន នួន ជា បានបញ្ចេញមតិជាច្រើន និងបានផ្តល់ការណែនាំពាក់ព័ន្ធនឹងសភាពការណ៍ព្រំដែនជាប់ប្រទេសវៀតណាម។ គាត់បានលើកឡើងថា ត្រូវមានវិធានការទាំងតាមផ្លូវនយោបាយការទូត ព្រមទាំងកម្លាំងយោធាផងដែរ[១០២០]។ នួន ជា ក៏មានវត្តមាន និងបានបញ្ចេញមតិនៅក្នុងកិច្ចប្រជុំផ្សេងៗទៀតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលពិភាក្សាអំពីសភាពការណ៍ព្រំដែនកម្ពុជាជាប់នឹងប្រទេសវៀតណាម[១០២១]។

៣៣៧. ទូរលេខជាច្រើនដែលនៅសេសសល់រហូតដល់ពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹងសភាពការណ៍នៅសមរភូមិ និងសភាពការណ៍នៅព្រំដែនជាប់វៀតណាម ត្រូវបានចម្លងជូនទៅ នួន ជា[១០២២]។ មាន

---

[១០២០] កំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/218 ERN (ជាភាសាខ្មែរ) 00000755-00000757។

[១០២១] កំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/217។ កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារ E3/221 ERN (ជាភាសាខ្មែរ) 00000812-00000813, 00000814-00000818 និង 00000825-00000826។

[១០២២] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារ E3/893 (រាយការណ៍អំពីកិច្ចប្រជុំមួយជាមួយគណៈប្រតិភូ វៀតណាម ពាក់ព័ន្ធនឹងបញ្ហាជាច្រើនអំពីដែនដី និង ព្រំដែន)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/871 (ជម្រាបដំណឹងដល់បង ប៉ុល ពត ស្តីពីសភាពការណ៍ព្រំដែន និងការចាប់ជនជាតិវៀត-ណាម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ E3/240 (ជម្រាបជូនអង្គការអំពីការចាប់ខ្លួនទាហានវៀតណាម ២០៩ នាក់ និង ស្នើសុំយោបល់/សម្រេចពីអង្គការអំពីថាតើមានវិធានការយ៉ាងណា)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ ឯកសារ E3/882 (ជូនដំណឹងដល់អង្គការថា "កងទ័ពកម្ពុជាបានសម្លាប់ប្រជាជនស៊ីវិលវៀតណាម ១០០០ នាក់ នៅហាតៀន ក្នុងខេត្តគាន យ៉ាង")។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/885 (រាយការណ៍អំពីសភាពការណ៍នៅសមរ- ភូមិ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ E3/895 (រាយការណ៍អំពីសភាព-ការណ៍នៅតាមផ្លូវលេខ ២២ ដែលកម្លាំងខ្មាំងត្រូវរងការវាយប្រហារ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារ E3/908 (ស្នើសុំការណែនាំ និង សេចក្តីសម្រេចរបស់អង្គការ យោងតាមសភាពការណ៍ដែលបានកើតឡើង នៅពេលយួនដណ្តើមបានចម្ការកៅស៊ូមេមត់ និង តំបន់ជុំវិញ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨ ឯកសារ E3/243 (ជម្រាបបង ប៉ុល ពត ឲ្យបានជ្រាបសភាពការណ៍នៅតំបន់ ២៣ តំបន់ ២៤ និង សមរភូមិនៅតាមផ្លូវលេខ ២២)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារ E3/1021 (ជូនដំណឹងអំពីសភាពការណ៍នៅតាមព្រំដែន នៅលើផ្លូវលេខ ១៩)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ E3/976 (ជូនដំណឹងថា ការណែនាំអំពីការលុកលុយរបស់ខ្មាំងចូលមកក្នុងតំបន់ត្រពាំងផ្លុងនោះ ត្រូវបានធ្វើឡើងដោយមហាជោគជ័យ និងមហាអស្ចារ្យ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ E3/998 (រាយការណ៍អំពីការងារកម្ទេចពួក

ភ័ស្តុតាងបញ្ជាក់ផងដែរថា នៅក្នុងកាលៈទេសៈមួយចំនួន នួន ជា បានផ្តល់មតិ និងការណែនាំលើបញ្ហាទាំងអស់នេះ[១០២៣]។

៣៣៨. បន្ថែមទៅលើបញ្ហាជម្លោះជាមួយប្រទេសវៀតណាម នួន ជា ក៏បានចូលរួមក្នុងកិច្ចការពាក់ព័ន្ធនឹងសកម្មភាពយោធាផងដែរ។ គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ-អចិន្ត្រៃយ៍នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ដែលនៅក្នុងកិច្ចប្រជុំនេះ មានពិភាក្សាអំពីការសង់រោង-ចក្រសម្រាប់ផលិតអាវុធ និង ការសាងសង់អាកាសយានដ្ឋាន។ គាត់ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំមួយទៀតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានធ្វើឡើងនៅខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដែលពិភាក្សាលើបញ្ហាជាច្រើនពាក់ព័ន្ធនឹងការការពារជាតិ[១០២៤]។ ដូចគ្នានេះដែរ នួន ជា ក៏មានវត្តមានក្នុងកិច្ចប្រជុំមួយទៀតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលធ្វើឡើងនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ដែលពិភាក្សាអំពីកិច្ចការយោធាក្នុងការការពារ និងកសាងប្រទេស និងការចូលរួមរបស់យោធានៅក្នុង

---

អាខ្មាំងយួន នៅភូមិពោង និង ត្រពាំងផ្លុង។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារ E3/155 (រាយការណ៍អំពីសភាពការណ៍របស់ខ្មាំងខាងក្រៅ និង ខ្មាំងខាងក្នុងបក្ស)។ ទូរលេខកម្ពុជាប្រជា-ធិបតេយ្យ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ ឯកសារ E3/892 (រាយការណ៍ផងដែរ អំពីការចាប់ខ្លួនជនជាតិវៀតណាម និង សួរថាតើគួរបញ្ជូនអ្នកទាំងនេះទៅមន្ទីរ ៨៧០ ឬយ៉ាងណា)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ E3/867។ ទូរលេខដទៃទៀត និយាយសំដៅលើសភាពការណ៍ខ្មាំង នៅតាមព្រំដែនថៃ៖ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ ឯកសារ E3/1144។ *សូមមើលផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/974 ដែលមានចុះកាលបរិច្ឆេទមិនត្រឹមត្រូវ។ ទូរលេខ កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៧៧ ឯកសារ E3/883។

[១០២៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាំ ផាន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ E3/58, ERN (ជាភាសាខ្មែរ) 00239937 (គូសបញ្ជាក់ថា កំណត់ហេតុវាយអង្គលីលេខពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ត្រូវបានបញ្ជូនទៅ នួន ជា ហើយ នួន ជា "ណែនាំជាប្រចាំស្តីពីបញ្ហាសន្តិសុខ ដូចជាឲ្យប្រុងប្រយ័ត្នខ្មាំងវៀតណាម ឬ ខ្មាំងខាងក្នុងមហិច្ឆតាប្រទេសវៀតណាម និងភារកិច្ចខាងសតិអារម្មណ៍សម្រាប់អប់រំដល់កម្រិតថ្នាក់ស្រុក")។ ពិសៀវភៅនិពន្ធដោយ ខៀវ សំផន៖ ចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/16, ERN (ជាភាសាខ្មែរ) 00380434-00380435 (យោងទៅសម្តីរបស់ យ៉ា ថា នៅក្នុងខែ មិថុនា/កក្កដា ឆ្នាំ ១៩៧៦ នួន ជា បានណែនាំឲ្យសរសេរទូរលេខមួយប្រាប់ទៅកម្មាភិបាលទាក់ទងរបស់វៀតណាមម្នាក់ ដោយស្នើឲ្យផ្អាកការវាយគ្នា ហើយស្នើឲ្យមានការជួបគ្នា ដើម្បីចរចា ដោះស្រាយបញ្ហាព្រំដែន)។

[១០២៤] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារ E3/222។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ E3/229។

ការបង្កបង្កើនផលកសិកម្ម[១០២៥]។ ចុងក្រោយ ក្រៅពីទូរលេខពាក់ព័ន្ធនឹងសមរភូមិ និងប្រទេសវៀតណាមដូចខាងលើ នួន ជា ជាអ្នកទទួលទូរលេខដទៃទៀត ពាក់ព័ន្ធនឹងសកម្មភាពយោធា ជាពិសេស កងពលធំ ១៦៤ របស់កងទ័ពបដិវត្តន៍កម្ពុជាផងដែរ[១០២៦]។

៣៣៩. ឯកសារទស្សនាវដ្ដីទង់បដិវត្តលេខពិសេសសម្រាប់ ខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ ខែ មករា ឆ្នាំ ១៩៧៧ បានចុះផ្សាយឡើងវិញអំពីសុន្ទរកថាមួយក្នុងឱកាសបុណ្យខួបទី ៩ នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា[១០២៧]។ នៅក្នុងសវនាការ នួន ជា បានបដិសេធដោយលើកឡើងថា គាត់មិនបានថ្លែងសុន្ទរកថានោះទេ ហើយថា អ្នកដែលថ្លែងសុន្ទរកថានៅពេលនោះ គឺ សុន សេន[១០២៨]។ ក៏ប៉ុន្តែសេចក្ដីរាយការណ៍ព័ត៌មាននៅពេលនោះ ដែលបានដកស្រង់សុន្ទរកថាដដែលនេះ បានបញ្ជាក់ដូចៗគ្នាថា នួន ជា គឺជាអ្នកថ្លែងសុន្ទរកថានៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៧ ក្នុងឋានៈគាត់ជានាយករដ្ឋមន្ត្រីស្ដីទីនៃរបបកម្ពុជាប្រជាធិបតេយ្យ[១០២៩]។

---

[១០២៥] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារ E3/224។

[១០២៦] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារ E3/519 (ពាក់ព័ន្ធនឹងយុទ្ធជនពីរនាក់ដែលបានធ្វើដំណើរដោយគ្មានការអនុញ្ញាត និងគ្មានលិខិតសម្គាល់ខ្លួន និងស្នើសុំឱ្យជូនដំណឹងនេះដល់មេបញ្ជាការរបស់ពួកគេ ដើម្បីបញ្ជាក់អត្តសញ្ញាណពួកគេ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1135 ដែលមិនបានដាក់កាលបរិច្ឆេទត្រឹមត្រូវ (ពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ប្រពន្ធកម្មាភិបាលកងពលធំ ១៦៤ និង មានចំណារពី សុន សេន ផ្ញើជូនទៅ នួន ជា ស្នើសុំឱ្យចាត់វិធានការបន្ថែមចំពោះជនសង្ស័យ ដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នេះ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារ E3/915 (ទទួលស្គាល់ការទទួលបាននូវការណែនាំពីមជ្ឈិមបក្សទាក់ទងនឹងអ្នកឈ្លានពានជាជនជាតិវៀតណាម និងបញ្ជាក់អំពីការកំណត់យកកងពលធំ ១៦៤ ធ្វើជាឧបករណ៍ដាច់ខាតមួយសម្រាប់ការពារបក្ស កសិករ និង ប្រទេសប្រឆាំងនឹងខ្មាំងទាំងអស់)។ របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារ E3/928 (ជូនដំណឹងអំពីការធ្វើតេស្តគ្រាប់មីន និង ស្នើសុំកាំភ្លើងយន្ត)។ *សូមមើលផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/1222។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/1223។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ E3/1224។ ទូរលេខកម្ពុជា ប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ E3/1225។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៧៦ ឯកសារ E3/1226។ ទូរលេខមួយៗក្នុងចំណោមសារទូលេខប្រាំចុងក្រោយនេះ ត្រូវបានចម្លងជូន នួន ជា និង សុន សេន។

[១០២៧] ទង់បដិវត្ត ចុះខែ ធ្នូ-មករា ឆ្នាំ ១៩៧៦-១៩៧៧ ERN (ជាភាសាខ្មែរ) 00063014-00063057។

[១០២៨] ប្រតិចារឹក ថ្ងទី ១១ ខែ មករា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២៣-២៤។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-២០។

[១០២៩] *សមមិត្ត នួន ជា ថ្លែងក្នុងទិវាខួបកំណើតកងទ័ពបដិវត្តកម្ពុជា* (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ឯកសារ E3/147 ERN (ជាភាសាខ្មែរ) 00679792-00679794។ ខួបលើកទី ៩ នៃការ

៣៤០. នួន ជា ក៏ជាប់ពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាល និងយោធា ជាពិសេសអ្នកដែលមកពីភូមិភាគបូព៌ា។ នៅឆ្នាំ ១៩៧៨ គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយជាមួយមេដឹកនាំដទៃទៀតរបស់បក្ស រួមមាន ប៉ុល ពត សុន សេន និង តាម៉ុក ព្រមទាំងមេបញ្ជាការយោធាជាច្រើនរូបទៀត ដោយនៅក្នុងកិច្ចប្រជុំនោះ សមាជិករបស់ភូមិភាគបូព៌ា ជាពិសេស សោ ភឹម ត្រូវបានប្រកាសថាជាខ្មាំងផ្ទៃក្នុងរបស់បក្ស ដែលត្រូវបោសសម្អាត។ នៅក្នុងកិច្ចប្រជុំនោះ នួន ជា បាននិយាយអំពីការចាប់ខ្លួនសមាជិកជាច្រើនរបស់ភូមិភាគបូព៌ា[១០៣០]។

៣៤១. សមាជិកភាពពិតប្រាកដនៅក្នុងគណៈកម្មាធិការយោធា មិនសូវជាសំខាន់ប៉ុន្មានទេ ដោយសារ នួន ជា មានមុខតំណែងជាន់ខ្ពស់នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស។ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានទទួលព័ត៌មានលម្អិត និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយយោធារបស់កម្ពុជាប្រជាធិបតេយ្យ និងការអនុវត្តគោលនយោបាយនេះ។

### ៧.៦.៣ ការគ្រប់គ្រងមន្ទីរសន្តិសុខ ស-២១

៣៤២. នួន ជា បដិសេធថាគាត់មិនជាប់ពាក់ព័ន្ធអ្វីជាមួយនឹងប្រតិបត្តិការរបស់មន្ទីរ ស-២១ ទេ ហើយក្រោយមក គាត់បានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ នៅពេលមានការតាំងសំណួរពាក់ព័ន្ធនឹងចំណុចនេះ[១០៣១]។

៣៤៣. សាក្សី កាំង ហ្កេកអ៊ាវ ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ ចាប់ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ បានរៀបរាប់យ៉ាងច្រើនអំពីតួនាទីរបស់ នួន ជា ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខផ្ទៃក្នុង ជា

---

បង្កើតកងទ័ពបដិវត្ត ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៧ ឯកសារ E3/544, ERN (ជាភាសាខ្មែរ) S 00807441។ សុន្ទរកថារបស់លោក នួន ជា នៅក្នុងមេទិញទិវាខួបកងទ័ព (ក្នុង SWB/FE/5417/C1/1) ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៧ ឯកសារ E3/191, ERN (ជាភាសាខ្មែរ) 00649940-00649941។

[១០៣០] ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី ឈូក រីន) ទំព័រ ២២-២៣។ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី ឈូក រីន) ទំព័រ ៤១-៤២, ៨១-៨២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ១៥-១៦។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី រស់ ស៊ុយ) ទំព័រ ៤៣-៤៨ (ចូលរួមក្នុងវគ្គរៀនសូត្រ ដែល នួន ជា បាននិយាយថា សោ ភឹម និង កុយ ធួន ជាជនក្បត់)។

[១០៣១] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (ជនជាប់ចោទ នួន ជា) ទំព័រ ២-៦។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ២៧ ។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ជនជាប់ចោទ នួន ជា) ទំព័រ ៩-១០ (គូសបញ្ជាក់ថា គាត់មិនដែលជួប គ្រប់គ្រង ឬ ចេញបញ្ជាណាមួយទៅ កាំង ហ្កេកអ៊ាវ។

ពិសេសប្រតិបត្តិការរបស់មន្ទីរ ស-២១។ កាំង ហ្គេកអ៊ាវ រាយការណ៍ជាទៀងទាត់ទៅ នួន ជា អំពីសកម្មភាពរបស់គាត់នៅមន្ទីរ ស-២១ ហើយ ជារឿយៗ នួន ជា បានផ្តល់ការណែនាំពាក់ព័ន្ធនឹងចម្លើយសារភាព និងការប្រព្រឹត្តិលើអ្នកជាប់ឃុំឃាំង[១០៣២]។ ជាក់លាក់ជាងនេះទៀត នួន ជា បានស្នើឲ្យ កាំង ហ្គេកអ៊ាវ ដកឈ្មោះសមាជិកបក្សមួយចំនួនចេញពីចម្លើយសារភាព ដែលបានចោទប្រកាន់សមាជិកទាំងនោះថាបានក្បត់បក្ស ក្នុងនោះមានទាំងឈ្មោះជនជាប់ចោទ ខៀវ សំផន ម្នាក់ផងដែរ[១០៣៣]។ កាំង ហ្គេកអ៊ាវ បានផ្តល់សក្ខីកម្មថា ការចូលរួមរបស់ នួន ជា ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់មន្ទីរ ស-២១ មានកាន់តែខ្លាំងនៅក្នុងខែ សីហា ឆ្នាំ ១៩៧៧ ក្រោយពេលដែលសុន សេន ត្រូវបានបញ្ជូនទៅកាន់ព្រំដែនកម្ពុជាវៀតណាម ស្របពេលដែលជម្លោះរវាងប្រទេស

[១០៣២] ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ១៧-១៨។ ប្រតិចារឹក ថ្ងៃទី ២៦ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៦៧។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៨ (គូសបញ្ជាក់ថា នួន ជា បានណែនាំឲ្យបញ្ឈប់ការថតសម្លេងចម្លើយសារភាព និង បានណែនាំឲ្យរៀបចំចម្លើយសារភាពទាំងនេះជាឯកសារសរសេរជំនួសវិញ) ទំព័រ ៣៦-៤១ (ពិភាក្សាកិច្ចប្រជុំទាំងនេះជាមួយ នួន ជា អំពីសកម្មភាពរបស់ ស-២១)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៨-៩ (គូស-បញ្ជាក់ថា នួន ជា ស្នើឲ្យថតរូបអ្នកទោស ស-២១ មួយចំនួន ដើម្បីបញ្ជាក់ឲ្យច្បាស់ថា ពួកគេពិតជាបានស្លាប់ពិតប្រាកដមែន)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៧-៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ E3/351 ទំព័រ ១៦-១៨ ERN (ជាភាសាខ្មែរ) 00162891-00162893 (គូសបញ្ជាក់ថា កាំង ហ្គេកអ៊ាវ តែងតែបញ្ជូនចម្លើយសារភាព ស-២១ ទៅកាន់គណៈ-មជ្ឈិម ដែលគាត់ដឹងថាមាន នួន ជា ម្នាក់នៅក្នុងនោះដែរ)។ (ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៨៤-៨៥។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សី វ៉ាចាម តុន) ទំព័រ ៣៦-៣៨ (គូសបញ្ជាក់ថា ក្នុងករណីមានកំហុសធ្ងន់ក្នុងចម្លើយសារភាព ស-២១ ពាក់ព័ន្ធនឹងបុគ្គលិកនៅក្រសួងការបរទេស នួន ជា រាយការណ៍ទៅ អៀង សារី)។

[១០៣៣] ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៤៣-៤៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៦៤-៦៥។ *សូមមើលផងដែរ* ចម្លើយរបស់ ចាប មុិត នៅមន្ទីរស-២១ ឯកសារ E3/1688, ERN (ជាភាសាខ្មែរ) 00226401 (មានចំណារមួយពី កាំង ហ្គេកអ៊ាវ ថា នួន ជា ណែនាំឲ្យដកឈ្មោះបុគ្គលមួយចំនួនចេញពីចម្លើយសារភាពនេះ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៥, ទំព័រ ២៦-២៧ (គូសបញ្ជាក់ថា កាំង ហ្គេកអ៊ាវ ចារលើចម្លើយសារភាព ចាប មុិត និងសន្និដ្ឋានថា នួន ជា បានពិនិត្យមើលចម្លើយសារភាពនោះឡើងវិញ និង បានដឹងអំពីប្រតិបត្តិការ ស-២១)។

វៀតណាមជាមួយនឹងប្រទេសកម្ពុជាកាន់តែរីករាលដាលខ្លាំងឡើង[១០៣៤]។ ចម្លើយសារភាពមួយចំនួនរបស់មន្ទីរ ស-២១ ដែលមាននៅក្នុងសំណុំរឿង មានចំណារដែលបញ្ជាក់ថា ចម្លើយសារភាពទាំងអស់នេះត្រូវបានបញ្ជូនទៅ នួន ជា[១០៣៥]។ សាក្សី សួត ទៀង ជាអង្គរក្ស និងអ្នកបើកបររបស់ នួន ជា បានបញ្ជាក់ផងដែរថា គាត់ធ្លាប់បានយកឯកសារជាច្រើនពី កាំង ហ្កេកអ៊ាវ ទៅប្រគល់ជូន

---

[១០៣៤] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៣០-៣១, ៣៦-៣៧ ។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្កេកអ៊ាវ) ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (សាក្សី  កាំង ហ្កេកអ៊ាវ) ទំព័រ ១១១២-, ៣០៣១-, ៣៦។៣៧-

[១០៣៥] ចម្លើយសារភាពនៅ ស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត ឯកាសារ E3/1565, ERN (ភាសាអង់គ្លេស) 00182773។ ចម្លើយសារភាពនៅ ស-២១ របស់ ទីវ ម៉ី ហៅ សន្តិភាព ឯកសារ E3/1537 ERN (ភាសាខ្មែរ) 00174754។ ចម្លើយសារភាពនៅ ស-២១ របស់ ចាប ម៉ុត ឯកសារ E3/1688 ERN (ភាសាខ្មែរ) 00226401។ ចម្លើយសារភាពនៅ ស-២១ របស់ ខែក ប៊ុន ហៅ ស៊ូ ឯកសារ E3/1706 ERN (ភាសាខ្មែរ) 00174021។ ចម្លើយសារភាពនៅ ស-២១ របស់ ទិត ស៊ាន ឯកសារ E3/1828, ERN (ភាសាខ្មែរ) 00000881។ ចម្លើយសារភាពនៅ ស-២១ របស់ ភន ផល ឯកសារ E3/1879, ERN (ភាសាខ្មែរ) 00001020។ ចម្លើយ សារភាពនៅ ស-២១ របស់ គុណ ឌីម ឯកសារ E3/3697 ERN (ភាសាខ្មែរ) 00175293។ ចម្លើយ សារភាពនៅ ស-២១ របស់ ហែម សុត ហៅ សៀន ឯកសារ E3/1842 ERN (ភាសាខ្មែរ) 00017272។ ចម្លើយ សារភាពនៅ ស-២១ របស់ ផេង ស៊ន់ ហៅ ជ័យ ឯកសារ E3/3665 ERN (ភាសាខ្មែរ) 00174108។ ចម្លើយ សារភាពនៅ ស-២១ របស់ ជុំ ពេញ ឯកសារ E3/2129 ERN (ភាសាខ្មែរ) 00017413។ ចម្លើយសារភាពនៅ ស-២១ របស់ សោ តុងលី ឯកសារ E3/1889 ERN (ភាសាខ្មែរ) 00017492-00017493។ ចម្លើយសារភាពនៅ ស-២១ របស់ ពេជ ចយ ឯកសារ E3/1875 ERN (ភាសាខ្មែរ) 00017468។ ចម្លើយសារភាពនៅ ស-២១ របស់ សៀង ប៉ូយ ហៅ ស៊ាន ឯកសារ E3/1894 ERN (ភាសាខ្មែរ) 00005357។ ចម្លើយសារភាពនៅ ស-២១ របស់ ចាប វឿន ឯកសារ E3/1882 ERN (ភាសាខ្មែរ) 00005261។ ចម្លើយសារភាពនៅ ស-២១ របស់ ជា ស្រេង ហៅ ថៃ ឯកសារ E3/1831 ERN (ភាសាខ្មែរ) 00005463។ ចម្លើយសារភាពនៅ ស-២១ របស់ លុន អិន ឯកសារ E3/3689 ERN (ភាសាខ្មែរ) 00174874។ ចម្លើយសារភាពនៅ ស-២១ របស់ ឌី ឡេង ហៅ ភាព ឯកសារ E/1839។ ចម្លើយសារភាពនៅ ស-២១ របស់ អ៊ឹម ឈា ឯកសារ E3/1841 ERN (ភាសាខ្មែរ) 00017453-00017454។ ចម្លើយសារភាពនៅ ស-២១ របស់ ម៉ៅ ជឿន ហៅ លី ឯកសារ E3/3645, ERN (ភាសាអង់គ្លេស) 00223137។ ចម្លើយសារភាពនៅ ស-២១ របស់ សៀង ផុន ហៅ ផា ឯកសារ E3/3648 ERN (ភាសាខ្មែរ) 00173881, 00173882។ ចម្លើយសារភាពនៅ ស-២១ របស់ សក់ ម៉ាន ហៅ វឿន ឯកសារ E3/1886 ERN (ភាសាខ្មែរ) 00679114។ ចម្លើយសារភាពនៅ ស-២១ របស់ ជួត ញ៉ៅ ឯកសារ E3/1687 ERN (ភាសាខ្មែរ) 00005403។ ចម្លើយសារភាពនៅ ស-២១ របស់ ហង់ បូ ឯកសារ E3/1843, ERN (ភាសាខ្មែរ) 00005160, 00005185។ ចម្លើយសារភាពនៅ ស-២១ របស់ តាំង អាន ហៅ អេន ឯកសារ E3/1826 ERN (ភាសាខ្មែរ) 00017220, 00017244។

នួន ជា និងបញ្ជូនត្រឡប់មកវិញ[១០៣៦]។ នៅក្នុងកិច្ចសម្ភាសន៍ដែលថតជាវីដេអូមួយនៅក្រោយរបប-កម្ពុជាប្រជាធិបតេយ្យ នួន ជា បានថ្លែងបញ្ជាក់ប្រាប់អ្នកសារព័ត៌មានម្នាក់ថា គាត់ទទួលបានចម្លើយសារភាព និងបានប្រើប្រាស់ចម្លើយសារភាពខ្លះ ដើម្បីបញ្ចូលក្នុងមេរៀនអប់រំកម្មាភិបាលឲ្យប្រឆាំងនឹងខ្មាំង ប៉ុន្តែគាត់បានបញ្ជាក់ផងដែរថា ចម្លើយសារភាពមាន "ច្រើនពេក" ដែលធ្វើឲ្យគាត់គ្មានពេលគ្រប់គ្រាន់ដើម្បីអានឲ្យបានអស់នោះទេ[១០៣៧]។

៣៨៤. សហព្រះរាជអាជ្ញាក៏លើកឡើងដែរថា កាំង ហ្គេកអ៊ាវ បានកំណត់អត្តសញ្ញាណចំណារលើចម្លើយសារភាពនៅមន្ទីរ ស-២១ និងឯកសារពាក់ព័ន្ធដទៃទៀតថា ជាចំណាររបស់ នួន ជា[១០៣៨]។ ដោយហេតុថា ការស្គាល់របស់ កាំង ហ្គេកអ៊ាវ ចំពោះអក្សរសរសេរដោយដៃរបស់ នួន ជា នៅមានកម្រិតនោះ ដូច្នេះ នាំឲ្យមានបញ្ហាពាក់ព័ន្ធមួយចំនួនចោទឡើងថា តើចំណារទាំងអស់នោះគឺពិតជាចំណារផ្ទាល់ដៃរបស់ នួន ជា មែន ឬ មិនមែន[១០៣៩] ។

៣៨៥. ជនបរទេសជាច្រើននាក់ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ផងដែរ។ ក្នុងចំណោមអ្នកជាប់ឃុំទាំងនេះ មានទាហានវៀតណាម ដែលការចាប់ខ្លួន និងឃុំខ្លួនពួកគេនៅមន្ទីរ ស-២១ ត្រូវបាន

---

[១០៣៦] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សួត ទឿង) ទំព័រ ៣៧-៣៧។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ (សាក្សី សួត ទឿង) ទំព័រ ១១-១៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២៩១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ២៩ (បញ្ជាក់ថា សួត ទឿង បានប្រមូលចម្លើយសារភាព ស-២១ ឲ្យ នួន ជា)។

[១០៣៧] កិច្ចសម្ភាសន៍របស់ នួន ជា ជាមួយ ថេត សម្បត្តិ ក្រោមចំណងជើងថា នួន ជា ឆ្លើយសារភាព ឯកសារ E93/7.3R, ERN V00717048។

[១០៣៨] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ (សវនាការលើឯកសារ) ទំព័រ ៤៦-៥០ យោងទៅឯកសារ និងចំណារដូចតទៅ៖ ចម្លើយសារភាពនៅ ស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត ឯកសារ E3/1565 ERN (ភាសាខ្មែរ) 00017305 ("សម្រង់ផ្ញើជូនកម្មាភិបាល ពក")។ ចម្លើយសារភាពនៅ ស-២១ របស់ សាន់ អ៊ាប ហៅ ខុន ឯកសារ E3/175 ERN (ភាសាខ្មែរ) 00173883 ("នឹងតាមដានពិនិត្យ ឡើងវិញ")។ ចម្លើយសារភាពនៅ ស-២១ របស់ ម៉ុក សំអុល ហៅ ហុង ឯកសារ E3/1546 ERN (ភាសាខ្មែរ) 00173049 ("ត្រូវបានដោះស្រាយរួចរាល់ហើយ")។ ចម្លើយសារភាពនៅ ស-២១ របស់ សាន់ ប៉ូ ឯកសារ E3/1548 ERN (ភាសាខ្មែរ) 00174132 ("បង វ៉ាន់")។

[១០៣៩] ប្រតិចារឹក ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៥៨-៥៩, ៦៤-៦៦ (ដែលបញ្ជាក់ផងដែរថា ជាលើកទីមួយដែលគាត់បានឃើញចំណាររបស់ នួន ជា នៅលើចម្លើយសារភាពនៃមន្ទីរ ស-២១ នៅក្នុងឆ្នាំ ១៩៩៩)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៣-៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៤២។

រាយការណ៍ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស រួមទាំង នួន ជា ផងដែរ[១០៤០]។ កាំង ហ្គេកអ៊ាវ បានផ្តល់សក្ខីកម្មថា នៅមុនពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានបញ្ជាឲ្យគាត់ "កម្ទេច" (មានន័យថា សម្លាប់)[១០៤១] អ្នកជាប់ឃុំឃាំងទាំងអស់ដែលនៅសេសសល់នៅមន្ទីរស-២១។ នៅពេលនោះ អ្នកជាប់ឃុំទាំងអស់ដែលកំពុងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ មានប្រហែល ៥០០ នាក់[១០៤២]។

៣៨៦. អង្គជំនុំជម្រះសូមរម្លឹកថា ការចោទប្រកាន់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា ចំពោះប្រតិបត្តិការនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានបំបែកចេញពីសំណុំរឿង ០០២/០១ ហើយនឹងត្រូវយកមកពិចារណានៅក្នុងកិច្ចដំណើរការនីតិវិធីនៅថ្ងៃខាងមុខ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងមិនធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងចំណុចនេះនៅក្នុងសាលក្រមនេះទេ។

## ៧.៧ សេចក្តីសន្និដ្ឋាន

៣៨៧. ទោះបីនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ថាតើគាត់ជាសមាជិកគណៈកម្មាធិការ-យោធាក៏ដោយ ក៏ការពាក់ព័ន្ធរបស់ នួន ជា ក្នុងកិច្ចការយោធា និងសន្តិសុខ មានភាពទាក់ទងគ្នាដោយស្វ័យប្រវត្តិទៅនឹងអំណាចដ៏យូរឆ្នាំរបស់គាត់នៅក្នុងបក្ស។ នួន ជា បានចូលរួមយ៉ាងសកម្ម

---

[១០៤០] ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៥៤-៥៨ (បានគូសបញ្ជាក់ថា នួន ជា បានបញ្ជាឲ្យសម្លាប់ជនបរទេស)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ២-៤, ១៤-១៦។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/867 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ERN (ជាភាសាខ្មែរ) 00017024 (គូសបញ្ជាក់ថា ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួនម្នាក់ នឹងត្រូវបញ្ជូនទៅ ស-២១)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ឯកសារ E3/181 (គូសបញ្ជាក់ថា ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួនពីរនាក់នោះ ត្រូវបានស្នើឲ្យបញ្ជូនទៅ ស-២១)។ *សូមមើលផងដែរ* ឧទាហរណ៍ បញ្ជីអ្នកទោសនៅ ស-២១ ដែលស្ថិតក្នុងប្រភេទជាជនបរទេស ឯកសារ E3/2195។

[១០៤១] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/453 ទំព័រ ៣ ERN (ជាភាសាខ្មែរ) 00146569-00146570។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ ឯកសារ E3/449 ទំព័រ ៧-៨ ERN (ជាភាសាខ្មែរ) 00158841-00158842។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២០ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ១៤-១៦។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៤។ សៀវភៅ និពន្ធដោយ S. HEDER: *Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge* ឯកសារ E3/48 ឆ្នាំ ២០០៤ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00742609-00742610។

[១០៤២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៨-១០។ ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ២-៤។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (សាក្សី កាំង ហ្គេកអ៊ាវ) ទំព័រ ៧១-៧២។

ក្នុងប្រតិបត្តិការរបស់កងទ័ពបដិវត្តន៍កម្ពុជា ជាពិសេសពាក់ព័ន្ធនឹងសង្គ្រាមប្រឆាំងនឹងវៀតណាម គាត់បានទទួលរបាយការណ៍ជាប្រចាំ និងបានផ្តល់ការណែនាំពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ទាំងដោយផ្ទាល់ ឬ តាមរយៈសេចក្តីសម្រេចរបស់បក្ស។ តួនាទីរបស់ នួន ជា ពាក់ព័ន្ធនឹងឃោសនាការ និងអប់រំមានលក្ខណៈទូលំទូលាយ រួមបញ្ចូលទាំងផ្នែកវិន័យរបស់បក្ស និងកិច្ចការសន្តិសុខផ្ទៃក្នុង ព្រមទាំងសភាពការណ៍ខ្មាំងជាទូទៅ និងការគាំទ្រឲ្យវែកមុខ និងកំចាត់ខ្មាំងផងដែរ។

៣៤៨. ដោយសារមានតួនាទីខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ទទួលខុសត្រូវលើសកម្មភាពទាំងអស់របស់បក្ស ដែលលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ជូនគាត់ជាផ្លូវការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមយោបល់របស់អ្នកជំនាញ David CHANDLER និង Philip SHORT ថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស។ ក្នុងឋានៈជាអនុលេខាបក្ស ការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំងកិច្ចការយោធាថែមទៀតផងដែរ[១០៤៣]។ សម្រាប់ហេតុផលទាំងអស់នេះហើយ អង្គជំនុំជម្រះយល់ឃើញថា នួន ជា មានតួនាទី និងបានអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនដើម្បីបង្កើត និងអនុវត្តនូវគោលនយោបាយ និងសេចក្តីសម្រេចរបស់បក្សកុម្មុយ-នីស្តកម្ពុជា ។

[១០៤៣] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ២៧-២៨ (គូសបញ្ជាក់ថា នួន ជា សកម្មក្នុងវិស័យជាច្រើននៅក្នុងរបបនោះ រួមទាំងកិច្ចការយោធាផង)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ២៧-២៨។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ៤៥, ៤៨-៥០ (គូសបញ្ជាក់ថា ប៉ុល ពត និង នួន ជា ចែករំលែកការទទួលខុសត្រូវគ្នា នៅគ្រប់ផ្នែកនៃការងារបក្ស) ទំព័រ ៥៦-៥៨, ៥៩-៦១ (គូសបញ្ជាក់ថា ទោះបី នួន ជា មិនមែនជាផ្នែកមួយនៃគណៈកម្មាធិការយោធាក៏ដោយ ក៏បក្សគ្រប់គ្រងយោធាផងដែរ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ២៥-២៧។ សូមមើលផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២ ។

## ៨. តួនាទី និងមុខងាររបស់ ខៀវ សំផន

៣៤៩. យោងតាមដីកាដំណោះស្រាយ ខៀវ សំផន គឺជាសមាជិកដ៏សំខាន់មួយរូបនៃមជ្ឈិមបក្ស។ ការទទួលខុសត្រូវរបស់មជ្ឈិមបក្សរួមមានតួនាទីនៅមន្ទីរ ៨៧០ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គណៈប្រធានរដ្ឋ និងក្រសួងពាណិជ្ជកម្ម[១០៤៤]។

៣៥០. នៅពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដី ខៀវ សំផន បានធ្វើសេចក្ដីថ្លែងបើក[១០៤៥]។ ខៀវ សំផន បានឆ្លើយសំណួរជាបន្តបន្ទាប់ទាក់ទិននឹងអត្តសញ្ញាណ និងសាវតាររបស់គាត់ ព្រមទាំងបានបញ្ចេញយោបល់ទៅលើកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយ តាមរយៈការអានសេចក្ដីថ្លែងការណ៍ដែលបានរៀបចំទុកជាមុន[១០៤៦]។ ខៀវ សំផន ក៏បានឆ្លើយតបដោយត្រួសៗទៅនឹងការចោទសួររបស់អង្គជំនុំជម្រះអំពីឯកសារជាក់លាក់នានានៅក្នុងសំណុំរឿង[១០៤៧]។ បន្ទាប់មកទៀត ខៀវ សំផន បានសម្រេចចិត្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប និងបដិសេធមិនឆ្លើយទៅនឹងការចោទសួរទាំងឡាយ ប៉ុន្តែ គាត់បានបញ្ជាក់ថា គាត់នឹងឆ្លើយសំណួរទាំងឡាយ ក្រោយពីការបង្ហាញភ័ស្តុតាងទាំងអស់ពីសំណាក់សហព្រះរាជអាជ្ញា[១០៤៨]។ នៅខែ ឧសភា និង ខែ មិថុនា ឆ្នាំ ២០១៣ ខៀវ សំផន បានឆ្លើយទៅនឹងសំណួរមួយចំនួនពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណី[១០៤៩]។ បន្តិចក្រោយមក ខៀវ សំផន ជម្រាបទៅអង្គជំនុំជម្រះថាគាត់អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបជាថ្មីម្ដងទៀត[១០៥០]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ខៀវ សំផន បានធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយនៅចំពោះមុខអង្គជំនុំជម្រះ[១០៥១] ។

---

[១០៤៤] តួនាទី និងមុខងាររបស់ ខៀវ សំផន ត្រូវបានពិភាក្សានៅក្នុងកថាខណ្ឌ ១១៣១-១១៥២ នៃដីកាដំណោះស្រាយ។ លើសពីនេះទៀត កថាខណ្ឌ ១៥៣៦-១៥៣៧ ពាក់ព័ន្ធទៅនឹងការចូលរួមរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម។

[១០៤៥] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦-១៣។

[១០៤៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤២-៦៥។

[១០៤៧] ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ខៀវ សំផន) ទំព័រ ៤២-៤៣, ៤៦-៤៧,៥១, ៥៤-៥៥, ៦៣ ។

[១០៤៨] ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ខៀវ សំផន) ទំព័រ ៦៣។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២ (ខៀវ សំផន) ទំព័រ ៥៥-៥៦។

[១០៤៩] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៥-១៨, ២០-២១, ៤១, ៦៣-៦៥ ។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៤-១៥, ៦៩-៧០ ។ ប្រតិចារឹក ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ២០-២១, ៥៣-៥៥, ៨៧-៨៨។

[១០៥០] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ២៩-៣១។

[១០៥១] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៥២-៥៥។

# ៨.១ ព័ត៌មានអំពីសាវតារ និងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ

## ៨.១.១ ជីវិតកុមារភាព និងវិជ្ជាជីវៈ

៣៥១. ខៀវ សំផន ហៅ “ហែម” ឬ “ណាន” កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ នៅឃុំ ចេក ឬរំចេក ស្រុករំដួល ខេត្តស្វាយរៀង[១០៥២] ។ ខៀវ សំផន រៀននៅសាលាបឋមសិក្សាក្នុងខេត្ត កំពង់ចាម រួចទៅរៀនបន្តនៅអនុវិទ្យាល័យព្រះសីហនុ ដែលស្ថិតនៅក្នុងខេត្តកំពង់ចាមដដែល។ នៅទីនោះ ខៀវ សំផន បានជួប ប៉ុល ពត (ដែលកាលនោះមានឈ្មោះថា សាឡុត ស) ជាលើកទី មួយ[១០៥៣]។ ក្រោយពីបញ្ចប់ការសិក្សានៅអនុវិទ្យាល័យព្រះសីហនុ ខៀវ សំផន បានមករៀនបន្តនៅ វិទ្យាល័យស៊ីសុវត្ថិ[១០៥៤] ។ ក្រោយពីរៀនចប់នៅវិទ្យាល័យនេះនៅឆ្នាំ ១៩៥១ ខៀវ សំផន បានចាប់

---

[១០៥២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤២-៤៣ (ដោយទទួលស្គាល់ការប្រើឈ្មោះ “ហែម” និង “ណាន” និង ថ្លែងថាឈ្មោះផ្លូវការនៃភូមិកំណើតរបស់គាត់គឺ “ភូមិចេក” ឬ “ភូមិរំចេក”)។ កំណត់ហេតុនៃការ សួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00156612 (ដោយ ហៅឈ្មោះភូមិកំណើតរបស់ ខៀវ សំផន ថាភូមិរំចេក)។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/579 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00424225 (ដោយដាក់ថ្ងៃខែឆ្នាំកំណើត របស់ ខៀវ សំផន ២៧ ខែ សីហា ឆ្នាំ ១៩៣១ និង ទីកន្លែងកំណើត ខេត្តស្វាយរៀង)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២(កាំង ហ្គេកអ៊ាវ)ទំព័រ៣៩-៤០ (ដោយបញ្ជាក់ថា “ហែម” គឺជាឈ្មោះបដិវត្តរបស់ ខៀវ សំផន)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៧២-៧៤ (ដោយបញ្ជាក់ថា ខៀវ សំផន ក៏មានឈ្មោះ មួយទៀតដែរគឺ ឈ្មោះ “ហែម”)។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៣២-៣៣ (ដោយបញ្ជាក់អំពីការប្រើឈ្មោះ “ហែម”)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន ឯកសារ E3/58 ចុះថ្ងៃ ទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00239937 (ដោយថ្លែងថា ខៀវ សំផន បានចុះហត្ថលេខា លើឯកសារ ហើយដាក់ឈ្មោះថា “ហែម”) ។

[១០៥៣] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៥។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/713 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៧ ERN 00177979។ *សូមមើលផងដែរ* សៀវភៅ និពន្ធ ដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២០៩-២១០ ERN (ភាសាខ្មែរ) 00862474-00862475។ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ៣១, ៣៣-៣៤ ERN (ភាសាអង់គ្លេស) 00396223, 00396225។

[១០៥៤] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៥. *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ D. Chandler៖ *បងទីមួយ* ឯកសារ E3/17 ទំព័រ ២១ ERN (ភាសាអង់គ្លេស) 00392935។ សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២០៩-២១០ ERN (ភាសាខ្មែរ) 00862474-00862475។

ផ្តើមសិក្សាច្បាប់នៅទីក្រុងភ្នំពេញ[១០៥៥]។ នៅឆ្នាំ ១៩៥៣ ក្រោយពីបានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលកម្ពុជា ខៀវ សំផន បានទៅប្រទេសបារាំងដើម្បីសិក្សាច្បាប់ និងសេដ្ឋកិច្ច[១០៥៦]។

៣៩២. ក្រោយពេលទៅដល់ទីក្រុងប៉ារីសបានពីរបីខែ ខៀវ សំផន បានចូលក្នុង"ក្រុមម៉ាក្សនិយម" ដែលបង្កើតឡើង និងមានការចូលរួមជាទៀងទាត់ដោយនិស្សិតខ្មែរនៅប្រទេសបារាំង ក្នុងនោះរួមមាន អៀង សារី, សាឡុត ស, អៀង ធីរិទ្ធ និង សុន សេន[១០៥៧] ។ មួយរយៈពេលខ្លីក្រោយមក ខៀវ សំផន ចាកចេញពីទីក្រុងប៉ារីសឆ្ពោះទៅកាន់ទីក្រុង Montpellier ដែលនៅទីនោះ ខៀវ សំផន បានចូលរៀនមុខវិជ្ជាច្បាប់ និងសេដ្ឋកិច្ច[១០៥៨]។ ខៀវ សំផន បានបន្តចូលរួមសកម្មភាពនានារបស់ក្រុមម៉ាក្សនិយមដោយចូលរួមដើរកំសាន្តជាមួយសមាជិកដទៃទៀតនៅក្នុងវិសមកាលរដូវក្តៅ[១០៥៩]។

---

[១០៥៥] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៩។ *សូមមើលផងដែរ* កំណត់ហេតុជីវប្រវត្តិ ដោយ S. Sher ឯកសារ E3/110 មិនមានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00702682។

[១០៥៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៥, ៥០ ។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/579 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00424225។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២១៤-២១៥ ERN (ភាសាខ្មែរ) 00862479-00862480។

[១០៥៧] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៥៦ ។ បទសម្ភាសន៍របស់ Elizabeth Becker ជាមួយ អៀង ធីរិទ្ធ ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ៥-៧, ១២-១៣ ERN (ភាសាខ្មែរ) 00741087-00741089, 00741094-00741095 ។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ៧២-៧៦, ៨១-៨២ ERN (ភាសាខ្មែរ) 00232070-00232074, 00232079-00232080។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ៣-៤ (ដោយលើកមកសំអាងនូវឯកសារភាពយន្តរបស់លោក D. Aronowitsch និង S. Lindberg ដែលមានចំណងជើងថា៖ Facing Genocide - Khieu Samphan and Pol Pot, E109/2.3R, 2010)។ ប៉ុន្តែ សាឡុត ស បានចាកចេញពីប្រទេសបារាំងក្នុងឆ្នាំ១៩៥២ មុនពេល ខៀវ សំផន មកដល់។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៩។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ ឯកសារ E3/713 ចុះ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៧ ERN 00177979។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍* ឯកសារ E3/1593 ទំព័រ xv ERN (ភាសាអង់គ្លេស) 00678484។

[១០៥៨] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥០ ។ *សូមមើលផងដែរ* កំណត់ហេតុជីវប្រវត្តិរបស់ Sacha Sher ឯកសារ E3/110 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00702682-00702683។

[១០៥៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥០។ *សូមមើលផងដែរ* កំណត់ហេតុជីវប្រវត្តិរបស់ S. Scher ឯកសារ E3/110 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00702682-83។

៣៩៣. នៅឆ្នាំ ១៩៥៦ ខៀវ សំផន ត្រឡប់មកកាន់ទីក្រុងប៉ារីស ដើម្បីបន្តការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ច[១០៦០]។ ខៀវ សំផន ចាប់ផ្ដើមចូលរួមប្រជុំជាទៀងទាត់នៅក្នុងក្រុមម៉ាក្សនិយមនេះ ហើយបានក្លាយទៅជាមេដឹកនាំក្រុមនៅពេល អៀង សារី ចាកចេញទៅ[១០៦១]។ ខៀវ សំផន ក៏ដូចជាសមាជិកដទៃទៀតដែរ បានចូលបក្សកុម្មុយនីស្តបារាំង[១០៦២]។ ខៀវ សំផន ក៏កាន់តួនាទីជាមេដឹកនាំនៃសហភាពនិស្សិតខ្មែរ (‘Union des Étudiants Khmers’ ឬ ‘UEK’)[១០៦៣] ដែលបង្កើតឡើងដោយ “ក្រុមនិស្សិតចម្រើន” (ដូចដែលសាក្សី សួង ស៊ីគឿន ជាអតីតសមាជិកនៃសហភាពនិស្សិតខ្មែរ បានថ្លែងរួចមកហើយ) ក្រោមឥទ្ធិពលនៃបក្សកុម្មុយនីស្តបារាំង[១០៦៤]។

---

[១០៦០] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥០. *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ១២០-១២១ ERN (ភាសាអង់គ្លេស) 00396312-00396313។

[១០៦១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង) ទំព័រ ៦១-៦២ (ដកស្រង សៀវភៅនិពន្ធដោយ អុង ថុង ហឿង៖ *ត្រឡប់មើលក្រោយវិញនៃរឿងដ៏សែនខ្លោចផ្សាមួយ* ឯកសារ E3/1713)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៥៦។ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ១២០ ERN (ភាសាអង់គ្លេស) 00396312។

[១០៦២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥១-៥២, ទំព័រ ៦២។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣០, ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៧-៣៨ ។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៣៨-៣៩ 34 ERN (ភាសាខ្មែរ) 00103827 (ដោយបានទទួលស្គាល់ថាគាត់បានចូលបក្សកុម្មុយនីស្តបារាំង ប៉ុន្តែបានអះអាងថា គាត់មិនបានធ្វើកាតសមាជិកបក្សសាថ្មីឡើយ បន្ទាប់ពីប័ណ្ណសម្គាល់ខ្លួនរបស់គាត់អស់សុពលភាពក្រោយឆ្នាំ១៩៥៧)។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍* ឯកសារ E3/1593ទំព័រ xv ERN (ភាសាអង់គ្លេស) 00678484។

[១០៦៣] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philip JULLIAN-GAUFRES) ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៦៣-៦៤។

[១០៦៤] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៥៨-៥៩. *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អុង ថុង ហឿង ឯកសារ E3/97 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00270684-00270686។ សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២១៤-២១៦ ERN (ភាសាខ្មែរ) 00862479-00862481 (ដោយហៅស្ថាបនិកសហភាពនិស្សិតខ្មែរថាជា “និស្សិតចម្រើន” ហើយកត់សម្គាល់ថា សហភាពនិស្សិតខ្មែរមាន “តំណាង” ម្នាក់ “នៅក្នុងបក្សកុម្មុយនីស្តបារាំង”)។ សហភាពនិស្សិតខ្មែរជំនួសសមាគមនិស្សិតខ្មែរ (‘Association des Étudiants Khmers’ ឬ ‘AEK’), ដែលត្រូវបានហាមឃាត់ ឬ

៣៩៤. នៅឆ្នាំ ១៩៥៩ ខៀវ សំផន បានឡើងការពារនិក្ខេបបទថ្នាក់បណ្ឌិត ដែលមានចំណងជើងថា: 'L'Economie du Cambodge et ses Problèmes d'Industrialisation' ("សេដ្ឋកិច្ចកម្ពុជា និង បញ្ហាឧស្សាហូបនីយកម្ម") នៅសាកលវិទ្យាល័យប៉ារីស[១០៦៥]។ នៅក្នុងនិក្ខេបបទនេះ ខៀវ សំផន បានចាត់ទុកសេដ្ឋកិច្ចកម្ពុជាថា "ដើរថយក្រោយ" និង "មិនទាន់លូតលាស់" ដែលមួយផ្នែកបណ្តាលមកពី "សមាហរណកម្មអន្តរជាតិ" និងបានស្នើឲ្យមានការកែទម្រង់ជាដុំកំភួនផ្នែករចនាសម្ព័ន្ធរបស់រដ្ឋ (ដូចជា ឯកសិទ្ធិរបស់រដ្ឋទៅលើពាណិជ្ជកម្មក្រៅប្រទេស ការបន្ថយតម្លៃថ្លៃឈ្នួលដី និងប្រព័ន្ធក្រេឌីតសម្រាប់វិស័យកសិកម្ម) ដែលមានបំណងលើកតម្កើងប្រជាជាតិមួយឲ្យមានស្វ័យ-ម្ចាស់ការ[១០៦៦]។ ខៀវ សំផន បានសរសេរថា វាជាការចាំបាច់ក្នុងការបញ្ឈប់សកម្មភាពគ្មានផលប្រយោជន៍របស់ម្ចាស់ដី អ្នកលក់រាយ និងអ្នកចងការប្រាក់មានអត្រាការប្រាក់ខ្ពស់ និង "លើកទឹកចិត្តពួកគាត់ឲ្យចូលរួមក្នុងផលិតកម្ម" ព្រមទាំង "ផ្ទេរមូលធនពីផ្នែកពាណិជ្ជកម្មដែលសកម្មហួសហេតុ មកផ្នែកដែលមានការផលិតផ្ទាល់ច្រើនជាង"[១០៦៧]។ ខៀវ សំផន ក៏បានលើកឡើងផងដែរថា "ការចាត់តាំងកម្លាំងកសិករប្រកបដោយរបៀបជាក្រុម និងជាសហករណ៍ នឹងពង្រីកប្រសិទ្ធភាពនៃការផលិត លើស ១០ ដង និងធ្វើឲ្យមានការរានដីថ្មី ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធបញ្ចេញបញ្ចូលទឹក"[១០៦៨]។

---

រំសាយនៅក្នុងឆ្នាំ១៩៥២ ឬ ឆ្នាំ១៩៥៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ម៉ុម (THIOUNN Mumm) ឯកសារ E3/5304 ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ២-៥ ERN (ភាសាខ្មែរ) 00347079-00347082។ សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ទំព័រ ២១២-២១៣ ERN (ភាសាខ្មែរ) 00862477-00862478។

[១០៦៥] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥១។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន៖ សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម (បកប្រែដោយ Laura Summers) ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩ ទំព័រ ២១ ERN (ភាសាអង់គ្លេស) 00750554។

[១០៦៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥១។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន៖ សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម (បកប្រែដោយ Laura Summers) ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩ ទំព័រ ៤៩-៥១, ៥៧-៥៨, ៧៥, ១០១-១១០, ១៤៣-១៤៨ ERN (ភាសាខ្មែរ) 00767341-00767343, 00767349-00767350, 00767367, 00767393-00767402, 00767435-00767440។

[១០៦៧] និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន៖ សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម (បកប្រែដោយ Laura Summers) ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩ ទំព័រ ៩៩-១០២ ERN (ភាសាខ្មែរ) 00767391-00767394។

[១០៦៨] និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន៖ សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩ ទំព័រ ១៥១-១៥២ ERN (ភាសាខ្មែរ) 00767443-00767444។

៣៩៥. ទោះជាយ៉ាងនេះក្តី និក្ខេបបទបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃឧស្សាហូបនីយកម្ម និង បច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ហើយមិនបានគាំទ្រដល់ការលុបបំបាត់រូបិយវត្ថុ ឬ កម្មសិទ្ធិឯកជនឡើយ[១០៦៩]។ អង្គជំនុំជម្រះយល់ស្របជាមួយអ្នកជំនាញ Philip SHORT ថា ផ្នែក មួយចំនួននៃគំនិតដែលសរសេរនៅក្នុងនិក្ខេបបទរបស់ ខៀវ សំផន បង្ហាញជាមុននូវទិដ្ឋភាពនៃ មនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាក៏ពិតមែន ប៉ុន្តែវាមិនមែនជា "ប្លង់លម្អិត" សម្រាប់ គោលនយោបាយដែលចុងបញ្ចប់ត្រូវបានអនុម័ត នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនោះ ឡើយ[១០៧០]។

៣៩៦. មិនយូរប៉ុន្មានក្រោយពីការវិលត្រឡប់មកប្រទេសកម្ពុជាវិញ ខៀវ សំផន បានធ្វើជាចាង-ហ្វាងកាសែតជាភាសាបារាំងមួយ ដែលមានឈ្មោះថា 'L'Observateur'[១០៧១]។ ខៀវ សំផន បាន បដិសេធថា កាសែតនោះមិនមែនជាកាសែតកុម្មុយនីស្តទេ ប៉ុន្តែ ច្រើនលើកច្រើនសា កាសែតនេះ ច្រើនតែរិះគន់ដល់រដ្ឋាភិបាលសម្តេច នរោត្តម សីហនុ។ ចំណែកឯអ្នកគាំទ្រផ្នែកហិរញ្ញវត្ថុដ៏សំខាន់ មួយចំនួន (រួមទាំង អៀង ធីរិទ្ធ) ផង បានចងសម្ព័ន្ធភាពជាមួយក្រុមចលនាកុម្មុយនីស្តនៅក្នុង ប្រទេសកម្ពុជា[១០៧២]។ ជាលទ្ធផល ខៀវ សំផន ត្រូវបានអាជ្ញាធរតាមឃ្លាំមើល និងយាយី។ មាន

[១០៦៩] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤២-៤៣។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥១-៥២។ និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន៖ សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហា ឧស្សាហូបនីយកម្ម (បកប្រែដោយ Laura Summers) ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩។

[១០៧០] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤០-៤១ ។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៣-៣៥។

[១០៧១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤១-៤២។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និង គោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧ ERN (ភាសាខ្មែរ) 00103811។ បទសម្ភាសន៍របស់ Steve Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤០-៤១ ERN (ភាសាខ្មែរ) 00062491-00062492។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣៨-៣៩។

[១០៧២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥២-៥៤, ៥៤-៥៥។ ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤១-៤២។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និង គោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧ ERN (ភាសាខ្មែរ) 00103811។ បទសម្ភាសន៍របស់ Elizabeth Becker ជាមួយ អៀង ធីរិទ្ធ ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ២៦-២៨ ERN (ភាសាខ្មែរ) 00741108-00741110 ។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ

ករណីមួយនោះ ខៀវ សំផន ត្រូវបានវាយលោភបំពាននៅតាមផ្លូវផ្ទាល់នៅក្រៅការិយាល័យរបស់គាត់ ពីសំណាក់មនុស្សមួយក្រុមដែលប្រហែលជាភ្នាក់ងារប៉ូលិសសម្ងាត់[១០៧៣]។នៅឆ្នាំ ១៩៦០ ខៀវ សំផន ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ដោយគ្មានការចោទប្រកាន់ អស់រយៈពេលជាងមួយខែ ហើយ កាសែត 'L'Observateur' នោះក៏ត្រូវបានបិទ[១០៧៤]។

៣៥៧. ក្រោយពីបិទកាសែត 'L'Observateur' ខៀវ សំផន បានចូលរួមជាមួយគណបក្ស "សង្គមរាស្ត្រនិយម" ដែលជាគណបក្សនយោបាយមួយបង្កើតឡើងដោយសម្តេច នរោត្តម សីហនុ[១០៧៥]។ នៅឆ្នាំ ១៩៦២ ខៀវ សំផន ត្រូវបានជ្រើសរើសឱ្យបំពេញមុខងារនៅក្នុងរដ្ឋសភា តាមរយៈការយល់ព្រមផ្ទាល់ពីសម្តេច នរោត្តម សីហនុ និងទទួលបានការតែងតាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម[១០៧៦]។ ខៀវ សំផន បានលើកឡើងថា ការយល់ព្រម និងការតែងតាំងនេះគឺជាការប៉ុនប៉ងរបស់សម្តេច នរោត្តម សីហនុ ក្នុងការបញ្ចុះបញ្ចូលឱ្យគាត់ចូលខាងរដ្ឋាភិបាល ហើយបើនិយាយឱ្យកាន់តែទូលាយទៅទៀតនោះ គឺដើម្បីយកចិត្តបណ្តារដ្ឋដែលកាន់

---

E3/20 ទំព័រ ១១៧-១១៩ ERN (ភាសាខ្មែរ) 00232115-00232117។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៨០-៨១។

[១០៧៣] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥២, ៥៣-៥៥។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/581 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00424229-00424230។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/582 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00424231។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២១-១២២ ERN (ភាសាខ្មែរ) 00232119-00232119។

[១០៧៤] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៤-៥៥។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ឆ្នាំ ១៩៧២ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00711436។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២១-១២២ ERN (ភាសាខ្មែរ) 00232119-00232119។

[១០៧៥] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៧-៥៨។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/581 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00424229-00424230។

[១០៧៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៧-៥៨។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៩ ERN (ភាសាខ្មែរ) 00103812។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/579 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00424225។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២៩-១៣០ ERN (ភាសាខ្មែរ) 00232127-00232128។

លទ្ធិកុម្មុយនីស្ត[១០៧៧]។ នៅក្នុងកម្រិតណាមួយនោះគឺថាសម្ដេច នរោត្តម សីហនុ មានបំណងប្រើប្រាស់ឯកទេសផ្នែកសេដ្ឋកិច្ចរបស់ ខៀវ សំផន[១០៧៨]។ នៅក្នុងតួនាទីថ្មីរបស់ខ្លួន ខៀវ សំផន ក៏ចាប់ផ្ដើមអនុវត្តការកែទម្រង់សេដ្ឋកិច្ច[១០៧៩]។

៣៥៨. នៅខែ មីនា ឆ្នាំ ១៩៦៣ ក្រោយពីមានបាតុកម្មនិស្សិតនៅខេត្តសៀមរាប សម្ដេច នរោត្តម សីហនុ ដែលស្ដីបន្ទោសទៅលើជនកុម្មុយនីស្តថាជាអ្នករៀបចំកុបកម្មទាំងនោះ ក៏បានចេញផ្សាយបញ្ជីឈ្មោះមនុស្សចំនួន ៣៤ នាក់ដែលគេស្គាល់ ឬសង្ស័យថាជាអ្នកឆ្វេងនិយម (រួមមាន ខៀវ សំផន, ប៉ុល ពត និង អៀង សារី) ហើយត្រូវបានចោទលទោសជា "ជនក្បត់ជាតិ"[១០៨០]។ យ៉ាងណាក៏ដោយ ខៀវ សំផន នៅតែរក្សាបាននូវតំណែងក្នុងគណៈរដ្ឋមន្ត្រី រហូតដល់ពេលដែលគាត់ត្រូវបានបង្ខំឲ្យលាលែងចេញពីតំណែងនៅពាក់កណ្ដាលឆ្នាំ ១៩៦៣[១០៨១]។

---

[១០៧៧] បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/581 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00424230។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២៩-១៣០ ERN (ភាសាខ្មែរ) 00232127-00232128។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៦ ERN (ភាសាខ្មែរ) 00191351។

[១០៧៨] សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២៩-១៣០ ERN (ភាសាខ្មែរ) 00232127-00232128។

[១០៧៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៧-៦០។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២៩-១៣១ ERN (ភាសាខ្មែរ) 00232127-00232129។

[១០៨០] ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៤៣-៤៤។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៤២-១៤៥ ERN (ភាសាខ្មែរ) 00380376-00380379។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហរ របស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៥ ERN (ភាសាខ្មែរ) 00103815។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១៣២-១៣៤ ERN (ភាសាខ្មែរ) 00232130-00232132។

[១០៨១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៩-៦០។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៥-១៧ ERN (ភាសាខ្មែរ) 00103815-00103816។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១៣៦-១៣៧ ERN (ភាសាខ្មែរ) 00232134-00232135។ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ១៥១ ERN (ភាសាអង់គ្លេស) 00396351។ សៀវភៅនិពន្ធដោយ

៣៥៩. ខៀវ សំផន នៅរក្សាអាសនៈរដ្ឋសភារបស់គាត់ ក្រោយពេលលាលែងពីតំណែងនៅគណៈរដ្ឋមន្ត្រី ហើយត្រូវបានជាប់ឆ្នោតសាជាថ្មីទៅក្នុងរដ្ឋសភាសម្រាប់អាណត្តិទី ២ ក្នុងឆ្នាំ ១៩៦៦[១០៨២]។

៣៦០. ក្នុងនាមជាថាងហ្វាងកាសែត និងជាអ្នកតំណាងរាស្ត្រ ខៀវ សំផន មានកិត្តិស័ព្ទល្បីខ្ទរខ្ទារថា ជាបុគ្គលសុចរិត និងមានកិត្តិយស។ ខៀវ សំផន ត្រូវបានចាត់ទុកជាទូទៅថាជាបុគ្គលដែលមានមនសិការ ស្អាតស្អំ មានគោលការណ៍ច្បាស់លាស់ និងរស់នៅជាប្រជាជនសាមញ្ញ[១០៨៣]។

### ៨.១.២ សមាជិកបក្ស

៣៦១. នៅខែ មេសា ឆ្នាំ ១៩៦៧ សម្តេច នរោត្តម សីហនុ បានចោទប្រកាន់ជាសាធារណៈមកលើ ខៀវ សំផន និង សហការីឆ្វេងនិយមរបស់គាត់ចំនួនពីររូបដែលមានអាសនៈនៅក្នុងរដ្ឋសភាពោលគឺ ហ៊ូ នឹម និង ហ៊ូ យន់ ថាបានញុះញង់ឲ្យកសិករបះបោរនៅស្រុកសំឡូត ខេត្តបាត់ដំបង

---

B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍* ឯកសារ E3/1593 ទំព័រ xv ERN (ភាសាអង់គ្លេស) 00678484។

[១០៨២] បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/579 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00424225។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ឆ្នាំ ១៩៧២ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00711436។ *ខៀវសំផន៖ ចេញពីក្នុងព្រៃ* (ទស្សនាវដ្តី Time Magazine) ឯកសារ E3/4424 ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៧-៩ ERN (ភាសាខ្មែរ) S 00858673-00858675។ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ១៥១ ERN (ភាសាអង់គ្លេស) 00396351។ សៀវភៅ និពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១៣៦-១៣៨ ERN (ភាសាខ្មែរ) 00232134-00232136។ *ខៀវ សំផន និយាយការពារអំពើប្រល័យពូជសាសន៍ដោយការធ្វើមិនដឹង* (កាសែត Le Monde ដោយ Jean-Clau Pomonti) ឯកសារ E3/4603 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៤ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00002731-00002732។

[១០៨៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៤១-៤២។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៨១-៨២។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧៣-៧៤ ។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (Francois PONCHAUD) ទំព័រ ៩-១០។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philip JULLIAN-GAUFRES) ទំព័រ ៥៤-៥៦ ។ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៥-៥៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ២៩-៣០។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១២៩-១៣១ ERN (ភាសាខ្មែរ) 00232127-00232129។

ហើយថែមទាំងបានគំរាមថានឹងយកអ្នកទាំងបីនាក់ឡើងទៅតុលាការសឹកទៀតផង[១០៨៤]។ ដោយការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួន អ្នកទាំងបីក៏ចាកចេញពីភ្នំពេញ ហើយដោយមានការអញ្ជើញរបស់បក្សកុម្មុយនីស្តកម្ពុជាផងនោះ ពួកគាត់ក៏បានទៅជ្រកកោននៅទីជនបទជិតអង្គតាសោម ក្នុងខេត្តតាកែវ ក្រោមកិច្ចការពាររបស់ តាម៉ុក[១០៨៥]។

៣៦២. ក្នុងចន្លោះឆ្នាំ ១៩៦៧ និង ១៩៧០ ខៀវ សំផន បានផ្លាស់ប្តូរទីកន្លែងពីភូមិមួយទៅភូមិមួយជុំវិញខេត្តកំពង់ស្ពឺ តាកែវ និងកំពង់ឆ្នាំង ដោយមានការជួយគាំទ្រពីសំណាក់ខ្សែរយៈបង្កប់របស់បក្សកុម្មុយនីស្តកម្ពុជា[១០៨៦]។ នៅឆ្នាំ ១៩៦៩ ខៀវ សំផន នៅជាមួយ តាម៉ុក នៅមន្ទីររបស់តាម៉ុកស្ថិតនៅក្បែរភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ[១០៨៧]។ ទោះបីជា អៀង សារី និង ជនជាប់ចោទ នួន ជា បាន

[១០៨៤] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៩-៦០។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ២៣-២៤ ERN (ភាសាខ្មែរ) 00103819-00103820។ *ខៀវសំផន៖ ចេញពីក្នុងព្រៃ* (ទស្សនាវដ្តី Time Magazine) ឯកសារ E3/4424 ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) S 00858673-00858675។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ១៤០-១៤២ ERN (ភាសាខ្មែរ)00232138-00232140។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ១៦៤-១៧១ ERN (ភាសាខ្មែរ) 00380398-00380405។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00711436-00711437។

[១០៨៥] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៣១, ៣៤-៣៥។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/581 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00424230។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ២៣-២៥, ២៧, ២៩-៣០ ERN (ភាសាខ្មែរ) 00103819-00103820, 00103821, 00103822-00103823។

[១០៨៦] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ២៧, ៣១ ERN (ភាសាខ្មែរ) 00103821, 00103823។

[១០៨៧] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦០-៦១, ៦២។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៨២-៨៤។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៤០-៤១ ERN (ភាសាខ្មែរ) 00103828។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156614-00156615។

លើកឡើងថា ខៀវ សំផន នៅពេលនោះជាសមាជិកបក្សកុម្មុយនីស្តកម្ពុជារួចទៅហើយក្តី[១០៨៨] ប៉ុន្តែ ភ័ស្តុតាងរបស់ជនជាប់ចោទទាំងពីរនេះមិនស៊ីសង្វាក់គ្នា និងមិនបានធ្វើឱ្យអង្គជំនុំជម្រះមានសំអាងហេតុគ្រប់គ្រាន់លើសពីវិមតិសង្ស័យទៅលើសក្ខីកម្មរបស់ ខៀវ សំផន ដែលថា គាត់មិនបានចូលបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ ១៩៦៩ឡើយ[១០៨៩]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មានទំនាក់ទំនងក្រៅផ្លូវការជាមួយសមាជិកជាន់ខ្ពស់នៃបក្សកុម្មុនីស្តកម្ពុជាតាំងពីយូរមកហើយ ជាពិសេស គាត់ "នៅកៀក" ជាមួយគណៈកម្មាធិការបក្សក្រុងភ្នំពេញ ដែលជាអង្គការមួយ ដែលវិវត្តជាបន្តបន្ទាប់ទៅជាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុនីស្តកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ ១៩៦០[១០៩០]។

៣៦៣. ខៀវ សំផន ទទួលស្គាល់ថាគាត់បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម-បក្សកុម្មុយនីស្តកម្ពុជា ក្នុងឆ្នាំ ១៩៧១ និងជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦[១០៩១]។ សមាជិកភាពរបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការមជ្ឈិមត្រូវបានបញ្ជាក់ដោយសាក្សី និងអ្នកជំនាញនានាដែលបានផ្តល់សក្ខីកម្មនៅក្នុងពេលសវនាការ[១០៩២]។

---

[១០៨៨] បទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤០-៤១ ERN (ភាសាខ្មែរ) 00062491-00062492 (ដោយបង្ហាញថា ខៀវ សំផន បានចូលបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៥៥)។ បទសម្ភាសន៍របស់ ខែម ងុន ជាមួយ នួន ជា ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00078196 (ដោយលើកឡើងថា ខៀវ សំផន ចូលបក្សកុម្មុសនីស្តកម្ពុជាក្នុងឆ្នាំ១៩៦៣)។

[១០៨៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦២។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ខៀវ សំផន) ទំព័រ ១៦។

[១០៩០] ប្រតិចារឹក ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៧-១៨, ២០-២១។ ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ និពន្ធដោយ ខៀវ សំផន ឯកសារ E3/16 ទំព័រ ១២៣-១២៥ ERN (ភាសាខ្មែរ) 00380357-59។ *សូមមើល* ផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៤ ។

[១០៩១] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦២-៦៣។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ៨-៩ ERN (ភាសាខ្មែរ) 00156619-00156620។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៦៦-១៦៧ ERN (ភាសាខ្មែរ) 00103891។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥, ១២៧, ១៣៣-១៣៤, ១៤២។ ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២ ។

[១០៩២] *សូមមើល ឧទា.* ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៨-៣៩។ ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥១។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៣១។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៧-៥៨។ ប្រតិចារឹក ថ្ងៃ

### ៨.១.៣ ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥

៣៦៤. នៅខែ មីនា ឆ្នាំ ១៩៧០ ក្រោយពីរាជរដ្ឋាភិបាលរបស់សម្តេចត្រូវបានផ្តួលរំលំដោយ លន់ នល់ សម្តេច នរោត្តម សីហនុ បានប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា[១០៩៣]។ ប៉ុល ពត បានផ្ញើសារគាំទ្រទៅកាន់សម្តេចក្នុងនាម ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់[១០៩៤]។ នៅរយៈកាល រវាងខែ មីនា និង ខែ កញ្ញា ឆ្នាំ ១៩៧០ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ បានចាកចេញពីមូលដ្ឋាន របស់ តាម៉ុក នៅភ្នំឱរ៉ាល់ ទៅកាន់ទីស្នាក់ការកណ្តាលរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរ ស-៧១ ស្ថិតនៅជិតស្ទឹងជីនិត[១០៩៥]។ ខៀវ សំផន បានលើកឡើងថា នៅទីនោះហើយដែល គាត់បានជួប នួន ជា និង ប៉ុល ពត ជាលើកដំបូង[១០៩៦]។ ប៉ុន្តែ នួន ជា បានផ្តល់សក្ខីកម្មថា គាត់ បានជួប ខៀវ សំផន ខណៈដែល ខៀវ សំផន នៅភ្នំឱរ៉ាល់នៅឡើយ ហើយទោះបីជាខ្លួន មិនបាន ស្គាល់អត្តសញ្ញាណពិតប្រាកដរបស់ ប៉ុល ពត រហូតដល់ឆ្នាំ ១៩៧០ ក្តី ក៏ ខៀវ សំផន ស្គាល់ ប៉ុល ពត តាំងពីពេលរៀននៅសាលាជាមួយគ្នានៅកំពង់ចាម មកម្ល៉េះ[១០៩៧]។

៣៦៥. នៅឆ្នាំ ១៩៧០ ខៀវ សំផន មានតួនាទីជា អនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជា

---

ទី ២៦ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ២-៣។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧៧-៧៨, ៨៤-៨៥។

[១០៩៣] *សូមមើល* ផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្រ្ត កថាខណ្ឌ ៩៧ ។

[១០៩៤] *សូមមើល* ផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្រ្ត កថាខណ្ឌ ៩៧ ។

[១០៩៥] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្រ្តកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៤៣-៤៤ ERN (ភាសាខ្មែរ) 00103829-00103830 (ដោយបង្ហាញថា ពួកគាត់បានចាកចេញពីភ្នំឱរ៉ាល់ "ក្រោយពីរដ្ឋប្រហារ ខែមីនា ឆ្នាំ១៩៧០ ភ្លាម")។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156614-00156615 (ដោយថ្លែងថាពួកគាត់ទៅតំបន់ស្ទឹង ជីនិត "ប្រហែលខែកញ្ញា ឆ្នាំ១៩៧០") ។ *សូមមើលផងដែរ* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១១ ជើង ទំព័រ៦៤៩ ។

[១០៩៦] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្រ្តកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៤៣-៤៤ ERN (ភាសាខ្មែរ) 00103829-00103830។

[១០៩៧] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ៣៤។ បទសម្ភាសន៍របស់វិទ្យុអាស៊ីសេរីជាមួយ ខៀវ សំផន ឯកសារ E3/713 ចុះខែ ធ្នូ ឆ្នាំ ២០០៧ ERN 00177979-00177980។ សូមមើលផ្នែកទី ៧ ស្តីពីតួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៩ ។ ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥១ ។

អគ្គមេបញ្ជាការកងទ័ពរំដោះប្រជាជនកម្ពុជា[១០៩៨]។ តាមពិត ខៀវ សំផន មិនមានអំណាចយោធាដោយផ្ទាល់ឡើយ ហើយ ប៉ុល ពត ឯណោះទេ ដែលទទួលបន្ទុកកងទ័ពរំដោះប្រជាជនកម្ពុជានោះ[១០៩៩]។ ខៀវ សំផន បានកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិ[១១០០]។ ទោះបីជាគាត់បានជម្រាបអង្គជំនុំជម្រះថា តួនាទីទាំងនេះគ្មានន័យអ្វីទាំងអស់ក្តី ក៏ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានដើរតួនាទី "សំខាន់ បើទុកជាមិនមែនមិនអាចខ្វះបានក្តី" ក្នុងទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងសម្តេច នរោត្តម សីហនុ[១១០១]។ ហ៊ូ នឹម និង ហ៊ូ យន់ ក៏មានឈ្មោះជារដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែរ[១១០២]។ ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់ បានក្លាយទៅជាតំណាងចលនាប្រឆាំងនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០[១១០៣]។

---

[១០៩៨] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156615។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦៥-៦៦។ ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៧៧-៧៨។

[១០៩៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦១-៦២។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ (សាឡូត បាន) ទំព័រ ៣៤-៣៥។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៤០-៤១, ៤៤។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧៥។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ១៨៦-១៨៧ ERN (ភាសាខ្មែរ) 00232184-00232185។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ប្រសិទ្ធ ឯកសារ E3/96 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ១៥-១៧ ERN (ភាសាខ្មែរ) 00348329-00348331 (ដោយថ្លែងថា ប៉ុល ពត គឺជាមេបញ្ជាការកងទ័ពពិតប្រាកដនៅមុនឆ្នាំ១៩៧៥)។

[១១០០] *សូមមើល* ផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៨ ។

[១១០១] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ៤៥-៤៦ ERN(ភាសាខ្មែរ) 00103831-00103832។ ប្រតិចារឹកថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០១១(ខៀវ សំផន) ទំព័រ ៦២-៦៣។ *សូមមើលបន្ថែម* ផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៨ ។

[១១០២] របាយការណ៍រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សមាសភាពរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅអង្គការសហប្រជាជាតិ ឯកសារ E3/28 ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៧៣ ERN (ភាសាខ្មែរ) 00290197។ ផ្នែកទី ៤ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១-៧៣៤ ។

[១១០៣] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156615។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥៤-៥៥។ សុន្ទរកថារបស់ នួន ជា ជូនចំពោះបក្សកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00224459-00224460។ ឯកសាររបស់ S. Heder៖ *ប៉ុល ពត និង ខៀវ សំផន* ឯកសារ E3/3169 ឆ្នាំ ១៩៩១ ទំព័រ ១០-១២ ERN (ភាសាខ្មែរ) 00711372-00711374។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន ហៅ

ដោយរួមគ្នាទាំងបីនាក់ ពួកគាត់ត្រូវបានគេហៅថា "ខ្មោចទាំងបី"។ នេះជាការនិយាយយោងដល់ពាក្យចចាមអារ៉ាមថាអ្នកទាំងបីបានស្លាប់ ដែលឮល្បីតៗគ្នាក្នុងអំឡុងពេលដែលពួកគាត់កំពុងលាក់ខ្លួន[១១០៤]។

៣៦៦. ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ខៀវ សំផន នៅក្នុងតំបន់ជាប់ជាមួយ ប៉ុល ពត និង នួន ជា ហើយអ្នកទាំងបីជួបគ្នា ធ្វើការជាមួយគ្នា និងបរិភោគជាមួយគ្នាជាញឹកញាប់[១១០៥]។

៣៦៧. នៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ ខៀវ សំផន បានជួយរៀបចំសម្ភារៈឃោសនារបស់រណសិរ្ស-រួបរួមជាតិកម្ពុជា និង ជួយបង្រៀនវគ្គរៀនសូត្រនយោបាយ[១១០៦]។ រវាងឆ្នាំ ១៩៧០ និង ១៩៧៥ វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជាបានផ្សាយសេចក្តីអំពាវនាវរបស់ ខៀវ សំផន (ជួនកាលមាន សំឡេង ហ៊ូ នឹម និង ហ៊ូ យន់ ផងដែរ) ដោយជំរុញឲ្យប្រជាពលរដ្ឋចូលរួម ឬគាំទ្រចលនាតស៊ូ ប្រឆាំងនឹងរបប លន់ នល់[១១០៧]។ ក្នុងខែ មករា ឆ្នាំ ១៩៧៥ មានការអំពាវនាវឲ្យប្រជាជន

---

ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00204067-00204068។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ឆ្នាំ ១៩៧២ ទំព័រ ១៥ ERN (ភាសាខ្មែរ) 00711437។

[១១០៤] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD)ទំព័រ ៨-៩។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ១៥ (Please check date again)។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ១២-១៣។

[១១០៥] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156615។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦០។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៤២-៤៣។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៤៦ ។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ២៥។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៤៧។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ (ឡុង នរិន្ទ) ទំព័រ ៧៣-៧៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00204743-00204744។

[១១០៦] ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៦៨-៦៩, ៧១-៧២។ ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គីម វុន) ទំព័រ ៥៤-៥៦ ។ ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ (គីម វុន) ទំព័រ ៦៥-៦៦។

[១១០៧] *សូមមើល ឧទា.* ទូរលេខរបស់ស្ថានទូតអាមេរិក កម្មវត្ថុ៖ របាយការណ៍ស្ថានភាពប្រទេសកម្ពុជា ឯកសារ E3/3292 ចុះខែ តុលា ឆ្នាំ ១៩៧០ ERN (ភាសាខ្មែរ) 00726578-00726579។ ទូរលេខរបស់ស្ថានទូតអាមេរិក

"ផ្តួលរំលំ និងកំចាត់" និង "បែរកាណុងកាំភ្លើងដាក់" បន "ក្បត់ លន់ នល់" វិញ[១១០៨]។ សុន្ទរកថាផ្សេងៗទៀតរបស់ ខៀវ សំផន បញ្ជាក់ថា គាត់បានដឹងអំពីប្រតិបត្តិការយោធារបស់កងទ័ពរំដោះជាតិកម្ពុជា[១១០៩]។

៣៦៨. ខៀវ សំផន អមដំណើរ ប៉ុល ពត និង នួន ជា ក្នុងដំណើរទស្សនកិច្ចតាមជនបទ និងតំបន់ "រំដោះ" របស់បក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ ១៩៧១ និង ១៩៧២[១១១០]។ នៅឆ្នាំ ១៩៧៣ ខៀវ សំផន បានទទួលសម្តេច នរោត្តម សីហនុ នៅក្នុងព្រះរាជទស្សនកិច្ចរបស់ព្រះអង្គមកកាន់កម្ពុជា[១១១១]។ មួយឆ្នាំក្រោយមក ខៀវ សំផន បានទទួលគណៈប្រតិភូរដ្ឋាភិបាលប្រជាជនបដិវត្ត

---

កម្មវត្ថុ៖ របាយការណ៍ស្ថានភាពប្រទេសកម្ពុជា ឯកសារ E3/3294 ចុះខែ វិច្ឆិកា ឆ្នាំ ១៩៧១ ERN (ភាសាខ្មែរ) 00790037។ *ខៀវ សំផន អំពាវនាវដល់ជនរួមជាតិ និង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00783131-00783134។ *ខៀវ សំផន អំពាវនាវឲ្យបង្កើនការតស៊ូប្រយុទ្ធ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/120 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700233-00700238។ *លោក ខៀវ សំផន ចេញផ្សាយសេចក្តីថ្លែងការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700267-00700269។

[១១០៨] *ប្រធានគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជាអំពាវនាវដល់ប្រជាពលរដ្ឋនៅក្នុងក្រុងភ្នំពេញ* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/488 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00973737-00973739 ។

[១១០៩] *សូមមើល ឧទា. ខៀវ សំផន អំពាវនាវដល់ជនរួមជាតិ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ មករា ឆ្នាំ ១៩៧៥) ឯកសារ E3/30 ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00783131-00783134។ *ខៀវ សំផន អំពាវនាវឲ្យបង្កើនការតស៊ូប្រយុទ្ធ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/120 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700233-00700238។

[១១១០] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៥៤ ERN (ភាសាខ្មែរ) 00103835។ បទយកការណ៍ពិសេស ឯកសារ E3/637 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00442333។

[១១១១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥១-៥២។ ភាពយន្តឯកសាររបស់លោក D. Aronowitsch and S. Lindberg ដែលមានចំណងជើងថា: Facing Genocide - Khieu Samphan and Pol Pot E109/2.3R, 2010, 00.20.25-00.21.07 (ដោយបានពិពណ៌នាអំពី ខៀវ សំផន ជួបជាមួយព្រះអង្គម្ចាស់ សីហនុ)។ របាយការណ៍របស់ Henri Locard៖ ព្រៃសាន៖ ភូមិភាគព្រៃសាន ឯកសារ E3/3255 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00747507-00747508 (ដែលសរសេរកាលបរិច្ឆេទរបស់ព្រះអង្គម្ចាស់ សីហនុ ខែមីនា ឆ្នាំ ១៩៩៣ ប៉ុន្តែផ្អែកលើបរិបទជាក់ស្តែងជាការច្បាស់ណាស់ ថាវាគឺជាកំហុសបច្ចេកទេស ហើយកាលបរិច្ឆេទពិត

នៃសាធារណរដ្ឋវៀតណាមខាងត្បូង[១១១២]។ ខៀវ សំផន និង អៀង សារី ក៏បានដឹកនាំគណៈប្រតិភូទៅកាន់បរទេសដើម្បីស្វែងរកការគាំទ្រណសិរ្សរួបរួមជាតិកម្ពុជា និងការទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផងដែរ[១១១៣]។

៣៦៩. នៅចុងឆ្នាំ ១៩៧២ ឬ ដើមឆ្នាំ ១៩៧៣ ខៀវ សំផន បានរៀបអាពាហ៍ពិពាហ៍ជាមួយ សូ សុជាតិ ដែលជាចុងភៅនៅមន្ទីរ ស-៧១[១១១៤]។ អ្នកទាំងពីរបង្កើតបានកូនដំបូងនៅឆ្នាំ ១៩៧៤[១១១៥]។

៣៧០. នៅខែ កុម្ភៈ ឆ្នាំ ១៩៧៥ សេចក្ដីប្រកាសព័ត៌មានរបស់រណសិរ្សរួបរួមជាតិកម្ពុជាបានសរសេរថា “សមាជជាតិ” នៃរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានអះអាងថាបានប្រព្រឹត្តទៅនៅថ្ងៃទី ២៤ និង ២៥ ខែ កុម្ភៈ និងមាន ខៀវ សំផន ធ្វើជាគណៈអធិបតីនោះ បានសម្រេចថា

---

ប្រាកដគឺខែ មីនា ឆ្នាំ ១៩៧៣)។ *ខៀវ សំផន និយាយការពារអំពើប្រល័យពូជសាសន៍ដោយការធ្វើមិនដឹង* (កាសែត Le Monde ដោយ Jean-Clau Pomnti) ឯកសារ E3/4603 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៤ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00002733-00002734។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥១-៥២។.

[១១១២] *គណៈប្រតិភូរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង និងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ធ្វើដំណើរទស្សនកិច្ចពីថ្ងៃទី ២៥-២៩ ខែ ធ្នូ* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00701456-00701461។

[១១១៣] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (ស្វង ស៊ីគឿន) ទំព័រ ៧៤-៧៧។ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥០-៥១។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នឹម សែម ឯកសារ E3/43 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00357222-00357223។ *AKI ស្វាគមន៍សមាគមមិត្តភាពនិងទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/488 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00663976-00663977។ ព្រឹត្តិបត្រសារព័ត៌មានរណសិរ្សរួបរួមជាតិកម្ពុជា ឯកសារ E3/1242 ចុះថ្ងៃទី ១-២ ខែ មេសា ឆ្នាំ ១៩៧៤ ។ ព្រឹត្តិបត្រសារព័ត៌មានរណសិរ្សរួបរួមជាតិកម្ពុជា ឯកសារ E3/113 ចុះថ្ងៃទី ២-៣ ខែ មេសា ឆ្នាំ ១៩៧៤ ។ ទូរលេខស្ថានទូតអាមេរិក កម្មវត្ថុ៖ ដំណើរទស្សនៈកិច្ចរបស់ ខៀវ សំផន ឯកសារ E3/3315 ចុះខែ ឧសភា ឆ្នាំ ១៩៧៤។

[១១១៤] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៤៦, ៥០។

[១១១៥] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៣-៤ ។ ផ្នែកទី ៣ ស្ដីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៩ ។

01006611



“បនក្បត់ទាំង៧នាក់”នៃរបប លន់ នល់ ត្រូវតែសម្លាប់ចោល[១១១៦]។ ទោះបីជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះពុំបានបញ្ជាក់ថាមានកិច្ចប្រជុំបែបនេះក្តី ក៏ ខៀវ សំផន បាននិយាយយោងដល់សន្និបាតឆ្នាំ ១៩៧៥ នោះ និងសេចក្តីសម្រេចនានាដែលត្រូវបានអះអាងថាបានចេញនៅទីនោះតាមរយៈសុន្ទរកថាមួយដែល ខៀវ សំផន ធ្វើឡើងនៅឆ្នាំបន្ទាប់[១១១៧]។

៣៧១. មុនពេលភ្នំពេញដួលរលំបន្តិច ខៀវ សំផន បានផ្លាស់ទៅមន្ទីរ ប-៥ ដើម្បី “តាមដានការវាយលុកចុងក្រោយមកលើរដ្ឋធានីឲ្យបានកាន់តែជិតដល់”[១១១៨]។ ខណៈដែលកងទ័ពបក្សកុម្មុយនីស្តកម្ពុជា/រណសិរ្សរួបរួមជាតិកម្ពុជា/កងទ័ពរំដោះប្រជាជនកម្ពុជា ហ៊ុំព័ទ្ធភ្នំពេញជិតទៅហើយនោះ ខៀវ សំផន បានបន្តអំពាវនាវដល់ប្រជាជនឲ្យងើបឈរឡើងប្រឆាំងនឹងរបប លន់ នល់[១១១៩]។

៣៧២. អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ដែលជាបុគ្គលម្នាក់មានការគោរពខ្ពស់នោះ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទាញការគាំទ្រដល់ចលនាប្រឆាំង ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥។ ការទទួលយកតំណែងនានានៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា តួនាទីរបស់គាត់ក្នុងការធានាចំពោះសាធារណៈជនអំពីផែនការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ការបំពេញភារកិច្ចផ្នែកការទូតក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តួនាទីក្នុងការទាក់ទងជាមួយសម្តេចនរោត្តម សីហនុ កិច្ចការរៀបចំ និងផ្សព្វផ្សាយឯកសារឃោសនាការ និងការឯកភាពរបស់

---

[១១១៦] *លោក ខៀវ សំផន ធ្វើជាអធិបតីនៃសមាជរណសិរ្សរួបរួមជាតិកម្ពុជា ដែលបានចេញសេចក្តីប្រកាសរួមមួយ* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/488 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00663978-00663984។ អំពី “ជនក្បត់ទាំង ៧ ” *សូមមើល* ផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០ ជើងទំព័រ ៣៤៣។

[១១១៧] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៦-៦៧ (ដោយសង្ស័យថាពុំមានសន្និបាតនោះឡើយ)។ *របាយការណ៍របស់ ខៀវ សំផន* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00657438-00657440។

[១១១៨] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៦០ ERN (ភាសាខ្មែរ) 00103838។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00156614។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន) ទំព័រ ៤៦-៤៧។ *សូមមើលបន្ថែម* ផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៧។

[១១១៩] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន) ទំព័រ ៥៣។ *លោក ខៀវ សំផន អំពាវនាវឲ្យប្រជាពលរដ្ឋទីក្រុងភ្នំពេញចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី ១៤ ខែ មេសា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700275-00700278។

ខៀវ សំផន ទៅលើការតស៊ូដោយហឹង្សាប្រឆាំងនឹងរបប លន់ នល់ នៅក្នុងសុន្ទរកថានានា ដែលផ្សព្វផ្សាយជាសាធារណៈ សុទ្ធតែបានរួមចំណែកបម្រើដល់ការគាំទ្រ និងផ្តល់ភាពស្របច្បាប់ឲ្យចលនាតស៊ូដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា[១១២០]។

## ៨.២ កន្លែងស្នាក់នៅ ការធ្វើការងារ និងទីតាំងធ្វើដំណើរក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

៣៧៣. នៅឆ្នាំ ១៩៧៥ ក្រោយពីត្រឡប់មកភ្នំពេញវិញ ខៀវ សំផន ស្នាក់នៅរយៈពេលខ្លីជាមួយមេដឹកនាំបក្សកុម្មុនីស្តកម្ពុជាដទៃទៀត នៅស្ថានីយរថភ្លើងភ្នំពេញ មុនពេលផ្លាស់ទៅនៅអគារអតីតក្រសួងសេដ្ឋកិច្ចប្រហែលជា ២ សប្តាហ៍ ហើយបន្ទាប់មកបានទៅនៅវិហារព្រះកែវមរកតក្នុងព្រះបរមរាជវាំងមួយរយៈពេលខ្លី[១១២១]។ ខៀវ សំផន បានរស់នៅ និងធ្វើការនៅមន្ទីរ ក-១ អស់រយៈពេលប៉ុន្មានខែ[១១២២] មុនពេលផ្លាស់ទៅមន្ទីរ ក-៣ ដែលអមដោយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជាដូចលើកមុនៗដែរ[១១២៣]។ ក្នុងអំឡុងពេលស្នាក់នៅមន្ទីរ ក-៣ ជារឿយៗ

[១១២០] *សូមមើល* ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ២៣។

[១១២១] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥ ERN (ភាសាខ្មែរ) 00156615។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សួ សុជាតិ) ទំព័រ ៥៤-៥៦ (ដែលជាការបញ្ជាក់ថា ក្រោយពីវិលត្រឡប់មកភ្នំពេញ មុនដំបូងគាត់ស្នាក់នៅស្ថានីយរថភ្លើង រួចមកស្នាក់នៅវិហារព្រះកែវមរកត ប៉ុន្តែមិនស្នាក់នៅជាមួយខៀវ សំផន ទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ាចាម គុន ហៅ ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204069-00204070។

[១១២២] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156676-00156677។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សួ សុជាតិ) ទំព័រ ៥៥-៥៧។

[១១២៣] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន) ទំព័រ ៧២-៧៣។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ៨-៩, ១១-១៣។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿន) ទំព័រ ៦០-៦១។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៥-៣៦។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156676-00156677។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00204742-00204743។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/57 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ៤-៥ ERN (ភាសាខ្មែរ) 00287703-00287704។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ឯកសារ E3/67 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00294538។

ខៀវ សំផន ទៅលេងមន្ទីរ ក-១ ដែល ប៉ុល ពត នៅតែបន្តស្នាក់នៅទីនោះនៅឡើយ[១១២៤]។ សាក្សី សូ សុជាតិ អះអាងថា ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន និង វន វ៉េត ក៏រស់នៅ មន្ទីរ ក-៣ ដែរ ប៉ុន្តែ ក្រោយពីបានស្នាក់នៅអស់រយៈពេល ៤ ទៅ ៥ ខែ ពួកគាត់ទាំងអស់គ្នាក៏ចាកចេញអស់ទៅ[១១២៥]។ ក៏ប៉ុន្តែ សាក្សីដទៃទៀត ដែលរម្លឹកថាពួកគាត់បានឃើញ ខៀវ សំផន រស់នៅជាមួយមេដឹកនាំជាន់ខ្ពស់នៅមន្ទីរ ក-៣ នោះ ពុំបានលើកឡើងអំពីការចាកចេញដែលបានអះអាងនេះឡើយ ហើយអង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់សាក្សី សូ សុជាតិ ដែលជាសហព័ទ្ធរបស់ ខៀវ សំផន មានលក្ខណៈមិនគួរឲ្យជឿទុកចិត្តឡើយ[១១២៦]។ ជាងនេះទៅទៀត នៅក្នុងកិច្ចសម្ភាសន៍មួយកាលពីឆ្នាំ ២០០៧ ខៀវ សំផន ខ្លួនឯងក៏បានថ្លែងថា គាត់ "តែងតែរស់នៅជិតៗថ្នាក់ដឹកនាំកម្ពុជាជានិច្ច"[១១២៧]។

៣៧៤. ខៀវ សំផន បានធ្វើដំណើរទៅកាន់ប្រទេសចិន និងកូរ៉េខាងជើង ដើម្បីបំពេញទស្សនកិច្ចផ្លូវការនៅឆ្នាំ ១៩៧៥ ក្នុងគោលបំណង (យ៉ាងហោចណាស់មួយផ្នែក) ពិភាក្សាលក្ខខណ្ឌនៃការ

---

[១១២៤] ប្រតិចារឹក ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ (ស រី) ទំព័រ ១០-១១, ៧២-៧៣។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ១៥, ៨២។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៥-៣៦, ៣៧-៤០។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១៣ ។

[១១២៥] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦១-៦៣។

[១១២៦] *សូមមើល ឧទា.* ប្រតិចារឹកថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៣៩-៤០ (ដោយថ្លែងថា មន្ទីរ ក-៣ គឺជាមន្ទីររួម ដែលប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន ធ្វើការ)។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ១១-១៣ (ដែលជាការបញ្ជាក់ថាខៀវ សំផន នួន ជា និង អៀង សារី មានផ្ទះនៅមន្ទីរ ក-៣)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៥-៣៦ (ដោយថ្លែងថា ខៀវ សំផន និង នួន ជា ស្នាក់នៅ ក៣ ចំណែកឯ ប៉ុល ពត នៅមន្ទីរ ក-១)។ ប្រតិចារឹក ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៩ (ដែលបញ្ជាក់ថា ខៀវ សំផន, វន វ៉េត និង នួន ជា រស់នៅជាមួយគ្នានៅ "អគារជិតច្រាំង" ជាប់មាត់ទន្លេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/57 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00287703-00287704 (ដោយលើកឡើងថា ក៣ គឺជាកន្លែងធ្វើការរបស់ ខៀវ សំផន និង នួន ជា)។ សក្ខីកម្មរបស់ សាក្សី សូ សុជាតិ មានភាពមិនស៊ីសង្វាក់គ្នាមួយចំនួនអំពីកិច្ចការផ្ទៃក្នុង ព្រមទាំងមានការឆ្លើយពង្វាងសំណួរថែមទៀតផង ដែលអង្គជំនុំជម្រះយល់ឃើញថាវាបានកាត់បន្ថយភាពគួរឲ្យជឿទុកចិត្តជាទូទៅរបស់គាត់។ សូមមើលផ្នែកទី ៣ ស្តីពី បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៩ ។

[១១២៧] បទសម្ភាសន៍រវាងលោក ខៀវ សំផន ជាមួយវិទ្យុបារាំង France Culture ឯកសារ E289.1.1 ចុះខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00934560-00934561។

យាងវិលត្រឡប់មកភ្នំពេញវិញរបស់សម្តេច នរោត្តម សីហនុ[១១២៨]។ នៅឆ្នាំ ១៩៧៦ ខៀវ សំផន បានចូលរួមជាតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកិច្ចប្រជុំកំពូលនៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅប្រទេសស្រីលង្កា[១១២៩]។ ខៀវ សំផន ក៏បានធ្វើដំណើរទៅជនបទនៃប្រទេសកម្ពុជាដើម្បីពិនិត្យមើលការដ្ឋាននានានៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ[១១៣០]។

## ៨.៣ តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

៣៧៥. ខៀវ សំផន បានកាន់តួនាទីផ្លូវការមួយចំនួនក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ យោងតាមដីកាដំណោះស្រាយ ខៀវ សំផន មានតួនាទីជាប្រធានគណៈប្រធានរដ្ឋ ជាសមាជិកថ្នាក់ដឹកនាំម្នាក់នៃមន្ទីរ៨៧០ មានការទទួលខុសត្រូវផ្នែកពាណិជ្ជកម្ម និង (នៅក្នុងរយៈកាលនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) មានតួនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការកងទ័ពរំដោះជាតិកម្ពុជា[១១៣១]។ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ផងដែរថា ខៀវ សំផន ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុនីស្តកម្ពុជា និងមានវត្តមាន ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើនលើកផងដែរ[១១៣២]។

### ៨.៣.១ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងអគ្គមេបញ្ជាការ

៣៧៦. ក្រោយពីការដួលរលំនៃទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់សម្តេច នរោត្តម សីហនុ ក៏បានកាន់អំណាចជាផ្លូវការនៅក្នុងប្រទេសកម្ពុជា ទោះបីជា

---

[១១២៨] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ខៀវ សំផន ចេញដំណើរទៅ កូរ៉េខាងជើង ឯកសារ E3/3350 ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00740886-00740887។ *ការគាំទ្រជានិមិត្តរូបរបស់ចិនចំពោះព្រះអង្គម្ចាស់សីហនុ* (សារព័ត៌មាន The Times ដោយ David Bonavia) ឯកសារ E3/3727 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៥។ សៀវភៅនិពន្ធដោយ ណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ៤៧-៤៨ ERN (ភាសាខ្មែរ) 00191352-00191353។ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ទំព័រ ៣២៩ ERN (ភាសាអង់គ្លេស) 00396537។ សូមមើលផ្នែកទី ១៤ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៦-៧៦២ ។

[១១២៩] *សូមមើល* ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន *ជើងទំព័រ* ១១៥៤ ។

[១១៣០] *សូមមើល* ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន *ជើងទំព័រ* ១១៤៤ ។

[១១៣១] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៣៥-១១៤៦។

[១១៣២] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៣១-១១៣៤។

សម្តេច នរោត្តម សីហនុ ព្រះអង្គមិនទាន់យាងត្រឡប់មកមាតុប្រទេសរហូតដល់ខែ កញ្ញា ឆ្នាំ ១៩៧៥ ក្តី[១១៣៣]។ ខៀវ សំផន រក្សាតួនាទីរបស់ខ្លួនជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពរំដោះប្រជាជនកម្ពុជា[១១៣៤] ហើយក៏បានបន្តមុខងារការទូតជាក់លាក់របស់ខ្លួនមួយចំនួនទៀត ដូចជាជួបជាមួយគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា និងដឹកនាំគណៈប្រតិភូកម្ពុជាទៅធ្វើទស្សនកិច្ចនៅបរទេស[១១៣៥]។ ខៀវ សំផន នៅតែបន្តធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈគាំទ្រដល់កងទ័ពរំដោះប្រជាជនកម្ពុជា និងរបបថ្មី ដោយបកអាក្រាតរបប លន់ នល់ និងជំរុញឲ្យប្រជាជនកម្ពុជាទាំងអស់ខិតខំកសាងប្រទេសឡើងវិញ[១១៣៦]។

---

[១១៣៣] បដិសណ្ឋារកិច្ចទទួលស្វាគមន៍សម្តេចសីហនុ៖ សន្ទរកថាដោយលោក ខៀវ សំផន និងសម្តេច សីហនុ (ក្នុងកម្រង SWB/FE/5006/B) ឯកសារ E3/711 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) S 00743935 ។ សូមមើលបន្ថែម ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣១ ។

[១១៣៤] *"សមាជជាតិពិសេស" ជ្រើសតាំងសម្តេច សីហនុ និងសម្តេច ប៉ែន នុត* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ មេសា ឆ្នាំ ១៩៧៥) ឯកសារ E3/118 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700284-00700288។ ទូរលេខពីសម្តេច នរោត្តម សីហនុ ឯកសារ E3/1106 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៥។

[១១៣៥] *សូមមើល ឧទា. ជំនួបជាមួយសម្តេច សីហនុ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/274 ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00700116។ *ប្រតិភូដឹកនាំដោយ ខៀវ សំផន ធ្វើដំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតចិន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/119 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00681237-00681241។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ទស្សនកិច្ចរបស់លោក ខៀវ សំផន ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ឯកសារ E3/619 ចុះខែ សីហា ឆ្នាំ ១៩៧៥។ *កិច្ចប្រជុំរវាង នរោត្តម សីហនុ, ខៀវ សំផន និង គីម អ៊ីលស៊ុង* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/119 ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00681247-00681248។

[១១៣៦] *សូមមើល ឧទា. សារអបអរសាទរជ័យជម្នះ ធ្វើឡើងនាថ្ងៃទី ២១ ខែ មេសា របស់ ខៀវ សំផន តាមវិទ្យុទីក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00846160-00846164។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00172081 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គាំ កែក ឯកសារ E3/433 ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00363538-00363539 ។ *របាយ-ការណ៍របស់ ខៀវ សំផន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00657436-00657440។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៣៥-៣៦។

៣៧៧. សេចក្តីរាយការណ៍តាមវិទ្យុផ្សាយសំឡេងអះអាងថា ខៀវ សំផន ក៏ធ្វើជាគណៈអធិបតី "សមាជជាតិពិសេស" ផងដែរ ដែលធ្វើឡើងចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ដូចគ្នាទៅនឹងសមាជរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានអះអាងថាបានប្រព្រឹត្តទៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា វាពុំមានភាពច្បាស់លាស់ទេ ថាតើកិច្ចប្រជុំ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ពិតជាបានប្រព្រឹត្តឡើងមែន ឬយ៉ាងណានោះ ប៉ុន្តែកិច្ចប្រជុំនោះត្រូវបានសារព័ត៌មានអន្តរជាតិរាយការណ៍យ៉ាងទូលំទូលាយ[១១៣៧]។ សមាជជាតិលើកទីបីត្រូវគេអះអាងថាបានប្រព្រឹត្តទៅនៅខែ ធ្នូ ឆ្នាំ ១៩៧៥ ក្រោយពី ខៀវ សំផន ប្រកាសអំពីការអនុម័តនូវសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា[១១៣៨]។

៣៧៨. អង្គជំនុំជម្រះមិនអាចកំណត់បានថាតើ ខៀវ សំផន នៅរក្សាតួនាទីជាអគ្គមេបញ្ជាការដដែល នៅពេលដែលកងទ័ពរំដោះប្រជាជនកម្ពុជាត្រូវបានបញ្ចូលទៅក្នុងកងទ័ពបដិវត្តកម្ពុជានៅខែ កក្កដា ឆ្នាំ ១៩៧៥[១១៣៩] ឬយ៉ាងណានោះទេ។ នៅក្នុងករណីណាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា បើទោះជាមានការទទួលខុសត្រូវផ្នែកយោធាក្តី ក៏ខៀវ សំផន មិនដែលមានការទទួលខុសត្រូវផ្ទាល់ក្នុងវិស័យនេះទេ[១១៤០]។ ក៏ប៉ុន្តែ ខៀវ សំផន ពិតជាបានចូលរួមប្រជុំជាមួយមេដឹកនាំ

---

[១១៣៧] *"សមាជជាតិពិសេស" ជ្រើសតាំងសម្តេច សីហនុ និងសម្តេច ប៉ែន នុត* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700284-00700286។ *សូមមើល ឧទា. កម្ពុជារៀបចំមហាសន្និបាតពិសេស* (កាសែត The Guardian) ឯកសារ E3/3722 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៥។ *ដំណើរដ៏វែងឆ្ងាយចាកចេញពីភ្នំពេញ* (កាសែត The Time) ឯកសារ E3/4430 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00645764-00645765។

[១១៣៨] *សមាជជាតិត្រូវបានប្រារព្ធឡើង ហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/1356 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00663892-00663894។

[១១៣៩] *សូមមើល* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០-២៤៤ ។

[១១៤០] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៥។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៧៥។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ១៩-២១។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ២១។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/452 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00146550-00146552 (ដែលជាការបញ្ជាក់ថា ខៀវ សំផន មិនមានសិទ្ធិអំណាចទៅលើ ស២១ឡើយ)។ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៣ (អ៊ុង រ៉ែន) ទំព័រ ៣៤, ៦៨-៦៩ (ដោយថ្លែងថា សុន សេន និង ប៉ុល ពត ទទួលបន្ទុកយោធា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន់ ឯកសារ E3/58 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00239937 (ដោយថ្លែងថា

ជាន់ខ្ពស់ និងមេបញ្ជាការយោធា ឬកម្មាភិបាលថ្នាក់ភូមិភាគ ឬ តំបន់ដែលនៅក្នុងកិច្ចប្រជុំទាំងនោះគឺមានការពិភាក្សាអំពីបញ្ហាយោធា[១១៤១]។

៣៧៩. មិនត្រឹមតែធ្វើសុន្ទរកថាតែប៉ុណ្ណោះទេ ប៉ុន្តែ ខៀវ សំផន ថែមទាំងបានដើរតួនាទី ក្នុងការអប់រំអ្នកទាំងឡាយដែលត្រឡប់ពីបរទេសមកប្រទេសកម្ពុជាវិញ ដោយបានបើកវគ្គអប់រំនយោបាយយ៉ាងហោចណាស់មួយលើកដែរនៅក្នុងឆ្នាំ ១៩៧៥ សម្រាប់អ្នកដែលត្រឡប់មកប្រទេសកម្ពុជាវិញ[១១៤២]។ សាក្សីមួយចំនួនដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ បានអះអាងថា ពួកគាត់បានចូលរួមវគ្គអប់រំនយោបាយទ្រង់ទ្រាយធំនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងវគ្គនោះ ខៀវ សំផន ជាអ្នកឡើងធ្វើបាឋកថា ឬជាអ្នកបង្រៀន[១១៤៣]។

៣៨០. នៅដើមឆ្នាំ ១៩៧៦ ខៀវ សំផន បានអមព្រះរាជដំណើររបស់សម្តេច នរោត្តម សីហនុ នៅក្នុងព្រះរាជទស្សនកិច្ចរបស់ព្រះអង្គយាងទៅកាន់ទីជនបទនៃប្រទេសកម្ពុជា។ នៅក្នុងព្រះរាជ

---

របាយការណ៍អំពី "បញ្ហាក្រៅពីសន្តិសុខ"ត្រូវបានផ្ញើទៅខៀវ សំផន) ។ *សូមមើលបន្ថែម* ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥ ។

[១១៤១] ប្រតិចារឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២(វ៉ាចាម គុន) ទំព័រ ៥៣-៥៤, ៥៥-៥៧។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៤៥-៤៨។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៥-៦។

[១១៤២] ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (អ៊ុង ចុងហឿង) ទំព័រ ៨៤-៨៥។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១២-១៤ (ដកស្រង់ សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9)។ សៀវភៅនិពន្ធដោយ B. Kiernan៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍* ឯកសារ E3/1593 ទំព័រ ២១៦-២១៨ ERN (ភាសាខ្មែរ) 00637571-00637573។

[១១៤៣] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ៦៧-៧៤, ៧៤-៧៥។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ២៤-២៦។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ៣៤-៤១, ៥៣-៥៤, ៦៦-៦៩, ៧៣-៧៥, ៧៦-៨៣។។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ២៨-៣៣, ៦៤។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម គុន) ទំព័រ ៥២-៥៥។ ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម គុន) ទំព័រ ៧៥-៧៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៧-៥៨។

ដំណើរទស្សនកិច្ចនោះ សម្តេច និង ខៀវ សំផន បានយាងទត និងពិនិត្យការដ្ឋាននានា ព្រមទាំងពលករវាប់ពាន់នាក់ផងដែរដែលកំពុងធ្វើការងារផ្នែកកសិកម្ម[១១៩៤]។

### ៨.៣.២ ប្រធានគណៈប្រធានរដ្ឋ

៣៨១. នៅខែមេសា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានលាលែងពីតំណែង ដើម្បីបើកផ្លូវឲ្យមានការបង្កើតរដ្ឋាភិបាលថ្មីមួយស្របតាមរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ[១១៩៥]។ ផ្ទុយពីរាជាធិបតេយ្យ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិប-តេយ្យចែងថា គណៈប្រធានរដ្ឋមានភារៈតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេស និងក្រៅប្រទេស[១១៩៦]។ គណៈប្រធានរដ្ឋមានសមាសភាព៖ ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២។ ទោះបីជាគោលការណ៍ តំណែងទាំងនេះត្រូវជ្រើសរើសដោយសភាតំណាងប្រជាជនក្តី ក៏ប៉ុន្តែតាមការជាក់ស្តែង ខៀវ សំផន ត្រូវបានតែងតាំងជាប្រធាន ដោយគណៈកម្មាធិការមជ្ឈិមបក្ស-កុម្មុយនីស្តកម្ពុជា មុនពេលសភាតំណាងប្រជាជនបានកោះប្រជុំទៅទៀត[១១៩៧]។ ការតែងតាំង

---

[១១៩៤] *សម្តេចសីហនុបំពេញព្រះរាជទស្សនកិច្ចរយៈពេលបីថ្ងៃនៅភូមិភាគឧត្តរ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00657454-00657455។ បទសម្ភាសន៍រវាងលោក ខៀវ សំផន ជាមួយវិទ្យុបារាំង France Culture ឯកសារ E289.1.1 ចុះខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00934562-00934563 (ដែលថ្លែងថាគាត់បានធ្វើទស្សនកិច្ចនៅជនបទជាមួយសម្តេច ប៉ុន្តែ "បានឃើញមនុស្សម្នានានាមិនមែនធ្លាក់ខ្លួនស្គមស្បែកដណ្តប់ឆ្អឹងនោះទេ" ហើយ "បានឃើញប្រជាជនទូទៅដែលធ្វើការនៅការដ្ឋានមានសភាពធម្មតា")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204741-00204742។ សៀវភៅនិពន្ធដោយណាយ៉ាន់ ចាន់ដា៖ *សត្រូវបងប្អូនឯង* ឯកសារ E3/2376 ទំព័រ ២៥៩ ERN (ភាសាខ្មែរ) 00191564។

[១១៩៥] *សូមមើល* សូមមើលផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៦ ។

[១១៩៦] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១០ ជំពូក ៨ ERN (ភាសាខ្មែរ) 00089848។

[១១៩៧] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១០ ជំពូក ៨ ERN (ភាសាខ្មែរ) 00089848។ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ទាក់ទងនឹងបញ្ហាមួយចំនួន ឯកសារ E3/12 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00003140-00003141។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល។ សមាជិកផ្សេងទៀតនៃគណៈប្រធានរដ្ឋគឺ សោ ភឹម (អនុប្រធានទីមួយ) និង រស់ ញឹម (អនុប្រធានទីពីរ៖ *សូមមើល* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១៩, ២៣៥, ជើងទំព័រ ៦៩២, ៦៩៣។

ខៀវ សំផន នេះត្រូវបានអះអាងជាផ្លូវការនៅក្នុងពិធីបើកសម័យប្រជុំសភាតំណាងប្រជាជន[១១៤៨]។ តាមស្មារតីរដ្ឋធម្មនុញ្ញប្រធានពុំមានអំណាចប្រតិបត្តិទេ។ ក្នុងនាមជាប្រមុខរដ្ឋ តួនាទីរបស់ ខៀវ សំផន ជាទូទៅ គឺគ្រាន់តែជាតួនាទីនិមិត្តរូបតែប៉ុណ្ណោះ[១១៤៩]។

៣៨២. ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បន្តបំពេញមុខងារការទូត និង ពិធីផ្សេងៗ ដូចជា ទទួលសារតាំងពីអ្នកការទូត[១១៥០] ស្វាគមន៍គណៈប្រតិភូបរទេស[១១៥១] ធ្វើជាម្ចាស់ផ្ទះ និង

---

[១១៤៨] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៥-២៣៦ ។ សោ ភឹម ត្រូវបានតែងតាំងជា អនុប្រធានទីមួយ និង រស់ ញឹម ជាអនុប្រធានទីពីរ៖កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៤៧ ERN (ភាសាខ្មែរ) 00053634។

[១១៤៩] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៩១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៩២-៩៣។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥២។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៤-៣៥ ។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00156618-00156619។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156677។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ឯកសារ E3/446 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00492962-00492963។

[១១៥០] ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡេង ឈឿង) ទំព័រ ១៩, ៧៥-៧៧។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156677។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៩-៨០ ERN (ភាសាខ្មែរ) 00103847-00103848។ *ខៀវ សំផន និយាយការពារអំពើប្រល័យពូជសាសន៍ដោយការធ្វើមិនដឹង* (កាសែត Le Monde ដោយ Jean Clau Pomonti) ឯកសារ E3/4603 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៤ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00002733-00002734។ *ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិនប្រគល់សារតាំង* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/276 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00658198។ *លោក ខៀវ សំផន ទទួលស្វាគមន៍ឯកអគ្គរដ្ឋទូតបរទេស* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/277 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00663901។ ទូរលេខរបស់ COREU កម្មវត្ថុ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកទៅកាន់ប្រទេសកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00583716។

[១១៥១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម វុន ឯកសារ E3/380 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00357201-00357202។ *លោក ខៀវ សំផន ទទួលស្វាគមន៍គណៈប្រតិភូស្ត្រីឡាវដែលបានមកទស្សនកិច្ចកម្ពុជាប្រជាធិបតេយ្យ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/286 ចុះថ្ងៃទី ២៩ ខែ

ចូលរួមលាងសាយភោជន៍ថ្នាក់រដ្ឋ[១១៥២] ផ្ញើ និងទទួលកំណត់ទូតក្នុងនាមជាតំណាងរបបកម្ពុជាប្រជាធិបតេយ្យ[១១៥៣] ព្រមទាំងដឹកនាំគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យក្នុងដំណើរទស្សនកិច្ចទៅក្រៅប្រទេស[១១៥៤]។

៣៨៣. ក្នុងនាមជាប្រធាន ខៀវ សំផន ក៏បានបន្តធ្វើសុន្ទរកថា សរសើរប្រជាជនកម្ពុជា និងកងទ័ពបដិវត្ត ដែលបានដើរតួនាទីនៅក្នុង "ការរំដោះ" ទីក្រុងភ្នំពេញ[១១៥៥] គាំទ្រការបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មីមួយ និងស្ថាប័ននានារបស់ខ្លួន[១១៥៦] យល់ស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការប្រើប្រាស់សហករណ៍ របបហូបចុក ពលកម្មកុមារ និង

---

មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00681223-00681224។ *គណៈប្រតិភូភូមាជួបជាមួយលោក ខៀវ សំផន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/143 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00658436-00658438។

[១១៥២] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៩-៨០ ERN (ភាសាខ្មែរ) 00103847-00103848។ *លោក ខៀវ សំផន រៀបចំពិធីជប់លៀងជូន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/291 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00657475-00657476។ *ដំណើរទស្សនកិច្ចរបស់ Ne Win មកកាន់ប្រទេសកម្ពុជា* (ក្នុងកម្រង SWB/FE/5678/A3) ឯកសារ E3/298 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) S 00725158-S 00725169។ *ប្រធានាធិបតីឡាវក្នុងប្រទេសកម្ពុជា* (ក្នុងកម្រង SWB/FE/5700/A3) ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារ E3/301 ERN (ភាសាខ្មែរ) S 00651225។

[១១៥៣] *ការអបអរសាទរមន្ត្រីរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង (PRGRSV) ចំពោះជ័យជម្នះថ្ងៃទី ៣០ មេសា* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/276 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00658195-00658197។ *វន្ទនាការបន្ថែមទៀតពី មេដឹកនាំបរទេសក្នុងទិវាបុណ្យជាតិ* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/286 ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៧ ERN (ភាសាខ្មែរ) 00681210-00681211។ *ខៀវ សំផន សម្តែងវន្ទនាការ ចំពោះលោក Al-Qadhdhafi ក្នុងទិវាបុណ្យជាតិនៃប្រទេសលីប៊ី* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស ខែ កញ្ញា ឆ្នាំ ១៩៧៧) ឯកសារ E3/143 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៧៧ ERN (ភាសាអង់គ្លេស) 00168724។

[១១៥៤] ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៥៨-៥៩ ។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00156677-00156678។

[១១៥៥] *ការគោរពពិធីខួបជ័យជម្នះ ថ្ងៃទី ១៧ ខែ មេសា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/275 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00896389-00896394។

[១១៥៦] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00053610-00053617។

ការដ្ឋាន[១១៥៧] សរសើរអំពីសមិទ្ធផលនានាដែលគេអះអាងថា សម្រេចបានក្នុងការកសាងជាតិ និងការកែលម្អជីវភាពរស់នៅ[១១៥៨] និងបកអាក្រាតចំពោះ "ការឈ្លានពាន"ពីសំណាក់វៀតណាម[១១៥៩]។ ខៀវ សំផន បានថ្លែងប្រាប់សហចៅក្រមស៊ើបអង្កេតថា អត្ថន័យនៃសុន្ទរកថារបស់គាត់ "ត្រូវបានបង្គាប់បញ្ជាដោយ" ប៉ុល ពត ហើយថ្លែងទៀតថា ទោះបីជាភាគច្រើនគាត់យល់ស្របតាមអ្វីដែលគាត់បាននិយាយក៏ពិតមែន ក៏ប៉ុន្តែជាបុគ្គល គាត់បង្ហាញការមិនយល់ស្របចំពោះឯកសារមួយចំនួនដូចជាឯកសារពាក់ព័ន្ធនឹងការលុបបំបាត់រូបិយវត្ថុជាដើម[១១៦០]។

### ៨.៣.៣ សមាជិកភាពនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍

៣៨៤. ខៀវ សំផន បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុនីស្តកម្ពុជានៅ ឆ្នាំ ១៩៧៦ ក្រោយពីបានធ្វើជាសមាជិកត្រៀមចាប់តាំងពីឆ្នាំ ១៩៧១ មក[១១៦១]។ ទោះបីជា ខៀវ សំផន បានអះអាងថា គណៈកម្មាធិការមជ្ឈិមមិនមែនជា "អង្គការប្រតិបត្តិ" និងគ្រាន់តែពិភាក្សាអំពីការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ប៉ុណ្ណោះក៏ដោយ ក៏ ខៀវ សំផន បានអះអាងថា គណៈកម្មាធិការមជ្ឈិមបានចេញសេចក្តីបង្គាប់នានាដែលមានបំណងណែនាំដល់ "ការប្រព្រឹត្តិហួសហេតុ" និងកែលម្អលក្ខខណ្ឌមួយចំនួននៅតាមជនបទទៀតផង[១១៦២]។

---

[១១៥៧] *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (ក្នុងកម្រង SWB/FE/5490/C) ឯកសារ E3/201 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00292803-00292815។

[១១៥៨] *ការគោរពពិធីខួបជ័យជម្នះ ថ្ងៃទី ១៧ ខែ មេសា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/275 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00896397-00896398។ *សុន្ទរកថា របស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (ក្នុងកម្រង SWB/FE/5490/C) ឯកសារ E3/201 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00292804-00292814។

[១១៥៩] *សេចក្តីថ្លែងរបស់ ខៀវ សំផន* (ក្នុងកម្រងឯកសារផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/1359 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ភាសាអង់គ្លេស) 00169517-00169525។*សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ឈឿង ឯកសារ E3/385 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00357213។

[១១៦០] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00156677-00156678។

[១១៦១] *សូមមើល* កថាខណ្ឌ ៣៦២ ខាងលើ។ សូមមើលផ្នែកទី ៨ ស្តីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣ ។

[១១៦២] សៀវភៅនិពន្ធដោយ ខៀវ សំផនៈ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៦៤-៦៦ ERN (ភាសាខ្មែរ) 00103840-00103841។

៣៨៥. ខៀវ សំផន មិនដែលធ្លាប់ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ជាផ្លូវការម្តងណាឡើយ[១១៦៣]។ ខៀវសំផនបានទទួលស្គាល់ថា គាត់បានចូលរួមអ្វីដែលគាត់ហៅថាកិច្ចប្រជុំ "បើកចំហ" ឬកិច្ចប្រជុំ "បើកទូលាយ" នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុន្តែគាត់បានអះអាងដោយស៊ីសង្វាក់ថា គាត់មិនដែលមានមតិ ឬ ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅអំឡុងកិច្ចប្រជុំទាំងនោះទេ[១១៦៤]។ សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា ខៀវ សំផន គឺ ជាសមាជិកគណៈកម្មាធិការ-អចិន្ត្រៃយ៍តាមព្រឹត្តហេតុ ហើយថា វត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំទាំងនេះ បានធ្វើឲ្យ ខៀវ សំផន ក្លាយជាសមាជិកក្នុងក្រុមតូចមួយរបស់មជ្ឈិមបក្ស ដែលមានអំណាច និងទទួលបានព័ត៌មានពេញលេញ[១១៦៥]។

៣៨៦. កំណត់ហេតុប្រជុំចំនួន២៣ច្បាប់ត្រូវបានដាក់ជូនអង្គជំនុំជម្រះ។ ក្នុងចំណោមកំណត់ហេតុនៃកិច្ចប្រជុំទាំងនេះមាន ១៩ ច្បាប់ ដែលមានបញ្ជីឈ្មោះអ្នកចូលរួមប្រជុំ ហើយ១៦ច្បាប់នៃកំណត់ហេតុកិច្ចប្រជុំបានកត់ត្រាថា "សមមិត្តហែម" (ខៀវ សំផន) មានវត្តមាន[១១៦៦]។ កំណត់ហេតុជាភ័ស្តុតាងនេះធ្វើឡើងនៅក្នុងចន្លោះពេលពីខែ សីហា ឆ្នាំ ១៩៧៥ ដល់ខែ មិថុនា ឆ្នាំ ១៩៧៦ ប៉ុន្តែ

---

[១១៦៣] ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ ១-២ ។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT), ទំព័រ៥៤-៥៥ ។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន),ទំព័រ ៦-៧ ។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២(កាំង ហ្កេកអ៊ាវ), ទំព័រ ៤០ ។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00156619-00156620។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ឯកសារ E3/446 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១០ ទំព័រ ៦ ERN (ភាសាខ្មែរ) 00492962-00492963។

[១១៦៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន), ទំព័រ ៦៤-៦៦ ។ កំណត់ហេតុនៃកិច្ចពិភាក្សាដេញ-ដោល ឯកសារ E3/557 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00153234-00153235។ លិខិតរបស់ ខៀវ សំផន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ E3/112 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣-៦ ERN (ភាសាខ្មែរ) 00157635-00157638។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00156619-00156620។ *ខៀវ សំផន និយាយការពារអំពើប្រល័យពូជសាសន៍ដោយការធ្វើមិនដឹង* (កាសែត Le Monde) ឯកសារ E3/4603 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៤ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00002735-00002736។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧០-៧១ ERN (ភាសាខ្មែរ) 00103843។

[១១៦៥] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/1 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦១, ៥២៧, ៥៣៧-៥៤១។

[១១៦៦] *សូមមើល* ផ្នែកទី៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣ ជើងទំព័រ ៦២៤ ។

មិនតំណាងឲ្យកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅអំឡុងពេលនោះ ឬពេញមួយរយៈកាលកម្ពុជាប្រជាធិបតេយ្យឡើយ[១១៦៧]។ តាមរយៈវត្តមានជាប្រចាំរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅចន្លោះ ឆ្នាំ ១៩៧៥ ដល់ ១៩៧៦ អង្គជំនុំជម្រះ សន្និដ្ឋានថារយៈពេលក្រោយមកទៀត ខៀវ សំផន ក៏នៅតែបន្តចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាប្រចាំស្រដៀងគ្នានឹងអំឡុងពេលខាងលើនេះដែរ។ ចំណុចនេះស៊ីសង្វាក់គ្នាជាមួយភ័ស្តុតាងដែលបង្ហាញថា ខៀវ សំផន បានចេញចូលមន្ទីរ ក-១ ជាច្រើនដង[១១៦៨] ដែលនៅទីនោះយ៉ាងហោចណាស់ក៏មានការរៀបចំកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែរ[១១៦៩] ហើយ ខៀវ សំផន ក៏បានទទួលស្គាល់ថា ប៉ុល ពត "មានការទុកចិត្តមកលើគាត់"[១១៧០]។

៣៨៧. កំណត់ហេតុដែលនៅសល់មកដល់សព្វថ្ងៃបញ្ជាក់ថា ខៀវ សំផន បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ទោះបីជា ខៀវ សំផន លើកឡើងផ្ទុយពីនេះក្តី។ ទោះបីជាកំណត់ហេតុទាំងនោះមិនបញ្ជាក់សេចក្តីសង្កេតរបស់អ្នកចូលរួមក្នុងកិច្ចប្រជុំក្តី ក៏ប៉ុន្តែវាបង្ហាញថា ខៀវ សំផន បានរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ យ៉ាងហោចណាស់

---

[១១៦៧] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ១៧-១៨។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣ ជើងទំព័រ ៦២៤ ។ ផ្នែកទី ៦ ស្តីពីរចនាសម្ព័ន្ធទំនាក់ទំនង កថាខណ្ឌ ២៧១ ។

[១១៦៨] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ (ស វិ) ទំព័រ ១០-១១, ១៨-១៩ (ដោយបានផ្តល់សក្ខីកម្មថា ខៀវ សំផន អៀង សារី និង នួន ជា មក ក១ ជាញឹកញាប់ក្នុងចន្លោះឆ្នាំ១៩៧៦ ដល់១៩៧៩)។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ឡុង ឈឿង) ទំព័រ ១៦ (ដោយថ្លែងថា គាត់បានបើកឡានជូន ខៀវ សំផន ទៅក១ "ម្តងម្កាល"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ឈឿង ឯកសារ E3/385 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00357212 (ដែលជាការបញ្ជាក់ថាគាត់បានបើកឡានជូនខៀវ សំផនទៅ ក១ ពីរ ឬ៣ ដងក្នុងមួយសប្តាហ៍។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣៦, ៣៦-៣៧, ៤៥ (ដោយថ្លែងថា ខៀវ សំផន បានចូលរួមប្រជុំនៅមន្ទីរ ក-១ "ជាទៀងទាត់" ប្រហែលមួយខែម្តង ឬ កន្លះខែម្តង)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៣-៦៤ (ដោយថ្លែងថា ខៀវ សំផន ទៅក១ "យូរៗម្តង")។

[១១៦៩] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156676-00156677។

[១១៧០] បទសម្ភាសន៍រវាងលោក ខៀវ សំផន ជាមួយវិទ្យុបារាំង France Culture ឯកសារ E289.1.1 ចុះខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00934560-00934561។

ពីរលើកដែរ អំពីការទាក់ទងជាមួយសម្ដេច នរោត្តម សីហនុ និង "ការបោះឆ្នោត" នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦[១១៧១]។

៣៨៨. ជាងនេះទៅទៀត ទោះបីជា ខៀវ សំផន អះអាងម្ដងហើយម្ដងទៀតថា គាត់ពុំបានទទួលព័ត៌មានពេញលេញនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[១១៧២] និង បដិសេធអំពីការដឹងឮជាក់លាក់អំពីការចាប់ខ្លួនយ៉ាងណាក្ដី[១១៧៣] ក៏ ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅអំឡុងពេលនៃកិច្ចប្រជុំនីមួយៗ តែងតែមានការពិភាក្សាអំពីការចាប់ខ្លួន[១១៧៤] ឃោសនាការ[១១៧៥] ជីវភាពរស់នៅនៅតាមទីជនបទ (រួមមានជំងឺដង្កាត់ ការស្លាប់ និងការខ្វះស្បៀងអាហារ)[១១៧៦] *ការងារពលកម្មកុមារ*[១១៧៧] *កិច្ចការបរទេស*[១១៧៨] *ការពារជាតិ*[១១៧៩] ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម[១១៨០] និងពាណិជ្ជកម្ម[១១៨១] ។

---

[១១៧១] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-២, ៤-៥ ERN (ភាសាខ្មែរ) 00000744-00000745, 00000747-00000748 (ដោយបានពិភាក្សាអំពីបំណងរបស់ព្រះអង្គក្នុងការលាឈប់ និង លទ្ធភាពនៃការឆ្លើយតបនានា)។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00017116 (ដោយបានពិភាក្សាអំពីគោលការណ៍ គោលបំណង និង វិធីសាស្ត្រ "បោះឆ្នោត" នាពេលខាងមុខ និង វិធីសាស្ត្រអប់រំ និង ឃោសនា)។

[១១៧២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន), ទំព័រ ៦៤-៦៦។ បទសម្ភាសន៍រវាងលោក ខៀវ សំផន ជាមួយវិទ្យុបារាំង France Culture ឯកសារ E289.1.1 ចុះខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៥-៦, ៩-១០ ERN (ភាសាខ្មែរ) 00934560-00934561, 00934564-00934565។ *ខៀវ សំផន និយាយការពារអំពើប្រល័យពូជសាសន៍ដោយការធ្វើមិនដឹង* (កាសែត Le Monde ដោយ Jean Clau-Pomonti) ឯកសារ E3/4603 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៤ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00002733-00002734។

[១១៧៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៥-៦៦ ។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៥២-១៥៣, ១៦៧-១៦៨ ERN (ភាសាខ្មែរ) 00103884, 00103891-00103892។

[១១៧៤] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00017118-00017120។

[១១៧៥] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/231 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦។

[១១៧៦] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤, ៤-៥, ៦-៧ ERN (ភាសាខ្មែរ) 00017118-00017119, 00017119-00017120, 00017121-00017122។

៣៨៩. ដើម្បីបញ្ជាក់បន្ថែមអំពីកម្រិតនៃការយល់ដឹងរបស់គាត់ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានរួមចំណែកទទួលខុសត្រូវជាមួយ ប៉ុល ពត ក្នុងការធ្វើឲ្យមានការបាត់ខ្លួនមិត្តភក្តិ និង សហការីរបស់ខ្លួន នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ "តែងតែមានសង្ឃឹមជានិច្ចថា ថ្ងៃណាមួយ ប៉ុល ពត នឹងត្រឡប់បកក្រោយ"[១១៨២]។ ខៀវ សំផន ក៏បានទទួលស្គាល់ផងដែរថា នៅពាក់កណ្តាលឆ្នាំ ១៩៧៨ គាត់ដឹងអំពី "ការចាប់ចង និង អំពើឃោរឃៅ" នៅក្នុងខេត្តព្រះវិហារ ជាពិសេសអំពីការចាប់ខ្លួន និងការធ្វើបាបមកលើបងប្អូនរបស់សហព័ទ្ធរបស់គាត់[១១៨៣]។ ស៊ីសង្វាក់ជាមួយនឹងចំណុចនេះផងដែរ សាក្សី មាស វឿន ជាកម្មាភិបាលយោធា ដែលធ្វើដំណើរទៅភូមិភាគឧត្តរថ្មី ក្នុងឆ្នាំ ១៩៧៨[១១៨៤] បានផ្តល់សក្ខីកម្មថា ខៀវ សំផន បានបញ្ជូនទូរលេខមួយច្បាប់មកឲ្យគាត់ក្នុងឆ្នាំ ១៩៧៨ ដោយផ្តាំផ្ញើការសាកសួរសុខទុក្ខបងប្អូនគាត់ និងបញ្ជាឲ្យគេបញ្ជូនបងប្អូនគាត់មកភ្នំពេញ បើពួកគេជួបការលំបាក[១១៨៥]។ ជាលទ្ធផល សាក្សី មាស វឿន បានសួរដំណឹង ហើយក៏បានធានាឲ្យមានការដោះលែងប្អូន/បងថ្លៃស្រីរបស់ ខៀវ សំផន ដែលជាប់ឃុំនៅមន្ទីរសន្តិសុខនៅ

---

[១១៧៧] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/226 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ២-៣, ៦-៧ ERN (ភាសាខ្មែរ) 00017148-00017149, 00017152-00017153។ កំណត់ហេតុនៃអង្គប្រជុំគណៈ-អចិន្ត្រៃយ៍ ឯកសារ E3/230 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00000711។

[១១៧៨] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/219 ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/223 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦។

[១១៧៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/229 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/224 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00000772-00000773។

[១១៨០] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/218 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-៤, ៦-៧ ERN (ភាសាខ្មែរ) 00000751-00000753, 00000756-00000757។

[១១៨១] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/233 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/220 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦។

[១១៨២] បទសម្ភាសន៍រវាងលោក ខៀវ សំផន ជាមួយវិទ្យុបារាំង France Culture ឯកសារ E289.1.1 ចុះខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00934560-00934561។

[១១៨៣] សំបុត្រចំហររបស់ ខៀវ សំផន ជូនបងប្អូនរួមជាតិទាំងអស់ ឯកសារ E3/205 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ERN (ភាសាខ្មែរ) 00002796 ទំព័រ ៣។

[១១៨៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៥៤-៥៥។

[១១៨៥] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៥៧- ៥៩។

សៀមរាប[១១៨៦]។ សាក្សី កាំង ហ្កេកអ៊ាវ បានថ្លែងថា កង ចាប ដែលជាលេខាភូមិភាគឧត្តរថ្មី ត្រូវបាន ប៉ុល ពត ផ្តន្ទាទោសពាក់ព័ន្ធនឹងតួនាទីរបស់គាត់ក្នុងហេតុការណ៍នេះ[១១៨៧]។ នៅក្នុងលិខិតចំហមួយច្បាប់ដែលចុះផ្សាយនៅក្នុងសារព័ត៌មានជាតិនៅឆ្នាំ ២០០១ ខៀវ សំផន ទំនងជាទទួលស្គាល់ថា ការឃុំខ្លួនបងប្អូនរបស់គាត់បាននាំដល់ការចាប់ខ្លួន "លេខាបក្សភូមិភាគ" មួយចំនួន[១១៨៨]។

### ៨.៣.៤ សមាជិកភាពមន្ទីរ ៨៧០

៣៩០. មន្ទីរ ៨៧០ គឺជាមន្ទីរដែលត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចនានារបស់គណៈ-កម្មាធិការអចិន្ត្រៃយ៍។ មន្ទីរនេះមានសមាជិកពីររូបគឺ សឿ វ៉ាស៊ី ហៅ ឌឿន ដែលត្រូវបានតែងតាំងជាប្រធានមន្ទីរនៅខែ តុលា ឆ្នាំ ១៩៧៥ និង ខៀវ សំផន ដែលចូលរួមប្រហែលជាស្របពេលជាមួយគ្នាដែរ[១១៨៩]។ មន្ទីរ ស-៧១ ដែលដឹកនាំដោយ ឈឹម សំអោក ហៅ ប៉ង់ អាចស្ថិតនៅក្រោមមន្ទីរ ៨៧០។ ទំនាក់ទំនងជាក់លាក់រវាងមន្ទីរទាំងពីរនេះមិនមានលក្ខណៈច្បាស់លាស់ទេ[១១៩០]។

៣៩១. សហព្រះរាជអាជ្ញាចោទថា ខៀវ សំផន បន្តតំណែងពី ឌឿន ជាប្រធានមន្ទីរ៨៧០ នៅឆ្នាំ ១៩៧៦ ឬ ១៩៧៧[១១៩១]។ ខៀវ សំផន បានបដិសេធម្តងហើយម្តងទៀតថា ខ្លួនមិនដែលបានធ្វើជាប្រធានមន្ទីរ ៨៧០ ឡើយ ហើយបានអះអាងថា ខ្លួនទទួលខុសត្រូវតែទៅលើការរក្សាទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ ការកំណត់តម្លៃផលិតផលដែលសហករណ៍ផ្សេងៗបង្កើតបាន និង អង្គភាពសេដ្ឋកិច្ចដទៃទៀត អនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ទាក់ទិននឹង

---

[១១៨៦] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៥៨-៥។

[១១៨៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៨២-៨៣ ។*សូមមើលផងដែរ* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០ ។

[១១៨៨] សំបុត្រចំហរបស់ ខៀវ សំផន ជូនបងប្អូនរួមជាតិទាំងអស់ ឯកសារ E3/205 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ទំព័រ ៥ ERN (ភាសាខ្មែរ) 00002796។

[១១៨៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00019108។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00156676។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៣-៧៤ ERN (ភាសាខ្មែរ) 00103844-00103845។ *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៧-២១០ ។

[១១៩០] *សូមមើល* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១១-២១២។

[១១៩១] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៥៧-៥៥៨។

ការបែងចែកផលិតផលផ្សេងៗទៅកាន់បណ្តាភូមិភាគ និងធ្វើការជាមួយក្រុមហ៊ុនខ្មែរសម្រាប់ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាប្រជាធិបតេយ្យ ("FORTRA") លើផ្នែកនាំចូលតែប៉ុណ្ណោះ[១១៩២]។ តាមការជាក់ស្តែង ដូចដែល ខៀវ សំផន បានទទួលស្គាល់ហើយថា ពុំមានការផ្លាស់ប្តូរទំនិញរវាងសហករណ៍ឡើយ ហេតុដូចនេះការទទួលខុសត្រូវរបស់ខ្លួនទៅលើការរៀបចំតម្លៃផលិតផលគឺគ្រាន់តែមានជាទ្រឹស្តីតែប៉ុណ្ណោះ[១១៩៣]។

៣៩២. ខៀវ សំផន បានអះអាងថា ខ្លួនពុំបានដឹងអំពីតួនាទីជាក់លាក់របស់ ឌឿន ជាប្រធានមន្ទីរ ៨៧០ ឡើយ ទោះបីជាខ្លួនបានទទួលស្គាល់ថា ឌឿន ទទួលរបាយការណ៍ពីបណ្តាភូមិភាគ និង "ទទួលកិច្ចការនយោបាយ"ក្តី[១១៩៤]។ ឌឿន ត្រូវបានចាប់ខ្លួន និង នាំមកមន្ទីរ ស-២១ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៧[១១៩៥]។ ទោះជាយ៉ាងនេះក្តី មន្ទីរ៨៧០ នៅតែបន្តបំពេញមុខនាទីរបស់ខ្លួនយ៉ាងហោច

[១១៩២] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៣-៧៤ ERN (ភាសាខ្មែរ) 00103844-00103845។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156676-00156677។ កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ឯកសារ E3/557 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00153232-00153233។ បទសម្ភាសន៍របស់ វីអូរេ ជាមួយ ខៀវ សំផន ឯកសារ E3/204 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00424211-00424212។ លិខិតរបស់ ខៀវ សំផន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ E3/112 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-៣ 00157633-00157635។ *សូមមើលផងដែរ* វិក្កយបត្រ FORTRA ឯកសារ E3/2056 ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00663866 (សរសេរឈ្មោះពេញសម្រាប់ពាក្យ FORTRA)។

[១១៩៣] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00156677។ លិខិតរបស់ ខៀវ សំផន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ E3/112 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00157633-00157635។

[១១៩៤] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00156676។ កំណត់ត្រានៃបទសម្ភាសន៍ជាមួយ ខៀវ សំផន SOAS/HRW ឯកសារ E3/198 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00078213-00078214។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ទំព័រ ២២៤-២២៦ ជើងទំព័រ ១៩៣ ERN (ភាសាខ្មែរ) 00380458-00380460។

[១១៩៥] បញ្ជីអ្នកទោសនៅ ស-២១ ដែលបានពិនិត្យឡើងវិញ ឯកសារ E3/342 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤១៦ ERN (ភាសាខ្មែរ) 00330011។ ចម្លើយរបស់ សឿ វ៉ាស៊ី ហៅ ឌឿន នៅមន្ទីរ ស-២១ ឯកសារ E3/1625 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៧។

ណាស់រហូតឆ្នាំ ១៩៧៨។ ខៀវ សំផន បានថ្លែងថា គាត់បានធ្វើការនៅមន្ទីរ៨៧០ រហូតដល់ឆ្នាំ ១៩៧៨ ហើយទូរលេខនានាដែលបានផ្ញើទៅ "មន្ទីរ ម-៨៧០" ឬ ចម្លងជូន "មន្ទីរ" គឺបានផ្ញើចេញពេញអំឡុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨[១១៩៦]។

៣៩៣. ខៀវ សំផន បានលើកឡើងថា ប៉ង់ អាចឡើងជំនួស ឌឿន ជាប្រធានមន្ទីរ៨៧០។ ប៉ុន្តែ ខៀវ សំផន បានត្រឹមតែថ្លែងថាវាជា "ការសន្មត" តែប៉ុណ្ណោះ[១១៩៧]។ សាក្សី សាឡុត បាន និង ភី ភួន (អ្នកទាំងពីរធ្វើការនៅក្រសួងការបរទេសក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ) បានផ្តល់សក្ខីកម្មថា ប៉ង់គឺជាប្រធានមន្ទីរ៨៧០ ប៉ុន្តែកាលបរិច្ឆេទដែលសាក្សីទាំងពីររូបបានផ្តល់ទាក់ទិននឹងតួនាទីជាប្រធាន នេះមានលក្ខណៈផ្ទុយគ្នាទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលកំណត់ហេតុទាំងនោះ បង្ហាញថា ឌឿន ទទួលបន្ទុកមន្ទីរ៨៧០ នៅឆ្នាំ ១៩៧៥[១១៩៨]។ សាក្សីដទៃទៀតក៏បានថ្លែងថា ប៉ង់ គឺជាប្រធានមន្ទីរ៨៧០ ប៉ុន្តែមិនបាននិយាយដល់ ឌឿន ឡើយ។ ការនិយាយខ្វះភាពស៊ីសង្វាក់គ្នាបែបនេះធ្វើឲ្យអង្គជំនុំជម្រះសន្និដ្ឋានថា សាក្សីទាំងនោះមានការ

---

[១១៩៦] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៤ ERN (ភាសាខ្មែរ) 00103845។ *សូមមើល ឧទា.* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1200 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៧។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/890 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/902 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/908 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/916 ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/913 ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/932 ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៨។ ទូរលេខកម្ពុជា-ប្រជាធិបតេយ្យ ឯកសារ E3/247 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៧៨។

[១១៩៧] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00156675។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៨១-១៨២ ERN (ភាសាខ្មែរ) 00103898-00103899។

[១១៩៨] សាក្សី សាឡុត បាន ថ្លែងថា ប៉ង់ ទទួលបន្ទុកមន្ទីរ៨៧០ ចាប់ពីឆ្នាំ១៩៧៥ ឬ មុនឆ្នាំ១៩៧៥: ប្រតិចារឹក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន), ទំព័រ ៥-៦, ៨-៩។ សាក្សី រ៉ចាម តុន ថ្លែងថា ប៉ង់ ទទួលបន្ទុកមន្ទីរ៨៧០ រហូតដល់គាត់បាត់ខ្លួនតែម្តង ហើយ ឌឿន ជំនួសគាត់៖ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៧៥-៧៦ ប៉ុន្តែ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បង្ហាញថា ឌឿន ទទួលបន្ទុកមន្ទីរ ៨៧០ នៅឆ្នាំ១៩៧៥។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00019108។ ក៏ប៉ុន្តែ នៅពេលដែលប៉ង់ បាត់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៨ ឌឿន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស២១ ស្រេចទៅហើយ។*សូមមើល* ផ្នែកទី ៥ ស្តីពី រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១៤ ។

ភ័ន្តច្រឡំរវាងមន្ទីរ៨៧០ និង មន្ទីរ ស-៧១[១១៩៩]។ អង្គជំនុំជម្រះយល់ឃើញថា ប៉ង់ ពុំធ្លាប់ធ្វើជាប្រធានមន្ទីរ ៨៧០ ម្តងណាឡើយ។

៣៩៤. សាក្សី និងអ្នកជំនាញមួយចំនួនទៀតដែលបានមកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះសាលាដំបូង បានផ្តល់សក្ខីកម្មថា ខៀវ សំផន គឺជាអ្នកឡើងជំនួស ឌឿន ជាប្រធានមន្ទីរ៨៧០។

៣៩៥. សាក្សី រ៉ចាម តុន អះអាងថា ខៀវ សំផន ទទួលបន្ទុកមន្ទីរ៨៧០ ក្រោយពេល ឌឿន ត្រូវបានចាប់ខ្លួន ទោះបីជាការយល់ឃើញរបស់សាក្សីរូបនេះអំពីលំដាប់លំដោយពេលវេលានៃព្រឹត្តិ-ការណ៍ (ដូចលើកឡើងខាងលើ) មានភាពផ្ទុយគ្នាទៅនឹងភ័ស្តុតាងឯកសារដែលមានចំពោះមុខអង្គជំនុំជម្រះក៏ដោយ[១២០០]។ ការទាក់ទងរបស់សាក្សី រ៉ចាម តុន ជាមួយ ខៀវ សំផន ពាក់ព័ន្ធជាចម្បងទៅនឹងការទទួលភ្ញៀវ ហើយការយល់ឃើញរបស់គាត់ចំពោះតំណែងរបស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ គឺផ្អែកលើពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ[១២០១]។

៣៩៦. នៅក្នុងសក្ខីកម្មរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ សាក្សី កាំង ហ្គេកអ៊ាវ បានហៅមន្ទីរដែលមាន ឌឿន ជាប្រធានថាជា "មន្ទីរមជ្ឈិម"[១២០២]។ ក៏ប៉ុន្តែ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយមុនៗរបស់ខ្លួនដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត កាំង ហ្គេកអ៊ាវ ហៅអង្គភាពដដែលនេះថា "មន្ទីរ៨៧០"[១២០៣]។ កាំង ហ្គេកអ៊ាវ ថ្លែងថា ខៀវ សំផន មានតួនាទីនៅមន្ទីរ

---

[១១៩៩] *សូមមើល ឧទា.* ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន), ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ (នឹម សែម) ទំព័រ ៣៩-៤០។*សូមមើលបន្ថែម*ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១២ ។

[១២០០] *សូមមើល* ជាឧទា. ផ្នែកទី ៣ ស្តីពីបរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៧ ។

[១២០១] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៤៣-៤៤។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៧៨ (ដោយថ្លែងថា អៀង សារី បានប្រាប់លោក ថា ខៀវ សំផន គឺត្រូវជំនួសតួនាទីរបស់ ឌឿន)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៦៤-៦៥ ("សាធារណជនទូទៅដឹងអំពី ខៀវ សំផន ហើយពួកគេនិយាយថាពេល ឌឿន បាត់ខ្លួន គាត់ទទួលបន្ទុកមន្ទីរ៨៧០") ។

[១២០២] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៧៥។ ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៧។

[១២០៣] *សូមមើល ឧទា.* កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/107 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00197975-00197976។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/456 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00198873-00198874។

៨៧០ ធំជាង ឌឿន ទៅទៀត ហើយក្រោយពេល ឌឿន ចេញទៅ ខៀវ សំផន ក៏កាន់តំណែងនេះ[១២០៤]។ សាក្សី កាំង ហ្កេកអ៊ាវ បានសារភាពថា គាត់ដឹងតិចតួចណាស់អំពីកិច្ចការនៅមន្ទីរ ៨៧០[១២០៥] ហើយថា សេចក្តីថ្លែងរបស់គាត់អំពីតួនាទីរបស់ ខៀវ សំផន នៅមន្ទីរនោះហាក់ដូចជាការសន្និដ្ឋានចេញពីតួនាទីជាន់ខ្ពស់ជាទូទៅរបស់ ខៀវ សំផន នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[១២០៦] ពីអត្ថបទសិក្សាស្រាវជ្រាវ[១២០៧] និងពីពាក្យចចាមអារ៉ាម[១២០៨]។

៣៩៧. កិច្ចសម្ភាសន៍ចំនួនពីររបស់សាក្សី Steve HEDER បង្ហាញថា ខៀវ សំផន បានក្លាយជាប្រធានមន្ទីរ៨៧០ បន្ទាប់ពី ឌឿន។ កិច្ចសម្ភាសន៍ទីមួយគឺជាកិច្ចសម្ភាសន៍ជាមួយ វ៉ាន់ រិត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ សព្វថ្ងៃ វ៉ាន់ រិត បានទទួលមរណភាព

---

កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/355 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00239832។

[១២០៤] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ), ទំព័រ ៧-៩, ១០។ កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/456 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00198873-00198874។

[១២០៥] ចម្លើយរបស់ កាំង ហ្កេកអ៊ាវ ជាលាយលក្ខណ៍អក្សរ ឯកសារ E3/15 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00234074។

[១២០៦] ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៧-៩ (ដែលបង្ហាញថា ឌឿន មិនអាចធ្វើជាប្រធានមន្ទីរ៨៧០ឡើយ ពីព្រោះគាត់ "មានឥទ្ធិពលតិច" "ក្មេង" និង "មានឋានៈតូច"ជាងខៀវ សំផន)។ កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/456 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00198873-00198874 (ដោយនិយាយយោងដល់តួនាទីរបស់ ខៀវ សំផន ក្នុងគណៈប្រធានរដ្ឋ ខណៈដែលពិភាក្សាអំពីមន្ទីរ៨៧០) ។

[១២០៧] *សូមមើល ឧទា.* កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/456 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00198873-00198874 (ដោយយោងដល់ស្នាដៃនិពន្ធរបស់)។ កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/355 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00239832 (ដោយយោងដល់សៀវភៅនិពន្ធដោយ David Chandler) ។

[១២០៨] *សូមមើល ឧទា.* កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/107 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00197975-00197976 ("គេប្រាប់ខ្ញុំថា [ខៀវ សំផន] ត្រូវបានតែងតាំងជាប្រធានមន្ទីរ៨៧០")។ កំណត់ហេតុនៃការស្តួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/448 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥ ERN (ភាសាខ្មែរ) 00154927 (ដែលជាការបង្ហាញថា គាត់ឮពីប៉ង់ អំពីតួនាទីរបស់ ខៀវ សំផន) ។

ទៅហើយ[១២០៩]។ បើទោះបីជា លោក Steve HEDER គឺជាសាក្សីដែលអង្គជំនុំជម្រះយល់ថា អាច ជឿទុកចិត្តបានជាទូទៅក្តី ហើយបានផ្តល់សក្ខីកម្មទាក់ទិននឹងកាលៈទេសៈនៃការធ្វើកិច្ចសម្ភាសន៍នេះក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចជឿថា កំណត់សម្គាល់របស់គាត់ទៅលើកិច្ចសម្ភាសន៍នោះមានតម្លៃ ជាភ័ស្តុតាងសំខាន់ឡើយ[១២១០]។ កិច្ចសម្ភាសន៍ទីពីរគឺជាកិច្ចសម្ភាសន៍ជាមួយ អៀង សារី[១២១១]។ ប៉ុន្តែ ដោយហេតុថា គ្មានកំណត់ហេតុពេញលេញ ឬជាផ្លូវការនៃកិច្ចសម្ភាសន៍នោះ ហើយបន្ទាប់មក អៀង សារី បដិសេធថាមិនបាននិយាយថា ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានមន្ទីរ ៨៧០ ទេនោះ សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍នេះនៅក្នុងសំណុំរឿង មិនអាចមានទម្ងន់ជាភ័ស្តុតាង ទេនៅត្រង់ចំណុចនេះ[១២១២]។

៣៩៨. នៅក្នុងដំណើរការនៃការស្រាវជ្រាវប្រវត្តិសាស្ត្ររបស់ខ្លួន អ្នកជំនាញលោក Philip SHORT និងលោក David CHANDLER សុទ្ធតែពុំបានឃើញនូវឯកសារណាមួយដែលបញ្ជាក់ថា ខៀវ សំផន ជំនួសតំណែងរបស់ ឌឿន ជាប្រធានមន្ទីរ៨៧០ ឡើយ[១២១៣]។ ឯកសារបែបនេះក៏ពុំបានដាក់ជូនអង្គជំនុំជម្រះដែរ។ ក៏ប៉ុន្តែ លោក Philip SHORT បានថ្លែងប្រាប់អង្គជំនុំជម្រះថា

---

[១២០៩] បទសម្ភាសន៍របស់ Stephen Heder ជាមួយ វ៉ាន់ រិទ្ធ ឯកសារ E3/5699 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៤ ទំព័រ ១ ERN (ភាសាខ្មែរ) 00742277។

[១២១០] ប្រតិចារឹកថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៥-៦។ អង្គជំនុំជម្រះបានបញ្ជាក់ពីជំហររបស់ខ្លួនពីមុនរួចហើយទៅលើភាពអាចទទួលយកបាន និង តម្លៃជាភ័ស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយបុគ្គលដែលទទួលមរណភាពៈ *សូមមើល* សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E299 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៩។ ពាក់ព័ន្ធនឹង ឯកសារ E3/5699, អង្គជំនុំជម្រះបានពិចារណាទៅលើអង្គហេតុដែលថាពុំមានប្រតិចារឹក ឬកំណត់ហេតុស្តាប់ចម្លើយពេញលេញឡើយ។ សេចក្តីសង្ខេបនៃកិច្ចសម្ភាសន៍ពុំមានហត្ថលេខារបស់ វ៉ាន់ រិត ហើយកិច្ចសម្ភាសន៍នោះ ធ្វើឡើងក្រៅផ្លូវការ ។

[១២១១] បទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/190 ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៩ ERN (ភាសាខ្មែរ) 00172248។ បទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ឯកសារ E3/573 ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៩ ERN (ភាសាខ្មែរ) 00640499-00640500។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៣។

[១២១២] សេចក្តីប្រកាសរបស់ អៀង សារី ឯកសារ E3/515 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩។

[១២១៣] ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៨ ។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៧៤-៧៥។

ផ្អែកលើឯកសារនានាដែលលោកបានអាន លោកមានហេតុផលដែលនាំឱ្យសន្និដ្ឋានបានថា ខៀវ សំផន "មានតួនាទីសំខាន់" នៅក្នុងមន្ទីរនោះ ក្រោយពី ឡើន ចេញទៅ[១២១៤]។ លោក David CHANDLER ក៏បានសន្និដ្ឋានថា ខៀវ សំផន ជំនួសតំណែង ឡើន ក្រោយពេល ឡើន ត្រូវបានចាប់ខ្លួន[១២១៥]។

៣៩៩. ដោយពិចារណាទៅលើភ័ស្តុតាងនានា អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនដែលធ្លាប់បានធ្វើជាប្រធានមន្ទីរ ៨៧០ ឡើយ។ ហេតុដូចនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ខៀវ សំផន មិនអាចបានឃើញទូរលេខ និងឯកសារទាំងអស់ដែលឆ្លងកាត់ ឬចម្លងជូនមន្ទីរ៨៧០ នោះទេ ជាពិសេសទូរលេខ និងឯកសារទាំងឡាយ ដែលមិនពាក់ព័ន្ធទៅនឹងផ្នែកជាក់លាក់នៃការទទួលខុសត្រូវ របស់គាត់។

### ៨.៣.៥ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម (ក្រសួងពាណិជ្ជកម្ម)

៤០០. នៅខែ តុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុនីស្តកម្ពុជាបានតែងតាំង ខៀវ សំផន ឱ្យទទួលខុសត្រូវផ្នែក "រណសិរ្ស និង រាជរដ្ឋាភិបាល និង ពាណិជ្ជកម្ម ខាងបញ្ជី និង តម្លៃ"[១២១៦]។ កុយ ធួន ហៅ ធុច ត្រូវបានប្រគល់តួនាទីទទួលខុសត្រូវផ្នែក "ពាណិជ្ជកម្មក្នុងប្រទេសនិងក្រៅប្រទេស"។ វន វេត ទទួលខុសត្រូវផ្នែក "ឧស្សាហកម្ម អយស្ម័យយាន និង នេសាទ"[១២១៧]។ នៅខែ មីនា ឆ្នាំ ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានតែងតាំង ខៀវ សំផន ទៅក្នុងគណៈកម្មាធិការសម្រាប់ "ពិនិត្យរៀបចំទំនិញដែលត្រូវទិញ"។ សមាជិកដទៃទៀតនៃគណៈ-

---

[១២១៤] ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៨-១៩ ។ ប្រតិចារឹក ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៦-៦៧។

[១២១៥] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៨១-៨៣, ៨៩-៩០។ ប្រហែលជាពិតមែនហើយថាអ្នកជំនាញ David CHANDLER សន្និដ្ឋានបែបនេះដោយផ្អែកលើការស្រាវជ្រាវរបស់សាក្សី Stephen HEDER: *សូមមើល* សៀវភៅនិពន្ធដោយ D. Chandler៖ *សម្លេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ៧៣-៧៤, ២០៩-២១០ ERN (ភាសាខ្មែរ) 00191901-00191902, 00192049-00192050។

[១២១៦] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00019108។

[១២១៧] *សូមមើលបន្ថែម* ផ្នែកទី ៥ ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣២ ។

កម្មាធិការនោះរួមមាន កុយ ធួន (ប្រធាន) អៀង សារី, វន វ៉េត និង សឿ វ៉ាស៊ី ហៅ ឌឿន[១២១៨]។ ស្របពេលនោះដែរ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការមួយបង្កើតឡើងដើម្បីពិនិត្យបញ្ហាធនាគារ។ សមាជិកដទៃទៀតនៃគណៈកម្មាធិការនោះរួមមាន កុយ ធួន, អៀង សារី និង ឌឿន[១២១៩]។

៤០១. ឋានានុក្រមនៃការទទួលខុសត្រូវកិច្ចការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈស្មុគស្មាញ ដោយសារមានការចាប់ខ្លួនកម្មាភិបាលថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជាជាញឹកញាប់។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបានធ្វើឱ្យអង្គជំនុំជម្រះយល់ដឹងអំពីលំដាប់លំដោយដ៏សមស្របនៃព្រឹត្តិការណ៍ទាំងនោះ។

៤០២. ក្រោយពេលខ្មែរក្រហមកាន់អំណាច បុគ្គលទីមួយដែលទទួលបន្ទុកសេដ្ឋកិច្ចគឺ កុយ ធួន។ កុយ ធួន ត្រូវបានចាប់ខ្លួននៅខែ មេសា ឆ្នាំ ១៩៧៦ និង យកទៅមន្ទីរ ស-២១ ក្នុងឆ្នាំ ១៩៧៧[១២២០]។

៤០៣. នៅអំឡុងពេលចាប់ខ្លួន កុយ ធួន សភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់ថា វន វ៉េត គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច ដែលមានគណៈកម្មាធិការចំនួន

[១២១៨] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/233 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00000749។ 'សមមិត្ត ទូច' ត្រូវបានចាត់តាំងក្នុងគណៈកម្មាធិការជា "សមាជិកកត់ត្រា" ដែលតាមសន្មតជាអ្នកកត់កំណត់ហេតុ។

[១២១៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/233 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00000749-00000750។ ជាថ្មីម្តងទៀត 'សមមិត្តទូច' ត្រូវបានចាត់តាំងជា "សមាជិកកត់ត្រា" ។

[១២២០] ប្រតិចារឹក ថ្ងៃទី 0២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ (ស៊ឹម ហោ), ទំព័រ ៥៦-៥៧។ ចម្លើយរបស់ កុយ ធួន ហៅ ធុច នៅមន្ទីរ ស-២១ ឯកសារ E3/1604 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន អេង ឯកសារ E3/473 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00205040 ។ សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ២៤៣-២៤៤, ២៩០-២៩២, ៣៥២-៣៥៣ERN (ភាសាខ្មែរ) 00232241-00232242, 00232288-00232290, 00232350-00232351។ សៀវភៅនិពន្ធដោយ D. Chandler៖ *សម្លេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ៦៧, ៦៩-៧០ ERN (ភាសាខ្មែរ) 00191882, 00191897-00191898។

ប្រាំមួយនៅក្រោមចំណុះ រួមទាំងគណៈកម្មាធិការពាណិជ្ជកម្មផងដែរ[១២២១]។ គណៈកម្មាធិការពាណិជ្ជកម្ម (ឬក្រសួងពាណិជ្ជកម្ម[១២២២]) ទទួលខុសត្រូវខាងការផ្ទុក ការនាំចូល និងនាំចេញទំនិញនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ ប្រតិបត្តិការរបស់គណៈកម្មាធិការនេះរួមមានឃ្លាំងរដ្ឋដែលផ្ទុកទំនិញមកពីបណ្ដាភូមិភាគ និងរៀបចំសម្រាប់នាំចេញ[១២២៣] ទៅផែកំពង់សោម[១២២៤] និងក្រុមហ៊ុន រ៉ឺនហ្វុង (Ren Fung) ដែលជាក្រុមហ៊ុនមានការិយាល័យនៅទីក្រុង ហុងកុង បង្កើតឡើងដោយគណៈកម្មាធិការពាណិជ្ជកម្ម។ ក្រុមហ៊ុនរ៉ឺនហ្វុង និង ហ្វ៊ត្រា (FORTRA)[១២២៥] ធ្វើឲ្យកម្ពុជា

---

[១២២១] កំណត់ហេតុអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារ E3/165 ចុះថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៤៨-៤៩ ERN (ភាសាខ្មែរ) 00053635។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម លួត) ទំព័រ ១៣-១៥។

[១២២២] ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម លួត) ទំព័រ ១២-១៣។

[១២២៣] ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ឹម ហោ) ទំព័រ ៦៩-៧០, ទំព័រ ៧៩-៨០។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ឹម ហោ ឯកសារ E3/472 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00170626-00170627។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ិន គុជ ឯកសារ E3/437 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00373523-00373524។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន រី ឯកសារ E3/4624 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ២៣-២៤ ERN (ភាសាខ្មែរ) 00055300-0005530។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ុត ណា ឯកសារ E3/5647 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ ទំព័រ ១០ ERN (ភាសាខ្មែរ) 00054410។ ទោះបីជាតាមផ្លូវការ ឃ្លាំងរដ្ឋនៅភ្នំពេញប្រតិបត្តិការដោយ គណៈកម្មាធិការមួយដែលដឹកនាំដោយ “សមមិត្តរឿង” ឃ្លាំងរដ្ឋទាំងនោះទំនង ជាស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ គណៈកម្មាធិការពាណិជ្ជកម្ម: ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ) ទំព័រ ២០-២១, ៥៤-៥៥។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/235 ចុះថ្ងៃទី ១៩-២១ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00019143។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ រស់ ស៊ុយ ឯកសារ E3/4594 ទំព័រ ១៨-២០ ERN (ភាសាខ្មែរ) 00008345-00008347 (ដោយថ្លែងថា ឌឿន ធ្វើទស្សនកិច្ចនៅឃ្លាំងនានាជាញឹកញាប់)។ *សូមមើលបន្ថែម* ផ្នែកទី ៨ ស្ដីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៦ ។

[១២២៤] ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ឹម ហោ) ទំព័រ ៦៩-៧០។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន រី ឯកសារ E3/4624 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ២១-២៣ ERN (ភាសាខ្មែរ) 00055298-00055300 (ដោយថ្លែងថាកំពង់ផែកំពង់សោមស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈកម្មាធិការ ពាណិជ្ជកម្ម រហូតដល់ឆ្នាំ១៩៧៦)។

[១២២៥] ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម លួត), ទំព័រ ៥៧-៥៨។ វិក្កយបត្រលក់សណ្ដែកបាយឲ្យទៅចិន ឯកសារ E3/2056 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00663869 ។ លិខិតរបស់ FORTRA ផ្ញើជូនក្រុមហ៊ុនរ៉ឺនហ្វ៊ុង ហុងកុង ឯកសារ E3/1619 (also ឯកសារ E3/1620, ឯកសារ E3/1735 និង ឯកសារ E3/2517) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00278325-00278326។

ប្រជាធិបតេយ្យធ្វើពាណិជ្ជកម្មនៅលើទីផ្សារអន្តរជាតិ[១២២៦]។ វន វ៉េត រក្សាតួនាទីត្រួតពិនិត្យរហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ប៉ុន្តែគាត់មិនគ្រប់គ្រងផ្ទាល់ជាប្រចាំទៅលើគណៈកម្មាធិការពាណិជ្ជកម្មនេះទេ[១២២៧]។

៤០៤. ក្រោយពី វន វ៉េត ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីភ្លាម គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុនីស្តកម្ពុជាបានតែងតាំង វ៉ាន់ រិត, ព្រំ ញ៉ែម ហៅ ទិត, ស៊ុន ហៅ ញ៉ែម និង "សមមិត្តឈឿន" ជាសមាជិកនៃគណៈកម្មាធិការពាណិជ្ជកម្ម[១២២៨]។ ប៉ុន្មានសប្តាហ៍ក្រោយមក ពោលគឺនៅថ្ងៃ ទី០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍ បានចាត់តាំង នង សួន ហៅ ជ័យ

---

[១២២៦] ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម ល្មុត) ទំព័រ ៥០-៦០។

[១២២៧] ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម ល្មុត) ទំព័រ ៣០-៣១។(ដោយបានថ្លែងថា វន វ៉េត "មើលខុសត្រូវ"ខាងពាណិជ្ជកម្មនិងឧស្សាហកម្ម ប៉ុន្តែមិនមែនជាប្រធានគណៈកម្មាធិការទេ)។ ប្រតិចារឹក ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១២ (សគឹម ល្មុត),ទំព័រ ២០-២១ (ដែលបង្ហាញថាគាត់មិនឃើញ វន វ៉េត នៅកន្លែងគណៈកម្មាធិការពាណិជ្ជ-កម្មឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ២២-២៣ (ដោយថ្លែងថា វន វ៉េត ត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៨)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* ឯកសារ E3/20 ទំព័រ ៤២៩-៤៣០ ERN (ភាសាខ្មែរ) 00232427-00232428 (ដោយបញ្ជាក់អំពីការចាប់ខ្លួន វន វ៉េត នៅខែវិច្ឆិកា ឆ្នាំ១៩៧៨)។ សៀវភៅនិពន្ធដោយ D. Chandler៖ *សម្លេងពីមន្ទីរ ស-២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* ឯកសារ E3/1684 ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00191853-00191854 (ដោយយោងដល់ការសម្លាប់ វន វ៉េត នៅ មន្ទីរ ស-២១ នៅឆ្នាំ១៩៧៨)។ *សូមមើលបន្ថែម* ផ្នែកទី ៨ ស្តីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៦ ។

[១២២៨] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/235 ចុះថ្ងៃទី ១៩-២១ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00019142។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធឹង លាប ឯកសារ E3/5224 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00236038-00236039។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អួង ធា ឯកសារ E3/5223 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00236043-00236044។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម ហោ ឯកសារ E3/363 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00236033។ Timothy Carney "ការរៀបចំអំណាច" *នៅក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ ១៩៧៥-១៩៧៨៖ ការណាត់ជួបនឹងមរណៈ* ឯកសារ E3/49 ទំព័រ ១០១ ERN (ភាសាអង់គ្លេស) 00105150 (ដែលទាំងអស់នេះសុទ្ធតែបញ្ជាក់ថា 'ញ៉ែម' នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម គឺជា ព្រំ ញ៉ែម ហៅ ទិត ស៊ុន ដែលគ្រប់គ្រងកំពង់ផែកំពង់សោម)។ ញ៉ែម ចុងក្រោយត្រូវបានចាប់ខ្លួន និងយកទៅដាក់ ស-២១: បញ្ជីអ្នកទោសនៅ ស-២១ ដែលបានពិនិត្យឡើងវិញ ឯកសារ E3/342 ទំព័រ ៤៧០ ERN (ភាសាខ្មែរ) 00330065។

ដែលទទួលបន្ទុកកសិកម្ម[១២២៩] "ឲ្យមកកាន់កាប់ពាណិជ្ជកម្ម"។ សឿ វ៉ាស៊ី ហៅ ឌឿន ក៏ត្រូវបានបញ្ជាឲ្យ "ចុះទៅកាន់ផ្នែកពាណិជ្ជកម្ម" រហូតដល់ខែ កក្កដា ឆ្នាំ ១៩៧៦ ដោយធ្វើការនៅមន្ទីរ ៨៧០ ផង និងធ្វើការនៅផ្នែកពាណិជ្ជកម្មនេះផង[១២៣០]។ អង្គជំនុំជម្រះមិនអាចកំណត់បានថាតើ នង សួន មានតួនាទីភារកិច្ចអ្វីទាក់ទិននឹងគណៈកម្មាធិការពាណិជ្ជកម្ម ប្រសិនបើមាន។ សាក្សី កាំង ហ្គេកអ៊ាវ បានប្រាប់សហចៅក្រមស៊ើបអង្កេតថា ឌឿន គឺជាអ្នកកាន់កាប់គណៈកម្មាធិការនោះក្រោយពី កុយ ធួន ត្រូវបានចាប់ខ្លួន[១២៣១]។ ទោះយ៉ាងណាក៏ដោយ គណៈកម្មាធិការពាណិជ្ជកម្មបានចាប់ផ្ដើមរាយការណ៍ទៅ ឌឿន ត្រឹមខែ សីហា ឆ្នាំ ១៩៧៦[១២៣២] ហើយនៅត្រឹមខែ វិច្ឆិកា ឆ្នាំ ១៩៧៦ នង សួន ត្រូវបានចាប់ខ្លួនយកទៅមន្ទីរ ស-២១[១២៣៣]។

៤០៥. នៅខែ តុលា ឆ្នាំ ១៩៧៦ គណៈកម្មាធិការពាណិជ្ជកម្មឈប់ធ្វើរបាយការណ៍ជូន ឌឿន[១២៣៤]។ ក្រោយពីពេលនោះមក វ៉ាន់ រិត បានក្លាយទៅជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម (រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម) ជាតំណែងមួយដែលគាត់កាន់កាប់រហូតដល់ចុងសម័យកម្ពុជាប្រជាធិបតេយ្យ[១២៣៥]។ ឌឿន ត្រូវបានចាប់ខ្លួននៅខែ កុម្ភៈ ឆ្នាំ ១៩៧៧[១២៣៦]។

---

[១២២៩] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ), ទំព័រ ១៨-១៩ (ដែលបំភ្លឺបញ្ជាក់ថា 'សមមិត្តជ័យ' គឺ នង សួន)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stepen HEDER), ទំព័រ ២៣-២៤។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00019109-00019110។

[១២៣០] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/220 ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00000827។

[១២៣១] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ E3/355 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00239832។

[១២៣២] របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2036 ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៧៦។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2037 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦។ របាយ-ការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3568 ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៧៦។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2038 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគីម ល្មុត) ទំព័រ ៨-៩។

[១២៣៣] ចម្លើយរបស់ ជ័យ សួន នៅមន្ទីរ ស-២១ ឯកសារ E190.1.14 ចុះថ្ងៃទី ១៧-២០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។

[១២៣៤] *សូមមើល* ផ្នែកទី ៨ ស្ដីពី តួនាទី និងមុខងាររបស់ ខៀវ សំផន *ជើងទំព័រ* ១២៣៨ ។

[១២៣៥] ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ុំ ហោ) ទំព័រ ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគីម ល្មុត) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន), ទំព័រ ៨០។

៤០៦. ទោះបីជា ខៀវ សំផន មិនដែលបានធ្វើជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក៏ដោយ ក៏ឯកសារដែលនៅសេសសល់បង្ហាញថា ខៀវ សំផន មានតួនាទីសំខាន់ទាក់ទិននឹងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យដែលស្របនឹងការសារភាពរបស់គាត់ថា គាត់ជាសមាជិកមន្ទីរ ៨៧០ ទទួលបន្ទុកពាណិជ្ជកម្ម[១២៣៧]។ នៅខែ តុលា ឆ្នាំ ១៩៧៦ គណៈកម្មាធិការពាណិជ្ជកម្មបានចាប់ផ្ដើមរាយការណ៍ជូន ខៀវ សំផន មិនមែនរាយការណ៍ជូន ខៀន ឡើយ[១២៣៨]។ ឯកសារនានាដែលផ្ញើជូន ឬចម្លងជូន ខៀវ សំផន រួមមាន របាយការណ៍នៃការពិភាក្សាជាមួយគណៈប្រតិភូពាណិជ្ជកម្មបរទេស និងទំនាក់ទំនងផ្សេងៗទៀត ទាក់ទិននឹងពាណិជ្ជកម្មអន្តរជាតិ[១២៣៩] របាយការណ៍ស្ដីពីបរិមាណស្រូវ អង្ករ ដែលបញ្ជូនទៅឃ្លាំងរដ្ឋពីសំណាក់ភូមិភាគនានា និងរបាយការណ៍ស្ដីពីការនាំចេញស្រូវ អង្ករ

---

កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យិន អេង ឯកសារ E3/473 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00205040 ។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន រី ឯកសារ E3/4624 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ២៦-២៧ ERN (ភាសាខ្មែរ) 00055303-00055304 ។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ុត ណា ឯកសារ E3/5647 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០២ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00054381-00054382 ។ របាយការណ៍មួយចំនួនរបស់គណៈកម្មាធិការពាណិជ្ជកម្មមានហត្ថលេខារបស់ វ៉ាន់ រិត។ *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2507 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៧៧។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2527 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2510 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៨។ លិខិតរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1640 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/319 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[១២៣៦] *សូមមើល* ផ្នែកទី ៨ ស្ដីពី តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៩២ *ជើងទំព័រ* ១១៩។

[១២៣៧] *សូមមើល* ផ្នែកទី ៨ ស្ដីពីតួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៩១ ។

[១២៣៨] *សូមមើល* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2038 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៨៦ (របាយការណ៍ចុងក្រោយបង្អស់ជូនចំពោះ"បងខៀនជាទីគោរពស្នេហា")។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2040 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៦ (របាយការណ៍ដំបូងបង្អស់ជូនចំពោះ "បង ហែម ជាទីគោរពស្នេហា")។

[១២៣៩] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2040 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៦។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/304 ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1616 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3510 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៧។ លិខិតរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1640 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៨។

និងទំនិញផ្សេងៗទៀត[១២៤០] សំណើសុំទិញពីក្រសួងនានា និងបញ្ជីសម្ភារៈនាំចូលពីប្រទេសចិន[១២៤១] របាយការណ៍ស្ដីពីការប្រើប្រាស់ឥណទានរបស់ចិនពីសំណាក់កម្ពុជាប្រជាធិបតេយ្យ[១២៤២] និងសារផ្ញើទៅមករវាងហ្វ័ត្រា (FORTRA) និង រ៉ែនហ្វុង (REN FUNG)[១២៤៣]។ គណៈកម្មាធិការពាណិជ្ជកម្មជាញឹកញាប់បានស្នើសុំ សេចក្ដីណែនាំ និងយោបល់ពី ខៀវ សំផន[១២៤៤]។ របាយការណ៍ទាំងនោះគឺ

---

[១២៤០] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3511 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៧។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ ស្ថិតិនាំចូល (ពីខែ មករា ដល់ខែ កញ្ញា) និងស្ថិតិនាំចេញក្នុងឆ្នាំ ១៩៧៤ (ពីខែ មករា ដល់ខែ កញ្ញា) ឯកសារ E3/2059 ឆ្នាំ ១៩៧៨។ ស្ថិតិនាំចេញរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3533 ឆ្នាំ ១៩៧៨។

[១២៤១] *សូមមើល ឧទា.* បញ្ជីសំណើទិញ ឯកសារ E3/3516 ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម៖ បញ្ជីសម្ភារៈនាំចូលពីប្រទេសចិន តាមកប៉ាល់ សៀង សាន ឯកសារ E3/3413 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៧។ បញ្ជីសម្ភារៈនាំចូលរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3518 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨។ បញ្ជីសម្ភារៈនាំចូលរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3528 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៨។ បញ្ជីសម្ភារៈនាំចូលរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3534 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៧៨។

[១២៤២] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/325 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៧។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/329 ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/311 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/317 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/319 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[១២៤៣] *សូមមើល ឧទា.* លិខិតរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/324 ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៧៧។ លិខិត FORTRA ឯកសារ E3/2525 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៨។ លិខិត FORTRA ឯកសារ E3/2521 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ លិខិត FORTRA ឯកសារ E3/2520 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៧៨។

[១២៤៤] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1615 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ២ ERN (ភាសាខ្មែរ) 00067709។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3514 ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN(ភាសាខ្មែរ) 00002856-00002857។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3455 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៧៨។ លិខិតរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/334 ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទំព័រ ១ ERN (ភាសាខ្មែរ) 00069092។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3461 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00188538។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1637 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00278399-00278400។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ (សតីម ល្មុត) ទំព័រ ៨-១០ (ដែលជាការបញ្ជាក់ថា វ៉ាន់ រិត ពុំអាចធ្វើសេចក្ដីសម្រេចមួយចំនួន ហើយត្រូវគោរពតាម វន វ៉េត និង ខៀវ សំផន) ។

ច្រើនតែចម្លងជូន ប៉ុន្តែមិនផ្ញើជូនចំឈ្មោះ វន វ៉េត ឡើយ។ ឈ្មោះ វន វ៉េត ជាទូទៅសរសេរបន្ទាប់ពីឈ្មោះ ខៀវ សំផន នៅក្នុងបញ្ជីឈ្មោះអ្នកទទួល[១២៤៥]។ មានតែរបាយការណ៍តិចតួចប៉ុណ្ណោះដែលត្រូវបានផ្ញើចេញ ឬចម្លងជូន វន វ៉េត តែម្នាក់[១២៤៦]។ ខៀវ សំផន បន្តទទួលរបាយការណ៍ និងលិខិតអំពីបញ្ហាពាណិជ្ជកម្ម ក្រោយពី វន វ៉េត ត្រូវបានចាប់ខ្លួន[១២៤៧]។

៤០៧. ខៀវ សំផន បានទៅមើលឃ្លាំងរដ្ឋជាមួយ វ៉ាន់ រិត ដែលនៅទីនោះ ខៀវ សំផន បានពិនិត្យផលិតផលដែលត្រូវនាំចេញ និង ជំរុញឱ្យកម្មករប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់[១២៤៨]។ តាមរយៈការសារភាពរបស់ខ្លួន ខៀវ សំផន មានការទទួលខុសត្រូវផ្នែកចែកចាយទំនិញទៅបណ្តាភូមិភាគ[១២៤៩]។ សាក្សី ខៀវ នៅ និង សៅ សារុន រម្លឹកថាខ្លួនបានផ្ញើសំណើទៅ ខៀវ សំផន សុំ

---

[១២៤៥] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/2054 ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។ របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្មៈ បញ្ជីសម្ភារៈនាំចូលពីប្រទេសចិន តាមកប៉ាល់ សៀង សាន ឯកសារ E3/3413 ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៧៧។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/1613 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/327 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៧៧។ បញ្ជីសំណើទិញរបស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3516 ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3460 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3566 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៧៨។ បញ្ជីសម្ភារៈរបស់គណៈកម្មាធិការពាណិជ្ជកម្ម នាំចូល ឯកសារ E3/4548 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[១២៤៦] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/3453 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៧៦។

[១២៤៧] *សូមមើល ឧទា.* របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ឯកសារ E3/829 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៧៨។ លិខិត FORTRA ឯកសារ E3/2520 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៧៨។

[១២៤៨] ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ (ស៊ឹម ហោ) ទំព័រ ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ), ទំព័រ ២៧-២៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ឯកសារ E3/469 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00172051-00172052។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ិន គុជ ឯកសារ E3/437 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00373523-00373524។

[១២៤៩] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៩-៧០ ។ សៀវភៅនិពន្ធដោយ ខៀវ សំផនៈ *ប្រវត្តិសាស្ត្រកម្ពុជា ថ្មីៗ នេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១៦៨-១៦៩, ១៨១-១៨២ ERN (ភាសាខ្មែរ) 00103892, 00103898-00103899។

បែងចែកសម្ភារៈមួយចំនួនទៅកាន់ភូមិភាគរបស់ខ្លួន[១២៥០]។ សាក្សី នង សុផង់ និង ផាន វ៉ាន សុទ្ធតែជាអ្នកសរសេរ និងបកប្រែទូរលេខ។ សាក្សីទាំងពីររូបបានឃើញសំណើសុំសម្ភារៈដែលផ្ញើទៅ និងបញ្ជាឲ្យចែកចាយដោយ ខៀវ សំផន[១២៥១]។

## ៨.៤ សេចក្តីសន្និដ្ឋាន

៤០៨. ខៀវ សំផន អះអាងថា ឋានៈរបស់ខ្លួនជាបញ្ញវន្តបានធ្វើឲ្យខ្លួនលែងនៅកៀកជាមួយនឹងក្រុមផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា[១២៥២]។ ប៉ុន្តែ តាមការពិត តួនាទីរបស់ ខៀវ សំផន នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យបង្ហាញថា ខៀវ សំផន មានជំនឿចិត្ត និងទំនុកចិត្តពីសំណាក់សមាជិកមជ្ឈិមបក្សដទៃទៀត[១២៥៣]។ ខៀវ សំផន ត្រូវបានគេជឿទុកចិត្តឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅក្នុងនោះ ព័ត៌មានត្រូវផ្សព្វផ្សាយ ហើយសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង។ ខៀវ សំផន ក៏ត្រូវបានគេជឿទុកចិត្តឲ្យរស់នៅ និងធ្វើការកៀកជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតរបស់បក្សកុម្មុនីស្តកម្ពុជាទាំងនៅមុនឆ្នាំ ១៩៧៥ និងបន្ទាប់មក នៅមន្ទីរ ក-៣ និងមន្ទីរ ក-១។ ខៀវ សំផន ត្រូវបានគេជឿ

[១២៥០] ប្រតិចារឹក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ (ខៀវ នៅ) ទំព័រ ៣៧-៣៨។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន), ទំព័រ ៤៨-៤៩ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឯកសារ E3/367 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00251439-00251440។

[១២៥១] ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២(នង សុផង់) ទំព័រ៤៥-៤៦។ ប្រតិចារឹក ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៣៥ ។ ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ផាន វ៉ាន) ទំព័រ ៨-៩។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៣-៦៤ (ដោយថ្លែងថា សំណើសុំ “សម្ភារៈចែកចាយទៅមូលដ្ឋាន”ក៏ត្រូវបានស្នើទៅ ខៀវ សំផន ផងដែរតាមរយៈទូរស័ព្ទ) ។

[១២៥២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦២-៦៣, ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (ខៀវ សំផន), ទំព័រ ៥១-៥២។ ប្រតិចារឹក ថ្ងៃ ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៥៣-៥៩។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៦៨-៧៤ (ដោយពន្យល់ថា បកក បានបែងចែកដាច់ពីគ្នាជាសម្ងាត់រវាងសមាជិកបក្ស និង “រណសិរ្ស” ហើយ សមាជិករណសិរ្ស ត្រូវបានប្រើជាអ្នកកាទូតសម្រាប់ទំនាក់ទំនងជាមួយបរទេស។)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/362 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00210211-00210212។

[១២៥៣] ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣៣-៣៥ ។ (Philip SHORT) ទំព័រ ២២។

ទុកចិត្តឲ្យធ្វើជាតំណាងរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងនៅក្នុងដំណើរទៅក្រៅប្រទេសទៀតផង។

៤០៩. បើទោះបីជា ខៀវ សំផន បានកាន់តួនាទីជាច្រើនក្តី ប៉ុន្តែភ័ស្តុតាងបង្ហាញថា ខៀវ សំផន មានសិទ្ធិធ្វើសេចក្តីសម្រេចតែទៅលើបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្ម មួយចំនួនប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ខៀវ សំផន មានសិទ្ធិអំណាចធំជាងនេះ តាមរយៈតំណែងជាន់ខ្ពស់របស់គាត់ ដូចដែលបានស្តែងចេញតាមរយៈសមត្ថភាពក្នុងការធានាសុវត្ថិភាពនៃសមាជិកគ្រួសារមួយចំនួនរបស់គាត់នៅជនបទ។ តាមរយៈវត្តមានរបស់ខ្លួននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងមន្ទីរ៨៧០ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម និងអត្ថន័យនៃសុន្ទរកថានានាដែលខ្លួនបានរៀបរៀង ខៀវ សំផន ពិតជាបានដឹងឮអំពីគោលនយោបាយ និងមានសិទ្ធិទទួលព័ត៌មានអំពីសភាពការណ៍ទូទៅនៅក្នុងប្រទេសកម្ពុជា រួមទាំងការដឹងអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ជាច្រើន ដូចជា កុយ ធួន, ឌឿន និង វន វ៉េត។

## ៩. ច្បាប់ជាធរមានៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

### ៩.១ ការធ្វើមនុស្សឃាត

៤១០. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទការធ្វើមនុស្សឃាត ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[១២៥៤]។

៤១១. ពុំមានការជំទាស់ទេដែលថា ការធ្វើមនុស្សឃាតត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាឆ្នាំ ១៩៧៥[១២៥៥]។ ពាក់ព័ន្ធ

---

[១២៥៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៥, ១៣៧៧, ១៣៧៩-១៣៨០។ *សូមមើលផងដែរ* ឧបសម្ព័ន្ធៈ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង ០០២/ ០១ ដែលត្រូវបានកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ២។

នឹងការវិវត្តនៃបទឧក្រិដ្ឋនេះបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ជនជាប់ចោទអាចប្រមើលមើលបានថា ក្នុងនាមជាសមាជិកនៃអាជ្ញាធរដែលមានអំណាចត្រួតត្រាប្រទេសកម្ពុជា ជនជាប់ចោទអាចនឹងត្រូវចោទប្រកាន់ពីបទការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីឆ្នាំ១៩៧៥។ លើសពីនេះទៀត និយមន័យនៃការធ្វើមនុស្សឃាត ដែលបានវិវត្តន៍នៅក្រោយយុត្តិសាស្ត្រដែលមានបន្ទាប់ពីសង្គ្រាមលោកលើកទី២ ក៏អាចឲ្យជនជាប់ចោទដឹងច្បាស់នាពេលនោះផងដែរ។

៤១២. យុត្តិសាស្ត្រនានា ដែលបានបញ្ជាក់អំពីភាពខុសគ្នារវាងសំណៅជាភាសាអង់គ្លេស និងភាសាបារាំងនៃឯកសារដែលពាក់ព័ន្ធនាសម័យនោះ បានកំណត់ថា វាគឺជាការធ្វើមនុស្សឃាត (“*meurtre*”) និងមិនមែនជាឃាតកម្មគិតទុកជាមុន (“*assassinat*”) នោះទេ ដែលកំណត់ជាបទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ[១២៥៦]។ ធាតុផ្សំរបស់បទល្មើសការធ្វើមនុស្សឃាតមានដូចខាងក្រោម៖

---

[១២៥៥] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៣១។ *សូមមើលផងដែរ* មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការ Nuremberg (ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងឆ្នាំ ១៩៤៥ សម្រាប់ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជន សំខាន់ៗនៃឧក្រិដ្ឋកម្មសង្គ្រាមរបស់ក្រុមសម្ព័ន្ធមិត្តអឺរ៉ុប) ដែលចាត់ទុកការធ្វើមនុស្សឃាតថាជាបទល្មើសជាក់លាក់ ដែលស្ថិតនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការធ្វើមនុស្សឃាត (ឬ “ការធ្វើមនុស្សឃាតគិតទុកជាមុន” ក្នុងសំណៅឯកសារបារាំង) ត្រូវបានដាក់បញ្ចូលទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរក្នុងមាត្រា II (គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ឆ្នាំ ១៩៤៥ និង មាត្រា ៥(គ) នៃធម្មនុញ្ញ Tokyo និងសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៩៥(ឈ) (ឯកភាពលើគោលការណ៍របស់តុលាការ Nuremberg និងចាត់ទុកការធ្វើមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។ *សូមមើលផងដែរ* របាយការណ៍ ILC ១៩៥០, គោលការណ៍ VI(គ) (ឯកភាពថា ការធ្វើមនុស្សឃាតគឺជាបទល្មើសមួយដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទូទៅ) (ឬ “ការធ្វើមនុស្សឃាតគិតទុកជាមុន” ក្នុងសំណៅឯកសារបារាំង) និងសាលក្រមរបស់តុលាការ*Nuremberg*,ទំព័រ ២៩១-២៩៣, ៣០១ (ផ្តន្ទាទោសជនជាប់ចោទ Kaltenbrunner និងFrickពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមទាំងការធ្វើមនុស្សឃាតមួយផង)។ *សូមមើលបន្ថែមទៀត* សាលក្រម*ផ្នែកវេជ្ជសាស្ត្រ* ទំព័រ ១៩៨, ២០៧, ២៤០-២៤១, ២៤៨, ២៦៣, ២៧១, ២៩០ (អនុលោមតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងផ្តន្ទាទោសជនជាប់ចោទ Karl Brandt, Handloser, Rudolf Brandt, Mrugowsky, Sievers, Rose និង Hoven ពីបទធ្វើមនុស្សឃាតដែលជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងតួនាទីរបស់ពួកគេនៅក្នុងការធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រ និងកម្មវិធីសម្លាប់អ្នកជំងឺ (euthanasia)។

[១២៥៦] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥៥៨។ សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២១៦។

(១) អំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬ របស់ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬ អកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ និង

(២)ចេតនារបស់ជនជាប់ចោទ ឬ ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់នេះ ឬ ការបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថាអំពើសកម្ម ឬ អកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស[១២៥៧]។

៤១៣. ធាតុផ្សំនៃការធ្វើមនុស្សឃាតអាចនឹងត្រូវបំពេញ ទោះបីជាសាកសពរបស់ជនរងគ្រោះត្រូវបានរកឃើញ ឬ មិនត្រូវបានរកឃើញក្តី។ អង្គហេតុនៃការបាត់បង់ជីវិតរបស់ជនរងគ្រោះអាចត្រូវបានសន្និដ្ឋានតាមរយៈការបង្ហាញភ័ស្តុតាងនានា ។ អ្វីដែលតម្រូវឱ្យធ្វើការសន្និដ្ឋានពីភ័ស្តុតាងនោះ គឺការទាញសេចក្តីសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ដែលថា ជនរងគ្រោះស្លាប់ដោយសារអំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬ ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើនោះ[១២៥៨]។

## ៩.២ ការសម្លាប់រង្គាល

៤១៤. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទសម្លាប់រង្គាលដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[១២៥៩]។

---

[១២៥៧] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣១, ៣៣៣។ សាលដីកាក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៣៧។

[១២៥៨] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣២។ សាលដីកាក្នុងរឿងក្តី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ២៦០។

[១២៥៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១, ១៣៨៧-១៣៨៩។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុង

ដីកាដំណោះស្រាយបានចោទប្រកាន់ថា "មនុស្សជាច្រើន" បានស្លាប់ដែលជាលទ្ធផលនៃលក្ខខណ្ឌដែលមាននៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) ជាពិសេស ដោយសារការទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និង អនាម័យ[១២៦០]។

៤១៥. ពុំមានការជំទាស់ទេដែលថា ការសម្លាប់រង្គាលត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ ១៩៧៥[១២៦១]។ ហេតុដូចនេះ ជនជាប់ចោទអាចប្រមើលមើលដឹងថា ក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា ជនជាប់ចោទអាចនឹងត្រូវចោទប្រកាន់ពីបទការសម្លាប់រង្គាល ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីឆ្នាំ១៩៧៥ ហើយពួកគាត់ក៏អាចយល់ដឹងពីនិយមន័យនៃការធ្វើមនុស្សឃាតនៅពេលដែលឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់នោះ ត្រូវបានប្រព្រឹត្ត។

៤១៦. *ធាតុផ្សំសត្យានុម័ត* (អំពើឧក្រិដ្ឋ) នៃការសម្លាប់រង្គាលរួមមាន អំពើសកម្ម អំពើអកម្ម ឬ ការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឲ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[១២៦២]។ ការកំណត់ទៅលើការសម្លាប់រង្គាលមិនចាំបាច់ត្រូវបង្ហាញនូវចំនួននៃជនរងគ្រោះក្នុងកំរិតអប្បបរមាណាមួយនោះទេ[១២៦៣]។ លក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំ ត្រូវវាយតម្លៃទៅតាមករណីនីមួយៗដោយ

---

ការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ២។

[១២៦០] ដីកាដំណោះស្រាយ កថាខណ្ឌ កថាខណ្ឌ ១៣៨៧ (យោងទៅស្ថានភាពក្នុងមន្ទីរសន្តិសុខផងដែរ)។

[១២៦១] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៣៤។*សូមមើលផងដែរ* មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការ Nuremberg (ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងឆ្នាំ ១៩៤៥ សម្រាប់ការចោទប្រកាន់ និង ការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជនសំខាន់ៗនៃឧក្រិដ្ឋកម្មសង្គ្រាមរបស់ក្រុមសម្ព័ន្ធមិត្តអឺរ៉ុប) ចាត់ទុកការសម្លាប់រង្គាលជាបទល្មើសជាក់លាក់ដែលស្ថិតនៅក្រោមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សាលក្រមរបស់តុលាការ *Nuremberg*, ទំព័រ ២៨៧-២៨៨, ២៩១-២៩៣, ២៩៥-២៩៦, ៣០០-៣០១ (ផ្តន្ទាទោសជនជាប់ចោទ Von Ribbentrop, Kaltenbrunner, Rosenberg, Frank និង Frick ពីបទសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។

[១២៦២] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៣៤។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៨៩។

[១២៦៣] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៣៦។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៦០។ សារណារបស់ក្រុមមេធាវីការពារក្តី NUON Chea ដែលថា ជនរងគ្រោះ "ត្រូវតែក្រុមមួយដែលមានចំនួនជាតួលេខសមស្រប" ត្រូវបានបដិសេធ ដោយសារសារណានោះលើកឡើងថា ជនរងគ្រោះត្រូវតែមានចំនួនអប្បបរមាមួយជាចាំបាច់។ *សូមមើល* សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ របស់ក្រុមមេធាវី

ផ្នែកលើកត្តានៃពេលវេលា និងទីកន្លែងនៃការសម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងអំពីការសម្លាប់ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែទៅលើជនរងគ្រោះម្នាក់ៗ[១២៦៤]។ ចារីអាចចូលរួមប្រព្រឹត្តពីចម្ងាយ ឬ ដោយប្រយោល[១២៦៥] និងអាចរួមបញ្ចូលទាំងការបង្កើតនូវលក្ខខណ្ឌនៃការរស់នៅ ដែលមានគោលបំណងកំទេចប្រជាជន ដូចជាការមិនផ្គត់ផ្គង់ម្ហូបអាហារ ឬ ថ្នាំពេទ្យជាដើម[១២៦៦]។

៤១៧. *ធាតុផ្សំអត្តនោម័ត* (ចេតនាឧក្រិដ្ឋក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋ) នៃការសម្លាប់រង្គាលរួមមានចេតនា៖

(១) សម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ

(២) បង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬ បង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការស្លាប់ដោយមានហេតុផលដឹងថា អំពើសកម្ម ឬ អកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្សជាច្រើន (*ចេតនាដោយមិនចំពោះ*)[១២៦៧]។

ទោះបីជា*ធាតុផ្សំអត្តនោម័ត* ចំពោះបទឧក្រិដ្ឋនៃការសម្លាប់រង្គាលពុំត្រូវបានកំណត់និយមន័យយ៉ាងស៊ីសង្វាក់គ្នានៅក្នុងយុត្តិសាស្ត្រនៃតុលាការ ICTY និងតុលាការ ICTR ក៏ដោយ ក៏យុត្តិសាស្ត្ររបស់តុលាការកំពូលនៃតុលាការទាំងនេះ ហាក់ដូចឈានទៅលុបចោល*ចេតនាដោយមិនចំពោះ*

ការពារក្តី នួន ជា ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២១៥។ សារណារបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលថា"ការសម្លាប់មនុស្សម្នាក់ ឬ ការសម្លាប់មនុស្សក្នុងចំនួនកំណត់មួយ មិនអាចចាត់ទុកថាជាការសម្លាប់រង្គាល" ដែលមិនចាំបាច់ចាត់ទុកថាជាសេណារីយ៉ូមួយ គឺមិនពាក់ព័ន្ធនឹងអង្គហេតុនៃករណីនេះនោះទេ។ *សូមមើល*ឧបសម្ព័ន្ធ ក៖ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/10.2 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦។

[១២៦៤] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣៦។ សាលដីកាក្នុងរឿងក្តី *Lukić និង Lukić* កថាខណ្ឌ ៥៣៨។

[១២៦៥] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣៥។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៨៩។

[១២៦៦] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣៥។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៨៩។ សាលក្រមក្នុងរឿងក្តី *Krstic* កថាខណ្ឌ ៤៩៨។

[១២៦៧] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៣៨។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៤៩៥។

ចេញពីនិយមន័យនៃ*ធាតុផ្សំអត្តនោម័ត*ចំពោះការសម្លាប់រង្គាល[១២៦៨]។ អង្គជំនុំជម្រះយល់ឃើញថា មិនមានមូលដ្ឋានណាមួយអាចឱ្យអង្គជំនុំជម្រះសាលាដំបូង ងាកចេញពីវិធីសាស្ត្រដំបូងដែលបាន អនុវត្តនៅក្នុងសាលក្រមក្នុងរឿងក្តី *Krstic* ដែលក្តោបរួមទាំង *ចេតនាដោយមិនចំពោះ* និង យុត្តិសាស្ត្រដែលមាននៅមុនឆ្នាំ១៩៧៥ នោះទេ។

៤១៨. ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សារណាចំនួនពីរ ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តនៃ ការសម្លាប់រង្គាលនេះ។ សារណាទីមួយ គឺបានផ្អែកលើសាលក្រមក្នុងរឿងក្តី *Vasiljević* ដែល លើកឡើងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ តម្រូវឱ្យជនជាប់ចោទបានដឹងថា អំពើ របស់ខ្លួនគឺជាផ្នែកមួយនៃ "ការសម្លាប់ក្នុងទ្រង់ទ្រាយធំមួយ" ដែលក្នុងនោះ មានមនុស្សមួយចំនួន ធំត្រូវបានកំណត់ជាគោលដៅសម្រាប់ការសម្លាប់។ សារណាទីពីរ គឺបានផ្អែកលើសាលក្រមក្នុង រឿងក្តី *Bagosora* ដែលលើកឡើងថាបទដ្ឋានត្រឹមត្រូវនៃធាតុផ្សំអត្តនោម័ត តម្រូវឱ្យជនជាប់ចោទ មានចេតនាសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ បង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការ ស្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ មានលក្ខណៈជាប្រព័ន្ធ (មានគូសបញ្ជាក់បន្ថែម)[១២៦៩]។

៤១៩. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាលដីកាក្នុងរឿងក្តី *Stakić* បានបដិសេធមិនចាត់ទុក "ការដឹងអំពីផែនការនៃការសម្លាប់រួម" ថាជាលក្ខខណ្ឌតម្រូវសម្រាប់ធាតុផ្សំអត្តនោម័តនៃការ សម្លាប់រង្គាលឡើយ ។ អង្គជំនុំជម្រះយល់ឃើញថា គ្មានការគាំទ្រចំពោះធាតុផ្សំដែលបានចោទ ប្រកាន់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការនោះទេ[១២៧០]។ ចំពោះថាតើការដឹងនេះគឺជាធាតុផ្សំមួយនៅ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ដែរ ឬ យ៉ាងណានោះ តាមការពិនិត្យលើសាលក្រម ក្នុងរឿងក្តី *Vasiljević* បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងនោះបានសន្និដ្ឋានថា លក្ខខណ្ឌតម្រូវ បែបនេះមានអត្ថិភាព ដោយផ្អែកលើសាលក្រមក្នុងរឿងក្តី *Eichmann* និងការផ្តន្ទាទោស ជនជាប់ចោទ Sauckel និង Fritzsche នៅតុលាការ Nuremberg[១២៧១]។ ពាក់ព័ន្ធនឹងការណ៍ដែល តុលាការ Nuremberg កំណត់យកការដឹងរបស់ជនជាប់ចោទអំពីផែនការទាំងឡាយ ដែលត្រូវបាន ចោទប្រកាន់ថា ជនជាប់ចោទបានចូលរួមនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការលើក

---

[១២៦៨] *សូមមើល ឧទាហរណ៍* សាលដីកាក្នុងរឿងក្តី *Lukić* កថាខណ្ឌ ៥៣៦ (ដែលប្រើប្រាស់ឃ្លា "នឹងនាំឱ្យ")។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥២២ ("នាំឱ្យ...ដោយជៀសមិនរួច")។

[១២៦៩] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ របស់ នួន ជា ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២១៦-២១៩។

[១២៧០] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៥៨។

[១២៧១] សាលក្រមក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ២២៤ និង ២២៨ (លេខចុងទំព័រ ៥៨៨)។

ឡើងទាំងនោះរបស់តុលាការ Nuremberg មិនបង្កើតបានជាលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័ត គ្រប់គ្រាន់នោះទេ ដោយការលើកឡើងរបស់តុលាការនេះគ្រាន់តែជាការឆ្លុះបញ្ចាំងអំពីអង្គហេតុនៃករណីនីមួយៗតែប៉ុណ្ណោះ[១២៧២]។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសារណារបស់ក្រុមមេធាវីការពារក្តី នួន ជា ។

៤២០. នៅក្នុងសារណាផ្សេងទៀតរបស់ខ្លួន ក្រុមមេធាវីការពារក្តី នួន ជា បានយោងទៅលើសាលក្រមក្នុងរឿងក្តី *Bagosora* ដែលសម្រេចថា "*ធាតុផ្សំអត្តនោម័ត* នៃការសម្លាប់រង្គាល តម្រូវ

---

[១២៧២] សាលក្រមរបស់សាលាក្តី Nuremberg ភាគ ១ ទំព័រ ២៨៧ (យល់ឃើញថា "កិច្ចខំប្រឹងប្រែងផ្នែកការទូតរបស់ Von Ribbentrop មានភាពពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធទៅនឹងសង្គ្រាម ដែលគាត់មិនអាចថា មិនដឹងអំពីអំពើហិង្សានៃសកម្មភាពរបស់ Hitler ឡើយ"), ទំព័រ ២៩៣ (យល់ឃើញថា Kaltenbrunner ក្នុងឋានៈជាប្រធាន RSHA បានទទួលព័ត៌មានអំពីសកម្មភាពរបស់ RSHA ក្នុងការ ត្រួសត្រាយដែនដីដែលខ្លួនកាន់កាប់ និងតំបន់រណបដទៃទៀតរបស់ក្រុមសម្ព័ន្ធមិត្ត ដើម្បីរៀបចំសម្រាប់ការនិរទេសជនជាតិជ្វីហ្វ (Jews) ទៅកាន់កន្លែងសម្រាប់សម្លាប់រង្គាលទាំងនេះ), ទំព័រ ២៩៥ (Rosenberg បានដឹងអំពីការប្រព្រឹត្តិយង់ឃ្នង និងភាពភ័យខ្លាចដែលប្រជាជននៅភាគខាងកើតបានទទួលរង...។ គាត់បានដឹង និងបានចូលរួមយ៉ាងសកម្មក្នុងការដកហូតវត្ថុធាតុដើម និងចំណីអាហារពីដែនដីភាគខាងកើត"), ទំព័រ២៩៨ (យល់ឃើញថា "Frank គឺជាអ្នកចូលរួមម្នាក់ដោយស្ម័គ្រចិត្ត និងដឹងមុន" នៅក្នុងកម្មវិធីដែលមានលក្ខណៈទូលំទូលាយ ឧទាហរណ៍ ការប្រើអំពើភេរវកម្ម ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចរបស់ប្រទេសប៉ូឡូញ ដែលនាំទៅរកការស្លាប់មនុស្សចំនួនច្រើន ដោយសារអត់អាហារ និងការនិរទេសជនជាតិ ប៉ូឡូញជាងមួយលាននាក់ទៅកាន់ប្រទេសអាល្លឺម៉ង់ ទៅឱ្យធ្វើជាទាសករ) ទំព័រ ៣០១ (យល់ឃើញថា ក្នុងឋានៈជាអាជ្ញាធរជាតិជាន់ខ្ពស់នៅ Bohemia និង Moravia "Frick បានដឹងយ៉ាងច្បាស់អំពីគោលនយោបាយត្រួតត្រាអឺរ៉ុបរបស់ពួក Nazi ជាពិសេសពាក់ព័ន្ធនឹងពួកជនជាតិជ្វីហ្វ (Jews)") ទំព័រ ៣១៩ (យល់ឃើញថា Von Schirach បានចូលរួមក្នុងការនិរទេសជនជាតិជ្វីហ្វ (Jews) ចេញពីទីក្រុងវីយែន (Vienna) បន្ទាប់ពីគាត់បានក្លាយជាប្រធានបក្សនៃទីក្រុងវីយែន (Vienna) និង "បានដឹងថាជនជាតិជ្វីហ្វ(Jews) ដឹងខ្លួនថាចៀសមិនផុតពីស្ថានភាពវេទនានៅក្នុងតំបន់ដែលមានការរើសអើងនៅភាគខាងកើត។ នៅក្នុងការិយាល័យរបស់គាត់ មានព្រឹត្តប័ត្រព័ត៌មានដែលពិពណ៌នាអំពីការសម្លាប់រង្គាលជនជាតិជ្វីហ្វ (Jews)") ទំព័រ ៣២០-៣២១ (ក្នុងឋានៈជាឧត្តមសេនីយ៍ពេញសមត្ថភាព Sauckel មានការទទួលខុសត្រូវរួមលើកម្មវិធីពលកម្មដោយបង្ខំ និងបានដឹងអំពីវិធីសាស្ត្រគ្មានធម៌មេត្តា និង ស្ថានភាពអាក្រក់ដែលពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីនេះ) ទំព័រ ៣៣៩-៣៤០ (Bormann ចូលរួមយ៉ាងសកម្មបំផុតក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ (Jews) និងបានចូលរួមក្នុងកិច្ចពិភាក្សាដែលនាំទៅរកនិរទេសជនជាតិជ្វីហ្វ (Jews) ០៦ ម៉ឺននាក់ចេញពីទីក្រុងវីយែន ទៅកាន់ប្រទេស ប៉ូឡូញ និងបានចុះហត្ថលេខាលើក្រឹត្យច្បាប់ប្រកាសថា ការបំបាត់ជនជាតិជ្វីហ្វ (Jews) ជាអចិន្ត្រៃយ៍នៅលើទឹកដីធំទូលាយនៃប្រទេសអាល្លឺម៉ង់ អាចធ្វើទៅបានទាល់តែប្រើប្រាស់ "កម្លាំងគ្មានធម៌មេត្តា" និង បទបញ្ជាមួយបង្គាប់ឱ្យដកហូតច្បាប់ការពារតាមផ្លូវតុលាការចេញពីជនជាតិជ្វីហ្វ (Jews) និងដាក់ពួកគេឱ្យស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់ប៉ូលិសសម្ងាត់របស់រដ្ឋ Himmler)។

ឲ្យជនជាប់ចោទមានចេតនាសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ បង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឲ្យមានការស្លាប់មនុស្ស*ជាទ្រង់ទ្រាយធំ ឬ មានលក្ខណៈជាប្រព័ន្ធ*"[១២៧៣] ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋាននេះមានបំណងចង់ផ្តុះបញ្ចាំងឲ្យឃើញនូវបរិបទនៃធាតុផ្សំ ចំពោះរាល់បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ដែលតម្រូវថាបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាលក្ខណៈទូទៅ ឬ មានលក្ខណៈជាប្រព័ន្ធ) នៅក្នុងនិយមន័យនៃបទល្មើសការសម្លាប់រង្គាល។ វាច្បាស់ណាស់ដែលថា យុត្តិសាស្ត្រអន្តរជាតិពុំតម្រូវឲ្យមាននូវ*ធាតុផ្សំអត្តនោម័ត*នេះបន្ថែមចំពោះបទល្មើសការសម្លាប់រង្គាលនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសារណារបស់ក្រុមមេធាវីការពារក្តី នួន ជា នេះ។

៤២១. ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងថា នៅមានធាតុផ្សំបន្ថែមមួយទៀតពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល នោះគឺថា ជនរងគ្រោះ "ប្រាកដជាត្រូវប្រឈមនឹងលក្ខខណ្ឌ *ដែលចៀសមិនរួចពី* សេចក្តីស្លាប់នោះឡើយ"[១២៧៤] ។ នៅក្នុងផ្នែកដែលពាក់ព័ន្ធនៃសាលដីកាក្នុងរឿងក្តី *Ntakirutimana* ដែលក្រុមមេធាវីការពារក្តី អៀង សារី យកមកធ្វើជាសំអាង អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញថា៖

> បទល្មើសនៃការសម្លាប់រង្គាល តម្រូវឲ្យមានភ័ស្តុតាងដែលបង្ហាញថា ជនជាប់ចោទបានចូលរួមក្នុងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ បង្កើតនូវលក្ខខណ្ឌនៃការរស់នៅដែលត្រូវប្រឈមនឹងលក្ខខណ្ឌ *ដែលចៀសមិនរួច* ពីសេចក្តីស្លាប់មនុស្សចំនួនច្រើន និងថា ជនជាប់ចោទមានចេតនាចង់បានលទ្ធផលបែបនេះតាមរយៈអំពើសកម្ម ឬ អកម្មរបស់ខ្លួន[១២៧៥]។

៤២២. ទោះបីជាសាលដីកានេះបញ្ជាក់ច្បាស់អំពីលក្ខខណ្ឌតម្រូវដែលថា លក្ខខណ្ឌរស់នៅ "ចៀសមិនរួចពីសេចក្តីស្លាប់" យ៉ាងណាក្តី ក៏អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ទំនាក់ទំនងរវាងការប្រព្រឹត្ត និងលទ្ធផល ពុំមែនជាបញ្ហាចោទនៅក្នុងករណីនេះទេ ហើយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Ntakirutimana* មិនបានលើកឡើងដោយផ្ទាល់អំពីធាតុផ្សំនៃបទល្មើសនេះនៅក្នុងសំអាងហេតុរបស់ខ្លួនឡើយ។ មិនតែប៉ុណ្ណោះ អង្គជំនុំជម្រះតុលាការកំពូលក៏មិនបាន

---

[១២៧៣] សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១៩១ (មានគូសបញ្ជាក់បន្ថែម)។

[១២៧៤] ឧបសម្ព័ន្ធ កៈ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E163/5/10.2 កថាខណ្ឌ ១៦ (គូសបញ្ជាក់បន្ថែមតាមច្បាប់ដើម)។

[១២៧៥] សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥២២ (មានគូសបញ្ជាក់បន្ថែម)។

កំណត់អំពីប្រភពណាមួយនៃបទដ្ឋានដែលអង្គជំនុំជម្រះនេះយកមកធ្វើជាមូលដ្ឋានដែរ[១២៧៦]។ ដូចគ្នានេះដែរ ទោះបីជាសាលក្រមនៅក្នុងរឿងក្ដីផ្សេងៗទៀត ប្រើប្រាស់និយមន័យនៃធាតុផ្សំអត្តនោម័តនៃការសម្លាប់រង្គាលដូចក្នុងករណី *Ntakirutimana* ក៏ដោយ ក៏សញ្ញាណនៃពាក្យថា "ចៀសមិនរួចពីសេចក្ដីស្លាប់" នេះ មិនត្រូវបានលើកយកមកបកស្រាយនៅក្នុងសាលក្រមណាមួយឡើយ[១២៧៧]។

៤២៣. សាលដីកាបន្តបន្ទាប់ជាច្រើនទៀតពីតុលាការ *មិនអចិន្ត្រៃយ៍នានា* បានពឹងផ្អែកលើសាលដីកាក្នុងរឿងក្ដី *Stakić* និង *Ntakirutimana* ដែលតាំងពីពេលនោះមក បានកំណត់និយមន័យនៃធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល ត្រឹមតែជាអំពើនៃការសម្លាប់មនុស្ស ជាទ្រង់ទ្រាយធំប៉ុណ្ណោះ[១២៧៨]។

៤២៤. តាមទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលនេះ សញ្ញាណនៃពាក្យថា "ចៀសមិនរួចពីសេចក្ដីស្លាប់" ដែលត្រូវបានលើកឡើងក្នុងសាលដីកាក្នុងរឿងក្ដី *Ntakirutimana* ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាលនោះគឺមិនមានមូលដ្ឋានគាំទ្រទេ។ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសារណារបស់ក្រុមមេធាវីការពារក្ដី អៀង សារី។

## ៩.៣ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ

៤២៥. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងអំឡុងពេលនៃ

---

[១២៧៦] សាលដីកាក្នុងរឿងក្ដី *Ntakirutimana* កថាខណ្ឌ ៥១២-៥២១។

[១២៧៧] សាលដីកាក្នុងរឿងក្ដី *Stakić* កថាខណ្ឌ ២៥៩ (ពាក់ព័ន្ធនឹងថាតើការដឹងអំពី "គម្រោងធំនៃការសម្លាប់មនុស្សរួម" ជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្លាប់រង្គាលឬយ៉ាងដូចម្ដេច)។ សាលដីកាក្នុងរឿងក្ដី *Gacumbitsi* កថាខណ្ឌ ៨៦ (ពាក់ព័ន្ធនឹងថាតើអង្គជំនុំជម្រះសាលាដំបូង បានអនុវត្តលក្ខខណ្ឌតម្រូវត្រឹមត្រូវនៃធាតុផ្សំអត្តនោម័តរួចហើយឬនៅ នៅពេលអង្គជំនុំជម្រះយល់ឃើញថា អំពើរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍បង្ហាញនូវ "ចេតនាចូលរួមក្នុងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ នៅ Nyarubuye")។ សាលក្រមក្នុងរឿងក្ដី *Martić* កថាខណ្ឌ ៦២ (បង្ហាញអំពីច្បាប់ជាធរមានស្ដីពីការសម្លាប់រង្គាល)។ សាលក្រមក្នុងរឿងក្ដី *Kanyarukiga* កថាខណ្ឌ ៦៥៨ (បង្ហាញអំពីច្បាប់ជាធរមានស្ដីពីការសម្លាប់រង្គាល)។ សាលក្រមក្នុងរឿងក្ដី *Rukundo* កថាខណ្ឌ ៥៨៦ (បង្ហាញអំពីច្បាប់ជាធរមានស្ដីពីការសម្លាប់រង្គាល)។ សាលក្រមក្នុងរឿងក្ដី *Gatete* កថាខណ្ឌ ៦៣៦ (បង្ហាញអំពើជាធរមានស្ដីពីការសម្លាប់រង្គាល)។

[១២៧៨] សាលដីកាក្នុងរឿងក្ដី *Lukić និង Lukić* កថាខណ្ឌ ៥៣៦។ សាលដីកាក្នុងរឿងក្ដី *Bagosora និង Nsengiyumva* កថាខណ្ឌ ៣៩៤។ សាលដីកាក្នុងរឿងក្ដី *Rukundo* កថាខណ្ឌ ១៨៥។

ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ ដីកាដំណោះស្រាយចោទប្រកាន់ថា អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជនជាប់ចោទផង បានកំណត់ក្រុមមនុស្សជាច្រើនថាជា "ខ្មាំង" ដោយផ្អែកលើទស្សនៈនយោបាយជាក់ស្តែង ឬសន្មត ឬ ដោយសារមូលហេតុនៃការប្រឆាំងផ្នែកនយោបាយរបស់ពួកគេ ទៅនឹងអ្នកកាន់អំណាចក្នុងបក្សកុម្មុយនីស្តកម្ពុជា និងត្រូវបានដាក់ឱ្យពួកគេស្ថិតក្រោមគោលនយោបាយបែបរើសអើងផ្សេងៗ[១២៧៩]។

៤២៦. អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* បានតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការធ្វើទុក្ខបុកម្នេញ គឺជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិនាឆ្នាំ ១៩៧៥[១២៨០]។ ពាក់ព័ន្ធនឹងការវិវត្តនៃបទឧក្រិដ្ឋនេះបន្ទាប់ពីសង្គ្រាមលោកលើកទី២ ជនជាប់ចោទអាចប្រមើលមើលបានថា ក្នុងនាមជាសមាជិកនៃអាជ្ញាធរដែលមានអំណាចត្រួតត្រាប្រទេសកម្ពុជា ជនជាប់ចោទអាចនឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ពីឆ្នាំ១៩៧៥។ លើសពីនេះទៀត និយមន័យនៃការធ្វើទុក្ខបុកម្នេញ ដែលបានវិវត្តន៍នៅក្រោយយុត្តិសាស្ត្រដែលមានបន្ទាប់ពីសង្គ្រាមលោកលើកទី២ ក៏អាចឱ្យជនជាប់ចោទដឹងច្បាស់នាពេលនោះផងដែរ។

៤២៧. អង្គជំនុំជម្រះតុលាការកំពូលក៏បានគាំទ្រនិយមន័យនៃការធ្វើទុក្ខបុកម្នេញ ដូចខាងក្រោមនេះដែរ៖

---

[១២៧៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៤-១៤១៨, ១៤២៣-១៤២៥។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និង ផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ២។

[១២៨០] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៤។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២២៥ និង ២៨០ (បានកត់សម្គាល់បន្ថែមថា ជនជាប់ចោទ *កាំង ហ្គេកអ៊ាវ* អាចប្រមើលមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង ក្នុងឋានៈពួកគាត់ជាសមាជិកម្នាក់នៃអាជ្ញាធរដែលមានអំណាចត្រួតត្រាប្រទេសកម្ពុជានាឆ្នាំ ១៩៧៥)។

(១) អំពើសកម្ម ឬ អកម្មដែល [...] ពិតជារើសអើង ហើយដកហូត ឬ រំលោភទៅលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ឬ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១២៨១] និង

(២) ការប្រព្រឹត្តិអំពើសកម្ម ឬ អកម្មដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[១២៨២]។

៤២៨. ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តនៃការរើសអើងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ការរើសអើងជាក់ស្តែង" កើតមានឡើងនៅពេលដែលជនរងគ្រោះណាម្នាក់ត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះនោះជាសមាជិកនៅក្នុងក្រុមណាមួយ ដែលចារីបានកំណត់ ដោយផ្អែកលើមូលហេតុជាក់លាក់មួយចំនួន ពោលគឺ មូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[១២៨៣] ហើយជនរងគ្រោះនោះត្រូវតែស្តែងឲ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬ សាសនាណាមួយ[១២៨៤] ដែលផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលជាលក្ខខណ្ឌតម្រូវនោះ ត្រូវតែកើតមានទៅលើក្រុមនោះ[១២៨៥]។

៤២៩. ពាក់ព័ន្ធនឹងធាតុផ្សំ*អត្តនោម័ត* ទោះបីជាចេតនាជាក់លាក់មិនអាចទាញចេញដោយផ្ទាល់ពីលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារនោះក៏ដោយ ប៉ុន្តែអាចទាញចេញពីបរិបទនេះបាន ប្រសិនបើការពិចារណាទៅលើអង្គហេតុនៃរឿងក្តី កាលៈទេសៈជុំវិញការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់ បញ្ជាក់អំពីអត្ថិភាពនៃចេតនាដូច្នោះ ។ កាលៈទេសៈដែលអាចយកមកពិចារណា រួមមាន លក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើក្រុមមួយ និងចរិត

---

[១២៨១] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៦។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៧១-២៧៨។

[១២៨២] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៩។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៣៦-២៤០។

[១២៨៣] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៧។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៧២។

[១២៨៤] សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៧៤, ២៧៧។

[១២៨៥] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៧។ សាលដីកាក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៧៦។

លក្ខណៈទូទៅនៃចារីដែលត្រូវបានចោទប្រកាន់ ដែលស្តែងឡើងតាមរយៈការប្រព្រឹត្តិរបស់ចារីនោះ[១២៨៦]។

៤៣០. ផ្ទុយពីទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសាលដីកាក្នុងរឿងក្តី *កាំង ហ្កេក-អ៊ាវ* ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា និយមន័យនៃ "ក្រុមនយោបាយ" តម្រូវឱ្យបុគ្គលទាំងនោះប្រកាន់យកទស្សនៈនយោបាយឬជាសមាជិករបស់ក្រុមនយោបាយ ឬបក្សណាមួយ[១២៨៧]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បុគ្គលទាំងឡាយដែលប្រកាន់យកទស្សនៈនយោបាយ ឬ ជាសមាជិកនៃក្រុមនយោបាយ ឬ បក្សណាមួយ គឺជាឧទាហរណ៍ជាក់ស្តែងបំផុតមួយនៃអ្នកដែលអាចជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[១២៨៨]។ ប៉ុន្តែ ទោះបីយុត្តិសាស្ត្រអន្តរជាតិមួយចំនួនបានបកស្រាយពាក្យថា "មូលហេតុនយោបាយ" ក្នុងន័យចង្អៀត[១២៨៩] ក៏ដោយ តែយុត្តិសាស្ត្រអន្តរជាតិដទៃទៀតបានយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយកើតមានឡើងនៅក្នុងករណីដែលមានការរើសអើងត្រូវបានកើតមានឡើង ស្របទៅតាមឆន្ទៈនយោបាយ ឬ កម្មវិធីនយោបាយមួយ ប្រឆាំងទៅនឹងក្រុមណាមួយ បើទោះបីជាក្រុមនោះមិនបានប្រកាន់យកទស្សនៈនយោបាយណាមួយក៏ដោយ[១២៩០] ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង

---

[១២៨៦] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៨០។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៨៥។

[១២៨៧] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០១ របស់ នួន ជា ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២២៣-២២៥។ ទោះបីសេចក្តីសន្និដ្ឋានរបស់ នួន ជា យោងទៅកថាខណ្ឌ ២១៥-២២៥ នៃសាលដីកាក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* យ៉ាងណាក្តី អង្គជំនុំជម្រះយល់ឃើញថា តាមពិតសេចក្តីសន្និដ្ឋានមានបំណងយោងទៅកថាខណ្ឌ ២៧២។

[១២៨៨] *សូមមើល* រឿងក្តី *Simić និងអ្នកផ្សេងទៀត*។ សាលក្រម កថាខណ្ឌ ៦៨៥។ សាលក្រមក្នុងរឿងក្តី *Naletelić និង Martinović* កថាខណ្ឌ ៦៨១។ សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១៧៨, ២២១២។ សាលក្រមក្នុងរឿងក្តី *Hategikimana* កថាខណ្ឌ ៧១១។ សាលដីកាក្នុងរឿងក្តី *Hategikimana* កថាខណ្ឌ ៦៣។ *សូមមើលផងដែរ* សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២៣៥។

[១២៨៩] សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ៤៥៤។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៤៧១។ ប៉ុន្តែផ្ទុយទៅនឹងសារណារបស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Nahimana* មិនបានបញ្ជាក់ឱ្យបានច្បាស់ថា មជ្ឈដ្ឋានជន Hutu មិនអាចបង្កើតបានជា"ក្រុមនយោបាយ"មួយនោះទេ៖ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ របស់ នួន ជា ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២២៤។

[១២៩០] *សូមមើល* រឿងក្តី *Kvočka និងអ្នកផ្សេងទៀត*។ សាលដីកា កថាខណ្ឌ ៤៥៦ (យល់ឃើញថា ប្រសិនបើបំណងធ្វើទុក្ខបុកម្នេញលើអ្នកដែលមិនមែនជាជនជាតិ Serb បានឈរលើករណីដែលថា ពួកគេបានគាំទ្រការបែកបក្សពួក

បដិសេធការបកស្រាយពាក្យថា "ក្រុមនយោបាយ" ក្នុងន័យចង្អៀតដូចដែលក្រុមមេធាវីការពារក្ដី នួន ជា បានលើកឡើង។

៤៣១. អំពើជាក់លាក់ដែលនាំឲ្យមានការធ្វើទុក្ខបុកម្នេញ ត្រូវតែធ្វើការចោទប្រកាន់ឲ្យបានច្បាស់លាស់[១២៩១]។ ពាក់ព័ន្ធនឹងចំណុចនេះ ក្រុមមេធាវីការពារក្ដី ខៀវ សំផន លើកឡើងថា ត្រូវតែមានការ

---

អង្គហេតុដែលបានចោទប្រកាន់ត្រូវតែផ្អែកលើមូលហេតុនយោបាយ ហេតុដូចនេះ បំណងមានលក្ខណៈគ្រប់គ្រាន់ដើម្បីគាំទ្រការធ្វើទុក្ខបុកម្នេញ)។ សាលក្រម ក្នុងរឿងក្ដី *Tadić* កថាខណ្ឌ ៧១៤ (យល់ឃើញថា ជនជាប់ចោទបានប្រព្រឹត្តអំពើសកម្មមួយចំនួនប្រឆាំងលើអ្នកដែលមិនមែនជាជនជាតិ Serb ដោយមានចេតនាពន្លឿនការបង្កើតប្រទេស Serbia ឲ្យកាន់តែធំមួយ និងយល់ឃើញថា គាត់មានទស្សនៈរួមមួយថា អ្នកដែលមិនមែនជាជនជាតិ Serb គួរតែនិរទេសចេញដោយបង្ខំពីទឹកដីនោះ។ ដោយហេតុនេះ អំពើសកម្មទាំងនេះបង្ហាញឲ្យឃើញនូវមូលដ្ឋាននៃការរើសអើង ហើយការរើសអើងនេះធ្វើឡើងដោយសារមូលហេតុសាសនា និង នយោបាយ) ទំព័រ ៧១៧-៧១៨។ សាលក្រមក្នុងរឿងក្ដី *Kordić និង Čerkez* កថាខណ្ឌ ៥២០, ៨២៧ (យល់ឃើញថា មានយុទ្ធនាការធ្វើទុក្ខបុកម្នេញមួយនៅទូទាំងរយៈកាលនៃការចោទប្រកាន់ នៅផ្នែកកណ្ដាលនៃប្រទេសបូស្នី (និងលើសពីនេះ) ធ្វើឡើងសំដៅលើជនជាតិ Bosnian Muslims ទោះបីមូលហេតុនៃការរើសអើងជាក់លាក់ មិនត្រូវបានបញ្ជាក់ក៏ដោយ), ទំព័រ ៨២៩ (យល់ឃើញថា Kordić គឺជាមេដឹកនាំនយោបាយរបស់ Bosnian Croats នៅតំបន់កណ្ដាលបូស្នី ដែលបានចូលរួមដោយស្ម័គ្រចិត្តនៅក្នុងផែនការនៃការធ្វើទុក្ខបុកម្នេញរួម) ទំព័រ ៣០៦ (ផ្ដន្ទាទោស Kordić ចំពោះការធ្វើទុក្ខម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា)។ សាលដីកាក្នុងរឿងក្ដី *Kordić និង Čerkez* កថាខណ្ឌ ៦៧៩, ៧១៨, ៧២១-៧២៣ (បានយល់ស្របថាការផ្ដន្ទាទោស Kordić ចំពោះការធ្វើទុក្ខបុកម្នេញ គឺមានភាពពាក់ព័ន្ធគ្នាទៅនឹងសកម្មភាព និងបំណងនយោបាយរបស់ Kordić និងជំហរជាតិនិយម និងជាតិពន្ធុខ្លាំងក្លារបស់គាត់ និងសេចក្ដីប្រាថ្នាចង់បានរដ្ឋក្រូអាតមួយដែលមានអធិបតេយ្យនៅក្នុងទឹកដីបូស្នី និង Herzegovina ទោះជាត្រូវលះបង់អ្វីក៏ដោយ)។ សាលក្រមក្នុងរឿងក្ដី *Blagojević និង Jokić* កថាខណ្ឌ ៦២៩, ៦២១ (យល់ឃើញថា មាន"យុទ្ធនាការធ្វើទុក្ខបុកម្នេញមកលើប្រជាជន Bosnian Muslim" ដោយសារមូលហេតុពូជសាសន៍ សាសនា ឬ នយោបាយ ដោយសំអាងទៅលើអង្គហេតុដែលថា"ទាហាន VRS ជាច្រើនបានប្រទេចផ្ដាសាដាក់ជនជាតិ Bosnian Muslims និងដៀលឈ្មោះពួកគេ។ ទាហាន VRS បានប្រាប់ទៅជនភៀសខ្លួនឲ្យចាកចេញពីតំបន់នោះ ដោយពួកគេចាត់ទុកវាថាជា "ប្រទេស Serb" និងផ្នែក "ធំទូលាយជាងនេះរបស់ប្រទេស Serbia" [និង] នៅពេលអ្នកទោស Bosnian Muslim បានមកដល់មន្ទីរឃុំឃាំង ពួកគេត្រូវបានបង្ខំឲ្យអានតាមឃ្លាដែលគាំទ្រជនជាតិ Serb ថា"តំបន់នេះជាប្រទេស Serbia")។ សាលក្រមក្នុងរឿងក្ដី *Stakić* កថាខណ្ឌ ៨១៩ (យល់ឃើញថា មានយុទ្ធនាការធ្វើទុក្ខបុកម្នេញមួយ ដោយផ្អែកលើចេតនារើសអើងលើអ្នកដែលមិនមែនជាជនជាតិ Serbs ឬ អ្នកដែលមិនគាំទ្រផែនការបង្រួបបង្រួមការត្រួតត្រា និងអំណាចខ្លាំងនៅក្នុងក្រុង Prijedor របស់ពួក Serbian)។ សាលដីកាក្នុងរឿងក្ដី *Stakić* ទំព័រ ១៤២ (បានយល់ស្របតាមការផ្ដន្ទាទោសចំពោះការធ្វើទុក្ខបុកម្នេញ)។

[១២៩១] សាលដីកាក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១៣៩។ រឿងក្ដី *Kupreškić និងអ្នកផ្សេងទៀត*។ សាលដីកា កថាខណ្ឌ ៩៨។

ពាក់ព័ន្ធគ្នារវាងអំពើ នៃការធ្វើទុក្ខបុកម្នេញ និងបទល្មើសជាក់លាក់ផ្សេងៗទៀតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ដោយអនុលោមតាមមាត្រា ៩ នៃកិច្ចព្រមព្រៀង អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចអនុវត្តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ឆ្នាំ ១៩៩៨[១២៥២]។

៤៣២. ផ្ទុយទៅនឹងសារណានេះ និងអនុលោមតាមគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តនិយមន័យនៃការធ្វើទុក្ខបុកម្នេញ ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុង ឆ្នាំ ១៩៧៥[១២៥៣]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* បានកត់សម្គាល់ថា តុលាការ Nuremberg និងតុលាការយោធាក្រោយៗទៀត បានផ្ដន្ទាទោសជនជាប់ចោទចំពោះអំពើនៃការធ្វើទុក្ខបុកម្នេញជាច្រើនប្រភេទដែលមានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងលក្ខន្តិកៈនីមួយៗរបស់តុលាការទាំងនេះ ។ ការធ្វើទុក្ខបុកម្នេញនេះគ្របដណ្ដប់ទៅលើអំពើទាំងឡាយដែលបានប្រព្រឹត្តពាក់ព័ន្ធទៅនឹងបទល្មើសដទៃទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ក៏ដូចជាអំពើទាំងឡាយដែលមិនត្រូវបានរៀបរាប់នៅក្នុងលិខិតុបករណ៍គតិយុត្តផ្សេងទៀត ហើយដែលមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងលិខិតុបករណ៍ទាំងនោះ[១២៥៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា៖

> រហូតដល់ត្រឹមឆ្នាំ ១៩៧៥ យុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី ២ បានបង្ហាញយ៉ាងច្បាស់ថា ក្រៅពីបទល្មើសជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ ឧក្រិដ្ឋកម្មសង្គ្រាម ការធ្វើទុក្ខបុកម្នេញអាចគ្របដណ្ដប់ "អំពើផ្សេងៗទៀត" ដែលមិន

---

[១២៥២] សារណារបស់ ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមានដែលអាចអនុវត្តបាន ឯកសារ E163/5/9 ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤-២៦, ៦៨។

[១២៥៣] សាលក្រមក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៦-២៨, ៣០-៣៤។ សាលដីកាក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៨៩-៩៧ ។ អង្គជំនុំជម្រះកត់សម្គាល់ថា ច្បាប់ អ.វ.ត.ក ដែលអនុវត្តកិច្ចព្រមព្រៀង ពុំមានចែងអំពីលក្ខខណ្ឌតម្រូវដែលថា ការធ្វើទុក្ខបុកម្នេញត្រូវតែមានទំនាក់ទំនងគ្នាជាមួយនឹងបទល្មើសផ្សេងមួយទៀត ក្នុងយុត្តាធិការរបស់តុលាការនេះនោះទេ។ *សូមមើល*ផ្នែកទី២ បញ្ញាបឋម កថាខណ្ឌ ១៩។

[១២៥៤] សាលក្រមក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៨។ សាលដីកាក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៥៣-២៥៤។ សូមមើល សាលដីកាក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៤៤-២៤៥, ២៥២។

មានចែងក្នុងធម្មនុញ្ញតុលាការទាំងនេះ និងក្រៅពីលទ្ធិច្បាប់ស្ដីពីប្រភេទអំពើដូចគ្នា (*ejusdem generis*)ដែលអំពើនេះបានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់នៃបទល្មើសជាក់លាក់ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបណ្ដាលឲ្យមានការរំលោភបំពានលើសិទ្ធិជាសារវន្តរបស់មនុស្ស[១២៩៥]។

៤៣៣. ហេតុដូចនេះ អង្គជំនុំជម្រះបដិសេធសារណារបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ ។ អំពើធ្វើទុក្ខបុកម្នេញអាចគ្របដណ្ដប់បទល្មើសជាក់លាក់ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (មានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណ្ណកម្ម) ព្រមទាំងអំពើដទៃទៀត ដែលមានស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរស្មើគ្នា រួមបញ្ចូលទាំងអំពើទាំងឡាយដែលមិនត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១២៩៦]។ ក្នុងការសម្រេចថាតើលក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញហើយ ឬ យ៉ាងណានោះ គេមិនត្រូវពិចារណាទៅលើតែការប្រព្រឹត្តិតែឯកឯងនោះទេ ពោលគឺ គប្បីពិនិត្យមើលបរិបទ និងអានុភាពនៃអំពើទាំងនេះទាំងមូល[១២៩៧]។

## ៩.៤ អំពើអមនុស្សធម៌ផ្សេងៗទៀត

៤៣៤. ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទពីបទប្រព្រឹត្ត "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជាការបាត់ខ្លួនដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ[១២៩៨]។

---

[១២៩៥] សាលដីកាក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ២៦១។

[១២៩៦] សាលក្រមក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៧៨។ សាលដីកាក្នុងរឿងក្ដី *Brđanin* កថាខណ្ឌ ២៩៦។

[១២៩៧] សាលដីកាក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១៣៥។ សាលដីកាក្នុងរឿងក្ដី *Krnojelac* កថាខណ្ឌ ១៩៩, ២២១។

[១២៩៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧០-១៤៧៨ (ការបាត់ខ្លួនដោយបង្ខំ), កថាខណ្ឌ ១៤៤៨-១៤៦៩ (ការជម្លៀសដោយបង្ខំ), កថាខណ្ឌ ១៤៣៤-១៤៣៦, ១៤៣៩-១៤៤០ (ការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ២-៣។ បទល្មើសទាំងនេះត្រូវបានកំណត់

៤៣៥. "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនឆ្នាំ ១៩៧៥ ហេតុដូច្នេះ ជនជាប់ចោទអាចប្រមើលមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង[១២៩៩]។

៤៣៦. មេធាវីការពារក្តី នួន ជា លើកឡើងថា ដោយគោរពគោលការណ៍នីត្យានុកូលភាពនោះ សញ្ញាណទាំងឡាយដែលជាទម្រង់នៃការប្រព្រឹត្តិ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះ-ស្រាយ មិនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ នៅក្នុងអំឡុងពេលនោះ។ ជាបច្ច័យនាំឲ្យជនជាប់ចោទមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[១៣០០] ។ ផ្ទុយទៅនឹងទស្សនៈនេះ អំពើដែលកំណត់ថាជាបទល្មើសជាក់លាក់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនចាំបាច់មានឋានៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ។ អង្គបុរេជំនុំជម្រះបានសម្រេចកាលពីមុនរួចហើយថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាឧក្រិដ្ឋកម្មដែលស្ថិតក្រោមច្បាប់អន្តរជាតិ។ ហេតុដូច្នេះ មិនចាំបាច់ត្រូវបង្ហាញថា ប្រភេទនីមួយៗនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងវិសាលភាពនៃបទល្មើសនេះ គឺជាបទល្មើសព្រហ្មទណ្ឌនោះទេ[១៣០១]។ ផ្ទុយទៅវិញ គោលការណ៍នីត្យានុកូលភាព គឺភ្ជាប់ទៅនឹងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាំងមូល មិនមែនភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើសនេះនោះទេ[១៣០២]។ អង្គជំនុំជម្រះ

---

ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាជាងត្រូវបានចោទប្រកាន់ជាបទល្មើសដាច់ដោយឡែកប្រឆាំងនឹងមនុស្សជាតិដោយយោងទៅតាមសិទ្ធិរបស់វាផ្ទាល់។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៧៦-៣៧៧។

[១២៩៩] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៦៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសាលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៨៥, ៣៩៥-៣៩៦, ៣៩៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៣០-១៣១, ១៥៧, ១៦៥។ *សូមមើលផងដែរ* សាលដីកាលើក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥។

[១៣០០] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៨-៩។

[១៣០១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៧១, ៣៧៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៥៦។

[១៣០២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៧៨។

សាលាដំបូងយល់ស្របជាមួយសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធចោលសារណារបស់ក្រុមមេធាវីការពារក្តី នួន ជា ។

៤៣៧. "អំពើអមនុស្សធម៌ផ្សេងៗទៀត" បំពេញមុខងារជាប្រភេទបទល្មើសនៅសេសសល់[១៣០៣] ដែលត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះអំពើដែលបំពេញលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបំពេញលក្ខខណ្ឌនៃបទល្មើសណាមួយ ក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតនោះឡើយ[១៣០៤]។ ធាតុផ្សំនៃបទល្មើសជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាអំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬ អ្នកនៅក្រោមបង្គាប់របស់ខ្លួន៖

(១) ដែលបណ្តាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរមកលើរាងកាយ ឬ ផ្លូវចិត្ត ឬ បង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[១៣០៥] និង

(២) ដែលបានប្រព្រឹត្តឡើងដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរ មកលើរូបរាង-កាយ ឬ ផ្លូវចិត្ត ឬ ប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរ មកលើជនរងគ្រោះដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬ អកម្មនោះ[១៣០៦]។

៤៣៨. អំពើសកម្ម ឬ អកម្ម ត្រូវតែមានលក្ខណៈ និងមានស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ផ្សេងទៀត[១៣០៧]។ ភាពធ្ងន់ធ្ងរនៃអំពើនេះ គឺត្រូវបានវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាលើកាលៈទេសៈរបស់បុគ្គលនីមួយៗនៅក្នុងរឿងក្តី

---

[១៣០៣] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៦៧។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥-៣១៦ ដែលសម្អាង លើសាលក្រមក្នុងរឿងក្តី *Kupreškić និងជនជាប់ចោទផ្សេងទៀត* កថាខណ្ឌ ៥៦៣។

[១៣០៤] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៦៧។ សាលដីកាក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ១១៧។

[១៣០៥] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៦៨។ សាលដីកាក្នុងរឿងក្តី *Dragomir Milošević* កថាខណ្ឌ ១០៨។

[១៣០៦] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៧១។ សាលដីកាក្នុងរឿងក្តី *Dragomir Milošević* កថាខណ្ឌ ១០៨។

[១៣០៧] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៣៦៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩៥-៣៩៦។ *សូមមើល* សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣៣១។

នោះ[១៣០៨] ។ កាលៈទេសៈទាំងនេះអាចរួមបញ្ចូលនូវប្រភេទនៃអំពើសកម្ម ឬអកម្ម បរិបទដែលវាបានកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ព្រមទាំងផលប៉ះពាល់នៃអំពើនោះ មកលើជនរងគ្រោះផង[១៣០៩]។ សារណារបស់មេធាវីការពារក្តី នួន ជា ដែលលើកឡើងថា "ការខកខាននៅក្នុងអំឡុងពេលពាក់ព័ន្ធដើម្បីកំណត់លក្ខណៈឬចោទប្រកាន់អំពើជាក់លាក់ណាមួយថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទំនងជាចង់បង្ហាញថា អំពើនេះមិនត្រូវបានមើលឃើញថាមានស្ថានទម្ងន់គ្រប់គ្រាន់ដល់កម្រិតមួយ ដែលអាចជា "អំពើអមនុស្សធម៌មួយផ្សេងទៀត"[១៣១០] នោះទេ ។ ប៉ុន្តែការលើកឡើងនេះមិនបានគិតពីលក្ខខណ្ឌដែលតម្រូវថា ភាពធ្ងន់ធ្ងរនៃអំពើនេះ គឺត្រូវវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាទៅលើកាលៈទេសៈរបស់បុគ្គលនីមួយៗនៅក្នុងរឿងក្តីនោះឡើយ។ ហេតុដូច្នេះ បើទោះជាការកំណត់លក្ខណៈ ឬការចោទប្រកាន់អំពើណាមួយពីមុនថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបង្ហាញឲ្យឃើញជាទូទៅនូវភាពធ្ងន់ធ្ងរណាមួយក៏ដោយ ក៏ប៉ុន្តែ ភាពធ្ងន់ធ្ងរនៃអំពើនេះមិនមែនជាលក្ខខណ្ឌកំណត់ដាច់ខាតនៅក្នុងរឿងក្តីជាក់លាក់ណាមួយនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចបដិសេធសារណានេះចោល។

៤៣៩. មិនមានលក្ខខណ្ឌតម្រូវថា ការឈឺចាប់នោះមានផលប៉ះពាល់រយៈពេលយូរអង្វែងនោះឡើយ ទោះបីវាអាចត្រូវបានយកមកពិចារណា វាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[១៣១១]។

៤៤០. នេះមានន័យថា ដើម្បីឲ្យអំពើនោះស្ថិតនៅក្នុងវិសាលភាពនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះគ្រាន់តែពិចារណា អំពីថាតើការបាត់ខ្លួនដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិមានភាពធ្ងន់ធ្ងរ និងមានលក្ខណៈស្រដៀងគ្នាទៅនឹងបទល្មើសជាក់លាក់ដទៃទៀតដែលមានចែងនៅក្នុងលក្ខន្តិកៈនេះដែរឬទេ។

---

[១៣០៨] សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៦៩។ សាលដីកាក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ១១៧។

[១៣០៩] សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១៦៥។ សាលដីកាក្នុងរឿងក្តី *Brima និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៨៤។ *សូមមើល ផងដែរ* សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៣៦៩។

[១៣១០] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៩ លេខយោងជើងទំព័រ ១៩។

[១៣១១] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៩ លេខយោងជើងទំព័រ ១៩។

### ៩.៤.១ ការបាត់ខ្លួនដោយបង្ខំ

៤៤១. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទ ចំពោះការបាត់ខ្លួនដោយបង្ខំ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន (នៅដំណាក់កាលទី២)[១៣១២]។

៤៤២. អង្គបុរេជំនុំជម្រះមិនបានដោះស្រាយ អំពីថាតើការបាត់ខ្លួនដោយបង្ខំគឺជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"ដែរឬអត់នោះទេ ដោយអង្គបុរេជំនុំជម្រះយល់ឃើញថា ចំណុចនេះ គឺជាបញ្ហាលាយឡំគ្នារវាងអង្គច្បាប់ និងអង្គហេតុ ដែលបញ្ហានេះអង្គជំនុំជម្រះសាលាដំបូងគប្បីត្រូវសម្រេចនៅក្នុងសាលក្រមរបស់ខ្លួន[១៣១៣]។

៤៤៣. មេធាវីការពារក្តី ខៀវ សំផន និង នួន ជា បានលើកឡើងថា ការបាត់ខ្លួនដោយបង្ខំមិនអាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" បានទេ ដោយយោងទៅលើមូលដ្ឋានថា ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ[១៣១៤]។ អង្គជំនុំជម្រះសម្រេចបដិសេធសារណានេះចោល ដោយសំអាងទៅលើមូលដ្ឋានថា អំពើមួយអាចត្រូវបានចាត់ទុកថាជា "អំពើអមនុស្សធម៌" បាន ដោយមិនចាំបាច់តម្រូវថា អំពើនោះគឺជាផ្នែកមួយនៃបទល្មើសជាក់លាក់ ដូចបានពិភាក្សាខាងលើរួចមកហើយនោះទេ[១៣១៥]។ ដោយយោងទៅលើសំអាងហេតុដូច

[១៣១២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧០-១៤៧៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ៣។

[១៣១៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩៧។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៦១-៦២ និង ១៦៦។

[១៣១៤] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២៩-៣២, ៦៨។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២២៨-២២៩។

[១៣១៥] *សូមមើល* ផ្នែកទី៩ ច្បាប់ជាធរមានៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤៣៤-៤៤០ ។

គ្នានេះ អង្គជំនុំជម្រះសម្រេចបដិសេធសារណារបស់មេធាវីការពារក្តី នួន ជា ដែលថាត្រូវតែមានភ័ស្តុតាងអំពីចេតនាឧក្រិដ្ឋនាសម័យនោះ ពាក់ព័ន្ធនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាពិសេសចំពោះការបាត់ខ្លួនដោយបង្ខំនេះ។ ផ្ទុយទៅវិញ នៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះជឿជាក់ច្បាស់ថា អំពើនៃការបាត់ខ្លួនដោយបង្ខំទាំងនេះ មានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដែលអាចកំណត់បានជា "អំពើអមនុស្សធម៌" បាន។

៤៤៤. ការបាត់ខ្លួនដោយបង្ខំ ត្រូវបានយល់ឃើញកាលពីពេលមុនថាជាអំពើឧក្រិដ្ឋ ។ នៅក្នុងសាលក្រមរបស់តុលាការ Nuremberg ចៅក្រមបានសម្រេចថា អ្នកគ្រប់គ្រងដែនដីរបស់ប្រទេសអាល្លឺម៉ង់ ដែលប្រើក្រឹត្យច្បាប់ "Nacht និង Nebel" (រាត្រី និងអ័ព្ទចចក) របស់ពួក Nazi ដែលជាគោលនយោបាយរដ្ឋដ៏ជាក់លាក់មួយ សម្រាប់បង្កើតឲ្យមានការបាត់ខ្លួនដោយបង្ខំក្នុងគោលបំណងពង្រីកការភ័យខ្លាចនៅក្នុងចំណោមប្រជាជនទាំងអស់ និងដើម្បីបង្ក្រាបក្រុមប្រឆាំង[១៣១៦] នោះគឺជាការរំលោភបំពានទៅលើមាត្រា ៤៦ នៃបទប្បញ្ញត្តិទីក្រុងឡាអេ ឆ្នាំ ១៩០៧។ ហេតុដូច្នេះ អំពើនេះត្រូវបានសម្រេចថាជាឧក្រិដ្ឋកម្មសង្គ្រាម[១៣១៧] ។ សេនាប្រមុខ Keitel ត្រូវបានផ្តន្ទាទោសចំពោះតួនាទីរបស់គាត់ក្នុងការអនុវត្តគោលនយោបាយនេះ[១៣១៨] ។ ទោះជាមិនមានភាពច្បាស់លាស់ពីសាលក្រមរបស់តុលាការ Nuremberg ថាតើអំពើរបស់សេនាប្រមុខរូបនេះដែលពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំ ត្រូវបានពិចារណាថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ឬ យ៉ាងណានោះ អំពើនេះត្រូវបានមើលឃើញយ៉ាងច្បាស់ថា មានភាពធ្ងន់ធ្ងរបំផុត។

៤៤៥. ការអនុវត្តក្រឹត្យច្បាប់រាត្រី និងអ័ព្ទចចក ក៏ត្រូវបានសម្រេចថាជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងរឿងក្តី*ក្រសួងយុត្តិធម៌*[១៣១៩] ។ ជាការជាប់ពាក់ព័ន្ធខ្លាំងបំផុតនោះ រឿងក្តីនេះបានថ្កោលទោសចំពោះកម្មវិធីនយោបាយ រាត្រី និងអ័ព្ទចចក នេះថាជាការប្រព្រឹត្តិដោយអមនុស្សធម៌ ដោយយោងទៅលើផលប៉ះពាល់របស់គោលនយោបាយនេះ ដោយវាមិនមែនប៉ះពាល់តែទៅលើបុគ្គលទាំងឡាយណាដែលបានបាត់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ប៉ះពាល់ទៅ

---

[១៣១៦] *សូមមើល* សាលក្រម*ក្រសួងយុត្តិធម៌* ទំព័រ ៧៥។ សាលក្រមតុលាការ Nuremberg ទំព័រ ២៣២-២៣៣។

[១៣១៧] សាលក្រមតុលាករ Nuremberg ទំព័រ ២៣២-២៣៣។

[១៣១៨] សាលក្រមតុលាការ Nuremberg ទំព័រ ២៩០-២៩១។

[១៣១៩] សាលក្រមក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ១០៧៥, ១០៥៨ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ), ១០៦១ (ឧក្រិដ្ឋកម្មសង្គ្រាម)។

លើក្រុមគ្រួសាររបស់អ្នកជាប់ឃុំ ដែលពួកគេត្រូវបានគេបដិសេធមិនផ្តល់ព័ត៌មានអំពីជោគវាសនា សាច់ញាតិរបស់ពួកគេដែលត្រូវបានជាប់ឃុំនោះ[១៣២០]។

៤៤៦. លិខិតុបករណ៍ និងយុត្តិសាស្ត្រក្រោយឆ្នាំ ១៩៧៥ ក៏ទទួលស្គាល់ថា អំពើបែបនេះអាចត្រូវបានចាត់ទុកថាមានភាពធ្ងន់ធ្ងរបំផុត។ ក្នុងឆ្នាំ ១៩៧៨ មហាសន្និបាត អ.ស.ប និងតុលាការសិទ្ធិមនុស្សបានទទួលស្គាល់ថា ការបាត់ខ្លួនដោយបង្ខំ គឺជាប់ពាក់ព័ន្ធជាមួយសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស សេរីភាពរួចផុតពីការធ្វើទារុណកម្ម សេរីភាពរួចផុតពីការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ និងសិទ្ធិត្រូវបានទទួលស្គាល់នៅចំពោះមុខច្បាប់[១៣២១]។គណៈកម្មាធិការសិទ្ធិមនុស្សបានយល់ឃើញដូចគ្នានេះថា ការបាត់ខ្លួនដោយបង្ខំគឺជាការប្រព្រឹត្តិដោយអមនុស្សធម៌ ឬ ដោយការបន្ទាបបន្ថោកតម្លៃជាមនុស្ស[១៣២២] ។ លិខិតុបករណ៍អន្តរជាតិនាពេលថ្មីៗបំផុតនេះ ក៏បានសង្កត់ធ្ងន់ថា អំពើនៃការបាត់ខ្លួនដោយបង្ខំ មានភាពធ្ងន់ធ្ងរបំផុតដែលស្រដៀងគ្នានឹងបទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្ម

---

[១៣២០] *ឧ. សូមមើល* សាលក្រមក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ៧៥, ១០៤២, ១០៥៧-១០៥៨ (ចុងចោទឈ្មោះ von Ammon អ្នកជំនាញប្រចាំក្រសួងយុត្តិធម៌ដែលគ្រប់គ្រងកម្មវិធីរាត្រី និងអ័ព្ទ បានធ្វើអត្ថាធិប្បាយថា ចំណុចសំខាន់នៃកម្មវិធីរាត្រី និងអ័ព្ទ បានធ្វើឲ្យបាត់ខ្លួនអ្នកទោសពីដែនដីដែលខ្លួនក្តោបក្តាប់ និងមិនឲ្យសាច់ញាតិមិត្តភ័ក្ត្រ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ដឹងពីជោគវាសនារបស់អ្នកទាំងនោះ ក្នុងគោលបំណងបង្កើតឲ្យមានបរិយាកាសភ័យខ្លាច និងខ្វាយខ្វល់ជាប់ជានិច្ច។

[១៣២១] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣៣/១៧៣ ស្តីពី ការបាត់ខ្លួន ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៨ បុព្វកថា និងសេចក្តីប្រកាសឆ្នាំ ១៩៩២ មាត្រា ១(២)។ *សូមមើលផងដែរ រឿងក្តីរវាង Velasquez-Rodriguez ទល់នឹង ប្រទេសហុងឌូរ៉ាស*, តុលាការ IACtHR, សាលក្រម ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨, Inter-Am.Ct.H.R., (ស៊េរី C) លេខ ៤ (១៩៨៨) កថាខណ្ឌ ១៥៥-១៥៧។ *រឿងក្តីរវាង Aslakhanova ទល់នឹង ប្រទេសរុស្ស៊ី* សំណុំរឿងលេខ ២៩៤៤/០៦ និង ៨៣០០/០៧, ៥០១៨៤/០៧, ៣៣២/០៨, ៤២៥០៩/១០, តុលាការ ECtHR, សាលក្រម ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៣១-១៣៣។ *រឿងក្តីរវាង Kurt ទល់នឹង ប្រទេសតួគី* សំណុំរឿងលេខ ១៥/១៩៩៧/៧៩៩/១០០២, តុលាការ ECtHR, សាលក្រម ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១២៤។

[១៣២២] *រឿងក្តីរវាង Mojica ទល់នឹង សាធារណរដ្ឋដូមីនិកខែន*, គណៈកម្មាធិការសិទ្ធិមនុស្ស, សំណុំរឿងលេខ ៤៤៩/១៩៩១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៥.៧។ *រឿងក្តីរវាង Laureano ទល់នឹង ប្រទេស ប៉េរូ*, គណៈកម្មាធិការសិទ្ធិមនុស្ស, សំណុំរឿងលេខ ៥៤០/១៩៩៣ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៨.៥។

ប្រឆាំងនឹងមនុស្សជាតិ ។ លិខិតុបករណ៍អន្តរជាតិខ្លះបានផ្តន្ទាទោសចំពោះការបាត់ខ្លួនដោយបង្ខំដូចគ្នានឹងបទល្មើសដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ[១៣២៣]។

៤៤៧. យុត្តិសាស្ត្រនៃតុលាការអន្តរជាតិ *មិនអចិន្ត្រៃយ៍* នានា ក៏បានទទួលស្គាល់ផងដែរថា ការបាត់ខ្លួនដោយបង្ខំអាចមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឬ ការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឲ្យតែលក្ខខណ្ឌទាំងឡាយផ្សេងទៀតត្រូវបានបំពេញ[១៣២៤] ។ លក្ខន្តិកៈទីក្រុងរ៉ូមក៏ទទួលស្គាល់ការបាត់ខ្លួនដោយបង្ខំថាជាបទល្មើសដាច់ដោយឡែកមួយ ដែលជាមូលដ្ឋានកំណត់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ[១៣២៥]។

៤៤៨. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការបាត់ខ្លួនដោយបង្ខំអាចមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទល្មើសផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ។ ហេតុដូច្នេះ ការបាត់ខ្លួនដោយបង្ខំនេះវាអាចស្ថិតនៅក្នុងវិសាលភាពនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ។ ការបាត់ខ្លួនដោយបង្ខំកើតមានឡើងនៅពេលដែល៖ (i) បុគ្គលណាម្នាក់អាចត្រូវបានដកហូតសេរីភាពរបស់ខ្លួន (ii) ការដកហូតសេរីភាពនេះត្រូវបានធ្វើឡើងតាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬ ទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬ មិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធីចំពោះបុគ្គលនោះ និង (iii) ធាតុផ្សំទីមួយ និង

---

[១៣២៣] *ឧ. សូមមើល* សេចក្តីប្រកាស OAS ឆ្នាំ ១៩៨៣។ សេចក្តីប្រកាសស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ, សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៤៧/១៣៣ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២។ អនុសញ្ញាអន្តរអាមេរិកកាំង ស្តីពីការបាត់ខ្លួនមនុស្សដោយបង្ខំ (ដែលបានចូលជាធរមាននៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦) ។ អនុសញ្ញាអន្តរជាតិពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦ (ដែលបានចូលជាធរមាននៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១០)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៣។

[១៣២៤] *Brima និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ១៨៤ (អំពើអមនុស្សធម៌ផ្សេងទៀត)។ *Kupreškić និងអ្នកផ្សេងទៀត* សាលក្រម កថាខណ្ឌ ៥៦៦ (អំពើអមនុស្សធម៌ផ្សេងទៀត)។ *Kvočka និងអ្នកផ្សេងទៀត* សាលក្រម កថាខណ្ឌ ២០៨ (អំពើអមនុស្សធម៌ផ្សេងទៀត)។ *Gotovina និងអ្នកផ្សេងទៀត* សាលក្រម កថាខណ្ឌ ១៨៣៩(ការធ្វើទុក្ខបុកម្នេញ)។

[១៣២៥] លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC មាត្រា ៧(១)(i)។

ទីពីរ ត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋ ឬ ដោយមានការអនុញ្ញាត ការគាំទ្រ ឬ ការយល់ព្រមពីរដ្ឋ ឬ អង្គការនយោបាយណាមួយ[១៣២៦]។

### ៩.៤.២ ការផ្លាស់ទីលំនៅដោយបង្ខំ

៤៤៩. ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទចំពោះការជម្លៀសដោយបង្ខំនៅក្នុងដែនដីប្រទេសកម្ពុជាថា ជា"អំពើអមនុស្សធម៌ផ្សេងៗទៀត"តាមរយៈការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)[១៣២៧]។

៤៥០. ការជម្លៀសដោយបង្ខំគឺៈ (i) ចេតនា[១៣២៨] (ii) នៃការផ្លាស់ទីលំនៅដោយបង្ខំ[១៣២៩] របស់បុគ្គលជាច្រើន (iii) ឲ្យចាកចេញពីតំបន់មួយដែលពួកគេរស់នៅដោយស្របច្បាប់[១៣៣០] (iv) ដោយ

---

[១៣២៦] សាលក្រមក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ៧៥, ១០៧៥ ។ *សូមមើល ផងដែរ* រឿងក្តីរវាង *Gotovina និង អ្នកផ្សេងទៀត*, សាលក្រម, កថាខណ្ឌ១៨៣៧។រឿងក្តីរវាង*រដ្ឋអាជ្ញា ទល់នឹង Rašević និង Todović*,តុលាការ BiH, សំណុំរឿងលេខ X-KR/06/275 សាលក្រម ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៩៨ (ធាតុផ្សំនៃបទល្មើសបាត់ខ្លួនដោយបង្ខំ ដូចមានចែងក្នុងមាត្រា ១៧២(១)(i) នៃក្រមព្រហ្មទណ្ឌសម្រាប់តុលាការ BiH។ លក្ខន្តិកៈរបស់តុលាការ ICC មាត្រា ៧(២)(i)។ ធាតុផ្សំនៃបទល្មើសសម្រាប់តុលាការ ICC មាត្រា ៧(១)(1)។

[១៣២៧] ដីកាណោះស្រាយ កថាខណ្ឌ ១៤៤៨-១៤៦៩។ *សូមមើលផងដែរ* ឧបសម្ព័ន្ធៈ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ទំព័រ ២។

[១៣២៨] ជនជាប់ចោទត្រូវតែមានចេតនាឧក្រិដ្ឋដែលជាធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងអស់ៈ សាលក្រមក្នុងរឿងក្តីរបស់*ក្រសួង នានា* ទំព័រ ៤៧៣, ៤៩៧, ៦៤៥, ៦៦០, ៨៦០។ សាលក្រមក្នុងរឿងក្តីរបស់*មេបញ្ជាការជាន់ខ្ពស់* ទំព័រ ៦០៧, ៦០៩, ៦៧៩។ សាលក្រមក្នុងរឿងក្តី*ចំណាប់ខ្មាំង* ទំព័រ ១២៨១។ សាលក្រមក្នុងរឿងក្តី *Milch*, Phillips Concurrence, ទំព័រ ៨៧១។ សាលក្រមក្នុងរឿងក្តី *Pohl* ទំព័រ ៩៨៤, ១០៥៩ (សម្រេចឲ្យរួចផុតពីផ្នែកខ្លះនៃបទចោទ ដោយយោងទៅលើការមិនដឹងអំពីគោលបំណងទុច្ចរិតនៃ "ការជម្លៀសដោយបង្ខំ"។ សាលក្រមក្នុងរឿងក្តី *Farben* ទំព័រ ១១៨៩។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣៣២។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២៤៥-២៤៦។

[១៣២៩] "ការបង្ខំ" រួមមាន ការបង្ខិតបង្ខំ ការបំភាន់ ការកេងប្រយោជន៍ពីភាពស្លន់ស្លោ និងការគាបសង្កត់ឲ្យមានការភ័យខ្លាចៈ *ឧ. សូមមើល* សាលក្រមតុលាការ Nuremberg ទំព័រ ២៤៤-២៤៦។ សាលក្រមក្នុងរឿងក្តី *Milch*, Musmanno Concurrence ទំព័រ ៨០០។ សាលក្រមក្នុងរឿងក្តី *RuSHA* ទំព័រ ១២៧។ សាលក្រមក្នុងរឿងក្តីរបស់

គ្មានយុត្តិកម្មសមស្រប តាមរយៈការព្រួយបារម្ភអំពីសន្តិសុខរបស់ជនស៊ីវិល ឬ ភាពចាំបាច់ណាមួយខាងផ្នែកយោធា[១៣៣១]។ ការជម្លៀសដោយបង្ខំ ដែលធ្វើឡើងដើម្បីជាប្រយោជន៍ដល់សន្តិសុខរបស់ជនស៊ីវិល ឬភាពចាំបាច់ខាងយោធា ដូចនឹងវិធានការទាំងអស់ដែលរឹតបន្តឹងសេរីភាពក្នុងការដើរហើរដែរ "ត្រូវតែឲ្យស្របទៅនឹងគោលការណ៍សមាមាត្រ ។ វិធានការទាំងនោះត្រូវតែមានលក្ខណៈសមស្របដើម្បីសម្រេចមុខងារការការពាររបស់វាបាន ។ វិធានការទាំងនោះត្រូវតែធ្វើឡើងតាមមធ្យោបាយដែលមិនបង្កនូវផលប៉ះពាល់ធំដុំ ក្នុងចំណោមវិធានការទាំងឡាយដែលអាចយកមកប្រើដើម្បីសម្រេចគោលដៅដែលចង់បាន ហើយជាពិសេសវិធានការទាំងនោះត្រូវតែសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវការពារ"[១៣៣២] ។ ដើម្បីឲ្យការជម្លៀសត្រូវបានចាត់ទុកថាមានភាពសមាមាត្រនោះ ជនដែលត្រូវជម្លៀសត្រូវតែទទួលបាន "ការបញ្ជូនឲ្យវិលត្រឡប់មកកាន់ផ្ទះសម្បែងរបស់ខ្លួនវិញភ្លាមៗ បន្ទាប់ពីភាពប្រទូសរ៉ាយនៅក្នុងតំបន់នោះបានបញ្ចប់"[១៣៣៣]។ បន្ថែមពី

---

*ក្រសួងនានា* ទំព័រ ៤៩១ (ជនរងគ្រោះត្រូវបានផ្តល់ការព្រមានតែក្នុងរយៈពេល១ ឬ ២ ម៉ោងប៉ុណ្ណោះ)។ សាលក្រមក្នុងរឿងក្តីរបស់*មេបញ្ជាការជាន់ខ្ពស់* ទំព័រ ៦០៣។ សាលក្រមក្នុងរឿងក្តី *Eichmann* កថាខណ្ឌ ៦៤-៦៦, ៩៦(ក), ២៣៧ (ការធានាអះអាងទាំងមិនពិតថា ការផ្លាស់ទីលំនៅរបស់ពួកគេ គឺគ្រាន់តែជាបណ្តោះអាសន្នប៉ុណ្ណោះ)។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ២៨១។ សាលដីកាក្នុងរឿងក្តី *Blagojević និង Jokić* កថាខណ្ឌ១០៩ (ការបង្ខំអាចត្រូវបានបង្ហាញឡើងតាមរយៈ "កាលៈទេសៈដោយបង្ខិតបង្ខំ [ដែលជនរងគ្រោះ] យល់ឃើញដោយខ្លួនឯង ហើយមហន្តរាយផ្នែកមនុស្សធម៌ត្រូវបានបង្កឡើងតាមរយៈ[សកម្មភាពរបស់ជនល្មើស]")។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២៩ ("វាជាការមិនមានជម្រើសពិតប្រាកដ ដែលធ្វើឲ្យការផ្លាស់ទីលំនៅមិនស្របច្បាប់")។

[១៣៣០] លំនៅដ្ឋាន "ស្របច្បាប់" រួមមាន ជនភៀសខ្លួន និងជនដែលគ្មានសញ្ជាតិត្រឹមត្រូវ៖ *ឧ. សូមមើល* សាលក្រមក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ៤៨០, ៤៩៦, ៥០០, ៦៣៣-៦៣៤, ៦៥៤។ សាលក្រមក្នុងរឿងក្តីរបស់*មេបញ្ជាការជាន់ខ្ពស់* ទំព័រ ៥៧២។ សាលក្រមក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ៩៧១-៩៧៤។ សាលក្រមក្នុងរឿងក្តី *Eichmann* កថាខណ្ឌ ១០០, ១១១។

[១៣៣១] ការផ្លាស់ប្តូរទីលំនៅអាចត្រូវបានធ្វើយុត្តិកម្មដោយសារសន្តិសុខជនស៊ីវិល ឬភាពចាំបាច់ខាងយោធាតែប៉ុណ្ណោះ៖ *ឧ. សូមមើល* សាលក្រមក្នុងរឿងក្តី *Krupp* ទំព័រ ១៤៣២-១៤៣៣។ សាលក្រមក្នុងរឿងក្តី *Milch*, Phillips Concurrence, ទំព័រ ៨៦៦។ អនុសញ្ញាទីក្រុងហ្សឺណែវ មាត្រា ២, ២៧, ៤២, ៤៩។ សាលក្រមក្នុងរឿងក្តី *Farben* ទំព័រ ១១៨២, ១១៨៧។ *សូមមើល ផងដែរ* សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣៣១, ៣៣៣។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២២។

[១៣៣២] *អត្ថបទអត្ថាធិប្បាយលេខ ២៧៖ សេរីភាពក្នុងការធ្វើដំណើរ (មាត្រា ២),* CCPR/C/21/Rev.1/Add.9, ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៤។ មាត្រា ១២ នៃ ICCPR។

[១៣៣៣] អនុសញ្ញាទីក្រុងហ្សឺណែវ (IV), មាត្រា ៤៩។

លើនេះទៀត អ្នកដែលទទួលខុសត្រូវចំពោះការជម្លៀស "ត្រូវធានាក្នុងកម្រិតដែលអាចអនុវត្តជាក់ស្តែងបានថា កន្លែងស្នាក់អាស្រ័យសមរម្យត្រូវបានផ្តល់ជូន ដើម្បីទទួលជនដែលត្រូវទទួលបានការការពារ ហើយការផ្លាស់ទីលំនៅត្រូវធ្វើឡើងនៅក្នុងលក្ខខណ្ឌល្អផ្នែកអនាម័យ សុខភាព សុវត្ថិភាព និងអាហាររូបត្ថម្ភ ហើយសមាជិកគ្រួសារមិនត្រូវបានបំបែកចេញពីគ្នាឡើយ"[១៣៣៤]។ ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការផ្លាស់ទីលំនៅមិនអាចធ្វើយុត្តិកម្មបានទេ នៅក្នុងករណីដែលស្ថានភាពមនុស្សធម៌ ឬ ស្ថានភាពយោធានោះ បណ្តាលមកពីអំពើមិនស្របច្បាប់របស់ជនជាប់ចោទខ្លួនឯង ដែលបណ្តាលឲ្យមានការផ្លាស់ទីលំនៅដូច្នេះ[១៣៣៥]។

៤៥១. សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង ទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងអស់ រួមទាំង ការមិនមានយុត្តិកម្មចំពោះការជម្លៀសដោយបង្ខំ ដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ[១៣៣៦]។ ដើម្បីឲ្យអំពើមួយអាចត្រូវបានទទួលស្គាល់នៅក្រោមច្បាប់អន្តរជាតិត្រូវមានការវាយតម្លៃអំពីបរិបទនៃអង្គហេតុនៃករណីនីមួយៗ[១៣៣៧]។ បរិបទនៃអង្គហេតុនេះ ត្រូវតែពិនិត្យចាប់តាំងពីពេលដែលសេចក្តីសម្រេចក្នុងការជម្លៀសត្រូវបានធ្វើឡើង[១៣៣៨]។ ហេតុដូច្នេះ ភ័ស្តុតាងដែលថាផែនការ ឬ គោលនយោបាយនៃការជម្លៀសប្រជាជនត្រូវបានរៀបចំឡើង "ក្នុងរយៈពេលមួយដ៏យូរ" នៅមុនពេលជម្លៀសនោះបង្ហាញឲ្យឃើញថា ការជម្លៀសនេះមិនត្រូវបានធ្វើឡើង "ក្រោមហេតុផលចាំបាច់ណាមួយខាងផ្នែកយោធានោះឡើយ"[១៣៣៩]។

---

[១៣៣៤] អនុសញ្ញាទីក្រុងហ្សឺណែវ (IV), មាត្រា ៤៩។

[១៣៣៥] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៨៧។

[១៣៣៦] ចំពោះបញ្ហាទូទៅ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាង ដែលជាប់ទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងអស់: វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ សាលដីកាក្នុងរឿងក្តី *Ntawukulilyayo* កថាខណ្ឌ ៣០១-៣០៤។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY បានសង្កត់ធ្ងន់ថា នៅក្នុងករណីដែលធាតុផ្សំនៃបទល្មើសតម្រូវថា ធាតុផ្សំនោះត្រូវបានធ្វើឡើងដោយមិនមានមូលហេតុដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់អន្តរជាតិ នោះរដ្ឋអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាង៖ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៣៧ (ទាក់ទងនឹងការបំផ្លេចបំផ្លាញយ៉ាងខុសច្បាប់)។

[១៣៣៧] សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៣៧។

[១៣៣៨] សាលក្រមក្នុងរឿងក្តីអំពី *ចំណាប់ខ្មាំង* ទំព័រ ៤០១។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២៦។

[១៣៣៩] សវនាការក្នុងរឿងក្តី *von Manstein* ទំព័រ ៥២២-៥២៣។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២៦-៥២៧។

៤៥២. មេធាវីការពារក្តី នួន ជា លើកឡើងថា ការជម្លៀសដោយបង្ខំ មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩នោះទេ[១៣៤០]។ អង្គជំនុំជម្រះសម្រេចបដិសេធសារណានេះ ដោយផ្អែកទៅលើមូលដ្ឋានថា អំពើដែលបង្កើតបានជា "អំពើអមនុស្សធម៌មួយផ្សេងទៀត" មិនចាំបាច់បង្កើតបានជាបទល្មើសដាច់ដោយឡែក ដូចបានពិភាក្សាខាងលើរួចមកហើយនោះទេ[១៣៤១]។ ប៉ុន្តែ អង្គជំនុំជម្រះត្រូវតែជឿជាក់ថា អំពើនៃការផ្លាស់ទីលំនៅដោយបង្ខំមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបង្កើតបានជា "អំពើអមនុស្សធម៌មួយផ្សេងទៀត" នៅក្នុងរឿងក្តីនេះ។

៤៥៣. មេធាវីការពារក្តី នួន ជា ក៏បានលើកឡើងផងដែរថា អំពើនៃការជម្លៀសដោយបង្ខំមិនមានលក្ខណៈធ្ងន់ធ្ងរដូចបទឧក្រិដ្ឋដទៃទៀត ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះឡើយ។ ហេតុដូច្នេះ មិនអាចបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះទេ។ ទាក់ទងនឹងបញ្ហានេះ មេធាវីការពារក្តីលើកឡើងថា ការផ្លាស់ទីលំនៅដើម្បីសម្រេចគោលបំណងផ្នែកសេដ្ឋកិច្ចត្រូវបានអនុវត្តយ៉ាងទូលំទូលាយ នៅមុនពេល ក្នុងអំឡុងពេល និងភ្លាមៗបន្ទាប់ពីយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក[១៣៤២] ហើយនៅមុនឆ្នាំ ១៩៧៥ ការផ្លាស់ទីលំនៅក្នុងទឹកដីមួយ អាចនឹងឈានដល់កម្រិតធ្ងន់ធ្ងរដូចនឹងបទល្មើសជាក់លាក់ផ្សេងទៀត បានតែក្នុងករណីដែលការផ្លាស់ទីលំនៅនោះ ត្រូវបានអនុវត្តនៅក្នុងបរិបទនៃការកាន់កាប់ដោយបំពាន ក្នុងគោលបំណងឧក្រិដ្ឋ ឬ មានចរិតលក្ខណៈឧក្រិដ្ឋតែប៉ុណ្ណោះ[១៣៤៣]។ អង្គជំនុំជម្រះយល់ឃើញថា សារណាទាំងនេះមិនមានភាពគួរឲ្យជឿនោះទេ។ លិខិតុបករណ៍ និងយុត្តិសាស្ត្រផ្សេងៗមុនឆ្នាំ១៩៧៥ បង្ហាញថា ការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងព្រំដែនជាតិ ដែលត្រូវបានធ្វើឡើងដោយសារតែមូលហេតុផ្សេងៗក្រៅពីបញ្ហាសន្តិសុខរបស់ប្រជាជន ឬ ភាពចាំបាច់ខាងផ្នែកយោធា គឺមានភាពធ្ងន់ធ្ងរបំផុត។

---

[១៣៤០] [នួន ជា] សេចក្តីសន្និដ្ឋានបឋមពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១០-២៧។

[១៣៤១] *សូមមើល*ផ្នែកទី៩, ច្បាប់ជាធរមាន: ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ៤៣៤-៤៤០ ។

[១៣៤២] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣-២៣។

[១៣៤៣] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១០-១២, ២៤-២៧។ *សូលមើលផងដែរ* ឧបសម្ព័ន្ធ កៈ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E163/5/10.2 កថាខណ្ឌ ១៩-២០។

៤៥៤. ធម្មនុញ្ញទីក្រុងតូក្យូ ធម្មនុញ្ញតុលាការ Nuremberg និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង សុទ្ធតែបានកំណត់ការផ្លាស់ទីលំនៅដោយខុសច្បាប់ថាជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៣៤៤] ។ តុលាការ Nuremberg និងតុលាការជាតិ ដែលអនុវត្តច្បាប់អន្តរជាតិនៅមុនឆ្នាំ ១៩៧៥ បានផ្តន្ទាទោសជាច្រើនករណីចំពោះការជម្លៀសប្រជាជនដោយបង្ខំ រួមទាំងការផ្លាស់ទីលំនៅនៅក្នុងដែនដីជាតិ ដែលប្រព្រឹត្តឡើងដោយសារតែមូលហេតុផ្សេងៗដែលមិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ដូចជា បញ្ហាសន្តិសុខរបស់ប្រជាជន ឬ ភាពចាំបាច់ខាងយោធាជាដើម[១៣៤៥]។ នៅចន្លោះពីឆ្នាំ ១៩៤៩ ដល់ឆ្នាំ ១៩៧៥ លិខិតុបករណ៍អន្តរជាតិបានទទួលស្គាល់ទម្រង់នៃការផ្លាស់ទីលំនៅ ដោយមិនគិតពីការឆ្លងព្រំដែនណាមួយឡើយ ថាជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៣៤៦]។

[១៣៤៤] ធម្មនុញ្ញទីក្រុងតូក្យូ មាត្រា ៥។ ធម្មនុញ្ញតុលាការ Nuremberg មាត្រា ៦(ខ)-(គ)។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មាត្រា II(១)(ខ)-(គ)។ *សូមមើល ផងដែរ* សាលក្រមក្នុងរឿងក្តី *ក្រសួងយុត្តិធម៌* ទំព័រ ៩៦៦-៩៦៧, ៩៧១-៩៨៤។

[១៣៤៥] ការផ្តន្ទាទោសទាំងនេះ ត្រូវបានធ្វើឡើងចំពោះការផ្លាស់ប្តូរទីលំនៅដែលស្ថិតនៅក្នុងព្រំប្រទល់បូរណភាពដែនដីដូចខាងក្រោម៖ សាលក្រមក្នុងរឿងក្តី *Pohl* ទំព័រ ៩៨៥ (*សូមមើល ផងដែរ* សាលក្រមបន្ថែមក្នុងរឿងក្តី *Pohl* ទំព័រ ១១៧៤-១១៧៥។ សាលក្រមក្នុងរឿងក្តី *Pohl*, Musmanno Concurrence, ទំព័រ ១១២២-១១២៣)។ សាលក្រមក្នុងរឿងក្តី *ក្រសួងយុត្តិធម៌* ទំព័រ ៤៧៤, ៥៧៩, ៥៩៨-៥៩៩។ សាលក្រមក្នុងរឿងក្តី *មេបញ្ជាការជាន់ខ្ពស់* ទំព័រ ៥៧៣-៥៧៤, ៥៧៦, ៦០៦។ សាលក្រមក្នុងរឿងក្តី *ចំណាប់ខ្មាំង* ទំព័រ ១៣០៣-១៣០៥។ សាលក្រមក្នុងរឿងក្តី *Farben* ទំព័រ ១១៨៥-១១៨៦, ១១៩១។ សាលក្រមក្នុងរឿងក្តី *RuSHA* ទំព័រ ៩៤, ១២៦-១២៧, ១៣០, ១៥៨។ សាលក្រមក្នុងរឿងក្តី *Eichmann* ទំព័រ ៧៣, ៧៥, ២០៧-២០៩។ សវនាការក្នុងរឿងក្តី *Becker* ទំព័រ ៧១។ ជាពិសេស ដោយមិនមានការព្រួយបារម្ភចំពោះស្ថានភាពនៃផ្នែកខ្លះរបស់ប្រទេសប៉ូឡូញដែលត្រូវបានដាក់ជាឧបសម្ព័ន្ធ ឬត្រួតត្រានោះ តុលាការបានយល់ឃើញថា ប្រជាជនស៊ីវិលប៉ូឡូញត្រូវបាន "និរទេស" ទៅកាន់ជំរុំពិឃាដនៅក្នុងប្រទេសប៉ូឡូញ៖ សាលក្រមបន្ថែមក្នុងរឿងក្តី *Pohl* ទំព័រ ៩៨៥ (*សូមមើលផងដែរ* សាលក្រមបន្ថែមក្នុងរឿងក្តី *Pohl* ទំព័រ ១១៧៤-១១៧៥)។ សាលក្រមក្នុងរឿងក្តី *Pohl*, Musmanno Concurrence, ទំព័រ ១១៤៦។ សាលក្រមក្នុងរឿងក្តី *Eichmann* ទំព័រ ១២២-១២៧, ១៣៧, ១៤១, ១៩៨, ២១៧។ សវនាការក្នុងរឿងក្តី *Greiser* ទំព័រ ៩១, ៩២, ៩៥។ សវនាការក្នុងរឿងក្តី *Goeth* ទំព័រ ៣។

[១៣៤៦] *ឧទាហរណ៍ សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ២, ២៧, ៤២, ៤៩។ គោលការណ៍ Nuremberg មាត្រាVI(ខ)-(គ)។ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ មាត្រា II។ អនុសញ្ញាបន្ថែមប្រឆាំងនឹងការដាក់ឱ្យទៅជាទាសករ មាត្រា ៣(៣), ៦, ៧(គ)។ អនុសញ្ញាប្រឆាំងនឹងការរើសអើង មាត្រា ៥(ឃ)(i)។ គោលការណ៍ជាមូលដ្ឋានសម្រាប់ការការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ, សេចក្តីសម្រេចលេខ A/RES/2675 (XXV) ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧០។ អនុសញ្ញាស្តីពីរបបអាផាថេត (Apartheid មាត្រា II។ សេចក្តីប្រកាសរបស់អង្គការ

៤៥៥. យុត្តិសាស្ត្រនាពេលថ្មីៗពីតុលាការព្រហ្មទណ្ឌអន្តរជាតិ[១៣៤៧] ក៏ដូចជាមាត្រា ៧(១)(ឃ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងបញ្ជាក់បន្ថែមថា ការជម្លៀសដោយបង្ខំអាចត្រូវបានចាត់ទុកថាមានភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលគ្នាទៅនឹងឧក្រិដ្ឋកម្មដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្លាស់ទីលំនៅដោយបង្ខំ គឺជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាស្រ័យទៅលើកាលៈទេសៈនៃករណីនេះ។

### ៩.៤.៣ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ

៤៥៦. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ថា ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ បណ្តាលមកពីការដកហូតពីជនស៊ីវិលនូវរបបអាហារ ជម្រកស្នាក់នៅ ថ្នាំសង្កូវ និងស្ថានភាពអនាម័យក្នុងកម្រិតអប្បរមា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)[១៣៤៨]។

៤៥៧. យោងតាមយុត្តិសាស្ត្រអន្តរជាតិ ការមិនផ្តល់ចំណីអាហារ ទឹក ជម្រកស្នាក់នៅ និងជំនួយថ្នាំសង្កូវឲ្យបានគ្រប់គ្រាន់ ព្រមទាំងស្ថានភាពអនាម័យកម្រិតទាប នៅក្នុងបរិបទនៃការឃុំឃាំងបង្កើតបានជាការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អ្នកជាប់ឃុំឃាំង និងជាបទល្មើសនៃការ

---

សហប្រជាជាតិស្តីពីការការពារស្ត្រី និងកុមារ នៅក្នុងភាពអាសន្ន និងជម្លោះប្រដាប់អាវុធ សេចក្តីសម្រេចលេខ A/RES/3318(XXIX) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៤ កថាខណ្ឌ ៥។ *សូមមើលផងដែរ* ពិធីសារបន្ថែមលើកទី I មាត្រា ៨៥(៤)(ក)។ ពិធីសារបន្ថែមលើកទី II មាត្រា ១៧។ អត្ថបទអត្ថាធិប្បាយចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ទំព័រ ២៧៩។

[១៣៤៧] សវនាការក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៧។ សាលដីកា កថាខណ្ឌ ៣៣០-៣៣១។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយល់ឃើញប្រហាក់ប្រហែលគ្នា ថាតើការជម្លៀសដោយបង្ខំមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទល្មើសដទៃទៀតដែលបានរៀបរាប់ដែរឬអត់ នៅពេលពិចារណា ថាតើការជម្លៀសដោយបង្ខំអាចបង្កើតបានជាការធ្វើទុក្ខបុកម្នេញដែរ ឬអត់នោះ (សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២២២)។

[១៣៤៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣៤-១៤៣៦, ១៤៣៩-១៤៤០។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១ ឯកសារលេខ E124/7.3 ទំព័រ ២។

ប្រព្រឹត្តិដោយអមនុស្សធម៌ ដែលជាការរំលោភច្បាប់ ឬ ទំនៀមទម្លាប់នៃសង្គ្រាម នៅក្រោមលក្ខន្តិកៈរបស់តុលាការ ICTY[១៣៤៩] ។ ការដកហូតស្រដៀងគ្នានេះក៏ត្រូវបានបកស្រាយថាជាការប្រព្រឹត្តិដោយឃោរឃៅ និងអមនុស្សធម៌ ដែលអាចឈានដល់កម្រិតធ្ងន់ធ្ងរនៃបទល្មើសជាក់លាក់ដទៃទៀតនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៣៥០] ។ នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ ការដកហូតផ្សេងៗដូចគ្នានេះត្រូវបានពិចារណាថាជា ភ័ស្តុតាងស្តីពីស្ថានភាពរស់នៅដែលអាចបណ្តាលឲ្យមានការបំផ្លិចបំផ្លាញផ្នែករាងកាយរបស់ក្រុមមនុស្សណាមួយ[១៣៥១]។

៤៥៨. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការដកហូតបែបនេះអាចមានភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលគ្នានឹងបទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលនាំឲ្យអំពើនេះស្ថិតក្នុងវិសាលភាពនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត”។

---

[១៣៤៩] សាលក្រមក្នុងរឿងក្តី *Prlić និងអ្នកផ្សេងទៀត* ភាគ ៣ កថាខណ្ឌ ១១៥៩, ១១៦១, ១១៦៤, ១១៦៧-១១៦៨, ១១៧០-១១៧២, ១១៧៦-១១៧៨, ១១៨១-១១៨២, ១១៨៤, ១១៩២-១១៩៤, ១១៩៧-១១៩៩, ១២០១-១២០២, ១២០៤-១២០៥។ សាលក្រមក្នុងរឿងក្តី *Limaj និងអ្នកផ្សេងទៀត* កថាខណ្ឌ ២៨៨-២៨៩, ៣៣៣, ៦៥២។ សាលក្រមក្នុងរឿងក្តី *Delalić និងអ្នកផ្សេងទៀត* ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១១១៩។ *សូមមើលផងដែរ* សាលក្រមក្នុងរឿងក្តី *Prlić និងអ្នកផ្សេងទៀត* ភាគ ៣ កថាខណ្ឌ ១១០២-១១១១, ១១១៤-១១១៦, ១១១៨-១១២០, ១១២៤-១១២៦, ១១២៩-១១៣០, ១១៣២, ១១៣៥-១១៣៧, ១១៤០-១១៤២, ១១៤៥-១១៤៧, ១១៤៩-១១៥០, ១១៥២-១១៥៣ (យល់ឃើញថា ការប្រព្រឹត្តបែបនេះក៏បង្កើតបានជាបទល្មើសនៃការប្រព្រឹត្តដោយអមនុស្សធម៌ នៅក្រោមមាត្រា ២(ខ) នៃលក្ខន្តិកៈរបស់តុលាការ ICTY ផងដែរ។

[១៣៥០] សាលដីកាក្នុងរឿងក្តី *Prlić Blaškić* កថាខណ្ឌ ១៥៥។ សាលក្រមក្នុងរឿងក្តី *Stanisić និង Župljanin* កថាខណ្ឌ ២០៣, ២២៤, ២២៦, ៦៧៨-៦៧៩, ៦៨១, ៦៨៣, ៧០១, ៩២៨, ៩៣០, ៩៣៦-៩៣៧, ៩៦៩, ៩៨៤-៩៨៥, ១១២០-១១២១, ១១៩១-១១៩២, ១២៤៩-១២៥០, ១២៨៦-១២៨៨, ១៣៤១, ១២៥៦-១៣៥៨, ១៤៨៤, ១៤៩៨-១៥០០, ១៥៥៣-១៥៥៥។ សាលក្រមក្នុងរឿងក្តី *Blagojević និង Jokić* កថាខណ្ឌ ៦០៦, ៦១០, ៦២០-៦២១។ សាលក្រមផ្តន្ទាទោស *Duško Sikirica* កថាខណ្ឌ ១២៧, ១៦១, ២០៣។

[១៣៥១] រឿងក្តី *Karadžic*, សាលដីកាអនុលោមតាមវិធាន ៩៨*ស្ទួន* (AC) កថាខណ្ឌ ៤៨-៤៩។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩១។ សាលក្រមក្នុងរឿងក្តី *Kayishema និង Ruzindana* កថាខណ្ឌ ១១៥-១១៦។

# ១០. ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១)

## ១០.១ ដីកាដំណោះស្រាយ

៤៥៩. យោងតាមដីកាដំណោះស្រាយ ក្រោយពីកងទ័ពខ្មែរក្រហមបានកាន់កាប់ក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយបានប្រើប្រាស់ការគំរាមកំហែង និងអំពើហិង្សា ពួកគេបានជម្លៀសប្រជាជនទាំងអស់នៅក្នុងទីក្រុងដោយបង្ខំឲ្យទៅកាន់ទីជនបទ ហើយប្រជាជនទាំងនោះភាគច្រើនជាប្រជាជនស៊ីវិល[១៣៥២] ។ ការជម្លៀសនេះ ពុំមានយុត្តិកម្មស្របតាមមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិនោះទេ[១៣៥៣] ។ ដីកាដំណោះស្រាយបញ្ជាក់ថា នៅក្នុងពេលធ្វើការជម្លៀសប្រជាជនស៊ីវិល និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើននាក់ ជាពិសេស អ្នកដែលមានឋានន្តរសក្តិខ្ពស់ ត្រូវបានសម្លាប់ ឬ បាត់ខ្លួន[១៣៥៤]។ ម្យ៉ាងវិញទៀត នៅក្នុងអំឡុងពេលជម្លៀសអ្នកដែលត្រូវបានជម្លៀសបានឆ្លងកាត់ស្ថានភាពទុក្ខលំបាកវេទនា និងគ្មានស្បៀងអាហារ ទឹក សេវាវេជ្ជសាស្ត្រ ឬ កន្លែងស្នាក់នៅ ជាហេតុបណ្តាលឲ្យប្រជាជនជាច្រើនធ្លាក់ខ្លួនឈឺ ឬស្លាប់[១៣៥៥] ។ ដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទពីបទធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ក្រោមទម្រង់នៃ (i) ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និង (ii) ការជម្លៀសដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)[១៣៥៦]។

---

[១៣៥២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៤, ២២៤-២៣៣, ១៤៤៨-១៤៥០។

[១៣៥៣] ដីកាដំណោះស្រាយ កថាខណ្ឌ ២៤២-២៤៩, ១៤៤៩, ១៤៥២-១៤៦៩។

[១៣៥៤] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៦-២០៩, ២៣២, ២៣៤-២៣៥។

[១៣៥៥] ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៦-២៤០, ១៤៣៥-១៤៣៦។

[១៣៥៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៧ (ការធ្វើមនុស្សឃាត) កថាខណ្ឌ ១៣៨១, ១៣៨៧ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៤១៦ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) កថាខណ្ឌ ១៤៣៤-១៤៣៦ (អំពើអមនុស្សធម៌ផ្សេងៗទៀតដែលរួមមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) កថាខណ្ឌ ១៤៤៨-១៤៥៣, ១៤៥៥, ១៤៥៨-១៤៥៩, ១៤៦១, ១៤៦៨-១៤៦៩ (អំពើអមនុស្សធម៌ផ្សេងៗទៀតដែលរួមមានការជម្លៀសដោយបង្ខំ)។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ អនុលោមតាមដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កថាខណ្ឌ ២២១-២៦០ នៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងបទល្មើសនានាដែលត្រូវបានចោទប្រកាន់ គឺស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង ០០២/០១។

## ១០.២ ហេតុការណ៍ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃបន្តបន្ទាប់

### ១០.២.១ ការអនុវត្ត

៤៦០. នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមមកពីតាមភូមិភាគនានានៅទូទាំងប្រទេសកម្ពុជា[១៣៥៧] បានវាយសម្រុកចូលទីក្រុងភ្នំពេញពីគ្រប់មុខព្រួញ[១៣៥៨] ។ ជាធម្មតា

---

*សូមមើល* ឧបសម្ព័ន្ធៈបញ្ជីកថាខណ្ឌ និងផ្នែកផ្សេងៗនៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ឯកសារ E124/7.3 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១-៤។

[១៣៥៧] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១០-១២ (កងពលមកពីភូមិភាគនិរតី ភូមិភាគបូព៌ា និងភូមិភាគឧត្តរ ត្រូវបានបញ្ជូនទៅវាយចូលទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/356 ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ១០-១១ ERN (ភាសាខ្មែរ)00242893-94(កងទ័ពភូមិភាគនិរតី កងទ័ពភូមិភាគពិសេស កងទ័ពភូមិភាគបូព៌ា និងកងទ័ពភូមិភាគឧត្តរ បានចូលមកទីក្រុងភ្នំពេញនៅក្នុងពេលជម្លៀសក្នុងខែ មេសា ឆ្នាំ ១៩៧៥ ហើយភូមិភាគនីមួយៗមានមេបញ្ជាការខុសៗគ្នា)។ ភូមិភាគឧត្តរៈ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អ៊ាន ឯកសារ E3/376 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00270172 (សាក្សីធ្លាប់ជាកងទ័ពនៅក្នុងវរសេនាធំមួយមកពីភូមិភាគឧត្តរ និងបានវាយចូលទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00204739-40 (សាក្សីបាននាំទ័ពពីភូមិភាគ ៣០៤ ចូលទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00172079 (សាក្សីស្ថិតក្នុងចំណោម“ទ័ពឧត្តរ” ដែលបានចូលទៅទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម ឯកសារ E3/3959 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00270163 (សាក្សីបានចូលរួមវាយចូលទីក្រុងភ្នំពេញក្នុងនាមជាប្រធានកងនៅក្នុងកងពលមួយរបស់ភូមិភាគឧត្តរ)។ ភូមិភាគនិរតីៈ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ E3/419 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00407747 (សាក្សីបានចូលរួមវាយចូលទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា។ សាក្សីស្ថិតនៅក្នុងភូមិភាគនិរតី)។ ភូមិភាគពិសេសៈ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ កែវ ឯកសារ E3/5173 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00189264 (សាក្សីនៅក្នុងកងវរសេនាធំនៅក្នុងភូមិភាគពិសេស ដែលបានចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។

[១៣៥៨] ប្រតិចារឹកថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ (អ៊ុង រ៉េន)ទំព័រ៣៤ (ស្ថិតក្នុងក្រុមវាយចូលពីភូមិភាគនិរតី ពីពោធិ៍ចិនតុងនៅពេលកងទ័ពនិរតីបានវាយតាមផ្លូវជាតិលេខ ៤)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៣ (អ៊ុង រ៉េន) ទំព័រ ៣៩, ៦៩-៧០(ស្ថិតក្នុងក្រុមវាយពីពោធិ៍ចិនតុង)។ ប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣(ឆោម សែ)ទំព័រ ៤៧ (កងទ័ពប្រុសកងទ័ពស្រីចូលមកតាមពោធិ៍ចិនតុង ហើយទៅដល់ក្រសួងឃោសនាការ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៧-៩, ១៧-១៨ (ស្ថិតក្នុងក្រុមវាយមកពីបាសិត ភាគខាងជើងក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៥៩ (បានស្តាប់ឮថា យោធាភូមិភាគផ្សេងៗនឹងវាយប្រហារមកពីមុខព្រួញ

កងទ័ពខ្មែរក្រហម រួមមានទាំងក្មេងៗ និងក្មេងជំទង់ ត្រូវបានគេមើលឃើញថា ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ពាក់ស្បែកជើងកង់ឡាន បង់កក្រមា ឬ មួក និងប្រដាប់ដោយអាវុធពាសពេញខ្លួន[១៣៥៩]។ ទោះបីជា កងទ័ពខ្មែរក្រហមបានទទួលបញ្ជាឲ្យកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៨ ខែ

---

ផ្សេងៗគ្នា)។ប្រតិចារឹក ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២(មាស រឿន)ទំព័រ ៧៣-៧៤ (កងពលរបស់សាក្សីទទួលខុសត្រូវលើការវាយប្រហារពីភូមិភាគនិរតី ពោលគឺ ពោធិ៍ចិនតុង ស្ទឹងមានជ័យ និងបឹងប្រយ៉ាប ព្រមទាំងទន្លេសាប)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៤២ (កងវរសេនាតូចរបស់គាត់បានវាយប្រហារពីតំបន់រ៉ាសំរោងស្ថានីយ៍រថភ្លើងសំរោងដែលស្ថិតនៅខាងជើងពោធិ៍ចិនតុង និងខាងត្បូងទួលលាប)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧២ (នៅថ្ងៃទី ១៧ ខែ មេសា វេលាម៉ោងប្រហែល ៦ ព្រឹក បានឃើញកងទ័ពខ្មែរក្រហមជាច្រើននាក់ចូលទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨០ (ពួកគេបានមកតាមព្រែកព្នៅ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៥ (បានឃើញឡានដឹកមនុស្សពេញៗមកពីទិសខាងជើង មកក្បែរស្ថានទូតបារាំងនៅវេលាម៉ោង ៨ ព្រឹក ហើយក្រុមដទៃទៀតមកពីតាមទិសដៅផ្សេងៗទៀត)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៩-២០ (ពួកគេទាំងអស់ចូលមកពីគ្រប់ទិសនៅក្នុងព្រឹកនោះ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៧។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១២ (មាស រឿន) ទំព័រ ៧៣-៧៤ (បានឃើញកងទ័ពខ្មែរក្រហមធ្វើដំណើរមកតាមផ្លូវពីទិសខាងលិច ហើយកងទ័ពជាច្រើននាក់ទៀតមកពីឆ្ងាយៗ)។ *វិទ្យុវណសិរ្សរួបរួមជាតិកម្ពុជា៖ កងទ័ពរំដោះជាតិប្រជាជនកម្ពុជានៅចំកណ្តាលក្រុងភ្នំពេញ ហើយវិទ្យុវណសិរ្សរួបរួមជាតិកម្ពុជាផ្សាយអំពីការរំដោះទីក្រុងភ្នំពេញ និងការកាន់កាប់ស្ថានទូតសហរដ្ឋអាមេរិក* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166972 ERN (ភាសាខ្មែរ) 00846158-00846159 (ឯកសារទាំងពីរនេះគូសបញ្ជាក់អំពីការធ្វើដំណើរចូលក្នុងទីក្រុងភ្នំពេញពីទិសឧត្តរ ទក្សិណ បូព៌ា និងបស្ចិម)។

[១៣៥៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១២ (ទាហានស្លៀកពាក់ឈុតខ្មៅ ឬ ឈុតពណ៌កាគី ហើយខ្លះស្ពាយកាំភ្លើង និងលីកាំភ្លើងដូចត្រយ៉ូងចេក)ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៨ (កងទ័ព ខ្មែរក្រហមបានចូលក្នុងក្រុង ដោយមានស្ពាយកាំភ្លើង និងសីរ៉ាន់ធីណៃ ហើយក្រោយមក ជុំ សុខា បានឃើញរថក្រោះ និងឡានយោធាមក)។ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ)ទំព័រ៥៨,៦៦-៦៧ (ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅបង់កក្រមាពណ៌ក្រហម និងមានបំពាក់អាវុធពាសពេញខ្លួន)។ ប្រតិចារឹកថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ៧៤-៧៥, ៧៦-៧៧។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨០-៨១។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៧ (និយាយសំដៅលើរូបថតមួយសន្លឹកដែល Alan ROCKOFF បានថតក្មេងប្រុសខ្មែរក្រហមម្នាក់ប្រដាប់ដោយអាវុធ នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារ E3/3986) ១៦-១៧ (រម្លឹកថា កងទ័ពគឺជាក្មេងជំទង់ៗ អាយុប្រហែល ១៦ ឆ្នាំ) ១៨-២១, ៨០ (ពួកគេគឺជាក្មេងៗដែលកងទ័ពខ្មែរក្រហមបានយកមកឲ្យធ្វើកងទ័ព) ២២-២៣, ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៩-២០, ២៣។ ប្រតិចារឹក ថ្ងៃទី ២៣

មេសា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏ទីក្រុងភ្នំពេញត្រូវបានរំដោះនៅមុនថ្ងៃនេះ ដោយសារកងកម្លាំងនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងទីក្រុងភ្នំពេញពុំមានភាពរឹងទទឹង[១៣៦០]។ បើទោះជាមានហេតុការណ៍

---

ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០ (ពួកគេប្រដាប់ដោយអាវុធ)។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សាវ៉ាន់) ទំព័រ ៧៣-៧៥។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នូន ផល្លី) ទំព័រ ៤១-៤២ (ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ហើយនឹងតី ឬ ក្រណាត់ពណ៌ក្រហម។ គាត់ក៏បានឃើញតីពណ៌ខៀវចងជាប់នឹងឡានរបស់ខ្មែរក្រហមដែលបើកចូលមកក្នុងក្រុង)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៦-៧, ៣៥-៣៦ (កងទ័ពខ្មែរក្រហមទាំងប្រុសទាំងស្រី ប្រដាប់ដោយអាវុធ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ កំពុងដើរនៅតាមផ្លូវជាមួយនឹងទឹកមុខមាំ ហើយបាញ់កាំភ្លើងឡើងលើមេឃ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៩៥ (កងទ័ពខ្មែរក្រហមស្លៀកសម្លៀកបំពាក់សុទ្ធតែពណ៌ខ្មៅ ហើយរុំកនឹងក្រមា ប្រដាប់ដោយកាំភ្លើងវែង)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូរ ហ៊ាន់) ទំព័រ ២៦ (ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ពាក់ស្បែកជើងកង់ឡាន កាន់កាំភ្លើង AK ៤៧ និងពាក់មួកកន្ទឹប)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៣-៥៤, ៥៥ (ក៏បានឃើញកងទ័ពស្លៀកសម្លៀកបំពាក់ពណ៌បៃតង) ៥៥-៥៦។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៧-១៨, ២១-២២ (ពិពណ៌នាមនុស្សវ័យក្មេងៗ ខ្លះស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ និងខ្លះទៀតពណ៌បៃតង កាន់កាំភ្លើងវែងខុសៗគ្នា) ៤៩ (ពិពណ៌នាកងទ័ព២ក្រុម ក្រុមទីមួយជាកងទ័ពក្មេងៗអាយុប្រហែល ១៤-១៥ ឆ្នាំ និងក្រុមទីពីរ អាយុប្រហែល ៣០ ឆ្នាំ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៧-៨ (ពិពណ៌នាកងទ័ពខ្មែរក្រហមពាក់មួកកាតិបម៉ៅនិយម) ៣៥-៣៦, ៧៩-៨០ (កងទ័ពខ្មែរក្រហមក្មេងៗអាយុប្រហែល ១៣-១៤ ឆ្នាំ យាមកាមពួកគាត់នៅស្ថានទូតបារាំង)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ២៣-២៤, ៣៧-៣៨, ៤៧ (ជាកងទ័ពខ្មែរក្រហមម្នាក់ គាត់បានពិពណ៌នាថាគាត់នៅក្មេងដែរ អាយុប្រហែល ១៦ ឬ ១៧ ឆ្នាំ ប៉ុណ្ណោះ នៅពេលចូលក្នុងទីក្រុងភ្នំពេញ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា យោងតាមថ្ងៃខែឆ្នាំកំណើតរបស់គាត់ នៅពេលនោះ គាត់ទំនងជាមានអាយុ ១៨ ឆ្នាំ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៥០-៥១ (ពិពណ៌នាអំពីទាំងកងទ័ពក្មេងៗ និងកងទ័ពចំណាស់ៗ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៦-៧ (កងទ័ពក្មេងៗបានជម្លៀសគាត់)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣២ (ពិពណ៌នាកងទ័ពក្មេងៗស្ពាយកាំភ្លើងនៅជិតសាលាច្បាប់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484907 (ពិពណ៌នាអំពីកងទ័ពខ្មែរក្រហមចំនួន ៥ នាក់ មានសំលៀកបំពាក់ពណ៌ខ្មៅ ពាក់ស្បែកជើងកង់ឡានពណ៌ខ្មៅ ប្រដាប់ដោយកាំភ្លើងអាកា)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៥-១០ ERN (ភាសាខ្មែរ) 00644701-05 (ពិពណ៌នាកងទ័ពខ្មែរក្រហម ដែលសម្បូរដោយក្មេងជំទង់ៗកំពុងស្ថិតក្នុងរថយន្ត។ កងទ័ពម្នាក់ពាក់មួកទន់ធម្មតាដូច ម៉ៅ សេទុង និងកងទ័ពស្លៀកពាក់ឯកសណ្ឋានខ្មៅ ហើយកងទ័ពខ្លះកម្រមានកម្ពស់ខ្ពស់ជាងកាំភ្លើងអាកា-៤៧ ណាស់)។

[១៣៦០] ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស រឿន) ទំព័រ ៥-៨, ៧៣-៧៥។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៧៤-៧៥ (ពុំបានឃើញទាហាន លន់ នល់ វាយប្រឆាំងនឹងការឈ្លានពានរបស់ខ្មែរ

បាញ់កាំភ្លើងបន្តិចបន្តួចរវាងកងទ័ពខ្មែរក្រហម និងទាហានក៏ដោយ[១៣៦១] ក៏ការវាយប្រយុទ្ធគ្នានោះជាទូទៅ បានបញ្ចប់នៅក្រោយពេលចូលមកដល់ទីក្រុងភ្នំពេញ[១៣៦២] ។ កងពលនានារបស់កងទ័ពខ្មែរក្រហមបានកាន់កាប់តំបន់ខុសៗគ្នា នៅក្នុងទីក្រុងភ្នំពេញ[១៣៦៣]។

---

ក្រហមនោះទេ ប៉ុន្តែគាត់បានឃើញទាហាន លន់ នល់ ជាច្រើនបានដាក់អាវុធចុះ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៥០ (ពួកគេបានគិតថា នឹងមានការវាយប្រយុទ្ធគ្នាខ្លាំងនៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែពុំមានការវាយប្រយុទ្ធគ្នាបែបនេះទាល់តែសោះ។ ពួកគេអាចគ្រប់គ្រងទីក្រុងភ្នំពេញដោយគ្មានការវាយប្រយុទ្ធគ្នា ហើយប្រជាជនមានអារម្មណ៍ធូរស្បើយនៅពេលនោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373416 (អតីតកងទ័ពខ្មែរក្រហមម្នាក់បាននិយាយថា ពួកគេជួបប្រទះនឹងការប្រយុទ្ធទប់ទល់គ្នាខ្លះនៅជិតទីក្រុងភ្នំពេញ ប៉ុន្តែមិនមានការប្រយុទ្ធទប់ទល់ទេនៅពេលពួកគេមកដល់ទីក្រុងភ្នំពេញ ដោយសារទាហាន លន់ នល់ បានចុះចាញ់ហើយ)។

[១៣៦១] *ស្ថានទូតកម្ពុជានៅក្នុងទីក្រុងបាងកកបាត់ការទាក់ទងជាមួយនឹងទីក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166971 (ប្រភពនេះលើកឡើងថា ការវាយប្រយុទ្ធគ្នាបានបន្តនៅម្តុំកន្លែងតូចតាចដែលនៅបន្តកាន់កាប់ដោយទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងទីក្រុងភ្នំពេញនៅឡើយ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ សេចក្តីរាយការណ៍របស់ប្រជាជនអាមេរិកស្តីពីស្ថានភាពទីក្រុងភ្នំពេញបន្ទាប់ពីការដួលរលំ ឯកសារ E3/4148 ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ កថាខណ្ឌ ២ ERN (ភាសាខ្មែរ) 00663996 (ជនជាតិអាមេរិកម្នាក់ដែលត្រូវបានជម្លៀសចេញបានរាយការណ៍ថា ការប្រយុទ្ធគ្នាបានធ្វើឡើងក្នុងអំឡុងពេលប្រហែលជាមួយសប្តាហ៍ទៅ១០ ថ្ងៃ បន្ទាប់ពីការដួលរលំរបបទីក្រុងភ្នំពេញ។ បន្ទាប់ពីពេលនោះមក គាត់បានប៉ាន់ស្មានថា ឃ្លាំងអាវុធទាំងអស់របស់កងកម្លាំងប្រដាប់អាវុធជាតិខ្មែរ (FANK) ត្រូវបានរឹបអូស) ។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (យិន រំដួល) ទំព័រ ៥៨, ៧២-៧៣ (ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា កងទ័ពខ្មែរក្រហមបានបាញ់កាំភ្លើងចូលក្នុងផ្ទះអ្នកជិតខាងរបស់គាត់ ហើយការបាញ់តទល់គ្នាបានកើតឡើងរវាងអ្នកនៅក្នុងផ្ទះនោះដែលមានអាវុធ និងជាវរសេនីយ៍ឯកនៅក្នុងជួរយោធា)។ *សូមមើលផងដែរ* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ចាខណ្ឌ ៥១០។

[១៣៦២] ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៧ (យើងបានប្រើប្រាស់កាំភ្លើងធំនៅពេលយើងវាយប្រហារ និងទៅដល់ពោធិ៍ចិនតុង ប៉ុន្តែនៅពេលយើងនៅក្នុងទីក្រុងភ្នំពេញ យើងលែងប្រើប្រាស់កាំភ្លើងធំទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៩ (ពុំបានសង្កេតឃើញមានជនស៊ីវិលស្លាប់នៅក្នុងពេលសម្រុកចូលទីក្រុងភ្នំពេញនោះទេ) ៧៤-៧៥ (ពុំបានឃើញទាហាន លន់ នល់ វាយប្រយុទ្ធនឹងការសម្រុកចូលរបស់កងទ័ពខ្មែរក្រហមនោះទេ។ អាវុធដែលពួកគេបានដាក់ចុះ បានប្រមូលគរនៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៧ (ក្រោយកងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម អត់មានបាញ់គ្នាទេ ពីព្រោះទាហាន លន់ នល់ ចុះចាញ់ និងដាក់អាវុធចុះហើយ។ ប៉ុន្តែ កងទ័ពខ្មែរក្រហមបានរំលោភបំពានលើទាហាន លន់ នល់ និងប្រជាជន)។

### ១០.២.២ ការចាក់ផ្សាយតាមវិទ្យុ

៤៦១. មានការចាក់ផ្សាយតាមវិទ្យុ និងសេចក្តីប្រកាសមួយចំនួនដោយភាគីផ្សេងៗ រួមទាំង ហែម កេតដារ៉ា (អ្នកតំណាងម៉ូណាស៊ីយ៉ូ ឬ *ចលនាជាតិ*)[១៣៦៤] និងសម្តេចសង្ឃទាំងពីរគណៈនៅក្នុងអំឡុងពេលព្រឹក[១៣៦៥]។ ក្រោយមក ឧត្តមសេនីយ៍ ម៉ី ស៊ីចន អ្នកនាំពាក្យឲ្យកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល បានអញ្ជើញកម្មាភិបាលតំណាងខ្មែរក្រហមមកទីក្រុងភ្នំពេញ និងបានអំពាវនាវឲ្យទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងអស់នៅទូទាំងប្រទេសដាក់អាវុធចុះ[១៣៦៦] ។ ក្រោយពេល

---

[១៣៦៣] ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស រឿន) ទំព័រ ៥-៧។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៨-៩, ២១-២២, ៥៩-៦០ (សាក្សីទទួលបន្ទុកពីតំបន់ខាងជើងវត្តភ្នំរហូតដល់ស្ពានជ្រោយចង្វារ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ២៦-២៨ (ទីក្រុងភ្នំពេញត្រូវបានបែងចែកជាតំបន់ផ្សេងៗគ្នា យោងតាមកងពលដែលមករំដោះទីក្រុងភ្នំពេញ ដែលនៅពេលនោះ កងពលទាំងនេះទំនងជាគេឲ្យការពារតំបន់ទាំងអស់នោះ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ២៧-២៨ (កងពលរបស់គាត់ទទួលបន្ទុកតាមដានតំបន់នៅជុំវិញផ្សារថ្មី) ៣០ (កងពលមកពីភូមិភាគពិសេសក៏ទទួលបន្ទុកតាមដានក្រុងផងដែរ)។ ប្រតិចារឹក ថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២(ស៊ុំ ជា)ទំព័រ ៦៧-៦៨ (ក្រុងត្រូវបានបែងចែកទៅតាមភូមិភាគ។ ភូមិភាគ បូព៌ាមើលការខុសត្រូវចាប់ពីផ្សារថ្មីទៅខាងត្បូង។ ភូមិភាគនិរតីមើលការខុសត្រូវចាប់ពីផ្សារថ្មីទៅប៉ែកខាងលិចក្រុង ជិតពោធិ៍ចិនតុង។ ពីផ្សារថ្មីរហូតដល់មាត់ទន្លេត្រូវបានកាន់កាប់ និងមើលការខុសត្រូវដោយភូមិភាគឧត្តរ) ទំព័រ ៧៩ (ហាក់ ប្រធានកងវរសេនាតូច បាននិយាយប្រាប់យើងអំពីវិធីដែលគេបែងចែកក្រុងទៅជាតំបន់ ហើយក្រុមកងទ័ពខុសៗគ្នាទទួលការងារការពារតំបន់របស់ពួកគេរៀងៗខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ហឿន ឯកសារ E3/5280 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00287555 (ត្រូវបានគេបញ្ជាឲ្យទៅការពារស្ថានីយ៍វិទ្យុវត្តភ្នំ)។

[១៣៦៤] *"មេដឹកនាំចលនាអ្នកជាតិនិយម" អំពាវនាវឲ្យទម្លាក់អាវុធចុះចាញ់តាមវិទ្យុក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166972-73 (អ្នកតំណាងចលនាអ្នកជាតិនិយមបានពាវនាវឲ្យមេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធជាតិ បញ្ជាទៅកងទ័ពរបស់ពួកគេឲ្យដាក់អាវុធចុះ និងអញ្ជើញអ្នកតំណាងនៃក្រុមផ្សេងទៀតមកកាន់ក្រសួងព័ត៌មាន) ។ សៀវភៅ François PONCHAUD *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ERN (ភាសាខ្មែរ) ០០៨៦២២៨៨-៩ (ការបញ្ជាក់អំពីម៉ូណាស៊ីយ៉ូ គឺ ចលនាជាតិ)។

[១៣៦៥] *ព្រះសង្ឃរាជទាំងពីរគណៈអំពាវនាវឲ្យមានបទឈប់បាញ់ ដោយស្នើឲ្យខ្មែរក្រហមចូលក្នុងកិច្ចប្រជុំ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905194 (អំពាវនាវឲ្យភាគីបញ្ឈប់ការប្រយុទ្ធគ្នា)។

[១៣៦៦] *ឧត្តមសេនីយ៍រដ្ឋាភិបាលអញ្ជើញអ្នកតំណាងភាគីម្ខាងទៀតឲ្យចូលភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905195។ ប្រតិចារឹកថ្ងៃទី ០៧

ប្រកាសនោះតែប៉ុន្មាននាទីប៉ុណ្ណោះ ខ្មែរក្រហមក៏បានកាន់កាប់ស្ថានីយ៍វិទ្យុ ហើយបានច្រានចោលចំពោះការអញ្ជើញឲ្យមានការចរចាជាមួយនឹង "បនក្សត់ណាមួយរបស់ លន់ នល់ ដែលគួរឲ្យស្អប់ខ្ពើម" ដោយបានអះអាងថា ពួកគេកំពុង "ចូលទីក្រុងភ្នំពេញតាមរយៈកម្លាំងប្រដាប់អាវុធ" ហើយបានអញ្ជើញមេបញ្ជាការនៃកងទ័ពរំដោះជាតិកម្ពុជាដែលបានទទួលជោគជ័យ ឲ្យធ្វើដំណើរទៅកាន់ក្រសួងព័ត៌មាន និងបញ្ជា "ឲ្យសមាជិកនៃបនក្សត់ លន់ នល់ ដែលនៅសេសសល់ទំលាក់អាវុធចុះ និងប្រគល់ទៅឲ្យ"គណៈកម្មាធិការនៃកងកម្លាំងរណសិរ្សរួបរួមជាតិកម្ពុជាដែលមកពីតំបន់ឧត្តរ និងបូព៌ា [១៣៦៧]។

៤៦២. ក្រោយនោះបន្តិច មេដឹកនាំខ្មែរក្រហមម្នាក់ដែលពុំបានបង្ហាញអត្តសញ្ញាណបានប្រកាសថា ក្រោយពីបានជួបជាមួយនឹង ឈឹម ឈួន, លន់ ណុន និងសម្តេចសង្ឃទាំងពីរគណៈ ទាហាននៃរបបសាធារណរដ្ឋខ្មែរបានយល់ព្រមទម្លាក់អាវុធចុះ និងព្រមចុះចូល។ ដូច្នេះ មេដឹកនាំរូបនេះបាន

---

ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៣០ (សេចក្តីប្រកាសធ្វើឡើងដោយឧត្តមសេនីយ៍ ម៉ី ស៊ីចន)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨ (មន្ត្រីតំណាងទាហាន លន់ នល់ បានបញ្ជាក់ច្បាស់ថា នៅពេលនេះ យើងចាញ់ហើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418273 (បានឃើញឧត្តមសេនីយ៍ ម៉ី ស៊ីចន ជាមួយកងទ័ពខ្មែរក្រហម ៣ នាក់ អមដំណើរគាត់ទៅកាន់វិទ្យុជាតិ ដើម្បីស្រែកប្រកាសតាមវិទ្យុនៅទីនោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មឿង សុន ឯកសារ E3/1745 ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៣, ៥ ERN (ភាសាខ្មែរ) 00304326, 00304328 (គាត់រស់នៅក្នុងក្រុងកំពង់សោម ហើយបានស្តាប់ឮការប្រកាសតាមវិទ្យុឲ្យកងទ័ពទាំងអស់ទម្លាក់អាវុធចុះ)។ *សូមមើលផងដែរ* S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១១៣ ERN (ភាសាខ្មែរ) 00963951 (អ្នកនាំពាក្យឲ្យទីបញ្ជាការយោធាទីក្រុងភ្នំពេញ ដែលបានបរាជ័យ ឈ្មោះឧត្តមសេនីយ៍ ម៉ី ស៊ីចន ក៏បានចេញមកអំពាវនាវតាមវិទ្យុទៅដល់ពលទាហានទាំងអស់ឲ្យសុំចុះចាញ់ ហើយសហការជាមួយនឹងអ្នកទទួលជ័យជម្នះ)។ យោងតាម ហ៊ុន ឈុនលី លន់ ណុន (ប្អូនប្រុសរបស់ លន់ នល់) ក៏បានធ្វើការប្រកាសដូចគ្នានេះដែរ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ ៣០-៣១។

[១៣៦៧] *តំណាងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាប្រាប់ឲ្យកងទ័ពរដ្ឋាភិបាលចុះចាញ់* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00166974។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418273 (ភាសាខ្មែរ) (ក្រោយពីឧត្តមសេនីយ៍ ម៉ី ស៊ីចន បានអំពាវនាវឲ្យទាហាន លន់ នល់ ទម្លាក់អាវុធចុះចាញ់រួចមក ខ្មែរក្រហមបានប្រកាសតាមវិទ្យុថា៖ "យើងមកនេះមិនមែនមកចរចាទេ គឺមកដោយញើសឈាម និងចុងអាវុធ")។

01006677



អំពាវនាវ "ឲ្យរដ្ឋមន្ត្រី និងគ្រប់ឧត្តមសេនីយ៍ផ្សេងទៀតដែលពុំទាន់បានរត់ទៅទីណានោះ ចូលខ្លួនទៅកាន់ក្រសួងព័ត៌មានជាបន្ទាន់ ដើម្បីជួយបង្កើតវិធានការស្តារសណ្តាប់ធ្នាប់ឡើងវិញ" និងបានប្រកាសថានឹងបង្កើតគណៈកម្មាធិការមួយក្នុងពេលដ៏ខ្លីខាងមុខ ដែលមានសមាសភាពជាកម្មាភិបាលរណសិរ្សរួបរួម និងរណសិរ្សរំដោះ ដែលមកពីទូទាំងប្រទេស មកចូលរួមប្រជុំ[១៣៦៨]។

៤៦៣. នៅត្រឹមពាក់កណ្តាលព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានកាន់កាប់គ្រប់ទីកន្លែងទាំងអស់ក្នុងទីក្រុងភ្នំពេញ[១៣៦៩]។

### ១០.២.៣ បរិយាកាសនៅក្នុងទីក្រុងភ្នំពេញ និងសេចក្តីប្រកាសស្តីពីការជម្លៀស

៤៦៤. ក្នុងរយៈពេលប៉ុន្មានម៉ោង ក្រោយពេលកងទ័ពខ្មែរក្រហមបានចាប់ផ្តើមចូលមកដល់ក្នុងទីក្រុងកងទ័ពខ្មែរក្រហមក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ[១៣៧០] បាននិយាយឡើងថា "សង្គ្រាមបានបញ្ចប់

---

[១៣៦៨] *តាមការរាយការណ៍ថ្ងៃទី ១៧ ខែ មេសា ថាកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលចុះចាញ់* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905196-00905197។

[១៣៦៩] *ស្ថានទូតកម្ពុជានៅក្នុងទីក្រុងបាងកកបាត់ការទាក់ទងជាមួយនឹងទីក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166971 (ប្រភពមួយបានរាយការណ៍អំពីព័ត៌មានដែលទទួលបានមកពីស្ថានទូតរបស់បស្ចិមប្រទេសមួយនៅក្នុងទីក្រុងភ្នំពេញ បាននិយាយថាកងទ័ពខ្មែរក្រហមបានកាន់កាប់ទីក្រុងគ្រប់កន្លែងទាំងអស់នៅត្រឹមម៉ោង ១០ ព្រឹក)។ *វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាផ្សាយអំពីការរំដោះទីក្រុងភ្នំពេញ និងការកាន់កាប់ស្ថានទូតសហរដ្ឋអាមេរិក* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00846158-00846159 (សម្លេងវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាបានប្រកាសថា "នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅម៉ោង ០៩:៣០ នាទី យើងបានរំដោះទីក្រុងភ្នំពេញជាស្ថាពរ" និងពិពណ៌នាអំពីរបៀបដែល "កងកម្លាំងប្រជាជនយើងកំពុងគ្រប់គ្រង និងកាន់កាប់គ្រប់ទីតាំងសំខាន់ៗរបស់ខ្មាំងនៅទីក្រុងភ្នំពេញ" រួមទាំង វត្តភ្នំ ទួលគោក ស្ថានីយ៍រថភ្លើង និងទីតាំងក្រសួងដែលស្ថិតនៅខាងត្បូងស្ថានីយ៍រថភ្លើង ស្ថានីយ៍វិទ្យុស្ទឹងមានជ័យ តំបន់ក្បាលថ្នល់ វិមានចំការមន ស្ថានទូតអាមេរិក បឹងកេងកង បញ្ជាការសេនាធិការ និងតំបន់នៅម្តុំជ្រោយចង្វារ និងត្រើយខាងលិចទន្លេ)។ *វិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាថ្ងៃទី ១៩ ខែ មេសា រាយការណ៍ថា ទីក្រុងត្រូវបានរំដោះ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905200-00905201 (ប្រកាសថា ទីក្រុងភ្នំពេញ "ត្រូវបានរំដោះ" នៅម៉ោង ០៩:៣០ នាទីព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។

[១៣៧០] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ទាហានចលនាជាតិនិយមរបស់ ហែម កេតដារ៉ា ក៏មានវត្តមាននៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានអះអាងថា បានទទួលខុសត្រូវលើការកាន់កាប់ទីក្រុងភ្នំពេញផងដែរ។

ហើយ" ហើយប្រជាជនសប្បាយរីករាយ ដោយសារតែការប្រទូសរ៉ាយគ្នាបានបញ្ចប់ទៅ[១៣៧១]។ ប្រជាជនបានមកឈរនៅតាមផ្លូវដើម្បីប្រារព្ធ និងអបអរសាទរដល់កងទ័ពខ្មែរក្រហម ដោយ

---

*សូមមើល* អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00644702-00644703 (ពិពណ៌នាថា ហែម កេតដារ៉ា កូនប្រុសរដ្ឋមន្ត្រីមួយរូប និងតាមការអះអាង គឺជាអគ្គមេបញ្ជាការដឹកនាំចលនាជាតិនិយម បាន "រំដោះ" ទីក្រុង ហើយបានអួតអាងថាបានកាន់កាប់ទីក្រុង "ដោយមានកូនទាហានតែ ៣០០ នាក់ ប៉ុណ្ណោះ") ។ *បន្សុទ្ធកម្មនៅក្នុងប្រទេសកម្ពុជា* (កាសែត Newsweek) E3/4429 ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00445259 (ពិពណ៌នាអំពី "ការចាប់យក" ទីក្រុងភ្នំពេញដោយ "កងទ័ពគ្មានសណ្តាប់ធ្នាប់ចំនួន ២០០ នាក់" ក្រោមការដឹកនាំរបស់ ហែម កេតដារ៉ា)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៦៨ (បានឮថា ហែម កេតដារ៉ា និងចលនាជាតិនិយម ត្រូវបានចាត់ទុកថាជាខ្មែរក្រហមក្លែងក្លាយ)។

[១៣៧១] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៥, ៦៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៩ (កងទ័ពខ្មែរក្រហមបានប្រាប់ជនស៊ីវិលឲ្យស្ងប់ស្ងៀម និងកុំឲ្យភ័យខ្លាចដោយសារការវាយប្រយុទ្ធបានចប់ហើយ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គឹម) ទំព័រ ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៣ (ជួន ធី) ទំព័រ ៤២-៤៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៣-៤ (មនុស្សគ្រប់គ្នាពោរពេញដោយក្តីសប្បាយរីករាយនៅពេលនោះ ពីព្រោះពួកគេគិតថាសង្គ្រាមបានបញ្ចប់ហើយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហ៊ូ ចន្ថា) ទំព័រ ៥៤ (ពួកគេស្រែកឡើងថា សង្គ្រាមបានបញ្ចប់ហើយ ហើយសន្តិភាពបានមកដល់ហើយ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨ (សម្តេច ហ្លួត តាត បានមានសង្ឃដីកាប្រាប់ប្រជាជនថា យើងបានចាញ់សង្គ្រាមហើយ សង្គ្រាមផុតទៅហើយ។ ឥឡូវនេះ សូមញ្ញោមរួមកសាងប្រទេសជាមួយគ្នា។ យើងសុទ្ធតែបងប្អូនគ្នា។ ដូច្នេះ សូមទទួលអ្នកដែលមានជ័យជម្នះ សូមកុំវាយតទៅមុខទៀត ប្រហែលម៉ោង ១០) ។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ៣ ERN (ភាសាខ្មែរ) 00541003 (នៅខាងមុខមន្ទីរពេទ្យព្រះអង្គឌួង ក្រុមមនុស្សបានស្រែកឡើងថា "ជយោ សន្តិភាព! សង្គ្រាមចប់ហើយ"។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៩ ទំព័រ៤ ERN (ភាសាខ្មែរ) 00557817 (កងទ័ពខ្មែរក្រហមស្លៀកពាក់ខ្មៅស្រែកជយោ និងជ័យជម្នះ) ។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុៈ សារសម្រាប់ព័ត៌មាន *Le Monde* ឯកសារ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00486890។ *អ្នកនិពន្ធការសែត Kyodo សរសេរអំពីភាពគ្មានសណ្តាប់ធ្នាប់នៅភ្នំពេញបន្ទាប់ពីការចុះចាញ់* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905198-00905199 (ពិពណ៌នាអំពីពួកទាហាន និងប្រជាជនបានចាប់រលាក់ដៃគ្នា ហើយនៅដៃម្ខាងៗមានស្ពាយកាំភ្លើង)។

ជឿជាក់ថា សន្តិភាពនឹងកើតមានឡើងវិញនៅក្នុងប្រទេសកម្ពុជា[១៣៧២]។ ទោះបីជាយ៉ាងនេះក្តី ក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយមកបន្តិច បរិយាកាសបានផ្លាស់ប្តូរនៅពេលដែលខ្មែរក្រហមបានចាប់ផ្តើមណែនាំប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់[១៣៧៣]។

---

[១៣៧២] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩ (ប្រជាជនបានចេញមកស្វាគមន៍ និងអបអរសាទរពួកគេ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣។ ប្រតិចារឹក ថ្ងៃទី ២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៣-៥៤។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៨-៣០ (គាត់បានឈរនៅតាមផ្លូវ និងគ្រវីទង់ស ដើម្បីស្វាគមន៍កងទ័ពខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៣ (ប្រជាជនឈរតម្រៀបជួរគ្នានៅតាមផ្លូវដើម្បីអបអរការមកដល់របស់កងទ័ព)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៨៥ (ប្រជាជនទីក្រុងភ្នំពេញកំពុងអបអរជ័យជម្នះ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤៧-៤៨។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៣-៥៤។

[១៣៧៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១២-១៣ (យើងសប្បាយខ្លាំងណាស់នៅពេលព្រឹកប្រហែលជាម៉ោង ៩ ព្រឹក ប៉ុន្តែ មកដល់ត្រឹមម៉ោង ៣ រសៀល ស្ថានភាពបានផ្លាស់ប្តូរទាំងស្រុង។ យើងមានការតក់ស្លុតនឹងការផ្លាស់ប្តូរយ៉ាងលឿនដូច្នេះ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ២៨,៦៨ (នៅប្រហែលជាពេលថ្ងៃត្រង់ បរិយាកាសមានការផ្លាស់ប្តូរ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៤-១៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៣-៤ (មកដល់ត្រឹមពេលរសៀល ខ្មែរក្រហមបានប្រាប់ពួកគេថា ពួកគេត្រូវចាកចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (សុភមង្គលរបស់ប្រជាជនពុំបានយូរនោះទេ ពីព្រោះកងទ័ពប្រដាប់ដោយអាវុធបានស្រែកដាក់គាត់ ហើយនិងអ្នកជិតខាងគាត់ ឲ្យចាកចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨០-៨១។ ប្រតិចារឹក ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៩, ៣៨-៣៩។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ១៩-២១។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ (Denise AFFONÇO) ទំព័រ ៧៧-៧៨។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០, ៧៨-៧៩ (នៅម៉ោងប្រហែល ៣ រសៀល កងទ័ពបានប្រកាសឲ្យប្រជាជនចាកចេញជាប្រញាប់) ទំព័រ ៣១ (ពួកគេបានចាកចេញនៅវេលាម៉ោងប្រហែល ៦:៣០ នាទីល្ងាច)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៧-៥៩ (កងទ័ពខ្មែរក្រហមបានណែនាំឪពុករបស់គាត់ថា ឪពុកគាត់មានពេល ១៥ នាទី ដើម្បីវេចបង្វេចចេញ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣០-៣១, ៤៤។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សតិម ល្អុត) ទំព័រ ៤-៥។ ប្រតិចារឹក ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១២ (មុម សំអឿន) ទំព័រ ៦-៨ (បានឮរថក្រោះបើកចូលក្នុងទីក្រុងនៅពេលព្រឹក ហើយពួកគេត្រូវចាកចេញពីផ្ទះនៅវេលាម៉ោងប្រហែល ៩ ព្រឹក) ១៩ (កងទ័ពបានចូលក្នុងផ្ទះរបស់គាត់នៅវេលាម៉ោងប្រហែល ៧ ព្រឹក) ៣៦ (ពួកគេបានចាកចេញពីផ្ទះនៅវេលាម៉ោង ៩ ព្រឹក)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ

## ១០.២.៤ លក្ខណៈបណ្ដោះអាសន្ន និងការវិលត្រឡប់មកវិញ "ក្នុងរយៈពេល៣ថ្ងៃ"

៤៦៥. ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនថា ការជម្លៀសធ្វើឡើងជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ហើយសាក្សីភាគច្រើនត្រូវបានគេប្រាប់ថា ពួកគេចាំបាច់ត្រូវជម្លៀសរយៈពេល ៣ឬ ៤ថ្ងៃតែប៉ុណ្ណោះ ក្រោយពីពេលនោះ ពួកគេអាចវិលត្រឡប់មកផ្ទះវិញបាន[១៣៧៤]។

---

៣៩-៤០, ៦៦ (បានឮហេតុការណ៍នេះប៉ុន្មានថ្ងៃក្រោយថ្ងៃទី១៧ ខែមេសា)។ ប្រតិចារឹក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ (មាស សារ៉ាន់) ទំព័រ ៧៦-៧៧ (នៅវេលាម៉ោងប្រហែល ១០ ព្រឹក គាត់បានឮពីបុគ្គលិកពេទ្យម្នាក់ថា កងទ័ពកំពុងបង្ខំពួកគេឲ្យចាកចេញពីមន្ទីរពេទ្យជាបន្ទាន់)។ ប្រតិចារឹក ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ៧៣-៧៦។ ប្រតិចារឹកថ្ងៃទី២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២០-២១។ ប្រតិចារឹក ថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៩ (នៅវេលាម៉ោង ១២:០០ បានឮថា ខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនចាមចាកចេញពីទីក្រុង ហេតុដូច្នេះ ពួកគេអាចត្រឡប់ទៅកាន់ស្រុកកំណើតរបស់គេវិញ)។ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ (Sydney SCHANBERG) ទំព័រ ១០-១១ (ដោយដកស្រង់ S. Schanberg: *កំណត់ហេតុស្ដីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ៦០ ERN (ភាសាខ្មែរ) 00963944 កត់សម្គាល់ថា ក្នុងរយៈពេលពីរបីម៉ោង បរិយាកាសបានផ្លាស់ប្ដូរទាំងស្រុង ទំព័រ ៦៥ ERN (ភាសាខ្មែរ) 00963949 កត់សម្គាល់ឃើញដូចគ្នាថាទាហានរដ្ឋាភិបាលដែលបានឱបអ្នកទទួលជ័យជម្នះកាលពីបីបួនម៉ោងមុន ពេលនេះកំពុងដោះឯកសណ្ឋានរបស់ខ្លួនចេញដោយសារការភ័យខ្លាចនៅទូទាំងទីក្រុងទាំងមូល)។

[១៣៧៤] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នូន ផល្លី) ទំព័រ ៣៤- ៣៦។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៩។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២១។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៣៨-៣៩។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៨២-៨៣, ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៨,៣៣-៣៤,៦១-៦២ ។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី)ទំព័រ ៧៧-៧៨, ៨១។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៣-៧៥, ៨៣។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៤, ៨៥។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២១។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦០-៦១, ៧២-៧៣។ ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ (បេ សុផានី) ទំព័រ ៧-៨, ៣២-៣៣, ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី០៤ ខែ តុលា ឆ្នាំ ២០១២ (មាស រឿន) ទំព័រ ១២-១៤ (មេបញ្ជាការខ្មែរក្រហមម្នាក់បានឮថា ជនស៊ីវិលនឹងចាកចេញពីទីក្រុងប្រហែលមួយអាទិត្យ និងវិលត្រឡប់មកវិញក្រោយពេលទីក្រុងត្រូវបានរៀបចំស្រួលបួល)។ កំណត់ហេតុនៃការស្ដាប់

៤៦៦. ដោយសារមានការណែនាំឲ្យយកតែរបស់របរបន្តិចបន្តួចទៅជាមួយ ហើយជឿជាក់ថា ពួកគេនឹងវិលត្រឡប់មកវិញក្នុងរយៈពេល ៣ ថ្ងៃ ខាងមុខនោះ ប្រជាជនភាគច្រើនបានចាកចេញ

---

ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ៥-៦ ERN (ភាសាខ្មែរ)00375523-00375524។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373407 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា សារី បានប្រាប់យើងឲ្យនិយាយ "បែបនេះ" ពោលគឺ ពួកគេនឹងត្រឡប់មកវិញក្នុងរយៈពេលមួយអាទិត្យ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ាត់ លី ឯកសារ E3/4720 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418292 (កងទ័ពអង្គការបានប្រាប់ពួកគេថា ពួកគេនឹងត្រឡប់មកវិញ ហើយពុំចាំបាច់យកអ្វីច្រើនពេកទេ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526067 (កងទ័ពបានប្រកាសថា យើងនឹងឲ្យត្រឡប់មកវិញ ២-៣ ថ្ងៃទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លឹង លិញ ឯកសារ E3/4956 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00552103-00552104។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ៣-៤ ERN (ភាសាខ្មែរ) 00557816-00557817។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សម ស័ក្ក ឯកសារ E3/5033 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ភាសាខ្មែរ) 00562498 (ទើបពួកគេវិលត្រឡប់ចូលលំនៅដ្ឋានក្រុងភ្នំពេញវិញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេតណាតា រ៉ូស្ទាន ឯកសារ E3/5076 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00641840-00641841។ *សូមមើលផងដែរ* បទសម្ភាសន៍ជាមួយ ទឹង លាប ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5683 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ១ ERN (ភាសាខ្មែរ) 00184210 (អតីតកងទ័ពខ្មែរក្រហមម្នាក់បាននិយាយថា យុទ្ធជនបានប្រាប់អ្នកដែលត្រូវបានជម្លៀសថា ពួកគេចាកចេញបណ្តោះអាសន្នតែប៉ុណ្ណោះ ទោះបីជា លាប មិនដែលធ្លាប់បានឮថា ពួកគេត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញក្រោយពេល ៣ ថ្ងៃក៏ដោយ)។ អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៧ ERN (ភាសាខ្មែរ) 00062458 (អៀង សារី បានលើកឡើងថា នៅពេលនោះគេគិតថា អ្នកដែលត្រូវជម្លៀសខ្លះនឹងត្រូវជម្លៀសជាបណ្តោះអាសន្ន ហើយមួយចំនួននឹងត្រូវជម្លៀសរហូត។ ពួកគេចាំមើលប្រតិកម្មរបស់ប្រជាជន ហើយអាមេរិកនឹងធ្វើយ៉ាងម៉េច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00172079 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា **ជា** ដែលជាប្រធានវរសេនាតូចលេខ ១១ បានប្រាប់ពួកគេឲ្យប្រាប់ប្រជាជនថា ឲ្យចេញតែ ៣ ថ្ងៃ តែប៉ុណ្ណោះ)។ *កម្ពុជានិយាយថា សហរដ្ឋអាមេរិក វៀតណាម បានជួយដល់ការប៉ុនប៉ងធ្វើរដ្ឋប្រហារ ៣ ដង* (សារព័ត៌មាន Los Angeles Times) ឯកសារ E3/622 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៨ (បានដកស្រង់សំដី អៀង សារី ដែលបាននិយាយថា ការជម្លៀសទីក្រុងភ្នំពេញដើមឡើយគឺជាវិធានការបណ្តោះអាសន្ន)។ *សារី៖ ការជម្លៀសប្រជាជនចេញពីទីក្រុងជាវិធានការបណ្តោះអាសន្ន* (សារព័ត៌មានបាងកកប៉ុស្តិ៍) ឯកសារ E3/3322 ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៧៨។

ជាមួយនឹងរបស់របរជាប់ខ្លួនបន្តិចបន្តួចតែប៉ុណ្ណោះ[១៣៧៥] ។ ប្រជាជនភាគច្រើនបានប្រមូលយកតែសមាជិកគ្រួសារ និងយករបស់របរបន្តិចបន្តួចដែលពួកគេអាចយកទៅជាមួយបាន ដូចជាក្រដាសប្រាក់ជាដើម[១៣៧៦] ។ ប្រជាជនខ្លះទៀតត្រូវបានបង្ខំឲ្យចាកចេញដោយគ្មានសមាជិកគ្រួសារមួយចំនួន ឬ ទាំងអស់ទៅជាមួយឡើយ[១៣៧៧]។

---

[១៣៧៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៥។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី)ទំព័រ ៨២ (កងទ័ពបានប្រាប់គាត់ថា គាត់ពុំចាំបាច់យករបស់របរទៅជាមួយឡើយ ពួកគាត់អាចទិញរបស់របរនៅតាមផ្លូវបាន ហើយបើយកទៅនាំតែធ្ងន់ ដោយសារពួកគាត់ត្រូវចាកចេញតែក្នុងរយៈពេល៣ថ្ងៃ ត្រឡប់មកវិញហើយ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៤-៥៥, ៨៥ (គេបានណែនាំពួកគាត់ឲ្យយករបស់របរតិចតួចទៅជាមួយបានហើយ។ គាត់បានយករបស់របរដែលគាត់ត្រូវការតែពាក់កណ្ដាលទៅជាមួយប៉ុណ្ណោះ ដែលភាគច្រើនជារបស់មានតម្លៃផ្ទាល់ខ្លួនដែលគាត់មាន រួមទាំងអត្តសញ្ញាណប័ណ្ណ សៀវភៅកូនរបស់គាត់ ។ល។)។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សាវ៉ាន់) ទំព័រ ៨២-៨៣, ៨៥ (បានជឿជាក់ថា ពួកគេនឹងទៅតែពីរបីថ្ងៃប៉ុណ្ណោះ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៦៩-៧០ (ពួកគេគ្មានអ្វីទាំងអស់ក្រៅពីសម្លៀកបំពាក់ដែលពួកគេស្លៀកជាប់នឹងខ្លួន)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៧ (គេបានប្រាប់គាត់ថា ពួកគាត់នឹងចាកចេញតែ៣ថ្ងៃប៉ុណ្ណោះ ហើយគេបានណែនាំពួកគេកុំឲ្យយករបស់របរច្រើនពេកទៅជាមួយពីព្រោះពួកគាត់នឹងវិលត្រឡប់មកក្រុងភ្នំពេញវិញ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥ (បានវេចខ្ចប់តែស្បៀងអាហារ និងសម្លៀកបំពាក់គ្រប់គ្រាន់សម្រាប់ពួកគាត់រស់នៅតែរយៈពេល៣ថ្ងៃប៉ុណ្ណោះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (ខ្លះគ្មានស្បៀងអាហារបន្តិចបន្តួចសោះឡើយ ខ្លះទៀតមានខោអត់អាវ មានអាវអត់ខោ បាតជើងទទេក៏មាន ប្រកបដោយភាពភ័យខ្លាច និងទឹកភ្នែក)។

[១៣៧៦] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហ្វ ចន្ថា) ទំព័រ ៥៤-៥៥ (ខ្លះរែកទូលរបស់របរនៅលើស្មា និងក្បាល)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៧ (មិនអាចយួររបស់របរបានច្រើនដោយសារគាត់មានកូនបីនាក់នៅជាប់នឹងគាត់ ប៉ុន្តែគាត់មានសម្លៀកបំពាក់ និងដបទឹកដោះគោខ្លះសម្រាប់កូនៗគាត់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៤-៧៥។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៤។ ប្រតិចារឹក ថ្ងៃទី ២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២២ (មិនបានយកអង្ករទៅជាមួយដោយសារវាធ្ងន់ពេក គាត់មានតែប្រាក់រៀលដោយគិតថា គាត់អាចចាយវានៅតាមផ្លូវបាន)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២ (ពួកគាត់បានចាកចេញដោយមិនយកអ្វីទៅជាមួយក្រៅពីលុយឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៤២-៤៣។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៣១-៣២។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៤ (ភ័យខ្លាចបាត់កូនគាត់២ នាក់ និងក្មួយប្រុសគាត់២ នាក់នៅក្នុងហ្វូងមនុស្ស ដូច្នេះ គាត់បានចងពួកគេជាប់គ្នា ហើយវេចខ្ចប់សម្លៀកបំពាក់ ទឹក និងថ្នាំពេទ្យទៅជាមួយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារាស) ទំព័រ ៥ (កូនៗត្រូវចាកចេញហើយទុកឪពុកម្ដាយចោល)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៨១

៤៦៧. យោងតាមប្រភពចំនួនពីរ ខ្មែរក្រហមខ្លះបានប្រាប់ប្រជាជនដែលបានចាកចេញ ឬ កំពុងចាកចេញពីទីក្រុងថា ពួកគេនឹងមិនវិលត្រឡប់មកវិញទេ[១៣៧៨]។

---

(គេបានប្រាប់ពួកគាត់ឱ្យយករបស់របរតិចតួចបំផុត ពីព្រោះ ពួកគាត់នឹងវិលត្រឡប់មកវិញក្នុងរយៈពេល៣ថ្ងៃ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៣៩-៤០, ៤១ (បានយកក្មួយប្រុស២នាក់ និងរបស់របរបន្តិចបន្តួច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ផាន ឯកសារ E3/5143 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00204123 (ប្រជាជនដែលចេញពីភ្នំពេញមានស្តាយអីវ៉ាន់សំពីងសំពោង និងមានការយំស្រែកដោយសារការព្រាត់ប្រាស់ម្តាយឪពុក និងកូនរបស់ពួកគេ)។

[១៣៧៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៥ (គ្រួសាររបស់សាក្សី និងគ្រួសារឪពុកមាសាក្សីបានចាកចេញបែកពីគ្នា)។ ប្រតិចារឹក ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៣-១៤ (គាត់បានចាកចេញជាមួយនឹងសមាជិកគ្រួសារតិចតួចបំផុត ហើយខ្មែរក្រហមមិនអនុញ្ញាតឱ្យគាត់នៅរង់ចាំរហូតដល់សមាជិកគ្រួសារមកជុំគ្នាឡើយ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ណុប ផានី ឯកសារ E3/5401 ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១-៤ ERN (ភាសាខ្មែរ) 00480098-00480101 (នៅក្នុងគ្រួសាររបស់ពួគាត់ មានកូន ១០ នាក់ ហើយពួកគាត់អាចយកតែកូនតូចៗ ទៅពោធិ៍សាត់ កូនដទៃទៀតត្រូវបានបំបែកចេញពីពួកគាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ឹម ណាន ឯកសារ E3/4735 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00484498 (គាត់ និងស្វាមីរបស់គាត់ត្រូវបានបង្ខំឱ្យចាកចេញចោលកូនទាំង៣នាក់របស់ពួកគេដែលមិនទាន់មកដល់ផ្ទះ នៅពេលកងទ័ពបានចូលមកដល់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (ត្រូវចាកចេញដោយគ្មានឪពុកម្តាយទៅជាមួយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (សមាជិកគ្រួសារត្រូវបានបំបែកចេញពីគ្នានៅពេលនោះ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ តុប នី ឯកសារ E3/5452 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00471469 (ពួកគេមិនឱ្យគាត់ឆ្លងកាត់មករកឪពុកម្តាយរបស់គាត់ឡើយ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហៀក ណារ៉េន ឯកសារ E3/5376 ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00477266 (ឪពុកម្តាយរបស់គាត់ត្រូវបានជម្លៀសផ្សេងគ្នាពីក្រុមគ្រួសារឪពុកមារបស់គាត់)។ សូមប្រៀបធៀបជាមួយនឹងប្រតិចារឹកថ្ងៃទី១០ ខែមេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៣២ (បានឮពីជនភៀសខ្លួនថា ធម្មតា អង្គការបានអនុញ្ញាតឱ្យសមាជិកគ្រួសារនៅជុំគ្នានៅក្នុងពេលជម្លៀស)។

[១៣៧៨] ទូរលេខស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងបាងកក កម្មវត្ថុៈ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ២ ERN (ភាសាខ្មែរ) 00495557 (បានរាយការណ៍អំពីអ្នកដែលត្រូវបានជម្លៀសម្នាក់បានលើកឡើងថា ពួកខ្មែរកុម្មុយនីស្ត "បានព្យាយាមធ្វើឱ្យអ្នកធ្វើដំណើរគ្មានសង្ឃឹមថានឹងបានត្រឡប់ទៅភ្នំពេញវិញទេ" ទោះបីជាគេមិនដឹងច្បាស់ថាការលើកឡើងនេះត្រូវបានធ្វើឡើងនៅពេលណាក៏ដោយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧

## ១០.២.៥ ការអះអាងអំពីការព្រួយបារម្ភផ្នែកសន្តិសុខ

៤៦៨. កងទ័ពខ្មែរក្រហមបានប្រាប់ប្រជាជនដែលនៅតាមលំនៅដ្ឋានថា ពួកគេត្រូវតែជម្លៀសគឺដើម្បីការពារខ្លួនឲ្យរួចផុតពីការទម្លាក់គ្រាប់បែកដែលនឹងធ្វើឡើងបន្តទៀត ដោយសហរដ្ឋអាមេរិក[១៣៧៩]។

---

ទំព័រ ៣ ERN (ភាសាខ្មែរ) 00152235 (នៅលើស្ពានមុនីវង្ស ក្នុងពេលជម្លៀស កងទ័ពបាននិយាយថា គេជម្លៀសពួកបងឯងចេញទៅស្រែ ហើយ "កុំសង្ឃឹមថា បានត្រឡប់មកវិញ អង្គការយកទៅលត់ដំហើយ")។

[១៣៧៩] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២(យឹម សុវណ្ណ)ទំព័រ៥៨-៥៩, ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ២១-២២។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ២៤ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ២៣, ៤៤។ ប្រតិចារឹកថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៦-៧, ៨-៩, ៣០-៣៣។ ប្រតិចារឹក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៧៥-៧៧, ៧៩-៨០, ៨១-៨២, ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៨, ៣៣-៣៤, ៦១ ។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៤, ៧៧-៧៨។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៣-៤។ ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ (ចាន់ សុជាតិ)ទំព័រ ៣២-៣៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៨៦-៨៧។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៧-៨, ៣២-៣៣, ៣៥-៣៦។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ២៨ (កម្មាភិបាលបាននិយាយពាក្យពេចន៍ទាំងនេះតាម មេក្រូថា អាមេរិកនឹងមកទម្លាក់គ្រាប់បែក)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៩-១០។ ប្រតិចារឹកថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ (François PONCHAUD) ទំព័រ១៩, ២១។ ប្រតិចារឹក ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៣ (Denise AFFONÇO) ទំព័រ ៨។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ៧៣-៧៥។ ប្រតិចារឹក ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០១២ (សាឡុត បាន) ទំព័រ ៥៥ (សាឡុត បាន ក្មួយរបស់ ប៉ុល ពតបានឮថា សហរដ្ឋអាមេរិក មាន "ផែនការចុះចាញ់" ដែលក្រោយមក គាត់យល់ថាមានន័យថា សហរដ្ឋអាមេរិកនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (ស្អួង ស៊ីគឿន) ទំព័រ ៨៥-៨៦។ (បានឮថា គោលបំណងនៃការជម្លៀសគឺចង់ឲ្យក្រុងភ្នំពេញរួចផុតពីការទម្លាក់គ្រាប់បែក)។ *សូមមើលផងដែរ* ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ២១ ឯកសារ E3/2688 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (បានរាយការណ៍ថា ទាហានរបស់រណសិរ្សរួបរួមជាតិកម្ពុជាបានចល័តនៅតាមវិថីសំខាន់ៗក្នុងទីក្រុង និងបានប្រកាសថា ទីក្រុងត្រូវប្រឈមមុខនឹងការបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ឯកសារ E3/5137 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00163090។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ កែវ ឯកសារ E3/5173 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00189263-189264។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចែម សែម

ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00198940-00198942។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មៀច ប៉ុណ្ណ ឯកសារE3/5523 ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ២-៣ ERN (ភាសាខ្មែរ) 00414423-00414424។ ទម្រង់បែបបទព័ត៏មានជនរងគ្រោះ កែវ ឆែម ឯកសារ E3/5407 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00480203-00480205។ ទម្រង់បែបបទព័ត៏មានជនរងគ្រោះ ស៊ុន ដារ៉ា ឯកសារ E3/5428 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00483352-00483353។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ស៊ិនថូ ឯកសារ E3/4774 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00496962-00496963។ ព័ត៏មានបន្ថែមរបស់ ឈុំ ម៉ៅ ឯកសារ E3/4955 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ារឌី ឯកសារ E3/5613 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00491047-00491049។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00526067-00526068។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង ស៊ីន ឯកសារ E3/4841 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00526084-00526085។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ៅ គីមសូហ្វី ឯកសារ E3/5077 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00641221-00641222។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នីកូឡាស វេសនាកែវ ឯកសារ E3/5088 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00873721-00873722។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខេវិន ឡេងសូ ឯកសារ E3/5092 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ភាសាខ្មែរ) 00863669។ ទម្រង់បែបបទព័ត៏មានជនរងគ្រោះ ខឹម ទីន ឯកសារ E3/5404 ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00480148-00480149។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ តូច មុនិន្ទ ឯកសារ E3/4668 ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ ទំព័រ៤-៥ ERN (ភាសាខ្មែរ) 00211324-00211325។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង មួង សុខន ឯកសារ E3/4681 ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០៨ ទំព័រ៨ ERN (ភាសាខ្មែរ) 00323606។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខឹម ណារ៉េត ឯកសារ E3/4687 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ៣-៥ ERN (ភាសាខ្មែរ) 00356377-00356379។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត សែម ឯកសារ E3/4689 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ៧-៩ ERN (ភាសាខ្មែរ)00358732-00358734។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00368783។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស មុត ឯកសារ E3/4703 ចុះថ្ងៃទី២២ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00368981។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ទំព័រ ៤-៦ ERN (ភាសាខ្មែរ) 00418272-00418274 ។ ទម្រង់បែបបទព័ត៏មានជនរងគ្រោះ ហេនរី ស៊ុន ឯកសារ E3/5457 ចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៩ ERN (ភាសាខ្មែរ) 00824580។ ទម្រង់បែបបទព័ត៏មានជនរងគ្រោះ កែវ សារុន ឯកសារ E3/5458 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ២១ ERN (ភាសាខ្មែរ) 00806074។

ទោះបីជាប្រជាជនដែលនៅតាមលំនៅដ្ឋានទាំងនោះ មិនជឿលើការពន្យល់ហេតុផលនេះក៏ដោយ ក៏ពួកគេត្រូវតែជម្លៀសចេញដែរ ដោយសារតែប្រឈមនឹងការគំរាមកំហែងពីសំណាក់កងទ័ពខ្មែរក្រហម[១៣៨០]។

៤៦៩. រីឯ ប្រជាជនដែលនៅតាមលំនៅដ្ឋានផ្សេងៗទៀតត្រូវបានប្រាប់ថា ការជម្លៀសនេះត្រូវធ្វើឡើងដើម្បីតែសុវត្ថិភាពប្រជាជនខ្លួនឯងទេ ដោយហេតុថា អង្គការចាំបាច់ត្រូវ "បោស" ឬ "សម្អាត" ខ្មាំងដែលនៅសេសសល់នៅក្នុងទីក្រុង រៀបចំទីក្រុង ឬ បំបែកបណ្ដាញគិញ្ចរបស់ខ្មាំងដែលតាមការចោទប្រកាន់ រួមមានទាំង គិញ្ចក្រពត្តិអាមេរិកនៅក្នុងទីក្រុងភ្នំពេញផងដែរ[១៣៨១]។

---

[១៣៨០] ប្រតិចារឹក ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៧ (គាត់មិនជឿថា អាមេរិកនឹងទម្លាក់គ្រាប់បែកនោះទេ ដោយសារអាមេរិកបានចាកចេញពីក្រុង និងប្រទេសនេះ តាំងពីដើមខែមេសារួចអស់ហើយ)។ ប្រតិចារឹក ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៣២-៣៣ (មិនជឿថា ការទម្លាក់គ្រាប់បែកនឹងចាប់ផ្ដើមធ្វើឡើងក្នុងពេលឆាប់ៗនោះទេ ពីព្រោះគាត់ជឿថា សង្គ្រាមបានបញ្ចប់អស់ទៅហើយ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៨១ (គាត់ និងគ្រួសារគាត់ពុំជឿថា ការគំរាមកំហែងនេះអាចជឿជាក់បាននោះទេ ដោយសារសហរដ្ឋអាមេរិកទើបតែទម្លាក់ស្បៀងអាហារនាពេលថ្មីៗ មកឲ្យប្រជាជនដែលត្រូវបានខ្មែរក្រហមឡោមព័ទ្ធនៅតាមជាយទីក្រុងភ្នំពេញ ហើយគាត់មិនជឿថា សហរដ្ឋអាមេរិកនឹងទម្លាក់គ្រាប់បែកលើទីក្រុងនោះទេ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ឯកសារ E3/5137 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00163090 (ពួកគេបានឮថា ពួកអាមេរិកនឹងទម្លាក់គ្រាប់បែកលើទីក្រុង ប៉ុន្តែគ្មានអ្នកណាម្នាក់ជឿឡើយ)។ *សូមមើលផងដែរ* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧១-៤៧៥ ខាងក្រោយ។

[១៣៨១] ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២(អោ រី)ទំព័រ ៨០។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៤ (កងទ័ពបានប្រាប់ពួកគាត់ឲ្យចាកចេញ ពីព្រោះពួកគេត្រូវការបោសសម្អាតក្រុង)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤៤-៤៥ (ពួកគេត្រូវជម្លៀសប្រជាជនចេញពីទីក្រុងឲ្យអស់ ដើម្បីពិនិត្យមើលខ្មាំងចុងក្រោយ និងមិនចង់ឲ្យប្រជាជននៅលាយឡំជាមួយនឹងខ្មាំង)។ ប្រតិចារឹក ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៣ (គេកំពុងបោសសម្អាត ឬ ជម្លៀសខ្មាំងឲ្យអស់។ នៅពេលនោះ គាត់មិនយល់ពាក្យ "ខ្មាំង" នេះទេ)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣២-៣៣ (កងទ័ពខ្មែរក្រហមបានប្រាប់គាត់ថា ពួកគាត់ចាំបាច់ត្រូវចាកចេញពីផ្ទះរបស់ពួកគាត់ដើម្បីឲ្យខ្មែរក្រហមអាចកម្ទេចខ្មាំង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស)ទំព័រ៤(ខ្មែរក្រហមបានប្រាប់ពួកគាត់ថា ពួកគាត់ត្រូវចេញពីទីក្រុងភ្នំពេញទុកឲ្យរដ្ឋាភិបាលបោសសម្អាតក្រុង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ទា) ទំព័រ ៥៥ (កងទ័ពបានស្រែកដាក់គាត់ និងអ្នកជិតខាងគាត់ថា ពួកគាត់ត្រូវចាកចេញពីក្រុងដោយសារកងទ័ពចាំបាច់ត្រូវបោសសម្អាតក្រុងរយៈពេល៣ថ្ងៃ)។ ប្រតិចារឹកថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៧ (អង្គការចាំបាច់ត្រូវបោសសម្អាតក្រុង)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០ (គាត់ជាអតីតទាហាន លន់ នល់។ គាត់បាន

លើកឡើងថា ខ្មែរក្រហមបានប្រកាសថា ពួកគេត្រូវបោសសម្អាតខ្មាំងដែលនៅសេសសល់ពីទីក្រុង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ទំព័រ ៧ ERN (ភាសាខ្មែរ) 00865602 (ដើម្បីពួកគេអាចបោសសម្អាតឲ្យអស់នៅក្នុងទីក្រុង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ដៃ យឹន ឯកសារ E3/4824 គ្មានចុះកាលបរិច្ឆេទ ទំព័រ 2 ERN (ភាសាខ្មែរ) 00523379 (ពួកគេជម្លៀសប្រជាជនចេញដើម្បីសំអាតខ្មាំងចេញពីទីក្រុង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នង សារ៉ន ឯកសារ E3/4653 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ)00484385(កូនក្មេងស្លៀកពាក់ខោអាវពណ៌ខ្មៅបានប្រាប់ថាអង្គការត្រូវការបោសសំអាតទីក្រុង) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (ឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានដើម្បីធ្វើការរៀបចំ និងសំអាតខ្មាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ាត់ លី ឯកសារ E3/4720 ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418292 (កងទ័ពអង្គការបានប្រាប់ពួកគេថា ពួកគេត្រូវចាកចេញ ដោយសារអង្គការធ្វើការបោសសម្អាតខ្មាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00152235 (ពួកគេបាននិយាយថា អង្គការឲ្យចេញដើម្បីបោសសម្អាតខ្មាំងផ្ទៃក្នុងឲ្យអស់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាន់ ស៊ីណាង ឯកសារ E3/4697 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00365377 (ប្រជាជនត្រូវចាកចេញដើម្បីឲ្យអង្គការរៀបចំបោសសម្អាតខ្មាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង សុខុម ឯកសារ E3/4702 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00368960 (អង្គការចង់បោសសម្អាតខ្មាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពុធ ពុំ ឯកសារ E3/4714 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ៤ ERN(ភាសាខ្មែរ)00397780 (គេប្រាប់ពួកយើងថា អង្គការត្រូវការសម្អាតទីក្រុង និងសម្អាតខ្មាំងផ្ទៃក្នុងឲ្យអស់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឃុត ជា ឯកសារ E3/5438 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00497732 (អង្គការត្រូវការរៀបចំក្រុង សំអាតពួកខ្មាំង)។ *សូមមើលផងដែរ បក្សកុម្មុយនីស្តកម្ពុជាលាតត្រដាងជាផ្លូវការអំពីខួបនៃការបង្កើតបក្ស* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/2678 ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ១៩៧៧ ERN(ភាសាខ្មែរ)00715808-00715809 (ដកស្រង់សេចក្តីថ្លែងការណ៍របស់ ប៉ុល ពត នៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៥ ថា ការជម្លៀសប្រជាជនចេញពីទីក្រុងមានគោលបំណងបំបែក "អង្គការចារកម្ម")។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៧ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១២៧ ERN (ភាសាខ្មែរ) 00963965 ដែលបានកត់សម្គាល់ថា អ្នកនៅក្នុងស្ថានទូតបានលើកពីលទ្ធភាពថា ការជម្លៀសក្រុងមានចេតនាមួយក្នុងចំណោមចេតនាផ្សេងទៀតគឺដើម្បីបោសសំអាតអ្នកតស៊ូប្រដាប់អាវុធមួយចំនួន និងដើម្បីស្វែងរកមន្ត្រី រដ្ឋាភិបាលដែលបានលាក់ខ្លួន)។ គេបានប្រាប់អ្នកខ្លះថា ខ្មែរក្រហម "កំពុងរៀបចំក្រុងឡើងវិញ"ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦០-៦១, ៨៦-៨៧។ ប្រតិចារឹកថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១-៨២។ ប្រតិចារឹក ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ១២-១៣។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00526041-00526042។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់

យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00556117-00556118។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សម ស័ក្ត ឯកសារ E3/5033 គ្មានចុះកាលបរិច្ឆេទ ទំព័រ៧ ERN (ភាសាខ្មែរ)00562498 (អង្គការធ្វើការបោសសម្អាតទីក្រុងឲ្យបានស្អាត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហ៊ុល ពៅ ឯកសារ E3/4696 ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00365315-00365316។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ស៊ុំ សុខ ឯកសារ E3/5470 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00506761។

ហេតុការណ៍នេះត្រូវបានបញ្ជាក់ដោយអតីតកងទ័ពខ្មែរក្រហមជាច្រើននាក់៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (ស្នួង ស៊ីគឿន) ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (ស្នួង ស៊ីគឿន) ទំព័រ ៥-៦, ៨ (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា ទីក្រុងភ្នំពេញក៏ត្រូវជម្លៀសផងដែរ ដើម្បីបំបែកបណ្តាញគិញរបស់វា)។ ប្រតិចារឹក ថ្ងៃទី១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ៤០, ៤៣ (ជាកងទ័ពម្នាក់ ហើយបានដឹងថា ហេតុផលមួយដែលមេបញ្ជាការចេញបញ្ជាឲ្យជម្លៀសគឺដោយសារពួកគេមានការភ័យខ្លាចថា ខ្មាំងនឹងនៅបង្កប់នៅក្នុងចំណោមប្រជាជន ហើយប្រជាជននឹងលាក់ខ្មាំង)។ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ (ពាន យ៉ាន) ទំព័រ ៥៥-៥៦ (គាត់គឺ ជានិរសារខ្មែរក្រហមម្នាក់។ គាត់បានយល់ថា ប្រជាជនត្រូវចេញពីទីក្រុង ពីព្រោះវាងាយក្នុង “ការបោសសម្អាតខ្មាំង”។ គាត់បានយល់ថា ខ្មាំងនេះសំដៅលើប្រជាជនមកពីរបប លន់ នល់ ព្រមទាំងពួក សេ.អ៊ី.អា)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៥៣ (គាត់គឺជាកងទ័ពខ្មែរក្រហមម្នាក់។ គេបានប្រាប់កងទ័ពថា បើទោះជាខ្មាំងចុះចាញ់ហើយក៏ដោយ ក៏វានៅមានសល់កន្លែងខ្មាំងនៅក្នុងទីក្រុងភ្នំពេញដែរ)។ បទសម្ភាសន៍ជាមួយ ទឹង លាប ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5683ចុះថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ១ ERN(ភាសាអង់គ្លេស) 00184210(គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ មេកងវរសេនាតូចរបស់គាត់បានប្រាប់គាត់ថា មានផែនការយកប្រជាជនដែលហួសពីកម្រិតចំនួននៅក្នុងក្រុង ដើម្បីឲ្យតំបន់ក្រុងអាចរៀបចំឡើងវិញ អាចបោសសម្អាតខ្មាំង បង្កើតសន្តិសុខ និងបោសសម្អាត បន្ទាប់មក ទើបប្រជាជនអាចវិលត្រឡប់មកវិញបាន)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផុយ ប៉ុក ឯកសារ E3/5167 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ភាសាខ្មែរ) 00196060 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា គាត់បានដឹងតាមបញ្ជាពីមេរបស់គាត់ចំនួន៣នាក់ថា មូលហេតុដែលមានការជម្លៀសប្រជាជនចេញពីទីក្រុងគឺដើម្បីរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលស្ថិតក្នុងជួរប្រជាជន និងរៀបចំទីក្រុងទាំងមូលឲ្យមានរូបរាងថ្មី)។

តាមការចោទប្រកាន់ថា ខ្មាំង រួមទាំងគិញចក្រពត្តិអាមេរិកផងដែរ៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៤០-៤១។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ៥៥។ គេបានប្រាប់ ក្លាន ហ្វិត ថា ក្រុងភ្នំពេញត្រូវបានជម្លៀស ពីព្រោះវារងគ្រោះថ្នាក់នឹងការវាយប្រហារដោយវៀតណាម៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ (ក្លាន វ៉ុត) ទំព័រ ៨៥-៨៦ ។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៥-៤៦ (ដកស្រង់ សៀវភៅនិពន្ធដោយ ពិន យ៉ាថៃ៖ *ជីវិតកូនថ្លៃ កូនត្រូវតែរស់* ឯកសារ E3/3988 ERN (ភាសាខ្មែរ) 00588190 មិត្តប៊ិចដែលជាមន្ត្រីខ្មែរក្រហមជាន់ខ្ពស់ម្នាក់នៅក្នុងឋានានុក្រមខេត្ត បានប្រាប់គាត់ថា គេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដើម្បីបោសបំបាត់ឫសគល់ពួកប្រឆាំងនឹងបដិវត្តន៍ កម្ទេចគ្រប់ការតស៊ូទាំងអស់ កម្ទេចសំបុកនានារបស់ពួកប្រតិកិរិយា និងពួកឈ្មួញមូលធននិយម)។

៤៧០. កងពលធំជាច្រើន បានចូលរួមនៅក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[១៣៨២]។ អង្គភាពខ្មែរក្រហមខ្លះទទួលភារកិច្ចបណ្តេញប្រជាជនចេញពីផ្ទះរបស់ពួកគេ ចំណែកអង្គភាពខ្លះទៀតទទួលបន្ទុកត្រួតពិនិត្យមើលការជម្លៀស ឬ ការលួច ឆក់ ប្លន់ នៅក្នុងទីក្រុង[១៣៨៣]។ សាក្សី

---

[១៣៨២] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/394 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00398226 (កងទ័ពមកពីភូមិភាគបូព៌ា ភូមិភាគឧត្តរចាស់ ភូមិភាគពិសេស និងភូមិភាគនិរតី បានជម្លៀសប្រជាជនចេញនៅថ្ងៃទី ១៧ ខែ មេសា) ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ជា ឯកសារ E3/3961 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00205057-00205058 (គាត់ជាកងទ័ពភូមិភាគឧត្តរ ហើយគាត់បានចូលរួមនៅក្នុងការជម្លៀសថ្ងៃទី ១៧ ខែ មេសា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាច សៀក ឯកសារ E3/5165 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00186769 (គាត់ជាកងទ័ពនៅក្នុងកងពលលេខ ១ ហើយគាត់បានទទួលបញ្ជាពីមេឈ្មោះ អឿន ឲ្យជម្លៀសប្រជាជនចេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ម៉ុន ឯកសារE3/369 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៦ ERN (ភាសាខ្មែរ) 00195439 (កងទ័ពភូមិភាគនិរតីចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ឯកសារ E3/5263 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00270177-00270178 (គាត់ជាយុទ្ធជននៅក្នុងភូមិភាគពិសេស ហើយគាត់បានទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។

[១៣៨៣] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៧២-៧៤, ៨៨-៨៩។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៤៧-៤៩ (អង្គភាពផ្ទាល់របស់គាត់ពុំទទួលការងារជម្លៀសនៅក្នុងរយៈពេល៣ថ្ងៃដំបូងនោះទេ។ ការងារនេះជាការងាររបស់អង្គភាពជំនាញ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ២៩-៣១ (កងទ័ពដែលឈរជើងនៅក្រៅក្រុងទទួលការងារជម្លៀស កងពលផ្សេងទៀតទទួលខុសត្រូវតាមដាន)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៤០-៤៥ (អតីតកងទ័ពខ្មែរក្រហមដែលបានទទួលបញ្ជាឲ្យជម្លៀសប្រជាជន មិនបានចូលរួមនៅក្នុងការជម្លៀសប្រជាជនពីផ្ទះរបស់ពួកគេនោះទេ។ ប៉ុន្តែ គាត់ទទួលការងារអមដំណើរប្រជាជនតាមទូកទៅកំពង់ចាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ កែវ ឯកសារ E3/5173 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00189264 (កងរបស់គាត់មិនបានចូលរួមជម្លៀសប្រជាជនទេ ដោយឈរជើងនៅតាមផ្ទះ រួចគាត់ជួយព្យាបាលទាហានដែលមានរបួស)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373404 (គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់ដែលត្រូវបានចាត់ឲ្យប្រមូលសម្ភារៈជ័យភណ្ឌពីផ្ទះដែលគ្មានមនុស្សនៅ។ បទសម្ភាសន៍ជាមួយ អួ លាង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5685 ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ទំព័រ ៩ ERN (ភាសាខ្មែរ) 00201141 (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់ដែលបានចូលរួមនៅក្នុងការជម្លៀស។ គេឲ្យគាត់សម្អាតផ្ទះមួយឲ្យស្អាតម្ដុំៗ និងឲ្យដើរប្រមូលអីវ៉ាន់យកទៅដាក់ម្ដុំ។ សម្ភារៈណាសំខាន់ៗយកទៅដាក់ឃ្លាំងទៅ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជិន ម៉េត ឯកសារ E3/4717 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00418417 (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា ពួកមេដឹកនាំបានបញ្ជូនក្រុមយុវនារីឲ្យទៅប្រមូលជ័យភណ្ឌតាមផ្ទះរបស់ប្រជាជនយកមកទុកដាក់ក្នុងឃ្លាំង

រ៉ាចាម គុន ដែលបានយាមកាមនៅក្នុងកិច្ចប្រជុំនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះ មានការពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[១៣៨៤] បានឱ្យដឹងថា ការជម្លៀសនឹងត្រូវធ្វើឡើងតែក្នុងរយៈពេលមួយសប្តាហ៍តែប៉ុណ្ណោះ[១៣៨៥]។

### ១០.២.៦ ការជម្លៀស "ដោយប្រើប្រាស់គ្រប់មធ្យោបាយ"

៤៧១. សាក្សី ស៊ុំ ជា ជាកងទ័ពខ្មែរក្រហមម្នាក់ដែលបានចូលរួមនៅក្នុងការជម្លៀសប្រជាជន បានទទួលបញ្ជាពីឈ្មោះ ហាក់ ដែលជាប្រធានកងវរសេនាតូចរបស់គាត់[១៣៨៦] ឱ្យជម្លៀសប្រជាជន[១៣៨៧]។ យោងតាម ស៊ុំ ជា ឈ្មោះ ហាក់ បាននិយាយថា ប្រសិនបើមិនធ្វើបាបប្រជាជនខ្លះទេនោះ ពួកគេនឹងមិនអាចជម្លៀសប្រជាជនចេញពីទីក្រុងឱ្យអស់នោះទេ[១៣៨៨]។ ក្រុមដែលត្រូវបានចាត់តាំងឱ្យបណ្តេញប្រជាជនចេញពីទីក្រុង ត្រូវតែប្រើប្រាស់មធ្យោបាយអ្វីក៏ដោយដើម្បីអាចធ្វើយ៉ាងណាឱ្យប្រជាជនចាកចេញ[១៣៨៩]។ ទោះបីជាសាក្សី ស៊ុំ ជា បានអះអាងថា កងពលរបស់គាត់

---

ឬទុកតាមផ្ទះរបស់មេដឹកនាំធំៗ)។ បទសម្ភាសន៍ជាមួយ វង់ វៃ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥ ទំព័រ13-14 ERN (ភាសាខ្មែរ) 00874660-61 (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់ដែលបានចូលរួមនៅក្នុងការជម្លៀស។ គាត់បានលើកឡើងថា ពួកគេចែកគ្នាជម្លៀសទៅតាមមុខព្រួញផ្សេងៗគ្នា)។

[១៣៨៤] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន) ទំព័រ ១១-១២ (គាត់អាចស្តាប់ឮការប្រជុំនេះបានពីព្រោះគាត់គឺជាអ្នកយាមម្នាក់នៅក្នុងពេលប្រជុំនេះ)។ *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៤៤-១៤៧។

[១៣៨៥] ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន) ទំព័រ ១៥-១៦។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373407 (គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា សារី ដែលជាមេរបស់គាត់បានបញ្ជាឱ្យពួកគាត់ជម្លៀសប្រជាជនស៊ីវិលក្នុងរយៈពេលមួយអាទិត្យ)។

[១៣៨៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១០-១១ (ប៉ុន្តែមិនបានដឹងថានរណាចេញបញ្ជាឱ្យ ហាក់ ធ្វើសកម្មភាពនេះឡើយ) ១២-១៣ (និយាយសំដៅបង ហាក់)។

[១៣៨៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១០-១១, ១២-១៣,២០។

[១៣៨៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២០។

[១៣៨៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១២ (មានក្រុមដែលត្រូវបានចាត់តាំងឱ្យបង្ខំប្រជាជនចេញ ហើយពួកគេត្រូវងាកទៅប្រើប្រាស់មធ្យោបាយអ្វីក៏ដោយដែលអាចមានវិធានការខ្លាំង ដើម្បីធ្វើយ៉ាងណាឱ្យប្រជាជនទាំងអស់ចាកចេញពីក្រុងឱ្យបានឆាប់)។

ពុំធ្វើបាបប្រជាជនក៏ដោយ[១៣៥០] គាត់បានដឹងពីឈ្មោះ ហាក់ ថាកងទ័ពផ្សេងទៀតត្រូវប្រើប្រាស់វិធានការនានា ដូចជាការបណ្តេញប្រជាជនចេញដោយភ្ជង់កាំភ្លើង ការបាញ់កាំភ្លើង ការវាយដំ និងការធ្វើបាបប្រជាជនស៊ីវិលដែលមិនព្រមចាកចេញ និងនៅក្នុងករណីធ្ងន់ធ្ងរបំផុតនោះ មានការបាញ់ប្រជាជន[១៣៥១]។ អតីតកងទ័ពខ្មែរក្រហមម្នាក់ទៀតបាននិយាយថា គាត់បានទទួលបញ្ជាពីថ្នាក់លើរបស់គាត់ឱ្យចាប់ទាញប្រជាជនដែលនៅតាមលំនៅដ្ឋាន និងគ្រវែងរបស់របរពួកគេចេញពីក្នុងផ្ទះ ប្រសិនបើប្រជាជនទាំងនេះមិនព្រមចាកចេញ[១៣៥២]។ សាក្សីជាច្រើននាក់បានផ្តល់សក្ខីកម្មថា ក្រោយពីទទួលបញ្ជាទាំងនេះហើយ នៅក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា និងថ្ងៃបន្តបន្ទាប់មកទៀត[១៣៥៣] កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធបានចូលតាមផ្ទះប្រជាជន និងសូម្បីតែទីវត្តអារាម

---

[១៣៥០] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១១-១២, ១២-១៣, ២០ (ទោះបីទទួលការងារជម្លៀសប្រជាជនពីផ្សារថ្មី និងជ្រោយចង្វារទៀតក៏ដោយ ក៏កងពលរបស់គាត់ពុំបានធ្វើបាបប្រជាជនទេ ហើយប្រជាជនត្រូវបានជម្លៀសយ៉ាងងាយស្រួល)។

[១៣៥១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១១-១២ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ជា ឯកសារ E3/3961 ERN (ភាសាខ្មែរ) 00205057-00205058), 24-25 (បងហាក់បានប្រាប់គាត់ថាក្រុងផ្សេងទៀតបានធ្វើបាបប្រជាជន)។

[១៣៥២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373406-00373407។

[១៣៥៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១,៩៦-៩៧ (កងទ័ពខ្មែរក្រហមបានវិលត្រឡប់មកផ្ទះរបស់គាត់វិញនៅម៉ោង ៨ យប់នោះ ហើយបានគំរាមពួកគាត់ឱ្យចាកចេញជាប្រញាប់)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៤ (បានលើកឡើងថា ពុំមានការជម្លៀសនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នោះទេ ប៉ុន្តែគេបានបញ្ជាពួកគាត់ឱ្យចាកចេញពីផ្ទះនៅថ្ងៃស្អែកឡើង)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៩, ៧១-៧៣ (នៅថ្ងៃទី ១៧ ពួកគាត់បានចាកចេញទៅវត្តឧណ្ណាលោម។ ជាថ្មីម្តងទៀត គេបានបង្ខំពួកគាត់ឱ្យធ្វើដំណើរបន្តទៅទៀតនៅថ្ងៃបន្ទាប់គឺ ថ្ងៃទី ១៨ ខែ មេសា នៅពេលកងទ័ពខ្មែរក្រហមបានមកដល់វត្តឧណ្ណាលោម។ ពិន យ៉ាថៃ និងគ្រួសាររបស់គាត់បានចាកចេញនៅព្រឹកថ្ងៃទី ១៨ ខែ មេសា ប៉ុន្តែបានឈប់នៅសាលាច្បាប់រយៈពេល៣ថ្ងៃ។ កងទ័ពខ្មែរក្រហមបានឱ្យពួកគេបន្តដំណើរទៅមុខទៀតនៅថ្ងៃទីបួន)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៣៩-៤០ (ខ្មែរក្រហមបានប្រកាសឱ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញរយៈពេល២ ឬ៣ថ្ងៃ ក្រោយថ្ងៃទី ១៧ ខែ មេសា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00556117 (ពួកគេបានចាប់ផ្តើមបណ្តេញប្រជាជនចេញ៣ថ្ងៃ ក្រោយថ្ងៃទី ១៧ ខែ មេសា)។

ក៏ចូលដែរ ហើយបានបណ្តេញប្រជាជនឲ្យចាកចេញដោយភ្ជង់កាំភ្លើង[១៣៩៤]។ ដើមបណ្តឹងរដ្ឋប្បវេណី មុម សំអឿន នៅពេលគាត់នៅក្នុងផ្ទះ គាត់ត្រូវបានបញ្ជាឲ្យចាកចេញដោយសមាជិកនៃកងទ័ពខ្មែរ

---

[១៣៩៤] ប្រតិចារឹក ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០១៣ (ចាន់ សុជាតិ) ទំព័រ៣៣ (នៅវេលាម៉ោង៩ ព្រឹក ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ បានចូលមកក្នុងផ្ទះរបស់គាត់ ហើយបានប្រាប់គាត់ និងគ្រួសារគាត់ថា ពួកគាត់ចាំបាច់ត្រូវចាកចេញពីផ្ទះ)។ ប្រតិចារឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៨-៩, ១១-១២ (កងទ័ពខ្មែរក្រហមបានភ្ជង់កាំភ្លើងបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ៣៩-៤០ (បានឃើញសមាជិកគ្រួសាររបស់គាត់ត្រូវបានបង្ខំដោយចុងកាំភ្លើងឲ្យចាកចេញ ពីអគារជាន់ទីបី)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨០, ៩៥ (កងទ័ពខ្មែរក្រហមប្រដាប់ដោយកាំភ្លើងវែងបានចូលមកក្នុងផ្ទះរបស់ពួកគាត់ និងបានចាប់ផ្តើមកម្ទេចរបស់របរនៅក្នុងផ្ទះ)។ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៨ (កងទ័ពខ្មែរក្រហម ទាំងស្រី ទាំងប្រុសបានមកផ្ទះរបស់គាត់បំពាក់ដោយអាវុធពាសពេញខ្លួន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចៅ នី ឯកសារ E3/3969 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00421599 (កងទ័ពមានគ្នា២នាក់កាន់កាំភ្លើងភ្ជង់ឲ្យគ្រួសាររបស់គាត់ចេញពីផ្ទះ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ស៊ុន ដារ៉ា ឯកសារ E3/5428 ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ទំព័រ 6 ERN (ភាសាខ្មែរ) 00443352 (កងទ័ពចំនួន៣នាក់កាន់កាំភ្លើងអាកាជាប់នឹងដៃបានបាញ់គំរាមដោយយកកាំភ្លើងអាកាមកភ្ជង់ឪពុកគាត់ហើយនិយាយថាត្រូវតែចេញពីទីនេះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហុង សារ៉ាត ឯកសារ E3/5591 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418447 (នៅពេលដែលកងទ័ពខ្មែរក្រហមមកដល់ផ្ទះគាត់ ពួកគេបានភ្ជុងកាំភ្លើង ហើយដាក់ខ្នោះឪពុកគាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ វ៉ា ប៊ុនថា ឯកសារ E3/4827 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00523423 (ពួកកងទ័ពខ្មែរក្រហមមានស្ពាយកាំភ្លើងវែងគ្រប់ដៃ ហើយបានមកគំរាមគ្រួសារគាត់ឲ្យចេញដោយបង្ខំ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00871750 (ខ្មែរក្រហមបានប្រើចុងកាណុងកាំភ្លើងគំរាមកំហែងឲ្យចេញពីផ្ទះតែម្តង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៧ ERN (ភាសាខ្មែរ) 00865602 (នៅពេលពួកគេបើកទ្វារ ពួកខ្មែរក្រហមក៏បានយកកាំភ្លើងភ្ជង់ពួកគេ ហើយប្រាប់ឲ្យពួកគេចាកចេញ)។ ទម្រង់បែបបទព័ត៌មាន ជនរងគ្រោះ សេន ផាប់ ឯកសារ E3/5391 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479075 (កងទ័ពខ្មែរក្រហមជាង ១០ នាក់ មានកាន់កាំភ្លើងអាកាគ្រប់ដៃ និងយកចំពុះទុងអាវុធមករុញច្រានគ្រួសារគាត់ឲ្យចាកចេញពីវត្ត)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ព្រាប ខេន ឯកសារ E3/5406 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ៧ ERN (ភាសាខ្មែរ)00480181 (ពួកគាត់ត្រូវបានភ្ជង់នឹងកាំភ្លើង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ តូច មុនិន្ទ ឯកសារ E3/4668 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00211324 (គ្រប់គ្នាត្រូវបានជម្លៀសចេញពីផ្ទះនៅទួលគោក និងត្រូវបានកងទ័ពខ្មែរក្រហមភ្ជង់កាំភ្លើងបង្ខំឲ្យដើរ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង មួង សុខន ឯកសារ E3/4681 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00323606 (ពួកគេត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញក្រោមការគំរាមកំហែងដោយអាវុធ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជួន សំអាត ឯកសារ E3/4707 ចុះថ្ងៃទី

ក្រហមម្នាក់ ដោយភ្ជង់កាំភ្លើងមកគាត់[១៣៩៥] ស្រដៀងគ្នានេះដែរ ម្ដាយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឆេង អេងលី និងមនុស្សចាស់ៗផ្សេងទៀតនៅក្នុងទីក្រុងត្រូវបានភ្ជង់កាំភ្លើងបង្ខំឲ្យចាកចេញដូចគ្នា[១៣៩៦]។

៤៧២. សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើននាក់ទៀត បានផ្ដល់សក្ខីកម្មអំពីភាពកាចសាហាវរបស់កងទ័ព និងការស្រែកគំហកមកលើប្រជាជន ឬ ការបាញ់កាំភ្លើងឡើងលើ ដើម្បីជំរុញឲ្យប្រជាជនចាកចេញពីផ្ទះរបស់ពួកគេ និងធ្វើដំណើរចាកចេញ[១៣៩៧] ។ អតីតកងទ័ព

---

២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00387630 (កងទ័ពខ្មែរក្រហមបានភ្ជង់ក្រុមគ្រួសាររបស់គាត់នឹងចុងកាំភ្លើង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស្វាយ ណេត ឯកសារ E3/4722 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00421213 (ពួកគេបានបាញ់កាំភ្លើងផង ភ្ជង់គំរាមផង ហើយបង្ខំឲ្យប្រជាជនទាំងអស់រួមទាំងគ្រួសាររបស់គាត់ផងចាកចេញ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហេនរី ស៊ុន ឯកសារ E3/5457 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00824580 (កងទ័ពខ្មែរក្រហមបានយកកាំភ្លើងភ្ជង់ពួកគេឲ្យចាកចេញពីផ្ទះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00152235 (ចេញពីទីក្រុងក្រោមការគំរាមកំហែងពីកងទ័ពខ្មែរក្រហមដោយកាំភ្លើង)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯម ភឿង ឯកសារ E3/5133 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00165259 (កងទ័ពខ្មែរក្រហមបានចូលមកដល់ក្នុងវត្តភ្ជង់ពួកគេនឹងកាំភ្លើង)។

[១៣៩៥] ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៦-៨ (បានភ្ជង់កាំភ្លើងដាក់គាត់ និងត្រូវបានបង្ខំឲ្យចាកចេញ។ ពួកគេបានប្រើប្រាស់ពាក្យសម្ដីមិនពិរោះស្ដាប់) ទំព័រ ១៩-២០ ទំព័រ ២២-២៣ (នៅពេលទៅដល់ផ្ទះណា កងទ័ពបានតម្រង់កាំភ្លើងដាក់ប្រជាជននៅក្នុងផ្ទះឲ្យចុះចេញមកដើរតាមក្បួន ចូលរួមជាមួយនឹងហ្វូងមនុស្ស បើមិនដូច្នេះទេ នឹងត្រូវបាញ់សម្លាប់ចោល)ទំព័រ ៣០-៣១ ទំព័រ ៣៣ (ទៅរកទូដែកយករបស់របរមានតម្លៃ ហើយមុនពេលគាត់បានដឹងថាមានអ្វីកើតឡើង សមាជិកខ្មែរក្រហមម្នាក់បានភ្ជង់គាត់នឹងកាំភ្លើង)។

[១៣៩៦] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៧៨-៧៩។

[១៣៩៧] បានស្រែកដាក់ និងមានភាពកាចសាហាវៈ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៦-៧៧ (បានស្រែកដាក់ពួកគាត់)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារ៉ា-ស) ទំព័រ ៣-៤ (កងទ័ពផ្សេងទៀតបានត្រឡប់មកវិញ ហើយប្រែជាកាចសាហាវ ដោយទាមទារឲ្យពួកគាត់ចាកចេញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆេង អេងលី ឯកសារ E3/5736 ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00918045 (ខ្មែរក្រហមបានប្រើពាក្យជេរប្រទេចមកលើពួកគាត់ដែលគាត់មិនចង់រម្លឹកឡើងវិញនោះទេ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង សុខុម ឯកសារ E3/4702 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00368961 (កងទ័ពខ្មែរក្រហមកាន់កាំភ្លើង ស្រែកគំរាមឲ្យគ្រួសារគាត់ និងប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញ)។

បានគំរាមបាញ់ពួកគេចោល៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៥ (គេបាញ់ឡើងលើដើម្បីបំបែកក្រុមមនុស្សដែលនៅជុំៗគ្នា ហើយគេបានបង្ខំពួកគាត់ឲ្យដើរតទៅទៀត)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ២៣-២៤ (បានឮកងទ័ពខ្មែរក្រហមបាញ់កាំភ្លើងចេញពីក្នុងផ្ទះគាត់)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ២៨ (បានឃើញកងទ័ពខ្មែរក្រហមបាញ់កាំភ្លើងឡើងលើដើម្បីបង្ខំឲ្យប្រជាជនចុះទៅជាន់ក្រោម។ នរណាប្រឆាំងត្រូវបានភ្ជង់នឹងកាំភ្លើងបង្ខំឲ្យចុះ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៧៣ (នៅវត្តចិនដំដែក នៅវេលាម៉ោងប្រហែល ២.៣០ រសៀល កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធបានឡោមព័ទ្ធពួកគាត់ ហើយបានបាញ់កាំភ្លើងឡើងលើឲ្យពួកគាត់ចាកចេញពីកន្លែងនោះរយៈពេល ៣ថ្ងៃ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ  ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (ខ្មែរក្រហមបានបាញ់កាំភ្លើងឡើងលើដើម្បីគំរាមពួកគាត់)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៧, ៣៣-៣៦ (ពួកគេបានបាញ់កាំភ្លើងឡើងលើដើម្បីបណ្តេញប្រជាជនឲ្យចាកចេញពីផ្ទះ និងចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២២។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00484907(ពិពណ៌នាពីកងទ័ពមួយក្រុមស្លៀកពាក់ខ្មៅ មួរជើងខោ ម្ខាង លី បេ ៤០ ឈរបាញ់សំដៅទៅមូលដ្ឋានដែលប្រជាជនរស់នៅ ហើយខ្មែរក្រហមមួយក្រុមទៀតកំពុងតែគំរាមប្រជាជនឲ្យធ្វើដំណើរតាមផ្លូវធំ  ហើយពួកគេបានបាញ់រះពីលើក្បាល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មៀច ប៉ុណ្ណ ឯកសារ E3/5523 ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00414423 (ពួកគេបាញ់រះឡើងលើគំរាមកំហែងប្រជាជន)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ថាច់ យ៉ូង ឯកសារ E3/5427 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ១ ERN (ភាសាខ្មែរ) 00483320 (ពួកគេបាញ់រះឡើងលើផង និងបានស្រែកផង)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី ឯកសារ E3/4608 ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ៣ ERN (ភាសាខ្មែរ) 00418469 (នៅថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានមកដល់ពហុកីឡាដ្ឋានអូឡាំពិក  ហើយបានបញ្ជាឲ្យប្រជាជនទាំងនោះចាកចេញពីបន្ទប់របស់ពួកគេ។ ខ្មែរក្រហមបានបាញ់រះទៅក្នុងបន្ទប់មួយដែលមានមនុស្ស៤នាក់នៅក្នុងបន្ទប់នោះ ខណៈដែលពួកគេមិនធ្វើតាមបញ្ជារបស់ពួកខ្មែរក្រហម)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00556117 (ពួកគេបានបាញ់គំរាមកំហែងប្រជាជនស្ទើរគ្រប់ទិសទីកន្លែង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ  សេន ផាប់ ឯកសារ E3/5391 ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479075 (ពួកគេបានបាញ់សម្លុត)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៣២ ERN (ភាសាខ្មែរ) 00836109 (ខ្មែរក្រហមបាញ់ឡើងលើ ហាមមិនឲ្យត្រឡប់ក្រោយ។ មនុស្សជាច្រើនហែលទឹក ប៉ុន្តែខ្មែរក្រហមបាញ់ពួកគេ។ គេដុតចោលផ្ទះមួយជួរតាមបណ្តោយទន្លេ និងផ្សារនៅក្បាលថ្នល់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ  ថាច់ យួង ឯកសារ E3/5427 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ១ ERN (ភាសាខ្មែរ) 00483320 (កងទ័ពខ្មែរក្រហមបានស្រែកបញ្ជាឲ្យពួកគាត់ធ្វើដំណើរឲ្យលឿន ដោយពួកគេស្រែកផងបាញ់រះឡើងលើផង ហើយពួកគាត់ទាំងអស់គ្នាភ័យតក់ស្លុតគ្រប់គ្នា)។

ខ្មែរក្រហម ២ នាក់ ដែលបានចូលរួមនៅក្នុងការជម្លៀសនោះបានបញ្ជាក់ថា កងទ័ពបានបណ្ដេញប្រជាជនដែលនៅក្នុងផ្ទះឱ្យចេញដោយបង្ខំ និងគ្រវែងរបស់របរពួកគេចេញពីក្នុងផ្ទះ[១៣៩៨] ។ លើសពីនេះទៀត Sydney SCHANBERG បានពិពណ៌នាអំពីក្រុមកងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធដែលបានស្រែកគំហក និងបានបាញ់កាំភ្លើងឡើងលើដើម្បីបង្ហាញប្រាប់ថា ពួកគេមិនមែននិយាយលេងសើចនោះទេ នៅពេលក្រុមគ្រួសារទាំងឡាយបានធ្វើដំណើរយឺតយ៉ាវពេក[១៣៩៩]។

៤៧៣. ប្រជាជនដែលត្រូវបានជម្លៀស ក៏បានទទួលរងនូវការបំពានលើរូបរាងកាយផងដែរ ។ ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានរៀបរាប់ឡើងវិញអំពីការចាប់ចង ការវាយដំ និងទាត់ធាក់របស់កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធមកលើស្វាមីរបស់គាត់ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណី ពេជ្រ ស្រីផល បានឃើញអ្នកដែលតវ៉ាមិនព្រមចាកចេញត្រូវបានវាយដំនឹងស្ទាយកាំភ្លើង[១៤០០]។

៤៧៤. កងទ័ពខ្មែរក្រហមក៏បានគំរាមសម្លាប់ផងដែរ ចំពោះប្រជាជនណាដែលមិនព្រមធ្វើតាមបញ្ជារបស់ពួកគេ និងមិនព្រមចាកចេញ[១៤០១] ។ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើន

---

[១៣៩៨] កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373407 (គាត់គឺជាអតីតកងទ័ពខ្មែរក្រហម។ គាត់បានលើកឡើងថា គាត់បានទទួលបញ្ជាពីមេរបស់គាត់ថា ប្រសិនបើប្រជាជនមិនចង់ចេញទេ កងទ័ពបានបោះសម្ភារៈរបស់ពួកគេចេញពីផ្ទះ ហើយទាញពួកគេចេញពីផ្ទះ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៨៩-៩០ (គាត់គឺជាកងទ័ពខ្មែរក្រហមម្នាក់។ គាត់ទទួលខុសត្រូវអូសអ្នករឹងទទឹងចេញពីផ្ទះរបស់ពួកគេ)។

[១៣៩៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៦-៧ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្ដីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១២០ ERN (ភាសាខ្មែរ) 00963958។

[១៤០០] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨០-៨១,៩៥-៩៦ (កងទ័ពខ្មែរក្រហមប្រដាប់ដោយកាំភ្លើងវែងបានចូលក្នុងផ្ទះរបស់ពួកគាត់ ចាប់ចង វាយ ទាត់ធាក់ប្ដីរបស់គាត់)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល)ទំព័រ ១៤, ៥៩ (បានឃើញគេវាយអ្នកតវ៉ាមិនព្រមចាកចេញនឹងស្ទាយកាំភ្លើងនៅជិតផ្សារឃ្លាំងរំសេវ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ហុង សាវ៉ាត ឯកសារ E3/5591 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418447 (ខ្មែរក្រហមសម្លុតគ្រួសាររបស់គាត់ ហើយវាយឪពុកគាត់ដែលព្យាយាមតដៃ)។

[១៤០១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៣ (ខ្មែរក្រហមបានគំរាមថា ប្រសិនបើពួកគេវិលត្រឡប់មកវិញនៅថ្ងៃហ្នឹង ត្រូវតែឃើញចាកចេញឱ្យអស់ បើសិនជាមិនចេញទេ គេមកវិញដឹងហើយ)។ នៅពេលពួកគេវិលត្រឡប់មកវិញ ពួកគេបានប្រាប់យើងថា ពួកយើងប្រថុយនឹងការបាញ់សម្លាប់)។ ប្រតិចារឹក ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១២ (អោ រី) ទំព័រ ៨១ (បានគំរាមសម្លាប់អ្នកមិនចង់ចាកចេញ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៧ (កងទ័ពខ្មែរក្រហមបានប្រាប់ឪពុកគាត់ថា គេនឹងបាញ់ឪពុកគាត់ចោលប្រសិនបើឪពុកគាត់

មិនព្រមចាកចេញ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ៣៥ (កងទ័ពខ្មែរក្រហមបានប្រាប់ថា ប្រជាជនដែលមិនគោរពតាមការណែនាំនឹងត្រូវគេបាញ់ចោល)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធារី) ទំព័រ ១១ (ខ្មែរក្រហមមានអាវុធ និងគំរាមប្រជាជនទាំងអស់គ្នានឹងចុងកាំភ្លើង ហើយប្រសិនបើនរណារឹងទទឹង ពួកគេអាចប្រចុយនឹងគេបាញ់ចោល។ យើងមានការភ័យខ្លាចខ្លាំង។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១ (ក្រោយពីសុំអង្វរកងទ័ពខ្មែរក្រហមដើម្បីឲ្យពួកគាត់ចាកចេញនៅព្រឹកស្អែក កងទ័ពបានព្រមានពួកគាត់ថា ប្រសិនបើពួកគាត់ខកខានមិនព្រមចាកចេញជាប្រញាប់ទេ ពួកគេនឹងកម្ទេចឲ្យខ្ទេចទាំងអស់ និងគំរាមដល់អាយុជីវិតទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆេង អេងលី ឯកសារ E3/5736 ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00918045 (ខ្មែរក្រហមបានគំរាមសម្លាប់ពួកគាត់ចោលប្រសិនបើពួកគាត់មិនស្តាប់តាមបញ្ជា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផល្លាឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00484907 (នៅពេលបែរក្បាលត្រឡប់ក្រោយមើលមកផ្ទះគាត់ និងប្តីរបស់គាត់ត្រូវបានកងទ័ពខ្មែរក្រហមស្រែកគំរាមឲ្យដើរទៅមុខ បើដើរថយក្រោយមួយជំហាន គេរកបាញ់សម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ ណារិន ឯកសារ E3/4773 គ្មានចុះកាលបរិច្ឆេទ ទំព័រ៣ ERN (ភាសាខ្មែរ)00496951(ក្នុងពេលជម្លៀសនោះ កងទ័ពខ្មែរក្រហមក៏បានគំរាមថា បើសិននរណារឹងរូសមិនស្តាប់តាមបញ្ជារបស់ពួកគេ ពួកគេនឹងសម្លាប់ចោល នេះជាបញ្ជារបស់អង្គការ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ម៉េង ឯកសារ E3/5142 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00204118 (គាត់បានឃើញ និងឮកងទ័ពនិយាយថាឲ្យចេញពីភ្នំពេញរយៈពេល ៣ ថ្ងៃ ហើយអ្នកណាមិនព្រមចេញ គេសម្លាប់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថែម សែម ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00198941 (ខ្មែរក្រហមបានគំរាមថា បើអ្នកណាមិនចេញ ត្រូវកម្ទេច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ គីន ឯកសារ E3/5273 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00282940 (គាត់ជាអតីតកងទ័ពខ្មែរក្រហម។ គាត់បានឮកងទ័ពខ្មែរក្រហមប្រាប់ប្រជាជនថា បើមិនស្តាប់តាម នឹងកម្ទេចចោល)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហាន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00375523 (កងទ័ពបានប្រាប់ថា អ្នកណាក៏ដោយដែលមិនស្តាប់តាមបញ្ជារបស់ពួកគេ នោះនឹងត្រូវបាញ់សម្លាប់ចោល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00398495 (កងទ័ពខ្លះដើរតាមផ្ទះដោយសម្លុតឲ្យប្រជាជនចាកចេញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត ណារី ឯកសារ E3/4921 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00586773 (បានគំរាមកំហែងគ្រួសារដែលរឹងរូសឲ្យធ្វើការចាកចេញជាបន្ទាន់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00526041 (ពួកកងទ័ពខ្មែរក្រហម មានកាន់កាំភ្លើងគ្រប់ដៃ ហើយពួកគេគំរាមកំហែងយើង បើមិនចេញទេ ពួកគេនឹងសម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00556117 (បានគំរាមកំហែងថា នរណាមិនចេញ នឹងត្រូវបាញ់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ទីន ឯកសារ E3/5004 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557722 (កងទ័ពបានគំរាមសម្លាប់ឪពុកម្តាយរបស់គាត់)។ ទម្រង់បែបបទ

01006697



នាក់បានរៀបរាប់ឡើងវិញអំពីការបាញ់សម្លាប់ចោលភ្លាមៗនៅនឹងកន្លែង ចំពោះប្រជាជនណាដែលមិនព្រមស្តាប់តាមបញ្ជា[១៤០២] ។ ជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណី Denise AFFONÇO

---

ព័ត៌មានជនរងគ្រោះ សេន ផាប់ ឯកសារ E3/5391 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479075 (ពួកវាបានប្រកាសថា គ្រួសារណាដែលនៅរឹងទទឹងជាមួយនឹងអង្គការ គឺគ្រួសារនោះសុទ្ធតែពួកខ្មាំង ឬពួក សេ អ៊ី អា របស់អាមេរិចកាំងបង្កប់ ត្រូវបាញ់ចោលទាំងអស់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ខឹម ទីន ឯកសារ E3/5404 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១ ERN (ភាសាខ្មែរ) 00480148 (ប្រជាជនត្រូវជម្លៀសឲ្យចេញពីទីក្រុង បើមិនទៅ ត្រូវបាញ់សម្លាប់ចោល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ គុប នី ឯកសារ E3/5452 ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ទំព័រ៩ ERN (ភាសាខ្មែរ) 00471471 (ត្រូវបានបង្ខំឲ្យចុះចេញពីផ្ទះដោយគំរាមបាញ់សម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាន់ ស៊ីណាង ឯកសារ E3/4697 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00365377 (បើអ្នកណាមិនព្រមចេញ កងទ័ពខ្មែរក្រហមបាញ់សម្លាប់ចោល ហើយចោទថាខ្មាំងប្រឆាំងនឹងអង្គការ)។ កំណត់ហេតុនៃការ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សេង ចុន ឯកសារ E3/5562 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00390283 (បើអ្នកណារឹងទទឹងមិនព្រមចេញទៅ ឬចេញទៅហើយត្រឡប់មកផ្ទះវិញ ពួកខ្មែរក្រហមនឹងបាញ់សម្លាប់ចោលជាមិនខាន ទោះបីជាគាត់មិនបានឃើញការបាញ់សម្លាប់ផ្ទាល់ភ្នែកក៏ដោយ)។

[១៤០២] *សារណារបស់រដ្ឋាភិបាល ន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1804 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣២ ERN (ភាសាខ្មែរ) 00228748 (ផាម មឿន អនុសេនីយ៍ទោក្នុងរបប លន់ នល់ បានលើកឡើងថា ប្រជាជនណាដែលមិនចង់ចាកចេញពីផ្ទះរបស់ពួកគាត់ ឬ វិលត្រឡប់មកវិញ ត្រូវបានគេសម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត សែម ឯកសារ E3/4689 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨ ERN (ភាសាខ្មែរ) 00358733 (គេបានបញ្ជាឲ្យពួកគាត់ចេញទៅតាមផ្លូវជាតិលេខ ១ បើអ្នកណាប៉ិនជំទាស់គេបាញ់សម្លាប់ចោលតែម្តង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ុក សាឯម ឯកសារ E3/4724 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00421489 (អ្នកណាប៉ិនប្រឆាំងបញ្ជាឲ្យចាកចេញ គេនឹងបាញ់សម្លាប់ចោលតែម្តង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្លួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ៤ ERN (ភាសាខ្មែរ) 00484412 (បើអ្នកណាប៉ិនប្រឆាំងនឹងបញ្ជា គេនឹងសម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មា ឈិន ឯកសារ E3/4680 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ១៣ ERN (ភាសាខ្មែរ) 00323593 (ពួកខ្មែរក្រហមបានបាញ់ប្រហារទៅលើប្រជាជនដែលមិនព្រមចាកចេញ) ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែន សុផុន ឯកសារ E3/4821 គ្មានចុះកាលបរិច្ឆេទ ទំព័រ៤ ERN(ភាសាខ្មែរ) 00523263 (អ្នកខ្លះតដៃ ហើយត្រូវពួកខ្មែរក្រហមបាញ់សម្លាប់ដូចសត្វធាតុ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ដៃ យ៉ឺន ឯកសារ E3/4824 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523379-00523380 (ប្រជាជនខ្លះត្រូវពួកគេសម្លាប់នៅលើផ្ទះដោយសារប្រជាជនទាំងនេះមិនព្រមចាកចេញតាមបញ្ជារបស់ពួកគេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00526067-00526068 (អ្នកណាដែលមិនចង់ចេញ ឬ ធ្វើស្ទាក់ស្ទើរនោះ ពួកគាត់ត្រូវបានបាញ់សម្លាប់ភ្លាមៗ)។ ពាក្យសុំតាំងខ្លួនជា

01006698



បានពិពណ៌នាអំពីការសម្លាប់មិត្តរួមសាលារបស់គាត់ម្នាក់នៅនឹងកន្លែង ដោយសារគេនៅរង់ចាំស្វាមីរបស់ខ្លួន ហើយដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានរៀបរាប់ឡើងវិញអំពីកងទ័ពម្នាក់ដែលបានបាញ់ទៅលើក្មេងប្រុសម្នាក់ដែលព្យាយាមត្រឡប់ទៅផ្ទះវិញដើម្បីយករបស់របរ ដោយបាននិយាយថា "នេះជាអ្វីដែលបានកើតឡើងលើអ្នកមិនគោរពតាមបញ្ជា"[១៤០៣] ។ ការរៀបរាប់ជាលាយលក្ខណ៍អក្សររបស់បុគ្គលផ្សេងទៀត អំពីហេតុការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែក ក៏រៀបរាប់អំពីការកាប់សម្លាប់បែបនេះដែរ[១៤០៤] ។ ការរៀបរាប់អំពីប្រជាជនដែលរឹងទទឹងនឹងការ

---

ដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00556117 (ពួកគេបាញ់សម្លាប់គ្រួសារអ្នកជិតខាងរបស់គាត់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ អៀម ទៀង ឯកសារ E3/5482 ចុះថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ទំព័រ ៩ ERN (ភាសាខ្មែរ) 00512863 (កងទ័ពបានបាញ់សម្លាប់ដល់បងប្អូនដែលសុំជួបជុំបងប្អូនដើម្បីចេញដំណើរជាមួយគ្នា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស មុត ឯកសារ E3/4703 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00368981 (កងទ័ពខ្មែរក្រហមបាញ់សម្លាប់គ្រួសារមួយដែលស្តាយទ្រព្យសម្បត្តិប្រកែកមិនចេញ) ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418273 (អ្នកចេញមិនទាន់ ឬ អ្នកដឹកអីវ៉ាន់ដាក់រថយន្ត រ៉ឺម៉ក ត្រូវបានខ្មែរក្រហមសម្លាប់ចោល)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ១១៨ ERN (ភាសាខ្មែរ) 00836195 (និស្សិតច្បាប់ម្នាក់បានលើកឡើងថា អ្នកដែលមិនអនុវត្តភ្លាមៗតាមបញ្ជាត្រូវបានសម្លាប់ចោល ហើយគេមិននិយាយពីរដងទេ) ទំព័រ ២១៨ ERN (ភាសាខ្មែរ) 00836295 (អ្នកខ្លះបានបោះបង់ចោលរបស់របរដោយខ្លួនឯង បើសិនពួកគេចាំសិនពួកគេត្រូវរងការបាញ់សម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខឹម ណារ៉េត ឯកសារ E3/4687 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00356378 (គ្រួសាររបស់គាត់បានសម្រេចចាកចេញក្រោយពីបានដឹងថា គេបាញ់សម្លាប់គ្រួសារមួយដែលមិនព្រមចាកចេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ណារ៉េត ឯកសារ E3/1747 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ERN (ភាសាខ្មែរ) 00206387 (គេបានប្រាប់គាត់ថា ប្រជាជនដែលមិនព្រមចេញ គេបាញ់សម្លាប់ចោល)។ *សូមប្រៀបធៀបជាមួយនឹង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ឯកសារ E3/424 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418519 (គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា គ្មានការណែនាំពីថ្នាក់លើរបស់ខ្មែរក្រហមឲ្យបាញ់សម្លាប់ប្រជាជនដែលប្រឆាំងមិនព្រមចេញនោះទេ)។

[១៤០៣] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៦។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៤ (ដកស្រង់ សៀវភៅនិពន្ធដោយ ពិន យ៉ាថៃ៖ *ជីវិតកូនថ្លៃ កូនត្រូវតែរស់* ឯកសារ E3/3988 ERN (ភាសាខ្មែរ) 00588135-00588136).

[១៤០៤] លិខិតរបស់ស្ថានទូតបារាំងនៅក្នុងទីក្រុងបាងកក កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន អតីតឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ (FANK) ឯកសារ E3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៣ ERN (ភាសាខ្មែរ) 00499663 (ឧត្តមសេនីយ៍ត្រី សរ ប៊ុន បានលើកឡើងថា ជនណាដែលរឹងរូស និងមិនបានស្តាប់តាមបញ្ជាឲ្យធ្វើការជម្លៀសចេញនេះ នឹងត្រូវសម្លាប់ចោលបន្ទាប់ពីត្រូវបានគំរាមចំនួនពីរដងរួចមក ហើយគាត់

ជម្លៀស ហើយត្រូវបានបាញ់សម្លាប់ចោលនោះ ក៏មានភាពស៊ីសង្វាក់ជាមួយនឹងការរៀបរាប់របស់ ស៊ុំ ជា ដែលជាកងទ័ពខ្មែរក្រហមម្នាក់ផងដែរនោះ[១៤០៥]។

៤៧៥. ប្រជាជនខ្លះបានលើកឡើងថា ពួកគេពុំបានឃើញការរឹងរូសមិនស្តាប់តាមបញ្ជា ឬ អំពើហិង្សាដែលកើតមាននាពេលក្រោយមកនោះទេ[១៤០៦] ។ ជាការពិត ក្រោយពីបានឃើញកងទ័ព

---

ខ្លួនឯងបានឃើញហេតុការណ៍នេះផ្ទាល់ភ្នែក នៅពេលជនណាម្នាក់បានប្រកែកពុំព្រមធ្វើការចាកចេញពីគេហដ្ឋានរបស់ខ្លួនចំនួន ៣ ដង) ទំព័រ ៦ 00499666 (ពិពណ៌នាអំពីការកាប់សម្លាប់ភ្លាមៗនៅនឹងកន្លែង បន្ទាប់ពីការវាយកាន់កាប់បានទីក្រុងភ្នំពេញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហ៊ុំ ប៊ុណាក់ ឯកសារ E3/4759 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ទំព័រ១ ERN (ភាសាខ្មែរ) 00490224 (បានឃើញអ្នកដែលប្រឆាំងនឹងបញ្ជាត្រូវសម្លាប់ចោលភ្លាមៗនៅនឹងមុខគាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុត សែម ឯកសារ E3/4654 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00390312 (បានឃើញកងទ័ពខ្មែរក្រហមបាញ់មនុស្សស្លាប់ពីរបីនាក់ដែលអ្នកនោះទំនងជាម្ចាស់ផ្ទះ ហើយតវ៉ាមិនព្រមចេញពីផ្ទះរបស់ខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00398495 (បានឃើញមានការបាញ់សម្លាប់ប្រជាជន ដោយសារពួកគេរារែកមិនដឹងថាត្រូវទៅផ្លូវណា)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00375523 (បានឃើញ នរណាដែលប្រឆាំងតបទៅនឹងការបង្ខំឱ្យចាកចេញពីទីក្រុងភ្នំពេញនេះ ត្រូវបានបាញ់សម្លាប់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ភួង មុំ ឯកសារ E3/5416 ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480918 (បានឃើញ អ្នកដែលពុំចេញពីផ្ទះ ឬ នៅពន្យារពេលបង្អែបង្អង់នៅរង់ចាំសាច់ញាតិបងប្អូនត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ភ្លាមៗ។ ពេលខ្លះ ពួកគេបានបាញ់សម្លាប់ទាំងក្រុមគ្រួសារតែម្តង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហេនរី ស៊ុន ឯកសារ E3/5457 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00824580-0000824581 (គាត់ជាអតីតអគ្គនាយកនៃរតនាគារ ហើយគាត់បានលើកឡើងថា នរណាម្នាក់ងាកក្រោយ និងតវ៉ា នឹងត្រូវបាញ់សម្លាប់ចោល។ គាត់បានឃើញពួកខ្មែរក្រហមបាញ់ទម្លុះទ្វារ រួចហើយចូលទៅសម្លាប់មនុស្សគ្រប់គ្នានៅក្នុងផ្ទះតែម្តង)។

[១៤០៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១៩-២០ (ប្រជាជនដែលរឹងទទឹងនឹងការជម្លៀសត្រូវបានគេបាញ់ចោល។ ជាការពិតណាស់ ក្រុមផ្សេងទៀតនៃកងទ័ពខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជនមួយចំនួនតូចដើម្បីបំភ័យប្រជាជនផ្សេងទៀត)។

[១៤០៦] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (នោម សៃ) ទំព័រ ២៨-៣០ (អង្គភាពរបស់គាត់ប្រឈមមុខនឹងការរឹងទទឹងតវ៉ាពីប្រជាជន)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៣៤-៣៥ (ពុំបានឃើញគេប្រើប្រាស់កងទ័ពទប់ទល់ប្រឆាំងនឹងប្រជាជនដែលកំពុងចាកចេញពីក្រុងនោះទេ ទោះបីជាគាត់បានឮរឿងរ៉ាវរៀបរាប់មួយចំនួននៅស្ថានទូតបារាំងក៏ដោយក្តី)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២៣-២៤ (នៅក្នុងតំបន់របស់គាត់ ខ្មែរក្រហមពុំបានប្រើប្រាស់ការបង្ខំលើរូបរាងកាយដើម្បីបណ្តេញប្រជាជនចេញនោះទេ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ

ប្រដាប់ដោយអាវុធមានភាពម៉ឺងម៉ាត់ ប្រជាជនជាច្រើននាក់ដែលត្រូវបានជម្លៀស បានគិតថា ពួកគាត់មិនអាចមិនធ្វើតាមការបញ្ជាឲ្យជម្លៀសចេញនោះបានទេ ហើយក៏មិនហ៊ានរឹងទទឹងដែរ[១៤០៧] ។

---

១០ (ពុំបានឃើញខ្មែរក្រហមធ្វើបាបប្រជាជននោះទេ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជា ឡេង ឯកសារ E3/5231 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00267730 (ពួកខ្មែរក្រហមខ្លះមានកាំភ្លើង និងខ្លះអត់។ ប៉ុន្តែ មិនមានការបាញ់សម្លាប់ទេ ព្រោះប្រជាជនគ្មានការតវ៉ា)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សុខា ឯកសារ E3/5788 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373217 (គាត់មិនបានឃើញកងទ័ពខ្មែរក្រហមធ្វើបាបប្រជាជនទេ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373187 (មិនបានឃើញការធ្វើបាបប្រជាជន)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ERN(ភាសាខ្មែរ)003734078 (គាត់ជាអតីតកងទ័ពខ្មែរក្រហម ហើយគាត់បានលើកឡើងថា ក្នុងតំបន់ដែលគាត់ធ្វើការ ប្រជាជននិយាយស្ដាប់គ្នាបាន គាត់មិនបានឃើញការប្រព្រឹត្តិអំពើហិង្សាទេ)។ បទសម្ភាសន៍ជាមួយ អ៊ំ ទិត ធ្វើឡើងដោយក្រុមប្រឹក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឯកសារ E3/5548 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៨៦ ទំព័រ ២ ៤ ERN (ភាសាខ្មែរ) 00763949, 00763951 (ទោះបីជា កងទ័ពប្រដាប់ដោយអាវុធបានបង្ខំឲ្យព្រះសង្ឃជាង ៧០០ អង្គចាកចេញពីវត្ត និងមានសាកសពជាច្រើននៅតាមផ្លូវក៏ដោយ ក៏ព្រះអង្គមិនបានឃើញមានហេតុការណ៍អ្វីទេ នៅពេលជម្លៀស)។ បទសម្ភាសន៍ជាមួយ ទឹង លាប ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5683 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00184210 (គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បាននិយាយថា ប្រជាជនស្ទើរតែទាំងអស់បានទៅដោយគ្មានរអ៊ូរទាំ ពីព្រោះពួកគេមានការតក់ស្លុតនឹងអំពើហិង្សានៃការវាយប្រយុទ្ធគ្នាចុងក្រោយ។ ពួកគេបានធ្វើទៅតាមអ្វីដែលគេប្រាប់ ដោយសារភ័យខ្លាចមិនហ៊ានធ្វើអ្វីក្រៅពីនេះឡើយ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00172079 (គាត់ជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បាននិយាយថា នៅកន្លែងដែលគាត់ធ្វើការជម្លៀសនោះ មិនមាននរណារឹងទទឹងមិនព្រមចេញទេ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផាច សៀក ឯកសារ E3/5165 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00186769 (គាត់គឺជាកងទ័ពខ្មែរក្រហមម្នាក់។ គាត់មិនឃើញមានប្រជាជនត្រូវបានសម្លាប់ទេ ព្រោះពួកគេព្រមចាកចេញ)។

[១៤០៧] ប្រតិចារឹកថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៥-៧៦ (ខ្មែរក្រហមម្នាក់ៗដែលមកផ្ទះរបស់គាត់មានស្ពាយកាំភ្លើង។ ពួកគាត់មិនហ៊ានតវ៉ានោះទេពីព្រោះពួកគាត់បានឃើញពួកខ្មែរក្រហមស្ពាយកាំភ្លើង ហើយអាកប្បកិរិយារបស់ពួកគេមានភាពម៉ឺងម៉ាត់)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២១ (ពួកគាត់មានការភ័យខ្លាចគេបាញ់ចោលប្រសិនបើពួកគាត់មិនព្រមទៅ) ទំព័រ ២៣-២៤ (ទោះបីជាពួកខ្មែរក្រហមពុំបានគំរាមកំហែងពួកគាត់ក៏ដោយ នៅពេលពួកគាត់បានឃើញកាំភ្លើង ពួកគាត់មានការភ័យខ្លាចបាត់ទៅហើយ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៦-៥៧ (ទោះបីជាពួកខ្មែរក្រហមមានអាវុធក៏ដោយ ក៏ពួកគេមិនបានភ្ជង់កាំភ្លើងដាក់សាក្សីនោះទេ។ គ្មាននរណាម្នាក់ដែលគាត់បានឃើញមានភាពរឹងទទឹងនោះទេ។ ប្រសិនបើពួកគាត់មិនចាកចេញ ពួកខ្មែរក្រហមនឹងចាត់ទុកពួកគាត់ថាជាជនក្បត់ ពួកចក្រពត្តិ និងជាប្រជាជនដែល

យោងតាម PONCHAUD ខ្មែរក្រហមបានប្រើប្រាស់ការគាបសង្កត់ផ្លូវចិត្ត និងទឹកមុខគំរាមកំហែង។ ការសម្លុតសម្លឹងរបស់កងទ័ពទៅកាន់ប្រជាជន គឺជាការគ្រប់គ្រាន់ដើម្បីបំភិតបំភ័យប្រជាជនឲ្យស្តាប់តាមបញ្ជារបស់កងទ័ព[១៤០៨]។

គាំទ្ររបបចាស់ ហើយពួកគេនឹងសម្លាប់រង្គាលពួកគាត់) ទំព័រ ៧៨ (ការជម្លៀសច្បាស់ណាស់ មិនមែនថាអាចធ្វើតាមចិត្តបានឡើយ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុំង រ៉ែន) ទំព័រ ៣៦-៣៧ (បានយល់ស្រេបថា មិនមាននរណាម្នាក់យល់ព្រមចាកចេញពីផ្ទះរបស់ពួកគាត់នោះទេ លើកលែងតែមានការបង្ខិតបង្ខំ និងត្រូវបានរុញច្រានឲ្យចេញ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៧៨-៧៩ (ពាក់ព័ន្ធនឹងបញ្ជារបស់បក្សឲ្យជម្លៀសក្រុង "នៅពេលពួកគេនិយាយអ្វីមួយនោះ ពួកគេមិនមែនលេងសើចនោះទេ")។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៨-១០ (ពុំបានឃើញភាពរឹងទទឹងនឹងការជម្លៀសនោះទេ ប៉ុន្តែសន្មតថាជនភៀសខ្លួនចំនួន ២ លាននាក់ពុំចាប់អារម្មណ៍នឹងការស្នាក់នៅក្នុងទីក្រុងភ្នំពេញនោះទេ ហើយចង់វិលត្រឡប់ទៅកន្លែងដើមកំណើតរបស់ពួកគេវិញ។ ទោះក្នុងករណីណាក៏ដោយ ដោយសារខ្មែរក្រហមមានកាំភ្លើងអាកា និងមានអំណាច ហើយប្រសិនបើពួកគេស្នើឲ្យចាកចេញ តើអ្នកនឹងធ្វើយ៉ាងម៉េចដែរ?) ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៣៧ (គ្មាននរណាម្នាក់ហ៊ានរឹងទទឹងដោយសារភ័យខ្លាចនឹងការបាញ់ចោល)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00375523 (ទោះបីពួកគាត់មិនចង់ចាកចេញក៏ដោយ ក៏ប៉ុន្តែពួកកងទ័ពទាំងនោះហាក់ដូចជាកាចណាស់ ពួកគេមានអាវុធទៀតផង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484907 (កងទ័ពខ្មែរក្រហមចំនួន ៥ នាក់ បានអាមេអាវុធនៅពេលមកដល់មុខផ្ទះ ហើយបង្ខំឲ្យពួកគាត់ចាកចេញ ក្រោយមកគាត់បានឃើញកងទ័ពទាំងនេះ "បានចូលលុកលុយ" ផ្ទះរបស់ពួកគាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (ជាទូទៅ ប្រជាជនចេញទៅដោយបង្ខំ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ឯកសារ E3/5788 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373217 (ប្រជាជនខ្លាចទាំងគ្រាប់បែក និងទាំងសកម្មភាពដែលខ្មែរក្រហមអាចធ្វើ ប្រសិនបើពួកគេមិនចាកចេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00373186 (បើយើងមិនព្រមចាកចេញទេ ពួកគេនឹងបាញ់យើងហើយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ឡេង ឯកសារ E3/5231 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00267730 (ប្រជាជនទាំងអស់មិនចង់ចាកចេញទៅទេ ព្រោះស្តាយទ្រព្យសម្បត្តិរបស់ពួកគេ)។

[១៤០៨] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៩-២០, ២២-២៣, ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៩-១០។

### ១០.២.៧ គ្មានការលើកលែង

៤៧៦. ប្រជាជនគ្រប់គ្នាត្រូវបានជម្លៀស[១៤០៩] រួមទាំងព្រះសង្ឃ[១៤១០] មនុស្សចាស់ កូនក្មេង អ្នកជំងឺ អ្នករបួស មកពីតាមមន្ទីរពេទ្យក្នុងទីក្រុង[១៤១១] ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបតែសម្រាលកូន

---

[១៤០៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២១-២២ (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា ប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងមូលត្រូវបានជម្លៀស សូម្បីអ្នកជំងឺនៅតាមមន្ទីរពេទ្យ ជនពិការ ឬ អ្នកអសមត្ថភាព កូនក្មេង មនុស្សចាស់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជិន ម៉េត ឯកសារ E3/4717 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00418417 (គាត់គឺជាអតីតកងទ័ពខ្មែរក្រហម ម្នាក់។ គាត់បានលើកឡើងថា កង យុវជនត្រូវបានបញ្ជូនឲ្យទៅជម្លៀសប្រជាជន ១៧ មេសា ចេញពីទីក្រុងភ្នំពេញឲ្យអស់ បោសសម្អាតឲ្យអស់ចំពោះប្រជាជន ១៧ មេសា ដោយមិនឲ្យមានសេសសល់ម្នាក់ឡើយ)។

[១៤១០] បទសម្ភាសន៍ជាមួយ អ៊ំ ទិត ធ្វើឡើងដោយក្រុមប្រឹក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឯកសារ E3/5548 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៨៦ ទំព័រ ៤ ERN (ភាសាខ្មែរ) 00763951 (ព្រះអង្គជាភិក្ខុមួយអង្គនៅវត្តមហាមន្ត្រី។ ព្រះអង្គ និងព្រះសង្ឃជាង ៧០០ អង្គផ្សេងទៀតដែលនិមន្តមកពីវត្តរបស់ព្រះអង្គ ត្រូវបានជម្លៀស។ ព្រះសង្ឃ២អង្គដែលមានជំងឺ ហើយប្រកែកមិនព្រមចេញពីវត្តនេះ ក្រោយមកត្រូវបានយកចេញទៅបាត់)។ បទសម្ភាសន៍ជាមួយ ហ៊ូល សុវណ្ណ ធ្វើឡើងដោយក្រុមប្រឹក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឯកសារ E3/5550 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៨៦ ERN (ភាសាខ្មែរ) 00766089 (ព្រះអង្គជាព្រះសង្ឃមួយអង្គគង់នៅវត្តសំពៅមាស។ ព្រះអង្គបានមានសង្ឃដីកាថា ព្រះសង្ឃប្រមាណពី ១៥០ ទៅ ១៧៥អង្គ ត្រូវបានជម្លៀសចេញពីវត្តរបស់ព្រះអង្គ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុត អ៊ីន ឯកសារ E3/5130 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00165221 (ព្រះសង្ឃទាំងអស់ ៤០០ អង្គ មកពីវត្តកោះ ត្រូវបានជម្លៀស)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង ប៉ុណ្ណា ឯកសារ E3/5131 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00165226(មានព្រះសង្ឃប្រហែល ៤០០ អង្គ មកពីវត្តសារាវ័ន្ត ត្រូវបានជម្លៀស)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៦-១៧, ១៩ (ខ្មែរក្រហមបានមកវត្តឧណ្ណាលោមដើម្បីជម្លៀសអ្នកដែលជ្រកនៅក្នុងវត្តនោះ ព្រមទាំងជម្លៀសព្រះសង្ឃផងដែរ។ អ្នកនៅវត្តឧណ្ណាលោមត្រូវបានស្នើសុំឲ្យចាកចេញ។ ដោយសារ វ័យជរា សម្តេចសង្ឃ ហួត តាត និងព្រះសង្ឃមួយចំនួនតូចផ្សេងទៀតពុំទៅនោះទេ ប៉ុន្តែ ពិន មិនដឹងថាមានអ្វីកើតឡើងក្រោយពេលគាត់បានចាកចេញពីទីនោះឡើយ)។

[១៤១១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២១-២២ (គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានលើកឡើងថា ប្រជាជនក្រុងភ្នំពេញទាំងមូលត្រូវបានជម្លៀស សូម្បីតែអ្នកជំងឺនៅតាមមន្ទីរពេទ្យ ជនពិការ ឬ អ្នកអសមត្ថភាព កូនក្មេង មនុស្សចាស់ ពោលគឺ ពួកគេទាំងអស់គ្នាត្រូវបានជម្លៀសទៅតាមទិសដៅផ្សេងៗគ្នា)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (មានជនពិការ មនុស្សចាស់ និងក្មេងៗ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៦២ (ក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសមានទាំងចាស់ ក្មេង និងកុមារ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៣-៣៤ (មនុស្សចាស់ និងអ្នករបួសមានការលំបាកខ្លាំង)។ ប្រតិចារឹកថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ៥៨។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៣៣ (លើកលែងតែជនបរទេសដែលបានទៅស្ថានទូតបារាំង

ក្រៅពីនោះ គេជម្លៀសមនុស្សគ្រប់គ្នាដោយគ្មានការរើសអើងឡើយ) ទំព័រ ៤៥-៤៦ (មនុស្សគ្រប់វ័យ កុមារ ស្ត្រី និងអ្នកជំងឺត្រូវបានជម្លៀសទាំងអស់។ ប្រាកដណាស់ថា ពួកគេនឹងស្លាប់)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ) ទំព័រ ៧៤ (ប្រជាជនមកពីគ្រប់ស្រទាប់វណ្ណៈ អ្នកឈឺ ប្រជាជនដែលមានឪពុកម្ដាយឈឺធ្ងន់ដែលមិនអាចដើរបាន)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២២ (នៅមន្ទីរពេទ្យកាល់ម៉ែត កូនក្មេង ឬ អ្នកជាទីស្រឡាញ់ បានរុញសាច់ញាតិរបស់ខ្លួននៅលើរទេះ ហើយអ្នកជំងឺដើរទាំងលំបាកលំបិន)ទំព័រ៤៤ ទំព័រ៥២ (កាល់ម៉ែតគ្មានមនុស្សទេ ក្នុងរយៈពេលតែ២ថ្ងៃ)។ ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៦-៥៧, ៧៦-៧៧។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥-១៧។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៥៤ (ពួកគាត់ត្រូវបានបញ្ជាឲ្យជម្លៀសមនុស្សគ្រប់រូបចេញជាប្រញាប់ដោយគ្មានការលើកលែង។ តាមការអនុវត្តជាក់ស្ដែង មនុស្សទាំងនោះរួមទាំង ស្ត្រីមានផ្ទៃពោះ អ្នកជំងឺក្នុងមន្ទីរពេទ្យ មនុស្សចាស់ និងជនពិការផងដែរ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៥០ (ខ្មែរក្រហមបានជម្លៀសអ្នកជំងឺពីមន្ទីរពេទ្យ។ គាត់បានឮថា ខ្មែរក្រហមបានជម្លៀសមនុស្សចេញពីមន្ទីរពេទ្យព្រះកេតុមាលា ទោះបីជានៅទីនោះមានទាហានរបួសច្រើននាក់ នៅគ្រប់ទីកន្លែងក្នុងមន្ទីរពេទ្យក៏ដោយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៣ (បានឃើញប្រជាជនមានសេរ៉ូមចាក់ជាប់នឹងដៃ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១០ (មិនថាមានជំងឺធ្ងន់ប៉ុណ្ណា អ្នកជំងឺទាំងនោះត្រូវបានយកចេញពីមន្ទីរពេទ្យ ហើយមន្ទីរពេទ្យគ្មានមនុស្សទេ)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៧-៨ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្ដីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១២៨ ERN (ភាសាខ្មែរ) 00963966 Murray Carmichael គ្រូពេទ្យមួយរូបនៅក្នុងក្រុមវះកាត់របស់កាកបាទក្រហមដែលបានរៀបរាប់ អំពីមន្ទីរពេទ្យមួយក្នុងចំណោមមន្ទីរពេទ្យនានាបានបញ្ជាក់ថា៖ "ពួកគេបានទាញអ្នកគ្រប់គ្នាឲ្យចេញ សូម្បីតែអ្នកសន្លប់ អ្នកជំងឺធ្ងន់ធ្ងរ និងអ្នកកំពុងព្យួរសេរ៉ូមក៏ឲ្យចេញដែរ។ មនុស្សជាច្រើននឹងស្លាប់។ វាអាក្រក់ណាស់") ទំព័រ ៩ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្ដីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១៤០ ERN (ភាសាខ្មែរ) 00963978 (បានកត់សម្គាល់ថា នៅថ្ងៃទី ១៩ ខែ មេសា គិលានុបដ្ឋាយិកាម្នាក់មកពីមន្ទីរពេទ្យកាល់ម៉ែតបាននិយាយថា កងទ័ពខ្មែរក្រហមបានបញ្ជាឲ្យអ្នកជំងឺស្ទើរតែទាំងអស់ចេញពីមន្ទីរពេទ្យក្នុងរយៈពេល២ថ្ងៃចុងក្រោយ ហើយអ្នកមិនអាចដើររួចបាន ត្រូវដាក់លើគ្រែរុញលើផ្លូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ២ ៣ ERN (ភាសាខ្មែរ) 00541002, 00541003 (នៅមន្ទីរពេទ្យព្រះអង្គឌួងជាមួយឪពុករបស់គាត់ដែលជាគ្រូពេទ្យ នាពេលនោះ ខ្មែរក្រហមបានបញ្ជាឲ្យអ្នកដែលដើរបានត្រូវតែចេញមុនពេលពួកគេផ្ដាច់សេរ៉ូមពីអ្នករបួស)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ូ សុធាវី ឯកសារ E3/4607 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00279728 (ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺដែលមិនអាចដើរបាន និងប្រជាជនទាំងអស់ ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយត្រូវបានចាត់ទុកដូចជាសត្វធាតុ ដោយមិនគិតពីអាយុ រូបរាងកាយ ស្ថានភាពផ្លូវចិត្ត ឬ ជាបុរស ឬ ស្ត្រីអ្វីនោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484412 (តាមផ្លូវពេញ ណែនទៅដោយមនុស្ស មានក្មេងមានចាស់ រួមទាំងអ្នកខ្លះទើបសម្រាលកូនរួច អ្នកខ្លះចាស់ជរា និងអ្នកខ្លះទៀតកំពុងមានជំងឺផង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ

រួច[១៤១២]។ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា បានឃើញអ្នកជំងឺ និងអ្នករបួសត្រូវបានជម្លៀសឱ្យដើរលោតៗ ទាំងដៃកាន់ឈើច្រត់ត្រូវបានរុញនៅលើគ្រែពេទ្យ លើរទេះរុញ ឬ លើកៅអីរុញទាំងមានសេរ៉ូម ឬ ធុងអុកស៊ីហ្សែននៅជាប់ជាមួយនៅឡើយ[១៤១៣] ចំណែកអ្នកជំងឺ និងជនពិការ "វារដូចជន្លេន" នៅមុខផ្ទះដែល PONCHAUD កំពុងឈរ[១៤១៤]។

---

E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ១៧៩ ERN (ភាសាខ្មែរ) 00836256 (នៅថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ ១៩៧៦ ពេជ្រ លឹមកុង បាននិយាយថា អ្នកជំងឺនៅតាមមន្ទីរពេទ្យ ត្រូវបានជម្លៀសដូចមនុស្សទូទៅដែរ។ អ្នកដែលអាចដើរបានត្រូវដើរ ហើយអ្នកដែលកំពុងព្យួរសេរ៉ូម ពួកគេផ្ដាច់សេរ៉ូមចេញ ហើយត្រូវបានជម្លៀសចេញដូចគ្នា)ទំព័រ២១៨ ERN (ភាសាខ្មែរ)00836295(គាត់បានឃើញផ្ទាល់ភ្នែក ពួកគេបណ្ដេញអ្នកជម្ងឺធ្ងន់ ស្រាល ដោយគ្មានការបែងចែកឱ្យចាកចេញពីមន្ទីរពេទ្យរុស្សី អ្នកជំងឺដែលទើបវះកាត់ដៃ ឬ ជើងរួចថ្មីៗ ពិតណាស់ អ្នកជំងឺរាប់រយនាក់បានវារចេញពីមន្ទីរពេទ្យ។ អ្នកជំងឺវារតាមចញ្ចើមថ្នល់នៅមុខពេទ្យរាប់រយនាក់ ភាគច្រើនមិនអាចដើរម្នាក់ឯងបានទេ។ ពួកគេបណ្ដេញគ្រូពេទ្យវះកាត់ដែលកំពុងវះក្នុងបន្ទប់វះកាត់ ហើយអ្នកជំងឺវះកាត់ក៏ស្លាប់ទៅ)។

[១៤១២] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២-៨៣។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៣-៥, ១២-១៣ (សូម្បីម្ដាយគាត់ដែលទើបសម្រាលកូនរួច និងបងស្រីគាត់ដែលមានរបួសត្រូវបានជម្លៀសជាប្រញាប់)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣-៧៤ (ទើបសម្រាលកូនថ្មីៗ បានពរកូន២នាក់ និងកំពុងធ្វើដំណើរដោយថ្មើរជើងក្រោមកំដៅថ្ងៃ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៣២-៣៣, ទំព័រ ៥០-៥១ (សុខភាពគាត់មិនល្អដោយសារគាត់ទើបតែសម្រាលកូនរួច)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (ស្ត្រីដែលទើបសម្រាលកូនរួច ត្រូវបានបង្ខំឱ្យដើរក្រោមភ្លៀង និងថ្ងៃ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ១១-១២ (បានឃើញស្ត្រីមានផ្ទៃពោះរុញរទេះក្នុងពេលជម្លៀស)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤៥-៤៦ (ស្ត្រី ដែលទើបសម្រាលកូនរួចមានឱកាសរស់តិចណាស់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្រី ខែម ឯកសារ E3/546 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00204039 (បានឃើញម្ដាយដែលទើបសម្រាលកូនរួច)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១៨ ERN (ភាសាខ្មែរ) 00836195 (និស្សិតច្បាប់ម្នាក់បានលើកឡើងថា នៅមន្ទីរពេទ្យព្រះកេតុមាលា ពួកគេអូសអ្នករបួសទម្លាក់ពីលើគ្រែ ហើយសូម្បីតែស្ត្រីទើបសម្រាលកូនក៏ដូច្នោះដែរ)។

[១៤១៣] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៧-៧៨ (អ្នកជំងឺខ្លះនៅជាប់សេរ៉ូមនៅឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧-៨, ទំព័រ ១៩-២៥ (បានឃើញអ្នកជំងឺដែលត្រូវបានជម្លៀសពីមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ត្រូវបានរុញនៅលើគ្រែ សែងតាមប្រង់កា ឬ មានអ្នកផ្សេងទៀតសែង)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ២១-២២ (បានឃើញអ្នកជំងឺក្នុងមន្ទីរពេទ្យ២នាក់ដើរទាំងនៅជាប់សេរ៉ូម)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារ៉ា-ស) ទំព័រ ៥-៦ (បានឃើញអ្នកឈឺជាប់សេរ៉ូមនៅលើគ្រែនៅតាមផ្លូវក្រោមថ្ងៃក្ដៅហែង និងអ្នកដែលមិនអាចដើរបាន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (អ្នកជំងឺខ្លះនៅជាប់សេរ៉ូមនៅនឹងដៃនៅឡើយ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ

៤៧៧. នៅតាមមន្ទីរពេទ្យ អ្នកជំងឺដែលរបួសធ្ងន់ (ភាគច្រើនជាទាហានដែលបានរងរបួសនៅក្នុងការវាយប្រយុទ្ធពីពេលមុន) និងអ្នកជំងឺដែលមានកម្លាំងខ្សោយដែលមិនអាចជម្លៀសបាន ត្រូវបានទុកចោលឲ្យស្លាប់ ខណៈពេលដែលអ្នកផ្សេងទៀតត្រូវបានជម្លៀសចេញ[១៤១៥] ។ សក្ខីកម្មពីរបាន

---

កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៧ (បានឃើញគេរុញអ្នកជំងឺនៅលើគ្រែពេទ្យចាកចេញពីទីក្រុងទៅតាមផ្លូវមុនីវង្ស)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៨-៩ (បានឃើញជនពិការ និងអ្នកដែលប្រើប្រាស់ធុងអុកស៊ីហ្សែន)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៤៨, ៦៣ (បានឃើញគេរុញអ្នកជំងឺនៅលើគ្រែ និងអ្នកដើរដោយប្រើឈើច្រត់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANDBERG) ទំព័រ ៦-៧ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១២០ ERN (ភាសាខ្មែរ) 00963958 (មានមនុស្សរបួសរាប់ពាន់នាក់មកពីមន្ទីរពេទ្យ ខ្លះដើរខ្ញើចៗ ខ្លះមានឈើច្រត់ ដោយរួមមាន អ្នកដាច់ដៃជើង និងអ្នកជំងឺខ្លះទៀតត្រូវបានសាច់ញាតិរុញនឹងរទេះរុញ និងកៅអីរុញ និងអ្នកជំងឺខ្លះនៅលើគ្រែពេទ្យដែលមានសេរ៉ូមផ្លាសស្មានៅជាប់នឹងដៃរបស់ពួកគេ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៩ (ដកស្រង់ S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១៤០ ERN (ភាសាខ្មែរ) 00963978 (បានកត់សម្គាល់ថា នៅថ្ងៃទី ១៩ ខែ មេសា គិលានុបដ្ឋាយិការម្នាក់មកពីមន្ទីរពេទ្យកាល់ម៉ែតបាននិយាយថា អ្នកដែលត្រូវបានជម្លៀសដែលមិនអាចដើររួចត្រូវបានដាក់លើគ្រែរុញលើផ្លូវ)។ *សូមមើលផងដែរ* សារទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញនៅថ្ងៃទី ១៨ ខែ មេសា វេលាម៉ោង៨ ឯកសារ E3/2691 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ (បានរាយការណ៍អំពី “មនុស្ស ១.០០០.០០០ នាក់កំពុងភៀសខ្លួនចេញ។ អ្នកជំងឺបានចាកចេញពីមន្ទីរពេទ្យកាល់ម៉ែតទាំងនៅលើគ្រែ”)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ឯកសារ E3/5137 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00163091 (បានឃើញមនុស្សដើរដោយមានរុំរបួសក្បាល)។ ទម្រង់បែបបទសុំព័ត៌មានបន្ថែម សូ សារី ឯកសារ E3/4951 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00587131 (ប្តីរបស់គាត់ដែលជាអតីតទាហាន លន់ នល់ កំពុងមានជំងឺដើរមិនរួច ហើយគាត់អូសស្វាមីគាត់តាមរទេះរហូត ដោយគាត់មានផ្ទៃពោះ ៨ ខែ ផង។

[១៤១៤] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨។ *សូមមើលផងដែរ* សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២១៨ ERN (ភាសាខ្មែរ) 00836295 (គាត់បានឃើញផ្ទាល់ភ្នែកពួកវាបណ្តេញអ្នកជំងឺធ្ងន់ ស្រាល ដោយគ្មានការបែងចែកចេញពីមន្ទីរពេទ្យរុស្សី អ្នកជំងឺដែលទើបវះកាត់ដៃ ឬ ជើងរួចថ្មីៗ ពិតណាស់ អ្នកជំងឺរាប់រយនាក់ វារចេញពីមន្ទីរពេទ្យ។ អ្នកជំងឺវារតាមចញ្ចើមថ្នល់នៅមុខមន្ទីរពេទ្យជាច្រើននាក់ ភាគច្រើនមិនអាចដើរម្នាក់ឯងបានទេ)។

[១៤១៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១២ (បានឃើញអ្នកជំងឺដែលមិនទទួលបានការព្យាបាលត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យ), ទំព័រ ៣៩ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ជា ឯកសារ E3/3961 ERN (ភាសាខ្មែរ) 00205058, នៅមន្ទីរពេទ្យកាល់ម៉ែត អ្នកដែលមិនមានសាច់ញាតិ ត្រូវទុកចោលនៅក្នុងមន្ទីរពេទ្យរហូតដល់ស្លាប់), ទំព័រ ៦៣ (មានតែអ្នកជំងឺដែលគ្មានអ្នកជួយប៉ុណ្ណោះដែលនៅក្នុងទីនោះ)។ ប្រតិចារឹក ថ្ងៃទី

បង្ហាញពីការដេញគ្រូពេទ្យវះកាត់ចេញពីបន្ទប់វះកាត់របស់កាកបាទក្រហម នៅសណ្ឋាគារឡឺភ្នំ (Le Phnom) និងមន្ទីរពេទ្យរុស្ស៊ី នៅពេលដែលគ្រូពេទ្យទាំងនោះកំពុងតែធ្វើការវះកាត់ ដោយទុកចោលអ្នកជំងឺឲ្យស្លាប់នៅលើតុវះកាត់[១៤១៦]។ លោក Sydney SCHANBERG បានកត់សម្គាល់ថា

---

២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៦៣-៦៥ (នៅមន្ទីរពេទ្យបុរីកីឡា អ្នកជំងឺត្រូវបានទុកចោលដោយគ្មានការមើលថែរហូតដល់ស្លាប់), ទំព័រ ៨២ ដល់៨៣ (គ្មាននរណាម្នាក់មើលថែអ្នកជំងឺទេ ពួកគាត់នៅទីនោះ ហើយស្លាប់ ឬក៏ហូរឈាមរហូតដល់ស្លាប់ គាត់ចាំបាច់ត្រូវបោះបង់ ពូ និងភរិយារបស់គាត់ដែលរងរបួសចោល គេប្រាប់គាត់ថាអ្នកទាំងនោះត្រូវបានប្រមូលយកទៅទុកចោលមួយកន្លែង ប៉ុន្តែគាត់មិនដឹងថាមានអ្វីកើតឡើង ឬក៏តើពួកគេទាំងនោះត្រូវបានយកទៅចោលនៅទីណានោះទេ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ២៣-២៤ (ក្នុងនាមជាបុគ្គលិកពេទ្យ គាត់មានអារម្មណ៍មិនល្អសោះ ដែលត្រូវទុកអ្នកជំងឺចោល គាត់គិតថាពួកគេនឹងស្លាប់)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ២៩ (នៅមន្ទីពេទ្យព្រះកេតុមាលាដែលត្រូវបានបណ្តេញចេញអស់ហើយនោះ គាត់ឃើញមានសាកសពនៅលើកម្រាលឥដ្ឋ និងអ្នករបួសជាច្រើន)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៩ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥ E236/1/4/3.1, ទំព័រ ១៤០ ERN (ភាសាខ្មែរ) 00963978, បានកត់សម្គាល់ថានៅថ្ងៃទី ១៩ ខែ មេសា មានគិលានុប្បដ្ឋាយិកាម្នាក់មកពីមន្ទីរពេទ្យកាល់ម៉ែត បាននិយាយថា ក្នុងការជម្លៀស បុគ្គលិកមន្ទីរពេទ្យត្រូវទុកចោលអ្នករបួសធ្ងន់ធ្ងរ និងអ្នកដែលទើបវះកាត់ហើយថ្មីៗដែលមិនអាចធ្វើដំណើរបាន ហើយក្នុងចំណោមអ្នកដែលត្រូវបានទុកចោលនោះ គឺមានទារកដែលខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរចំនួន ៥ នាក់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ២, ៣ ERN (ភាសាខ្មែរ) 00541002, 00541003 (នៅមន្ទីរពេទ្យព្រះអង្គឌួងជាមួយឪពុករបស់គាត់ នៅពេលនោះជាវេជ្ជបណ្ឌិត កងកម្លាំងខ្មែរក្រហមបានសម្លាប់អ្នកជំងឺមួយចំនួនកំពុងសម្រាកនៅលើគ្រែពេទ្យ យ៉ាងសាហាវយង់ឃ្នង) ។ *ការធ្វើវិភាគមួយតាងនាមឲ្យគណៈកម្មការដោយប្រធានរបស់អនុគណៈកម្មការនេះ ស្តីពីឯកសារនានាដែលបានដាក់ជូនអនុគណៈកម្មការនេះ និងគណៈកម្មការសិទ្ធិមនុស្សតាមសេចក្តីសម្រេចលេខ៩ របស់គណៈកម្មការសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារE3/2060ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៩, ទំព័រ ១៨ ERN (ភាសាខ្មែរ) 00294953 (ការដកស្រង់ពីចម្លើយសាក្សីបញ្ជាក់ថា បន្ទាប់ពីត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ អ្នកដែលទើបទទួលការវះកាត់ថ្មីៗ ដោយសារតែមិនទទួលបានការថែរក្សា ទើបត្រូវស្លាប់បាត់បង់ជីវិត, ផ្នែកជំងឺកុមារបានក្លាយទៅជាផ្នូរកប់សាកសពរួម ដោយសារតែគេមិនអនុញ្ញាតឲ្យនរណាម្នាក់ចូលទៅយកកុមារទាំងនោះបាន)។ របាយការណ៍ប្រចាំឆ្នាំ១៩៧៥ របស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ឯកសារ E3/4090 ចុះខែ ធ្នូ ឆ្នាំ ១៩៧៥ ទំព័រ ៨ ERN (ភាសាខ្មែរ) 00654834 (អង្គការកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមបានបញ្ជូនក្រុមគ្រូពេទ្យវះកាត់អង់គ្លេស ទៅកាន់មន្ទីរពេទ្យព្រះកេតុមាលា ជាមន្ទីរពេទ្យដែលត្រូវបានក្រុមគ្រូពេទ្យវះកាត់បោះបង់ចោល ប៉ុន្តែក្រុមគ្រូពេទ្យអង់គ្លេសទាំងនោះមិនអាចឆ្លងកាត់របាំងផ្លូវបានឡើយ)។

[១៤១៦] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៦-៨ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១២៨ ERN (ភាសាខ្មែរ) 00963966, Murray

គិលានុបដ្ឋាយិកាម្នាក់មកពីមន្ទីរពេទ្យកាល់ម៉ែតបាននិយាយថា បុគ្គលិកសង្ឃឹមថា វេជ្ជបណ្ឌិតខ្មែរក្រហមនឹងមក ហើយធ្វើការថែទាំអ្នករបួសធ្ងន់ធ្ងរ និងអ្នកដែលទើបត្រូវបានវះកាត់ហើយ ដែលមិនអាចផ្លាស់ទីបាន ប៉ុន្តែពួកគាត់មិនបានឃើញក្រុមគ្រូពេទ្យខ្មែរក្រហមណាមកឡើយ ដោយឃើញតែពួកកងទ័ពតែប៉ុណ្ណោះ[១៤១៧] ។ លោក មាស សារ៉ាន់ ដែលជាគិលានុបដ្ឋាកនៅមន្ទីរពេទ្យបុរីកីឡានៅពេលនោះ ក៏បានរៀបរាប់ថា បើទោះបីជាអ្នករបួសដែលមិនទាន់ទទួលបានការព្យាបាលយ៉ាងច្រើនត្រូវបានបញ្ជូនមកដល់មន្ទីរពេទ្យក៏ដោយ ក៏ពួកខ្មែរក្រហមមិនបានធ្វើការគ្រប់គ្រងចាត់ចែងនៅក្នុងមន្ទីរពេទ្យ ឬ ក៏ជួយដល់បុគ្គលិកពេទ្យដើម្បីជម្លៀសអ្នកជំងឺចេញពីមន្ទីរពេទ្យឡើយ[១៤១៨]។ យោងតាម នួន ជា ថ្នាក់ដឹកនាំខ្មែរក្រហមមិនមានពេលវេលាក្នុងការកំណត់ថាតើមានមន្ទីរពេទ្យ ឬអ្នកជំងឺប៉ុន្មាននាក់ដែលត្រូវទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចក្នុងការជម្លៀសនោះទេ[១៤១៩]។

៤៧៨. សណ្ឋាគារឡឺភ្នំ (Le Phnom) ដែលជាតំបន់អព្យាក្រឹតប្រកាសដោយអង្គការកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម (ICRC) ដែលមកទល់រយៈពេលមួយសប្តាហ៍មុនថ្ងៃទី ១៧ ខែ មេសា ត្រូវបានប្រើប្រាស់ជាជម្រករបស់ទាហានរងរបួស និងជនភៀសខ្លួននោះ[១៤២០] ក៏ត្រូវបានជម្លៀសដោយបង្ខំដែរ ហើយកងទ័ពខ្មែរក្រហមបានបណ្តេញប្រជាជនកម្ពុជាដែលជ្រកកោននៅទីនោះ ព្រម

---

Carmichael ដែលជាវេជ្ជបណ្ឌិតផ្នែកវះកាត់កាកបាទក្រហមបានប្រាប់ថា កងទ័ពខ្មែរក្រហមបានបង្ខំឱ្យគាត់ទុកចោលអ្នកជំងឺដែលកំពុងតែវះកាត់នៅក្នុងបន្ទប់វះកាត់កាកបាទក្រហមក្នុងសណ្ឋាគារ Le Phnom) ។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២១៨ ERN (ភាសាខ្មែរ) 00836295។

[១៤១៧] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៩ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១៤០ ERN (ភាសាខ្មែរ) 00963973)។

[១៤១៨] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ១៦-២២។

[១៤១៩] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៣-១៥។

[១៤២០] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ១៣-១៧ (នៅសណ្ឋាគារ Le Phnom ប្រធានកាកបាទក្រហមបានបង្កើតជាជំរំជនភៀសខ្លួនមួយបែបសម្រាប់ជនស៊ីវិល និងទាហានដែលរំសាយ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ១៣-១៤ (ប្រហែលមួយសប្តាហ៍មុនចប់សង្គ្រាម គឺប្រហែលនៅពេលដែលអាមេរិកដកចេញនៅថ្ងៃទី១២ ខែមេសា អង្គការកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម បានប្រកាសទីនេះថាជាតំបន់សុវត្ថិភាព ហើយបានព្យួរផ្ទាំងក្រណាត់រូបកាកបាទក្រហមដ៏ធំមួយនៅពីមុខសណ្ឋាគារ ។ ពួកគេបានបង្កើតបន្ទប់វះកាត់នៅផ្នែកខាងក្រោយសណ្ឋាគារហើយទទួលអ្នកដែលត្រូវការជំនួយវេជ្ជសាស្ត្របន្ទាន់ចាំបាច់។ មានមនុស្សរាប់ពាន់នាក់នៅកកកុញជុំវិញ ដើម្បីព្យាយាមចូលទៅក្នុងសណ្ឋាគារ)។

ទាំងបុគ្គលិកអង្គការកាកបាទក្រហម និងជនបរទេសឱ្យចេញពីទីនោះផងដែរ[១៤២១]។ ជនបរទេសទាំងនោះ ដែលរួមទាំង Alan ROCKOFF និង Sydney SCHANBERG ត្រូវបានបង្គាប់ឱ្យធ្វើដំណើរទៅកាន់ស្ថានទូតបារាំងដែលនៅទីនោះ មានជនបរទេស និងជនជាតិខ្មែរជាច្រើននាក់បានព្យាយាមសុំការជ្រកកោន[១៤២២]។

---

[១៤២១] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ១៣-១៤ (សណ្ឋាគារនេះត្រូវបានប្រកាសថាជាតំបន់សុវត្ថិភាពដោយអង្គការកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ប៉ុន្តែ នៅថ្ងៃទី ១៧ ខែ មេសា គ្រប់គ្នាត្រូវបានបណ្តេញចេញពីទីនោះដោយមិនលើកលែង), ទំព័រ ៦១ ដល ៦២ (កាកបាទក្រហមត្រូវបានជម្លៀសចេញ រួមជាមួយអ្នកដទៃទៀត)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ១១-១២ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ១៩៧៥, E236/1/4/3.1, ទំព័រ ១១៣ ERN (ភាសាខ្មែរ) 00963951, បានរៀបរាប់ថា នៅពេលជិតដល់ម៉ោង ៣ រសៀល ពួកកងទ័ពខ្មែរក្រហមបានបាញ់រះកាំភ្លើងរ៉ុកកែ្កត និងសព្វាវុធផ្សេងៗទៀតដើម្បីព្យាយាមសម្រុកចូលទៅក្នុងតំបន់សុវត្ថិភាពនៅសណ្ឋាគារ Le Phnom ។ បេសកកម្មរបស់ពួកគេហាក់ដូចជាស្វែងរកមន្ត្រីយោធារដ្ឋាភិបាល។ ជនបរទេសដែលចាកចេញពីសណ្ឋាគារបាននិយាយថាកងទ័ពខ្មែរក្រហមប្រាប់ពួកគាត់ថាពួកគាត់មានពេលកន្លះម៉ោងដើម្បីចាកចេញពីសណ្ឋាគារ ហើយទៅស្ថានទូតបារាំង)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៦ ERN (ភាសាខ្មែរ) S00644711 (នៅម៉ោង ៤ និង ៥៥ នាទី រសៀល កងទ័ពខ្មែរក្រហមបានសម្រុកចូលទៅក្នុងសណ្ឋាគារ Le Phnom គំរាមកំហែងអ្នកនៅខាងក្នុងដោយរ៉ុកកែ្កតបេ ៤០, ដោយធ្វើការកោះហៅប្រធានប្រតិភូកាកបាទក្រហមមក ពួកគេបានប្រាប់គាត់ដោយទ្រគោះបោះបោកថា ត្រូវតែចេញឱ្យអស់ពីកន្លែងនេះក្នុងរយៈពេលកន្លះម៉ោង)។

[១៤២២] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៣៤-៣៥ (ជនបរទេសបានស្វែងរកការជ្រកកោន នៅក្នុងស្ថានទូតតាំងពីមុន ថ្ងៃទី១៧ ខែ មេសា មកម្ល៉េះ) ទំព័រ ៣៥-៣៦, ៤២, ៤៤-៤៥ (បន្ទាប់ពីនោះ គាត់និងលោក Schanberg បានធ្វើដំណើរទៅស្ថានទូតបារាំង តាមការបញ្ជា),ទំព័រ ៧៣-៧៤ (ពួកអាល្លឺម៉ង់ខាងកើត ក៏ត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យចេញពីស្ថានទូតរបស់ពួកគេដោយប្រើចុងកាំភ្លើងផងដែរ ហើយត្រូវបានបញ្ជូនទៅស្ថានទូតបារាំង), ទំព័រ៧៩-៨០ (ស្ថានទូតមិនបានរាំងមនុស្សមិនឱ្យឆ្លោះរបងចូលនោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៨០-៨១ (បុគ្គលិកស្ថានទូតរុស្ស៊ីក៏ត្រូវបានយកទៅដាក់នៅស្ថានទូតបារាំងដែរ)។ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ២៧-២៨ (មានជនបរទេសប្រហែល ៥០០ នាក់ និងជនជាតិខ្មែរប្រហែល ៥០០ ស្នាក់នៅក្នុងស្ថានទូត), ទំព័រ ៣១-៣២ (សូម្បីតែជនជាតិអាល្លឺម៉ង់ខាងកើតដែលជាពួកកុម្មុយនីស្តក៏ត្រូវបានយកទៅដាក់នៅស្ថានទូតដែរ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ១១-១២ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១១៣ ERN (ភាសាខ្មែរ) 00963951 ជនបរទេសដែលបានចាកចេញពីសណ្ឋាគារ Le Phnom បាននិយាយថា ពួកគាត់ត្រូវប្រាប់ថា មានពេលតែកន្លះម៉ោងដើម្បីចាកចេញពីទីនេះទៅស្ថានទូតបារាំង)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៧, ១៨

៤៧៩. ដោយបានព្យាយាមចូលទៅក្នុង និងធ្វើការឆែកឆេរក្នុងបរិវេណស្ថានទូត ជាច្រើនលើកច្រើនសា[១៤២៣] ពួកខ្មែរក្រហម នៅពេលក្រោយមកបានគិតថា ស្ថានទូតបានក្លាយជា "មជ្ឈមណ្ឌលប្រមូលផ្តុំ" សម្រាប់ជនបរទេសតែប៉ុណ្ណោះ និងបានប្រកាសថា ស្ថានទូតនេះបានបាត់បង់ឋានៈរបស់ខ្លួនហើយ[១៤២៤]។ ជាលទ្ធផល ប្រជាជនកម្ពុជារាប់រយនាក់ដែលបានជ្រកកោននៅទីនោះ ត្រូវបានតម្រូវ

---

ERN (ភាសាខ្មែរ) S00644712, S00644713 (បន្ទាប់ពីត្រូវបានបណ្តេញចេញពីសណ្ឋាគារ Le Phnom មានការឯកភាពគ្នាជារួមថា ទៅស្ថានទូតបារាំងដែលនៅក្បែរនោះ, នៅព្រឹកថ្ងៃទី១៨ ខែមេសា មានមនុស្សប្រហែល ១.៥០០ នាក់ កំពុងស្នាក់នៅក្នុងស្ថានទូត ហើយមានជនភៀសខ្លួនបន្ថែមទៀតបានផ្លោះរបងចូលមកក្នុងស្ថានទូត)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ២១ ឯកសារ E3/2688 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (រាយការណ៍ថាមានមនុស្ស ១០០០ នាក់ បានផ្លោះរបង រត់ចូលមកជ្រកកោននៅក្នុងបរិវេណស្ថានទូត)។

[១៤២៣] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ឯកសារ E3/2689 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00490995, (បានកត់សម្គាល់ថា កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា (FUNK) បានប៉ុនប៉ងចូលទៅក្នុងស្ថានទូតចំនួនបីដង ដើម្បីធ្វើការឆែកឆេរ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ១០ និង ៣០ នាទី ឯកសារ E3/2692 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00490997 (រាយការណ៍ថា មនុស្សមួយក្រុមរបស់រណសិរ្សរួបរួមជាតិកម្ពុជា (FUNK) បានមានវត្តមានសាជាថ្មីនៅចំពោះមុខខ្លោងទ្វារនៃស្ថានទូត ហើយបានស្នើសុំចូលទៅក្នុងបរិវេណស្ថានទូតរបស់យើង ដើម្បីធ្វើការឆែកឆេររថយន្តរបស់យើង។ ពួកយើងបានបញ្ចៀសនូវឧប្បត្តិហេតុយ៉ាងប្រផិតប្រផៅយបំផុត)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅក្នុងស្ថានទូតរបស់យើង ឯកសារ E3/2698 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ (បានកត់សម្គាល់ថា ចាប់តាំងពីម្សិលមិញ ស្ថានទូតត្រូវបានឡោមព័ទ្ធដោយកងទ័ពរបស់រណសិរ្សរួបរួមជាតិកម្ពុជា(FUNK)។ ពុំមាននរណាម្នាក់អាចចូល និងចាកចេញពីបរិវេណស្ថានទូតដោយគ្មានការអនុញ្ញាតពីពួកគេបានឡើយ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ១៣- ១៤ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១៥០ ERN (ភាសាខ្មែរ) 00963988, រម្លឹកពីការដែលមន្ត្រីខ្មែរក្រហមចំនួន៣នាក់ ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ មានកាន់សៀវភៅកំណត់ត្រា ហើយការពារដោយមនុស្ស២នាក់កាន់កាំភ្លើងវែង បានចូលក្នុងស្ថានទូត។ កុងស៊ុល Dyrac ជាអ្នកនាំផ្លូវពួកគេ។ ពួកគេដើរទៅ ដើរមកដោយទឹកមុខស្លូត មើលមនុស្សដោយយកចិត្តទុកដាក់ សួរសំណួរ កត់ត្រា និងពិភាក្សាការងារជាមួយគ្នាគេ។) ROCKOFF បានលើកឡើងពីការដែលពួកខ្មែរក្រហមចូលមកក្នុងស្ថានទូតជាបន្តបន្ទាប់ដើម្បីស្វែងរកឧបករណ៍ផ្សាយសម្លេងវិទ្យុ ដោយអះអាងថាមានការផ្សាយវិទ្យុដោយខុសច្បាប់ ចេញពីក្នុងស្ថានទូត។ ប្រតិចារឹកថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៦៤-៦៥។ ប្រតិចារឹកថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៣៧-៣៨។

[១៤២៤] ប្រតិចារឹក ថ្ងៃ ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៤៥-៤៦ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១៤២ ERN (ភាសាខ្មែរ)

ឲ្យចាកចេញពីបរិវេណស្ថានទូត ដោយក្នុងចំណោមនោះ បុរសកម្ពុជាដែលបានរៀបការជាមួយជនបរទេសត្រូវបានបំបែកចេញពីភរិយាជាជនបរទេសរបស់ពួកគាត់ ហើយស្ត្រីកម្ពុជាដែលមិនទាន់ទទួលបានសញ្ជាតិបរទេស បើទោះបីជាខ្លួនបានរៀបការជាមួយជនបរទេសហើយក៏ដោយ ក៏ត្រូវបានតម្រូវឲ្យចាកចេញផងដែរ[១៤២៥]។ ដោយសារតែស្ត្រីកម្ពុជាដែលមានលិខិតឆ្លងដែនបរទេស

---

00963980, ដោយកត់សម្គាល់ថាក្នុងកិច្ចប្រជុំចុងក្រោយ ខ្មែរក្រហមបានប្រាប់កុងស៊ុល Dyrac ថា ពួកគេលែងទទួលស្គាល់ទីនេះជាស្ថានទូតដែលមានអភ័យឯកសិទ្ធិផ្នែកការទូតទៀតហើយ ដោយគ្រាន់តែចាត់ទុកថាទីនេះជា“តំបន់ប្រមូលផ្តុំ” សម្រាប់ជនបរទេសតែប៉ុណ្ណោះ ដោយច្រានចោលលទ្ធភាពនៃការស្វែងរកសិទ្ធិជ្រកកោន និងតម្រូវឲ្យជនជាតិកម្ពុជាចាកចេញពីបរិវេណស្ថានទូត។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៣០-៣១ ERN (ភាសាខ្មែរ) S00644726-727 (រាយការណ៍ថា នៅថ្ងៃទី ២០ ខែមេសា ស្ថានទូតបានបាត់បង់ឋានៈជាផ្លូវការរបស់ខ្លួន)។

[១៤២៥] ប្រតិចារឹក ថ្ងៃ ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៤៥-៤៦ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥, E236/1/4/3.1, ទំព័រ ១៤១ ERN (ភាសាខ្មែរ) 00963979, ដោយកត់សម្គាល់ថា នៅវេលាម៉ោង ៧.៣០ ព្រឹក បុគ្គលិកស្ថានទូតបានចាប់ផ្តើមប្រាប់ប្រជាជនកម្ពុជាដែលមិនមានឯកសារជាជនជាតិបារាំងថា ពួកគេត្រូវតែចាកចេញពីស្ថានទូត ហើយត្រូវទៅចូលរួមជាមួយការធ្វើដំណើរទៅកាន់ទីជនបទ តែបើពួកគេនៅទីនេះ អាចនឹងមានបញ្ហា)។ ប្រតិចារឹក ថ្ងៃ ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៥០ (ប្រជាជនខ្មែរជាច្រើនត្រូវបានបង្ខំឲ្យចាកចេញពីស្ថានទូត ក្រោយថ្ងៃទីមួយ ឬថ្ងៃទីពីរ), ទំព័រ ៥០ (ជនជាតិភាគតិចមួយក្រុម មកពីត្រើយម្ខាងទន្លេមេគង្គ មានគ្នាប្រហែល៣០០ នាក់ ត្រូវបានភ្លូងបង្ខំឲ្យចាកចេញពីស្ថានទូត), ទំព័រ ៥២-៥៤ (ប្រជាជនខ្មែរជាច្រើនបានចាកចេញពីស្ថានទូតនៅថ្ងៃទី ២០ ខែ មេសា) ទំព័រ ៧២-៧៤, ៧៤-៧៥ (ប្រជាជនខ្មែរជាច្រើនបានចាកចេញដោយស្ម័គ្រចិត្ត ដោយសារតែខ្មែរក្រហមគំរាមថានឹងចូលមកក្នុង ហើយរុករកក្នុងបរិវេណស្ថានទូត)។ ប្រតិចារឹកថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ២៧, ២៨-២៩ (ជារួមបុរសជនជាតិកម្ពុជាដែលរៀបការជាមួយស្ត្រីជនជាតិបារាំង ត្រូវតែចាកចេញទៅធ្វើការជាមួយប្រជាជនកម្ពុជា ដូច្នេះនៅថ្ងៃទី ២០ ខែ មេសា មានបុរសជនជាតិកម្ពុជាប្រហែល ២៥ នាក់ដែលបានរៀបការជាមួយស្ត្រីជនជាតិបារាំង ត្រូវបានបំបែកចេញពីគូស្នេហ៍របស់ពួកគេ), ទំព័រ ៣១-៣២ (បន្ទាប់ពីការចាកចេញ មាននៅសល់មនុស្សប្រហែល ៥០០ នាក់ទៀត)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ២៨ ,៣០ ERN (ភាសាខ្មែរ) S00644723, S00644725 (រាយការណ៍ថានៅថ្ងៃទី ២០ ខែមេសា ប្រជាជនកម្ពុជា វៀតណាម និងចិនរាប់រយនាក់ត្រូវបានស្នើឲ្យចាកចេញពីស្ថានទូត ស្ត្រីជនជាតិកម្ពុជាដែលបានរៀបការជាមួយបុរសជនជាតិបារាំង តែមិនទាន់បានទទួលសញ្ជាតិបារាំង ឬក៏បានត្រឹមរៀបការតាមច្បាប់កម្ពុជា ត្រូវបានបង្ខំឲ្យចាកចេញ ដែលធ្វើឲ្យមានការបែកបាក់គ្រួសារ,នៅថ្ងៃទី២១ ខែ មេសា ជនជាតិម៉ុងតាញ៉ាចំនួន១៥០ នាក់ត្រូវបានតម្រូវឲ្យចាកចេញពីស្ថានទូតផងដែរ)។ *ភ្នំពេញ៖ ការដួលរលំ និងការឡោមព័ទ្ធខុសពីធម្មតា* (កំណត់ហេតុដោយ J.J. Cazaux) ឯកសារ E3/2684 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៤ ERN (ភាសាអង់គ្លេស) 00710314 (នៅថ្ងៃទី ១៨ ខែ មេសា លោកកុងស៊ុល បានយល់ព្រមជាមួយពួកខ្មែរក្រហមថា ជនជាតិខ្មែរដែលនៅក្នុងស្ថានទូត

ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅក្នុងស្ថានទូតជាមួយស្វាមីជាជនបរទេសរបស់ខ្លួននោះ[១៤២៦] ទើបមានការរៀបអាពាហ៍ពិពាហ៍យ៉ាងលឿនមួយចំនួន ក្នុងគោលបំណងជួយសង្គ្រោះស្ត្រីកម្ពុជាមួយ

---

បារាំង ត្រូវតែចាកចេញពីបរិវេណស្ថានទូត, នៅថ្ងៃទី១៩ ខែមេសា ជនជាតិខ្មែរជាច្រើនបានសម្រេចចិត្តចាកចេញ), ទំព័រ ៩ ERN (ភាសាអង់គ្លេស) 00710319 (នៅថ្ងៃទី២០ ខែ មេសា ម៉ោង ៨ព្រឹក Dyrac បានប្រាប់ប្រជាជនកម្ពុជាដែលមានវត្តមានទីនោះថា នេះជាពេលវេលាដ៏ល្អបំផុតក្នុងការចាកចេញ ដើម្បីជៀសផុតពីការឆែកឆេរ នៅច្រកទ្វារ, នៅម៉ោង ៩ ព្រឹក ទ្រង់សិរិមតៈ និងលោកប្រធានរដ្ឋសភា បានបង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់អាជ្ញាធរ កងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ នៅខាងមុខស្ថានទូត ហើយបានចាកចេញតាមរថយន្តហ្សីប ហើយពួកគាត់គឺជាជនភៀសខ្លួនកម្ពុជាដំបូងគេនៅក្នុងស្ថានទូតដែលសម្រេចចិត្តចាកចេញ, ថ្ងៃទី២១ ខែមេសា ម៉ោង៧ព្រឹក ជនភៀសខ្លួនកម្ពុជាមួយក្រុមធំបានចាកចេញ ដោយមានការខកចិត្ត។ អ្នកខ្លះខូចចិត្តខ្លាំង ហើយអ្នកខ្លះទៀតបានសុំឲ្យប្រធានវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យកាល់ម៉ែត ចាក់ថ្នាំសម្លាប់ពួកគាត់ និងកូនៗ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ការចាកចេញរបស់ជនភៀសខ្លួន ឯកសារ E3/2702 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00492870 (បានរាយការណ៍ថា ក្រៅពីការចាកចេញរបស់ទ្រង់សិរិមតៈ និងអ្នកដទៃទៀតដែលមានឈ្មោះនៅក្នុងទូរលេខកាលពីលើកមុន នៅមានប្រជាជនកម្ពុជាប្រហែលមួយរយនាក់ដែលប្រុងប្រៀបចូលខ្លួនឲ្យគេចាប់នៅព្រឹកស្អែក)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ឯកសារ E3/2707 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00492871 (បានកត់សម្គាល់ថា មានប្រជាជនកម្ពុជាជាងមួយពាន់នាក់នៅក្នុងទីធ្លា។ អ្នកស្ម័គ្រចិត្តមុនគេ ដោយដឹងរួចស្រេចហើយថាមិនមានដំណោះស្រាយអ្វីក្រៅពីការចាកចេញនោះ បានប្រមូលផ្តុំគ្នានៅក្នុងសួន ហើយពួកគេត្រៀមខ្លួនទទួលយកជីវិតថ្មីរបស់ពួកគេដែលនឹងត្រូវចាប់ផ្តើមឡើង ដោយការធ្វើដំណើរក្នុងចម្ងាយផ្លូវដ៏សែនឆ្ងាយ។ ការឈឺចាប់គឺមិនអាចទ្រាំទ្របានសម្រាប់ពួកគេ... ហើយអ្នកខ្លះត្រូវបែកគ្នាបន្ទាប់ពីបានរួមរស់ជាមួយគ្នាអស់រយៈពេល១៥ ឬ ២០ឆ្នាំមកហើយ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ជនភៀសខ្លួនបរទេសនៅក្នុងស្ថានទូតបារាំង ឯកសារ E3/2715 ចុះថ្ងៃទី២៣ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00813074 (បានកត់សម្គាល់ថា ពួកខ្មែរក្រហមបានបំបែកភរិយាជាជនបរទេស ពីស្វាមីជាជនជាតិខ្មែរ ហើយពួកគេមិនអនុញ្ញាតឲ្យប្រជាជនកម្ពុជាចូលទៅក្នុងស្ថានទូតបារាំងទេ។ ខ្មែរក្រហមក៏បានយកបុគ្គលិកជាតិធ្វើការនៅស្ថានទូតចេញ ដូចជាអ្នកយាម និងអ្នកបើកបរ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ឯកសារ E3/5137 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00163091 (បានរៀបរាប់ពីការចាកចេញពីស្ថានទូតរបស់ប្រជាជនកម្ពុជាមួយចំនួន ហើយមានការមន្ទិលថា ពួកគេអាចទទួលបានការការពារដែរឬទេ, អ្នកដែលមិនចាកចេញដោយស្ម័គ្រចិត្ត ត្រូវបានបង្ខំឲ្យចាកចេញនៅពេលចុងក្រោយ ព្រោះសាររបស់ខ្មែរក្រហមនិយាយយ៉ាងច្បាស់ថា "ពួកគេត្រូវចាកចេញ បើមិនដូច្នោះទេយើងត្រូវបណ្តេញពួកគេ"។ ជាការពិតគឺមិនមានដំណោះស្រាយឡើយ [...] ខ្មែរក្រហមមិនយល់ពីសញ្ញាណនៃសិទ្ធិស្វែងរកការជ្រកកោន ឬសិទ្ធិមិនអាចប៉ះពាល់បានរបស់ស្ថានទូតនោះទេ[...] គឺជនជាតិកម្ពុជាទេដែលជាអ្នកជួយយើងឲ្យរួចផុតពីបញ្ហានេះ ដោយពួកគេព្រមទទួលយកថាពួកគេត្រូវតែចាកចេញដោយស្ម័គ្រចិត្ត)។

[១៤២៦] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ២៧ (ស្ត្រីជនជាតិកម្ពុជាដែលរៀបការជាមួយជនជាតិបារាំងអាចស្នាក់នៅក្នុងស្ថានទូតបារាំងបាន)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន

ចំនួន ហើយទារក ទារិកាខ្លះ ត្រូវបានទុកឲ្យនៅជាមួយជនបរទេស ឬ ត្រូវបានទទួលចិញ្ចឹមដោយជនបរទេសដែលមានសង្ឃឹមថាអាចចាកចេញពីប្រទេសកម្ពុជា[១៤២៧]។

៤៨០. ដោយស្របតាមសេចក្តីថ្លែងការណ៍របស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលបានធ្វើឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៥[១៤២៨] ជនបរទេសពិតជាត្រូវបានជម្លៀសទៅកាន់ព្រំដែនថៃ នៅប៉ុន្មានសប្តាហ៍ក្រោយមក ពិតប្រាកដមែន[១៤២៩]។

---

London Times)ឯកសារ E3/51ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៥ ទំព័រ ២៨-២៩ ERN (ភាសាខ្មែរ) S 00644723-S 00644724 (បានរាយការណ៍ថាស្ត្រីជនជាតិកម្ពុជាដែលបានរៀបការជាមួយបុរសជនជាតិបារាំង ហើយមានលិខិតឆ្លងដែនបារាំង អាចអនុញ្ញាតឲ្យស្នាក់នៅ ប៉ុន្តែស្ត្រីណាដែលបានត្រឹមតែរៀបការតាមច្បាប់កម្ពុជា ត្រូវបានបង្ខំឲ្យចាកចេញ ធ្វើឲ្យពួកគេបែកបាក់គ្រួសារ)។

[១៤២៧] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៥០-៥១ (គ្រួសារខ្លះបានទទួលចិញ្ចឹមក្មេងកំព្រាកម្ពុជា)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ១២-១៤ (Dyrac) ដែលជាមន្ត្រីនាំមុខរបស់ស្ថានទូត បានប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ រៀបចំពិធីអាពាហ៍ពិពាហ៍ ដើម្បីជួយដល់អ្នកដែលមិនត្រូវបានអនុញ្ញាតឲ្យចេញ។ ខ្មែរក្រហមបានដឹងពីរឿងនេះ ហើយបានប្រាប់គាត់ឲ្យបញ្ឈប់។ ប្តីប្រពន្ធជនជាតិកម្ពុជាមួយគូ បានប្រគល់កូនរបស់ខ្លួនទៅឲ្យស្ត្រីជនជាតិបារាំងម្នាក់ដែលបានសន្យាថា គាត់នឹងជួយរកក្រុមគ្រួសារថ្មីឲ្យទារកនោះ)។ ក្រសួងការបរទេសបារាំង ទូរលេខចូល, ឯកសារ E3/2707, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00492871 (បញ្ជូនដោយអ្នកវាយទូរលេខរបស់ស្ថានទូត, គាត់បានឃើញទារកតូចមួយទើបនឹងកើតកាលពីម្សិលមិញ នៅក្នុងស្ថានទូត ហើយម្តាយរបស់វា ត្រូវចាកចេញនៅថ្ងៃបន្ទាប់ ដូច្នេះគាត់ក៏យកទារកនេះធ្វើជាកូនចិញ្ចឹម)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN (ភាសាខ្មែរ) 00003281 (រាយការណ៍ថាប្តីប្រពន្ធកម្ពុជាមួយគូបានប្រគល់ទារកអាយុ ៧ ខែម្នាក់របស់ខ្លួនទៅអ្នកដទៃ ដោយដឹងថាមិនអាចទ្រាំទ្រការធ្វើដំណើរទៅទីជនបទបាន ហើយ Jean-Jaques Cazaux បានរៀបការជាមួយសង្សាជនជាតិកម្ពុជារបស់គាត់ ដើម្បីឲ្យនារីនោះទទួលបានសញ្ជាតិបារាំង។ លោកកុងស៊ុលបានកែកាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍មកថ្ងៃទី ១២ ខែ មេសា វិញ ដើម្បីបញ្ឆោតពួកខ្មែរក្រហម)។

[១៤២៨] ទូរលេខពីរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឯកសារ E3/189 ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៥ (ដោយភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍ដែលចេញដោយសមាជជាតិលើកទី២របស់កម្ពុជាដែលបានធ្វើនៅថ្ងៃទី ២៤ និង ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ក្រោមអធិបតីភាពលោក ខៀវ សំផន ហើយត្រូវបានបញ្ជូនដោយប្រទេសចិន ដើម្បីធ្វើការចែកចាយដល់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់។ សេចក្តីថ្លែងការណ៍នោះ រៀបរាប់លម្អិតចំណុចទាំងប្រាំបីដែលកំណត់ពីគោលនយោបាយរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលក្នុងនោះចំណុច ៦ បានចែងថា៖ “សមាជជាតិ តាងនាមឲ្យជាតិ និងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា សូមអំពាវនាវជាថ្មីម្តងទៀតដល់ស្ថានទូត និងទីភ្នាក់ងារបរទេសទាំងអស់ដែលប្រចាំការនៅក្នុងរបបពួកក្បត់ សូមដកបុគ្គលិក និង

គ្រួសាររបស់ពួកគេកុំបង្អង់ពីទីក្រុងភ្នំពេញ និងរបបក្រោមការត្រួតត្រារបស់ខ្មាំងជាបណ្តោះអាសន្ន ដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមាន។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបដិសេធមិនទទួលខុសត្រូវចំពោះគ្រោះថ្នាក់បែបនេះទេ”)។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងឃោសនាការ និងព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាស្តីអំពីការចាកចេញរបស់ជនបរទេសពីប្រទេសកម្ពុជា ឯកសារ E3/4129 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00491779 (ដោយពន្យល់ថា នៅក្នុងខណៈពេលដែលកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា បើកការវាយប្រយុទ្ធនៅជុំវិញទីក្រុងភ្នំពេញ និងនៅភ្នំពេញ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានចេញសេចក្តីអំពាវនាវជាច្រើនលើកច្រើនសា និងស្ទើរតែរៀងរាល់ថ្ងៃដល់បណ្តាអង្គទូត អ្នកសារព័ត៌មានបរទេស និងជនបរទេសទាំងឡាយដែលមកបម្រើការងារជាមួយរបបពួកក្បត់ និងរស់នៅក្នុងរបបនេះ ឲ្យបញ្ឈប់នូវគ្រប់សកម្មភាពទាក់ទងជាមួយពួកក្បត់ ហើយធ្វើការចាកចេញពីប្រទេសកម្ពុជា ក្នុងកាលវេលាដែលអាចធ្វើទៅបាន ក្នុងពេលដែលមួយចំនួនបានចាកចេញ មានមួយចំនួននៅបន្ត)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៥១ ដល់៥២ (នៅក្នុងឆ្នាំដំបូងៗ នៅពេលដែលការវាយប្រយុទ្ធកាន់តែខ្លាំងឡើងៗ អាជ្ញាធរបារាំងបានចាប់ផ្តើមណែនាំពលរដ្ឋរបស់ខ្លួនឲ្យចាកចេញពីកម្ពុជា ប៉ុន្តែគាត់សម្រេចចិត្តថាមិនធ្វើតាមការណែនាំនេះទេ ហើយគាត់បន្តរស់នៅក្នុងប្រទេសកម្ពុជាជាមួយស្វាមីជនជាតិចិនរបស់គាត់)។ សៀវភៅនិពន្ធដោយ François Ponchaud: កម្ពុជា ឆ្នាំសូន្យ, E243.1 ERN (ភាសាខ្មែរ) 00862327 (“ពួកយើង [ជាជនបរទេសនៅក្នុងស្ថានទូតបារាំង] គឺជាអ្នកបង្កបញ្ហាដែលមិនបានគោរពតាមបញ្ជារបស់អង្គការដែលឲ្យជនបរទេសទាំងអស់ត្រូវតែចាកចេញពីកម្ពុជានៅ ខែ មីនា ឆ្នាំ ១៩៧៥”)។

[១៤២៩] ប្រតិចារឹកថ្ងៃ ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៦៤-៦៥ (នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ទោះបីជាមិនមានការប្រាប់ហេតុផលជាក់លាក់ពីការដែលជនបរទេសចាំបាច់ត្រូវតែបណ្តេញចេញក៏ដោយជនបរទេសដែលនៅសេសសល់ត្រូវបានដឹកជញ្ជូនតាមផ្លូវគោកទៅកាន់ប្រទេសថៃ ដោយខ្មែរក្រហមបាននិយាយថា ពួកគេចង់ឲ្យជនបរទេសទាំងនោះបានឃើញពីអ្វីៗដែលខ្មែរក្រហមបានធ្វើ), ទំព័រ ៨៣-៨៤ (គាត់ជិះរថយន្តទីមួយ នៅក្នុងក្បួនទីពីរដែលបានចាកចេញពីស្ថានទូតបារាំង)។ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ (Alan ROCKOFF), ទំព័រ ១៧-១៨ (ជនបរទេសចុងក្រោយគេបំផុតចាកចេញពីប្រទេសកម្ពុជា ត្រឹមថ្ងៃទី ០៩ ខែ ឧសភា)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD),ទំព័រ៣២ (ក្បួនរថយន្តដឹកជនបរទេសដំបូងគេបានចាកចេញពីស្ថានទូតបារាំងនៅថ្ងៃទី៣០ ខែមេសា ហើយក្បួនទីពីរចាកចេញនៅថ្ងៃទី០៧ ខែឧសភា)។ *សូមមើលផងដែរ ភ្នំពេញ៖ ការដួលរលំ និងការឡោមព័ទ្ធខុសពីធម្មតា* (កំណត់ហេតុដោយ J.J. Cazaux) ឯកសារ E3/2684 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00712054 (នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ អាជ្ញាធរថ្មីក្នុងទីក្រុងភ្នំពេញបានសម្រេចថា គ្រប់តំណាងទូត និងអ្នកតំណាងអន្តរជាតិទាំងអស់ ត្រូវចាកចេញពីទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី ៣០ ខែ មេសា ហើយរដ្ឋាភិបាលកម្ពុជានឹងទទួលរ៉ាប់រងក្នុងការបញ្ជូនជនជាតិបរទេសចេញពីទីក្រុងភ្នំពេញ រហូតទៅដល់ព្រំដែនថៃ។ នៅថ្ងៃទី ៣០ ខែ មេសា ជនបរទេសបានធ្វើដំណើរចាកចេញតាមរថយន្ត) សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងឃោសនាការ និងព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាស្តីអំពីការចាកចេញរបស់ជនបរទេសពីប្រទេសកម្ពុជា ឯកសារ E3/4129 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00491779 (បានពន្យល់ថា បន្ទាប់ពីរំដោះទីក្រុងភ្នំពេញ រដ្ឋាភិបាលកម្ពុជាបានស្នើសុំជាថ្មីដល់ជនបរទេសដែលនៅសេសសល់ឲ្យចាកចេញពីកម្ពុជា

## ១០.២.៨ ការធ្វើដំណើរចេញពីទីក្រុងភ្នំពេញ

៤៨១. កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធដែលមានវត្តមាននៅតាមដងផ្លូវសំខាន់ៗ និងបានគ្រប់គ្រងទៅលើការជម្លៀសនោះ បានបង្គាប់ឲ្យប្រជាជនបន្តធ្វើដំណើរចាកចេញពីទីក្រុងឆ្ពោះទៅមុខ[១៤៣០]។ ប្រជាជនដែលត្រូវបានជម្លៀសមួយចំនួន ត្រូវបានរារាំងមិនឲ្យស្វែងរកសមាជិកគ្រួសារ

---

ហើយរដ្ឋាភិបាលកម្ពុជា បានប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីដឹកជញ្ជូនជនបរទេសទាំងនោះទៅទីកន្លែងមួយដែលរដ្ឋាភិបាល ឬ មិត្តភ័ក្តិរបស់ពួកគេអាចមកជួប ទទួលយកចេញដោយសុវត្ថិភាពពីកម្ពុជា)។

[១៤៣០] ប្រតិចារឹកថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុម ជា) ទំព័រ ១៩-២០ (ឈរជើងនៅតាមផ្លូវឆ្ពោះទៅកាន់ស្ពានទូតបារាំង ហើយបានបញ្ជាក់ថា ប្រជាជនត្រូវបានជម្លៀសចេញដោយងាយស្រួល ក្រោមការត្រួតពិនិត្យរបស់ពួកគេ)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៤ (មានកងទ័ពនៅសងខាងផ្លូវ ចង្អុលប្រាប់ទិសដៅដែលពួកគេចង់ឲ្យប្រជាជនធ្វើដំណើរទៅ)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារ៉ា-ស) ទំព័រ ៥-៦ (កងទ័ពខ្មែរក្រហមបង្ខំគ្រួសារគាត់ឲ្យបន្តដំណើរទៅមុខទៀត ហួសពីគីឡូម៉ែត្រលេខ ១៣)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ២០ (កងទ័ពខ្មែរក្រហមមិនបានដើរអមពួកគាត់ទេ តែគាត់ឃើញកងទ័ពនៅតាមផ្លូវដែលពួកគាត់ធ្វើដំណើរ)។ ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ (មាស សារ៉ាន់) ទំព័រ៣៣ (ឃើញមានខ្មែរក្រហមនៅតាមផ្លូវ អ្នកខ្លះដើរ អ្នកខ្លះធ្វើដំណើរតាមយានយន្ត ប៉ុន្តែពួកគេមិនបានបញ្ជាពួកគាត់ថាត្រូវធ្វើអ្វីនោះឡើយ)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៦, ២០, ៣៩ (កងទ័ពខ្មែរក្រហមគំរាមពួកគាត់ឲ្យធ្វើដំណើរឲ្យលឿន មិនត្រូវមើលមកក្រោយ ហើយយកកាំភ្លើងភ្ជង់ពួកគាត់)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥-១៦ (ប្រជាជនមិនអាចដើរដោយសេរីបានទេ ព្រោះកងទ័ពប្រដាប់ដោយអាវុធ ឈរអមហ្វូងមនុស្សនៅតាមផ្លូវ)។ ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ១០ (មិនចាំថាតើមានកងទ័ពខ្មែរក្រហមនៅយាមប្រជាជនដែរឬអត់នោះទេ នៅពេលពួកគាត់ចាកចេញពីទីក្រុងភ្នំពេញ ប៉ុន្តែចាំថាមានកងទ័ពខ្មែរក្រហមនៅតាមផ្លូវ)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1804 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២១ ERN (ភាសាខ្មែរ) 00228737 (គង្ស សម្រេច បានសង្កេតឃើញថា នៅពេលដែលគាត់ចាកចេញពីផ្ទះ ឃើញមានទាហានស្លៀកពាក់ខ្មៅ ពីរបីនាក់នៅឈរយាមតាមផ្លូវប្រសព្វគ្នា)។កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី ឯកសារ ឯកសារ E3/4608 ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418469 (នៅពេលជម្លៀស ពួកខ្មែរក្រហមតាមត្រួតពិនិត្យពួកយើង ហើយយើងត្រូវស្តាប់បញ្ជាពួកគេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថែម សែម ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00198942 (មានកងទ័ពខ្មែរក្រហមនៅគ្រប់ទីកន្លែង តាមផ្លូវ និងនៅកន្លែងដែលខ្ញុំស្នាក់នៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៩, ទំព័រ ៤ ERN (ភាសាខ្មែរ) 00398496 (ពួកខ្មែរក្រហមឈរនៅតាមផ្លូវ ហើយចង្អុល និងស្រែកប្រាប់ប្រជាជនឲ្យធ្វើដំណើរទៅមុខ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ)00373408 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានបញ្ជាក់ថា កងទ័ពខ្មែរក្រហមយាមកាមប្រជាជន

របស់ពួកគេនៅប៉ែកផ្សេងៗក្នុងទីក្រុងឡើយ ។ Denise AFFONÇO និង François PONCHAUD បានរៀបរាប់ពីការជម្លៀសប្រជាជន ដោយផ្អែកតាមតំបន់ដែលពួកគេរស់នៅ ហើយអ្នកដែលរស់នៅក្នុងប៉ែកខាងត្បូងមិនអាចធ្វើដំណើរទៅប៉ែកខាងជើងនៃទីក្រុងបានឡើយ ដោយសារតែមានរបាំងបិទផ្លូវនៅគ្រប់ទីកន្លែង។ Denise AFFONÇO ខ្លួនគាត់ផ្ទាល់មិនអាចរួមដំណើរជាមួយម្តាយរបស់គាត់ដែលនៅប៉ែកខាងលិចនៃទីក្រុងបានឡើយ[១៤៣១]។

---

ដែលត្រូវបានជម្លៀសនៅគ្រប់ផ្លូវក្នុងទីក្រុងភ្នំពេញ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៦០ ERN (ភាសាខ្មែរ) 00836237 (នី ប៊ុនលី បានបញ្ជាក់ថា ពួកខ្មែរក្រហមខ្លះបានរុញច្រានប្រជាជនពីក្រោយ ហើយបាននិយាយគំរាមកំហែងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ រយ ឯកសារ E3/4838 គ្មានចុះកាលបរិច្ឆេទ ទំព័រ៤ ERN (ភាសាខ្មែរ) 00526053 (ធ្វើដំណើរថ្មើរជើង ក្រោមការតាមដានយ៉ាងប្រុងប្រយ័ត្នពីសំណាក់កងទ័ពខ្មែរក្រហមដែលមានកាំភ្លើងគ្រប់ដៃ នៅតាមផ្លូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤ ERN (ភាសាខ្មែរ) 00526067 (កងទ័ពរាប់ពាន់នាក់បានភ្ជង់កាំភ្លើងប្រជាជន ហើយប្រាប់ឲ្យពួកគាត់ចាកចេញពីទីក្រុង), ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (កងទ័ពបានភ្ជង់កាំភ្លើងប្រជាជន ហើយស្រែកដាក់ប្រជាជន ដោយបង្ខំឲ្យពួកគាត់ដើរឲ្យបានលឿន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ទីន ឯកសារ E3/5004 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557722 (មានកងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ នៅតាមផ្លូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៧ ERN (ភាសាខ្មែរ) 00865602 (ពួកគេត្រូវបានបង្ខំឲ្យដើរក្នុងទិសដៅតែមួយ ហើយកងទ័ពឈរបិទផ្លូវប្រសព្វគ្នាទាំងអស់ ដោយតម្រូវឲ្យធ្វើដំណើរត្រង់ទៅមុខជាមួយប្រជាជនដទៃទៀត)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373187 (កងទ័ពខ្មែរក្រហមត្រូវបានដាក់ពង្រាយនៅតាមផ្លូវ ដើម្បីតាមមើលការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀស)។ *សូមប្រៀបធៀបជាមួយនឹង* ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣៦-៣៧(មិនមានអ្នកឈរយាមនៅតាមផ្លូវទេ)។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ៤១-៤២ (អតីតកងទ័ពខ្មែរក្រហម ដែលបានទទួលបញ្ជាឲ្យចូលរួមក្នុងការជម្លៀស ត្រូវមានភារកិច្ចយាមកាមជនស៊ីវិលនៅលើកាណូតទៅព្រែកពោធិ៍ ក្នុងខេត្តកំពង់ចាម។ ជនស៊ីវិលត្រូវបានអមដោយកងទ័ពក្នុងពេលធ្វើដំណើរតាមកាណូត និងពេលក្រោយមកទៀតដើម្បីការពារពួកគាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម ភឿង ឯកសារ E3/5133 ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00165260 (កងទ័ពខ្មែរក្រហម អមដំណើរពួកគេ ហើយចង្អុលបង្ហាញផ្លូវ ដើម្បីកុំឲ្យពួកគេធ្វើដំណើរខុសទិសដៅ)។ *សូមមើលផងដែរ* សាលក្រម ឧបសម្ព័ន្ធ III-ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ។

[១៤៣១] ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៥៩-៦១។ ប្រតិចារឹកថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ២២ (ប្រជាជនត្រូវចាកចេញពីទីក្រុងតាមទិសដៅផ្សេងៗគ្នា អាស្រ័យ

៤៨២. ការធ្វើដំណើររបស់ប្រជាជនរាប់ពាន់នាក់ចេញពីទីក្រុងភ្នំពេញ ត្រូវបានរៀបរាប់ថា មានលក្ខណៈកកកុញ វឹកវរ ច្របូកច្របល់ និងពិបាក ដោយសារតែអ្នកត្រូវបានជម្លៀសជួបការលំបាកជាមួយសមាជិកគ្រួសារដែលជាកុមារតូចៗ និងមនុស្សចាស់ជរា[១៤៣២]។ Denise AFFONÇO បាន

---

ទៅតាមតំបន់ស្នាក់នៅរបស់ពួកគាត់ក្នុងទីក្រុងភ្នំពេញ។ ប្រជាជនដែលស្នាក់នៅប៉ែកខាងជើងទីក្រុង ត្រូវតែចាកចេញពីប៉ែកខាងជើង)។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៤៨-៥០, ៥០-៥១, ៨០-៨១ (គាត់ និងប្តីជាជនជាតិចិនរបស់គាត់ មិនត្រូវបានអនុញ្ញាតឲ្យទៅស្ថានទូតបារាំងនោះឡើយ។ ដោយសារតែផ្លូវត្រូវបានបិទ ពួកគាត់ត្រូវបានបញ្ជូនទៅប៉ែកខាងត្បូងវិញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហ៊ុំ ប៉ូណាក់ ឯកសារ E3/4759 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00490224 (ត្រូវបានបំបែកចេញពីគ្រួសាររបស់គាត់ ដោយសារតែកងទ័ពខ្មែរក្រហមមិនអនុញ្ញាតឲ្យគាត់ទៅជួបក្រុមគ្រួសារនៅស្ថានទូតបារាំងឡើយ)។

[១៤៣២] ប្រតិចារឹកថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៣-៧៤ (មានការកកស្ទះ និងមានមនុស្សពេញតាមផ្លូវ ដូច្នេះពួកគាត់ត្រូវធ្វើដំណើរដោយយឺតៗ។ ពីកោះពេជ្រ ទៅដល់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រត្រូវចំណាយពេលមួយព្រឹកពេញ។ ទើបតែនឹងសម្រាលកូនផង គាត់ត្រូវពកូន២នាក់ទៀត ដែលម្នាក់អាយុ៥ឆ្នាំ និងម្នាក់ទៀតអាយុ៣ឆ្នាំ ហើយគាត់ត្រូវធ្វើដំណើរដោយថ្មើរជើង)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៥-៧៧ (ផ្លូវជាតិលេខ៦ ត្រូវកកស្ទះដោយសារមនុស្ស)។ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨១ (មនុស្សជាច្រើនត្រូវចាកចេញជាមួយគ្នា ហើយមានភាពកកកុញ)។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ទំព័រ ៧៤ (នៅពេលអនុវត្តផែនការជម្លៀសប្រជាជន ផ្លូវថ្នល់ពោរពេញទៅដោយហ្វូងមនុស្សដែលធ្វើដំណើរចេញពីទីក្រុង ហើយវាមានភាពវឹកវរខ្លាំង)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២១ (ស្ថានភាពគឺច្របូកច្របល់នៅតាមផ្លូវជាតិ ដោយសារតែផ្លូវពោរពេញទៅដោយមនុស្ស)។ ប្រតិចារឹកថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ៦០, ទំព័រ ៨៦ ដល់៨៧ (លើកឡើងពីមនុស្សរាប់ម៉ឺននាក់ដែលត្រូវបានជម្លៀស)។ ប្រតិចារឹកថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ២៩-៣០ (ឃើញមនុស្សដើរជាហ្វូងកាត់មុខគាត់ នៅពេលដែលគាត់ត្រូវបានកងទ័ពខ្មែរក្រហមឃាត់ខ្លួន បណ្តោះអាសន្ននៅក្រោមស្ពានជប៉ុន ហើយប្រជាជនដែលចាកចេញ ដើរយ៉ាងលឿន។ ប្រតិចារឹកថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៦៨ (សង្កេតឃើញថា នៅតាមផ្លូវកកកុញទៅដោយមនុស្ស)។ ប្រតិចារឹកថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទៀង) ទំព័រ ៦៥ (ឃើញមនុស្សជាច្រើនចាកចេញពីទីក្រុង ភ្នំពេញស្ថិតក្នុងភាពវឹកវរ ហើយមនុស្សកំពុងតែចាកចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុំង រ៉ែន) ទំព័រ ៣៥-៣៦ ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៤៥-៤៦ (ឃើញមនុស្សប្រហែល ២០០ ទៅ ៣០០ នាក់ ត្រូវបានជម្លៀសចេញតាមមហាវិថីព្រះមុនីវង្ស)។ប្រតិចារឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ៣២-៣៣ (មានបងប្អូននៅតូចៗជាច្រើន ហើយការជម្លៀសមានការលំបាកក្រៃលែង។ វាគួរឲ្យរន្ធត់ណាស់ នៅពេលឃើញហ្វូងមនុស្សនៅលើផ្លូវមុនីវង្ស)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហ៊ូ ចន្ថា) ទំព័រ ៥៤-៥៥ (ស្ថានភាពនេះធ្វើឲ្យពួកគាត់ច្របូលច្របល់ ហើយនិងភ័យខ្លាច។ គាត់ឃើញមនុស្សនៅកកកុញតាមផ្លូវ)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney

លើកឡើងពីភាពរីករវល់ហួសនឹងថ្លែង ដោយមានប្រជាជនយ្យូរឥវ៉ាន់ ដើរក្រោមកំដៅថ្ងៃជាមួយកូនតូចៗកំពុងតែយំ[១៨៣៣]។ Jon Swain បានពណ៌នាយ៉ាងត្រឹមត្រូវពីការធ្វើដំណើរថា ជាមហាក្បួននៃទុក្ខវេទនារបស់មនុស្សជាតិ[១៨៣៤] ។

៤៨៣. នៅតាមផ្លូវ មានមនុស្សកកកុញហើយពិបាកក្នុងការផ្លាស់ទី[១៨៣៥]។ យោងតាម មុម សំអឿន គាត់ និងគ្រួសាររបស់គាត់ត្រូវចំណាយពេល ៦ ម៉ោង ដើម្បីធ្វើដំណើរពីផ្ទះរបស់គាត់នៅខាងត្បូង

---

SCHANBERG), ទំព័រ ១២-១៣ (ឃើញមនុស្សរាប់ពាន់នាក់ដើរតាមផ្លូវជាតិលេខ ៥ សំដៅទៅសៀមរាប)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00172080 (ជាអតីតកងទ័ពខ្មែរក្រហមម្នាក់ ពេលបណ្តេញប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញ ឃើញមានអ្នកខ្លះរុញរទេះ អ្នកខ្លះរុញអ្នកជំងឺ អ្នកខ្លះទៀតមានដឹកអ្នកចាស់ជរា ដូចជាវេទនាណាស់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ តុប នី ឯកសារ E3/5452 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00471469 (មនុស្សរាប់សែននាក់ធ្វើដំណើរយ៉ាងវេទនាតាមផ្លូវជាតិលេខ ៥ ដោយចាប់ផ្តើមពីភ្នំពេញ ទៅស្រុកឧត្តុង្គ ដោយធ្វើដំណើរទាំងយប់ ទាំងថ្ងៃ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចែម សែម ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00198942 (អ្នកខ្លះយកខ្សែចងកដៃកូនៗភ្ជាប់ជាមួយខ្លួនការពារកុំឲ្យវង្វេង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00152235 (មានមនុស្សរាប់លាននាក់នៅតាមផ្លូវ ដូច្នេះពួកគេអាចបើកឡានបានចម្ងាយត្រឹម ៤០ ទៅ ៥០ ម៉ែត្រប៉ុណ្ណោះក្នុងមួយថ្ងៃ)។ រូបថតពីលំហអាកាស ឯកសារ E3/3000 ចុះថ្ងៃទី១៨ ខែ មេសា ឆ្នាំ ១៩៧៥។

[១៨៣៣] ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៥៧។

[១៨៣៤] អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៨ ERN (ភាសាខ្មែរ) S00644713។

[១៨៣៥] ប្រតិចារឹកថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣២-៣៤ (ពួកគេដើរតាមហ្វូងមនុស្សដែលដើរទៅទិសខាងត្បូង មានមនុស្សកកកុញ ហើយពិបាកក្នុងការធ្វើដំណើរ អ្នកជំងឺ និងមនុស្សចាស់ជរាពិបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរ), ទំព័រ៤៤ ប្រតិចារឹកថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៧-១៨, ៧២-៧៣ (ការធ្វើដំណើរទៅទិសខាងត្បូង តាមមហាវិថីមុនីវង្ស គឺទៅមុខយឺតៗបំផុត ព្រោះថាផ្លូវកកស្ទះទៅដោយហ្វូងមនុស្សយ៉ាងកកកុញ)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៨ (ផ្លូវកកស្ទះខ្លាំង មួយជំហានៗ ត្រូវចំណាយពេលយ៉ាងយូរដើម្បីដើរទៅមុខ)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១-៨២ (ពួកគេជិះម៉ូតូទៅស្ពានមុនីវង្សដែលនៅទីនោះពួកគេឃើញមនុស្សជាច្រើនធ្វើដំណើរចាកចេញពីទីក្រុង ពួកគាត់ដើរបានត្រឹមប្រហែល ៥ ម៉ែត្រ ក៏ត្រូវឈប់ដោយសារទើសមនុស្ស ប៉ុន្តែពួកគាត់ត្រូវតែបន្តដំណើរ ហើយពួកគាត់ដើរឈប់ ដើរឈប់)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥ ដល់១៦ (មានមនុស្សជាច្រើនធ្វើដំណើរជាមួយគ្នាក្នុងទិសដៅតែមួយ ហើយពួកគេមិនអាចដើរបានលឿននោះឡើយ)។

វិមានឯករាជ្យ ទៅដល់ស្ពានមុនីវង្ស[១៨៣៦] ដោយសារតែមានមនុស្សកកកុញពេក[១៨៣៧]។ នៅក្នុងពេលមានភាពវឹកវរ និងកកកុញនៃការជម្លៀសនេះ មនុស្សជាច្រើន រួមទាំងកូនក្មេងផង ត្រូវបានបែកពីក្រុមគ្រួសាររបស់ពួកគេនៅតាមផ្លូវ[១៨៣៨]។ Denise AFFONÇO បានវង្វេងបាត់ប្អូនថ្លៃប្រុសរបស់

---

[១៨៣៦] អង្គជំនុំជម្រះសាលាដំបូងប៉ាន់ប្រមាណថា មានចម្ងាយប្រហែល៣គីឡូម៉ែត្រ។

[១៨៣៧] ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ៦, ៣៦។

[១៨៣៨] ប្រតិចារឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ន់) ទំព័រ ២១ (ស្ថានភាពតាមបណ្តោយផ្លូវជាតិគឺច្របូកច្របល់ ដោយសារតែមានមនុស្សកកកុញ ហើយមានអ្នកខ្លះដើររកសមាជិកគ្រួសាររបស់ខ្លួន)។ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៧ ដល់៦៨ (ពូមីងរបស់គាត់ត្រូវបានជម្លៀសទៅតំបន់មួយនៅក្បែរគាត់ ប៉ុន្តែពួកគាត់វង្វេងគ្នា ហើយក៏បែកគ្នា ដូច្នេះពួកគាត់មិនដឹងថាពួកគេនៅទីណានោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ ណារិន ឯកសារ E3/4773 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00496951 (ក្នុងពេលជម្លៀសដែលមានលក្ខណៈវឹកវរ អ្នកខ្លះវង្វេងបាត់កូន អ្នកខ្លះបែកពីឪពុកម្តាយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ រយ ឯកសារ E3/4838 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526054 (ក្មេងៗយំ ដោយសារតែវង្វេងរកម្តាយមិនឃើញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00398495 (នៅជិតចំការមន មានប៉ុស្តិ៍ត្រួតពិនិត្យមួយដែលនៅទីនោះគ្រួសារត្រូវបែកគ្នា ដោយសារតែបុរសៗត្រូវបានបញ្ជូនទៅរោងចក្រកែវ ហើយនារីៗត្រូវបន្តដំណើរទៅមុខ)។ របាយការណ៍ដោយលោក Henri LOCARD៖ *នៅតំបន់ប្ញហ៊ា* ឯកសារ E3/3209 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦៩ ERN (ភាសាខ្មែរ) 00822974 (វង្ស សុភាព បានបែកពីគ្រួសាររបស់គាត់ដែលមានគ្នា៩នាក់ នៅពេលជម្លៀសចេញពីទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ផាន ឯកសារ E3/5143 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00204123 (ប្រជាជនដែលចាកចេញពីទីក្រុងភ្នំពេញយំសោក ដោយសារតែបែកពីឪពុកម្តាយ និងកូនរបស់ខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ណារ៉េត ឯកសារ E3/1747 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00206387 (ដោយសារតែមានមនុស្សច្រើន ម្តាយរបស់គាត់បានបែកពីគាត់ និងក្រុមគ្រួសារបងស្រីរបស់គាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នង សារ៉ន ឯកសារ E3/4653 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00484386 (ឃើញក្មេងតូចៗកំពុងតែយំ ដោយសារតែវង្វេងម្តាយឪពុក)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង មួង សុខន ឯកសារ E3/4681 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00323606 (បានវង្វេងបាត់កូនទីបួនរបស់ពួកគាត់ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅក្នុងហ្វូងមនុស្ស)។ ទំរង់បែបបទសុំព័ត៌មានបន្ថែម ញាណ រិន ឯកសារ E3/4832 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០ ទំព័រ ៣ ERN (ភាសាខ្មែរ) 00584420 (បន្ទាប់ពីខ្មែរក្រហមរំដោះទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ គាត់ និងម្តាយរបស់គាត់បានបែកពីឪពុក និងបងស្រីរបស់គាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ៣ ERN (ភាសាខ្មែរ) 00526041 (អ្នកខ្លះវង្វេងបាត់កូន អ្នកខ្លះបាត់ឪពុកម្តាយ និងបងប្អូន)។

គាត់ដែលបានជិះកង់តាមពីក្រោយឡានរបស់ក្រុមគ្រួសារ ហើយគាត់លែងបានជួបប្អូនថ្លៃនោះ ជារៀងរហូត[១៤៣៩] ។

៤៨៤. ប្រជាជនក្នុងទីក្រុងបានចាកចេញតាមគ្រប់មធ្យោបាយដែលខ្លួនមាន ដោយភាគច្រើនធ្វើដំណើរដោយថ្មើរជើង ប៉ុន្តែមានអ្នកខ្លះធ្វើដំណើរតាមកង់ តាមរទេះរុញ ឬ តាមរថយន្ត[១៤៤០]។ ប្រជាជនដែលធ្វើដំណើរតាមរថយន្តត្រូវអស់ប្រេង ឬ ត្រូវបានកងទ័ពខ្មែរក្រហមរឹបអូសយក

---

[១៤៣៩] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៧៨-៧៩។

[១៤៤០] ភាគច្រើនពួកគេធ្វើដំណើរដោយថ្មើរជើង: ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៩០ (មិនមានមធ្យោបាយធ្វើដំណើរ។ គ្រួសាររបស់គាត់ត្រូវដើររហូត)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣០-៣២ (រៀបរាប់អំពីមនុស្សធ្វើដំណើរដោយថ្មើរជើង), ៤៨ (គ្រួសាររបស់គាត់បណ្តើរម៉ូតូ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៣ (អ៊ុង រ៉ែន) ទំព័រ៣៥-៣៦ (ពួកគាត់ដើរ ដោយដាក់អីវ៉ាន់នៅលើរទេះរុញ និងលើកង់)។ ប្រតិចារឹក ថ្ងៃ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ១៨ (ឃើញមនុស្សធ្វើដំណើរដោយថ្មើរជើងចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៦៣-៦៤ (ភាគច្រើនដើរ)។ ក៏មានប្រើប្រាស់កង់ រទេះរុញ និងរថយន្តផងដែរ៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦១ (ប្រជាជនរុញឡានអស់សាំងដែលមានផ្ទុកសម្ភារៈ របស់ខ្លួន ហើយត្រូវលី និងទូលទំនិញផ្សេងៗផង)។ ប្រតិចារឹក ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០១២ (គង់ គឹម) ទំព័រ ៤៣។ ប្រតិចារឹក ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៥៤,ទំព័រ ៥៦ ដល់៥៧ (តាមរថយន្ត ដោយថ្មើរជើង និងកង់ អ្នកឈឺនៅលើស្នែង)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៣១។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣(Alan ROCKOFF), ទំព័រ ៤៨-៤៩, ៦៣-៦៤, ៧៩-៨០ (អ្នកជំងឺម្នាក់ត្រូវបានរុញនៅលើគ្រែពេទ្យ, មិនមានកង់ច្រើនទេ, អ្នកខ្លះ រួមទាំងបុគ្គលិកកាកបាទក្រហមត្រូវរុញឡានរបស់ខ្លួន ដោយមិនបើកនោះទេ ព្រោះពួកខ្មែរក្រហមនឹងរារាំងមិនឲ្យបើកឡាន តែបើរុញឡានគឺមិនមានបញ្ហាទេ)។ ប្រតិចារឹក ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ (មាស រឿន) ទំព័រ ៩ (គាត់សង្កេតឃើញជនស៊ីវិលបានចាកចេញពីទីក្រុងភ្នំពេញ ដោយអ្នកខ្លះយួរអីវ៉ាន់ ឬរុញរទេះ អ្នកខ្លះទៀតរុញឡានដែលអស់សាំង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ចាន់ដារា-ស) ទំព័រ ៤-៥ (ចាកចេញទៅដោយជិះឡាន២គ្រឿង តែទៅដល់កន្លែងមួយត្រូវរុញឡានទាំង២គ្រឿងនោះ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៤-៥៥ (អ្នកខ្លះបើកយានយន្តយឺតៗ អ្នកខ្លះជិះម៉ូតូ ហើយអ្នកខ្លះបណ្តើរម៉ូតូ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៧-១៨, ៧២-៧៣ (គាត់ព្រមទាំងសមាជិកគ្រួសារគាត់ប្រហែល ៣០ នាក់ បានធ្វើដំណើរតាមរថយន្ត៣គ្រឿង ម៉ូតូ២គ្រឿង និងកង់១គ្រឿង)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១ (ដោយជិះម៉ូតូ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤៨។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ១៥ (ឡានរបស់ពួកគាត់អស់សាំង ដូច្នេះពួកគាត់ត្រូវរុញឡាន), ១៩ (អ្នកដទៃទៀតជិះកង់ ជិះស៊ីក្លូ ឬ ដើរ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ) ទំព័រ ៧៤ (អ្នកដែលជិះឡាន ហើយអស់ប្រេងត្រូវតែរុញឡាន)។

រថយន្តនៅពេលធ្វើដំណើរទើបតែបានបន្តិច[១៤៤១]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា បានរៀបរាប់ពីការដែលគាត់ និងគ្រួសាររបស់គាត់ត្រូវបានបង្ខំឲ្យធ្វើដំណើរដោយថ្មើរជើង បន្ទាប់ពីអង្គការបានដកឡានហ្ស៊ីបដែលពួកគាត់កំពុងតែប្រើប្រាស់ ដោយអះអាងថា ឡាននោះជារបស់ពួកចក្រពត្តិ និងជារបស់ជ័យភណ្ឌសង្គ្រាម[១៤៤២]។

### ១០.២.៩ គោលដៅដែលត្រូវទៅ

៤៨៥. នៅពេលជម្លៀសនោះ ប្រជាជនជាច្រើនមិនបានដឹងថាខ្លួនត្រូវទៅទីណានោះទេ ក្រៅតែពីដឹងថាត្រូវចាកចេញពីទីក្រុង[១៤៤៣] ។ ប្រជាជនខ្លះត្រូវបានបង្គាប់ឲ្យត្រឡប់ទៅភូមិកំណើតរបស់ខ្លួន

---

[១៤៤១] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣២។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៤៨ ដល់៤៩, ៦៣ ដល់៦៤ (នៅប៉ែកខាងជើងទីក្រុងភ្នំពេញ ទោះជាយ៉ាងណា ក៏អ្នកនឹងបាត់បង់យានយន្ត និងទ្រព្យសម្បត្តិទាំងអស់)។ ប្រតិចារឹក ថ្ងៃទី០៨ ខែ តុលា ឆ្នាំ ២០១២ (មាស រឿន) ទំព័រ៩ (អស់ប្រេង)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣១-៣២។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ចាន់ដារា-ស) ទំព័រ៤-៥ (ពួកគេដកហូតយកឡាន២គ្រឿង)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១២, ១៩-២០ (ឡាន Volkswagen របស់គាត់ត្រូវបានកងទ័ពខ្មែរក្រហមដកហូតយក)។

[១៤៤២] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣២។

[១៤៤៣] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០, ៣១ (ពិបាកដោយសារតែគ្មានទិសដៅច្បាស់លាស់ដែលត្រូវទៅ ពួកគេគ្រាន់តែប្រកាសឲ្យយើងចាកចេញពីទីក្រុង)។ ទំព័រ ៨១ ដល់៨៣។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ២១ ដល់ ២២។ ប្រតិចារឹក ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣១ ដល់ ៣២ (គាត់មិនដឹងថាត្រូវទៅទីណា), ទំព័រ ៣២ ដល់៣៣ (នៅថ្ងៃបន្ទាប់ ពួកគាត់ត្រូវបានបង្គាប់ឲ្យទៅទិសខាងកើត)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៤ (កងទ័ពឈរជាជួរតាមផ្លូវ ហើយគ្រាន់តែចង្អុលឲ្យប្រជាជនចាកចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ (Denise AFFONÇO), ទំព័រ ៧៩-៨០, ទំព័រ ៨៥ (គាត់មិនដឹងថាពួកគេទៅទីណាទេ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៣១-៣២ (ពួកខ្មែរក្រហមមិនបានប្រាប់ពួកគាត់ថាត្រូវធ្វើអ្វីនោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៦-៧ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ១៩៧៥, E236/1/4/3.1, ទំព័រ ១២០ ERN (ភាសាខ្មែរ) 00963958, សង្កេតឃើញថាប្រជាជនត្រូវបានបង្គាប់ឲ្យតម្រង់ទៅទីជនបទ ហើយគេប្រាប់ថាពួកគាត់នឹងទទួលបានការណែនាំបន្ថែមពេលដែលចេញដល់ក្រៅក្រុង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី វៀម ឯកសារ E3/4980 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00554819 (ពួកគាត់ធ្វើដំណើរដោយថ្មើរជើង ដោយគ្មានគោលដៅច្បាស់លាស់ ហើយមិនដឹងថាត្រូវទៅទីណា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ទីន ឯកសារ E3/5004 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557722 (ពួកគាត់ទទួលបញ្ជាឲ្យដើរបន្តទៀត ប៉ុន្តែពួកគាត់មិនដឹងថាតើត្រូវបន្តឆ្ពោះទៅទីណាទៀតនោះទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ

ឬ ទៅទីជនបទ[១៤៤៤]។ ក៏ប៉ុន្តែ នី កន ដែលជាបងប្អូនប្រុសរបស់ សុន សេន និងជាសមាជិកនៃគណៈកម្មាធិការឃោសនាការរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ថា គាត់ត្រូវបានគេណែនាំឲ្យប្រាប់ប្រជាជនផ្លាស់ទីលំនៅទៅតាមការជ្រើសរើសរបស់ពួកគេ ដោយគ្មាននរណាម្នាក់ត្រូវបានបង្ខំឲ្យទៅទីកន្លែងដែលខ្លួនមិនធ្លាប់នៅនោះឡើយ[១៤៤៥]។ អ្នកដែលត្រូវបានជម្លៀសចេញពីភ្នំពេញ

---

២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373187 (ខ្មែរក្រហមមិនបានប្រាប់ពួកគាត់ថាត្រូវទៅទីណាទេ គឺគ្រាន់តែថាចាកចេញពីទីក្រុងភ្នំពេញមួយរយៈ)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (សាក្សីអ្នកជំនាញ David CHANDLER), ទំព័រ ៨៩ (ប្រជាជនត្រូវបានបណ្តេញចេញ ដោយមិនដឹងថាត្រូវទៅទីណានោះទេ)។

[១៤៤៤] ប្រតិចារឹកថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២(គឹម វ៉ាន់ឌី)ទំព័រ៧៩-៨០ (ពួកគាត់ត្រូវបានស្នើឲ្យទៅនៅទីជនបទ),៨៦ (ម្តាយរបស់គាត់ត្រូវបានប្រាប់ឲ្យត្រឡប់ទៅស្រុកកំណើត), ទំព័រ ៨៩ ដល់៩០ (មានការប្រកាសថាពួកគាត់គួរតែត្រឡប់ទៅភូមិកំណើតខ្លួនវិញ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៨ ដល់៥៩ (កងទ័ពបានប្រាប់យឹម សុវណ្ណ និងគ្រួសាររបស់គាត់ ឲ្យត្រឡប់ទៅភូមិកំណើត ត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ)។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៦១ ដល់៦២ (ពួកគេគ្រាន់តែចង់ឲ្យប្រជាជនចាកចេញពីទីក្រុងហើយត្រឡប់ទៅភូមិកំណើតវិញ), ទំព័រ ៨៦ ដល់៨៧ (ពិតជាមិនយល់ពីស្ថានការណ៍៖ “ខ្ញុំក៏មិនយល់ដែរ ព្រោះពួកគាត់ត្រូវបានបង្គាប់ឲ្យ ត្រឡប់ទៅភូមិកំណើតវិញបណ្តោះអាសន្ន ឬក៏យ៉ាងម៉េច?”)។ ប្រតិចារឹកថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០១៣(បេ សុផានី) ទំព័រ ៧ ដល់៩ (ត្រូវបានពួកខ្មែរក្រហមបង្គាប់ឲ្យទៅក្បាលថ្នល់ និងច្បារអំពៅ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣២ដល់៣៣ (នៅវត្តអង្គក្តួច អង្គការបានប្រាប់យើងថា យើងមិនបាច់បន្តដំណើរទៅណាទៀតទេ គឺត្រឡប់ទៅភូមិកំណើតយើងទៅ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៨ (ពេលទៅហួសស្ទឹងមានជ័យរាប់គីឡូម៉ែត្រ គាត់បានឮតាមរយៈមេក្រូថា ប្រជាជនអាចទៅស្រុកកំណើតរបស់ខ្លួនបាន ប្រសិនបើចង់ទៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ឡេង ឯកសារ E3/5231 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00267730 (ខ្មែរក្រហមប្រាប់ប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញ ហើយត្រឡប់ទៅស្រុកកំណើតខ្លួនវិញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00556117 (នៅទីក្រុងភ្នំពេញ ពួកគេប្រកាសថា គ្រប់គ្នាត្រូវតែត្រឡប់ទៅតាមស្រុកកំណើតរៀងៗខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សេង ចុន ឯកសារ E3/5562 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00390284 (ទោះបីថាពេលដំបូង ពួកគេមិនបានប្រាប់ថាឲ្យទៅទីណា ប៉ុន្តែនៅពេលដែលគាត់មកដល់ច្រាំងទន្លេខាងកើត ពួកគេប្រកាសថាប្រជាជនត្រូវទៅភូមិកំណើតរបស់ខ្លួន) សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២១៨, ERN (ភាសាខ្មែរ) 00836295 (អនុសេនីយ៍ត្រី ណុប ថុល បញ្ជាក់ថា នៅពេលជម្លៀស ពួកគេជិះឡាន ប្រកាសប្រាប់ថា ទាំងអស់គ្នាត្រូវតែត្រឡប់ទៅភូមិកំណើតរបស់ខ្លួន លើកលែងតែអ្នកកើតនៅទីក្រុងភ្នំពេញដែលត្រូវនៅក្រោមបញ្ជារបស់អង្គការ)។

[១៤៤៥] **បាត់ដំបង៖** ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៦៤ ដល់៦៥ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២០-២១ (កងទ័ពម្នាក់បានប្រាប់គាត់ថា គាត់ត្រូវដើរទៅទៀត ដូច្នេះគាត់ក៏ បន្តដំណើរសំដៅទៅរកទិសភូមិកំណើតរបស់គាត់ នៅក្នុងខេត្តព្រៃវែង)។

បានទៅតាំងទីលំនៅនៅតាមតំបន់ជនបទក្នុងភូមិភាគផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ នៅគ្រប់ទីកន្លែងក្នុងប្រទេស ដូចជា ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងខេត្តតាកែវ[១៤៤៦] ។

---

[១៤៤៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន សែម ឯកសារ E3/5286 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00316510 (ឃើញប្រជាជនមកពីទីក្រុងភ្នំពេញ មករស់នៅភ្នំស្រុក ខេត្ត បាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុយ ហ៊ុយ ឯកសារ E3/5283 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ៣ ERN(ភាសាខ្មែរ) 00295942(ឃើញគ្រួសារប្រជាជនថ្មីរាប់រយគ្រួសារមកពីទីក្រុងភ្នំពេញ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហៀក ណារ៉េន ឯកសារ E3/5376 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00477266 (អស់រយៈពេល បី បួន ខែ ទើបពួកយើងបានធ្វើដំណើរដល់បាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ ហុច ឯកសារ E3/5270 ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00279129 (មានបីបួនគ្រួសារមកពីទីក្រុងភ្នំពេញ មករស់នៅក្នុងផ្ទះរបស់គាត់)។ **កំពង់ចាម៖** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុក ហឿន ឯកសារ E3/5256 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00243079 (អ្នកត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ មកដល់ភូមិរបស់គាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាយ គីមហួន ឯកសារ E3/5257 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00243101 (អ្នកត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញមកដល់ខេត្តកំពង់ចាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម គីមសាន ឯកសារ E3/5528 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ 2 ERN (ភាសាខ្មែរ) 00418590 (សាច់ញាតិរបស់គាត់ដែលត្រូវបានជម្លៀស បានមកដល់ភូមិរបស់គាត់ក្នុងខេត្តកំពង់ចាម) **កំពង់ឆ្នាំង៖** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ដៃ យឹន ឯកសារ E3/4824 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤ ERN (ភាសាខ្មែរ) 00523380 (ពួកគាត់ដើរអស់រយៈពេល២ខែ ទើបមកដល់ភូមិថ្នល់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ លឿ ឯកសារ E3/5233 ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00269049 (ឃើញអ្នកដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញមករស់នៅតាមភូមិផ្សេងៗគ្នា នៅក្រាំងល្វារ ខេត្តកំពង់ឆ្នាំង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុក ផូ ឯកសារ E3/4633 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00407742 (អ្នកដែលត្រូវបានជម្លៀសជាច្រើនមកពីទីក្រុងភ្នំពេញ មករស់នៅត្បែងខ្ពស់ ខេត្តកំពង់ឆ្នាំង ក្រោយថ្ងៃ១៧ ខែ មេសា)។ **កំពង់ស្ពឺ៖** ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤៧-៤៩ (ទៅភូមិថ្នល់ដាច់)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុត សែម ឯកសារ E3/4654 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00390313 (ជាអតីតទាហាន លន់ នល់ ដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យទៅអ្នកលឿង គាត់ និងភរិយារបស់គាត់រស់នៅអស់រយៈពេលមួយខែ នៅតាមភូមិនានា ក្នុងឃុំក្រាំងអំពិល ខេត្តកំពង់ស្ពឺ)។ **កំពង់ធំ៖** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ២ ERN (ភាសាខ្មែរ) 00239906 (ជាមេភូមិ ព្រៃស្រង៉ែ ក្នុងឆ្នាំ ១៩៧៥ គាត់បានឲ្យអ្នកភូមិជួយអ្នកដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ដែលគេស្គាល់ថាជា "ពួក ១៧ មេសា" ឬ "ពួកថ្មី")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ជី ឯកសារ E3/5265 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00271396 (ឃើញប្រជាជន ១៧ មេសា មកពីទីក្រុងភ្នំពេញ មករស់នៅក្នុងភូមិ

ជ័យមង្គល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត សេង ឯកសារ E3/5267 ចុះថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00271403 (ត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ គាត់ទៅរស់នៅភូមិកងសៅ)។ **កំពត៖** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខៀវ រុន ឯកសារ E3/4750 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00484823 (ធ្វើដំណើរទៅឃុំ ក្នុងខេត្តកំពត)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00375523 (ចាកចេញពីទីក្រុងភ្នំពេញ ហើយធ្វើដំណើរដល់កៀនស្វាយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ភន ឯកសារ E3/5499 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00368658 (ប្រជាជន ១៧ មេសា មករស់នៅក្នុងឃុំ ត្នោតចាង ស្រុកអង្គជ័យ)។ **កណ្តាល៖** ប្រតិចារិក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ២០-២១ (គាត់ និងគ្រួសាររបស់គាត់បានមកដល់ឈើខ្មៅ ក្នុងខេត្តកណ្តាល)។ ប្រតិចារិក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហ៊ូ ចន្ថា) ទំព័រ ៥៦ (ធ្វើដំណើរទៅភូមិពុកឬស្សី)។ ប្រតិចារិក ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៩-១១, ១៤-១៥, ២១-២២។ ប្រតិចារិក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ទំព័រ ៧៩-៨១ (មកដល់ទូកវិលក្រោយមួយថ្ងៃ)។ ប្រតិចារិក ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៣-៣៤ (គ្រួសាររបស់គាត់ទៅស្រុកកៀនស្វាយ)។ ប្រតិចារិក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (យិន វំដួល) ទំព័រ ៥៩ (គាត់ និងគ្រួសាររបស់គាត់ទៅកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល)។ ប្រតិចារិក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨២, ទំព័រ ៩២-៩៤ (ដើររហូតដល់ពួកគាត់មកដល់ស្រុកកំណើតរបស់ ប៉ូ ឌីណា គឺភូមិកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល)។ **ព្រៃវែង៖** ប្រតិចារិក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ២៧-២៩, ទំព័រ ៣០-៣២ (គាត់ និងគ្រួសាររបស់គាត់បានទៅឃុំព្រែកញ្ចៀ ស្រុកព្រែកញ្ចៀ ខេត្តព្រៃវែង)។ ប្រតិចារិក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ (នូវ ហ៊ាន់) ទំព័រ ២០-២១ (ទៅដល់ភូមិកំណើតរបស់គាត់ នៅព្រៃវែង)។ ប្រតិចារិក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ (អែម អឿន) ទំព័រ ៦២-៦៣ (ក្នុងឆ្នាំ ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីនេះ បានឃើញអ្នកត្រូវបានជម្លៀសជាច្រើនមកពីទីក្រុងភ្នំពេញ មកដល់តំបន់២០ (ព្រៃវែង) ជាកន្លែងដែលគាត់រស់នៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ម៉ោង រ៉េត ឯកសារ E3/5592 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00422464 (ប្រជាជនជាច្រើនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ បានមកដល់ភូមិរបស់គាត់ គឺភូមិឡឹក ស្រុកព្រះស្តេច ខេត្តព្រៃវែង)។ **ពោធិ៍សាត់៖** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឌុក ទី ឯកសារ E3/4751 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00484851 (ចាកចេញពីទីក្រុងភ្នំពេញទៅឃុំមួយក្នុងខេត្តពោធិ៍សាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00273426 (ជាអតីតទាហាន លន់ នល់ បានចាកចេញពីទីក្រុងភ្នំពេញ ហើយមកដល់ឃុំព្រៃតោ ស្រុកបាកាន ខេត្តពោធិ៍សាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហុង សាវ៉ាត ឯកសារ E3/5591 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ)00418447 (គ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់)។ **ស្វាយរៀង៖**ប្រតិចារិក ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊្វ សុទ្ធាវី) ទំព័រ ៨-៩, ទំព័រ ២០ (ធ្វើដំណើរទៅវត្តចំប៉ា ស្រុកគគីរ មុនពេលបន្តរដំណើរទៅមុខ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00398494 (បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានត្រឡប់មកស្រុកកំណើតរបស់គាត់ នៅភូមិតាណ ឃុំ

### ១០.២.១០ បន្ទាប់ពីរយៈពេល៣ថ្ងៃ

៤៨៦. បន្ទាប់ពីរយៈពេល៣ថ្ងៃដំបូងបានកន្លងផុតទៅ[១៤៤៧] គ្មានការប្រកាសឲ្យត្រឡប់មកទីក្រុងភ្នំពេញវិញនោះទេ ផ្ទុយទៅវិញអ្នកដែលត្រូវជម្លៀស ត្រូវបានប្រាប់ឲ្យបន្តស្នាក់នៅតទៅទៀត[១៤៤៨]។

---

ស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម សាម៉ុន ឯកសារ E3/5260 ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00250705 (សង្កេតឃើញថា ប្រជាជនមកពីស្វាយរៀង និងភ្នំពេញ បានមកដល់ភូមិរបស់គាត់ ហើយផ្ទះធំៗ ត្រូវតែទទួលយកប្រជាជន១៧មេសា ឲ្យស្នាក់នៅជាមួយពួកគេ)។ **តាកែវ៖** ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៤០-៤១ (បានមកដល់ស្រុកបាទី ឃុំត្រពាំងសាប ខេត្តតាកែវ)។ ប្រតិចារឹក ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៩ (គាត់ និងគ្រួសាររបស់គាត់បានមកដល់ពោធិ៍បាន ភូមិលេខ៥ ជាកន្លែងដែលពួកគាត់ត្រូវស្នាក់នៅរហូតដល់ដើមឆ្នាំ ១៩៧៦)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ ២៨ (សាច់ញាតិរបស់គាត់នៅទីក្រុងភ្នំពេញ ត្រូវបានជម្លៀសទៅភូមិកំណើតរបស់ពួកគេនៅស្រុកត្រាំកក់ ខេត្តតាកែវ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សេន ផាប់ ឯកសារ E3/5391 ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479075 (ទៅខេត្តតាកែវ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00484908 (ដើររហូតដល់ពួកគាត់ទៅដល់កន្លែងមួយដែលមិនធ្លាប់ស្គាល់ នៅជាប់ព្រំដែនវៀតណាមខាងត្បូង គឺ ព្រះបាទជាន់ជុំ ស្រុកគីរីវង្ស ខេត្តតាកែវ)។

[១៤៤៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៥។

[១៤៤៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ទំព័រ ៨៥-៨៧ (៣ថ្ងៃក្រោយ ម្តាយរបស់គាត់បានសួរកងទ័ពម្នាក់ ហើយគេប្រាប់គាត់ឲ្យបន្តដំណើរទៅភូមិកំណើតរបស់គាត់), ទំព័រ ៨៩-៩០ (៣ថ្ងៃក្រោយមក មិនមានការប្រកាសឲ្យប្រជាជនត្រឡប់មកទីក្រុងភ្នំពេញវិញនោះទេ មានតែការប្រកាសឲ្យប្រជាជន ត្រឡប់ទៅភូមិកំណើតរៀងៗខ្លួនប៉ុណ្ណោះ)។ ប្រតិចារឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៣៥-៣៦, ទំព័រ ៦៧, ទំព័រ ៨១-៨២ (បន្ទាប់ពី៣ថ្ងៃដំបូងបានកន្លងផុតទៅ នៅពេលមានការសាកសួរ កម្មាភិបាលខ្មែរក្រហមម្នាក់បានប្រាប់ជីដូនជីតារបស់ ជុំ សុខា ថាពួកគាត់ត្រូវតែចាកចេញ ៧ ថ្ងៃ ពីព្រោះអង្គការមិនទាន់បោសសម្អាតទីក្រុងរួចរាល់នៅឡើយ ហើយពួកគាត់ត្រូវបានបញ្ជាឲ្យត្រឡប់ទៅភូមិកំណើតរបស់ពួកគាត់ គឺមិនមែនត្រឡប់ទៅទីក្រុងនោះទេ។ បន្ទាប់ពីរយៈពេល៧ថ្ងៃកន្លងទៅ ជីដូនជីតារបស់ ជុំ សុខា បានសួរម្តងទៀត ប៉ុន្តែពួកគាត់មិនត្រូវបានឲ្យត្រឡប់មកទីក្រុងវិញនោះទេ ពួកគាត់ត្រូវបានអនុញ្ញាតិឲ្យទៅភូមិកំណើតរបស់ខ្លួន)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៨ (នៅជិតស្ទឹងមានជ័យ មុនដល់ចំការដូង គាត់បានឮគេប្រកាសថា ប្រជាជនអាចផ្លាស់ទីទៅស្រុកកំណើតរបស់ខ្លួន ប៉ុន្តែមិនអនុញ្ញាតិឲ្យត្រឡប់ក្រោយនោះទេ)។*សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១៤-១៥ (បន្ទាប់ពីរយៈពេល៣ថ្ងៃ ពួកយើងមិនដែលទទួលបានព័ត៌មានអ្វីពីការត្រឡប់ទៅវិញនោះឡើយ)។

អ្នកដែលត្រូវបានជម្លៀសចង់ត្រឡប់មកភ្នំពេញវិញត្រូវបានគម្រាម ហើយប្រាប់ឱ្យបន្តដំណើរទៅមុខ[១៤៤៩]។ អ្នកដែលរឹងទទឹងព្យាយាមត្រឡប់មកភ្នំពេញវិញត្រូវបានបាញ់សម្លាប់ចោល[១៤៥០]។

៤៨៧. ហេតុដូច្នេះទើបអ្នកដែលត្រូវបានជម្លៀសបន្តធ្វើដំណើរទៅមុខក្នុងរយៈពេលជាច្រើនថ្ងៃនិងច្រើនសប្តាហ៍[១៤៥១]។ លក្ខខណ្ឌជាច្រើននៅពេលធ្វើដំណើរមានភាពលំបាកវេទនា ហើយភាគច្រើន

---

[១៤៤៩] ប្រតិចារឹក ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល)ទំព័រ ១៧-១៨ (ឃើញកងទ័ពខ្មែរក្រហម ឃាត់មនុស្ស៣នាក់ដែលដើរត្រឡប់ក្រោយទៅភ្នំពេញក្នុងពេលជម្លៀស ហើយប្រាប់ពួកគេថា ប្រសិនបើដើរចេញពីខ្សែរគំនូស ពួកគេនឹងត្រូវសម្លាប់)។

[១៤៥០] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៧-៧៨ (ត្រូវបានប្រាប់ថា សាកសពដែលពួកគាត់ឃើញនៅតាមផ្លូវ ត្រូវបានបាញ់ ព្រោះអ្នកទាំងនោះចង់ត្រឡប់ក្រោយវិញ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៣-២៤ (ទាហាននិយាយថា ប្រជាជនដែលត្រូវបានជម្លៀសត្រូវបន្តដំណើរទៅមុខ ហើយប្រសិនបើពួកគេត្រឡប់ក្រោយ ពួកគេនឹងត្រូវសម្លាប់។ គាត់ឮសូរស្នូរកាំភ្លើង)។

[១៤៥១] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៧៩-៨១ (មកដល់កោះទឹកវិល៣ថ្ងៃក្រោយមក)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១២-១៣, ទំព័រ ១៥-១៦ (បន្ទាប់ពីបីថ្ងៃ មុម សំអឿន និងគ្រួសាររបស់គាត់ បានមកដល់ឃុំ សំរោង ដែលមានចម្ងាយប្រហែល ៤0 គីឡូម៉ែត្រពីភ្នំពេញ ហើយពួកគាត់ស្នាក់នៅទីនោះប្រហែល ២ យប់ មុនពេលគេបញ្ជាឱ្យទៅព្រែកគយដែលមានចម្ងាយប្រហែល ១០ ទៅ ២០ គីឡូម៉ែត្រ ពីសំរោង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៧៤-៧៥ (អ្នកដែលត្រូវបានជម្លៀសចំណាយពេលរាប់ថ្ងៃទម្រាំទៅដល់ទីដៅរបស់ពួកគេ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤០-៤១ (ធ្វើដំណើរដោយថ្មើជើងអស់ដប់ថ្ងៃ ទើបទៅដល់ស្រុកបាទី ឃុំត្រពាំងសាប ខេត្តតាកែវ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦០-៦១ (បន្តដំណើរជាមួយគ្រួសាររបស់គាត់តាមផ្លូវជាតិលេខ៣ អស់ ៥ ទៅ ៦ ថ្ងៃ ទើបទៅដល់ស្ទឹងកំពង់ទួល), ទំព័រ ៦៩ (ពួកគាត់ចំណាយពេលមួយខែទើបទៅដល់ពោធិ៍បានភូមិលេខ៥ ដែលនៅទីនោះពួកគាត់ស្នាក់នៅរហូតដល់ដើមឆ្នាំ ១៩៧៦)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ២០-២១ (ដប់ថ្ងៃ, គាត់ និងគ្រួសាររបស់គាត់បានមកដល់ឈើខ្មៅ នៅថ្ងៃទី ២៧ ខែ មេសា)។ ប្រតិចារឹក ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣១-៣៣, ៣៤-៣៥ (ពួកគាត់បន្តដំណើរទៅទិសខាងត្បូង ហើយមកដល់ក្បាលថ្នល់ នៅថ្ងៃបន្ទាប់ ហើយពួកគាត់ត្រូវបានបង្គាប់ឱ្យធ្វើដំណើរទៅខាងកើតវិញ), ទំព័រ ៤៧-៤៩ (ត្រូវចំណាយពេលប្រហែល ១១ ថ្ងៃ ១១ យប់ ទើបទៅដល់ភូមិថ្នល់ដាច់ដែលពេលវេលានេះរួមបញ្ចូលទាំងពេលដែលពួកគាត់ត្រូវឈប់នៅតាមកន្លែងផ្សេងៗច្រើនទៀត)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ២៧-២៩, ទំព័រ ៣០-៣២ (គាត់ និងគ្រួសាររបស់គាត់ ត្រូវដើរ ១៥ ថ្ងៃ ទើបទៅដល់គោលដៅរបស់ពួកគាត់ គឺឃុំព្រែកខ្មៅ ស្រុកព្រែកខ្មៅ ខេត្តព្រៃវែង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហួ ចន្ថា) ទំព័រ ៥៦ (ការធ្វើដំណើរទៅភូមិពុកឫស្សី ត្រូវចំណាយពេល ១៥ ថ្ងៃ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៨-៩, ២០ (ធ្វើដំណើររហូតមកដល់វត្តចំប៉ា ក្នុងស្រុកគគីរ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥ ហើយគាត់ស្នាក់នៅទីនេះ ២ សប្តាហ៍ មុនពេលបន្តទៅមុខទៀត)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២០-២១

មានការខ្វះទាំងឧបករណ៍សាមញ្ញបំផុតសម្រាប់ដាំស្លផង[១៤៥២] ។ មនុស្សជាច្រើន មានស្បៀងអាហារ និងទឹកតិចតួច ឬ ក៏គ្មានសោះ[១៤៥៣] ។ មនុស្សជាច្រើនត្រូវបង្ខំឲ្យដោះដូរទ្រព្យសម្បត្តិរបស់ខ្លួន រួមទាំង សម្លៀកបំពាក់ ឬ ក៏ត្រូវសុំអាហារគេ[១៤៥៤] ដើររករុក្ខជាតិ បន្លែ និងចាប់សត្វល្អិតធ្វើជាអាហារ ហើយត្រូវផឹកទឹកមិនស្អាតនៅក្នុងស្រះ ឬ ត្រពាំងតាមផ្លូវដើម្បីរស់[១៤៥៥]។

---

(ចំណាយពេលប្រហែលមួយខែ ទើបទៅដល់ភូមិកំណើតរបស់គាត់នៅក្នុងខេត្តព្រៃវែង)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣៨-៣៩, ៨៥-៨៦ (ធ្វើដំណើរប្រហែលមួយខែ ទើបទៅដល់ភូមិកំណើតរបស់ឪពុកគាត់)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ  បូនី) ទំព័រ ៧ (ការធ្វើដំណើររបស់ពួកគាត់ចំណាយពេលអស់ប្រហែលមួយខែ)។

[១៤៥២] ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី), ទំព័រ ៨៧-៩០ ប្រតិចារឹក (នៅតាមផ្លូវ នៅប៉ែកខាងកើតនៃទន្លេ ស្ថានភាពមានការលំបាកខ្លាំង។ ក្រុមគ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីខ្វះខាតសព្វគ្រប់ តាំងពីអាហារ និងស្ងួម្បីតែចានឆ្នាំង ហើយពួកគាត់រស់មួយថ្ងៃ សម្រាប់មួយថ្ងៃ ដោយសង្ឃឹមថាស្ថានភាពនឹងមិនបន្តយូរឡើយ)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា), ទំព័រ ៨២-៨៣ (ពួកគាត់មិនមានម្ហូបអាហារ ឬ សូម្បីតែស្លាបព្រា ឬ ចាន ឆ្នាំង នៅតាមផ្លូវ ហើយការរស់នៅ គឺវេទនាណាស់)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន), ទំព័រ ៩-១០ (គាត់និងគ្រួសាររបស់គាត់ ដោះដូរទំនិញជាមួយឆ្នាំងដាំបាយ)។

[១៤៥៣] ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៣៦-៣៧, ៣៨-៣៩ (ក្នុងខែដែលពួកគាត់ធ្វើដំណើរនោះ ពួកគាត់ត្រូវស្វះស្វែងរកទឹកស្អាតដើម្បីផឹក និងដាំបាយ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២-៨៣ (ប្អូនៗរបស់គាត់យំ ដោយសារតែពួកគេឃ្លាន ហើយម្ដាយរបស់គាត់អង្វរពួកគេឲ្យអត់ទ្រាំ រហូតដល់ពេលទៅដល់ភូមិកំណើត)។ ប្រតិចារឹកថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល), ទំព័រ ១៩-២០ (ពេលដែលអាហារដែលពួកគាត់បានយកតាមសម្រាប់រយៈពេល៣ថ្ងៃជិតអស់នោះ ពួកគាត់ដាំតែបបរដើម្បីសន្សំអង្ករទុកខ្លះ)។ ប្រតិចារឹកថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគឹម ល្មុត), ទំព័រ ៥-៨ (នៅក្នុងសហករណ៍ទីមួយដែលគាត់បានទៅដល់ មិនមានការរៀបចំត្រឹមត្រូវសម្រាប់ឲ្យប្រជាជនមានអាហារគ្រប់គ្រាន់នោះទេ គឺគ្រួសារទាំងអស់ត្រូវស្វែងរកអាហារសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ខ្លួនដោយខ្លួនឯង)។ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន), ទំព័រ ១១, ១៣-១៤ (ត្រឹមថ្ងៃ ១៩ ខែ មេសា គ្រួសាររបស់គាត់មិនមានម្ហូបអាហារផ្ទាល់ខ្លួនសម្រាប់បរិភោគទេ។ នៅថ្ងៃទី ២០ ខែ មេសា ពួកគាត់ទទួលបានអាហារពីម្ចាស់ផ្ទះនៅមូលដ្ឋាននោះ)។ ប្រតិចារឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ (យឹម សុវណ្ណ),ទំព័រ ៦១-៦២ (គ្មានលុយ គ្មានអាហារ គ្មានទឹកនៅតាមផ្លូវទេ)។

[១៤៥៤] ប្រតិចារឹកថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៨០-៨១ (បានសុំពោតពីប្រជាជនមូលដ្ឋាន ដោយដោះដូរជាមួយរបស់របរខ្លះដែលគាត់មាន)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា), ទំព័រ ៣៥-៣៦ (ត្រូវដោះដូរមាស និងគ្រឿងអលង្ការ ជាមួយអាហារ និងវត្ថុមួយចំនួនដែលចាំបាច់ដើម្បីរស់)។ ប្រតិចារឹកថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី), ទំព័រ ៤៥-៤៦ (ក្នុងអំឡុងពីរបីខែដំបូង ពួកគាត់ត្រូវដោះដូររបស់របរជាមួយអាហារដើម្បីរស់)។ ប្រតិចារឹកថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ), ទំព័រ ៧៣-៧៤ (ប្រជាជនត្រូវឈប់កណ្ដាលផ្លូវ ដើម្បីដោះដូរសម្លៀកបំពាក់ជាមួយអាហារខ្លះៗ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ

៤៨៨. អ្នកដែលត្រូវបានជម្លៀស ត្រូវបានបង្ខំឱ្យសង់ជម្រកស្នាក់នៅជាបណ្ដោះអាសន្ននៅតាមផ្លូវ។ ពួកគេស្នាក់នៅកន្លែងផ្សេងៗគ្នានៅតាមចិញ្ចើមផ្លូវ នៅក្នុងផ្សារដែលគ្មានមនុស្ស នៅតាមក្លោងទ្វារវត្ត នៅផ្ទះដែលគេបោះបង់ចោល ឬ ពេលខ្លះស្នាក់នៅក្រោមដើមឈើ[១៤៥៦]។ បន្ទាប់ពី

---

១៧៣ ERN (ភាសាខ្មែរ) 00836250 (ប៉ុក សារិត បញ្ជាក់ថា ពួកគាត់អាចនៅរស់បាន ដោយការដោះដូរសម្ភារៈរបស់ខ្លួនជាមួយអង្ករ ក្នុងរយៈពេល ៦ ខែក្រោយ) ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឈឹម គង់ ឯកសារ E3/4917 ចុះគ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00544534 (ពួកគាត់ដោះដូរសម្លៀកបំពាក់ ឬសម្ភារៈដែលខ្លួនមាន ជាមួយអង្ករដើម្បីបន្តជីវិតក្នុងពេលធ្វើដំណើរ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៨ ERN (ភាសាខ្មែរ) 00865603 (នៅពេលដែលពួកគាត់អស់អាហារ ពួកគាត់ត្រូវដោះដូរសម្លៀកបំពាក់ជាមួយអង្ករ ឬក៏សុំអង្ករពីអ្នកភូមិដែលខ្លួនឆ្លងកាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (ដោយសារតែមិនមានអ្វីទទួលទាននៅតាមផ្លូវ ពួកគាត់ត្រូវសុំអាហារគេទទួលទាន)។

[១៤៥៥] ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៣៦-៣៧ (ប្រសិនបើពួកគាត់រកទឹកទទួលទាន ឬសម្រាប់ដាំបាយមិនបាន ពួកគាត់ត្រូវតែស្វែងរកត្រពាំង ឬបឹងនៅក្បែរ ដើម្បីអាចយកទឹកមកប្រើប្រាស់)។ ប្រតិចារឹកថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០១២ (មុម សំអឿន),ទំព័រ ១១ (រម្លឹកពីការដែលគាត់ និងគ្រួសាររបស់គាត់ដើរបេះបន្លែព្រៃយកមកធ្វើជាម្ហូប)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា), ទំព័រ ៥៦ (គាត់ស្រេកទឹកយ៉ាងខ្លាំងនៅថ្ងៃទីពីរ បន្ទាប់ពីជម្លៀស ដូច្នេះគាត់ផឹកទឹកក្នុងត្រពាំង បើទោះបីជាទឹកនោះធុំក្លិនអាក្រក់ ហើយមើលទៅមិនស្អាតក៏ដោយ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ), ទំព័រ ៦៨-៦៩ (មានទឹកតិចតួច ដូច្នេះពួកគាត់ត្រូវបង្ខំផឹកទឹកត្រពាំង)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ អតីតឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499664 (ដើម្បីរស់ ប្រជាជនត្រូវទទួលទានសម្ពន្ធរុំពីរុក្ខជាតិ ធាងដើមចេកកាត់ជាដុំៗ និង ឫស)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ថាច់ យ៉ុង ឯកសារ E3/5427 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00483321 (ម្ដាយពួកគាត់ត្រូវដើររកបន្លែ និងស្លឹកឈើដើម្បីស្លរហូប ព្រោះពួកគាត់អស់អង្ករ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុត ណារី ឯកសារ E3/4921 ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00586773 (ឪពុកម្ដាយលោកស្រីត្រូវចិញ្ចឹមគ្រួសារយ៉ាងលំបាកជាមួយឫសរុក្ខជាតិ សត្វល្អិត ឬ ការបរបាញ់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សេង ចុន ឯកសារ E3/5562 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00390284 (ពេលស្រេកទឹកយើងត្រូវទទួលទានទឹកតាមត្រពាំងដែលមិនស្អាត)។

[១៤៥៦] ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៣៦-៣៧, ៨១-៨៣ (ពួកគាត់សម្រាកនៅតាមផ្លូវ ឬនៅខ្លោងទ្វារវត្ត ឬពេលខ្លះនៅក្រោមដើមឈើ។ មិនមានអ្នកណាប្រាប់ឱ្យច្បាស់លាស់ថាត្រូវប្រមូលផ្ដុំ និងសម្រាកនៅទីណាឡើយ)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី), ទំព័រ ៨-៩ (តាមផ្លូវធ្វើដំណើរ ពួកគាត់ឈប់សម្រាកនៅក្នុងផ្ទះរបស់គ្រួសារចិនដែលគ្មានមនុស្សរស់នៅ)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៧-១៨ (គាត់ត្រូវសម្រាក់យប់ដំបូងនៅលើចិញ្ចើមផ្លូវ នៅស្ទឹងមានជ័យ ហើយអ្នកខ្លះសម្រាកនៅលើគ្រែក្នុងតូបផ្សារ ឯអ្នកខ្លះទៀតសម្រាកនៅលើថ្នល់តែម្ដង ដោយសារតែមិនមានចរាចរណ៍), ទំព័រ ២០ (ពួកគាត់យប់ត្រង់ណា

ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី និងកូនៗរបស់គាត់ត្រូវបានបណ្តេញឲ្យទៅនៅជាយភូមិត្រើយស្លា រួចមក ពួកគាត់បានសង់ជម្រកមួយធ្វើពីស្លឹកត្នោត និងមែកឈើ[១៤៥៧]។ ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា បានរៀបរាប់ថា មានព្រឹកមួយនោះ គាត់ដឹងថា ពួកគាត់បានទទួលទានដំណេកនៅក្បែរសាកសពមនុស្សម្នាក់ ដូច្នេះ ពួកគាត់ត្រូវតែរើទៅកន្លែងផ្សេងទៀត ដើម្បីស្នាក់នៅសម្រាប់យប់បន្ទាប់[១៤៥៨]។

---

សម្រាកនៅត្រង់នោះ ដោយប្រើស្លឹកឈើក្រាល ហើយសម្រាកលើនោះតែម្តង)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា), ទំព័រ ៨១-៨២ (ពួកគាត់សម្រាកនៅតាមផ្លូវ ហើយបន្តដំណើរទៅមុខដោយមិនដឹងថាត្រូវទៅទីណានោះឡើយ)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន), ទំព័រ ៩-១១ (បានរម្លឹកពីការដែលគាត់និងគ្រួសាររបស់គាត់ត្រូវសម្រាកនៅលើកម្រាលឥដ្ឋក្នុងវត្តមួយ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២-៨៣ (នៅពេលយប់ ដោយគិតថាពួកគាត់អាចដើរផ្លូវកាត់បាន ពួកគាត់សម្រាកផ្ទាល់ដី នៅកណ្តាលព្រៃមូសរោមខាំ)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00375523 (ពួកគាត់សម្រាកនៅក្នុងផ្ទះដែលគ្មានមនុស្ស ឬពេលខ្លះនៅក្រោមដើមឈើ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៨ ERN (ភាសាខ្មែរ) 00865603 (ពួកគាត់សម្រាកនៅលើដី)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ រយ ឯកសារ E3/4838 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ)00526054 (កន្លែងណាក៏ពួកគាត់សម្រាកបាន ពេលខ្លះនៅក្រោមដើមឈើ ហើយពេលខ្លះដែលមានភ្លៀងគាត់ឱបកូនៗ ទទឹកជោកទៅដោយទឹកភ្លៀង)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សេង ចុន ឯកសារ E3/5562 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00390284 (ពួកគាត់សម្រាកលើកម្រាលនៅតាមផ្លូវ ដោយគ្មានមុង ហើយត្រូវមូសខាំរាល់យប់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នង សារ៉ន ឯកសារ E3/4653 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00484386 (សម្រាកនៅតាមវាលស្រែ និងក្នុងវត្ត។ ចាស់ៗខ្លះដែលមិនអាចដើរបានត្រូវសម្រាកនៅតាមផ្លូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង មួង សុខន ឯកសារ E3/4681 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00323606 (ពួកគាត់ត្រូវដើរប្រហែលមួយខែ សម្រាកនៅតាមវាល នៅតាមផ្លូវ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00484908 (ពួកគាត់ដាំស្ល និងសម្រាកនៅតាមចិញ្ចើមផ្លូវ ដោយគ្មានគោលដៅ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ថាច់ យួង ឯកសារ E3/5427 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00483321 (ឪពុកគាត់បានសង់រោងមួយដោយយកកក់មកប្រក់ធ្វើជាដំបូល)។

[១៤៥៧] ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី), ទំព័រ ៩-១១។

[១៤៥៨] ប្រតិចារឹកថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា), ទំព័រ ៣៤។ *សូមមើលផងដែរ* សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៤២ ERN (ភាសាខ្មែរ) 00836119 (លោក សុខា ជាអ្នកត្រូវបានសម្ភាសន៍ បានបញ្ជាក់ថា គាត់ដើរបានត្រឹម ២ ទៅ ៣ គីឡូម៉ែត្រប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយសម្រាកនៅតាមចិញ្ចើមផ្លូវ

### ១០.២.១១ អំពើហិង្សាដែលបានទទួលរង

៤៨៩. ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀស ភាគច្រើនបានជួបប្រទះការភ័យខ្លាច និង ការគម្រាមកំហែង ឬ ក៏ហេតុការណ៍អំពើហិង្សាផ្សេងៗពីសំណាក់កងទ័ពខ្មែរក្រហម។ ភ័ស្តុតាងមួយចំនួនបង្ហាញថា អ្នកដែលត្រូវបានជម្លៀសខ្លះត្រូវបានភ្ជង់កាំភ្លើងឲ្យដើរទៅមុខក្នុងចម្ងាយមួយ[១៤៥៩] ហើយអ្នកខ្លះទៀតត្រូវបានពួកខ្មែរក្រហមវាយធ្វើបាប[១៤៦០] ។ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី បានផ្តល់សក្ខីកម្មពីការរំលោភផ្លូវភេទលើមិត្តភ័ក្តិរបស់គាត់ម្នាក់[១៤៦១]។

៤៩០. មានព្រឹត្តិការណ៍ជាច្រើនទៀតដែលកងទ័ពខ្មែរក្រហមបានបាញ់ និងសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលជម្លៀស ដែលជនរងគ្រោះទាំងនោះរួមមានទាំងតារាភាពយន្តល្បីៗ មនុស្សជាច្រើននាក់ដែលបើកបរយានយន្ត និងសូម្បីតែមនុស្សដែលខ្សោយកម្លាំងខ្លាំងមិនអាចបន្តដំណើរទៅមុខបានក៏

---

នៅលើសាកសពដែលគេទើបតែកប់ហើយថ្មីៗ ហើយមានម្តងនោះពេលដែលគាត់កំពុងតែងូតទឹកទន្លេ មានមនុស្សស្រែក ហើយរត់ចេញពីទឹក ដោយសារតែមានសាកសពមួយអណ្តែតក្នុងទឹកទន្លេ តែគាត់មិនខ្វល់ពីសាកសពអណ្តែតទឹកនេះទេ ហើយគាត់បន្តមុជទឹកទៀត)។

[១៤៥៩] ប្រតិចារឹកថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី), ទំព័រ ២៧-២៨ (គាត់ និងឪពុកម្តាយរបស់គាត់ ព្រមទាំងបងប្អូន៤នាក់ទៀត ត្រូវបានភ្ជង់កាំភ្លើងបង្ខំឲ្យធ្វើដំណើរពីតាមបណ្តោយផ្លូវមុនីវង្ស រហូតមកដល់ស្ពានក្បាលថ្នល់ ហើយឆ្លងទៅផ្លូវជាតិលេខ១)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី វៀម ឯកសារ E3/4980 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00554819 (ពួកគាត់ធ្វើដំណើរដោយថ្មើរជើង ដោយមានពួកកងទ័ពខ្មែរក្រហមតាមពីក្រោយ ហើយពួកនោះជាញឹកញាប់មានការបាញ់កាំភ្លើងដើម្បីគម្រាម និងបង្ខំពួកគាត់ឲ្យបន្តដំណើរ)។

[១៤៦០] ប្រតិចារឹកថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០១២(យឹម សុវណ្ណ), ទំព័រ៥៧-៥៨ (នៅខាងមុខវត្តព្រះពុទ្ធ គាត់ឃើញកងទ័ពខ្មែរក្រហម វាយមនុស្សនឹងកាំភ្លើង)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី), ទំព័រ ៧៧-៧៩ (បានឃើញកងទ័ពខ្មែរក្រហមម្នាក់ វាយបុរសម្នាក់ដោយកាំភ្លើងចំកណ្តាលខ្នង ដោយបុរសនោះបានលុតជង្គង់អង្វរសុំត្រឡប់ទៅរកកូនរបស់គាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (បានរម្លឹកពីការដែលកងទ័ពខ្មែរក្រហមក្មេងៗបីបួននាក់ ប្រដាប់ដោយកាំភ្លើងអាកា៤៧ និង បេ៤០ ចំនួន២ដើម បានស្រែកដាក់គាត់ឲ្យគាត់ទៅ មុនពេលដែលពួកគេទាត់គាត់ និងវាយគាត់នឹងស្នាយកាំភ្លើងរហូតដល់គាត់សន្លប់។ គាត់ដឹងខ្លួនវិញនៅថ្ងៃបន្ទាប់ ហើយក៏បន្តដើរទៅទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (អ្នកណាដែលប្រកែកមិនព្រមចាកចេញ ត្រូវគេវាយនឹងកាំភ្លើង)

[១៤៦១] ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី), ទំព័រ ៨-១០ (គាត់បានជួបមិត្តម្នាក់នៅវត្តនិរោធ ដែលប្រឡាក់ជោគទៅដោយឈាម ហើយមិត្តម្នាក់នេះបានប្រាប់គាត់ថា ខ្លួនត្រូវបានគេរំលោភ ហើយវាយធ្វើបាប ដោយគេស៊កផ្លែគ្រាប់ចូលទៅក្នុងរន្ធគូទ) ។ *សូមប្រៀបធៀបជាមួយនឹង* ប្រតិចារឹកថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៤៥-៤៦ (មិនដែលឮពីការបំពារបំពានផ្លូវភេទលើស្ត្រីក្នុងពេលជម្លៀសនោះទេ)។

ត្រូវបានបាញ់សម្លាប់ផងដែរ[១៤៦២]។ ឆេង អេងលី បានរម្លឹកថា គាត់បានឃើញកងទ័ពខ្មែរក្រហមម្នាក់ចាប់ហែកទារកម្នាក់ដែលកំពុងយំ ហើយវារលើសាកសពម្ដាយនៅលើស្ពានមុនីវង្ស[១៤៦៣]។

---

[១៤៦២] ឧទាហរណ៍ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ), ទំព័រ ៦០-៦១, ៦២-៦៣ (ឃើញកងទ័ពខ្មែរក្រហមបាញ់អ្នកបើកបរឡានម្នាក់ស្លាប់)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស), ទំព័រ ៤-៥ (បានឮសូរកាំភ្លើង ហើយឃើញបុរសម្នាក់ត្រូវបានសម្លាប់)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល), ទំព័រ ៤៦-៤៧ (ឃើញកងទ័ពខ្មែរក្រហមបាញ់អ្នកបើកឡាន GMC ម្នាក់នៅវត្តចិនដំដែក ដោយបុរសម្នាក់នោះអង្គុយនៅកៅអីអ្នកបើកបរ)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន), ទំព័រ ១២-១៣ (បានឃើញគេបាញ់មនុស្សនៅតាមផ្លូវ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៧៥-៧៦ (កងទ័ពខ្មែរក្រហមបាញ់ជនស៊ីវិល នៅពេលដែលជនស៊ីវិលទាំងនោះព្យាយាមចូលទៅក្នុងឃ្លាំងយកអង្ករ។ មានអ្នកស្លាប់ និងអ្នករបួសយ៉ាងច្រើន)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ មាស សារ៉ាន់, ឯកសារ E3/3966, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨, ទំព័រ ៤ ERN (ភាសាខ្មែរ) 00362176 (ឃើញមនុស្សជាច្រើនត្រូវបានគេសម្លាប់ដោយមិនដឹងមូលហេតុនៅតាមផ្លូវ)។ ទម្រង់បែបបទព័ត៌មាន ជនរងគ្រោះ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ៣ ERN (ភាសាខ្មែរ) 00541003 (នៅមន្ទីរពេទ្យព្រះអង្គឌួង ដែលឪពុករបស់គាត់ជាវេជ្ជបណ្ឌិត ពួកកងទ័ពខ្មែរក្រហមផ្ដាច់ទុយោសេរ៉ូមពីអ្នករបួស ហើយបានសម្លាប់អ្នកជំងឺមួយចំនួននៅលើគ្រែពេទ្យយ៉ាងសាហាវឃោរឃៅ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ គង់ ណារិន ឯកសារ E3/4773 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00496951 (ឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់មនុស្ស ៦ នាក់ ប៉ុន្តែមិនដឹងថាដោយសារហេតុអ្វីនោះទេ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សី នង ប៊ុណ្ណា, ឯកសារ E3/5131, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ២ ERN (ភាសាខ្មែរ) 00165226 (នៅខាងក្រៅវត្ត ពួកគេបាញ់សម្លាប់មនុស្ស)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ កែវ ឆែម, ឯកសារ E3/5407 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480203 (ក្នុងពេលជម្លៀស គាត់ឃើញខ្មែរក្រហមបង្ខំ បាញ់សម្លាប់ ហើយកាប់សម្លាប់តាមចិត្ត)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២៤ ERN (ភាសាខ្មែរ) 00836101 (ក្នុងពេលមួយដែលមិនចាំពីកាលបរិច្ឆេទ បុគ្គលិកក្រុមហ៊ុនជាតិ អាហរ័ណ នីហរ័ណ (សូណិចស៊ីម)បញ្ជាក់ថា ខ្មែរក្រហមបានកាត់ក្បាលលោក គង់ សាវួន ដែលជាតារាភាពយន្តល្បី ហើយទុកសាកសពគាត់នៅលើថ្នល់។ គ្មាននរណាហ៊ានយកសាកសពគាត់ចេញទេព្រោះខ្លាចការសងសឹក) ទំព័រ ១៧៩ ERN (ភាសាខ្មែរ) 00836256 (នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៦ លោក ពេជ្រ លឹមកុង បានបញ្ជាក់ថា អ្នកជំងឺធ្ងន់ធ្ងរនៅក្នុងមន្ទីរពេទ្យ ត្រូវបានគេសម្លាប់នៅក្នុងមន្ទីរពេទ្យ ចំណែកជនពិការត្រូវបានគេដឹកតាមឡានធំៗ យកទៅចោល ហើយកប់នៅតាមរណ្ដៅទម្លាក់គ្រាប់បែក)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484907 (ពួកខ្មែរក្រហមដែលយាមស្ពានក្បាលថ្នល់នៅផ្នែកខាងលិច បានហាមប្រជាជនមិនឲ្យឆ្លងស្ពាន ហើយពួកវាបាញ់សម្លាប់អ្នកណាដែលហ៊ានហែលឆ្លងទន្លេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (អ្នកខ្លះត្រូវពួកវាច្រាន ឬ ចាប់ទាញទម្លាក់មកដីឲ្យស្លាប់យ៉ាងអាណោចអាធម្ម។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ លី រៀម ឯកសារ E3/4980 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00554819 (ក្នុងពេលធ្វើដំណើរពីភូមិកំណើតនៅជាយ

01006731



ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ បានរម្លឹកថា គាត់បានឃើញកងទ័ពខ្មែរក្រហមបាញ់ទម្លុះទ្វារដែលជាប់សោរ ហើយបន្ទាប់មកបានបាញ់ទៅលើមនុស្សដែលចេញពីក្នុងផ្ទះនៅម្តុំផ្សារអូរឫស្សី[១៨៦៤]។ ជនរងគ្រោះម្នាក់ទៀត បានរៀបរាប់ពីការដែលគាត់កំពុងតែរុញរទេះដឹកប្តីគាត់ ដែលជាអតីត

---

ក្រុងភ្នំពេញ ទៅគីរីរម្យក្នុងខេត្តកំពង់ស្ពឺ បានឃើញមនុស្សជាច្រើនត្រូវបានកងទ័ពខ្មែរក្រហមបាញ់សម្លាប់។ អ្នកដែលមិនអាចដើរទៅមុខទៀតបាន ត្រូវបានបាញ់សម្លាប់ម្តងមួយៗនៅតាមផ្លូវ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ទៀង សុខុម ឯកសារ E3/5402 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480111 (ឃើញមនុស្សម្នាក់ត្រូវបានពួកកងឈ្លបបាញ់សម្លាប់ ដោយសារតែបានបេះផ្លែស្វាយហូប។ ពួកខ្មែរក្រហមសម្លាប់ប្រជាជនដោយមិនរើសមុខ ដោយគ្មានហេតុផល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កែវ ឆែម ឯកសារ E3/5407 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480203 (ក្នុងពេលជម្លៀស គាត់ឃើញខ្មែរក្រហមបង្ខំ បាញ់សម្លាប់ ហើយកាប់សម្លាប់តាមចិត្ត)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ជូ គឹមឡូន ឯកសារ E3/5469 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00506462 (ក្នុងពេលជម្លៀស គាត់ឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់ ឬ បើកឡានបុកសម្លាប់អ្នកត្រូវបានជម្លៀស ដោយមិនដឹងពីមូលហេតុ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហេនរី ស៊ុន ឯកសារ E3/5457 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ១០ ERN (ភាសាខ្មែរ) 00824581 (បានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់អ្នកបើកកាណូតដឹកក្រុមគ្រួសាររបស់ ស៊ុន ហេនរី ឆ្លងកាត់ទន្លេ នៅចំពោះមុខលោក ស៊ុន ហេនរី និងគ្រួសាររបស់គាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (អ្នកខ្លះដែលមិនធ្វើតាមបញ្ជារបស់ពួកវា ដោយធ្វើដំណើរតាមផ្លូវផ្សេងត្រូវបានបាញ់សម្លាប់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00323529 (កងទ័ពខ្មែរក្រហមដែលប្រដាប់ដោយកាំភ្លើងអាកា៤៧ មិនមានការស្ទាក់ស្ទើរក្នុងការសម្លាប់ជនណាដែលមិនដើរតាមផ្លូវដែលបានកំណត់ ឬ ដើរចេញពីផ្លូវនោះទេ។ គាត់បានឃើញការសម្លាប់បែបនេះ)។ *សូមមើលផងដែរ* ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៣ (Sydney SCHANBERG),ទំព័រ ៣-៤ (ដកស្រង់ S. Schanberg: កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ១៩៧៥, E236/1/4/3.1, ទំព័រ ១២១ ERN (ភាសាខ្មែរ) 00963959, បានកត់សម្គាល់ថា ជនបរទេសដែលចូលទៅក្នុងស្ថានទូតនៅថ្ងៃក្រោយៗមក បានរាយការណ៍ពីការសម្លាប់ ប៉ុន្តែពួកគាត់ទាំងនោះមិនមែនជាសាក្សីដែលឃើញផ្ទាល់ភ្នែកនោះឡើយ)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ អតីតឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499663 (លោកឧត្តមសេនីយ៍បានរាយការណ៍ថា នៅតាមផ្លូវពេលជម្លៀសចេញ ជនណាដែលមិនចង់ ឬ មិនអាចជម្លៀសបាន ក៏ត្រូវបានពួកខ្មែរក្រហមសម្លាប់ចោលផងដែរ)។

[១៨៦៣] ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី), ទំព័រ ៦៨-៦៩, ៧៣។

[១៨៦៤] ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ), ទំព័រ ៥៩។

ទាហាន លន់ នល់ ដែលកំពុងឈឺមិនអាចដើររួច ដោយនៅពេលនោះកងទ័ពខ្មែរក្រហមបានទាញរទេះពីគាត់ រួចវាយប្ដីរបស់គាត់ និងអារកប្ដីរបស់គាត់នៅចំពោះមុខគាត់[១៨៦៥]។

### ១០.២.១២ លក្ខខណ្ឌផ្សេងៗដែលបានទទួលរង

៨៩១. លើសពីនេះទៅទៀត ក្រៅពីភាពមិនប្រាកដប្រជាអំពីជោគវាសនា និងអនាគតរបស់ពួកគាត់ ព្រមទាំងអំពើហិង្សា និងការភ័យខ្លាចដែលបានទទួលរងក្នុងពេលជម្លៀសនោះ[១៨៦៦] អ្នកដែលត្រូវបានជម្លៀសទាំងនោះ ក៏បានជួបប្រទះនូវលក្ខខណ្ឌដ៏លំបាកនៅក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ ដូចជា ស្ថិតនៅក្រោមកម្ដៅថ្ងៃខ្លាំង ខ្វះស្បៀងអាហារ ទឹកស្អាត ថ្នាំពេទ្យ ឬ ជម្រកស្នាក់នៅជាដើម[១៨៦៧] ។ ដោយត្រូវបានបណ្ដេញចេញនៅក្នុងរដូវក្ដៅ[១៨៦៨] ហើយត្រូវបានបង្ខំឲ្យដើរអស់

---

[១៨៦៥] ទំរង់បែបបទសុំព័ត៍មានបន្ថែម សូ សារី ឯកសារ E3/4951 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00587131។

[១៨៦៦] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៥, ៤៨៩-៤៩០។

[១៨៦៧] ប្រតិចារឹកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន), ទំព័រ ៥៥-៥៧ (បានឮពីអ្នកមូលដ្ឋាន និងពីកងទ័ពថាអ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវទទួលរងការលំបាកយ៉ាងច្រើន)។ ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ (ជុំ សុខា),ទំព័រ ៨៥-៨៧ (ពួកគាត់មិនមានកន្លែងស្នាក់នៅសមរម្យ និងចំណីអាហារទេ ពួកគាត់ត្រូវរកដុំថ្មដើម្បីធ្វើជាចង្ក្រាន ហើយត្រូវរកទឹកដើម្បីដាំស្ល។ ដោយសារតែវាជារដូវប្រាំង មានការលំបាកក្នុងការរកក្ដាមតាមបឹងឬត្រពាំង។ ប្អូនរបស់គាត់ហើមជើង ហើយដោយសារតែគ្មានថ្នាំពេទ្យ និងគ្មានគ្រូពេទ្យ ពួកគាត់ត្រូវដើររករុក្ខជាតិជាឱសថដើម្បីព្យាបាលប្អូនស្រី)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់), ទំព័រ ៦-៧ (អាកាសធាតុក្ដៅខ្លាំងដោយសារតែចំពាក់កណ្ដាលរដូវប្រាំង ហើយដោយសារតែប្រជាជនមិនបានយកទ្រព្យសម្បត្តិច្រើនតាមខ្លួន ទើបអ្នកខ្លះងាកទៅប្រើដើមចេកធ្វើជាស្បែកជើង។ មានសត្វរុយគ្រប់កន្លែង ហើយដោយគ្មានបង្គន់ ប្រជាជនត្រូវតែចូលទៅក្នុងព្រៃដើម្បីបន្ទោរបង់។ ការប្រឈមធំគឺកង្វះអាហារ និងការព្យាបាលបែបវេជ្ជសាស្ត្រ។ ពួកគាត់មិនដឹងថាត្រូវទៅរកអាហារ និងថ្នាំពេទ្យនៅឯណានោះទេ។ អង្ករមានតម្លៃខ្ពស់ ។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ ឯកសារ E3/5787 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00373423 (ក្នុងពេលធ្វើដំណើរពួកគាត់មិនបានទទួលអ្វីទាំង អស់។ គ្មានអាហារ គ្មានទឹក គ្មានថ្នាំពេទ្យ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆេង អេងលី ឯកសារ E3/5736 ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00918045 (សីតុណ្ហភាពដល់ទៅ ៤០ ដឺក្រេសេ នៅក្នុងម្លប់ ខែមេសា ជាខែដែលក្ដៅបំផុតក្នុងប្រទេសកម្ពុជា ពួកយើងដើរដោយគ្មានគោលដៅ ដោយគ្មានទឹក ដោយគ្មានអាហារ ឬ ជម្រក ហើយ ផ្លូវថ្នល់គ្រប់ដណ្ដប់ដោយហ្វូងមនុស្សខ្មៅងងឹត។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ព្រាប ខេន ឯកសារ E3/5406 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480181 (នៅពេលយប់ពួកគាត់សម្រាកកណ្ដាលវាល ហើយមានហ្វូងមូសយ៉ាងច្រើន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេតណាតា រ៉ូស្នាន ឯកសារ E3/5076 ចុះថ្ងៃ

រយៈពេលជាច្រើនថ្ងៃ ឬ ក៏អាចច្រើនសប្តាហ៍ផងនោះ អ្នកដែលត្រូវបានជម្លៀស និងជាពិសេសកុមារតូចៗ ត្រូវបានទទួលរងការអស់កម្លាំងយ៉ាងខ្លាំង និងសឹងតែមិនអាចដើរទៅមុខរួច[១៤៦៩]។

---

ទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00641840 (នៅតាមផ្លូវ ពួកគាត់ដើររំលងសាកសព។ អាកាសធាតុក្តៅខ្លាំង ហើយជារដូវប្រាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្នួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484412 (ពួកគាត់ត្រូវជួបការលំបាកវេទនាយ៉ាងខ្លាំងក្នុងពេលធ្វើដំណើរ ដោយសារតែកូនៗពួកគាត់នៅតូចៗ ហើយពួកគាត់ត្រូវដើរជើងទទេរ មិនមានមធ្យោបាយធ្វើដំណើរ ហើយដើរក្រោមកំដៅថ្ងៃដ៏ក្តៅ និងមិនមានទឹកផឹកគ្រប់គ្រាន់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ប៉ាក់ សុន ឯកសារ E3/5432 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483658 (ឪពុកគាត់ត្រូវប្រឈមការលំបាកយ៉ាងច្រើនបន្ទាប់ពីចាកចេញពីភ្នំពេញ ដោយសារតែមិនមានអ្វីបរិភោគ ការធ្វើដំណើរនៅវែងឆ្ងាយ ហើយម្តាយរបស់គាត់មានជំងឺរ៉ាំរ៉ៃ)។

[១៤៦៨] អង្គជំនុំជម្រះកត់សម្គាល់ថា រដូវក្តៅមានសីតុណ្ហភាពជាមធ្យម ៣៥ អង្សាសេ ប៉ុន្តែជាញឹកញាប់អាចឡើងដល់ ឬក៏អាចហួស ៤0 អង្សាសេ។

[១៤៦៩] ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ), ទំព័រ ៦៤ (ជាកុមារនៅពេលនោះ ពួកគេត្រូវធ្វើដំណើរដោយថ្មើជើងពេញមួយថ្ងៃ ហើយអស់កម្លាំងយ៉ាងខ្លាំង)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី), ទំព័រ ៨៧-៩០ (ជាកុមានៅពេលនោះ គ្រួសាររបស់គាត់ធ្វើដំណើរអស់រយៈពេល៣ ទៅ៤ថ្ងៃ ហើយអស់កម្លាំងទន់ជើងសឹងតែដើរទៅមុខមិនរួច។ នៅពេលដែលពួកគាត់ដើរទៅមុខលែងរួច ក៏សម្រាកនៅកន្លែងនោះ ១ ឬ ២ ថ្ងៃដើម្បីយកកម្លាំងមុននឹងបន្តដំណើរទៀត)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី), ទំព័រ ៣៥-៣៦ (អាចឃើញថាប្រជាជនមានការលំបាកយ៉ាងច្រើន ក្នុងពេលជម្លៀស ទាំងក្មេង ទាំងចាស់ត្រូវតស៊ូដើរទៅមុខ ទោះជាអស់កម្លាំង និងគ្មានអាហារ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា), ទំព័រ ៥៥ (ជនពិការខ្លះ ព្រមទាំងមនុស្សចាស់ និងយុវជន ពួកគាត់ហេវហត់យ៉ាងខ្លាំង ឯក្មេងៗស្រែកយំដោយសារឈឺជើង)។ ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៧៨-៨០ (ចាស់ៗជាច្រើនត្រូវតស៊ូដើរទៅ ហើយប្រជាជនទទួលរងការលំបាកលំបិនក្នុងការផ្លាស់ទី)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្វាយ ណេត ឯកសារ E3/4722 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00421213 (ការធ្វើដំណើរមានការលំបាកយ៉ាងខ្លាំង ដោយសារតែគាត់ទើបតែសម្រាលកូនកាលពី ២ សប្តាហ៍មុន។ គាត់ត្រូវដើររាប់រយគីឡូម៉ែត្រដោយគ្មានទឹក និងអាហារក្រោមកំដៅថ្ងៃខែក្តៅ។ កូនតូចៗរបស់គាត់យំញឹកញាប់ដោយសារតែពួកគេឃ្លាន និងអស់កម្លាំងដោយសារការដើរច្រើន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ុក សាឯម ឯកសារE3/4724 ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00421489 (គាត់ទទួលរងការលំបាកយ៉ាងខ្លាំងដោយសារតែគាត់ទើបតែសម្រាលកូន ហើយកូនដទៃទៀតរបស់គាត់ក៏នៅតូចៗ។ កាន់តែលំបាកនោះគឺគ្មានទឹកគ្រប់គ្រាន់ គ្មានអាហារ និងទីជម្រកសមរម្យ។ ជាញឹកញាប់ ឮសូរសម្លេងកូនតូចៗរបស់គាត់ និងអ្នកដទៃស្រែកយំខ្លាំងៗដោយសារតែពួកគេហេវហត់ និងឃ្លានព្រោះពួកគេដើរក្រោមកំដៅថ្ងៃក្តៅហែង។ នៅពេលដែលគាត់ទន់ជើង ដើរទៅមុខលែងរួច ប្តីរបស់គាត់ច្នៃធ្វើរទេះអូសគាត់យ៉ាងលំបាក។

ស៊ូ សុទ្ធាវី បានរៀបរាប់ពីការដែលពួកគាត់ត្រូវដើរទាំងថ្ងៃទាំងយប់ ហើយត្រូវបានអនុញ្ញាតឲ្យឈប់តែនៅពេលដែលទៅដល់គោលដៅតែប៉ុណ្ណោះ ។ ពួកគាត់ត្រូវដើរអស់រយៈពេលជាច្រើនថ្ងៃ ដោយអត់អាហារ ហើយមិនមានពេលសម្រាកគ្រប់គ្រាន់ឡើយ[១៤៧០]។ ជាលទ្ធផល មនុស្សជាច្រើនហើមដៃជើង[១៤៧១]។ អ្នកដែលត្រូវបានជម្លៀសជាច្រើនបានធ្លាក់ខ្លួនខ្សោយ ឬ មានជំងឺ ដោយសារតែលក្ខខណ្ឌទាំងនេះ ហើយមានអ្នកខ្លះបានស្លាប់បាត់បង់ជីវិតផង[១៤៧២]។ ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានរម្លឹកពីការចុះខ្សោយសុខភាពរបស់គាត់ ដោយគាត់បានចុះស្គម ព្រមទាំងមានជំងឺគ្រុនក្តៅនៅក្នុងពេលគាត់ធ្វើដំណើរទៅស្រុកផ្អាវ។ដោយសារតែគ្មានថ្នាំសង្កូវត្រឹមត្រូវ គាត់បានបេះស្លឹកឈើល្វីងៗតាមផ្លូវយកមកបុកដាំទឹកផឹកធ្វើជាថ្នាំ[១៤៧៣] ។ ដោយគាត់ទើបតែសម្រាលកូនមុនពេលជម្លៀសតែបន្តិច ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ក៏ជួបប្រទះការលំបាក ដោយកូនស្រីពៅ

---

[១៤៧០] ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី), ទំព័រ ១២-១៣។

[១៤៧១] ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៣២-៣៤, ៨៦-៨៧ (ប្អូនស្រីរបស់គាត់ដើរលែងរួចដោយសារតែហើមជើង។ ម្តាយរបស់គាត់ត្រូវដោះដូរគ្រឿងអលង្ការ ព្រមទាំងសម្លៀកបំពាក់ ដើម្បីឲ្យប្អូនស្រីគាត់បានជិះរទេះ ដោយមិនចាំបាច់ដើរ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ទីន ឯកសារ E3/5004 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557722 (បន្ទាប់ពីធ្វើដំណើរអស់៥ ថ្ងៃ អ្នកខ្លះហើមជើង មិនអាចដើរទៅមុខរួច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន ឯកសារ E3/5294 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00348828 (ជាប្រធានភូមិខ្មែរក្រហម គាត់បានសង្កេតឃើញថា អ្នកដែលមកដល់សុទ្ធតែហើមជើង ដោយសារតែពួកគេមិនធ្លាប់ដើរឆ្ងាយបែបនេះ)។

[១៤៧២] ប្រតិចារឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា), ទំព័រ ៨១-៨២ (ពួកគាត់ដើររហូតដល់ដួលសន្លប់ គាត់និងប្តីរបស់គាត់សន្លប់ទាំង២ នាក់ ដោយសារតែពួកគាត់ទន់ខ្សោយកម្លាំង ពួកគាត់ត្រូវគេវាយដំ ហើយការរស់នៅមានការលំបាកវេទនា)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវត្ថា), ទំព័រ ៧៣-៧៤ (ពេលខ្លះ គាត់អស់កម្លាំង និងស្រេកទឹកខ្លាំង ពេលនៅក្រោមកំដៅថ្ងៃដ៏ក្តៅ)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល), ទំព័រ ៦៣-៦៤ (បានឃើញមនុស្សជាច្រើនដែលមានជំងឺ ទាំងក្មេងទាំងចាស់ មុនពេលគាត់មកដល់ព្រែកក្តាម)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី), ទំព័រ ៨-១០ (ជាពេលវេលាក្តៅបំផុតប្រចាំឆ្នាំ ហើយត្រូវចំណាយពេលរាប់ថ្ងៃដើម្បីចាកចេញពីភ្នំពេញ។ គាត់ និងកូនរបស់គាត់ត្រូវជ្រកក្រោមដើមស្វាយនៅពេលយប់មួយដែលមានភ្លៀងធ្លាក់ ដែលក្រោយមក ពួកគាត់ក៏គ្រុនផ្តាសាយ)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ អតីត ឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499664. *សូមមើលផងដែរ* ផ្នែកទី១០ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៧-៤៤៩៨ (ពាក់ព័ន្ធអ្នកដែលត្រូវបានជម្លៀសបានស្លាប់ដោយសារតែស្ថានភាពនោះ)។

[១៤៧៣] ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល), ទំព័រ ៦០-៦១, ៦៤-៦៥។

01006735



របស់គាត់មានបញ្ហាពោះវៀន និងរាគរូសខ្លាំង ហើយសមាជិកគ្រួសារគាត់ទាំងអស់មានជំងឺគ្រុនក្តៅ[១៤៧៤]។

៤៩២. ស្ត្រីមានផ្ទៃពោះត្រូវសម្រាលកូននៅតាមផ្លូវ ដោយគ្មានទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រឡើយ ហើយស្ត្រីមួយចំនួនបានរលូតកូន[១៤៧៥]។ ទោះបីជានៅក្រោមកាលៈទេសៈបែបណាក៏ដោយ អ្នកដែលត្រូវបានជម្លៀសត្រូវបានបង្ខំឱ្យបន្តដំណើរទៅមុខបើទោះបីជាត្រូវបោះបង់ចោលសមាជិកគ្រួសារចាស់ជរា ឬ ខ្សោយកំលាំងនៅតាមផ្លូវក៏ដោយ[១៤៧៦]។ ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល

[១៤៧៤] ប្រតិចារឹកថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៨០-៨១ (កូនស្រីរបស់គាត់មានបញ្ហាពោះវៀនដែលមិនអាចរក្សាអាហារ ហើយពួកគាត់មិនមានឱសថដើម្បីព្យាបាលកូនឡើយ), ទំព័រ ៧៩-៨០ (ពួកគាត់ឈប់សម្រាករយៈពេល ២ សប្តាហ៍នៅវត្ត ដោយសារតែគាត់ទើបតែសម្រាលកូន ហើយមិនស្រួលខ្លួន)។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៩-១១ (កូនស្រីរបស់គាត់រាគរូសធ្ងន់ធ្ងរ ហើយសមាជិកគ្រួសារគាត់កើតគ្រុនក្តៅទាំងអស់គ្នា)។

[១៤៧៥] ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៨, ៣២-៣៣ (បានឃើញម្តាយស្រែកយំនៅពេលសម្រាលកូន)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស), ទំព័រ ៥ (ឃើញស្ត្រីសម្រាលកូននៅតាមផ្លូវ)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន), ទំព័រ ៧-៨, ទំព័រ ២១-២២ (បានឃើញផ្ទាល់ស្ត្រីដែលរលូតកូនដោយសារតែបញ្ហានៃការជម្លៀសដោយបង្ខំ)។, ទំព័រ ៤៨ (ស្ត្រីមួយរូបទៀតរលូតកូន ដោយសារដើរជាន់អ្វីមួយហើយរអិលដួល។គ្មាននរណាមកជួយគាត់ទេពីព្រោះគ្មាននរណាហ៊ានឈប់ ឬ តវ៉ាឡើយ)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ កាន់ សុន្ធរ៉ា ឯកសារ E3/4671 ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00211394 (ជាស្ត្រីមានផ្ទៃពោះនៅពេលជម្លៀសនោះ គាត់ត្រូវសម្រាលកូន បានកូនប្រុសមួយដោយគ្មានការថែទាំផ្នែកវេជ្ជសាស្ត្រ ឬ ចំណីអាហារអ្វីនោះទេ ក្នុងរយៈពេល៣ថ្ងៃ នៅក្នុងភូមិសិត្បូរ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (ស្ត្រីមានផ្ទៃពោះខ្លះត្រូវសម្រាលកូនតាមផ្លូវ ហើយបន្ទាប់មកពួកខ្មែរក្រហមបង្ខំឲ្យពួកគាត់បន្តដំណើរទៅមុខទៀត)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ទៀង សុខុម ឯកសារ E3/5402 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00480112 (បានឃើញស្ត្រីមានផ្ទៃពោះជាច្រើន បានសម្រាលកូនដោយគ្មានជំនួយផ្នែកវេជ្ជសាស្ត្រ)។

[១៤៧៦] ប្រតិចារឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣(នូវ ហ៊ន់),ទំព័រ ៦-៧ (ពួកគាត់ត្រូវបានអង្គការបង្ខំឲ្យបន្តដំណើរទៅមុខ ហើយអ្នកខ្លះត្រូវបោះបង់សមាជិកគ្រួសារដែលមានជំងឺចោល)។ ប្រតិចារឹកថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៨១ (មានគ្រួសារមួយបានបោះបង់មនុស្សចាស់ម្នាក់ដែលគេទុកនៅលើគ្រែតាមបណ្តោយផ្លូវ) ។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០ (បានរម្លឹកពីការមើលឃើញអ្នកជំងឺដែលដើរដួលហើយងើបអង្គុយនៅលើចិញ្ចើមផ្លូវ ហើយគ្មានអ្នកណាអាចជួយអ្នកណាបានឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ងួន ទីន ឯកសារ E3/5004 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ)

បានរៀបរាប់ពីការដែលពួកកងទ័ពខ្មែរក្រហម តែងតែរុញច្រានអ្នកដែលត្រូវបានជម្លៀសឲ្យធ្វើដំណើរទៅមុខ ហើយមិនអនុញ្ញាតឲ្យនៅចាំសមាជិកគ្រួសារចាស់ជរាដែលមិនអាចដើរបាននោះឡើយ ព្រោះថាវាអាចបង្កឲ្យស្ទះចរាចរណ៍[១៤៧៧]។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវុត្ថា បានឃើញបុរសចំណាស់ម្នាក់ដេកសឹងតែមិនកម្រើកនៅលើថ្នល់ ហើយមានស្រមោចវារលើខ្លួនគាត់ និងចូលភ្នែករបស់គាត់ទៀតផង ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានផ្តល់សក្ខីកម្មថាមនុស្សចាស់ ជាពិសេសជាអ្នកដែលត្រូវគេបោះបង់ចោលនៅតាមផ្លូវ[១៤៧៨]។

---

00557722 (ពួកខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនដើរឲ្យលឿន ប្រជាជនមិនអាចឈប់រង់ចាំសមាជិកគ្រួសារចាស់ជរា និងមានជំងឺដែលដើរមិនរួចនោះឡើយ គេបញ្ជាឲ្យបោះបង់ចោលសមាជិកគ្រួសារដែលចាស់ជរា)។ សេចក្តីពណ៌នារបស់អ្នកស្រី មុម សំអឿន (ឧបសម្ព័ន្ធ ៤) ឯកសារ E3/3963 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00198399 (កូនស្រីច្បងរបស់គាត់ខ្យល់គ ពួកគាត់ក៏សុំកងទ័ពខ្មែរក្រហមដែលបានឃើញហេតុការណ៍នេះ ដើម្បីសម្រាកមួយភ្លែត ចាំនាងធូរស្រាលសិន។ ប្រហែលជាកន្លះម៉ោងក្រោយ នៅពេលដែលកូនស្រីដឹងខ្លួនវិញ កងទ័ពខ្មែរក្រហមផ្សេងទៀតបានធ្វើសញ្ញាឲ្យពួកគាត់បន្តដំណើរទៅទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ដៃ យឺន ឯកសារ E3/4824 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤ ERN (ភាសាខ្មែរ) 00523380 (ពួកគាត់ត្រូវបានបង្ខំឲ្យធ្វើដំណើរទៅមុខ ហើយមិនអនុញ្ញាតឲ្យសម្រាកទេ ទោះបីជាអាកាសធាតុក្តៅខ្លាំងយ៉ាងណាក៏ដោយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត ណារី ឯកសារ E3/4921 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00586773 (ធ្វើដំណើរយ៉ាងវែងឆ្ងាយតាមផ្លូវជាតិ ផ្លូវដី និងក្នុងព្រៃ ដោយមិនអាចឈប់សម្រាកបានឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេតណាតា រ៉ូស្នាន ឯកសារ E3/5076 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00641840 (ពួក ខ្មែរក្រហមរុញច្រានពួកគាត់ឲ្យដើរយ៉ាងលឿន ហើយដើរដល់យប់ជ្រៅ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ព្រាប ខេន ឯកសារ E3/5406 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480181 (ពួកគាត់ត្រូវបានបង្ខំរហូតឲ្យបន្តដំណើរទៅមុខ)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ អៀម ទៀង ឯកសារ E3/5482 ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១០, ទំព័រ ១០ ERN (ភាសាខ្មែរ) 00512863 (បានឃើញចាស់ជរា និងអ្នកជំងឺ ត្រូវបានគេបោះបង់ចោលនៅតាមផ្លូវ ចាប់ពីពេទ្យលោកសង្ឃ ទៅដល់ពោធិ៍ចិនតុង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557817 (ពួកខ្មែរក្រហមបង្ខំស្ត្រីមានផ្ទៃពោះដែលទើបសម្រាលកូនរួចតាមផ្លូវឲ្យបន្តដំណើរទៅមុខ)។

[១៤៧៧] ប្រតិចារឹកថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល), ទំព័រ ១៥-១៧, ២០-២១។

[១៤៧៨] ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវុត្ថា), ទំព័រ ៨៣-៨៤។

៤៩៣. សូម្បីតែអ្នកមានលុយក៏មិនអាចចាយលុយនោះដើម្បីទិញម្ហូបអាហារ ឬថ្នាំពេទ្យបានឡើយ ដោយសារតែកងទ័ពខ្មែរក្រហមបានប្រកាសថា លុយលែងមានប្រយោជន៍ទៀតហើយ ក្រោមការដឹកនាំថ្មីនេះ[១៤៧៩]។

### ១០.២.១៣ ជំនួយដែលត្រូវបានផ្ដល់

៤៩៤. សាក្សី ខៀវ នៅ ដែលជាព្រះសង្ឃ បានផ្ដល់ភ័ស្ដុតាងដែលបង្ហាញអំពីការត្រៀមរៀបចំផ្នែកសុខុមាលភាពក្នុងកម្រិតមួយ សម្រាប់អ្នកដែលត្រូវបានជម្លៀសនៅតាមផ្លូវ ទៅកាន់តំបន់ជនបទ ។ ខៀវ នៅ បានឃើញកម្មាភិបាលខ្មែរក្រហមធ្វើដំណើរ និងរៀបចំកន្លែងស្នាក់នៅឲ្យអ្នកដែលត្រូវបានជម្លៀស[១៤៨០] ។ សាក្សីជាច្រើនផ្សេងទៀតក៏បានផ្ដល់ភ័ស្ដុតាងអំពីព្រឹត្តិការណ៍នៃការ

---

[១៤៧៩] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី), ទំព័រ ៨១-៨៣ (ចង់ទិញម្ហូបអាហារ ប៉ុន្តែត្រូវបានគេប្រាប់ថា លុយលែងត្រូវបានគេទទួលយកទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៧៤ (នៅពេលគាត់ចាកចេញពីទីក្រុង គាត់បានឮប្រជាជនថា ពួកគាត់ឈប់ប្រើក្រដាសប្រាក់ទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ២២(លុយរបស់ពួកគាត់លែងត្រូវបានគេប្រើទៀតហើយ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៣៦-៣៨ (២ ឬ ៣ ថ្ងៃក្រោយការលុកលុយទីក្រុងភ្នំពេញ គាត់បានឮសេចក្ដីប្រកាសថា លុយលែងត្រូវបានគេចរាចរទៀតហើយ)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ។

(រ៉ុចាម តុន), ទំព័រ ៥៥-៥៧ (បានឃើញគ្រួសារមួយដែលត្រូវបានគេជម្លៀស បានស្ដាយកាបូបដាក់លុយចំនួនពីរ និងបានប្រាប់ពួកគាត់កុំឲ្យខ្វល់នឹងលុយ ព្រោះនៅភូមិភាគរំដោះ លុយលែងត្រូវបានគេចាយទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា), ទំព័រ ៥៥ (បានឮពាក្យចចាមរាមថា លុយត្រូវបានគេលុបចោល។ គាត់ព្យាយាមរក្សាលុយគាត់ ប៉ុន្តែវាបែរជាគ្មានប្រយោជន៍)។ ប្រតិចារឹក ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ), ទំព័រ ២១-២២ (ដំបូង ប្រជាជនអាចដោះដូរទំនិញជាមួយនឹងលុយដែលពួកគាត់មាន ប៉ុន្តែឆ្ងាយពីភ្នំពេញបន្តិច លុយរៀលលែងត្រូវបានចាយទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ (នូវ ហ៊ាន់), ទំព័រ ៧ (ពួកគាត់មិនដឹងទៅទីណាដើម្បីរកបានម្ហូបអាហារ ឬ ថ្នាំពេទ្យ ហើយលុយដែលគាត់មាន គេលែងចាយទៀត)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល), ទំព័រ ២១-២៣ (ប្រហែលមួយគីឡូម៉ែត្រពីកន្លែងត្រួតពិនិត្យ ហួសចំការដូង គ្រួសាររបស់គាត់ត្រូវបានគេប្រាប់ថា លុយលែងត្រូវបានចាយទៀតហើយ ហើយទាហានបានយកលុយពីគាត់ទៅដុតចោល។ នៅពេលនោះ គ្រួសារគាត់គិតថា ពួកគាត់នឹងស្លាប់ ដោយសារតែពួកគាត់ពឹងផ្អែកតែលើលុយទាំងនោះ ហើយពួកគាត់លែងមានវិធីណាមួយដើម្បីទិញម្ហូបអាហារ ឬរបស់របរផ្សេងៗនោះទេ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៧-៥៨ (លុយរាយពេញផ្លូវ)។ *សូមមើលផងដែរ* S. Schanberg៖ *កំណត់ហេតុស្ដីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១៧៣-១៧៤ ERN (ភាសាខ្មែរ) 00964011។

[១៤៨០] ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (ខៀវ នៅ), ទំព័រ ៨៨-៩០ (ព្រះសង្ឃមួយអង្គ បានលើកឡើងថា ទោះបីជាគាត់មិនបានពិនិត្យមើលគ្រប់កន្លែង និងមិនអាចនិយាយជាទូទៅអំពីការរៀបចំចាត់ចែងលើប្រជាជន ក៏គាត់

ផ្តល់ជំនួយ ជាពិសេសការដឹកជញ្ជូន[១៤៨១] ទោះបីជាព្រឹត្តិការណ៍ទាំងនេះហាក់ដូចជាមិនកើតមានជាទៀងទាត់ក្តី។ ជាការពិត អ្នកដែលត្រូវបានជម្លៀសមួយរូបបានទទួលស្គាល់ថា ក្រុមគ្រួសារដែលគិតថាមានការរៀបចំរួចជាស្រេច ដោយសារតែគាត់បានឃើញកម្មាភិបាលខ្មែរក្រហមបានធ្វើដំណើរ និងរៀបចំកន្លែងស្នាក់សម្រាប់អ្នកជម្លៀស)។ *សូមមើលផងដែរ* លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រីសរ ប៊ុន ឯកសារ អតីត ឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499664-00499665 (សំដៅទៅលើ "ចំណុចរួម" ដែលអ្នកជម្លៀសបានទទួលអង្ករម្តងឬពីរដងក្នុង ១ សប្តាហ៍ ទោះបីជាយើងមិនច្បាស់ថាតើ គាត់និយាយសំដៅលើតំបន់ណាមួយក្នុងប្រទេសកម្ពុជាក្តី)។

[១៤៨១] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៨១-៨២ (អតីតទាហាន លន់ នល់ បានលើកឡើងថា ទោះបីជាការជម្លៀសធ្វើឡើងភាគច្រើនដោយធនធានផ្ទាល់របស់ខ្លួនក្តី នៅឃុំបាបោង ពួកគាត់ត្រូវបានដឹកជញ្ជូនទៅស្រុកសំរោងដោយឡានមួយដែលកងទ័ពខ្មែរក្រហមចាប់បាន។ ពួកគាត់ត្រូវបានដឹកជញ្ជូនតាមឡានក្នុងពេលនោះតែប៉ុណ្ណោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចែម សែម ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00198942 (ពួកកម្មាភិបាលខ្មែរក្រហម និងប្រជាជនមូលដ្ឋានខ្លះនៅក្បែរស្ពានកំពង់ស្នាច់ អាណិតរូបគាត់ និងបានឱ្យអង្ករខ្លះមកគាត់។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ម៉ាត់ សា ឯកសារ E3/5326 ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00451835-00451836 (ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញតាមឡានដែលបើកដោយពួកកងទ័ពខ្មែរក្រហម)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហេង ង៉ែត ឯកសារ E3/5364 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00476648 (គាត់ត្រូវបានជម្លៀសចេញ ហើយគាត់បានសុំជិះឡានកងទ័ពខ្មែរក្រហម ទោះបីជាក្រោយពេលមកដល់បែកចាន ខ្មែរក្រហមបញ្ជាឱ្យពួកគាត់ចុះដើរទាំងអស់គ្នា)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៤២ ERN (ភាសាខ្មែរ) 00836119 (ដោយមិនដឹងកាលបរិច្ឆេទ លោក S រួមជាមួយនឹងខ្មែរទាំងអស់ដែលត្រូវបានបណ្តេញចេញពីស្ថានទូតផងនេះ ត្រូវបានគេ នាំទៅស្តាត Lambert។ ជនទាំងឡាយណាដែលនៅស្តាតពេញមួយយប់ បានសុំម្ហូបអាហារពីពួកខ្មែរក្រហម ដែលបានសម្លាប់ជ្រូកឱ្យពួកគាត់។ នៅពេលលោក S បដិសេធមិនចាកចេញដោយថ្មើរជើងទេ និងសុំជិះឡាន ពួកខ្មែរក្រហមក៏ឱ្យគាត់ជិះឡាន), ទំព័រ ១៧៨-១៧៩ ERN (ភាសាខ្មែរ) 00836255-00836256 (កាលពីថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ១៩៧៦ ពេជ្រ លឹមកុង បានលើកឡើងថា ពួកគាត់បានប្រើប្រាស់គ្រប់ទម្រង់នៃការដឹកជញ្ជូនទាំងអស់ ទាំងផ្លូវគោកនិងផ្លូវទឹក ដើម្បីធានាថា ប្រជាជនបានចាកចេញពីទីក្រុងភ្នំពេញឱ្យបានឆាប់រហ័សតាមតែអាចធ្វើបាន)។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ២ ERN (ភាសាខ្មែរ) 00658220 (បានរាយការណ៍ថា អ្នកជម្លៀសបានលើកឡើងថា ពេលខ្លះ មានរបបអាហារ ប៉ុន្តែនៅកន្លែងខ្លះ ខ្មែរក្រហមមិនត្រឹមតែមិនឱ្យអាហារទេ ថែមទាំងដកយកសម្លៀកបំពាក់នៅសល់ពីអ្នកធ្វើដំណើរទៀតផង), ៣ ERN (ភាសាខ្មែរ) 00658221-00658222 (បានរាយការណ៍ថា បន្ទាប់ពីកើតមានជំងឺអាសន្នរោគ ខ្មែរកុម្មុយនីស្តបានចាក់វាក់សាំងពីរប្រភេទឱ្យអ្នកធ្វើដំណើរ៖ មួយប្រភេទបានពីវិទ្យាស្ថានប៉ាស្ទ័រសម្រាប់ជំងឺអាសន្នរោគ និងមួយប្រភេទទៀតគឺ "ថ្នាំ BGI" ជាថ្នាំព្យាបាលជំងឺគ្រប់ប្រភេទដែលប្រើប្រាស់សម្រាប់អ្នកជំងឺ ឬ អ្នករងរបួសគ្រប់គ្នា ប៉ុន្តែថ្នាំនេះមិនមានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺអាសន្នរោគនោះទេ)។

មានឋានៈខ្ពស់ទទួលបានសិទ្ធិពិសេសលើសគេ ដោយពួកគាត់ត្រូវបានជម្លៀសដែរ តែត្រូវបានពួកខ្មែរក្រហមផ្តល់ម្ហូបអាហារ និងទឹក ក្នុងអំឡុងពេលគាត់ស្នាក់នៅរយៈពេលមួយសប្តាហ៍នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រោយមក នៅពេលពួកគាត់ត្រូវបានជម្លៀសតាមឡានទៅពោធិ៍សាត់[១៤៨២]។

៤៩៥. ផ្ទុយទៅវិញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានរៀបរាប់ថា នៅតាមផ្លូវ កងទ័ពខ្មែរក្រហមមិនបានផ្តល់ម្ហូបអាហារទឹក ថ្នាំពេទ្យ ឬ ការដឹកជញ្ជូនឲ្យពួកគាត់នោះទេសូម្បីតែការជួយដល់អ្នកដែលត្រូវបានជម្លៀសដែលមានសុខភាពទន់ខ្សោយ ចាស់ជរា ឬ អ្នកដែលរងរបួសក៏គ្មានដែរ[១៤៨៣]។ យោងតាមសាក្សី រ៉ចាម តុន ដែលបានឃាមកាមនៅក្នុងកិច្ចប្រជុំនៅខែ មេសា ឆ្នាំ

---

ខ្មែរក្រហមក៏បានឲ្យជំនួយតិចតួចមួយចំនួនដល់អ្នកទាំងឡាយណាដែលនៅស្ថានទូតបារាំងផងដែរ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៤៨-៤៩ (ខ្មែរក្រហមអនុញ្ញាតឲ្យស្ថានទូតបារាំងទទួលបានជ្រូកមួយក្បាលក្នុងមួយថ្ងៃ និងបន្លែមួយចំនួនផងដែរ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៥១ (នៅស្ថានទូតបារាំង ខ្មែរក្រហមបានផ្តល់អង្ករ និងទឹកគ្រប់គ្រាន់)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានភាពនៅភ្នំពេញនាថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ នៅវេលាម៉ោង ១៥ ម៉ោងនៅស្រុកខ្មែរ ឯកសារ E3/2690 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ (ភាសាខ្មែរ) 00491975-00491976 (បានរាយការណ៍ថា មេដឹកនាំខ្មែរក្រហមបានធានាផ្តល់សុវត្ថិភាព និងឧបត្ថម្ភចំណីអាហារទៅតាមដែលគេអាចធ្វើទៅបានដល់ស្ថានទូត)។

[១៤៨២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហុង សាវ៉ាត ឯកសារ E3/5591 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00418447-00418448 (ពួកខ្មែរក្រហមបានចាប់ខ្លួនគាត់ និងគ្រួសារគាត់ និងបានយកពួកគាត់ទៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ដែលគាត់បានស្នាក់នៅកន្លែងនោះរយៈពេលមួយសប្តាហ៍ជាមួយគ្រួសារមួយរយៈផ្សេងទៀត ដែលជាគ្រួសារអ្នកមាន ឬអ្នកមានឋានៈខ្ពស់ ឬ គ្រួសារដែលមានឈ្មោះនៅក្នុងសង្គម។ គ្រួសាររបស់គាត់ត្រូវបានអនុញ្ញាតឲ្យអង្គុយនៅក្នុងកាប៊ីនឡាន ហើយគាត់បានទទួលស្គាល់ថា ការអង្គុយក្នុងកាប៊ីននេះ គឺជាសិទ្ធិពិសេស)។

[១៤៨៣] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន), ទំព័រ ៣៦ (មិនមានការដឹកជញ្ជូនណាមួយសម្រាប់អ្នកជម្លៀសនោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី), ទំព័រ ៧៦-៧៧ (មិនបានឃើញកងទ័ពយកចិត្តទុកដាក់ចំពោះអ្នករងរបួសនោះទេ។ ពួកកងទ័ពមិនយកចិត្តទុកដាក់ចំពោះអ្នកឈឺទេ) ទំព័រ ៨៥-៨៦ (កងទ័ពខ្មែរក្រហមនៅតាមផ្លូវ មិនបានឲ្យអ្វីសោះដល់ពួកគាត់នោះទេ) ទំព័រ ៩០ (មិនមានការដឹកជញ្ជូន មិនមានជំនួយណាមួយដែលពួកកងទ័ពខ្មែរក្រហម ឬប្រជាជនមូលដ្ឋាន ផ្តល់ឲ្យនោះទេ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២។ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ១៣។ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO), ទំព័រ ៥៨, ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សាវ៉ាន់), ទំព័រ ៨១-៨២។ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សាវ៉ាន់), ទំព័រ ៣៧។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ

១៩៧៥ ដែលនៅពេលនោះ មានការពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ នៅក្នុង

---

ស្រីផល), ទំព័រ ១៩-២០ (ពួកគាត់មិនត្រូវបានគេផ្ដល់ម្ហូបអាហារ ទឹក ទីជម្រក និងថ្នាំពេទ្យនោះទេ)។ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា), ទំព័រ ៣៤, ៤៨-៤៩ (ពួកខ្មែរក្រហមមិនបានឲ្យអ្វីទាល់តែសោះ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ), ទំព័រ ៦១-៦៣, ៦៨។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគីម ល្មុត), ទំព័រ ៥-៦។ ប្រតិចារឹក ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០១៣ (អួន ផល្លី), ទំព័រ ៣០-៣១ (គ្មាននរណាម្នាក់ឲ្យអ្វីនោះទេ)។ ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០១៣ (ពិន យ៉ាថៃ), ទំព័រ១៨-១៩ (អង្គការមិនបានយកចិត្តទុកដាក់ដល់សុខុមាភាព និងសុខភាពរបស់យើង ឬ ជួយយើង ឬផ្ដល់ឲ្យយើងនូវថ្នាំពេទ្យណាមួយនោះទេ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី), ទំព័រ ១២-១៣ (ពួកគាត់មិនមានថ្នាំពេទ្យ នៅពេលពួកគាត់ឈឺនោះទេ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់), ទំព័រ ៦ (អ្នកទាំងឡាយណាដែលឈឺ មិនអាចរកអ្នកណាជួយបានទេ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា), ទំព័រ ៨១-៨៣ (ការចាកចេញពីទីក្រុងភ្នំពេញ ធ្វើឡើងតាមលទ្ធភាពរៀងៗខ្លួន។ គ្មាននរណាម្នាក់យកចិត្តទុកលើអ្នកជំងឺនោះទេ។ អ្នកជំងឺនឹងស្ថិតនៅមួយកន្លែង ហើយស្លាប់ ឬហូរឈាមរហូតដល់ស្លាប់។ ពួកគាត់សម្រាកនៅតាមផ្លូវដោយខ្លួនឯង ដោយសារតែគ្មាននរណាណែនាំគាត់ជាក់លាក់ថាតើគាត់ត្រូវជួបជុំគ្នា និងសម្រាកនៅកន្លែងណានោះទេ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី), ទំព័រ ៨០ (មិនបានឃើញពួកកងទ័ពខ្មែរក្រហមណាមួយ យកចិត្តទុកដាក់ចំពោះប្រជាជននោះទេ)។ ប្រតិចារឹក ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១១ (មិនមានចែកម្ហូបអាហារនោះទេ), ទំព័រ ៣៧ (មិនមានការដឹកជញ្ជូន និងមិនមានចែកទឹក ម្ហូបអាហារ ឬថ្នាំពេទ្យនោះទេ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF), ទំព័រ ៤៨-៤៩ (គាត់មិនបានឃើញពួកខ្មែរក្រហមផ្ដល់ជំនួយអ្វីនោះទេ លើកលែងតែផ្ដល់ម្ហូបអាហារនៅស្ថានទូតបារាំងប៉ុណ្ណោះ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៨ (ពួកខ្មែរក្រហមមិនបានប្រាប់ប្រជាជនថា ពួកគាត់អាចនឹងទទួលបានជំនួយណាមួយក្នុងអំឡុងពេលនៃការធ្វើដំណើររបស់គាត់នោះទេ) ។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ១៥-១៦។ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៩-១០ (គាត់បានឃើញថា ខ្មែរក្រហមមិនបានផ្ដល់មធ្យោបាយធ្វើដំណើរ ម្ហូបអាហារ ឬ ទឹក ឬជំនួយផ្សេងៗទៀតដល់អ្នកជម្លៀសនោះទេ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី ឯកសារ E3/4608 ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00418469-00418470 (ពួកគាត់មិនបានទទួលអ្វីទាំងអស់ពីខ្មែរក្រហម)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373187 (ពួកគាត់មិនបានទទួលជំនួយអ្វីនោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00865602-00865602 (ខ្មែរក្រហមមិនបានផ្ដល់ម្ហូបអាហារដល់ពួកគាត់ទេ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារE3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៣២ ERN (ភាសាខ្មែរ) 00836109 (លោក R ដែលជាអ្នកត្រូវបានគេសម្ភាសន៍ បាននិយាយថា ពួកគាត់ព្រួយបារម្ភអំពីការស្វែងរកម្ហូបអាហារ ដោយសារតែខ្មែរក្រហមមិនបានផ្ដល់ម្ហូបអាហារអ្វីនោះទេ ។ មានឡានដឹកថ្នាំពេទ្យចំនួន ៣ ឡាន ប៉ុន្តែពួកខ្មែរក្រហមមិនបានចែកថ្នាំនោះទេ។ មានគេនិយាយថា ពួកខ្មែរក្រហមបានយកថ្នាំទាំងនេះទៅវៀតណាម)។

កិច្ចប្រជុំនោះ មិនមានការពិភាក្សាលម្អិតអំពីរបៀបផ្តល់ម្ហូបអាហារដល់ប្រជាជន ឬ ការយកចិត្តទុកដាក់ដល់មនុស្សចាស់ជរា កូនក្មេង ឬ អ្នកជំងឺ នៅក្នុងអំឡុងពេលជម្លៀសនោះទេ[១៤៨៤]។

៤៩៦. អតីតកងទ័ពខ្មែរក្រហមដែលបានចូលរួមនៅក្នុងការជម្លៀសបានបញ្ជាក់ថា កងរបស់ពួកគាត់នីមួយៗ មិនបានជួយ ឬ ផ្តល់ជំនួយណាមួយដល់អ្នកដែលត្រូវបានជម្លៀសទាំងឡាយដែលចាកចេញពីទីក្រុងឬក៏បានទទួលការណែនាំឲ្យជួយដល់អ្នកដែលត្រូវបានជម្លៀសនោះទេ[១៤៨៥]។ ស៊ុំ ជា បានបញ្ជាក់ថា អ្នកដែលត្រូវបានជម្លៀសត្រូវថែទាំខ្លួនឯង ដោយសារតែមិនមានគោលនយោបាយក្នុងការជួយពួកគាត់នោះទេ ។ ជាការពិត កងវរសេនាតូចរបស់គាត់មិនបានផ្តល់ម្ហូបអាហារ ឬ ទឹកដល់អ្នកដែលត្រូវបានជម្លៀសនោះទេ ដោយសារតែកងទ័ពមិនមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ហូបខ្លួនឯងផង[១៤៨៦] ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ជារួមកងទ័ពខ្មែរក្រហមមិនបានផ្តល់ម្ហូបអាហារ ទឹក ការព្យាបាលជំងឺ ឬ កន្លែងស្នាក់នៅគ្រប់គ្រាន់ដល់អ្នកដែលត្រូវបានបង្ខំឲ្យចាកចេញពីភ្នំពេញនោះទេ។

---

[១៤៨៤] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន), ទំព័រ ៦៧-៦៨ (ក្នុងអំឡុងកិច្ចប្រជុំ ព័ត៌មានលម្អិតតិចតួចប៉ុណ្ណោះ ត្រូវបានគេបកស្រាយ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម គុន), ទំព័រ ១២-១៣ (គាត់អាចចូលរួមស្តាប់កិច្ចប្រជុំ ដោយសារតែគាត់គឺជាអ្នកយាមកាមក្នុងអំឡុងកិច្ចប្រជុំនេះ)។ *សូមមើលផងដែរ* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៤៤-១៤៧។

[១៤៨៥] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី), ទំព័រ ៤៣-៤៤ (កងរបស់គាត់មិនបានទទួលការណែនាំណាមួយពីមេបញ្ជាការកងវរសេនាតូចរបស់គាត់ឲ្យជួយប្រជាជនដែលកំពុងចាកចេញពីទីក្រុងនោះទេ), ទំព័រ ៦៣-៦៤ (គាត់ត្រូវបានគេប្រាប់ថា អាជ្ញាធរមូលដ្ឋានគឺជាអ្នកទទួលខុសត្រូវចំពោះការទទួលប្រជាជនទាំងនោះ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន), ទំព័រ ៦៤-៦៦, ៦៧-៦៨ (អតីតកងទ័ពខ្មែរក្រហមមួយរូបដែលពាក់ព័ន្ធនៅក្នុងការជម្លៀសប្រជាជនបានសង្កេតឃើញថា មនុស្សចាស់ជរា អ្នកជំងឺ និងអ្នកមានផ្ទៃពោះ ត្រូវ "ទៅតាមលទ្ធភាព" ខ្លួនឯង និងដើរថ្មើរ ជើង។ អតីតកងទ័ពរូបនេះក៏បានលើកឡើងទៀតថា មានការណែនាំ ហើយប្រជាជននៅមូលដ្ឋានត្រូវបានគេប្រាប់ឲ្យទទួលប្រជាជនទាំងអស់ ហើយត្រូវផ្តល់ និងចែកអាហារឲ្យប្រជាជនថ្មី។ បញ្ហាលម្អិត ដូចជា អាហារ ទឹក និងកន្លែងស្នាក់នៅមិនមាននៅក្នុងគម្រោងនោះទេ។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00384417 (កងទ័ពខ្មែរក្រហមមួយរូបបាននិយាយថា ពួកគាត់មិនបានផ្តល់ជំនួយអ្វីទាល់តែសោះដល់ជនស៊ីវិល)។

[១៤៨៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២៣, ៣៨-៣៩, ៤៤ (ប្រជាជនមិនត្រូវបានគេជួយនោះទេ។ មិនមានការណែនាំឲ្យជួយប្រជាជននោះទេ)។

## ១០.២.១៤ ការស្លាប់

៤៩៧. នៅពេលជួបប្រទះនឹងលក្ខខណ្ឌលំបាកខ្លាំង និងឥតឈប់ឈរ នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន អ្នកដែលត្រូវបានជម្លៀសមួយចំនួនបានធ្វើអត្តឃាត ឬ បានស្លាប់ភ្លាមៗដោយសារតែការអស់កម្លាំងខ្លាំង ការហូបមិនគ្រប់គ្រាន់ ឬ មានជំងឺ[១៤៨៧]។ សាក្សីជាច្រើនបានរៀបរាប់

[១៤៨៧] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ), ទំព័រ ២១-២២ (បានឃើញស្ត្រី ២ រូបចងកខ្លួនឯងនៅកន្លែង ២ ផ្សេងគ្នា និងបានឃើញប្រជាជននឿយហត់យ៉ាងខ្លាំងក្នុងការធ្វើដំណើរ ដូចនេះបានសម្រាកនៅតាមសងខាងផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG), ទំព័រ ៣ (ដកស្រង់ S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១២២-១២៣ ERN (ភាសាខ្មែរ) 00963960-00963961 បានកត់សម្គាល់ថា ជនបរទេសដែលហូរចូលស្ថានទូតជារៀងរាល់ថ្ងៃ បានលើកឡើងអំពីរឿងរ៉ាវសាកសពនៅតាមផ្លូវ និងមនុស្សដែលស្លាប់ដោយសារជំងឺ ឬ ហត់នឿយពេលដើរតាមផ្លូវ)។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៣ ERN (ភាសាខ្មែរ) 00658221 (បានរាយការណ៍ថា អ្នកជម្លៀសបាននិយាយអំពីទឹកមិនគ្រប់គ្រាន់ ឬ ទឹកកខ្វក់ និងកំដៅថ្ងៃខ្លាំងដែលបានសម្លាប់មនុស្សចាស់ និងពួកក្មេងៗ ហើយជំងឺអាសន្នរោគបានកើតមានឡើង។ នៅពេលដែលពួកគាត់បានមកដល់ខេត្តកំពង់ចាម មនុស្សពី៤ ទៅ៥ នាក់ បានស្លាប់ដោយសារជំងឺអាសន្នរោគជារៀងរាល់ថ្ងៃ)។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ កម្ពុជាថ្មី ឯកសារ E3/3006 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៦ ERN (ភាសាខ្មែរ) 00702181 (ជនជាតិឥណ្ឌា និងជនជាតិហ្វីលីពីនត្រូវបានគេច្រឡំបង្ខំឲ្យចេញពីភ្នំពេញ បាននិយាយថា មនុស្សចាស់ៗ កូនក្មេងតូចៗ អ្នកជំងឺជាច្រើន បានស្លាប់ក្នុងអំឡុងពេលពួកគាត់បានដើរឆ្ពោះទៅខាងជើងបានបន្តិច ដោយសារតែមានជំងឺអាសន្នរោគ ខ្វះខាតម្ហូបអាហារ និងមិនមានទឹកស្អាត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផាត់ ហន ឯកសារ E3/4756 ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484884 (ចាស់ជរាមួយចំនួន ដែលលែងអាចដើររួច បានស្លាប់នៅតាមផ្លូវ)។ ទំរង់បែបបទសុំព័ត៏មានបន្ថែមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឈឹម មន ឯកសារ E3/4910 ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣ ERN (ភាសាខ្មែរ) 00578147 (នៅតាមផ្លូវបានឃើញថា មនុស្សចាស់ជរា និងកូនក្មេងមួយចំនួនបានស្លាប់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១៥៩-១៦០ ERN (ភាសាខ្មែរ) 00836236-00836237 (នី ប៊ុនលី បានលើកឡើងថា នៅពេលពួកគេបានបង្ខំឲ្យប្រជាជនធ្វើដំណើរទាំងថ្ងៃទាំងយប់ ប្រជាជនជាច្រើនបានស្លាប់ក្នុងពេលធ្វើដំណើរ។ អ្នកជំងឺដែលត្រូវបានដឹកមកពីមន្ទីរពេទ្យ បានស្លាប់ដោយសារពួកគាត់មិនអាចដើរបាន។ ស្ត្រីដែលទើបតែសម្រាលកូនហើយ បានស្លាប់ដោយសារតែខ្វះថ្នាំពេទ្យ។ អ្នកត្រូវរបួសដោយសង្គ្រាម ត្រូវបានខ្មែរក្រហមសម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី រៀម ឯកសារ E3/4980 គ្មានចុះកាលបរិច្ឆេទ ទំព័រ៤ ERN (ភាសាខ្មែរ) 00554820 (បានលើកឡើងថា ប្រជាជនប្រហែល២០០ ប៉ុណ្ណោះ បានមកដល់ភូមិ ពីព្រោះតែប្រជាជនមួយចំនួនស្លាប់ដោយសារតែអត់ឃ្លាន និងជំងឺ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557816-00557817 (ស្ត្រីមានផ្ទៃពោះមួយចំនួនដែលបានសម្រាលកូននៅតាមផ្លូវ និងត្រូវបាន

ថា បានឃើញប្រជាជនស្លាប់នៅលើផ្លូវ និងតាមចិញ្ចើមផ្លូវ[១៤៨៨]។ ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានរៀបរាប់ថា នៅពេលដែលពួកគាត់ធ្វើដំណើរកាន់តែឆ្ងាយពីទីក្រុង អ្នកជំងឺ អ្នករបួស អ្នកពិការ និងមនុស្សចាស់ កាន់តែត្អូញត្អែរអំពីការអស់កម្លាំងខ្លាំង ហើយពួកគាត់ចាប់ផ្តើមឃើញ សាកសពកាន់តែច្រើនឡើងៗទុកចោលនៅតាមដងផ្លូវ រហូតដល់គាត់លែងខ្លាចនៅពេលឃើញ

---

បង្ខំឱ្យបន្តការធ្វើដំណើរ មិនអាចទ្រាំនឹងការលំបាកបាននោះទេ។ ស្ត្រីមួយចំនួនបានទុកទារករបស់ពួកគាត់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត ណាវី ឯកសារ E3/4921 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00586773 (នៅតាមផ្លូវ គាត់បានឃើញការធ្វើអត្តឃាត អ្នកផ្សេងទៀតស្លាប់ដោយសារ អត់អាហារ។ ប្អូនប្រុសម្នាក់ និងប្អូនស្រីរបស់គាត់ដែលនៅបៅដោះ ស្លាប់ដោយសារអត់អាហារ)។ ទម្រង់បែបបទ ព័ត៌មានជនរងគ្រោះ លាស់ វណ្ណាន ឯកសារ E3/5327 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៧ ERN (ភាសាខ្មែរ) 00451929 (អ្នកជម្លៀសបានស្លាប់នៅតាមផ្លូវ ហើយសាកសពរបស់ពួកគាត់ស្អុយរលួយ ខណៈពេលដែលអ្នកជម្លៀស មួយចំនួនធ្លាក់ខ្លួនឈឺដោយសារម្ហូបអាហារមិនគ្រប់គ្រាន់ ហើយការធ្វើដំណើរវែងឆ្ងាយ និងនឿយហត់ខ្លាំង)។ ទម្រង់ បែបបទព័ត៌មានជនរងគ្រោះ ព្រាប ខេន ឯកសារ E3/5406 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសា ខ្មែរ) 00480181 (បានឃើញមនុស្សជាច្រើនស្លាប់នៅតាមផ្លូវដោយសារតែអត់ឃ្លាន និងអាយុច្រើន)។ ទម្រង់បែបបទ ព័ត៌មានជនរងគ្រោះ កែម កួន ឯកសារ E3/5418 ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480987 (ឪពុករបស់គាត់បានស្លាប់បន្ទាប់ពីគាត់បានមកដល់ស្រុកកំណើតរបស់គាត់ក្នុងរយៈពេល ២ ទៅ ៣ ថ្ងៃ ដោយសារតែដើរឆ្ងាយ និងមិនមានអាហារបរិភោគ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ តូច មុនិន្ទ ឯកសារ E3/4668 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00211324-00211325 (មនុស្ស ចាស់ជរាមិនអាចធ្វើដំណើរទៅមុខបាន និងបានស្លាប់ក្នុងអំឡុងពេលធ្វើដំណើរនោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្នី ឯកសារ E3/5555 ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00363532-00363533 (ម្តាយក្មេករបស់គាត់បានស្លាប់ក្នុងអំឡុងពេលជម្លៀសប្រជាជនដោយសារតែអាយុចាស់)។

[១៤៨៨] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦០-៦២ (ប្រជាជនស្លាប់នៅតាមផ្លូវ។ ប្រជាជន ក៏បានស្លាប់ដោយសាររត់ជាន់គ្នាពេលចាកចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា), ទំព័រ ១២-១៣ (បានឃើញប្រជាជនស្លាប់នៅតាមដងផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣២-៣៣ (ប្រជាជនមួយចំនួនស្លាប់នៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៦៨-៦៩ (បានឃើញប្រជាជនជាច្រើនបានស្លាប់នៅតាមផ្លូវក្នុងអំឡុងពេលនៃការជម្លៀស)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ៦ (ប្រជាជនមួយចំនួនបានស្លាប់ និងត្រូវបានទុកចោលនៅតាមផ្លូវ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២៨ ERN (ភាសាខ្មែរ) 00836105 (លោក M ដែលជាអ្នកត្រូវបានគេសម្ភាសន៍ រាយការណ៍ថាបានឃើញសាកសពស្អុយរលួយមិនទាន់កប់រាប់ពាន់ សាកសពនៅតាមផ្លូវ។ ការស្លាប់ដោយសារតែខ្វះម្ហូបអាហារ ជំងឺ និងថ្នាំពេទ្យមិនគ្រប់គ្រាន់)។ ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេតណាតា រ៉ូស្មាន ឯកសារ E3/5076 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00641840 (គាត់បានឃើញទារកដេកលើដីយំក្បែរសាកសពម្តាយរបស់ខ្លួននៅតាមផ្លូវ)។

សាកសពទាំងនោះ[១៤៤៩] ។ ពេជ ស្រីផល បានលើកឡើងថា នៅពេលដែលពួកគាត់បានទៅដល់ស្ទឹងមានជ័យ ពួកគាត់បានឃើញសាកសពនៅលើគ្រែពេទ្យដែលត្រូវបានទុកចោលនៅលើចិញ្ចើមផ្លូវនៅជាយទីក្រុងភ្នំពេញ[១៤៥០]។

៤៩៨. ក្មេងៗ ជាពិសេស បានស្លាប់ដោយសារអត់ឃ្លាន និងជំងឺផ្សេងៗ ដែលក្មេងៗទាំងនោះបានឈឺនៅពេលធ្វើដំណើរតាមផ្លូវ[១៤៥១]។ វេជ្ជបណ្ឌិតកម្ពុជាម្នាក់ឈ្មោះ ហៃ បានលើកឡើងថា នៅពេលធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ពួកគាត់ពិតជាបានឃើញសាកសពក្មេងម្នាក់នៅតាមផ្លូវ រៀងរាល់ចម្ងាយផ្លូវប្រហែល២០០ ម៉ែត្រ។ ក្មេងភាគច្រើនស្លាប់ដោយសារការឈឺក្រពះ ពោះវៀនដែលបណ្ដាលមកពីការខ្សោះជាតិទឹកក្នុងខ្លួនទាំងស្រុង។ ក្មេងៗត្រូវការសម្រាក និងថ្នាំពេទ្យ ប៉ុន្តែក្មេងៗទាំងនោះមិនបានទទួលការសម្រាក និងថ្នាំពេទ្យដែលត្រូវការទេ[១៤៥២] ។ ដោយមិនមាន

---

[១៤៤៩] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៤ (ដកស្រង់ សៀវភៅនិពន្ធដោយ ពិន យ៉ាថៃ៖ *ជីវិតកូនថ្លៃ កូនត្រូវតែរស់* ឯកសារ E3/3988 ERN (ភាសាខ្មែរ) 00588145-00588146)។

[១៤៥០] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥-១៧ (គាត់ជឿជាក់ថា ប្រជាជនអាចធ្លាក់ខ្លួនឈឺធ្ងន់ និងដោយសារតែស្ថានភាពបែបនេះ ប្រជាជនមិនអាចរស់រានបានទេ ដូចនេះសាកសពពួកគេត្រូវបានទុកចោលគ្មានអ្នកណាមើលនោះទេ)។

[១៤៥១] ឧទាហរណ៍ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៤៣ ERN (ភាសាខ្មែរ) 00836120 (លោក S បានរៀបរាប់ថា នៅបន្ទាយ កូនក្មេងអាយុ ៧ ឆ្នាំ ដែលបានដើរជាមួយឪពុកម្ដាយក្នុងអំឡុងពេលម៉ោងក្ដៅបំផុតនៅពេលថ្ងៃបានស្លាប់ប៉ុន្មានម៉ោងក្រោយមកបន្ទាប់ពីផឹកទឹកតាមបឹង)។ ទំព័រ ១៧២-១៧៤ ERN (ភាសាខ្មែរ) 00836249-00836251 (កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ប៉ុក សារិត បានរៀបរាប់អំពីការស្លាប់របស់ទារកអាយុមួយខែ ដែលបានឈឺ ហើយសល់តែស្បែក និងឆ្អឹងប៉ុណ្ណោះ។ នៅព្រែកពោធិ៍ ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ខ្មែរក្រហមបានឆែកឆេរពួកគាត់ និងបានយកថ្នាំពេទ្យដែលគាត់ទុកឲ្យកូនដែលកំពុងតែឈឺ។ ២ ថ្ងៃក្រោយមក កូនរបស់ពួកគាត់បានស្លាប់ដោយសារមិនមានថ្នាំពេទ្យ។ ... ១៥ ថ្ងៃក្រោយមក កូនទីបួនរបស់ពួកគាត់អាយុ ៤ ឆ្នាំ បានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារតែមិនមានថ្នាំពេទ្យ), ទំព័រ ២១៩ ERN (ភាសាខ្មែរ) 00836296 (កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៧៦ អនុសេនីយ៍ត្រី ណុប ចុល បានលើកឡើងថា ក្នុងចំណោមកូនទាំងអស់ចំនួន ៧ នាក់ដែលចាកចេញពីភ្នំពេញជាមួយគាត់ កូនបីនាក់បានស្លាប់ដោយសារជំងឺ និងភាពអត់ឃ្លានក្នុងរយៈពេល៣ខែ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុត ណារី ឯកសារ E3/4921 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00586773 (ប្អូនប្រុស និងប្អូនស្រីរបស់គាត់ដែលនៅបៅដោះ បានស្លាប់ដោយសារអត់អាហារ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កែម កួន ឯកសារ E3/5418 ថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480987 (កូនប្រុសទីបីរបស់គាត់ ស្លាប់ដោយសារភាពអត់ឃ្លាននៅតាមផ្លូវ)។

[១៤៥២] របាយការណ៍រាជរដ្ឋាភិបាលចក្រភពអង់គ្លេស៖ *ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3319 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ កថាខណ្ឌ ៦ ERN (ភាសាខ្មែរ) 00699212-00699213។ *ការធ្វើវិភាគ*

ទឹកដោះ ទឹកដោះគោ ឬ ថ្នាំពេទ្យសម្រាប់ទារករបស់គាត់ ពេជ ស្រីផល អាចត្រឹមតែផ្ដល់ទឹកដល់ទារករបស់គាត់ប៉ុណ្ណោះ។ មិនយូរប៉ុន្មាន កូនរបស់គាត់បានស្លាប់ ហើយគាត់ត្រូវបានណែនាំឱ្យកប់សពកូនរបស់គាត់នៅក្នុងព្រៃ[១៤៩៣]។ អ្នកផ្សេងទៀត ដូចជា កូនស្រីពៅរបស់ បេ សុផានី ដែលមានជំងឺរាគមួល និងក្អួត បានស្លាប់ដោយសារខ្វះការថែទាំផ្នែកវេជ្ជសាស្ត្រ។ បេ សុផានី បានរៀបរាប់អំពីរបៀបដែលកូនស្រីរបស់គាត់បានឆ្លងរោគភ្លាមៗ និងបានស្លាប់ បន្ទាប់ពីពេទ្យកងទ័ពដែលគាត់យកកូនទៅឱ្យពិនិត្យនោះ បានចាក់បញ្ចូលអ្វីមួយទៅក្នុងក្បាលកូនស្រីរបស់គាត់។ បេ សុផានី ក៏បានកប់សពកូនរបស់គាត់នៅក្នុងព្រៃក្បែរនោះ[១៤៩៤]។

### ១០.២.១៥ សាកសព

៤៩៩. ទោះបីជាប្រជាជនមួយចំនួនបានអះអាងថា ពួកគាត់មិនបានឃើញសាកសពនៅតាមផ្លូវក៏ដោយ[១៤៩៥] ក៏មានភស្តុតាងជាច្រើនបង្ហាញអំពីអ្នករងរបួស ឬ សាកសពជាច្រើននៅតាមដងផ្លូវចេញពីទីក្រុងភ្នំពេញ[១៤៩៦]។ យោងតាមសាក្សី គង់ គីម ដែលជាអតីតកងទ័ពខ្មែរក្រហមបាន

---

*មួយតាងនាមឱ្យគណៈកម្មការដោយប្រធានរបស់អនុគណៈកម្មការនេះ ស្ដីពីឯកសារនានាដែលបានដាក់ជូនអនុគណៈកម្មការនេះ និងគណៈកម្មការសិទ្ធិមនុស្សតាមសេចក្ដីសម្រេចលេខ ៩ របស់គណៈកម្មការសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/2060 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ១៧-១៨ ERN (ភាសាខ្មែរ) 00294952-00294954។

[១៤៩៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២០-២១។

[១៤៩៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ១០-១១។

[១៤៩៥] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ១២-១៣ (គាត់មិនបានឃើញប្រជាជនណាមួយស្លាប់ក្នុងអំឡុងនៃការជម្លៀសនោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២៣-២៦ (មិនបានឃើញសាកសពនៅតាមផ្លូវទៅព្រែកព្នៅក្រោយថ្ងៃទី ១៧ ខែ មេសា ៥ ឬ ៦ ថ្ងៃនោះទេ), ទំព័រ ៣១-៣២។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (ជួន ធី) ទំព័រ ៧៤-៧៥ (កងទ័ពខ្មែរក្រហមមួយរូបបានលើកឡើងថា គាត់មិនដែលឃើញសាកសព ឬ ប្រជាជនត្រូវរបួសនោះទេ)។

[១៤៩៦] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៤-៥, ទំព័រ ២៩-៣០ (បានឃើញសាកសពនៅលើស្ពានមុនីវង្ស)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧៥-៧៧ (បានឃើញប្រជាជនត្រូវរបួស), ទំព័រ ៨៩-៩០ (បានឃើញសាកសពទាហានលន់ នល់ ៣នាក់នៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៩-១០ (បានឃើញសាកសពក្នុងអំឡុងពេលដែលកំពុងប្រយុទ្ធគ្នាខ្លាំង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០ (សង្កេតឃើញថា ប្រជាជនឈឺ និងស្លាប់នៅតាមចិញ្ចើមផ្លូវលើផ្លូវជាតិលេខ២)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៥-១៧ (ត្រឹមយប់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ពួកគាត់បានឃើញប្រជាជនស្លាប់នៅតាមផ្លូវទៅស្ទឹងមានជ័យ)។ ប្រតិចារឹក ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១២

(ជុំ សុខា) ទំព័រ ៣០-៣១, ទំព័រ ៣២-៣៤, ទំព័រ ៧៤-៧៦ (បានឃើញសាកសពនៅតាមចញ្ចើមផ្លូវ នៅពេលគាត់ និងគ្រួសារគាត់បានចាកចេញពីទីក្រុងតាមផ្លូវជាតិលេខ៤ នៅប្រហែលម៉ោង ៦៖៣០ ឬ ៧ នាល្ងាចថ្ងៃទី១៧ ខែ មេសា ហើយគាត់ក៏បានឃើញផ្សែង និងសាកសពដែលគេដុតនៅក្បែរព្រលានយន្តហោះពោធិ៍ចិនតុង និងផ្នែកដឹកជញ្ជូន (បន្ទាយត្រង់ស្ព័រ)។ គាត់ក៏បានឃើញសាកសពនៅតាមផ្លូវជាតិលេខ ៣ ក្បែរកំពង់ទួលផងដែរ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ៤០-៤១ (បានឃើញសាកសពនៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៦៨-៦៩, ទំព័រ ៧៩-៨០ (នៅពេលគាត់ដើរតាមផ្លូវជាតិលេខ ១ និងតាមទន្លេ គាត់បានឃើញសាកសពអណ្តែត ទោះបីជាគាត់មិនបានដឹងថាតើសាកសពទាំងនោះ គឺជាសាកសពជនស៊ីវិល ឬ ទាហាននោះទេ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨៣ (បានឃើញសាកសពនៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៨-៨០។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៥-២៦ (បានឃើញសាកសពជន ស៊ីវិល និងកូនក្មេងនៅឃុំ ព្រែកប្រា។ បានឃើញសាកសព ១ ឬ ២ នៅតាមផ្លូវចេញពីភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ២០-២១ (បានឃើញសាកសពប្រហែល ២០ សាកសព នៅតាមផ្លូវទៅកាន់ព្រែកសំរោង។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤១ (នៅតាមផ្លូវជាតិលេខ២ ចេញពីភ្នំពេញ បានសង្កេតឃើញប្រជាជនស្លាប់នៅតាមចិញ្ចើមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣២-៣៣ (បានឃើញសាកសពនៅខាងកើតស្ពានមុនីវង្សតាមបណ្តោយមាត់ទន្លេនៅថ្ងៃទីពីរក្រោយពីការជម្លៀស) ទំព័រ ៣៤-៣៥ (បានឃើញសាកសពទាហានដាច់ក្បាលនៅតាមផ្លូវ)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ អតីត ឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499663-00499664។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00658221 កថាខណ្ឌ ៣។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២១-២២ ERN (ភាសាខ្មែរ) 00228737-00228738 (គង្ស សម្រេច បានឃើញសាកសពស្អុយរលួយនៅតាមចិញ្ចើមផ្លូវ និងនៅតាមមាត់ទន្លេមេគង្គ និងសាកសពចំនួន ៤ នៅវត្តវាលស្បូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែន សុផុន ឯកសារ E3/4821 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523262-00523263(សាកសពដេកសន្ធឹកតាមសងខាងផ្លូវនានា ជាពិសេសនៅតំបន់មន្ទីរពេទ្យរុស្ស៊ី)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00398496 (ឃើញសាកសពរួញស្វិតឡើងខ្មៅជាច្រើននៅតាមត្រើយខាងកើតអ្នកលឿង និងសាកសពរាប់រយស្ថិតនៅតាមផ្លូវនៅកំពង់សឹង្ហ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង សុខុម ឯកសារ E3/4702 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00368960-00368961 (មានសាកសពមនុស្សជាច្រើននៅតាមផ្លូវ ប៉ុន្តែគាត់មិនបានប្រាប់បានថាតើសាកសពទាំងនោះគឺជាជនស៊ីវិល ឬ ទាហាននោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00152235-00152236 (នៅតាមផ្លូវមុនីវង្សចេញពីភ្នំពេញ បានឃើញសាកសពទាហានជាច្រើនត្រូវបានគេសម្លាប់នៅក្នុងសង្គ្រាម និងជនស៊ីវិលជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់

អះអាងថា មានសាកសពជាច្រើនដែលពួកគាត់ត្រូវបានបញ្ជាឲ្យយកចេញពីផ្លូវ ហើយពួកគាត់ត្រូវប្រើប្រាស់ត្រាក់ទ័រដើម្បីរុញសាកសពទាំងនោះចូលទៅក្នុងទន្លេ[១៤៩៧]។

៥០០. ជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណថាជាទាហានសាធារណរដ្ឋខ្មែរ[១៤៩៨] ឬ ជាជនស៊ីវិលមានទាំងក្មេង ទាំងចាស់[១៤៩៩]។ កាលៈទេសៈពិតប្រាកដនៃការស្លាប់របស់សាកសពដែលមាននៅ

---

ដោយសារប្រកែកមិនព្រមចាកចេញពីផ្ទះពួកគាត់តាមបញ្ជារបស់ពួកខ្មែរក្រហម), ទំព័រ ៤ ERN (ភាសាខ្មែរ) 00152236 (ខណៈពេលដែលនៅវត្តចម្បារ បានឃើញសាកសព ប្រុសៗដែលត្រូវបានគេចងមុខ អណ្តែតនៅក្នុងទឹក)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ជុយ ប៉ុក ឯកសារ E3/5167 គ្មាន ចុះកាលបរិច្ឆេទ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00196060-00196061 (អតីតកងទ័ពខ្មែរក្រហមមួយរូប បានឃើញសាកសពជាច្រើននៅតាមផ្លូវនានា ជាពិសេសមនុស្សចាស់ជរា និងកូនក្មេង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ម៉ន ឯកសារ E3/5278 ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩ ទំព័រ២-៣ ERN (ភាសាខ្មែរ) 00287524-00287525 (អតីតកងទ័ពខ្មែរក្រហមមួយរូប បានឃើញសាកសពជាច្រើននៅតាមផ្លូវ ជាពិសេសនៅរង្វង់មូលចោមចៅក្បែរពោធិ៍ចិនតុង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុត សេង ឯកសារ E3/5267 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00271405 (នៅតាមផ្លូវ គាត់បានឃើញតែខ្មោចមនុស្សដែលបានស្លាប់ ដែលមានលក្ខណៈក្រៀមអស់ទៅហើយ ហើយគេបានដើរជាន់ពីលើឡើងស្មៀត។ សាកសពខ្លះត្រូវបានឆ្កែហែកស៊ីទៀតផង។

[១៤៩៧] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៨៦-៨៧។

[១៤៩៨] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន) ទំព័រ ៤៨-៥១ (នៅថ្ងៃទី ១៩ ខែ មេសា បានធ្វើដំណើរចូលទីក្រុងភ្នំពេញជាមួយ សុន សេន និងបានឃើញសាកសពជាច្រើននៅតាមផ្លូវជាតិលេខ ៤ និងតាមព្រលានយន្តហោះពោធិ៍ចិនតុង។ សាកសពទាំងនោះ ប្រហែលជាពួកទាហាន បើផ្អែកតាមមួកដែលបានពាក់ ដោយរួមទាំងសាកសពខ្លះដែលបានស្អុយរលួយទៅហើយ)។ ប្រតិចារឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៩-៦១ (បានឃើញសាកសពទាហាន លន់ នល់ តាមផ្លូវទៅពោធិ៍ចិនតុង នៅពេលដែលគាត់បានចាកចេញពីផ្សារដេប៉ូ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៧០-៧១, ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៤-៣៥ (បានឃើញសាកសពទាហាន លន់ នល់ ដែលដាច់ក្បាល)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៩-៩០ (បានឃើញសាកសពទាហាន លន់ នល់ ៣នាក់នៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៥៧-៥៨, ទំព័រ ៧៩-៨០ (បានឃើញសាកសពទាហាន លន់ នល់ ស្អុយរលួយនៅចំការមន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥ (សាកសពទាហាន លន់ នល់ ដេកជាជួរនៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ២០-២១ (សាកសពតាមផ្លូវទៅព្រែកសំរោងដែលរួមមានទាហាន លន់ នល់ ផងដែរ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៣-៦៤ (បានឃើញសាកសពទាហានគរលើគ្នាក្បែរផ្សារព្រែកព្នៅ)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២០-២១ ERN (ភាសាខ្មែរ) 00228736-00228737 (គង្ស សម្រេច បានឃើញសាកសពចំនួន ៥ ដោយសារត្រូវគ្រាប់ផ្លោង ហើយសាកសពទាំងនោះពាក់អាវក្រាស់ និងស្លាកសម្គាល់) ទំព័រ

៣២-៣៣ ERN (ភាសាខ្មែរ) 00228748-00228749 (នៅលើដីគ្របដណ្ដប់ដោយសាកសពទាហានជាច្រើននាក់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថែម សែម ឯកសារ E3/5191 ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00198941-00198942 (បានឃើញសាកសពទាហាន លន់ នល់ ក្នុងឯកសណ្ឋាន ប៉ាវ៉ា នៅតាមផ្លូវជាតិលេខ ៣)។

[១៤៩៩] ប្រតិចារឹក ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៨-៨០ (បានរកឃើញសាកសពថ្មីៗនៅសហគមន៍ចាមនៅព្រែកប្រា ដែលក្នុងនោះមានស្ត្រី និងកូនក្មេងផងដែរ។ អ្នកផ្សេងទៀតបានប្រាប់គាត់ថា ពួកគេក៏បានឃើញសាកសពផងដែរ)។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៧០-៧១, ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សាវ៉ាន់) ទំព័រ ២៨-៣០ (ឃើញសាកសពប្រុសចំនួន២ នាក់ក្នុងសម្លៀកបំពាក់ស៊ីវិលក្បែរស្ថានមុនីវង្ស)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៧៩-៨០ (បានឃើញមនុស្សផ្សេងទៀត ដូចជាជនស៊ីវិលដែលត្រូវបានគេបំបាត់ចោល ហើយសាកសពរប៉ាត់រប៉ាយនៅតាមផ្លូវ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៣-៦៤ (ឃើញសាកសពជនស៊ីវិលក្បែរខ្សែលួសនៅតាមផ្លូវបន្ទាប់ពីគាត់ចាកចេញពីព្រៃញ៉ៅ។ ប្រតិចារឹក ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ២០-២១ (សាកសពតាមផ្លូវទៅព្រែកសំរោង រួមទាំង ជនស៊ីវិលផងដែរ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នាង មួង សុខន ឯកសារ E3/4681 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00323606 (មានសាកសពជាច្រើន តាមចិញ្ចើមផ្លូវ ជាពិសេសកូនក្មេងតូចៗ និងមនុស្សចាស់។ សាកសពទាំងនោះស្អុយរលួយ និងមានក្លិនស្អុយខ្លាំង)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង ចុន ឯកសារ E3/5562 ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00390283 (នៅស្ថានមុនីវង្សរហូតដល់ច្រាំងទន្លេខាងលិច គាត់បានឃើញសាកសពជាច្រើននៅរោងកុនចន្ទ្រា ដែលសុទ្ធតែជាជនស៊ីវិលទាំងអស់)។

រៀបរាប់ទាំងទាហាន និងជនស៊ីវិល៖ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៩-១០, ទំព័រ ១១-១២ (បានឃើញសាកសពជាច្រើន នៅពេលគាត់មកដល់ព្រែកហូរ ដែលក្នុងនោះរួមមានសាកសពទាហាន លន់ នល់ ព្រះសង្ឃ និងជនស៊ីវិល)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦០-៦១ (ក្នុងអំឡុងពេលធ្វើដំណើរ គាត់បានឃើញសាកសពនគរបាល យោធា និងជនស៊ីវិលដែលក្នុងនោះមានខ្លះក្មេង និងចាស់)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៨-៩ (បានឃើញសាកសពទាហាន លន់ នល់ មនុស្សចាស់ កូនក្មេង ស្ត្រីមានផ្ទៃពោះ ដេកសណ្ដូកតាមផ្លូវ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៨ ERN (ភាសាខ្មែរ) 00836275 (សេង យុទ្ធារិទ្ធិ បានកត់សម្គាល់ថា កាលពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានឃើញសាកសពប្រហែល ២០០ រប៉ាត់រប៉ាយតាមផ្លូវនៅរោងចក្រ PEPSI Cola ដែលភាគច្រើនជាកុមារ ខ្លះស្លាប់ដោយត្រូវគេបាញ់ ខ្លះទៀតត្រូវបានគេចាប់ចង និងវ៉ៃរហូតដល់ស្លាប់។ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ពេលដើរតាមផ្លូវ ពួកគាត់បានឃើញអ្នកស្លាប់ជាច្រើននាក់ ក្នុងនោះមានជនស៊ីវិល និងទាហាន និងមានបន្សល់ទុកគ្រាប់រំសេវជាច្រើនផងដែរ)។

តាមផ្លូវមិនមានភាពច្បាស់លាស់នោះទេ[១៥០០]។ សាកសពមួយចំនួន ជាពិសេស ទាហាន ទំនងជាត្រូវបានសម្លាប់នៅក្នុងអំឡុងពេលវាយប្រយុទ្ធមុនពេលកាន់កាប់បានទីក្រុងភ្នំពេញ។ ទោះជាយ៉ាងនេះក្តី ដោយពិចារណាលើភស្តុតាងដែលត្រូវបានលើកមកពិភាក្សា នៅក្នុងផ្នែក ១០.២.១៤ ("ការស្លាប់") អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សាកសពដែលត្រូវបានឃើញនៅពេលជម្លៀសនោះ រួមមាន ទាំងសាកសពទាហានដែលបានស្លាប់នៅក្នុងអំឡុងពេលប្រយុទ្ធគ្នា និងសាកសពអ្នកដែលត្រូវបានជម្លៀសផងដែរ។

### ១០.២.១៦ ការប្រព្រឹត្តិមកលើអ្នករដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ

៥០១. ក្រោយពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ឧត្តមសេនីយ៍ ម៉ី ស៊ីចន បានធ្វើការប្រកាសតាមវិទ្យុមួយដោយអំពាវនាវឲ្យទាហានសាធារណរដ្ឋខ្មែរទម្លាក់អាវុធចុះ[១៥០១]។ ខ្មែរក្រហម

---

[១៥០០] *ឧទាហរណ៍ សូមមើល* ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៩-៩០ (នៅតាមផ្លូវ បានឃើញសាកសពទាហាន លន់ នល់ ៣នាក់ ដែលអាចស្លាប់ពេលប្រយុទ្ធគ្នា ដោយសារតែសាកសពឡើងហើម និងមានរុយរោមច្រើន)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ៤០-៤១ (បានគិតថា សាកសពដែលឃើញតាមផ្លូវ អាចជាសាកសពអ្នកដែលមិនព្រមស្តាប់តាមបញ្ជាខ្មែរក្រហម)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ២១ (គិតថា សាកសពមួយចំនួនអាចនឹងស្លាប់ដោយសារអស់កម្លាំង។ តាមផ្លូវចេញពីភ្នំពេញតាមផ្លូវជាតិលេខ២ បានសង្កេតឃើញមនុស្សឈឺដួល)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៩-១០ (២សប្តាហ៍ក្រោយមក នៅពេលពួកយើងត្រូវបានគេយកចេញពីភ្នំពេញ យើងឃើញមានសាកសពតាមផ្លូវដែលត្រូវបានគេបង្ខំឲ្យចាកចេញ។ គាត់បានសន្និតថា សាកសពមួយចំនួនបានស្លាប់នៅតាមផ្លូវចេញពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៥២-៥៣ (នៅពេលដំបូង ពួកគាត់បានឃើញសាកសពទាហាន និងជនស៊ីវិលកម្ពុជានៅតាមចិញ្ចើមផ្លូវ ដែលបានកើតមានឡើងនៅពេលជម្លៀសចុងក្រោយ)។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២(Denise AFFONÇO) ទំព័រ៧៩-៨០ (សាកសពរាយប៉ាយនៅតាមផ្លូវ។ គាត់មិនបានត្រឡប់ទៅវិញដើម្បីរកអំពីមូលហេតុនៃការស្លាប់របស់អ្នកទាំងនោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ សារឿន ឯកសារ E3/5338 កែវ សារឿន ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00454027-00454028 (រៀបរាប់ថាគាត់បានឃើញទាហាន លន់ នល់ ស្លាប់ ២ នាក់នៅពេលវាយប្រហារនៅភ្នំពេញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00368783-00368784 (តាមផ្លូវទៅខេត្តកំពង់ចាម គាត់បានឃើញសាកសពទាហានដែលស្លាប់ដោយសារសង្គ្រាម)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុយ សឿង ឯកសារ E3/5375 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00477206-00377207 (បានឃើញសាកសពជាច្រើននៅតាមផ្លូវទៅតាកែវ ប៉ុន្តែមិនដឹងថាហេតុអ្វីពួកគាត់ស្លាប់)។

[១៥០១] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦១ ។

បានជូនដំណឹងដល់ប្រជាជនក្នុងទីក្រុងភ្នំពេញតាមរយៈមេក្រូថា ពួកគាត់អាចទៅបំពេញការងាររបស់ពួកគាត់បានធម្មតា ហើយមានតែជនក្បត់ជាតិ ៧ រូបប៉ុណ្ណោះ ដែលរួមទាំង លន់ នល់ សិរិមតៈ និង ចេង ហេង នឹងត្រូវសម្លាប់ចោល[១៥០២]។ នៅពេលនោះ អ្នករដ្ឋការជាន់ខ្ពស់មួយចំនួនដែលត្រូវបានកំណត់អត្តសញ្ញាណពីមុនរួចហើយតាមរយៈវិទ្យុ រួមទាំង លន់ នល់ ផងនោះ បានរត់គេចខ្លួនចេញពីប្រទេស[១៥០៣]។ ឡុង បូរេត សិរិមតៈ និងអ្នករដ្ឋការជាន់ខ្ពស់ផ្សេងមួយចំនួនទៀតកំពុងស្ថិតនៅក្នុងប្រទេសកម្ពុជានៅឡើយ[១៥០៤]។

៥០២. ក្រោយពីការប្រកាសតាមវិទ្យុរួចមក ទាហាននៃរបបសាធារណរដ្ឋខ្មែរបានទម្លាក់អាវុធចុះគ្រវីទង់ជ័យស សុំចុះចាញ់ និងបានដោះឯកសណ្ឋានរបស់ខ្លួនចេញ[១៥០៥]។ អង្គភាពកងទ័ពខ្មែរក្រហមត្រូវបានណែនាំមិនឲ្យបាញ់អ្នកដែលគ្រវីទង់ជ័យសនោះទេ[១៥០៦]។

---

[១៥០២] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៨-២៩, ទំព័រ ៧៦-៧៨ *សូមមើលផងដែរ* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១២០។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១១-១២ (បានឮអំពីការរាយការណ៍តាមវិទ្យុ នៅខែ កុម្ភៈ មីនា និងដើមខែ មេសា ឆ្នាំ១៩៧៥ ដែលសំដៅទៅលើពួកក្បត់ជាតិដែលបានផ្តួលរំលំសីហនុ និងបានលើកឡើងថា គាត់បានឮថា ពួកក្បត់ លន់ នល់ ត្រូវសម្លាប់ចោល)។

[១៥០៣] *សូមមើល* ផ្នែកទី៣,បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៦៤ ។

[១៥០៤] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ការសុំសិទ្ធិជ្រកកោននយោបាយ ឯកសារ E3/2694 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ (កុងស៊ុលស្ថានទូតបារាំងឈ្មោះ Dyrac បានរាយឈ្មោះបុគ្គលទាំងឡាយដែលមានវត្តមាននៅស្ថានទូត គឺព្រះអង្គម្ចាស់សិរិមតៈ មន្ត្រីគាត់ ២ នាក់ ព្រះនាង មុំ ម៉ានីវង្ស (ព្រះយាជាទីបីរបស់សម្តេចសីហនុ) និងកូនស្រី កូនប្រសារប្រុស និងចៅប្រុសស្រីរបស់គាត់ អ៊ុង ប៊ុនហ៊ី (ប្រធានរដ្ឋសភាជាតិ) និងលឿង ណាល់ (រដ្ឋមន្ត្រីក្រសួងសុខាភិបាល)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ការចាកចេញនៃជនភៀសខ្លួន ឯកសារ E3/2700 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00504002 (Dyrac បានកត់សម្គាល់ថា សមាជិកក្រុមរណសិរ្សរួបរួមដើម្បីរំដោះជាតិសាសន៍ចំនួន ១៥៥ នាក់ និងលោក អ៊ី បែនសួក អតីតចៅហ្វាយខេត្តរតនគីរី ក៏មានវត្តមាននៅស្ថានទូតផងដែរ)។ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ទំព័រ ៥៥-៥៧ (ក្រុមហ្វូលរ៉ូ (FULRO) គឺជាសហព័ន្ធដើម្បីរំដោះជនជាតិភាគតិចដែលទទួលរងនូវការគាបសង្កត់ ដែលជាក្រុមជនជាតិភាគតិចម៉ុងតាញ៉ា (Montagnard) ដែលបានវាយប្រយុទ្ធនៅខាងអាមេរិក ក្នុងអំឡុងសង្គ្រាមវៀតណាម និងសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជា)។

[១៥០៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៨-៩, ទំព័រ ៣៨-៣៩, ទំព័រ ៤៥-៤៦ (កងពលធំរបស់គាត់ ត្រូវបានទទួលស្វាគមន៍នៅទីក្រុងភ្នំពេញដោយជនស៊ីវិល និងទាហាន លន់ នល់ ដែលលើកទង់ស និងសង្កេតឃើញអាវុធរប៉ាត់រប៉ាយនៅតាមផ្លូវ។ ទាហាន លន់ នល់ មិនមានអាវុធទេ នៅពេលចូលទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៧-៨ (អតីតមេបញ្ជាការខ្មែរក្រហមមួយរូប បានឃើញជនស៊ីវិល

គ្រវីទង់សពីផ្ទះពួកគាត់)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៥-១៦, ទំព័រ ២២-២៤, ទំព័រ ២៥-២៦, ទំព័រ ៧៧, ទំព័រ ៨០ (ចំណាយពេលមួយម៉ោងថតរូបការប្រមូលអាវុធច្រើនឡើងៗ និងការទម្លាក់អាវុធរបស់ទាហាន លន់ នល់ នៅចំណុចប្រសព្វផ្លូវមុនីវង្សនិងផ្លូវព្រះសីហនុ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហួ ចន្ថា) ទំព័រ ៥៤-៥៥ (គ្រួសាររបស់ ហួ ចន្ថា និងអ្នកជិតខាងមួយចំនួនលើកទង់ជ័យស)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨១-៨២ (ឃើញប្រជាជនគ្រវីទង់ស)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ២៨ (ទាហាន លន់ នល់ ដែលរត់គេចខ្លួន បានដោះចេញឯកសណ្ឋានរបស់ខ្លួនមួយចំនួន។ ទាហានមួយចំនួន ដែលរួមទាំងរូបគាត់ផង បានកាន់ទង់ជ័យសតាមផ្លូវ) ទំព័រ ៧៣-៧៤ (ក្នុងនាមជាសមាជិកម្នាក់នៃកងទ័ពអាកាសរបស់ លន់ នល់ គាត់បានលាក់ឯកសណ្ឋាន និងកាំភ្លើងរបស់គាត់ និងបានស្លៀកពាក់ស៊ីវិលក្នុងអំឡុងពេលនៃការឈ្លានពានទីក្រុងភ្នំពេញ ដើម្បីជៀសវាងការកំណត់អត្តសញ្ញាណថាជាទាហាន លន់ នល់។ កងទ័ពខ្មែរក្រហមម្នាក់បានយកឯកសណ្ឋានមួយកំប្លេពីគាត់ ប៉ុន្តែមិនបានធ្វើអ្វីចំពោះគាត់នោះទេ), ទំព័រ ៧៤-៧៥ (បានឃើញទាហាន លន់ នល់ ជាច្រើនទម្លាក់អាវុធចុះ),ទំព័រ ៧៩-៨១ (ទំនងជាមានទាហាន លន់ នល់ ជាច្រើនស្លៀកពាក់ជាជនស៊ីវិលក្នុងចំណោមអ្នកជម្លៀសនានា ប៉ុន្តែ មិនមានអ្នកណាម្នាក់ស្លៀកពាក់ឯកសណ្ឋានយោធានោះទេ)។ ប្រតិចារឹក ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ៧១-៧២ (ប្ដីរបស់គាត់ដែលជាទាហាន លន់ នល់ បានដោះឯកសណ្ឋានរបស់គាត់ចេញ មុនពេលចូលឆ្នាំខ្មែរ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៤-១៥, ទំព័រ ៥៩ (ខ្មែរក្រហមបានប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់មានឯកសណ្ឋានទាហាន ឬ អាវុធ ពួកគាត់ត្រូវតែប្រគល់មកឲ្យពួកវា។ គាត់បានអាវុធដែលត្រូវបានគេប្រគល់ឲ្យ និងបោះចោលតាមផ្លូវ និងបានឃើញដោយផ្ទាល់ភ្នែក ខ្មែរក្រហមបានឲ្យប្រុសៗក្នុងឯកសណ្ឋានយោធា ដោះឯកសណ្ឋានរបស់ខ្លួនចេញ ហើយអ្នកទាំងនោះបន្តដំណើរដោយគ្មានសម្លៀកបំពាក់)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨ (យើងបានឃើញអ្នកផ្សេងទៀតបានចុះចាញ់ និងត្រូវបានគេដកហូតអាវុធ និងពួកក្មេងបានឆែកអ្នកផ្សេងទៀតរកអាវុធ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ លឹង លិញ ឯកសារ E3/4956 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00552103-00552104 (អតីតទាហាន លន់ នល់ មួយរូបនៅភ្នំពេញនៅពេលដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុង បានដោះសម្លៀកបំពាក់ទាហានគាត់ចេញមកពាក់សម្លៀកបំពាក់កូនសិស្សវិញ ដោយខ្លាចគេបាញ់សម្លាប់គាត់ និងក្រោយមកត្រូវបានជម្លៀសជាមួយអ្នកផ្សេងទៀត)។ *សូមមើលផងដែរ សៀវភៅនិពន្ធដោយ R. Neveu៖ ការបែកទីក្រុងភ្នំពេញ* ឯកសារ E3/3208 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាអង់គ្លេស) 00432453, 00432469, 00432480-82, 00432484-85 *(រូបភាពបានបង្ហាញអំពីការប្រមូលអាវុធ)* ។

[១៥០៦] ប្រតិចារឹក ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ទំព័រ ៦៩-៧០ (ដកស្រង់ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស វឿន ឯកសារ E3/424 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00418518-00418519)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៤៥-៤៧ (យើងបានចាត់ទុកអ្នកដែលគ្រវីទង់ជ័យសថាជាអ្នកចុះចាញ់ និងទម្លាក់អាវុធរួចហើយ)។ *សូមប្រៀបធៀបជាមួយនឹង* ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ទំព័រ ៧០-៧១ (អតីតកងទ័ពខ្មែរក្រហមបានអះអាងថា មានការបាញ់កាំភ្លើងគ្រប់កន្លែង ដូច្នេះពួកគាត់មិនប្រាកដថាតើពួកគេលើកទង់ជ័យសដើម្បីចុះចាញ់ និងចុះចូលខណៈពេលដែលមានអ្នកផ្សេងក្នុងចំណោមនោះផងដែរ។ ពួកគាត់ត្រូវតែបាញ់អ្នកទាំងឡាយដែលនៅទីនោះ)។

៥០៣. ក្រោយពីបានត្រួតត្រាក្រសួងព័ត៌មាន ជនមិនស្គាល់អត្តសញ្ញាណម្នាក់បានប្រកាសក្នុងនាមជាខ្មែរក្រហម ដោយទាមទារឲ្យ "រដ្ឋមន្ត្រី និងឧត្តមសេនីយ៍ផ្សេងៗទាំងអស់ដែលមិនទាន់បានរត់ចេញនៅឡើយ សូមចូលខ្លួនភ្លាមៗមកកាន់ក្រសួងព័ត៌មានដើម្បីរក្សាសណ្ដាប់ធ្នាប់"[១៥០៧]។ ឆ្លើយតបទៅនឹងការប្រកាសតាមវិទ្យុនេះ ឧត្តមសេនីយ៍ និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរជាច្រើន បានមករាយការណ៍នៅក្រសួងព័ត៌មានដែលរួមមានទាំងឧត្តមសេនីយ៍ត្រី លន់ ណុន (ប្អូនប្រុសរបស់សេនាប្រមុខ លន់ នល់) ឧត្តមសេនីយ៍ត្រី ឈឹម ឈួន និងនាយករដ្ឋមន្ត្រី ឡុង បូរេត និងប្រពន្ធរបស់គាត់ផងដែរ[១៥០៨]។ កងទ័ពខ្មែរក្រហមក៏បានស្វែងរកចាប់ខ្លួនអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណ-

---

[១៥០៧] *សូមមើល* ផ្នែកទី១០ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦២ តំណាងកងទ័ពរំដោះជាតិប្រជាជនកម្ពុជាប្រាប់ឲ្យកងទ័ពរដ្ឋាភិបាលចុះចាញ់ និង*តាមការរាយការណ៍ថ្ងៃទី ១៧ ខែ មេសា ថាកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលចុះចាញ់* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00905195-00905197។ ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ (François PONCHAUD) ទំព័រ៣៥ (មិនមានការចរចានោះទេ។ ម៉ី ស៊ីចន ចង់ឲ្យទាហានចុះចាញ់ ទាហានសាធារណរដ្ឋទម្លាក់អាវុធចុះ និងមិនមានការចរចានោះទេ។ សម្ដេច ហួត តាត (HUOT Tat) បានណែនាំឲ្យអ្នកគ្រប់គ្នារួមគ្នាធ្វើការជាមួយគ្នាដើម្បីកសាងប្រទេស)។ ប្រតិចារឹក ថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៣-៣៤ (ដកស្រង់ *កំណត់ហេតុប្រចាំថ្ងៃ* S. Schanberg៖ *កំណត់ហេតុស្ដីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១១១-១១៤ ERN (ភាសាខ្មែរ) 00963949-00963952 សេចក្ដីប្រកាសបដិវត្តន៍បានលើកឡើងថា៖ "យើងបានយកឈ្នះលើបនក្បត់ លន់ នល់។ ហេតុដូច្នេះ យើងអំពាវនាវឲ្យមេបញ្ជាការនៃកងក្បត់ទាំងអស់ដាក់អាវុធចុះ ហើយចុះចាញ់។ ទាហានណាមួយដែលប្រកែក ត្រូវតែដាក់ទណ្ឌកម្មធ្ងន់ធ្ងរ"។ សារផ្សេងទៀត ដែលចាក់ផ្សាយច្រើនដង បានអញ្ជើញរដ្ឋមន្ត្រី និងឧត្តមសេនីយ៍ទាំងអស់ឲ្យមកជួបគ្នាភ្លាមៗជាមួយមេដឹកនាំខ្មែរក្រហមនៅក្រសួងព័ត៌មានដើម្បីជួយគ្នាបង្កើតវិធានការរក្សាសណ្ដាប់ធ្នាប់)។

[១៥០៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៣-៣៤ (ដកស្រង់ S. Schanberg៖ *កំណត់ហេតុស្ដីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១១៧-១១៨ ERN (ភាសាខ្មែរ) 00963955-00963956, បានកត់សម្គាល់ឃើញថា អ្នកទោសប្រហែល ៥០ នាក់ ឈរនៅខាងមុខអគារក្រសួងក្នុងនោះ មានឧត្តមសេនីយ៍ត្រី លន់ ណុន ប្អូនប្រុសរបស់សេនាប្រមុខ លន់ នល់ និងឧត្តមសេនីយ៍ត្រី ឈឹម ឈួន), ទំព័រ ៣៤-៣៧ (ឡុង បូរេត ក៏បានមកដល់តាមក្រោយផងដែរនៅក្នុងថ្ងៃនោះ។ កងទ័ពខ្មែរក្រហមប្រហែល ១០ ទៅ ១៥ នាក់ ប្រដាប់ដោយអាវុធពាសពេញបានឡោមព័ទ្ធពួកគេ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៣៥-៣៦, ទំព័រ ៣៩ (បានឃើញអ្នកមុខអ្នកការប្រហែល ២០ នាក់ មកពីរបប លន់ នល់ និងខ្មែរក្រហមខ្លះនៅក្រសួង) ទំព័រ ៣៥-៣៦, ទំព័រ ៤១-៤២ (នាយករដ្ឋមន្ត្រី ឡុង បូរេត និងប្រពន្ធរបស់លោក ដែលនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមក៏បានមកដល់ ហើយត្រូវបានពួកគេយកចេញទៅប្រហែល ២០ នាទីក្រោយមក), ទំព័រ ៣៧-៣៨ (ក្រៅពី ឡុង បូរេត គាត់មិនស្គាល់មន្ត្រីនៃរបប លន់ នល់ ផ្សេងទៀតនៅក្រសួងព័ត៌មាននោះឡើយ ដោយសារគាត់មិនមានទំនាក់ទំនងផ្ទាល់ជាមួយពួកគេ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Alan

01006753



រដ្ឋខ្មែរដែលជ្រកកោននៅស្ថានទូតបារាំង។ Sydney SCHANBERG បានរៀបរាប់ថា គាត់បានឃើញដោយផ្ទាល់ភ្នែកនៅពេលដែលព្រះអង្គម្ចាស់ សិរិមតៈ និង អ៊ុង ប៊ុនហ៊ (ប្រធានរដ្ឋសភាជាតិ) ដែលអ្នកទាំងពីររូបបានជ្រកកោននៅក្នុងស្ថានទូតបារាំង បានចេញពីស្ថានទូតជាមួយនឹងកងទ័ពខ្មែរក្រហម បន្ទាប់ពីពួកកងទ័ពទាំងនោះបានចូលឆែករកពួកគាត់[១៥០៩]។ មន្ត្រីជាន់ខ្ពស់ជាច្រើន

---

ROCKOFF)ទំព័រ ៣៦-៣៧ (នៅទីនោះ មានយោធា និងជនស៊ីវិលលាយឡំគ្នា ប៉ុន្តែ ដោយសារតែអ្នកមុខអ្នកការជាង ២០ នាក់ សុទ្ធតែស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល គេពិបាកប្រាប់ថាតើពួកគេគឺមានឋានៈជាយោធា ឬ ជាអ្នករដ្ឋការ)។ អនុស្សារណៈសេតវិមានវ៉ាស៊ីនតោន ស្តីពីកំណត់ហេតុនៃកិច្ចសន្ទនា ឯកសារ E3/3467 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00635591 (បានកត់សម្គាល់ឃើញថា ឡុង បូរេត សិរិមតៈ និង លន់ នល់ ត្រូវបានចាប់ខ្លួន។ ទោះបីជានិយាយសំដៅលើឈ្មោះ លន់ នល់ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការនិយាយនេះគឺចង់សំដៅលើ លន់ ណុន។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១៦-១៧ ERN (ភាសាខ្មែរ) 00644711-00644712 (នៅម៉ោង៤:00 រសៀល ពិពណ៌នាអ្នកទោស ៥០ នាក់ នៅមុខក្រសួងព័ត៌មាន រួមទាំង លន់ ណុន ឧត្តមសេនីយ៍មួយចំនួន និងលោក ហ៊ូ ហង្សស៊ិន ប្រធានខុទ្ទកាល័យរបស់លោក ឡុង បូរេត ហើយនៅម៉ោង ៤:៥០ រសៀល ការមកដល់របស់លោក ឡុង បូរេត)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៨ ERN (ភាសាខ្មែរ) 00836275 (និស្សិតច្បាប់មួយរូបបានលើកឡើងថា កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅម៉ោង ១០ ព្រឹក គាត់បានឃើញខ្មែរក្រហមបាននាំខ្លួនវរសេនីយ៍ឯក ម៉ាត់ សាហ្វ៉េន (MAT Safran) ទៅក្រសួងព័ត៌មាន)។

[១៥០៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤០-៤១, ទំព័រ ៤២-៤៣, ទំព័រ ៤៤-៤៥ (*ដកស្រង់ S. Schanberg៖ កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1, ទំព័រ ១៤៤-១៤៥ ERN (ភាសាខ្មែរ) 00963982-00963983 បានកត់សម្គាល់ឃើញថា នៅថ្ងៃទី ២០ ខែ មេសា កងទ័ពខ្មែរក្រហមមួយកងបំពាក់ដោយអាវុធពាសពេញបានមករកមន្ត្រីជាន់ខ្ពស់ដែលបានលាក់ខ្លួននៅក្នុងស្ថានទូត។ នៅវេលាម៉ោង ២ រសៀល ក្រោយពេលពិភាក្សាគ្នាជាមួយ Dyrac នៅច្រកទ្វារ មនុស្សប្រហែលជាង ១០ នាក់ដែលគេចង់បានបានចេញមកក្រៅ ក្នុងនោះរួមមាន ស្ត្រី និងកុមារ សិរិមតៈ និង អ៊ុង ប៊ុនហ៊ ដែលជាប្រធានរដ្ឋសភា)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ការចាកចេញនៃជនភៀសខ្លួន ឯកសារ E3/2700 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00491981 (Dyrac បានពិពណ៌នាអំពីវិធីដែលគណៈកម្មាការក្រុងបានអនុញ្ញាតឲ្យជនជាតិខ្មែរទាំងអស់ ដែលបានរត់ភៀសខ្លួនចូលក្នុងស្ថានទូត ហើយពួកគេបានចាកចេញទៅតាមទិសខាងជើងនៃទីក្រុង លើកលែងតែឥស្សរជននៃរបបចាស់ដែលត្រូវស្ថិតនៅក្នុងក្រុមមួយទៀត។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ការចាកចេញរបស់ជនភៀសខ្លួន ឯកសារ E3/2702 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00492870 (Dyrac រាយការណ៍ថា ទ្រង់សិរិមតៈ និងឥស្សរជនទាំងឡាយដែលមានរាយនាមនៅក្នុងទូរលេខរបស់គាត់នាពេលមុន ត្រូវបានសមាជិកនៃគណៈកម្មាធិការអនាមិកមួយ ពោលគឺ ក្រុមរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ឬ កងទ័ពជាតិ រំដោះយកចេញពីស្ថានទូត)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៥២-៥៤, ទំព័រ ៥៤-៥៧, ទំព័រ ៧៤-៧៥ (ក្រុមទាហានហ្វុលរ៉ូ (FEULRO)

ទោះបីជាមិនទាំងអស់ក្តីដែលក្នុងនោះ បានបាត់ខ្លួន ហើយក្រោយមក មានការបញ្ជូនព័ត៌មានតាមរយៈការទូត និងប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា មន្ត្រីជាន់ខ្ពស់ទាំងនោះរួមទាំងនាយករដ្ឋមន្ត្រី ឡុង បូរេត ឧត្តមសេនីយ៍ត្រី លន់ ណុន និងព្រះអង្គម្ចាស់ សិរិមតៈ ត្រូវបានសម្លាប់[១៥១០]។

---

យ៉ាងហោចណាស់ ចំនួន ៣០០ នាក់ [សហព័ន្ធរំដោះជនជាតិភាគតិច ដែលរងការគាបសង្កត់ជនជាតិភាគតិចម៉ុងតាញ៉ាដែលវាយប្រយុទ្ធខាងអាមេរិក នៅក្នុងអំឡុងពេលនៃសង្គ្រាមវៀតណាម និងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា] ត្រូវបានភ្ជង់នឹងចុងកាំភ្លើងបង្ខំឱ្យចាកចេញពីស្ថានទូតបារាំង។ ក្រោយពេលពួកគេចាកចេញទៅ ហើយក្រោយពេលអ្នកទាំងនេះស្ទើរទាំងអស់ចាកចេញផុតទៅ គាត់បានឮសម្លេងបាញ់កាំភ្លើងនៅបរិវេណទីលានកីឡាខាងជើងស្ថានទូត។ ប៉ុន្មានឆ្នាំក្រោយមក គេបានប្រាប់គាត់ថា មានរបាយការណ៍ថា ប្រជាជនទាំងនេះត្រូវបានគេបាញ់ចោលនៅក្នុងបរិវេណទីលានកីឡាអស់ហើយ)។ *សូមប្រៀបធៀបជាមួយនឹង* សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៤២ ERN (ភាសាខ្មែរ) 00836119 (លោក S ដែលជាអ្នកត្រូវបានគេសម្ភាសន៍ បានលើកឡើងថា គាត់ និងខ្មែរជាច្រើននាក់ ដែលត្រូវបានបណ្តេញចេញពីស្ថានទូតបារាំងត្រូវបានយកទៅស្តាតឡំព៊ីក។ នៅស្តាតនោះ គាត់បាននិយាយថា ពួកគេបានបំបែកចេញជាបីក្រុម៖ មន្ត្រីជាន់ខ្ពស់ និងយោធា (រួមមាន Dibellon, Dibalene, Plek Phuon, Cadet, Paul Y Bun Suor និងសមាជិកប្រហែល ១០០ នាក់ នៃរណសិរ្សរួបរួមរំដោះពូជសាសន៍ត្រូវគេជិះជាន់) ត្រូវបានដឹកតាមឡាន ខណៈពេលអ្នកផ្សេងទៀតបានដេកក្បែរៗគ្នានៅលើដីក្នុងខ្ទមនៅពេលយប់)។

[១៥១០] *ការទទួលស្គាល់ពីទំនាក់ទំនងនាពេលប្រជាជនចាកចេញ និងការទទួលស្គាល់ថាមានការប្រហារជីវិត* (បណ្តាញសារព័ត៌មាន *Relation*) ឯកសារ E3/604 ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ERN (ភាសាខ្មែរ) 00632772 (រាយការណ៍អំពីការបញ្ជាក់របស់ អៀង សារី ដែលលើកឡើងថា ឡុង បូរេត និង លន់ ណុន ត្រូវបានប្រហារជីវិត)។ ប្រតិចារឹក ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ (Sydney SCHANBERG) ទំព័រ ៣៦-៣៧ (នេះគឺជាលើកចុងក្រោយដែលគាត់បាននិយាយជាមួយ ឡុង បូរេត)។ ក្រោយមក ពួកវាបានប្រកាសថា ពួកវាបានសម្លាប់គាត់ហើយ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១១ (បានឮពីមន្ត្រីស្ថានទូតបារាំងថា ឡុង បូរេត និងសិរិមតៈត្រូវបានគេសម្លាប់ចោល)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤-៥ (បានឃើញសេចក្តីថ្លែងការណ៍របស់មេដឹកនាំខ្មែរក្រហមដែលទទួលស្គាល់ថា ពួកវាបានសម្លាប់ ឡុង បូរេត សិរិមតៈ និងអ្នកផ្សេងទៀត)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ៤២-៤៤ (បានឮក្រោយមកថា អ្នករដ្ឋការរបប លន់ នល់ បានធ្វើដំណើរទៅកាន់ទីលានលេងកីឡា (ស្ថានទូតអាមេរិកបច្ចុប្បន្ន) ដែលនៅទីនោះ អ្នករដ្ឋការរបប លន់ នល់ ត្រូវបានគេវាយរហូតដល់ស្លាប់។ គាត់មិនដែលឃើញ ឡុង បូរេត ឬ លន់ នល់ ម្តងទៀតនោះទេ)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ២១-២៣, ទំព័រ ២៧-២៨ (បានដឹងពីបងប្អូនជីដូនមួយឈ្មោះ យួន ថា នៅពេលខ្មែរក្រហមចូលមកដល់ភ្នំពេញ ឧត្តមសេនីយ៍ ថាច់ ត្រូវបានគេហៅទៅក្រសួងព័ត៌មាន។ យួន បានឃើញដោយផ្ទាល់នូវការសម្លាប់ឧត្តមសេនីយ៍នោះ)។ ទូរលេខស្ថានទូតអាមេរិក កម្មវត្ថុ៖ ទស្សកិច្ចរបស់ អៀង សារី មកកាន់ប្រទេសថៃ ឯកសារ E3/3358 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ១៩៧៥ កថាខណ្ឌ ៥ ERN (ភាសាខ្មែរ) 00602535 (កត់សម្គាល់ឃើញថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌កម្ពុជា

៥០៤. គ្រប់ទីកន្លែងក្នុងទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានព្យាយាមស្វែងរកសមាជិកដែលនៅសេសសល់នៃរបបសាធារណរដ្ឋខ្មែរដែលបានដួលរលំ និង "ជនសមគំនិត" ជាមួយសមាជិកទាំងនោះ[១៥១១]។ ដូច្នេះ ពួកកងទ័ពខ្មែរក្រហមបានស្វែងរកទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋ-

---

មានឱកាសម្តងទៀតដើម្បីជម្រាបភាគីថៃថា គាត់បានឮថា ក្នុងចំណោមជនក្បត់ ៧ រូប ដែលត្រូវប្រហារជីវិតជនទាំងឡាយណាដែលនៅក្នុងប្រទេស ក្នុងនោះរួមមាន ឡុង បូរេត និងសិរិមតៈ ត្រូវបានសម្លាប់ហើយ)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ អ៊ុង បូណាវ៉ាន់ ឯកសារ E3/4679 ERN (ភាសាខ្មែរ) 00323576 (ជាកូនប្រុសរបស់លោក អ៊ុង ប៊ុនហ៊ី ដែលនៅពេលនោះជាប្រធានរដ្ឋសភាជាតិនៃរបបសាធារណរដ្ឋខ្មែរ បានលើកឡើងថា គាត់ពុំទទួលបានដំណឹងអ្វីអំពីឪពុករបស់គាត់ឡើយ ចាប់តាំងពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ជាថ្ងៃដែលមន្ត្រីស្ថានទូតបារាំងបានប្រគល់គាត់ទៅឱ្យពួកខ្មែរក្រហម)។ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R (ឈុតវីដេអូបន្ថែម ៖ *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* (*One day at Po Chrey*)) ត្រង់ចំណុច 22.07 - 22.11 (នួន ជា បានអះអាងថា "បទបញ្ជានយោបាយ" របស់បក្សកុម្មុយនីស្តកម្ពុជាដែលថា ពួកជនមហាក្បត់ "ត្រូវតែកម្ចាត់" នោះ តាមពិតត្រូវបានអនុវត្ត)។ *សូមមើលផងដែរ*សហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៨២៤-៨២៦ និងលេខយោងជើងទំព័រ ២៦០២។

[១៥១១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២០-២១ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3961 ERN (ភាសាខ្មែរ) 00205057-00205058 មេបញ្ជាការវរសេនាតូចឈ្មោះ ហាក់ បានប្រាប់គាត់ថា ពួកគេត្រូវការជម្លៀសប្រជាជនចេញពីទីក្រុងដើម្បីបោសសម្អាតទាហាន លន់ នល់), ទំព័រ ៣៧ (អតីតទាហានខ្មែរក្រហមមួយរូប បានលើកឡើងថា ពួកគេចាត់ទុកទាហាន លន់ នល់ និងពួកសមគំនិតថាជាសត្រូវ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00373187 (ខ្មែរក្រហមបានប្រាប់ពួកគាត់ថាត្រូវសំអាតទីក្រុង និងបោសសំអាតទាហាន លន់ នល់)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ខាត់ ខេ ឯកសារ E3/5598 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ទំព័រ ១៦-១៨ ERN (ភាសាខ្មែរ) 00020697-00020699 (អតីតសមាជិកមួយរូបនៃកងពិសេសកាំភ្លើងធំនៃកងភូមិភាគឧត្តរ បាននិយាយថា កងទ័ពត្រូវបានគេប្រាប់ថា ការជម្លៀសគឺដើម្បី "ដេញខ្មាំងឲ្យអស់" ដែលមានន័យថា ទាហាន លន់ នល់ កំពុងលាក់ខ្លួននៅគ្រប់ទីកន្លែង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ E3/419 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00407747 (អតីតកងទ័ពខ្មែរក្រហមមួយរូបបានថ្លែងថា គាត់បានចូលរួមប្រជុំជាមួយ សំ ប៊ិត នៅពេលដែល សំ ប៊ិត បានប្រាប់ឲ្យពួកគាត់ជម្លៀសប្រជាជនចេញពីទីក្រុងក្នុងគោលបំណងដើម្បីពិនិត្យមើលអ្នកណាខ្លះជាទាហាន លន់ នល់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00172079-00172080 (អតីតកងទ័ពខ្មែរបានរៀបរាប់ថា មុនពេលចូលភ្នំពេញ ពួកគាត់ត្រូវបានគេប្រាប់ឲ្យវាយប្រហារលើពួកចក្រពត្តិអាមេរិក និងពួកអាយ៉ង លន់ នល់)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៧-៦៨ (ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលត្រូវបានគេជម្លៀសចេញ បាននិយាយថា ពួកវាចោទប្រកាន់គាត់ថាជាសត្រូវ ឬទាហាន លន់ នល់ និងបានប្រាប់ឲ្យពួកគាត់ចាកចេញ)។ ទម្រង់បែបបទសុំព័ត៌មានបន្ថែម

ខ្មែរនៅតាមកន្លែងផ្សេងៗ រួមទាំងនៅមន្ទីរពេទ្យ សណ្ឋាគារឡឺភ្នំ (Le Phnom) និងនៅស្ថានទូតបារាំងនៅពេលក្រោយៗមកទៀត[១៥១២]។ស៊ុំ ជា ដែលជាកងទ័ពខ្មែរក្រហមមួយរូប បានផ្តល់សក្ខីកម្ម

---

ប៉ាល់ រតនៈ ឯកសារ E3/4840 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ១ ERN (ភាសាខ្មែរ) 00581468 (គាត់ត្រូវបានពួកទាហានខ្មែរក្រហមរុញផង វាយផង ដោយសារតែចោទគាត់ថាជាទាហាន)។
*ពាក់ព័ន្ធនឹងអ្នកសមគំនិត សូមមើល* ប្រតិចារឹក ថ្ងៃទី០៩ ខ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៣៥-៣៦, ទំព័រ ៧១-៧៣ (បានរាយការណ៍ថា កងទ័ពខ្មែរក្រហមដែលគាត់បានដឹកជុំវិញភ្នំពេញកាលពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ មិនខ្លាចទាហាន លន់ នល់ នោះទេ ប៉ុន្តែបែរជាសួររកកន្លែងទាហានអាមេរិកទៅវិញ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ៅ គីមសូហ្វី ឯកសារ E3/5077 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00641221-00641222 (ពួកវាបាននិយាយថា ពួកវានឹងសម្អាតខ្មាំងចូលដៃអាមេរិកាំងដែលកំពុងលាក់ខ្លួនឲ្យអស់ពីទីក្រុង)។ អត្ថបទរបស់ Jon SWAIN (សារព័ត៌មាន London Times) ឯកសារ E3/51 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១១-១៦ ERN (ភាសាខ្មែរ) S 00644706-00644711 (Swain រាយការណ៍ថា ខ្មែរក្រហមបានប្រាប់ ឌិត ប្រាន ថា ពួកវាតាមចាប់តែអ្នកមាន និងអ្នកមានជីវភាពមធ្យមប៉ុណ្ណោះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00323529-00323530 (នៅភូមិមួយដែលគ្រួសារគាត់ឈប់សម្រាកក្នុងអំឡុងពេលជម្លៀស ខ្មែរក្រហមជារឿយៗបានប្រកាសតាមមេក្រូថា (យ៉ាងហោចណាស់ពីរលើកក្នុងមួយថ្ងៃ) អ្នកដែលត្រូវបានជម្លៀសមិនអាចត្រឡប់ទៅភ្នំពេញវិញទេ ដោយសារតែនៅមានពួកក្បត់ និងពួកអាមេរិកកាំងលាក់ខ្លួននៅទីនោះ)។
[១៥១២] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00541002-00541003 (ជាមួយនឹងឪពុកគាត់ ដែលជាគ្រូពេទ្យនៅមន្ទីរពេទ្យព្រះអង្គដួង នាពេលនោះ កងកម្លាំងខ្មែរក្រហមបានទម្លាយបង្ខូចនៃបន្ទប់ជាប់សោរដើម្បីស្វែងរកទាហាន លន់ នល់។ ឪពុករបស់គាត់បើកសោរបន្ទប់ដើម្បីបង្ហាញថាមិនមានទាហាន លន់ នល់ នោះទេ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ១៤ ឯកសារ E3/2693 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៥ ERN (ភាសាខ្មែរ) 00490999 (ខ្មែរក្រហមក៏បានសើុបសួរថាតើកងទ័ពខ្មែរក្រហមស្ថិតនៅក្នុងចំណោមអ្នកត្រូវរបួសនៅមន្ទីរពេទ្យកាល់ម៉ែតដែរឬយ៉ាងណា)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣២-៣៣ ERN (ភាសាខ្មែរ) 00228748-00228749 (ផាម មឿន បាននិយាយថា នៅមុំស្ថានីយវិទ្យុស្ទឹងមានជ័យ ខ្មែរក្រហមបានធ្វើការឆែកឆេររកឧត្តមសេនីយ៍ នាយទាហាន នាយទាហានរង និងពលទាហាន ព្រមទាំងនិយោជិកស្រីប្រុសផងដែរ)។ ប្រតិចារឹកថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១១-១២ (*ដកស្រង់* S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១១៣ ERN (ភាសាខ្មែរ) 00963951 នៅវេលាម៉ោងប្រហែល ៣ រសៀល នៅថ្ងៃទី ១៧ ខែ មេសា ខណៈពេលគាត់ត្រូវបានចាប់ខ្លួន កងទ័ពខ្មែរក្រហមដែលបានបាញ់រះគ្រាប់រ៉ុកកែត និងអាវុធផ្សេងទៀតដើម្បីព្យាយាមចូលក្នុង “តំបន់អព្យាក្រឹត្យ” គឺ សណ្ឋាគារលើភ្នំ។ បេសកកម្មចំបងរបស់ពួកគេ គឺដើម្បីឆែកឆេររកមន្ត្រីយោធារដ្ឋាភិបាល) ទំព័រ ១១-

ថា កន្លែងត្រួតពិនិត្យជាច្រើនក៏ត្រូវបានបង្កើតឡើងនៅក្នុង និងជុំវិញទីក្រុង នៅស្ពានជ្រោយចង្វារ និងផ្សារថ្មី ដើម្បីស្វែងរកអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និងអ្នកផ្សេងទៀត[១៥១៣]។

៥០៥. អង្គភាពកងទ័ពខ្មែរក្រហមផ្សេងៗបានទទួលបញ្ជាថា ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលបានទម្លាក់អាវុធចុះអាចនឹងត្រូវជម្លៀសចេញជាមួយប្រជាជន ឬ យកទៅអប់រំកសាង ប៉ុន្តែចំពោះអ្នកដែលរឹងទទឹងអាចនឹងត្រូវបាញ់សម្លាប់ចោល[១៥១៤]។

---

១៣ (គាត់បានដឹងពីអ្នកផ្សេងទៀតដែលនៅសណ្ឋាគារលើភ្នំនោះ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤០-៤១, ៤៤-៤៥ (*ដកស្រង់* S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១៣៩ ERN (ភាសាខ្មែរ) 00963977 បានកត់សម្គាល់ឃើញថា នៅថ្ងៃទី ១៨ ខែ មេសា នៅវេលាម៉ោងប្រហែល ៤:៣០ រសៀល រថយន្តបំពាក់ដោយមេក្រូ បានឆ្លងកាត់ស្ពានទូតបារាំងពីរបីដង ដោយបានប្រកាសដោយសំឡេងលាន់ឮ ខ្លាំងថា “នៅមានជនក្បត់ និងកំពូលជនក្បត់នៅក្នុងទីក្រុង។ យើងត្រូវស្វែងរកពួកវា”។ ទំព័រ ១៤៤ ERN (ភាសាខ្មែរ) 00963982 បានកត់សម្គាល់ថា នៅថ្ងៃទី២០ ខែ មេសា កងទ័ពមួយកងបំពាក់ដោយអាវុធពាសពេញបានមករកមន្ត្រីជាន់ខ្ពស់ដែលបានលាក់ខ្លួននៅក្នុងស្ពានទូត)។

[១៥១៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ៣៩-៤០ (និងដើម្បីធានាថា ប្រជាជនមិនអាចចូលទីក្រុងសាជាថ្មី)។ *សូមមើលផងដែរ* ទូរលេខស្ពានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ១១ ERN (ភាសាខ្មែរ) 00658224 (ស៊ិន ម៉ៅ បានកត់ឃើញសម្គាល់ថា ពួកទាហានដែលធ្វើដំណើរ ត្រូវបានទទួលការតាមដានយ៉ាងល្អិតល្អន់នៅកន្លែងត្រួតពិនិត្យជាងជនស៊ីវិល)។

[១៥១៤] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៨៩-៩១ (កងទ័ពខ្មែរក្រហមម្នាក់ បានលើកឡើងថា ទាហាន លន់ នល់ ដែលមិនរឹងទទឹង ត្រូវបានគេទុកជីវិតឲ្យ និងអាចត្រូវបានជម្លៀស។ អ្នករឹងទទឹងនឹងត្រូវគេបាញ់ចោល)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៤១-៤៣ (ដូចគ្នា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថា សុត ឯកសារ E3/464 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00204740 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា មេរបស់គាត់ កុយ ធួន បានប្រាប់ថា បើរឹងរូស ឲ្យបាញ់សម្លាប់ចោល។ បទសម្ភាសន៍ជាមួយ ឃឹម សំណាង ដោយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5660 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00183453 (សំណាងបានលើកឡើងថា បញ្ជារបស់គាត់គឺឲ្យបន្តវាយប្រយុទ្ធកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ រហូតទាល់តែពួកគេចុះចាញ់ ហើយអ្នកចុះចាញ់ត្រូវទុកជីវិតឲ្យរស់មិនសម្លាប់ចោលទេ ប៉ុន្តែយកទៅកសាង)។ បទសម្ភាសន៍ជាមួយ ខាត់ ខេ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5598 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ទំព័រ១ ERN(ភាសាអង់គ្លេស)00526857 (គាត់គឺជាអតីតសមាជិកម្នាក់នៃកងពិសេសកាំភ្លើងធំរបស់ភូមិភាគឧត្តរ។ គាត់បានលើកឡើងថា ប្រសិនបើទាហាន លន់ នល់ ដោះសម្លៀកបំពាក់ពួកគេចេញដាក់អាវុធចុះ និងចុះចូល ពួកគេទុកឲ្យរួចខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃន ប្រាក់ ឯកសារ E3/509 ចុះថ្ងៃទី០៨ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00270158 (អតីតកងទ័ពខ្មែរក្រហមម្នាក់ ដែល

៥០៦. អ្នករដ្ឋការស៊ីវិលនៃបបរសាធារណរដ្ឋខ្មែរ ទាហានដែលបានចុះចូលដែលមិនត្រូវបានចាប់ខ្លួន ឬ មិនត្រូវបានបញ្ជូនត្រឡប់មក“ធ្វើការងារ”នៅភ្នំពេញវិញ ហើយលែងស្លៀកពាក់ឯកសណ្ឋានរួមទាំងគ្រួសាររបស់ពួកគាត់ ត្រូវបានជម្លៀសចេញជាមួយប្រជាជនស៊ីវិលផ្សេងៗទៀត[១៥១៥]។

---

បានចូលរួមប្រជុំ៣ថ្ងៃមុនវាយចូលក្រុងភ្នំពេញ ដែល តា យឹម បានប្រាប់កងទ័ពទាំងអស់ថា ពេលដែលយើងវាយចូលដល់ភ្នំពេញ ធ្វើយ៉ាងម៉េចនិយាយជាមួយទាហាន លន់ នល់ ថា ទោះអ្នកឯងសក្តិប៉ុន្មានក៏ដោយ ត្រូវទម្លាក់អាវុធ ហើយយើងនឹងឲ្យអ្នកឯងចូលកាន់តំណែងវិញរយៈពេល៣ថ្ងៃក្រោយ។ គាត់ផ្ទាល់បានចូលបន្ទាយសក្តិ៣ នៅពោធិ៍ចិនតុង ហើយប្រាប់សក្តិ៣ នោះឲ្យទម្លាក់អាវុធចុះ ហើយឲ្យកូនទាហានរបស់លោកផ្តុំអាវុធទុកមួយកន្លែង ហើយទាំងអស់គ្នាត្រូវស្លៀកពាក់ជាប្រជាជនធម្មតា ហើយដើរចេញ។ កំណត់ហេតុនៃការ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373406-00373407 (អតីតកងទ័ពខ្មែរក្រហមម្នាក់ បានលើកឡើងថា គាត់បានទទួលបញ្ជាពីមេរបស់គាត់ឈ្មោះ សារី ថា ប្រសិនបើពួកគាត់រកឃើញមានទាហាន លន់ នល់ ពួកគាត់អាចសម្លាប់ពួកគេភ្លាម។ សម្រាប់អ្នកដែលចុះចាញ់ ត្រូវបានចាប់ខ្លួនជាអ្នកទោស ហើយដឹកជញ្ជូនតាមឡាន ប៉ុន្តែគាត់មិនដឹងថា គេយកអ្នកទាំងនោះទៅទីណាទេ។ បទសម្ភាសន៍ជាមួយ ទឹង លាប ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5683 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ៣៣-៣៤ ERN (ភាសាខ្មែរ) 00057214-00057215 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា កងពលលេខ ១ បានដើរជុំវិញទួលគោក ដកហូតអាវុធពីទាហាន លន់ នល់ ហើយក្រោយមកទាហានទាំងនេះត្រូវបានបញ្ជូនទៅតាមទីជនបទនៅប៉ែកខាងជើងក្រុងភ្នំពេញជាមួយនឹងប្រជាជន ដែលត្រូវបានជម្លៀសទៅតាមផ្លូវជាតិលេខ៥), ៣៣-៣៤ ERN (ភាសាខ្មែរ) 00057267-00057268 (ទាហាន លន់ នល់ បានចេញពីក្រុងដូចប្រជាជនធម្មតាដែរ)។ កំណត់ហេតុនៃការស្តាប់ចម្លើយ សែម ហឿន ឯកសារ E3/5152 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00170630 (អតីតកងទ័ពខ្មែរក្រហមក្នុងកងពល ៣១០ បានប្រាប់ទាហាន លន់ នល់ ឲ្យដោះខោអាវ ហើយឲ្យជម្លៀសខ្លួនជាមួយប្រជាជនចេញទៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អ៊ាន ឯកសារ E3/470 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00170622 (កងទ័ពខ្មែរក្រហមម្នាក់ បានលើកឡើងថា កងទ័ពខ្មែរក្រហមបានឲ្យទាហាន លន់ នល់ ដោះខោអាវ រួចហើយទម្លាក់កាំភ្លើងចោល ហើយក្រោយពីនេះទៅ ពួកគេអាចទៅណាក៏ទៅចុះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ឯកសារ E3/471 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00172079 (កងទ័ពខ្មែរក្រហមម្នាក់ បានលើកឡើងថា គាត់ឲ្យទាហាន លន់ នល់ ទាំងអ្នកស្លៀកសម្លៀកបំពាក់ឯកសណ្ឋាន និងទាំងអ្នកស្លៀកសម្លៀកបំពាក់ស៊ីវិល ចេញពីទីក្រុងដូចគ្នានឹងប្រជាជនស៊ីវិលដែរ)។

[១៥១៥] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៥៩-៦០, ទំព័រ ៨៤-៨៥ (នគរបាលម្នាក់នៅក្រោមរបប លន់ នល់ ត្រូវបានកងទ័ពខ្មែរក្រហមប្រាប់គាត់ឲ្យដោះស្បែកជើងកវែង និងមួកកន្ត្របនគរបាលរបស់គាត់ចេញ ដែលជាសញ្ញាបង្ហាញថា ខ្មែរក្រហមបានវាយទាហាន លន់ នល់ ឲ្យចុះចាញ់។ គាត់នៅបន្តស្លៀកសម្លៀកបំពាក់គាត់ដដែល ហើយបានបន្តដំណើរទៅមុខទៀត។ កងទ័ពខ្មែរក្រហមបានឆែកឆេរគាត់រកអាវុធនៅស្ពានជ្រោយចង្វារ ហើយគេបាន អនុញ្ញាតឲ្យគាត់បន្តដំណើរទៅមុខទៀត)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុត

បើទោះបីជា ទាហាន និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរត្រូវបានបញ្ជូនទៅកាន់ភូមិនានា ដើម្បីធ្វើការងារ ឬ អប់រំកសាងក៏ដោយ[១៥១៦] ក៏ភស្តុតាងខ្លះដែលមាននៅចំពោះមុខអង្គជំនុំជម្រះ

---

សែម ឯកសារ E3/4654 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00390312 (អតីតទាហាន លន់ នល់ ម្នាក់ បានលើកឡើងថា ចំពោះអ្នកខ្លះដែលមានខោអាវទាហាន និងកាំភ្លើង ត្រូវទុករបស់ទាំងនោះនៅតាមផ្លូវជាមុនសិន មុននឹងចាកចេញទៅ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ប្រុស ឯកសារ E3/5412 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00480405-00480406 (គាត់គឺជាទាហាន លន់ នល់ ម្នាក់ នៅបន្ទាយទាហាន លន់ នល់ ក្បែរវត្តភ្នំ។ នៅពេលខ្មែរក្រហមចូលមកដល់ គាត់បានលើកឡើងថា កងទ័ពខ្មែរក្រហមមួយក្រុមទៀតបានដឹកគាត់ និងមិត្តភក្តិគាត់យកទៅស្អាង។ ក្រោយពេលព្យាយាមរត់គេចត្រឡប់ទៅក្រុងភ្នំពេញវិញ ពួកគាត់ត្រូវបានចាប់ខ្លួន ហើយបង្ខំឱ្យចេះតែដើរទៅរហូតដល់រកាកោង ហើយស្នាក់នៅទីនោះបាន ១ ខែ)។

[១៥១៦] ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៤ ERN (ភាសាខ្មែរ) 00658221 (ស៊ិន ម៉ៅ បានកត់សម្គាល់ឃើញថា ប្រហែល ១២ គីឡូម៉ែត្រ ខាងកើតកំពង់ចម្លងព្រែកក្តាម ខ្មែរក្រហមបានចាប់ផ្តើមបែងចែកអ្នកជម្លៀស៖ ទាហាន នគរបាល និងភ្នាក់ងារសន្តិសុខផ្ទៃក្នុងត្រូវបានដាក់នៅក្នុងប្រភេទតែមួយ ដែល ស៊ិន ម៉ៅ បានយល់ឃើញថា គេយកអ្នកទាំងនោះទៅឱ្យដឹកប្រឡាយ និងលើកទំនប់។ អ្នករដ្ឋការស៊ីវិលជាន់ខ្ពស់ត្រូវបានចាត់បញ្ចូលក្នុងប្រភេទផ្សេងមួយទៀត ដែលឱ្យធ្វើការងារស្រាលៗជាង។ ខ្មែរក្រហមបានបំបែកអ្នកនៅក្នុងក្រុមប្រភេទទាំងពីរនេះចេញពីគ្រួសាររបស់ពួកគេ។ គេបានបញ្ជូនវរសេនីយ៍ទោទ័ពជើងអាកាសម្នាក់ដែលជាអ្នកឯកទេសខាងមេកានិកទៅវគ្គអប់រំរៀនសូត្រ។ ពួកទាហានជើងទឹកមួយចំនួនដែលពួកខ្មែរក្រហមស្អប់ខ្លាំង ត្រូវបានគេឱ្យសែងដីនៅក្បែរស្រែវាល ខាងលិចក្រុងកំពង់ចាម។ ក្រោយមក នៅសៀមរាប ស៊ិន ម៉ៅ បានដឹងថា គេឱ្យនាយទាហានមកពីកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ កាប់ឈើនៅក្នុងព្រៃភ្នំគូលេន រីឯកូនទាហានរបស់កងកម្លាំងប្រដាប់អាវុធជាតិខ្មែរត្រូវទៅឆ្ការព្រៃនៅក្បែរជើងភ្នំ។ គ្រួសាររបស់ពួកគេត្រូវផ្លាស់ទៅនៅរលួស។ តាមផ្លូវជាតិលេខ ៦ នៅក្រឡាញ់ ស៊ិន ម៉ៅ បានដឹងថា ខ្មែរក្រហមបានបំបែកទាហាន ៨០ នាក់ ប្រហែលជានាយទាហានផង ឱ្យចេញពីគ្រួសាររបស់ពួកគេ និងបានបញ្ជូនពួកគេឱ្យទៅ "កសាងខ្លួន" ដែលអ្នកភូមិបាននិយាយថាមានទាំងការងារ និងការរៀនសូត្រ។ ប្រសិនបើមនុស្សម្នាក់មិនឃើញត្រឡប់មកពីកន្លែងអប់រំរៀនសូត្រវិញក្នុងរយៈពេល ៦ ខែទេ ប្រហែលជាខ្មែរក្រហមសម្លាប់គាត់ហើយ។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ព្រំ សុខា ឯកសារ E3/5392 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00479119-00479120 (កូនស្រីរបស់ប្រធានហិរញ្ញវត្ថុនៅក្រសួងការពារជាតិសម័យ លន់ នល់ បានថ្លែងថា ខ្មែរក្រហមបានប្រមូលនាយទាហានជាន់ខ្ពស់ លន់ នល់ មកដាក់នៅបន្ទាយទាហានការពារព្រះបរមរាជវាំង និងបំបែកនាយទាហានចេញពីពួកទាហាន ទោះបីជាសមាជិកគ្រួសាររបស់នាយទាហានត្រូវបានគេដឹកចេញមួយសប្តាហ៍ក្រោយមកទៅភូមិប្រាសាទតាយោ ស្រុកលើកដែក ខេត្តកណ្តាល ដែលនៅទីនោះ ពួកគាត់បានធ្វើស្រែអស់រយៈពេល២ខែ ហើយក្រោយមក ពួកគាត់ត្រូវបានគេដឹកឡានទៅស្រុករមាសហែក ខេត្តស្វាយរៀង ដែលជាស្រុកកំណើតរបស់ឪពុកម្តាយគាត់ និងជាកន្លែងដែលគាត់ត្រូវបានបញ្ជាឱ្យចូលរួមក្នុងកងកុមារ) ។ *សូមមើលផងដែរ* របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៤៣ ERN (ភាសាខ្មែរ) 00324715 (អតីតនិស្សិតរបស់ ជ័យ សួន បានលើកឡើងថា នៅ

# សាលាដំបូងហាក់បង្ហាញថា នាពេលក្រោយមក មានមនុស្សជាច្រើននាក់ក្នុងចំណោមអ្នកទាំងនោះ

ក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសមកពីក្រុងភ្នំពេញ មានអតីតទាហាន លន់ នល់ ក្នុងចំណោមនោះ មានតែទាហានដែលទទួលខុសត្រូវលើការកាប់សម្លាប់ជាច្រើន និងនាយទាហានប៉ុណ្ណោះ ដែលត្រូវបានគេចាត់ទុកថាជាខ្មាំង) ១០២-១០៣ ERN (ភាសាខ្មែរ) 00324774-00324775 (គាត់ជាទាហាន លន់ នល់ ម្នាក់ ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧០ និងត្រូវបានឃុំខ្លួននៅអមលាំង ដែលនៅទីនោះគេឃុំទាហាន លន់ នល់ ដែលចាប់ខ្លួនបានតាំងពីឆ្នាំ១៩៧០មក។ គាត់បានលើកឡើងថា ក្នុងចំណោមក្រុមប្រជាជនថ្មីមួយក្រុមចំនួន ៣០០០ នាក់ ដែលទើបមកដល់នៅក្នុងឆ្នាំ ១៩៧៥ ដែលភាគច្រើនជាទាហាន និងអ្នករដ្ឋការ នាយទាហានត្រូវបានគេសម្លាប់ចោលភ្លាមៗ ចំណែកអ្នកផ្សេងត្រូវបានគេឲ្យទៅធ្វើការងារនៅតារ៉ង ភ្ជួររាស់ ដាំកប្បាស ឬ ដាំស្រូវ)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ ២៩-៣១, ទំព័រ ៥៤-៥៦, ទំព័រ ៥៧-៥៨ (គាត់គឺជាកងទ័ពខ្មែរក្រហមម្នាក់។ នៅពេលវាយចូលក្រុងភ្នំពេញ គាត់បានទទួលការណែនាំថា ទាហាន លន់ នល់ ដែលចាប់ខ្លួនបាន ត្រូវបញ្ជូនត្រឡប់ទៅវិញ ហើយមិនឲ្យធ្វើទារុណកម្មនោះទេ។ ដូច្នេះ នៅពេលគាត់ប៉ះទង្គិចជាមួយនឹងទាហាន លន់ នល់ គាត់បានដកហូតអាវុធពីពួកគេ ហើយបានបញ្ជូនពួកគេត្រឡប់ទៅសមរភូមិក្រោយវិញ។ គាត់មិនដែលធ្លាប់ទទួលបានបញ្ជាឲ្យធ្វើបាប ឬកាប់សម្លាប់ទាហាន លន់ នល់ នោះឡើយ)។

យោងតាមការរៀបរាប់របស់ទាហាន លន់ នល់ ដែលត្រូវបានជម្លៀសចេញពីភ្នំពេញទៅតាមជនបទ ទាហានទាំងនេះបានលាក់អត្តសញ្ញាណរបស់ពួកគេនៅក្នុងពេលជម្លៀស ឬ មិនបញ្ជាក់ផ្ទៀងផ្ទាត់អត្តសញ្ញាណពួកគេថាជាទាហាន ឬអ្នករដ្ឋការនៃរបប លន់ នល់ នោះទេ នៅពេលចាកចេញពីក្រុងភ្នំពេញ៖ ប្រតិចារឹក ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៣០-៣១, ទំព័រ ៧៣-៧៤ (គាត់បានលាក់ឯកសណ្ឋាន និងអាវុធរបស់មិត្តគាត់ មុនពេលខ្មែរក្រហមចូលលុកលុយ ហើយគាត់បានស្លៀកខោអាវជនស៊ីវិល ដើម្បីជៀសវាងកុំឲ្យគេស្គាល់អត្តសញ្ញាណថាជាទាហាន លន់ នល់។ គាត់ជម្លៀសខ្លួនចេញជាមួយនឹងអ្នកផ្សេងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុត សូត្រ ឯកសារ E3/4823 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523356-00523357 (បានរៀបការជាមួយនឹងទាហានជើងទឹកសម័យ លន់ នល់ បានរៀបរាប់ថា កងទ័ពខ្មែរក្រហមបានចូលបន្ទាយក្បែរជ្រោយចង្វារ និងបានចាប់ខ្លួនទាហានរដ្ឋាភិបាល។ ប្ដីរបស់គាត់បានត្រឡប់មកផ្ទះ ហើយជម្លៀសចេញជាមួយគាត់ និងកូនស្រី ២ នាក់តាមកាណូតទៅត្រើយខាងកើតតាមផ្លូវជាតិលេខ៦)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យ៉ាង សុខន ឯកសារ E3/5096 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00865679-00865680 (អតីតទាហាន លន់ នល់ មួយរូប ដែលឈរជើងនៅព្រំប្រទល់ខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ បានត្រឡប់មកភ្នំពេញវិញ នៅពេលពួកគាត់ចាញ់សង្គ្រាម ហើយក៏ត្រូវបានជម្លៀសជាមួយអ្នកផ្សេងទៀត។ គាត់ និងគ្រួសារគាត់បានត្រឡប់មកភូមិកំណើតពួកគាត់ ហើយត្រូវបានគេចាត់ឲ្យពួកគាត់ធ្វើការងារ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុក សុត ឯកសារ E3/5075 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00567990 (អតីតទាហាន លន់ នល់ នៅភ្នំពេញ កាលពីពេលខ្មែរក្រហមបានជម្លៀសចេញពីទីក្រុង បានទៅជនបទជាមួយអ្នកផ្សេងទៀត និងត្រូវបានចាត់ឲ្យធ្វើការងារ)។

ត្រូវបានសម្លាប់ចោលនៅកន្លែងដែលពួកគេត្រូវបញ្ជូនទៅ[១៥១៧]។ ដោយយល់ឃើញថា ការសម្លាប់នៅតាមការដ្ឋាន និងនៅតាមសហករណ៍ មិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង នឹងមិនពិចារណាទៅលើការសម្លាប់ទាំងនេះនៅក្នុងការសម្រេចរបស់ខ្លួនទៅលើបទចោទជាក់លាក់ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) នោះទេ។

---

[១៥១៧] ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ម៉ី ណារី ឯកសារ E3/5397 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480825 (បងប្រុសគាត់ ដែលជាតម្រួតឃោឃាសម័យ លន់ នល់ និងគ្រួសាររបស់បងប្រុសគាត់ត្រូវបានគេជម្លៀសទៅឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាមដែលជាកន្លែងខ្មែរក្រហមសម្លាប់ពួកគាត់ចោលដោយចោទថាជាអ្នករដ្ឋការ លន់ នល់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កែវ ម៉ៃ ឯកសារ E3/5403 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00480137-00480138 (២ សប្តាហ៍ក្រោយពេលគ្រួសាររបស់គាត់ចេញពីភ្នំពេញ បានមកដល់ភូមិឫស្សីដំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ប្តីរបស់គាត់ដែលជាអតីតទាហាន លន់ នល់ ត្រូវបានចាត់ទុកថាជា “ប្រជាជនថ្មី” ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងយកទៅមន្ទីរសន្តិសុខ តា ម៉ន់ ។ ចាប់ពីពេលនោះមក គាត់មិនដែលទទួលដំណឹងពីប្តីគាត់ទៀតទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេវ ឡាំ ឯកសារ E3/4630 ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00201484 (អតីតកងទ័ពខ្មែរក្រហមម្នាក់រូបបានលើកឡើងថា នៅពេលប្រជាជន១៧ មេសាចេញពីភ្នំពេញមកដល់ស្រុក១២ ផ្អែកលើជីវប្រវត្តិរបស់ពួកគេ អ្នកទាំងនោះត្រូវបានបែងចែកជាមនុស្សធម្មតា (ឧទាហរណ៍ កសិករ) និងប្រជាជនមិនធម្មតា (ឧទាហរណ៍ ទាហាន អ្នករដ្ឋការ និងពួកសក្តិភូមិ)ហើយក្រោយមកត្រូវបានសម្លាប់ចោលទាំងអស់)។ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៉ាក់ សុន ឯកសារ E3/5432 ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00483658 (បន្ទាប់ពីពួកគាត់បានមកដល់ភូមិ តា អាំ ពួក ប៉ុល ពត បានស៊ើបអង្កេត និងបានរកឃើញថាឪពុករបស់គាត់គឺជាទាហាន ដូច្នេះពួកខ្មែរក្រហមបានយកឪពុកគាត់ទៅសម្លាប់ចោលភ្លាមៗនៅព្រឹកនោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ឯកសារ E3/5511 ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00402500-00402501 (បងថ្លៃគាត់ដែលជាអតីតនគរបាលដែលត្រូវបានជម្លៀសពីភ្នំពេញទៅខេត្តតាកែវ ត្រូវបានចាប់ខ្លួននៅថ្ងៃដែលគាត់បានមកដល់ភូមិ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឯក អ៊ិន ឯកសារ E3/5413 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00480471-00480472 (ប្អូនប្រុសគាត់ដែលជាពេទ្យទាហានសក្តិ៣ សម័យ លន់ នល់ ត្រូវបានជម្លៀសចេញពីភ្នំពេញទៅស្រុកកំណើតរបស់ពួកគាត់ ប៉ុន្តែគាត់បានឮថា ប្អូនប្រុសគាត់ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៧)។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ១០៣ ERN (ភាសាខ្មែរ) 00324775 (ទាហាន លន់ នល់ មួយរូប ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧០ ហើយត្រូវបានបញ្ជូនទៅអមលាំង ដែលនៅទីនោះ គាត់បានអះអាងថា ទាហាន លន់ នល់ ដែលចាប់ខ្លួនបាននៅចន្លោះឆ្នាំ ១៩៧០-១៩៧២ ត្រូវបានគេឃុំនៅទីនោះ។ គាត់បានលើកឡើងថា ក្រុមប្រជាជនថ្មីមួយក្រុមដែលទើបមកដល់នៅឆ្នាំ ១៩៧៥ ចំនួនប្រហែល៣.០០០ នាក់ ដែលភាគច្រើនជាទាហាន និងអ្នករដ្ឋការ និងនាយទាហាន ត្រូវបានគេសម្លាប់ចោលភ្លាមៗ)។

ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសាលាដំបូងបញ្ចូលភ័ស្តុតាងទាំងនេះ គឺក្នុងគោលបំណងដើម្បីបង្ហាញអំពីព្រឹត្តិការណ៍ទាំងស្រុងនាពេលនោះតែប៉ុណ្ណោះ។

៥០៧. ទោះបីជាយ៉ាងណាក៏ដោយ ទាហាន និងអ្នករដ្ឋការស៊ីវិលផ្សេងៗជាច្រើននាក់នៃរបបសាធារណរដ្ឋខ្មែរ ដែលក្នុងចំណោមអ្នកទាំងនោះ រួមមានអ្នកដែលបានចុះចាញ់ បានរងរបួស ឬត្រូវបានឃុំខ្លួន ហើយអ្នកទាំងនោះ គឺជាអ្នកដែលបានបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ (*hors de combat*) ក៏ត្រូវបានសម្លាប់ចោលនៅនឹងកន្លែងក្នុងទីក្រុងភ្នំពេញផងដែរ[១៥១៨]។

---

[១៥១៨] សក្ខីកម្មរបស់ជនអៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១៨ ERN (ភាសាខ្មែរ) 00836195 (និស្សិតច្បាប់មួយរូបបានរៀបរាប់ថា ខ្មែរក្រហមបានសម្លាប់ទាហាននៅមន្ទីរពេទ្យព្រះកេតុមាលា)។ បទសម្ភាសន៍ជាមួយ ខាត់ ខេ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5598 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00526857 (អតីតសមាជិកម្នាក់នៃកងពិសេសកាំភ្លើងធំរបស់ភូមិភាគឧត្ដរ បានលើកឡើងថា ទាហាន លន់ នល់ ភាគច្រើនដែលត្រូវបានរកឃើញ២ ឬ ៣ ថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ត្រូវបានគេសម្លាប់ចោល ទោះបីជាមានខ្លះត្រូវបានយកទៅអប់រំកែប្រែក៏ដោយ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឃិន សុខ ឯកសារ E3/5556 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00373186 (បានឃើញទាហានខ្មែរក្រហមបាញ់ទៅលើទាហាន លន់ នល់ ដែលមិនមានអាវុធ និងមានពាក់ឯកសណ្ឋាន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ឹម គ្រេះ ឯកសារ E3/4822 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00523343-00523344 (ទាហាន លន់ នល់ ម្នាក់ដែលបានចុះចាញ់ ហើយត្រូវបានខ្មែរក្រហមចាប់ខ្លួនក្បែរបន្ទាយរបស់គាត់ ត្រូវបានគេចងដៃទៅក្រោយខ្នងគាត់ និងត្រូវបានចងជាមួយនឹង ១២ នាក់ផ្សេងទៀត ហើយត្រូវបានបណ្ដើរទៅច្រាំងទន្លេ។ នៅច្រាំងទន្លេ គាត់បានឃើញខ្មែរក្រហមបាញ់សម្លាប់ទាហាន លន់ នល់ មួយរូបស្លាប់។ បន្ទាប់មកមេបញ្ជាការខ្មែរក្រហមមិនស្គាល់មួយ បានផ្ដល់សញ្ញាបញ្ជាតាមរយៈទង់ជ័យក្រហម ខ្មែរក្រហមក៏បានបាញ់ទាហាន លន់ នល់ ស្លាប់៥ នាក់បន្ថែមទៀត)។ នៅពេលនោះ ជីវិតរបស់គាត់ត្រូវបានរួចផុតពីការសម្លាប់ ប៉ុន្តែគាត់ត្រូវបានបញ្ជូនជាមួយប្រជាជនចំនួន ៥០០ នាក់ផ្សេងទៀត ទៅកាន់គុក ដើម្បីអប់រំកែប្រែ) ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុត សូត្រ ឯកសារ E3/4823 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523356-00523357 (បានរៀបការជាមួយនឹងទាហានជើងទឹកពិការជើងសម័យ លន់ នល់។ គាត់បានឃើញទាហានរដ្ឋាភិបាល ត្រូវបានពួកខ្មែរក្រហមចង និងបាញ់សម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥ ERN (ភាសាខ្មែរ) 00526068 (ក្នុងអំឡុងពេលជម្លៀស គាត់បានឃើញទាហាន លន់ នល់ រាប់សិបនាក់ត្រូវបានគេចងដៃជាមួយអំបោះឆៅតំរៀបគ្នាជាជួរបណ្ដើរឡើងឡាន ដោយពួកខ្មែរក្រហមបានស្រែកគំរាមថា បើនរណាហ៊ានធ្វើឲ្យដាច់ខ្សែអំបោះនោះ ពួកគេនឹងសម្លាប់ចោលភ្លាម។ ទាហានពីរបីនាក់បានរត់គេចចេញពីទីនោះ ដោយរត់កាត់តាមហ្វូងអ្នកដែលត្រូវបានជម្លៀសត្រូវបានពួកវាបាញ់រះដោយឥតញញើត ហើយពេលនោះក៏មានអ្នកដែលត្រូវបានជម្លៀសមួយចំនួន បានស្លាប់ក្នុងអំឡុងពេលបាញ់រះនោះផងដែរ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ព្រំ សុខា ឯកសារ E3/5392 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧-៨ ERN

៥០៨. ពួកទាហាននៃរបបសាធារណរដ្ឋខ្មែរផ្សេងទៀតត្រូវបានចាប់ខ្លួន[១៥១៩] ឬ ត្រូវបានបំបែកចេញពីប្រជាជនស៊ីវិល[១៥២០] ទោះបីជាវាសនារបស់ពួកគេមិនមានភាពច្បាស់លាស់ក្តី ពីព្រោះ

---

(ភាសាខ្មែរ) 00479119-00479120 (កូនស្រីរបស់ប្រធានហិរញ្ញវត្ថុនៅក្រសួងការពារជាតិសម័យ លន់ នល់ បានថ្លែងថា ក្រោយពីខ្មែរក្រហមចូលទីក្រុង ខ្មែរក្រហមបានប្រមូលនាយទាហានជាន់ខ្ពស់ លន់ នល់ មកដាក់នៅបន្ទាយទាហានការពារព្រះបរមរាជវាំង និងបំបែកនាយទាហានចេញពីពួកពលទាហាន) ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00479120-00479121 (នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានឃុំខ្លួនឪពុករបស់គាត់ និងអតីតមេបញ្ជាការយោធាជាច្រើនរូបទៀតនៅបន្ទាយទាហានការពារព្រះបរមរាជវាំង និងបានចងអ្នកទាំងនោះ ដឹកចេញយកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃបំផុត)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ម៉ី ណារី ឯកសារ E3/5397 ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480825 (ឪពុកធំ បងស្រីជីដូនមួយ និងក្មួយៗដែលជាទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមសម្លាប់នៅក្រោយសាលាយោធាឫស្សីកែវ ជិតស្ថានីយ៍រថភ្លើងភ្នំពេញ ពេលដែលពួកគាត់ត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញ)។*សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣២-៣៣ ERN (ភាសាខ្មែរ) 00228748-00228749 (ផាម មឿន បាន និយាយថា ឧត្តមសេនីយ៍ នាយទាហាន នាយទាហានរង ពលទាហាន និងនិយោជិកដែលខ្មែរក្រហមរកឃើញ ត្រូវបានប្រមូលផ្តុំ និងយកចេញនៅយប់នោះទៅកំពង់កន្ទួត ជាកន្លែងដែលពួកគេត្រូវបានប្រហារជីវិត។ ផាម មឿន មានវត្តមាននៅពេលសម្លាប់ពួកទាហានពាក់ឯកសណ្ឋាននៅលើមហាវិថីម៉ៅសេទុង)។របាយការណ៍របស់ H. Locard៖ *តំបន់បូព៌ា* ឯកសារ E3/3209 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៦-១៧ ERN (ភាសាខ្មែរ) 00822921-00822922 (ប្តីរបស់លោកស្រី ឈៀវ ស៊ីឡាង ត្រូវបានសម្លាប់ក្នុងអំឡុងពេលជម្លៀស ពីព្រោះតែគាត់គឺជាទាហាន លន់ នល់), ទំព័រ ៣៣-៣៤ ERN (ភាសាខ្មែរ) 00822938-00822939 (កេត ឃាន បានឃើញការបាញ់សម្លាប់ទាហានសក្តិ ៣)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុត សេង ឯកសារ E3/5267 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00271405 (នៅកំពង់ចម្លងព្រែកក្តាម គាត់បានឃើញកងទ័ពនារីរបស់ប៉ុល ពត បានចង និងដោះអាវមនុស្ស២ អ្នកចេញអស់រលីង ហើយអ្នកទាំងពីរនោះប្រហែលជាយោធា ហើយក៏បានបាញ់រះដោយកាំភ្លើងស្វ័យប្រវត្តិទៅលើអ្នកទាំងពីរនោះ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៧១-៧៣, ៨០-៨១។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ១៦-១៨ (ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី បានរៀបរាប់អំពីដំណើររឿងរបស់ឪពុកមារបស់គាត់ដែលពាក់ស័ក្តិ៥ ស្លៀកសម្លៀកបំពាក់ប៉ារ៉ា បានចតឡាននៅមុខផ្ទះរបស់គាត់ នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយនៅពេលនោះកងទ័ពខ្មែរក្រហមម្នាក់បានស្ទុះមកបាញ់ឪពុកមារបស់គាត់ ដោយបានបញ្ជាក់ថា "ហ្នឹងហើយពួកអាក្បត់" ហើយថាត្រូវកម្ទេចពួកអាក្បត់ទាំងអស់)។

[១៥១៩] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Alan ROCKOFF) ទំព័រ ១៥-១៦, ទំព័រ ២៤-២៦ (បានឃើញយោធាគ្មានអាវុធរាប់រយនាក់ធ្វើដំណើរក្រោមការឃាមកាម និងឱ្យដើរទៅទិសខាងលិចពីផ្លូវកែងមុនីវង្សនិងសីហនុឆ្ពោះទៅស្តាតអូឡាំពិក។ ប្រមាណមួយភាគបីនៃយោធា លន់ នល់ បានលើកដៃឡើង និងមិនសូវមានខ្មែរក្រហម ច្រើនធ្វើដំណើរជាមួយអ្នកទាំងនោះទេ), ទំព័រ ២៦ (ដកស្រង់ *សូមមើលផងដែរ សៀវភៅ និពន្ធដោយ* Roland NEVEU៖ *ការបែកទីក្រុងភ្នំពេញ* ឯកសារ E3/3208 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាអង់គ្លេស) 00432470 រូបភាពបង្ហាញ

ប្រសិនបើពួកគេមិនត្រូវបានសម្លាប់ភ្លាមៗនោះទេ ក៏ពួកគេបានបាត់ខ្លួនរហូត ហើយគ្រួសាររបស់ពួកគេមិនដែលបានជួបអ្នកទាំងនោះឡើយ។ អ្នកខ្លះបានរាយការណ៍ថា ពួកទាហានត្រូវបានយកទៅសម្លាប់នៅកន្លែងផ្សេងទៀត[១៥២១] ហើយអ្នកខ្លះទៀតបានលើកឡើងថា ពួកទាហានត្រូវបានយកទៅដាក់គុក[១៥២២]។

---

អំពីព្រឹត្តិការណ៍ដូចគ្នា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៊ុត សូត្រ ឯកសារ E3/4823 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523356-00523357 (បានរៀបការជាមួយនឹងទាហានជើងទឹកសម័យ លន់ នល់ បានរៀបរាប់ថា ទាហានខ្មែរក្រហមបានចូលដល់បន្ទាយក្បែរជ្រោយចង្វារ និងបានចាប់ខ្លួនទាហានរដ្ឋាភិបាល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ឹម ត្រេះ ឯកសារ E3/4822 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00523343-00523344 (ទាហាន លន់ នល់ ម្នាក់ ដែលបានចុះចាញ់ ហើយត្រូវបានខ្មែរក្រហមចាប់ខ្លួនក្បែរបន្ទាយរបស់គាត់នៅជ្រោយចង្វារ ត្រូវបានគេចងដៃទៅក្រោយខ្នងគាត់ និងត្រូវបានចងជាមួយនឹង ១២ នាក់ផ្សេងទៀត ហើយត្រូវបានបណ្តើរទៅច្រាំងទន្លេ។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៨ ERN (ភាសាខ្មែរ) 00836275 (និស្សិតច្បាប់មួយរូបបានលើកឡើងថា កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ គាត់បានឃើញវរសេនីយ៍ទោ ហាក់ ម៉ាត់ណូ និងមេបញ្ជាការ ង៉ូវ ពេជ អត្តលេខ ២៦៦ ត្រូវបានគេបាញ់សម្លាប់។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ គាត់បានឃើញខ្មែរក្រហម ចាប់វរសេនីយ៍ឯកនៃកងវរសេនាតូចលេខ៥ នាយទាហាន និងរដ្ឋមន្ត្រីជាច្រើន ហើយបើកដឹកពួកអ្នកទាំងនោះតាមឡានហ្ស៊ីប ប្រហែល២០គ្រឿងទៅកាន់ភ្នំបាសិទ្ធ។ គាត់គិតថាអ្នកទាំងនោះត្រូវបានគេសម្លាប់ចោល)។*សំណើបន្ថែមរបស់រដ្ឋាភិបាលកាណាដា តាមរយៈសេចក្តីសម្រេចលេខ៩ របស់គណៈកម្មការសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/1806 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ១០ ERN (ភាសាខ្មែរ) 00284359 (សក្ខីកម្មសាក្សីដែលភ្ជាប់មក បានរៀបរាប់ថា មារបស់គាត់ដែលជាមន្ត្រីយោធា លន់ នល់ ត្រូវបានចាប់ខ្លួននៅចំពោះមុខគាត់)។

[១៥២០] *ឧទាហរណ៍* សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៨ ERN (ភាសាខ្មែរ) 00836276 (និស្សិតច្បាប់មួយរូបបានលើកឡើងថា គាត់ និងគ្រួសារគាត់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅលើភ្លឺស្រែ ហើយខ្មែរក្រហមយកពួកទាហានទៅកន្លែងផ្សេង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00398495 (អតីតទាហាន លន់ នល់ មួយរូបបានឃើញថា នៅប៉ុស្តិ៍ត្រួតពិនិត្យមួយនៅចំការមន (ព្រះបរមរាជវាំង) ប្រុសៗត្រូវបានគេបំបែកចេញ និងបញ្ជូនទៅរោងចក្រកែវ ហើយបន្ទាប់មកបានចេញពីរោងចក្រដោយត្រូវចងខ្សែអំបោះជាប់នឹងមេដៃ និងត្រូវបានបណ្តើរជាជួរដោយក្នុងមួយជួរៗមានមនុស្សយ៉ាងតិច១០នាក់ ឆ្ពោះទៅភ្នំតាម៉ៅ)។

[១៥២១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00398496 (អតីតទាហាន លន់ នល់ មួយរូប ដែលបានឃើញប្រុសៗត្រូវបានគេបំបែកនៅកន្លែងត្រួតពិនិត្យនៅចំការមន [ព្រះបរមរាជវាំង] ហើយក្រោយមកត្រូវបានគេចងមេដៃជាមួយគ្នា បានរៀបរាប់ថា បុរសម្នាក់ក្នុងចំណោមអ្នកទាំងអស់នោះដែលបានលួចរត់ បានប្រាប់គាត់ថា អ្នកដែលគេចងដៃទាំងអស់ ត្រូវបានគេសម្លាប់អស់ហើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សូ សារី ឯកសារ E3/5372 ចុះថ្ងៃទី ២៧ ខែ សីហា

ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00477074 (នៅស្គន់ ប្ដីរបស់គាត់ដែលជាអតីតទាហានតេអូសម័យ លន់ នល់ និងកូនស្រីគាត់អាយុ ១០ ឆ្នាំ ត្រូវបានទាហានខ្មែរក្រហមយកទៅសម្លាប់ចោល។ គាត់មិនបានដឹងអំពីមូលហេតុនោះទេ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ គឹម សារូ ឯកសារ E3/5435 ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483738 (នៅពេលខ្មែរក្រហមចូលទីក្រុងភ្នំពេញ ពួកវាបានចាប់បងប្រុសគាត់២នាក់ ដែលអ្នកទាំងពីរគឺជាទាហាន លន់ នល់ ហើយបានយកបងប្រុសគាត់ទៅសម្លាប់ចោលដោយគ្មានមូលហេតុអ្វីសោះ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សោ ធឿន ឯកសារ E3/5436 ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483749 (ខ្មែរក្រហមបានចាប់ខ្លួនឪពុករបស់គាត់ ឈ្មោះ  គឹម សិដ្ឋ ដែលជាទាហានមួយរូប ហើយបានយកគាត់ទៅសម្លាប់ចោល)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៧៨-១៧៩ ERN (ភាសាខ្មែរ) 00836255-00836256 (កាលពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៦ ពេជ្រ លឹមកុង បានលើកឡើងថា ក្នុងអំឡុងពេលដឹកជញ្ជូនចេញ ពួកខ្មែរក្រហមបានសង្កត់ធ្ងន់សុំឲ្យនាយទាហានត្រូវប្រមូលផ្ដុំនៅកន្លែងផ្សេងមួយដោយឡែក ដោយប្រកាសថា នាយទាហាននឹងត្រូវដឹកត្រឡប់ទៅធ្វើការនៅភ្នំពេញវិញ។ បន្ទាប់ពីប្រមូលផ្ដុំរួចហើយ ពួកវាបានដឹកឡានយកទៅសម្លាប់ចោលទាំងអស់)។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ១០៣ ERN (ភាសាខ្មែរ) 00324774 (គាត់គឺជាទាហាន លន់ នល់ ម្នាក់ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧០ ហើយត្រូវបានបញ្ជូនទៅអមលាំង ដែលនៅទីនោះ គាត់បានអះអាងថា ទាហាន លន់ នល់ ដែលចាប់ខ្លួនបាននៅចន្លោះឆ្នាំ ១៩៧០ - ឆ្នាំ ១៩៧២ ត្រូវបានគេឃុំនៅទីនោះ។ គាត់បានលើកឡើងថា ក្រុមប្រជាជនថ្មីមួយក្រុមដែលភាគច្រើនជាទាហាន និងអ្នករដ្ឋការទាំងអស់ចំនួនប្រហែលជា ៣០០០ នាក់ ដែលទើបមកដល់អមលាំងនៅក្នុងឆ្នាំ ១៩៧៥ និងនាយទាហានត្រូវបានសម្លាប់ចោលភ្លាមៗ ចំណែកអ្នកផ្សេងត្រូវបានបានឲ្យទៅធ្វើការងារនៅតារ៉ង ឆ្ការព្រៃ ដាំកប្បាស ឬ ដាំស្រូវ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផាន់ យឹម ឯកសារ E3/5424 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ១ ERN (ភាសាខ្មែរ) 00481187 (ខណៈពេលធ្វើដំណើរទៅដល់មុំផ្លូវបំបែកចោមចៅ ប្ដីខ្ញុំត្រូវបានគេចាប់ដាក់ឡានដឹកមកភ្នំពេញវិញ ព្រោះគាត់ជាទាហាន លន់ នល់។ ពេលចាប់នោះ គេថាយកទៅធ្វើការ ប៉ុន្តែយកទៅបាត់រហូត។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រូ រ៉េន ឯកសារ E3/4694 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00365047-00365048 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពួកគេបានចាប់ឪពុករបស់គាត់យកទៅឃុំឃាំងនៅមន្ទីរ ១៥ ដោយចោទថាជាមេ ៥០ ខ្នង សម័យ លន់ នល់។ មិនយូរប៉ុន្មាន គាត់បានឮដំណឹងថា ឪពុកគាត់ត្រូវបានគេធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងររួចសម្លាប់ចោលនៅមន្ទីរ ១៥)។

[១៥២២] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ាង ថាន ឯកសារ E3/5020 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00560584-00560585 (ប្ដីរបស់គាត់ដែលជាអ្នករដ្ឋការសម័យ លន់ នល់ ដែលមានតួនាទីនៅធនាគារជាតិ បានបាត់ខ្លួនកាលពីថ្ងៃទី ១៧ ខែ មេសា ហើយចាប់ពីពេលនោះមក បានបាត់ដំណឹងសូន្យ មិនដឹងគាត់នៅទីកន្លែងណានោះទេ។ មានគេប្រាប់ថា គាត់ត្រូវបានគេយកទៅគុកទួលស្លែង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ុម គ្រេះ ឯកសារ E3/4822 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00523343-00523345 (ទាហាន លន់ នល់ ម្នាក់ ដែលបានចុះចាញ់ ហើយត្រូវបានខ្មែរក្រហមចាប់ខ្លួនក្បែរបន្ទាយរបស់គាត់នៅជ្រោយចង្វារ ត្រូវបានគេចងដៃទៅក្រោយខ្នងគាត់ និងត្រូវបានចងជាមួយនឹង១២នាក់ផ្សេងទៀត ហើយ

៥០៩. នៅពេលដែលការជម្លៀសកំពុងបន្ត អតីតកងទ័ពខ្មែរក្រហមបានរាយការណ៍ថា ពួកគាត់ត្រូវបានណែនាំឱ្យសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងអស់ ដែលត្រូវបានកំណត់អត្តសញ្ញាណ[១៥២៣]។ ជាក់ស្តែង បើតាម គង់ គីម ដោយសារតែទាហាននៃរបប លន់ នល់ បានដោះឯកសណ្ឋានរបស់ពួកគេចេញ ហើយបានចូលលាយឡំជាមួយនឹងប្រជាជនស៊ីវិល ទើបខ្មែរក្រហមបានបញ្ជាឱ្យបាញ់សម្លាប់ប្រជាជនដែលនៅសេសសល់នៅទីក្រុងភ្នំពេញ[១៥២៤]។

៥១០. នៅក្នុងពេលពីរបីថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា យោងតាមការណែនាំឱ្យធានាថា មានតែកងទ័ពខ្មែរក្រហមប៉ុណ្ណោះស្ថិតនៅក្នុងទីក្រុង ហើយគ្រប់គ្នាត្រូវបានជម្លៀសចេញអស់ហើយនោះ កងទ័ពខ្មែរក្រហមបានធ្វើការឆែកឆេរម្តងទៀតនៅក្នុងទីក្រុង និងបង្ខំអ្នកដែលកំពុងលាក់ខ្លួនឱ្យចាក

---

ត្រូវបានបណ្តើរទៅច្រាំងទន្លេ។ គាត់ និងប្រជាជនរាប់រយនាក់ផ្សេងទៀត ត្រូវបានបង្ខំឱ្យឡើងទូក ហើយដឹកពួកគាត់ទៅត្រើយខាងកើតទន្លេមេគង្គ ខេត្តកណ្តាល ដែលនៅទីនោះមេបញ្ជាការខ្មែរក្រហមមិនស្គាល់មួយរូបបាននិយាយថា អង្គការឱ្យអ្នកទាំងនោះរស់ ប៉ុន្តែពួកគាត់ត្រូវបញ្ជូនឱ្យទៅរៀនសូត្រ។ ក្រោយមក ពួកគាត់បានដើរអស់រយៈពេល ២ ថ្ងៃកាត់តាមព្រៃដើម្បីមកដល់ភូមិមួយនៅស្រុកខ្វង ខេត្តកំពង់ចាម ដែលនៅទីនោះ ខ្មែរក្រហមបានស៊ើបប្រវត្តិរបស់ប្រជាជន ៥០០ នាក់អស់រយៈពេល ៥ ថ្ងៃ មុនពេលយកប្រជាជនទាំង ៥០០ នាក់ ទៅដាក់គុកនៅគុកបដិវត្តន៍ជីហែទន្លេបិទ)។

[១៥២៣] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡុង ម៉ារី ឯកសារ E3/5540 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373406 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា ពួកគេចង់ទប់ស្កាត់កុំឱ្យជនស៊ីវិលនៅលាយឡំជាមួយទាហាន លន់ នល់ ដោយសារទាហាន លន់ នល់ បានបន្លំខ្លួននៅជាមួយប្រជាជនស៊ីវិល។ អង្គភាពរបស់គាត់បានទទួលបញ្ជាពីមេរបស់គាត់ឈ្មោះ សារី ថា ប្រសិនបើពួកគាត់រកឃើញមាន ទាហាន លន់ នល់ ពួកគាត់អាចសម្លាប់ពួកគេ។ បទសម្ភាសន៍ជាមួយ ខាត់ ខេ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5598 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00526857 (អតីតសមាជិកម្នាក់នៃកងពិសេសកាំភ្លើងធំរបស់ភូមិភាគឧត្តរ បានលើកឡើងថា ទាហាន លន់ នល់ ដែលត្រូវបានរកឃើញ២ ឬ ៣ថ្ងៃក្រោយថ្ងៃទី១៧ ខែមេសា ត្រូវបានសម្លាប់ចោល ទោះបីជាមានខ្លះត្រឹមតែត្រូវបានយកទៅអប់រំកែប្រែក៏ដោយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង ចាន់ ឯកសារ E3/5505 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00398496 (អតីតទាហាន លន់ នល់ បានឮខ្មែរក្រហមនិយាយថាឱ្យតែស្គាល់ថានរណាជាទាហានសម្លាប់ចោលទាំងអស់ ខណៈពេលគាត់ឆ្លងទៅដល់ត្រើយខាងកើតអ្នកលឿង ក្នុងគោលបំណងឆ្ពោះទៅស្រុកកំណើតរបស់គាត់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៩៤-៩៥ (ដកស្រង់ S. Schanberg៖ *កំណត់ហេតុស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១៦៤ បានកត់សម្គាល់ឃើញថា នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៥ បុរសជំនួញជនជាតិបារាំងនៅក្នុងបរិវេណស្ថានទូតបានរាយការណ៍ថា ខ្មែរក្រហមបាននិយាយថា ពួកគេកំពុងតែបោសសម្អាតពួកទាហានរបបចាស់ ដែលបានសម្ងំលាក់ខ្លួននៅក្នុងទីក្រុង)។

[១៥២៤] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៨៥-៨៦។

ចេញតាមរយៈការកាត់ផ្តាច់ការផ្គត់ផ្គង់ទឹក[១៥២៥]។ ប្រជាជនទាំងឡាយណាដែលត្រូវបានរកឃើញ និងប្រឆាំងមិនព្រមចាកចេញ បន្ទាប់ពីការបញ្ជាឲ្យធ្វើការជម្លៀសនៅពេលដំបូង ត្រូវបានចាត់ទុកថាជាសត្រូវ និងត្រូវចាប់ខ្លួន បាញ់ ឬ សម្លាប់ចោល[១៥២៦]។ កងទ័ពខ្មែរក្រហមបានបាញ់គ្នាទៅវិញ

---

[១៥២៥] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៧២-៧៤ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3959), ទំព័រ ៧៤ (ពួកគេត្រូវធ្វើយ៉ាងណាឲ្យប្រជាជនមួយចំនួនតូចដែលនៅមិនទាន់ចាកចេញពីក្រុង ក៏ត្រូវចាកចេញដូចគ្នាដែរ), ទំព័រ ៧៧ (ដកស្រង់ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3959 ERN (ភាសាខ្មែរ) 00270164-00270165 បានលើកឡើងថា ពួកគាត់ត្រូវឡើងឆែកឆេរ ដេញប្រជាជនចេញ។ ពួកគាត់បានទទួលបញ្ជាឲ្យផ្តាច់ទឹក ផ្តាច់ភ្លើងចំនួនកន្លះខែ។ ពួកគាត់ចាប់បានប្រជាជនដែលចុះមក រួចក៏បញ្ជូនទៅឲ្យមេៗ)។ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៤៤-៤៥, ទំព័រ ៤៧-៤៨ (ផែនការបន្ថែមនេះបានប្រាប់មកគាត់ក្រោយពេលប្រជាជនភាគច្រើនបានចាកចេញអស់ហើយ។ ពួកគេទទួលការងារបណ្តេញអ្នកដែលនៅសេសសល់ពីក្នុងផ្ទះរបស់ពួកគេ ហើយបានទទួលបញ្ជាឲ្យផ្តាច់ការផ្គត់ផ្គង់ទឹកដើម្បីបង្ខំឲ្យប្រជាជនចុះមកក្រោមដើម្បីចាកចេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម អំ ឯកសារ E3/5149 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00170633 (អតីតកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងថា ដោយសារកន្លែងខ្លះមានទាហានពួននៅតាមផ្ទះថ្មដើម្បីតស៊ូ ពួកគាត់បានបិទទីក្រុង ហើយបិទទឹកចំនួន១ខែ ដើម្បីបង្ខំឲ្យទាហានទាំងនោះចេញមក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហន ឯកសារ E3/5150 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00172067 (អតីតកងទ័ពខ្មែរក្រហមម្នាក់ដែលឈរជើងនៅឧត្តុង្គបានលើកឡើងថា គាត់បានទទួលការណែនាំមួយអាទិត្យក្រោយថ្ងៃទី ១៧ ខែ មេសា ឲ្យចូលបោសសម្អាតក្នុងទីក្រុងភ្នំពេញ ទោះបីជាទីក្រុងអស់មនុស្សហើយក៏ដោយ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៧៨-១៧៩ ERN (ភាសាខ្មែរ) 00836255-00836256 (កាលពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៦ ពេជ្រ លឹមកុង បានលើកឡើងថា ពួកគេបានផ្តាច់ទឹក និងអគ្គិសនីដើម្បីស្រួលជម្លៀសប្រជាជនចេញ ហើយនៅពេលប្រជាជនចេញអស់ហើយ ពួកវាបានឆែកឆេរតាមផ្ទះទាំងអស់ក្រែងលោមានមនុស្សនៅសល់)។ *សូមមើលផងដែរ* ទូរលេខស្ថានទូតបារាំង ឯកសារ E3/4135 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥*(រាយការណ៍ថា ផ្នែកមួយចំនួននៅទីក្រុងកំពុងឆាបឆេះ ការផ្គត់ផ្គង់ទឹកត្រូវបានកាត់ផ្តាច់ និងស្ថានីយ៍ផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរាយការណ៍ថាត្រូវបានបំផ្លាញ)។*

[១៥២៦] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៧២-៧៤ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3959 ERN (ភាសាខ្មែរ) 00270165 តា យឹម បានបញ្ជាឲ្យពួកគាត់សម្លាប់ប្រជាជនណាដែលមិនចាកចេញ), ទំព័រ ៧៧ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3959 ERN (ភាសាខ្មែរ) 00270164 បានសង្កេតឃើញថា គ្មានវិន័យថាមិនឲ្យបាញ់ប្រជាជនឡើយ។ ប្រសិនបើអ្នកណាបានបាញ់ហើយនោះគាត់មិនដែលឃើញមានទោសអ្វីឡើយ) ទំព័រ ៨៥-៨៦, ទំព័រ ៨៨-៨៩ (ក្រោយពេលប្រជាជនភាគច្រើនត្រូវបានជម្លៀសរួចរាល់ហើយនោះ ក្រុមពិសេស និងកងដែលនៅសេសសល់ ត្រូវដោះស្រាយជាមួយប្រជាជនដែលនៅសេសសល់។ ពុំមានបញ្ជាឲ្យចាត់ទុកប្រជាជនដែលនៅសេសសល់ជាសត្រូវ ដែលអាចបាញ់សម្លាប់ចោលនៅពេលឱកាសមកដល់នោះឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៣៨-៤០ (បានរៀបរាប់ពីរបៀប

ទៅមកជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានរកឃើញ ក្នុងអំឡុងពេលឆែកឆេរនាពេលក្រោយៗមក ដោយបានសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរមួយចំនួន ព្រមទាំងបង្កឲ្យរងរបួស និងស្លាប់ជនស៊ីវិលមួយចំនួនផងដែរ[១៥២៧]។

៥១១. នៅប៉ុន្មានថ្ងៃបន្ទាប់ពីជម្លៀស ខ្មែរក្រហមបានប្រកាសតាមវិទ្យុ និងតាមមេក្រូនៅតាមកន្លែងជាច្រើនក្នុងទីក្រុងភ្នំពេញថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវចូលបង្ហាញខ្លួន បង្ហាញពីឋានៈ តួនាទី កាលពីមុនរបស់ខ្លួន និងត្រឡប់ទៅទីក្រុងភ្នំពេញវិញដើម្បីសហការ ឬ ចូលរួមជាមួយកងទ័ពខ្មែរក្រហម[១៥២៨]។ យោងតាម ស៊ុំ ជា ថាអតីតមេបញ្ជាការកងពលធំ ឈ្មោះ គឿន

---

ពួកគេឆែកឆេរអគារបន្ទាប់ពីមានការគប់គ្រាប់បែកពីលើអគារនោះសំដៅមកពួកគេ ហើយបានរកឃើញទាហាន លន់ នល់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម អំ ឯកសារ E3/5149 ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ)00170633-00170634(គាត់គឺជាអតីតកងទ័ពខ្មែរក្រហមម្នាក់។ គាត់បានឃើញកងទ័ពខ្មែរក្រហមសម្លាប់អ្នកចុះចូលដែលត្រូវបានពួកគេរកឃើញនាពេលក្រោយនៅស្ពានជ្រោយចង្វារ។ ក្នុងចំណោមទាហានទាំងនោះមាន៤ដល់១០នាក់ ខ្លះដាច់ដៃ ដាច់ជើង ត្រូវបានគេច្រានទម្លាក់ទឹកតែម្តង។ គាត់ក៏បានឃើញផ្ទាល់ភ្នែកតែម្តងដោយប្រធានកងធំម្នាក់ក្នុងកងពល ៣១០ បាញ់ទាហាន លន់ នល់ ៣ នាក់ នៅកន្លែងផែមុខវាំង។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៧៣ ERN (ភាសាខ្មែរ) 00324744 (អ៊ុំ សម្អាង មកពីតំបន់ ២១ តំបន់បូព៌ា បានលើកឡើងថា នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ អំពីការប៉ះទង្គិចគ្នាខ្លះនៅភ្នំពេញ។ នោះគឺជាការបង្ក្រាបទៅលើទាហាន លន់ នល់ និងមនុស្សដែលនៅសេសសល់)។ បទសម្ភាសន៍ជាមួយ វង់ វៃ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥ ទំព័រ ១១ ERN (ភាសាខ្មែរ) 00020546 (អតីតកងទ័ពខ្មែរក្រហមដែលបានចូលរួមនៅក្នុងការជម្លៀសបានលើកឡើងថា កងទ័ពបានបញ្ជាឲ្យប្រជាជនចាកចេញ ហើយអ្នកដែលរឹងទទឹងនៅទៀតត្រូវចាត់ទុកជាខ្មាំង។ ពួកគេត្រូវបានចាប់ខ្លួន ហើយដាក់នៅវរសេនាតូច)។

[១៥២៧] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ទំព័រ ៧២-៧៣, ទំព័រ ៧៧, ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ទំព័រ ៨-៩, ទំព័រ ២០-២១។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ទំព័រ ៤១ (មិនមានបាញ់កាំភ្លើង ឬប្រយុទ្ធគ្នាក្នុងអំឡុងពេលជម្លៀសនោះទេ ប៉ុន្តែមានការប្រយុទ្ធគ្នាច្រើនឡើង ក្រោយពីការជម្លៀស)។

[១៥២៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១៣-១៤, ទំព័រ ២៤-២៥ (ដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3961 ERN (ភាសាខ្មែរ) 00205058 (បានពី ៧ ទៅ ៨ ថ្ងៃ គេដាក់មេក្រូផ្សាយចំពោះទាហាន លន់ នល់ ថា បើអ្នកណាមានសក្តិប៉ុន្មានៗ ធ្លាប់ធ្វើការនៅកន្លែងណា ឲ្យចូលមកធ្វើការនៅកន្លែងដើមវិញ។ គេប្រាប់ប្រជាជនឲ្យបង្ហាញសារតាររបស់ពួកគាត់ ឧទាហរណ៍ តើពួកគាត់ពាក់សក្តិប៉ុន្មានកាលពីមុន ដូច្នេះពួកគាត់អាចទទួលបានឋានៈដូចពីមុន នៅពេលពួកគាត់ចូលរួមជាមួយខ្មែរក្រហម។ ការផ្សព្វផ្សាយនោះត្រូវបានធ្វើឡើងទៅកាន់មនុស្សគ្រប់រូប ដោយមិនគិតអំពីឋានៈតួនាទីរបស់ពួកគាត់កាលពីមុនឡើយ) ទំព័រ ២៦-២៧ (៤ ឬ ៥ ថ្ងៃ

បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ) ទំព័រ ៤៩-៥០ (គាត់ឮមនុស្សនៅក្នុងក្រុម គឿន និយាយថា គេដាក់មេក្រូដើម្បីផ្សព្វផ្សាយ) ទំព័រ ៥៧-៥៨ (គឿន ដែលជាអតីតមេបញ្ជាការកងវរសេនាធំ គឺជាមនុស្សហ៊ានណាស់ និងអនុវត្តបទបញ្ជាភ្លាមៗតែម្តង) ទំព័រ ៧៦-៧៧ (គឿន បានប្រកាស អំពាវនាវតាមមេក្រូឲ្យប្រជាជនមកធ្វើការនៅទីក្រុងភ្នំពេញវិញ) ទំព័រ ៧៧-៧៨ (សាក្សីមិនដែលបានឮការប្រកាសនោះឡើយ ប៉ុន្តែ គឿន បានប្រាប់គាត់អំពីរឿងរ៉ាវទាំងនោះហើយថា គឿន រៀបចំចេញទៅប្រកាសផ្សព្វផ្សាយតាមមេក្រូឲ្យ ប្រជាជនចេញទៅ)។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៨៥-៨៧ (៤ ឬ៥ថ្ងៃ បន្ទាប់ពីជម្លៀសទីក្រុង ភ្នំពេញ មានការប្រកាសតាមមេក្រូអំពាវនាវឲ្យអ្នករដ្ឋការ ទាហាន និងនាយទាហានវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ ដើម្បីជួយកសាងប្រទេស ពីព្រោះសង្គ្រាមបានបញ្ចប់ហើយ។ ទោះបីជាមនុស្សមួយចំនួនបានសម្រេចចិត្តវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ ដោយសារតែការប្រកាសនេះក៏ដោយ ក៏ មាស ដែលជាអតីតអ្នករដ្ឋការម្នាក់ មិនបានវិលត្រឡប់ទៅវិញឡើយ ពីព្រោះគាត់សង្ស័យថាមានអ្វីខុសប្រក្រតីហើយ)។ *សារណារបស់រដ្ឋាភិបាល ន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២១ ERN (ភាសាខ្មែរ) 00228737 (គង្ស សម្រេច បានបញ្ជាក់ថា មានមនុស្សរាប់រយនាក់បានមកចុះឈ្មោះ បន្ទាប់ពីមានការប្រកាសតាមប្រដាប់បំពងសំឡេងនៅច្បារអំពៅ ដែលអំពាវនាវឲ្យមន្ត្រី សមាជិកតំណាងរាស្ត្រ មន្ត្រីជាន់ខ្ពស់ទាំងអស់មកចុះឈ្មោះដោយខ្លួនឯង មុនពេលវិលត្រឡប់ទៅកាន់ភ្នំពេញវិញ ដើម្បីបន្តមុខងាររបស់ខ្លួន)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ទូន សាម៉េត ឯកសារ E3/5453 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00471518 (៤ ឬ ៥ថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា នៅតាមផ្លូវជាតិលេខ១ ពីភ្នំពេញដល់កៀនស្វាយ ឃើញមានឡានដាក់មេក្រូប្រកាសហៅរកក្នុងចំណោមអ្នកផ្សេងទៀត ទាហាន ពាក់សក្តិ ១ ដល់សក្តិ៥ ឲ្យមកជួបជុំគ្នានៅច្បារអំពៅ ដើម្បីនាំយកទៅភ្នំពេញវិញឲ្យធ្វើការ។ ចុងក្រោយ អ្នកទាំងអស់នោះ ត្រូវបានគេសម្លាប់ចោលទាំងអស់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ណារ៉េត ឯកសារ E3/1747 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00206387 (នៅថ្នល់ទទឹង ទាហានខ្មែរក្រហមបានប្រកាសតាមមេក្រូថា បងប្អូនណាដែលធ្លាប់ធ្វើជាទាហាន ប៉េអឹម នគរបាលធ្លាប់ពាក់សក្តិប៉ុន្មាន ពាក់ឡើងវិញ អង្គការនឹងយកទៅបម្រើការងារឲ្យបក្សវិញ។ គាត់បានឃើញទាហាន ជួបជុំគ្នា ប៉ុន្តែមិនដឹងថា គេយកទៅណាទេ ពីព្រោះគាត់បានបន្តដំណើរទៅមុខទៀត) ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00152235-00152236 (នៅហ្លួសវត្តចំប៉ា មានកម្លាំងខ្មែរក្រហម ៦ ឬ ៧នាក់ បានដើរប្រកាសតាមមេក្រូថាមានអ្នកណាធ្វើធំ ឲ្យចូលមកបង្ហាញខ្លួន)។ កំណត់ហេតុនៃការស្តាបចម្លើយសាក្សី សំ សិទ្ធី ឯកសារ E3/5201 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00212121 (នៅវត្តច្រកស្តេច ខ្មែរក្រហមបានប្រកាសតាមមេក្រូ សួររកអ្នកដែលជាមន្ត្រីរបស់របប លន់ នល់ ដោយគេនិយាយថា សូមអញ្ជើញបងប្អូន ដែលធ្លាប់ធ្វើការអ្វីកាលពីមុន គេឲ្យទៅធ្វើការងារចាស់នោះវិញ)។ ឧបសម្ព័ន្ធនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ារឌី (អត្ថបទដកស្រង់ពីសៀវភៅ) ឯកសារ E3/5614 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00717131 (ការប្រកាសស្នើឲ្យអតីតមន្ត្រីស៊ីវិល និងយោធាវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ បានលាន់រំពងតាមមេក្រូ ពីព្រោះគេត្រូវការជំនួយពីអ្នកទាំងនោះជាចាំបាច់។ អង្គការសន្យាចិញ្ចឹម និងថែរក្សាគ្រួសាររបស់អ្នកទាំងឡាយដែលបានវិលត្រឡប់ទៅវិញ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៤៨ ERN (ភាសាខ្មែរ)

បានប្រាប់កងវរសេនាធំរបស់ ស៊ុំ ជា ឲ្យធ្វើការប្រកាសបែបនេះ ដើម្បីអូសទាញពួកអតីតទាហាន លន់ នល់ ឲ្យចូលមកវិញ ហើយបន្ទាប់មកអ្នកទាំងនោះនឹងត្រូវយកទៅសម្លាប់ចោល[១៥២៩]។ មានភ័ស្តុតាងបង្ហាញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការអំពាវនាវទាំងនេះត្រូវបានយកទៅសម្លាប់ចោល នៅតាមទីកន្លែងផ្សេងៗនៅក្នុង និងនៅជុំវិញទីក្រុងភ្នំពេញ រួមទាំងនៅកន្លែងមួយនៅខាងលិចព្រែកព្នៅ និងនៅទួលគោក ឬ ក៏បាត់ខ្លួនតែម្តង[១៥៣០]។

---

00836225 (អ្នកផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា ឡានផ្សាយវិទ្យុប្រកាសថា ចាប់ពីវរសេនីយ៍ទោឡើងទៅ ត្រឡប់ទៅភ្នំពេញវិញ) ទំព័រ ២២០-២២១ ERN (ភាសាខ្មែរ) 00836297-00836298 (នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៧៦ អនុសេនីយ៍ត្រី ណុប ថុល បានបញ្ជាក់ថា នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ពួកវានិយាយថា សង្គ្រាមរំដោះបានបញ្ចប់ហើយ ហើយអង្គការអំពាវនាវដល់ទាហានគ្រប់ឋានន្តរសក្តិទាំងអស់ អ្នកបច្ចេកទេសផ្នែកកងទ័ព និងកម្មកររោងចក្រទាំងអស់ ចេញមកបង្ហាញខ្លួនភ្លាមៗ ដើម្បីវិលត្រឡប់ទៅជួយបង្កើតកងទ័ព ក្រសួង និងរោងចក្រឡើងវិញ)។

[១៥២៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១៣-១៤ (*ដកស្រង់*កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/3961 ERN (ភាសាខ្មែរ) 00205058)។

[១៥៣០] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១៤-១៥ (អ្នកណាដែលបង្ហាញមុខចេញមក ត្រូវគេចាប់ខ្លួនភ្លាម ក្រោយមកក៏យកទៅសម្លាប់ចោល) ទំព័រ ១៨-២០ (ប្រជាជនបានចេញបង្ហាញខ្លួនបន្ទាប់ពីមានការប្រកាសតាមមេក្រូ នៅពេលនោះហើយទើបគេអាចចាប់បានទាហាន លន់ នល់ មួយចំនួន)។ ទំព័រ ២៤-២៧, ទំព័រ ៨៦-៨៧ (ទោះបីជាគាត់ អះអាងថា គាត់មិនដែល ឃើញការសម្លាប់ទាហាន លន់ នល់ ដោយផ្ទាល់ភ្នែកក៏ដោយ ក៏គាត់បានបានឮពីអ្នកដទៃប្រាប់ថា ៤ ឬ ៥ ថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ទាហាន លន់ នល់ ត្រូវបានគេនាំយកទៅសម្លាប់ចោលនៅកន្លែងមួយ ខាងលិចព្រែកព្នៅ ដែលមាន គឿន ជាអ្នកបញ្ជាឲ្យសម្លាប់ ហើយក៏ជាអ្នកសម្លាប់ផ្ទាល់ដែរដែរ។ វាមានរយៈពេល ១ ថ្ងៃ ១ យប់) ទំព័រ ៣៣-៣៤ (មិនមែនមន្ត្រីទេ ប៉ុន្តែគឺជាទាហាន លន់ នល់ ដែលត្រូវបានគេយកទៅសម្លាប់នៅទួលគោក បន្ទាប់ពីការប្រកាសដែលគេបញ្ឆោតឲ្យអ្នកទាំងនោះបង្ហាញអត្តសញ្ញាណរបស់ពួកគេ) ទំព័រ ៤៦ (គឿន បានប្រាប់គាត់ថា អតីតទាហាន លន់ នល់ ដែលបានស្តាប់តាមការប្រកាសផ្សព្វផ្សាយនោះ ហើយបានកុហកថាពាក់សក្តិធំ ក៏ត្រូវគេសម្លាប់ចោលដែរ) ទំព័រ ៤៩-៥១ (ពួកគេត្រូវបានដឹកតាមឡានទាហានយកទៅសម្លាប់ចោល)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៤-២៦ (បងថ្លៃរបស់អ្នកស្រីម្នាក់ដែលជាវរសេនីយ៍ឯក បានរៀបចំអីវ៉ាន់ត្រឡប់ទៅភ្នំពេញ បន្ទាប់ពីឮគេប្រកាសឲ្យនាយទាហានទាំងអស់វិលត្រឡប់ទៅទីក្រុងភ្នំពេញវិញដើម្បីធ្វើការងារបន្តរបស់ពួកគេ។ វរសេនីយ៍ឯករូបនោះបានបាត់ខ្លួនតាំងពីថ្ងៃនោះមក ហេតុដូច្នេះគ្រួសារសន្និដ្ឋានថា គាត់ត្រូវបានពួកខ្មែរក្រហមសម្លាប់ចោលបាត់ទៅហើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈរ ដាណា ឯកសារ E3/4664 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00152235-00152236 (បន្ទាប់ពីការប្រកាសនៅវត្តចំប៉ារួចមក ឪពុករបស់អ្នកស្រីឈ្មោះ ឈរ សៀន ដែលជាអតីតចៅហ្វាយខេត្ត និងជាបញ្ជាការកងពលប្រចាំខេត្តកណ្តាល និងមនុស្ស៧នាក់ផ្សេងទៀត បានចេញបង្ហាញខ្លួនចំពោះមុខពួកខ្មែរក្រហម ដែលបានកត់ឈ្មោះពួកគាត់ និងរុញពួកគាត់បញ្ចូលឡាន។ គ្រួសាររបស់អ្នកស្រីរង់ចាំដំណឹងឪពុក រយៈពេល ៣ ខែ

## ១០.២.១៧ ប៉ុស្តិ៍ត្រួតពិនិត្យ

៩១២. នៅតាមប៉ុស្តិ៍ត្រួតពិនិត្យតាមផ្លូវចេញពីទីក្រុងភ្នំពេញ និងនៅទីប្រជុំជនមួយចំនួនផ្សេងទៀត អ្នកដែលត្រូវបានជម្លៀសត្រូវបានឆែកឆេរ និងសួរអំពីប្រវត្តិរូបរបស់ពួកគេ រួមទាំង សមាជិក

---

តែបាត់ដំណឹងសូន្យ)។ កំណត់ហេតុនៃការស្តាបចម្លើយសាក្សី សំ សិទ្ធី ឯកសារ E3/5201 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00212121 (បន្ទាប់ពីចុះឈ្មោះអ្នកដែលបានចូលខ្លួនមក ក្រោយពីការប្រកាសតាម មេក្រូនៅវត្តច្រកស្តេច និងចែកអង្ករឲ្យពួកគាត់រួចមក ប្រជាជនទាំងនោះត្រូវបានបែងចែកជាក្រុមតូចៗ ហើយត្រូវ បានពួកខ្មែរក្រហមនាំយកចេញទៅ។ មនុស្សក្នុងក្រុមដែល សំ សិទ្ធី នៅជាមួយនោះ ត្រូវបានគេនាំយកទៅបាញ់ សម្លាប់ចោល ប៉ុន្តែ កាលនោះ គាត់ជាកុមារ ហើយបានរស់រានមានជីវិត)។ *សូមមើលផងដែរ* កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី ខឹម សំហួន ឯកសារ E3/3962 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00287536 (អតីតប្រធានកងអនុសេនធំនៃកងពលធំ ៣១០ បានបញ្ជាក់ថា នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ មានបញ្ជាពី ថ្នាក់លើឲ្យចាប់មនុស្សដែលជាអ្នករាជការមានឋានន្តរសក្តិធំៗរបស់របប លន់ នល់ ហើយដែលមិនព្រមចាកចេញពីទី ក្រុងភ្នំពេញ ព្រមទាំងអ្នកជំងឺដែលជាទាហាន លន់ នល់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា។ អ្នក ដែលចូលរួមចាប់មនុស្សនោះបាននិយាយប្រាប់គាត់ផ្ទាល់ថា គេចាប់មន្ត្រី លន់ នល់ យ៉ាងច្រើន និងអ្នកបម្រើរបស់ពួក គេពីទីក្រុងភ្នំពេញយកទៅវៃសម្លាប់ទម្លាក់ក្នុងអណ្តូងនៅតំបន់ទួលគោក។ ថ្នាក់លើនោះទំនងជា សុន សេន ដែលបាន គ្រប់គ្រងកងពលធំទាំងអស់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ារឌី ឯកសារ E3/5613 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣, ៥ ERN (ភាសាខ្មែរ) 00491045, 00491046 (២ ឬ៣ថ្ងៃបន្ទាប់ពីការជម្លៀស និង បន្ទាប់ពីមានការអំពាវនាវពីសំណាក់រដ្ឋាភិបាល ឪពុករបស់គាត់បានស្ម័គ្រចិត្តត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ។ ពេល នោះហើយជាពេលដែលគាត់បានឃើញមុខឪពុករបស់គាត់ជាលើកចុងក្រោយ)។ ឧបសម្ព័ន្ធនៃកំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី សេង ម៉ារឌី (អត្ថបទដកស្រង់ពីសៀវភៅ) ឯកសារ E3/5614 គ្មានចុះកាលបរិច្ឆេទ (អត្ថបទ ដកស្រង់ពីសៀវភៅ Theary C. SENG's ) “Daughter of Killing Fields: Asrei's Story”) ឯកសារE3/5614 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00717131 (ឪពុករបស់គាត់បានវិលត្រឡប់ទៅភ្នំពេញវិញ បន្ទាប់ពី មានការប្រកាសស្នើឲ្យអតីតមន្ត្រីស៊ីវិល និងយោធាវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ និងដោយជឿទៅលើការសន្យា របស់អង្គការថានឹងចិញ្ចឹម និងថែរក្សាគ្រួសាររបស់អ្នកទាំងឡាយដែលបានវិលត្រឡប់ទៅវិញ។ រហូតទាល់តែ៣-៤ខែ ក្រោយមកទើបគាត់បានដឹងកាន់តែច្បាស់ថា ខ្មែរក្រហមបានបញ្ឆោតអតីតទាហាន និងមន្ត្រីស៊ីវិលរបស់ លន់ នល់ ដែលជាខ្មាំងនៃរបបថ្មី (ក្បត់ជាតិ) យកទៅប្រហារជីវិត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ម៉ុន ឯកសារ E3/369 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00272719 (អតីតទាហានខ្មែរក្រហមម្នាក់ នៅក្នុងកងពលធំ ១៧០ បានបញ្ជាក់ថា គាត់បានឲ្យទាហាន លន់ នល់ ទម្លាក់អាវុធរបស់ពួកគេ និងដោះខោអាវរបស់ ពួកគេចេញ ពួកគេមិនធ្វើអីអ្នកទាំងនោះឡើយ ប៉ុន្តែពួកកងទ័ពភូមិភាគនិរតី បានស្នើឲ្យនាយទាហាន លន់ នល់ ឡើង ជិះឡានដើម្បីជ្រើសរើសឲ្យកាន់តំណែងរបស់ពួកគេឡើងវិញ។ អតីតទាហាន និងអ្នកទាំងឡាយដែលបានឡើងជិះឡាន ទាំងអស់នោះ អាចត្រូវបានគេយកទៅសម្លាប់ចោល)។

គ្រួសាររបស់ពួកគេ និងការងារដែលពួកគេធ្លាប់ធ្វើនៅក្នុងទីក្រុងភ្នំពេញ[១៥៣១]។

---

[១៥៣១] ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ (យស ផល) ទំព័រ ៦០, ៨៤-៨៦ (អតីតនគរបាល លន់ នល់ ម្នាក់ដែលស្ថិតក្នុងឯកសណ្ឋាននៅឡើយ ត្រូវបានទាហានខ្មែរក្រហមមួយក្រុមស្លៀកពាក់ស៊ីវិល ប្រដាប់ដោយកាំភ្លើង បានឆែកឆេរខ្លួនគាត់រកអាវុធនៅពេទ្យចិន) ទំព័រ ៦០-៦៣, ៧៨ (ក្រោយមក ទាហានខ្មែរក្រហមស្រុកផ្អាវ បានសួរគាត់ម្តងទៀតអំពីប្រវត្តិរូប និងការងាររបស់គាត់។ ដោយកត់សម្គាល់ឃើញថា នគរបាល និងទាហាន លន់ នល់ ត្រូវបានគេសម្លាប់ចោលនោះ យស បានលាក់អត្តសញ្ញាណរបស់គាត់ និងបាននិយាយថា គាត់ជាអ្នករដ្ឋការ) ទំព័រ ៦៤-៦៥, ៧៧-៧៨ (នៅវត្តជើងព្រៃ គាត់ត្រូវបានគេសាកសួរម្តងទៀត)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ៨១-៨២។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ២៦ (នៅប៉ុស្តិ៍ត្រួតពិនិត្យមួយនោះ គេបានប្រាប់ពួកគាត់មិនឲ្យធ្វើដំណើរទៅមុខទៀតទេ ហើយថា ពួកគាត់គួរតែចូលទៅក្នុងភូមិ កុំដើររហេតរហូត)។ ប្រតិចារឹក ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៨-៨៩ (បានពិពណ៌នាអំពីប៉ុស្តិ៍ត្រួតពិនិត្យចល័តដែលកងទ័ពខ្មែរក្រហមបានដើរល្បាតដោយថ្មើរជើង ឬជិះកង់)។ ប្រតិចារឹក ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៣២, ៣៣-៣៤(នៅជិតកំពង់ទួល ឪពុករបស់គាត់ និងឪពុកមារបស់គាត់ ត្រូវបានគេស្នើឲ្យចុះឈ្មោះរបស់ពួកគាត់នៅពេលពួកគាត់បានជួបកងទ័ពខ្មែរក្រហម។ កងទ័ពបានតម្រូវឲ្យបុរសទាំងអស់ដែលមានអាយុចាប់ពី ៣០ ឆ្នាំ ឡើង ទៅចុះឈ្មោះ)។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ (Denise AFFONÇO) ទំព័រ ៥៧-៥៨, ៨៦ (នៅប៉ុស្តិ៍ត្រួតពិនិត្យមួយចេញពីតាខ្មៅបន្តិច ខ្មែរក្រហមបានហែកអត្តសញ្ញាណបណ្ណសញ្ជាតិបារាំងរបស់អ្នកស្រី ដោយនិយាយថា “ចាប់ពីពេលនេះទៅ លែងមានបារាំង ឬ វៀតណាម ឬ ចិនអីទៀតហើយ នៅទីនេះមានតែខ្មែរទេ។ ទៅមុខទៀតទៅ! អង្គការចាំអ្នកទាំងអស់គ្នានៅមុខ”)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៤-៨ (នៅតាមផ្លូវពួកខ្មែរក្រហមបានបញ្ជប់អ្នកត្រូវបានជម្លៀសនៅតាមប៉ុស្តិ៍ត្រួតពិនិត្យមួយចំនួន ហើយបានសួរប្រជាជនអំពីស្រុកកំណើតរបស់ពួកគាត់ តើគ្រួសាររបស់ពួកគាត់ជានរណា និងថាតើពួកគាត់ធ្វើការអ្វីនៅភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២២-២៣ (ប្រហែលជានៅថ្ងៃទី២៨ ខែ មេសា ឆ្នាំ១៩៧៥ នៅប៉ុស្តិ៍ត្រួតពិនិត្យមួយជិតចម្ការដូង ពួកទាហានបានឆែកឆេរមនុស្សគ្រប់គ្នានិងបានប្រាប់អ្នកដែលត្រូវបានជម្លៀសថា អង្គការបានស្នើឲ្យទុកអីវ៉ាន់ទាំងអស់របស់ពួកគាត់ ហើយប្រសិនបើពួកគាត់មិនព្រមទុកអីវ៉ាន់របស់ពួកគាត់ទេនោះ គេនឹងចោទពួកគាត់ថាជាខ្មាំងរបស់អង្គការ។ ពួកទាហានបានឆែកឆេរយកមាស សំលៀកបំពាក់ និងថ្នាំសង្កូវរបស់ពួកគាត់)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ១៩-២១ (នៅកោះធំ ពួកខ្មែរក្រហមបានដកយកឯកសាររបស់គាត់ និងគ្រួសាររបស់គាត់ និងបានប្រាប់ពួកគាត់ឲ្យបន្តដំណើរទៅមុខទៀត។ មួយគីឡូម៉ែត្រទៅមុខទៀត គេបានសួរឈ្មោះរបស់ពួកគាត់ ចំនួនសមាជិកគ្រួសាររបស់ពួកគាត់ អាយុ និងការងាររបស់ពួកគាត់ និងចំនួនលុយដុល្លារ និងលុយរៀលដែលពួកគាត់មាន។ ពួកកងទ័ពខ្មែរក្រហមបានដកយកលុយប្រហែល ៣.០០០ ដុល្លារ និងឲ្យពួកគាត់ទុកលុយរៀលដែលពួកគាត់មាន)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៣ (ប៉ូ ឌីណា) ទំព័រ ៩២-៩៤ (នៅពេលពួកគាត់មកដល់ពោធិ៍សាត់ កងទ័ពខ្មែរក្រហមបានស្រាវជ្រាវប្រវត្តិរូបរបស់ ប៉ូ ឌីណា និងប្តីរបស់គាត់ម្តងទៀត ដោយពួកវាសង្ស័យថាពាក់សក្តិ៥)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៣៧-៣៩ (គេបានបញ្ឈប់ដំណើររបស់ពួកគាត់ និងបានឆែកឆេរពួកគាត់ នៅកំពង់ទួលនិងម្តងទៀតនៅភូមិត្បូងក្តី)។ប្រតិចារឹក ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២

៥១៣. ទោះបីជាមានការពិពណ៌នាមួយដែលបានរៀបរាប់អំពី វិធីដែលកងទ័ពខ្មែរក្រហមក្មេងៗ បានសម្លាប់អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាទាហាន លន់ នល់ ភ្លាមៗនៅនឹងកន្លែង[១៩៣២]

---

(មុម សំអឿន) ទំព័រ ១១-១៣ (កងទ័ពខ្មែរក្រហមបានឃ្លាំមើលពួកគាត់យ៉ាងតឹងរ៉ឹង និងបានជជីកសួរអំពីការងារពីមុនរបស់ប្តីគាត់។ ពួកវាបានគំរាមពួកគាត់ឱ្យប្រាប់ការពិតអំពីមុខងារពីមុនរបស់ពួកគាត់ ដោយនិយាយថា ប្រសិនបើកងទ័ពរកឃើញថាពួកគាត់និយាយកុហក ជីវិតគាត់ និងក្រុមគ្រួសាររបស់គាត់នឹងមានគ្រោះថ្នាក់)*សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣៣-៣៤ ERN (ភាសាខ្មែរ) 00228749-00228750 (ផាម មឿន បានបញ្ជាក់ថា នៅពេលគាត់ទៅដល់ចំបក់នៅថ្ងៃទី ២២ ខែ មេសា ពួកខ្មែរក្រហមបានស្នើឱ្យគាត់ប្រាប់ពីប្រវត្តិរបស់គាត់ថាតើជាជនស៊ីវិល ឬជាយោធា)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៣១ ERN (ភាសាខ្មែរ) 00836108 (អ្នក ផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា នៅទម្ការលើ នៅក្នុងភូមិមួយជិតស្វាយទាប អ្នកដែលត្រូវបានជម្លៀស ត្រូវធ្វើប្រវត្តិរូបបួនដងបន្តបន្ទាប់គ្នា។ គេមានតុ ៣ និងបញ្ជីឈ្មោះ៖ អ្នករដ្ឋការ ជនស៊ីវិល និងយោធា)ទំព័រ៤៣ ERN (ភាសាខ្មែរ)00836120 (S បានបញ្ជាក់ថា នៅស្គន់ គេឱ្យពួកគាត់ចុះឈ្មោះក្នុងបញ្ជី ៤ ដងក្នុងពេលខុសគ្នា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភួង ផល្លា ឯកសារ E3/4757 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00864243 (នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ គាត់ និងគ្រួសាររបស់គាត់ត្រូវបានគេឃុំខ្លួន និងសួរចម្លើយរយៈពេល២ថ្ងៃ ២យប់នៅមន្ទីរឃុំឃាំងនៅវត្តភ្នំដិន ជាទីកន្លែងដែលខ្មែរក្រហមបានចោទប្រកាន់ពួកគាត់ថាជាខ្មែរក្រោម ឬថាជាក្បាលយួនខ្លួនខ្មែរ មុនពេលគេដោះលែងពួកគាត់ និងបានបញ្ជូនទៅស្រុកគីរីវង្ស ខេត្តតាកែវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ឹម គ្រេះ ឯកសារ E3/4822 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦ ERN (ភាសាខ្មែរ) 00893354 (ទាហាន លន់ នល់ ម្នាក់ដែលត្រូវបានកងទ័ពខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនទៅត្រើយខាងកើតទន្លេមេគង្គនៅក្នុងខេត្ត កណ្តាល ជាមួយនឹងមនុស្សរាប់រយនាក់ផ្សេងទៀត បានបញ្ជាក់ថា នៅពេលពួកគាត់បានទៅដល់ភូមិមួយក្នុងស្រុកក្នុងខេត្តកំពង់ចាម ពួកខ្មែរក្រហមបានស្រាវជ្រាវប្រវត្តិរូបមនុស្សទាំង ៥០០ នាក់ រយៈពេល ៥ ថ្ងៃ មុនពេលឃុំខ្លួនមនុស្ស ៥០០ នាក់នោះ នៅក្នុងគុកបដិវត្តន៍ជីហែទន្លេបិទ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៥៩ ERN (ភាសាខ្មែរ) 00836236 (នី ប៊ុនលី បានបញ្ជាក់ថា នៅតាមផ្លូវ គាត់បានឃើញកងទ័ពខ្មែរក្រហមនៅជាក្រុមៗ ៣ ឬ ៤ នាក់ ចាំឆែក និងយកនាឡិកា វិទ្យុ មាស និងត្បូងពេជ្រ)។

[១៩៣២] លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ អតីត ឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៦ ERN (ភាសាខ្មែរ) 00499666 (ទាហានដែលត្រូវបានជម្លៀសចេញទៅជាមួយក្រុមគ្រួសាររបស់ពួកគេ ត្រូវបានស្គាល់អត្តសញ្ញាណយ៉ាងងាយស្រួលបំផុតនៅឯប៉ុស្តិ៍ត្រួតពិនិត្យ និងត្រូវបានបង្ខំឱ្យដោះស្បែកជើង និងឯកសណ្ឋានចេញ ហើយត្រូវបានបាញ់សម្លាប់ភ្លាមៗតែម្តង។ នៅចន្លោះពីភ្នំពេញ និងព្រែកក្តាម គាត់បានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់នាយទាហានជាច្រើន ដោយនារីវ័យជំទង់កុម្មុយនីស្តដែលមានអាយុពី ១៥ ទៅ ២០ ឆ្នាំ ដោយពួកនាងៗទាំងនោះបានប្រើកាំភ្លើងស្វ័យប្រវត្តិបាញ់សំដៅទៅលើខ្នងរបស់នាយទាហានទាំងនោះ បន្ទាប់ពីពួកគេត្រូវបានបញ្ជាឱ្យដើរទៅមុខប្រហែល ២០ ម៉ែត្រ រួចមក)។

ក៏ដោយ ជាទូទៅ ពួកគេត្រូវបានប្រមូលយកទៅដាក់មួយកន្លែង បានចាប់ខ្លួន ឬ ចង និងយកចេញទៅបាត់[១៥៣៣]។ ដោយយោងទៅតាមជនភៀសខ្លួនម្នាក់ផ្សេងទៀតបានរៀបរាប់ថា ទាហានដែល

---

[១៥៣៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២២ (កត់សម្គាល់ថា អ្នកទាំងឡាយណាដែលត្រូវបានគេស្គាល់ថាជាទាហាន លន់ នល់ ត្រូវបានគេយកទៅដាក់មួយឡែក)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៣ (ម្តាយរបស់អ្នកស្រី បានប្រាប់អ្នកស្រីថា សមាជិកគ្រួសារម្នាក់ដែលទាហានពាក់សក្តិ៥ ត្រូវបានគេប្រមូលចូលទៅភ្នំពេញវិញដើម្បីធ្វើការងារនៅក្នុងទីក្រុងភ្នំពេញ តាមតែគេបានប្រាប់គាត់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៩ (អ្នកទាំងឡាយណាដែលបានចុះឈ្មោះរបស់ពួកគេ ពុំបានបន្តដំណើរទៅមុខដូចពួកយើងទេ កងទ័ពខ្មែរក្រហមបានដាក់ពួកគេមួយឡែក ហើយក្រុមមួយផ្សេងទៀតបាននាំយកពួកគេចេញទៅ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣១-៣៣ (ឪពុករបស់គាត់ដែលជាអតីតទាហាន លន់ នល់ និងឪពុកមារបស់គាត់ ត្រូវបានគេបំបែកចេញពីក្រុមនៅឯប៉ុស្តិ៍ត្រួតពិនិត្យ ប៉ុន្តែក្រោយមក ពួកគាត់បានរត់គេចខ្លួន ហើយបានស្វែងរកក្រុម គ្រួសាររបស់គាត់វិញ) ទំព័រ ៣៦ (នៅពេលដែលពួកគេបានសួរប្រជាជន ហើយប្រជាជនបានប្រាប់ពួកគេថា ពួកគេគឺជាទាហាន លន់ នល់ អ្នកទាំងនោះក៏ត្រូវបានគេចាប់ចងយកទៅឃុំខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ឯកសារ E3/5788 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373216-00373217 (នៅតាមកន្លែងជាច្រើនតាមផ្លូវទៅកាន់ភូមិ កងទ័ពខ្មែរក្រហមបានចែកម្ហូបអាហារ និងបានសម្ភាសន៍ប្រជាជនអំពីព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគាត់ ហើយប្រសិនបើពួកវារកឃើញថាមានបញ្ហា គេនឹងយកប្រជាជននោះទៅ។ ឧទាហរណ៍ នៅភូមិកំពង់ទួល ពួកវាបានចាប់ឪពុករបស់គាត់ នៅពេលពួកវាបានរកឃើញថា គាត់ជាទាហាន លន់ នល់។ ទាហាន លន់ នល់ ត្រូវបានចងនឹងខ្សែអំបោះ ហើយអ្នកទាំងឡាយដែលត្រូវបានចាប់ខ្លួននោះ ត្រូវបានគេសម្លាប់ចោល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឯកសារ E3/4628 ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ៧ ERN (ភាសាខ្មែរ) (ជាសមាជិកគណៈស្រុកម្នាក់ដែលបានមកស្វាគមន៍អ្នកដែលត្រូវបានជម្លៀសនៅក្នុងតំបន់របស់គាត់ គាត់ត្រូវបានប្រពន្ធរបស់ទាហានដែលបានមកដល់តំបន់របស់គាត់ប្រាប់ថា ក្នុងអំឡុងពេលនៃការជម្លៀស កងទ័ពខ្មែរក្រហមបានឈរជើងនៅតាមផ្លូវ ចាប់យកទាហាន លន់ នល់ ពីក្នុងចំណោមហ្វូងមនុស្សម្តងមួយម្តងមួយ ប៉ុន្តែបានអនុញ្ញាតឲ្យប្រពន្ធរបស់ទាហានទាំងនោះធ្វើដំណើរទៅមុខទៀត)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ទៀង សុខុម ឯកសារ E3/5402 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480111 (បានឃើញគ្រួសារមួយមានគ្នា ៤ នាក់ ត្រូវបានពួកកងឈ្លបចាប់យកទៅភូមិមួយនៅក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ បន្ទាប់ពីសមាជិកគ្រួសារម្នាក់ត្រូវបានគេស្គាល់ថាជាអតីតវរសេនីយ៍ឯកក្នុងរបប លន់ នល់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ នួន មុំ ឯកសារ E3/5425 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00481225 (បានឃើញប្តីរបស់អ្នកស្រីដែលធ្លាប់ធ្វើជាទាហាន លន់ នល់ ត្រូវបានចាប់ខ្លួននៅតាមផ្លូវ នៅវត្តវិហារខ្ពស់ ឃុំលាយបូរ ដោយចោទថាជាទាហាន លន់ នល់។ បន្ទាប់ពីកងទ័ពខ្មែរក្រហម២នាក់បានចាប់ខ្លួនគាត់ និងមនុស្សដទៃទៀតជាខ្សែៗយកទៅ អ្នកស្រីមិនដឹងថា គេយកគាត់ទៅទីណាទេ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កឹម រើន ឯកសារ E3/5431 ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483582 (នៅក្បាលថ្នល់ កងកម្លាំងយោធាខ្មែរក្រហមបានសួរឪពុករបស់អ្នកស្រីអំពីការងាររបស់គាត់ក្នុងជំនាន់ លន់ នល់។ បន្ទាប់ពីឪពុករបស់អ្នកស្រីបានប្រាប់តាមត្រង់ថាធ្វើជាទាហាន លន់ នល់ ពួកខ្មែរក្រហម បានឲ្យឪពុករបស់អ្នកស្រី

កំពុងធ្វើដំណើរនៅពេលនោះ ត្រូវបានត្រួតពិនិត្យយ៉ាងម៉ត់ចត់នៅតាមប៉ុស្តិ៍ត្រួតពិនិត្យជាងប្រជាជនស៊ីវិល[១៩៣៤]។ សាក្សី មាស សារ៉ាន់ បានពិពណ៌នាអំពីស្ថានភាពដែលអ្នកត្រូវបានជម្លៀសនៅឯប៉ុស្តិ៍ត្រួតពិនិត្យបានបាត់ខ្លួន បន្ទាប់ពីពួកខ្មែរក្រហមបានបញ្ឈប់ដំណើរ និងបានសួរពួកគេ[១៩៣៥] ។ អ្នកដែលត្រូវបានជម្លៀសជាច្រើន បានឃើញទាហាននៃរបបសាធារណរដ្ឋខ្មែរដើរជាជួរដោយដៃមានជាប់ចំណងបន្តគ្នា[១៩៣៦] បើទោះជាមានមនុស្សតិចតួចបានរៀបរាប់លំអិតអំពីជោគវាសនានៃ

---

ឈរនៅម្ខាង និងបានប្រាប់ឲ្យប្រពន្ធ និងកូនរបស់គាត់ធ្វើដំណើរបន្តទៅស្រុកកំណើតនៅស្វាយរៀង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418273 (នៅវត្តបាក់ក ចន្លោះខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ខ្មែរក្រហមបានសាកសួរប្រវត្តិរូបរបស់ពួកគាត់ ដោយសន្យាថា នរណាធ្លាប់ធ្វើអីពីមុនមក នឹងចាត់ឲ្យទៅធ្វើការងារដដែលហ្នឹងវិញ។ អ្នកទាំងឡាយដែលបាននិយាយថា ពួកគាត់ធ្វើជាគ្រូបង្រៀន ពេទ្យ ទាហាន ឬអ្នកដែលមានសក្តិ ត្រូវបានខ្មែរក្រហមរើសដាក់ដោយឡែក ហើយបានបញ្ជូនយកទៅសម្លាប់ចោល)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ៣-៤ ERN (ភាសាខ្មែរ) 00420971-00420972 (ប្តីរបស់អ្នកស្រីជាអតីតទាហាន លន់ នល់ ត្រូវបានគេនាំយកចេញទៅ ក្នុងខណៈពេលដែលពួកគាត់កំពុងជម្លៀស។ អង្គការនិយាយថា ពួកគេត្រូវការគាត់ដើម្បីយកទៅជួយបោសសម្អាតខ្មាំងក្នុងទីក្រុង)។

[១៩៣៤] ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ១១ ERN (ភាសាខ្មែរ) 00658224។

[១៩៣៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៤-៨ (នៅតាមផ្លូវ ពួកខ្មែរក្រហមបានបញ្ឈប់អ្នកដែលត្រូវបានជម្លៀសនៅតាមប៉ុស្តិ៍ត្រួតពិនិត្យមួយចំនួន ហើយបានសួរសំណួរប្រជាជនទាំងនោះ ហើយអ្នកដែលត្រូវបានគេសួរនោះ បានបាត់ខ្លួនជាបណ្តើរៗ។ នាយទាហានម្នាក់បានលាក់អត្តសញ្ញាណរបស់គាត់ និងបានបាំងមុខរបស់គាត់។ មាស សារ៉ាន់ក៏បានកុហកអំពីប្រវត្តិរបស់គាត់ដែរ និងបាននិយាយថាគាត់ជាអ្នកបើកតាក់ស៊ី ពីព្រោះគាត់មិនទុកចិត្តខ្មែរក្រហម)។

[១៩៣៦] ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣២-៣៣, ៣៤-៣៥, ៣៥-៣៦ (ឪពុករបស់គាត់ជាអតីតទាហាន លន់ នល់ ដែលត្រូវបានគេយកទៅដាក់មួយឡែកនៅឯប៉ុស្តិ៍ត្រួតពិនិត្យ ប៉ុន្តែបានរត់គេចខ្លួន និងបានស្វែងរកក្រុមគ្រួសាររបស់គាត់វិញនោះ បាននិយាយថា គាត់បានឃើញទាហាន លន់ នល់ ជាច្រើន ត្រូវបានចាប់យកទៅឃុំខ្លួនដោយពួកកងទ័ពខ្មែរក្រហម និងត្រូវបានចងជាជួរ។ប្រហែលពី ១០ ថ្ងៃ ទៅ ២ សប្តាហ៍ ក្រោយរំដោះដើមបណ្តឹងរដ្ឋប្បវេណីក៏បានឃើញកងទ័ពខ្មែរក្រហមបណ្តើរប្រជាជនពីរជួរ ដែលមានចំនួនសរុបជាង ២០ នាក់ ក្នុងសំលៀកបំពាក់ស៊ីវិល និងទាហាន ដោយចងភ្ជាប់គ្នាដោយខ្សែអំបោះពណ៌ស និងក្រហម។ អ្នកជាប់ឃុំមួយចំនួន ត្រូវបានគេចងមេដៃ ហើយអ្នកផ្សេងទៀតត្រូវបានគេចងស្លាបសេក)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨៣, ៩២-៩៣ (នៅជិតតំបន់បឹងស្នោរ បានឃើញទាហាន នៅក្នុងរដ្ឋការ លន់ នល់ ត្រូវបានគេចង និងបង្ខំឲ្យដើរជាជួរក្នុងទិសដៅផ្ទុយគ្នាឆ្ពោះទៅទីក្រុងភ្នំពេញវិញ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៦-៧៧។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៤-២៥ (ត្រូវបានអ្នកដទៃប្រាប់

ទាហានទាំងនោះក៏ដោយ។ ទោះបីជាមនុស្សមួយចំនួនក្រោយមកបានដឹងថា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរមួយចំនួនត្រូវបានសម្លាប់ចោលក៏ដោយ[១៩៣៧] ក៏មនុស្សផ្សេងទៀតមិនដែលទទួលបានព័ត៌មានណាមួយ អំពីសមាជិកគ្រួសារអ្នកដែលត្រូវបាននាំយកទៅបាត់នោះទេ[១៩៣៨]។ សាក្សី ពេជ្រ ជឹម ជាសមាជិកគណៈកម្មាធិការស្រុកម្នាក់ដែលបានស្វាគមន៍អ្នកដែលត្រូវបានជម្លៀសទៅនៅក្នុងតំបន់របស់គាត់ បានឲ្យដឹងថាស្ត្រីភាគច្រើនដែលគាត់បានជួប បន្ទាប់ពីរំដោះបានទីក្រុង

---

ថា ទាហាន លន់ នល់ ត្រូវបានគេចាប់ចងស្លាប សេក។ ពួកខ្មែរក្រហមអាចមើលទៅកជើងរបស់ប្រជាជន ហើយដឹងថាពួកគាត់ជាអតីតនាយទាហាន ឬជាទាហាន)។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ ណារិន ឯកសារ E3/4773 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00496951 (បានឃើញជនជាតិអាមេរិកម្នាក់ត្រូវបានខ្មែរក្រហមចាប់ចងជាប់នឹងជើងសរសរវត្តស្វាយជ្រំ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៊ុត សូត្រ ឯកសារ E3/4823 ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00523356 (អ្នកស្រីបានរៀបការជាមួយទាហានជើងទឹកម្នាក់ក្នុងរបប លន់ នល់ ក្នុងអំឡុងពេលនៃការជម្លៀសពីទីក្រុងភ្នំពេញ អ្នកស្រីបានឃើញទាហានរដ្ឋាភិបាល ត្រូវបានគេចងខ្សែ និងបណ្តើរតាមផ្លូវ)។

[១៩៣៧] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ឯកសារ E3/5788 ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373216-00373217 (ទាហាន លន់ នល់ ត្រូវបានគេចងនឹងខ្សែអំបោះ ហើយអ្នកទាំងឡាយដែលត្រូវបានគេចាប់ខ្លួននោះ ត្រូវបានគេយកទៅសម្លាប់ចោល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ទៀង សុខុម ឯកសារ E3/5402 ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00480111 (ក្រោយមកអ្នកស្រីបានដឹងថា គ្រួសារមួយដែលមានសមាជិក ៤ នាក់ ដែលត្រូវបានគេចាប់ខ្លួនបន្ទាប់សមាជិកគ្រួសារម្នាក់ត្រូវបានគេស្គាល់ថាជាអតីតវរសេនីយ៍ឯកក្នុងរបប លន់ នល់ ត្រូវបានគេយកទៅសម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ បេង បឿន ឯកសារ E3/4719 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00418273 (នៅវត្តបាក់ក ចន្លោះខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ អ្នកទាំងឡាយដែលបាននិយាយថា ពួកគាត់ធ្វើជាគ្រូបង្រៀន ពេទ្យទាហាន ឬ អ្នកដែលមានសក្តិ ត្រូវបានខ្មែរក្រហមរើសដាក់ដោយឡែក ហើយបានបញ្ជូនយកទៅសម្លាប់ចោល)។

[១៩៣៨] ទម្រង់បែបបទព័ត៌មានជនរងគ្រោះ នួន មុំ ឯកសារ E3/5425 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00481225 (ប្តីរបស់អ្នកស្រី ដែលធ្លាប់ធ្វើជាទាហាន លន់ នល់ ត្រូវបានចាប់ខ្លួននៅតាមផ្លូវ នៅវត្តវិហារខ្ពស់ ឃុំលាយបូរ ហើយត្រូវបានគេនាំយកទៅបាត់រហូតតាំងពីពេលនោះមក)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ កឹម រើន ឯកសារ E3/5431 ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483582 (អ្នកស្រីពុំបានទទួលព័ត៌មានអំពីឪពុករបស់អ្នកស្រីឡើយ ចាប់តាំងពីឪពុករបស់អ្នកស្រីបានប្រាប់ពួកខ្មែរក្រហមថាគាត់គឺជាអតីតទាហាន លន់ នល់ នៅក្បាលថ្នល់នោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00420971-00420972 (អ្នកស្រីមិនដែលបានឃើញប្តីរបស់អ្នកស្រីដែលជាអតីតទាហាន លន់ នល់ ទៀតឡើយ ចាប់តាំងពីគេយកគាត់ចេញពីអ្នកស្រីទៅ ក្នុងពេលដែលពួកគាត់កំពុងត្រូវបានជម្លៀស និងមិនដឹងថាមានអ្វីកើតឡើងចំពោះគាត់ឡើយ)។

ភ្នំពេញ ហើយស្ត្រីទាំងនោះជាភរិយារបស់អតីតទាហាន លន់ នល់ នោះ បានប្រាប់គាត់ថា កងទ័ព បានចាប់យកប្តីរបស់ពួកគេនៅពេលកំពុងធ្វើដំណើរ ដោយចំណុចនេះមានន័យថា អ្នកទាំងនោះ បានបាត់ខ្លួន ហើយស្ត្រីទាំងនោះនៅមេម៉ាយ[១៥៣៩]។ ប៉ុន្តែការពិពណ៌នាមួយផ្សេងទៀតបានបញ្ជាក់ ថា នៅចំការលើជិតស្វាយទាប អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាទាហាន ត្រូវបានបញ្ជូន ទៅស្ទឹង ដែលនៅទីនោះ ទាហានទាំងនោះត្រូវកាប់ឆ្ការព្រៃយកដី និងដាំដំណាំ[១៥៤០]។

៥១៤. នៅតាមកន្លែងមួយចំនួន អតីតនាយទាហាន អ្នករដ្ឋការ និងអ្នកមានវិជ្ជាជីវៈផ្សេងៗទៀត ក្នុងចំណោមអ្នកដែលត្រូវបានជម្លៀស ត្រូវបានជំរុញឱ្យចុះឈ្មោះរបស់ពួកគេជាមួយនឹងកងទ័ព ខ្មែរក្រហម ដោយមានការសន្យាថានឹងអាចវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ ប៉ុន្តែពួកគេជាច្រើន នាក់មិនជឿទៅលើការសន្យានោះទេ[១៥៤១]។ សាក្សី François PONCHAUD ត្រូវបានបុរសម្នាក់

[១៥៣៩] ប្រតិចារឹក ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ២៦-២៧ (អះអាងបញ្ជាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ E3/4626 ERN (ភាសាខ្មែរ) 00373467)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៧-៣៨ (ទោះបីជាមានទាហាន និងនគរបាលត្រូវបានគេជម្លៀសពីទីក្រុងភ្នំពេញក៏ដោយ ក៏អ្នកស្រី និងគ្រួសាររបស់អ្នកស្រី មិនដែលបានឃើញពួកគេរស់នៅជាមួយនឹងប្រជាជនមូលដ្ឋានទៀតឡើយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00420971-00420972 (អ្នកស្រីមិនដឹងថាមានអ្វីកើតឡើងចំពោះប្តីរបស់អ្នកស្រីឡើយ ដែលប្តីរបស់អ្នកស្រីគឺជាអតីតទាហាន លន់ នល់ ដែលត្រូវបានគេយកចេញពីអ្នកស្រីទៅ ក្នុងអំឡុងពេលដែលពួកគាត់កំពុងត្រូវបានជម្លៀស)។

[១៥៤០] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៣១ ERN (ខ្មែរ) 00836108។

[១៥៤១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៨ (បានឮថា អតីតទាហាន អ្នករដ្ឋការ គ្រូបង្រៀន វេជ្ជបណ្ឌិត តម្រូវឱ្យមកធ្វើការនៅក្នុងទីក្រុងភ្នំពេញវិញ បន្ទាប់ពីទីក្រុងត្រូវបានរៀបចំរួចរាល់ជាស្ថាពរ ហើយអ្នកទាំងនោះ នឹងត្រូវបានអនុញ្ញាតឱ្យត្រឡប់មកវិញ។ ដូច្នេះអ្នកទាំងនោះត្រូវចុះឈ្មោះរបស់ពួកគេជាមួយនឹងកងទ័ពខ្មែរក្រហម)។ ប្រតិចារឹក ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១-៨២, ៩២-៩៤ (នៅព្រែកឯង ពួកគាត់បានឮការប្រកាសតាមមេក្រូប្រាប់ដល់ប្រជាជន ដែលធ្លាប់ធ្វើការនៅក្នុងទីក្រុងភ្នំពេញឱ្យមកចុះឈ្មោះ។ ដោយមានការសង្ស័យ ប៉ូ ឌីណា និងប្តីរបស់អ្នកស្រី បានសម្រេចចិត្តមិនមកចុះឈ្មោះ ហើយបានបន្តដំណើរទៅខេត្តកណ្តាល ប៉ុន្តែនៅពេលពួកគាត់បានទៅដល់ទៅនោះ ពួកគាត់ត្រូវបានគេកត់ឈ្មោះទាំងអស់គ្នា)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១-៨២, ៩២-៩៤ (នៅវត្តចំប៉ា និងវត្តច្បារអំពៅ មានការសរសេរនៅលើក្តារខៀនខ្មៅមួយថា អ្នករដ្ឋការ នាយនគរបាល ឬនាយទាហាន គួរតែមកចុះឈ្មោះដើម្បីវិល ត្រឡប់ទៅទីក្រុងភ្នំពេញ ដើម្បីរៀបចំប្រទេសឡើងវិញ។ ក្នុង ខណៈដែលមនុស្សមួយចំនួនបានមកចុះឈ្មោះ នូវ ហ៊ន់ មិនជឿថាគេយកគាត់ត្រឡប់ទៅភ្នំពេញវិញទេ គាត់ដឹងថា មានតែរង់ចាំសេចក្តីស្លាប់ប៉ុណ្ណោះ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១ ERN (ភាសាខ្មែរ) 00836188 (អតីតទាហានលន់ នល់ ម្នាក់ ដែលបាន

អាយុ៥០ ឆ្នាំ ប្រាប់គាត់អំឡុងថ្ងៃទី២២ និងថ្ងៃទី២៣ ខែ មេសា ឆ្នាំ១៩៧៥ អំពីការអំពាវនាវឲ្យមកចុះឈ្មោះនៅកៀនស្វាយ ហើយគាត់បានទទួលពត៌មានស្រដៀងគ្នានេះដែរនៅបាត់ដំបង បន្ទាប់មកអ្នកដែលបានចុះឈ្មោះទាំងនោះត្រូវបានប្រមូលផ្ដុំយកទៅសម្លាប់ចោល[១៥៤២]។ ការពិពណ៌នាមួយចំនួនបានបញ្ជាក់ថា អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបាននាំយកទៅបាត់ ហើយមិនដែលឃើញវិលត្រឡប់មកវិញឡើយ[១៥៤៣]។

---

ស្លៀកពាក់ជាជនស៊ីវិលបន្ទាប់ពីទីក្រុងភ្នំពេញបានដួលរលំ បានរង់ចាំនៅដីឥដ្ឋរយៈពេលជាងមួយខែ ជាមួយនឹងមនុស្សជាច្រើននាក់ផ្សេងទៀត រួមមាន នាយទាហាន អ្នករដ្ឋការជាច្រើន ដោយសង្ឃឹមថាអាចត្រឡប់ទៅភ្នំពេញវិញ បានបញ្ជាក់ថា ពួកខ្មែរក្រហមបានសរសេរលើក្ដារខៀនខ្មៅថា នាយទាហាន ចាប់ពីថ្នាក់អនុសេនីយ៍ត្រីឡើងទៅ ត្រូវចុះឈ្មោះត្រឡប់ទៅភ្នំពេញវិញ។ គាត់អត់បានចុះឈ្មោះទេ ពីព្រោះគាត់មានអារម្មណ៍ថាមិនស្រួល) ទំព័រ ១២១ ERN (ភាសាខ្មែរ) 00836198 (នៅជ្រោយអំពិល ផ្លូវជាតិលេខ១ គាត់បានឃើញ យោធា និងតំណាងរាស្ត្រជាច្រើននាក់ រួមមាន អ៊ិត សួង, ហ៊ុង ហុងសាក់, ណារ៉ាឌីប៉ូ និង ឡាយ ស៊ិញងួន។ បន្ទាប់ពីពួកខ្មែរក្រហមបានសរសេរលើក្ដារខៀនខ្មៅថា នាយទាហាន និងតំណាងរាស្ត្រ ត្រូវទៅចុះឈ្មោះ ពួកគេជាច្រើនបានទៅចុះឈ្មោះ។ នៅព្រែកពោធិ៍ ដូចជានៅគគីរដែរ មេក្រុប្រកាសថា អតីតទាហាន អ្នករដ្ឋការ គ្រូពេទ្យ ត្រូវទៅចុះឈ្មោះ ប៉ុន្តែគ្មានអ្នកណាទៅចុះឈ្មោះទេ។ អ្នកទាំងអស់គ្នាកុហកថាជាពលករ) ទំព័រ ១៦០ ERN (ភាសាខ្មែរ) 00836237 (នី ប៊ុនលី បានបញ្ជាក់ថា ប្រហែលជានៅថ្ងៃទី ២៥ ខែ មេសា នៅវត្តកក់ សាក្សីបានឃើញខ្មែរក្រហមម្នាក់ចុះឈ្មោះនាយទាហាន មន្ត្រី រដ្ឋការជាន់ខ្ពស់ ឥស្សរជន។ ពួកគេនិយាយថា ពួកគេយកពួកគាត់ទៅជួយធ្វើការនៅទីក្រុង។ ក្នុងក្រុមអ្នកដែលពួកគេនាំទៅ គាត់ស្គាល់ ហង់ ធុនហាក់, ប៉ាន់ សុទ្ធី, ភី ធានឡាយ, អ៊ុក យន់, ស៊ី ចៃ (មេធាវី), ស៊ី តឹក (មេបញ្ជាការកងវិស្វកម្ម), ស៊ីសុវត្ថិ ដួងសុជីវិន ព្រមទាំងនាយទាហានជាច្រើនអ្នកផ្សេងទៀតដែលគាត់មិនស្គាល់) ទំព័រ ១៧៣ ERN (ភាសាខ្មែរ) 00836250 (អតីតទាហាន លន់ នល់ ម្នាក់បានបញ្ជាក់ថា នៅក្រោយវត្តចំប៉ា ពួកខ្មែរក្រហមបានសរសេរទុកលើក្ដារខៀនថា នាយទាហាន ចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ត្រូវទៅចុះឈ្មោះទៅភ្នំពេញ។ គ្រូបង្រៀន និស្សិត និង សាស្ត្រាចារ្យ ចាំពេលក្រោយ។ រាល់ថ្ងៃ គាត់ឃើញនាយទាហានជាច្រើនទៅចុះឈ្មោះ ហើយខ្មែរក្រហមដឹកពួកគេចេញតាមឡានធំៗ ដូចជា ឧត្តមសេនីយ៍ ឆាយ ឡាយ, ឧត្តមសេនីយ៍ ប៉ែន រ៉ាដា, វរសេនីយ៍ឯក នាង សន, វរសេនីយ៍ទោ ញ៉ុង ចាន់សូរ៉ាត, វរសេនីយ៍ទោ គោក អុល និងនាយទាហានដទៃទៀតជាច្រើន។ ពួកគាត់បានទុកក្រុមគ្រួសារនៅឯវត្ត នៅជ្រោយអំពិល)។

[១៥៤២] ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៩-១០, ១៨-១៩, ៣៨-៣៩។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៨-១៩ (ភរិយារបស់នាយទាហានបានប្រាប់គាត់ថា បន្ទាប់ពីអង្គការបានចាត់តាំងស្នាមីរបស់ពួកគាត់ត្រឡប់ទៅភ្នំពេញដើម្បីកសាងជាតិនោះ ពួកគេក៏បានត្រឡប់ទៅភ្នំពេញវិញ ប៉ុន្តែពួកខ្មែរក្រហមបានសម្លាប់ពួកគេចោល។ ករណីដូចគ្នានេះក៏កើតមាននៅបាត់ដំបង និងកៀនស្វាយដែរ)។

[១៥៤៣] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១១ ERN (ភាសាខ្មែរ) 00836188 (នាយទាហានជាច្រើនជឿតាម ហើយបានចុះឈ្មោះ។ ខ្មែរក្រហមបានចែកអង្ករឲ្យ ហើយបន្ទាប់មកដឹក

៥១៥. ទោះបីជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើន ត្រូវបានបញ្ជូនទៅតាមភូមិនានាដើម្បីឱ្យទៅធ្វើការ ឬ យកទៅអប់រំកសាងនៅប៉ុន្មានថ្ងៃក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[១៥៤៤] ក៏ដោយ ប៉ុន្តែ ដោយពិចារណាទៅលើការស្វែងរកគោលដៅ ការប្រកាស និងការសួរអ្នកដែលត្រូវបានជម្លៀសនៅឯប៉ុស្តិ៍ត្រួតពិនិត្យ ដែលសកម្មភាពទាំងអស់នេះត្រូវបានធ្វើឡើងដើម្បីបង្ខំឱ្យអ្នករដ្ឋការទាំងនោះចេញមកបង្ហាញខ្លួននោះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា កងទ័ពខ្មែរក្រហមបានកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយថាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើនត្រូវបានចាប់ខ្លួន ហើយក្រោយមកក៏បានបាត់ខ្លួន ឬ ក៏ត្រូវបានសម្លាប់ចោលនៅប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

### ១០.២.១៨ ការប្រព្រឹត្តិមកលើអ្នកដែលត្រូវបានជម្លៀសនៅពេលទៅដល់ភូមិ

៥១៦. ចំពោះអ្នកដែលត្រូវបានជម្លៀសបានទៅដល់គោលដៅ ពួកគេទទួលបានការស្វាគមន៍ខុសៗគ្នាទៅតាមគោលដៅរបស់ពួកគេ។ ដោយសារតែមនុស្សមួយចំនួនត្រូវបានប្រាប់ជាមុនឱ្យរៀបចំទទួលអ្នកដែលត្រូវបានជម្លៀស[១៥៤៥] ជាដំបូង អ្នកទើបមកដល់ថ្មីមួយចំនួនទទួលបានការស្វាគមន៍ និងការជួយជ្រោមជ្រែងពីសំណាក់ "អ្នកមូលដ្ឋាន" ឬ "ប្រជាជនចាស់" ដោយបានផ្តល់ម្ហូបអាហារ

---

តាមឡានយកទៅបាត់ រហូត។ មានវរសេនីយ៍ឯក ឧត្តមសេនីយ៍ ។ល។ គាត់មិនបានចុះឈ្មោះទេ ហើយក៏បានបន្តដំណើរទៅមាត់ក្រសារ) ទំព័រ ១២១ ERN (ភាសាខ្មែរ) 00836198 (នៅជ្រោយអំពិល អ្នកទាំងឡាយដែលបានចុះឈ្មោះ ត្រូវបានគេនាំយកទៅបាត់ដំណឹងរហូត។ គ្រួសារពួកគេមានការព្រួយបារម្ភ។ ពួកវាថែមទាំងនាំគ្រួសារខ្លះដែលទទូចសុំទៅជាមួយប្តីពេក)។

[១៥៤៤] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៦, ៥១៣។

[១៥៤៥] របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៦០ ERN (ភាសាខ្មែរ) 00324731 (បុរសម្នាក់មកពីតំបន់ ១៣ (តាកែវ) នៅក្នុងភូមិភាគនិរតី បានបញ្ជាក់ថា នៅក្នុងការត្រៀមរៀបចំជម្លៀសទីក្រុងភ្នំពេញ អង្គការបានស្តុកស្រូវ នៅក្នុងឃ្លាំងស្តុកនៅតាមភូមិនានា)។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ ឯកសារ E3/3004 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៧៥ កថាខណ្ឌ ១, ៥ ERN (ភាសាខ្មែរ) 00658220-00658222 (នៅប៉ុស្តិ៍ត្រួតពិនិត្យមួយ ក្នុងភូមិភាគឧត្តរ នៅផ្លូវជាតិលេខ ៦ ចម្ងាយ ១២ គីឡូម៉ែត្រ ពីកំពង់ចម្លងព្រែកក្តាម មេគ្រួសារដែលត្រូវបានជម្លៀស បានទទួលទម្រង់ក្រដាសពី "គណៈកម្មការទទួលអ្នកជម្លៀសភូមិភាគឧត្តរ")។

និងជម្រកដល់អ្នកដែលត្រូវបានជម្លៀសទាំងនោះ ហើយថែមទាំងបានសាងសង់ជម្រកឲ្យអ្នកទាំងនោះស្នាក់នៅទៀតផង[១៥៨៦]។

[១៥៨៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៦-៨៨ (ប្រជាជនមូលដ្ឋាននៅក្នុងភូមិទូល បានឲ្យអង្ករខ្លះទៅគ្រួសារ របស់គាត់ ដើម្បីដូរយកសំលៀកបំពាក់ដែលពួកគាត់មាន)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៩ (នៅពេល ពួកគាត់បានទៅដល់ត្រើយស្លា អ្នកស្រី និងកូនៗរបស់អ្នកស្រីបានស្នាក់នៅផ្ទះប្រជាជនមូលដ្ឋាន ហើយអ្នកមូលដ្ឋាននោះ បានឲ្យអាហារពួកគាត់ហូប)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៨១ (ពួកគាត់ទទួលបានអាហារ និងដំឡូង)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៣-៨៤ (នៅភូមិត្បូងដំរី យាយតារបស់យើងបានស្វាគមន៍យើង ហើយបានឲ្យម្ហូបអាហារយើងហូប ហើយយើងបានស្នាក់នៅជាមួយពួកគាត់ពីរបីថ្ងៃ)។ ប្រតិចារឹកថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ២៤-២៥, ៤៥-៤៦ (សមាជិកគណៈស្រុកខ្មែរក្រហមម្នាក់ ដែលបានមកស្វាគមន៍អ្នកដែលត្រូវបានជម្លៀសនៅក្នុងតំបន់របស់គាត់ បាននិយាយថា ពួកគេមានកិច្ចប្រជុំមួយនៅឃុំពេលដើម្បីទទួលអ្នកដែលត្រូវបានជម្លៀស ដែលនៅទីនោះពួកគេបានផ្តល់ម្ហូបអាហារ និងទឹកឲ្យអ្នកដែលត្រូវបានជម្លៀស និងបានឲ្យពួកគាត់ស្នាក់នៅក្នុងផ្ទះដែលមានដំបូលប្រក់ស្លឹកត្នោត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ឯកសារ E3/4839 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦ ERN (ភាសាខ្មែរ) 00526069 (នៅពេលគាត់បានទៅដល់ព្រៃវែង ខ្មែរក្រហមបានចាត់តាំងឲ្យគាត់ទៅនៅផ្ទះជាមួយប្រជាជនចាស់មួយចំនួន ក្នុងភូមិចម្ការគួយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00239907 (គាត់បានឲ្យអ្នកភូមិជួយធ្វើផ្ទះដើម្បីឲ្យអ្នកដែលត្រូវបានជម្លៀសទាំងនោះរស់នៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃឹម បុាំង ឯកសារ E3/5510 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00402492-00402494 (ជាប្រធានភូមិ គាត់បានសង់ផ្ទះចំនួន ១០ ឲ្យអ្នកដែលត្រូវបានជម្លៀស។ គាត់ក៏ត្រូវបាន តា ខាវ ប្រាប់ផងដែរឲ្យចិញ្ចឹមពួកគេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណុប កាន ឯកសារ E3/4884 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00539342-00539343 (នៅពេលប្រជាជនថ្មីដែលមកពីទីក្រុងភ្នំពេញ បានមកដល់ ស្រុកឈូក ខេត្តកំពត មេភូមិ និងមេឃុំបានប្រាប់ប្រជាជនថ្មីឲ្យសង់ផ្ទះស្នាក់នៅជាមួយប្រជាជនមូលដ្ឋាន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ម ផៃបួន ឯកសារ E3/4901 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ទំព័រ ១១ ERN (ភាសាខ្មែរ) 00541005 (នៅភូមិស្តុក ក្នុងខេត្តកំពង់ស្ពឺ ប្រជាជនមូលដ្ឋានមានចិត្តល្អ និងចាត់ទុកអ្នកត្រូវបានជម្លៀសដូចជាបងប្អូន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ យ៉ែម ឯកសារ E3/415 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00373283 (អ្នកដែលត្រូវបានជម្លៀសមកពីភ្នំពេញជាច្រើន បានមកដល់ភូមិរបស់អ្នកស្រី។ មានការណែនាំពីថ្នាក់លើឲ្យមានការរៀបចំសម្រាប់ប្រជាជនដែលទើបត្រូវបានជម្លៀសមកថ្មី ៖ ពួកគេមានការរៀបចំទទួល បាយ ទឹក ផ្ទះសម្បែង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន ឯកសារ E3/5294 ចុះថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00348828 (មេភូមិខ្មែរក្រហមបានបញ្ជាក់ថា មានការប្រជុំគ្នារវាងសមាជិកគណៈស្រុកដើម្បីឲ្យត្រៀមរៀបចំទទួលអ្នកដែលត្រូវបានជម្លៀស)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00323531 (ភូមិទាំងឡាយដែលពួក

៥១៧. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានបង្កើតឱ្យមានការស្អប់ខ្ពើមចំពោះអ្នកទីក្រុង[១៥៤៧]។ ដូច្នេះ អ្នកដែលត្រូវបានជម្លៀសជាច្រើនផ្សេងទៀត បានរៀបរាប់អំពីរបៀបដែលពួកគេត្រូវបានដាក់ឈ្មោះថាជា "ប្រជាជន ១៧ មេសា" ឬ "ប្រជាជនថ្មី" ដើម្បីបែងចែកពួកគេពីប្រជាជនមូលដ្ឋាន (ដែលគេហៅថាជា "ប្រជាជន ១៨ មីនា" "ប្រជាជនចាស់" ឬ "អ្នកមូលដ្ឋាន") ដោយពួកគេត្រូវបានចាត់ទុកថាជាពួកមូលធន ឬ ពួកសក្តិភូមិ ហើយត្រូវបានបណ្តេញចេញ និងប្រាប់ឱ្យធ្វើដំណើរបន្តទៅមុខទៀត[១៥៤៨] ។ បេ សុផានី បានរៀបរាប់អំពីស្ថានភាពដែលកងទ័ពខ្មែរក្រហមបាន

---

គាត់បានឆ្លងកាត់ ទោះបីជាត្រូវបានកាន់កាប់ដោយពួកខ្មែរក្រហមក៏ដោយ ក៏អ្នកភូមិបានផ្តល់ឱ្យពួកគាត់នូវម្ហូបអាហារ និងជម្រកស្នាក់អាស្រ័យប្រកបដោយភាពរាក់ទាក់)។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៤៦ ERN (ភាសាខ្មែរ) 00324717 (អតីតនិរសារបស់ ជ័យ សួន ហៅ នង សួន បានបញ្ជាក់ថា នៅក្នុងតំបន់ ២៥ ពួកគេត្រូវបានគេប្រាប់ឱ្យរៀបចំទទួល អ្នកដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥។ ពួកគេត្រូវបានណែនាំឱ្យរៀបចំម្ហូបអាហារ ទឹក និងកន្លែងស្នាក់នៅសម្រាប់អ្នកដែលត្រូវបានជម្លៀសមក និងកាប់គោក្របីដើម្បីឱ្យពួកគេហូប និងផ្តល់អង្ករឱ្យពួកគេ។ ស្រុកនីមួយៗ ត្រូវបានគេតម្រូវឱ្យទទួលយកអ្នកដែលត្រូវបានជម្លៀសតាមចំនួនដែលគេកំណត់ ហើយវត្តមានរបស់ពួកគេគឺបណ្តោះអាសន្នតែប៉ុណ្ណោះ។ ប្រសិនបើអ្នកដែលត្រូវបានជម្លៀសទាំងនោះបានធ្វើឱ្យមានបន្ទុកធ្ងន់ដល់សហករណ៍ ពួកគេគួរតែទៅជួបគណៈស្រុក ឬ ឃុំ ដើម្បីស្នើសុំផលិតផលបន្ថែមក្នុងការដោះស្រាយបញ្ហានេះ) ទំព័រ ៦០ ERN (ភាសាខ្មែរ) 00324731 (បុរសម្នាក់មកពីតំបន់ ១៣ (តាកែវ) នៅក្នុងភូមិភាគនិរតី បានបញ្ជាក់ថា មាគ៌ារបស់អង្គការគឺថា ជាទូទៅអ្នកដែលត្រូវបានជម្លៀស គឺជាផ្នែកមួយនៃប្រជាជនកម្ពុជា និងមិនមែនជាសត្រូវទាំងអស់ទេ)។

[១៥៤៧] *សូមមើលផងដែរ* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១១២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៥៦-៥៧ (បានឮពីអ្នកមូលដ្ឋាន និងកងទ័ពថា អ្នកដែលត្រូវបានជម្លៀសមកពីភ្នំពេញធ្លាប់រស់នៅស្រួល ដូច្នេះហើយឱ្យពួកគេលំបាកខ្លះទៅ ដូចអ្នកដទៃទៀតជាច្រើនដែលធ្លាប់លំបាកជាយូរមកហើយ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៦-៧ (ខ្មែរក្រហមបានចាត់ទុកអ្នកទីក្រុងជាមនុស្សពុករលួយ និងជាមនុស្សមិនល្អ ពីព្រោះពួកគេមានសក់វែង និងស្លៀកសំលៀកបំពាក់មិនសមរម្យ)។

[១៥៤៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ទំព័រ ៨៦-៨៩ (គេបានប្រាប់គ្រួសាររបស់គាត់ថា ពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យស្នាក់នៅក្នុងភូមិទួលទេ ពីព្រោះពួកគាត់ជាប្រជាជន ១៧ មេសា។ អ្នកទាំងឡាយដែលរស់នៅក្នុងភូមិដែលត្រូវបានរំដោះកាលពីមុននោះ គឺជាប្រជាជន ១៨ មេសា) ទំព័រ ៩១ (គាត់ និងគ្រួសាររបស់គាត់ត្រូវបានគេស្នើឱ្យតាំងទីលំនៅក្នុងស្រុកប៉ាលេឡៃ។ ប្រជាជនមូលដ្ឋាន និងប្រជាជន ១៨ មីនា មិនរាក់ទាក់ដាក់គាត់ និងគ្រួសាររបស់គាត់ទេ។ ពួកគាត់ត្រូវបានគេប្រាប់ឱ្យរស់នៅមួយក្រុម មិនឱ្យលាយឡំជាមួយប្រជាជន ១៨ មីនា ឡើយ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៣-៨៥, ៨៥-៨៧។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

(ប៉ូ ឌីណា) ទំព័រ ៨២-៨៤ (នៅពេលពួកគាត់ទៅដល់ខេត្តកណ្ដាល ដែលជាស្រុកកំណើតរបស់គាត់ ពួកគាត់ត្រូវបានប្រាប់ថា ពួកគាត់គឺជាប្រជាជន ១៧ មេសា ហើយមិនអាចឈប់នៅទីនោះឡើយ។ ទោះបីជាអ្នកស្រីអង្វរពួកគេសុំស្នាក់នៅទីនោះមួយរយៈ ពីព្រោះពួកគាត់អស់កម្លាំងយ៉ាងណាក៏ដោយ ក៏ពួកគេបដិសេធមិនឲ្យពួកគាត់ស្នាក់នៅឡើយ ដោយអះអាងថា ភូមិរបស់ពួកគេខ្វះខាតម្ហូបអាហារ ដូច្នេះពួកគាត់ត្រូវដើរទៅមុខទៀត)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ៦២-៦៤ (ប្រជាជនមកពីភ្នំពេញដែលបានចូលទៅរស់នៅក្នុងតំបន់ ២០ ជាទីកន្លែងដែលគាត់រស់នៅនោះ ត្រូវបានគេហៅថាជាប្រជាជន ១៧ មេសា ឬប្រជាជនថ្មី )។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៣-៦៤ (នៅភូមិពោធិ៍បាន អ្នកស្រី និងគ្រួសាររបស់គាត់ ត្រូវបានគេហៅថាជាប្រជាជន ១៧ មេសា ហើយត្រូវបានប្រជាជនមូលដ្ឋានធ្វើបាប) ទំព័រ ៦៤-៦៥ (បានទៅដល់វត្តកាយរូង ហើយពួកគាត់បានស្នាក់នៅទីនោះរយៈពេល៣ថ្ងៃ មុនពេលគេជម្លៀសពួកគាត់ចេញពីទីនោះម្ដងទៀត)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៦៧-៦៩ (ពិពណ៌នាអំពីភាពខុសគ្នាក្នុងការប្រព្រឹត្តទៅលើប្រជាជន ១៧ មេសា និងប្រជាជនមូលដ្ឋាន) ទំព័រ ៨៣-៨៤ (គាត់ និងគ្រួសាររបស់គាត់មិនទទួលបានការស្វាគមន៍កក់ក្ដៅឡើយ នៅពេលពួកគាត់ទៅដល់ស្រុកកំណើតរបស់ពួកគាត់ ពីព្រោះ “ប្រជាជន ១៧ មេសា” ត្រូវបានគេចាត់ទុកថាផ្នែកមួយនៃវណ្ណៈជិះជាន់ ដែលមិនស្មោះត្រង់ចំពោះបដិវត្តន៍)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១៤, ២៤-២៥, ២៩-៣០ (នៅឃុំសំរោង កងទ័ពខ្មែរក្រហមម្នាក់បានមកបន្ទោសអ្នកស្រីយ៉ាងខ្លាំងៗថា អ្នកស្រីមកពីវណ្ណៈសក្ដិភូមិ មិនចេះប្រើកូនឲ្យធ្វើអីៗទេ ថ្នមកូន)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤២-៤៣ (នៅក្នុងឃុំត្រពាំងសាប គាត់ត្រូវបានគេប្រាប់ថា គាត់គួរតែប្ដូរឈ្មោះរបស់គាត់ដើម្បីលាក់បាំងសាវតាររបស់គាត់ជាខ្មែរក្រោម ។ គាត់ក៏ធ្វើតាមគេប្រាប់ ពីព្រោះខ្លាចគេយកទៅសម្លាប់ចោល) ៤២-៤៣, ៤៤-៤៥ (នៅក្នុងឃុំត្រពាំងសាប ដែលជាទីកន្លែងដែលគាត់ស្នាក់នៅរយៈពេលពី ១០ថ្ងៃ ទៅ ១ខែ ប្រជាជនមូលដ្ឋានបានចាត់ទុកគាត់ជាអ្នក ១៧ មេសា និងជាពួកនាយទុន ដែលកេងប្រវ័ញ្ចលើកសិករ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៣-៨៥ (ដោយសារតែភូមិត្បូងដំរីស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ទៅហើយនោះ ប្រជាជនទីក្រុងភ្នំពេញត្រូវបានគេចាត់ទុកថាជាអ្នកចំណូលថ្មី ដែលមិនអាចលាយឡំជាមួយនឹងប្រជាជនមូលដ្ឋានឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ) ទំព័រ ៧៣-៧៦ (កម្មាភិបាលខ្មែរក្រហមពុំបានផ្ដល់ការយកចិត្តទុកដាក់ដល់ប្រជាជនដែលទើបមកដល់ថ្មីឡើយ ពួកគាត់ត្រូវបានចាត់ទុកថាជាប្រជាជន ១៧ មេសា ឬ ប្រជាជនថ្មី ហើយបានទទួលការប្រព្រឹត្តិមកលើខុសគ្នា។ ទោះបីជាប្រជាជន ទាំងនេះបានវិលត្រឡប់ទៅស្រុកកំណើត ឬ កន្លែងដែលពួកគាត់មានសាច់ញាតិរស់នៅទីនោះក៏ដោយ ក៏ប្រជាជនទាំងនោះ ហាក់ដូចជាមានការប្រុងប្រយ័ត្នមែនទែនក្នុងការចែករំលែកម្ហូបអាហារទៅឲ្យអ្នកដែលទើបមកដល់ថ្មីទាំងនោះ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ ហន ឯកសារ E3/5559 ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00375524 (នៅពេលដែលពួកគាត់បានមកដល់ស្រុកកំណើតរបស់ពួកគាត់ ពួកគាត់ត្រូវបានគេប្រាប់ថា ពួកគាត់នៅតែត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី ពីព្រោះពួកគាត់បានចាកចេញពីភូមិក្នុងឆ្នាំ ១៩៧២។ ក្នុងនាមជាប្រជាជនថ្មី ពួកគាត់មិនត្រូវបានគេចាត់ទុកថាជាប្រជាជនរបស់អង្គការខ្មែរក្រហមទេ ប៉ុន្តែជាប្រជាជនរបស់របបសាធារណរដ្ឋខ្មែរ ហើយគេប្រព្រឹត្តមកលើពួកគាត់ខុសគ្នា។ រយៈពេលមួយខែក្រោយមក ពួកគាត់ត្រូវបានគេប្រាប់ឲ្យទៅរស់នៅក្នុងជំរំជនភៀសខ្លួន)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សេន ផាប់ ឯកសារ E3/5391 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧ ERN

(ភាសាខ្មែរ) 00479075 (នៅពេលពួកគាត់បានទៅដល់ខេត្តតាកែវ ពួកគាត់ត្រូវបានគេចាត់ឲ្យទៅរស់នៅក្នុងភូមិស្តែង ឃុំគោកព្រិច ស្រុកគិរីវង់ ដែលនៅទីនោះ ប្រជាជនមូលដ្ឋានបានហៅពួកគាត់ថាជាប្រជាជន ១៧ មេសា ឬទាហានសេសសល់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ដៃ យឹន ឯកសារ E3/4824 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤ ERN (ភាសាខ្មែរ) 00523380 (ប្រជាជនដែលត្រូវបានគេជម្លៀស ត្រូវបានចាត់ទុកថាជា "ប្រជាជន ១៧ មេសា"។ ពួកគាត់ត្រូវបានគេតាមដាន និងត្រួតពិនិត្យមើលគ្រប់ពេល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាង ស៊ឹន ឯកសារ E3/4841 គ្មានចុះកាលបរិច្ឆេទ ទំព័រ 2 ERN (ភាសាខ្មែរ) 00893378 (នៅពេលពួកគាត់ទៅដល់ភូមិព្រៃកតូច ស្រុកស្អាង ខេត្តកណ្តាល កាលពីដំបូង ខ្មែរក្រហមបានហាមឃាត់មិនឲ្យអ្នកដែលត្រូវបានជម្លៀសស្នាក់នៅផ្ទះសាច់ញាតិរបស់ពួកគាត់ឡើយ ប៉ុន្តែបានបង្ខំឲ្យពួកគាត់ស្នាក់នៅជាមួយនឹងអ្នកភូមិរយៈពេលមួយសប្តាហ៍។ បន្ទាប់មក អ្នកចំណូលថ្មីត្រូវបានគេបញ្ជាឲ្យស្នាក់នៅដាច់ដោយឡែកពីអ្នកស្រុក រួមទាំងមិនឲ្យនៅជាមួយសាច់ញាតិរបស់ពួកគាត់ផង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឃុយ ប៊ុនថា ឯកសារ E3/4941 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ភាសាខ្មែរ) 00551851 (នៅពេលពួកគាត់បានមកដល់ភូមិកំណើតរបស់ពួកគាត់ កម្មាភិបាលខ្មែរក្រហមបានប្រមូលផ្តុំប្រជាជនថ្មីទាំងអស់ និងបានចាត់ពួកគាត់ឲ្យទៅរស់នៅក្នុងភូមិថ្មីមួយដែលមានសុទ្ធតែប្រជាជនថ្មីទាំងអស់ ដែលមានឈ្មោះថា ភូមិថ្មី ឃុំកក់ ស្រុកគងពិសី (បច្ចុប្បន្នជាស្រុកបសេដ្ឋ) ខេត្តកំពង់ស្ពឺ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ខឹម ទីន ឯកសារ E3/5404 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00480149 (នៅពេលពួកគាត់មកដល់ស្រុកកំណើតរបស់ពួកគាត់ ពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យនិយាយ ឬរស់នៅជាមួយនឹងឪពុកម្តាយរបស់ពួកគាត់ឡើយ។ ពួកគាត់ត្រូវបានអ្នកគ្រប់គ្រងភូមិប្រាប់ថា ប្រជាជនទាំងអស់ដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញគឺជាខ្មាំង ហើយថា ពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យនិយាយជាមួយនឹងប្រជាជនមូលដ្ឋានឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មា ឈិន ឯកសារ E3/4680 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323598 (ប្រជាជនចាស់ត្រូវបានគេដុសខាត់ស្មារតីអស់ជាច្រើនឆ្នាំរួចមកហើយ ហើយត្រូវបានគេប្រាប់មិនឲ្យទុកចិត្តប្រជាជនថ្មីឡើយ និងស្អប់ខ្ពើមពួកគាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម ទុន ឯកសារ E3/5199 ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00212109 (ជាអតីតកងទ័ពខ្មែរក្រហមម្នាក់ គាត់បានបញ្ជាក់ថា ប្រជាជន ១៧ មេសា ដែលត្រូវបានគេជម្លៀសមកពីទីក្រុងភ្នំពេញ ទៅស្រុក ១២ ត្រូវបានចោទប្រកាន់ថាជាខ្មាំង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ណុប ណន ឯកសារ E3/5423 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00481176 (យើងត្រូវបានគេចាត់ទុកថាជាប្រជាជន ១៧ មេសា ដូច្នេះពួកវាឃ្លាំមើលពួកយើងគ្រប់ពេលវេលាទាំងអស់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្នួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484412 (នៅពេលពួកគាត់ទៅដល់ស្រុកកំណើតរបស់ពួកគាត់ មិនសូវមានសាច់ញាតិមកទទួលរាក់ទាក់ឡើយ ដោយសារតែឋានៈខុសគ្នា)។ *សូមមើលផងដែរ* របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៤៦ ERN (ភាសាខ្មែរ) 00324717 (អតីតនិរសាររបស់ ជ័យ សួន គាត់បានបញ្ជាក់ថា នៅក្នុងតំបន់ ២៥ ពួកគេត្រូវបានប្រាប់ថា ក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ អតីតទាហាន លន់ នល់ ជាពិសេសនាយទាហានដែលទទួលខុសត្រូវក្នុងការសម្លាប់មនុស្សជាច្រើន ត្រូវបានចាត់ទុកថាជាខ្មាំង ហើយថា លើកលែងតែនៅតាមក្រសួងនានា មន្ត្រីរាជការស៊ីវិល

ស្តីបន្ទោសអ្នកមូលដ្ឋានចំពោះការឱ្យម្ហូបអាហារដល់ពួកគាត់ ដោយសារតែអ្នកស្រី និងគ្រួសាររបស់គាត់ត្រូវបានចាត់ទុកថាជា"ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា"។ គាត់បានផ្តល់សក្ខីកម្មថា ពួកគាត់ត្រូវបានចាត់ទុកជាអ្នកមានវណ្ណៈទាប ហើយថា គាត់ និងកូនៗរបស់គាត់ត្រូវបានបណ្តេញឱ្យចេញទៅចុងភូមិដែលនៅទីនោះគាត់ត្រូវសាងសង់ជម្រកដោយខ្លួនឯង[១៥៤៩]។ ក្រោយមកអ្នកផ្សេងទៀតបានទទួលបញ្ជាឱ្យចាកចេញពីទីនោះ ឬ ក៏ផ្លាស់ទៅកន្លែងផ្សេងទៀត[១៥៥០]។

### ១០.២.១៩ ការបញ្ចប់ការផ្លាស់ទីលំនៅប្រជាជន

៥១៨. ទីក្រុងភ្នំពេញទាំងមូលគ្មានមនុស្សរស់នៅ តែក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីការជួលរលំនៃទីក្រុងនេះ[១៥៥១]។ ទោះបីជា អៀង សារី បានបញ្ជាក់នៅក្នុងបទសម្ភាសន៍តាមសារព័ត៌មានក្នុងខែ

---

មិនត្រូវបានចាត់ទុកថាជាខ្មាំងឡើយ)។ សក្ខីកម្មរបស់ជនអៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១២១ ERN (ភាសាខ្មែរ) 00836198 (អ្នកដែលត្រូវបានគេ "រំដោះ" តាំងពីយូរហើយ នៅនឹងកន្លែង ប៉ុន្តែអ្នកមកដល់ថ្មីត្រូវចេញ)។

[១៥៤៩] ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៩។

[១៥៥០] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៥-៦៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ១៥-១៦,៣៩-៤០ (បន្ទាប់ពីជម្លៀសពីទីក្រុងភ្នំពេញទៅឃុំសំរោង អ្នកស្រី និងគ្រួសាររបស់អ្នកស្រីត្រូវបានគេបញ្ជាឱ្យទៅព្រែកកុយ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ន់) ទំព័រ ២២-២៤ (បន្ទាប់ពីទៅដល់ភូមិកំណើតរបស់គាត់ ក្នុងខេត្តព្រៃវែង គាត់ស្នាក់នៅទីនោះរយៈពេលមួយសប្តាហ៍ មុនពេលគេបញ្ជូនគាត់ទៅភូមិមួយផ្សេងទៀត ដែលមានចម្ងាយប្រហែល ៣ គ.ម)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៣-៨៤, ៨៥-៨៧ (បន្ទាប់ពីអ្នកស្រីស្នាក់នៅក្នុងភូមិត្បូងដំរី ដែលជាភូមិកំណើតរបស់អ្នកស្រី បាន ២-៣ ថ្ងៃ ពួកគាត់ក៏ត្រូវបានគេបញ្ជាឱ្យចាកចេញពីទីនោះ ដោយសារតែពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យតាំងទីលំនៅនៅទីនោះទេ)។

[១៥៥១] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន) ទំព័រ ៤៨-៥១ (នៅត្រឹមថ្ងៃទី ១៩ ខែ មេសា មាននៅសល់តែប្រជាជនតិចតួចប៉ុណ្ណោះ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានភាពនៅទីក្រុងភ្នំពេញ នាព្រឹកថ្ងៃទី ១៩ ខែ មេសា ឯកសារ E3/2703 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00491788 (រាយការណ៍ថា ការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញហាក់ដូចជាកំពុងត្រូវបានបញ្ចប់)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ សំណើជម្លៀសទូទៅជាបន្ទាន់ ឯកសារ E3/2701 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00492868-00492869 (រាយការណ៍ថា ក្នុងទីក្រុងគ្មានមនុស្សមួយនាក់ទាល់តែសោះ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ១៣, ២៣, ៤៤-៤៥ (រយៈពេល ៥ ទៅ ៦ ថ្ងៃ គឺជម្លៀសប្រជាជនអស់ពីទីក្រុង)។ ប្រតិចារឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ (នោម សៃ) ទំព័រ ២៧-២៨, ២៩-៣០ (ត្រូវចំណាយពេល ៧ ថ្ងៃ ដើម្បីជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង)។ ប្រតិចារឹក

កញ្ញា ឆ្នាំ១៩៧៥ ថា ប្រជាជន ១០០.០០០ នាក់ បានវិលត្រឡប់មកទីក្រុងវិញ ហើយ ប្រជាជនជាច្រើនទៀតអាចវិលត្រឡប់ទៅកាន់ទីក្រុងវិញបាន ប្រសិនបើពួកគេចង់វិលត្រឡប់ទៅវិញក៏

---

ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គីម) ទំព័រ ៩-១០ (បន្ទាប់ពីរយៈពេលមួយសប្ដាហ៍ ភាពច្របូកច្របល់បានធូរស្រាល ហើយប្រជាជនស្ទើរតែត្រូវបានជម្លៀសចេញទាំងស្រុង។ នៅក្នុងរយៈពេលមួយខែ មាននៅសល់តែទាហានខ្លះដែលនៅសេសសល់ និងប្រជាជនស៊ីវិល ដែលពួនសំងំនៅតាមផ្ទះជាន់លើ)។ អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ERN (ភាសាខ្មែរ) 00417604 (ទីក្រុងភ្នំពេញទទេស្អាតនៅត្រឹមថ្ងៃទី ២២ ឬ ២៤ ខែ មេសា នៅពេល អៀង សារី មកដល់)។ ប្រតិចារឹក ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១២ (លោក ខាំ ផាន់ ហៅ ផាន វ៉ាន់) ទំព័រ ៣៤-៣៥ (ទីក្រុងភ្នំពេញទទេស្អាត និងស្ងាត់ជ្រងំ ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ប្រជាជនមិនហ៊ានដើរចេញទៅក្រៅទេ ហើយពុំមានឡាន ឬម៉ូតូឡើយ មានតែទាហានពីរបីនាក់ឈរយាម)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ ៣៧-៤០ (ជាកងទ័ពខ្មែរក្រហម គាត់ត្រូវបានអនុញ្ញាតឲ្យចូលក្នុងទីក្រុងភ្នំពេញ ក្រោយការជម្លៀសប្រជាជនរយៈពេលប្រហែល ២ ទៅ ៣ សប្ដាហ៍ គាត់ឃើញទីក្រុងស្ងាត់ជ្រងំ ហើយមានតែកងទ័ពខ្មែរក្រហមប៉ុណ្ណោះនៅទីនោះ)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៣ (អាល់ រ៉ុក្សហ្វ) ទំព័រ ៥៧-៥៨ (ចាកចេញពីទីក្រុងភ្នំពេញប្រហែលជានៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៥ បានពិពណ៌នាថាមិនមានប្រជាជនស៊ីវិលឡើយ ស្ងាត់ជ្រងំ មានតែកងទ័ពខ្មែរក្រហមកាន់អាវុធ នៅតាមកន្លែងខ្លះៗប៉ុណ្ណោះ) ទំព័រ ៦៣ (ការជម្លៀសប្រជាជនប្រើរយៈពេល ២-៣ ថ្ងៃ) ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ២០១៣ (ហ្វ្រង់ស្វ័រ ប៉ុងស្ងួដ៍) ទំព័រ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី០២ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៨៥-៨៦ (ការជម្លៀសប្រជាជន ស្ទើរតែចប់សព្វគ្រប់ទៅហើយ នៅពេលដែលគាត់បានចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៤-៥ (នៅពេលគាត់បានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ពុំមានប្រជាជននៅក្នុងទីក្រុងឡើយ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥២-៥៣, ៥៤-៥៥ (បានដឹងអំពីការជម្លៀស នៅពេលគាត់បានមកដល់ទីក្រុងភ្នំពេញនៅ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៥ និងបានឃើញទីក្រុងទទេស្អាត។ បានបញ្ជាក់ប្រាប់ថា ការជម្លៀសប្រជាជនបានបញ្ចប់នៅថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ទំព័រ ៤៨-៤៩ (បានអះអាងថា ការជម្លៀសប្រជាជន បានចប់សព្វគ្រប់នៅក្នុងរយៈពេល៣ខែ)។ ប្រតិចារឹកថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ទំព័រ ១៦-១៧, ១៩-២០ (បានមកដល់ទីក្រុងភ្នំពេញនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រយៈពេលប្រហែល៤ខែ ហើយបានឃើញទីក្រុងស្ងាត់ជ្រងំ)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៣២-៣៣, ៧៤-៧៥, ៧៦-៧៧ (បានចូលមកទីក្រុងភ្នំពេញក្រោយ ប៉ុល ពត ២ សប្ដាហ៍ និងបានឃើញទីក្រុងទទេស្អាត)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣(ស៊ីដនី ស្តេនប៊ឹក) ទំព័រ ១៦-១៧ (*ដកស្រង់* S. Schanberg: *កំណត់ហេតុស្តីពីប្រទេសកម្ពុជា ឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១៨៧-១៩១ ERN (ភាសាខ្មែរ) 00964025-00964029៖ ថ្ងៃទី៣០ ខែមេសា៖ ពិពណ៌នាថា នៅពេលដែលពួកគាត់ជម្លៀសចេញ នៅតាមផ្លូវមុនីវង្ស និងជាយទីក្រុងភ្នំពេញ ស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ។ ក្រៅតែពីជនភៀសខ្លួនមួយចំនួនដែលកំពុងដើរតាមផ្លូវ ពុំមានប្រជាជនស៊ីវិលឡើយ មានតែកងទ័ពខ្មែរក្រហម)។ រូបថតផ្សារធំថ្មី ថតពីលើអាកាស ឯកសារ E3/3002 ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥។

ដោយ[១៥៥២] ក៏ការអះអាងនេះ ពិតជាមិនត្រឹមត្រូវឡើយ។ ទោះបីជាមានភស្តុតាងបង្ហាញថា ប្រជាជនមួយចំនួនបានវិលត្រឡប់ទៅកាន់ជាយក្រុងភ្នំពេញភ្លាមៗបន្ទាប់ពីការជម្លៀស[១៥៥៣] ហើយមានប្រជាជនរហូតដល់ ២០.០០០ នាក់ បានរស់នៅក្នុងទីក្រុងភ្នំពេញ ក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យនោះយ៉ាងណាក៏ដោយ[១៥៥៤] ប្រសិនបើមិនទាំងអស់គ្នាទេ ក៏ភាគច្រើនក្នុងចំណោមពួកគេដែលបានវិលត្រឡប់ទៅកាន់ទីក្រុងភ្នំពេញវិញ ត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នោះមែន ដើម្បីជួយគាំទ្រ

---

[១៥៥២] កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយកាសែត Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00291035-00291036 ("សំណួរ៖ តើភ្នំពេញនៅតែគ្មានមនុស្សនៅឬ? ចម្លើយ៖ ទេ មានប្រជាជនប្រហែល ១០០.០០០ នាក់ បានវិលត្រឡប់ចូលមកវិញ ហើយប្រជាជនផ្សេងទៀតកំពុងវិលចូលមកភ្នំពេញជាបណ្តើរៗ។ សាលារៀន មន្ទីរពេទ្យ និងរោងចក្រ បានចាប់បើកទ្វារធ្វើសកម្មភាពវិញជាបណ្តើរៗហើយ។ ប្រជាជនអាចវិលត្រឡប់ចូលភ្នំពេញវិញ ប្រសិនណាបើពួកគេចង់ ឬក៏ពួកគេអាចស្នាក់នៅជនបទ")។ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨ អៀង សារី ក៏បានអះអាងផងដែរថា មានមនុស្សប្រហែលជា ២០០.០០០នាក់ រស់នៅក្នុងរាជធានី ហើយថាប្រជាជនមានការពេញចិត្តជាមួយនឹងជីវិតនៅជនបទ ហើយពួកគេពុំចង់ត្រឡប់មកកាន់ទីក្រុងវិញទេ៖ *កម្ពុជានិយាយថា សហរដ្ឋអាមេរិក វៀតណាម បានជួយដល់ការប៉ុនប៉ងធ្វើរដ្ឋប្រហារ ៣ ដង* (សារព័ត៌មាន Los Angeles Times) ឯកសារ E3/622 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៨។

[១៥៥៣] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារ E3/2716 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00555743 (កត់សម្គាល់ថា ចំនួនប្រជាជនថ្មីដែលវិលត្រឡប់មកទីក្រុងវិញមានតិចតួចខ្លាំង ហើយពាក់ព័ន្ធតែសង្កាត់ដែលស្ថិតនៅតាមខ្សែក្រវាត់ក្រុងប៉ុណ្ណោះ។ ទីក្រុងនៅតែជាទីក្រុងខ្មោចដដែល។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ កម្ពុជាថ្មី ឯកសារ E3/3006 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៧ ERN (ភាសាខ្មែរ) 00702181 (កត់សម្គាល់ឃើញសញ្ញានាពេលថ្មីៗថា ប្រជាជនកំពុងចូលមកទីក្រុងភ្នំពេញបន្តិចម្តងៗ)។

[១៥៥៤] ប្រតិចារឹក ថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ២២-២៣ (បានប៉ាន់ប្រមាណថា មានប្រជាជនប្រហែល ២០.០០០ នាក់ រស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយពួកគេភាគច្រើនជាអ្នករដ្ឋការ និងទាហាន)។ *អ្នកបើកឧទ្ធម្ភាគចក្រ ខ្មែរក្រហមផ្តាច់ខ្លួន រៀបរាប់ពីជីវិតក្នុងក្រុងភ្នំពេញ* (សារព័ត៌មាន The Times) ឯកសារ E3/4063 ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00752667-00752668 (អនុសេនីយ៍ទោ លីម គួន បានរាយការណ៍ថា នៅត្រឹមខែ ឧសភា ឆ្នាំ ១៩៧៦ មានប្រជាជានប្រហែល ២០.០០០នាក់ ដោយក្នុងចំណោមអ្នកទាំងនោះ មានកងទ័ពខ្មែរក្រហមពី ៨.០០០ នាក់ ទៅ ១២.០០០ នាក់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៥៩ ERN (ភាសាខ្មែរ) 00836236 (ភ្នំពេញនៅស្ងាត់ដូចវាលរហោស្ថានដដែល៖ មានមនុស្សតែ ២០.០០០ នាក់ ប៉ុណ្ណោះ ដែលរស់នៅទីនោះ) ទំព័រ ១៧៩-១៨០ ERN (ភាសាខ្មែរ) 00836256-00836257 (នៅទីក្រុងភ្នំពេញពុំមានប្រជាជនទេ មានតែកងទ័ព អង្គការ ស្ថានទូតបរទេស និងអតីតកម្មករមួយចំនួន។ សព្វថ្ងៃនេះ មានមនុស្សរស់នៅក្នុងទីក្រុងភ្នំពេញតែ ២០.០០០ នាក់ ប៉ុណ្ណោះ។ ពួកអ្នកទាំងអស់នេះបានចូលមក បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ)។

ដល់តម្រូវការប្រតិបត្តិការរបស់របបនោះ[១៥៥៥] ។ តាមពិតដើម្បីចូលមកទីក្រុងភ្នំពេញវិញ ចាំបាច់ត្រូវមានការអនុញ្ញាត[១៥៥៦]។

---

[១៥៥៥] ប្រតិចារឹក ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៨៥-៨៧ (ជាមួយនឹងអង្គភាពសិល្បៈរបស់រដ្ឋាភិបាល បានមកដល់ស្ពាតអូឡាំពិក ប្រហែលជា៤ថ្ងៃ ក្រោយថ្ងៃទី ១៧ ខែ មេសា)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ (ស សៀក) ទំព័រ ៥៦-៥៨, ៥៩ (ទីវ អុល និងហ៊ូ នឹម បានណែនាំ ស សៀក និងផ្នែកសិល្បៈ ឲ្យពន្យារការចូលមកទីក្រុងភ្នំពេញរយៈពេល៣ថ្ងៃ ដើម្បីទុកពេលឲ្យអ្នកដែលត្រូវបានជម្លៀសចាកចេញ)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ១៦-១៧, ១៩-២១, ៦២-៦៣ (ត្រូវបានបញ្ជូនត្រឡប់ទៅទីក្រុងភ្នំពេញវិញ រយៈពេល១សប្តាហ៍ ប្រហែលជា ៤ខែ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មុនពេល គេផ្លាស់ទៅកំពង់សោម)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ទំព័រ ៣៨-៣៩ (ជាកងទ័ពខ្មែរក្រហមម្នាក់ បានសុំការអនុញ្ញាតចូលទីក្រុងភ្នំពេញ ហើយត្រូវបានគេអនុញ្ញាតឲ្យចូលប្រហែលជា ៣ សប្តាហ៍ក្រោយការជម្លៀស) ។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៨-៤០ (បានមកដល់ទីក្រុងភ្នំពេញនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ និងបានពិពណ៌នាអំពី វត្តមានរបស់ប្រជាជនមួយចំនួន ដែលបក្សបានទុកដើម្បីឲ្យបំពេញកិច្ចការមួយចំនួន)។ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ (រស់ ស៊ុយ) ទំព័រ ១៦, ៧២-៧៣ (បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនចេញពីទីក្រុង អង្គភាពរបស់គាត់ត្រូវបានរំសាយ ហើយត្រូវបានគេស្នើឲ្យផ្លាស់ទៅទីក្រុងភ្នំពេញ ដែលនៅទីនោះ មានការបង្កើតអង្គភាពថ្មីមួយ)។ ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ព័ត៌មានអំពីក្រុងភ្នំពេញ និងតំបន់កំពង់ចាម ឯកសារ E3/3003 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៤ ERN (ភាសាខ្មែរ) 00658216 (រាយការណ៍ថា ទីក្រុង និងដែនដីជាច្រើនគីឡូម៉ែត្រជុំវិញក្រុង គ្រប់ទិសទាំងអស់ បានក្លាយជាតំបន់ពិសេស ដែលគេមិនអនុញ្ញាតឲ្យនរណាចេញចូលដោយគ្មានការអនុញ្ញាតឡើយ) កថាខណ្ឌ ៦ ERN (ភាសាខ្មែរ) 00658217 (ដែលកត់សម្គាល់អំពីវត្តមានរបស់កងទ័ពខ្មែរកុម្មុយនីស្តតិចតួចប៉ុណ្ណោះនៅក្នុងទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ខែម ឯកសារ E3/546 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00204037 (ត្រូវបានគេស្នើឲ្យបើកឡានដឹកភ្ញៀវចិន និងកូរ៉េ ចូលមកទីក្រុងភ្នំពេញ ប្រហែលជាមួយខែក្រោយរំដោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ម៉េង ឯកសារ E3/5142 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00204119 (ត្រូវបានគេបញ្ជូនទៅទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៦ ដោយសារគាត់ចេះធ្វើសំណង់)។ របាយការណ៍ដោយលោក ឡេអុង ទ្រីវ៉ៀរ៖ *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ចុះខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៤១-៤២ ERN (ភាសាខ្មែរ) 00538874-00538875 (រាយការណ៍ថា យោងតាមទីភ្នាក់ងារព័ត៌មាននៃប្រទេសកម្ពុជា “AKI” និងទីភ្នាក់ងារព័ត៌មានចិន “Pékin Information” នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ សកម្មភាពសេដ្ឋកិច្ច និងឧស្សាហកម្ម កំពុងចាប់ដំណើរការឡើងវិញនៅក្នុងទីក្រុងភ្នំពេញ ហើយថា នៅកំពង់ផែភ្នំពេញ កងទ័ព និងកម្មករកំពង់ផែរាប់ពាន់នាក់ ធ្វើការទាំងថ្ងៃទាំងយប់ ដឹកទំនិញទៅកាន់តំបន់ផ្សេងៗលើផ្ទៃប្រទេស)។

[១៥៥៦] ទូរលេខស្ថានទូតសហរដ្ឋអាមេរិក កម្មវត្ថុ៖ ព័ត៌មានអំពីក្រុងភ្នំពេញ និងតំបន់កំពង់ចាម ឯកសារ E3/3003 ចុះថ្ងៃទី១០ ខែ តុលា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៤ ERN (ភាសាខ្មែរ) 00658216 (រាយការណ៍ថា ទីក្រុង និងដែនដីជាច្រើន

01006788



៥១៩. អ្នកដែលត្រូវបានផ្លាស់ទីលំនៅភាគច្រើនមិនបានវិលត្រឡប់មកទីក្រុងភ្នំពេញវិញទេ រហូតដល់ក្រោយថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ទើបបានត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ[១៥៥៧]។

## ១០.២.២០ ចំនួនប្រជាជនសរុបដែលត្រូវបានផ្លាស់ទីលំនៅ

៥២០. ពុំមានតួលេខច្បាស់លាស់ អំពីចំនួនប្រជាជនសរុបដែលត្រូវបានផ្លាស់ទីលំនៅចេញពីទីក្រុងភ្នំពេញ ទៅកាន់ទីជនបទ ចាប់ពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលត្រូវបានអះអាងថា បានធ្វើឡើងជាបណ្តោះអាសន្ននោះទេ។ ទោះបីជាមិនអាចកំណត់បានច្បាស់ អំពីចំនួនអ្នកដែលត្រូវបានជម្លៀសដែលត្រូវបានផ្លាស់ទីលំនៅចុងក្រោយក៏ដោយ ក៏ នួន ជា បានផ្តល់សក្ខីកម្មថា មុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គណៈកម្មាធិការភូមិភាគបានពិភាក្សា អំពីវិធីដែលភូមិភាគពាយ័ព្យអាចទទួលអ្នកដែលត្រូវបានជម្លៀសបានចំនួន ១.៤០០.០០០ នាក់ ភូមិភាគនិរតីអាចទទួលយកប្រជាជនថែមទៀត ហើយភូមិភាគផ្សេងៗទៀតអាចទទួលយកអ្នករស់នៅទីក្រុងភ្នំពេញក្នុងចំនួនតិចតួចប៉ុណ្ណោះ[១៥៥៨] ។ លើសពីនេះទៀត យោងតាមក្រសួងការបរទេសសហរដ្ឋអាមេរិក

---

គីឡូម៉ែត្រជុំវិញក្រុង គ្រប់ទិសទាំងអស់ បានក្លាយជាតំបន់ពិសេសដែលគេមិនអនុញ្ញាតឲ្យនរណាចេញចូលដោយគ្មានការអនុញ្ញាតឡើយ)។

[១៥៥៧] ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ២០-២១ (បានឃើញប្រជាជនជាច្រើនដែលត្រូវបានជម្លៀសចេញក្នុងឆ្នាំ ១៩៧៥ បានវិលត្រឡប់មកផ្ទះសម្បែងវិញ នៅមុនពេលខ្មែរក្រហមដួលរលំក្នុងឆ្នាំ ១៩៧៩)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ៥០-៥១ (ចាប់តាំងពីអ្នកស្រីចាកចេញពីផ្ទះក្នុងឆ្នាំ ១៩៧៤ អ្នកស្រីមិនអាចវិលត្រឡប់មកផ្ទះវិញបានឡើយ រហូតដល់ឆ្នាំ ១៩៧៩។ អ្នកស្រីមិនដឹងថា ហេតុអ្វីបានជាគេមិនអនុញ្ញាតឲ្យអ្នកស្រីវិលត្រឡប់មកនោះឡើយ អ្នកស្រី គ្រាន់តែដឹងថា អ្នកស្រីមិនអាចវិលត្រឡប់បាន ហើយគេមិនអនុញ្ញាតឲ្យអ្នកស្រីរអ៊ូរទាំឡើយ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៦៧ (៣ថ្ងៃប្រែក្លាយជា ៣ឆ្នាំ ៨ ខែ និង២០ថ្ងៃ ហើយពួកគាត់មិនអាចតវ៉ា ឬសួរថាហេតុអ្វីបានឡើយ។ ពួកគាត់ បានត្រឹមតែស្តាប់តាមបញ្ជារបស់ពួកគេប៉ុណ្ណោះ ហើយធ្វើដំណើរចេញពីកន្លែងមួយទៅកន្លែងមួយទៀត)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ៤៥-៤៦ (បានវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញក្នុងឆ្នាំ ១៩៨០)។ ប្រតិចារឹក ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៤-៣៥ (គាត់មិនដែលបានឃើញប្រជាជនទីក្រុងភ្នំពេញវិលត្រឡប់មកទីក្រុងវិញឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ារី ជា ឯកសារ E3/5085 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨ ERN (ភាសាខ្មែរ) 00875443 (បានវិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ បន្ទាប់ពីការដួលរលំរបប ប៉ុល ពត)។

[១៥៥៨] អង្គជំនុំជម្រះជ្រើសយកប្រតិចារឹកភាសាខ្មែរ ដែលជាភាសាជនជាប់ចោទបានផ្តល់សក្ខីកម្មៈ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ 30-31 (ភាសាអង់គ្លេស) ទំព័រ ១៨-២០ (ភាសាខ្មែរ)។

ការទំនាក់ទំនងរបស់ខ្មែរក្រហមដែលបានធ្វើឡើងនៅចន្លោះថ្ងៃទី ១៨ និងថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៧៥ បានបង្ហាញថា ភូមិភាគបូព៌ាត្រូវបានរាយការណ៍ថាបានទទួលមនុស្សចំនួនពី ៥០០.០០០ នាក់ ទៅ ៦០០.០០០នាក់[១៥៥៩]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានការប្រយ័ត្នប្រយែង ចំពោះតម្លៃជាភស្តុតាងដែលបានផ្តល់ឲ្យដោយការវិភាគរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដោយផ្អែកលើមូលដ្ឋានដែលថា ចំនួនប្រជាជនទីក្រុងភ្នំពេញនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ មានប្រមាណពី២.០០០.០០០ នាក់ ទៅ ២.៥០០.០០០នាក់ ក៏ដោយ[១៥៦០] ហើយដោយកត់សម្គាល់ទៅលើសក្ខីកម្មផ្ទាល់មាត់ដ៏ច្រើនលើសលុប និងស៊ីសង្វាក់គ្នាដែលពិពណ៌នាថា ទីក្រុងភ្នំពេញស្ងាត់ជ្រងំគ្មានមនុស្សរស់នៅបន្ទាប់ពីការជម្លៀសនោះ[១៥៦១] អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងហោចណាស់មានប្រជាជនចំនួន ២.០០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅចេញពីទីក្រុងទៅកាន់ទីជនបទ ។

### ១០.២.២១ ចំនួនមនុស្សស្លាប់សរុប

៥២១. ដូចគ្នានេះដែរ ពុំមានតួលេខច្បាស់លាស់អំពីចំនួនមនុស្សសរុបដែលបានស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ និងក្នុងពេលធ្វើដំណើរឆ្ពោះទៅទីជនបទនាពេលក្រោយៗមកទៀតនោះឡើយ។ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ប្រជាជនចំនួនពី ២.០០០ នាក់ ទៅ ២០.០០០ នាក់ បានស្លាប់ក្នុងអំឡុងពេលនៃការជម្លៀស និងក្នុងពេលធ្វើដំណើរក្រោយៗមកទៀតដែលការបង្ហាញនេះ ពុំមានលទ្ធភាពក្នុងការកំណត់ចំនួនអ្នកស្លាប់ឲ្យបានច្បាស់លាស់នោះទេ[១៥៦២]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា នៅពេលមានការបណ្តេញចេញនោះ

---

[១៥៥៩] អនុស្សរណៈសេតវិមានវ៉ាស៊ីនតោន ទៅកាន់រដ្ឋមន្ត្រី ឃីស៊ីងជ័រ កម្មវត្ថុ៖ ខ្លឹមសារព័ត៌មានបន្ថែម ឯកសារ E3/3007 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00658229។

[១៥៦០] *សូមមើល* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៧ ។

[១៥៦១] *សូមមើល* ផ្នែកទី១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៨។

[១៥៦២] *អ្វីៗដែលយើងកំពុងធ្វើនៅពេលនេះមិនធ្លាប់អនុវត្តពីមុនឡើយ* (ដកស្រង់ពីបទសម្ភាសន៍របស់ Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00796759-00796760 (ក្នុងកិច្ចសម្ភាសន៍ឆ្នាំ ១៩៧៧ អៀង សារី បានបញ្ជាក់ថា រយៈពេលប៉ុន្មានខែដំបូងបន្ទាប់ពីរំដោះ មានសភាពលំបាកគ្រាន់បើ។ ប្រជាជនប្រមាណពី ២.០០០ ទៅ ៣.០០០ នាក់ បានស្លាប់ក្នុងអំឡុងពេលជម្លៀស)។ សៀវភៅនិពន្ធដោយ Ben KIERNAN៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម* ឆ្នាំ ១៩៧៥-១៩៧៩ ឯកសារ E3/1593 ទំព័រ ៧៦ ERN (ភាសាខ្មែរ) 00637431 (ការសិក្សាផ្អែកតាមបទពិសោធន៍ សន្និដ្ឋានថា ប្រជាជនចំនួន ១០.៦០០ នាក់ ក្នុងចំណោមប្រជាជន ២.០០០.០០០ នាក់ ទំនងជាបានស្លាប់)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Phillip SHORT) ទំព័រ ២៩-៣១ (បានកត់សម្គាល់ថា មានការប៉ាន់ស្មានផ្សេងៗគ្នា៖ Ben

ប្រជាជនទីក្រុងភ្នំពេញ បានជួបប្រទះនូវការហ៊ុមព័ទ្ធរយៈពេលយូរ ដោយមានការខ្វះម្ហូបអាហារ[១៥៦៣] ដូច្នេះហើយ ប្រជាជនមានសភាពទន់ខ្សោយយ៉ាងខ្លាំង ។ នៅក្នុងស្ថានភាពសុខភាពទន់ខ្សោយបែបនេះ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើដំណើរចាកចេញទៅទីជនបទនានា ក្នុងអំឡុងពេលដែលមានអាកាសធាតុក្ដៅបំផុត និងក្នុងពេលដែលស្ទើរតែគ្មានម្ហូបអាហារ ទឹក ការថែទាំផ្នែកវេជ្ជសាស្ត្រ កន្លែងស្នាក់អាស្រ័យ ឬ មធ្យោបាយដឹកជញ្ជូនទាល់តែសោះ[១៥៦៤] ។ ដោយបានពិចារណាទៅលើភ័ស្តុតាងទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលរៀបរាប់ អំពីការស្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលនៃការជម្លៀស ដោយសារតែការសម្លាប់ ភាពអត់ឃ្លាន និងការហេវហត់អស់កម្លាំង[១៥៦៥] អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងហោចណាស់ ប្រជាជនរាប់ពាន់នាក់បានស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ ទៅកាន់ទីជនបទ ។ ក្នុងចំណោមជនរងគ្រោះទាំងនោះមាន ទារក កុមារ អ្នកជំងឺ និងមនុស្សចាស់[១៥៦៦]។

### ១០.២.២២ ផលប៉ះពាល់ទៅលើអ្នកដែលត្រូវបានជម្លៀស

៥២២. ក្រៅពីការរងរបួសផ្នែករាងកាយក្នុងអំឡុងពេលនៃការជម្លៀសរបស់ពួកគេ ប្រជាជនកម្ពុជាជាច្រើន បន្តទទួលរងនូវជំងឺថប់អារម្មណ៍ ដោយសារពួកគេបានឆ្លងកាត់នូវបទពិសោធន៍នៃការបាត់បង់យ៉ាងធ្ងន់ធ្ងរ[១៥៦៧] ។ ចំពោះប្រជាជនដែលបានបាត់បង់អ្នកជាទីស្រឡាញ់ ព្រមទាំងទ្រព្យសម្បត្តិ របស់របរ និងផ្ទះសម្បែងរបស់ពួកគេ ការប៉ះទង្គិចផ្លូវចិត្ត អាចកាន់តែមានភាពធ្ងន់ធ្ងរថែមទៀត ដោយអ្នកទាំងនោះងាយនឹងមានអារម្មណ៍ឯកោ និងធ្លាក់ទឹកចិត្តនៅក្នុងជីវិតរបស់

---

Kiernan ប៉ាន់ស្មាន ១០.០០០នាក់, ការប៉ាន់ស្មានផ្សេងទៀតនោះ គឺ ៣៥.០០០ នាក់ ចំណែកឯ អៀង សារី នៅពេលមួយនោះ បានបញ្ជាក់ថា ពី ២.០០០ ទៅ ៣.០០០ នាក់)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Philip SHORT៖ *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ 275 ERN (ភាសាអង់គ្លេស) 00396483 (ប៉ាន់ប្រមាណថា មនុស្សស្លាប់មានចំនួន ២០.០០០ នាក់ ក្នុងអំឡុងពេលនៃការជម្លៀសទីក្រុងភ្នំពេញ)។

[១៥៦៣] *សូមមើល* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ , កថាខណ្ឌ ១៥៩។ ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី១) កថាខណ្ឌ ៥៣៧។

[១៥៦៤] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩១-៤៩២, ៤៩៥-៤៩៦។

[១៥៦៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៤, ៤៨៦-៤៨៧, ៤៩០-៤៩២, ៤៩៧-៤៩៨, ៥០៣, ៥០៧, ៥១១, ៥១៣, ៥១៥ ។

[១៥៦៦] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៧-៤៩៨។

[១៥៦៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុផារ៉ា) ទំព័រ ៥៥-៥៦។

ពួកគេ[១៥៦៨]។ Denise AFFONÇO បានពិពណ៌នាអំពីជីវិតរបស់លោកស្រីដែល "បានធ្លាក់ចូលទៅក្នុងឋាននរក" ភ្លាមៗ នៅពេលដែលលោកស្រី និងអ្នកផ្សេងទៀតត្រូវបានបណ្តេញចេញពីផ្ទះសម្បែងរបស់ពួកគេ ហើយទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានដកហូត[១៥៦៩] ដោយឡែក នូ ហ៊ាន់ នៅតែមានអារម្មណ៍មួម៉ៅចំពោះការបាត់បង់ទ្រព្យសម្បត្តិរបស់គាត់ រួមទាំងរូបថតក្រុមគ្រួសារ និងសំបុត្រកំណើតកូនៗរបស់គាត់ ហើយចាត់ទុកការបាត់បង់ទាំងនេះថាជាការបាត់បង់ច្រើនដែលមិនអាចពិពណ៌នាបាន[១៥៧០]។

៥២៣. ជនរងគ្រោះដែលត្រូវបានផ្លាស់ទីលំនៅ បានបាត់បង់ផ្ទះសម្បែង បាត់បង់ទំនាក់ទំនងជាមួយសមាជិកគ្រួសារ បរិស្ថានជុំវិញខ្លួនពួកគេ និងទីកន្លែងគោរពបូជា មានអារម្មណ៍បាត់បង់ "សុវត្ថិភាពផ្នែកផ្លូវកាយ និងផ្លូវចិត្ត"[១៥៧១] ។ ជាពិសេស កុមារដែលត្រូវបានផ្លាស់ទីកន្លែង ហើយយកចេញឆ្ងាយពីមជ្ឈដ្ឋានដែលពួកគេធ្លាប់រស់នៅ បានបាត់បង់ឱកាសប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃ ព្រមទាំងលទ្ធភាពក្នុងការរៀបចំផែនការអនាគត ហើយពួកគេក៏ជួបប្រទះនូវការលំបាកក្នុងការបន្សាំខ្លួនទៅនឹងមជ្ឈដ្ឋានរស់នៅថ្មីផងដែរ[១៥៧២]។

៥២៤. ការឃើញដោយផ្ទាល់ភ្នែក ឬ ការស្តាប់ឮព្រឹត្តការណ៍ដែលធ្វើឲ្យប៉ះទង្គិចផ្លូវចិត្ត ក៏ធ្វើឲ្យមានជំងឺផ្លូវចិត្ត និងវិបល្លាសផ្លូវចិត្តផងដែរ[១៥៧៣]។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី មុម សំអឿន ទទួលរងជំងឺធ្លាក់ទឹកចិត្តដែលអ្នកស្រីជឿថា បណ្តាលមកពីការប៉ះទង្គិចផ្លូវចិត្តដោយសារការបាត់បង់កូនៗ និងស្វាមីរបស់អ្នកស្រី ព្រមទាំងឃើញសាកសពជាច្រើនក្នុងអំឡុងពេលផ្លាស់ទីលំនៅដោយបង្ខំចេញពីទីក្រុងភ្នំពេញ[១៥៧៤] ។ អ្នកស្រីនៅតែមានអារម្មណ៍ភ័យខ្លាច និងបាក់ស្បាតដោយសារតែឃើញមានសាកសពនៅរាយពាសពេញផ្លូវ បន្ទាប់ពីអ្នកស្រីដើរតាមផ្លូវចេញពីទីក្រុង

---

[១៥៦៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៦៥។

[១៥៦៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៧៤-៧៦។

[១៥៧០] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ១១-១៣។

[១៥៧១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៣-៧៤។

[១៥៧២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៦២-៦៤។

[១៥៧៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៤-៧៦។

[១៥៧៤] ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៥១ (និងព្រឹត្តិការណ៍ហិង្សាមួយដែលអ្នកស្រីបានឃើញនៅកោះខ្សាច់ទន្លា)។

ភ្នំពេញ[១៩៧៥] ។ Denise AFFONÇO ក៏បានរៀបរាប់ផងដែរថា រយៈពេល ៣០ ឆ្នាំ បន្ទាប់ពីរបប នោះបានកន្លងផុតទៅ អ្នកស្រីនៅតែមានសុបិនអាក្រក់ ភ័យខ្លាចដោយសារតែបទពិសោធន៍របស់ អ្នកស្រី ហើយអ្នកស្រីមិនចង់ឈានជើងចូលមកប្រទេសកម្ពុជាឡើយ[១៩៧៦]។

## ១០.៣ គោលនយោបាយ និងយុត្តិកម្មចំពោះការជម្លៀស

៩២៥. ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានអះអាងថា “ការជម្លៀស ដោយបង្ខំ” ដែលត្រូវបានចោទប្រកាន់នោះ តាមពិតគឺជាគោលនយោបាយធម្មានុរូបក្នុងការតាំង ទីលំនៅថ្មីរបស់ប្រជាជន ដែលធ្វើឡើងដើម្បីស្តារសេដ្ឋកិច្ចកម្ពុជា និងជួយសម្រាលដល់ស្ថានភាព សេដ្ឋកិច្ច និងមនុស្សធម៌ដ៏អាក្រក់ដែលកើតមាននៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងប្រទេសកម្ពុជានៅ ត្រឹមឆ្នាំ១៩៧៥ [១៩៧៧]។ មេធាវីការពារក្តី ខៀវ សំផន ក៏បានអះអាងបន្ថែមទៀតថា ការជម្លៀស ប្រជាជនមានហេតុផលចាំបាច់ខាងយោធា ដោយសារតែមានភាពមិនច្បាស់លាស់នៃសកម្មភាព របស់អាមេរិក និងការបះបោរប្រឆាំងពីសំណាក់ក្រុមទាហាន លន់ នល់[១៩៧៨]។

### ១០.៣.១ ការធ្វើឱ្យមានសន្តិសុខដើម្បីប្រឆាំងនឹងសត្រូវ និងការធ្វើឱ្យសត្រូវចុះខ្សោយ

៩២៦. មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការចាំបាច់ ដើម្បីការពាររបបថ្មីប្រឆាំងនឹងកងទ័ពអាមេរិក និងវៀតណាមដែលនៅពេលនោះ កងទ័ពប្រទេសទាំងពីរនេះត្រូវបានយល់ថា ជាសត្រូវប្រជែងផលប្រយោជន៍[១៩៧៩]។ នៅក្នុងកិច្ច

---

[១៩៧៥] ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៥២។

[១៩៧៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៧៦។

[១៩៧៧] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤៤-២៥៨។ សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤-៣៦, ៤៤-៥៣។

[១៩៧៨] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤-៤៣។

[១៩៧៩] ជាពិសេស បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកសហរដ្ឋអាមេរិកថាជាសត្រូវចក្រពត្តិ ត្រង់ចំណុចដែលពួកគេបានគាំទ្ររបបសាធារណរដ្ឋខ្មែរ លន់ នល់ នឹងបានគាំទ្រវៀតណាមខាងត្បូង នៅក្នុងការវាយប្រយុទ្ធប្រឆាំងនឹងកុម្មុយនីស្តវៀតណាមខាងជើង។ លើសពីនេះទៀត បក្សកុម្មុយនីស្តកម្ពុជា បានចាត់ទុកវៀតណាម ទោះបីជាកុម្មុយនីស្តក៏ដោយ ថាជាគូប្រជែង និងជាការគំរាមកំហែងមួយ ត្រង់ចំណុចដែលពួកគេត្រូវបានចោទប្រកាន់ថាបានស្វះស្វែងពង្រីកផលប្រយោជន៍កុម្មុយនីស្ត ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ,

សម្ភាសន៍ជាសាធារណៈ អៀង សារី បានបញ្ជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹងអំពីផែនការរបស់អាមេរិកក្នុងការធ្វើឱ្យច្របូកច្របល់ និងធ្វើឱ្យរបបថ្មីនេះចុះខ្សោយបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម ហើយប្រជាជនក្នុងទីក្រុងភ្នំពេញ ត្រូវបានជម្លៀសចេញដើម្បីទប់ស្កាត់ផែនការនេះ[១៥៨០]។ ជាពិសេស ជនជាប់ចោទ នួន ជា បានអះអាងថា បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ថ្នាក់ដឹកនាំបក្សកុម្មុនីស្តកម្ពុជាមានការបារម្ភថា អាមេរិកនឹង

---

កថាខណ្ឌ ៨០-៩៥ ។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៣៧-៤០ (គូសបញ្ជាក់ថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានត្រួតត្រាដោយវៀតណាម ដែលបានស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ) ទំព័រ ៤០-៤២ (ប្រសិនបើកម្ពុជាមិនខិតខំការពារខ្លួនឯងទេនោះ វៀតណាមនឹងត្រួតត្រាកម្ពុជាជាក់ជាមិនខាន) ទំព័រ ៤០-៤២ (គោលបំណងរបស់បក្សពលករវៀតណាម គឺធ្វើការត្រួតត្រាទាំងស្រុងទៅលើទឹកដីកម្ពុជា)។ កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយគណៈប្រតិភូអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00775906-00775907 (បញ្ជាក់ថា មានបញ្ហាក្នុងការការពារប្រទេសប្រឆាំងនឹងផែនការរបស់ចក្រពត្តិអាមេរិក និងបរិវារ)។ កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង ស្ទូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00347034-00347035 (ប៉ុល ពត ចង់ឱ្យរួចផុតពី សេ.អ៊ី.អា និង វៀតណាម) ទំព័រ ១៧ ERN (ភាសាខ្មែរ) 00347047 (សហរដ្ឋអាមេរិក និងវៀតណាម គឺជាសត្រូវរបស់របបគាត់)។

[១៥៨០] កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយកាសែត Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00291036 (កត់សម្គាល់ថា ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនចំពោះការជម្លៀស ប្រជាជននោះ គឺ ការរកឃើញឯកសារមួយដែលនិយាយលម្អិត អំពីផែនការនយោបាយយោធាសម្ងាត់មួយរបស់ភ្នាក់ងារសម្ងាត់កណ្តាលសហរដ្ឋអាមេរិក និងរបប លន់ នល់ ដួលរលំ ក្នុងការធ្វើឱ្យមានការភ័ន្តច្រឡំបន្ទាប់ពីជ័យជម្នះរបស់យើង)។ *ប្រទេសកម្ពុជាការពារទឹកដី ការបិទប្រទេសនៅឆ្នាំ ៧៥ ដើម្បីការពារសង្គ្រាមស៊ីវិលក្នុងប្រទេស* (សារព័ត៌មាន New York Times) ឯកសារ E3/616 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ១៩៧៨ (អៀង សារី បានបញ្ជាក់ថា អ្នកបដិវត្តន៍បានចាត់ទុកការជម្លៀសប្រជាជនជាការចាំបាច់ដើម្បីការពារប្រឆាំងនឹងទីក្រុងមួយដែលពោរពេញទៅដោយភ្នាក់ងារ ឃ្លាំងអាវុធ និងឧបាយកលទុច្ចរិតផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់របបថ្មី)។ *ការពិនិត្យពិច័យលើកប៉ាល់ម៉ាយ៉ាហ្គេស* (សារព័ត៌មានហ្វាអ៊ីស្ទើនអេខូណូមិករីវ្យូ) ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ( អៀង សារី បានការពារការជម្លៀសប្រជាជនថា ជាផ្នែកមួយនៃយុទ្ធសាស្ត្រទប់ទល់របស់ខ្មែរក្រហម ដើម្បីបង្អាក់ផែនការ ៣ ចំណុច ដែលបង្កើតឡើងដោយសហរដ្ឋអាមេរិក ដើម្បីធ្វើឱ្យរដ្ឋាភិបាលថ្មីគ្មានស្ថេរភាព)។ *បទសម្ភាសន៍ជាមួយឧបនាយករដ្ឋមន្ត្រីខ្មែរ អៀង សារី៖ ប្រទេសកម្ពុជាមិនអាចបិទនៅឯកោទេ* (និទានុប្បវត្តិ Le Quotidien) ឯកសារ E3/572 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00498217-00498218 (គោលបំណង គឺក្នុងចំណោមប្រការផ្សេងទៀត ដើម្បីធ្វើឱ្យផែនការរបស់សត្រូវបរាជ័យ)។

បន្តយុទ្ធនាការទម្លាក់គ្រាប់បែករបស់ខ្លួន[១៥៨១] និងលទ្ធភាពដែលថា អស្ថេរភាពផ្ទៃក្នុងដែលកើតឡើងនៅពេលក្រោយទៀត នឹងផ្តល់ឱកាសឲ្យប្រទេសវៀតណាមដែលមាននិន្នាការវាតទីនិយម ធ្វើអន្តរាគមន៍ចូលក្នុងកិច្ចការប្រទេសកម្ពុជា[១៥៨២] ។ គណៈកម្មាធិការមជ្ឈិមមានការបារម្ភថា កងទ័ពវៀតណាមបានជ្រៀតចូលក្នុងទីក្រុងភ្នំពេញរួចហើយ ហើយយល់ឃើញថា វានឹងមានមហន្តរាយធ្ងន់ធ្ងរចំពោះការវាយប្រយុទ្ធគ្នានៅក្នុងទីក្រុងភ្នំពេញ ហើយនៅពេលនោះនឹងមានមនុស្សស្លាប់ និងរបួសច្រើន[១៥៨៣]។ ជនជាប់ចោទ ខៀវ សំផន ក៏បានលើកឡើងផងដែរអំពីហានិភ័យចេញពីភ្នាក់ងារ

---

[១៥៨១] *សូមមើលផ្នែក*ទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៣-១៥៦។

[១៥៨២] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ២១ (បន្ទាប់ពីការរំដោះបានទីក្រុងភ្នំពេញ វាមិនច្បាស់ឡើយ ថាតើសហរដ្ឋអាមេរិកនៅបន្តជាប់ពាក់ព័ន្ធ ឬយ៉ាងណា)។ ប្រតិចារឹក ថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ២៧-៣២ (ក្នុងអំឡុងការផ្តល់សក្ខីកម្មរបស់ Sydney SCHANBERG នួន ជា បានលើកនូវចម្ងល់ថាតើអាមេរិកនឹងទម្លាក់គ្រាប់បែកបន្ទាប់ពីកងទ័ពខ្មែរក្រហមកាន់កាប់បានទីក្រុងឬយ៉ាងណា)។*សូមមើលផងដែរ* សេចក្តីថ្លែងការណ៍របស់ នួន ជា ទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00224474, 00224475-00224476 (គាត់បានបញ្ជាក់ថា គេដឹងសុសសាយថា សហរដ្ឋអាមេរិកមានផែនការក្តាប់អំណាចពីយើង ៦ ខែ បន្ទាប់ពីការរំដោះ។ ផែនការនេះ គឺជាសកម្មភាពរួមគ្នារបស់សហរដ្ឋអាមេរិក ក.ហ្សេ.បេ និងវៀតណាម ប៉ុន្តែ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកម្ទេចផែនការនោះ ដោយជម្លៀសប្រជាជនចេញពីទីក្រុង បន្ទាប់ពីរំដោះបាន និងបង្ខំឲ្យភ្នាក់ងារ សេ.អ៊ី.អា, ក.ហ្សេ.បេ និងវៀតណាមចាកចេញទៅកាន់ទីជនបទ ហើយពួកគេមិនអាចអនុវត្តផែនការនេះបានឡើយ)។ *ប្រទេសកម្ពុជានិយាយការពារការបិទប្រទេសនៅក្នុងឆ្នាំ ៧៥ ថាជាការបង្ការសង្គ្រាមស៊ីវិល* (សារព័ត៌មាន New York Times) ឯកសារ E3/624 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៧៨ (បានរាយការណ៍ថា រដ្ឋមន្ត្រីក្រសួងការបរទេស កម្ពុជា លោក អៀង សារី បានបញ្ជាក់ថា ការបិទប្រទេស និងការជម្លៀសទីក្រុងភ្នំពេញ ក្រោយពីជនកុម្មុយនីស្តបានចូលកាន់កាប់នៅក្នុងឆ្នាំ ១៩៧៥ គឺជាការចាំបាច់ ដើម្បីបញ្ចៀសមិនឲ្យមានសង្គ្រាមស៊ីវិល ជាហេតុនាំឲ្យមានការស្លាប់ និងលទ្ធភាពនៃការចូលជ្រៀតជ្រែកពីប្រទេសជិតខាង)។ *សារី៖ ការជម្លៀសប្រជាជនចេញពីទីក្រុង ជាវិធានការបណ្តោះអាសន្ន* (សារព័ត៌មានបាងកកប៉ុស្តិ៍) ឯកសារ E3/3322 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៨ (អៀង សារី បានឆ្លើយការពារការជម្លៀសប្រជាជនថាជាវិធានការមួយដើម្បីបញ្ចៀសមិនឲ្យមានសង្គ្រាមស៊ីវិលកើតឡើងជាថ្មី ដែលអាចនាំឲ្យមានការបង្កើតរដ្ឋាភិបាលអាយ៉ង ឬ ការលូកដៃអន្តរាគមន៍ពីកងទ័ពវៀតណាមឬកងទ័ពថៃ)។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ១៧ ERN (ភាសាខ្មែរ) 00324688 (សេចក្តីបញ្ជាក់របស់ សៅ គឹមហុង កត់សម្គាល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានគោលបំណងការពារ ប្រទេសកម្ពុជាមិនឲ្យក្លាយជាប្រទេសរណបវៀតណាម)។

[១៥៨៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៣-១៥។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ៩-១០ ERN (ភាសាខ្មែរ) 00000900-00000901។

សេ.អ៊ី.អា ដែលជាសម្ព័ន្ធមិត្តជាមួយនឹងទាហាន លន់ នល់ និងពួកកុម្មុយនីស្តវៀតណាម ក្នុងការធ្វើឱ្យខ្មែរក្រហមបរាជ័យ និងហានិភ័យនៃការឈ្លានពានរបស់វៀតណាម[១៥៨៤]។

៥២៧. ការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងប្រទេសកម្ពុជាបានបញ្ចប់នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ ១៩៧៣ ហើយព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកផ្សេងទៀតនៅប៉ុន្មានថ្ងៃមុនខែ មេសា ឆ្នាំ ១៩៧៥ អាចជាប្រតិបត្តិការដែលធ្វើឡើង សំដៅទៅទាហានអាកាសនៃរបបសាធារណរដ្ឋខ្មែរដែលនៅសេសសល[១៥៨៥]។ ដោយមានការបោះឆ្នោតព្រឹទ្ធសភាសហរដ្ឋអាមេរិកនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៣ ដែលសម្រេចបញ្ឈប់ការផ្តល់មូលនិធិទាំងអស់ចំពោះប្រតិបត្តិការទម្លាក់គ្រាប់បែកនៅក្នុងតំបន់[១៥៨៦] និងការវិវត្តផ្សេងៗនៅក្នុងប្រទេសវៀតណាម ដែលកងទ័ពសហរដ្ឋអាមេរិកកំពុងតែដកចេញទាំងស្រុងដោយសារតែកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅខែ មករា ឆ្នាំ ១៩៧៣[១៥៨៧] ស្ថានភាពនយោបាយ និងយោធាដែលកំពុងកើតមានក្នុងអំឡុងពេលនៃការវាយប្រហារដោយការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់របស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជានោះ បានផ្លាស់-

---

សេចក្តីថ្លែងការណ៍របស់ នួន ជា ទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១៨ ERN (ភាសាខ្មែរ) 00224474។ *សូមមើលផងដែរ ក្នុងកិច្ចសម្ភាសន៍អតីតឧបនាយករដ្ឋមន្ត្រីកម្ពុជា លោក អៀង សារី ទទួលស្គាល់ថា...* (សារព័ត៌មាន New York Times) ឯកសារ E3/675 ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៨០ (អៀង សារី បានអះអាងថា ការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង គឺបណ្តាលមកពីការភ័យខ្លាចថា ពួកវៀតណាមជ្រៀតលុកលុយចូលនៅតាមទីក្រុង ហើយធ្វើឃាតមេដឹកនាំរបស់រដ្ឋាភិបាល)។

[១៥៨៤] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៦ ERN (ភាសាខ្មែរ) 00156617។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/16 ERN (ភាសាខ្មែរ) 00380493-00380494។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ឯកសារ E3/413 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00357526 (គាត់បានឮគេនិយាយថា ចារកម្មរបស់អាមេរិកកាំង មានបំណងបង្កប់ចារកម្មរបស់គេរាប់ពាន់នាក់ ហើយប្រសិនបើដោះស្រាយមិនស្រួលទេ ក្នុងមួយសប្តាហ៍ពួកវាអាចវាយបកយកវិញបាន។ ដូច្នេះត្រូវតែជម្លៀសប្រជាជនឱ្យទៅនៅទីជនបទ)។

[១៥៨៥] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៣-១៥៦។

[១៥៨៦] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៥៦-៥៨ ERN (ភាសាខ្មែរ) 00103836-00103837 ("[…] ព្រឹទ្ធសភាអាមេរិក បានបោះឆ្នោតផ្អាកថវិកាសង្គ្រាម ដោយកំណត់ឱ្យឈប់ទម្លាក់គ្រាប់បែកលើកម្ពុជា នៅពាក់កណ្តាលខែ សីហា ឆ្នាំ ១៩៧៣")។

[១៥៨៧] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៣-១៥៦។

ប្តូរ។ បរិបទថ្មីនេះបង្ហាញថា យុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា ទំនងជាមិនបន្តទៀតទេ បន្ទាប់ពីការរំដួលរលំទីក្រុងភ្នំពេញ[១៥៨៨]។

៥២៨. ក្រោយឆ្នាំ ១៩៧៣ មានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែករបស់អាមេរិកតែម្តងគត់ នៅក្នុងខែឧសភា ឆ្នាំ ១៩៧៥ នៅពេលដែលមានការទម្លាក់គ្រាប់បែកទៅលើរោងចក្រស្តុប្រេង និងកំពង់ផែក្រុងព្រះសីហនុ (ពីមុនកំពង់សោម) ដែលជាប្រតិកម្មឆ្លើយតបចំពោះកងទ័ពខ្មែរក្រហមដែលបានចាប់នាវាដឹកទំនិញ *Mayaguez* របស់សហរដ្ឋអាមេរិក បន្ទាប់ពីមានបញ្ជាពីប្រធានាធិបតីសហរដ្ឋអាមេរិក[១៥៨៩]។ ព្រឹត្តិការណ៍នេះមិនអាចត្រូវបានប្រមើលមើលឃើញជាមុនបានឡើយ នៅប៉ុន្មានថ្ងៃមុនថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយមិនមែនជាផ្នែកមួយនៃយុទ្ធនាការទម្លាក់គ្រាប់បែកមុនៗរបស់សហរដ្ឋអាមេរិកនោះទេ ដូច្នេះ ព្រឹត្តិការណ៍នេះ មិនជួយគាំទ្រដល់ទឡ្ហីករណ៍របស់ នួន ជា ដែលថា មានការភ័យខ្លាចអាមេរិកទម្លាក់គ្រាប់បែកទៀតនោះឡើយ ។ លើសពីនេះទៅទៀតដោយពិចារណាទៅលើចំណុចដែលថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងផ្ទាល់បានមកទីក្រុងភ្នំពេញនៅរយៈពេលប៉ុន្មានថ្ងៃ ក្រោយថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥[១៥៩០] ហើយបានបង្កើត

---

[១៥៨៨] *លោក ខៀវ សំផន អំពាវនាវឲ្យប្រជាពលរដ្ឋទីក្រុងភ្នំពេញចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា* (នៅក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700275-00700277 (លើកឡើងថា "ពួកចក្រពត្តិអាមេរិក […] នៅថ្ងៃទី ១២ ខែ មេសា បាននាំយកឧទ្ធម្ភាគចក្រចំនួន ៥០ គ្រឿង […] ដើម្បីជម្លៀសសហសេវិករបស់ពួកគេចាកចេញពីទីក្រុងភ្នំពេញ")។

[១៥៨៩] កំណត់ហេតុនៃកិច្ចប្រជុំនៃក្រុមប្រឹក្សាសន្តិសុខជាតិ នៃសហរដ្ឋអាមេរិក ឯកសារ E3/3446 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00738447 (កត់សម្គាល់ថា នេះគឺជាអំពើប្លន់តាមសមុទ្រ)។ អនុស្សារណៈសេតវិមានវ៉ាស៊ីនតោន ស្តីពីកំណត់ហេតុនៃកិច្ចសន្ទនា ឯកសារ E3/3449 ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00738473 (កត់សម្គាល់អំពីការបញ្ជាឲ្យយន្តហោះវាយប្រហារគោលដៅយោធាមួយចំនួនដែលបានកំណត់ជាមុននៅកំពង់សោម ដែលជាកន្លែងមានកងទ័ពជើងទឹកកម្ពុជា និងព្រលានយន្តហោះនៅរាម)។ ប្រតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ឹម ហោ) ទំព័រ ៥-៨ (បានឃើញការវាយប្រហារពីយន្តហោះអាមេរិកទៅលើឃ្លាំងនៅកំពង់សោម នៅចុងខែ ឧសភា ឆ្នាំ ១៩៧៥ និងបានផ្តល់សក្ខីកម្មថា ពុំមានគ្រោះថ្នាក់ដល់អាយុជីវិតទេ ប៉ុន្តែអ្នកផ្សេងទៀតបានរាយការណ៍ថាមានមនុស្សមួយចំនួនរងរបួស)។ *កម្ពុជាបដិសេធថាមិនបានបញ្ជាឲ្យចាប់កប៉ាល់ទេ* (សារព័ត៌មាន Washington Post) ឯកសារ E3/646 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ១៩៧៥។

[១៥៩០] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ុចាម តុន) ទំព័រ ៥១-៥៣ (នួន ជា និង ខៀវ សំផន បានមកដល់ទីក្រុងភ្នំពេញ នៅពេលក្រោយមកទៀត ដោយ នួន ជា ប្រហែលជាមកដល់នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥។ អៀង សារី បានមកដល់ទីក្រុងភ្នំពេញ ប្រហែលជាមួយសប្តាហ៍ ឬជាងមួយសប្តាហ៍បន្ទាប់ពីការកាន់កាប់បានទីក្រុងភ្នំពេញ។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00156614 (គាត់បានមកដល់ប្រហែលជាពី ៧ ទៅ ១០ថ្ងៃ ក្រោយ) ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00156615-

មូលដ្ឋានរបស់ពួកគេនៅតាមទីកន្លែងសំខាន់ៗ ដោយជាក់ស្តែងពុំមានការរៀបចំប្រុងប្រយ័ត្នជាមុនអ្វីឡើយដើម្បីទប់ទល់នឹងការទម្លាក់គ្រាប់បែកនោះ[១៥៥១] អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជា មានការបារម្ភអំពីការទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗខាងមុខនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ដែលត្រូវបានប្រើជាយុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ មិនអាចជឿបានឡើយ[១៥៥២]។ បើទោះជាអង្គជំនុំជម្រះសាលាដំបូងត្រៀមទទួលស្គាល់ថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យមានជំនឿថា ការទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗខាងមុខនេះ អាចនឹងកើតមានក៏ដោយ ក៏ពុំមានការផ្តល់ការពន្យល់ណាមួយឡើយអំពីចំណុចដែលថា ហេតុអ្វីបានជាបទបញ្ជាឲ្យមានការជម្លៀសភ្លាមៗនោះ មិនត្រូវបានអនុវត្តចំពោះជនបរទេស[១៥៥៣] ដែលមិនត្រូវបានជម្លៀសចេញឡើយ រហូតដល់ពេល ២ ទៅ ៣ សប្តាហ៍ក្រោយពីការជម្លៀសប្រជាជននៅពេលនោះ[១៥៥៤]។

---

00156616 (នួន ជា និង ប៉ុល ពត បាននាំគាត់ពីឧត្តុង្គមកភ្នំពេញ ហើយពួកគេបានស្នាក់នៅអគារស្ថានីយរថភ្លើងរយៈពេលប្រហែល ១ ខែ មុននឹងចេញទៅស្នាក់នៅប្រាសាទប្រាក់ និងបន្ទាប់មកដូរទៅស្នាក់នៅមុខទន្លេបាសាក់)។ *អ្នកឈ្នះ៖ ពេលនេះជាអ្វី?* (សារព័ត៌មាន Newsweek) ឯកសារ E3/3721 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00655257 (រាយការណ៍ អំពីការវិលត្រឡប់មកទីក្រុងភ្នំពេញរបស់ ខៀវ សំផន កាលពីសប្តាហ៍មុន)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ឯកសារ E3/2710 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00491374 (Arnaud រាយការណ៍ថា នរោត្តម សីហនុ បានប្រាប់គាត់ថា អនុប្រធានរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNC) បានទៅដល់ទីក្រុងភ្នំពេញ ឬក៏ទៅដល់ទីកន្លែងដែលនៅជិតៗទីក្រុងភ្នំពេញហើយ)។ *សូមមើលផងដែរ វិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលបានផ្សាយអំពីការរំដោះទីក្រុងភ្នំពេញ ការកាន់កាប់បានស្ថានទូតសហរដ្ឋអាមេរិក* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00166977 (យើងកាន់កាប់បានវិមានចំការមន និងតំបន់នៅជុំវិញ នៅថ្ងៃទី ១៦ ខែ មេសា (ភាសាអង់គ្លេស) 00166988 (នៅថ្ងៃទី ១៧ ខែ មេសា)។

[១៥៥១] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៣ លេខយោងជើងទំព័រ ១៣៦៩។

[១៥៥២] ចំពោះបញ្ហានេះ *សូមមើលផងដែរ* ៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៣២-៣៣ (ខ្មែរក្រហមអាចបានដឹងថា អាមេរិកកាំងចាកចេញទៅបាត់ហើយ ហើយនឹងមិនត្រឡប់មកវិញទេ)។ ប្រតិចារឹក ថ្ងៃទី០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Phillip SHORT) ទំព័រ ១៧-១៩ (ពន្យល់ថា ការភៀសខ្លួនចេញពីការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកនោះ គឺមានចេតនាបំភ័ន្តតែម្តង។ ខ្មែរក្រហមដឹងថា ពុំមានលទ្ធភាពក្នុងការទម្លាក់គ្រាប់បែកទេ)។

[១៥៥៣] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ១៤ ឯកសារ E3/2693 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ កថាខណ្ឌ ១ ERN (ភាសាខ្មែរ) 00490998 (Dyrac បាន

៥២៩. នៅក្នុងសុន្ទរកថាមួយថ្លែងទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាក នៅក្នុងឆ្នាំ ១៩៧៨ ជនជាប់ចោទ នួន ជា បានទទួលស្គាល់ថា ការអះអាងចំពោះផែនការរបស់អាមេរិកនោះ ត្រូវបានរំពឹងថានឹងកើតឡើងនៅក្នុងរយៈពេល ៦ ខែ ក្រោយ បន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញ[១៥៥៥]។ រយៈពេលនេះ ធ្វើឱ្យការលើកឡើងអំពីភាពចាំបាច់ក្នុងការជម្លៀសប្រជាជនចេញជាបន្ទាន់ នៅពេលដែលចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មិនអាចឱ្យជឿបានទេ ហើយក៏មិនស្របទៅនឹងការប្រកាសដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញធ្វើឡើងជាបណ្ដោះអាសន្ន និងកំណត់ត្រឹមតែ៣ថ្ងៃនោះ។

៥៣០. សក្ខីកម្មរបស់សាក្សី ស៊ុំ ជា ដែលជាកងទ័ពខ្មែរក្រហមម្នាក់ ដែលបានចូលរួមនៅក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ បានធ្វើឱ្យការអះអាងបន្ថែមទៀតរបស់មេធាវីការពារក្ដីដែលថា ថ្នាក់ដឹកនាំជឿជាក់ថាមានភាពចាំបាច់ជាបន្ទាន់ក្នុងការជម្លៀសប្រជាជនចេញនោះ កាន់តែមិនអាចគួរឱ្យជឿបានឡើយ។ អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា ប្រជាជនដែលត្រូវបានជម្លៀសត្រូវបានគេប្រាប់ថា ពួកគេត្រូវតែជម្លៀសចេញ ដើម្បីការពារពីការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកជាបន្តទៀត និងដើម្បីការពារសុវត្ថិភាពសាធារណៈ ពីព្រោះថា អង្គការត្រូវ "បោសសំអាត" ឬ "សំអាត"ខ្មាំងដែលនៅសេសសល់ចេញពីទីក្រុង[១៥៥៦]។ សំខាន់ជាងនេះទៀត ស៊ុំ ជា បានផ្ដល់សក្ខីកម្មថា កងពលធំរបស់គាត់បានទទួលបញ្ជាឱ្យកុហកប្រជាជនទីក្រុងភ្នំពេញ

---

រាយការណ៍អំពីការជួបជាមួយនឹងគណៈប្រតិភូអនាមិកចំនួន ៣ រូប មកពីគណៈកម្មាធិការរដ្ឋធានី ដែលបាននិយាយថា ការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង ដែលត្រូវបានចាត់ទុកថាជាការចាំបាច់ត្រូវធ្វើនោះ ពុំអនុវត្តចំពោះស្ថានទូតនានា ហើយជាពិសេស ពុំអនុវត្តទៅលើជនជាតិបារាំងឡើយ។

[១៥៥៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨០ ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងករណីខ្លះ ជនបរទេសដែលរស់នៅក្នុងទីក្រុងភ្នំពេញ ក៏ត្រូវបានជម្លៀសចេញផងដែរ ឧទាហរណ៍ Denise AFFONÇO។

[១៥៥៥] សេចក្ដីថ្លែងការណ៍របស់ នួន ជា ទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ (ភាសាខ្មែរ) 00224474, 00224477 (គាត់បានបញ្ជាក់ថា គេដឹងជាទូទៅថា សហរដ្ឋអាមេរិក ដែលធ្វើសកម្មភាពរួមគ្នាជាមួយនឹង កា.ហ្សេ.បេ និងវៀតណាមមានផែនការក្ដាប់អំណាចពីយើង ៦ ខែ បន្ទាប់ពីការរំដោះ។ ប៉ុន្តែថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានកម្ទេចផែនការរបស់ពួកគេ ដោយជម្លៀសប្រជាជនចេញពីទីក្រុងបន្ទាប់ពីរំដោះ និងបានបង្ខំឱ្យភ្នាក់ងារ សេ.អ៊ី.អា និងភ្នាក់ងារ កា.ហ្សេ.បេ ចាកចេញទៅកាន់ទីជនបទ ដូច្នេះហើយពួកវាមិនអាចអនុវត្តផែនការនោះបានឡើយ)។

[១៥៥៦] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៨-៤៦៩ ។

ដោយប្រាប់ប្រជាជនទាំងនោះថា ត្រូវតែជម្លៀសចេញជាចាំបាច់ ព្រោះនឹងមានការប្រយុទ្ធគ្នាកើតឡើង មានការទម្លាក់គ្រាប់បែក ហើយពួកគេទាំងអស់គ្នាអាចនឹងស្លាប់[១៥៩៧]។ នេះគឺជាការបញ្ជាក់យ៉ាងច្បាស់ថា ខ្មែរក្រហមបានប្រើប្រាស់គំនិតនៃការទម្លាក់គ្រាប់បែករបស់អាមេរិក មកធ្វើជាលេសដើម្បីអនុវត្តផែនការរបស់ខ្លួន។ មេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា ក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ពុំមានការទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញឡើយ[១៥៩៨]។

៥៣១. ដោយមានការឃាមកាមនៅក្នុងកិច្ចប្រជុំខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ រ៉ចាម គុន ហៅ ភី ភួន ដែលមានវត្តមាននៅក្នុងពេលនោះផងដែរបានបញ្ជាក់ថា អ្នកចូលរួមក្នុងកិច្ចប្រជុំនោះយល់ឃើញថា មានការលំបាកក្នុងការគ្រប់គ្រងប្រជាជននៅក្នុងទីក្រុងភ្នំពេញ ប្រសិនបើមិនជម្លៀសពួកគេចេញពីទីក្រុងទេនោះ ពីព្រោះថា តាមបទពិសោធន៍ពីមុនរបស់បក្សកុម្មុយនីស្តកម្ពុជាបានបង្ហាញថា ទីប្រជុំជនទាំងឡាយដែលត្រូវរំដោះបាន ត្រូវបានជម្លៀសប្រជាជនចេញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មាភិបាលក្នុងការគ្រប់គ្រងប្រជាជន[១៥៩៩]។ ដូចដែលបានទទួលស្គាល់នៅពេលក្រោយ

---

[១៥៩៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២០-២១, ៣៨-៣៩ (កងទ័ពខ្មែរក្រហមម្នាក់ បានចូលរួមក្នុងការជម្លៀសប្រជាជន។ ស៊ុំ ជា បានផ្តល់សក្ខីកម្មថា កងពលធំរបស់គាត់បានទទួលបទបញ្ជាឲ្យបញ្ចេញប្រជាជនទីក្រុងភ្នំពេញ ដោយប្រាប់ពួកគេថា ពួកគេចាំបាច់ត្រូវជម្លៀសចេញ ពីព្រោះការប្រយុទ្ធគ្នានឹងផ្ទុះឡើង ហើយប្រយ័ត្នគេទម្លាក់គ្រាប់បែកស្លាប់ទាំងអស់គ្នា)។ សូមមើលផង*ដែរ* ប្រតិចារឹក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ៤០-៤១,៤៣ (កងទ័ពខ្មែរក្រហមម្នាក់ បានដឹងថា ហេតុផលមួយដែលមេបញ្ជាការបញ្ជាឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងនោះ គឺដោយសារតែពួកគេខ្លាចមានការទម្លាក់គ្រាប់បែក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីឡាយ អ៊ាន ឯកសារE3/470 ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ ទំព័រ២ ERN (ភាសាខ្មែរ)00170622 (កងទ័ពខ្មែរក្រហមម្នាក់ បានបញ្ជាក់ថា ប្រធានឈ្មោះ ឈាង បានបញ្ជាពួកកងទ័ពក្នុងកងពលរបស់ខ្ញុំ ឲ្យប្រាប់ប្រជាជនចាកចេញពីទីក្រុងព្រោះខ្លាចពួកអាមេរិកកាំងទម្លាក់គ្រាប់បែក)។

[១៥៩៨] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៥៧-៥៩, ៦០-៦២ (ទឡ្ហីករណ៍ដោយផ្ទាល់មាត់របស់មេធាវី)។

[១៥៩៩] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម គុន) ទំព័រ ៥៣-៥៥ (នៅពេលពួកកងទ័ពខ្មែរក្រហម វាយរំដោះបាន ភូមិភាគណាមួយហើយ ពួកគេជម្លៀសប្រជាជនចេញ និងផ្លាស់ទីលំនៅប្រជាជនទាំងនោះ។ វាងាយស្រួលគ្រប់គ្រង ពីព្រោះខ្មាំងបង្កប់ក៏មិនមានអីនឹងពិបាករកទេ)។ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ (រ៉ចាម គុន) ទំព័រ ១១-១២ (គាត់អាចស្តាប់ឮការប្រជុំនោះ ពីព្រោះកាលនោះគាត់គឺជាអ្នកយាមក្នុងអំឡុងពេលប្រជុំនោះ ទំព័រ ១២-១៣។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៤០-៤១។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (អ្នកជំនាញ David CHANDLER) ទំព័រ ៦៩-៧០ (តាមទស្សនៈ

មកទៀត តាមរយៈការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ ពួកខ្មែរក្រហមបានកម្ទេច "ឧបាយកលដ៏ខ្មៅ និង...ផែនការឧក្រិដ្ឋ" របស់អាមេរិក។ បន្ទាប់ពីកាន់កាប់អំណាចនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានលើកសរសើរថា "គ្មានទុកឲ្យសេសសល់នាំអំពល់វរល់យើងទេ" ហើយ "ពួកចក្រពត្តិក៏គ្មានកម្លាំងមកវាយប្រហារយើងពីខាងក្នុងបានទេ"[១៦០០]។

៥៣២. តាមពិត ក្នុងរយៈពេល៣ខែបន្ទាប់ពីប្រតិបត្តិការជម្លៀសមក ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពន្យល់ថា ប្រសិនបើមិនជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេនោះ

> ប្រហែលជាខ្មាំងនឹងវាយសង្គ្រប់យើងពីក្រោយទៅវិញ កម្ទេចកម្លាំងបដិវត្តយើងខ្ទេចខ្ទីអស់ ឬយ៉ាងហោចណាស់ ក៏ខ្មាំងស៊ីរូងផ្ទៃក្នុងខាងគោលជំហរបដិវត្តយើង ធ្វើឲ្យផ្ទៃក្នុងជួរបដិវត្តច្របូកច្របល់ ឥតអង្គការវិន័យ បែកបាក់សាមគ្គី សាបរលាបខាងគោលជំហរបដិវត្ត[១៦០១]។

៥៣៣. លើសពីនេះទៀត នៅក្នុងឆ្នាំ ១៩៧៧ ប៉ុល ពត បានអះអាងថា "យើងបានសម្រេចចិត្តជម្លៀសប្រជាជនចេញពីទីក្រុងចាប់តាំងពី ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ពីព្រោះបើមិនធ្វើបែបនេះទេ យើងមិនអាចកម្ទេចពួកគិញ ពួកបង្កវិទ្ធេទកម្ម និងពួកសាបព្រោះចលាចលដទៃទៀតបានឡើយ"[១៦០២]។

---

ប្រវត្តិសាស្ត្រ គោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុងដែលត្រូវបានកាន់កាប់ មានយុត្តិសាស្ត្រមួយចំនួននៅអាស៊ី និងធានាថា អំណាចដែលចូលកាន់កាប់នោះនឹងមិនប្រឈមជាមួយនឹងការប្រឆាំងជំទាស់ដែលអាចបង្កើតបានជាចលនាប្រឆាំងមួយឡើង)។ សៀវភៅនិពន្ធដោយ Philip SHORT៖ *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ 287 ERN (ភាសាអង់គ្លេស) 00396495 (ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនក្នុងការជម្លៀសប្រជាជននោះ គឺដើម្បីលុបបំបាត់មូលដ្ឋានគាំទ្រសម្តេចសីហនុ) (សម្រាប់ភាសាខ្មែរ សូមមើល ឯកសារ E3/2124 (ភាសាខ្មែរ។

[១៦០០] *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/749 ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៤ ERN (ភាសាខ្មែរ) 00399104 (ពាក់ព័ន្ធនឹងភាពចាំបាច់ក្នុងការកម្ទេច "ឧបាយកលដ៏ខ្មៅ និង ... ផែនការឧក្រិដ្ឋ" របស់អាមេរិក)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/759 ចុះខែមេសា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00062747-00062748 (រម្លឹកអំពីវិធីដែលពួកចក្រពត្តិត្រូវបានបណ្តេញចេញ ក្រោយថ្ងៃរំដោះទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដូច្នេះ "គ្មានទុកឲ្យសេសសល់ អំពល់វរល់យើងទេ" ហើយ "ពួកចក្រពត្តិ ក៏គ្មានកម្លាំងមកវាយប្រហារយើងពីខាងក្នុងបានទេ"។

[១៦០១] *យុវជន និងយុវនារីបដិវត្ត ឯកសារ* [E169/4/1.1.1] ខែកក្កដា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00809799។

[១៦០២] ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00752090 (ដែលបញ្ជូនបន្តថា ប៉ុល ពត បានពិពណ៌នាថា ពួកគេបានសម្រេចចិត្តជម្លៀសប្រជាជនចេញពីទីក្រុង ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ១៩៧៥ ពីព្រោះបើមិនធ្វើបែបនេះទេ យើង មិនអាចកម្ទេច

៩៣៤. ដោយពិចារណាទៅលើការមកដល់ទីក្រុងភ្នំពេញភ្លាមៗរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបន្ទាប់ពីការជម្លៀស សុន្ទរកថារបស់ នួន ជា ថ្លែងទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាកក្នុងឆ្នាំ ១៩៧៨ និងសក្ខីកម្មរបស់ ស៊ុំ ជា រួចមក អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ថ្នាក់ដឹកនាំមិនជឿថា មានការគំរាមកំហែងណាមួយដែលបានលើកឡើង កើតមាននៅពេលនោះឡើយ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សេចក្តីសម្រេចដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនត្រូវបានជម្រុញដោយការប៉ងប្រាថ្នាថា ចង់ការពារប្រជាជនពីការទម្លាក់គ្រាប់បែករបស់អាមេរិកនោះទេ។ ប៉ុន្តែ ការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថា ដោយផ្អែកទៅលើបទពិសោធន៍ និងការអនុវត្តពីមុនរបស់បក្សក្នុងការជម្លៀសប្រជាជនចេញពីតំបន់ដទៃទៀត[១៦០៣] និងសម្រាប់ហេតុផលយោធា សេដ្ឋកិច្ច និងមនោគមវិជ្ជានោះ ថ្នាក់ដឹកនាំបានសម្រេចចិត្តជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដើម្បីឲ្យថ្នាក់ដឹកនាំអាចគ្រប់គ្រងប្រជាជនបានល្អ និងការពារកុំឲ្យខ្មាំងបង្កអស្ថេរភាពដល់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា។

### ១០.៣.២ ការខ្វះស្បៀងអាហារ និងលក្ខខណ្ឌនៅក្នុងទីក្រុងភ្នំពេញ នាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥

៩៣៥. ក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងថានៅពេលចូលមកដល់ទីក្រុងភ្នំពេញខ្មែរក្រហមយល់ឃើញថា ស្បៀងដែលមាន ជិតអស់ទៅហើយ ដោយមានអង្ករនៅសេសសល់សម្រាប់តែរយៈពេល ៦ ថ្ងៃ ប៉ុណ្ណោះនៅក្នុងរដ្ឋធានី[១៦០៤]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តី នួន ជា បាន

---

ពួកគិញ ពួកបង្កវិច្ឆេទកម្ម និងពួកសាបព្រោះចលាចលដទៃទៀតបានឡើយ។ ដូច្នេះ យើងបានធ្វើឲ្យពួកវាបែកខ្ញែកគ្នានៅក្នុងសហករណ៍ ក្រោមការត្រួតពិនិត្យរបស់យើង)។ សូមមើលផងដែរ *សន្និសីទកាសែតរបស់ ប៉ុលពត នៅទីក្រុងប៉េកាំង* (កម្រងឯកសារ SWB) ឯកសារ E3/2072 ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00296205 (នៅក្នុងការការពារផ្តែផ្តាបដិវត្តន៍ កត្តាមួយក្នុងចំណោមកត្តាសំខាន់ជាច្រើនទៀតនោះ គឺការជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅនៅទីជនបទ។ សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងនៅមុនពេលទទួលបានជ័យជម្នះ នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ពីព្រោះយើងបានដឹងថា មុនពេលកម្ទេចអង្គការចារកិច្ចរបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ កម្លាំងរបស់យើងមិនទាន់ខ្លាំងគ្រប់គ្រាន់អាចការពាររបងបដិវត្តន៍បានទេ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៥-៤៦។ *សូមមើលផងដែរ*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១១៨។

[១៦០៣] *សូមមើល* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១០៤-១១២។ ផ្នែកទី៤, ទិដ្ឋភាពទូទៅ, ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩, កថាខណ្ឌ ១៧០។ ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤១-៥៤២។

[១៦០៤] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១

អះអាងថា វិបត្តិស្បៀងអាហារបានធ្វើឲ្យមានតម្រូវការជាបន្ទាន់មួយដើម្បីធ្វើការជម្លៀស បើទោះជាក្រុមមេធាវីការពារក្តីបានទទួលស្គាល់ថា ប្រជាជននៅទីក្រុងនឹងត្រូវជម្លៀស និងបញ្ជូនទៅកាន់សហករណ៍នានា បើទោះជាគ្មានវិបត្តិស្បៀងអាហារនោះក្តី[១៦០៥]។

៥៣៦. អៀង សារី ក៏បានយោងទៅលើការខ្វះស្បៀងអាហារ ការលំបាកក្នុងការផ្គត់ផ្គង់ស្រូវអង្ករដល់ប្រជាជននៅក្នុងទីក្រុង និងតម្រូវការបង្កើនការបង្កបង្កើនផល ចំណែកជនជាប់ចោទ ខៀវ សំផន វិញបានលើកឡើងថា ពេលនោះមិនមានជម្រើសអ្វីក្រៅពីគោលនយោបាយជម្លៀសប្រជាជនទៅកាន់សហករណ៍នោះទេ ដោយសារតែមានប្រជាជនដល់ទៅ ៣.០០០.០០០ នាក់ ឯណោះនៅក្នុងទីក្រុងភ្នំពេញដែលមិនមានស្បៀងអាហារ[១៦០៦]។

---

ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤១, ២៥១។

[១៦០៥] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤១, ២៥១។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា) ទំព័រ ៥៩-៦០។

[១៦០៦] ទូរលេខរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកទៅកាន់ប្រទេសកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00583719-00583721។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយកាសែត Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00291035-00291036 (ប្រកាសថា កង្វះខាតស្បៀងអាហារ គឺជាមូលហេតុមួយដែលនាំឲ្យឈានដល់ការជម្លៀសប្រជាជន ដោយសារពួកគេបានគិតថា មានប្រជាជនចំនួន ២.០០០.០០០ នាក់នៅទីក្រុងភ្នំពេញ ប៉ុន្តែ នៅពេលពួកគេចូលមកដល់ ពួកគេបានដឹងថាមានប្រជាជនដល់ទៅ ៣.០០០.០០០ នាក់ឯណោះ។ កាលពីមុន សហរដ្ឋអាមេរិកបានដឹកជញ្ជូនស្បៀងចំនួនពី ៣០.០០០ ទៅ ៤០.០០០ តោនក្នុងមួយខែចូលមកភ្នំពេញ ដូច្នេះ ពេលនេះប្រជាជនត្រូវធ្វើដំណើរទៅកាន់ទីកន្លែងដែលមានស្បៀង ព្រោះថ្នាក់ដឹកនាំពុំមានមធ្យោបាយគ្រប់គ្រាន់ដើម្បីជញ្ជូនស្បៀងចូលមកក្នុងទីក្រុងទេ និងបានលើកឡើងផងដែរថា ថ្នាក់ដឹកនាំត្រូវតែផ្គត់ផ្គង់ស្បៀងអាហារ ក្នុងខណៈពេលកំពុងតែរក្សាឯករាជ្យ និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ដោយមិនពឹងពាក់ប្រទេសដទៃឡើយ)។ ទំព័រ ១ ERN (ភាសាខ្មែរ) 00498217 (បន្ទាប់ពីយល់ឃើញថា ពួកគេត្រូវចិញ្ចឹមប្រជាជនប្រហែលបីលាននាក់ អៀង សារី បាននិយាយថា "យើងគ្រាន់តែជូនដំណឹងដល់អ្នកដែលនៅទីក្រុងភ្នំពេញថា ប្រសិនបើពួកគេចង់រស់នៅ និងមានអាហារបរិភោគគ្រប់គ្រាន់ ទោះជាមិនសូវសម្បូរហូរហៀរក្តី ពួកគេអាចចេញទៅទីជនបទបាន"។ *ប្រទេសកម្ពុជាការពារទឹកដី ការបិទប្រទេសនៅឆ្នាំ៧៥ ដើម្បីការពារសង្គ្រាមស៊ីវិលក្នុងប្រទេស* (សារព័ត៌មាន NY Times) ឯកសារ E3/616 ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៨ ERN (ភាសាខ្មែរ)00738366-00738367(ការលំបាកនៃការផ្គត់ផ្គង់ស្រូវអង្ករទៅឲ្យប្រជាជននៅទីក្រុង)។ កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយ ហេង រស្មី ឯកសារ E3/586 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00424197 (លើកឡើងអំពីគ្រោះអត់ឃ្លាននៅក្នុងប្រទេសកម្ពុជា និង

៥៣៧. អង្គជំនុំជម្រះកត់សម្គាល់ថា មានការហូរចូលជនភៀសខ្លួនពីជនបទមកក្នុងទីក្រុងភ្នំពេញនៅចន្លោះពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ហើយប្រជាជនភាគច្រើនបានជួបប្រទះការខ្វះខាតស្បៀងអាហារយ៉ាងខ្លាំង និងថាលក្ខខណ្ឌរស់នៅជាទូទៅក្នុងទីក្រុងភ្នំពេញនៅក្នុងអំឡុងពេលនោះ មានលក្ខណៈលំបាកយ៉ាងខ្លាំង[១៦០៧]។ លើសពីនេះទៀត ក្រោយពេលដែលខ្មែរក្រហមកាន់កាប់ទន្លេមេគង្គក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៥ មក និងបានធ្វើឲ្យរាំងស្ទះដល់ការផ្គត់ផ្គង់ស្បៀងអាហារមកក្នុងទីក្រុង[១៦០៨]

---

លើកឡើងថា កុមារចំនួន ១៥.០០០ នាក់បានស្លាប់រួចទៅហើយនៅខែ មករា ឆ្នាំ ១៩៧៥)។ *សូមមើលផងដែរ* កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៤-៧ ERN (ភាសាខ្មែរ) 00347034-00347037 (ដោយសារការទម្លាក់គ្រាប់បែក ប្រជាជនបានផ្លាស់ប្តូរទីកន្លែងទៅទីក្រុងភ្នំពេញ។ នៅឆ្នាំ ១៩៧៥ មានប្រជាជនរហូតដល់ ៣.០០០.០០០ នាក់រស់នៅក្នុងទីក្រុង ហើយពួកគេជួបប្រទះគ្រោះអត់ឃ្លាន។ ប៉ុល ពត បានសម្រេចជម្លៀសប្រជាជនឲ្យទៅនៅជនបទ និងរស់នៅក្នុងសហករណ៍ដូច្នេះ ពួកគេអាចចែករំលែកចំណីអាហារគ្នាបាន)។ កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយគណៈប្រតិភូអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00775906-00775907 (ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានគិតថា មិនអាចចិញ្ចឹមអ្នកទីក្រុងរាប់លាននាក់បានទេ ដោយសារវាហួសលទ្ធភាពរបស់ពួកគេ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៧ (ដកស្រង់សម្តីរបស់ S. Schanberg៖ *កំណត់ត្រាប្រចាំថ្ងៃស្តីពីប្រទេសកម្ពុជាឆ្នាំ ១៩៧៥* ឯកសារ E236/1/4/3.1 ទំព័រ ១២៦-១២៧ ERN (ភាសាខ្មែរ) 00963964-00963965 លើកឡើងថា ប្រជាជនបានសន្និតថា ការជម្លៀសគឺជាមធ្យោបាយមួយដើម្បីជៀសវាងកាតព្វកិច្ចដែលមិនអាចធ្វើទៅបានក្នុងការចិញ្ចឹមជនភៀសខ្លួនដែលហូរចូលមកក្នុងទីក្នុងជាង ២.០០០.០០០ នាក់ ក្នុងពេលកំពុងមានការខ្វះខាតស្រូវអង្ករយ៉ាងខាំងបំផុតនោះ)។

[១៦០៧] *សូមមើល* ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៧។

[១៦០៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ១៣-១៥។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៤៣-៤៥។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៨-៩ ។ *សូមមើលផងដែរ សារចុះថ្ងៃទី ១៤ ខែ មករា របស់លោក ខៀវ សំផន ផ្ញើជូនយុទ្ធជននៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00701478-00701481 (ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍មួយច្បាប់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៧៥ ដោយប្រកាសថា “ផ្លូវទឹកដ៏ចម្បងសម្រាប់ដឹកជញ្ជូនស្រូវ និងអាហារផ្សេងទៀត ប្រេងឥន្ធនៈ និងគ្រាប់រំសេវពីប្រទេសវៀតណាម ដើម្បីផ្គត់ផ្គង់ក្រុមពួកក្បត់ លន់ នល់ និងបក្ខពួក ត្រូវបានកាត់ផ្តាច់ទាំងស្រុង”)។ *ខៀវ សំផន អំពាវនាវដល់ជនរួមជាតិ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/30 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00783131-00783134 (ផ្លូវដឹកជញ្ជូនតាមទន្លេមេគង្គ ដែលជាផ្លូវដឹកជញ្ជូនដ៏សំខាន់តែមួយគត់របស់ខ្មាំងសម្រាប់ដឹកជញ្ជូនជំនួយផ្គត់ផ្គង់ទៅកាន់ទីក្រុងភ្នំពេញ បច្ចុប្បន្នត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ដូច្នេះ នៅទីក្រុងភ្នំពេញនិងទីរួមខេត្តមួយចំនួនដែលស្ថិត

ដែលធ្វើឱ្យស្ថានភាពស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញ កាន់តែមានភាពលំបាកខ្លាំងជាងមុនទៅទៀត[១៦០៩]។

៩៣៨. ទោះបីជាមានការលំបាកក្នុងការប៉ាន់ប្រមាណថា តើស្បៀងអាហារដែលមានស្រាប់នៅក្នុងទីក្រុងភ្នំពេញ អាចនឹងជួយទ្រទ្រង់ដល់ប្រជាជនបានរយៈពេលប៉ុន្មាននៅក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក៏ដោយ[១៦១០] ក៏វាច្បាស់ណាស់ថា កងកម្លាំងរបស់ខ្មែរក្រហម នៅពេលនោះបានគ្រប់គ្រងផ្លូវដឹកជញ្ជូនទាំងអស់ រួមទាំងទន្លេមេគង្គ និងកំពង់ផែកំពង់សោមដែលអាចត្រូវបាន

---

ក្រោមការគ្រប់គ្រងរបស់ខ្មាំង កង្វះខាតអង្ករដែលមានចំនួនតិចតួចបំផុតរួចមកហើយនោះ នឹងកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀតនៅពេលអនាគត)។ *សេចក្តីអត្ថាធិប្បាយសាទរជ័យជម្នះរបស់កងទ័ពប្រជាជនរួបរួមជាតិកម្ពុជានៅជុំវិញក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/488 ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00973756 (ចាប់តាំងពីដើមខែ កុម្ភៈ មក គ្មានក្បួននាវាខ្មាំងណាមួយអាចបើកឆ្លងកាត់ទន្លេមេគង្គបានឡើយ។ ដូច្នេះ ទន្លេមេគង្គដែលត្រូវបានបិទការធ្វើចរាចរណ៍នៅក្នុងខែ មករា និងដើមខែ កុម្ភៈ នឹងត្រូវកាត់ផ្តាច់ជារៀងរហូត។ ដូច្នេះ ស្ថានភាពយ៉ាប់យ៉ឺនទាំងឡាយនៅក្នុងទីក្រុងភ្នំពេញ នឹងកាន់តែកើនឡើងជាងនេះទៅទៀត។ ស្រូវ ប្រេងឥន្ធនៈ ទឹកហូប និងអគ្គិសនីកំពុងតែខ្វះខាត ហើយនៅថ្ងៃខាងមុខ គ្រឿងចាំបាច់ទាំងនេះនឹងអស់ជាមិនខាន។ គេមិនអាចរស់នៅក្នុងទីក្រុងភ្នំពេញបានឡើយ)។ *លោក ខៀវ សំផន អបអរសាទរកងទ័ពរំដោះជាតិប្រជាជនកម្ពុជានៅថ្ងៃជ័យជម្នះនៅអ្នកលឿង* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00700269-00700274 (ប្រកាសថា ចាប់តាំងពីថ្ងៃទី ០១ ខែ មករា នៅសមរភូមិមុខទន្លេមេគង្គក្រោម និងផ្លូវជាតិលេខ ១ កងទ័ពរំដោះជាតិប្រជាជនកម្ពុជា បានចាប់ផ្តើមវាយប្រហារយ៉ាងខ្លាំងបំផុតប្រឆាំងនឹងខ្មាំង ដោយរំដោះបានផ្នែកខ្លះនៃទន្លេមេគង្គ និងបានកម្ទេចក្បួននាវាទាំងអស់របស់ខ្មាំង។ ចាប់ពីពេលនេះទៅ កងទ័ពរំដោះជាតិប្រជាជនកម្ពុជារបស់យើង គឺជាម្ចាស់ទាំងស្រុងលើប្រវែងផ្លូវ ១០០ គីឡូម៉ែត្រ លាតសន្ធឹងតាមបណ្តោយទន្លេមេគង្គចន្លោះពីភ្នំពេញ និងតាំងចូវ ដែលនេះគឺជាជោគជ័យមួយ ក្នុងចំណោមជ័យជម្នះដ៏អស្ចារ្យបំផុតរបស់យើង)។

[១៦០៩] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៩។

[១៦១០] ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៦ (យោងតាមបទពិសោធន៍របស់គាត់ជាមួយនឹង Caritas ក្នុងការផ្គត់ផ្គង់ស្បៀងអាហារដល់ជនភៀសខ្លួនរាប់រយពាក់នាក់នោះ លោក PONCHAUD យល់ថា គេអាចចិញ្ចឹមប្រជាជននៅក្នុងទីក្រុងភ្នំពេញបានរយៈពេល២ខែទៀត។ យើងបានរក្សាទុកអង្ករខ្លះ ព្រោះយើងបារម្ភថា ខ្មែរក្រហមអាចនឹងកាត់ផ្តាច់ទន្លេមេគង្គ ហេតុដូច្នេះ យើងមិនអាចមានអង្ករបន្ថែមទៀតទេ)។ របាយការណ៍ USAID៖ *របាយការណ៍បញ្ចប់ជំនួយនៅកម្ពុជា ភាគទី១* ឯកសារ E3/4178 ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00759725 (នៅត្រឹមពាក់កណ្តាលខែមេសា រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មានអង្ករស្តុកទុកសម្រាប់ប្រជាជនត្រឹមតែប្រមាណពី ២.០០០.០០០ ទៅ ៣.០០០.០០០ នាក់ប៉ុណ្ណោះ ដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងនៅតំបន់ដែលពួកឧទ្ទាមឡោមព័ទ្ធ ឬ សម្រាប់ប្រជាជនដែលចូលបម្រើក្នុងជួរកងទ័ពជាតិកម្ពុជា (ហៅថា “ប្រជាជនដែលខ្វះខាតអង្ករ” ហើយអង្ករស្តុកទុកនោះមានចំនួនប្រហែលជា ៦៥.០០០ តោន)។

ប្រើប្រាស់ដើម្បីអនុញ្ញាតឲ្យមានការដឹកជញ្ជូនស្បៀងអាហារចូល[១៦១១]។ ជាងនេះទៅទៀត ទោះបីជារងការខូចខាតក្តី ក៏ព្រលានយន្តហោះពោធិ៍ចិនតុងនៅតែមានដំណើរការ ដូចដែលបានបញ្ជាក់ដោយអង្គហេតុថា ព្រលានយន្តហោះនេះបានទទួលយន្តហោះមួយចំនួនមកពីប្រទេសចិននៅក្នុងខែឧសភា ឆ្នាំ១៩៧៥[១៦១២] ។ ទោះជាយ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំខ្មែរក្រហមបានបដិសេធមិនទទួលជំនួយមនុស្សធម៌ពីបណ្តាប្រទេសទាំងឡាយដែលពួកគេចាត់ទុកថាជាសត្រូវនោះទេ ដោយអនុវត្តគោលជំហរ "ឯករាជ្យម្ចាស់ការ" ដែលសម្រេចដោយបក្ស[១៦១៣] ។ ក្រោយពីការជួលរលំទីក្រុងភ្នំពេញមក

---

[១៦១១] លោក Sydney SCHANBERG និងអ្នកជំនាញ Philip SHORT លើកឡើងថា ប្រសិនបើខ្មែរក្រហមមានចេតនាចង់ចិញ្ចឹមប្រជាជននៅក្នុងទីក្រុងភ្នំពេញមែន អាចជាការគ្រប់គ្រាន់ហើយសម្រាប់ឲ្យខ្មែរក្រហមបើកទន្លេមេគង្គដែលជាប្រភពផ្គត់ផ្គង់ចម្បងរបស់ពួកគេ ឬ ស្នើសុំឲ្យបញ្ជូនអង្ករចូលៈ ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៧-៩។ ។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (អ្នកជំនាញ Philip SHORT) ទំព័រ ២៣-២៤។

[១៦១២] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុៈ យន្តហោះចិននៅកម្ពុជា ឯកសារ E3/4139 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00634304 (រាយការណ៍អំពីការចុះចតរបស់យន្តហោះប៊ូអ៊ីងចិន នៅព្រលានយន្តហោះពោធិ៍ចិនតុង ដោយបានដឹកឱសថ និងឥស្សរជនខ្មែរ តាមសំណើសុំរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា)។ *សេចក្តីរាយការណ៍តាមវិទ្យុស្តីពីការជួសជុលបណ្តាញទំនាក់ទំនង* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00167046។ ការជួសជុលព្រលានយន្តហោះពោធិ៍ចិនតុងឡើងវិញ (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00167058។

[១៦១៣] ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD), ទំព័រ ៥៣ (នៅក្នុងអំឡុងពេលនេះដែរ ខ្មែរក្រហមមិនបានស្វាគមន៍ទទួលយន្តហោះដែលដឹកជញ្ជូនឱសថមកពីទីក្រុងបាងកកទេ ដោយអះអាងថា ប្រទេសរបស់ខ្លួនមិនត្រូវការជំនួយនេះទេ)។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយលោកស្រី អេលីហ្សាប៉ែត ប៉ែកឃើ ឯកសារ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ទំព័រ ១ ERN (ភាសាខ្មែរ) 00578892 (អៀង សារី បានលើកឡើងថា ពេលនោះ យើងបានគិតថា ជំនួយអន្តរជាតិតែងតែមានលក្ខខណ្ឌ។ ពួកចិនបានផ្តល់ជំនួយមកឲ្យដោយគ្មានលក្ខខណ្ឌទេ)។ របាយការណ៍ដោយលោក ឡោអុង ទ្រីវ៉ៀរ៖ *ប្រទេសចិន និងប្រទេសកម្ពុជា* ឯកសារ E3/482 ចុះខែវិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣៥-៣៦ ERN (ភាសាខ្មែរ) 00538868-00538869 (អៀង សារី បាននិយាយថា ពួកគាត់ត្រូវផ្តល់ស្បៀងអាហារដល់ប្រជាជនទាំងអស់នោះ ដោយរក្សានូវឯករាជ្យភាព និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ដោយមិនទៅសុំជំនួយពីប្រទេសណាមួយនោះឡើយ) ។ (*សូមមើលផងដែរ* ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុៈ កិច្ចសម្ភាសន៍ជាមួយ ស៊ាន អាន ឯកអគ្គរាជទូតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/2720 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00523983-00523984 (លោក Richer៖ សេចក្តីរាយការណ៍អំពីការសន្ទនាជាមួយលោក ស៊ាន អាន ដែលជាឯកអគ្គរាជទូតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយស្នើសុំចុះចតយន្តហោះដើម្បីជម្លៀសអ្នកដែលស្ថិតនៅក្នុងស្ថានទូតបារាំង "ចុះរឿងជំនួយបរទេសវិញ? ការ

ទោះបីជាអាជ្ញាធរកម្ពុជាបានបញ្ជាក់ថា ពួកគេមានបំណងទទួលយកជំនួយបរទេសដែលជំនួយនោះមិនមានលក្ខខណ្ឌផ្សេងៗក៏ដោយ[១៦១៤] ក៏បញ្ហានេះមិនបានធ្វើឱ្យស្ថានភាពទាំងឡាយមានភាពធូរស្រាលឡើងវិញភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ នោះដែរ។

៩៣៩. ផ្ទុយទៅវិញ ថ្នាក់ដឹកនាំបានយល់ឃើញថា វាទំនងជាការបណ្តេញប្រជាជនចេញពីទីក្រុងដោយមានផែនការជាមុនបន្តិចបន្តួច ឬ មិនមានទាល់តែសោះក្នុងការដោះស្រាយពីបញ្ហាសុខុមាលភាពរបស់ប្រជាជនដែលត្រូវបានជម្លៀសនៅក្នុងអំឡុងពេលនៃការធ្វើដំណើរ គឺជាវិធីល្អជាងការអនុវត្តការជម្លៀសមួយដំណាក់កាលម្តងៗ ដែលជាគំនិតមួយត្រូវបានលើកឡើងនៅក្នុងអង្គប្រជុំ ប៉ុន្តែត្រូវបានបដិសេធ[១៦១៥]។ ការអះអាងដែលថា ការដឹកជញ្ជូនអង្ករចូលមកក្នុងទីក្រុងបង្កឱ្យមានការលំបាកជាច្រើន ឬ ថាដំណើរការនៃការកំណត់អត្តសញ្ញាណប្រជាជនដែលមានភាពសមស្របសម្រាប់ការជម្លៀសលើកដំបូងនោះ ជាកិច្ចការលំបាកមួយដែលមិនអាចធ្វើបាន[១៦១៦] គឺជាការ

---

អនុញ្ញាតឱ្យយន្តហោះ Transall ចុះចតអាចជាការផ្តល់បុព្វសិទ្ធិមួយដល់ប្រទេសបារាំង ហើយប្រទេសដទៃទៀតអាចនឹងរិះគន់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាចំពោះបញ្ហានេះ។ សង្ខេបមក រឿងនេះដូចជាប្រព័ន្ធស្តីគ្រឿងចក្រអញ្ចឹង៖ កាលណាយើងគ្មានអ្វី យើងក៏ពុំអាចសុំអ្វីពីគេដែរ")។

[១៦១៤] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00019124 (រាយការណ៍ថា ជំនួយអាចនឹងទទួលយកបាន តែក្នុងករណីដែលជំនួយនេះមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យ និងម្ចាស់ការរបស់កម្ពុជាតែប៉ុណ្ណោះ)។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/230 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00000711-00000712 (កថាខណ្ឌ៤ លើកឡើងថា "ជំនួយពីប្រទេសយូហ្គោស្លាវី ៣.០០០.០០០ ដុល្លារ ស្នើទិញថ្នាំពេទ្យចំនួន ១.០០០.០០០ ដុល្លារ ...។ កថាខណ្ឌ ៧ រៀបរាប់អំពីការថែងថាយអង្ករជំនួយពីប្រទេសចិន)។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/238 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00072458 (រាយការណ៍ថា កម្ពុជាអាចទទួលជំនួយចំនួន ៥.០០០.០០០ ដុល្លារ និង ៤.០០០.០០០ ដុល្លារ ពីប្រទេសនីមួយៗ ហើយគេថាជំនួយគេគ្មានលក្ខខណ្ឌអ្វីទេ)។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/223 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ២-៣, ៦-៧ ERN (ភាសាខ្មែរ) 00000830-00000831, 00000834-00000835 (ទាក់ទងនឹងការទទួលជំនួយពីប្រទេសប្លុកខាងកើតចំនួន៣ - អាល្លឺម៉ង់ខាងកើត ហុងគ្រី និងឆេកូស្លូវ៉ាគី ដោយសម្រេចថា "យើងមិនទទួល តែយើងក៏មិនប្រឆាំងដែរ")។

[១៦១៥] អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារ E3/89, ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00062458-00062459 (អៀង សារី បានលើកឡើងថា អ្នកខ្លះបានផ្តល់មតិឱ្យកំណត់អត្តសញ្ញាណអ្នកមកពីខាងក្រៅទីក្រុងជាមុនសិន សម្រាប់ការជម្លៀសលើកដំបូង ព្រោះពួកគេមានផ្ទះសម្បែងនៅជនបទ។)

[១៦១៦] *សូមមើល* សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៥៨ (ថា ដំណើរការកំណត់

អះអាងដែលមិនគួរឲ្យជឿបានទេ នៅពេលប្រៀបធៀបទៅនឹងជម្រើសផ្សេងទៀតនៃការជម្លៀសប្រជាជនទីក្រុងភ្នំពេញទាំងមូលដោយបង្ខំ ដោយមានតែផែនការបន្តិចបន្តួច ឬ មិនមានទាល់តែសោះចំពោះសុខុមាលភាពរបស់ប្រជាជនទាំងនោះ នៅក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ ដែលការជម្លៀសនេះពិតជាតម្រូវឲ្យមានការរៀបចំផ្នែកភ័ស្តុភារយ៉ាងលំបាកមួយ ប្រសិនបើធ្វើឲ្យបានត្រឹមត្រូវ ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងការកត់សម្គាល់របស់អ្នកជំនាញ Phillip SHORT ដែលបានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចជ្រើសរើសយកការចិញ្ចឹមប្រជាជនដែលមិនបម្លាស់ទី មានភាពងាយស្រួលជាងការចិញ្ចឹមប្រជាជនរាប់លាននាក់ដែលធ្វើដំណើរចេញពីទីក្រុងឆ្ពោះទៅកាន់គ្រប់ទិសទីនោះ[១៦១៧]។

៩៤០. ដោយពិចារណាទៅលើការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវតែធ្វើឡើងដោយចៀសមិនរួចនិងភាពមិនសមហេតុផលនៃការអះអាងថា ការជម្លៀសប្រជាជនទៅកាន់ទីជនបទ មានភាពងាយស្រួលជាងការនាំយកស្បៀងអាហារចូលមកក្នុងទីក្រុង ឬ ការជម្លៀសជាដំណាក់កាលៗ ហើយផ្អែកតាមសំអាងហេតុខាងក្រោម អង្គជំនុំជម្រះយល់ឃើញថា ស្ថានភាពស្បៀងដ៏លំបាកនេះមិនមែនជាមូលហេតុចម្បងក្នុងការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញភ្លាមៗនោះទេ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងមិនទទួលយកការលើកឡើងដែលថា នួន ជា និង ខៀវ សំផន មិនបានដឹងជាមុនពីចំនួនប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហេតុដូច្នេះហើយ ធ្វើឲ្យពួកគាត់បង្ខំចិត្តត្រូវគាំទ្រដល់ការជម្លៀសប្រជាជនចេញពីទីក្រុងដើម្បីអាចផ្គត់ផ្គង់ស្បៀងអាហារដល់ប្រជាជនបាន។

### ១០.៣.៣ ផែនការដែលត្រូវបានបង្កើតទុកជាមុន និងគោលនយោបាយរួម

៩៤១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយទូលំទូលាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំមួយចំនួន ចាប់ពីខែមិថុនា

---

អត្តសញ្ញាណមិនអាចធ្វើទៅបានទេ)។ *ប្រទេសកម្ពុជាការពារទឹកដី ការបិទប្រទេសនៅឆ្នាំ ៧៥ ដើម្បីការពារសង្គ្រាមស៊ីវិលក្នុងប្រទេស* (សារព័ត៌មានញូវយ៉កថែម NY Times) ឯកសារ E3/616 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧៨ (អៀង សារី បញ្ជាក់ពីការលំបាកក្នុងការផ្គត់ផ្គង់ស្រូវអង្ករទៅទីក្រុង)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00000900-00000901 (គ្មានមធ្យោបាយដឹកជញ្ជូនស្រូវអង្ករទេ)។

[១៦១៧] ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Expert Philip SHORT), ទំព័រ ២៣-២៤។

ឆ្នាំ១៩៧៤ ដែលរួមមាន ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជន *ទាំងអស់* ដែលត្រូវបានវាយដណ្តើមកាន់កាប់បាន ឲ្យទៅរស់នៅទីជនបទ ។ ទីប្រជុំជនដទៃទៀត មានជោគ-វាសនាដូចគ្នាបេះបិទទៅនឹងទីក្រុងភ្នំពេញ នៅពេលដែលខ្មែរក្រហមកាន់កាប់បានទីប្រជុំជនទាំងនោះ ហើយគួរកត់សម្គាល់ថា ការជម្លៀសប្រជាជនចេញពីរដ្ឋធានីដែលមានទំហំប៉ុនទីក្រុងភ្នំពេញ ដែលមិនធ្លាប់មានពីមុនមកនោះ ត្រូវបានអនុវត្តឡើងតាមវិធីសាស្ត្រអនុវត្តដូចគ្នា[១៦១៨] ។ យ៉ាងណាក៏ដោយ ការលើកយុត្តិកម្មអំពីការការពារប្រជាជនឲ្យរួចពីការទម្លាក់គ្រាប់បែកពីលើអាកាស ត្រូវបានធ្វើឡើង សម្រាប់តែទីក្រុងភ្នំពេញដែលមានការលំបាកក្នុងការផ្លាស់ទីលំនៅប្រជាជនជាងកន្លែងផ្សេងទៀត ដោយសារតែទំហំ និងលក្ខណៈជារដ្ឋធានី ។ បក្សកុម្មុយនីស្តកម្ពុជាត្រូវការការជម្រុញដើម្បីលើកទឹកចិត្តប្រជាជនឲ្យព្រមចាកចេញ ដើម្បីធានាឲ្យការជម្លៀសនោះទទួលបានជោគជ័យ។ ប្រសិនបើការខ្លាចការទម្លាក់គ្រាប់បែកពីលើអាកាសរបស់សហរដ្ឋអាមេរិក ពិតជាមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប្រាកដមែននោះ សនិទានកម្មគួរតែមានសម្រាប់គ្រប់ទីប្រជុំជនក្នុងប្រទេសកម្ពុជាជាមិនខាន ប៉ុន្តែ មិនមានការលើកសនិទានកម្មនេះនៅក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងផ្សេងៗទៀតនោះទេ រួមទាំង តំបន់មួយចំនួនដែលមានលក្ខណៈសំខាន់ជាយុទ្ធសាស្ត្រផង។

៥៤២. អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ការជម្លៀសប្រជាជនចេញពីទីប្រជុំជននានា ដែលខ្មែរក្រហមបានកាន់កាប់នោះ បង្កើតបានជាគោលនយោបាយច្បាស់លាស់មួយដែលមានតាំងពីមុនខែ មេសា ឆ្នាំ ១៩៧៥ មកម្ល៉េះ[១៦១៩] ។ លើសពីនេះទៀត នៅថ្ងៃ និងក្រោយថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានផ្លាស់ទីលំនៅចេញពីទីរួមខេត្តនានា នៅទូទាំងប្រទេសកម្ពុជា[១៦២០] ។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនមែនជាករណីលើកលែងនោះទេ ដោយហេតុថា ការជម្លៀសនេះត្រូវបានធ្វើឡើងដោយមានការកំណត់ទុកជាមុនអំពីយុទ្ធសាស្ត្រយោធា សេដ្ឋកិច្ច និងមនោគមវិជ្ជា ដែលតម្រូវឲ្យខេត្តក្រុងទាំងអស់ដែលត្រូវបានកាន់កាប់ និង "រំដោះបាន" ត្រូវធ្វើការ

[១៦១៨] *សូមមើល*ផ្នែកទី១៤, សហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៨៧-៧៩០ ។

[១៦១៩] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១០៤-១១២។

[១៦២០] *សូមមើលផងដែរ* ផ្នែកទី៤, ទិដ្ឋភាពទូទៅ: ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៧០។

ជម្លៀសនាពេលក្រោយមក[១៦២១] ។ តាមពិតទៅ សេចក្តីសម្រេចឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានរៀបចំឡើងតាមរយៈកិច្ចប្រជុំមួយចំនួន ដែលចាប់ផ្តើមធ្វើពីខែ មិថុនា ឆ្នាំ ១៩៧៤ នៅមុនពេលខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ[១៦២២] ហើយភ័ស្តុតាងបង្ហាញថា នៅតាម

---

[១៦២១] ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ), ទំព័រ ៤៩, ៥២-៥៣ (តែងតែមានផែនការជម្លៀសប្រជាជនក្រោយពីទទួលបានជ័យជម្នះនៅកន្លែងមួយ ដើម្បីបញ្ចៀសឧប្បត្តិហេតុនៃការប្រយុទ្ធគ្នានៅក្នុងតំបន់ដែលបានកាន់កាប់ថ្មីៗ)។ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ), ទំព័រ ២៧-២៨, ៥៣-៥៤ (ការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការបញ្ជារួម ដែលត្រូវបានអនុវត្តនៅគ្រប់សមរភូមិ ដោយសារត្រូវតែជម្លៀសចេញពីទីប្រជុំជនទីមួយៗ។ ផែនការជម្លៀសត្រូវបានបង្កើតឡើង មុនការជម្លៀសត្រូវបានអនុវត្ត)។ (*សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូវ៉ង្ស ពិត ឯកសារ E3/87 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00270047-00270048 (ការជម្លៀសចេញពីទីក្រុងនានា តែងតែត្រូវបានធ្វើឡើងជាញឹកញាប់ និងសន្សឹមៗក្នុងពេលរំដោះ។ នៅពេលណាដែលទីក្រុងមួយត្រូវបានកាន់កាប់ភ្លាម នោះប្រជាជនត្រូវបានជម្លៀសទៅកាន់ជនបទដើម្បីធ្វើខ្លួនឲ្យស្អាតស្អំ និងជម្រះចោលទម្លាប់នៅទីក្រុង។ អៀង សារី នៅតែនិយាយការពារការជម្លៀសចេញពីទីក្រុងភ្នំពេញនេះរហូតដល់ទីបំផុត)។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៥៩-៦០ ERN (ភាសាខ្មែរ) 00324730-00324731 (បុរសម្នាក់មកពីតំបន់ ១៣ (តាកែវ) ក្នុងភូមិភាគនិរតី និងជាអ្នកគាំទ្របក្សបានគិតថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាផ្នែកមួយនៃគោលនយោបាយរួមរយៈពេលយូរព្រោះនោះគឺជាអ្វីដែល "យើង" តែងតែបានធ្វើតាំងពីមុន នៅពេលដែល"យើង" រំដោះបានតំបន់របស់សត្រូវ។ ប្រជាជនត្រូវបានគេជម្លៀសចេញពីភូមិភាគនានាដែលបានរំដោះព្រោះ "យើង" ខ្លាចក្រែងថា យើងមិនអាចគ្រប់គ្រងតំបន់ទាំងនេះទប់ទល់នឹងការវាយបកវិញបាន ហើយហេតុដូច្នេះ មិនអាចរក្សាសន្តិសុខរបស់ប្រជាជនបាន។ លើសពីនេះទៀត ប្រជាជនគឺជាប្រភពនៃកម្លាំងពលកម្ម ហើយប្រសិនបើអាចប្រមូលផ្តុំប្រជាជនបាន នោះ "យើង" អាចមានកម្លាំងធ្វើឲ្យខ្លាំងបរាជ័យបាន។ គាត់បានយល់ឃើញថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមានគោលបំណងពីរ៖ (១) ដើម្បីរក្សាសន្តិសុខនៃរបបថ្មីរបស់យើង ហើយជាមួយនេះផងដែរ (២) ដើម្បីដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជនទាំងនោះ, ទំព័រ ៨១-៨២ ERN (ភាសាខ្មែរ) 00324763 ឡុញ ហៅ លន សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ក្រុងកំពង់សោម បានលើកឡើងថា ប្រសិនបើយើងវាយបានភ្នំពេញក្នុងឆ្នាំ ១៩៧៤ ក៏នៅតែត្រូវជម្លៀសប្រជាជនដដែល ព្រោះថានេះជាផែនការតាំងពីយូរមកហើយ។ ពាក្យស្លោកនិយាយថា "រំដោះប្រជាជនពីដៃខ្មាំង"។ សេចក្តីសន្និដ្ឋានបញ្ចប់ការ ពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤១ (លើកឡើងថា ការអនុវត្តផ្នែកយោធាពីឆ្នាំ ១៩៧០-១៩៧៥ គឺដើម្បីជម្លៀសប្រជាជនចេញពីតំបន់ដណ្តើមកាន់កាប់បាន ដោយខ្លាចក្រែងខ្មាំងវាយដណ្តើមយកទីតាំងនោះបានទៅវិញ)។

[១៦២២] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៣២-១៥២។

ទីជនបទនានា មានការប្រាប់ជាមុនឲ្យត្រៀមរៀបចំទទួលប្រជាជនដែលនឹងត្រូវបានជម្លៀស ដែលនឹងមកដល់នាពេលខាងមុខ[១៦២៣]។

៩៤៣. អាស្រ័យហេតុនេះ ការអនុវត្តការជម្លៀសប្រជាជនចេញពីខេត្ត ក្រុង នានា ដែលត្រូវបានកំណត់ទុកជាមុននោះ ធ្វើឲ្យការអះអាងរបស់មេធាវីការពារក្ដីដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើឡើងដោយសារតែការភ័យខ្លាចយ៉ាងខ្លាំងពីការទម្លាក់គ្រាប់បែករបស់អាមេរិកនាពេលឆាប់ៗខាងមុខ ឬ តម្រូវការក្នុងការដោះស្រាយស្ថានភាពមនុស្សធម៌ដ៏លំបាកនៅក្នុងទីក្រុង មិនអាចឲ្យជឿបានទេ។

### ១០.៣.៤ គុណតម្លៃផ្នែកមនោគមវិជ្ជា និងបដិវត្តន៍កសិកម្ម

៩៤៤. ជនជាប់ចោទ នួន ជា និង ខៀវ សំផន ក៏បានអះអាងផងដែរថា ប្រជាជនត្រូវបានជម្លៀសដើម្បីជួយកសាងមូលដ្ឋានកសិកម្ម ដែលនឹងធ្វើឲ្យប្រទេសកម្ពុជាឯករាជ្យខាងផ្នែកសេដ្ឋកិច្ច[១៦២៤]។ បញ្ហាសំខាន់ៗនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត នៅក្នុងរយៈពេលប៉ុន្មានខែ បន្ទាប់ពីការកាន់កាប់បានទីក្រុងភ្នំពេញបង្ហាញថា ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ បានបំពេញ និងបានជួយធ្វើឲ្យគោលបំណងមនោគមវិជ្ជាវណ្ណៈរបស់បដិវត្តជឿនលឿនទៅមុខក្នុងពេលកន្លងមក ដោយ "ពួកអាណានិគម និងពួកសក្ដិភូមិ" មានន័យថា អ្នកទីក្រុង បញ្ញវន្ត អ្នករដ្ឋការ និងពួកអនុធន ត្រូវ

---

[១៦២៣] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៦។

[១៦២៤] កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្រ្ត លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី០៩-១១ ខែមិថុនា ឆ្នាំ២០០៦ទំព័រ ៧ ERN (ភាសាខ្មែរ) 00347037 (បញ្ជាក់ថា ការជម្លៀសគឺជាគម្រោងផែនការរបស់កុម្មុយនីស្ត តែវាស្របសម្រាប់សភាពការណ៍នៅក្នុងប្រទេសកម្ពុជា។ គាត់ជឿថា ទីមួយ យើងត្រូវការចាំបាច់ដើម្បីធ្វើឲ្យប្រទេសយើងឯករាជ្យសិន)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00000904-00000905។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈូក រីន ឯកសារ E3/362 ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00210210-00210211 (បានរាយការណ៍ថា នៅក្នុងកិច្ចប្រជុំមួយដើម្បីពីភាក្សាអំពីការជម្លៀសប្រជាជនចេញពីក្រុងកំពត ដែលបានប្រារព្ធធ្វើនៅភ្នំសររយៈពេលប្រហែលមួយខែមុនការដួលរលំទីក្រុងភ្នំពេញ តា ម៉ុក បាននិយាយថា ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ"។

បានវាយរំលំ ប្រែក្លាយទៅជាកសិករ និង "ត្រូវបានធ្វើឱ្យខ្ចាត់ខ្ចាយយ៉ាងអាម៉ាស់"[១៦២៥]។ ក្នុងឆ្នាំ ១៩៧៦ ទស្សនាវដ្តីទង់បដិវត្តបានប្រកាសថា "នៅពេលយើងបានជម្លៀសប្រជាជនចេញពីទីប្រជុំជននានា យើងបានអនុវត្តការតស៊ូវណ្ណៈ"[១៦២៦]។ អង្គជំនុំជម្រះយល់ស្របជាមួយនឹងការវាយតម្លៃរបស់លោក François PONCHAUD ដែលលើកឡើងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានឆ្លុះបញ្ចាំងពីទស្សនៈថ្មីមួយអំពីសង្គមដែលធ្វើឱ្យមិនមានកន្លែងណាមួយជាទីក្រុងឡើយ។ ដោយយោងទៅតាមខ្មែរក្រហម សាវតាររបស់ទីក្រុងភ្នំពេញដែលថា ជាសមិទ្ធផលរបស់ពួកអាណានិគមនិយមបារាំង ការធ្វើពាណិជ្ជកម្មរបស់ជនជាតិចិន និងជាការិយាធិបតេយ្យរបស់រាជានិយម និងក្រោយមកទៀតជារបស់របបសាធារណរដ្ឋខ្មែរ ត្រូវតែធ្វើការបោសសម្អាត និងជំនួសដោយសង្គមកសិកម្មជនបទដោយស្មើភាពគ្នាមួយ ដើម្បីឱ្យមនុស្សដឹងថា "ខ្លួនកើតមកពីគ្រាប់ស្រូវមួយគ្រាប់"[១៦២៧]។

៩៤៥. ដោយឆ្លុះបញ្ចាំងឱ្យឃើញថា ការផ្លាស់ទីលំនៅអ្នកដែលរស់នៅក្នុងទីក្រុង ត្រូវបានធ្វើឡើងដោយសារកត្តាផ្សេងៗជាច្រើននៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ ក្នុងឱកាសប្រារព្ធខួប ១ ឆ្នាំ នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អត្ថបទមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តបានលើកឡើងថា "ពិតមែនតែយើងដកប្រជាជនយើងពីទីក្រុងទៅជនបទហាក់ដូចជាមិនត្រឹមត្រូវ... ប៉ុន្តែដោះស្រាយ

---

[១៦២៥] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/5 ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១២ ERN (ភាសាខ្មែរ) 00063322 (បើយើងទុកឱ្យនៅភ្នំពេញ ពួកគេអាចនឹងមានអានុភាពខ្លាំង។ នៅពេលយើងចូលមកភ្នំពេញ យើងរណបវា។ តែយើងមិនទុកវាឱ្យនៅភ្នំពេញទេ។ ដល់អញ្ចើងទៅ កម្មសិទ្ធិឯកជន វាគ្មានអានុភាពទេ)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/749 ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00399101-00399103។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៤៩ ERN (ភាសាខ្មែរ) 00063164 (ប្រកាសថា នៅថ្ងៃទី ១៧ មេសា ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចភារកិច្ចទាំងពីររបស់ខ្លួនទាំងស្រុង ដែលបានកំណត់ឡើងដោយមាគ៌ាបក្ស គឺការលុបបំបាត់ពួកចក្រពត្តិ និងរបបសក្តិភូមិម្ចាស់ដី និងកំប្រាឌ័រ ប្រតិកិរិយាពីសង្គមកម្ពុជា)។ (*សូមមើលផងដែរ* សេចក្តីថ្លែងការណ៍របស់ នួន ជា ទៅកាន់បក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00224477 (បានលើកឡើងថាតើពួកនាយទុននិយមកំប៉ិកកំប៉ុកដែលត្រូវបានជម្លៀសចេញពីទីក្រុង មានការលំបាកបែបណាដែរក្នុងការរស់នៅតាមទីជនបទ ប៉ុន្តែ ជាបណ្តើរៗ ពួកគេមានមោទនភាពចំពោះបដិវត្តន៍)។

[១៦២៦] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/10 ចុះខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៦១-៦៣ ERN (ភាសាខ្មែរ) 00063095-00063096។

[១៦២៧] សៀវភៅនិពន្ធដោយ F. Ponchaud៖ *កម្ពុជា ឆ្នាំសូន្យ* ឯកសារ E243.1 ERN (ភាសាខ្មែរ) 00862307-00862308។ *សូមមើលផងដែរ* ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦ ។

01006812



ប្រជាជាតិទាំងមូលបាន ... ប្រជាជន ... ស្បៀង ... សេដ្ឋកិច្ច .. នយោបាយ និងយោធាបានថែម ទៀត"[១៦២៨]។

## ១០.៤ សម្អាងច្បាប់

៩៤៦. ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទ៖ ការធ្វើមនុស្សឃាតការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជា (១) ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និង (២) ការជម្លៀសដោយបង្ខំដែលជាឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិចំពោះបទល្មើសនានា ដែលបានប្រព្រឹត្តនៅក្នុង (ដំណាក់កាលទី១) នៃការ ជម្លៀសប្រជាជន[១៦២៩]។ អង្គជំនុំជម្រះបានសម្រេចកាលពីមុនរួចមកហើយថា លក្ខខណ្ឌទូទៅនៃ មាត្រា ៥ ត្រូវបានបំពេញរួចហើយ[១៦៣០]។

### ១០.៤.១ ការផ្លាស់ទីលំនៅដោយបង្ខំ

៩៤៧. មានការបង្ហាញឲ្យឃើញថា យ៉ាងហោចណាស់ក៏មានប្រជាជនចំនួន ២.០០០.០០០ នាក់ ដែរ ដែលត្រូវបានកងទ័ពខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញដោយបង្ខំ ទៅកាន់ទីជនបទនានា

---

[១៦២៨] *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/759 ចុះខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ២១-២៣ ERN (ភាសាខ្មែរ) 00062756-00062757។ *សូមមើលផងដែរ* ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ សារសម្រាប់ ព័ត៌មាន *Le Monde* ឯកសារ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00491977-00491978 (ទទួល ស្គាល់ថា ការជម្លៀសប្រជាជនប្រហែលជាមធ្យោបាយមួយសម្រាប់គ្រប់គ្រងរាជធានី ដោះស្រាយបញ្ហាហូបចុក និងធ្វើបដិវត្តទីក្រុង)។

[១៦២៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៧ (ការធ្វើមនុស្សឃាត) កថាខណ្ឌ ១៣៨១, ១៣៨៧ (ការ សម្លាប់រង្គាល) កថាខណ្ឌ ១៤១៦ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ) កថាខណ្ឌ ១៤៣៤, ១៤៣៦ (អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) កថាខណ្ឌ ១៤៤៨, ១៤៥៣, ១៤៥៥, ១៤៥៨-១៤៥៩, ១៤៦១, ១៤៦៨-១៤៦៩ (អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ អនុលោមតាមដីកាសម្រេចបំបែកកិច្ចដំណើរការ នីតិវិធី អង្គជំនុំជម្រះបានបញ្ជាក់ថា កថាខណ្ឌ ២២១-២៦០ នៃដីកាដំណោះស្រាយទាក់ទងនឹង ការជម្លៀសប្រជាជន នៅដំណាក់កាលទី១ និង បទល្មើសដទៃទៀតដែលត្រូវបានចោទប្រកាន់ គឺស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/ ០១។ *សូមមើល* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់ កាលដំបូងនៅក្នុងសំណុំរឿង ០០២ ឯកសារ E124/7.3 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១-៤។

[១៦៣០] *សូមមើល*ផ្នែកទី៤, ទិដ្ឋភាពទូទៅ: ចាប់ពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៩៨។

ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មក[១៦៣១]។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានអនុវត្តតាមគោលនយោបាយផ្នែកយោធា សេដ្ឋកិច្ច និងមនោគមវិជ្ជារបស់បក្ស ដែលត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំមួយចំនួននៅឆ្នាំ ១៩៧៤ និងឆ្នាំ ១៩៧៥[១៦៣២]។ យោងទៅលើកិច្ចប្រជុំទាំងនេះ ក៏ដូចជាការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំ និងរបៀបសម្របសម្រួលដល់ការជម្លៀសនេះ អង្គជំនុំជម្រះយល់ឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើឡើងដោយចេតនា។

៥៤៨. ប្រជាជននៅទីក្រុងភ្នំពេញនាពេលនោះ មានទាំងប្រជាជនដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងទីក្រុង និងប្រជាជនដែលមកពីតាមតំបន់នានានៃប្រទេស ដើម្បីស្វែងរកការជ្រកកោននៅក្នុងទីក្រុង[១៦៣៣]។ មិនមានការលើកឡើងថា ប្រជាជនទាំងនោះស្នាក់នៅក្នុងទីក្រុងភ្នំពេញដោយខុសច្បាប់នោះទេ ហើយក្រុមមេធាវីការពារក្តីក៏មិនជំទាស់ទៅលើបញ្ហានេះដែរ។ កាលៈទេសៈទាំងឡាយនាពេលនោះបង្ហាញថា ការជម្លៀសនេះមិនបានធ្វើឡើងដោយស្ម័គ្រចិត្តនោះទេ ទោះបីជាមានជនភៀសខ្លួនមួយចំនួននៅក្នុងទីក្រុងភ្នំពេញ អាចមានការសប្បាយរីករាយដោយបានវិលត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ ដោយសារតែលក្ខខណ្ឌរស់នៅមិនល្អក្នុងទីក្រុងភ្នំពេញក៏ដោយ។ ដើម្បីធ្វើឲ្យការជម្លៀសនេះមានប្រសិទ្ធភាព កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ បានបោកបញ្ឆោតប្រជាជនទីក្រុង និងបានកេងយកប្រយោជន៍ពីការភ័យខ្លាច និងការទុកចិត្តរបស់ប្រជាជនចំពោះជនជាតិខ្មែរដូចគ្នា ដែលបានប្រាប់ទៅពួកគេថា ពួកគេអាចនឹងរងគ្រោះពីការទម្លាក់គ្រាប់បែក[១៦៣៤] គំរាមសម្លាប់ពួកគេ និងបានបាញ់ប្រហារទៅលើអ្នកដែលមិនធ្វើតាមបញ្ជាភ្លាមៗ[១៦៣៥] និងបានឈរនៅតាមដងផ្លូវណែនាំឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ[១៦៣៦]។ សូម្បីតែអ្នកដែលមិនធ្លាប់មានបទពិសោធន៍ជួបប្រទះអំពើហិង្សាក៏ដោយ ក៏មានអារម្មណ៍ថា ការបញ្ជាទាំងនេះត្រូវតែធ្វើតាម[១៦៣៧]។ ចំពោះកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា កងទ័ពខ្មែរ

---

[១៦៣១] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២០។
[១៦៣២] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៣២-១៣៣, ១៤៣-១៤៤។
[១៦៣៣] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៧។
[១៦៣៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣០។
[១៦៣៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៤។
[១៦៣៦] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨១។
[១៦៣៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៥។

ក្រហមបានប្រើប្រាស់ការបង្ខិតបង្ខំ ការគំរាមកំហែង និងការបោកបញ្ឆោត ហើយប្រជាជនដែលត្រូវបានជម្លៀសមិនមានជម្រើសពិតប្រាកដណាមួយ ថាតើត្រូវនៅក្នុងទីក្រុងភ្នំពេញតទៅទៀត ឬត្រូវចាកចេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឡើយ។

៩៤៩. ចំពោះបញ្ហា ថាតើមានមូលដ្ឋានដែលត្រូវបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនទាំងនោះមិនមែនត្រូវបានជម្លៀសដោយសារតែមូលហេតុខាងផ្នែកយោធាជាចាំបាច់នោះទេ ។ ការផ្តល់យុត្តិកម្មថាការជម្លៀសនេះ មានបំណងដើម្បីការពារប្រជាជនឱ្យរួចផុតពីការទម្លាក់គ្រាប់បែករបស់អាមេរិកនោះ គឺជាការបោកបញ្ឆោតពិតប្រាកដ[១៦៣៨]។ លើសពីនេះទៀត ជម្លោះដែលនៅបន្តជាមួយរបបសាធារណរដ្ឋខ្មែរត្រូវបានបញ្ចប់ ហើយទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទូទាំងប្រទេសបានចុះចាញ់[១៦៣៩]។ ក្រុមមេធាវីការពារក្តី នួន ជា ក៏បានបដិសេធយ៉ាងច្បាស់លាស់ចំពោះការអះអាងថាការជម្លៀសនេះមានគោលបំណងផ្នែកមនុស្សធម៌ ដែលជាគោលជំហរមួយ ផ្ទុយគ្នាទៅនឹងការអះអាងរបស់ខ្លួនដែលថា ការជម្លៀសប្រជាជន គឺបណ្តាលមកពីតម្រូវការក្នុងការការពារប្រជាជនពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក[១៦៤០]។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន អះអាងថា ការជម្លៀសនេះគឺជាគោលនយោបាយតាំងទីលំនៅស្របច្បាប់មួយ ដែលមានគោលបំណងធ្វើឱ្យសេដ្ឋកិច្ចមានភាពប្រសើរឡើង ដូច្នេះ អាចជួយសម្រាលដល់ស្ថានភាពមនុស្សធម៌នៅក្នុងទីក្រុងភ្នំពេញ[១៦៤១] ។ គោលនយោបាយផ្នែកសេដ្ឋកិច្ចមិនមែនជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានទាំងឡាយដែលត្រូវបានទទួលស្គាល់នៅក្រោមច្បាប់អន្តរជាតិ ដែលអាចយកមកធ្វើយុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំបាននោះទេ ។ លើសពីនេះទៀត ចំពោះទឡ្ហីករណ៍ដែលអះអាងថា ការជម្លៀសនេះ គឺមានបំណងធ្វើឱ្យស្ថានភាពស្បៀងអាហារមានលក្ខណៈល្អប្រសើរឡើងនោះ អង្គជំនុំជម្រះបានបដិសេធរួចមកហើយចំពោះមូលហេតុដែលបាន

---

[១៦៣៨] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៩-៥៣០, ៥៣៤។

[១៦៣៩] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦០-៤៦៣។

[១៦៤០] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៥៤។

[១៦៤១] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៤០-២៥៨។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤-៣៦, ៤៤-៥៣។

អះអាងដើម្បីគាំទ្រដល់ការបកស្រាយនេះ[១៦៤២]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានករណីលើកលែងណាមួយចំពោះការហាមឃាត់ជាទូទៅនៃការជម្លៀសប្រជាជនដោយបង្ខំត្រូវបានយកមកអនុវត្តចំពោះសកម្មភាពរបស់កងទ័ពខ្មែរក្រហម ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះទេ។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការជម្លៀសនេះមិនមានយុត្តិកម្មដោយភាពចាំបាច់នោះឡើយ។

៥៥០. ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា ស្ថានភាពមនុស្សធម៌ ឬ សេដ្ឋកិច្ច អាចធ្វើយុត្តិកម្មដល់ការជម្លៀសក្តី ក៏ការជម្លៀសនេះ មិនបានគោរពដល់លក្ខខណ្ឌនៃភាពសមាមាត្រនោះឡើយ។[១៦៤៣] ទីមួយ ទោះបីជាមានការសន្យាថា ការជម្លៀសនេះធ្វើឡើងជាបណ្តោះអាសន្នក៏ដោយ ក៏សាក្សីជាច្រើនត្រូវបានគេប្រាប់ឲ្យដឹងថា ពួកគេនឹងមិនវិលត្រឡប់មកវិញទេ[១៦៤៤]។ តាមពិតទៅប្រជាជន ដែលត្រូវបានជម្លៀសស្ទើរតែទាំងអស់ ដែលនៅរស់រានមានជីវិតមិនបានវិលត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញបានទេ រហូតដល់ក្រោយពេលរបបនេះដួលរលំនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩[១៦៤៥]។ ផ្ទុយទៅវិញ ប្រជាជនដែលត្រូវបានជម្លៀសត្រូវបានផ្លាស់ទីលំនៅជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានខែឆ្នាំក្រោយមក ដើម្បីបំពេញតម្រូវការផលិតកម្មនៅក្នុងប្រទេស[១៦៤៦]។ហេតុដូច្នេះ ថ្នាក់ដឹកនាំខកខានមិនបានបញ្ជូនប្រជាជនដែលត្រូវបានជម្លៀស ឲ្យវិលត្រឡប់ទៅកាន់ផ្ទះសម្បែងរបស់ពួកគេវិញភ្លាមៗទេ បើទោះបីជាក្រោយពីខ្លួនបានដឹងច្បាស់ថា មិនមានការគំរាមកំហែងខាងយោធា និងខាងមនុស្សធម៌ដែលអាចផ្តល់យុត្តិកម្មជាបន្តបន្ទាប់ នៃវិធានការទាំងនោះក៏ដោយ។ លើសពីនេះទៀត ទោះបីជាមានភ័ស្តុតាងបង្ហាញថាស្បៀងអាហារ ជម្រក ថ្នាំសង្កូវ និងការដឹកជញ្ជូនត្រូវបានផ្តល់ជូននៅក្នុងអំឡុងពេលជម្លៀសនេះក៏ដោយ ក៏ការផ្តល់ជូនទាំងនេះត្រូវបានធ្វើឡើងជាអន្លើៗ និងមិនមានលក្ខណៈគ្រប់គ្រាន់នោះទេដោយសារតែថា ចំនួនប្រជាជនដែលត្រូវជម្លៀស

---

[១៦៤២] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៨-៥៤០។

[១៦៤៣] *សូមមើល*ផ្នែកទី៩, ច្បាប់ជាធរមានៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ៤៥០។

[១៦៤៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១), កថាខណ្ឌ ៤៦៥ (លេខយោងជើងទំព័រ ១៣៧៨), ៤៨៦។

[១៦៤៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៩ (លេខយោងជើងទំព័រ ១៥៥៧)។

[១៦៤៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦, ៥៨០-៥៨១។

ចេញពីទីក្រុងភ្នំពេញមានច្រើនឥតគណនា[១៦៤៧]។ ចុងក្រោយ ប្រជាជនដែលត្រូវបានជម្លៀសជាច្រើននាក់ ត្រូវបានគេជម្លៀសដោយមិនមានសមាជិកគ្រួសារទាំងអស់របស់ខ្លួនទៅជា មួយឡើយ ហើយត្រូវគេបង្ខំឲ្យទុកចោលសមាជិកគ្រួសារដែលទន់ខ្សោយនៅតាមផ្លូវ ឬ ត្រូវគេបំបែកចេញពីសមាជិកគ្រួសារនៅកន្លែងត្រួតពិនិត្យតាមផ្លូវនៅពេលកំពុងធ្វើដំណើរ[១៦៤៨]។

៥៥១. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនសមហេតុផលឡើយ ដោយផ្អែកទៅលើភាពចាំបាច់ផ្នែកសន្តិសុខសម្រាប់ជនស៊ីវិល ឬ យោធានោះ ហើយទោះជាក្នុងករណីណាក៏ដោយ ក៏ការជម្លៀសនេះមិនមានភាពសមាមាត្រនោះឡើយ។

៥៥២. អង្គជំនុំជម្រះយល់ឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ បានធ្វើឲ្យជនរងគ្រោះទទួលរងព្យសនកម្មទាំងផ្នែករាងកាយ និងទាំងផ្លូវចិត្តធ្ងន់ធ្ងរ ដែលបន្តជាប់ជារៀងរហូត[១៦៤៩] ដោយសារផលប៉ះពាល់ពីការជម្លៀសនេះដែលមានលក្ខណៈកាន់តែធ្ងន់ធ្ងរ ដោយសារតែកាលៈទេសៈនៃការបង្ខិតបង្ខំ និងការគំរាមកំហែងដែលត្រូវបានអនុវត្តនៅក្នុងការជម្លៀសនេះ[១៦៥០] រួមទាំង ស្ថានភាពអមនុស្សធម៌ដែលអ្នកត្រូវបានជម្លៀសបានជួបប្រទះ ក្នុងអំឡុងពេលធ្វើដំណើរនោះ[១៦៥១]។ អំពើទាំងនេះប្រព្រឹត្តដោយចេតនា អមនុស្សធម៌ និងមានកម្រិតធ្ងន់ធ្ងរ ដែលជាបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កម្មាភិបាល និងកងទ័ពខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនេះ។

### ១០.៤.២ ការធ្វើមនុស្សឃាត

៥៥៣. នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់ ដែលត្រូវបានគេកំណត់ជាគោលដៅជាសាធារណៈសម្រាប់ការប្រហារជីវិត មុនពេលកាន់កាប់ទីក្រុងភ្នំពេញ ហើយដែលមិនបានរត់គេច

[១៦៤៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៤-៤៩៦។

[១៦៤៨] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៦, ៤៩២, ៥១៣។

[១៦៤៩] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២២-៥២៤។

[១៦៥០] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧១-៤៧៥, ៤៨៩-៤៩០។

[១៦៥១] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩១-៤៩២ (ក្រោមកំដៅថ្ងៃ និងអស់កម្លាំង) ៤៩៥ (ខ្វះខាតជំនួយ) ៤៩៧-៤៩៨ (ឃើញមនុស្សកំពុងដាច់ខ្យល់ស្លាប់) ៤៩៩ (ឃើញសាកសព)។

ខ្លួន ត្រូវបានគេសម្លាប់ចោល[១៦៥២]។ លើសពីនេះទៀត ជនរងគ្រោះជាច្រើន ដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាទាហាន ឬ មន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងពេលជម្លៀស ត្រូវបានគេចាប់យកទៅដោយឡែកដើម្បីសម្លាប់ចោលនៅកន្លែងផ្សេង[១៦៥៣]។ ចុងក្រោយ ជនរងគ្រោះជាច្រើនដែលបានបដិសេធមិនព្រមចាកចេញពីផ្ទះរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជាអ្នកដែលមិនបានធ្វើតាមការណែនាំភ្លាមៗរបស់កងទ័ពខ្មែរក្រហម នៅក្នុងពេលធ្វើដំណើរចេញពីទីក្រុង ត្រូវបានគេបាញ់ និងសម្លាប់ចោលនៅនឹងកន្លែង[១៦៥៤]។ មានភស្តុតាងជាច្រើនផងដែរបញ្ជាក់ថា ការសម្លាប់ជនរងគ្រោះ ទាំងនៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងអំឡុងពេលនៃការជម្លៀស គឺធ្វើឡើងដោយគ្មានហេតុផលអ្វីឡើយ[១៦៥៥] ។ ដោយសារតែជនរងគ្រោះត្រូវបានបាញ់សម្លាប់នៅក្នុងចម្ងាយជិត ដូចដែលបានលើកឡើងនេះ ឬ ដោយសារតែមានការខិតខំប្រឹងប្រែងរួមគ្នាដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ មុនពេលបញ្ជូនពួកគេទៅកន្លែងផ្សេងដើម្បីសម្លាប់ចោលនោះ អង្គជំនុំជម្រះយល់ឃើញថា ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការសម្លាប់ជនរងគ្រោះទាំងអស់នោះ។

៥៥៤. ក្រោយពីបានពិចារណាទៅលើភស្តុតាង ពាក់ព័ន្ធនឹងកាលៈទេសៈរបស់បុគ្គលម្នាក់ៗដែលបានស្លាប់ អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះទាំងអស់ រួមមានទាំងជនស៊ីវិលធម្មតា និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏ដូចជា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានគេឃុំខ្លួន បាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ឬ ក៏លែងចូលរួមយ៉ាងសកម្មនៅក្នុងការប្រយុទ្ធ នៅពេលដែលពួកគេត្រូវបានសម្លាប់ ហើយថាចារីបានដឹងអំពីបញ្ហានេះ។ ពាក់ព័ន្ធនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងពេលធ្វើការផែកផេរទីក្រុងលើកទីពីរ[១៦៥៦] ការសម្លាប់ទាំងនេះបានកើតឡើងនៅក្នុងបរិបទមួយដែលអាចមានហេតុផលថា ដោយសារស្ថានភាពប្រយុទ្ធគ្នា ។ ភស្តុតាងទាំងនេះមិនមានភាពគ្រប់គ្រាន់ក្នុងការបង្ហាញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងនោះ គឺជាទាហានដែលបាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ឬ ក៏ថា មិនបានចូលរួមយ៉ាងសកម្មនៅក្នុង

[១៦៥២] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[១៦៥៣] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៨, ៥១១, ៥១៣, ៥១៥ ។

[១៦៥៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៥, ៤៨៦។

[១៦៥៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩០, ៥០៧, ៥១៣។

[១៦៥៦] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១០។

ការប្រយុទ្ធនៅពេលដែលពួកគេត្រូវបានសម្លាប់នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹង មិនពិចារណាទៅលើការសម្លាប់ទាំងនេះនៅក្នុងការសម្រេចនេះឡើយ។

៥៥៥. ពាក់ព័ន្ធនឹងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានគេកំណត់អត្តសញ្ញាណ ហើយក្រោយមកបានបាត់ខ្លួននៅតាមកន្លែងត្រួតពិនិត្យនានា ដោយជោគវាសនារបស់អ្នកទាំងនោះ មិនត្រូវបានគេដឹងនោះ[១៦៥៧] ភស្តុតាងបានបង្ហាញថា មិនមែនមានមូលហេតុតែមួយដែលថា ពួកគេ ទាំងនោះត្រូវបានសម្លាប់ចោលនោះទេ ដោយហេតុថា មានភស្តុតាងបញ្ជាក់ថា ទាហាន និងមន្ត្រី រដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើន ក៏ត្រូវបានគេបញ្ជូនទៅកាន់ភូមិនានា ដើម្បីធ្វើការ ឬ អប់រំ កែប្រែផងដែរ[១៦៥៨]។

៥៥៦. ជនរងគ្រោះជាច្រើនក៏បានស្លាប់នៅតាមផ្លូវផងដែរ ដោយសារតែមូលហេតុផ្សេងៗរួមទាំង ជំងឺដែលបណ្តាលមកពីកងទ័ពខ្មែរក្រហមខកខានក្នុងការផ្តល់ចំណីអាហារ ទឹក ជំនួយវេជ្ជសាស្ត្រ ជម្រក ឬ សម្ភារៈអនាម័យ ដល់អ្នកដែលត្រូវបានជម្លៀសទាំងនោះ[១៦៥៩]។ ចំពោះ*ចេតនា*របស់ចារី ពាក់ព័ន្ធទៅនឹងការស្លាប់ជនរងគ្រោះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នៅពេលកងទ័ពខ្មែរ ក្រហមបានធ្វើសកម្មភាពនោះ ពួកគេអាចប្រមើលមើលដឹងអំពីលទ្ធភាពនៃអំពើរបស់ខ្លួនដែលអាច បណ្តាយឱ្យមានមនុស្សស្លាប់ ប៉ុន្តែ ពួកគេបានបន្តអនុវត្តសម្មភាពរបស់ខ្លួនដោយ*ចេតនាដោយមិន ចំពោះ* (*dolus eventualis*)។[១៦៦០] ទីមួយ អង្គជំនុំជម្រះរម្លឹកថា ខ្មែរក្រហមធ្លាប់មានបទពិសោធន៍ ក្នុងការជម្លៀសប្រជាជនចេញពីតំបន់ដែលខ្លួនបានកាន់កាប់ ទៅកាន់តំបន់រំដោះ នៅមុន ខែ មេសា ឆ្នាំ១៩៧៥ រួចទៅហើយ ហើយភស្តុតាងខ្លះបញ្ជាក់ថា ការស្លាប់ និងការអត់ឃ្លានបានបណ្តាល មកពីលក្ខខណ្ឌផ្សេងៗដែលបានកើតមានឡើងនៅពេលជម្លៀសប្រជាជនទាំងនោះ[១៦៦១]។ ទោះបីជា ការជម្លៀសទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនរាប់ម៉ឺននាក់ក៏ដោយ ក៏ការជម្លៀសប្រជាជនយ៉ាង ហោចណាស់ ២.០០០.០០០នាក់ ចេញពីទីក្រុងភ្នំពេញ ជាចំនួនមួយដែលមិនអាចប្រៀបធៀបបាន ទាំងបរិមាណ និងភាពស្មុគស្មាញ ជាមួយនឹងបទពិសោធន៍ពីមុនរបស់ថ្នាក់ដឹកនាំទាំងនោះ។ លើស

[១៦៥៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៣-៥១៤។

[១៦៥៨] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៣។

[១៦៥៩] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩១-៤៩២, ៤៩៥-៤៩៨។

[១៦៦០] *សូមមើល*ផ្នែកទី៩, ច្បាប់ជាធរមាន: ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ៤១៧។

[១៦៦១] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១២៥ លេខយោងជើងទំព័រ ៣៦៥។

ពីនេះទៅទៀត ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កើតចេញពីការវាយប្រយុទ្ធដែលបានអូសបន្លាយរយៈពេលជាច្រើនឆ្នាំ និងការឡោមព័ទ្ធយ៉ាងយូរ[១៦៦២]។ ប្រជាជនបានជួបប្រទះនឹងការខ្វះស្បៀងអាហារអស់រយៈពេលយ៉ាងយូរនៅពេលនោះ ហេតុដូច្នេះ ពួកគេបានចុះខ្សោយយ៉ាងខ្លាំងរួចទៅហើយមកទល់នឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ [១៦៦៣]។ នៅក្នុងកាលៈទេសៈទាំងនេះ ប្រជាជនត្រូវបានបណ្តេញចេញពីទីក្រុងដោយមិនមានការជូនដំណឹង និងមិនមានការផ្គត់ផ្គង់ឲ្យបានគ្រប់គ្រាន់ នៅក្នុងស្ថានភាពមួយដែលកាន់តែមានភាពធ្ងន់ធ្ងរឡើងៗ ដោយសារតែឧបាយកលបោកបញ្ឆោតដោយចេតនាដែលថា ពួកគេនឹងបានវិលត្រឡប់មកវិញក្នុងរយៈពេល ៣ ថ្ងៃខាងមុខ ហេតុដូច្នេះ មិនចាំបាច់យករបស់របរអ្វីទៅច្រើននោះទេ[១៦៦៤]។ ស្ថានភាពនេះកាន់តែមានភាពធ្ងន់ធ្ងរថែមទៀត ដោយសារតែប្រជាជនត្រូវបានបណ្តេញចេញនៅក្នុងអំឡុងពេលដែលមានអាកាសធាតុក្តៅបំផុត និងស្ទើរតែគ្មានការជួយទំនុកបម្រុង ឬ ជំនួយអ្វីសោះឡើយ។

៥៥៧. ទោះបីជាមានភស្តុតាងខ្លះបង្ហាញពីការត្រៀមរៀបចំមុនពេលជម្លៀស ដោយការដឹងជាមុនអំពីការមកដល់របស់អ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ មកកាន់ទីជនបទក៏ដោយ[១៦៦៥] ក៏អតីតកងទ័ពខ្មែរក្រហមដែលបានចូលរួមនៅក្នុងការជម្លៀសទាំងនោះ បានបញ្ជាក់ថា *នៅក្នុងអំឡុងពេល* ជម្លៀសនោះ អង្គភាពនីមួយៗរបស់ពួកគេមិនបានជួយ ឬ ផ្តល់ជំនួយណាមួយដល់អ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុង ឬ បានទទួលការណែនាំឲ្យធ្វើបែបនេះនោះទេ[១៦៦៦]។ ចំពោះអ្នកជំងឺដែលបានស្នាក់នៅក្នុងមន្ទីរពេទ្យ ខ្មែរក្រហមបានជម្លៀសចេញទាំងអស់ដោយគ្មានការលើកលែង រួមទាំងអ្នកទន់ខ្សោយ អ្នកជំងឺ និងអ្នករបួស[១៦៦៧] ដោយគ្មានការពិចារណាទៅលើផលប៉ះពាល់ដែលនឹងកើតមានចំពោះបុគ្គលទាំងនេះឡើយ ។ ជាចំណុចគួរឲ្យកត់សម្គាល់បំផុតនោះគឺថា មិនមានផែនការអ្វីក្នុងការជួយអ្នកទាំងនោះឡើយ សូម្បីតែចំពោះអ្នកដែលងាយរងគ្រោះថ្នាក់បំផុត ដូចជា ទារក កុមារ អ្នកជំងឺ អ្នករបួស ដែលខ្លះទើបត្រូវបានវះកាត់ថ្មីៗ ក៏ដូចជាស្ត្រីមានផ្ទៃពោះ ចាស់ជរា និងអ្នកទន់ខ្សោយក្តី។ វ៉ាចាម តុន ហៅ ភី ភួន បានបញ្ជាក់ថា ផែនការលម្អិតដូចជា ថាតើ

---

[១៦៦២] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៦១-១៦៧ ។

[១៦៦៣] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១៥៧-១៦០។

[១៦៦៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៤-៤៦៧។

[១៦៦៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៦, ៥៤១-៥៤២។

[១៦៦៦] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៤-៤៩៦។

[១៦៦៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៦។

ត្រូវផ្តល់ចំណីអាហារដល់ប្រជាជន ឬ យកចិត្តទុកដាក់ចំពោះមនុស្សចាស់ជរា កុមារ ឬ អ្នកជំងឺរបៀបណានៅក្នុងពេលជម្លៀសនោះ មិនត្រូវបានលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំកាលពីខែមេសា ឆ្នាំ ១៩៧៥ ដែលគាត់បានឃាមកាមនោះទេ[១៦៦៨] ។ ជនជាប់ចោទ នួន ជា បានទទួលស្គាល់ថា ថ្នាក់ដឹកនាំមិនមានពេលវេលាក្នុងការកំណត់ថាតើមានមន្ទីរពេទ្យ ឬ អ្នកជំងឺប៉ុន្មាននាក់ដែលនឹងត្រូវបានប៉ះពាល់ដោយសារតែសេចក្តីសម្រេចជម្លៀសនេះទេ[១៦៦៩]។

៥៥៨. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នៅក្នុងការបណ្តេញប្រជាជនចេញពីទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានដឹងថា យ៉ាងហោចណាស់ការជម្លៀសក្រុមដែលងាយរងគ្រោះថ្នាក់បំផុតដែលស្ថិតនៅក្នុងលក្ខខណ្ឌលំបាកខ្លាំងយ៉ាងនេះ ដូចដែលអង្គជំនុំជម្រះបានរៀបរាប់រួចមកហើយនោះ នឹងបណ្តាលឲ្យអ្នកទាំងនោះស្លាប់ ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាមានចេតនាក្នុងការធ្វើមនុស្សឃាត។

៥៥៩. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស្លាប់របស់ជនរងគ្រោះ ដែលត្រូវបានបាញ់ និងត្រូវបានសម្លាប់នៅក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ ក៏ដូចជាអ្នកដែលបានស្លាប់ដោយសារតែលក្ខខណ្ឌផ្សេងៗ និងការខ្វះការផ្តល់ជំនួយ គឺជាការធ្វើមនុស្សឃាត។

### ១០.៤.៣ ការសម្លាប់រង្គាល

៥៦០. អង្គជំនុំជម្រះយល់ឃើញថា ការស្លាប់របស់ជនរងគ្រោះ ដែលត្រូវបានគេបាញ់ និងសម្លាប់នៅក្នុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ (លើកលែងតែអ្នកដែលបានស្លាប់ខណៈពេលមានការវាយប្រយុទ្ធគ្នា) ក៏ដូចជាអ្នកដែលបានស្លាប់ដោយសារតែលក្ខខណ្ឌផ្សេងៗ និងការខ្វះការផ្តល់ជំនួយនៅក្នុងអំឡុងពេលនៃការធ្វើដំណើររបស់ពួកគាត់ទៅកាន់ភូមិកំណើត គឺជាការធ្វើមនុស្សឃាត[១៦៧០]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនអាចកំណត់បាន ថាតើមានជនរងគ្រោះប៉ុន្មាននាក់ដែលបានស្លាប់ដោយសារតែការសម្លាប់ និងប៉ុន្មាននាក់ទៀតបានស្លាប់ដោយសារតែលក្ខខណ្ឌដែលត្រូវបានរៀបចំសម្រាប់ពេលធ្វើដំណើរនោះ ហើយដោយផ្អែកទៅលើភស្តុតាងទាំងអស់ដែលអង្គជំនុំជម្រះមានដែលបង្ហាញពីការស្លាប់ ដែលបានកើតមានក្នុងអំឡុងពេលធ្វើដំណើរនោះ ជារួម អង្គជំនុំជម្រះ

---

[១៦៦៨] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៥។

[១៦៦៩] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៧។

[១៦៧០] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៩។

យល់ឃើញថា ធាតុផ្សំនៃទំហំដែលត្រូវបានកំណត់ចំពោះបទល្មើសនៃការសម្លាប់រង្គាលត្រូវបានបំពេញហើយ។

៥៦១. ក្រោយពីបានកំណត់ថា ការធ្វើមនុស្សឃាតដែលបានរៀបរាប់ខាងលើ បានបំពេញលក្ខខណ្ឌស្ដីពីទំហំនៃបទល្មើសការសម្លាប់រង្គាល នាពេលនេះ អង្គជំនុំជម្រះពិនិត្យទៅលើចេតនារបស់ចារី។ ពាក់ព័ន្ធនឹងការសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណក្រោយពីការឆែកឆេរនៅក្នុងទីក្រុងភ្នំពេញ នៅតាមប៉ុស្តិ៍ត្រួតពិនិត្យ ឬ បន្ទាប់ពីការប្រកាសតាមវិទ្យុនោះ អង្គជំនុំជម្រះអាចធ្វើការសន្និដ្ឋានបានដោយសមហេតុផល ដោយផ្អែកទៅលើភ័ស្តុតាងដែលបញ្ជាក់ថា មានប្រតិបត្តិការទ្រង់ទ្រាយធំ មានការរៀបចំ និងគិតទុកជាមុន ដើម្បីសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទោះបីជាមិនមែនថាមន្ត្រីរដ្ឋការទាំងអស់បានជួបប្រទះជោគវាសនាបែបនេះដូចគ្នាក៏ដោយ ។ ដោយយោងទៅលើប្រតិបត្តិការទ្រង់ទ្រាយធំនេះ អង្គជំនុំជម្រះជឿជាក់ថា កងទ័ពខ្មែរក្រហមមានចេតនាសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងទ្រង់ទ្រាយធំ ហើយតាមរយៈអំពើទាំងនេះ ពួកគេបានប្រព្រឹត្តការសម្លាប់រង្គាល។

៥៦២. ពាក់ព័ន្ធនឹងជនរងគ្រោះដែលបានស្លាប់ដោយសារតែលក្ខខណ្ឌលំបាកផ្សេងៗ ដែលតម្រូវឲ្យមាននៅក្នុងពេលជម្លៀស អង្គជំនុំជម្រះយល់ឃើញថា កងទ័ពខ្មែរក្រហមបានប្រព្រឹត្តដោយមាន *ចេតនាដោយមិនចំពោះ*[១៦៧១]។ ដោយប្រើប្រាស់សំអាងហេតុដូចគ្នានេះដែរ ដែលបានកំណត់រួចមកហើយទាក់ទងនឹងចេតនារបស់ចារីចំពោះបទល្មើសនៃការធ្វើមនុស្សឃាត និងដោយបានពិចារណាទៅលើទំហំប្រតិបត្តិការជម្លៀសនេះ និងការកំណត់គោលដៅចំពោះប្រជាជននៅទីក្រុងភ្នំពេញទាំងអស់នាពេលនោះ ដែលមានចំនួនយ៉ាងហោចណាស់ ២.០០០.០០០ នាក់ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថាក្នុងការអនុវត្តការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមមានចេតនាបង្កើតលក្ខខណ្ឌនៃការរស់នៅ ដែលបណ្ដាលឲ្យមានការស្លាប់ ដោយមានការដឹងគ្រប់គ្រាន់ថា អំពើសកម្មឬ អកម្មបែបនេះ ទំនងជានឹងបណ្ដាលឲ្យមានមនុស្សស្លាប់ជាច្រើន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា តាមរយៈអំពើទាំងនេះ ពួកគេបានប្រព្រឹត្តការសម្លាប់រង្គាល។

---

[១៦៧១] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៦-៥៥៨។

### ១០.៤.៤ អំពើអមនុស្សធម៌ផ្សេងៗទៀតដែលជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ

៥៦៣. យ៉ាងហោចណាស់ ក៏មានប្រជាជននៅទីក្រុងភ្នំពេញចំនួន ២.០០០.០០០ នាក់ដែរ ដែលត្រូវបានកងទ័ពខ្មែរក្រហមបណ្ដេញចេញពីផ្ទះសម្បែងរបស់ខ្លួនដោយភ្លង់កាំភ្លើង ដោយស្ទើរតែគ្មានការប្រាប់ជាមុន និងនៅក្នុងកាលៈទេសៈគួរឲ្យភ័យរន្ធត់និងប្រកបដោយហិង្សា[១៦៧២]។ ប្រជាជនទាំងនោះត្រូវបានបង្ខំឲ្យបោះបង់ចោលផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ខ្លួន ក្រោមការបោកបញ្ឆោតថា ពួកគេនឹងបានវិលត្រឡប់មកវិញនៅក្នុងរយៈពេល៣ថ្ងៃខាងមុខ[១៦៧៣]។ ប្រជាជនភាគច្រើនបានមើលឃើញផ្ទាល់នឹងភ្នែក នូវការវាយដំ ការបាញ់ប្រហារ និងការសម្លាប់ ព្រមទាំងបានឃើញសាកសពរាប់មិនអស់នៅតាមផ្លូវ នៅពេលពួកគាត់ចាកចេញពីទីក្រុងភ្នំពេញ[១៦៧៤]។ ប្រជាជនខ្លះបានដេកនៅក្បែរសាកសពទៀតផង[១៦៧៥]។

៥៦៤. ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀសទាំងនោះ ត្រូវបានគេកត់សម្គាល់ឃើញថាស្ទើរតែគ្មានស្បៀងអាហារ ទឹក ថ្នាំពេទ្យ ជម្រក និងសម្ភារៈអនាម័យ ទាល់តែសោះ នៅក្នុងអំឡុងពេលជាច្រើនថ្ងៃ ទៅច្រើនសប្ដាហ៍នោះ[១៦៧៦]។ រួមផ្សំនឹងកំដៅថ្ងៃខ្លាំងបំផុតផង និងដោយត្រូវបានគេបោកបញ្ឆោតឲ្យជឿថា ពួកគាត់នឹងចេញទៅតែក្នុងរយៈពេល៣-៤ថ្ងៃនោះ អ្នកដែលត្រូវបានជម្លៀសជាច្រើននាក់ បានចាកចេញដោយមិនបានរៀបចំអ្វី និងត្រូវបានគេបង្ខំឲ្យរកស្បៀងអាហារ និងកន្លែងស្នាក់អាស្រ័យ នៅក្នុងស្ថានភាពដ៏លំបាកនេះ[១៦៧៧]។ ជាពិសេស អ្នកជំងឺ អ្នករបួស ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ និងក្មេងៗ បានទទួលរងការលំបាក ហើយជនរងគ្រោះរាប់មិនអស់ត្រូវទ្រាំទ្រនឹងស្ថានភាពដែលមិនអាចស៊ូទ្រាំបានទាំងនោះ នៅគ្រប់ពេលក្នុងអំឡុងពេលនៃការធ្វើដំណើរនេះ។ ប្រជាជនជាច្រើនក៏ត្រូវបានគេបង្ខំឲ្យកប់សាកសពកូនៗរបស់ពួកគេនៅក្នុងព្រៃ ឬ ឲ្យ

---

[១៦៧២] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៤, ៤៦៨, ៤៧១-៤៧៤។

[១៦៧៣] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៥-៤៦៦។

[១៦៧៤] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៣-៤៧៤, ៤៨៦, ៤៨៩-៤៩១, ៤៩៧-៤៩៨។

[១៦៧៥] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៨។

[១៦៧៦] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៧-៤៨៨, ៤៩១, ៤៩៥-៤៩៦។

[១៦៧៧] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៦, ៤៨៧-៤៨៨។

បោះបង់ចោលសមាជិកគ្រួសារដែលមានជំងឺ ឬ ចាស់ជរា នៅតាមផ្លូវ ដែលប្រឈមនឹងការស្លាប់ជាមិនខាន[១៦៧៨]។ លើសពីនេះទៀត ប្រជាជនជាច្រើននៅតែមិនដឹងអំពីជោគវាសនារបស់សមាជិកគ្រួសាររបស់គេដែលត្រូវបានយកចេញទៅបាត់នោះ[១៦៧៩]។

៥៦៥. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា កាលៈទេសៈដែលប្រកបដោយហិង្សានៅជុំវិញការជម្លៀសប្រជាជនចេញពីទីក្រុង លក្ខខណ្ឌដ៏លំបាកទាំងឡាយដែលអ្នកត្រូវបានជម្លៀសបានជួបប្រទះដែលកាន់តែមានភាពធ្ងន់ធ្ងរដោយសារតែរយៈពេលនៃការធ្វើដំណើររបស់ពួកគាត់ទៅកាន់ស្រុកកំណើតរបស់ខ្លួន និងការធ្វើបាបមកលើពួកគាត់ពីសំណាក់កងទ័ពខ្មែរក្រហម នៅគ្រប់ពេលក្នុងអំឡុងពេលធ្វើដំណើរនេះ បានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងបានបណ្តាលឱ្យជនរងគ្រោះទទួលរងព្យសនកម្មធ្ងន់ធ្ងរទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត[១៦៨០]។ លើសពីនេះទៀត យោងទៅលើលក្ខណៈនៃការរៀបចំជាមុន ជាប្រព័ន្ធ ទំហំ និងរយៈពេលនៃប្រតិបត្តិការនេះ អង្គជំនុំជម្រះក៏ជឿជាក់ថា អំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា។ អង្គជំនុំជម្រះជឿជាក់ថា អំពើដែលត្រូវបានលើកឡើងខាងលើ មានកម្រិតធ្ងន់ធ្ងរដែលជាបទល្មើសផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា កម្មាភិបាល និងកងទ័ពខ្មែរក្រហម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

### ១០.៤.៥ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៥៦៦. អំពើជាក់លាក់មួយចំនួនដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញ ត្រូវតែមានការចោទប្រកាន់យ៉ាងច្បាស់លាស់[១៦៨១]។ នៅក្នុងការសម្រេចថាតើលក្ខខណ្ឌនេះត្រូវបានបំពេញ ឬ យ៉ាងណានោះ អង្គជំនុំជម្រះនឹងពិចារណាទៅលើការសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងផ្នែកពាក់ព័ន្ធ

[១៦៧៨] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩២, ៤៩៧-៤៩៨។

[១៦៧៩] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១១, ៥១៣-៥១៤។

[១៦៨០] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២២-៥២៤។

[១៦៨១] *សូមមើល*ផ្នែកទី៩, ច្បាប់ជាធរមានៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ៤៣១។

នានានៃដីកាដំណោះស្រាយ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១[១៦៨២]។

៩៦៧. យោងទៅលើដីកាដំណោះស្រាយ ខ្មែរក្រហមបានប្រព្រឹត្តការធ្វើទុក្ខបុកម្នេញតាមមធ្យោបាយជាច្រើន មកលើនាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់ ដោយសារអ្នកទាំងនោះត្រូវបានដកចេញជាស្វ័យប្រវត្តិពីគោលបំណងនៃការកសាងសង្គមនិយម ដោយប្រឆាំងមកលើមន្ត្រីជាន់ទាបដែលត្រូវបានចាប់ខ្លួន ហើយជារឿយៗត្រូវបានសម្លាប់ចោល និងប្រឆាំងមកលើ "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ដោយសារតែអ្នកទាំងនោះត្រូវបានកំណត់ជាគោលដៅដើម្បីធ្វើការអប់រំកែប្រែ។ នៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជននេះ ខ្មាំងពិតប្រាកដ ឬ បុគ្គលដែលត្រូវបានសន្មតថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានកំណត់ជាគោលដៅដោយការធ្វើបាប និងលក្ខខណ្ឌរស់នៅយ៉ាងលំបាកវេទនា ដើម្បីអប់រំកែប្រែពួកគាត់ឡើងវិញ ឬ កំណត់អត្តសញ្ញាណថាជាខ្មាំងនៅក្នុងចំណោមក្រុមគោលដៅជាក់លាក់មួយចំនួន[១៦៨៣]។

៩៦៨. យោងតាមការអានដីកាដំណោះស្រាយជារួម អង្គជំនុំជម្រះយល់ឃើញថា អំពើផ្សេងៗដែលត្រូវបានចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានអនុវត្តតាមរយៈឧក្រិដ្ឋកម្មមួយចំនួន។ ការដកចេញមន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានធ្វើឡើងតាមរយៈការធ្វើមនុស្សឃាត[១៦៨៤]។ លើសពីនេះទៀត ការចាប់ខ្លួន[១៦៨៥] និងការសម្លាប់មន្ត្រី

---

[១៦៨២] អង្គជំនុំជម្រះគួរតែពិចារណាទៅលើដីកាចោទប្រកាន់ទាំងមូល នៅក្នុងការសម្រេចថាតើវាមានអំណះអំណាងគ្រប់គ្រាន់ចំពោះអង្គហេតុ និងការកំណត់បទល្មើសទាំងនោះដែរ ឬ យ៉ាងណា៖ សាលដីកាក្នុងសំណុំរឿង Seromba កថាខណ្ឌ ២៧។ សាលដីកាក្នុងសំណុំរឿង Gacumbitsi កថាខណ្ឌ ១២៣។

[១៦៨៣] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧-១៤១៨។

[១៦៨៤] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៨ (ការប្រកាសជាសាធារណៈនាខែ កុម្ភៈ ឆ្នាំ ១៩៧៥ អំពីចេតនាក្នុងការសម្លាប់ឥស្សរជនជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ បន្ទាប់ពីបានទទួលជ័យជម្នះ ត្រូវបានបន្តធ្វើបន្ទាប់ពីថ្ងៃ ១៧ មេសា ១៩៧៥ បន្ទាប់ពីមានសេចក្តីសម្រេចសម្ងាត់មួយឲ្យសម្លាប់មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និង "*សម្រេចធ្វើយ៉ាងម៉េចកុំឲ្យពួកហ្នឹងវាងើបឡើងប្រឆាំងបដិវត្តបាន*" កថាខណ្ឌ ២០៩ (ក្នុងពេលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជាពិសេសមន្ត្រីជាន់ខ្ពស់ ត្រូវបានគេកំណត់មុខសញ្ញាដើម្បីចាប់ខ្លួន និងសម្លាប់ចោល) កថាខណ្ឌ ១១០៨ (លើកឡើងពីសមាជជាតិលើកទីពីរ ដែលសមាជនោះបានអំពាវនាវឲ្យសម្លាប់ "*ជនក្បត់ ៧ រូបនៅក្នុងទីក្រុងភ្នំពេញ*") កថាខណ្ឌ ១១១០ (និយាយអំពីការសម្លាប់ ឡុង បូរេត និង សិរិមតៈ) កថាខណ្ឌ ១១១៣ (នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៨៦ អៀង សារី បាននិយាយនៅក្នុងបទសម្ភាសន៍មួយថា គាត់មិនបានដឹងឮអ្វីទាំងអស់អំពីផែនការសម្លាប់ទាហាន ព្រមទាំងមន្ត្រីរដ្ឋការ លន់ នល់ ក្នុងអំឡុងពេលមានការជម្លៀសអ្នកទាំងនោះចេញពីភ្នំពេញ) កថាខណ្ឌ ១១៥០ (ខ្លឹមសារនៅក្នុងសុន្ទរកថារបស់ ខៀវ សំផន និងឯកសារ ដទៃទៀត រួមមាន ការ

រដ្ឋការជាន់ទាបនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានអនុវត្តតាមរយៈការធ្វើមនុស្សឃាត និង/ឬ ការសម្លាប់រង្គាល[១៦៨៦]។ ជាចុងក្រោយ ការធ្វើបាបយ៉ាងខ្លាំងមកលើ "ប្រជាជនថ្មី" ដែលត្រូវបានចាត់ទុកថាជាការអប់រំកែប្រែ ត្រូវបានអនុវត្តតាមរយៈការជម្លៀសដោយបង្ខំ[១៦៨៧] និងការប្រព្រឹត្តការធ្វើមនុស្សឃាត និង/ឬ ការសម្លាប់រង្គាល[១៦៨៨] ឬ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[១៦៨៩]។

---

ផ្តួលរំលំពួកក្បត់ លន់ នល់ និងការកម្ចាត់សមាជិកមួយចំនួននៃរបបនេះ) កថាខណ្ឌ ១១៥៨ (លើកឡើងអំពីសេចក្តីប្រកាសព័ត៌មានមួយតាងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ដោយបានប្រកាសថា "ពួកក្បត់ទាំង៧នៅទីក្រុងភ្នំពេញ ... លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរេត និង *Sosthene Fernandez*" ត្រូវសម្លាប់ចោល កថាខណ្ឌ ១១៩៣ (ដូចគ្នា)។

[១៦៨៥] ដីកាដំណោះស្រាយ កថាខណ្ឌ ២៣៤ (បានលើកឡើងថា ទាហាន លន់ នល់ ខ្លះទៀតត្រូវបានកំណត់អត្តសញ្ញាណដោយការសួរចម្លើយ និងត្រូវបានបំបែកចេញពីប្រជាជនដែលចាកចេញពីទីក្រុង ... ទាហាន លន់ នល់ មន្ត្រីរដ្ឋការ និងមន្ត្រីនគរបាលដែលស្នើឲ្យណែនាំខ្លួនដើម្បីធ្វើការបំរើបក្ស បន្ទាប់មក ត្រូវបានយកទៅកាន់កន្លែងដែលគ្មាននរណាដឹងមុន នឹងបាត់ខ្លួន)។

[១៦៨៦] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៨ (ការប្រកាសជាសាធារណៈនាខែ កុម្ភៈ ឆ្នាំ ១៩៧៥ អំពីចេតនាក្នុងការសម្លាប់ឥស្សរជនជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរបន្ទាប់ពីបានទទួលជ័យជម្នះ ត្រូវបានបន្តធ្វើក្រោយថ្ងៃ ១៧ មេសា ១៩៧៥ បន្ទាប់ពីមានសេចក្តីសម្រេចសម្ងាត់មួយឲ្យសម្លាប់មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និង *"សម្រេចធ្វើយ៉ាងម៉េចកុំឲ្យពួកហ្នឹងវាងើបឡើងប្រឆាំងបដិវត្តបាន"*) កថាខណ្ឌ ២០៩(ក្នុងពេលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជាពិសេសមន្ត្រីជាន់ខ្ពស់ ត្រូវបានគេកំណត់មុខសញ្ញាដើម្បីចាប់ខ្លួន និងសម្លាប់ចោល) កថាខណ្ឌ ២៣៥ (សាក្សីខ្លះបាននិយាយថា ពួកគាត់បានមើលឃើញការសម្លាប់ទាហាន លន់ នល់ និងបានឃើញសាកសពទាហាន លន់ នល់ នៅតាមផ្លូវ)។

[១៦៨៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១ (គោលដៅមួយក្នុងចំណោមគោលដៅទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជនគឺក្នុងគោលបំណងនៃការដកហូតសិទ្ធិនយោបាយ និងសេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងអតីតអ្នករដ្ឋការ និងដើម្បីប្រែក្លាយពួកគេឲ្យទៅជាកសិករ)កថាខណ្ឌ២២៧(ប្រជាជនដែលមកពីភ្នំពេញត្រូវបានផ្តល់អត្តសញ្ញាណថាជា ប្រជាជនថ្មី ឬ ប្រជាជន ១៧ មេសា ឬ ក៏ជាប្រជាជនបញ្ញើ ហើយត្រូវបានកំណត់ជាមុខសញ្ញានៅពេលមកដល់ដោយផ្អែកលើអត្តសញ្ញាណនេះ) កថាខណ្ឌ ២៤៨ (អៀង សារី បាននិយាយថា វាជាការចាំបាច់ដើម្បីលត់ដំប្រជាជនដែលមកពីទីក្រុង ឲ្យស៊ូទ្រាំនឹងការលំបាកទាំងផ្លូវកាយ និងផ្លូវចិត្ត តាមរយៈពលកម្មធ្ងន់ធ្ងរ)។

[១៦៨៨] ដីកាដំណោះស្រាយ កថាខណ្ឌ ២៣២ (កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានបាញ់សម្លាប់ប្រជាជន ប្រសិនបើពួកគេបដិសេធមិនព្រមចាកចេញពីផ្ទះ) ២៤០ (ប្រជាជនត្រូវបានគេសម្លាប់ដោយសារតែបញ្ហាតូចតាច ដូចជាមិនចង់បោះបង់ចោលកង់របស់ខ្លួន)។

[១៦៨៩] ដីកាដំណោះស្រាយ កថាខណ្ឌ ២៣១ (កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានជាប់ពាក់ព័ន្ធក្នុងការគំរាមកំហែង និងការប្រើប្រាស់កម្លាំងដើម្បីធ្វើឲ្យប្រាកដថា ប្រជាជនចាកចេញពីផ្ទះរបស់ខ្លួន) កថាខណ្ឌ ២៣៣ (មានការលើកឡើង

៩៦៩. ខ្មែរក្រហមបានកំណត់អត្តសញ្ញាណក្រុមមនុស្សមួយចំនួន ដែលគេបានចាត់ទុកថាជាខ្មាំង ឬ ជាឧបសគ្គ ចំពោះការខិតខំប្រឹងប្រែងសម្រេចរបៀបវារៈនយោបាយនៃកំណែទម្រង់សង្គមនិយម របស់ខ្លួន ជាពិសេសចំពោះនាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់ ដែលក្នុងចំណោមអ្នកទាំង នោះ មានជនក្បត់ ៧ នាក់ ដែលត្រូវបានពួកគេកំណត់អត្តសញ្ញាណជាសាធារណៈតាមវិទ្យុ ដោយ ប្រកាសថា ចាំបាច់ត្រូវតែប្រហារជីវិតអ្នកទាំងនោះ។ ហើយអ្នកមានតួនាទីនៅក្នុងអតីតនៃរបប សាធារណរដ្ឋខ្មែរ ទាំងទាហាន និងអ្នករដ្ឋការស៊ីវិល និងប្រជាជន ដែលរស់នៅក្នុងទីក្រុង ដែលគេ ហៅថាជា “ប្រជាជន ១៧ មេសា” ឬ “ប្រជាជនថ្មី” ក៏ស្ថិតនៅក្នុងចំណោមអ្នកទាំងនោះផងដែរ។ ដោយសារតែក្រុមមនុស្សទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ ហើយប្រវត្តិរូបរបស់អ្នកទាំងនោះអាចត្រូវបាន ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ដូចដែលបានបង្ហាញតាមរយៈប៉ុស្តិ៍ត្រួតពិនិត្យ និងការសួរចម្លើយចំពោះ ទាហាន និងមន្ត្រីរដ្ឋការស៊ីវិល នៅតាមផ្លូវនោះ អង្គជំនុំជម្រះជឿជាក់ថា ការកំណត់អត្តសញ្ញាណ ចំពោះក្រុមនីមួយៗអាចធ្វើបានដោយមានប្រសិទ្ធភាព។

៩៧០. អង្គជំនុំជម្រះយល់ឃើញថា ការសម្លាប់នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់ ដែល ត្រូវបានប្រកាសជាសាធារណៈថានឹងត្រូវធ្វើការប្រហារជីវិត មុនពេលចូលកាន់កាប់ទីក្រុងភ្នំពេញ គឺជាបទល្មើសនៃការធ្វើមនុស្សឃាត[១៦៥០]។ អង្គជំនុំជម្រះក៏បានយល់ឃើញដែរថា ការសម្លាប់មន្ត្រី ផ្សេងទៀតនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងពេល ឬ នៅក្រោយពេលកាន់កាប់ទីក្រុងភ្នំពេញ បង្កើតបានជាបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល (លើកលែងតែអ្នកដែលត្រូវ បានសម្លាប់ខណៈពេលមានការវាយប្រយុទ្ធគ្នា)[១៦៥១]។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញ ថា ការសម្លាប់ជនស៊ីវិលដែលរស់នៅទីក្រុងភ្នំពេញ ការជម្លៀសពួកគេដោយបង្ខំនិងការធ្វើទុក្ខបុក ម្នេញផ្សេងៗដែលប្រជាជនទទួលរងក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ (ការផ្លាស់ទីលំនៅ ប្រជាជន (ដំណាក់កាលទី១)) បង្កើតបានជាបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត រួមទាំង

---

ផងដែរ អំពីការធ្វើបាប និងការប្រើប្រាស់អំពើហិង្សាផ្សេងៗប្រឆាំងនឹងប្រជាជនស៊ីវិល ដូចជាការវាយដំ និងបាញ់ ឡើងលើ) កថាខណ្ឌ ២៣៩ (លើកឡើងពីការខ្វះចំណីអាហារ ទឹក សន្តិសុខ ការការពារ ជម្រក ឬ ថ្នាំសង្កូវ ឬ ការ ព្យាបាលនៅក្នុងពេលជម្លៀសនេះ) កថាខណ្ឌ ២៤០ (សាកសពមនុស្សនៅតាមផ្លូវ)។

[១៦៥០] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៣។

[១៦៥១] *សូមមើល*ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៣, ៥៦១។

ការជម្លៀសដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា ក្រោយពេលចូលមកដល់ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានចាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរជាច្រើននាក់ បើទោះបីជាក្រោយពេលដែលរបបសាធារណរដ្ឋខ្មែរបានប្រកាសចុះចាញ់ហើយក៏ដោយ។ ក្រោយមក ទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងនោះ ត្រូវបានគេឃុំខ្លួន ឬបាត់ខ្លួនតែម្តង ដោយគ្មានការពន្យល់អ្វីដល់សមាជិកក្រុមគ្រួសាររបស់ពួកគេនោះឡើយ ដែលនៅក្នុងករណីជាច្រើន សមាជិកគ្រួសារនៅតែមិនបានទទួលព័ត៌មានរហូតមកដល់សព្វថ្ងៃនេះ[១៦៥២]។ ពេលនេះ អង្គជំនុំជម្រះនឹងពិចារណា ថាតើអំពើដូចបានបញ្ជាក់ខាងលើ ពិតជាមានការរើសអើង និងត្រូវបានប្រព្រឹត្តដោយមានការគិតទុកជាមុន និងមានចេតនារើសអើងប្រឆាំងនឹងក្រុមមនុស្សទាំងនោះ និងដែលត្រូវបានចាត់ទុកផងដែរថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែរ ឬ យ៉ាងណា។

៥៧១. ដោយពិចារណាឃើញថា កងទ័ពខ្មែរក្រហមបានប្រឹងប្រែងស្វែងរកសមាជិកទាំងឡាយនៃរបបសាធារណរដ្ឋខ្មែរនៅទូទាំងទីក្រុងភ្នំពេញ នៅតាមប៉ុស្តិ៍ត្រួតពិនិត្យ តាមរយៈការប្រកាសតាមវិទ្យុ ដោយបោកបញ្ឆោតឱ្យទាហានទាំងនោះធ្វើការបង្ហាញខ្លួន មុនពេលធ្វើការចាប់ខ្លួន និងសម្លាប់ពួកគេចោល និងដោយឃើញថា ទាហានទាំងនោះត្រូវបានចាត់ទុកថាជាខ្មាំងនោះ[១៦៥៣] អង្គជំនុំជម្រះជឿជាក់ថា ការចាប់ខ្លួន និងការសម្លាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានប្រព្រឹត្តដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ ។ ដោយបានពិចារណាផងដែរ ទៅលើអាកប្បកិរិយារបស់ខ្មែរក្រហម និងកងទ័ពរបស់ខ្លួនចំពោះប្រជាជនទីក្រុង ភ័ស្តុតាងដែលបញ្ជាក់ពីការរើសអើងដែលថា ប្រជាជនទាំងនោះជាពួកមូលធននិយម ហើយដោយសារតែអ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវបានគេហៅឈ្មោះថាជា "ប្រជាជន ១៧ មេសា" ឬ "ប្រជាជនថ្មី" និងត្រូវបានគេធ្វើបាប ដោយសារតែមានការសង្ស័យនៅតាមភូមិនានា[១៦៥៤] នោះអង្គជំនុំជម្រះជឿជាក់ថា កងទ័ពខ្មែរក្រហមមានចេតនារើសអើងប្រឆាំងនឹងប្រជាជនទីក្រុងដែលត្រូវបានជម្លៀសដោយមូលហេតុនយោបាយ។ ផ្អែកទៅលើចំណុចនេះ អង្គជំនុំជម្រះយល់ឃើញថា

---

[១៦៥២] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៨, ៥១៣, ៥១៥។

[១៦៥៣] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៤ (លេខយោងជើងទំព័រ ១៥១១) ៥១១-៥១៥។

[១៦៥៤] *សូមមើល* ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៧។

កងទ័ពខ្មែរក្រហមបានប្រព្រឹត្តដោយមានចេតនារើសអើង នៅពេលធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

៥៧២. ជាការពិត អំពើដែលបានលើកឡើងខាងលើ ក៏មានលក្ខណៈរើសអើងផងដែរ ដោយសារតែជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យនានា នៅក្នុងអំឡុងពេលនៃការជម្លៀស ទាំងចំពោះមន្ត្រីជាន់ខ្ពស់ និងមន្ត្រីថ្នាក់ទាបនៃរបបសាធារណរដ្ឋខ្មែរ (ស៊ីវិល និងយោធា) ក៏ដូចជាប្រជាជនទីក្រុង។ លើសពីនេះទៀត ក្រុមដែលគេអាចស្គាល់អត្តសញ្ញាណទាំងនេះ ត្រូវបានខ្មែរក្រហមកំណត់ជាគោលដៅ ដោយសារតែការរើសអើង ដោយលើកឡើងថា ក្រុមទាំងនេះអាចផ្តល់ទីកន្លែងជ្រកកោន ដល់អ្នកដែលប្រឆាំងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដែលថា ដោយសារតែទិសដៅចុងក្រោយរបស់ខ្មែរក្រហម គឺត្រូវប្រព្រឹត្តមកលើប្រជាជនដូចៗគ្នានោះ ហេតុដូច្នេះ មិនមានការប្រព្រឹត្តិដែលខុសគ្នានោះទេ ដូច្នេះហើយ មិនមានការរើសអើង ឬ ការធ្វើទុក្ខបុកម្នេញឡើយ[១៦៥៥]។ ជាមួយនឹងសំអាងហេតុដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងក៏បដិសេធសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដែលថាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមិនមានការរើសអើងនោះទេ ហេតុដូច្នេះហើយ មិនអាចបង្កើតបានជាការធ្វើទុក្ខបុកម្នេញឡើយ[១៦៥៦]។

៥៧៣. អំពើនានាដែលត្រូវបានប្រព្រឹត្តមកលើក្រុមមនុស្សទាំងនេះ បានធ្វើឲ្យប៉ះពាល់ និងបានរំលោភទៅលើសិទ្ធិជាមូលដ្ឋាន និងសេរីភាពជាសារវ័ន្តដែលទាក់ទងនឹងការធ្វើដំណើរ[១៦៥៧]

---

[១៦៥៥] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧៦-២៨៨។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា) ទំព័រ ៧១។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៦-១២០។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន) ទំព័រ ៩៨-១០០។ ។

[១៦៥៦] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧៦-២៨៨។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៦-១២០។

[១៦៥៧] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៤៩។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៣។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃ

01006829



ទ្រព្យសម្បត្តិ[១៦៩៨] ក្រុមគ្រួសារ[១៦៩៩] អាយុជីវិត[១៧០០] សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន[១៧០១] សេរីភាព និង សន្តិសុខ[១៧០២] សេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ឬ ខុសច្បាប់[១៧០៣] ការទទួលបានការ

---

ការរើសអើងពូជសាសន៍ មាត្រា ៥(ឃ)(i)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១២ (១)។ ពិធីសារលេខ ៤ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ២។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ២២ (៥)។ *សូមមើលផងដែរ សាលដីកាក្នុងរឿងក្តី Stakić* កថាខណ្ឌ ៣១៧។

[១៦៩៨] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៣៣, ៥៣, ៩៧-៩៨, ១១៤។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៧(២)។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥(ឃ)(v)។ ពិធីសារលេខ ៤ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ១ ។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ២១។ *សូមមើលផងដែរ សាលដីកាក្នុងរឿងក្តី Blaškić* កថាខណ្ឌ ១៤៥។

[១៦៩៩] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ២៧, ៤៩, ៨២។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១២, ១៦។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៧, ២៣។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៨, ១២។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ១៧។

[១៧០០] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៣(១)(ក)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៣(១)(ក)។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥(ខ)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦។អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ២។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៤។ *សូមមើលផងដែរសាលដីកាក្នុងរឿងក្តី Kordić និង Čerkez* កថាខណ្ឌ ១០៦។

[១៧០១] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៣(១)(គ)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១, ២២, ២៣(៣)។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧, ១០។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៥-៦។ *សូមមើលផងដែរ សាលដីកាក្នុងរឿងក្តី Kordić និង Čerkez* កថាខណ្ឌ ១០៦។

[១៧០២] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៣(១)(ខ) (ដែលហាមឃាត់ការចាប់ធ្វើជាចំណាប់ខ្មាំង)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៣។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥(ខ)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(១)។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៥។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៧។

[១៧០៣] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៤២ (ដែលអនុញ្ញាតឲ្យមានការដកហូតសេរីភាពរបស់បុគ្គលដែលទទួលបានការការពារ តែក្នុងករណី ដែលបុគ្គលនោះបានបង្កការគំរាមកំហែងដល់សន្តិសុខរបស់ភាគីដែលបាត់បង់សិទ្ធិ)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

ជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ និងសមភាពនៅចំពោះមុខច្បាប់[១៧០៤] ដូចមានចែងនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ។

៩៧៤. អំពើដែលត្រូវបានចោទប្រកាន់ជាការធ្វើទុក្ខបុកម្នេញ រួមមាន បទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ដូចជា អំពើនានា ដែលអំពើទាំងនោះ មិនចាំបាច់បង្កើតបានជាបទល្មើស (ជាពិសេស ការចាប់ខ្លួន) នោះទេ ។ ដោយពិនិត្យមើលទៅលើអំពើទាំងនេះរួមគ្នា និងពិចារណាទៅលើបរិបទដែលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើង អង្គជំនុំជម្រះជឿជាក់ថា អំពើទាំងនោះឈានដល់កម្រិតធ្ងន់ធ្ងរដែលជាលក្ខខណ្ឌកំណត់ ដែលត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ករណីនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការចាប់ខ្លួន និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ត្រូវបានប្រព្រឹត្តតាមរូបភាពផ្សេងៗប្រឆាំងមកលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនទីក្រុង គឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

## ១១. ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)

៩៧៥. យោងតាមដីកាដំណោះស្រាយ ប្រហែលជានៅចន្លោះខែកញ្ញា ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ ប្រជាជនរាប់ពាន់នាក់ត្រូវបានផ្លាស់ទីលំនៅពីភូមិភាគ (ឧត្តរចាស់) កណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម[១៧០៥]) ទៅកាន់តំបន់ ១០៣ (ខេត្តព្រះវិហារ) តំបន់ ១០៦ (ខេត្តសៀមរាប) ភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ រួមទាំងខេត្តប៉ៃលិន និងខេត្ត

---

មាត្រា ៩។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(១)។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៥។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៧(៣)។

[១៧០៤] ចំពោះភ័ស្តុតាងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ មាត្រា ៣(១)(ឃ) (ដែលពាក់ព័ន្ធនឹងការចេញសេចក្តីសម្រេចផ្តន្ទាទោស និងការធានាផ្លូវតុលាករ)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា៦,១០។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥(ក)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(២)-(៤), ១៤។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៦ ។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៧(៦), ៨។

[១៧០៥] ការយោងទាំងអស់ទៅខេត្តកំពង់ចាមនៅក្នុងផ្នែកនេះ សំដៅទៅលើខេត្តនេះនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលរួមបញ្ចូលខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ នាពេលបច្ចុប្បន្ននេះ។ ខេត្តត្បូងឃ្មុំ ត្រូវបានកាត់ចេញពីខេត្តកំពង់ចាម ដោយព្រះរាជក្រឹត្យចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣។

បន្ទាយមានជ័យ (ក្នុងពេលបច្ចុប្បន្ន) ផងដែរ[១៧០៦]) និងភូមិភាគ (ឧត្តរចាស់) កណ្តាល (រួមទាំងទៅតំបន់ខ្លះនៃខេត្តកំពង់ធំ និងខេត្តកំពង់ចាម)[១៧០៧]។ ដីកាដំណោះស្រាយចោទប្រកាន់ទៀតថា ប្រជាជនក៏ត្រូវបានផ្លាស់ទីលំនៅពីភូមិភាគបូព៌ា ទៅកាន់ខេត្តក្រចេះ (តំបន់៥០៥) ឬ ផ្លាស់ទីលំនៅនៅក្នុងភូមិភាគបូព៌ា (ខេត្តព្រៃវែង និងខេត្តស្វាយរៀង) នៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងនៅក្នុងខេត្តបាត់ដំបងផងដែរ[១៧០៨]។ យោងតាមដីកាដំណោះស្រាយ មូលហេតុចម្បងក្នុងការសម្រេចផ្លាស់ទីលំនៅប្រជាជន គឺដើម្បីព្យាយាមប្រមូលកម្លាំងពលកម្មឱ្យមកផ្តោតសំខាន់លើកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ទាំងនោះ ជាពិសេស នៅក្នុងភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ ដែលជាញឹកញាប់ត្រូវបានគេចាត់ទុកថាជាតំបន់ដែលដីមានជីជាតិ និងសម្បូរអាហារជាងតំបន់ផ្សេងទៀត[១៧០៩]។ លើសពីនេះទៀតដីកាដំណោះស្រាយក៏ចោទប្រកាន់ផងដែរថា“ប្រជាជនថ្មី” ត្រូវបានផ្លាស់ទីលំនៅដើម្បីប្រែក្លាយពួកគេឱ្យទៅជាកសិករ[១៧១០]។ ចុងក្រោយ ដីកាដំណោះស្រាយចោទប្រកាន់ថា “ប្រជាជនថ្មី” ត្រូវបានផ្លាស់ទីលំនៅពីតំបន់នៅតាមព្រំដែនរវាងភូមិភាគបូព៌ា និងប្រទេសវៀតណាម ក្រោយពីសង្គ្រាមបានផ្ទុះឡើងនៅក្នុងឆ្នាំ ១៩៧៥ ឬ ឆ្នាំ ១៩៧៦[១៧១១]។

## ១១.១ ទិដ្ឋភាពទូទៅ

៥៧៦. ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ការការពារ និងកសាងប្រទេស បានក្លាយជាមាគ៌ាចម្បងរបស់បក្ស[១៧១២]។ បក្សបានផ្តោតសំខាន់លើការកសាង និងការពង្រីកសហករណ៍ ក្នុង

---

[១៧០៦] ខេត្តបន្ទាយមានជ័យមិនត្រូវបានកាត់ចេញពីខេត្តបាត់ដំបង រហូតដល់ឆ្នាំ ១៩៨៨។ បន្ថែមពីលើនេះ ខេត្តប៉ៃលិនមិនត្រូវបានកាត់ចេញពីខេត្តបាត់ដំបងរហូតដល់ឆ្នាំ ១៩៩៦។ ការយោងទាំងអស់ទៅលើខេត្តបាត់ដំបងនៅក្នុងផ្នែកនេះសំដៅទៅលើខេត្តនេះនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (ដោយរួមបញ្ចូលខេត្តបាត់ដំបង ខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ)។

[១៧០៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣, ២៦២, ១៤៤៨។

[១៧០៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣, ២៦៣, ១៤៤៨។

[១៧០៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១, ១៦៥, ២៧៦-២៧៧, ១៤៦០។

[១៧១០] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១, ១៦៥, ២៧៧, ១៤៦០។

[១៧១១] ដីកាដំណោះស្រាយ កថាខណ្ឌ ២៧៨។

[១៧១២] ប្រតិចារិក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៦-១៨ (ដំណាក់កាលបដិវត្តលើកទី២ គឺជាដំណាក់កាលបដិវត្តសង្គមនិយម និងការកសាងរបបកុម្មុយនីស្ត)។ ប្រតិចារិក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ៤១-៤៣ (មេដឹកនាំចង់ប្រមូលកងកម្លាំងជាតិរួមមួយដើម្បីរារាំងការឈ្លានពានមកលើប្រទេសកម្ពុជា និងដើម្បីរំដោះប្រទេសកម្ពុជាពីពួកចក្រពត្តិ)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/729 ចុះខែ តុលា ឆ្នាំ

01006832



គោលបំណងឲ្យការតស៊ូវណ្ណៈ ពោលគឺ "ភាពផ្តាច់ការនៃវណ្ណៈអធន" និងការបង្កបង្កើនផលកសិកម្មរីកចម្រើនលឿនទៅមុខដើម្បីធានាបាននូវបដិវត្តន៍សង្គមនិយម[១៧១៣]។ ដើម្បីកសាង និងពង្រីកសហករណ៍ឲ្យបាននោះ បក្សត្រូវផ្លាស់ទីលំនៅប្រជាជន។ ថ្នាក់ដឹកនាំបក្សមានជំនឿថា ការផ្លាស់ទីលំនៅប្រជាជន អនុញ្ញាតឲ្យបក្សអាចជម្នះលើបញ្ហាប្រឈមនានាក្នុងការកសាង និងការពារប្រទេស និងក្នុងការរៀបចំប្រជាជន សេដ្ឋកិច្ច នយោបាយ និងយោធាឡើងវិញ[១៧១៤]។

---

១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00063399-00063400 (គោលបំណងថ្មីចំនួន២របស់បក្សក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គឺដើម្បីកសាង និងការពារប្រទេសជាតិ)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/734 ចុះខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ១-៥ ERN (ភាសាខ្មែរ) 00064118-00064120 (ចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៥ បក្សមានគោលបំណងថ្មីពីរ៖ ការការពារ និងការកសាងប្រទេស)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥០-៥១។

[១៧១៣] សេចក្តីសម្រេចចិត្តរបស់សន្និបាតគណៈកម្មាធិការបក្សគ្រប់កងពល ឯកសារ E3/790 ថ្ងៃទី ១០-១៤ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00441995-00441996 (ទាក់ទិននឹងការបន្តអនុវត្តផែនការរបស់បក្សឆ្នាំ ១៩៧៦ នៅ ខែកក្កដា ឆ្នាំ ១៩៧៦ សេចក្តីសម្រេចបានគូសបញ្ជាក់ថា ការតស៊ូលុបបំបាត់ចោលផ្នែកសេសសល់នៃកម្មសិទ្ធិឯកជនទាំងអស់របស់ពួកសក្តិភូមិ ពួកមូលធន អនុធន និងវណ្ណៈមិនមែនអធនផ្សេងទៀត លើកកម្ពស់ និងពង្រឹងការបង្កបង្កើនផលកសិកម្ម ការកសាង និងការការពារជាតិ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៣២-៣៣ (នៅខែ ឧសភា ឆ្នាំ ១៩៧៥ បក្សបានបង្គាប់ឲ្យបង្កើតសហករណ៍នៅខាងក្រៅភូមិភាគរំដោះ)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ១១១-១១២ ERN (ភាសាខ្មែរ) 00063177-00063178 (ភាពផ្តាច់ការនៃវណ្ណៈពលករ ត្រូវបានអនុវត្តចំពោះជនទាំងឡាយដែលប្រឆាំងនឹងបក្ស)។ *សូមមើលផងដែរ* ផ្នែកទី៣, បរិបទប្រវត្តិសាស្រ្ត, កថាខណ្ឌ ១១៣។ ផ្នែកទី៤, ទិដ្ឋភាពទូទៅ: កថាខណ្ឌ ១៦៩។

[១៧១៤] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ២១-២២ ERN (ភាសាខ្មែរ) 00062756-00062757 ; ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានចុងក្រោយរបស់ នួន ជា) ទំព័រ ២២-២៣ (ការជម្លៀសគឺចាំបាច់ដើម្បីធានាសុវត្ថិភាព និងរំដោះប្រជាជនចេញពីទាសភាព និងភាពអយុត្តិធម៌)។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ឯកសារ E3/13 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ០៦ ERN (ភាសាខ្មែរ) 00052407 (ប្រសិនបើបក្សចាកចោលប្រជាជន និងមិនបានជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន បក្សនឹងមិនមានសន្តិភាព ហើយក្រោយមកប្រជាជននឹងទទួលបានភាពស្ងប់ស្ងាត់។ ប្រសិនបើបក្សមិនដាច់ខាតក្នុងការបង្កើត សហករណ៍ និងមិនដាច់ខាតក្នុងការបង្កើតសង្គមនិយម យើងនឹងមិនបានទទួលជោគជ័យ និងរស់នៅដោយសុខ សន្តិភាពនោះទេ)។ ទូរលេខរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅប្រទេសកម្ពុជា៖ ទស្សនកិច្ចផ្លូវការរបស់លោក ប៉ុល ពត នៅចិន និងកូរ៉េខាងជើង ឯកសារ E3/484 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ៨ ERN(ភាសាខ្មែរ)00797662 (រាយការណ៍ថា ប៉ុល ពត បានលើកឡើងអំពីការជម្លៀសប្រជាជនពីខេត្តក្រុង ហើយការជម្លៀសត្រូវបានធ្វើឡើងនៅសរទរដូវ ឆ្នាំ១៩៧៥ គឺដើម្បីបំបែកអង្គការចារកម្ម)។

៥៧៧. គោលនយោបាយរបស់បក្សពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទនានា ដែលត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងយុទ្ធនាការឃោសនានៅក្នុងវគ្គរៀនសូត្រ និងនៅក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្ស ដើម្បីធ្វើឲ្យការអនុវត្តមានភាពតឹងរ៉ឹង និងមានប្រសិទ្ធភាព។ នៅរៀងរាល់៣ ខែ ទៅ ៦ ខែម្តង ថ្នាក់ដឹកនាំបក្សបានបោះពុម្ពផ្សាយគោលនយោបាយ ផែនការ និងការណែនាំរបស់បក្សចំពោះសមាជិករបស់ខ្លួននៅក្នុង*ទស្សនាវដ្តីទង់បដិវត្ត និងទង់យុវជន និងយុវនារីបដិវត្ត*[១៧១៥]។ លើសពីនេះទៀត មេដឹកនាំ និងតំណាងបក្សរួមទាំង ប៉ុល ពត និង នួន ជា បានធ្វើដំណើរទៅទូទាំងប្រទេសដើម្បីផ្សព្វផ្សាយមាគ៌ារបស់បក្សដល់លេខាភូមិភាគ និងតំបន់ សមាជិកសភា និងគណៈកម្មាធិការនានា[១៧១៦]។ មានការជួបប្រជុំរវាងលេខាស្រុក និងលេខាតំបន់ជាមួយនឹងតំណាងនានានៅក្នុងទីក្រុងភ្នំពេញផងដែរ ដើម្បីពិភាក្សាអំពីបញ្ហាពាក់ព័ន្ធនឹងភាពចាំបាច់ក្នុងការកសាង និងការពារប្រទេស[១៧១៧]។ នៅថ្នាក់មូលដ្ឋានវិញ កិច្ចប្រជុំ វគ្គរៀនសូត្រ និងវគ្គទិតៀនស្វ័យទិតៀនត្រូវបានរៀបចំឡើងយ៉ាងទៀងទាត់ ដើម្បីធ្វើយ៉ាង

---

[១៧១៥] *សូមមើល*ផ្នែកទី៦, រចនាសម្ព័ន្ធទំនាក់ទំនងការងារ, កថាខណ្ឌ ២៦១-២៦៦។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/743 ខែ កក្កដា ឆ្នាំ ១៩៧៧ ទំព័រ ៤២ ERN (ភាសាខ្មែរ) 00062903 (ជាការសំខាន់ណាស់ក្នុងការយកចិត្តទុកដាក់លើការផ្សព្វផ្សាយគោលនយោបាយឲ្យបានល្អ ដើម្បី "បំផុសចេញជាចលនាខ្លាំងក្លា" ត្រឹមត្រូវតាមមាគ៌ារបស់បក្ស)។

[១៧១៦] *សូមមើល*ផ្នែកទី៦, រចនាសម្ព័ន្ធទំនាក់ទំនងការងារ, កថាខណ្ឌ ២៦៩-២៩៧។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ៥៧-៥៩; ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ១៦-១៧ (ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អឿន តាន ដែលជាអង្គរក្សរបស់ប៉ុល ពត បានអមដំណើរ ប៉ុល ពត នៅពេលធ្វើទស្សនកិច្ចទៅកាន់ព្រែកជីក និងវាលស្រែនៅខេត្តបាត់ដំបង កំពង់ចាម និងសៀមរាប។ ប៉ុល ពត បានជួបជាមួយគណៈតំបន់នៅពេលធ្វើទស្សនកិច្ចទាំងនេះ)។ ប្រតិចារឹក ថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទឿង) ទំព័រ ៣១-៣៣, ៣៩-៤៦, ៥៥-៦០ (សូត្រ ទឿង ដែលជាអង្គរក្ស និងជានីរសាររបស់ នួន ជា នៅចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ បានផ្តល់សក្ខីកម្មថា នួន ជា បានធ្វើដំណើរទៅកាន់ខេត្តមួយចំនួនដើម្បីធ្វើជាអធិបតីក្នុងកិច្ចប្រជុំ និងបណ្តុះបណ្តាកម្មាភិបាល ។ ជាញឹកញាប់ គាត់បានធ្វើដំណើរទៅកាន់ទំនប់ទឹក និងការដ្ឋានផ្សេងទៀត ឧទាហរណ៍ ទំនប់ ១ មករា ដែលជាទំនប់នៅទន្លេជីនិត វាលស្រែនៅខេត្តកំពង់ឆ្នាំង និងកន្លែងផ្សេងទៀត។ នួន ជា បានជួបជាប្រចាំជាមួយ តា ម៉ុក នៅខេត្តតាកែវ សោ ភឹម នៅភូមិភាគបូព៌ា និង តា ញឹម (រស់ ញឹម) នៅក្បែរក្រុងបាត់ដំបង ព្រមទាំងមេដឹកនាំតំបន់ផ្សេងទៀត)។

[១៧១៧] ប្រតិចារឹក ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ (ស្មីវ ហេងឆ័រ) ទំព័រ ៧៥-៧៨ (នៅចន្លោះខែ ឧសភា និងខែ មិថុនា ឆ្នាំ១៩៧៥ មានកិច្ចប្រជុំលេខាស្រុក និងលេខាតំបន់ និងតំណាងកងកម្លាំង និងកងផ្សេងៗទៀតទាំងអស់ដែលក្នុងខណៈនោះ នួន ជា បាននិយាយអំពីតម្រូវការ "កម្ទេចចោល" និង "លុបបំបាត់ចោល" អតីតយោធា និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

ណាឲ្យមាគ៌ាបក្សត្រូវបានផ្សព្វផ្សាយបន្តទៅដល់សហករណ៍ កម្មាភិបាល និងប្រជាជន[១៧១៨]។ ដូច្នេះ សូម្បីតែកងទ័ពសាមញ្ញរបស់ខ្មែរក្រហម ក៏បានដឹងឮដែរអំពីផែនការជម្លៀសនេះ នៅចន្លោះពាក់កណ្តាលឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧[១៧១៩]។

៥៧៨. លើសពីនេះទៀត បក្សបានគ្រប់គ្រងលើមធ្យោបាយ និងវិធីសាស្ត្រដឹកជញ្ជូនដែលមានភាពចាំបាច់ដើម្បីឲ្យការផ្លាស់ទីលំនៅប្រជាជនអាចដំណើរការទៅបាន។ មជ្ឈិមបក្ស គណៈកម្មាធិការភូមិភាគ តំបន់ និងស្រុក ត្រូវតែផ្លាស់ទីលំនៅប្រជាជននៅតាមទីកន្លែងនីមួយៗរបស់ពួកគេ[១៧២០]។

---

[១៧១៨] *សូមមើល*ផ្នែកទី៦, រចនាសម្ព័ន្ធទំនាក់ទំនងការងារ, កថាខណ្ឌ ២៦៩-២៩៧។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ទំព័រ ៣១-៣៣, ៣៦-៣៨ (ប្រជាជនត្រូវបានអប់រំនៅថ្នាក់ភូមិភាគ និងបានចែករំលែកចំណេះដឹងរបស់ពួកគេឲ្យទៅថ្នាក់តំបន់។ ចាប់ពីចុងឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៧ នី កន បានផ្តល់ការអប់រំដល់គ្រប់សមាសភាពទាំងអស់នៅតំបន់៣២ ភូមិភាគបស្ចិម ដោយរួមបញ្ចូលទាំងប្រជាជនសាមញ្ញផង។ គោលបំណងនៃការឃោសនា គឺដើម្បីបង្កើនការបង្កបង្កើនផល។ លេខាភូមិភាគកណ្តាលបានណែនាំ នី កន ទាក់ទិននឹងខ្លឹមសារនៃវគ្គអប់រំនយោបាយ ដោយរួមបញ្ចូលទាំងការកសាងព្រែកជីក និងការដាំដុះស្រូវ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៣៣-៣៤, ៤២-៤៣, ៧៥-៧៧ (ប្រាក់ យុត នៅខេត្តកំពតចាប់ពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ដើមឆ្នាំ១៩៧៧។ យ៉ាងហោចណាស់រៀងរាល់៣ខែ នៅខេត្តកំពត មានកិច្ចប្រជុំគណៈស្រុកដើម្បីពិភាក្សាអំពីទិសដៅការងារ ដោយរួមបញ្ចូលទាំងការកសាងទំនប់ ភ្លឺស្រែ និង ជីកប្រឡាយ ព្រែក)។

[១៧១៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ E3/419 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ៧-៨ ERN (ភាសាខ្មែរ) 00407747-00407748, 00407751-00407752 (រ៉េន ដែលជាកូនប្រសារតា ម៉ុក គឺជាមេបញ្ជាការវរៈសេនាធំលេខ ១១ នៃកងពលតូចលេខ២។ អៀង ផាន ដែលជាមេបញ្ជាការកងវរសេនាតូចពិសេសលេខ២០៣ នៃកងពលតូចលេខ០២ ។ បានឮពីឈ្មោះ រ៉េន ផ្ទាល់ដែលនិយាយអំពីផែនការនៃការជម្លៀសនៅពាក់កណ្តាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ និងបានឃើញគេជម្លៀសប្រជាជនដោយផ្ទាល់។ ជាទូទៅ សូម្បីតែយុទ្ធជនធម្មតារបស់ខ្មែរក្រហម ក៏បានដឹង និងបានឮគេនិយាយអំពីផែនការនោះដែរ)។

[១៧២០] លិខិតពី ខៀវ សំផន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ E3/112 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00157635 (មានវិន័យទូទៅមួយទៀតហាមមិនឲ្យទៅណាមកណាដោយមិនមានហេតុផលជាការច្បាស់លាស់)។ ឯកសារគណៈកម្មធិការពាណិជ្ជកម្ម៖ លិខិតអនុញ្ញាតិ ឯកសារ E3/1905 ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00076285 វិត ដែលជាគណៈកម្មាធិការពាណិជ្ជកម្មរដ្ឋ បានអនុញ្ញាតឲ្យកម្មាភិបាលម្នាក់ទៅប្រតិបត្តិការនៅក្រុងភ្នំពេញ និងខេត្តកំពង់ចាម)។ សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់ ដោយ ខៀវ សំផន ឯកសារ E3/205 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ទំព័រ ៤ ERN (ភាសាខ្មែរ) 00002796 (វិន័យហាមខ្ញុំមិនឲ្យដើរហើរដោយគ្មានការអនុញ្ញាត)។ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១២ (ខៀវ នៅ) ទំព័រ ៥៥-៥៦ (រាល់អ្នកបើកបរឡាន អ្នកលើកដាក់ត្រូវបង្ហាញលិខិតអនុញ្ញាតដើម្បីធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតនៅក្នុងភូមិភាគនិរតី។ លិខិតនេះ ចេញដោយ តា ម៉ុក ឬ ដោយគណៈភូមិភាគ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ១២-១៣ (ស្រុកត្រូវតែអនុញ្ញាតដល់ការធ្វើដំណើរណាមួយ ហើយក្រោយឆ្នាំ១៩៧៥

ស្ថានីយ៍រថភ្លើងភ្នំពេញ-មង្គលបុរី ដែលបំពេញតួនាទីជាមធ្យោបាយសំខាន់មួយក្នុងការផ្លាស់ទីលំនៅប្រជាជននៅចន្លោះ ខែ កញ្ញា ឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៧ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គភាពរថភ្លើងក្រុងភ្នំពេញ[១៧២១]។ កងទ័ពខ្មែរក្រហមគឺជាអ្នកទទួលខុសត្រូវលើការងារដឹកជញ្ជូនតាមផ្លូវដែក ហើយរាយការណ៍ទៅតែក្រុងភ្នំពេញប៉ុណ្ណោះ[១៧២២]។ នៅក្នុងខែ តុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍ បានចាត់តាំង វន វ៉េត ឲ្យទទួលខុសត្រូវលើ “ឧស្សាហកម្មអាយស្ម័យយាន និងនេសាទ”[១៧២៣]។ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៦ ម៉ី ប្រាង គឺជារដ្ឋមន្ត្រីគមនាគមន៍និងដឹកជញ្ជូន។ នៅក្នុងតួនាទីនេះ គាត់មានភារកិច្ចផ្សេងៗទៀត ក្រៅពីការទទួលខុសត្រូវលើអង្គភាពរថភ្លើង[១៧២៤]។ គណៈកម្មាធិការគមនាគមន៏ និងដឹកជញ្ជូន ព្រមទាំង គណៈកម្មាធិការ

---

“ប្រជាជនសាមញ្ញ” កម្រត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរណាស់)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ៤១-៤២ (ការរៀបចំការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀសទៅកាន់ខេត្តពោធិសាត់ ត្រូវបានធ្វើឡើងដោយអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជា)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៤៤ (“មធ្យោបាយផលិតកម្ម រួមទាំង [...] សម្បត្តិធម្មជាតិលើដី ក្នុងដី ទាំងអស់ [...] [ស្ថិត] នៅក្នុងកណ្តាប់ដៃបក្សកុម្មុយនីស្តកម្ពុជាតែម្នាក់ឯងគត់)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00709586-00709588 (ការធ្វើដំណើរ សូម្បីតែពីភូមិក្បែរគ្នា ក៏មិនអាចធ្វើបានទេ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្ស។ ខ្មែរក្រហមបានហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះការធ្វើដំណើរ ដើម្បីធ្វើឲ្យប្រជាជនមានការលំបាកក្នុងការរត់គេចខ្លួន ឬបង្កការលំបាកដល់ពួកសមាសភាពតស៊ូក្នុងការចល័តខ្លួន។ សំណើសុំការធ្វើដំណើរ ជាញឹកញាប់ ត្រូវបានបដិសេធទោះបីជាបុគ្គលនោះពិតជាឈឺធ្ងន់ធ្ងរក៏ដោយ។ ប្រសិនបើអនុញ្ញាតឲ្យធ្វើដំណើរវិញ ជននោះនឹងត្រូវខ្មែរក្រហមអមដំណើរ ឬ ចេញលិខិតឆ្លងកាត់)។

[១៧២១] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ២៥-២៦, ៦១-៦២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ១០ ERN (ភាសាខ្មែរ) 00414480។

[១៧២២] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ២៣-២៤ (កម្មាភិបាលភូមិភាគ និងតំបន់ មិនបានជួយការងារនៅលើរថភ្លើង ឬការជម្លៀសប្រជាជននោះទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ១០ ERN (ភាសាខ្មែរ) 00414480 (កម្មាភិបាលខ្មែរក្រហមដែលធ្វើការងារនៅផ្លូវរថភ្លើង បានរាយការណ៍ទៅភ្នំពេញ តែប៉ុណ្ណោះ)។

[១៧២៣] ផ្នែកទី៥, រចនាសម្ព័ន្ធរដ្ឋបាល, កថាខណ្ឌ ២៣២។ ផ្នែកទី១៤, សហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៥២ ។ កំណត់ហេតុការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ១-៣ ERN (ភាសាខ្មែរ) ០០០១៩១០៨-០០០១៩១១០ ។

[១៧២៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (ស សារិន) ទំព័រ ១៩-២០ (ម៉ី ប្រាង ខាងគមនាគមន៍ និងផ្លូវដែក)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ (សគឹម ល្មុត) ទំព័រ ៨៤ (ម៉ី ប្រាង ទទួលខុសត្រូវលើស្ថានីយរថភ្លើង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សគឹម ល្មុត ឯកសារ E3/105 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00418555 (ម៉ី ប្រាង ជាប្រធានខាងគណៈកម្មាធិការផ្លូវរថភ្លើង)។ កិច្ចសម្ភាសន៍ជាមួយលោក ស

ពាណិជ្ជកម្ម ដែលនៅដើម ខែ កញ្ញា ឆ្នាំ ១៩៧៥ បានទទួលភារកិច្ចរៀបចំការផ្លាស់ទីលំនៅប្រជាជន[១៧២៥] ស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច ដែលដឹកនាំដោយ វន វ៉េត[១៧២៦]។

៥៧៩. ជារួម មិនមានភ័ស្តុតាងច្បាស់លាស់បញ្ជាក់អំពីចំនួនប្រជាជនជាក់លាក់ដែលត្រូវបានផ្លាស់ទីលំនៅទៅតាំងទីលំនៅថ្មីនៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧ នោះទេ ហើយដោយសារតែស្ថានភាពនៃការផ្លាស់ទីលំនៅទាំងនោះមានភាពមិនច្បាស់លាស់ ដូច្នេះ ចំនួនប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះ នៅតែមិនអាចដឹងច្បាស់លាស់បាន ។ ទោះបីជាកំណត់ហេតុផ្លូវការនៃរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅនេះ ជាញឹកញាប់បានបញ្ជាក់អំពីចំនួនប្រជាជនដែលត្រូវបានរៀបចំឱ្យធ្វើការផ្លាស់ទីលំនៅ រួមទាំង ចំនួនប្រជាជនដែលធ្វើការងារនៅតាមទីតាំង ឬ ការដ្ឋានការងារជាក់លាក់ផ្សេងៗក៏ដោយ ក៏មានព័ត៌មានផ្លូវការតិចតួចតែប៉ុណ្ណោះពាក់ព័ន្ធនឹងចំនួនប្រជាជនជាក់លាក់ដែលត្រូវបានគេផ្លាស់ទីលំនៅ ។ ទោះបីជាបែបនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមកំណត់ចំនួនអប្បបរមា អំពីប្រជាជនដែលត្រូវបានផ្លាស់ទី

---

សារិន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/4596 ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៥១ ERN (ភាសាខ្មែរ) 00482811 (ម៉ី ប្រាង រដ្ឋមន្ត្រីគមនាគមន៍ និងផ្លូវដែក)។ របាយការណ៍របស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជាប្រចាំខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/491 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00704452 (ម៉ី ប្រាង គឺជារដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍ បានដឹកនាំគណៈប្រតិភូទៅបរទេសក្នុងនាមជារដ្ឋមន្ត្រី)។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/235 ចុះថ្ងៃទី ១៩-២១ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ២៦ ERN (ភាសាខ្មែរ) 00000802 (សមមិត្ត ប្រាង រាយការណ៍អំពីគមនាគមន៍ និងការដឹកជញ្ជូនខាងផ្លូវរថភ្លើង)។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/235 ចុះថ្ងៃទី ១៩-២១ ខែ មេសា ឆ្នាំ១៩៧៦ ទំព័រ ២ ERN(ភាសាខ្មែរ)00019143(ត្រូវបានតែងតាំងជាលេខានៃគណៈកម្មាធិការផ្លូវដែក)។ *ការបះបោរនៅប្រទេសកម្ពុជា ដាក់របបគ្រប់គ្រងប្រឈមនឹងការដួលរលំ* (កម្រងឯកសារ SWB) ឯកសារ E3/565 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00289827 (ម៉ី ប្រាង ជាប្រធានគណៈកម្មាធិការគមនាគមន៍)។

[១៧២៥] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែកញ្ញា ឆ្នាំ១៩៧៥ ទំព័រ ២០-២១ ERN (ភាសាខ្មែរ) 00072386-00072387 (ក្រសួងពាណិជ្ជកម្មរបស់រដ្ឋទទួលភារកិច្ចដឹកជញ្ជូនប្រជាជនរាប់សែននាក់)។ របាយការណ៍ក្រសួងពាណិជ្ជកម្ម ឯកសារ E3/1110 ចុះថ្ងៃទី២៥-២៦ ខែ កក្កដា ឆ្នាំ១៩៧៦ ទំព័រ ១០ ERN (ភាសាខ្មែរ) 00381704 (“បំផុសចលនាមហាជនឱ្យផុសផុលខ្លាំងក្លា វាយឱ្យចំទិស ទាំងកម្លាំងមនុស្ស និងកម្លាំងសម្ភារៈ សំដៅសម្រេច ៣តោន ក្នុង១ហិកតា និងប្រព័ន្ធភ្លឺថ្មី ៣០ ភាគរយ ទូទាំងប្រទេស”)។ របាយការណ៍ក្រសួងពាណិជ្ជកម្ម ឯកសារ E3/1159 ចុះថ្ងៃទី ២៥-២៦ ខែ កក្កដា ឆ្នាំ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00188205-00188207 (ក្រសួងពាណិជ្ជកម្មបានរួមចំណែកវាយសម្រុក ៣ តោន មួយហិចតា និងលើកភ្លឺស្រែថ្មី)។

[១៧២៦] ផ្នែកទី៥, រចនាសម្ព័ន្ធរដ្ឋបាល, កថាខណ្ឌ ២៣៥។ ផ្នែកទី១៤, សហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៦៦។

លំនៅនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ដោយផ្អែកលើភស្តុតាងដែលមានស្រាប់។ នៅពេលកំណត់ចំនួននេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចំនួនប្រជាជនពិតប្រាកដដែលបានទៅតាំងទីលំនៅថ្មី ទំនងជាច្រើនជាងចំនួនប៉ាន់ស្មានកម្រិតអប្បបរមារបស់អង្គជំនុំជម្រះ។

៥៨០. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅ ពីតំបន់ទក្សិណ ទៅតំបន់ឧត្តរ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍ បានរៀបចំផែនការបញ្ជូនប្រជាជនក្នុងចំនួនចន្លោះពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)[១៧២៧]។ ប្រជាជនចំនួន ២០.០០០ នាក់ ត្រូវបានបញ្ជូនបន្ថែមទៀតទៅកាន់ខេត្តព្រះវិហារ (តំបន់ ១០៣)[១៧២៨] ។ នៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៧ ការរៀបរាប់របស់ជនរងគ្រោះបញ្ជាក់ថា នៅក្នុងដំណាក់កាលផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជនរាប់រយ រាប់ពាន់ រាប់ម៉ឺននាក់ ត្រូវបានផ្លាស់ទីលំនៅពីភូមិរបស់ពួកគេរៀងៗខ្លួន[១៧២៩] ប្រជាជនរាប់ពាន់នាក់បានរង់ចាំនៅតាមកន្លែងប្រមូលផ្តុំជាច្រើន[១៧៣០] ហើយបន្ទាប់មក ប្រជាជន

---

[១៧២៧] កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ឯកសារ E3/216 ថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00008492-00008493។

[១៧២៨] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣១-៣២ ERN (ភាសាខ្មែរ) 00072397-00072398។

[១៧២៩] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ីម ឯកសារ E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤-៧ ERN (ភាសាខ្មែរ) 00565831-00565834។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00323530-00323531 (សែម វីរៈ គ្រួសាររបស់គាត់ និងអ្នកផ្សេងទៀតប្រហែល ២.០០០ នាក់ ត្រូវបានបញ្ជូនទៅភូមិជ្រៃកឃ្មុំ ខេត្តព្រៃវែង ។ នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ពួកគេត្រូវបានផ្លាស់ទីលំនៅទៅកាន់ទីក្រុងភ្នំពេញ រួចទៅកាន់បាត់ដំបង ហើយពួកគេត្រូវបានបញ្ជូនទៅកាន់ស្រុកផ្សេងៗគ្នា)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00228741-00228742 (ប្រហែលខែធ្នូ ឆ្នាំ១៩៧៥ ប្រជាជនប្រហែល ៣៥.០០០នាក់ដែលពីមុនត្រូវបានជម្លៀសចេញពីភ្នំពេញ ត្រូវបានជម្លៀសម្តងទៀតពីស្រុកកោះសូទិន ខេត្តកំពង់ចាម ទៅកាន់ខេត្តកំពង់ធំ)។

[១៧៣០] ប្រតិចារឹកថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣(ពិន យ៉ាថៃ)ទំព័រ៥-៧ (អ្នកធ្វើដំណើររាប់ពាន់នាក់មកពីកន្លែងផ្សេងៗ ត្រូវបានឲ្យមកជួបជុំគ្នានៅអង្គរកា)។កំណត់ហេតុបទសម្ភាសន៍ជាមួយ គីម ហេង ដោយការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E3/5639 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00845882 (ប្រជាជនត្រូវបាន

រាប់រយ រាប់ពាន់នាក់ ត្រូវបានដឹកជញ្ជូនតាមឡាន[១៧៣១] តាមកាណូត កប៉ាល់[១៧៣២] និងតាមរថភ្លើង ដោយឡែកៗពីគ្នា[១៧៣៣] ។ ជាការពិតណាស់ ភូមិភាគបូព៌ាបានបញ្ជូនរបាយការណ៍មួយច្បាប់ទៅ

---

ប្រមូលផ្តុំគ្នាដំបូងនៅជ្រៃព្រះញ៉ៅ ត្រាំខ្នា ក្នុងខេត្តកំពង់ស្ពឺ។ ក្រោយពីរង់ចាំនៅទីនោះអស់រយៈពេលពីរបីថ្ងៃ ខ្មែរក្រហម បានដឹកអ្នកត្រូវបានជម្លៀសប្រហែល ៣០០០ នាក់ទៅក្រុងពោធិ៍សាត់ ដែលមានឡាន៦០-៧០គ្រឿង ហើយក្នុងឡាន នីមួយៗមានមនុស្សចំនួន៤០-៥០ នាក់ ។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ-កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៩-៣១១ ERN (ភាសាខ្មែរ) 002323307-00232309 (ប្រជាជនថ្មីរាប់ពាន់នាក់ បានបោះជំរំនៅខាងក្រៅស្ថានីយរថភ្លើងនៅខេត្តពោធិ៍សាត់ដើម្បីរង់ចាំការដឹកជញ្ជូនបន្តទៀត)។

[១៧៣១] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ០៥-០៦ ERN (ភាសាខ្មែរ) 00349497-00349498 (ចាប់ពីស្រុកពញាឮ ប្រជាជនរាប់រយនាក់ ត្រូវបាន យកទៅស្ថានីយរថភ្លើងដំណាក់ស្នាច់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00323530-00323531 (សែម វីរៈ គ្រួសាររបស់គាត់ និងអ្នកផ្សេងទៀតប្រហែល ២.០០០ នាក់ ត្រូវបានបញ្ជូនទៅក្រុងព្រៃវែង ហើយបន្ទាប់មកឡានដឹកមកកាន់ភ្នំពេញ)។ បន្ទាប់ពីត្រូវបានផ្លាស់ទីលំនៅដោយបង្ខំចេញពីទីក្រុងភ្នំពេញ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ សែម វីរៈ និងគ្រួសាររបស់ គាត់ ត្រូវបានផ្លាស់ទីលំនៅទៅកាន់ភូមិជ្រែកឃ្មុំ ខេត្តព្រៃវែង និងក្រោយមក នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ពួកគេត្រូវ បានផ្លាស់ទីលំនៅទៅកាន់ទីក្រុងភ្នំពេញ ដោយធ្វើដំណើរតាមកាណូត និងចុងក្រោយត្រូវបានដឹកតាមឡាន និងរថភ្លើង ឆ្ពោះទៅកាន់បាត់ដំបង ដែលជាកន្លែងគ្រួសាររបស់គាត់ និងអ្នកផ្សេងទៀតប្រហែល ២.០០០ នាក់ ត្រូវបានបញ្ជូន ចេញនៅយប់មួយ ទៅកាន់ស្រុកផ្សេងៗគ្នា)។ ប្រតិចារឹក ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ ៤១ (នៅ ដើមឆ្នាំ ១៩៧៧ ប្រជាជនប្រហែល ២.០០០ នាក់ ត្រូវបានគេផ្លាស់ប្តូរទីលំនៅពីកំពង់ឆ្នាំងមកកាន់ពោធិ៍សាត់តាម ឡាន)។ ប្រតិចារឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ០៦-០៧ (ក្រោយ ២ ឬ ៣ សប្តាហ៍ នៅអង្គរកា ពិន យ៉ាថៃ គ្រួសាររបស់គាត់ និងអ្នកផ្សេងទៀតប្រហែល ២.០០០ នាក់ បានឡើងជិះឡានដែលមានចំនួនពី២០-៣០ ឡាន ឆ្ពោះទៅកាន់បាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ៤០-៤១, ៤៩ (ប្រហែល ជាដើមឆ្នាំ ១៩៧៧ ប្រជាជនប្រហែល ២.០០០ នាក់ត្រូវបានជម្លៀសតាមឡានពីកំពង់ឆ្នាំងមកកាន់ខេត្តពោធិ៍សាត់)។ ប្រតិចារឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ (ព្រុំ ស៊ូ) ទំព័រ១០-១២, ៣៧-៤០ (អ្នកត្រូវបានជម្លៀសប្រហែល៣.០០០ នាក់ ត្រូវបានដឹកតាមឡានពីកំពង់ធំមកកាន់តំបន់ ១០៣)។

[១៧៣២] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤, ៤៣-៤៤ (ចាន់ សុជាតិ គ្រួសាររបស់ គាត់ និងរាប់រយគ្រួសារផ្សេងទៀត បានឡើងជិះទូក ឬ កាណូត នៅខេត្តកណ្តាល ដើម្បីឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ៤ ERN (ភាសាខ្មែរ) 00559763 (មនុស្សរាប់រយនាក់បានឡើងជិះសាឡាង)។

[១៧៣៣] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414417-00414418។

ប៉ុល ពត នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនចំនួន ៥០.០០០ នាក់ ទៅកាន់ភូមិភាគ(ឧត្តរចាស់)កណ្តាល[១៧៣៤] ។ នៅក្នុងខែ មករា ឆ្នាំ ១៩៧៦ ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ាបានរាយការណ៍ថា នៅក្នុងរយៈពេល ២ ខែ ចុងឆ្នាំ ១៩៧៥ ប្រជាជនចំនួន ៣០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅទៅកាន់ខេត្តបាត់ដំបង[១៧៣៥]។ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ គណៈកម្មាធិការតំបន់ ៥ ក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) បានរាយការណ៍ថា ប្រជាជនភាគច្រើននៅក្នុងតំបន់នេះ គឺជា "ប្រជាជនថ្មី" ។ នៅក្នុងចំណោមស្រុកចំនួនបួននៅក្នុងតំបន់ ៥ មានស្រុកចំនួនពីរដែលមានប្រជាជនចំនួនជិត ១២០.០០០ នាក់ មកពីក្រុងភ្នំពេញ[១៧៣៦]។ ចុងក្រោយ តួលេខប៉ាន់ស្មានបណ្តោះអាសន្នបញ្ជាក់ថា ប្រជាជនចំនួនចន្លោះពី ៣០០.០០០ នាក់ ទៅ៤០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅនៅក្នុងដំណាក់កាលទី២នេះ[១៧៣៧]។ ផ្អែកតាមកំណត់ត្រា

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414475-00414478។

[១៧៣៤] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/154 ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00008494។

[១៧៣៥] *ប្រទេសកម្ពុជាស្ថិតក្នុងកណ្តាប់ដៃដែករបស់ខ្មែរក្រហម* (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា) ឯកសារ E3/4441 ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00708572-00708573 (យោងតាមជនភៀសខ្លួន ក្នុងអំឡុង២ ខែចុងក្រោយក្នុងឆ្នាំ១៩៧៥ ជនភៀសខ្លួនចំនួន៣០០.០០០ នាក់មកពីភ្នំពេញ ត្រូវបានជម្លៀសម្តងទៀតតាមកាណូតខ្លះ និងតាមរថភ្លើងខ្លះទៅកាន់ខេត្តបាត់ដំបង)។

[១៧៣៦] របាយការណ៍តំបន់ ៥ ឯកសារ E3/1181 ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ១-៥ ERN (ភាសាខ្មែរ) 00214486-00214490 (គណៈតំបន់ ៥ នៅភូមិភាគពាយ័ព្យ បានរាយការណ៍ថា ប្រជាជនភាគច្រើននៅស្រុកថ្មពួក គឺជា "ប្រជាជនក្រោយថ្ងៃ១៧ មេសា"។ នៅស្រុក ស៊ីសុផុន ស្ទើរតែប្រជាជនទាំងអស់ចំនួន ៥០០.០០០ នាក់ គឺជាប្រជាជនថ្មីដែលលាយបញ្ចូលគ្នារវាងប្រជាជនមុនរំដោះ និងក្រោយរំដោះថ្ងៃទី ១៧ ខែ មេសា។ ក្នុងចំណោមប្រជាជន ៧០.០០០ នាក់ នៅស្រុកភ្នំស្រុក ប្រជាជនប្រហែល ៥០.០០០ នាក់ មកពីភ្នំពេញ ហើយប្រជាជនមូលដ្ឋានថ្មីមានជាង ២០.០០០ នាក់។ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅស្រុកព្រះនេត្រព្រះ មានប្រជាជន ១៥០ គ្រួសារ។ ត្រឹមថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៧ ប្រជាជនជាង ៧០.០០០ នាក់ មកពីភ្នំពេញ)។

[១៧៣៧] សៀវភៅនិពន្ធដោយ Michael VICKERY ៖ កម្ពុជាឆ្នាំ ១៩៧៥ -១៩៨២ ឯកសារ E3/1757 ទំព័រ ៤៤-៤៧ ERN (ភាសាខ្មែរ) 00789212-00789215 (PONCHAUD បានសរសេរ "រាប់ម៉ឺននាក់"។ ប្រវត្តិព័ត៌មានឆ្នាំ១៩៧៦ ដោយផ្អែកលើការរៀបរាប់របស់ជនភៀសខ្លួន បានកំណត់តួលេខដល់សាមសិបម៉ឺននាក់។ ហើយ VICKERY បានលើកឡើងថាសែសិបម៉ឺននាក់ គឺជាតួលេខអតិបរមាបំផុត ដែលតួលេខនេះស៊ីសង្វាក់គ្នានឹងការរៀបរាប់អំពីការចាប់អារម្មណ៍របស់ជនភៀសខ្លួនផ្សេងៗទៀត)។ *សូមមើលផងដែរ សាលក្រម ឧបសម្ព័ន្ធ III-ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)* ។

តួលេខមិនពេញលេញនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ទក្សិណទៅកាន់តំបន់ឧត្តរនៃប្រទេសកម្ពុជា ត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំ។ ក្នុងកម្រិតអប្បបរមាយ៉ាងហោចណាស់ក៏មានប្រជាជនចំនួនពី ៣០០.០០០ នាក់ ទៅ ៤០០.០០០ នាក់ ដែរ ដែលត្រូវបានផ្លាស់ទីលំនៅ។

៥៨១. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់ទក្សិណ និងតំបន់កណ្ដាល ពុំឃើញមានកំណត់ត្រា ឬ តួលេខប៉ាន់ស្មានអំពីចំនួនប្រជាជនសរុបដែលត្រូវបានផ្លាស់ទីលំនៅឡើយ។ ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ថ្នាក់ដឹកនាំបក្សមានបំណងចង់ឲ្យសហករណ៍នីមួយៗមានប្រជាជនចំនួន ១.០០០ គ្រួសារ ហើយក៏បានដាស់តឿនថា ការផ្លាស់ទីលំនៅប្រជាជននឹងនៅតែបន្តធ្វើដោយសារតែតម្រូវការកម្លាំងពលកម្ម រហូតទាល់តែសហករណ៍នីមួយៗមានប្រជាជនគ្រប់ចំនួន[១៧៣៨]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅនីមួយៗ ទៅកាន់ និងមកពីសហករណ៍ និងការដ្ឋានធ្វើការងារនានា ពួកគាត់បានឃើញប្រជាជនរាប់រយ រាប់ពាន់ រាប់ម៉ឺននាក់ ត្រូវបានផ្លាស់ទីលំនៅ[១៧៣៩]។ នៅក្នុងឆ្នាំ ១៩៧៧ ខៀវ សំផន បានរាយការណ៍ថា គម្រោងធារាសាស្រ្តកំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេសដោយមានប្រជាជនធ្វើការងារប្រមាណ ពី ១០.០០០ នាក់ ទៅ ៣០.០០០ នាក់ នៅតាមការដ្ឋាន

---

[១៧៣៨] *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៥៨ ERN (ភាសាខ្មែរ) 00063270 របាយការណ៍ស្ដីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១០-១៤ ERN (ភាសាខ្មែរ) 00442212-00442214 (បក្សបានបញ្ជាឲ្យពង្រឹង និងពង្រីកសហករណ៍ ដោយដាក់បញ្ចូលគ្រួសារចំនួន ១.០០០ គ្រួសារ)។

[១៧៣៩] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៨-៣៩ (នៅខែ ធ្នូ ឆ្នាំ ១៩៧៥ ប្រជាជនប្រហែល១.០០០ នាក់ ដំបូងត្រូវបានជម្លៀសទៅភូមិ ៧ និងបន្ទាប់មកទៅ ដូនអី ខេត្តបាត់ដំបង នៅខែ មករា ឆ្នាំ ១៩៧៦)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារ E3/5187 ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00197917-00197919 (ព្រំ សារុន ត្រូវបានបញ្ជូនទៅការដ្ឋានកំពីងពួយ ខេត្តបាត់ដំបង ជាមួយនឹងប្រជាជនរាប់ពាន់នាក់ផ្សេងទៀតពីកន្លែងផ្សេងៗនៅខេត្តបាត់ដំបង រយៈពេល៣ខែរៀងរាល់ឆ្នាំ ក្រោយបញ្ចប់ការច្រូតកាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ មាស ច័ន្ទថន ឯកសារ E3/4730 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១០-១៨ ERN (ភាសាខ្មែរ) 00485966-00485974 (នៅដើមខែ ធ្នូ ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានប្រមូលគ្រួសារជាង ២០០ គ្រួសារ ដាក់នៅក្នុងមន្ទីរ រួមមានមន្ត្រី ទាហាន និងប៉ូលីសរបស់ លន់ នល់។ នៅព្រឹកបន្ទាប់ រទេះចំនួន ៣០ បានដឹកពួកគាត់ទៅមន្ទីរសហករណ៍ជំនុំ ឃុំជំនុំ។ ថ្ងៃបន្ទាប់ទៀត ពួកគាត់ត្រូវបានឲ្យធ្វើដំណើរដោយថ្មើរជើងទៅភូមិរហាត់ទឹក ដែលស្ថិតនៅចម្ងាយប្រហែល ១៥ គីឡូម៉ែត្រ។ ពួកគាត់ត្រូវបាននាំទៅភូមិចក។

នីមួយៗ[១៧៤០]។ ឧទាហរណ៍ នៅក្នុងឆ្នាំ១៩៧៧ ប្រជាជនប្រមាណពី៨.០០០នាក់ទៅ ២០.០០០នាក់ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានទំនប់ ១ មករា[១៧៤១]។ ប្រជាជនចំនួន ២០.០០០ នាក់ ដោយមួយចំនួននៅតាមកងចល័តបានលើកទំនប់ ១៧ មករា ហើយប្រជាជនចំនួន ២៣.០០០ នាក់ទៀតបានលើកទំនប់ ៥ មករា និងទំនប់ ៦ មករា[១៧៤២]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាការផ្លាស់ទីលំនៅនៅក្នុងតំបន់ នៅអំឡុងពេលប្រហែល ពី ខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ ក៏ត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំដូចគ្នាផងដែរ។ ទោះបីជាយ៉ាងនេះក្តី ដោយសារពុំមានភស្តុតាងបន្ថែមបញ្ជាក់អំពីភាគរយនៃប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទៅតាមសហករណ៍ និងទៅតាមការដ្ឋានធ្វើការងារនានានោះ អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែអាចធ្វើការប៉ាន់ស្មានក្នុងចំនួនអប្បបរមាតែប៉ុណ្ណោះថា យ៉ាងហោចណាស់មានប្រជាជនចំនួន ៣០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅនៅក្នុងតំបន់ផ្សេងៗ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចំនួនប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅនោះ ទំនងជាមានចំនួនច្រើនជាងចំនួនប៉ាន់ស្មាននេះ ប្រសិនបើពិចារណាលើវិសាលភាពភូមិសាស្ត្រ ពេលវេលានៃការផ្លាស់ទីលំនៅទាំងនេះ ចំនួនសហករណ៍ និងការដ្ឋានធ្វើការងារដែលមាននៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងចំនួនប្រជាជននៅតាមសហករណ៍ និងការដ្ឋានធ្វើការងារនីមួយៗ។

---

[១៧៤០] *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/200 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៤-៦ ERN (ភាសាខ្មែរ) S 00292806-00292808។

[១៧៤១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ចេង ឯកសារ E3/5249 ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00229062-00229063 (ប្រជាជនប្រមាណ ៨.០០០ នាក់ មកពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ ត្រូវបានប្រមូលផ្តុំគ្នាដើម្បីធ្វើការនៅការដ្ឋានទំនប់ ១ មករា ដែលទំនប់នេះត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៧ និងត្រូវបានបញ្ចប់នៅឆ្នាំនោះដែរ)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00239907-00239908 (ប្រជាជនប្រហែល ២០.០០០ នាក់ មកពីតំបន់៤១, ៤២ និង ៤៣ បានធ្វើការនៅការដ្ឋានទំនប់ ១ មករា នៅខេត្តកំពង់ធំ)។ *សូមមើល* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣២០-៣២១ ERN (ភាសាខ្មែរ) 00232318-00232319 (សហករណ៍ដែលនៅក្បែរៗទំនប់ បានបញ្ជូនកម្លាំងពលកម្មរាប់ពាននាក់)។

[១៧៤២] អត្ថបទរបស់ François PONCHAUD៖ *កម្ពុជា៖ សេដ្ឋកិច្ចបែបបដិវត្តន៍* ឯកសារ E3/2412 ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00812345-00812347។ *សូមមើលផងដែរ សាលក្រម ឧបសម្ព័ន្ធ III- ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)*។

៥៨២. ក្រោយមក ឯកសារបោះពុម្ពផ្សាយរបស់បក្សបានទទួលស្គាល់ថា ការចល័តប្រជាជនបែប នេះបានធ្វើឲ្យមាន "ការលំបាក" នៅក្នុងអំឡុងពេល និងក្រោយពេលផ្លាស់ទីលំនៅ[១៧៤៣]។ ក្រោយ ពេលផ្លាស់ទីលំនៅរួចមក ប្រជាជនត្រូវបានបង្ខំឲ្យសម្របខ្លួន និងរៀនរស់នៅកន្លែងថ្មី ហើយខ្លះ បានវង្វេងនឹងទីតាំងភូមិសាស្ត្រទាំងនោះ[១៧៤៤]។ ក្មេងៗដែលទម្លាប់ធម្មតារបស់ពួកគេត្រូវបានផ្លាស់ ប្តូរទាំងស្រុងធ្វើឲ្យបាត់បង់លទ្ធភាពក្នុងការទប់ទល់ជាមួយនឹងការប៉ះទង្គិចផ្លូវចិត្ត (Trauma) ដែល ពួកគេបានឆ្លងកាត់នៅក្នុងអំឡុងពេលជម្លៀស និងផ្លាស់ទីលំនៅជាប្រចាំនោះ ។ ពួកគេមានការ លំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកផ្សេងទៀត ហើយមើលមិនឃើញអំពីអនាគតនោះ ទេ។ ក្មេងៗដែលបានបាត់បង់ឪពុកម្តាយទាំងនោះ បានទទួលរងនូវភាពសោកសង្វេគយូរអង្វែង ហើយក្មេងៗទាំងនោះ ខ្លះដែលសព្វថ្ងៃក្លាយជាឪពុកម្តាយ បានធ្វើបាបកូនៗរបស់ខ្លួនឯង[១៧៤៥]។ ឪពុកម្តាយដែលបាត់បង់កូន បានទទួលរងការឈឺចាប់ជាប់រហូត។ លើសពីនេះទៀត "ប្រជាជនថ្មី" បានបាត់បង់នូវអត្តសញ្ញាណរបស់ខ្លួន និងមានស្លាកស្នាមទុរយសបន្សល់ទុក[១៧៤៦]។

៥៨៣. ខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងនឹងលើកឡើងអំពីការផ្លាស់ទីលំនៅប្រជាជន ដែលបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយថា ជាការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ទៅតាមហេតុផល និងគោលដៅដែលបានចោទប្រកាន់៖ ការបែងចែកសាជាថ្មីលើកម្លាំងពលកម្ម តាមបណ្តាខេត្តប៉ែកទក្សិណ ទៅកាន់បណ្តាខេត្តនៅប៉ែកឧត្តរ (ផ្នែក១១.២) ការចល័តកម្លាំង ការងារនៅក្នុងតំបន់ទៅតាមរដូវកាល (ផ្នែក១១.៣) ការផ្លាស់ទីលំនៅនៅក្នុងតំបន់សម្រាប់គោល បំណងនៃការតស៊ូវណ្ណៈ (ផ្នែក១១.៤) និងការផ្លាស់ទីលំនៅចេញពីព្រំប្រទល់ជាប់នឹងប្រទេស វៀតណាម (ផ្នែក១១.៥) ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះបានពិចារណាលើការផ្លាស់ទីលំនៅ ទៅកាន់ មកពី និងនៅក្នុងទីតាំងនានាដែលមិន បានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ ដោយហេតុថា ការផ្លាស់ទីលំនៅទាំងនេះបានផ្តល់នូវបរិបទ និងភស្តុតាងបង្ហាញអំពីបែបបទនៃការប្រព្រឹត្តិ ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូង

---

[១៧៤៣] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៤៤-៤៦ ERN (ភាសាខ្មែរ) 00063262-00063263។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/166 ខែ កុម្ភៈ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៤០-៤៥ ERN (ភាសាខ្មែរ) 00063211-00063213។

[១៧៤៤] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៤-៧៥។

[១៧៤៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៦២-៦៤។

[១៧៤៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៦៤-៦៦។

នឹងរៀបចំផ្នែកសំអាងច្បាប់របស់ខ្លួនតែទៅលើឧក្រិដ្ឋកម្មផ្សេងៗ ដែលត្រូវបានចោទប្រកាន់លើទីតាំងទាំងនោះ ជាពិសេស ទីតាំងដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយតែប៉ុណ្ណោះ។

## ១១.២ ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ទក្សិណ ទៅកាន់តំបន់ឧត្តរនៃប្រទេស

៥៨៤. ចាប់ផ្តើមពីពាក់កណ្តាលខែមេសា ឆ្នាំ ១៩៧៥ យ៉ាងហោចណាស់មានប្រជាជនចំនួន ២.០០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅពីទីក្រុងនានា ទៅកាន់ទីជនបទ[១៧៤៧]។ នៅពេលរដូវដកស្ទូងបានចាប់ផ្តើមចូលមកដល់នៅក្នុងខែកក្កដា និងខែ សីហា ឆ្នាំ ១៩៧៥ ការផ្លាស់ទីលំនៅប្រជាជននៅតែបន្តធ្វើនៅឡើយ[១៧៤៨]។ ដូច្នេះការបង្កបង្កើនផលនៅក្នុងឆ្នាំនោះ ពុំអាចមានលទ្ធភាពបង្កើនទិន្នផលបានឡើយ[១៧៤៩]។ ទោះបីជាយ៉ាងនេះក្តី នៅត្រឹមចុងឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សបានទទួលស្គាល់ថា ស្បៀងអាហារ និងធនធានទាំងឡាយ ត្រូវបានប្រើប្រាស់ស្ទើរតែអស់ទៅហើយ ដូច្នេះ ថ្នាក់ដឹកនាំបក្សក៏បានពិចារណាថា បក្សត្រូវតែរៀបចំកម្លាំងមនុស្សនេះឡើងវិញ[១៧៥០]។

៥៨៥. នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខេត្តបាត់ដំបងមានផលស្រូវច្រើនជាងគេបំផុតនៅក្នុងប្រទេសដោយសល់ស្រូវច្រើនជាទៀងទាត់[១៧៥១]។ នៅក្នុងខែសីហា ឆ្នាំ១៩៧៥ គណៈកម្មាធិការ

---

[១៧៤៧] *សូមមើលផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២០ ។* *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/166 ខែ កុម្ភៈ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥៥-៥៩ ERN (ភាសាខ្មែរ) 00063219-00063221។

[១៧៤៨] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/166 ខែ កុម្ភៈ មីនា ឆ្នាំ ១៩៧៦ ទំព័រ៥៧-៥៩ ERN(ភាសាខ្មែរ) 00063220-00063221។

[១៧៤៩] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/166 ខែ កុម្ភៈ មីនា ឆ្នាំ ១៩៧៦ ទំព័រ៥៩-៦៤ ERN (ភាសាខ្មែរ) 00063221-00063223។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៤០-៤២ ERN (ភាសាខ្មែរ) 00442229-00442230 (ទើបតែនៅខែ ឧសភា ឆ្នាំ ១៩៧៥ [បន្ទាប់ពីរដូវដាំដុះ] បក្សបានចាប់ផ្តើមធ្វើកសិកម្ម ។ ប្រទេសទើបតែត្រូវបានរំដោះ ហើយបក្សត្រូវដោះស្រាយបញ្ហាស្មុគស្មាញមួយចំនួន ពោលគឺការផ្គត់ផ្គង់ស្បៀង អំបិល ការជម្លៀសប្រជាជន ផ្ទះសំបែង និងការដឹកជញ្ជូន)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ-កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ២៩២-២៩៣ ERN (ភាសាខ្មែរ) 00232290-00232291 (ការច្រូតកាត់នៅខែ ធ្នូ ឆ្នាំ ១៩៧៥ បានធ្វើឲ្យពួកមជ្ឈិមខកចិត្ត)។

[១៧៥០] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/25 ខែធ្នូ ឆ្នាំ ១៩៧៦ - មករា ឆ្នាំ ១៩៧៧ ទំព័រ ១៦-១៧ ERN (ភាសាខ្មែរ) 00063010-00063011។

[១៧៥១] របាយការណ៍ USAID៖ *របាយការណ៍បញ្ចប់ជំនួយនៅកម្ពុជា ភាគទី១* ឯកសារ E3/4178 ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣ ERN (ភាសាខ្មែរ) 00759720។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Michael VICKERY ៖ កម្ពុជាឆ្នាំ ១៩៧៥ -១៩៨២ ឯកសារ E3/1757 ទំព័រ ៤៤-៤៧ ERN (ភាសាខ្មែរ) 00789212-00789215។

អចិន្ត្រៃយ៍បានធ្វើទស្សនកិច្ចនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ហើយបានសង្កេតឃើញថា "ប្រជាជនថ្មី" ដែលបានផ្លាស់ទីលំនៅនាពេលមុនទៅកាន់ទីនោះ កំពុងជួបនឹងបញ្ហាកង្វះស្បៀងអាហារ[១៧៥២]។ គណៈកម្មាធិការអចិន្ត្រៃយ៍ ក៏បានសង្កេតឃើញមានការខ្វះទឹកនៅក្នុងខេត្តពោធិ៍សាត់ និងមានទឹកជំនន់នៅក្នុងខេត្តបាត់ដំបង[១៧៥៣] ។ ទោះបីជាយ៉ាងនេះក្តី គណៈកម្មាធិការអចិន្ត្រៃយ៍បានពិចារណាឃើញថា ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) មានស្រែ ដីមានជីជាតិ និងភូមិសាស្ត្រល្អជាងគេ ហេតុដូច្នេះត្រូវទទួលប្រជាជនបន្ថែមទៀត[១៧៥៤]។

៥៨៦. ថ្នាក់ដឹកនាំបក្សបានពិចារណាឃើញថាប្រជាជនចំនួន ១.០០០.០០០នាក់ដែលជាប្រជាជនខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) នៅក្នុងខែសីហា ឆ្នាំ១៩៧៥ មិនគ្រប់គ្រាន់សម្រាប់សម្រេចទិសដៅរបស់បក្សបាននោះទេ ។ បក្សយល់ឃើញថា ចាំបាច់ត្រូវបង្កើនកម្លាំងពលកម្មបន្ថែមឲ្យបានពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ទៀត[១៧៥៥] ។ ចំនួននេះត្រូវបានចាត់ទុកថាជាចំនួនសមស្របហើយ ដោយសារនៅតាមកន្លែងផ្សេងទៀតនៅត្រូវការកម្លាំងពលកម្មនៅ

---

[១៧៥២] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00008485-00008486។

[១៧៥៣] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00008486-00008487។

[១៧៥៤] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៧-៩ ERN (ភាសាខ្មែរ) 00008491-00008493។ (បក្សយល់ឃើញថា វានឹងមិនចំណេញទេក្នុងការបញ្ជូនប្រជាជនទៅភូមិភាគផ្សេងទៀតដែលដីមិនសូវមានជីវជាតិ)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៨-២០ (ភូមិភាគពាយព្យ មានស្បៀងស្តុកច្រើន និងអាចទទួលយកប្រជាជនច្រើន)។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានចុងក្រោយរបស់ នួន ជា) ទំព័រ ១៧-១៩; *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ-កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៨-៣០៩ ERN (ភាសាខ្មែរ) 00232306-00232307 (មានប្រជាជនតិចតួចប៉ុណ្ណោះនៅភូមិភាគពាយ័ព្យ ភ្លួរស្រែ ឬ កាប់ឆ្ការព្រៃ)។

[១៧៥៥] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ឯកសារ E3/216ចុះថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ ទំព័រ៨-៩ ERN (ភាសាខ្មែរ) 00008492-00008493។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ទំព័រ ៣១-៣២ ERN (ភាសាខ្មែរ) 00072397-00072398។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្តីដកស្រង់មតិណែនាំរបស់សមមិត្តតំណាង អង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ ១៩៧៦ នៅក្នុង ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213 ទំព័រ ៣៩-៤៧ ERN (ភាសាខ្មែរ) 00062860-00062864 (ឧបករណ៍ ធនធាន និងកម្លាំងពលកម្មល្អបំផុត គួរផ្តល់ឲ្យភូមិភាគពាយព្យ)។

ឡើយ[១៧៥៦] ។ ឧទាហរណ៍ ក្នុងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្ដាល) នៅត្រូវការប្រជាជនដោយសារខ្វះកម្លាំងពលកម្ម[១៧៥៧]។ នៅក្នុងខេត្តព្រះវិហារ (តំបន់១០៣) ដែល ប៊ូ ផាត ហៅ ហង្ស ជាលេខា រហូតដល់ ឆ្នាំ ១៩៧៨[១៧៥៨] ត្រូវការកម្លាំងមនុស្សដើម្បីលើកភ្លឺស្រែ និងឆ្ការព្រៃ[១៧៥៩]។ តំបន់ ១០៣ បានស្នើសុំប្រជាជនចំនួន ៥០.០០០ នាក់ បន្ថែមទៀត ប៉ុន្តែ ជាបឋមនោះ មានប្រជាជនចំនួនត្រឹមតែ ២០.០០០ នាក់ ប៉ុណ្ណោះដែលត្រូវបានបញ្ជូនទៅឲ្យ[១៧៦០]។

---

[១៧៥៦] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00008492-00008493។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្ដារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ទំព័រ ៣១-៣២ ERN (ភាសាខ្មែរ) 00072397-00072398។

[១៧៥៧] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្ដារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ទំព័រ ៣២-៣៣ ERN (ភាសាខ្មែរ) 00072398-00072399។

[១៧៥៨] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៥ (ហង្ស គឺជាលេខាតំបន់ ១០៣)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សុន ឯកសារ E3/4606 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00407771 (ហង្សគឺជាប្រធានតំបន់ ១០៣ រហូតដល់ពេលចាប់ខ្លួនគាត់នៅក្នុងឆ្នាំ ១៩៧៨)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ ស៊ូ ឯកសារ E3/420 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00407775 (ហង្សគឺជាលេខាតំបន់ ១០៣ រហូតដល់ពេលចាប់ខ្លួនគាត់នៅក្នុងឆ្នាំ ១៩៧៨)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង គឹមអឿន ឯកសារ E3/425 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418569 (ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ហង្សគឺជាលេខាតំបន់ ១០៣ រហូតដល់ពេលចាប់ខ្លួនគាត់)។ *សូមមើលផងដែរ* កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00017119-00017123 (សមមិត្ត ហង្ស បានរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍អំពីស្ថានភាពនៅក្នុងតំបន់ ១០៣ ហើយបានស្នើសុំ និងបានទទួលការណែនាំនានា)។

[១៧៥៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00017120-00017121។

[១៧៦០] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្ដារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក*ឯកសារ E3/781ចុះខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣១-៣២ ERN (ភាសាខ្មែរ) 00072397-00072398 ។ *សូមមើលផងដែរ* កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00017122-00017123 (គណៈកម្មាធិការអចិន្ត្រៃយ៍ បានស្នើសុំរបាយការណ៍អំពីទំនប់ទឹក និងទិន្នផលស្រូវនៅភូមិភាគឧត្តរ (រួមបញ្ចូលតំបន់១០៣) ជាប្រចាំសប្ដាហ៍)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/154 ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00008494 (កាលពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ

៥៨៧. តំបន់ដែលដីពុំសូវមានជីជាតិ ជាពិសេសនៅភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ត្រូវបានជ្រើសរើសកម្លាំងមនុស្សសម្រាប់ផ្តល់ទៅឲ្យតំបន់ ១០៣ ភូមិភាគពាយ័ព្យ និងភូមិភាគ (ឧត្តរចាស់) កណ្តាល[១៧៦១] ។ ថ្នាក់ដឹកនាំបក្សបានណែនាំថា មានតែប្រជាជនដែលត្រូវការចាំបាច់សម្រាប់ធ្វើស្រែនៅតំបន់ទាំងនេះតែប៉ុណ្ណោះដែលទុកនៅទីនោះ ហើយក្រៅពីនេះត្រូវផ្លាស់ទីលំនៅពួកគេ[១៧៦២] ។ ថ្នាក់ដឹកនាំបក្សមានបំណងចង់ឲ្យភូមិភាគដែលបង្កបង្កើនផលបានច្រើនជាងគេផលិតស្បៀងអាហារ និងទុនសម្រាប់តំបន់ផ្សេងៗទៀត ដែលមិនមានអំណោយផលពីដីមានជីជាតិ[១៧៦៣]។

---

១៩៧៥ ភូមិភាគបូព៌ា បានរាយការណ៍ជូន ប៉ុល ពត ដោយចម្លងជូន នួន ជា ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចំនួន ៥០.០០០ នាក់ ទៅភូមិភាគឧត្តរនៅស្ទឹងត្រង់ និង ព្រះប្រសព្វ)។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) (នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ សោ ភឹម បានរាយការណ៍ទៅ ប៉ុល ពត និងនួន ជា ទាក់ទិននឹង កែ ពក បានបដិសេធការជម្លៀសប្រជាជន)។

[១៧៦១] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00072372-00072373 (នៅស្វាយរៀង ដីមិនសូវមានជីវជាតិនោះទេ),ទំព័រ ១៦ ERN (ភាសាខ្មែរ) 00072382 (ភូមិភាគបស្ចិមទទួលទិន្នផលទាបជាងនិរតី)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២-៦៣ ERN (ភាសាខ្មែរ) 00836139-00836140។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ៖ កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៧-៣០៩ ERN (ភាសាខ្មែរ) 00232305-00232307 (តា ម៉ុក ដែលជាលេខាភូមិភាគនីរតី បានត្អូញត្អែរអំពីប្រជាជនច្រើនពេក និងភូមិភាគពាយព្យទទួលប្រជាជនថ្មីតិចតួច ក្រោយការជម្លៀសចេញពីភ្នំពេញ)។ សៀវភៅនិពន្ធដោយ Michael VICKERY ៖ កម្ពុជា ឆ្នាំ ១៩៧៥ -១៩៨២ ឯកសារ E3/1757 ទំព័រ ៤៤-៤៨ ERN (ភាសាខ្មែរ) 00789212-00789216។

[១៧៦២] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែកញ្ញា ឆ្នាំ១៩៧៥ ទំព័រ៣១-៣៣ ERN (ភាសាខ្មែរ) 00072397-00072399 ។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/135 ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ៣០-៣១ ERN (ភាសាខ្មែរ) 00069816 (ពាក្យស្លោកនៅឆ្នាំ ១៩៧៧ គឺ "អ្វីដែលមិនចាំបាច់ត្រូវដកចោល")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សឿន ឯកសារ E3/5531 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00418510-00418511 (ប្រជាជនតិចតួចប៉ុណ្ណោះរស់នៅក្នុងភូមិកំណើតរបស់ខ្លួនក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប្រជាជនថ្មីមិនចេះធ្វើស្រែ ហេតុដូច្នេះទុកពួកគាត់នៅភូមិភាគបូព៌ា មិនបានប្រយោជន៍ទេ)។

[១៧៦៣] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្តីដកស្រង់មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ១៩៧៦ នៅក្នុង ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213 ទំព័រ ៤៨-៥៤ ERN (ភាសាខ្មែរ) 00062865-00062867។

៥៨៨. ចាប់ផ្តើមពីខែកញ្ញា ឆ្នាំ ១៩៧៥ រហូតដល់ដើមឆ្នាំ ១៩៧៧ ប្រជាជនរាប់សែននាក់នៅក្នុងភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (រួមទាំង ខេត្តកំពង់ស្ពឺ[១៧៦៤] ខេត្តកណ្តាល[១៧៦៥] ខេត្តតាកែវ[១៧៦៦] ខេត្តព្រៃវែង[១៧៦៧] ខេត្តស្វាយរៀង[១៧៦៨] និងខេត្តកំពង់ចាម[១៧៦៩]) ត្រូវបានផ្លាស់ទីលំនៅ

---

[១៧៦៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារ៉ា-ស) ទំព័រ ៣-៦ (កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ធុច ផាន់ដារ៉ា-ស និងគ្រួសាររបស់គាត់ ត្រូវបានជម្លៀសពីភ្នំពេញ ទៅភូមិអង្គរមាស ខេត្តកំពង់ស្ពឺ មុនពេលត្រូវបានជម្លៀសម្តងទៀតទៅពោធិ៍សាត់)។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់ដារ៉ា-ស ឯកសារ E3/5732 ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00916998-00916999។

[១៧៦៥] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣២-៣៤ (ចាន់ សុជាតិ និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសពីភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយមកស្នាក់នៅស្រុក កៀនស្វាយ រយៈពេល ៦ ខែ មុនពេលត្រូវបានជម្លៀសម្តងទៀត) ។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៨-៧០ (យឹម សុវណ្ណ និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសចេញពីភ្នំពេញកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ជាចុងក្រោយបានមកដល់ភូមិលេខ៥ ឃុំពោធិ៍បាន ខេត្តកណ្តាល មុនពេលគាត់ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀតនៅដើមឆ្នាំ១៩៧៦)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៣៨-៤៤, ៤៥ (កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ សូផាន់ សូវណ្ណី និងគ្រួសារគាត់ត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ មកដល់ចុងក្រោយនៅភូមិរកាកោង ខេត្តកណ្តាល មុនពេលគាត់ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀត)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨១-៨៣ (កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឡាយ បូនី និងគ្រួសារគាត់ ត្រូវបានជម្លៀសពីភ្នំពេញ និងឈប់សម្រាកជាច្រើនកន្លែងមុនពេលមកឈប់ចុងក្រោយនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ក្រោយមក ពួកគាត់ត្រូវបានជម្លៀសទៅបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២-៣, ៤៥ (បានមកដល់ខេត្តបាត់ដំបងនៅឆ្នាំ១៩៧៦)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អោ រី ឯកសារ E3/3967 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00565893-00565894 (អោ រី និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសពីភ្នំពេញទៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលនៅខែមេសា ឆ្នាំ១៩៧៥ មុនពេលត្រូវបានជម្លៀសម្តងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00526041-00526042 (សួន សុផា និងគ្រួសារគាត់ ត្រូវបានជម្លៀសពីភ្នំពេញទៅខេត្តព្រៃវែង និងបន្ទាប់មកជម្លៀសទៅខេត្តកណ្តាលនៅខែកក្កដា ឆ្នាំ១៩៧៥ មុនពេលគាត់ត្រូវបានផ្លាស់ទីលំនៅម្តងទៀត)។

[១៧៦៦] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥-៦ (កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពិន យ៉ាថៃ និងគ្រួសារគាត់ត្រូវបានជម្លៀសពីភ្នំពេញ ហើយរស់នៅមួយរយៈពេលយូរនៅ ឈើខ្មៅ ខេត្តកណ្តាល (ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥-ខែ កក្កដា ឆ្នាំ ១៩៧៥) និងនៅ សមរលាវ ខេត្ត តាកែវ (ខែកក្កដា-កញ្ញា ឆ្នាំ ១៩៧៥) មុនពេលគាត់ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀតនៅខែកញ្ញា ឆ្នាំ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ២៩-៣៦ (ទឹង សុខា និងគ្រួសារគាត់ត្រូវបានជម្លៀសពីភ្នំពេញទៅស្រុកបាទី ខេត្តតាកែវនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលជាកន្លែងពួកគាត់រស់នៅអស់រយៈពេល ០៥ ខែ មុនពេលពួកគាត់ត្រូវបានគេផ្លាស់ទីលំនៅជា

ថ្មីម្តងទៀតនៅចុងឆ្នាំ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ០៣-០៧ ERN (ភាសាខ្មែរ) 00420971-00420975 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គង់ វាច និងគ្រួសារគាត់ ត្រូវបានជម្លៀសចេញពីភ្នំពេញ (ប្តីគាត់ធ្លាប់ជាទាហាន លន់ នល់ និងត្រូវបានយកទៅបាត់ក្នុងអំឡុងពេលនៃការជម្លៀសចេញពីភ្នំពេញ) ទៅភូមិ ចក ខេត្ត តាកែវ មុនពេលពួកគាត់ត្រូវបានផ្លាស់ទីលំនៅម្តងទៀត)។

[១៧៦៧] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ូន ផល្លី) ទំព័រ ២៧-២៩ (អ៊ូន ផល្លី និងគ្រួសារគាត់ ត្រូវបានជម្លៀសចេញពីភ្នំពេញកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានធ្វើដំណើរអស់រយៈពេល១៥ថ្ងៃ ទៅកាន់ខេត្តព្រៃវែង មុនពេលពួកគាត់ត្រូវបានផ្លាស់ទីលំនៅម្តងទៀតទៅកាន់ខេត្តបាត់ដំបង នៅចុងឆ្នាំ១៩៧៦ ឬ ឆ្នាំ១៩៧៧)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00323529-00323531 (សែម វីរៈ និងគ្រួសារគាត់ ត្រូវបានជម្លៀសចេញពីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅកាន់ជ្រែកឃ្មុំ ខេត្តព្រៃវែង មុនពេលគាត់ត្រូវបានគេផ្លាស់ទីលំនៅម្តងទៀត)។ ទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ២-៤ ERN (ភាសាខ្មែរ) 00559761-00559763 (ឆិត សារុន និងគ្រួសារគាត់ ត្រូវបានជម្លៀសចេញពីបាក្រុង ខេត្តស្វាយរៀង ទៅកាន់ក្រសាំង ខេត្តព្រៃវែង មុនពេលពួកគាត់ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀត)។

[១៧៦៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ារឌី E3/5613 ឯកសារ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00491045-00491046 (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ សេង ម៉ារឌី និងគ្រួសារគាត់ត្រូវបានជម្លៀសពីភ្នំពេញទៅកៀនស្វាយ ខេត្តកណ្តាល។ មុនរដូវច្រូតកាត់បន្តិចនៅឆ្នាំ១៩៧៥ សេង ម៉ារឌី និងគ្រួសារគាត់បានទៅព្រៃវែងដើម្បីបន្តដំណើរទៅកាន់ភូមិកំណើតរបស់ពួកគាត់នៅខេត្តស្វាយរៀង។ នៅស្វាយរៀង សេង ម៉ារឌី និងគ្រួសារគាត់បានស្នាក់នៅមួយរយៈពេលខ្លី មុនពេលពួកគាត់ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពុធ ពុំ ឯកសារ E3/4714 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00397780-00397781 (ពុធ ពុំ និងគ្រួសារគាត់ ត្រូវបានជម្លៀសពីភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅកាន់ស្វាយរៀង ដែលជាកន្លែងគាត់ស្នាក់នៅកាលពីខែមិថុនា ឆ្នាំ១៩៧៥ មុនពេលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ រយៈពេល៣ខែ។ គាត់ត្រូវបានចាត់ឲ្យទៅភូមិតាជ័យ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងរយៈពេល៣ខែមុនពេលត្រូវបានផ្លាស់ប្តូរទីលំនៅម្តងទៀត)។

[១៧៦៩] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជួន សំអាត ឯកសារ E3/4707 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00387631 (ជួន សំអាត និងគ្រួសារគាត់ត្រូវបានជម្លៀសពីភ្នំពេញទៅស្រុកអរិយក្សត្រ និង ២ ខែក្រោយមក (ប្រហែលខែមិថុនា/កក្កដា ឆ្នាំ១៩៧៥) ត្រូវបានជម្លៀសទៅអូររាំងឪ ខេត្តកំពង់ចាម មុនពេលត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00368783-00368784 (កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ សាយ កាណាល់ និងគ្រួសារគាត់ ត្រូវបានជម្លៀសពីភ្នំពេញទៅកាន់ព្រៃរំដេង ខេត្តកំពង់ចាម មុនពេលត្រូវបានផ្លាស់ទីលំនៅម្តងទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ីម ឯកសារ

ក្នុងពេលជម្លៀស "ដំណាក់កាលទី២"[១៧៧០]។ នៅតំបន់ខ្លះមានតែ "ប្រជាជនថ្មី" តែប៉ុណ្ណោះ ដែលត្រូវបានផ្លាស់ទីលំនៅ[១៧៧១] ចំណែកនៅតំបន់ផ្សេងទៀត ទាំង "ប្រជាជនចាស់" ទាំង "ប្រជាជនថ្មី"

---

E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៤-៧ ERN (ភាសាខ្មែរ) 00565831-00565834 (លី ហ៊ីម និងគ្រួសារគាត់ត្រូវបានជម្លៀសចេញពីភ្នំពេញទៅខេត្តកំពង់ចាម មុនពេលត្រូវបានផ្លាស់ទីលំនៅម្តងទៀត)។

[១៧៧០] ប្រតិចារឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣-៧៤ (មេដឹកនាំរបស់កងការងាររបស់ យឹម សុវណ្ណ បានប្រាប់គាត់ថា នេះគឺជាផ្នែកនៃការជម្លៀសដំណាក់កាលទី២)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៤៩។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្តីដកស្រង់មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ១៩៧៦ នៅក្នុង ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213 ទំព័រ ៥៣-៥៦ ERN (ភាសាខ្មែរ) 00062868-00062869។ *កម្ពុជា៖ របាយការណ៍របស់សារព័ត៌មាន The New York Times អំពីការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀតដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស* (AFP) ឯកសារ E3/4170 ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00548749 (ចាប់តាំងពីខែតុលា ឬដើមខែវិច្ឆិកា ឆ្នាំ១៩៧៦ ប្រជាជនខ្មែរជាច្រើនត្រូវបានជម្លៀសពីតំបន់មួយទៅតំបន់មួយទៀតនៃប្រទេសភាគច្រើនខេត្តបាត់ដំបង)។ *សេចក្តីសន្និដ្ឋានពីគណៈកម្មការអន្តរជាតិនៃអ្នកជំនាញផ្នែកច្បាប់តាមរយៈសេចក្តីប្រកាស លេខ ៩ របស់គណៈកម្មការសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/1804 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00235804-00235805 (ចាប់ផ្តើមនៅខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៥ ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីភ្នំពេញ ត្រូវបានគេផ្លាស់ទីលំនៅម្តងទៀតទៅកាន់ភូមិភាគពាយ័ព្យ)។ *ប្រទេសកម្ពុជាស្ថិតក្នុងកណ្តាប់ដៃដែករបស់ខ្មែរក្រហម* (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា) ឯកសារ E3/4441 ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00708572-00708573 (យោងតាមជនភៀសខ្លួនក្នុងអំឡុង២ខែចុងក្រោយក្នុងឆ្នាំ១៩៧៥ជនភៀសខ្លួនចំនួន ៣០០.០០០ នាក់ មកពីភ្នំពេញ ត្រូវបានជម្លៀសម្តងទៀតតាមកាណូតខ្លះ និងតាមរថភ្លើងខ្លះ ទៅកាន់ខេត្តបាត់ដំបង)។

[១៧៧១] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣-៧៥ (ប្រជាជន ១៧ មេសា ត្រូវបានផ្លាស់ទីលំនៅម្តងទៀតនៅពេលជម្លៀសដំណាក់កាលទី២)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សួផាន់ សូវណ្ណី) ទំព័រ ៤៥ (គេបានប្រកាសថា ប្រជាជនថ្មីនៅភូមិរកាកោង នឹងត្រូវជម្លៀស)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO)ទំព័រ៦៥-៦៦ (អង្គការបានផ្តល់បញ្ជីឈ្មោះដែលសុទ្ធតែប្រជាជនថ្មីដែលត្រូវជម្លៀស)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៧-៣៨ (ប្រជាជនដែលចេះដឹង រួមទាំង ទឹង សុខា និងគ្រួសារគាត់ ត្រូវបានជម្លៀសផងដែរ)។ ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ (អូន ផល្លី) ទំព័រ ៣៧-៣៨, ៤២-៤៣ (ប្រជាជន១៧ មេសា ទាំងអស់ត្រូវបានជម្លៀស ប៉ុន្តែប្រជាជនមូលដ្ឋានមិនត្រូវបានជម្លៀសនោះទេ)។ ប្រតិចារឹក ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៤-៨៦ (ប្រជាជន ១៧ មេសាតែប៉ុណ្ណោះ ត្រូវបានជម្លៀសពីស្រុកស្អាង ខេត្តកណ្តាល)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៦-៨៧ (ប្រជាជនថ្មីប៉ុណ្ណោះត្រូវបានបញ្ជូនចេញ ប៉ុន្តែរក្សាទុកប្រជាជនមូលដ្ឋាន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អោ រី ឯកសារ E3/3967 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00565893-00565894 (នៅចុងឆ្នាំ១៩៧៥ "អ្នកមកថ្មី"ទាំងអស់ ត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង)។ កំណត់ហេតុនៃការ

ត្រូវបានផ្លាស់ទីលំនៅ[១៧៧២]។ កម្មាភិបាលខ្មែរក្រហម[១៧៧៣] រួមទាំងប្រធានភូមិ[១៧៧៤] និងអង្គការ[១៧៧៥] បានបញ្ជាឲ្យប្រជាជនចាកចេញ បើមិនដូច្នោះទេនឹងប្រឈមជាមួយនឹងផលវិបាកនានា ដូចជាការ

---

ស្តាប់ចម្លើយសាក្សី ថេង ហ៊ុយ ឯកសារ E3/5244 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00224796-00224797 (ប្រជាជនភាគច្រើនមកពីស្វាយអន្ទរ ខេត្តព្រៃវែង គឺជាប្រជាជន ១៧ មេសា ឬប្រជាជនថ្មី)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ីម ឯកសារ E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00565832-00565834 (ប្រជាជនថ្មីរាប់រយនាក់ត្រូវបានជម្លៀសចេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN 00249909-00249910 (នៅចុងឆ្នាំ១៩៧៦ កម្មាភិបាលខ្មែរក្រហមបានហៅប្រជាជនថ្មីទាំងអស់ រួមមានប្រជាជនទាំងឡាយដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ និងក្រុងស្វាយរៀង ទៅប្រជុំនៅស្វាយយា ខេត្តស្វាយរៀង។ ពួកគេបានប្រកាសថា យោងតាមគោលនយោបាយ "មហាអស្ចារ្យ មហាលោតផ្លោះ" ប្រជាជនថ្មីត្រូវតែទៅខេត្តពោធិ៍សាត់។ ពួកគេមានបញ្ជីឈ្មោះអ្នកដែលត្រូវជម្លៀសចេញ។ ៣០គ្រួសារដែលជាប្រជាជនថ្មីទាំងអស់ ត្រូវបានផ្លាស់ទីលំនៅ។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00349497-00349498 (ប្រជាជន១៧ មេសា តែប៉ុណ្ណោះ ត្រូវបានជម្លៀសពីខ្នុររកា ស្រុកល្វាឯម ខេត្តកណ្តាល)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦០-៦១ ERN (ភាសាខ្មែរ) 00836137-00836138 (នៅខែមេសា និងខែមិថុនា ឆ្នាំ១៩៧៥ ប្រជាជនក្នុងមួយភូមិនៅស្រុកស្អាង បានកើនឡើងដោយសារមានប្រជាជនថ្មីរាប់ពាន់នាក់។ នៅខែកញ្ញា/តុលា ឆ្នាំ១៩៧៥ នៅសល់តែ ៧ ឬ ៨ គ្រួសារប៉ុណ្ណោះ ក្រោយពីការជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ)។

[១៧៧២] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៧-៤៨, ៥៣-៥៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ព្រឿន ឯកសារ E3/5132 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00165245-00165246 (ប្រជាជនចាស់សុខចិត្តឲ្យគេជម្លៀស)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦០-៦១ ERN (ភាសាខ្មែរ) 00836137-00836138 (ប្រជាជនចាស់ជាច្រើនត្រូវបានជម្លៀសចេញ)។

[១៧៧៣] បទសម្ភាសន៍ SOAS ជាមួយ ប៊ុត សាវន ឯកសារ E3/4659 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00788308-00788309 (បទបញ្ជាចេញមកពីថ្នាក់ស្រុកឲ្យជម្លៀសប្រជាជន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00323530-00323531 (នៅដើមឆ្នាំ ១៩៧៦ មេភូមិខ្មែរក្រហមបានទទួលបញ្ជាជាលាយលក្ខណ៍អក្សរពីថ្នាក់លើរបស់គាត់ ដើម្បីបញ្ជូនប្រជាជនដែលមកពីភ្នំពេញទាំងអស់ទៅកាន់ខេត្តបាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557954-00557955 ("ពួកខ្មែរក្រហម" បានជម្លៀស សាន មុំ និងគ្រួសារ ពី ភូមិ ក្ការ ខេត្ត ស្វាយរៀង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២-៦៣ ERN (ភាសាខ្មែរ) 00836139-00836140 ("ខ្មែរក្រហម" បានបញ្ជាឲ្យប្រជាជនចាកចេញ)។

ឃុំខ្លួន ការអប់រំកែប្រែ ឬការផ្លាស់ទីលំនៅនាពេលក្រោយៗទៀត[១៧៧៦]។ ប្រធានភូមិ និងកម្មាភិបាលខ្មែរក្រហមខ្លះ បានសួររកអ្នកស្ម័គ្រចិត្ត[១៧៧៧]។

---

[១៧៧៤] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៧-៤៨, ៥៣-៥៤ (នៅចុងឆ្នាំ១៩៧៥ មេភូមិបានបញ្ជា សាំង រ៉ាត់ ប្តីគាត់ កូនប្រុសគាត់៤នាក់ និង៤ ឬ ៥ គ្រួសារផ្សេងទៀត ឲ្យចាកចេញពីភូមិរបស់ពួកគាត់ នៅស្រុកសំរោង ខេត្តកំពង់ស្ពឺ ទៅកាន់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ពួកគាត់បានស្នើសុំឲ្យនៅកន្លែងដដែល ប៉ុន្តែនេះជា "បញ្ជាដាច់ខាត" ហើយពួកគាត់ត្រូវតែចាកចេញ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៤-៨៦ (មេភូមិបានណែនាំឲ្យប្រជាជនថ្មីនៅស្រុកខ្សាច់កណ្តាលរៀបចំចាកចេញ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៣៦-៣៧ (មេភូមិបានបញ្ជាឲ្យពួកគាត់ចាកចេញ)។

[១៧៧៥] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤៥ (តាមរយៈសេចក្តីបង្គាប់របស់អង្គការ ពួកគាត់ត្រូវបានផ្លាស់ទីលំនៅ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ណុប ណន ឯកសារ E3/5423 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ៧-៨ ERN (ភាសាខ្មែរ) 00481176-00481177 (នៅដើមឆ្នាំ១៩៧៦ អង្គការបានជម្លៀស ណុប ណន និងគ្រួសារគាត់ ជាមួយនឹងអ្នកផ្សេងទៀតចេញពីខេត្តកំពង់ស្ពឺ។ ពួកគាត់ត្រូវបានបញ្ជាឲ្យចាកចេញ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឃ្លោក ផាត ឯកសារ E3/5467 ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៩-១១ ERN (ភាសាខ្មែរ) 00506066-00506068 (អង្គការបានប្រាប់ម្តាយ និងសាច់ញាតិឲ្យផ្លាស់ទីលំនៅទៅពោធិ៍សាត់ដែលជាកន្លែងមានស្រូវច្រើនលើសលុប)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សូ សាមិត ឯកសារ E3/5393 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00479161-00479162 (បងប្អូនប្រុស និងបងប្អូនស្រីរបស់គាត់ ត្រូវបានអង្គការជម្លៀសចេញពីខេត្តកណ្តាល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ចាច់ យ៉ួង ឯកសារ E3/5427 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00483320-00483321 (គ្រួសាររបស់បងប្រុសរបស់ចាច់ យ៉ួង ជាមួយនឹងប្រជាជនជាច្រើនផ្សេងទៀត ត្រូវបានអង្គការជម្លៀសពីខេត្តកណ្តាល)។ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផាន់ យីម ឯកសារ E3/5424 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00481187-00481188 (ផាន់ យីម និងគ្រួសារគាត់ត្រូវបានអង្គការជម្លៀសពីខេត្តតាកែវ)។

[១៧៧៦] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ៣៦-៣៨ (ពួកគាត់ត្រូវបានបញ្ជាឲ្យចាកចេញពីខេត្តព្រៃវែង ហើយពួកគាត់ត្រូវតែគោរពតាមបទបញ្ជានេះ ឬ ប្រឈមនឹងផលវិបាក។ ពួកខ្មែរក្រហមបានបង្ខំឲ្យពួកគាត់ធ្វើតាមបញ្ជា)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣ (ពួកគាត់ត្រូវបានប្រាប់ថា ប្រសិនបើពួកគាត់បដិសេធមិនព្រមចាកចេញ ពួកគាត់នឹងត្រូវឃុំខ្លួន)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា)ទំព័រ ៥៣-៥៥(ទឹង សុខា និងអ្នកផ្សេងទៀតដែលបានលួចរត់ចូលព្រៃដើម្បីកុំឲ្យគេជម្លៀស ត្រូវបានគេចាប់បាន និងត្រូវបានជម្លៀសទៅពាយ័ព្យប្រហែលមួយខែក្រោយមក)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ឯកសារ E3/5787 ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00373425 (ប្រជាជន ១៧ មេសា ត្រូវបានបញ្ជាឲ្យចាកចេញ។ ប្រសិនបើ យឹម សុវណ្ណ ចង់ស្នាក់នៅពោធិ៍បាន គាត់នឹងត្រូវបានយកទៅមន្ទីរសន្តិសុខ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00349498-00349499 (ប្រជាជនត្រូវបានប្រាប់ថា អ្នកណាបដិសេធមិន

៥៨៩. ប្រជាជនត្រូវបានប្រាប់មូលហេតុផ្សេងៗគ្នាអំពីការតាំងទីលំនៅថ្មីរបស់ពួកគេ។ ប្រជាជនភាគច្រើនត្រូវបានប្រាប់ ឬ ជឿថា ស្បៀងអាហារនៅតាមតំបន់របស់ពួកគេនៅក្នុងភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ពុំគ្រប់គ្រាន់សម្រាប់ចិញ្ចឹមអ្នកមកថ្មីឡើយ[១៧៧៨] ស្បៀងអាហារមានច្រើននៅខេត្តបាត់ដំបង[១៧៧៩] និងខេត្តពោធិ៍សាត់[១៧៨០] ដីនៅខេត្តបាត់ដំបង[១៧៨១]មានជីជាតិជាង

---

ព្រមទៅ នឹងត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ហើយអង្គការនឹងយកអ្នកទាំងនោះទៅអប់រំ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN 00249910 (គ្មាននរណាម្នាក់ត្រូវបានគេទុកជីវិតនោះទេ សូម្បីតែកូនក្មេងក៏គ្មានដែរ)។

[១៧៧៧] ប្រតិចារឹក ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣(ពិន យ៉ាថៃ) ទំព័រ៥-៦ (នៅខែ កញ្ញា ឆ្នាំ ១៩៧៥ មេភូមិបានអំពាវនាវរកអ្នកស្ម័គ្រចិត្តដើម្បីផ្លាស់ទីលំនៅពីស្រុកសមរលាភ ខេត្តតាកែវ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ព្រឿន ឯកសារ E3/5132 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00165245-00165246 (ប្រជាជនចាស់បានស្ម័គ្រចិត្តចេញពីខេត្តកំពង់ចាម)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង សុខុម ឯកសារ E3/4702 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00368960-00368961 (នៅដើមឆ្នាំ១៩៧៦ ទាហានខ្មែរក្រហមបានអំពាវនាវរកអ្នកស្ម័គ្រចិត្តដើម្បីទៅពោធិ៍សាត់ ឬបាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00526041-00526042 (ខ្មែរក្រហមបានអំពាវនាវរកអ្នកស្ម័គ្រចិត្តដើម្បីផ្លាស់ទីលំនៅទៅបាត់ដំបង)។

[១៧៧៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៥-៨៧។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៣៦-៣៨ (ប្រធានភូមិបានរៀបរាប់ថា ពួកគាត់ត្រូវតែចាកចេញ ដោយសារតែស្បៀងមានមិនគ្រប់គ្រាន់នៅខេត្តកណ្តាល ហើយស្បៀងមានច្រើននៅបាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ព្រឿន ឯកសារ E3/5132 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00165245-00165246 (ពួកខ្មែរក្រហមបាននិយាយថា មានស្រូវជាច្រើននៅពោធិ៍សាត់ និងបាត់ដំបង ខណៈពេលដែលនៅកំពង់ចាម មានតែបបររាវៗ ប៉ុណ្ណោះ)។

[១៧៧៩] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៥៤-៥៥ (ទាហានខ្មែរក្រហមបានប្រាប់ សាំង រ៉ាត់ ថាគេបញ្ជូនគាត់ទៅបាត់ដំបង ដែលជាកន្លែងមានស្បៀងជាច្រើន)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៧ (អ្នកគ្រប់គ្នានៅកម្ពុជា បានដឹងថា ខេត្តបាត់ដំបងគឺជាខេត្តសម្បូរហូរហៀរ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៣ (សួផាន់ សូវណ្ណី) ទំព័រ៤៥ (ពួកខ្មែរក្រហមបាននិយាយថា មានស្បៀងច្រើននៅបាត់ដំបង និងពោធិ៍សាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប ព្រឿន ឯកសារ E3/5132 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00165245-00165246 (ពួកខ្មែរក្រហមបាននិយាយថា មានស្រូវជាច្រើននៅពោធិ៍សាត់ និងបាត់ដំបង)។ បទសម្ភាសន៍ SOAS ជាមួយ ប៊ុត សាវន ឯកសារ E3/4659 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ ទំព័រ១-២ ERN (ភាសាខ្មែរ)00788308-00788309 (ប្រជាជនជាច្រើនគិតថា នៅបាត់ដំបងប្រហែលជាស្រួលជាង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00526041-00526042 (ពួកគាត់បានគិតថា អាចមានស្រូវគ្រប់គ្រាន់

និង/ឬ នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ពុំមានកម្លាំងមនុស្សគ្រប់គ្រាន់ឡើយ[១៧៨២]។ ប្រជាជនផ្សេងទៀតត្រូវបានគេប្រាប់ថា ពួកគេកំពុងត្រូវបានបញ្ជូនត្រឡប់ទៅស្រុកកំណើតរបស់ពួកគេវិញ[១៧៨៣]។ ជាលទ្ធផល ប្រជាជនខ្លះសប្បាយចិត្ត ហើយស្ម័គ្រចិត្តចាកចេញ[១៧៨៤]។ ប្រជាជនផ្សេងទៀត

---

សម្រាប់បរិភោគនៅបាត់ដំបង ដោយសារតែនៅទីនោះត្រូវបានគេដឹងថាមានស្រូវច្រើន)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Michael VICKERY ៖ កម្ពុជាឆ្នាំ ១៩៧៥ -១៩៨២ ឯកសារ E3/1757 ទំព័រ ៤៤-៤៨ ERN (ភាសាខ្មែរ) 00789212-00789216។

[១៧៨០] ប្រតិចារឹក ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣-៧៤។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ ឯកសារ E3/5787 ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00373425 (ខ្មែរក្រហមមួយរូប បានប្រាប់ យឹម សុវណ្ណ ថាមានស្រូវច្រើននៅពោធិ៍សាត់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថេង ហ៊ុយ ឯកសារ E3/5244 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00224796-00224797 (មុនជម្លៀស គណៈស្រុកបានប្រកាសនៅកន្លែងប្រជុំប្រជាជន និងរដ្ឋអំណាចមូលដ្ឋានថាមានផ្លែឈើ និងស្រូវជាច្រើននៅខេត្តពោធិ៍សាត់)។

[១៧៨១] កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី គៀង វណ្ណារី ឯកសារ E3/5310 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00349486-00349487 (ខ្មែរក្រហមបានប្រាប់ពួកគាត់ឲ្យផ្លាស់ទីលំនៅដោយសារតែមានដីមានជីវជាតិជាច្រើននៅបាត់ដំបង)។

[១៧៨២] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៊ុត សូត្រ ឯកសារ E3/4823 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00523356-00523357 (ខ្មែរក្រហមបានប្រាប់ពួកគាត់ថា មានវាលស្រែជាច្រើននៅខេត្តបាត់ដំបង ប៉ុន្តែមិនមានប្រជាជនគ្រប់គ្រាន់ដើម្បីច្រូតកាត់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជា ឡេង ឯកសារ E3/5231 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00267730 (ខ្មែរក្រហមបានរៀបរាប់ថាកន្លែងមួយចំនួននៅខេត្តពោធិ៍សាត់ខ្វះកម្លាំងមនុស្ស)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00709583-00709584 (ជនភៀសខ្លួនមួយរូបបានលើកឡើង ថា ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង មានដីទំនេរច្រើនដែលខ្មែរក្រហមចង់ឲ្យបង្កបង្កើនផលបានច្រើន)។

[១៧៨៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤ (ចាន់ សុជាតិ និងគ្រួសារគាត់ ត្រូវបាន “មេដឹកនាំអង្គការ” ប្រាប់ថា ពួកគាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ពីស្រុកកៀនស្វាយ ទៅ ភ្នំពេញវិញ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជា ឡេង ឯកសារ E3/5231 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00267730 (ពួកគាត់ត្រូវបានប្រាប់ថា គេនឹងនាំពួកគាត់ទៅស្រុកកំណើតវិញ ប៉ុន្តែបែរជានាំពួកគាត់ទៅពោធិ៍សាត់វិញ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២០៧-២០៨ ERN (ភាសាខ្មែរ) 00836284-00836285 (ប្រជាជនត្រូវបានប្រាប់ថា ពួកគាត់នឹងត្រូវបានឲ្យត្រឡប់ទៅភ្នំពេញ ដែលមានកន្លែងស្នាក់នៅស្រាប់ហើយ ដូច្នេះពួកគាត់មិនបាច់យកអ្វីតាមខ្លួននោះទេ) ទំព័រ ២១៤-២១៥ ERN (ភាសាខ្មែរ) 00836291-00836292 (ពួកគាត់ត្រូវបានប្រាប់ថា រដ្ឋាភិបាលបានអនុញ្ញាតឲ្យប្រជាជនដែលមកពីបាត់ដំបង កំពង់ធំ និងកំពង់ឆ្នាំង

ពុំទទួលបានការពន្យល់អ្វីឡើយ[១៧៨៥] ។ ប្រជាជនផ្សេងទៀតយល់ឃើញថា ការនៅក្បែរព្រំប្រទល់ប្រទេសថៃអាចជួយសម្រួលពួកគេក្នុងការរត់គេចខ្លួនពីខ្មែរក្រហម[១៧៨៦] ។ ប្រជាជនជាច្រើននាក់

---

ត្រឡប់ទៅភូមិកំណើតវិញ។ តាមការពិត គេប្រាប់ដូច្នេះដើម្បីបង្ខំប្រជាជនឲ្យទៅខេត្តបាត់ដំបងវិញ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ទំព័រ ៣០៨-៣០៩ ERN (ភាសាខ្មែរ) 00232306-00232307។

[១៧៨៤] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៦-៨៧។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៦-២៧ (ពួកគាត់សប្បាយចិត្តនៅពេលត្រូវបានជម្លៀស ទោះបីជាគាត់មិនមានជម្រើសក៏ដោយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤ (ពួកគាត់សប្បាយចិត្តអំពីលទ្ធភាពអាចត្រឡប់មកផ្ទះរបស់ពួកគាត់វិញ។ ឪពុករបស់គាត់ជឿជាក់ថា រដ្ឋាភិបាលថ្មីនឹងត្រូវការវិស្វករដូចគាត់ ហើយជីវិតនឹងមានភាពប្រសើរនៅទីក្រុងភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថេង ហ៊ុយ ឯកសារ E3/5244 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00224796-00224797 (មុនពេលការជម្លៀស គណៈស្រុកបានប្រកាសនៅកន្លែងជួបប្រជុំប្រជាជន និងអាជ្ញាធរមូលដ្ឋានថា មានផ្លែឈើ និងអង្ករជាច្រើននៅខេត្តពោធិ៍សាត់។ ប្រជាជនថ្មី និងប្រជាជនចាស់មួយចំនួន បានស្ម័គ្រចិត្ត ប៉ុន្តែប្រជាជនមួយចំនួនដែលមិនស្ម័គ្រចិត្ត ក៏ត្រូវបានបង្ខំឲ្យទៅដែរ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឃ្លោក ផាត ឯកសារ E3/5467 ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៩-១១ ERN (ភាសាខ្មែរ) 00506066-00506068 (នៅខេត្តកណ្តាល មិនមានស្បៀងគ្រប់គ្រាន់ទេ។ នៅឆ្នាំ១៩៧៦ អង្គការបានប្រាប់ម្តាយគាត់ និងបងប្អូនគាត់ឲ្យផ្លាស់ទៅពោធិ៍សាត់ដែលជាកន្លែងមានស្រូវច្រើន។ ដោយសារតែប្រជាជនអត់ឃ្លាននៅកៀនស្វាយ ពួកគាត់មិនបានបដិសេធនោះទេ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ-កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៨-៣០៩ ERN (ភាសាខ្មែរ) 00232306-00232307 (ប្រជាជនត្រូវបានប្រាប់ថា ពួកគាត់នឹងត្រូវត្រឡប់មកផ្ទះវិញនៅភ្នំពេញ ប្រជាជនថ្មីបានលះបង់ដោយស្ម័គ្រចិត្តនូវផ្លែផ្កាការងាររបស់ពួកគេចោលនៅក្នុងភូមិភាគនិរតី បានបោះបង់ចំណែកច្រូតកាត់របស់ពួកគេ និងបានទៅភាគខាងជើងដែលជាកន្លែងមានការខ្វះខាតស្បៀងអាហារ ឬទីជម្រកតិចតួច)។

[១៧៨៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៥-៨៦។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ដេនីស អាហ្វុងសូ) ទំព័រ ៦៥-៦៦, ទំព័រ ៤១-៤២ (ពួកគាត់មិនមានព័ត៌មានទាក់ទិននឹងមូលហេតុនៃការជម្លៀស ឬ គោលដៅរបស់ពួកគេនោះទេ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៥-១៩៦ ERN (ភាសាខ្មែរ) 00836272-00836273 (ពួកគាត់បានផ្លាស់ទីលំនៅទៅខេត្តបាត់ដំបង ដោយមិនមានការព្រមានជាមុន និងមិនមានព័ត៌មានទាក់ទិននឹងទិសដៅរបស់ពួកគាត់នោះទេ)។

[១៧៨៦] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥-៦ (ដោយយល់ឃើញថា បាត់ដំបងនៅក្បែរព្រំដែនថៃ និងឱកាសលួចរត់ ពិន យ៉ាថៃ សុខចិត្តលួចរត់)។

ដែលពុំត្រូវបានផ្លាស់ទីលំនៅ ពុំទទួលបានព័ត៌មានបន្ថែមអំពីប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះឡើយ[១៧៨៧]។

៥៩០. ក្រោយពីត្រូវបានផ្លាស់ទីលំនៅចេញពីភូមិរបស់ពួកគេ ប្រជាជនត្រូវបានជម្លៀសជា៣ដំណាក់កាល។ នៅក្នុងដំណាក់កាលទី១ ពួកគេត្រូវបានប្រមូលយកទៅដាក់នៅតាមទីតាំងប្រមូលផ្តុំ (ផ្នែក១១.២.១) បន្ទាប់មក ពួកគេត្រូវបានដឹកញ្ជូនតាមរថភ្លើង ឬ តាមឡាន ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តព្រះវិហារ (តំបន់១០៣) (ផ្នែក១១.២.២) និងដំណាក់កាលចុងក្រោយ ពួកគេត្រូវបានដឹកជញ្ជូនទៅដាក់នៅតាមសហករណ៍ ឬ ការដ្ឋានធ្វើការងារដែលបានកំណត់ (ផ្នែក ១១.២.៣)[១៧៨៨]។

---

[១៧៨៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៤១-៤២ (នូ ម៉ៅ មានសាច់ញាតិដែលត្រូវបានជម្លៀសពីភូមិភាគនិរតី ទៅកាន់កំពង់ឆ្នាំង ហើយគាត់លែងបានដំណឹងអំពីជោគវាសនារបស់ពួកគេទៀតឡើយ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ចាច់ យ៉ុង ឯកសារ E3/5427 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00483320-00483321 (គ្រួសាររបស់បងប្រុសគាត់ ជាមួយនឹងអ្នកផ្សេងជាច្រើនទៀត ត្រូវបានអង្គការជម្លៀសទៅពោធិ៍សាត់។ ពួកគេបានបាត់ខ្លួនទាំងអស់គ្នា)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ គឹម បូហាណារុទ្ធី ឯកសារ E3/5478 ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ១១-១៦ ERN (ភាសាខ្មែរ) 00512494-00512499 ERN (ប្រហែលជាខែតុលា ឆ្នាំ ១៩៧៥ បងស្រីគាត់ បងថ្លៃ និងបងប្អូនជីដូនមួយគាត់ ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង។ ក្រោយពីពេលនោះមក គាត់មិនដែលទទួលព័ត៌មានអំពីពួកគេនោះទេ)។

[១៧៨៨] *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤៣-៤៤ (ប្រជាជនត្រូវបានដឹកជញ្ជូនតាមរថភ្លើងមកភ្នំពេញ និងបន្ទាប់មកដឹកទៅកាន់បាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សឿន ឯកសារ E3/5531 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00418510-00418511 (ប្រជាជនថ្មីត្រូវបានជម្លៀសទៅកាន់ទន្លេ រួចបញ្ជូនតាមកាណូតមកទីក្រុងភ្នំពេញ ហើយបន្តដំណើរទៅខេត្តពោធិ៍សាត់ និងខេត្តផ្សេងៗទៀតតាមរថភ្លើង)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ៤១-៤២ (ប្រជាជនថ្មីត្រូវបានដឹកដោយរថភ្លើង និងឡានមកពីភ្នំពេញ ហើយត្រូវបានបញ្ជូនទៅភូមិផ្សេងៗ)។ *ប្រទេសកម្ពុជាស្ថិតក្នុងកណ្តាប់ដៃដែករបស់ខ្មែរក្រហម* (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា) ឯកសារ E3/4441 ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) S00708572-00708573 (យោងតាមជនភៀសខ្លួន ក្នុងអំឡុង២ ខែចុងក្រោយក្នុងឆ្នាំ ១៩៧៥ ជនភៀសខ្លួនចំនួន ៣០០.០០០ នាក់មកពីភ្នំពេញ ត្រូវបានជម្លៀសម្តងទៀតតាមកាណូតខ្លះ និងតាមរថភ្លើងខ្លះទៅកាន់ខេត្តបាត់ដំបង)។

### ១១.២.១ ដំណាក់កាលទី១៖ ការបញ្ជូនទៅដាក់នៅទីតាំងប្រមូលផ្តុំ

៥៩១. ប្រជាជនត្រូវបានដឹកជញ្ជូនតាមឡាន តាមកាណូត ឬ កប៉ាល់ តាមរទេះគោ និងដើរដោយថ្មើរជើងទៅកាន់ទីតាំងប្រមូលផ្តុំ ។ លក្ខខ័ណ្ឌនៃការផ្លាស់ទីលំនៅរបស់ពួកគេ អាស្រ័យទៅតាមមធ្យោបាយនៃការដឹកជញ្ជូនជាក់លាក់ ។ ឡានដែលបើកទៅកាន់ទីតាំងប្រមូលផ្តុំ រួមទាំង នៅក្រុងភ្នំពេញ និងខេត្តកំពង់ឆ្នាំង (ភូមិភាគបស្ចិម) មានមនុស្សជិះណែន[១៧៨៩]។ ប្រជាជនត្រូវបានគេតាមដានជាប្រចាំ គ្មានទឹក និងគ្មានស្បៀងអាហារហូបគ្រប់គ្រាន់ ហើយពុំត្រូវបានអនុញ្ញាតឲ្យយករបស់របរទៅតាមខ្លួនឡើយ[១៧៩០]។ ប្រជាជនឈឺនៅតាមឡាន ប៉ុន្តែពុំទទួលបានការជួយឧបត្ថម្ភអ្វី

---

[១៧៨៩] ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៦ (ខ្មែរក្រហមបានដឹក ធុច ផាន់ដារា-ស និងគ្រួសាររបស់គាត់តាមឡានដែលដំបូងទៅកំពង់ឆ្នាំង) ។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់ដារា-ស ឯកសារ E3/5732 ថ្ងៃទី១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00916998-00916999 (ក្រោយពីរយៈពេល៣ខែ គ្រួសាររបស់គាត់ត្រូវបានដឹកតាមឡាន)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣-៧៤។ ប្រតិចារឹក ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ៣៧-៣៨ (ពួកគាត់បានណែនាំឲ្យឡើងឡានមកភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២(Denise AFFONÇO) ទំព័រ ៦៦-៦៨ (កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធបានដឹកពួកគាត់តាមឡានឆ្ពោះទៅកន្លែងជួបជុំគ្នានៅពោធិ៍សាត់)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៨-៤៩ (នៅប្រហែលម៉ោង ៥ ល្ងាច គ្រួសាររបស់ សាំង រ៉ាត់ និងប្រជាជនចំនួន ៤-៥ គ្រួសារផ្សេងទៀត បានឡើងលើឡានដែលចង្អៀតណែនណាន់តាន់តាប់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00323530-00323531 (នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ សែម វីរៈ និងគ្រួសាររបស់គាត់ត្រូវបានផ្លាស់ទីលំនៅមកពីទីក្រុងភ្នំពេញ បន្ទាប់មកពួកគេត្រូវបានជម្លៀសទៅភូមិជ្រៃកឃុំ ក្នុងខេត្តព្រៃវែង។ នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ពួកគេត្រូវបានផ្លាស់ទីលំនៅតាមទូកមកកាន់ទីក្រុងភ្នំពេញ និងបន្ទាប់មក តាមឡាន និងតាមរថភ្លើងទៅកាន់ខេត្តបាត់ដំបង ដែលនៅទីនោះ គ្រួសាររបស់គាត់ និងប្រជាជនប្រហែលជា ២.០០០ នាក់ទៀត ត្រូវបានគេបញ្ជូនទៅតាមស្រុកផ្សេងៗគ្នា)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ីម ឯកសារ E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00565832-00565834។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557955 (សាន មុំ និងអ្នកផ្សេងទៀត ត្រូវបានទាហានខ្មែរក្រហមដប់នាក់បញ្ជាឲ្យឡើងឡានពីអ្នកលឿង ខេត្តកណ្តាល ដើម្បីដឹកពួកគាត់ទៅស្ថានីយរថភ្លើងនៅភ្នំពេញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00349497-00349498 (ពីស្រុកពញាឮ ប្រជាជនរាប់រយនាក់ត្រូវបានយកទៅស្ថានីយរថភ្លើងដំណាក់ស្នាច់)។

[១៧៩០] ប្រតិចារឹក ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៨-៤៩, ទំព័រ ៥៣-៥៥ (កូនរបស់គាត់ស្រែកយំដោយសារតែកូនគាត់មិនមានអាហារបរិភោគ ឬ ទឹកផឹក ហើយពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យយកចង្ក្រាន ឬ អ្វី

សោះឡើយ[១៧៩១]។ នៅពេលទៅដល់តាមទីតាំងប្រមូលផ្តុំនានា ឡានបានឈប់ ហើយប្រជាជនបាន រង់ចាំនៅខាងក្រៅដោយពុំមានស្បៀងអាហារ ឬ ទឹកហូបគ្រប់គ្រាន់រហូតដល់ទៅពីរបីថ្ងៃ[១៧៩២]។

៥៩២. ប្រជាជនមួយចំនួន រួមទាំង អ្នកជំងឺ និងអ្នករបួស ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែងរស់នៅ ដោយត្រូវធ្វើដំណើរដោយថ្មើរជើងចេញពីភូមិរបស់ពួកគេ ហើយត្រូវដើរទៅកាន់ស្ថានីយ៍រថភ្លើង ឬ ផ្សារ ដើម្បីឲ្យគេដឹកជញ្ជូនបន្តទៀត[១៧៩៣]។ ដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច បានរៀបរាប់ថា

---

ផ្សេងទៀតមកជាមួយនោះទេ។ ពួកគាត់ត្រូវបានទាហានខ្មែរក្រហមត្រួតពិនិត្យជាប្រចាំ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៨៣-៨៤ (ពួកគាត់មិនបានទទួលអាហារ ឬ ទឹកនោះទេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557954-00557955។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៩-៣១០ ERN (ភាសាខ្មែរ) 00232307-00232308 (ទាហានបានឈរយាមកាម និងរឹបអូសរបស់របរគាត់)។

[១៧៩១] ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ដេនីស អាហ្វុងសូ) ទំព័រ ៦៧-៦៨, ទំព័រ ៨៤-៨៥ (ពួកគាត់បានស្នើសុំជំនួយ ប៉ុន្តែមិនបានទទួលការឆ្លើយតបនោះទេ)។

[១៧៩២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៧-៣៨ (ពួកគាត់ត្រូវបានទម្លាក់ចោលនៅស្ថានីយរថភ្លើងដែលជាកន្លែងពួកគាត់បានរង់ចាំអស់រយៈពេល២យប់)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៤-៧៥ (បន្ទាប់ពីឡានមកដល់វត្តសំប៉ានលើ ពួកគាត់បានស្នាក់នៅខាងក្រៅដើម្បីរង់ចាំរថភ្លើងមកដល់។ ពួកគាត់បានផឹកទឹកត្រពាំង និងគ្មាននរណាឲ្យម្ហូបអាហារនោះទេ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៨-៤៩ (ពួកគាត់បានមកដល់កន្លែងប្រមូលផ្តុំនៅពោធិ៍សាត់នៅផ្លូវជាតិលេខ៥ នៅពេលព្រឹកព្រលឹម បន្ទាប់ពីបានធ្វើដំណើរពេញមួយយប់ មកពីកំពង់ស្ពឺ។ ពួកគាត់ត្រូវបានឲ្យបាយហូបក្នុងអំឡុងពេល២យប់ដែលពួកគាត់កំពុងរង់ចាំនៅទីនោះ)។ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ (Denise AFFONÇO) ទំព័រ ៦៧-៦៨ (ពួកគាត់ត្រូវបានឲ្យអង្ករមួយកំប៉ុង ប៉ុន្តែអត់មានទឹកនោះទេ ហើយបានរង់ចាំអស់ចំនួន៣ថ្ងៃនៅក្បែរផ្លូវរថភ្លើង) ទំព័រ ៨២-៨៣ (កន្លែងនេះមានប្រជាជនច្រើនពេកមកពីកន្លែងផ្សេងៗដើម្បីរង់ចាំធ្វើដំណើរបន្តទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557954-00557955។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២២០-២២១ ERN (ភាសាខ្មែរ) 00836297-00836298 (ពួកគាត់ត្រូវបានប្រាប់ឲ្យឡើងឡានចិន ៨០ គ្រឿង និងត្រូវបានយកទៅស្ថានីយប្រទាឡាង(ប្រទះឡាង))។

[១៧៩៣] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00420971-00420973; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១០

ដៃម្ខាងរបស់គាត់បីកូនខ្ចី ដៃម្ខាងទៀតដឹកដៃកូនតូចៗ ហើយខ្នងរបស់គាត់ស្ពាយបង្វេច[១៧៩៤]។ កូនៗគ្មានស្បៀងអាហារហូបឡើយ។ នៅពេលឈប់សម្រាកមួយស្របក់នៅផ្សារសំរោងយ៉ោង កូនប្រុសរបស់ គង់ វ៉ាច ដែលមានជំងឺរាគ និងហើមដៃជើង បានស្លាប់នៅទីនោះ។ កងទ័ពខ្មែរក្រហមបានបញ្ជា គង់ វ៉ាច ឲ្យទុកសាកសពកូនរបស់គាត់ចោលជាមួយនឹងពួកកងទ័ពទាំងនោះ តែគាត់មិនបានដឹងថា ពួកគេបានធ្វើអ្វីលើសាកសពនោះទេ[១៧៩៥]។ បន្ទាប់មក គង់ វ៉ាច និងប្រជាជនដទៃទៀតត្រូវបានឲ្យឡើងជិះឡានដែលបើកសំដៅទៅខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៧៩៦]។

៥៩៣. ប្រជាជនផ្សេងទៀត ត្រូវបានផ្លាស់ទីលំនៅតាមរទេះគោទៅកាន់វត្តអង្គរកា នៅតាមផ្លូវជាតិលេខ៣[១៧៩៧]។ អ្នកធ្វើដំណើររាប់ពាន់នាក់មកពីទីតាំងផ្សេងៗគ្នាត្រូវបានប្រមូលផ្តុំ ដាក់នៅវត្តអង្គរកា[១៧៩៨]។ មានពាក្យចចាមអារ៉ាមថា សម្តេច នរោត្តម សីហនុ បានយាងត្រឡប់ចូលស្រុកវិញ ហើយត្រូវការអ្នកបច្ចេកទេស វេជ្ជបណ្ឌិត មន្ត្រីយោធា និងបញ្ញាជន ដើម្បីកសាងប្រទេសឡើងវិញ[១៧៩៩]។ មនុស្សចំនួនប្រហែលជា ៤០ នាក់ នៅវត្តអង្គរកា បានស្ម័គ្រចិត្តទៅធ្វើការងារជូន

---

ERN (ភាសាខ្មែរ) 00865605 (នៅរដូវប្រមូលផលនាដើមឆ្នាំ ១៩៧៦ គាត់ និងគ្រួសាររបស់គាត់ ដែលរួមទាំងប្តី និងជីតារបស់គាត់ដែលមានជំងឺគ្រុនចាញ់ ត្រូវបានខ្មែរក្រហមប្រាប់ឲ្យរៀបចំរបស់របរទាំងអស់ និងត្រៀមចាកចេញ។ ពួកគាត់បានសែងជីតារបស់គាត់ ដោយសារតែគាត់មិនអាចដើររួច។ ប្តីរបស់គាត់អាចដើរបានយ៉ាងពិបាកដោយប្រើឈើច្រត់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សោ ធឿន ឯកសារ E3/5436 ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00483749។

[១៧៩៤] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098។

[១៧៩៥] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៧ ERN (ភាសាខ្មែរ) 00420971-00420975។

[១៧៩៦] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00420973-00420974។

[១៧៩៧] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥-៦ (ពិន យ៉ាថៃ និងគ្រួសាររបស់គាត់ ដែលមានមនុស្សចំនួន ១៨ នាក់ ត្រូវបានដឹកតាមរទេះគោ)។

[១៧៩៨] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥-៧។

[១៧៩៩] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៧-៣៩។

រដ្ឋាភិបាលថ្មី ហើយត្រូវបានបញ្ជូនទៅកាន់ក្រុងភ្នំពេញ[១៨០០]។ ពុំមានដំណឹងអ្វីសោះពីអ្នកទាំងនោះ ហើយក្រោយមកក៏មានឮពាក្យចចាមអារ៉ាមមួយថា អ្នកទាំងនោះត្រូវបានគេសម្លាប់ចោល[១៨០១]។ ប្រជាជនដែលនៅសេសសល់បានរង់ចាំនៅវត្តអង្គរការអស់រយៈពេលប្រហែលជា ២ សប្តាហ៍[១៨០២]។

៥៩៤. នៅមានប្រជាជនផ្សេងទៀតត្រូវបានផ្លាស់ទីលំនៅតាមរទេះគោ ឬ ដោយថ្មើរជើង ទៅកាន់ច្រាំងទន្លេមេគង្គ ក្រោមការឃាមកាមដោយកងកម្លាំងប្រដាប់អាវុធ[១៨០៣]។ ក្រោយពេលទៅដល់មាត់ទន្លេ ប្រជាជនខ្លះបានរង់ចាំក្នុងស្ថានភាពលំបាករហូតដល់មួយសប្តាហ៍ ដោយស្ថិតនៅក្រោមការឃាមកាមរបស់កងកម្លាំងប្រដាប់អាវុធ[១៨០៤] ។ ប្រជាជនជាច្រើននាក់មានជំងឺ[១៨០៥] ។

---

[១៨០០] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៨-៣៩។

[១៨០១] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៨-៣៩ (គ្រួសាររបស់ពួកគាត់កំពុងរង់ចាំព័ត៌មាន ប៉ុន្តែមិនដែលបានទទួលព័ត៌មានអ្វីទាល់តែសោះ)។

[១៨០២] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥-៧។

[១៨០៣] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៨៦-៨៧ (ឡាយ បូនី និងអ្នកផ្សេងទៀត បានធ្វើដំណើរដោយរទេះគោទៅកាន់មាត់ទន្លេ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៥-៨៦ (ពួកគាត់ត្រូវដើរទៅព្រែកតាមាក់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពុធ ពុំ ឯកសារ E3/4714 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00397781 (ពួកគាត់ត្រូវបានបង្ខំឲ្យដើរទៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ហើយថ្ងៃបន្ទាប់ ពួកគាត់ត្រូវបានបង្ខំឲ្យដើរទៅអ្នកលឿង។ ពួកគាត់ស្នាក់នៅទីនោះអស់រយៈពេល២យប់ មុនពេលឡើងជិះកប៉ាល់មកច្បារអំពៅដែលជាកន្លែងពួកគាត់ស្នាក់នៅពេញមួយយប់)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 00228741-00228742 (ជនភៀសខ្លួនបានរាយការណ៍ថា ប្រជាជនត្រូវបានដឹកទៅទន្លេមេគង្គដើម្បីឡើងជិះសាឡាង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763 (ដោយទុកចោលទ្រព្យសម្បត្តិរបស់ខ្លួន ពួកគេត្រូវបានបញ្ជូនមកអ្នកលឿនដែលជាកន្លែងពួកគេបានរង់ចាំ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN 00249910 (ពួកគេត្រូវបានអមដំណើរដោយកម្មាភិបាលខ្មែរក្រហម ដើម្បីឆ្ពោះមកកាន់អ្នកលឿងដែលជាកន្លែងពួកគេបានរង់ចាំកប៉ាល់រហូតដល់ម៉ោង ១១ យប់)។

[១៨០៤] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៦-៨៧។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557954-00557955។

ក្រោយមក ពួកគេត្រូវបានដឹកជញ្ជូនតាមកាណូត ឬ កប៉ាល់ ក្រោមការយាមកាមដោយកងកម្លាំងប្រដាប់អាវុធ[១៨០៦] ក្នុងទិសដៅឆ្ពោះទៅកាន់ក្រុងភ្នំពេញ ឬ ឆ្លងកាត់ទន្លេមេគង្គឆ្ពោះទៅកាន់ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល)[១៨០៧]។ កាណូត ឬ កប៉ាល់ ខ្លះពុំសូវមានមនុស្សជិះណែននោះទេ ហើយនៅសល់កន្លែងសម្រាប់ទម្រេតខ្លួនបាន[១៨០៨]។ កាណូត ឬ កប៉ាល់ផ្សេងទៀតគ្របជិត

---

[១៨០៥] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១១-១៣។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763។

[១៨០៦] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៧ (មានអ្នកយាមប្រដាប់ដោយអាវុធ២នាក់នៅខាងមុខទូក ឬ កាណូត និង២នាក់នៅខាងក្រោយ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤៥។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ៣-៤។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ 5-6 ERN (ភាសាខ្មែរ) 00349497-00349498 (ប្រជាជននៅគ្រប់ភូមិទាំងអស់នៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល ត្រូវបានជម្លៀសចេញតាមកាណូតដែលដឹកមនុស្សរាប់រយនាក់)។

[១៨០៧] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ូន ផល្លី) ទំព័រ ២៨-២៩ (ថ្ងៃមួយនៅចុងឆ្នាំ ១៩៧៦ ឬ ឆ្នាំ ១៩៧៧ នៅពេលព្រឹកព្រលឹម អ៊ូន ផល្លី ជីដូនគាត់ និងប្រជាជនផ្សេងៗទៀត ត្រូវបានដឹកតាមកាណូតទៅកាន់ទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤, ទំព័រ ៤៣-៤៤ (ចាន់ សុជាតិ គ្រួសាររបស់គាត់ និងរាប់រយគ្រួសារផ្សេងទៀត បានឡើងជិះកាណូតនៅក្នុងខេត្តកណ្តាល ឆ្ពោះទៅទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យ៉ឹម សុវណ្ណ) ទំព័រ ៧៣-៧៤ (ពួកគាត់ត្រូវបានដឹកតាមកាណូតឆ្លងកាត់ទន្លេ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៧-៨៨ (ពួកគាត់ត្រូវបានដឹកយកទៅព្រែកឆ្មៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ 5-6 ERN (ភាសាខ្មែរ) 00349497-00349498។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ៤ ERN(ភាសាខ្មែរ) 00559763។ (ប្រជាជនរាប់រយនាក់ត្រូវបានដឹកតាមសាឡាង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២ ERN (ភាសាខ្មែរ) 00836139។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00368783 (ពួកគាត់ធ្វើដំណើរដោយជិះកាណូតពីភូមិព្រៃរំដេង ឆ្ពោះទៅកាន់ពាមជីកង ទើបជិះរថយន្តបន្តទៅស្រុកស្ទោង ខេត្តកំពង់ធំ)។ *សូមមើលផងដែរ សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២៤-២៥ ERN (ភាសាខ្មែរ) 00228740-00228741។

[១៨០៨] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៣ (មានប្រជាជនតិចជាង ១០០ នាក់ ជិះលើកប៉ាល់ ដែលអ្នកទាំងអស់នោះមកពីស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល)។

ហើយប្រជាជនត្រូវបានដឹកជញ្ជូនក្នុងភាពចង្អៀតសូន្យឈឹង[១៨០៩] ។ ខ្មែរក្រហមពុំបានចែកចាយស្បៀងអាហារដល់ប្រជាជនទាំងនោះឡើយ[១៨១០]។ ក្មេងខ្លះនៅលើកាណូត ឬ កប៉ាល់ បានស្រែកយំដោយសារស្រេកឃ្លាន ហើយកងទ័ពខ្មែរក្រហមបានសម្លុតថា បោះពួកគេចេញពីកាណូត ឬ កប៉ាល់[១៨១១]។ ប្រជាជនជាច្រើននាក់នៅលើកាណូត ឬ កប៉ាល់ មានជំងឺ ប៉ុន្តែកងទ័ពខ្មែរក្រហមពុំខ្វល់នឹងពួកគេទេ[១៨១២]។ នៅពេលកាណូត ឬកប៉ាល់ បើកប៉ះរលកធំ ហើយក្រឡាប់ គេពុំឃើញមានការជួយសង្គ្រោះអ្វីឡើយ ហើយប្រជាជនខ្លះបានលង់ទឹកស្លាប់នៅពេលនោះ[១៨១៣]។

៥៩៥. ប្រជាជនខ្លះត្រូវបានឲ្យចុះពីលើកាណូត ឬ កប៉ាល់ នៅខេត្តកណ្ដាល (ភូមិភាគនិរតី)[១៨១៤]។ កាណូត ឬ កប៉ាល់ ផ្សេងទៀតបានបន្តដំណើរទៅកាន់ក្រុងភ្នំពេញ ដោយនៅទីនោះ ពួកគេត្រូវបានឲ្យចុះពីលើកាណូត ឬ កប៉ាល់ នៅមុខព្រះបរមរាជវាំង ហើយត្រូវបានដឹកទៅកាន់ស្ថានីយ៍រថភ្លើង ដោយនៅទីនោះ ពួកគេបានរង់ចាំអស់រយៈពេលជាច្រើនម៉ោង[១៨១៥]។ កាណូត ឬ កប៉ាល់ ខ្លះទៀតបានបើកបន្តដំណើរឆ្លងកាត់ក្រុងភ្នំពេញ[១៨១៦] ។ នៅពេលដើមបណ្ដឹងរដ្ឋប្បវេណី ចាន់ សុជាតិ

---

[១៨០៩] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៧។

[១៨១០] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១០ ERN (ភាសាខ្មែរ) 00865605 (ពួកគាត់ត្រូវបានឡើងជិះកប៉ាល់ ហើយពុំទទួលបានម្ហូបអាហារឡើយ)។

[១៨១១] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សួផាន់ សុវណ្ណី) ទំព័រ ៤៥។

[១៨១២] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ១២-១៣។

[១៨១៣] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557955 (ទឹកហូរក្ដួចខ្លាំងបណ្ដាលឲ្យកប៉ាល់មួយ នៅជើងទីពីរលិច ហើយអ្នកជិះស្លាប់ទាំងអស់ ព្រោះគ្មានការធ្វើអន្តរាគមន៍ពីសំណាក់ពួកខ្មែរក្រហមទេ)។

[១៨១៤] ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៧-៨៨ (ពួកគាត់ត្រូវបានដាក់ចុះនៅព្រែកឆ្លៅ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ២៨-២៩ (ពួកគាត់បានមកដល់ទីក្រុងភ្នំពេញប្រហែលជាម៉ោង៦ល្ងាច ហើយត្រូវបាននាំយកទៅស្ថានីយរថភ្លើង ដែលពួកគាត់ត្រូវរង់ចាំប្រហែលជាមួយម៉ោង ដើម្បីឡើងជិះរថភ្លើង ឆ្ពោះទៅកាន់ខេត្តបាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៤ ERN (ភាសាខ្មែរ) 00557955។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ៦ ERN(ភាសាខ្មែរ)00349498 (ពួកគេបានចុះពីកាណូត នៅក្នុងស្រុកពញាឮ ខេត្តកណ្ដាលហើយត្រូវបានផ្ទេរពីកាណូតឲ្យឡើងជិះឡាន)។

[១៨១៥] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763។

[១៨១៦] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២ ERN (ភាសាខ្មែរ) 00836139។

គ្រួសារគាត់ និងគ្រួសាររាប់រយផ្សេងទៀត បានឆ្លងកាត់ព្រះបរមរាជវាំង បុរសម្នាក់បានស្រែកឡើងថា "ជយោ! យើងដល់ភ្នំពេញហើយ"[១៨១៧]។ កងទ័ពខ្មែរក្រហមបានហៅបុរសនោះចេញមកក្រៅហើយក៏បាញ់គាត់សម្លាប់[១៨១៨]។ កាណូត ឬ កប៉ាល់ ទាំងនោះបានបើកបន្តដំណើរឆ្លងកាត់ក្រុងភ្នំពេញ ហើយបានចំណាយពេលពេញមួយថ្ងៃទើបបានទៅដល់ខេត្តកំពង់ឆ្នាំង(ភូមិភាគបស្ចិម)[១៨១៩]។ នៅពេលទៅដល់ទីនោះ ប្រជាជនខ្លះត្រូវបានផ្តល់ស្បៀងអាហារឲ្យ ហើយពួកគេបានរង់ចាំជាមួយប្រជាជនផ្សេងទៀតដើម្បីទទួលការដឹកជញ្ជូនបន្តទៀត[១៨២០] ។ ក្រោយពេលចុះពីលើកាណូត ឬ កប៉ាល់ ប្រជាជនផ្សេងទៀតត្រូវបានដឹកជញ្ជូនតាមឡានទៅកាន់ស្ថានីយ៍រថភ្លើង ដោយនៅទីនោះពួកគេបានរង់ចាំរហូតដល់ទៅមួយសប្តាហ៍ ក្រោមការយាមកាមដោយកងកម្លាំងប្រដាប់អាវុធ ហើយត្រូវបានគេផ្តល់របបអង្ករឲ្យ[១៨២១]។

## ១១.២.២ ដំណាក់កាលទី២៖ ការបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគ (ឧត្តរចាស់) កណ្តាល និងតំបន់ ១០៣

៥៩៦. កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យ[១៨២២] ប្រជាជនរាប់ពាន់នាក់ដែលត្រូវបានប្រមូលផ្តុំនៅតាមស្ថានីយ៍រថភ្លើង នៅតាមទីតាំងផ្សេងៗ រួមទាំងនៅក្រុងភ្នំពេញ និងខេត្តកំពង់ឆ្នាំង

---

[១៨១៧] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤, ទំព័រ ៤៣-៤៤។

[១៨១៨] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤។

[១៨១៩] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤-៣៥, ទំព័រ ៤៣-៤៤។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00373248-00373249។

[១៨២០] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤-៣៥, ទំព័រ ៤៣-៤៤។ (គេចែកអង្ករឲ្យពួកគាត់៣ កំប៉ុង ១ កំប៉ុង ៣នាក់ នៅក្នុងខេត្តកំពង់ឆ្នាំង ហើយពួកគាត់រង់ចាំនៅស្ថានីយទន្លេលាប)។

[១៨២១] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្នួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី 0៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00349497-98 (កាណូតឈប់នៅស្រុកពញាឮ ជាទីកន្លែងដែលពួកគាត់ត្រូវបានផ្ទេរឲ្យឡើងជិះឡានទៅកាន់ស្ថានីយរថភ្លើងដំណាក់ស្មាច់។ ពួកគាត់នៅទីនោះមួយអាទិត្យ ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកយាមប្រដាប់ដោយអាវុធ ពេលនោះពួកខ្មែរក្រហមបានផ្តល់របបអង្ករឲ្យពួកគាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះថ្ងៃទី 0៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ៣ ERN 00249910 (ពួកគាត់ចុះនៅផ្សារតូចមួយថ្ងៃ បន្ទាប់ពីចេញពីអ្នកលឿង ហើយឡើងជិះឡានទៅផ្សារថ្មី ដើម្បីរង់ចាំឡើងជិះរថភ្លើង)។

[១៨២២] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៧-៣៨។ (ខ្មែរក្រហមបានប្រាប់ឲ្យពួកគាត់ឡើងជិះឡាន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ២៣-២៤ (ពួកគាត់គ្មានជម្រើស

(ភូមិភាគបស្ចិម) ឲ្យឡើងជិះរថភ្លើងឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៨២៣]។ មានរថភ្លើងធ្វើដំណើរម្តងក្នុងមួយសប្តាហ៍ និងពេលខ្លះពីរដងក្នុង ១ សប្តាហ៍[១៨២៤]។

---

ឡើយ ក្រៅពីឡើងជិះរថភ្លើង ហើយពួកទាហានបានរុញពួកគាត់ឲ្យឡើងលើរថភ្លើង។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៤៧-៤៩, ទំព័រ ៤៩-៥០, ទំព័រ ៥៧ (នៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦ ចៅ នី និងគ្រួសាររបស់គាត់ត្រូវបានបង្ខំឲ្យឡើងជិះរទេះភ្លើងដោយទាហានខ្មែរក្រហម ១០ នាក់ ដែលប្រដាប់ដោយអាវុធ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ៦៨ (គេដាក់ពួកគាត់ឲ្យជិះលើរទេះភ្លើង)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៥៦-៥៨ (ពួកគាត់ជិះនៅក្នុងទូកដឹកទំនិញរបស់រថភ្លើងឆ្ពោះទៅកាន់ស្ថានីយ៍គោកត្រុំ)។ ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៤៤-៤៥ (ប្រជាជនពុំមានជម្រើស ថាតើត្រូវជិះ ឬមិនជិះរថភ្លើងឡើយ។ ពួកគាត់ត្រូវបានបង្ខំ ដោយពួកយោធាប្រដាប់ដោយអាវុធ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤៥-៤៦ (យើងត្រូវបានរុញបញ្ចូលទៅក្នុងរថភ្លើង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផាន់ យឹម ឯកសារ E3/5424 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00481187 (ពួកគាត់ត្រូវបានបញ្ជាឲ្យឡើងជិះរថភ្លើង ទៅកាន់ភ្នំធិបដេ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ៣ ERN 00249910 (ពួកគាត់ឡើងជិះរថភ្លើងនៅផ្សារថ្មី នៅម៉ោង ៩ យប់ ហើយទៅដល់ពោធិ៍សាត់ នៅម៉ោង ៣ ភ្លឺ)។

[១៨២៣] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៧០-៧១ (នៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦ មានប្រជាជនរាប់ពាន់នាក់នៅលើរថភ្លើង ដែល ចៅ នី ជិះឆ្ពោះទៅកាន់ខេត្តបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១១-១២, ទំព័រ ១៦-១៧, ទំព័រ ១៨-២០ (ប្រជាជនដែលដឹកយកទៅនោះ រួមមាន ក្មេង ចាស់ និង អ្នក ជំងឺ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣៨, ទំព័រ ៤១ (ពីភូមិភាគនិរតី ប្រជាជនត្រូវបានជម្លៀសតាមរថភ្លើង ទៅកាន់ខេត្តកំពង់ឆ្នាំង ហើយបន្ទាប់មក ទៅកាន់ខេត្តបាត់ដំបង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00414418 (ស្ត្រី កុមារ និងមនុស្សចាស់ អង្គុយនៅលើកម្រាលក្នុងទូរថភ្លើងដែលមានមនុស្សកកកុញ)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៨-២៩, ទំព័រ ៤៦-៤៧ (រថភ្លើងបានបន្តដំណើរការរហូតដល់ឆ្នាំ ១៩៧៩)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00557954-55។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00349497។

[១៨២៤] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ២៤-២៥ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00414418។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00414475។

មានកងទ័ព ២ នាក់នៅក្នុងទូរថភ្លើងនីមួយៗ ហើយមានកងទ័ព៣ ឬ ៤នាក់នៅក្នុងទូក្បាលរថភ្លើងជាមួយអ្នកបើក[១៨២៥] ។ ទ្វារទូរថភ្លើងនីមួយៗមានរនុកឈើស៊ិកឃាំងបិទ[១៨២៦] ។ ជារៀងរាល់ពេលកងទ័ពដដែលទាំងនោះស្ថិតនៅលើរថភ្លើងចេញពីក្រុងភ្នំពេញ និងរថភ្លើងដែលវិលត្រឡប់មកវិញ[១៨២៧]។ រថភ្លើងទទេបានបើកត្រឡប់មកក្រុងភ្នំពេញវិញ ដោយមានតែអ្នកធ្វើការនៅលើរថភ្លើង និងកងទ័ពតែប៉ុណ្ណោះ[១៨២៨]។

៥៩៧. រថភ្លើងនីមួយៗមានពី ២០ ទៅ ២៥ ទូ[១៨២៩]។ ទូនីមួយៗអាចដាក់មនុស្សបាន ពី ៤០ ទៅ ៥០ នាក់ ប៉ុន្តែជាធម្មតាមានមនុស្សពី ២០ ទៅ ២៥ នាក់ នៅក្នុងទូនីមួយៗ[១៨៣០]។ ទូខ្លះពុំមានអ្នកជិះណែនទេ ដូច្នេះ អ្នកជិះអាចអង្គុយក្នុងទូនោះ ឬ ក៏ឈរបាន[១៨៣១]។ ទូរថភ្លើងផ្សេងទៀត មានអ្នកជិះ

---

[១៨២៥] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១១-១៣, ទំព័រ ១៧-១៨។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៨-៣៩។ (មានទាហានខ្មែរក្រហមប្រដាប់ដោយអាវុធនៅក្នុងទូរថភ្លើងនីមួយៗ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤៩, ទំព័រ ៧០-៧២ (ទាហានខ្មែរក្រហមបានអមដំណើរ រថភ្លើង និងត្រួតពិនិត្យមើលអ្នកធ្វើដំណើរក្នុងពេលធ្វើដំណើរ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៩-៧០ (ខ្មែរក្រហមឃ្លាំចាំមើលពួកគាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414417-00414418។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00414475-00414476។

[១៨២៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៧-៣៩។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤៥-៤៦ (នៅពេលទូរថភ្លើងពេញ ពួកគេបានបិទទ្វារ និងដាក់គន្លឹះខ្ទាស់)។

[១៨២៧] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ២៣-២៤។

[១៨២៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ២៣-២៤។

[១៨២៩] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414417-00414418។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៧ ERN (ភាសាខ្មែរ) 00414475-00414477។

[១៨៣០] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414417-00414418 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414475-00414476។

[១៨៣១] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៨-២០, ទំព័រ ៣៣។

ប្រុស ស្រី ក្មេង ចាស់ ណែនណាន់តាន់តាប់[១៨៣២]។ អ្នកជិះក្នុងរថភ្លើងពុំមានស្បៀងអាហារគ្រប់គ្រាន់ទេហើយពុំត្រូវបានអនុញ្ញាតឲ្យយករបស់របរទៅតាមខ្លួនឡើយ[១៨៣៣]។ កងទ័ពខ្មែរក្រហមពុំបានជួយដល់អ្នកជំងឺ ឬ អ្នកងាយរងគ្រោះនោះទេ[១៨៣៤]។ អ្នកជិះត្រូវសុំកងទ័ពទាំងនោះឲ្យរថភ្លើង

---

[១៨៣២] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤៩, ទំព័រ ៦៩-៧០ (រថភ្លើងផ្ទុកទៅដោយបុរស ស្ត្រី កុមារ និងមនុស្សចាស់។ ពួកគេអង្គុយទល់មុខគ្នា)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤០-៤១ (ពួកវាបានញាត់មនុស្សចូលទៅក្នុងរថភ្លើង រហូតដល់ទូនីមួយៗពេញណែន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ២៣-២៤ (រថភ្លើងផ្ទុកទៅដោយមនុស្សយ៉ាងណែន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៤៣-៤៥ (រថភ្លើងក៏មានដឹកសត្វផងដែរ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៩ (មានមនុស្សយ៉ាងណែននៅលើរថភ្លើង)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៨ (មិនមានកន្លែងទម្រេតខ្លួនឡើយ ពីព្រោះទូរថភ្លើងនីមួយៗពេញទៅដោយឥវ៉ាន់ និងទំនិញ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414475-00414476។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៩-១១ ERN (ភាសាខ្មែរ) 00865604-00865606 (រថភ្លើងមានដឹកទាំងមនុស្ស និងសត្វ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (ពួកវារុញយើងចូលរថភ្លើង ដូចសត្វ គោ ក្របី។ ទូនីមួយៗដាក់មនុស្សបាន ១៥០ នាក់)។

[១៨៣៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៨-៤០ (ពួកគាត់មិនទទួលបានម្ហូបអាហារ ទឹក ឬ សំលៀកបំពាក់ឡើយ )។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៩-២១។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤៩ (ពួកគាត់មិនទទួលបានម្ហូបអាហារ ឬទឹកឡើយ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៨៣-៨៤ (ពួកគាត់មិនទទួលបានម្ហូបអាហារ ឬ ទឹកឡើយ)។ ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ (ចាន់ សុជាតិ) ទំព័រ ៤៤-៤៥ (គេមិនបានផ្តល់ទឹកឲ្យពួកគាត់ទេ ពួកគាត់ត្រូវចុះទៅដងទឹកដោយខ្លួនឯងនៅពេលឈប់ រីឯអង្ករ នៅពេលធ្វើដំណើរដល់មួយដំណាក់ គឺគេចែកឲ្យមួយដំណាក់)។ ប្រតិចារឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ (យឹម សុវណ្ណ)ទំព័រ ៧៤-៧៥ (ពួកគាត់ទទួលបាននំប៉័ងមួយ នៅពេលពួកគាត់ឡើងជិះរថភ្លើង នំប៉័ងមួយនេះ មិនគ្រប់គ្រាន់ទេ ហើយបន្ទាប់មកទៀត ពួកគាត់មិនទទួលបានអ្វីឡើយ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤៥-៤៦ (ពួកគាត់អត់មានម្ហូបអាហារ ឬ ទឹកឡើយ ហើយនៅពេលឈប់ ពួកគាត់ផឹកទឹកដែលពួកគាត់អាចរកបាននៅជិតៗនោះ ដោយមិនខ្វល់ថាតើទឹកនោះស្អាត ឬមិនស្អាតឡើយ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤៣-៤៤ (ប្រជាជនទទួលបានម្ហូបអាហារ និងទឹកមិនគ្រប់គ្រាន់ឡើយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00349499 (ប្រជាជនផឹកទឹកត្រពាំង ទឹកស្រះ ហើយគេផ្តល់នំប៉័ងឲ្យពួកគាត់)។

[១៨៣៤] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៤-៧៥។

ឈប់ដើម្បីបន្ទោរបង់[១៨៣៥]។ អ្នកជិះនៅលើរថភ្លើងបានស្លាប់ដោយសារហេវហត់អស់កម្លាំង ឬ អត់អាហារនៅក្នុងអំឡុងពេលធ្វើដំណើរ[១៨៣៦]។ ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល បានផ្តល់សក្ខីកម្មថា កងទ័ពខ្មែរក្រហម បានបោះសាកសពអ្នកជិះដែលបានស្លាប់ចេញពីរថភ្លើងដែលកំពុងធ្វើដំណើរទៅមុខ[១៨៣៧]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ ឌី រឿន បានផ្តល់សក្ខីកម្មអំពីក្មេងៗដែលវង្វេងឪពុកម្តាយនៅលើរថភ្លើងយំជាប់រហូត ហើយបានឃើញកងទ័ពខ្មែរក្រហមបោះក្មេងខ្លះចេញតាមបង្អួចរថភ្លើង[១៨៣៨]។ ក្រោយមក សាកសពត្រូវបានគេឃើញនៅតាមផ្លូវរថភ្លើង[១៨៣៩]។ សាក្សី សុខ ឈិន ដែលជាកម្មករជួសជុលផ្លូវរថភ្លើង បានកប់សាកសពរលួយនៅតាមផ្លូវរថភ្លើង។ កន្លែងនោះ

---

[១៨៣៥] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤០-៤១។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ស្វផាន់ សូវណ្ណី) ទំព័រ ៤៥-៤៦ (នៅពេលមួយនោះ ពួកខ្មែរក្រហមបានឲ្យពួកស្រីៗចុះពីរថភ្លើងទៅបន្ទោរបង់ ដោយមានការយាមដោយភ្ជង់កាំភ្លើងទៅលើពួកគាត់។ ពួកគាត់មិនអាចបន្ទោរបង់កើតទេ ពីព្រោះពួកគាត់ភ័យរន្ធត់នឹងការភ្ជង់កាំភ្លើង)។

[១៨៣៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ូន ផល្លី) ទំព័រ ៣២ (ប្រជាជនខ្លះបានស្លាប់នៅពេលធ្វើដំណើរ ដោយសារតែស្ថានភាពលំបាកពេក)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៤១ (មានប្រជាជនស្លាប់ច្រើនណាស់ ក្នុងអំឡុងពេលនៃការជម្លៀស)ទំព័រ ៤៣ (ពុំមានអាហារគ្រប់គ្រាន់ក្នុងអំឡុងពេលជម្លៀសទេ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ត្រិះ អ៊ាល ឯកសារ E3/5324 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00451229-00451230 (យាយរបស់គាត់បាន ស្លាប់នៅលើរថភ្លើង ដោយសារតែខ្វះអាហារ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៤៣-៤៤ (ដោយសារស្ថានភាពអមនុស្សធម៌នៅលើរថភ្លើង មានមនុស្សស្លាប់ច្រើនណាស់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (កុមារ និងមនុស្សចាស់ជាច្រើននាក់បានស្លាប់ ព្រោះគ្មាន អាហារ និងដោយសារស្ថានភាពលំបាក)។

[១៨៣៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៩-៤០។

[១៨៣៨] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឌី រឿន ឯកសារ E3/4656 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00544560-00544561។ Stephen HEDER បានបញ្ជាក់ថា ការរៀបរាប់របស់ ឌី រឿន ផ្ទុះបញ្ចាំងពីស្ថានភាពនៃការដឹកជញ្ជូនដែលជនភៀសខ្លួននៅតាមព្រំដែនប្រទេសថៃ បានរាយការណ៍ប្រាប់គាត់ (ប្រតិចារឹក ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (Stephen Heder) ទំព័រ ៦៣-៦៦)។

[១៨៣៩] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៨-១៩, ទំព័រ ២១-២២។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣២ (អ៊ូន ផល្លី បានឃើញសាកសពដែលត្រូវបានគ្របក្រណាត់ស)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦០ ERN (ភាសាខ្មែរ) 00836137 (មានសាកសពនៅតាមផ្លូវ)។

ស្វាត់ ហើយមានមនុស្សតិចតួចប៉ុណ្ណោះរស់នៅក្បែរនោះ។ ដោយសារហេតុផលនេះហើយ ទើបគាត់សន្និដ្ឋានថា សាកសពដែលគាត់បានឃើញនោះ គឺជាសាកសពអ្នកជិះរថភ្លើង[១៨៤០]។

៥៩៨. ក្រៅពីរថភ្លើង មានឡានយោធា និងឡានស៊ីវិល ក៏បានដឹកជញ្ជូនប្រជាជនស៊ីវិលរាប់ពាន់នាក់ពីទីតាំងប្រមូលផ្តុំនានានៅទូទាំងភាគខាងត្បូងនៃប្រទេសកម្ពុជា ទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៨៤១] ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល)[១៨៤២] និងខេត្ត

[១៨៤០] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១៨-១៩។

[១៨៤១] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤១ (ប្រជាជនប្រហែល ២.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅពីខេត្តកំពង់ឆ្នាំង ទៅកាន់ខេត្តពោធិ៍សាត់ តាមឡានធំៗ នៅដើមឆ្នាំ ១៩៧៧)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៧-៨៨ (ពួកគាត់ចុះពីកាណូតនៅព្រែកព្នៅ បន្ទាប់មក ពួកអ្នកយាមប្រដាប់ដោយអាវុធបានប្រាប់ ពួកគាត់ឲ្យឡើងជិះឡាន ឆ្ពោះទៅពោធិ៍សាត់ និងបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៦-៧ (បន្ទាប់ពីស្នាក់នៅអង្គរកាបាន២ទៅ៣សប្តាហ៍ ពិន យ៉ាថៃ គ្រួសាររបស់គាត់ និងប្រជាជនផ្សេងទៀតប្រហែល ២.០០០ នាក់ បានឡើងជិះឡានប្រមាណ ២០ ទៅ ៣០ គ្រឿង ឆ្ពោះទៅកាន់ខេត្តបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៣-៧៤។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251 (ឡានឈប់នៅកោះជុំ ខេត្តពោធិ៍សាត់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២ ERN (ភាសាខ្មែរ) 00836139។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៧ ERN (ភាសាខ្មែរ) 00420971-00420975។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៩ ទំព័រ៧-៨ ERN(ភាសាខ្មែរ) 00365097-00365098 (ខ្មែរក្រហមបានបង្ខំឲ្យពួកគាត់ឡើងជិះឡានពីខេត្តតាកែវ)។ កំណត់ហេតុបទសម្ភាសន៍ជាមួយ គីម ហេង ដោយការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E3/5639 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00845882 (ដំបូងប្រជាជនត្រូវបានប្រមូលផ្តុំនៅជ្រៃព្រះព្នៅ ត្រាំខ្នា ខេត្តកំពង់ស្ពឺ។ បន្ទាប់ពីរង់ចាំនៅទីនោះ២ទៅ៣ថ្ងៃមក ខ្មែរក្រហមបានដឹកអ្នកជម្លៀសប្រហែល ៣.០០០ នាក់ តាមឡានពី ៦០ ទៅ ៧០ គ្រឿង ដោយក្នុងឡាននីមួយៗមានមនុស្សពី ៤០ ទៅ ៥០ នាក់ ឆ្ពោះទៅក្រុងពោធិ៍សាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484412។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គៀង វណ្ណារី ឯកសារ E3/5310 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00349486-00349487។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ព្រឿង ឯកសារ E3/3957 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00414475-00414476។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡឹម សារ៉ុន ឯកសារ E3/5296 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ២-៣ ERN (ភាសាខ្មែរ) 00355444-00355445 (ឡឹម សារ៉ុន (ពីមុនជាព្រះសង្ឃ) ត្រូវបានជម្លៀសចេញពីស្រុកចន្ទ្រា ខេត្តស្វាយរៀង ទៅកាន់ខេត្តពោធិ៍សាត់ នៅចុងឆ្នាំ

ព្រះវិហារ (តំបន់ ១០៣)[១៨៤៣]។ ពួកគេត្រូវបានដឹកជញ្ជូន និងយាមកាម ដោយកងទ័ពខ្មែរក្រហម ប្រដាប់ដោយអាវុធ[១៨៤៤] ។ កងទ័ពខ្មែរក្រហមបានបាញ់សំដៅទៅអ្នកដែលបានព្យាយាមរត់គេចខ្លួន[១៨៤៥] ។ ឡានមានមនុស្សជិះណែនណាន់តាន់តាប់។ ស្ថានភាពនៅលើឡានមានភាពលំបាកណាស់[១៨៤៦] ហើយអ្នកជិះត្រូវបន្ទោរបង់នៅលើឡានផ្ទាល់តែម្តង[១៨៤៧] ។ អ្នកជិះជាច្រើននាក់ ឈឺ

---

១៩៧៦)។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៩ ERN (ភាសាខ្មែរ) 00232307 (ម៉ៃ ស៊ីសូផា និងគ្រួសាររបស់គាត់ត្រូវបានដឹកតាមឡានប្រមាណ ២០ គ្រឿង ពីខេត្តតាកែវ ទៅកាន់ភ្នំពេញ)។

[១៨៤២] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ 4 ERN (ភាសាខ្មែរ) 00368783 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ សាយ កាណាល់ និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសពីភ្នំពេញទៅកាន់ព្រៃរំដេង ខេត្តកំពង់ចាម។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ពួកគាត់ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ធំ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189 (នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ប្រជាជនថ្មីទាំងអស់នៅតំបន់មួយ ត្រូវបាននាំយកពីខេត្តកំពង់ចាម ទៅកាន់ខេត្តកំពង់ធំ)។ *សារណារបស់រដ្ឋាភិបាល ន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២៤-២៦ ERN (ភាសាខ្មែរ) 00228740-00228742 (ប្រហែលជានៅខែ ធ្នូ ឆ្នាំ ១៩៧៥ ប្រជាជនចំនួន ៣៥.០០០ នាក់ ដែលពីមុនត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ត្រូវបានជម្លៀសជាថ្មីម្តងទៀត ពីស្រុកកោះសូទិន ខេត្តកំពង់ចាម ទៅកាន់ខេត្តកំពង់ធំ)។

[១៨៤៣] ប្រតិចារិក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ូ) ទំព័រ ១០-១២, ទំព័រ ៣៧-៣៩ (អ្នកជម្លៀសប្រមាណ ៣០០០ នាក់ ត្រូវបានជម្លៀសតាមឡានពីខេត្តកំពង់ធំ ទៅកាន់តំបន់ ១០៣)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឈឹម សារុំ ឯកសារ E3/5333 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00453090 (ឈឹម សារុំ និងគ្រួសារ របស់គាត់ត្រូវបានជម្លៀសពីចាក់អង្រែ ទៅកាន់ស្រុកកោះធំ ខេត្តកណ្តាល។ នៅចុងឆ្នាំ ១៩៧៥ ពួកគាត់ត្រូវបានជម្លៀសទៅខេត្តព្រះវិហារ)។

[១៨៤៤] ប្រតិចារិក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨៩-៩០ (មានទាហានខ្មែរក្រហម និងប្រធានកង។ ទាហានខ្មែរក្រហមប្រដាប់ដោយអាវុធ ហើយស្លៀកសំលៀកបំពាក់ពណ៌ខ្មៅ និងពាក់ស្បែកជើងសង្រែកទាំងអស់គ្នា)។ ប្រតិចារិក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៤-៥ (មានទាហានខ្មែរក្រហម៤នាក់នៅលើឡាននីមួយៗ ដែលរួមមានតៃកុងឡានម្នាក់ ព្រូឡានម្នាក់ និង២នាក់ទៀតប្រដាប់ដោយអាវុធនៅក្នុងឡាន)។ ប្រតិចារិក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៩-៤០ (តៃកុងឡាន និងទាហានផ្សេងទៀតស្លៀកខោអាវខ្មៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251។

[១៨៤៥] ប្រតិចារិក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤០-៤១។

[១៨៤៦] ប្រតិចារិក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៦-៧ (មានប្រជាជនប្រមាណពី ៨០-១០០ នាក់ ឈរនៅលើឡាននីមួយៗ។ វាជារដូវភ្លៀង ដូច្នេះពួកគាត់ទទឹកខ្លួនជោគ)។ ប្រតិចារិកថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង

និងមានជំងឺរាគរូស[១៨៤៨]។ ដោយសារការហេវហត់អស់កម្លាំង ការអត់អាហារ ឬ ដោយសារជំងឺ អ្នកជិះខ្លះបានស្លាប់[១៨៤៩]។

៥៩៩. រយៈពេលពីរបីថ្ងៃក្រោយមក ហើយពេលខ្លះរហូតដល់មួយសប្តាហ៍ រថភ្លើង និងឡានទាំងនោះបានទៅដល់ខេត្តពោធិ៍សាត់ និងបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៨៥០] ខេត្តកំពង់ធំ (ភូមិភាគ

---

សុខា) ទំព័រ ៤០-៤១, ៥៧ (មនុស្សលើឡានឡើងណែនក្តន់ ផ្លូវពិបាកមែនទែន ហើយគេមិនអនុញ្ញាតឱ្យប្រជាជនចុះពីលើឡានឡើយ)។ ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ១០៨ (ជាឡានទ្រុង ហើយមនុស្សទាំងអស់ត្រូវឈរ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៤-៥ (ឡានដឹកមនុស្សឡើងណែនៗ)។ កំណត់ហេតុបទសម្ភាសន៍ជាមួយ គីម ហេង ដោយការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E3/5639 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៤ ERN 00845882 (បន្ទាប់ពីរង់ចាំនៅទីនោះ២ទៅ៣ថ្ងៃមក ខ្មែរក្រហមបានដឹកអ្នកជម្លៀសប្រហែល ៣.០០០ នាក់ តាមឡានដែលមានចំនួនពី ៦០ ទៅ ៧០ គ្រឿង ដោយក្នុងឡាននីមួយៗ មានមនុស្សពី ៤០ ទៅ ៥០ នាក់ ឆ្ពោះទៅក្រុងពោធិ៍សាត់)។ សក្ខីកម្មរបស់ជនរងគ្រោះ... សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ២០៨ ERN (ភាសាខ្មែរ) 00836285 (ឡានមានដំបូលក្រណាត់កៅស៊ូ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៩ ERN (ភាសាខ្មែរ) 00232307 (មានប្រជាជនប្រមាណ ២០០-៣០០ នាក់ ជិះនៅក្នុងឡានធំ "ណែនក្តន់ស្ទើរតែគ្មានកន្លែងដកដង្ហើមឡើយ")។

[១៨៤៧] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៦-៧ (ប្រជាជនបន្ទោរបង់នៅលើឡានតែម្តង)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៥៦-៥៧ (ពួកខ្មែរក្រហមបានឈប់ចុះបន្ទោរបង់ ប៉ុន្តែអ្នកនៅលើឡានមិនត្រូវបានអនុញ្ញាតឱ្យចុះពីលើឡានទេ ក្នុងពេលធ្វើដំណើរពេញមួយថ្ងៃ រហូតពួកគាត់ទៅដល់ពោធិ៍សាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ម សុខលី ឯកសារ E3/5022 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៩ ERN (ភាសាខ្មែរ) 00561594។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (ឡានឈប់រៀងរាល់ ៥ ឬ ៦ ម៉ោងម្តង ដើម្បីឱ្យប្រជាជនចុះបន្ទោរបង់។ ឡានមានដំបូលក្រណាត់កៅស៊ូ)។

[១៨៤៨] ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤១-៤២។

[១៨៤៩] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៤-៣៦ (ពិន យ៉ាថៃ បានឃើញមនុស្ស២នាក់សន្លប់ ហើយក្រោយមកក៏បានស្លាប់ទៅ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098 (ភ្លាមៗបន្ទាប់ពីឡានចាកចេញពីផ្សារសំរោង ក្នុងខេត្តតាកែវ កូនស្រីពៅរបស់ គង់ វ៉ាច បានស្លាប់ដោយសារគ្មានទឹកដោះគោបៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៧ ERN (ភាសាខ្មែរ) 00420971-00420975។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189 (ក្នុងអំឡុងពេលធ្វើដំណើរ កុមារស្លាប់ដោយសារហេវហត់ អស់កម្លាំង និងជំងឺ)។

(ឧត្តរចាស់) កណ្តាល)[១៨៥១] និងខេត្តព្រះវិហារ (តំបន់ ១០៣)[១៨៥២]។ ទីតាំងដែលអ្នកជិះឡានត្រូវបានដាក់ចុះនោះ ជាធម្មតាពុំមែនជាកន្លែងដែលពួកគេត្រូវបានប្រាប់ថាជាកន្លែងដែលត្រូវបញ្ជូនទៅនោះទេ[១៨៥៣]។

---

[១៨៥០] ប្រតិចារឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៦-៧ (ពួកគាត់ឈប់នៅកំពង់ឆ្នាំងមួយយប់ ហើយនៅថ្ងៃបន្ទាប់បានមកដល់ខេត្តបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៥-៦ (បន្ទាប់ពីពួកគាត់ជិះឡានមួយថ្ងៃ ទើបពួកគាត់បានមកដល់ពោធិ៍សាត់)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១១-១៣។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៤៥។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៩-៧០, ៧៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៩-១១ ERN (ភាសាខ្មែរ) 00865604-00865606។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ឹម ឯកសារ E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00565833។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557955 (ពួកគាត់ចាប់ផ្តើមធ្វើដំណើរនៅពេលយប់ ហើយទៅដល់នៅពេលព្រឹកឡើង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១២៥ ERN (ភាសាខ្មែរ) 00836202 (ឡានធ្វើដំណើរគ្មានឈប់រយៈពេល៣ថ្ងៃកន្លះ ពីភ្នំពេញទៅបាត់ដំបង) ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (បន្ទាប់ពីជិះរថភ្លើងរយៈពេលមួយថ្ងៃ ពួកគាត់បានទៅដល់ស៊ីសុផុន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ៣ ERN 00249910 (ពួកគាត់ឡើងជិះរថភ្លើងនៅផ្សារថ្មី នៅម៉ោង ៩ យប់ ហើយទៅដល់ពោធិ៍សាត់នៅម៉ោង ៣ ភ្លឺ)។

[១៨៥១] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00368783 (នៅក្នុងខែធ្នូ ឆ្នាំ ១៩៧៥ ពួកគាត់ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ធំ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189 (នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ប្រជាជនថ្មីទាំងអស់នៅក្នុងតំបន់មួយក្នុងខេត្តកំពង់ចាម ត្រូវបាននាំយកទៅខេត្តកំពង់ធំ)។ *សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២៤-២៦ ERN (ភាសាខ្មែរ) 00228740-42 (ប្រហែលជានៅខែ ធ្នូ ឆ្នាំ ១៩៧៥ ប្រជាជនចំនួន ៣៥.០០០ នាក់ ដែលពីមុនត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ត្រូវបានជម្លៀសជាថ្មីម្តងទៀត ពីស្រុកកោះសូទិន ខេត្តកំពង់ចាម ទៅកាន់ខេត្តកំពង់ធំ)។

[១៨៥២] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រំ ស្ញូ) ទំព័រ ១០-១១, ៣៧-៣៩។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈឹម សារុំ ឯកសារ E3/5333 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00453090 (នៅចុងឆ្នាំ ១៩៧៥ ពួកគាត់ត្រូវបានជម្លៀសទៅខេត្តព្រះវិហារ)។

### ១១.២.៣ ដំណាក់កាលទី៣៖ ការចាត់តាំងទៅតាមការដ្ឋានធ្វើការងារ និងសហករណ៍

៦០០. បន្ទាប់ពីត្រូវបានបង្ខំឱ្យចុះពីលើឡាន និងរថភ្លើងមក ប្រជាជនត្រូវបានសួរអំពីប្រវត្តិរូបពីមុនរបស់ពួកគេ ហើយត្រូវបានណែនាំឱ្យរង់ចាំ ដោយប្រជាជនខ្លះត្រូវស្ថិតនៅក្រោមការឃាមកាមដោយកងកម្លាំងប្រដាប់អាវុធ[១៨៥៤]។ ប្រជាជនជាច្រើននាក់ដែលទន់ខ្សោយដោយសារអត់អាហារ

---

[១៨៥៣] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៧។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៥។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251 (គេប្រាប់ពួកគាត់ថា ធ្វើដំណើរទៅបាត់ដំបង ប៉ុន្តែគេបញ្ជូនពួកគាត់ទៅកោះជុំ ខេត្តពោធិ៍សាត់។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៧-៣០៩ ERN (ភាសាខ្មែរ) 00232305-00232307 (ខ្មែរ ក្រហមបានបោកបញ្ឆោតប្រជាជនអំពីគោលបំណងពិតប្រាកដនៃការធ្វើដំណើរ)។

[១៨៥៤] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១២-១៣,១៨, ២៩-៣១ (នៅពេលទៅដល់លាច គេបានស្រង់ប្រវត្តិរូបប្រជាជន ហើយគេបានប្រាប់ប្រជាជនឱ្យស្នាក់នៅជិតផ្លូវរថភ្លើង ក្រោមការត្រួតពិនិត្យពីសំណាក់ពួកអ្នកយាមប្រដាប់ដោយអាវុធ)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៧-២៨ (ពួកគាត់ត្រូវបានសួរអំពីការងារកាលពីមុន)។ កំកំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00373248-00373251។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៧ (ប្រជាជនប្រមាណ ២០០០ នាក់ ត្រូវបានដាក់ចុះពីលើឡាននៅលាច ហើយប្រមូលផ្តុំនៅក្នុងជំរំមួយជិតស្ទឹង ដើម្បីរង់ចាំគេដឹកជញ្ជូនបន្តទៅមុខទៀតនៅថ្ងៃបន្ទាប់)។ ប្រតិចារឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ (ទឹង សុខា) ទំព័រ ៥១-៥២, ៥៧ (ពួកគាត់ត្រូវបានទាញទម្លាក់ចុះពីលើរថភ្លើងនៅពេលជិតយប់ ហើយត្រូវបានប្រាប់ឱ្យរង់ចាំនៅជិតផ្លូវរថភ្លើង។ បន្ទាប់មក ពួកគាត់ត្រូវបានបញ្ជូនទៅកាន់សហករណ៍នានា បន្ទាប់ពីត្រូវបានចុះឈ្មោះ និងកត់ត្រាអំពីការងាររបស់ពួកគាត់រួចមក)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១១ ERN (ភាសាខ្មែរ) 00865606 (បន្ទាប់ពីចុះពីលើរថភ្លើង ពួកខ្មែរក្រហមបានស្រង់ព័ត៌មានពីពួកគាត់ មុនពេលចាត់ពួកគាត់ឱ្យទៅតាមកន្លែងធ្វើការ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763 (នៅពេលទៅដល់លាច មេខ្មែរក្រហមរង់ចាំទទួល ហើយពួកគាត់សម្រាកនៅស្ថានីយរថភ្លើងមួយយប់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៦១ ERN (ភាសាខ្មែរ) 00836239 (បន្ទាប់ពីមកដល់ពោធិ៍សាត់ ពួកគេត្រូវបានដឹកតាមរថភ្លើងទៅកាន់ភ្នំធិបតី ដែលនៅទីនោះ ពួកខ្មែរក្រហមបានបញ្ជាឱ្យពួកគាត់ចុះនៅទីនោះ។

រួចទៅហើយនោះ[១៨៥៥] ពុំត្រូវបានផ្តល់ទឹក ស្បៀងអាហារ សម្ភារៈអនាម័យ អង្រឹង ឬ មុងទេ[១៨៥៦]។ ប្រជាជនខ្លះទៀតបានរង់ចាំអស់រយៈពេលពីរបីថ្ងៃ ឬ រហូតដល់មួយសប្តាហ៍ ដោយស្ថិតនៅក្នុងស្ថានភាពបែបនេះ[១៨៥៧]។ នៅតាមទីតាំងផ្សេងទៀត រទេះគោដែលបរដោយកម្មាភិបាលខ្មែរក្រហមបានរង់ចាំដឹកប្រជាជននៅពេលដែលពួកគេមកដល់[១៨៥៨]។

៦០១. កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានបែងចែកប្រជាជនទៅតាមទីតាំងដែលត្រូវបញ្ជូនទៅ ដោយពេលខ្លះ បានបំបែកសមាជិកក្នុងគ្រួសារផងដែរ[១៨៥៩] ចំណែកប្រជាជនខ្លះទៀត ត្រូវបាន

---

[១៨៥៥] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២ ERN (ភាសាខ្មែរ) 00836139 (ប្រជាជនថ្មីដែលមកដល់ ព្រះវិហារ មើលទៅមានកម្លាំងខ្សោយខ្វះជីវជាតិ)។

[១៨៥៦] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ៣៨-៣៩ (ពួកគាត់ផឹកទឹក និងងូតទឹកនៅក្នុងវាលស្រែតែមួយ)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៧-៥០, ៥៤-៥៥ (នៅពេលទៅដល់ខេត្តបាត់ដំបង គេមិនបានផ្តល់អាហារឲ្យពួកគាត់ទេ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៥៨-៥៩ (មានភ្លៀងធ្លាក់ ប៉ុន្តែពុំមានជម្រក និងអាហារឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឌី រឿន ឯកសារ E3/4656 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00544561 (ឌី រឿន និងអ្នកជម្លៀសផ្សេងទៀត បានដេកនៅស្ថានីយរថភ្លើងមួយយប់ក្នុងខេត្តពោធិ៍សាត់ ប៉ុន្តែគ្មានអ្វីហូបទេ ហើយត្រូវបានបង្ខំឲ្យដេកនៅលើដីដោយគ្មានមុង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (ពួកគាត់ទទួលបានអង្ករ អំបិល ប៉ុន្តែគ្មានជម្រក ឬជំរំទេ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ- កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣០៩-៣១០ ERN (ភាសាខ្មែរ) 00232307-00232308 (ពួកអ្នកថ្មីរាប់ពាន់នាក់បានបោះជំរំនៅឃ្លាំងទុកសម្ភារៈរថភ្លើងក្នុងខេត្តពោធិ៍សាត់ ដោយនៅទីនោះ មានពាសពេញទៅដោយអាចម៍មនុស្ស និងសត្វមូសច្រើនឥតគណនា។ ពុំមានអាហារហូប និងទឹកផឹកគ្រប់គ្រាន់ទេ ហើយក៏គ្មានកន្លែងសម្រាប់ទម្រេតខ្លួនដែរ)។

[១៨៥៧] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ទំព័រ ១១-១២,១៨-១៩ (ពីរបីថ្ងៃទៅមួយសប្តាហ៍)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៧ (មួយថ្ងៃ)។

[១៨៥៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៤៩-៥០ (នៅពេលពួកគាត់ចុះពីរថភ្លើងនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង មានរទេះគោកំពុងរង់ចាំនៅទីនោះ) ទំព័រ ៥៩ (អ្នកបររទេះគោស្លៀកសំលៀកបំពាក់ខ្មៅ និងបង់កក្រមា ស្រដៀងគ្នាទៅនឹងពួកទាហានខ្មែរក្រហមដែរ)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៥-៦ ។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៤៥។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00373250-00373251។

[១៨៥៩] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧៥ (យឹម សុវណ្ណ បង/ប្អូនប្រុស និងឪពុករបស់គាត់ ត្រូវបានចាត់តាំងឲ្យទៅកងផ្សេងៗគ្នា)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៧០-៧១

អនុញ្ញាតឲ្យជ្រើសរើសឃុំដែលពួកគេត្រូវទៅ[១៨៦០] ។ ខ្មែរក្រហមបាននិយាយថា ពួកគេយកប្រជាជនមួយចំនួនទៅសហករណ៍ថ្មី ប៉ុន្តែប្រជាជនទាំងនេះបានបាត់ខ្លួនរហូត[១៨៦១]។ ប្រជាជនខ្លះទៀតធ្វើដំណើរដោយថ្មើរជើង ដោយការដឹកជញ្ជូនដោយឡាន ឬ ដោយរទេះគោ ក្រោមការឃាមកាមរបស់កងកម្លាំងប្រដាប់អាវុធទៅកាន់សហករណ៍ និងការដ្ឋានធ្វើការងារនៅក្នុងខេត្តពោធិ៍សាត់

(ពួកគាត់មិនអាចជ្រើសរើសទិសដៅដែលពួកគាត់ចង់ទៅឡើយ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៩-៧០ (កូនៗរបស់គាត់ត្រូវបានបញ្ជូនទៅការដ្ឋាន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង ស្ងផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00414418-19 (ការបង្គាប់ឲ្យយកប្រជាជនទៅទីណានោះ គឺធ្វើឡើងដោយគណៈស្រុក)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៩-៥០ (ពួកមេក្រុមខ្មែរក្រហមបានបែងចែកអ្នកដែលទីបបានមកដល់ថ្មី ទៅដាក់នៅតាមភូមិនានា ហើយកូនៗ និងប្តីរបស់គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅកងផ្សេងទៀត)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៥ (បន្ទាប់ពីទៅដល់ភូមិចម្ការតាប៉ូ អោ រី ត្រូវបានបំបែកពីបងប្អូន និងឪពុកម្តាយរបស់គាត់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤១ (ពេជ ស្រីផល និងប្តីរបស់គាត់ត្រូវបានបំបែកចេញពីគ្នានៅពេលទៅដល់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពុធ ពុំ ឯកសារ E3/4714 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00397781 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឆិត សារុន ឯកសារ E3/5006 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00559763 (ដោយបំបែកគាត់ចេញពីគ្រួសាររបស់គាត់ ខ្មែរក្រហមបានបញ្ជាឲ្យ ឆិត សារុន ទៅច្រូតស្រូវនៅក្បែរស្ពានម៉ុទៅរលាប)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុំ សឿន ឯកសារ E3/5055 ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00565524 (ប្រធានឈ្លបមិនស្គាល់ឈ្មោះម្នាក់បានបែងចែកពួកគាត់ជាកងជាក្រុម។ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ហើយក្មេងៗត្រូវបានយកទៅដាក់នៅក្នុងកងចល័ត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ៣ ERN 00249910 (ពួកគាត់ត្រូវបានទាហានប្រដាប់ដោយអាវុធមកចាំទទួល យកទៅរស់នៅភូមិបាក់មេឃ ឃុំបឹងខ្នា ខេត្តពោធិ៍សាត់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៦ ERN (ភាសាខ្មែរ) (នៅកន្លែងថ្មី ពួកវាបំបែកសមាជិកក្រុមគ្រួសារឲ្យនៅឆ្ងាយពីគ្នា ហើយកុមារត្រូវបានដាក់នៅក្នុងកងចល័ត និងគ្មានទទួលបានដំណឹងពីគ្រួសារពួកគេ អស់រយៈពេលជាច្រើនខែ)។

[១៨៦០] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៤៥ ។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00373250-00373251 (ពួកគាត់បានសម្រេចស្នាក់នៅកោះជុំបន្តទៀត)។

[១៨៦១] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00373251-00373252។

01006874



(ភូមិភាគពាយ័ព្យ)[១៨៦២] ខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៨៦៣] ខេត្តព្រះវិហារ (តំបន់ ១០៣)[១៨៦៤] និងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្ដាល)[១៨៦៥]។ សហករណ៍ពុំអាចផ្គត់ផ្គង់សម្ភារៈឲ្យបានគ្រប់

---

[១៨៦២] ប្រតិចារឹកថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១៣(សូផាន់ សូវណ្ណី) ទំព័រ ៤៦-៤៧ (សហករណ៍ពោធិ៍ពីរ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់)។ ប្រតិចារឹក ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០១៣ (ពិន យ៉ាថៃ)ទំព័រ ៧ (ពួកគាត់ត្រូវបានបំបែកជាក្រុម និងផ្លាស់ទៅកន្លែងផ្សេងទៀត អ្នកខ្លះធ្វើដំណើរតាមឡាន និងអ្នកខ្លះទៀត ធ្វើដំណើរដោយថ្មើរជើង។ ពិន យ៉ាថៃ និងគ្រួសាររបស់គាត់ធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅវាលវង់ ជើងភ្នំក្រវាញ)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៧០ (ក្បាល ឈើពុក)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៩-៥០ (សាំង រ៉ាត់ ត្រូវបានបញ្ជូនទៅកាន់សហករណ៍វត្តចាស់ដោយនៅទីនោះគាត់ធ្វើការងារជីកព្រែកប្រឡាយ និងធ្វើស្រែ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤០-៤១, ៤៩ (ប្រហែលជានៅដើមឆ្នាំ ១៩៧៧ ប្រជាជនប្រមាណ ២.០០០ នាក់ ត្រូវបានដឹកតាមរថយន្ត ពី ខេត្តកំពង់ឆ្នាំង យកទៅខេត្តពោធិ៍សាត់ដែលនៅទីនោះ ពួកគាត់ត្រូវបានចាត់ឲ្យទៅធ្វើការនៅក្នុងសហករណ៍ចំនួន ២ កន្លែង និងស្នួងស្រូវនៅក្នុងភូមិស្ទឹង សហករណ៍ហ្លួង )។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៦ (ភ្នំជើងទិញ)។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់តារា-ស ឯកសារ E3/5732 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00916998-00916999 (ដឹកតាមរទេះគោទៅកាន់ភ្នំជើងធិន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤-៣៥ (ពួកគាត់ត្រូវបានបង្ខំឲ្យដើរពីអូរលៀប ទៅភូមិព្រៃទទឹង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៥-៦ (ចម្ការតាប៉ូ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00557817-00557818 (មានរទេះគោជាច្រើនចាំជាស្រេច ហើយពួកគាត់ត្រូវបានដឹកទៅកាន់ភូមិអូរ ដោយមានទាហានស្លៀកខោខ្មៅ អាវខ្មៅត្រួតពិនិត្យមើល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឌី វឿន ឯកសារ E3/4656 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ៤ ERN (ភាសាខ្មែរ) 00544561 (ព្រឹកឡើង មូសខាំពួកគាត់ស្ទើរសុះសាច់ ហើយពួកគាត់ដើរទៅសហករណ៍នានានៅក្នុងខេត្ត ដោយមានគេកាន់អាវុធដើរពីក្រោយ។ ឌី វឿន ត្រូវបានបញ្ជូនទៅសហករណ៍បាក់ព្រីង ឃុំខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧ ERN (ភាសាខ្មែរ) 00349499 (នៅពេលទៅដល់ ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅភូមិផ្សេងៗ។ សួង ស៊ីម ត្រូវបានបញ្ជូនទៅភូមិសំរោង ឃុំកោះខ្សាច់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00557955 (ពួកគាត់បានធ្វើដំណើរចេញពីស្ថានីយរថភ្លើងត្រពាំងជង តាមបញ្ជារបស់ទាហានខ្មែរក្រហម ដែលដើរត្រួតពិនិត្យពីមុខ និងពីក្រោយ)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាន់ សាវឿន ឯកសារ E3/5258 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ៣ ERN 00249910 (ភូមិបាក់មេឃ ឃុំបឹងខ្នា ខេត្តពោធិ៍សាត់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦២ ERN (ភាសាខ្មែរ) 00836139 (ពួកគាត់ដើរទៅភ្នំ ឬវាលទំនាប ខាងលិចពោធិ៍សាត់)។

[១៨៦៣] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤១ (ប្រហែលជានៅដើមឆ្នាំ ១៩៧៧ ប្រជាជនត្រូវបានជម្លៀសពីប៉ែកទក្សិណប្រទេសកម្ពុជាទៅខេត្តបាត់ដំបង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី)

ទំព័រ ៥០-៥១, ៦០ (តា ហ៊ើយ ក្រោយមកត្រូវបានស្គាល់ថាជា ចក ធំ)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៩ (ពួកគាត់ត្រូវបានមេភូមិខ្មែរក្រហមនាំយកទៅភ្នំត្រឡាច ដើរដោយថ្មើរជើង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សូផាត ឯកសារ E3/5525 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00414417-00414419 (ភ្នំស្រុក)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារ E3/5590 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00420973-00420974។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារ E3/4695 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00365097-00365098 (ធិបដេ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារ E3/4678 ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ៧ ERN (ភាសាខ្មែរ) 00323531 (ពួកគាត់បានដើររយៈពេលមួយថ្ងៃទៅកាន់ក្លាំងងារ ជាមួយនឹងមនុស្ស ២០០ នាក់ទៀត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុវត្ថា ឯកសារ E3/5084 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ទំព័រ ១១ ERN (ភាសាខ្មែរ) 00865606 (ព្រះនេត្រព្រះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ីម ឯកសារ E3/3978 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៦ ERN (ភាសាខ្មែរ) 00565833 (អូរតាគី)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួន សុផា ឯកសារ E3/4837 ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00526042 (អូរតាប៉ោង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ស៊ិន ឯកសារ E3/4872 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00533871 (នៅក្នុងខែតុលា ឆ្នាំ ១៩៧៦ ពួកខ្មែរក្រហមបានបញ្ជូន ឡុង ស៊ិន ឲ្យទៅរស់នៅភូមិថ្មី ស្រុកកំពត ហើយបន្ទាប់មកនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦ ក៏ជម្លៀសគាត់ទៅ បាក់ចៀន ខេត្ត បាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុំ សឿន ឯកសារ E3/5055 ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ភាសាខ្មែរ) 00565524 (ស៊ុំ សឿន និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសតាមរថភ្លើង ទៅកាន់ភ្នំតាប្លេ ហើយរថភ្លើងបានឈប់ដើម្បីដាក់ប្រជាជនខ្លះនៅទីនោះ ហើយរថភ្លើងក៏បានបន្តដំណើរទៅថ្មគោលទៀត)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ណុប ណន ឯកសារ E3/5423 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00481176-00481177 (គាត់អត់ស្គាល់ភូមិសាស្ត្រទេ នៅពេលគាត់ទៅដល់ខេត្តបាត់ដំបង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផាន់ យឹម ឯកសារ E3/5424 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00481187-00481188 (គាត់ត្រូវបានបញ្ជូនទៅភូមិថ្មី ខេត្តបាត់ដំបង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៦១ ERN (ភាសាខ្មែរ) 00836238 (ខ្មែរក្រហមប្រមាណ ២០ នាក់ នាំប្រជាជនទៅកាន់ភូមិនានានៅក្នុងខេត្តបាត់ដំបង ) ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285 (ប្រជាជនត្រូវបានដឹកតាមត្រាក់ទ័រទៅភ្នំស្រុក ហើយបន្ទាប់មកដឹកតាមរទេះគោទៅកន្លែងដ៏ឆ្ងាយមួយ)ទំព័រ ២២១ ERN(ភាសាខ្មែរ) 00836298 (ប្រជាជនត្រូវបានដឹកតាមរទេះគោយកទៅតាមភូមិផ្សេងៗ ក្នុងខេត្តបាត់ដំបង៖ ពួកខ្មែរក្រហមនិយាយថាពួកវានាំយកទៅឲ្យជួយធ្វើស្រែ)។

[១៨៦៤] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ួ) ទំព័រ ១០-១២,៣៧-៣៩ (ស្រុករៀង)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឈឹម សារុំ ឯកសារ E3/5333 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00453090។

01006876



គ្រាន់សម្រាប់ប្រជាជនជាច្រើនដែលទើបមកដល់នោះទេ ជាពិសេសចំពោះសហករណ៍ថ្មីៗនៅក្នុងព្រៃ[១៨៦៦]។ នៅពេលប្រជាជនមកដល់ របស់របរទាំងឡាយត្រូវបានដកហូត ហើយប្រជាជនខ្លះត្រូវសង់ជម្រកស្នាក់នៅដោយខ្លួនឯង[១៨៦៧]។

---

[១៨៦៥] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ 4 ERN (ភាសាខ្មែរ) 00368783 (ពួកគាត់ត្រូវបានដឹកតាមរទេះគោទៅកាន់ភូមិចំបក់បញ្ញា ស្រុកបន្ទាយស្ទោង ខេត្តកំពង់ធំ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189។ ទំរង់បែបបទសុំព័ត៌មានបន្ថែម ឈីន គីមលាង ឯកសារ E3/4941 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ១ ERN (ភាសាខ្មែរ) 00582317 (នៅក្នុងឆ្នាំ ១៩៧៧ ជិន គីមលាង និងគ្រួសារមីងរបស់គាត់ ត្រូវបានជម្លៀសពីខេត្តកំពត ទៅកាន់ស្រុកស្ទោង ខេត្តកំពង់ធំ)។

[១៨៦៦] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (ព្រុំ ស៊ូ) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី)ទំព័រ ៤៦-៤៧ (ពុំមានអ្វីឡើយ ក្រៅពីព្រៃ ហើយពួកគាត់ត្រូវកាប់ឆ្ការព្រៃ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ផាន់ យឹម ឯកសារ E3/5424 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00481187-00481188 (ពួកគាត់ត្រូវបានបញ្ជាឲ្យឡើងជិះរថភ្លើងឆ្ពោះទៅកាន់ភ្នំធិបដេ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដោយរស់នៅក្នុងព្រៃក្រាស់។ បន្ទាប់មក គាត់ក៏ត្រូវបានបញ្ជូនទៅភូមិថ្មី ខេត្តបាត់ដំបង)។

[១៨៦៧] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១២-១៣ (នៅសហករណ៍កោះជុំ ពួកគាត់ត្រូវសង់ជម្រកដោយខ្លួនឯង ដោយប្រើបង្គោល និងឈើ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ២៤-២៥ (វាលវង់ ស្ថិតនៅក្នុងព្រៃនៅជើងភ្នំក្រវាញ ហើយពួកគាត់ត្រូវសង់ជម្រកស្នាក់នៅដោយខ្លួនឯង ដោយគេពុំបានផ្តល់សម្ភារៈឲ្យពួកគាត់ឡើយ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៤-៣៥ (នៅភូមិព្រៃទទឹង នៅក្នុងព្រៃ ពួកគាត់ត្រូវសង់ជម្រកស្នាក់នៅដោយខ្លួនឯង)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៦ (នៅភ្នំជើងទិញ ពួកគាត់ត្រូវសង់ខ្ទមស្នាក់នៅដោយខ្លួនឯង)។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់តារា-ស ឯកសារ E3/5732 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00916998-00916999។ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ៤៦-៤៧ (នៅសហករណ៍ពោធិ៍ពីរ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ពួកគាត់ត្រូវសង់ជម្រកស្នាក់នៅដោយខ្លួនឯង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សួង ឃិត ឯកសារ E3/4734 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484412 (ភូមិឡបឹងស្វាយ ខេត្តបាត់ដំបងគឺជាតំបន់ព្រៃដាច់ស្រយាល ដែលនៅទីនោះ សម្ភារៈប្រើប្រាស់របស់ពួកគាត់ស្ទើរតែទាំងអស់ ត្រូវដកហូតយកទៅដាក់រួម ហើយពួកគាត់ ត្រូវធ្វើជម្រកស្នាក់នៅដោយខ្លួនឯង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពុធ ពុំ ឯកសារ E3/4714 ចុះថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00397781 (ពួកគាត់ត្រូវសង់កន្លែងស្នាក់នៅដោយខ្លួនឯង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១២៥ ERN (ភាសាខ្មែរ) 00836202 (បន្ទាប់ពីមកដល់ក្នុងព្រៃ ពួកគាត់មានពេលមួយថ្ងៃដើម្បីសង់ខ្ទមពីមែកឈើ ហើយនៅថ្ងៃបន្ទាប់ គេនាំទៅធ្វើស្រែចំការ) ទំព័រ ១៦១-១៦២ ERN (ភាសាខ្មែរ) 00836238-00836239 (នៅក្នុងភូមិជៀវ ពួកគាត់ត្រូវបានបញ្ជាឲ្យសង់ផ្ទះមួយ ក្នុង

## ១១.៣ ទិសដៅនៃការបង្កបង្កើនផល៖ ការផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់ទក្សិណ និងតំបន់កណ្ដាល

៦០២. ក្រៅពីការបែងចែកឡើងវិញលើកម្លាំងមនុស្សក្នុងទ្រង់ទ្រាយធំ ពីតាមបណ្ដាខេត្តនានានៅប៉ែកទក្សិណដែលមានមនុស្សរស់នៅច្រើនកកកុញ ឲ្យទៅខេត្តពោធិ៍សាត់ និងបាត់ដំបង (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគ(ឧត្តរចាស់)កណ្ដាល) និងខេត្តព្រះវិហារ (តំបន់ ១០៣) ប្រជាជននៅក្នុងតំបន់ក៏ត្រូវបានបែងចែកកម្លាំងផងដែរទៅតាមរដូវកាល[១៨៦៨]។ ថ្នាក់ដឹកនាំបក្សជឿថា ការរៀបចំឡើងវិញបែបនេះអាចដោះស្រាយការខ្វះខាតទឹក និងស្បៀងអាហារដែលនឹងផ្ដល់ប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាជន[១៨៦៩]។ ថ្នាក់ដឹកនាំបក្សបានពិចារណាឃើញថា ការពន្លឿនការបង្កបង្កើនផលកសិកម្ម និងបង្កើនផលស្រូវ នឹងធ្វើឲ្យមានទុនចាំបាច់សម្រាប់ទិញសត្វចិញ្ចឹម ឧបករណ៍ ម៉ាស៊ីន បច្ចេកទេស និងសម្ភារៈផ្គត់ផ្គង់ ដែលចាំបាច់សម្រាប់ឲ្យប្រទេសអាចប្រែក្លាយទៅជាប្រទេសដែលមានសេដ្ឋកិច្ចកសិកម្មទំនើបមួយក្នុងរយៈពេលពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ហើយក្រោយមកនឹងក្លាយជារដ្ឋឧស្សាហកម្មមួយ[១៨៧០]។ ទោះបីជាយ៉ាងនេះក្ដី នៅក្នុងពេលនោះ ដោយ

---

រយៈពេល ៥ ថ្ងៃ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៧ ERN (ភាសាខ្មែរ) 00709583 (ជាធម្មតា ពួកខ្មែរក្រហមដាក់ប្រជាជនឲ្យនៅតាមវាល ឬនៅតាមព្រៃ មិនដឹងថាកន្លែងណាទេ ហើយប្រាប់ពួកគេឲ្យកសាងភូមិដើម្បីរស់នៅ។ ជនភៀសខ្លួនម្នាក់បានរំឭកថា នៅពេលទៅដល់ខេត្តបាត់ដំបង ក្នុងខែ តុលា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានបែងចែកជាកងដែលមានគ្នា ៥០ ទៅ ៦០ នាក់ ដោយកងនីមួយៗបង្កើតបានជាភូមិថ្មីមួយ)។ សូមមើលផងដែរសៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣១១ ERN (ភាសាខ្មែរ) 00232309។

[១៨៦៨] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១០៧ ERN (ភាសាខ្មែរ) 00836184 (ទោះបីជាមិនមានការជម្លៀសហ្វូងមនុស្សច្រើនក៏ដោយ ក៏តែងតែមានការជម្លៀសតូចៗក្នុងទឹកដីតែមួយ មួយខែនៅទីនេះ មួយខែនៅទីនោះ ទៅតាមការចង់បានរបស់អ្នកមានអំណាចនៅនឹងកន្លែង។ ប្រជាជនត្រូវបានចាត់ទុកថាជាឈ្លើយសឹក)។

[១៨៦៩] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/170 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១៣-១៥ ERN (ភាសាខ្មែរ) 00064762-00064763។

[១៨៧០] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN (ភាសាខ្មែរ) 00008491 (ទិសដៅរបស់បក្ស គឺបង្កបង្កើនផល និងកសាងប្រទេស)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្ដីដកស្រង់មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ ១៩៧៦ នៅក្នុង ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213ទំព័រ ៥-៦ ERN (ភាសាខ្មែរ)

សារកម្លាំងមនុស្ស និងដីធ្លី គឺជាទុនដែលមានស្រាប់តែមួយមុខគត់[១៨៧១] ទើបត្រូវបានបែងចែកកម្លាំងមនុស្សតាមយុទ្ធសាស្ត្រ[១៨៧២]។

---

00075821-0075822។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/762 ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00063277-00063278 (បក្សឈរលើកសិកម្មជាមូលដ្ឋាន ដើម្បីយកទុនខាងកសិកម្មទៅពង្រឹង និងពង្រីកខាងឧស្សាហកម្មទៀត អភិវឌ្ឍន៍ទៅរកកសិកម្មទំនើបក្នុងរយៈពេល ១០-១៥ ឆ្នាំ និងទិញគ្រឿងម៉ាស៊ីន។

[១៨៧១] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៨ ERN (ភាសាខ្មែរ) 00008492។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក*ឯកសារ E3/781 ចុះខែកញ្ញា ឆ្នាំ១៩៧៥ ទំព័រ១០-១១ ERN (ភាសាខ្មែរ) 00072376-00072377 (ដោយពុំមានប្រជាជនច្រើន ចាំបាច់ត្រូវមានគ្រឿងម៉ាស៊ីនច្រើន។ ប្រជាជនថ្មីត្រូវបំបែកចេញពីគ្នា ដោយមិនអនុញ្ញាតឲ្យនៅផ្តុំគ្នាត្រូវបណ្ដុះបណ្ដាល និងអប់រំ)។ សេចក្ដីសម្រេចចិត្តរបស់សន្និបាតគណៈកម្មាធិការបក្សគ្រប់កងពល ឯកសារ E3/790 ថ្ងៃទី ១០-១៤ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១២ ERN (ភាសាខ្មែរ) 00442006 (ដោយគោក្របីរបស់យើងដោះស្រាយភ្ជួរដីបានតែ៣០ ភាគរយ យើងត្រូវរៀបចំកម្លាំងដើម្បីកាប់ដី ៧០ ភាគរយដែលនៅសល់។ កុំពឹងផ្អែកលើគោក្របី ឬត្រាក់ទ័រជាមូលដ្ឋាន ត្រូវពឹងលើកម្លាំងមនុស្សជាមូលដ្ឋាន)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៦០ ERN (ភាសាខ្មែរ) 00836137 (ពួកវាព្យាយាមកេងចំណេញដោយ “ប្រើមនុស្សឲ្យធ្វើការដូចគោក្របី”)។

[១៨៧២] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៦១-៦២ 27, ERN (ភាសាខ្មែរ) 00063342-00063343 (បក្សសង្កត់ធ្ងន់ថា មានដីល្អច្រើនណាស់ ទាំងដីដែលយើងបានធ្វើរួចហើយពីមុន និងដីដែលយើងមិនទាន់ធ្វើ។ វានៅតែបញ្ហារឿងរៀបចំកម្លាំងឲ្យត្រឹមត្រូវទៅប្រើប្រាស់ដីនេះឲ្យបានល្អជាអតិបរមា)។ របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារE3/216 ចុះថ្ងៃទី២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN (ភាសាខ្មែរ) 00008491 (ត្រូវចែកកម្លាំងទៅកន្លែងដីទំនេរ ដើម្បីបង្កបង្កើនផល។ ត្រូវប្រមូលកម្លាំងទៅកន្លែងណាដែលមានលទ្ធភាពជាងគេ)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00072373-00072374 (កម្លាំងប្រជាជនត្រូវប្រមូលទៅធ្វើការនៅកន្លែងណាដែលដីល្អ មានជីជាតិ)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/11 ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ១០០-១០១ ERN (ភាសាខ្មែរ) 00063171 (កត្តាកំណត់នៃកម្លាំងផលិតកម្ម គឺមនុស្ស)។ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរសេនាធំ ឯករាជ ឯកសារ E3/819 ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00383776-0038377 (ដើម្បីសម្រេចបានទិសដៅបង្កបង្កើនផល បក្សយល់ឃើញថា ត្រូវចេះប្រើប្រាស់កម្លាំង “ឲ្យចំទិស”។ កុំពង្រាយកម្លាំង ត្រូវចេះប្រមូលកម្លាំងបុកកន្លែងដែលសំខាន់)។ សេចក្តីសម្រេចចិត្តរបស់សន្និបាតគណៈកម្មាធិការបក្សគ្រប់កងពល ឯកសារ E3/790 ថ្ងៃទី ១០-១៤ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៨-១២, ១៧ ERN (ភាសាខ្មែរ) 00442202-00442006, 00442011 (ត្រូវប្រមូលកម្លាំងដើម្បីវាយឲ្យចំដីមានជីជាតិ និងបន្តលើកទំនប់ ភ្លឺស្រែ និងប្រឡាយ)។

៦០៣. នៅតាមសហករណ៍នីមួយៗមានកងចល័តដែលត្រូវបានចាត់ឲ្យធ្វើការងារចល័ត ជាទៀង-ទាត់ ហើយជានិច្ចកាល កងចល័តទាំងនោះត្រូវប្រចាំការរហូត[១៨៧៣] ។ ថ្នាក់ដឹកនាំបក្សបានពិចារណាឃើញថា សហករណ៍ត្រូវតែពង្រីកពី ១០ ឬ ២០ គ្រួសារ ទៅ ១.០០០ គ្រួសារ ដើម្បីមានលទ្ធភាពផ្តល់កម្លាំងមនុស្សសម្រាប់គ្រប់សកម្មភាពទាំងអស់ ទើបបក្សអាចជៀសវាងមិនផ្លាស់ទីលំនៅប្រជាជនបន្តទៀត[១៨៧៤]។

### ១១.៣.១ ទិសដៅឆ្នាំ ១៩៧៦៖ ៣ តោន ក្នុង ១ ហិកតា

៦០៤. នៅចន្លោះខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបពិភាក្សាអំពីគោលនយោបាយការពារ និងកសាងប្រទេស[១៨៧៥]។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៥ សន្និបាតសេដ្ឋកិច្ចរបស់បក្សទូទាំងប្រទេសលើកទី១ បានដាក់ចេញផែនការដែលអាចនឹងប្រែក្លាយប្រព័ន្ធកសិកម្មអន់ថយមួយរបស់ប្រទេសឲ្យទៅជាប្រព័ន្ធកសិកម្មទំនើបមួយ ក្នុងរយៈពេល ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ខាង

---

[១៨៧៣] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ១២-១៣ (កងចល័តគឺជាកម្លាំងសំខាន់នៅក្នុងសហករណ៍នីមួយៗ និងសម្រាប់ប្រើសំរុកក្នុងការសាងសង់ទំនប់ ភ្លឺស្រែ និងការធ្វើស្រែចម្ការ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១៣ ERN (ភាសាខ្មែរ) 00709589 (ក្រុមចល័តត្រូវបានចាត់តាំងឲ្យធ្វើការងារធ្ងន់នៅឆ្ងាយពីភូមិ។ ពួកគេដេកនៅតាមការដ្ឋាន)។ អត្ថបទរបស់ François PONCHAUD ៖ *កម្ពុជា៖ សេដ្ឋកិច្ចបែបបដិវត្តន៍* ឯកសារ E3/2412 ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00812356 (កងចល័តធ្វើដំណើរផ្លាស់ទីដែលតម្រូវទៅតាមភាពចាំបាច់ តាមតំបន់ ហើយពួកទាំងនេះហើយដែលទទួលខុសត្រូវជាអាទិភាពក្នុងការសាងសង់សំណង់ធំៗ)។

[១៨៧៤] *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៥៧-៥៨ ERN (ភាសាខ្មែរ) 00063269-00063270។

[១៨៧៥] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១៦-១៧ ERN (ភាសាខ្មែរ) 00019123-00019124 (នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ គណៈអចិន្ត្រៃយ៍បានរៀបចំប្រជុំមួយដែលមានវត្តមាន នួន ជា និង ខៀវ សំផន។ គណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជាក់ថា មាគ៌ារួម គឺកសាង និងការពារប្រទេស ដោយផ្អែកលើ និងដោយរៀបចំកម្លាំងមហាជន)។ អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00062453-00062454 (នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ មានការប្រជុំថ្នាក់គណៈកម្មាធិការអចិន្ត្រៃយ៍មួយ ស្តីអំពីវិធីសាស្ត្រក្នុងការ ការពារប្រទេស។ មានការពិភាក្សាអំពីកសិកម្ម និងការផ្គត់ផ្គង់ទឹក។

មុខ[១៨៧៦]។ ថ្នាក់ដឹកនាំបក្សបានសម្រេចថា បក្សនឹងពង្រីកសហករណ៍ លើកភ្លឺស្រែ ជីកប្រឡាយ និង លើកទំនប់ ហើយផ្តោតសំខាន់លើដីដែលមានជីជាតិបំផុតដើម្បីសម្រេចផលស្រូវ ៣ តោន ក្នុង ១ ហិកតា ឱ្យបានត្រឹមឆ្នាំ ១៩៧៦[១៨៧៧]។ កំណត់ហេតុនៃកិច្ចប្រជុំនាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ដែលនៅពេលនោះ ខៀវ សំផន និង នួន ជា មានវត្តមាន[១៨៧៨] បានបញ្ជាក់ថា បក្សសម្រេចបាន ទិសដៅឆ្នាំ ១៩៧៦ ចំនួន ៣០ ភាគរយ ហើយបានវាយតម្លៃថា ជោគជ័យនេះកើតឡើងដោយសារ

---

[១៨៧៦] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១០-១៩ ERN (ភាសាខ្មែរ) 00063245-00063247។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/760 ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ៣០-៣២ ERN (ភាសាខ្មែរ) 00062855-00062856។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00072367 (ចំណុចនេះគឺចាំបាច់ខ្លាំងណាស់ដើម្បីការពារប្រទេស និង ជាយថាហេតុធ្វើឲ្យប្រទេសប្រែក្លាយទៅជាប្រទេសកសិកម្មទំនើប។

[១៨៧៧] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00072373-00072374 ទំព័រ ១ ERN (ភាសាខ្មែរ) 00072367 (ទិសដៅនេះតម្រូវឲ្យមានការបែងចែកកម្លាំងពលកម្មឲ្យបានត្រឹមត្រូវ ដើម្បីបញ្ចៀសនូវភាពអសកម្ម និងដើម្បីធានា សម្រេចផែនការជាបន្តបន្ទាប់)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/139 ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00064962-00064963 (នៅក្នុងឆ្នាំ ១៩៧៦ ការងារដ៏សំខាន់បំផុត គឺបង្កើនផលិតផលស្រូវ ដោយកំណត់ទិសដៅ ធ្វើស្រែឲ្យបាន៣តោនក្នុងមួយហិកតា)។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/230 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00000711 (នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍ស្នើឲ្យជំរុញការងារនៅទំនប់គីរីរម្យបន្ថែមទៀត)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/734 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00064119-00064120 (ចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៥ បក្សមានទិសដៅថ្មីពីរ៖ ការពារ និងកសាងប្រទេស។ ដើម្បីសម្រេចបានទិសដៅនេះ និងដើម្បីធានានូវជីវភាពរស់នៅរបស់ប្រជាជន ចាំបាច់ត្រូវបង្កបង្កើនផលស្រូវឲ្យបាន ៣ តោនក្នុងមួយហិកតា។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/760 ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00062838-00062839 (កម្លាំងត្រូវចាត់ចែងតាមតម្រូវការ និងយុទ្ធសាស្ត្របក្ស)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/166 ខែ កុម្ភៈ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៤៨-៤៩, ៦២-៦៤ ERN (ភាសាខ្មែរ) 00063215-00063216, 000632223-000632224 (កម្លាំងមិនត្រូវប្រមូលផ្តុំនៅតែកន្លែងមួយនោះទេ ត្រូវផ្លាស់ទៅជួយសហករណ៍ផ្សេងៗទៀតនៅពេលមានតម្រូវការ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១៨ ERN (ភាសាខ្មែរ) 00709594 (ការឃោសនារបស់កម្ពុជាបានបង្ហាញថា អាទិភាពខ្ពស់បំផុតសម្រាប់ថ្នាក់ដឹកនាំបក្ស គឺការធ្វើស្រែ លើកទំនប់ និងជីកប្រឡាយទឹក)។

[១៨៧៨] កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00017116។

ការរៀបចំផែនការបានហួត់ចត់ និងប្រុងប្រយ័ត្ន[១៨៧៩]។ គិតមកត្រឹមខែ ឧសភា ឆ្នាំ ១៩៧៦ ស្រែត្រូវបានភ្ជួររាស់យ៉ាងហោចណាស់បានម្តង ហើយការសាបព្រោះ និងដកស្ទូងបានចាប់ផ្តើមរួចទៅហើយ[១៨៨០]។

៦០៥. ទោះបីជាយ៉ាងនេះក៏ដោយ ថ្នាក់ដឹកនាំបក្សបានចាប់ផ្តើមដឹងថា ពួកគេបានប្រឈមមុខនឹងការលំបាកនៅក្នុងការសម្រេចទិសដៅ ៣ តោនក្នុង ១ ហិកតា ឲ្យបានត្រឹមឆ្នាំ ១៩៧៦។ ក្រោយពីបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៅដើមឆ្នាំ១៩៧៦ អៀង ធីរិទ្ធ បានធ្វើដំណើរទៅពិនិត្យមើលស្ថានភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេសកម្ពុជា។ គាត់បានរាយការណ៍ជូនថ្នាក់ដឹកនាំ (រួមទាំង"នាយករដ្ឋមន្ត្រី")ថា ប្រជាជននៅក្នុងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) មានជំងឺ ហើយត្រូវទៅធ្វើការឆ្ងាយពីភូមិរបស់ពួកគេ ព្រមទាំងគ្មានផ្ទះសម្បែងស្នាក់នៅ[១៨៨១]។ ស្ថានភាពរស់នៅស្រដៀងគ្នានេះ ក៏ត្រូវបានគេរាយការណ៍ថាបានកើតឡើងនៅក្នុងខេត្តព្រះវិហារ (តំបន់ ១០៣) ផងដែរ ដោយនៅទីនោះកម្លាំងការងារចំនួន ៤០ ភាគរយ បានបាត់បង់ដោយសារជំងឺ[១៨៨២]។ នៅតាមការដ្ឋានសាងសង់នានា គេបានរាយការណ៍ថា ការរីកចម្រើនមានសភាពយឺតយ៉ាវដោយសារមិនមានគ្រឿងចក្រ ឬ ឧបករណ៍ប្រើប្រាស់[១៨៨៣]។ ក្រសួងពាណិជ្ជកម្មបានរាយការណ៍ថា នៅដើមឆ្នាំ ១៩៧៦ កម្លាំងពលកម្មខ្លះពុំត្រូវបានបែងចែកតាមយុទ្ធសាស្ត្រឡើយ

---

[១៨៧៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00017120-00017121។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/25 ខែ ធ្នូ ឆ្នាំ ១៩៧៦ - មករា ឆ្នាំ ១៩៧៧ ទំព័រ ១៦ ERN (ភាសាខ្មែរ) 00063010 (ការរៀបចំថ្មីជាផែនការជាខ្សែសង្វាក់ ក្នុងឆ្នាំ ១៩៧៦)។

[១៨៨០] របាយការណ៍ស្តីពីខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៤០-៤១ ERN (ភាសាខ្មែរ) 00442229។

[១៨៨១] ប្រតិចារឹកខ្សែអាត់សម្លេងនៃបទសម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ៣៥-៣៦ ERN (ភាសាខ្មែរ) 00741117-00741118។

[១៨៨២] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232 ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00017118។

[១៨៨៣] កំណត់ហេតុនៃអង្គប្រជុំការងារ ឯកសារ E3/237 ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00072474-00072475 (នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៧៦ ក្រសួងសាធារណការបានបើកអង្គប្រជុំមួយដែលពិភាក្សាអំពីការវិវឌ្ឍន៍ទៅមុខយ៉ាងយឺតនៃទំនប់គិរីរម្យ (ពួកគេត្រូវបំបែកថ្មដោយខ្លួនឯង) និងស្ពានជ្រោយចង្វារ (បញ្ហាចោទគឺពុំមានម៉ាស៊ីនស្ទូចស្ពានដែលអាចស្ទូចបានជាង ១០០ តោន))។

ឧទាហរណ៍ កម្លាំងទាំងនោះបានដកយកទៅជីកស្រះ ចិញ្ចឹមអណ្តើក និងដាំដុះដំណាំលើដីដែលគ្មានជីជាតិ[១៨៨៤]។

៦០៦. នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៦ ក្នុងកិច្ចប្រជុំស្តីពីការងារសុខាភិបាល និងសង្គមកិច្ចដែលនៅពេលនោះ ខៀវ សំផន បានចូលរួមផងដែរ[១៨៨៥] ថ្នាក់ដឹកនាំបក្សបានលើកឡើងសាជាថ្មីថា ប្រសិនបើមិនអាចសម្រេចបាន ៣ តោន ក្នុង ១ ហិកតា ទេនោះ បក្សនឹងមិនមានលទ្ធភាពចិញ្ចឹមប្រជាជន ឬ ការពារប្រទេសបានឡើយ[១៨៨៦]។ ក្នុងខែនោះដែរ តំណាងបក្សបានណែនាំឲ្យមានការជួបប្រជុំនៅភូមិភាគបស្ចិម ដើម្បីបែងចែកកម្លាំងមនុស្សតាមយុទ្ធសាស្ត្រនៅទូទាំងប្រទេស ទៅតាមការចាំបាច់[១៨៨៧] ។ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៦ ក្រសួងពាណិជ្ជកម្មបានរាយការណ៍ថា ខ្លួនបានចូលរួម

---

[១៨៨៤] របាយការណ៍ក្រសួងពាណិជ្ជកម្ម ឯកសារ E3/1159 ចុះថ្ងៃទី ២៥-២៦ ខែ កក្កដា ឆ្នាំ១៩៧៦ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00188210-00188211។

[១៨៨៥] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/226 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00017147។

[១៨៨៦] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/226 ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៩៧៦ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00017154-00017155។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៣៨-៤៤ ERN (ភាសាខ្មែរ) 00062766-00062769។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/733 ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៥-១២ ERN (ភាសាខ្មែរ) 00064007-00064011 (នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ បក្សបានពន្យល់ថា ៣តោនក្នុងមួយហិកតា នឹងអាចដោះស្រាយជីវភាពប្រជាជន កសាង និងការពារប្រទេស)។

[១៨៨៧] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្តីដកស្រង់មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ១៩៧៦ នៅក្នុង ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213 ទំព័រ ១៧-២០, ២៨-២៩, ៣៧-៤៣ ERN (ភាសាខ្មែរ) 00062847-00062849, 00062854, 00062859-0062862 (ត្រូវរៀបចំកម្លាំងពលកម្ម នៅទូទាំងប្រទេស ដើម្បីធានាថា ទាំងនៅសមរភូមិមុខ និងសមរភូមិក្រោយ មានកម្លាំងគ្រប់គ្រាន់)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/4 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១២-២៣ ERN (ភាសាខ្មែរ) 00062913-00062918 (ត្រូវធ្វើការវាយសម្រុកតាមមាគ៌ាសកម្មត្រឹមត្រូវ និងសក្តិសិទ្ធិបំផុត រួមមាន ការពង្រឹង និងការពង្រីកសហករណ៍ ដោយផ្តោតទៅលើទឹក និងការសម្រេចឲ្យបាន ៣ តោនក្នុងមួយហិកតា តាមរយៈការរៀបចំ និងការចាត់ចែងដោយប្រុងប្រយ័ត្ន និងស៊ីសង្វាក់គ្នា)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៣៨-៤៤ ERN (ភាសាខ្មែរ) 00062766-00062769 (សំខាន់ខ្លាំងណាស់ក្នុងការសាងសង់ភ្លឺស្រែ ប្រឡាយ និងទំនប់នៅទូទាំងប្រទេស។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/237 ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ)00072476-00072477 (យើងត្រូវប្រមូលផ្តុំ ដើម្បីពង្រីកផ្លូវ ស្ពាន)។ របាយការណ៍ភូមិភាគបូព៌ា ឯកសារ E3/1218 ថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00021111 (នៅថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ភូមិភាគបូព៌ាបានទទួលរបាយការណ៍មួយពាក់ព័ន្ធនឹង *ក្នុងចំណោមប្រការផ្សេងទៀត* ការប្រមូល

ចំណែកដល់ការការពារ និងអភិវឌ្ឍន៍ជាតិ ដោយបានផ្ដល់កម្លាំងមនុស្សសម្រាប់ការបង្កបង្កើនផលកសិកម្ម[១៨៨៨]។

៦០៧. ចាប់ផ្ដើមពីចុងឆ្នាំ ១៩៧៥ រហូតដល់ពេញឆ្នាំ ១៩៧៦ កម្លាំងការងារតាមរដូវកាលដែលមានចំនួនប្រជាជនរាប់ម៉ឺននាក់ត្រូវបានផ្លាស់ទីលំនៅនៅក្នុងខេត្ត និងរវាងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)[១៨៨៩] នៅក្នុងខេត្ត និងរវាងខេត្តកំពត[១៨៩០] ខេត្តតាកែវ[១៨៩១] និងខេត្ត

---

កម្លាំងពលកម្មចល័តដើម្បីសម្រុកការច្រូតកាត់ស្រូវនៅកន្លែងណាដែលមានស្រូវទុំច្រើន ។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/762 ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ២៨-៣១ ERN (ភាសាខ្មែរ) 00063290-00063291 (ទឹកគឺជាអាទិភាព ហើយត្រូវប្រមូលកម្លាំងច្រើនឃុំ ដើម្បីដោះស្រាយទឹកនៅឃុំ ឬ ស្រុកណាមួយទៀត)។

[១៨៨៨] របាយការណ៍ក្រសួងពាណិជ្ជកម្ម ឯកសារ E3/1110 ចុះថ្ងៃទី២៥-២៦ ខែ កក្កដា ឆ្នាំ១៩៧៦ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00381695-00381697។ របាយការណ៍ក្រសួងពាណិជ្ជកម្ម ឯកសារ E3/1159 ចុះថ្ងៃទី ២៥-២៦ ខែ កក្កដា ឆ្នាំ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00188206-00188207 (ក្នុងអំឡុងសន្និបាតក្រសួងពាណិជ្ជកម្មនៅចុងឆ្នាំ ១៩៧៦ មានការរាយការណ៍ថា ក្រសួងពាណិជ្ជកម្មបានវាយសម្រុក ដើម្បីសម្រេចទិសដៅ ៣ តោនក្នុងមួយហិកតា និងលើកប្រព័ន្ធភ្លឺស្រែថ្មី)។

[១៨៨៩] ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅជាថ្មីនៅក្នុងភូមិភាគពាយ័ព្យ រួមទាំង ប្រជាជនដែលធ្លាប់បានរស់នៅភូមិភាគពាយ័ព្យមុនខែ មេសា ឆ្នាំ ១៩៧៥ ផង ក៏ដូចជា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅមកពីប៉ែកទក្សិណប្រទេសកម្ពុជាក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៣៨-៣៩ (ក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមម្នាក់បានមកដល់វាលវង់ ខេត្តពោធិ៍សាត់ ហើយបានស្នើឲ្យអ្នកស្ម័គ្រចិត្តចេញដំណើរ។ ប្រជាជនចំនួនប្រហែល ១.000 នាក់ បានស្ម័គ្រចិត្ត។ ដំបូងឡើយ ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅកាន់ភូមិប្រាំពីរ និងបន្ទាប់មក ទៅកាន់ដូនអី ខេត្តបាត់ដំបង នៅក្នុងខែ មករា ឆ្នាំ ១៩៧៦)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អួន ផល្លី ឯកសារ E3/5740 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៩, ERN (ភាសាខ្មែរ) 00552941 (នៅក្នុងខេត្តបាត់ដំបង កុមារៗត្រូវបានប្រមូលឲ្យទៅធ្វើការនៅការដ្ឋានភ្នំត្រជាក់ចិត្ត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុខ មឿន ឯកសារ E3/4918 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00544578-00544579 (សុខ មឿន និងក្រុមគ្រួសារត្រូវបានជម្លៀសនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ចេញពីភូមិកោះខ្សាច់ ទៅកាន់ភូមិ តា យុក ស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅចុងឆ្នាំ ១៩៧៥ ពួកគាត់ត្រូវបានជម្លៀសទៅកាន់ឫស្សីកូនខ្លា ហើយក្រោយមក ទៅកាន់ សហករណ៍សំរោងយា ភូមិថ្មី ឃុំខ្នារ ដែលស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់)។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី មួរ សេដ្ឋា ឯកសារ E3/5311 ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៧, ERN (ភាសាខ្មែរ) 00365588-00365592 (មួរ សេដ្ឋា ដែលមានឪពុកធ្វើជាចៅក្រមក្នុងរបប លន់ នល់ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានជម្លៀសចេញពីភូមិត្រពាំងជង ឃុំខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ទៅកាន់ភូមិព្រះចំបក់ ខេត្តពោធិ៍សាត់ ក្នុងខែមេសា ឆ្នាំ១៩៧៥។ ៥ ឬ ៦ ខែ ក្រោយមក (ប្រហែលជានៅក្នុងខែ កញ្ញា ឬ តុលា ឆ្នាំ ១៩៧៥) មួរ សេដ្ឋា បងស្រី ២នាក់ និងបងប្រុស២ នាក់របស់គាត់ត្រូវបាន

01006884



ព្រៃវែង[១៨៩២] ខេត្តកណ្តាល[១៨៩៣] ខេត្តស្វាយរៀង[១៨៩៤] និងខេត្តកំពង់ស្ពឺ[១៨៩៥] (ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា) និងទៅកាន់ខេត្តក្រចេះ (តំបន់ ៥០៥)[១៨៩៦]។ យ៉ុង យ៉ែម គឺជាលេខាតំបន់

---

ខ្មែរក្រហមចាត់ឲ្យទៅនៅក្នុងកងចល័តជួរមុខ នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលនៅទីនោះ ពួកគេបានជីកប្រឡាយនៅការដ្ឋានទំនប់ ១៧ មករា) ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារ E3/5187 ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៥, ERN (ភាសាខ្មែរ)00197919 (ព្រំ សារុន ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅការដ្ឋានកំពីងពួយ ក្នុងខេត្តបាត់ដំបង ជាមួយនឹងមនុស្សរាប់ម៉ឺននាក់ដែលត្រូវបានបញ្ជូនមកពីគ្រប់ស្រុកក្នុងខេត្តបាត់ដំបង សម្រាប់រយៈពេល៣ ខែក្នុងមួយឆ្នាំៗ បន្ទាប់ពីរដូវច្រូតកាត់ផុតទៅ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២១១, ERN (ភាសាខ្មែរ) 00836288 (ពួកខ្មែរក្រហមបានបំបែកគ្រួសារឲ្យនៅផ្សេងពីគ្នាដោយបញ្ជូនឪពុកឲ្យទៅធ្វើការនៅក្នុងព្រៃរយៈពេល៣ខែ ហើយមនុស្សវ័យជំទង់ និងកុមារ ត្រូវបានឲ្យលើកភ្លឺស្រែ និងលើកទំនប់ នៅតាមទីកន្លែងផ្សេងៗឆ្ងាយពីផ្ទះ)។ អត្ថបទរបស់ នង ឧត្តារ៖ *ការដកហូតសិទ្ធិសេរីភាព* នៅក្នុងទស្សនាវដ្តីរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា (អត្ថបទជាភាសាអង់គ្លេសលេខពិសេស ចុះខែ កក្កដា ឆ្នាំ ២០០៣) ឯកសារ E3/1800 ទំព័រ ៥៦, ERN (ភាសាអង់គ្លេស) 00080450 (ក្រោយពីបានជម្លៀសទៅកាន់ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង នៅក្នុងរដូវវស្សាឆ្នាំ ១៩៧៥ រួចមក ប្រជាជនទាំងនោះ ត្រូវបានជម្លៀសពីស្រុកមួយទៅកាន់ស្រុកមួយ ទៀត។ នៅក្នុងពាក់កណ្តាលឆ្នាំ ១៩៧៦ ប្រជាជនត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅគោកតាយូ ចំណែកឯអ្នកផ្សេងទៀតត្រូវបានឃុំឃាំងនៅសេរីសោភ័ណ្ឌ)។

[១៨៩០] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី យស ផល ឯកសារ E3/4611 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00418484-00418485 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ យស ផល "ប៉ូលីស" ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។ ដំបូងឡើយ គាត់បានធ្វើដំណើរទៅដល់ខេត្តកំពង់ចាម ក្រោយមក ក៏បានទៅដល់ខេត្តតាកែវ និងចុងក្រោយ គាត់បានទៅដល់ឡអាចម៍ស្វា ក្នុងខេត្តកំពត។ នៅចុងឆ្នាំ ១៩៧៥ គាត់ និងក្រុមគ្រួសារត្រូវបានផ្លាស់ទីលំនៅទៅកាន់ភូមិត្រពាំងធំ ឃុំរនាម ដែលនៅទីនោះ គាត់បានធ្វើការនៅក្នុងកងចល័តអស់រយៈពេល៣ឆ្នាំ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ស៊ិន ឯកសារ E3/4872 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00533871 (បន្ទាប់ពីថ្ងៃ ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានបញ្ជូន ឡុង ស៊ិន ពីខេត្តតាកែវ ទៅកាន់ភូមិសាយរៀង ខេត្តកំពត។ ក្នុងខែ តុលា ឆ្នាំ ១៩៧៦ ឡុង ស៊ិន ត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ឃុំថ្មី ខេត្តកំពត)។ ទំរង់បែបបទសុំព័ត៌មានបន្ថែម ឈើន គីមលាង ឯកសារ E3/4941 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ១, ERN (ភាសាខ្មែរ) 00582317។

[១៨៩១] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យ៉ាន ញ៉ ឯកសារ E3/4987 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00556117-00556118 (យ៉ាន ញ៉ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនចេញពីទីក្រុងភ្នំពេញ ទៅ កាន់ភូមិអូរអន្ស្សា ស្រុកគីរីវង់ ខេត្តតាកែវ បន្ទាប់ពីថ្ងៃ ១៧ មេសា ១៩៧៥។ នៅឆ្នាំ ១៩៧៦ ពួកគាត់ត្រូវបានបញ្ជូនទៅកាន់ភូមិស្វាយស ស្រុកគីរីវង់ ខេត្តតាកែវ)។

[១៨៩២] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ម៉ាត់ ឯកសារ E3/5053 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៤, ERN (ភាសាខ្មែរ) 00565015 (នៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ លី ម៉ាត់ និងគ្រួសាររបស់គាត់ ត្រូវបានបញ្ជូន

01006885



៥០៥ ចាប់ពីឆ្នាំ ១៩៧១ ដល់ ឆ្នាំ ១៩៧៦។ នៅចន្លោះឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៨ ប៊ិន ណាន ហៅ យី គឺជាលេខា[១៨៩៧]។

៦០៨. ពីមួយរដូវទៅមួយរដូវ ប្រជាជនទាំងនេះ ជាពិសេសកងចល័តដែលបានបង្កើតនៅតាមសហករណ៍នីមួយៗ ត្រូវបានផ្លាស់ទីលំនៅជាញឹកញាប់ ដោយថ្មើរជើង ក្រោមការយាមកាម និង

---

ចេញពីស្រុកមុខកំពូល ឆ្ពោះទៅកាន់ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ៣ខែក្រោយមក គាត់ត្រូវបានបញ្ជូនទៅកាន់មីមល ទន្លេតូច ស្រុកសរព្រះច័ន្ទ ខេត្តព្រៃវែង។

[១៨៩៣] ប្រតិចារឹក ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០១២(គឹម វ៉ាន់ឌី)ទំព័រ៩-១១ (នៅក្នុងឆ្នាំ ១៩៧៦ គេបានហៅប្រជាជន ១៧ មេសា ឲ្យទៅប្រជុំនៅស្រុកមួយក្នុងខេត្តកណ្ដាល។ ពួកគេបានប្រាប់ប្រជាជនឲ្យរៀបចំឥវ៉ាន់ ដើម្បីអាចឲ្យពួកគេជម្លៀសប្រជាជនទៅកាន់ទំនប់ព្រៃផ្ដៅ។ នៅឯការដ្ឋានធ្វើការងារ ប្រជាជនត្រូវបានបង្ខំឲ្យរែកដី កើបភក់ និងលើកទំនប់)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សូ សាមិត ឯកសារ E3/5393 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧, ERN (ភាសាខ្មែរ) 00479161 (នៅឆ្នាំ ១៩៧៦ សូ សាមិត ត្រូវបានជម្លៀសចេញពីច្បារអំពៅ ទៅកាន់ស្វាយប្រទាល ព្រំប្រទល់ស្រុកស្អាង ខេត្តកណ្ដាល។ នៅចុងឆ្នាំ ១៩៧៦ សូ សាមិត ត្រូវបានជម្លៀសចេញពីស្វាយប្រទាលទៅកាន់ប្រាសាទទុយោ ស្រុកកោះធំ ខេត្តកណ្ដាល)។

[១៨៩៤] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រាជ យ៉េន ឯកសារ E3/5019 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00594147-00594148 (រាជ យ៉េន ត្រូវបានជម្លៀស ២ លើកនៅក្នុងស្រុករំដួល និងជម្លៀសទៅកាន់ស្រុកសំរោង ក្នុងខេត្តស្វាយរៀង។

[១៨៩៥] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស៊ុំ សឿន ឯកសារ E3/5055 ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤, ERN (ភាសាខ្មែរ) 00565523 (ស៊ុំ សឿន និងប្អូនប្រុសរបស់គាត់ ត្រូវបានចាត់ឲ្យលើកទំនប់នៅបឹងកក់ ឃុំកំពង់អុស ស្រុកពញាឮ)។

[១៨៩៦] កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ឯកសារ E3/436 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៩, ERN (ភាសាខ្មែរ) 00405492 (មុនពេល ហេង ឡៃហ៊ាង ចាកចេញពីខេត្តក្រចេះ ប្រជាជនមកពីតំបន់ផ្សេងទៀត ត្រូវបានជម្លៀសមកកាន់ខេត្តក្រចេះ ដើម្បីសាងសង់ផ្លូវ លើកទំនប់ និងធ្វើស្រែ)។

[១៨៩៧] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យន់ គីម) ទំព័រ ២១ (យ៉ែមគឺជាលេខាតំបន់ ៥០៥ ពីឆ្នាំ ១៩៧១ ដល់ ឆ្នាំ១៩៧៦ ហើយ បន្ទាប់មក ពីឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៨ យី គឺជាលេខា)។ បទសម្ភាសន៍ជាមួយ សេង សឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5643ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រ ២០-២១ ERN (ភាសាខ្មែរ) 00059326-00059327 (យ៉ុង យ៉ែម គឺជាលេខាតំបន់ក្រចេះនៅមុនឆ្នាំ ១៩៧៥ រហូតដល់ពេលតែងតាំងគាត់ឲ្យធ្វើជាអគ្គរដ្ឋទូតនៅកូរ៉េ។ បន្ទាប់មក យី ទទួលបន្ទុកជាលេខា)។ *សូមមើលផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/501 ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00021508 (ទូរលេខដែល យី ផ្ញើជូន ៨៧០ ពាក់ព័ន្ធនឹងប្រជាជនដែលលុកលុយចូលមកក្នុងតំបន់ ៥០៥ ដោយគ្មានការអនុញ្ញាត)។ *ដំណើរទស្សនកិច្ចរបស់ ចេន យ៉ុងគៀយ* (កម្រងឯកសារ SWB) ឯកសារ E3/1405 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00651220-00651221 (យ៉ុង យ៉ែម ត្រូវបានគេកំណត់អត្តសញ្ញាណថាជាកុងស៊ុលស្ថានទូត)។

ដោយគ្មានស្បៀងអាហារ ឬ កន្លែងស្នាក់នៅគ្រប់គ្រាន់[១៨៩៨] ដើម្បីឲ្យទៅធ្វើស្រែ និងកសាងហេដ្ឋារចនាសម្ព័ន្ធ រួមទាំង ទំនប់ទឹក និងប្រព័ន្ធធារាសាស្ត្រ[១៨៩៩]។ អង្គការបានប្រាប់ប្រជាជនថា

---

[១៨៩៨] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ៣៧-៣៩។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៦២, ERN (ភាសាខ្មែរ) 00836239 (ប្រជាជនត្រូវបានបង្ខំឲ្យធ្វើដំណើរឆ្ងាយ។ ចម្ងាយនេះមិនចោទជាបញ្ហាអ្វីទេ លើកលែងតែថាពួកគេមិនបានផ្តល់ចំណីអាហារឲ្យប្រជាជនហូបចុក) ទំព័រ ២៧៣ ERN (ភាសាខ្មែរ) 00836350 (ខ្មែរក្រហមមិនខ្វល់នឹងការផ្តល់ទីជម្រក អាហារ ឬ ថ្នាំសង្កូវ មកឲ្យកងចល័តទេ)។ កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី ឯកសារ E3/794 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១៥, ERN (ភាសាខ្មែរ) 00000791 (មិនមានជម្រកគ្រប់គ្រាន់សម្រាប់កងចល័តទេ ហើយជម្រកដែលមាន គ្រាន់តែជាជម្រកបណ្តោះអាសន្នប៉ុណ្ណោះ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00709590 (កងចល័តនានា រួមទាំងនៅភ្នំស្រុកផង គឺស្ថិតនៅក្រោមការត្រួត ពិនិត្យដោយកម្លាំងប្រដាប់អាវុធ ទាំងនៅតាមវាលស្រែ ឬនៅតាមការដ្ឋានរបស់ពួកគេ រួមទាំង ការដ្ឋានជីកប្រឡាយនៅក្នុងរដូវវស្សាផងដែរ។ ដោយសារពួកគេឈរត្រាំទឹកពេញមួយថ្ងៃ អ្នកខ្លះក៏បានស្លាប់។ ប្រជាជនត្រូវបានបញ្ជូនចេញឲ្យទៅធ្វើការ ប្រសិនបើមានតម្រូវការពលកម្មនៅកន្លែងផ្សេង)។

[១៨៩៩] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី ឯកសារ E3/794 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១៣, ERN (ភាសាខ្មែរ) 00000789 (ប្រជាជនរាប់ពាន់នាក់នៅការដ្ឋានធ្វើការងារទូទាំងភូមិភាគពាយ័ព្យ ភូមិភាគនិរតី ភូមិភាគបូព៌ា និងភូមិភាគបស្ចិម ត្រូវបានប្រមូលឲ្យទៅជីកប្រឡាយ) ទំព័រ ១៩, ERN (ភាសាខ្មែរ) 00000795 (កងចល័តខ្លះយកចិត្តទុកដាក់ទៅលើការបង្កបង្កើនផលស្រូវ ហើយត្រូវបានបញ្ជូនឲ្យទៅជួសជុលផ្លូវរថភ្លើងនៅរដូវប្រាំង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ៀន សារ៉េត ឯកសារ E3/4755 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00484872-00484873 (ប៉ៀន សារ៉េត ត្រូវបានបញ្ជូនទៅកាន់សហករណ៍ផ្សេងៗដែលជាផ្នែកមួយនៃកងចល័តនៅក្នុងខេត្តបាត់ដំបង។ គាត់ត្រូវបានបញ្ជូនឲ្យទៅដកស្ទូង ច្រូតស្រូវ និងលើកភ្លឺស្រែ នៅពេលផ្លាស់ប្តូររដូវកាល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អេង ហុងស៊ុំ ឯកសារ E3/5091 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៩, ERN (ភាសាខ្មែរ) 00881755 (ក្នុងឆ្នាំ ១៩៧៦ នៅពេលស្រូវទុំ គេបានជម្លៀសយើងទៅភូមិក្រាំងស្វាត នៅក្នុងខេត្តបាត់ដំបង) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុខ មឿន ឯកសារ E3/4918 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00544579 (នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៦ សុខ មឿន ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ែល យ៉ាស់ ឯកសារ E3/4975 ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00555515 (បន្ទាប់ពីត្រូវបានផ្លាស់ទីលំនៅជាថ្មីនៅក្នុងខេត្តពោធិ៍សាត់ក្នុងឆ្នាំ ១៩៧៥ រួចមក អ៊ែល យ៉ាស់ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនទៅភូមិជម្លង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់។ នៅពេលច្រូតស្រូវវស្សារួចរាល់ហើយ ពួកគាត់ត្រូវបានបញ្ជាឲ្យទៅធ្វើស្រែប្រាំងនៅឫស្សី ១០០ គុម្ព ស្រុកបាកាន ខេត្តពោធិ៍សាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារ E3/5187 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00197916-00197917 (ព្រំ សារុន ត្រូវបានបញ្ជូនទៅការដ្ឋានធ្វើការងារនៅកំពីងពួយ ក្នុងខេត្តបាត់ដំបង ជាមួយមនុស្សរាប់ម៉ឺននាក់មកពី ទូទាំងខេត្តបាត់ដំបង រយៈពេល៣ខែជារៀងរាល់ឆ្នាំ ក្រោយពីច្រូតកាត់

មូលហេតុនៃការផ្លាស់ទីលំនៅនេះ គឺដោយសារតែកម្លាំងមនុស្សមិនគ្រប់គ្រាន់នៅតាមកន្លែងគោលដៅដែលពួកគេត្រូវទៅ[១៩០០]។

៦០៩. ក្រោយពីកងចល័ត និងប្រជាជនដទៃទៀតដែលផ្លាស់ទីលំនៅទៅតាមរដូវកាល ត្រូវបានចាត់ឲ្យទៅទីតាំងថ្មីនោះ ប្រជាជនដែលរស់នៅកន្លែងដដែលពុំបានទទួលព័ត៌មានបន្ថែមពាក់ព័ន្ធនឹងទីកន្លែងរបស់ប្រជាជនដែលបានផ្លាស់ទីលំនៅនោះឡើយ[១៩០១]។ ក្រោយមក ប្រជាជនមួយចំនួនក្នុង

---

រួចរាល់)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៧៤,ERN(ភាសាខ្មែរ) 00836151 (បន្ទាប់ពីរដូវច្រូតកាត់ ប្រជាជនត្រូវបានបង្ខំឲ្យទៅនៅកន្លែងផ្សេង ដោយចាប់ផ្ដើមជាថ្មីឡើងវិញដោយគ្មានអ្វីសោះ) ទំព័រ ១៦៣, ERN (ភាសាខ្មែរ) 00836240 (នៅក្នុងខែ កញ្ញា/តុលា ឆ្នាំ ១៩៧៥ យុវជន និងយុវនារីទាំងអស់ដែលនៅក្នុងកងស្រួច ត្រូវបានដកឲ្យទៅលើកភ្លឺស្រែនៅដំណាក់សៀម) ទំព័រ ២១១, ERN (ភាសាខ្មែរ) 00836288 (យុវជន-យុវនារីត្រូវបានបញ្ជូនឲ្យទៅច្រូតកាត់ ឬសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកនៅឆ្ងាយពីសហករណ៍របស់ពួកគេ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ អួន យឹន ឯកសារ E3/5394 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00479452-53 (គាត់ត្រូវបានចាត់ឲ្យទៅនៅកងចល័ត និងត្រូវបានបញ្ជូនទៅពេលខែ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ នៅទីនោះ គាត់ត្រូវបានឲ្យលើកទំនប់ និងធ្វើប្រព័ន្ធប្រឡាយ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ- កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ៣១៩ ERN (ភាសាខ្មែរ) 00232305 (ប្រជាជននៅភូមិភាគពាយ័ព្យត្រូវបានបញ្ជូនឲ្យធ្វើការ ពីគម្រោងការងារមួយទៅគម្រោងការងារមួយទៀត ហើយបន្ទាប់មកឲ្យត្រឡប់ទៅធ្វើស្រែវិញ)។ អត្ថបទរបស់ François PONCHAUD៖ កម្ពុជា៖ សេដ្ឋកិច្ចបែបបដិវត្តន៍ ឯកសារ E3/2412 ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ៦, ERN (ភាសាខ្មែរ) 00812348 (PONCHAUD បានកត់សម្គាល់ថា ក្នុងពេលដែលប្រជាជនមួយចំនួនត្រូវបានចាត់ឲ្យសាងសង់គម្រោងទំនប់ទឹកធំៗ មានប្រជាជនខ្លះទៀតត្រូវបានបញ្ជូនឲ្យទៅកាប់រានព្រៃ។ ក្នុងឆ្នាំ ១៩៧៦ ប្រជាជនមួយចំនួនធំដែលបានបញ្ជូនឲ្យទៅធ្វើការនៅលើដីថ្មី ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅលើដីដែលធ្លាប់ដាំដុះពីមុនវិញ) ទំព័រ ១៦, ERN (ភាសាខ្មែរ) 00812358 (នៅក្នុងរដូវប្រាំង អ្នកធ្វើការនៅតាមសហករណ៍មួយភាគធំ ត្រូវបានបញ្ជូនទៅការដ្ឋានធ្វើការងារ)។

[១៩០០] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កែវ សារឿន ឯកសារ E3/5338 កែវ សារឿន ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៩, ERN (ភាសាខ្មែរ) 00454029 (គាត់ត្រូវបានឲ្យទៅនៅកងចល័ត ដើម្បីលើកទំនប់ និងជីកប្រឡាយ នៅព្រៃមាន់ និងដើម គ ៣ ដើម)។

[១៩០១] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឌី រឿន ឯកសារ E3/4656 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00544561 (នៅខេត្តកណ្ដាល នាដើមឆ្នាំ ១៩៧៦ ឪពុកម្ដាយ និងបងប្អូន៣នាក់របស់ ឌី រឿន ត្រូវបានជម្លៀសពីស្រុកស្អាង ខេត្តកណ្ដាល ទៅស្រុកបាទី ខេត្តតាកែវ។ ឌី រឿន មិនបានដឹងអំពីសុខទុក្ខរបស់ពួកគេទេ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៩៦, ERN (ភាសាខ្មែរ) 00836273 (នៅកន្លែងថ្មី សមាជិកក្រុមគ្រួសារត្រូវបានបំបែកឲ្យនៅឆ្ងាយពីគ្នា ហើយកុមារត្រូវឲ្យទៅនៅក្នុង

ចំណោមប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ បានព្យាយាមវិលត្រឡប់ទៅសហករណ៍របស់ពួកគេវិញ[១៩០២]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ួន ផល្លី បានពន្យល់ថា ប្រជាជនមួយចំនួនដែលបានព្យាយាមរត់គេចខ្លួន ត្រូវបានកងទ័ពខ្មែរក្រហមដេញចាប់។ គាត់បានឮសម្រែករបស់ពួកគេស្រែក ក្រោយពីពួកគេត្រូវបានចាប់ខ្លួន ទោះបីជាគាត់ពុំបានបញ្ជាក់អំពីជោគវាសនារបស់ពួកគេឲ្យបានច្បាស់លាស់ក៏ដោយ[១៩០៣]។

### ១១.៣.២ ទិសដៅ ឆ្នាំ១៩៧៧៖ ៣ តោន ឬ ៦ តោន ក្នុង ១ ហិកតា

៦១០. អត្ថបទមួយច្បាប់ដែលបានបោះពុម្ពផ្សាយនៅក្នុងទង់បដិវត្តន៍ ចុះខែ មិថុនា ឆ្នាំ ១៩៧៦ បង្ហាញឲ្យឃើញថា ថ្នាក់ដឹកនាំបក្សបានដឹងថា បក្សពុំមានលទ្ធភាពអនុវត្តទៅតាមផែនការការងារនៅក្នុងឆ្នាំ១៩៧៦។ អត្ថបទនេះបានកត់សម្គាល់ថា កម្លាំងមនុស្សពុំត្រូវបានបែងចែកទៅតាមការវិនិច្ឆ័យឲ្យបានត្រឹមត្រូវនោះទេ ពោលគឺ ពេលខ្លះ ប្រជាជនទាំងអស់ត្រូវបានគេបញ្ជូនទៅការដ្ឋានការងារ ដោយមិនបានទុកប្រជាជនសូម្បីម្នាក់ (មនុស្សចាស់ ឬ កូនក្មេង) សម្រាប់ដាំដុះបន្លែ ឬដំណាំផ្សេងទៀតនោះឡើយ។ នៅក្នុងអត្ថបទដដែលនេះ បក្សបានស្នើឡើងថា គោលការណ៍ណែនាំអំពីរបៀបប្រើប្រាស់កម្លាំងមនុស្ស គួរស្វែងយល់ឲ្យបានប្រសើរជាងនេះនាពេលអនាគត ហើយការអនុវត្តផែនការការងារទាំងនេះបានផ្លាស់ប្តូរនៅក្នុងឆ្នាំ ១៩៧៧[១៩០៤]។ នៅថ្ងៃទី ១៧ និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំបក្សបានរៀបចំសន្និបាតសេដ្ឋកិច្ចរបស់បក្សទូទាំងប្រទេសលើកទី២ ក្នុងនោះបក្សបានអនុម័តផែនការជាក់លាក់ ឆ្នាំ ១៩៧៧[១៩០៥]។ ផែនការជាក់លាក់នេះ បានកំណត់

---

កងចល័ត និងមិនបានដឹងដំណឹងអំពីគ្រួសាររបស់ពួកគេអស់រយៈពេលជាច្រើនខែ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាន់ សារឿន ឯកសារ E3/5258 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00249910 (ប្រជាជនខ្លះដែលត្រូវបានបញ្ជូនឲ្យទៅច្រូតស្រូវ បានបាត់ខ្លួនរហូតមិនដែលឃើញត្រឡប់មកវិញទេ)។

[១៩០២] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ួន ផល្លី) ទំព័រ ៣២-៣៣។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ួន ផល្លី ឯកសារ E3/5740 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00552920-00552921។

[១៩០៣] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ួន ផល្លី) ទំព័រ ៣២។

[១៩០៤] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/760 ខែ មិថុនា ឆ្នាំ ១៩៧៦ ទំព័រ ២៩-៣២, ERN (ភាសាខ្មែរ) 00062864-00062867។

[១៩០៥] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/139 ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00064962-00064963។

ទិសដៅថ្មីមួយគឺ ៣ តោនក្នុង ១ ហិកតា ឬ ៦ តោន ក្នុង ១ ហិកតា នៅតាមកន្លែងទាំងឡាយណាដែលអាចបង្កបង្កើនផលស្រូវទាំងក្នុងរដូវវស្សា និងរដូវប្រាំង[១៥០៦]។ ថ្នាក់ដឹកនាំបក្សមានបំណងចង់ឲ្យបញ្ជូនកម្លាំងមនុស្សទៅតាមកន្លែងទាំងឡាយណាដែលមានទឹកគ្រប់គ្រាន់ និងដីមានជីជាតិជាមុនសិន[១៥០៧]។ លើសពីនេះទៀត ដោយសារតែជួបប្រទះគ្រោះរាំងស្ងួតរហូតដូច្នេះ[១៥០៨] នៅពេលមានកម្លាំងមនុស្សទំនេរ កម្លាំងទាំងនោះត្រូវបានចាត់ឲ្យទៅលើកភ្លឺស្រែ និងជីកប្រឡាយ[១៥០៩]។ នៅក្នុង

---

[១៥០៦] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/742 ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៣-៥, ERN (ភាសាខ្មែរ) 00062983-00062985។

[១៥០៧] របាយការណ៍ស្ដីពីខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ២៣-២៥, ERN (ភាសាខ្មែរ) 00442229-00442231 (ត្រូវចាត់ចែងកម្លាំងឲ្យបានហ្មត់ចត់ ទៅតាមតម្រូវការជាក់ ស្ដែង) ទំព័រ ៤០-៤៣ ERN (ភាសាខ្មែរ) 00442246-9។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/742 ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ១៨-២០ ERN (ភាសាខ្មែរ) 00062994-00062995 (ដើម្បីសម្រេច ៣ តោន និង ៦ តោនក្នុង ១ ហិកតា នៅឆ្នាំ ១៩៧៧ ចាំបាច់ត្រូវប្រមូលកម្លាំងកាយ)។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/135 ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00062811 (កងចល័តយើងចាត់ចែងទៅណាក៏បាន ធ្វើអាងទឹកក៏បាន ដាំដំឡូងក៏បាន ដាំចេកក៏បាន។ល។ ប៉ុន្ដែ នៅក្នុងឆ្នាំ ១៩៧៧ បក្សបានកត់សម្គាល់ឃើញថា ការចាត់ចែងប្រើប្រាស់កម្លាំងទាំងនេះមិនទាន់សមស្របទេ ដោយសារមានកម្លាំងខ្លះមិនទាន់ត្រូវបានប្រើប្រាស់នៅឡើយ, ទំព័រ ២៧-២៨, ៤៣-៤៤, ERN (ភាសាខ្មែរ) 00062815-6, 00062831-2 (ជាការចាំបាច់ ត្រូវចាត់ចែងកម្លាំងតាមមាគ៌ាសកម្មភាពឲ្យបានត្រឹមត្រូវ គឺការងារណាមិនចាំបាច់ទុកមួយអន្លើសិន។ កម្លាំងដែលមិនត្រូវការត្រូវដកចេញ), ទំព័រ ២៧-២៨, ERN (ភាសាខ្មែរ) 00062815-6 (កម្លាំងដែលមិនចាំបាច់ ត្រូវចាត់ចែងឡើងវិញដើម្បីឲ្យទៅធ្វើស្រែ)។ កិច្ចសម្ភាសន៍ជាមួយ ជា ស៊ីម ដោយលោក Stephen HEDER ឯកសារ E3/1568 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00713922-3 (មានបញ្ជាមកពីមជ្ឈិមថា ត្រូវប្រមូលយុវជន និងយុវនារី ដើម្បីបង្កើតជាជំរំ និងធ្វើស្រែនៅលើដីដែលអាចផ្ដល់ទិន្នផលបាន៦តោនក្នុងមួយហិកតា)។

[១៥០៨] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/743 ខែ កក្កដា ឆ្នាំ ១៩៧៧ ទំព័រ ៣, ៦-៧, ERN (ភាសាខ្មែរ) 00062879, 00062882-3 (នៅក្នុងខែ មេសា ឆ្នាំ ១៩៧៧ បក្សបានណែនាំថា ត្រូវយកចិត្តទុកដាក់ប្រមូលកម្លាំងពលកម្ម និងប្រើប្រាស់កម្លាំងនេះជាយុទ្ធសាស្ត្រទាំងនៅសមរភូមិមុខ និងសមរភូមិក្រោយ ក៏ដូចជាការប្រែក្លាយស្ថានភាពរាំងស្ងួតដោយការបង្កើតជាប្រព័ន្ធផ្គត់ផ្គង់ទឹក និងផលដំណាំ)។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/170 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ៣៥, ERN (ភាសាខ្មែរ) 00064788 (ក្នុងឆ្នាំ ១៩៧៧ មាន "ភាពរាំងស្ងួត និងកាន់តែរាំងស្ងួតតទៅទៀត" ហើយការលើកទំនប់ ជីកប្រឡាយ អាង ទឹកធំៗ និងការលើកភ្លឺស្រែ នៅតែជាអាទិភាព)។

[១៥០៩] របាយការណ៍ស្ដីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ២៤-២៥, ៤១-៤៤, ERN (ភាសាខ្មែរ) 00442230-1, 00442247-9។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/742 ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ១៤-១៥, ERN (ភាសាខ្មែរ) 00062994-5។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/135 ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ២២-២៣, (ភាសាខ្មែរ) 00062810-1។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/11

សុន្ទរកថារំលឹកខួបលើកទី២ នៃថ្ងៃរំដោះក្រុងភ្នំពេញ ខៀវ សំផន បានប្រកាសថា គម្រោងធារាសាស្ត្រកំពុងត្រូវបានសាងសង់ ដោយ "អង្គភាពចម្រើន" នៅទូទាំងប្រទេស។ គាត់បានរាយការណ៍ថា ការដ្ឋានសាងសង់នីមួយៗមានប្រជាជនធ្វើការប្រហែលពី ១០.០០០ នាក់ ទៅ ៣០.០០០ នាក់[១៩១០]។

៦១១. នៅក្នុងឆ្នាំ ១៩៧៧ ការផ្លាស់ទីលំនៅប្រជាជនត្រូវបានរាយការណ៍ថា បានកើតឡើងជាថ្មីម្តងទៀតនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)[១៩១១]។ ប្រជាជនត្រូវបានផ្លាស់ទីលំនៅពីថ្កោលទៅបឹងគល់ ខេត្តពោធិ៍សាត់ ដើម្បីឱ្យទៅធ្វើស្រែ[១៩១២]។ ប្រជាជនផ្សេងទៀតនៅក្នុងខេត្តពោធិ៍សាត់ត្រូវបានចាត់ឱ្យទៅនៅកងចល័ត ហើយត្រូវបានផ្លាស់ទីលំនៅទៅទីតាំងថ្មីៗ ទៅតាមរដូវកាល[១៩១៣]។ ទោះបីយ៉ាងណាក៏ដោយ ប្រជាជនផ្សេងទៀតនៅតែត្រូវបានផ្លាស់ទីលំនៅទៅ

---

ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៦៦, ERN (ភាសាខ្មែរ) 00063181 (បក្សបានអបអរសាទរការខិតខំប្រឹងប្រែងកសាងប្រព័ន្ធស្រោចស្រព ដោយបានលើកទំនប់ស្ទឹងជីនិត ទំនប់ស្ទឹងពោធិ៍សាត់ ទំនប់ស្ទឹងបាត់ដំបង និងទំនប់ដទៃទៀត)។

[១៩១០] *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/200 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៥, ERN (ភាសាខ្មែរ) 00292807 (គាត់បានលើកឡើងថា នៅការដ្ឋានធ្វើការងារទាំងនេះ អ្វីៗគ្រប់យ៉ាងត្រូវបានធ្វើឡើងដោយមិនចាំបាច់ពឹងផ្អែកទៅលើគ្រឿងម៉ាស៊ីនទេ)។

[១៩១១] *សេចក្តីសន្និដ្ឋានពីគណៈកម្មការអន្តរជាតិនៃអ្នកជំនាញផ្នែកច្បាប់ តាមរយៈសេចក្តីប្រកាសលេខ ៩ របស់គណៈកម្មការសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/1804 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00235804។

[១៩១២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ១២, ERN (ភាសាខ្មែរ) 00373254 (នៅក្នុងឆ្នាំ ១៩៧៧ បន្ទាប់ពីត្រូវបាន "កសាងខ្លួន" នៅគុកថ្កោល ខេត្តពោធិ៍សាត់រួចមក ឡាយ បូនី និងអ្នកទោសខ្លះទៀត ត្រូវបានបញ្ជូនឱ្យទៅធ្វើស្រែនៅបឹងគល់ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់)។

[១៩១៣] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាម ផា ឯកសារ E3/5005 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00557818 (ក្នុងឆ្នាំ ១៩៧៧ សោម ផា ត្រូវបានអង្គការជម្លៀសទៅកាន់ស្ទឹងមួយដើម្បីរកត្រី និងធ្វើស្រែប្រាំងនៅរដូវទឹកស្រក)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ែល យ៉ាស់ ឯកសារ E3/4975 ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ៣-៥, ERN (ភាសាខ្មែរ) 005555514-6។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤, ERN (ភាសាខ្មែរ) 00557955។

ការដ្ឋានធ្វើការងារ ឬ រោងចក្រនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)[១៩១៤] ។ ប្រជាជនខ្លះទៀតដែលត្រូវបានផ្លាស់ទីលំនៅនៅចុងឆ្នាំ ១៩៧៧ បានបាត់ខ្លួននៅតាមផ្លូវ[១៩១៥]។

៦១២. នៅចន្លោះខែធ្នូ ឆ្នាំ១៩៧៦ និងខែធ្នូ ឆ្នាំ១៩៧៧ កងចល័តត្រូវបានបញ្ជូនឲ្យទៅលើកទំនប់នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តកំពត (ភូមិភាគនិរតី) ផងដែរ[១៩១៦]។ គ្មានគ្រឿងចក្រសម្រាប់លើកទំនប់ទេ ដូច្នេះគេប្រើប្រាស់កម្លាំងមនុស្ស[១៩១៧]។ ជាពិសេសប្រជាជនចំនួនរាប់ពាន់នាក់[១៩១៨] ត្រូវបានប្រមូលផ្តុំពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ

---

[១៩១៤] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុខ មឿន ឯកសារ E3/4918 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00544579 (ក្នុងឆ្នាំ ១៩៧៧ ខ្មែរក្រហមបានជម្លៀស សុខ មឿន និងប្រជាជនដទៃទៀតឲ្យទៅធ្វើការនៅរោងចក្រកទួលតាឯក ក្នុងខេត្តបាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ស៊ន ឯកសារ E3/4872 ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00533871 (ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានជម្លៀស ឡុង ស៊ន ពីបាក់ចៀន ខេត្តបាត់ដំបង ទៅនៅភ្នំថ្មបាំង ខេត្តពោធិ៍សាត់វិញ)។

[១៩១៥] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00373249-50។

[១៩១៦] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៧៥-៧៦, ៧៧-៧៩ (នៅពេលដែល ប្រាក់ យុត ធ្វើជាលេខាស្រុកកំពង់សៀម ខេត្តកំពង់ចាម គាត់បានបញ្ជូនប្រជាជនចេញពីកំពង់សៀមឲ្យទៅលើកទំនប់ ដូចជានៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។ តំបន់អាចស្នើឲ្យបញ្ជូនប្រជាជនទាំងនេះពីស្រុកផ្សេងៗ។ ប្រជាជនប្រហែលជា ៥០ នាក់ក្នុងមួយស្រុក ក៏ត្រូវបានជ្រើសរើសឲ្យទៅលើកទំនប់នៅកោះស្លា ដែលជាទំនប់ដ៏ធំមួយនៅខេត្តកំពត)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៣៣-៣៤ (ប្រាក់ យុត បានធ្វើជាលេខាស្រុកកំពង់សៀមរយៈពេល២ ខែ ចាប់ផ្តើមនៅក្នុងខែ មករា ឬ មេសា ឆ្នាំ១៩៧៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្នួន តៃរ៉េន ឯកសារ E3/5564 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00405499-00405500។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហួ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២-៤, ERN (ភាសាខ្មែរ) 00239906-8 (ឱ ហួ ធ្លាប់ធ្វើជាប្រធានភូមិស្រង៉ែ ឃុំបល្ល័ង្ក ស្រុលបារាយណ៍ ខេត្តកំពង់ធំ ពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ខែ កក្កដា ឆ្នាំ ១៩៧៧។ នៅដើមឆ្នាំ ១៩៧៦ គេបានជម្លៀសប្រជាជនថ្មី ពីនិរតីឲ្យមកនៅភូមិនេះ។ (*សូមមើលផងដែរ* អត្ថបទរបស់ François PONCHAUD៖ *កម្ពុជា៖ សេដ្ឋកិច្ចបែបបដិវត្តន៍* ឯកសារ E3/2412 ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 0081245-7 (ទំនប់ ១៧ មេសា ដែលត្រូវបានកសាងឡើងដោយកសិករ និងយុវជនកងចល័ត នៅដើម ខែ ឧសភា ឆ្នាំ ១៩៧៧ ។ យុវជនជាង ២៣.០០០ នាក់ បានកសាងអាងស្តុកទឹកទំនប់ ៦ មករា)។

[១៩១៧] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ (ប្រាក់ យុត) ទំព័រ ៧៨។

[១៩១៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ថេង ឯកសារ E3/5249 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ៣, ERN (ភាសាខ្មែរ) 00229063 (ប្រជាជនប្រហែលជា ៨.០០០ នាក់ ត្រូវបានប្រមូលពីខេត្តកំពង់ចាម និងកំពង់ធំ ឲ្យមកធ្វើការនៅទំនប់ ១ មករា ដែលត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ១៩៧៧ ហើយបានបញ្ចប់នៅឆ្នាំ

(ភូមិភាគ (ឧត្តរចាស់) កណ្តាល) ឲ្យទៅលើកទំនប់ ១ មករា ដែលស្ថិតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយការសាងសង់ទំនប់ទាំងមូលបានចាប់ផ្តើមនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦[១៩១៩]។ កងចល័តបានដើរពីការដ្ឋានលើកទំនប់មួយទៅការដ្ឋានលើកទំនប់មួយទៀត ទោះជិត ឬ ឆ្ងាយក៏ដោយ និងពុំត្រូវបានឲ្យស្បៀងអាហារ ទឹក ឬ មុងនោះទេ[១៩២០]។ ពេលខ្លះ ពួកគេដើរទៅដោយគ្មានអ្នកនាំផ្លូវទៅជាមួយឡើយ[១៩២១] ។ ទោះបីជាយ៉ាងនេះក្តី គ្មានប្រជាជនណាម្នាក់មិនព្រមផ្លាស់ទីលំនៅនោះទេ លើកលែងតែពួកគេឈឺ ឬ មិនអាចដើរបាន[១៩២២]។

---

ជដែលនេះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00239907-8 (ប្រជាជនប្រហែលជា ២០.០០០ នាក់ មកពីតំបន់ ៤១ តំបន់ ៤២, និងតំបន់ ៤៣ បានមកធ្វើការនៅការដ្ឋានទំនប់ ១ មករា ក្នុងខេត្តកំពង់ធំ)។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Elizabeth BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅ - កម្ពុជា និងបដិវត្តខ្មែរក្រហម* ឯកសារ E3/20 ទំព័រ ២៤០, ERN (ភាសាអង់គ្លេស) 00237945 (សហករណ៍នៅគ្រប់ទីកន្លែងបានបញ្ជូនកម្លាំងពលកម្មរាប់ពាន់នាក់ឲ្យមកលើកទំនប់)។

១៩១៩ ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ២២-២៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ថេង ឯកសារ E3/5249 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២, (ភាសាខ្មែរ) 00229062។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00239907-8 (ទោះបីជាការសាងសង់ទំនប់ ១ មករា ត្រូវបានសម្ពោធដោយ ប៉ុល ពត នៅខែមករា ឆ្នាំ ១៩៧៧ ក៏ដោយ ក៏ទំនប់នោះត្រូវបានចាប់ផ្តើមធ្វើ តាំងពីខែ ធ្នូ ឆ្នាំ ១៩៧៦ មកម្ល៉េះ)។ (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពូក ប៊ុន ឯកសារ E3/5247 ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣, (ភាសាខ្មែរ) 00229058-9 (នៅក្នុងឆ្នាំ ១៩៧៦ ពូក ប៊ុន ត្រូវបានបញ្ជូនពីភូមិល្បើក ឃុំគគីធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឲ្យទៅធ្វើការនៅការដ្ឋានទំនប់ ១ មករា នៅឃុំបឹង ស្រុកសន្ទុក ខេត្តកំពង់ធំ។ មានប្រជាជនប្រហែលមួយម៉ឺននាក់ធ្វើការនៅទំនប់ ១ មករា។ ប្រជាជនទាំងនោះមកពីខេត្ត៣៖ កំពង់ចាម កំពង់ធំ និង ក្រចេះ។

១៩២០ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00557954-5។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួន តៃវ៉េន ឯកសារ E3/5564 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00405499-00405500។

១៩២១ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួន តៃវ៉េន ឯកសារ E3/5564 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00405499-00405500។

១៩២២ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សួន តៃវ៉េន ឯកសារ E3/5564 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00405500។ (ប្រសិនបើកងទ័ពខ្មែរក្រហមពិនិត្យមើលឃើញថាអ្នកនោះឈឺមែន អ្នកជំងឺនោះអាចនៅបាន) ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុៈ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១៣-១៤, ERN (ភាសាខ្មែរ) 00709589-90 (ក្មេងៗ អ្នកជំងឺ និងមនុស្សចាស់ធ្វើការនៅក្បែរៗភូមិ)។

## ១១.៤ ការតស៊ូវណ្ណៈប្រឆាំងនឹង "ប្រជាជនថ្មី"៖ ការផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់ទក្សិណ និងតំបន់កណ្តាល

៦១៣. ក្រៅពីការផ្លាស់ទីលំនៅទៅតាមរដូវកាល ដើម្បីវាយសម្រុកការបង្កបង្កើនផលកសិកម្ម ប្រជាជនក៏ត្រូវបានផ្លាស់ទីលំនៅនៅក្នុងតំបន់ឧត្តរ តំបន់កណ្តាល និងតំបន់ទក្សិណ ដើម្បីជំរុញដល់ការតស៊ូវណ្ណៈផងដែរ។ "ការតស៊ូវណ្ណៈ" សំដៅលើទំនាស់របស់បក្សទៅនឹង "ប្រជាជនថ្មី"[១៩២៣]។ "ប្រជាជនថ្មី" រួមមានអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បញ្ញាជន ម្ចាស់ដី នាយទុន សក្តិភូមិ និងអនុធន[១៩២៤]។ ថ្នាក់ដឹកនាំបក្សបានពិចារណាឃើញថា ទោះបីជាពួកគេបរាជ័យ ហើយវណ្ណៈរបស់

[១៩២៣] *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/729 ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១៤-១៤, ERN (ភាសាខ្មែរ) 00063410-1 (នេះគឺជាផ្នែកមួយនៃការតស៊ូវណ្ណៈដ៏តឹងតែង និងស្មុគស្មាញ ក្នុងដំណាក់កាលថ្មីនៃបដិវត្ត។ ការតស៊ូវណ្ណៈ គឺជាបញ្ហាស្លាប់រស់)។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ២៦, ERN (ភាសាខ្មែរ) 00442232 (កម្មសិទ្ធិឯកជន កើតមកពីសង្គមដែលមានការបែងចែកវណ្ណៈ រវាងវណ្ណៈជិះជាន់គេ និងវណ្ណៈត្រូវគេជិះជាន់។ កម្មសិទ្ធិឯកជនបានពង្រឹង រក្សាទុក និងពង្រីកវណ្ណៈជិះជាន់ ក្នុងនោះរួមមាន វណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន និងវណ្ណៈដទៃទៀត)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/4 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00062908-9 (ពាក្យស្លោករបស់បក្សសម្រាប់ឆ្នាំ ១៩៧៦ បានប្រកាសថា៖ "បន្តវាយសម្រុក ធ្វើការ តស៊ូវណ្ណៈ ក្នុងបក្ស ក្នុងកងទ័ព ក្នុងជួរបដិវត្តទាំងអស់ ក្នុងប្រជាជន និងក្នុងសង្គមជាតិទាំងមូលជាដាច់ខាត! (*ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៤៥, ERN (ភាសាខ្មែរ) 00063103 (ឯកម្មសិទ្ធិឯកជនរបស់វណ្ណៈនាយទុន ម្ចាស់ដី កសិករមានបានក្រាស់ ទាមទារឲ្យមានការតស៊ូខ្លាំងក្លា និងដាច់ខាត។ វាទាមទារនូវវណ្ណៈផ្តាច់ការ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ (កាំងហ្គេកអ៊ាវ) ទំព័រ ២១។

[១៩២៤] *សូមមើល*ផ្នែកទី៤, ទិដ្ឋភាពទូទៅ: ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩, កថាខណ្ឌ ១៦៩។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១០-១៣, ERN (ភាសាខ្មែរ) 00063320-3។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00063258។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៣៥-៣៦, ERN (ភាសាខ្មែរ) 00063093-4 (នៅក្នុងកសិករថ្មីមាន ពួកអនុធន នាយទុន សក្តិភូមិ មានកម្មករ និងពលករផ្សេងទៀត។ ហេតុដូច្នេះមានទំនាស់ស្លាប់រស់)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/743 ខែ កក្កដា ឆ្នាំ ១៩៧៧ ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00062886-7 ("ខ្មាំង" រួមមាន ចក្រពត្តិណ្ណានពាន និងបរិវាររបស់វាគ្រប់ប្រភេទ ខ្មាំងជាវណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន និងខ្មាំងជាវណ្ណៈជិះជាន់គ្រប់ប្រភេទ)។

ពួកគេត្រូវបានវាយរំលំក៏ដោយ ក៏ទស្សនៈ និងសេចក្តីប៉ងប្រាថ្នារបស់ពួកគេនៅតែមានដដែល[១៩២៥]។ ជាពិសេស អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់មុខសញ្ញាជាសត្រូវធំបំផុត[១៩២៦]។ ខ្មាំងដែលគ្រោះថ្នាក់បំផុតត្រូវបានបោសសំអាត[១៩២៧]។ "ប្រជាជនថ្មី" ផ្សេងទៀតត្រូវបានផ្លាស់ទីលំនៅចេញពីទីកន្លែងកំណើតរបស់ពួកគេ ដូច្នេះហើយពួកគេត្រូវបានផ្តាច់ចេញពីទ្រព្យសម្បត្តិ និងជីវិតនាយទុន និងសក្តិភូមិរបស់ពួកគេ។ ក្នុងខណៈពួកគេត្រូវបានផ្លាស់ទីលំនៅ ហើយក្រោយពេលទៅដល់គោលដៅរបស់ពួកគេ "ប្រជាជនថ្មី" អាចត្រូវបានកសាងខ្លួនឲ្យទៅជាកសិករ[១៩២៨] ។ តាមរយៈការផ្លាស់ទីលំនៅ ការបោសសម្អាតវណ្ណៈនាយទុន និងការលុបបំបាត់កម្មសិទ្ធិឯកជន "ខ្មាំង" ទាំងនេះគ្មានកម្លាំងមកប្រឆាំងនឹងបក្សទៀតទេ[១៩២៩]។

---

[១៩២៥] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១១-១៣, ៣០-៣១, ERN (ភាសាខ្មែរ) 00063321-3, 00063340-2។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ឆ្នាំ ១៩៧៥ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00063258។

[១៩២៦] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១២០-១២៧។ ផ្នែកទី១៤, សហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៨៣៥-៨៣៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៣៤-៣៩ (កាកសំណល់ពីសង្គមចាស់ ត្រូវបានចាត់ទុកជាខ្មាំងដ៏សំខាន់របស់បក្ស)។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០ (កាកសំណល់នៃអតីតរបប លន់ នល់ ត្រូវបានកំណត់គោលដៅថាជា "ខ្មាំងដ៏សំខាន់"។

[១៩២៧] កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសនាធំឯករាជ ឯកសារ E3/13 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ១៣, ERN (ភាសាខ្មែរ) 00052414 (ខ្មាំងមានបីប្រភេទគឺ ប្រភេទអន្តរាយ ត្រូវសំរិតសំរាំងដាច់ខាត ប្រភេទសេរី ធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ និងប្រភេទពួកខ្មាំងទើបញ្ចុះញ្ចង់ ត្រូវអប់រំកសាងគេ)។

[១៩២៨] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ១១-១៣, ៣៥-៣៧, ERN (ភាសាខ្មែរ) 00063321-3, 00063345-7។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១៩៧៥ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00063258។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ១០-១៩, ERN (ភាសាខ្មែរ) 00063068-77 (កាកសំណល់ពីរបបសក្តិភូមិ និងនាយទុននៅសេសសល់នៅឡើយ និងត្រូវលុបបំបាត់ដោយការអប់រំ កសាង ទិទៀន និងស្វ័យទិទៀនជាបន្តបន្ទាប់)។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ឯកសារ E3/797 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ៤, ERN (ភាសាខ្មែរ) 00052379 (នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ បក្សបាន ណែនាំលេខា និងអនុលេខាឲ្យយកចិត្តទុកដាក់កសាងបក្សពិសេសកសាងឲ្យយល់ពីភារកិច្ច អប់រំ និងកសាងមហាជនឲ្យម្ចាស់ការរឹងមាំ)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារE3/729ខែតុលា ឆ្នាំ១៩៧៥ ទំព័រ៤-៥, ERN (ភាសាខ្មែរ) 00063400-1 (ពាក់ព័ន្ធនឹងប្រជាជនថ្មី សហករណ៍ត្រូវសម្របសម្រួលចាត់ចែងកម្លាំងពលកម្ម ហើយត្រូវតាមដាន និងអប់រំកសាងផ្នែកមនោគមវិជ្ជាដល់អ្នកជម្លៀសមកពីទីក្រុងនៅតាមសហករណ៍)។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ទំព័រ៣៧, ERN (ភាសាខ្មែរ) 00442243 (ប្រជាជនម្នាក់ៗអាចត្រូវបានអប់រំកសាងខ្លួន

៦១៤. ក្រោយពីត្រូវបានផ្លាស់ទីលំនៅរួចមក "ប្រជាជនថ្មី" ជាច្រើននាក់បានបាត់ខ្លួន[១៩៣០] ។ "ប្រជាជនថ្មី" ផ្សេងទៀត បន្ទាប់ពីបានកសាងខ្លួននៅក្នុងសហករណ៍ ត្រូវបានច្របាច់បញ្ចូលទៅក្នុងប្រព័ន្ធរបស់បក្ស[១៩៣១]។ រហូតដល់ពេលនោះ ថ្នាក់ដឹកនាំបក្សបានណែនាំថា "សមាសភាពមិនល្អ" ត្រូវយកទុកម្ដុំ[១៩៣២]។

---

ដោយឱ្យទៅធ្វើការនៅក្នុងសហករណ៍ លើកភ្លឺ និងជីកប្រឡាយ)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្ដាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00072402-3 (អតីតអ្នករដ្ឋការ អនុធន ឈ្មួញ នាយទុនជាតិ កុំប្រាដ័រ និងអភិជន ត្រូវបានចាត់ជាប្រភេទកសិករថ្មី។ កសិករថ្មីទាំងនេះគ្មានរបបនយោបាយចាស់ និងគ្មានមូលដ្ឋានសេដ្ឋកិច្ចដូចពីមុនទៀតទេ ជាពិសេស ក្រោយពីពេលពួកគេបានតាំងទីលំនៅនៅតាមជនបទរួចមក។ មូលដ្ឋាននយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់របបចាស់ ត្រូវបានជីកកកាយ និងបំផ្លាញចោល)។

[១៩២៩] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១១-១៣, ៣០-៣១, ៣៥-៣៧, ERN (ភាសាខ្មែរ) 00063321-3, 00063340-2, 00063345-7។ *ស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២៣, ERN (ភាសាខ្មែរ) 00063258។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/4 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៦, ERN (ភាសាខ្មែរ) 00062910 (តទៅមុខទៀត យើងត្រូវបន្តការតស៊ូវណ្ណៈ វាយរំលំវណ្ណៈសក្តិភូមិ នាយទុន និងវណ្ណៈប្រតិកិរិយាផ្សេងទៀតឱ្យអស់រលីង ទើបខ្មាំងជ្រៀតចូលមិនបាន), ទំព័រ ៦, ERN (ភាសាខ្មែរ) 00062910 (បក្សត្រូវតែវាយកម្ទេច និងកំចាត់កំចាយកម្លាំងប្រឆាំងទាំងអស់ ទើបការពារប្រទេសបាន),ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00062911-2 (ទាល់តែវណ្ណៈសក្តិភូមិ វណ្ណៈនាយទុនវាអស់ ទាល់តែកម្លាំងប្រឆាំងរបស់វាខ្សោយ ទើបបក្សដើរលឿនបាន។ បក្សមិនអាចរវើរវាយអំពីបញ្ហានេះបានទេ និងមិនអាចធូររលុងអំពីបញ្ហានេះបានទេ)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៣០, ERN (ភាសាខ្មែរ) 00063088 (ទាល់តែកំចាត់នូវអ្វីៗដែលជាវណ្ណៈនាយទុន អ្វីៗដែលជាវណ្ណៈជិះជាន់ អ្វីៗដែលជាឯកជន ទើបបក្សអាចបំផុសចលនាកសាងសង្គមនិយមបានរហ័សបានល្អ)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/25 ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ ១៩៧៧ ទំព័រ ៤០, ៤២-៤៤, ERN (ភាសាខ្មែរ) 00063039, 00063041-3 (បក្សបានណែនាំថា សមាជិកទាំងអស់កុំសង្ឃឹមទៅអង្វរករទាហានខ្មាំងធ្វើនយោបាយធម្មតាជាមួយពួកគេ វាយហើយចលនាដើម្បីឱ្យពួកគេចុះចូល និងមករស់នៅជាមួយប្រជាជនធម្មតាវិញ)។

[១៩៣០] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ទំព័រ ៣៥, ៤១-៤២។

[១៩៣១] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥-៧ (ក្នុងឆ្នាំ ១៩៧៨ នៅក្នុងវគ្គរៀនសូត្រមួយដែលមានវត្តមាន ប៉ុល ពត និង នួន ជា ប៉ុល ពត បាននិយាយថា ប្រជាជនភ្នំពេញត្រូវបានឱ្យ "លត់ដំខ្លួន" នៅតាមសហករណ៍ ហើយ២ ឬ ៣ ឆ្នាំក្រោយមក ពួកគេអាចរួមរស់ជាមួយគ្នានៅក្នុងសហករណ៍បាន)។ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសនាធំឯករាជ ឯកសារ E3/13 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ១៣, ERN (ភាសាខ្មែរ) 00052414 (អ្នកដែលខ្លាំងទើបញុះញង់ ត្រូវអប់រំកសាងគេ)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សេចក្ដីដកស្រង់មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាតភូមិភាគមួយ ខែមិថុនា ឆ្នាំ ១៩៧៦ នៅក្នុង*

## ១១.៤.១ ការកសាងខ្លួននៅក្នុងសហករណ៍ (ខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៦)

៦១៥. នៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានពិចារណាឃើញថា នៅតាមសហករណ៍ "ប្រជាជនចាស់" គឺជាស្នូល ចំណែក "ប្រជាជនថ្មី" ត្រូវបានចាត់ទុកថានៅក្រៅសង្គម ដោយត្រូវរៀនសូត្រពី "ប្រជាជនចាស់" ហើយត្រូវបានកសាងខ្លួនឲ្យទៅជាកសិករ តាមរយៈ

---

*ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត* ឯកសារ E3/213 ទំព័រ ៣០, ERN (ភាសាអង់គ្លេស) 00104013 (ទិន្នផលស្រូវ គឺជាមេរៀនដ៏ធំធេងមួយ។ អ្នកទីក្រុងមិនស្គាល់ថាវាលស្រែជាអ្វី គោជាអ្វី និងការច្រូតកាត់ជាអ្វីនោះទេ។ ក្រោយពីការផ្លាស់ទីលំនៅ ពួកគេបានស្គាល់ និងយល់ ហើយពួកគេលែងខ្លាចគោ ក្របីទៀតហើយ។ កម្មវត្ថុនៃការរៀនសូត្រនេះ គឺជាការងារជាក់ស្តែង។ ការងារជាក់ស្តែងបានផ្តល់បទពិសោធ)។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (សួន កានិល) ទំព័រ ៥-៦ (មុនពេលប្រើប្រាស់ប្រជាជនថ្មី ដំបូងត្រូវជ្រើសរើស និងសំរិតសំរាំងបំផុត) *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៣៥-៣៦, ERN (ភាសាខ្មែរ) 00063093-4 (ពេលណាប្រជាជនថ្មីកែប្រែខ្លួន នោះវាមិនមានទំនាស់ស្លាប់-រស់ទេ ប៉ុន្តែ ពួកគេមិនបានកែប្រែខ្លួនដោយងាយៗនោះទេ)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ៣៩-៤០, ERN (ភាសាខ្មែរ) 00063097-8 (ត្រូវអប់រំ និងកសាងកសិករថ្មីទាំងនេះ ឲ្យក្លាយទៅជាកម្មករ-កសិករ។ បក្សមានសក្តានុពលដើម្បីកែប្រែពួកគេមួយចំនួន។ ពួកគេខ្លះមិនអាចកែប្រែខ្លួនបានទេ ពួកគេស្វែងរកឱកាសជាបន្តបន្ទាប់ដើម្បីប្រឆាំងនឹងបដិវត្ត)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/11 ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៦២, ERN (ភាសាខ្មែរ) 00063177 (ផ្តាច់ការវណ្ណៈអធន ត្រូវបានអនុវត្តចំពោះអ្នកដែលប្រឆាំងនឹងបក្ស)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/729 ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00063400-1 (ពាក់ព័ន្ធនឹងប្រជាជនថ្មី សមាជិកជើងចាស់របស់បក្ស និងប្រជាជនមូលដ្ឋានត្រូវសម្របសម្រួលចាត់ចែងកម្លាំងពលកម្ម ហើយត្រូវធ្វើការតាមដាន និងអប់រំកសាងផ្នែកមនោគមវិជ្ជាដល់អ្នកជម្លៀសមកពីទីក្រុង នៅតាមសហករណ៍)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/729 ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 000400-2 (តាមរយៈការអប់រំ និងការកែប្រែជាប់ជានិច្ច សហករណ៍បានក្លាយជាសកលវិទ្យាល័យដ៏ធំបំផុតសម្រាប់ការរៀនសូត្រចំណោះដឹងបដិវត្ត។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00442212-3 (នៅក្នុងសហករណ៍ កម្លាំងវណ្ណៈថ្នាក់លើមិនមានជម្រើសអ្វី ក្រៅតែពីត្រូវដើរតាមកសិករក្រ និងកសិករថ្នាក់កណ្តាល។ បក្សបានបញ្ជាថា ត្រូវតែពង្រឹង និងពង្រីក ដើម្បីឈានទៅជាសហករណ៍ ១.០០០ គ្រួសារ), ទំព័រ ១០-១១, ERN (ភាសាខ្មែរ) 00442217-8 (សហករណ៍ គឺជាមធ្យោបាយប្រយុទ្ធ លុបបំបាត់ និងកំចាត់ចោលពួកសក្តិភូមិ នាយទុន ឈ្មួញកណ្តាល និងកសិករមាន), ទំព័រ ៣៧, ERN (ភាសាខ្មែរ) 00442243 (ប្រជាជនម្នាក់ៗអាចត្រូវបានអប់រំកសាងខ្លួន ដោយឲ្យទៅធ្វើការនៅក្នុងសហករណ៍ ឲ្យលើកភ្លឺ និងជីកប្រឡាយ)។

[១៩៣២] កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ឯកសារ E3/798 ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ២, ៣, ERN (ភាសាខ្មែរ) 0052381, 0052382 ("សមាសភាពមិនល្អ" រួមមានក្រុមគ្រួសាររបស់ពួកដែលយើងបានបោសសំអាតហើយ ពួកដែលយើងដកចេញពីមុខតំណែង និងប្រជាជនថ្មីដែលពុំទាន់យល់។

ពលកម្មធ្ងន់ៗ[១៩៣៣]។ ថ្នាក់ដឹកនាំបក្សបានព្រមាននៅក្នុងខែ តុលា ឆ្នាំ ១៩៧៥ ថា "ភ្នាក់ងារខ្មាំង និងសមាសភាពមិនល្អផ្សេងទៀត" នៅលាយឡំច្របូកច្របល់ក្នុងចំណោម "ប្រជាជនថ្មី" ជាង ២.០០០.០០០ នាក់ ដែលទើបចុះទៅរស់នៅជនបទ[១៩៣៤]។ ដូច្នេះ នៅចុងឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៦ បក្សបាន "វាយជាខ្សែសង្វាក់ វាយគ្រប់ផ្នែក ជីករំលើង [សមាសភាពមិនល្អក្នុងចំណោម "ប្រជាជនថ្មី"] ទាំងឫសធំ ទាំងឫសតូច"[១៩៣៥]។

---

[១៩៣៣] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៤-៦, ៨, ERN (ភាសាខ្មែរ) 00008488-90, 00008492។ *សូមមើលផងដែរ ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/10 ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ទំព័រ ១៩, ERN (ភាសាខ្មែរ) 00063076 (បក្សត្រូវបន្តពង្រឹង និងពង្រីកទីតាំងសមូហភាព)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/139 ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ១៣, ERN (ភាសាខ្មែរ) 00064970 (ត្រូវប្រមូលប្រជាជន និងឲ្យពួកគេទៅនៅសហករណ៍)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/11 ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៥៨-៥៩, ERN (ភាសាខ្មែរ) 00063173-4 (ចាំបាច់ត្រូវពង្រីកទំហំសហករណ៍)។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ទំព័រ៦-៧, ERN (ភាសាខ្មែរ) 00442212-3(នៅក្នុងសហករណ៍ កម្លាំងវណ្ណៈថ្នាក់លើមិនមានជម្រើសអ្វីក្រៅតែពីត្រូវដើរតាមកសិករក្រ និងកសិករថ្នាក់កណ្តាលនោះឡើយ។ បក្សបានបញ្ជាថា ត្រូវតែពង្រឹង និងពង្រីក ដើម្បីឈានទៅជាសហករណ៍ ១.០០០ គ្រួសារ)។ ឯកសារ កម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00072403-4 (កសិករថ្មីបានពង្រីកសហករណ៍ និងកម្លាំងសម្រាប់កសិកម្មនៅតាមមូលដ្ឋាន។ ត្រូវបង្រៀន និងប្រមូលផ្តុំប្រជាជនថ្មី ដើម្បីការពារ និងកសាងប្រទេស)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00709583-4 (ការអនុវត្តជាទូទៅរបស់ពួកខ្មែរក្រហម គឺត្រូវត្រួតត្រាទៅលើប្រជាជនដែលទើបរំដោះបានថ្មីៗ ជាពិសេស ប្រជាជនទាំងឡាយដែលត្រូវបានបណ្តេញចេញពីទីក្រុងនានា គឺដាក់បញ្ចូលប្រជាជនទាំងនោះទៅក្នុងភូមិនានា ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេជាយូរមកហើយ)។

[១៩៣៤] *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/729 ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00063400-1។

[១៩៣៥] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/25 ខែធ្នូ ឆ្នាំ ១៩៧៦ - មករា ឆ្នាំ ១៩៧៧ ទំព័រ ៤, ERN (ភាសាខ្មែរ) 00063003 (ក្នុងឆ្នាំ ១៩៧៦ ពួកសក្តិភូមិម្ចាស់ដី និងពួកនាយទុន ក៏ដូចជាវណ្ណៈផ្សេងៗទៀតដែលមិនមែនជាវណ្ណៈអធន និងរបស់ពួកអនុធន របស់កសិករឯកជន របស់កម្មករឯកជន និងរបស់ពលករឯកជន ត្រូវបានយើងគាស់រំលើងផងដែរ)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/170 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១៧, ERN (ភាសាខ្មែរ) 00064770 (នៅចន្លោះពីឆ្នាំ ១៩៧៥ និង១៩៧៦ បក្សបានបោសសម្អាតខ្មាំងយ៉ាងជ្រះស្រឡះ ហើយបានចាប់ផ្តើមយកចិត្តទុកដាក់ទៅលើកម្មាភិបាលនៅក្នុងសហករណ៍)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ

៦១៦. នៅពាក់កណ្តាលឆ្នាំ ១៩៧៦ បក្សបានប្រកាសថា បក្សបានចាត់តាំង កសាង ពង្រឹង និង ពង្រីករបបសម្ភូហភាព វាយរបបនាយទុន និងបញ្ចប់របបសក្តិភូមិម្ចាស់ដី[១៩៣៦] ។ ហេតុដូច្នេះ នៅពាក់កណ្តាល ឆ្នាំ ១៩៧៦ ការផ្តោតចម្បងជាសំខាន់នោះ គឺការចាប់ផ្តើមងាកទៅរកខ្មាំងនៅក្នុងបក្ស[១៩៣៧]។ ទោះបីជាយ៉ាងនេះក្តី បក្សនៅតែយល់ឃើញថា បក្សចាំបាច់ត្រូវវាយ "ប្រជាជនថ្មី"

---

១៩៧៥ ទំព័រ ១៨-១៩, ERN (ភាសាខ្មែរ) 00063253-4 (ដើម្បីសម្រេចបានទិន្នផលបីតោនក្នុងមួយហិកតា ចាំបាច់ត្រូវពង្រឹងរដ្ឋអំណាចរបស់បក្ស និងផ្តាច់ការវណ្ណៈអធន។ តាមការអនុវត្តជាក់ស្តែង និងជារូបី ចំណុចនេះមានន័យ *ក្នុងចំណោមបញ្ហាជាច្រើន*ថា បន្តការតស៊ូវណ្ណៈឲ្យកាន់តែខ្លាំងក្លាថែមទៀត ដោយបន្តកំទេចឥតឈប់ឈរឲ្យសាបសូន្យជាស្ថាពរនូវវណ្ណៈ និងរបបសក្តិភូមិ ម្ចាស់ដី និងនាយទុន ដើម្បីកុំឲ្យវាមានឱកាសងើបក្បាលមកធ្វើជាបង្អែកឲ្យពួកចក្រពត្តិ)។

[១៩៣៦] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ១៣-១៦, ២១, ERN (ភាសាខ្មែរ) 00062755-8, 00062763 (នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៦ ដែលជាថ្ងៃប្រារព្ធខួបរំដោះទីក្រុងភ្នំពេញ តំណាងរបស់បក្សបានប្រកាសថា របបសក្តិភូមិ-ម្ចាស់ដី ត្រូវបានបញ្ចប់ទាំងស្រុង និងជាស្ថាពរហើយ។ បក្សក៏បានវាយប្រយុទ្ធផ្តួលរំលំ និងជីករំលើងរបបមូលធនដល់ឫសគល់។ ទីបំផុត បក្សបានរៀបចំ កសាង ពង្រឹង និងពង្រីករបបសម្ភូហភាព)។*ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/762 ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៥, ERN (ភាសាខ្មែរ) 00063286 (ការតស៊ូប្រឆាំងនឹងរបបចាស់ និងសំណល់ចាស់របស់ពួកសក្តិភូមិ ម្ចាស់ដី នាយទុន ចក្រពត្តិនិយម និងអាណានិគមនិយមផ្សេងៗ បានជឿនលឿនមួយកម្រិតថែមទៀត នៅក្នុងខែសីហា ឆ្នាំ ១៩៧៦ ជាងអ្វីដែលធ្លាប់បានធ្វើពីមុន។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/734 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១២-១៣, ១៦, ERN (ភាសាខ្មែរ) 00064127-8, 00064131 (នៅឆ្នាំ ១៩៧៦ ការគំរាមកំហែងចម្បង គឺសមាសធាតុនាយទុនដែលបានជ្រៀតចូលក្នុងជួរបក្ស។ វណ្ណៈសក្តិភូមិ និងនាយទុន ត្រូវបានបំបែកបំបាក់ទាំងស្រុង (មូលដ្ឋានសេដ្ឋកិច្ច និងរបបនយោបាយរបស់ពួកវា ត្រូវបានផ្តួលរំលំ និងរំលាយចោលទាំងស្រុង) សមាជិកនៃវណ្ណៈនេះនៅសល់តែជាបុគ្គលប៉ុណ្ណោះ។ រីឯបុគ្គលសក្តិភូមិ នាយទុនទាំងនេះ ត្រូវបានធ្វើឲ្យបែកខ្ញែកខ្ចាត់ខ្ចាយ និងចុះទៅបង្កបង្កើន ផលនៅជនបទដែលពួកគេរស់នៅក្រោមក្របខណ្ឌសហករណ៍កសិករយើងទាំងស្រុង)។

[១៩៣៧] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/4 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១០-១១, ១៣, ១៨, ២១-២៩, ERN (ភាសាខ្មែរ) 00062914-5, 00062917, 00062922, 00062925-33។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/762 ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ៩, ១២-១៤, ២៥, ៣២, ERN (ភាសាខ្មែរ) 00063280, 00063283-5, 00063296, 00063303។ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២(កាំង ហ្កេកអ៊ាវ) ទំព័រ ១៩-២០។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ២៩-៣០ (ខ្មាំងរួមមានអ្នកដែលបានរារាំងដល់កិច្ចការបក្ស ឬបំពេញការងារមិនបានល្អ សូម្បីតែពួកគេជាសាច់ញាតិផ្ទាល់ក្តី)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៤៦-៤៨ (មេដឹកនាំជាន់ខ្ពស់នៃកងទ័ពខ្មែរក្រហមជាច្រើនរូបត្រូវបានចាប់ខ្លួន។ ពួកគេចោទដាក់គ្នាទៅវិញទៅមកថាជាខ្មាំង ទោះបីជាគាត់មិនអាចយល់បានច្បាស់លាស់ថា ពួកគេជាភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេក៏ដោយ)។

ដែលជាសំណល់ពីសក្តិភូមិ និងនាយទុន[១៩៣៨]។ នៅក្នុងឆ្នាំ ១៩៧៦ សហករណ៍បានបន្តពង្រីកបន្ថែមទៀត ជាមធ្យមមានចំនួន ចន្លោះពី ១០០ គ្រួសារ ទៅ ៣០០ គ្រួសារ ហើយសហករណ៍ខ្លះមានរហូតដល់ ៥០០ គ្រួសារ និងនៅឃុំខ្លះទៀត សហករណ៍មានរហូតដល់ ១.០០០ គ្រួសារ[១៩៣៩]។

៦១៧. រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៦ កងទ័ពខ្មែរក្រហមបានប្រមូលអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេរាប់រយនាក់ ដោយបានដឹកជញ្ជូនពួកគេតាមរទេះគោ និងឲ្យពួកគេធ្វើដំណើរដោយថ្មើរជើងទៅកាន់ទីតាំងនានា រួមទាំង ថ្កោល នៅក្នុងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)[១៩៤០] បឹងកន្ទួត[១៩៤១] ចក[១៩៤២] និងអូរពងមាន់[១៩៤៣] ក្នុងខេត្តបាត់ដំបង (ភូមិភាគ

---

[១៩៣៨] *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/733 ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១២, ERN (ភាសាខ្មែរ) 00064014។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/734 ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ១៣, ERN (ភាសាខ្មែរ) 00064128 (តទៅអនាគត គឺត្រូវបន្តវាយកំទេចកាកសំណល់នៃរបបនាយទុន)។

[១៩៣៩] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/762 ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៩, ERN (ភាសាខ្មែរ) 00063290។ របាយការណ៍ស្តីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧, ១៣-១៤, ERN (ភាសាខ្មែរ) 00442212-3, 00442219-20 (នៅក្នុងសហករណ៍ កម្លាំងវណ្ណៈថ្នាក់លើមិនមានជម្រើសអ្វីក្រៅតែពីត្រូវដើរតាមកសិករក្រ និងកសិករថ្នាក់កណ្តាលនោះឡើយ។

[១៩៤០] ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ១៤-១៦ ។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៩-១២, ERN (ភាសាខ្មែរ) 00373251-4។ (ប្តីរបស់អ្នកស្រី ឡាយ បូនី ជាអតីតទាហាន លន់ នល់ ម្នាក់ ហើយនៅពេលដែលខ្មែរក្រហមបានរកឃើញអត្តសញ្ញាណប្តីរបស់គាត់ ពេលនោះ ឡាយ បូនី និងប្តីរបស់គាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខថ្កោល) ។

[១៩៤១] ប្រតិចារឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣(ធុច ផាន់ដារា-ស)ទំព័រ ៧-៨។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់តារា-ស ឯកសារ E3/5732 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ភាសាខ្មែរ) 00916999។

[១៩៤២] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស ច័ន្ទថន ឯកសារ E3/4730 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ១០-១៦, ERN (ភាសាខ្មែរ) 00485966-74 (នៅដើមខែធ្នូ ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានប្រមូលប្រជាជនជាង ២០០ គ្រួសារ រួចបញ្ជូនទៅក្នុងមន្ទីរ ក្នុងនោះរួមមាន មន្ត្រី ទាហាន និង ប៉ូលីសរបប លន់ នល់។ ព្រឹកឡើង ពួកខ្មែរក្រហមបានយករទេះចំនួន ៣០ មកដឹកពួកគេយកទៅកាន់សហករណ៍ជំនុំ ស្ថិតនៅក្នុងឃុំជំនុំ។ នៅថ្ងៃបន្ទាប់ ខ្មែរក្រហមបានឲ្យពួកគេធ្វើដំណើរដោយថ្មើរជើងទៅភូមិរហាត់ទឹក ដែលស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រ។ បន្ទាប់មក ពួកគេត្រូវបានបញ្ជូនទៅភូមិចុក)។

[១៩៤៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារ E3/5187 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00197917-8 (នៅពាក់កណ្តាលឆ្នាំ ១៩៧៦ ទាហាន លន់ នល់ និងក្រុមគ្រួសាររបស់គេត្រូវបានជម្លៀសចេញពីខេត្តបាត់ដំបង ហើយអ្នកខ្លះត្រូវបានបញ្ជូនទៅកាន់មូលដ្ឋានអូរពងមាន់)។

ពាយ័ព្យ) និងឃុំថ្មី ខេត្តក្រចេះ (តំបន់ ៥០៥)[១៩៤៤] ។ នៅតាមផ្លូវ ពួកគេពុំត្រូវបានផ្តល់ស្បៀងអាហារឱ្យទេ ហើយពួកគេត្រូវបានឈ្លេចសួរអំពីប្រវត្តិរូប ដោយគម្រាមនឹងអាវុធដែលមានគ្រាប់ពេញ[១៩៤៥] ។ ឪពុកធំរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស ច័ន្ទថន មិនអាចដើរបាន ហើយគ្រួសារចាំបាច់ត្រូវសែងគាត់[១៩៤៦] ។ ក្រោយពីបានចេញដំណើរ ប្រជាជនទាំងនោះក៏ត្រូវបានផ្លាស់ទីលំនៅឱ្យមកនៅតាមទីតាំងថ្មី ហើយប្រជាជនខ្លះទៀតត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ[១៩៤៧]។

៦១៨. នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ នៅក្តោល ក្នុងខេត្តពោធិ៍សាត់ ប្រជាជនជាច្រើននាក់ត្រូវបានគេដោះលែងក្រោយពីសួរចម្លើយរួច និងបញ្ជូនទៅតាមភូមិភាគដែលគេអះអាងថាមាន

---

[១៩៤៤] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ឯកសារ E3/436 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៩, ERN (ភាសាខ្មែរ) 00405492 (ខ្មែរក្រហមបានប្រមូលអតីតទាហាន និងប៉ូលីសរបប លន់ នល់ ហើយបានបញ្ជូនពួកគេទៅកាន់ការដ្ឋានធ្វើការងារនៅក្នុងឃុំថ្មី ខេត្តក្រចេះ ដែលនៅទីនោះ ពួកគេបានធ្វើពលកម្មដោយដៃ និងធ្វើស្រែចម្ការ) *សូមមើលផងដែរ* អត្ថបទរបស់ Ben KIERNAN៖ *"ក្បាលឃ្មុនខ្លួនខ្មែរ" ភូមិភាគបូព៌ានៃកម្ពុជាឆ្នាំ ១៩៧៥-១៩៧៨* ឯកសារ E3/2310 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៣, ERN (ភាសាខ្មែរ) 00693724-5 (នៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ ផ្នែកខ្លះនៃខេត្តក្រចេះ ដែលចំណុះឱ្យភូមិភាគបូព៌ា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរជាង ១០០ នាក់ និងគ្រូបង្រៀនមួយចំនួន ត្រូវបានយកទៅរៀនសូត្រ ហើយបានបាត់ខ្លួនរហូត)។

[១៩៤៥] ប្រតិចារឹកថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៣(ធុច ផាន់ដាវា-ស)ទំព័រ៦-៧។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់តារា-ស ឯកសារ E3/5732 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ភាសាខ្មែរ) 00916999។(ធុច ផាន់ដាវា-ស គ្រួសាររបស់គាត់ និងប្រជាជនយ៉ាងហោចណាស់ចំនួន ៦ គ្រួសារទៀត ត្រូវបានសម្លុតដោយប្រើអាវុធភ្ជង់គំរាមកំហែង និងបានសួរអំពីប្រវត្តិរូបរបស់ពួកគេ នៅបឹងកន្ទួត នៅជិតខេត្តបាត់ដំបង)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស ច័ន្ទថន ឯកសារ E3/4730 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១០-១៦, ERN (ភាសាខ្មែរ) 00485966-74។

[១៩៤៦] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស ច័ន្ទថន ឯកសារ E3/4730 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១០-១៦, ERN (ភាសាខ្មែរ) 00485966-74។

[១៩៤៧] ប្រតិចារឹក ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដាវា-ស) ទំព័រ ៨។ ព័ត៌មានបន្ថែមទៅលើសក្ខីកម្មរបស់លោកស្រី ធុច ផាន់តារា-ស ឯកសារ E3/5732 ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ទំព័រ ២, ERN (ភាសាខ្មែរ) 00916999 (ពួកគេត្រូវបានដោះលែង និងបំបែកឱ្យរស់នៅភូមិផ្សេងគ្នាចម្ងាយ ៣ ឬ ៤ គីឡូម៉ែត្រពីភូមិមួយទៅភូមិមួយ។ លោកស្រី ធុច ប្តី និង កូនៗរបស់លោកស្រីត្រូវបានបញ្ជូនឱ្យទៅនៅភូមិភ្នំថ្មី ចំណែកឪពុកម្តាយរបស់លោកស្រី និងកូនៗរបស់ប្អូនប្រុសគាត់ត្រូវបានផ្លាស់ទៅកាន់បឹងកន្ទួត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស ច័ន្ទថន ឯកសារ E3/4730 ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ១០-១៦, ERN (ភាសាខ្មែរ) 00485966-74។

ស្បៀងអាហារច្រើន[១៩៤៨]។ប្រជាជនទាំងនេះបានបាត់ខ្លួន រួមទាំងស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ផងដែរ[១៩៤៩]។ ឡាយ បូនី ក៏បាននិយាយផងដែរថា ខោអាវរបស់អ្នកបាត់ខ្លួនខ្លះត្រូវបានយកត្រឡប់មកចោលវិញដើម្បីទុកឱ្យអ្នកផ្សេងទៀតប្រើប្រាស់[១៩៥០]។ ក្រោយមក គេបានប្រាប់គាត់ថា ប្រជាជនខ្លះត្រូវបានសម្លាប់ចោល ប៉ុន្តែគ្មាននរណាម្នាក់ធ្លាប់បានឃើញសាកសពរបស់ពួកគេឡើយ[១៩៥១] ។ នៅចុងឆ្នាំ ១៩៧៦ ខ្មែរក្រហមបានរកឃើញថា ជីដូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្បួង ស៊ីម ជាអ្នកលក់គ្រឿងទេសនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ហើយពូរបស់គាត់ជាអ្នកចេះដឹង ។ ពួកគេត្រូវបានផ្លាស់ទីលំនៅពីភូមិសំរោង ស្រុកបាកាន ទៅកាន់របងរមាស ខេត្តពោធិ៍សាត់ ហើយមិនដែលឃើញវិលត្រឡប់មកវិញឡើយ[១៩៥២]។

៦១៩. នៅប៉ែកទក្សិណនៃប្រទេសកម្ពុជា ខ្មែរក្រហមបានបញ្ជូន "ប្រជាជនថ្មី" និងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរដើម្បីឱ្យទៅកសាងខ្លួននៅតាមទីតាំងនានា ដូចជា គុកតានៃ ខេត្តកំពត[១៩៥៣]

---

[១៩៤៨] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៦, ៣៧ (បានប៉ាន់ប្រមាណថា ប្រជាជនប្រហែល ១០០.០០០ នាក់ត្រូវបានដោះលែង)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៩-១២, ERN (ភាសាខ្មែរ) 00373251-4។

[១៩៤៩] ប្រតិចារឹក ថ្ងៃទី២៤ ខែ តុលា ឆ្នាំ ២០១២(ឡាយ បូនី) ទំព័រ១៥-១៧, កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៩-១២, ERN (ភាសាខ្មែរ) 00373251-4។

[១៩៥០] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ១១-១២, ERN (ភាសាខ្មែរ) 00373253-4។

[១៩៥១] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៣៧។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ឯកសារ E3/3958 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ១១-១២, ERN (ភាសាខ្មែរ) 00373253-4។

[១៩៥២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្បួង ស៊ីម ឯកសារ E3/4657 ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៧-៩, ERN (ភាសាខ្មែរ) 00349499-01។

[១៩៥៣] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី លឿង ប៊ុន្នី ឯកសារ E3/5543 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣-៨, ERN (ភាសាខ្មែរ) 00375537-42 (ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ លឿង ប៊ុន្នី ដែលឪពុករបស់គាត់ជាអ្នកគ្រប់គ្រងឃ្លាំងរដ្ឋនៅមុនឆ្នាំ១៩៧៥ ហើយគ្រួសាររបស់គាត់ ត្រូវបានជម្លៀសចេញពីក្រុងព្រះសីហនុ ឱ្យទៅកាន់ទីកន្លែងផ្សេងៗក្នុងស្រុកព្រៃនប់ ខេត្តកំពត ហើយបន្ទាប់មក គេបានបញ្ជូនឱ្យទៅនៅសហករណ៍កសាង នៅក្នុងខេត្តកំពត ហើយក្រោយមកទៀត នៅចុងឆ្នាំ ១៩៧៥ ត្រូវបានបញ្ជូនទៅគុកតានៃ។ នៅក្នុងឆ្នាំ ១៩៧៦ ខ្មែរក្រហមបានចោទឪពុករបស់គាត់ថាជាទាហាន លន់ នល់។ គាត់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅគុកតានៃ ស្រុកព្រៃនប់ ខេត្ត

និងភ្នំស្វក់ ខេត្តកំពង់ស្ពឺ (ភូមិភាគនិរតី និងភូមិភាគបស្ចិម)[១៩៥៤]។ ប្រជាជនប្រហែលជា ៥០ នាក់ ដែលបានបញ្ជូនទៅកសាងខ្លួននៅលើភ្នំស្វក់ ត្រូវបានផ្លាស់ទីលំនៅ ក្រោមការឃាមកាម និងពុំត្រូវបានផ្តល់ស្បៀងអាហារ ឬ ទឹកឲ្យហូបឡើយ[១៩៥៥]។ នៅពេលទៅដល់ ពួកគេគ្មានជម្រកស្នាក់នៅ គ្មានស្បៀងអាហារ គ្មានទឹក ឬ គ្មានថ្នាំសង្កូវអ្វីសោះឡើយ[១៩៥៦]។ បន្ទាប់ពីពេលនោះមក ប្រជាជនជាច្រើននាក់បានស្លាប់ដោយសារជ្រូកព្រៃដេញវ៉ៃ អត់អាហារ ខ្សោះជាតិទឹក និងជំងឺ[១៩៥៧]។ ប្រហែលជា ២ ខែ ក្រោយមក អង្គការបានប្រកាសថា អ្នកនៅរស់រានមានជីវិតចំនួន ២០ នាក់ ត្រូវបានកសាងខ្លួនរួចហើយ ហើយពួកគេត្រូវបានអនុញ្ញាតឲ្យចុះពីលើភ្នំនោះ[១៩៥៨]។ នៅជើងភ្នំ អង្គការបានឲ្យពួកគេឡើងឡានដើម្បីនាំយកទៅស្ថានីយរថភ្លើងនៅក្នុងក្រុងភ្នំពេញ ដោយនៅទីនោះ ពួកគេត្រូវបានឲ្យឡើងជិះរថភ្លើងបន្តឆ្ពោះទៅកាន់ខេត្តកំពង់ឆ្នាំង (ភូមិភាគបស្ចិម)[១៩៥៩]។

---

កំពត។ ៥ ថ្ងៃក្រោយមក លឿង ប៊ុន្នី និងក្រុមគ្រួសាររបស់គាត់ក៏ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅគុកតានៃ។ ក្រោយមក ក្រុមគ្រួសាររបស់គាត់ត្រូវបានបញ្ជូនទៅគុកកំពង់សិលា ភូមិបាក់រនាស់ ឃុំចំប៉ា ស្រុកកំពង់សីលា ខេត្តកោះកុង រហូតដល់ឆ្នាំ ១៩៧៩។

[១៩៥៤] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២៨ (លោកស្រីបានគេចខ្លួនទៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយបានស្នាក់នៅទីនោះអស់រយៈពេល ៥ ថ្ងៃ មុនពេលប្រគល់ខ្លួនឲ្យកងទ័ពខ្មែរក្រហម ហើយត្រូវបានបញ្ជូនទៅភ្នំ ស្វក់), ទំព័រ ៣៤-៣៦, ៤៨, ៥៤ (ពេជ ស្រីផល ប្តីរបស់លោកស្រី និងប្រជាជនថ្មីប្រហែលជា ៥០ នាក់ ត្រូវបានកងទ័ពខ្មែរក្រហមបញ្ជូនទៅភ្នំស្វក់ ខេត្តកំពង់ស្ពឺ ដើម្បីអប់រំកែប្រែ)។

[១៩៥៥] ប្រតិចារឹក ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ ៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ឯកសារ E3/3970 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00422474 (គេមិនឲ្យចំណីអាហារ ឬទឹកហូបទេ)។

[១៩៥៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៤-៣៥។

[១៩៥៧] ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៥-៣៦។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ឯកសារ E3/3970 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00422474។

[១៩៥៨] ប្រតិចារឹកថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២(ពេជ ស្រីផល)ទំព័រ ៣៥-៣៦។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ឯកសារ E3/3970 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៩ ទំព័រ ទំព័រ ៥, ERN (ភាសាខ្មែរ) 00422474 (ដំបូង គេយកប្រជាជនចំនួន ៥០ នាក់ទៅកាន់ភ្នំនោះ។ ពួកគេនៅទីនោះអស់រយៈពេលប្រហែលជា២ ទៅ ៣ខែ ហើយក្រោយមកត្រូវបានអនុញ្ញាតឲ្យចាកចេញពីភ្នំនោះ។ ពួកខ្មែរក្រហមបានប្រាប់ប្រជាជនទាំងនោះថា ពួកគាត់ត្រូវបានអប់រំកសាងខ្លួនរួចហើយ)។

[១៩៥៩] ប្រតិចារឹកថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៧, ៤៨-៤៩, ៥៤-៥៥។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ឯកសារ E3/3970 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥, ERN (ភាសាខ្មែរ) 00422474។

៦២០. នៅក្នុងឆ្នាំ១៩៧៦ មានប្រជាជនប្រហែលជា ៦០០ គ្រួសារ ត្រូវបានជម្លៀសពីខេត្តព្រៃវែង និងខេត្តកំពង់ចាម (ភូមិភាគបូព៌ា) ទៅកាន់ខេត្តមណ្ឌលគីរី (ភូមិភាគឦសាន)[១៩៦០]។ គ្រួសារភាគច្រើនត្រូវបានយកទៅដាក់នៅម្ដុំស្រែសង្គម ស្រុកកោះញែក ប៉ុន្តែ "ប្រជាជនមិនល្អ" ត្រូវបានយកទៅដាក់នៅការដ្ឋានរយ៉[១៩៦១]។

## ១១.៤.២ ការបែងចែកសមាសភាពឲ្យបានច្បាស់លាស់ (ឆ្នាំ ១៩៧៧)

៦២១. ថ្នាក់ដឹកនាំបក្សជឿថា បក្សចាំបាច់ត្រូវមាន "ប្រជាជនល្អ" (ស្របតាមមាគ៌ារបស់បក្សស្តីពីវណ្ណៈ មានន័យថា អ្នកដែលត្រូវបានយល់ឃើញថាជាប្រជាជនល្អ គឺផ្អែកលើវណ្ណៈសង្គមរបស់ពួកគេ) ឲ្យមកធ្វើស្រែនៅលើដីមានជីជាតិបំផុត ដើម្បីបង្កើនការបង្កបង្កើនផល និងដើម្បីដោះស្រាយបញ្ហាទឹក[១៩៦២]។ កសិករកណ្តាល និងវណ្ណៈអនុធនដែលបក្សមិនសូវទុកចិត្ត ត្រូវបានចាត់ឲ្យបំពេញភារកិច្ចបន្ទាប់បន្សំ នៅលើដីមានជីជាតិ ក្រោមការដឹកនាំរបស់វណ្ណៈអធន ឬ សមាជិកបក្សដែលមានដើមកំណើតពីវណ្ណៈមូលដ្ឋាន[១៩៦៣]។ ដូច្នេះ នៅក្នុងឆ្នាំ ១៩៧៧ នៅតាមសហករណ៍នានា

---

[១៩៦០] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ឡឹងចូយ ឯកសារ E3/5178 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ១១, ERN (ភាសាខ្មែរ) 00197865។

[១៩៦១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ឡឹងចូយ ឯកសារ E3/5178 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ១១, ERN (ភាសាខ្មែរ) 00197865។

[១៩៦២] *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/193 ចុះខែ សីហា ឆ្នាំ ១៩៧៧ ទំព័រ ២៦-២៧, ERN (ភាសាខ្មែរ) 00062971-2។

[១៩៦៣] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/170 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ២៤, ៥២-៥៥, ERN (ភាសាខ្មែរ) 00064777, 00064805-8។ សេចក្តីរាយការណ៍របស់គណៈកម្មាធិការតំបន់ ៥ ប្រចាំអាទិត្យ ឯកសារ E3/178 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ១-២, ៣-៤, ៧, ១០-១១, ERN (ភាសាខ្មែរ) 00275587-8, 00275589-90, 00275593, 000275596-7 (តំបន់ ៥ មានសមាសភាព ១៧ មេសា ច្រើនកុះករ ហេតុដូច្នេះ សហករណ៍ និងកម្លាំងកំពុងត្រូវបានរៀបចំដោយផ្អែកទៅលើកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម។ សមាសភាព ១៧ មេសា កំពុងត្រូវបានបញ្ជូនទៅកាន់សហករណ៍ ហើយកំពុងត្រូវបានប្រមូល និងចាត់តាំងជាយុទ្ធសាស្ត្រ ក្រោមការដឹកនាំរបស់វណ្ណៈអធន។ សមាសភាព ១៧ មេសា ក៏ត្រូវបានស្តីបន្ទោសដោយសារតែការបណ្តែតបណ្តោយឲ្យគោចុះស្គម)។ *ស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/193 ចុះខែ សីហា ឆ្នាំ ១៩៧៧ ទំព័រ ១៧, ERN (ភាសាខ្មែរ) 00062962 (សមាសភាពក្រោយរំដោះមួយចំនួននៅទូទាំងប្រទេសអត់ចាត់ទុកគោក្របីជាយុទ្ធមិត្តរបស់ខ្លួនទេ)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/25 ខែធ្នូ ឆ្នាំ ១៩៧៦-មករា ឆ្នាំ ១៩៧៧ ទំព័រ ២១-២២, ERN (ភាសាខ្មែរ) 00063020-1 (ក្នុងឆ្នាំ ១៩៧៧ កាកសំណល់នៃវណ្ណៈជិះជាន់ផ្សេងៗ នៅតែជាការគំរាមកំហែង) ទំព័រ៤០-៤២, ERN (ភាសាខ្មែរ) 00063039-41 (ក្នុងឆ្នាំ១៩៧៧ សហករណ៍ត្រូវបានពង្រឹង និងពង្រីកថែមទៀត)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/135 ខែ មិថុនា

ជាការចាំបាច់ត្រូវបែងចែកប្រជាជនឲ្យបានច្បាស់លាស់រវាង "សមាជិកសហករណ៍ពេញសិទ្ធិ" (ប្រជាជនមូលដ្ឋាននៅតាមសហករណ៍) "សមាជិកសហករណ៍ត្រៀម" ប្រជាជនមូលដ្ឋានទាំងឡាយណាដែលមានស្ថានភាពហិរញ្ញវត្ថុប្រសើរនៅមុន ឆ្នាំ ១៩៧៥ និង "សមាជិកបញ្ញើរបស់សហករណ៍" (ប្រជាជន "១៧ មេសា") ដើម្បីកុំឲ្យមានការច្របូកច្របល់នៅក្នុងការគ្រប់គ្រង និងប្រមូលកម្លាំង[១៥៦៤]។

៦២២. នៅក្នុងឆ្នាំ១៩៧៧ លេខាស្រុកសំបូរ ឈ្មោះ បាន បានបញ្ជាឲ្យសាក្សី យុន គីម លេខាឃុំសំបូរ ខេត្តក្រចេះ បែងចែកប្រជាជនទៅតាមប្រភេទផ្សេងៗគ្នា[១៥៦៥]។ នៅក្នុងឆ្នាំនោះ ជួន សំអាត ដែលជម្លៀសមកពីក្រុងភ្នំពេញ ហើយត្រូវបានផ្លាស់ទីលំនៅបីប្អួនដងទៀត នាពេលក្រោយមក ត្រូវបានខ្មែរក្រហមចោទថា គាត់គឺជាគ្រូបង្រៀន ហើយត្រូវបានខ្មែរក្រហមចាប់ខ្លួនទាំងគ្រួសារ រួចដឹកតាមរទេះគោ ពីភូមិបុស្សមាស ទៅប្រស្រា ស្រុកសំបូរ ខេត្តក្រចេះ (តំបន់ ៥០៥)[១៥៦៦]។

៦២៣. នៅក្នុងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) "ថ្នាក់លើ" បានជ្រើសរើស "ប្រជាជនថ្មី" ដើម្បីផ្លាស់ទីលំនៅទៅកាន់ភូមិថ្មីៗ[១៥៦៧]។ កម្មាភិបាលមូលដ្ឋានត្រូវបានគេប្រគល់បញ្ជីឲ្យនិងណែនាំឲ្យរៀបចំប្រជាជនទាំងនោះដើម្បីឲ្យឡើងជិះឡានដែលតំបន់បានបញ្ជូនមក[១៥៦៨]។ ប្រជាជនដែលត្រូវបានចោទថាជាអ្នកចេះដឹង ឬជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានដឹក

ឆ្នាំ ១៩៧៧ ទំព័រ ៣១, ERN (ភាសាខ្មែរ) 00062819 (វណ្ណៈកណ្តាល និងវណ្ណៈលើ អាចទុកចិត្តបានតិចជាងវណ្ណៈមូលដ្ឋាន)។

[១៥៦៤] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/742 ខែ មេសា ឆ្នាំ១៩៧៧ ទំព័រ ១៦-១៨, ERN (ភាសាខ្មែរ) 00062996-8។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៣-២៥។

[១៥៦៥] ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ៥០-៥៤។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ទំព័រ ២៤-២៥។

[១៥៦៦] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជួន សំអាត ឯកសារ E3/4707 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00387631 (ក្នុងឆ្នាំ ១៩៧៦ ជួន សំអាត ត្រូវបានជម្លៀសចេញពីខេត្តកំពង់ចាម ឲ្យទៅនៅភូមិបុស្សមាស ស្រុកសំបូរ ខេត្តក្រចេះ)។

[១៥៦៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២-៥, ERN (ភាសាខ្មែរ) 00239906-9។

[១៥៦៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱ ហូ ឯកសារ E3/5255 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២-៥, ERN (ភាសាខ្មែរ) 00239906-9។

ទៅកាន់ទីតាំងថ្មីៗនៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្ដាល) ខេត្ត តាកែវ និងខេត្តកំពត (ភូមិភាគនិរតី) ហើយក្រោយមកប្រជាជនខ្លះទៀតបានបាត់ខ្លួន[១៩៦៩]។ នៅក្នុង ភូមិរំចក់ ខេត្តតាកែវ (ភូមិភាគនិរតី) "ប្រជាជនថ្មី" ទាំងអស់ រួមទាំងប្រជាជនដែលជម្លៀសមកពី ក្រុងភ្នំពេញពីមុនមកត្រូវបានផ្លាស់ទីលំនៅទាំងអស់[១៩៧០]។

## ១១.៥ ការផ្លាស់ទីលំនៅចេញឲ្យឆ្ងាយពីព្រំដែនវៀតណាម

៦២៤. នៅតាមជួរព្រំដែនជាប់ជាមួយនឹងវៀតណាម ការលុកលុយបានបន្តកើតមានចាប់តាំងពីចុង ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧[១៩៧១] ។ ប្រជាជនត្រូវបានបញ្ជូនចេញពីទីតាំងនានានៅក្នុងភូមិភាគបូព៌ា

---

[១៩៦៩] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាយ កាណាល់ ឯកសារ E3/4699 ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00368783-4 (នៅដើមឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានចាប់ផ្ដើមចាប់ប្រជាជន ថ្មី និងចាត់ ឲ្យទៅរស់នៅភូមិបង្កើតថ្មី។ បងស្រី និងបងថ្លៃប្រុសរបស់ សាយ កាណាល់ ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ ១៩៧៧។ បងថ្លៃប្រុសរបស់គាត់បានប្រាប់ពួកខ្មែរក្រហមថា នៅមុនថ្ងៃ ១៧ មេសា ១៩៧៥ គាត់ធ្វើជាគ្រូបង្រៀន ដោយគិតថា ខ្មែរក្រហមសម្លាប់តែទាហានទេ។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហុន ស៊ីកែម ឯកសារ E3/5390 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧-១០, ERN (ភាសាខ្មែរ) 00479049-52 (នៅរដូវប្រាំងនាឆ្នាំ ១៩៧៧ ហុន ស៊ាត ដែលមានផ្ទៃពោះ៤ខែ ប្ដីរបស់គាត់ដែលជាអតីតទាហាន លន់ នល់ កូនៗរបស់គាត់ និងប្រជាជនចំនួន១០ គ្រួសារទៀត ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់ស្រុកពញាក្រែក។ អ្នកស្រីទើបតែបានដឹងក្រោយឆ្នាំ ១៩៧៩ ថា ពួកគេត្រូវបានសម្លាប់ចោលអស់ហើយ។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ឯកសារ E3/4611 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៥-៦, ERN (ភាសាខ្មែរ) 00418486-7 (នៅក្នុងឆ្នាំ ១៩៧៧ ក្រោយមានគេរាយការណ៍ថា គាត់ធ្លាប់ធ្វើជាប៉ូលីស លន់ នល់ ពាក់ស័ក្ដិ១ គាត់ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ជើងចាបស្ថិតនៅក្នុងខេត្តកំពត ។ អ្នកទោសទាំងអស់នៅទីនោះជាអតីតទាហាន ឬប៉ូលីស ហើយពួកគេត្រូវបានសួរ ចម្លើយពី ២ ទៅ៣ ដង។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ញ៉ែម យ៉ង់ ឯកសារ E3/5361 ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៧, ERN (ភាសាខ្មែរ) 00463415 (នៅក្នុងឆ្នាំ ១៩៧៧ ប្រជាជនថ្មីនៅខេត្តតាកែវ ត្រូវបានយកទៅ ដាំដូង មានន័យថា យកទៅសម្លាប់ចោល)។

[១៩៧០] ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ញ៉ែម យ៉ង់ ឯកសារ E3/5361 ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ ៧, ERN (ភាសាខ្មែរ) 00463415។

[១៩៧១] សេចក្ដីរាយការណ៍ពីភូមិភាគនីរតី ឯកសារ E3/853 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសា ខ្មែរ) 00052825 (នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ ភូមិភាគនីរតីបានរាយការណ៍ជូនអង្គការថា វៀតណាមកំពុងតែបាញ់ ផ្លោងនៅតាមព្រំដែន ហើយវាបានបញ្ជូនកម្លាំង ៣ គីឡូម៉ែត្រពីព្រំដែនខេត្តកំពត)។ ប្រតិចារឹកខ្សែអាត់សម្លេងនៃបទ សម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ៤១-៤៣, ERN (ភាសាខ្មែរ) 00741123-5 (អៀង ធីរិទ្ធ បានពន្យល់ថា ក្រោយពីវៀតណាមបានចូលមកឈ្លានពាន

តាមព្រំដែនជាប់ជាមួយនឹងវៀតណាម រួមទាំង ខេត្តកំពង់ចាម (ស្ពានរោង និងមេមត់)[១៩៧២] និង ខេត្តស្វាយរៀង (ឃុំសំរោង ឃុំសថ្ងក ឃុំប្រាសាទ ឃុំស្វាយធំ និងឃុំបាវិត)[១៩៧៣]។

៦២៥. ខ្មែរក្រហមបានប្រាប់ប្រជាជនទាំងនោះថា ពួកគេត្រូវជម្លៀសដើម្បីការពារខ្លួន[១៩៧៤]។ ផ្ទុយទៅវិញសមាសភាពមិនល្អត្រូវបានជម្លៀសទៅជួរក្រោយដើម្បីអប់រំកែប្រែបែងចែកនិងសម្រិតសម្រាំង[១៩៧៥]។ ក្រោយមក ប្រជាជនខ្លះដែលត្រូវបានជម្លៀសទៅជួរក្រោយ ត្រូវបានហៅឲ្យមកធ្វើ

---

នៅក្នុងខែធ្នូ ឆ្នាំ១៩៧៦ និង/ឬ ខែមករា ឆ្នាំ១៩៧៧ រដ្ឋាភិបាលបានចាត់វិធានការដើម្បីការពារប្រជានជនស៊ីវិល និងបានជម្លៀសពួកគេពីបូព៌ាទៅបស្ចិម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ឡឹងចូយ ឯកសារ E3/5178 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ភាសាខ្មែរ) 00197858 (ប្រជាជនក្នុងស្រុកកែវសីមា តំបន់ ៥ ខេត្តមណ្ឌលគីរី ភូមិភាគឦសាន ទុកមិនទាន់ជម្លៀសរហូតដល់ឆ្នាំ ១៩៧៧ ដោយសារមានដីស្រែ ទំនប់ និងប្រឡាយ។ នៅក្នុងឆ្នាំ ១៩៧៧ ខ្មែរក្រហមបានប្រយុទ្ធជាមួយវៀតណាម ដូច្នេះ ប្រជាជនស្រុកកែវសីមាក៏ត្រូវបានជម្លៀស)។

[១៩៧២] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/908 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00020923(ភ្លួងបានរាយការណ៍ជូនមន្ទីរ ៨៧០ និងបានចម្លងជូន នួន ជា ថា ក្រោយពីមានការឈ្លានពានពីវៀតណាម កម្មករទាំងអស់នៅភូមិស្ពានរោង និងរោងចក្រមេមត់ ត្រូវបានដកចេញ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/ 912 ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00020896។

[១៩៧៣] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/889 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00183616 (ក្នុងសារទូរលេខដែលផ្ញើជូន "ម-៧០" និងចម្លងជូន នួន ជា នោះ ឆុន បានរាយការណ៍ថា ពួកគេបានជម្លៀសប្រជាជនមូលដ្ឋាន និងកងចល័ត ចេញពីឃុំសំរោង ឃុំសថ្ងក ឃុំប្រាសាទ និងឃុំបាវិត ខេត្តស្វាយរៀង ហើយកំពុងតែជម្លៀសបន្ថែមទៀត។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឹម ឡេង ឯកសារ E3/5539 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៨, ERN (ភាសាខ្មែរ) 00373239 (នៅដើមឆ្នាំ ១៩៧៧ ទាហានវៀតណាមបានចូលមកក្នុងខេត្តស្វាយរៀង ហើយ ខឹម ឡេង ក្រុមគ្រួសាររបស់គាត់ និងប្រជាជនជាច្រើននាក់ទៀត ត្រូវបានជម្លៀសចេញពីភូមិ ស្វាយធំ ឲ្យទៅកាន់កន្លែងមួយនៅជិតក្រុងស្វាយរៀង)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00381016 (នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ឥន្ទ វុទ្ធី និងប្រជាជនទាំងអស់នៅឃុំប្រាសាទ ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានជម្លៀសចេញពីឃុំព្រៃគគីរទៅទិសបស្ចិម គឺទៅកាន់ភូមិដូនស ខាងជើងក្រុងស្វាយរៀង ហើយនៅដំណាច់ឆ្នាំ ១៩៧៧ ត្រូវបានគេបញ្ជូនចេញពីភូមិជ្រៃ ឃុំថ្វាង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង)។

[១៩៧៤] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00381016។

[១៩៧៥] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/243 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ២, ERN (ភាសាខ្មែរ) 00020939។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ារឌី ឯកសារ E3/5613 ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣-៦, ១៣, ERN (ភាសាខ្មែរ) 00491045-9, 00491055 (ហេតុផលតែមួយគត់ដែលអាចឲ្យ សេង ម៉ារឌី គិត

ការងារនៅកន្លែងផ្សេងវិញ[១៩៧៦]។ ពួកគេបានទៅតាមកងទ័ពខ្មែរក្រហម ហើយក្រោយមកបានបាត់ខ្លួន[១៩៧៧]។ សាច់ញាតិរបស់ពួកគេបានសន្មតថា ពួកគេត្រូវបានសម្លាប់ បន្ទាប់ពីខ្មែរក្រហមបានចែកសម្លៀកបំពាក់របស់ពួកគេ នាពេលក្រោយមក[១៩៧៨]។ ក្នុងខណៈពេលនោះដែរ កងចល័តត្រូវបានបញ្ជូនត្រឡប់មកជួរមុខវិញដើម្បីប្រមូលផលស្រូវ[១៩៧៩] លីគ្រាប់រំសេវ[១៩៨០] និងសែងកងទ័ពខ្មែរក្រហមដែលរងរបួសពីសមរភូមិ[១៩៨១]។

---

ឃើញដល់ការចាប់ខ្លួនឪពុករបស់គាត់នោះ គឺដោយសារតែឪពុករបស់គាត់ជានាយទាហាន លន់ នល់ ឬដោយសារពួកគាត់ជាប្រជាជនថ្មី។ “សមាធាតុមិនល្អ” ក៏ទំនងជាកំពុងត្រូវបានដកចេញពីព្រំប្រទល់ដទៃទៀត ដូចជា តំបន់ ១០៣ និងភូមិភាគព្លសាន [*សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ៧៨-៨០ (ប្រជាជននៅស្រុកកែវសីមា ខេត្តមណ្ឌលគីរី ត្រូវបានដកចេញនៅឆ្នាំ ១៩៧៨ ដោយសារពួកខ្មែរក្រហមខ្លាចប្រជាជនទាំងនោះឃុបឃិតជាមួយវៀតណាម។ ពួកគេត្រូវបានផ្លាស់ទីលំនៅទៅកាន់ស្រុកកោះញែក)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/918 ចុះថ្ងៃទី ១២ មករា ឆ្នាំ ១៩៧៨ ទំព័រ ១, ERN (ភាសាខ្មែរ) 00001060 ( ដែលបានចម្លងជូន ប៉ុល ពត និង នួន ជា ព្រមទាំងសមាជិកដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍)]។

[១៩៧៦] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00381019-20។

[១៩៧៧] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00381019-20។

[១៩៧៨] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00381019-20។

[១៩៧៩] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/243 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ២, ERN (ភាសាខ្មែរ) 00020939 (ដែលបានចម្លងជូន នួន ជា នោះ ឆុន បានរាយការណ៍ថា កងចល័តត្រូវបានរៀបចំចាត់ចែងឲ្យទៅច្រូតកាត់នៅជួរមុខ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឹម ឡេង ឯកសារ E3/5539 ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៩ ទំព័រ ៨, ERN (ភាសាខ្មែរ) 00373239 ។ *សូមមើល ផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/906 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00020922 (កងទ័ពវៀតណាមបានចាប់សមាជិកកងចល័តដែលកំពុងច្រូតស្រូវចំនួន ១០០ នាក់)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/978 ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00020884 (បន្ទាប់ពីបានរាយការណ៍ជូន “ម-៨៧០” ចម្លងជូន នួន ជា និងសមាជិកដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ថា មានការឈ្លានពានពីសំណាក់វៀតណាមរួចមក ធួន ឃួន បានបញ្ជាក់ថា មានតម្រូវការប្រើប្រាស់កម្លាំងមហាជនទាំងអស់ដើម្បីដោះស្រាយបញ្ហាទឹក និងរៀបចំកម្លាំងធ្វើស្រែនៅកន្លែងណាដែលមានទឹក)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/984 ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ១, ERN (ភាសាខ្មែរ) 00020904 (កងទ័ពវៀតណាមបានចូលមកដល់ការដ្ឋានកំពីងពួយ បានបំផ្លាញទំនប់ត្រសេក និងបានចាប់សមាជិកកងចល័ត)។

01006908



៦២៦. នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅចេញពីព្រំដែនវៀតណាម ប្រជាជនបានធ្វើដំណើរដោយថ្មើរជើង[១៨៨២] ។ ស្បៀងអាហារត្រូវបានដឹកមកជាមួយប្រជាជនទាំងនេះ ហើយខ្មែរក្រហមបានគ្រប់គ្រងលើការបែងចែកស្បៀងអាហារនេះ[១៨៨៣] ។ មនុស្សចាស់ និងអ្នកជំងឺ ត្រូវបានគេសែងដោយអង្រឹង[១៨៨៤]។

## ១១.៦ សម្អាងច្បាប់

៦២៧. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីបទការសម្លាប់រង្គាល[១៨៨៥] ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[១៨៨៦] និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការបាត់ខ្លួនដោយបង្ខំ[១៨៨៧] ការជម្លៀសដោយបង្ខំ[១៨៨៨] និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស[១៨៨៩]។ ការផ្លាស់ទីលំនៅជនជាតិភាគតិចចាម បង្កើតជាមូលដ្ឋាននៃបទចោទ ទាំងការជម្លៀសដោយបង្ខំ

---

[១៨៨០] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឹម ឡេង ឯកសារ E3/5539 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៨, ERN (ភាសាខ្មែរ) 00373239 ។

[១៨៨១] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00373239 ។

[១៨៨២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឹម ឡេង ឯកសារ E3/5539 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៨, ERN (ភាសាខ្មែរ) 00373239 ។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00373239 ។

[១៨៨៣] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00373239 *។សូមមើលផងដែរ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/914, ទំព័រ ១, ERN (ភាសាខ្មែរ) 00329531 (ដែលបានរាយការណ៍ជូន “ម-៨៧០” ថា ប្រជាជននៅតាមសហករណ៍ និងកម្មករដែលបានជម្លៀសចេញពីមេមត់ និងក្រែក កំពុងធ្វើដំណើរមកខាងទន្លេ ហើយមានការខ្វះខាតស្បៀងអាហារ និងស្នើសុំជំនួយ)។

[១៨៨៤] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឥន្ទ វុទ្ធី ឯកសារ E3/5542 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៧, ERN (ភាសាខ្មែរ) 00373239 ។

[១៨៨៥] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១-១៣៩០។

[១៨៨៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៨, ១៤២៤-១៤២៥។

[១៨៨៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧០-១៤៧៨។

[១៨៨៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤៨-១៤៦៩។

[១៨៨៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣៤-១៤៤១។

និងការធ្វើទុកបុកម្នេញដោយមូលហេតុសាសនា ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)[១៩៥០]។ បទចោទចុងក្រោយ អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ នោះទេ[១៩៥១]។ ដោយហេតុថា មូលដ្ឋានអង្គហេតុនៃបទចោទទាំងពីរនេះដូចគ្នា ហើយបទចោទជាប់ពាក់ព័ន្ធគ្នាពុំអាចញែកចេញពីគ្នាបាន អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើការសម្រេចត្រង់ចំណុចនេះនៅក្នុងសាលក្រមនេះ ដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំលើប្រជាជនចាម ដែលត្រូវបានចោទប្រកាន់ផងដែរថា ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានោះទេ។

៦២៨. ទោះបីជាក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា ទទួលស្គាល់ថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅនៅក្នុងដំណាក់កាលទី២ក៏ដោយ ក៏ក្រុមមេធាវីការពារក្តីទាំងពីរបានតវ៉ាអំពីលក្ខណៈនៃការបង្ខំ និងលក្ខណៈឧក្រិដ្ឋនៃការផ្លាស់ទីលំនៅទាំងនោះ ព្រមទាំងការគ្រប់គ្រងដែលធ្វើឡើងដោយមជ្ឈិមបក្ស[១៩៥២]។ នៅក្នុងសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ក្រុមមេធាវី

---

[១៩៥០] ដីកាដំណោះស្រាយ កថាខណ្ឌ ២២៦, ២៦៨, ២៨១, ៩០១, ១៤២០, ១៤៦៨។

[១៩៥១] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/ ០១ (E163) ឯកសារ E124/7.3។ *សូមមើលផងដែរ* សំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E284/5 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១១ (កត់សម្គាល់ឃើញថា ពុំមានសាក្សីណាម្នាក់ត្រូវបានធ្វើការស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការជម្លៀសជនជាតិចាមនោះទេ និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ដកចេញឱ្យបានជាក់លាក់ពីការពិចារណារបស់ខ្លួននូវការចោទប្រកាន់នានាដែលទាក់ទងនឹងជនជាតិចាម ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកថាខណ្ឌមួយចំនួនដែលពិភាក្សាអំពីការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២។

[១៩៥២] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣១៨-៣១៩ (សេចក្តីសម្រេចធ្វើឡើងដោយមេភូមិភាគ មិនមែនមជ្ឈិមទេ) កថាខណ្ឌ ៣២១-៣៣៣ (មិនមានភស្តុតាងបង្ហាញអំពីការស្លាប់ក្នុងទ្រង់ទ្រាយធំ ឬមានចេតនាជាក់លាក់ដើម្បីសម្លាប់មនុស្សនោះទេ) កថាខណ្ឌ ៣៣៤-៣៤៤ (មិនមានភស្តុតាងបង្ហាញអំពីការប្រព្រឹត្តិខុសៗគ្នា ឬ មានចេតនាជាក់លាក់ដើម្បីធ្វើទុក្ខបុកម្នេញនោះទេ) កថាខណ្ឌ ៣៥២-៣៥៩ (មិនមានភស្តុតាងបង្ហាញអំពីការបាត់ខ្លួនដោយបង្ខំនោះទេ) កថាខណ្ឌ៣៦០-៣៦៤ (មិនមានភស្តុតាងបង្ហាញអំពីការវាយប្រហារមកលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិនោះទេ) កថាខណ្ឌ ៣៦៥-៣៦៨ (មិនមានភស្តុតាងបង្ហាញអំពីការជម្លៀសដោយបង្ខំនោះទេ

ការពារក្តី ខៀវ សំផន ក៏បានសន្និដ្ឋានផងដែរថា ពេលវេលា និងភូមិសាស្ត្រនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) មានលក្ខណៈស្រពិចស្រពិល ហើយការចោទប្រកាន់ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ពុំគ្របដណ្តប់ដល់ឆ្នាំ ១៩៧៧ នោះឡើយ[១៩៩៣]។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ការតវ៉ាអំពីទម្រង់នៃដីកាដំណោះស្រាយ និងភាពគ្រប់គ្រាន់នៃការជូនដំណឹង ពុំត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។ អនុលោមតាមវិធាន ៦៧(២) និងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង នៅពេលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានដោះស្រាយចប់រួចរាល់នោះ បញ្ហាពាក់ព័ន្ធនឹងទម្រង់នៃដីកាមិនអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានឡើយ។ ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំបានលើកការតវ៉ានេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរយៈពេលកំណត់ ដែលអនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុងស្តីពីការដាក់អញ្ញត្រកម្ម ឬ នៅក្នុងអំឡុងពេលណាមួយ នៅមុនពេលដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនោះឡើយ។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពាក់ព័ន្ធនឹងការតវ៉ារបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន លើទម្រង់នៃដីកាដំណោះស្រាយ សេចក្តីសន្និដ្ឋានដែលបានដាក់យឺតពេលនេះមិនអាចទទួលយកបានទេ។

៦២៩. ទោះក្នុងករណីណាក៏ដោយ ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីដែលថា ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ពុំត្រូវបានចោទប្រកាន់គ្របដណ្តប់រហូតដល់ឆ្នាំ ១៩៧៧ នោះ គឺជាទឡ្ហីករណ៍គ្មានមូលដ្ឋាន។ យោងតាមដីកាដំណោះស្រាយ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) បានចាប់ផ្តើមនៅក្នុងអំឡុងខែ កញ្ញា ឆ្នាំ ១៩៧៥ និងបន្តរហូតដល់ឆ្នាំ ១៩៧៧[១៩៩៤]។

---

និងបានជំទាស់តវ៉ានៅក្នុងចំណោមបញ្ហាជាច្រើនថាជាការជម្លៀសនោះធ្វើឡើងដោយស្ម័គ្រចិត្ត)។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៦១-៦៤ (នៅមានភាពច្រពិចស្រពិលចំពោះភស្តុតាងដែលជាប់ទាក់ទិននឹងការជម្លៀសលើកទី២ ហើយក៏បានលើកឡើងផងដែរថា ខៀវ សំផន មិនពាក់ព័ន្ធទេ) កថាខណ្ឌ ៦៥-៦៩ (ការជម្លៀសនោះត្រូវបានអះអាងថា ដោយសារមូលហេតុសេដ្ឋកិច្ច) កថាខណ្ឌ ៧០ (ការពាក់ព័ន្ធរបស់មជ្ឈិម) កថាខណ្ឌ ៧១ (ការជម្លៀសនោះមានបំណងដោះស្រាយស្ថានភាពសេដ្ឋកិច្ច និងមនុស្សធម៌)។

[១៩៩៣] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៦១-៦២។

[១៩៩៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣, ២៦២។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះ

ជាការគាំទ្រដល់ចំណុចពេលវេលានេះ ដីកាដំណោះស្រាយបានដកស្រង់យ៉ាងច្បាស់នូវកំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងអំពីការផ្លាស់ទីលំនៅ នៅដើមឆ្នាំ ១៩៧៧ ពាក់កណ្តាលឆ្នាំ ១៩៧៧ និងចុងឆ្នាំ ១៩៧៧[១៩៩៥] ។ ទោះបីជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តីទំនងជាធ្វើការតវ៉ាអំពីកម្រិតគ្រប់គ្រាន់នៃភស្តុតាង[១៩៩៦] ដែលអង្គជំនុំជម្រះសាលាដំបូងនឹងឆ្លើយតបនៅក្នុងផ្នែកសំអាងច្បាប់ខាងក្រោមរបស់ខ្លួន។

### ១១.៦.១ ការជម្លៀសដោយបង្ខំ

៦៣០. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៧ យ៉ាងហោចណាស់ មានប្រជាជនចំនួនពី ៣០០.០០០ នាក់ ទៅ ៤០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅពីទីតាំងផ្សេងៗនៅក្នុងខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង និងខេត្តស្វាយរៀង (ភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា) ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តព្រះវិហារ (តំបន់១០៣)[១៩៩៧]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងខែធ្នូ ឆ្នាំ ១៩៧៧ ប្រជាជនចំនួនជាង ៣០.០០០ នាក់[១៩៩៨] ក៏ត្រូវបានផ្លាស់ទីលំនៅទៅកាន់ខេត្តក្រចេះ (តំបន់៥០៥) និងនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង(ភូមិភាគបូព៌ា) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) ផងដែរ[១៩៩៩]។ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅ ទៅកាន់ខេត្តសៀមរាប (តំបន់១០៦) និងទៅកាន់

សាលា ដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ឯកសារ E124/7.3។

[១៩៩៥] ដីកាដំណោះស្រាយ លេខជើងទំព័រ ១០០៣។

[១៩៩៦] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៦១-៦៤។

[១៩៩៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨០, ៥៨៤-៦០១។

[១៩៩៨] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨១។

[១៩៩៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២-៦២៦។

ខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានរកឃើញភស្តុតាងគ្រប់គ្រាន់គាំទ្រដល់ការចោទប្រកាន់ទាំងនេះនៅក្នុងសំណុំរឿង០០២/០១ នោះឡើយ។

៦៣១. ភស្តុតាងបានបង្ហាញថា ប្រជាជនភាគច្រើនលើសលុបដែលត្រូវបានផ្លាស់ទីលំនៅនៅក្នុងដំណាក់កាលទី២ គឺជាប្រជាជនកម្ពុជាដែលត្រូវបានខ្មែរក្រហមផ្លាស់ទីលំនៅរួចមកហើយ នៅមុនខែ កញ្ញា ឆ្នាំ ១៩៧៥[២០០០]។ ជាក់ស្តែង អង្គហេតុដែលថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅរួចហើយ ពីទីកន្លែងកំណើតរបស់ពួកគេទៅទីកន្លែងណាមួយនោះពុំមែនមានន័យថា ទីកន្លែងដែលបានផ្លាស់ទីទៅនោះជាកន្លែងខុសច្បាប់នោះទេ។ លើសពីនេះទៀត ប្រជាជនខ្លះដែលត្រូវបានផ្លាស់ទីលំនៅនៅក្នុង (ដំណាក់កាលទី២) គឺជាប្រជាជនកម្ពុជាដែលរស់នៅស្របច្បាប់នៅតាមទីកន្លែងកំណើតរបស់ពួកគេ[២០០១]។

៦៣២. ភស្តុតាងយ៉ាងច្រើនលើសលុបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ប្រជាជនភាគច្រើនត្រូវបានបញ្ជាឲ្យចាកចេញ និងត្រូវបានផ្លាស់ទីលំនៅក្រោមការឃាមកាមដោយកងកម្លាំងប្រដាប់អាវុធ[២០០២]។ ប្រជាជនណាដែលមិនព្រមផ្លាស់ទីលំនៅ ឬ ព្យាយាមរត់គេចខ្លួន ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ ផ្លាស់ទីលំនៅជាថ្មីម្តងទៀត[២០០៣]។ កងទ័ពខ្មែរក្រហមពុំបានផ្តល់ជំនួយណាមួយហើយជាញឹកញាប់ក៏ពុំផ្តល់ព័ត៌មានអំពីគោលដៅដែលពួកគេត្រូវទៅនោះឡើយ ។ ប្រជាជនមានការភ័យខ្លាច ហើយរស់នៅក្នុងស្ថានភាពភ័យរន្ធត់ ដោយមិនហ៊ាន ឬ មិនមានលទ្ធភាពអាចប្រឆាំង ឬ សួរដេញដោលអំពីបញ្ហាទាំងនោះឡើយ[២០០៤]។

៦៣៣. មានភស្តុតាងបង្ហាញថា ប្រជាជនខ្លះដែលត្រូវបានផ្លាស់ទីលំនៅពីប៉ែកទក្សិណនៃប្រទេសកម្ពុជាទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) បានយល់ព្រមផ្លាស់ទីលំនៅ

---

[២០០០] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៨៨-៥៨៩, ៦២២-៦២៣។

[២០០១] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨។

[២០០២] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨, ៥៩៤-៥៩៨, ៦០០-៦០១, ៦០៨-៦០៩, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។ ។

[២០០៣] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨, ៥៩៨, ៦០៩។

[២០០៤] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨២, ៥៨៩, ៥៩១, ៥៩៤-៥៩៥, ៥៩៧-៥៩៩, ៦០១, ៦០៩, ៦១១-៦១២, ៦១៧, ៦២៤-៦២៥។

ដោយស្ម័គ្រចិត្ត ដោយសារតែស្ថានភាពរស់នៅលំបាករបស់ពួកគេនៅក្នុងភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា[២០០៥]។ នៅមុនខែ កញ្ញា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជាជនជាច្រើននាក់ ពីលំនៅដ្ឋានរបស់ពួកគេនៅក្នុងទីក្រុងភ្នំពេញ និងនៅតាមទីតាំងផ្សេងៗទៀត ទៅកាន់តំបន់ដែលមានប្រជាជនរស់នៅច្រើនក្នុងភូមិភាគបស្ចិម ភូមិភាគនិរតី និងភូមិភាគបូព៌ាដែលនៅទីនោះ ដីពុំមានជីជាតិ ហើយពុំមានធនធាន និងស្បៀងអាហារគ្រប់គ្រាន់[២០០៦]។ ដូច្នេះ ខ្មែរក្រហមបានបង្កើតស្ថានភាពមួយដែលធ្វើឲ្យប្រជាជនខ្លួនឯងយល់ឃើញថា ត្រូវតែផ្លាស់ទីលំនៅ នៅចន្លោះពី ខែ កញ្ញា ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ ។ ដូច្នេះ ការស្ម័គ្រចិត្តផ្លាស់ទីលំនៅ មិនអាចត្រូវបានចាត់ទុកថាជាការអនុវត្តសិទ្ធិជ្រើសរើសដោយពិតប្រាកដនោះឡើយ។ ប្រជាជនត្រូវបានប្រាប់និងជឿថាដី និងធនធានដែលប្រសើរជាងនេះកំពុងរង់ចាំពួកគេនៅតាមគោលដៅដែលពួកគេត្រូវទៅ ឬ ថាពួកគេនឹងត្រូវបានផ្លាស់ទីលំនៅត្រឡប់មកលំនៅដ្ឋានដើមវិញ[២០០៧] ។ ប្រជាជនជាច្រើននាក់ពុំត្រូវបានផ្លាស់ទីលំនៅឲ្យត្រឡប់មកលំនៅដ្ឋានដើមវិញឡើយ ឬ មិនត្រូវបានផ្លាស់ទីលំនៅទៅតាមគោលដៅដែលពួកគេត្រូវបានប្រាប់ថានឹងត្រូវបញ្ជូនទៅនោះឡើយ[២០០៨]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ប្រជាជនពុំមានជម្រើសពិតប្រាកដពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅរបស់ពួកគេនោះឡើយ ហើយកងទ័ព និងកម្មាភិបាលខ្មែរក្រហម បានផ្លាស់ទីលំនៅប្រជាជនទាំងនេះដោយបង្ខំដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា រួមទាំង ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ការបង្ខិតបង្ខំ និងការបោកបញ្ឆោត។

៦៣៤. កម្មាភិបាលរបស់បក្សភាគច្រើន បានផ្តល់យុត្តិកម្មលើការផ្លាស់ទីលំនៅប្រជាជនដោយយកលេសថា ដោយសារពួកគេយកចិត្តទុកដាក់លើប្រជាជន ហើយអះអាងថា ការផ្លាស់ទីលំនៅពួកគេទៅតាមភូមិភាគដែលដីមានជីជាតិ ដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនគ្រប់គ្នាមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ។ បក្សក៏បានពិចារណាឃើញផងដែរថា ការផ្លាស់ទីលំនៅទាំងនេះនឹងអនុញ្ញាតឲ្យបក្សរកឃើញ និងកាត់ផ្តាច់ការគម្រោងកំហែងលើការកសាង និងការពារសង្គមនិយម រួមទាំងគិញ ភ្នាក់ងារបរទេស អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង "ប្រជាជនថ្មី" ទាំង

---

[២០០៥] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៩។

[២០០៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៨៥។ ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៥, ៥១៦-៥១៧។

[២០០៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៩។

[២០០៨] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៥, ៥៩៩។

ឡាយណាដែលមិនអាចកែប្រែបាន។ ដូចបានកត់សម្គាល់ខាងលើ ស្ថានភាពអមនុស្សធម៌យ៉ាងខ្លាំងនៃមហន្តរាយនេះ ក្នុងនោះ ការមានស្បៀងអាហារមិនគ្រប់គ្រាន់ជាផ្នែកមួយដ៏សំខាន់ដែលបណ្តាលមកពីចំណាត់ការរបស់បក្សខ្លួនឯង[២០០៩] ។ អាស្រ័យហេតុនេះ ការលើកឡើងបែបនេះមិនអាចយកមកធ្វើជាយុត្តិកម្មសម្រាប់ការផ្លាស់ទីលំនៅ ដោយផ្អែកទៅលើមូលដ្ឋាននៃសន្តិសុខសម្រាប់ប្រជាជនស៊ីវិល ឬ ភាពចាំបាច់ផ្នែកយោធាឡើយ ។

៦៣៥. ទោះបីជាយុត្តិកម្មខាងលើត្រូវបានទទួលយកក៏ដោយ ក៏ការផ្លាស់ទីលំនៅនៅក្នុងដំណាក់កាលទី២ ពុំមានភាពចាំបាច់ ឬ ពុំមានសមាមាត្រឡើយ។ ទីមួយ គ្មានភ័ស្តុតាងណាមួយបង្ហាញថាប្រជាជនត្រូវបានឱ្យត្រឡប់មកលំនៅដ្ឋានដើមរបស់ពួកគេវិញឡើយ ឬ ថាប្រជាជនភាគច្រើនមិនអាចស្នាក់នៅដោយមានស្ថេរភាពឡើយ សូម្បីនៅក្រោយការផ្លាស់ទីលំនៅហើយក៏ដោយ។ ផ្ទុយទៅវិញ ប្រជាជនជាច្រើនត្រូវបានផ្លាស់ទីលំនៅជាប្រចាំនៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ១៩៧៧ ដោយប្រជាជនខ្លះស្ថិតក្នុងកម្លាំងការងារតាមរដូវកាល[២០១០]។ ទីពីរ ទោះបីជាមានភ័ស្តុតាងបង្ហាញថា ស្បៀងអាហារ ការស្នាក់នៅ និងការជួយជ្រោមជ្រែង ត្រូវបានផ្តល់ឱ្យខ្លះៗនៅក្នុងអំឡុងពេល ឬ ក្រោយពេលផ្លាស់ទីលំនៅហើយក៏ដោយ ក៏ការផ្តល់ឱ្យទាំងនោះមិនគ្រប់គ្រាន់ឡើយ[២០១១]។ ប្រជាជនបានប្រជ្រៀតគ្នានៅតាមឡាន រថភ្លើង រទេះគោ ឬ ត្រូវបានបង្ខំឱ្យធ្វើដំណើរដោយថ្មើរជើងដោយគ្មានសម្ភារៈអនាម័យឡើយ[២០១២]។ នៅក្នុងអំឡុងពេលឈប់សម្រាក ពួកគេត្រូវដេកផ្ទាល់ដី ហាលភ្លៀង ហាលខ្យល់ ដោយពុំមានការផ្តល់មុង កម្រាល និងស្បៀងអាហារឱ្យហូបគ្រប់គ្រាន់ឡើយ[២០១៣]។ នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅ ប្រជាជនខ្លះបានស្លាប់ដោយសារការហេវហត់អស់កម្លាំង ឬ អត់អាហារ[២០១៤]។ ក្រោយពេលទៅដល់តាមការដ្ឋានធ្វើការងារ និងសហករណ៍ដែលត្រូវបានចាត់ឱ្យទៅនោះ ប្រជាជនជាច្រើននាក់ដែលត្រូវបានបំបែកចេញពីគ្រួសាររបស់

---

[២០០៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣៣ ។ ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៤, ៥៣៧-៥៤០, ៥៤១-៥៤៣, ៥៤៥។

[២០១០] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៨៨-៥៨៩, ៦០៧-៦០៨, ៦១១-៦១២, ៦១៧-៦១៩, ៦២២-៦២៣, ៦២៥។

[២០១១] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១, ៥៩៤, ៥៩៧។

[២០១២] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០១៣] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៥៩៥, ៦០០។

[២០១៤] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩២, ៥៩៧-៥៩៨។

ពួកគេ ត្រូវសង់លំនៅដ្ឋានសម្រាប់ខ្លួនឯង និងពុំទទួលបានការជួយផ្គត់ផ្គង់ ឬ ផ្តល់កន្លែងស្នាក់នៅឡើយនៅក្នុងពេលនោះ[២០១៥] ។ ចំណុចចុងក្រោយ ជាពិសេសពាក់ព័ន្ធនឹងប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅចេញពីព្រំដែនវៀតណាម អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា កងទ័ពនិងកម្មាភិបាលខ្មែរក្រហម បានផ្លាស់ទីលំនៅប្រជាជនទាំងនេះមួយចំនួន ដើម្បីយកទៅអប់រំកែប្រែដោយមានប្រជាជនខ្លះបានបាត់ខ្លួន ឬ យកទៅជួរមុខដើម្បីធ្វើការ[២០១៦]។ ការដាក់ប្រជាជនទាំងនេះឱ្យស្ថិតនៅក្នុងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់ខ្ពស់បែបនេះ មិនមែនជាយុត្តិកម្មដោយផ្អែកលើបញ្ហាសន្តិសុខសម្រាប់ប្រជាជននោះទេ។

៦៣៦. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការជម្លៀសដោយបង្ខំនៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧ ពុំមានយុត្តិកម្មផ្អែកតាមមូលដ្ឋាននៃសន្តិសុខសម្រាប់ប្រជាជនស៊ីវិល ឬ ភាពចាំបាច់ផ្នែកយោធាឡើយ ហើយក្នុងករណីណាក៏ដោយ ការជម្លៀសដោយបង្ខំនេះពុំមានភាពចាំបាច់ ឬ ពុំសមាមាត្រនោះឡើយ។

៦៣៧. ការផ្លាស់ទីលំនៅក្នុងដំណាក់កាលទី២ ត្រូវបានធ្វើឡើងទៅតាមផែនការ និងគោលនយោបាយរបស់បក្ស ដោយផែនការ និងគោលនយោបាយទាំងនេះ ត្រូវបានផ្សព្វផ្សាយនៅគ្រប់កម្រិតនៃឋានានុក្រមរបស់ខ្មែរក្រហម[២០១៧] ។ ការផ្លាស់ទីលំនៅទាំងនេះ ត្រូវបានផ្តួចផ្តើម បញ្ជា និងអនុវត្តក្រោមការឃាមកាមដោយកងកម្លាំងប្រដាប់អាវុធ និងកម្មាភិបាលរបស់ខ្មែរក្រហម[២០១៨] ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្លាស់ទីលំនៅនេះធ្វើឡើងដោយចេតនា។

៦៣៨. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៧ កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានអនុវត្តការផ្លាស់ទីលំនៅប្រជាជនដោយចេតនា និងដោយបង្ខំ ដោយគ្មានមូលដ្ឋានដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិឡើយ យ៉ាងហោចណាស់ ប្រជាជនចំនួនពី ៣០០.០០០ នាក់ ទៅ ៤០០.០០០ នាក់ ដែលតាំងទីលំនៅដោយស្រប

---

[២០១៥] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០១, ៦១២, ៦១៧, ៦១៩។

[២០១៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២៥។

[២០១៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦-៥៧៧, ៥៨៤-៥៨៧, ៦០២-៦០៦, ៦១០, ៦១៣-៦១៦, ៦២១, ៦២៥។

[២០១៨] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨, ៥៩៤-៥៩៨, ៦០០-៦០១, ៦០៨-៦០៩, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

ច្បាប់នៅតាមទីតាំងនានានៅក្នុងខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង និងខេត្តស្វាយរៀង (ភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា) ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តព្រះវិហារ (តំបន់ ១០៣)។ អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញផងដែរថា នៅចន្លោះខែ កញ្ញា ឆ្នាំ១៩៧៥ និងខែ ធ្នូ ឆ្នាំ១៩៧៧ កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានអនុវត្តការផ្លាស់ទីលំនៅប្រជាជនដោយចេតនា និងដោយបង្ខំ ដោយគ្មានមូលដ្ឋានដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ ចំពោះប្រជាជនចំនួនជាង ៣០០.០០០ នាក់ ដែលតាំងទីលំនៅដោយស្របច្បាប់ ទៅកាន់ខេត្តក្រចេះ (តំបន់ ៥០៥) មកពី និងនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង (ភូមិភាគបូព៌ា) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) ។

៦៣៩. ការផ្លាស់ទីលំនៅទាំងនេះ ត្រូវបានធ្វើឡើងក្រោមល័ក្ខខ័ណ្ឌអមនុស្សធម៌ ដោយជាញឹកញាប់ ប្រជាជនត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ និងពុំទទួលបាន ឬ ទទួលបានដោយមិនគ្រប់គ្រាន់នូវការជួយផ្តល់កន្លែងស្នាក់នៅ និងភាពសុខដុមរមនា[២០១៩]។ ប្រជាជនជាច្រើនត្រូវបានជម្លៀសចេញពីខេត្ត ក្រុង និងទីប្រជុំជន ឬ ជម្លៀសពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទមួយទៀត មុនពេលត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀតនៅក្នុង (ដំណាក់កាលទី២) ។ ផលប៉ះពាល់ និងទុក្ខវេទនានេះកើតមានជាប់រហូត[២០២០]។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កងទ័ពខ្មែរក្រហមបានធ្វើឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅលើផ្នែករាងកាយ និងផ្លូវចិត្តរបស់ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅនៅក្នុង (ដំណាក់កាលទី២) ហើយពួកខ្មែរក្រហមមានចេតនាធ្វើដូច្នេះ។ ការផ្លាស់ទីលំនៅទាំងនេះបានរំលោភលើសិទ្ធិជាច្រើន រួមទាំង សេរីភាពក្នុងការដើរហើរដែលត្រូវបានការពារ ដូចមានចែងនៅក្នុងបទល្មើសផ្សេងៗដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាពិសេស ការនិរទេស ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដែលបានធ្វើឡើង នៅចន្លោះខែកញ្ញា ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ បានឈានដល់កម្រិតមួយដែលទាក់ទងគ្នា នឹងបទល្មើសផ្សេងៗដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ។សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កម្មាភិបាល

---

[២០១៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០២០] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨២។

និងកងទ័ពខ្មែរក្រហម បានប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស-ជាតិ តាមរយៈការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ។

### ១១.៦.២ ការបាត់ខ្លួនដោយបង្ខំ

៦៤០. ការផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី២) មានលក្ខណៈជាការដកហូតសេរីភាពបុគ្គលដោយភ្នាក់ងាររបស់រដ្ឋ ។ កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានបញ្ជាឲ្យប្រជាជនចាកចេញ ដោយដឹកជញ្ជូនពួកគេតាមឡានបិទជិត ក្រោមការយាមកាមដោយកងកម្លាំងប្រដាប់អាវុធ និងបានដេញតាម និងចាប់ខ្លួនប្រជាជនទាំងឡាយដែលបានប៉ុនប៉ងរត់គេចខ្លួន[២០២១]។ លើសពីនេះទៀត កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានធ្វើការគ្រប់គ្រងលើគ្រប់សមាសភាពទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជន[២០២២] ។ កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានកំណត់អំពីវិធីសាស្ត្រក្នុងការផ្លាស់ទីលំនៅប្រជាជន ពេលវេលាពួកគេត្រូវបន្ទោរបង់ ទីកន្លែង និងពេលវេលាពួកគេត្រូវសម្រាក ម្ហូបអាហារ និងទឹក ដែលពួកគេត្រូវបរិភោគ នៅពេលណាគ្រួសាររបស់ពួកគេត្រូវនៅជុំគ្នា និងទីតាំងណាមួយដែលពួកគេត្រូវបញ្ជូនទៅ[២០២៣]។

៦៤១. ការដកហូតសិទ្ធិសេរីភាពទាំងនេះ បានកើតឡើងរួមជាមួយនឹងការបដិសេធដោយចេតនា មិនផ្តល់ព័ត៌មានត្រឹមត្រូវពាក់ព័ន្ធនឹងជោគវាសនា ឬ ទីកន្លែងរបស់បុគ្គលពាក់ព័ន្ធ ហើយកងទ័ព និងកម្មាភិបាលខ្មែរក្រហម ពុំបានផ្តល់ព័ត៌មាន ឬ បានផ្តល់ព័ត៌មានមិនពិត ពាក់ព័ន្ធនឹងជោគវាសនា ឬ គោលដៅដែលត្រូវបញ្ជូនទៅ[២០២៤] ។ ក្រោយមក សមាជិកគ្រួសារមួយចំនួនបានសន្និដ្ឋានអំពីជោគវាសនានៃប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ ដូចជា នៅពេលឃើញខោអាវរបស់ពួកគេត្រូវបាន

---

[២០២១] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨, ៥៩៤-៥៩៨, ៦០០-៦០១, ៦០៨-៦០៩, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០២២] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០២៣] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០២៤] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៣, ៥៩៥, ៥៩៩, ៦០១, ៦០៩, ៦១១, ៦១៤, ៦១៨, ៦២៣, ៦២៥។

ចែកមកឲ្យអ្នកដទៃប្រើប្រាស់[២០២៥] ។ ប្រជាជនដទៃទៀតបានឮពាក្យចចាមអារ៉ាមថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅត្រូវបានសម្លាប់[២០២៦] ។ ប្រជាជនខ្លះទៀតក៏ពុំមានតម្រុយ ឬ ព័ត៌មានបញ្ជាក់សោះឡើយ ។ ទើបតែក្រោយសម័យកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះដែលសមាជិកគ្រួសារភាគច្រើន និងអ្នកផ្សេងទៀតដែលមានចំណងនៃសេចក្តីស្រឡាញ់ ពិសេសជាមួយនឹងប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះ អាចមានលទ្ធភាពបញ្ជាក់ថា ការសន្មត និងពាក្យចចាមអារ៉ាមទាំងនោះ គឺជាការពិត ឬ អាចស៊ើបសួរពីជោគវាសនាអ្នកដែលត្រូវបានផ្លាស់ទីលំនៅ[២០២៧]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង ពុំបានរកឃើញភ័ស្តុតាងបង្ហាញថា ប្រជាជនបានស្នើសុំព័ត៌មានបញ្ជាក់ពីបក្សអំពីប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញច្បាស់ថា ខ្មែរក្រហមបានបង្កើតបរិយាកាសមួយដែលធ្វើឲ្យប្រជាជនមានការភ័យខ្លាច មិនហ៊ានសាកសួរ ឬ ស្នើសុំព័ត៌មានពីបក្សឡើយ[២០២៨]។

៦៤២. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានដកហូតសេរីភាពពីប្រជាជន និងបដិសេធមិនផ្តល់ព័ត៌មានពាក់ព័ន្ធនឹងជោគវាសនា ឬ ទីកន្លែងរបស់ប្រជាជនមួយចំនួន ដែលត្រូវបានផ្លាស់ទីលំនៅ ពីប៉ែកទក្សិណប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងខេត្តព្រះវិហារ(តំបន់១០៣) ព្រមទាំងខេត្តក្រចេះ (តំបន់ ៥០៥) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) និងនៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)។

៦៤៣. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការបាត់ខ្លួនដោយបង្ខំទាំងនេះឈានដល់កម្រិតមួយដែលបង្កើតបានជាបទល្មើសជាក់លាក់ផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ។ ការបាត់ខ្លួនដោយបង្ខំបានបង្កការឈឺចាប់ធ្ងន់ធ្ងរចំពោះប្រជាជនទាំងឡាយដែលបានបាត់ខ្លួន ព្រមទាំងចំពោះសមាជិកគ្រួសារ និងអ្នកផ្សេងទៀតដែលមានចំណងនៃសេចក្តី

---

[២០២៥] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៣, ៥៩៥, ៥៩៩, ៦០១, ៦០៩, ៦១១, ៦១៤, ៦១៨, ៦២៣, ៦២៥។

[២០២៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៣, ៦១៨, ៦២៥។

[២០២៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២៣, លេខយោងជើងទំព័រ ១៩៦៩។

[២០២៨] *សូមមើល*ផ្នែកទី៥, រចនាសម្ព័ន្ធរដ្ឋបាល, កថាខណ្ឌ ១៩៩ (ការសម្លាប់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា) ។

ស្រឡាញ់ពិសេសជាមួយនឹងអ្នកដែលត្រូវបានបាត់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ដោយគ្រប់គ្រងលើគ្រប់ទិដ្ឋភាពនៃការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី២ កងទ័ព និងកម្មាភិបាលខ្មែរក្រហម មានចេតនាដកហូតសេរីភាពរបស់ប្រជាជនទាំងនោះ មានចេតនាមិនផ្តល់ព័ត៌មានអំពីទីកន្លែងដែលពួកគេត្រូវទៅ និងមានចេតនាធ្វើឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់អ្នកទាំងឡាយដែលបានបាត់ខ្លួន ព្រមទាំងអ្នកដែលរស់នៅក្នុងតំបន់ដែលត្រូវបានផ្លាស់ទីលំនៅ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ។

### ១១.៦.៣ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

៦៤៤. ប្រជាជនភាគច្រើនដែលបានបាត់បង់ទ្រព្យសម្បត្តិ និងផ្ទះសម្បែងរបស់ពួកគេ ព្រមទាំងមានការឈឺចាប់ខាងរាងកាយ និងផ្លូវចិត្ត នៅក្នុងពេលផ្លាស់ទីលំនៅនៅមុនខែ កញ្ញា ឆ្នាំ ១៩៧៥ រួចហើយនោះ[២០២៩] ត្រូវបានផ្លាស់ទីលំនៅជាថ្មីម្តងទៀត យ៉ាងហោចណាស់ លើសពីម្តង នៅចន្លោះខែ កញ្ញា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧[២០៣០]។ នៅក្នុងអំឡុងពេលធ្វើដំណើរជាច្រើនថ្ងៃ ឬ ច្រើនសប្តាហ៍ កងទ័ព និងកម្មាភិបាលខ្មែរក្រហម ពុំបានផ្តល់ស្បៀងអាហារ ទឹក ជម្រក ជំនួយផ្នែកវេជ្ជសាស្ត្រ និងសម្ភារៈអនាម័យគ្រប់គ្រាន់ឡើយ[២០៣១]។ ដោយសារស្ថានភាពទាំងនេះហើយ ទើបធ្វើឱ្យប្រជាជនខ្លះស្លាប់[២០៣២]។សាកសពរបស់ពួកគេត្រូវបានបោះចោលនៅតាមផ្លូវ ដោយសាកសពខ្លះត្រូវបានបោះចេញតាមបង្អួចរថភ្លើងខណៈពេលរថភ្លើងកំពុងបើក ដែលនេះជាការដកហូតឱកាសរបស់គ្រួសារពួកគេក្នុងការធ្វើបុណ្យ កាន់ទុក្ខសម្រាប់អ្នកស្លាប់[២០៣៣] ។ ជាញឹកញាប់ គ្រួសារត្រូវ

---

[២០២៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៨៨-៥៨៩, ៦២២-៦២៣ ។ ការផ្លាស់ទីលំប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២២-៥២៤។

[២០៣០] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៨៨-៥៨៩, ៦០៧-៦០៨, ៦១១-៦១២, ៦១៧-៦១៩, ៦២២-៦២៣, ៦២៥។

[២០៣១] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០៣២] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩២, ៥៩៧-៥៩៨។

[២០៣៣] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩២, ៥៩៧។

បានបំបែកចេញពីគ្នានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន[២០៣៤] ។ លក្ខខណ្ឌទាំងនេះត្រូវបានបង្កើតឡើងជាប្រព័ន្ធ និងនៅគ្រប់ពេលវេលាក្នុង (ដំណាក់កាលទី២) ។ ស្ថានភាពទាំងនេះបានបង្កឲ្យមានការឈឺចាប់លើរូបរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរជាប់រហូត[២០៣៥] ។

៦៤៥. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ស្ថានភាពនៃការផ្លាស់ទីលំនៅប្រជាជន ពីប៉ែកទក្សិណនៃប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តព្រះវិហារ(តំបន់១០៣) និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្ដាល) ព្រមទាំងខេត្តក្រចេះ (តំបន់ ៥០៥) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្ដាល) និងនៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) ត្រូវបានធ្វើឡើងដោយចេតនា ដែលបង្កឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅលើរាងកាយ ឬ ផ្លូវចិត្ត និងឈានទៅដល់កម្រិតមួយបង្កើតជាបទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កម្មាភិបាល និងកងទ័ពខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ ដូចបានកំណត់នៅក្នុងច្បាប់ អ.វ.ត.ក ។

### ១១.៦.៤ ការសម្លាប់រង្គាល

៦៤៦. នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ពីប៉ែកទក្សិណ ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌអមនុស្សធម៌ នៅក្នុងពេលផ្លាស់ទីលំនៅ រួមទាំងការព្រងើយកន្ដើយ និងការខកខានក្នុងការជួយឧបត្ថម្ភ[២០៣៦]។ កងទ័ពខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជន[២០៣៧] ។ មិនមានព័ត៌មានអំពីចំនួនប្រជាជនស្លាប់ពិតប្រាកដក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) នោះឡើយ។

៦៤៧. ទោះបីជាយ៉ាងនេះក្ដី ប្រជាជនរាប់សែននាក់ត្រូវបានផ្លាស់ទីលំនៅ ដោយទទួលបានជម្រក និងការជួយឧបត្ថម្ភគាំទ្រ មិនគ្រប់គ្រាន់ និងស្ថិតនៅក្នុងលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ។ មនុស្ស

[២០៣៤] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០១, ៦១៧។

[២០៣៥] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨២។

[២០៣៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩២, ៥៩៤, ៥៩៧-៥៩៨។។

[២០៣៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៥។

ចាស់ កូនក្មេង និងអ្នកជំងឺ ត្រូវបានផ្លាស់ទីលំនៅនៅក្នុងរយៈពេលជាច្រើនថ្ងៃ ឬ រហូតដល់មួយសប្តាហ៍ ដោយគ្មានទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រ គ្មានអាហារ ឬ ទឹកគ្រប់គ្រាន់ គ្មានជម្រក ឬ សម្ភារៈអនាម័យនៅតាមផ្លូវ ឬ នៅក្នុងអំឡុងពេលឈប់សម្រាក នៅលើឡាន និងនៅលើរថភ្លើង ដែលមានអ្នកជិះណែនតាន់តាប់[២០៣៨]។ មានភស្តុតាងបង្ហាញថា ប្រជាជនជាច្រើនបានស្លាប់ដោយសារអត់អាហារ ការហេវហត់អស់កម្លាំង និងដោយសារតែកងទ័ពខ្មែរក្រហមនៅក្នុងអំឡុងពេល និងនៅក្នុងដំណាក់កាលផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជន[២០៣៩] ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែលបង្ហាញអំពីការស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ពីប៉ែកទក្សិណនៃប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) គឺជាភស្តុតាងតំណាងអំពីចំនួនសរុប ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ប្រជាជនដែលបានស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ គឺមានចំនួនច្រើន។

៦៤៨. នៅក្នុងដំណាក់កាលទី១ ប្រជាជនត្រូវបានផ្លាស់ទីលំនៅក្រោមលក្ខខណ្ឌស្រដៀងៗគ្នា ដែលបណ្តាលឱ្យមនុស្សស្លាប់ជាច្រើននាក់[២០៤០] ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ថ្នាក់ដឹកនាំបក្សមិនបានគិតគូរអំពីមេរៀនផ្សេងៗដែលទទួលបានពីការផ្លាស់ទីលំនៅដំណាក់កាលទី១ទេ ហើយមិនបានចាត់វិធានការដើម្បីធានាថា ប្រជាជនបានទទួលជំនួយឧបត្ថម្ភ ឬ កន្លែងស្នាក់នៅគ្រប់គ្រាន់ នៅក្នុងការផ្លាស់ទីលំនៅដំណាក់កាលទី២។ លើសពីនេះទៀត ការផ្លាស់ទីលំនៅនៅក្នុងដំណាក់កាលទី២ ត្រូវបានធ្វើឡើង ភាគច្រើនដោយកងទ័ព និងកម្មាភិបាលដដែលៗដែលទទួលខុសត្រូវលើការផ្លាស់ទីលំនៅប្រជាជននាពេលមុន[២០៤១] ។ ដូច្នេះ អង្គជំនុំជម្រះ

[២០៣៨] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៦០១, ៦០៧-៦០៩, ៦១១-៦១២, ៦១៧-៦២០, ៦២២-៦២៣, ៦២៥-៦២៦។

[២០៣៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩២, ៥៩៤-៥៩៥, ៥៩៧-៥៩៨។

[២០៤០] *សូមមើល* ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៧-៤៩៨, ៥២១។

[២០៤១] *សូមមើល* អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កងទ័ពដែលទទួលខុសត្រូវចំពោះការផ្លាស់ទីលំនៅប្រជាជននៅក្នុងអំឡុងពេលដំណាក់កាលទី១ របស់ភូមិភាគ និងកងកម្លាំងយោធារបស់មជ្ឈិម ដែលក្រោយមក បានអនុវត្តការផ្លាស់ទីលំនៅក្នុងអំឡុងពេលដំណាក់កាលទី២ (ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១) កថាខណ្ឌ ៤៦០, លេខយោងជើងទំព័រ ១៣៥៧ (កងកម្លាំងភូមិភាគឧត្តរ, ភូមិភាគនិរតី, ភូមិភាគបូព៌ា និងភូមិភាគពិសេស, ក្នុងចំណោមភូមិភាគទាំងនោះដែលបាន "រំដោះ" ទីក្រុងភ្នំពេញ។

សាលាដំបូងយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានបង្កើតលក្ខខណ្ឌជាប្រព័ន្ធ និងដោយចេតនាលើប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ ពីប៉ែកទក្សិណនៃប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ដែលទំនងនាំឲ្យមានការស្លាប់ក្នុងចំនួនច្រើន។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីបទការសម្លាប់រង្គាលនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ពីប៉ែកទក្សិណនៃប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ។

### ១១.៦.៥ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៦៤៩. អំពើជាក់លាក់មួយចំនួនដែលអាចត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញបាន ទាល់តែមានការចោទប្រកាន់ច្បាស់លាស់[២០៤២]។ នៅក្នុងការកំណត់ ថាតើលក្ខខណ្ឌតម្រូវនេះបានបំពេញដែរឬទេ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវពិនិត្យមើលសំអាងហេតុ និងសំអាងច្បាប់នៅក្នុងផ្នែកទាំងនោះនៃដីកាដំណោះស្រាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ និងដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)[២០៤៣]។

៦៥០. យោងតាមដីកាដំណោះស្រាយ ខ្មែរក្រហមបានប្រព្រឹត្តការធ្វើទុក្ខបុកម្នេញតាមវិធីជាច្រើនដូចជា៖ ការប្រឆាំងនឹងមន្ត្រីយោធាជាន់ខ្ពស់ និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយពួកគេត្រូវបានផាត់ចេញដោយស្វ័យប្រវត្តិពីគោលបំណងនៃការកសាងលទ្ធិសង្គមនិយម ការប្រឆាំងនឹងមន្ត្រីថ្នាក់ទាបដែលត្រូវបានចាប់ខ្លួន ហើយជាញឹកញាប់ ត្រូវបានសម្លាប់ និងការប្រឆាំងនឹង "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ដោយពួកគេត្រូវរងការប្រព្រឹត្តិមកលើតឹងរ៉ឹងជាងប្រជាជនផ្សេងទៀត ក្នុងគោលបំណងដើម្បីអប់រំកែប្រែពួកគេ។ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ខ្មាំងពិតប្រាកដ និងអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំង បានរងការប្រព្រឹត្តិមកលើតឹងរ៉ឹង

---

[២០៤២] *សូមមើល*ផ្នែកទី៩, ច្បាប់ជាធរមាន: ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ៤៣១។

[២០៤៣] ជារួម អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាទៅលើក្របខណ្ឌនៃការចោទប្រកាន់ទាំងមូលនៅពេលកំណត់ថាតើវាគ្រប់គ្រាន់សម្រាប់ការអះអាង និងការកំណត់បទចោទតាមផ្លូវច្បាប់លើអង្គហេតុទាំងនោះដែរឬទេ។ (សាលដីកា *Seromba* កថាខណ្ឌ ២៧; សាលដីកា *Gacumbitsi* កថាខណ្ឌ ១២៣)។

ជាង និងលក្ខខណ្ឌរស់នៅលំបាកវេទនាជាងប្រជាជនផ្សេងទៀត ក្នុងគោលបំណងដើម្បីអប់រំកែប្រែពួកគេ ឬ កំណត់អត្តសញ្ញាណខ្មាំងក្នុងចំណោមក្រុមគោលដៅផ្សេងៗ[២០៤៤]។

៦៥១. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) គ្មានការយោងជាក់លាក់ណាមួយនៅក្នុងផ្នែកសំអាងហេតុដែលពាក់ព័ន្ធក្នុងដីកាដំណោះស្រាយដែលថា អ្នករដ្ឋការថ្នាក់ខ្ពស់ និងថ្នាក់ទាបនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានចាត់ទុកជាក្រុមដោយឡែកដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញឡើយ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយពុំត្រូវបានចោទប្រកាន់ប្រឆាំងនឹងក្រុមទាំងនេះទេ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) នោះ។

៦៥២. ដីកាដំណោះស្រាយចោទប្រកាន់ថា នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាចប្រជាជនទាំងអស់ដែលស្ថិតនៅតាមទីប្រជុំជន រួមទាំងប្រជាជនទាំងឡាយដែលជាប់ពាក់ព័ន្ធ ឬ ជាប់ទាក់ទងទៅនឹងរបបសាធារណរដ្ឋខ្មែរ ត្រូវបានចាត់ទុកថាជា “ប្រជាជនថ្មី” និងរងការប្រព្រឹត្តិមកលើតឹងរ៉ឹងជាង “ប្រជាជនចាស់”[២០៤៥]។ នៅក្នុងផ្នែកពាក់ព័ន្ធនៃដីកាដំណោះស្រាយពុំបានបែងចែក រវាងការប្រព្រឹត្តិមកលើប្រជាជនទាំងឡាយដែលជាប់ទាក់ទងទៅនឹងរបបសាធារណរដ្ឋខ្មែរ និងប្រភេទ “ប្រជាជនថ្មី” នោះឡើយ[២០៤៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានតែការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹង “ប្រជាជនថ្មី” ដែលជាក្រុមមួយរួមបញ្ចូលទាំងប្រជាជនទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះ ដែលត្រូវបានចោទប្រកាន់ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ។ ផ្អែកតាមការអានដីកាដំណោះស្រាយទាំងមូល អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ការ

---

[២០៤៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧ -១៤១៨។

[២០៤៥] *សូមមើល ឧ.* ដីកាដំណោះស្រាយ កថាខណ្ឌ ២២៧ (ប្រជាជនដែលមកពីក្រុងភ្នំពេញត្រូវបានផ្តល់អត្តសញ្ញាណថាជា “ប្រជាជនថ្មី”, ១៤១៧ (ប្រជាជនទាំងអស់ដែលស្ថិតនៅតាមទីប្រជុំជន នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ត្រូវបានចាត់ទុកជា “ប្រជាជនថ្មី”)។

[២០៤៦] ដីកាដំណោះស្រាយ កថាខណ្ឌ ២៦៥ (“ប្រជាជនថ្មី” និងប្រជាជនទាំងឡាយណាដែលមានជាប់ទាក់ទងទៅនឹងរបប លន់ នល់ ត្រូវបានផ្លាស់ទីលំនៅ, កថាខណ្ឌ ១៤៦៨ (សំដៅលើការកំណត់គោលដៅ ក្នុងគោលបំណងនៃការជម្លៀសដោយបង្ខំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ចំពោះប្រជាជនទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា “អ្នកដែលល្មើស ឬ អាចនឹងល្មើស” ទៅនឹងគោលនយោបាយនៃផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា រួមបញ្ចូលទាំង “ប្រជាជនថ្មី” និងអ្នកដែលមានការពាក់ព័ន្ធនឹងរបប លន់ នល់)។

ប្រព្រឹត្តិមកលើ "ប្រជាជនថ្មី" ដែលបានចោទប្រកាន់ថាបានធ្វើឡើងដោយតឹងរ៉ឹងជាងប្រជាជនផ្សេងទៀត តាមរយៈការអប់រំកែប្រែនោះ ជាពិសេស ត្រូវបានអនុវត្តក្រោមរូបភាពនៃការជម្លៀសដោយបង្ខំ[២០៤៧] និងការបាត់ខ្លួនដោយបង្ខំ[២០៤៨]។

៦៥៣. បក្សបានកំណត់អត្តសញ្ញាណ "ប្រជាជនថ្មី" ថាជាក្រុមមួយដែលមានទំនាស់ផ្នែកនយោបាយ និងផ្នែកសង្គមជាមួយនឹងបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា[២០៤៩] ។ ដូច្នេះ "ប្រជាជនថ្មី" ត្រូវបានកំណត់ដោយគោលនយោបាយបក្សថាជាគោលដៅសម្រាប់អប់រំកែប្រែ[២០៥០]។ គោលនយោបាយនេះត្រូវបានផ្សព្វផ្សាយនៅគ្រប់ជួរបក្ស រួមទាំង ក្នុងចំណោមកងទ័ពខ្មែរក្រហមសាមញ្ញផងដែរ[២០៥១]។ កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យគ្រប់គ្រង "ប្រជាជនថ្មី" និង "ប្រជាជនចាស់" ដាច់ដោយឡែកពីគ្នា[២០៥២]។ តាមពិតទៅ នៅក្នុងដំណាក់កាលផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានសួរប្រជាជនអំពី

---

[២០៤៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១ (ជាទូទៅ ការផ្លាស់ទីលំនៅរបស់ប្រជាជនត្រូវបានធ្វើឡើងក្នុងគោលបំណងជាច្រើន ក្នុងនោះ គឺ ដើម្បីដកហូតសិទ្ធិគោលនយោបាយ និងសេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងដើម្បីប្រែក្លាយពួកគេឲ្យទៅជាកសិករ) ២៦៥ ("ប្រជាជនថ្មី" និងប្រជាជនទាំងឡាយណាដែលមានជាប់ទាក់ទងទៅនឹងរបប លន់ នល់ ត្រូវបានផ្លាស់ទីលំនៅ។ សាក្សីមួយចំនួនបានលើកឡើងថា មានតែ "ប្រជាជនថ្មី" តែប៉ុណ្ណោះ ដែលត្រូវបានផ្លាស់ទីលំនៅ) ៩០១ (នួន ជា បានដឹងអំពីភាពចាំបាច់ត្រូវផ្លាស់ទីលំនៅប្រជាជនថ្មី) ១៣៦៨ (គោលបំណងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) គឺសំដៅលើ "ប្រជាជនថ្មី") ១៤៦៨ (សំដៅលើការកំណត់គោលដៅក្នុងគោលបំណងនៃការជម្លៀសដោយបង្ខំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ចំពោះប្រជាជនទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា "អ្នកដែលល្មើស ឬ អាចនឹងល្មើស" ទៅនឹងគោលនយោបាយនៃផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា រួមបញ្ចូលទាំង "ប្រជាជនថ្មី" និងអ្នកដែលមានការពាក់ព័ន្ធនឹងរបប នល់ នល់) ១៥២៥ (i) (គោលនយោបាយពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនជាច្រើនដង រួមទាំងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដើម្បីជាមធ្យោបាយនៃការអនុវត្ត)។

[២០៤៨] ដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤ (កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានកត់ប្រវត្តិរូបប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ ក្រោយមក មានប្រជាជនខ្លះ ត្រូវបានបញ្ជូនទៅរៀនសូត្រ) ២៧០ (ដែលបានលើកឡើងថា ប្រជាជនមួយចំនួនបានបាត់ខ្លួននៅអំឡុងនៃការផ្លាស់ទីលំនៅនេះ ហើយយោងតាមភ័ស្តុតាងខ្លះបានបង្ហាញថា អ្នកដែលមិនព្រមចាកចេញត្រូវបានបញ្ជូនទៅរៀនសូត្រ ហើយមិនដែលវិលត្រឡប់មកវិញនោះទេ)។

[២០៤៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៦, ៦២១។

[២០៥០] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៦, ៦២១។

[២០៥១] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២០៥២] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២១-៦២២។

ប្រវត្តិរូបរបស់ពួកគេ ដើម្បីផ្ទៀងផ្ទាត់មើលថាតើប្រជាជនទាំងនេះអាចចាត់ទុកថាជា "ប្រជាជនថ្មី" ដែរឬទេ[២០៥៣]។ ដោយសារតែក្រុមនេះ ត្រូវបានកំណត់អត្តសញ្ញាណទៅតាមលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់ដោយថ្នាក់ដឹកនាំខ្មែរក្រហម ហើយប្រវត្តិរូបរបស់ក្រុមនេះ អាចផ្ទៀងផ្ទាត់បានដូចបានបង្ហាញតាមរយៈការសួរសំណួរដោយកងទ័ពខ្មែរក្រហម ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា "ប្រជាជនថ្មី" គឺជាក្រុមដែលត្រូវបានកំណត់ជាគោលដៅជាក់ច្បាស់មួយ។

៦៥៤. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញពីខាងដើមថា អំពើអមនុស្សធម៌ផ្សេងទៀតដែលរួមមានការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ពិតជាបានកើតឡើងជាប់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)[២០៥៤]។ នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណា ថាតើឧក្រិដ្ឋកម្មទាំងនេះមានធាតុរើសអើង និងត្រូវបានប្រព្រឹត្តដោយមានចេតនារើសអើងដែរឬទេ។

៦៥៥. ក្រោយពីបានពិនិត្យមើលទៅលើការអនុវត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅតាមទីតាំងជាច្រើន មានតែ "ប្រជាជនថ្មី" ទេដែលត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅ[២០៥៥] ចំណែកនៅតាមទីតាំងខ្លះទៀត ទាំង "ប្រជាជនចាស់" ទាំង "ប្រជាជនថ្មី" ត្រូវបានផ្លាស់ទីលំនៅតែម្តង ។ ការផ្លាស់ទីលំនៅ ទាំង "ប្រជាជនចាស់" និងទាំង "ប្រជាជនថ្មី" នេះ បានកើតឡើងដោយសារហេតុផលជាក់លាក់ គឺដោយសារការមិនទុកចិត្តចំពោះប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិភាគបូព៌ា នៅតាមបណ្តោយព្រំដែនជាប់ប្រទេសវៀតណាម ឬ ដោយសារការជំរុញរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្រេចគោលដៅសម្រាប់ការបង្កបង្កើនផលរបស់ពួកគេ[២០៥៦] ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅមុនពេល ឬ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានសួរប្រជាជនអំពីប្រវត្តិរូបរបស់ពួកគេ ដើម្បីកំណត់អត្តសញ្ញាណ "ប្រជាជនថ្មី" ។ ជាញឹកញាប់ ការសួរសំណួរនេះ ត្រូវបានធ្វើឡើងដើម្បីកំណត់ទីតាំងដែលត្រូវបញ្ជូនប្រជាជនទាំង

---

[២០៥៣] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០០, ៦១៧។

[២០៥៤] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣០-៦៤៣។

[២០៥៥] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៨, ៦១៧-៦១៩, ៦២២-៦២៣។

[២០៥៦] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៨, ៦០២-៦០៦, ៦១០, ៦២៤-៦២៥។

នេះទៅ រួមទាំង ព្រៃដែលប្រជាជនទាំងនោះត្រូវទៅកាប់ឆ្ការ និងសង់ទីជម្រករបស់ពួកគេផង ដែរ[២០៥៧]។ "ប្រជាជនថ្មី" ផ្សេងទៀតត្រូវបានយកទៅកសាង ឬ អប់រំកែប្រែនៅតាមមន្ទីរសន្តិសុខ នានា[២០៥៨]។ ក្រោយពេលដែល "ប្រជាជនថ្មី" ខ្លះត្រូវបានកំណត់អត្តសញ្ញាណនៅតាមសហករណ៍ ឬ ការដ្ឋានធ្វើការងារនានារួចមក ប្រជាជនទាំងនោះត្រូវបានផ្លាស់ទីលំនៅ ហើយបានបាត់ខ្លួន តែម្តង[២០៥៩]។

៦៥៦. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា កងទ័ព និងកម្មាភិបាលខ្មែរក្រហមមាន ចេតនារើសអើងប្រឆាំងនឹង "ប្រជាជនថ្មី" ដោយមូលហេតុនយោបាយ ដោយបានធ្វើការផ្លាស់ ទីលំនៅដោយបង្ខំ ជាពិសេសចំពោះ "ប្រជាជនថ្មី" មកពីតាមទីតាំងមួយចំនួននៅប៉ែកទក្សិណនៃ ប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តព្រះវិហារ (តំបន់ ១០៣) និងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) ព្រមទាំង ខេត្តក្រចេះ (តំបន់ ៥០៥) នៅក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម(ភូមិភាគ (ឧត្តរចាស់) កណ្តាល) មកពី និងនៅក្នុង ខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)។ អង្គជំនុំជម្រះសាលាដំបូងក៏ជឿជាក់ផងដែរថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម មានចេតនា រើសអើងប្រឆាំងនឹង "ប្រជាជនថ្មី" ដោយមូលហេតុនយោបាយ ដោយបានធ្វើការដកហូតសេរី ភាពពួកគេ ហើយបានបដិសេធមិនផ្តល់ព័ត៌មានពាក់ព័ន្ធនឹងទីកន្លែងរបស់ពួកគេ (ការបាត់ខ្លួនដោយ បង្ខំ) នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅមកពីតាមទីតាំងមួយចំនួននៅប៉ែកទក្សិណនៃប្រទេស កម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តព្រះវិហារ (តំបន់១០៣) និងខេត្តកំពង់ធំ (ភូមិភាគ (ឧត្តរចាស់) កណ្តាល) ព្រមទាំង ខេត្តក្រចេះ (តំបន់ ៥០៥) នៅក្នុងខេត្ត កំពង់ធំ និងខេត្តកំពង់ចាម (ភូមិភាគ (ឧត្តរចាស់) កណ្តាល) មកពី និងនៅក្នុងខេត្តស្វាយរៀង និង ខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងនៅក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)។

៦៥៧. ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំទាំងនេះ បានរំលោភលើសិទ្ធិ និងសេរីភាព ជាសារវ័ន្តដែលពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅ[២០៦០] ទ្រព្យសម្បត្តិ[២០៦១] គ្រួសារ[២០៦២] ជីវិត[២០៦៣] និង

---

[២០៥៧] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០០-៦០១, ៦១៧។

[២០៥៨] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៤, ៦១៧-៦១៩, ៦២២-៦២៣។

[២០៥៩] *សូមមើល*ផ្នែកទី១១, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៤, ៦១៨, ៦២៣។

[២០៦០] អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ៤៩។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៣។ អនុសញ្ញាស្តីពីការរើសអើងពូជសាសន៍ មាត្រា ៥(ឃ)(i)។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១២(១)។

សេចក្តីថ្លៃថ្នូរបស់មនុស្ស[២០៦៤]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អំពើអមនុស្សធម៌ផ្សេងទៀតទាំងនេះដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានឈានទៅដល់កម្រិតធ្ងន់ធ្ងរដែលអាចចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញបាន។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា យោងតាមអង្គហេតុ កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានរើសអើងដោយចេតនាប្រឆាំងនឹង “ប្រជាជនថ្មី” ដោយមូលហេតុនយោបាយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើអមនុស្សធម៌ផ្សេងៗនៃការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ។

## ១២ ទួលពោធិ៍ជ្រៃ

៦៥៨. ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[២០៦៥] ដីកាដំណោះស្រាយបានចោទប្រកាន់ថា ចាប់តាំងពីចុងខែ មេសា ឆ្នាំ ១៩៧៥ មក ទួលពោធិ៍ជ្រៃត្រូវបានប្រើប្រាស់ជាកន្លែងសម្លាប់មនុស្ស ដែលនៅទី

---

ពិធីសារលេខ ៤ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ២។ អនុសញ្ញាសិទ្ធិមនុស្សអាមេរិក មាត្រា ២២(៥)។ *សូមមើលផងដែរ* សាលដីកា *Stakić* កថាខណ្ឌ ៣១៧។

[២០៦១] អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ៣៣, ៥៣, ៩៧-៩៨, ១១៤។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៧(២)។ អនុសញ្ញាស្តីពីការរើសអើងពូជសាសន៍ មាត្រា ៥(ឃ)(v)។ ពិធីសារលេខ ១ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ១។ អនុសញ្ញាសិទ្ធិមនុស្សអាមេរិក មាត្រា ២១។ *សូមមើលផងដែរ* សាលដីកា *Blaškić* កថាខណ្ឌ ១៤៥។

[២០៦២] អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ២៧ ៤៩ ៨២។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១២, ១៦។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៧, ២៣។ អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៨, ១២។ អនុសញ្ញាសិទ្ធិមនុស្សអាមេរិក មាត្រា ១៧។

[២០៦៣] អនុសញ្ញាទីក្រុងហ្សឺណែវ (IV)មាត្រា ៣(១)(ក)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៣(១)(ក)។ អនុសញ្ញាស្តីពីការរើសអើងពូជសាសន៍ មាត្រា ៥(ខ)។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦។ អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ២។ អនុសញ្ញាសិទ្ធិមនុស្សអាមេរិក មាត្រា ៤។ *សូមមើលផងដែរ* សាលក្រម *Kordić* និង *Čerkez* កថាខណ្ឌ ១០៦។

[២០៦៤] អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ៣(១)(គ)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១, ២២, ២៣(៣)។ អនុសញ្ញាស្តីពីការរើសអើងពូជសាសន៍ មាត្រា ៥ ។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧, ១០។ អនុសញ្ញាសិទ្ធិមនុស្សអាមេរិក មាត្រា ៥-៦។ *សូមមើលផងដែរ* សាលក្រម *Kordić* និង *Čerkez* កថាខណ្ឌ ១០៦។

[2065] អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានតែការសម្លាប់ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ដែលបានកើតឡើងភ្លាមៗបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះនឹងមិនវិនិច្ឆ័យទៅលើការសម្លាប់ ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ នៅឆ្នាំបន្ទាប់ៗមកទៀត។

នោះមានការសម្លាប់អតីតទាហាន និងប្រជាជនស៊ីវិលក្នុងទ្រង់ទ្រាយធំ។ ទីតាំងនេះត្រូវបានគេរៀបរាប់ថា រាប់បញ្ចូលទាំងបន្ទាយរបស់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ (ហៅថា បន្ទាយភូមិពោធិ៍) និងបឹងមួយដែលគេបានបោះសាកសពចូលទៅក្នុងនោះ។ ទួលពោធិ៍ជ្រៃមានទីតាំងស្ថិតនៅក្នុងស្រុកកណ្តៀង តំបន់ ៧ នៃភូមិភាគពាយ័ព្យ[២០៦៦]។

៦៥៩. យោងតាមដីកាដំណោះស្រាយ ក្នុងរយៈពេលប៉ុន្មានថ្ងៃ ក្រោយពីខេត្តពោធិ៍សាត់ត្រូវបានកាន់កាប់ដោយកងទ័ពភូមិភាគពាយ័ព្យនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ មក អភិបាលខេត្តពោធិ៍សាត់ ទាហាន និងមន្ត្រីរដ្ឋការនៃអតីតរបប លន់ នល់ ត្រូវបានកោះហៅឲ្យទៅចូលរួមប្រជុំនៅសាលាខេត្តពោធិ៍សាត់។ មេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលជាគណៈភូមិភាគពាយ័ព្យ គណៈតំបន់ ៧ និងគណៈស្រុកកណ្តៀង ក៏បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ។ មន្ត្រីរដ្ឋការនៃអតីតរបប លន់ នល់ ដែលមានវត្តមាននៅទីនោះប្រហែលជា ៣.០០០ នាក់ ត្រូវបានគេប្រាប់ថាឲ្យទៅរៀនសូត្រដើម្បីធ្វើសមាហរណកម្ម ចូលទៅក្នុងរចនាសម្ព័ន្ធកងទ័ពថ្មី។ ដោយយល់ឃើញបែបនេះ ក្រោយពេលប្រជុំចប់ អ្នកចូលរួមប្រជុំក៏បានឡើងជិះឡានដោយស្ម័គ្រចិត្ត ហើយត្រូវដឹកទៅកាន់ទួលពោធិ៍ជ្រៃ និងត្រូវបានសម្លាប់ចោលនៅទីនោះ។ ការសម្លាប់នេះត្រូវបានអនុវត្តតាមបញ្ជារបស់ តា ញឹម[២០៦៧] និង តា សុត[២០៦៨] ដែលបញ្ជាថា “ពួកទាហាន និងប៉ូលីសជំនាន់ លន់ នល់ ឲ្យតែអ្នកណាមានពាក់ស័ក្តិ” ត្រូវតែយកទៅសម្លាប់ចោលទាំងអស់[២០៦៩]។

---

*សូមមើល* សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿង ០០២/០១ (E163) ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ៣។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ១១៧។

[២០៦៦] ដីកាដំណោះស្រាយ កថាខណ្ឌ ៦៩៨-៧០០, ៧០៤។

[២០៦៧] *សូមមើល*ផ្នែកទី៥, រចនាសម្ព័ន្ធរដ្ឋបាល, កថាខណ្ឌ ២១៩ ( តា ញឹម)។

[២០៦៨] យោងតាមដីកាដំណោះស្រាយ តា សុត ដែលជាលេខាតំបន់ ៧ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៧។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំង ឆាត់ ឯកសារ E3/4598, E3/5774 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣, ERN (ជាភាសាខ្មែរ) 00277329 (បញ្ជាក់អត្តសញ្ញាណថា តា សុត លេខាតំបន់ ៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00407760 (តំបន់ ៧ គណៈតំបន់ឈ្មោះ តា សុត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/5723 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00699626 (តា សុត លេខាតំបន់ ៧ រហូតដល់ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃការស្តាប់ចម្លើយ

៦៦០. សាក្សីចំនួន៣នាក់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះអំពីព្រឹត្តិការណ៍នេះ។ សាក្សី លឹម សាត ដែលជាអនុបញ្ជាការកងអនុសេនាតូចនៃកងទ័ពខ្មែរក្រហម បានចូលរួមនៅក្នុងការប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ នៅក្នុងខេត្តពោធិ៍សាត់។ សាក្សី ស៊ុម អាឡាត់ ដែលជាទាហាន លន់ នល់ ត្រូវបានគេដាក់ឱ្យយាមប្រចាំការនៅសមរភូមិស្វាយដូនកែវ នៅពេលដែលកម្លាំង លន់ នល់ បានចុះចាញ់ ហើយសាក្សី អ៊ុំង ឆាត់ ដែលធ្វើជាកងទ័ពខ្មែរក្រហម ត្រូវបានគេឱ្យយាមប្រចាំការនៅច្រកទ្វារចូលទៅកាន់សាលាខេត្តពោធិ៍សាត់ ក្នុងអំឡុងពេលប៉ុន្មានថ្ងៃ បន្ទាប់ពីកងទ័ពខ្មែរក្រហមបានកាន់កាប់ខេត្តពោធិ៍សាត់[២០៧០]។

## ១២.១ ការបរាជ័យនៅខេត្តពោធិ៍សាត់ និងកិច្ចប្រជុំរបស់គណៈភូមិភាគ

៦៦១. ក្នុងរយៈពេល៣ ទៅ ៤ឆ្នាំ កងកម្លាំងខ្មែរក្រហមដែលស្ថិតនៅក្រោមបញ្ជារបស់ តា ខ្លែង មេបញ្ជាការកងទ័ពភូមិភាគពាយ័ព្យ បានចូលរួមនៅក្នុងការវាយប្រយុទ្ធដណ្តើមខេត្តពោធិ៍សាត់ពីពួកទាហាន លន់ នល់[២០៧១] ដែលដឹកនាំដោយមេបញ្ជាការឈ្មោះ ប៊ុល និងអនុបញ្ជាការឈ្មោះ រុន[២០៧២]។ នៅពេលនោះ មានបន្ទាយទាហាន លន់ នល់ ជាច្រើននៅទូទាំងខេត្តពោធិ៍សាត់ ដែលនៅ

---

សាក្សី ស៊ុយ សេងឈន ឯកសារ E3/4638 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ២ (ជាភាសាខ្មែរ) 00196819 (តា សុត ជាប្រធានគណៈតំបន់ដំបូង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ជាភាសាខ្មែរ) 00196814 (លេខាតំបន់ឈ្មោះ តា សុត)។

[២០៦៩] ដីកាដំណោះស្រាយ កថាខណ្ឌ ៧០២, ៧០៥-៧១១។

[២០៧០] លឹម សាត បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី ០២ និងថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣។ ស៊ុម អាឡាត់ បានផ្តល់សក្ខីកម្មនៅថ្ងៃទី ០៣ និងថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣ និង អ៊ុំង ឆាត់ បានផ្តល់សក្ខីកម្មនៅថ្ងៃទី ២៩ និងថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣។

[២០៧១] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៦-៨, ១០-១១, ៧០។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៣-៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៣៦-៤០។

[២០៧២] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១១-១២, ៧២-៧៣។ ទោះបីជា លឹម សាត ដែលជាទាហាន លន់ នល់ ម្នាក់ មិនបានដឹងថា មេបញ្ជាការឈ្មោះ ប៊ុល និងអនុបញ្ជាការឈ្មោះ រុន ជាអ្នកណាក៏ដោយ ក៏អង្គជំនុំជម្រះទទួលយកការពន្យល់របស់គាត់ថា គាត់ត្រូវបានគេដាក់ឱ្យឈរជើងប្រចាំការនៅសមរភូមិស្វាយដូនកែវ ជិតព្រំប្រទល់រវាងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ ហេតុដូច្នេះ គាត់មិនចាំបាច់ត្រូវស្គាល់ថា មេបញ្ជាការនៅទួលពោធិ៍ជ្រៃជាអ្នកណាខ្លះនោះទេ។ ប្រតិចារឹក ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៥៣-៥៥។ ទាក់ទងនឹងការប្រកបឈ្មោះរបស់អនុបញ្ជាការរូបនេះ អង្គជំនុំជម្រះសំអាងទៅលើប្រតិចារឹកជា

ទីនោះមានទាហាន លន់ នល់ ប្រចាំការ[២០៧៣]។ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អនុបញ្ជាការកងទ័ពខ្មែរក្រហមឈ្មោះ លឹម សាត និងកម្លាំងរបស់គាត់ ក៏បានឈរជើងប្រចាំការនៅក្នុងតំបន់នេះដែរ និងបានចូលរួមក្នុងការវាយប្រយុទ្ធនៅបន្ទាយទួលពោធិ៍ជ្រៃ[២០៧៤]។ ទួលពោធិ៍ជ្រៃជាទីកន្លែងដែលទាហាន លន់ នល់ ប្រមាណពី ៣០ ទៅ ២០០ នាក់ ត្រូវបានដាក់ឲ្យប្រចាំការនៅទីនោះ គឺជាសមរភូមិវាយប្រយុទ្ធគ្នាមួយរវាងកងកម្លាំងបដិបក្ស[២០៧៥]។

៦៦២. ទោះបីជាថ្ងៃរំដោះរបស់ខ្មែរក្រហមមានភាពមិនច្បាស់លាស់ក៏ដោយ ក៏ខ្មែរក្រហមបានកាន់កាប់ និងគ្រប់គ្រងខេត្តពោធិ៍សាត់ បន្ទាប់ពីបានរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥[២០៧៦]។ នៅក្នុងការផ្សាយតាមវិទ្យុកាលពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពីទីក្រុងភ្នំពេញ ហើយដែលគេបានស្តាប់ឮនៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជានោះ ឧត្តមសេនីយ៍ ម៉ី ស៊ីចន តំណាងទាហាន លន់ នល់ បានអំពាវនាវដល់ទាហាន លន់ នល់ នៅទូទាំងប្រទេសឲ្យចុះចាញ់[២០៧៧]។

---

ភាសាខ្មែរចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ជាភាសាដែលសាក្សី លឹម សាត បានផ្តល់សក្ខីកម្ម។ ប្រតិចារឹកសវនាការជាភាសាខ្មែរបានសរសេរឈ្មោះអនុបញ្ជាការថា រុន មិនមែនឈ្មោះ រុម (Rum) ដូចសរសេរនៅក្នុងប្រតិចារឹកជាភាសាអង់គ្លេសនោះទេ ឬ រូន (Roun) ដូចសរសេរនៅក្នុងប្រតិចារឹកជាភាសាបារាំង។

[២០៧៣] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៧១-៧៣។

[២០៧៤] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៥៥, ៧០-៧១។

[២០៧៥] ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១៨-២០ ។ (របប លន់ នល់ មានមូលដ្ឋានកងទ័ពមួយកន្លែងនៅជិតទួលពោធិ៍ជ្រៃ ដែលមានទាហានបីក្រុមដែលមានគ្នាចំនួនពី ៣០-៤០ នាក់)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៧០-៧២។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ២-៣ (ប៉ាន់ប្រមាណថា មានទាហាន លន់ នល់ ចំនួនប្រហែល ១០០ នាក់)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៤១-៤២ (ប៉ាន់ប្រមាណថា អាចមានទាហាន លន់ នល់ ចំនួនប្រហែល ២០០ នាក់)។

[២០៧៦] ប្រតិចារឹក ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១០-១១។ ប្រតិចារឹក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត), ទំព័រ ២ (បញ្ជាក់ថា ថ្ងៃរំដោះនេះបានកើតមានឡើងនៅប្រហែលជាម៉ោង ១១:០០ ព្រឹក នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្រោយពីការប្រយុទ្ធគ្នាអស់រយៈពេលពី៣ទៅ៤ឆ្នាំមក)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់), ទំព័រ ៣៣-៣៥ (ថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដូចភ្នំពេញដែរ)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៥៦-៥៧ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំង ឆាត់ ឯកសារ E3/4598 និង E3/5774 ដែលលើកឡើងថា ថ្ងៃរំដោះគឺថ្ងៃទី ១៩ មេសា ១៩៧៥)។

[២០៧៧] *ឧត្តមសេនីយ៍របស់រដ្ឋាភិបាលអញ្ជើញប្រតិភូរបស់ភាគីម្ខាងទៀតឲ្យចូលមកកាន់ទីក្រុងភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ជាភាសាខ្មែរ)

បន្ទាប់ពីការផ្សព្វផ្សាយនេះ ទាហាន លន់ នល់ នៅក្នុងអង្គភាពរបស់ ស៊ុម អាឡាត់ នៅបន្ទាយស្វាយដូនកែវ នៅតាមព្រំប្រទល់រវាងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង បានលើកទង់ស ទម្លាក់អាវុធចុះ និងបានចូលរួមជាមួយខ្មែរក្រហមនៅក្នុងពិធីអបអរសាទរមួយ[២០៧៨]។ យោងតាមសម្ដីរបស់សាក្សី ស៊ុម អាឡាត់ គាត់ផ្ទាល់បានឃើញទាហាន លន់ នល់ នៅបន្ទាយពោធិ៍ជ្រៃចុះចាញ់ដោយលើកទង់សនៅគ្រប់បន្ទាយទាំងអស់ ហើយក្រោយមក ខ្មែរក្រហមបានប្រមូលអាវុធពីទាហានទាំងនោះ[២០៧៩] ។ ទាហាន លន់ នល់ នៅបន្ទាយនោះមិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីបន្ទាយទេ ហើយបានបន្តនៅទីនោះនៅក្នុងឯកសណ្ឋានទាហានរបស់ពួកគេដដែល[២០៨០]។

៦៦៣. សាក្សី លឹម សាត បានបញ្ជាក់ថាសមាជិកគណៈភូមិភាគ និងគណៈតំបន់របស់ខ្មែរក្រហមបានបើកការប្រជុំផ្ទៃក្នុងមួយ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃ បន្ទាប់ពីបានកាន់កាប់ខេត្តពោធិ៍សាត់រួចមក[២០៨១] ដោយនៅក្នុងកិច្ចប្រជុំនោះ តា ញឹម តា កន ដែលជាលេខា និងជាអនុលេខាគណៈភូមិភាគ និង តា សុត ដែលជាលេខាគណៈតំបន់[២០៨២] បានចេញបញ្ជាដល់មេបញ្ជាការកងទ័ព

---

00909156។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (សាក្សី ហ៊ុន ឈុនលី) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២ (សាក្សី ហ៊ុន ឈុនលី) ទំព័រ ៣០។ ប្រតិចារឹក ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១២ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៥។

[២០៧៨] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៥-៦, ៧-៨, ៤៩-៥១។

[២០៧៩] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ២-៤។

[២០៨០] ប្រតិចារឹក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ២-៥, ១៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១៣(សាក្សី ស៊ុម អាឡាត់) ទំព័រ ៥៣-៥៤ (នៅចន្លោះពីពេលដែលខ្មែរក្រហមចូលកាន់កាប់ និងពេលប្រជុំនៅសាលាខេត្តលើកដំបូង ទាហាន លន់ នល់ ស្ថិតនៅក្នុងកន្លែងរបស់ពួកគេដដែល ដើម្បីរង់ចាំទទួលបញ្ជា)។

[២០៨១] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៧-១៨, ៣៩-៤០។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00242422 (ប្រហែលជានៅថ្ងៃទី ១៩ ឬថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00407760 (រយៈពេលពី៤ទៅ៥ថ្ងៃ ក្រោយពីការរំដោះទីក្រុងភ្នំពេញរួចមក)។

[២០៨២] ពាក់ព័ន្ធជាមួយ តា ញឹម *សូមមើល*ផ្នែកទី៥, រចនាសម្ព័ន្ធរដ្ឋបាល, កថាខណ្ឌ ២១៩។ ពាក់ព័ន្ធជាមួយ តា កន *សូមមើល* ប្រតិចារឹក ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០១៣ (សាក្សី លឹម សាត) ទំព័រ ៦៧ (តា កន មកពីគណៈភូមិភាគ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២

ខ្មែរក្រហមថា ពួកទាហាន និងប៉ូលីសមកពីរបប លន់ នល់ ត្រូវ “ប្រមូលដាក់ម៉ុំ” និង “សម្លាប់ចោល”[២០៨៣]។ ទោះបីជា លឹម សាត មិនបានចូលរួមនៅក្នុងកិច្ចប្រជុំនោះក៏ដោយ ក៏ក្រោយពីកិច្ចប្រជុំនោះបញ្ចប់ភ្លាម គាត់បានទទួលបញ្ជាពីមេបញ្ជាការកងវរៈសេនាធំនៃកងទ័ពបដិវត្តន៍កម្ពុជាម្នាក់ឈ្មោះ ហួន[២០៨៤]។

៦៦៤. យោងតាមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត បញ្ជាទាំងនេះគឺឲ្យប្រមូលផ្តុំមន្ត្រីរដ្ឋការ លន់ នល់ រួចហើយសម្លាប់ចោលទាំងអស់[២០៨៥]។ ប៉ុន្តែ ក្រោយមក នៅក្នុងសវនាការសាក្សីរូបនេះបានឆ្លើយបញ្ជាក់ថា គាត់មិនបានដឹងថា មន្ត្រីរដ្ឋការសម័យ លន់ នល់ ទាំងនោះត្រូវ

---

ERN (ជាភាសាខ្មែរ) 00407760 (កំណត់អត្តសញ្ញាណ តា កន ថាជាអនុប្រធានគណៈភូមិភាគ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ឯកសារ E3/394 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៩ ទំព័រ ៧, ERN (ជាភាសាខ្មែរ)00398226 (កំណត់អត្តសញ្ញាណ តា កឺ ថាជា គង់ សុផល ដែលជាអនុលេខាភូមិភាគពាយ័ព្យ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារលេខ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00242422 (តា កន គឺជា “គណៈភូមិភាគ”)។

[២០៨៣] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៤-១៥ (ដែលកំណត់អត្តសញ្ញាណ តា ញឹម និង តា កន) ទំព័រ ៣៩-៤០ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ទំព័រ៣-៤, ERN(ជាភាសាខ្មែរ)00407761-00407762 ដែលកំណត់អត្តសញ្ញាណ តា ញឹម និងតា សុត)។ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥-១៦ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ដែលលើកឡើងពីការណែនាំឲ្យប្រមូលផ្តុំ និងសម្លាប់ចោល), ទំព័រ ១៧-១៨ (ពាក់ព័ន្ធតែនឹងការណែនាំឲ្យប្រមូលផ្តុំប៉ុណ្ណោះ)។

[២០៨៤] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៨-២០, ៣៩-៤០ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥-១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00242422។

[២០៨៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00242422 (“ខ្ញុំបានទទួលបញ្ជាឲ្យប្រមូលផ្តុំទាហាន និងប៉ូលីសដែលមានបណ្តាស័ក្តិទាំងតូចទាំងធំ ដែលមាននិន្នាការសម័យ លន់ នល់ យកទៅសម្លាប់ចោលនៅបន្ទាយពោធិ៍ជ្រៃ ក្នុងស្រុកកណ្តៀង”)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារលេខ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00407760 (ខ្លឹមសារប្រជុំ គឺប្រាប់មេៗខ្មែរក្រហមថា ពួកទាហាន និងប៉ូលីសជំនាន់ លន់ នល់ ឲ្យតែអ្នកណាមានពាក់ស័ក្តិ ត្រូវតែយកទៅសម្លាប់ចោលទាំងអស់)។

បានគេយកទៅសម្លាប់ចោលនោះទេ[២០៨៦] ហើយថា បញ្ជារបស់ ហួន គឺត្រឹមតែឱ្យប្រមូលផ្ដុំទាហាន និងប៉ូលីស ដែលមាននិន្នាការសម័យ លន់ នល់ ឱ្យទៅរៀនសូត្រសិន ហើយពេលត្រឡប់មកពីរៀនសូត្រវិញ អ្នកដែលធ្លាប់ធ្វើការនៅថ្នាក់កណ្ដាល នឹងត្រូវបានអនុញ្ញាតឱ្យធ្វើការនៅកន្លែងដដែល[២០៨៧]។

៦៦៥. លឹម សាត ដែលបានឃាមនៅឯកិច្ចប្រជុំក្រោយមកទៀតនោះ គឺជាសាក្សីតែម្នាក់គត់ដែលផ្ដល់សក្ខីកម្មអំពីការបញ្ជាទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា គាត់ត្រូវបានជំរុញឱ្យបន្ធូរបន្ថយ ឬ កែប្រែការទទួលខុសត្រូវរបស់គាត់ចំពោះការពាក់ព័ន្ធនៅក្នុងព្រឹត្តិការណ៍ផ្សេងៗ ដែលចោទជាបញ្ហានេះ។ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់ លឹម សាត ពាក់ព័ន្ធនឹងការដឹងដោយមានកម្រិតរបស់គាត់អំពីគោលបំណងឧក្រិដ្ឋនៃការបញ្ជាទាំងនេះ មិនគួរឱ្យជឿជាក់បានទេ។ ប៉ុន្ដែ សក្ខីកម្មដំបូងរបស់គាត់នៅចំពោះសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងខ្លឹមសារនៃការបញ្ជាទាំងនេះ គឺស៊ីសង្វាក់គ្នាទៅនឹងលំនាំនៃការប្រព្រឹត្ត។ ក្រោយពីខ្មែរក្រហមបានកាន់កាប់ទីក្រុងរួចមក អតីតមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានកោះហៅឱ្យទៅចូលរួមប្រជុំដែលគេចាត់ទុកថាជាវគ្គរៀនសូត្រ ឬ ជាឱកាសដើម្បីទៅគាល់សម្ដេច សីហនុ ហើយក្រោយមកត្រូវបានគេសម្លាប់ចោលតែម្ដង[២០៨៨]។ លើសពីនេះទៀត សក្ខីកម្មរបស់ លឹម សាត ពាក់ព័ន្ធនឹងស្ថានភាពនៃការទទួលបញ្ជាដែល "ថ្នាក់លើ" ផ្សព្វផ្សាយនោះ ក៏ស្របគ្នានឹងសំអាងហេតុរបស់អង្គជំនុំជម្រះអំពីប្រព័ន្ធទំនាក់ទំនងផងដែរ[២០៨៩]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់ទាក់ទងនឹងខ្លឹមសារនៃការបញ្ជាទាំងនេះ គឺគួរឱ្យជឿជាក់បាន។

---

[២០៨៦] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៦។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ២០។

[២០៨៧] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៩-២១, ៣៩-៤០ (*ដកស្រង់*កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥-១៦, ២០។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00242422។

[២០៨៨] *សូមមើល*ផ្នែកទី៣, បរិបទប្រវត្តិសាស្ត្រ, កថាខណ្ឌ ១១៧-១១៨។ ផ្នែកទី១០, ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣, ៥១១, ៥១៤។

[២០៨៩] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៨-៩ (បញ្ជាក់ថា បញ្ជាទាំងនោះអាចមកពីថ្នាក់លើបញ្ជាទៅថ្នាក់ភូមិភាគ ដែលបានបញ្ជូនបញ្ជាទាំងអស់នេះទៅកាន់អង្គភាពនានា ដែលជាអ្នកអនុវត្តបញ្ជាទាំង

៦៦៦. ក្រោយមក អតីតទាហាន លន់ នល់ ត្រូវបានអញ្ជើញឱ្យទៅចូលរួមការប្រជុំមួយនៅសាលាខេត្តពោធិ៍សាត់ ដែលដឹកនាំដោយ តា ញឹម និង តា កន មកពីគណៈភូមិភាគ និង តាសុត មកពីគណៈតំបន់[២០៩០]។ ការអញ្ជើញនេះត្រូវបានបញ្ជូនបន្តទៅអភិបាលខេត្ត និងថ្នាក់ដឹកនាំរបប លន់ នល់ ដែលបានបញ្ជូនបន្តទៅកូនចៅរបស់ខ្លួនដោយផ្ទាល់មាត់ និងតាមការផ្សព្វផ្សាយ[២០៩១]។

## ១២.២ កិច្ចប្រជុំជាមួយអ្នករដ្ឋការ លន់ នល់ នៅសាលាខេត្តពោធិ៍សាត់

៦៦៧. អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សី ស៊ុម អាឡាត់, លឹម សាត និង អ៊ុង ឆាត់ អំពីកិច្ចប្រជុំជាបន្តបន្ទាប់នៅសាលាខេត្តពោធិ៍សាត់។ ភ័ស្តុតាងទទួលបានពីស៊ុម អាឡាត់ ដែលជាអតីតពលទាហាននៃរបប លន់ នល់ នៅក្នុងពេលវេលានៃព្រឹត្តិការណ៍ទាំងនោះ និងជាសាក្សីតែម្នាក់គត់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងនោះ[២០៩២] ។ ភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ និងអ្នកចូលរួម ត្រូវបានរៀបរាប់លម្អិត និងគួរឱ្យជឿជាក់បាន។ ភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងការសន្យានានាចំពោះអ្នករដ្ឋការនៃរបប លន់ នល់ នៅក្នុងកិច្ចប្រជុំទាំងនោះ និងការដឹក

---

នេះ។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥-១៦ (បញ្ជាទាំងនេះចេញមកពីគណៈភូមិភាគ ហើយត្រូវបានបញ្ជូនទៅគណៈតំបន់ និងបន្តទៅថ្នាក់ក្រោមៗទៀត)។ *សូមមើល*ផ្នែកទី៦, រចនាសម្ព័ន្ធទំនាក់ទំនង, កថាខណ្ឌ ២៨៦, លេខយោងជើងទំព័រ ៨៩៣។

[២០៩០] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៨-២០ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ទំព័រ ៣-៤, ERN (ជាភាសាខ្មែរ) 00407761-00407762 ដែលកំណត់អត្តសញ្ញាណ តា ញឹម, តា កន និង តា សុត)។

[២០៩១] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៦ (សារនេះត្រូវបានបញ្ជូនទៅមេក្រុមដែលជាអ្នកបញ្ជូនបន្តទៅកូនចៅ និងទាហានរបស់ខ្លួន) ទំព័រ ១៧-១៩។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៥២-៥៣ (ស្តាប់ឮពីមាត់មួយទៅមាត់មួយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00273437 (ជាកសិករម្នាក់រស់នៅខេត្តពោធិ៍សាត់ ដែលបានស្តាប់ឮការប្រកាសរបស់ខ្មែរក្រហមថា ទាហាន លន់ នល់ ត្រូវយកទៅរៀនសូត្រ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហែម សារ៉ន ឯកសារ E3/4808 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ជាភាសាខ្មែរ) 00518541 (ដែលរស់នៅខេត្តពោធិ៍សាត់ បានស្តាប់ឮការប្រកាសរបស់ខ្មែរក្រហមតាមមេក្រុថា អតីតទាហាន ប៉ូលីស និងអ្នករដ្ឋការ ត្រូវមកកាន់សាលាខេត្តពោធិ៍សាត់ ដើម្បីពិភាក្សាគ្នាអំពីការទៅបន្តរៀនសូត្របន្ថែមទៀត)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637 ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ជាភាសាខ្មែរ) 00198611 (គណៈតំបន់ឈ្មោះ សុត បានស្នើឱ្យឧត្តមសេនីយ៍ ព្រុំ លីហ្សួន អភិបាលខេត្តពោធិ៍សាត់ ឱ្យទៅជួបគាត់នៅសាលាខេត្ត)។

[២០៩២] ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១-២, ៤៩។

ជញ្ជូនពួកគេនៅពេលបញ្ចប់ពីប្រជុំទៅកាន់ទួលពោធិ៍ជ្រៃគឺស៊ីសង្វាក់គ្នានឹងសក្ខីកម្មរបស់សាក្សី អ៊ុំង ឆាត់ ដែលជាកងទ័ពខ្មែរក្រហមមួយរូប និងសាក្សី លឹម សាត[២០៩៣]។ ស៊ុម អាឡាត់ បានផ្តល់សក្ខីកម្មអំពីកិច្ចប្រជុំផ្សេងៗដែលមានរយៈពេល២ថ្ងៃជាប់គ្នា។ ទោះបីជា លឹម សាត និង អ៊ុំង ឆាត់ បាននិយាយអំពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតមានតែក្នុងកិច្ចប្រជុំមួយថ្ងៃក៏ដោយ ក៏សក្ខីកម្មរបស់ពួកគេបញ្ជាក់ថា យ៉ាងហោចណាស់ ក៏ការប្រជុំទាំងនោះមានរយៈពេល ២ ថ្ងៃដែរ[២០៩៤]។ ទាក់ទងនឹងខ្លឹមសារនៃសក្ខីកម្មរបស់ពួកគេ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ព្រឹត្តិការណ៍ដែល

---

[២០៩៣] អ៊ុំង ឆាត់ បានសួរសហការីរបស់គាត់ និងប្រជាជនខ្លះដែលបានចូលរួមប្រជុំ អំពីខ្លឹមសារនៃកិច្ចប្រជុំនេះ ហើយពួកគេបានប្រាប់គាត់ថា អ្នករដ្ឋការទាំងនោះត្រូវបានគេសន្យាឲ្យទៅរៀនសូត្រ ដែលអាចផ្តល់ឱកាសឲ្យពួកគេទទួលបានការតម្លើងបុណ្យស័ក្តិមួយកម្រិត៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៦៤។ ប្រតិចារឹក ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៣១, ៥៣-៥៤។ លឹម សាត មិនបានចូលរួមនៅក្នុងកិច្ចប្រជុំនេះទេ ប៉ុន្តែគាត់បានដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំនេះពីមេបញ្ជាការកងវរៈសេនាធំរបស់គាត់ គឺមេបញ្ជាការឈ្មោះ ហួន។ ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៩-២០ (*ដកស្រង់*កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារលេខ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ២, ERN (ជាភាសាខ្មែរ) 00242422 ដែលបង្ហាញថា នៅក្នុងកិច្ចប្រជុំនោះ អ្នកទាំងនោះត្រូវបានគេបោកប្រាស់ថាឲ្យទៅរៀនសូត្រ បន្ទាប់មកនឹងឲ្យតួនាទីដូចដើមវិញ។ ទោះបីជាការបកប្រែជាភាសាបារាំងនៃកំណត់ហេតុស្តាប់ចម្លើយរបស់ លឹម សាត បានលុបចោលការលើកឡើងអំពីការបោកប្រាស់នេះក្តី ក៏កំណត់ហេតុស្តាប់ចម្លើយសំណៅដើមរបស់ លឹម សាត ជាភាសាខ្មែរ លើកឡើងអំពីការបោកប្រាស់លើអ្នកចូលរួមរៀនសូត្រផងដែរ៖ *សូមមើល* ERN (ជាភាសាខ្មែរ) 00242422 និង ERN (ជាភាសាបារាំង) 00282197។

[២០៩៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១៦-១៧, ២២-២៣។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៨-៩ (គេប្រាប់ប្រជាជនតាំងពីមុនមកថា ឲ្យប្រជាជនទៅរៀនសូត្រ ហើយប្រជាជនបានត្រៀមខ្លួនដើម្បីទៅរៀនសូត្រ។ ប្រជាជនមិនអាចទៅទីនោះដោយដៃទទេបានទេ), ទំព័រ ១៧-១៨ (មានការប្រជុំមួយដែលគេបានប្រាប់ប្រជាជនថាឲ្យប្រជាជនទៅរៀនសូត្រ និងឲ្យប្រជាជនត្រៀមរៀបចំឥវ៉ាន់។ ព័ត៌មាននេះមិនមែនគ្រាន់តែឲ្យត្រៀមរៀបចំ និងចាកចេញភ្លាមៗនោះទេ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៥០-៥១ (មិនអាចចាំបានថាតើការប្រជុំនោះមានរយៈពេលប៉ុន្មានថ្ងៃនោះទេ។ វាអាចមានរយៈពេល ១ ថ្ងៃ ឬ ២ ថ្ងៃ) ។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជ័យ យ៉ាន ឯកសារ E3/4857 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ៣, ERN (ជាភាសាខ្មែរ) 00530043 (គេបានប្រកាសឲ្យមន្ត្រីរដ្ឋការដែលជាអ្នករស់នៅស្រុកបាកាន ទៅរៀនសូត្ររយៈពេល៣ថ្ងៃ)។ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ នៅត្រង់ម៉ោង ៩.៦៦ (អ្នកបើកបរបាននិយាយថា ទាហានទាំងនោះនិយាយលេងសើចដាក់គ្នាថា “តើប្រពន្ធឯងបានខ្ចប់អ្វីឲ្យឯង?”។

បានរៀបរាប់ដោយ លឹម សាត និង អ៊ុង ឆាត់ បានកើតឡើងនៅថ្ងៃទីពីរដែល ស៊ុម អាឡាត់ បានផ្តល់សក្ខីកម្ម។

៦៦៨. យោងតាមសម្តី ស៊ុម អាឡាត់ អាជ្ញាធរខេត្ត និងទាហាន លន់ នល់ បានបន្តធ្វើការងារដូចធម្មតា ក្រោយពីខ្មែរក្រហមបានកាន់កាប់ខេត្តពោធិ៍សាត់ នៅថ្ងៃទី ១៧ ឬ អំឡុងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ហើយទាហាន លន់ នល់ នៅតែបន្តស្លៀកពាក់ឯកសណ្ឋានរបស់ពួកគេដដែល[២០៩៥]។ ប្រហែលជាមួយសប្តាហ៍ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានន័យថា នៅអំឡុងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥ មន្ត្រីរដ្ឋការ លន់ នល់ បានចូលរួមនៅក្នុងកិច្ចប្រជុំដែលគេបានប្រកាសនោះ នៅសាលាខេត្តពោធិ៍សាត់[២០៩៦]។ ទោះបីជាទាហាន និងមន្ត្រីរដ្ឋការជាច្រើនត្រូវបានអង្គភាពកងទ័ពខ្មែរក្រហមដឹកជញ្ជូនទៅចូលរួមប្រជុំក៏ដោយ ក៏ភ័ស្តុតាងបង្ហាញថា ការចូលរួមប្រជុំរបស់ពួកគេ គឺជាការស្ម័គ្រចិត្ត[២០៩៧]។

---

[២០៩៥] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ៥១-៥២, ៥២-៥៤។ ទោះបីជា ស៊ុម អាឡាត់ បានប្រចាំការនៅស្វាយដូនកែវ នៅតាមព្រំប្រទល់រវាងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងក្តី ក៏គាត់បានផ្តល់សក្ខីកម្មថា ពេលដែលកងទ័ពខ្មែរក្រហមបានរំដោះតំបន់នោះ គាត់បានដោះឯកសណ្ឋានទាហាន លន់ នល់ ចោល នៅពេលគាត់ទៅ ដល់ស្វាយហ្លួង ដោយភ័យខ្លាចថា ប្រសិនបើអ្នកណាម្នាក់ឃើញគាត់ស្លៀកពាក់ឯកសណ្ឋាន នោះគាត់នឹងត្រូវគេសម្លាប់ ចោលជាមិនខាន។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ៥-៦, ៧-១០, ៧៨-៧៩។

[២០៩៦] ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៦-១៨។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ៣៤-៣៥, ៥២ (ប្រហែលជារយៈពេល២សប្តាហ៍ ក្រោយថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ អាចនៅថ្ងៃទី ២៤ ឬ ២៥ ខែ មេសា)។ *ប្រៀបធៀបនឹង* ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ នៅត្រង់ម៉ោង ៩.២៦ (បុរសម្នាក់ដែលគេមិនស្គាល់អត្តសញ្ញាណ ដែលជាអតីតអ្នកបើកបរឡានធំដែលបានដឹកជញ្ជូនទាហានទាំងនោះទៅកាន់ទួលពោធិ៍ជ្រៃ បានបញ្ជាក់ថា ព្រឹត្តិការណ៍នេះបានកើតឡើងនៅថ្ងៃទីបី បន្ទាប់ពីការរំដោះភ្លាម)។ ទោះជា អ៊ុង ឆាត់ បានកំណត់ថា ការប្រជុំនោះគឺអំឡុងថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ជាថ្ងៃដែលគាត់បានធ្វើដំណើរចូលទៅទីរួមខេត្តក៏ដោយ ក៏ក្រោយមក គាត់បានទទួលស្គាល់ថា គាត់បានស្ថិតនៅក្នុងខេត្តពោធិ៍សាត់ពីរបីថ្ងៃ មុនការប្រជុំនោះកើតឡើង។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុង ឆាត់)ទំព័រ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុង ឆាត់) ទំព័រ ៤៩-៥១។ ហេតុដូច្នេះ សក្ខីកម្មរបស់គាត់គាំទ្រសក្ខីកម្មរបស់ លឹម សាត និង ស៊ុម អាឡាត់ ទាក់ទងនឹងពេលវេលានៃកិច្ចប្រជុំនោះ ហើយអង្គជំនុំជម្រះយល់ឃើញថា កិច្ចប្រជុំនោះធ្វើឡើងនៅអំឡុងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥។

[២០៩៧] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៧-២០ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ដែលបញ្ជាក់ថា មន្ត្រីរដ្ឋការ និង ទាហាន លន់ នល់ ទាំងអស់ត្រូវ

៦៦៩. ទោះបីជាមានភាពមិនស៊ីសង្វាក់គ្នា ចំពោះភ័ស្តុតាងទាក់ទងនឹងចំនួនអ្នកចូលរួមប្រជុំ[២០៥៨] និងវត្តមានជនស៊ីវិលនៅក្នុងកិច្ចប្រជុំនោះក៏ដោយ[២០៥៩] ក៏អង្គជំនុំជម្រះកត់សម្គាល់ថា ដោយសារតែ

---

បានគេដឹកជញ្ជូនយកទៅសាលាខេត្តតាមរថយន្តដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំដែលបានប្រកាសនោះ), ទំព័រ ៥៩-៦០ (បញ្ជាក់ថា គាត់មិនមែនជាអ្នកទទួលខុសត្រូវក្នុងការប្រមូលទាហានទាំងអស់នោះទេ អ្នកដទៃទេ ដែលជាអ្នកប្រមូល)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៦៤-៦៥ (បានឃើញគេដឹកទាហានទាំងនោះតាមឡានធំជាច្រើនគ្រឿង)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ធឹម ឯកសារ E3/5500 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00366516 (កសិករម្នាក់ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់នាពេលនោះ បានឃើញពួកខ្មែរក្រហមប្រមូលទាហានទៅប្រជុំនៅសាលាខេត្ត ប៉ុន្តែ ពួកមន្ត្រីរដ្ឋការ និងទាហានខ្លះបានមកចូលរួមប្រជុំដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហែម សារ៉ន ឯកសារ E3/4808 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤, ERN (ជាភាសាខ្មែរ) 00518541 (ដែលរស់នៅខេត្តពោធិ៍សាត់ បានឆ្លើយថា ពួកខ្មែរក្រហមបានបញ្ជូនឡានយោធាធំៗមកដឹកអ្នកដែលត្រូវទៅចូលរួមប្រជុំ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន ប៊ុន ឯកសារ E3/5344 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩, ERN (ជាភាសាខ្មែរ) 00461100 (ដែលជាប្រជាជនរស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ បានឃើញទាហានខ្មែរក្រហមដើរប្រមូលនាយទាហាន និងកូនទាហានពីភូមិស្វាយអាត់ ស្រុកបាកាន)។ ចំពោះការស្ម័គ្រចិត្តចូលរួមប្រជុំនេះ *សូមមើល* ៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ១៦-១៧ (កងទ័ពខ្មែរក្រហមមិនបានប្រមូលទាហានទាំងនោះដោយផ្ទាល់ទេ តែផ្ទុយទៅវិញ មន្ត្រីរដ្ឋការ លន់ នល់ ដែលបានស្តាប់ឮការប្រកាសឲ្យទៅចូលរួមប្រជុំនៅ សាលាខេត្តទេ បានទៅចូលរួម)។ ប្រតិចារឹក ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១១-១៣ (ទាហាន លន់ នល់ ម្នាក់បានដឹងអំពីកិច្ចប្រជុំនេះតាមរយៈបណ្តាញទំនាក់ទំនង ដែលរបប លន់ នល់ បានរក្សា និងបានទៅចូលរួមប្រជុំតាមសហការីរបស់គាត់។ ប្រតិចារឹក ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៣ (សាក្សី អ៊ុំង ឆាត់)ទំព័រ ៦៤-៦៥ (អ្នកខ្លះបានទៅចូលរួមប្រជុំតាមមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន)។

[២០៥៨] បើទោះជា ស៊ុម អាឡាត់ បានប៉ាន់ប្រមាណថា មានអ្នកចូលរួមប្រហែល ៥០០ នាក់នៅឯសាលាខេត្ត នៅថ្ងៃនីមួយៗ នោះ អ៊ុំង ឆាត់ បានកំណត់ថា មានទាហាន លន់ នល់ ប្រហែល ២០០ នាក់ និងមានប្រជាជនស៊ីវិលខ្លះនៅក្នុងសាលាខេត្ត៖ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១១-១២ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637), ទំព័រ ១២-១៤, ២២-២៣, ៦១-៦២, ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៦៤, ៦៥-៦៦។ ប្រតិចារឹកថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៥៥។ ផ្ទុយទៅវិញ លឹម សាត ដែលបានយាមប្រចាំការនៅចម្ងាយប្រហែលជា ៥ គីឡូម៉ែត្រពីកន្លែងប្រជុំនោះ នៅពេលដែលទាហាន លន់ នល់ បានមកដល់សាលាខេត្ត បានប៉ាន់ប្រមាណថា គាត់បានឃើញឡានយោធាធំៗ ចំនួនពី ៣០ ទៅ ៤០ គ្រឿងបើកឆ្លងកាត់ផ្លូវឆ្ពោះទៅកាន់សាលាខេត្ត ដែលឡាននីមួយៗអាចដឹកមនុស្សបានយ៉ាងហោចណាស់ក៏ ៣០ នាក់ដែរ៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៧-១៩ (ដកស្រង់ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364)។ ក្រោយមក លឹម សាត បានផ្តល់សក្ខីកម្មថា មានឡានធំចំនួនពី ១០ ទៅ ១៥ គ្រឿងតែប៉ុណ្ណោះ ប៉ុន្តែគាត់បានទទួលស្គាល់ថា ចំនួននេះដូចជាមិនត្រឹមត្រូវទេ៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត)

ពេលវេលាយូរចាប់តាំងពីមានព្រឹត្តិការណ៍ទាំងនោះ ការចងចាំអាចមានភាពខុសៗគ្នាក្នុងកម្រិតមួយ។ ប៉ុន្តែលើកលែងតែចំពោះសក្ខីកម្មរបស់ លឹម សាត អំពីចំនួនអ្នកចូលរួមប្រជុំនោះ ភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ថា យ៉ាងហោចណាស់ក៏មានមនុស្សជាច្រើនរយនាក់ រួមទាំងជនស៊ីវិលផងដែរដែលបានចូលរួមប្រជុំនៅសាលាខេត្តនោះ។ ទោះជាយ៉ាងណាក៏ដោយ តាមការប៉ាន់ប្រមាណទាំង

---

ទំព័រ ៥៨-៦១។ *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ជាភាសាខ្មែរ)00273426 (អតីតទាហាន លន់ នល់ ម្នាក់មកពីភ្នំពេញ ដែលត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅភូមិពោធិ៍ ២ ក្នុងខេត្តពោធិ៍សាត់ ក្រោយថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានប៉ាន់ប្រមាណថា ឡានទាហានពណ៌សដែលដឹកជញ្ជូនទាហាន លន់ នល់ ទៅកាន់ទួលពោធិ៍ជ្រៃដែលគាត់បានឃើញរយៈពេលប្រហែលជាមួយខែក្រោយពេលរំដោះទីក្រុងភ្នំពេញ អាចដឹកមនុស្សប្រមាណ ៣០ នាក់ ក្នុងមួយឡាន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ទំព័រ ២-៣, ERN (ជាភាសាខ្មែរ) 00273437-00273438 (ជាកសិករម្នាក់រស់នៅខេត្តពោធិ៍សាត់ ដែលបានឃើញឡានទាហានទាំងនោះ បានប៉ាន់ប្រមាណថា ឡានធំនីមួយៗអាចដឹកមនុស្សបានប្រហែលជា ៤០ នាក់)។

[២០៩៩] លឹម សាត បានផ្តល់សក្ខីកម្មថា ការប្រមូលផ្តុំនោះធ្វើឡើងសម្រាប់តែទាហានដែលស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ហើយ ជនស៊ីវិលពុំមានភារកិច្ចនៅទីនោះទេ៖ ប្រតិចារឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ (សាក្សី លឹម សាត)១៧-១៩, ២២-២៤។ ស៊ុំ អាឡាត់ បានបញ្ជាក់អំពីវត្តមាននៃអតីតមន្ត្រីរដ្ឋការ លន់ នល់ ទាំងអស់ ទាំងទាហាន និងស៊ីវិល។ ក្នុងចំណោមអ្នកចូលរួមប្រជុំទាំង ៥០០ នាក់ ស៊ុម អាឡាត់ បានប៉ាន់ប្រមាណថា អ្នកចូលរួមចំនួនជាង ២០០ គឺជាទាហាន លន់ នល់ មក ពីអង្គភាពយោធាផ្សេងៗគ្នានៅទូទាំងខេត្តពោធិ៍សាត់ ដែលក្នុងចំណោមនេះមានទាហាន លន់ នល់ ចំនួន ៣០ នាក់ មកពីទួលពោធិ៍ជ្រៃ៖ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១១-១២ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637) ទំព័រ ១២-១៥, ១៨-២០, ២២-២៣, ៦១-៦៤, ៦៦-៦៧, ៦៨-៦៩។ អ៊ុំង ឆាត់ ក៏បានផ្តល់សក្ខីកម្មអំពីវត្តមានរបស់ជនស៊ីវិលនៅសាលាខេត្តនោះដែរ៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៦៤, ៦៥-៦៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ៥៥។ *សូមមើល ផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ឆឹម ឯកសារE3/5500 ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ជាភាសាខ្មែរ) 00366516 (ជាកសិករដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់បានឃើញទាហាននិងមន្ត្រីរដ្ឋការ លន់ នល់ មានវត្តមាននៅទីនោះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ ជ័យ យ៉ាន់ ឯកសារ E3/4857 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៣, ERN (ជាភាសាខ្មែរ) 00530043 (ដែលនៅពេលនោះគាត់ជាប្រជាជនរស់នៅស្រុកបាកាន បាននិយាយថា មន្ត្រីរដ្ឋការ រួមទាំងប្តីរបស់គាត់ផង ត្រូវបានគេឲ្យទៅចូលរួមរៀនសូត្រ ហើយពួកទាហានត្រូវបានគេសម្លាប់ចោលទាំងអស់)។ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា - ខេត្តពោធិ៍សាត់* ឯកសារ E3/2066 ឆ្នាំ ១៩៩៧ ERN (ជាភាសាខ្មែរ) 00292768 (*ធ្វើការកត់សម្គាល់ថា* នៅដំណាក់កាលទី១ក្នុងឆ្នាំ ១៩៧៥ អភិបាលខេត្តពិធ៍សាត់ ប្រធានស្រុក ប្រធានឃុំ មន្ត្រី និងទាហានគ្រប់ជាន់ថ្នាក់ទូទាំងខេត្តពោធិ៍សាត់ ត្រូវបានគេប្រមូលយកទៅសម្លាប់ចោល)។

អស់ដែលបានឆ្លើយនោះ មានអ្នកចូលរួមប្រជុំមិនដល់ ៣.០០០ នាក់ ដូចដែលបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនោះទេ[២១០០]។

៦៧០. កិច្ចប្រជុំលើកទី១បានចាប់ផ្តើមនៅម៉ោង ២ រសៀល និងមានរយៈពេលពី២ទៅ៣ម៉ោង ដែលនៅក្នុងកិច្ចប្រជុំនោះ អ្នកចូលរួមត្រូវបានអប់រំអំពីគោលនយោបាយនៃការផ្សះផ្សា និងការកសាងប្រទេស ហើយត្រូវបានជំរុញឲ្យទុកចិត្តខ្មែរក្រហមទាក់ទងនឹងការប្រជុំនាពេលខាងមុខជាមួយអង្គការនៅទួលពោធិ៍ជ្រៃ[២១០១]។ អ្នកចូលរួមប្រជុំទាំងអស់ត្រូវបានគេប្រាប់ឲ្យមកចូលរួមប្រជុំសាជាថ្មីនៅថ្ងៃបន្ទាប់ គឺនៅថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីឲ្យគេអាចបញ្ជូនអ្នកទាំងអស់នោះរួមគ្នាទៅជួបជាមួយអង្គការ[២១០២]។ ស៊ុម អាឡាត់ មានសុទិដ្ឋិនិយម បន្ទាប់ពីការប្រជុំលើកទី១ រួចមក។ គាត់ និងអ្នកចូលរួមប្រជុំដទៃទៀត ឆ្អែតនឹងការវាយប្រយុទ្ធគ្នា មានអារម្មណ៍ថាការទៅជួបជាមួយអង្គការ អាចនឹងផ្តល់ឱកាសមួយក្នុងការផ្សះផ្សា និងកសាងប្រទេស[២១០៣]។ ហេតុដូច្នេះ ស៊ុម អាឡាត់ និងអ្នកចូលរួមដទៃទៀតបានទៅចូលរួមការប្រជុំនៅថ្ងៃបន្ទាប់នោះ[២១០៤]។

៦៧១. មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ដែលប្រដាប់ដោយអាវុធ និងស្លៀកខោអាវពណ៌ខ្មៅ បានចូលរួមនៅក្នុងកិច្ចប្រជុំលើកទី១ នោះ ។ ក្នុងចំណោមមេដឹកនាំទាំងនោះមាន តា តួយ អនុលេខាតំបន់ ៧[២១០៥] និង តាសុត ជាលេខាតំបន់ ៧ ។ តាសុត បានចូលរួមប្រជុំទាំងពីរលើក ប៉ុន្តែគាត់បាន

---

[២១០០] ដីកាដំណោះស្រាយ កថាខណ្ឌ ៧០៨ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ERN (ជាភាសាខ្មែរ) 00242422។

[២១០១] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១១-១២ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637), ទំព័រ ១៦-១៧។

[២១០២] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១៦-១៧។

[២១០៣] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១៧-១៨។

[២១០៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ២២-២៣, ៦៦-៦៧, ៦៨-៦៩ (បញ្ជាក់ថា ការប្រជុំនោះមានរយៈពេលពី ២ ទៅ ៣ ម៉ោង។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ឹង ឆាត់) ទំព័រ ៦៤ (បញ្ជាក់ថា ការប្រជុំនោះមានរយៈពេលពី ៣ ឬ ៤ ម៉ោង ឬប្រហាក់ប្រហែលនេះឯង)។

[២១០៥] គេក៏បានហៅឈ្មោះគាត់ថា តា តួយ ផងដែរ។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុយ សេងឈន ឯកសារ E3/4638 ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៨ ទំព័រ ២, ERN (ជាភាសាខ្មែរ) 00196817 (តា តួយ ជាអនុលេខាតំបន់រហូតដល់ឆ្នាំ១៩៧៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆាត់ ឯកសារ E3/4598, E3/5774 ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៩ ទំព័រ៣, ERN(ជាភាសាខ្មែរ) 00277329 (តា តួយ ជាអនុលេខាតំបន់៧)។

និយាយតែនៅក្នុងកិច្ចប្រជុំលើកទី១ ប៉ុណ្ណោះ[២១០៦]។ តា កន និង តា វ៉ាញ មកពីគណៈភូមិភាគ[២១០៧] ព្រមទាំងតំណាងមកពីគណៈតំបន់ ក៏បានចូលរួមប្រជុំដែរ ទោះបីវាមិនច្បាស់ថាតើពួកគេបានចូលរួមប្រជុំតែមួយលើក ឬ ទាំងពីរលើក[២១០៨]។ គ្មានអ្នកណាម្នាក់មកពីខាង លន់ នល់ មានកាន់អាវុធនោះទេ[២១០៩]។

៦៧២. ទាំង លឹម សាត និង អ៊ុំង ឆាត់ ស្ថិតនៅខាងក្រៅសាលាខេត្តក្នុងអំឡុងកិច្ចប្រជុំលើកទី២[២១១០] បន្ទាប់មក "អាជ្ញាធរថ្នាក់លើ" បានប្រាប់ដល់កងការពារខ្មែរក្រហម ឲ្យទៅនាំជនទាំងឡាយណាដែលចូលរួមនៅក្នុងកិច្ចប្រជុំ ទៅទីតាំងមួយក្បែរបឹងទន្លេសាបដើម្បីអប់រំរៀនសូត្រ

---

[២១០៦] ប្រតិចារឹក ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ (សាក្សី ស៊ុម អាឡាត់)ទំព័រ ១៥-១៦ (មានមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់បំផុតពី ៥ ទៅ៧ នាក់ ដែលក្នុងចំណោមនោះ គាត់ស្គាល់តែ តា សុត ម្នាក់គត់ ដែលជាលេខាតំបន់, ទំព័រ ៦៨-៧០ (គាត់បានឃើញពួកគេឈរនៅក្បែរ តា សុត ដោយមានពាក់មួកត្រឹមត្រូវ ដែលគាត់បានសន្និដ្ឋានថា មានតែមេដឹកនាំជាន់ខ្ពស់បំផុតទេដែលពាក់ឯកសណ្ឋាន ឬ សម្លៀកបំពាក់បែបនោះ។ គាត់មិនបានចាប់អារម្មណ៍ទៅលើអ្នកដទៃទៀតដែលបានឡើងនិយាយនោះទេ។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (សាក្សី អ៊ុំង ឆាត់) ទំព័រ ២៩-៣០ (មានបុរសម្នាក់ទៀតផងដែរឈ្មោះ តូយ ទោះបីជាគាត់មិនស្គាល់ តា តូយ ច្បាស់ក៏ដោយ) ទំព័រ ៣១, ៦០-៦១ (តា សុត និង តា តូយ ដែលជាសមាជិកគណៈតំបន់ បានចូលរួមនៅក្នុងប្រជុំនោះ ទោះបីជាគាត់មិនដែលបានជួបមុខដោយផ្ទាល់ក៏ដោយ។ គាត់ គ្រាន់តែបានឮគេនិយាយថា ពួកគេជាមេបញ្ជាការតំបន់នៅពេលនោះ)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥ (តា សុត ជាប្រធានតំបន់ ៧។ គាត់បានដឹងថា អ្នកមកពីភូមិភាគនិងតំបន់ មានវត្តមាននៅទីនោះ)។

[២១០៧] នៅក្នុងកិច្ចសម្ភាសន៍លើកទី២របស់គាត់ លឹម សាត បានកំណត់អត្តសញ្ញាណ តាវ៉ាញ ថាជាគណៈតំបន់ ២ ទោះបីជាក្នុងកិច្ចសម្ភាសន៍លើកទីបីរបស់គាត់ និងនៅក្នុងសវនាការ គាត់បានឆ្លើយថា តាវ៉ាញ ជាសមាជិកគណៈភូមិភាគ៖ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ជាភាសាខ្មែរ) 00407760 (គណៈតំបន់)។ *ប្រៀបធៀបនឹង* ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ៦៧ (គណៈភូមិភាគ)។

[២១០៨] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (សាក្សី លឹម សាត) ទំព័រ ១៥-១៦។

[២១០៩] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (សាក្សី ស៊ុម អាឡាត់) ទំព័រ ១៥-១៦។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុយ សេងឈន ឯកសារ E3/4638 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤ (ជាភាសាខ្មែរ) 00196819។

[២១១០] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១៦, ៦៧-៦៨, ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២០ (គាត់ឈរលើផ្លូវដើម្បីយាមឡាន)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) ទំព័រ ៦៣-៦៤, ៦៧។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត់) ទំព័រ ៣០, ៥០-៥២, ៥៣-៥៤, ៥៨-៥៩, ៦៣-៦៤ (គាត់កំពុងឈរនៅខាងក្រៅ និងយាមសាលាខេត្ត)។

បន្ទាប់មកពួកគេអាចត្រឡប់ទៅធ្វើការងារពីមុនរបស់ខ្លួនវិញ[២១១១] ។ មេបញ្ជាការ ហួន បានប្រាប់ លឹម សាត ថា ប៉ូលីស និងទាហាន ត្រូវបានកោះហៅឱ្យចូលរួមប្រជុំ ពីព្រោះខ្មែរក្រហមបារម្ភថា ប៉ូលីស និងទាហានទាំងនោះ អាចធ្វើបដិវត្តប្រឆាំងនឹងពួកគេ[២១១២]។ នៅពេលដែលពួកគេចេញពី សាលាខេត្ត ទាហាន លន់ នល់ បានប្រាប់ទៅសាច់ញាតិរបស់ខ្លួនថា ពួកគេនឹងជួបជាមួយសម្តេច

---

[២១១១] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត់) ទំព័រ ៦៤, ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២០ (គេប្រាប់គាត់ថា មន្ត្រីទាំងឡាយនឹងត្រូវគេបញ្ជូនឱ្យទៅវគ្គអប់រំរៀនសូត្រ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ឆឹម ឯកសារ E3/5500 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ១-២ ERN (ជាភាសាខ្មែរ) 00366515-00366516 (កសិករម្នាក់នៅមន្ទីរពេទ្យក្នុងខេត្តពោធិ៍សាត់នាពេលនោះបានលើកឡើងថា ខ្មែរក្រហមបានប្រកាសតាមឧគ្ឃោសនស័ព្ទថា មន្ត្រីរដ្ឋាភិបាល និងទាហាន ត្រូវទៅរៀនសូត្រ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់នៅក្នុងខេត្តពោធិ៍សាត់នាពេលនោះបានលើកឡើងថា មានការប្រកាសថា ទាហាន លន់ នល់ នឹង ទៅរៀនសូត្រនៅអង្គរវត្ត ហើយក្រោយពីរៀនសូត្រ គេនឹងតម្លើងតំណែងឱ្យ)។ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា - ខេត្តពោធិ៍សាត់* ឯកសារ E3/2066 ឆ្នាំ ១៩៩៧ ERN (ជាភាសាខ្មែរ) 00292768 (*កត់សម្គាល់*ថា កន្លែងសម្លាប់ មានចម្ងាយ៦គីឡូម៉ែត្រពីបឹងទន្លេសាប) ERN (ជាភាសាខ្មែរ) 00292767-00292768 (*កត់សម្គាល់ថា* នៅក្នុងអំឡុងពេលនៃដំណាក់កាលទី១ក្នុងឆ្នាំ ១៩៧៥ "ទាហានប៉ុល ពត" បានបោកបញ្ឆោតឱ្យគិតថា អង្គការថ្នាក់លើបានអនុញ្ញាតឱ្យពួកគេចូលវគ្គសិក្សាអន្តរកាល ហើយថាពួកគេនឹងមានឱកាសជួបអ្នកដឹកនាំជាន់ខ្ពស់បំផុតដោយផ្ទាល់ ហើយក្រោយមកពួកគេអាចត្រឡប់ទៅបន្តការងារពីមុនរបស់ខ្លួនវិញ)។ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ១.៥០ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បាននិយាយថា ពួកគេត្រូវបានយកទៅរៀនសូត្រ ប៉ុន្តែ តាមពិត ត្រូវបានគេយកទៅសម្លាប់ចោល) ត្រង់ម៉ោង ២.០៩-២.១៣ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បាននិយាយថា ពួកគេបានលើកឡើងថាទាហានក្នុងឋានន្តរសក្តិវរសេនីយ៍ឯកត្រូវបានគេបញ្ជូនទៅរៀនសូត្រ ដូច្នេះ ម្នាក់ៗបានព្យាយាមឡើងជិះឡាន) ត្រង់ម៉ោង ៩.៤១-៩.៤៧ (បុរសបើកឡានមិនស្គាល់អត្តសញ្ញាណម្នាក់ដែលបើកដឹកទាហានទៅទួលពោធិ៍ជ្រៃបានលើកឡើងថា ពួកគេគិតថាពួកគេទៅតែប៉ុន្មានយប់ប៉ុណ្ណោះទេ ហើយក្រោយពេលជួបជាមួយសម្តេច ពួកគេនឹងត្រឡប់មកធ្វើការងារចាស់របស់ពួកគេវិញ) ត្រង់ម៉ោង ១៦.៤៤ (បុរសបើកឡានដែលពុំស្គាល់អត្តសញ្ញាណម្នាក់ដែលបើកដឹកទាហានទៅទួលពោធិ៍ជ្រៃបានលើកឡើងថា ទាហានចង់ជួបសម្តេចដើម្បីចង់ឱ្យតម្លើងសក្តិដល់ពួកគេ)។

[២១១២] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១៩-២១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ជាភាសាខ្មែរ) 00407761-00407762 (បានលើកឡើងថា គេបានប្រាប់មេខ្មែរក្រហមថា អ្នកមានឋានន្តរសក្តិទាំងអស់ ទាំងទាហាន ទាំងប៉ូលីសនៅក្នុងរបប លន់ នល់ ត្រូវយកទៅសម្លាប់ចោល ដើម្បីជៀសវាងការបះបោរនាពេលក្រោយ)។

នរោត្តម សីហនុ[២១១៣]។

## ១២.៣ ការដឹកជញ្ជូនទៅទួលពោធិ៍ជ្រៃ

៦៧៣. ភ្លាមៗ បន្ទាប់ពីកិច្ចប្រជុំលើកទីពីរបានបញ្ចប់ ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានគេដឹកតាមឡាន រួមទាំងតាមឡានទាហានផង[២១១៤] ហើយក៏មានការអះអាងថា បុគ្គលទាំងនោះ គឺត្រូវបានគេដឹកយកទៅអប់រំរៀនសូត្រ[២១១៥]។ មនុស្សជាច្រើនចង់ទៅចូលរួមទទួលអង្គការ ហេតុដូចនេះ មិនមានឡានគ្រប់គ្រាន់ ដើម្បីដឹកអ្នកទាំងអស់នោះទេ ដែលក្នុងនោះ រួមទាំង ស៊ុម អាឡាត់ផងដែរ[២១១៦]។

---

[២១១៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុង ឆាត) ទំព័រ ៣-៤, ៥៣-៥៤។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទេស បុប្ផា ឯកសារ E3/4811 ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១០ ទំព័រ ៣-៤ ERN (ជាភាសាខ្មែរ) 00518752-00518753 (អតីតមន្ត្រីរដ្ឋការម្នាក់បានលើកឡើងថា ក្រោយខ្មែរក្រហមចូលកាន់អំណាចនៅខេត្តពោធិ៍សាត់ ពួកគេបានប្រកាសថា "យើង" នឹងទៅរៀនសូត្ររយៈពេល៣ថ្ងៃ ដើម្បីស្វាគមន៍ សម្តេច នរោត្តម សីហនុ។ ក្រោយពេលស្តាប់ឮថា អ្នកដែលត្រូវបានគេអញ្ជើញឲ្យទៅរៀនសូត្រ ត្រូវបានគេសម្លាប់ចោល គាត់ និងប្តីរបស់គាត់ ដែលជាមន្ត្រីរដ្ឋការម្នាក់ផងនោះ បានលាក់បាំងប្រវត្តិរូបរបស់ពួកគេមិនឲ្យខ្មែរក្រហមដឹងទេ)។

[២១១៤] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៤-២៦ (ត្រូវបានរៀបរាប់ថា ជាឡានទាហានឯកជន)។ ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៧-១០, ១០ (បានរៀបរាប់អំពីឡានទាហាន និងឡានស៊ីវិល ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ដឹកជញ្ជូនទំនិញ។ ឡានទាំងនេះមិនបិទបាំងផ្នែកខាងក្រោយទាំងស្រុងនោះទេ)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២៣-២៤ (ឡានទាំងនេះជាឡានរបស់ប្រទេសអូស្ត្រាលីផ្តល់ជាអំណោយជូនដល់ទាហាន ឡានទាំងនេះធំ ហើយមានសំណាញ់បាំងសងខាង)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ជាភាសាខ្មែរ) 00273426 (បានរៀបរាប់អំពីឡានទាហានពណ៌សដែលគ្របជិត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿន ឯកសារ E3/5235 ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់ដែលរស់នៅក្នុងខេត្តពោធិ៍សាត់ បានឃើញខ្មែរក្រហមដឹកទាហានតាមឡានយោធាខុសៗគ្នា ហើយកសិករនេះបាននិយាយថា មានឡានគ្រប់ប្រភេទជាច្រើនគ្រឿង)។

[២១១៥] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុង ឆាត) ទំព័រ ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុង ឆាត) ទំព័រ៤, ៣១, ៦២-៦៣។ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ (លឹម សាត)ទំព័រ ២០-២១, ២៥-២៦ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/4601)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣ (ស៊ុម អាឡាត់)ទំព័រ ២០-២២, ៧១ (បន្ទាប់ពីការប្រជុំលើកទី២ដែលគាត់បានផ្តល់សក្ខីកម្ម)។

[២១១៦] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២០-២១ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637) ២១-២៤ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ិន ប៊ុន ឯកសារ E3/5344 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧-១០ ERN ជាភាសាខ្មែរ 00461098-00461101

៦៧៤. ឡានទាំងនោះគឺត្រូវបានបើកដោយអ្នកមកពីភូមិភាគ[២១១៧] ។ មេបញ្ជាការភូមិភាគឈ្មោះ តា ខ្លែង បានជ្រើសរើសទួលពោធិ៍ជ្រៃ ជាកន្លែងជួបជុំប៉ូលីស និងទាហាន លន់ នល់[២១១៨]។

៦៧៥. ការដឹកជញ្ជូនមនុស្សពីសាលាខេត្តទៅទួលពោធិ៍ជ្រៃ ប្រើរយៈពេលពេញមួយថ្ងៃ[២១១៩] និងមានការដឹកជញ្ជូនជាច្រើនដង[២១២០] ។ កងរបស់ លឹម សាត បានទទួលបញ្ជាតាមវិទ្យុទាក់ទងពីកងទ័ពខ្មែរក្រហមនៅបន្ទាយទួលពោធិ៍ជ្រៃ ឲ្យបញ្ជូនឡានដឹកមនុស្សមកបន្តទៀត បន្ទាប់ពីឡានមុន

---

(*កត់សម្គាល់ថា* គាត់បានឃើញទាហានដែលមានការសប្បាយចិត្ត)។ *សូមមើលផងដែរ* ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ២.០៩-២.១៣ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បាននិយាយថា ពួកគេបានលើកឡើងថា ទាហានក្នុងឋានន្តរសក្តិវរសេនីយ៍ឯកត្រូវបានគេបញ្ជូនទៅរៀនសូត្រ ដូច្នេះ ម្នាក់ៗបានព្យាយាមឡើងជិះឡាន)។

[២១១៧] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៥-២៦។

[២១១៨] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១៦។

[២១១៩] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៣ (លឹម សាត) ទំព័រ ២៥-២៦ (ពីម៉ោង ៩ ព្រឹក ដល់ ម៉ោង ៥ ល្ងាច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿន ឯកសារ E3/5235 ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់ដែលរស់នៅក្នុងខេត្តពោធិ៍សាត់បានឃើញខ្មែរក្រហមដឹកទាហានពេញមួយថ្ងៃ ចាប់ពីពេលព្រឹករហូតដល់ពេលល្ងាច)។ *ប្រៀបធៀបនឹង* ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ៩.០៩ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់ពី 'កងការពារ' បាននិយាយថា ពួកគេបានចាប់ផ្តើមឲ្យឡានបើកជិតមកដល់ទួលពោធិ៍ជ្រៃ នៅម៉ោង ៧ ព្រឹក)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ឆឹម ឯកសារ E3/5500 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ១-២ ERN (ជាភាសាខ្មែរ) 00366515-00366516 (កសិករនៅមន្ទីរពេទ្យក្នុងខេត្តពោធិ៍សាត់នាពេលនោះបានលើកឡើងថា គេកោះហៅទៅប្រជុំនៅប្រហែលម៉ោង ៩ ព្រឹក)។

[២១២០] តាមសក្ខីកម្មសាក្សី លឹម សាត បានបញ្ជាក់ថា មានឡានចំនួន២គ្រឿងបានបើកចេញពីសាលាខេត្តម្តងៗ ហើយឡានទាហានដូចគ្នានេះបានបើកត្រឡប់មកវិញបីទៅបួនដងក្នុងពេលគាត់នៅយាមកាមនៅកន្លែងគាត់៖ ប្រតិចារឹក ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៣(លឹម សាត)ទំព័រ២០-២១, ២៤-២៦។ ផ្ទុយមកវិញ សាក្សី ស៊ុម អាឡាត់ បានផ្តល់សក្ខីកម្មថា ឡានបើកជាជួរៗចេញពីសាលាខេត្ត ហើយក្រោយពេលរង់ចាំរយៈពេល២ម៉ោងដើម្បីដឹកជញ្ជូនលើកទី២ដែលពុំឃើញមាននោះ គាត់និងមនុស្ស ៥០ ទៅ ៦០ នាក់ផ្សេងទៀតដែលនៅក្រោយគេ បានវិលត្រឡប់ទៅផ្ទះវិញ៖ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២៥-២៧, ៣០-៣១។ បើទោះជាសាក្សី ស៊ុម អាឡាត់ មិនបាននៅសាលាខេត្តយូរ ហើយមិនបានឃើញការដឹកជញ្ជូនជើងទី២ក៏ដោយ ប៉ុន្តែភ័ស្តុតាងរបស់គាត់ស៊ីសង្វាក់នឹងភ័ស្តុតាងរបស់សាក្សី លឹម សាត ដែលលើក ឡើងថា មានការដឹកជញ្ជូនជាច្រើនជើងទៅទួលពោធិ៍ជ្រៃ។

បានត្រឡប់ទៅវិញ[២១២១]។

៦៧៦. ភស្តុតាងអំពីចំនួនឡានដែលចូលរួមក្នុងការដឹកជញ្ជូន មានចំនួនតួលេខផ្សេងៗគ្នា។ បើផ្អែកតាម លឹម សាត មានចំនួនពី ៦ ទៅ ៨ ឡាន ប៉ុន្តែបើតាមយោបល់របស់កសិករម្នាក់នៅកន្លែងនោះ មានចំនួនរហូតដល់ ១០០ ឡាន[២១២២]។ តាមការប៉ាន់ស្មានរបស់ លឹម សាត ចំនួនឡានដែលចូលរួមក្នុងការដឹកជញ្ជូន មានចំនួន (ចាប់ពី ៦ ទៅ ១៥ ឡាន) ដែលតួលេខនេះមិនស្របគ្នានឹងការប៉ាន់ស្មានរបស់គាត់ដែលបានលើកឡើងថា ទាហាន លន់ នល់ មានជិត ២.០០០ នាក់ ត្រូវបានដឹកជញ្ជូនទៅទួលពោធិ៍ជ្រៃនោះទេ[២១២៣]។ ដោយសារសក្ខីកម្មរបស់ លឹម សាត ដែលលើកឡើងថា មានការប្រើប្រាស់ឡានចំនួនពី១០ ទៅ ១៥ ឡាន គឺស្របគ្នាជាមួយនឹងសក្ខីកម្មរបស់ ស៊ុម អាឡាត់ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[២១២៤] អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មាន

---

[២១២១] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២២-២៣, ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៩-១០។

[២១២២] លឹម សាត បានផ្តល់សក្ខីកម្មខុសៗគ្នាថា ឡានចំនួន ០៦ ទៅ ០៨ គ្រឿង ហើយបន្ទាប់មក ១០ ទៅ ១៥ គ្រឿង ត្រូវបានគេយកមកប្រើប្រាស់សម្រាប់ការដឹកជញ្ជូន៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២០-២១, ២៩-២៧ (គាត់បានអះអាងថា មានឡានចំនួន២គ្រឿងបានបើកចេញពីសាលាខេត្តម្តងៗ ហើយលោកបានឃើញឡានទទេរ បើកត្រឡប់មកពីទួលពោធិ៍ជ្រៃបី ឬ បួនដង មកកាន់សាលាខេត្តមុនពេលលោកបញ្ចប់ភារកិច្ចនៅក្នុងថ្ងៃនោះ)។ *ប្រៀបធៀបនឹង* ប្រតិចារឹក ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៦-២៧, ៤២, ៥៨-៦០, ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១២-១៣ (បានផ្តល់សក្ខីកម្មថា ឡានប្រហែលជា ១០ ទៅ ១៥ គ្រឿង បានដឹក ប៉ូលីស និងទាហាន ពីសាលាខេត្តទៅកាន់ទួលពោធិ៍ជ្រៃ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុយ សេងឈន ឯកសារ E3/4638 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ERN (ជាភាសាខ្មែរ) 00196819-00196820 (កសិករម្នាក់នៅមូលដ្ឋានក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ បានឃើញឡាន ១០០ គ្រឿង ដែលមានមនុស្សជិះណែនណាន់តាន់តាប់)។ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/4001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ១.៤៤ (សំណួរ៖ តើមានឡានច្រើនគ្រឿងឆ្លងកាត់ដែរឬទេ?...ចម្លើយ៖ [...] មានឡានជាច្រើន)។

[២១២៣] *ដូចខាងលើ*។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៦-២៧ (ទាហាន លន់ នល់ ចំនួន ២០០០ នាក់)។

[២១២៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២០-២១ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637) ២១, ២២-២៥ (បានសង្កេតឃើញថា មានឡាន ១៣ ទៅ ១៥ គ្រឿង ដែលបានដឹកមនុស្សពេញៗចាកចេញទៅ) ៧១-៧២, ៧៣-៧៤ (គាត់បានព្យាយាមឡើងជិះឡានទីប្រាំពីរ ឬ ប្រាំបី ប៉ុន្តែត្រូវបានគេរុញទម្លាក់ចុះមកវិញ ហើយគេប្រាប់ឱ្យចាំជិះឡានជើងក្រោយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន ប៊ុន ឯកសារ E3/5344 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧-១០ ERN (ជាភាសាខ្មែរ)

ឡានយ៉ាងហោចណាស់ ១០ ឡាន បានដឹកអ្នកទាំងនោះទៅចូលរួមកិច្ចប្រជុំនៅទួលពោធិ៍ជ្រៃ ដោយឡាននីមួយៗ ដឹកមនុស្សបាន យ៉ាងហោចណាស់ ២៥ នាក់ ដែរ[២១២៥]។

៦៧៧. សក្ខីកម្មមិនស្របគ្នាពាក់ព័ន្ធនឹងចំណុចថាតើអ្នកដែលត្រូវបានដឹកជញ្ជូន គឺជាទាហាន ឬជាជនស៊ីវិល ឬ ស្លៀកពាក់សម្លៀកបំពាក់ទាហាន ឬ ស៊ីវិលនោះ[២១២៦] មិនប៉ះពាល់ដល់ភាពគួរឲ្យ

---

00461098-00461101 (អ្នកស្រុកបាកាន ក្នុងខេត្តពោធិ៍សាត់ នៅដើមឆ្នាំ ១៩៧៥ បានឃើញឡានចំនួន ១២ គ្រឿង)។ អង្គជំនុំជម្រះបានពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំណៅដើមជាភាសាខ្មែរ ដែលបានលើកឡើងថាមានឡានចំនួន ១២ គ្រឿង និងកត់សម្គាល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបកប្រែជាភាសាបារាំង លើកឡើងថា គាត់បានឃើញឡានចំនួន ០២ គ្រឿង ដែលការបកប្រែនេះច្បាស់ជាមានកំហុស៖ សូមមើល ERN (ជាភាសាបារាំង) 00887730 និង ERN (ជាភាសាខ្មែរ) 00461101។

[២១២៥] ទោះបីជា ស៊ុម អាឡាត់ បានអះអាងថា ឡានមួយគ្រឿងអាចដឹកមនុស្សពី ៥០ ទៅ ៦០ នាក់ក៏ដោយ ក៏ភស្តុតាងផ្សេងបានបង្ហាញថា មានមនុស្សជាមធ្យមប្រហែល ២៥ ទៅ ៣០ នាក់ ក្នុងមួយឡាន៖ *សូមមើល* ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២០-២១ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637) ២១, ២២-២៥ (បានសង្កេតឃើញឡានដឹកមនុស្សពេញៗចាកចេញទៅ ដោយឡានមួយគ្រឿងៗអាចដឹកមនុស្សបានពី ៥០ ទៅ ៦០ នាក់)។ *ប្រៀបធៀប* ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១៧-១៩ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សាត ឯកសារ E3/364 ដោយបានប៉ាន់ស្មានថា ឡានដែលដឹកមន្ត្រីទៅចូលរួមប្រជុំនៅសាលាខេត្តអាចដឹកយ៉ាងហោចណាស់មនុស្ស ៣០ នាក់ ក្នុងមួយឡាន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន ប៉ុន ឯកសារ E3/5344 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧-១០ ERN ជាភាសាខ្មែរ 00461098-00461101 (បានប៉ាន់ស្មានថាមានទាហាន ២៥ ទៅ ៣០ នាក់ក្នុងមួយឡាន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ជាភាសាខ្មែរ) 00273426 (អតីតមន្ត្រី លន់ នល់ ម្នាក់ពីទីក្រុងភ្នំពេញដែលត្រូវបានបញ្ជូនទៅធ្វើការនៅភូមិពោធិ៍២ ក្នុងខេត្តពោធិ៍សាត់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានប៉ាន់ស្មានថា ឡានទាហានពណ៌សដែលគាត់បានឃើញដឹកទាហាន លន់ នល់ ទៅទួលពោធិ៍ជ្រៃប្រហែលមួយខែក្រោយរំដោះទីក្រុងភ្នំពេញ អាចដាក់មនុស្សបាន ៣០ នាក់ក្នុងមួយឡាន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់រស់នៅក្នុងខេត្តពោធិ៍សាត់ដែលបានឃើញឡាន បានប៉ាន់ស្មានថា ឡានមួយគ្រឿងៗអាចដឹកមនុស្សបាន ៤០ នាក់)។

[២១២៦] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៨-១០ (គ្មានជនស៊ីវិលឡើងជិះឡាននោះទេ មានតែទាហានប៉ុណ្ណោះ) ១០-១១ (ទាហានដែលស្លៀកពាក់ឯកសណ្ឋាន និងពាក់សឹង ឃើញជិះនៅលើឡានបាំងខាងក្រោយ) ១២-១៣ (គាត់មិនដែលបានឃើញអ្នកជិះនៅលើឡានស្លៀកពាក់សម្លៀកបំពាក់ជនស៊ីវិលនោះទេ)។ *ប្រៀបធៀបនឹង* ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ៦៧-៦៩, ៧២-៧៣ (បានផ្តល់សក្ខីកម្មថាមនុស្សភាគតិចនៅលើឡានស្លៀកពាក់សម្លៀកបំពាក់យោធា ហើយគាត់ខ្លួនឯងស្ថិតនៅក្នុងសម្លៀកបំពាក់ជនស៊ីវិល)។ *សូមមើលផងដែរ* កំណត់ ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ

ជឿជាក់បាននៃការរៀបរាប់របស់សាក្សីអំពីការដឹកជញ្ជូននោះទេ។ អង្គជំនុំជម្រះយល់ឃើញថា ទាំងជនស៊ីវិល និងទាហាន បានចូលរួមនៅក្នុងកិច្ចប្រជុំនៅសាលាខេត្ត ហើយអ្នកដែលត្រូវបានដឹកជញ្ជូនបន្ទាប់ពីប្រជុំនៅសាលាខេត្តទៅកាន់ទួលពោធិ៍ជ្រៃ ក៏មានទាំងអតីតទាហាន លន់ នល់ ដែលមិនមានអាវុធនៅពេលនោះ និងមន្ត្រីរដ្ឋការស៊ីវិលនៃរបប លន់ នល់ ផងដែរ។

## ១២.៤ ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ

៦៧៨. ទោះបីជាគ្មានសាក្សីណាម្នាក់ ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្ម មានវត្តមាននៅទីតាំងទួលពោធិ៍ជ្រៃ ដែលបានឃើញដោយផ្ទាល់អំពីវាសនានៃអ្នកដែលត្រូវបានដឹកជញ្ជូនទៅទីនោះក្តី អង្គជំនុំជម្រះបានពិនិត្យមើលភ័ស្តុតាងជាច្រើន អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើង ដែលអង្គជំនុំជម្រះ អាចទាញការសន្និដ្ឋានបានពីភ័ស្តុតាងទាំងនេះ ។ ជាពិសេស ៣ថ្ងៃក្រោយពីការដឹកជញ្ជូនទាំងនោះ ស៊ុម អាឡាត់ បាននិយាយជាមួយទាហាន លន់ នល់ ២ រូប ដែលមានឈ្មោះ ផាត និង ដោ ដែលអ្នកទាំងពីរបានរត់រួចពីការសម្លាប់នោះ។ ពួកគេបានប្រាប់ ស៊ុម អាឡាត់ ថា អ្នកនៅលើឡានទាំងអស់ ត្រូវបានបង្ខំឲ្យចុះពីលើឡាននៅចំណុចមួយដែលមានចំងាយប្រហែលជា ៧០០

---

២០០៩ ទំព័រ ៣ ERN (ជាភាសាខ្មែរ) 00273426 (អតីតទាហាន លន់ នល់ ម្នាក់ ពីទីក្រុងភ្នំពេញដែលត្រូវបានគេបញ្ជូនទៅធ្វើការនៅភូមិពោធិ៍ពីរ ក្នុងខេត្ត ពោធិ៍សាត់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានឃើញទាហាន លន់ នល់ស្ថិតនៅក្នុងសម្លៀកបំពាក់ និងពាក់សក្តិរបស់ពួកគេបានឡើងជិះឡានពីសាលាខេត្តទៅទួលពោធិ៍ជ្រៃ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់រស់នៅក្នុងខេត្តពោធិ៍សាត់ បានឃើញមានពេទ្យស្រីម្នាក់ស្ថិតនៅក្នុងសម្លៀកបំពាក់ពេទ្យទាហាន ប្រុសស្ថិតក្នុងសម្លៀកបំពាក់ទាហាន និងអ្នកខ្លះស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល)។ ភ័ស្តុតាងបានបង្ហាញបន្ថែមទៀតថា ទាហានស្លៀកពាក់សម្លៀកបំពាក់ជនស៊ីវិល ដែលធ្វើឲ្យយើងពិបាកបែងចែករវាងទាហាន និងជនស៊ីវិលណាស់៖ ប្រតិចារឹក ថ្ងៃទី២៩ ខែ មេសាឆ្នាំ ២០១៣ (អ៊ុង ឆាត់) ទំព័រ ៦៣, ៦៥-៦៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុង ឆាត់) ទំព័រ ១០-១២, ២៨-៣០, ៥៣-៥៤, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង ឆាត់ ឯកសារ E3/4600 ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00369242-00369243 (មនុស្សគ្រប់គ្នាស្លៀកសម្លៀកបំពាក់ជនស៊ីវិល ដូច្នេះ វាអាចមានទាំងទាហាន និងមន្ត្រីរដ្ឋាភិបាលនៅក្នុងសាលាខេត្ត)។ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ១០.០៥ (បុរសបើកឡានមិនស្គាល់អត្តសញ្ញាណម្នាក់ដែលបើកឡានដឹកទាហានទៅទួលពោធិ៍ជ្រៃ បានលើកឡើងថា ទាហានទាំងនោះស្លៀកសម្លៀកបំពាក់ស៊ីវិល)។

ម៉ែត្រទៅ១គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃ ហើយបន្ទាប់មក អ្នកទាំងនោះត្រូវបានគេចងបណ្ដើរទៅចូលជាមួយក្រុមផ្សេងទៀត និងត្រូវបានសម្លាប់ចោល[២១២៧]។

៦៧៩. ទោះបីជាទួលពោធិ៍ជ្រៃស្ថិតនៅឆ្ងាយពីទីតាំងឈរជើងរបស់ លឹម សាត ដែលធ្វើឲ្យគាត់មិនអាចឮស្នូរកាំភ្លើងដោយផ្ទាល់ក្តី គាត់បានផ្តល់ភ័ស្តុតាងថា គាត់បានឮស្នូរកាំភ្លើងជាច្រើននៅក្នុងការទំនាក់ទំនងគ្នាតាមវិទ្យុពីទួលពោធិ៍ជ្រៃ ហើយគាត់បានឮថា មានមនុស្សម្នាក់បានរត់គេចខ្លួន[២១២៨]។ ទាំង អ៊ុំង ឆាត់ និង លឹម សាត បានកត់សម្គាល់ថា ឡានដែលបានដឹកអ្នកចូលរួមកិច្ចប្រជុំនៅទួលពោធិ៍ជ្រៃ គឺបានត្រឡប់មកសាលាខេត្តវិញ ហើយសុទ្ធតែជាឡានទទេ[២១២៩]។ អ៊ុំង ឆាត់ក៏បានឮថា អ្នកភូមិដែលបានឮស្នូរកាំភ្លើង បានទៅមើលកន្លែងនោះ ហើយបានឃើញសាកសពដែលមានដៃជាប់ចំណង[២១៣០]។ រហូតមកទល់ថ្ងៃផ្តល់សក្ខីកម្ម ស៊ុម អាឡាត់ មិនបានទទួលព័ត៌មានអ្វីទាំងអស់ពីមិត្តរបស់គាត់ដែលត្រូវបានគេយកទៅទីនោះទេ[២១៣១]។

---

[២១២៧] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២៨-២៩, ៧៤-៧៦។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៤-២៥ (ក៏បានស្តាប់ឮតាមរយៈវិទ្យុទាក់ទងពីទួលពោធិ៍ជ្រៃថា មានមនុស្សម្នាក់រត់រួច)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៥ ERN (ជាភាសាខ្មែរ) 00273440 (មនុស្ស២នាក់បានរត់រួច)។

[២១២៨] ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣(លឹម សាត)ទំព័រ ២៤-២៥ (គាត់បានឮស្នូរបាញ់កាំភ្លើង និងឮតាមវិទ្យុទាក់ទងថាមានមនុស្សម្នាក់រត់រួច), ៧៤ (អ្នកធ្វើការជាមួយគាត់ដែលមានវិទ្យុទាក់ទងបានប្រាប់គាត់អំពីករណីនេះ)។

[២១២៩] ប្រតិចារឹកថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៣ (អ៊ុំង ឆាត់)ទំព័រ ៦៧-៦៩។ ប្រតិចារឹក ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) ទំព័រ ៥-៦, ១០-១១។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៥-២៦។

[២១៣០] ប្រតិចារឹក ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត់) ទំព័រ ៩-១២, ១៥-១៧, ១៨-២០, ២១-២៤, ៧៥-៧៧។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (កសិករម្នាក់រស់នៅក្នុងខេត្តពោធិ៍សាត់ គាត់បានឃើញសាកសពនៅថ្ងៃបន្ទាប់។ សាកសពត្រូវបានគេចងជាប់គ្នា ដោយគេចងដៃទៅខាងក្រោយ ហើយឃើញមានស្នាមគ្រាប់កាំភ្លើង)។

[២១៣១] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ៣១-៣២។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទេស បុប្ផា ឯកសារ E3/4811 ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ ២០១០ ទំព័រ ៣-៤ ERN (ជាភាសាខ្មែរ) 00518752-00518753 (អតីតមន្ត្រីរដ្ឋការម្នាក់ដែលលាក់បាំងអត្តសញ្ញាណរបស់ខ្លួន បានលើកឡើងថា គ្មានមន្ត្រីរដ្ឋការ ណាម្នាក់ដែលត្រូវបានគេបញ្ជូនឲ្យទៅរៀនសូត្រ និងទទួលសម្តេច នរោត្តម សីហនុ នៅខែ មេសា ឆ្នាំ ១៩៧៥ ក្នុងខេត្តពោធិ៍សាត់ បានវិលត្រឡប់មកវិញនោះទេ)។

៦៨០. ខ្មែរក្រហមបានដោះយកស្បែកជើង នាឡិកាដៃ និងកាបូបស្ពាយពីអ្នកដែលត្រូវគេសម្លាប់នៅទួលពោធិ៍ជ្រៃ ហើយយករបស់របរទាំងនេះត្រឡប់មកវិញ[២១៣២]។ ការសម្លាប់នៅទួលពោធិ៍ជ្រៃត្រូវបានធ្វើឡើងដោយកងទ័ពមកពីភូមិភាគពាយ័ព្យ ចំណែកឯកងទ័ពមកពីកងវរសេនាតូចលេខ ២០១ ឬ ២០២ មានភារកិច្ចយាមផ្លូវ[២១៣៣]។ ក្រោយមក ជនរងគ្រោះដែលត្រូវសម្លាប់ ត្រូវបានកប់នៅកន្លែងទួលពោធិ៍ជ្រៃ ឬ ត្រូវបានឈូសទម្លាក់ក្នុងត្រពាំង ដោយប្រើប្រាស់ឧបករណ៍របស់គណៈភូមិភាគ ដែលត្រូវបានបញ្ជូនទៅទួលពោធិ៍ជ្រៃ[២១៣៤]។

---

[២១៣២] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ១១-១២។

[២១៣៣] ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៤១-៤២, ៦១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ) 00273437-00273438 (ទាហានខ្មែរក្រហមពុំធ្វើដំណើរអមទៅជាមួយនឹងទាហានទៅទីនោះទេ ប៉ុន្តែទាហានខ្មែរក្រហមនៅទីកន្លែងនោះចាំសម្លាប់ទាហានដែលទៅដល់) ទំព័រ ៥ ERN (ជាភាសាខ្មែរ) 00273440 (ទាហានដែលធ្វើការកាប់សម្លាប់ និងអ្នកបើកឡានត្រាក់ទ័រឈូស "មកពីឆ្ងាយ")។ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ៨.៣៣ (បុរសមិនស្គាល់ អត្តសញ្ញាណម្នាក់ពី 'កងការពារ' បាននិយាយថា ទាហានមកពីភូមិភាគ និងកង១៨ និងកង១៩ ស្ថិតនៅទួលពោធិ៍ជ្រៃ)។ លឹម សាត បានប៉ាន់ស្មានថា មានខ្មែរក្រហម ៥០ ទៅ ៦០ នាក់ នៅទួលពោធិ៍ជ្រៃនៅពេលនោះ៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២២-២៣។

[២១៣៤] ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២៨, ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៦-២៧ (បានឃើញឡានត្រាក់ទ័រត្រឡប់មកពីទួលពោធិ៍ជ្រៃ)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត់) ទំព័រ ១៦-១៧, ២២-២៤ (គាត់ក៏បានឃើញកំទេចសាកសព ឆ្អឹង នៅពេលគាត់ទៅមើលទីតាំងនោះជាមួយអ្នកស៊ើបអង្កេតនាពេលក្រោយមក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី ឯកសារ E3/5234 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ទំព័រ៤-៥ ERN (ជាភាសាខ្មែរ) 00273427-00273428 (អតីតទាហាន លន់ នល់ ម្នាក់ ដែលធ្វើការនៅភូមិពោធិ៍ពីរក្នុងខេត្តពោធិ៍សាត់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានឆ្លងកាត់ទីកន្លែងនោះ ហើយបានឃើញស្នាមត្រាក់ទ័រជីកកាយកប់សាកសពទាំងអស់បាត់អស់ទៅហើយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿន ឯកសារ E3/5235 ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ជាភាសាខ្មែរ) 00273438-00273439 (នៅថ្ងៃបន្ទាប់ ត្រាក់ទ័រជីកកាយ២គ្រឿងត្រូវបានគេឃើញនៅទីនោះ ហើយបានរៀបរាប់ពិពណ៌នាអំពីស្រះទឹក)។ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា - ខេត្តពោធិ៍សាត់* ឯកសារ E3/2066 ឆ្នាំ ១៩៩៧ ERN ជាភាសាខ្មែរ 00292763-00292764, 00292767-00292768។ *សូមមើលផងដែរ* មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា-ខេត្តពោធិ៍សាត់* ឯកសារ E3/2066 ឆ្នាំ ១៩៩៧ ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ៧.១២ (នារីមិនស្គាល់អត្តសញ្ញាណម្នាក់បានរៀបរាប់ថា គាត់បានឃើញសាកសពដែលត្រូវបានកប់ក្នុងស្រះទឹក) ត្រង់ម៉ោង ១៣.៥១-១៣.៥៧ (បុរសមិនស្គាល់

៦៨១. ការសន្និដ្ឋានសមហេតុផលដែលទាញចេញពីភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ គឺថា មន្ត្រីរដ្ឋការនៃរបប លន់ នល់ ដែលត្រូវបានដឹកទៅទួលពោធិ៍ជ្រៃប្រហែលថ្ងៃទី២៥ ឬ ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានគេសម្លាប់ចោល[២១៣៥]។ ទោះបីជាភ័ស្តុតាងមានភាពខុសៗគ្នាអំពីចំនួនជាក់លាក់នៃរងគ្រោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា យ៉ាងហោចណាស់ អតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ ចំនួន ២៥០ នាក់ បានសម្លាប់នៅក្នុងពេលនោះ[២១៣៦]។

---

អត្តសញ្ញាណម្នាក់បានលើកឡើងថា "ពួកគេចង់លាក់ [លាក់សាកសព] ទាំងអស់នៅក្នុងស្រះទឹក។ ប៉ុន្តែ ស្រះទឹកនោះមិនធំល្មមនោះទេ។ នៅពេលស្រះទឹកពេញ ពួកគេបានទុកសាកសពនៅលើវាល") ត្រង់ម៉ោង១៤.៣២ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បានលើកឡើងថា "សាកសពនៅព័ទ្ធជុំវិញស្រះទឹក") ត្រង់ម៉ោង ១៨.១៥ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បានលើកឡើងថា ខ្មែរក្រហមបានប្រើត្រាក់ទ័រឈូសកប់សាកសព)។ ប្រតិចារឹក ថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២៦-២៧ (គណៈភូមិភាគបានបញ្ជូនត្រាក់ទ័រឈូស)។

[២១៣៥] *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សារុធ ឯកសារ E3/5177 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០៨ ទំព័រ៤-៥ ERN (ជាភាសាខ្មែរ) 00196805-00196806 (បានលើកឡើងថា អតីតទាហាន និងមន្ត្រី លន់ នល់ ត្រូវបានគេបាញ់សម្លាប់ចោល)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជ័យ យ៉ាន ឯកសារ E3/4857 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ៣ ERN (ជាភាសាខ្មែរ) 00530043 (អ្នកស្រុកបាកានបានលើកឡើងថា អ្នកដែលត្រូវបានគេយកទៅរៀនសូត្រត្រូវបានគេសម្លាប់ចោល)។ ភ័ស្តុតាងផ្សេងទៀតបង្ហាញស្របដូច្នេះថា ទាហាន លន់ នល់ ត្រូវបានគសម្លាប់ចោលនៅទួលពោធិ៍ជ្រៃ ទោះបីជាវាពុំបង្ហាញច្បាស់ថាភស្តុតាងនេះពាក់ព័ន្ធនឹងអំឡុងពេលណាក៏ដោយ៖ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុតវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ១.៥១ (ពួកគេត្រូវបានគេសម្លាប់ចោល) ត្រង់ម៉ោង ២.២៤ (យ៉ុង សុខញ៉ិប (Yong Sok Nheb) បានលើកឡើងថា ក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ សាកសពបានគរលើគ្នានៅទួលពោធិ៍ជ្រៃ) ត្រង់ម៉ោង ៣.២៧-៣.៤៤, ៤.៥០-៥.៥០ (ប៉ូ ចៀន បានលើកឡើងថា គាត់ទៅទួលពោធិ៍ជ្រៃនៅព្រឹកបន្ទាប់ ហើយបានឃើញសាកសពនៅគ្រប់ទីកន្លែង ដែលត្រូវគេចងជាប់គ្នាជាមួយនឹងខ្សែ ហើយសាកសពទាំងនោះមិនទាន់រលួយនៅឡើយទេ) ត្រង់ម៉ោង ១០'៥៥-១១'១៥ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់បាន និយាយថា ក្រោយពេលទាហានចុះពីលើឡាន គេចងដៃពួកគេ បណ្តើរទៅវាលពិឃាត ដែលនៅទីនោះពួកគេត្រូវបានគេបាញ់សម្លាប់ចោលម្នាក់ម្តងៗ)។

[២១៣៦] *សូមមើល*ផ្នែកទី១២, ទួលពោធិ៍ជ្រៃ, កថាខណ្ឌ ៦៧៦។ ទោះបីជាសាក្សី លឹម សាត បានប៉ាន់ស្មានថា ទាហាន លន់ នល់ ចំនួនជិត២.០០០ នាក់ ត្រូវបានដឹកទៅទួលពោធិ៍ជ្រៃក៏ដោយ ភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងចំនួនឡាន និងអ្នកចូលរួមប្រជុំ ជាទូទៅ គឺមានភាពច្របូកច្របល់គ្នា៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ២០-២១, ២៤-២៧។ សាក្សី សៀម សឿម បានឃើញសាកសពជិត ១.០០០ សាកសព នៅទួលពោធិ៍ជ្រៃនៅក្នុងហេតុការណ៍ក្រោយខែមេសា ឆ្នាំ១៩៧៥៖ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀម សឿម ឯកសារ E3/5235 ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ជាភាសាខ្មែរ)00273437-00273438។ទោះបីជា ស៊ុម

01006950



## ១២.៥ សម្អាងច្បាប់

៦៨២. ដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទពីបទការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ[២១៣៧]។ នៅផ្នែកខាងលើ អង្គជំនុំជម្រះបានសន្និដ្ឋានថា លក្ខខណ្ឌ *ទូទៅ* នៃមាត្រា៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ[២១៣៨]។

---

អាឡាត់ បានផ្តល់សក្ខីកម្មថា សេង ឈន អតីតប្រធានឃុំស្វាយលួង ស្រុកកណ្តៀង បានប្រាប់គាត់ថា ជនរងគ្រោះ ២.០០០ នាក់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃក៏ដោយ ក៏គាត់ពុំបានបញ្ជាក់ឲ្យបានច្បាស់ ថាតើការសម្លាប់នេះ គឺជាប់ពាក់ព័ន្ធនឹងអំឡុងពេលមួយជាក់លាក់ឬក៏យ៉ាងណា។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ទំព័រ ២៩-៣០ (*ដកស្រង់* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ ឯកសារ E3/4637)។ *ប្រៀបធៀបនឹង* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុយ សេងឈន ឯកសារ E3/4638 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤-៥ ទំព័រ ៤-៦ ERN (ជាភាសាខ្មែរ) 00196819-00196821 (កសិករមូលដ្ឋានម្នាក់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ បានប៉ាន់ស្មានថាបានឃើញសាកសពប្រហែល៣.០០០ សាកសពនៅទីនោះ ហើយបានលើកឡើងថា មានសាកសព ៥.០០០ សាកសពទៀតនៅក្នុងស្រះ)។ ‘គម្រោងគូសផែនទីវាលពិឃាត’ ធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារ កម្ពុជា (DC-Cam) នៅក្នុងឆ្នាំ ១៩៩៧ បានប៉ាន់ស្មានថា ប្រជាជន ១០.៣៦៣ នាក់ ត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៨ ក្នុងនោះមានជនរងគ្រោះ ៦.៨៦៣ ជាទាហាន គ្រូបង្រៀន សាស្ត្រាចារ្យ ឬ ប្រជាជនធម្មតា រួមទាំងអភិបាលខេត្ត ព្រំ លីហួន។ គម្រោងគូសផែនទី ពុំបង្ហាញថាតើមានជនរងគ្រោះទាំងនេះប៉ុន្មាននាក់ត្រូវបានគេសម្លាប់ចោលនៅក្នុងហេតុការណ៍ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នោះទេ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា - ខេត្តពោធិ៍សាត់* ឯកសារ E3/2066 ឆ្នាំ ១៩៩៧ ERN (ជាភាសាខ្មែរ) 00292763-00292764, 00292768-00292769 និង មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *ការគូសផែនទីវាលពិឃាតកម្ពុជា -កន្លែងឧក្រិដ្ឋកម្ម* ឯកសារ E3/2066 ឆ្នាំ១៩៩៧ ERN (ជាភាសាខ្មែរ) 00292775។ *សូមមើលផងដែរ* ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ឈុត វីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ត្រង់ម៉ោង ១៥.០៩ (បុរសមិនស្គាល់អត្តសញ្ញាណម្នាក់មកពី ‘កងការពារ’ បានលើកឡើងថា គាត់បានសួរសមាជិកនៃ “កងកម្ទេច” ថា ទាហានប៉ុន្មាននាក់ទំនងត្រូវបានសម្លាប់ ហើយត្រូវបានគេប្រាប់ថា “មានមនុស្សចំនួនជិត ១០.០០០ នាក់”) ត្រង់ម៉ោង ១៥.៣៥-១៥.៤៧ (បុរសមិនស្គាល់អត្តសញ្ញាណពី “កងការពារ” បាននិយាយជាមួយនឹង បុល (Bol) ដែលជាកម្មាភិបាលជ្រើសរើសសមាជិកនៅក្នុង “កងកម្ទេច” ដែលបានប៉ាន់ស្មានថា មនុស្សប្រមាណពី ៩.០០០ ទៅ ១០.០០០ នាក់ត្រូវបានសម្លាប់ចោល)។

[២១៣៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣ (ការធ្វើមនុស្សឃាត), កថាខណ្ឌ ១៣៨១ (ការសម្លាប់រង្គាល), កថាខណ្ឌ ១៤១៦ (ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ)។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ អនុលោមតាមដីកាបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺថា កថាខណ្ឌ ៦៩៨-៧១១ នៃដីកាដំណោះស្រាយពាក់ព័ន្ធនឹង

៦៨៣. *ការធ្វើមនុស្សឃាត* ៖ បុគ្គលដែលត្រូវបានបញ្ជូនពីសាលាខេត្តទៅកាន់ទួលពោធិ៍ជ្រៃ រួមមានទាំងអតីតទាហាន លន់ នល់ ដែលបានចុះចាញ់និងមិនមានអាវុធនៅពេលបញ្ជូនខ្លួន និងអតីតមន្ត្រីរដ្ឋការស៊ីវិលនៃរបប លន់ នល់ ។ ជនរងគ្រោះនៃការសម្លាប់នៅទួលពោធិ៍ជ្រៃ រួមមានជនស៊ីវិល និងអតីតទាហាននៃរបប លន់ នល់ ដែលបានចុះចាញ់ និងលែងចូលរួមក្នុងការប្រយុទ្ធទៀតហើយនៅពេលដែលត្រូវបានគេដឹកជញ្ជូន និងសម្លាប់នៅទួលពោធិ៍ជ្រៃនោះ។ ដោយពិចារណាទៅលើសំអាងហេតុទាក់ទងនឹងការដឹកជញ្ជូន និងការសម្លាប់មន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ[២១៣៩] អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវគតិយុត្តិចំពោះបទល្មើសការធ្វើមនុស្សឃាតគឺត្រូវបានបំពេញ (ពោលគឺជនរងគ្រោះទាំងនេះបានស្លាប់ ហើយការស្លាប់របស់ជនទាំងនោះបណ្តាលមកពីការប្រព្រឹត្តិរបស់កងទ័ពខ្មែរក្រហមមកពីភូមិភាគពាយ័ព្យ) ។ លើសពីនេះទៀត ដោយពិចារណាទៅលើចំនួនច្រើននៃមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដែលត្រូវបានដឹកបញ្ជូន និងសម្លាប់ ការដឹកជញ្ជូនជាច្រើនដងទៅកាន់កន្លែងសម្លាប់ ព្រមទាំង របៀបនៃការសម្លាប់នោះ អង្គជំនុំជម្រះយល់ឃើញថា កងទ័ពខ្មែរក្រហមមកពីភូមិភាគពាយ័ព្យនៅទួលពោធិ៍ជ្រៃមានចេតនាសម្លាប់ជនរងគ្រោះទាំងអស់នេះ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសម្លាប់មន្ត្រីរដ្ឋការនៃរបប លន់ នល់ ទាំងនោះ គឺជាបទមនុស្សឃាត។

៦៨៤. *ការសម្លាប់រង្គាល៖* ការសម្លាប់មន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ប្រហែល ១ សប្តាហ៍បន្ទាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដែលមានចំនួនយ៉ាងហោចណាស់ ២៥០ នាក់នោះ គឺស្ថិតក្នុងកម្រិតមួយដែលបានបំពេញលក្ខខណ្ឌនៃការសម្លាប់រង្គាល[២១៤០]។ ដោយពិចារណាលើចំនួនមន្ត្រីរដ្ឋការនៃរបប លន់ នល់ ជាច្រើន ដែលត្រូវបានដឹកយកទៅនិងសម្លាប់ ការដឹកជញ្ជូនជាច្រើនដងទៅកន្លែងសម្លាប់ ព្រមទាំងវិធីនៃការសម្លាប់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា

---

ទួលពោធិ៍ជ្រៃ និងបទល្មើសដែលបានចោទប្រកាន់ ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ *សូមមើល* ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២ ឯកសារ E124/7.3 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៨ ទំព័រ ១-២។

[២១៣៨] *សូមមើល*ផ្នែកទី៤, ទិដ្ឋភាពទូទៅ: ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៩៨។

[២១៣៩] *សូមមើល*ផ្នែកទី១២, ទួលពោធិ៍ជ្រៃ, កថាខណ្ឌ ៦៨១។

[២១៤០] *សូមមើល*ផ្នែកទី១២, ទួលពោធិ៍ជ្រៃ, កថាខណ្ឌ ៦៨១។

កងទ័ពខ្មែរក្រហមមកពីភូមិភាគពាយ័ព្យនៅទួលពោធិ៍ជ្រៃ មានចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ តាមរយៈអំពើរបស់ពួកគេដែលបានប្រព្រឹត្ត ការសម្លាប់រង្គាល។

៦៨៥. *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖* អំពើមនុស្សឃាត និងការសម្លាប់រង្គាល ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ គឺមានគោលដៅទៅលើមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដែលជាក្រុមត្រូវបានគេស្គាល់យ៉ាងច្បាស់។ អំពើទាំងនេះបានរំលោភបំពាន និងបដិសេធនូវសិទ្ធិរស់រានមានជីវិតជាសារវ័ន្តរបស់បុគ្គលទាំងនេះ ដូចមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[២១៤១]។ អំពើទាំងនេះ ពិតជាការរើសអើង ដោយសារតែជនរងគ្រោះ គឺជាអតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់។

៦៨៦. អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញថា ការសម្លាប់ទាំងនោះបានប្រព្រឹត្តឡើងដោយមានចេតនារើសអើងទៅលើអតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដោយសារមូលហេតុនយោបាយ។ ការសន្និដ្ឋាននេះ ធ្វើឡើងដោយផ្អែកទៅលើភ័ស្តុតាងនៃការប្រកាសជាផ្លូវការតាមវិទ្យុពាសពេញប្រទេស ដែលកំណត់អតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ ថាជាសត្រូវ និងអង្គហេតុដែលថា អំពើស្រដៀងគ្នានេះជាច្រើនត្រូវបានប្រព្រឹត្តទៅលើមន្ត្រីរដ្ឋការនៃរបប លន់ នល់ ពេញប្រទេសកម្ពុជា

---

[២១៤១] ពាក់ព័ន្ធនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *សូមមើល* សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាត 217A (III), UN GAOR, សម័យប្រជុំលើកទីបី ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ៣។ អនុសញ្ញាទីក្រុងហ្សឺណែវទី I-IV ឆ្នាំ ១៩៤៩ មាត្រា ៣ (១)(ក) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៥៨។ អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលបើកឱ្យចុះហត្ថលេខានៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ 213 UNTS 221 (ចូលជាធរមាននៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៥៣) ដែលត្រូវបានធ្វើវិសោធនកម្មតាមរយៈ ពិធីសារលេខ ១១ និង ១៤ មាត្រា ២។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦។ *សូមមើលផងដែរ* សាលដីការឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ១០៦ (ពិចារណាឃើញថា សិទ្ធិរស់រានមានជីវិត និងរួចផុតពីការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មដ៏សាហាវ អមនុស្សធម៌ ឬបន្ទាបបន្ថោក ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងមានចែងនៅក្នុងមាត្រា ៦ និង ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ២ និងមាត្រា ៣ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប)។ យុត្តិសាស្ត្រពីតុលាការអន្តរជាតិបង្ហាញច្បាស់ថា អំពើសម្លាប់ដោយចេតនា ការធ្វើមនុស្ស ឃាត និងអំពើបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ និងបញ្ញាស្មារតី មានស្ថានទម្ងន់គ្រប់គ្រាន់ បើប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មផ្សេងទៀត ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ។ ហេតុដូច្នេះ អំពើទាំងនេះអាចចាត់ទុកជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ)។

ទាំងមូល ក្រោយពីពេលកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥[២១៤២]។ ការសន្និដ្ឋាននេះត្រូវបានគាំទ្របន្ថែមទៀត ដោយកាលៈទេសៈផ្សេងៗជុំវិញការប្រព្រឹត្តិបទល្មើស ដែលជាលក្ខណៈរើសអើង និងការកំណត់គោលដៅនៃបញ្ជារបស់សមាជិកគណៈភូមិភាគពាយ័ព្យឈ្មោះ តា ញឹម និង តា កន និងអត្តសញ្ញាណដូចគ្នានៃក្រុមជនរងគ្រោះដែលជាអតីតសមាជិកនៃរបប លន់ នល់។

៦៨៧. *សេចក្តីសន្និដ្ឋាន៖* ដោយយល់ឃើញថា លក្ខខណ្ឌទូទៅ នៃមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបំពេញ ដូចនេះ ការសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ គឺជាបទល្មើសការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## ១៣. ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល

### ១៣.១ សេចក្តីផ្តើម

៦៨៨. *មាត្រា* ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីទម្រង់ជាធរមាននៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលក្នុងនោះមាន ការប្រព្រឹត្តិ ការរៀបចំផែនការ ការញុះញង់[២១៤៣] ការបញ្ជា ការជួយ និងការជំរុញ[២១៤៤] និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទថា បានប្រព្រឹត្តតាមរយៈអំពើសកម្ម និងអំពើអកម្មរបស់ពួកគេ (និងតាមរយៈសហឧក្រិដ្ឋកម្មរួម) បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយ និងបានជំរុញឱ្យមានបទឧក្រិដ្ឋដែលបានចោទប្រកាន់[២១៤៥]។ លើសពីនេះទៀត ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់។ អង្គជំនុំជម្រះ

---

[២១៤២] *សូមមើល* ផ្នែកទី៤ ទិដ្ឋភាពទូទៅ: ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៧២។ ផ្នែកទី៦ រចនាសម្ព័ន្ធទំនាក់ទំនង កថាខណ្ឌ ២៥៤-២៦០។

[២១៤៣] ភាពខុសគ្នារវាងសំណៅភាសាខ្មែរ អង់គ្លេស និងបារាំងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពាក់ព័ន្ធនឹងសញ្ញាណនៃពាក្យថា ការជំរុញ (instigation) និងការញុះញង់ (incitement) សូមមើល ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៩ លេខជើងទំព័រ ២១៧៩។

[២១៤៤] ភាពខុសគ្នារវាងសំណៅភាសាខ្មែរ អង់គ្លេស និងបារាំងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពាក់ព័ន្ធនឹងសញ្ញាណនៃពាក្យថា ការជួយ និងការជំរុញ និង "ការសមគំនិត" សូមមើល ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧០៣ លេខជើងទំព័រ ២១៩៤។

[២១៤៥] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣។ ផ្នែកទី ១៖ សេចក្តីផ្តើម កថាខណ្ឌ ១១។

01006954



អាចជ្រើសរើសទម្រង់មួយ ឬច្រើន ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលមានលក្ខណៈត្រឹមត្រូវបំផុតអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះមិនតម្រូវឱ្យធ្វើសំអាងហេតុលម្អិតទៅលើគ្រប់បទចោទទាំងអស់នោះទេ[២១៤៦]។ ក្នុងករណីជនជាប់ចោទត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវផ្ទាល់ និងត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើទាក់ទងនឹងអំពើដូចគ្នា អង្គជំនុំជម្រះត្រូវផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវផ្ទាល់ ហើយចាត់ទុកឋានៈជាថ្នាក់លើរបស់ជនជាប់ចោទជាស្ថានទម្ងន់ទោសនៅពេលសម្រេចអំពីទោស[២១៤៧]។

៦៨៩. អង្គជំនុំជម្រះត្រូវកំណត់ថាតើទម្រង់នៃការទទួលខុសត្រូវនីមួយៗបានបំពេញគោលការណ៍នីត្យានុកូលភាពដែរ ឬ ទេ ពោលគឺ ថាតើទម្រង់នៃការទទួលខុសត្រូវនីមួយៗនេះមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬនៅក្នុងច្បាប់កម្ពុជានៅចន្លោះឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៩ ដែរ ឬ យ៉ាងណា ហើយថាតើជនជាប់ចោទអាចប្រមើលឃើញ និងអាចដឹងគ្រប់គ្រាន់ថាទម្រង់នៃការទទួលខុសត្រូវនីមួយៗនេះមានចែងនៅក្នុងច្បាប់ដែរ ឬ ទេ[២១៤៨]។

## ១៣.២ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម

៦៩០. ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ("JCE") អាចចាត់ទុកជាការប្រព្រឹត្តិនៅក្នុងវិសាលភាពនៃមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[២១៤៩]។ តុលាការកំពូល ICTY បានសម្រេចថា សហឧក្រិដ្ឋកម្មរួមមានបីទម្រង់៖

- **ទម្រង់មូលដ្ឋាន** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី I") គឺនៅពេលអ្នកចូលរួមទាំងអស់ប្រព្រឹត្តទៅតាមគោលបំណងរួម និងមានចេតនាឧក្រិដ្ឋតែមួយដូចគ្នា[២១៥០]

---

[២១៤៦] វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៤៧២។

[២១៤៧] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣៩។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៩១។

[២១៤៨] ផ្នែកទី ២៖ បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ១៦-២០។

[២១៤៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (អ.ប.ជ) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩។ សាលក្រមនៅក្នុងរឿងក្តី *កាំងហ្គេក អ៊ាវ* កថាខណ្ឌ ៥១១។

[២១៥០] សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៩៦-២០១។

- **ទម្រង់ជាប្រព័ន្ធ** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី II") គឺសំដៅលើករណីនៃការធ្វើបាបនៅក្នុងស្ថាប័នដែលមានរចនាសម្ព័ន្ធចាត់តាំង ដូចជា ជំរុំប្រមូលផ្តុំជាដើម[២១៥១] និង

- **ទម្រង់ទូលាយ** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី III") គឺនៅពេលអ្នកចូលរួមបានព្រមព្រៀងលើគោលបំណងរួមមួយដែលនាំឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ និង ទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋនោះ ទោះបីជាវានៅក្រៅគោលបំណងរួមក៏ដោយ ឲ្យតែអំពើឧក្រិដ្ឋទាំងនោះគឺជាផលវិបាកជាធម្មជាតិ និងដែលអាចប្រមើលដឹងជាមុនបានចំពោះផលវិបាកនៃគោលបំណងរួមនេះ[២១៥២]។

៦៩១. អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ នៅក្នុងច្បាប់កម្ពុជានោះទេត្រឹមឆ្នាំ ១៩៧៥[២១៥៣]។ ហេតុដូចនេះ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនត្រូវបានយកមកពិចារណាបន្ថែមទៀតឡើយ។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ឡើងវិញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី I និងសហឧក្រិដ្ឋកម្មរួមទម្រង់ទី II គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩[២១៥៤]។ នៅពេលពិចារណាលើតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងលក្ខណៈទំនៀម

---

[២១៥១] សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២០២-២០៣។

[២១៥២] សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២០៤។

[២១៥៣] សេចក្តីសម្រេចចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៣១, ៣៥, ៣៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (អ.ប.ជ) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៧៧, ៨៣, ៨៧-៨៨។

[២១៥៤] សេចក្តីសម្រេចចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (អ.ប.ជ) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៥៧-៦៩, ៧២។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥១២។ សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២០, ២២៦។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តី អៀង សារី លើកទឡ្ហីករណ៍មុនៗដដែលរបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីI និងទម្រង់ទី II មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេត្រឹមឆ្នាំ ១៩៧៥ ហើយពុំបានបង្ហាញអង្គហេតុ

ទម្លាប់នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I និងសហឧក្រិដ្ឋកម្មរួមទម្រង់ទី II ត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវនេះអាចឲ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់បានថាមានច្បាប់ចែងនាពេលនោះ[២១៥៥]។

៦៩២. សហឧក្រិដ្ឋកម្មរួមគ្រប់ទម្រង់មានធាតុផ្សំសត្យានុម័តចំនួនបី។ ធាតុផ្សំទី១ ចាំបាច់ត្រូវមានមនុស្សច្រើន។ បើទោះជាមានភាពចាំបាច់ក្នុងការចង្អុលបង្ហាញថាមានមនុស្សជាច្រើនចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមក៏ដោយ ក៏ប៉ុន្តែមិនចាំបាច់ក្នុងការកំណត់ឈ្មោះរបស់បុគ្គលដែលពាក់ព័ន្ធម្នាក់ៗឡើយ[២១៥៦]។ ធាតុផ្សំទី២ ចាំបាច់ត្រូវមានគោលបំណងរួមដែលស្មើទៅនឹង ឬ ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ[២១៥៧]។ ធាតុផ្សំទី៣ ជនជាប់ចោទចាំបាច់ត្រូវចូលរួមនៅក្នុងគោលបំណងរួមដោយបានចូលរួមចំណែកដ៏សំខាន់ ក៏ប៉ុន្តែមិនមែនមិនអាចខ្វះបាននោះទេ[២១៥៨]។

៦៩៣. ការចូលរួមនៅក្នុងគោលបំណងរួមអាចតាមរយៈអំពើសកម្ម ឬ អំពើអកម្ម[២១៥៩]។ ភាពសំខាន់នៃការចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួមនឹងត្រូវកំណត់ទៅតាមករណីនីមួយៗ ដោយ

---

ថ្មី ឬ កាលៈទេសៈថ្មីណាមួយដែលលេចចេញ ចាប់តាំងពីពេលដែលសេចក្ដីសម្រេចនានាត្រូវបានធ្វើឡើងដោយផ្អែកលើសេចក្ដីសន្និដ្ឋានមុនៗទាំងនេះ។ (ឧបសម្ព័ន្ធ កៈ សារណារបស់ អៀង សារី ស្ដីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/10.2 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣២-៣៣)។ ដូច្នេះ សំណើសុំការពិចារណាសាជាថ្មីនេះមិនអាចទទួលយកបានឡើយ។

[២១៥៥] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (អ.ប.ជ) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៦៩, ៧២។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦-៤០៧ (តួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ)។

[២១៥៦] សាលក្រមនៅក្នុងរឿងក្ដី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥០៨។ សាលដីកានៅក្នុងរឿងក្ដី *Krajišnik* កថាខណ្ឌ ១៥៦។

[២១៥៧] សាលក្រមនៅក្នុងរឿងក្ដី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥០៨។ សាលដីកានៅក្នុងរឿងក្ដី *Tadić* កថាខណ្ឌ ២២៧។

[២១៥៨] សាលក្រមនៅក្នុងរឿងក្ដី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥០៨។ សាលដីកានៅក្នុងរឿងក្ដី *Brđanin* កថាខណ្ឌ ៤៣០។

[២១៥៩] សាលដីកានៅក្នុងរឿងក្ដី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៨៧, ៤២១, ៥៥៦។ ជាគោលការណ៍ទូទៅ តុលាការកំពូល ICTY និង តុលាការកំពូល ICTR បានសម្រេចស្របគ្នាថា បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលអាចនាំឲ្យមានពិរុទ្ធ ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់ វិធានការ ហើយថា ជនជាប់ចោទអាចទទួលខុសត្រូវដោយផ្ទាល់ចំពោះការចូលរួមចំណែកចំពោះបទឧក្រិដ្ឋតាមរយៈអំពើ អកម្មនោះ ក្នុងស្ថានភាពដែលជនជាប់ចោទមានកាតព្វកិច្ចត្រូវចាត់វិធានការ (*សូមមើល ឧ.* សាលដីកានៅក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ៦៦៣។

ពិចារណាលើកត្តាជាច្រើន រួមទាំង តួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ហើយនិងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់បទឧក្រិដ្ឋ[២១៦០]។ ការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួម មិនតម្រូវថា ទាល់តែមានការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ណាមួយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ (ឧទាហរណ៍ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ឬ ការធ្វើទារុណកម្ម) ប៉ុន្តែវាអាចជាទម្រង់នៃការជួយជ្រោមជ្រែង ឬ ការចូលរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួមនោះ[២១៦១]។ អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចតម្រូវឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយចារីដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ប្រសិនបើត្រូវបានរកឃើញថា ឧក្រិដ្ឋកម្មទាំងនោះអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវ យ៉ាងហោចណាស់ទៅលើអ្នកចូលរួមណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម ហើយអ្នកចូលរួមនេះបានប្រើប្រាស់ចារីដើម្បីសម្រេចគោលបំណងរួមនោះ[២១៦២]។

៦៩៤. ចំពោះ *ធាតុផ្សំអត្តនោម័ត* នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ជនជាប់ចោទត្រូវមានចេតនាចូលរួមនៅក្នុងគោលបំណងរួម ហើយអ្នកចូលរួមផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមត្រូវមានចេតនានេះផងដែរ[២១៦៣]។ សម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ទី II ជនជាប់ចោទត្រូវដឹងអំពីចរិតលក្ខណៈនៃឧក្រិដ្ឋកម្មដែលមានការធ្វើបាបជាប្រព័ន្ធ និងមានចេតនាជួយជ្រោមជ្រែងប្រព័ន្ធធ្វើបាបជារួមនេះ[២១៦៤]។ គេត្រូវបង្ហាញថា អ្នកចូលរួមនៅក្នុងទម្រង់ណាមួយនៃសហឧក្រិដ្ឋកម្មរួម មានចេតនាដូចគ្នានឹងចារីរួមទាំងចេតនាជាក់លាក់ ដែលតម្រូវឲ្យមានសម្រាប់បទឧក្រិដ្ឋខ្លះ ដូចជា អំពើធ្វើទុក្ខបុកម្នេញ ជាដើម[២១៦៥]។ "ភាពសំខាន់ និងវិសាលភាពនៃការចូលរួមជាក់ស្តែងរបស់បុគ្គលណាម្នាក់នៅក្នុង

---

សាលដីកានៅក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៦៨, ១៧៥។ សាលដីកានៅក្នុងរឿងក្តី *Ntagerura និងអ្នកផ្សេងទៀត* កថាខណ្ឌ ៣៣៤)។

[២១៦០] សាលក្រមនៅក្នុងរឿងក្តី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ៣១១។

[២១៦១] សាលដីកានៅក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១០០។

[២១៦២] សាលដីកានៅក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២២៥។

[២១៦៣] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥០៩។ សាលដីកានៅក្នុងរឿងក្តី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ៨២, ១១៨។

[២១៦៤] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥០៩។ សាលដីកានៅក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១០១។

[២១៦៥] សេចក្តីសម្រេចចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៦។ សាលដីកានៅក្នុងរឿងក្តី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ១១០។

សហឧក្រិដ្ឋកម្មរួម ក៏អាចជាប់ពាក់ព័ន្ធនៅក្នុងការកំណត់ ថាតើបុគ្គលនេះមាន*ធាតុផ្សំអត្តនោម័ត* ដែលជាលក្ខខណ្ឌតម្រូវដែរឬទេ”[២១៦៦]។

៦៩៥. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានសន្និដ្ឋានថា ជនជាប់ចោទអាចត្រូវបានចាត់ទុកថា បានចូលរួមនៅក្នុងគោលបំណងឧក្រិដ្ឋរួមជាក់លាក់ តែក្នុងករណីដែលគោលបំណងរួមនេះមាន ចរិតឧក្រិដ្ឋប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្តីបានលើកឡើងថា ដីកាដំណោះស្រាយបានចោទប្រកាន់ ទៅលើគោលដៅស្របច្បាប់មួយពោលគឺ “បដិវត្តន៍នយោបាយសង្គមនិយមនៅក្នុងប្រទេសកម្ពុជា” ហើយថា ក្រោយពេលបង្កើតកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ទើបគោលនយោបាយឧក្រិដ្ឋត្រូវ បានអនុវត្តឡើង។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីជំទាស់ថា ចេតនានៃការប្រព្រឹត្តិបទឧក្រិដ្ឋមិន អាចត្រូវបានសន្និដ្ឋាន ដោយគ្រាន់តែផ្អែកទៅលើការចូលរួមនៅក្នុងរបបមួយនោះឡើយ[២១៦៧]។ ស្រដៀងគ្នានេះដែរ ក្រុមមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា អំពើឧក្រិដ្ឋមិនអាចផ្តាច់ចេញពី គោលបំណងរួមនេះបានទេ[២១៦៨]។

៦៩៦. ជាទូទៅ សេចក្តីសន្និដ្ឋានទាំងនេះ គឺច្រំដែលជាមួយនឹងអញ្ញត្រកម្មដែលក្រុមមេធាវីការពារ ក្តី អៀង សារី បានលើកឡើង[២១៦៩]។ អង្គជំនុំជម្រះបានច្រានចោលអញ្ញត្រកម្មទាំងនេះនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ រួចហើយ ដោយយល់ឃើញថា គោលបំណងរួមមួយត្រូវតែមានគោលដៅ របស់វាជាបទឧក្រិដ្ឋមួយ ឬ មានការពិចារណាលើការប្រព្រឹត្តិបទឧក្រិដ្ឋដែលជាមធ្យោបាយមួយ ក្នុងការសម្រេចគោលដៅរបស់វា[២១៧០]។ នៅក្នុងរឿងក្តីនេះ ទោះបីជាសហចៅក្រមស៊ើបអង្កេតបាន

---

[២១៦៦] សាលដីកានៅក្នុងរឿងក្តី *Kvočka និងអ្នកផ្សេងទៀត* កថាខណ្ឌ ៩៧, ១៨៨។

[២១៦៧] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៣-៥៧។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣១១-៣១៣។

[២១៦៨] សេចក្តីសន្និដ្ឋានបឋម [របស់ នួន ជា] ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៧។

[២១៦៩] សារណារបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី ឯកសារ E58 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៣-៦។ សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី ឯកសារ E51/4 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤(ឃ)។

[២១៧០] សេចក្តីសម្រេចចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៧។

ទទួលស្គាល់ថា គោលបំណងរួមនេះ "មិនមែនមានលក្ខណៈជាឧក្រិដ្ឋកម្មទាំងស្រុង" ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ការអនុវត្តគោលបំណងរួមនេះនាំឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ[២១៧១]។ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ថា អំពើសកម្ម និងអំពើអកម្មរបស់ជនជាប់ចោទបង្ហាញឲ្យឃើញថា ជនជាប់ចោទក៏មានចេតនាឲ្យការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះធ្វើឡើងតាមរយៈគោលបំណងរួមដែលបណ្តាលឲ្យមាន ឬ ជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនោះ[២១៧២]។ អាស្រ័យហេតុនេះ ជនជាប់ចោទខកខានមិនបានបង្ហាញឲ្យឃើញនូវការភ័ន្តច្រឡំណាមួយនោះឡើយ។

## ១៣.៣ ការរៀបចំផែនការ

៦៩៧. ត្រឹមឆ្នាំ ១៩៧៥ ការរៀបចំផែនការ គឺជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[២១៧៣]។ ដោយសារតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងដោយសារថា ការរៀបចំផែនការនេះត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវមួយទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅក្នុងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវនេះអាចឲ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង[២១៧៤]។

---

[២១៧១] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤។ កថាខណ្ឌបន្ទាប់បង្ហាញអំពីសកម្មភាពឧក្រិដ្ឋនានាដែល "បណ្តាលឲ្យ" ឬ "ត្រូវបានប្រព្រឹត្តដោយសមាជិក និងអ្នកមិនមែនសមាជិកសហឧក្រិដ្ឋកម្មរួម (ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥)។

[២១៧២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១, ១៥៣៣, ១៥៣៧។

[២១៧៣] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៧៥, ៤៧៨។ នៅមុនឆ្នាំ ១៩៧៥ លិខិតុបករណ៍អន្តរជាតិនានាបានចែងបញ្ចូលការទទួលខុសត្រូវលើការរៀបចំផែនការ (ធម្មនុញ្ញទីក្រុងតូក្យូ មាត្រា ៥ ធម្មនុញ្ញ, Nuremberg មាត្រា ៦, ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យអាល្លឺម៉ង់ លេខ ១០ មាត្រា II(2)(ឃ), គោលការណ៍ Nuremberg គោលការណ៍ VI អនុសញ្ញាស្តីពីចំណាប់ខ្មាំង មាត្រា ៤(ក))។ តុលាការ Nuremberg បានផ្តន្ទាទោសជនជាប់ចោទដែលត្រូវបាន រកឃើញថាបានរៀបចំផែនការលើបទឧក្រិដ្ឋអន្តរជាតិ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ (*សូមមើល ឧ.* សាលក្រម *Nuremberg* ទំព័រ ២៧៩-២៨២, ២៨៥-២៨៨, ២៩៤-២៩៦, ៣០៥-៣០៧, ៣១៦, ៣២២-៣២៥, ៣៣៩-៣៤១ សាលក្រមនៅក្នុងរឿងក្តី *Ministries* ទំព័រ ៤០១)។

[២១៧៤] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៧៤។ *សូមមើលផងដែរ* ផ្នែកទី ២៖ បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ១៦, ១៩, ២០។ ការរៀបចំផែនការត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ២២៣, ២៣៩ និង ២៩០ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

៦៩៨. ដើម្បីដាក់ឲ្យទទួលខុសត្រូវលើការរៀបចំផែនការ ជនជាប់ចោទតែម្នាក់ឯង ឬ រួមជាមួយនឹងអ្នកផ្សេងទៀត ត្រូវតែបានរៀបចំការប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយក្រោយមក ការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនោះពាក់ព័ន្ធ ឬ បង្កើតឲ្យមានបទឧក្រិដ្ឋ[២១៧៥]។ ផែនការនេះត្រូវបង្កើតឡើងមុន ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅប្រព្រឹត្តបទឧក្រិដ្ឋ[២១៧៦]។ ជនជាប់ចោទត្រូវតែមានចេតនា ឬ បានដឹងអំពីលទ្ធភាពខ្ពស់នៃការប្រព្រឹត្តិបទឧក្រិដ្ឋនៅពេលអនុវត្តផែនការនោះ[២១៧៧]។

## ១៣.៤ ការញុះញង់

៦៩៩. ការញុះញង់ក៏ត្រូវបានទទួលស្គាល់ ជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរត្រឹមឆ្នាំ ១៩៧៥[២១៧៨]។ បើទោះបីជាសំណៅភាសាខ្មែរ និងបារាំងនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រើពាក្យថា ការញុះញង់ ("inciter") ក៏ដោយ ក៏សញ្ញាណនៃពាក្យថា ការជំរុញ (instigation) និងការញុះញង់ (incitement) ត្រូវបានចាត់ទុកថាជាពាក្យមានន័យដូចគ្នា[២១៧៩]។ ដោយសារតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងដោយសារថា ការញុះញង់នេះត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវមួយ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅក្នុងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះយល់ឃើញថា

---

[២១៧៥] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥១៨។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ២៦។

[២១៧៦] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥១៨។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ២៦។ សាលដីកានៅក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* លេខយោងជើងទំព័រ ២១១៦។

[២១៧៧] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥១៩។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៣១។

[២១៧៨] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥៧៥។ ការជំរុញ និងការញុះញង់ត្រូវបានចែងបញ្ចូលនៅក្នុងលិខិតុបករណ៍អន្តរជាតិនាមុនឆ្នាំ ១៩៧៥ (ធម្មនុញ្ញ Nuremberg មាត្រា ៦, អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា ៣, អនុសញ្ញាបន្ថែមស្តីពីទាសភាព មាត្រា ៦, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ២០, អនុសញ្ញាស្តីពីការរើសអើង មាត្រា ៤, អនុសញ្ញាស្តីពីអាជ្ញាយុកាល មាត្រា II, អនុសញ្ញាស្តីពីការរើសអើងតាមប្រព័ន្ធអាប៉ាថេទ មាត្រា III(ក), អនុសញ្ញាស្តីពីចំណាប់ខ្មាំង មាត្រា ៤(ក))។ តុលាការ Nuremberg បានផ្តន្ទាទោសជនជាប់ចោទដែលញុះញង់ និងជំរុញឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សាលក្រម *Nuremberg* ទំព័រ ៣០២-៣០៤។ សាលក្រមនៅក្នុងរឿងក្តី *Ministries* ទំព័រ ៥៦៥-៥៧៦)។

[២១៧៩] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៤៧៨។

ទម្រង់នៃការទទួលខុសត្រូវនេះ អាចឲ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង[២១៨០]។

៧០០. ដើម្បីដាក់ឲ្យទទួលខុសត្រូវលើការញុះញង់ ជនជាប់ចោទម្នាក់ៗតាមរយៈអំពើសកម្ម ឬ អកម្ម ជំរុញបុគ្គលផ្សេងទៀតឲ្យប្រព្រឹត្តបទឧក្រិដ្ឋ[២១៨១]។ ការទទួលខុសត្រូវនេះអាចជាលទ្ធផលនៃការជំរុញជាលាយលក្ខណ៍អក្សរច្បាស់លាស់ ឬ ដោយទម្រង់ស្ងៀមស្ងាត់ផ្សេងទៀត[២១៨២]។ ការញុះញង់មិនតម្រូវឲ្យជនជាប់ចោទមានអំណាចណាមួយលើចារីនោះទេ[២១៨៣]។ អំពើសកម្ម ឬ អកម្មត្រូវកើតឡើងមុន ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅប្រព្រឹត្តបទឧក្រិដ្ឋ មិនមែនត្រឹមតែការជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋតែប៉ុណ្ណោះនោះទេ[២១៨៤]។ ជនជាប់ចោទត្រូវតែមានចេតនា ឬ បានដឹងអំពីលទ្ធភាពខ្ពស់ នៃការប្រព្រឹត្តិបទឧក្រិដ្ឋដោយសារតែការញុះញង់នេះ[២១៨៥]។

---

[២១៨០] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៧៤។ សូមមើលផងដែរ ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦-៤០៧ (តួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ)។ ការញុះញង់ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ៨៣ និង ៨៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[២១៨១] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២២។ សាលក្រមនៅក្នុងរឿងក្តី *Ministries* ទំព័រ ៥៧៦។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ២៧។

[២១៨២] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២២។ សាលក្រមនៅក្នុងរឿងក្តី *Orić* កថាខណ្ឌ ២៧១-២៧៣។

[២១៨៣] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២២។ សាលក្រមនៅក្នុងរឿងក្តី *Orić* កថាខណ្ឌ ២៧១-២៧៣។

[២១៨៤] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២២។ សាលក្រម *Nuremberg* ទំព័រ ៣៣៦-៣៣៨ (សម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទមួយផ្នែកដោយផ្អែកលើមូលដ្ឋានថា ការញុះញង់មិនច្បាស់លាស់ ឬ មិនចោទប្រកាន់ផ្ទាល់ឲ្យបានគ្រប់គ្រាន់)។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ២៧។ សាលដីកានៅក្នុងរឿងក្តី *Nahimana និងអ្នកផ្សេងទៀត* លេខយោងជើងទំព័រ ២១១៦។

[២១៨៥] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២៤។ សាលក្រម *Nuremberg* ទំព័រ ៣០៣ (ដែលកត់សម្គាល់ថា ជនជាប់ចោទបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការវិត្តថ្មីៗនៃដំណោះស្រាយចុងក្រោយ ហើយ “បានបន្តសរសេរ និងបោះពុម្ពផ្សាយការឃោសនារបស់ខ្លួនអំពីមរណភាព”) កថាខណ្ឌ ៣៣៨។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ៣២។

## ១៣.៥ ការបញ្ជា

៧០១. ត្រឹមឆ្នាំ ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានទទួលស្គាល់ការបញ្ជាជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល[២១៨៦]។ ដោយសារតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និង ដោយសារថា ការបញ្ជានេះត្រូវបានទទួលស្គាល់ជាទម្រង់មួយនៃការទទួលខុសត្រូវទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅក្នុងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវមួយនេះ អាចឱ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង[២១៨៧]។

៧០២. លក្ខខណ្ឌនៃការបញ្ជាតម្រូវថា ជនជាប់ចោទក្នុងឋានៈជាអ្នកមានអំណាច*តាមព្រឹត្តិហេតុ* (អំណាចជាក់ស្តែង) ឬ *តាមផ្លូវច្បាប់* (នៅក្នុងច្បាប់) បង្គាប់បុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ទំនាក់ទំនងជាផ្លូវការរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់ មិនមែនជាលក្ខខណ្ឌតម្រូវនោះទេ[២១៨៨]។ ការទទួលខុសត្រូវអាចកើតមាននៅពេលជនជាប់ចោទចេញបញ្ជា ឬ ផ្ទេរការបញ្ជា ដែលរួមទាំងតាមរយៈអន្តរការីផងដែរ[២១៨៩]។ គ្មានលក្ខខណ្ឌដែលថា ការបញ្ជានោះត្រូវតែចេញជាទម្រង់ពិសេស

---

[២១៨៦] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៤៧៥។ នៅមុនឆ្នាំ ១៩៧៥ ការបញ្ជាត្រូវបានចែងបញ្ចូលនៅក្នុងលិខិតុបករណ៍អន្តរជាតិនានា (អនុសញ្ញាទីក្រុងហ្សឺណែវ (IV) មាត្រា ៤៩, ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យអាល្លឺម៉ង់លេខ១០ មាត្រាII(2)(ខ)។ តុលាការនាសម័យ Nuremberg បានផ្តន្ទាទោសជនជាប់ចោទចំពោះការបញ្ជាលើឧក្រិដ្ឋ-កម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សាលក្រម *Nuremberg* ទំព័រ ២៨៩-២៩១, ៣១១-៣១៥។ សាលក្រមនៅក្នុងរឿងក្តី*មេបញ្ជាការ* ទំព័រ ៥៦០-៥៦១, ៦៦៥, ៦៩៣។ សាលក្រមនៅក្នុងរឿងក្តី *RuSHA* ទំព័រ ១០៦ សាលក្រមនៅក្នុងរឿងក្តី*ក្រសួងយុត្តិធម៌* ទំព័រ ១១១៩)។

[២១៨៧] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៤៧៤។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦-៤០៧ (តួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ)។ ការបញ្ជាត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ៨៣ និង ៨៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[២១៨៨] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥២៧។ សាលក្រមនៅក្នុងរឿងក្តី *RuSHA* ទំព័រ ១០៦។ សាលក្រមនៅក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៤៨៧-៤៨៨។ សាលដីកានៅក្នុងរឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ២៨។

[២១៨៩] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥២៧។ សាលក្រមនៅក្នុងរឿងក្តី*មេបញ្ជាការ* ទំព័រ ៦១៦-៦១៧ (អ្នកដែលបញ្ជូនបញ្ជាអាចទទួលខុសត្រូវ ប្រសិនបើបញ្ជានោះមើលទៅមានលក្ខណៈឧក្រិដ្ឋ ឬ ប្រសិនបើបញ្ជានោះអាច អនុវត្តក្នុងរបៀបជាឧក្រិដ្ឋកម្ម ហើយបញ្ជានោះមិនផ្សព្វផ្សាយដោយរង់ចាំការធានា ឬការបញ្ជាក់បំភ្លឺជាចាំបាច់)។

ណាមួយនោះទេ ហើយអត្ថិភាពនៃការបញ្ជាអាចនឹងបង្ហាញតាមរយៈភ័ស្តុតាងតាមស្ថានភាពផង ដែរ[២១៩០]។ ការបញ្ជានេះត្រូវធ្វើឡើងមុន ហើយចូលរួមចំណែកយ៉ាងសំខាន់មួយដល់ការប្រព្រឹត្ត បទឧក្រិដ្ឋ[២១៩១]។ ជនជាប់ចោទត្រូវមានចេតនា ឬ បានដឹងអំពីលទ្ធភាពខ្ពស់ថា ការអនុវត្តតាមការ បញ្ជានេះទំនងនឹងបណ្តាលឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ[២១៩២]។

## ១៣.៦ ការជួយ និងការជំរុញ

៧០៣. ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ថា ការជួយ និងការជំរុញ គឺជាទម្រង់នៃការ ទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលត្រឹមឆ្នាំ ១៩៧៥[២១៩៣]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ ឃើញថា សំណៅជាភាសាបារាំងនៃមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រដូច ពាក្យ *"ការជួយ និងការជំរុញ"* ទៅនឹងសញ្ញាណនៃពាក្យ "*ការសមគំនិត*"។ ទោះបីជាឃ្លា *"ការ ជួយ និងការជំរុញ"* និងពាក្យ "*ការសមគំនិត*" មានលក្ខណៈខ្លះរួមគ្នាក៏ដោយ ក៏អង្គជំនុំជម្រះបាន កំណត់រួចហើយថា ឃ្លា "*ការជួយ និងការជំរុញ*" ឆ្លុះបញ្ចាំងកាន់តែច្បាស់អំពីលក្ខណៈនៃការ ទទួលខុសត្រូវចំពោះការជួយ និងការជំរុញនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយស្របគ្នានឹង

---

[២១៩០] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២៧។ សាលដីកានៅក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៧៦។

[២១៩១] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២៧។ សាលដីកានៅក្នុងរឿងក្តី *មេបញ្ជាការ* ទំព័រ ៦៨៣ (ដែលពិចារណាឃើញថា មន្ត្រីយោធាដែលធ្វើសេចក្តីព្រាងបញ្ជាផ្អែកលើការណែនាំ និងគំនិតជារួមរបស់មេបញ្ជាការ អាចទទួលខុសត្រូវ ប្រសិនបើពួកគេត្រូវបានមើលឃើញថាមានគំនិតផ្តួចផ្តើមខ្លះ ដោយពុំមែន "ត្រឹមតែសរសេរតាម បញ្ជាដើមប៉ុណ្ណោះនោះទេ")។

[២១៩២] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥២៨។ សាលដីកានៅក្នុងរឿងក្តី *មេបញ្ជាការ* ទំព័រ ៥១១។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤១-៤២។

[២១៩៣] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៧៥។ ការទទួលខុសត្រូវលើបទសមគំនិត រួមទាំង ការ ជួយ និងការជំរុញ ត្រូវបានទទួលស្គាល់ជាគោលការណ៍ច្បាប់អន្តរជាតិ ហើយត្រូវបានចែងបញ្ចូលនៅក្នុងលិខិតុបករណ៍ អន្តរជាតិនានា នៅមុនឆ្នាំ ១៩៧៥ (ធម្មនុញ្ញ Nuremberg មាត្រា ៦, ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យអាល្លឺម៉ង់ លេខ ១០ មាត្រា II(2) (ខ), គោលការណ៍ Nuremberg គោលការណ៍ VII, អនុសញ្ញាបន្ថែមស្តីពីទាសភាព មាត្រា ៣, ៥-៦។ អនុសញ្ញាស្តីពីអាជ្ញាយុកាល មាត្រា II,អនុសញ្ញាស្តីពីការរើសអើងតាមប្រព័ន្ធអាប៉ាថេទ មាត្រា III(ខ),អនុសញ្ញាស្តីពី ចំណាប់ខ្មាំង មាត្រា១(២)(ខ),៤(ក)។ អនុសញ្ញាស្តីពីបុគ្គលដែលត្រូវបានការពារ មាត្រា២(១)(ង))។ តុលាការ Nuremberg បាន ផ្តន្ទាទោសពីបទការជួយ និងការជំរុញលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (*សូមមើល* សាលក្រមនៅក្នុងរឿងក្តី *ក្រសួងយុត្តិធម៌* ទំព័រ ១១១៨, សាលក្រមនៅក្នុងរឿងក្តី *Pohl* ទំព័រ ១០៣១, ១០៣៩ ។ សាលក្រមនៅក្នុងរឿងក្តី *Ministries* ទំព័រ ៦៤៥-៦៤៦)។

សំណៅជាភាសាខ្មែរ និងសំណៅជាភាសាអង់គ្លេសនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[២១៩៤]។ ដោយសារតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងដោយសារថាការជួយ និងការជំរុញនេះ ត្រូវបានទទួលស្គាល់ជាទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅក្នុងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះយល់ឃើញថា ការជួយ និងការជំរុញ អាចឲ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង[២១៩៥]។

៧០៤. អ្នកជួយ ឬ អ្នកជំរុញ ត្រូវផ្តល់ការជួយជាក់ស្តែង ការលើកទឹកចិត្ត ឬ ការគាំទ្រខាងស្មារតីដែលមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋដែលពិតជាបានប្រព្រឹត្តឡើង[២១៩៦]។ ភ័ស្តុតាងទាក់ទងនឹងផែនការ ឬ ការព្រមព្រៀងរវាងអ្នកជួយ ឬ អ្នកជំរុញ ជាមួយនឹងចារី មិនតម្រូវឲ្យមាននោះទេ[២១៩៧]។ ដើម្បីរកឃើញពិរុទ្ធលើការជួយ និងការជំរុញ ជនជាប់ចោទត្រូវតែបានដឹងថា បទឧក្រិដ្ឋមួយអាចនឹងត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់ខ្លួននេះបានជួយ ឬ សម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនោះ[២១៩៨]។ បន្ថែមពីនេះទៀត ជនជាប់ចោទត្រូវដឹងអំពីធាតុផ្សំសំខាន់ៗនៃ

---

[២១៩៤] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣២។

[២១៩៥] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣៤។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦-៤០៧ (តួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ)។ ការជួយ និងការជំរុញត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ៨៣ និង ៨៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[២១៩៦] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥២៨, ៥៣៣។ សាលក្រមនៅក្នុងរឿងក្តី *Flick* ទំព័រ ១២១៧ ("អ្នកដែលបានចូលរួមចំណែកដោយចេតនាតាមរយៈឥទ្ធិពល និងលុយរបស់ខ្លួន នៅក្នុងការគាំទ្រដូចបានលើកឡើងនៅក្នុងទំព័រនេះ យោងតាមគោលការណ៍ច្បាប់ជាធរមាន ត្រូវចាត់ទុកថាជាអ្នកសមគំនិតនៅក្នុងបទល្មើសបែបនេះ បើទោះជាពុំមែនត្រូវបានចាត់ទុកថាជាចារីក៏ដោយ"។ សាលក្រមនៅក្នុងរឿងក្តី *ក្រសួងយុត្តិធម៌* ទំព័រ ១១១៨, ការជំនុំជម្រះលើរឿងក្តី *Schonfeld* ទំព័រ ៦៤, ៧០ (ដែលបានផ្តល់ "ទំនុកចិត្តបន្ថែមលើដៃគូរបស់ខ្លួន")។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៥-៤៦, ៤៨។

[២១៩៧] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣៤។ សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៩។

[២១៩៨] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣៤-៥៣៥។ សាលក្រមនៅក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៥៦៩ ("នៅក្នុងការតាមរក ការវាយតម្លៃ និងការប្រគល់បញ្ជីឈ្មោះអ្នកមុខអ្នកការនៃបក្សកុម្មុយនីស្តជូនដល់អង្គនីតិប្រតិបត្តិនៃអង្គការរបស់ខ្លួន ហើយខ្លួនបានដឹងថា មនុស្សនៅក្នុងបញ្ជីឈ្មោះនោះនឹងត្រូវបានសម្លាប់ចោលប្រសិនបើតាមរកឃើញនោះ")។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៥-៥០។

បទល្មើសដែលត្រូវបានប្រព្រឹត្តឡើងដោយចារី ប៉ុន្តែមិនចាំបាច់មានចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដូចចារីទេ រួមទាំងចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានា ដូចជា អំពើធ្វើទុក្ខបុកម្នេញ[២១៩៩]។

៧០៥. ក្រុមមេធាវីការពារក្តី ខៀវ សំផន លើកឡើងបញ្ហាចំនួនបីចំណុចពាក់ព័ន្ធនឹង*ធាតុផ្សំសត្យានុម័ត* នៃការជួយ និងការជំរុញ៖ (១) ថាតើជនជាប់ចោទអាចជួយ ឬ ជំរុញ តាមរយៈអំពើអកម្មបានដែរ ឬទេ (២) ថាតើអំពើរបស់ជនជាប់ចោទត្រូវតែមានគោលដៅយ៉ាងជាក់លាក់ដើម្បីសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋដោយចារីដែរ ឬ ទេ និង (៣) ថាតើការទទួលខុសត្រូវអាចកើតចេញពីការជួយជ្រោមជ្រែង ក្រោយពីការប្រព្រឹត្តិបទឧក្រិដ្ឋដែរ ឬ ទេ។

### ១៣.៦.១ ការជួយ និងការជំរុញតាមរយៈអំពើអកម្ម

៧០៦. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានសន្និដ្ឋានថា ការជួយ និងការជំរុញ តម្រូវឲ្យមានអំពើវិជ្ជមានមួយ ហើយបានជំទាស់ថា ការអនុវត្តយុត្តិសាស្ត្រដ៏ចម្រូងចម្រាស់របស់តុលាការ ICTY ដែលបានយល់ឃើញថា ការជួយ និងការជំរុញ អាចធ្វើឡើងតាមរយៈអំពើអកម្ម នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព[២២០០]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ផ្ទុយនឹងការលើកឡើងនេះ យុត្តិសាស្ត្រនាសម័យ Nuremberg បានទទួលស្គាល់ថា ជនជាប់ចោទអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើអកម្មដែលបានជួយ និងជំរុញដល់ការប្រព្រឹត្តិបទ-ឧក្រិដ្ឋ[២២០១]។ ករណីដែលថា តើអំពើអកម្មបាន ឬ មិនបានជួយ ឬ ជំរុញឲ្យមានបទឧក្រិដ្ឋនោះ វាជាបញ្ហាដែលត្រូវយកមកកំណត់ទៅតាមករណីនីមួយៗ[២២០២]។ ការកំណត់នេះនឹងទំនងជាត្រូវ

---

[២១៩៩] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥៣៥។ សាលក្រមនៅក្នុងរឿងក្តី *Blagojević* និង *Jokić* កថាខណ្ឌ ១២៧។

[២២០០] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥៩-៦១។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣២១។

[២២០១] *សូមមើល ឧ.* សាលក្រមនៅក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៥៧២។ ការជំនុំជម្រះនៅក្នុងរឿងក្តី *Essen Lynching* ទំព័រ ៩០។ *សូមមើលផងដែរ* សាលដីកានៅក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៧៧។

[២២០២] សាលដីកានៅក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧៥។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៧។

ពិនិត្យទៅលើតួនាទី និងអំណាចរបស់ជនជាប់ចោទ[២២០៣]។ ហេតុដូច្នេះ ការសន្និដ្ឋានបែបនេះត្រូវបានច្រានចោលយោងតាមហេតុផលនេះ។

### ១៣.៦.២ គោលដៅជាក់លាក់

៧០៧. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានសន្និដ្ឋានថា ការផ្តន្ទាទោសលើការជួយ និងការជំរុញ អាចធ្វើឡើងតែក្នុងករណីដែលការជួយ ឬ ការជំរុញរបស់ជនជាប់ចោទមាន "គោលដៅជាក់លាក់" ដើម្បីជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋ (ដែលហៅជាទូទៅថា "គោលដៅជាក់-លាក់")[២២០៤]។ ក្រុមមេធាវីការពារក្តីផ្អែកការសន្និដ្ឋាននេះទៅលើសាលដីកាក្នុងរឿងក្តី *Perišić* ដែលវាផ្ទុយនឹងការអនុវត្តនៅ អ.វ.ត.ក[២២០៥]។ បើទោះជាអង្គជំនុំជម្រះសាលាដំបូងមិនមានកាតព្វកិច្ចគោរពតាមយុត្តិសាស្ត្ររបស់តុលាការកំពូល ICTY ក៏ដោយ ក៏អង្គជំនុំជម្រះអាចពឹងផ្អែកលើយុត្តិសាស្ត្រនេះ ហើយកន្លងមក អង្គជំនុំជម្រះធ្លាប់បានពឹងផ្អែកផងដែរទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត នៅពេលកំណត់អំពីធាតុផ្សំផ្សេងៗនៃបទល្មើស[២២០៦]។

៧០៨. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ តុលាការកំពូលក្នុងរឿងក្តី *Perišić* តាមសម្លេងភាគច្រើនរបស់ចៅក្រម បានសម្រេចថា *ធាតុផ្សំសត្យានុម័ត* នៃការជួយ និងការជំរុញ តម្រូវឱ្យបង្ហាញភ័ស្តុតាងនៃគោលដៅជាក់លាក់[២២០៧]។ ចៅក្រមភាគច្រើនបានសម្រេចបន្ថែមទៀតថា ក្រោយពីពិនិត្យអង្គហេតុបង្ហាញថា "គោលដៅជាក់លាក់បង្កើតជាចំណងទុច្ចរិតរវាងការជួយជ្រោមជ្រែង

---

[២២០៣] សាលក្រមនៅក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៥៧២ (អំពើអកម្មរបស់បុគ្គលណាម្នាក់ដែលមានតួនាទីអំណាចខ្ពស់អាចលើកទឹកចិត្តឱ្យជនជាប់ចោទប្រព្រឹត្តបទល្មើសបាន) ៥៧៥ (សម្រេចឱ្យជនជាប់ចោទរួចពីបទចោទក្រោយពីពិចារណាលើតួនាទីថ្នាក់ទាបរបស់ជនជាប់ចោទ ហើយនឹងក្រោយពីបានពិចារណាឃើញថា ជនជាប់ចោទមិនស្ថិតនៅក្នុង "ស្ថានភាពមួយអាចជំទាស់បាន")។ ការជំនុំជម្រះនៅក្នុងរឿងក្តី *Essen Lynching* ទំព័រ ៨០។ សាលដីកានៅក្នុងរឿងក្តី *Orić* កថាខណ្ឌ ៤២។

[២២០៤] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ [ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣២១-៣២៣។

[២២០៥] គ្មានចៅក្រមនៃ អ.វ.ត.ក ឬ អង្គជំនុំជម្រះណាមួយ បានទាមទារលក្ខខណ្ឌនៃគោលដៅជាក់លាក់នោះទេ (ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥០។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៣៣។ កាំង ហ្គេកអ៊ាវ ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១។

[២២០៦] ផ្នែកទី២៖ បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ១៦។

[២២០៧] សាលដីកានៅក្នុងរឿងក្តី *Perišić* កថាខណ្ឌ ៣៦។

ដែលផ្តល់ដោយជនជាប់ចោទជាមួយនឹងបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយចារី” ម្យ៉ាងទៀតសំអាងហេតុលើគោលដៅជាក់លាក់ ត្រូវបង្ហាញឲ្យបានច្បាស់លាស់ក្នុងករណីដែលអំពើរបស់ជនជាប់ចោទនៅឆ្ងាយពីទីកន្លែងឧក្រិដ្ឋកម្ម បើគិតទាំងពេលវេលា និងទីតាំងភូមិសាស្ត្រ[២២០៨]។ តុលាការកំពូលក្នុងរឿងក្តី *Perišić* បានចាប់ផ្តើមពិចារណាលើបញ្ហានេះនៅក្នុងសាលដីកាក្នុងរឿងក្តី *Tadić* ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ដោយលើកឡើងថា “អ្នកជួយ និងអ្នកជំរុញ ធ្វើអំពើផ្សេងៗ *ក្នុងគោលដៅជាក់លាក់* ដើម្បីជួយជ្រោមជ្រែង លើកទឹកចិត្ត ឬផ្តល់ការគាំទ្រខាងស្មារតីដល់ការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ណាមួយ...ហើយការគាំទ្រនេះ មានអានុភាពធំធេងនៅពេលប្រព្រឹត្តបទឧក្រិដ្ឋ”[២២០៩]។ បន្ទាប់មក តុលាការកំពូលនេះបានពិនិត្យមើលឡើងវិញលើយុត្តិសាស្ត្ររបស់តុលាការកំពូលនៃតុលាការ *មិនអចិន្ត្រៃយ៍*ផ្សេងទៀតលើចំណុចនេះ រួមទាំងការលើកឡើងហាក់ដូចជាជាក់លាក់នៅក្នុងសាលដីកាក្នុងរឿងក្តី *Mrkšić* និង *Šljivančanin* ដែលថា “តុលាការកំពូលបានបញ្ជាក់ថា “គោលដៅជាក់លាក់” មិនមែនជាធាតុផ្សំសំខាន់នៃធាតុសត្យានុម័តនៃការជួយ និងការជំរុញនោះឡើយ”[២២១០]។ សរុបសេចក្តីមក ការពិនិត្យមើលឡើងវិញនេះ បាននាំឲ្យចៅក្រមភាគច្រើននៃតុលាការកំពូលក្នុងរឿងក្តី *Perišić* សន្និដ្ឋានថា មកទល់ពេលបច្ចុប្បន្ន គ្មានសាលដីកាណាមួយនៃតុលាការកំពូលបានរកឃើញហេតុផលគួរឲ្យជឿជាក់ អាចឲ្យងាកចេញពីនិយមន័យនៃការទទួលខុសត្រូវចំពោះការជួយ និងការជំរុញ ដូចបានកំណត់នៅក្នុងសាលដីកានៃរឿងក្តី *Tadić* ដែលតម្រូវឲ្យបង្ហាញភ័ស្តុតាងនៃគោលដៅជាក់លាក់នោះទេ។

៧០៩. ក្រោយពីមានសាលដីកានៅក្នុងរឿងក្តី *Perišić* និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះតុលាការកំពូល ICTY បានចេញសាលដីកានៅក្នុងរឿងក្តី *Šainović* ដែលក្នុងនោះបានច្រានចោលនូវវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងរឿងក្តី *Perišić* ដោយលើកឡើងពីច្បាប់ជាធរមានដែលថែងថា “គោលដៅជាក់លាក់មិនមែនជា *ធាតុផ្សំសត្យានុម័ត* សំខាន់មួយនៃការជួយ និងការជំរុញនោះ

---

[២២០៨] សាលដីកានៅក្នុងរឿងក្តី *Perišić* កថាខណ្ឌ ៣៧-៤០។ ផ្ទុយមកវិញ ចៅក្រមភាគច្រើននៃតុលាការកំពូលបានបញ្ជាក់ថា ក្នុងករណីជនជាប់ចោទមានវត្តមាននៅទីតាំងបទល្មើស គោលដៅជាក់លាក់អាចមានលក្ខណៈប្រយោលតាមរយៈការពិភាក្សាលើធាតុផ្សំផ្សេងទៀត ដូចជា ការចូលរួមចំណែកដ៏សំខាន់ជាដើម។

[២២០៩] សាលដីកានៅក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៩ (គូសបញ្ជាក់បន្ថែម)។

[២២១០] សាលដីកានៅក្នុងរឿងក្តី *Perišić* កថាខណ្ឌ ២៧-៣៦ *ដែលយោងលើ* សាលដីកានៅក្នុងរឿងក្តី *Mrkšić* និង *Šljivančanin* កថាខណ្ឌ ១៥៩។

ទេ”[២២១១]។ ដោយលើកឡើងពីការប្រឈមនឹងសេចក្តីសម្រេចនាពេលមុនរបស់ខ្លួននៅក្នុងសាលដីកានៅក្នុងរឿងក្តី *Perišić*[២២១២] អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Šainović* យល់ឃើញថាខ្លួនត្រូវកំណត់វិធីសាស្ត្រឲ្យបានត្រឹមត្រូវ[២២១៣]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនេះបានធ្វើការវិភាគយ៉ាងច្រើនទៅលើយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* នានា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Šainović* រួមមានការពិនិត្យស៊ីជម្រៅឡើងវិញលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II ដែលឆ្លុះបញ្ចាំងសម្រាប់បរិបទរបស់ អ.វ.ត.ក។ យុត្តិសាស្ត្រទាំងនេះតម្រូវឲ្យកំណត់ថា តើគោលដៅជាក់លាក់គឺជាផ្នែកមួយនៃការជួយ និងការជំរុញដែរ ឬ ទេ ដោយសារលក្ខខណ្ឌតម្រូវនេះមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩[២២១៤]។ ក្នុងចំណោមចំណុចនានា សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Šainović* បានកំណត់យកយុត្តិ-សាស្ត្រពីតុលាការយោធានៃចក្រភពអង់គ្លេស តុលាការយោធានៃប្រទេសបារាំង ការជំនុំជម្រះនានាដែលបានធ្វើឡើងនៅក្រោមលក្ខខណ្ឌនៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងសាលក្រមតុលាការ Nuremberg[២២១៥]។ ផ្អែកតាមការពិនិត្យមើលឡើងវិញ អង្គជំនុំជម្រះតុលាការកំពូលនេះបានធ្វើ “សេចក្តីសន្និដ្ឋានគួរឲ្យជឿជាក់” មួយថា គោលដៅជាក់លាក់មិនមែនជាធាតុផ្សំមួយនៃការទទួលខុសត្រូវលើការជួយ និងការជំរុញក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ហើយ *ធាតុផ្សំ*

---

[២២១១] សាលដីកានៅក្នុងរឿងក្តី *Šainović* និងជនផ្សេងទៀត កថាខណ្ឌ ១៦៥០។

[២២១២] សាលដីកានៅក្នុងរឿងក្តី *Mrkšić* និង *Šljivančanin* និងសាលដីកានៅក្នុងរឿងក្តី *Lukić* និង *Lukić* ។

[២២១៣] សាលដីកានៅក្នុងរឿងក្តី *Šainović* និងជនផ្សេងទៀត កថាខណ្ឌ ១៦២២។

[២២១៤] សាលដីកានៅក្នុងរឿងក្តី *Šainović* ក៏រួមមានការពិនិត្យលម្អិតឡើងវិញលើច្បាប់ជាតិស្តីពីការជួយ និងការជំរុញផងដែរ។ ទោះបីជាការពិនិត្យឡើងវិញនេះផ្តោតសំខាន់លើច្បាប់ដែលត្រូវបានអនុម័តក្រោយអំឡុងពេលដែល អ.វ.ត.ក មានយុត្តាធិការក៏ដោយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជាការសំខាន់ត្រូវកត់សម្គាល់ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលនេះថា “មិនមានគោលការណ៍រួមជាក់លាក់មួយ” អាចនឹងត្រូវបានទាញចេញពីប្រព័ន្ធច្បាប់សំខាន់ៗនៅលើពិភពលោក” ហើយលក្ខខណ្ឌតម្រូវនៃគោលដៅជាក់លាក់សម្រាប់ការទទួលខុសត្រូវលើការជួយ និងការជំរុញ ពុំមែនជាការអនុវត្តទូទៅរួមមួយនៅក្នុងយុត្តាធិការជាតិនោះទេ (សូមមើល កថាខណ្ឌ ១៦៤៤, ១៦៤៦) ។

[២២១៥] សាលដីកានៅក្នុងរឿងក្តី *Šainović* និងជនផ្សេងទៀត កថាខណ្ឌ ១៦២៧-១៦៤២។

*សត្យានុម័ត* រួមមាន "ការជួយ ការលើកទឹកចិត្ត ឬការគាំទ្រផ្លូវចិត្តជាក់ស្តែងណាមួយ ដែលមានអានុភាពធំធេងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[២២១៦]។

៧១០. ស្រដៀងគ្នានេះដែរ សាលដីកាក្នុងរឿងក្តី *Taylor* របស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) ដែលត្រូវបានចេញក្រោយសាលដីកានៅក្នុងរឿងក្តី *Perišić* បានធ្វើការពិនិត្យឡើងវិញគួរឲ្យជឿជាក់ទៅលើយុត្តិសាស្ត្រ និងលិខិតុបករណ៍អន្តរជាតិ រួមទាំងយុត្តិ-សាស្ត្រ និងលិខិតុបករណ៍អន្តរជាតិទាំងឡាយដែលបានធ្វើឡើងនៅមុនឆ្នាំ ១៩៧៥[២២១៧] ហើយបានសម្រេចថា "បញ្ហាសំខាន់ ថាតើអំពើសកម្ម និងការប្រព្រឹត្តិរបស់ជនជាប់ចោទ អាចនិយាយបានថាមានអានុភាពធំធេងទៅលើការប្រព្រឹត្តិបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដែរ ឬ ទេ"[២២១៨]។ ផ្អែកតាមការសិក្សាលម្អិតលើយុត្តិសាស្ត្រ និងលិខិតុបករណ៍នានានៅក្នុងសាលដីកានៃរឿងក្តី *Šainović* និង *Taylor* អង្គជំនុំជម្រះនេះយល់ឃើញថា ជំហរលើកឡើងនេះគួរឲ្យជឿជាក់ និងជាការឆ្លុះ-បញ្ចាំងយ៉ាងត្រឹមត្រូវនៃច្បាប់ត្រឹមឆ្នាំ ១៩៧៥។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានហេតុផលគួរឲ្យជឿជាក់ណាមួយអាចឲ្យងាកចេញពីនិយមន័យពីមុននៃការជួយ និងការជំរុញនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះច្រានចោលនូវសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងគោលដៅជាក់លាក់នេះ។

### ១៣.៦.៣ ការជួយជ្រោមជ្រែងក្រោយពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៧១១. ជាចុងក្រោយ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានសន្និដ្ឋានថា ទំនាក់ទំនងហេតុ និងផល មិនមានអត្ថិភាពនៅចន្លោះពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង និងការជួយជ្រោមជ្រែងដែលបានផ្តល់ឲ្យក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា បុគ្គលដែលជួយជ្រោមជ្រែង ក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនអាចទទួលខុសត្រូវលើការជួយ និងការជំរុញបទឧក្រិដ្ឋបានទេ[២២១៩]។

---

[២២១៦] សាលដីកានៅក្នុងរឿងក្តី *Šainović* និងជនផ្សេងទៀត កថាខណ្ឌ ១៦៤៩។

[២២១៧] សាលដីកានៅក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨-៣៨៥។

[២២១៨] សាលដីកានៅក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨។

[២២១៩] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [របស់ ខៀវ សំផន] ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៦២-៦៥។

៧១២. តុលាការកំពូល ICTY បានសម្រេចយ៉ាងច្បាស់ថា "*ធាតុផ្សំសត្យានុម័ត* នៃការជួយ និងការជំរុញបទឧក្រិដ្ឋមួយអាចកើតឡើងនៅមុន នៅក្នុងអំឡុងពេល ឬ *ក្រោយ* បទឧក្រិដ្ឋសំខាន់ត្រូវបានប្រព្រឹត្តឡើង"[២២២០]។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា វិធីសាស្ត្ររបស់តុលាការ ICTY ផ្ទុះបញ្ចាំងពីការយល់ឃើញមួយថា ការផ្តល់ការសន្យាដែលធ្វើឡើងនៅមុន ឬ នៅក្នុងអំឡុងពេលនៃការប្រព្រឹត្តិបទឧក្រិដ្ឋថានឹងជួយជ្រោមជ្រែងក្រោយពីការប្រព្រឹត្តិបទឧក្រិដ្ឋ អាចជម្រុញឱ្យ ឬ ផ្តល់ការគាំទ្រខាងស្មារតីដល់ចារី ហេតុដូច្នេះហើយ ការសន្យាថានឹងផ្តល់ការជួយជ្រោមជ្រែងនេះ អាចមានអានុភាពធំធេងលើការប្រព្រឹត្តិបទឧក្រិដ្ឋ[២២២១]។ វិធីសាស្ត្រនេះត្រូវបានទទួលយកច្រើននៅក្នុងយុត្តិសាស្ត្រមួយចំនួននាសម័យក្រោយសង្គ្រាមលោកលើកទី២ ផងដែរ[២២២២]។

៧១៣. អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវសំខាន់បំផុតគឺថា ការជួយជ្រោមជ្រែង ការលើកទឹកចិត្ត ឬការគាំទ្រខាងផ្នែកស្មារតី ត្រូវតែមានអានុភាពធំធេងលើការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ[២២២៣]។ ហេតុដូច្នេះ នៅពេលមិនមានទម្រង់នៃការជួយជ្រោមជ្រែង ការលើកទឹកចិត្ត ឬការគាំទ្រខាងផ្នែកស្មារតីជាមុនណាមួយ ការជួយជ្រោមជ្រែងដែលផ្តល់ឱ្យក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋមិនអាចបំពេញលក្ខខណ្ឌតម្រូវនេះបានឡើយ។ ទំនាក់ទំនងហេតុ និងផលមានអត្ថិភាពតែនៅពេលដែលអានុភាពនៃការលើកទឹកចិត្ត ឬការគាំទ្រផ្នែកស្មារតីកើតមានឡើងតែប៉ុណ្ណោះ[២២២៤]។ អង្គជំនុំជម្រះមិនចាំបាច់កំណត់អត្តសញ្ញាណតាមទ្រឹស្តី ចំពោះការប្រព្រឹត្តិទាំងអស់ដែលអាចមានអានុភាពយ៉ាង

[២២២០] សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៨ (គូសបញ្ជាក់បន្ថែម)។

[២២២១] សាលក្រមនៅក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ២៣០។ សាលក្រមនៅក្នុងរឿងក្តី *Aleksovski* កថាខណ្ឌ ៦២។ *សូមមើលផងដែរ* សាលដីកានៅក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២២៧ ("ការលើកទឹកចិត្ត និងការគាំទ្រតាមផ្លូវចិត្តអាចបង្កើតជាការរួមចំណែកសំខាន់មួយចំពោះបទល្មើសនៅពេលចារីបានដឹងអំពីបទល្មើសនេះ")។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាលក្រមនៅក្នុងរឿងក្តី *Blagojević* "តម្រូវឱ្យមានការជួយ និងការជំរុញ*នៅក្រោយការប្រព្រឹត្តិបទឧក្រិដ្ឋ* ដោយទាមទារលក្ខខណ្ឌថា នៅពេលមានការរៀបចំផែនការ ការត្រៀមរៀបចំ ឬ ការប្រព្រឹត្តិបទល្មើស ការព្រមព្រៀងជាមុនមួយមានអត្ថិភាព រវាងចារី និងអ្នកជួយ និងអ្នកជំរុញ" (សាលក្រមនៅក្នុងរឿងក្តី *Blagojević និង Jokić* កថាខណ្ឌ ៧៣១)។ មកទល់ពេលបច្ចុប្បន្ន វិធីសាស្ត្រនេះពុំត្រូវបានទទួលស្គាល់ដោយតុលាការកំពូល ICTY នោះទេ។

[២២២២] ការជំនុំជម្រះនៅក្នុងរឿងក្តី *Schonfeld* ទំព័រ ៧០។ ការជំនុំជម្រះនៅក្នុងរឿងក្តី *Rohde* ទំព័រ ៥៦។

[២២២៣] *សូមមើល* ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧០៤ ។

[២២២៤] *សូមមើល* ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧០៨-៧១០ ។

ខ្លាំងលើការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ ប៉ុន្តែ ចំណុចនេះអាស្រ័យទៅលើការវាយតម្លៃលើភ័ស្តុតាងទៅតាមករណីនីមួយៗតែប៉ុណ្ណោះ[២២២៥]។

## ១៣.៧ ការទទួលខុសត្រូវរបស់ថ្នាក់លើ

៧១៤. ការទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចយកមកអនុវត្តចំពោះទាំងថ្នាក់លើក្នុងជួរយោធា និងទាំងថ្នាក់លើក្នុងជួរស៊ីវិល ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥[២២២៦]។ ដោយសារតែតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងដោយសារថា ការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ទម្រង់នៃការទទួលខុសត្រូវមួយនេះអាចឱ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង[២២២៧]។

៧១៥. ដើម្បីអាចឱ្យថ្នាក់លើម្នាក់ទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់ថ្នាក់ក្រោមបាននោះ ទីមួយ ចាំបាច់ត្រូវមានទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់ រវាងជនជាប់ចោទ នឹងបុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។ ថ្នាក់លើចាំបាច់ត្រូវមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារី

---

[២២២៥] សាលដីកានៅក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧៥។ សាលដីកានៅក្នុងរឿងក្តី *Blagojević និង Jokić* កថាខណ្ឌ ១៣៤។

[២២២៦] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៤៧៦-៤៧៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៩០-២៣២។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ)ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤១៣-៤៦០។ *សូមមើលផងដែរ* រឿងក្តី *Hadžihasanović* និង *Kubura* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំដែលជំទាស់តវ៉ាបញ្ហាយុត្តាធិការពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ (អង្គជំនុំជម្រះតុលាការកំពូល) កថាខណ្ឌ ២៩។

[២២២៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៣២។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ៤៦០។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦-៤០៧ (តួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ)។

ក្នុងន័យថាថ្នាក់លើមានលទ្ធភាពជាក់ស្តែងដើម្បីទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មលើបទឧក្រិដ្ឋបាន[២២២៨]។ ចំណុចទីពីរ ថ្នាក់លើត្រូវតែបានដឹង ឬ មានហេតុផលដឹងថា បទឧក្រិដ្ឋបម្រុងនឹងត្រូវបានប្រព្រឹត្ត ឬ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន[២២២៩]។ ថ្នាក់លើត្រូវតែដឹងថា អ្នកនៅក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋ មិនមែនគ្រាន់តែដឹងអំពីការកើតមាននៃបទឧក្រិដ្ឋប៉ុណ្ណោះទេ[២២៣០]។ ថ្នាក់លើមានហេតុផលដែលអាចដឹងថា បទឧក្រិដ្ឋបម្រុងនឹងត្រូវបានប្រព្រឹត្ត ឬ ត្រូវបានប្រព្រឹត្តនៅពេលដែលគាត់មានព័ត៌មានគ្រប់គ្រាន់ដែលតម្រូវឱ្យធ្វើការស៊ើបអង្កេតថែមទៀត[២២៣១]។

៧១៦. ចំណុចចុងក្រោយ ថ្នាក់លើខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របក្នុងការទប់ស្កាត់បទឧក្រិដ្ឋ ឬ ដាក់ទណ្ឌកម្មលើចារី[២២៣២]។ វិធានការចាំបាច់ គឺជាវិធានការសមស្របទាំងឡាយសម្រាប់ថ្នាក់លើក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយបង្ហាញពីកិច្ចខិតខំប្រឹងប្រែងពិតប្រាកដក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម។ វិធានការសមស្រប គឺជាវិធានការទាំងឡាយណាដែល

---

[២២២៨] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៩(ថ្មី)។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ៥៤០-៥៤២។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៩។ សាលដីកានៅក្នុងរឿងក្តី *Delalić និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៩១-១៩២, ១៩៨, ២០៦, ២៥២។

[២២២៩] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៩ (ថ្មី)។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៣-៥៤៤។ *សូមមើលផងដែរ* សាលក្រមនៅក្នុងរឿងក្តី *RuSHA* ទំព័រ ១០៦។ សាលក្រមនៅក្នុងរឿងក្តី *មេបញ្ជាការ* ទំព័រ ៥៤៥។ សាលក្រមនៅក្នុងរឿងក្តី *ចំណាប់ខ្មាំង* ទំព័រ ១២៣០, ១២៧១ (ថ្នាក់លើ "អាចទាមទារឱ្យមានរបាយការណ៍គ្រប់គ្រាន់អំពីហេតុការណ៍ ទាំងអស់ដែលបានកើតឡើងនៅក្នុងវិសាលភាពនៃអំណាចរបស់ខ្លួន...ប្រសិនបើខកខានមិនទាមទារ និងប្រមូលព័ត៌មានឱ្យបានពេញលេញទេនោះ ការធ្វេសប្រហែសចំពោះកាតព្វកិច្ច គឺធ្លាក់លើខ្លួន ហើយថ្នាក់លើមិនមានលទ្ធភាពយកការធ្វេសប្រហែសនេះមកសំអាងជាការការពារខ្លួនបានឡើយ") ១២៨១ ("ថ្នាក់លើមិនអាចបិទភ្នែករបស់ខ្លួនចំពោះអ្វីដែលកំពុងកើតឡើងនៅជុំវិញខ្លួន ហើយទាមទារឱ្យរួចផុតពីទណ្ឌកម្មពីព្រោះតែខ្លួនមិនបានដឹងអំពីអ្វីដែលខ្លួនមានកាតព្វកិច្ចត្រូវដឹងនោះទេ")។ សាលក្រមនៅក្នុងរឿក្តី *Toyoda* ទំព័រ ៥០០៦ (ថ្នាក់លើអាចទទួលខុសត្រូវ ប្រសិនបើ "បានដឹង ឬ គួរតែបានដឹងតាមរយៈការយកចិត្តទុកដាក់របស់ខ្លួនឱ្យបានសមស្រប")។ សាលដីកានៅក្នុងរឿងក្តី *Delalić និងអ្នកផ្សេងទៀត* កថាខណ្ឌ ២២៨-២៤១។

[២២៣០] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៣។ សាលដីកានៅក្នុងរឿងក្តី *Orić* កថាខណ្ឌ ៥៧-៥៩។

[២២៣១] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៤។ សាលដីកានៅក្នុងរឿងក្តី *Hadžihasanović* និង *Kubura* កថាខណ្ឌ ២៨។

[២២៣២] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៩ (ថ្មី) ។ សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៥-៥៤៧។ សាលក្រមនៅក្នុងរឿងក្តី *Einsatzgruppen* ទំព័រ ៤៨៥-៤៨៦។

ស្ថិតនៅក្នុងអំណាចជាក់ស្តែងរបស់ថ្នាក់លើ។ វិធានការចាំបាច់ និងវិធានការសមស្រប ត្រូវយកមកពិចារណាទៅតាមករណីជាក់ស្តែងនីមួយៗ[២២៣៣]។ ការខកខានក្នុងការទប់ស្កាត់ និងការខកខានក្នុងការដាក់ទណ្ឌកម្ម កើតមាននៅក្នុងពេលខុសៗគ្នា គឺការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងការទប់-ស្កាត់បទឧក្រិដ្ឋកើតឡើងនៅមុនពេលប្រព្រឹត្តបទឧក្រិដ្ឋនោះ ចំណែកការទទួលខុសត្រូវលើការដាក់ទណ្ឌកម្មចំពោះចារីវិញ កើតឡើងក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋ[២២៣៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលលើកឡើងថា *ធាតុផ្សំសត្យានុម័ត* នៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវតែកើតមុនបទឧក្រិដ្ឋ[២២៣៥]។

៧១៧. ក្រុមមេធាវីការពារក្តី នួន ជា លើកបញ្ហាចំនួនបីចំណុចពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ៖ (១) ឋានៈនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ (២) ថាតើថ្នាក់លើត្រូវតែមានកាតព្វកិច្ចនៅក្នុងការចាត់វិធានការដែលត្រូវបានកំណត់ជាមុននៅក្នុងច្បាប់ជាតិក្នុងពេលពាក់ព័ន្ធណាមួយដែរ ឬ ទេ និង (៣) ថាតើថ្នាក់លើត្រូវទទួលខុសត្រូវតែចំពោះអំពើរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់ដែរ ឬ ទេ។

### ១៣.៧.១ ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

៧១៨. ក្រុមមេធាវីការពារក្តី នួន ជា រក្សាជំហរថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ត្រឹមឆ្នាំ ១៩៧៥។ ដើម្បីគាំទ្រដល់ការសន្និដ្ឋានបែបនេះ ក្រុមមេធាវីការពារក្តីភាគច្រើន បានបញ្ចូលដោយលើកយោងនូវទឡ្ហីករណ៍ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ នៅក្នុងបណ្តឹងឧទ្ធរណ៍

[២២៣៣] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៥។ សាលដីកានៅក្នុងរឿងក្តី *Halilović* កថាខណ្ឌ ៦៣។

[២២៣៤] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤៦។ សាលដីកានៅក្នុងរឿងក្តី *Hadžihasanović* និង *Kubura* កថាខណ្ឌ ៤០ (ទំនាក់ទំនងហេតុ និងផលរវាងការខកខានក្នុងការដាក់ទណ្ឌកម្មជាមួយនឹងបទឧក្រិដ្ឋ ពុំមែនជាលក្ខខណ្ឌ តម្រូវឡើយ) ២៥៩-២៦០។

[២២៣៥] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៦៦-៦៧។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ កៈ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/10.2 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤១។

ប្រឆាំងនឹងដីកាដំណោះស្រាយ[២២៣៦]។ អង្គបុរេជំនុំជម្រះបានដោះស្រាយ និងច្រានចោលសេចក្តីសន្និដ្ឋានទាំងនេះរួចអស់ហើយ។ ក្រោយពីពិនិត្យមើលយុត្តិសាស្ត្រនាសម័យ Nuremberg អង្គបុរេជំនុំជម្រះបានយល់ឃើញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចអនុវត្តបានទាំងចំពោះថ្នាក់លើនៅក្នុងជួរយោធា និងទាំងថ្នាក់លើនៅក្នុងជួរស៊ីវិល មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ រួចទៅហើយ[២២៣៧]។ អង្គជំនុំជម្រះសាលាដំបូងទទួលយកសំអាងហេតុនេះ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិនិត្យមើលសេចក្តីសន្និដ្ឋានទាំងនេះឡើងវិញឡើយ។

៧១៩. ក្រុមមេធាវីការពារក្តី នួន ជា សន្និដ្ឋានបន្ថែមទៀតថា ការខ្វះភាពច្បាស់លាស់នៅក្នុងនិយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈការសម្រេចលើបទដ្ឋានពាក់ព័ន្ធស្តីពី *ធាតុផ្សំអត្តនោម័ត* នៅក្នុងយុត្តិសាស្ត្រនៃប្រទេសអាមេរិក នៅក្នុងរឿងក្តី *Yamashita* និង *Medina*[២២៣៨]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដើម្បីឲ្យវិធានមួយត្រូវបានបង្កើតឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការអនុវត្តដែលជាលទ្ធផលនៃវិធាននេះ មិនចាំបាច់ត្រូវតែ

[២២៣៦] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៩ *ដែលដកស្រង់* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ ២៨៣-៣០២ និងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៨១-៩៤។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក៖ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/10.2 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៧-៤០។

[២២៣៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៩០-២៣២។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤១៣-៤៦០។

[២២៣៨] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤០ *ដែលដកស្រង់* រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង យ៉ាម៉ាស៊ីតា* 327 US 1 (1946) ("រឿងក្តី *យ៉ាម៉ាស៊ីតា*")និងរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង ម៉េឌីនណា* CM 427162 (ACMR 1971) ("រឿងក្តី *ម៉េឌីនណា*") ដូចបានរាយការណ៍នៅក្នុង FRIEDMAN *ច្បាប់សង្គ្រាម៖ ប្រវត្តិសាស្ត្រដែលបានចងក្រងទុកជាឯកសារ* (New York, Random House Vol II., 1972) ទំព័រ ១៧៣២។

"គោរពយ៉ាងតឹងរ៉ឹងដាច់ខាតតាមវិធាននោះឡើយ"[២២៣៩]។ អាស្រ័យហេតុនេះ បើទោះជាមតិខុសគ្នារវាងតុលាការកំពូលនៃសហរដ្ឋអាមេរិក (*Yamashita*) និងចៅក្រមយោធានៃសាលាដំបូង (*Medina*) បង្ហាញអំពីភាពមិនច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រអាមេរិកពាក់ព័ន្ធនឹងចំណុចសំខាន់នៃលក្ខខណ្ឌតម្រូវនៃធាតុចេតនាក៏ដោយ[២២៤០] ក៏ភាពមិនស៊ីសង្វាក់គ្នារវាងរឿងក្ដីទាំងពីរនៅក្នុងរដ្ឋតែមួយនេះ អាចត្រូវបានយកមកធ្វើជាសម្អាងថា ទម្រង់នៃការទទួលខុសត្រូវមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះបានឡើយ[២២៤១]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្ដីខកខានមិនបានផ្ដល់ហេតុ-ផលគួរឱ្យជឿជាក់ដើម្បីច្រានចោលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានកំណត់ឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥[២២៤២]។

---

[២២៣៩] សាលក្រម *នីខារ៉ាហ្គា ទល់នឹង សហរដ្ឋអាមេរិក* ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៦ របាយការណ៍នៃតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៨៦ កថាខណ្ឌ ១៨៦។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារលេខ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤៥៨-៤៦០ (ដែលទទួលស្គាល់ថា "ការបញ្ជាក់ច្បាស់អំពីធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្ដីនេះ មិនមែនតែងតែច្បាស់លាស់ ឬ ពេញ-លេញនោះទេ" ក៏ប៉ុន្ដែ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានកំណត់ឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិរួច ទៅហើយនៅត្រឹមឆ្នាំ ១៩៧៥ នោះ។

[២២៤០] ក្រុមមេធាវីការពារក្ដីអះអាងដោយមិនត្រឹមត្រូវថា រឿងក្ដី *Medina* គឺធ្វើឡើងនៅចំពោះមុខសាលាឧទ្ធរណ៍យោធានៃសហរដ្ឋអាមេរិក (សេចក្ដីសន្និដ្ឋានបឋម របស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារលេខ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤០)។ ទោះបីជាយ៉ាងនេះក្ដី ព្យសនកម្មនៅក្នុងរឿងក្ដី *Medina* បានធ្វើឱ្យជនជាប់ចោទរួចផុតពីបទចោទទាំងអស់ ហើយពុំដែលមានសវនាការលើបណ្ដឹងឧទ្ធរណ៍នោះទេ (Michael Smidt, Yamashita, Medina និង Beyond: ការទទួលខុសត្រូវរបស់មេបញ្ជាការនៅក្នុងប្រតិបត្តិការយោធានាសម័យនោះ *ទស្សនាវដ្ដីច្បាប់យោធា* Vol. 164 (ខែ មិថុនា ឆ្នាំ ២០០០) ទំព័រ ១៩៩ (ដែលកត់សម្គាល់ថា ការណែនាំរបស់ចៅក្រមចំពោះព្យសនកម្មនៅក្នុងរឿងក្ដី *Medina* មានតម្លៃជាយុត្តិសាស្ត្រតិចតួចបំផុត)។

[២២៤១] សាលក្រម *ចក្រភពអង់គ្លេស ទល់នឹង ប្រទេសន័រវេ* ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៥១ របាយការណ៍នៃតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៥១ ទំព័រ ១៣៨ ("មិនចាំបាច់ផ្ដល់សារៈសំខាន់ខ្លាំងពេកចំពោះភាពពុំប្រាកដប្រជា ឬភាពផ្ទុយគ្នាមួយចំនួននោះទេ [នៅក្នុងការអនុវត្តរបស់រដ្ឋ] ការពិតប្រាកដ ឬជាក់ស្ដែង")។

[២២៤២] សាលក្រមនៅក្នុងរឿងក្ដី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៤៧៦-៤៧៧។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/2/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៩០-២៣២។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤១៣-៤៦០។

01006976



## ១៣.៧.២ កាតព្វកិច្ចក្នុងការចាត់វិធានការ

៧២០. ក្រុមមេធាវីការពារក្តី នួន ជា ក៏បានសន្និដ្ឋានថា ទាំងថ្នាក់លើនៅក្នុងជួរយោធា និងទាំងថ្នាក់លើនៅក្នុងជួរស៊ីវិល ចាំចាច់ត្រូវតែមានកាតព្វកិច្ចផ្លូវច្បាប់ ចាត់វិធានការដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជាក្នុងពេលពាក់ព័ន្ធណាមួយ[២២៤៣]។ ក្រុមមេធាវីការពារក្តីបានអះអាងបន្ថែមទៀតថា ថ្នាក់លើនៅក្នុងជួរស៊ីវិល អាចដាក់ឲ្យទទួលខុសត្រូវបានតែក្នុងករណីដែលការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្លួនលើអ្នកនៅក្រោមបង្គាប់ គឺមានភាពស្រដៀងគ្នាទៅនឹងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ថ្នាក់លើនៅក្នុងជួរយោធាតែប៉ុណ្ណោះ[២២៤៤]។ អង្គជំនុំជម្រះបានកំណត់រួចហើយថា តុលាការអាចផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន ក្នុងករណីដែលចរិតលក្ខណៈនៃបទឧក្រិដ្ឋអន្តរជាតិ ឬ ទម្រង់នៃការទទួលខុសត្រូវមិនមានចែងនៅក្នុងច្បាប់ជាតិ[២២៤៥]។ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពត្រឹមឆ្នាំ ១៩៧៥ មិនមានបុរេលក្ខខណ្ឌតម្រូវឲ្យថ្នាក់លើមានកាតព្វកិច្ចក្នុងការចាត់វិធានការដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិឡើយ[២២៤៦]។ ដោយមិនគិតថា តើជនជាប់ចោទជាថ្នាក់លើនៅក្នុងជួរស៊ីវិល ឬ ថ្នាក់លើនៅក្នុងជួរយោធានោះទេ កាតព្វកិច្ចក្នុងការចាត់វិធានការកើតចេញពីការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ថ្នាក់លើមកលើអ្នកនៅក្រោមបង្គាប់របស់ខ្លួន និងលទ្ធភាពជាក់ស្តែងក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិអំពើឧក្រិដ្ឋណាមួយ[២២៤៧]។ ការសម្រេចថា តើថ្នាក់លើមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព

---

[២២៤៣] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៩-៤៥។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក៖ សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលអាចអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E163/5/10.2 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤១។

[២២៤៤] សេចក្តីសន្និដ្ឋានបឋម [របស់ នួន ជា] ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៦។

[២២៤៥] ផ្នែកទី ២៖ បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ១៨។

[២២៤៦] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥៧៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤៥៩។

[២២៤៧] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៥៧៧។ សាលក្រមបន្ថែមនៅក្នុងរឿងក្តី *Pohl* ទំព័រ ១១៧៦ (ជនជាប់ចោទពុំមានអំណាចផ្លូវច្បាប់នោះទេ ប៉ុន្តែ “បានបង្កើតឱកាស” សម្រាប់ខ្លួនឯងនៅក្នុងជួរឋានានុក្រម)។ សាលដីកានៅក្នុងរឿងក្តី *Delalić និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៩៦-១៩៧។

ដែរ ឬ ទេ នោះគឺជាបញ្ហាភ័ស្តុតាងតែប៉ុណ្ណោះ មិនមែនជាបញ្ហាច្បាប់ឡើយ ដូច្នេះត្រូវវាយតម្លៃទៅលើបញ្ហានេះទៅតាមករណីជាក់ស្តែងនីមួយៗ[២២៤៨]។

### ១៣.៧.៣ ទំនាក់ទំនងរបស់អ្នកនៅក្រោមបង្គាប់

៧២១. ចំណុចចុងក្រោយ ក្រុមមេធាវីការពារក្តី នួន ជា អះអាងថា ថ្នាក់លើអាចដាក់ឱ្យទទួលខុសត្រូវបានចំពោះតែការប្រព្រឹត្តិរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់តែប៉ុណ្ណោះ[២២៤៩]។ ផ្ទុយមកវិញ យុត្តិសាស្ត្រនាសម័យ Nuremberg បានបង្ហាញថា ការទទួលខុសត្រូវរបស់ថ្នាក់លើ "មិនកម្រិតត្រឹមការគ្រប់គ្រងលើអង្គភាពនៅក្រោមការបញ្ជាផ្ទាល់របស់ថ្នាក់លើនោះឡើយ"[២២៥០]។ ហេតុដូច្នេះ អង្គជំនុំជម្រះតម្កល់សំអាងហេតុមុនៗរបស់ខ្លួនថា "ការទទួលខុសត្រូវរបស់ថ្នាក់លើអាចកើតចេញពីមូលដ្ឋាននៃទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលរបស់អ្នកនៅក្រោមបង្គាប់"[២២៥១]។

## ១៤. សហឧក្រិដ្ឋកម្មរួម

៧២២. យោងតាមដីកាដំណោះស្រាយ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (ថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩) បក្សកុម្មុយនីស្តកម្ពុជាមានគោលបំណងរួមដើម្បីធ្វើបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សមួយតាមរយៈ "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ (ផ្នែក ១៤.១)[២២៥២]។ ដីកាដំណោះ-ស្រាយចោទប្រកាន់ថា បុគ្គលជាច្រើនរួមមាន សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដូចជា នួន ជា និង អៀង សារី សមាជិកនៃគណៈកម្មាធិការមជ្ឈិម ដូចជា ខៀវ សំផន ថ្នាក់ដឹកនាំក្រសួងនៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំង អៀង ធីរិទ្ធ លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត និងលេខា

---

[២២៤៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤៥៩ ។ សាលដីកានៅក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៦៩។

[២២៤៩] សេចក្តីសន្និដ្ឋានបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5/11 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៧-៤៩។

[២២៥០] សាលក្រមនៅក្នុងរឿងក្តី *ចំណាប់ខ្មាំង* ទំព័រ ១២៦០។ សាលក្រមនៅក្នុងរឿងក្តី *មេបញ្ជាការ* ទំព័រ ៥៤៣។ សាលក្រមនៅក្នុងរឿងក្តី *Pohl* ទំព័រ ១០៥២-១០៥៣។

[២២៥១] សាលក្រមនៅក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៥៤២។

[២២៥២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦, ១៥៨, ១៥២៤, ១៥២៨។

កងពលផ្សេងៗរបស់មជ្ឈិមបក្ស[២២៥៣] មានគោលបំណងរួម និងបានចូលរួមនៅក្នុងគោលបំណងរួមនេះ។

៧២៣. ដូចបានកំណត់នៅក្នុងសំណុំរឿង ០០២/០១ ដីកាដំណោះស្រាយចោទប្រកាន់ថា អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម បានរៀបចំបង្កើត និងអនុវត្តគោលនយោបាយខាងក្រោមក្នុងចំណោមគោលនយោបាយផ្សេងទៀតក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ៖

i. ការផ្លាស់ទីលំនៅប្រជាជនជាច្រើនលើកច្រើនសាចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ("គោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន") ដរាបណាគោលនយោបាយនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ផ្នែក ១៤.២) និង

ii. ការកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំង មន្ត្រីរាជការអតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ("គោលនយោបាយស្តីពីការកំណត់គោលដៅ") ដរាបណាគោលនយោបាយនេះពាក់ព័ន្ធនឹងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ (ផ្នែក ១៤.៣)[២២៥៤]។

## ១៤.១ គោលបំណងរួម

៧២៤. ថ្នាក់ដឹកនាំបក្សបានព្យាយាមសម្រេចគោលបំណងរួមមួយដើម្បីរំដោះប្រទេសកម្ពុជា និងបង្កើតរដ្ឋសង្គមនិយមក្នុងបួនដំណាក់កាល៖ ដំណាក់កាលកសាងបក្ស (ខែ កញ្ញា ឆ្នាំ ១៩៦០- ខែ មករា ឆ្នាំ ១៩៦៨)(ផ្នែក ១៤.១.១) ដំណាក់កាលផ្តួចផ្តើមបដិវត្តន៍ប្រដាប់អាវុធ (ខែ មករា ឆ្នាំ ១៩៦៨ - ខែ មីនា ឆ្នាំ ១៩៧០)(ផ្នែក ១៤.១.២) ដំណាក់កាលបដិវត្តន៍ប្រជាធិបតេយ្យ (ខែ មីនា

---

[២២៥៣] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៩, ៨៩៥-៩០១, ៩៧៥-៩៧៧, ១១៥៣-១១៦២, ១១៩១-១១៩៣, ១៥២៩, ១៥៣២-១៥៣៣, ១៥៣៦-១៥៣៧។

[២២៥៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧-១៥៨, ១៥២៥, ១៥២៨។ ឧបសម្ពន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។ *សូមមើលផងដែរ* ផ្នែកទី ១៖ សេចក្តីផ្តើម កថាខណ្ឌ ៩-១១។ ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០២។

ឆ្នាំ ១៩៧០ - ខែ មេសា ឆ្នាំ ១៩៧៥)(ផ្នែក ១៤.១.៣) និងដំណាក់កាលបដិវត្តន៍សង្គមនិយម (ខែ មេសា ឆ្នាំ ១៩៧៥ - ខែ មករា ឆ្នាំ ១៩៧៩)(ផ្នែក ១៤.១.៤)[២២៥៥]។

៧២៥. ក្នុងចំណោមដំណាក់កាលទាំងនេះ អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការតែលើដំណាក់កាលបដិវត្តន៍សង្គមនិយមតែប៉ុណ្ណោះ ដែលបានចាប់ផ្តើមនៅពេលខ្មែរក្រហមបានបញ្ចប់ជម្លោះប្រដាប់អាវុធជាមួយនឹងរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះសាលាដំបូងក៏បានកំណត់យុត្តាធិការពេលវេលាពាក់ព័ន្ធនេះផងដែរ ដោយកម្រិតត្រឹមចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧ ទៅតាមវិសាលភាពនៃយុត្តាធិការពេលវេលាលើឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០២/០១។ ទោះបីជាយ៉ាងនេះក៏ដោយ គោលនយោបាយ និងផែនការទាំងឡាយសម្រាប់អនុវត្តគោលបំណងរួមនៅក្នុងអំឡុងរយៈពេលនេះត្រូវបានបង្កើតឡើង នៅមុនយុត្តាធិការពេលវេលារបស់តុលាការនេះទៅទៀត។ លើសពីនេះទៀត អ្នកចូលរួមសំខាន់ៗបំផុតបានចូលរួមនៅក្នុងគោលបំណងរួមនេះ តាំងពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកម្លេះ។ ហេតុដូច្នេះ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីគោលគំនិតនៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់ត្រូវលើកឡើងអំពីការវិវត្តនៃគោលនយោបាយ និងផែនការនានា ព្រមទាំងដំណាក់កាលផ្សេងៗដែលអ្នកចូលរួមទាំងនោះត្រូវបានគេស្គាល់។

---

[២២៥៥] *សូមមើល ឧទាហរណ៍* សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៣-១០, ១៨-២០ ERN (ភាសាខ្មែរ) 00324812-00324819, 00324827-00324829 (ការតស៊ូប្រដាប់អាវុធបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៦៨។ ក្រោយមកចាប់ពីខែ មីនា ឆ្នាំ ១៩៧០ រហូតដល់ ខែ មេសា ឆ្នាំ ១៩៧៥ ការតស៊ូនេះគឺជាការតស៊ូរួមគ្នាក្នុងចំណោមគ្រប់ក្រុមទាំងអស់ដើម្បីរំដោះជាតិពីពួកចក្រពត្តិអាមេរិក។ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ នេះជារយៈពេលនៃការតស៊ូដើម្បីការពារជាតិនៅក្នុងបដិវត្តន៍សង្គមនិយម)។ កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00333332-00333344 (បក្សត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៦០។ ក្រោយពីពេលនេះមក មាគ៌ាបក្សត្រូវបានរៀបចំរួចជាស្រេច។ ចាប់ពីឆ្នាំ ១៩៦៨ ដល់ ឆ្នាំ ១៩៧០ សង្គ្រាមស៊ីវិលប្រដាប់អាវុធបានចាប់ផ្តើមឡើង។ ក្រោយមកពីខែ មីនា ឆ្នាំ ១៩៧០ ដល់ ខែ មេសា ឆ្នាំ ១៩៧៥ មានសង្គ្រាមរំដោះប្រទេសពីពួកចក្រពត្តិ។ ចាប់ពីឆ្នាំ ១៩៧៥ នេះជារយៈពេលបដិវត្តន៍សង្គមនិយម)។

### ១៤.១.១ ដំណាក់កាលទី១៖ ការកសាងបក្ស

៧២៦. នៅចន្លោះឆ្នាំ ១៩៥៨ និងឆ្នាំ ១៩៦០ ប៉ុល ពត នួន ជា និងអ្នកផ្សេងទៀត បានព្រាងលក្ខន្តិកៈបក្សជាលើកដំបូង និងបានចាប់ផ្តើមបង្កើតមាគ៌ានយោបាយបក្ស រួមទាំង តម្រូវការចាំបាច់ក្នុងការតស៊ូប្រដាប់អាវុធ ការបង្កើតរដ្ឋសង្គមនិយម "ប្រជាធិបតេយ្យប្រមូលផ្តុំ"[២២៥៦] និងការផ្តោតសំខាន់លើស្មារតីខ្លួនទីពឹងខ្លួន[២២៥៧]។ ក្នុងពេលមហាសន្និបាតបក្សលើកទី១ ក្នុងខែ កញ្ញា ឆ្នាំ ១៩៦០ ទូ សាមុត (លេខា) នួន ជា (អនុលេខា) ប៉ុល ពត សុន សេន អៀង សារី វន វេត សោ ភឹម និងអ្នកផ្សេងទៀត[២២៥៨] បានអនុម័តកម្មវិធីនយោបាយបីចំណុច ដែលក្នុងនោះមាន ការប្រយុទ្ធប្រឆាំងនឹងចក្រពត្តិនិយម ការរំដោះប្រទេស និងប្រជាជន និងការធ្វើបដិវត្តន៍ឲ្យបានជោគជ័យ[២២៥៩]។ ដើម្បីសម្រេចគោលបំណងទាំងនេះ បក្សបានកំណត់ថា បក្សនឹងប្រើយុទ្ធសាស្ត្រផ្តោតលើកម្លាំងរបស់កសិករនៅតាមមូលដ្ឋានដាច់ស្រយាល ដោយធ្វើការតស៊ូនយោបាយនិងតស៊ូប្រដាប់អាវុធ ខ្លួនទីពឹងខ្លួន និងការតស៊ូវណ្ណៈ[២២៦០]។ មហាសន្និបាតបានសម្រេចជាផ្លូវការថា ពួកចក្រពត្តិបរទេស

---

[២២៥៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៦-៨៨។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៣-២២៨។

[២២៥៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៦-៨៨ ។ ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥។ *សូមមើលផងដែរ បទសម្ភាសន៍ជាមួយឧបនាយករដ្ឋមន្ត្រីលោក អៀង សារី* (សារព័ត៌មាន The Call) ឯកសារ E3/652 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00710297-00710299 (ជនបដិវត្តន៍កម្ពុជាបានជឿជាក់ថា ការតស៊ូប្រដាប់អាវុធចាំបាច់ត្រូវធ្វើឡើងដើម្បីលុបបំបាត់សក្តិភូមិនិយម និងមូលធននិយម និងបង្កើតរដ្ឋសង្គមនិយម។ ដោយសារសូវៀតបានជំទាស់នៅពេលជនបដិវត្តន៍ កម្ពុជាស្នើសុំលុយដើម្បីបោះពុម្ពកាសែត ដូច្នេះពួកគេដឹងថា ពួកគេត្រូវម្ចាស់ការលើខ្លួនឯង)។

[២២៥៨] នៅចន្លោះថ្ងៃទី ២៨ និងថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦០ មហាសន្និបាតបក្សលើកទី ១ បានអនុម័តលក្ខន្តិកៈ បានតែងតាំង ទូ សាមុត ជាលេខា និង នួន ជា ជាអនុលេខា បានបង្កើតគណៈកម្មាធិការមជ្ឈិម ដោយសមាជិកមានទាំង វន វេត ជាសមាជិកនៃគណៈកម្មាធិការនេះផងដែរ ហើយបានតែងតាំង នួន ជា, ប៉ុល ពត, សុន សេន, អៀង សារី និង សោ ភឹម ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣)។

[២២៥៩] សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00224458-00224459។ បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00078194-00078195។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00752089-00752090 (ពាក់ព័ន្ធនឹងកម្មវិធីបីចំណុចដែលត្រូវបានអនុម័តក្នុងពេលមហាសន្និបាតបក្សលើកទី១)។

[២២៦០] ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ២-៤។ សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00224458-

"បរិវារ" ឬ អ្នកបម្រើរបស់ពួកគេ និង "សក្តិភូមិ នាយទុន និងប្រតិកិរិយា" គឺជាខ្មាំងវណ្ណៈទាំងអស់[២២៦១]។ ទោះបីជាបដិវត្តន៍ត្រូវបានបន្តធ្វើឡើងនៅតាមខេត្តក្រុងក៏ដោយ ក៏មហាសន្និបាតបានសម្រេចថា ខេត្ត-ក្រុងមិនអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋាននោះទេ ដោយសារវិសាលភាពភូមិ-សាស្ត្រតូច ហើយខ្មាំងនៅគ្រប់ទីកន្លែងទាំងអស់[២២៦២]។ ចំណុចចុងក្រោយ បក្សចាំបាច់ត្រូវរក្សាការសម្ងាត់ដើម្បីកុំឲ្យគេរកឃើញមេដឹកនាំ ហើយបដិវត្តន៍នេះបានបញ្ចប់ដោយមិនទាន់ទាំងបានចាប់ផ្តើមនៅឡើយ[២២៦៣]។ ក្នុងខណៈពេលកំពុងបន្តការតស៊ូនយោបាយ[២២៦៤] នៅក្នុងឆ្នាំ ១៩៦១ បក្សបានចាប់ផ្តើមបង្កើតកងការពារសម្ងាត់ និងអប់រំសមាជិកអំពីភាពចាំបាច់ក្នុងការតស៊ូប្រដាប់អាវុធ[២២៦៥]។

---

00224459។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00078194-00078195 (ក្នុងពេលមហាសន្និបាតបក្សលើកទី ១ បក្សបានកំណត់ថា បដិវត្តន៍ផ្អែកលើពាក្យស្លោក តស៊ូយូរអង្វែង លំបាកវេទនា ខ្លួនឧបត្ថម្ភខ្លួន ម្ចាស់ការ ឯករាជ្យ។ កម្លាំងដើម្បីសម្រេចបដិវត្តន៍នេះគឺសម្ព័ន្ធភាពកម្មករ-កសិករ)។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00752089-00752090 (បក្សកុម្មុយនីស្តកម្ពុជាបានជ្រើសរើសយកគោលការណ៍រក្សាការសម្ងាត់ និងហិង្សា តាំងពីដើមដំបូង ដោយសារបក្សបានដឹងថា សភានឹងមិនយល់ព្រមតាមទេ)។ បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ២៩-៣៥, ៣៨-៤១, ៤៣-៤៦ ERN (ភាសាខ្មែរ) 00442106-00442109, 00442111-00442112, 00442113-00442115 (ភារកិច្ចនៃបដិវត្តន៍រួមមាន ការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម និងការតស៊ូប្រឆាំងវណ្ណៈ)។

[២២៦១] ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (នួន ជា), ទំព័រ៥៨-៦២។ ប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (នួន ជា), ទំព័រ ១៣-១៥។ *សមមិត្ត នួន ជា ថ្លែងក្នុងទិវាខួបកំណើតកងទ័ពបដិវត្តន៍កម្ពុជា* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/147 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00679796-00679798។ *ទស្សនាវដ្តី ទង់បដិវត្ត* ខែធ្នូ ឆ្នាំ ១៩៧៦ - មករា ឆ្នាំ ១៩៧៧ ឯកសារ E3/25 ERN (ភាសាខ្មែរ) 00063023 (ត្រូវវាយរំលំសក្តិភូមិ នាយទុន ប្រតិកិរិយា)។

[២២៦២] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៥៩-៦២ ERN (ភាសាខ្មែរ) 00442122-00442124។

[២២៦៣] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៣២-៣៥ ERN (ភាសាខ្មែរ) 00442108-00442109។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00224458-00224459។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00224459-00224461។

៧២៧. ក្នុងពេលមហាសន្និបាតបក្សលើកទី២ ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៦៣ ប៉ុល ពត (ដែលនៅពេលនោះ ជាលេខាបក្ស) នួន ជា (អនុលេខា) អៀង សារី វន វេត រស់ ញឹម តា ម៉ុក សោ ភឹម និងទំនងជាមាន សុន សេន ព្រមទាំងអ្នកផ្សេងទៀត បានលើកឡើងបញ្ជាក់អំពីមាគ៌ាបក្សដែលត្រូវបានអនុម័តនៅក្នុងមហាសន្និបាតបក្សលើកទី១ ដោយមាគ៌ាទាំងនោះ រួមទាំងបដិវត្តន៍នយោបាយ និងបដិវត្តន៍ប្រដាប់អាវុធ[២២៦៦]។ នៅចន្លោះឆ្នាំ ១៩៦៣ និងឆ្នាំ ១៩៦៧ មានការប្រជុំផ្សេងៗរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមនៅក្នុងព្រៃម៉ាកគី[២២៦៧] ដោយការប្រជុំខ្លះ

---

[២២៦៤] សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00224459-00224461 (ក្រោយឆ្នាំ ១៩៦០ បក្សបានបន្តការងារនយោបាយមួយចំនួននៅក្នុងសភា រដ្ឋាភិបាល និងសារព័ត៌មាន ដើម្បីប្រមូលកម្លាំងប្រជាជន) ទំព័រ ២៣-២៥ ERN (ភាសាខ្មែរ) 00224479-00224481 (ការតស៊ូតាមផ្លូវច្បាប់នៅក្នុងខេត្តក្រុង រួមមានដូចជា ការផ្សព្វផ្សាយតាមកាសែត ការធ្វើបាតុកម្ម សភា និងការអូសទាញអ្នកនយោបាយជាដើម)។

[២២៦៥] ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៥-៦ (កងការពារសម្ងាត់មានគោលបំណងការពារ និងអមដំណើរកម្មាភិបាលដែលធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀត)។ *សុន្ទរកថារបស់លោក នួន ជា នៅក្នុងមិទ្ទិញទិវាខួបកងទ័ព* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/209 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00649942-00649944 (នៅក្នុងឆ្នាំ ១៩៦១ ពួកគេបានចាប់ផ្តើមរៀបចំកងការពារសម្ងាត់។ ត្រឹមឆ្នាំ ១៩៦៦ នៅក្នុងកងការពារសម្ងាត់នីមួយៗនៅតាមមូលដ្ឋានទូទាំងប្រទេស មានសមាជិកយ៉ាងហោចណាស់បីនាក់)។ *បទសម្ភាសន៍ជាមួយឧបនាយករដ្ឋមន្ត្រីលោក អៀង សារី* (សារព័ត៌មាន The Call) ឯកសារ E3/652 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00710297-00710299 (ពួកគេនៅមានការងារមនោគមវិជ្ជាត្រូវធ្វើ រួមទាំង ការអប់រំសមាជិកឲ្យយល់ថា ការតស៊ូដើម្បីកំណែទម្រង់មានសារៈសំខាន់ ក៏ប៉ុន្តែមានតែការតស៊ូប្រដាប់អាវុធតែប៉ុណ្ណោះ ដែលអាចផ្តល់អំណាចនយោបាយជូនបក្សបាន)។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00224459-00224461។

[២២៦៦] លេខាបក្ស ទូ សាមុត ទំនងត្រូវបានចាប់ខ្លួនប្រហែលជាក្នុងខែ កុម្ភៈ ឆ្នាំ ១៩៦២ និងបានបាត់ខ្លួន ដែលករណីនេះចាំបាច់ឲ្យមានការកោះប្រជុំមហាសន្និបាតបក្សមួយទៀតដើម្បីជ្រើសតាំងលេខាថ្មីម្នាក់។ សមាជិកពេញសិទ្ធិនៃគណៈ-កម្មាធិការអចិន្ត្រៃយ៍រួមមាន ប៉ុល ពត, សោ ភឹម, អៀង សារី, តា ម៉ុក, និង នួន ជា។ ប៉ុល ពត ត្រូវបានជ្រើសតាំងជាលេខាបក្ស ហើយ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាសាជាថ្មី (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៩។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣)។

[២២៦៧] ភ្លាមៗក្រោយពីមហាសន្និបាតបក្សលើកទី ២ នៅពេលប្រឈមនឹងកំណើនសម្ពាធពីរដ្ឋាភិបាល មេដឹកនាំបក្សជាច្រើននាក់បានរត់ចូលព្រៃម៉ាកគី (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៩។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣។ ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣០៩)។

មានវត្តមាន នួន ជា ចូលរួមផងដែរ[២២៦៨]។ នៅក្នុងអំឡុងពេល នៃដំណាក់កាលបដិវត្តន៍កសាងបក្ស នេះ បក្សមានអាទិភាពចំនួនបី គឺ ការបង្កើនចលនារបស់ប្រជាជន ការការពារហិង្សាបដិវត្តន៍ និង ការ តស៊ូប្រដាប់អាវុធ និងការកសាងមូលដ្ឋានបដិវត្តន៍[២២៦៩]។ ក្រោយមកទៀត អៀង សារី បាន ឱ្យនិយមន័យមូលដ្ឋានថាជាទីតាំងដែលប្រជាជនយល់អំពីបដិវត្តន៍ ស្អប់ខ្ពើមខ្លាំង ម្ចាស់ការលើខ្លួន ឯង និងមានកងការពារសម្ងាត់[២២៧០]។

### ១៤.១.២ ដំណាក់កាលទី២៖ ការផ្តួចផ្តើមបដិវត្តន៍ប្រដាប់អាវុធ

៧២៨. ក្រោយការបះបោររបស់កសិករ និងការធ្វើបាតុកម្មរបស់មហាជន រួមទាំងការបះបោរនៅ សំឡូតក្នុងឆ្នាំ ១៩៦៧[២២៧១] រួចមក រដ្ឋាភិបាលបានទម្លាក់កំហុសការបះបោរនេះទៅលើ ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់។ អ្នកទាំងអស់នេះបានរត់ចូលព្រៃម៉ាកគីដែលនៅទីនោះមានបក្សជាអ្នក ការពារពួកគេ[២២៧២]។ ខៀវ សំផន បានលើកឡើងថា ទោះបីជារូបភាព និងសកម្មភាពរបស់ខ្មែរ

---

[២២៦៨] ប្រតិចារឹកថ្ងៃទី 0៦ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៦-៧, ៨-៩ (នួន ជា បានជួបជាមួយ ប៉ុល ពត និងមេដឹកនាំផ្សេងទៀតប្រហែលជារៀងរាល់ ១ ទៅ ២ ខែ ម្តង បន្ទាប់ពីពួកគេបានទៅព្រៃម៉ាកគី)។ ប្រតិចារឹកថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ១៣-១៧ (ចន្លោះឆ្នាំ ១៩៦៣ និងឆ្នាំ ១៩៦៦ មានកិច្ចប្រជុំមជ្ឈិម ដែលក្នុងពេលប្រជុំខ្លះ មានវត្តមាន នួន ជា ចូលរួមផងដែរ)។ បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00078196-00078197 (នួន ជា ធ្វើដំណើរទៅវិញទៅមករវាងខេត្តកំពង់ចាម ក្រោយមក ខេត្តរតនគិរី ដែលជាទីស្នាក់របស់ ប៉ុល ពត ស្ថិតនៅ និងទីក្រុងភ្នំពេញ)។

[២២៦៩] កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៨-១០ ERN (ភាសាខ្មែរ) 00333338-00333340។ សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00224458-00224459។ របាយការណ៍ OTAN កម្មវត្ថុៈ ដំណើរវិវត្តន៍ថ្មីៗក្នុងវិស័យនយោបាយនៅប្រទេសកម្ពុជា ឯកសារ E3/493 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00693768-00693769។

[២២៧០] កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៨-១០ ERN (ភាសាខ្មែរ) 00333338-00333340។

[២២៧១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩១។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦១។

[២២៧២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៩, ៩២។ ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣០៩។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦១។ *សូមមើល ផងដែរ* ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦០ (“ខ្ញុំក្លាយជារបស់មួយដែលមានតម្លៃ ដែលធ្លាក់ទៅលើដៃរបស់បក្សកុម្មុយនីស្តកម្ពុជា។ ការដែលខ្ញុំត្រូវបង្ខំចិត្តរត់ចេញពីភ្នំពេញបានក្លាយទៅជាឱកាសមួយរបស់គេ ដើម្បីយកខ្ញុំទៅមួយគេ”)។

ក្រហមបែបនេះក៏ដោយ គាត់បានជ្រើសរើសចូលរួមជាមួយខ្មែរក្រហម ដោយសារខ្មែរក្រហមវាយប្រយុទ្ធទាមទារឯករាជ្យ និងអធិបតេយ្យសម្រាប់ប្រទេសកម្ពុជា[២២៧៣]។

៧២៩. នៅចុងឆ្នាំ ១៩៦៧ ឬ ដើមឆ្នាំ ១៩៦៨ ប៉ុល ពត នួន ជា និងអ្នកផ្សេងទៀត បានកំណត់ថា បដិវត្តន៍ប្រដាប់អាវុធគួរត្រូវចាប់ផ្តើម[២២៧៤]។ នៅក្នុងខែ មករា ឆ្នាំ ១៩៦៨ នួន ជា បានកោះប្រជុំ

---

[២២៧៣] ប្រតិចារឹកថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់ ខៀវ សំផន) ទំព័រ៨-១០ (ខៀវ សំផន បានចូលរួមចំណែកដល់ការផ្សះផ្សាជាតិ ដើម្បីការពារប្រទេសឱ្យមានឯករាជ្យ និងអធិបតេយ្យ)។ ប្រតិចារឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ (ខៀវ សំផន) ទំព័រ៦២ (ខៀវ សំផន មានអារម្មណ៍ថា គាត់មិនអាចឱ្យប្រទេសរបស់គាត់ធ្លាក់ក្នុងកណ្តាប់ដៃរបស់វៀតណាមនោះទេ ដូច្នេះ គាត់បានចូលបក្សនៅក្នុងឆ្នាំ ១៩៦៩)។ ការឆ្លើយឆ្លងជាមួយលោក ខៀវ សំផន ឯកសារ E3/3193 គ្មានចុះកាលបរិច្ឆេទ 00704257-00704258 (ខៀវ សំផន បានលើកឡើងសាជាថ្មីថា គាត់មិនអាចគេចផុតពីការជ្រើសរើសយកខាងណាម្ខាងនោះទេ ដោយមិនខ្វល់ពីស្ថានភាពរបស់ពួកគេ បើទោះបីជាសកម្មភាពរបស់ពួកគេមានទំនាស់នឹងគ្នាខ្លាំងក៏ដោយ ដោយសារពួកគេកំពុងតែប្រយុទ្ធដើម្បីការពារអធិបតេយ្យភាពរបស់ប្រទេសជាតិយើង)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3196 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00807451-00807452 (“ខ្ញុំចូលដៃជាមួយ ប៉ុល ពត ដើម្បីតស៊ូ ទោះបីជាខ្ញុំពុំមានអំណាច ឬបុព្វសិទ្ធិក៏ដោយ ហើយខ្ញុំត្រូវបានតម្លើងក្នុងមុខតំណែងខ្ពស់”។ ខ្មែរក្រហម មានគោលបំណងប្រឆាំងនឹងការឈ្លានពានរបស់បរទេសមកលើប្រទេសកម្ពុជា។ “នេះហៅថាស្នេហាជាតិនិយម”)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3203 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00802929-00802931 (“ខៀវ សំផន បានចូលបក្សកុម្មុយនីស្តកម្ពុជានៅពេលគាត់រត់ចូលព្រៃ”)។ លិខិតពី ខៀវ សំផន ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ E3/112 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00157636-00157638 (ដោយសារព្រឹត្តិការណ៍នានា គាត់ត្រូវសម្របតាមព្រឹត្តិការណ៍ទាំងនេះ ហើយធ្លាក់ទៅនៅក្រោមកិច្ចការពារនៃចលនាមួយដែលមិនសូវស្របនឹងទម្លាប់រស់នៅរបស់គាត់ តាមការដែលគាត់បានទទួលការអប់រំរៀនសូត្រ)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៣២-៣៣ ERN (ភាសាខ្មែរ) 00103824-00103873 (គាត់រំភើបចិត្តដែលបានឃើញកម្លាំងជាតិថ្មីមួយ ពោលគឺកម្លាំងជាតិពិតប្រាកដ ផុសចេញពីបេះដូងរបស់កសិកររស់នៅតាមទីជនបទ និងមានអារម្មណ៍ធូរស្បើយក្នុងចិត្ត)។

[២២៧៤] ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៦២-៦៣ (នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៦៨ លេខាទាំងអស់ និងមេដឹកនាំផ្សេងទៀតបានជួប និងសម្រេចផ្តួចផ្តើមការតស៊ូប្រដាប់អាវុធ)។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00224461-00224462 (នៅក្នុងពេលប្រជុំក្នុងខែ មករា ឆ្នាំ ១៩៦៨ បក្សបានសម្រេចចាប់ផ្តើមការតស៊ូអាវុធ)។ កិច្ចសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៥-១៦ ERN (ភាសាខ្មែរ) 00078197-00078198 (នៅចុងឆ្នាំ ១៩៦៧ នួន ជា, ម៉ា ម៉ង់, តា ម៉ុក, សោ ភឹម, និង វន វេត បានជួបគ្នា និងសម្រេចចាប់ផ្តើមការតស៊ូអាវុធ)។ កិច្ចសម្ភាសន៍ជាមួយ ជា ស៊ីម ដោយលោក Stephen HEDER ឯកសារ

មួយនៅក្នុងទីក្រុងភ្នំពេញជាមួយនឹងមេដឹកនាំភូមិភាគមួយចំនួន រួមទាំង សោ ភឹម រស់ ញឹម និង តា ម៉ុក។ ពួកគេបានពិភាក្សារួមគ្នាអំពីភាពចាំបាច់ត្រូវចាប់ផ្ដើមការតស៊ូប្រដាប់អាវុធប្រឆាំងនឹងអ្នកកាន់អំណាច ពោលគឺ ក្រុម លន់ នល់ ដែលកំពុងគ្រប់គ្រងរដ្ឋាភិបាលនាពេលនោះ នៅតាមតំបន់ដែលពួកគេយល់ឃើញថា ក្រុម លន់ នល់ កំពុងធ្វើ "សកម្មភាពជិះជាន់សង្កត់សង្កិន" មកលើពួកគេកាន់តែខ្លាំងឡើង[២២៧៥]។ ម្យ៉ាងវិញទៀត នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៦៩ នៅក្នុងកិច្ចប្រជុំធំមួយនៃគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងខេត្តរតនគិរី ដែលមានវត្តមាន នួន ជា ប៉ុល ពត អៀង សារី និង កុយ ធួន ចូលរួម[២២៧៦] អង្គប្រជុំបានសម្រេចថា បក្សកុម្មុយនីស្តកម្ពុជានឹងប្រមូលកម្លាំងទាំងអស់ដើម្បីវាយប្រឆាំងនឹង លន់ នល់ និងក្រុមស្ដាំនិយមនៃរដ្ឋាភិបាល លន់ នល់[២២៧៧]។

---

E3/1568 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00713919-00713920 (នៅក្នុងឆ្នាំ ១៩៦៨ បញ្ហាចេញមកពីមជ្ឈិមឲ្យកាន់អាវុធក្រោកឈរប្រឆាំង)។ បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៦២-៦៥ ERN (ភាសាខ្មែរ) 00442124-00442125 (ក្រោយពាក់កណ្ដាលឆ្នាំ ១៩៦៧ បក្សបានសម្រេចចាប់ផ្ដើមការតស៊ូប្រដាប់អាវុធប្រឆាំងនឹងខ្មាំងឲ្យបានឆាប់រហ័ស។ ប្រសិនបើមិនដូច្នេះទេ ខ្មាំងប្រាកដណាស់នឹងបំផ្លាញបក្ស)។ *ទស្សនាវដ្ដី ទង់បដិវត្ត* ឯកសារ E3/11 ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៦២-៦៥, ERN (ភាសាខ្មែរ) 00063151-00063152 (នៅពាក់កណ្ដាលឆ្នាំ ១៩៦៧ បក្សបានសម្រេចចាប់ផ្ដើមការតស៊ូប្រដាប់អាវុធ)។ *សូមមើល ផងដែរ* ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៤។

[២២៧៥] ប្រតិចារឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៦២-៦៣; ប្រតិចារឹកថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ២៣-២៥ (ដកស្រង់កំណត់ត្រាប្រើប្រាស់ដោយជនជាប់ចោទ នួន ជា នៅក្នុងពេលសវនាការនាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E148 ដែលយោងលើកិច្ចប្រជុំនាថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៦៨ ជាមួយលេខាភូមិភាគដែលនៅពេលនោះបានសម្រេចផ្ដួចផ្ដើមការតស៊ូប្រដាប់អាវុធ)។ ប្រតិចារឹកថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ៣១-៣២ (ការតស៊ូប្រដាប់អាវុធបានផ្ដួចផ្ដើមនៅក្នុងឆ្នាំ ១៩៦៨ ដោយសារ "ការជិះជាន់សង្កត់សង្កិនពីពួករដ្ឋបាលដូចជា គូ រុន និង ពួក លន់ នល់")។ សេចក្ដីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្ដដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១៥-១៧ ERN (ភាសាខ្មែរ) 00224471-00224473 (ក្នុងពេលប្រជុំគណៈកម្មាធិការមជ្ឈិមបក្សមួយ នាខែ មករា ឆ្នាំ ១៩៦៨ បក្សបានសម្រេចថា ពួកគេពុំអាចបន្តការតស៊ូតាមផ្លូវច្បាប់ទៀតទេ ហើយត្រូវចាប់ផ្ដើមឲ្យមានការបះបោរ)។

[២២៧៦] ប្រតិចារឹកថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ២៤-២៦ (ដកស្រង់ បទសម្ភាសន៍ជាមួយ នួន ជា ដោយ ខែម ងុន ឯកសារ E3/3 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៧ ERN (ភាសាខ្មែរ) 00078199)។ កំណត់ត្រាប្រើប្រាស់ដោយជនជាប់ចោទ នួន ជា នៅក្នុងពេលសវនាការនាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E148 ចុះខែ ធ្នូ ឆ្នាំ ២០១១ ERN (ភាសាខ្មែរ) 00757830-0075783 (កត់សម្គាល់ថា នៅក្នុងឆ្នាំ ១៩៦៩ នួន ជា បានទៅរតនគិរី)។

៧៣០. ក្រោយមក បក្សបានយកថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៦៨ ជាថ្ងៃប្រារព្ធខួបកងទ័ពបដិវត្តន៍កម្ពុជា។ ថ្ងៃនេះហើយដែលជាថ្ងៃកងការពារសម្ងាត់ត្រូវបានរៀបចំសាជាថ្មីបង្កើតជាកងឧទ្ទាម និងវាយប្រហារនៅបាយដំរាំ[២២៧៨]។ ចាប់ពីខែ មេសា ឆ្នាំ ១៩៦៨ ដល់ ខែ មីនា ឆ្នាំ ១៩៧០ បដិវត្តន៍ប្រដាប់អាវុធត្រូវបានរាយការណ៍ថា បានធ្វើការវាយប្រហារនៅក្នុងខេត្តចំនួន១៧ ក្នុងចំណោមខេត្តចំនួន ១៩[២២៧៩]។ ក្រោយមក ប៉ុល ពត នួន ជា និង ខៀវ សំផន បានអះអាងថា នៅមុនថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ បក្សមានធនធានតិចតួច ហើយកម្លាំងបក្សនៅឯកោ[២២៨០]។

---

ប្រតិ-ចារឹកថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៦៤-៦៥ (នួន ជា បានមករតនគិរីម្តងនៅចុងឆ្នាំ ១៩៦៩ រយៈពេលពីរបីថ្ងៃ និងបានជួបជាមួយ ប៉ុល ពត, អៀង សារី និង កុយ ធួន)។

[២២៧៧] ឯកសារបោះពុម្ពផ្សាយនៃសម័យកម្ពុជាប្រជាធិបតេយ្យ៖ *សៀវភៅខ្មៅ* ឯកសារ E3/23 ចុះខែ កញ្ញា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00289675 (នៅក្នុងឆ្នាំ ១៩៦៩ គណៈកម្មាធិការមជ្ឈិមបានចងក្រងឯកសារមួយលើកឡើងថា បក្សគួរវាយប្រហារពួកចក្រពត្តិអាមេរិក និងពួកក្បត់ លន់ នល់ មិនមែន សីហនុ នោះទេ ហើយគួរប្រមូលកម្លាំងទាំងអស់ដែលអាចប្រមូលបានដើម្បីវាយខ្លាំងឲ្យនៅឯកោ)។ *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063332-00063334 (នៅក្នុងឆ្នាំ ១៩៦៩ "យើងបានវាយពួកក្បត់ លន់ នល់")។

[២២៧៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៣។

[២២៧៩] *សុន្ទរកថារបស់លោក នួន ជា នៅក្នុងមិទ្ទិញទិវាខួបកងទ័ព* (SWB) ឯកសារ E3/209 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00649942-00649944។ កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ១០-១២ ERN (ភាសាខ្មែរ) 00333340-00333342។

[២២៨០] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៦២-៦៥ ERN (ភាសាខ្មែរ) 00442124-00442125។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00752090។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៣៧-៣៨ ERN (ភាសាខ្មែរ) 00103826-00103827 (នៅសំឡូត បក្សកុម្មុយនីស្តកម្ពុជាស្ថិតក្នុងសភាពគ្រោះថ្នាក់បំផុត លើកលែងតែបក្សនេះកាន់អាវុធប្រឆាំងនឹង លន់ នល់ ប៉ុន្តែ បក្សគ្មានអាវុធ) ទំព័រ ៤០-៤១ ERN (ភាសាខ្មែរ) 00103828 (ការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ ១៩៦៨ និងឆ្នាំ ១៩៦៩ មានសភាពលំបាកដោយសារមានអាវុធ គ្រាប់រំសេវ ឬ ស្បៀងអាហារតិចតួច ហើយការលះបង់នោះគឺច្រើនមហិមា)។

### ១៤.១.៣ ដំណាក់កាលទី៣៖ បដិវត្តន៍ប្រជាធិបតេយ្យ

៧៣១. ប៉ុល ពត បានពន្យល់ថា ក្នុងចំណោមភារកិច្ចចំនួនពីររបស់បក្ស ដែលជាការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម និងការតស៊ូវណ្ណៈ ភារកិច្ចតស៊ូប្រឆាំងនឹងចក្រពត្តិនិយមត្រូវធ្វើមុន[២២៨១]។ ដើម្បីរំដោះប្រទេសពីពួកចក្រពត្តិ បក្សចាំបាច់ត្រូវកសាងរណសិរ្សតស៊ូមួយដើម្បីធ្វើបដិវត្តន៍ប្រជាធិបតេយ្យ ច្របាច់បញ្ចូលគ្រប់ក្រុមទាំងអស់ប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ រួមទាំង ពួកនាយទុន ពួកសក្តិភូមិ ព្រះសង្ឃ និងអ្នករដ្ឋការស៊ីវិល[២២៨២]។ បក្សត្រូវបន្តរក្សាការសម្ងាត់ដោយសារបក្សនៅមិនទាន់មានរចនាសម្ព័ន្ធត្រឹមត្រូវនៅឡើយ ហើយបក្សភ័យខ្លាចមានផលវិបាក ប្រសិនគេស្គាល់បក្ស និងមេដឹកនាំបក្សជាសាធារណៈនោះ[២២៨៣]។ ហេតុនេះ បក្សត្រូវការការជួយជ្រោមជ្រែងរបស់បុគ្គលនានា ដូចជាសម្តេច នរោត្តម សីហនុ ដែលទ្រង់មានឥទ្ធិពលនៅលើឆាកអន្តរជាតិ និងត្រូវបានទទួលស្គាល់ក្នុងចំណោមគ្រប់ក្រុមទាំងអស់នៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យទ្រង់ដឹកនាំរណសិរ្ស

---

[២២៨១] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៤៩-៥១ ERN (ភាសាខ្មែរ) 00442117-00442118។

[២២៨២] ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៣-៤ (ពួកចក្រពត្តិមិនអាចកម្ចាត់ភ្លាមៗនោះទេ ដោយសារពួកគេនៅមានសារៈសំខាន់នៅក្នុងដំណាក់កាលបដិវត្តន៍ប្រជាធិបតេយ្យ)។ សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ចុះថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៧-១៨, ERN (ភាសាខ្មែរ) 00065898-00065899 (ការតស៊ូព្យាយាមដើម្បីកសាងកម្លាំងរបស់ពួកគេនៅគ្រប់វិស័យទាំងអស់ ដើម្បីអាចខ្លួនទីពឹងខ្លួនបាន)។ ទូរលេខរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅប្រទេសកម្ពុជា៖ ទស្សនកិច្ចផ្លូវការរបស់លោក ប៉ុល ពត នៅចិន និងកូរ៉េខាងជើង ឯកសារ E3/484 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00797658-00797659 (ប៉ុល ពត បានប្រកាសថា ក្រោយ រដ្ឋប្រហារក្នុងខែ មីនា ឆ្នាំ ១៩៧០ បក្សបានសម្រេចយកតាមគោលនយោបាយជួរមុខ ដោយផ្អែកលើសម្ព័ន្ធភាព កម្មករ-កសិករ ដែលពាក់ព័ន្ធនឹងពួកនាយទុនស្នេហាជាតិ និងព្រះសង្ឃ)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00072400-00072401 (កម្លាំងជួរមុខ រួមទាំងនិស្សិត និងអ្នករដ្ឋការ ត្រូវបានប្រមែលប្រមូលនៅក្នុងអំឡុងពេលបដិវត្តន៍)។ បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៥៣-៥៧ ERN (ភាសាខ្មែរ) 00442119-00442121 (បើសិនមិនមានគោលនយោបាយសម្រាប់ជួរមុខទេ គ្មានវិធីណាដែលពួកគេអាចឈ្នះបដិវត្តន៍នោះទេ)។

[២២៨៣] ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ១៥-១៦។

រួបរួមមួយ[២២៨៤]។ ការទម្លាក់សម្តេច នរោត្តម សីហនុ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ បានផ្តល់ឱកាសនេះដល់ថ្នាក់ដឹកនាំបក្ស។ តាមពិតទៅ ថ្នាក់ដឹកនាំបក្សបានអះអាងថា ពួកគេរំពឹងរង់ចាំព្រឹត្តិការណ៍នេះ ដោយបានរៀបចំនៅមុនខែ មីនា ឆ្នាំ ១៩៧០ ដើម្បីត្រៀមធ្វើបដិវត្តន៍ប្រជាធិបតេយ្យដឹកនាំរណសិរ្សរួបរួមមួយ[២២៨៥]។ ក្រោយពេល ប៉ុល ពត សន្យាថា ខ្មែរក្រហមនឹងគាំទ្រដល់រណសិរ្សរួបរួមជាតិកម្ពុជានេះ សម្តេច នរោត្តម សីហនុ បានបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅក្នុងខែ ឧសភា ឆ្នាំ ១៩៧០[២២៨៦]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់រួចហើយថា រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺគ្រាន់តែជាសម្បកខាងក្រៅមួយប៉ុណ្ណោះ។

---

[២២៨៤] បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00000898-00000899 (ខ្មែរក្រហមបានគាំទ្រ នរោត្តម សីហនុ ដោយសារឥទ្ធិពលរបស់ទ្រង់នៅលើពិភពលោក)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសចិន និងប្រទេសកម្ពុជា ឯកសារ E3/2699 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00498201-00498202 (ព្រះអង្គម្ចាស់ហាក់ដូចជាមានតួនាទីបង្រួបបង្រួមក្រុមប្រជាជនដែលមាននិន្នាការខុសៗគ្នា)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៤៥-៤៦ ERN (ភាសាខ្មែរ) 00103830-00103831 (កម្លាំងដែលដើរតួសំខាន់មានពីរនៅក្នុងការសង្គ្រោះប្រទេស៖ បក្សកុម្មុយនីស្តកម្ពុជាដែលមានកម្លាំងអាចប្រយុទ្ធបាននៅនឹងកន្លែង ហើយសម្តេច នរោត្តម សីហនុ មានឥទ្ធិពលនៅលើឆាកអន្តរជាតិ)។

[២២៨៥] សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ២២-២៣ ERN (ភាសាខ្មែរ) 00224478-00224479 (ខ្មែរក្រហមជាអ្នកគ្រប់គ្រងស្ថានការណ៍។ ពួកគេមានកងទ័ព និងអាវុធខ្លះ។ ដូច្នេះ ពួកគេអាចបង្កើតរណសិរ្សរួបរួមមួយជាមួយនឹង នរោត្តម សីហនុ ដោយបន្ថយទ្រង់មិនឲ្យមានអំណាចអ្វីទាំងអស់ និងឲ្យខ្មែរក្រហមជាអ្នកគ្រប់គ្រងលើអ្វីៗទាំងអស់ ទាំងនៅតាមខេត្តក្រុង និងទាំងនៅតាមទីជនបទ)។ *កិច្ចសម្ភាសន៍ជាមួយប្រជាជនបដិវត្តកម្ពុជា* (សារព័ត៌មាន Le Monde) ឯកសារ E3/597 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧២ ទំព័រ ៣៧-៤០, ERN (ភាសាខ្មែរ) 00744037-00744040 (អៀង សារី បានពន្យល់ថា ពួកគេបានទាយស្មានថានឹងមានរដ្ឋប្រហារជាយូរមកហើយ ដូច្នេះ មុនពេលរដ្ឋប្រហារនេះ បក្សបានសម្រេចបានការប្រមូលកម្លាំងមហាជនតាមរូបភាពនយោបាយក្នុងទស្សនៈដើម្បីដឹកនាំសង្គ្រាមតស៊ូរយៈពេលយូរ)។ កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្រ្ត លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៦-៩, ERN (ភាសាខ្មែរ) 00347037-00347039 ទំព័រ ៦-៩ (ខៀវ សំផន បានពន្យល់ថា ប៉ុល ពត បានទាយស្មានជាមុនថា លន់ នល់ នឹងធ្វើរដ្ឋប្រហារប្រឆាំងនឹងសម្តេច នរោត្តម សីហនុ)។

[២២៨៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៨។

តាមពិតទៅ ខ្មែរក្រហមជាអ្នកគ្រប់គ្រងលើសកម្មភាពបដិវត្តន៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាលនៅតាមតំបន់រំដោះ[២២៨៧]។

៧៣២. នៅក្នុងខែ តុលា ឆ្នាំ ១៩៧០ គណៈកម្មាធិការមជ្ឈិម រួមទាំង ប៉ុល ពត នួន ជា អៀង សារី តា ម៉ុក សោ ភឹម កុយ ធួន និងលេខាភូមិភាគផ្សេងទៀត បានពិភាក្សាអំពីផែនការរំដោះប្រទេសកម្ពុជាពីពួកចក្រពត្តិអាមេរិក និងរបបសាធារណរដ្ឋខ្មែរ ហើយបានបញ្ជាក់អំពីគោលនយោបាយខ្លួនទីពឹងខ្លួន និងគោលនយោបាយឯករាជ្យរបស់បក្ស[២២៨៨]។ ក្រោយមក ចាប់ពីខែ តុលា ឆ្នាំ ១៩៧០ រហូតដល់ ឆ្នាំ ១៩៧៥ ខៀវ សំផន នួន ជា ប៉ុល ពត និងមេដឹកនាំបក្សផ្សេងទៀតបានជួបគ្នាជាប្រចាំ ដើម្បីពិភាក្សាអំពីការបន្តធ្វើបដិវត្តន៍ និងការគ្រប់គ្រងនៅតាមតំបន់រំដោះ[២២៨៩]។ នៅ

---

[២២៨៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០០។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣០។

[២២៨៨] ឯកសារបោះពុម្ពផ្សាយនៃសម័យកម្ពុជាប្រជាធិបតេយ្យ៖ *សៀវភៅខ្មៅ* ឯកសារ E3/23 ចុះខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ៤៧-៤៩ ERN (ភាសាខ្មែរ) 00289690-00289692 (ក្នុងខែ តុលា ឆ្នាំ ១៩៧០ គណៈកម្មាធិការមជ្ឈិម បានពិចារណាលើស្ថានភាពនៅក្នុងប្រទេសដើម្បីធ្វើការតស៊ូរំដោះជាតិ។ ពួកគេបានឯកភាពគោរពតាមគោលជំហរឯករាជ្យ ខ្លួនទីពឹងខ្លួន ដើម្បីប្រមែប្រមូលកម្លាំងទាំងអស់)។ ប្រតិចារឹកថ្ងៃ ទី០៦ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ៩-១០ (ប៉ុល ពត បានកោះប្រជុំគណៈកម្មាធិការមជ្ឈិមនៅក្នុងខេត្តកំពង់ធំ ក្នុងឆ្នាំ ១៩៧០)។ ប្រតិចារឹកថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ២៦-២៧ (ក្នុងកិច្ចប្រជុំក្នុងខែ តុលា ឆ្នាំ ១៩៧០ នួន ជា និងសមាជិកគណៈកម្មាធិ-ការមជ្ឈិមត្រូវបានតែងតាំងឲ្យគ្រប់គ្រងភូមិភាគនីមួយៗ រួមទាំង តា ម៉ុក (និរតី) សោ ភឹម (បូព៌ា) កុយ ធួន (ឧត្តរ)។

[២២៨៩] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00156614-00156616 (ក្រោយរដ្ឋប្រហារ ខៀវ សំផន បានជួបជាមួយ ប៉ុល ពត និង នួន ជា។ ក្រោយមក គាត់បានស្នាក់នៅជាមួយ ប៉ុល ពត ហើយលេខាភូមិភាគផ្សេងទៀតបានមកជួបជាមួយ ប៉ុល ពត)។ ប្រតិចារឹកថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ (ស្វ សុជាតិ) ទំព័រ ៦០-៦២។ (ខៀវ សំផន, ប៉ុល ពត, និង នួន ជា នៅជាមួយគ្នាក្នុងឆ្នាំ ១៩៧២ នៅពេល ខៀវ សំផន រៀបការរួចហើយនោះ)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អឿន តាន) ទំព័រ ២៥-២៧ (នៅពាក់កណ្ដាលឆ្នាំ ១៩៧០ អៀង សារី, ខៀវ សំផន, ប៉ុល ពត, និង នួន ជា បានជួបគ្នានៅខេត្តកំពង់ចាម)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អឿន តាន ឯកសារ E3/33 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00231798-00231799។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភីភួន) ទំព័រ ៣-៤ (នៅពេល ប៉ុល ពត មិននៅ ស-៧១, ខៀវ សំផន និង នួន ជា នៅទីនោះ) ទំព័រ ៤-៦ (នួន ជា ទៅជួបជាមួយមេដឹកនាំភូមិភាគ ព្រមទាំង ធ្វើដំណើរទៅជួបជាមួយ រស់ ញឹម នៅភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧២ ផងដែរ) ទំព័រ ៨-៩ (មានកិច្ចប្រជុំទៀងទាត់នៅថ្នាក់មជ្ឈិម រួមទាំង ថ្នាក់មេដឹកនាំភូមិភាគផងដែរ។ មានកិច្ចប្រជុំធំៗ និងវគ្គរៀនសូត្រ ជាពិសេសនៅក្នុងឆ្នាំ ១៩៧១ និងឆ្នាំ ១៩៧៤។ នៅក្នុងគ្រប់កិច្ចប្រជុំទាំងអស់ នឹងមានព័ត៌មានថ្មីៗអំពីស្ថានការណ៍ទូទៅស្ដីការចលនាតស៊ូ និងការវិវត្តនៅតាមតំបន់រំដោះ ដោយមានរបាយការណ៍មកពីតាមភូមិភាគផងដែរ) ទំព័រ ១៤-១៩ (ក្រោយ ប-៥ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៣ មេដឹកនាំផ្សេងទៀតមានមន្ទីរនៅជិតទីនោះ រួម

ពីក្រោយរណសិរ្សរួបរួមជាតិកម្ពុជា /រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានតែសម្បកខាងក្រៅ[២២៩០] បក្សបានវាយប្រឆាំងនឹងខ្មាំងដែលពួកគេកំណត់ថាជាពួកចក្រពត្តិអាមេរិក និង "បរិវាររបស់ពួកគេ" និង "បនក្បត់" នៅក្នុងរបប លន់ នល់[២២៩១]។ ក្នុងអំឡុងពេលសង្គ្រាម បក្សបានធ្វើការតស៊ូទាំងខាងយោធា និង ខាងនយោបាយដោយផ្អែកលើមូលដ្ឋានយុទ្ធវិធីចម្បងចំនួនបួន៖ យកមនុស្សពីខ្មាំង ផ្តាច់ស្បៀងខ្មាំង កម្ចាត់ខ្សែចារកម្មផ្សេងៗរបស់ខ្មាំង និងទាញក្រុមខ្មាំងឲ្យមកចុះចូល[២២៩២]។

---

ទាំង វន វ៉េត, ចេង អន, សុន សេន និង តា ម៉ុក)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៨-១៩ (ប-៥ គឺជាមន្ទីរដែលត្រូវបាន បង្កើតឡើងក្នុងអំឡុងពេលវាយប្រហារទីក្រុងភ្នំពេញ ដែល ប៉ុល ពត ពេលខ្លះ នួន ជា និងមេដឹកនាំភូមិភាគ ជួបប្រជុំ គ្នានៅទីនោះ)។ *សូមមើល ផងដែរ* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧១។ ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៦។

[២២៩០] សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00224459-00224461 (ខ្មាំងស្គាល់ឈ្មោះមេដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា ប៉ុន្តែពុំស្គាល់ឈ្មោះមេដឹកនាំពិតប្រាកដនោះទេ ដែលអាចឲ្យមេដឹកនាំទាំងនេះធ្វើការងារបានយ៉ាងមានសុវត្ថិភាព) ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00224462-00224464 (ក្រោយរដ្ឋប្រហារបក្សនៅតែបន្តយកការតស៊ូដោយសម្ងាត់មកធ្វើជាយុទ្ធវិធីជាមូលដ្ឋាន)។

[២២៩១] សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ចុះថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៥-១៨ ERN (ភាសាខ្មែរ) 00065897-00065899 (ក្រោយរដ្ឋប្រហារថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ សហរដ្ឋអាមេរិកមានការក្តោបក្តាប់យោធានៅក្នុងប្រទេសកម្ពុជា និង "បានប្រើប្រាស់កងទ័ពអាយ៉ងរបស់ ធីវ គី និងរបស់បនក្បត់ លន់ នល់ ជាឧបករណ៍នៃការឈ្លានពានរបស់ពួកវា")។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៧២ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00711425-0711426 (ពួកគេកំពុងវាយប្រឆាំងនឹង "ក្រុមក្បត់ជាតិ" ដែលពឹងផ្អែកទាំងស្រុងលើជំនួយអាមេរិក)។ សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៧-១០ ERN (ភាសាខ្មែរ) 00324816-00324819 ទំព័រ ៩ ERN (ភាសាខ្មែរ) 00324818 (សង្គ្រាមស៊ីវិលចន្លោះឆ្នាំ ១៩៦៨ និងខែ មីនា ឆ្នាំ ១៩៧០ គឺជារយៈពេលនៃការតស៊ូដើម្បីរំដោះជាតិពីពួកចក្រពត្តិ)។ កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00333332-00333344 (អៀង សារី បានពន្យល់ថា ចាប់ពីខែ មីនា ឆ្នាំ ១៩៧០ ដល់ ខែ មេសា ឆ្នាំ ១៩៧៥ មានសង្គ្រាមរំដោះប្រទេសពី ចក្រពត្តិអាមេរិក)។

[២២៩២] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៨០ ERN (ភាសាខ្មែរ) 00442133។

វណ្ណៈដែលបានផ្តល់នូវកងកម្លាំងដ៏សំខាន់សម្រាប់បដិវត្តន៍នៅតែជាកសិករ។ ពួកនាយទុនគឺជាសម្ព័ន្ធមិត្តដ៏ចាំបាច់ ប៉ុន្តែមិនអាចទុកចិត្តបានទេ ពីព្រោះពួកគេ "តាមខ្យល់"[២២៩៣]។

៧៣៣. នៅក្នុងមហាសន្និបាតបក្សលើកទី៣ ក្នុងឆ្នាំ ១៩៧១ នួន ជា ប៉ុល ពត ខៀវ សំផន (នៅពេលនោះ ជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម) អៀង សារី កុយ ធួន កែ ពក ឌឿន សោ ភឹម វន វេត តា ម៉ុក រស់ ញឹម និងអ្នកផ្សេងទៀត បានសម្រេចប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា ហើយបានបង្កើតភូមិភាគពិសេសមួយនៅក្បែរទីក្រុងភ្នំពេញ ព្រមទាំងបានបញ្ជាក់ជាថ្មីអំពីមាគ៌ាបក្សតាំងពីពេលមហាសន្និបាតបក្សលើកទី១ និងលើកទី២ រួមទាំងបានប្តេជ្ញាតស៊ូវណ្ណៈផងដែរ[២២៩៤]។

៧៣៤. ក្រោយមហាសន្និបាតបក្សលើកទី៣ នៅចុងឆ្នាំ ១៩៧១ ក្នុងឆ្នាំ ១៩៧២ និង ជាពិសេសក្នុងឆ្នាំ ១៩៧៣ គោលនយោបាយសមូហភាវូបនីយកម្មបានចាប់ផ្តើមអនុវត្តតាមរយៈក្រុមប្រវាស់ដៃគ្នា និងក្រោយមក តាមរយៈសហករណ៍ នៅតាមទីជនបទនានា[២២៩៥]។ នៅក្នុងឆ្នាំ ១៩៧២ អៀង សារី បានពន្យល់ថា យោងតាមកម្មវិធីនយោបាយនៅតាមតំបន់រំដោះ កសិកម្មមានសារៈសំខាន់យ៉ាងខ្លាំង។ បក្សបានចាត់វិធានការប្រមូលកសិករ និងរំដោះពួកគេចេញពីរចនាសម្ព័ន្ធចាស់ ជាហេតុធ្វើឲ្យផលិតផលមានការកើនឡើង និងធ្វើឲ្យចលនាសមូហភាពបោះជំហានទៅមុខ[២២៩៦]។ "មាគ៌ាខ្លួន

---

[២២៩៣] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៥១-៥៣ ERN (ភាសាខ្មែរ) 00442118-00442119។ នៅក្នុងន័យនេះ ខៀវ សំផន បានកត់សម្គាល់ថា ពីដំបូង ប៉ុល ពត ពុំព្រមជួប នរោត្តម សីហនុ នោះទេ ដោយសារបានគិតឃើញអំពីគោលបំណងចុងក្រោយរបស់បដិវត្តន៍ (ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦០-៦២)។

[២២៩៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥។ *សូមមើល ផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ១២៤ ERN (ភាសាខ្មែរ) 00103870 (នៅពាក់កណ្តាលឆ្នាំ ១៩៧១ មានកិច្ចប្រជុំរវាងកម្មាភិ-បាលមកពីមូលដ្ឋានផ្សេងៗ ដែល ប៉ុល ពត បានប្រកាសថា បក្សកុម្មុយនីស្តកម្ពុជាបានធំធាត់មកពីបក្សបានឆ្លងកាត់ការតស៊ូវណ្ណៈ និងការតស៊ូជាតិយ៉ាងតឹងតែង និងមកពីបក្សផ្អែកលើកម្លាំងកសិករ)។

[២២៩៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ ១១៣។

[២២៩៦] កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៧២ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00711428-0711431 (ដីរបស់ពួកក្បត់ត្រូវបានបែងចែកទៅជាសម្បត្តិរួម ឬឲ្យទៅកសិករដែលគ្មានដី។ កម្មវិធីនយោបាយរួមមាន៖ ការបំផុសបំផុតការងារដើម្បីជំរុញកសិករឲ្យចំគោល-

ទីពឹងខ្លួន” តម្រូវឲ្យប្រជាជនផ្គត់ផ្គង់តម្រូវការខ្លួនឯងផ្ទាល់ និងផ្គត់ផ្គង់ដល់ការតស៊ូ[២២៩៧]។ យោង តាម នួន ជា ដោយសារការឈឺចាប់ និងភាពលំបាកលំបិន មាគ៌ាបក្សពាក់ព័ន្ធនឹងការតស៊ូវណ្ណៈ និងភាពស្អប់ខ្ពើម បានចាក់ឫសនៅក្នុងចិត្តប្រជាជននៅតាមតំបន់រំដោះ[២២៩៨]។ ក្នុងខណៈពេលវាយ ប្រឆាំងពួកចក្រពត្តិក្រោមរូបភាពបិទបាំង និងក្រោមការជួយជ្រោមជ្រែងពីរណសិរ្សរួបរួមជាតិ កម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បក្សក៏បានចាប់ផ្តើមបដិវត្តន៍សង្គមនិយមនៅតាមតំបន់ រំដោះរួចដែរ[២២៩៩]។

៧៣៥. នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ សមាជិក និងសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ដែលមាន ប៉ុល ពត នួន ជា ខៀវ សំផន សោ ភឹម កុយ ធួន តា ម៉ុក វន វេត រស់ ញឹម និង សុន សេន[២៣០០] តាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ បានរៀបចំផែនការវាយសម្រុកចុងក្រោយ ដើម្បីរំដោះប្រទេស និងជម្លៀសប្រជាជនចេញពីខេត្ត-ក្រុងឲ្យទៅរស់នៅតាមទីជនបទនានា[២៣០១]។ ក្រោយមក ខៀវ សំផន ប៉ុល ពត នួន ជា មេបញ្ជាការកងទ័ព និង/ឬ លេខាភូមិភាគ បានជួបគ្នា នៅមន្ទីរ ប-៥ ខាងលិចឧត្តុង្គ ជាពិសេស នៅក្នុងខែ កុម្ភៈ និងដើមខែ មេសា ឆ្នាំ ១៩៧៥ ដើម្បី ប្រជុំពាក់ព័ន្ធនឹងការវាយសម្រុកចុងក្រោយ ការផ្លាស់ទីលំនៅប្រជាជន និងវិធានការផ្សេងៗទៀត ដែលត្រូវអនុវត្តក្រោយពេលទទួលបានជ័យជម្នះ[២៣០២]។

---

នយោបាយកសិកម្ម និងរៀបចំកសិករទាំងអស់ ដែលទទួលយកកំណែទម្រង់ខាងវិស័យកសិកម្មរបស់យើងទៅជា សមាគមកសិករស្នេហាជាតិ។ យើងបានលើកទឹកចិត្តដល់ការបង្កើតសហករណ៍ និងការប្រវាស់ដៃគ្នា)។

[២២៩៧] កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Courrier du Vietnam ឯកសារ E3/111 ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៧២ ទំព័រ ៩-១១ ERN (ភាសាខ្មែរ) 00711431-0711433។

[២២៩៨] សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00224462-00224464។

[២២៩៩] ដូចខាងលើ។

[២៣០០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៤២។

[២៣០១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៤២។

[២៣០២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៣-១៤៧។ *សូមមើល ផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៦០-៦១ ERN (ភាសាខ្មែរ) 00103838 (នៅចុងខែ មីនា ឆ្នាំ ១៩៧៥ គាត់ត្រូវបានអញ្ជើញទៅកាន់ទីស្នាក់ការ ប៉ុល ពត នៅខាងលិចឧត្តុង្គ ដើម្បី តាមដានការវាយសម្រុកចុងក្រោយ។ ជារៀងរាល់ថ្ងៃ គាត់បានតាមដានការវិវត្តនៅតាមសមរភូមិតាមវិទ្យុជាមួយនឹង មន្ត្រីយោធាមួយចំនួនផ្សេងទៀត)។

### ១៤.១.៤ ដំណាក់កាលទី៤៖ បដិវត្តន៍សង្គមនិយម

៧៣៦. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបាន "រំដោះ" ប្រទេសបានជោគជ័យ ហើយបក្សបានឈានចូលដំណាក់កាលថ្មីមួយ គឺដំណាក់កាលបដិវត្តន៍សង្គមនិយម[២៣០៣]។ ខៀវ សំផន បានលើកឡើងថា ជោគជ័យនេះគឺបានមកដោយសារបក្សបានអនុវត្តតាមមាគ៌ាបក្សដ៏ត្រឹមត្រូវនៅក្នុងដំណាក់កាលបដិវត្តន៍មុនៗ[២៣០៤]។ ហេតុដូច្នេះហើយ បក្សបានផ្អែកលើគោលនយោបាយ និងគោលបំណងដែលព្យាយាមសម្រេចនៅក្នុងដំណាក់កាលបដិវត្តន៍សង្គមនិយម ទៅលើបទពិសោធន៍របស់ខ្លួននៅក្នុងអំឡុងពេលសង្គ្រាម និងនៅតាមតំបន់រំដោះ[២៣០៥]។

---

[២៣០៣] *សុន្ទរកថារបស់លោក នួន ជា នៅក្នុងមិទ្ទិញទិវាខួបកងទ័ព* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/209 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00649946-00649947 (ដំណាក់កាលថ្មីនៃបដិវត្តន៍គឺត្រូវកសាង និងការពារប្រទេស)។ សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៣៤, ៤៤, ៤៨ ERN (ភាសាខ្មែរ) 00291025-00291026 កថាខណ្ឌ ៥១ ERN (ភាសាអង់គ្លេស) 00079813 (ប្រជាជនកម្ពុជាកំពុងតស៊ូដើម្បីការពារ និងកសាងប្រទេសនៅក្នុងដំណាក់កាលបដិវត្តន៍ថ្មីរបស់ពួកគេ ពោលគឺ តស៊ូដើម្បីការពារផល-ចំណេញពីបដិវត្តន៍។ ស្ថានភាពនេះបានទទួលជោគជ័យតាមរយៈការអប់រំជាដរាបដោយបក្សកុម្មុយនីស្តកម្ពុជា)។ កំណត់សម្គាល់ដោយអ្នកតំណាងបក្សម៉ាស៊ីស នៃប្រទេសន័រវេ ឯកសារ E3/564 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00333332-00333344 (អៀង សារី បានពន្យល់ថា ចាប់ពីឆ្នាំ ១៩៧៥ នេះជារយៈពេលនៃបដិវត្តន៍សង្គមនិយម និងការកសាង)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្ដាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២-៦ ERN (ភាសាខ្មែរ) 00072401-00072405 (ពីមុន បក្សបានប្រមូលកម្លាំងវាយខ្មាំង និងរំដោះប្រទេស ហើយក្នុងពេលបច្ចុប្បន្នកំពុងប្រមូលកម្លាំងដើម្បីការពារ និងកសាងប្រទេស)។ *សូមមើលផងដែរ* ផ្នែកទី១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦។

[២៣០៤] សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ចុះថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៧ ERN (ភាសាខ្មែរ) 00065898។

[២៣០៥] *អ្វីៗដែលយើងកំពុងធ្វើនៅពេលនេះមិនធ្លាប់អនុវត្តពីមុនឡើយ* (ដកស្រង់ពីបទសម្ភាសន៍របស់ Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00796757-00796759 (អៀង សារី បានពន្យល់ថា ដោយសារពួកគេពុំបានផ្អែកលើ គំរូណាមួយនោះហើយ ទើបពួកគេរៀនពីបទពិសោធន៍វិញ)។ កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Stephen HEDER ឯកសារ E3/573 ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ ១៩៩៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00640500-0064051 (អៀង សារី បានលើកឡើងថា ក្រោយពេលឈ្នះសង្គ្រាម ប៉ុល ពត និង នួន ជា ជឿជាក់ថា ពួកគេធ្វើមិនខុសឡើយ ហើយអ្វីៗបានផ្អែកលើមាគ៌ាពីចន្លោះឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៥)។

01006994



៧៣៧. ដូចអ្នកដែលបានចូលរួមនៅក្នុងជម្លោះនេះ រួមទាំង មេដឹកនាំខ្មែរក្រហមខ្លួនឯងផងដែរនោះ បានរំពឹងទុកថា ប្រទេសត្រូវប្រឈមនឹងកង្វះស្បៀងអាហារ និងធនធានផ្សេងទៀត ប៉ុន្តែ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិចារណាឃើញថា អាទិភាពដំបូងគឺចាំបាច់ត្រូវធ្វើយ៉ាងណាកុំឲ្យប្រទេសកម្ពុជារងការគំរាមកំហែងទាំងនៅក្នុងប្រទេស និងទាំងពីក្រៅប្រទេស[២៣០៦]។ ដូច្នេះ ដើម្បីសង្គ្រោះប្រទេសឲ្យបាន និងដើម្បីឲ្យប្រទេសបោះជំហានទៅមុខយ៉ាងលឿន ឈានដល់ដំណាក់កាលបដិវត្តន៍បន្ទាប់ទៀតនោះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិចារណាថា គោលនយោបាយតឹងរ៉ឹងគួរត្រូវបានអនុវត្តជាប្រញាប់[២៣០៧]។ លើសពីនេះទៀត ដើម្បីកសាងគ្រឹះឲ្យបានរឹងមាំក្នុង

---

[២៣០៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៨ (ពុំមានស្បៀងអាហារគ្រប់គ្រាន់ និងមានបញ្ហាសង្គមផ្សេងទៀត)។ បទអន្តរាគមន៍របស់លោក អៀង សារី នៅក្នុងមហាសន្និបាតលើកទី ៣១ របស់អង្គការសហប្រជាជាតិ ឯកសារ E3/607 ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00816623-00886624 (ប្រទេសកម្ពុជាស្ថិតនៅក្នុងសភាពក្រីក្រ (រួមទាំង រោងចក្រ ស្រែ និងសត្វចិញ្ចឹម) នៅពេលខ្មែរក្រហមកាន់កាប់អំណាច)។ *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/200 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ១-៤, ១០-១២ ERN (ភាសាខ្មែរ) 00292803-00292806, 00292812-00292814 (ក្រោយសង្គ្រាម ពួកគេត្រូវបានគេដកហូតស្បៀងអាហារ សម្ភារៈ ឧបករណ៍ និងគោបី)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00000901-00000902 (នៅពេលខ្មែរក្រហមកាន់កាប់អំណាច ពួកគេប្រឈមនឹងជំងឺ ការខ្វះខាតអាហារ និងក្រុមអាក្រក់)។ ទូរលេខរបស់ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ បទសម្ភាសន៍សារព័ត៌មាន ញូវវីកជាមួយ អៀង សារី (Newsweek) ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00635944-00635945 (អៀង សារី បានពន្យល់ក្នុងពេលសន្និសីទកំពូលនៃប្រទេសមិនចូលបក្សសម្ព័ន្ធថា នៅក្នុងប្រទេសកម្ពុជាមានបញ្ហាច្រើនណាស់បន្ទាប់ការបំផ្លិចបំផ្លាញដោយសង្គ្រាម)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4048 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00788401-00788402 (សូម្បីនៅតាមជនបទ ប្រជាជនពិបាកក្នុងការចិញ្ចឹមខ្លួនឯង)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ៩ ERN (ភាសាខ្មែរ) 00003768 (កត្តាលំបាកលំបិនរួមមាន ការខ្វះខាតស្បៀងអាហារ គោក្របី និងជំងឺជាច្រើនទៀត) ទំព័រ ៥១ ERN (ភាសាអង់គ្លេស) 00003287 (មានការខ្វះខាតស្បៀងអាហារ ថ្នាំ សង្កូវ និងទីជម្រក)។

[២៣០៧] កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ៩-១០ ERN (ភាសាខ្មែរ) 00347039-00347040។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៦-៧៧ ERN (ភាសាខ្មែរ) 00103846 (ពិពណ៌នាថាបដិវត្តន៍សង្គមនិយម គឺជានយោបាយលឿនជ្រុលហួស) ទំព័រ ១២០-១២១ ERN (ភាសាខ្មែរ) 00103868 (ខ្មែរក្រហមមាននយោបាយជ្រុលហួសនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៨)។ *សូមមើលផងដែរ* ផ្នែកទី ១០៖ ការផ្លាស់ទី

គោលបំណងទប់ទល់នឹងការវាយប្រហាររបស់ខ្មាំងខាងក្រៅនោះ បដិវត្តន៍សង្គមនិយមត្រូវធ្វើឲ្យលឿន[២៣០៨]។ ប្រជាជនគ្រប់រូប ទាំងយោធា ទាំងស៊ីវិល ត្រូវប្រមូលយកមកឲ្យបានលឿនសម្រាប់យកមកកសាង និងការពារប្រទេសក្នុងគោលបំណងព្យាយាមធានាឲ្យបាននូវសន្តិសុខសម្រាប់ពេលខាងមុខ និងធានាសុខុមាលភាពរបស់ប្រជាជនតាមរយៈបដិវត្តន៍សង្គមនិយមនេះ[២៣០៩]។ មាគ៌ា

---

លំនៅ(ដំណាក់កាលទី១) កថាខណ្ឌ ៥២៦, ៥៣០-៥៣៤ (ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការភ័យខ្លាចលើផែនការរបស់គិញបរទេស និងអតីតអ្នករដ្ឋការរបស់ លន់ នល់ និងភាពចាំបាច់ត្រូវជៀសវាងការឈ្លានពានរបស់បរទេស)។

[២៣០៨] អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00062452-0062453 (ចាំបាច់ត្រូវមានមូលដ្ឋានកុម្មុយនីស្តដ៏អស្ចារ្យជាងនេះមួយនៅក្នុងប្រទេសកម្ពុជាដើម្បីការពារមូលដ្ឋាននេះពីការគំរាមកំហែងពីខាងក្រៅ ដូចជា វៀតណាម។ ហេតុដូច្នេះហើយ ទើបបដិវត្តន៍លឿន)។ ប្រតិចារឹកខ្សែអាត់សម្លេងនៃបទសម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ៥៤ ERN (ភាសាខ្មែរ) 00741136 (គោលនយោបាយដែលបានអនុវត្តដោយសារការភ័យខ្លាចវៀតណាម រួមមាន សហករណ៍ និងការផ្លាស់ទីលំនៅប្រជាជន ពីព្រោះពួកគេបានដឹងថាវៀតណាមមានផែនការរួចជាស្រេចនៅក្នុងទីក្រុងភ្នំពេញក្នុងការទម្លាក់ពួកគេ)។ *បងទី២ មិនចាំអ្វីៗដែលកន្លងទៅ* (សារព័ត៌មានភ្នំពេញប៉ុស្តិ៍) ឯកសារ ចុះថ្ងៃទី ១២-២៥ ខែ មករា ឆ្នាំ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00526869-00526870 (បក្សជឿជាក់ថា បក្សត្រូវអភិវឌ្ឍប្រទេសឲ្យបានឆាប់ បើមិនដូច្នេះទេ នឹងនៅចុងប៉ូចគេដដែល)។ *សុន្ទរកថារបស់សមមិត្ត នួន ជា* (ព្រឹត្តិប័ត្រព័ត៌មាន កម្ពុជាប្រជាធិបតេយ្យ) ឯកសារ E3/78 ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00705172-00705173 (ដើម្បី ធានាដល់ការការពារប្រទេស ពួកគេត្រូវកសាងប្រទេសឲ្យលឿន)។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/3198 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៧ ERN (ភាសាខ្មែរ) 00806471 (វៀតណាមមានមហិច្ឆតាគ្រប់គ្រងកម្ពុជា៖ "ដូច្នេះ យើងត្រូវរត់ឲ្យបានលឿន")។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4022 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00784345 (ប៉ុល ពត នៅតែនិយាយដដែលៗថា បក្សកុម្មុយនីស្តកម្ពុជាត្រូវតែរត់ឲ្យលឿនដើម្បីកុំឲ្យវៀតណាមតាមទាន់។ ក្រោយរំដោះ ដោយមើលឃើញការអត់ឃ្លាន និងការគំរាមកំហែងពីវៀតណាម យើងអត់មានពេលវេលាត្រូវពន្យារបានយូរនោះទេ)។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4022 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២ ERN (ភាសាខ្មែរ) 00780960 (ពេលវេលាចេះតែបន្តទៅមុខ បដិវត្តន៍ត្រូវតែរត់ទៅមុខឲ្យលឿន៖ "ពាក្យស្លោកមួយក្នុងចំណោមពាក្យស្លោករបស់យើងគឺ យើងចាំបាច់រត់ឲ្យលឿន"។ ក្រោយសង្គ្រាម "យើងត្រូវបន្តរត់ រត់ឲ្យលឿនជាងមុន")។

[២៣០៩] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៤៥ ERN (ភាសាអង់គ្លេស) 00079813 (កងទ័ពទាំងអស់ត្រូវប្រមូលយកមកសម្រាប់កសាងប្រទេស និងសម្រាប់ឲ្យមានការរីកចម្រើនលឿននៅក្នុងកម្រិតជីវិតរបស់ប្រជាជន)។ សុន្ទរកថាដោយ អៀង សារី ក្នុងពិធីភោជនាហារនាពេលល្ងាច ស្វាគមន៍ ផ្តល់កិត្តិយសដល់សមមិត្តសមាជិកមជ្ឈិមបក្សកុម្មុយនីស្ត Maxist-Leninist សហរដ្ឋអាមេរិក ឯកសារ E3/211 ថ្ងៃទី ២២ ខែ មេសា

បក្ស ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស បានផ្តែកលើគោលការណ៍ "ឯករាជ្យ អធិបតេយ្យ" សម្ញូហភាវូបនីយកម្មនិយម និងខ្លួនទីពឹងខ្លួន[២៣១០]។ ដូចនេះ ការបែងចែកវណ្ណៈនឹងត្រូវបំបាត់ចោល[២៣១១] គ្មានជំនួយអន្តរជាតិណាមួយនឹងត្រូវទទួលយក លើកលែងតែជំនួយនោះគ្មាន

---

ឆ្នាំ ១៩៧៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) S 00801571-00801572 (យើងងាយនឹងប្រមូលកម្លាំងទាំងអស់)។ សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ១៩ ERN (ភាសាខ្មែរ) S 00324828 (គ្មានកម្លាំងណា ឬ នរណា នៅ "អសកម្ម" ក្នុងការការពារ និងកសាងប្រទេសឱ្យបានលឿននោះទេ)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00291036 (ប្រទេសកម្ពុជាដូចជារោងជាងធំមួយ។ ប្រជាជនយើងទាំងអស់កំពុងធ្វើការងារទាំងថ្ងៃទាំងយប់ដើម្បីកសាងប្រទេសឡើងវិញ)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00003767-00003768 (បុគ្គលគ្រប់គ្នាដាក់ផលប្រយោជន៍ជាតិ និងសម្ញូហភាពនៅខាងលើអ្វីៗផ្សេងទៀតទាំងអស់។ គ្មាននរណាម្នាក់មិនស្ថិតនៅក្រោមការក្តោបក្តាប់ឡើយ)។

[២៣១០] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៦១, ៦៥ ERN (ភាសាអង់គ្លេស) 00079815 (ថ្នាក់ដឹកនាំបក្សបានផ្តោតលើគោលការណ៍ឯករាជ្យ និងខ្លួនទីពឹងខ្លួន)។ សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ១៨-២០ ERN (ភាសាខ្មែរ) 00324827-00324829 ។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00003761-00003763 (បដិវត្តន៍សង្គមនិយមគឺដើម្បីកម្ទេចកម្មសិទ្ធិផ្ទាល់ខ្លួន។ ដើម្បីកម្ទេចកម្មសិទ្ធិផ្ទាល់ខ្លួន បក្សបានគោរពតាមគោលការណ៍ឯករាជ្យម្ចាស់ការ និងខ្លួនទីពឹងខ្លួន) ទំព័រ ១០ ERN (ភាសាខ្មែរ) 00003769 (គោលជំហរមូលដ្ឋានក្នុងការអនុវត្តការងារកសាងជាតិ និងការពារប្រទេស រួមមាន ខ្លួនទីពឹងខ្លួន សម្ញូហភាវូបនីយកម្ម និងការតស៊ូប្រយុទ្ធយូរអង្វែង)។

[២៣១១] សុន្ទរកថាដោយ អៀង សារី ក្នុងពិធីភោជនាហារនាពេលល្ងាច ស្វាគមន៍ ផ្តល់កិត្តិយសដល់សមមិត្តសមាជិកមជ្ឈិមបក្សកុម្មុយនីស្ត Maxist-Leninist សហរដ្ឋអាមេរិក ឯកសារ E3/211 ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) S 00801571-00801572 (កម្លាំងប្រជាជនទទួលខុសត្រូវលើការធ្វើឱ្យប្រទេសប្រសើរឡើងដោយគ្មានវណ្ណៈកេងប្រវ័ញ្ច និងវណ្ណៈដែលត្រូវគេកេងប្រវ័ញ្ច)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ៨១-៨២ ERN (ភាសាខ្មែរ) 00003840-00003841 (នៅក្នុងដំណាក់កាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ត្រូវមានការលះបង់ចំពោះវណ្ណសិរ្ស ចំណែកនៅក្នុងដំណាក់កាលសង្គមនិយម វណ្ណៈផ្សេងទៀតត្រូវតែលុបបំបាត់ចោល។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧៤-៧៥ ERN

លក្ខខណ្ឌ[២៣១២] ហើយស្ថានទូតទាំងអស់នឹងត្រូវបិទដំណើរការ យ៉ាងហោចណាស់ក្នុងរយៈពេលបណ្តោះអាសន្ន[២៣១៣]។ លើសពីនេះទៀត បក្សបានពិចារណាឃើញថា បក្សចាំបាច់ត្រូវបន្តវិធីបិទបាំង និងរក្សាការសម្ងាត់[២៣១៤] ដើម្បីការពារកុំឲ្យខ្មាំងជ្រៀតចូល[២៣១៥] និងដើម្បីកសាងមូលដ្ឋាន

---

(ភាសាខ្មែរ) 00103845 (ការជំរុញឲ្យប្រទេសកម្ពុជាឈានឲ្យបានឆាប់រហ័សដល់សង្គមកុម្មុយនីស្ត ទាមទារឲ្យមានការខិតខំបំផុសចលនាមនោគមន៍វិជ្ជាមួយម៉ឺងម៉ាត់ បំពាក់ជំហរវណ្ណៈឲ្យកសិករ)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៤។

[២៣១២] ប្រតិចារឹកខ្សែអាត់សម្លេងនៃបទសម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00771129-00771131 (ពួកគេបដិសេធជំនួយបរទេសដោយផ្អែកមូលដ្ឋានលើការផ្គត់ផ្គង់គ្រប់គ្រាន់ដោយខ្លួនឯងយ៉ាងច្បាស់លាស់)។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយលោកស្រី Elizabeth BECKER ឯកសារ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578892-00578893 (ប្រទេសកម្ពុជាបដិសេធជំនួយអន្តរជាតិក្រោយជ័យជម្នះក្នុងឆ្នាំ ១៩៧៥ ដោយសារហេតុផលជាច្រើន ក្នុងនោះរួមទាំង ការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់អាមេរិកផងដែរ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា ឯកសារ E3/2667 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00491782 (គឹម អ៊ីលស៊ុង បានផ្តល់ជំនួយត្រាក់ទ័រ ១០.០០០ គ្រឿងដល់ប្រទេសកម្ពុជា។ ខៀវ សំផន បានឆ្លើយតបថា តាមរយៈការខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសស្រាក់សស្រាំ ប្រជាជនកម្ពុជាមានលទ្ធភាពទិញម៉ាស៊ីនដែលអាចឲ្យផលិតត្រាក់ទ័រ ១០.០០០ គ្រឿង ឬ ច្រើនជាងនេះបានដោយខ្លួនឯង សម្រាប់តម្រូវការប្រើប្រាស់នាពេលអនាគត)។

[២៣១៣] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កិច្ចសម្ភាសន៍ជាមួយ ស៊ាន អាន ឯកអគ្គរាជទូតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/2720 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00523983-00523984។ សេចក្តីថ្លែងការណ៍របស់ ថៅ សេង សមាជិកនៃការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាលនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជាប្រេសិតពិសេសរបស់ប្រមុខរដ្ឋកម្ពុជាប្រចាំទ្វីបអឺរ៉ុប ឯកសារ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00517761-00517762។

[២៣១៤] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/229 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00000715 (យកចិត្តទុកដាក់លើបញ្ហារក្សាការសម្ងាត់ កុំឲ្យបងប្អូនឆ្វេចឆ្វាច។ ទាក់ទងគ្នាក៏ត្រូវស្ងាត់)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (សាឡុត បាន) ទំព័រ ១២, ១៣-១៤ (វគ្គរៀនសូត្របានបង្រៀនគោលការណ៍រក្សាការសម្ងាត់ជាមួយនឹងពាក្យស្លោក "បែកការណ៍គឺស្លាប់ លាក់ការណ៍សម្ងាត់បាន គឺឈ្នះ ៨០%"។ ប្រតិចារឹក ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ (គឹម វុន) ទំព័រ ៥០-៥១ (វគ្គរៀនសូត្រនយោបាយនៅមន្ទីរ ប-២០ បានពិភាក្សាអំពី សារៈសំខាន់នៃជំហររឹងប៉ឹង និងការរក្សាការសម្ងាត់)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៣-១៤ (ការរក្សាការសម្ងាត់គឺជាគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ ចំណេះដឹងគឺសម្រាប់តែអ្នកដែលត្រូវការវាតែប៉ុណ្ណោះ)។

និងដោះស្រាយបញ្ហាផ្ទៃក្នុងឲ្យបានរួចរាល់មុនពេលស្វាគមន៍បរទេស[២៣១៦]។ បក្សមិនអត់ឱនចំពោះការប្រឆាំងដោយចំហចំពោះមាគ៌ាបក្សនោះទេ[២៣១៧]។

---

[២៣១៥] សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១២-១៥ ERN (ភាសាខ្មែរ) 00224468-00224470 (គោលការណ៍សម្ងាត់មាននៅក្នុងគ្រប់ទិដ្ឋភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ (រួមទាំង ការបោះឆ្នោត កន្លែងមេដឹកនាំរស់នៅ ពេលវេលា និងទីកន្លែងប្រជុំ) មានសារៈសំខាន់ដើម្បីការពារប្រទេសពីគ្រោះថ្នាក់នៃការជ្រៀតចូលរបស់ខ្មាំង)។

[២៣១៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៦-១៧ (នៅពេលបក្សមានរចនាសម្ព័ន្ធត្រឹមត្រូវជាមួយនឹងការគាំទ្រពីមហាជន និងបរទេសរួចហើយនោះ បក្សនឹងប្រកាសអំពីអត្ថិភាពរបស់ខ្លួន)។ ប្រតិចារឹកខ្សែអាត់សម្លេងនៃបទសម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00771129-00771134 (នៅក្នុងដំណាក់កាលដំបូង ពួកគេត្រូវកសាងប្រទេស មានមូលដ្ឋានរឹងមាំគ្រប់គ្រាន់សិន មុនពេលអាចបើកចំហប្រទេសបាន)។

[២៣១៧] ការពិភាក្សាជាមួយ អៀង សារី ដោយ Stephen HEDER ឯកសារ E3/190 ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៩ ទំព័រ ១ ERN (ភាសាខ្មែរ) 00172247 (ប្រសិនបើគាត់ជំទាស់ជាចំហជាមួយនឹងមាគ៌ាបក្ស ឬ ព្យាយាមផ្តាច់ខ្លួន ពួកគេទាំងអស់ត្រូវបានចាប់ខ្លួនទាំងអស់)។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយបណ្តាញទូរទស្សន៍ ABC ឯកសារ E3/93 ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00224443-00224444 (អៀង សារី ពុំបាននិយាយប្រឆាំងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះទេ ដោយសារហេតុផលសាមគ្គីភាពជាមួយនឹងការតស៊ូ)។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00442254-00442255 (បក្សបានជំទាស់នឹងក្រុមប្រឆាំង និងអំពើបង្កជាបក្សពួក) ទំព័រ ១៩-២០ ERN (ភាសាខ្មែរ) 00442262-00442263 (អ្នកដែលជំទាស់នឹងបក្ស ហើយនឹងធ្វើឲ្យប្រេះឆា នឹងត្រូវទទួលការទិតៀន និងព្រមាន ការផ្លាស់ប្តូរភារកិច្ច ឬ ការដកភារកិច្ច ឬ ដកចេញពីបក្ស)។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4028 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២ ERN (ភាសាខ្មែរ) 00782542 (នៅពេលបុគ្គលគ្រប់គ្នានៅក្នុងបក្ស (កម្មាភិបាល និងថ្នាក់ដឹកនាំ) ឈរលើមាគ៌ាតែមួយ គ្មានជម្លោះនឹងផ្ទុះឡើងនោះទេ ពោលគឺ នេះគឺជាវិធីដែលអ្វីៗត្រូវដោះស្រាយ)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/210 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00782542 (ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជា មានអារម្មណ៍ថាទទួលការគំរាមកំហែងពីវៀតណាម៖ ស្ថានភាពនេះមានន័យថា ពួកគេពុំអាចមើលឃើញជាមុននូវការប្រឆាំងនោះទេ)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៥ ERN (ភាសាខ្មែរ) 00156616 (បក្សបានណែនាំមិនឲ្យនរណាម្នាក់បង្ហាញអារម្មណ៍ ឬមតិយោបល់ផ្ទាល់ខ្លួនរបស់ពួកគេនោះទេ លើកលែងតែនៅក្នុងពេលប្រជុំតែប៉ុណ្ណោះ)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00003762 (បក្សបានជំទាស់នឹងគំនិតបុគ្គលនិយម)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/37 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00156677-00156678 (បក្សពុំចង់ឲ្យសាធារណជនដឹងថា បក្សមានការខ្វែងយោបល់គ្នានៅក្នុងជួរបក្សនោះទេ)។

៧៣៨. នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងសុន្ទរកថា កិច្ចសម្ភាសន៍ និងសេចក្ដីថ្លែងការណ៍នានារបស់មេដឹកនាំបក្ស រួមទាំង ប៉ុល ពត ក្នុងឆ្នាំ ១៩៧៧[២៣១៨] និងក្នុងឆ្នាំ ១៩៧៨[២៣១៩] នួន ជា ក្នុងឆ្នាំ ១៩៧៧[២៣២០] និងក្នុងឆ្នាំ ១៩៧៨[២៣២១] អៀង សារី ក្នុងឆ្នាំ ១៩៧៥[២៣២២]

---

[២៣១៨] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីកម្ពុជានៅប្រទេសចិន ឯកសារ E3/2725 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00810739-00810740 (ប៉ុល ពត បានថ្លែងសុន្ទរកថាមួយដែលបានគូសបញ្ជាក់អំពីការផ្គត់ផ្គង់ខ្លួនឯងការរួបរួម និងឯកភាពនៅក្នុងប្រទេស)។ បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00442092-00442093 (ប្រជាជនត្រូវកសាង និងការពារប្រទេស។ ពាក្យស្លោក៖ មហាលោតផ្លោះ មហាអស្ចារ្យ)។

[២៣១៩] សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ១៨-២០ ERN (ភាសាខ្មែរ) 00324827-00324829 (ភារកិច្ចចម្បងរបស់បក្សគឺការពារកម្ពុជាប្រជាធិបតេយ្យ បន្តធ្វើបដិវត្តន៍សង្គមនិយម និងអប់រំសង្គមនិយម)។ ប៉ុល ពត សម្ភាសន៍ជាមួយតំណាងសារព័ត៌មានទីក្រុងហុងកុង ឯកសារ E3/5712 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៧៨ ទំព័រ ១៧ ERN (ភាសាខ្មែរ) 00816538 (ភ្លាមៗក្រោយពេលរំដោះ ពួកគេបានចាប់ផ្ដើមធ្វើឲ្យសេដ្ឋកិច្ចប្រសើរឡើង កសាងប្រទេស ដោះស្រាយបញ្ហាការផ្គត់ផ្គង់ស្បៀងអាហារ និងការប្រកាន់ខ្ជាប់ឯករាជ្យភាព ខ្លួនទីពឹងខ្លួន)។

[២៣២០] *សុន្ទរកថារបស់លោក នួន ជា នៅក្នុងមិទ្ទិញទិវាខួបកងទ័ព* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/209 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00649946-00649947 (ដំណាក់កាលថ្មីនៃបដិវត្តន៍គឺត្រូវកសាង និងការពារប្រទេស)។

[២៣២១] សេចក្ដីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00224464-00224465 (ការងារចម្បងគឺការពារប្រទេស និងកសាងសង្គម-និយម)។ *សុន្ទរកថារបស់សមមិត្ត នួន ជា* (ព្រឹត្តិប័ត្រព័ត៌មាន កម្ពុជាប្រជាធិបតេយ្យ) ឯកសារ E3/78 ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00705172-00705173 (បក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនមានភារកិច្ចចំនួន ៣៖ ការពារជាតិ ធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ដើម្បីការពារប្រទេស ពួកគេត្រូវកសាងប្រទេសឲ្យបានលឿន)។

[២៣២២] ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ លោក អៀង សារី ធ្វើទស្សនកិច្ចនៅប្រទេសថៃ ឯកសារ E3/3360 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00740796-00740797 (អៀង សារី បានប្រាប់អ្នកតំណាងថៃម្នាក់ថា ប្រទេសកម្ពុជានឹងពឹងលើខ្លួនឯង ហើយមិនទទួលយកជំនួយនោះទេ)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ប្រសាសន៍របស់នាយករដ្ឋមន្ត្រី Khukrit នាឱកាសដំណើរទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ឯកសារ E3/3558 ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00789299-00789300។ ទូរលេខរបស់ក្រសួងការបរទេសនៃសហរដ្ឋអាមេរិកកម្មវត្ថុ៖ សេចក្ដីថ្លែងការណ៍របស់ឧបនាយករដ្ឋមន្ត្រីកម្ពុជា អៀង សារី នៅព្រលានយន្តហោះ ខេណិតឌី ឯកសារ E3/620 ចុះ

ឆ្នាំ ១៩៧៦[២៣២៣] ឆ្នាំ ១៩៧៧[២៣២៤] និង ឆ្នាំ ១៩៧៨[២៣២៥] និង ខៀវ សំផន ក្នុងឆ្នាំ ១៩៧៥[២៣២៦] ឆ្នាំ ១៩៧៦[២៣២៧] ឆ្នាំ ១៩៧៧[២៣២៨] និងឆ្នាំ ១៩៧៨[២៣២៩] បានបញ្ជាក់ និងអនុម័តជាសាធារណៈទៅលើ

---

ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00709534 (អៀង សារី បានមកដល់ទីក្រុងញូវយ៉កដើម្បីចូលរួមប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ ហើយបានប្រកាសថា ប្រទេសកម្ពុជាប្តេជ្ញាកសាងប្រទេសឡើងវិញ និងជារោងជាងធំមួយ។ គាត់បានពន្យល់ ថា ពួកគេកំពុងសាងសង់ប្រព័ន្ធធារាសាស្ត្រធំមួយដើម្បីគាំទ្រការច្រូតកាត់ប្រមូលផលពីរដងជាជាងម្តង ហើយនៅត្រឹមចុងឆ្នាំ ១៩៧៥ ពួកគេសង្ឃឹមថានឹងអាចបំពេញតម្រូវការស្បៀងអាហារបាន)។ ទូរលេខរបស់ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ បទសម្ភាសន៍សារព័ត៌មាន ញូវវីក (Newsweek) ជាមួយ អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (អៀង សារី បានពន្យល់ក្នុងពេលសន្និសីទកំពូលនៃប្រទេសមិនចូលបក្សសម្ព័ន្ធថា ប្រទេសកម្ពុជា គឺ ដូចជារោងជាងដ៏មហាធំមួយដែលប្រជាជនទាំងអស់ធ្វើការទាំងយប់ទាំងថ្ងៃ)។

[២៣២៣] សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី អៀង សារី ថ្លែងក្នុងពិធីលៀងសាយភោជន៍ជាកិត្តិយសដល់អង្គទូតនានាប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/606 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00504127-00504128 (ប្រជាជនបានរួបរួមគ្នាមួយឆ្នាំមុននេះ ដើម្បីប្រឹងប្រែងកសាងប្រទេសតាមរយៈការច្រូតកាត់ និងប្រព័ន្ធធារាសាស្ត្រ)។ ការផ្តោតសំខាន់ គឺលើឯករាជ្យ អធិបតេយ្យ ខ្លួនទីពឹងខ្លួន)។ បទអន្តរាគមន៍របស់លោក អៀង សារី នៅក្នុងមហាសន្និបាតលើកទី ៣១ របស់អង្គការសហប្រជាជាតិ ឯកសារ E3/607 ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ៦-៩ ERN (ភាសាខ្មែរ) 00816623-00886626 (មានចលនាបដិវត្តន៍មហាជនដើម្បីការពារ និងកសាងប្រទេស។ មាគ៌ានយោបាយគឺ ឯករាជ្យ អធិបតេយ្យ ខ្លួនទីពឹង ខ្លួន)។

[២៣២៤] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៣៤, ៤៤, ៤៨ ERN (ភាសាខ្មែរ) 00291025-00291026 កថាខណ្ឌ ៥១ ERN (ភាសាអង់គ្លេស) 00079813 (ប្រជាជនកម្ពុជាកំពុងតស៊ូ ដើម្បីការពារ និងកសាងប្រទេសនៅក្នុងដំណាក់កាលបដិវត្តន៍ថ្មីរបស់ពួកគេ ពោលគឺ តស៊ូដើម្បីការពារផលចំណេញពីបដិវត្តន៍។ ស្ថានភាពនេះបានទទួលជោគជ័យតាមរយៈការអប់រំជាដរាប)។ *គណៈប្រតិភូរដ្ឋាភិបាលភូមាក្នុងប្រទេសកម្ពុជា* (កម្រងឯកសារ SWB) ឯកសារ E3/1590 ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ១-៣ ERN (ភាសាខ្មែរ) S 00654818-00654820 (បក្សកុម្មុយនីស្តកម្ពុជាបានផ្តោតលើភារកិច្ចការពារ និងកសាងប្រទេស ដោយគោរពតាមជំហរឯករាជ្យ ខ្លួនទីពឹងខ្លួន)។

[២៣២៥] *សមមិត្តឧបនាយករដ្ឋមន្ត្រី អៀង សារី បានរៀបចំពិធីជប់លៀងដើម្បីជាកិច្ចស្វាគមន៍ដល់បណ្តាអគ្គរដ្ឋទូតដែលបានបំពេញបេសកកម្មនៅកម្ពុជាប្រជាធិបតេយ្យ* (ព្រឹត្តិប័ត្រព័ត៌មានកម្ពុជាប្រជាធិបតេយ្យ) ឯកសារ E3/1396 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៧៨ ទំព័រ ២ ERN (ភាសាខ្មែរ) S 00743389 (អៀង សារី បានប្រាប់អង្គទូតថា ពួកគេនឹងមើលឃើញនូវកិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនក្នុងការកសាងប្រទេស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដោយគោរពតាមជំហរ ឯករាជ្យ អធិបតេយ្យ ខ្លួនទីពឹងខ្លួន)។ សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាទអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី១០ ឯកសារ E3/547 ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៨ ទំព័រ ១១-១៣ ERN (ភាសាខ្មែរ) 00329501-00329503 ។ សុន្ទរកថាដោយ អៀង សារី ក្នុងពិធីភោជនាហារនាពេលល្ងាច ស្វាគមន៍ ផ្តល់

កិត្តិយសដល់សមមិត្តសមាជិកមជ្ឈិមបក្សកុម្មុយនីស្ត Maxist-Leninist សហរដ្ឋអាមេរិក ឯកសារ E3/211 ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ២ ERN (ភាសាខ្មែរ) S 00801571។ សុន្ទរកថារបស់ អៀង សារី ក្នុងឱកាសពិធីជប់លៀងសាយភោជនស្វាគមន៍ក្រសួងការបរទេសថៃ ឯកសារ E3/1587 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ២-៥ ERN (ភាសាខ្មែរ) S 00663754-00663757 (កម្ពុជាប្រជាធិបតេយ្យតែងតែមានការប្ដេជ្ញាខ្លាំងក្លាចំពោះគោលការណ៍មិនជ្រៀតជ្រែកប្រទេសដទៃ ឯករាជ្យ ខ្លួនទីពឹងខ្លួន និងគោលការណ៍មិនឈ្លានពានប្រទេសដទៃ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/4605 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00813070 (អៀង សារី បានជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អនុគណៈកម្មការប្រឆាំងនឹងវិធានការរើសអើង និងការពារជនភាគតិច។ សេចក្ដីសម្រេចថ្កោលទោសការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ហើយប្រកាសថាក្រោយរយៈពេល ៣ ឆ្នាំ កម្ពុជាប្រជាធិបតេយ្យបានទទួលជោគជ័យលើការដោះស្រាយបញ្ហាជាមូលដ្ឋាន មានស្បៀងអាហារផ្គត់ផ្គង់ខ្លួនឯង កសាង និងការពារប្រទេស និងពុំផ្អែកលើអ្វីទាំងអស់ពីពួកចក្រពត្តិ)។

[២៣២៦] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ឯកសារ E3/619 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00635938-00635939 (ក្នុងខណៈពេលនៅទីក្រុងប៉េកាំង ខៀវ សំផន បានគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងប្រទេសឡើងវិញ។ គាត់បានលើកឡើងភារកិច្ចថ្មីៗរបស់ប្រទេសកម្ពុជា ដោយរួមបញ្ចូលភារកិច្ចការពារប្រទេស ភារកិច្ចស្តារសេដ្ឋកិច្ច និងកសាងប្រទេសក្នុងល្បឿនឲ្យបានលឿន។ គាត់បាននិយាយថាប្រទេសទាំងមូលបានក្លាយជាការដ្ឋានសាងសង់ធំមួយ)។ *សារអបអរសាទរជ័យជម្នះធ្វើឡើងនាថ្ងៃទី ២១ ខែ មេសា របស់ ខៀវ សំផន តាមវិទ្យុទីក្រុងភ្នំពេញ* ឯកសារ E3/118 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00846162-00846163 (ខៀវ សំផន បានកោតសរសើរការលះបង់របស់ប្រជាជននៅតាមតំបន់រំដោះ និងកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើភ្លឺ លើកទំនប់ ជីកប្រឡាយ)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧-៨, ១២-១៤ (ក្នុងខែ តុលា ឆ្នាំ ១៩៧៥ ខៀវ សំផន បានឧទ្ទេសនាមបញ្ញាជនរាប់រយនាក់ដែលបានវិលត្រឡប់មកប្រទេសវិញនៅវិទ្យាស្ថានបច្ចេកទេសខ្មែរសូវៀត ដោយបានពន្យល់ក្នុងនោះថាការជម្លៀសខេត្តក្រុងចាំបាច់ធ្វើឡើងដើម្បីកម្ទេចទ្រព្យសម្បត្តិឯកជន)។

[២៣២៧] សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទកំពូលលើកទី៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ចុះថ្ងៃទី ១៦-១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ១៣-១៤ ERN (ភាសាខ្មែរ) 00065895-00065896 (កម្ពុជាប្រជាធិបតេយ្យបានប្ដេជ្ញាគោរពតាមគោលការណ៍ខ្លួនទីពឹងខ្លួន ឯករាជ្យភាព និងអព្យាក្រឹត្យភាព)។

[២៣២៨] *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/200 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ១-៤, ១០-១២ ERN (ភាសាខ្មែរ) 00292803-00292806, 00292812-00292814 (បានបន្តផ្តោតលើការកសាង ការការពារ និងការថែរក្សាផលនៃបដិវត្តន៍ និងខ្លួនទីពឹងខ្លួន)។ *សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន* (ក្នុងកម្រងឯកសារ SWB) ឯកសារ E3/267 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00000898-00000899 (បក្សកុម្មុយនីស្តកម្ពុជាគឺជាបក្សភ្លឺស្វាងមួយ។ កងទ័ពកម្ពុជា និងប្រជាជនបានវាយចក្រពត្តិអាមេរិក និងបរិវាររបស់វាឲ្យបរាជ័យហើយ។ មូលដ្ឋានគាំទ្រត្រូវបង្កើនការបង្កបង្កើនផលដោយគោរពឲ្យបានខ្ជាប់ខ្ជួនទៅតាមជំហរឯករាជ្យ)។

មាគ៌ាបក្សដើម្បីការពារ និងកសាងប្រទេសឲ្យបានលឿនតាមរយៈបដិវត្តន៍សង្គមនិយម ដោយផ្អែកលើគោលការណ៍រក្សាការសម្ងាត់ ឯករាជ្យ អធិបតេយ្យ ខ្លួនទីពឹងខ្លួន និងសម្ងាត់បរិយាកាសបនីយកម្ម។

### ១៤.១.៤.១ ការកាន់កាប់ និងការគ្រប់គ្រងអំណាចជាបណ្ដោះអាសន្នរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោយពេលរំដោះ

៧៣៩. ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ យ៉ាងយូរបំផុត ខណៈពេលដែលការជម្លៀសប្រជាជនចេញពីទីខេត្ត-ក្រុងកំពុងបន្តធ្វើឡើង ទីក្រុងភ្នំពេញស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អង្គភាពយោធា ក្រោមការបញ្ជារបស់លេខាភូមិភាគ រួមទាំង សោ ភឹម កុយ ធួន តា ម៉ុក និង វន វេត[២៣៣០]។ ស្របតាមនីតិវិធីដែលធ្លាប់បានអនុវត្តក្នុងអំឡុងពេលយុទ្ធនាការយោធានៅចន្លោះពីឆ្នាំ ១៩៧០ និងឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់ទទួលរបាយការណ៍ និងចេញការណែនាំទៅដល់មេដឹកនាំភូមិភាគដែលបញ្ជាកងទ័ពនៅមូលដ្ឋាន រីឯលេខាភូមិភាគដែលបញ្ជាអង្គភាពយោធាគ្រប់គ្រងទីក្រុងក្រោយពីរំដោះ បានស្នើសុំ និងទទួលការណែនាំពី ប៉ុល ពត នួន ជា សុន សេន និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ជាពិសេសសមាជិកនៃគណៈកម្មាធិការមជ្ឈិម

---

[២៣២៩] សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងទិវាបុណ្យខួបលើកទី៣ នៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/169 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) S00704516-00704518 (នៅក្នុងការថ្លែងទៅកាន់សមាជិកបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងការជួបជុំជាសាធារណៈមួយ ខៀវ សំផន បានបញ្ជាក់ថា សមាជិកបក្សកុម្មុយនីស្តកម្ពុជាប្ដេជ្ញាចិត្តបំពេញយ៉ាងសកម្មនូវភារកិច្ចបដិវត្តន៍ដ៏ថ្លៃថ្នូរដែលបក្សបានប្រគល់ឲ្យ និងបន្តសម្រេចបានជោគជ័យ មហាលោតផ្លោះ មហាអស្ចារ្យ) ទំព័រ ១២ ERN (ភាសាខ្មែរ) S00704526 (“យើងត្រូវធ្វើការការពារប្រទេស បដិវត្តន៍ អំណាច ប្រជាជន កងទ័ព បក្ស និងពូជសាសន៍កម្ពុជាជាដាច់ខាត។ យើងអាចធ្វើការការពារប្រទេសយើងបាន តែក្នុងលក្ខខណ្ឌដែលយើងអនុវត្តតាមមាគ៌ារបស់បក្ស ទាំងនៅក្នុងការការពារប្រទេសពីខាងក្រៅ និងពីខាងផ្ទៃក្នុងប្រទេស។ រាល់អង្គភាពទាំងអស់នៅទូទាំងប្រទេសត្រូវតែបន្តបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ [...] យើងត្រូវបន្តអនុវត្តឲ្យបានខ្លាំងក្លា និងយ៉ាងសកម្ម នូវភារកិច្ចកសាងជាតិទាំងនៅជនបទ ក៏ដូចជានៅតាមរោងចក្រ ផ្នែក និងអង្គភាពនានា”) ទំព័រ ៣ ERN (ភាសាខ្មែរ) S00704517 (“យើងត្រូវឆ្លៀតយកឱកាសដ៏វិសេសវិសាលនេះ ដើម្បីបំពេញនូវភារកិច្ចឆ្នាំ ១៩៧៨ របស់បក្សឲ្យកាន់តែក្លៀវក្លា ហើយដណ្ដើមបាននូវជ័យជម្នះលើគ្រប់វិស័យ មហាលោតផ្លោះ មហាអស្ចារ្យ”) ទំព័រ ៤-៦ ERN (ភាសាខ្មែរ) S00704518- S00704520 (ដែលបញ្ជាក់ថា មាគ៌ាបក្សផ្អែកទៅលើការការពារកម្ពុជា និងការកសាងជាតិ)។

[២៣៣០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៨-១៥១។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦០។

នៅមន្ទីរ ប-៥[២៣៣១]។ លើសពីនេះទៀត ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការមួយដែលត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការមជ្ឈិមនៅក្នុង ខែ

[២៣៣១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៨-១៥២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៥-៣៦ (មេដឹកនាំយោធាខ្មែរក្រហមម្នាក់នៅក្រសួងព័ត៌មានបានលើកឡើងនៅថ្ងៃទី ១៧ ខែ មេសា ថា ជោគវាសនា របស់អ្នករដ្ឋការទាំងអស់ដែលបានប្រមូលផ្តុំមកជួបជុំគ្នានោះ គឺអាស្រ័យលើរដ្ឋាភិបាល ហើយបានលើកឡើងបន្ថែមថា មេដឹកនាំក្នុងរដ្ឋាភិបាល និងមេដឹកនាំនយោបាយកំពូលៗខ្លះមិននៅឆ្ងាយពីទីក្រុងនោះទេ)។ សមាជិកគណៈកម្មាធិការមជ្ឈិមបានចេញសេចក្តីណែនាំនៅក្នុងអំឡុងពេលវាយសម្រុកលើទីក្រុងភ្នំពេញ (*សូមមើលឧទាហរណ៍* ឯកសាររបស់ កែ ពក៖*ស្វ័យជីវប្រវត្តិរបស់ កែ ពក ពីឆ្នាំ ១៩៤៩-១៩៨៥* ឯកសារ E3/2782 ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00095550-00095551 (គណៈកម្មាធិការមជ្ឈិមបានកោះប្រជុំមួយនៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៤ ដែលនៅពេលនោះ ពួកគេបានចាត់តាំងគាត់ឲ្យទៅសៀមរាបការពារអង្គរ។ គាត់បានលាលែងពីមុខតំណែងរបស់គាត់ជាសេនាធិការភូមិភាគក្នុងគោលបំណងការពារអង្គរ។ កុយ ធួន បានទទួលបញ្ជាឲ្យទទួលខុសត្រូវលើកទ័ពរបស់គាត់ដឹកនាំចូលក្នុងទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦៤ (ប៉ុល ពត បានហៅ ខៀវ សំផន ទៅកាន់ទីស្នាក់ការដើម្បីចូលរួមស្តាប់នូវអ្វីដែលគាត់បានធ្វើជាមួយនឹងកម្មាភិបាលយោធាមកពីសមរភូមិនានា ដែលមករាយការណ៍ជូនគាត់ និងស្តាប់គាត់អំពីរបៀបដែលគាត់ចេញការណែនាំត្រឡប់ឲ្យទៅកម្មាភិបាលទាំងនោះវិញ ដើម្បីឲ្យ ខៀវ សំផន អាចយល់អំពីស្ថានការណ៍បដិវត្តន៍ និងអាចរាយការណ៍ជូន នរោត្តម សីហនុ វិញ)។ ជាទូទៅ នៅពេញមួយអំឡុងពេលបដិវត្តន៍ ប៉ុល ពត នួន ជា និងគណៈកម្មាធិការមជ្ឈិមគ្រប់គ្រងតាមដានលើយុទ្ធនា-ការយោធា (*សូមមើលឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៣១-៣២ (នៅក្នុងអំឡុងពេលវាយប្រហារលើទីរួមខេត្តកំពង់ចាម ក្នុងឆ្នាំ ១៩៧៣ មេដឹកនាំជាន់ខ្ពស់ ដូចជា ប៉ុល ពត នួន ជា នៅជិតមន្ទីរ ស-៧១ ហើយ សុន សេន នៅទីស្នាក់ការរបស់គាត់នៅបុសខ្នុរ។ កងទ័ពបានចូលរួមនៅក្នុងការវាយប្រហារគឺមកពីមជ្ឈិម និង តំបន់ “៣០៤”។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ទំព័រ ២៩-៣០ (ផែនការត្រៀមវាយប្រហារឧត្តុង្គ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់មេបញ្ជាការ កងពលតូច ចេង អន ។ ក៏ប៉ុន្តែ មានផែនការរួមមួយសម្រាប់កងពលតូច ពោលគឺ កងកម្លាំងនិរតីត្រូវវាយប្រហារឧត្តុង្គ ហើយកងវរសេនាធំត្រូវត្រៀមវាយប្រហារខាងត្បូងឧត្តុង្គ) ទំព័រ ៣០-៣១ (ក្រោយកាវាយប្រហារឧត្តុង្គ ពួកគេទទួលបានព័ត៌មានថា មានការរៀបចំពីថ្នាក់លើឲ្យគ្រប់គ្រងមុខព្រួញនៃកងកម្លាំងនិរតី កងកម្លាំងភូមិភាគពិសេស ហើយ សុន សេន បានមកដល់) ទំព័រ ៣១-៣២ (ទទួលភារកិច្ចពិសេស ដូចជា ការវាយសមរភូមិ ថ្នាក់លើមិនត្រឹមកោះហៅកងពលតូចនោះទេ ថែមទាំងកោះហៅវរសេនាធំផងដែរឲ្យមកជួបជុំគ្នា ហើយបានបញ្ជូនបញ្ជាបន្តដើម្បីធ្វើការវាយប្រហារបន្តទៀត)។ ឯកសាររបស់ កែ ពក៖ *ស្វ័យជីវប្រវត្តិរបស់ កែ ពក ពីឆ្នាំ ១៩៤៩-១៩៨៥* ឯកសារ E3/2782 ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00095548-00095551 (ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧២ គណៈកម្មាធិការមជ្ឈិមបានបញ្ជាឲ្យគាត់សហការជាមួយអង្គភាពមជ្ឈិម ពោលគឺ អង្គភាព ៣៩ ដឹកនាំដោយ ខៀវ សំផន ធ្វើការបោសសម្អាតខ្មាំងនៅជុំវិញកំពង់ធំ។ ពួកគេបានត្រៀមកងកម្លាំង និងវាយប្រហារក្នុងពេលជាមួយគ្នា។ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៣ គាត់បានត្រៀមកងកម្លាំងវាយប្រហារតាមផ្លូវជាតិលេខ ៦ ។ ពួកគេបានបោសសម្អាតទីតាំងទាំងនោះ បានដោយជោគជ័យ។ បន្ទាប់មក គណៈកម្មាធិការមជ្ឈិមបានប្រាប់គាត់ឲ្យរៀបចំកងកម្លាំងយោធាភូមិភាគ ដើម្បីចាប់យកកំពង់ចាមជាពីរក្រុម។

មិថុនា ឆ្នាំ ១៩៧៤ ដែលមាន សុន សេន ធ្វើជាប្រធាន និងរួមទាំង កុយ ធួន និងមេដឹកនាំភូមិភាគផ្សេងទៀតផង[២៣៣២]។

៧៤០. ដោយបានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញទាំងអស់គ្នា យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នោះ[២៣៣៣] នួន ជា ប៉ុល ពត ខៀវ សំផន អៀង សារី និង សុន សេន បានបង្កើតគណៈកម្មាធិការដឹកនាំរួមមួយ[២៣៣៤]។ ពួកគេបានជួបប្រជុំជាទៀតទាត់ជាមួយលេខាភូមិភាគ

---

គាត់ និង កុយ ធួន ដឹកនាំម្នាក់មួយក្រុម។ នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៣ មជ្ឈិមបានប្តេជ្ញាវាយប្រហារដណ្តើមយកប្រទេសទាំងមូល និងបានរៀបចំផែនការជាច្រើន រួមទាំងផែនការថា ភូមិភាគបូព៌ាត្រូវវាយប្រហារពីតាមផ្លូវជាតិលេខ ១ ភូមិភាគនិរតីពីតាមផ្លូវជាតិលេខ ២, ៣ និង ៤ ហើយភូមិភាគបស្ចឹមពីចន្លោះផ្លូវជាតិលេខ ៤ និង ៥។ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00095550-00095551 (ក្រោយការគ្រប់គ្រងទីតាំងនេះ បានរយៈពេលកន្លះខែ បងៗថ្នាក់លើៗបានសម្រេចធ្វើការវាយសម្រុកឧត្តុង្គ)។

[២៣៣២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣១-៥៣៣។

[២៣៣៣] កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ១៥-១៦, ERN (ភាសាខ្មែរ) 00775913-00775914 (ប៉ុល ពត ត្រឡប់មកភ្នំពេញវិញ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00156613-00156614 (ខៀវ សំផន ចូលមកដល់ទីក្រុងភ្នំពេញនៅប្រហែល ៧ ទៅ១០ ថ្ងៃ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។ ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00156615-00156616 (ខៀវ សំផន នួន ជា និងប៉ុល ពត ចូលមកជាមួយគ្នា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន ហៅ ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204069-00204070 (សាក្សីបានចូលទីក្រុងភ្នំពេញជាមួយ សុន សេន នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៥០-៥២ (ត្រឹមថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ មេបញ្ជាការកងពលធំនៅតាមសមរភូមិជុំវិញទាំងអស់ រួមមាន កុយ ធួន សោ ភឹម វ៉ន វេត ចេង អន និងតា ម៉ុក បានជួបប្រជុំគ្នានៅស្ថានីយរថភ្លើង។ នួន ជា មកក្រោយ គឺប្រហែលជានៅថ្ងៃទី ២១ ខែ មេសា។ ប៉ុល ពត និង ខៀវ សំផន មកក្រោយពេលនេះទៀត)។ អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៧-៨, ERN (ភាសាខ្មែរ) 00062458-0062459 (អៀង សារី ត្រឡប់មកវិញនៅអំឡុងថ្ងៃ ២៣ ទៅ ២៥ ខែ មេសា ឆ្នាំ ១៩៧៥)។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៣។

[២៣៣៤] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ចាម តុន ហៅ ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204069-00204070 (ចាប់ពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ មក រ៉ចាម តុន ហៅ ភី ភួន នៅជាមួយប៉ុល ពត ខៀវ សំផន នួន ជា និង សុន សេន ជាគណៈដឹកនាំរួម នៅស្ថានីយរថភ្លើង។ ពួកគេនៅទី

និងលេខាតំបន់ស្វយ័តនានា និងអ្នកផ្សេងទៀត ដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការនានា ដើម្បីកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ ខ្លួនទីពឹងខ្លួន ក៏ដូចជាការបង្កើតសហករណ៍ផងដែរ[២៣៣៥]។

៧៤១. នៅក្នុងអំឡុងពេលនោះ និងនៅគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ដែលត្រូវរាយការណ៍ដោយផ្ទាល់ទៅមជ្ឈិមបក្ស ឬក៏ជាផ្នែកមួយនៃស្ថាប័នមជ្ឈិមបក្ស បានចូលរួមក្នុងកិច្ចប្រជុំដែលពិភាក្សា និងសម្រេចពីគោលនយោបាយ និងផែនការបក្ស។ ចន្លោះពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ អ្នកទាំងនោះរួមមាន រស់ ញឹម (ពាយ័ព្យ) សោ ភឹម (បូព៌ា) តា ម៉ុក (និរតី) ជូ ជេត (បស្ចឹម) កុយ ធួន (ភូមិភាគកណ្តាល (ឧត្តរចាស់) រហូតដល់ ឆ្នាំ ១៩៧៥) កែ ពក (ភូមិភាគកណ្តាល (ឧត្តរចាស់) ចាប់ពីឆ្នាំ ១៩៧៥) ចាន់ សំ (ភូមិភាគឧត្តរ ចាប់ពីពេលបង្កើតឡើងនៅអំឡុងឆ្នាំ ១៩៧៧) ម៉ែន សាន (យ៉ា)[២៣៣៦] ឬ៊ី ផាត (តំបន់ ១០៣ រហូតដល់ពេលតំបន់នេះត្រូវច្របាច់បញ្ចូលជាមួយភូមិភាគឧត្តរ ក្នុងអំឡុងឆ្នាំ ១៩៧៧) យ៉ុង យ៉ែម (តំបន់ ៥០៥ រហូតដល់ ឆ្នាំ ១៩៧៦) និង ប៊ិន ណាន (តំបន់ ៥០៥ ចាប់ពីឆ្នាំ ១៩៧៦)[២៣៣៧]។

---

នេះជិតមួយសប្តាហ៍។ មេបញ្ជាការយោធា ប្រធានភូមិភាគ បានមកជួបពួកគាត់ ហើយធ្វើការជាមួយគ្នាជារៀងរាល់ថ្ងៃ។ បន្ទាប់មកពួកគេបានមកនៅអគារអតីតក្រសួងហិរញ្ញវត្ថុចាស់ អស់រយៈពេលជាងពីសប្តាហ៍)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន ហៅ ភី ភួន) ទំព័រ ៥១-៥៣, ទំព័រ ៥៥-៥៧។

[២៣៣៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉ូចាម តុន ហៅ ភី ភួន ឯកសារ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00204069-00204070 (ពួកគេពិភាក្សាពីសភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងការអនុវត្តបដិវត្តសង្គមនិយម។ ប៉ុល ពត ជាអ្នកឧទ្ទេសនាមឯកសារ ហើយ នួន ជា ដឹកនាំការពិភាក្សា)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៣-៦ (សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដោយសម្រេចថា រណសិរ្សលែងមានប្រយោជន៍តទៅទៀតហើយ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ូចាម តុន ហៅ ភី ភួន) ទំព័រ ៥៥-៥៧ (អៀង សារី ខៀវ សំផន នួន ជា សុន សេន ប៉ុល ពត កុយ ធួន វន វេត តា ម៉ុក សោ ភឹម និងអ្នកដទៃទៀតបានជួបគ្នាជាទៀងទាត់) ទំព័រ ៥៨-៦០ (ក្នុងចំណោមប្រធានបទដទៃទៀត ពួកគេបានពិភាក្សាគ្នាអំពីបដិវត្តសង្គមនិយម ការកសាង និងការពារប្រទេស និងការកសាងសហករណ៍)។

[២៣៣៦] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០។

[២៣៣៧] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៧។

៧៤២. ចន្លោះពីថ្ងៃទី ២៥ ដល់ ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន ត្រូវបានចោទប្រកាន់ថាបានដឹកនាំមហាសន្និបាតជាតិពិសេសមួយ[២៣៣៨] ដែលបានសម្រេចថារចនាសម្ព័ន្ធរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានឹងត្រូវរក្សាទុកនៅដដែល ហើយបានបញ្ជាក់ថា មិនអនុញ្ញាតឲ្យមានមូលដ្ឋានកងទ័ពបរទេសនៅក្នុងប្រទេសកម្ពុជាឡើយ។ មហាសន្និបាតក៏បានប្រកាសពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលថ្មី ក្នុងការកសាងសង្គមដែលគ្មានវណ្ណៈ គ្មានការកេងប្រវ័ញ្ច ហើយជាសង្គមមួយដែលប្រជាជនទាំងអស់រួមគ្នាកសាង និងការពារប្រទេស[២៣៣៩]។ ទោះបីជា អង្គជំនុំជម្រះជឿជាក់ថា មិនមានភស្តុតាងដែលបង្ហាញថាមហាសន្និបាតនេះពិតជាបានប្រារព្ធឡើងក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា មានរបាយការណ៍ស្តីពីសេចក្តីសម្រេចដែលស្រដៀងទៅនឹងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ[២៣៤០] និងតំណាងឲ្យមាគ៌ានយោបាយដែលបានសម្រេចដោយបក្សកុម្មុយនីស្តកម្ពុជា។

៧៤៣. ក្នុងរយៈពេលប្រមាណជាដប់ថ្ងៃ ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ប៉ុល ពត នួន ជា និង ខៀវ សំផន ព្រមទាំងអ្នកដទៃទៀតដែលរួមមានទាំងតំណាងមកពីគ្រប់ភូមិភាគ បានជួបប្រជុំគ្នានៅព្រះវិហារព្រះកែវមរកត ដើម្បីស្តាប់ទឡ្ហីករណ៍ចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ព្រមទាំងមានការផ្តល់អាទិភាពទៅលើតម្រូវការក្នុងការកសាង និងការពារប្រទេសយ៉ាងឆាប់រហ័ស តាមរយៈ

---

[២៣៣៨] អង្គជំនុំជម្រះសាលាដំបូងមិនជឿជាក់ថា មហាសន្និបាតនេះពិតជាបានប្រារព្ធឡើងនោះឡើយ (ផ្នែកទី ៨៖ តួនាទីនិងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៧)។

[២៣៣៩] កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00775902-007759004 (មហាសន្និបាតជាតិពិសេសដែលបានប្រព្រឹត្តទៅកាលពីចុងខែមេសា ឆ្នាំ ១៩៧៥ បានបញ្ជាក់ថា កម្មករ កសិករ បានចូលរួមក្នុងបដិវត្ត ហើយក៏ត្រូវទទួលបានផលពីបដិវត្តផងដែរ។ បំណងប្រាថ្នារបស់យើង គឺ កសាងសង្គមមួយដែលមិនមានវណ្ណៈ គ្មានការជិះជាន់ ហើយជាសង្គមមួយដែលប្រជាជនទាំងអស់រួមគ្នាបង្កបង្កើនផល និងការពារជាតិ)។ *កម្ពុជារៀបចំ “មហាសន្និបាតពិសេស”* (សារព័ត៌មាន The Guardian) ឯកសារ E3/3722 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១-៤, ERN (ភាសាខ្មែរ) S 00656237-00656240 (អ្នកចូលរួមមហាសន្និបាតពិសេស បានអនុម័តជាឯកច្ឆន្ទលើសេចក្តីប្រកាសដែលសង្កត់ធ្ងន់ទៅលើតួនាទីដ៏សំខាន់របស់កសិករ និងការលុបបំបាត់វណ្ណៈ)។

[២៣៤០] ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា មួយឆ្នាំបន្ទាប់មក ឯកសារ E3/2657 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៥, ERN (ភាសាខ្មែរ) 00538790 (រដ្ឋធម្មនុញ្ញថ្មី គឺដូចគ្នានឹងសេចក្តីសម្រេចរបស់មហាសន្និបាតពិសេសខែ មេសា ឆ្នាំ ១៩៧៥)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា (សម្រាប់ការពិគ្រោះយោបល់រវាងប្រទេសបារាំង និងសហភាពសូវៀត) ឯកសារ E3/2668 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២, ERN (ភាសាខ្មែរ) 00491785 (រដ្ឋធម្មនុញ្ញ គឺប្រហាក់ប្រហែលខ្លាំងទៅនឹងកម្មវិធីនយោបាយដែលបានអនុម័តដោយមហាសន្និបាតពិសេសនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥)។

ការបង្កើតសហករណ៍ និងការកសាងទំនប់ និងប្រឡាយ[២៣៤១]។ បន្ទាប់ពីនោះ នៅក្នុងអំឡុងពេលពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ប៉ុល ពត ខៀវ សំផន អៀង ធីរិទ្ធ សុន សេន និងអ្នកដទៃទៀត បានចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិចក៏មួយដែរ ដែលប្រារព្ធឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ឬក៏នៅវិទ្យាស្ថានបច្ចេកទេសខ្មែរ-សូវៀត។ នួន ជា ប៉ុល ពត និងអ្នកផ្សេងទៀតបានបង្គាប់ដល់តំណាងទាំងអស់ដែលមកពីគ្រប់អង្គភាពទ័ព ព្រមទាំងលេខាស្រុក តំបន់ ភូមិភាគឱ្យរៀបចំបង្កើតសហករណ៍ លុបបំបាត់ទ្រព្យសម្បត្តិឯកជន លុបបំបាត់រូបិយប័ណ្ណ និងបិទទីផ្សារព្រមទាំងកសាងទំនប់ ប្រឡាយ[២៣៤២]។

---

[២៣៤១] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៥-១៦ (គណៈកម្មាធិការមជ្ឈិម បានជួបប្រជុំក្នុងខែ មេសា ឬ ឧសភា នៅព្រះវិហារព្រះកែវមរកត។ ប៉ុល ពត បានប្រកាសពីការចាប់ផ្តើមបដិវត្តសង្គមនិយម ហើយបានបញ្ជាក់ពីការបញ្ចប់នៃរណសិរ្សរួបរួម។ ដីធ្លីបានក្លាយជាទ្រព្យរួម ហើយទំនប់ និងប្រឡាយត្រូវកសាងឱ្យបានលឿន)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៧ ERN (ភាសាខ្មែរ) 00156618 (ក្នុងអំឡុងពេលប្រជុំនៅព្រះវិហារព្រះកែវមរកត មានការពន្យល់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ែចាម តុន ហៅ ភី ភួន) ទំព័រ ៥៧-៥៩ (មានរយៈពេលប្រហែលជាដប់ថ្ងៃនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នៅព្រះវិហារព្រះកែវមរកត មេដឹកនាំភូមិភាគ បានចូលរួមវគ្គរៀន សូត្រ។ ប៉ុល ពត និង នួន ជា ដឹកនាំកិច្ចប្រជុំ ព្រមទាំងសង្ខេបពីស្ថានភាព និងគូសវាសពីផែនការសម្រាប់បដិវត្តសង្គមនិយមដែលរួមមាន ការកសាង និងការពារប្រទេស ព្រមទាំងការបង្កើតសហករណ៍)។

[២៣៤២] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ២០-២២, ២២-២៤, ២៥-៣០, ៣៦-៣៨, ៤៦-៤៨, ៤៩-៥០ (សាក្សីមានវត្តមាននៅក្នុងកិច្ចប្រជុំដែលមានរយៈពេលបីថ្ងៃនៅភ្នំពេញ។ គាត់មិនចាំច្បាស់ពីកាលបរិច្ឆេទនោះទេ ប៉ុន្តែមិនមែនក្រោយការរំដោះភ្នំពេញយូរនោះទេ គឺប្រហែលត្រឹមដប់ថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ គាត់ត្រូវបានខាងតំបន់បង្គាប់ឱ្យទៅចូលរួម។ មានអ្នកចូលរួមមកពីគ្រប់កន្លែងក្នុងប្រទេស តំណាងឱ្យខាងតំបន់ និង យោធា។ ប៉ុល ពត និង នួន ជា បង្រៀនថា ប្រទេសត្រូវបានរំដោះ ត្រូវដឹកនាំប្រជាជនទៅធ្វើស្រែ ដើម្បីជៀសវាងពីភាពអត់ឃ្លាន។ ពួកគាត់បានពិភាក្សាពីបញ្ហានយោបាយ ការរៀបចំសហករណ៍ ការហាមឃាត់លើរូបិយ-ប័ណ្ណ ការបិទទីផ្សារ ទ្រព្យសម្បត្តិឯកជន ការកសាងប្រព័ន្ធធារាសាស្ត្រ និងការបិទទ្វារវត្តអារាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឯកសារ E3/367 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00251437 (នួន ជា និង ប៉ុល ពត គឺជាអ្នកឧទ្ទេសនាម បើកវគ្គកិច្ចប្រជុំដែលធ្វើឡើងនៅសាលាមិត្តភាពកម្ពុជា-សូវៀត ដែលធ្វើឡើងនៅប្រហែលបួនទៅដប់ថ្ងៃ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឯកសារ E3/384 ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00345906-00345907 (បង្កើតសហករណ៍)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (ខាំ ផាន់) ទំព័រ ២៧-២៩ (ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ មានមិទ្ទិញមួយដែលធ្វើឡើងនៅខាងក្រៅស្តាតអូឡាំពិច ដែលមានអ្នកចូលរួមរាប់ម៉ឺននាក់ មកពីគ្រប់កន្លែងក្នុងប្រទេស)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ (ខាំ ផាន់) ទំព័រ ៧២-៧៣ (ឪពុករបស់ ខាំ ផាន់ បានចូលរួម

៧៤៤. ចន្លោះពីខែ មិថុនា ដល់ខែ សីហា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំទាំងអស់ស្ថិតនៅក្នុងទីក្រុងភ្នំពេញ បានរៀបចំ និងបង្កើតក្រសួង និងមន្ទីររៀងៗខ្លួន[២៣៤៣]។ មន្ទីរ និងក្រសួងទាំងនេះដំណើរការដោយស្ថិតក្រោមការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍[២៣៤៤]។ នៅពេលដែលក្រសួង មន្ទីរសំខាន់ៗត្រូវបានបង្កើតរួចហើយ ថ្នាក់ដឹកនាំបក្សបានបង្កើនល្បឿននៃការប្រឹងប្រែងរបស់ខ្លួនក្នុងការកសាង និងការពារប្រទេស និងជំរុញការតស៊ូវណ្ណៈ[២៣៤៥]។

---

កិច្ចប្រជុំនៅពេលចូលឆ្នាំខ្មែរ និងនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នៅទីក្រុងភ្នំពេញ)។ កិច្ចសម្ភាសន៍ជាមួយ ជា ស៊ីម ដោយលោក Stephen HEDER ឯកសារ E3/1568 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713924-00713928 (មានកិច្ចប្រជុំថ្នាក់ជាតិនៅទីក្រុងភ្នំពេញថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ជាមួយលេខាស្រុក លេខាតំបន់ និងលេខាភូមិភាគ។ ការប្រជុំនេះមានរយៈពេលប្រាំថ្ងៃ។ នួន ជា ឡើងថ្លែងនៅថ្ងៃទីមួយ ប៉ុល ពត ឡើងថ្លែងនៅថ្ងៃទីពីរ។ របៀបវារៈនៃកិច្ចប្រជុំនោះរួមមានមាគ៌ាបក្ស និងគោលការណ៍កសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ។ ក្នុងរយៈពេល ១០ ទៅ ១៥ឆ្នាំ បក្សមានផែនការធ្វើទំនើបកម្មវិស័យកសិកម្មតាមរយៈមធ្យោបាយវិទ្យាសាស្ត្រ ដោយការរៀបចំប្រព័ន្ធធារាសាស្ត្រ ទំនប់ ប្រឡាយ និងធ្វើទំនើបកម្មឧស្សាហកម្ម។ ប៉ុល ពត និង នួន ជា បាននិយាយអំពីចំណុចទាំងប្រាំបីដែលរួមមាន ការបង្កើតសហករណ៍ ការបិទទីផ្សារ និងការលុបបំបាត់រូបិយប័ណ្ណ)។ កិច្ចសម្ភាសន៍ជាមួយ ហេង សំរិន ដោយ Stephen HEDER ឯកសារ E3/1568 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713947-00713949 (នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ មានកិច្ចប្រជុំមួយនៅស្តាតអូឡាំពិកដើម្បីទទួលផែនការពីមជ្ឈិម សម្រាប់អនុវត្តទូទាំងប្រទេស ហើយកិច្ចប្រជុំនេះចូលរួមដោយកម្មាភិបាល ទាំងយោធា និងស៊ីវិល។ ផែនការនោះគឺពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងការមិនប្រើប្រាស់រូបិយប័ណ្ណ)។

[២៣៤៣] បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Elizabeth BECKER ឯកសារ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578892-00578893 (ក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ កម្មករ និងក្រសួងបានត្រឡប់មកភ្នំពេញវិញ)។ អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00062461-00062462 (អៀង សារី មានតួនាទីបី៖ បង្កើតក្រសួងការបរទេស រៀបចំ និងបោសសម្អាតផ្ទះអ្នកដែលត្រូវបានជម្លៀស ដើម្បីឲ្យអ្នកដែលត្រូវរស់នៅភ្នំពេញមានទីកន្លែងស្នាក់នៅសមរម្យ និងរក្សាទំនាក់ទំនងឲ្យល្អបំផុតតាមដែលអាចធ្វើបានជាមួយចិន)។ *សូមមើលផងដែរ* ទូរលេខក្រសួងការបរទេសនៃសហរដ្ឋ-អាមេរិក កម្មវត្ថុ៖ សេចក្តីប្រកាសព័ត៌មានអំពីឧបនាយករដ្ឋមន្ត្រីថ្មីពីររូប នៅកម្ពុជា ឯកសារ E3/3348 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00635936 (នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៥ អៀង សារី ត្រូវបានប្រកាសថាជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការបរទេស និង សុន សេន គឺជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ)។

[២៣៤៤] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៧។

[២៣៤៥] អត្ថបទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១-៤ ERN (ភាសាខ្មែរ) 00062452-00062455 (បដិវត្តឆាប់រហ័សគឺជាគំនិតមួយដែលមានតាំងពីដំបូង ប៉ុន្តែនៅចុងឆ្នាំ ១៩៧៥ ទើបថ្នាក់ដឹកនាំបក្សសម្រេចអនុវត្ត "កុម្មុយនីស្តភាវូបនីយកម្មយ៉ាងឆាប់រហ័ស" ដើម្បីកុំឲ្យវៀតណាមអាច

៧៤៥. គណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានចាប់ផ្ដើមឡើងក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧៥ ដែលរួមមានទាំងសមាជិកពេញសិទ្ធិ គឺ នួន ជា ប៉ុល ពត អៀង សារី សោ ភឹម តា ម៉ុក វន វេត (ជាសមាជិកពេញសិទ្ធិ ឬ សមាជិកត្រៀម) និង សុន សេន (ជាសមាជិកត្រៀម ឬ សមាជិកបំរុង) ផងដែរនោះ បានជួបប្រជុំទៀងរាល់សប្ដាហ៍ ហើយនៅក្នុងពេលបន្ទាន់ ការប្រជុំនេះអាចលើសពីម្ដងក្នុងមួយសប្ដាហ៍[២៣៤៦]។ ខៀវ សំផន ក៏ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នេះជាទៀងទាត់ផងដែរ[២៣៤៧]។ នៅចុងខែ សីហា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានចុះទស្សនកិច្ចនៅខេត្តបាត់ដំបង និងខេត្តពោធិសាត់ (ភូមិភាគពាយ័ព្យ) ដើម្បីទទួល និងវាយតម្លៃរបាយការណ៍ពីតំបន់នានា ពាក់ព័ន្ធនឹងស្ថានភាពប្រជាជន ខ្មាំង យោធា កសិកម្ម និងឧស្សាហកម្ម[២៣៤៨]។ បន្ទាប់ពីនោះ គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចបញ្ជូនមនុស្សប្រមាណពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ ទៅកាន់ខេត្តបាត់ដំបង និងពោធិសាត់ (ភូមិភាគពាយ័ព្យ)។ ដោយសង្កេតឃើញថា “សមាសភាពអាក្រក់” នៅមានក្នុងចំណោម “ប្រជាជនថ្មី” នោះ ទើបគណៈកម្មាធិការអចិន្ត្រៃយ៍ពិចារណាឃើញថាសហករណ៍មានគោលដៅ “ស្រូប” “ប្រជាជនថ្មី” ហើយបានបង្គាប់ឲ្យបន្ត “ស្មារតីប្រុងប្រយ័ត្ន” ប្រឆាំង “សមាសភាពមិនល្អ”។

៧៤៦. របាយការណ៍ទាក់ទងនឹងដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ទៅកាន់ភូមិភាគពាយ័ព្យមិនបានបញ្ជាក់ថាអ្នកណាខ្លះបានចូលរួមក្នុងដំណើរទស្សនកិច្ចនោះទេ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នួន ជា មានវត្តមាននៅក្នុងប្រទេសកម្ពុជានៅចុងខែ សីហា ឆ្នាំ ១៩៧៥ និងមានសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយបំផុត ហើយគាត់គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ជាយូរមកហើយ និងបានបំពេញតួនាទីយ៉ាងសំខាន់ និងជាបន្តបន្ទាប់នៅក្នុងការធ្វើឲ្យគោលនយោបាយបក្សមានការរីកចំរើន[២៣៤៩]។ ទោះបីជាមិនមានភ័ស្តុតាង

---

យកកម្ពុជាបាន)។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្ដាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២-៦ ERN (ភាសាខ្មែរ) 00072401-00072405។

[២៣៤៦] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣។

[២៣៤៧] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៦។

[២៣៤៨] របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/216 ចុះថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១ ដល់ ២ ERN (ភាសាខ្មែរ) 00008485-00008486។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥។

[២៣៤៩] ផ្នែកទី ៧៖ តួនាទី និង មុខងាររបស់ នួន ជា កថាខណ្ឌ ៣១៣-៣១៧, ៣៤៨។

បញ្ជាក់ថា នួន ជា បានធ្វើដំណើររួមគ្នាជាមួយនឹងសមាជិកដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ទៅកាន់ភូមិភាគពាយ័ព្យ នៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា យ៉ាងហោចណាស់ គាត់បានចូលរួមនៅក្នុងការរៀបចំ និងសម្រេចទៅលើផែនការ និងគោលនយោបាយនានា ដែលត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុអំពីទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោយពីដំណើរទស្សនកិច្ចនេះរួចមក។

៧៤៧. ម្យ៉ាងវិញទៀត ខៀវ សំផន កំពុងតែធ្វើដំណើរទៅកាន់ប្រទេសចិន និងប្រទេសកូរ៉េខាងជើង នៅចុងខែ សីហា ឆ្នាំ ១៩៧៥ ខណៈពេលដែលគណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើដំណើរទស្សនកិច្ចទៅកាន់ភូមិភាគពាយ័ព្យ[២៣៥០]។ មិនមានភ័ស្តុតាងដែលបញ្ជាក់ថា គាត់បានចូលរួមដោយផ្ទាល់នៅក្នុងការរៀបចំផែនការដែលឈានទៅដល់ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅចុង ខែ សីហា ឆ្នាំ ១៩៧៥ នោះទេ។ យ៉ាងណាក៏ដោយ ក្រោយពីបានពិចារណាទៅលើសិទ្ធិអំណាចរបស់គាត់ខាងផ្នែកសេដ្ឋកិច្ច ការចូលរួមប្រជុំជាទៀងទាត់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងនៅក្នុងស្ថាប័នដទៃទៀតរបស់មជ្ឈិមបក្ស និងការចូលរួមជាបន្តបន្ទាប់នៅក្នុងការរៀបចំគោលនយោបាយបក្សនៅគ្រប់ពេលក្នុងការធ្វើបដិវត្តប្រជាធិបតេយ្យ និងសង្គមនិយមនោះ អង្គជំនុំជម្រះជឿជាក់ថា ក្រោយពីគាត់ត្រឡប់មកដល់ប្រទេសកម្ពុជាវិញភ្លាមៗ គាត់បានទទួលការជូនដំណឹងអំពីដំណើរទស្សនកិច្ចនេះ ការកត់សម្គាល់ផ្សេងៗដែលបានលើកឡើង និងផែនការផ្សេងៗដែលបានសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៅចុងខែ សីហា ឆ្នាំ ១៩៧៥។

៧៤៨. ឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥ បានលើកឡើងពីសារៈសំខាន់ក្នុងការជំរុញ "ចលនាមហាជននៅក្នុងការអនុវត្តមាគ៌ាកសិកម្មរបស់បក្ស" និងបានបញ្ជាក់ថា កន្លែងខ្លះ ដែលប្រមូលកម្លាំងប្រជាជនបានផុសផុល "ប្រជាជនបានសម្រុកបង្កបង្កើនផលយ៉ាងសកម្ម ទាំងយប់ទាំងថ្ងៃ មិនថាភ្លៀង ឬខ្យល់ឡើយ"។ ឯកសារនេះក៏បានកត់សម្គាល់ផងដែរថា ប្រជាជន "ខំធ្វើការណាស់ ១ ថ្ងៃ ធ្វើការ ១៥ ម៉ោង" ហើយថា ការប្រឹងប្រែងធ្វើការបែបនេះ "នាំឲ្យប៉ះពាល់ដល់សុខភាពប្រជាជន"។ ឯកសារនេះបានកំណត់ និងបញ្ជាក់ យ៉ាងច្បាស់អំពីតម្រូវការក្នុងការកសាងទំនប់ ភ្លឺ និងប្រឡាយ ដោយរួមទាំង ការធ្វើការជាក្រុមធំ និងដោយដៃ ដោយមិនប្រើប្រាស់គ្រឿងម៉ាស៊ីន ឬឧបករណ៍អ្វីឡើយ ព្រមទាំងគោលដៅផលិតឲ្យបាន ៣ តោន ក្នុង ១ ហិកតា ការចាំបាច់ក្នុងការនាំស្រូវចេញដើម្បីបង្កើតមូលធន ការខ្វះខាតថ្នាំពេទ្យ និងចំណីអាហារ ដែលប៉ះពាល់ ជា

[២៣៥០] *សូមមើល* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៨។

ពិសេសដល់ "ប្រជាជនថ្មី" ការផ្លាស់ទីលំនៅដែលបានគ្រោងទៅខេត្តបាត់ដំបង និងពោធិសាត់ (ភូមិភាគពាយ័ព្យ) ព្រះវិហារ (តំបន់១០៣) និងកំពង់ធំ (ភូមិភាគកណ្ដាល (ខត្តរចាស់)) ការចូលរួមរបស់គណៈកម្មាធិការពាណិជ្ជកម្មក្នុងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនរាប់សែននាក់ និងភាពចាំបាច់ក្នុងការគិតគូរដល់ "ប្រជាជនចាស់" ដោយសារតែ "ប្រជាជនថ្មី" មិនអាចត្រូវបាន "ធានា"[២៣៥១]។ ឯកសារនេះមិនបានបញ្ជាក់ឈ្មោះអ្នកនិពន្ធ ឬអ្នកដែលទទួលខុសត្រូវចំពោះផែនការ និងគោលនយោបាយដែលបានកំណត់នោះទេ ហើយឯកសារនេះក៏មិនបានបង្ហាញថា តើផែនការ និងគោលនយោបាយទាំងនេះ ត្រូវបានសម្រេចនៅពេលណានោះដែរ។

៧៤៩. ទោះជាយ៉ាងណាក៏ដោយ គោលបំណងជាក់លាក់របស់ឯកសារនេះគឺដើម្បីពិនិត្យមើលការអនុវត្តមាគ៌ាបក្សក្នុងការកសាងប្រទេស។ ឯកសារនេះក៏បានផ្ដល់ចំណុចលម្អិតបន្ថែម និងការបង្គាប់ណែនាំអំពីការផ្លាស់ទីលំនៅប្រជាជន ព្រមទាំងលក្ខខណ្ឌនៅទីជនបទ[២៣៥២]។ យោងតាម ខៀវ សំផន គោលបំណងរួមរបស់គណៈកម្មាធិការមជ្ឈិម គឺ ដើម្បីធ្វើការវិភាគ ព្រមទាំងដាក់ចេញនូវសេចក្ដីណែនាំបែបនេះ[២៣៥៣]។ អៀង សារី បានបញ្ជាក់ថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំបក្ស កាលពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនោះក៏មានវត្តមានរបស់ ខៀវ សំផន ប៉ុល ពត នួន ជា សោ ភឹម សុន សេន តា ម៉ុក វ៉ន វេត រស់ ញឹម កុយ ធួន និងមេបញ្ជាការយោធា

---

[២៣៥១] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ដល់ ៣១ ERN (ភាសាខ្មែរ) 00072367-00072397 (*សូមមើលជាពិសេស* ERN (ភាសាខ្មែរ) 00072369-00072370, 00072372-00072373, 00072376-00072377, 00072395-00072397)។ សូមមើលផងដែរ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤-៦០៩។

[២៣៥២] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ឯកសារ E3/781 ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ដល់ ៣១ ERN (ភាសាខ្មែរ) 00072367-00072397 (*សូមមើលជាពិសេស* ERN (ភាសាខ្មែរ) 00072369-00072370, 00072372-00072373, 00072376-00072377, 00072395-00072397)។ សូមមើលផងដែរ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤-៦០៩។

[២៣៥៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៤ (គណៈកម្មាធិការមជ្ឈិម បានជួបគ្នាដើម្បីពិភាក្សាពីការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីចេញសេចក្ដីណែនាំ កែតម្រូវ "ការរំលោភបំពាន" និងដើម្បីលើកកម្ពស់ស្ថានភាពនៅក្នុងទីជនបទ)។

មួយចំនួនទៀត ដែលពិភាក្សាអំពីបញ្ហាការពារ កសិកម្ម “បញ្ហាទឹក” និងឧស្សាហកម្ម[២៣៥៤]។ អ្នកជំនាញ លោក Philip SHORT ក៏បានសរសេររៀបរាប់ពីកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមកាលពីពាក់កណ្តាលខែ កញ្ញា ដែលពិភាក្សាពីបញ្ហាកសិកម្ម សង្គមកិច្ច និងការការពារ បើទោះបីជាប្រភពព័ត៌មានរបស់គាត់សម្រាប់ចំណុចនេះមិនមានភាពច្បាស់លាស់ក្តី[២៣៥៥]។ លើសពីនេះទៀត ទង់បដិវត្តចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ បានលើកឡើងថា “មហាសន្និបាតរបស់មជ្ឈិមបក្ស” បានសម្រេចជាឯកច្ឆន្ទទៅលើគោលដៅផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា តាំងពីមុនខែ វិច្ឆិកា ឆ្នាំ ១៩៧៥[២៣៥៦] ដែលជាគោលដៅផលិតកម្មដែលត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ ជាចុងក្រោយ អ្នកជំនាញលោក David CHANDLER បានពន្យល់ថាផែនការសេដ្ឋកិច្ចរួមដែលបានលេចឡើងនៅចុងឆ្នាំ ១៩៧៥ ហើយនាំឲ្យមានការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយ ទៅកាន់ទីជនបទមួយទៀត ជាពិសេសនៅដើមឆ្នាំ ១៩៧៦ នោះ គឺជាលទ្ធផលនៃការដឹកនាំរួមរបស់មជ្ឈិម “ដែលពេលខ្លះស្ថិតនៅចំណុចស្នូលរបស់គណៈកម្មាធិការមជ្ឈិម”[២៣៥៧]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា មានកិច្ចប្រជុំថ្នាក់ដឹកនាំបក្សមួយនៅដើមខែ កញ្ញា ឆ្នាំ ១៩៧៥ ពាក់ព័ន្ធទៅនឹងគោលនយោបាយសេដ្ឋកិច្ច ហើយដែលក្រោយមកត្រូវបានពន្យល់នៅក្នុងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥។ ដោយកត់សម្គាល់ពីតួនាទីក្នុងការសម្រេចចិត្តថ្នាក់មជ្ឈិមរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមតាំងពីយូរមកហើយនោះ[២៣៥៨] អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា មានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។

---

[២៣៥៤] អត្ថបទសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ២ ដល់ ៥ ERN (ភាសាខ្មែរ) 00062453-00062456។ ប្រតិចារឹកថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៣ (Stephen HEDER) ទំព័រ ៤៤-៤៥ (HEDER បញ្ជាក់ពីភាពត្រឹមត្រូវនៃអត្ថបទសម្ភាសន៍ ឯកសារ E3/89)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤ ជើងទំព័រ ១៨៧៥។

[២៣៥៥] សៀវភៅនិពន្ធដោយ Philip SHORT៖ *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ 305-8 ERN (ភាសាអង់គ្លេស) 00396513-16។

[២៣៥៦] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១៥-២៥ ERN (ភាសាខ្មែរ) 00063245-00063250។

[២៣៥៧] ប្រតិចារឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ (David CHANDLER) ទំព័រ៥៦-៥៧, ៥៩-៦១។

[២៣៥៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៣-៣១៦, ៣៤៨។

៧៥០. ពាក់ព័ន្ធទៅនឹងវត្តមានរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា គាត់បានត្រឡប់មកប្រទេសកម្ពុជាវិញ យ៉ាងយូរត្រឹមថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ បន្ទាប់ពីបានទៅទស្សនកិច្ចប្រទេសចិន និង កូរ៉េខាងជើង[២៣៥៩]។ អៀង សារី បានអះអាងថា គាត់បានចូលរួមក្នុងកិច្ចប្រជុំនេះ។ ដោយសារតែមានការរាយការណ៍ថា អៀង សារី បានចូលរួមពិធីបដិសណ្ឋារកិច្ចនៅទីក្រុងញូវយ៉ក នៅល្ងាចថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដូច្នេះ បើទោះបីជាគាត់បានចាកចេញមួយថ្ងៃបន្ទាប់មកនោះ ក៏គាត់មិនអាចត្រឡប់មកដល់ប្រទេសកម្ពុជានៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដែរ[២៣៦០]។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា អៀង សារី ត្រូវបានរាយការណ៍ថាស្ថិតនៅក្នុងទីក្រុងប៉ារីស យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៥[២៣៦១]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលយ៉ាងលឿនបំផុត គឺ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ និងយ៉ាងយូរបំផុត ត្រឹមថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៥ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើការសន្និដ្ឋានដោយប្រាកដប្រជាថា កិច្ចប្រជុំនេះត្រូវបានធ្វើឡើងនៅក្រោយពេលដែល ខៀវ សំផន បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ នោះទេ ហើយដែរគាត់មានឱកាសក្នុងការចូលរួមនៅក្នុងកិច្ចប្រជុំនោះ។

៧៥១. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកពីការសម្រេចរបស់ខ្លួនទាក់ទងទៅនឹងការសិក្សា បទពិសោធន៍ក្នុងវិស័យសេដ្ឋកិច្ចរបស់ ខៀវ សំផន ក៏ដូចជាតួនាទីដ៏សំខាន់របស់គាត់ក្នុងវិស័យសេដ្ឋកិច្ចដែលគាត់បានអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[២៣៦២]។ ជាការពិត ខៀវ សំផន បានពន្យល់ដល់អង្គជំនុំជម្រះសាលាដំបូងថា ជាទូទៅ គាត់ត្រូវបានគេអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់មជ្ឈិមបក្ស ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ប្រទេស[២៣៦៣]។ អង្គជំនុំជម្រះសាលាដំបូង

---

[២៣៥៩] *សូមមើល* ផ្នែកទី ១៤៖ សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ កថាខណ្ឌ ៧៥៨។

[២៣៦០] *សូមមើលជាឧទាហរណ៍ កិច្ចស្វាគមន៍របស់ឥណ្ឌូចិន* (សារព័ត៌មាន The Guardian) ឯកសារ E3/3729 ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) S 00810824 (អៀង សារី បានចូលរួមក្នុងពិធីបដិសណ្ឋារកិច្ច នៅល្ងាចថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥)។

[២៣៦១] *សូមមើលជាឧទាហរណ៍* ការបញ្ចប់ទស្សនកិច្ចឯកជនរបស់ អៀង សារីនៅទីក្រុងប៉ារីស (AFP) ឯកសារ E3/3302 ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00705323 (អៀង សារី គ្រោងនឹងចាកចេញពីទីក្រុងប៉ារីស នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៥។

[២៣៦២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥១-៣៥៥, ៤០០, ៤០៦-៤០៧។

[២៣៦៣] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន), ទំព័រ ៦៤-៦៥។

បានរកឃើញរួចហើយថា គាត់បានចូលរួមកិច្ចប្រជុំកាលពីខែ មិថុនា ឆ្នាំ ១៩៧៤ ដែលក្នុងកិច្ចប្រជុំនេះមានការពិភាក្សាពីការជម្លៀសប្រជាជនចេញពីទីក្រុង ហើយគាត់ក៏បានចូលរួមក្នុងកិច្ចប្រជុំនៅចុងខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនេះ បានដោះស្រាយលើបញ្ហាគោលនយោបាយសេដ្ឋកិច្ចដទៃទៀត រួមទាំងការបង្កើតសហករណ៍ផងដែរ[២៣៦៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន ដែលជាសមាជិកត្រៀមរបស់គណៈកម្មាធិការមជ្ឈិម ក្នុងខែកញ្ញា ឆ្នាំ ១៩៧៥ ពិតជាបានចូលរួមក្នុងការបង្កើតផែនការផ្សេងៗដែលត្រូវបានលើកឡើងនៅក្នុងឯកសារគោលនយោបាយ ខែ កញ្ញា ឆ្នាំ ១៩៧៥។

៧៥២. នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានអនុម័ត និងកំណត់ការទទួលខុសត្រូវសម្រាប់ ខៀវ សំផន (ផ្នែកពាណិជ្ជកម្ម គណនេយ្យ និងកំណត់តម្លៃ ការទំនាក់ទំនងជាមួយរណសិរ្សរួបរួមជាតិ/រាជរដ្ឋាភិបាលរួបរួមជាតិ) សម្រាប់ នួន ជា (ផ្នែកការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ ដោយរួមទាំងវគ្គរៀនសូត្រ និងការជ្រើសតាំង) សម្រាប់ អៀង សារី (ផ្នែកកិច្ចការបរទេស) សម្រាប់ ប៉ុល ពត (ទទួលខុសត្រូវរួមលើផ្នែកយោធា និងសេដ្ឋកិច្ច) សម្រាប់ កុយ ធួន (ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស) សម្រាប់ សុន សេន (សេនាធិការ និងសន្តិសុខ) សម្រាប់ វន វេត (ឧស្សាហកម្ម រថភ្លើង និងនេសាទ) សម្រាប់ អៀង ធីរិទ្ធ (វប្បធម៌ សង្គមកិច្ច និងកិច្ចការបរទេស) និងសម្រាប់ យុន យ៉ាត (ផ្នែកឃោសនាការ និងអប់រំ)[២៣៦៥]។ គណៈកម្មាធិការអចិន្ត្រៃយ៍ក៏បានបញ្ជាក់ផងដែរថា មាគ៌ាទូទៅគឺត្រូវកសាង និងការពារប្រទេស ព្រមទាំងរៀបចំកម្លាំងមហាជន[២៣៦៦]។

៧៥៣. ទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ បានរាយការណ៍ថា សន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយ ដែលត្រូវបានចូលរួមដោយកម្មាភិបាលផ្នែកសេដ្ឋកិច្ច បានកំណត់ថា ទាំងអស់គ្នាត្រូវប្រឹងប្រែងធ្វើការដើម្បីកសាង និងការពារប្រទេសឲ្យបានឆាប់ ដើម្បីសម្រេចឲ្យបានសេដ្ឋកិច្ចខាងកសិកម្មបែបទំនើបក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ ដោយបានបញ្ជាក់

---

[២៣៦៤] *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤២, ១៤៥-១៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥, ៧៤០-៧៤១, ៧៤៣។

[២៣៦៥] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣២ ។

[២៣៦៦] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ឯកសារ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១៦-១៧, ERN (ភាសាខ្មែរ) 00019123-00019124។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។

អំពីគោលដៅផលិតកម្ម ៣ តោន ក្នុង ១ ហិកតា សម្រាប់ឆ្នាំ ១៩៧៦។ សន្និបាតក៏បានសម្រេចថា ការប្រយុទ្ធប្រឆាំងនឹងពួកចក្រពត្តិនិយម និង "បរិវារបស់ពួកវា" នៅតែជាការចាំបាច់ បានជំរុញការបង្កើនការតស៊ូវណ្ណៈ និងការពង្រីកសហករណ៍ ហើយបានណែនាំថាត្រូវរៀបចំកម្លាំងទាំងអស់សម្រាប់គម្រោងបន្តបន្ទាប់ទៅតាមរដូវកាល[២៣៦៧]។ ទោះបីជាមិនមានភស្តុតាងផ្សេងក្រៅតែពីទស្សនាវដ្តីទង់បដិវត្ត ដែលបង្ហាញថាសន្និបាតនេះត្រូវបានប្រារព្ធឡើងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ទស្សនាវដ្តីនេះបានពន្យល់ថា ផែនការ និងគោលនយោបាយដែលទាក់ទងទៅនឹងទិសដៅនៃការបង្កបង្កើនផលស្រូវឲ្យបាន ៣ តោន ក្នុង ១ ហិកតា បានអនុមត័នៅក្នុងសន្និបាតដែលត្រូវបានសម្រេច និងយល់ព្រមដោយ "សន្និបាតមជ្ឈិមបក្ស"[២៣៦៨]។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាឃើញផងដែរថា សេចក្តីសម្រេចរបស់សន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយលើបញ្ហានេះ បានឆ្លុះបញ្ចាំងដូចគ្នាពីខ្លឹមសារនៃឯកសារគោលនយោបាយ ខែកញ្ញា ឆ្នាំ ១៩៧៥។ ដោយពិចារណាទៅលើការយល់ឃើញខាងលើរបស់ខ្លួនពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនានាដែលចាប់ផ្តើមយ៉ាងយូរបំផុតត្រឹមខែ ឧសភា ឆ្នាំ ១៩៧៥ ហើយបន្តរហូតដល់ចុងឆ្នាំ ១៩៧៥ នោះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សេចក្តីសម្រេច ដែលក្រោយមកត្រូវបានផ្សព្វផ្សាយ ដែលជាលទ្ធផលនៃសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយនោះ តំណាងឲ្យគោលនយោបាយដែលបានអនុម័តដោយថ្នាក់ដឹកនាំបក្ស រួមទាំង ខៀវ សំផន ផងដែរ។

### ១៤.១.៤.២ ការចងក្រងបង្កើតមាគ៌ាបក្ស

៧៩៤. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៥ ខៀវ សំផន ត្រូវបានអះអាងថាបានដឹកនាំសន្និបាតជាតិ ដោយគាត់បានធ្វើការពន្យល់អំពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យថ្មី។ សុន្ទរកថារបស់ ខៀវ សំផន បានផ្តោតទៅលើចំណុចជាច្រើន ក្នុងនោះរួមមានចំណុចដែលថា ប្រជាជនទាំងអស់អាចធ្វើការជា

---

[២៣៦៧] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១៥-៣៤, ERN (ភាសាខ្មែរ) 00036245-00063256។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៥។

[២៣៦៨] *ទស្សនាវដ្តី ទង់បដិវត្ត* ឯកសារ E3/748 ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ទំព័រ ១៥-៣៤, ERN (ភាសាខ្មែរ) 00036245-00063256 (បញ្ជាក់បន្ថែមថា "មហាសន្និបាតរបស់មជ្ឈិមបក្ស" បានសម្រេចជាឯកច្ឆន្ទលើផែនការបីតោនក្នុងមួយហិកតា តាំងពីមុនមហាសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយ ក្នុងដើមខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយបញ្ជាក់ថា សេចក្តីសម្រេចរបស់មហាសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីមួយត្រូវបានអនុម័តដោយ "មជ្ឈិមបក្ស")។

សម្ហូភាព ទាំងនៅក្នុងរោងចក្រ ឬ នៅតាមវាលស្រែ[២៣៦៩]។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលមានលក្ខណៈដូចទៅនឹងសេចក្ដីសម្រេចរបស់សន្និបាតជាតិពិសេស ដែលត្រូវបានរាយការណ៍ថាបានប្រព្រឹត្តឡើងក្នុងខែ មេសា ឆ្នាំ ១៩៧៥ នោះ[២៣៧០] បានបង្កើតមាគ៌ាបក្ស ដោយធានាឲ្យមានសង្គមមួយដែលគ្មានវណ្ណៈ ហើយជាសង្គមដែលប្រជាជនទាំងអស់ប្រឹងប្រែងដើម្បីបង្កើនផលិតកម្មកសិកម្ម និងក្រោយមកទៀត ឧស្សាហកម្ម ដើម្បីកសាង និងការពារប្រទេស។ គោលនយោបាយទាំងអស់ផ្អែកទៅលើគោលការណ៍ខ្លួនទីពឹងខ្លួន ឯករាជ្យ និងសម្ហូហារូបនីយកម្ម។ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យក៏មានចែងផងដែរពីការបោះឆ្នោតសភាជាតិដើម្បីជ្រើសតាំងប្រមុខរដ្ឋ និងរដ្ឋាភិបាល ដែលត្រូវជំនួសរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[២៣៧១]។

---

[២៣៦៩] *សន្និបាតជាតិត្រូវបានប្រារព្ធឡើង ហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/1356 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៥ ទំព័រ ១-៣, ERN (ភាសាខ្មែរ) 00663892-00663894។ *របាយការណ៍របស់ ខៀវ សំផន* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ៦ ERN (ភាសាខ្មែរ) 00657436។

[២៣៧០] ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា មួយឆ្នាំបន្ទាប់មក ឯកសារ E3/2657 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00538787, ទំព័រ ៥ ដល់៦, ERN (ភាសាខ្មែរ) 00538790-00538791។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា (សម្រាប់ការពិគ្រោះយោបល់រវាងប្រទេសបារាំង និងសហភាពសូវៀត) ឯកសារ E3/2668 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២-៣, ERN (ភាសាខ្មែរ) 00491785-00491786។

[២៣៧១] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/259 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២, ERN (ភាសាខ្មែរ) 00089844 (បុព្វកថា៖ មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ អធិបតេយ្យក្នុងបូរណភាពដែនដីរបស់ខ្លួន ដោយគ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេ គ្មានវណ្ណៈត្រូវគេជិះជាន់។ ជាសង្គមមួយដែលប្រជាជនរួមគ្នាប្រកបការងារ ពលកម្ម បង្កបង្កើនផលកសាងប្រទេស និងការពារប្រទេស។ ជំពូក១ មាត្រា ១៖ កម្ពុជាប្រជាធិបតេយ្យជារដ្ឋឯករាជ្យ មិនចូលបក្សសម្ព័ន្ធ និងមានអធិបតេយ្យក្នុងបូរណភាពដែនដីរបស់ខ្លួន។ កម្ពុជាប្រជាធិបតេយ្យជារដ្ឋរបស់ប្រជាជន កម្មករ កសិករ និងពលករកម្ពុជា។ ជំពូក ២ មាត្រា ២៖ មធ្យោបាយផលិតកម្មសំខាន់ៗ ជាទូទៅជាកម្មសិទ្ធិរួមរបស់រដ្ឋប្រជាជន និងជាកម្មសិទ្ធិរួមរបស់ប្រជាជនសម្ហូភាព។) ទំព័រ ៥ ERN (ភាសាខ្មែរ) 00089845 (ជំពូក ៣ មាត្រា ៣៖ វប្បធម៌របស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីបម្រើភារកិច្ចការពារប្រទេស និងកសាងប្រទេស។ វប្បធម៌នេះប្រឆាំងដាច់ខាតវណ្ណៈជិះជាន់ អាណានិគមនិយម និងចក្រពត្តិនិយម។ ជំពូក ៤ មាត្រា ៤ កម្ពុជាប្រជាធិបតេយ្យ អនុវត្តរបបសម្ហូភាពក្នុងការដឹកនាំ និងការធ្វើការងារ) ទំព័រ ១២ ERN (ភាសាខ្មែរ) 00089849 (ជំពូក ៩ មាត្រា ១៤៖ ប្រជាជនកម្ពុជាគ្រប់រូប មានករណីយកិច្ច ការពារប្រទេស និងកសាងប្រទេស ទាំងអស់គ្នា តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។ ជំពូក ១២ មាត្រា ១៧៖ សញ្ញាជាតិ គឺមានប្រព័ន្ធភ្លឺស្រែ និងប្រឡាយទឹក ជានិមិត្តរូបនៃកសិកម្មជឿនលឿន មានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម), ទំព័រ ១៦ ERN (ភាសាខ្មែរ) 00089851 (ជំពូក ១៦ មាត្រា ២១៖ គោលនយោបាយក្រៅ

៧៩៥. នៅក្នុងមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជាលើកទីបួនក្នុងខែ មករា ឆ្នាំ ១៩៧៦[២៣៧២] ថ្នាក់ដឹកនាំបក្សបានជ្រើសតាំង ខៀវ សំផន ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការមជ្ឈិម[២៣៧៣] ហើយបានអនុម័ត ទៅលើលក្ខន្តិកៈដែលត្រូវបានធ្វើវិសោធនកម្មបន្តិចបន្តួច។ លក្ខន្តិកៈនេះបានចែងថា បក្សកុម្មុយនីស្តកម្ពុជាគឺជាអង្គការកំពូលនៅកម្ពុជា ដែលបញ្ជាទៅលើគ្រប់ការងារទាំងអស់នៅក្នុងការធ្វើបដិវត្តសង្គមនិយម[២៣៧៤]។ បក្ខជន ឬថ្នាក់បក្សណាមួយដែលប្រឆាំងទៅនឹងគោលជំហរអង្គការបក្ស គឺរំលោភបំពានទៅលើគោលការណ៍បក្ស ហើយត្រូវទទួលទណ្ឌកម្ម ដែលរួមមាន ការដកចេញពីតួនាទី និងពីបក្ស[២៣៧៥]។ លក្ខន្តិកៈក៏បានបញ្ជាក់ពីតម្រូវការចាំបាច់ក្នុងការតស៊ូវណ្ណៈប្រជាធិបតេយ្យប្រមូលផ្តុំ ស្មារតីប្រុងប្រយ័ត្នចំពោះខ្មាំង និងការប្រកាន់ខ្ជាប់នូវគោលការណ៍ខ្លួនទីពឹងខ្លួន[២៣៧៦]។ មាគ៌ាបក្សដែលបានចងក្រងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនិងលក្ខន្តិកៈបក្ស

---

ប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ គឺ ផ្អែកលើឯករាជ្យ អព្យាក្រិត មិនចូលបក្សសម្ព័ន្ធ សន្តិភាព។ ប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីខាងក្រៅ មកក្នុងកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា ព្រមទាំងប្រឆាំងដាច់ខាតអំពើវិទ្ធង្សនា ឈ្លានពានគ្រប់បែបយ៉ាងមកលើកម្ពុជាប្រជាធិបតេយ្យ)។

[២៣៧២] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០០។

[២៣៧៣] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣។

[២៣៧៤] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១, ERN (ភាសាខ្មែរ) 00442253 (ក្រោយពីបក្សដឹកនាំ សម្រេចបដិវត្តប្រជាជាតិ ប្រជាធិបតេយ្យបានទាំងស្រុង និងជាស្ថាពរ បក្សបន្តដឹកនាំបដិវត្តសង្គមនិយម និងកសាងសង្គមនិយមតទៅទៀត ដោយផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែក។ បក្សកុម្មុយនីស្តកម្ពុជា គឺជាអគ្គបញ្ជាការ គ្រប់គ្រង និងចាត់ចែងការងារបដិវត្តទាំងអស់), ទំព័រ ៤៩ , ERN (ភាសាខ្មែរ) 00442277 (មាត្រា ២៣ ចែងថា ភារកិច្ចរបស់ គណៈកម្មាធិការមជ្ឈិម គឺ ណែនាំគ្រប់ភូមិភាគ និងតំបន់ ដើម្បីធ្វើសកម្មភាពតាមមាគ៌ានយោបាយបក្ស គោលជំហរ តាមភារកិច្ចការពារប្រទេស)។

[២៣៧៥] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៩, ERN (ភាសាខ្មែរ) 00442262 (មាត្រា ៤ អំពីវិន័យបក្ស)។

[២៣៧៦] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/130 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣, ERN (ភាសាខ្មែរ) 00442254 (បក្សមានទស្សនៈអធន ហើយប្រឆាំងបដិវត្តរបស់អនុធន នាយទុន សក្តិភូមិ ចក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់។ ដោយចាត់តាំងឡើងតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ បក្សប្រឆាំងដាច់ខាតនឹងអំពើបង្កជាបក្សពួក។ បក្សត្រូវប្រុងប្រយ័ត្នបដិវត្តខ្ពស់ចំពោះគ្រប់សកម្មភាព និងគ្រប់កលល្បិចរបស់ខ្មាំង ជាផ្ទាល់ ឬជាប្រយោល ជាចំហ ឬជាសម្ងាត់ ដែលប៉ងប្រាថ្នាបំផ្លិចបំផ្លាញបក្ស), ទំព័រ ៥ ERN (ភាសាខ្មែរ) 00442255 (បក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់នូវគោលការណ៍ ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាបដិវត្តខ្លួន ដោយខ្លួនឯងដាច់ខាត) ទំព័រ ៨

ត្រូវបានផ្លុះបញ្ចាំងបន្ថែមនៅក្នុងលក្ខន្តិកៈសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុម័តនៅដើមឆ្នាំ១៩៧៦[២៣៧៧]។

### ១៤.១.៤.៣ ការរំលាយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

៧៥៦. បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងនៅមុនពេលដែលរដ្ឋាភិបាលថ្មីអាចត្រូវបានបង្កើតឡើងជាផ្លូវការនោះ[២៣៧៨] ថ្នាក់ដឹកនាំបក្សត្រូវតែសម្រេចពីជោគវាសនារបស់មន្ត្រីមួយចំនួននៃរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាពិសេស គឺ សម្តេច នរោត្តម សីហនុ ប៉ែន នុត និងអ្នកមួយចំនួនដែលស្មោះស្ម័គ្រជាមួយពួកគេ។

៧៥៧. ថ្នាក់ដឹកនាំបក្សបានទទួលការព្រមានពីអាជ្ញាធរប្រទេសចិនថា ការបែកបាក់ណាមួយរវាងសម្តេច នរោត្តម សីហនុ និងខ្មែរក្រហម នឹងបើកផ្លូវឲ្យមានការចូលអន្តរាគមន៍ពីបរទេសនៅក្នុងប្រទេសកម្ពុជា[២៣៧៩]។ សម្តេច នរោត្តម សីហនុ នៅតែមានប្រជាប្រិយភាពនៅលើឆាកអន្តរជាតិ ក៏ដូចជាចំពោះប្រជាជនកម្ពុជាផងដែរ[២៣៨០]។ ក៏ប៉ុន្តែ ថ្នាក់ដឹកនាំបក្សបានពិចារណាថា ប្រសិនបើ

---

ERN (ភាសាខ្មែរ) 00442257 (សមាជិកត្រូវមានវណ្ណៈភាពល្អ ជាវណ្ណៈភាពដើម ហើយមានប្រវត្តិរូបច្បាស់លាស់), ទំព័រ ២៧, ERN (ភាសាខ្មែរ) 00442266 (ថ្នាក់ដឹកនាំត្រូវខ្លួនទីពឹងខ្លួន មានវណ្ណៈភាពល្អ ហើយមានជំហរវណ្ណៈកម្មករ)។

[២៣៧៧] លក្ខន្តិកៈសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ឯកសារ E3/1607 ចុះខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ៣ ដល់ទំព័រ ៦, ERN (ភាសាខ្មែរ) 00442362-00442364 (ឥឡូវនេះបដិវត្តបានសម្រេចទាំងស្រុង និងជាស្ថាពរហើយ បដិវត្តសង្គមនិយមត្រូវតែបន្ត និងកសាងរហូតឈានដល់កុម្មុយនីស្តនិយម។ សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងលោកទស្សនៈមិនអធន រួមមាន នាយទុន សក្តិភូមិ និងចក្រពត្តិ។ សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា អនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ និងប្រកាន់ខ្ជាប់គោលជំហរខ្លួនទីពឹងខ្លួន)។

[២៣៧៨] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៩-២៣០។

[២៣៧៩] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា ឯកសារ E3/2667 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១, ERN (ភាសាខ្មែរ) 00491781 (នាយករដ្ឋមន្ត្រីចិន លោក ជូ អេនឡាយ បានព្រមានដល់ខៀវ សំផន និង នរោត្តម សីហនុថា ការបែកបាក់គ្នារវាងពួកសីហនុនិយម និងពួកខ្មែរក្រហម នឹងបើកទ្វារដល់ការអន្តរាគមន៍ពីបរទេស)។

[២៣៨០] អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្រវត្តិកម្ពុជា (ខែ មករា ឆ្នាំ ១៩៧៦) ឯកសារ E3/490 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៦, ERN (ភាសាខ្មែរ) 00522390 (ប្រជាជននៅបន្តរក្សាគោរព នរោត្តម សីហនុ យ៉ាងខ្ពង់ខ្ពស់)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន អតីតឧត្តមសេនីយ៍នៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរE3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៨, ERN (ភាសាខ្មែរ) 00499668 (ជនភៀសខ្លួន ឧត្តមសេនីយ៍ សរ ប៊ុន បានពន្យល់ថា ប្រជាជនជាច្រើននៅក្នុងប្រទេសសង្ឃឹមថា នរោត្តម

សម្តេច នរោត្តម សីហនុ ប៉ែន នុត និងអ្នកស្មោះស្ម័គ្រមួយចំនួនទៀតបន្តរស់នៅបរទេស ពួកគេមិនអាចស្ថិតក្រោមការគ្រប់គ្រងបានទេ ហើយអាចបង្កជាការគំរាមកំហែងដល់បដិវត្តសង្គម-និយម[២៣៨១]។ ហេតុដូច្នេះ ទើបនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ ខៀវ សំផន បានប្រកាសថា អ្នកការទូតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលបានជួយដល់ការតស៊ូនៅបរទេស នឹងត្រូវកោះហៅឲ្យមកស្នាក់នៅទីជនបទរយៈពេលមួយឆ្នាំ មុនពេលទទួលបានការតែងតាំងថ្មី[២៣៨២]។ នៅថ្ងៃទី ០២ ខែ វិច្ឆិកា

---

សីហនុ និងត្រឡប់មកវិញ "ដើម្បីកម្ចាត់ឧបទ្រពចង្រៃ"។ អនុស្សារណៈក្រុមប្រឹក្សាសន្តិសុខជាតិនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃឥណ្ឌូចិន ឯកសារ E3/3471 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤, ERN (ភាសាខ្មែរ) 00723764 (ដើម្បីយកជាដើមទុនពីជំហររបស់ នរោត្តម សីហនុ ក្នុងប្រទេសតតីយលោក និងប្រហែលជាដោយសារតែភាពខុសគ្នាជាមួយចៅហ្វាយចិនរបស់ នរោត្តម សីហនុនោះ ពួកខ្មែរក្រហមប្រហែលជាកំពុងរៀបចំទទួលយកតួនាទីមិនមែនកុម្មុយនីស្តដែលគ្រាន់ជានិមិត្តរូបមួយ ទៅក្នុងរដ្ឋាភិបាលរបស់ពួកគេ សម្រាប់ពេលវេលាមិនកំណត់មួយ)។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការលេចមុខមេដឹកនាំឧទ្ទាមខ្មែរ ខៀវ សំផន លើឆាកអន្តរជាតិ ឯកសារ E3/3310 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៤ ទំព័រ ៥, ERN (ភាសាខ្មែរ) 00740846 (ការទម្លាក់ នរោត្តម សីហនុ នឹងធ្វើឲ្យខ្មែរក្រហមបាត់បង់ការគាំទ្រពីអន្តរជាតិ ដូចជាពីពួកនិយមកណ្តាលទ្វីបអាហ្វ្រិក ដែលជឿជាក់ថា នរោត្តម សីហនុ គឺជាអ្នកអព្យាក្រិត ស្នេហាជាតិ ដែលត្រូវបានទម្លាក់ដោយពួកឃោឃាក្នុងឆ្នាំ ១៩៧0)។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ជាភាសាបារាំងពាក់ព័ន្ធនឹងប្រទេសកម្ពុជា ឯកសារ E3/3318 ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៤ ទំព័រ ៦, ERN (ភាសាខ្មែរ) 00790019 (ការបញ្ជាក់ពីឥរិយាបទផ្ទាល់ខ្លួនពិតប្រាកដមួយ ចំពោះ ខៀវ សំផន ពីសំណាក់ប្រជាជនអាល់ហ្សេរី បង្ហាញថាពួកគេចង់រក្សាតួនាទីលេខមួយសម្រាប់ នរោត្តម សីហនុ)។

[២៣៨១] ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤ , ERN (ភាសាខ្មែរ) 00072403។

[២៣៨២] ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ អំពីប្រទេសកម្ពុជា ឯកសារ E3/2662 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៣, ERN (ភាសាខ្មែរ) 00492861។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស* ឯកសារ E3/99 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ៣ ដល់៤, ERN (ភាសាខ្មែរ) 00072402-00072403 (បញ្ញាជន និងអ្នកដទៃទៀតដែលបានត្រឡប់មកពីបរទេស ត្រូវធ្វើការងារដោយកម្លាំងកាយ នៅពេលដែលពួកគេមកដល់ភ្លាម ដើម្បីបណ្តុះបណ្តាល និងអប់រំកែប្រែ)។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា ឯកសារ E3/2667 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៣, ERN (ភាសាខ្មែរ) 00491783 (ខៀវ សំផនចំណាយពេលវេលាយ៉ាងច្រើននៅទីក្រុងប៉េកាំង ដើម្បីបំពាក់បំប៉នមនោគមន៍វិជ្ជាដល់ យុវជនខ្មែរនៅទីនោះ ហើយបានដាស់តឿនថា នៅពេលដំបូង ពួកគេត្រូវទៅធ្វើស្រែនៅជនបទ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៦៨-៧៣ (អ្នកការទូតនៅបរទេស ត្រូវបានកោះហៅមកភ្នំពេញវិញ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ទំព័រ ៤០-

ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងកិច្ចប្រជុំមួយដែលចូលរួមដោយ ប៉ុល ពត នួន ជា អៀង សារី វន វេត សុន សេន ខៀន ខៀវ សំផន និងអ្នកផ្សេងទៀត បានសម្រេចថា នរោត្តម ភូរីស្សារា ដែលជារដ្ឋមន្ត្រីមួយរូបរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលត្រូវបានគេយល់ថា ស្មោះស្ម័គ្រជាមួយសម្តេច នរោត្តម សីហនុ មិនអាចទុកចិត្តបានទេ ដូច្នេះហើយ ចាំបាច់ត្រូវតែចាត់វិធានការប្រឆាំងនឹងទ្រង់[២៣៨៣]។ អតីតរដ្ឋមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលស្មោះស្ម័គ្រនឹងសម្តេច នរោត្តម សីហនុ និង/ឬអ្នកដែលត្រូវបានកោះហៅពីបរទេស រួមមានទាំង នរោត្តម ភូរីស្សារា ផងនោះ ដែលក្រោយមក ត្រូវបានអប់រំកែប្រែនៅបឹងត្របែក ហើយអ្នកខ្លះបានបាត់ខ្លួន[២៣៨៤]។ ខៀវ សំផន បានដឹកនាំវគ្គបណ្តុះបណ្តាលផ្នែកមនោគមន៍វិជ្ជានយោបាយ ចំពោះបញ្ញាជន និងមន្ត្រីដែលបានត្រឡប់មកស្រុកវិញ នៅចុងឆ្នាំ ១៩៧៥ និងក្នុងឆ្នាំ ១៩៧៦ នៅមន្ទីរ ក-១៥។ ក្នុងអំឡុងវគ្គទាំងនេះ ខៀវ សំផន បានផ្តល់យុត្តិកម្មសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុង ដោយគាត់បានអះអាងថា បានលុបបំបាត់ទ្រព្យសម្បត្តិឯកជន និងទប់ស្កាត់ការអត់ឃ្លាន ហើយគាត់បាន

---

៤៣ (ថ្នាក់ដឹកនាំជាច្រើនរូប បានអំពាវនាវដល់សិស្ស និស្សិត ព្រមទាំងអ្នកដទៃទៀត ឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (ស្ហួង ស៊ីគឿន) ទំព័រ ១៦-១៩ (បញ្ញាជនត្រូវបានប្រាប់ឲ្យត្រៀមខ្លួនសម្រាប់ពលកម្មធ្ងន់ នៅពេលដែលពួកគេត្រឡប់មកវិញ)។

[២៣៨៣] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/227 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ១, ERN (ភាសាខ្មែរ) 00019127 (ប៉ុល ពត នួន ជា អៀង សារី វ៉ន វេត សុន សេន ខៀន ខៀវ សំផន និងអ្នកផ្សេងទៀត មានវត្តមាន), ទំព័រ ៦, ERN (ភាសាខ្មែរ) 00019132 (ភូរីស្សារ៉ា និងសមាសភាពមួយចំនួនទៀតមិនធានាទេ "យើងត្រូវប្រយ័ត្នប្រយែងឲ្យមែនទែន")។

[២៣៨៤] សេចក្តីប្រកាសរបស់ ស៊ីសុវត្ថិ អៃវ៉ាវ៉ាឌី ឯកសារ E3/5679 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៨៩ ទំព័រ ១ ដល់ ៣, ERN (ភាសាខ្មែរ) 00322743-00322745 (រួមមាន នរោត្តម ភូរីស្សារ៉ា សារិន ឆាក (អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានមូលដ្ឋាននៅប៉េកាំង) និងអ្នកដទៃទៀត)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (ស្ហួង ស៊ីគឿន), ទំព័រ ៦៨-៧៣ (សាក្សីបានដឹងនៅឆ្នាំ ១៩៧៩ថា អ្នកការទូតមួយចំនួនដែលត្រឡប់មកវិញនោះ ត្រូវបានបាត់ខ្លួន)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង) ទំព័រ ៨៩-៩០ (អ្នកដែល ត្រឡប់មកវិញមួយចំនួនបានបាត់ខ្លួន ហើយក្រោយមកទើបសាក្សីបានដឹងថា អ្នកទាំងនោះត្រូវបានសម្លាប់)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង), ទំព័រ ៦៤-៦៨ (អ្នកដែលត្រឡប់មកវិញមួយចំនួនត្រូវបានបញ្ជូនទៅបឹងត្របែក ហើយនៅទីនោះពួកគាត់ត្រូវធ្វើការ ហើយទទួលការទិតៀន ផ្អែកតាមការតស៊ូវណ្ណៈ)។

បង្រៀនថា ចំណេះដឹងដែលទទួលបានពីការអប់រំ ដោយពួកអាណានិគមនិយម និងពួកចក្រពត្តិនិយម ត្រូវតែលុបបំបាត់ចោល[២៣៨៥]។

៧៥៨. នៅពាក់កណ្តាលខែ សីហា ឆ្នាំ ១៩៧៥ ប្រតិភូដែលដឹកនាំដោយ ខៀវ សំផន ហើយរួមមាន អៀង សារី (ដែលពេលនោះ គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស) និង អៀង ធីរិទ្ធ ផងនោះ បានធ្វើដំណើរទៅប្រទេសចិន ហើយបន្ទាប់មក ទៅប្រទេសកូរ៉េខាងជើងដើម្បីចរចាយាងសម្តេច នរោត្តម សីហនុ ឲ្យត្រឡប់ចូលមកប្រទេសវិញ[២៣៨៦]។ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ សម្តេច នរោត្តម សីហនុ បានយាងនិវត្តមកទីក្រុងភ្នំពេញ ដោយមាន ខៀវ សំផន អមដំណើរជាមួយផង[២៣៨៧]។

---

[២៣៨៥] ប្រតិចារឹក ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង) ទំព័រ ៨៤។ ប្រតិចារឹក ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១២-១៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុង ថុង ហឿង ឯកសារ E3/97 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ១៦-១៨, ERN (ភាសាខ្មែរ) 00270695-7។ សៀវភៅនិពន្ធដោយ Ben KIERNAN៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហម* ឆ្នាំ ១៩៧៥-១៩៧៩ ឯកសារ E3/1593 ទំព័រ ២១៦-២១៧, ERN (ភាសាខ្មែរ) 00637571-00637572 *សូមមើលផងដែរ* ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ខៀវ សំផន កថាខណ្ឌ ៣៧៩។

[២៣៨៦] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់លោក ខៀវ សំផន និងលោក អៀង សារី នៅទីក្រុងប៉េកាំង ឯកសារ E3/2717 ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១, ERN (ភាសាខ្មែរ) 00820657។ ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ លោក ខៀវ សំផន និងលោក អៀង សារី ធ្វើទស្សនកិច្ចនៅប្រទេសចិន ឯកសារ E3/2721 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00662227-00662228។ ទូរលេខរបស់ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ទស្សនកិច្ចរបស់លោក ខៀវ សំផន ទៅកាន់សាធារណៈរដ្ឋប្រជាមានិតចិន ឯកសារ E3/619 ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១, ERN (ភាសាខ្មែរ) 00635938។ ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ លោក ខៀវ សំផន ចេញដំណើរទៅកូរ៉េខាងជើង ឯកសារ E3/3350 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១-២, ERN (ភាសាខ្មែរ) 00740886-00740887។ *សូមមើលផងដែរ* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៩១។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន ៣៧៤។

[២៣៨៧] ទូរលេខក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ថ្ងៃទី ១០ ខែ កញ្ញា សារព័ត៌មានសង្ខេប EA ឯកសារ E3/3355 ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១, ERN (ភាសាខ្មែរ) 00740893។

៧៩៩. គណៈកម្មាធិការអចិន្ត្រៃយ៍បានចាត់តាំង ខៀវ សំផន ឱ្យបន្តធ្វើជាអ្នកទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា នឹងសម្តេច នរោត្តម សីហនុ[២៣៨៨]។ ដើម្បីបំពេញភារកិច្ចនេះឱ្យបានសម្រេច ខៀវ សំផន បានអមព្រះរាជដំណើរសម្តេច នរោត្តម សីហនុ ទៅទស្សនកិច្ចនៅទីជនបទផ្សេងៗ[២៣៨៩]។ ខៀវ សំផន ពេញចិត្តជាមួយនឹងគម្រោងធារាសាស្ត្រ និងកសិកម្ម ដែលត្រូវបានអនុវត្តដោយបាតដៃទទេរបស់ប្រជាជន ហើយគាត់ព្យាយាមបង្ហាញពីផលប្រយោជន៍ និងជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះជូនទៅសម្តេច នរោត្តម សីហនុ ថែមទៀត[២៣៩០]។ តាមពិតទៅ ខៀវ សំផន មានបំណងជួយរបបនេះតាមគ្រប់វិធីដែលគាត់អាចធ្វើទៅបាន ហើយគាត់ព្យាយាមមិនធ្វើអ្វីមួយដែល

---

[២៣៨៨] ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/3196 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៩, ERN (ភាសាខ្មែរ) 00807450 (ខៀវ សំផន ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍តែងតាំងឱ្យធ្វើការទាក់ទងជាមួយ នរោត្តម សីហនុ ក្នុងនាមបក្ស)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/182, ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥, ទំព័រ ១, ERN (ភាសាខ្មែរ) 00019108។ *សូមមើលផងដែរ* ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥។

[២៣៨៩] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ខៀវ សំផន កថាខណ្ឌ ៣៦៨, ៣៨០។

[២៣៩០] កំណត់ហេតុកិច្ចសម្ភាសន៍ ខៀវ សំផន, ឯកសារ E3/3196, គ្មានចុះកាលបរិច្ឆេទ, ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00807449-00807450 (ខៀវ សំផន មានអារម្មណ៍ច្របូកច្របល់នៅមុនពេលជម្លៀស ប៉ុន្តែក្រោយថ្ងៃទី ១៧ ខែ មេសា គឺបន្ទាប់ពីជម្លៀស គាត់បានឃើញទំនប់ និងប្រឡាយ ទើបគាត់មានអារម្មណ៍ពេញចិត្ត។ នៅពេលដែល ខៀវ សំផន អមដំណើរព្រះករុណាទៅទតទំនប់ប្រឡាយនៅតាមជនបទនោះ គាត់រីករាយនឹងជម្រាបថ្វាយព្រះករុណាថា ពួកគេកសាងដោយផ្ទាល់ដៃ។ ខៀវ សំផន ជឿជាក់ថា បក្សកុម្មុយនីស្តកម្ពុជាឯកភាពគ្នាជាផ្លុងមួយ ហើយគាត់បានឃើញទំនប់ធំៗលេចឡើង និងវាលស្រែដ៏រាបស្មើ)។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន, ឯកសារ E3/3198, គ្មានចុះកាលបរិច្ឆេទ, ទំព័រ ១៥, ERN (ភាសាខ្មែរ) 00807469 (ខៀវ សំផន បានចុះទស្សនកិច្ចនៅតំបន់ជនបទជាមួយសម្តេច នរោត្តម សីហនុ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានឃើញប្រជាជនកសាងទំនប់ ដូចជា ទំនប់នៅកំពីងពួយ ខាងលិចបាត់ដំបង។ នៅពេលដែល ខៀវ សំផន បានឃើញទំនប់ ប្រឡាយ និងវាលស្រែ គាត់មានអារម្មណ៍រំភើប ហើយរីករាយខ្លាំង។ គាត់គិតថា ប្រទេសកម្ពុជាលែងមានឈ្មោះជាប្រទេសដែលមានកសិកម្មអន់ថយទៀតហើយ កម្ពុជានឹងមានស្រូវអង្ករគ្រប់គ្រាន់។ គាត់ជឿជាក់ថា ប្រជាជនដែលត្រូវបានជម្លៀសពីភ្នំពេញក៏នឹងយល់ឃើញដូចជាគាត់ដែរ)។, ទំព័រ ១៥ ដល់ ១៦, ERN (ភាសាខ្មែរ) 00807469-00807470 (នៅពេលដែល ខៀវ សំផន អមព្រះរាជដំណើរសម្តេច នរោត្តម សីហនុ ទៅបំពេញព្រះរាជទស្សនកិច្ចនៅទំនប់ប្រឡាយនៅតាមទីជនបទ ហើយបានឃើញប្រជាជនធ្វើការដោយដៃ និងជើងទទេ គាត់ព្យាយាមពន្យល់សម្តេច នរោត្តម សីហនុ ថា អត្ថន័យនៃការងារនេះគឺធំធេងណាស់ ព្រោះពួកគេកំពុងកសាង និងការពារប្រទេស។ គាត់ចង់ឱ្យសម្តេច នរោត្តម សីហនុ យល់ថា ទាំងនេះគឺជាការចាំបាច់ដើម្បីអភិវឌ្ឍន៍ប្រទេស។ ខៀវ សំផន ឃើញទំនប់ធំៗជាច្រើនបានលេចរូបរាងឡើងយ៉ាងឆាប់រហ័ស)។

អាចរាំងស្ទះដល់ចលនានេះទេ[២៣៩១]។ សម្តេច នរោត្តម សីហនុ បានច្រានចោលការព្យាយាមទាក់ទាញរបស់ ខៀវ សំផន ដោយបញ្ជាក់អំពីបំណងរបស់ទ្រង់ដែលបានបង្ហាញនាពេលកន្លងមក គឺការលាឈប់ពីមុខតំណែងជាប្រមុខរដ្ឋ[២៣៩២]។

៧៦០. នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦ ប៉ុល ពត ខៀវ សំផន នួន ជា អៀង សារី វន វេត សុន សេន និង ខឿន បានចូលរួមក្នុងកិច្ចប្រជុំមួយ ដែលនៅក្នុងកិច្ចប្រជុំនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ បានសម្រេចទទួលយកការលាឈប់របស់សម្តេច នរោត្តម សីហនុ ហេតុនេះហើយ "សក្តិភូមិនិយម" ត្រូវបានបញ្ចប់នៅក្នុងប្រទេសកម្ពុជានៅពេលនោះ[២៣៩៣]។ សេចក្តីសម្រេចនេះត្រូវបានគាំទ្រដោយគណៈកម្មាធិការមជ្ឈិម នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[២៣៩៤]។

៧៦១. នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ បានដាក់លិខិតលាលែងរបស់គាត់ជាសាធារណៈ ហើយនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៦ លិខិតលាលែងនេះត្រូវបានរដ្ឋាភិបាលទទួលយក[២៣៩៥]។ ខៀវ សំផន បានប្រកាសតាមវិទ្យុពីការចូលនិវត្តរបស់សម្តេច នរោត្តម

---

[២៣៩១] សៀវភៅនិពន្ធដោយ ខៀវ សំផនៈ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់, ឯកសារ E3/18, ទំព័រ ១៣៣-១៣៤, ERN (ភាសាខ្មែរ) 00103874-00103875 (ខៀវ សំផន បានឃើញសមិទ្ធផលមួយចំនួននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ជាពិសេស ប្រព័ន្ធធារាសាស្ត្រនៅតាមទីជនបទ។ ដោយសារតែអាងស្តុកទឹកនៅត្រពាំងថ្ម នៅភ្នំស្រុក និងនៅកំពីងពួយ ក្នុងខេត្តបាត់ដំបង ទើបមានវាលស្រែដាច់កន្ទុយភ្នែកបែបនេះ។ ទំនុកចិត្តដែលរបបនេះទទួលបានពីជ័យជម្នះរបស់ខ្លួន បានជំរុញឲ្យគាត់ចង់ជួយតាមអ្វីដែលគាត់អាចជួយបាន ហើយរារាំងគាត់មិនឲ្យធ្វើអ្វីដែលអាចរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់ចលនា)។

[២៣៩២] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៣-៤, ERN (ភាសាខ្មែរ) 00000746-00000747។

[២៣៩៣] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00000747-00000748។

[២៣៩៤] សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន, ឯកសារ E3/12, ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៦, ERN (ភាសាខ្មែរ) 00003141 (គណៈកម្មាធិការមជ្ឈិមសម្រេចឲ្យសម្តេច នរោត្តម សីហនុ ចូលនិវត្តតាមសំណូមពររបស់គាត់ ដោយគាត់មិនអាចដំណើរទៅមុខទៀតបានទេ)។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧។ [និយមន័យនៃការកម្ទេច]។

[២៣៩៥] អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុៈ កាលប្បវត្តិកម្ពុជា (ខែ មករា ឆ្នាំ ១៩៧៦), ឯកសារ E3/490, ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១៩, ERN (ភាសាខ្មែរ) 00522403។

សីហនុ[២៣៩៦]។ នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៧៦ ប៉ែន នុត បានដាក់លិខិតសុំរំលាយរាជរដ្ឋាភិបាលរបស់គាត់ គឺរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[២៣៩៧]។

៧៦២. លក្ខខណ្ឌនៃការចូលនិវត្តរបស់សម្តេច នរោត្តម សីហនុ ត្រូវបានសម្រេចនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កាលពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦។ បន្ទាប់ពីបានស្តាប់ការរាយ-ការណ៍របស់ ខៀវ សំផន ស្តីពីការសម្រេចរបស់ សម្តេច នរោត្តម សីហនុ ក្នុងការលាលែងនោះ ប៉ុល ពត បានធ្វើការសង្ខេបលក្ខខណ្ឌទាំងនេះ ដែលរួមមាន សម្តេច នរោត្តម សីហនុ មិនត្រូវបានអនុញ្ញាតឲ្យចាកចេញទៅក្រៅប្រទេស ត្រូវបញ្ជូនទូរលេខទៅកូនៗរបស់គាត់ឲ្យត្រឡប់មកកម្ពុជាវិញជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាឲ្យបាន "ស្អាត" ហើយរាល់ជំនួបនានារវាង សម្តេច នរោត្តម សីហនុ នឹងមន្ត្រីទូតបរទេសត្រូវបញ្ឈប់ជាបន្ទាន់[២៣៩៨]។ ទោះជាយ៉ាងនេះក្តី ប៉ែន នុត និង សម្តេច នរោត្តម សីហនុ នៅតែជាឧបករណ៍ដែលមានប្រយោជន៍សម្រាប់ខ្មែរក្រហម[២៣៩៩] ដោយត្រូវទៅទស្សនកិច្ចនៅទីជនបទ ដើម្បីជំរុញលើកទឹកចិត្តប្រជាជន និងបង្ហាញជាសាធារណៈពីការគាំទ្ររបស់ពួកគាត់ចំពោះរបបខ្មែរក្រហម[២៤០០]។

---

[២៣៩៦] ខៀវ សំផន អានសារឆ្លើយតបរបស់រាជរដ្ឋាភិបាល (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស), ឯកសារ E3/275, ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៧៦, ERN (ភាសាខ្មែរ) 00896407។

[២៣៩៧] អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្រវត្តិកម្ពុជា (ខែ មេសា ឆ្នាំ ១៩៧៦), ឯកសារ E3/490, ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ២០, ERN (ភាសាខ្មែរ) 00522404។

[២៣៩៨] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៤ ដល់ ៥ ERN (ភាសាខ្មែរ) 00000747-00000748 (រៀបរាប់ថាសម្តេច នរោត្តម សីហនុ គឺជាខ្លាដែលគេផ្សាំង រង់ចាំតែថ្ងៃស្លាប់។ ក្នុងពេលជាមួយគ្នានេះ គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចរក្សាទុកគាត់ជាឥស្សរជនមួយរូប តែនឹងបញ្ចប់ ឋានៈនេះ បើសិនគាត់នៅបន្តតស៊ូដើម្បីខ្លួនគាត់)។

[២៣៩៩] កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/197 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00000746 (គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលស្គាល់ថាសម្តេច នរោត្តម សីហនុ មានគុណបំណាច់ជាពិសេសនៅលើឆាកអន្តរជាតិ)។

[២៤០០] *សូមមើលជាឧទាហរណ៍* អ្វីៗដែលយើងកំពុងធ្វើនៅពេលនេះ មិនធ្លាប់អនុវត្តពីមុនឡើយ (Der Spiegel) ឯកសារ E3/1589, ឆ្នាំ ១៩៧៧, ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00796759-00796761 (សម្តេច នរោត្តម សីហនុ នៅកាន់កាប់រាជវាំង បន្ទាប់ពីលាលែងពីតំណែង។ អៀង សារី ពន្យល់ថា ធ្វើបែបនេះដើម្បីជាប្រយោជន៍ដល់ សម្តេច នរោត្តម សីហនុ និងកម្ពុជាប្រជាធិបតេយ្យ ដែល សម្តេច នរោត្តម សីហនុ បន្តរស់នៅក្នុងប្រទេសកម្ពុជា)។ ទូរលេខក្រសួងការបរទេសបារាំង៖ ខួបនៃការរំដោះប្រទេសកម្ពុជា- សាររបស់ព្រះអង្គម្ចាស់ សីហនុ និង ប៉ែន នុត, ឯកសារ

### ១៤.១.៤.៤ កម្ពុជាប្រជាធិបតេយ្យ

៧៦៣. នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ហ៊ូ នឹម បានប្រកាសពីការបោះឆ្នោតសភាតំណាងប្រជាជនដែលត្រូវធ្វើឡើងនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦[២៤០១]។ នៅថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ ប៉ុល ពត នួន ជា ខៀវ សំផន និង ឌឿន បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួនពីរ ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសសភាតំណាងប្រជាជន នាពេលខាងមុខ។ ប៉ុល ពត បានប្រកាសថា សភាតំណាងប្រជាជន “គ្មានតម្លៃ” ទេ[២៤០២]។ ទោះជាយ៉ាងនេះក្តី ការបោះឆ្នោត

---

E3/2733, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៨, ទំព័រ ១, ERN (ភាសាខ្មែរ) 00810741 (សម្តេច នរោត្តម សីហនុ និង ប៉ែន នុត បានផ្ញើលិខិតពីច្បាប់ ក្នុងឱកាសខួបលើកទីបី នៃការរំដោះទីក្រុងភ្នំពេញ ហើយបានបង្ហាញពីការបន្តការគាំទ្រដល់របបបច្ចុប្បន្ន)។ *ព្រះរាជសារលិខិតរបស់សម្តេច នរោត្តម សីហនុ ផ្ញើជូនគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា* ឯកសារ E3/169 ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) S00854279-S00854282។ អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជា (ខែ មករា ឆ្នាំ ១៩៧៦), ឯកសារ E3/490, ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ៦, ERN (ភាសាខ្មែរ) 00522390 (ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ បានយាងទៅបំពេញទស្សនកិច្ចនៅតាមទំនប់បង្ហៀរ ដែលកំពុងសាងសង់ ព្រមទាំងបំពេញទស្សនកិច្ចនៅចំការកៅស៊ូ និងរោងចក្រនៅខេត្តភាគខាងជើង។ នេះជាដំណើរព្រះរាជទស្សនកិច្ចលើកទីពីររបស់ទ្រង់ ដើម្បីជួបជាមួយប្រជាជនដែលនៅតែគោរពទ្រង់យ៉ាងខ្ពង់ខ្ពស់), ទំព័រ ១២ ដល់ ១៣ ERN (ភាសាខ្មែរ) 00522396-00522397 (ដោយប្រឈមជាមួយបណ្តាហេតុការណ៍រំលោភបំពានសិទ្ធិមនុស្សនោះ កម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ២០ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ០៥ ខែមីនា ឆ្នាំ ១៩៧៦ បានស្វាគមន៍អ្នកការទូត ៧ រូប មកពីប្រទេសជាមិត្ត។ សម្តេច នរោត្តម សីហនុ និង ប៉ែន នុត ស្ថិតក្នុងចំណោមថ្នាក់ដឹកនាំដែលទទួលបដិសណ្ឋារកិច្ច), ទំព័រ ២០ ដល់ ២១, ERN (ភាសាខ្មែរ) 00522404-00522405 (សម្តេច នរោត្តម សីហនុ ត្រូវបានប្រកាសជាកំពូលឥស្សរជនស្នេហាជាតិ និងទទួលបានប្រាក់សោធននិវត្តប្រចាំឆ្នាំ។ ប៉ែន នុត ទទួលបានតំណែងកិត្តិយស និងត្រូវបានតែងតាំងជាទីប្រឹក្សាជាន់ខ្ពស់នៃគណៈប្រធានរដ្ឋ)។ អនុស្សរណៈ OTAN, កម្មវត្ថុ៖ ដំណើរវិវត្តន៍ថ្មីៗក្នុងវិស័យនយោបាយនៅប្រទេសកម្ពុជា, ឯកសារ E3/493, ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧, ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00693772-00693773 (បក្សបានផ្សព្វផ្សាយកិច្ចសម្ភាសន៍ជាមួយ ប៉ែន នុត ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៧ និងបានអានលិខិតគាំទ្រដល់កម្ពុជាប្រជាធិបតេយ្យ ដែលសរសេរដោយសម្តេច នរោត្តម សីហនុ នៅចុងខែ តុលា ឆ្នាំ ១៩៧៧)។

[២៤០១] អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជា (ខែ កុម្ភៈ ឆ្នាំ ១៩៧៦), ឯកសារ E3/490, ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ៨, ERN (ភាសាខ្មែរ) 00522392។

[២៤០២] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/232, ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៣, ERN (ភាសាខ្មែរ) 00017118 (“បើមានគេសួរ យើងត្រូវពន្យល់ កុំច្រងេងច្រងាង កុំឲ្យឃើញថា យើងចង់បង្ក្រាប។ ទន្ទឹមនេះ ក៏កុំនិយាយលេងពីសភានៅមុខប្រជាជន ឲ្យគេឃើញថាយើងចង់បន្ទឹមបន្ថ ហើយសភាយើងគ្មានតម្លៃអី”)។

សភាត្រូវចាត់ទុកថា ជាការចាំបាច់។ គណៈកម្មាធិការមជ្ឈិមបានយល់ថា កេរ្តិ៍ឈ្មោះប្រទេសនៅលើឆាកអន្តរជាតិ នឹងមានភាពប្រសើរឡើង បន្ទាប់ពីពិភពលោកទទួលបានឱកាសក្នុងការពិនិត្យមើលទៅលើរដ្ឋធម្មនុញ្ញ និងការបោះឆ្នោតរបស់កម្ពុជា[២៤០៣]។

៧៦៤. បន្ទាប់ពីការបោះឆ្នោតថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦ សភាតំណាងប្រជាជន ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិប្រាំឆ្នាំម្តង ហើយទទួលភារកិច្ចតែងតាំងគណៈប្រធានរដ្ឋ រដ្ឋាភិបាល និងតុលាការក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន[២៤០៤]។ នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ នៅមុនសម័យប្រជុំលើកទីមួយរបស់សភាតំណាងប្រជាជន គណៈកម្មាធិការមជ្ឈិមបានប្រកាសថា រដ្ឋាភិបាលជាអង្គការមួយដែលស្ថិតនៅក្រោមបក្ស ហើយបក្សតែងតាំងសមាជិករដ្ឋាភិបាលថ្មីមួយចំនួន[២៤០៥]។ គណៈកម្មាធិការមជ្ឈិមក៏ជាអ្នកសម្រេចថា ស្ថាប័នភូមិភាគ និងមជ្ឈិមណាខ្លះដែលមានសិទ្ធិ "កម្ទេច" ទាំងក្នុងជួរ និងក្រៅជួរបក្ស បង្កើតប្រព័ន្ធរាយការណ៍ប្រចាំសប្តាហ៍ទៅមន្ទីរ ៨៧០ អំពីបញ្ហានានាពាក់ព័ន្ធនឹងទិសដៅសម្រេច ៣ តោនក្នុង ១ ហិកតា។ គណៈកម្មាធិការនេះបានសម្រេចថា គោលដៅបដិវត្តគឺត្រូវផ្តល់អំណាចទៅដល់កសិករ ព្រមទាំងបានប្រកាសថា ស្រុកគំរូដែលបង្កើនផលបាន ៣ តោនក្នុង ១ ហិកតា ដោយបានរៀបចំកម្លាំងពលកម្មដោយខ្លួនឯងបាន "ល្អនិងសមស្រប" នឹងត្រូវជូនទង់ "មហាលោតផ្លោះ"[២៤០៦]។ គណៈកម្មាធិការមជ្ឈិមកំណត់ថ្ងៃឈប់សម្រាកផ្លូវការ និងការប្រារព្ធពិធីនានា ដែលរួមមាន ការប្រារព្ធថ្ងៃបុណ្យឯករាជ្យ (ថ្ងៃទី ១៥ ដល់ ១៧ ខែ មេសា) ដែលមានចេតនាវាយប្រហារពួកចក្រពត្តិ លាតត្រដាងពី

---

*សូមមើលផងដែរ* កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/231, ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ១-៣, ERN (ភាសាខ្មែរ) 00017124-00017126។

[២៤០៣] សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន, ឯកសារ E3/12, ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៦, ERN (ភាសាខ្មែរ) 00003141។

[២៤០៤] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៥។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៩-៣២០។

[២៤០៥] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៣-២៣៦។

[២៤០៦] សេចក្តីសម្រេចរបស់គណៈកម្មធិការមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន, ឯកសារ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១-៣, ៤-៥ ERN (ភាសាខ្មែរ) 00003136-00003138, 00003139-00003140។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧។

ពលិកម្មដែលធ្វើឡើងដោយប្រជាជន កោតសរសើរដល់កងទ័ពបដិវត្ត និង “បំផុសការប្តេជ្ញាចិត្ត កសាង និងការពារប្រទេសឲ្យបានមហាលោតផ្លោះ មហាអស្ចារ្យ”[២៤០៧]។

៧៦៥. ខៀវ សំផន នួន ជា ប៉ុល ពត អៀង ធីរិទ្ធ និងថ្នាក់ដឹកនាំដទៃទៀត បានចូលរួមក្នុងសម័យប្រជុំលើកទីមួយរបស់សភាតំណាងប្រជាជន ដែលត្រូវបានប្រព្រឹត្តឡើងពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦។ ខៀវ សំផន បានថ្លែងសុន្ទរកថាបើកនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ដោយអះអាងថាការបោះឆ្នោតដោយយុត្តិធម៌ និងស្មោះត្រង់ត្រូវបានធ្វើឡើង ហើយបានអនុម័តគោលនយោបាយ ពាក់ព័ន្ធនឹងការដ្ឋាន សហករណ៍ និងការតស៊ូវណ្ណៈដែលកំពុងមាន[២៤០៨]។ អង្គ-ជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា ការបោះឆ្នោតនេះ គឺគ្រាន់តែជាការធ្វើឡើងតែសំបកក្រៅប៉ុណ្ណោះ ដែលដូចគ្នានឹងសភាដែលពួកគេបានជ្រើសរើសនោះដែរ[២៤០៩]។

៧៦៦. បន្ទាប់មក សភាតំណាងប្រជាជនបានជ្រើសតាំងរដ្ឋាភិបាលថ្មីជាផ្លូវការ ដែល ខៀវ សំផន គឺជាប្រធានរដ្ឋ ហើយ សោ ភឹម និង រស់ ញឹម ត្រូវបានតែងតាំងជាអនុប្រធានរដ្ឋនៃគណៈប្រធានរដ្ឋ[២៤១០]។ ក្រោយមក ខៀវ សំផន បានពន្យល់ថា គាត់ទទួលយកតួនាទីជាប្រធាននេះដោយសារតែជាភារកិច្ចស្នេហាជាតិ ហើយគាត់មិនចង់ឲ្យចលនាមួយនេះចុះអន់ខ្សោយនោះទេ[២៤១១]។ ប៉ុល ពត ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី នួន ជា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាង

[២៤០៧] សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន, ឯកសារ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៤ ERN (ភាសាខ្មែរ) 00003139។

[២៤០៨] ឯកសារស្តីពីអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា, ឯកសារ E3/165, ចុះថ្ងៃទី ១១ ដល់ ១៣ ខែ មេសា ឆ្នាំ ១៩៧៦, ទំព័រ ៩-២១, ERN (ភាសាខ្មែរ) 00053610-00053617។

[២៤០៩] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៤។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២០។

[២៤១០] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៥។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១។

[២៤១១] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់, ឯកសារ E3/18, ទំព័រ ៧៦-៧៧, ERN (ភាសាខ្មែរ) 00103846 (គាត់គិតថា ប្រសិនបើគាត់បដិសេធតួនាទីប្រមុខរដ្ឋ គាត់នឹងមិនបានបំពេញតួនាទីជាអ្នកស្នេហាជាតិរបស់ខ្លួន។ គាត់មិនចង់ឃើញកម្លាំងរួបរួមជាតិដែលខ្មែរក្រហមជាតំណាងធ្លាក់ចុះខ្សោយនោះឡើយ)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន), ទំព័រ ៥៣-៥៤ (គាត់ចង់ឲ្យបក្សកុម្មុយនីស្តកម្ពុជា ទទួលជោគជ័យក្នុង “ភារកិច្ចដ៏ធំធេង” របស់បក្ស ហើយគាត់មានជំនឿ និងទំនុកចិត្តទៅលើផែនការបដិវត្តរបស់ពួកគេ)។

ប្រជាជន អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការពារជាតិ វន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ជួន ជឿន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការ យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងវប្បធម៌ បណ្តុះបណ្តាល និងអប់រំ[២៤១២]។ គណៈកម្មាធិការក៏ត្រូវបានកំណត់ឲ្យជួយគាំទ្រដល់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ដោយរួមទាំងគណៈកម្មាធិការផ្នែកកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទំនាក់ទំនង និងចំការកៅស៊ូផងដែរ[២៤១៣]។ គណៈកម្មាធិការអចិន្ត្រៃយ៍ បានតែងតាំងសមាជិកសម្រាប់គណៈកម្មាធិការទាំងនេះអំឡុងពេលកិច្ចប្រជុំដែលត្រូវបានធ្វើឡើងពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៦។ ម៉ី ប្រាំង គឺ ជាប្រធានគណៈកម្មាធិការផ្នែកទំនាក់ទំនង និងដឹកជញ្ជូន ដោយត្រូវត្រួតពិនិត្យមើលលើអង្គភាពរថភ្លើង[២៤១៤]។ គណៈកម្មាធិការអចិន្ត្រៃយ៍ក៏បានសម្រេចផងដែរថា ខ្លួនត្រូវតែចុះទៅមើលតាមមូលដ្ឋាន ក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ដើម្បី "ជំរុញ" ការដាំដុះស្រូវដើមរដូវ ជាពិសេសនៅភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល (ឧត្តរចាស់) ភូមិភាគនិរតី និងនៅសៀមរាប (តំបន់ ១០៦)[២៤១៥]។

៧៦៧. នៅក្នុងពិធីរម្លឹកខួបជ័យជម្នះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានប្រកាសពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលថ្មី ក្នុងការការពារឯករាជ្យភាពប្រទេស និងផ្តោតទៅលើការកសាងជាតិឡើងវិញ[២៤១៦]។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីដំបូង នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦ ប៉ុល ពត

---

[២៤១២] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៥។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៨-៣២០។

[២៤១៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៣។

[២៤១៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨។

[២៤១៥] សរុបសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/235, ចុះថ្ងៃទី ១៩ ដល់ ២១ ខែ មេសា ឆ្នាំ ១៩៧៦, ទំព័រ ៦-៧, ERN (ភាសាខ្មែរ) 00019147-00019148។

[២៤១៦] អនុស្សរណៈក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្រវត្តិកម្ពុជា (ខែ មេសា ឆ្នាំ ១៩៧៦), ឯកសារ E3/490, ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ២៣, ERN (ភាសាខ្មែរ) 00522407។ ការប្រារព្ធពិធីខួបជ័យជម្នះ ថ្ងៃទី ១៧ ខែ មេសា ការថ្លែងសន្ទរកថា របស់ ខៀវ សំផន (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/275 ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00896389-00896404។ អត្ថបទនៃសន្ទរកថាលោក អៀង សារី ក្នុងពិធីបដិសណ្ឋារកិច្ច ថ្ងៃទី ១៧ ខែ មេសា (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/275 ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00700133-00700138។ ហ៊ូ នឹម ចេញសេចក្តីប្រកាសព័ត៌មានអំពីសភាតំណាង

បានបញ្ជាក់អំពីកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការគោរពតាមមាគ៌ាបក្ស[២៤១៧]។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទីពីរ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ ប៉ុល ពត បានកោតសរសើរចំពោះសមិទ្ធផលរបស់បដិវត្តសង្គមនិយម ដែលរួមមាន ការបង្កើត និងពង្រីកសហករណ៍ និងការប្រមូលផ្តុំកម្លាំងរាប់ពាន់នាក់នៅតាមការដ្ឋានសាងសង់ប្រព័ន្ធធារាសាស្ត្រដែលមាន[២៤១៨]។ ប៉ុល ពត ក៏បានលើកឡើងពីចំណុចខ្សោយ ដែលរួមមាន កង្វះម្ហូបអាហារ ជំងឺដង្កាត់ ព្រមទាំង ជំរកមិនគ្រប់គ្រាន់ ជាពិសេសសម្រាប់ "កងចល័តយុវជន"[២៤១៩] ហើយក៏បានលើកឡើងថា "ផ្នែករថភ្លើង" បានរៀបចំចលនា ដោយសហការជាមួយនឹងមូលដ្ឋាន ដើម្បីប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាព[២៤២០]។ ក្រោយមក ម៉ី ប្រាង បានរាយការណ៍ពីការដឹកជញ្ជូនតាមរថភ្លើង ដោយលើកឡើងអំពីបទពិសោធន៍ក្នុងការដឹកជញ្ជូន "ទំនិញ" ក្នុងបរិមាណច្រើន[២៤២១]។

៧៦៨. ក្នុងពេលជាមួយគ្នានេះដែរ គណៈកម្មាធិការអចិន្ត្រៃយ៍បន្តកិច្ចប្រជុំពាក់ព័ន្ធនឹងការអនុវត្តមាគ៌ានយោបាយបក្ស និងរដ្ឋបាលសម្រាប់ប្រទេស។ កំណត់ហេតុកិច្ចប្រជុំដែលត្រូវបានធ្វើឡើងពីខែ សីហា ឆ្នាំ ១៩៧៥ ដល់ខែ មិថុនា ឆ្នាំ ១៩៧៦[២៤២២] ដែលបង្ហាញពីវត្តមានរបស់ថ្នាក់ដឹកនាំបក្សជាច្រើន ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយជាញឹកញាប់ ថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតដែលមិនត្រូវបានបញ្ជាក់ថាជាសមាជិករបស់គណៈ-កម្មាធិការនេះ រួមទាំង ខៀវ សំផន អៀង ធីរិទ្ធ និងលេខាភូមិភាគ និងតំបន់ស្វ័យតជាច្រើន បាន

---

ប្រជាជន (កម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/275 ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00700123-00700129។

[២៤១៧] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៧។

[២៤១៨] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី, ឯកសារ E3/794, ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១២-១៤, ERN (ភាសាខ្មែរ) 00000788-00000790។

[២៤១៩] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី, ឯកសារ E3/794, ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១៣-១៥, ERN (ភាសាខ្មែរ) 00000789-00000791។

[២៤២០] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី, ឯកសារ E3/794, ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១៦-១៧, ERN (ភាសាខ្មែរ) 00000792-00000793។

[២៤២១] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី, ឯកសារ E3/794, ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ២៤-២៧, ERN (ភាសាខ្មែរ) 00000800-00000803។

[២៤២២] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៦។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៦។

ពិចារណា និងសម្រេចទៅលើបញ្ហានានាពាក់ព័ន្ធនឹងឃោសនាការ និងកិច្ចការបរទេស[២៤២៣] ពាណិជ្ជកម្ម និងជំនួញ[២៤២៤] កិច្ចការការពារជាតិ[២៤២៥] និងបញ្ហាសេដ្ឋកិច្ចនានា ដូចជា ផលិតកម្ម កសិកម្ម និងឧស្សាហកម្ម ព្រមទាំងផ្នែកសង្គមកិច្ចផងដែរ[២៤២៦]។

[២៤២៣] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/219, ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-២, ERN (ភាសាខ្មែរ) 00000768-00000769 (ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី វន វេត និង ទូច បាន ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងគោលនយោបាយបរទេស និងពិភាក្សាពីសន្និសីទអន្តរជាតិនៅប្រទេសអាល់ហ្សេរី)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/225, ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦, ទំព័រ ១-១០, ERN (ភាសាខ្មែរ) 00000837-00000846 (ប៉ុល ពត នួន ជា និង ហ៊ូ នឹម បានចូលរួមក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងឃោសនាការ និងការប្រើប្រាស់ខ្សែភាពយន្ត រូបថត ទូរពុម្ព សិល្បៈ សំដែង និងស្ថានីយវិទ្យុ)។

[២៤២៤] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/233, E3/234, ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ១ ដល់ ២, ERN (ភាសាខ្មែរ) 00000749-00000750 (ខៀវ សំផន នួន ជា និង អៀង សារី បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការបង្កើតគណៈកម្មាធិការពាណិជ្ជកម្ម និងធនាគារ។ សមាជិកភាពរបស់ ខៀវ សំផន ក្នុងគណៈកម្មាធិការបញ្ជាទិញ និងជាប្រធានគណៈកម្មាធិការធនាគារត្រូវបានសម្រេច)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/220, ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ១៩៧៦, ទំព័រ ១-២, ERN (ភាសាខ្មែរ) 00000827-00000828 (ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី ឌឿន និង ទូច បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងទំនាក់ទំនងពាណិជ្ជកម្ម និងធនាគារជាមួយចិន)។

[២៤២៥] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/227, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥, ទំព័រ ១ ដល់ ៩, ERN (ភាសាខ្មែរ) 00019127-00019135 (ខៀវ សំផន នួន ជា ប៉ុល ពត អៀង សារី វន វ៉ត សុន សេន កុយ ធួន ឌឿន និង យ៉ែម បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងបញ្ហាព្រំដែន និងការផលិតអំបិល)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/229, ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦, ទំព័រ ១-៨ , ERN (ភាសាខ្មែរ) 00000713-00000716 (ប៉ុល ពត ខៀវ សំផន នួន ជា វន វេត ឌឿន សុន សេន និង កុយ ធួន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងបញ្ហាយោធា និងការពារជាតិ)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/232, ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ៤-៨, ERN (ភាសាខ្មែរ) 00017119-00017123 (ប៉ុល ពត នួន ជា ខៀវ សំផន និង ឌឿន បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីបញ្ហាខ្មាំងលេចធ្លោនានានៅខេត្តព្រះវិហារ (តំបន់ ១០៣) និងសៀមរាប (តំបន់ ១០៦)។ កំណត់ហេតុកិច្ចប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/217, ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ១-៤, ERN (ភាសាខ្មែរ) 00000736-00000739 (ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី វន វេត សុន សេន កុយ ធួន និង ឌឿន បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងបញ្ហានៅសមរភូមិមុខប៉ែកបូព៌ា)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ , ឯកសារ E3/218, ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ១-៧, ERN (ភាសាខ្មែរ) 00000751-00000757 (ខៀវ សំផន នួន ជា សុន សេន យា និង ឌឿន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ដែល

នួន ជា គឺជាប្រធាននៃកិច្ចប្រជុំ ដោយផ្តោតលើការវាយប្រយុទ្ធ និងការចរចាជាមួយវៀតណាម)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/221, ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-១៧, ERN (ភាសាខ្មែរ) 00000810-00000826 (ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី សុន សេន វន វេត និង មេដឹកនាំភូមិភាគបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងបញ្ហាការប៉ះទង្គិចដោយអាវុធនៅតាមព្រំដែនជាមួយវៀតណាម)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/222, ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-២, ERN (ភាសាខ្មែរ) 00000770-00000771 (ខៀវ សំផន នួន ជា ប៉ុល ពត សុន សេន និង ខឿន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អំពីបញ្ហាការពារជាតិ រួមមានការបង្កើតការរៀបចំរោងចក្រ និងអាកាសយានដ្ឋាន។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/223, ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-៨, ERN (ភាសាខ្មែរ) 00000829-00000836 (ប៉ុល ពត ខៀវ សំផន នួន ជា អៀង សារី និងមេដឹកនាំភូមិភាគបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីកិច្ចការបរទេស)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/224, ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-៥, ERN (ភាសាខ្មែរ) 00000772-00000776 (ប៉ុល ពត នួន ជា ខៀវ សំផន សុន សេន និង វន វេត បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ទាក់ទងនឹងតួនាទីរបស់កងទ័ពក្នុងផលិតកម្មកសិកម្ម)។

[២៤២៦] កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/227, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥, ទំព័រ ១ ដល់ ៩, ERN (ភាសាខ្មែរ) 00019127-00019135។ (ខៀវ សំផន នួន ជា ប៉ុល ពត អៀង សារី វន វេត សុន សេន កុយ ធួន ខឿន និង យ៉ែម បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងបញ្ហាព្រំដែន និងការផលិតអំបិល)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/230, ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦, ទំព័រ ១-២, ERN (ភាសាខ្មែរ) 00000711-00000712 (ប៉ុល ពត ខៀវ សំផន នួន ជា អៀង សារី វន វេត សុន សេន កុយ ធួន និង ខឿន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដោះស្រាយបញ្ហាសេដ្ឋកិច្ច ដូចជាការផ្លាស់ទីយុវជនពីមូលដ្ឋានទៅឧស្សាហកម្ម និងការជំរុញទៅមុខទំនប់គីរីរម្យ និងការបែងចែងស្បៀង)។ កំណត់ហេតុកិច្ចប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/232, ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ ១-៨, ERN (ភាសាខ្មែរ) 00017116-00017123 (ប៉ុល ពត នួន ជា ខៀវ សំផន និង ខឿន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីការងារមូលដ្ឋាន ដោយស្តាប់របាយការណ៍ស្តីពីកង្វះស្បៀងអាហារ និងជំងឺនានា នៅក្នុងតំបន់ ១០៣ និង ១០៦។ គណៈកម្មា-ធិការអចិន្ត្រៃយ៍បានសម្រេចលើគោលដៅនាំស្រូវចេញសម្រាប់ឆ្នាំ ១៩៧៧ ព្រមទាំងបញ្ជាក់ថា តំបន់ត្រូវបែងចែកកម្លាំងពលកម្មប្រកបដោយយុទ្ធសាស្ត្រ យោងតាមគោលដៅរបស់បក្ស។ តំបន់ និងភូមិភាគ ត្រូវបានបង្គាប់ឲ្យរាយ-ការណ៍ប្រចាំសប្តាហ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/224, ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦, ទំព័រ ១-៥, ERN (ភាសាខ្មែរ) 00000772-00000776 (ប៉ុល ពត នួន ជា ខៀវ សំផន សុន សេន និង វន វេត បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងតួនាទីរបស់កងទ័ពក្នុងផលិតផលកសិកម្ម)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ឯកសារ E3/226, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦, ទំព័រ ១-១៤, ERN (ភាសាខ្មែរ) 00017147-00017160 (ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី និងអ្នកដទៃទៀត បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងចំណុចខ្សោយរបស់ក្រសួងសុខាភិបាល និង

៧៦៩. អៀង សារី ក៏បានអះអាងផងដែរថា ថ្នាក់ដឹកនាំបក្សបានជួបប្រជុំក្នុងឆ្នាំ ១៩៧៦ ហើយបានសម្រេចលើការបំបែកប្រជាជនពីគ្នាទៅតាមវណ្ណៈរបស់ពួកគេ[២៤២៧] ដោយចំណុចនេះគឺជាគោលនយោបាយមួយ ដែលត្រូវបានបន្តអនុវត្តរហូតក្នុងអំឡុងពេលដែលពាក់ព័ន្ធក្នុងសំណុំរឿង ០០២/០១ នេះ[២៤២៨]។ នៅដើមឆ្នាំ ១៩៧៨ ប៉ុល ពត និង ខៀវ សំផន សុទ្ធតែបានបញ្ជាក់ថា ថ្នាក់ដឹកនាំបក្សនៅតែចាត់ទុកជនដែលមានប្រភពចេញពីវណ្ណៈផ្សេង ក្រៅពីវណ្ណៈកសិករ ថាជាជនសង្ស័យ[២៤២៩]។

៧៧០. នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ បក្សបានបើកសន្និបាតសេដ្ឋកិច្ចទូទាំងប្រទេសលើកទីពីររបស់ខ្លួន។ បន្ទាប់ពីបានវិភាគទៅលើជោគជ័យ និងបរាជ័យនៅក្នុងឆ្នាំ ១៩៧៦ រួចមក តំណាង "អង្គការបក្ស" បានដាក់ចេញផែនការឆ្នាំ ១៩៧៧ ដែលរួមមាន ទិសដៅផលិតផល ៣ តោន ក្នុង ១ ហិកតា និង ៦ តោន ក្នុង ១ ហិកតា សម្រាប់តំបន់ណាដែលអាចផលិតបានទាំងស្រូវប្រាំង និងស្រូវវស្សា។ ថ្នាក់ដឹកនាំបក្សមានបំណងថា កម្លាំងមនុស្សត្រូវបានបញ្ជូនជាមុនទៅកាន់តំបន់ដែលមានទឹកគ្រប់គ្រាន់ និងដីមានជីជាតិ ហើយនៅពេលណាដែលកម្លាំងមនុស្សទំនេរ ត្រូវចាត់ចែងឲ្យ

---

ក្រសួងសង្គមកិច្ច ការទទួលខុសត្រូវលើផលិតកម្ម ការបែងចែកឱសថ និងការការពារជំងឺ ការបែងចែកពលកម្ម កង្វះឱសថ និងអាហារ ព្រមទាំងការប្រើប្រាស់ពលកម្មកុមារ)។

[២៤២៧] បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Elizabeth BECKER,ឯកសារ E3/94, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១, ទំព័រ ៨-៩, ERN (ភាសាខ្មែរ) 00578899-00578900 (សេចក្តីសម្រេចរបស់ សោ ភឹម និង រស់ ញឹម ដើម្បីបំបែកមនុស្សនៅក្នុងភូមិភាគរបស់ពួកគេតាមវណ្ណៈនោះ ត្រូវបានទទួលស្គាល់ជាសមូហភាព ដោយថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំមួយក្នុងឆ្នាំ ១៩៧៦)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣។

[២៤២៨] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៥-៦២៣, ៦៥៣។

[២៤២៩] សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៧, ERN (ភាសាខ្មែរ) 00324816 (វណ្ណៈកសិករថ្នាក់ទាប សុទ្ធសាធ និងវណ្ណៈកណ្តាលថ្នាក់ក្រោម គឺជាប្រភពដ៏ប្រសើរសម្រាប់កងទ័ព វណ្ណៈអធន និងវណ្ណៈពាក់កណ្តាលអធន។ ការជ្រើសរើសយុទ្ធជនពីប្រភពដទៃទៀតនឹងធ្វើឲ្យខូចខាតដល់កងទ័ព)។ *ភ្នំពេញប្រមូលផ្តុំអបអរសាទរខួប ១៧ មេសា* (SWB) (សម្រង់សុន្ទរកថា ថ្លែងដោយ ខៀវ សំផន ប្រធាននៃគណៈប្រធានរដ្ឋ), ឯកសារ E3/562, ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ទំព័រ ៤-៥, ERN (ភាសាខ្មែរ) 00249992-00249993 (កំហឹងវណ្ណៈបានកើនឡើង)។

លើកទំនប់ និងជីកប្រឡាយ។ ប្រជាជនត្រូវបែងចែកទៅតាមវណ្ណៈរបស់ខ្លួន ដើម្បីធានាថា "ប្រជាជនថ្មី" ដែលមិនអាចទុកចិត្តបាន ត្រូវបានចាត់តាំងឲ្យបំពេញការងារបន្ទាប់បន្សំ[២៤៣០]។

៧៧១. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា "អង្គការបក្ស" ដែលបានសម្រេចទៅលើផែនការនេះ គឺជាសមាជិករបស់មជ្ឈិមបក្ស ដែលរួមទាំង សមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម[២៤៣១]។ ផែនការនេះ ធ្វើការវិភាគពីជោគជ័យ និងបរាជ័យ ក្នុងឆ្នាំ ១៩៧៦ ហើយផ្តល់ការណែនាំដើម្បីកែតម្រូវលើកំហុសឆ្គង និងធ្វើឲ្យស្ថានភាពល្អប្រសើរឡើងនៅតាមទីជនបទ។ យោងតាម ខៀវ សំផន ការវិភាគ និងការណែនាំបែបនេះ ជាទូទៅ ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម[២៤៣២]។ ដោយពិចារណាទៅលើការទទួលខុសត្រូវរបស់ពួកគេ ជាពិសេសទាក់ទងទៅនឹងផ្នែកសេដ្ឋកិច្ច[២៤៣៣] ព្រមទាំងការចូលរួមរបស់ពួកគេនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម ក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ ដែលក្នុងកិច្ចប្រជុំទាំងនេះបានធ្វើការសម្រេច និងបញ្ជាក់អំពីផែនការឆ្នាំ ១៩៧៦ ព្រមទាំងបានបង្កើតសមាសធាតុផ្សេងៗនៃផែនការឆ្នាំ ១៩៧៧ នោះ[២៤៣៤] អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នួន ជា និង ខៀវ សំផន បានចូលរួមក្នុងការរៀបចំបង្កើតផែនការឆ្នាំ ១៩៧៧ ដែលត្រូវបានផ្សព្វផ្សាយដោយតំណាងរបស់ "អង្គការបក្ស" ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ។

---

[២៤៣០] *ទស្សនាវដ្តីទង់បដិវត្ត*, ឯកសារ E3/139, ចុះខែ វិច្ឆិកា ឆ្នាំ ១៩៧៦, ទំព័រ ១-៥២, ERN (ភាសាខ្មែរ) 00064960-00064989។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២១។

[២៤៣១] ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER), ទំព័រ ៥៦-៥៧, ៥៩-៦០ (យោងទៅលើផែនការឆ្នាំ ១៩៧៦ ប៉ុន្តែបានបញ្ជាក់ថា ជាទូទៅ ផែនការសេដ្ឋកិច្ចបក្ស គឺជាលទ្ធផលនៃថ្នាក់ដឹកនាំមជ្ឈិមសមូហភាព, "ដែលជាស្នូលនៃគណៈកម្មាធិការមជ្ឈិមនៅពេលខ្លះ")។

[២៤៣២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៤។

[២៤៣៣] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៤។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០០-៤០៧។

[២៤៣៤] *សូមមើលឧទាហរណ៍* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៩, ៧៤៣, ៧៤៥, ៧៥២។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន), ទំព័រ ៦៧ ដល់ ៦៩ (គាត់ត្រូវបានស្នើឲ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ប្រទេស)។ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារ E3/232, ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, ទំព័រ១-៨, ERN (ភាសាខ្មែរ) 00017116-00017123 (ប៉ុល ពត នួន ជា ខៀវ សំផន និង ខឿន បានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានសម្រេចលើគោលដៅនាំចេញស្រូវអង្ករសម្រាប់ឆ្នាំ ១៩៧៧ ព្រមទាំងបញ្ជាក់ថា តំបន់ត្រូវបែងចែកពលកម្មប្រកបដោយយុទ្ធសាស្ត្រ យោងតាមគោលដៅបក្ស)។

៧៧២. ក្រៅពីការចូលរួមក្នុងកិច្ចប្រជុំរបស់មជ្ឈិម កម្មាភិបាល និងលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ដូចជា រស់ ញឹម ក៏បានមកទីក្រុងភ្នំពេញយ៉ាងទៀងទាត់ ដើម្បីជួបប្រជុំជាមួយមេដឹកនាំបក្ស ក្នុងនោះ រួមទាំង ជាមួយ នួន ជា ផងដែរ[២៤៣៥]។ មេដឹកនាំបក្ស រួមទាំង ប៉ុល ពត ខៀវ សំផន និង នួន ជា បានដឹកនាំវគ្គរៀនសូត្រក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្តើមវគ្គរៀនសូត្រទាំងនោះភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ពួកគេបានធ្វើបទឧទ្ទេសនាមចំពោះកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការលើកភ្លឺស្រែ ជីកប្រឡាយ និងការបំពេញការងារ និងបង្កបង្កើនផលតាមផែនការកំណត់[២៤៣៦]។

៧៧៣. មេដឹកនាំបក្ស រួមទាំង ប៉ុល ពត នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ក៏បានធ្វើដំណើរទៅតាមភូមិភាគនានាដើម្បីសង្កេតមើលដំណើរការបដិវត្តន៍សង្គមនិយម និងដើម្បីជួបប្រជុំជាមួយនឹងកម្មាភិបាល និងមេដឹកនាំភូមិភាគផងដែរ[២៤៣៧]។ យោងតាមសាក្សី សូត្រ ទៀង នួន ជា ធ្វើដំណើរ

---

[២៤៣៥] *សូមមើលឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទៀង) ទំព័រ ៦៣ (រស់ ញឹម បានមកទីក្រុងភ្នំពេញ "យ៉ាងទៀងទាត់" ជារឿយៗក្នុងអំឡុងពេលភ្ជុំបិណ្ឌ និងស្នាក់នៅ ក-១ រយៈពេល ១០ ទៅ ១៥ថ្ងៃ)។

[២៤៣៦] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ៦៧-៧៤, ៧៤-៧៦។ ប្រតិចារឹក ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ៣៤-៣៩, ៥៣, ៦៦-៨៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ), ទំព័រ ២៨-៣៤, ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចម តុន ហៅ ភី ភួន), ទំព័រ ៥២-៥៥។ ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចម តុន ហៅ ភី ភួន) ទំព័រ ៧៥-៧៧។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (ហ្វីលីព ស្សូត) ទំព័រ ៥៧-៥៩។ ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ២០-២១។ *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៨។

[២៤៣៧] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧, ៦០៥។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ ខៀវ សំផន៖ សៀវភៅនិពន្ធដោយ ខៀវ សំផន ៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោល-ជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ១៥៥-១៥៦ ERN (ភាសាខ្មែរ) 00103885-00103886 (ខ្ញុំត្រូវបានអនុញ្ញាតឲ្យទៅទស្សនកិច្ចនៅភូមិភាគបស្ចិម និងភូមិភាគនិរតី ព្រមទាំងឲ្យអមព្រះរាជដំណើរសម្តេច នរោត្តម សីហនុ នៅភូមិភាគកណ្តាល និងភូមិភាគពាយ័ព្យ។ ដូច្នេះ គាត់បានឃើញការប្រឹងប្រែង រៀបចំរបស់អង្គការនៅតាមទីជនបទ)។ សៀវភៅនិពន្ធដោយ សម្តេច នរោត្តម សីហនុ៖ *សង្គ្រាម និងសេចក្តីសង្ឃឹម* ឯកសារ E3/1819 ទំព័រ ៤ ERN (ភាសាខ្មែរ) 00763545 (រួមទាំង រូបថត សម្តេច នរោត្តម សីហនុ ខៀវ សំផន

ទៅខេត្តបាត់ដំបងដើម្បីជួបប្រជុំជាមួយនឹង រស់ ញឹម រៀងរាល់ ៣ ទៅ ៤ ខែម្តង[២៤៣៨]។ លើសពីនេះទៀត ទូរលេខមួយចំនួនដែលនៅសេសសល់ពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨ បង្ហាញថា កម្មាភិបាល និងលេខាភូមិភាគ ដូចជា រស់ ញឹម និង សោ ភឹម បានរាយការណ៍ជូនអង្គការ ឬ ថ្នាក់ដឹកនាំ ដោយបានចម្លងជូន ប៉ុល ពត សុន សេន វន វ៉េត នួន ជា និង/ឬ មន្ទីរ ៨៧០ អំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងស្ថានការណ៍ខ្មាំងផ្សេងទៀត និងអំពីការវាយប្រយុទ្ធនៅតាមព្រំដែនជាមួយនឹងវៀតណាម។ ពួកគេក៏បានស្នើសុំការណែនាំផ្សេងៗផងដែរ[២៤៣៩]។

---

និងអ្នកផ្សេងទៀតនៅក្នុងខេត្តសៀមរាបក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៦)។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៦-១៧ (នៅក្នុងឆ្នាំ ១៩៧៦ គាត់បានឃើញប្រឡាយ និងទំនប់នានា រួមទាំងនៅទំនប់ត្រពាំងថ្ម និងទំនប់មួយទៀតនៅខាងលិចខេត្តបាត់ដំបង។ ដោយសារមានទំនប់ទាំងអស់នេះហើយ ទើបដីស្រែស្ងួតបែកក្រហែងបានប្រែក្លាយទៅជាដីស្រែដូចក្រឡាចត្រង្គ លាតសន្ធឹងដល់ជើងមេឃ "ជាហេតុធ្វើឲ្យខ្ញុំរំភើបចិត្ត")។

[២៤៣៨] ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សូត្រ ទឿង) ទំព័រ ៥៨, ៦២-៦៣។

[២៤៣៩] *សូមមើល* ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១២, ៣៣៧, ៣៣៨។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/889 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៧ (ឈុន បានរាយការណ៍ជូន ម-៨៧០ និងចម្លងជូនអ្នកផ្សេងទៀត ក្នុងនោះរួមមាន នួន ជា ដោយស្នើកម្លាំងរបស់អង្គការជួយបន្ទាន់)។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/908 ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ភួង បានរាយការណ៍ជូន ម-៨៧០ និងចម្លងជូនអ្នកផ្សេងទៀត ក្នុងនោះ រួមមាន នួន ជា អំពីស្ថានការណ៍លើបញ្ហាបរាជ័យ និងស្ថានការណ៍លើបញ្ហាយួន។ "យើងខ្ញុំផ្ទាល់ខ្លួនស្នើសុំឲ្យអង្គការជួយធ្វើអន្តរាគមន៍ឲ្យឆាប់" ស្នើកម្លាំងរបស់អង្គការជួយបន្ទាន់ ស្នើអង្គការអនុញ្ញាតឲ្យពួកគេចាត់តាំងកម្លាំង និងស្នើឲ្យអង្គការផ្តល់អាវុធ។ ទូរលេខនេះបានសរុបថា ពួកគេសូមអង្គការមានមតិណែនាំ និងសម្រេចតាមសភាពការណ៍)។ ទូរលេខនៃ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/918 ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៧៨ (សែ បានរាយការណ៍ជូន ម-៨៧០ និងចម្លងជូន នួន ជា និង ប៉ុល ពត អំពីការវាយប្រយុទ្ធគ្នាជាមួយខ្មាំង)។ របាយការណ៍ ម៥៦០ ឯកសារ E3/179 (ដែលអាចមើល E3/180) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ (ម-៥៦០ បានរាយការណ៍ជូនអង្គការអំពីសភាពការណ៍ខ្មាំង)។ របាយការណ៍ ម៥៦០ ឯកសារ E3/1179 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00214271-00214272 (ម-៥៦០ បានរាយការណ៍ជូនអង្គការអំពីសភាពការណ៍ខ្មាំង និងបានសន្និដ្ឋានថាខ្មាំងដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយនោះ ត្រូវបានចាប់ខ្លួន និងកម្ទេចជាបន្តបន្ទាប់)។ របាយកាណ៍នៃកម្ពុជា-ប្រជាធិបតេយ្យ ឯកសារ E3/950 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00021043 (ញឹម បានរាយការណ៍ជូនអង្គការថា ពួកគេបានកម្ទេចខ្មាំងខាងក្នុងដែលបានវាយយើងនៅថ្ងៃទី ០៥ ខែ ឧសភា រួចអស់ហើយ) ERN (ភាសាខ្មែរ) 00021043-00021044 (បានរាយការណ៍អំពីវិធានការដោះស្រាយ។ គាត់បានកត់សម្គាល់ថា "ការពារឲ្យបានម៉ឺងម៉ាត់ថែមទៀត ប្រុងប្រយ័ត្នឲ្យខ្ពស់ថែម វាយកម្ទេចខ្មាំងឈ្លានពាន លួចនេះលួចនោះឲ្យអស់")។ របាយកាណ៍នៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1183 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៧៧ (តំបន់ ៣ បានរាយការណ៍ជូន ម-៥៦០ ថា ខ្មាំងវណ្ណៈដែលលាក់ខ្លួនក្នុងស្រុក សហករណ៍ និងក្នុងចំណោមប្រជាជននៅតែបន្តបង្កឲ្យមានហេតុ-ការណ៍ប្រឆាំងបដិវត្តន៍ ហើយបានរៀបរាប់ហេតុការណ៍ទាំងនោះ)។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ

៧៧៤. ទោះបីជានៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាប្រឈមមុខកាន់តែខ្លាំងឡើងជាមួយនឹងរបាយការណ៍អន្តរជាតិស្តីអំពីការរំលោភសិទ្ធិមនុស្សក៏ដោយ ក៏អាជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើទំនាក់ទំនងការទូតជាមួយនឹងប្រទេសកុម្មុយនីស្ត ប្រទេសជិតខាង និងប្រទេសមិនចូលបក្សសម្ព័ន្ធ ព្រមទាំងអង្គការនានាផងដែរ[២៤៤០]។ ទោះបីជាយ៉ាងនេះ ក៏

E3/1120 ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (សាន (ម-៥៦០) បានរាយការណ៍ជូន ញឹម និងចម្លងជូន ក្នុងចំណោមនោះ នួន ជា អំពីវិធានការណ៍ដោះស្រាយរបស់តំបន់ពាក់ព័ន្ធនឹងខ្មាំង ពោលគឺ បានកំណត់អត្តសញ្ញាណខ្មាំង ឃោសនា និងអប់រំប្រជាជនអំពីបដិវត្តន៍សង្គមនិយម មូលដ្ឋាន និងយោធាត្រូវសហការគ្នាជិតស្និទ្ធដើម្បីកម្ទេចខ្មាំងគ្រប់បែបយ៉ាង)។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/243 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨ (សោ ភឹម (ផុន) បានរាយការណ៍ជូនបង ប៉ និងចម្លងជូន ក្នុងចំណោមនោះ អ៊ុំ នួន)។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/910 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ញឹម បានរាយការណ៍ជូនអង្គការ ៨៧០ ស្នើសុំមតិយោបល់អំពីការវាយទីតាំងដែលឃើញមានខ្មាំងចូលដៃជើងជាមួយមហាក្បត់ អ៊ិន តាំ)។ របាយកាណ៍នៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/860 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៨ (ញឹម បានរាយការណ៍ជូនអង្គការអំពីវិធីដោះស្រាយ ក្នុងនោះ ចំពោះទាហានមកពីរបបមុនៗ និងអំពីស្ថានភាពសុខភាពរបស់គាត់)។

[២៤៤០] អនុស្សារណៈរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជាប្រចាំខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ E3/490 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១២ ERN (ភាសាខ្មែរ) 00522396 (ដោយមានលេចឮព័ត៌មានទាក់ទងនឹងការបង្ខំប្រជាជនឲ្យធ្វើការជាទម្ងន់ ទុរ្ភិក្ស ឬ ការសម្លាប់ដោយគ្មានការជំនុំជម្រះជាមុន រួចមក ខ្មែរក្រហមទំនងដូចជាសម្រេចចិត្តបង្កើបទ្វារទីក្រុងភ្នំពេញ។ ទស្សនកិច្ចរបស់ភ្ញៀវទាំងនោះ ផ្លាស់វេនជាបន្តបន្ទាប់គ្នាក្នុងរយៈពេល ១៥ ថ្ងៃម្តង)។ អនុស្សារណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិ កម្មវត្ថុ៖ ការវាយតម្លៃលើការវិវត្តន៍នៅឥណ្ឌូចិនចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00742974-00742975 (ប្រទេសកម្ពុជាបានភ្ជាប់ទំនាក់ទំនងការទូតឡើងវិញជាមួយនឹងប្រទេសវៀតណាម ចិន កូរ៉េខាងជើង អាល់បានី យូហ្គោស្លាវី គុយបា ឡាវ និងថៃ។ ប្រទេសកម្ពុជាក៏ភ្ជាប់ចំណងមិត្តភាពជាមួយប្រជាជាតិអាស៊ីអាគ្នេយ៍ផងដែរ)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ទំព័រ ២០ ERN (ភាសាអង់គ្លេស) 00003256 (ដើម្បីចូលរួមចំណែកក្រសួងការបរទេសនឹងពង្រីកមិត្តភាព ជាពិសេស ជាមួយនឹងបណ្តាប្រទេសបដិវត្តន៍ បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ កម្លាំងចម្រើននៅតាមបណ្តាប្រជាជាតិមិនចូលបក្សសម្ព័ន្ធ និងប្រទេសតតីយលោក)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ទំព័រ ៥២ ERN (ភាសាអង់គ្លេស) 00003288 (មិត្តជិតស្និទ្ធជាមួយរបបកម្ពុជាប្រជាធិបតេយ្យរួមមាន ប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសអាល់បានី។ ប្រទេសយូហ្គោស្លាវី និងបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធក៏ជាប្រទេសជាមិត្តផងដែរ)។ ទូរលេខពីក្រសួងការបរទេសអាមេរិក៖ បទសម្ភាសន៍សារព័ត៌មានញូវវីក (Newsweek) ជាមួយ លោក អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (វត្តមានរបស់អៀង

ដោយ ការគ្រប់គ្រងបក្សនៅក្នុងប្រទេសកម្ពុជានៅមិនទាន់ចាត់ទុកថាមានភាពរឹងមាំគ្រប់គ្រាន់ដែលអាចបើកចំហប្រទេសនៅឡើយទេ[២៤៤១]។ នៅចុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ដោយប្រឈមនឹងជម្លោះជាមួយវៀតណាមកាន់តែខ្លាំងឡើង បក្សបានកំណត់ថា បក្សត្រូវធ្វើការកែប្រែប្រទេសវិញ និងថា ប្រទេសកម្ពុជាមិនអាចនៅឯកកោពីឆាកអន្តរជាតិបានឡើយ[២៤៤២]។

៧៧៥. នៅថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ ដោយសារបញ្ហាសុខភាព នាយករដ្ឋមន្ត្រី ប៉ុល ពត ត្រូវបានជំនួសភារកិច្ចជាបណ្តោះអាសន្ន ហើយ នួន ជា បានបំពេញភារកិច្ចជានាយករដ្ឋមន្ត្រីបណ្តោះអាសន្ននេះ[២៤៤៣]។ នៅក្នុងសុន្ទរកថាមួយដែលត្រូវបានចាក់ផ្សាយក្នុងវិទ្យុទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៧ ប៉ុល ពត បានចេញមុខជានាយករដ្ឋមន្ត្រី និងជាលេខាបក្សឡើងវិញ ហើយគាត់បានបញ្ជាក់ជាសាធារណៈជាលើកដំបូង អំពីអត្ថិភាពនៃបក្សកុម្មុយនីស្តកម្ពុជា និងមាគ៌ាបក្សក្នុងការកសាង និងការការពារប្រទេស[២៤៤៤]។

---

សារី ក្នុងពេលសន្និសីទកំពូលនៃប្រទេសមិនចូលបក្សសម្ព័ន្ធបានចង្អុលបញ្ជាក់ថា ប្រទេសកម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការផុសចេញពីការលាក់បាំងនៃទុក្ខវេទនា ដើម្បីស្វែងរកទំនាក់ទំនងអន្តរជាតិឲ្យបានទូលំទូលាយជាងមុន។

[២៤៤១] ប្រតិចារឹកខ្មែរអាត់សម្លេងនៃបទសម្ភាសន៍ជាមួយ អៀង ធិរិទ្ធ ដោយ Elizabeth BECKER ឯកសារ E3/659 ចុះខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00771134-00771135 (ទើបតែចាប់ពីឆ្នាំ ១៩៧៨ មក ទើបប្រទេសចាត់ទុកថាមានភាពរឹងមាំគ្រប់គ្រាន់អាចបើកចំហបាន)។

[២៤៤២] *ឱកាសជួបជាមួយ ខៀវ សំផន* (សារព័ត៌មាន The Nation) ឯកសារ E3/660 ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៨១ ទំព័រ ៤-៨ ERN (ភាសាខ្មែរ) 00665526-00665530 (នៅទីបំផុត បក្សបានដឹកថា កម្ពុជាប្រជាធិបតេយ្យពុំអាចនៅឯកោបានឡើយ)។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00224470-00224471 (កម្ពុជាប្រជាធិបតេយ្យពុំបានធ្វើការងារឃោសនាគ្រប់គ្រាន់ក្នុងឆាកអន្តរជាតិនោះទេ ខណៈវៀតណាមធ្លាប់បានធ្វើការងារនេះបានច្រើនណាស់)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Elizabeth BECKER ឯកសារ E3/94 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578895-00578896 (ហេតុផលចម្បងលើការបើកទំនាក់ទំនងនៅក្នុងឆ្នាំ ១៩៧៨ គឺមកពីការគំរាមកំហែងរបស់វៀតណាម និងការទទួលស្គាល់ថា កម្ពុជាប្រជាធិបតេយ្យមិនអាចពឹងផ្អែកលើខ្លួនឯងបានឡើយ។ កម្ពុជាប្រជាធិបេតេយ្យ ត្រូវការការគាំទ្រផ្នែកការទូត និងមិនអាចបន្តគោលនយោបាយនៃខ្លួនទីពឹងខ្លួនផ្នែកសេដ្ឋកិច្ចនេះបានឡើយ)។

[២៤៤៣] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២២-៣២៣។

[២៤៤៤] បទឧទ្ទេសនាមរបស់តំណាងបក្សក្នុងឱកាសអបអរខួបទី ១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00442092-00442093។ *សូមមើលផងដែរ* ទូរលេខរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅប្រទេសកម្ពុជា៖ ទស្សនកិច្ចផ្លូវការ

៧៧៦. នៅក្នុងអំឡុងពេលសន្និបាតបក្សលើកទី ៥ ថ្ងៃទី ០១ និង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ បក្សបានបញ្ជាក់ថា បក្សនឹងនៅតែបន្តផ្តោតជាចំបងទៅលើផ្នែកកសិកម្ម សេដ្ឋកិច្ច និងកិច្ចការការពារប្រទេស[២៤៤៥]។

### ១៤.១.៥ សំអាងច្បាប់

៧៧៧. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងយូរបំផុតត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ រហូតដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ មនុស្សជាច្រើនមានគោលបំណងរួមដើម្បី "បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈមធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"[២៤៤៦]។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម រដ្ឋមន្ត្រីនៃរដ្ឋាភិបាល លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត រួមទាំង នួន ជា ខៀវ សំផន[២៤៤៧] ប៉ុល ពត[២៤៤៨] អៀង សារី[២៤៤៩] សុន សេន[២៤៥០] វន វេត[២៤៥១] តា

---

របស់លោក ប៉ុល ពត នៅចិន និងកូរ៉េខាងជើង ឯកសារ E3/484 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00797656-00797657។ កំណត់ត្រារបស់ OTAN កម្មវត្ថុ៖ ដំណើរវិវត្តន៍ថ្មីៗក្នុងវិស័យនយោបាយនៅប្រទេសកម្ពុជា ឯកសារ E3/493 ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00693767-00693768។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00752089-00752090។

[២៤៤៥] កំណត់ហេតុនៃការប្រជុំសន្និបាតបក្សលើកទី៥ ឯកសារ E3/816 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00800744-00800746 (ក្នុងចំណោមគណៈកម្មាធិការដែលត្រូវបានចាត់តាំង គណៈកម្មាធិការចំនួនពីរសម្រាប់សេដ្ឋកិច្ច មួយសម្រាប់កសិកម្ម និងពីរសម្រាប់យោធា)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ទំព័រ ១៧-២៧, ២៥-៣០។

[២៤៤៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦, ១៥៨, ១៥២៤, ១៥២៨។

[២៤៤៧] *សូមមើល* ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៦២។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៣។

[២៤៤៨] ប៉ុល ពត បានដឹកតួនាទីដឹកនាំនៅក្នុងការបង្កើតមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ ១៩៥៨។ គាត់បានក្លាយជាសមាជិកម្នាក់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងមហាសន្និបាតបក្សលើកទី ១ នាខែ កញ្ញា ឆ្នាំ ១៩៦០ ត្រូវបានតែងតាំងជាលេខានៅក្នុងមហាសន្និបាតបក្សលើកទី ២ ក្នុងឆ្នាំ ១៩៦៣ មានវត្តមាន បានចូលរួម និងធ្វើជាអធិបតីក្នុងពេលមហាសន្និបាតបក្សផ្សេងទៀត ព្រមទាំងក្នុងពេលប្រជុំសំខាន់ៗរបស់មជ្ឈិម ស្ទើរតែទាំងអស់ ដែលក្នុងពេលនោះមាគ៌ាបក្ស និងយុទ្ធសាស្ត្របក្សត្រូវបានយកមកពិភាក្សា និងសម្រេចពេញមួយអំឡុងពេលនៃបដិវត្តន៍ និងរបបកម្ពុជាប្រជាធិបតេយ្យ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧, ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២)។

ម៉ុក[២៤៥២] សោ ភឹម[២៤៥៣] រស់ ញឹម[២៤៥៤] កុយ ធួន[២៤៥៥] កែ ពក[២៤៥៦] ចាន់ សំ[២៤៥៧] ជូ ជេត[២៤៥៨] ប៉ូ ផាត[២៤៥៩] យ៉ុង យ៉ែម[២៤៦០] ប៊ន ណាន[២៤៦១] អៀង ធីរិទ្ធ[២៤៦២] និង ម៉ី ប្រាង[២៤៦៣] គឺជាសមាជិកនៃក្រុម

---

[២៤៤៩] អៀង សារី បានក្លាយជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងពេលមហាសន្និបាតបក្សនាខែ កញ្ញា ឆ្នាំ ១៩៦០។ ក្រោយមក គាត់មានវត្តមាន និងបានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗស្ទើរតែទាំងអស់ និងក្នុងពេលមហាសន្និបាត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានយកមកពិភាក្សា និងសម្រេច។ ម្យ៉ាងវិញទៀត ពេញមួយអំឡុងពេលនៃបដិវត្តន៍ និងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ទទួលខុសត្រូវលើកិច្ចការបរទេស ការការពារបក្សកុម្មុយនីស្តកម្ពុជា ការឯកភាព និងការតស៊ូមតិសម្រាប់មាគ៌ាបក្ស (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣)។

[២៤៥០] សុន សេន បានចូលរួមគ្រប់មហាសន្និបាតបក្សទាំងអស់ និងទំនងជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងបានចូលរួមគ្រប់កិច្ចប្រជុំ និងមហាសន្និបាតជាច្រើន ដែលនៅពេលនោះ មាគ៌ាបក្ស ជាពិសេស ពាក់ព័ន្ធនឹងការការពារប្រទេសត្រូវបានពិភាក្សា និងសម្រេច។ ពេញមួយអំឡុងពេលនៃបដិវត្តន៍ និងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់មានអំណាចយោធា ដំបូង ជារដ្ឋមន្ត្រីសញ្ញាវុធ និង ក្រោយមក រដ្ឋមន្ត្រីការពារជាតិ និងជានាយសេនាធិការ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧, ១៣៣។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣, ២០៤, ២៣៦)។

[២៤៥១] វន វ៉េត បានចូលរួមគ្រប់មហាសន្និបាតបក្សទាំងអស់ និងទំនងជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់មានវត្តមាន និងបានចូលរួមកិច្ចប្រជុំសំខាន់ៗ ស្ទើរតែទាំងអស់ ដែលនៅពេលនោះ មាគ៌ាបក្ស ជាពិសេស ពាក់ព័ន្ធនឹង សេចដ្ឋកិច្ចត្រូវបានពិភាក្សា និងសម្រេច។ ក្នុងអំឡុងពេលនៃបដិវត្តន៍ គាត់គឺជាលេខាភូមិភាគពិសេស និងដាក់ឲ្យទទួលខុសត្រូវលើការងារសេដ្ឋកិច្ចក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧, ១៣៣។ ផ្នែកទី ៥៖ រចនាសម្ព័នរដ្ឋបាល កថាខណ្ឌ ២០៣, ២៣៥)។

[២៤៥២] ត្រឹមឆ្នាំ ១៩៦៣ តា ម៉ុក គឺជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង ក្រោយមក បានចូលរួមគ្រប់មហាសន្និបាតបក្សទាំងអស់។ គាត់ក៏ជាលេខាភូមិភាគនិរតី និងបានចូលរួមប្រជុំរបស់មជ្ឈិមយ៉ាងទៀងទាត់ក្នុងទីក្រុងភ្នំពេញ ឬ ក្នុងភូមិភាគរបស់គាត់ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៩, ១២៤, ១៣៣។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣, ២១៩។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤០)។

[២៤៥៣] ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៦០ សោ ភឹម គឺជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងបានចូលរួមគ្រប់មហាសន្និបាតបក្សទាំងអស់។ គាត់ក៏ជាលេខាភូមិភាគបូព៌ា អនុប្រធានគណៈប្រធានរដ្ឋ និងបានចូលរួមប្រជុំរបស់មជ្ឈិមយ៉ាងទៀងទាត់ក្នុងទីក្រុងភ្នំពេញ ឬ ក្នុងភូមិភាគរបស់គាត់ (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣, ២១៩)។

[២៤៥៤] ត្រឹមឆ្នាំ ១៩៦៣ រស់ ញឹម គឺជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង ក្រោយមក បានចូលរួមគ្រប់មហាសន្និបាតបក្សទាំងអស់។ គាត់ក៏ជាលេខាភូមិភាគពាយ័ព្យ អនុប្រធានគណៈប្រធានរដ្ឋ និងបានចូលរួមប្រជុំរបស់មជ្ឈិមយ៉ាងទៀងទាត់ក្នុងទីក្រុងភ្នំពេញ ឬក្នុងភូមិភាគរបស់គាត់ (ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២១៩។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១)។

[២៤៥៥] នៅក្នុងអំឡុងពេលបដិវត្តន៍ កុយ ធួន បានក្លាយជាសមាជិកម្នាក់នៃគណ:កម្មាធិការមជ្ឈិម និងបានចូលរួមប្រជុំយ៉ាងទៀងទាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត។ គាត់ក៏ជាលេខាភូមិភាគកណ្ដាល (ឧត្តរចាស់) និងត្រូវបានចាត់តាំងឲ្យមើលខុសត្រូវបញ្ហាពាណិជ្ជកម្មនៅក្នុងឋានានុក្រមបក្សរហូតដល់ពេលចាប់ខ្លួនគាត់នាចុងឆ្នាំ ១៩៧៥។ ក្នុងតួនាទីទាំងនេះ គាត់បានកោះប្រជុំក្នុងភូមិភាគរបស់គាត់ពាក់ព័ន្ធនឹងការអនុវត្តមាគ៌ាបក្ស និងបានចូលរួមប្រជុំនានាដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានយកមកសម្រេច (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤១, ១៦២។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០, ២៣២។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០០)។

[២៤៥៦] នៅក្នុងអំឡុងពេលបដិវត្តន៍ កែ ពក បានក្លាយជាសមាជិកម្នាក់នៃគណ:កម្មាធិការមជ្ឈិម និងបានចូលរួមប្រជុំយ៉ាងទៀងទាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត។ ក្រោយពេលចាប់ខ្លួន កុយ ធួន នាចុងឆ្នាំ ១៩៧៥ រួចមកគាត់ បានក្លាយជាលេខាភូមិភាគកណ្ដាល (ឧត្តរចាស់)។ គាត់បានចូលរួមទាំងមហាសន្និបាតបក្សលើកទី ៣ និងលើកទី ៤ ព្រមទាំងកិច្ចប្រជុំផ្សេងៗទៀត ពាក់ព័ន្ធនឹងការអនុវត្តមាគ៌ានយោបាយនៅក្នុងភូមិភាគរបស់គាត់ និង/ឬ ដែលក្នុងពេលនោះ មាគ៌ាបក្សត្រូវបានយកមកពិភាក្សា និងសម្រេច (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥)។

[២៤៥៧] ចាន់ សំ ត្រូវបានតែងតាំងជាលេខាភូមិភាគឧត្តរ ក្រោយពេលបង្កើតភូមិភាគនេះប្រហែលជានៅក្នុងឆ្នាំ ១៩៧០។ ក្នុងតួនាទីនេះ គាត់បានកោះប្រជុំពាក់ព័ន្ធនឹងការអនុវត្តមាគ៌ានយោបាយ និងបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០)។

[២៤៥៨] ជូ ជេត គឺជាលេខាភូមិភាគបស្ចិម។ គាត់បានកោះប្រជុំនៅក្នុងភូមិភាគរបស់គាត់ពាក់ព័ន្ធនឹងការអនុវត្តមាគ៌ានយោបាយ និងបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២០)។

[២៤៥៩] ប៊ូ ផាត គឺជាលេខាតំបន់ស្វយ័ត ១០៣ រហូតដល់ពេលតំបន់នេះច្របាច់ចូលជាមួយភូមិភាគឧត្តរប្រហែលជានៅក្នុងឆ្នាំ ១៩៧៧។ ក្នុងតួនាទីនេះ គាត់បានកោះប្រជុំពាក់ព័ន្ធនឹងការអនុវត្តមាគ៌ាបក្សនៅក្នុងតំបន់របស់គាត់ និងបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦)។

[២៤៦០] យ៉ុង យ៉ែម គឺជាលេខាតំបន់ស្វយ័ត ៥០៥ រហូតដល់ឆ្នាំ ១៩៧៦ នៅពេលគាត់ត្រូវបានតែងតាំងតួនាទីទូតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានកោះប្រជុំពាក់ព័ន្ធនឹងការអនុវត្តមាគ៌ាបក្សនៅក្នុងតំបន់របស់គាត់ និងបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៧)។

[២៤៦១] ប៊ិន ណាន គឺជាលេខាតំបន់ស្វយ័ត ៥០៥ ពីឆ្នាំ ១៩៧៦។ គាត់បានកោះប្រជុំពាក់ព័ន្ធនឹងការអនុវត្តមាគ៌ាបក្សនៅក្នុងតំបន់របស់គាត់ និងបានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៧)។

ដែលមានគោលបំណងរួមដូចបានបញ្ជាក់នេះ។ ភ័ស្តុតាងបង្ហាញថា គោលបំណងរួមក្នុងការការពារ និងកសាងប្រទេសឲ្យបានឆាប់រហ័សតាមរយៈបដិវត្តន៍សង្គមនិយមនេះ ផ្អែកតាមគោលការណ៍រក្សាការសម្ងាត់ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យប្រមូលផ្តុំ ខ្លួនទីពឹងខ្លួន និងសមូហភាវូបនីយកម្ម ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់នៅត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ និងបានបន្តមានអត្ថិភាពយ៉ាងហោចណាស់ រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧។

៧៧៨. គ្រាន់តែមានគោលបំណងរួមដូច្នេះគឺមិនមានភាពគ្រប់គ្រាន់ ឬមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ។ តែទោះបីជាយ៉ាងណាក៏ដោយ ដីកាដំណោះស្រាយចោទប្រកាន់ថា អ្នកចូលរួមបានអនុវត្តគោលបំណងរួមនេះតាមរយៈគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន (ផ្នែក ១៤.២) និងគោលនយោបាយស្តីពីការកំណត់គោលដៅ (ផ្នែក ១៤.៣) ដែលធ្វើឲ្យមាន និង/ឬ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម[២៤៦៤]។

---

[២៤៦២] អៀង ធីរិទ្ធ គឺជាសមាជិកបក្សម្នាក់ចាប់តាំងពីបក្សបានបង្កើតឡើង និងកាន់តួនាទីឃោសនាការ និងសង្គមកិច្ចពេញមួយអំឡុងពេលនៃបដិវត្តន៍ និងសម័យកម្ពុជាប្រជាធិបតេយ្យ។ គាត់ត្រូវបានតែងតាំងជារដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៦។ គាត់បានចូលរួមប្រជុំយ៉ាងទៀតទាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣២, ២៥៤។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៥)។

[២៤៦៣] ម៉ី ប្រាង ត្រូវបានតែងតាំងជារដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍ ក្នុងខែ មេសា ឆ្នាំ ១៩៧៦។ នៅក្នុងតួនាទីនេះ គាត់បានចូលរួមប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលនៅពេលនោះ មាគ៌ាបក្សត្រូវបានពិភាក្សា និងសម្រេច (ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨)។

[២៤៦៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧-១៥៨, ១៥២៥,១៥២៨។ *សូមមើល ផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០២-១១២, ១៣២-១៥២។ ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧២។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ខណៈសំណៅភាសាអង់គ្លេសនៃដីកាដំណោះស្រាយចោទប្រកាន់ថា គោលនយោបាយនានាដែលបង្កើតជាផ្នែកមួយនៃគោលបំណងរួម “នាំឲ្យមាន និង/ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម” សំណៅភាសាបារាំងចោទប្រកាន់ថា គោលនយោបាយនានា “នាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម”។ អង្គជំនុំជម្រះសាលាដំបូងផ្អែកលើសំណៅភាសាអង់គ្លេសនៃដីកាដំណោះស្រាយ ជាពិសេស ក្រោយពីបានពិចារណាឃើញថា សំណៅភាសាខ្មែរដូចគ្នានឹងសំណៅភាសាអង់គ្លេស។ ហេតុដូច្នេះ ជនជាប់ចោទទទួលបានការជូនដំណឹងសមស្រប។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងក៏កត់សម្គាល់ឃើញថា សំណៅភាសាបារាំងនៃសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងការអនុវត្តទៅបាននៃសហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក បានបកស្រាយអត្ថន័យនៃភាសាពាក់ព័ន្ធនេះក្នុងន័យថា ការអនុវត្ត

## ១៤.២ គោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន

៧៧៩. យោងតាមដីកាដំណោះស្រាយ គោលបំណងនៃគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន រួមមាន ការឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មសម្រាប់សហករណ៍ និងការដ្ឋានការធានាស្បៀងអាហារ និងការពារសន្តិសុខរបស់ប្រជាជន និងដកហូតសិទ្ធិផ្នែកគោលនយោបាយ និងសេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងពីអតីតអ្នករដ្ឋការ[២៤៦៥]។ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជនក្នុងបីដំណាក់កាល នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដែលជាផ្នែកមួយនៃវិធីសាស្ត្រក្នុងការជម្លៀសប្រជាជន[២៤៦៦]។ មានតែដំណាក់កាលទី១ ដែលចាប់ផ្តើមនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងដំណាក់កាលទី២ ដែលចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ១៩៧៥ រហូតដល់ ឆ្នាំ ១៩៧៧ ប៉ុណ្ណោះ ដែលត្រូវបានបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[២៤៦៧]។

៧៨០. សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ជនជាប់ចោទ ចំពោះការសម្លាប់រង្គាលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និង ទី២)[២៤៦៨] និងអំពើអមនុស្សធម៌ផ្សេងទៀតក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ក៏ដូចជាបទល្មើសផ្សេងៗទៀតដែរ[២៤៦៩]។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារថាសំណុំរឿង ០០២/០១ បានកម្រិតវិសាលភាព ត្រឹមការអនុវត្តគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដូច្នេះ ដីកាដំណោះស្រាយមិនបានចោទប្រកាន់ជនជាប់ចោទថា បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការ

គោលនយោបាយ “នាំឲ្យមាន” ឬ “ត្រូវបានប្រព្រឹត្តដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម” (សេចក្តីសម្រេចលើភាពអាច អនុវត្តទៅបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៩)។

[២៤៦៥] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១។

[២៤៦៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦០, ១៦២-១៦៤។

[២៤៦៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣។ ឧបសម្ពន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។

[២៤៦៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១-១៣៨៣, ១៣៨៧-១៣៩០។

[២៤៦៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១។

សម្លាប់រង្គាល ឬ អំពើអមនុស្សធម៌ផ្សេងទៀតក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ តាមរយៈសហឧក្រិដ្ឋកម្មរួមឡើយ[២៤៧០]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិចារណាទៅលើឧក្រិដ្ឋកម្មទាំងពីរនេះ នៅក្នុងផ្នែកនៃសំអាងហេតុខាងក្រោមពាក់ព័ន្ធនឹងសហ-ឧក្រិដ្ឋកម្មរួមនេះឡើយ។

៧៨១. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយក៏បានភ្ជាប់ទំនាក់ទំនងរវាងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយចំនួន នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និង ទី២) យ៉ាងច្បាស់លាស់ទៅនឹងគោលនយោបាយស្តីពីការកំណត់គោលដៅផងដែរ[២៤៧១]។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយពិចារណាទៅលើវិសាលភាពនៃសំណុំរឿង ០០២/០១ បន្ទាប់ពីមានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានកម្រិតការពិនិត្យមើលទៅលើការទទួលខុសត្រូវ របស់ជនជាប់ចោទចំពោះគោលនយោយបាយស្តីពីការកំណត់គោលដៅត្រឹមតែទៅលើការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[២៤៧២]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ តែចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) (ដោយមិនពិចារណាទៅលើការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការបាត់ខ្លួនដោយបង្ខំ) ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជនតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា គោលបំណងមួយក្នុងចំណោមគោលបំណងនានានៃគោលនយោបាយ ស្តីពី

---

[២៤៧០] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥ (១)។ ឧបសម្ពន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។

[២៤៧១] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៩។

[២៤៧២] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។

ការផ្លាស់ទីលំនៅប្រជាជនគឺដើម្បីដកហូតសិទ្ធិផ្នែកនយោបាយ និងសេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងពីអតីតអ្នករដ្ឋការ[២៤៧៣]។

## ១៤.២.១ ទិដ្ឋភាពទូទៅ

៧៨២. ថ្នាក់ដឹកនាំបក្សមានផែនការកសាង និងការពារប្រទេស តាមរយៈការប្រមូលកម្លាំងទាំងអស់មកផ្តោតលើកសិកម្ម ដោយចុងក្រោយ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានសេដ្ឋកិច្ចបែបកសិកម្មសម័យទំនើប និងក្រោយមកជាប្រទេសឧស្សាហកម្ម[២៤៧៤]។ ផ្អែកលើគោល-

---

[២៤៧៣] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១។

[២៤៧៤] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៥៦ ERN (ភាសាអង់គ្លេស) 00079814 (កសិកម្ម គឺជាកត្តាមូលដ្ឋាននៅក្នុងការកសាងប្រទេស។ ដូច្នេះ កសិកម្មចាំបាច់សម្រាប់ការកសាងឧស្សាហកម្ម និងប្រែក្លាយកម្ពុជាប្រជាធិបតេយ្យទៅជាប្រទេសឧស្សាហ៍កម្ម)។ *អៀង សារី ស្តីពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច* (SWB)ឯកសារ E3/649 ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ១ ERN (ភាសាខ្មែរ) S 00716623 (ការបង្កបង្កើនស្រូវ គឺជាភោគទ្រព្យចំបងសម្រាប់ការកសាង និងការពារប្រទេស)។ កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00347034-00347035 (ប្រជាជនត្រូវជឿជាក់លើកសិកម្មដើម្បីចិញ្ចឹមប្រជាជន និងកសាងប្រទេស។ ពួកគេមិនអាចខ្លាចការលំបាកលំបិននោះទេ។ ទស្សនៈរបស់ ប៉ុល ពត គឺផ្តល់ទឹកឲ្យប្រជាជន និងឲ្យប្រជាជនធ្វើការងារនៅក្នុងស្រែដើម្បីកសាងប្រទេស)។ *អ្វីដែលយើងកំពុងធ្វើនៅពេលនេះ មិនធ្លាប់អនុវត្តពីមុនឡើយ* (Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00796756-00796757 (កសិកម្មគឺជាមូលដ្ឋាននៃការរៀបចំជាតិឡើងវិញ។ ផលចំណេញពីកសិកម្មនឹងត្រូវបានយកទៅប្រើប្រាស់ដើម្បីបង្កើតឧស្សាហកម្ម ដែលក្រោយមក នឹងបម្រើតម្រូវការកសិកម្ម)។ បទសម្ភាសន៍រវាង នួន ជា និង អ្នក សារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៣ ERN (ភាសាខ្មែរ) 00000905 (មូលដ្ឋានគឺផ្អែកលើកសិកម្ម បន្ទាប់មក កសាងឧស្សាហកម្មតូច ឧស្សាហកម្មមធ្យម និងចុងក្រោយ ឧស្សាហកម្មធំ ក្នុងទិសខ្លួនទីពឹងខ្លួន ខ្លួនតស៊ូដោយខ្លួនឯង បានវាខ្លាំង)។ កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00775904-00775905 (គោលបំណង និងផែនការគឺដើម្បីអភិវឌ្ឍឧស្សាហកម្មដោយប្រើប្រាស់កសិកម្មជាមូលដ្ឋាន)។ សរាចរក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិប្រទេសកម្ពុជាប្រចាំខែ វិច្ឆិកា-ធ្នូ ឆ្នាំ ១៩៧៦ ឯកសារ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00679762-00679763 (បីភាគបួននៃកម្មវិធីវិទ្យុរបស់ខ្មែរក្រហម ត្រូវបានបង្កើតទៅជាកម្មវិធីស្តីពីកសិកម្ម ការណែនាំប្រជាជនឲ្យដើរតាមទិសដៅដឹកនាំស្តីពីការលើកភ្លឺ និងការបង្កបង្កើនផលស្រូវ និងការផ្តល់ការណែនាំស្តីពីរបៀបទប់ទល់នឹងជំនន់ទឹក និងសត្វល្អិត)។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ ខៀវ សំផន ឯកសារ E3/4050 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786553-00786554 (ទាំងអ្នក

ការណ៍ខ្លួនទីពឹងខ្លួន អាទិភាពត្រូវបានផ្តោតទៅលើការកសាងគម្រោងធារាសាស្ត្រ[២៤៧៥] ការពង្រីកដីស្រែ[២៤៧៦] ព្រមទាំងការអភិវឌ្ឍសកម្មភាពឧស្សាហកម្មទាំងឡាយដែលបម្រើដល់ការអភិវឌ្ឍផ្នែក

---

ឈើ ទាំងអ្នកជា ត្រូវធ្វើការងារ ប្រសិនបើមិនធ្វើការងារឲ្យរហ័សរហួននោះទេ ប្រជាជនជាច្រើននាក់ទៀតនឹងមិនមានអាហារហូប)។ *សូមមើលផងដែរ* ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៩៣, ១៩៥, ១៩៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២,៦០៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨។

[២៤៧៥] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៥៧ ERN (ភាសាខ្មែរ) 00291026-00291027 (យើងផ្តល់អាទិភាពក្នុងការដោះស្រាយបញ្ហាទឹក ពោលគឺ កសាងអាងស្តុកទឹក លើកទំនប់ និងជីកប្រឡាយនៅទូទាំងប្រទេស ដោយផ្អែកតែលើកម្មករ-កសិករយើងតែប៉ុណ្ណោះ)។ *អៀង សារី ស្តីពីកសិកម្ម និងការផ្គត់ផ្គង់ស្បៀង* (SWB) ឯកសារ E3/552 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00717026-00717027 (ពាក់ព័ន្ធនឹងកសិកម្ម ការផ្តោតសំខាន់គឺលើការដោះស្រាយទឹកដើម្បីបង្កើនការបង្កបង្កើនផលស្រូវ)។ *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (SWB) ឯកសារ E3/200 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៤-៦ ERN (ភាសាខ្មែរ) 00292806-00292808 (ទំនប់ អាងស្តុកទឹក និងប្រឡាយទឹកត្រូវបាន កសាងឡើង ហើយ "អង្គភាពរីកចម្រើន" ស្ថិតនៅតាមការដ្ឋានការងារនានាដើម្បីធ្វើការងារកសាងទំនប់ អាងស្តុកទឹក និងប្រឡាយទឹក។ មានកម្មករ ១០.០០០ ២០.០០០ ឬ ៣០.០០០ នាក់ នៅតាមការដ្ឋានសាងសង់នីមួយៗ)។ សុន្ទរកថាដោយសមមិត្ត ខៀវ សំផន នៅឯកិច្ចប្រជុំមហាជនមួយក្នុងឱកាសខួបលើកទី៣ នៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/202 ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00287222-00287223 (មានការរីកចម្រើនលឿនលើវិស័យកសិកម្ម និងការដាំដុះស្រូវ និងទឹកប្រើប្រាស់។ បញ្ហាទាំងនេះត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស)។ *អៀង សារី ស្តីពីការ រីកចម្រើនផ្នែកសេដ្ឋកិច្ច* (SWB) ឯកសារ E3/649 ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ១ ERN (ភាសាខ្មែរ) S00716623 (ចលនាទៅដោះស្រាយបញ្ហាទឹក និងជីបានផ្អែកលើ ឯករាជ្យម្ចាស់ការ តឹងរ៉ឹងលើសកម្មភាពការងារ ខ្លួនទីពឹងខ្លួន និងសមូហភាវូបនីយកម្ម)។ សេចក្តីថ្លែការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00224464-00224465 (តាមរយៈគម្រោង ធារាសាស្ត្រ ប្រទេសកំពុងប្រមូលទុនសម្រាប់ការអភិវឌ្ឍដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ឯករាជ្យ ខ្លួនទីពឹងខ្លួន)។ *សុន្ទរកថារបស់លោក នួន ជា នៅក្នុងមិទ្ទិញទិវាខួបកងទ័ព* (SWB) ឯកសារ E3/209 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00649946-00649947 (តាមរយៈគម្រោងប្រព័ន្ធប្រលាយទឹក ប្រទេសកំពុងប្រមូលទុនសម្រាប់ការអភិវឌ្ឍដោយផ្អែកមូលដ្ឋានលើឯករាជ្យ ខ្លួនទីពឹងខ្លួន)។ កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ១-៤ ERN (ភាសាខ្មែរ) 00775899-00775902 (ជោគជ័យ ផ្នែកកសិកម្មអាស្រ័យលើទឹក)។ ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា មួយឆ្នាំបន្ទាប់មក ឯកសារ E3/2657 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00538791-00538792 (ការដ្ឋានសាងសង់ថ្មីៗរីកដុះដូចផ្សិតនៅទូទាំង

កសិកម្ម[២៤៧៧]។ ការនាំចេញផ្នែកកសិកម្ម ជាពិសេស ការនាំចេញនៅចន្លោះ ពីចុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ នឹងធានាបាននូវទុនចាំបាច់សម្រាប់កសាង និងការពារប្រទេស[២៤៧៨]។ រហូតដល់ពេល

---

ប្រទេសដើម្បីកសាងប្រព័ន្ធប្រឡាយទឹក)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៦០៨។

[២៤៧៦] *ភ្នំពេញប្រមូលផ្តុំអបអរសាទរខួប ១៧ មេសា* (កម្រងឯកសារ SWB) ឯកសារ E3/562 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ១៩៧៨ ទំព័រ ៣ ERN (ភាសាអង់គ្លេស) S 00010560 (ខៀវ សំផន បានប្រកាសថា នៅក្នុងឆ្នាំ ១៩៧៧ ប្រជាជនបានពង្រីកដីស្រែបានយ៉ាងឆាប់រហ័ស)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៦០៥។

[២៤៧៧] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៥៦ ERN (ភាសាអង់គ្លេស) 00079814 (ចំពោះឧស្សាហកម្ម ថ្នាក់ដឹកនាំបក្សកំពុងផ្តោតលើរោងចក្រដែលបម្រើដល់ការអភិវឌ្ឍកសិកម្ម)។ *ការស្តារឧស្សាហកម្មឡើងវិញ* (SWB) ឯកសារ E3/649 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) S 00716623 (រោងចក្រត្រូវបានស្តារឡើងវិញ ហើយរោងចក្រថ្មីៗត្រូវបានកសាងឡើងដើម្បីគាំទ្រដល់ចលនាកសិកម្ម ដោយប្រើប្រាស់វត្ថុធាតុដើមដែលមានស្រាប់នៅក្នុងស្រុកស្របតាមជំហរឯករាជ្យ និងខ្លួនទីពឹងខ្លួន)។ *អ្វីដែលយើងកំពុងធ្វើនៅពេលនេះ មិនធ្លាប់អនុវត្តពីមុនឡើយ* (Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00796756-00796757 (ផលចំណេញពីកសិកម្មនឹងត្រូវបានយកទៅប្រើប្រាស់ដើម្បីបង្កើតឧស្សាហកម្ម ដែលក្រោយមក នឹងបម្រើតម្រូវការកសិកម្ម)។

[២៤៧៨] សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៥៧ ERN (ភាសាខ្មែរ) 00291026-00291027 (ការនាំចេញអង្ករ កៅស៊ូ និងផលិតផលកសិកម្មផ្សេងទៀតធ្វើឡើងដើម្បីប្រមូលទុនសម្រាប់ការពារ និងកសាងប្រទេស)។ *អៀង សារី ស្តីពីកសិកម្ម និងការផ្គត់ផ្គង់ស្បៀង* (SWB) ឯកសារ E3/552 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00717026-00717027 (ស្រូវកំពុងត្រូវបាននាំចេញរាប់ម៉ឺនតោនដើម្បីបង្កើនមូលធនក្នុងការផ្តល់ជាហិរញ្ញវត្ថុដល់វិស័យការពារជាតិ និងកិច្ចខិតខំប្រឹងប្រែងកសាងរបស់យើង)។ សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ក្នុងឱកាសពិធីខួបលើកទី ៣ នៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/169 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ៥ ERN (ភាសាអង់គ្លេស) 00280393 (នៅក្នុងឆ្នាំ ១៩៧៧ ពួកគេអាចនាំចេញ ដែលការនាំចេញនេះបានរកទុនបានសម្រាប់ការកសាងជាតិ)។ កិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយនឹងអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ១-៤ ERN (ភាសាខ្មែរ) 00775899-00775902 (ត្រឹមឆ្នាំ ១៩៧៧ ពួកគេបានសម្រេចផែនការបង្កបង្កើនផល ដូច្នេះពួកគេអាច នាំអង្ករចេញដើម្បីនាំចូលសម្ភារៈប្រើប្រាស់ចាំបាច់នានាមកវិញ) ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00775904-00775905 (កសិកម្មកសាងទុន ហើយបន្ទាប់មក ទុនអាចយកមកប្រើប្រាស់ដើម្បីកសាងឧស្សាហកម្ម)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២។

នោះ ដោយគ្មានធនធាន ឬ សម្ភារៈបរិក្ខារមិនគ្រប់គ្រាន់ ទុនតែមួយគត់ដែលថ្នាក់ដឹកនាំបក្សមានដើម្បីសម្រេចគោលដៅនេះ គឺប្រជាជន[២៤៧៩]។

៧៨៣. ខៀវ សំផន បានពន្យល់ថា ដើម្បីកសាងប្រទេសឲ្យបានលឿន ដើម្បីដោះស្រាយបញ្ហាខ្វះខាតស្បៀងអាហារ និងដើម្បីផលិតស្រូវឲ្យលើសពីតម្រូវការ ក្នុងគោលបំណងអាចឲ្យប្រទេសប្រែក្លាយទៅជាប្រទេសឧស្សាហាភាវូនីយកម្ម យើងត្រូវបង្ខំប្រជាជនឲ្យចូលរួមក្នុងសហករណ៍[២៤៨០]។

---

[២៤៧៩] បទអន្តរាគមន៍របស់ អៀង សារី នៅក្នុងមហាសន្និបាតលើកទី ៣១ របស់អង្គការសហប្រជាជាតិ ឯកសារ E3/607 ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ១៦-១៨ ERN (ភាសាខ្មែរ) 00816633-00816635 (កិច្ចខិតខំកសាងសេដ្ឋកិច្ចត្រូវផ្អែកមូលដ្ឋានលើកម្លាំងមិនចេះរីងស្ងួត និងច្នៃប្រឌិតរបស់ប្រជាជន ក៏ដូចជាការប្រើប្រាស់ធនធាន និងសក្តានុពលទាំងអស់របស់ជាតិ)។ *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (SWB) ឯកសារ E3/200 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៤-៦ ERN (ភាសាខ្មែរ) 00292806-00292808 (អ្វីៗត្រូវបានធ្វើឡើងដោយផ្អែកលើកម្លាំងរបស់ប្រជាជន)។ *អៀង សារី ស្តីពីកសិកម្ម និងការផ្គត់ផ្គង់ស្បៀង* (SWB) ឯកសារ E3/552 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00717026-00717027 (ទំនប់ ប្រឡាយ និងអាងស្តុកទឹកត្រូវបានកសាងដោយកម្មករ និងកសិករសុទ្ធសាធដោយផ្អែកទាំងស្រុងលើការខិតខំប្រឹងប្រែងរបស់ពួកគេ)។ សុន្ទរកថាដោយសមមិត្ត ខៀវ សំផន នៅឯកិច្ចប្រជុំមហាជនមួយក្នុងឱកាសខួបលើកទី៣ នៃការបង្កើត កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/202 ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៨ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00287224-00287225 (ដើម្បីកសាងប្រទេស យើងចាំបាច់ផ្អែកជាមូលដ្ឋានលើកម្លាំងប្រជាជន)។ ការឆ្លើយឆ្លងជាមួយ ខៀវ សំផន ឯកសារ E3/3193 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00704255។ សរាចរក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្រវត្តិប្រទេសកម្ពុជាប្រចាំខែ វិច្ឆិកា-ធ្នូ ឆ្នាំ ១៩៧៦ ឯកសារ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00679762-00679763 (កត្តាតែមួយគត់នៃការបង្កបង្កើនផល ពោលគឺ ពលកម្មដោយប្រើកម្លាំង ត្រូវបានប្រើប្រាស់ជាប្រយោជន៍ទាំងស្រុង)។ *សូមមើលផងដែរ*ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២។

[២៤៨០] ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4049 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00780962-00780963 (ប្រជាជននឹងមិនចូលរួមក្នុងសហករណ៍ដោយស្ម័គ្រចិត្តនោះទេ សូម្បីកសិករក្រក៏មិនទទួលយកសហករណ៍កម្រិតខ្ពស់ផងដែរ។ ហេតុដូច្នេះ ដំបូង យើងត្រូវបង្ខិតបង្ខំសិនហើយ)។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4050 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786553-00786554 (ដំបូង ប្រជាជនត្រូវបានបង្ខំ រួមទាំង អ្នកទីក្រុងផងដែរ)។ កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ERN (ភាសាខ្មែរ) 003470-003470 (នៅក្នុងឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានជម្លៀសឲ្យទៅរស់នៅតាមសហករណ៍។ ដំបូង ពួកគេត្រូវបានបង្ខំ។ ប៉ុន្តែពួកគេមានអាហារគ្រប់គ្រាន់ហូប ហើយការការពារមានលក្ខណៈងាយស្រួលជាងមុន)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗ*

នៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ គាត់បានសរសេរថា យើងចាំបាច់ត្រូវយកប្រជាជនខ្លះ ដែលខ្មែរក្រហមបានកំណត់អត្តសញ្ញាណថាជា "ប្រជាជនថ្មី" នាពេលក្រោយមក (រួមទាំង ម្ចាស់ដី អ្នកជំនួញតូចតាច និងអ្នកចងការប្រាក់) ចេញពីសកម្មភាពដែលមិនផ្តល់ផលច្រើនឱ្យទៅចូលរួមក្នុងការបង្កបង្កើនផល[២៤៨១]។ គាត់ក៏បានផ្តល់ទឡ្ហីករណ៍ថា "ការរៀបចំប្រកបដោយវិធីសាស្ត្រនូវថាមពលនេះ ជាដំបូង ជាក្រុមកាងារដើម្បីជួយគ្នាទៅវិញទៅមក ហើយបន្តបន្ទាប់មកទៀត ជាសហករណ៍" នឹងបង្កើនផលិតផល បង្កើតដីថ្មីៗ និងធ្វើឱ្យប្រព័ន្ធធារាសាស្ត្រមានភាពប្រសើរឡើង[២៤៨២]។ នៅទីបំផុត ខៀវ សំផន បានជឿថា ប្រជាជននឹងក្លាយជាអ្នកចូលរួមដោយស្ម័គ្រចិត្តនៅក្នុងបដិវត្តន៍សង្គមនិយម។ ពួកគេនឹងមើលឃើញផ្លែផ្កាកើតចេញពីកម្លាំងពលកម្មរបស់ពួកគេ និងទទួលយកតួនាទីរបស់ពួកគេជាកសិករទាំងអស់គ្នានៅក្នុងការការពារ និងកសាងប្រទេសកម្ពុជាឡើងវិញ[២៤៨៣]។

---

*នេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦៦-៦៩ ERN (ភាសាខ្មែរ) 00103841-00103842 (សហករណ៍កម្រិតខ្ពស់ត្រូវចាត់តាំងលើប្រជាជន ពីព្រោះគ្មានកសិករនៅក្នុងប្រទេសណាមួយសុខចិត្តប្រគល់ផលទាំងអស់នៃការខិតខំភ្ជួររាស់ដាំដុះទៅឱ្យអង្គការនោះទេ) ទំព័រ ១២៨-១៣១ ERN (ភាសាខ្មែរ) 00103872-00103873 (ប៉ុល ពត ជឿជាក់ថា វិធីតែមួយគត់ដែលអាចឱ្យប្រជាជនដែលបានផ្លាស់ទីលំនៅរស់បាន គឺត្រូវបង្កើត "សមូហភាវូបនីយកម្មដោយបង្ខំ")។ *សូមមើលផងដែរ*ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦-៥៧៧ (ពាក់ព័ន្ធនឹងឯកសារបោះពុម្ពផ្សាយ និងសេចក្តីណែនាំរបស់បក្សឱ្យបញ្ជូនប្រជាជនទៅកសាង និងពង្រីកសហករណ៍ និងឱ្យផ្លាស់ទីលំនៅប្រជាជនរហូតទាល់តែសហករណ៍នីមួយៗអាចផ្តល់កម្លាំងពលកម្មសម្រាប់គ្រប់សកម្មភាពទាំងអស់ដោយខ្លួនឯងបាន)។

[២៤៨១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥៤។

[២៤៨២] និក្ខេបបទរៀបរៀងដោយ ខៀវ សំផន៖ *សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម* ឯកសារ E3/123 ខែ មីនា ឆ្នាំ ១៩៧៩ ទំព័រ ១៥០-១៥១ ERN (ភាសាខ្មែរ) 00767442-00767443។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ខៀវ សំផន កថាខណ្ឌ ៣៥៤។

[២៤៨៣] ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4050 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786553-00786554 (នៅពេលប្រជាជនឃើញស្រែ វាបង្ហាញឱ្យឃើញច្បាស់ ហើយពួកគេសប្បាយរីករាយដោយសារពួកគេបានចូលរួមកសាងប្រទេសឡើងវិញ។ ម្នាក់ៗមានគំនិតយល់ឃើញថា ពួកគេគឺជាកសិករ)។ សុន្ទរកថារបស់ ខៀវ សំផន ក្នុងឱកាសពិធីខួបលើកទី ៣ នៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/169 ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ៨ ERN (ភាសាអង់គ្លេស) 00280396 (ប្រជាជនបានយល់ឃើញថា របបសមូហភាពនេះអាចការពារ និងកសាងប្រទេសយ៉ាងមានប្រសិទ្ធភាព ហើយនឹងបង្កើនជីវភាពរស់នៅកាន់តែប្រសើរជាងមុនយ៉ាងឆាប់រហ័ស)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ សៀវភៅនិពន្ធ ដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រ កម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៦៦-៦៩ ERN (ភាសាខ្មែរ) 00103841-00103842 (យើង

៧៨៤. លើសពីនេះទៀត នៅពេលផ្លាស់ទីលំនៅប្រជាជន បណ្ដាញខ្មាំងនឹងត្រូវបំបែក ពិសេសខ្មាំងដែលបានបង្កប់ក្នុងចំណោម "ប្រជាជនថ្មី" ដែលតែងតែត្រូវបានសង្ស័យជាដរាបមក។ ដូច្នេះ ការបះបោរ និង/ឬការជ្រៀតជ្រែកពីបរទេស អាចនឹងត្រូវទប់ស្កាត់បាន[២៤៨៤]។ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅទាំងនេះ និងនៅតាមសហករណ៍ និងការដ្ឋានគោលដៅនានារបស់ពួកគេ "ប្រជាជនថ្មី" អាចត្រូវបានអប់រំកែប្រែឡើងវិញ ហើយការបែងចែកវណ្ណៈអាចត្រូវលុបបំបាត់នៅខណៈពេលដែលប្រជាជនទាំងអស់គ្នាធ្វើការងារដើម្បីសម្រេចទិសដៅផលិតរបស់បក្ស[២៤៨៥]។

---

ចាំបាច់ត្រូវពេលយូរពន្យល់ដោយអត់ធ្មត់ ទម្រាំកសិករសុខចិត្តប្រគល់ផលទាំងអស់នៃការខិតខំភ្ជួររាស់ដាំដុះទៅឱ្យសហករណ៍។ យើងក៏ត្រូវបង្ហាញភស្តុតាងជាក់លាក់ថា ប្រព័ន្ធនៃការបង្កបង្កើនផលនេះនឹងធ្វើឱ្យជីវិតរបស់ពួកគេប្រសើរឡើង)។ *សូមមើលផងដែរ* ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3196 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00807445-00807446 ("ខៀវ សំផន បានអះអាងថា មានសេចក្ដីណែនាំមួយបានបញ្ជូនទៅឱ្យកម្មាភិបាល ដោយបានណែនាំពួកគេឱ្យពន្យល់ប្រាប់ប្រជាជនអំពីបញ្ហាខ្វះអង្ករ និងថ្នាំពេទ្យដោយសារប្រទេសទើបតែងើបពីសង្គ្រាម")។

[២៤៨៤] *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៨, ១១០, ១៥៣, ១៦៩។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៥-៥២៦។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៧។

[២៤៨៥] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/10 ចុះខែ កញ្ញា-ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ៦១-៦៣ ERN (ភាសាខ្មែរ) 00063095-00063096 (ការជម្លៀសជម្រុញដល់ការតស៊ូវណ្ណៈ)។ របាយការណ៍ស្ដីពីខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ឯកសារ E3/50 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ១៦-១៨ ERN (ភាសាខ្មែរ) 00442215-00442217 (ការជម្លៀសបានវាយប្រហារ និងកម្ចាត់វណ្ណៈសក្តិភូមិម្ចាស់ដី និងវណ្ណៈនាយទុន)។ កំណត់ហេតុនៃការប្រជុំលេខាអនុលេខាកងពល និងវរៈសេនាធំឯករាជ្យ ឯកសារ E3/13 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00052407-00052408 (ប្រសិនបើបក្សបានទុកប្រជាជនចោល និងមិនធ្វើការជម្លៀសពួកគេពីខេត្តក្រុង និងទីប្រជុំជន បក្សនឹងពុំមានសន្តិភាព និងភាពស្ងប់ស្ងាត់ដែលខ្លួនទទួលបាននាពេលក្រោយមកនោះទេ។ ប្រសិនបើបក្សមិនដាច់ខាតលើការបង្កើតសហករណ៍ ហើយមិនដាច់ខាតលើការបង្កើតសង្គមនិយមទេនោះ បក្សមិនបានទទួលជ័យជម្នះ និងមិនរស់នៅប្រកបដោយសន្តិភាពនោះទេ)។ សុន្ទរកថាដោយ អៀង សារី ក្នុងពិធីភោជនាហារនាពេលល្ងាច ស្វាគមន៍ ផ្ដល់កិត្តិយសដល់សមមិត្តសមាជិកមជ្ឈិមបក្សកុម្មុយនីស្ត Maxist-Leninist សហរដ្ឋអាមេរិក ឯកសារ E3/211 ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) S 00801571-00801572 (ប្រទេសមានមូលដ្ឋានកាន់តែច្រើនជាបន្តបន្ទាប់មកសម្រាប់ដោះស្រាយទំនាស់រវាងកម្មករ និងកសិករ និងរវាងខេត្តក្រុង និងជនបទ)។ សរាចរក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្រវត្តិប្រទេសកម្ពុជាប្រចាំខែ វិច្ឆិកា-ធ្នូ ឆ្នាំ ១៩៧៦ ឯកសារ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00679761-00679762 (ផ្អែកតាមរបាយការណ៍ស៊ើបសង្ងាក់គ្នារបស់ជនភៀសខ្លួន និងសេចក្ដីណែនាំផ្សព្វផ្សាយតាមវិទ្យុ យើងអាច

“ប្រជាជនថ្មី” មិនអាចទុកចិត្តបានទេ ដរាបណាពួកគេមិនទាន់បានឆ្លងកាត់ការតស៊ូ និងការលំបាកនៅក្នុងបដិវត្តន៍សង្គមនិយម និងមិនទាន់បានរៀនពីរបៀបធ្វើស្រែ និងធ្វើការងារ ហើយលុះត្រាតែទស្សនៈរបស់ពួកគេដូចនឹងទស្សនៈរបស់បក្សដែរ[២៤៨៦]។

៧៨៥. ក្រោយពេលជម្លៀស ប្រជាជនស្រេកឃ្លាន ហើយជារឿយៗ ពួកគេគ្មានជម្រក។ បញ្ហាខ្វះស្បៀងអាហារកើតមាននៅទូទាំងប្រទេស[២៤៨៧] លើកលែងតែនៅមជ្ឈិមបក្ស ដែលនៅទីនោះ ថ្នាក់

---

យល់អំពីសេដ្ឋកិច្ចកម្ពុជាបាន។ ទ្រព្យសម្បត្តិឯកជនត្រូវបានលុបបំបាត់ចោល។ គ្រប់មធ្យោបាយផលិតកម្ម និងចិញ្ចឹមជីវិតជារបស់សមូហភាព។ សង្គមមិនមានវណ្ណៈ ហើយអ្នកដែលមានអំណាច ទ្រព្យ សម្បត្តិ និងចំណេះដឹងត្រូវបានកម្ទេចចោល)។ *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០២-១១៨។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៦, ៥៤៥។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២-៦២៣។

[២៤៨៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦២ (ដើម្បីក្លាយជាសមាជិកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា បុគ្គលទាមទារមានបទពិសោធន៍លើការតស៊ូ និងចលនាបដិវត្តន៍)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨ ERN (ភាសាខ្មែរ) 00000900 ។ ការឆ្លើយឆ្លងជាមួយ ខៀវ សំផន ឯកសារ E3/3193 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៣ ERN (ភាសាខ្មែរ) 00704255 ។ ទូរលេខរបស់ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00709578-00709579 (ភ្លេងជាតិកម្ពុជាលើកឡើងថា ឈាមកម្មករកសិករ និងយុទ្ធជនរំដោះពួកគេពីទាសភាព)។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4045 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00784359-00784360 (ប្រជាជននៅទីក្រុងភ្នំពេញពុំដែលធ្លាប់តស៊ូ និងពុំយល់អ្វីៗនោះទេ)។ *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (SWB) ឯកសារ E3/200 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ១-៤, ១០-១២ ERN (ភាសាខ្មែរ) 00292803-00292806, 00292812-00292814 (វណ្ណៈមកពីទីក្រុងភ្នំពេញកាន់តែមានភាពស្នេហាជាតិ ដោយសារពួកគេបានយល់ថា ផ្លូវទៅរកឯករាជ្យភាពមានភាពលំបាកលំបិន)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦២៣។

[២៤៨៧] ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4048 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00788401-00788402 (សូម្បីនៅតាមជនបទ ប្រជាជនក៏ពិបាកក្នុងការចិញ្ចឹមខ្លួនឯងផងដែរ)។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន E3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00499664-00499665 (នៅតាមតំបន់រំដោះដែលឧត្តមសេនីយ៍ សរ ប៊ុន បានឆ្លងកាត់នៅពេលគាត់រត់គេចចេញពីប្រទេសកម្ពុជា ជារឿយៗ អ្នកភូមិមិនអាចផ្តល់អ្វីៗឱ្យគាត់ហូបនោះទេ)។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ទំព័រ៥១ ERN (ភាសាអង់គ្លេស) 00003287 (បញ្ហានៅកើតមានលើស្បៀងអាហារ និងជម្រកនៅឡើយ) ទំព័រ៥២

ដឹកនាំទំនងជាមានអាហារហូបគ្រប់គ្រាន់ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[២៤៨៨]។ ស្ថានភាពនេះបានប៉ះពាល់ដល់អ្នកដែលត្រូវបានជម្លៀសខ្លាំងជាងគេ[២៤៨៩]។ នួន ជា និង ខៀវ សំផន បានទទួលស្គាល់ថា បក្សបានដឹងថា ប្រជាជននឹងត្រូវលះបង់ និងជួបប្រទះការលំបាក។ ដូច្នេះ ទាំងក្នុងអំឡុងពេល និង ក្រោយពេលជម្លៀស ពួកគេបានទទួលស្គាល់ថា ប្រជាជនជាច្រើននាក់បានទទួលរងគ្រោះ ឬបានស្លាប់ដោយសារជំងឺ ឬការអត់អាហារ[២៤៩០]។ ខៀវ សំផន បានពន្យល់នាពេល

---

ERN (ភាសាអង់គ្លេស) 00003288 (ឆ្នាំ ១៩៧៦ គឺជាឆ្នាំសំខាន់មួយសម្រាប់ការបង្កបង្កើនផល ពីព្រោះក្នុងឆ្នាំ ១៩៧៥ ប្រជាជនចំនួន ៣.០០០.០០០ នាក់ មកពីទីក្រុងភ្នំពេញត្រូវការ ការផ្គត់ផ្គង់ជម្រក និងស្បៀងអាហារ)។

[២៤៨៨] ប្រតិចារឹកថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ទំព័រ៧៣-៧៥ *យោង*សៀវភៅនិពន្ធដោយ P. SHORT៖ *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ E3/9 ឆ្នាំ ២០០៤ ទំព័រ ៣៤៦-៣៤៨ ERN (ភាសាអង់គ្លេស) 00396554-00396556 (ថ្នាក់ដឹកនាំមាននំប៉័ងថ្មីៗ រៀងរាល់ព្រឹក ម្ហូបអាហារច្រើនជាមួយសាច់មាន់ សាច់ជ្រូក ស្រា និងបាយដំណើប។ ការពិត មេដឹកនាំទាំងអស់ រួមទាំង ប៉ុល ពត នួន ជា និង ខៀវ សំផន ឡើងគីឡូ ហើយស្បែកឡើងកន្ទួលក្រហមៗ។ ទោះបីជាមេដឹកនាំទាំងនេះពុំមានអាហារវិសេសក៏ដោយ ក៏គម្លាតរវាងម្ហូបអាហារដែលពួកគេហូប និងម្ហូបអាហារដែលប្រជាជនមាន គឺខុសគ្នាសម្បើមណាស់)។

[២៤៨៩] ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារ E3/4041 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00782544-00782545 (ប្រជាជនជាច្រើននាក់បានស្លាប់ដោយសារការអត់អាហារ និងស្ថានភាពបានដាក់បន្ទុកធ្ងន់លើអ្នកដែលត្រូវបានជម្លៀស។ ស្ថានភាពនេះគេចមិនផុតឡើយ)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកទៅកាន់ប្រទេសកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00583720-00583721 (អៀង សារី បានទទួលស្គាល់ថា ការជម្លៀសបង្ហាញឲ្យឃើញនូវការលំបាក ហើយមនុស្ស ២.០០០ នាក់ បានស្លាប់នៅតាមផ្លូវ។ ប្រជាជនមិនសុំនឹងការរស់នៅតាមទីជនបទ ដូច្នេះ រយៈពេលក្រោយការជម្លៀស មានសភាពយ៉ាប់យ៉ឺនដោយសារការផ្ទុះឡើងនៃជំងឺគ្រុនចាញ់)។ កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយនឹង អៀង ធីរិទ្ធ ឯកសារ E3/659 ចុះខែ តុលា-ខែ វិច្ឆិកា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00771123-00771124 (ប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ពុំសប្បាយចិត្តឡើយ)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/198 ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00078213-00078214 (សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការជម្លៀសទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀត ធ្វើឲ្យអ្នកដែលត្រូវបានជម្លៀសមិនសប្បាយចិត្ត និងទម្លាក់បន្ទុកលើប្រជាជនមូលដ្ឋាន)។ *សូមមើលផងដែរ* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២១, ៥៣៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥។

[២៤៩០] *អ្វីដែលយើងកំពុងធ្វើនៅពេលនេះមិនធ្លាប់អនុវត្តពីមុនឡើយ* (Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00796757-00796759 (ប៉ុន្មានខែដំបូងក្រោយរំដោះមានសភាពតឹងតែគ្រាន់បើ៖ ប្រជាជន ២.០០០ ទៅ ៣.០០០ នាក់ បានស្លាប់នៅក្នុងអំឡុងពេលនៃការជម្លៀសក្រុងភ្នំពេញ និងពីរបីពាន់នាក់ទៀតបានស្លាប់នៅតាមវាលស្រែ)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00000901-00000902 (ការស្លាប់មានច្រើនប្រភេទក្នុងអំឡុងពេលនៃសម័យកម្ពុជា

ក្រោយមកថា ថ្នាក់ដឹកនាំខ្មែរក្រហមស្ថិតក្នុងសភាពទាល់ច្រក។ បើមិនជម្លៀសក៏ស្លាប់។ បើជម្លៀសក៏ស្លាប់[២៤៩១]។ ទាំង នួន ជា ទាំង ខៀវ សំផន បានជឿថា ការងារជាអាទិភាព គឺការ

---

ប្រជាធិបតេយ្យ រួមទាំង ដោយសារជំងឺ ការខ្វះស្បៀងអាហារ និងអ្នកដែលត្រូវបានកម្ទេចដោយក្រុមអាក្រក់។ នួន ជា បានទទួលស្គាល់ថា កម្ពុជាប្រជាធិបតេយ្យជាអ្នកទទួលខុសត្រូវលើការកាប់សម្លាប់ប្រជាជនដែលមានចំណេះដឹង ប៉ុន្តែការកាប់សម្លាប់នេះគឺអចេតនានោះទេ)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3198 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២-១៣ ERN (ភាសាខ្មែរ) 00807466-00807467 (ការងារលំបាក ហើយប្រជាជនខ្លះត្រូវ "លះបង់បងប្អូនកូនចៅរបស់ពួកគេ។ ប៉ុន្តែ ប្រជាជនមិនគួរគិតអំពីកំហឹងផ្ទាល់ខ្លួននោះទេ។ ពួកគេគួរគិតអំពីអនាគតរបស់ប្រទេស និងអ្វីដែលសំខាន់បំផុតនោះគឺអ្នកដែលហ៊ានវាយប្រឆាំងដើម្បីរំដោះ ដើម្បីជោគជ័យនៅក្នុងការការពារអធិបតេយ្យជាតិ)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4037 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00784645-00785646 (ឆ្លើយតបទៅនឹងសំណួរអំពីការជម្លៀស និងការស្លាប់នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បាននិយាយថា ពួកគេខិតខំព្យាយាមតស៊ូជិតស្លាប់ដើម្បីការពារប្រទេសប្រឆាំងនឹងការគ្រប់គ្រងរបស់បរទេស)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4043 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00780960-00780961 (ការស្លាប់ភាគច្រើនគឺដោយសារការខ្វះថ្នាំសង្កូវ និងការអត់អាហារ។ អ្វីៗកាន់តែមានសភាពអាក្រក់ទៅៗនៅពេលពេលវេលាបន្តដើរទៅមុខនោះ)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ឯកសារ E3/210 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00156690-00156691 (ខៀវ សំផន បានដឹងថា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនទំនងជាអាចស្លាប់នៅតាមផ្លូវ)។ សៀវភៅនិពន្ធដោយ GINA T. និង ថេត សម្បត្តិ៖ *នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហម និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់* ឯកសារ E3/4202 ទំព័រ ១៦ ERN (ភាសាអង់គ្លេស) 00757484 (នួន ជា បានទទួលស្គាល់ថា នៅពេលធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ ភ្លាមៗក្រោយពេលជម្លៀសនោះ គាត់ខ្លួនឯងផ្ទាល់បានឃើញអ្នកដែលត្រូវបានជម្លៀស ដើរតាមផ្លូវ ហើយគាត់បានទទួលស្គាល់ថា ពួកគេពិបាកធ្វើដំណើរ។ ក្រោយមក គាត់បានឃើញសាកសពនៅក្នុងផ្ទះក្នុងទីក្រុងភ្នំពេញ)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦១-៦២ ERN (ភាសាខ្មែរ) 00103838-00103839 (គាត់បានគិតដល់ប្រជាជនទាំងអស់ ទាំងចាស់ ទាំងស្ត្រីមានផ្ទៃពោះ ទាំងក្មេង និងទាំងអ្នកឈឺដែលត្រូវធ្វើដំណើរដោយថ្មើរជើងក្រោមកំដៅថ្ងៃក្តៅហែង មិនដឹងថាពួកគេអាចយករបស់របររបស់ពួកគេទៅជាមួយបានដែរឬក៏អត់នោះទេ) ទំព័រ ១៤០-១៤១ ERN (ភាសាខ្មែរ) 00103878 (ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងបានធ្វើឲ្យខ្ញុំរន្ធត់ចិត្ត ស្មុគស្មាញ និងទំនាស់ក្នុងខ្លួន រកគិតអ្វីពុំឃើញទេ ដូច្នេះខ្ញុំក៏ពុំអាចសម្រេចនិយាយស្តីអ្វីបានទេ ដើម្បីប្រឆាំងនឹងអំពើហិង្សាដែលបានប្រព្រឹត្តក្នុងនាមខ្ញុំ។ សតិសម្បជញ្ញៈរបស់ខ្ញុំបញ្ជាឲ្យខ្ញុំរួមចំណែកការពារសិទ្ធិរបស់ប្រទេសខ្ញុំ)។

[២៤៩១] ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4040 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២ ERN (ភាសាខ្មែរ) 00780958។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4048 គ្មានចុះ កាលបរិច្ឆេទ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00788401-00788403។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4041 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00782543-00782544។

កសាង និងការពារប្រទេស។ មានតែនៅក្រោយពេលសម្រេចគោលបំណងបដិវត្តន៍រួចហើយ ប៉ុណ្ណោះ ដោយការធ្វើឱ្យប្រទេសឯករាជ្យ អាចទីពឹងខ្លួនឯងបាន និងជាប្រទេសសង្គមនិយម ទើប បញ្ហាសិទ្ធិមនុស្សនឹងត្រូវបានធានា[២៤៩២]។

៧៨៦. អង្គជំនុំជម្រះសាលាដំបូង នឹងលើកឡើងអំពីគោលនយោបាយជាក់លាក់ស្ដីពីការជម្លៀស ប្រជាជនចេញពីទីក្រុង (ផ្នែក ១៤.២.២ ) និងការផ្លាស់ទីលំនៅប្រជាជន ពីទីជនបទមួយ ទៅទី ជនបទផ្សេងទៀត (ផ្នែក ១៤.២.៣) នៅក្នុងផ្នែកខាងក្រោមនេះ។ គោលនយោបាយទាំងនេះមាន ដើមកំណើត និងផ្អែកលើបទពិសោធន៍របស់បក្សនៅមុនឆ្នាំ ១៩៧៥[២៤៩៣]។ អង្គជំនុំជម្រះសាលា ដំបូងបានសម្រេចរួចហើយថា នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បក្សមានគោលនយោបាយ មួយ គឺការជម្លៀសប្រជាជនចេញពីទីប្រជុំជន និងទីក្រុង[២៤៩៤]។

[២៤៩២] បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១៤ ERN (ភាសាខ្មែរ) 00000906 (ដោះស្រាយជីវភាពសេដ្ឋកិច្ច ពុំដែលមានភាពងាយស្រួលនោះទេ។ អ្នកខ្លះរស់ អ្នកខ្លះស្លាប់ ប៉ុន្តែ បើប្រៀបធៀបទៅ ជាតិនៅរក្សាបាន។ សិទ្ធិមនុស្ស និងឯករាជ្យភាព អាស្រ័យគ្នាទៅវិញទៅមកដោយសារថា បើមិនមានឯករាជ្យ សិទ្ធិ មនុស្សក៏គ្មានដែរ)។ សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និង គោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៣៤ ERN (ភាសាខ្មែរ) 00103825 (បានប្រកាសថា នៅពេលសិទ្ធិមនុស្ស និងការការពារប្រទេសទំនាស់គ្នា "ការការពារអធិបតេយ្យភាពប្រទេសជាការ ត្រឹមត្រូវគ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងទាំងអស់")។

[២៤៩៣] កិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00062456-00062457។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយបណ្ដាញទូរទស្សន៍ ABC ឯកសារ E3/93 ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00224443-00224444 (អៀង សារី បានពិភាក្សាជាមួយ ប៉ុល ពត នៅក្នុងឆ្នាំ ១៩៧៤ អំពីការជម្លៀសស្ទឹងត្រែង និងក្រចេះ)។ សៀវភៅ និពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ចុះខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៦៣-៦៤ ERN (ភាសាខ្មែរ) 00103839-00103840 (ប៉ុលពតបានប្រាប់ ខៀវ សំផន ថា ការជម្លៀស គឺជាផ្នែកមួយនៃគោលនយោបាយស្ដីពីសមូហភាវូបនីយកម្មដែលបានអនុវត្តរួចហើយនៅតាមទីជនបទ មុនពេលសង្គ្រាមបានបញ្ចប់)។

[២៤៩៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤-១០៥, ១១១-១១២, ១៤៦។

## ១៤.២.២ ការជម្លៀសប្រជាជនចេញពីខេត្ត-ក្រុង

### ១៤.២.២.១ គោលនយោបាយ

៧៨៧. ថ្នាក់ដឹកនាំបក្ស រួមទាំង ប៉ុល ពត និង នួន ជា យល់ឃើញថា ខេត្ត ក្រុងគឺជាកន្លែងគំរាមកំហែង ដោយសារមានខ្មាំងជាច្រើននៅតាមខេត្ត ក្រុង ដែលជាទីស្នាក់ការនៃវណ្ណៈគ្រប់គ្រងគេ និងជា "ឧបករណ៍ជិះជាន់" របស់វណ្ណៈនេះ[២៤៩៥]។ នៅក្នុងសុន្ទរកថាផ្សេងៗ ខៀវ សំផន មានការសង្ស័យ និងមិនទុកចិត្តដូច្នេះដែរ[២៤៩៦] ហើយក្រោយមក បានបញ្ជាក់ថា នេះគឺជាមាគ៌ាបក្សនៅគ្រប់

[២៤៩៥] សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ឯកសារ E3/196 ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១៥-១៧ ERN (ភាសាខ្មែរ) 00224471-00224473 (ជាពិសេស សមាជិកបក្សត្រូវប្រុងប្រយ័ត្ននៅពេលត្រូវធ្វើការងារនៅក្នុងខេត្តក្រុងក្នុងរយៈកាលបដិវត្តន៍) ទំព័រ ២០-២២ ERN (ភាសាខ្មែរ) 00224476-00224478 (ទោះបីនៅក្នុងខេត្តក្រុង ជីវភាពរស់នៅប្រសើរជាងក៏ដោយ ក៏នៅទីនេះ មានខ្មាំងច្រើនណាស់ដែរ) ទំព័រ ២២-២៣ ERN (ភាសាខ្មែរ) 00224478-00224479 (ទីក្រុងគឺជាទីស្នាក់ការរបស់វណ្ណៈគ្រប់គ្រង និងឧបករណ៍ជិះជាន់របស់វណ្ណៈនេះ)។ កិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយនឹងអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00775906-00775907 (មានចំណុចខ្សោយនៅក្នុងខេត្តក្រុង និងចំណុចខ្លាំងនៅក្នុងប្រទេស)។ *ទស្សនាវដ្តីទង់បដិវត្ត* ឯកសារ E3/11 ចុះខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៤២-៤៥ ERN (ភាសាខ្មែរ) 00631140-00631141 (ចាប់តាំងពីដើមដំបូងមក បក្សបានទទួលស្គាល់ថា "ដំណោះស្រាយរួម" ចំពោះការដោះស្រាយ "ទំនាស់" គឺ បំផុសកសិករឲ្យតស៊ូ និងវាយវណ្ណៈជិះជាន់ជាសក្តិភូមិម្ចាស់ដី។ ពួកគេបំផុសឲ្យវណ្ណៈកសិករឃើញទំនាស់ ហើយមានកំហឹងវណ្ណៈដើម្បីតស៊ូ) ទំព័រ ៦០-៦២ ERN (ភាសាខ្មែរ) 00631150-00631151 ("មាគ៌ាដំណើរការ" របស់បក្ស "គឺជនបទជាបង្អែក" ពីព្រោះ "សំណាញ់របស់ខ្មាំងវាណែនណាស់" នៅទីក្រុង ហើយ "ខ្មាំងវានៅពេញ)។ *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១-១១២។

[២៤៩៦] *របាយការណ៍របស់ ខៀវ សំផន* (សេវាផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១២-១៤ ERN (ភាសាខ្មែរ) 00657442-00657444 (នៅក្នុងមតិយោបល់របស់គាត់ស្តីពីសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី និងជាពិសេស លើបញ្ញត្តិពាក់ព័ន្ធនឹងវប្បធម៌ ខៀវ សំផន បានលើកឡើងថា យើងចាំបាច់ "ប្រឆាំងជាដាច់ខាតចំពោះអំពើពុករលួយទាំងអស់ វប្បធម៌ប្រតិកិរិយានៃវណ្ណៈសង្កត់សង្កិន និងវប្បធម៌ពួកចក្រពត្តិនិយម និងអាណានិគមបែបថ្មីនៅកម្ពុជា។ [...] ផ្ទះទាំងឡាយនៅទីក្រុងភ្នំពេញពោរពេញទៅដោយរឿងរ៉ាវដែលមិននឹកស្មានដល់។ ខ្ញុំមិនដឹងរៀបរាប់យ៉ាងដូចម្តេចទេ។ [...] ប្រសិនបើយើងអនុញ្ញាតឲ្យវប្បធម៌ពុករលួយប្រភេទនេះបំផ្លិចបំផ្លាញប្រទេសយើង វាប្រាកដជាធ្វើឲ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់យើងក្នុងការការពារប្រទេស ការការពារឯករាជ្យភាព និងអធិបតេយ្យភាពយើងជាមិនខាន")។

ពេលនៃបដិវត្តន៍[២៤៩៧]។ ដូច្នេះ ខ្មែរក្រហមបានបំពាក់បំប៉នកម្មាភិបាល និងប្រជាជននៅតាមមូលដ្ឋានឲ្យមានការសង្ស័យលើប្រជាជនទីក្រុង និងធ្វើជាសត្រូវចំពោះពួកគេ[២៤៩៨]។ ជាលទ្ធផល ភាពស្អប់ខ្ពើម និងការមិនទុកចិត្តលើ "ប្រជាជនថ្មី" ត្រូវបានចិញ្ចឹមក្នុងចិត្តរបស់អ្នកទាំងនេះ[២៤៩៩] ហើយពួកគេត្រូវបានជំរុញឲ្យមានអារម្មណ៍ទាំងនេះ នៅគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[២៥០០]។

---

[២៤៩៧] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ ទំព័រ ១៣២-១៣៤ ERN (ភាសាខ្មែរ) 00380366-00380368 (មាគ៌ាបក្សគឺជនបទជាមូលដ្ឋានសំខាន់សម្រាប់បដិវត្តន៍ ចំណែកទីក្រុងជាក្បាលម៉ាស៊ីនសម្រាប់វណ្ណៈកាន់អំណាច និងពួកចក្រពត្តិ ជាកន្លែងដែលសត្រូវបដិវត្តន៍ អាចប្រមូលកម្លាំងកម្ទេចយើង)។

[២៤៩៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី François PONCHAUD ឯកសារ E3/4591 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ៣-៥ ERN (ភាសាខ្មែរ) 00897586-00897588 (មនោគមន៍វិជ្ជាជាហេតុផល ពោលគឺ កម្មាភិបាលម្នាក់បានប្រាប់ PONCHAUD ថា ទីប្រជុំជនគ្មានអ្វីល្អនោះទេ ដោយសារគ្មានអ្វីផលិត ហើយនឹងមានអំពើពុករលួយនៅទីកន្លែងទាំងនោះ)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (ឈូក រីន) ទំព័រ ៤៤-៤៦ (សាក្សីបានបញ្ជាក់ថា គេបានដឹងជាទូទៅថា នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អ្នកដែលរស់នៅតាមខេត្តក្រុងពុំទាន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនោះទេ ហើយខេត្តក្រុងត្រូវបានកាន់កាប់ដោយខ្មាំង។ ក្នុងនាមជាយោធាម្នាក់ សាក្សីបានដឹងថា អ្នកដែលកាន់កាប់ខេត្តក្រុងគឺជាខ្មាំង)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧៩-៨០ (ខ្មាំងមាននិយមន័យច្បាស់លាស់ ពោលគឺ អ្នកដែលនៅក្នុងខេត្តក្រុង។ ការត្រូវរ៉ូវជាមួយនឹងខ្មាំងគឺដូចនឹងការទទួលស្គាល់ថា អ្នកទុកចិត្តពួកគេ ប៉ុន្តែខ្មែរក្រហមមិនទុកចិត្តប្រជាជននៅក្នុងក្រុងឡើយ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៨-១៩ (មានការបែងចែកច្បាស់លាស់រវាងប្រជាជននៅតាមតំបន់រំដោះ និងប្រជាជននៅតាមខេត្តក្រុង។ ប្រជាជននៅតាមខេត្តក្រុងត្រូវបានមើលឃើញថាបានជ្រើសរើសនៅជាមួយនឹងលន់ នល់ ដូច្នេះ ក្រោយមក ពួកគេទទួលបានការប្រព្រឹត្តិមិនប្រសើរឡើយ)។ *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១-១១២។

[២៤៩៩] *សូមមើល*ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១-១១២។

[២៥០០] *សូមមើល ឧទាហរណ៍ ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍* ចុះខែ កក្កដា ឆ្នាំ ១៩៧៥ ឯកសារ E3/724 ERN (ភាសាខ្មែរ) 00663861-00663862 (សូម្បីក្រោយរំដោះទីក្រុងភ្នំពេញហើយក៏ដោយ ក៏បរិយាកាសសក្តិភូមិ នាយទុនជាមួយនឹងសម្ភារៈទំនើប បានធ្វើឲ្យយុវជន យុវនារី និងកម្មាភិបាល វក់វីវង្វេង ធ្វើឲ្យពួកគេបាត់ម្ចាស់ការ និងភ្លេចជំហរបដិវត្តន៍របស់ពួកគេអស់។ *របាយការណ៍របស់ ខៀវ សំផន* (សេវាផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១២-១៤ ERN (ភាសាខ្មែរ) 00657442-00657444។ កំណត់ហេតុរបស់ Elizabeth BECKER ស្តីពីស្ថានភាពនៅប្រទេសកម្ពុជា ឯកសារ ចុះថ្ងៃទី ១៣-១៤ ខែ ធ្នូ ឆ្នាំ១៩៧៨ ទំព័រ ១១-១២ ERN (ភាសាខ្មែរ) 00726613-00726614 (នៅពេល BECKER បានប្រាប់កម្មាភិបាលខ្មែរក្រហមថា គាត់នៅក្នុងទីក្រុង ភ្នំពេញនៅក្នុងអំឡុងពេលនៃសង្គ្រាម កម្មាភិបាលរូបនោះឆ្លើយតបដោយមិនជឿ ហើយបានអះអាងថា មាន

៧៨៨. នៅក្នុងឆ្នាំ ១៩៧៤ និង បន្ទាប់មក ក្នុងខែ កុម្ភៈ និងខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សបានសម្រេចថា ក្រោយពេលរំដោះប្រទេសបានហើយនោះ ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីខេត្ត-ក្រុង គឺជាការងារអាទិភាពដំបូងរបស់ពួកគេនៅក្នុងអំឡុងពេលបដិវត្តន៍សង្គមនិយម[២៥០១]។ ផែនការនេះមិនបានលើកឡើងអំពីសុខុមាលភាព របស់អ្នកដែលត្រូវបានផ្លាស់ទីលំនៅនោះទេ ជាពិសេស អ្នកដែលងាយរងគ្រោះ។ នួន ជា បានពន្យល់ថា ថ្នាក់ដឹកនាំបក្សមិនមានពេលពិចារណាអំពីវិធានការជម្លៀសពិសេសសម្រាប់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យនោះទេ[២៥០២]។ យ៉ាងណាក៏ដោយ គាត់បានអះអាងថា ថ្នាក់ដឹកនាំបក្សបានជឿថា បក្សអាចគ្រប់គ្រងបានទៅលើការជម្លៀសប្រជាជន យ៉ាងហោចណាស់ ចំនួន ២.០០០.០០០ នាក់ ពីព្រោះអ្នកជំងឺនៅមន្ទីរពេទ្យ និងអ្នកជំងឺផ្សេងទៀត បានទទួលការជួយជ្រោមជ្រែង ហើយអ្នកដែលមានឡាន និងរទេះ អាចប្រើប្រាស់បានឱ្យតែពួកគេអាចចេញពីទីក្រុងភ្នំពេញបាន[២៥០៣]។ ហេតុផលចំបងនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជនត្រូវបានពិភាក្សា និងផ្សព្វផ្សាយនៅក្នុងឯកសារបោះពុម្ពផ្សាយ និងកិច្ចប្រជុំរបស់បក្ស ជាពិសេស ដើម្បីកំណត់អត្តសញ្ញាណខ្មាំងក្នុងចំណោម “ប្រជាជនថ្មី” អប់រំកែប្រែ “ប្រជាជនថ្មី” និងរៀបចំ និងបែងចែកកម្លាំងការងារយកមកផ្តោតអាទិភាពលើផ្នែកកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ[២៥០៤]។ តាមរយៈការជម្លៀសប្រជាជន ថ្នាក់ដឹកនាំបក្សជឿថា បក្សអាចរក្សាសមិទ្ធផលបដិវត្តន៍ និងកម្ចាត់វណ្ណៈនាយទុន និងសក្តិភូមិបាន[២៥០៥]។

---

តែជនក្បត់ និងគិញតែប៉ុណ្ណោះដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលនៃសង្គ្រាម)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៦, ៦២១-៦២៣។

[២៥០១] ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៦-៧៣៧។

[២៥០២] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៧៧។

[២៥០៣] ប្រតិចារឹក ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ទំព័រ ១៤-១៥។

[២៥០៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦-៥៧៧, ៦១៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧០, ៧៧២។

[២៥០៥] ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត ឯកសារ E3/1762 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00752089។ សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ទំព័រ ៤៦ ERN (ភាសាអង់គ្លេស) 00003282។

## ១៤.២.២.២ យុត្តិកម្ម

៧៨៩. ផ្អែកលើបទពិសោធន៍ពីការជម្លៀសប្រជាជននៅចន្លោះឆ្នាំ ១៩៧០ និងឆ្នាំ ១៩៧៥ ប៉ុល ពត ជឿថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជននានា គឺជាដំណោះស្រាយតែមួយគត់លើបញ្ហាទាំងឡាយដែលពួកគេអះអាង មើលឃើញ និង/ឬរំពឹងថា នឹងកើតឡើងក្រោយពេលរំដោះទីក្រុងភ្នំពេញ និងខេត្តក្រុងដទៃទៀត[២៥០៦]។ អៀង សារី [២៥០៧] ខៀវ សំផន[២៥០៨] នួន ជា[២៥០៩] និង ប៉ុល ពត[២៥១០] បានអះអាងថា ទីក្រុងភ្នំពេញ និងទីប្រជុំជនដទៃទៀត ត្រូវជម្លៀសដោយសារជនភៀសខ្លួនបានធ្វើឲ្យប្រជាជនក្នុងទីប្រជុំជនទាំងនេះកើនឡើងយ៉ាងខ្លាំងត្រឹម ខែ មេសា

---

[២៥០៦] កិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00062456-00062457។

[២៥០៧] *ការពិនិត្យពិច័យករណីកប៉ាល់* “*Mayaguez*” (*ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា*) ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-៤ ERN (ភាសាខ្មែរ) S 00651204 - S 00651207។ ទូរលេខពីក្រសួងការបរទេសអាមេរិក៖ កិច្ចសម្ភាសន៍របស់សារព័ត៌មាន Newsweek ជាមួយ អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (អៀង សារី បានអះអាងថា គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនស្បៀងអាហារចំនួន ៣០.០០០ ទៅ ៤០.០០០ តោន ទៅកាន់ទីក្រុងនោះទេ ដូច្នេះពួកគេត្រូវផ្លាស់ទីលំនៅប្រជាជនទៅរកស្បៀងអាហារវិញ)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកទៅកាន់ប្រទេសកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00583719-00583720 (សេចក្តីសម្រេចជម្លៀសទីក្រុងភ្នំពេញគឺដោយសារបញ្ហាការខ្វះស្បៀងអាហារ)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00291035-00291036 (អៀង សារី បាននិយាយថា ពួកគេត្រូវបញ្ជូនប្រជាជនទៅកាន់ទីតាំងដែលមានស្បៀងអាហារ)។

[២៥០៨] ប្រតិចារឹកបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4048 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00788401 ទំព័រ ២ ERN (ភាសាខ្មែរ) 00788402 (គេមិនអាចដឹកអង្ករពីជនបទមកបានទេ ដោយសារស្ពានផ្លូវត្រូវបានបំផ្លិចបំផ្លាញ និងដោយសារពុំមានឡានដឹកគ្រប់គ្រាន់)។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4051 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00786555-00786555 (គណៈកម្មាធិការអចិន្ត្រៃយ៍បានយល់ព្រមលើការជម្លៀសពីព្រោះប្រសិនបើមិនជម្លៀស ប្រជាជននឹងអត់អាហារស្លាប់)។

[២៥០៩] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៩ (ទោះបីស្បៀងអាហារពុំមានច្រើនហូរហៀរនៅគ្រប់កន្លែងក៏ដោយ ស្ថានការណ៍មានភាពប្រសើរជាងមុននៅតាមទីជនបទ)។

[២៥១០] កិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយនឹងអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00775906-00775907 (ប៉ុល ពត បានពន្យល់ថា ហេតុផលមួយនាំដល់ការជម្លៀសខេត្តក្រុងគឺដោយសារការពិចារណាលើបញ្ហាសេដ្ឋកិច្ច ដូចជា ការផ្តល់ស្បៀងអាហារចិញ្ចឹមប្រជាជនរាប់លាននាក់។ ដូច្នេះ វាជាការប្រសើរ ប្រសិនបើយកប្រជាជនទៅតាមទីជនបទ ហើយបែងចែកពួកគេទៅតាមសហករណ៍)។

ឆ្នាំ ១៩៧៥ ដោយសារបញ្ហាខ្វះស្បៀងអាហារដែលបណ្តាលមកពីកំណើនប្រជាជននេះ និង ដោយសារមិនមានមធ្យោបាយដឹកជញ្ជូនស្បៀងអាហារមកកាន់ខេត្តក្រុង។ ពួកគេក៏បានអះអាងថា ផែនការខ្មាំងក្នុងការលបបផ្តួលរំលំខ្មែរក្រហមបានពឹងផ្អែកលើប្រជាជននៅតាមខេត្ត-ក្រុងទាំងនោះ។ ប្រសិនបើប្រជាជននៅតាមខេត្ត-ក្រុងមិនត្រូវបានផ្លាស់ទីលំនៅទេនោះ បញ្ហាស្បៀងអាហារនឹងមិន អាចដោះស្រាយបានឡើយ ហើយប្រជាជនទាំងនេះនឹងបះបោរតាមការញុះញង់របស់គិញ្ញ បរទេស[២៥១១]។ ទាហាន លន់ នល់ និងគិញ្ញបរទេសដែលបានបង្កប់ខ្លួនក្នុងចំណោមប្រជាជននៅ តាមខេត្ត-ក្រុង នឹងឆក់យកឱកាសនេះដើម្បីធ្វើការបះបោរ[២៥១២] ហើយឥទ្ធិពលនៃរបបចាស់ និង

---

[២៥១១] *ការពិនិត្យពិច័យករណីកប៉ាល់ "Mayaguez" (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា)* ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-៤ ERN (ភាសាខ្មែរ) S 00651204 - S 00651207។ ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4048 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១ ERN (ភាសាខ្មែរ) 00788401 ទំព័រ ២ ERN (ភាសា ខ្មែរ) 00788402 (ប្រជាជនពុំបានស្ម័គ្រចិត្តដាក់អាវុធចុះរង់ចាំសេចក្តីស្លាប់នោះទេ។ ប្រសិនបើគ្មានស្បៀងអាហារ ពួកគេបះបោរ)។ ប្រតិចារឹកបទនៃសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/4045 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00784359-00784360 (ក្នុងពេលលំបាក វាអាចមានការតស៊ូប្រឆាំង ដូច្នេះប្រជាជនថ្មីត្រូវបាន បំបែកចេញពីគ្នា។ មានតែកម្មាភិបាលមូលដ្ឋានតែប៉ុណ្ណោះ ដែលបានតស៊ូក្នុងពេលសង្គ្រាម បានដឹងអំពីមាគ៌ាបក្ស និង បានដឹងអំពីគោលការណ៍ស្តីពីភាពអាសន្ន និងការរក្សាការសម្ងាត់)។ ទូរលេខពីក្រសួងការបរទេសអាមេរិកៈ កិច្ច សម្ភាសន៍របស់សារព័ត៌មាន Newsweek ជាមួយ អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (អៀង សារី ក៏បានអះអាងថា ពួកគេបានរកឃើញឯកសារ មួយច្បាប់ រៀបរាប់លម្អិតអំពីផែនការនយោបាយយោធាសម្ងាត់របស់ សេ.អ៊ី.អា និង លន់ នល់ ដែលបង្កបញ្ហាតាម រយៈគិញ្ញរបស់ពួកវាក្នុងចំណោមប្រជាជន ប្រសិនបើខ្មែរក្រហមមិនអាចដោះស្រាយបញ្ហាស្បៀងអាហារនេះបានទេ នោះ)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00291036 (ខ្មែរក្រហមបានរកឃើញផែនការរបស់ សេ. អ៊ី. អា ចង់បង្ក បញ្ហា ប្រសិនបើខ្មែរក្រហមមិនអាចផ្តល់ស្បៀងអាហារចិញ្ចឹមប្រជាជនបានទេនោះ)។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៥, ១៥៩។ ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៦, ៥៣១-៥៣៣។

[២៥១២] *ការពិនិត្យពិច័យករណីកប៉ាល់ "Mayaguez" (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា)* ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-៤ ERN (ភាសាខ្មែរ) S 00651204 - S 00651207។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ១៩ (ប្រសិនបើក្រុងភ្នំពេញពុំត្រូវបានជម្លៀសទេនោះ យើងនឹងពិបាកធ្វើចំណាត់ការលើទាហាន លន់ នល់)។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍ ខៀវ សំផន ឯកសារ E3/4054 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00784363-00784364 (ក្រោយមក ខៀវ សំផន បានដឹងថា Frank SNEPP ប្រធាន សេ អ៊ី អា នៅ សាយហ្គនបាននិយាយថា ការជម្លៀសទាំងនេះបានបំបែកភ្នាក់ងារ សេ.អ៊ី.អា នៅក្នុងប្រទេសកម្ពុជា)។ ប្រតិចារឹកនៃ បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3196 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00807445-

ឥទ្ធិពលមកពីតាមខេត្ត-ក្រុងនឹងអូសទាញកម្មាភិបាលខ្មែរក្រហមឲ្យលែងស្មោះត្រង់[២៥១៣]។ សម្តេច នរោត្តម សីហនុ បានអះអាងថា នៅពេលទ្រង់ត្រៀមខ្លួនវិលត្រឡប់មកទីក្រុងភ្នំពេញនៅថ្ងៃទី ១៧

---

00807446 ("ខៀវ សំផន បានដឹងថា គិញអាមេរិកមួយចំនួននៅសេសសល់ក្រោយរំដោះ ប៉ុន្តែ ពួកគេត្រូវបានខ្ចាត់ខ្ចាយយ៉ាងលឿន។ ប្រជាជនទាំងអស់ដែលត្រូវបានជម្លៀសចេញពីខេត្តក្រុងត្រូវបានចាត់ទុកជាខ្មាំង")។ ទូរលេខពីក្រសួងការបរទេសអាមេរិក៖ បទសម្ភាសន៍សារព័ត៌មានញូវវីក (Newsweek) ជាមួយ លោក អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (អៀង សារី ក៏បានអះអាងថា ពួកគេបានរកឃើញឯកសារមួយច្បាប់ រៀបរាប់លម្អិតអំពីផែនការនយោបាយយោធាសម្ងាត់របស់ សេ.អ៊ី.អា និង លន់ នល់ ដែលធ្វើឲ្យមានភាពច្របូកច្របល់ក្រោយជ័យជម្នះ។ អ្នកខ្លះបានលាក់អាវុធ និងបំណងវាយប្រហារយើង)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅកម្ពុជា៖ ទស្សនកិច្ចផ្លូវការរបស់ ប៉ុល ពត នៅប្រទេសចិន និងប្រទេសកូរ៉េខាងជើង ឯកសារ E3/484 ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ ទំព័រ ៨ ERN (ភាសាអង់គ្លេស) 00771187 (ប៉ុល ពត បាននិយាយថា ការជម្លៀសប្រជាជននៅតាមទីប្រជុំជនក្រោយបែកទីក្រុងភ្នំពេញ និងបន្ទាប់មក ក្នុងរដូវស្លឹកឈើជុះក្នុងឆ្នាំ ១៩៧៥ គឺដើម្បីបំបែកអង្គការចាត់តាំងរបស់គិញ)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកទៅកាន់ប្រទេសកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00583728-00583721 (អៀង សារី បានពន្យល់ថា អ្នកគាំទ្រ លន់ នល់ នឹងប៉ុនប៉ងដណ្តើមអំណាចវិញ។ អ្នកគាំទ្រទាំងនេះនៅពាសពេញក្នុងចំណោមជនស៊ីវិលក្នុងសម្លៀកបំពាក់ធម្មតា។ ពួកគេរឹតតែងាយនឹងអាចកំណត់អត្តសញ្ញាណបានក្រោយពេលផ្លាស់ទីលំនៅរបស់ពួកគេទៅកាន់ទីជនបទ)។ បទសម្ភាសន៍រវាង នួន ជា និងអ្នកសារព័ត៌មានជប៉ុន ឯកសារ E3/26 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00000900-00000901 (គណៈកម្មាធិការយោធា ដែលធ្វើជាអធិបតីដោយ ប៉ុល ពត បានសម្រេចថា អាមេរិកគ្រោងនឹងកម្ទេចបក្សនៅក្នុងទីក្រុងភ្នំពេញ។ ដូច្នេះ ប្រជាជនត្រូវតែជម្លៀសចេញដើម្បីកុំឲ្យមានគ្រោះថ្នាក់ដោយសារសង្គ្រាម)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00291036 (ទាហាន លន់ នល់ ជាច្រើននាក់ ដែលបានចុះចាញ់ បានលាក់អាវុធរបស់ពួកគេ ហើយនឹងធ្វើការវាយប្រហារក្រោយពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ)។ កិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយនឹងអ្នកសារព័ត៌មានយូហ្គោស្លាវី ឯកសារ E3/5713 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00775906-00775907 (ប៉ុល ពត បានពន្យល់ថា ហេតុផលមួយនៃការជម្លៀសខេត្តក្រុង រួមមាន ដើម្បីការពារប្រទេសពីផែនការរបស់អាមេរិក និងបរិវាររបស់វា ក្នុងការដុតបញ្ឆេះ និងប៉ុនប៉ងទម្លាក់ខ្មែរក្រហមពី បដិវត្តន៍។ ប្រជាជនត្រូវបានផ្លាស់ទីលំនៅដើម្បីការពារកុំឲ្យមានការអនុវត្តផែនការនេះបាន)។ *សូមមើលផងដែរ*ផ្នែកទី១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៦, ៥៣១-៥៣៣។

[២៥១៣] *ការពិនិត្យពិច័យករណីកប៉ាល់ "Mayaguez" (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា)* ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-៤ ERN (ភាសាខ្មែរ) S 00651204 - S 00651207។ ទូរលេខពីក្រសួងការបរទេសអាមេរិក៖ កិច្ចសម្ភាសន៍របស់សារព័ត៌មាន Newsweek ជាមួយ អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00635941-00635943 (អៀង សារី ក៏បានអះអាងថា ពួកគេបានរកឃើញ

ខែ មេសា ឆ្នាំ ១៩៧៥ រួចហើយនោះ ខៀវ សំផន បានឆ្លើយតបថានៅក្នុងទីក្រុងភ្នំពេញមានជំងឺរាតត្បាត ដែលតម្រូវឲ្យខ្មែរក្រហមជម្លៀសប្រជាជនទៅតាមទីជនបទ[២៥១៤]។

៧៩០. អង្គជំនុំជម្រះសាលាដំបូង បានបដិសេធយុត្តិកម្មដែលបានអះអាងទាំងនេះរួចហើយ ជាពិសេស ទាក់ទិនទៅនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[២៥១៥]។ អង្គជំនុំជម្រះសាលាដំបូងក៏ជឿជាក់ផងដែរថា យុត្តិកម្មទាំងនេះមិនបានបង្ហាញថា គោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ត្រូវបានផ្អែកទៅលើបញ្ហាសន្តិសុខប្រជាជនស៊ីវិល ឬភាពចាំបាច់ផ្នែកយោធានោះឡើយ។ គោលនយោបាយជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងដោយប្រើការបោកបញ្ឆោត[២៥១៦]ត្រូវបានអនុវត្តឡើង អនុលោមតាមមាគ៌ានយោបាយរបស់បក្ស

---

ឯកសារមួយច្បាប់ រៀបរាប់លម្អិតអំពីផែនការនយោបាយយោធាសម្ងាត់របស់ សេ.អ៊ី.អា និង លន់ នល់ ចង់ធ្វើឲ្យកងទ័ពខ្មែរក្រហមលែងស្មោះត្រង់)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00291036 (សេ. អ៊ី. អា មានផែនការចង់ធ្វើឲ្យកងទ័ពខ្មែរក្រហមលែងស្មោះត្រង់ និងបំបាក់ស្មារតីពួកគេជាមួយនឹងស្រី ស្រា និងលុយ)។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍* ចុះខែ កក្កដា ឆ្នាំ ១៩៧៥ ឯកសារ E3/724 ERN (ភាសាខ្មែរ) 00663861-00663862។ *របាយការណ៍របស់ ខៀវ សំផន* (សេវាផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/273 ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៦ ទំព័រ ១២-១៤ ERN (ភាសាខ្មែរ) 00657442-00657444។ *សូមមើលផងដែរ* ផ្នែកទី១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៦, ៥៣១-៥៣៣។

[២៥១៤] ព្រះរាជប្រកាសរបស់សម្តេច នរោត្តម សីហនុ ឯកសារ IS 10.78 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00662214។ ទោះបីជាឯកសារនេះពុំបានកំណត់លេខ E3 ក៏ដោយ ក៏ឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងរួចហើយ (ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២)។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងឯកសារនេះនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ (ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ៦២-៦៣)។ ការជំទាស់នេះត្រូវបានច្រានចោលហើយ ឯកសារនេះត្រូវបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញាក្នុងអំឡុងពេលសវនាការបង្ហាញឯកសារសំខាន់ៗនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ (ប្រតិចារឹក ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២១)។

[២៥១៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៥៦។ ផ្នែកទី១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៧-៥៣៤។

[២៥១៦] ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២១-២២ (ខ្មែរក្រហមបានប្រើល្បិចបោកបញ្ឆោតក្នុងការជម្លៀសប្រជាជន)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៥-១៦ (ច្បាស់ណាស់ថា ខ្មែរក្រហមបានកុហកប្រជាជន នៅពេលជម្លៀសពួកគេ ដែលការកុហកនេះជារឿងធម្មតា) ៣៨-៣៩ (អង្គការបានប្រើពាក្យកុហក ដើម្បីធ្វើឲ្យប្រជាជនជឿតាមពួកគេ ជម្លៀសប្រជាជនចេញពីទីក្រុង និងគ្រប់គ្រង

តាំងពីយូរណាស់មកហើយ ដោយផ្តោតទៅលើការបង្កបង្កើនផលកសិកម្ម និងផ្អែកទៅលើគោល-ការណ៍ខ្លួនទីពឹងខ្លួន និងសមូហភាវូបនីយកម្ម[២៥១៧]។ គោលនយោបាយនេះមិនមែនជាការឆ្លើយតបទៅនឹងស្ថានភាពពិសេសណាមួយទេ ហើយមិនមានសមាមាត្រ ឬភាពចាំបាច់ឡើយ ដូចដែលបានបង្ហាញឲ្យឃើញតាមរយៈវិធីសាស្ត្រដូចៗគ្នា និងមានការកើនឡើង ដែលបានអនុវត្តដោយពួកខ្មែរក្រហមនៅក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីទីប្រជុំជនទៅតាមទីជនបទនានា[២៥១៨]។

### ១៤.២.២.៣ វិធីសាស្ត្រ

៧៩១. ជនភៀសខ្លួនម្នាក់បានអះអាងថា នៅដើមឆ្នាំ ១៩៧២ ខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជា-ជនដោយបង្ខំចេញពីតំបន់ដែលគ្រប់គ្រងដោយរបប លន់ នល់ ដើម្បីយកទៅឲ្យធ្វើការនៅតាមវាលស្រែនៅក្នុងតំបន់រំដោះ[២៥១៩]។ នៅចន្លោះឆ្នាំ ១៩៧៣ និងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានជម្លៀសដោយបង្ខំចេញពីខេត្តក្រចេះ បាណន់ ឧត្តុង្គ ខេត្តកំពង់ចាម[២៥២០] ទីកន្លែងនានានៅក្នុងខេត្តបាត់ដំបង[២៥២១] ខេត្តស្វាយរៀង[២៥២២] និងខេត្តព្រៃវែង[២៥២៣]។ ក្នុងអំឡុងពេលវាយដណ្តើម

---

ស្ថានការណ៍)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៨-៥៩ (ការកុហកគឺជាមូលដ្ឋានដ៏សំខាន់នៅក្នុងគ្រប់សកម្មភាពទាំងអស់របស់របបនេះ)។

[២៥១៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៦, ១១០, ១១៥-១១៦, ១១៨។ ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦, ៧៣២, ៧៣៤, ៧៣៧-៧៣៨, ៧៥៤-៧៥៥, ៧៧៧។

[២៥១៨] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤៥០។

[២៥១៩] *សេចក្តីបន្ថែមរបស់គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ តាមសេចក្តីសម្រេចលេខ៩ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/3327 ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៧៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00723754-00723755 (ជនភៀសខ្លួនម្នាក់មកពីខេត្តកំពង់ចាមបានពន្យល់ថា ពួកខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញពីភូមិនានាដែលពួកគេត្រួតត្រា ឲ្យទៅធ្វើការតាមវាលស្រែ នៅឆ្នាំ ១៩៧១ និងឆ្នាំ ១៩៧២)។

[២៥២០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤-១០៩។

[២៥២១] កំណត់សម្គាល់របស់លោក H. LOCARD៖ *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៦ ERN (ភាសាខ្មែរ) 00233387 (ខ្មែរក្រហមបានទៅដល់តាគ្រាម ខេត្តបាត់ដំបងនៅក្នុងឆ្នាំ ១៩៧៤ ហើយបាន ផ្លាស់ប្តូរទីលំនៅក្រុមគ្រួសារទាំងនោះឲ្យទៅរស់នៅជិតភ្នំសំពៅ)។

[២៥២២] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឹម ឡេង ឯកសារ E3/5539 ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00373234-00373235 (នៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបាន

យកទីក្រុងភ្នំពេញ ពួកខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីតំបន់នានាដែលពួកគេដណ្តើមបាន រួមទាំងអ្នកទាំងឡាយដែលកំពុងរស់នៅជិតផ្លូវជាតិលេខ១ នៅចន្លោះពីអ្នកលឿង និងទីក្រុងភ្នំពេញ[២៥២៤]។

៧៩២. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញ។ ពួកគេបានចាប់ផ្តើមជម្លៀសប្រជាជនទាំងអស់ដោយបង្ខំជាបន្ទាន់ រួមទាំងអ្នកជំងឺ ក្មេងៗ និងមនុស្សចាស់។ នៅក្នុងពេលជម្លៀសនេះ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា។ ប្រជាជនត្រូវបានវាយ និងបាញ់សម្លាប់។ ម្ហូបអាហារ ទឹក ឬកន្លែងស្នាក់អាស្រ័យតិចតួច អាចត្រូវបានផ្តល់ឲ្យប្រសិនបើមាន។ ស្ថិតនៅក្រោមស្ថានភាពទាំងនេះ អ្នកដែលត្រូវបានជម្លៀសមួយចំនួនបានធ្វើអត្តឃាត ឬ ស្លាប់ដោយសារភាពហេវហត់ អស់កម្លាំង ការខ្វះខាតអាហារូបត្ថម្ភ និង/ឬដោយសារជំងឺ។ នៅក្នុងពេលនោះដែរ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រមូលផ្តុំ ឬកំណត់អត្តសញ្ញាណ រួមទាំងនៅតាមប៉ុស្តិ៍ត្រួតពិនិត្យនានា ដោយពួកគេខ្លះត្រូវបានចាប់ខ្លួន ខ្លះត្រូវបាននាំខ្លួនយកទៅ ហើយអ្នកផ្សេងទៀតត្រូវបានសម្លាប់នៅនឹងកន្លែងតែម្តង[២៥២៥]។

៧៩៣. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃបន្តបន្ទាប់ពីនេះទៀត ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីទីរួមខេត្តនានានៅទូទាំងប្រទេសកម្ពុជាផងដែរ រួមទាំង ទីរួមខេត្តកំពង់ស្ពឺ ទីរួមខេត្តតាកែវ ទីរួមខេត្តកំពត ក្រុងព្រះសីហនុ (កាលពីមុនជាក្រុងកំពង់សោម) ទីរួមខេត្តកំពង់ធំ ក្រុងប៉ៃលិន ទីរួមខេត្តកំពង់ចាម ទីរួមខេត្តកំពង់ឆ្នាំង ទីរួមខេត្តសៀមរាប ក្រុងប៉ោយប៉ែត ទីរួមខេត្តបាត់

---

បណ្តេញប្រជាជនទាំងអស់ចេញពីខេត្តស្វាយរៀង)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡឹម សាវ៉ុន ឯកសារ E3/5296 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00355444-00355445។

[២៥២៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ហ៊ែល ឯកសារ E3/5251 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00233286-00233287 (មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជននៅក្នុងទីរួមខេត្តព្រៃវែង ត្រូវបានជម្លៀស)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ប៊្លូន ឯកសារ E3/5508 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN 00398450។

[២៥២៤] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរហូរចូលអ្នកលឿង ឯកសារ E3/4185 ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៤ ទំព័រ ១ ERN (ភាសាខ្មែរ) 00658192។

[២៥២៥] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៤, ៥១៣, ៥១៥។

ដំបង និងទីរួមខេត្តពោធិ៍សាត់[២៥២៦]។ នៅត្រឹមខែ ឧសភា ឆ្នាំ ១៩៧៥ ប្រជាជននៅតាមទីប្រជុំជនទាំងអស់នៅតាមបណ្តោយផ្លូវជាតិលេខ៥រហូតដល់ព្រំដែនថៃត្រូវបានផ្លាស់ទីលំនៅ[២៥២៧]។ យ៉ាងហោចណាស់ នៅត្រឹម ខែ មិថុនា ឆ្នាំ ១៩៧៥ ប្រជាជននៅតាមទីប្រជុំជនទាំងអស់នៅតាមបណ្តោយផ្លូវជាតិលេខ ៦ ចន្លោះពី ព្រែកក្តាម និង សៀមរាប ក៏ត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំផងដែរ[២៥២៨]។

៧៩៤. ភាគច្រើននៃការជម្លៀសប្រជាជនចេញពីទីក្រុងទាំងនេះ ត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ និងផែនការរបស់បក្សដែលបានអនុវត្តតាមវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នាមួយ៖ ប្រជាជនត្រូវបានជម្លៀសដោយបង្ខំឲ្យចេញពីទីក្រុង និងទីប្រជុំជន ក្រោមលេសបោកបញ្ឆោតដោយមិនបានគិតគូរអំពីសុខុមាលភាពរបស់ពួកគេឡើយ។ ប្រជាជនទាំងនោះបានទទួលរងនូវអំពើហិង្សា និងការភ័យតក់ស្លុត ហើយត្រូវបានយកទៅការដ្ឋាន និងសហករណ៍ ដើម្បីកសាងខ្លួន តាមរយៈការធ្វើពលកម្ម និងការបំពាក់បំប៉នស្មារតី[២៥២៩]។ នៅមុនពេល ក្នុងអំឡុងពេល ឬភ្លាមៗ បន្ទាប់

[២៥២៦] ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧០។

[២៥២៧] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការជម្លៀសជនបរទេសពីប្រទេសកម្ពុជា ឯកសារ E3/4147 ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00738372-00738373 (SCHANBERG និងអ្នកផ្សេងទៀត បានទៅដល់ព្រំដែន។ ពួកគេពុំបានប្រទះឃើញជនស៊ីវិលណាម្នាក់ទេនៅក្នុងភូមិ និងទីប្រជុំជនតាមផ្លូវពីទីក្រុងភ្នំពេញ)។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ សេចក្តីរាយការណ៍របស់ប្រជាជនអាមេរិក ស្តីពីស្ថានភាពទីក្រុងភ្នំពេញបន្ទាប់ពីការដួលរលំ ឯកសារ E3/4148 ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៨ ERN (ភាសាខ្មែរ) 00664001 (ប្រជាជនក្នុងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងក្រុងបាត់ដំបង និងនៅតាមបណ្តាភូមិមួយចំនួន ក៏ត្រូវបានជម្លៀសចេញផងដែរ)។

[២៥២៨] ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00499663-00499664 (ឧត្តមសេនីយ៍ សរ ប៊ុន បានភៀសខ្លួនដោយបានធ្វើដំណើរឆ្លងកាត់ខេត្តកំពង់ធំ ទៅខេត្តសៀមរាប ហើយបន្ទាប់មកទៅប៉ែកខាងជើងឆ្ពោះទៅប្រទេសថៃ។ ប្រជាជនទាំងអស់នៅតាមទីប្រជុំជននានា តាមផ្លូវជាតិលេខ ៦ ចម្ងាយ ៤០០ គ.ម នៅចន្លោះពីព្រែកក្តាម រហូតទៅដល់សៀមរាប ត្រូវបានជម្លៀសចេញ)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៥៩-៦០ (ប្អូនថ្លៃប្រុសរបស់គាត់បានប្រាប់គាត់ថា នៅទន្ទឹមពេលមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានការរៀបចំជម្លៀសប្រជាជនចេញពីខេត្តកំពង់ធំ។ ប្រជាជនដែលជិះឡាន គឺគេយកទៅកម្ទេច ហើយអ្នកដែលគេឲ្យដើរ គឺគេទុកឲ្យរស់)។

[២៥២៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី François PONCHAUD ឯកសារ E3/4591 ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ១-២, ៥ ERN (ភាសាខ្មែរ) 00897584-00897585, 00897588 (មានផែនការជម្លៀសប្រជាជនចេញពីទីប្រជុំជនទាំងអស់ដែលជាផែនការមួយច្បាស់លាស់ រៀបចំទុកជាមុន។ ការអនុវត្តដូចគ្នានេះបានកើតមានឡើងនៅ

ពីការជម្លៀសជាច្រើនក្នុងចំណោមការជម្លៀសទាំងនេះ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបំបែកចេញដោយឡែកដើម្បីយកទៅសម្លាប់ចោល និងចាប់ខ្លួន[២៩៣០]។

## ១៤.២.៣ ការផ្លាស់ទីលំនៅក្នុងទីជនបទ

### ១៤.២.៣.១ គោលនយោបាយ

៧៩៥. នៅពេលជម្លៀសប្រជាជនចេញពីទីក្រុង និងទឹកដីដែលគ្រប់គ្រងដោយសត្រូវ ឬពួកដែលគេយល់ថាជាសត្រូវរួចមក ខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជាជននៅក្នុងតំបន់នានា ឬពីតំបន់មួយ

---

គ្រប់ទីកន្លែង ឧទាហរណ៍ ខេត្តបាត់ដំបង ក្រុងព្រះសីហនុ។ ការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង និងទីប្រជុំជននានា ត្រូវបានធ្វើឡើងទៅតាមវិធីសាស្ត្រត្រឹមត្រូវ)។ អនុស្សរណៈរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជាប្រចាំខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/491 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ ២ ERN (ភាសាខ្មែរ) 00704451 (ប្រជាជនត្រូវបានជម្លៀសជាប្រព័ន្ធ អ្នកទីក្រុងត្រូវជម្លៀសឲ្យទៅរស់នៅតាមទីជនបទ អ្នករស់នៅក្នុងភូមិត្រូវជម្លៀស ទៅភូមិមួយទៀត និងត្រូវរស់នៅតាមបែបសហគមន៍នៅទូទាំងប្រទេស)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៣៩-៤០ (វិធីសាស្ត្រនៃការជម្លៀសដោយបង្ខំម្តងហើយម្តងទៀត បានឈានដល់ កម្រិតកំពូលក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ទំព័រ ២១-២២ (ខ្មែរក្រហមបានប្រើល្បិចបោកបញ្ឆោតក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៥-១៦ (ច្បាស់ណាស់ថា ខ្មែរក្រហម បានកុហកប្រជាជននៅពេលជម្លៀសពួកគេ ដែលការកុហកនេះជារឿងធម្មតា) ៣៨-៣៩ (អង្គការបានប្រើពាក្យ កុហកដើម្បីធ្វើឲ្យប្រជាជនជឿតាមពួកគេ ជម្លៀសប្រជាជនចេញពីទីក្រុង និងគ្រប់គ្រងស្ថានការណ៍)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៨-៥៩ (ការកុហកគឺជាមូលដ្ឋានដ៏សំខាន់នៅក្នុងគ្រប់សកម្មភាពទាំងអស់របស់របបនេះ)។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរហូរចូលអ្នកលឿង ឯកសារ E3/4185 ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៤ ទំព័រ ១ ERN (ភាសាខ្មែរ) 00658192 (បន្ទាប់ពីការជម្លៀសប្រជាជននៅតំបន់នានាដែលវាយដណ្តើមបានក្នុងអំឡុងការវាយលុកទីក្រុងភ្នំពេញ ប្រជាជនបានទទួលការបំពាក់បំប៉ននយោបាយ ធ្វើពលកម្មដោយបង្ខំ ធ្វើស្រែចម្ការ និងនេសាទត្រីដើម្បីទ្រទ្រង់ដល់ពួកខ្មែរក្រហម)។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤-១១៨, ១៥៣។ ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៦៩-១៧០។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៥-៤៧៥, ៤៨១-៤៩៨។

[២៩៣០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២៧។ ផ្នែកទី ៤៖ ទិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កថាខណ្ឌ ១៧២, ១៩៧។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៥-៥០៩, ៥១១, ៥១៣-៥១៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៤-៨៣៦។

ទៅតំបន់មួយទៀត ដើម្បីបែងចែកកម្លាំងទៅតាមការប៉ាន់ស្មានរបស់ពួកគេ ផ្អែកលើតម្រូវការពលកម្ម និងទិសដៅផលិតកម្ម ព្រមទាំងដើម្បីជំរុញការតស៊ូវណ្ណៈ[២៥៣១]។ កងចល័តត្រូវបានប្រើប្រាស់នៅក្នុងសហករណ៍នីមួយៗ។ ការអនុវត្តបែបនេះនឹងបន្តរហូតដល់សហករណ៍ទាំងអស់មានលទ្ធភាពអាចផ្តល់កម្លាំងពលកម្មផ្ទាល់ខ្លួនបាន[២៥៣២]។ ថ្នាក់ដឹកនាំបក្សជឿថា ការរៀបចំកម្លាំងពលកម្មឡើងវិញ នឹងអាចដោះស្រាយចំពោះបញ្ហាកង្វះខាតទឹក និងស្បៀងអាហារ ការអប់រំកែប្រែ "ប្រជាជនថ្មី" ការកំណត់អត្តសញ្ញាណខ្មាំងនៅក្នុងចំណោមជួរ "ប្រជាជនថ្មី" និងអាចឲ្យបក្សជំរុញផែនការរបស់ខ្លួនឲ្យរីកចម្រើនទៅមុខ ដើម្បីប្រែក្លាយឲ្យទៅជាប្រទេសដែលមានសេដ្ឋកិច្ចកសិកម្មទំនើបមួយ នៅក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ និងបន្ទាប់មក ប្រែក្លាយឲ្យទៅជាប្រទេសឧស្សាហកម្មមួយ[២៥៣៣]។

៧៩៦. នៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានចេញបញ្ជាឲ្យមានការផ្លាស់ទីលំនៅប្រជាជនចន្លោះពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ ទៅកាន់ខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)[២៥៣៤]។ ថ្នាក់ដឹកនាំបក្សក៏បានបញ្ជាឲ្យមានការផ្លាស់ទីលំនៅប្រជាជនចំនួន ២០.០០០ នាក់ ទៅកាន់ខេត្តព្រះវិហារផងដែរ (តំបន់ ១០៣) និងផ្លាស់ទីលំនៅប្រជាជនផ្សេងៗទៀតទៅកាន់ខេត្តកំពង់ធំ (ភូមិភាគកណ្តាល (ឧត្តរចាស់))[២៥៣៥]។ មានការសម្រេចថា តំបន់ដែលដីមិនសូវមានជីជាតិនៅក្នុងភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ដែលមានប្រជាជនច្រើនពេកនោះ នឹងផ្តល់កម្លាំងមនុស្សទៅឲ្យតំបន់ ១០៣ ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាល (ឧត្តរចាស់)[២៥៣៦]។ ទិសដៅនៃការបង្កបង្កើនផលគឺត្រូវសម្រេចឲ្យបានផលស្រូវ ៣ តោន ក្នុង ១ ហិកតា[២៥៣៧]។ លើសពីនេះទៀត ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិចារណាថា "ប្រជាជនថ្មី" ត្រូវតែផ្លាស់ទីលំនៅ និងបំបែកចេញពីគ្នា ពីព្រោះភ្នាក់ងារខ្មាំងនៅលាយឡំក្នុងចំណោមប្រជាជនថ្មីទាំងនោះ[២៥៣៨]។

[២៥៣១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦។

[២៥៣២] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨១។

[២៥៣៣] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៦, ៦០២, ៦០៤, ៦១៣។

[២៥៣៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦។

[២៥៣៥] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦។

[២៥៣៦] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៧។

[២៥៣៧] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។

[២៥៣៨] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣។

៧៩៧. នៅចុងឆ្នាំ ១៩៧៦ បក្សបានកំណត់ទិសដៅបង្កបង្កើនផលថ្មីសម្រាប់ឆ្នាំ ១៩៧៧ ពោលគឺ ៣ តោន ក្នុង ១ ហិកតា និង ៦ តោន ក្នុង ១ ហិកតា នៅក្នុងតំបន់ទាំងឡាយដែលអាចបង្កបង្កើនផលស្រូវ ទាំងក្នុងរដូវវស្សា និងរដូវប្រាំង[២៥៣៩]។ ដោយសារជួបប្រទះនឹងគ្រោះរាំងស្ងួតនៅក្នុងឆ្នាំ ១៩៧៧ ការសាងសង់ទំនប់ ជីកប្រឡាយ លើកភ្លឺស្រែ គឺជាកិច្ចការសំខាន់យ៉ាងខ្លាំង[២៥៤០]។ លើសពីនេះទៀត បក្សបានចេញបញ្ជាឲ្យមានការបែងចែកចំណាត់ថ្នាក់ប្រជាជនទៅជាប្រភេទផ្សេងៗ រួមមាន "ពេញសិទ្ធិ" (ប្រជាជនមូលដ្ឋាននៅតាមសហករណ៍) "ត្រៀម" (ប្រជាជនមូលដ្ឋានដែលមានស្ថានភាពហិរញ្ញវត្ថុប្រសើរនៅមុនឆ្នាំ ១៩៧៥) និង "ជនបញ្ញើ" (ប្រជាជន ១៧ មេសា) ដើម្បីកុំឲ្យមានការច្របូកច្របល់នៅក្នុងការគ្រប់គ្រង និងប្រមូលកម្លាំង[២៥៤១]។

៧៩៨. នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាល និងលេខាភូមិភាគ បានរាយការណ៍ទៅ ប៉ុល ពត នួន ជា វន វ៉េត សុន សេន ខៀវ និង/ឬ មន្ទីរ ៨៧០ អំពីការផ្លាស់ទីលំនៅប្រជាជន ហើយពេលខ្លះបានស្នើសុំការណែនាំបន្ថែមទៀតផង[២៥៤២]។

---

[២៥៣៩] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១០។

[២៥៤០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១០-៦១២។

[២៥៤១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២១។

[២៥៤២] *សូមមើល* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦ (ជាពិសេស ទាក់ទិននឹងការជម្លៀសប្រជាជននៅចុងឆ្នាំ ១៩៧៧ នៅក្នុងភូមិភាគបូព៌ា និងការប៉ុនប៉ងជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៥)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ) ទំព័រ ៣២-៣៣ (នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ សោ ភឹម បានរាយការណ៍ទៅ ប៉ុល ពត និង នួន ជា អំពីការជម្លៀសប្រជាជន ហើយ កែ ពក មិនព្រមទទួល)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ទំព័រ ៣៥-៣៦ (នង សុផង់ បានអះអាងថា ទូរលេខនេះត្រូវបញ្ជូនទៅ នួន ជា ផងដែរ ពីព្រោះអ្នកគ្រប់គ្រងសារទូរលេខដឹងថា បញ្ហានេះគួរបញ្ជូនទៅ "អ្នកទទួលខុសត្រូវខាងប្រជាជនដើម្បីដោះស្រាយ")។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1188 ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៧៦ (ប៊ុត ផ្ញើជូនបងជាទីគោរព ចម្លងជូនបង នួន រាយការណ៍ថា ប្រជាជនដែលជម្លៀសមកពីឡាវ ត្រូវបានបញ្ជូនឲ្យទៅរស់នៅតាមភូមិចំនួនបួន នៅក្នុងឃុំលេខ៣)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/243 ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨(សោ ភឹម (ឆុន) ផ្ញើជូនបង ប៉ និងចម្លងជូន ក្នុងចំណោមអ្នកផ្សេងទៀត អ៊ំ នួន បានរាយការណ៍អំពីការប្រយុទ្ធគ្នានៅក្នុងតំបន់ ២៣ និង ២៤ និង អំពីវិធីដែលពួកគេប្រមូលប្រជាជនបានមកវិញមួយភាគធំដែលត្រូវបានខ្មាំងយួនកៀរយកទៅគ្រប់គ្រងបណ្ដោះអាសន្ន និងបានរៀបចំយកមកខាងក្រោយវិញដើម្បីអប់រំ និងបែងចែកសម្រិតសម្រាំង)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/898 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៧៧ (សែ ផ្ញើជូនគណៈ ៨៧០ និងចម្លងជូនអ៊ំ នួន បានបញ្ជាក់ថា ស្រុកសៀមរាប មានប្រជាជន ៤០.០០០ នាក់ ដែលភាគច្រើនជា "ប្រជាជនថ្មី" ត្រូវតែចែកទៅតាមស្រុកមួយចំនួនទៀត)។

## ១៤.២.៣.២ យុត្តិកម្ម

៧៩៩. មេដឹកនាំបក្ស និងឯកសារបោះពុម្ពផ្សាយនានា បានលើកឡើងថា ការផ្លាស់ទីលំនៅប្រជាជននៅក្នុងទីជនបទ ត្រូវបានធ្វើឡើងដោយផ្អែកលើសន្តិសុខប្រជាជនស៊ីវិល និងភាពចាំបាច់ផ្នែកយោធា[២៥៤៣]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធយុត្តិកម្មនេះរួចហើយទាក់ទិននឹងការផ្លាស់ទីលំនៅទាំងនេះ ដែលមាននៅក្នុងវិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ អង្គជំនុំជម្រះក៏រកឃើញផងដែរថា ការដែលមិនបានគិតគូរអំពីតថភាពនៃយុត្តិកម្មទាំងនេះ ការផ្លាស់ទីលំនៅទាំងនេះមិនមានលក្ខណៈសមស្រប និងមានភាពចាំបាច់ឡើយ[២៥៤៤]។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា យុត្តិកម្ម និងការដោះសាទាំងនេះ មិនបានបង្ហាញឲ្យឃើញថា មានគោល-នយោបាយផ្លាស់ទីលំនៅប្រជាជននៅក្នុងទីជនបទ ដោយផ្អែកទៅលើសន្តិសុខប្រជាជនស៊ីវិល និងភាពចាំបាច់ផ្នែកយោធានោះឡើយ។ ស្ថិរភាព និងការកំណត់ជាមុនចំពោះគោលនយោបាយបែបនេះបង្ហាញថា គោលនយោបាយនេះ មិនមែនជាការឆ្លើយតបក្នុងពេលដំណាលគ្នាទៅនឹងការព្រួយបារម្ភដោយផ្អែកលើបញ្ហាសន្តិសុខរបស់ប្រជាជន ឬភាពចាំបាច់ខាងផ្នែកយោធា ដែលបានលើកឡើងនៅក្នុងស្ថានការណ៍ពិសេសណាមួយនោះទេ ដូច្នេះមិនអាចថា គោលនយោបាយនេះត្រូវបានរៀបចំឡើងដោយផ្អែកទៅលើគោលការណ៍នៃភាពចាំបាច់ ឬសមាមាត្រនោះទេ[២៥៤៥]។ ភាពមិនសមា-មាត្រ និងមិនចាំបាច់នៃការជម្លៀសប្រជាជនដោយសារតែគោលនយោបាយនេះ ត្រូវបានស្តែងឲ្យឃើញបន្ថែមទៀត តាមរយៈវិធីសាស្ត្រនៃការអនុវត្តដ៏ស៊ីសង្វាក់គ្នាមួយ។

## ១៤.២.៣.៣ វិធីសាស្ត្រ

៨០០. ចាប់ពីឆ្នាំ ១៩៧២ ឬ អាចថាមុនឆ្នាំនេះទៀត ប្រជាជនត្រូវបានផ្លាស់ទីលំនៅនៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម ដើម្បីបង្កើត និងពង្រីកសហករណ៍ បែងចែកកម្លាំងពលកម្មទៅតាមរដូវកាល និងបំបែកពួកគេចេញពីខ្មាំង[២៥៤៦]។ ខ្មែរក្រហមបានរៀបចំកងចល័តដែលរួមមាន

---

[២៥៤៣] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣៤។

[២៥៤៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣៥។

[២៥៤៥] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤៥០។

[២៥៤៦] បទសម្ភាសន៍ជាមួយ វ៉ាចាម គុន ហៅ ភី ភួន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5815 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១០ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00660823-00660824 (នៅក្នុងឆ្នាំ ១៩៦៨ និងឆ្នាំ ១៩៦៩ ខ្មែរក្រហមបានបង្កើតចលនាធ្វើស្រែ ដោយប្រើប្រាស់កងចល័ត និងអ្នកភូមិ)។ បទសម្ភាសន៍ជាមួយ ខូ វណ្ណី ដោយមជ្ឈមណ្ឌល

ប្រជាជនស៊ីវិល និង/ឬ កម្មាភិបាល ដែលត្រូវបានបំបែកចេញពីក្រុមគ្រួសាររបស់ពួកគេ ដើម្បីជួយធ្វើស្រែ និងជួយដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ទំនប់ ស្ពាន និងផ្លូវថ្នល់[២៥៤៧]។

៨០១. ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបន្តអនុវត្តការផ្លាស់ទីលំនៅប្រជាជនដដែលដោយសំអាងលើហេតុផលដូចមុន ប៉ុន្តែធ្វើឡើងក្នុងទ្រង់ទ្រាយធំជាងមុន។ នៅពាក់កណ្តាលខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនជាច្រើនក្នុងចំណោមអ្នកដែលត្រូវបានផ្លាស់ទីលំនៅចេញពីទីក្រុង

---

ឯកសារកម្ពុជា ឯកសារ E3/4660 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00602356-00602357 (អ្នក ដែលត្រូវបានជម្លៀសនឹងត្រូវបញ្ជូនទៅសហករណ៍ ដែលមានតាំងពីឆ្នាំ ១៩៧៣ មកម្ល៉េះ ហើយប្រការនេះនឹងអាចជួយថែរក្សាប្រជាជនទាំងអស់នោះ)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៦៩-៧១។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពៅ ស៊ីនួន ឯកសារ E3/5545 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ៣ ERN (ភាសាខ្មែរ) 00385096 (នៅក្នុងឆ្នាំ១៩៧៣ ខ្មែរក្រហមបានជម្លៀសពៅ ស៊ីនួន និងក្រុមគ្រួសារ ពីភូមិរំលេចទៅកាន់ភូមិកោះខ្នាយក្នុងខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្រោមការត្រួតត្រាដោយខ្មែរក្រហម "ដើម្បីគេចចេញពីការវាយប្រហាររបស់ទាហាន លន់ នល់")។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣។

[២៥៤៧] ប្រតិចារឹក ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៣-៥ (កម្មាភិបាលនៅក្នុងកងចល័តត្រូវចូលរួមធ្វើស្រែ)។ បទសម្ភាសន៍ជាមួយ រ៉ចាម តុន ហៅ ភី ភួន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5815 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១០ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00660823-00660824។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃន ប្រាក់ ឯកសារ E3/509 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00270157 (នៅឆ្នាំ ១៩៧២ គាត់នៅក្នុងកងចល័ត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គឹម ឯកសារ E3/360 ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00186338 (នៅចុងឆ្នាំ ១៩៧៤ គាត់ត្រូវបានគេចាត់តាំងឲ្យទៅនៅកងចល័ត នៅទូកមាស ដែលនៅទីនោះគេឲ្យគាត់ធ្វើស្ពាន និងថ្នល់)។ ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង ០០១ (សាក្សី ចាន់ ខន) ឯកសារ E3/2980 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៦៧ ERN (ភាសាខ្មែរ) 00322535 (នៅក្នុងឆ្នាំ ១៩៧៣ ឬឆ្នាំ ១៩៧៤ ឌុច បានបញ្ជាឲ្យគាត់ទៅធ្វើស្រែនៅខាងលិចត្រពាំងព្រាល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ផាន ឯកសារ E3/5143 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00204122 (នៅក្នុងឆ្នាំ ១៩៧៣ អ្នកស្រី ត្រូវបានចាត់ឲ្យទៅនៅក្នុងចល័តក្នុងខេត្តស្វាយរៀង ដែលនៅទីនោះអ្នកស្រីលើកទំនប់ ជីកប្រឡាយ)។ បទសម្ភាសន៍ជាមួយ សោម ធឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/5596 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ៦ ERN (ភាសាខ្មែរ) 00058883 (នៅក្នុងឆ្នាំ ១៩៧៤ ឬឆ្នាំ ១៩៧៥ អ្នកស្រីត្រូវយកទៅដាក់នៅក្នុងកងចល័តនៅក្នុងខេត្តកំពត ដើម្បីឲ្យលើកទំនប់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង ណន ឯកសារ E3/4640 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00181830 (នៅឆ្នាំ ១៩៧៣ គាត់ត្រូវបានចាត់ឲ្យទៅនៅកងចល័ត ដើរជីកព្រែក ជីកប្រឡាយ "គ្រប់កន្លែង")។

និងទីប្រជុំជនទាំងនោះ ត្រូវបានផ្លាស់ទីលំនៅជាបន្តទៀត។ ការផ្លាស់ទីលំនៅរបស់ពួកគេនៅតែបន្តធ្វើឡើងនៅឡើយ នៅចុងខែ កក្កដា និងខែ សីហា ឆ្នាំ ១៩៧៥ នៅពេលរដូវដកស្ទូងបានចូលមកដល់[២៥៤៨]។ បន្ទាប់ពីបានបង្កើតរដ្ឋាភិបាលនៅក្នុងទីក្រុងភ្នំពេញរួចមក នៅចុងឆ្នាំ១៩៧៥ គណៈ-កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ដែលរួមមានទាំង នួន ជា ប៉ុល ពត អៀង សារី និង ខៀវ សំផន បានចាប់ផ្តើមបង្វែរការយកចិត្តទុកដាក់របស់ពួកគេទៅលើការទាញយកផលប្រយោជន៍ជាយុទ្ធសាស្ត្រពីប្រជាជនដែលត្រូវបានបណ្តេញចេញពីទីក្រុង និងទីប្រជុំជនទាំងនេះ[២៥៤៩]។

៨០២. ចាប់ផ្តើមពីខែ កញ្ញា ឆ្នាំ ១៩៧៥ និងបន្តទៅដល់ដើមឆ្នាំ ១៩៧៧ ប្រជាជនរាប់រយពាន់នាក់ត្រូវបានផ្លាស់ទីលំនៅចេញពីខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយ-រៀង ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ទៅកាន់ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តព្រះវិហារ និងខេត្តកំពង់ធំ[២៥៥០]។ ក្រៅពីការផ្លាស់ទីលំនៅទ្រង់ទ្រាយធំពីតំបន់នៅប៉ែកខាងត្បូង ទៅកាន់តំបន់ប៉ែកខាងជើង ប្រជាជនរាប់ម៉ឺននាក់ក៏ត្រូវបានផ្លាស់ទីលំនៅតាមមធ្យោបាយផ្សេងៗផងដែរ នៅក្នុងតំបន់នានា នៅចន្លោះពីចុងឆ្នាំ ១៩៧៥ ដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដូចជានៅខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តក្រចេះ ខេត្តកំពត ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃ-វែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តមណ្ឌលគីរី[២៥៥១]។

៨០៣. នៅក្នុងអំឡុងពេលនៃការជម្លៀសទាំងនេះ វិធីសាស្ត្រអនុវត្តដ៏ស៊ីសង្វាក់គ្នា បានលេចជារូបរាងឡើង។ ជារឿយៗ "ប្រជាជនថ្មី" ត្រូវបានកំណត់គោលដៅសម្រាប់ការផ្លាស់ទីលំនៅ។ ប្រជាជនត្រូវបានបង្ខិតបង្ខំ គំរាម ឬ បោកបញ្ឆោតឲ្យធ្វើការផ្លាស់ទីលំនៅ។ ដូច្នេះ ប្រជាជនជាច្រើនបានធ្វើដំណើរដោយថ្មើរជើង ទោះជិត ឬ ឆ្ងាយ ឬ ត្រូវបានដឹកជញ្ជូនតាមកាណូត កប៉ាល់ ឡាន ឬ រថភ្លើងដែលមានមនុស្សជិះយ៉ាងច្រើនណែនណាន់តាន់តាប់។ ពួកគេទទួលបានម្ហូបអាហារ ទឹក ឬកន្លែងស្នាក់អាស្រ័យតិចតួច ប្រសិនបើមាន ទាំងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ឬ នៅពេលទៅ

---

[២៥៤៨] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤។

[២៥៤៩] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦, ៥៨៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨២។

[២៥៥០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៧។

[២៥៥១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤-៥៨៨។

ដល់គោលដៅរបស់ពួកគេ។ ប្រជាជនជាច្រើនបានស្លាប់ដោយសារជំងឺ ភាពអត់ឃ្លាន និង/ឬ ភាពហេវហត់អស់កម្លាំង។ ប្រជាជនផ្សេងទៀតត្រូវបានពួកកងទ័ពខ្មែរក្រហមបាញ់សម្លាប់ ឬបានបាត់ខ្លួន[២៥៥២]។

## ១៤.២.៤ សំអាងច្បាប់

៨០៤. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បានបង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ ទីមួយ ភ័ស្តុតាងបានបង្ហាញថា មនុស្សជាច្រើន រួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានយល់ស្របទៅនឹងគោលបំណងរួម ដែលរួមមាន ការអនុវត្តបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា[២៥៥៣]។ ទីពីរ ក៏មានការបង្ហាញឲ្យឃើញផងដែរថា ទោះបីជា គោលបំណងរួមនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ ក៏គោលនយោបាយ ដែលខ្មែរក្រហមបានបង្កើតឡើងពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលជាមធ្យោបាយមួយក្នុងការសម្រេចផែនការរួមនេះ។ គោលនយោបាយទាំងនេះ នាំឲ្យមាន និង/ឬរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា រួមទាំង ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការប៉ះ-ពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការផ្លាស់ទីលំនៅប្រជាជនទាំងពីរដំណាក់កាលនេះ (ដំណាក់កាលទី១ និងទី២) អនុវត្តតាមវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នាមួយ នៅក្នុងករណីនីមួយៗ ដែលរួមទាំង និងមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ចំណុចនេះបញ្ជាក់ថា គោលនយោបាយទាំងនេះ មានលក្ខណៈឧក្រិដ្ឋ និងត្រូវបានអនុម័តជាមុន ដើម្បីធានាថាគោលបំណងរួមនេះអាចសម្រេចបាន។

៨០៥. ជាពិសេស ការផ្លាស់ទីលំនៅដោយបង្ខំដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ព និងកម្មាភិបាលខ្មែរក្រហម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) ត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ សេចក្តីសម្រេច និងការណែនាំច្បាស់លាស់របស់ថ្នាក់ដឹកនាំបក្ស។ លើសពីនេះទៀត ការផ្លាស់ទីលំនៅទាំងនេះត្រូវបានធ្វើឡើងជាផ្នែកមួយនៃវិធីសាស្ត្រក្នុងការផ្លាស់ទីលំនៅដោយបង្ខំ លក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ និងមិនបានគិតគូរដល់សុខុមាលភាពរបស់ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះឡើយ។ ការធ្វើមនុស្សឃាត និងការប៉ះពាល់ដល់

[២៥៥២] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៥៩៩។

[២៥៥៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៧៧៧។

សេចក្តីថ្លៃថ្នូររបស់មនុស្ស បានកើតឡើងដោយសារលក្ខខណ្ឌអមនុស្សធម៌នៃការជម្លៀស អំពើបំភិតបំភ័យរបស់កម្មាភិបាលខ្មែរក្រហម និងការបង្ខិតបង្ខំ។ គោលបំណងនៃគោលនយោបាយបក្សគឺថាការធ្វើឲ្យឈឺចាប់វេទនា និងការលះបង់បែបនេះនឹងអាចអប់រំកែប្រែ "ប្រជាជនថ្មី" បាន ហើយក៏ជាការវាយប្រហារទៅលើវណ្ណៈផងដែរ។ ផ្អែកទៅលើមូលដ្ឋាននេះ "ប្រជាជនថ្មី" ត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ចុងក្រោយ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទី១ អំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ បានកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលជាក្រុមមនុស្សមួយក្រុមដែលគោលនយោបាយបក្សចាត់ទុកថាមិនត្រូវគ្នាជាមួយនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាង និងការពារប្រទេស។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើង ដោយអនុលោមតាមគោលនយោបាយបក្សក្នុងការកម្ទេចខ្មាំងសត្រូវទាំងនេះ និងបានបង្កើតជាផ្នែកនៃវិធីសាស្ត្រនៃការចាប់ខ្លួន និងការសម្លាប់ដែលបានកើតឡើងភ្លាមៗ មុនពេល ក្នុងអំឡុងពេល ឬភ្លាមៗក្រោយពេលផ្លាស់ទីលំនៅប្រជាជន។

៨០៦. ដូចដែលបានបង្ហាញខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) និងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) អាចត្រូវបានដាក់ឲ្យអ្នកដែលចូលរួមនៅក្នុងសហ-ឧក្រិដ្ឋកម្មរួមទទួលខុសត្រូវ នៅពេលដែលអ្នកចូលរួមនេះ បានប្រើប្រាស់ចារីដើម្បីសម្រេចគោលបំណងរួមនោះ[២៥៥៤]។

៨០៧. សមាជិកនៃគណៈកម្មាធិការមជ្ឈិម ដែលមានបុគ្គលខ្លះក៏ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរនោះ បានជួបប្រជុំគ្នានៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ហើយបានសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បានបញ្ជាក់អំពីសេចក្តីសម្រេចនេះនៅក្នុងខែ កុម្ភៈ និងដើមខែ មេសា ឆ្នាំ ១៩៧៥។ បទបញ្ជាផ្សេងៗត្រូវបានផ្សព្វផ្សាយបន្ត តាមរយៈអ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំនោះ រួមទាំង តាម៉ុក ផងដែរ។

---

[២៥៥៤] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៣។ *សូមមើលផងដែរ* សាលដីកាលើរឿងក្តី *Krajišnik* កថាខណ្ឌ ២២៦ (ទំនាក់ទំនងគ្រប់គ្រាន់ មានអត្ថិភាព នៅពេលដែលសមាជិកសហ-ឧក្រិដ្ឋកម្មរួមម្នាក់បានស្នើយ៉ាងច្បាស់លាស់ ឬដោយប្រយោលឲ្យអ្នកដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមប្រព្រឹត្តបទឧក្រិដ្ឋ ឬបានញុះញង់ បានបញ្ជា បានលើកទឹកចិត្ត ឬបានប្រើប្រាស់អ្នកដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្ត បទឧក្រិដ្ឋ ដែលជាផ្នែកនៃគោលបំណងរួម)។

សុន សេន គឺ ជាប្រធានគណៈកម្មាធិការ ដោយរួមទាំង កុយ ធួន គឺជាអ្នកទទួលភារកិច្ចរៀបចំការជម្លៀសប្រជាជន។ លើសពីនេះទៀត កងកម្លាំងយោធាដែលបានវាយដណ្តើមយកទីក្រុងភ្នំពេញ ស្ថិតក្រោមបញ្ជារបស់លេខាភូមិភាគ រួមមាន សោ ភឹម កុយ ធួន តាម៉ុក និង វន វ៉េត។ ពួកគេបានស្នើសុំ និងបានទទួលការណែនាំពី ប៉ុល ពត នួន ជា សុន សេន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅមន្ទីរ ប-៥។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមដែលរួមមានយ៉ាងហោចណាស់ សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ដូចជា ប៉ុល ពត តា ម៉ុក សុន សេន សោ ភឹម វន វ៉េត និង កុយ ធួន អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវ នៅក្នុងសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

៨០៨. ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) បានចាប់ផ្តើមឡើង ដោយមានសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ឲ្យផ្លាស់ទីលំនៅប្រជាជនពីតំបន់នៅប៉ែកខាងត្បូងប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគកណ្តាល (ឧត្តរចាស់)) និងខេត្តព្រះវិហារ (តំបន់ ១០៣)។ ក្រោយមកទៀត សេចក្តីណែនាំ និងគោលនយោបាយស្តីអំពីការបែងចែកកម្លាំងពលកម្ម ទិសដៅបង្កបង្កើនផល និងអាទិភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានសម្រេចដោយថ្នាក់ដឹកនាំបក្ស ដែលរួមទាំងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ផង។ សេចក្តីណែនាំពីគណៈកម្មាធិការមជ្ឈិម[២៥៥៥] ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានបញ្ជូនទៅលេខាភូមិភាគ និងលេខាតំបន់ស្វយ័តនានា ដែលតាមរយៈសេចក្តីណែនាំនេះ ប្រជាជនត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលដំណាក់កាលទី២។ អ្នកទាំងនោះ រួមមាន រស់ ញឹម (ភូមិភាគពាយ័ព្យ) សោ ភឹម (ភូមិភាគបូព៌ា) តាម៉ុក (ភូមិភាគនិរតី) កុយ ធួន (ភូមិភាគកណ្តាល (ឧត្តរ ចាស់)) រហូតដល់ចុងឆ្នាំ ១៩៧៥) កែ ពក (ភូមិភាគកណ្តាល (ឧត្តរចាស់)) ចាប់ពីចុងឆ្នាំ ១៩៧៥) ចាន់ សំ (ភូមិភាគឧត្តរ ចាប់ពីការបង្កើតដំបូងនៅក្នុងឆ្នាំ ឬប្រហែលជានៅឆ្នាំ ១៩៧៧) ជូ ជេត (ភូមិភាគបស្ចិម) បូ ផាត (តំបន់ ១០៣) យ៉ុង យ៉ែម (តំបន់ ៥០៥ រហូតដល់ឆ្នាំ ១៩៧៦) និង ប៊ិន ណាន (តំបន់ ៥០៥ ចាប់ពីឆ្នាំ ១៩៧៦)។

[២៥៥៥] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៣, ២៦៥។ ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៨០, ២៨៦។

៨០៩. ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នៅពេលមានការប្រមូលផ្តុំរួចហើយ ប្រជាជនមួយចំនួនត្រូវបានដឹកយកចេញទៅតាមរថភ្លើង ដោយមានការឃាមកាមពីសំណាក់កងទ័ពខ្មែរក្រហមមកពីទីក្រុងភ្នំពេញ។ នៅពេល សុន សេន ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ កងទ័ពមជ្ឈិមត្រូវស្ថិតនៅក្រោមបញ្ជារបស់គាត់និងសេនាធិការ។ គណៈកម្មាធិការពាណិជ្ជកម្ម (ស្ថិតនៅក្រោម កុយ ធួន ចាប់ពីខែ តុលា ឆ្នាំ ១៩៧៥ រហូតដល់មានការចាប់ខ្លួនគាត់នៅចុងឆ្នាំនោះ) ក៏បានជាប់ពាក់ព័ន្ធផងដែរនៅក្នុងការរៀបចំដឹកជញ្ជូនប្រជាជន យ៉ាងហោចណាស់ ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ មក។ លើសពីនេះទៀតកម្មាភិបាលផ្លូវរថភ្លើង ត្រូវរាយការណ៍ទៅអង្គភាពរថភ្លើងនៅភ្នំពេញ។ ចាប់ពីខែ តុលា ឆ្នាំ ១៩៧៥ វន វេត បានទទួលបន្ទុកផ្នែក "ឧស្សាហកម្ម ផ្លូវរថភ្លើង និងនេសាទ"។ យ៉ាងហោចណាស់ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៦ អង្គភាពរថភ្លើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគមនាគមន៍ និងដឹកជញ្ជូន ដែលមាន ម៉ី ប្រាង ជាប្រធាន។ ទាំងគណៈកម្មាធិការពាណិជ្ជកម្ម និងគណៈកម្មាធិការគមនាគមន៍ និងដឹកជញ្ជូន ស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ចរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្រោមការដឹកនាំរបស់ វន វេត ដែលត្រូវបានតែងតាំងឲ្យកាន់តួនាទីនេះនៅក្នុងខែ មេសា ឆ្នាំ ១៩៧៦។

៨១០. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចកំណត់បានថាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលរួមមានយ៉ាងហោចណាស់សមាជិកមួយចំនួននៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ រដ្ឋមន្ត្រីរបស់រដ្ឋាភិបាល និងលេខាតំបន់ស្វយ័ត និងលេខាភូមិភាគ ដូចជា វន វេត ម៉ី ប្រាង សុន សេន កុយ ធួន កែ ពក ចាន់ សំ ជូ ជេត តាម៉ុក រស់ ញឹម សោ ភឹម បូ ផាត យ៉ុង យ៉ែម និង ប៊ិន ណាន គឺទទួលខុសត្រូវចំពោះការជម្លៀសប្រជាជនពីភូមិភាគនិរតី ភូមិភាគបស្ចិមភូមិភាគបូព៌ា និងភូមិភាគកណ្តាល (ឧត្តរចាស់) ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាល (ឧត្តរចាស់) តំបន់ ១០៣ និងតំបន់ ៥០៥ ព្រមទាំងនៅក្នុងភូមិភាគពាយ័ព្យ ភូមិភាគបូព៌ា និងភូមិភាគកណ្តាល (ឧត្តរចាស់) ផងដែរ។

## ១៤.៣ គោលនយោបាយកំណត់គោលដៅ

៨១១. យោងតាមដីកាដំណោះស្រាយ គោលបំណងនៃគោលនយោបាយកំណត់គោលដៅ ដូចដែលបានកំណត់នៅក្នុងសំណុំរឿង ០០២/០១ រួមមាន ការបង្កើតឡើងនូវសង្គមមួយដែលមិនមាន

ការបែងចែកវណ្ណៈ និងការលុបបំបាត់ខ្មាំង[២៥៥៦]។ ដីកាដំណោះស្រាយចោទប្រកាន់ថា វិធានការដែលធ្វើឡើងប្រឆាំងនឹងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ រួមមាន អ្នករដ្ឋការ អតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ បានចាប់ផ្ដើមអនុវត្តនៅមុនឆ្នាំ ១៩៧៥ និងបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[២៥៥៧]។

៨១២. ដីកាដំណោះស្រាយទាំងមូលចោទប្រកាន់ជនជាប់ចោទពីបទមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ តាមរយៈការសម្លាប់ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ[២៥៥៨]។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការអានផ្នែកនានានៃដីកាដំណោះស្រាយក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងជាពិសេស ផ្នែកដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយកំណត់គោលដៅ ជនជាប់ចោទមិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តតាមរយៈសហ-ឧក្រិដ្ឋកម្មរួមនូវបទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទាក់ទិននឹងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃនោះទេ[២៥៥៩]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិចារណាទេ ថាតើឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តឡើងក្រោមទម្រង់នៃការទទួលខុសត្រូវដូច្នេះដែរ ឬ យ៉ាងណានោះឡើយ។

៨១៣. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតការពិចារណារបស់ខ្លួនអំពីគោលនយោបាយកំណត់គោលដៅនេះត្រឹមឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ទាក់ទិននឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[២៥៦០]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងដីកា

---

[២៥៥៦] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៧។

[២៥៥៧] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៥-២០៦, ២០៨-២០៩។

[២៥៥៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៨។

[២៥៥៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥(iv)។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំ-ជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។

[២៥៦០] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពី

ដំណោះស្រាយ ការសម្លាប់នៅទួលពោធិ៍ជ្រៃមានទំនាក់ទំនងយ៉ាងច្បាស់ទៅនឹងគោលនយោបាយ ទីបី ស្តីអំពីការលត់ដំសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង[២៥៦១]។ គោលនយោបាយនេះមិនត្រូវបាន ដាក់បញ្ចូលនៅក្នុងវិសាលភាពសំណុំរឿង ០០២/០១ នោះទេ[២៥៦២]។ ទោះបីជាវិធាន ៩៨(២) នៃ វិធានផ្ទៃក្នុងកម្រិតការវិនិច្ឆ័យត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាដំណោះស្រាយ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមិនចងកាតព្វកិច្ចត្រូវគោរពតាមនូវការវិភាគអង្គហេតុដែលមាន នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតនោះទេ ជាពិសេសគឺបទចោទទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយជាក់លាក់នៃសហឧក្រិដ្ឋកម្មរួម[២៥៦៣]។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ទាំងគោលនយោបាយកំណត់គោលដៅ និងគោល នយោបាយទីបី យ៉ាងហោចណាស់នៅផ្នែកខ្លះ មានគោលបំណងរួមមួយដែលសំដៅទាំងការ “លុប បំបាត់ខ្មាំង” និងការ “សម្លាប់ខ្មាំង”។ ហេតុនេះ ទោះបីជាការសម្លាប់នៅទួលពោធិ៍ជ្រៃ មិនមាន ទំនាក់ទំនងច្បាស់លាស់ ទៅនឹងគោលនយោបាយកំណត់គោលដៅនៅក្នុងដីកាដំណោះស្រាយក៏ ដោយ ក៏ការសម្លាប់ទាំងនេះ គឺជាឧទាហរណ៍នៃវិធីសាស្ត្រទូទៅនៃការកំណត់គោលដៅចំពោះអ្នក រដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្រោមគោលនយោបាយកំណត់ គោលដៅនេះ[២៥៦៤]។ ហេតុដូច្នេះ ដោយពិចារណាទៅលើលក្ខណៈនៃបទចោទដែលទាក់ទងនឹងការ សម្លាប់នៅទួលពោធិ៍ជ្រៃ ជនជាប់ចោទបានទទួលការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទប្រឆាំងនឹង

---

បញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំ រឿងលេខ០០២/០១ (E163) ឯកសារ E124/7.3។

[២៥៦១] ដីកាដំណោះស្រាយ កថាខណ្ឌ ១៧៨, ៦៩៨-៧១៤ (ការចោទប្រកាន់តាមអង្គហេតុ ស្ថិតនៅក្នុងផ្នែក VIII(គ) នៃ ដីកាដំណោះស្រាយ ដែលលើកឡើងអំពីការអនុវត្តគោលនយោបាយទីបី ទាក់ទិននឹងការលត់ដំសមាសភាពមិនល្អ និង ការសម្លាប់ខ្មាំង)។

[២៥៦២] ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿងលេខ ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពី បញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំ រឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3។

[២៥៦៣] សាលដីកា រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច កថាខណ្ឌ ១២៨, ១៦៣។

[២៥៦៤] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៦ ជើងទំព័រ ៦៩៨ (យោងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម អាឡាត់ (E3/4637) ទាក់ទិននឹងការសម្លាប់នៅទួលពោធិ៍ជ្រៃ)។

ពួកគេ។ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធនឹងគោលនយោបាយកំណត់គោលដៅនេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណា ថាតើសហឧក្រិដ្ឋកម្មរួមមានអត្ថិភាពដែរ ឬយ៉ាងណាដែលបានបណ្តាលឲ្យមានការប្រព្រឹត្តិអំពើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។

### ១៤.៣.១ គោលនយោបាយ

៨១៤. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា ខ្មែរក្រហមមានគោលនយោបាយកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅមុនឆ្នាំ ១៩៧៥[២៥៦៥]។ ដូចរៀបរាប់ខាងក្រោមនេះ គោលនយោបាយនេះបានបន្តអនុវត្តពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេស ក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១។

៨១៥. យោងតាម នួន ជា គោលការណ៍កុម្មុយនីស្តកំណត់ឲ្យលុបបំបាត់អ្នកទាំងឡាយណាដែលគំរាមកំហែងដល់ប្រទេស និងអ្នកទាំងឡាយណាដែលមិនអាចអប់រំកែប្រែបាន[២៥៦៦]។ ការលុបបំបាត់នេះ រួមបញ្ចូលទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលថ្នាក់ដឹកនាំបក្សជឿជាក់ថានឹងមិនបោះបង់ចោលនូវយុទ្ធសាស្ត្ររបស់ពួកគេក្នុងការដាក់បង្កប់ភ្នាក់ងារ និងបង្កការបះបោរប្រឆាំងនោះឡើយ ទោះបីជាពួកគេទទួលបរាជ័យប៉ុន្មានដងក៏ដោយ[២៥៦៧]។ ចាប់ផ្តើមតាំងពីមុនថ្ងៃទី ១៧ ខែ

---

[២៥៦៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៨, ១២០-១២៣។

[២៥៦៦] ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ទំព័រ ២៧, ២៩។

[២៥៦៧] សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ 86 ERN (ភាសាអង់គ្លេស) 00003322 (ការលុបបំបាត់ "បរិវារ" ពួកមូលធន ពួកសក្តិភូមិ និងពួកចក្រពត្តិ បានបង្ហាញឲ្យឃើញអំពីជ័យជម្នះយ៉ាងធំធេង។ ទោះបីជាខ្មាំងទទួលនូវបរាជ័យយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏ពួកគេមិនចុះចាញ់ឡើយ ដោយនៅតែព្យាយាមដាក់បង្កប់ភ្នាក់ងារដើម្បីបង្កចលាចលបះបោរផ្ទៃក្នុង)។ ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ៖ *មេរៀនសង្ខេបស្តីអំពី ប្រវត្តិនៃចលនាបដិវត្តកម្ពុជាដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា* ឯកសារ E3/1 គ្មានចុះកាលបរិច្ឆេទ ទំព័រ ៩ ERN (ភាសាខ្មែរ) 00699272 (អតីតវណ្ណៈកខ្វក់ខ្លះមិនទាន់បានដោះស្រាយនៅឡើយ ហើយនៅមានវណ្ណៈដើមដែលនៅជាប់កាកសំណល់ពីសង្គមចាស់)។ ការពិនិត្យពិច័យករណីកប៉ាល់ Mayaguez (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា) ឯកសារ E3/647 ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ៣ ERN (ភាសាខ្មែរ) S 00651206 (អៀង សារី បាននិយាយថា ខ្មែរក្រហមគិតថា នឹងមានបញ្ហាក្នុងការដាក់បញ្ចូលកងទ័ពខ្មាំងទៅក្នុងជួរ កងទ័ពខ្មែរក្រហម ហើយថា ពួកគេនឹងប្រឆាំងមកលើកងទ័ពយើង។ នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ ខៀវ សំផន បាន ចោទប្រកាន់នៅឯពិធីជប់លៀងក្នុងទីក្រុងប៉េកាំងថា ក្រៅពីសកម្មភាពបង្កវិទ្ធង្សនា និងការរំខាន សហរដ្ឋអាមេរិក និង "បរិវារ" របស់ខ្លួនកំពុងបន្តយុទ្ធនាការឃោសនាដ៏ខ្មៅកខ្វក់ ប្រឆាំងនឹងកម្ពុជា ក្នុងចេតនាអាក្រក់ដើម្បីរារាំងដល់ការ ស្តារប្រទេសកម្ពុជា

មេសា ឆ្នាំ ១៩៧៥ និងបន្ត យ៉ាងហោចណាស់ រហូតដល់ឆ្នាំ ១៩៧៦ ថ្នាក់ដឹកនាំបក្សបានចាត់ទុកអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ថាជាសត្រូវទីមួយ[២៥៦៨]។ ទាំង ខៀវ សំផន និង អៀង សារី បានលើកឡើងថា ប្រជាជន និងកម្មាភិបាលមានការស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ និង បានដឹងអំពី "ចរិតពិត" របស់ពួកគេ ដូច្នេះហើយមាន "ការប្រុងប្រយ័ត្នបដិវត្តន៍ជានិច្ច"[២៥៦៩]។ ខៀវ សំផន បានលើកឡើងទៀតថា ដើម្បីបញ្ចៀសការជ្រៀតជ្រែកពី

---

ឡើងវិញ)។ សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទកំពូលលើកទី៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ថ្ងៃទី ១៦-១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ២២ ERN 00065901 (ពួកខ្មាំងនៅតែប៉ុនប៉ងព្យាយាមបំផ្លាញលទ្ធផលបដិវត្ត)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1024 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00052349 (ពួកខ្មាំងបានបំផុសក្នុងប្រជាជនប្រឆាំងសហករណ៍)។ *ទស្សនាវដ្ដីយុវជន និង យុវនារីបដិវត្ត* ឯកសារ E3/146 ខែសីហា-កញ្ញា ឆ្នាំ ១៩៧៤ ERN (ភាសាខ្មែរ) 00283409 (សក្តិភូមិ-អភិជន គឺសំដៅទៅលើពួកសក្តិភូមិកាន់អំណាច និងរួមទាំងស្តេច នាម៉ឺន កុង្សី ចៅហ្វាយខេត្ត ចៅហ្វាយស្រុក រហូតដល់មេឃុំ និងជំទប់)។ *ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/146 ខែសីហា-កញ្ញា ឆ្នាំ ១៩៧៤ ទំព័រ ១៨-១៩ ERN (ភាសាខ្មែរ) 00283409 (សក្តិភូមិ-អភិជន គឺសំដៅទៅលើពួកសក្តិភូមិកាន់អំណាច និងរួមទាំង ស្តេច នាម៉ឺន កុង្សី ចៅហ្វាយខេត្ត ចៅហ្វាយស្រុក រហូតដល់មេឃុំ និងជំទប់)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/5 ខែសីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063322-00063323 ("អ្នកទាំងនេះជាកសិករថ្មី ចេញពីអនុធន សក្តិភូមិ នាយទុន ... ដូច្នេះវាទំនាស់ជាមួយបដិវត្តតទៅទៀត")។ ឯកសារកម្ពុជាប្រជាធិបតេយ្យ៖ *សំរួចសតិអារម្មណ៍នៃវណ្ណៈអធនឱ្យមុតស្រួច និងខ្លាំងក្លាបំផុត* ឯកសារ E3/138 គ្មានចុះកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00442434 (នៅមានទំនាស់ជាមួយវណ្ណៈសក្តិភូមិជាម្ចាស់ដីជាអភិជន (ពោលគឺ មេឃុំ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត អ្នករដ្ឋការ នគរបាល និង ទាហាន)។ សូមមើលផងដែរ សៀវភៅកំណត់ត្រាកម្ពុជាប្រជាធិបតេយ្យ៖ *ការបែងចែកវណ្ណៈ ទំនាស់វណ្ណៈ និងការតស៊ូវណ្ណៈនៅក្នុងសង្គមកម្ពុជា* ឯកសារ E3/1233 មិនមានចុះកាលបរិច្ឆេទ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00032921-00032922 (វណ្ណៈសក្តិភូមិអភិជន គឺសំដៅទៅលើព្រះរាជវង្សានុវង្ស នាម៉ឺន ដែលជាអ្នកមានអំណាច រួមមាន ស្តេច ចៅហ្វាយខេត្ត និងចៅហ្វាយស្រុក) ទំព័រ ១៤ ERN (ភាសាខ្មែរ) 00032927 (វណ្ណៈអនុធន រួមបញ្ចូល ទាំងអ្នករដ្ឋការផងដែរ) ទំព័រ ២៤-២៥ ERN (ភាសាខ្មែរ) 00032937-00032938 (នគរបាល និងទាហាន គឺជាប្រភេទវណ្ណៈពិសេស ដែលកាន់អាវុធបម្រើរដ្ឋអំណាចផ្តាច់ការ ពួកគេគឺឧបករណ៍នៃកម្លាំងប្រដាប់អាវុធរបស់ខ្មាំងវណ្ណៈ និងជា 'ប្រតិកិរិយាដាច់ខាត')។

[២៥៦៨] សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ១៨ ERN (ភាសាអង់គ្លេស) 00003254។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២១-១២៣។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣ ។

[២៥៦៩] បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/3198 គ្មានចុះកាលបរិច្ឆេទ ទំព័រ ១២ ERN (ភាសាខ្មែរ) 00807466 (មហាជនមានសន្ទុះស្នេហាជាតិ និងស្អប់ លន់ នល់ ដែលបានលក់ប្រទេសទៅឲ្យអាមេរិក)។ សុន្ទរកថារបស់ អៀង សារី នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣២ សម័យប្រជុំពេញអង្គលើកទី ២៨ ឯកសារ E3/1586 ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៤៧ ERN (ភាសាខ្មែរ) 00291026 (ប្រជាជន និង

បរទេស ខ្មែរក្រហមបានរៀនសូត្រមេរៀនដ៏សំខាន់មួយបន្ទាប់ពីសហរដ្ឋអាមេរិកបានចូលមកកម្ពុជាតាមរយៈរដ្ឋប្រហាររបស់ លន់ នល់ នៅ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០។ តាមរយៈការសម្លាប់ខ្មាំង ថ្នាក់ដឹកនាំខ្មែរក្រហមសង្ឃឹមថានឹងអាចការពារមិនឲ្យមានការឈ្លានពានពីបរទេសម្តងទៀត[២៩៧០]។ ដូច្នេះ ថ្នាក់ដឹកនាំខ្មែរក្រហមបានខិតខំលុបបំបាត់ "ពួកនៅសេសសល់" ទាំងអស់នៃរបបសក្តិភូមិ ចក្រពត្តិ និងមូលធននិយម[២៩៧១] នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[២៩៧២]។

---

កងទ័ពបដិវត្ត មានការប្រុងប្រយ័ត្នចំពោះចរិតពិតនៃពួកក្បត់ ចក្រពត្តិអាមេរិក ឈ្លានពាន ទេសានុពន្ធនិយម និង សាហាវឃោរឃៅ និងបរិវាររបស់ពួកគេដែលជាសត្រូវរបស់ប្រជាជនយើងគ្រប់គ្នា។ ជានិច្ចកាល ប្រជាជនមានភាពប្រុងប្រយ័ត្នបដិវត្ត)។ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ទំព័រ ៦៤-៦៥ (ប្រជាជនអស់សង្ឃឹមចំពោះ របប លន់ នល់ នឿយណាយដោយឃើញអំពើឃោរឃៅ អំពើឧក្រិដ្ឋ និងសកម្មភាពអាណាធិបតេយ្យ)។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១២, ១២១។

[២៩៧០] កំណត់ហេតុនៃការសម្ភាសន៍ជាមួយ ខៀវ សំផន និង នួន ជា ដោយ អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង ឯកសារ E3/108 (មានក្នុងឯកសារ E3/122) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៩-១០ ERN (ភាសាខ្មែរ) 00347039-00347040។

[២៩៧១] សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ 20 ERN (ភាសាអង់គ្លេស) 00003256 (ត្រូវតែកាត់បន្ថយខ្មាំងឲ្យនៅត្រឹមកម្រិតអប្បបរមា ដូច្នេះពួកគេមិនអាចបំបែកខ្មែរក្រហមបានឡើយ)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ២៥-២៦ (មានគោលនយោបាយ "សម្លាប់ឈ្លើយសឹក" ចោលតែម្តងតាំងពីដំបូងម្ល៉េះ)។ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ២ (គាត់សន្និដ្ឋានថា មានគោលនយោបាយកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយផ្អែកទៅលើលំនាំនៃឧបទ្ទេវហេតុដែលបានកើតឡើង)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៧០-៧១ (SHORT ជឿជាក់ថា មានគោលនយោបាយកំណត់គោលដៅ និងសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពីព្រោះវាកើតឡើងនៅគ្រប់ទីកន្លែងទាំងអស់)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ទំព័រ ៤២ (លន់ នល់ និងទាហានរបស់គេគឺជាសត្រូវ ហើយប្រសិនបើពួកគេត្រូវបានចាប់ខ្លួន ពួកគេនឹងត្រូវកម្ទេចចោល)។ បទសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារ E3/203 គ្មានចុះកាលបរិច្ឆេទ ទំព័រ ២១ ERN (ភាសាខ្មែរ) 00385406 (លន់ នល់ នៅមានឫសនៅក្នុងសង្គមកម្ពុជា ដោយសារតែមានរចនាសម្ព័ន្ធរដ្ឋាភិបាល និងកងទ័ពជាប្រព័ន្ធ ប៉ុន្តែឫសទាំងនេះបានរបេះជាបណ្តើរៗហើយ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០ (នៅឆ្នាំ ១៩៧៥ ខ្មែរក្រហមមានគោលដៅបំផ្លាញអ្នកទាំងឡាយដែលធ្វើការបម្រើឲ្យអាមេរិក និងរបបលន់ នល់)។ ទូរលេខក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ស្តីពីប្រទេសកម្ពុជា ឯកសារ E3/2719 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00574325-00574326 (រដ្ឋមន្ត្រីក្រសួងការបរទេសរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា លោក សារិន ឆាក បាននិយាយថា ពុំអាចមានការបន្តអ្វីទាំងអស់ពីរបបចាស់ ហើយថាចាំបាច់ត្រូវបំបាត់អតីតកាលចោលឲ្យអស់)។ បទឧទ្ទេសនាមរបស់តំណាងបក្ស ក្នុងឱកាសអបអរសាទរខួបទី ១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ឯកសារ E3/145 ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ៧៤-៧៦ ERN

៨១៦. នៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ដែលគណៈកម្មាធិការមជ្ឈិមបានរៀបចំផែនការវាយសម្រុកចុងក្រោយដើម្បីរំដោះប្រទេសជាតិនោះ នួន ជា ប៉ុល ពត ខៀវ សំផន ព្រមទាំងមេដឹកនាំភូមិភាគ តំបន់ និងមេដឹកនាំយោធា បានពិភាក្សាគ្នាអំពីបទពិសោធន៍របស់បក្សនៅឧត្តុង្គ ដែលនៅពេលនោះ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានគេសម្លាប់ជាទ្រង់ទ្រាយធំ។ ក្រោយពីបានពិចារណាទៅលើ "ជោគជ័យ" នាពេលមុនមកនេះ ថ្នាក់ដឹកនាំបក្សបានសម្រេចទៅលើយុទ្ធសាស្ត្រវាយសម្រុកចុងក្រោយរបស់ខ្លួននេះ។ ផែនការនេះត្រូវបានបញ្ជាក់នៅក្នុងអំឡុងកិច្ចប្រជុំ ដើមខែ មេសា ឆ្នាំ ១៩៧៥[២៩៧៣]។

៨១៧. លើសពីនេះទៀត មានភស្តុតាងយ៉ាងច្រើនលើសលុបបង្ហាញថា គោលនយោបាយក្នុងការកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ជា និងបញ្ជាក់យ៉ាងច្បាស់លាស់ដោយថ្នាក់ដឹកនាំបក្សនៅក្នុងអំឡុងពេលវាយសម្រុកចុងក្រោយដើម្បីរំដោះប្រទេសជាតិ និងក្រោយៗមកទៀត នៅគ្រប់ពេលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[២៩៧៤]។ ក្រោយពីការ

---

(ភាសាខ្មែរ) 00442130-00442131។ សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ឯកសារ E3/637 ខែ មករា ឆ្នាំ ១៩៧៣ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00442327-00442328 (របបសាធារណរដ្ឋខ្មែរត្រូវរំលាយចោល)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣, ៦១៦។

[២៩៧២] សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងអង្គប្រជុំមហាជនដែលប្រារព្ធខួបលើកទី១០នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ឯកសារ E3/349 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៦-៨, ៩ ERN (ភាសាខ្មែរ) S 00324815-00324817, 00324818 (ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ មានដំណាក់កាលតស៊ូការពារជាតិ។ វាជាដំណាក់កាលវាយប្រយុទ្ធប្រឆាំងនឹងពួកចក្រពត្តិ និងបរិវាររបស់ពួកគេ)។ សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប (បណ្តុំឯកសារ SWB) ឯកសារ E3/200 ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ១-២, ១១-១២ ERN (ភាសាខ្មែរ) 00292803-00292804, 00292813-00292814 (ត្រូវតែរក្សាឲ្យបាននូវស្មារតីប្រុងប្រយ័ត្នបដិវត្តគ្រប់ពេលវេលា និងបន្តវាយប្រយុទ្ធ និងបង្ក្រាបខ្មាំងសត្រូវទាំងអស់)។

[២៩៧៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៣-១៤៧។

[២៩៧៤] *សូមមើលឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម សំហួន ឯកសារ E3/3962 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00287536 (នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ សុន សេន បានចេញបញ្ជាឲ្យចាប់ខ្លួន អ្នករដ្ឋការស៊ីវិលមានឋានន្តរស័ក្តិធំៗ និងទាហានរបប លន់ នល់)។ អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅឥណ្ឌូចិន ចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00742970-00742971 (វាយការណ៍ថា ខ្មែរក្រហមបានចេញបញ្ជាឲ្យសម្លាប់នាយទាហាន និងអ្នករដ្ឋការស៊ីវិលនៃរដ្ឋាភិបាល លន់ នល់ ទាំងអស់)។ *សេចក្តីបន្ថែមរបស់គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ តាមសេចក្តីសម្រេចលេខ៩ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិ*

រំដោះខេត្តពោធិ៍សាត់ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គណៈកម្មាធិការភូមិភាគពាយ័ព្យ បានចេញបញ្ជា ឲ្យប្រមូលផ្តុំអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងយកទៅសម្លាប់ចោល[២៩៧៥]។ យោងតាម អៀង សារី នៅអំឡុងថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ មជ្ឈិមបក្សក៏បានចេញសេចក្តីសម្រេចមួយឲ្យសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីធានាថា ពួកគេមិនអាចងើបបះបោរប្រឆាំងនឹងបដិវត្តន៍បាន[២៩៧៦]។ នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ សមមិត្ត ពិន នៅភូមិភាគពិសេស បានបញ្ជាឲ្យសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចំនួន ១៧ នាក់ ដែលបក្សបានសម្រេច “កម្ទេច” ហើយបានកំណត់អត្តសញ្ញាណសមាជិកក្រុមគ្រួសាររបស់ពួកគេថាជា “ពួកក្បត់” និង “បានស្នើឲ្យ” កម្មាភិបាលទាំងអស់ “អនុវត្តគោលនយោបាយរបស់បក្សនេះ”[២៩៧៧]។ នៅក្នុងអំឡុងកិច្ចប្រជុំក្នុងខែ កញ្ញា ឆ្នាំ ១៩៧៦ បន្ទាប់ពីបានទទួលព័ត៌មានអំពីផែនការវាយប្រហាររបស់ពួកចក្រពត្តិពី បង ៨៩ (សុន សេន) កងពលធំយោធាខ្មែរក្រហមលេខ ១៦៤ ត្រូវបានបញ្ជាឲ្យបន្តប្រមូលយកប្រវត្តិរូប និងប្រមូលផ្តុំ “សមាសភាពទាហាន”[២៩៧៨]។ បន្ទាប់ពីមានការណែនាំស្រដៀងគ្នានេះដែរ ពី “អង្គការ” កម្មាភិបាលស្រុក តំបន់ និងភូមិភាគនានា បានរាយការណ៍នៅក្នុងឆ្នាំ ១៩៧៦ ឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ថា “ពួកនៅសេសសល់” នៃរបបមុនបន្ថែមទៀត រួមទាំងអ្នករដ្ឋការ ទាហាន នគរបាល និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវបាន

---

*មនុស្ស (XXXIV)* (ECOSOC) ឯកសារ E3/3327 ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៧៨ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00723754-00723755 (វាគឺជាសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមក្នុងការបោសសំអាតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦)។ ប្រតិចារឹកបទសម្ភាសន៍ជាមួយ អៀង ផាន ឯកសារ E3/419.1 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00909627 (គាត់ត្រូវបានណែនាំឲ្យរកមើលទាហាន លន់ នល់)។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៤២-៤៣ ទំព័រ ៤២-៤៣ (ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៦ ផ្នែកសន្តិសុខបានទទួលសញ្ញាពីថ្នាក់ដឹកនាំបក្សថា ពួកគេត្រូវតែប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ដើម្បីកំណត់អត្តសញ្ញាណអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានរត់គេចខ្លួន)។

[២៩៧៥] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦២-៦៦៣ ។

[២៩៧៦] អត្ថបទសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00062461-00062462។

[២៩៧៧] សេចក្តីសម្រេចកម្ទេច (Execution Order) ឯកសារ E3/832 ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00068914។

[២៩៧៨] កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ឯកសារ E3/813 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00162490។*សូមមើលឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ E3/5762 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00164319។

កំណត់អត្តសញ្ញាណ ចាប់ខ្លួន និង/ឬសម្លាប់។ របាយការណ៍មួយចំនួនក្នុងចំណោមរបាយការណ៍ទាំងនេះត្រូវបានបញ្ជូនទៅ ឬ ចម្លងជូនទៅ ប៉ុល ពត អៀង សារី នួន ជា វន វេត និង/ឬ សុន សេន និងមន្ទីរ ឬ គណៈ ៨៧០[២៩៧៩]។

[២៩៧៩] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/511 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00000766 (កែ ពក បានរាយការណ៍ទៅ ប៉ុល ពត នួន ជា និង សុន សេន អំពីសភាពការណ៍ខ្មាំងនៅក្នុងភូមិភាគឧត្តរ រួមទាំងអតីតទាហានដែលបានបិទបង្ហាញរូបថតរបស់ លន់ នល់ និងសេចក្តីថ្លែងការណ៍របស់វា នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០)។ សេចក្តីរាយការណ៍ផ្ញើទៅស្រុកត្រាំកក់ ឯកសារ E3/4141 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ (“ក្រោយពីទទួលបានការណែនាំជាបន្តបន្ទាប់ពីអង្គការ ក្នុងការប្រុងប្រយ័ត្នខ្មាំង និងបោសសម្អាតពួកទាហានខ្មាំងដែលមានបណ្តាសក្តិ ក្នុងនោះបានតាមដានពិនិត្យឃើញមានឈ្មោះដូចខាងក្រោម”)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/1144 ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00069447-00069449 (តំបន់ ៨០១ បានរាយការណ៍ទៅ ប៉ុល ពត នួន ជា អៀង សារី វន វេត និង សុន សេន ថា អតីតអ្នករដ្ឋការ នគរបាល និង ទាហាន ត្រូវបានរកឃើញជាបន្តបន្ទាប់ មាននៅសល់តិចតួចប៉ុណ្ណោះ)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/995 ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00019201-00019202 (ប៉ុល ពត អៀង សារី នួន ជា និង វន វេត បានទទួលរបាយការណ៍មួយដែលទាក់ទងនឹងសត្រូវដែលនៅសល់ “ពួកខ្មាំងដែលនៅសេសសល់” រួមមាន នគរបាល ទាហាន និងអ្នករដ្ឋការស៊ីវិលដែលបានបន្លំខ្លួនធ្វើជាប្រជាជនថ្មី។ យើងបានស្គាល់មុខពួកវាច្បាស់ យើងក៏បាន “បោសសំអាត” ពួកវាមួយចំនួន ហើយអ្នកដែលនៅសល់បានរត់បាត់)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/996 ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00001084-00001085 (លេខាភូមិភាគឧត្តរ បានរាយ-ការណ៍ទៅគណៈ ៨៧០ ដោយចម្លងជូន ប៉ុល ពត នួន ជា អៀង សារី និង វន វេត ថា ពួកខ្មាំងដែលនៅសេសសល់ បានងើបក្បាលធ្វើសកម្មភាពឡើងវិញ ហើយត្រូវបានយើងបោសសំអាតជាខ្សែសង្វាក់ ប៉ុន្តែនគរបាល ទាហាន និងអ្នករដ្ឋការស៊ីវិលមួយចំនួនបានរត់បាត់)។ លិខិតបញ្ជាក់ កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/2450 ចុះថ្ងៃទី ១៧-១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00270746 (បានបញ្ជាក់ប្រាប់ អាន់ ថា សក្តិ ២ ចំនួន ២ នាក់ និង សក្តិ ១ ចំនួន ១ នាក់ ត្រូវបានបញ្ជូនទៅឲ្យ អាន់ ពីព្រោះវាជាការសម្រេចរបស់បក្ស ដោយសារពួកទាំងនេះជាអ្នកមានបណ្តាសក្តិខ្ពស់) ទំព័រ ២ ERN (ភាសាខ្មែរ) 00270747 (សក្តិ ១ ម្នាក់ និង សមាជិក ២ នាក់នៃកងទ័ពអាកាសត្រូវបានអង្គការសម្រេចឲ្យបញ្ជូនទៅ អាន់) ទំព័រ ៣ ERN (ភាសាខ្មែរ) 00270748 (តាមមតិណែនាំរបស់អង្គការសម្រេចឲ្យចាប់ខ្លួនស្ត្រីមេម៉ាយ ប្រពន្ធសក្តិ ៤ កន្លះ។ គាត់និយាយថា ជីវិតកាលពីនៅរបបចាស់ស្រួលជាងនេះ)។ របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/2048 ចុះថ្ងៃទី ២៨ ខែ មីនា-ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ៦ ERN (ភាសាខ្មែរ) 00079092 (ស្នើសុំឲ្យបញ្ជូនអតីតទាហានទៅមន្ទីរសន្តិសុខ)។ របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/4103 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00143476 (ប្តេជ្ញាបំផ្លាញ និងកម្ទេចខ្មាំង “ឲ្យអស់ទាំងស្រុង” អតីតអ្នករដ្ឋការដែលមានបណ្តាសក្តិខ្ពស់នឹងត្រូវបញ្ជូនទៅស្រុក និងស្នើសុំយោបល់ ទាក់ទិននឹងអតីតទាហាន និងគ្រូបង្រៀន)។

៨១៨. គោលនយោបាយរបស់បក្សពាក់ព័ន្ធនឹង "ខ្មាំង" ត្រូវបានផ្សព្វផ្សាយតាមរយៈវគ្គអប់រំបំពាក់បំប៉នដែលធ្វើឡើងដោយមេដឹកនាំបក្ស រួមទាំង នួន ជា និង ខៀវ សំផន[២៥៨០] និងតាមរយៈទស្សនាវដ្ដី *ទង់បដិវត្ត និងយុវជន និងយុវនារីបដិវត្ត*នានា[២៥៨១] ដែលនៅពេលនោះមានការលើកសរសើរអំពីការលុបបំបាត់ខ្មាំងផងដែរ រួមទាំង អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[២៥៨២]។

[២៥៨០] ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ៣០-៣១ (នៅឯវគ្គរៀនសូត្រទាំងនេះ ពួកគេបានទទួលការណែនាំឱ្យចេះធ្វើការ វាយតម្លៃ តាមដាន ចាប់ខ្លួន និង 'កម្ទេច' ដែលមានន័យថា បំបាត់ចោល ឬសម្លាប់ខ្មាំង)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ៦៧-៧៤, ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ ២៥-២៦។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ទំព័រ ៣៤-៤១, ៥៣-៥៤, ៦៦-៨៣។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២ (ជា សាយ) ទំព័រ ២៨-៣៤, ៦៤។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៥២-៥៥។ ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ទំព័រ ៧៥-៧៦។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៧-៥៨។ *សូមមើលផងដែរ* ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៩។

[២៥៨១] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/742 ខែ មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00062986 (ត្រូវតែបន្តវាយសម្រុកជានិច្ចប្រឆាំងនឹងខ្មាំង ដេញសំពង និងជាន់កញ្ចួកវា ដើម្បីកុំឱ្យពួកវាងើបក្បាលរួច) 00062992 (ត្រូវសម្រិតសម្រាំង ជម្រុះ និងបោសសំអាតសមាសភាពមិនល្អ និងសមាសភាពខ្មាំង) 00062993 (ត្រូវរែកមុខ និងបោសសំអាតឱ្យស្អាតជាស្ថាពរ ពួក សេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងាររបស់ពួកវា និងស្មែបម្រើរបស់ពួកវា)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/135 ខែ មិថុនា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00062809-00062810 (វាយសម្រុកខ្មាំងវណ្ណៈ ខ្មាំងបង្កប់ និងភ្នាក់ងាររបស់ពួកវា)។ *ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត* ឯកសារ E3/726 ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទំព័រ ១៤-១៥ ERN (ភាសាខ្មែរ) 00063491 (ត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តឱ្យខ្ពស់ជាប់ជានិច្ច ដោយសារខ្មាំងគ្រប់ប្រភេទព្យាយាមរកឱកាសដើម្បីបំផ្លាញបដិវត្ត)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/727 ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00064578 (ដូច្នេះ ភារកិច្ចរបស់យើង គឺវាយកម្ទេចខ្មាំងឱ្យខ្ទេចខ្ទី ខ្ចាត់ខ្ចាយ និងរលំរលាយទាំងស្រុង) 00064579 (យើងត្រូវតែឃើញមុខមាត់ខ្មាំងឱ្យច្បាស់ បោសសំអាតខ្មាំងទាំងនេះ បោសហើយបោសទៀត គ្មានឈប់ឈរ ដើម្បីឱ្យកម្លាំងបក្សរបស់យើងស្អាត)។ *សូមមើលផងដែរ* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦១-២៦៦។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២៥៨២] *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063336 (បន្ទាប់ពីវាយបោសសំអាត តែប៉ុន្មានខែ ខ្មាំងត្រូវខ្ទេច)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00062748 (បន្ទាប់ពី រំដោះទីក្រុងភ្នំពេញ ពួកចក្រពត្តិជាមេក្លោង ត្រូវបណ្ដេញចេញអស់ ហើយបរិវាររបស់ពួកវាត្រូវរលំរលាយសាបសូន្យ និងជាស្ថាពរ។ នេះគឺជាលទ្ធផលទី១នៃមហាជ័យជម្នះ មហាអស្ចារ្យ)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/5 ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ១២ ERN (ភាសាខ្មែរ) 00063318 (យើងកំចាត់ការទាក់ទងផលិតកម្មចាស់ជិះជាន់ បានជាមូលដ្ឋាន។ ក្នុងតំបន់រំដោះប្រភេទទី១ កំចាត់ទាំងស្រុង។ ក្នុងតំបន់រំដោះប្រភេទទី២ កំចាត់បានជា

សាក្សីឈ្មោះ ពេជ្រ ជឹម ជាលេខាស្រុកត្រាំកក់ បានចូលរួមក្នុងវគ្គរៀនសូត្ររយៈពេលមួយខែ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ដែលជាវគ្គរៀនសូត្រសម្រាប់លេខាស្រុកទាំងអស់។ ក្នុងអំឡុងវគ្គរៀនសូត្រនោះ នួន ជា បានបង្រៀនមនុស្សប្រហែល ៨០០ នាក់ អំពីប្រធានបទខ្មាំង។ ពេជ្រ ជឹម បានបញ្ជាក់ថា ប្រសិនបើគ្មានការបង្រៀនរបស់ នួន ជា ទេនោះ "គេនឹងមិនដឹងអំពីរបៀបបែងចែកឲ្យដាច់រវាងខ្មាំង និងមិត្តឡើយ"[២៥៨៣]។

## ១៤.៣.២ យុត្តិកម្ម និងការបដិសេធ

៨១៩. នៅមុនពេលរំដោះទីក្រុងភ្នំពេញ និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ខ្មែរក្រហមបានបដិសេធចំពោះក្ដីបារម្ភ និងបានបង្វែរមិនឲ្យមានការចាប់អារម្មណ៍ទៅលើគោលនយោបាយរបស់ខ្លួនក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយអះអាងថាមានតែ "ពួកជនមហាក្បត់" ចំនួន ៧ នាក់ ប៉ុណ្ណោះ នឹងត្រូវសម្លាប់ចោល និងដោយបានជំរុញឲ្យអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចាកចេញពីប្រទេស (ផ្នែក ១៤.៣.២.១)។ ខ្មែរក្រហមបានអះអាងថា សង្គ្រាមរវាងខ្មែរក្រហម និង "ពួកចក្រពត្តិ" បានកើតមានជាបន្តទៀត ដោយលើកឡើងអំពីការវាយប្រហាររបស់សហរដ្ឋអាមេរិក ដូចជាព្រឹត្តិការណ៍នាវាម៉ាយាហ្គេស (*Mayaguez*) និងការទម្លាក់គ្រាប់បែកនៅសៀមរាប (ផ្នែក ១៤.៣.២.២) ហើយខ្មែរក្រហមបានអះអាងថាទាហាននៃរបបសាធារណរដ្ឋខ្មែរ មិនត្រូវបានសម្លាប់ទេ ប៉ុន្តែត្រូវបានបញ្ជូនទៅតាមទីជនបទជាមួយនឹង "ប្រជាជនថ្មី" ដទៃទៀត (ផ្នែក ១៤.៣.២.៣)។ ចំណុចខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើយុត្តិកម្ម និងការបដិសេធទាំងនេះម្ដងមួយៗ ដោយហេតុថាយុត្តិកម្ម និងការបដិសេធទាំងនេះ អាចបង្ហាញឲ្យឃើញពីអត្ថិភាព ឬក៏អំពីគោលនយោបាយកំណត់គោលដៅចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

---

មូលដ្ឋាន ជាទូទៅដែរ។ ឈ្មួញ បញ្ញាំ ប្រវាស់ បណ្ដាក់ អស់រលើងហើយ)។ *ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/746 ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00064487-00064495, 00064499-00064500 (ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវបានវែកមុខ។ យើងអាចរក្សា និងការពារកម្លាំងបដិវត្ត និងពង្រីកកម្លាំងបដិវត្ត បោសសម្អាតសមាសភាពមិនល្អ និងបន្តដឹកនាំមហាជនក្នុងការតស៊ូ និងទទួលបានជ័យជម្នះបន្ថែមទៀត) 00064502 (ជាពិសេសទៀត ក្នុងមហាចលនា មហាជនវាយកម្ទេច... នាំមកនូវជ័យជន្នះយុទ្ធសាស្ត្រជូនជាតិ ប្រជាជន បក្ស និងបដិវត្ត)។*សូមមើលផងដែរ* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦១-២៦៦។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២៥៨៣] ប្រតិចារឹក ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ទំព័រ ៣១-៣៣។

## ១៤.៣.២.១ សេចក្តីប្រកាសរបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

៨២០. នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៤ សម្តេច នរោត្តម សីហនុ ដែលទំនងជាមិនបានពិគ្រោះជាមួយខ្មែរក្រហម បានប្រកាសថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នឹងលើកលែងទោសឲ្យទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានដឹងអំពីកំហុសរបស់ខ្លួន ហើយបានចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជា[២៥៨៤]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា សម្តេច នរោត្តម សីហនុ មិនមានអំណាចក្នុងការអនុវត្តតាមការសន្យាបែបនេះឡើយ និងមិនមានការគ្រប់គ្រងទៅលើអ្វីដែលកំពុងតែកើតឡើងនៅក្នុងប្រទេសនោះទេ[២៥៨៥]។ នៅក្នុង ខែ មីនា ឆ្នាំ ១៩៧៥ រណសិរ្សរួបរួមជាតិកម្ពុជាបានចេញសេចក្តីថ្លែងការណ៍មួយ បន្ទាប់ពីមានការអះអាងថា មានមហាសន្និបាតជាតិមួយនៅចុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ដែលមាន ខៀវ សំផន ធ្វើជាអធិបតី[២៥៨៦] ហើយបានប្រកាសថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរគ្រប់ប្រភេទ មានសិទ្ធិពេញលេញក្នុងការចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ប្រសិនបើពួកគេឈប់បម្រើឲ្យ "ពួកជនមហាក្បត់" ទាំង ៧ នាក់ ភ្លាមនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ជា "ការចាំបាច់ដាច់ខាត" ដែលត្រូវតែសម្លាប់ "ពួកជនមហាក្បត់" ទាំង ៧ នាក់ នេះ ទោះបីជាពួកគេបានចុះចូលក៏ដោយ។ សេចក្តីថ្លែងការណ៍ដែលផ្សព្វផ្សាយតាមវិទ្យុនេះមានចុះហត្ថលេខារបស់ ខៀវ សំផន[២៥៨៧]។ បន្ទាប់មក ខៀវ សំផន បានគាំទ្រជា

---

[២៥៨៤] សារទូរលេខក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ដំណើរប្រែប្រួលនៃកិច្ចការកម្ពុជា ឯកសារ E3/2680 ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៤ ទំព័រ ៣ ERN (ភាសាខ្មែរ) 00810735 (ព្រះអង្គបានសម្រុកធ្វើការចចារ ដោយមិនបានទំនាក់ទំនងជាមួយនឹងចលនាតស៊ូក្នុងប្រទេស និងបានប្រកាសថា រដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រៀមផ្តល់ការលើកលែងទោសដល់ពួកជនក្បត់ដែលបានដឹងអំពីទោសកំហុសរបស់ខ្លួន ដោយចូលរួមជាមួយកម្លាំងរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខ្មែរក្រហមទំនងជាមិនពេញចិត្តនឹងការសម្រេចបែបនេះទេ។

[២៥៨៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១។

[២៥៨៦] អង្គជំនុំជម្រះសាលាដំបូងមិនជឿជាក់ទៅលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែលថា មហាសន្និបាតនេះពិតជាបានប្រារព្ធធ្វើនោះឡើយ (ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧០)។

[២៥៨៧] ខៀវ សំផន ធ្វើជាអធិបតីសម័យប្រជុំមហាសន្និបាតរបស់រណសិរ្សរួបរួមជាតិកម្ពុជា៖ សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្សព្វផ្សាយ (FBIS) ឯកសារ E3/117 ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ទំព័រ១-២ ERN (ភាសាខ្មែរ) 00242308-00242309 ។ ទូរលេខរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/189 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00896371-00896372 (ជនមហាក្បត់ទាំង ៧ នាក់ ដែលត្រូវបានផ្តន្ទាទោសដោយមហាសន្និបាតជាតិនៅថ្ងៃទី ២៤ និង ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ គឺ លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន

សាធារណៈចំពោះការលុបបំបាត់ "ពួកជនមហាក្បត់" ទាំង ៧ នាក់នោះ ដោយធានាថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដទៃទៀតនឹងរួចផុតពីសេចក្តីស្លាប់ ប្រសិនបើពួកគេចូលរួមក្នុងចលនាតស៊ូនេះឲ្យបានទាន់ពេលវេលា[២៥៨៨]។

៨២១. របាយការណ៍ការទូតជាច្រើននៅក្នុងពេលនោះបានសន្និដ្ឋានថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ដើម្បីបដិសេធចំពោះក្តីបារម្ភរបស់សហគមន៍អន្តរជាតិ អំពីលទ្ធភាពនៃការសម្លាប់រង្គាលបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម[២៥៨៩]។ ទោះបីជា សម្តេច នរោត្តម សីហនុ បដិសេធចំពោះក្តីបារម្ភរបស់អន្តរជាតិដែលថានឹងមានការសម្លាប់រង្គាលបន្ទាប់ពីជ័យជម្នះនោះ ដោយសំអាងថាមានតែ "ពួកជនមហាក្បត់" ចំនួន ៧ នាក់ប៉ុណ្ណោះ នឹងត្រូវសម្លាប់ចោលក៏ដោយ[២៥៩០] ក៏មានសេចក្តីរាយការណ៍ថា ព្រះអង្គបានព្យាករណ៍ថា ប្រជាជនកម្ពុជានឹងលុបបំបាត់ចោលឲ្យអស់មន្ត្រី និងអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងបានអំពាវនាវឲ្យ "ពួកជនមហាក្បត់" ចំនួន ១៦ នាក់ផ្សេងទៀតទទួលខុសត្រូវចំពោះ "ឧក្រិដ្ឋកម្មសង្គ្រាម" របស់ពួកគេ[២៥៩១]។

៨២២. ទោះបីជាយ៉ាងណាក៏ដោយ មិនដូចជាសេចក្តីប្រកាសរបស់សម្តេច នរោត្តម សីហនុ កាលពីខែ ធ្នូ ឆ្នាំ ១៩៧៤ ឡើយ សេចក្តីប្រកាសក្រោយៗមកទៀត រួមទាំងសេចក្តីប្រកាសរបស់

---

តាំ ឡុង បូរ៉េត និង សុសស្តែន ហ្វៀរណាង់ដេស)។ សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/1352 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00498213-00498214។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ភាសាខ្មែរ ចុះខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ E3/3334 ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00740865-00740868។

[២៥៨៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២៧។

[២៥៨៩] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ភាសាខ្មែរ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ E3/3336 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័ ៦ ERN (ភាសាខ្មែរ) 00635049 ។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ថ្ងៃទី ១១ ខែ មីនា សង្ខេបអត្ថបទកាសែត EA ឯកសារ E3/3337 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00810766-00810767។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ កិច្ចសម្ភាសន៍រវាងលោក John Burns និងសម្តេចសីហនុ ឯកសារ E3/3339 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ១ ERN (ភាសាខ្មែរ) 00632770។

[២៥៩០] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ ថ្ងៃទី ១១ ខែ មីនា សង្ខេបអត្ថបទកាសែត EA ឯកសារ E3/3337 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00810766-00810767។

[២៥៩១] *សេចក្តីថ្លែងការណ៍របស់សម្តេច នរោត្តម សីហនុ* (ទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ឯកសារ E3/1287 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៤ ERN (ភាសាខ្មែរ) 00351594។

សន្និបាតរណសិរ្សរួបរួមជាតិកម្ពុជា បានផ្តល់ការលើកលែងទោសមួយដែលមានកម្រិត។ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនឹងទទួលបានការលើកលែងទោស តែក្នុងករណីដែលពួកគេឈប់សហការជាបន្ទាន់ជាមួយនឹងជនមហាក្បត់ទាំង ៧ នាក់ នោះឲ្យបានទាន់ពេលវេលាប៉ុណ្ណោះ[២៥៩២]។ ការអត់ឱននេះនឹងត្រូវបានបដិសេធផងដែរ ក្នុងករណីពួកអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចុះចូលជាមួយខ្មែរក្រហមបន្ទាប់ពីខ្មែរក្រហមបានក្តោបក្តាប់ទីក្រុងភ្នំពេញ[២៥៩៣]។

៨២៣. នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានអះអាងថា ពួកគេបានរកឃើញផែនការរបស់សត្រូវដែលត្រូវបានចោទប្រកាន់ថានឹងធើបបះបោរប្រឆាំង ប្រសិនបើខ្មែរក្រហមឈ្នះសង្គ្រាម[២៥៩៤]។ ជាពិសេស អៀង សារី បានអះអាងថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង ភ្នាក់ងារស៊ើបការសម្ងាត់ (សេ.អ៊ី.អា) មានផែនការធ្វើឃាតមេដឹកនាំខ្មែរក្រហម និងធ្វើរដ្ឋ-

---

[២៥៩២] ទូរលេខរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/189 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00323158 (មហាសន្និបាតជាតិបានអំពាវនាវឲ្យអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបោះបង់ចោល ពួកជនមហាក្បត់ទាំង ៧ នាក់នោះ "ក្នុងខណៈដែលមិនទាន់ហួសពេល")។ ទូរលេខក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ខ្មែរ ចុះខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ E3/3334 ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៦-៨ ERN (ភាសាខ្មែរ) 00740865-00740868 (អ្នកនយោបាយ និងឥស្សរជនជាន់ខ្ពស់ផ្សេងទៀត អាចចូលរួមជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា ប្រសិនបើពួកគេឈប់សហការជាមួយអ្នកទាំង ៧ នាក់ "នាពេលនេះ")។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ភាសាខ្មែរ - ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ E3/3341 ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00631505-00631506។ ខៀវ សំផន ធ្វើជាអធិបតីសម័យប្រជុំមហាសន្និបាតរបស់រណសិរ្សរួបរួមជាតិកម្ពុជា៖ សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្សព្វផ្សាយ (FBIS) ឯកសារ E3/117 ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ទំព័រ១-២ ERN (ភាសាខ្មែរ) 00242308-00242309 (អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរមានសិទ្ធិពេញលេញ ក្នុងការចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា/រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រសិនបើពួកគេ "បោះបង់ចោលការងាររបស់ពួកគេក្នុងការបម្រើជនក្បត់ទាំង ៧ នាក់នោះ")។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៩៦ (មានការអំពាវនាវពី ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់ ឲ្យមកចូលរួមជាមួយខ្មែរក្រហមជាបន្ទាន់ មិនត្រូវនៅយូរទេ)។

[២៥៩៣] ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ សារព័ត៌មានសង្ខេប EA ថ្ងៃទី ១២ ខែ មីនា ឯកសារ E3/3338 ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៦-៧ ERN (ភាសាខ្មែរ) 00740878-00740879។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ កិច្ចសម្ភាសន៍រវាងលោក John Burns និងសម្តេចសីហនុ ឯកសារ E3/3339 ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00632771។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ របាយការណ៍ភាសាខ្មែរ - ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ E3/3341 ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៨ ERN (ភាសាខ្មែរ) 00631508។

[២៥៩៤] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥២៦។

ប្រហារ[២៥៥៥]។ ដូច្នេះ កិច្ចសហការណាមួយនៅពេល ឬ ក្រោយពេលរំដោះ គឺជាការយឺតពេល។ បន្ទាប់ពីរំដោះ ទាហាន អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង "ភ្នាក់ងារសម្ងាត់" ត្រូវបានកំណត់គោលដៅ និងស្វែងរកចាប់ខ្លួន និងសម្លាប់ចោល[២៥៥៦]។

៨២៤. ក្រសួងការបរទេសសហរដ្ឋអាមេរិកបានធ្វើសេចក្តីរាយការណ៍នៅក្នុង ខែ ឧសភា ឆ្នាំ ១៩៧៥ ថា ក្រៅពីបុគ្គលចំនួន ២ នាក់ ក្នុងចំណោម "ពួកជនមហាក្បត់" ទាំង ៧ នាក់ (សិរិមតៈ និង ឡុង បូរ៉េត) អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ៥ នាក់ ផ្សេងទៀត ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល។ អ្នកដែលត្រូវបានសម្លាប់ទាំងនោះរួមមាន អ៊ុង ប៊ុនហរ (ប្រធានសភាជាតិ) ថោង លឹមហួង (រដ្ឋមន្ត្រីក្រសួងព័ត៌មាន) ឈឹម ឈួន (បញ្ជាការភូមិភាគពិសេសទីក្រុងភ្នំពេញ) ស្រី យ៉ា (បញ្ជាការកងពលតូច ឆ័ត្រយោង) និង លន់ ណុន (ឧត្តមសេនីយ៍ត្រីដែលបានលាឈប់ពីការងារ និងជាប្អូនប្រុសរបស់ លន់ នល់)[២៥៥៧]។ មិនមានបុគ្គលណាម្នាក់ក្នុងចំណោមអតីតអ្នករដ្ឋ-

---

[២៥៥៥] អត្ថបទសម្ភាសន៍ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១០-១១ ERN (ភាសាខ្មែរ) 00062461-00062462។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតប្រទេសដាណឺម៉ាកនៅកម្ពុជា ឯកសារ E3/480 ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៨ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00583720-00583721។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00291035-00291036។ សូមមើលផងដែរ ប្រតិចារឹកបទសម្ភាសន៍ ជាមួយ ខៀវ សំផន ឯកសារ E3/3196 មិនមានចុះកាលបរិច្ឆេទ ទំព័រ៤ ERN (ភាសាខ្មែរ) 00807445 (គាត់បានដឹងថា នៅសល់ភ្នាក់ងារអាមេរិកខ្លះ ប៉ុន្តែភ្នាក់ងារទាំងនេះ ខ្ចាត់ខ្ចាយយ៉ាងឆាប់រហ័ស)។

[២៥៥៦] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន) ដំណាក់កាលទី១កថាខណ្ឌ ( ៥០៣-៥១៣។

[២៥៥៧] សារទូលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ សេចក្តីរាយការណ៍របស់ប្រជាជនអាមេរិកស្តីអំពីស្ថានភាពទីក្រុងភ្នំពេញបន្ទាប់ពីការដួលរលំ ឯកសារ E3/4148 ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN (ភាសាខ្មែរ) 00664000។ សូមមើលផងដែរ របាយការណ៍លើកលែងទោសអន្តរជាតិ៖ កម្ពុជាប្រជាធិបតេយ្យ (ប្រទេសកម្ពុជា) ឯកសារ E3/3865 ឆ្នាំ ១៩៧៥-១៩៧៦ ទំព័រ ១ ERN (ភាសាខ្មែរ) 00597825 (អៀង សារី បានអះអាងនៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ក្នុងអំឡុងដំណើរទស្សនកិច្ចទៅកាន់ប្រទេសថៃ ថា មេដឹកនាំបីរូបនៃរបបចាស់ត្រូវបានប្រហារជីវិតហើយ៖ ឡុង បូរ៉េត ព្រះអង្គម្ចាស់ សិរិមតៈ និង លន់ នន់)។ ទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក កម្មវត្ថុ៖ លោក អៀង សារី ធ្វើទស្សនកិច្ចនៅប្រទេសថៃ ឯកសារ E3/3360 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣ ERN (ភាសាខ្មែរ) 00740797 (អៀង សារី បានបញ្ជាក់ថា ឡុង បូរ៉េត និង លន់ នន់ ត្រូវបានប្រហារជីវិតហើយ)។ ភាពយន្តឯកសារ ដោយ THET S. និង R. LEMKIN៖ សត្រូវរបស់ប្រជាជន (Enemies of the People) ឯកសារ E3/40001R ឆ្នាំ ២០០៧ (ឈុតវីដេអូបន្ថែម៖ *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* (*One day at Po*

ការនៃរបបសាធារណរដ្ឋខ្មែរទាំងនេះ ត្រូវបានវិនិច្ឆ័យទោស ដោយមហាសន្និបាតជាតិថាជា "ពួកជនមហាក្បត់" ទាំង ៧ នាក់នោះឡើយ[២៥៩៨]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសុន្ទរកថាមួយដែលត្រូវបានថ្លែងនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៥ សម្តេច នរោត្តម សីហនុ បានពង្រីកបញ្ជីឈ្មោះ "ពួកជនមហាក្បត់" ដោយបានរាយឈ្មោះ "ឧក្រិដ្ឋជនសង្គ្រាម" ចំនួន ១៦ នាក់ បន្ថែមទៀត រួមទាំង លន់ ណុន ផងដែរ ដែលត្រូវនាំខ្លួនយកទៅទទួលខុសត្រូវ[២៥៩៩]។

៨២៥. ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក៏បានអះអាងផងដែរថា រណសិរ្សរួបរួមជាតិកម្ពុជា/រដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានអំពាវនាវឲ្យអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចាកចេញពីប្រទេសនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយបានបញ្ជាក់ថា មិនមានគោលនយោបាយសម្លាប់ពួកគេឡើយ[2600]។ ប៉ុន្តែ ទោះបីជាពួកគេបានរត់គេចខ្លួនក៏ដោយ ក៏អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនមានសុវត្ថិភាពឡើយ។ ខ្មែរក្រហមបានស្វះស្វែងយ៉ាងសកម្មផងដែរដើម្បីឲ្យមានការបញ្ជូន "ជនក្បត់" ជាន់ខ្ពស់ ដែលបានរត់ភៀសខ្លួន ឲ្យត្រឡប់មកវិញ រួមទាំង Sosthene Fernandez ឧត្តមសេនីយ៍ សេក សំសៀត វរសេនីយ៍ឯក កេត រ៉េត វរសេនីយ៍ឯក ជូ ដេត និង បាន សាង ដែលជាអតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[២៦០១]។ នៅក្នុងឆ្នាំ

---

*Chrey*)) ត្រង់ចំណុច 22.07 - 22.11 (ទួន ជា បានអះអាងថា "បទបញ្ជានយោបាយ" របស់បក្សកុម្មុយនីស្តកម្ពុជាដែលថា ពួកជនមហាក្បត់ "ត្រូវតែកម្ចាត់" នោះ តាមពិតត្រូវបានអនុវត្ត)។ សូមមើលផងដែរ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[២៥៩៨] ទូរលេខរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/189 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00896371-00896372។

[២៥៩៩] សេចក្តីថ្លែងការណ៍របស់សម្តេច នរោត្តម សីហនុ (ទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ឯកសារ E3/1287 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ៤ ERN (ភាសាខ្មែរ) 00351594។

[២៦០០] ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ បទសម្ភាសន៍ជាមួយលោក ប៉ែន នុត ឯកសារ E3/4132 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00491367-00491368។

[២៦០១] សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ E3/1352 ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00498213-00498214 (រម្លឹកដល់សហគមន៍អន្តរជាតិថា សុសស្តែន ហ្វែរណង់ដេស ដែលបានភៀសខ្លួនទៅប្រទេសបារាំង នៅតែជាជនក្បត់ម្នាក់ក្នុងចំណោមជនក្បត់ទាំងឡាយដែលត្រូវបានកាត់ទោសដោយមហាសន្និបាតជាតិ និងបានលើកទឹកចិត្តឲ្យប្រជាជនទាំងអស់ឲ្យគាំទ្រដល់សេចក្តីប្រកាសរបស់មហាសន្និបាតជាតិ។ អនុស្សារណៈរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជាប្រចាំខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារ E3/491 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៦ ទំព័រ៥ ERN (ភាសាខ្មែរ) 00704454 (អាជ្ញាធរកម្ពុជាបានស្នើសុំប្រទេសថៃជាច្រើនដងឲ្យបញ្ជូនជនភៀសខ្លួនខ្មែរមកកម្ពុជា ជាពិសេស អ្នកដែលជិតស្និទ្ធ

១៩៧៦ មានសេចក្ដីរាយការណ៍ថា ជនភៀសខ្លួននៅក្នុងប្រទេសថៃដែលត្រូវបានបញ្ជូនត្រឡប់មកខ្មែរក្រហមវិញ រួមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងនោះ ត្រូវបានសម្លាប់[២៦០២]។

៨២៦. ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សេចក្ដីប្រកាសរបស់រណសិរ្សរួបរួមជាតិកម្ពុជា/រដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅពី "ពួកជនមហាក្បត់" ចំនួន ៧ នាក់ នឹងទទួលបានការលើកលែងទោស ព្រមទាំងការអំពាវនាវឲ្យអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចាកចេញពីប្រទេសនោះ មិនបានបង្ហាញអំពីគោលនយោបាយនៃផ្នែកណាមួយរបស់ពួកខ្មែរក្រហម ដើម្បីទុកជីវិតរបស់ពួកគេឡើយ។ សេចក្ដីប្រកាសទាំងនេះគឺគ្រាន់តែជាការលាក់បាំងនៅការព្យាយាម ដើម្បីធ្វើការបដិសេធឲ្យសមហេតុផលនៅលើឆាកអន្តរជាតិប៉ុណ្ណោះ ដូចគ្នាទៅនឹងអង្គការដែលបានចេញសេចក្ដីប្រកាសទាំងនោះដែរ[២៦០៣]។ តាមពិត មន្ត្រីម្នាក់

---

ជាមួយរបប លន់ នល់ រួមមាន ឧត្តមសេនីយ៍ សេក សំសៀត វរសេនីយ៍ឯក កេត រ៉េត វរសេនីយ៍ឯក ជូ ដេត និង បាន សាង ដែលជាអតីតរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌)។

[២៦០២] អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅឥណ្ឌូចិន ចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00742970-00742971 (ជនភៀសខ្លួនចំនួន ៣៥០ នាក់ រួមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ជូនត្រឡប់មកពីប្រទេសថៃ ហើយត្រូវបានសម្លាប់ចោល)។ លិខិតពីអង្គការលើកលែងទោសអន្តរជាតិ ផ្ញើជូន ខៀវ សំផន ឯកសារ E3/3864 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00323619-00323621 (ជម្រាបជូន ខៀវ សំផន អំពីការចោទប្រកាន់ថា ជនភៀសខ្លួនចំនួន ២៦ នាក់ ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញត្រូវបានសម្លាប់ចោល)។ អនុស្សរណៈរបស់អង្គការលើកលែងទោសអន្តរជាតិ កម្មវត្ថុ៖ កម្ពុជាប្រជាធិបតេយ្យ ព័ត៌មាន និងសកម្មភាពថ្មីៗ ឯកសារ E3/3307 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00630464-00630465 (លិខិតមួយច្បាប់ត្រូវបានផ្ញើទៅ ខៀវ សំផន ពាក់ព័ន្ធនឹងសេចក្ដីរាយការណ៍អំពី ការសម្លាប់ជនភៀសខ្លួនចំនួន ២៦ នាក់ ដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃនៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ការបញ្ជូនជនភៀសខ្លួនកម្ពុជាឲ្យត្រឡប់ទៅកាន់ប្រទេសកំណើតវិញ ឯកសារ E3/2742 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00807801-00807802 (ជនភៀសខ្លួនចំនួន ២៦ នាក់ រួមទាំង គយម្នាក់ នគរបាលម្នាក់ ចៅហ្វាយស្រុកម្នាក់ និងអតីតទាហាន ត្រូវបានបញ្ជូនទៅឲ្យខ្មែរក្រហម។ ជនភៀសខ្លួនទាំងនេះគឺជាការបាក់មុខរបស់ខ្មែរក្រហម ជាពិសេស ជនភៀសខ្លួនដែលជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ បន្ទាប់ពីវិលត្រឡប់របស់ពួកគេ ជនភៀសខ្លួនទាំងនោះត្រូវបានបណ្ដើរជាសាធារណៈ ហើយមិនមានការសង្ស័យពីជោគវាសនារបស់ពួកគេនោះទេ)។

[២៦០៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០០។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១។

នៅក្នុងខុទ្ទកាល័យរបស់សម្តេច នរោត្តម សីហនុ នៅក្នុងទីក្រុងប៉េកាំង បានប្រាប់អ្នកការទូតបារាំង នៅថ្ងៃទី ១៧ ខែ មេសា ថា ខ្មែរក្រហមកំពុងព្យាយាមធ្វើយ៉ាងណាកុំឱ្យសហគមន៍អន្តរជាតិចូលមកជ្រៀតជ្រែកក្នុងខណៈដែលខ្មែរក្រហមធ្វើការជម្រះបញ្ជី[២៦០៤]។

### ១៤.៣.២.២ សង្គ្រាមជាមួយពួកចក្រពត្តិនៅតែបន្ត

៨២៧. នៅក្នុងឆ្នាំ ១៩៧៦ ឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ អង្គការលើកលែងទោសអន្តរជាតិ បានអំពាវនាវម្តងហើយម្តងទៀតឱ្យ ប៉ែន នុត ខៀវ សំផន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ស៊ើបអង្កេត ឬ អនុញ្ញាតឱ្យអ្នកសង្កេតការណ៍ឯករាជ្យ ស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្ស ដែលត្រូវបានចោទប្រកាន់ រួមទាំង ការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[២៦០៥]។ ការចោទប្រកាន់អំពីការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានរាយការណ៍នៅលើ

[២៦០៤] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ យោងសារទូរលេខរបស់លោកលេខ ៣៤៧ ឯកសារ E3/2718 ចុះថ្ងៃទី ១៧ ខែ មេសាឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00821492 ។

[២៦០៥] *សេចក្តីថ្លែងការណ៍លើកឡើងដោយអង្គការលើកលែងទោសអន្តរជាតិ* (ECOSOC) ឯកសារ E3/4198 ចុះខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00338195 (ស្នើសុំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឱ្យអ្នកសង្កេតការណ៍ឯករាជ្យធ្វើការស៊ើបអង្កេតនៅក្នុងប្រទេស និងបង្កើតយន្តការសមស្របនានា ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋម្នាក់ៗ)។ លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិផ្ញើជូន ខៀវ សំផន ឯកសារ E3/3864 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00323620-00323621 (ដោយទាញចំណាប់អារម្មណ៍របស់ ខៀវ សំផន ចំពោះការការចោទប្រកាន់ថា ជនភៀសខ្លួនចំនួន ២៦ នាក់ដែលបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ នោះត្រូវបានសម្លាប់ចោល ហើយប្រជាជនត្រូវបាននាំខ្លួនយកចេញទៅបាត់ និងសម្លាប់ចោល ដោយសារតែសកម្មភាពរបស់សមាជិកក្រុមគ្រួសារពួកគេ)។ របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ៖ *របបកម្ពុជាប្រជាធិបតេយ្យ (ប្រទេសកម្ពុជា)* ឯកសារ E3/3865 ឆ្នាំ ១៩៧៥-១៩៧៦ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00597826-00597827 (នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ អង្គការលើកលែងទោសអន្តរជាតិបានសម្តែងការព្រួយបារម្ភជូនលោក ប៉ែន នុត អំពីរបាយការណ៍នានាស្តីពីការរំលោភសិទ្ធិមនុស្ស។ ក្រោយពីការបង្កើតរដ្ឋាភិបាលថ្មីរួចមក អង្គការលើកលែងទោសអន្តរជាតិបានសរសេរលិខិតផ្ញើជូនលោក ខៀវ សំផន នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦។ អង្គការលើកលែងទោសអន្តរជាតិពុំបានទទួលចម្លើយតបមកវិញទេ)។ អនុស្សរណៈរបស់អង្គការលើកលែងទោសអន្តរជាតិ៖ *ព័ត៌មាន និងសកម្មភាពថ្មីៗអំពីរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3307 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៧ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00630464-00630465 (លិខិតមួយច្បាប់ត្រូវបានផ្ញើជូនលោក ខៀវ សំផន ពាក់ព័ន្ធនឹងសេចក្តីរាយការណ៍អំពីការសម្លាប់ជនភៀសខ្លួនចំនួន ២៦ នាក់ដែលត្រូវបានបញ្ជូនមកពីប្រទេសថៃវិញនៅ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ អង្គការលើកលែងទោសអន្តរជាតិក៏បានផ្ញើលិខិតជាច្រើនច្បាប់ផងដែរនៅក្នុងឆ្នាំ ១៩៧៦ ហើយមានគម្រោងចេញផ្សាយសេចក្តីថ្លែងការណ៍ជាសាធារណៈ ប្រសិនបើអង្គការលើកលែងទោសអន្តរជាតិមិនបានទទួលការឆ្លើយតបណាមួយនោះទេ)។

ឆាកអន្តរជាតិ ដោយបណ្តារដ្ឋ និងអង្គការនានា[២៦០៦]។ នៅចុងឆ្នាំ ១៩៧៥ អៀង សារី បានរិះគន់ថា សហគមន៍អន្តរជាតិបានផ្តោតការយកចិត្តទុកដាក់ទៅលើជោគវាសនារបស់ "ពួកក្បត់ជាតិ" និងឧក្រិដ្ឋជនសង្គ្រាមខ្លាំងពេក[២៦០៧]។ ដើម្បីបង្ហាញការគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា សហរដ្ឋអាមេរិក និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលត្រូវបានគេដឹងថាជាភ្នាក់ងាររបស់ពួកគេនៅក្នុងប្រទេសកម្ពុជា) បានបន្តជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់ខ្លួន ខ្មែរក្រហមបានប្រកាសជាសាធារណៈដោយបានចោទប្រកាន់ថា មានការវាយប្រហារមកលើបូរណភាពដែនដីរបស់កម្ពុជា ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ជាពិសេស ខ្មែរក្រហមបានលើកឡើងអំពីករណីកប៉ាល់ *Mayaguez* ដែលបណ្តាលឲ្យមានការទម្លាក់គ្រាប់បែកនៅក្រុងព្រះសីហនុ នៅក្នុង

---

[២៦០៦] *សូមមើលជាឧទាហរណ៍* អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃអំពីឥណ្ឌូចិន ឯកសារ E3/3471 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤ ERN (ភាសាខ្មែរ) 00723764 (គោលនយោបាយចាប់ខ្លួន និងសម្លាប់មន្ត្រីរដ្ឋការចាស់នៅទូទាំងប្រទេស)។ អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅឥណ្ឌូចិន ចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00742970 (សមាជិកនៃឥស្សរជននយោបាយ ការិយាល័យធិបតេយ្យ និងទាហានរបស់រដ្ឋាភិបាលមុន គ្មានអភ័យឯកសិទ្ធិទេ និងជាមុខសញ្ញាដ៏សំខាន់ក្នុងការសម្លាប់ រួមទាំងគ្រួសាររបស់អ្នកទាំងនោះផងដែរ)។ *សេចក្តីថ្លែងការណ៍លើកឡើងដោយអង្គការលើកលែងទោសអន្តរជាតិ* (ECOSOC) ឯកសារ E3/4198 ចុះខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00338190 (មានសេចក្តីរាយការណ៍ថា មានការប្រហារជីវិតអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងគ្រួសាររបស់ពួកគេ ដោយគ្មានការជំនុំជម្រះអ្វីឡើយ និងមានការបាត់ខ្លួនជាលក្ខណៈទ្រង់ទ្រាយធំ ជាពិសេសក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦)។ *របាយការណ៍របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស យោងតាមសេចក្តីសម្រេចលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/1802 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៨ ERN (ភាសាខ្មែរ) 00224342 (អតីតទាហាន សិស្សនិស្សិត និងមន្ត្រីរដ្ឋាភិបាលទាំងអស់ កំពុងត្រូវបានលុបបំបាត់ចោល)។ *របាយការណ៍ដាក់ជូនដោយរាជរដ្ឋាភិបាលចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង យោងតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/3400 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00654876 (ក្នុងខណៈដែលពួកគេបានបណ្តេញប្រជាជនចេញពីទីក្រុង ខ្មែរក្រហមបានផ្តើមស៊ើបអង្កេតទៅលើប្រវត្តិរូបប្រជាជនគ្រប់ៗគ្នា ដោយបំបែកអ្នករដ្ឋការចាស់ឲ្យនៅដាច់ដោយឡែក ហើយបន្ទាប់មក អ្នកទាំងនោះត្រូវបានគេយកចេញទៅបាត់ ដោយសារហេតុផលនានា រួចហើយក៏សម្លាប់ចោលតែម្តង)។

[២៦០៧] ទូរលេខរបស់ក្រសួងការបរទេសអាមេរិក កម្មវត្ថុ៖ បទសម្ភាសន៍របស់សារព័ត៌មាន Newsweek ជាមួយលោក អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00635944-00635945 (ទោះបីជា ឡុង បូរ៉េត ស្លាប់ ឬមិនស្លាប់ក៏ដោយ ក៏បុគ្គលនេះ គឺជាជនក្បត់ជាតិដែលត្រូវបានវិនិច្ឆ័យទោសដោយប្រជាជន និងមហាសន្និបាតដែរ)។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00291036-00291038។

ខែ ឧសភា ឆ្នាំ ១៩៧៥[២៦០៨] និងការចោទប្រកាន់អំពីការទម្លាក់គ្រាប់បែករបស់អាមេរិកមកលើក្រុងសៀមរាប[២៦០៩]។

---

[២៦០៨] នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ខ្មែរក្រហមចាប់បានកប៉ាល់ *Mayaguez* និងកងនាវិកនៅលើកប៉ាល់នេះ ដោយការអះអាងថា កប៉ាល់ *Mayaguez* នេះ បានឈ្លានពានលុកលុយចូលមកក្នុងដែនទឹករបស់កម្ពុជា និងមានបំពាក់ឧបករណ៍ស៊ើបការណ៍ទៀតផង។ ក្រោយពីអាមេរិកមានបំណងសង្គ្រោះយកកប៉ាល់នេះទៅវិញជាច្រើនលើករួចមក រួមទាំងការទម្លាក់គ្រាប់បែកនៅក្រុងព្រះសីហនុផង ខ្មែរក្រហមបានអះអាងថា វិធានការទាំងនេះវាឆាប់ពេក និងថា ខ្លួនបានសម្រេចរួចមកហើយ ប៉ុន្តែគ្រាន់តែមិនទាន់បានប្រកាសថា ក្រុមនាវិកទាំងនោះនឹងត្រូវបានដោះលែងតែប៉ុណ្ណោះ (*កម្ពុជាបដិសេធថា មិនបានបញ្ជាឱ្យចាប់កប៉ាល់នោះទេ)* (កាសែត The Washington Post) ឯកសារ E3/646 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-៣ ERN (ភាសាខ្មែរ) S 00710292-00710294 (អៀង សារី បាន ពន្យល់ថា ប្រធានាធិបតី Ford បានទទួលដំណឹងអំពីស្ថានភាពរបស់កប៉ាល់នោះនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៥។ មានកិច្ចខិតខំប្រឹងប្រែងខាងការទូត នៅចន្លោះពីថ្ងៃទី ១២-១៤ ខែ ឧសភា ហើយបន្ទាប់មក នៅថ្ងៃទី ១៤ ខែ ឧសភា អាមេរិកបានចាប់ផ្តើមបើកការវាយប្រហាររបស់ខ្លួនតែម្តង។ នៅថ្ងៃដដែលនោះ លោក ហ៊ូ នឹម បានប្រកាសតាមវិទ្យុថា កប៉ាល់ *Mayaguez* និងក្រុមនាវិក នឹងត្រូវបានដោះលែង)។ ការពិនិត្យពិច័យករណីកប៉ាល់ *'Mayaguez'* (ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា) ឯកសារ E3/647 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00651204-00651205 (អៀង សារី បានប្រសាសន៍ថា កប៉ាល់របស់អាមរិកមួយគ្រឿង ត្រូវបានមេបញ្ជាការប្រចាំនៅតំបន់ឈូងសមុទ្រថៃចាប់បាន។ ប៉ុន្តែ ខណៈពេលកម្ពុជាកំពុងរៀបចំដោះលែងកប៉ាល់នោះ អាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែក និងវាយប្រហារមកលើកកោះតាង ដែលជាកន្លែងឃាត់ទុកកប៉ាល់នោះ ក៏ដូចជាកំពង់ផែក្រុងព្រះសីហនុ និងឆ្នេរសមុទ្ររាមផងដែរ។ កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយសារព័ត៌មាន Newsweek ឯកសារ E3/550 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១-២ ERN (ភាសាខ្មែរ) S 00651204-00651205 (កម្ពុជាបានធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវចំពោះការចាប់នាវា Mayaguez នោះ ដោយសារនាវានោះស្ថិតនៅក្នុងដែនទឹករបស់កម្ពុជា ហើយវាជានាវាស៊ើបការណ៍ទៀតផង)។ ទូរលេខរបស់ក្រសួងការបរទេសអាមេរិក កម្មវត្ថុ៖ បទសម្ភាសន៍របស់សារព័ត៌មាន Newsweek ជាមួយលោក អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00635943-00635944។

[២៦០៩] នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៦ ខ្មែរក្រហមបានប្រកាសជាសាធារណៈថា យន្តហោះរបស់អាមេរិកបានទម្លាក់គ្រាប់បែកមកលើក្រុងសៀមរាប។ ក្រសួងការបរទេសអាមេរិកបានប្រកាសថា ការចោទប្រកាន់នោះជាការគួរឱ្យអស់សំណើច និងមិនពិតទាល់តែសោះ។ អ្នកការទូតបរទេស ដែលបានទៅពិនិត្យដល់កន្លែងទម្លាក់គ្រាប់បែកនោះ តាមការអញ្ជើញរបស់ខ្មែរក្រហម មិនជឿជាក់ថា ការទម្លាក់គ្រាប់បែកនោះបណ្តាលមកពីការវាយប្រហារផ្លូវអាកាស ឬក៏បានកើតឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៦ នោះទេ (កំណត់ហេតុរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ កាលប្បវត្តិកម្ពុជា (ខែ កុម្ភៈ ឆ្នាំ ១៩៧៦) ឯកសារ E3/490 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៨-១០ ERN (ភាសាខ្មែរ) 00522392-00522394 (ក្រសួងការបរទេសអាមេរិកបានបកស្រាយការចោទប្រកាន់នោះថា "ជាការគួរឱ្យអស់សំណើច និងមិនពិតទាល់តែសោះ")។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ ព័ត៌មាន និងសក្ខីកម្មអំពីប្រទេសកម្ពុជា ឯកសារ E3/485 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៧៧ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00524037-00524038 (បន្ទាប់

៨២៨. ដោយមិនគិតពីការពិតនៃការចោទប្រកាន់ទាំងនេះ សេចក្តីថ្លែងការណ៍ជាសាធារណៈនានាអំពីការវាយប្រហារមកលើបូរណភាពដែនដីកម្ពុជា មានបំណងបង្ហាញថា សង្គ្រាមប្រឆាំងនឹងចក្រពត្តិអាមេរិក និង "បរិវារ" មិនទាន់ចប់ទាំងស្រុងនៅឡើយទេ[២៦១០]។ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ មន្ទីរ ៨៧០ បានចេញផ្សាយព័ត៌មាន និងសេចក្តីណែនាំផ្សេងៗទាក់ទងនឹងការទម្លាក់គ្រាប់បែកមកលើក្រុងសៀមរាប។ គណៈកម្មាធិការអចិន្ត្រៃយ៍បានសន្និដ្ឋានថា អាមេរិកគឺជាអ្នកទទួលខុសត្រូវចំពោះការទម្លាក់គ្រាប់បែកនេះ ដោយធ្វើការពន្យល់ថា ក្រោយពីការជម្លៀសប្រជាជនចេញពីទីប្រជុំជននានាមក ផែនការវាយប្រហាររបស់ពួកចក្រពត្តិ "ត្រូវបែកបាក់ និងខ្ចាត់ខ្ចាយ" ហើយពួកវាមានបំណងវាយប្រហារមកលើប្រទេសកម្ពុជាជាបន្តបន្ទាប់។ គណៈកម្មាធិការអចិន្ត្រៃយ៍បានណែនាំថា ការទម្លាក់គ្រាប់បែកមកលើក្រុងសៀមរាប ត្រូវយកមកអប់រំផ្ទៃក្នុងបក្ស សំដៅបំផុសកំហឹងឲ្យក្តៅគគុក ឲ្យមានការប្រុងប្រយ័ត្ន និងមានការប្តេជ្ញាសម្រេចឲ្យបាន ៣ តោន ក្នុងមួយហិកតា[២៦១១]។ ក្រោយមក ដោយលើកយោងទៅព្រឹត្តិការណ៍កប៉ាល់ *Mayaguez* ខៀវ សំផន បានអំពាវនាវម្តងហើយម្តងទៀតឲ្យប្រជាជន និងកងទ័ពស្វែងរក និងកម្ចាត់ខ្មាំង ដោយគាត់បានប្រកាសថា ពួកនេះនឹងមិនព្រមចុះចាញ់ឡើយ[២៦១២]។ ពេលវេលានៃការវាយប្រហារដែលត្រូវបាន

---

ពីដំណើរទស្សនកិច្ចរបស់គាត់មកកាន់ប្រទេសកម្ពុជា ឯកអគ្គរដ្ឋប្រទេសហ្គីណេមិនជឿជាក់ចំពោះការយល់ឃើញរបស់កម្ពុជាអំពីព្រឹត្តិការណ៍ទាំងនោះដែលថា យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែកមកលើក្រុងសៀមរាប កាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ នោះទេ ដោយគាត់យល់ឃើញថា អ្វីដែលបានកើតឡើងនៅទីកន្លែងកើតហេតុនោះអាចកើតឡើងតាំងពីយូរមកហើយ។ បើតាមសម្តីរបស់គាត់ថា នេះគឺជាអំពើរបស់ពួកខ្មាំងខ្មែរ)។ កំណត់ហេតុរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ប្រទេសកម្ពុជា [សម្រាប់ការពិគ្រោះយោបល់រវាងប្រទេសបារាំង និងសហភាព-សូវៀត) ឯកសារ E3/2668 ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00491786 (ការបាញ់ផ្លោងចូលសៀមរាប និងការពន្យល់ដែលគួរឲ្យងឿងឆ្ងល់ដែលបានលើកឡើងចំពោះបញ្ហានោះ អាចជាសញ្ញានៃការបាក់បែកគ្នានៅក្នុងជួរថ្នាក់ដឹកនាំរបស់កម្ពុជា)។

[២៦១០] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារ E3/18 ទំព័រ ៧០-៧១ ERN (ភាសាខ្មែរ) 00103843 (មានសញ្ញាណបង្ហាញថា ខ្មែរក្រហមមិនជឿថា ការដួលរលំនៃរបប លន់ នល់ គឺជាការបញ្ចប់សង្គ្រាមប្រឆាំងនឹងចក្រពត្តិនោះទេ។ មេៗខ្មែរក្រហម ជាពិសេស ប៉ុល ពត ជឿជាក់ថា សហរដ្ឋអាមេរិក "ដែលបានបង្ខំចិត្តទទួលយកការចុះចាញ់របស់ខ្លួននោះ មានឆន្ទៈដើម្បីត្រឡប់មកកម្ពុជាវិញ")។

[២៦១១] មតិណែនាំរបស់គណៈ ៨៧០ ឯកសារ E3/1173 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ទំព័រ ១-២ ERN (ភាសាខ្មែរ) 00072484-00072485។

[២៦១២] សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ឯកសារ E3/549 ចុះថ្ងៃទី ១៦-១៩ ខែ សីហា ឆ្នាំ ១៩៧៦ ទំព័រ ២០-២៤ ERN (ភាសាខ្មែរ) 00065900-00065901 (ត្រូវបន្តការប្រុងប្រយ័ត្ន

ចោទប្រកាន់ និងសេចក្តីប្រកាសជាសាធារណៈដែលអមមកជាមួយនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងការកំណត់គោលដៅជាបន្ត ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនាពាក់កណ្តាលចុងក្រោយនៃឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦[២៦១៣]។

### ១៤.៣.២.៣ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរកំពុងធ្វើការនៅតាមជនបទ

៨២៩. អៀង សារី និង ប៉ុល ពត បានអះអាងថា អតីតអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋ-ខ្មែរមិនត្រូវបានសម្លាប់នោះទេ តែផ្ទុយទៅវិញ ស្ថិតក្នុងសម្លៀកបំពាក់ធម្មតា និងបានធ្វើដំណើរទៅកាន់ទីជនបទដើម្បីធ្វើការងារ បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មក[២៦១៤]។ សក្ខីកម្មរបស់

---

បដិវត្តជាប់ជានិច្ច ព្រោះថា សត្រូវមិនដែលបោះបង់ចោលផែនការខ្មៅងឹងតរបស់ពួកវាទេ ដូចបានបង្ហាញឲ្យឃើញតាមរយៈការទម្លាក់គ្រាប់បែកមកលើក្រុងសៀមរាប និងរឿងកប៉ាល់ Mayaguez ជាដើម”។ *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00292805 (ត្រូវរក្សាការពារសមិទ្ធផលបដិវត្តកម្ពុជារបស់យើង តាមរយៈការទប់ស្កាត់ជាដាច់ខាតនូវសត្រូវគ្រប់ប្រភេទទាំងអស់ រារាំងពួកវាមិនឲ្យឈ្លានពាន ជ្រៀតជ្រែក ឬធ្វើវិទ្ធង្សនា។ ត្រូវបោសសម្អាតខ្មាំងទាំងអស់)។ *ភ្នំពេញប្រមូលផ្តុំអបអរសាទរខួប ១៧ មេសា* (កម្រងឯកសារ SWB) ឯកសារ E3/562 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ១៩៧៨ ទំព័រ ១ ERN (ភាសាខ្មែរ) 00249989 (គ្រប់ផ្នែកទាំងអស់ត្រូវបន្តលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តឲ្យបានរឹងមាំ និងការពារប្រទេសឲ្យរួចផុតពីខ្មាំងទាំងក្នុង និងក្រៅប្រទេសឲ្យបាន)។ *សូមមើលផងដែរ* សំបុត្ររបស់ស្ថានឯកអគ្គរដ្ឋទូតបារាំង ឯកសារ E3/487 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00687115-00687116 (នៅក្នុងឱកាសប្រារព្ធខួបលើកទី ២ នៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ ភារៈធារីអមស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវបានប្រកាសថា កម្ពុជាប្រជាធិបតេយ្យបានវាយបំបាក់ជាបន្តបន្ទាប់នូវឧបាយកល និងសកម្មភាពវិទ្ធស្សនារបស់ពួកចក្រពត្តិនិយមអាមេរិក និងពួកប្រតិកិរិយា)។ *សូមមើលផងដែរ* សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/925 ឆ្នាំ ១៩៧៦-១៩៧៩ ទំព័រ ៩ ERN (ភាសាខ្មែរ) 00003768 (ពួកចក្រពត្តិរបស់វាមានបំណងបន្តបំផ្លិចបំផ្លាញបដិវត្ត ឧទាហរណ៍រឿងព្រឹត្តិការណ៍នាវា *Mayaguez* និងការទម្លាក់គ្រាប់បែកនៅសៀមរាប)។

[២៦១៣] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (២ដំណាក់កាលទី)។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម។

[២៦១៤] ទូរលេខរបស់ក្រសួងការបរទេសអាមេរិក កម្មវត្ថុ៖ បទសម្ភាសន៍សារព័ត៌មាន Newsweek ជាមួយ អៀង សារី ឯកសារ E3/621 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤-៥ ERN (ភាសាខ្មែរ) 00635944-00635945 (ក្រុមមន្ត្រីរបស់របប លន់ នល់ កំពុងចូលរួមក្នុងការបង្កបង្កើនផល។ អ្នកមកពីរបបចាស់ដែលស្មោះត្រង់កំពុងត្រូវបានប្រើប្រាស់)។ *អ្វីៗដែលយើងកំពុងធ្វើនៅពេលនេះមិនធ្លាប់អនុវត្តពីមុនមកទេ* (Der Spiegel) ឯកសារ E3/1589 ឆ្នាំ ១៩៧៧ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00796757-00796759 (នៅពេលរំដោះភ្នំពេញ អតីតទាហានបានគ្រវែងឯកសណ្ឋានរបស់គេចោល ហើយស្លៀកពាក់សម្លៀកបំពាក់ធម្មតា និងបានចូលរួមជាមួយនឹងប្រជាជនទូទៅ ហើយ

ជនភៀសខ្លួន និងជនរងគ្រោះបញ្ជាក់ថា ទាហានខ្លះត្រូវបាននាំយកទៅឲ្យធ្វើការជាទម្ងន់[២៦១៥] ចំណែកឯអ្នកដែលបានលាក់បាំងអត្តសញ្ញាណរបស់ខ្លួន ត្រូវបានបញ្ជូនចេញដូច "ប្រជាជនថ្មី" ដទៃទៀតដែរ[២៦១៦]។ នៅចុងឆ្នាំ ១៩៧៥ ក្រោយពីបានកំណត់គោលដៅទៅលើអ្នករដ្ឋការដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់រួចមក ជនភៀសខ្លួនបានរាយការណ៍ថា ខ្មែរក្រហមបានបន្តកំណត់គោលដៅមកលើអ្នករដ្ឋការតូចតាច ក្រុមគ្រួសាររបស់ពួកគេ និងអ្នកដែលបានលាក់បាំងប្រវត្តិរូប[២៦១៧]។

---

នៅពេលនេះ ពួកគេបានធ្វើការងារដូចអ្នកដទៃទៀតដែរ)។ ប៉ុល ពត សំណេះសំណាលជាមួយគណៈប្រតិភូបែលហ្ស៊ិក-កម្ពុជា ឯកសារ E3/5712 ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ១០ ERN (ភាសាខ្មែរ) 00816531 (អតីតមន្ត្រីរបប លន់ នល់ កំពុងរស់នៅ និងធ្វើការនៅតាមសហករណ៍)។

[២៦១៥] *សូមមើលឧទាហរណ៍* កំណត់សម្គាល់របស់លោក H. LOCARD៖ *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៤ ERN (ភាសាខ្មែរ) 00233385 (ពួកទាហានត្រូវបានគេនាំទៅទិសខាងលិចឆ្ពោះទៅប៉ៃលិនដើម្បីឲ្យធ្វើការជាទម្ងន់នៅក្នុងជំរំពិសេស)។ ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ E3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN (ភាសាខ្មែរ) 00499667 (លោកឧត្តមសេនីយ៍បានឃើញក្រុមនាយទាហានរងនៅក្នុងជំរំមួយដែលស្ថិតនៅជិតសៀមរាប ដែលគេបានចងភ្ជាប់ឲ្យអួសរទេះ ដោយស្ថិតនៅក្រោមការឃាមកាមរបស់ខ្មែរក្រហម)។

[២៦១៦] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៤-១៥ (ប្តីរបស់លោកស្រីជាទាហាន លន់ នល់ ម្នាក់ដែលបានលាក់អាជីពរបស់គាត់)។ កំណត់សម្គាល់របស់លោក H. LOCARD៖ *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ២៦ ERN (ភាសាខ្មែរ) 00233407 (នៅភ្នំស្រុក ផុន វេ អាចលាក់មិនឲ្យគេដឹងថា គាត់ធ្លាប់ធ្វើជាទាហាន លន់ នល់ នៅមុនឆ្នាំ ១៩៧៥ នោះទេ)។ ព័ត៌មានបន្ថែមរបស់លោក CHEN François ឯកសារ ចុញថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១ ERN (ភាសាខ្មែរ) 00894686 (ធ្វើការផ្នែកសន្តិសុខនៅតុលាការយោធានៃរបបសាធារណរដ្ឋខ្មែរនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បានស្លៀកពាក់ដូចអ្នកសត្តឃាត ហើយត្រូវបានជម្លៀសចេញជាមួយនឹងប្រជាជនដទៃទៀតដែរ)។

[២៦១៧] ទូរលេខរបស់ស្ថានទូតអាមេរិក កម្មវត្ថុ: ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣០ ERN (ភាសាខ្មែរ) 00709606 (មានការផ្តោតទៅលើកូនទាហាន និងសមាជិកគ្រួសាររបស់ពួកគេដោយសារទាហាន និងមន្ត្រីរដ្ឋការស៊ីវិលដទៃទៀតត្រូវបានសម្លាប់រួចទៅហើយ។ ខ្មែរក្រហមបានបន្តស្វែងរកមន្ត្រីរដ្ឋការស៊ីវិលដែលលាក់ប្រវត្តិរូបផងដែរ)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ សាន់ ជា (មជ្ឈមណ្ឌលឯកសារកម្ពុជា) ឯកសារ E3/5368 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៧-៨ ERN (ភាសាខ្មែរ) 00477806-00477807 (គាត់ និងប្រពន្ធរបស់គាត់ត្រូវបានបង្ខំឲ្យធ្វើប្រវត្តិរូបនៅក្នុងឆ្នាំ ១៩៧៦ នៅខេត្តតាកែវ ដោយសារឪពុកមារបស់គាត់ជាទាហាន លន់ នល់)។ *របាយការណ៍របស់រដ្ឋាភិបាលន័រវេ តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/1805 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00228748-00228753 (សក្ខីកម្មរបស់ជនភៀសខ្លួនដែលផ្តល់ដោយអតីតអនុសេនីយ៍ទោដែលរួចផុតពីការសម្លាប់ទាហាន លន់ នល់ និងសមាជិកគ្រួសាររបស់ពួកគេ។ អតីតទាហានទាំងនោះត្រូវបានហៅឲ្យទៅបង្ហាញប្រាប់

ជនភៀសខ្លួនម្នាក់បានពន្យល់ថា ខ្មែរក្រហមបានដឹងថា មិនមែនតែអ្នករដ្ឋការនៃរបបសាធារណ-រដ្ឋខ្មែរនោះទេ ប៉ុន្តែក្រុមគ្រួសាររបស់ពួកគេក៏ត្រូវបានសម្លាប់ចោលផងដែរ បើមិនដូច្នេះទេ អាចនឹងមានការគំរាមកំហែងបះបោរឡើង[២៦១៨]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ទោះបីជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរខ្លះមិនត្រូវបានដកភ្លាមៗចេញពី "ប្រជាជនថ្មី" ដើម្បីធ្វើបាប និងបញ្ជូនទៅកាន់ទីជនបទដើម្បីឲ្យធ្វើការក៏ដោយ ក៏ខ្មែរក្រហមបានប្ដេជ្ញាអនុវត្តគោលនយោបាយកំណត់គោលដៅចំពោះគ្រប់សមាសភាពទាំងអស់ ពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីចាប់ខ្លួនសម្លាប់ និង/ឬ ធ្វើឲ្យបាត់ខ្លួន។

### ១៤.៣.៣ វិធីសាស្ត្រ

៨៣០. យោងតាមសក្ខីកម្មនានា ដែលបានផ្ដល់ដោយជនភៀសខ្លួនម្នាក់ ដែលជាអតីតទាហាន លន់ នល់ ក្នុងឆ្នាំ ១៩៧២ ទាហានរបស់របបសាធារណរដ្ឋខ្មែរចំនួន ៥០០ នាក់ដែលត្រូវបានចាប់ខ្លួន ត្រូវបានខ្មែរក្រហមសម្លាប់ចោលទាំងអស់នៅក្នុងភូមិភ្លើងឆេះ[២៦១៩]។ ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៣ កងទ័ពខ្មែរក្រហមបានកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុង

---

ពីអត្តសញ្ញាណរបស់ពួកគេ ដោយមានការកុហកថា ខ្មែរក្រហមកំពុងស្វែងរកតែជនមហាក្បត់ទាំង ៧ នាក់ប៉ុណ្ណោះ)។ *សំណើបន្ថែមរបស់រដ្ឋាភិបាលកាណាដា តាមរយៈសេចក្ដីសម្រេចលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/1806 ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៧៨ ទំព័រ ១០, ១៦ ERN (ភាសាខ្មែរ) 00284359, 00284365 (ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ គ្រួសាររបស់ទាហាន ក៏ដូចជាអតីតអ្នករដ្ឋការនានាដែលបានលាក់បាំងការពិតនោះ បានបាត់ខ្លួន។ ខ្មែរក្រហមមិនមានជម្រើសអ្វីក្រៅតែពីសម្លាប់អតីតអ្នករដ្ឋការ និងក្រុមគ្រួសាររបស់គេទាំងអស់ទេ បើមិនដូច្នេះទេ ពួកគេអាចនឹងបង្កើតការតស៊ូ)។ *សូមមើលផងដែរ* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៦៧-៥៦៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣៣។

[២៦១៨] *របាយការណ៍បន្ថែមរបស់គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ តាមរយៈសេចក្ដីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/3327 ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00723755 (កាលពីមុន សម្ដេច នរោត្តម សីហនុ បានសម្លាប់ពួកអ្នកបដិវត្តន៍ ហើយប្រពន្ធកូន និងសាច់ញាតិរបស់ពួកគេ បានរួមរួមគ្នាប្រឆាំងនឹងព្រះអង្គវិញ។ រឿងបែបនេះមិនអាចកើតឡើងម្ដងទៀតចំពោះបក្សកុម្មុយនីស្តបានទេ)។

[២៦១៩] បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា ដោយ S. Heder និង M. Matsushita ឯកសារ E3/1714 ចុះខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ១០៦ (ភាសាខ្មែរ) 00324777។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ២២-២៣។

ពេលជម្លៀសប្រជាជនចេញពីទីរួមខេត្តកំពង់ចាម[២៦២០]។ ក្នុងខែ មីនា ឆ្នាំ១៩៧៤ ទាហាន និងអ្នករដ្ឋការ ត្រូវបានសម្លាប់ជាក្រុមៗ ក្រោយពេលខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងឧត្តុង្គ[២៦២១]។ ក្នុងខែ កក្កដា ឆ្នាំ ១៩៧៤ ទាហានដែលបានចុះចាញ់ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានសម្លាប់នៅក្នុងខេត្តបាត់ដំបង[២៦២២]។ ក្នុងខែ មីនា ឆ្នាំ ១៩៧៥ មានសេចក្តីរាយការណ៍ជាច្រើនពីជនភៀសខ្លួនថា ខ្មាំង រួមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ភ្នាក់ងាររបស់ពួកគេ និងអ្នកដែលបានប្រឆាំងនឹងមាគ៌ានយោបាយរបស់បក្ស ត្រូវបានសម្លាប់នៅក្នុងដែនដីដែលគ្រប់គ្រងដោយខ្មែរក្រហម[២៦២៣]។

៨៣១. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញ[២៦២៤]។ ក្រោយមក អៀង សារី បានអះអាងថា ការឆែកឆេរបានរកឃើញអាវុធដែលអាចជួយគាំទ្រដល់ផែនការធ្វើរដ្ឋប្រហារ[២៦២៥]។ ហេតុដូច្នេះ មុនពេលពួកគេមានឱកាសអនុវត្តផែនការសម្ងាត់នេះ អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណ រួមទាំងនៅតាមកន្លែងត្រួតពិនិត្យផង ត្រូវបានចាប់ខ្លួន អ្នកខ្លះត្រូវបាននាំយកទៅ ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់នៅនឹងកន្លែងតែម្តង[២៦២៦]។ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ត្រូវបានកោះហៅមកប្រជុំតាមរយៈការប្រកាស

---

[២៦២០] ប្រតិចារឹក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ៦៥-៦៩។

[២៦២១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២២ ។

[២៦២២] របាយការណ៍របស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅតណ្ឌូចិនចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៦ ERN (ភាសាខ្មែរ) 00742973 (នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៧៤ រយៈពេល ៥ នាទី បន្ទាប់ទាហានបានចុះចូលនៅខេត្តបាត់ដំបង ខ្មែរក្រហមបានចាប់ផ្តើមបាញ់សម្លាប់ក្រុមដែលបានចុះចូលនោះមិនរើសមុខ ដោយបានសម្លាប់មនុស្សចំនួន ២០០ នាក់ ហើយបន្ទាប់ពីនោះមក ក៏ចាប់ផ្តើមសម្លាប់ជាប្រព័ន្ធចំពោះពួកប្រុសៗទាំងអស់)។ អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ព័ត៌មានសំខាន់ៗអំពីប្រទេសកម្ពុជា ឯកសារ E3/4197 ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ៥ ERN (ភាសាខ្មែរ) 00939695 (ជនស៊ីវិល និងទាហានដែលបានចុះចាញ់ចំនួន ប្រហែល ៧០០ នាក់ ត្រូវបានគេសម្លាប់ចោល នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៧៤)។

[២៦២៣] អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ព័ត៌មានសំខាន់ៗអំពីប្រទេសកម្ពុជា ឯកសារ E3/4197 ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៥ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00939692-00939694។

[២៦២៤] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦០។

[២៦២៥] អត្ថបទសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ឯកសារ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១០ ERN (ភាសាខ្មែរ) 00062461។

[២៦២៦] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៥, ៥០៧-៥០៩, ៥១១, ៥១៣-៥១៥។

តាមមេក្រូ។ ឧត្តមសេនីយ៍ និងរដ្ឋមន្ត្រីមួយចំនួន រួមទាំង ឡុង បូរ៉េត បានសុំចុះចាញ់[២៦២៧]។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មេកងទ័ពខ្មែរក្រហមម្នាក់បានលើកឡើងនៅឯក្រសួងព័ត៌មានថា ជោគវាសនារបស់អ្នករដ្ឋការដែលត្រូវបានប្រមូលផ្តុំអាស្រ័យលើរដ្ឋាភិបាល ហើយបានបន្ថែមថា អ្នកនយោបាយកំពូលៗ និងមេដឹកនាំរដ្ឋាភិបាលនៅមិនឆ្ងាយពីទីក្រុងទេ[២៦២៨]។ ក្នុងខណៈនោះ សិរិមតៈ និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដទៃទៀតបានជ្រកកោននៅស្ថានទូតបារាំង[២៦២៩]។ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិបានថ្កោលទោសស្ថានទូតបារាំង ចំពោះការផ្តល់សិទ្ធិជ្រកកោនដល់ឧក្រិដ្ឋជនសង្គ្រាមរាប់រយនាក់[២៦៣០]។ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ សិរិមតៈ និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដទៃទៀតត្រូវបានយកចេញពីស្ថានទូតបារាំង[២៦៣១]។ កងទ័ពខ្មែរក្រហមក៏បានសម្តែងនូវការព្រួយបារម្ភអំពីវត្តមានរបស់ទាហាននៃរបបសាធារណរដ្ឋខ្មែរ នៅមន្ទីរពេទ្យកាល់ម៉ែត និងបន្ទាប់ពីបានស្នើសុំឱ្យស្ថានទូតបារាំងផ្តល់បញ្ជីឈ្មោះរបស់អ្នកជំងឺ ដែលបានសម្រាកនៅទីនោះ[២៦៣២]។ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាច្រើនដែលបានសុំចុះចាញ់នៅទីក្រុងភ្នំពេញ ត្រូវបានសម្លាប់ចោល ដោយមិនគិតថាអ្នកទាំងនោះស្ថិតក្នុងចំណោម "ពួកជនមហាក្បត់" ទាំង ៧ នាក់ ឬយ៉ាងណានោះឡើយ[២៦៣៣]។

៨៣២. នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានប្រកាសថា កងទ័ពបានទទួលជ័យជម្នះនៅក្នុង "ការវាយប្រហារឥតស្រាកស្រាន និងធ្វើឱ្យខ្មាំងចុះខ្សោយ" ដោយពួកខ្មាំងបានស្លាប់

---

[២៦២៧] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[២៦២៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ទំព័រ ៣៦-៣៧។

[២៦២៩] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[២៦៣០] សេចក្តីថ្លែងការណ៍របស់លោក ថៅ សេង ប្រេសិតពិសេសរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាប្រចាំទ្វីបអឺរ៉ុប ឯកសារ E3/1340 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២-៣ ERN (ភាសាខ្មែរ) 00517761-00517762។

[២៦៣១] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[២៦៣២] ទូរលេខក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង កម្មវត្ថុ៖ ស្ថានការណ៍នៅទីក្រុងភ្នំពេញ វេលាម៉ោង ១៤ ឯកសារ E3/2693 ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២ ERN (ភាសាខ្មែរ) 00490999។

[២៦៣៣] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣, ៥១៤-៥១៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២៣, ៨២៧-៨២៩។

ទាំងក្តីឈឺចាប់បំផុត[២៦៣៤]។ ប៉ុន្តែ ពួកខ្មាំងមិនទាន់ស្លាប់ទាំងអស់នៅឡើយទេ។ ការកំណត់គោលដៅចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ តាមរយៈការចាប់ខ្លួន ការសម្លាប់ និងការធ្វើឲ្យបាត់ខ្លួន បានបន្តរហូតដល់ចុងខែ មេសា និង ខែ ឧសភា ឆ្នាំ ១៩៧៥ នៅមុនពេល ក្នុងអំឡុងពេល ឬក្រោយការជម្លៀស រួមទាំងនៅខេត្តបាត់ដំបង[២៦៣៥] ខេត្តកំពង់ធំ[២៦៣៦] ខេត្តពោធិ៍សាត់[២៦៣៧] ខេត្ត

---

[២៦៣៤] *សារជ័យជម្នះ ចុះថ្ងៃទី ២១ ខែ មេសា របស់ ខៀវ សំផន ដែលបានប្រកាសតាមវិទ្យុភ្នំពេញ* (ក្នុងកម្រងផ្សព្វផ្សាយព័ត៌មានទៅបរទេស) ឯកសារ E3/118 ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ ១៩៧៥ ទំព័រ ២៦ (ភាសាខ្មែរ) 00905203។

[២៦៣៥] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារុន ឯកសារ E3/5187 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៤ ERN (ភាសាខ្មែរ) 00197918 (បន្ទាប់ពីខ្មែរក្រហមបានកាន់អំណាច ទាហានដែលមានស័ក្តិត្រូវបានគេសម្លាប់ ហើយទាហានខ្លះត្រូវបាននាំទៅកាន់មូលដ្ឋាន។ គាត់ក៏បានឃើញខ្មែរក្រហមសម្លាប់ទាហានម្នាក់ និងប្រពន្ធរបស់ទាហាននោះដោយផ្ទាល់នៅជិតភ្នំក្រពើ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ឯកសារ E3/5211 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00221544 (ក្រោយថ្ងៃរំដោះ ទាហាន លន់ នល់ ដែលត្រូវបានប្រមូលផ្តុំ តាមរយៈការប្រកាសមេក្រូ ត្រូវបានដឹកចេញតាមឡាន និងបានសម្លាប់ចោលនៅស្រុកភ្នំសំពៅ)។ កំណត់សម្គាល់របស់លោក H. LOCARD៖ *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៣ ERN (ភាសាខ្មែរ) 00233384 (នៅចន្លោះពីថ្ងៃទី ២០ ដល់ថ្ងៃទី ២២ ខែ មេសា នៅក្នុងទីរួមខេត្តបាត់ដំបង ខ្មែរក្រហមបានប្រកាសថា អ្នកដែលមានតំណែងទទួលខុសត្រូវនៅក្នុងរបបចាស់ ត្រូវទៅស្វាគមន៍សម្តេចឪនៅភ្នំពេញ។ ទាហានទាំងនោះត្រូវបានតម្រូវឲ្យពាក់គ្រឿងសម្គាល់ឋានន្តរស័ក្តិទាំងអស់។ ទាហានប្រហែល ១.០០០ នាក់បានមកបង្ហាញមុខ។ នាយទាហានជាន់ខ្ពស់ទាំងនោះត្រូវបានធ្វើពិធីជប់លៀងជូន ហើយនៅពេលផឹកស្រាស្រវឹង គេក៏បានបាញ់សម្លាប់តែម្តង) ទំព័រ ៤ ERN (ភាសាខ្មែរ) 00233385 (នាយទាហានជាន់ទាបរហូតដល់កម្រិត ៣ និងថ្នាក់អនុសេនីយ៍ ត្រូវបានសម្លាប់ចោលយ៉ាងឃោរឃៅ ហើយកូនទាហានធម្មតាត្រូវបាននាំឆ្ពោះទៅប៉ៃលិន ដើម្បីឲ្យធ្វើការជាទម្ងន់នៅក្នុងជំរំពិសេស) ទំព័រ ២១ ERN (ភាសាខ្មែរ) 00233402 (អ្នកធ្វើដំណើរទាំងនោះ ត្រូវបានបង្អាក់នៅតាមផ្លូវធ្វើដំណើររបស់ពួកគេ ក្រោយពីការជម្លៀសចេញពីបាត់ដំបង ដោយមានការសម្លាប់ទាហាន និងកូនទាហានចំនួនពី ៥០០ នាក់ ទៅ ១.០០០ នាក់។ ទាហានទាំងនោះត្រូវបានគេឲ្យមកជួបជុំគ្នានៅវិទ្យាល័យមួយក្នុងខេត្តបាត់ដំបងដើម្បីទៅស្វាគមន៍សម្តេច នរោត្តម សីហនុ)។*សូមមើលផងដែរ* ប្រតិចារិកថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ទំព័រ៣២-៣៤។ ពាក្យបណ្តឹងជនរងគ្រោះ ថាច់ សាលី ឯកសារ E3/4966 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 0056514-00565116 (ទាហាន លន់ នល់ ចំនួន ៦០០ នាក់ត្រូវបានគេយកទៅបាញ់សម្លាប់ចោល នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ នៅស្រុកម៉ោងឫស្សី។ ទាហានទាំងនោះត្រូវបានបញ្ជាឲ្យទៅទទួលសម្តេច នរោត្តម សីហនុ។ នៅចន្លោះពីថ្ងៃទី ២០ ដល់ថ្ងៃទី ២២ ខែមេសាអតីតទាហាន លន់ នល់ ជាច្រើនពាន់នាក់ទៀតក៏ត្រូវសម្លាប់ចោលដែរ)។ ទូរលេខរបស់ស្ថានទូតអាមេរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ១៩៧៦ ទំព័រ ៥ ERN (ភាសាខ្មែរ) 00709581 (នៅថ្ងៃទី ២០ ខែ

កំពង់ឆ្នាំង[២៦៣៨] ខេត្តកណ្ដាល[២៦៣៩] ខេត្តតាកែវ[២៦៤០] និងខេត្តសៀមរាប[២៦៤១]។ នៅថ្ងៃទី ឬ អំឡុងថ្ងៃទី ២៥ ឬ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៥ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរយ៉ាងតិចចំនួន ២៥០ នាក់ ត្រូវបានយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ[២៦៤២]។

---

មេសា ខ្មែរក្រហមបានសម្លាប់មន្ត្រីយោធា មន្ត្រីរដ្ឋការ ប្រធានភូមិ អ្នកជំនួញ និងកងឈ្លបមូលដ្ឋាន ព្រមទាំងក្រុមគ្រួសាររបស់ពួកគេផងដែរនៅភ្នំស្រុក)។

[២៦៣៦] ទូរលេខរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី សរ ប៊ុន ឯកសារ E3/2666 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៦ ERN (ភាសាខ្មែរ) 00499666 (ទាហានទាំងឡាយដែលមិនត្រូវបានគេបាញ់សម្លាប់ ត្រូវបានប្រមូលផ្តុំនៅតាមជំរំនានា។ គាត់ស្គាល់ជំរំមួយកន្លែងនៅក្នុងខេត្តកំពង់ធំ ដែលមានការសម្លាប់ស្ទើររៀងរាល់ថ្ងៃ)។

[២៦៣៧] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពៅ ស៊ីនួន ឯកសារ E3/5545 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00385096 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឪពុករបស់លោកស្រី ដែលជាទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមបាញ់សម្លាប់)។ *សូមមើលផងដែរ* ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៧៨-៦៨១។

[២៦៣៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សំអាត ឯកសារ E3/5232 ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00269055 (ទាហានទាំងនោះត្រូវបានបំបែកឱ្យនៅដោយឡែកពីប្រជាជន ដែលបានជម្លៀសចេញពីខេត្តកំពង់ឆ្នាំង ដោយការប្រកាសតាមមីក្រូ ហើយត្រូវបានប្រមូលយកទៅដាក់នៅកន្លែងមួយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី យស ផល ឯកសារ E3/4611 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00418484-00418485 (ខ្មែរក្រហមកំពុងស្វែងរកអតីតទាហាន លន់ នល់ ដោយប្រាប់អ្នកទាំងនោះថាពួកគេនឹងត្រូវបញ្ជូនឱ្យទៅរៀនសូត្រ)។

[២៦៣៩] ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ៩-១០ (នៅកៀនស្វាយ ខ្មែរក្រហមបានណែនាំដល់មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរឱ្យសរសេរឈ្មោះរបស់ពួកគេនៅលើក្តារខៀន។ អ្នកទាំងនោះត្រូវបានប្រមូលផ្តុំ ហើយក្រោយមកក៏យកទៅសម្លាប់ចោល)។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឈា លាងហ៊ន ឯកសារ E3/5329 ទំព័រ ៧ ERN (ភាសាខ្មែរ) 00452608 (ប្អូនប្រុសរបស់គាត់បានចូលខាង លន់ នល់ ហេតុដូច្នេះហើយក៏ត្រូវគេសម្លាប់ចោល)។

[២៦៤០] ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៦៦ (ក្រោយពីអ្នកដែលត្រូវបានជម្លៀសចេញពីភ្នំពេញបានមកដល់ស្រុកបាទី ទាហាននៃរបបសាធារណរដ្ឋខ្មែរក៏បានបាត់ខ្លួន)។ របាយការណ៍របស់រដ្ឋាភិបាលចក្រភពអង់គ្លេស៖ ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ ឯកសារ E3/3319 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៧៨ ERN (ភាសាខ្មែរ) 00699230-00699231 (នៅខែ ឧសភា ឆ្នាំ ១៩៧៥ ក្រោយពីធ្វើការងារលើកទំនប់រួចហើយ នគរបាលម្នាក់ដែលមានឋានៈអនុសេនីយ៍ ត្រូវបាននាំទៅកាន់វត្តថ្មត្រាប ដែលនៅទីនោះ គាត់បានស្គាល់នគរបាល និងទាហានដទៃទៀត ដែលត្រូវបានគេយកទៅសម្លាប់ចោល នៅក្នុងខណៈពេលដែលគាត់អាចរត់គេចខ្លួនរួច)។

៨៣៣. នៅចុងឆ្នាំ ១៩៧៥ ឆ្នាំ ១៩៧៦ និងក្រោយមកទៀត តាមរយៈការចាប់ខ្លួន ការសម្លាប់ និង/ឬការធ្វើឲ្យបាត់ខ្លួន ខ្មែរក្រហមបានបន្តកំណត់គោលដៅមកលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ[២៦៤៣] រួមទាំងនៅខេត្តបាត់ដំបង[២៦៤៤] ខេត្តកណ្តាល[២៦៤៥] ខេត្ត

---

[២៦៤១] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៤-២៥ (ខ្មែរក្រហមនឹងចាប់ប្រុសៗដែលនៅកជើងមានស្នាមពាក់ស្បែកជើងកវែង។ នៅព្រែកឯង មានការប្រកាសតាមមីក្រូថា នាយទាហានទាំងអស់អាចវិលត្រឡប់ចូលមកទីក្រុងភ្នំពេញវិញដើម្បីធ្វើការងារបន្ត។ បងថ្លៃរបស់លោកស្រីដែលពាក់ស័ក្តិប្រាំ នៅក្នុងរបបសាធារណរដ្ឋខ្មែរក៏បានទៅ ហើយបានបាត់ខ្លួន)។ ប្រតិចារឹក ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ទំព័រ ៥៤ (នៅពេលជម្លៀសប្រជាជនចេញពីខេត្តសៀមរាប កងទ័ពខ្មែរក្រហមបានយាមកាម និងបានធ្វើការសួរចម្លើយ។ មានរថយន្តដឹកអតីតមន្ត្រីរដ្ឋការទាំងនោះយកទៅសម្លាប់ចោល) ទំព័រ ៥៧-៥៨ មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានជម្លៀសទៅកំពង់ក្តី មិនត្រូវបានឃុំឃាំងខ្លួនទេ។ អ្នកទាំងនោះត្រូវបានសាកសួរ សួរចម្លើយ និងសម្លាប់ចោលតែម្តង) ទំព័រ ៧០-៧១ (ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានជម្លៀសនៅឆ្នាំ ១៩៧៥ មិនត្រូវបានចាប់ខ្លួនទេ។ ពួកគេត្រូវបានសម្លាប់ចោលភ្លាមៗ ក្រោយពេលចាប់ខ្លួន)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិក វ៉ាន់ថន ឯកសារ E3/5188 ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ២ ERN (ភាសាខ្មែរ) 00217485 (ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្តីរបស់លោកស្រីដែលធ្វើជាទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមប្រមូល និងយកទៅសម្លាប់ចោល)។

[២៦៤២] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨១។

[២៦៤៣] របាយការណ៍របស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅឥណ្ឌូចិនចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00742970-00742971 (សេចក្តីរាយការណ៍បង្ហាញថា ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ១៨៧៦ មក ខ្មែរក្រហមបានសម្លាប់អតីតគ្រូបង្រៀន និសិត្ស និងក្រុមមន្ត្រីថ្នាក់ក្រោម ដែលស្ថិតនៅក្នុងកងកម្លាំងទាហានរបប លន់ នល់)។ ទូរលេខរបស់ក្រសួងការបរទេសអាមេរិក៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ១, ៣-៤, ២៩-៣១ ERN (ភាសាខ្មែរ) 00709577, 00709579-00709580, 00709605-00709607 (ជនភៀសខ្លួនមួយចំនួនមកពីខេត្តនានាក្នុងប្រទេសកម្ពុជា ដែលនៅជាប់នឹងព្រំដែនថៃ បានរាយការណ៍អំពីការសម្លាប់គ្រូបង្រៀន និស្សិត និងកូនទាហាន លន់ នល់ ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ១៨៧៦ ជាពិសេស អ្នកដែលបានលាក់ខ្លួនពីមុនមក)។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយលោកស្រី Elizabeth BECKER ឯកសារ E3/94 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ទំព័រ ៨-៩ ERN (ភាសាខ្មែរ) 00578899-00578900 (នៅឆ្នាំ ១៩៧៦ ប្រជាជនដែលគាំទ្រ លន់ នល់ ត្រូវបានបំបែកចេញដោយឡែក)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ៥៤ (ក្នុងអំឡុង ឬក្រោយឆ្នាំ ១៩៧៥ កូនទាហាន និងនាយទាហាន លន់ នល់ ត្រូវបានប្រមូលផ្តុំ និងកម្ទេចចោល)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ទំព័រ ១២ (កំណត់អត្តសញ្ញាណពីបញ្ជីអ្នកទោសដែលត្រូវបានកម្ទេចនៅមន្ទីរ ស-២១ ដែលក្នុងនោះរួមមាន ទាហាន លន់ នល់ ផងដែរ)។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ២០ (នៅឆ្នាំ ១៩៧៥ វាជាបដិវត្តប្រជាជាតិ។ ខ្មែរក្រហមមានបំណង

កម្មេចប្រជាជនទាំងអស់ដែលបម្រើការងារឲ្យពួកអាមេរិក ឬ របប លន់ នល់ ដែលត្រូវបានចាត់ទុកថាជាជនក្បត់)។ *របាយការណ៍ពីអង្គការលើកលែងទោសអន្តរជាតិ យោងតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៩ (XXXIV)* (ECOSOC) ឯកសារ E3/4521 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ ទំព័រ ១-៣ ERN (ភាសាខ្មែរ) 00664694-00664696 (មានសេចក្តីរាយការណ៍ជាច្រើនពីការសម្លាប់ក្រៅច្បាប់មកលើប្រជាជនជាច្រើន ដោយសារពួកគេធ្លាប់មានតំណែងនៅក្នុងរដ្ឋបាលមុន ហើយនៅក្នុងករណីមួយចំនួន សាច់ញាតិរបស់អ្នកដែលត្រូវបានចាត់ទុកថាជាជនក្បត់ ឬខ្មាំង ក៏ត្រូវសម្លាប់ផងដែរ។ ជនភៀសខ្លួនជាច្រើនបានចោទប្រកាន់ថា ការសម្លាប់ក្រៅច្បាប់ទ្រង់ទ្រាយធំមកលើអតីតនាយទាហាននៃរបបសាធារណរដ្ឋខ្មែរ បានកើតឡើងនៅ ឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦ ដោយពេលខ្លះរួមទាំងអ្នកនៅក្នុងបន្ទុកគ្រួសាររបស់ពួកគេផងដែរ។ អ្នកទាំងនោះអាចត្រូវបានសម្លាប់ ឬចាប់យកទៅបាត់ ហើយពុំដែលបានឮដំណឹងអ្វីឡើយ)។

[២៦៤៤] កំណត់សម្គាល់លោក H. LOCARD៖ *កំណត់ត្រាស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៥-៦ ERN (ភាសាខ្មែរ) 00233386-00233387 (ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ខ្មែរក្រហមចាប់ជ្រើសរើសទាហាន និងបញ្ជាជនយកទៅសម្លាប់ចោលនៅភូមិតាគ្រាម ចំណែកឯអ្នកដទៃទៀតត្រូវបានសម្លាប់នៅជិតភ្នំសំពៅ) ទំព័រ ២២ ERN (ភាសាខ្មែរ) 00233403 (បន្ទាប់ពីមានការបះបោរនៅមូលដ្ឋានមួយក្នុងឃុំសំរោង នៅខែ កុម្ភៈ ឆ្នាំ ១៩៧៦ អតីតអ្នកបើកយន្តហោះក្នុងរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានយកទៅសម្លាប់នៅចំការខ្នុរ) ទំព័រ ២៥-២៦ ERN (ភាសាខ្មែរ) 0023340600233407 (នៅខែ មករា ឆ្នាំ ១៩៧៦ មានអតីតអ្នករដ្ឋការជាង ៥០០ នាក់ ត្រូវបានយកទៅសម្លាប់នៅក្បែរជើងភ្នំត្រយូង នៅស្រុកភ្នំស្រុក។ អតីតប្រធានក្រុមហ៊ុនរ៉ាប់រងជាតិ និងអតីតចៅហ្វាយខេត្តកំពង់ស្ពឺ ត្រូវបាននាំខ្លួនទៅកាន់គុកមួយកន្លែង)។ អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិក កម្មវត្ថុ៖ ការវាយតម្លៃលើការវិវឌ្ឍនៅឥណ្ឌូចិនចាប់តាំងពីក្រោយពេលបញ្ចប់សង្គ្រាម ឯកសារ E3/3472 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ទំព័រ ៣-៤ ERN (ភាសាខ្មែរ) 00742970-00742971 (សក្ខីកម្មមួយរៀបរាប់អំពីការសម្លាប់អតីតក្រុមមន្ត្រីរដ្ឋការជាន់ខ្ពស់១០ នាក់ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេផង (សរុបប្រហែល ៦០ នាក់) នៅមង្គលបុរី)។ ទូរលេខរបស់ក្រសួងការបរទេសអាមេរិក៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២៩-៣០ ERN (ភាសាខ្មែរ) 00709605-00709606។

[២៦៤៥] កំណត់សម្គាល់ លោក H. LOCARD៖ *កំណត់ត្រាស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារ* E3/2071 ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៣៥ ERN (ភាសាខ្មែរ) 00233416 (នៅចុងឆ្នាំ ១៩៧៥ នៅកោះធំ ខេត្តកណ្តាល ខ្មែរក្រហមបានសុំឲ្យអ្នកធ្វើការនៅធនាគារ និស្សិត និងអ្នករដ្ឋការទាំងឡាយ ទៅស្វាគមន៍សម្តេចនរោត្តម សីហនុ។ មនុស្សចំនួន ៤០០ នាក់បានទៅ ប៉ុន្តែឃើញនៅសល់តែ ២៥ នាក់ប៉ុណ្ណោះ)។ របាយការណ៍រាជរដ្ឋាភិបាលចក្រភពអង់គ្លេស៖ *ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3319 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00699236-00699237។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចក់ ធឿន ឯកសារ E3/5541 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00369904 (នៅឆ្នាំ ១៩៧៨ អ្នកដែលគេចោទថា ជាទាហាន លន់ នល់ និងជាភ្នាក់ងារ សេ.អ៊ី.អា ត្រូវបានចាប់ខ្លួន និងសួរចម្លើយនៅខេត្តកណ្តាល)។

តាកែវ[២៦៤៦] ខេត្តសៀមរាប/ឧត្តរមានជ័យ[២៦៤៧] ខេត្តកំពង់ធំ[២៦៤៨] ខេត្តកំពង់ចាម[២៦៤៩] ខេត្តពោធិ៍សាត់[២៦៥០] ខេត្តស្វាយរៀង[២៦៥១] និងខេត្តព្រៃវែង ផងដែរ[២៦៥២]។

---

[២៦៤៦] ប្រវត្តិនៃជនភៀសខ្លួន ឯកសារ E3/5776 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ២៣៦-២៣៧ ERN (ភាសាខ្មែរ) 00840883-00840884 (នៅឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៨ អតីតអ្នករដ្ឋការស៊ីវិល និងមន្ត្រីរដ្ឋាភិបាលត្រូវបានចាប់ខ្លួន និងសម្លាប់នៅ បុស ចាស់ ក្រោយពីខ្មែរក្រហមកាន់តែបង្កើនការស៊ើបសួរប្រវត្តិរូបរបស់ពួកគេឥតឈប់ឈររួចមក)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៨៩-១៩០ ERN (ភាសាខ្មែរ) 00836266-00836267 (នៅខែ មករា ឆ្នាំ ១៩៧៦ នាយទាហានទាំងនោះត្រូវបានសម្លាប់យ៉ាងឃោរឃៅ និងបានបាត់ខ្លួន បន្ទាប់ពីត្រូវបានគេបោកបញ្ឆោតឲ្យជឿជាក់ថា ពួកគេនឹងត្រូវបញ្ជូនឲ្យទៅធ្វើការនៅកន្លែងផ្សេងវិញ)។

[២៦៤៧] ទូរលេខរបស់ក្រសួងការបរទេសអាមរិក៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ៣ ERN (ភាសាខ្មែរ) 00709579 (ជនភៀសខ្លួនម្នាក់ដែលជាអតីតនាយទោបានរាយការណ៍ថា ខ្មែរក្រហមកំពុងព្យាយាមស្វែងរកអ្នកណាដែលជាអតីតទាហាន ហើយក្រោយមកបានយកពួកគេទៅសម្លាប់ចោលនៅខេត្តសៀមរាប) ទំព័រ ២៩-៣០ ERN (ភាសាខ្មែរ) 00709605-00709606។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ជុយ ឯកសារ E3/5215 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៨ ទំព័រ ៣ ERN (ភាសាខ្មែរ) 00224048 (នៅឆ្នាំ ១៩៧៨ អតីតទាហាន នគរបាល និងអ្នករដ្ឋការត្រូវបានឃុំឃាំងនៅខេត្តសៀមរាប ហើយក្រោយមកពួកគេត្រូវបានដឹកតាមឡានយកចេញទៅបាត់)។

[២៦៤៨] ទូរលេខរបស់ក្រសួងការបរទេសអាមេរិក៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារ E3/3559 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ទំព័រ ២៩-៣០ ERN (ភាសាខ្មែរ) 00709605-00709606។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ស៊ឹម ហ៊ីប ឯកសារ E3/5355 ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៧-៩ ERN (ភាសាខ្មែរ) 00462347-00462349 (អតីតទាហាន លន់ នល់ ត្រូវបានយកទៅសម្លាប់ រួមទាំងនៅក្នុងឆ្នាំ ១៩៧៧ ផងដែរ)។

[២៦៤៩] កំណត់ហេតុសម្ភាសន៍ជាមួយ ស៊ឹង លឹម (ក.ស.ព) ឯកសារ E3/4649 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00744607-00744609 (ប្រជាជនណាដែលជាប់ពាក់ព័ន្ធនឹងរបបចាស់ ឬមានស័ក្តិនៅក្នុងសង្គមចាស់ ត្រូវបានដឹកតាមរថយន្តយកទៅសម្លាប់ចោលនៅឆ្នាំ ១៩៧៧ និង ១៩៧៨ នៅខេត្តកំពង់ចាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស្រុន ឯកសារ E3/1692 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ២-៤ ERN (ភាសាខ្មែរ) 00218551-00218553 (នៅដើមឆ្នាំ ១៩៧៦ ពួកទាហានត្រូវបានចាប់ខ្លួន ហើយយកទៅឃុំឃាំង)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ១៤៨-១៤៩ ERN (ភាសាខ្មែរ) 00836225-00836226 (អតីតនាយទាហានត្រូវបានហៅឲ្យមកជួបជុំ ដោយមានការប្រកាសតាមវិទ្យុ ហើយអ្នកទាំងនោះត្រូវបានយកទៅអូររាំងឪ និងក្រោយមកត្រូវបានដឹកជញ្ជូនតាមឡានទៅកាន់ទីកន្លែងផ្សេងៗទៀតដែលជាកន្លែងពួកគេបានធ្វើការងារជាមួយទាហានដទៃទៀត រួមទាំងក្រុមគ្រួសាររបស់ទាហានទាំងនោះផង។ ក្រោយមក ពួកគេក៏ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខនានា ហើយអ្នកខ្លះក៏ត្រូវបានសម្លាប់ចោល)។

[២៦៥០] ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ១៤-១៨ (ក្រោយពេលមកដល់ខេត្តពោធិ៍សាត់ ខ្មែរក្រហមបានដឹងថា ប្តីរបស់គាត់ធ្លាប់ធ្វើជាទាហាន លន់ នល់។ គាត់ និងប្តីរបស់គាត់ត្រូវបានចាប់ខ្លួន ហើយប្តីរបស់

៨៣៤. មានវិធីសាស្ត្រច្បាស់លាស់ នៅក្នុងការកំណត់អត្តសញ្ញាណអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រោយពីការបញ្ចប់ជម្លោះប្រដាប់អាវុធ និងគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សី François PONCHAUD និងអ្នកជំនាញ Philip SHORT បានផ្តល់សក្ខីកម្មថា ការភូតកុហកដែលត្រូវបានយកមកប្រើប្រាស់ដើម្បីគ្រប់គ្រងទៅលើស្ថានភាព និងប្រជាជន គឺជា "មូលដ្ឋានដ៏សំខាន់" របស់របបនោះ[២៦៥៣]។ម្យ៉ាងវិញទៀត ខ្មែរក្រហមបានប្រើប្រាស់ការបោកបញ្ឆោតដើម្បីល្បួងលោមអតីតអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ឲ្យបង្ហាញអត្តសញ្ញាណរបស់ពួកគេ ដោយប្រាប់ទៅអ្នកទាំងនោះថា ពួកគេនឹងត្រូវបញ្ជូនឲ្យទៅគាល់ សម្តេច នរោត្តម សីហនុ ឲ្យទៅរៀនសូត្រ ឬ ធ្វើសមាហរណកម្មបញ្ចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធថ្មី[២៦៥៤]។ ក្រោយមក

---

គាត់ត្រូវបានសម្លាប់ចោល)។ *សូមមើលផងដែរ* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៨។

[២៦៥១] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សុគាត ឯកសារ E3/5169 ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៤-៧ ERN (ភាសាខ្មែរ) 00186329-00186332 (នៅឆ្នាំ ១៩៧៦ ឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ទាហាន លន់ នល់ ត្រូវបានគេកំណត់គោលដៅសម្រាប់ការចាប់ខ្លួន និងការឃុំឃាំងខ្លួននៅក្នុងខេត្តស្វាយរៀង)។

[២៦៥២] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាំង រី ឯកសារ E3/4919 ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00545277 (នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៦ ឪពុករបស់លោកស្រីដែលជាទាហាន លន់ នល់ ត្រូវខ្មែរក្រហមបាញ់សម្លាប់នៅស្រុកកំពង់លាវ ខេត្តព្រៃវែង)។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ អ៊ុន រឿន ឯកសារ E3/5395 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479581 (អតីតទាហាន លន់ នល់ ត្រូវបានសម្លាប់ក្រោយពេលធ្វើការងារនៅពោធិបុរី អស់មួយរយៈ)។

[២៦៥៣] ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ទំព័រ ១៥-១៦ (ខ្មែរក្រហមបានកុហកភូតភរ ហើយវាជាធម្មតាទៅហើយសម្រាប់ពួកគេ ហេតុផលពិតប្រាកដនោះ គឺជាមនោគមន៍វិជ្ជា), ៣៨-៣៩ (អង្គការបានប្រើប្រាស់ការកុហកដើម្បីល្បួងលោមប្រជាជនឲ្យដើរតាមខ្លួន និងដើម្បីត្រួតត្រាទៅលើស្ថានភាព ជាពិសេស នៅពេលពួកគេសម្លាប់ប្រជាជនស្លូតត្រង់)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៨-៥៩ (ការកុហកគឺជាមូលដ្ឋានដ៏សំខាន់នៅក្នុងគ្រប់សកម្មភាពទាំងអស់របស់របបនេះ)។

[២៦៥៤] ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៩៧-៩៨។ របាយការណ៍រាជរដ្ឋាភិបាលចក្រភពអង់គ្លេស៖ *ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3319 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ កថាខណ្ឌ ៨ ERN (ភាសាខ្មែរ) 00699213។ របាយការណ៍ដោយ Stephen HEDER និង Masato MATSUSHITA៖ *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ឯកសារ E3/1714 ចុះខែកុម្ភៈ-មីនា ឆ្នាំ ១៩៨០ ទំព័រ ៧៥-៧៦ ERN (ភាសាខ្មែរ) 00324746-00324747។ ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ទំព័រ ២៣-២៤។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD)។

អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានចាប់ខ្លួន សម្លាប់ចោល ឬបានបាត់ខ្លួន[២៦៥៥]។ វិធីសាស្ត្រដូចគ្នានេះត្រូវបានប្រើប្រាស់នៅទូទាំងប្រទេស[២៦៥៦]។ សាក្សី François PONCHAUD[២៦៥៧] Philip SHORT[២៦៥៨] និងអ្នកជំនាញ David CHANDLER[២៦៥៩] បានបញ្ជាក់ថា គោលនយោបាយសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានអនុវត្តនៅទូទាំងប្រទេស។

### ១៤.៣.៤ សំអាងច្បាប់

៨៣៥. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ បានបង្ហាញឲ្យឃើញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ ទីមួយ ភស្តុតាងបានបង្ហាញថា មានបុគ្គលជាច្រើននាក់ រួមទាំងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផងដែរនោះ បានឯកភាពទៅលើគោលបំណងរួមដែលពាក់ព័ន្ធនឹងការអនុវត្តបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា[២៦៦០]។ ទីពីរ ភស្តុតាងក៏បានបង្ហាញឲ្យឃើញផងដែរថា ទោះបីជាគោលបំណងរួម

---

[២៦៥៥] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារ E3/4590 កាលបរិច្ឆេទផ្សេងៗគ្នា ទំព័រ ៨ ERN (ភាសាខ្មែរ) 00836085 (ជនភៀសខ្លួនទាំងអស់បានផ្តល់ចម្លើយដូចៗគ្នាថា ប្រជាជនបានបាត់ខ្លួន ឬត្រូវគេសម្លាប់ចោល)។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៥៦-៥៧ (ប្រជាជនណាមានការជាប់ពាក់ព័ន្ធជាមួយនឹងរបប លន់ នល់ រួមទាំងជាមួយ នាយទាហាន ភ្នាក់ងារ ឬមន្ត្រីស៊ើបការណ៍ ឬមន្ត្រីជាន់ខ្ពស់ ត្រូវបានឃុំឃាំងខ្លួន)។

[២៦៥៦] *សូមមើល* លេខយោងជើងទំព័រនៅក្នុងផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣៣។

[២៦៥៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី François PONCHAUD ឯកសារ E3/370 ទំព័រ ១៥ ERN (ភាសាខ្មែរ) 00286615 (យោងតាមសក្ខីកម្មរបស់ជនភៀសខ្លួនជាច្រើនដែលគួរឲ្យជឿជាក់បាន PONCHAUD បានសន្និដ្ឋានថា ការសម្លាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរបានកើតឡើងនៅទូទាំងប្រទេស)។

[២៦៥៨] ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៩៣-៩៤ (ការកំណត់គោលដៅនៅទូទាំងប្រទេសមានសណ្ឋានដូចគ្នា ដោយមានលក្ខណ:ខុសគ្នាបន្តិចបន្តួចនៅកន្លែងមួយចំនួន)។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ៥៥-៥៦ (មានលំនាំដូចគ្នានៅទូទាំងប្រទេស ក្នុងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

[២៦៥៩] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ១៨-១៩ (នៅដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មាំងចម្បងជាងគេបំផុត គឺអ្នកដែលបានធ្វើកិច្ចការអ្វីមួយជាមួយអតីតនៃរបបសាធារណរដ្ឋខ្មែរ ឬជាទាហាន)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ទំព័រ ៦-៧ (ការសម្លាប់អ្នកនៅក្នុងរបបចាស់ ត្រូវបានទទួលស្គាល់យ៉ាងទូលាយដោយអ្នកនិពន្ធផ្សេងៗថាជាដំណាក់កាលដំបូង។ គោលនយោបាយនេះបានបន្តអនុវត្ត និងត្រូវបានចងក្រងជាឯកសារយ៉ាងពេញលេញនៅក្នុងសក្ខីកម្មរបស់ជនរងគ្រោះ និងឯកសារកម្ពុជាប្រជាធិបតេយ្យ)។

[២៦៦០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧-៧៧៨។

នេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ ក៏គោលនយោបាយដែលខ្មែរក្រហមបានបង្កើតឡើងពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាមធ្យោបាយដើម្បីសម្រេចលទ្ធផលនៃគោលបំណងរួមនេះ។ នៅក្នុងករណីនេះ មានគោលនយោបាយក្នុងការកំណត់គោលដៅចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបណ្តាលឲ្យមានការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ គោលនយោបាយនេះ ក៏ត្រូវបានបង្ហាញឲ្យឃើញតាមរយៈវិធីសាស្ត្រក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលមានលក្ខណៈស៊ីសង្វាក់គ្នា ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃផងដែរ។

៨៣៦. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ផងដែរថា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ អាចត្រូវបានដាក់ឲ្យអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវ នៅពេលដែលអ្នកចូលរួមនោះ បានប្រើប្រាស់ចារីដើម្បីសម្រេចគោលបំណងរួម[២៦៦១]។ គណៈកម្មាធិការភូមិភាគពាយ័ព្យបានបញ្ជាឲ្យមានការប្រមូលផ្តុំ និងសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យបានធ្វើជាអធិបតីនៅក្នុងអង្គប្រជុំមួយ ដែលបានចេញសេចក្តីណែនាំនេះ។ តា សុត ដែលជាលេខាតំបន់ ៧ (ដោយរួមបញ្ចូលទាំងទួលពោធិ៍ជ្រៃផង) ក៏មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ។ បន្ទាប់មក តា សុត ក៏ដូចជាតំណាងមកពីគណៈកម្មាធិការភូមិភាគ និងគណៈកម្មាធិការតំបន់ បានចូលរួមនៅក្នុងអង្គប្រជុំមួយចំនួន ដែលគេបានប្រមូលផ្តុំអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយបន្ទាប់ពីនោះមក អ្នកទាំងនោះត្រូវបានដឹកយកទៅសម្លាប់ចោលនៅទួលពោធិ៍ជ្រៃ។ អ្នកទាំងនោះត្រូវបានដឹកតាមរថយន្ត ដែលបើកបរដោយអ្នកបើកបរមកពីភូមិភាគ ហើយមេបញ្ជាការភូមិភាគបានជ្រើសរើសយកទួលពោធិ៍ជ្រៃធ្វើជាទីតាំងសម្លាប់មនុស្ស។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ អាចត្រូវបានដាក់ឲ្យអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវ យ៉ាងហោចណាស់ចំពោះ រស់ ញឹម ដែលជាអ្នកចូលរួមម្នាក់ នៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ។

---

[២៦៦១] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៣។ *សូមមើលផងដែរ* សាលដីកាលើរឿងក្តី*Krajišnik* កថាខណ្ឌ ២២៦ (ទំនាក់ទំនងគ្រប់គ្រាន់ មានអត្ថិភាព នៅពេលដែលសមាជិកសហឧក្រិដ្ឋកម្មរួមម្នាក់បានស្នើយ៉ាងច្បាស់លាស់ ឬដោយប្រយោលឲ្យអ្នកដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមប្រព្រឹត្តបទឧក្រិដ្ឋ ឬបានញុះញង់ បានបញ្ជា បានលើកទឹកចិត្ត ឬបានប្រើប្រាស់អ្នកដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាផ្នែកនៃគោលបំណងរួម)។

៨៣៧. អង្គជំនុំជម្រះសាលាដំបូងនឹងលើកយកមកពិភាក្សាខាងក្រោមនេះ នៅក្នុងផ្នែកពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ ការចូលរួមរបស់ នួន ជា និង ខៀវ សំផន នៅក្នុងសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវចំពោះការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ ដែលបណ្តាលឲ្យមានឧក្រិដ្ឋកម្មផ្សេងៗ ប្រសិនបើមាន (ផ្នែកទី ១៥ និងផ្នែកទី ១៦)។

## ១៥. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា

៨៣៨. ផ្អែកតាមដីកាដំណោះស្រាយ ដូចដែលបានកំណត់វិសាលភាពក្នុងសំណុំរឿង ០០២/០១ នួន ជា តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចខាងក្រោម៖

> ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)៖ ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។
>
> ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)
>
> ទួលពោធិ៍ជ្រៃ៖ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ទៅលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[២៦៦២]។

ដីកាដំណោះស្រាយបានចោទប្រកាន់ នួន ជា ថាបានចូលរួមដោយចេតនា ឬ បានរួមចំណែកក្នុងការរៀបចំ និងអនុវត្តគោលបំណងរួមដែលបណ្តាលឲ្យមានឧក្រិដ្ឋកម្ម និង/ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទាំងមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[២៦៦៣]។ នៅក្នុងតួនាទីរបស់គាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការឃោផា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដីកាដំណោះស្រាយបានចោទប្រកាន់ថា នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នានា ដែលមានការបង្កើតគោលនយោបាយ ព្រមទាំងបាន

---

[២៦៦២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥ និង ១៥៤០។ *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៩-៧៨១, ៨១១-៨១៣។

[២៦៦៣] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៣៣។

ចូលរួមនៅក្នុងការពន្យល់បង្ហាញអំពីឯកសារគោលនយោបាយជាផ្លូវការនានារបស់បក្សកុម្មុយនីស្ត កម្ពុជា និងនៅក្នុងការអនុម័តិ និងជំរុញគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈ ការធ្វើសុន្ទរកថា ការឃោសនា និងវគ្គសិក្សានយោបាយ[២៦៦៤]។

ដោយផ្អែកលើមូលដ្ឋាននេះ ដីកាដំណោះស្រាយបានចោទប្រកាន់ នួន ជា បន្ថែមទៀតថា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឬ ម្យ៉ាងទៀត ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[២៦៦៥]។

## ១៥.១ ការដឹង ដែលទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ

៨៣៩. ការដឹងរបស់ នួន ជា អំពីគោលនយោបាយ វិធីសាស្ត្រនៃការអនុវត្ត និងឧក្រិដ្ឋកម្មជាក់លាក់នានាដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ មានទំនាក់ទំនងទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងទម្រង់ទាំងអស់នៃការទទួលខុសត្រូវ[២៦៦៦] ហើយបញ្ហាទាំងអស់នេះនឹងត្រូវលើកយកមកពិចារណាមុនគេ។ កម្រិតនៃការដឹង ដែលអាចមានការប្រែប្រួល អាស្រ័យទៅលើថា តើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ កើតមាននៅមុនពេល នៅក្នុងអំឡុងពេល ឬក៏នៅក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[២៦៦៧]។ ហេតុដូច្នេះ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះនឹងធ្វើការពិនិត្យថាតើ មុនពេលប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នោះ ជនជាប់ចោទបានដឹងអំពីភវនីយភាពច្បាស់លាស់អំពីហេតុការណ៍ដែលកើតមានឡើង នៅពេលក្រោយមកដែរ ឬទេ (ផ្នែក ១៥.១.១) និងថាតើជនជាប់ចោទបានដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងពេលប្រព្រឹត្ត (ផ្នែក ១៥.១.២) ឬក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្មដែរ ឬយ៉ាងណា (ផ្នែក ១៥.១.៣) ។

---

[២៦៦៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៣២។

[២៦៦៥] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤២, ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤, ១៥៥៩-១៥៦០។

[២៦៦៦] សម្រាប់ច្បាប់ជាធរមានស្តីអំពីទម្រង់នីមួយៗនៃការទទួលខុសត្រូវ សូមមើល ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល។

[២៦៦៧] សូមមើល ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៤,៦៩៨,៧០០, ៧០២, ៧០៤, ៧១៥។

៨៤០. នួន ជា គឺជាអ្នកគាំទ្រយ៉ាងខ្លាំងក្លាចំពោះការធ្វើ "ការតស៊ូវណ្ណៈ"[២៦៦៨] និងមានការទទួលខុសត្រូវចម្បងលើបញ្ហាទាក់ទងនឹងការឃោសនា[២៦៦៩]។ គាត់បានបង្ហាញមុខជាប្រធាន ជាអ្នកបណ្តុះបណ្តាល ឬ ជាអ្នកឧទ្ទេសនាមនៅក្នុងកិច្ចប្រជុំ វគ្គរៀនសូត្រ ឬ វគ្គបណ្តុះបណ្តាលនានា ដោយនៅពេលនោះ គាត់បានជំរុញមាគ៌ាបក្សដល់អ្នកនៅថ្នាក់ក្រោមឲ្យមានការប្រុងប្រយ័ត្នចំពោះខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ[២៦៧០]។ នួន ជា បានដឹងថា ការបំពាក់បំប៉នមនោគមន៍វិជ្ជាឲ្យមានការស្អប់ខ្ពើមបែបនេះ ប្រាកដជានឹងនាំឲ្យមានអំពើហិង្សា និងបានទទួលស្គាល់ថា ដោយសារការឈឺចាប់ និងភាពលំបាកលំបិនមួយរយៈមក មាគ៌ាបក្សពាក់ព័ន្ធនឹងការតស៊ូវណ្ណៈ និងភាពស្អប់ខ្ពើម បានចាក់ឫសនៅក្នុងចិត្តប្រជាជននៅតាមតំបន់រំដោះនានា[២៦៧១]។ នួន ជា បានគាំទ្រទស្សនៈដែលថា បដិវត្តគួរពឹងផ្អែកលើកសិករថ្នាក់ទាបបំផុត ដើម្បីឲ្យវណ្ណៈអធនគ្រប់គ្រងតឹងតែងលើប្រទេសកម្ពុជា។ ភាគច្រើននៃអ្នកដែលស្ថិតនៅក្នុងវណ្ណៈដឹកនាំថ្មីនេះ បានទទួលការអប់រំជាផ្លូវការតិចតួចណាស់។ ពួកគេទាំងអស់មានវិន័យតឹងរ៉ឹង ទទួលបានការបំពាក់បំប៉នមនោគមន៍វិជ្ជា ហើយត្រូវបានបង្រៀនឲ្យបោកបញ្ឆោតប្រជាជន និងអនុវត្តតាមគោលការណ៍រក្សាការសម្ងាត់។ នួន ជា មិនអាចមិនដឹងទេថា ការផ្តល់អំណាចយ៉ាងច្រើនទៅឲ្យពួកគេទាំងនោះ បែបនេះ នឹងធ្វើឲ្យមានការអនុវត្តមាគ៌ាបក្ស ដោយគ្មានការពិចារណាឲ្យបានត្រឹមត្រូវឡើយ។ ដោយហេតុផលនេះ ការរំពឹងទុកសមហេតុផលតែមួយគត់គឺថា ប្រជាជនយ៉ាងច្រើននឹងត្រូវស្លាប់នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅដោយបង្ខំ ដោយសារតែលក្ខខណ្ឌនៃការជម្លៀស និងថា ការផ្លាស់ទីលំនៅបែបនេះ មុខជានឹងនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានចំនួនច្រើន។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមនៅក្នុងសកម្មភាពឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលអំពីការប្រុងប្រយ័ត្ននឹងខ្មាំងសត្រូវ ការបំពាក់បំប៉នមនោគមន៍វិជ្ជាដ៏តឹងរ៉ឹងដល់កសិករអំពីការតស៊ូវណ្ណៈ រួមទាំងការកំណត់ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំងនោះ នួន ជា បានដឹងថា មានភវនីយភាពច្បាស់លាស់ដែលថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗ។

៨៤១. នួន ជា បានទទួលស្គាល់ជាច្រើនលើកច្រើនសា ពាក់ព័ន្ធនឹងការដឹងជាទូទៅរបស់គាត់ពីគោលនយោបាយ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយពួកខ្មែរក្រហម ដូចមានបញ្ជាក់ខាង

[២៦៦៨] សូមមើល ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៥-៣១២។

[២៦៦៩] សូមមើល ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៤។

[២៦៧០] សូមមើល ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥, ៣៤៧។

[២៦៧១] សូមមើល ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៤។

ក្រោមនេះ។ លើសពីនេះទៀត នៅក្នុងអំឡុងពេលវេលាពាក់ព័ន្ធនៃសំណុំរឿង ០០២/០១ នោះ នួន ជា ទទួលបានព័ត៌មានយ៉ាងទូលំទូលាយទាក់ទងទៅនឹងឧក្រិដ្ឋកម្មនានា។

### ១៥.១.១ ការដឹងអំពីភាវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៨៤២. នៅក្នុងគម្រោងការមួយដែលត្រូវបានផ្តួចផ្តើមឡើងកាលពីខែ ឧសភា ឆ្នាំ ១៩៧២ ហើយត្រូវបានអនុម័តជាផ្លូវការមួយឆ្នាំក្រោយមកនោះ គណៈកម្មាធិការមជ្ឈិមបានសម្រេចបិទផ្សារនៅក្នុងតំបន់រំដោះ ហើយបង្កើតសហករណ៍ ដោយប្រមូលផ្តុំកម្លាំងពលកម្មដើម្បីដាំដុះស្រូវ និងដើម្បី "វាយអានុភាពរបស់វណ្ណៈសក្តិភូមិ ម្ចាស់ដី និងវណ្ណៈនាយទុន"[២៦៧២]។ នៅក្នុងខែ មករា ឆ្នាំ ១៩៧២ អៀង សារី បានផ្តល់កិច្ចសម្ភាសន៍ជាសាធារណៈមួយ ទាក់ទងនឹងសមូហភាវូបនីយកម្មនៅក្នុងតំបន់រំដោះ[២៦៧៣]។ សេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានចាត់តាំងប្រជាជនឲ្យទៅបង្កបង្កើនផលកសិកម្មជាសមូហភាព[២៦៧៤]។ លើសពីនេះ លក្ខខណ្ឌនៃការដឹកជញ្ជូន ឬសុខុមាលភាពរបស់ប្រជាជនមិនមែនជាកត្តាដែលត្រូវយកចិត្តទុកដាក់ឡើយ។ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ខែ កក្កដា ឆ្នាំ ១៩៧៣ ថ្នាក់ដឹកនាំបក្ស ដោយបានកត់សម្គាល់ពីការខ្វះខាតនៅតាមតំបន់រំដោះ នោះ បានប្រកាសពីការប្តេជ្ញារបស់ខ្លួនក្នុងការបន្តការជម្លៀសដោយបង្ខំ ដោយទុកឲ្យប្រជាជនដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯងផ្ទាល់[២៦៧៥]។ យោងតាមគោលនយោបាយនេះ នៅតាមតំបន់រំដោះ មានការអនុវត្តវិធីសាស្ត្រដូចៗគ្នាក្នុងការជម្លៀសដោយបង្ខំចេញពីទីក្រុង និងការផ្លាស់ទីលំនៅពីតំបន់ជនបទមួយ ទៅតំបន់ជនបទមួយទៀត ដោយមានទាំងការធ្វើបាប ការរើសអើងប្រឆាំងនឹងប្រជាជនដែលមកពីតំបន់ខ្មាំង និងការប្រឆាំងនឹងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយមានការស្លាប់ដែលបណ្តាលមកពីអំពើព្រៃផ្សៃផ្សេងៗ លក្ខខណ្ឌនៃការជម្លៀស និងការប្រើប្រាស់ហិង្សា[២៦៧៦]។

៨៤៣. ដោយផ្អែកលើបទពិសោធន៍ពីមុននេះ នួន ជា បានចូលរួមក្នុងការបង្កើតគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងដំណើរការធ្វើសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំបក្សដែលបានបណ្តាលឲ្យមានឧក្រិដ្ឋកម្មជាច្រើន ឬជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានានៅក្នុងសំណុំរឿង

[២៦៧២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣, ១១៥។

[២៦៧៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៤។

[២៦៧៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣។

[២៦៧៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤។

[២៦៧៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤, ៨០០-៨០៣។

០០២/០១[២៦៧៧]។ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងជាថ្មីម្តងទៀត នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្ស រួមទាំង នួន ជា ផងដែរនោះ បានរៀបចំផែនការរួមគ្នា ដើម្បីជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង[២៦៧៨]។ ផែនការនេះបានប្រមើលឃើញ និង/ឬ ជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)[២៦៧៩]។ លើសពីនេះទៀត ផ្អែកលើបទពិសោធន៍ពីមុន ជាពិសេសបទពិសោធន៍នៅឧត្តុង្គ ផែនការខែ មិថុនា ឆ្នាំ ១៩៧៤ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ បន្ទាប់ពីបានរំដោះប្រទេសរួច ប្រាកដជាបានប្រមើលឃើញ និង/ឬជាប់ពាក់ព័ន្ធនឹងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីសម្លាប់ចាប់ខ្លួន ឬធ្វើឲ្យបាត់ខ្លួន បន្ទាប់ពីបានរំដោះតំបន់មួយ[២៦៨០]។ ក្រោយខែ មិថុនា ឆ្នាំ ១៩៧៤ ការប្រើប្រាស់វិធីសាស្ត្រនៃការជម្លៀសប្រជាជនចេញពីទីក្រុង និងការកំណត់គោលដៅចំពោះមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមានកាន់តែច្រើនឡើង ជាពិសេសក្នុងអំឡុងពេលវាយលុកចុងក្រោយដើម្បីរំដោះប្រទេស[២៦៨១]។

៨៤៤. អង្គជំនុំជម្រះយល់ឃើញថា ថ្នាក់ដឹកនាំបក្សបានបង្កើត និងអនុវត្តគោលនយោបាយកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយបានបន្តអនុវត្តគោលនយោបាយនេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[២៦៨២]។ នួន ជា បានទទួលស្គាល់ថា មានគោលនយោបាយ និង

---

[២៦៧៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៤៧។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៥-៣១៦, ៣២៥, ៣៣៤-៣៣៥។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៨-៨៨២។

[២៦៧៨] សូមមើល ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៣៣, ១៤៤-១៤៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥, ៧៨៨។

[២៦៧៩] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៣៣, ១៤៤-១៤៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥, ៧៨៨។

[២៦៨០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២៤-១២៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៦។

[២៦៨១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៣៤។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤១-៥៤២។

[២៦៨២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៨, ១២០-១២៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៤។

គោលបំណងដើម្បីលុបបំបាត់សមាសភាពមិនល្អ ដែលបានផ្តល់យុត្តិកម្មចំពោះ "ការកម្ទេច" ឬការលុបបំបាត់ប្រជាជន ប្រសិនបើពួកគេមិនអាចអប់រំកែប្រែបាន[២៦៨៣]។ ពាក់ព័ន្ធនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះបានរកឃើញភស្តុតាងអំពីគោលនយោបាយរបស់ថ្នាក់ដឹកនាំបក្សក្នុងការកំណត់គោលដៅអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរថាជាសមាសភាពមិនល្អ ដែលមិនអាចអប់រំកែប្រែបាន[២៦៨៤]។ នួន ជា បានបញ្ជាក់ថា "បទបញ្ជានយោបាយ" របស់បក្សកុម្មុយនីស្តកម្ពុជាដែលថា ពួកជនមហាក្បត់ "ត្រូវតែកម្ចាត់" នោះ តាមពិតត្រូវបានអនុវត្តរួចហើយ[២៦៨៥]។ យោងតាម នួន ជា ដោយសារការឈឺចាប់ និងភាពលំបាកលំបិនមួយរយៈមក មាគ៌ាបក្សពាក់ព័ន្ធនឹងការតស៊ូវណ្ណៈ និងភាពស្អប់ខ្ពើម បានចាក់ឫសនៅក្នុងចិត្តប្រជាជននៅតាមតំបន់រំដោះ[២៦៨៦]។ ដោយពិចារណាទៅលើតួនាទីរបស់គាត់នៅក្នុងថ្នាក់ដឹកនាំបក្ស ដែលបានរៀបចំ និងអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីគោលនយោបាយទាំងអស់នេះ ព្រមទាំងវិធីសាស្ត្រក្នុងការអនុវត្តគោលនយោបាយនេះ[២៦៨៧]។

៨៤៥. លើសពីនេះទៀត ពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស ផែនការរបស់បក្សក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងយុត្តិកម្មចំពោះការជម្លៀសនេះ គោលនយោបាយក្នុងការបែងចែកកម្លាំងពលកម្មដោយមានយុទ្ធសាស្ត្រ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ការប្រព្រឹត្តិខុសគ្នាចំពោះប្រជាជនថ្មី និងការណែនាំរបស់បក្សឲ្យលុបបំបាត់ និងរក្សាការប្រុងប្រយ័ត្នប្រឆាំងនឹងសមាសភាពទាំងអស់ និង "ពួកនៅសេសសល់" នៃរបបសាធារណរដ្ឋខ្មែរនោះ មិនមែនជាការសម្ងាត់ទៀតទេនៅក្នុងឋានានុក្រមបក្ស។ ភាពកើតមានពិតប្រាកដ សកម្មភាព និងគោលនយោបាយទាំងនេះ ត្រូវបានពិភាក្សា កោតសសើរ និងលើកទឹកចិត្ត នៅក្នុងអំឡុងវគ្គសិក្សារៀនសូត្រ សន្និសីទ ពិធីប្រារព្ធបុណ្យឯករាជ្យ មហាសន្និបាតនានា និងនៅក្នុងទស្សនាវដ្តី *ទង់បដិវត្ត* និងទស្សនាវដ្តី *យុវជន-យុវនារីបដិវត្ត* នៅគ្រប់

[២៦៨៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៥។

[២៦៨៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៥។

[២៦៨៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២៤ ជើងទំព័រ ២៥៩៨។

[២៦៨៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៤។

[២៦៨៧] *សូមមើល*ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៧-៣៤៨។

ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[២៦៨៨] នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម។ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំនានាដែលពិភាក្សាអំពីបញ្ហាទាំងនេះ និងចេញសេចក្តីណែនាំនានា[២៦៨៩]។ អង្គជំនុំជម្រះយល់ឃើញថា នួន ជា គឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមអ្នកនិពន្ធសំខាន់ៗនៃ *ទស្សនាវដ្តីទង់បដិវត្ត*[២៦៩០] ហើយជឿជាក់ថា គាត់បានដឹងអំពីបញ្ហាទាំងនេះ ដែលត្រូវបានលើកឡើងនៅក្នុងអត្ថបទបោះពុម្ពផ្សាយនានា។

៨៤៦. ឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង ០០២/០១ គឺជាផ្នែកនៃវិធីសាស្ត្រអនុវត្តដ៏ស៊ីសង្វាក់គ្នា ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេស នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តអនុវត្តនាពេលក្រោយៗមកទៀត[២៦៩១]។ ដោយពិចារណាទៅលើការទទួលបានរបាយការណ៍ និងព័ត៌មានដែលទាក់ទងនឹងស្ថានភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទ និងការអនុវត្តគោលបំណងរួម និងគោលនយោបាយនានានោះ អង្គជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់គឺថា នួន ជា បានដឹងអំពីវិធីសាស្ត្រអនុវត្តដ៏ស៊ីសង្វាក់គ្នា នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមវិសាលភាពសំណុំរឿង ០០២/០១ ហើយវិធីសាស្ត្រក្នុងការអនុវត្តនោះគឺជាផ្នែកមួយនៃឧក្រិដ្ឋកម្មទាំងនេះ[២៦៩២]។ លើសពីនេះទៀត អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលស្របទៅនឹងវិធីសាស្ត្រអនុវត្តទាំងនេះ ការអនុវត្តផែនការ និងគោលនយោបាយជម្លៀសប្រជាជនចេញពីតំបន់ទីប្រជុំជន និងការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបណ្តាលឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា នៅក្នុងអំឡុងពេលនៃការជម្លៀសដំណាក់កាលដំបូងនៃការជម្លៀសប្រជាជនទាំងពីរដំណាក់កាល និងនៅទួលពោធិ៍ជ្រៃ។

---

[២៦៨៨] *សូមមើលឧទាហរណ៍* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៤-៥៤៥។

[២៦៨៩] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤៤-១៤៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣១។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២៦៩០] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៤។ ផ្នែទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១១។

[២៦៩១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧-១១៨, ១២០-១២៣។

[២៦៩២] *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩៨។

## ១៥.១.២ ការដឹងនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៨៤៧. នួន ជា ក្នុងនាមជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកពេញសិទ្ធិនៃគណៈ-កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា[២៦៩៣] មានសិទ្ធិទទួលបានការជូនដំណឹង នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនានារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការដែលបានទទួលរបាយការណ៍ បានចូលរួមពិភាក្សា និងបានរៀបចំផែនការក្នុងការធ្វើបដិវត្តប្រជាធិបតេយ្យ និងបដិវត្តសង្គមនិយម ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការជម្លៀសប្រជាជនដោយបង្ខំនាពេលក្រោយៗមកទៀត ស្ថានភាពរស់នៅរបស់ប្រជាជននៅទីជនបទ និងការលុបបំបាត់ខ្មាំង និងការលុបបំបាត់សមាសភាពនៃរបបសាធារណរដ្ឋខ្មែរ[២៦៩៤]។ អង្គជំនុំជម្រះយល់ឃើញថា តួនាទីរបស់គណៈកម្មាធិការមជ្ឈិមមួយផ្នែក គឺត្រូវធ្វើការវិភាគទៅលើការអនុវត្តគោលនយោបាយរបស់បក្ស កែតម្រូវការរំលោភបំពាន និងចេញសេចក្តីណែនាំពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទ[២៦៩៥]។ កំណត់ហេតុប្រជុំនានាបង្ហាញថា គណៈកម្មាធិការអចិន្ត្រៃយ៍ (រួមទាំង នួន ជា) បានទទួលរបាយការណ៍ និងបានពិភាក្សាអំពីបញ្ហាកង្វះខាតម្ហូបអាហារ ថ្នាំសង្កូវ និងបញ្ហាជំងឺនានា[២៦៩៦]។ ក្រៅពីការចូលរួមកិច្ចប្រជុំផ្លូវការរបស់បក្ស នួន ជា ក៏បានស្នាក់នៅ ទទួលទានអាហារ និងបានជួបក្រៅផ្លូវការជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតរបស់បក្សផងដែរ[២៦៩៧] ដោយគាត់បានពិភាក្សាជាមួយមេដឹកនាំជាន់ខ្ពស់ទាំងនោះ អំពីប្រធានបទនានារួមទាំងការធ្វើបដិវត្តប្រជាធិប-តេយ្យ និងបដិវត្តសង្គមនិយម ដែលមានពីរដំណាក់កាលក្នុងការវិវត្តនៃគោលបំណងរួម[២៦៩៨]។ ក្រៅ

[២៦៩៣] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៤, ៣១៣, ៣១៥-៣១៦។

[២៦៩៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២៧, ១៣២-១៣៣, ១៤៤។ ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧១។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧, ៥៨៥, ៦០៤, ៦១៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៧២៩, ៧៥៧, ៧៦៨, ៧៧១, ៧៨៨, ៨០៧, ៨១៦

[២៦៩៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៩។ *សូមមើលផងដែរ* ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៤។

[២៦៩៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៦៨។

[២៦៩៧] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧១។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧។

[២៦៩៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១-៧៧៦។

ពីតួនាទីទាំងនេះ នួន ជា ត្រូវបានចាត់ឲ្យទទួលខុសត្រូវដោយផ្ទាល់ចំពោះគោលនយោបាយផ្នែកសង្គមកិច្ច[២៦៩៩]។ អង្គជំនុំជម្រះរកឃើញថា ដោយសារតែគាត់មានតួនាទីជាន់ខ្ពស់នៅក្នុងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នួន ជា ទទួលខុសត្រូវលើសកម្មភាពទាំងអស់របស់បក្ស ដែលលើសពីតួនាទី និង ការទទួលខុសត្រូវដែលត្រូវបានប្រគល់ឲ្យគាត់ជាផ្លូវការ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[២៧០០]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីឧក្រិដ្ឋកម្មនានា ក្នុងនាមគាត់ជាអនុលេខាបក្ស និងតាមរយៈសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍។

៨៤៨. ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក៏បានទទួលរបាយការណ៍ពីមេដឹកនាំយោធាស្តីអំពីដំណើរការវិវត្តផ្សេងៗនៅឯសមរភូមិ នៅក្នុងកិច្ចប្រជុំខែ មេសា ឆ្នាំ ១៩៧៥ នៅមន្ទីរ ប-៥[២៧០១]។ ទូរលេខជាច្រើនដែលនៅសេសសល់រហូតដល់ពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹងសភាពការណ៍នៅឯសមរភូមិ និងនៅព្រំដែនជាប់វៀតណាម ត្រូវបានចម្លងជូនទៅ នួន ជា[២៧០២]។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា កងកម្លាំងយោធាដែលបានវាយដណ្តើមយកទីក្រុងភ្នំពេញ ស្ថិតនៅក្រោមបញ្ជារបស់លេខាភូមិភាគនានា ដែលស្នើសុំ និងទទួលការណែនាំពី ប៉ុល ពត នួន ជា សុន សេន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅមន្ទីរ ប-៥[២៧០៣]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានទទួលព័ត៌មានលម្អិតអំពីសកម្មភាពនានារបស់កងទ័ពខ្មែរក្រហម និងស្ថានការណ៍នៅមូលដ្ឋាន។

### ១៥.១.២.១ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)

៨៤៩. នួន ជា បានទទួលស្គាល់ថា គាត់បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[២៧០៤]។ គាត់បាននិយាយថា នៅពេលធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញភ្លាមៗក្រោយពេលជម្លៀសនោះ គាត់ខ្លួនឯងផ្ទាល់បានឃើញអ្នកត្រូវបានជម្លៀសដើរតាមផ្លូវ ហើយបាន

[២៦៩៩] ព្រមទាំងគោលនយោបាយផ្នែកសិក្សាធិការ ឃោសនាការ វប្បធម៌ និងការងារបក្ស៖ *សូមមើល* ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣២។

[២៧០០] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

[២៧០១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៥-១៤៦។

[២៧០២] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៨។

[២៧០៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៧។

[២៧០៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤៤-១៤៥។

ទទួលស្គាល់ថា ពួកគេពិបាកក្នុងការធ្វើដំណើរ។ គាត់បានទទួលស្គាល់ថា ក្រោយមកគាត់បានឃើញសាកសពនៅក្នុងផ្ទះក្នុងទីក្រុងភ្នំពេញ[២៧០៥]។ នួន ជា ក៏បានទទួលស្គាល់ដែរថា មានការស្លាប់ជាច្រើនបែប ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង ការស្លាប់ដោយសារជំងឺ និងការអត់អាហារ ទាំងនៅក្នុងអំឡុងពេលជម្លៀស និងពេលក្រោយៗមកទៀត[២៧០៦]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

### ១៥.១.២.២ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)

៨៥០. នួន ជា បានទទួលស្គាល់ថា គាត់បានដឹងថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២[២៧០៧]។ គាត់បានទទួលស្គាល់ថា បក្សបានដឹងថាប្រជាជននឹងត្រូវលះបង់ ហើយនិងជួបប្រទះភាពលំបាកលំបិន ដោយសារតែការជម្លៀសទាំងនេះ[២៧០៨]។ ដូចដែលបានកត់សម្គាល់ខាងលើ នួន ជា ក៏បានទទួលស្គាល់ដែរថា មានការស្លាប់ជាច្រើនបែបក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង ការស្លាប់ដោយសារជំងឺ និងការអត់អាហារ ទាំងនៅក្នុងអំឡុងពេលនៃការជម្លៀស និងពេលក្រោយៗមកទៀត[២៧០៩]។

៨៥១. ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថា នៅក្នុងដំណាក់កាលទី២ មានការអនុវត្តវិធីសាស្ត្រផ្លាស់ទីលំនៅដោយបង្ខំពីតំបន់ទីជនបទមួយទៅតំបន់ទីជនបទមួយទៀត ដោយមានការធ្វើបាប ការរើសអើងប្រឆាំង "ប្រជាជនថ្មី" និងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌក្នុងការដឹកជញ្ជូន អំពើរបស់កងទ័ពខ្មែរក្រហមដែលបង្កឲ្យមានការភ័យខ្លាច និងការប្រើប្រាស់កម្លាំង[២៧១០]។ ភូមិភាគ និងតំបន់ស្វយ័ត បានរាយការណ៍ទៅមជ្ឈិម ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនក្នុង

[២៧០៥] សូមមើល ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។

[២៧០៦] សូមមើល ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។

[២៧០៧] សូមមើល ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២៨។

[២៧០៨] សូមមើល ឧទាហរណ៍ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។

[២៧០៩] សូមមើល ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។

[២៧១០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៤, ៦២៧-៦៥៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០០-៨០៣។

ដំណាក់កាលទី២[២៧១១]។ ប្រជាជនរាប់ពាន់នាក់ត្រូវបានផ្លាស់ទីលំនៅ តាមកាណូត កប៉ាល់ ឡាន និង រថភ្លើង សំដៅទៅទីក្រុងភ្នំពេញ កាត់តាមទីក្រុងភ្នំពេញ និងចេញពីទីក្រុងភ្នំពេញ ដែលជាទីក្រុងត្រូវបានគេបោះបង់ចោល[២៧១២]។ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការធ្វើដំណើររបស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានដឹងអំពីស្ថានភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស[២៧១៣]។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានទៅពិនិត្យមើលគម្រោងសាងសង់ និងគម្រោងកសិកម្មនានា និងបានជួបជាមួយមេដឹកនាំភូមិភាគផ្សេងៗផងដែរ[២៧១៤]។ គាត់ក៏បានជួបជាមួយលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត និងកម្មាភិបាលផ្សេងៗ ដូចជា រស់ ញឹម ជាដើម នៅក្នុងទីក្រុងភ្នំពេញ[២៧១៥]។ ក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍ បានធ្វើទស្សនកិច្ចទៅកាន់ភូមិភាគពាយ័ព្យ ហើយបានឃើញប្រជាជនថ្មីជួបប្រទះការខ្វះខាតទាំង ស្បៀងអាហារ និងថ្នាំសង្កូវ[២៧១៦]។ នួន ជា បានធ្វើដំណើរជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោយមកបានដឹងពីដំណើរទស្សនកិច្ចនោះ។

៨៥២. ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនានា នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

### ១៥.១.២.៣ ការសម្លាប់នៅទួលពោធិ៍ជ្រៃ

៨៥៣. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃក្រោយមកទៀត ទីក្រុងនានានៅក្នុងប្រទេសកម្ពុជាត្រូវបានរំដោះ ហើយក៏មានការចាប់ខ្លួន ការសម្លាប់ ការបាត់ខ្លួន និងការធ្វើបាបផ្សេងៗទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅពេលមុនការជម្លៀសបន្តិច ក្នុងពេលជម្លៀស និងក្រោយ

---

[២៧១១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩៨។

[២៧១២] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៥៩៥។

[២៧១៣] *សូមមើល* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២៧១៤] *សូមមើល* ផ្នែកទី៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៣។

[២៧១៥] *សូមមើល* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧២។

[២៧១៦] សូមមើល ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៥។

ការជម្លៀសបន្ថិច[២៧១៧]។ ដូចគ្នាទៅនឹងវិធីសាស្ត្រអនុវត្ត ដែលកំពុងអនុវត្តនៅពេលនោះ បន្ទាប់ពីរំដោះបានខេត្តពោធិ៍សាត់ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រមូលផ្តុំតាមរយៈមធ្យោបាយបោកបញ្ឆោត ហើយត្រូវបានយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ។ ការសម្លាប់នៅទួលពោធិ៍ជ្រៃបានកើតឡើងនៅថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥[២៧១៨]។ នួន ជា គឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមអ្នកនិពន្ធសំខាន់ៗនៃ*ទស្សនាវដ្តីទង់បដិវត្ត*[២៧១៩] ដែលជាមធ្យោបាយផ្សព្វផ្សាយគោលនយោបាយរបស់បក្សទាក់ទងនឹង "ខ្មាំង" និងលើកសរសើរអំពីការលុបបំបាត់ខ្មាំង និងការលុបបំបាត់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[២៧២០]។ គោលនយោបាយរបស់បក្សទាក់ទងនឹង "ខ្មាំង" ត្រូវបានផ្សព្វផ្សាយតាមរយៈវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ដែលត្រូវធ្វើឡើងដោយមេដឹកនាំបក្សនានា រួមទាំង នួន ជា ផងដែរ[២៧២១]។

៨៥៤. បើទោះបីជាមិនមានភ័ស្តុតាងបង្ហាញថា គាត់បានដឹងអំពីចរិតលក្ខណៈនៃឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីវិធីសាស្ត្រដែលកំពុងអនុវត្តក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយមានការចាប់ខ្លួន ការសម្លាប់ ការធ្វើឲ្យបាត់ខ្លួន និងការធ្វើបាបផ្សេងៗទៀត បន្ទាប់ពីបានរំដោះតំបន់មួយ និងជម្លៀសប្រជាជនចេញ។ ហេតុដូច្នេះ គាត់បានដឹងថា ប្រជាជននៅក្នុងខេត្តពោធិ៍សាត់ ក៏ដូចជា ទីក្រុងរំដោះដទៃទៀតនៅទូទាំងប្រទេសត្រូវបានជម្លៀស និងថា ផ្អែកតាមគោលនយោបាយក្នុងការកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ យ៉ាងហោចណាស់ក៏បានដឹងថា មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមួយចំនួនដែលរកឃើញនៅក្នុងខេត្តពោធិសាត់ ត្រូវបានគេសម្លាប់នៅខណៈពេលដែលមានការសម្លាប់នៅទួលពោធិ៍ជ្រៃនោះ។

---

[២៧១៧] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១៣-៦១៤, ៦៤៩-៦៥៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣០-៨៣៤។

[២៧១៨] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦២, ៦៦៨, ៦៧០, ៦៨១។

[២៧១៩] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៤។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១១។

[២៧២០] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៨។

[២៧២១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៨។

### ១៥.១.៣ ការដឹងនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៨៥៥. បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ដំណាក់កាលទី២ និងនៅទួលពោធិ៍ជ្រៃរួចមក គោលនយោបាយ ព្រមទាំងឧក្រិដ្ឋកម្មដែលកើតចេញ ពីគោលនយោបាយទាំងនេះ ក៏ត្រូវបានលើកឡើងនៅក្នុងវគ្គសិក្សារៀនសូត្រ ក្នុងសន្និសីទ ក្នុងពិធី ប្រារព្ធបុណ្យឯករាជ្យ នៅក្នុងមហាសន្និបាត ព្រមទាំងនៅក្នុងឯកសារនយោបាយ និងក្នុងទស្សនាវដ្ដី *ទង់បដិវត្ត* និង ទស្សនាវដ្ដី*យុវជន-យុវនារីបដិវត្ត* ដែរ។ នួន ជា មិនត្រឹមតែមានសិទ្ធិពិនិត្យមើល ទស្សនាវដ្ដី *ទង់បដិវត្ត* និងទស្សនាវដ្ដី *យុវជន-យុវនារីបដិវត្ត* ប៉ុណ្ណោះទេ គាត់ថែមទាំងជាអ្នកនិពន្ធ ម្នាក់ក្នុងចំណោមអ្នកនិពន្ធសំខាន់ៗនៃទស្សនាវដ្ដី*ទង់បដិវត្ត* ទៀតផង។

៨៥៦. នួន ជា ក៏មានសិទ្ធិទទួលបានរបាយការណ៍នានាពីបណ្ដារដ្ឋ អង្គការអន្តរជាតិ និងទី ភ្នាក់ងារសារព័ត៌មានអន្តរជាតិផ្សេងៗទៀតផងដែរ។ ប្រភពព័ត៌មានក្រៅប្រទេសទាំងនេះរាយ-ការណ៍ជាសាធារណៈពីការចោទប្រកាន់ផ្សេងៗអំពីអំពើឃោរឃៅដែលមាននៅក្នុងអំឡុងពេល និង ក្រោយពេលមានការប្រព្រឹត្តិអំពើទាំងនេះ ដែលមានទាំង ការផ្លាស់ទីលំនៅដោយបង្ខំ លក្ខខណ្ឌ អមនុស្សធម៌ ការរើសអើងប្រឆាំងនឹង "ប្រជាជនថ្មី" និងការរើសអើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃ របបសាធារណរដ្ឋខ្មែរ ការកំណត់គោលដៅចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយ មានការចាប់ខ្លួន ការសម្លាប់ និងការធ្វើឲ្យបាត់ខ្លួន និងការស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២[២៧២២]។ អង្គជំនុំជម្រះយល់ឃើញថា គណៈកម្មាធិការ អចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាឲ្យក្រសួងឃោសនាការ និងព័ត៌មានរបស់របបកម្ពុជា ប្រជាធិបតេយ្យ ធ្វើការត្រួតពិនិត្យសេចក្ដីរាយការណ៍ ព័ត៌មានបរទេសឲ្យបានដិតដល់ ហើយថា នីតិវិធីលម្អិតត្រូវបានបង្កើតឡើងសម្រាប់ឲ្យក្រសួងឃោសនាការ សង្ខេប និងរាយការណ៍ពីព័ត៌មាន នានាជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍[២៧២៣]។ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈរបាយការណ៍ របស់ក្រសួងទាំងនេះ នួន ជា ដែលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ពិតជាបានដឹងអំពីសេចក្ដី រាយការណ៍ព័ត៌មានដែលរៀបរាប់លម្អិតអំពីឧក្រិដ្ឋកម្មទាំងនេះ។

---

[២៧២២] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៧-២៦៨។

[២៧២៣] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៧។

៨៥៧. ដោយផ្អែកទៅលើមូលដ្ឋានដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ក៏បានទទួលព័ត៌មានអំពីឧក្រិដ្ឋកម្មនានា បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះផងដែរ។

## ១៥.២ ការទទួលខុសត្រូវរបស់ភូមិភាគនានាចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត

៨៥៨. មេធាវីការពារក្តី នួន ជា បានលើកឡើងថា (ក) ភូមិភាគគឺជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តផែនការក្នុងការជម្លៀសទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ព្រមទាំងព្រឹត្តិការណ៍នានានៅទួលពោធិ៍ជ្រៃ មិនមែនមជ្ឈិមបក្សនោះទេ[២៧២៤] និង (ខ) ការជម្លៀសប្រជាជនគឺជាការទទួលខុសត្រូវរបស់យោធា ហើយ នួន ជា មិនមែនជាអ្នកទទួលខុសត្រូវឡើយ[២៧២៥]។

៨៥៩. ទោះបីជាទទួលស្គាល់ថា ភូមិភាគបានអនុវត្តគោលនយោបាយរបស់បក្សទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ភូមិភាគទាំងនោះមិនមែនអនុវត្តដោយឯករាជ្យនោះឡើយ ហើយមជ្ឈិមបក្សរួមទាំង នួន ជា ផង បានពឹងផ្អែកទៅលើភូមិភាគនានា ដែលលេខាភូមិភាគទាំងនោះ ជាធម្មតាគឺជាសមាជិកគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ និងផ្អែកតាមរចនាសម្ព័ន្ធឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការធ្វើឱ្យគោលនយោបាយ និងសេចក្តីសម្រេចនានារបស់បក្សកុម្មុយនីស្តកម្ពុជាមានប្រសិទ្ធភាព។ ចំណុចនេះគឺស្របទៅនឹងបទប្បញ្ញត្តិនៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា[២៧២៦] និងក៏ជាតថភាពជាក់ស្តែងផងដែរ។ គណៈកម្មាធិការមជ្ឈិមដែលមាន នួន ជា ជាអនុលេខានោះ ទទួលបន្ទុកក្នុងការណែនាំថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងអង្គការបក្សដទៃទៀត ឱ្យអនុវត្តសកម្មភាពនានាស្របទៅតាមមាគ៌ានយោបាយរបស់បក្ស ហើយសេចក្តីណែនាំពីមជ្ឈិមបក្សត្រូវបានបញ្ជូនបន្តទៅថ្នាក់ភូមិភាគ និងនៅថ្នាក់ក្រោមៗទៀត[២៧២៧]។

---

[២៧២៤] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/3 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣០៥-៣១៥, ៣១៨-៣១៩, ៤១២-៤២១, ៤២៧-៤៣៨, ៤៥២-៤៥៤។ ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨-២១។

[២៧២៥] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ទំព័រ ១៨។

[២៧២៦] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៩។

[២៧២៧] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២។ ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៩, ២៨៦។

៨៦០. អង្គជំនុំជម្រះបានយល់ឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជន ក្រោយៗមកទៀត ត្រូវបានអនុវត្តឡើងនៅក្នុងលក្ខណៈដូចគ្នា[២៧២៨]។ ស្រដៀងគ្នានេះដែរ ទោះបីជា ឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥ បានស្នើឲ្យថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក ធ្វើផែនការ និងរៀបចំជាចាំបាច់ ដើម្បីសម្រេចគោលដៅរបស់បក្សក៏ដោយ[២៧២៩] ក៏មានការបង្ហាញយ៉ាងច្បាស់ថា មជ្ឈិមបក្សបានរៀបចំ សម្របសម្រួល និងអនុញ្ញាតឲ្យមានការផ្លាស់ទីលំនៅប្រជាជនទាំងនេះ[២៧៣០]។ បក្សក៏បានគ្រប់គ្រងផងដែរទៅលើមធ្យោបាយ និងរបៀបនៃការដឹកជញ្ជូន ដើម្បីអនុវត្តការផ្លាស់ទីលំនៅប្រជាជនក្រោយៗមកទៀត ដោយគណៈ-កម្មាធិការភូមិភាគ តំបន់ និងស្រុក មានអំណាចក្នុងការជម្លៀស ឬផ្លាស់ទីលំនៅទាំងនេះ[២៧៣១]។ សេចក្តីណែនាំរបស់បក្សទាក់ទងនឹងខ្មាំង និងការកំណត់គោលដៅអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ក៏ត្រូវបានផ្សព្វផ្សាយចេញពីមជ្ឈិមបក្សទៅដល់កម្មាភិបាលថ្នាក់ក្រោមៗផងដែរ តាមរយៈវគ្គសិក្សារៀនសូត្រ ការឃោសនា និងទស្សនាវដ្តី*ទង់បដិវត្ត*នានា ដើម្បីយកទៅអនុវត្ត។ ដូច្នេះ អង្គជំនុំជម្រះបដិសេធការលើកឡើងនេះ។

## ១៥.៣ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម

### ១៥.៣.១ ការរួមចំណែក

៨៦១. អង្គជំនុំជម្រះយល់ឃើញថា នួន ជា ក្នុងឋានៈជាអនុលេខាបក្សដែលមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយជាមួយនឹង ប៉ុល ពត[២៧៣២] មិនត្រឹមតែបានចូលរួមនៅក្នុងការរៀបចំគោលនយោបាយដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែក៏បានចូលរួមយ៉ាងសកម្មនៅក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១ នៅក្នុងការអនុវត្តគោលនយោបាយទាំងនោះជាបន្ត។ ជាការកត់សម្គាល់ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំជាច្រើនលើក ដែលពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយគាត់ក៏បានឯកភាពទៅលើផែនការនេះផង

---

[២៧២៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៨-១៥១។

[២៧២៩] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។

[២៧៣០] កត់សម្គាល់ សេចក្តីសម្រេចរបស់គណៈកម្មាធិការ ក្នុងការបញ្ជូនប្រជាជនចំនួន ២០.០០០នាក់ ទៅខេត្តព្រះវិហារ គឺជាការឆ្លើយតបទៅនឹងសំណើរបស់រដ្ឋអំណាចខេត្តនេះ ក្នុងការទទួលយកប្រជាជនចំនួន ៥០.០០០ នាក់។

[២៧៣១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៥៩៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៨០៩។

[២៧៣២] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

ដែរ។ នួន ជា ក៏បានដឹង និងបានអនុម័តចំពោះការផ្លាស់ទីលំនៅប្រជាជននាពេលបន្ទាប់មកទៀត ព្រមទាំងបានចូលរួមចំណែកក្នុងការរៀបចំ និងជំរុញគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងការកំណត់គោលដៅមកលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

៨៦២. ដូចបានពន្យល់លម្អិតខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នួន ជា បានចូលរួមនៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែលការរួមចំណែករបស់គាត់មានឥទ្ធិពលខ្លាំងក្លា។ ដើម្បីឲ្យ នួន ជា ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយកងទ័ពខ្មែរក្រហម ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះ ត្រូវតែបង្ហាញឲ្យឃើញថា សមាជិកណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ហើយសមាជិកនោះ បានប្រើប្រាស់ចារីដោយផ្ទាល់ដើម្បីសម្រេចគោលបំណងរួម[២៧៣៣]។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញអំពីការសម្រេចរបស់ខ្លួនថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះបាន[២៧៣៤]។ ការយល់ឃើញនៅផ្នែកខាងក្រោមដោយអង្គជំនុំជម្រះដែលថា នួន ជា បានរៀបចំផែនការ បានបញ្ជា បានញុះញង់ បានជួយ និងជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់នោះ (ផ្នែក ១៥.៤) ក៏បង្ហាញគ្រប់គ្រាន់ផងដែរពីទំនាក់ទំនងរវាង ចារី និង នួន ជា[២៧៣៥]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា អាចត្រូវដាក់ឲ្យទទួលខុសត្រូវដោយផ្ទាល់ចំពោះ ឧក្រិដ្ឋកម្មទាំងនេះ។

### ១៥.៣.១.១ ការបង្កើតគោលនយោបាយ ៖ ការរៀបចំផែនការអនុវត្តគោលបំណងរួម

៨៦៣. នួន ជា ត្រូវបានតែងតាំងជាអនុលេខាបក្សនៅក្នុងមហាសន្និបាតបក្សលើកទី១ នាខែ កញ្ញា ឆ្នាំ ១៩៦០ ដោយគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំតាក់តែងគោលជំហររបស់បក្សស្តីពីហិង្សាបដិវត្តន៍ និងការប្រើប្រាស់ការតស៊ូប្រដាប់អាវុធ ដើម្បីសម្រេចគោលដៅរបស់បក្ស។

---

[២៧៣៣] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៣ ។

[២៧៣៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៧-៨១០, ៨៣៦។

[២៧៣៥] សាលដីកាលើរឿងក្តី *Krajišnik* កថាខណ្ឌ ២២៦ (មានទំនាក់ទំនងគ្រប់គ្រាន់ នៅពេលដែលសមាជិកសហឧក្រិដ្ឋកម្មរួមម្នាក់ បានស្នើយ៉ាងច្បាស់លាស់ ឬមិនច្បាស់លាស់ ឲ្យអ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬបានញុះញង់ បានបញ្ជា បានលើកទឹកចិត្ត ឬបានប្រើប្រាស់អ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមនោះឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកមួយនៃគោលបំណងរួម)។

គាត់ក៏បានចូលរួមនៅក្នុងមហាសន្និបាតបក្សលើកទី២ និងលើកទី៣ (នៅខែ កុម្ភៈ ឆ្នាំ ១៩៦៣ និង ឆ្នាំ ១៩៧១) ដែលបានបញ្ជាក់អំពីមាគ៌ានយោបាយដដែលនេះ[២៧៣៦]។ នៅក្នុងមហាសន្និបាតបក្សលើកទីមួយ បក្សក៏បានកំណត់គោលដៅបដិវត្តន៍សង្គមនិយមរបស់ខ្លួន និងបានសម្រេចថា ពួកចក្រពត្តិបរទេស "បរិវារ" ឬអ្នកបំរើរបស់ពួកនេះ ព្រមទាំង "ពួកសក្តិភូមិ ពួកមូលធន និងពួកប្រតិកិរិយា" ទាំងអស់ គឺជា ខ្មាំងវណ្ណៈ[២៧៣៧]។ ក្នុងឋានៈគាត់ជាអនុលេខាបក្ស ហើយគាត់បានរួមចំណែកចំពោះគោលជំហររបស់បក្ស នួន ជា បានជួយផ្តួចផ្តើម និងបានអនុម័តជាផ្លូវការនូវមាគ៌ារបស់បក្ស។

៨៦៤. នៅឆ្នាំ ១៩៦៧ ឬនៅដើមឆ្នាំ ១៩៦៨ នួន ជា រួមជាមួយនឹងមេដឹកនាំដទៃទៀត បានសម្រេចថា ត្រូវតែចាប់ផ្តើមធ្វើបដិវត្តប្រដាប់អាវុធ[២៧៣៨]។ នៅពេលដែលបដិវត្តបានធ្វើដំណើរទៅមុខ នួន ជា បានជួបជាមួយនឹងមេដឹកនាំផ្សេងៗទៀតរបស់បក្ស និងបានផ្តល់យោបល់ថា ដល់ពេលដែលត្រូវធ្វើការតស៊ូប្រដាប់អាវុធប្រឆាំងនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរហើយ[២៧៣៩]។ នៅខែ តុលា ឆ្នាំ ១៩៧០ គណៈកម្មាធិការមជ្ឈិម ដែលរួមមាន នួន ជា និងមេដឹកនាំនយោបាយសំខាន់ៗដទៃទៀត បានពិភាក្សាអំពីផែនការរំដោះប្រទេសកម្ពុជាចេញពីពួកចក្រពត្តិអាមេរិក និងរបបសាធារណរដ្ឋខ្មែរ និងបានបញ្ជាក់អំពីគោលនយោបាយខ្លួនទីពឹងខ្លួន និងឯករាជ្យម្ចាស់ការរបស់បក្ស[២៧៤០]។ ៥ ឆ្នាំ ក្រោយមក នួន ជា និងមេដឹកនាំបក្សដទៃទៀត បានជួបប្រជុំគ្នាយ៉ាងទៀងទាត់ពាក់ព័ន្ធនឹងការបន្តធ្វើបដិវត្ត និងការគ្រប់គ្រងតំបន់រំដោះ[២៧៤១]។

៨៦៥. នៅក្នុងអំឡុងពីឆ្នាំ ១៩៧៤ ដល់ឆ្នាំ ១៩៧៥ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំនានាដែលពិភាក្សាអំពីការរំដោះ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ គាត់បានទទួលស្គាល់ថា

---

[២៧៣៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៧-៨៩, ៩៥។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦-៧២៧។

[២៧៣៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦។

[២៧៣៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៩។

[២៧៣៩] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៩។

[២៧៤០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣២។

[២៧៤១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣២។

បានចូលរួមធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅក្នុងកិច្ចប្រជុំមួយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤[២៧៤២]។ បន្ទាប់ពីកិច្ចប្រជុំនេះមក នួន ជា បានធ្វើដំណើរទៅប្រទេសវៀតណាម ដើម្បីជម្រាបមេដឹកនាំបក្សកុម្មុយនីស្តវៀតណាមអំពីផែនការវាយប្រយុទ្ធចុងក្រោយមកលើទីក្រុងភ្នំពេញ និងដើម្បីស្នើសុំឲ្យផ្តល់អាវុធបន្ថែមទៀត បើទោះបីជាការស្នើសុំអាវុធនេះ មិនបានទទួលជោគជ័យក៏ដោយ[២៧៤៣]។ នៅឯកិច្ចប្រជុំចុងក្រោយនាដើមខែ មេសា ឆ្នាំ ១៩៧៥ នៅមន្ទីរ ប-៥ ភ្លាមៗមុនការវាយប្រយុទ្ធមកលើទីក្រុងភ្នំពេញ នួន ជា បានឯកភាពជាថ្មីម្តងទៀតចំពោះសេចក្តីសម្រេចក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងទាំងមូល[២៧៤៤]។

៨៦៦. នួន ជា និងមេដឹកនាំសំខាន់ៗដទៃទៀត ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនាខែ ឧសភា ឆ្នាំ ១៩៧៥ នៅព្រះវិហារព្រះកែវមរកត ដែលបានពិភាក្សាអំពីផែនការរបស់ថ្នាក់ដឹកនាំឆ្ពោះទៅកាន់បដិវត្តន៍សង្គមនិយម តាមរយៈការអនុវត្តសម្ហហភាវូបនីយកម្ម[២៧៤៥]។ ការអនុវត្តផែនការនេះ ជាក់ស្តែងលុបចោលលទ្ធភាពដែលថា អ្នកដែលត្រូវបានផ្លាស់ទីលំនៅចេញពីទីក្រុងភ្នំពេញនឹងអាចត្រឡប់មកកាន់ផ្ទះសម្បែងរបស់ខ្លួនវិញបាន លើកលែងតែករណីមួយចំនួនតូចប៉ុណ្ណោះ។ នួន ជា មិនបានបដិសេធចំពោះផែនការនេះទេ។

៨៦៧. បន្ទាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យក្នុងខែ សីហា ឆ្នាំ ១៩៧៥ រួចមក គណៈកម្មាធិការនេះ បានសម្រេចផ្លាស់ទីលំនៅប្រជាជនចំនួនពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ ឲ្យមកកាន់តំបន់នេះ[២៧៤៦]។ របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីដំណើរទស្សនកិច្ចនេះបានផ្តល់នូវ "មតិណែនាំរបស់អង្គការ" ស្តីពីបញ្ហាសំខាន់ៗនៃ "ការចាត់ចែងកម្លាំងពលកម្ម" សហករណ៍នានា និងការចាត់ចែងចំពោះទីក្រុង។ របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ បានបង្ហាញពីឥរិយាបទខឹងសម្បាររបស់សមាជិកគណៈកម្មាធិការ

---

[២៧៤២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣។

[២៧៤៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤១។

[២៧៤៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៣៤, ១៤៤-១៤៥។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៥។

[២៧៤៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០-៧៤៣។

[២៧៤៦] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៧៤៥។

អចិន្ត្រៃយ៍ចំពោះប្រជាជនថ្មី។ របាយការណ៍នេះបានកំណត់អំពីផែនការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការបង្ខំឲ្យប្រជាជនថ្មីទាំងអស់រស់នៅក្នុងសហករណ៍[២៧៤៧]។ អង្គជំនុំជម្រះយល់ឃើញថា របាយការណ៍នេះ បានបង្កើតផែនការដែលមានការគ្រោងទុកយ៉ាងប្រយ័ត្នប្រយែងរបស់ថ្នាក់ដឹកនាំដើម្បីបង្កើន និងធ្វើឲ្យការការពារជាតិ (តាមរយៈការបង្កើតសហករណ៍នានា) និងសេដ្ឋកិច្ច (តាមរយៈការផ្លាស់ទីលំនៅប្រជាជន) មានភាពល្អប្រសើរឡើង។ ដោយសារគណៈកម្មាធិការអចិន្ត្រៃយ៍បានជួបប្រជុំរៀងរាល់សប្តាហ៍ ហើយកាន់តែញឹកញាប់ទៀតនៅពេលមានស្ថានភាពបន្ទាន់ចាំបាច់[២៧៤៨] អង្គជំនុំជម្រះជឿជាក់ថា ទោះបីជា នួន ជា មិនបានចូលរួមដោយផ្ទាល់នៅក្នុងដំណើរទស្សនកិច្ច ទៅកាន់ភូមិភាគពាយ័ព្យក្តី ក៏តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់គណៈកម្មាធិការអចិន្ត្រៃយ៍នោះ គាត់បានដឹងពីលទ្ធផលនៃដំណើរទស្សនកិច្ចនេះ សេចក្តី-សម្រេចដែលបានធ្វើឡើងនាពេលក្រោយមក និងបញ្ហាផ្សេងៗដែលប្រជាជនថ្មីនៅក្នុងភូមិភាគនោះកំពុងប្រឈម។ យោងតាមសេចក្តីថ្លែងការណ៍មុនៗរបស់ នួន ជា[២៧៤៩] អង្គជំនុំជម្រះក៏ជឿជាក់ថាគាត់មានទស្សនៈយល់ឃើញដូចគ្នា ទៅនឹងទស្សនៈយល់ឃើញរបស់ថ្នាក់ដឹកនាំដែលបានលើកឡើងនៅក្នុងរបាយការណ៍ពាក់ព័ន្ធនឹងប្រជាជនថ្មីនេះ។

៨៦៨. នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សបានផ្សព្វផ្សាយឯកសារមួយច្បាប់ ដែលវិភាគអំពីការរីកចម្រើននៅក្នុងការអនុវត្តគោលនយោបាយកសិកម្មរបស់បក្សក្នុងរយៈពេលពី ៤ ទៅ ៥ ខែមុន[២៧៥០]។ ឯកសារគោលនយោបាយនេះ បានរៀបរាប់ពីផែនការជម្លៀសប្រជាជនជាង ៥០០.០០០ នាក់ ទៅកាន់ភូមិភាគដទៃទៀត ដើម្បីឆ្លើយតបទៅនឹងគោលដៅផលិតស្រូវ និងបានទទួលស្គាល់ពីកង្វះថ្នាំសង្កូវ និងស្បៀងអាហារ ជាពិសេស ការប៉ះពាល់មកលើ "ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ[២៧៥១]។ ឯកសារនេះបានពិនិត្យយ៉ាងច្បាស់លាស់ទៅលើមាគ៌ាបក្សផ្នែក "សង្គមកិច្ច" និង "វប្បធម៌" ដែល នួន ជា ត្រូវបានចាត់តាំងនៅក្នុង

---

[២៧៤៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៥។

[២៧៤៨] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣។

[២៧៤៩] *សូមមើលឧទាហរណ៍* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៧។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៦៦។

[២៧៥០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨-៧៤៩។

[២៧៥១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨។

កិច្ចប្រជុំរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ឲ្យទទួលខុសត្រូវលើការងារទាំងពីរផ្នែកនេះដែរ[២៧៥២]។ នៅថ្ងៃដដែលនោះ គណៈកម្មាធិការអចិន្ត្រៃយ៍បានអនុម័តទៅលើគោលនយោបាយទូទៅស្តីពីការកសាង និងការពារប្រទេស "ដោយពឹងផ្អែកលើកម្លាំងមហាជន"[២៧៥៣]។ នៅពេលនោះ នួន ជា បានបន្តមុខតំណែងជាអនុលេខាបក្សផង[២៧៥៤] និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផង។ នៅចន្លោះពីខែ កញ្ញា និងខែ តុលា ឆ្នាំ ១៩៧៥ គណៈ-កម្មាធិការអចិន្ត្រៃយ៍ រួមទាំង នួន ជា ផង បានជួបពិភាក្សាអំពីគោលនយោបាយការពារ និងកសាងប្រទេស[២៧៥៥]។ ក្រោយមកទៀត គោលនយោបាយក្នុងការរៀបចំចាត់ចែងកម្លាំងពលកម្មទៅតាមតម្រូវការ និងតាមរដូវកាល ក៏ត្រូវបានអនុម័តនៅក្នុងមហាសន្និបាតជាតិលើកទីមួយស្តីពីសេដ្ឋកិច្ច ហើយត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយនៅក្នុង*ទស្សនាវដ្តីទង់បដិវត្ត* ខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥[២៧៥៦]។ យោងតាមមូលហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានដឹង និងបានគាំទ្រដល់ផែនការផ្លាស់ទីលំនៅប្រជាជនដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាជនជាង ៥០០.០០០ នាក់។

៨៦៩. តាមរយៈការរួមចំណែករបស់គាត់នៅក្នុងមហាសន្និបាតបក្ស និងនៅក្នុងកិច្ចប្រជុំនានាជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត អង្គជំនុំជម្រះជឿជាក់ថា នួន ជា មិនត្រឹមតែបានចូលរួមគាំទ្រដល់ផែនការរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំតាក់តែងខ្លឹមសារផែនការរួមនេះផងដែរ។

### ១៥.៣.១.២ ការឃោសនា ការអប់រំ និងការបណ្តុះបណ្តាលមហាជន៖ ការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួម

៨៧០. អង្គជំនុំជម្រះយល់ឃើញថា ទាំងនៅក្នុងប៉ុន្មានឆ្នាំមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទាំងក្នុងអំឡុងពេលក្រោយៗមកទៀតនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ នួន ជា បានធ្វើការយ៉ាងសកម្មនៅក្នុងការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហមនៅតាមទី

---

[២៧៥២] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៩, ៧៥២។

[២៧៥៣] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។

[២៧៥៤] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៣។

[២៧៥៥] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០៤។

[២៧៥៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៣។

01007127



ជនបទ ដោយគាំទ្រដល់គោលនយោបាយបដិវត្ត និងសេដ្ឋកិច្ចរបស់បក្ស ការបង្កើតសហករណ៍ និងការប្រុងប្រយ័ត្នចំពោះខ្មាំង[២៧៥៧]។ នួន ជា ក៏ធ្លាប់ធ្វើជាប្រធាន ជាគ្រូបណ្តុះបណ្តាល ឬ ជាអ្នកឧទ្ទេសនាមនៅក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ឬ វគ្គសិក្សារៀនសូត្រ ដែលគាត់បានជំរុញមាគ៌ារបស់បក្សស្តីពីការប្រុងប្រយ័ត្នចំពោះខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ក្នុងចំណោមកម្មាភិបាលថ្នាក់ក្រោមផងដែរ[២៧៥៨]។

៨៧១. ភ្លាមៗបន្ទាប់ពីកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅឯព្រះវិហារព្រះកែវមរកត នួន ជា រួមជាមួយនឹង ប៉ុល ពត ព្រមទាំងមេដឹកនាំសំខាន់ៗដទៃទៀត បានដឹកនាំកិច្ចប្រជុំមួយចំនួន។ នៅចន្លោះពីថ្ងៃទី ២០ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា ព្រមទាំងមេដឹកនាំដទៃទៀត បានណែនាំដល់តំណាងនានាមកពីអង្គភាពកងទ័ព និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់ អំពីគោលនយោបាយរបស់បក្សពាក់ព័ន្ធនឹងការរៀបចំសហករណ៍ ការលុបបំបាត់កម្មសិទ្ធិឯកជន ការហាមមិនឲ្យចាយលុយ ការបិទទីផ្សារ ការលើកទំនប់ និងជីកប្រឡាយ។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ថ្នាក់ក្រោមបានអនុវត្តសេចក្តីណែនាំទាំងឡាយដែលពួកគេបានទទួល[២៧៥៩]។

៨៧២. អង្គជំនុំជម្រះសូមរម្លឹកថា ចាប់ពីចុងឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៧ ទស្សនាវដ្តីទង់-បដិវត្តជាច្រើនលេខដែល នួន ជា បានដើរតួយ៉ាងសំខាន់នៅក្នុងការចេញផ្សាយនេះ[២៧៦០] បានគាំទ្រដល់តម្រូវការក្នុងការចល័តកម្លាំងពលកម្ម ផ្អែកលើសេចក្តីត្រូវការ និងយុទ្ធសាស្ត្ររបស់បក្ស[២៧៦១]។ ក្រោយមក ទស្សនាវដ្តីជាច្រើនលេខដែលបានបោះពុម្ពផ្សាយ បានជំរុញឲ្យកម្មាភិបាលធ្វើការតស៊ូវណ្ណៈប្រឆាំងនឹង "ពួកសក្តិភូមិ"។ ទស្សនាវដ្តីទង់បដិវត្តទាំងនេះបានពន្យល់យ៉ាងច្បាស់ថា "ពួកសក្តិភូមិ" គឺសំដៅលើពួកម្ចាស់ដី និងពួកអភិជន[២៧៦២]។

---

[២៧៥៧] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១០, ៣២៥។

[២៧៥៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥, ៣៤៧។

[២៧៥៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៣-៧៤៤។

[២៧៦០] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៤។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១១។

[២៧៦១] អង្គជំនុំជម្រះបានពិនិត្យឡើងវិញទៅលើផ្នែកពាក់ព័ន្ធនៃទស្សនាវដ្តីទង់បដិវត្ត សម្រាប់រយៈពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៧ នៅក្នុងផ្នែកដែលនិយាយអំពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

[២៧៦២] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៦។

៨៧៣. ដូចបង្ហាញតាមរយៈទស្សនាវដ្តីទង់បដិវត្ត សុន្ទរកថា និងសេចក្តីថ្លែងការណ៍ជាច្រើន នួន ជា បានជួយបែងចែកប្រជាជន ដោយញែកចេញរវាងកសិករ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី" អ្នកដែលជម្លៀសមកពីទីប្រជុំជន[២៧៦៣]។ ជាពិសេស នួន ជា បានអះអាងយ៉ាងច្បាស់ថា អ្នកទីក្រុងជាមនុស្សពុករលួយ[២៧៦៤] ហើយខេត្ត-ក្រុងនានាបានផ្តល់ជម្រកលាក់ខ្លួនដល់ "ពួកខ្មាំង"[២៧៦៥]។ ក្រោយមក "ការតស៊ូវណ្ណៈ" ត្រូវបានកំណត់ជាអាទិភាពរបស់បក្សនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ ដែលត្រូវបានអនុម័តនៅក្នុងមហាសន្និបាតបក្សលើកទីបួន[២៧៦៦]។ បក្សដែលមាន នួន ជា ជាបុគ្គលដ៏សំខាន់ បានបណ្តុះមនោគមន៍វិជ្ជាដល់អ្នកដែលគាំទ្រខ្លួនឲ្យស្អប់ប្រជាជនដែលរស់នៅក្នុងទីក្រុង ហើយបានបន្តធ្វើនៅគ្រប់ពេលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយយកលេសទៅលើការធ្វើបដិវត្តសង្គមនិយម និងការតស៊ូវណ្ណៈ[២៧៦៧]។ សេចក្តីថ្លែងការណ៍របស់បក្ស និងរបស់ នួន ជា ដែលទាក់ទងនឹង "ខ្មាំង" និង "ការតស៊ូវណ្ណៈ បានសាបព្រោះការមិនទុកចិត្តគ្នានៅក្នុងចំណោមកម្មាភិបាលរបស់បក្ស និងក្នុងចំណោមប្រជាជននៅតាមទីជនបទភាគច្រើនដែលបានចាត់ទុកអ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងប្រជាជនទីក្រុងទាំងអស់ថាជា "ប្រជាជនថ្មី" ដែលមិនអាចទុកចិត្តបាន និងបានដាក់ការសង្ស័យមកលើប្រជាជនថ្មីទាំងនោះ[២៧៦៨]។

៨៧៤. អង្គជំនុំជម្រះយល់ឃើញថា តាមរយៈតួនាទីរបស់គាត់នៅក្នុងយុទ្ធនាការឃោសនា (រួមទាំងតួនាទីសំខាន់របស់គាត់នៅក្នុងការចេញផ្សាយទស្សនាវដ្តីទង់បដិវត្ត) និងការបណ្តុះបណ្តាលកម្មាភិបាលទាំងនៅពេលមុន និងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានរួមចំណែកយ៉ាងធំធេងនៅក្នុងការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួមនេះ។

---

[២៧៦៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២១។

[២៧៦៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១។

[២៧៦៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៧។ ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១។

[២៧៦៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ជើងទំព័រ ១៥៤៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៤០។

[២៧៦៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៧។

[២៧៦៨] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥១៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦២១-៦២៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៧។

01007129



### ១៥.៣.២ ចេតនា

៨៧៥. ក្នុងឋានៈគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងតាមរយៈទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និងមេដឹកនាំកំពូលៗដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា[២៧៦៩] នួន ជា គឺជាតួអង្គដ៏សំខាន់ដែលទទួលខុសត្រូវចំពោះការរៀបចំតាក់តែងគោលនយោបាយរបស់បក្ស។ នួន ជា ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនានាមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលអនុម័តទៅលើផែនការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ហើយក្រោយពីនោះមក នៅគ្រប់ពេលទាំងអស់ គាត់គឺជាសមាជិកដ៏សំខាន់ម្នាក់នៃគណៈកម្មាធិការទាំងពីរ ដែលបានអនុម័តទៅលើការផ្លាស់ទីលំនៅប្រជាជនជាបន្តបន្ទាប់ នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១។ ក្នុងចំណោមចំណុចជាច្រើនទៀត គាត់ក៏ជាអ្នកគាំទ្រដ៏ខ្លាំងក្លាម្នាក់ ឲ្យមាន "សង្គ្រាមវណ្ណៈ" ប្រឆាំងនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងបានដើរតួនាទីនាំមុខនៅក្នុងការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលដើម្បីសម្រេចគោលបំណងនេះ។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះ ឥទ្ធិពលនៃតួនាទីរបស់គាត់ កាន់តែកើនឡើងថែមទៀតដោយសារតែមានបុគ្គលតិចតួចណាស់ដែលមានតួនាទីជា "ថ្នាក់លើ"។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជឿជាក់ថា ក្នុងនាមជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម[២៧៧០] នួន ជា បានរួមចំណែកដ៏សំខាន់ក្នុងការសម្រេចគោលបំណងរួម ហើយគាត់មានចេតនាជំរុញឲ្យមានការអនុវត្តគោលបំណងរួមនេះបន្ថែមទៀត តាមរយៈសកម្មភាពទាំងឡាយរបស់គាត់។

៨៧៦. យោងតាមមូលហេតុខាងលើនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ក៏មានចេតនាដូចសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ ក្នុងការសម្រេចឲ្យបាននូវគោលបំណងរួម[២៧៧១] តាមរយៈការអនុវត្តគោលនយោបាយរបស់បក្សស្តីពីការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ គាត់ក៏មានចេតនាដូចទៅនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ក្នុងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) ក៏ដូចជា ការធ្វើមនុស្ស

---

[២៧៦៩] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៣, ៣១៥, ៣១៧។

[២៧៧០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧។

[២៧៧១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧។

ឃាត និងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅទួលពោធិ៍ជ្រៃផងដែរ។ លើសពីនេះទៀត យោងទៅលើការរួមចំណែករបស់គាត់ក្នុងការរៀបចំមាគ៌ារបស់បក្សស្តីពីការតស៊ូវណ្ណៈ និងគោលនយោបាយកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា ក៏មានចេតនារើសអើង ដែលជាលក្ខខណ្ឌតម្រូវនៃបទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)) ដូចនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ។

#### ១៥.៣.៣ សេចក្តីសន្និដ្ឋាន

៨៧៧. អង្គជំនុំជម្រះយល់ឃើញថា តាមរយៈសហឧក្រិដ្ឋកម្មរួម (ទម្រង់មូលដ្ឋាន) នួន ជា បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំង ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាតព្រមទាំងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ គាត់បានចូលរួមជាមួយសមាជិកដ៏ទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

## ១៥.៤ ទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវ

### ១៥.៤.១ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១)

#### ១៥.៤.១.១ ការរៀបចំផែនការ

៨៧៨. អង្គជំនុំជម្រះជឿជាក់ថា នួន ជា រួមជាមួយនឹងអ្នកដទៃទៀត បានរៀបចំផែនការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ការវាយប្រហារចុងក្រោយដើម្បីរំដោះប្រទេស

និងគោលនយោបាយជម្លៀសប្រជាជនចេញពីខេត្ត-ក្រុងនានា ត្រូវបានរៀបចំផែនការ និងបានបញ្ជាតាមរយៈកិច្ចប្រជុំមួយចំនួននៅចន្លោះពីឆ្នាំ ១៩៧៣ និងដើមខែ មេសា ឆ្នាំ ១៩៧៥[២៧៧២]។ នួន ជា គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ [២៧៧៣] ដែលមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំនានា ហើយពិតជាបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះមែន[២៧៧៤]។

៨៧៩. នៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ គណៈកម្មាធិការមជ្ឈិមបានពិភាក្សាលម្អិតអំពី "ជ័យជម្នះ" នៅឧត្តុង្គ ដែលប្រជាជន រួមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានជម្លៀសដោយបង្ខំ ត្រូវបានគេធ្វើបាប ហើយប្រជាជនជាច្រើននាក់ត្រូវបានសម្លាប់ចោល[២៧៧៥]។ ទោះបីជាបក្សធ្លាប់មានបទពិសោធន៍ និងដឹងថាមានកង្វះស្បៀងអាហារនៅទូទាំងប្រទេសរួចមកហើយក៏ដោយ ហើយជាពិសេសនៅទីក្រុងភ្នំពេញ ក៏គណៈកម្មាធិការមជ្ឈិម រួមទាំង នួន ជា បានសម្រេចជម្លៀសប្រជាជនឱ្យអស់ចេញពីទីប្រជុំជននានា រួមទាំងទីក្រុងភ្នំពេញផងដែរ[២៧៧៦] ដោយខកខានក្នុងការចាត់វិធានការនានា ដែលមានការយល់ព្រមពីប្រជាជនដែលនឹងត្រូវជម្លៀស ឬ ផ្តល់សុខុមាលភាពដល់ពួកគេនៅក្នុងអំឡុងពេលជម្លៀសនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាអ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ បានរៀបចំផែនការរួមគ្នា ដែលបានប្រមើលឃើញ និងជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

៨៨០. នៅដើមខែ មេសា ឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់ រួមទាំង នួន ជា បានជួបប្រជុំគ្នាដើម្បីដោះស្រាយបញ្ហានៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បទពិសោធន៍មុនៗជាមួយនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជននានា ទៅតាមទីជនបទ[២៧៧៧] ដែលបង្កើតជាផ្នែក

---

[២៧៧២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៣៣, ១៤៤-១៤៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥, ៧៨៨។

[២៧៧៣] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣១៥។

[២៧៧៤] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៥, ៣៤០។

[២៧៧៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២៤-១២៦, ១៣៤។

[២៧៧៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៤, ១៤១, ១៤៥-១៤៦។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៥-៥៤០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៧, ៧៨៨។

[២៧៧៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៥។

មួយនៃវិធីសាស្ត្រអនុវត្តដែលបានចាប់ផ្តើមនៅមុនខែ មេសា ឆ្នាំ ១៩៧៥[២៧៧៨] នោះ ត្រូវបានយកមកពិភាក្សា និងពិនិត្យឡើងវិញ។ ក្រោយមក នួន ជា និងមេដឹកនាំដទៃទៀតដែលបានចូលរួមប្រជុំបានគាំទ្រចំពោះសេចក្តីសម្រេចផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[២៧៧៩]។ យ៉ាងណាក៏ដោយ ទោះបីជាបានពិនិត្យមើលឡើងវិញទៅលើបទពិសោធន៍មុនៗក្នុងការផ្លាស់ទីលំនៅប្រជាជនដែលធ្វើឲ្យប្រជាជនមានការឈឺចាប់ ហិង្សានៃការរើសអើងមកលើ "ប្រជាជនថ្មី" និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនៃការផ្លាស់ទីលំនៅ ការប្រើប្រាស់កម្លាំង និងការបំភិតបំភ័យ ក៏ដោយ ក៏មិនមានការឧបត្ថម្ភណាមួយត្រូវបានធ្វើឡើងដើម្បីដោះស្រាយស្ថានភាពនានា ដែលត្រូវបានប្រមើលឃើញជាមុន ដូចគ្នាទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញដែលមានផែនការជាមុននោះដែរ។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាផែនការនេះបានប្រមើលឃើញថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

៨៨១. ផែនការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបាន នួន ជា និងសមាជិកដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម បានរៀបចំឡើង ដាក់ឲ្យដំណើរការ និងបានចូលរួមចំណែកយ៉ាងច្រើនដល់ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១។ ផែនការនេះ ត្រូវបានផ្សព្វផ្សាយនៅក្នុងជួរបក្សបន្ទាប់ពីបានសម្រេចនៅក្នុងកិច្ចប្រជុំដែលពិភាក្សាពីផែនការនេះ[២៧៨០]។ ក្នុងការអនុវត្តតាមផែនការ និងការបញ្ជាទាំងនេះ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមអនុវត្តផែនការនេះតែក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញ។ ដោយផែនការដែលបានរៀបចំនេះ មានភាពស៊ីសង្វាក់ទៅនឹងវិធីសាស្ត្រដែលធ្លាប់បានអនុវត្តនៅពេលមុន និងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[២៧៨១] ប្រជាជនទីក្រុងភ្នំពេញត្រូវបានជម្លៀស ដោយមានការប្រើប្រាស់កម្លាំង ការបង្ខិតបង្ខំ និងបោកបញ្ឆោត ដោយមានការសម្របសម្រួល ឬការផ្តល់ជំនួយតិចតួចបំផុត ប្រសិនបើមាន។ អ្នកដែល

---

[២៧៧៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤។

[២៧៧៩] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៦។

[២៧៨០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៣៤, ១៤១, ១៤៨-១៥១។

[២៧៨១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤។

ត្រូវបានជម្លៀសដោយបង្ខំភាគច្រើនបានស្លាប់ ហើយអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់ជាគោលដៅសម្រាប់ការចាប់ខ្លួន និងការប្រហារជីវិត[២៧៨២]។

៨៨២. អង្គជំនុំជម្រះយល់ឃើញថា ក្នុងការរៀបចំផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នួន ជា បានដឹងថា ការជម្លៀសនេះនឹងបណ្តាលឲ្យមានការសម្លាប់ក្នុងទ្រង់ទ្រាយធំ រួមទាំងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រព្រឹត្តដោយបានដឹងថា ប្រជាជនជាច្រើននាក់អាចនឹងស្លាប់នៅក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជននាពេលក្រោយៗមកទៀតជាមិនខាន[២៧៨៣]។ អង្គជំនុំជម្រះជឿជាក់ថា ក្នុងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ នួន ជា មានចេតនា ឬ យ៉ាងហោចណាស់បានដឹងអំពីភវនីយភាពច្បាស់លាស់ថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយនៅពេលអនុវត្តផែនការនេះ។

៨៨៣. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ដែលជាផែនការមួយពាក់ព័ន្ធការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

### ១៥.៤.១.២ ការបញ្ជា

៨៨៤. អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា ទោះបីជាមិនចាំបាច់ត្រូវបង្ហាញឲ្យឃើញពីទំនាក់ទំនងជាផ្លូវការរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ក៏ដោយ ក៏លក្ខខណ្ឌនៃការបញ្ជាតម្រូវថា ជនជាប់ចោទ ក្នុងឋានៈជាអ្នកមានអំណាចតាមព្រឹត្តិហេតុ ឬតាមផ្លូវច្បាប់ បង្គាប់បុគ្គលផ្សេងទៀតឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ភ័ស្តុតាងក៏ត្រូវតែបង្ហាញឲ្យឃើញផងដែរថាជនជាប់ចោទបាន បញ្ជាបញ្ជូនបញ្ជា ឬបើមិនដូច្នេះទេ ផ្សព្វផ្សាយបញ្ជា តែម្នាក់ឯង ឬរួមជាមួយនឹងអ្នកផ្សេងទៀត រួមទាំងតាម រយៈអន្តរការីផងដែរ។ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានបញ្ជាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋ-កម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ នួន ជា រួមជាមួយ

[២៧៨២] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧-៥៧៤។

[២៧៨៣] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៤០, ៨៤២-៨៤៦។

នឹង ប៉ុល ពត បានអនុវត្តសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស[២៧៨៤] និងប្រើប្រាស់សិទ្ធិអំណាចនេះតាមផ្លូវច្បាប់ (*de jure*) និងតាមព្រឹត្តិហេតុ (*de facto*) ដើម្បីបង្គាប់ទៅកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការជម្លៀសដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស។ ក្រោយពីកិច្ចប្រជុំនាខែមិថុនា ឆ្នាំ ១៩៧៤ ដែលបានសម្រេចថា ត្រូវតែជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនេះមក អ្នកដែលបានចូលរួមប្រជុំត្រូវបានណែនាំឲ្យផ្សព្វផ្សាយព័ត៌មានអំពីសេចក្ដីសម្រេចនានាដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំនេះ នៅក្នុងភូមិភាគនីមួយៗដែលពួកគេមានសមត្ថកិច្ច[២៧៨៥]។ ក្រោយពីកិច្ចប្រជុំមួយទៀតដែលបានធ្វើឡើង នៅដើមខែ មេសា ឆ្នាំ ១៩៧៥ ដែលបានពិភាក្សាអំពីការជម្លៀសប្រជាជននោះមក បទបញ្ជាទាំងឡាយក៏ត្រូវបានបញ្ជូនទៅឲ្យមេបញ្ជាការកងទ័ពជាថ្មីទៀតដើម្បីធ្វើការអនុវត្ត[២៧៨៦]។ សេចក្ដីសម្រេចជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញត្រូវបានអនុវត្តនៅពេលក្រោយមកទៀតនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥។ នួន ជា បានបញ្ជាក់ថា "បទបញ្ជាខាងនយោបាយ" របស់បក្សកុម្មុយនីស្តកម្ពុជាដែលថា ពួកជនមហាក្បត់ "ត្រូវតែកម្ចាត់" ពិតជាត្រូវបានអនុវត្តមែន[២៧៨៧]។

៨៨៥. អង្គជំនុំជម្រះជឿជាក់ថា សេចក្ដីសម្រេច និងសេចក្ដីណែនាំនានារបស់គណៈកម្មាធិការមជ្ឈិម ដែលមាន នួន ជា ផងដែរនោះ គឺជាបញ្ជាដែលត្រូវបានអនុវត្ត[២៧៨៨]។ អង្គជំនុំជម្រះក៏ជឿជាក់ថា កម្មាភិបាលថ្នាក់ក្រោមបានទទួលអំណាច និងសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា។ បញ្ជាទាំងនេះ ត្រូវបានផ្ដល់ទៅឲ្យមុនពេលប្រព្រឹត្ត និងបានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការប្រព្រឹត្តិ

---

[២៧៨៤] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

[២៧៨៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤១។

[២៧៨៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៨-១៥១។

[២៧៨៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២៤។

[២៧៨៨] ពិតហើយថា ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានពិចារណាដូចគ្នានេះ។ *សូមមើល ទស្សនាវដ្ដីទង់បដិវត្ត* ឯកសារ E3/193 ខុះខែ សីហា ឆ្នាំ ១៩៧៧ ទំព័រ ២ ERN (ភាសាខ្មែរ) 00062948 (កាលពីថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៧៧ នៅក្នុងសន្និបាតកម្មាភិបាលភូមិភាគបស្ចិម តំណាងមជ្ឈិមបក្សបានធ្វើ "បទឧទ្ទេសនាមទាក់ទងនឹងសេចក្ដីណែនាំរបស់បក្សស្ដីពីបញ្ហាសំខាន់ៗមួយចំនួន" ដែលត្រូវតែអនុវត្តនៅក្នុងឆមាសទីពីរនៃឆ្នាំ ១៩៧៧)។

ឧក្រិដ្ឋកម្មនានា។ កម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមបានចាប់ផ្តើមអនុវត្តបញ្ជាទាំងនេះ តែក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយពីការរំដោះទីក្រុងភ្នំពេញ។

៨៨៦. យោងតាមសំអាងហេតុដែលបានលើកឡើងខាងលើទាក់ទងនឹង "ការរៀបចំផែនការ"[២៧៨៩] អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជននាពេលក្រោយៗមកទៀត នួន ជា មានចេតនា ឬយ៉ាងហោចណាស់បានដឹងអំពីភវនីយភាពច្បាស់លាស់ថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងពេលអនុវត្តសេចក្តីណែនាំរបស់បក្សជាមិនខាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៥.៤.១.៣ ការញុះញង់

៨៨៧. ដូចដែលបានបញ្ជាក់ពីពេលមុនរួចហើយថា ការញុះញង់តម្រូវថា អំពើរបស់ជនជាប់ចោទបានជំរុញ ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលមានន័យថា អំពើសកម្ម ឬអកម្មរបស់គាត់ *បានរួមចំណែកយ៉ាងសំខាន់* ដល់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយផ្ទាល់។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា បានរៀបចំផែនការរួមគ្នាក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ហើយថា ផែនការនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស ហើយបានប្រើប្រាស់អំណាចតាមផ្លូវ ច្បាប់ (*de jure*) និងតាមព្រឹត្តិហេតុ (*de facto*) បង្គាប់ឲ្យកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់ កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេស នៅក្នុងការអប់រំកម្មាភិបាលឲ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណ

---

[២៧៨៩] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨២។

“ប្រជាជនថ្មី” និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង។ អង្គជំនុំជម្រះជឿជាក់ថា ការចូលរួមរបស់ នួន ជា ជាមួយនឹងមេដឹកនាំដទៃទៀត នៅក្នុងការរៀបចំតាក់តែងគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងកំណត់គោលដៅលើក្រុមជាក់លាក់ មានតាំងពីពេលមុនមកម្ល៉េះ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ លើសពីនេះទៀត ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះជឿជាក់ថា ការបណ្តុះបណ្តាល សេចក្តីថ្លែងការណ៍ និងការចូលរួមពាក់ព័ន្ធរបស់គាត់នៅក្នុងការចេញផ្សាយ *ទស្សនាវដ្តីទង់បដិវត្ត* ត្រូវបានកងទ័ព និងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមយល់ថា ជាការជំរុញពួកគេឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា “ខ្មាំង”។ ទង្វើនេះក៏បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈអំពើរបស់គាត់ នួន ជា បានជម្រុញឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មនានា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

៨៨៨. ជាចុងក្រោយ យោងតាមសម្អាងហេតុដូចដែលបានគូសបញ្ជាក់ខាងលើទាក់ទងនឹង “ការរៀបចំផែនការ”[២៧៥០] អង្គជំនុំជម្រះជឿជាក់ថា នៅក្នុងការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនក្រោយៗមកទៀត នួន ជា មានចេតនា ឬយ៉ាងហោចណាស់បានដឹងអំពីភវនីយភាពច្បាស់លាស់ថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងពេលអនុវត្តសេចក្តីណែនាំរបស់បក្សជាមិនខាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

[២៧៥០] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨២។

### ១៥.៤.១.៤ ការជួយ និងជំរុញ

៨៨៩. អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រខាងផ្លូវចិត្តដល់ចារី នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ ការលើកទឹកចិត្ត និងការគាំទ្រខាងផ្លូវចិត្តនេះបានស្តែងចេញឲ្យឃើញយ៉ាងច្បាស់តាមរយៈតួនាទីរបស់គាត់នៅមុន និងក្រោយឧក្រិដ្ឋកម្ម នៅក្នុងពេលឃោសនា និងអប់រំកម្មាភិបាល ដែលជំរុញឲ្យធ្វើការតស៊ូវណ្ណៈ ផ្តល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនពីខេត្ត-ក្រុង និងកោតសរសើរអំពីឧក្រិដ្ឋ-កម្មកន្លងមក[២៧៩១]។

៨៩០. ការលើកទឹកចិត្ត និងការគាំទ្រខាងផ្លូវចិត្តរបស់ នួន ជា មានឥទ្ធិពលខ្លាំងក្លាដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ ពាក្យសម្តី និងសកម្មភាពរបស់ នួន ជា នៅក្នុងពេលផ្សព្វផ្សាយគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងគោលនយោបាយនៃការកំណត់គោលដៅ ដល់កម្មាភិបាល និងនៅក្នុងការជំរុញការអនុវត្តគោលនយោបាយទាំងនេះ បានលើកទឹកចិត្តឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្ម។ លើសពីនេះទៀត ការអនុម័តិគោលនយោបាយទាំងនេះដោយបក្សកុម្មុយនីស្តកម្ពុជា មានឥទ្ធិពលផ្លូវច្បាប់ ដែលបានជួយសម្រួលដល់ការអនុវត្តឧក្រិដ្ឋកម្ម។

៨៩១. នួន ជា បានដឹងថា ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ទំនងជានឹងត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់គាត់បានជួយជ្រោមជ្រែង ឬបានជួយសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។ អង្គជំនុំជម្រះ ក៏ជឿជាក់ថា នួន ជា យ៉ាងហោចណាស់ បានដឹងអំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មទាំងនេះ។ អង្គជំនុំជម្រះបានសម្រេចរួចហើយថា នួន ជា មិនត្រឹមតែបានដឹងថា ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងដំណាក់កាលទី១នៃការផ្លាស់ទីលំនៅប្រជាជន ទំនងជានឹងត្រូវបានប្រព្រឹត្តឡើងប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះទៀតផង។ ដោយសារបានដឹង និងមានចេតនានេះហើយ ទើប នួន ជា បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រខាងផ្លូវចិត្តចំពោះចារីនៃឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១នោះ។ ដូច្នេះ អង្គជំនុំជម្រះយល់

---

[២៧៩១] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៤-៣២៩, ៣៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៨។

ឃើញថា នួន ជា ត្រូវទទួលខុសត្រូវលើការជួយ និងជំរុញ ដល់ចារីឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជន (ដំណាក់កាលទី១)។

### ១៥.៤.១.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

៨៩២. ការទទួលខុសត្រូវរបស់ថ្នាក់លើ ផ្អែកទៅលើសមត្ថភាពរបស់ជនជាប់ចោទក្នុងការអនុវត្តអំណាចជាក់ស្ដែងលើអ្នកក្រោមបង្គាប់ ដែលនោះគឺជាអំណាចពិតប្រាកដក្នុងការចាត់វិធានការចាំបាច់ និងសមស្របដើម្បីទប់ស្កាត់ និងដាក់ទោសដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ អំណាចជាក់ស្ដែង ទោះបីជាតាមផ្លូវច្បាប់ ឬតាមព្រឹត្តិហេតុក៏ដោយ ត្រូវតែមានអត្ថិភាពនៅក្នុងរចនាសម្ព័ន្ធនៃការបញ្ជា នៅក្នុងន័យដែលថា ជនជាប់ចោទមានសមត្ថភាពចេញបទបញ្ជាទៅអ្នកក្រោមបង្គាប់របស់ខ្លួន។ យោងតាមដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង ០០២/០១ នួន ជា ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ និងមានអំណាចជាក់ស្ដែងលើកងទ័ពបដិវត្តន៍កម្ពុជា សមាជិកគណៈកម្មាធិការភូមិភាគ គណៈកម្មាធិការតំបន់ និងគណៈកម្មាធិការស្រុក កងឈ្លប និងកម្មាភិបាលមូលដ្ឋាន[២៧៩២]។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពខ្មែរក្រហម ដែលបានវាយប្រយុទ្ធក្នុងនាមជាកងកម្លាំងប្រជាជនរំដោះជាតិកម្ពុជា និងបានបំពេញភារកិច្ចក្រោមការគ្រប់គ្រងផ្ទាល់របស់មេបញ្ជាការ និងលេខាភូមិភាគរបស់ពួកគេ[២៧៩៣]។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលក្រោយៗ មកទៀត ត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពខ្មែរក្រហមមកពីភូមិភាគ

---

[២៧៩២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៩។

[២៧៩៣] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦០, ៤៦១, ៤៧០។

ផ្សេងៗ ដែលបានបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធថ្មីរបស់កងទ័ពបដិវត្តន៍កម្ពុជា និងដោយកម្មាភិបាលដែលបានបំពេញភារកិច្ចនៅក្នុងឋានានុក្រមរដ្ឋបាលដែលមានស្រាប់[២៧៩៤]។

## ១៥.៤.១.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់

៨៩៣. នួន ជា គឺជាអនុលេខាបក្សរហូតមក និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម។ នួន ជា បានអនុវត្តអំណាចធ្វើសេចក្ដីសម្រេចចុងក្រោយរួមជាមួយនឹង ប៉ុល ពត ដែលជាថ្នាក់លើផ្លូវការតែម្នាក់គត់ ដែលនៅពីលើគាត់[២៧៩៥]។ ទោះបីជាកងទ័ពខ្មែរក្រហមដែលបានវាយសម្រុកចូលមកទីក្រុងភ្នំពេញ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ មិនមែននៅក្រោមមជ្ឈិមបក្សក៏ដោយ[២៧៩៦] ក៏នៅក្នុងអំឡុងពេលមុនឆ្នាំ ១៩៧៥ បន្តិច កងទ័ពខ្មែរក្រហមបានអនុវត្តតាមបញ្ជាជាច្រើនមកពីថ្នាក់ដឹកនាំបក្ស ដែលរួមទាំង បញ្ជាមកពី នួន ជា ឲ្យវាយសម្រុក និងផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីខេត្ត-ក្រុងនានា ក្រោយពេលវាយដណ្ដើមបាននោះ[២៧៩៧]។ លើសពីនេះទៀត នៅដើមខែ មេសា ឆ្នាំ ១៩៧៥ ភ្លាមៗនៅមុនពេលវាយសម្រុកចូលមកទីក្រុងភ្នំពេញ លេខាភូមិភាគ និងមេបញ្ជាការយោធា មានវត្តមាននៅមន្ទីរ ប-៥ និងបានរាយការណ៍ជូន នួន ជា និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតអំពីការវិវត្តនៃការវាយសម្រុករបស់កងទ័ពខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ[២៧៩៨]។

៨៩៤. ក្រោយពីបានពិនិត្យមើលអង្គហេតុខាងលើនេះរួចមក អង្គជំនុំជម្រះជឿជាក់ថា សមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្ដកម្ពុជាភាគច្រើន រួមទាំង នួន ជា ផងនោះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបញ្ជាឲ្យមានការវាយប្រហារជាក់លាក់នានា ដែលបានធ្វើឡើងនាពេលក្រោយមក។ អង្គជំនុំជម្រះទទួលយកការយល់ឃើញរបស់អ្នកជំនាញ Phillip SHORT ដែលបានលើកឡើងថា "វាមិនអាចទៅរួចនោះទេ ដែលមេបញ្ជាការភូមិភាគបានអនុវត្តប្រឆាំង ឬអនុវត្តផ្សេងក្រៅពីគោល

[២៧៩៤] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០, ២៤២-២៤៣។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨, ៥៨៨, ៥៩១-៥៩៩, ៦០៩, ៦១៧, ៦៣៣, ៦៣៧។

[២៧៩៥] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

[២៧៩៦] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០។

[២៧៩៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម។

[២៧៩៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៦។

នយោបាយដែលបានសម្រេចដោយមជ្ឈិមនោះ”[២៧៩៩]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ពិតជាកើតមានទំនាក់ទំនងតាមព្រឹត្តិហេតុ (*de facto*) រវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់រវាង នួន ជា ជាមួយនឹងលេខាភូមិភាគ និងមេបញ្ជាការយោធានៅក្នុង ខែ មេសា ឆ្នាំ ១៩៧៥។

៨៩៥. លើសពីនេះទៀត លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា សមាជិកបក្ស ឬ សាខាបក្សណាក៏ដោយដែលជំទាស់នឹងជំហរចាត់តាំងរបស់បក្ស បានរំលោភទៅនឹងវិន័យបក្ស និងត្រូវទទួលទណ្ឌកម្ម រួមទាំង ការដកចេញពីមុខនាទី និងការដកចេញពីជួរបក្ស[២៨០០]។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា ក្រៅពីទទួលខុសត្រូវលើការឃោសនា និងការអប់រំកម្មាភិបាល នួន ជា ក៏ត្រូវបានចាត់ឲ្យទទួលខុសត្រូវលើបញ្ហាវិន័យផងដែរ[២៨០១]។

៨៩៦. ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា យោងតាមស្មារតីនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងភារកិច្ចដែលបានចាត់តាំងឲ្យគាត់ទទួលខុសត្រូវនោះ នួន ជា មានអំណាចតាមផ្លូវច្បាប់ (*de jure*) និងតាមព្រឹត្តិហេតុ (*de facto*) ក្នុងការដាក់វិន័យដល់សមាជិកក្រោមបង្គាប់បក្ស និងយោធា។

### ១៥.៤.១.៥.២ បានដឹង ឬ មានហេតុផលដឹង

៨៩៧. ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះជឿជាក់ថា នួន ជា តាមរយៈតួនាទីដឹកនាំរបស់គាត់ បានដឹង ឬមានហេតុផលដឹងថា កងទ័ពខ្មែរក្រហមនឹងប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[២៨០២]។ ឧទាហរណ៍ នួន ជា បានដឹងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នឹងបណ្តាលឲ្យមានការកាប់សម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំក្នុងចំណោមនោះ រួមទាំង អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងដែរ[២៨០៣]។

### ១៥.៤.១.៥.៣ ការខកខានក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម

៨៩៨. ទោះបីជាមានភស្តុតាងដែលបង្ហាញអំពីការស្លាប់ ដែលបណ្តាលមកពីការផ្លាស់ទីលំនៅប្រជាជននៅមុនខែ មេសា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏ នួន ជា ខកខានក្នុងការចាត់វិធានការសមស្រប

---

[២៧៩៩] ប្រតិចារឹក ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ទំព័រ ១៤២។

[២៨០០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៥។

[២៨០១] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៨-៣២៩។

[២៨០២] *សូមមើល*ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់ នួន ជា កថាខណ្ឌ ៨៤២-៨៤៦។

[២៨០៣] *សូមមើល*ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់ នួន ជា កថាខណ្ឌ ៨៤២-៨៤៦។

ដើម្បីទប់ស្កាត់កុំឱ្យមានការស្លាប់ និងការកាប់សម្លាប់មនុស្សបន្ថែមទៀតនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ លើសពីនេះទៀត ទោះបីជាគាត់ខ្លួនឯងផ្ទាល់បានឃើញមនុស្សស្លាប់នៅក្នុងទីក្រុងភ្នំពេញដោយផ្ទាល់ភ្នែក[២៨០៤] និងបានដឹងថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេបន្តកំណត់ជាមុខសញ្ញា និងថែមទាំងត្រូវបានគេសម្លាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមកទៀតក៏ដោយ[២៨០៥] នួន ជា មិនបានស្នើសុំឱ្យមានការស៊ើបអង្កេត ឬ ដាក់ទណ្ឌកម្មនាពេលក្រោយមក លើកងទ័ពខ្មែរក្រហមចំពោះការកាប់សម្លាប់មនុស្សដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញនោះទេ។ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### **១៥.៤.២ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)**

#### **១៥.៤.២.១ ការរៀបចំផែនការ**

៨៩៩. អង្គជំនុំជម្រះជឿជាក់ថា នៅក្នុងពេលប្រជុំជាបន្តបន្ទាប់ចាប់ផ្ដើមពីចុងឆ្នាំ ១៩៧៥ និងបានបន្តពេញអំឡុងពេលពាក់ព័ន្ធនេះ នួន ជា រួមជាមួយនឹងអ្នកផ្សេងទៀត បានរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ

[២៨០៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់ នួន ជា កថាខណ្ឌ ៨៤៩។

[២៨០៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៧។ ចាប់ពីឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៨ នួន ជា ត្រូវបានកម្មាភិបាលភូមិភាគ តំបន់ និងស្រុក សរសេរចម្លងជូន ដោយបានរាយការណ៍ថា "អ្នកនៅសេសសល់" ផ្សេងទៀតពីរបបមុន រួមមានដូចជា កម្មាភិបាល ទាហាន ប៉ូលីស និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវបានកំណត់អត្តសញ្ញាណ ចាប់ខ្លួន និង/ឬ កំទេចចោលអស់ហើយ។

ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជន (ដំណាក់កាលទី២)។

៩០០. យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានជួបប្រជុំជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត អំពីគោលនយោបាយកសាង និងការពារប្រទេសដែលមានឯករាជ្យខ្លួនទីពឹងខ្លួន និងសង្គមនិយម[២៨០៦]។ ផែនការនេះមានគោលបំណងបង្កើតសង្គមគ្មានវណ្ណៈមួយ ដែលប្រជាជនគ្រប់គ្នានឹងត្រូវបានរៀបចំបញ្ចូលទៅក្នុងសហករណ៍ ដើម្បីការពារ និងកសាងប្រទេសឱ្យបានជឿនលឿន ដោយផ្ដោតជាពិសេសលើការបង្កបង្កើនផល និងគម្រោងធារាសាស្ត្រ[២៨០៧]។ ផែនការទាំងនេះ ពីដំបូង បានកើតចេញមកពី និងផ្អែកលើបទពិសោធន៍របស់បក្សនៅតាមតំបន់រំដោះ ដើម្បីផ្គត់ផ្គង់កម្លាំងមនុស្សដែលត្រូវការ ដើម្បីសម្រេចផែនការនេះ ហើយវិធីសាស្ត្រនៃការជម្លៀស និងផ្លាស់ទីលំនៅមានលក្ខណៈដូចៗគ្នា ពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តអនុវត្តក្រោយពីពេលនេះរហូតមក[២៨០៨]។ ទោះបីជាធ្លាប់មានបទពិសោធន៍ដូចនេះក៏ដោយ ក៏គ្មានភ័ស្តុតាងណាមួយបង្ហាញថា ផែនការនេះមានវិធានការនានាដែលផ្ដល់សុខុមាលភាពដល់ប្រជាជនដែលត្រូវបានជម្លៀស ឬ មានការយល់ព្រមពីប្រជាជនដែលនឹងត្រូវប្រមូលផ្ដុំទៅនៅសហករណ៍នោះឡើយ។ ដូច្នេះ ផែនការនេះបានប្រមើលឃើញថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

៩០១. នួន ជា បានចូលរួមជាមួយនឹងមេដឹកនាំសំខាន់ៗផ្សេងទៀតនៅក្នុងកិច្ចប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីផែនការរបស់ថ្នាក់ដឹកនាំក្នុងការសម្រេចឱ្យបាននូវបដិវត្តន៍សង្គមនិយម តាមរយៈការអនុវត្តសមូហភាវូបនីយកម្ម[២៨០៩] ដែលជាការរារាំងយ៉ាងពិតប្រាកដមិនឱ្យអ្នកដែលត្រូវបានផ្លាស់ទីលំនៅពីទីក្រុងភ្នំពេញ មានលទ្ធភាពវិលត្រឡប់មកផ្ទះសម្បែងរបស់ពួកគេវិញ ហើយបែរជាបន្តផ្លាស់ទីលំនៅពួកគេទៅកន្លែងផ្សេងទៀត។

៩០២. នៅចុងឆ្នាំ ១៩៧៥ នួន ជា រួមជាមួយនឹងអ្នកផ្សេងទៀត បានរួមគ្នាបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់អំពីការខ្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ ជា

---

[២៨០៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០។

[២៨០៧] សផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤២-៧៤៣។

[២៨០៨] សផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៦, ៧៩១-៧៩៤, ៨០០-៨០៣។

[២៨០៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៣។

ពិសេស ប៉ះពាល់លើ "ប្រជាជនថ្មី"។ ទោះបីជាយ៉ាងនេះក្ដី ផែនការនេះពាក់ព័ន្ធនឹងការបែងចែកកម្លាំងពលកម្មទៅតាមយុទ្ធសាស្ត្រដែលជាគោលដៅនៃការផលិតស្រូវរបស់បក្ស និងអាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងមានគោលបំណងពង្រីកសហករណ៍ និងផ្ដល់ការលើកទឹកចិត្តដល់ "ប្រជាជនចាស់" ដែលធ្វើឲ្យប៉ះពាល់ដល់ "ប្រជាជនថ្មី" ដែលស្ថិតនៅក្រោមការសង្ស័យ។ ក្រោយពេល គណៈកម្មាធិការអចិន្ត្រៃយ៍ បានចុះធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ (ដំណើរទស្សនកិច្ចដែលមានការចូលរួមពី នួន ជា ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីដំណើរទស្សនកិច្ចនេះ តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ) គណៈកម្មាធិការអចិន្ត្រៃយ៍ បានសម្រេចបែងចែកជាថ្មីដោយបញ្ជូនប្រជាជន ចំនួន ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់ បន្ថែមទៀតទៅឲ្យតំបន់នេះ[២៨១០]។ ថ្នាក់ដឹកនាំបក្សក៏បានរៀបចំផែនការ និងបានបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនចំនួន ២០.០០០ នាក់ ទៅកាន់ខេត្តព្រះវិហារ (តំបន់ ១០៣) និងប្រជាជនខ្លះទៀតទៅកាន់ខេត្តកំពង់ធំ (ភូមិភាគកណ្ដាល (ឧត្តរចាស់))[២៨១១]។ នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ គណៈ-កម្មាធិការមជ្ឈិម រួមទាំង នួន ជា ដែលជាសមាជិកពេញសិទ្ធិផងដែរនោះ បានឯកភាពគាំទ្រលើសេចក្ដីសម្រេចចុះខែ សីហា ឆ្នាំ ១៩៧៥[២៨១២]។ ថ្នាក់ដឹកនាំបក្សបានផ្សព្វផ្សាយឯកសារមួយដែលវិភាគអំពីការវិវត្តនៅក្នុងការអនុវត្តគោលនយោបាយកសិកម្មរបស់បក្ស កាលពី ៤ ទៅ ៥ ខែមុន និងបានគូសបញ្ជាក់ពីផែនការផ្លាស់ទីលំនៅប្រជាជនជាង ៥០០.០០០ នាក់ ទៅកាន់ភូមិភាគផ្សេងៗ ដើម្បីបំពេញតម្រូវការនៃការបង្កបង្កើនផលស្រូវ ហើយបានទទួលស្គាល់ថា ការខ្វះខាតថ្នាំសង្កូវ និងស្បៀងអាហារ បានប៉ះពាល់លើ "ប្រជាជនថ្មី" ជាពិសេស អ្នកដែលត្រូវបានជម្លៀសដោយបង្ខំមកពីទីក្រុងភ្នំពេញ[២៨១៣]។ ទោះបីជាបក្សមានបទពិសោធន៍ជាច្រើនចំពោះបញ្ហាធ្ងន់ធ្ងរមួយចំនួនដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំពីទីប្រជុំជន និងការផ្លាស់ទីលំនៅពីទីជនបទមួយទៅទីជនបទមួយទៀតក៏ដោយ ក៏គ្មានភស្តុតាងណាមួយបង្ហាញថា ផែនការដែលលេចជារូបរាងឡើងនៅចុងឆ្នាំ ១៩៧៥ នោះ រួមមានវិធានការនានាដែលមានការយល់ព្រមពីប្រជាជនដែលនឹងត្រូវជម្លៀស ឬវិធានការនានាដែលផ្ដល់សុខុមាលភាពដល់អ្នកទាំងនោះឡើយ។ អាស្រ័យហេតុនេះ

---

[២៨១០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៧៤៥។

[២៨១១] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦។

[២៨១២] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៩។

[២៨១៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨។

ផែនការនៅចុងឆ្នាំ ១៩៧៥ ក្នុងការធ្វើការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយទៅទីជនបទមួយទៀត បានប្រមើលឃើញថានឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជនក្នុងដំណាក់កាលទី២។

៩០៣. អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា គោលនយោបាយបក្សតម្រូវឲ្យយកខ្មាំងដែលជាប្រជាជននៅតាមខេត្ត-ក្រុង ឬ "ប្រជាជនថ្មី" ព្រមទាំង អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[២៨១៤] មកធ្វើការអប់រំកែប្រែ ឬកម្ទេចចោល[២៨១៥]។ បក្ស រួមទាំង នួន ជា ផងដែរនោះ មានចេតនាឲ្យគោលនយោបាយនេះត្រូវអនុវត្តមួយផ្នែកតាមរយៈការផ្លាស់ទីលំនៅប្រជាជន និងតាមរយៈការបង្កើតសហករណ៍ ដែលការធ្វើដូច្នេះ បក្សអាចកំណត់អត្តសញ្ញាណអ្នកដែលត្រូវបានចាត់ទុកជា "ខ្មាំង" បាន[២៨១៦]។

៩០៤. ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផងដែរនោះ បានរៀបចំផែនការ និងបង្កើតគោលនយោបាយ ដែលធ្វើឲ្យបក្សអាចកំណត់អត្តសញ្ញាណ "ខ្មាំង" និងអប់រំកែប្រែ ឬ ធ្វើឲ្យបាត់ខ្លួន។ អង្គជំនុំជម្រះជឿជាក់ទៀតថា ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផងដែរនោះ បានរៀបចំផែនការ និងបង្កើតគម្រោងផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២ នេះ។ ក្រោយពេលរៀបចំបង្កើតផែនការរួចហើយ ផែនការទាំងនេះត្រូវបានផ្សព្វផ្សាយតាមរយៈជួរបក្ស រួមទាំងនៅក្នុងឯកសារគោលនយោបាយ និង*ទស្សនាវដ្តីទង់បដិវត្ត* ផងដែរ[២៨១៧]។ មជ្ឈិមបក្ស រួមជាមួយនឹងកម្មាភិបាលភូមិភាគ តំបន់ និងស្រុក បានគ្រប់គ្រងមធ្យោបាយ និងវិធីសាស្ត្រនៃការដឹកជញ្ជូន[២៨១៨]។ ដូចមាននៅក្នុងផែនការ និងស្របតាមវិធីសាស្ត្រដែលធ្លាប់អនុវត្ត ប្រជាជនត្រូវបាន

[២៨១៤] *សូមមើលឧទាហរណ៍* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤-១១២, ១២០-១២៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៤-៨០៥។

[២៨១៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៧-១១៨។

[២៨១៦] *សូមមើល* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១១-១១២, ១១៨។

[២៨១៧] *សូមមើល* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧៤-២៨៨។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[២៨១៨] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨។

បញ្ជូនទៅតាមការដ្ឋានធ្វើការងារ និងទៅតាមតំបន់ដែលសន្មតថាដីមានជីជាតិបំផុត[២៨១៩]។ ដូច្នេះ តាមរយៈការអនុម័តិទៅលើផែនការក្នុងការផ្លាស់ទីលំនៅប្រជាជននៅជុំវិញប្រទេស និងការដឹងថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នឹងត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយកម្មាភិបាលថ្នាក់ក្រោម និងកងទ័ពខ្មែរក្រហមនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា កម្មាភិបាល និងកងទ័ពខ្មែរក្រហមនឹងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ដោយហេតុថាឧក្រិដ្ឋកម្មទាំងនេះបានឆ្លុះបញ្ចាំងអំពីការអនុវត្តគោលនយោបាយបក្ស ដូចនេះ ផែនការបក្សបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គល លើការរៀបចំផែនការក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

### ១៥.៤.២.២ ការបញ្ជា

៩០៥. ដូចបានលើកឡើងខាងលើ ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផងនោះ បានសម្រេចផ្លាស់ទីលំនៅប្រជាជន ដែលបានធ្វើឡើងពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ថ្នាក់ដឹកនាំក៏បានបង្កើតគោលនយោបាយដែលផ្ដល់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណ "ខ្មាំង" និងអប់រំកែប្រែ ឬធ្វើឲ្យបាត់ខ្លួន ហើយថ្នាក់ដឹកនាំបានគូសបញ្ជាក់ជាហូរហែអំពីសារៈសំខាន់នៃគោលការណ៍រក្សាការសម្ងាត់។ អង្គជំនុំជម្រះបានរកឃើញពីខាងលើរួចហើយថា នួន ជា ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើសេចក្ដីសម្រេចរបស់ថ្នាក់ដឹកនាំបក្ស ហើយសេចក្ដីសម្រេចទាំងនេះត្រូវបានផ្សព្វផ្សាយតាមរយៈឋានានុក្រមរដ្ឋបាល និងយោធា ហើយបន្ទាប់មកត្រូវបានអនុវត្តដោយកងទ័ពខ្មែរក្រហម[២៨២០]។ ការដែលកម្មាភិបាលថ្នាក់ក្រោមៗបានទទួលស្គាល់អំណាចតាមព្រឹត្តិហេតុ *(de facto)* និងសេចក្ដីសម្រេចរបស់ នួន ជា តាមរយៈមជ្ឈិមបក្ស និងបានអនុវត្តគោលនយោបាយផ្លាស់ទី

---

[២៨១៩] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤-៦២៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៨០០-៨០៣។

[២៨២០] *សូមមើល* ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨៤-៨៨៦, ៨៩៩-៩០៤។

លំនៅប្រជាជន និងកំណត់អត្តសញ្ញាណខ្មាំង បង្ហាញឲ្យឃើញថា សេចក្តីសម្រេចទាំងនេះគឺជាបញ្ជា។

៩០៦. នៅក្នុងការបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនដើម្បីបំពេញតម្រូវការបង្កបង្កើនផល និងដើម្បីសម្រួលដល់ការស្វែងរកខ្មាំង អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីភវនីយភាពច្បាស់លាស់ ដែលថា នឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

៩០៧. ការបញ្ជារបស់បក្សឲ្យជម្លៀសប្រជាជន និងការកំណត់អត្តសញ្ញាណខ្មាំង បានចូលរួមចំណែកយ៉ាងខ្លាំងក្លាដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មជាបន្តបន្ទាប់។ នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស[២៨២១] និងបានប្រើប្រាស់អំណាចនេះតាមផ្លូវច្បាប់ *(de jure)* និងតាមព្រឹត្តិហេតុ *(de facto)* លើកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមៗ ក្នុងការបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គល ដោយសារបានបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅទាំងនេះ។

### ១៥.៤.២.៣ ការញុះញង់

៩០៨. ដូចដែលបានបញ្ជាក់ពីពេលមុនរួចហើយថា ការញុះញង់តម្រូវថា អំពើរបស់ជនជាប់ចោទបានជំរុញ ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលមានន័យថា អំពើសកម្ម ឬអកម្មរបស់គាត់ *បានរួមចំណែកយ៉ាងសំខាន់* ដល់អំពើរបស់ចារីក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះបានយល់ឃើញថា នួន ជា បានរៀបចំផែនការរួមគ្នាជាមួយនឹងអ្នកផ្សេងទៀត ក្នុងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ហើយថា ផែនការនេះបានរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចធ្វើ

[២៨២១] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

សេចក្តីសម្រេចចុងក្រោយរបស់បក្ស និងបានប្រើប្រាស់អំណាចតាមផ្លូវច្បាប់ (*de jure*) និងតាមព្រឹត្តហេតុ (*de facto*) បង្គាប់ឲ្យកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេស ពាក់ព័ន្ធនឹងការអប់រំកម្មាភិបាលឲ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណចំពោះ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង។

ដូចបានលើកឡើងខាងលើ ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផងនោះ បានបង្កើតគោលនយោបាយដែលបានផ្តល់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណ "ខ្មាំង" និងអប់រំកែប្រែ ឬ ធ្វើឲ្យបាត់ខ្លួន ហើយថ្នាក់ដឹកនាំបានគូសបញ្ជាក់ជាហូរហែអំពីសារៈសំខាន់នៃគោលការណ៍រក្សាការសម្ងាត់។ អង្គជំនុំជម្រះជឿជាក់ថា ការចូលរួមរបស់ នួន ជា ជាមួយនឹងមេដឹកនាំដទៃទៀត នៅក្នុងការរៀបចំតាក់តែងគោលនយោបាយទាំងនេះ មានតាំងពីពេលមុនមកម្ល៉េះ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ លើសពីនេះទៀត ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះជឿជាក់ថា ការបណ្តុះបណ្តាល សេចក្តីថ្លែងការណ៍ និងការចូលរួមរបស់គាត់នៅក្នុងការចេញផ្សាយ *ទស្សនាវដ្តីទង់បដិវត្ត* ត្រូវបានកងទ័ព និងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម យល់ថាជាការជំរុញដោយផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា "ខ្មាំង"។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈអំពើរបស់គាត់ នួន ជា បានជម្រុញឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

៩០៩. ជាចុងក្រោយ ផ្អែកតាមសំអាងហេតុខាងលើពាក់ព័ន្ធនឹង "ការរៀបចំផែនការ"[២៨២២] អង្គ-ជំនុំជម្រះជឿជាក់ថា តាមរយៈការរៀបចំ និងបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជន នួន ជា មានចេតនា ឬ យ៉ាងហោចណាស់បានដឹងអំពីភវនីយភាពច្បាស់លាស់ថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងពេលអនុវត្តសេចក្តីណែនាំរបស់បក្ស។ ដូច្នេះអង្គជំនុំជម្រះជឿជាក់ថា នួន ជា ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន

[២៨២២] *សូមមើល* ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៩០២-៩០៥។

ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

### ១.៤.២.៤ ការជួយ និងជំរុញ

៩១០. អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រខាងផ្លូវចិត្តដល់ចារីនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ នៅក្នុងសម្ភារៈឯកសារសម្រាប់ឃោសនា និងវគ្គបំពាក់បំប៉ន នួន ជា បានផ្សព្វផ្សាយ អនុម័ត កោតសរសើរ និងជំរុញគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស ដែលបានផ្តល់យុទ្ធសាស្ត្រក្នុងការបែងចែកកម្លាំងការងារ និងការតស៊ូវណ្ណៈ[២៨២៣]។

៩១១. សកម្មភាពនេះមានឥទ្ធិពលខ្លាំងក្លាទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះជឿជាក់ថា សកម្មភាពនេះបានលើកទឹកចិត្តឲ្យកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមៗ និងកងទ័ព បំពេញភារកិច្ចយ៉ាងក្លៀវក្លានៅក្នុងការអនុវត្តគោលនយោបាយរបស់បក្ស។

៩១២. អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា នួន ជា បានដឹងថា សកម្មភាព និងការគាំទ្រទាំងឡាយរបស់គាត់ទៅលើគោលនយោបាយរបស់បក្សក្នុងការផ្លាស់ទីលំនៅប្រជាជន និងការកំណត់អត្តសញ្ញាណខ្មាំងវណ្ណៈ បានផ្តល់ជាហេតុផលស្របច្បាប់ និងបានបង្កើនការប្តេជ្ញាចិត្តរបស់កងទ័ព និងកម្មាភិបាលខ្មែរក្រហម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ តាមរយៈការគាំទ្ររបស់គាត់ទៅលើគោលបំណងរួម និងគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជន និងក្នុងការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា នួន ជា បានដឹងអំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្ម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងការជួយ និងជំរុញ ដល់ចារីឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

---

[២៨២៣] *សូមមើលឧទាហរណ៍* ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥-៣២៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨,៨១៨។

### ១៥.៤.២.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

#### ១៥.៤.២.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់

៩១៣. ភ័ស្តុតាងបានបង្ហាញឲ្យឃើញថា នួន ជា បានរក្សាទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងបានអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើកងទ័ពខ្មែរក្រហមនៅក្នុងអំឡុងពេលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១[២៨២៤]។ ដោយពិចារណាទៅលើតួនាទីជាន់ខ្ពស់របស់គាត់ក្នុងនាមជាអនុលេខាបក្ស និងទៅលើរចនាសម្ព័ន្ធរដ្ឋបាលដែលត្រូវបានបង្កើតឡើងតាមរយៈលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា នួន ជា មានអំណាចតាមផ្លូវច្បាប់ (*de jure*) លើបុគ្គលទាំងឡាយនៅក្នុងខ្សែសង្វាក់បញ្ជាដែលមាន។ លើសពីនេះទៀត ដោយពិចារណាលើខ្សែសង្វាក់នៃការរាយការណ៍ដ៏ច្បាស់លាស់ ដែលថ្នាក់ក្រោមបានផ្តល់ព័ត៌មានសង្ខេបដល់ថ្នាក់លើអំពីបញ្ហាសំខាន់ៗ និងស្នើសុំការណែនាំនោះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា ក៏បានអនុវត្តអំណាចតាមព្រឹត្តិហេតុ (*de facto*) លើកម្មាភិបាលខ្មែរក្រហមទាំងអស់ផងដែរ។

៩១៤. នៅពេលនេះ អង្គជំនុំជម្រះនឹងវាយតម្លៃទៅលើអំណាចរបស់ នួន ជា លើរចនាសម្ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា ដែលទើបតែរៀបចំថ្មីឡើងវិញ។ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ ក្រោយពីការច្របាច់បញ្ចូលរវាងកងទ័ពខ្មែរក្រហមទៅក្នុងកងទ័ពបដិវត្តន៍កម្ពុជារួចមក កងពលតូចនៃភូមិភាគជាច្រើនត្រូវបានដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម ជាពិសេស នៅក្រោមបញ្ជារបស់អគ្គសេនាធិការ ដែលដឹកនាំដោយ សុន សេន[២៨២៥]។ នៅពេលដែល សុន សេន បានទទួលព័ត៌មានអំពីកិច្ចការយោធា និងការការពារជាតិ គាត់ក៏បានរាយការណ៍សង្ខេបជូនគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់ក៏បានបញ្ជូនសារបន្ត និងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីមេបញ្ជាការយោធាផ្ញើជូនមេដឹកនាំផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួន ជា ផងដែរ ដោយមានចំណារជាលាយលក្ខណ៍អក្សរ និងស្នើសុំការណែនាំផ្សេងៗ[២៨២៦]។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានអនុម័តនៅក្នុងខែ មករា ឆ្នាំ ១៩៧៦ ក្នុងមហាសន្និបាតបក្សលើកទី ៤ បានចែងថា កងទ័ពបដិវត្តន៍កម្ពុជាចំណុះទាំងស្រុង និងស្ថិតនៅក្រោម "ការដឹកនាំផ្តាច់មុខ ដាច់

---

[២៨២៤] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៩៣-៨៩៦។

[២៨២៥] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០។

[២៨២៦] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៩៥។

ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា"[២៨២៧]។ តាមភ័ស្តុតាងទូរលេខដែលនៅសេសសល់មួយចំនួនពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨ ភូមិភាគមិនត្រឹមតែរាយការណ៍អំពីស្ថានការណ៍សមរភូមិ និងការវាយប្រយុទ្ធនៅតាមព្រំដែនជាមួយវៀតណាមជូនដល់ "អង្គការ" ឬ ថ្នាក់ដឹកនាំបក្ស និង ចម្លងជូន នួន ជា ប៉ុណ្ណោះទេ ភូមិភាគថែមទាំងស្នើសុំការណែនាំផងដែរ[២៨២៨]។ ដូច្នេះ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា បក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួន ជា ផងដែរ បានរក្សាទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងបានបន្តអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព លើរចនាសម្ព័ន្ធកងទ័ពខ្មែរក្រហមដែលទើបតែបានរៀបចំថ្មីឡើងវិញ ដែលមានឈ្មោះថា កងទ័ពបដិវត្តន៍កម្ពុជា ក្រោយខែ កក្កដា ឆ្នាំ ១៩៧៥។

### ១៥.៤.២.៥.២ បានដឹង ឬ មានហេតុផលដឹង

៩១៥. ដូចបានគូសបញ្ជាក់ខាងលើ[២៨២៩] អង្គជំនុំជម្រះជឿជាក់ថា នួន ជា តាមរយៈតួនាទីជាមេដឹកនាំជាន់ខ្ពស់របស់គាត់ បានដឹង ឬ មានហេតុផលដឹងថា កងទ័ពខ្មែរក្រហមនឹងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ លើសពីនេះទៀត ការដឹងរបស់គាត់ថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ក៏ធ្វើឲ្យ នួន ជា បានទទួលការជូនដំណឹងដែរថា ឧក្រិដ្ឋកម្មទាំងឡាយនឹងត្រូវប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលក្រោយៗមកទៀត។

### ១៥.៤.២.៥.៣ ការខកខានក្នុងការទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម

[២៨២៧] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤១។

[២៨២៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៧។

[២៨២៩] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៤២-៨៤៦។ *សូមមើលផងដែរ*ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៩៧។

៩១៦. ទោះបីជាបានដឹងដូច្នេះក៏ដោយ ក៏ នួន ជា បានខកខានក្នុងការចាត់វិធានការសមស្របក្នុងការទប់ស្កាត់ដើម្បីកុំឲ្យឧក្រិដ្ឋកម្មផ្សេងទៀត ត្រូវបានប្រព្រឹត្តឡើងដោយកងទ័ព និងកម្មាភិបាលខ្មែរក្រហម នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលក្រោយៗមកទៀត។ នួន ជា មិនបានស្នើសុំឲ្យមានការស៊ើបអង្កេត ឬ ដាក់ទណ្ឌកម្មចំពោះចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនានា ក្រោយពីពេលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះឡើយ។

៩១៧. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ព និង កម្មាភិបាលខ្មែរក្រហម នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដែលបានចាប់ផ្តើមអនុវត្តចាប់ពីចុងឆ្នាំ ១៩៧៥ មកនោះ។

### ១៥.៤.៣ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ

#### ១៥.៤.៣.១ ការរៀបចំផែនការ

៩១៨. គ្រប់ពេលក្នុងអំឡុងបដិវត្តន៍ប្រជាធិបតេយ្យ អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរត្រូវបានគេកំណត់មុខសញ្ញាសម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន ក្រោយពេលពួកគេបានចុះចាញ់ ឬ បានក្លាយជា *ទាហានដែលបោះបង់ការប្រយុទ្ធ*[២៨៣០]។ គោលនយោបាយនេះបានឯកភាពដោយមេដឹកនាំបក្ស។ ជាការពិត នៅត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ គោលនយោបាយនេះជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន ដោយការផ្លាស់ទីលំនៅប្រជាជនទៅតាមសហករណ៍បានជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ និងការកម្ចាត់ភ្នាក់ងាររដ្ឋាភិបាលគិញ និងភ្នាក់ងារសន្តិនិយម[២៨៣១]។ នៅក្នុងពេលប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ គណៈកម្មាធិការមជ្ឈិម រួមទាំង នួន ជា ផងដែរ បានសម្រេចទៅលើផែនការវាយសម្រុកចុងក្រោយដើម្បីរំដោះ

---

[២៨៣០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២៧។

[២៨៣១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៨។

ប្រទេស[២៨៣២]។ បទពិសោធន៍មុនៗ ជាពិសេស នៅឧត្តុង្គ ដែលអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានយកទៅសម្លាប់ជាទ្រង់ទ្រាយធំនោះ ត្រូវបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំនេះ និងបាន បង្កើតជាមូលដ្ឋានសម្រាប់ផែនការក្នុងការសម្លាប់អ្នកទាំងនោះ។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ផែនការនេះបានប្រមើលឃើញថានឹងមានការចាប់ខ្លួន ការកាប់សម្លាប់ និងការបាត់ខ្លួនអ្នករដ្ឋការ នៃរបបសាធារណរដ្ឋខ្មែរ រួមជាមួយនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជនផង ដែរ[២៨៣៣]។ នៅក្នុងអំឡុងពេលប្រជុំរបស់មេដឹកនាំជាន់ខ្ពស់នាដើមខែ មេសា ឆ្នាំ ១៩៧៥ ដែល នួន ជា មានវត្តមាន និងបានចូលរួមផងដែរនោះ បានសម្រេចយកផែនការវាយសម្រុកចុងក្រោយ នេះ[២៨៣៤]។

៩១៩. អង្គជំនុំជម្រះបានសម្រេចរួចហើយថា មេដឹកនាំជាន់ខ្ពស់ ដូចជា នួន ជា និង ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ថា ឧក្រិដ្ឋកម្មនានានឹងកើតមានក្នុងទ្រង់ទ្រាយធំចេញពីគោល នយោបាយដែលមានមូលដ្ឋានពីគោលការណ៍រក្សាការសម្ងាត់ ចេញពីការបំពាក់បំប៉នផ្នែកមនោគមន៍ វិជ្ជាយ៉ាងតឹងរ៉ឹងលើកសិករដែលគ្មានការអប់រំអំពីការតស៊ូវណ្ណៈ រួមទាំងការកំណត់អត្តសញ្ញាណលើ គ្រប់ "ប្រជាជនថ្មី" ទាំងអស់ និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ថាជាខ្មាំង និងចេញមក ពីគោលដៅនៃការទាមទារឲ្យបាននូវឯករាជ្យជាតិ ទោះជាត្រូវចំណាយអ្វីក៏ដោយ[២៨៣៥]។ ផែនការ ដែលត្រូវបានឯកភាពពាក់ព័ន្ធនឹងការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវ បានអនុវត្តស្របតាមគោលនយោបាយ និងដើម្បីសម្រេចបាននូវគោលនយោបាយទាំងនេះ[២៨៣៦]។ អង្គជំនុំជម្រះយល់ឃើញថា ជាទូទៅ ផែនការទាំងនេះមានភាពចាំបាច់ពាក់ព័ន្ធនឹងការប្រមើលឃើញ ថា ឧក្រិដ្ឋកម្មនានានឹងត្រូវបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ រួមទាំង នៅទួលពោធិ៍ជ្រៃផងដែរ។

៩២០. ផែនការនេះបានកើតឡើងមុនពេលប្រព្រឹត្ត និងបានចូលរួមចំណែកយ៉ាងខ្លាំងក្លាដល់ការ ប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ ផែនការនេះត្រូវបានផ្សព្វផ្សាយតាមរយៈខ្សែសង្វាក់បញ្ជា

---

[២៨៣២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣០-១៣៨។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៨-៨៧៩។

[២៨៣៣] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៨-៨៧៩។

[២៨៣៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៥។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨០-៨៨២។

[២៨៣៥] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៤២-៨៤៦។

[២៨៣៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣៥-៨៣៧។

ដោយអ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំក្នុងអំឡុងពីខែ មិថុនា ឆ្នាំ ១៩៧៤ ដល់ខែ មេសា ឆ្នាំ ១៩៧៥[២៨៣៧]។ ប៉ុន្មានថ្ងៃក្រោយថ្ងៃរំដោះខេត្តពោធិ៍សាត់ ដែលអង្គជំនុំជម្រះបានរកឃើញថាបានកើតឡើងមិនយូរប៉ុន្មានក្រោយថ្ងៃរំដោះក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គណៈ-កម្មាធិការភូមិភាគពាយ័ព្យ ដែលបានដឹកនាំដោយលេខាភូមិភាគ រស់ ញឹម បានបញ្ជាឲ្យប្រមូលផ្តុំ និងកាប់សម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងខេត្តពោធិ៍សាត់[២៨៣៨]។ បញ្ជានេះស្របទៅនឹងផែនការវាយសម្រុកចុងក្រោយ និងវិធីសាស្ត្រអនុវត្តដែលបានប្រព្រឹត្តនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តអនុវត្តនាពេលក្រោយៗមកទៀត[២៨៣៩]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា បញ្ជានេះត្រូវបានធ្វើឡើងតាមផែនការដែលត្រូវបានសម្រេចនៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ និងបានសម្រេចម្តងទៀតនៅក្នុងកិច្ចប្រជុំក្នុងខែ មេសា ឆ្នាំ ១៩៧៥។ ក្រោយពេលចេញបញ្ជានេះ កម្មាភិបាលខ្មែរក្រហម ដែលបំពេញភារកិច្ចក្រោមអំណាចរបស់គណៈកម្មាធិការភូមិភាគពាយ័ព្យ និងលេខាភូមិភាគ រស់ ញឹម បានចាប់ផ្តើមប្រមូលផ្តុំអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប្រហែលជានៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយមកប្រហែលជានៅថ្ងៃទី ២៥ ឬ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៥ ដោយបញ្ជូនអ្នកទាំងនោះទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់ចោល[២៨៤០]។

៩២១. អង្គជំនុំជម្រះបានសម្រេចរួចហើយថា នួន ជា បានដឹងអំពីភវនីយភាពច្បាស់លាស់ថានឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា រួមទាំងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃផងដែរ[២៨៤១]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការរៀបចំផែនការវាយសម្រុកចុងក្រោយដើម្បីរំដោះប្រទេស នួន ជា មានចេតនា ឬបានដឹងអំពីភវនីយភាពច្បាស់លាស់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះក្រោយពេលអនុវត្តផែនការនេះ។

៩២២. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើ

[២៨៣៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤១, ១៤៨។

[២៨៣៨] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦៣-៦៦៦។

[២៨៣៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨០-៨៣៤។

[២៨៤០] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦៧-៦៨១។

[២៨៤១] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៤៦។

មនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

### ១៥.៤.៣.២ ការបញ្ជា

៩២៣. ដូចដែលបានលើកឡើងពីខាងលើ[២៨៤២] នួន ជា មានអំណាចតាមព្រឹត្តិហេតុ (*de facto*) និងតាមផ្លូវច្បាប់ (*de jure*) ទៅលើកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម។ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានប្រើសិទ្ធិអំណាចនេះ ដើម្បីបញ្ជាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ នៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ គណៈកម្មាធិការមជ្ឈិម ដែលរួមទាំង នួន ជា បានអនុម័តផែនការមួយក្នុងការវាយសម្រុកចុងក្រោយ ដើម្បីរំដោះប្រទេស ហើយដូចដែលបានបង្ហាញពីខាងលើ ផែនការនេះបានប្រមើលឃើញថា នឹងមានការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងមានការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជនផងដែរ[២៨៤៣]។ អ្នកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ត្រូវបានបង្គាប់ឲ្យផ្សព្វផ្សាយព័ត៌មានអំពីការសម្រេចនេះទៅកាន់ភូមិភាគនានាដែលពួកគេមានសមត្ថកិច្ច បន្ទាប់ពីការប្រជុំបានបញ្ចប់[២៨៤៤]។ នៅក្នុងការប្រជុំក្រោយៗមកទៀត ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ នៅដើមខែ មេសា ឆ្នាំ ១៩៧៥ នួន ជា ក៏មានវត្តមាន និងបានចូលរួមក្នុងការសម្រេចលើផែនការវាយសម្រុកចុងក្រោយផងដែរ[២៨៤៥] បញ្ជាត្រូវបានគេបញ្ជូនជាថ្មីម្តងទៀតទៅមេបញ្ជាការកងទ័ពដើម្បីអនុវត្ត[២៨៤៦]។ នៅខែ មេសា ឆ្នាំ ១៩៧៥ គណៈភូមិភាគពាយ័ព្យ ដែលដឹកនាំដោយលេខាភូមិភាគ រស់ ញឹម បានបញ្ជាឲ្យប្រមូលផ្តុំ និងសម្លាប់អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនៅក្នុងខេត្តពោធិ៍សាត់ ដែលនេះគឺជាផ្នែកមួយនៃការផ្សព្វ-ផ្សាយបញ្ជាតាមរយៈឋានានុក្រម។ នៅក្នុងការអនុវត្តតាមបញ្ជានេះ កម្មាភិបាលខ្មែរក្រហម ដែលបំពេញភារកិច្ចក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការភូមិភាគពាយ័ព្យ និងលេខាភូមិភាគ រស់ ញឹម បានចាប់ផ្តើមប្រមូលផ្តុំអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រហែលជានៅថ្ងៃទី ២៤ ខែ

---

[២៨៤២] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៤៦។

[២៨៤៣] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៨-៨៨៣, ៩១៨-៩២២។

[២៨៤៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤១។

[២៨៤៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៦។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨០។

[២៨៤៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៥១។

មេសា ឆ្នាំ ១៩៧៥ ហើយក្រោយមកទៀតនៅថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥ ដោយបញ្ជូនអ្នកទាំងនោះទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់ចោល[២៨៤៧]។

៩២៤. នួន ជា រួមជាមួយនឹង ប៉ុល ពត បានប្រើប្រាស់សិទ្ធិអំណាចចុងក្រោយក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមបក្ស[២៨៤៨] ព្រមទាំងប្រើប្រាស់សិទ្ធិអំណាចនេះ តាមព្រឹត្តិហេតុ (*de facto*) និងតាមផ្លូវច្បាប់ (*de jure*) ទៅលើកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ដើម្បីបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះជឿជាក់ថា សេចក្តីសម្រេច និងសេចក្តីណែនាំរបស់ថ្នាក់ដឹកនាំ គឺជាបញ្ជាដែលត្រូវបានអនុវត្ត[២៨៤៩] ហើយ កម្មាភិបាលថ្នាក់ក្រោមទទួលស្គាល់នូវសិទ្ធិអំណាច និងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា។ ការបញ្ជាទាំងនេះត្រូវបានធ្វើឡើងពីពេលមុន ហើយរួមចំណែកយ៉ាងខ្លាំងក្លាដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

៩២៥. ផ្អែកលើសំអាងហេតុដូចបានរៀបរាប់ខាងលើពាក់ព័ន្ធនឹង "ការរៀបចំផែនការ"[២៨៥០] អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការបញ្ជាឲ្យវាយសម្រុកចុងក្រោយនេះ នួន ជា មានបំណង ឬយ៉ាងហោចណាស់ក៏បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តនៅពេលអនុវត្តសេចក្តីណែនាំរបស់បក្ស។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ។

---

[២៨៤៧] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦៧-៦៨១។

[២៨៤៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

[២៨៤៩] ច្បាស់លាស់ណាស់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានពិចារណាដូចគ្នា។ សូមមើល *ទស្សនាវដ្តីទង់បដិវត្ត*, ឯកសារ E3/193, ចុះខែ សីហា ឆ្នាំ ១៩៧៧, ទំព័រ ២, ERN (ភាសាខ្មែរ) 00062948 (នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៧៧ នៅក្នុងសន្និសីទកម្មាភិបាលភូមិភាគបញ្ចឹម តំណាងរបស់មជ្ឈឹមបក្សបាន "ឧទ្ទេសនាមអំពីសេចក្តីណែនាំរបស់បក្ស លើបញ្ហាមួយចំនួនសំខាន់ៗ" សម្រាប់អនុវត្តក្នុងឆមាសទីពីរ ឆ្នាំ ១៩៧៧)។

[២៨៥០] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៩១៨-៩២២។

### ១៥.៤.៣.៣ ការញុះញង់

៩២៦. អង្គជំនុំជម្រះបានរកឃើញថា នួន ជា បានរៀបចំផែនការរួមគ្នាក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ដែលគាត់បានរួមចំណែកនៅក្នុងការអនុម័ត និងផ្សព្វផ្សាយនូវគោលនយោបាយទាំងនេះ ក្នុងគោលបំណងដាក់ចូលនូវវិធានការជាក់លាក់ប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយថា ផែនការនេះបានចូលរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា។ អង្គជំនុំជម្រះក៏បានរកឃើញថា នួន ជា រួមជាមួយនឹង ប៉ុល ពត បានអនុវត្តអំណាចធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស និងបានប្រើប្រាស់អំណាចតាមផ្លូវច្បាប់ (*de jure*) និងអំណាចតាមព្រឹត្តិហេតុ (*de facto*) បង្គាប់ឲ្យកម្មាភិបាល និងកងទ័ពខ្មែរក្រហមថ្នាក់ក្រោមប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ។ នួន ជា បានដើរតួនាទីនាំមុខនៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់កម្មាភិបាល និងកងទ័ពខ្មែរក្រហម ជាពិសេសនៅក្នុងការអប់រំកម្មាភិបាលឲ្យរក្សាការប្រុងប្រយ័ត្នចំពោះខ្មាំង និងនៅក្នុងការបំពាក់បំប៉នយ៉ាងច្បាស់លាស់ដល់កសិករអំពីការតស៊ូវណ្ណៈ ដែលរួមទាំងការកំណត់អត្តសញ្ញាណចំពោះ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង។ ដូចបានលើកឡើងខាងលើ ថ្នាក់ដឹកនាំ រួមទាំង នួន ជា ផង នោះ បានបង្កើតគោលនយោបាយដែលបាន ផ្ដល់លទ្ធភាពឲ្យមានការកំណត់អត្តសញ្ញាណ "ខ្មាំង" និងអប់រំកែប្រែ ឬធ្វើឲ្យបាត់ខ្លួន ហើយថ្នាក់ដឹកនាំបានបញ្ជាក់ជាហូរហែអំពីសារៈសំខាន់នៃគោលការណ៍នៃការរក្សាការសម្ងាត់។ អង្គជំនុំជម្រះជឿជាក់ថា ការចូលរួមរបស់ នួន ជា ជាមួយនឹងមេដឹកនាំដទៃទៀត នៅក្នុងការរៀបចំតាក់តែងគោលនយោបាយទាំងនេះមានតាំងពីពេលមុនមកម្ល៉េះ ហើយបានរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅទួលពោធិ៍ជ្រៃ។ លើសពីនេះទៀត ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះជឿជាក់ថា ការបណ្ដុះបណ្ដាលសេចក្ដីថ្លែងការណ៍ និងការចូលរួមរបស់គាត់នៅក្នុងការចេញផ្សាយ *ទស្សនាវដ្ដីទង់បដិវត្ត* ត្រូវបានកងទ័ព និង កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមយល់ថា ជាការជំរុញដោយផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានាប្រឆាំងនឹងអ្នកទាំងឡាយដែលត្រូវបានចាត់ទុកថាជា "ខ្មាំង" ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈអំពើរបស់គាត់ នួន ជា បានជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅទួលពោធិ៍ជ្រៃ ដោយហេតុថា តាមរយៈការចូលរួមរបស់គាត់ផ្ទាល់នេះហើយ ទើបគាត់បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះអំពើរបស់ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់។ ដូចដែលបានលើកឡើងខាងលើ ថ្នាក់ដឹកនាំបក្ស រួមទាំង នួន ជា បានរៀបចំ និងបញ្ជាឲ្យមានការវាយសម្រុកចុងក្រោយដើម្បី

រំដោះប្រទេស ដូចដែលបានគូសបញ្ជាក់ខាងលើ ហើយផែនការនេះបានប្រមើលឃើញថា នឹងមានការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីតំបន់ទីប្រជុំជននានាផងដែរ[២៨៥១]។ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈតួនាទីរបស់គាត់ក្នុងការបង្កើតសេចក្ដីសម្រេចរបស់ថ្នាក់ដឹកនាំបក្ស ដែលត្រូវបានផ្សព្វផ្សាយបន្តតាមរយៈឋានានុក្រមរដ្ឋបាល និងកងទ័ព ហើយបន្ទាប់មកត្រូវអនុវត្តដោយកងទ័ពខ្មែរក្រហមនោះ នួន ជា បានជម្រុញ ឬញុះញង់ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅទួលពោធិ៍ជ្រៃ។

៩២៧. ផ្អែកតាមសំអាងហេតុដូចបានបញ្ជាក់ខាងលើពាក់ព័ន្ធនឹង "ការរៀបចំផែនការ"[២៨៥២] អង្គជំនុំ-ជម្រះជឿជាក់ថា តាមរយៈការបញ្ជាឲ្យវាយសម្រុកចុងក្រោយនោះ នួន ជា មានបំណង ឬ យ៉ាងហោចណាស់ក៏បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តនៅពេលអនុវត្តសេចក្ដីណែនាំរបស់បក្ស។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការញុះញង់ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

### ១៥.៤.៣.៤ ការជួយ និងជំរុញ

៩២៨. អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានផ្ដល់ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្តដល់ចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្តនេះ បានស្ដែងឲ្យឃើញតាមរយៈការចូលរួមរបស់គាត់ នៅក្នុងការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងការវាយសម្រុកចុងក្រោយដើម្បីរំដោះប្រទេស ដូចដែលបានគូសបញ្ជាក់ខាងលើ ហើយបានប្រមើលឃើញថា នឹងមានការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីប្រជុំជននានាផងដែរ។ លើសពីនេះទៀត គាត់បានផ្ដល់ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្តដល់ចារី តាមរយៈតួនាទីរបស់គាត់ ទាំងនៅមុនពេល និងនៅក្រោយពេលមានឧក្រិដ្ឋកម្ម នៅក្នុងឯកសារសម្ភារៈសម្រាប់ឃោសនា និងនៅក្នុងវគ្គសិក្សារៀន

---

[២៨៥១] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៨-៨៨៣, ៩១៨-៩២២។

[២៨៥២] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៩១៨-៩២២។

ស្នូត្រ ការជំរុញឲ្យកំណត់អត្តសញ្ញាណមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការបោសសម្អាតអ្នកទាំងនោះ[២៨៥៣]។

៩២៩. ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្តរបស់ នួន ជា មានឥទ្ធិពលខ្លាំងក្លាដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ ពាក្យសម្ដី និងសកម្មភាពរបស់ នួន ជា ក្នុងការផ្សព្វផ្សាយ និងការជំរុញដល់ការអនុវត្តគោលនយោបាយ បានជំរុញឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្ម។ លើសពីនេះទៀត ការអនុម័តរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើគោលនយោបាយ បានផ្តល់ហេតុផលសមស្រប ដែលជួយសម្រួលដល់ការសម្រេចឲ្យបាននូវឧក្រិដ្ឋកម្មទាំងនេះ។ ដោយរម្លឹកឡើងវិញថា ការប្រព្រឹត្តនៅមុនថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធនឹងការបោសសម្អាតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ ត្រូវតែយកមកពិចារណានៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ។ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីជាឯកសារសម្ភារៈសម្រាប់ឃោសនាទាំងនោះ មិនបានញែកពីគ្នារវាងទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ឯកសារសម្ភារៈទាំងអស់នោះបានលើកទឹកចិត្តដល់កងទ័ពដែលកំពុងជាប់ប្រយុទ្ធ រួមទាំងការកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងដែរ។

៩៣០. ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គាត់នៅក្រោយហេតុការណ៍នេះ អង្គជំនុំជម្រះជឿជាក់ថា គោលនយោបាយក្នុងការកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានតាំងពីពេលមុន ហើយតួនាទីរបស់ នួន ជា ក្នុងការបណ្តុះបណ្តាល និងឃោសនា ក៏មានតាំងពីពេលមុនមកដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ចារីបានរំពឹង និងបានប្រមើលឃើញថា នួន ជា នឹងបន្តធ្វើយុត្តិកម្ម លើកទឹកចិត្ត និងស្វែងរកនូវការគាំទ្របន្ថែមដល់បដិវត្ត តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការឃោសនា និងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជា។ ហេតុដូច្នេះ ការធ្វើបែបនេះគឺជាការជំរុញដល់ចារី ដែលសម្រួល និងមានឥទ្ធិពលខ្លាំងក្លាដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

៩៣១. អង្គជំនុំជម្រះបានរកឃើញរួចមកហើយថា នួន ជា មិនត្រឹមតែដឹងថា ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការជម្លៀសដំណាក់កាលទី១ អាចនឹងត្រូវបានប្រព្រឹត្តឡើងនោះទេ ប៉ុន្តែគាត់មានបំណងធ្វើឲ្យមានឧក្រិដ្ឋកម្មទាំងនេះទៀតផង។ គាត់ក៏បានដឹងអំពីវិធីសាស្ត្រដដែលក្នុងការសម្លាប់ដែលមានពីពេលមុន ក្នុងអំឡុងពេល និងក្រោយពេលមានឧក្រិដ្ឋកម្មនៅទួល

[២៨៥៣] *សូមមើលឧទាហរណ៍*ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៨៩-៩២៨។

ពោធិ៍ជ្រៃផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងការជួយ និងជំរុញ ដល់ចារីឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅទួលពោធិ៍ជ្រៃ។

### ១៥.៤.៣.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

៩៣២. អង្គជំនុំជម្រះយល់ឃើញថាមានភ័ស្តុតាងបញ្ជាក់ថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម នៅក្រោមបញ្ជារបស់គណៈកម្មាធិការភូមិភាគពាយ័ព្យ បានប្រព្រឹត្តការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅទួលពោធិជ្រៃ។

#### ១៥.៤.៣.៥.១ ទំនាក់ទំនងរវាងថ្នាក់លើ នឹងអ្នកនៅក្រោមបង្គាប់

៩៣៣. មានភ័ស្តុតាងបង្ហាញថា នួន ជា មានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងមានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើកងទ័ពខ្មែរក្រហម និងលេខាភូមិភាគ នៅពេលចូលកាន់កាប់ទីក្រុងភ្នំពេញ[២៨៥៤]។ អង្គជំនុំជម្រះជឿជាក់ថា ការវិភាគនេះអាចធ្វើឡើងដូចគ្នាជាមួយនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ ដែលបានកើតមាននៅភូមិភាគពាយ័ព្យ នៅប៉ុន្មានថ្ងៃក្រោយការចូលកាន់កាប់ទីក្រុងភ្នំពេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគពាយ័ព្យ ឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម។ អង្គជំនុំជម្រះកត់សម្គាល់ថា នួន ជា និង រស់ ញឹម មានទំនាក់ទំនងការងារជាប់រហូតតាំងពីយូរមកហើយនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ រស់ ញឹម គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម ហើយគាត់បានចូលរួមក្នុងមហាសន្និបាតបក្សលើកទី២ និងលើកទី៣ ជាមួយ នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដែលធ្វើឡើងនៅក្នុងឆ្នាំ ១៩៦៣ និងក្នុងឆ្នាំ ១៩៧១[២៨៥៥]។ នួន ជា បានទៅជួប រស់ ញឹម នៅសំឡូតជាច្រើនលើក[២៨៥៦] ហើយ រស់ ញឹម មានវត្តមាននៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួម

[២៨៥៤] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៩៣-៨៩៦។

[២៨៥៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៨៩, ៩៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៧, ៧៣៣។

[២៨៥៦] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ៣០៩។

ទាំង នួន ជា ផងនោះ បានសម្រេចឲ្យមានការផ្លាស់ទីលំនៅប្រជាជនឲ្យអស់ចេញពីទីក្រុងនានា រួមទាំងទីក្រុងភ្នំពេញ នៅពេលរំដោះប្រទេសបាន[២៨៥៧]។

៩៣៤. ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រស់ ញឹម និងលេខាភូមិភាគដទៃទៀត បានចូលរួមនៅក្នុងកិច្ចប្រជុំជាទៀងទាត់ជាមួយអ្នកដទៃទៀត ជាអាទិ នួន ជា ផង ដើម្បីពិភាក្សាពីការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[២៨៥៨] រួមទាំងនៅក្នុងកិច្ចប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នៅព្រះវិហារព្រះកែវមរកត[២៨៥៩]។ បន្ទាប់ពីពេលនោះមក គ្រប់ពេលនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានធ្វើដំណើរទៅខេត្តបាត់ដំបង ៣ ទៅ ៤ ខែម្តង ដើម្បីជួប រស់ ញឹម[២៨៦០] ដែលមានតួនាទីកិត្តិយសជាអនុប្រធានទីពីរនៃគណៈប្រធានរដ្ឋ ដើម្បីបង្ហាញពីការជឿទុកចិត្តដែលមជ្ឈិមបក្សមានចំពោះគាត់[២៨៦១]។ រស់ ញឹម ក៏ធ្វើដំណើរមកភ្នំពេញ "ជាទៀងទាត់" ដើម្បីជួបជាមួយថ្នាក់ដឹកនាំបក្ស រួមទាំង នួន ជា ផងដែរ[២៨៦២]។ ទូរលេខដែលនៅសេសសល់ ហើយមាននៅចំពោះមុខអង្គជំនុំជម្រះ ដែលចេញពី រស់ ញឹម ទៅកាន់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានរាយការណ៍ជាទៀងទាត់ពីខ្លាំងផ្ទៃក្នុង[២៨៦៣] និងបានស្នើសុំយោបល់ ឬការណែនាំផងដែរ[២៨៦៤]។ ទោះបីជាទូរលេខទាំងនេះមានកាលបរិច្ឆេទក្រោយហេតុការណ៍នៅទួលពោធិ៍ជ្រៃយូរក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ទូរលេខទាំងនេះបង្ហាញថា នួន ជា បានប្រើប្រាស់សិទ្ធអំណាចតាមព្រឹត្តិហេតុ (*de facto*) ទៅលើ រស់ ញឹម។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ពិតជាមានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ រវាង រស់ ញឹម នៅក្នុងតួនាទីជាលេខាភូមិភាគពាយ័ព្យ ជាមួយនឹងសមាជិកមជ្ឈិមបក្ស រួមទាំង នួន ជា នោះ គឺមានចាប់តាំងពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទៅទៀត។

---

[២៨៥៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣។ ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៣៥ ជើងទំព័រ ១០១៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥។

[២៨៥៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០។

[២៨៥៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៣។

[២៨៦០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៧៧៣។ *សូមមើលផងដែរ* ប្រតិចារិកចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ (សួត្រ ទៀង), ទំព័រ ៥៨, ៦៧។

[២៨៦១] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ៣០៩។

[២៨៦២] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧២។

[២៨៦៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៣។

[២៨៦៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៣។

### ១៥.៤.៣.៥.២ បានដឹង ឬ មានហេតុផលដឹង

៩៣៥. មេធាវីការពារក្តី នួន ជា បានលើកឡើងថា មិនមានភស្តុតាងបង្ហាញថា នួន ជា ទទួលបានការជូនដំណឹងអំពីហេតុការណ៍នៅទួលពោធិ៍ជ្រៃនោះទេ[២៨៦៥] ប៉ុន្តែក្រោយមក បានទទួលស្គាល់ថា "នួន ជា ចាំថាទទួលបានរបាយការណ៍ដែលមិនបានបញ្ជាក់ថា ការសម្លាប់អាចកើតមានឡើងនោះទេ"[២៨៦៦]។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា នួន ជា មិនដឹងច្បាស់លាស់ពីហេតុការណ៍នៅទួលពោធិ៍ជ្រៃក៏ដោយ ក៏មិនមានលក្ខខណ្ឌតម្រូវថា ជនជាប់ចោទត្រូវតែដឹងពីឧក្រិដ្ឋកម្មជាក់លាក់របស់អ្នកនៅក្រោមបង្គាប់ខ្លួន ដើម្បីឲ្យជនជាប់ចោទទទួលខុសត្រូវក្នុងនាមជាថ្នាក់លើនោះឡើយ។ ការទទួលខុសត្រូវរបស់ជនជាប់ចោទកើតមានឡើង នៅពេលដែលគាត់បានដឹង ឬមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់បានចូលរួម កំពុងចូលរួម ឬបម្រុងនឹងចូលរួមនៅក្នុងអំពើឧក្រិដ្ឋ[២៨៦៧]។

៩៣៦. អង្គជំនុំជម្រះយល់ឃើញថា តាមរយៈតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់គាត់ នួន ជា បានដឹងតាមរយៈបទពិសោធន៍កន្លងមកថា កងទ័ពខ្មែរក្រហមដែលចូលរួមនៅក្នុងការរំដោះទីក្រុង/ទីប្រជុំជន ក្នុងបណ្តាឆ្នាំកន្លងមកមុនខែ មេសា ឆ្នាំ ១៩៧៥ បានសម្លាប់ក្នុងទ្រង់ទ្រាយធំទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយសារតែអ្នកទាំងនោះត្រូវបានគេចាត់ទុកថាជាខ្មាំង[២៨៦៨]។ ដោយពិចារណាទៅលើតួនាទីរបស់គាត់ ក្នុងការបង្កើតគោលនយោបាយកំណត់មុខសញ្ញានេះ[២៨៦៩] អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹង និងមានចេតនាឲ្យមានការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំទៅលើក្រុមមនុស្ស រួមទាំង អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងដែរ និងនៅក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីប្រជុំជននានា បន្ទាប់ពីបានចូលកាន់កាប់ទីក្រុងភ្នំពេញ។

---

[២៨៦៥] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/3, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៤៤៤, ៤៤៧ ដល់៤៥១។

[២៨៦៦] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/3, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៤៥២។ អង្គជំនុំជម្រះនឹងមិនពឹងផ្អែកទៅលើឯកសារនេះ សម្រាប់គោលបំណងនៃការវិភាគក្នុងពេលបច្ចុប្បន្ននេះឡើយ ដោយសារតែមានភាពមិនច្បាស់លាស់ ថាហេតុការណ៍ណាមួយដែលឯកសារនេះជាប់ពាក់ព័ន្ធ។

[២៨៦៧] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧១៥។

[២៨៦៨] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨២២, ៩១៨។

[២៨៦៩] *សូមមើល*ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៨៣៥-៨៣៦។

៩៣៧. ដោយពិចារណាទៅលើការសម្លាប់ជាទ្រង់ទ្រាយធំ ទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបានកើតឡើងនាពេលកន្លងមក អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់មានចេតនារើសអើង ហើយដឹងថា អំពើប្រព្រឹត្តរបស់ពួកគេនឹងបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

### ១៥.៤.៣.៥.៣ ការមិនបានទប់ស្កាត់ ឬ ដាក់ទណ្ឌកម្ម

៩៣៨. នៅក្នុងកិច្ចសម្ភាសន៍មួយ នួន ជា បានអះអាងថា ប្រសិនបើគាត់បានដឹងអំពីការសម្លាប់នៅទួលពោធិ៍ជ្រៃ គាត់គួរតែបានចាត់វិធានការដើម្បីបញ្ឈប់ពួកគេ[២៨៧០]។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះ តួនាទីរបស់ នួន ជា ក្នុងការបង្កើតគោលនយោបាយកំណត់មុខសញ្ញា បានបង្ហាញផ្សេងពីនេះទៅវិញ។ លើសពីនេះទៀត បើទោះបីជាមានភស្តុតាងនៃការសម្លាប់ និងការធ្វើទុក្ខបុកម្នេញទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅមុនពេលជម្លៀសពីទីប្រជុំជន រួមទាំងទីក្រុងភ្នំពេញក៏ដោយ ក៏ នួន ជា មិនបានចាត់វិធានការសមស្របណាមួយដើម្បីទប់ស្កាត់មិនឲ្យមានការធ្វើទុក្ខបុកម្នេញបន្ថែមទៀតឡើយ។ ដោយសារតែសហព្រះរាជអាជ្ញាមិនបានបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលថានៅពេលក្រោយមក នួន ជា បានដឹងពីហេតុការណ៍ជាក់លាក់នៅទួលពោធិ៍ជ្រៃនោះ អង្គជំនុំជម្រះនឹងមិនពិចារណាថាតើ នួន ជា បានដាក់ទណ្ឌកម្ម ឬ មិនដាក់ទណ្ឌកម្មដល់អ្នកនៅក្រោមបង្គាប់របស់គាត់ បន្ទាប់ពីហេតុការណ៍នៅទួលពោធិ៍ជ្រៃនោះទេ។ ទោះក្នុងស្ថានភាពណាក៏ដោយ បើទោះបីជាមេធាវីការពារក្តី នួន ជា បានលើកឡើងថាមានភស្តុតាងបង្ហាញថា មានការចាត់វិធានការខ្លះៗ ដើម្បីបញ្ឈប់ការសម្លាប់អ្នករដ្ឋការនៃរបបមុន ជាពិសេសនៅទីក្រុងភ្នំពេញ ពីខែ ឧសភា ដល់ខែ តុលា ឆ្នាំ ១៩៧៥ ក៏ដោយ[២៨៧១] ក៏ភស្តុតាងទាំងនោះ មានភាពស្រពិចស្រពិល ហើយមិនបានបង្ហាញឲ្យច្បាស់លាស់ពីអ្នកដែលត្រូវទទួលខុសត្រូវចំពោះវិធាន

[២៨៧០] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/3, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៤៤៨ ដកស្រង់ ភាពយន្តឯកសារនិពន្ធដោយ THET S. R. LEMKIN៖ *សត្រូវប្រជាជន* ឯកសារ E3/40001R ខ្សែវីដេអូបន្ថែម៖ មួយថ្ងៃនៅទួលពោធិ៍ជ្រៃ ("បើខ្ញុំបានដឹងពេលនោះ ខ្ញុំនឹងចាត់វិធានការដើម្បីបញ្ឈប់ការកាប់សម្លាប់បែបនេះ")។

[២៨៧១] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/3, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៤៥២ ដល់៤៥៤, ដកស្រង់សៀវភៅ និពន្ធដោយ B. Kiernan៖ របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍, ឯកសារ E3/1593, ERN (ភាសាអង់គ្លេស) 00678541។

ការទាំងនោះទេ។ ដូច្នេះភស្តុតាងនេះ ប្រសិនបើមាន មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ពីវិសាល ភាពនៃតួនាទីរបស់ នួន ជា ទេ។

៩៣៩. ជាលទ្ធផល ដោយសារការមិនបានទប់ស្កាត់ឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃដោយកងទ័ពខ្មែរក្រហម និងកម្មាភិបាលភូមិភាគពាយ័ព្យ។

## ១៥.៥ សេចក្តីសន្និដ្ឋាន

៩៤០. អង្គជំនុំជម្រះយល់ឃើញថា នួន ជា តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ព្រមទាំង ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំ-ជម្រះក៏យល់ឃើញផងដែរថា ជនជាប់ចោទបានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញដល់ឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងនៅទួលពោធិ៍ជ្រៃ។ ដោយពិចារណាថា ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម បានគ្របដណ្តប់ទៅលើអំពើទាំងអស់ដែលបង្កើតបានជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត អង្គជំនុំជម្រះនឹងសម្រេចផ្តន្ទាទោសតែចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ តាមរយៈសហឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ។

៩៤១. លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់ និងទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងនៅទួលពោធិ៍ជ្រៃ។ ដោយយល់ឃើញថាជនជាប់ចោទត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈការ

ចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះបដិសេធមិនធ្វើការផ្តន្ទាទោស ដោយផ្អែកទៅលើគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ។ ជាការជំនួសវិញ នៅក្នុងការផ្តន្ទាទោស អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើតួនាទីជាថ្នាក់លើរបស់ជនជាប់ចោទ។

៩៤២. អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា នួន ជា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញដល់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល (ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២) និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការបាត់ខ្លួនដោយបង្ខំ) (ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២)។ ជាចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញដល់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (នៅទួលពោធិ៍ជ្រៃ)។

## ១៦. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន

៩៤៣. ផ្អែកតាមដីកាដំណោះស្រាយ ដូចដែលបានកំណត់វិសាលភាពក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចខាងក្រោម៖

> ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)៖ ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)
>
> ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) និង
>
> ទួលពោធិ៍ជ្រៃ៖ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[២៨៧២]។

---

[២៨៧២] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥ និង ១៥៤០។ *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១១-៨១៣។

ដីកាដំណោះស្រាយចោទប្រកាន់ ខៀវ សំផន ថាបានចូលរួមដោយចេតនា ឬបានរួមចំណែកក្នុងការរៀបចំ និងការអនុវត្តគោលបំណងរួម ដែលធ្វើឱ្យមាន និង/ឬ មានការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើនទាំងមុនពេល និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមានទាំងសមាជិកភាពរបស់គាត់នៅគណៈកម្មាធិការមជ្ឈិម និងមន្ទីរ ៨៧០ ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ថាបានចូលរួម និងរួមចំណែកក្នុងកិច្ចប្រជុំនានា រួមទាំងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅក្នុងកិច្ចប្រជុំនេះមានការពិភាក្សា និងការផ្សព្វផ្សាយគោលនយោបាយ។ គាត់ ក៏បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈបំពេញតួនាទីការទូត និងចូលរួមក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាផងដែរ។ ដែលនៅក្នុងនោះ គាត់បានគាំទ្រ និងផ្សព្វផ្សាយគោលបំណងរួម ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស[២៨៧៣]។ ដោយផ្អែកលើមូលដ្ឋាននេះ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ជនជាប់ចោទបន្ថែមទៀតថា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឬក៏ជាអ្នកទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[២៨៧៤]។

## ១៦.១ ការដឹង ដែលទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ

៩៤៤. ការដឹងរបស់ ខៀវ សំផន អំពីគោលនយោបាយ វិធីសាស្ត្រនៃការអនុវត្ត និងឧក្រិដ្ឋកម្មជាក់លាក់នានាដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ហើយបញ្ហាទាំងអស់នេះនឹងត្រូវលើកយកមកពិចារណាមុនគេ។ លក្ខខណ្ឌតម្រូវនៃការដឹងមានកម្រិតខុសៗគ្នា អាស្រ័យលើថា តើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់-ចោទ កើតមាននៅមុនពេល នៅក្នុងអំឡុងពេល ឬក៏នៅក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[២៨៧៥]។ ហេតុដូច្នេះ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះនឹងធ្វើការពិនិត្យថាតើ មុនពេលប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នោះ ជនជាប់ចោទបានដឹងអំពីភវនីយភាពច្បាស់លាស់អំពីហេតុការណ៍ដែលកើតមានឡើង នៅពេលក្រោយមកដែរ ឬទេ (ផ្នែក ១៦.១.១) និងថាតើ

[២៨៧៣] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៣៦ ដល់ ១៥៣៧។

[២៨៧៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤ និង ១៥៥៩។

[២៨៧៥] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៤, ៦៩៨, ៧០០, ៧០២, ៧០៤, ៧១៥។

ជនជាប់ចោទបានដឹងអំពីឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងពេលប្រព្រឹត្ត (ផ្នែក ១៦.១.២) ឬក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្មដែរ ឬយ៉ាងណា (ផ្នែក ១៦.១.៣)។

៩៤៥. តាមរយៈសុន្ទរកថានានារបស់គាត់ និងតាមរយៈវគ្គរៀនសូត្រនានា ខៀវ សំផន បានចូលរួមផ្ទាល់ក្នុងការបំពាក់បំប៉នមនោគមន៍វិជ្ជាដល់ប្រជាជន អំពីការតស៊ូវណ្ណៈ និងភាពចាំបាច់ក្នុងការធានាឲ្យប្រទេសកម្ពុជាមានឯករាជ្យ។ តាមរយៈសកម្មភាពទាំងនេះ គាត់ក៏បានរួមចំណែកក្នុងការកំណត់អត្តសញ្ញាណពួកនាយទុន និងពួកមូលធននិយម ថាជាខ្មាំង ហើយគាត់ក៏បានកំណត់ជាទូទៅថា "ប្រជាជនថ្មី" ទាំងអស់គឺជាប្រជាជនដែលត្រូវតែទទួលការលត់ដំ។ ខៀវ សំផន ដឹងថាការបំពាក់បំប៉នមនោគមន៍វិជ្ជាឲ្យស្អប់ខ្ពើម ប្រាកដជានឹងនាំឲ្យមានអំពើហិង្សា។ គាត់ក៏បានយល់ស្របជាមួយទស្សនៈដែលថា បដិវត្តគួរពឹងផ្អែកលើកសិករថ្នាក់ទាបបំផុត ដើម្បីជួយឲ្យវណ្ណៈអធនគ្រប់គ្រងប្រទេសកម្ពុជាដោយតឹងរ៉ឹង។ អ្នកដែលស្ថិតក្នុងវណ្ណៈដឹកនាំថ្មីនេះ ទទួលការអប់រំក្នុងប្រព័ន្ធតិចតួចបំផុត ប៉ុន្តែពួកគេមានវិន័យតឹងរ៉ឹង ទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា ហើយត្រូវបានបង្រៀនឲ្យចេះបោកបញ្ឆោតប្រជាជន និងអនុវត្តតាមគោលការណ៍រក្សាការសម្ងាត់។ ខៀវ សំផន មិនអាចមិនដឹងទេថា ការផ្តល់អំណាចយ៉ាងច្រើនទៅឲ្យពួកគេទាំងនោះ បែបនេះ នឹងធ្វើឲ្យមានការអនុវត្តមាគ៌ាបក្ស ដោយគ្មានការពិចារណាឲ្យបានត្រឹមត្រូវ។ ដោយហេតុផលនេះ ការរំពឹងទុកសមហេតុផលតែមួយគត់គឺថា ប្រជាជនយ៉ាងច្រើននឹងត្រូវស្លាប់នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅដោយបង្ខំ ដោយសារតែលក្ខខណ្ឌនៃការដឹកជញ្ជូន ហើយថា ការផ្លាស់ទីលំនៅបែបនេះនឹងនាំឲ្យការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានចំនួនច្រើន។ លើសពីនេះទៀត ដើម្បីកុំឲ្យមានបន្សល់ទុកនូវសាក្សី និងដើម្បីជៀសវាងការរិះគន់ជាអន្តរជាតិ ខៀវ សំផន គាំទ្រជានិច្ចដល់គោលការណ៍រក្សាការសម្ងាត់ និងរួមចំណែកក្នុងការសម្រេចជម្លៀសជនបរទេសទាំងអស់ដែលមានវត្តមាននៅក្នុងទីក្រុងភ្នំពេញ។ ជាការពិត គាត់ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរក្សាការសម្ងាត់ដែលបង្កើតឡើងដោយរបបនេះ ដោយបន្តលុបបំបាត់ និងលាក់បាំងការពិតនៃស្ថានភាពដែលប្រជាជនកម្ពុជាបានជួបប្រទះ។ ខៀវ សំផន បានដឹងថា ក្នុងការធ្វើដូច្នេះ គាត់បានការពារចារី និងបានអនុញ្ញាតឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាបន្ថែមទៀត។

៩៤៦. ខៀវ សំផន បានទទួលស្គាល់ជាច្រើនលើកច្រើនសា ពាក់ព័ន្ធនឹងការដឹងជាទូទៅរបស់គាត់អំពីគោលនយោបាយ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយពួកខ្មែរក្រហម។ គាត់ដឹងថាអំពើហិង្សាដែលមានលក្ខណៈជាឧក្រិដ្ឋកម្ម ត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ក្នុងការអនុវត្ត

គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[២៨៧៦]។ ប៉ុន្តែ គាត់ជឿជាក់ថាសិទ្ធិមនុស្សគឺជាបញ្ហាបន្ទាប់បន្សំ មិនសំខាន់ដូចបញ្ហាចម្បងនៃឯករាជ្យរបស់ប្រទេសកម្ពុជាទេ។ ការគិតគូរដល់សុខុមាលភាពរបស់ប្រជាជន និងការស្វែងរកការយល់ព្រមពីពួកគេសម្រាប់ការលះបង់ និងព្រមទទួលរងការឈឺចាប់ នៅក្នុងការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហម អាចនឹងពិចារណាតាមក្រោយ[២៨៧៧]។ តាមពិត ខៀវ សំផន ជឿជាក់ថា ការបង្ខិតបង្ខំគឺជាការចាំបាច់សម្រាប់បង្កើតសង្គមសមូហភាព។ គាត់បានដឹងថា គោលបំណងនៃការធ្វើសមូហភាវូបនីយកម្ម អាចធ្វើបានសម្រេច តែតាមរយៈការបង្ខំប៉ុណ្ណោះ ដូច្នេះហើយទើបគាត់គាំទ្រលើចំណុចមួយនេះ នៅក្នុងគោលនយោបាយ[២៨៧៨]។ គាត់ដឹងជាមុនថា ប្រជាជននឹងត្រូវស្លាប់ នៅក្នុងពេលផ្លាស់ទីលំនៅ[២៨៧៩] ហើយគាត់ក៏ដឹងផងដែរអំពីការភ័យខ្លាចរបស់បក្សដែលថា ប្រសិនបើមិនកម្ទេចមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចោលទេ ពួកគេអាចរៀបចំផែនការប្រឆាំងបដិវត្តក្រោយការរំដោះ[២៨៨០]។ ដូចដែលបានបង្ហាញនៅផ្នែកខាងក្រោមនេះ ខៀវ សំផន បានបង្ហាញបន្ថែមទៀតអំពីការដឹងរបស់គាត់អំពីគោលនយោបាយ និងឧក្រិដ្ឋកម្មនានានៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់គាត់ នៅក្នុងអំឡុងពេលបដិវត្តប្រជាធិបតេយ្យ និងបដិវត្តសង្គមនិយម[២៨៨១]។ លើសពីនេះទៀត នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នេះ ខៀវ សំផន បានទទួលបានព័ត៌មានយ៉ាងទូលំទូលាយទាក់ទងទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាជាច្រើន។

### ១៦.១.១ ការដឹងអំពីភាវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៩៤៧. នៅក្នុងគម្រោងការមួយដែលត្រូវបានផ្តួចផ្តើមឡើងកាលពីខែ ឧសភា ឆ្នាំ ១៩៧២ ហើយត្រូវបានអនុម័តជាផ្លូវការនៅមួយឆ្នាំក្រោយមកនោះ គណៈកម្មាធិការមជ្ឈិមបានសម្រេចបិទផ្សារនៅក្នុងតំបន់រំដោះ ហើយបង្កើតសហករណ៍ ប្រមូលផ្តុំកម្លាំងពលកម្មដើម្បីដាំដុះស្រូវ និងក្នុង

---

[២៨៧៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤។

[២៨៧៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។

[២៨៧៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨។ ផ្នែកទី៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥៤។

[២៨៧៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៦-៥៥៨។

[២៨៨០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៥។

[២៨៨១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤។

01007168



គោលបំណងដើម្បី "វាយអានុភាពរបស់វណ្ណៈសក្តិភូមិ ម្ចាស់ដី និងវណ្ណៈនាយទុន"[២៨៨២]។ នៅក្នុងឆ្នាំ ១៩៧២ អៀង សារី បានផ្តល់កិច្ចសម្ភាសន៍ជាសាធារណៈមួយ ទាក់ទងនឹងសមូហភាវូបនីយកម្មនៅក្នុងតំបន់រំដោះ[២៨៨៣]។ សេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានចាត់តាំងប្រជាជនឱ្យទៅបង្កបង្កើនផលកសិកម្មជាសមូហភាព [២៨៨៤]។ លើសពីនេះ លក្ខខណ្ឌនៃការដឹកជញ្ជូន ឬសុខុមាលភាពរបស់ប្រជាជន មិនមែនជាកត្តាដែលត្រូវយកចិត្តទុកដាក់ឡើយ។ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ខែកក្កដា ឆ្នាំ ១៩៧៣ ថ្នាក់ដឹកនាំបក្ស ដោយបានកត់សម្គាល់ពីការខ្វះខាតនៅតាមតំបន់រំដោះនោះ បានប្រកាសពីការប្តេជ្ញារបស់ខ្លួនក្នុងការបន្តការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយទុកឱ្យប្រជាជនដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯងផ្ទាល់[២៨៨៥]។ យោងតាមគោលនយោបាយនេះ នៅតាមតំបន់រំដោះ មានការអនុវត្តវិធីសាស្ត្រដូចៗគ្នាក្នុងការជម្លៀសដោយបង្ខំចេញពីទីក្រុង និងការផ្លាស់ទីលំនៅពីតំបន់ជនបទមួយ ទៅតំបន់ជនបទមួយទៀត ដោយមានទាំងការធ្វើបាប ការរើសអើងប្រឆាំងនឹងប្រជាជនដែលមកពីតំបន់ខ្មាំង និងការប្រឆាំងនឹងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយមានការស្លាប់ដែលបណ្តាលមកពីអំពើបំភិតបំភ័យ អំពើធ្វើឱ្យតក់ស្លុត លក្ខខណ្ឌនៃការជម្លៀស និងការប្រើប្រាស់ហិង្សា[២៨៨៦]។

៩៤៨. ដោយដកស្រង់ចេញពីបទពិសោធន៍លើកមុន ទើបនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងជាថ្មីម្តងទៀត នៅក្នុងខែ មេសាឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់ដែលរួមទាំង ខៀវ សំផន ផងដែរ បានរៀបចំផែនការរួមគ្នា ដើម្បីផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីប្រជុំជននានា។ ផែនការនេះបានប្រមើលឃើញថានឹងមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់

---

[២៨៨២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣, ១១៥។

[២៨៨៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៤។

[២៨៨៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៣។

[២៨៨៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០៤។

[២៨៨៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤, ៨០០-៨០៣។

មនុស្ស)[២៨៨៧]។ លើសពីនេះទៀត ដោយផ្អែកលើបទពិសោធន៍ពីមុន ជាពិសេសបទពិសោធន៍នៅក្រុងឧត្តុង្គ ផែនការខែ មិថុនា ឆ្នាំ ១៩៧៤ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងនានានៅពេលដែលរំដោះប្រទេសបាននោះ ប្រាកដជាបានប្រមើលឃើញ និង/ឬ មានការកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីសម្លាប់ ចាប់ខ្លួន ឬធ្វើឲ្យបាត់ខ្លួន បន្ទាប់ពីរំដោះបានតំបន់មួយ[២៨៨៨]។ ក្រោយខែ មិថុនា ឆ្នាំ ១៩៧៤ ទម្រង់នៃការផ្លាស់ទីលំនៅប្រជាជនឲ្យអស់ចេញពីទីប្រជុំជននានា និងការកំណត់គោលដៅចំពោះមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានកាន់តែខ្លាំងឡើង[២៨៨៩]។

៩៤៩. នៅពេលដែលគោលនយោបាយទាំងនេះត្រូវបានសម្រេច វិធីសាស្ត្រអនុវត្តបានលេចរូបរាងឡើង ហើយសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានចេញផ្សាយ និងសេចក្តីថ្លែងការណ៍ជាសាធារណៈលើប្រធានបទទាំងនេះ ត្រូវបានធ្វើឡើងដោយសមាជិកមជ្ឈិមបក្ស។ ខៀវ សំផន រស់នៅ និងធ្វើការជាប់ជាមួយមេដឹកនាំដទៃទៀត ដែលបានរួមគ្នាបង្កើតការឃោសនារបស់រណសិរ្សរួបរួមជាតិកម្ពុជា ធ្វើដំណើរទូទាំងតំបន់រំដោះ ព្រមទាំងបំពេញតួនាទីការទូត ដែលរួមមាន ការធ្វើទស្សនកិច្ចនៅទីក្រុង ប៉េ កាំង ដើម្បីទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ[២៨៩០]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងអស់នេះ និងបានដឹងអំពីវិធីសាស្ត្រអនុវត្តដែលបានអនុម័តឡើងដើម្បីអនុវត្តនូវគោលនយោបាយទាំងនោះ។

៩៥០. អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា រដ្ឋបរទេសផ្សេងៗជាច្រើនបានផ្សព្វផ្សាយរបាយ-ការណ៍នៃការសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងខ្មាំងដទៃទៀតនៅក្នុងតំបន់រំដោះ មុន

---

[២៨៨៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៤៧។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៧៣៥, ៧៥១, ៧៨៨។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៩៧-១០០៣។

[២៨៨៨] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៩៧-១០០៣, ១០៣៩-១០៤៣។ *សូមមើលផងដែរ* ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២៧។

[២៨៨៩] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៣៤, ១៤៣-១៤៧។ ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៧៨-៦៨១។

[២៨៩០] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៦-៣៦៨។ *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហ-ឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៧៣១,៩៦២។

ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[២៨៩១]។ ផ្អែកលើមូលដ្ឋាននៃតួនាទីការទូតរបស់គាត់ ខៀវ សំផន ខ្លួនឯងផ្ទាល់មានទំនាក់ទំនងជាមួយអ្នកការទូតបរទេសដែលទទួលបានព័ត៌មានទាំងអស់នេះ។ លើសពីនេះទៀត អ្នកការទូតបរទេសក៏មានទំនាក់ទំនងផងដែរជាមួយសម្តេច នរោត្តម សីហនុ និងមន្ត្រីរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលនៅខាងក្រៅដទៃទៀត[២៨៩២]។ ក្នុងនាមជាអ្នកមានទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងមន្ត្រីរណសិរ្សរួបរួមជាតិកម្ពុជា/រាជ-រដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន យ៉ាងហោចណាស់ ក៏ទទួលបានការជូនដំណឹងអំពីរបាយការណ៍ទាំងនោះមួយចំនួនផងដែរ។

៩៥១. ផ្អែកលើសំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានដឹងអំពីគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយ ទៅតំបន់ជនបទមួយទៀត ព្រមទាំងការកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងវិធីសាស្ត្រអនុវត្តដែលបានកើតឡើងមកជាមួយនោះ។ ហេតុដូច្នេះ គាត់ចាំបាច់ត្រូវតែបានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ប្រសិនបើអនុវត្តគោលនយោបាយទាំងអស់នេះបន្តទៀត ដោយប្រើប្រាស់វិធីសាស្ត្រអនុវត្តដែលកំពុងមាននោះ នឹងធ្វើឱ្យកើតមានឧក្រិដ្ឋកម្មនានា នៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ និងនៅទួលពោធិ៍ជ្រៃ។

៩៥២. ជាចុងក្រោយ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) អង្គជំនុំជម្រះ ក៏យល់ឃើញផងដែរថា ខៀវ សំផន ដឹងថា ស្ថានភាពរស់នៅនៅទូទាំងប្រទេស គឺលំបាកខ្លាំង បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយសារការខ្វះចំណីអាហារ និងបញ្ហាជំងឺ[២៨៩៣]។ ទោះជាយ៉ាងនេះក្តី នៅខែ មេសា ឆ្នាំ ១៩៧៥ នៅចុងឆ្នាំ ១៩៧៥ និងចុងឆ្នាំ ១៩៧៦ មេដឹកនាំបក្ស រួមទាំង ខៀវ សំផន ផងនោះ បានរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដំណាក់កាលទី២ ដោយមិនខ្វល់ពីសុខុមាលភាព ឬការយល់ព្រមពីសំណាក់អ្នកដែលត្រូវផ្លាស់ទីលំនៅនោះឡើយ។ ហេតុដូច្នេះ ផែនការទាំងនេះ បានប្រមើលឃើញថា នឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មនានាដោយចៀសមិនរួច នៅ

[២៨៩១] *សូមមើលផងដែរ* ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៨២៧។

[២៨៩២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

[២៨៩៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨។

ពេលក្រោយជាក់ជាមិនខាន[២៨៩៤]។ ផែនការទាំងនេះត្រូវបានផ្សព្វផ្សាយនៅក្នុងការប្រជុំណែនាំ ក្នុងឯកសារគោលនយោបាយ និងទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ចាប់តាំងពីមុន និងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី២[២៨៩៥]។ ទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ត្រូវបានចែកចាយទៅគ្រប់ក្រសួង និងមន្ទីរទាំងអស់របស់មជ្ឈិមបក្សនៃកម្ពុជាប្រជាធិបតេយ្យ[២៨៩៦]។ ដោយពិចារណាអំពីការចូលរួមរបស់ ខៀវ សំផន នៅក្នុងការរៀបចំផែនការឧក្រិដ្ឋក្នុងការផ្លាស់ទីលំនៅដំណាក់កាលទី២ អំពីការចូលរួមរបស់គាត់នៅក្នុងការប្រជុំណែនាំ និងអំពីលទ្ធភាពទទួលបានទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន យុវនារីបដិវត្ត អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន ចាំបាច់ត្រូវតែបានដឹងអំពីភាវនីយភាពច្បាស់លាស់ដែលថា ផែនការ និងគោលនយោបាយក្នុងការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយ ទៅតំបន់ជនបទមួយទៀត វិធីសាស្ត្រអនុវត្តដែលមានភាពស៊ីសង្វាក់គ្នា នឹងបណ្ដាលឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ។

### ១៦.១.២ ការដឹងនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម

#### ១៦.១.២.១ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)

៩៥៣. ក្នុងអំឡុងពេលកំពុងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយចាប់ផ្ដើមឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តទៅមួយសប្តាហ៍ក្រោយទៀតនោះ មេដឹកនាំកងទ័ពដែលមានកម្លាំងរបស់ខ្លួនកំពុងតែប្រព្រឹត្តអំពើឧក្រិដ្ឋនៅពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ បានស្នើសុំការណែនាំ និងបានទទួលការណែនាំពីមេដឹកនាំជាន់ខ្ពស់នៅមន្ទីរ ប-៥ ដែលជាមូលដ្ឋានប្រចាំការរបស់ ខៀវ សំផន[២៨៩៧]។ ក្នុងពេលជាមួយគ្នានោះ ភ្នាក់ងារសារព័ត៌មាន និងរដ្ឋជាច្រើនបានរាយការណ៍អំពីការជម្លៀសដោយបង្ខំ ដែលក្នុងនោះមានទាំងការធ្វើបាប ការស្លាប់ ការចាប់ខ្លួនមន្ត្រីរដ្ឋ

[២៨៩៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦, ៦០៤-៦០៦។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០២៣-១០២៩។

[២៨៩៥] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៥។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៤-៥៤៥។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧, ៦១០។

[២៨៩៦] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៣។

[២៨៩៧] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៧៣៩។

ការនៃរបបសាធារណរដ្ឋខ្មែរ និងយុត្តិកម្មនានាដែលបានលើកឡើងទាក់ទងនឹងអំពើទាំងនោះ[២៨៩៨]។ របាយការណ៍ការទូតទាក់ទិននឹងការជម្លៀសខ្លះ ត្រូវបានបញ្ជូនបន្តទៅឱ្យសម្តេច នរោត្តម សីហនុ និង ប៉ែន នុត ដែលមានទំនាក់ទំនងជាមួយមេដឹកនាំក្រុមតស៊ូផ្ទៃក្នុង ជាពិសេសជាមួយ ខៀវ សំផន ដែលជាអ្នកទំនាក់ទំនងដែលទទួលបានការចាត់តាំង[២៨៩៩]។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា មន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រួមទាំងមន្ត្រីក្រុមតស៊ូផ្ទៃក្នុង ដែលបានធ្វើដំណើរទៅបរទេស ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ ឬ ក៏បានប្រចាំការនៅទីក្រុងហាណូយ ដូចជា អៀង សារី និង អៀង ធីរិទ្ធ ពិតជាបានទទួលរបាយការណ៍ការទូត និងការរាយការណ៍ជាសាធារណៈអំពីបញ្ហានេះខ្លះៗមិនខាន។ មន្ត្រីទាំងនេះមានទំនាក់ទំនងជាមួយក្រុមតស៊ូផ្ទៃក្នុង តាមរយៈវិទ្យុទាក់ទង និងទូរលេខ ក្នុងអំឡុងពេលនៃបដិវត្តប្រជាធិបតេយ្យ[២៩០០] ហើយអង្គជំនុំជម្រះជឿជាក់ថា ទំនាក់ទំនងគ្នានេះនៅបន្តរហូតដល់ក្រោយ ថ្ងៃរំដោះទីក្រុងភ្នំពេញ។ ហេតុដូច្នេះ អង្គជំនុំ-ជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មនានា ដែលកើតឡើងនៅពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

### ១៦.១.២.២ ការសម្លាប់នៅទួលពោធិ៍ជ្រៃ

៩៥៤. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃបន្តបន្ទាប់ ទីក្រុងនានានៅក្នុងប្រទេសកម្ពុជាត្រូវបានរំដោះ ហើយក៏មានការចាប់ខ្លួន ការសម្លាប់ ការបាត់ខ្លួន និងការធ្វើបាបផ្សេងៗទៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរភ្លាមៗ មុនការផ្លាស់ទីលំនៅ ក្នុងពេលផ្លាស់ទីលំនៅ និងក្រោយការផ្លាស់ទីលំនៅប្រជាជនបន្ទិច[២៩០១]។ ដូចគ្នាទៅនឹងវិធីសាស្ត្រអនុវត្តដែលមាននៅពេលនោះ បន្ទាប់ពីខេត្តពោធិ៍សាត់ត្រូវបានរំដោះ មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រមូលផ្តុំតាមរយៈមធ្យោបាយបោកបញ្ឆោត ហើយត្រូវបានយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ នៅថ្ងៃទី ២៥ ឬ ២៦ ខែ មេសា ឆ្នាំ ១៩៧៥[២៩០២]។ មុនព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ខៀវ សំផន បានប្រចាំការនៅមន្ទីរ ប-៥

---

[២៨៩៨] *សូមមើលជាឧទាហរណ៍* ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៧-២៦៨។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥០៣។

[២៨៩៩] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៩, ៨២១។

[២៩០០] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៥៤-២៥៦,២៥១។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧,៣៧២។

[២៩០១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣០-៨៣៤។

[២៩០២] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦២, ៦៦៨, ៦៧០, ៦៨១។

ហើយក្នុងអំឡុងពេលនៃការសម្លាប់ទាំងនេះ គាត់បានប្តូរទីតាំងទៅនៅស្ថានីយរថភ្លើងក្រុងភ្នំពេញវិញ។ នៅទីតាំងទាំងពីរនេះ ខៀវ សំផន បានជួបជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត រួមទាំងលេខាភូមិភាគ និងមេបញ្ជាការកងទ័ព[២៩០៣]។

៩៥៥. ហេតុដូច្នេះ បើទោះបីជាមិនមានភ័ស្តុតាងដែលថា គាត់បានដឹងពីចរិតលក្ខណៈនៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា នៅពេលនោះ គាត់បានដឹងអំពីវិធីសាស្ត្រអនុវត្តដើម្បីកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវចាប់ខ្លួន សម្លាប់ បាត់ខ្លួន និងត្រូវធ្វើបាបក្នុងទម្រង់ផ្សេងៗ បន្ទាប់ពីបានរំដោះតំបន់មួយ។ ហេតុនេះយ៉ាងហោចណាស់គាត់ចាំបាច់ត្រូវតែបានដឹងថា មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរខ្លះត្រូវបានគេសម្លាប់ នៅពេលដែលការសម្លាប់នៅទួលពោធិ៍ជ្រៃបានកើតឡើង។

### ១៦.១.២.៣ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)

៩៥៦. នៅក្នុងដំណាក់កាលទី២ មានវិធីសាស្ត្រក្នុងការផ្លាស់ទីលំនៅដោយបង្ខំពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ដែលមានលក្ខណៈជាការធ្វើបាប ការរើសអើងប្រឆាំង “ប្រជាជនថ្មី” និងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌក្នុងការដឹកជញ្ជូន អំពើរបស់កងទ័ពខ្មែរក្រហមដែលបង្កឱ្យមានការភ័យខ្លាច និងការប្រើប្រាស់កម្លាំង[២៩០៤]។ ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ទៅមជ្ឈិម ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២[២៩០៥]។ ប្រជាជនរាប់ពាន់នាក់ត្រូវបានផ្លាស់ទីតាម កាណូត កប៉ាល់ ឡាន និងរថភ្លើង សំដៅទៅទីក្រុងភ្នំពេញ កាត់ទីក្រុងភ្នំពេញ និងចេញពីទីក្រុងភ្នំពេញ ជាទីក្រុងដែលគេស្ទើរតែបោះបង់ចោល[២៩០៦]។ ខៀវ សំផន ក៏បានធ្វើទស្សនកិច្ចទៅតាមទីជនបទផងដែរ ជាពិសេសនៅដើមឆ្នាំ ១៩៧៦ ដែលនៅទីនោះគាត់បានឃើញផ្ទាល់នូវស្ថានភាពរស់នៅរបស់មនុស្សរាប់ម៉ឺននាក់ ដែលធ្វើការដោយដៃទទេរ[២៩០៧]។ នៅក្នុងសេចក្តីថ្លែងការណ៍ជា

---

[២៩០៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០។

[២៩០៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០០-៨០៣។

[២៩០៥] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧៤-២៨០។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨, ៥៨០។

[២៩០៦] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤, ៥៩១, ៥៩៤-៥៩៩។

[២៩០៧] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤, ៣៨០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៩។

សាធារណៈមួយនៅពេលនោះ ខៀវ សំផន បានទទួលស្គាល់ថា មនុស្សរាប់ម៉ឺននាក់ត្រូវបានប្រមូលផ្ដុំនៅតាមការដ្ឋានផ្សេងៗគ្នាជាច្រើន [២៩០៨]។ អនុលោមតាមគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស និងការតស៊ូវណ្ណៈ ការបែងចែកកម្លាំងពលកម្មដោយបង្ខំត្រូវបានរាយការណ៍ និងលើកសរសើរនៅក្នុងកិច្ចប្រជុំណែនាំ និងនៅក្នុងការបោះពុម្ពផ្សាយរបស់បក្ស នៅពេលដែលឧក្រិដ្ឋកម្មកំពុងកើតឡើងនៅដំណាក់កាលទី២ នៃការផ្លាស់ទីលំនៅប្រជាជន[២៩០៩]។ ភ្នាក់ងារព័ត៌មាន និងរដ្ឋបរទេសជាច្រើនក៏បានរាយការណ៍អំពីការជម្លៀសដោយបង្ខំ អំពីស្ថានភាពដ៏អាក្រក់ក្នុងការដឹកជញ្ជូន និងការស្លាប់បណ្ដាលមកពីការដឹកជញ្ជូន ព្រមទាំងការរើសអើងប្រឆាំង "ប្រជាជនថ្មី" ក្នុងពេលដែលបទឧក្រិដ្ឋកំពុងកើតឡើងក្នុងដំណាក់កាលទី២[២៩១០]។ ក្រសួងឃោសនាការ និងក្រសួងការបរទេស បានប្រមូល និងចែកចាយព័ត៌មានទាំងអស់ទៅមេដឹកនាំជាន់ខ្ពស់[២៩១១]។

៩៥៧. ដោយផ្អែកលើសំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

### ១៦.១.៣ ការដឹងនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៩៥៨. បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ទី២ និងនៅទួលពោធិ៍ជ្រៃរួចមក ខៀវ សំផន បានថ្លែងនៅក្នុងសេចក្ដីប្រកាសជាសាធារណៈ ដោយបង្ហាញពីការដឹងរបស់គាត់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អំពីយុត្តិកម្មនៃការជម្លៀស ការប្រមូលផ្ដុំកម្លាំងពលកម្មនៅតាមការដ្ឋាន ព្រមទាំងគោលនយោបាយកំណត់គោលដៅខ្មាំង និងការរើសអើងដែលនៅមានបន្តចំពោះ "ប្រជាជនថ្មី"[២៩១២]។ គោលនយោបាយ ព្រមទាំងឧក្រិដ្ឋកម្ម

---

[២៩០៨] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨១, ៦១០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨, ៧៨៣, ៧៨៥។

[២៩០៩] *សូមមើលជាឧទាហរណ៍* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧, ៥៨១, ៥៨៤, ៥៨៧, ៦០២-៦០៦, ៦០៨, ៦១០, ៦១៣-៦១៦, ៦២១។

[២៩១០] *សូមមើលជាឧទាហរណ៍*ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៦, ៥៨០, ៥៨៥, ៥៨៨, ៦១១។

[២៩១១] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៥២, ២៥៦, ២៦៧-២៦៨។

[២៩១២] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

ដែលកើតចេញពីគោលនយោបាយទាំងនេះ ក៏ត្រូវបានយកមកពិភាក្សាក្រោយមកនៅក្នុងវគ្គសិក្សារៀនសូត្រ ក្នុងសន្និសិទ្ធ ការធ្វើសន្ទរកថាក្នុងថ្ងៃប្រារព្ធបុណ្យឯករាជ្យ ក្នុងមហាសន្និបាត ព្រមទាំងនៅក្នុងឯកសារនយោបាយ និងនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត បន្ទាប់ពីឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង។ ខៀវ សំផន បានចូលរួមក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ក្នុងមហាសន្និបាត និងសន្និសីទ ដែលបញ្ហាទាំងអស់នេះត្រូវបានលើកយកមកពិភាក្សា[២៩១៣]។ គាត់ក៏បានទទួលទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ដែលត្រូវបានបញ្ជូនទៅកាន់ក្រសួង មន្ទីរនានា របស់មជ្ឈិមបក្ស[២៩១៤]។ ជាចុងក្រោយ ភ្នាក់ងារសារព័ត៌មាន អង្គការអន្តរជាតិ និងរដ្ឋបរទេសជាច្រើនក៏បានរាយការណ៍ពីការចោទប្រកាន់អំពីភាពសាហាវយង់ឃ្នងនានា ដែលមានដូចជា ការជម្លៀសដោយបង្ខំ ស្ថានភាពអមនុស្សធម៌ ការរើសអើងប្រឆាំង “ប្រជាជនថ្មី” និងការសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ក្រសួងឃោសនាការ និងក្រសួងការបរទេស បានប្រមូល និងចែកចាយព័ត៌មានទាំងអស់ទៅមេដឹកនាំជាន់ខ្ពស់[២៩១៥]។ ដោយពិចារណាទៅលើមុខងារការទូតរបស់គាត់ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីការចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្ស ជាពិសេសគឺបញ្ហាទាំងអស់នេះប្រាកដជាត្រូវបានលើកឡើងដោយចៀសមិនរួច នៅក្នុងពេលបំពេញទស្សនកិច្ចនៅបរទេស ឬក៏ក្នុងកិច្ចប្រជុំរបស់គាត់ជាមួយមន្ត្រីបរទេសនានា។ តាមពិតទៅ របាយការណ៍មួយចំនួនត្រូវបានបញ្ជូនទៅឱ្យ ខៀវ សំផន ក្នុងតួនាទីរបស់គាត់ជាប្រធាននៃគណៈប្រធានរដ្ឋ[២៩១៦]។

៩៥៩. ដោយផ្អែកទៅលើមូលដ្ឋានដូចបានលើកឡើងពីខាងលើ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ក៏ទទួលបានការជូនដំណឹងអំពីឧក្រិដ្ឋកម្មនានា បន្ទាប់ពីឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងហើយដែរ។

[២៩១៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៣-៩៧៦។

[២៩១៤] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៣។

[២៩១៥] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៦៧-២៦៨។

[២៩១៦] *សូមមើលជាឧទាហរណ៍* ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧២, ៣៧៦, ៣៨២។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៤, ៨២១។

## ១៦.២ ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម

### ១៦.២.១ ការរួមចំណែក

៩៦០. មេធាវីការពារក្តី ខៀវ សំផន បានទទួលស្គាល់ថា ខៀវ សំផន បានរួមចំណែកជាមួយរបបខ្មែរក្រហម តាមរយៈតួនាទីរបស់គាត់ជាអ្នកការទូត ជាអ្នកមានទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងជាសេដ្ឋកិច្ចវិទូ។ ប៉ុន្តែមេធាវីការពារក្តីបានលើកឡើងថា ការរួមចំណែករបស់ ខៀវ សំផន មិនសំខាន់នោះទេ ព្រោះគាត់មិនមានតួនាទីដែលមានអំណាចឡើយ[២៩១៧]។ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានប្រើប្រាស់សិទ្ធិអំណាចខ្លះៗ ក្នុងអំឡុងពេលពាក់ព័ន្ធក្នុងសំណុំរឿង ០០២/០១ ជាពិសេសតាមរយៈតួនាទីជាន់ខ្ពស់ និងតួនាទីសេដ្ឋកិច្ចរបស់គាត់[២៩១៨]។ ប៉ុន្តែ នៅក្នុងផ្នែកដែលពិភាក្សាពីបទចោទដែលជនជាប់ចោទត្រូវទទួលខុសត្រូវ ក្នុងនាមជាថ្នាក់លើចំពោះបទឧក្រិដ្ឋនោះ អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើចារីនៃអំពើឧក្រិដ្ឋ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) ព្រមទាំងនៅទួលពោធិ៍ជ្រៃនោះទេ[២៩១៩]។ ទោះជាយ៉ាងនេះក្តី ដើម្បីកំណត់ ពីការរួមចំណែកដ៏សំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមនោះ ជនជាប់ចោទមិនតម្រូវឲ្យមានតួនាទីកាន់អំណាចជាក់ស្តែង ឬតាមផ្លូវច្បាប់នោះទេ បើទោះបីជាតួនាទីកាន់អំណាចនេះអាចនឹងយកមក ពិចារណា ដើម្បីកំណត់ពីការចូលរួមរបស់ជនជាប់ចោទក៏ដោយ[២៩២០]។

---

[២៩១៧] សារណាបញ្ចប់ការពិភាក្សាដេញដោល [របស់ខៀវ សំផន] ឯកសារ E295/6/4 ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២១២, ២១៥ ដល់ ២១៨, ២២១, ២២២, ២២៦, ២៣៣, ២៣៦, ២៧៩, ២៨៣, ២៨៨, ៣០០, ៣១៦ ដល់ ៣១៧។ *សូមមើលផងដែរ* ផ្នែកទី២៖ បញ្ហាអញ្ញត្រកម្ម កថាខណ្ឌ ១៤ (ពាក់ព័ន្ធការជំទាស់របស់ ខៀវ សំផន ទៅលើយុត្តាធិការបុគ្គល ដោយផ្អែកលើមូលដ្ឋានថា គាត់មិនមានតួនាទី កាន់អំណាចថ្នាក់លើ ឬអាចប្រើប្រាស់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនោះឡើយ។ អង្គជំនុំជម្រះបានច្រានចោលការជំទាស់នេះ ដោយអង្គជំនុំជម្រះយល់ឃើញថា តួនាទីថ្នាក់លើ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់គាត់ គឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ដូច្នេះហើយ គឺមិនអាចរារាំងដល់យុត្តាធិការនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះទេ)។

[២៩១៨] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៩។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦០-៩៩២។

[២៩១៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០១៦-១០២២, ១០៣៨។

[២៩២០] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៣, ៧០០, ៧០២, ៧០៦។

៩៦១. ចន្លោះពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ខៀវ សំផន គឺជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គ-មេបញ្ជាការកងទ័ពរំដោះប្រជាជនកម្ពុជា[២៩២១]។ ចាប់តាំងពីឆ្នាំ ១៩៧១ មក គាត់គឺជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម[២៩២២]។ នៅខែ តុលា ឆ្នាំ ១៩៧៥ ខៀវ សំផន ត្រូវបានចាត់តាំងជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៅមន្ទីរ ៨៧០ និងត្រូវបានតែងតាំងឲ្យទទួលខុសត្រូវផ្នែក "រណសិរ្ស និង រាជរដ្ឋាភិបាល និង ពាណិជ្ជកម្ម ខាងបញ្ចើ និង តម្លៃ"[២៩២៣]។ នៅខែ មករា ឆ្នាំ ១៩៧៦ ខៀវ សំផន បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម[២៩២៤]។ នៅខែ មីនា ឆ្នាំ ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសម្រាប់ពិនិត្យរៀបចំទំនិញដែលត្រូវទិញ និងជាប្រធានគណៈកម្មាធិការធនាគារ[២៩២៥]។ បន្ទាប់មកនៅខែ មេសា ឆ្នាំ ១៩៧៦ ខៀវ សំផន បានក្លាយជាប្រធាននៃគណៈប្រធានរដ្ឋជាផ្លូវការ[២៩២៦]។

៩៦២. ក្នុងពេលបំពេញតួនាទីទាំងអស់នេះ ខៀវ សំផន បានបញ្ជាក់ថាគាត់ព្រមធ្វើអ្វីៗគ្រប់យ៉ាងដែលគាត់អាចធ្វើបានដើម្បីជួយដល់ខ្មែរក្រហម និងមិនធ្វើអ្វីទាំងឡាយណាដែលអាចរារាំងដល់ខ្មែរក្រហមនោះទេ[២៩២៧]។ គាត់បានចូលរួមក្នុងការប្រជុំនយោបាយរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងមហាសន្និបាតបក្ស ដែលនៅក្នុងការប្រជុំទាំងអស់នេះ ផែនការ និងគោលបំណងរួម ត្រូវបានបង្កើតឡើង និងយកទៅអនុវត្ត (ផ្នែក ១៦.២.១.១)។ គាត់មានវត្តមាន និងចូលរួមក្នុងការប្រជុំដែលផ្សព្វផ្សាយពីការណែនាំ និងការបង្រៀនពាក់ព័ន្ធនឹងគោលបំណងរួម និងគោលនយោបាយនានា (ផ្នែក ១៦.២.១.២)។ គាត់មានតួនាទីផ្នែកសេដ្ឋកិច្ច ដែលតាមរយៈបទពិសោធន៍ និងការសិក្សារបស់គាត់ គាត់បានអនុវត្តធាតុផ្សំនៃគោលបំណងរួម ទាក់ទងនឹងពាណិជ្ជកម្ម ការនាំចេញ/នាំចូល និងជំនួញ (ផ្នែក ១៦.២.១.៣)។ គាត់បានថ្លែងសេចក្តីប្រកាសជាសាធារណៈគាំទ្រដល់គោលបំណងរួម និងគោលនយោបាយ ហើយជំរុញឲ្យទាំងអស់

---

[២៩២១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥, ៣៧៦។

[២៩២២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣។

[២៩២៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៩០, ៤០០។

[២៩២៤] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣, ៣៨៤។

[២៩២៥] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០០-៤០៧។

[២៩២៦] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១។

[២៩២៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៩, ៧៦៦។

គ្នាកសាង និងការពារប្រទេសស្របតាមមាគ៌ាបក្ស (ផ្នែក ១៦.២.១.៤)។ ជាចុងក្រោយ ក្នុងតួនាទីរបស់គាត់ជាអ្នកទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងជាអ្នកការទូត គាត់បានផ្តល់យុត្តិកម្ម បានការពារ និងបានលើកសរសើរដល់គោលបំណងរួម និងគោលនយោបាយ ធ្វើឲ្យមានការគាំទ្រដល់ខ្មែរក្រហម ហើយគាត់បានសម្របសម្រួលដល់ការអនុវត្តគោលបំណងរួម និងគោលនយោបាយទាំងនោះ ជាសម្ងាត់ និងមិនមានការរាំងស្ទះជាដុំកំភួន តាមរយៈគោលនយោបាយដាច់ខាត (ផ្នែក ១៦.២.១.៥)។

៩៦៣. តាមសម្អាងហេតុដែលនឹងត្រូវរៀបរាប់លម្អិតនៅផ្នែកខាងក្រោមនេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម។ ដើម្បីឲ្យ ខៀវ សំផន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ព និងកម្មាភិបាលខ្មែរក្រហម ដែលមិនមែនជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ ចាំបាច់ត្រូវតែមានការបង្ហាញឲ្យឃើញថា យ៉ាងហោចណាស់មានសមាជិកណាម្នាក់នៃសហ-ឧក្រិដ្ឋកម្មរួមត្រូវបានដាក់ឲ្យទទួលខុសត្រូវ ហើយសមាជិកនោះ បានប្រើប្រាស់ចារី (ដែលជាកងទ័ព ឬកម្មាភិបាលខ្មែរក្រហម ដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដោយផ្ទាល់) ដើម្បីសម្រេចគោលបំណងរួម[២៩២៨]។ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មទាំងនេះ អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះអ្នកចូលរួមផ្សេងទៀត នៅក្នុងសហឧក្រិដ្ឋកម្មរួម[២៩២៩]។ ការយល់ឃើញនៅផ្នែកខាងក្រោមដោយអង្គជំនុំជម្រះ ដែលថា ខៀវ សំផន បានរៀបចំផែនការ ញុះញង់ ជួយ និងជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់នោះ (ផ្នែក ១.៣ ដល់ ១.៥) ក៏បង្ហាញគ្រប់គ្រាន់ផងដែរ ពីទំនាក់ទំនងរវាងចារី និង ខៀវ សំផន[២៩៣០]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មទាំងនេះ។

---

[២៩២៨] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៦៩៣។

[២៩២៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៧, ៨១០, ៨៣៦។

[២៩៣០] សាលដីកា រឿងក្តី *Krajišnik* កថាខណ្ឌ ២២៦ (ទំនាក់ទំនងគ្រប់គ្រាន់មួយកើតមានឡើងនៅពេលដែលសមាជិកសហឧក្រិដ្ឋកម្មរួមម្នាក់បានស្នើសុំ ដោយត្រង់ ឬដោយប្រយោល ដល់អ្នកមិនមែនសមាជិកសហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋមួយ ដែលបង្កើតជាផ្នែកមួយនៃគោលបំណងរួម)។

## ១៦.២.១.១ កិច្ចប្រជុំគោលនយោបាយ៖ ការរៀបចំគោលបំណងរួម

៩៦៤. ខៀវ សំផន បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងសន្និបាតបក្សពេញមួយអំឡុងពេលបដិវត្តន៍ និងរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងកិច្ចប្រជុំទាំងនោះ មានការរៀបចំផែនការ និងសម្រេចលើគោលបំណងរួមដើម្បីធ្វើបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សមួយ និងការពារប្រទេស ព្រមទាំងគោលនយោបាយនានាដែលគាត់ទុកថាសំខាន់ដើម្បីសម្រេចបានគោលបំណងរួមនេះ។

៩៦៥. ខៀវ សំផន បានទាក់ទងជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចាប់ពីដើមឆ្នាំ ១៩៦០[២៩៣១]។ ក្រោយពីរត់គេចខ្លួនចូលព្រៃម៉ាគីនៅឆ្នាំ ១៩៦៧ គាត់បានផ្លាស់ទីលំនៅពីភូមិមួយទៅភូមិមួយនៅក្នុងតំបន់រំដោះ ក្រោមការការពារពីសំណាក់ខ្មែរក្រហម។ នៅឆ្នាំ ១៩៦៩ គាត់បានស្នាក់នៅកន្លែងដែលគ្រប់គ្រងដោយ តាម៉ុក ដែលបានឃើញដោយផ្ទាល់អំពីការចាប់ផ្តើមនៃការតស៊ូប្រដាប់អាវុធ[២៩៣២]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ត្រឹមឆ្នាំ ១៩៦៩ នៅពេលដែលគាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា[២៩៣៣] ខៀវ សំផន បានដឹងយ៉ាងច្បាស់អំពីគោលបំណងរួមដែលបានសម្រេចនៅក្នុងមហាសន្និបាតបក្សលើកទី១ និងលើកទី២ ព្រមទាំងការវិវត្តន៍ក្នុងអំឡុងកិច្ចប្រជុំរបស់មេដឹកនាំបក្សនៅក្នុងភូមិភាគរំដោះ និងបានឯកភាពទៅនឹងគោលបំណងរួមនេះ ដោយគាត់បាននិយាយថា គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា ទោះបីជាគាត់មិនយល់ស្របជាមួយសកម្មភាពមួយចំនួនរបស់បក្សក៏ដោយ ក៏ប៉ុន្តែការចូលរួមរបស់គាត់គឺដើម្បីជាប្រយោជន៍ដល់ឯករាជ្យរបស់ប្រទេសកម្ពុជា[២៩៣៤]។ នៅក្នុងមហាសន្និបាតបក្សលើកទី៣ នៅឆ្នាំ ១៩៧១ ខៀវ សំផន រួមជាមួយសមាជិកបក្សផ្សេងទៀត បានបញ្ជាក់អំពីមាគ៌ាយុទ្ធសាស្ត្ររបស់បក្សដែលបានសម្រេចនៅក្នុងមហាសន្និតបាតមុនៗ ដែលរួមមានការខិតខំប្រឹងប្រែងក្នុងការតស៊ូវណ្ណៈ[២៩៣៥]។

៩៦៦. នៅខែ មិថុនា ឆ្នាំ ១៩៧៤ ខៀវ សំផន ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត បានរៀបចំផែនការវាយលុកចុងក្រោយដើម្បីរំដោះប្រទេស។ ផែនការចុងក្រោយនេះ គឺការផ្លាស់ទី

---

[២៩៣១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥៦-៣៥៨, ៣៦២។

[២៩៣២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦២។

[២៩៣៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦២។

[២៩៣៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៨។

[២៩៣៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៣។

លំនៅប្រជាជនចេញពីទីក្រុង និងជាពិសេស អ្នកដែលរស់នៅក្នុងទីក្រុងភ្នំពេញ។ អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំ ត្រូវបានគេបញ្ជាឱ្យផ្សព្វផ្សាយផែនការនេះ[២៩៣៦]។ នៅដើមខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំមួយ ដែលបានបញ្ជាក់អំពីការសម្រេចឱ្យផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញក្រោយពេលរំដោះ ហើយក្រោយមក ការសម្រេចនេះត្រូវបានផ្សព្វផ្សាយនៅក្នុងជួរបក្ស[២៩៣៧]។

៩៦៧. យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានបង្កើតក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្នុងស្ថានីយ៍អាយស្ម័យយានភ្នំពេញ និងក្រោយមកនៅអតីតអគាររបស់ក្រសួងហិរញ្ញវត្ថុ និងនៅព្រះវិហារប្រាក់ (ព្រះវិហារព្រះកែវមរកត) ដែលកិច្ចប្រជុំត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការដើម្បីកសាង និងការពារប្រទេស ដែលអាចទីពឹងខ្លួនឯង ឯករាជ្យ និងសង្គមនិយម ដូចជាការបង្កើតសហករណ៍[២៩៣៨]។ ក្រោយមក ខៀវ សំផន មានមូលដ្ឋាននៅមន្ទីរ ក-៣ និងក្រោយពេល ប៉ុល ពត ផ្លាស់ប្តូរទីតាំង គាត់បានទៅលេងកន្លែងស្នាក់នៅរបស់ ប៉ុល ពត នៅមន្ទីរ ក-១ ជារឿយៗផងដែរ។ នៅកន្លែងទាំងពីរនេះ ខៀវ សំផន បានជួបជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត រួមទាំង នួន ជា ផងដែរ[២៩៣៩]។

៩៦៨. ខៀវ សំផន បានចូលរួមនៅក្នុងការរៀបចំផែនការ ដែលមាននៅក្នុងឯកសារគោលនយោបាយខែ កញ្ញា និងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ដើម្បីចាត់ចែងកម្លាំងពលកម្មដោយបង្ខំតាមយុទ្ធសាស្ត្រ ផ្អែកតាមទិសដៅបង្កបង្កើនផល និងអាទិភាពហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឱ្យបានទិន្នផលស្រូវ ៣ តោនក្នុង ១ ហិកតា ដោយយកចិត្តទុកដាក់ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រ និងការលើកទឹកចិត្តដល់ "ប្រជាជនចាស់" ប៉ុន្តែធ្វើឱ្យខូចប្រយោជន៍ដល់ "ប្រជាជនថ្មី"[២៩៤០]។ ក្នុងអំឡុងមហាសន្និបាតបក្សលើកទី ៤ នៅខែ មករា ឆ្នាំ ១៩៧៦ ដែលរួមជាមួយសមាជិកបក្សផ្សេងទៀត គាត់បានអនុម័តលក្ខន្តិកៈដែល

---

[២៩៣៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៣៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥, ៧៥១។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៩៧-១០០៣។

[២៩៣៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៩។

[២៩៣៨] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០។

[២៩៣៩] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៦, ៣៧៣, ៣៨៦, ៤០៨។

[២៩៤០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៦-៥៨៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨-៧៥០។

ត្រូវបានធ្វើវិសោធនកម្ម ដោយបានបញ្ជាក់អំពីតម្រូវការនៃការតស៊ូវណ្ណៈ ប្រជាធិបតេយ្យប្រមូលផ្តុំ[២៩៤១] ការប្រុងប្រយ័ត្នចំពោះខ្មាំង និងការប្តេជ្ញាចិត្តគោរពតាមគោលការណ៍ឯករាជ្យ អធិបតេយ្យភាព និងខ្លួនទីពឹងខ្លួន[២៩៤២]។

៩៦៩. នៅចន្លោះខែ កុម្ភៈ និងខែ មីនា ឆ្នាំ ១៩៧៦ ខៀវ សំផន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលនិយាយពីការបោះឆ្នោតនៅសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ការចូលនិវត្តន៍របស់សម្តេច នរោត្តម សីហនុ ការត្រួតពិនិត្យ និងការបញ្ជូនរបាយការណ៍ព័ត៌មានទៅគណៈកម្មាធិការអចិន្ត្រៃយ៍ ការយកឈ្នះទៅលើខ្មាំងសត្រូវ ការខ្វះស្បៀងអាហារ និងជំងឺ នៅតំបន់ ១០៣ និង១០៦ ការចែកចាយស្បៀងអាហារ គោលដៅនាំស្រូវចេញនៅឆ្នាំ ១៩៧៧ ប្រព័ន្ធរាយការណ៍ប្រចាំសប្តាហ៍ពីថ្នាក់តំបន់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ ការងារពាណិជ្ជកម្ម និងការបង្កើតគណៈកម្មាធិការសម្រាប់ធនាគារ និងការទិញដូរ បញ្ហាព្រំដែន និងផែនការចរចាជាមួយប្រទេសវៀតណាម[២៩៤៣]។

៩៧០. នៅខែ ឧសភា និងខែ មិថុនា ឆ្នាំ ១៩៧៦ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទាក់ទិននឹងគោលនយោបាយការបរទេស ទំនាក់ទំនងពាណិជ្ជកម្ម និងធនាគារជាមួយប្រទេសចិន បញ្ហាជម្លោះព្រំដែនជាមួយប្រទេសវៀតណាម បញ្ហាការពារជាតិ ដែលរួមមានការបង្កើតរោងចក្រផលិតសព្វាវុធ និងព្រលានយន្តហោះ កិច្ចការរបស់កងទ័ពក្នុងការការពារ និងការបង្កបង្កើនផលិតផលកសិកម្ម ភាពទន់ខ្សោយនៅក្នុងក្រសួងសុខាភិបាល និងសង្គមកិច្ច ការទទួលខុសត្រូវចំពោះការបង្កបង្កើនផល ការចែកចាយថ្នាំពេទ្យ ការទប់ស្កាត់ជំងឺ ការបែងចែកកម្លាំងពលកម្ម ការខ្វះខាតថ្នាំពេទ្យ និងស្បៀងអាហារ[២៩៤៤]។

៩៧១. នៅចុងឆ្នាំ ១៩៧៦ ខៀវ សំផន បានចូលរួមនៅក្នុងការរៀបចំផែនការសេដ្ឋកិច្ចឆ្នាំ ១៩៧៧ សម្រាប់ការបង្កបង្កើនផលកសិកម្ម ការបែងចែកកម្លាំងពលកម្ម និងការបែងចែកប្រជាជនទៅតាម

---

[២៩៤១] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០០-២០១, ២៣៣។

[២៩៤២] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៥។

[២៩៤៣] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៦-៣៨៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៦៨។

[២៩៤៤] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៦-៣៨៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៦៨។

ប្រភេទផ្សេងៗ។ ក្រោយមក ផែនការត្រូវបានផ្សព្វផ្សាយនៅក្នុងទង់បដិវត្ត ដែលចេញនៅខែ វិច្ឆិកា ឆ្នាំ ១៩៧៦[២៩៤៥]។

៩៧២. ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា វត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំ និងការផ្សព្វផ្សាយផែនការរបស់មជ្ឈិមបក្ស បានបង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួមនៅក្នុងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីតាមទីជនបទមួយទៅកាន់ទីជនបទមួយទៀត និងកំណត់គោលដៅចំពោះមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ថែមទាំងដើរតួនាទីសំខាន់នៅក្នុងការបង្កើតនូវខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយទៀតផង។

## ១៦.២.១.២ កិច្ចប្រជុំណែនាំ៖ ការផ្សព្វផ្សាយគោលបំណងរួម

៩៧៣. ខៀវ សំផន មានវត្តមាន និងបានចូលរួមនៅក្នុងកិច្ចប្រជុំណែនាំ និងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ដែលបានផ្សព្វផ្សាយគោលបំណងរួម និងគោលនយោបាយនានា។ ក្នុងអំឡុងពេលបដិវត្តប្រជាធិបតេយ្យ ខៀវ សំផន បានជួយរៀបចំឯកសារឃោសនារបស់រណសិរ្សរួបរួមជាតិកម្ពុជា និងបានបង្រៀនវគ្គរៀនសូត្រនយោបាយនៅតំបន់រំដោះ[២៩៤៦]។ វត្តមាន និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំណែនាំទាក់ទិននឹងមាគ៌ាបក្ស បានបន្តក្រោយពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

៩៧៤. នៅខែ ឧសភា ឆ្នាំ ១៩៧៥ ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ដែលរួមទាំងតំណាងមកពីភូមិភាគទាំងអស់ បានចូលរួមការប្រជុំរយៈពេល១០ថ្ងៃ នៅព្រះវិហារព្រះកែវមរកត។ នៅក្នុងការប្រជុំ មេដឹកនាំបក្សបានលើកហេតុផលដើម្បីជាយុត្តិកម្មក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង និងណែនាំឲ្យកសាង និងការពារប្រទេសឲ្យឆាប់រហ័សតាមរយៈការបង្កើតសហករណ៍ និងការលើកទំនប់ និងជីកប្រឡាយ[២៩៤៧]។ ក្រោយមក នៅចន្លោះប្រហែលថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត តំណាងមកពីអង្គភាពយោធាទាំងអស់ និងលេខាស្រុក តំបន់ និងភូមិភាគទាំងអស់ បានចូលរួមនៅក្នុងការប្រជុំទាំងនៅពហុ-

[២៩៤៥] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១០, ៦២១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧០-៧៧១។

[២៩៤៦] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។

[២៩៤៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩៧៤។

កីឡាដ្ឋានជាតិអូឡាំពិក ឬនៅវិទ្យាស្ថានបច្ចេកវិទ្យាខ្មែរ-សូវៀត។ ការណែនាំបានលើកឡើងអំពីការរៀបចំសហករណ៍ ការលុបបំបាត់ចោលទ្រព្យសម្បត្តិឯកជន ការហាមឃាត់មិនឲ្យមានផ្សារ និងការចាយលុយ[២៩៤៨]។

៩៧៥. ខៀវ សំផន ក៏បានដឹកនាំវគ្គរៀនសូត្រនៅក្នុងទីក្រុងភ្នំពេញ ពេញមួយអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ គាត់បានឧទ្ទេសនាមជូនកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំងកម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងកម្ចាត់ខ្មាំង ការបន្តការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការកសាងទំនប់ និងជីកប្រឡាយ និងការបំពេញតាមផែនការការងារ[២៩៤៩]។ យ៉ាងហោចណាស់ គាត់ក៏បានបង្រៀនវគ្គរៀនសូត្រនយោបាយដល់អ្នកដែលបានវិលត្រលប់មកវិញនៅចុងឆ្នាំ ១៩៧៥ ផងដែរ។ នៅក្នុងអំឡុងពេលនៃវគ្គរៀនសូត្រទាំងនេះ គាត់បានផ្តល់ហេតុផលអំពីការជម្លៀសទីក្រុង និងទីប្រជុំជន និងបានឧទ្ទេសនាមថា ចំណេះដឹងដែលបានទទួលមកពីការអប់រំដោយ “ពួកអាណានិគម និងពួកចក្រពត្តិនិយម” ត្រូវបំភ្លេចចោល[២៩៥០]។

៩៧៦. អង្គជំនុំជម្រះយល់ឃើញថា វត្តមាន និង/ឬ ការចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះបង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួម និង/ឬមានគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីតាមទីជនបទមួយទៅកាន់ទីជនបទមួយទៀត និងកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះនោះទេ គាត់ថែមទាំងបានដើរតួនាទីសំខាន់មួយនៅក្នុងការផ្សព្វផ្សាយខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយទាំងនេះថែមទៀត។ ក្រោយពីបានពិចារណាលើតួនាទីផ្លូវការ និងកេរ្តិ៍ឈ្មោះនៅក្នុងចំណោមប្រជាជននោះ ត្រឹមតែវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំទាំងនេះ បានជួយសម្រួលឲ្យការណែនាំទាំងនេះមានប្រសិទ្ធភាពរួចទៅហើយ។ ការណែនាំទាំងនេះបានបញ្ជាក់ប្រាប់អ្នកមានវត្តមានក្នុងកិច្ចប្រជុំថា គាត់បានឯកភាពលើគោលបំណងរួម និងគោលនយោបាយនានា។ ករណីនេះកាន់តែគូសបញ្ជាក់ឲ្យឃើញថែមទៀតនៅពេលគាត់បានចេញសេចក្តីណែនាំដោយខ្លួនឯង។

---

[២៩៤៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩៧៤។

[២៩៤៩] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧២, ៨១៨។

[២៩៥០] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៩។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៧។

## ១៦.២.១.៣ សេដ្ឋកិច្ចវិទូ៖ ការអនុវត្តគោលបំណងរួម

៩៧៧. ខៀវ សំផន បានដើរតួនាទីសំខាន់មួយនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជាពិសេស ក្នុងនាមគាត់ជាសមាជិកមួយរូបនៃមន្ទីរ ៨៧០។ គាត់ទទួលខុសត្រូវលើការចែកចាយសម្ភារៈទៅតាមភូមិភាគ ការដឹកជញ្ជូន និងការគ្រប់គ្រង ស្រូវអង្ករពីភូមិភាគទៅកាន់ឃ្លាំងរដ្ឋ ពាណិជ្ជកម្មអន្តរជាតិ និងការនាំចូល/ការនាំចេញ និងការប្រើប្រាស់ឥណទាន[២៩៥១]។ ប្រហែលជាចាប់ពីខែ តុលា ឆ្នាំ ១៩៧៦ គាត់បានអនុវត្តការត្រួតពិនិត្យក្នុងកម្រិតខ្លះលើគណៈកម្មាធិការពាណិជ្ជកម្មដែលជារឿយៗរាយការណ៍ជូនគាត់ដើម្បីស្នើសុំការណែនាំ[២៩៥២]។

៩៧៨. កម្មាភិបាលភូមិភាគបានធ្វើសំណើសុំឲ្យ ខៀវ សំផន ផ្គត់ផ្គង់សម្ភារៈ។ ខៀវ សំផន បានឆ្លើយតបជាមួយនឹងការបញ្ជាឲ្យផ្គត់ផ្គង់[២៩៥៣]។ ខៀវ សំផន ក៏បានចុះទៅទស្សនកិច្ចនៅឃ្លាំងរដ្ឋដែលនៅទីនោះ គាត់បានធ្វើអធិការកិច្ចលើផលិតផលគ្រោងសម្រាប់នាំចេញ និងបានលើកទឹកចិត្តឲ្យកម្មករប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់[២៩៥៤]។ ឯកសារទាំងឡាយដែលបានផ្ញើជូន និងចម្លងជូន ខៀវ សំផន រួមមានរបាយការណ៍ស្តីអំពីការពិភាក្សាជាមួយគណៈប្រតិភូពាណិជ្ជកម្មបរទេស និងលិខិតឆ្លើយឆ្លងផ្សេងទៀតពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ របាយការណ៍ស្តីពីបរិមាណស្រូវអង្ករបញ្ជូនទៅឃ្លាំងរដ្ឋ និងរបាយការណ៍ស្តីពីការនាំចេញស្រូវអង្ករ និងសម្ភារៈផ្សេងទៀត សំណើបញ្ជាទិញពីក្រសួងនានា និងបញ្ជីស្តីពីទំនិញនាំចូលមកពីប្រទេសចិន របាយការណ៍ស្តីពីការប្រើប្រាស់ឥណទានប្រទេសចិនផ្តល់ជូនកម្ពុជាប្រជាធិបតេយ្យ និងសារផ្ញើជូនមកពី ឬ ផ្ញើទៅមករវាងក្រុមហ៊ុន ហ្វតត្រា (FORTRA) និង រ៉ុនហ្វ៊ុង (Ren Fung)[២៩៥៥]។

៩៧៩. គោលបំណងរួមនេះមានគោលដៅចង់បង្កើតរដ្ឋមួយដែលខ្លួនទីពឹងខ្លួន រដ្ឋមួយដែលពឹងលើកសិកម្មសម័យទំនើបក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ ខាងមុខ និងក្រោយមក ជារដ្ឋមួយដែលពឹងលើសេដ្ឋកិច្ចឧស្សាហកម្ម។ ស្រូវអង្ករ និងផលកសិកម្មសម្រាប់នាំចេញផ្សេងទៀតនឹងផ្តល់ជាទុន

---

[២៩៥១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៩០, ៤០៦-៤០៧។

[២៩៥២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៦។

[២៩៥៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៦-៤០៧។

[២៩៥៤] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៧។

[២៩៥៥] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៦។

ចាំបាច់សម្រាប់បំពេញគោលដៅនេះ[២៩៥៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តួនាទីរបស់គាត់លើការងារសេដ្ឋកិច្ចបង្ហាញឱ្យឃើញថា គាត់មិនត្រឹមតែមានគោលបំណងរួមប៉ុណ្ណោះទេ តែគាត់ថែមទាំងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តផ្នែកមួយចំនួននៃគោលបំណងរួមនេះទៀត។

### ១៦.២.១.៤ សេចក្តីថ្លែងការណ៍ជាសាធារណៈ៖ ការឯកភាពលើគោល បំណងរួម

៩៨០. ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍នានា ក្នុងនាមកម្មាភិបាលជាន់ខ្ពស់បំផុតម្នាក់នៅក្នុងការតស៊ូក្នុងប្រទេស និងក្រោយមកនៅក្នុងនាមគាត់ជាថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ជាពិសេសជាគណៈប្រធានរដ្ឋ ដែលក្នុងសេចក្តីថ្លែងការណ៍ទាំងនោះ គាត់បានកោតសរសើរគោលនយោបាយ និងការធ្វើបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយម[២៩៥៧]។ គាត់បានគូសបញ្ជាក់អំពីជ័យជម្នះកាលពីអតីតកាល និងបានលើកទឹកចិត្តឱ្យបន្តធ្វើសកម្មភាព ជាពិសេស លើការបង្ក-បង្កើនផលកសិកម្ម ការកសាងគម្រោងធារាសាស្ត្រ និងការកម្ចាត់ខ្មាំង។ គាត់ក៏បានបញ្ជាក់ហេតុផលអំពីការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញផងដែរ។ ក្នុងមុខតំណែងដ៏ខ្ពង់ខ្ពស់ និងគួរឱ្យគោរព ខៀវ សំផន បានឯកភាព និងគាំទ្រលើគោលនយោបាយរបស់ខ្មែរក្រហម និងបានទទួលការគាំទ្រក្នុងចំណោមប្រជាជន និងពីមជ្ឈដ្ឋានអន្តរជាតិចំពោះបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយមនេះ។ សុន្ទរកថាជាសាធារណៈរបស់គាត់ក៏អាចឱ្យយល់ដឹងស៊ីជម្រៅខ្លះៗផងដែរអំពីរបបខ្មែរក្រហមទាំងលើឆាកអន្តរជាតិ និងទាំងនៅក្នុងប្រទេសកម្ពុជា ជាទីកន្លែងដែលការរក្សាការសម្ងាត់ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងជាទីបំផុត។

៩៨១. ក្នុងអំឡុងពេលបដិវត្តន៍ប្រជាធិបតេយ្យ[២៩៥៨] ខៀវ សំផន បានអំពាវនាវតាមវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាដល់ប្រជាជននៅក្នុង និងនៅក្រៅប្រទេស ឱ្យចូលរួមក្នុងចលនាតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ[២៩៥៩]។ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៣ និងដើមខែ មេសា ឆ្នាំ ១៩៧៥ គាត់បានអះអាងជាសាធារណៈថា រណសិរ្សរួបរួមជាតិកម្ពុជាធានាសេរីភាពជាមូលដ្ឋានជូនដល់ប្រជាជន

---

[២៩៥៦] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០២។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨, ៧៨២។

[២៩៥៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤ (ទាក់ទិននឹងដំណាក់កាលផ្សេងនៃបដិវត្ត)។

[២៩៥៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤ (ទាក់ទិននឹងដំណាក់កាលផ្សេងនៃបដិវត្ត)។

[២៩៥៩] ផ្នែកទី៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០០។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។

កម្ពុជា[២៥៦០]។ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ខៀវ សំផន បានប្រកាសតាមវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាអំពីការវាយសម្រុកចុងក្រោយលើទីក្រុងភ្នំពេញ[២៥៦១] ហើយនៅក្នុងខែ មករា ឆ្នាំ ១៩៧៥ គាត់បានអំពាវនាវឲ្យប្រជាជនកម្មេច បន "ក្បត់" លន់ នល់ ដោយបានអូសទាញប្រជាជនឲ្យចូលរួម និងគាំទ្រដល់ចលនាតស៊ូ[២៥៦២]។ នៅក្នុងខែ មីនា ឆ្នាំ ១៩៧៥ រណសិរ្សរួបរួមជាតិកម្ពុជាបានចេញសេចក្តីថ្លែងការណ៍មួយ ដែលតាមការអះអាងប្រហែលជានៅក្រោយមហាសន្និបាតជាតិនាចុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ក្រោមអធិបតីរបស់ ខៀវ សំផន ដោយបានប្រកាសថា "ជនមហាក្បត់" ទាំង ៧ នាក់ ត្រូវតែសម្លាប់ចោល ហើយបានបញ្ជាក់ថា អ្នករដ្ឋការទាំងអស់ផ្សេងទៀតនៃរបបសាធារណរដ្ឋខ្មែរនឹងត្រូវបានទុកជីវិតឲ្យ[២៥៦៣]។ ក្រោយមក គាត់បានលើកឡើងជាសាធារណៈដដែលអំពីសេចក្តីសម្រេចសម្លាប់ "ជនមហាក្បត់" និងធានាថា អ្នករដ្ឋការផ្សេងទៀតនៃរបបសាធារណរដ្ឋខ្មែរនឹងត្រូវបានទុកជីវិតឲ្យ ប្រសិនបើពួកគេចូលរួមជាមួយចលនាតស៊ូ "ទាន់ពេលវេលា"[២៥៦៤]។

៩៨២. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៥ ខៀវ សំផន បានអំពាវនាវឲ្យធ្វើការតស៊ូខ្លាំងឡើង និងអំពាវនាវឲ្យប្រជាជនចូលរួមបុព្វហេតុនៃការតស៊ូនៅក្នុងប្រទេស[២៥៦៥]។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានប្រកាសតាមវិទ្យុរណសិរ្សរួបរួមជាតិថា "ជនមហាក្បត់" ទាំង ៧ នាក់បានចាកចេញបាត់អស់ហើយ ឬកំពុងរៀបចំផែនការចាកចេញពីក្នុងប្រទេសដើម្បីគេចពីការដាក់ទណ្ឌកម្ម[២៥៦៦]។ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានកោតសរសើរកងទ័ពដែលបានរំដោះប្រទេសព្រមទាំងបានប្រកាសថាខ្មាំងសត្រូវបានស្លាប់យ៉ាងវេទនា និងបានកត់សម្គាល់ចំពោះការលះបង់

[២៥៦០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៩ ។

[២៥៦១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៧។

[២៥៦២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។

[២៥៦៣] ផ្នែកទី៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០។ ផ្នែកទី៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៩។

[២៥៦៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧០។

[២៥៦៥] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។

[២៥៦៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៦៤។

របស់ប្រជាជននៅតាមភូមិភាគរំដោះ និងការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលើកភ្លឺស្រែ ជីកប្រឡាយ និងលើកទំនប់ទឹក[២៥៦៧]។

៩៨៣. ក្រោយថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សបានចេញសេចក្ដីសម្រេចមួយ ដែលត្រូវបានអនុម័តយល់ព្រមនៅក្នុងមហាសន្និបាតជាតិក្រោមអធិបតីរបស់ ខៀវ សំផន ដោយបានប្រកាសថា រចនាសម្ព័ន្ធនៃរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅរក្សាទុកដដែលសម្រាប់ពេលបច្ចុប្បន្ន។ សេចក្ដីសម្រេចបានគូសបញ្ជាក់បន្ថែមទៀតថា គ្មានមូលដ្ឋានយោធាបរទេសណាមួយត្រូវបានអនុញ្ញាតឲ្យបោះទីតាំងនៅក្នុងប្រទេសកម្ពុជានោះទេ និងបានបញ្ជាក់សាជាថ្មីអំពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលលើការកសាងសង្គមមួយដែលគ្មានវណ្ណៈ គ្មានការកេងប្រវ័ញ្ច និងមានតែប្រជាជនដែលនឹងប្រឹងប្រែងកសាង និងការពារប្រទេសទាំងអស់គ្នា[២៥៦៨]។

៩៨៤. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៥ សុន្ទរកថារបស់ ខៀវ សំផន ដែលថ្លែងឡើងនៅក្នុងមហាសន្និបាតជាតិមួយទៀតនៃរណសិរ្សរួបរួមជាតិកម្ពុជា បានគូសបញ្ជាក់អំពីគោលនយោបាយសមូហភាពលើគ្រប់វិស័យ និងអំពីតម្រូវការឲ្យប្រជាជនទាំងអស់ទោះធ្វើការងារស្រែចម្ការក្ដី ឬ ការងាររោងចក្រក្ដី ត្រូវខិតខំបង្កបង្កើនផលស្រូវ និងខិតខំកសាងគម្រោងធារាសាស្ត្រ។ ខៀវ សំផន ក៏បានកោតសរសើរផងដែរលើកិច្ចខិតខំរបស់ប្រជាជន និងកងទ័ពនៅក្នុងអំឡុងពេលបដិវត្តន៍ប្រជាធិបតេយ្យ ហើយបាននិយាយសំដៅដល់ការថ្កោលទោសចំពោះ "ជនមហាក្បត់" ទាំង ៧ នាក់។ ចំណុចចុងក្រោយ គាត់បានលើកទឹកចិត្តឲ្យធ្វើការតស៊ូវណ្ណៈដោយគូសបញ្ជាក់អំពីភាពចាំបាច់ត្រូវប្រឆាំងនឹងវប្បធម៌ពុករលួយនៃវណ្ណៈជិះជាន់ ចក្រពត្តិនិយម និងអាណានិគមនិយម[២៥៦៩]។

៩៨៥. នៅក្នុងសុន្ទរកថាថ្លែងបើកសម័យប្រជុំលើកទីមួយ និងប្រហែលជាសម័យប្រជុំតែម្ដងគត់ប៉ុណ្ណោះនៃសភាតំណាងប្រជាជននៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ខៀវ សំផន បានភូតកុហកនៅពេលដែលគាត់បានអះអាងថា ការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ ត្រូវបានរៀបចំឡើង

---

[២៥៦៧] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣២។

[២៥៦៨] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤២។

[២៥៦៩] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧០, ៣៧៧។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៤។

ហើយថា គោលនយោបាយពាក់ព័ន្ធនឹងការដ្ឋានធ្វើការងារ សហករណ៍ និងការបន្តតស៊ូវណ្ណៈត្រូវបានគាំទ្រពីអ្នកបោះឆ្នោត[២៩៧០]។ នៅចន្លោះថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៦ ក្នុងពិធីប្រារព្ធទិវាឯករាជ្យជាតិ ខៀវ សំផន បានប្រកាសអំពីការតាំងចិត្តយ៉ាងមុតមាំរបស់រដ្ឋាភិបាលថ្មីក្នុងការការពារឯករាជ្យជាតិ និងការផ្តោតលើការកសាងជាតិឡើងវិញ។ គាត់ក៏បានកោតសរសើរផងដែរដល់ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍ចំពោះតួនាទីរបស់ពួកគេក្នុងការរំដោះទីក្រុងភ្នំពេញដែលជាពេលបញ្ចប់នៃរបបសក្តិភូមិ-ម្ចាស់ដី និងការបន្តធ្វើការតស៊ូវណ្ណៈដើម្បី "ផ្តួលរំលំ" និង "ជីករំលើង" ពួកមូលធន[២៩៧១]។

៩៨៦. មួយឆ្នាំក្រោយមក សុន្ទរកថារបស់ ខៀវ សំផន ក្នុងទិវាឯករាជ្យជាតិនេះបានលើកទឹកចិត្តឱ្យបន្តផ្តោតលើការកសាង និងការការពារប្រទេស ខ្លួនទីពឹងខ្លួន និងការរក្សាផ្លែផ្កានៃបដិវត្តន៍។ គាត់បានពន្យល់ថា នៅក្រោយសង្គ្រាម មានការខ្វះខាតស្បៀងអាហារ មាន់ ទា គោ ក្របី និងឧបករណ៍សម្ភារៈនានា។ គាត់បានកោតសរសើរកិច្ចខិតខំនៅក្នុងវិស័យកសិកម្ម ជាពិសេស ការបង្កបង្កើនផលស្រូវ និងការងាររបស់ "អង្គភាពចម្រើន" នៅតាមការដ្ឋានធ្វើការងារ ដែលមានអ្នកធ្វើការចន្លោះពី ១០.០០០ នាក់ ដល់ ៣០.០០០ នាក់ដែលបានប្រមូលផ្តុំនៅតាមការដ្ឋានធ្វើការងារនីមួយៗ។ គាត់បានឱ្យតម្លៃលើការលះបង់របស់ប្រជាជនដែលបានពឹងលើខ្លួនឯងក្នុងការបំពេញការងារដោយគ្មានការប្រើប្រាស់ម៉ាស៊ីន។ គាត់បានពន្យល់ថា "ប្រជាជនថ្មី" មកពីទីក្រុងភ្នំពេញកាន់តែស្នេហាជាតិនៅពេលពួកគេយល់ដឹងថា ផ្លូវទៅកាន់ឯករាជ្យមានភាពលំបាកលំបិន។ ចំណុចចុងក្រោយ គាត់បានគូសបញ្ជាក់ថា ជំហរប្រុងប្រយ័ត្នបដិវត្តន៍នៅតែមានភាពចាំបាច់ក្នុងការបន្តប្រយុទ្ធប្រឆាំងនឹងខ្មាំងទាំងអស់កុំឱ្យពួកវាធ្វើសកម្មភាពឈ្លានពាន ជ្រៀតជ្រែក ឬ វិទ្ធង្សនា[២៩៧២]។ នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ខៀវ សំផន បានប្រកាសថា បក្សកុម្មុយនីស្តកម្ពុជាគឺជាបក្ស "ដ៏ភ្លឺស្វាង"។ គាត់បានកោតសរសើរដល់កងទ័ព និងប្រជាជនដែលបានវាយប្រឆាំងពួកចក្រពត្តិអាមេរិក និងបរិវាររបស់វាឱ្យបរាជ័យ ព្រមទាំងបានរិះគន់ចំពោះការឈ្លានពានរបស់វៀតណាម និងលើក

---

[២៩៧០] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣៦។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៦៥។

[២៩៧១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣។ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៦១៦។ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៦៧។

[២៩៧២] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣។ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) កថាខណ្ឌ ៥៨១, ៦១០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨, ៧៨៣, ៧៨៥, ៨២៨។

ទឹកចិត្តឲ្យបង្កើនការបង្កបង្កើនផលតាមរយៈការគោរពឲ្យបានខ្ជាប់ខ្ជួន និងជាដរាបលើជំហរឯក-រាជ្យ[២៩៧៣]។

៩៨៧. សេចក្តីថ្លែងការណ៍ជាសាធារណៈទាំងនេះ ដែលបានគាំទ្រអស់ពីចិត្តថ្លើមលើបដិវត្តន៍ និងគ្មានតម្រុយនៃការរិះគន់ណាមួយ បង្ហាញឲ្យឃើញថា ខៀវ សំផន មានគោលបំណងរួម និងមានគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន បានផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងបានកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន។ សេចក្តីថ្លែងការណ៍ទាំងនេះក៏បានបង្ហាញផងដែរថា ទោះបីជាមុខតំណែង និងតួនាទីរបស់គាត់គឺគ្រាន់តែជារូបភាពខាងក្រៅក៏ដោយ ក៏មុខតំណែង និងតួនាទីទាំងនេះគឺបានដើរតួនាទីជាក់ស្តែងដ៏សំខាន់មួយយ៉ាងពិតប្រាកដដោយសារមុខតំណែង និងតួនាទីទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ការឯកភាពលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងសម្រាប់បោកបញ្ឆោតប្រជាជន។ ខៀវ សំផន បានប្រើប្រាស់តួនាទី និង មុខតំណែងទាំងនេះនៅពេលធ្វើសេចក្តីថ្លែងការណ៍ ដែលគាត់ខ្លួនឯងបានបង្ហាញវត្តមានក្នុងនាមជាមេដឹកនាំសំខាន់មួយរូប និងបានលើកទឹកចិត្តឲ្យប្រជាជនកម្ពុជា និងកម្មាភិបាលខ្មែរក្រហមបន្តអនុវត្តបដិវត្តន៍សង្គមនិយម ដោយបិទបាំងនូវតម្លាភាព ឬជាសាធារណភាព និងទប់ស្កាត់ការជ្រៀតជ្រែក និងការប្រឆាំងពីប្រជាជន និងសហគមន៍អន្តរជាតិ។

## ១៦.២.១.៥ កម្មាភិបាលតំណាងទូត៖ ការការពារគោលបំណងរួម

៩៨៨. តួនាទីផ្លូវការរបស់ ខៀវ សំផន ក្នុងនាមជាមេដឹកនាំការតស៊ូក្នុងប្រទេស និងក្នុងនាមជាប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យមានសារៈសំខាន់នៅក្នុងអំឡុងពេលបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយម ដោយសារខ្មែរក្រហមកាន់តែចង់បានការគាំទ្រខ្លាំងឡើងពីសម្តេច នរោត្តម សីហនុ ក្រុមផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា និងនៅលើឆាកអន្តរជាតិ[២៩៧៤]។ ខៀវ សំផន ត្រូវបានគេគោរពជាទូទៅថាជាមនុស្សទៀងត្រង់ និងមានសេចក្តីថ្លៃថ្នូរ ពោលគឺជាទូទៅ គេមើលឃើញថាគាត់គឺជាមនុស្សមានមនសិការ មិនពុករលួយ និងប្រកាន់គោលការណ៍ និង

---

[២៩៧៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៨។

[២៩៧៤] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១-៣៨៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៤។

រស់នៅក្នុងជីវភាពសាមញ្ញ[២៩៧៥]។ ហេតុដូច្នេះ ខៀវ សំផន បានពន្យល់ថា គាត់គឺជា “របស់មានតម្លៃមួយ” ដែលបក្សកុម្មុយនីស្តកម្ពុជាអន្ទះសាចង់បាន[២៩៧៦]។ ម្យ៉ាងវិញទៀត ដោយសារសម្តេច នរោត្តម សីហនុ មិនស្គាល់ ប៉ុល ពត កាតព្វកិច្ចក្នុងការបង្កើតទំនាក់ទំនងជាមួយនឹងសម្តេច នរោត្តម សីហនុ និងអ្នកគាំទ្ររបស់ព្រះអង្គត្រូវធ្លាក់មកលើ ខៀវ សំផន[២៩៧៧]។ ខៀវ សំផន បានបញ្ជាក់ថា តួនាទីនេះមានសារៈសំខាន់ បើទោះជាមិនមែនថាមិនអាចខ្វះបានក៏ដោយ[២៩៧៨]។

៩៨៩. នៅក្នុងឆ្នាំ ១៩៧៣ ខៀវ សំផន បានអមព្រះរាជដំណើរសម្តេច នរោត្តម សីហនុ ក្នុងព្រះរាជដំណើរទស្សនកិច្ចទៅកាន់តំបន់រំដោះ។ គាត់ក៏បានទទួលឥស្សរជនបរទេសជាច្រើនផ្សេងទៀត រួមទាំង ឥស្សរជនមកពីប្រទេសវៀតណាមនៅក្នុងឆ្នាំ ១៩៧៤ ផងដែរ និងបានធ្វើដំណើរទៅបរទេសក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ក្នុងនោះរួមទាំងដំណើរទស្សនកិច្ចទៅតាមបណ្តាប្រទេសជាច្រើននៅក្នុងឆ្នាំ ១៩៧៤ ផងដែរ[២៩៧៩]។ នៅក្នុងខែសីហា ឆ្នាំ ១៩៧៥ ខៀវ សំផន បានអំពាវនាវដល់មន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទាំងអស់ដែលនៅក្រៅប្រទេសឲ្យវិលត្រលប់មកប្រទេសកម្ពុជាវិញ។ បន្ទាប់មក គាត់បានធ្វើដំណើរទៅកាន់ប្រទេសចិន និងកូរ៉េខាងជើងដើម្បីចរចាឲ្យសម្តេច នរោត្តម សីហនុ វិលត្រលប់មកប្រទេសវិញ។ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ ខៀវ សំផន បានពន្យល់នៅក្នុងអំឡុងពេលថ្លែងសុន្ទរកថាក្នុងទីក្រុងប៉េកាំងថា កម្ពុជាកំពុងកសាងប្រទេសឲ្យបានលឿន និងកំពុងការពារប្រទេស ពោលគឺប្រទេសទាំងមូលបានក្លាយទៅជាការដ្ឋានសាងសង់យ៉ាងធំមួយរួចទៅហើយ[២៩៨០]។

៩៩០. បន្ទាប់ពីសម្តេច នរោត្តម សីហនុ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញក្រោយពេលរំដោះប្រទេស ខៀវ សំផន បានអមដំណើរទ្រង់ក្នុងព្រះរាជដំណើរទស្សនកិច្ចទៅតាមទីជនបទ នាដើមឆ្នាំ ១៩៧៦ រួមទាំង នៅតាមការដ្ឋានធ្វើការងារ ដែលប្រជាជនរាប់ម៉ឺននាក់កំពុងប្រឹងប្រែងធ្វើការងារលើគម្រោងធារាសាស្ត្រ។ ក្នុងដំណើរទស្សនកិច្ចទាំងនេះ គាត់បានកោតសរសើរចំពោះការ

---

[២៩៧៥] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦០។

[២៩៧៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៨។

[២៩៧៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ៩៨។

[២៩៧៨] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥។

[២៩៧៩] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

[២៩៨០] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៧-៧៥៨។

កសាងទំនប់ ប្រឡាយ និងការបង្កបង្កើនផលកសិកម្ម។ គាត់បានព្យាយាមបង្ហាញអំពីជោគជ័យ និងផលប្រយោជន៍ដែលទទួលបានពីបដិវត្តន៍សង្គមនិយម ដែលគាត់ខ្លួនឯងផ្ទាល់ជឿជាក់ ហើយដែលប្រជាជនទាំងអស់បានធ្វើការងារដោយដៃទទេ ក្នុងការកសាង និងការពារប្រទេស[២៩៨១]។

៩៩១. ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានបន្តបំពេញមុខងារការទូត និងមុខងារក្នុងពិធីផ្សេងៗ ស្វាគមន៍គណៈប្រតិភូបរទេស ទទួល និងចូលរួមពិធីបដិសណ្ឋារកិច្ច បញ្ជូន និងទទួលសារតាំង និងដឹកនាំគណប្រតិភូកម្ពុជាប្រជាធិបតេយ្យទៅបរទេស[២៩៨២]។ នៅក្នុងខែ សីហា ឆ្នាំ ១៩៧៦ ក្នុងសន្និសីទលើកទីប្រាំនៃប្រទេសមិនចូលបក្សសម្ព័ន្ធក្នុងប្រទេសស្រីលង្កា ខៀវ សំផន បានបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យប្តេជ្ញាគោរពតាម គោលការណ៍ខ្លួនទីពឹងខ្លួន ឯករាជ្យ និងអព្យាក្រឹត្យ។ គាត់បានពន្យល់ថា ខ្មែរក្រហមបានទទួល ជោគជ័យលើបដិវត្តន៍ប្រជាធិបតេយ្យ ដោយសារបានប្រកាន់ខ្ជាប់លើមាគ៌ាបក្សដ៏ត្រឹមត្រូវ។ នៅពេលនិយាយអំពីឧបទ្ទវហេតុកប៉ាល់ម៉ាយ៉ាហ្គេស (Mayaguez) និងការគប់គ្រាប់បែកនៅក្នុងខេត្តសៀមរាប គាត់បានប្រកាសថា ខ្មាំងនៅតែប៉ុនប៉ងកម្ទេចផលបដិវត្តន៍។ ហេតុនេះ យើងត្រូវមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ជានិច្ច[២៩៨៣]។

៩៩២. ខៀវ សំផន បានឯកភាពលើគោលបំណងរួម និងគោលនយោបាយលើការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន បានផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងបានកំណត់គោលដៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន។ កិច្ចខិតខំប្រឹងប្រែងផ្នែកការទូតរបស់គាត់ក៏បានបង្ហាញអំពីការបន្តចូលរួមចំណែករបស់គាត់នៅក្នុងគោលបំណងរួម និងគោលនយោបាយទាំងនេះផងដែរ។ តាមរយៈមុខងារផ្នែកការទូតរបស់គាត់ និងតួនាទីជាន់ខ្ពស់របស់គាត់ ខៀវ សំផន ដែលជាអ្នកនយោបាយ និងជាបញ្ញវន្តម្នាក់ដែលមានការគោរពនោះ បានទទួលបានការគាំទ្រពីបណ្តាអ្នកគាំទ្រខ្មែរក្រហមទាំងនៅក្នុងប្រទេសកម្ពុជា និងនៅបរទេស ក្នុងការខិតខំប្រឹងប្រែងរបស់គាត់ដើម្បីផ្តល់យុត្តិកម្ម និងលើកសរសើរដល់សកម្មភាព និងនយោបាយរបស់បក្ស និងដើម្បីបង្វែរការចាប់អារម្មណ៍ និងក្តីបារម្ភពីការជ្រៀតជ្រែក។

---

[២៩៨១] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤, ៣៨០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៩។

[២៩៨២] ផ្នែកទី ៨៖ តួនាទីរបស់ ខៀវ សំផន កថាខណ្ឌ ៣៨២។

[២៩៨៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣១-៧៣២, ៧៣៦, ៧៣៨ ៨១៧, ៨២៧។

### ១៦.២.២ ចេតនា

៩៩៣. ខៀវ សំផន នៅតែលើកឡើងដដែលថា គាត់ប្តេជ្ញាចង់ឲ្យប្រទេសកម្ពុជាឯករាជ្យ និងចង់បានសុខុមាលភាពសម្រាប់ប្រជាជននាពេលអនាគត ពោលគឺ គាត់មិនមានចេតនាណាមួយចង់ប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ហើយ ពីដំបូង គាត់បានចូលរួមជាមួយខ្មែរក្រហម ដោយសារតែមានការគំរាមកំហែងពីតុលាការយោធា និងការប្រហារជីវិតនៅក្នុងឆ្នាំ ១៩៦៧ តែប៉ុណ្ណោះ[២៩៨៤]។ ការជំរុញទឹកចិត្តរបស់ ខៀវ សំផន ឲ្យចូលរួមជាមួយខ្មែរក្រហម ហើយបន្ទាប់មកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម មិនអាចជាលេសចំពោះការប្រព្រឹត្តិរបស់គាត់ ឬមិនអាចជាការបដិសេធចំពោះចេតនាឧក្រិដ្ឋរបស់គាត់បាននោះទេ។ ជាការពិត អង្គជំនុំជម្រះយល់ឃើញដូចបានរៀបរាប់ខាងក្រោមថា ការបន្តចូលរួមដោយចេតនានៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយបានដឹងថាឧក្រិដ្ឋកម្មនានាកំពុងត្រូវបានប្រព្រឹត្តឡើងនោះ បញ្ជាក់ឲ្យឃើញនូវចេតនាឧក្រិដ្ឋរបស់គាត់។

៩៩៤. ខៀវ សំផន បានអះអាងថា គាត់បានចូលរួមបដិវត្តន៍ ដោយសារបដិវត្តន៍នេះមានបំណងកសាង និងការពារប្រទេសកម្ពុជាឲ្យមានឯករាជ្យ ខ្លួនទីពឹងខ្លួនតែប៉ុណ្ណោះ[២៩៨៥]។ ចាប់ពីឆ្នាំ ១៩៦៩ នៅពេលគាត់បានចូលបក្ស គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំ មហាសន្និបាត និងសន្និសីទនានាដែលនៅពេលនោះមានការសម្រេចបង្កើតគោលបំណងរួម ហើយគោលនយោបាយអនុវត្តគោលបំណងរួមនេះត្រូវបានអនុម័ត ដោយរួមទាំងការតស៊ូវណ្ណៈប្រឆាំងនឹង "ប្រជាជនថ្មី" ការកម្ចាត់គ្រប់សមាសភាពនៃអតីតរបបសាធារណរដ្ឋខ្មែរ ការជម្លៀសប្រជាជនពីទីក្រុង និងពីទីប្រជុំជនដោយបង្ខំ និងការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយទៅទីជនបទមួយទៀត[២៩៨៦]។ ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មទាំងឡាយនឹងកើតចេញពីលទ្ធផលនៃការអនុវត្តគោលនយោបាយទាំងនេះ[២៩៨៧]។ គាត់បានដឹងថា គោលនយោបាយទាំងនេះពិតជានឹងនាំឲ្យមានឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាល

---

[២៩៨៤] *សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល* [របស់ ខៀវ សំផន] ឯកសារ E295/6/4 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ២០៨, ២០៩, ២១២, ២១៤, ២៨៣, ២៩៣, ២៩៥-២៩៦, ៣០៨-៣០៩, ៣១៣, ៣១៩, ៣២៧។

[២៩៨៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២៨។

[២៩៨៦] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៤-៩៩២។

[២៩៨៧] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

ទី១ និងដំណាក់កាលទី២ និងនៅទួលពោធិ៍ជ្រៃ[២៩៨៨]។ គាត់ក៏បានទទួលការជូនដំណឹងនាពេលក្រោយមកទៀត ក្រោយពេលឧក្រិដ្ឋកម្មទាំងនោះបានប្រព្រឹត្តឡើងផងដែរ[២៩៨៩]។ ទោះបីជាគាត់បានដឹងដូច្នេះក៏ដោយ ក៏គាត់នៅតែបន្តចូលរួមចំណែក និងឯកភាពលើដំណើរការវិវត្តនៃបដិវត្តន៍ប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយមដដែល។ គាត់បានរៀបចំផែនការ ផ្សព្វផ្សាយ អនុវត្ត អនុម័ត និងការពារគោលបំណងរួម ដែលធ្វើឲ្យមានគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងពីទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន[២៩៩០]។ អង្គជំនុំជម្រះក៏បានយល់ឃើញទៀតដែរថា ឧក្រិដ្ឋកម្មដែលបានកើតមានឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ និងនៅទួលពោធិ៍ជ្រៃ ត្រូវបានប្រព្រឹត្តឡើងស្របតាមគោលនយោបាយ និងដើម្បីសម្រេចគោលនយោបាយទាំងនេះ[២៩៩១]។

៩៩៥. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មានចេតនារួមជាមួយនឹងអ្នកចូលរួមផ្សេងទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម ដើម្បីសម្រេចឲ្យបាននូវគោលនយោបាយរួមមួយតាមរយៈការអនុវត្តគោលនយោបាយរបស់បក្សស្តីពីការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅដែលបណ្តាលឲ្យមានឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងនៅទួលពោធិ៍ជ្រៃ។ គាត់មានចេតនារួមជាមួយនឹងអ្នកចូលរួមផ្សេងទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងៗទៀត រួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ការធ្វើមនុស្សឃាតក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ក៏ដូចជា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល នៅទួលពោធិ៍ជ្រៃផងដែរ។ម្យ៉ាងវិញទៀត ដោយពិចារណាឃើញនូវការចូលរួមចំណែករបស់គាត់ក្នុងការបង្កើត ផ្សព្វផ្សាយឯកភាព និងការពារមាគ៌ាបក្សស្តីពីការតស៊ូវណ្ណៈ និងគោលនយោបាយស្តីពីការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទើបអង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន រួមជាមួយនឹងអ្នក

---

[២៩៨៨] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៤-៨១០, ៨៣៥-៨៣៧។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៥៣-៩៥៧។

[២៩៨៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៧៥៨-៧៥៩។

[២៩៩០] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥៩, ៩៦៤-៩៩២។

[២៩៩១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧៧-៧៧៨, ៨០៤-៨១០, ៨៣៥-៨៣៧។

ចូលរួមផ្សេងទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម មានចេតនារើសអើងនៅក្នុងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជន ដំណាក់កាលទី១ និងទី២។

### ១៦.២.៣ ការសន្និដ្ឋាន

៩៩៦. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន តាមរយៈសហឧក្រិដ្ឋកម្មរួម (ទម្រង់មូលដ្ឋាន) បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើមនុស្សអមនុស្សធម៌ផ្សេងទៀត (រួមមានការផ្លាស់ទីលំនៅដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។

## ១៦.៣ ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ

### ១៦.៣.១ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)

#### ១៦.៣.១.១ ការរៀបចំផែនការ

៩៩៧. អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន រួមជាមួយអ្នកផ្សេងទៀត បានរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញដែលនាំឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ការវាយលុកចុងក្រោយដើម្បីរំដោះប្រទេស និងគោលនយោបាយផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងនានា ត្រូវបានរៀបចំឡើងនៅក្នុងកិច្ចប្រជុំជាហូរហែចន្លោះឆ្នាំ ១៩៧៣ និង ដើមឆ្នាំ ១៩៧៥[២៩៩២]។ ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំនៅក្នុងខែ មិថុនា ឆ្នាំ

---

[២៩៩២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៤៧។

១៩៧៤ និង ដើមខែ មេសា ឆ្នាំ ១៩៧៥[២៩៩៣]។ អង្គជំនុំជម្រះរម្លឹកឡើងវិញថា ខៀវ សំផន គឺជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងរយៈពេលដែលមានកិច្ចប្រជុំទាំងនេះ[២៩៩៤] ដូច្នេះហើយគាត់មានសិទ្ធិក្នុងការចូលរួមប្រជុំ ទោះបីជាគាត់មិនមាន "សិទ្ធិសម្រេច" ជាផ្លូវការក៏ដោយ[២៩៩៥]។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា អនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ គាត់មានសិទ្ធិចូលរួមក្នុងការពិភាក្សារបស់គណៈកម្មាធិការនេះ[២៩៩៦]។ អង្គជំនុំជម្រះយល់ឃើញថា គាត់បានបញ្ចេញយោបល់របស់គាត់នៅក្នុងកិច្ចប្រជុំខែ មេសា ឆ្នាំ ១៩៧៥ ប៉ុន្តែអង្គជំនុំ-ជម្រះមិនមានលទ្ធភាពក្នុងការសន្និដ្ឋានថា គាត់បានធ្វើអន្តរាគមន៍យ៉ាងសកម្មនៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ឡើយ។ ប៉ុន្តែ ទោះបីជាគាត់មិនបានធ្វើអន្តរាគមន៍យ៉ាងសកម្មក៏ដោយ ក៏គាត់មានសិទ្ធិធ្វើអន្តរាគមន៍បានដែរ ហើយតាមរយៈការនៅស្ងៀមរបស់គាត់នោះ គាត់បានបង្ហាញអំពីការយល់ព្រម[២៩៩៧]។ ដូច្នេះ គាត់បានចូលរួមក្នុងកិច្ចប្រជុំទាំងនេះ និងបានអនុម័តផែនការទាំងនេះ។

៩៩៨. អង្គជំនុំជម្រះយល់ឃើញរួចហើយថា មេដឹកនាំជាន់ខ្ពស់ ដូចជា នួន ជា និង ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មនឹងកើតមានឡើងក្នុងទ្រង់ទ្រាយធំ ដោយសារគោលនយោបាយដែលផ្អែកទៅលើគោលការណ៍សម្ងាត់ ការបំពាក់បំប៉នមនោគមន៍វិជ្ជាដ៏តឹងរ៉ឹងទៅលើកសិករដែលគ្មានការអប់រំ ស្តីអំពីការតស៊ូវណ្ណៈ រួមទាំងការកំណត់ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង និងគោលបំណងដើម្បីសម្រេចឱ្យបាននូវឯករាជ្យជាតិ ទោះជាត្រូវលះបង់អ្វីក៏ដោយ[២៩៩៨]។ ផែនការដែលបានសម្រេចឡើងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបានអនុវត្តស្របទៅតាមគោលនយោបាយ និងដើម្បីសម្រេចនូវគោលនយោបាយទាំងនេះ[២៩៩៩]។ អង្គជំនុំជម្រះយល់ឃើញថា ផែនការដែលបានអនុម័តនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥ ពិតជាមានអត្ថិភាព និងអាចប្រមើល

---

[២៩៩៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣-១៣៨, ១៤៤-១៤៧។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្ម-ទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៦។

[២៩៩៤] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៣, ៣៨៤។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្ម-ទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦១។

[២៩៩៥] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២។

[២៩៩៦] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៨។

[២៩៩៧] ផ្នែកទី៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤២, ១៤៧។

[២៩៩៨] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

[២៩៩៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨០៤-៨១០។

ឃើញថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាក្នុងទ្រង់ទ្រាយធំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

៩៩៩. នៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ គណៈកម្មាធិការមជ្ឈិមបានពិភាក្សាលម្អិតអំពី "ជោគជ័យ" របស់បក្សនៅឧត្តុង្គ ដែលប្រជាជននៅទីនោះត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ និងធ្វើបាប ហើយប្រជាជនជាច្រើនត្រូវបានសម្លាប់ រួមទាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[៣០០០]។ ដោយបានពិនិត្យទៅលើបទពិសោធន៍នេះ និងដោយបានដឹងថា មានការខ្វះខាតម្ហូបអាហាររួចទៅហើយនៅទូទាំងប្រទេស និងជាពិសេសនៅក្នុងទីក្រុងភ្នំពេញនោះ គណៈកម្មាធិការមជ្ឈិមក៏បានសម្រេចផ្លាស់ទីលំនៅប្រជាជនចេញពីតំបន់ប្រជុំជននានា រួមទាំងទីក្រុងភ្នំពេញផងដែរ[៣០០១] ដោយមិនបានចាត់វិធានការណាមួយដែលតម្រូវឲ្យមានការយល់ព្រមពីប្រជាជន និងដើម្បីធានាសុខុមាលភាពរបស់ប្រជាជនដែលត្រូវបានជម្លៀសនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា អ្នកទាំងឡាយ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ដោយមាន ខៀវ សំផន ចូលរួមផងដែរ នោះ បានរៀបចំផែនការរួមគ្នាមួយ ដែលអាចប្រមើលឃើញថា នឹងមានការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ពោលគឺការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

១000. នៅដើមខែ មេសា ឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់ រួមទាំង ខៀវ សំផន បានលើកឡើងជាថ្មីម្តងទៀតអំពី "ការជម្លៀស" ប្រជាជនចេញពីទីក្រុងភ្នំពេញ។ មានការពិភាក្សា និងការពិនិត្យឡើងវិញ អំពីបទពិសោធន៍មុនៗក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីទីប្រជុំជននានា ទៅតាមទីជនបទ[៣០០២] ដែលជាវិធីសាស្ត្រអនុវត្តដ៏ស៊ីសង្វាក់គ្នា នៅមុនខែ មេសា ឆ្នាំ ១៩៧៥[៣០០៣]។ នៅពេលនោះ ខៀវ សំផន និងអ្នកចូលរួមផ្សេងៗទៀតបានបញ្ជាក់អំពីសេចក្តីសម្រេចក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[៣០០៤]។ ប៉ុន្តែ ទោះបីជាការពិនិត្យឡើងវិញទៅលើបទ

[៣០០០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២៤-១២៥, ១៣៤។

[៣០០១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៤, ១៦១-១៦៧។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៣៥-៥៤០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៧, ៧៨៨។

[៣០០២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៥។

[៣០០៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤។

[៣០០៤] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៤-១៤៧។

ពិសោធន៍មុនៗក្នុងការជម្លៀសប្រជាជន ដែលត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈការរងទុក្ខវេទនា អំពើហិង្សាដោយរើសអើងប្រឆាំងនឹង “ប្រជាជន ថ្មី” និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការស្លាប់ដែលបណ្ដាលមកពីស្ថានភាពនៃការផ្លាស់ទីលំនៅ ការប្រើប្រាស់កម្លាំង និងការធ្វើឱ្យភ័យតក់ស្លុត ក៏ដោយ ក៏មិនមានការលើកឡើងនូវដំណោះស្រាយ ចំពោះស្ថានភាពដែលអាចប្រមើលឃើញស្រដៀងគ្នានេះ នៅក្នុងអំឡុងពេលនៃការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ផែនការនេះបានប្រមើលឃើញថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

១០០១.ផែនការនេះបានរៀបចំឡើងជាមុន និងបានរួមចំណែកយ៉ាងច្រើនចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត ក្នុងអំឡុងពេលនៃការផ្លាស់ទីលំប្រជាជននៅដំណាក់កាលទី១។ ផែនការនេះត្រូវបានផ្សព្វផ្សាយតាមរយៈខ្សែសង្វាក់នៃការបញ្ជារបស់បុគ្គលទាំងឡាយ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥[៣០០៥]។ វិធីសាស្ត្រ ស៊ីសង្វាក់គ្នាទៅនឹងវិធីសាស្ត្រអនុវត្តដែលបានចាប់ផ្ដើមនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តកើតមានក្រោយមកទៀតនោះ[៣០០៦] ត្រូវបានយោធាខ្មែរក្រហមចាប់ផ្ដើមអនុវត្តតែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីរំដោះទីក្រុងភ្នំពេញ[៣០០៧]។

១០០២.អង្គជំនុំជម្រះបានយល់ឃើញរួចហើយថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១[៣០០៨]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ក្នុងការរៀបចំផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខៀវ សំផន មានចេតនា ឬបានដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ នៅពេលមានការអនុវត្តផែនការនេះ។

១០០៣.អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការ

[៣០០៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤៤, ១៤៨-១៥១។

[៣០០៦] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤។

[៣០០៧] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៤។

[៣០០៨] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

សម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៦.៣.១.២ ការបញ្ជា

១០០៤. អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា ទោះបីជាមិនចាំបាច់ត្រូវបង្ហាញឲ្យឃើញពីទំនាក់ទំនងជាផ្លូវការរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ក៏ដោយ ក៏លក្ខខណ្ឌនៃការបញ្ជាតម្រូវថាជនជាប់ចោទ ក្នុងឋានៈជាអ្នកមានអំណាចតាមព្រឹត្តិហេតុ ឬតាមផ្លូវច្បាប់ បង្គាប់បុគ្គលផ្សេងទៀតឲ្យប្រព្រឹត្តបទឧក្រិដ្ឋមួយ[៣០០៩]។ ភ័ស្តុតាងក៏ត្រូវតែបង្ហាញឲ្យឃើញផងដែរថាជនជាប់ចោទបានបញ្ជា បញ្ជូនបញ្ជា ឬបើមិនដូច្នេះទេ ផ្សព្វផ្សាយបញ្ជា តែម្នាក់ឯង ឬរួមជាមួយនឹងអ្នកផ្សេងទៀត រួមទាំងតាមរយៈអន្តរការីផងដែរ។

១០០៥. ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា មិនមានភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា ខៀវ សំផន បានចេញបញ្ជាណាមួយតែម្នាក់ឯងដល់ចារី ក្នុងអំឡុងរយៈពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ឬថា ចារីណាម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មតាមបញ្ជាដែលទទួលបានពីរូបគាត់ឡើយ។ ខៀវ សំផន មិនស្ថិតនៅក្នុងផ្នែករចនាសម្ព័ន្ធយោធារបស់បក្សកុម្មុយនីស្តកម្ពុជាដោយផ្ទាល់នោះទេ ហើយតួនាទីផ្សេងទៀត ដែលគាត់បានកាន់កាប់ មិនបានផ្តល់នូវអំណាចយោធាគ្រប់គ្រាន់ដើម្បីបង្គាប់ឲ្យអ្នកផ្សេងទៀតប្រព្រឹត្តឧក្រិដ្ឋកម្មនោះដែរ។ ទោះបីជា ខៀវ សំផន ពិតជាមានឥទ្ធិពលទៅលើអ្នកដទៃទៀតតាមរយៈ សេចក្តីប្រកាសតាមវិទ្យុ និងសេចក្តីថ្លែងការណ៍ជាសាធារណៈក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា តួនាទីទាំងនេះមិនបានផ្តល់អំណាចក្នុងការចេញបញ្ជាទៅកាន់បញ្ជាការយោធាឡើយ។ អង្គជំនុំជម្រះ ជឿជាក់ថា ខៀវ សំផន មិនធ្លាប់មានការទទួលខុសត្រូវខាងផ្នែកយោធាដោយផ្ទាល់នោះទេ[៣០១០]។ ទោះបីជា នៅពេលគាត់បានទទួលតួនាទីជាប្រធានគណៈប្រធានរដ្ឋក៏ដោយ ក៏តួនាទីនេះជាតួនាទីដែលមិនមានអំណាច ហើយតាមពិតទៅមិនមានអំណាចចេញបញ្ជាឡើយ។

---

[៣០០៩] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧០២។

[៣០១០] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥, ៣៧៨, ៤០៩។

១០០៦. ការសម្រេចផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើឡើងរួមគ្នានៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ហើយត្រូវបានបញ្ជាក់នៅក្នុងកិច្ចប្រជុំដើមខែ មេសា ឆ្នាំ ១៩៧៥។ បន្ទាប់ពីកិច្ចប្រជុំទាំងពីរលើកនេះ សេចក្តីសម្រេចនេះត្រូវបានផ្សព្វផ្សាយតាមរយៈខ្សែសង្វាក់នៃការបញ្ជា[៣០១១]។ អង្គជំនុំជម្រះជឿជាក់ថា អំពើនេះមានចរិតលក្ខណៈពេញលេញជាការបញ្ជា។ ប៉ុន្តែ ទោះបីជា ខៀវ សំផន មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម និងបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗទៀតរបស់មជ្ឈិមបក្ស ដែលគាត់បានរួមចំណែកនៅក្នុងការរៀបចំផែនការរួមក្នុងការជម្លៀសប្រជាជនក៏ដោយ ក៏ការចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះមិនបានបង្ហាញថា គាត់មានអំណាចគ្រប់គ្រាន់ក្នុងការចេញបញ្ជារួមជាមួយនឹងអ្នកចូលរួមផ្សេងទៀតនៅក្នុងកិច្ចប្រជុំទាំងនេះឡើយ[៣០១២]។ ខៀវ សំផន ក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិម និងជាសមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ។ តួនាទីទាំងនេះធ្វើឱ្យគាត់អាចមានឥទ្ធិពលនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ជាពិសេសដោយសារតែ សេចក្តីសម្រេចទាំងនោះត្រូវបានធ្វើឡើង ដោយអនុលោមតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ហើយដោយសារតែមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត រួមទាំង ប៉ុល ពត មានទំនុកចិត្តខ្លាំងមកលើរូបគាត់។ ដូច្នេះ អង្គ-ជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងបង្ហាញថា ខៀវ សំផន បានកាន់តួនាទីមួយចំនួន ដែលមានអំណាចខ្លះ។ តាមពិតទៅ គាត់មានទំនាក់ទំនងជិតស្និតជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅគ្រប់ពេលក្នុងអំឡុងបដិវត្តសង្គមនិយម និងបដិវត្តប្រជាធិបតេយ្យ[៣០១៣] ហើយបានរួមចំណែកយ៉ាងសំខាន់ចំពោះគោលនយោបាយដែលរបបខ្មែរក្រហមបានសម្រេច និងអនុវត្ត សំខាន់តាមរយៈវត្តមានជាទៀតទាត់ និងការចូលរួមនៅក្នុងកិច្ចប្រជុំសំខាន់ៗរបស់មជ្ឈិមបក្ស ដែលបានរៀបចំគោលបំណងរួម និងគោលនយោបាយនានា រួមទាំងសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញផងដែរ[៣០១៤]។

១០០៧. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះពិចារណាឃើញថា ដោយមិនមានភ័ស្តុតាងណាមួយ ដែលបង្ហាញថា ខៀវ សំផន បានចេញបទបញ្ជានោះ ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយនឹងរបបខ្មែរក្រហម មិនអាចនាំឱ្យមានការសន្និដ្ឋានថា ជាការពិចារណាដែលសមហេតុផលតែ

---

[៣០១១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៤, ១៤២-១៤៥, ១៤៨។

[៣០១២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៥២។ ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២២៨។

[៣០១៣] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ៤០៨-៤០៩។

[៣០១៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាណ្ឌ ៩៦៤-៩៧៦។

មួយគត់ចេញពីភស្តុតាងដែលថាគាត់មានលទ្ធភាពក្នុងការចេញបញ្ជាដោយខ្លួនឯង ឬរួមជាមួយនឹងអ្នកផ្សេងទៀតនោះទេ។ នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋាននេះ អង្គជំនុំជម្រះក៏បានថ្លឹងថ្លែងអំពីការយកប្រជាធិបតេយ្យប្រមូលផ្ដុំធ្វើជាគោលនយោបាយ ក្នុងការធ្វើសេចក្ដីសម្រេចនៅក្នុងមជ្ឈិមបក្សដែរ។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានរកឃើញ ភស្តុតាងណាមួយដែលថា នៅមុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ឬក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ កំពុងតែបន្តកើតមាននៅសប្ដាហ៍បន្ទាប់នោះ ខៀវ សំផន មានអំណាចគ្រប់គ្រាន់ក្នុងការចេញបទបញ្ជាដោយខ្លួនឯង ឬរួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធចំពោះបទចោទដែលថា គាត់ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបញ្ជាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនានាក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៦.៣.១.៣ ការជួយ និងជំរុញ

១០០៨. អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានផ្ដល់ជំនួយជាក់ស្ដែង ការលើកទឹកចិត្ត និងជំនួយផ្នែកស្មារតីដល់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។ នៅក្នុងសុន្ទរកថាជាសាធារណៈក្នុងអំឡុងពេលនៃការវាយលុកផ្ដាច់ព្រាត់ទៅលើទីក្រុងភ្នំពេញ ខៀវ សំផន បានលើកសរសើរដល់ពួកខ្មែរក្រហម ហើយបានអះអាងថា ចលនាតស៊ូផ្ទៃក្នុងប្ដេជ្ញាចិត្តលើកកម្ពស់សិទ្ធិមនុស្ស និងបានប្រកាសនូវសេចក្ដីសម្រេចក្នុងការសម្លាប់ "ជនមហាក្បត់" ទាំង ៧ នាក់។ លើសពីនេះទៀត គាត់បានលើកទឹកចិត្តប្រជាជនដែលរស់នៅក្នុងទឹកដីគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរ និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឱ្យចូលរួមជាមួយខ្មែរក្រហម ដោយអះអាងថា មានតែ "ជនមហាក្បត់" ចំនួន ៧ នាក់ ប៉ុណ្ណោះ នឹងត្រូវផ្ដន្ទាទោស។ ខៀវ សំផន ក៏ជាអ្នកខិតខំឱ្យទទួលបានការគាំទ្រពី នរោត្ដម សីហនុ ដែលការលើកសរសើររបស់ព្រះអង្គចំពោះពួកខ្មែរក្រហម បានធ្វើឱ្យអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមានការជឿទុកចិត្ត។ ចុងក្រោយ បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្មរួចមក ខៀវ សំផន បានលើកសរសើរដល់កងទ័ព និងប្រជាជនកម្ពុជាចំពោះជ័យជម្នះរបស់ពួកគេ លើកសរសើរដល់គោលនយោបាយរបស់ខ្មែរក្រហមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយម តាមរយៈសមូហភាវូបនីយកម្ម។ ខៀវ សំផន បានថ្កោលទោសរបបមុន និងបានផ្ដល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅក្នុងសុន្ទរកថាថ្លែងទៅកាន់ប្រជាជនកម្ពុជា សេចក្ដីថ្លែងការណ៍ទៅកាន់សហគមន៍

អន្តរជាតិ និងនៅក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាចំពោះអ្នកដែលវិលត្រឡប់ចូលមកក្នុងប្រទេសវិញ[៣០១៥]។

១០០៩. ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និងជំនួយផ្នែកស្មារតីនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។ ខៀវ សំផន ដើរតួនាទីសំខាន់ជាមួយខ្មែរក្រហម បើទោះជាមិនមែនមិនអាចខ្វះបានក្តី ដោយសារតែកេរ្តិ៍ឈ្មោះ និងប្រជាប្រិយភាពរបស់គាត់ នៅក្នុងចំណោមប្រជាជន និងនៅលើឆាកអន្តរជាតិ[៣០១៦]។ ដោយផ្អែកទៅលើកេរ្តិ៍ឈ្មោះ តួនាទីជាផ្លូវការរបស់គាត់ នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រទាំងស្រុងរបស់គាត់ចំពោះខ្មែរក្រហមនោះ អង្គជំនុំជម្រះជឿជាក់ថា សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន បានលើកទឹកចិត្តដល់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

១០១០.អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា ដោយផ្អែកទៅលើកេរ្តិ៍ឈ្មោះរបស់គាត់ អ្នកទាំងឡាយដែលរស់នៅក្នុងទឹកដីគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរ និងជាពិសេស អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅពី "ជនមហាក្បត់" ទាំង ៧ នាក់នោះ ជឿថាពួកគេនឹងមិនត្រូវបានគេធ្វើបាបបន្ទាប់ពីរំដោះទេ។ ការណ៍នេះត្រូវបានបង្ហាញឲ្យឃើញតាមរយៈការស្វាគមន៍ដែលខ្មែរក្រហមបានទទួលនៅពេលរំដោះទីក្រុងភ្នំពេញ និងការយល់ព្រមរបស់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងការធ្វើតាមការណែនាំឲ្យប្រមូលផ្តុំគ្នា មុនពេលពួកគេត្រូវបានគេយកទៅសម្លាប់ចោលក្នុងទ្រង់ទ្រាយធំ[៣០១៧]។ ការបោកបញ្ឆោតថាមានសុវត្ថិភាព ដែល ខៀវ សំផន បានផ្សព្វផ្សាយនោះ បានធ្វើឲ្យមានលក្ខណៈកាន់តែងាយស្រួលថែមទៀត ក្នុងការបោកបញ្ឆោតប្រជាជននៅតាមទីក្រុង និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[៣០១៨]។

១០១១.ចុងក្រោយ អង្គជំនុំជម្រះជឿជាក់ថា ចារីបានដឹង ឬយ៉ាងហោចណាស់ បានប្រមើលឃើញនៅមុន និងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញថា ខៀវ សំផន

[៣០១៥] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

[៣០១៦] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧, ៣៧៦។

[៣០១៧] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៤, ៥០១-៥១៥។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣១។

[៣០១៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០។

នឹងផ្តល់ជំនួយ និងគាំទ្រនៅក្រោយព្រឹត្តិការណ៍នេះ។ តាមពិត ការរំពឹងទុកជាមុនដូច្នេះ ស្របគ្នាជាមួយនឹងការគាំទ្ររបស់គាត់ នៅក្នុងបដិវត្តន៍ប្រជាធិបតេយ្យទាំងមូល ជាពិសេសក្នុងអំឡុងពេលនៃការវាយលុកចុងក្រោយទៅលើទីក្រុងភ្នំពេញ និងនៅប៉ុន្មានថ្ងៃដំបូងបន្ទាប់ពី រំដោះ[៣០១៩]។ ខៀវ សំផន ក៏បានយល់ស្របទៅនឹងសេចក្តីសម្រេចផ្លាស់ទីលំនៅប្រជាជនផងដែរ[៣០២០]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ពឹងផ្អែកមួយផ្នែកទៅលើការធានាដែលថា ខៀវ សំផន នឹងបន្តផ្តល់ជំនួយនៅក្រោយព្រឹត្តិការណ៍នេះ។ ជំនួយនេះបានលើកទឹកចិត្តដល់ចារី និងមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ។

១០១២.ខៀវ សំផន បានដឹងថា ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ទំនងជានឹងត្រូវបានប្រព្រឹត្តឡើង[៣០២១] និងដឹងថា អំពើរបស់គាត់បានជួយ និងសម្របសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា ខៀវ សំផន យ៉ាងហោចណាស់ បានដឹងអំពីធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋ។ ដោយមានការដឹងអំពីធាតុផ្សំទាំងនេះ ហើយ ខៀវ សំផន បានផ្តល់ជំនួយ ការលើកទឹកចិត្ត និងជំនួយផ្នែកស្មារតី ទៅដល់ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

១០១៣. អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការជួយ និង ជំរុញឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៦.៣.១.៤ ការញុះញង់

១០១៤.មុនពេលចូលកាន់កាប់ទីក្រុងភ្នំពេញ ខៀវ សំផន បានថ្លែងសុន្ទរកថាជាសាធារណៈជាច្រើនដង ដោយបានលើកសរសើរដល់ខ្មែរក្រហម ប្រើប្រាស់កេរ្តិ៍ឈ្មោះរបស់គាត់ជួយដល់ផែនការរបស់មជ្ឈិមបក្ស និងជំរុញឲ្យកងទ័ពខ្មែរក្រហម និងកម្មាភិបាល ចាត់វិធានការដើម្បីអនុវត្តគោល

---

[៣០១៩] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩៨០-៩៨៧។

[៣០២០] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៥២។

[៣០២១] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥៧។

នយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[៣០២២]។ សុន្ទរកថារបស់គាត់ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយដោយសារតែជំនឿទុកចិត្តដែលសាធារណជនមានចំពោះរូបគាត់ កងទ័ព និងកម្មាភិបាលខ្មែរក្រហម ត្រូវបានជំរុញឱ្យអនុវត្តតាមការអំពាវនាវឱ្យប្រើអំពើហិង្សា ដែលមាននៅក្នុងសុន្ទរកថាទាំងអស់នេះ។ ខៀវ សំផន ក៏បានធ្វើឱ្យចារីចាត់វិធានការក្នុងការជួយជំរុញគោលនយោបាយបក្ស តាមរយៈវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំពិភាក្សាស្ដីពីការជម្លៀសប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញដោយបង្ខំ។ ជាពិសេស គាត់បានគាំទ្រដល់មជ្ឈិមបក្សចំពោះការធ្វើសេចក្ដីសម្រេចផ្សេងៗនៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ និងខែមេសា ឆ្នាំ ១៩៧៥ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង[៣០២៣]។ នៅក្នុងកិច្ចប្រជុំទាំងអស់នេះ ខៀវ សំផន បានកោតសរសើរដល់សេចក្ដីសម្រេចក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ លើសពីនេះទៀត ខៀវ សំផន បានចូលរួមដោយផ្ទាល់នៅក្នុងការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាដល់ប្រជាជន អំពីការតស៊ូវណ្ណៈ ហើយគាត់ក៏បានដឹងថា ការបំពាក់បំប៉នផ្នែកមនោគមន៍វិជ្ជាបែបនេះពិតជាធ្វើឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយជៀសមិនរួច[៣០២៤]។ ការរំពឹងទុកដោយសមហេតុផលតែមួយគត់ គឺថា ប្រជាជនយ៉ាងច្រើននឹងទទួលរងទុក្ខវេទនា និងឬ/ ស្លាប់នៅក្នុងពេលផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ។ នៅខណៈដែលលើកទឹកចិត្ត និងជំរុញយ៉ាងសកម្មដល់ប្រជាជនក្នុងប្រទេសកម្ពុជាឱ្យចូលរួមជាមួយខ្មែរក្រហម និងគោលនយោបាយរបស់បក្សនោះ ខៀវ សំផន មិនបានធ្វើអ្វីដើម្បីកាត់បន្ថយ ឬសម្រាលអំពើហិង្សាដែលមាននៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនោះឡើយ។ អំពើសកម្ម និងអកម្មទាំងអស់នេះ បានជួយរួមចំណែកយ៉ាងសំខាន់ដល់អំពើរបស់កងទ័ព និងកម្មាភិបាលខ្មែរក្រហម ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ។

១០១៥. អង្គជំនុំជម្រះបានយល់ឃើញរួចមកហើយថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី១។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការថ្លែងសុន្ទរកថាជាសាធារណៈ ការជំរុញដល់កងទ័ព និងកម្មាភិបាលខ្មែរក្រហម ខៀវ សំផន មានចេតនា ឬដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

---

[៣០២២] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨២។

[៣០២៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤២, ១៤៤, ១៤៦។

[៣០២៤] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩៧៣-៩៧៦។

ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការញុះញង់ឱ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៦.៣.១.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

១០១៦.ការទទួលខុសត្រូវរបស់ថ្នាក់លើ ផ្អែកទៅលើសមត្ថភាពរបស់ជនជាប់ចោទក្នុងការអនុវត្តអំណាចជាក់ស្តែងលើអ្នកក្រោមបង្គាប់ ដែលនោះគឺជាអំណាចពិតប្រាកដក្នុងការចាត់វិធានការចាំបាច់ និងសមស្របដើម្បីទប់ស្កាត់ និងដាក់ទោសដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[៣០២៥]។

១០១៧.ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ត្រូវបានប្រព្រឹត្តដោយយោធាខ្មែរក្រហមក្រោមអំណាចផ្ទាល់របស់មេបញ្ជាការលេខាភូមិភាគ និងលេខាតំបន់ស្វយ័តរបស់ពួកគេ[៣០២៦]។ ខៀវ សំផន មានវត្តមាននៅមន្ទីរ ប-៥ រួមជាមួយនឹងកម្មាភិបាលកងទ័ពដទៃទៀត ក្នុងអំឡុងពេលនៃការវាយលុកចុងក្រោយទៅលើទីក្រុងភ្នំពេញ [៣០២៧]។ គាត់បានថ្លែងទៅកាន់កងទ័ព នៅក្នុងការផ្សាយតាមវិទ្យុនានា[៣០២៨]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានយល់ឃើញរួចហើយថា ទោះបីជាគាត់បានចូលរួមក្នុងកិច្ចប្រជុំនានាដែលមានការពិភាក្សាអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏ ខៀវ សំផន មិនមានអំណាចគ្រប់គ្រាន់នោះទេ ក្នុងការបញ្ជាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ (ដូចដែលបានបញ្ជាក់ពីខាងលើ ទាក់ទិននឹងការចោទប្រកាន់អំពីការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មផ្នែក ១៦.៣.១.២)[៣០២៩]។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ខៀវ សំផន មិនមានអំណាចជាក់ស្តែង នៅមុនពេល ឬក្នុងអំឡុងពេលនៃការប្រព្រឹត្តិ

---

[៣០២៥] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧១៥។

[៣០២៦] *សូមមើល* ផ្នែកទី៥៖ រចនាសម្ព័ន្ធ កថាខណ្ឌ ២៤០។ ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦០-៤៦១, ៤៧០, ៤៩០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៨៨។

[៣០២៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៥។

[៣០២៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១០០។

[៣០២៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០០៧។

ឧក្រិដ្ឋកម្មនៅក្នុងដំណាក់កាលទី១ ឡើយ ដូច្នេះហើយគាត់មិនមានកាតព្វកិច្ចបន្ថែមដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនោះទេ។

១០១៨.បន្ទាប់មកទៀត អង្គជំនុំជម្រះពិចារណាទៅលើអំណាចជាក់ស្តែងរបស់ជនជាប់ចោទតាមផ្លូវច្បាប់ ឬតាមព្រឹត្តិហេតុ បន្ទាប់ពីមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងពិចារណាថាតើ គាត់មានកាតព្វកិច្ចបន្ថែមដើម្បីដាក់ទោសដល់ចារីដែរ ឬទេ។ ទោះបីជា ខៀវ សំផន កាន់តួនាទីជាន់ខ្ពស់ជាច្រើននៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងក្នុងរូបភាពបិទបាំងពីខាងក្រៅរបស់កម្ពុជាប្រជាធិបតេយ្យ ដែលបានបង្ហាញជាសាធារណៈថា គាត់ជាមេដឹកនាំជាន់ខ្ពស់បំផុតរបស់ចលនាតស៊ូផ្ទៃក្នុង និងជាប្រមុខរដ្ឋ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៦ ក៏ដោយ[៣០៣០] ក៏មិនមានភ័ស្តុតាងបង្ហាញថា គាត់បានចេញបទបញ្ជាណាមួយដល់ចារី ក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការកាន់តួនាទីទាំងនេះ និងការធ្វើសេចក្តីប្រកាសនានាជាសាធារណៈរបស់គាត់ពាក់ព័ន្ធនឹង "ពួកជនមហាក្បត់" ទាំង ៧ នាក់នោះ ខៀវ សំផន បានរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម ដូចជា ការផ្តល់ជំនួយ លើកទឹកចិត្ត ការពារ និងគាំទ្ររបបខ្មែរក្រហម[៣០៣១]។ ទោះបីជាយ៉ាងណាក៏ដោយ ភ័ស្តុតាងមិនបានបង្ហាញថា ខៀវ សំផន បានអនុវត្តអំណាចជាក់ស្តែងទៅលើចារីនៃឧក្រិដ្ឋកម្ម តាមរយៈតួនាទីទាំងនេះនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យឡើយ។

១០១៩.លើសពីនេះទៀត នៅក្នុងរចនាសម្ព័ន្ធបក្សគឺ នួន ជា ទេ ដែលជាអ្នកទទួលខុសត្រូវចំពោះការដាក់ទណ្ឌកម្មលើសមាជិកបក្ស មិនមែន ខៀវ សំផន ឡើយ[៣០៣២]។ ខៀវ សំផន គឺជាសមាជិកត្រៀម និងនៅត្រឹមខែ មករា ឆ្នាំ ១៩៧៦ គាត់គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថាប័ននេះមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចឡើយ។ ផ្ទុយទៅវិញគណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាស្ថាប័នខ្ពស់បំផុតក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[៣០៣៣]។ អង្គជំនុំជម្រះបានយល់ឃើញថា គោលការណ៍ប្រជាធិបតេយ្យ

---

[៣០៣០] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៣២-២៣៣។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៥៤, ៧៦៦។

[៣០៣១] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

[៣០៣២] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣២៥។

[៣០៣៣] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២០២-២០៣។

ប្រមូលផ្ដុំបានផ្ដល់ឱកាសឲ្យ ខៀវ សំផន ចូលរួមនៅក្នុងកិច្ចប្រជុំនានារបស់មជ្ឈិមបក្ស ជាពិសេស គាត់បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុន្តែមិនបានបង្ហាញថា គាត់បានអនុវត្តអំណាចជាក់ស្ដែងនោះឡើយ[៣០៣៤]។

១០២០.ខៀវ សំផន មិនមានអំណាចលើស្ថាប័នសេដ្ឋកិច្ចមួយចំនួនរបស់មជ្ឈិមបក្សឡើយ ពិសេសបន្ទាប់ពីគាត់ចាប់ផ្ដើមគ្រប់គ្រងទៅលើគណៈកម្មាធិការពាណិជ្ជកម្មនៅចុងឆ្នាំ ១៩៧៦[៣០៣៥]។ ទោះបីជាយ៉ាងណាក៏ដោយ ចារីនៃឧក្រិដ្ឋកម្មនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ មិនមែនជាសមាជិកនៃស្ថាប័នសេដ្ឋកិច្ចទាំងនេះទេ ហើយមិនមានភ័ស្ដុតាងបង្ហាញថា ខៀវ សំផន បានអនុវត្តអំណាចជាក់ស្ដែងទៅលើចារី តាមរយៈអំណាចផ្នែកសេដ្ឋកិច្ចរបស់គាត់ឡើយ។ អង្គជំនុំជម្រះបានយល់ឃើញថា ខៀវ សំផន បានអនុវត្តអំណាចក្នុងវិសាលភាពមួយដែលទូលំទូលាយជាងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ សំអាងហេតុនេះ គឺកំរិតទៅលើសមត្ថភាពរបស់គាត់ក្នុងការធានាសុវត្ថិភាពសមាជិកគ្រួសារមួយចំនួនរបស់គាត់នៅជនបទក្នុងឆ្នាំ ១៩៧៨[៣០៣៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចបង្កើតមូលដ្ឋាននៃសំអាងហេតុណាមួយដែលថា គាត់បានអនុវត្តអំណាចប្រកបដោយប្រសិទ្ធភាព នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០១ ឡើយ។

១០២១.ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ទៅលើភាពស្និតស្នាលជាបន្តបន្ទាប់របស់ ខៀវ សំផន ជាមួយនឹងមេដឹកនាំជាន់ខ្ពស់នានា នៅពេញទូទាំងរយៈពេលដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងសារៈសំខាន់របស់គាត់នៅក្នុងរបបខ្មែរក្រហម និងការចូលរួមយ៉ាងសំខាន់នៅក្នុង សហឧក្រិដ្ឋកម្មរួម ជាពិសេស វត្តមានយ៉ាងទៀងទាត់ និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំ និងការរៀបចំផែនការនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងស្ថាប័នផ្សេងៗទៀតរបស់មជ្ឈិមបក្ស[៣០៣៧]។ អង្គជំនុំជម្រះយល់ឃើញថា ភ័ស្ដុតាងទាំងនេះមិនអាចនាំឲ្យមានការសន្និដ្ឋានថា គាត់ បានអនុវត្ត

---

[៣០៣៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៩៧-១០០៣។

[៣០៣៥] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៣,៤០៦។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៩៧។

[៣០៣៦] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៩។

[៣០៣៧] ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៤០៨-៤០៩។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៤-៩៩២។

អំណាចប្រកបដោយប្រសិទ្ធភាពនោះឡើយ។ ឥទ្ធិពលជាសារធាតុតែមួយមុខ គឺមិនបង្កើតឲ្យមានប្រសិទ្ធភាពនៃការគ្រប់គ្រង នៅក្នុងរចនាសម្ព័ន្ធនៃការបញ្ជាឡើយ[៣០៣៨]។

១០២២.ដោយផ្អែកលើភ័ស្តុតាងទាំងអស់នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនមែនជាថ្នាក់លើឡើយ ដោយពិនិត្យទៅលើសមត្ថភាពក្នុងការសម្រេច និងចាត់វិធានការដើម្បីទប់ស្កាត់ និងដាក់ទោសចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ តាមពិត មានការសន្និដ្ឋានសមហេតុផលផ្សេងទៀត ដែលអាចទាញចេញពីភ័ស្តុតាងទាំងមូលបានថា ខៀវ សំផន មិនមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើចារីទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការចោទប្រកាន់ដែលថា ជនជាប់ចោទទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)។

### ១៦.៣.២ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)

#### ១៦.៣.២.១ ការរៀបចំផែនការ

១០២៣. អង្គជំនុំជម្រះជឿជាក់ថា នៅក្នុងកិច្ចប្រជុំជាបន្តបន្ទាប់ ចាប់ផ្តើមនៅចុងខែ មេសា ឆ្នាំ ១៩៧៥ និងបន្តពេញរយៈពេលដែលពាក់ព័ន្ធ ខៀវ សំផន រួមជាមួយអ្នកដទៃទៀត បានរៀបចំផែនការឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ អង្គជំនុំជម្រះបានយល់ឃើញរួចហើយថា មេដឹកនាំជាន់ខ្ពស់នានា ដូចជា នួន ជា និង ខៀវ សំផន បានដឹងអំពីភាវនីយភាពច្បាស់លាស់ថា ឧក្រិដ្ឋកម្មនឹងកើតមានឡើងក្នុងទ្រង់ទ្រាយធំ ដោយសារគោលនយោបាយដែលផ្អែកទៅលើគោលការណ៍សម្ងាត់ ការបំពាក់បំប៉នមនោគមន៍វិជ្ជាដ៏តឹងរ៉ឹងទៅលើកសិករដែលគ្មានការអប់រំ ស្តីអំពីការតស៊ូវណ្ណៈ ដែលរួមបញ្ចូលទាំងការកំណត់ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរទាំងអស់ថាជាខ្មាំង និងគោលបំណងដើម្បីសម្រេចឲ្យបាននូវឯករាជ្យជាតិ ទោះជាត្រូវលះបង់អ្វីក៏ដោយ[៣០៣៩]។ ផែនការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ត្រូវបានអនុវត្តឡើងដើម្បីសម្រេចនូវគោលនយោបាយទាំងនេះ[៣០៤០]។ អង្គជំនុំ-

---

[៣០៣៨] រឿងក្តី *Delalić និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ២៥៨, ២៦៦។

[៣០៣៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

[៣០៤០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាណ្ឌ ៨០៤-៨១០។

ជម្រះយល់ឃើញថា ផែនការដែលបានរៀបចំឡើងនេះ ពិតជាមាន និងបានប្រមើលឃើញថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាក្នុងទ្រង់ទ្រាយធំ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

១០២៤.យ៉ាងយូរបំផុត ចាប់ពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ ខៀវ សំផន បានជួបពិភាក្សាជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ពាក់ព័ន្ធនឹងគោលនយោបាយកសាង និងការពារប្រទេសសង្គមនិយម ឯករាជ្យ និងខ្លួនទីពឹងខ្លួន[៣០៤១]។ ផែនការនោះគឺដើម្បីបង្កើតសង្គមមួយដែលគ្មានវណ្ណៈដែលប្រជាជនទាំងអស់ត្រូវបានរៀបចំដាក់បញ្ចូលទៅក្នុងសហករណ៍ ក្នុងគោលបំណងដើម្បីកសាង និងការពារប្រទេសឲ្យបានឆាប់ ដោយផ្តោតជាពិសេសទៅលើការបង្កបង្កើនផលស្រូវ និងការកសាងប្រព័ន្ធធារាសាស្ត្រ[៣០៤២]។ ផែនការទាំងនេះមានដើមកំណើត និងបានផ្អែកលើបទ-ពិសោធន៍របស់បក្សនៅក្នុងតំបន់រំដោះ ដែលវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នានៃការជម្លៀសប្រជាជនចេញពីទីក្រុង និងការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយទៅទីជនបទមួយទៀត បានកើតមានឡើងនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តកើតមានឡើងជាបន្តបន្ទាប់មកទៀត[៣០៤៣]។ ទោះបីជាមានបទពិសោធន៍បែបនេះក៏ដោយ ក៏មិនមានភស្តុតាងបង្ហាញថា ផែនការនេះបានដាក់បញ្ចូលនូវវិធានការណាមួយដែលតម្រូវសម្រាប់ធានាសុខុមាលភាពប្រជាជន ឬការយល់ព្រមពីប្រជាជនដែលត្រូវបានគេប្រមូលផ្តុំដាក់ទៅក្នុងសហករណ៍នោះឡើយ។ ដូច្នេះ ផែនការដំបូងនេះបានប្រមើលឃើញថាមានឧក្រិដ្ឋកម្មដែលនឹងត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

១០២៥.នៅចុងឆ្នាំ ១៩៧៥ ខៀវ សំផន រួមជាមួយអ្នកផ្សេងទៀត បានបង្កើតផែនការសេដ្ឋកិច្ចជាក់លាក់មួយ។ ផែនការនេះបានទទួលស្គាល់នូវការខ្វះខាតម្ហូបអាហារ និងថ្នាំសង្កូវ ដែលប៉ះពាល់ជាពិសេសដល់ "ប្រជាជនថ្មី"។ ទោះបីជាយ៉ាងណាក៏ដោយ ផែនការនេះគឺដើម្បីបែងចែកកម្លាំងពលកម្មតាមបែបយុទ្ធសាស្ត្រ អនុលោមទៅតាមទិសដៅបង្កបង្កើនផលស្រូវរបស់បក្ស និងអាទិ-ភាពនៃហេដ្ឋារចនាសម្ព័ន្ធ ពង្រីកសហករណ៍ និងគិតគូរដល់ "ប្រជាជនចាស់" ដែលនាំឲ្យប៉ះពាល់

---

[៣០៤១] ផ្នែកទី៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៧៣។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤០។

[៣០៤២] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤២-៧៤៣។

[៣០៤៣] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៣៦, ៨០០-៨០៣។

ដល់ "ប្រជាជនថ្មី" ដែលត្រូវបានគេសង្ស័យ។ ជាក់ស្តែង ការផ្លាស់ទីលំនៅប្រជាជនក្នុងទ្រង់ទ្រាយធំក៏ត្រូវបានសម្រេចឡើងផងដែរ ដូចជា ការផ្លាស់ទីលំនៅប្រជាជនពីប៉ែកខាងត្បូងនៃប្រទេសកម្ពុជាទៅកាន់តំបន់ ១០៣ ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាល (ឧត្តរចាស់)[៣០៤៤]។ ទោះបីជាមានបទពិសោធន៍យ៉ាងទូលំទូលាយរបស់បក្សក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង និងការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយទៅទីជនបទមួយទៀតក៏ដោយ ក៏មិនមានភ័ស្តុតាងបង្ហាញថា ផែនការដែលបានលេចចេញជារូបរាងនៅចុងឆ្នាំ ១៩៧៥ បានដាក់បញ្ចូលនូវវិធានការណាមួយដែលតម្រូវសម្រាប់ធានាសុខុមាលភាព ឬការយល់ព្រមរបស់ប្រជាជនដែលត្រូវបានគេផ្លាស់ទីលំនៅនោះឡើយ។ ដូច្នេះ ផែនការចុងឆ្នាំ ១៩៧៥ ក្នុងការផ្លាស់ទីលំនៅប្រជាជនពីទីជនបទមួយទៅទីជនបទមួយទៀត បានប្រមើលឃើញថាមានឧក្រិដ្ឋកម្មដែលនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

១០២៦. ក្រោយមក ខៀវ សំផន ក៏បានចូលរួមនៅក្នុងការរៀបចំផែនការសេដ្ឋកិច្ចសម្រាប់ឆ្នាំ ១៩៧៧ ផងដែរ។ ផែនការឆ្នាំ ១៩៧៧ ដែលដូចគ្នាយ៉ាងច្រើនទៅនឹងគោលដៅ និងគោលនយោបាយនៅក្នុងផែនការមុនៗ ក៏បានកំណត់អំពីការបែងចែកកម្លាំងពលកម្មប្រកបដោយយុទ្ធសាស្ត្រជាថ្មី ស្របតាមអាទិភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំង ទិសដៅថ្មីដើម្បីបង្កបង្កើនផលឲ្យបានច្រើនលើសលប់ និងការបែងចែកប្រជាជនទៅតាមវណ្ណៈរបស់ពួកគេ[៣០៤៥]។ ប៉ុន្តែ ទោះបីជាបក្សធ្លាប់មានបទពិសោធន៍ពាក់ព័ន្ធនឹងផលវិបាកអាក្រក់ដែលកើតចេញពីទម្រង់ដដែលៗ នៃការជម្លៀសប្រជាជនចេញពីទីប្រជុំជននានា និងការផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅកាន់ជនបទមួយទៀតក៏ដោយ ក៏ផែនការនេះមិនបានដាក់បញ្ចូលនូវវិធានការណាមួយដើម្បីឲ្យមានការយល់ព្រម ឬធានាសុខុមាលភាពប្រជាជនដែលត្រូវផ្លាស់ទីលំនៅនាឆ្នាំ ១៩៧៧ នោះឡើយ។ ហេតុដូច្នេះ ផែនការឆ្នាំ ១៩៧៧ សម្រាប់ការផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅកាន់ជនបទមួយទៀត ពិតជាបានប្រមើលឃើញថាមានឧក្រិដ្ឋកម្មដែលនឹងត្រូវបានប្រព្រឹត្ត នៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នេះ។

---

[៣០៤៤] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៥-៥៨៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤៨-៧៤៩។

[៣០៤៥] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦១០, ៦២១។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧០-៧៧១។

១០២៧. ផែនការឆ្នាំ ១៩៧៥ និង ១៩៧៧ ទាំងនេះកើតមានឡើងជាមុន និងបានចូលរួមចំណែក យ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ ក្រោយពីបានសម្រេចរួចមក ផែនការទាំងនេះត្រូវបានផ្សព្វផ្សាយតាមរយៈជួរបក្ស រួមទាំងនៅក្នុង ឯកសារគោលនយោបាយ និងការចេញផ្សាយឯកសារ*ទង់បដិវត្ត*[៣០៤៦]។ គណៈកម្មាធិការមជ្ឈិមបក្ស រួមទាំងកម្មាភិបាលភូមិភាគ តំបន់ និងស្រុកបានគ្រប់គ្រងទៅលើមធ្យោបាយ និងរបៀបនៃការដឹក ជញ្ជូនអ្នកដែលត្រូវបានផ្លាស់ទីលំនៅ[៣០៤៧]។ ដូចដែលបានកំណត់នៅក្នុងផែនការទាំងនេះ ហើយស៊ី-សង្វាក់គ្នាទៅនឹងវិធីសាស្រ្តអនុវត្ត ប្រជាជនត្រូវបានបញ្ជូនទៅកាន់ការដ្ឋានធ្វើការងារ និងតំបន់នានា ដែលល្បីល្បាញថា ជាដីដែលមានជីជាតិបំផុត[៣០៤៨]។

១០២៨. អង្គជំនុំជម្រះយល់ឃើញរួចមកហើយថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ ដែលថា ឧក្រិដ្ឋកម្មនានាអាចនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងដំណាក់កាលទី២នេះ[៣០៤៩]។ ទោះបីជា មានការដឹងបែបនេះក៏ដោយ ក៏គាត់បានបន្តធ្វើផែនការគោលនយោបាយសេដ្ឋកិច្ច រួមគ្នាជាមួយនឹង អ្នកដទៃទៀត ដោយបានយោងទៅលើការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ថាជាចំណុចស្នូលមួយ ហើយបានធ្វើមិនដឹងមិនឮចំពោះគោលការណ៍ស្តីពីភាពចាំបាច់ និងសមាមាត្រ[៣០៥០]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មានចេតនា ឬបានដឹងអំពីភវនីយភាពច្បាស់លាស់នៃការ ប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ក្រោយពីការអនុវត្តផែនការទាំងនេះរួចមក។

១០២៩. អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរៀបចំ ផែនការឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ (រួមមាន ការផ្លាស់ទី លំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ដែល បានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

---

[៣០៤៦] ផ្នែកទី ៦៖ រចនាសម្ព័ន្ធទំនាក់ទំនងការងារ កថាខណ្ឌ ២៧៤-២៨៦។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជននៅ (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧។

[៣០៤៧] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨។

[៣០៤៨] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៨៤-៦២៦។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋ-កម្មរួម កថាខណ្ឌ ៨០០-៨០៣។

[៣០៤៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាណ្ឌ ៩៤៧-៩៥២។

[៣០៥០] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤៥០។

### ១៦.៣.២.២ ការបញ្ជា

១០៣០.អង្គជំនុំជម្រះជឿជាក់ថា សេចក្តីណែនាំដែលចេញដោយគណៈកម្មាធិការមជ្ឈិមគឺពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ហើយសេចក្តីណែនាំទាំងនោះ គឺជាការបញ្ជា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា មិនមានភ័ស្តុតាងបង្ហាញថា ខៀវ សំផន បានចេញបញ្ជាណាមួយដោយខ្លួនឯង ទៅចារីក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ ឬក៏ថា មានចារីណាម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មទៅតាមបញ្ជាដែលទទួលបានពីរូបគាត់នោះឡើយ។ ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មានឥទ្ធិពលទៅលើការបង្កើតគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានយកមកពិភាក្សាទៅតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ហើយដែលគាត់មានទំនាក់ទំនងជិតស្និតជាមួយនឹងមេដឹកនាំរបបខ្មែរក្រហមនោះ និងថាគាត់នៅកាន់កាប់តួនាទីផ្សេងៗទៀតក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងមានឋានៈជាប្រធានគណៈប្រធានរដ្ឋក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា គឺជាអំណះអំណាងដ៏សមហេតុផលតែមួយគត់ចេញពីភ័ស្តុតាងដែលថា គាត់មានលទ្ធភាពក្នុងការចេញបញ្ជាដោយខ្លួនឯង ឬរួមជាមួយនឹងអ្នកផ្សេងទៀតឡើយ[៣០៥១]។ អង្គហេតុដែលថា ខៀវ សំផន មានតួនាទីដែលមានអំណាចគ្រប់គ្រងទៅលើស្ថាប័នសេដ្ឋកិច្ច ជាពិសេស ចាប់ពីចុងឆ្នាំ ១៩៧៦ នៅពេលដែលគាត់បានទទួលអំណាចមួយចំនួន ក្នុងការគ្រប់គ្រងទៅលើគណៈកម្មាធិការពាណិជ្ជកម្មនោះ មិនបានផ្លាស់ប្តូរសម្អាងហេតុទាំងនេះឡើយ។ ជាការពិត ទោះបីជាគាត់មានឥទ្ធិពល និងបានចូលរួមនៅក្នុងការរៀបចំផែនការឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចរកឃើញថា តើគាត់មានអំណាចក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងផែនការទាំងនេះ និងថា តើការបញ្ជាទាំងនោះមានប្រភពចេញមកពីណា ឬត្រូវបានបញ្ជូនដោយ ខៀវ សំផន ដែរ ឬយ៉ាងណានោះទេ។ ក្នុងករណីណាក៏ដោយ ភ័ស្តុតាងមានលក្ខណៈមិនច្បាស់លាស់នោះទេទាក់ទងនឹងចំណុចជាក់លាក់ផ្សេងៗអំពីតួនាទីរបស់គាត់ ហើយអង្គជំនុំជម្រះមិនជឿជាក់ថា ភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលថា គណៈកម្មាធិការពាណិជ្ជកម្មនេះបានចេញបញ្ជាទៅចារីនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធបទចោទដែលថា ខៀវ សំផន បានបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) នេះ។

---

[៣០៥១] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០០៥-១០០៧។

### ១៦.៣.២.៣ ការញុះញង់

១០៣១. ក្រោយពីបានចូលរួមក្នុងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ខៀវ សំផន បានថ្លែងសុន្ទរកថាជាសាធារណៈជាច្រើនដង មុនពេល និងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយបានលើកសរសើរដល់ខ្មែរក្រហម និងគាំទ្រដល់គោល-នយោបាយកសាងសេដ្ឋកិច្ច តាមរយៈការងារជាសមូហភាពនៅតាមស្រែចម្ការ។ សុន្ទរកថាជាសាធារណៈទាំងអស់នេះ បានធ្វើឲ្យកងទ័ព និងកម្មាភិបាលខ្មែរក្រហម ធ្វើការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី២។ នៅខែ មេសា ឆ្នាំ ១៩៧៥ នៅចុងឆ្នាំ ១៩៧៥ និងចុងឆ្នាំ ១៩៧៦ នៅពេលដែលគាត់បានដឹងថា ស្ថានភាពរស់នៅក្នុងប្រទេសមានការលំបាកខ្លាំង ខៀវ សំផន រួមជាមួយនឹងថ្នាក់ដឹកនាំបក្សដទៃទៀត បានរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយមិនចាំបាច់មានការយល់ព្រម និងមិនគិតគូរអំពីបញ្ហាសុខុមាលភាពរបស់ប្រជាជនដែលត្រូវផ្លាស់ទីលំនៅឡើយ[៣០៥២]។ បន្ទាប់មក គាត់បានប្រកាសគាំទ្រដល់គោលនយោបាយទាំងអស់នេះជាសាធារណៈ។ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ ខៀវ សំផន បានថ្លែងសុន្ទរកថា ដោយសង្កត់ធ្ងន់ទៅលើគោលនយោបាយរួម និងលក្ខខណ្ឌតម្រូវដែលថា ប្រជាជនទាំងអស់ត្រូវធ្វើការនៅតាមស្រែចម្ការ ឬនៅក្នុងរោងចក្រ បង្កើនផលិតផលស្រូវ និងកសាងគម្រោងធារាសាស្ត្រ[៣០៥៣]។ គាត់ក៏បានលើកសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជន និងកងទ័ព។ ដូចគ្នានេះដែរ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៦ គាត់បានថ្លែងសុន្ទរកថាដោយអះអាងដោយមិនត្រឹមត្រូវថា គោលនយោបាយពាក់ព័ន្ធនឹងការដ្ឋាន សហករណ៍ និងការតស៊ូវណ្ណៈដែលកំពុងតែមាននៅពេលនោះ ត្រូវបានគាំទ្រដោយអ្នកបោះឆ្នោតនៃសភាតំណាងប្រជាជន។ គាត់ក៏បានលើកសរសើរផងដែរដល់ប្រជាជនកម្ពុជា និងកងទ័ពបដិវត្ត ចំពោះតួនាទីរបស់ពួកគេក្នុងការរំដោះទីក្រុងភ្នំពេញ នៅពេលដែលគាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលមាននៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ នោះ។ សុន្ទរកថាជាសាធារណៈទាំងអស់នេះ បានគាំទ្រអស់ពីចិត្តដល់ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយមិនមានការលើកឡើងណាមួយពីការរិះគន់អ្វីឡើយ។ ខៀវ សំផន ក៏នៅតែបន្តកាន់តួនាទីរបស់គាត់នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយបានផ្តល់ការគាំទ្រដល់ភាពស្របច្បាប់របស់ខ្មែរក្រហម ដោយ

[៣០៥២] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៥២។

[៣០៥៣] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨៤។

មិនបានដោះស្រាយបញ្ហារងទុក្ខវេទនាដែលមិនអាចជៀសបាន ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំទៅកាន់ការដ្ឋាន និងសហករណ៍នានានោះឡើយ[៣០៥៤]។

១០៣២. អង្គជំនុំជម្រះបានរកឃើញរួចមកហើយថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅក្នុងដំណាក់កាលទី២។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការថ្លែងសុន្ទរកថាជាសាធារណៈដែលជំរុញដល់កងទ័ព និងកម្មាភិបាលខ្មែរក្រហមនោះ ខៀវ សំផន មានចេតនា ឬបានដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ អំពើសកម្ម និងអកម្មទាំងអស់នេះ បានជម្រុញឱ្យកងទ័ព និងកម្មាភិបាលខ្មែរក្រហម ធ្វើការផ្លាស់ទីលំនៅប្រជាជនរាប់ពាន់នាក់ដោយបង្ខំ ទៅកាន់ការដ្ឋាន និងទៅកាន់ស្រែចម្ការ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ សកម្មភាពរបស់ ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការញុះញង់ឱ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

### ១៦.៣.២.៤ ការជួយ និងជំរុញ

១០៣៣. អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតីឱ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។ នៅក្នុងសេចក្តីថ្លែងការណ៍នានា រយៈពេលជាច្រើនខែមុន និងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី២ នេះ ខៀវ សំផន បានលើកសរសើរដល់ខ្មែរក្រហមបានផ្តល់យុត្តិកម្ម និងបានគាំទ្រដល់គោលនយោបាយរបស់ពួកគេក្នុងការកសាង និងការពារប្រទេស ដោយការបែងចែកកម្លាំងពលកម្មជាយុទ្ធសាស្ត្រ ស្របតាមទិសដៅបង្កបង្កើនផល អាទិភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការតស៊ូវណ្ណៈ និងបានធ្វើយុត្តិកម្ម ឬបានបដិសេធការប្រព្រឹត្តិឧក្រិដ្ឋកម្ម

[៣០៥៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨៣។

របស់ពួកគេ។ គាត់និយាយដដែលៗ អំពីប្រធានបទទាំងនេះនៅក្នុងវគ្គបំពាក់បំប៉ន មនោគមន៍វិជ្ជាផ្សេងៗ រួមទាំង ជាមួយបញ្ញវន្តដែលបានវិលត្រឡប់មកពីបរទេសវិញ។ ខៀវ សំផន ក៏បានបំពេញភារកិច្ចផ្នែកការទូត និងបានធ្វើការទាក់ទងជាមួយសម្ដេច នរោត្តម សីហនុ ដើម្បីធានាឲ្យមានការគាំទ្រ និងបានលើកសរសើរដល់ទង្វើរបស់បដិវត្តសង្គមនិយម រួមទាំង ពលកម្មដោយកម្លាំងគ្រប់ប្រភេទទាំងអស់ដើម្បីកសាង និងការពារប្រទេស[៣០៥៥]។

១០៣៤.ការផ្ដល់ជំនួយជាក់ស្ដែង ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតី មានឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នេះ។ ដោយសារតែកេរ្តិ៍ឈ្មោះ និងមុខងារផ្លូវការរបស់គាត់នៅក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រពេញទំហឹងរបស់ខ្មែរក្រហម[៣០៥៦] អង្គជំនុំជម្រះយល់ឃើញថា ចារីទាំងនោះត្រូវបានជំរុញដោយសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់គាត់។

១០៣៥. ខៀវ សំផន បានដឹងថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងដំណាក់កាលទី២ នេះអាចទំនងជានឹងត្រូវបានប្រព្រឹត្តឡើង[៣០៥៧] ហើយអំពើរបស់គាត់បានជួយ ឬបានសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ចារីទាំងនោះ។ អង្គជំនុំជម្រះក៏យល់ឃើញបន្ថែមថា យ៉ាងហោចណាស់ក៏ ខៀវ សំផន បានដឹងអំពីធាតុសំខាន់ៗនៃឧក្រិដ្ឋកម្មទាំងនោះដែរ។ ជាមួយនឹងការដឹងនេះ ខៀវ សំផន បានផ្ដល់ជំនួយ ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតីដល់ចារី ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងដំណាក់កាលទី២ នៃការផ្លាស់ទីលំនៅប្រជាជន។

១០៣៦.អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

---

[៣០៥៥] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

[៣០៥៦] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៦។

[៣០៥៧] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

### ១៦.៣.២.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

១០៣៧. ចារីនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំប្រជាជននៅដំណាក់កាលទី២ នេះ គឺជាកម្មាភិបាលខ្មែរក្រហម និងកម្មាភិបាលដែលស្ថិតនៅក្រោមសិទ្ធិអំណាចផ្ទាល់របស់ភូមិភាគ និង តំបន់ និងអគ្គសេនាធិការកងទ័ព ដោយអនុលោមតាមសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយបំផុតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍[៣០៥៨]។ ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ក៏ស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នាដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះតម្កល់សំអាងហេតុរបស់ខ្លួនខាងលើ ដែលយល់ឃើញថាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា ខៀវ សំផន បានអនុវត្តសិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាពទៅលើចារីទាំងនោះនៅក្នុងអំឡុងពេលពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០១ ទេ[៣០៥៩]។

១០៣៨.អង្គជំនុំជម្រះក៏បានពិចារណាផងដែរចំពោះភស្តុតាងដែលថា គណៈកម្មាធិការពាណិជកម្មបានដើរតួនាទីបឋម ក្នុងការរៀបចំផែនការឲ្យមានការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី២ [៣០៦០]។ ទោះបីជាយ៉ាងណា មិនមានភស្តុតាងបញ្ជាក់ច្បាស់លាស់ថាដូច្នេះនោះទេ ហេតុដូច្នេះហើយ អង្គជំនុំជម្រះមិនអាចធ្វើការសម្រេច ថាតើគណៈកម្មាធិការពាណិជ្ជកម្មបានអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើចារីទាំងនោះដែរ ឬយ៉ាងណានោះទេ។ អង្គជំនុំជម្រះក៏មិនអាចសម្រេចថា គណៈកម្មាធិការពាណិជកម្មបានបន្តដើរតួនាទីណាមួយនៅក្នុងការផ្លាស់ទីលំនៅប្រជាជនចាប់ពីដើមឆ្នាំ ១៩៧៦ ដែរ ឬយ៉ាងណានោះដែរ។ ហេតុដូច្នេះ ទោះបីជាជនជាប់ចោទបានអនុវត្តសិទ្ធិអំណាចខ្លះៗទៅលើស្ថាប័នសេដ្ឋកិច្ចជាក់លាក់មួយចំនួន ជាពិសេស ការគ្រប់គ្រងរបស់គណៈ-កម្មាធិការពាណិជ្ជកម្មចាប់ពីចុងឆ្នាំ ១៩៧៦ មកក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនេះមិនបានបង្ហាញឲ្យឃើញអំពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ ខៀវ សំផន ទៅលើចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅក្នុងដំណាក់កាលទី២ នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធការចោទប្រកាន់ដែលថា ខៀវ សំផន ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)។

---

[៣០៥៨] ផ្នែកទី ៥៖ រចនាសម្ព័ន្ធរដ្ឋបាល កថាខណ្ឌ ២៤០, ២៤២។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៧-៥៧៨។

[៣០៥៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០១៨-១០២២។

[៣០៦០] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៧៨។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាណ្ឌ ៧៤៨, ៨០៩។

## ១៦.៣.៣ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ

### ១៦.៣.៣.១ ការរៀបចំផែនការ

១០៣៩. នៅទូទាំងបដិវត្តប្រជាធិបតេយ្យ អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់ជាគោលដៅសម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន បន្ទាប់ពីអ្នកទាំងនោះបានចុះចាញ់ ឬត្រូវបានប្រគល់ខ្លួនក្នុងនាមជា*ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ*[៣០៦១]។ ចុងក្រោយបំផុត ថ្នាក់ដឹកនាំបក្សបានគាំទ្រដល់គោលនយោបាយកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមបក្សនាខែ មិថុនា ឆ្នាំ ១៩៧៤។ តាមពិតទៅ នៅខែ មិថុនា ឆ្នាំ ១៩៧៤ គោលនយោបាយកំណត់គោលដៅនេះជាប់ទាក់ទងទៅនឹងគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ហើយការជម្លៀសប្រជាជនទៅកាន់សហករណ៍ បានសម្រួលដល់ការកំណត់អត្តសញ្ញាណ និងការបោសសម្អាតភ្នាក់ងាររដ្ឋាភិបាល ភ្នាក់ងារចារកម្ម និងភ្នាក់ងារសន្តិនិយម[៣០៦២]។ នៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ ដែល ខៀវ សំផន បានចូលរួមប្រជុំដែរនោះ គណៈកម្មាធិការមជ្ឈិមបក្សបានអនុម័តផែនការវាយប្រយុទ្ធផ្តាច់ព្រាត់ដើម្បីរំដោះប្រទេស[៣០៦៣]។ បទពិសោធន៍មុនៗ ជាពិសេស នៅឧត្តុង្គ ដែលអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ ត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំនេះ និងបានបង្កើតជាមូលដ្ឋានសម្រាប់ផែនការ ដែលបណ្តាលឲ្យមានលទ្ធផលបែបនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ផែនការនេះបាននាំឲ្យមានការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលជាប់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីទីប្រជុំជននានា[៣០៦៤]។ ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំមួយរបស់មេដឹកនាំជាន់ខ្ពស់នាដើមខែ មេសា ឆ្នាំ ១៩៧៥ ហើយនៅក្នុងកិច្ចប្រជុំដែលគាត់បានចូលរួមនោះ ផែនការដើម្បីធ្វើការវាយលុកផ្តាច់ព្រាត់ ត្រូវបានសម្រេច[៣០៦៥]។

---

[៣០៦១] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០-១២៣។

[៣០៦២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១១៨។

[៣០៦៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣២-១៣៨។ *សូមមើល ផងដែរ* ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាណ្ឌ ៩៩៧-១០០៣។

[៣០៦៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាណ្ឌ ៩៩៧-១០០៣។

[៣០៦៥] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៤៥-១៤៧។ *សូមមើល ផងដែរ*ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាណ្ឌ ៩៩៧-១០០៣។

១០៤០. អង្គជំនុំជម្រះក៏យល់ឃើញថា មេដឹកនាំជាន់ខ្ពស់ ដូចជា នួន ជា និង ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា អាចនឹងបណ្តាលឲ្យមានឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំកើតចេញមកពីគោលនយោបាយដែលមានមូលដ្ឋាននៅក្នុងគោលការណ៍នៃការរក្សាភាពសម្ងាត់ ការបំពាក់បំប៉នមនោគមន៍វិជ្ជាយ៉ាងតឹងរ៉ឹងដល់កសិករដែលមិនមានចំណេះដឹង អំពីការតស៊ូវណ្ណៈ រួមទាំងការកំណត់អត្តសញ្ញាណ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរទាំងអស់ ថាជាខ្មាំង និងទិសដៅស្វែងរកឯកភាពជាតិតាមគ្រប់មធ្យោបាយទាំងអស់[៣០៦៦]។ ផែនការដែលជាប់ពាក់ព័ន្ធនឹងការកំណត់គោលដៅមកលើអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានអនុវត្តស្របតាម និងដើម្បីសម្រេចឲ្យបាននូវគោលនយោបាយទាំងនេះ[៣០៦៧]។ អង្គជំនុំជម្រះយល់ឃើញថា ផែនការដែលបានសម្រេចនេះ ពិតជាបានប្រមើលឃើញថា ឧក្រិដ្ឋកម្មទាំងនេះអាចនឹងត្រូវបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ រួមទាំងឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃផងដែរ។

១០៤១. ផែនការនេះបានចាប់ដំណើរការ និងបានចូលរួមចំណែកយ៉ាងខ្លាំងដល់ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។ ផែនការនេះត្រូវបានផ្សព្វផ្សាយតាមរយៈខ្សែសង្វាក់នៃការបញ្ជា ពីសំណាក់អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥[៣០៦៨]។ ក្នុងរយៈពេលតែប៉ុន្មានថ្ងៃក្រោយការរំដោះខេត្តពោធិ៍សាត់ ដែលអង្គជំនុំជម្រះយល់ឃើញថា បានកើតឡើងមិនជាយូប៉ុន្មាន បន្ទាប់ពីការរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកនោះ គណៈកម្មាធិការភូមិភាគពាយ័ព្យ ដែលដឹកនាំដោយលេខា រស់ ញឹម បានបញ្ជាឲ្យមានការប្រមូលផ្តុំ និងឲ្យសម្លាប់អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនៅក្នុងខេត្តពោធិ៍សាត់[៣០៦៩]។ ការបញ្ជានេះ គឺស៊ីសង្វាក់គ្នាទៅនឹងផែនការបើកការវាយប្រយុទ្ធផ្តាច់ព្រាត់ និងវិធីសាស្ត្រអនុវត្ត ដែលបានចាប់ផ្តើមឡើងនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយបានបន្តអនុវត្តរយៈពេលក្រោយៗមកទៀត[៣០៧០]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការបញ្ជានេះត្រូវបានអនុវត្តស្របតាមផែនការដែលបានសម្រេចនៅក្នុងកិច្ចប្រជុំកាលពីខែ មិថុនា ឆ្នាំ ១៩៧៤ ហើយដែលបានទទួលស្គាល់នៅក្នុងកិច្ចប្រជុំកាលពីខែ មេសា ឆ្នាំ ១៩៧៥។ បន្ទាប់មក តាមរយៈការបញ្ជានេះ

[៣០៦៦] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

[៣០៦៧] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៣៥-៨៣៦។

[៣០៦៨] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៤, ១៤៨-១៥១ ។

[៣០៦៩] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦២-៦៦៥។

[៣០៧០] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩១-៧៩៤។

កម្មាភិបាលខ្មែរក្រហមដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈកម្មាធិការភូមិភាគពាយ័ព្យ និង លេខា រស់ ញឹម បានចាប់ផ្ដើមប្រមូលផ្ដុំអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ គឺប្រហែលជានៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៥ ហើយក្រោយមក ប្រហែលជានៅថ្ងៃទី ២៥ ឬ ២៦ ក៏បញ្ជូនអ្នកទាំងនេះយកទៅសម្លាប់ចោលនៅទួលពោធិ៍ជ្រៃ[៣០៧១]។

១០៤២. អង្គជំនុំជម្រះក៏បានរកឃើញថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មនានា ដូចជា ឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ អាចត្រូវបានប្រព្រឹត្តឡើង[៣០៧២]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងការរៀបចំផែនការវាយប្រយុទ្ធផ្ដាច់ព្រាត់ដើម្បីរំដោះប្រទេសជាតិ ខៀវ សំផន មានចេតនា ឬ បានដឹងអំពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ បន្ទាប់ពីការអនុវត្តផែនការនោះរួចមក។

១០៤៣.ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរៀបចំផែនការឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

### ១៦.៣.៣.២ ការបញ្ជា

១០៤៤. យោងតាមភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះមិនអាចធ្វើសេចក្ដីសន្និដ្ឋានថា ខៀវ សំផន មានអំណាចតាមព្រឹត្តិហេតុ ឬតាមផ្លូវច្បាប់ ដើម្បីចេញបញ្ជាដែរ ឬយ៉ាងណានោះទេ នៅពេលដែលគោលនយោបាយពាក់ព័ន្ធ នឹងការលុបបំបាត់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្រេច ឬផ្សព្វផ្សាយហើយនោះ[៣០៧៣]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ខៀវ សំផន បានចូលរួមនៅក្នុងការផ្សព្វផ្សាយគោលនយោបាយនេះនៅក្នុងកិច្ចប្រជុំណែនាំមួយចំនួនដែលគាត់បានរៀបចំ ឬដែលគាត់បានចូលរួមចំណែក[៣០៧៤]។ ប៉ុន្តែ ការផ្សព្វផ្សាយនេះត្រូវបានធ្វើឡើង ក្រោយពីការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃរួចហើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេច

[៣០៧១] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦៧-៦៨១។

[៣០៧២] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

[៣០៧៣] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ១០០៥-១០០៧។

[៣០៧៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៤-៩៨៧។

បដិសេធការចោទប្រកាន់ដែលថា ខៀវ សំផន បានបញ្ជាឲ្យសម្លាប់អ្នករដ្ឋការនៃរបបសាធារណ-រដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។

### ១៦.៣.៣.៣ ការញុះញង់

១០៨៥. មុនពេលកាន់កាប់ទីក្រុងភ្នំពេញ ខៀវ សំផន បានថ្លែងសុន្ទរកថាជាសាធារណៈជាច្រើនដង ដោយលើកសរសើរដល់ខ្មែរក្រហម ប្រើប្រាស់កេរ្តិ៍ឈ្មោះរបស់គាត់ជួយដល់ផែនការរបស់មជ្ឈិមបក្ស និងធ្វើឲ្យកងទ័ព និងកម្មាភិបាលខ្មែរក្រហម ធ្វើការកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីធ្វើបាប[៣០៧៥]។ សុន្ទរកថារបស់គាត់ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយដោយសារតែជំនឿទុកចិត្តដែលសាធារណជនមានចំពោះរូបគាត់ ពួកគេទាំងនោះត្រូវបានជំរុញឲ្យអនុវត្តតាមការអំពាវនាវឲ្យមានអំពើហិង្សា ដែលមាននៅក្នុងសុន្ទរកថាទាំងអស់នេះ។ ហេតុដូច្នេះ សុន្ទរកថាជាសាធារណៈរបស់គាត់បានចូលរួមចំណែកយ៉ាងសំខាន់ដល់អំពើរបស់កងទ័ពខ្មែរក្រហម ដែលបានសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ខៀវ សំផន ក៏បានជំរុញឲ្យចារីចាត់វិធានការក្នុងការជួយជំរុញគោលនយោបាយបក្ស តាមរយៈវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំពិភាក្សា ដែលបញ្ជាក់គាំទ្រគោលនយោបាយកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[៣០៧៦]។ ជាពិសេស អង្គជំនុំជម្រះបានកត់សម្គាល់ថា ខៀវ សំផន បានគាំទ្រដល់មជ្ឈិមបក្សចំពោះការធ្វើសេចក្តីសម្រេចផ្សេងៗនៅក្នុងកិច្ចប្រជុំកាលពីខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥ ហើយការបញ្ជារបស់ រស់ ញឹម ឲ្យធ្វើការប្រមូលផ្តុំ និងសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមសេចក្តីសម្រេចទាំងអស់នេះ[៣០៧៧]។ ហេតុដូច្នេះ អំពើសកម្ម ឬអកម្មរបស់ខៀវ សំផន បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។

១០៨៦. អង្គជំនុំជម្រះបានរកឃើញរួចមកហើយថា ខៀវ សំផន បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា នឹងមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ដូចជា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងនៅទួលពោធិ៍ជ្រៃ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈការថ្លែងសុន្ទរកថាជាសាធារណៈ ដែលជំរុញដល់កងទ័ព និងកម្មាភិបាលខ្មែរក្រហមនោះ ខៀវ សំផន មានចេតនា ឬបានដឹងអំពីភវនីយភាព

[៣០៧៥] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨២។

[៣០៧៦] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤២, ១៤៤, ១៤៦។

[៣០៧៧] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៣៣, ១៤២, ១៤៤, ១៤៦។

ច្បាស់លាស់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការញុះញង់ឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលត្រូវបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ។

### ១៦.៣.៣.៤ ការជួយ និងជំរុញ

១០៤៧. អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតីដល់ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ និងកិច្ចប្រជុំណែនាំនៅមុន និងក្រោយពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃរួចមក ខៀវ សំផន នៅតែរក្សាជំហរថា មានតែ "ជនមហាក្បត់" ទាំង ៧ នាក់ ប៉ុណ្ណោះ នឹងត្រូវបានប្រហារជីវិត ហើយអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរដទៃទៀតនឹងត្រូវរួចជីវិត។ គាត់បានកោតសរសើរដល់ខ្មែរក្រហម និងកងទ័ព រួមទាំងជោគជ័យរបស់ពួកគេនៅក្នុងការយកជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ បានផ្តល់យុត្តិកម្ម និងបានផ្តល់ការគាំទ្រដល់គោលនយោបាយរបស់ខ្មែរក្រហម រួមទាំងបានបន្តការប្រុងប្រយ័ត្ន និងបោសសម្អាតគ្រប់សមាសធាតុទាំងអស់ពីអតីតរបបសាធារណរដ្ឋខ្មែរ និងបានដោះសារ ឬបដិសេធចំពោះឧក្រិដ្ឋកម្មនានា រួមទាំងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[៣០៧៨]។ កិច្ចខិតខំប្រឹងប្រែងខាងផ្នែកការទូតរបស់គាត់ ក៏បានទទួលការគាំទ្រពីសហគមន៍អន្តរជាតិខ្លះ និងពីភាគីដទៃទៀតនៅក្នុងប្រទេសកម្ពុជា រួចទាំង សម្តេច នរោត្តម សីហនុ ដែលបានកោតសរសើរដល់ខ្មែរក្រហម បាននាំឲ្យមានការទុកចិត្តពីសំណាក់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ[៣០៧៩]។

១០៤៨. ការផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតីនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ ដោយសារកេរ្តិ៍ឈ្មោះ និងតួនាទីផ្លូវការរបស់គាត់នៅក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ និងរបបកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រគ្មានលក្ខខណ្ឌរបស់ខ្មែរក្រហម[៣០៨០] អង្គជំនុំជម្រះយល់ឃើញថា ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីសម្រេចឲ្យបាននូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅចំពោះ

[៣០៧៨] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៣-៩៧៦, ៩៨០-៩៨៧។

[៣០៧៩] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨៨-៩៩២។

[៣០៨០] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៦។

អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ សម្រាប់ការសម្លាប់ ការចាប់ខ្លួន ឬការបាត់ខ្លួន ត្រូវបានជំរុញដោយសេចក្ដីថ្លែងការណ៍ជាសាធារណៈនានារបស់គាត់។ ការធានាអះអាងរបស់គាត់ថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅតែពី "ជនមហាក្បត់" ទាំង ៧ នាក់ នឹងត្រូវរួចជីវិតនោះ ក៏បានអូសទាញឲ្យអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជឿជាក់លើការធានាសន្តិសុខក្លែងក្លាយក្រោយការរំដោះរួចមក[៣០៨១]។ បន្ទាប់មក អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេបោកបញ្ឆោតយកចេញពីក្នុងចំណោមប្រជាជនទូទៅដោយប្រើលេសថា យកទៅរៀនសូត្រ និងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលដែលក្រោយមក អ្នករដ្ឋការទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ចោលក្នុងទ្រង់ទ្រាយធំ[៣០៨២] ដូចជា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានប្រមូលផ្ដុំ ហើយក្រោយមកត្រូវបានយកទៅសម្លាប់ចោលនៅទួលពោធិ៍ជ្រៃជាដើម។

១០៤៩. លើសពីនេះទៀត អង្គជំនុំជម្រះជឿជាក់ថា ចារីបានគិតថា ខៀវ សំផន នឹងបន្តជួយ និងលើកទឹកចិត្តពួកគេ ក្រោយពីការសម្លាប់ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ។ តាមពិតទៅ ក្ដីរំពឹងទាំងនេះ ស៊ីសង្វាក់គ្នាទៅនឹងចំណុចដែលថា គោលនយោបាយក្នុងការកំណត់គោលដៅចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលកើតចេញមកពីសេចក្ដីសម្រេចដែលត្រូវបានធ្វើឡើងនៅថ្នាក់លើបំផុតនៃបក្សកុម្មុយនីស្ដកម្ពុជា ចូលជាធរមានរួចហើយនៅពេលនោះ។ ក្ដីរំពឹងទុកទាំងនេះក៏ស៊ីសង្វាក់គ្នាផងដែរទៅនឹងចំណុចដែលថា ខៀវ សំផន បានបន្តផ្ដល់ការគាំទ្រដល់ខ្មែរក្រហមនៅក្នុងអំឡុងពេលបដិវត្តន៍ប្រជាធិបតេយ្យទាំងមូល ជាពិសេស ក្នុងអំឡុងពេលនៃការវាយសម្រុកចុងក្រោយទៅលើទីក្រុងភ្នំពេញ និងប៉ុន្មានថ្ងៃដំបូងបន្ទាប់ពីរំដោះប្រទេសបាន[៣០៨៣]។ ដូច្នេះ ចារីប្រាកដជាបានជឿជាក់ថា ការសម្លាប់ទាំងនេះត្រូវបានធ្វើឡើងស្របតាមគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយជឿជាក់ផងដែរថា មេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជានឹងបន្តគាំទ្រ និងជួយដល់ពួកគេនៅក្រោយព្រឹត្តិការណ៍នោះ ជាពិសេសគឺថា ខៀវ សំផន នឹងបន្តប្រឹងប្រែងផ្ដល់យុត្តិកម្ម។

---

[៣០៨១] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨១៧-៨២៣។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

[៣០៨២] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១២០។ ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២៩-៨៣៤។

[៣០៨៣] ផ្នែកទី ៣៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ១៦២, ១៦៤។ ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨១។

១០៥០. ជាការពិត ខៀវ សំផន បានធ្វើដូចការរំពឹងទុកមែន។ គាត់បានដឹងថា ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ទំនងជានឹងត្រូវបានប្រព្រឹត្តឡើង[៣០៨៤] ហើយអំពើរបស់គាត់បានជួយ ឬបានសម្រួលដល់ការប្រព្រឹត្តិរបស់ចារីទាំងនោះ។ អង្គជំនុំជម្រះជឿជាក់ផងដែរថា យ៉ាងហោចណាស់ក៏ ខៀវ សំផន បានដឹងពីធាតុសំខាន់នៃឧក្រិដ្ឋកម្មទាំងនោះដែរ។ ដោយការដឹងបែបនេះ ខៀវ សំផន បានផ្តល់ជំនួយ ការលើកទឹកចិត្ត និងការគាំទ្រខាងស្មារតី ដល់ចារីនៅមុន ឬក្រោយពេលការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះជឿជាក់ថា អំពើរបស់គាត់បានជួយ និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។

១០៥១. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

### ១៦.៣.៣.៥ ការទទួលខុសត្រូវរបស់ថ្នាក់លើ

១០៥២. ឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាល ដែលស្ថិតនៅក្រោមសិទ្ធិអំណាចផ្ទាល់របស់គណៈកម្មាធិការភូមិភាគពាយ័ព្យ និងលេខា រស់ ញឹម គឺប្រហែលជានៅចន្លោះថ្ងៃទី ២៤ និងទី ២៦ ខែ មេសា ឆ្នាំ ១៩៧៥។ នៅក្នុងអំឡុងពេលវាយលុកចុងក្រោយដើម្បីរំដោះប្រទេស។ អង្គជំនុំជម្រះយល់ឃើញថា មេបញ្ជាការភូមិភាគ និងមេបញ្ជាការកងទ័ពបានស្នើយោបល់ និងបានទទួលការណែនាំពីមេដឹកនាំជាន់ខ្ពស់ដែលមានមូលដ្ឋាននៅមន្ទីរ ប-៥ និងក្រោយពេលពួកគេវិលត្រឡប់មកទីក្រុងភ្នំពេញ យ៉ាងហោចណាស់គឺនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥ នៅស្ថានីយ៍រថភ្លើងភ្នំពេញ[៣០៨៥]។ ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ក៏ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ និងមេបញ្ជាការកងទ័ពតំបន់ឯករាជ្យដែលបានស្នើយោបល់ និងបានទទួលការណែនាំពីមេដឹកនាំជាន់ខ្ពស់ដែលមានមូលដ្ឋាននៅមន្ទីរ ប-៥[៣០៨៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋ-កម្មនៅទួលពោធិ៍ជ្រៃ ក៏ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមស្ថានភាពប្រហាក់ប្រហែលគ្នានឹងចារីដែល

---

[៣០៨៤] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៤៧-៩៥២។

[៣០៨៥] ផ្នែកទី ១៤៖ សហឧក្រិដ្ឋកម្មរួម ៨១៦-៨១៨។ សូមមើលផងដែរ កថាខណ្ឌ ៨៣៥-៨៣៦។

[៣០៨៦] ផ្នែកទី ១៣៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៧១៥។

បានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ដែរ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតម្កល់សម្អាងហេតុរបស់ខ្លួនដែលបានលើកឡើងនៅក្នុងផ្នែកនានាពាក់ព័ន្ធនឹងការចោទប្រកាន់ដែលថា ខៀវ សំផន ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ (ផ្នែក ១៦.៣.១.៥)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មិនបានអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើថារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃនោះទេ។ អង្គជំនុំជម្រះសម្រេចបដិសេធការចោទប្រកាន់ដែលថា ខៀវ សំផន ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

## ១៦.៤ សេចក្តីសន្និដ្ឋាន

១០៥៣.អង្គជំនុំជម្រះយល់ឃើញថា តាមរយៈសហឧក្រិដ្ឋកម្មរួម ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ព្រមទាំងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួល-ពោធិ៍ជ្រៃ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ជនជាប់ចោទបានរៀបចំផែនការ ញុះញង់ បានជួយ និងជំរុញឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដូចបានលើកឡើងខាងលើ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និង ទី២ និងនៅទួលពោធិ៍ជ្រៃ។ ដោយបានពិចារណាឃើញថា ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម គ្របដណ្តប់ទៅលើគ្រប់អំពើដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការយល់ឃើញរបស់អង្គជំនុំជម្រះ ទៅលើទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវ អង្គជំនុំជម្រះនឹងធ្វើការផ្តន្ទាទោសចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ តាមរយៈសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ។

១០៥៤. អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ខៀវ សំផន បានរៀបចំផែនការ ញុះញង់ បានជួយ និងជំរុញឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល (នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (នៅទួល-

ពោធិ៍ជ្រៃ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការបាត់ខ្លួនដោយបង្ខំ) (នៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២))។

## ១៧. ពិរុទ្ធពីបទល្មើសច្រើន

១០៥៥. ក្នុងករណីដែលអំពើរបស់ជនជាប់ចោទ បានបំពេញធាតុផ្សំបានជាបទល្មើសច្រើនផ្សេងៗគ្នា អង្គជំនុំជម្រះត្រូវវាយតម្លៃអំពីផលប៉ះពាល់នៃពិរុទ្ធពីបទល្មើសច្រើន។ ពិរុទ្ធពីបទល្មើសច្រើនមានតួនាទី "បង្ហាញអំពីពិរុទ្ធទាំងអស់របស់ជនជាប់ចោទណាមួយ ឬនៅក្នុងការផ្តល់នូវរូបភាពពេញលេញមួយដែលបង្ហាញពីអំពើល្មើសរបស់ជនជាប់ចោទរូបនេះ"[៣០៨៧]។ នៅពេលដែលអង្គជំនុំជម្រះបានរកឃើញពិរុទ្ធពីបទល្មើសច្រើន ដែលមាននៅក្នុងបទល្មើសមូលដ្ឋានដ៏ទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលកើតចេញពីអំពើសកម្ម ឬ អកម្ម ដូចគ្នារបស់ជនជាប់ចោទនោះ ការផ្តន្ទាទោសចំពោះបទល្មើសនីមួយៗ អាចធ្វើទៅបាន តែក្នុងករណីដែលបទល្មើសទាំងនោះ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ហើយដែលមិនមាននៅក្នុងបទល្មើសផ្សេងទៀត[៣០៨៨]។ ប្រសិនបើបទល្មើសពីរត្រូវបានចោទប្រកាន់ដោយផ្អែកលើអំពើតែមួយ ដែលមិនមានធាតុផ្សំដាច់ដោយឡែកពីគ្នាទាំងស្រុងយ៉ាងតិចមួយទេនោះ អង្គជំនុំជម្រះអាចធ្វើការផ្តន្ទាទោសជនជាប់ចោទបានតែចំពោះបទល្មើសណាដែលមានធាតុផ្សំជាក់លាក់ជាងមួយ ឬច្រើនតែប៉ុណ្ណោះ[៣០៨៩]។ ក្នុងពេលអនុវត្តលក្ខណៈវិនិច្ឆ័យចំពោះការផ្តន្ទាទោសត្រួតគ្នា អង្គជំនុំជម្រះត្រូវតែប្រៀបធៀបទៅលើលក្ខខណ្ឌតម្រូវទូទៅទាំងអស់នៃបទល្មើសដែលមានចែងក្នុងច្បាប់ ព្រមទាំងធាតុផ្សំនៃបទល្មើសជាមូលដ្ឋានដែលត្រូវបានចោទប្រកាន់ ដើម្បីសម្រេចថាតើ តាមផ្លូវច្បាប់ បទល្មើសនីមួយៗតម្រូវឲ្យមានការបង្ហាញធាតុផ្សំមួយ ដែលបទល្មើសដទៃទៀតមិនមានដែរ ឬ យ៉ាងណា[៣០៩០]។

១០៥៦. អង្គជំនុំជម្រះយល់ឃើញថា នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើ

---

[៣០៨៧] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៣៣០។ សាលដីកាលើរឿងក្តី *Kunarac,* កថាខណ្ឌ ១៦៩។

[៣០៨៨] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ៣១៨, ៣៣២។ សាលដីកាលើរឿងក្តី *Čelebići,* កថាខណ្ឌ ៤១២។

[៣០៨៩] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ២៩៨។ សាលដីកាលើរឿងក្តី *Čelebići,* កថាខណ្ឌ ៤១៣។

[៣០៩០] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៣២៥ ដល់ ៣២៦។

អមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះ-ពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

១០៥៧. ពាក់ព័ន្ធដល់ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការយល់ឃើញរបស់អង្គជំនុំ-ជម្រះចំពោះបទល្មើសការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ផ្អែកទៅលើការសម្លាប់តែមួយ[៣០៩១]។ ប្រហាក់ប្រហែលគ្នានេះដែរ ពាក់ព័ន្ធដល់ការសម្លាប់នៅទួលពោធិ៍ជ្រៃ ការយល់ឃើញរបស់អង្គ-ជំនុំជម្រះចំពោះបទល្មើសការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ផ្អែកទៅលើការសម្លាប់តែមួយ[៣០៩២]។ ទាំងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល តម្រូវឲ្យមានការស្លាប់ដោយអំពើសកម្ម ឬអកម្មដោយចេតនា។ ទោះបីជាអំពើមនុស្សឃាត មិនមានធាតុផ្សំផ្សេងទៀតក៏ដោយ តែការសម្លាប់រង្គាលតម្រូវបន្ថែមទៀតឲ្យមានការស្លាប់ក្នុងទ្រង់ទ្រាយធំ[៣០៩៣]។ អាស្រ័យហេតុនេះ ការសម្លាប់រង្គាល ដែលជាបទល្មើសជាក់លាក់ជាង បានស្រូបបញ្ចូលការធ្វើមនុស្សឃាត[៣០៩៤]។ ដូច្នេះ អង្គជំនុំជម្រះនឹងធ្វើការផ្តន្ទាទោសតែចំពោះការសម្លាប់រង្គាល ពាក់ព័ន្ធដល់ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) និងការសម្លាប់នៅទួលពោធិ៍ជ្រៃ តែប៉ុណ្ណោះ។

១០៥៨. លើសពីនេះទៀត អំពើជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះ ចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពឹងផ្អែកភាគច្រើនទៅលើអំពើតែមួយដែលជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះ ចំពោះបទល្មើសដទៃផ្សេងទៀត។ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) អំពើជាមូលដ្ឋាន រួមមាន ការសម្លាប់រង្គាល ការផ្លាស់ទីលំនៅដោយបង្ខំ និង ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ អំពើជាមូលដ្ឋានទាំងអស់នេះក៏បានបង្កើតជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះទៅលើការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)[៣០៩៥]។ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) អំពើជាមូលដ្ឋាននៃការយល់ឃើញរបស់

[៣០៩១] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥៣-៥៦២។

[៣០៩២] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨៣-៦៨៤។

[៣០៩៣] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤១០-៤២៤។

[៣០៩៤] សាលដីកាលើសំណុំរឿង កាំង ហ្កេកអ៊ាវ កថាខណ្ឌ ៥៦៦។ សាលដីកាលើសំណុំរឿង កាំង ហ្កេកអ៊ាវ កថាខណ្ឌ ៣៣៤។

[៣០៩៥] ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧-៥៧៤។ ទោះបីជាអង្គជំនុំជម្រះបានរកឃើញផងដែរថាមានអំពើមនុស្សឃាត ដូចរៀបរាប់ខាងលើក៏ដោយ តែអំពើមនុស្សឃាតត្រូវបានស្រូបយកដោយការសម្លាប់រង្គាល។

អង្គជំនុំជម្រះចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ។ អំពើជាមូលដ្ឋានទាំងអស់នេះក៏បានបង្កើតជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះចំពោះបទល្មើសអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)[៣០៩៦]។ ជាចុងក្រោយ ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ អំពើជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះ ចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមមាន ការសម្លាប់ដោយចេតនាជាទ្រង់ទ្រាយធំ។ អំពើជាមូលដ្ឋានទាំងអស់នេះក៏បង្កើតជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះចំពោះបទល្មើសការសម្លាប់រង្គាលដែរ[៣០៩៧]។

១០៥៩. បទល្មើសការធ្វើទុក្ខបុកម្នេញ យ៉ាងហោចណាស់ក៏មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័តមួយផ្សេងពីបទល្មើសការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលតម្រូវឱ្យបង្ហាញភ័ស្តុតាងពីចេតនារើសអើងជាក់លាក់ដែរ[៣០៩៨]។ ការសម្លាប់រង្គាលតម្រូវឱ្យមានការសម្លាប់ជាទ្រង់ទ្រាយធំ[៣០៩៩] ហើយបទល្មើសអំពើអមនុស្សធម៌ផ្សេងៗទៀត តម្រូវឱ្យមានអំពើសកម្ម ឬអកម្ម ដែលបង្កឱ្យមានព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬបង្កជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សយ៉ាងធ្ងន់ធ្ងរ[៣១០០]។ បទល្មើសការធ្វើទុក្ខបុកម្នេញ មិនតម្រូវឱ្យមានធាតុផ្សំទាំងនេះទេ។

១០៦០. ហេតុដូច្នេះ អង្គជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទចំពោះបទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ដោយសារតែបទល្មើសនីមួយៗមានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលមិនមាននៅក្នុងបទល្មើសផ្សេងៗទៀតទេ។

---

[៣០៩៦] ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៣០-៦៤៣, ៦៤៩-៦៥៧។

[៣០៩៧] ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨៣-៦៨៥។ ទោះបីជាអង្គជំនុំជម្រះបានរកឃើញផងដែរថា មានអំពើមនុស្សឃាត ដូចរៀបរាប់ខាងលើក៏ដោយ តែអំពើមនុស្សឃាតត្រូវបានស្រូបយកដោយការសម្លាប់រង្គាល។

[៣០៩៨] សាលដីកាលើសំណុំរឿង កាំង ហ្កេកអ៊ាវ កថាខណ្ឌ ៣៣៥។

[៣០៩៩] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤១៦។

[៣១០០] ផ្នែកទី ៩៖ ច្បាប់ជាធរមាន៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ ៤៣៧។

# ១៨. ការផ្តន្ទាទោស

## ១៨.១ សារណា

១០៦១.សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយពិចារណាទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ស្ថានទម្ងន់ទោស និងនត្ថិភាពនៃស្ថានសម្រាលទោសដែលពាក់ព័ន្ធនោះ អង្គជំនុំជម្រះសាលាដំបូងគប្បីសម្រេចផ្តន្ទាទោស នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត[៣១០១]។ សហព្រះ-រាជអាជ្ញាបានលើកទឡ្ហីករណ៍ថា មូលដ្ឋាន និងបរិបទនៃសំណុំរឿងនេះ គឺដូចគ្នាទៅនឹងសំណុំរឿង ០០១ ដែលក្នុងសំណុំរឿង ០០១ នោះ ជនជាប់ចោទត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមបណ្តឹងសាទុក្ខ។ ដោយធ្វើការប្រៀបធៀបសំណុំរឿងទាំងពីរ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ទោះបីជាបទល្មើសនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ (ដែលគ្របដណ្តប់ត្រឹមតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ខុសពីបទល្មើសនៅក្នុងសំណុំរឿង ០០១ ក៏ដោយ ក៏សហជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០១ គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយស្ថិតនៅចំណុចស្នូលនៃមជ្ឈិមបក្ស ចំណែកឯជនជាប់ចោទនៅក្នុងសំណុំរឿង ០០១ គឺ កាំង ហ្កេកអ៊ាវ មានឋានៈត្រឹមតែជាអ្នកនៅក្រោមបង្គាប់របស់សហជនជាប់ចោទទាំងពីរ និងត្រូវរាយការណ៍ទៅ នួន ជា ប៉ុណ្ណោះ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ចំនួនជនរងគ្រោះនៅក្នុងសំណុំរឿង ០០២/០១ ច្រើនជាងចំនួនជនរងគ្រោះនៅក្នុងសំណុំរឿង ០០១។ សហព្រះរាជអាជ្ញាបានលើកឡើងទៀតថា កត្តាទាំងអស់នេះ ក៏ដូចជា ការអនុវត្តស្តីពីការកំណត់ទោសប្រហាក់ប្រហែលគ្នានៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានគាំទ្រដល់ការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតសម្រាប់ជនជាប់ចោទម្នាក់ៗ[៣១០២]។

១០៦២. បើទោះបីជា នួន ជា បានបដិសេធនូវការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ[៣១០៣] ក៏នៅក្នុងអំឡុងពេលសវនាការ គាត់បានសំដែងការអាណិតអាសូរចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវ

---

[៣១០១] សារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/1, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៧១៩ ដល់ ៧៤៨។ *សូមមើលផងដែរ*, ប្រតិចារឹក ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៣ (សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា) ទំព័រ ៨៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់សហព្រះរាជអាជ្ញា), ទំព័រ ២៨, ៩៩។

[៣១០២] សារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/1, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៧៤៤ ដល់ ៧៤៨។

[៣១០៣] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១, ឯកសារ E72/3, ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៣, កថាខណ្ឌ 12, 15, 234, 305, 318, 320, 333, 344, 359, 364, 368, 369, 412, 439, 444; ប្រតិ-ចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់នួន ជា), ទំព័រ ៦៤-៦៤,

បានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានលើកឡើងថា គាត់សោកស្តាយដែល "ការដឹកនាំនេះ វាមិនបានដិតដល់"[៣១០៤]។ គាត់អះអាងថា គាត់ទទួលខុសត្រូវផ្នែកសីលធម៌ចំពោះ "អ្វីដែលបានកើតឡើង" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[៣១០៥] ប៉ុន្តែគាត់ក៏បានលើកឡើងផងដែរថា គាត់ "មិនមានអំណាចអ្វី" នៅក្នុងផ្នែកនីតិប្រតិបត្តិទេ[៣១០៦]។ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នួន ជា បានបន្ទោសទៅលើ "ពួកក្បត់" ចំពោះ "សោកនាដកម្មដែលបានកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និងបានអះអាងពីភាពគ្មានពិរុទ្ធរបស់គាត់។ នួន ជា បានសុំទោសដល់សាធារណជន ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងប្រជាជនកម្ពុជាទាំងអស់។ គាត់បានបញ្ជាក់សាជាថ្មីអំពីការទទួលខុសត្រូវផ្នែកសីលធម៌ ដែលគាត់យល់ថា ដោយសារតែបក្សកុម្មុយនីស្តកម្ពុជាមិនមានលទ្ធភាពក្នុងការគ្រប់គ្រង[៣១០៧]។

១០៦៣.នៅក្នុងអំឡុងពេលសវនាការ និងក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ខៀវ សំផន បានបដិសេធអំពីការដឹង ក៏ដូចជាការទទួលខុសត្រូវចំពោះហេតុការណ៍នានា ដែលនាំឱ្យមានការចោទប្រកាន់ដល់រូបគាត់[៣១០៨]។ គាត់បានស្នើឱ្យមានការលើកលែងការចោទប្រកាន់មកលើរូបគាត់ ហើយមេធាវីការពារក្តីរបស់គាត់មិនបានបង្ហាញឱ្យបានច្បាស់លាស់

---

៦៧, ៧១-៧២, ៧៣-៧៤, ៧៦; ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញ-ដោលរបស់ នួន ជា) ទំព័រ ៤៣-៤៤។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (Victor KOPPE) ទំព័រ ៥-៦។

[៣១០៤] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ១៨-២០, ៤១-៤២ ("អនុញ្ញាតឱ្យខ្ញុំបង្ហាញការគោរពដល់វិញ្ញាណក្ខន្ធប្រជាជនកម្ពុជា ព្រមទាំងចំពោះអ្នកនៅរស់រានមានជីវិត ដែលបានបាត់បង់សាច់ញាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ១៤-១៧; ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ១៩-២២។

[៣១០៥] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ៦៦-៧២។

[៣១០៦] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ជា) ទំព័រ ១៤-១៧, ៦៦-៧២។

[៣១០៧] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា), ទំព័រ ២, ២៥-២៦។

[៣១០៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៣-១៥; ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៨-៧១; ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៥-១៩; ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៤-១៦; ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៧-៧០; ប្រតិចារឹក ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៩-២១; ប្រតិ-ចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន) ទំព័រ ៥៥។

អំពីស្ថានសម្រាលទោសដែលអាចមាននោះឡើយ។ គាត់បានអះអាងថា សកម្មភាពរបស់គាត់ត្រូវបានធ្វើឡើងដើម្បីជំរុញដល់ការការពារអ្នកដែលទន់ខ្សោយ និងការកសាងកម្ពុជាមួយដែលមានឯករាជ្យ សន្តិភាព និងមានភាពរឹងមាំ[៣១០៩]។

១០៦៤. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចដោយមតិភាគច្រើនរបស់ចៅក្រម និងតម្កល់សេចក្តីសម្រេចដែលថា ដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលជាក្រុមតែមួយមិនអាចអន្តរាគមន៍ទៅលើបញ្ហាផ្សេងៗដែលទាក់ទងនឹងការផ្តន្ទាទោសបានឡើយ[៣១១០]។

## ១៨.២ ច្បាប់ជាធរមាន

### ១៨.២.១ បទប្បញ្ញត្តិ និងក្របខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនៅ អ.វ.ត.ក

១០៦៥. វិធាន ៩៨ (៥) នៃវិធានផ្ទៃក្នុងចែងថា "ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តន្ទាទោសជនជាប់ចោទឱ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុង"។ មាត្រា ១០ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត"។ មាត្រា៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងបន្ថែមទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដូចតទៅនេះ៖

> ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ ឆ្នាំរហូតដល់មួយជីវិត។

---

[៣១០៩] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ជនជាប់ចោទខៀវ សំផន) ទំព័រ ៥២-៥៣។

[៣១១០] ប្រតិចារឹក ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៨១-៨២ (CS) (សម្ងាត់-អសាធារណៈ) ដកស្រង់សេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០១៖ ប្រតិចារឹក ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ ៣១-៣២; សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ, ឯកសារ E72/3, ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩, ជាពិសេសគឺ កថាខណ្ឌ ៤០ និង ៤២។

ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងអាចសម្រេច រឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបាន ដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម។

ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ[៣១១១]។

១០៦៦. កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ជារួម មិនបាន ចែងអំពីគោលការណ៍ និងកត្តានានាដែលត្រូវយកមកពិចារណានៅពេលធ្វើការផ្តន្ទាទោសឡើយ។ ដូច្នេះ អង្គជំនុំជម្រះនឹងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកំណត់ទោសនេះ ទៅតាមកាលៈទេសៈ ជាក់ស្តែង ហើយយោងតាមមាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះនឹងស្វែង រកការណែនាំអនុវត្តស្តីពីការកំណត់ទោសនេះ តាមគោលការណ៍ និងកត្តាពាក់ព័ន្ធនានាដែលអនុវត្ត នៅកម្ពុជា និងនៅកម្រិតអន្តរជាតិ។

### ១៨.២.២ គោលការណ៍ និងកត្តានានាដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស

១០៦៧. នៅក្នុងការកាត់បន្ថយនូវឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយ និងវិសាលភាពធំ ឲ្យមកជា ឧក្រិដ្ឋកម្មដែលអាចផ្តន្ទាទោសជាលក្ខណៈឯកត្តបុគ្គលនោះ អង្គជំនុំជម្រះមានបំណងបង្ហាញដល់ ជនរងគ្រោះដែលនៅរស់រានមានជីវិត ក្រុមគ្រួសាររបស់ពួកគេ សាក្សី និងសាធារណជនទូទៅថា ច្បាប់ត្រូវបានយកមកអនុវត្តយ៉ាងពិតប្រាកដ ហើយអនុវត្តចំពោះជនគ្រប់រូប ដោយមិនគិតអំពីបុណ្យ ស័ក្តិ ឬឋានៈអ្វីឡើយ[៣១១២]។ លើសពីនេះទៀត ការផ្តន្ទាទោសក៏ធ្វើឡើងក្នុងគោលបំណងឲ្យមានការ ញញើត ទាំងជនជាប់ចោទ និងជនទូទៅ[៣១១៣] និងការផ្តន្ទាទោសស្របតាមអំពើប្រព្រឹត្ត ដែលមិន មែនជាការសងសឹកនោះទេ[៣១១៤]។ ការផ្តន្ទាទោសត្រូវតែមានលក្ខណៈឯកត្តបុគ្គល និងសមាមាត្រទៅ នឹងអំពើដែលឆ្លុះបញ្ចាំងពីពិរុទ្ធរបស់ជនជាប់ចោទ និងត្រូវផ្អែកលើការវិភាគដែលមានលក្ខណៈជា សត្យានុម័ត មានហេតុផលសមរម្យ និងមានការថ្លឹងថ្លែងត្រឹមត្រូវ ទាំងទៅលើអំពើរបស់ជនជាប់-

[៣១១១] *សូមមើលផងដែរ* មាត្រា ៣៨ នៃច្បាប់ អ.វ.ត.ក (ទោសប្បញ្ញត្តិទាំងអស់ត្រូវកម្រិតត្រឹមការដាក់ពន្ធនាគារ) ហើយមាត្រា ១៨៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវជាប់ទោសអស់មួយជីវិត)។

[៣១១២] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧៩។ សាលដីកាលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១០៧៣ និង ១០៨០។

[៣១១៣] សាលដីកាលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១០៧៣ និង ១០៧៦-១០៧៨។

[៣១១៤] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨០។ សាលដីកាលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១០៧៣ និង ១០៧៥។

ចោទ និងទាំងទៅលើព្យសនកម្មនានា ដែលជាផលវិបាកនៃការប្រព្រឹត្តិអំពើទាំងនោះ[៣១១៥]។ គោលការណ៍ទាំងនោះក៏ត្រូវបានទទួលស្គាល់ និងអនុវត្តនៅក្នុងច្បាប់កម្ពុជាផងដែរ[៣១១៦]។

១០៦៨. ដើម្បីសម្រេចអំពីទោសឱ្យបានសមស្រប ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តគឺជា "លក្ខណៈវិនិច្ឆ័យសំខាន់"[៣១១៧] ហើយតម្រូវឱ្យ "តុលាការត្រូវពិចារណាអំពីកាលៈទេសៈពិសេសនៃរឿងក្ដី ព្រមទាំងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនោះ"[៣១១៨]។ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់កត្តាមួយចំនួនដូចតទៅនេះ ថាជាកត្តាពាក់ព័ន្ធទៅនឹងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ៖ ចំនួនជនរងគ្រោះ និងភាពងាយរងគ្រោះរបស់ជនរងគ្រោះ ផលប៉ះពាល់នៃបទឧក្រិដ្ឋចំពោះជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ ចេតនារើសអើងរបស់ពិរុទ្ធជននៅពេលដែលចេតនានោះមិនទាន់ក្លាយជាធាតុផ្សំនៃបទឧក្រិដ្ឋ កម្រិត និងភាពសាហាវព្រៃផ្សៃនៃបទល្មើស និងតួនាទីរបស់ពិរុទ្ធជន[៣១១៩]។

១០៦៩. លើសពីនេះទៀត អង្គជំនុំជម្រះនឹងពិចារណាទៅលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសពាក់ព័ន្ធទាំងអស់នៅក្នុងការកំណត់ទោស[៣១២០]។ សហព្រះរាជអាជ្ញាត្រូវបង្ហាញអំពីស្ថានទម្ងន់ទោសនានាទៅតាមបទដ្ឋានមួយដូចគ្នានឹងបទដ្ឋានតម្រូវសម្រាប់ការបញ្ជាក់ពីពិរុទ្ធ ហើយមានតែកាលៈទេសៈពាក់ព័ន្ធផ្ទាល់ទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទ ហើយជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធដោយផ្អែកលើមូលដ្ឋាននៃកាលៈទេសៈនេះប៉ុណ្ណោះ នឹងត្រូវបានយកមកពិចារណាជាស្ថានទម្ងន់ទោស។ ធាតុផ្សំនៃបទល្មើសជាក់លាក់ណាមួយ មិន

---

[៣១១៥] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨០។ សាលដីកាលើរឿងក្ដី *Furundžija* កថាខណ្ឌ ២៤៩។

[៣១១៦] *សូមមើល* មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

[៣១១៧] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨២។ សាលដីកាលើរឿងក្ដី *Aleksovski* កថាខណ្ឌ ១៨២។

[៣១១៨] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨២ យោងលើសាលដីកាលើរឿងក្ដី *Stakić* កថាខណ្ឌ ៣៨០។ សូមមើលផងដែរ វិធាន ១៤៥(១)(គ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូចគ្នានេះដែរ មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា ក្នុងការសម្រេចទោស ត្រូវផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ។

[៣១១៩] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៣៧៥។

[៣១២០] ស្ថានទម្ងន់ និងស្ថានសម្រាល ក៏ត្រូវបានយកទៅពិចារណាដែរក្នុងការកំណត់ទោសនៅក្រោមច្បាប់កម្ពុជា។ *សូមមើល* មាត្រា ៧៧ ដល់ ៨២ និងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

អាចត្រូវបានយកមកពិចារណាថាជាស្ថានទម្ងន់ទោសឡើយ[៣១២១]។ បន្ថែមពីលើនេះ អង្គហេតុដូចគ្នា ក៏មិនអាចយកមកប្រើប្រាស់សម្រាប់ការបង្ហាញពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋផង និងស្ថានទម្ងន់ទោសផងបាននោះទេ[៣១២២]។ ជាចុងក្រោយ អង្គជំនុំជម្រះសម្រេចយកការណែនាំនានា ដែលពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស ដែលមានចែងក្នុងវិធាន ១៤៥(២)(ខ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) មកអនុវត្ត ក្នុងករណីមានការពាក់ព័ន្ធនឹងសំណុំរឿងដូចគ្នានេះ ដូចខាងក្រោម៖

(i) ការផ្តន្ទាទោសលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តពីពេលមុន ដែលឧក្រិដ្ឋកម្មទាំងនោះ ស្ថិតក្រោមយុត្តាធិការរបស់តុលាការ ICC ឬតុលាការមានលក្ខណៈស្រដៀងគ្នា។

(ii) ការរំលោភអំណាច ឬសមត្ថកិច្ចផ្លូវការ

(iii) ការប្រព្រឹត្តិបទល្មើសដែលជនរងគ្រោះមិនអាចការពារខ្លួនបាន

(iv) ការប្រព្រឹត្តិបទល្មើសយ៉ាងសាហាវឃោរឃៅ ឬមានជនរងគ្រោះច្រើន

(v) ការប្រព្រឹត្តិបទល្មើសដោយសារមានការជំរុញចិត្ត ដែលពាក់ព័ន្ធការរើសអើងដោយសារមូលហេតុដែលមានចែងនៅក្នុងមាត្រា ២១ កថាខណ្ឌ៣ (ពោលគឺ ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗ ជាតិសាសន៍ដើម ជាតិពន្ធុដើម ឬសង្គមដើម ទ្រព្យសម្បត្តិ កំណើត ឬវណ្ណៈផ្សេងៗទៀត)។

(vi) ស្ថានភាពផ្សេងៗទៀត បើទោះបីជាមិនមានចែងខាងលើ ប៉ុន្តែអាស្រ័យតាមលក្ខណៈរបស់វា គឺស្រដៀងគ្នានឹងអ្វីដែលមានចែងដែរ[៣១២៣]។

---

[៣១២១] *កាំង ហ្កេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៥៨៣។ សាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៦៩៣។

[៣១២២] *កាំង ហ្កេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៥៨៣។ សាលដីកាលើរឿងក្តី *Deronjić* លើបណ្តឹងសារទុក្ខលើការផ្តន្ទាទោស កថាខណ្ឌ ១០៦-១០៧។

[៣១២៣] *កាំង ហ្កេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៣។ ដកស្រង់វិធាន ១៤៥(២)(ខ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

១០៧០.យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដទៃទៀតបានកំណត់ថា បន្ទុកនៃការបង្ហាញភ័ស្តុតាងរបស់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងស្ថានសម្រាលទោស តម្រូវឲ្យមានបទដ្ឋានទាបជាងបន្ទុកនៃការបង្ហាញភ័ស្តុតាងរបស់ព្រះរាជអាជ្ញាអំពីស្ថានទម្ងន់ទោស[៣១២៤]។ ស្ថានសម្រាលទោសអាចនឹងត្រូវយកមកពិចារណា ដោយមិនគិតថាតើស្ថានសម្រាលទោសទាំងនោះពាក់ព័ន្ធដោយផ្ទាល់ ឬ មិនផ្ទាល់ទៅនឹងបទល្មើសដែលចោទប្រកាន់ដែរ ឬយ៉ាងណានោះទេ[៣១២៥]។ វិធាន ១៤៥(២)(ក) នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ស្ថានសម្រាលទោសដូចខាងក្រោមនេះ ដែលអង្គជំនុំជម្រះបានសម្រេចយកសាជាថ្មីទៀត៖

(i) កាលៈទេសៈដែលមានរយៈពេលខ្លីដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការដកចេញពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដូចជាការបង្ហាញអំពីសមត្ថភាពបញ្ញាស្មារតីមានបញ្ហាធ្ងន់ធ្ងរ ឬការបង្ខិតបង្ខំ។

(ii) អំពើរបស់ពិរុទ្ធជនក្រោយពីការប្រព្រឹត្តិបទល្មើស ដែលរួមបញ្ចូលនូវការខិតខំប្រឹងប្រែងរបស់បុគ្គលនោះដើម្បីសងសំណងដល់ជនរងគ្រោះ និងការសហការជាមួយតុលាការ[៣១២៦]។

១០៧១.អង្គជំនុំជម្រះកត់សម្គាល់ថា យោងតាមយុត្តិសាស្ត្រអន្តរជាតិដែលមានស្រាប់ ការសម្រេចទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅក្នុងអំឡុងពេលសវនាការមួយចំនួនមិនត្រូវបានចាត់ទុកថា ជាស្ថានទម្ងន់ទោស នៅពេលធ្វើការកំណត់ទោសនោះទេ[៣១២៧]។

### ១៨.២.៣ អានុភាពនៃការរកឃើញពិរុទ្ធពីបទល្មើសច្រើននៅពេលផ្តន្ទាទោស

១០៧២.បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងមិនបានចង្អុលបង្ហាញថាតើអង្គជំនុំជម្រះអាចធ្វើការផ្តន្ទាទោសសរុបរួមតែមួយ ក្រោយពីបានរក

---

[៣១២៤] *កាំង ហ្កេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៤។ សាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៦៨៧ កំណត់ជើងទំព័រលេខ ១៤៦៦។

[៣១២៥] *កាំង ហ្កេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៣។ សាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៦៩៦។

[៣១២៦] វិធាន ១៤៥(២)(ក) នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[៣១២៧] សាលដីកាលើរឿងក្តី *Blaškić*, កថាខណ្ឌ ៦៨៧។ សាលដីកាលើរឿងក្តី *Delalić ព្រមទាំងអ្នកដទៃទៀត*។ សាលដីកាលើរឿងក្តី *Limaj ព្រមទាំងអ្នកដទៃទៀត*, កថាខណ្ឌ ៧៨៣។ សាលក្រម កថាខណ្ឌ ៧២៩។

ឃើញពិរុទ្ធចំពោះបទល្មើសច្រើន នៅពេលដែលពិរុទ្ធនីមួយៗផ្អែកទៅលើអំពើឧក្រិដ្ឋដាច់ដោយឡែកពីគ្នារបស់ជនជាប់ចោទនោះទេ[៣១២៨]។ ប៉ុន្តែទោះជាយ៉ាងណា អង្គជំនុំជម្រះធ្លាប់បានសម្រេចកន្លងមកថា អង្គជំនុំជម្រះអាចប្រកាសទោសសរុបរួមតែមួយ ដែលឆ្លុះបញ្ចាំងពីអំពើឧក្រិដ្ឋរួមរបស់ជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន[៣១២៩]។

## ១៨.៣ សំអាងហេតុ

### ១៨.៣.១ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ

#### ១៨.៣.១.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ

១០៧៣. សហព្រះរាជអាជ្ញាអះអាងថា នៅក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ អង្គជំនុំជម្រះគួរពិចារណាអំពីចំនួនជនរងគ្រោះដ៏ច្រើន កាលៈទេសៈនៃការប្រព្រឹត្តបទល្មើសយ៉ាងសាហាវព្រៃផ្សៃ និងអមនុស្សធម៌ ផលវិបាករយៈពេលវែងនៃបទឧក្រិដ្ឋទាំងនោះទៅលើប្រជាជនកម្ពុជា និង តួនាទីដ៏សំខាន់របស់ជនជាប់ចោទទាំងពីរនៅក្នុងការរៀបចំ និងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[៣១៣០]។ អង្គជំនុំជម្រះយល់ស្របថា កត្តាទាំងអស់នេះ មានភាពពាក់ព័ន្ធទៅនឹងការសម្រេចពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ហើយក៏ស្របជាមួយនឹងការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលផងដែរ[៣១៣១]។

១០៧៤. អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។

---

[៣១២៨] អង្គជំនុំជម្រះកត់សម្គាល់ថា បញ្ហានេះខុសពីការផ្តន្ទាទោសត្រួត ដែលទាក់ទងដល់បញ្ហាថាតើជនជាប់ចោទអាចត្រូវទទួលការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មផ្សេងៗគ្នា ដោយផ្អែកលើអំពើជាមូលដ្ឋានដូចគ្នាមួយ ឬច្រើន ហើយដែលត្រូវបានដោះស្រាយរួចរាល់ហើយ។ សូមមើលផ្នែកទី ១៧៖ ពិរុទ្ធពីបទល្មើសច្រើន កថាខណ្ឌ ១០៥៥-១០៦០។

[៣១២៩] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៦ និង ៥៩០។

[៣១៣០] សារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/1, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៧២២ ដល់ ៧៣៥។

[៣១៣១] សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៣៧៥។ រម្លឹកពីខាងលើ។

១០៧៥.អង្គជំនុំជម្រះសាលាដំបូងរកឃើញថា យ៉ាងហោចណាស់ក៏មានមន្ត្រីរដ្ឋការ លន់ នល់ ចំនួន ២៥០ នាក់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ[៣១៣២] ហើយយ៉ាងហោចណាស់ក៏មានប្រជាជនពី ២.៣៣០.០០០ នាក់ ទៅ ២.៤៣០.០០០ នាក់ ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២[៣១៣៣]។ ចំនួនជនរងគ្រោះនៅក្នុងរឿងក្តីនេះ ស្ថិតនៅក្នុងចំណោមចំនួនជនរងគ្រោះដែលច្រើនបំផុតនៃរឿងក្តីដែលត្រូវបានជំនុំជម្រះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ។ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជាក្នុងអំឡុងពេលជិតពីរឆ្នាំ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋត្រូវបានឆ្លុះបញ្ចាំងតាមរយៈចំនួនជនរងគ្រោះដ៏ច្រើនលើសលប់ និងវិសាលភាពទូលាយផ្នែកទីតាំងភូមិសាស្ត្រ និងពេលវេលានៃការរងគ្រោះ។

១០៧៦.អង្គជំនុំជម្រះរកឃើញថា លក្ខខណ្ឌនៃការជម្លៀសដោយបង្ខំមានភាពធ្ងន់ធ្ងរ មិនយកចិត្តទុកដាក់ និងអមនុស្សធម៌។ លក្ខខណ្ឌទាំងនោះរួមមាន អាកាសធាតុក្តៅខ្លាំង ការខ្វះខាតម្ហូបអាហារ ទឹកស្អាត ថ្នាំពេទ្យ ឬ ទីកន្លែងស្នាក់នៅសមស្រប ការព្រាត់ប្រាស់ក្រុមគ្រួសារ ការធ្វើបាបយ៉ាងសាហាវព្រៃផ្សៃ ការភ័យរន្ធត់ ការគំរាមកំហែង ព្រមទាំងហេតុការណ៍ហិង្សាផ្សេងៗទៀត[៣១៣៤]។ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងដោយមិនបានគិតគូរដល់ជីវិតមនុស្ស ហើយជាញឹកញាប់មានភាពសាហាវព្រៃផ្សៃ ដែលបង្កើតបានជាភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទាំងនោះ។

១០៧៧.ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋត្រូវបានបង្ហាញបន្ថែមទៀត តាមរយៈផលប៉ះពាល់រយៈពេលយូរ និងធ្ងន់ធ្ងរចំពោះជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ ព្រមទាំងចំពោះប្រជាជនកម្ពុជាទូទៅ។ សម្រាប់ជនរងគ្រោះដែលបានបាត់បង់ជីវិតដោយសារតែឧក្រិដ្ឋកម្មទាំងនោះ គឺពិតជាទទួលរងផលប៉ះពាល់ពីឧក្រិដ្ឋកម្មនោះពិតប្រាកដ។ រីឯអ្នកដែលនៅរស់រានមានជីវិតវិញ គឺទទួលរងការប៉ះទង្គិច

---

[៣១៣២] សូមមើល ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៨១។

[៣១៣៣] សូមមើល ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៧។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២), កថាខណ្ឌ ៦៣០។

[៣១៣៤] សូមមើល ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៩-៤៩១, ៥៤៦-៥៧៤។ ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២), កថាខណ្ឌ ៦៣៥-៦៣៩។

ផ្លូវចិត្ត (Trauma) ជាប់ជារៀងរហូត ព្រមទាំងមានវិបល្លាសស្មារតី និងជំងឺផ្លូវចិត្ត[៣១៣៥]។ ផល ប៉ះពាល់ធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះទៅលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ គឺមានភាពរន្ធត់ និងជាប់ជារៀងរហូត។

១០៧៨.អង្គហេតុដូចគ្នាមិនអាចយកមកប្រើប្រាស់ សម្រាប់ការបង្ហាញពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋផង និងស្ថានទម្ងន់ទោសផងបានឡើយ[៣១៣៦]។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសម្រេច ថាតើកត្តាណាមួយដែលមានភាពសមស្របជាង ក្នុងការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ឬស្ថាន ទម្ងន់ទោសនោះ[៣១៣៧]។ នៅក្នុងកាលៈទេសៈជាច្រើន អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាទៅ លើភាពងាយរងគ្រោះរបស់ជនរងគ្រោះ នៅពេលវាយតម្លៃពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទេ ដោយ យល់ឃើញថា កត្តានេះមានភាពសមស្របជាង សម្រាប់ការពិចារណាពីស្ថានទម្ងន់ទោស។

### ១៨.៣.១.២ តួនាទីរបស់ នួន ជា

១០៧៩.អង្គជំនុំជម្រះរកឃើញថា នួន ជា គឺជាតួអង្គសំខាន់មួយដែលទទួលខុសត្រូវលើការបង្កើត គោលនយោបាយបក្ស[៣១៣៨]។ ក្នុងនាមជាអនុលេខាបក្ស គាត់មានអំណាចធ្វើសេចក្តីសម្រេចចុង ក្រោយជាមួយនឹង ប៉ុល ពត[៣១៣៩]។ នួន ជា បានដឹងថា អាចនឹងមានឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្ត ហើយគាត់បានចូលរួមនៅក្នុងគោលបំណងរួមនេះ ចាប់តាំងពីពេលដែលគោលបំណងនេះត្រូវបាន បង្កើតឡើងជាលើកដំបូង រហូតដល់ពេញអំឡុងពេលដែលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១ ដោយ រាប់តាំងពីការចូលរួមរបស់គាត់ នៅក្នុងដំណាក់កាលដំបូងនៃការបង្កើតគោលនយោបាយខាងលើ

[៣១៣៥] សូមមើល ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៥២។ ផ្នែកទី ១១៖ ការផ្លាស់ទី លំនៅប្រជាជន (ដំណាក់កាលទី២), កថាខណ្ឌ ៦៣៩, ៦៤៤។ ផ្នែកទី ១៩៖ សំណងរដ្ឋប្បវេណី កថាខណ្ឌ ១១៤១-១១៥០។

[៣១៣៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៥៨៣។ សាលដីកាលើផ្នែក សម្រេចសេចក្តី លើរឿងក្តី *Deronjić*, កថាខណ្ឌ ១០៦ ដល់ ១០៧។

[៣១៣៧] សាលក្រមលើរឿងក្តី *Popović និងអ្នកដទៃទៀត*។ សាលក្រម កថាខណ្ឌ ២១៣៨។ សាលដីកាលើរឿងក្តី *Vasiljević*, កថាខណ្ឌ ១៥៧។

[៣១៣៨] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៧-៣៤៨។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្ម-ទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៥។

[៣១៣៩] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៨។

រហូតដល់ពេលគាត់បានចូលរួមយ៉ាងសកម្ម នៅក្នុងការបន្តអនុវត្តគោលនយោបាយទាំងនេះ[៣១៤០]។ អង្គជំនុំជម្រះរកឃើញថា ឥទ្ធិពលនៃតួនាទីរបស់គាត់មានលក្ខណៈខ្លាំងក្លា ដោយសារតែមានមនុស្សតិចតួចណាស់ដែលមានតួនាទីជា "ថ្នាក់លើ"[៣១៤១]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការចូលរួមរបស់ នួន ជា នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ មានលក្ខណៈធំធេង និងមានឥទ្ធិពលខ្លាំងក្លា។

### ១៨.៣.១.៣ តួនាទីរបស់ ខៀវ សំផន

១០៨០. អង្គជំនុំជម្រះរកឃើញថា ខៀវ សំផន គឺជាតួអង្គសំខាន់មួយដែលទទួលខុសត្រូវលើការបង្កើតគោលនយោបាយបក្ស ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១។ នៅគ្រប់ពេលនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០២/០១ នេះ គាត់ក៏បានផ្សព្វផ្សាយ អនុម័ត និងការពារគោលបំណងរួម និងគោលនយោបាយទាំងនេះ ដោយបានផ្តល់ការលើកទឹកចិត្ត ការគាំទ្រ និងធ្វើជាតំណាងដ៏គួរឲ្យទុកចិត្ត និងគួរឲ្យគោរព ដែលបណ្តាលឲ្យឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តយ៉ាងសកម្ម[៣១៤២]។ ខៀវ សំផន បានដឹងថា អាចនឹងមានឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្ត ហើយគាត់បានចូលរួមនៅក្នុងគោលបំណងរួមនេះ ចាប់តាំងពីពេលដែលគោលបំណងនេះត្រូវបានបង្កើតឡើងជាលើកដំបូង រហូតដល់ពេញអំឡុងពេលដែលពាក់ព័ន្ធនៃសំណុំរឿង ០០២/០១។ នៅខណៈពេលនោះដែរ គាត់បានអនុវត្តកិច្ចការសេដ្ឋកិច្ចសំខាន់ៗនៃគោលបំណងរួមនេះ ដែលមានចេតនាធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជាប្រែក្លាយជាប្រទេសដែលមានកសិកម្មទំនើប ហើយក្រោយមកក្លាយជាប្រទេសឧស្សាហកម្មមួយ ដោយមិនគិតពីតម្លៃរបស់មនុស្សនៅក្នុងការអនុវត្តគោលបំណងរួមនេះទេ[៣១៤៣]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការចូលរួមរបស់ ខៀវ សំផន នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ មានលក្ខណៈធំធេង និងមានឥទ្ធិពលខ្លាំងក្លា។

---

[៣១៤០] ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៣៩-៨៥៧, ៨៦១។

[៣១៤១] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣៤៧-៣៤៨។ ផ្នែកទី ១៥៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា កថាខណ្ឌ ៨៧៥។

[៣១៤២] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៨០-៩៨៧។

[៣១៤៣] ផ្នែកទី ១៦៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៩។

## ១៨.៣.២ ស្ថានទម្ងន់ទោស

### ១៨.៣.២.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ

១០៨១.សហព្រះរាជអាជ្ញាលើកឡើងថា មានកត្តាមួយចំនួនដូចខាងក្រោមដែលអាចបង្កើនទម្ងន់ទោសចំពោះជនជាប់ចោទគឺៈ ជនជាប់ចោទម្នាក់ៗបានរំលោភបំពាន "ទាំងស្រុង" លើអំណាច និងតួនាទីផ្លូវការ ការគ្មានលទ្ធភាពទាល់តែសោះក្នុងការការពារខ្លួនរបស់ជនរងគ្រោះ និងចំនួនជន-រងគ្រោះដ៏ច្រើន ព្រមទាំងភាពសាហាវព្រៃផ្សៃ និងការងប់ងល់នឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[៣១៤៤]។

១០៨២.បុគ្គលដែលងាយរងគ្រោះជាច្រើន ដូចជា កុមារ ជនចាស់ជរា អ្នកជំងឺ និងអ្នករបួសដែលត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ និងស្ត្រីទើបឆ្លងទន្លេ គឺជាកម្មវត្ថុនៃឧក្រិដ្ឋកម្មនៅក្នុងដំណាក់កាលទាំងពីរនៃការជម្លៀសប្រជាជននេះ[៣១៤៥]។ លើសពីនេះទៀត អ្នកដែលត្រូវទទួលរងការជម្លៀសដោយបង្ខំ មិនអាចជួយខ្លួនឯងបាន ជាពិសេសតាមរយៈសកម្មភាពផ្ទាល់របស់ពួកខ្មែរក្រហម ជនរងគ្រោះទន់ខ្សោយ អស់កម្លាំង មានរបួស និងមានជំងឺ ដោយសារតែខ្វះចំណីអាហារ ទីកន្លែងស្នាក់នៅ ជំនួយ ឬ បង្គន់អនាម័យ[៣១៤៦]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គហេតុដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តចំពោះបុគ្គលដែលងាយរងគ្រោះ និងគ្មានមធ្យោបាយការពារខ្លួន គឺជាស្ថានទម្ងន់ទោស។

១០៨៣.ដោយសារតែចំនួនជនរងគ្រោះត្រូវបានយកមកពិចារណានៅក្នុងការវាយតម្លៃលើភាពធ្ងន់-ធ្ងរនៃបទឧក្រិដ្ឋនោះ[៣១៤៧] អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាលើកត្តានេះជាស្ថានទម្ងន់ទោសដូចដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាទេ។

---

[៣១៤៤] សារណាបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១, ឯកសារ E295/6/1, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ៧៣៦ ដល់ ៧៣៩។

[៣១៤៥] សូមមើល ផ្នែកទី ១០ៈ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៦-៥៧៤។ ផ្នែកទី ១១ៈ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៤៧។

[៣១៤៦] សូមមើល ផ្នែកទី ១០ៈ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៥៤៦-៥៧៤។ ផ្នែកទី ១១ៈ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦៤៧-៦៤៨។

[៣១៤៧] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៥៨៣។ សាលដីកាលើផ្នែកសម្រេចសេចក្តី លើរឿងក្តី *Deronjić*, កថាខណ្ឌ១០៦ ដល់ ១០៧។

### ១៨.៣.២.២ ការពិចារណាចំពោះ នួន ជា

១០៨៤. អង្គជំនុំជម្រះរកឃើញថា នួន ជា ត្រូវទទួលខុសត្រូវលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានទាំង ការផ្លាស់ទីលំនៅ ដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។ ការចូលរួម ចំណែករបស់ នួន ជា នៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ រួមមាន តាមរយៈការចូលរួមរបស់គាត់នៅ ក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើឡើងតាមរយៈតួនាទី ជាផ្លូវការរបស់គាត់ជាច្រើន ដូចជា ក្នុងនាម ជាអនុលេខាបក្ស កុម្មុយនីស្តកម្ពុជា នៅគ្រប់ពេលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងនាមជា សមាជិកពេញសិទ្ធិនៃ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្ត កម្ពុជា។ ការចូលរួមចំណែកនេះគឺជាការរំលោភបំពានលើតួនាទីដែលមានអំណាច និងមានឥទ្ធិពល របស់គាត់[៣១៤៨] ដូច្នេះបង្កើតបានជាស្ថានទម្ងន់ទោស។

១០៨៥. បើទោះបីជា នួន ជា បានខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទីរបស់គាត់ក៏ដោយ ក៏សហ-ព្រះរាជអាជ្ញាបានខកខានក្នុងការបង្ហាញថា នួន ជា មានការពេញចិត្តចំពោះសកម្មភាពឧក្រិដ្ឋរបស់ គាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាអំពីការពេញចិត្តថាជាស្ថានទម្ងន់ទោស ទេ។

១០៨៦. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា ក៏ជាបុគ្គលម្នាក់ដែលមានចំណេះដឹង ខ្ពង់ខ្ពស់ ដែលធ្វើឲ្យគាត់យល់ដឹងច្បាស់លាស់អំពីបច្ច័យទាំងឡាយដែលកើតចេញពីសកម្មភាព របស់គាត់[៣១៤៩]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គហេតុទាំងនេះបង្កើតបានជាស្ថាន ទម្ងន់ទោស។

### ១៨.៣.២.៣ ការពិចារណាចំពោះ ខៀវ សំផន

១០៨៧. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត)

---

[3148] សាលដីកាលើរឿងក្តី *Šainović និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៨០២។ សាលក្រមលើរឿងក្តី *Stanišić និង Župljanin* កថាខណ្ឌ ៩២៩ និង ៩៤៨។

[៣១៤៩] ផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៥។

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានទាំងការផ្លាស់ទីលំនៅដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។ ការចូលរួមចំណែករបស់ ខៀវ សំផន នៅក្នុងឧក្រិដ្ឋកម្ម រួមមាន តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើឡើងតាមរយៈតួនាទីជាផ្លូវការរបស់គាត់ជាច្រើន រួមមាន ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមាជិកមន្ទីរ-៨៧០ ប្រធានគណៈប្រធានរដ្ឋ និងជាកម្មាភិបាលជាន់ខ្ពស់បំផុតនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ទាំងអស់នេះ គឺជាការរំលោភបំពានលើតួនាទីដែលមានអំណាច និងមានឥទ្ធិពលរបស់គាត់[៣១៥០] ដូច្នេះបង្កើតបានជាស្ថានទម្ងន់ទោស។

១០៨៨. ឆន្ទៈ ក្នុងន័យនៃការស្ម័គ្រចិត្ត គឺជាធាតុផ្សំចាំបាច់នៃបទឧក្រិដ្ឋ ដូច្នេះ វាមិនមែនជាស្ថានទម្ងន់ទោសនោះទេ[៣១៥១]។ បើទោះបីជាភ័ស្តុតាងបានបង្ហាញថា ខៀវ សំផន បានបំពេញតួនាទីរបស់គាត់ដោយស្ម័គ្រចិត្ត និងដោយមានសម្បជញ្ញៈក៏ដោយ ក៏សហព្រះរាជអាជ្ញាបានខកខានក្នុងការបង្ហាញថា ខៀវ សំផន មានការពេញចិត្តចំពោះសកម្មភាពឧក្រិដ្ឋរបស់គាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាអំពីការពេញចិត្តថាជាស្ថានទម្ងន់ទោសទេ។

១០៨៩. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន គឺជាបុគ្គលម្នាក់ដែលមានចំណេះដឹងខ្ពង់ខ្ពស់[៣១៥២]។ គាត់បានបញ្ចប់ការសិក្សាថ្នាក់កម្រិតក្រោយឧត្តមសិក្សាទាំងផ្នែកច្បាប់ និងផ្នែកសេដ្ឋកិច្ចដោយជោគជ័យ ហេតុដូច្នេះ គាត់យល់ដឹងច្បាស់លាស់អំពីបច្ច័យទាំងឡាយដែលកើតចេញពីសកម្មភាពរបស់គាត់។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គហេតុទាំងនេះបង្កើតបានជាស្ថានទម្ងន់ទោស។

### ១៨.៣.៣ ស្ថានសម្រាលទោស

#### ១៨.៣.៣.១ ការពិចារណាជាទូទៅចំពោះជនជាប់ចោទទាំងពីរ

១០៩០. សហព្រះរាជអាជ្ញាអះអាងថា មិនមាន "ស្ថានសម្រាលទោសដែលពាក់ព័ន្ធ" ដើម្បីកាត់បន្ថយទោសជនជាប់ចោទណាម្នាក់នៅក្នុងរឿងក្តីនេះទេ ដោយសារតែមិនមានភ័ស្តុតាងបង្ហាញអំពី

---

3150 សាលដីកាលើរឿងក្តី *Šainović និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៨០២។ សាលក្រមលើរឿងក្តី *Stanišić និង Župljanin* កថាខណ្ឌ ៩២៩ និង ៩៤៨។

៣១៥១ សាលក្រមលើរឿងក្តី *Popović និងអ្នកដទៃទៀត*។ សាលក្រម កថាខណ្ឌ២១៥៤។

៣១៥២ សូមមើលផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥១-៣៥៥។

ការចុះខ្សោយផ្នែកបញ្ញាស្មារតី ឬ មានការបង្ខិតបង្ខំឡើយ ហើយជនជាប់ចោទមិនបានបង្ហាញអំពីវិប្បដិសារីចំពោះឧក្រិដ្ឋកម្មនានាដែលពួកគាត់បានប្រព្រឹត្ត ឬ ក៏សហការជាមួយនឹង អ.វ.ត.ក ឡើយ[៣១៥៣]។ ទោះបីជាជនជាប់ចោទមិនបានលើកឡើងដោយផ្ទាល់ទាក់ទងនឹងស្ថានសម្រាលទោសក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការពិចារណាអំពីកត្តាផ្សេងៗ ដែលអង្គជំនុំជម្រះយល់ឃើញថាមានលក្ខណៈជាស្ថានសម្រាលទោសដែរ[៣១៥៤]។

១០៩១. អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា មិនមានភ័ស្តុតាងបង្ហាញអំពីការចុះខ្សោយផ្នែកបញ្ញាស្មារតី ឬ មានការបង្ខិតបង្ខំឡើយ។

### ១៨.៣.៣.២ ការពិចារណាចំពោះ នួន ជា

១០៩២. នៅក្នុងអំឡុងសវនាការ នួន ជា បានសម្តែងនូវការសោកស្តាយរបស់គាត់ថា ការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ "មិនបានដិតដល់"[៣១៥៥] ប៉ុន្តែបានអះអាងថា គាត់មិនមានអំណាចអ្វីទេ ទាក់ទិននឹងអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាលនាពេលនោះ[៣១៥៦]។ នួន ជា បានបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យមាន "បំណងល្អ" ចំពោះជាតិ ហើយ "ម្នាក់ៗ" "លះបង់តស៊ូដើម្បីជាតិ"[៣១៥៧]។ គាត់បានចាត់ទុកអ្នកទាំងឡាយដែលបានលះបង់ជីវិតក្នុងអំឡុងពេលនោះថាជា "អ្នកដែលបាត់បង់ទៅ"[៣១៥៨]។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល នួន ជា បានលើកឡើងថា "បើទោះបីជាសោកនាដកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាលទ្ធផលដែលបង្កឡើងដោយពួកជនក្បត់ចលនាក៏ដោយ ក៏ក្នុងនាមខ្ញុំជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ដែលមានភារកិច្ចឃោសនា អប់រំ អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមទោសជាសាធារណៈ

---

[៣១៥៣] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១ ឯកសារ E295/6/1 ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៤០-៧៤៣។

[៣១៥៤] សាលក្រមលើរឿងក្តី *Simić និងអ្នកផ្សេងទៀត កថាខណ្ឌ ១០៦៦។ សាលក្រមលើរឿងក្តី **Krstić** កថាខណ្ឌ ៧១៣។ សាលដីកាលើរឿងក្តី **Taylor** កថាខណ្ឌ ៦៧៥។*

[៣១៥៥] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (នួន ជា) ទំព័រ ១៨-២០។

[៣១៥៦] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (នួន ជា) ទំព័រ ១៤-១៧។

[៣១៥៧] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (នួន ជា) ទំព័រ ៤១-៤២។

[៣១៥៨] ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (នួន ជា) ទំព័រ ៤១-៤២។

ចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូល”[៣១៥៩]។ នួន ជា បានថ្លែងបន្ថែមទៀតថា គាត់ទទួលខុសត្រូវផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានដិតដល់របស់បក្សកុម្មុយនីស្តកម្ពុជា[៣១៦០]។

១០៩៣.ដើម្បីទទួលបានស្ថានសម្រាលទោស ការបង្ហាញពីវិប្បដិសារី ត្រូវតែមានលក្ខណៈស្មោះត្រង់ និងពិតប្រាកដ[៣១៦១]។ ជនជាប់ចោទ អាចសំដែងនូវការសោកស្តាយដោយស្មោះត្រង់ ដោយមិនបានសារភាពអំពីការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មក៏ដោយ ក៏ការសំដែងនូវវិប្បដិសារីនេះតម្រូវឲ្យមានការទទួលយកនូវការទទួលខុសត្រូវខាងផ្នែកសីលធម៌ចំពោះកំហុសរបស់ខ្លួន[៣១៦២]។ អង្គជំនុំជម្រះយល់ឃើញថា ការសុំអភ័យទោសរបស់ នួន ជា មិនមានតម្លៃជាស្ថានសម្រាលទោសទេ ដោយសារតែគាត់មិនទទួលយកនូវការទទួលខុសត្រូវចំពោះកំហុសផ្ទាល់របស់គាត់។ ផ្ទុយទៅវិញ គាត់បានសូមទោសចំពោះអំពើរបស់ “ពួកជនក្បត់” និងបានកំណត់ការទទួលខុសត្រូវផ្ទាល់ខ្លួនគាត់ត្រឹមការខកខានមិនបានគ្រប់គ្រងឲ្យបានដិតដល់របស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើអ្នកទាំងឡាយដែលត្រូវបានសន្មតថាជាជនក្បត់ និងមិនត្រូវបានកំណត់អត្តសញ្ញាណ។

១០៩៤. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើបរិមាណ និងគុណភាពនៃព័ត៌មាន ដែល នួន ជា បានផ្តល់ឲ្យ អ.វ.ត.ក។ នួន ជា បានធ្វើការបញ្ជាក់ជាច្រើនដងទាក់ទងនឹងតួនាទី និងមុខងាររបស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពីដំបូង គាត់បានសហការជាមួយ អង្គជំនុំជម្រះដោយបានឆ្លើយសំណួរពាក់ព័ន្ធនឹងសាវតាររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនៅក្នុងអំឡុងពេលនោះគាត់បានបញ្ជាក់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងយូរមកហើយជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា តួនាទីរបស់គាត់ជាអនុលេខាបក្ស និងសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ រួមទាំងការតែងតាំងគាត់ជាប្រធានសភាតំណាងប្រជាជន[៣១៦៣]។

---

[៣១៥៩] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ជនជាប់ចោទ នួន ជា) ទំព័រ ២៥-២៧។

[៣១៦០] ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ជនជាប់ចោទ នួន ជា) ទំព័រ ២៤-២៦។ សូមមើល *ផងដែរ* ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (នួន ជា) ទំព័រ ៦៧-៧២។

[៣១៦១] សាលដីកាលើរឿងក្តី *Blaškić កថាខណ្ឌ ៧០៥*។

[៣១៦២] សាលដីកាលើរឿងក្តី *Strugar កថាខណ្ឌ ៣៦៦*។

[៣១៦៣] សូមមើលផ្នែកទី ៧៖ តួនាទី និងមុខងាររបស់ នួន ជា កថាខណ្ឌ ៣០៥-៣១១, ៣១៣-៣១៤, ៣១៩-៣២០, ៣៤៧-៣៤៨។

ទោះបីជាយ៉ាងណាក៏ដោយ ការសហការរបស់គាត់មានរយៈពេលខ្លី និងដោយពិចារណាទៅលើការសហការដ៏តិចតួចនេះ អង្គជំនុំជម្រះផ្តល់តម្លៃតិចតួចបំផុតដល់ការសហការនេះ ជាស្ថានសម្រាលទោស។

១០៩៥. អង្គជំនុំជម្រះទទួលស្គាល់ថា វ័យចាស់អាចត្រូវបានពិចារណាថាជាស្ថានសម្រាលទោស[៣១៦៤] ហើយផ្តល់ឱ្យនូវស្ថានសម្រាលតិចតួចបំផុតចំពោះវ័យចាស់នេះ។ ដោយកត់សម្គាល់ថាបញ្ហាសុខភាពអាចត្រូវបានពិចារណាថាជាស្ថានសម្រាល តែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[៣១៦៥] និង ដោយពិចារណាទៅលើការវាយតម្លៃអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទដោយអង្គជំនុំជម្រះសាលាដំបូងនោះ[៣១៦៦] អង្គជំនុំជម្រះមិនពិចារណាអំពីបញ្ហាសុខភាពថាជាស្ថានសម្រាលទោសនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះទេ។

### ១៨.៣.៣.៣ ការពិចារណាចំពោះ ខៀវ សំផន

១០៩៦. នៅក្នុងអំឡុងពេលសវនាការ និងក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ខៀវ សំផន បានបដិសេធថា គាត់មិនបានដឹង និងមិនទទួលខុសត្រូវចំពោះព្រឹត្តិការណ៍នានាដែល "អាចកើតមាន" បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនោះទេ ហើយគាត់បានបញ្ជាក់ថា ទោះក្នុងករណីណាក៏ដោយ គាត់មិនមានអំណាចក្នុងការធ្វើអន្តរាគមន៍ទេ[៣១៦៧]។ ខៀវ សំផន បានសូមទោសចំពោះការមិនបានដឹងអំពីការរងទុក្ខវេទនាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[៣១៦៨]។ អង្គជំនុំ-

[៣១៦៤] សាលដីកាលើរឿងក្តី *Đorđević* កថាខណ្ឌ ៩៣៤, ៩៨០។

[៣១៦៥] សាលក្រមប្រកាសទោស លើរឿងក្តី *Simić កថាខណ្ឌ ៩៧-៩៨។ សាលក្រមលើរឿងក្តី Kordić និង Čerkez កថាខណ្ឌ ៨៤៨។*

[៣១៦៦] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

[៣១៦៧] ប្រតិចារឹក ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៣ (ខៀវ សំផន) ទំព័រ ១៣-១៥។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៨-៧១។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ខៀវ សំផន) ទំព័រ ១៤-១៩។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (ខៀវ សំផន) ទំព័រ ១៤-១៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ៦៦-៧០។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (ខៀវ សំផន) ទំព័រ ១៩-២១។ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីថ្លែងចុងក្រោយរបស់ជនជាប់ចោទ ខៀវ សំផន) ទំព័រ ៥៣-៥៤, ៥៥។ ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៨៨។

[៣១៦៨] ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (ខៀវ សំផន) ទំព័រ ១៤-១៦។

ជម្រះយល់ឃើញថា ខៀវ សំផន បានបដិសេធក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើង ហើយគាត់ក៏មិនបានសម្តែងនូវវិប្បដិសារីចំពោះឧក្រិដ្ឋកម្មទាំងនោះឡើយ។ ហេតុដូច្នេះ វិប្បដិសារី មិនអាចត្រូវបានចាត់ទុកថាជាស្ថានសម្រាលទោសឡើយ។

១០៩៧. ការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការចូលរួមរបស់ ខៀវ សំផន នៅក្នុងសវនាការ បង្ហាញឱ្យឃើញពីការសហការតិចតួចជាមួយនឹង អ.វ.ត.ក។ ក្នុងអំឡុងពេលសវនាការ ខៀវ សំផន បានឆ្លើយសំណួរទាក់ទងនឹងអត្តសញ្ញាណ សាវតារផ្ទាល់ខ្លួនរបស់គាត់ និងឯកសារមួយចំនួននៅក្នុងសំណុំរឿង។ គាត់ក៏បានឆ្លើយទៅនឹងសំណួរមួយចំនួន ដែលដើមបណ្តឹងរដ្ឋប្បវេណីបានចោទសួរគាត់ផងដែរ[៣១៦៩] ដែលការឆ្លើយសំណួរនេះ អាចមានឥទ្ធិពលខ្លះនៅក្នុងការជួយសម្រួលដល់ការផ្សះផ្សា។ ដោយពិចារណាទៅលើការសហការដ៏តិចតួចនេះ អង្គជំនុំជម្រះផ្តល់តម្លៃតិចតួចបំផុតដល់ការសហការនេះ ជាស្ថានសម្រាលទោស។

១០៩៨. អង្គជំនុំជម្រះទទួលស្គាល់ថា វ័យចាស់អាចត្រូវបានពិចារណាថាជាស្ថានសម្រាលទោស[៣១៧០] និងផ្តល់ឱ្យនូវស្ថានសម្រាលតិចតួចបំផុតចំពោះវ័យចាស់នេះ។ ដោយកត់សម្គាល់ថា បញ្ហាសុខភាពអាចត្រូវបានពិចារណាថាជាស្ថានសម្រាលទោស តែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[៣១៧១] និងដោយពិចារណាទៅលើការវាយតម្លៃអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ ដោយអង្គជំនុំជម្រះសាលាដំបូង[៣១៧២] អង្គជំនុំជម្រះបដិសេធមិនពិចារណាអំពីបញ្ហាសុខភាពថាជាស្ថានសម្រាលទោសនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះទេ។

### ១៨.៣.៤ សាក្សីអំពីអត្តចរិតរបស់ជនជាប់ចោទ

១០៩៩. សាក្សីចំនួន ៥ នាក់ បានផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ ខៀវ សំផន[៣១៧៣]។ សាក្សីបានអះអាងថា ខៀវ សំផន ធ្លាប់មាន និងនៅតែមានប្រជាប្រិយភាពនៅក្នុងប្រទេសកម្ពុជា[៣១៧៤] និងជា

---

[៣១៦៩] សូមមើលផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន កថាខណ្ឌ ៣៥០។

[៣១៧០] សាលដីកាលើរឿងក្តី ***Đorđević*** កថាខណ្ឌ ៩៧៤, ៩៨០។

[៣១៧១] សាលក្រមប្រកាសទោសក្នុងរឿងក្តី *Simić កថាខណ្ឌ ៩៧-៩៨។ សាលក្រមលើរឿងក្តី Kordić និង Čerkez កថាខណ្ឌ ៨៤៨។*

[៣១៧២] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

[៣១៧៣] រួមមាន Philippe JULLIAN-GAUFRES, ថៅ សុគន្ធ, ទន់ សឿន, សុខ រឿ និង សូ សុជាតិ។

មនុស្សដែលមានការគោរពស្រឡាញ់[៣១៧៥] ស្មោះត្រង់[៣១៧៦] និងជាមនុស្សដែលចង់បានយុត្តិធម៌សង្គម និងសុខុមាលភាពសម្រាប់ប្រជាជនកម្ពុជា[៣១៧៧]។ សាក្សីចំនួន ២ នាក់ បានផ្តល់សក្ខីកម្មថា ខៀវ សំផន បានប្រព្រឹត្តចំពោះប្រជាជនដោយស្មើភាព និងមិនរើសអើងឡើយ[៣១៧៨]។ សាក្សីជាច្រើនបានបញ្ជាក់ថា ខៀវ សំផន មិនមែនជាមនុស្សកាច ឬ ជាមនុស្សសាហាវនោះឡើយ[៣១៧៩]។

១១០០.Philippe JULLIAN-GAUFRES បានជួប ខៀវ សំផន ជាលើកដំបូងនៅឯសាកលវិទ្យាល័យមួយក្នុងប្រទេសបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ បន្ទាប់មកទៀត បានជួបគាត់ជាច្រើនលើកនៅចន្លោះឆ្នាំ ១៩៦១ និងឆ្នាំ ១៩៦៦ ក្នុងប្រទេសកម្ពុជា[៣១៨០] និងក្រោយមកទៀត បានជួបគាត់នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ និងទសវត្សរ៍ឆ្នាំ ២០០០ នៅក្នុងប្រទេសកម្ពុជា ប្រទេសចិន និង

---

[៣១៧៤] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៦២-៦៣។ ឧបសម្ព័ន្ធ ៤ ៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៨-១០។ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៦-៥៧, ៥៨-៥៩។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (ទន់ សឿន) ទំព័រ ១១-១២។

[៣១៧៥] ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៥។

[៣១៧៦] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៦២-៦៣។ ឧបសម្ព័ន្ធ ៤ ៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៨-១០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣ (ទន់ សឿន) ទំព័រ ១១-១២។ ប្រតិ-ចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣ (សូ សុជាតិ) ទំព័រ ៦៦-៦៧។

[៣១៧៧] ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៤, ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៦២-៦៣។

[៣១៧៨] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣ (ទន់ សឿន) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៦-៦៧។

[៣១៧៩] ឧបសម្ព័ន្ធ ៤ ៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣ (ទន់ សឿន) ទំព័រ ១៣-១៤។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនេះ គឺ ចៅ សុគន្ធ ដែលធ្លាប់បានជួប ខៀវ សំផន តែប្អូនដងប៉ុណ្ណោះ ៖ ប្រតិចារឹក ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៣ (ចៅ សុគន្ធ) ទំព័រ ៥៣-៥៤។

[៣១៨០] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៤៩-៥៦។ ឧបសម្ព័ន្ធ ៤ ៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៣-៦។

ប្រទេសបារាំង[៣១៨១]។ គាត់បានសន្ទនាជាច្រើនជាមួយនឹងជនជាប់ចោទរូបនេះ[៣១៨២] ដោយក្នុងពេលសន្ទនានោះ ខៀវ សំផន បានប្រាប់គាត់ថា គោលបំណងសំខាន់របស់ ខៀវ សំផន គឺដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាតាមរយៈការធ្វើបដិវត្តសេដ្ឋកិច្ច[៣១៨៣] ហើយថា គាត់ចង់ឲ្យប្រទេសកម្ពុជាអភិវឌ្ឍន៍បន្តិចម្តងៗ និងដោយគ្មានអំពើឃោរឃៅ[៣១៨៤]។ សុខ រឿ ដែលជាអង្គរក្សរបស់ ខៀវ សំផន ចាប់ពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៥[៣១៨៥] បានផ្តល់សក្ខីកម្មថា ខៀវ សំផន បានណែនាំអ្នកនៅក្រោមបង្គាប់របស់គាត់ ជាជាងបង្គាប់បញ្ជាពួកគេ និងមិនដែលមើលងាយប្រជាជនក្រីក្រ ឬ កសិករ ឡើយ ហើយគាត់មិនដែលឃើញនរណាម្នាក់មិនសប្បាយចិត្តជាមួយនឹង ខៀវ សំផន ឡើយ[៣១៨៦]។

១១០១.សាក្សីមួយចំនួនបានផ្តល់សក្ខីកម្មអំពីអត្តចរិត និងសកម្មភាពរបស់ ខៀវ សំផន នៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ Philippe JULLIAN-GAUFRES បានបញ្ជាក់ថា ខៀវ សំផន បានលះបង់ពេលវេលាជួយដល់និស្សិតខ្មែរដែលបានមកដល់ទីក្រុងប៉ារីសក្នុងទសវត្សរ៍ឆ្នាំ ១៩៥០[៣១៨៧] គាត់បានខិតខំការពារកសិករកម្ពុជាប្រឆាំងនឹងពាណិជ្ជករដែលបំពាននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០[៣១៨៨] ហើយគាត់បានក្រោកឈរឡើងប្រឆាំងនឹងអាជ្ញាធរយោធា ដែលបានបង្ខិតបង្ខំដោយខុសច្បាប់ ឲ្យប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់គាត់ធ្វើការងារនានាដោយគ្មានមូលហេតុសមស្រប[៣១៨៩]។ កូនប្រសារប្រុសរបស់ ខៀវ សំផន ឈ្មោះ ទន់ សឿន ដែលបានរស់នៅជាមួយ

---

[៣១៨១] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៥៧-៥៩។

[៣១៨២] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៥៤-៥៥។

[៣១៨៣] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៦០-៦១។

[៣១៨៤] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៦០ ឧបសម្ព័ន្ធ ៤ ៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៥-៦។

[៣១៨៥] ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿ) ទំព័រ ៦០-៦១។

[៣១៨៦] ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (សុខ រឿ) ទំព័រ ៦២-៦៣, ៦៦។

[៣១៨៧] ឧបសម្ព័ន្ធ ៤៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៦-៧។

[៣១៨៨] ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ (Philippe JULLIAN-GAUFRES) ទំព័រ ៥៤-៥៥។

[៣១៨៩] ឧបសម្ព័ន្ធ ៤៖ សក្ខីកម្មគាំទ្រលោក ខៀវ សំផន របស់លោក Philippe JULLIAN-GAUFRES ឯកសារ E190/2.5 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៦-៧។

ជនជាប់ចោទចាប់ពីឆ្នាំ ១៩៨៨ ឬឆ្នាំ ១៩៨៩ រហូតដល់ឆ្នាំ ១៩៩៤[៣១៩០] បានផ្តល់សក្ខីកម្មថា ខៀវ សំផន មានទំនាក់ទំនងល្អជាមួយអ្នកជិតខាង ហើយមនុស្សគ្រប់គ្នាស្រឡាញ់រាប់អានគាត់[៣១៩១]។

១១០២.ភរិយារបស់ ខៀវ សំផន គឺអ្នកស្រី សូ សុជាតិ បានផ្តល់សក្ខីកម្មអំពីអត្តចរិត និងអាកប្ប-កិរិយារបស់ស្វាមីរបស់គាត់ នៅមុនពេល ក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីបានពិពណ៌នាថា ខៀវ សំផន ជាបញ្ញាជន និងជាអ្នកចេះដឹង[៣១៩២] ដែលមានអត្តចរិតសុភាព រាបសា ចិត្តល្អ និងអត់ធ្មត់[៣១៩៣]។ អ្នកស្រីបានបញ្ជាក់ថា គាត់មិនមានអត្តចរិតជាមនុស្សឃោរឃៅ ឬជាឃាតករនោះទេ[៣១៩៤] ហើយគាត់មិនមែនជាមនុស្សដែលប្រព្រឹត្តអំពើថោកទាប ឬ លោភលន់ចង់បានបុណ្យស័ក្តិអ្វីដែរ[៣១៩៥] ផ្ទុយទៅវិញ គាត់គឺជា "មនុស្សមានគុណធម៌ និងសីលធម៌" មិនដែលធ្វើឱ្យ សូ សុជាតិ ពិបាកចិត្តទេ និងជាមនុស្សស្មោះត្រង់ណាស់[៣១៩៦]។

១១០៣. អង្គជំនុំជម្រះទទួលស្គាល់ថា ខៀវ សំផន អាចធ្វើអំពើល្អជាមួយនឹងភរិយារបស់គាត់ និងមានសណ្តានចិត្តល្អចំពោះប្រជាជននៅក្នុងករណីមួយចំនួន។ ទោះបីជាយ៉ាងណាក៏ដោយ កត្តាទាំងអស់នេះ មិនមែនជាផ្នែកសំខាន់ដែលអាចសម្រាលទោសឧក្រិដ្ឋកម្ម ចំពោះភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនានាដែល ខៀវ សំផន ត្រូវបានរកឃើញថាមានពិរុទ្ធនោះ ហើយនឹងមិនត្រូវបានផ្តល់តម្លៃឱ្យផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់តម្លៃតិចតួចជាស្ថានសម្រាលទោសចំពោះអំណះអំណាងពីអត្តចរិតល្អនេះនៅពេលសម្រេចអំពីទោស។

១១០៤.មិនមានសាក្សីពីអត្តចរិតណាម្នាក់ពាក់ព័ន្ធនឹង នួន ជា ត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្មទេ[៣១៩៧]។

---

[៣១៩០] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (ទន់ សឿន) ទំព័រ ១២-១៣។

[៣១៩១] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (ទន់ សឿន) ទំព័រ ១២-១៤។

[៣១៩២] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៤៧-៤៩។

[៣១៩៣] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៤៧-៤៩, ៥១-៥៣, ៦៧។

[៣១៩៤] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៧-៦៨។

[៣១៩៥] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៧-៦៨។

[៣១៩៦] ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ (សូ សុជាតិ) ទំព័រ ៦៧-៦៨។

[៣១៩៧] សេចក្តីសម្រេចស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១០៦-១១១។

## ១៨.៣.៥ ការផ្តន្ទាទោស

### ១៨.៣.៥.១ ទោសជាប់ពន្ធនាគារ

១១០៥. នៅក្នុងការសម្រេចអំពីការផ្តន្ទាទោសឲ្យបានសមស្របចំពោះ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើកាលៈទេសៈទាំងអស់នៃរឿងក្តីនេះ រួមទាំងគោលការណ៍នៃការផ្តន្ទាទោសដែលពាក់ព័ន្ធ និងកត្តាទាំងអស់ដែលបានលើកឡើងខាងលើនេះ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា នៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដោយមតិភាគច្រើនលើសលុបថា អង្គជំនុំជំម្រះសាលាដំបូង នៅក្នុងរឿងក្តីនោះ "បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារដោយមានកំណត់រយៈពេលនោះថាមិនបានឆ្លុះបញ្ចាំងទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត[៣១៩៨]" ហើយក៏បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ធ្ងន់ធ្ងរជាង ខៀវ សំផន ក្តី ក៏ការសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារអស់មួយជីវិតសម្រាប់ជនជាប់ចោទម្នាក់ៗ គឺមានលក្ខណៈសមស្រប។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា មានកត្តានានាជាច្រើនបង្ហាញឲ្យឃើញថា ជនជាប់ចោទទាំងពីរនាក់នេះមានពិរុទ្ធធ្ងន់ធ្ងរជាងពិរុទ្ធរបស់ កាំង ហ្គេកអ៊ាវ ក្នុងសំណុំរឿង ០០១ ច្រើនណាស់ ដូចជា ចំនួនជនរងគ្រោះដ៏ច្រើនលើសលុប និង ចំនួនឧក្រិដ្ឋកម្ម និង ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទម្នាក់ៗត្រូវបានរកឃើញថាមានពិរុទ្ធនោះ។ យុត្តិសាស្ត្រដែលចេញដោយអង្គជំនុំជម្រះតុលាការកំពូល មិនបានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងជនជាប់ចោទ និង កាំង ហ្គេកអ៊ាវ ឬ ធ្វើការបែងចែកក្នុងការផ្តន្ទាទោសរវាងជនជាប់ចោទទាំងពីរនេះបានទេ។ តាមសំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតសម្រាប់ជនជាប់ចោទម្នាក់ៗ គឺជាការផ្តន្ទាទោសសមស្របបំផុត ។

១១០៦. តាមមូលដ្ឋាននៃសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស **នួន ជា** ដាក់ពន្ធនាគារ **អស់មួយជីវិត**។

[៣១៩៨] កាំង ហ្គេកអ៊ាវ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣៧៣។

១១០៧. តាមមូលដ្ឋាននៃសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស **ខៀវ សំផន** ដាក់ពន្ធនាគារ **អស់មួយជីវិត**។

### ១៨.៣.៥.២ ការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាប់ចោទ

១១០៨.អង្គជំនុំជម្រះបានទទួលស្គាល់ថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មិនមានទ្រព្យសម្បត្តិ ប្រាក់កាស ឬអចលនទ្រព្យផ្ទាល់ខ្លួនដែលទទួលបានដោយខុសច្បាប់ ឬ ដោយការប្រព្រឹត្តអំពើឧក្រិដ្ឋឡើយ[៣១៩៩]។ ហេតុដូច្នេះ មិនមានទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូស ស្របតាមបទប្បញ្ញត្តិមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ។

## ១៩. សំណងរដ្ឋប្បវេណី

### ១៩.១ សេចក្តីផ្តើម

១១០៩.វិធាន ២៣(១) នៃវិធានផ្ទៃក្នុងចែងថា "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖

ក. ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង

ខ. ទាមទារសំណងផ្លូវចិត្ត និងសមូហភាព [...]"។

ដោយពិចារណាទៅលើការលំបាកដែលធ្លាប់កើតមានកន្លងមកក្នុងសំណុំរឿង០០១ និងតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងការជំនុំជម្រះ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ត្រូវបានធ្វើវិសោធនកម្មនៅមុនដំណាក់កាលជំនុំជម្រះសំណុំរឿង ០០២[៣២០០]។ វិសោធនកម្មបានជួយបង្កើនប្រសិទ្ធភាព និងសម្រួលដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះ។

---

[៣១៩៩] ឯកសារ A151 សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តីអំពីភាពក្រីក្ររបស់លោក ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨។ ឯកសារ A49 សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តីអំពីភាពក្រីក្ររបស់លោក នួន ជា ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧។

[៣២០០] សូមមើល វិធាន ២៣, ២៣ស្ទួន, ២៣ស្ទួនពីរ, ២៣ស្ទួនបី និង ២៣ស្ទួនបួន នៃវិធានផ្ទៃក្នុង។

វិសោធនកម្ម ត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវផ្សេងៗនៃការជំនុំជម្រះឧក្រិដ្ឋ-កម្មដែលមានទ្រង់ទ្រាយធំ និងដើម្បីធានាឲ្យកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក បំពេញទៅតាមសេចក្តីត្រូវការរបស់ជនរងគ្រោះឲ្យបានពេញលេញជាងមុន។

១១១០. ជាដំបូង ការធ្វើវិសោធនកម្មសំខាន់ៗត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងរបៀបនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងការជំនុំជម្រះ។ បច្ចុប្បន្ន ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមជាលក្ខណៈបុគ្គលតែនៅក្នុងដំណាក់កាលមុនជំនុំជម្រះតែប៉ុណ្ណោះ។ ប៉ុន្តែ នៅក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលក្រោយៗមកទៀត ពួកគាត់ត្រូវរួមបញ្ចូលជាក្រុមតែមួយ ដែលផលប្រយោជន៍របស់ពួកគាត់ត្រូវបានតំណាងដោយសហមេធាវីនាំមុខជាតិ និងអន្តរជាតិ និងគាំទ្រដោយមេធាវីតំណាងដើម-បណ្តឹងរដ្ឋប្បវេណី[៣២០១]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចទាំងសារធាតុ និងភាពអាចទទួលយកបាននៃការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្រោយការកែប្រែលើវិធាន ភាពអាចទទួលយកបាននេះត្រូវសម្រេចជាចុងក្រោយនៅដំណាក់កាលមុនអង្គសេចក្តីតែប៉ុណ្ណោះ[៣២០២]។ ក្នុងពេលនេះ អង្គជំនុំជម្រះសម្រេចលើតែសារធាតុនៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាក្រុមរួមតែមួយតែប៉ុណ្ណោះ[៣២០៣]។

១១១១. សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១២៣ ត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២[៣២០៤]។ បន្ទាប់ពីមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ភ្លាមៗចុងក្រោយជាច្រើនរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី ២៤ ខែ មិថុនា និង ថ្ងៃទី

[៣២០១] *សូមមើល ឧទាហរណ៍* វិធាន ១២*ស្ទួនពីរ*, ២៣(៣), ២៣*ស្ទួន* និង ២៣*ស្ទួនពីរ និង* ២៣*ស្ទួនបួន* នៃវិធានផ្ទៃក្នុង។

[៣២០២] *សូមមើល* វិធានផ្ទៃក្នុង អ.វ.ត.ក (ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧) វិធាន ១០០ វិធាន ៧៧*ស្ទួន* វិធាន ១០០ នៃវិធានផ្ទៃក្នុង (វិ.លើកទី ៨)។ សាលក្រម *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៦៣៩។

[៣២០៣] វិធាន ១០០ នៃវិធានផ្ទៃក្នុងចែងថា “អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម” ។ វិធាន ២៣ *ស្ទួនបួន* នៃវិធានផ្ទៃក្នុង ដែលមានចំណងជើងថា “បណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី” ចែងជាក់លាក់អំពីមូលដ្ឋានដែលអង្គជំនុំជម្រះអាចយកមកសំអាងនៅពេលសម្រេចបង្គាប់សំណង។

[៣២០៤] ដើម្បីអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជាដើមបណ្តឹងរដ្ឋប្បវេណីបានបុគ្គលដែលអះអាងថាជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម រួមទាំងបទចោទប្រឆាំងនឹងជនជាប់ចោទ ត្រូវដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលជាអ្នកសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំរបស់ពួកគាត់។ សេចក្តីសម្រេចទាំងនេះ អាចអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ភ្លាមៗទៅកាន់អង្គបុរេជំនុំជម្រះបាន។ *សូមមើល* វិធាន ២៣(៣) និង វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។

០១ ខែ កក្កដា ឆ្នាំ ២០១១ ដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន ៣.៨៦៩ ត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះ និងត្រូវរួមបញ្ចូលក្នុងក្រុមដើមបណ្ដឹងរដ្ឋប្បវេណីតែមួយក្នុងពេលជំនុំជម្រះ[៣២០៥]។

១១១២. វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មបន្ថែម ដើម្បីពង្រីកវិសាលភាពនៃសំណងដែលមាននៅចំពោះមុខ អ.វ.ត.ក។ សោហ៊ុយនៃសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី អាចនៅតែជាបន្ទុករបស់ពិរុទ្ធជនដដែល[៣២០៦] ប៉ុន្តែត្រូវតែបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបាន និងការទាមទារដ៏តឹងរ៉ឹង ដែលជារឿយៗមានលក្ខណៈលំបាកនឹងបំពេញចិត្តដើមបណ្ដឹងរដ្ឋប្បវេណីណាស់[៣២០៧]។ ដូចឃើញជាភស្តុតាងស្រាប់នៅក្នុងសំណុំរឿង ០០១ នៅពេលពិរុទ្ធជនជាអ្នកទីទ័លក្រ

---

[៣២០៥] សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ។ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D250/3/2/1/8) ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១។ សាលដីកាសម្រេចអំពីការពិចារណាសា-ជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D364/1/6)។ *សូមមើលផងដែរ* មតិយោបល់ជំទាស់ដាច់ដោយឡែក និងដោយផ្នែករបស់លោកស្រីចៅក្រម Catherine MARCHI-UHEL សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ យោបល់ជំទាស់ដាច់ដោយឡែក និងដោយផ្នែករបស់លោកស្រីចៅក្រម Catherine MARCHI-UHEL សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ។ យោបល់ជំទាស់របស់លោកស្រីចៅក្រម Marchi-UHEL សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D250/3/2/1/8) ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ។ យោបល់ជំទាស់របស់លោកស្រីចៅក្រម Marchi-UHEL សាលដីកាសម្រេចអំពីការពិចារណាសាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D364/1/6) ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ។

[៣២០៦] *សូមមើល* ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន(៣)* នៃវិធានផ្ទៃក្នុង (អ.ជ.ស.ដ) (ឯកសារ E125) ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ។

[៣២០៧] សំណងដែលទាមទារក្នុងប្រភេទបែបនេះ អាចនឹងត្រូវផ្តល់ជូន ដោយជាបន្ទុកទាំងស្រុងរបស់ពិរុទ្ធជន។ ដើម្បីឲ្យមានប្រសិទ្ធភាព លក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់សំណង គឺការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីលក្ខណៈនៃសំណើ

គ្មានលទ្ធភាព ការផ្តល់សំណងនៅក្រោមទម្រង់ចាស់ដូចដែលធ្លាប់បានអនុវត្តកន្លងមកនោះ មិនអាចផ្តល់សំណងជាក់ស្តែងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីបាននោះទេ[៣២០៨]។

១១១៣. វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្ម ដើម្បីដោះស្រាយបញ្ហាទាំងនេះដោយបង្កើតនូវមធ្យោបាយផ្តល់សំណងបន្ថែមមួយចំនួន លើមធ្យោបាយផ្តល់សំណងរដ្ឋប្បវេណីដែលមានស្រាប់[៣២០៩]។ ជម្រើសបន្ថែមនេះ អនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា វិធានការសំណងជាក់លាក់ដែលបង្កើតឡើង ឬកំណត់ឡើងដោយមានការសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ មានលក្ខណៈសមស្របដើម្បីអាចអនុវត្តបានដោយប្រើប្រាស់មូលនិធិពីខាងក្រៅ។ ក្នុងអំឡុងពេលនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២ មធ្យោបាយនេះបានផ្តល់លទ្ធភាពឲ្យអង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្វែងរកមូលនិធិសម្រាប់ផ្តល់សំណងពីការបរិច្ចាគរបស់ម្ចាស់ជំនួយ និងបង្កើតគម្រោងទាំងនេះ ដោយមានកិច្ចសហការជាមួយស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដែលនៅក្រៅ អ.វ.ត.ក។

## ១៩.២ ក្របខណ្ឌច្បាប់

១១១៤. វិធាន ២៣*ស្ទួនបួន* (១) ចែងថា នៅពេលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណង "ផ្លូវចិត្ត និងជាសមូហភាព" ទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និង ជាសមូហភាព គឺជាវិធានការទាំងឡាយដែល៖

---

ទាមទារភាពពាក់ព័ន្ធរបស់វាទៅនឹងព្យសនកម្មដែលពួកគេទទួលរងដោយសារតែជនជាប់ចោទ និងចំនួនកំណត់ ឬបរិមាណសំណងដែលត្រូវទាមទារពីជនជាប់ចោទ។ *សូមមើល* វិធាន ២៣*ស្ទួនបួន* នៃវិធានផ្ទៃក្នុង។

[៣២០៨] *សូមមើល ឧទាហរណ៍* សាលក្រមក្នុងរឿងក្តី *កាំង ហ្គេកអ៊ាវ* កថាខណ្ឌ ៦៦៦ (គូសបញ្ជាក់ថា សំណងទូទៅដែលដើមបណ្តឹងរដ្ឋប្បវេណីទាមទារពីជនជាប់ចោទ ត្រូវតែជាបន្ទុកទាំងស្រុងរបស់ជនជាប់ចោទ ហើយ អ.វ.ត.ក ពុំមានសមត្ថកិច្ចក្នុងការអនុវត្តសំណងទាំងនេះបាននោះទេ។ ប្រសិនបើចាំបាច់ សំណងទាំងនេះអាចអនុវត្តបានតែក្នុងរង្វង់ប្រព័ន្ធតុលាការជាតិទូទៅតែប៉ុណ្ណោះ) និងកថាខណ្ឌ ៦៦៧-៦៧៥ (បដិសេធការទាមទារសំណងភាគច្រើន ដោយចាត់ទុកថាស្ថិតនៅក្រៅវិសាលភាពនៃក្របខណ្ឌច្បាប់របស់ អ.វ.ត.ក)។

[៣២០៩] វិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង។

ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទ ដែលត្រូវបានផ្តន្ទាទោស និង

ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ[៣២១០]។

១១១៥.វិធាន ២៣*ក្វួនឃួន*(១) ចែងច្បាស់ថា ផលប្រយោជន៍ទាំងនេះមិនត្រូវមានទម្រង់សំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយពាក្យ "សំណងផ្លូវចិត្ត" ថាជាការជួសជុលព្យសនកម្មផ្លូវចិត្ត មិនមែនជួសជុលព្យសនកម្មខាងសម្ភារៈនោះទេ ហើយពាក្យថា "សំណងសមូហភាព" បញ្ជាក់ពីការមិនផ្តល់សំណងហិរញ្ញវត្ថុជាលក្ខណៈបុគ្គលផងដែរ[៣២១១]។

១១១៦.សំណងដែលមាននៅចំពោះមុខ អ.វ.ត.ក មានលក្ខណៈខុសគ្នាពីសំណងដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ និងលិខិតុបករណ៍ជាច្រើនទៀត ឬនៅចំពោះមុខតុលាការសិទ្ធិមនុស្សក្នុងតំបន់មួយចំនួន ដែលទទួលបានសិទ្ធិអំណាចក្នុងការសម្រេចលើបញ្ហាស្តីពីការទទួលខុសត្រូវរបស់រដ្ឋ និងមានអំណាចចេញសេចក្តីបង្គាប់ឲ្យរដ្ឋទូទាត់សំណងដល់ប្រជាពលរដ្ឋរបស់ខ្លួន ក្នុងករណីរកឃើញថា រដ្ឋនោះទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងកម្រោលទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ អង្គជំនុំជម្រះមិនមានយុត្តាធិការដើម្បីបង្គាប់ឲ្យរាជរដ្ឋាភិបាលកម្ពុជាឬអាជ្ញាធរជាតិ ឬស្ថាប័នអន្តរជាតិ អនុវត្ត ឬចេញប្រាក់សម្រាប់វិធានការសំណងផ្សេងៗបានទេ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះក៏មិនអាចដាក់កាតព្វកិច្ចលើបុគ្គល ឬស្ថាប័នដែលមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន បាននោះឡើយ[៣២១២]។ ទោះជាយ៉ាងនេះក្តី ការអនុម័តវិធាន ២៣*ក្វួនឃួន*(៣)(ខ) នៃវិធានផ្ទៃក្នុង បានផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះទទួលស្គាល់ថា គម្រោង

---

[៣២១០] វិធាន ២៣*ក្វួនឃួន*(១) នៃវិធានផ្ទៃក្នុង។ ដើមបណ្តឹងរដ្ឋប្បវេណីគឺជាជនរងគ្រោះដែលបានស្ម័គ្រចិត្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ ដោយសារពួកគេបានបញ្ចូលគ្នាជាក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមមួយនៅដំណាក់កាលជំនុំជម្រះ សំណងផ្លូវចិត្ត និងសមូហភាពដែលត្រូវបានទាមទារជំនួសឲ្យពួកគាត់មិនអាចដោះស្រាយព្យសនកម្មដែលទទួលរងដោយក្រុមដែលបានកំណត់មួយនេះនោះទេ ប៉ុន្តែវាអាចផ្តល់ផលប្រយោជន៍រួមផងដែរដល់ជនរងគ្រោះជាច្រើនផ្សេងទៀតដែល គ្មានអ្នកតំណាង ដែលអ្នកទាំងអស់នោះបានទទួលរងព្យសនកម្មដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់ចោទមានពិរុទ្ធ។

[៣២១១] សាលដីកាក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៦៥៨។

[៣២១២] សាលក្រមក្នុងរឿងក្តី *កាំង ហ្កេកអ៊ាវ* កថាខណ្ឌ ៦៦២-៦៦៣។

ជាក់លាក់មានលក្ខណៈសមស្រប ឆ្លើយតបទៅនឹងសំណាងដែលទាមទារជំនួសមុខឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលរួមជាក្រុម ដើម្បីរួមចំណែកក្នុងការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មសាជាថ្មី និងការស្តារសេចក្តីថ្លៃថ្នូរឡើងវិញ ប្រសិនបើអាជ្ញាធរជាតិ ឬអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយផ្សេងទៀត ផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ និងទម្រង់ជំនួយផ្សេងៗទៀត ដើម្បីបង្ហាញអំពីសាមគ្គីភាពជាមួយជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។

១១១៧. វិធាន ២៣*ស្ទួនបួន*(២) នៃវិធានផ្ទៃក្នុង ចែងអំពីលក្ខខណ្ឌតម្រូវនៃការទាមទារសំណាងរួមតែមួយថា៖

សំណាងត្រូវតែស្នើឡើងជាសេចក្តីសន្និដ្ឋានរួមតែមួយ ដែលសេចក្តីសន្និដ្ឋាននេះ អាចធ្វើការទាមទារសំណាងមួយចំនួនមានកំណត់។ សេចក្តីសន្និដ្ឋាននេះត្រូវផ្តល់នូវ៖

ក) ការពិពណ៌នាអំពីសំណាងដែលត្រូវទាមទារ។

ខ) ទឡ្ហីករណ៍សមហេតុផលដូចជា ការលើកឡើងពីការខូចខាតដែលពួកគេទទួលរង និងក្នុងករណីដែលអាចអនុវត្តបាន បញ្ជាក់អំពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមរួមដែលពួកគេជាប់ពាក់ព័ន្ធ។

គ) ទម្រង់នៃការអនុវត្តជាក់លាក់តែមួយលើសំណាងនីមួយៗ ដែលមានចែងក្នុងវិធាន ២៣*ស្ទួនបួន* (៣)(ក) និង(ខ) ដែលទាមទារ។

១១១៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានកាតព្វកិច្ចក្នុងការចង្អុលបង្ហាញអំពីបែបបទជាក់លាក់នៃការអនុវត្តសំណាងពាក់ព័ន្ធនឹងសំណាងនីមួយៗដែលខ្លួនទាមទារ និងដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវខុសៗគ្នានៃជម្រើសដែលមាននៅក្នុងវិធាន ២៣*ស្ទួនបួន* (៣)(ក) និង(ខ) នៃវិធានផ្ទៃក្នុង[៣២១៣]។ ចំណុចនេះក៏ឆ្លុះបញ្ចាំងផងដែរថា មធ្យោបាយនៃការផ្តល់សំណាងចំនួន

[៣២១៣] អនុលោមតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក រាល់សំណាងទាំងអស់ត្រូវតែ "ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និងផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងអំពីការខូចខាតនេះ" និងអាចផ្តល់ជូនបាននៅក្រោយពេលដែលជនជាប់ចោទមួយរូប ឬ ច្រើន ត្រូវបានរកឃើញថាមានពិរុទ្ធតែប៉ុណ្ណោះ (វិធាន ២៣ស្ទួនបួន(១) និង ១០០ នៃវិធានផ្ទៃក្នុង)។

ពីរដែលមាននៅចំពោះមុខ អ.វ.ត.ក មិនមែនគ្រាន់តែមានលក្ខណៈខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែមធ្យោបាយនីមួយៗមានលក្ខណៈមិនអាស្រ័យគ្នានោះទេ។ ហេតុដូចនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែជ្រើសរើសយកមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយទាំងពីរនេះ។

១១១៩. ដើម្បីបង្កើតជម្រើសផ្សេងៗពាក់ព័ន្ធនឹងមធ្យោបាយផ្តល់សំណងនៅចំពោះមុខ អ.វ.ត.ក វិធានផ្ទៃក្នុងចែងថា "នៅពេលសម្រេចអំពីបែបបទនៃការអនុវត្តសំណង ពាក់ព័ន្ធនឹងសំណងនីមួយៗ អង្គជំនុំជម្រះអាចៈ

ក) បង្គាប់ថា សោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន ឬ

ខ) ទទួលស្គាល់នូវគម្រោងជាក់លាក់ដែលមានលក្ខណៈសមស្រប ឆ្លើយតបទៅនឹងសំណងដែលទាមទារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយអាចអនុវត្តបាន។ គម្រោងបែបនេះនឹងត្រូវបានបង្កើតឡើង ឬបង្ហាញច្បាស់លាស់ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ ហើយបានធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ"[៣២១៤]។

១១២០. កាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការរៀបចំបណ្តឹងទាមទារសំណងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលរួមជាក្រុមតែមួយ គួរពិចារណាពីវិធាន ២៣*ស្ទួនបួន*(១)(ក) នៃវិធានផ្ទៃក្នុង។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ការបំបែកបទចោទនឹងមិនធ្វើឲ្យមានការជ្រើសរើសចំនួនដើមបណ្តឹងរដ្ឋប្បវេណីក្នុងកំរិតជាក់លាក់ពីបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមជាក្រុមតែមួយនោះ ដើម្បីទទួលផលប្រយោជន៍ពីសំណងណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រគល់ ឬអនុម័ត ដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ[៣២១៥]។ អង្គជំនុំជម្រះក៏បានផ្តល់ការណែនាំដល់សហមេធាវីនាំមុខឲ្យបង្កើនការប្រឹងប្រែងរៀបចំឲ្យមានគម្រោងសំណងនានា ដែលរួមបញ្ចូលនូវវិធានការ

---

[៣២១៤] វិធាន ២៣*ស្ទួនបួន*(៣) នៃវិធានផ្ទៃក្នុង (មានគូសបញ្ជាក់បន្ថែម)។

[៣២១៥] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ឯកសារ E284) ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៨ ។

នៃការអនុវត្តប្រកបដោយអត្ថន័យ និងរួមបញ្ចូលបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយទាំងមូលផងដែរ។ ជាពិសេស អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ការបំបែកកិច្ចដំណើរការនីតិវិធីមិនមានផលប៉ះពាល់អ្វីឡើយចំពោះមធ្យោបាយផ្តល់សំណងថ្មី និងដាច់ដោយឡែក ដែលត្រូវបានបង្កើតឡើងដោយវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលអនុលោមតាមវិធាននេះ គំនិតផ្តួចផ្តើមដែលត្រូវបានស្នើសុំជាវិធានការដែលអាចមាន មិននាំឲ្យមានសំណងដែលអាចអនុវត្តប្រឆាំងនឹងជនជាប់ចោទឡើយ ហើយអាចត្រូវបានបង្កើតដំណាលគ្នាជាមួយការជំនុំជម្រះបាន[៣២១៦]។

១១២១. ដោយសារ អ.វ.ត.ក មានរយៈពេលកំណត់ ក្នុងអំឡុងពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវអំណាចរបស់ខ្លួនដោយអនុលោមតាមវិធាន ៨០*ស្ទួន*(៤) នៃវិធានផ្ទៃក្នុង ក្នុងការស្នើឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ផ្តល់ការចង្អុលបង្ហាញដំបូងអំពីប្រភេទនៃវិធានការសំណងដែលបានរៀបចំឡើងដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង និងផ្តល់ព័ត៌មានអំពីបច្ចុប្បន្នភាពទាក់ទិននឹងស្ថានភាពហិរញ្ញវត្ថុសម្រាប់គម្រោងទាំងនេះ។ ការធ្វើដូច្នេះគឺដោយពិចារណាទៅលើភាពចាំបាច់ដើម្បីធានាថា រាល់វិធានការនានាដែលត្រូវបានស្នើសុំដោយផ្អែកលើមូលដ្ឋានដូចដែលបានលើកឡើងនេះ អាចអនុវត្តទៅបានប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្របមួយ ដោយមានជំនួយពីមូលនិធិម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ[៣២១៧]។ ដោយពិចារណាអំពីមូលនិធិរបស់ម្ចាស់ជំនួយនិងធនធានមនុស្សមានកំណត់ ទាំងនៅផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងនៅអង្គភាពគាំពារជនរងគ្រោះ អង្គជំនុំជម្រះស្នើដល់សហមេធាវីនាំមុខឲ្យ "កំណត់ និងរៀបចំសម្រាប់ការអនុវត្តសំណងជាអាទិភាពមួយចំនួនតូច ក្នុងចំណោមសំណងទាំងឡាយដែលស្ថិតក្រោមការពិចារណាទាមទារនាពេល

[៣២១៦] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ឯកសារ E284) ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៨។

[៣២១៧] វិធាន ៨០ស្ទួន(៤) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះសាលាដំបូង អាចណែនាំសហមេធាវីនាំមុខ ឲ្យផ្តល់ខ្លឹមសារជាក់លាក់ស្តីពីសំណងដែលខ្លួនមានបំណងស្នើសុំក្នុងបណ្ដឹងទាមទារចុងក្រោយ សម្រាប់សំណងផ្លូវចិត្ត និងជាសមូហភាព ក្នុងអំឡុងពេលមួយជាក់លាក់ដែលបានកំណត់ដោយអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)(ខ) នៃវិធានផ្ទៃក្នុង។ នៅដំណាក់កាលក្រោយៗមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់សហមេធាវីនាំមុខ ក្នុងការដាក់បណ្ដឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាព"។ *សូមមើលផងដែរ* ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង(អ.ជ.ស.ដ)(ឯកសារ E218/7)ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ។

បច្ចុប្បន្នឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន* (៣)(ខ)”[៣២១៨]។

១១២២. ជាការឆ្លើយតបទៅនឹងការបញ្ជាក់ជាបឋមរបស់សហមេធាវីនាំមុខ អំពីគម្រោងសំណង អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការបញ្ជាក់ថាតើអង្គជំនុំជម្រះយល់ឃើញថា គម្រោងសំណងទាំងនេះមានលក្ខណៈសមស្របឆ្លើយតបទៅនឹងសំណង ដែលទាមទារដោយសហមេធាវីនាំមុខដែរ ឬយ៉ាងណា ហើយថាតើគម្រោងសំណងទាំងនេះអាចអនុវត្តបានដែរឬទេ[៣២១៩]។ អង្គជំនុំជម្រះយល់ឃើញថា ជាគោលការណ៍ វិធានការដែលបានស្នើសុំដោយសហមេធាវីនាំមុខបានទទួលស្គាល់យ៉ាងត្រឹមត្រូវអំពីព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយ ដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ និងបានផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងនូវព្យសនកម្មនេះ ហើយអង្គជំនុំជម្រះនឹងគាំទ្រគម្រោងផ្តួចផ្តើមទាំងនេះ ប្រសិនបើខ្លួនទទួលបានព័ត៌មានបន្ថែមទាក់ទិននឹងគម្រោងមួយចំនួន ក្នុងចំណោមគម្រោងទាំងនេះមិនឲ្យលើសពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនអាចគាំទ្រតែចំពោះវិធានការសំណងណាមួយ ដែលអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) ដែលមានការធានាមូលនិធិពេញលេញ (ដែលជាមូលនិធិពេញលេញជាជាងមូលនិធិតែមួយផ្នែក) និងមានការបង្ហាញភ័ស្តុតាងពីការយល់ព្រម និងកិច្ចសហប្រតិបត្តិការរបស់តតីយជនណាមួយប៉ុណ្ណោះ[៣២២០]។

---

[៣២១៨] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការ សម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ (អ.ជ.ស.ដ) (ឯកសារ E218) ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១៩។

[៣២១៩] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីគម្រោងអាទិភាពសម្រាប់ការអនុវត្តសំណង អនុលោមតាមវិធាន ៨០ស្ទួន(៤) នៃវិធានផ្ទៃក្នុង (E218/7/1) ឯកសារ E218/7/2 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

[៣២២០] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹង-រដ្ឋប្បវេណីអំពីគម្រោងអាទិភាពសម្រាប់ការអនុវត្តសំណងអនុលោមតាមវិធាន ៨០ស្ទួន(៤) នៃវិធានផ្ទៃក្នុង (E218/7/1) ឯកសារ E218/7/2 ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៦។ *សូមមើលផងដែរ* សេចក្តីសម្រេចជាបន្តបន្ទាប់ និង ចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពជាក់លាក់ដែលបានធ្វើបច្ចុប្បន្នភាពនៃគម្រោងសំណងជាអាទិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨១ស្ទួន(៤) (E218/7/3) ឯកសារ E218/7/4

## ១៩.៣ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី

១១២៣. ក្រោយពីមានសំណើរបស់អង្គជំនុំជម្រះឲ្យសហមេធាវីនាំមុខ ផ្តល់ព័ត៌មានជាក់លាក់បន្ថែមអំពីសំណងដែលពួកគេចង់ទាមទារនោះ ក្នុងអំឡុងពេលជំនុំជម្រះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ព័ត៌មានជាបន្តបន្ទាប់ស្តីពីស្ថានភាពថ្មីៗ និង បានគូសបញ្ជាក់លម្អិតអំពីគម្រោងទាមទារសំណងជាក់លាក់ជាច្រើននៅក្នុងសំណុំរឿង ០០២/០១[៣២២១]។ នៅក្នុងសំណើសុំទាមទារសំណងចុងក្រោយរបស់ខ្លួន សហមេធាវីនាំមុខបានទទួលស្គាល់យ៉ាងច្បាស់ថា ទម្រង់នៃការអនុវត្តសំណងចំនួនពីរដែលមានចែងនៅក្នុងវិធាន ២៣*ស្ទួនបួន*(៣)(ក)និង(ខ) មិនត្រឹមតែជាទម្រង់ពីរខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែទម្រង់ទាំងពីរនេះមិនអាស្រ័យគ្នាថែមទៀតផង។ ហេតុដូច្នេះការផ្តល់សំណងមិនអាចធ្វើឡើងតាមមធ្យោបាយទាំងពីរនេះ នៅក្នុងពេលតែមួយបាននោះទេ[៣២២២]។ ប៉ុន្តែ សហមេធាវីនាំមុខបែរជាអនុវត្តផ្ទុយពីនេះ ដោយប្រើប្រាស់ទម្រង់ទាំងពីរដើម្បីធ្វើការទាមទារសំណងទៅវិញ។ ដំបូង សហមេធាវីនាំមុខស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចលើគោលការណ៍រួមមួយដោយបង្គាប់ថាសោហ៊ុយនៃសំណងគឺជាបន្ទុករបស់ជនជាប់ចោទ និងបង្គាប់ថាសោហ៊ុយនៃសំណងទាំងនេះត្រូវផ្តល់ដោយមូលនិធិខាងក្រៅរបស់តតីយជន[៣២២៣]។ ក្នុងជម្រើសមួយផ្សេងទៀត អនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) ពួកគេស្នើសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់ថា គម្រោងសំណងដែលបានស្នើឡើងទាំងនេះឆ្លើយតបទៅនឹងសំណងដែលបានទាមទារ និងទទួលស្គាល់ថាការផ្តល់សំណងទាំងនេះអាចត្រូវបានផ្តល់មូលនិធិដោយតតីយជន[៣២២៤]។

---

ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣ (ស្នើសុំព័ត៌មានបន្ថែម ដូចជាគម្រោងប្តង់ និង/ឬ រូបភាព និងផែនការថវិកាសម្រាប់សំណើទាំងឡាយផងដែរ)។

[៣២២១] ដើម្បីជ្រាបច្បាស់ពីព័ត៌មានលម្អិតបន្ថែម សូមមើល ឧបសម្ព័ន្ធ ១៖ ប្រវត្តិនីតិវិធី។

[៣២២២] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧។

[៣២២៣] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣៨។

[៣២២៤] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣៨ និង សំណើសុំដំណោះស្រាយ។

១១២៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទនៅក្នុងសំណុំរឿង០០២ ត្រូវបានរកឃើញថាជាជនក្រីក្រគ្មានលទ្ធភាព[៣២២៥] និងថា នៅក្នុងដំណាក់កាលជំនុំជម្រះ សហមេធាវីនាំមុខមិនបានជំទាស់ទៅនឹងការសម្រេចនេះទេ ហើយក៏មិនបានផ្តល់ព័ត៌មានណាមួយ ដែលនាំឱ្យមានភាពមន្ទិលពាក់ព័ន្ធនឹងការគ្មានលទ្ធភាពរបស់ជនជាប់ចោទ ក្នុងការផ្តល់សំណងឱ្យមានប្រសិទ្ធភាពនោះដែរ។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា រាល់គម្រោងសំណងទាំងអស់ដែលបានចង្អុលបង្ហាញនៅក្នុងសំណើសុំទាមទារចុងក្រោយ និងបង្ហាញពីសេចក្តីសម្រេចផ្សេងៗរបស់អាជ្ញាធររដ្ឋាភិបាល និងការចូលរួមរបស់តតីយជន ឬមូលនិធិខាងក្រៅនោះ អាចអនុវត្តទៅបានលុះត្រាតែស្របតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើសុំសំខាន់ៗរបស់សហមេធាវីនាំមុខដែលផ្អែកលើមធ្យោបាយនៃការផ្តល់សំណងទាំងពីរដែលមានចែងនៅក្នុងវិធាន ២៣*ស្ទួនបួន*(៣)(ក) និង (ខ) ក្នុងពេលតែមួយ មិនត្រូវបានអនុញ្ញាតតាមផ្លូវច្បាប់ និងមិនស្របទៅនឹងការទទួលស្គាល់របស់សហមេធាវីនាំមុខដែលថាមធ្យោបាយទាំងពីរនេះមិនត្រឹមតែជាទម្រង់ពីរខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាមិនអាស្រ័យគ្នាថែមទៀតផង។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងករណីណាក៏ដោយ សំណើដែលបានស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ថា សោហ៊ុយសំណងត្រូវតែជាបន្ទុករបស់ជនជាប់ចោទនោះ មិនមានភាពស៊ីសង្វាក់គ្នាទៅនឹងការខកខានដែលសហមេធាវីនាំមុខមិនបានជំទាស់ទៅនឹងការសម្រេចក្នុងពេលសវនាការកន្លងមកអំពីភាពក្រីក្ររបស់ជនជាប់ចោទ និងលក្ខណៈនៃសំណងភាគច្រើនដែលបានទាមទារនោះទេ។ ហេតុដូចនេះ អង្គជំនុំជម្រះបដិសេធសំណើសុំសំណងរួមមួយនេះ ហើយ អង្គជំនុំជម្រះនឹងពិចារណាតែសំណើជាជម្រើសមួយទៀតរបស់សហមេធាវីនាំមុខ និងធ្វើ

---

[៣២២៥] *សូមមើល* សេចក្តីសម្រេចពីភាពក្រីក្ររបស់លោក ខៀវ សំផន (ឯកសារ A151) ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៨ ។ ការកំណត់អំពីមធ្យោបាយរបស់លោក នួន ជា (ឯកសារ A49) ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧ ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បានបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិដែលជនត្រូវចោទមាន រួមទាំងវិធានការក្នុងការថែរក្សាទ្រព្យសម្បត្តិទាំងនោះសម្រាប់គោលបំណងទូទាត់សំណង។ *សូមមើល* ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន (ឯកសារ D193/4) ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន (ឯកសារ D193/5/5) ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០។ ផ្នែកទី ១៨៖ ការផ្តន្ទាទោស កថាខណ្ឌ ១១០៨។

ការវាយតម្លៃ ថាតើគម្រោងសំណងទាំងនេះបំពេញទៅតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណា។

១១២៥.សហមេធាវីនាំមុខ ស្នើសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់តាមផ្លូវតុលាការនូវគម្រោងសំណង ចំនួន ១៣ ថាជាសំណងសមស្រប។ ពីដំបូង គម្រោងទាំងនេះបានកំណត់នៅក្នុងសំណើសុំសំណង ចុងក្រោយរបស់ពួកគេនាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ និងក្រោយមក ត្រូវបានធ្វើបច្ចុប្បន្នភាព បញ្ចូលព័ត៌មានថ្មីកាលពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៣ និងថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤[៣២២៦]។ គម្រោងនីមួយៗដែលបានស្នើសុំ នឹងត្រូវបង្ហាញជូនដូចខាងក្រោម។

### ១៩.៣.១ គម្រោងទី ១៖ ទិវាជាតិនៃការចងចាំ

១១២៦.សហមេធាវីនាំមុខ មានគោលបំណងបង្កើតឲ្យមានទិវាជាតិនៃការចងចាំជាផ្លូវការមួយ ដែលទទួលស្គាល់ដោយរដ្ឋាភិបាល សម្រាប់ជាការផ្តល់កិត្តិយសដល់ជនរងគ្រោះនៃរបបខ្មែរ ក្រហម ទាំងអ្នកដែលបានស្លាប់បាត់បង់ជីវិត និងអ្នកដែលនៅរស់រានមានជីវិត និងទទួលស្គាល់ពី ឧក្រិដ្ឋកម្មដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម។ សហមេធាវីនាំមុខអះអាងថា ការ បង្កើតឲ្យមានទិវាជាតិនៃការចងចាំនេះ នឹងផ្តល់នូវការទទួលស្គាល់ជាផ្លូវការ និងជាអចិន្ត្រៃយ៍ ចំពោះការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងលើកកម្ពស់ការចងចាំជារួមមួយ នូវឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តិក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះនឹងជួយស្តារសេចក្តីថ្លៃថ្នូរ និងជួយឲ្យមានការជាសះស្បើយ នូវការឈឺចាប់ផ្លូវចិត្តដែលជនរងគ្រោះនៃរបបខ្មែរក្រហមទទួល រងដោយសារតែឧក្រិដ្ឋកម្មដែលបានជំនុំជម្រះក្នុងសំណុំរឿង ០០២[៣២២៧]។ រាជរដ្ឋាភិបាលកម្ពុជា

[៣២២៦] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/6 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។ ព័ត៌មានបន្ថែមលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ *ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/6/1 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៣។ សំណើសុំការបំភ្លឺអំពីគម្រោងសំណង (អ.ជ.ស.ដ) ឯកសារ E218/7/7 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣។ *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។

[៣២២៧] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ

បានយល់ព្រមប្រកាសយកថ្ងៃទី ២០ ខែ ឧសភា ជារៀងរាល់ឆ្នាំ ជាថ្ងៃឈប់សម្រាកបុណ្យជាតិ សម្រាប់គោលបំណងនេះ ហើយសហមេធាវីនាំមុខបានទទួលលិខិតមួយពីទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាភ័ស្តុតាងបញ្ជាក់អំពីការគាំទ្ររបស់រដ្ឋាភិបាលចំពោះគម្រោងនេះ។ គម្រោងនេះមិនត្រូវការឲ្យមានការចំណាយថវិកានោះទេ[៣២២៨]។

## ១៩.៣.២ គម្រោងទី ២៖ គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រម្លឹកជាសាធារណៈ

១១២៧. គម្រោងទីពីរ មានគោលបំណងបង្កើតបូជនីយដ្ឋានសម្រាប់រម្លឹកជាសាធារណៈចំនួនប្រហែលប្រាំកន្លែងនៅទូទាំងប្រទេសកម្ពុជា។ ទីតាំងទាំងនេះនឹងត្រូវជ្រើសរើសឡើងដើម្បីធានាថាទីកន្លែងទាំងនេះអាចឲ្យគេទៅដល់បាន មាននិរន្តរភាព និងមានការប្រើប្រាស់ធនធាន និងសមត្ថភាពដែលមានស្រាប់។ បូជនីយដ្ឋានទាំងនេះនឹងមានផ្នែកអប់រំផងដែរ ដែលធ្វើឲ្យសាធារណជនមានការយល់ដឹងពីរបបខ្មែរក្រហម។ គម្រោងនេះត្រូវបានរៀបចំសម្រាប់អនុវត្តក្នុងរយៈពេល ៣៦ ខែ[៣២២៩]។ អង្គការក្តីករុណា និងអង្គការយុវសន្តិភាពនឹងទទួលអនុវត្តគម្រោងនេះ ដោយមានជំនួយប្រឹក្សាពីសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា។ សហមេធាវីនាំមុខលើកឡើងថាគម្រោងនេះទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលទាំងឡាយដែលបានរៀបរាប់ខាងលើ ដែលជាអង្គការអនុវត្តគម្រោងនេះ[៣២៣០]។ ទោះបីជាសហ-មេធាវីនាំមុខទទួលស្គាល់ថារហូតមកដល់ពេលនេះ នៅមិនទាន់មានការធានាផ្នែកថវិកាសម្រាប់

---

៨២-៩០។ ឧបសម្ព័ន្ធ ១ ឯកសារគាំទ្រសម្រាប់គម្រោងទី ១៖ ទិវាជាតិនៃការចងចាំ (ឯកសារ E218/7/6.1.1) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ។

[៣២២៨] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៩។

[៣២២៩] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៩១-១០១។ ឧបសម្ព័ន្ធ ២ ឯកសារគាំទ្រសម្រាប់គម្រោងទី ២៖ គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រម្លឹកជាសាធារណៈ (ឯកសារ E218/7/6.1.2) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ។

[៣២៣០] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៩៧-៩៩។

គម្រោងនេះនៅឡើយក៏ដោយ ក៏សហមេធាវីនាំមុខទទួចសុំឲ្យអង្គជំនុំជម្រះគាំទ្រគម្រោងនេះដែរ[៣២៣១]។

១១២៨. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា សំណើសុំគម្រោងនេះមិនមានការពិពណ៌នាលម្អិតគ្រប់គ្រាន់ ឬមិនមានខ្ទង់ថវិកា។ អង្គជំនុំជម្រះបានជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះនឹងទទួលយកព័ត៌មានបន្ថែមលើបញ្ហានេះរហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ បានកត់សម្គាល់យុត្តិសាស្ត្រ និងសេចក្តីអធិប្បាយស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលលើកឡើង អំពីសារសំខាន់នៃបូជនីយដ្ឋានសាធារណៈថាជាទម្រង់នៃសំណងមួយប្រភេទសម្រាប់បទឧក្រិដ្ឋធំៗ ហើយបានស្នើសុំអង្គជំនុំជម្រះឲ្យគូសបញ្ជាក់អំពីតួនាទីចម្បងនៃបូជនីយដ្ឋានសាធារណៈនេះ នៅក្នុងដំណើរការផ្តល់សំណង ដោយសារបូជនីយ-ដ្ឋានសាធារណៈនេះនឹងផ្តល់ជាទីកន្លែងសម្រាប់ជនរងគ្រោះប្រារព្ធពិធីរម្លឹកការចងចាំ[៣២៣២]។ មិនមានព័ត៌មានលម្អិតណាមួយបន្ថែមទៀតបានផ្តល់ឲ្យពាក់ព័ន្ធនឹងការពិពណ៌នាខ្ទង់ថវិកា និងមូលនិធិលើគម្រោងនេះឡើយ។

### ១៩.៣.៣ គម្រោងទី ៣៖ ការសាងសង់ស្តូបនៅរាជធានីភ្នំពេញសម្រាប់រម្លឹកដល់ជនរង-គ្រោះដោយសារការជម្លៀសដោយបង្ខំ

១១២៩. ដោយមានការផ្តល់មូលនិធិពីស្ថានទូតបារាំងនៅក្នុងប្រទេសកម្ពុជា និងសមាជិកសភានៃក្រុមមិត្តភាព កម្ពុជា-បារាំង នៃរដ្ឋសភាបារាំង គម្រោងនេះស្នើសុំឲ្យបញ្ចូលសិល្បករស្ទូនរូបខ្មែរ-បារាំងមួយរូបឈ្មោះ សេរ៉ា ដើម្បីបង្កើតជាបណ្តុំនៃរូបចម្លាក់ដាក់នៅក្នុងសួនរង្វង់មូលស្ពាតចាស់

---

[៣២៣១] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១០០-១០១។ *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើម-បណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៩។

[៣២៣២] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេ-ណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៩-១៤។

ខាងមុខវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្នុងរាជធានីភ្នំពេញ។ រូបចម្លាក់ទាំងនេះមានគោលបំណង បង្ហាញពីព្រឹត្តិការណ៍នៃការចាកចេញរបស់ប្រជាជនកម្ពុជាពីតំបន់នានា ក្នុងអំឡុងរបបខ្មែរក្រហម។ គម្រោងនេះអាចចាប់ផ្តើមអនុវត្តបានភ្លាមៗ និងអាចធ្វើរួចរាល់នៅមុនពិធីសម្ពោធដែលគ្រោងនឹង ធ្វើឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៥។ ថវិកាសរុបសម្រាប់គម្រោងនេះ ដែលមានទឹកប្រាក់ ចំនួន ៨៨.៤០០ ដុល្លារសហរដ្ឋអាមេរិក ត្រូវបានធានាថាមានគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះ ហើយសាលារាជធានីភ្នំពេញក៏បានឯកភាពលើគម្រោងនេះរួចហើយផងដែរ[៣២៣៣]។

### ១៩.៣.៤ គម្រោងទី ៤៖ ការសាងសង់ស្តូបសម្រាប់រម្លឹកដល់ជនរងគ្រោះរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរដែលរស់នៅប្រទេសបារាំង

១១៣០. សមាគមចំនួនពីរ គឺសមាគមជនរងគ្រោះនៃរបបខ្មែរក្រហម និងសហព័ន្ធសិទ្ធិមនុស្ស អន្តរជាតិ (FIDH) បានស្នើសុំឲ្យកសាងស្តូបមួយកន្លែងនៅក្នុងវត្ត Vincennes ក្នុងទីក្រុងប៉ារីស ដើម្បីធ្វើជាទីកន្លែងនៃការចងចាំ និងទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីខ្មែរដែលរស់នៅប្រទេស បារាំង។ គម្រោងនេះក៏អាចចាប់ផ្តើមអនុវត្តបានភ្លាមៗ និងអាចធ្វើរួចរាល់ក្នុងរយៈពេលមួយឆ្នាំផង ដែរ[៣២៣៤]។ សាលាក្រុងប៉ារីស បានឯកភាពលើគម្រោងនេះរួចហើយ ហើយថវិកាចំនួន ១០.០០០ អឺរ៉ូ ក្នុងចំនួនទឹកប្រាក់សរុប ៧០.១៤០ អឺរ៉ូ សម្រាប់គម្រោងនេះក៏បានទទួលការសន្យារួចហើយផងដែរ។ សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិបាន និងកំពុងស្វែងរកការផ្តល់ហិរញ្ញប្បទានលើចំនួនទឹកប្រាក់ដែល

---

[៣២៣៣] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១០២-១១៣។ *ឧបសម្ព័ន្ធសម្ងាត់ ៣៖ ឯកសារគាំទ្រសម្រាប់គម្រោងទីបី៖ បូជនីយដ្ឋានសម្រាប់ជនរងគ្រោះនៃរបប ខ្មែរក្រហម "សម្រាប់អ្នកដែលបាត់បង់ជីវិត" ឯកសារ* E128/7/6.1.3 *ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។ ព័ត៌មាន បន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោម តាមវិធាន៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារE218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ១៦។ *ឧបសម្ព័ន្ធសម្ងាត់ ២៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីបី៖ ការសាងសង់រូបសំណាកសាធារណៈដើម្បីរំឭក ដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមដោយ សេរ៉ា ឯកសារ* E128/7/8.1.2 *ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។*

[៣២៣៤] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/6 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១២០។ ឧបសម្ព័ន្ធ ៤ ឯកសារគាំទ្រសម្រាប់គម្រោង៖ ស្តូបរម្លឹកដល់ជនរងគ្រោះរបបខ្មែរក្រហមសម្រាប់ប្រជាជន ខ្មែរដែលរស់នៅប្រទេសបារាំង ឯកសារ E218/7/6.1.4 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។

នៅសេសសល់ ដោយបានអំពាវនាវដល់ម្ចាស់ជំនួយឲ្យជួយផ្តល់មូលនិធិសម្រាប់គម្រោងនេះ។ ហេតុដូច្នេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងជាយោបល់ថា អង្គជំនុំជម្រះគួរពិចារណាលើការផ្តល់មូលនិធិសម្រាប់គម្រោងនេះដើម្បីធានាឲ្យមានថវិកាពេញលេញ[៣២៣៥]។

## ១៩.៣.៥ គម្រោងទី ៥៖ វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម

១១៣១. សហមេធាវីនាំមុខ ស្នើសុំឲ្យអនុវត្តគម្រោងមួយដែលមានឈ្មោះថាវិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្មសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងសំណុំរឿង០០២។ គម្រោងនេះមានគោលបំណងផ្តល់ការព្យាបាលដ៏មានប្រសិទ្ធភាពមួយ ចំពោះការឈឺចាប់ផ្នែកផ្លូវចិត្តដោយសារតែឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម តាមរយៈការកត់ត្រាសក្ខីកម្មអំពីបទពិសោធន៍ដ៏តក់ស្លុត ដោយមានជំនួយពីអ្នកជំនាញផ្លូវចិត្ត។ សក្ខីកម្មដែលបានកត់ត្រាជាលាយលក្ខណ៍អក្សរទាំងនេះ នឹងត្រូវយកមកអាន និង ប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពិធីបុណ្យសាសនា ឬជំនឿ និងទំនៀមទម្លាប់វប្បធម៌របស់ជនរងគ្រោះ។ ពិធីទាំងនេះនឹងត្រូវរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា នៅក្នុង ឬនៅក្បែរសហគមន៍ដែលមានដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី អ្នកនៅរស់រានមានជីវិតដទៃទៀត សាច់ញាតិ សមាជិកសហគមន៍ មេដឹកនាំសាសនា និងជំនឿ និងតំណាងស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត។ បើតាមសហមេធាវីនាំមុខ គម្រោងនេះនឹងអនុញ្ញាតឲ្យជនរងគ្រោះរៀបរាប់អំពីបទពិសោធន៍ដ៏តក់ស្លុតរបស់ពួកគេ ស្តារសេចក្តីថ្លៃថ្នូរ ផ្តល់ជាភ័ស្តុតាងនៃការរំលោភសិទ្ធិមនុស្ស និងការគាំទ្រសេចក្តីត្រូវការ និងផលប្រយោជន៍របស់ពួកគេនៅក្នុងដំណើរការយុត្តិធម៌អន្តរកាល និងដំណើរការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា។ មូលនិធិមួយផ្នែកនៃគម្រោងនេះនឹងត្រូវយកទៅចំណាយដើម្បីជ្រើស

---

[៣២៣៥] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋវេណី អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨-១៩។ *ឧបសម្ព័ន្ធសម្ងាត់ ៣៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីបួន៖ ការសាងសង់បូជនីយដ្ឋានដើម្បីរំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមសម្រាប់ប្រជាជនខ្មែររស់នៅប្រទេសបារាំង* ឯកសារ E218/7/8.1.3 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ២២ ERN (ភាសាបារាំង) 00980937។

រើស និងបណ្តុះបណ្តាលអ្នកជំនាញផ្នែកផ្លូវចិត្តចំនួន ០៦ នាក់ ដោយក្នុងនោះមានម្នាក់នឹងធ្វើជាអ្នកសម្របសម្រួលគម្រោង[៣២៣៦]។

១១៣២. ពីដំបូង គម្រោងទី ៥ និងគម្រោងទី ៦ បានស្នើសុំឡើងសម្រាប់រយៈពេល ១៦ ខែ នៅតាមសហគមន៍ចំនួន ១២ ផ្សេងៗគ្នា[៣២៣៧]។ ក្រោយមក ថវិកាត្រូវបានកែសម្រួលឡើងវិញ ហើយមូលនិធិទទួលបានពីប្រទេសអូស្ត្រាលី រដ្ឋាភិបាលអាល្លឺម៉ង់ និងអង្គការ *Stiftung Kriegstrauma Therapie* របស់ប្រទេសស្វីស សម្រាប់គម្រោងក្នុងចំនួនទឹកប្រាក់សរុប ១៩៦.៥២២ ដុល្លារសហរដ្ឋអាមេរិក (សម្រាប់គម្រោងទាំងពីរ)[៣២៣៨]។ ដោយសារការកែសម្រួលថវិកានេះហើយទើបគម្រោងនេះនឹងកម្រិតតែនៅទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ បច្ចុប្បន្ននេះ សហមេធាវីនាំមុខកំពុងស្វះស្វែងរកមូលនិធិបន្ថែមពី ៨០០.០០០ ទៅ ១.០០០.០០០ ដុល្លារសហរដ្ឋអាមេរិក ដើម្បីអាចពង្រីកគម្រោងនេះ និងស្នើសុំអង្គជំនុំជម្រះឲ្យពិចារណាលើគម្រោងដែលបានស្នើសុំនេះទាំងមូលជាសំណងតែម្តង រួមទាំងផ្នែកដែលមិនទាន់ទទួលបានមូលនិធិ[៣២៣៩]។

---

[៣២៣៦] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/6 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១២៧។ ឧបសម្ព័ន្ធ ៥ និង ៦ ឯកសារគាំទ្រសម្រាប់គម្រោង។ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង ឯកសារ E218/7/6.1.5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ១០។ *សូមប្រៀបធៀបជាមួយឯកសារដដែល*ឧបសម្ព័ន្ធ ៥ និង ៦ ឯកសារគាំទ្រ សម្រាប់គម្រោង ៥ និង ៦៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង ឯកសារ E218/7/6.1.5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ២០ ERN (ភាសាអង់គ្លេស) 00950965 *(គួសបញ្ជាក់ថា នឹងត្រូវបណ្តុះបណ្តាលអ្នកជំនាញផ្លូវចិត្តចំនួន ០៤ រូប)*។

[៣២៣៧] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/6 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣៨-១៣៩, ១៤២, ១៥៥, ១៥៧។

[៣២៣៨] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋវេណី អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ២១។ *ឧបសម្ព័ន្ធសម្ងាត់ ៤៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំ និងទីប្រាំមួយ៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង* ឯកសារ E218/7/8.1.4 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00980939។

[៣២៣៩] ឧបសម្ព័ន្ធ៥ និង៦ ឯកសារគាំទ្រសម្រាប់គម្រោងទី៥ និងគម្រោងទី៦៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង ឯកសារ E218/7/6.1.5 ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៤, ២២ ERN (ភាសាអង់គ្លេស) 00950949 00950967។

### ១៩.៣.៦ គម្រោងទី ៦៖ ក្រុមជួយខ្លួនឯង

១១៣៣. គម្រោងសំណងនេះត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលដល់ក្រុមជួយខ្លួនឯង ដែលផ្តល់ការព្យាបាល និងរៀបចំឡើងដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលមានភាពសកម្មនៅក្នុងវិស័យសុខភាពផ្លូវចិត្តនៅកម្ពុជា។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតឲ្យជនរងគ្រោះនៃការជម្លៀសដោយបង្ខំ អាចរៀបរាប់អំពីការឈឺចាប់របស់ពួកគេ ជំរុញដំណើរការជាសះស្បើយពីជំងឺបាក់ស្បាតរបស់ពួកគេ។ គម្រោងនេះមានវគ្គព្យាបាលជាក្រុមចំនួន ៦ វគ្គ ដោយជួបគ្នារៀងរាល់ខែ និងដោយមានការពិគ្រោះយោបល់ជាមួយអ្នកព្យាបាលអាជីពម្នាក់ក្នុងរយៈពេល ៩ ខែ[៣២៤០]។ គម្រោងនេះបានចាប់ផ្តើមអនុវត្តរួចហើយដោយបានប្រើប្រាស់មូលនិធិដូចបានបញ្ជាក់ខាងលើ។ បច្ចុប្បន្នកំពុងមានការស្វែងរកថវិកាចំនួន ១.០០០.០០០ ដុល្លាសហរដ្ឋអាមេរិក បន្ថែមទៀតដើម្បីបន្តអនុវត្តគម្រោងនេះ និងគម្រោងទី ៥ ផងដែរ។ ស្ថាប័នដែលចូលរួមជាមួយគម្រោងនេះទាំងអស់សុទ្ធតែបានបញ្ជាក់អំពីឆន្ទៈក្នុងការជួយ និងផ្តល់ថវិកាដល់គម្រោងនេះ[៣២៤១]។

### ១៩.៣.៧ គម្រោងទី ៧៖ ការតាំងពិពណ៌ជាអចិន្ត្រៃយ៍

១១៣៤. សហមេធាវីនាំមុខ ស្នើសុំឲ្យបង្កើតកន្លែងសម្រាប់តាំងពិពណ៌អចិន្ត្រៃយ៍ជាសាធារណៈចំនួន ៥ ខេត្ត ដែលដាក់បង្ហាញរូបថត វត្ថុតាង ឯកសារ កំណត់ហេតុជាសម្លេង និង រូបភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិតផ្សេងៗទៀត ស្នាដៃសិល្បៈ ការតាំងបង្ហាញអំពីរឿងរ៉ាវប្រវត្តិសាស្ត្រ និងធនធានដទៃទៀត ដែលបង្កើតឡើងដើម្បីរក្សាទុករឿងរ៉ាវផ្សេងៗជំនាន់ខ្មែរក្រហម និងដើម្បីអប់រំសាធារណជនអំពីរបបខ្មែរក្រហម[៣២៤២]។ មូលនិធិសម្រាប់គម្រោងនេះ

---

[៣២៤០] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារE218/7/8 ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ២៧។ *ឧបសម្ព័ន្ធសម្ងាត់ ៤៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំ និងទីប្រាំមួយ៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង* ឯកសារ E218/7/8.1.4 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។

[៣២៤១] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៦។

[៣២៤២] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៩-១៧៣។ ឧបសម្ព័ន្ធ ៧ និង ៩ ឯកសារគាំទ្រសម្រាប់គម្រោង ៧ និង ៩៖ ការតាំងពិពណ៌អចិន្ត្រៃយ៍នៅតាមសារ-សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក សំណុំរឿង ០០២/០១/ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤/សាធារណៈ

ត្រូវបានធានាទាំងស្រុងរួចហើយ។ សហមេធាវីនាំមុខអះអាងថា រដ្ឋាភិបាលអាល្លឺម៉ង់បានសន្យាផ្តល់ប្រាក់ ៨០.០០០ អឺរ៉ូ សម្រាប់គម្រោងនេះ។ ដៃគូសហការក្នុងគម្រោងនេះសុទ្ធតែបានបញ្ជាក់ពីឆន្ទៈក្នុងការជួយ និងផ្តល់ថវិកាដល់គម្រោងនេះ[៣២៤៣]។

### ១៩.៣.៨ គម្រោងទី ៨៖ ការតាំងពិពណ៌ចល័ត និងគម្រោងអប់រំ៖ សិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រ និងយុត្តិធម៌អន្តរកាល

១១៣៥. សហមេធាវីនាំមុខស្នើសុំឲ្យបង្កើតគម្រោងតាំងពិពណ៌ និងអប់រំ ដើម្បីផ្សព្វផ្សាយដល់អ្នកដែលនៅរស់រានមានជីវិត និងប្រជាជនខ្មែរជំនាន់ក្រោយសង្គ្រាម ឲ្យបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម។ ដៃគូក្នុងគម្រោងនេះមានអង្គការមិនមែនរដ្ឋាភិបាល គឺអង្គការក្តីករុណា និងអង្គការយុវសន្តិភាព ដែលនឹងអនុវត្តគម្រោង ដោយមានជំនួយប្រឹក្សាពីសមាគមអាដហុក និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)[៣២៤៤]។ រដ្ឋាភិបាលអាល្លឺម៉ង់បានផ្តល់ថវិកាចំនួន ១០០.០០០ អឺរ៉ូ សម្រាប់អនុវត្តគម្រោងដំណាក់កាលដំបូងនៅក្នុងខេត្តចំនួន ៦

---

មន្ទីរខេត្តក្រុងចំនួន ៥ និងការកោសលុបជំពូកពិសេសស្តីពីការជម្លៀសដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ (ឯកសារ E218/7/6.1.6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។

[៣២៤៣] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧១។ *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយ ស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣០។

[៣២៤៤] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧៤-១៨៨។

សម្រាប់រយៈពេល ១២ ខែ[៣២៤៥]។ ក្រោយមក ថវិកាចំនួន ២៣.០០០ ដុល្លារសហរដ្ឋអាមេរិក បាន ទទួលបន្ថែម ដែលអាចឲ្យពង្រីកគម្រោងឲ្យបានរហូតដល់ទៅ ៣ ខេត្ត បន្ថែមទៀត[៣២៤៦]។

### ១៩.៣.៩ គម្រោងទី ៩៖ ការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និង ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា

១១៣៦. សហមេធាវីនាំមុខស្នើសុំបញ្ចូលជំពូកមួយស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងសៀវភៅសម្រាប់គ្រូបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) បានបោះពុម្ពផ្សាយសៀវភៅសម្រាប់គ្រូបណ្តុះបណ្តាលនេះ (ដោយសហការជាមួយក្រសួងអប់រំកម្ពុជា) ហើយសៀវភៅនេះណែនាំអំពីការបង្រៀនប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅគ្រប់កម្រិតមធ្យមសិក្សាទាំងអស់នៅកម្ពុជា[៣២៤៧]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូនជំពូកសៀវភៅដែលបានផ្អែកទាំងស្រុងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនៅក្នុងសំណុំរឿង ០០២/០១[៣២៤៨]។ របាយការណ៍អំពីគម្រោងដែលបានផ្តល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជាក់ថា

---

[៣២៤៥] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៨៥-១៨៦។ ឧបសម្ព័ន្ធ ៨ ឯកសារគាំទ្រសម្រាប់គម្រោងទី ៨៖ គម្រោងតាំងពិពណ៌ចល័តស្តីពីការជម្លៀសដោយបង្ខំ (ឯកសារE218/7/6.1.7) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ៧ ERN (ភាសាអង់គ្លេស) 00951014។

[៣២៤៦] ឧបសម្ព័ន្ធ ៨ ឯកសារគាំទ្រសម្រាប់គម្រោងទី ៨៖ គម្រោងតាំងពិពណ៌ចល័តស្តីពីការជម្លៀសដោយបង្ខំ (ឯកសារ E218/7/6.1.7) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។ *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣២-៣៤។ *ឧបសម្ព័ន្ធសម្ងាត់ ៥៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំបី៖ ការតាំងពិព័រណ៍ចល័ត* ឯកសារ E218/7/8.1.5 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤។

[៣២៤៧] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៨៩-១៩៨។

[៣២៤៨] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ-ប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៨។

ជំពូកសៀវភៅនេះត្រូវបានព្រាងយ៉ាងប្រុងប្រយ័ត្ន "ដើម្បីជៀសវាងការសន្និដ្ឋានតាមផ្លូវច្បាប់លើជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ឬលើសាលក្រមប្រវត្តិសាស្ត្រហួសពីវិសាលភាពនៃការស៊ើបសួរក្នុងសំណុំរឿង ០០២/០១ លើរបបកម្ពុជាប្រជាធិបតេយ្យ"[៣២៤៩]។ សៀវភៅណែនាំក្នុងនោះរួមមានជំពូកថ្មី នឹងចែកចាយបន្ទាប់ពីចេញសាលក្រមសំណុំរឿង ០០២/០១[៣២៥០]។ គម្រោងនេះក្នុងចំនួនទឹកប្រាក់សរុប ៥៧.១៦០ ដុល្លារសហរដ្ឋអាមេរិក បានទទួលមកពីអង្គការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ)[៣២៥១]។

### ១៩.៣.១០ គម្រោងទី ១០៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព

១១៣៧. សហមេធាវីនាំមុខ ស្នើសុំបង្កើតមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍មួយនៅវត្តសំរោងក្នុង ក្នុងខេត្តបាត់ដំបង ដែលនឹងរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពីឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម និងកិច្ចការរបស់ អ.វ.ត.ក។ គម្រោងនេះមានបំណងចង់បង្កើតបណ្ណាល័យមួយ និងរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់យុវជនកម្ពុជា ទៅកាន់ទីកន្លែងសម្លាប់មនុស្សមួយចំនួន។ គម្រោងនេះនឹងត្រូវបញ្ជាក់អំពីទីតាំងផ្លូវការ ដែលនឹងត្រូវអនុវត្តដោយអង្គការយុវសន្តិភាព និងទទួលបានការឧបត្ថម្ភថវិកាពីទីភ្នាក់ងារអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការប្រទេសស្វីស[៣២៥២]។

---

[៣២៤៩] *ឧបសម្ព័ន្ធសម្ងាត់ ៦៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំបួន៖ ការតាក់តែងជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ* ឯកសារ E218/7/8.1.6 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ១ ERN (ភាសាអង់គ្លេស) 00980953។

[៣២៥០] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩៧។ *ព័ត៌មានបន្ថែមលើកទីពីរ លើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៨, ៤០។

[៣២៥១] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៩។

[៣២៥២] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩៩-២១១។ ឧបសម្ព័ន្ធ ១០ ឯកសារគាំទ្រសម្រាប់គម្រោងទី ១០៖ មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ នៅសំរោងក្នុង (ឯកសារ E218/7/6.1.8) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ។

រហូតមកដល់ពេលនេះ មូលនិធិសម្រាប់អនុវត្តគម្រោងនេះត្រូវបានធានារួចហើយ ដែលមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះក្នុងចំនួនទឹកប្រាក់ ១២៦.០០០ ដុល្លាសហរដ្ឋអាមេរិក[៣២៥៣]។

## ១៩.៣.១១ គម្រោងទី ១១៖ គម្រោងបោះពុម្ពកូនសៀវភៅអំពីអង្គហេតុដែលត្រូវបានសម្រេចសេចក្ដីក្នុងសំណុំរឿង ០០២/០១ និងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

១១៣៨. សហមេធាវីនាំមុខ ស្នើសុំឲ្យមានការបោះពុម្ពកូនសៀវភៅដែលពន្យល់អំពីដំណើរការតុលាការនៅចំពោះមុខ អ.វ.ត.ក ដោយផ្ដោតលើការចងក្រងឯកសារអំពីឧក្រិដ្ឋកម្មនានាក្នុងសំណុំរឿង ០០២/០១ និងវិសាលភាពនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ គម្រោងនេះនឹងរួមបញ្ចូលទាំងសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើឡើងនៅក្នុងពេលសវនាការផងដែរ[៣២៥៤]។ ថវិកាសរុបសម្រាប់គម្រោងនេះមានចំនួន ៥.០០០ ដុល្លាសហរដ្ឋអាមេរិក ត្រូវបានធានាថានឹងផ្ដល់ជូនតាមរយៈអង្គការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ)[៣២៥៥]។

---

[៣២៥៣] *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្ដីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១។ *ឧបសម្ព័ន្ធសម្ងាត់ ៧៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីដប់៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព* ឯកសារ E218/7/8.1.7 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ១៧-១៩ ERN (ភាសាអង់គ្លេស) 00980998-00981000។

[៣២៥៤] សំណើសុំចុងក្រោយស្ដីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២២១-២២២។

[៣២៥៥] សំណើសុំចុងក្រោយស្ដីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6)ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២២០។ ឧបសម្ព័ន្ធ ១១ ឯកសារគាំទ្រសម្រាប់គម្រោងទី ១១៖ ដំណើររឿងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសៀវភៅរឿងនិទានអមដោយរូបភាព ស្ដីពីជនរងគ្រោះនៃរបបខ្មែរក្រហមចូលរួមនៅ អ.វ.ត.ក (ឯកសារ E218/7/6.1.10) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ ERN (ភាសាអង់គ្លេស) 00951106។ *ព័ត៌មានបន្ថែមលើកទីពីរលើសំណើសុំចុងក្រោយស្ដីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣។

### ១៩.៣.១២ គម្រោងទី ១២៖ បោះពុម្ព និងផ្សព្វផ្សាយសាលក្រមសំណុំរឿង ០០២/០១ ជាពីរប្រភេទ

១១៣៩. សហមេធាវីនាំមុខស្នើសុំឲ្យបោះពុម្ព និងផ្សព្វផ្សាយសាលក្រមនៃសំណុំរឿង ០០២/០១ ជាភាសាខ្មែរ ជាពីរប្រភេទ គឺសាលក្រមដែលមានសំអាងហេតុពេញលេញ និងសាលក្រមសង្ខេប។ យោងតាមសំណើសុំគម្រោងថវិកាចំនួន ៣០.០០០ ដុល្លារសហរដ្ឋអាមេរិក នឹងត្រូវការសម្រាប់អនុវត្តគម្រោងនេះបាន។ មកទល់បច្ចុប្បន្ន មូលនិធិនេះបានទទួលគ្រប់គ្រាន់សម្រាប់បោះពុម្ពផ្សាយសាលក្រមសង្ខេបចំនួន ៤.០០០ ក្បាល និងសាលក្រមពេញលេញចំនួន ១.២០០ ក្បាល (លើចំនួន ៤.០០០ ក្បាលដែលបានស្នើសុំ) ក្នុងរយៈពេល ៩ ខែ ក្រោយពេលចេញសាលក្រម[៣២៥៦]។

### ១៩.៣.១៣ គម្រោងទី ១៣៖ គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក

១១៤០. ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យបញ្ចូលឈ្មោះរបស់ពួកគេទៅក្នុងគេហទំព័ររបស់ អ.វ.ត.ក ដោយចាត់ទុកដូចជាមធ្យោបាយបន្ថែមមួយក្នុងការកត់ត្រាទុកនូវការចូលរួមរបស់ពួកគេនៅក្នុងការជំនុំជម្រះសំណុំរឿង ០០២ ។ អង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈ នឹងអនុវត្តគម្រោងនេះក្នុងរយៈពេលបីខែបន្ទាប់ពីចេញសាលក្រមនៃសំណុំរឿង ០០២/០១ ដោយមិនចាំបាច់ចំណាយថវិកាបន្ថែមទៀតឡើយ[៣២៥៧]។

---

[៣២៥៦] *ព័ត៌មានបន្ថែមលើកទីពីរ លើសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់* ឯកសារ E218/7/8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៩-៥០។ *ការបោះពុម្ព និងការផ្សព្វផ្សាយសាលក្រមនាពេលខាងមុខ ទាំងស្រុង និងដោយសង្ខេប* ឯកសារ E218/7/8.1.8 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ៣ ERN (ភាសាអង់គ្លេស) 00981004។ សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ *ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២២៣-២២៦។ ឧបសម្ព័ន្ធ ១២ និង ១៣ ឯកសារគាំទ្រសម្រាប់គម្រោងទី ១២ និង ១៣៖ ការបោះពុម្ពផ្សាយសាលក្រម និងឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E218/7/6.1.9 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣។

[៣២៥៧] សំណើសុំចុងក្រោយស្តីអំពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ (ឯកសារ E218/7/6) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២២៧-២២៩។

## ១៩.៤ ព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង

១១៤១. ជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាមានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២) និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ វិធាន ២៣ ស្ទួនបួន (១) តម្រូវឱ្យសំណងដែលបានសម្រេចផ្តល់ឱ្យដោយអង្គជំនុំជម្រះទទួលស្គាល់ និងឆ្លើយតបទៅនឹងព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណីដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋទាំងនេះ។

១១៤២.ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់ បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលនៃសវនាការលើសំណុំរឿង ០០២/០១។ ចាប់តាំងពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ដល់ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានលៃលកទុកសវនាការចំនួន ៤ ថ្ងៃ សម្រាប់ស្តាប់សក្ខីកម្មដោយផ្ទាល់មាត់ពីដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស អំពីវិធីដែលពួកគេបានទទួលរងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះក៏បានស្តាប់សក្ខីកម្មពីលោក ឈីម សុធារ៉ា អ្នកជំនាញចិត្តសាស្ត្រ និងវេជ្ជបណ្ឌិតសុខភាពផ្លូវចិត្តដែលធ្លាប់មានបទពិសោធន៍ធ្វើការងារជាមួយនឹងជនរងគ្រោះនៃរបបខ្មែរក្រហម (រួមទាំង ដើមបណ្តឹងរដ្ឋប្បវេណី)។ លោកបានពិភាក្សាអំពីផលប៉ះពាល់ផ្លូវចិត្តដោយសារហេតុការណ៍នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិប-តេយ្យ មកលើជនរងគ្រោះទាំងនេះ។ ចំណុចចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់បានរៀបរាប់រឿងរ៉ាវជាលាយលក្ខណ៍អក្សរអំពីព្យសនកម្មដែលពួកគេបានទទួលរង និងបទឧក្រិដ្ឋនានាដែលពួកគេបានឃើញនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ដែលអង្គជំនុំជម្រះក៏បានយកមកពិនិត្យពិចារណាផងដែរ។

១១៤៣. សក្ខីកម្មដែលបានផ្តល់ឱ្យដោយដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់ជារូបភាពយ៉ាងរស់រវើកឆ្លុះបញ្ចាំងអំពីវិធីដែលពួកគេបានទទួលរងគ្រោះ ដោយសារបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយជនជាប់ចោទ។

១១៤៤.ក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីមានការភិតភ័យខ្លាចបាត់បង់អាយុជីវិតនៅពេលដែលកងទ័ពខ្មែរក្រហម បានបង្ខំពួកគេឱ្យជម្លៀស

ចេញពីទីក្រុង[៣២៥៨]។ ពួកគេត្រូវបោះបង់ចោលផ្ទះសម្បែង សម្ភារៈ និងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ពួកគេស្ទើរតែទាំងអស់[៣២៥៩]។ អ្នកខ្លះត្រូវបានគេប្រាប់ឱ្យវេចបង្វេចសម្រាប់ការធ្វើដំណើររយៈពេលខ្លីតែប៉ុណ្ណោះ ហើយពួកគេនឹងវិលត្រលប់មកទីក្រុងភ្នំពេញវិញក្រោយរយៈពេលបីថ្ងៃ[៣២៦០]។ ដើមបណ្ដឹងរដ្ឋប្បវេណី ឡាយ បូនី និង អោ រី បានយកតែលុយទៅតាមខ្លួនប៉ុណ្ណោះ ដោយស្មានទាំងខុសថា ពួកគេនឹងអាចប្រើប្រាស់លុយទាំងនោះសម្រាប់ទិញរបស់របរដែលពួកគេត្រូវការ[៣២៦១]។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតបានយកយានយន្ត ឬ សម្ភារៈទៅជាមួយពួកគេ ប៉ុន្តែ ជាញឹកញាប់ យានយន្ត និងសម្ភារៈទាំងនោះត្រូវបានកងទ័ពខ្មែរក្រហមរឹបអូស ឬ ដកហូតនៅពេលពួកគេចាកចេញពីទីក្រុង[៣២៦២]។ ទោះក្នុងករណីណាក៏ដោយ ដោយសារគ្មានប្រេងឥន្ធនៈ

---

[៣២៥៨] សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១២ (យឹម សុវណ្ណ) ទំព័រ ៦៦-៦៩។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ២១-២២, ២២-២៣។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៤-៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ហូ ចន្ថា) ទំព័រ ៥៤-៥៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ចាន់ សុជាតិ) ទំព័រ ៣៣។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៣ (បេ សុផានី) ទំព័រ ៧-៨។ សូមមើល ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៨, ៤៧១-៤៧៥។

[៣២៥៩] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១២ (មាស សារ៉ាន់) ទំព័រ ៧៩-៨១។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៨-៩។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ឆេង អេងលី) ទំព័រ ៦៩-៧០។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ហូ ចន្ថា) ទំព័រ ៥៤-៥៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៣៩។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (ប៊ូ ឌីណា) ទំព័រ ៨១-៨២។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៦។

[៣២៦០] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៨១។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ២១-២២។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១២ (មុម សំអឿន) ទំព័រ ៦-៧។ ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១២ (មាស សារ៉ាន់) ទំព័រ ៧៩-៨០។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១២ (អោ រី) ទំព័រ ៨០-៨១។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១២ (ចៅ នី) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១២ (ទឹង សុខា) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ ១៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៣៩-៤០។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៦៥-៤៦៦។

[៣២៦១] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ៧៥។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ២២។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១២ (អោ រី) ទំព័រ ៨១-៨២។

[៣២៦២] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៣២។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១២ (មុម សំអឿន) ទំព័រ ១១-១២។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១២ (ទឹង សុខា) ទំព័រ ៣៤-

រថយន្ត ឬ ម៉ូតូ លែងមានប្រយោជន៍ ហើយត្រូវបានទុកចោល។ អ្នកខ្លះទៀតបានទុកចោលនូវរបស់របរមានតម្លៃដែលខ្លួនស្រលាញ់ ហើយមិនត្រឹមតែបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនប៉ុណ្ណោះនោះទេ ពួកគេក៏បានបាត់បង់នូវអនុស្សាវរីយ៍ដែលបានជិតជាប់ជាមួយ និងទិដ្ឋភាពផ្សេងទៀតនៃអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ[៣២៦៣]។

១១៤៥. ការជម្លៀសប្រជាជនបានកើតឡើងនៅក្នុងខែ មេសា ក្នុងអំឡុងពេលនៃរដូវប្រាំង។ ការបង្ខំឲ្យដើរក្នុងរយៈចម្ងាយឆ្ងាយ ក្រោមកំដៅព្រះអាទិត្យក្តៅហែងបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់បានទទួលរងនូវការឈឺចុកចាប់រូបកាយ និងអារម្មណ៍មិនស្រណុកក្នុងចិត្តយ៉ាងខ្លាំង[៣២៦៤]។ ការឈឺចុកចាប់រូបកាយ និងអារម្មណ៍មិនស្រណុកក្នុងចិត្តទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរដោយសារការខ្វះនូវស្បៀងអាហារ ទឹក និងពេលវេលាឈប់សម្រាក។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបានរាយការណ៍ថា ធ្លាប់បានឆ្លងកាត់ការអត់ឃ្លាន ការស្រេកទឹក និងការហេវហត់អស់កម្លាំង[៣២៦៥]។ មនុស្សជាច្រើនបានងាកទៅហូបអ្វី

---

៣៥។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២ (ពេជ ស្រីផល) ទំព័រ ២១-២២។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ២០-២១។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣ (ធុច ផាន់ដារ៉ា-ស) ទំព័រ ៤-៥។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (នូវ ហ៊ាន់) ទំព័រ ២២-២៣។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៥។

[៣២៦៣] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៣ (បេ សុផានី) ទំព័រ ១៦-១៧។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (នូវ ហ៊ាន់) ទំព័រ ១០-១១។

[៣២៦៤] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០១២ (ឡាយ បូនី) ទំព័រ ៧៤។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៣ (នូវ ហ៊ាន់) ទំព័រ ៥-៦។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៣ (បេ សុផានី) ទំព័រ ៨-៩។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩១។

[៣២៦៥] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨១-៨២ ។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២០។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ ៨៧-៨៩។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ១២-១៣។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ២៨។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ៧។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ឃិន វំដួល) ទំព័រ ៧៤។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨១, ៨៣។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវុត្ថា) ទំព័រ ៧៧។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន) ដំណាក់កាលទី១កថាខណ្ឌ ( ៤៨៧-៤៨៨, ៤៩១។

ក៏ដោយឲ្យតែពួកគេអាចរកឃើញនៅតាមផ្លូវ និងហូបទឹកកខ្វក់[៣២៦៦]។ ពួកគេបានសម្រាននៅតាមទីកន្លែងណាដែលពួកគេអាចរកមកធ្វើជាទីជម្រក ប៉ុន្តែ ជាញឹកញាប់ ពួកគេត្រូវទម្រេតនៅលើដីក្រោមដើមឈើ ឬ ហាលវាលហាលខ្យល់[៣២៦៧]។ ថ្នាំសង្កូវ ឬ ការថែទាំផ្នែកសុខភាពមិនមានឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី, ពេជ ស្រីផល, យស ផល, ឆេង អេងលី និង បេ សុផានី បានពិពណ៌នាអំពីសមាជិកគ្រួសាររបស់ពួកគេដែលបានធ្លាក់ខ្លួនឈឺ និង ក្នុងករណីខ្លះ បានស្លាប់បាត់បង់ជីវិត[៣២៦៨]។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះបានរម្លឹកអំពីការធ្វើដំណើររបស់ពួកគេទៅតាមទីជនបទ និងការខ្វះខាតតម្រូវការគ្រប់បែបយ៉ាង បានបន្តកើតមានរហូតដល់មួយខែ[៣២៦៩]។

១១៤៦.នៅក្នុងអំឡុងពេលធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ ក្នុងចម្ងាយផ្លូវដ៏វែងឆ្ងាយ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់បានឃើញហេតុការណ៍គួរឲ្យតក់ស្លុត។ ពួកគេបានដើរកាត់សាកសព និងមនុស្សជិតស្លាប់[៣២៧០]។ ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ដែលជាក្មេងជំទង់ម្នាក់ក្នុងឆ្នាំ

---

[៣២៦៦] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤០។ *សូមមើលបន្ថែម*ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៧។

[៣២៦៧] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ ៨២។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២០។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ទំព័រ ៨៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ទំព័រ ៥៥។ *សូមមើលបន្ថែម* ផ្នែកកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៨។

[៣២៦៨] ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៩-៨១។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ២១។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៤-៦៥។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៦៩-៧០។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៨-១១ ។ សូមមើលបន្ថែម ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩១, ៤៩៨។

[៣២៦៩] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣៨-៣៩។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២០។

[៣២៧០] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៧-៧៨។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៥។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៨។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៣៩-៤០។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៣៤,៣៥។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ

១៩៧៥ បានរាយការណ៍ថា គាត់មាន “ការភ័យតក់ស្លុត” នៅពេលឃើញសាកសព។ ដើមបណ្ដឹងរដ្ឋប្បវេណី ឡាយ បូនី ក៏នៅចងចាំស្រដៀងគ្នាថា “មានអារម្មណ៍ភ័យតក់ស្លត់” ដោយសារសាកសពទាំងនេះ[៣២៧១]។ នៅពេលគាត់បានធ្វើដំណើរបន្តទៅមុខទៀតឆ្ងាយពីទីក្រុង ហើយអ្នកដែលត្រូវបានជម្លៀសកាន់តែហេវហត់អស់កម្លាំងទៅៗនោះ ដើមបណ្ដឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានសុំនឹងការឃើញសាកសពទាំងនេះនៅតាមផ្លូវ[៣២៧២]។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏ឃើញមនុស្សចាស់ និងកូនក្មេងទទួលរងនូវជំងឺ និងការខ្វះអាហារូបត្ថម្ភផងដែរ ព្រមទាំងអ្នកដែលមានរបួសធ្ងន់ដោយសារការបៀតបៀន និងការរំលោភសេពសន្ថវៈ[៣២៧៣]។ នៅក្នុងករណីខ្លះ ដើមបណ្ដឹងរដ្ឋប្បវេណីបានមើលកងទ័ពខ្មែរក្រហមសម្លាប់អ្នកដែលត្រូវបានជម្លៀសផ្សេងទៀត រួមទាំងទារកយ៉ាងសាហាវព្រៃផ្សៃ[៣២៧៤]។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតបានទទួលការគំរាមកំហែង ភ្ជង់នឹង

---

១៥-១៧។ ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៧៩-៨០។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៩, ១១-១២។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ទំព័រ ៤០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ទំព័រ ២១។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ទំព័រ ៨៣។ ប្រតិចារឹក ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ទំព័រ ៨-៩។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវុត្ថា) ទំព័រ ៧៧, ៨៤-៨៥។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សឿន សុវណ្ឌី) ទំព័រ ៤៥-៤៦។ *សូមមើលបន្ថែម* ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩៧, ៤៩៩។

[៣២៧១] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៥៩-៦០។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ៧៨-៧៩។

[៣២៧២] ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៤។

[៣២៧៣] *សូមមើលឧទាហរណ៍*ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ទំព័រ ៨-៩។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣(យស ផល) ទំព័រ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៥-៦។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (យិន រំដួល) ទំព័រ ៧៣។ សូមមើលបន្ថែម ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៩, ៤៩២។

[៣២៧៤] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦០-៦១។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៤៤។។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ទំព័រ ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ទំព័រ ៧៣។ សូមមើលបន្ថែម ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៩០។

01007277



កាំភ្លើង ឬ ទទួលរងការវាយដំដោយកងទ័ពនៅពេលពួកគេចាកចេញពីផ្ទះរបស់ពួកគេ និងនៅពេលធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ[៣២៧៥]។

១១៤៧.ក្នុងសភាពចលាចលក្នុងពេលជម្លៀស ដើមបណ្តឹងរដ្ឋប្បវេណីខ្លះត្រូវបានបំបែកចេញពីក្រុមគ្រួសាររបស់ពួកគេ[៣២៧៦]។ នៅពេលចាកចេញពីទីក្រុងភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានព្យាយាមតាមរកប្រពន្ធគាត់ដែលកំពុងមានផ្ទៃពោះ តែរកមិនឃើញ។ គាត់ក៏មិនអាចរកប្រពន្ធគាត់ឃើញនៅក្នុងទីក្រុង ហើយលែងដែលបានជួបប្រពន្ធគាត់ជារៀងរហូត[៣២៧៧]។ ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតត្រូវបានបំបែកចេញពីសាច់ញាតិរបស់ពួកគេភ្លាមៗ ក្រោយពួកគេបានទៅដល់តាមទីតាំងថ្មី[៣២៧៨]។

១១៤៨.ដើមបណ្តឹងរដ្ឋប្បវេណីដែលជាប់ទាក់ទង នឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទីពីរ បានរាយការណ៍ថាបានឆ្លងកាត់ភាពលំបាកតោកយ៉ាកស្រដៀងគ្នា ហើយសម្រាប់អ្នកទាំងនេះភាគច្រើនបានទទួលនូវការលំបាកវេទនាកាន់តែអាក្រក់ថែមទៀត ដោយសារពួកគេបានទទួលរងនូវស្ថានភាពទន់ខ្សោយរួចមកហើយ ដែលបណ្តាលមកពីការផ្លាស់ទីលំនៅដោយបង្ខំក្នុងដំណាក់កាលទី១។ ពួកគេត្រូវបានបង្ខំឲ្យឡើងជិះរថភ្លើង និងឡានដែលណែនណាន់តាន់តាប់[៣២៧៩]។ ដើមបណ្តឹង

---

[៣២៧៥] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ទំព័រ ២៣-២៤។ ប្រតិចារឹក ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ ៦-៧។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ២៨។ សូមមើលបន្ថែម ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨៩។

[៣២៧៦] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ១៣-១៤។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២(Denise AFFONÇO)ទំព័រ៧៨-៧៩។ ប្រតិចារឹក ថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ន់) ទំព័រ ៦។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សឿន សុវណ្ណី) ទំព័រ ៤២។ សូមមើលបន្ថែម ផ្នែកទី ១០៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) កថាខណ្ឌ ៤៨១, ៤៨៣។

[៣២៧៧] ប្រតិចារឹក ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ៧៨-៨០។ ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ ២-៣, ២៥, ២៩-៣១។

[៣២៧៨] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ទំព័រ ២៨-២៩, ៣០-៣១។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវត្ថា) ទំព័រ ៨៤-៨៥។

[៣២៧៩] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ទំព័រ ៤៨-៤៩។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ៤០-៤១ ។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៤០។ ប្រតិចារឹក ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៦-៧។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ

រដ្ឋប្បវេណី ថៅ នី និងគ្រួសាររបស់គាត់មិនបានដឹងថា តើពួកគេកំពុងត្រូវបាននាំយកទៅសម្លាប់ចោល ឬក៏យ៉ាងណានោះឡើយ[៣២៨០]។ ជាទូទៅ ម្ហូបអាហារ ទឹកស្អាត ថ្នាំសង្កូវ និងការថែទាំវេជ្ជសាស្ត្រ មិនត្រូវបានផ្តត់ផ្គង់ឡើយ[៣២៨១]។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះ បានឃើញការកាប់សម្លាប់អ្នកដែលត្រូវជម្លៀសផ្សេងទៀតដោយកងទ័ពខ្មែរក្រហម[៣២៨២]។ ដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី នៅចាំថាបានឃើញសាកសពដែលគេទុកចោលនៅតាមផ្លូវ[៣២៨៣]។ គ្រួសារដើមបណ្តឹងរដ្ឋប្បវេណីខ្លះត្រូវបានគេបំបែកចេញពីគ្នានៅពេលទៅដល់ទីតាំងថ្មី[៣២៨៤]។

១១៤៩. ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ មានជនរងគ្រោះជាច្រើននាក់ផងដែរ ដែលបានអះអាងថា សាច់ញាតិរបស់ពួកគេ ជាទូទៅជា ទាហាន ឬ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងចំណោមអ្នកដែលត្រូវបានសម្លាប់ចោលនៅទួលពោធិ៍ជ្រៃ[៣២៨៥]។ ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតបានរៀបរាប់អំពីការបាត់ខ្លួនសមាជិកគ្រួសារដែលធ្លាប់បម្រើការងារនៅក្នុងរដ្ឋការ លន់ នល់ ។ ទោះបីជាពួកគេមិនបានដឹងអំពីវិធី ឬ ទីកន្លែងដែលសាច់ញាតិរបស់ពួកគេស្លាប់ក៏ដោយ កាលៈទេសៈនៃការបាត់ខ្លួនបង្ហាញដល់អង្គជំនុំជម្រះថា យ៉ាង

---

២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៦។ *សូមមើលបន្ថែម* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៦-៥៩៨។

[៣២៨០] ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ថៅ នី) ទំព័រ ៤៩-៥០។

[៣២៨១] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៣៩។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៨, ៨៣-៨៤។ សូមមើលបន្ថែមផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩១-៥៩២, ៥៩៧។

[៣២៨២] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ ៦២-៦៣។ ប្រតិចារឹក ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ទំព័រ៣៤។ *សូមមើលបន្ថែម* ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៥៩៥។

[៣២៨៣] ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ូន ផល្លី) ទំព័រ ៣២។

[៣២៨៤] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ទំព័រ ៦៩-៧០។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (យិន រំដួល) ទំព័រ ៦០-៦១។ សូមមើលបន្ថែម ផ្នែកទី ១១៖ ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) កថាខណ្ឌ ៦០១។

[៣២៨៥] *សូមមើល ឧទាហរណ៍* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ យឹម សាវ ឯកសារ E3/5347 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា សុខវ័ត្ថ ឯកសារ E3/5349 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សឿន សុខ ឯកសារ E3/5353 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨។ សូមមើល ផ្នែកទី ១២៖ ទួលពោធិ៍ជ្រៃ កថាខណ្ឌ ៦៦៨, ៦៧២។

ហោចណាស់ ក៏មានមនុស្សមួយចំនួនក្នុងចំណោមអ្នកទាំងនេះអាចត្រូវបានសម្លាប់ចោលនៅទួលពោធិ៍ជ្រៃផងដែរ[៣២៨៦]។

១១៥០. ក្រោយពីបានស្តាប់សក្ខីកម្មរបស់អ្នកជំនាញ អង្គជំនុំជម្រះជឿជាក់ថា ការឈឺចាប់ដែលបានបង្កឡើងលើដើមបណ្តឹងរដ្ឋប្បវេណី ដោយសារបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទជាចំណែកមួយធ្វើឱ្យកើតមានរោគសញ្ញានៃការឈឺចាប់ផ្លូវចិត្តក្នុងរយៈពេលវែង យោងតាមការរាយការណ៍ពីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់[៣២៨៧]។ អ្នកជំនាញ ឈឹម សុធារ៉ា បានពន្យល់ថា នៅក្នុងករណីជាច្រើន បទពិសោធន៍របស់ជនរងគ្រោះនៃរបបខ្មែរក្រហមបានបណ្តាលឱ្យមានជំងឺប៉ះទង្គិចផ្លូវចិត្តជារៀងរហូត ដូចជា សុបិនអាក្រក់ ជំងឺបាក់ស្បាត ការធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺសង្ស័យ (Paranoia)[៣២៨៨]។ ជំងឺបាក់ស្បាតអាចស្តែងចេញដោយខ្លួនវាតាមរយៈការនឹកឃើញឡើងវិញនូវហេតុការណ៍ពីអតីតកាលថាដូចនៅថ្មីៗ ការស្ទាក់ស្ទើរមិនពិភាក្សា ឬ មិនចង់ទៅមើលកន្លែងពីមុនៗ ការញ័រខ្លួនប្រាណ និងជំងឺដេកមិនលក់[៣២៨៩]។ អង្គជំនុំជម្រះយល់ឃើញថា ដោយសារផលវិបាកនៃបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើននាក់ទៀតបានទទួលរងនូវការឈឺចាប់ដែលមិនអាចវាស់បាន រួមមានដូចជា ការឈឺចាប់លើរូបកាយ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ការប៉ះទង្គិចផ្លូវចិត្ត (Trauma) និងការសោកសង្រេងដែលបណ្តាលមកពីការបាត់បង់សមាជិកគ្រួសារ ឬសាច់ញាតិជិតស្និទ្ធ[៣២៩០]។

---

[៣២៨៦] *សូមមើល ឧទាហរណ៍* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហែម សារ៉ន ឯកសារ E3/4808 ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទេស បុប្ផា ឯកសារ E3/4811 ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១០។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជ័យ យ៉ាន ឯកសារ E3/4857 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០។

[៣២៨៧] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៦៥ (ពិពណ៌នាអំពីផលប៉ះពាល់ផ្លូវចិត្តនៃការបាត់បង់អ្នកជិទីស្រលាញ់)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៣-៧៤ (ពិពណ៌នាអំពីផលប៉ះពាល់ផ្លូវចិត្តនៃការផ្លាស់ទីលំនៅ)។ ប្រតិចារឹក ថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៥-៧៦ (ពិពណ៌នាអំពីផលប៉ះពាល់ផ្លូវចិត្តនៃការឃើញព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្ត)។ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៧៧ (ពិពណ៌នាអំពីផលប៉ះពាល់ផ្លូវចិត្តនៃការអត់អាហារ)។

[៣២៨៨] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ ៥២-៥៤។

[៣២៨៩] ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (ឈឹម សុធារ៉ា) ទំព័រ៥៤-៥៥ ។

[៣២៩០] ផ្នែកទី ១៨៖ ការផ្តន្ទាទោស កថាខណ្ឌ ១០៧៧។

## ១៩.៥ ការវាយតម្លៃលើរាល់សំណងទាំងអស់ដែលសហមេធាវីនាំមុខបានស្នើសុំ

១១៥១.អង្គជំនុំជម្រះទទួលស្គាល់ថា ការផ្តល់សំណងដូចខាងក្រោមនេះ ដែលបំពេញទៅតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង គឺជាការជួសជុលព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ និងផ្តល់សំណងផ្លូវចិត្ត និងជាសមូហភាព ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ គម្រោងសំណងទាំងអស់នេះមានលក្ខណៈសមស្រប អាចផ្តល់អានុភាពលើការផ្តល់សំណងដែលសហមេធាវីនាំមុខបានទាមទារ និងអាចអនុវត្តបាន។

### ១៩.៥.១ គម្រោងទាក់ទងការចងចាំ និងបូជនីយដ្ឋានសម្រាប់រម្លឹកៈ គម្រោងទី ១ និងគម្រោងទី ៣

១១៥២.អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញតាំងពីមុនមកហើយថា ស្ថាប័នអន្តរជាតិខ្លះបានកំណត់ប្រភេទនៃការទទួលស្គាល់ជាផ្លូវការ អំពីការឈឺចាប់ដែលមានសារសំខាន់ជានិមិត្តរូបសម្រាប់ជនរងគ្រោះថាជាសំណង[៣២៩១]។ អង្គជំនុំជម្រះយល់ស្របជាមួយសហមេធាវីនាំមុខថា ការកំណត់ទិវាជាតិឈប់សម្រាកផ្លូវការ គឺជាការទទួលស្គាល់ជាផ្លូវការ និងទូទាំងប្រទេសអំពីព្យសនកម្មដែលជនរងគ្រោះបានទទួលរង។ បូជនីយដ្ឋានជាសាធារណៈ អាចជួយបន្ថែមទៀតដល់ការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ព្រមទាំងផ្តល់ការទទួលស្គាល់ជាសាធារណៈចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងព្យសនកម្មដែលបានទទួលរង និងជួយដល់ការព្យាបាលរបួសស្នាមរបស់ជនរងគ្រោះទាំងអស់ ដោយវាបានពង្រីកឥទ្ធិពលនៃសំណង មិនត្រឹមតែចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[៣២៩២]។ ការផ្តួចផ្តើមទាំងពីរនេះប្រហែលជាអាចលើកទឹកចិត្តបន្ថែមទៀត ដល់ការសិក្សាស្វែងយល់អំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ព្រមទាំងលើកកម្ពស់វប្បធម៌សន្តិភាព និងចូលរួមចំណែកដល់ការផ្សះផ្សាជាតិ[៣២៩៣]។

១១៥៣. ដោយសាររាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈច្បាស់លាស់ចង់ប្រកាសយកថ្ងៃទី ២០ ខែឧសភា ជាទិវានៃការចងចាំប្រចាំឆ្នាំ និងជាថ្ងៃឈប់សម្រាកផ្លូវការ ដូច្នេះ គ្មានខ្ទង់ចំណាយជាក់លាក់ផ្នែកហិរញ្ញវត្ថុណាមួយ ទំនងជាចាំបាច់ត្រូវដាក់ជូនសម្រាប់ផ្តល់អានុភាពលើការផ្តួចផ្តើម

[៣២៩១] សាលក្រមលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៦៦៧។

[៣២៩២] ឯកសារ F28 សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៦៨៣។

[៣២៩៣] ឯកសារ F28 សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៦៨៣។

នេះទេ។ ពាក់ព័ន្ធទៅនឹងគម្រោងទីពីរ មូលនិធិទាំងអស់ដែលត្រូវការសម្រាប់ការអនុវត្តគម្រោងនេះត្រូវបានធានារួចរាល់ ហើយសាលារាជធានីភ្នំពេញ ក៏បានឯកភាពទៅលើទីតាំងដែលបានស្នើសម្រាប់បូជនីយដ្ឋាននោះផងដែរ។ លើសពីនេះទៀត អ្នកអនុវត្តគម្រោងនេះ (ដែលរួមមានស្ថានទូតបារាំង ក្រុមមិត្តភាព បារាំង-កម្ពុជា នៃរដ្ឋសភាបារាំង និងលោក សេរ៉ា) បានបង្ហាញជាផ្លូវការអំពីឆន្ទៈចង់សម្រេចឲ្យបាននូវគម្រោងនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកគម្រោងទី ១ និងគម្រោងទី ៣។

### ១៩.៥.២ គម្រោងទាក់ទងវិធីសាស្ត្រព្យាបាល និងជំនួយផ្នែកផ្លូវចិត្តដល់ជនរងគ្រោះ៖ គម្រោង ទី ៥ និងគម្រោងទី ៦

១១៥៤. អង្គជំនុំជម្រះយល់ឃើញផងដែរថា គម្រោងទី ៥ និងគម្រោងទី ៦ ដែលមានគោល-បំណងផ្តល់ជាជំនួយផ្លូវចិត្តដល់ជនរងគ្រោះ គឺជាសំណង "ផ្លូវចិត្ត និងជាសមូហភាព" នៅក្នុងវិសាលភាពនៃក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ដូច្នេះវាបានបំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងវិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានទទួលស្គាល់កាលពីពេលមុនផងដែរថា ការផ្តល់ការថែទាំផ្នែកផ្លូវចិត្តគឺជាទម្រង់នៃសំណងដ៏សមស្របមួយ[៣២៩៤]។ បន្ថែមលើនេះទៀត ពិធីបុណ្យជាសាធារណៈដែលគ្រោងនឹងប្រារព្ធធ្វើឡើងនៅក្រោយបញ្ចប់គម្រោងទី៥ នោះ ក៏ប្រហែលជាអាចលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីព្យសនកម្មដែលជនរងគ្រោះក្នុងរបបខ្មែរក្រហមបានទទួលរង និងអាចចូលរួមចំណែកដល់ការផ្សះផ្សាជាតិ។

១១៥៥. ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ឃើញថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញថា មូលនិធិចាំបាច់នានាត្រូវបានធានារួចរាល់ហើយសម្រាប់ផ្នែកនៃគម្រោងដែលត្រូវធ្វើឡើងនៅទីក្រុងភ្នំពេញ ហើយដៃគូរគម្រោងបានប្តេជ្ញាថានឹងធានាឲ្យគម្រោងនេះអនុវត្តទៅបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកគម្រោងទី ៥ និងទី៦។ ទោះបីជា មិនមានមូលនិធិសម្រាប់ការពង្រីកគម្រោងនេះទៅក្រៅទីក្រុងភ្នំពេញក៏ដោយ ក៏អង្គជំនុំជម្រះអនុញ្ញាតឲ្យមានការពង្រីកគម្រោងនេះ ក្នុងករណីមានមូលនិធិបន្ថែម។

---

[៣២៩៤] ឯកសារ F28 សាលដីកាលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៧០១។

## ១៩.៥.៣ ការចងក្រងឯកសារ និងការអប់រំ៖ គម្រោងទី ៧, ៨, ៩, ១០, ១១, ១២, និង គម្រោងទី ១៣

១១៥៦.ចំពោះគម្រោងទី ៧, ៨, ៩, ១០ និងគម្រោងទី ១១ ដែលគម្រោងទាំងអស់នេះពាក់ព័ន្ធការចងក្រងឯកសារ និងការអប់រំនោះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា គម្រោងទាំងនេះក៏គោរពតាមលក្ខខណ្ឌតម្រូវនៃវិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង ហើយមានលក្ខណៈផ្លូវចិត្ត និងជាសមូហភាព ផងដែរ។ ការអប់រំជាសាធារណៈអំពីការឈឺចាប់របស់ជនរងគ្រោះ និងអំពីលក្ខណៈនៃរបបខ្មែរក្រហមនោះក៏ប្រហែលជាជួយដល់ការសម្រេចគោលដៅនៃការទទួលស្គាល់ ការចងចាំ និងការលើកកម្ពស់ការយល់ដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត និងភាពឈឺចាប់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មទាំងនេះផងដែរ។ ដូច្នេះហើយ វាប្រហែលជាមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះនោះទេ វាថែមទាំងចូលរួមចំណែកដល់ការផ្សះផ្សាជាតិផងដែរ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា មូលនិធិសម្រាប់ការអនុវត្តគម្រោងទាំងនេះត្រូវបានធានា ហើយដៃគូទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងទាំងនេះបានបង្ហាញឆន្ទៈច្បាស់លាស់ស្រុះគ្នាចង់ជួយឱ្យគម្រោងទាំងនេះបានសម្រេចចេញជារូបរាង។

១១៥៧. ចំពោះគម្រោងទី ៩ ការណែនាំកាលពីលើកមុនរបស់អង្គជំនុំជម្រះសាលាដំបូងបានរម្លឹកដើមបណ្តឹងរដ្ឋប្បវេណីថា "អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើការយល់ព្រមលើជំពូកណាមួយនៃសៀវភៅស្តីពីអង្គហេតុណាមួយដែលកំពុងស្ថិតក្រោមការពិចារណារបស់តុលាការ ហើយដែលនឹងត្រូវធ្វើការវិនិច្ឆ័យជាចុងក្រោយបានទេ"[៣២៩៥]។ ទោះជាយ៉ាងនេះក្តី សហមេធាវីនាំមុខបានដាក់នូវជំពូកសៀវភៅដែលបានស្នើឡើង ដែលពួកគេបានអះអាងថាមិនមែនជាការធ្វើសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ ជាពិសេសទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០១ នោះឡើយ។ សហមេធាវីនាំមុខក៏បានស្នើឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើការណែនាំមុនរបស់ខ្លួន។ អង្គជំនុំជម្រះទទួលស្គាល់ថា ការផ្តល់ជូននូវមូលដ្ឋានដ៏ត្រឹមត្រូវដល់សាលា-រៀនសម្រាប់ពិភាក្សាអំពីហេតុការណ៍នានានៅក្នុងអំឡុងសម័យខ្មែរក្រហមគឺជាគោលដៅដ៏ប្រសើរមួយ ហើយក៏ទទួលស្គាល់ថា ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនៅក្នុងជំពូកនោះ

[៣២៩៥] សេចក្តីសម្រេចជាបន្តបន្ទាប់ និងចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពជាក់លាក់ដែលបានធ្វើបច្ចុប្បន្ន-ភាព នៃគម្រោងសំណងជាអាទិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨១ ស្ទួន៤ (E218/7/3) ឯកសារ E218/7/4 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៨។

មានអត្ថប្រយោជន៍សម្រាប់ការពិភាក្សាបែបនេះផងដែរ។ ប៉ុន្តែអង្គជំនុំជម្រះសូមសង្កត់ធ្ងន់ថា ការសម្រេចអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ និងការកំណត់លើអង្គហេតុគឺជាបុព្វសិទ្ធិតែមួយគត់របស់ អ.វ.ត.ក ដោយត្រូវផ្អែកទៅលើការវាយតម្លៃពីភាពអាចជឿជាក់បានរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្លឹមសារនៃជំពូកសៀវភៅចាំបាច់ត្រូវស្វែងយល់ទៅតាមបរិបទនេះផងដែរ។ ហេតុដូច្នេះ វាជាការសមស្របដែលត្រូវដាក់សេចក្តីបដិសេធនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងជំពូកនេះ ហើយអង្គជំនុំជម្រះបង្គាប់ឲ្យធ្វើដូច្នេះ[៣២៥៦]។ ដរាបណាមានការគោរពតាមលក្ខខណ្ឌនេះទើបអង្គជំនុំជម្រះអនុម័តយល់ព្រមលើគម្រោងទី ៩ ។

១១៥៨.ចំពោះគម្រោងទី ១២ និងគម្រោងទី ១៣ វិញ ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់បញ្ចូលឈ្មោះទៅក្នុងសាលក្រមស្តាពរក្នុងសំណុំរឿង០០២។ នៅពេលដែលជួបប្រឈមនឹងសំណើប្រហាក់ប្រហែលគ្នាបែបនេះក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថាតាមលក្ខណៈបច្ចេកទេស វិធានការបែបនេះហួសពីវិសាលភាពនៃសំណងដែលមានក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក កាលពីពេលនោះ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នៅក្នុងសាលក្រមសំណុំរឿង ០០១ របស់ខ្លួនថា មានតែ អ.វ.ត.ក តែមួយគត់ដែលអាចសម្រេចលើសំណើទាំងនេះបាន ហើយស្ថាប័នអន្តរជាតិដទៃទៀតបានកំណត់ប្រភេទនៃការទទួលស្គាល់ជាផ្លូវការ អំពីការឈឺចាប់ដែលមានសារសំខាន់ជានិមិត្តរូបសម្រាប់ជនរងគ្រោះថាជាសំណងសម្រាប់ជនរងគ្រោះ។ ដោយសារតែគម្រោងទាំងនេះ បានផ្តល់ជាមធ្យោបាយរូបិយសម្រាប់ការទទួលស្គាល់ការឈឺចាប់ជាសមូហភាពរបស់ជនរងគ្រោះនោះ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកគម្រោងទាំងនេះ ក៏ដូចជាសំណើប្រហាក់ប្រហែលគ្នាផ្សេងៗទៀត[៣២៥៧]។ អង្គជំនុំ-ជម្រះសូមបញ្ជាក់សាជាថ្មីថា ការផ្តល់ជូនជាសាធារណៈនូវសាលក្រម និងព័ត៌មាននានាជុំវិញ

---

[៣២៥៦] អង្គជំនុំជម្រះពិចារណាថាការបដិសេធដូចតទៅនេះ គឺជាការបដិសេធដ៏សមស្រប "ជំពូកនេះគឺផ្អែកទៅលើសក្ខី-កម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី នៅចំពោះមុខ អ.វ.ត.ក។ ការសម្រេចពីការមានពិរុទ្ធ ឬមិនមានពិរុទ្ធរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលមានចែងក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយក្នុងករណីសមស្រប ត្រូវបានគាំទ្រ ឬកែប្រែ ដោយអង្គជំនុំជម្រះតុលាការកំពូល គឺជាការចងកាតព្វកិច្ចតាមផ្លូវច្បាប់តែមួយគត់ចំពោះបណ្តាព្រឹត្តិការណ៍នានាដែលបានបង្ហាញក្នុងជំពូកនេះ។

[៣២៥៧] សាលក្រមលើសំណុំរឿង កាំង ហ្កេកអ៊ាវ កថាខណ្ឌ ៦៦៧ ដល់ ៦៦៨។

សំណុំរឿង ០០២ អាចចូលរួមចំណែកយ៉ាងសំខាន់ដល់គំនិតផ្តួចផ្តើមនៃការផ្សះផ្សាជាតិនៅក្នុងសង្គមកម្ពុជាទូទៅ និងសម្រាប់ការអប់រំជាសាធារណៈផងដែរ[៣២៩៨]។

១១៥៩.អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់លើឆន្ទៈរបស់អង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈ ចង់ដាក់បញ្ចូលឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០២ ទៅលើគេហទំព័ររបស់ អ.វ.ត.ក ហើយដូចគ្នានោះដែរក៏យល់ព្រមឱ្យផ្នែកកិច្ចការសាធារណៈចែកចាយសាលក្រមសំណុំរឿង ០០២/០១ ឱ្យបានទូលំទូលាយបំផុតតាមលទ្ធភាពធនធានដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន ដែលទាំងអស់នេះគឺជាវិធានការដ៏មានតម្លៃសម្រាប់សំណងនៅក្នុងអត្ថន័យនៃវិធាន ២៣ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង។

១១៦០.ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកគម្រោងទី ៧, ៨, ៩, ១០, ១១, ១២ និងគម្រោងទី ១៣។

### ១៩.៥.៤ គម្រោងនានាដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនទទួលយក៖ គម្រោងទី២ និងគម្រោងទី៤

១១៦១.ទោះបីជាអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា សំណងដែលស្នើសុំក្នុងគម្រោងទី ២ និងទី៤ អាចជួសជុលបានយ៉ាងសមស្របចំពោះព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ ហើយអាចផ្តល់ជាសំណងផ្លូវចិត្ត និងជាសមូហភាពចំពោះការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏វិធាន ២៣ ស្ទួនបួន(៣)(ខ) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហមេធាវីនាំមុខបង្ហាញថា គម្រោងទាំងអស់នេះមានការធានាមូលនិធិគ្រប់គ្រាន់ពីស្ថាប័នខាងក្រៅ ដោយសារវាជាលក្ខខណ្ឌមួយសម្រាប់ការសម្រេចយល់ព្រមតាមផ្លូវតុលាការចំពោះការផ្តល់សំណង។

១១៦២.ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់យ៉ាងច្បាស់ហើយថា គម្រោងទី២ មិនមានការរៀបរាប់លម្អិតឱ្យបានគ្រប់គ្រាន់ ឬ ក៏បញ្ជាក់អំពីខ្ទង់ថវិកាជាក់លាក់ក៏ដោយ ក៏សហមេធាវីនាំមុខនៅតែមិនផ្តល់ព័ត៌មានបន្ថែមសំខាន់ៗដទៃទៀត ដូចជាទីតាំងបូជនីយដ្ឋានដែលត្រូវស្នើឡើងដែលបានគិតបម្រុងទុក ឬក៏កិច្ចព្រមព្រៀងជាមួយភាគីតតិយជនពាក់ព័ន្ធណាមួយដដែលនាពេលក្រោយមក។

[៣២៩៨] សាលក្រមលើសំណុំរឿង កាំង ហ្គេកអ៊ាវ កថាខណ្ឌ ៦៦៩។

១១៦៣. អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើង ដើម្បីផ្តល់ការបង្ហាញឱ្យបានរឹងមាំចំពោះគម្រោងទី ៤។ អង្គជំនុំជម្រះសាលាដំបូង ក៏បានកត់សម្គាល់ឃើញមានការឯកភាពពីសាលាក្រុងប៉ារីស ព្រមទាំងដំណើរការវិវឌ្ឍន៍នៃការសន្យាថវិកា។ ប៉ុន្តែ តាមដែលអង្គជំនុំជម្រះសាលាដំបូងបានដឹង យុទ្ធនាការស្វែងរកមូលនិធិនៅក្នុងដំណាក់កាលនេះកំពុងបន្តធ្វើឡើងនៅឡើយ។ បើទោះបីជាសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិបាន និងកំពុងបន្តស្វែងរកធនធានក្នុងការផ្តល់មូលនិធិសម្រាប់គម្រោងនេះក៏ដោយ ក៏ការព្យាយាមនេះមិនអាចធានាបានថាហិរញ្ញប្បទាននឹងប្រាកដជាអាចទទួលបាននោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចទទួលយកគម្រោងនេះបានឡើយ ដោយសារតែមិនមានការបង្ហាញឱ្យបានពេញលេញថា មានការធានាចំពោះការផ្តល់មូលនិធិពីខាងស្ថាប័នខាងក្រៅបានគ្រប់គ្រាន់នៅឡើយ។

១១៦៤. ជារួមមក អង្គជំនុំជម្រះសាលាដំបូង សូមស្វាគមន៍ចំពោះការផ្តួចផ្តើមនានាដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះ ការថែរក្សាការចងចាំរបស់ពួកគាត់បន្តទៀត ការទទួលស្គាល់ពីការឈឺចាប់របស់ជនរងគ្រោះ និងការដាស់ស្មារតីសាធារណជនឱ្យបានដឹង ដើម្បីជៀសវាងកុំឱ្យអំពើដដែលនេះកើតមានឡើងសាជាថ្មីម្តងទៀត។ អង្គជំនុំជម្រះក៏សូមរម្លឹកដល់ម្ចាស់ជំនួយនានាថា ពួកគេមានជម្រើសក្នុងការគាំទ្រដល់វិធានការនានាដែលមិនទាន់បានសម្រេចទទួលយកនៅក្នុងសាលក្រមនេះ។

## ២០. សេចក្តីសម្រេច

តាមសម្អាងហេតុខាងលើ និងក្រោយពីបានពិចារណាលើរាល់ភ័ស្តុតាង និងសេចក្តីសន្និដ្ឋានទាំងអស់របស់ភាគី **អង្គជំនុំជម្រះសាលាដំបូងសម្រេចដូចខាងក្រោម៖**

អនុលោមតាមមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ **នួន ជា** មានពិរុទ្ធពីបទ៖

> ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបញ្ចប់នៅឆ្នាំ ១៩៧៧។

ផ្អែកតាមមូលដ្ឋាននៃសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស **នួន ជា** ដាក់ពន្ធនាគារ**អស់មួយជីវិត**។

អនុលោមតាមមាត្រា ៥ មាត្រា និងមាត្រា ២៩ (ថ្មី) មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងរកឃើញថាជនជាប់ចោទ **ខៀវ សំផន** មានពិរុទ្ធពីបទ៖

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបញ្ចប់នៅឆ្នាំ ១៩៧៧។

ផ្អែកតាមមូលដ្ឋាននៃសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស **ខៀវ សំផន** ដាក់ពន្ធនាគារ**អស់មួយជីវិត**។

**ប្រកាសថា** ដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលជាក្រុម ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលជាឧបសម្ព័ន្ធ២ ពិតជាបានទទួលរងព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់កើតចេញពីបទឧក្រិដ្ឋដែល នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាមានពិរុទ្ធ និងដោយអនុលោមតាមមាត្រា ២៣ស្ទួនបួន (ខ)(៣) អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះនៃសំណើសុំសំណងផ្លូវចិត្ត និងជាសមូហភាព។ ដូចបានថែងលម្អិតនៅក្នុងផ្នែកទី១៩ នៃសាលក្រមនេះ អង្គជំនុំជម្រះសម្រេចទទួលយកនូវគម្រោងសំណងដែលមានលក្ខណៈសមស្រប និងដែលអាចអនុវត្តបានចំនួន ១១ គម្រោង ដែលទាក់ទងនិងទិវានៃការចងចាំចំពោះជនរងគ្រោះ និងពិធីរម្លឹកផ្សេងៗចំពោះភាពឈឺចាប់ដែលពួកគេទទួលរង វិធីព្យាបាលតាមរយៈការចងក្រងជាសក្ខីកម្ម និងការព្យាបាលជំងឺផ្លូវចិត្តដល់ជនរងគ្រោះ និងការតាំងពិពណ៌ឯកសារ និងគម្រោងអប់រំ។ អង្គជំនុំជម្រះសម្រេចបដិសេធគម្រោងសំណងដែលបានស្នើសុំចំនួន២ ដែលមិនស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន ២៣ស្ទួនបួន(ខ)(៣) ដូចមានថែងលម្អិតនៅក្នុងផ្នែកទី១៩។

អង្គជំនុំជម្រះ**ប្រកាសថា នួន ជា** ត្រូវបានឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ និងថា **ខៀវ សំផន** ត្រូវបានឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយជនជាប់ចោទទាំងពីរនាក់ ត្រូវរក្សាទុកនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ថ្ងៃប្រកាសសាលក្រម និងផ្តន្ទាទោស នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

សាលក្រមនេះប្រកាសជាសាធារណៈនៅសាលសវនាការធំនៃ អ.វ.ត.ក នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

បើកផ្លូវឱ្យភាគីប្តឹងសាទុក្ខតាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ដោយសារតែពិរុទ្ធជនត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរ **នួន ជា** និង **ខៀវ សំផន** ត្រូវរក្សាទុកនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់សាលក្រមនេះចូលជាស្ថាពរ លើកលែងតែមានការបញ្ជាផ្សេងពីនេះរបស់អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក។

សាលក្រមនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

**លឹម ស៊ុយហុង** Matteo CRIPPA

ចៅក្រម **និល ណុន**

ប្រធាន

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **យូរ ឧត្តរា**